


ព្រះគម្ពីរសញ្ញាថ្មី

សៀវភៅសិក្សាសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា



ព្រះគម្ពីរសញ្ញាថ្មី

សៀវភៅគ្រូបង្រៀនថ្នាក់សិក្ខាសាលា

បោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍

សូមថ្លែងអំណរគុណចំពោះរាល់មតិយោបល់ និងការកែតម្រូវទាំងអស់ ។ សូមផ្ញើមតិយោបល់មក រួមជាមួយនឹងកំហុសឆ្គងទាំងឡាយទៅកាន់ ៖

Seminaries and Institutes of Religion Curriculum Services
50 East North Temple Street
Salt Lake City, Utah 84150-0008
USA
អ៊ីម៉ែល ៖ ces-manuals@ldschurch.org

សូមសរសេរនាមត្រកូលពេញ អាសយដ្ឋាន រួដ និងស្តេករបស់អ្នក ។

សូមកុំភ្លេចសរសេរចំណងជើងសៀវភៅណែនាំការសិក្សា នៅពេលអ្នកផ្តល់មតិយោបល់របស់អ្នក ។

© 2016 by Intellectual Reserve, Inc.
រក្សាសិទ្ធិគ្រប់យ៉ាង ។

បោះពុម្ពនៅសហរដ្ឋអាមេរិក

អនុមតិជាភាសាអង់គ្លេស ៖ ២/១៥
អនុមតិការបកបកប្រែ ៖ ២/១៥
ការបកប្រែនៃ *New Testament Seminary Teacher Manual*
Cambodian
12339 258

មាតិកា

សេចក្តីណែនាំស្តីពីព្រះគម្ពីរសញ្ញាថ្មី សៀវភៅសិក្សាសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា vi
គោលបំណងរបស់យើង vi
ការរៀបចំមេរៀន vi
ការប្រើសៀវភៅសិក្សាសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ viii
កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ (ម៉ោងចេញ និង ម៉ោងព្រឹកព្រលឹម) x
ការប្រើមេរៀនសិក្សានៅផ្ទះ: xii
កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ: xiii
ធនធានដទៃទៀត xiv

មេរៀនប្រចាំថ្ងៃ និង មេរៀនសិក្សានៅផ្ទះ:
មេរៀនទី ១ សេចក្តីណែនាំស្តីពីព្រះគម្ពីរសញ្ញាថ្មី ១
មេរៀនទី ២ ផែនការនៃសេចក្តីសង្គ្រោះ ៤
មេរៀនទី ៣ តួនាទីរបស់សិស្ស ៧
មេរៀនទី ៤ ការសិក្សាព្រះគម្ពីរ ១១
មេរៀនទី ៥ បរិបទ និង ទិដ្ឋភាពទូទៅនៃព្រះគម្ពីរសញ្ញាថ្មី ១៤
មេរៀនសិក្សានៅផ្ទះ: ៖ ផែនការនៃសេចក្តីសង្គ្រោះ–សេចក្តីផ្តើម និង បរិបទនៃ ព្រះគម្ពីរសញ្ញាថ្មី (មេរៀនទី ១) ១៨

សេចក្តីណែនាំស្តីពីដំណឹងល្អយោងតាមម៉ាថាយ ២០
មេរៀនទី ៦ ម៉ាថាយ ១–២ . . . . ២១
មេរៀនទី ៧ ម៉ាថាយ ៣ . . . . ២៤
មេរៀនទី ៨ ម៉ាថាយ ៤ . . . . ២៧
មេរៀនទី ៩ ម៉ាថាយ ៥:១-១៦ . . . . ៣១
មេរៀនទី ១០ ម៉ាថាយ ៥:១៧-៤៨ . . . . ៣៥
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាថាយ ១-៥ (មេរៀនទី ២) ៣៨

មេរៀនទី ១១ ម៉ាថាយ ៦ . . . . ៤០
មេរៀនទី ១២ ម៉ាថាយ ៧ . . . . ៤៣
មេរៀនទី ១៣ ម៉ាថាយ ៨–១០ . . . . ៤៦
មេរៀនទី ១៤ ម៉ាថាយ ១១-១២ . . . . ៤៩
មេរៀនទី ១៥ ម៉ាថាយ ១៣:១-២៣ . . . . ៥២
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាថាយ ៦:១-១៣:២៣ (មេរៀនទី ៣) ៥៥

មេរៀនទី ១៦ ម៉ាថាយ ១៣:២៤-៥៨ . . . . ៥៧
មេរៀនទី ១៧ ម៉ាថាយ ១៤ . . . . ៦០
មេរៀនទី ១៨ ម៉ាថាយ ១៥ . . . . ៦៤
មេរៀនទី ១៩ ម៉ាថាយ ១៦ . . . . ៦៧
មេរៀនទី ២០ ម៉ាថាយ ១៧ . . . . ៧១
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាថាយ ១៣:២៤–១៧:២៧ (មេរៀនទី ៤) ៧៤

មេរៀនទី ២១ ម៉ាថាយ ១៨ . . . . ៧៦
មេរៀនទី ២២ ម៉ាថាយ ១៩-២០ . . . . ៧៩
មេរៀនទី ២៣ ម៉ាថាយ ២១:១-១៦ . . . . ៨៣
មេរៀនទី ២៤ ម៉ាថាយ ២១:១៧–២២: ១៤ . . . . ៨៧
មេរៀនទី ២៥ ម៉ាថាយ ២២:១៥-៤៦ . . . . ៩០
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាថាយ ១៨-២២ (មេរៀនទី ៥) ៩៣

មេរៀនទី ២៦ ម៉ាថាយ ២៣ . . . . ៩៥
មេរៀនទី ២៧ យ៉ូសែប ស្ម៊ីធ—ម៉ាថាយ: ម៉ាថាយ ២៤ . . . . ៩៨
មេរៀនទី ២៨ ម៉ាថាយ ២៥:១-១៣ . . . . ១០២
មេរៀនទី ២៩ ម៉ាថាយ ២៥:១៤-៤៦ . . . . ១០៥
មេរៀនទី ៣០ ម៉ាថាយ ២៦:១–៣០ . . . . ១០៩
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាថាយ ២៣:១-២៦:៣០ (មេរៀនទី ៦) ១១៣

មេរៀនទី ៣១ ម៉ាថាយ ២៦:៣១-៧៥ . . . . ១១៥
មេរៀនទី ៣២ ម៉ាថាយ ២៧:១-៥០ . . . . ១១៨
មេរៀនទី ៣៣ ម៉ាថាយ ២៧:៥១–២៨:២០ . . . . ១២១
សេចក្តីណែនាំស្តីពីដំណឹងល្អយោងតាមម៉ាកុស ១២៤
មេរៀនទី ៣៤ ម៉ាកុស ១ . . . . ១២៥
មេរៀនទី ៣៥ ម៉ាកុស ២-៣ . . . . ១២៨
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាថាយ ២៦:៣១- ម៉ាកុស ៣:៣៥ (មេរៀនទី ៧) ១៣២

មេរៀនទី ៣៦ ម៉ាកុស ៤-៥ . . . . ១៣៤
មេរៀនទី ៣៧ ម៉ាកុស ៦ . . . . ១៣៨
មេរៀនទី ៣៨ ម៉ាកុស ៧-៨ . . . . ១៤២
មេរៀនទី ៣៩ ម៉ាកុស ៩:១-២៩ . . . . ១៤៥
មេរៀនទី ៤០ ម៉ាកុស ៩:៣០-៥០ . . . . ១៤៨
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាកុស ៤-៩ (មេរៀនទី ៨) ១៥១

មេរៀនទី ៤១ ម៉ាកុស ១០ . . . . ១៥៣
មេរៀនទី ៤២ ម៉ាកុស ១១-១៦ . . . . ១៥៧
សេចក្តីណែនាំស្តីពីដំណឹងល្អយោងតាមលូកា ១៦០
មេរៀនទី ៤៣ លូកា ១ . . . . ១៦១
មេរៀនទី ៤៤ លូកា ២ . . . . ១៦៨
មេរៀនទី ៤៥ លូកា ៣-៤ . . . . ១៦៤
មេរៀនសិក្សានៅផ្ទះ: ៖ ម៉ាកុស ១០–លូកា ៤ (មេរៀនទី ៩) ១៧១

មេរៀនទី ៤៦ លូកា ៥ . . . . ១៧៣
មេរៀនទី ៤៧ លូកា ៦:១–៧:១៨ . . . . ១៧៦
មេរៀនទី ៤៨ លូកា ៧:១៨-៥០ . . . . ១៧៩
មេរៀនទី ៤៩ លូកា ៨-៩ . . . . ១៨៣
មេរៀនទី ៥០ លូកា ១០:១-៣៧ . . . . ១៨៦
មេរៀនសិក្សានៅផ្ទះ: ៖ លូកា ៥:១-១០:៣៧ (មេរៀនទី ១០) ១៨៩

មេរៀនទី ៥១ លូកា ១០:៣៨-១២:៥៩ . . . . ១៩១
មេរៀនទី ៥២ លូកា ១៣-១៤ . . . . ១៩៤
មេរៀនទី ៥៣ លូកា ១៥ . . . . ១៩៧
មេរៀនទី ៥៤ លូកា ១៦ . . . . ២០១
មេរៀនទី ៥៥ លូកា ១៧ . . . . ២០៤
មេរៀនសិក្សានៅផ្ទះ: ៖ លូកា ១០:៣៨–១៧:៣៧ (មេរៀនទី ១១) ២០៧

មេរៀនទី ៥៦ លូកា ១៨-២១ . . . . ២០៩
មេរៀនទី ៥៧ លូកា ២២ . . . . ២១១
មេរៀនទី ៥៨ លូកា ២៣ . . . . ២១៤
មេរៀនទី ៥៩ លូកា ២៤ . . . . ២១៧
សេចក្តីណែនាំស្តីពីដំណឹងល្អយោងតាមយ៉ូហាន ២២០
មេរៀនទី ៦០ យ៉ូហាន ១ . . . . ២២១
មេរៀនសិក្សានៅផ្ទះ: ៖ លូកា ១៨–យ៉ូហាន ១ (មេរៀនទី ១២) ២២៤

មេរៀនទី ៦១ យ៉ូហាន ២ . . . . ២២៦
មេរៀនទី ៦២ យ៉ូហាន ៣ . . . . ២២៩
មេរៀនទី ៦៣ យ៉ូហាន ៤ . . . . ២៣២
មេរៀនទី ៦៤ យ៉ូហាន ៥ . . . . ២៣៦
មេរៀនទី ៦៥ យ៉ូហាន ៦ . . . . ២៣៩
មេរៀនសិក្សានៅផ្ទះ: ៖ យ៉ូហាន ២-៦ (មេរៀនទី ១៣) ២៤៣

មេរៀនទី ៦៦ យ៉ូហាន ៧ . . . . ២៤៥
មេរៀនទី ៦៧ យ៉ូហាន ៨:១-៣០ . . . . ២៤៨

មេរៀនទី ៦៨ យ៉ូហាន ៨:៣១-៥៩ ..... ២៥១
មេរៀនទី ៦៩ យ៉ូហាន ៩ ..... ២៥៤
មេរៀនទី ៧០ យ៉ូហាន ១០ ..... ២៥៧
មេរៀនសិក្សានៅផ្ទះ ៖ យ៉ូហាន ៧-១០ (មេរៀនទី ១៤) ២៦០

មេរៀនទី ៧១ យ៉ូហាន ១១ ..... ២៦២
មេរៀនទី ៧២ យ៉ូហាន ១២ ..... ២៦៥
មេរៀនទី ៧៣ យ៉ូហាន ១៣ ..... ២៦៨
មេរៀនទី ៧៤ យ៉ូហាន ១៤ ..... ២៧១
មេរៀនទី ៧៥ យ៉ូហាន ១៥ ..... ២៧៨
មេរៀនសិក្សានៅផ្ទះ ៖ យ៉ូហាន ១១-១៥ (មេរៀនទី ១៥) ២៧៨

មេរៀនទី ៧៦ យ៉ូហាន ១៦ ..... ២៨០
មេរៀនទី ៧៧ យ៉ូហាន ១៧ ..... ២៨៣
មេរៀនទី ៧៨ យ៉ូហាន ១៨-១៩ ..... ២៨៦
មេរៀនទី ៧៩ យ៉ូហាន ២០ ..... ២៨៩
មេរៀនទី ៨០ យ៉ូហាន ២១ ..... ២៩២
មេរៀនសិក្សានៅផ្ទះ ៖ យ៉ូហាន ១៦-២១ (មេរៀនទី ១៦) ២៩៥

សេចក្តីណែនាំស្តីពីកិច្ចការរបស់ពួកសាវក ២៩៧
មេរៀនទី ៨១ កិច្ចការ ១:១-៨ ..... ២៩៨
មេរៀនទី ៨២ កិច្ចការ ១:៩-២៦ ..... ៣០១
មេរៀនទី ៨៣ កិច្ចការ ២ ..... ៣០៤
មេរៀនទី ៨៤ កិច្ចការ ៣ ..... ៣០៧
មេរៀនទី ៨៥ កិច្ចការ ៤-៥ ..... ៣១០
មេរៀនសិក្សានៅផ្ទះ ៖ កិច្ចការ ១-៥ (មេរៀនទី ១៧) ៣១៣

មេរៀនទី ៨៦ កិច្ចការ ៦-៧ ..... ៣១៥
មេរៀនទី ៨៧ កិច្ចការ ៨ ..... ៣១៩
មេរៀនទី ៨៨ កិច្ចការ ៩ ..... ៣២២
មេរៀនទី ៨៩ កិច្ចការ ១០-១១ ..... ៣២៦
មេរៀនទី ៩០ កិច្ចការ ១២ ..... ៣៣០
មេរៀនសិក្សានៅផ្ទះ ៖ កិច្ចការ ៦-១២ (មេរៀនទី ១៨) ៣៣៣

មេរៀនទី ៩១ កិច្ចការ ១៣-១៤ ..... ៣៣៥
មេរៀនទី ៩២ កិច្ចការ ១៥ ..... ៣៣៨
មេរៀនទី ៩៣ កិច្ចការ ១៦ ..... ៣៤១
មេរៀនទី ៩៤ កិច្ចការ ១៧ ..... ៣៤៤
មេរៀនទី ៩៥ កិច្ចការ ១៨-១៩ ..... ៣៤៧
មេរៀនសិក្សានៅផ្ទះ ៖ កិច្ចការ ១៣-១៩ (មេរៀនទី ១៩) ៣៥០

មេរៀនទី ៩៦ កិច្ចការ ២០-២២ ..... ៣៥២
មេរៀនទី ៩៧ កិច្ចការ ២៣-២៦ ..... ៣៥៥
មេរៀនទី ៩៨ កិច្ចការ ២៧-២៨ ..... ៣៥៨
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ពួករ៉ូម ៣៦១
មេរៀនទី ៩៩ រ៉ូម ១–៣ ..... ៣៦៦
មេរៀនទី ១០០ រ៉ូម ៤-៧ ..... ៣៦៦
មេរៀនសិក្សានៅផ្ទះ ៖ កិច្ចការ ២០–រ៉ូម ៧ (មេរៀនទី ២០) ៣៧០

មេរៀនទី ១០១ រ៉ូម ៨-១១ ..... ៣៧២
មេរៀនទី ១០២ រ៉ូម ១២-១៦ ..... ៣៧៥
សេចក្តីណែនាំស្តីពីសំបុត្រទីមួយរបស់ប៉ុលដល់ពួកកូរិនថូស ៣៧៨
មេរៀនទី ១០៣ កូរិនថូសទី១ ១–២ ..... ៣៧៩
មេរៀនទី ១០៤ កូរិនថូស ទី១ ៣-៤ ..... ៣៨២
មេរៀនទី ១០៥ កូរិនថូស ទី១ ៥-៦ ..... ៣៨៥
មេរៀនសិក្សានៅផ្ទះ ៖ រ៉ូម ៨–កូរិនថូស ទី១ ៦ (មេរៀនទី ២១) ៣៨៩

មេរៀនទី ១០៦ កូរិនថូសទី១ ៧-៨ ..... ៣៩១
មេរៀនទី ១០៧ កូរិនថូស ទី១ ៩-១០ ..... ៣៩៤
មេរៀនទី ១០៨ កូរិនថូស ទី១ ១១ ..... ៣៩៧

មេរៀនទី ១០៩ កូរិនថូស ទី១ ១២ ..... ៤០០
មេរៀនទី ១១០ កូរិនថូស ទី១ ១៣-១៤ ..... ៤០៣
មេរៀនសិក្សានៅផ្ទះ ៖ កូរិនថូស ទី១ ៧-១៤ (មេរៀនទី ២២) ៤០៧

មេរៀនទី ១១១ កូរិនថូស ទី១ ១៥:១–២៩ ..... ៤០៩
មេរៀនទី ១១២ កូរិនថូសទី១ ១៥:៣០–១៦:២៤ ..... ៤១២
សេចក្តីណែនាំស្តីពីសំបុត្រទីពីររបស់ប៉ុលដល់ពួកកូរិនថូស ៤១៦
មេរៀនទី ១១៣ កូរិនថូស ទី២ ១-៣ ..... ៤១៧
មេរៀនទី ១១៤ កូរិនថូស ទី២ ៤-៥ ..... ៤២០
មេរៀនទី ១១៥ កូរិនថូស ទី២ ៦-៧ ..... ៤២៣
មេរៀនសិក្សានៅផ្ទះ ៖ កូរិនថូស ទី១ ១៥–កូរិនថូស ទី២ ៧ (មេរៀនទី ២៣) ៤២៧

មេរៀនទី ១១៦ កូរិនថូស ទី២ ៨-៩ ..... ៤២៩
មេរៀនទី ១១៧ កូរិនថូសទី២ ១០–១៣ ..... ៤៣២
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ពួកកាឡាទី ៤៣៦
មេរៀនទី ១១៨ កាឡាទី ១-៤ ..... ៤៣៧
មេរៀនទី ១១៩ កាឡាទី ៥-៦ ..... ៤៣៩
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ពួកអេភេសូរ ៤៤២
មេរៀនទី ១២០ អេភេសូរ ១ ..... ៤៤៣
មេរៀនសិក្សានៅផ្ទះ ៖ កូរិនថូស ទី២ ៨—អេភេសូរ ១ (មេរៀនទី ២៤) ៤៤៦

មេរៀនទី ១២១ អេភេសូរ ២–៣ ..... ៤៤៨
មេរៀនទី ១២២ អេភេសូរ ៤ ..... ៤៥១
មេរៀនទី ១២៣ អេភេសូរ ៥–៦ ..... ៤៥៤
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ពួកភីលីព ៤៥៨
មេរៀនទី ១២៤ ភីលីព ១-៣ ..... ៤៥៩
មេរៀនទី ១២៥ ភីលីព ៤ ..... ៤៦៣
មេរៀនសិក្សានៅផ្ទះ ៖ អេភេសូរ ២–ភីលីព ៤ (មេរៀនទី ២៥) ៤៦៧

សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ពួកកូឡុស ៤៦៩
មេរៀនទី ១២៦ កូឡុស ៤៧០
សេចក្តីណែនាំស្តីពីសំបុត្រទីមួយរបស់ប៉ុលដល់ពួកថែស្សាឡូនីច ៤៧២
មេរៀនទី ១២៧ ថែស្សាឡូនីច ទី១ ១-២ ..... ៤៧៣
មេរៀនទី ១២៨ ថែស្សាឡូនីច ទី១ ៣-៥ ..... ៤៧៥
សេចក្តីណែនាំស្តីពីសំបុត្រទីពីររបស់ប៉ុលដល់ពួកថែស្សាឡូនីច ៤៧៩
មេរៀនទី ១២៩ ថែស្សាឡូនីច ទី២ ..... ៤៨០
សេចក្តីណែនាំស្តីពីសំបុត្រទីមួយរបស់ប៉ុលដល់ពួកធីម៉ូថេ ៤៨៣
មេរៀនទី ១៣០ ធីម៉ូថេ ទី១ ..... ៤៨៤
មេរៀនសិក្សានៅផ្ទះ ៖ កូឡុស–ធីម៉ូថេ ទី១ (មេរៀនទី ២៦) ៤៨៧

សេចក្តីណែនាំស្តីពីសំបុត្រទីពីររបស់ប៉ុលដល់ពួកធីម៉ូថេ ៤៨៩
មេរៀនទី ១៣១ ធីម៉ូថេ ទី២ ១-២ ..... ៤៩០
មេរៀនទី ១៣២ ធីម៉ូថេ ទី២ ៣-៤ ..... ៤៩៤
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ទីតុស ៤៩៨
មេរៀនទី ១៣៣ ទីតុស ៥០២
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ភីលេម៉ូន ៥០៦
មេរៀនទី ១៣៤ ភីលេម៉ូន ៥០៣
សេចក្តីណែនាំស្តីពីសំបុត្ររបស់ប៉ុលដល់ពួកហេព្រើរ ៥២៤
មេរៀនទី ១៣៥ ហេព្រើរ ១-៤ ..... ៥០៧
មេរៀនសិក្សានៅផ្ទះ ៖ ធីម៉ូថេ ទី២ ១–ហេព្រើរ ៤ (មេរៀនទី ២៧) ៥១០

មេរៀនទី ១៣៦ ហេព្រើរ ៥-៦ ..... ៥១២
មេរៀនទី ១៣៧ ហេព្រើរ ៧-១០ ..... ៥១៥
មេរៀនទី ១៣៨ ហេព្រើរ ១១ ..... ៥១៨
មេរៀនទី ១៣៩ ហេព្រើរ ១២-១៣ ..... ៥២១
សេចក្តីណែនាំស្តីពីសំបុត្រទូទៅរបស់យ៉ាកុប ៥២៤
មេរៀនទី ១៤០ យ៉ាកុប ១ ..... ៥២៥
មេរៀនសិក្សានៅផ្ទះ ៖ ហេព្រើរ ៥–យ៉ាកុប ១ (មេរៀនទី ២៨) ៥២៨

មេរៀនទី ១៤១ យ៉ាកុប ២ ..... ៥៣០
មេរៀនទី ១៤២ យ៉ាកុប ៣ ..... ៥៣៣
មេរៀនទី ១៤៣ យ៉ាកុប ៤-៥ ..... ៥៣៥
សេចក្តីណែនាំស្តីពីសំបុត្រទូទៅទីមួយរបស់ពេត្រុស ៥៣៨
មេរៀនទី ១៤៤ ពេត្រុស ទី១ ១-២ ..... ៥៣៩
មេរៀនទី ១៤៥ ពេត្រុស ទី១ ៣-៥ ..... ៥៤២
មេរៀនសិក្សានៅផ្ទះ ៖ យ៉ាកុប ២-ពេត្រុស ទី១ ៥ (មេរៀនទី ២៩) ៥៤៥

សេចក្តីណែនាំស្តីពីសំបុត្រទូទៅទីពីររបស់ពេត្រុស ៥៤៧
មេរៀនទី ១៤៦ ពេត្រុស ទី២ ១ ..... ៥៤៨
មេរៀនទី ១៤៧ ពេត្រុស ទី២ ២-៣ ..... ៥៥១
សេចក្តីណែនាំស្តីពីសំបុត្រទូទៅទីមួយរបស់យ៉ូហាន ៥៥៤
មេរៀនទី ១៤៨ យ៉ូហាន ទី១ ..... ៥៥៥
សេចក្តីណែនាំស្តីពីសំបុត្រទូទៅទីពីររបស់យ៉ូហាន ៥៥៨
សេចក្តីណែនាំស្តីពីសំបុត្រទូទៅទីបីរបស់យ៉ូហាន ៥៥៨
មេរៀនទី ១៤៩ យ៉ូហាន ២–យ៉ូហាន ៣ ..... ៥៥៩
សេចក្តីណែនាំស្តីពីសំបុត្រទូទៅរបស់យូដាស ៥៦១
មេរៀនទី ១៥០ យូដាស ៥៦២
មេរៀនសិក្សានៅផ្ទះ ៖ ពេត្រុស ទី២–យូដាស (មេរៀនទី ៣០) ៥៦៦

សេចក្តីណែនាំស្តីពីវិវរណៈរបស់យ៉ូហានដ៏បរិសុទ្ធ ៥៦៨
មេរៀនទី ១៥១ វិវរណៈ ១ ..... ៥៦៩
មេរៀនទី ១៥២ វិវរណៈ ២-៣ ..... ៥៧៣
មេរៀនទី ១៥៣ វិវរណៈ ៤-៥ ..... ៥៧៧
មេរៀនទី ១៥៤ វិវរណៈ ៦–១១ ភាគ ១ ..... ៥៨១
មេរៀនទី ១៥៥ វិវរណៈ ៦–១១ ភាគ ២ ..... ៥៨៥
មេរៀនសិក្សានៅផ្ទះ ៖ វិវរណៈ ១-១១ (មេរៀនទី ៣១) ៥៨៨

មេរៀនទី ១៥៦ វិវរណៈ ១២-១៣ ..... ៥៩០
មេរៀនទី ១៥៧ វិវរណៈ ១៤-១៦ ..... ៥៩៣
មេរៀនទី ១៥៨ វិវរណៈ ១៧-១៩ ..... ៥៩៦
មេរៀនទី ១៥៩ វិវរណៈ ២០ ..... ៥៩៩
មេរៀនទី ១៦០ វិវរណៈ ២១-២២ ..... ៦០១
មេរៀនសិក្សានៅផ្ទះ ៖ វិវរណៈ ១២-២២ (មេរៀនទី ៣២) ៦០៤

សេចក្តីបន្ថែម ៦០៧
តារាងការអានព្រះគម្ពីរ ៦០៧
ការណែនាំល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ ៦០៨
យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន ៦១០
ការណែនាំល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនមេរៀននៅផ្ទះ ៦១១
សេចក្តីណែនាំស្តីពីចំណេះចំណាននខគម្ពីរ ៦១៣
សកម្មភាពចំណេះចំណាននខគម្ពីរ ៦១៥
វគ្គចំណេះចំណាននខគម្ពីរទាំង ១០០ ..... ៦១៩
សេចក្តីណែនាំស្តីពីគោលលទ្ធិគ្រិះ ៦២០
គោលលទ្ធិគ្រិះ ៦២១
ការបង្រៀនដំណឹងល្អឲ្យមានការចុះសម្រុងគ្នា ៦២៥
ការងារបម្រើនៅក្នុងជីវិតរមែងស្លាប់សំខាន់ៗនៃព្រះយេស៊ូវគ្រីស្ទ ៦២៦
រូបភាពដៃលបានជ្រើសរើសសម្រាប់ព្រះគម្ពីរសញ្ញាថ្មី ៦២៨

សេចក្តីណែនាំស្តីពី ព្រះគម្ពីរសញ្ញាថ្មី សៀវភៅសិក្សាសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា

គោលបំណងរបស់យើង

គោលបំណងរបស់ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនាចែងថា ៖

« គោលបំណងរបស់យើង គឺដើម្បីជួយយុវវ័យ និងយុវមជ្ឈិមវ័យទាំងឡាយឲ្យយល់ និងពឹងផ្អែកលើការបង្រៀនទាំងនេះ និងលើជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ឲ្យមានភាពសក្តិសមសម្រាប់ពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួនពួកគេ ក្រុមគ្រួសារពួកគេ និងអ្នកដទៃទៀត សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ចជាមួយនឹងព្រះវរបិតារបស់ពួកគេដែលគង់នៅឋានសួគ៌ » (*ការបង្រៀន និងការរៀនសូត្រដ៏ឈ្លាស ៖ ក្បួនខ្នាតសម្រាប់គ្រូបង្រៀន និងថ្នាក់ដឹកនាំនៅក្នុងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា* [ឆ្នាំ ២០១២] ទំព័រ ១) ។

ដើម្បីសម្រេចបាននូវគោលលទ្ធបំណងរបស់យើង នោះយើងបង្រៀនសិស្សអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ដូចដែលមាននៅក្នុងព្រះគម្ពីរ និង ពាក្យសម្តីរបស់ព្យាការីទាំងឡាយ ។ គោលលទ្ធិ និង គោលការណ៍ទាំងនេះគឺត្រូវបានបង្រៀនតាមរបៀបមួយ ដែលដឹកនាំឲ្យមានការយល់ដឹង និង ការស្អាងឡើង ។ យើងជួយសិស្សទាំងឡាយឲ្យបំពេញតួនាទីរបស់ពួកគេ នៅក្នុងដំណើរការនៃការរៀនសូត្រ និង រៀបចំពួកគេឲ្យបង្រៀនដំណឹងល្អដល់អ្នកដទៃទៀត ។

ដើម្បីសម្រេចបានគោលបំណងទាំងនេះ នោះអ្នក និង សិស្សដែលអ្នកបង្រៀនត្រូវបានលើកទឹកចិត្តឲ្យសហការគ្នាធ្វើតាម មូលដ្ឋានគ្រឹះនៃការបង្រៀន និង ការរៀនដំណឹងល្អ នៅពេលអ្នកសិក្សាព្រះគម្ពីររួមគ្នាដូចខាងក្រោម ៖

« •បង្រៀន និង រៀនសូត្រដោយព្រះវិញ្ញាណ ។

« •បង្កើតបរិយាកាសរៀនសូត្រ ដែលពោរពេញដោយសេចក្តីស្រឡាញ់ ការគោរព និង មានគោលបំណង ។

« •សិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ និង អានមេរៀននៃវគ្គសិក្សា ។ [តារាងសម្រាប់តាមដានការអានព្រះគម្ពីរនៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូល អាចមាននៅជាមួយនឹង ប័ណ្ណចំណេះចំណានខគម្ពីរព្រះគម្ពីរសញ្ញាថ្មី នៅលើ LDS.org និងនៅលើ store.lds.org (ទំនិញ ល.រ. ១០៤៨០)] ។

« •យល់អំពីបរិបទ និង មាតិកានៃព្រះគម្ពីរ ព្រមទាំងពាក្យសម្តីរបស់ព្យាការីទាំងឡាយ ។

« •ស្វែងរក យល់ ដឹងអំពីសេចក្តីពិត និង សារៈសំខាន់នៃដំណឹងល្អ ហើយអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។

« •ពន្យល់ ចែកចាយ និង ថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។

« •រៀនឲ្យស្ទាត់អំពីវគ្គបទគម្ពីរសំខាន់ៗ និងគោលលទ្ធិគ្រឹះ » (*Gospel Teaching and Learning* ទំព័រ ១០) ។

បន្ថែមទៅលើការសម្រេចគោលបំណងទាំងនេះ អ្នកត្រូវតែជួយសិស្សឲ្យស្មោះត្រង់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយរៀនញែកដឹងសេចក្តីពិតចេញពីកំហុស ។ សិស្សអាចមានសំណួរអំពីគោលលទ្ធិ ប្រវត្តិសាស្ត្រ ឬគោលជំហរលើបញ្ហាសង្គមរបស់សាសនាចក្រ ។ អ្នកអាចរៀបចំសិស្សឲ្យលើកសំណួរបែបនេះឡើងដោយជួយពួកគេឲ្យ « ស្វែងរកការរៀនសូត្រ គឺដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង » (គ. និង ស. ៨៨:១១៨) និងដោយប្រើធនធាននានានៅក្នុងផ្នែក ស្វែងរកសេចក្តីពិត នៃ si.lds.org ។

សៀវភៅណែនាំសម្រាប់គ្រូបង្រៀននេះត្រូវបានរៀបចំឡើងដើម្បីជួយដល់អ្នកឲ្យទទួលបានជោគជ័យក្នុងការសម្រេចនូវគោលបំណងទាំងនេះ ។

ការរៀបចំមេរៀន

ព្រះអម្ចាស់បានបញ្ជាដល់អស់អ្នកដែលបង្រៀនដំណឹងល្អរបស់ទ្រង់ឲ្យ « បង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរបើប និង ព្រះគម្ពីរមរមន គឺជាភាពពោរពេញនៃដំណឹងល្អ » (គ. និង ស. ៤២:១២) ។ ទ្រង់បានត្រាស់បង្គាប់បន្ថែមទៀតថា សេចក្តីពិតទាំងនេះគួរតែត្រូវបានបង្រៀនដូចដែល « ត្រូវបានដឹកនាំពីព្រះវិញ្ញាណ » ដែល « ត្រូវបានប្រទានដល់អ្នក . . . ដោយពាក្យអធិស្ឋាននៃសេចក្តីជំនឿ » (គ. និង ស. ៤២:១៣–១៤) ។ នៅពេលរៀបចំមេរៀននីមួយៗ សូមអធិស្ឋានស្វែងរកការដឹកនាំពីព្រះវិញ្ញាណ ដើម្បីជួយអ្នកឲ្យយល់ពីព្រះគម្ពីរ និងគោលលទ្ធិ ព្រមទាំងគោលការណ៍នានាដែលមាននៅក្នុងព្រះគម្ពីរ ។ ដូចគ្នានេះដែរ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ នៅពេលអ្នកដាក់ផែនការអំពីរបៀបជួយសិស្សឲ្យយល់អំពីបទគម្ពីរ រៀនទទួលការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ហើយមានឆន្ទៈដើម្បីអនុវត្តអ្វីដែលពួកគេរៀន ។

នៅក្នុងវគ្គសិក្សានេះ ព្រះគម្ពីរសញ្ញាថ្មីគឺជាអត្ថបទចម្បងរបស់អ្នក នៅពេលអ្នករៀបចំ និងបង្រៀន ។ សូមសិក្សាជំពូកឬខគម្ពីរនានាដែលអ្នកនឹងបង្រៀនដោយការអធិស្ឋាន ។ សូមព្យាយាមយល់ពីបរិបទ និង មាតិកានៃបណ្តុំបទគម្ពីរ រួមទាំងខ្សែរឿងមនុស្ស ទីកន្លែង និងព្រឹត្តិការណ៍នានា ។ នៅពេលអ្នកកាន់តែស្គាល់បរិបទ និង មាតិកានៃបណ្តុំបទគម្ពីរ នោះសូមព្យាយាមស្វែងរកគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងខគម្ពីរនោះ ហើយសម្រេចចិត្តថាសេចក្តីពិតណាមួយដែលសំខាន់សម្រាប់សិស្សរបស់អ្នកដើម្បីយល់ ហើយអនុវត្តវានោះ ។ កាលណាអ្នកបានរកឃើញអ្វី ដែលអ្នកផ្តោតយកចិត្តទុកដាក់ហើយនោះ សូមកំណត់អំពីវិធីសាស្ត្រ យុទ្ធសាស្ត្រ និង សកម្មភាពណាមួយដែលនឹងជួយសិស្សរបស់អ្នកបានល្អបំផុតឲ្យរៀន និង អនុវត្តសេចក្តីពិតដ៏ពិសិដ្ឋដែលមាននៅក្នុងព្រះគម្ពីរនេះ ។

សៀវភៅសិក្សានេះត្រូវបានរៀបចំឡើង ដើម្បីជួយអ្នកក្នុងដំណើរការនេះ ។ សូមព្យាយាមរៀនដោយយកចិត្តទុកដាក់ ឲ្យស្របទៅនឹងបណ្តុំបទគម្ពីរដែលអ្នកនឹងបង្រៀន ។ អ្នកអាចជ្រើសប្រើប្រាស់យោបល់ណែនាំទាំងអស់ ឬមួយចំនួនសម្រាប់បណ្តុំបទគម្ពីរ ឬ អ្នកអាចសម្របសម្រួលទៅតាមតំនិត ដែលបានណែនាំទៅតាមតម្រូវការ និង ស្ថានភាពសិស្សដែលអ្នកបង្រៀន ។

វាសំខាន់ថា អ្នកជួយសិស្សឲ្យសិក្សាបណ្តុំបទគម្ពីរទាំងមូលនៅក្នុងមេរៀននីមួយៗ ។ ការធ្វើដូច្នេះនឹងជួយសិស្សឲ្យចាប់យកសារលិខិតពេញលេញ ដែលអ្នកសរសេរព្រះគម្ពីរមានបំណងចង់បង្ហាញ ។ ប៉ុន្តែ នៅពេលអ្នករៀបចំមេរៀនរបស់ខ្លួន អ្នកអាចរកឃើញថា អ្នកពុំមានពេលគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀនដើម្បីប្រើគ្រប់អស់ទាំងយោបល់នៃការបង្រៀននៅក្នុងសៀវភៅសិក្សានេះឡើយ ។ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណ ហើយពិចារណាដោយការអធិស្ឋានអំពីតម្រូវការនៃសិស្សរបស់អ្នកនៅពេលអ្នកសម្រេចចិត្តដើម្បីបញ្ចាក់អត្ថន័យលើផ្នែកណាមួយនៃបណ្តុំបទគម្ពីរ ដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍នៃសេចក្តីពិត និង សារៈសំខាន់របស់សេចក្តីពិតនៃដំណឹងល្អ ហើយអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។ ប្រសិនបើពេលវេលាខ្លី អ្នកត្រូវតែសម្របសម្រួលផ្នែកដទៃទៀតនៃមេរៀន ដោយសង្កេបក្រុមខគម្ពីរនោះឲ្យខ្លី ឬ តាមរយៈការនាំសិស្សឲ្យរកឃើញគោលការណ៍ ឬ គោលលទ្ធិមួយយ៉ាងលឿន ពីមុនបន្តទៅក្រុមខគម្ពីរបន្ទាប់ទៀត ។

នៅពេលអ្នកពិចារណាអំពីរបៀបដើម្បីសម្របសម្រួលមេរៀន សូមប្រាកដថាបានធ្វើតាមការប្រឹក្សានេះ ពីអែលឌើរ ដាល្លិន អេក អូក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ខ្ញុំស្តាប់ឮប្រធាន ឌាកកឺ លោកបានបង្រៀនជាញឹកញាប់ថា ជំបូងយើងត្រូវទទួលយក បន្ទាប់មកសម្របតាមវា ។ ប្រសិនបើយើងគ្រោងលើកយកមេរៀនដែលមាននៅក្នុងសៀវភៅ ដោយយកចិត្តទុកដាក់មុននឹងយើងបង្រៀន នោះយើងអាចធ្វើតាមព្រះវិញ្ញាណដើម្បីសម្របសម្រួលតាមវាបាន » (« 4.3.4 Decide through Inspiration » ដកស្រង់មកពី « A Panel Discussion with Elder Dallin H. Oaks » [Seminaries and Institutes of Religion satellite broadcast ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១២] LDS.org) ។

នៅពេលអ្នករៀបចំបង្រៀន សូមនឹកគិតដល់សិស្សដែលមានតម្រូវការជាពិសេសផង ។ សូមសម្របសម្រួលសកម្មភាពនានា និងការពឹងទុកទាំងឡាយដើម្បីជួយសិស្សឲ្យទទួលបានជោគជ័យ ។ ទំនាក់ទំនងជាមួយនឹងឪពុកម្តាយ និង អ្នកដឹកនាំដែលនឹងជួយអ្នកឲ្យដឹងអំពីតម្រូវការរបស់សិស្ស ហើយជួយអ្នកឲ្យបានជោគជ័យ ក្នុងការផ្តល់នូវបទពិសោធន៍ដ៏មានន័យសម្រាប់សិស្ស ។

អំឡុងពេលនៃការរៀបចំមេរៀនរបស់អ្នក អ្នកអាចជ្រើសរើសប្រើប្រាស់ឧបករណ៍កំណត់ចំណាំ និង សៀវភៅកំណត់ហេតុនៅលើគេហទំព័រ LDS.org ឬ នៅក្នុង Gospel Library សម្រាប់ឧបករណ៍ចល័តរបស់អ្នក ។ អ្នកអាចប្រើប្រាស់ឧបករណ៍ទាំងនេះដើម្បីគូសចំណាំព្រះគម្ពីរ សន្ទនាកថាសន្និសីទ អត្ថបទឧទ្ទេសនាវដ្តីនៃសាសនាចក្រ និង មេរៀននានា ។ អ្នកអាចបន្ថែម ឬ ក្សាទុកកំណត់ចំណាំនោះសម្រាប់ប្រើវាអំឡុងពេលអ្នកបង្រៀន ។ ដើម្បីរៀនបន្ថែមអំពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនេះ សូមមើល Notes and Journal Help នៅគេហទំព័រ LDS.org ។

សម្ភារមួយចំនួននៅក្នុងសៀវភៅសិក្សានេះបានប្រែសម្រួលមកពី New Testament Student Manual (Church Educational System Manual ឆ្នាំ ២០១៤) ។



ការប្រើសៀវភៅសិក្សាសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ

សេចក្តីផ្តើមនៃគម្ពីរ

សេចក្តីផ្តើមនៃគម្ពីរផ្តល់នូវទិដ្ឋភាពទូទៅនៃគម្ពីរនីមួយៗ ។ នៅក្នុងចំណោមរឿងផ្សេងទៀត វាពន្យល់ថា គម្ពីរនីមួយៗបានសរសេរឡើងដោយនរណា រៀបរាប់អំពីលក្ខណៈខុសប្លែកគ្នានៃគម្ពីរនីមួយៗ ហើយផ្តល់នូវសេចក្តីសង្ខេបមួយស្តីពីមាតិកានៃគម្ពីរនីមួយៗ ។

សេចក្តីណែនាំនៃបណ្តុំបទគម្ពីរ

សេចក្តីណែនាំនៃបណ្តុំបទគម្ពីរផ្តល់នូវទិដ្ឋភាពទូទៅដ៏ខ្លីមួយនៃបរិបទ និង មាតិកានៃបណ្តុំបទគម្ពីរសម្រាប់មេរៀននីមួយៗ ។

សេចក្តីសង្ខេបនៃក្រុមខគម្ពីរ និងបរិបទ

ជាញឹកញាប់ បណ្តុំបទគម្ពីរត្រូវបានបែងចែកចេញទៅជាវគ្គតូចៗ ឬ ក្រុមខគម្ពីរដែលផ្តោតលើប្រធានបទ ឬ សកម្មភាពជាក់លាក់មួយ ។ សេចក្តីយោងនៃក្រុមខគម្ពីរនីមួយៗ ត្រូវបានបន្តដោយសេចក្តីសង្ខេបខ្លីនៃហេតុការណ៍ ឬការបង្រៀននៅក្នុងក្រុមខគម្ពីរនោះ ។

ជំនួយក្នុងការបង្រៀន

ជំនួយក្នុងការបង្រៀននឹងពន្យល់អំពីគោលការណ៍ និង វិធីបង្រៀនដ៏ណែ្ល ។ វាអាចជួយអ្នកនៅក្នុងការខិតខំ ដើម្បីកែលម្អក្នុងនាមជាគ្រូបង្រៀនម្នាក់ ។

គួរសេចក្តីនៃមេរៀន

គួរសេចក្តីនៃមេរៀនមានសេចក្តីណែនាំសម្រាប់អ្នកនៅពេលអ្នកសិក្សា និង បង្រៀន ។ វាផ្តល់គំនិតបង្រៀន រួមមានសំណួរ សកម្មភាព ការដេកស្រង់ដ្យាក្រាម និង តារាងនានា ។

គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

នៅពេលគោលលទ្ធិ និងគោលការណ៍ទាំងឡាយលេចឡើងនៅក្នុងការសិក្សាអត្ថបទព្រះគម្ពីរ នោះវាត្រូវបានគូសបញ្ជាក់ជាអក្សរខ្មៅដិត ដើម្បីជួយអ្នកឲ្យរកឃើញ និងផ្តោតយកចិត្តទុកដាក់លើវានៅក្នុងការពិភាក្សារបស់អ្នកជាមួយសិស្ស ។

រូបភាព

រូបភាពនៃអ្នកដឹកនាំសាសនាចក្រ និង ព្រឹត្តិការណ៍នានាអំពីព្រះគម្ពីរ តំណាងឲ្យជំនួយចក្ខុវិស័យដែលអ្នកអាចបង្ហាញ ប្រសិនបើវាមាននៅពេលអ្នកបង្រៀន ។



សេចក្តីណែនាំ

ទៅកាន់ដំណឹងល្អស្របតាមលូកា

ហេតុអ្វី ត្រូវសិក្សាគម្ពីរនេះ ?


នៅទូទាំងអាណាចក្រុម ។ មនុស្សជាច្រើនបានជឿថា ម៉ាកុស ប្រហែលជាបាននៅជាមួយពេត្រុសនៅក្នុងទីក្រុងរ៉ូម អំឡុងក្រមួយដែលបានប៉ះទង្គិចទៅដោយការសាកល្បងដ៏ខ្ទេចខ្ទីទៅលើសេចក្តីជំនឿសមាជិកនៃសាសនាចក្រប្រកាន់ខ្ជាប់តាមពេញអាណាចក្រុម ។

មួយភាគបីនៃដំណើររឿងក្នុងដំណឹងល្អរបស់ ម៉ាកុស រៀបរាប់អំពីការបង្រៀន និង បទពិសោធន៍ទាំងឡាយរបស់ព្រះអង្គសង្គ្រោះ អំឡុងសប្តាហ៍ចុងក្រោយនៃជីវិតរបស់ទ្រង់ ។ ម៉ាកុស បានថ្លែងជាសាក្សីថាទ្រង់ជាព្រះបុត្រានៃព្រះ បានយកឈ្នះលើអំពើអាក្រក់ អំពើបាប និង សេចក្តីស្លាប់ ។ ទីបន្ទាល់នេះ មានន័យថា អ្នកដើរតាមព្រះអង្គសង្គ្រោះទាំងឡាយពុំចាំបាច់ភ័យខ្លាចឡើយ នៅពេលពួកគេប្រឈមមុខនឹងការបៀតបៀន

គម្រោង

ម៉ាកុស ១-៤ ព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹកដោយ យ៉ូហាន បាទីស្ទ ហើយបានចាប់ផ្តើមការផ្សាយ ការហៅពួកសិស្ស និងការធ្វើអព្ភូតហេតុជាច្រើន ។ នៅពេលមានការប្រឆាំងជំទាស់និងទ្រង់កាន់តែខ្លាំងឡើង នោះទ្រង់បង្រៀនជាញឹកញាប់ជាងមុន ។

ម៉ាកុស ៥-៨ ព្រះអង្គសង្គ្រោះបន្តធ្វើអព្ភូតហេតុជាច្រើន បង្ហាញពីឫទ្ធិអំណាចរបស់ទ្រង់ចំពោះអ្នកដទៃ ។ បន្ទាប់ពី យ៉ូហាន បាទីស្ទ ត្រូវបានគេសម្លាប់ ព្រះយេស៊ូវបានប្រទានអាហារដល់មនុស្សច្រើនជាងប្រាំពាន់នាក់ ហើយបានយាងលើទឹក ។ ពេលយេស៊ូវបង្រៀនទាស់នឹងទំនៀមទម្ល



មេរៀនទី ៤៦

លូកា ៥

សេចក្តីផ្តើម

បន្ទាប់ពីការចាប់បានត្រីជាច្រើនសន្ធឹកដោយអព្ភូតហេតុដែលមានជំនួយរបស់ព្រះអង្គសង្គ្រោះ នោះពេត្រុស យ៉ាកុប និង យ៉ូហាន បានបោះបង់ចោលអ្វីៗទាំងអស់ ដើរតាមព្រះអង្គសង្គ្រោះ ហើយក្លាយជាអ្នកនេសាទមនុស្សវិញ ។ ព្រះយេស៊ូវបានព្យាបាលមនុស្សឈ្លង់ម្នាក់ និងមនុស្សខ្វិនម្នាក់ ។ ទ្រង់បានហៅម៉ាថាយឲ្យធ្វើជាសិស្សមួយរូប ហើយបានបង្រៀនថា ទ្រង់យាងមកដើម្បីហៅអ្នកមានបាបឲ្យប្រែចិត្ត ។ ព្រះយេស៊ូវកំបានបង្រៀនរឿងប្រៀបប្រដូចពីស្រាទំពាំងបាយជូរថ្មីជាក់ក្នុងដបចាស់ ។

យោបល់សម្រាប់ការបង្រៀន

លូកា ៥:១-១១

ព្រះអម្ចាស់បានហៅពេត្រុស យ៉ាកុប និង យ៉ូហាន ឲ្យក្លាយជាអ្នកនេសាទមនុស្ស

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀន ៖ តើអ្នកគ្រាប់ត្រូវបានសុំឲ្យធ្វើអ្វីមួយ ដោយមិនដឹងពីមូលហេតុចំពោះការធ្វើការងារនោះនៅពេលណា ? ចូរសុំឲ្យសិស្សពិភាក្សាអំពីសំណួរ ហើយអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

- ហេតុអ្វីក៏វាជាការលំបាក ដើម្បីធ្វើតាមការណែនាំដោយពុំយល់ពីមូលហេតុនោះ ?
- តើបទពញ្ញត្តិ ឬការទូន្មានអ្វីខ្លះមកពីអ្នកដឹកនាំសាសនាចក្រ ដែលយូរវីយមួយចំនួនអាចដឹងឃើញថាមានការលំបាកដើម្បីគោរពតាម បើពួកគេយល់ដឹងពេញលេញពីមូលហេតុនោះ ? (សូមពិចារណាពីការសរសេរចម្លើយរបស់សិស្សលើក្តារខៀន ។)

សូមអញ្ជើញសិស្សឲ្យរកមើលការណែនាំមួយនៅក្នុងលូកា ៥:១-១១ដែលអាចជួយពួកគេ នៅពេលពួកគេពុំយល់ដឹងពេញលេញពីមូលហេតុដែលពួកគេត្រូវបានសុំឲ្យធ្វើតាមដំបូន្មាន ឬបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។

សូមសិស្សម្នាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ៥:១-៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលថាអ្វីខ្លះបានកើតឡើង បន្ទាប់ពីសីម៉ូនបានធ្វើតាមអ្វីដែលព្រះអម្ចាស់បានសុំ ។

- តើសីម៉ូនបានប្រាប់ព្រះអង្គសង្គ្រោះអ្វីខ្លះ អំពីការខិតខំកាលពីមុនរបស់គាត់ ដើម្បីចាប់ត្រី ?
- តើបទពិសោធន៍សេទៅត្រីរបស់សីម៉ូន អាចបានជាំគាត់ឲ្យគិតដូចម្តេច ពេលដែលព្រះអង្គសង្គ្រោះបានប្រាប់ដល់គាត់ឲ្យទម្លាក់អួនម្តងទៀតយ៉ាងណា ?
- តើសីម៉ូនបានឆ្លើយដូចម្តេច ដែលបង្ហាញថា គាត់ទុកចិត្តព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានលូកា ៥:៦-៩ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថាអ្វីខ្លះបានកើតឡើង បន្ទាប់ពីសីម៉ូនបានធ្វើតាមអ្វីដែលព្រះអម្ចាស់បានសុំ ។

- តើអានអ្វីខ្លះកើតឡើង នៅពេលសីម៉ូនបានធ្វើតាមអ្វីដែលព្រះអម្ចាស់បានសុំ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពីឯកន្ទុះរបស់សីម៉ូន ដើម្បីធ្វើន្ទអ្វីដែលព្រះអម្ចាស់បានសុំ ទោះជាគាត់មិនយល់ពីមូលហេតុក្តី ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគ្រាស្គាល់គោលការណ៍ដូចខាងក្រោមនេះ : **ប្រសិនបើយើងធ្វើអ្វីដែលព្រះអម្ចាស់សុំ ទោះជាយើងពុំយល់ពីមូលហេតុក៏ដោយ នោះទ្រង់អាចផ្តល់ពរដ៏មហិមាជាង ដែលយើងអាចរំពឹងទុក ។** ចូរប្រើពាក្យរបស់សិស្ស សរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

- តើការសរសៃរាមដំណឹងល្អតម្រូវឲ្យយើងទុកចិត្តលើព្រះយេស៊ូវក្រីស្ទតាមរបៀបណា ?

សូមជួយសិស្សឲ្យគ្រាប់ពីគោលការណ៍ដែលបានបង្កប់នៅ ។

គោលការណ៍ជាច្រើន ពុំបានថ្លែងដោយផ្ទាល់នៅក្នុងព្រះគម្ពីរទេ ប៉ុន្តែវាជាអត្ថន័យប្រយោលវិញ ។ គោលការណ៍ដែលបង្កប់ន័យជាញឹកញាប់អាចត្រូវបានកេរឃើញដោយការសួរថា « តើអ្វីជាភ័ន្តិតអប់រំ ឬជាចំនុចសំខាន់នៃរឿងនេះ ? សូមជួយសិស្សវិភាគលើសកម្មភាព ឬឃាបទ និង អាកប្បកិរិយាមនុស្សម្នាក់ៗ ឬជាក្រុមនៅក្នុងដំណើររឿងខគម្ពីរ ហើយប្រាប់ពីរបៀបដែលវាអាចអនុវត្តបាន ។ ការសិក្សាដំណើររឿងបទគម្ពីរតាមរបៀបនេះ អាចជួយធ្វើឲ្យគោលការណ៍នៃដំណឹងល្អដែលបង្កនូវន័យយ៉ាងកំបាំងបាត់ ។

- ជីវិតនេះជាបទពិសោធន៍មួយ នៅក្នុងការទុកចិត្តយ៉ាងជ្រាលជ្រៅ—ជាការទុកចិត្តលើព្រះយេស៊ូវក្រីស្ទ ការទុកចិត្តលើការបង្រៀនរបស់ទ្រង់ ការទុកចិត្តលើសមត្ថភាពរបស់យើង ដូចដែលបានគឺកន់ដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីគោរពប្រតិបត្តិដល់ការបង្រៀនទាំងនោះ ដើម្បីបានសុភមង្គលនាពេលឥឡូវនេះ និង នៅជីវិតនឹពោរពេញដោយគោលបំណង ជាជីវិតនឹរស់អស់កល្បជាអនិច្ចនីរភាពយប់ផុត ។ ដើម្បីទុកចិត្តមានន័យថា គោរពដោយស្ម័គ្រចិត្ត ដោយពុំដឹងពីទីបញ្ចប់ តាំងពីដំបូងមក (សូមមើល សុភ. ៣:៥-៧ឧ) ។ ដើម្បីកម្តើតជំហរថ្មី នោះការទុកចិត្តរបស់អ្នកលើព្រះអម្ចាស់ ត្រូវតែមានការកាន់តែខ្លាំងក្លា និង កាន់តែបឹតបៃ ជាងទំនុកចិត្តរបស់អ្នកលើអាមេរិកា និង បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក » (« Trust in the Lord» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១៧) ។

- តើយើងអាចបង្កើតការទុកចិត្តដូចគ្នានេះ នៅលើព្រះអង្គសង្គ្រោះយ៉ាងដូចម្តេចដែរ ?

ចំណេះចំណានខគម្ពីរ

វគ្គចំណេះចំណានខគម្ពីរទាំង ២៥ មាននៅក្នុងព្រះគម្ពីរសញ្ញាថ្មី ត្រូវបានគូសចំណាំនៅក្នុងបរិបទក្នុងមេរៀនដែលមានវា ។ មេរៀននីមួយៗក៏មាននូវគំនិតសម្រាប់ការបង្រៀនផងដែរ សម្រាប់វគ្គបទគម្ពីរទាំងនេះ ។ ដើម្បីជួយអ្នកឲ្យបង្រៀនវគ្គចំណេះចំណានខគម្ពីរដោទៀងទាត់ នោះមានសកម្មភាពរំឭកចំណេះចំណានខគម្ពីរដាច្រើននៅក្នុងសៀវភៅសិក្សានេះ ។ ចំពោះគំនិតបន្ថែមសម្រាប់ការបង្រៀនចំណេះចំណានខគម្ពីរ សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ ឬ Seminary Student Resources នៅគេហទំព័រ LDS.org ។

ចន្លោះជួរឈរ

ចន្លោះជួរឈរនៅក្នុងសៀវភៅសិក្សាសម្រាប់គ្រូ ដែលបានបោះពុម្ពអាចត្រូវបានប្រើសម្រាប់ការរៀបចំមេរៀនរួមមានការសរសេរកត់ចំណាំ គោលការណ៍ បទពិសោធន៍ ឬ គំនិតផ្សេងទៀត នៅពេលអ្នកទទួលបានការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ការដកស្រង់ និង ការពន្យល់បន្ថែមត្រូវបានផ្តល់ឲ្យនៅចុងបញ្ចប់មេរៀនមួយចំនួន ដើម្បីបន្ថែមការយល់ដឹងស្តីពីប្រវត្តិបរិបទ ទស្សនៈដាក់លាក់ ឬ វគ្គបទគម្ពីរនានា ។ សូមប្រើព័ត៌មាននៅក្នុងផ្នែកនេះ ដើម្បីរៀបចំឆ្លើយនឹងសំណួរ ឬ ផ្តល់ការយល់ដឹងបន្ថែមនៅពេលអ្នកបង្រៀន ។ សេចក្តីអធិប្បាយបន្ថែមផ្សេងទៀត អាចរកបាននៅក្នុងទម្រង់អេឡិចត្រូនិចនៃសៀវភៅសិក្សានេះ នៅគេហទំព័រ LDS.org និងនៅក្នុងកម្មវិធីបណ្ណាល័យដំណឹងល្អ ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

គំនិតបន្ថែមនានាសម្រាប់ការបង្រៀន មាននៅខាងចុងនៃមេរៀនមួយចំនួន ។ គំនិតនេះផ្តល់ជាយោបល់សម្រាប់ការបង្រៀនគោលលទ្ធិ និងគោលការណ៍ដែលពុំអាចរកឃើញ ឬ សង្កត់ធ្ងន់នៅក្នុងតួសេចក្តីនៃមេរៀន ។ វាក៏ផ្តល់ផងដែរនូវយោបល់ស្តីពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសោតទស្សន៍ ដូចជាឌី.វី.ឌី. បទបង្ហាញ និង វីដេអូនៅលើគេហទំព័រ LDS.org។ គំនិតបន្ថែមសម្រាប់ការបង្រៀនអាចរកបាន នៅក្នុងទម្រង់អេឡិចត្រូនិចនៃសៀវភៅសិក្សានេះនៅគេហទំព័រ LDS.org និងនៅក្នុងកម្មវិធីបណ្ណាល័យដំណឹងល្អ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

អំឡុងសប្តាហ៍ចុងក្រោយនៃថ្នាក់សិក្ខាសាលា ចូរពិចារណាធ្វើការផ្តល់ការប្រឡងចំណេះចំណានខគម្ពីរចុងក្រោយដល់សិស្ស ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសិក្សានៅផ្ទះ ឬ សិក្សាភ្លាមៗពីមុនការប្រឡង ។ ខាងក្រោមនេះ គឺជាការប្រឡងពីរបីប្រភេទដែលអ្នកអាចប្រើ (អ្នកអាចសម្របគំនិតទាំងនេះដើម្បីបំពេញតាមសេចក្តីត្រូវការរបស់សិស្ស) ៖

ការប្រឡងអំពីសេចក្តីយោង ៖ផ្តល់តម្រុយដល់សិស្សចេញមកពីវគ្គបទគម្ពីរចំណេះចំណានបទគម្ពីរ ។ តម្រុយទាំងនេះអាចជាពាក្យគោលលទ្ធិ ឬគោលការណ៍គន្លឹះ ឬសេចក្តីសង្ខេបនៃអត្ថន័យរបស់វគ្គបទគម្ពីរ ។ សូមអញ្ជើញសិស្សឲ្យសរសេរសេចក្តីយោងទៅវគ្គបទគម្ពីរដៅលើក្រដាសមួយសន្លឹក បន្ទាប់ពីអ្នកផ្តល់នូវតម្រុយនីមួយៗហើយ ។

ការប្រឡងគោលលទ្ធិ ៖ សរសេរគោលលទ្ធិគ្រិះៈនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សសរសេរសេចក្តីយោងចំណេះចំណានខគម្ពីរឆ្លើយឆ្លងគ្នានៅក្រោមគោលលទ្ធិនីមួយៗ ។ ពួកគេអាចធ្វើកិច្ចការនេះ ដោយរំឭកពីវគ្គចំណេះចំណានខគម្ពីរចេញពីការចងចាំ ឬដោយប្រើប្រាស់ឬមួយនៃចំណេះចំណានខគម្ពីរ ។

ការប្រឡងទន្ទេញចាំ ៖ សូមអញ្ជើញសិស្សឲ្យប្រើពាក្យ ដែលបានទន្ទេញចាំ និងគោលការណ៍ទាំងឡាយចេញមកពីវគ្គចំណេះចំណានខគម្ពីរ ដើម្បីពន្យល់អំពី គោលលទ្ធិគ្រិះមួយចំនួន ។ សូមអញ្ជើញពួកគេឲ្យសរសេរនូវការពន្យល់របស់ពួកគេ ហើយអានវាឲ្យពួកដល់សិស្សក្នុងថ្នាក់ ។

សូមចាំថា អ្នកត្រូវសរសើរដល់សិស្សក្នុងថ្នាក់របស់អ្នកចំពោះកិច្ចខិតខំរបស់ពួកគេ ក្នុងការទន្ទេញចាំវគ្គបទគម្ពីរគន្លឹះ និងគោលលទ្ធិគ្រិះទាំងនេះ ។ ចូរថ្លែងទីបន្ទាល់អំពីព្រះចេស្តាខាងវិញ្ញាណ និងទីបន្ទាល់ដែលយើងអាចទទួលបាន នៅពេលយើងខំទន្ទេញចាំវគ្គចំណេះចំណានខគម្ពីរ និងគោលលទ្ធិនានា ។

សេចក្តីអធិប្បាយ និង ព័ត៌មានសាច់រឿង

វិវរណៈ ១៣ ។ សត្វសាហាវ

ក្រៅពីចំណេះដឹងថា សត្វសហាវទាំងនោះតំណាងឲ្យនគរខាងលោកិយ យើងគ្មានការបកស្រាយណាមួយមកពីព្រះអម្ចាស់ទាក់ទងនឹងវាឡើយ ។ កាលកំពុងនិយាយពីអាថ៌កំបាំងនៃគម្ពីរវិវរណៈ ព្យាការី យ៉ូសែប ស៊្មីធ បានថ្លែងដូចតទៅ ៖

« នៅពេលណាក៏ដោយដែលព្រះបានប្រទានការនិមិត្តអំពីរូបភាព ឬ សត្វ ឬ រូបអ្វីក៏ដោយនោះទ្រង់មានទំនួលខុសត្រូវដោយអង្គទ្រង់ផ្ទាល់ដើម្បីប្រទានវិវរណៈ ឬ ការបកស្រាយអំពីអត្ថន័យនៃរូបទាំងនោះ៖ បើមិនដូច្នោះទេ យើងពុំទទួលខុសត្រូវចំពោះជំនឿរបស់យើងលើការនិមិត្តនោះឡើយ ។ . . .

« . . . ចូរកុំខ្វល់ខ្វាយពីការនិមិត្តនៃសត្វ និង ប្រធានបទដែលអ្នកពុំយល់នោះឡើយ » (នៅក្នុង *History of the Church*, ៥:៣៤៣, ៣៤៨) ។

វិវរណៈ ១៣:៨ ។ « កូនចៀមដែលត្រូវគេសំឡាប់ តាំងពីកំណើតលោកីយ៍មក »

ឃ្លាថា « កូនចៀមដែលត្រូវគេសំឡាប់ តាំងពីកំណើតលោកីយ៍មក » (វិវរណៈ ១៣:៨) សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។ « តាំងពីកំណើតលោកីយ៍មក » សំដៅទៅលើជីវិតមុនផែនដី ពីមុនពិភពលោកនេះត្រូវបានបង្កើតមកម៉្លេះ ។ ដូច្នេះហើយ យើងអាចយល់ចេញពីខគម្ពីរនេះបានថា តទ្ធិពលនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះត្រូវបានបង្កើតឡើងពីមុនព្រះយេស៊ូវបានប្រសូតមកទៅទៀត ។ ឧទាហរណ៍ មនុស្សដែលបានរស់នៅពីមុនជំនាន់ព្រះគ្រីស្ទអាចអនុវត្តសេចក្តីជំនឿលើព្រះគ្រីស្ទ ប្រែចិត្ត ហើយទទួលបានការអភ័យទោសពីអំពើបាប តាមរយៈអំណាចនៃដង្វាយធួនរបស់ទ្រង់ ទោះជាព្រះអង្គសង្គ្រោះពុំទាន់បានប្រសូតក្តី (សូមមើល គ. និង ស. ២០:២៤–២៦) ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

អេភេសូរ ៦:១១ ។ ការបង្ហាញវីដេអូ— « The Whole Armor of God »

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃការពាក់គ្រប់ទាំងគ្រឿងសឹករបស់ព្រះ សូមបង្ហាញវីដេអូ « The Whole Armor of God » (១៩:៣៥)ដែលរៀបរាប់ពីការអនុវត្តតាមការទុន្មានរបស់ប៉ុលនៅក្នុងសម័យទំនើប ។ វីដេអូនេះមាននៅក្នុង LDS.org ។

កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ (ម៉ោងសិក្សាអំពីសាសនា និង ម៉ោងព្រឹកព្រលឹម)

សៀវភៅសិក្សានេះ រួមមានមូលដ្ឋានគ្រឹះដូចខាងក្រោមសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ ៖ មេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀនចំនួន ១៦០ មេរៀន ជំនួយក្នុងការបង្រៀន សេចក្តីផ្តើមនៃគម្ពីរ និង ធនធានសម្រាប់ការបង្រៀនចំណេះចំណានខគម្ពីរ និង គោលលទ្ធិគ្រឹះទាំងឡាយ ។

សេចក្តីផ្តើមនៃគម្ពីរ

សេចក្តីផ្តើមនៃគម្ពីរគឺដាក់នៅពីមុនមេរៀនដំបូងនៃគម្ពីរនីមួយៗ ។ សេចក្តីផ្តើមនៃគម្ពីរផ្តល់នូវទិដ្ឋភាពទូទៅនៃគម្ពីរនីមួយៗ ដោយឆ្លើយនឹងសំណួរដូចតទៅនេះ ៖ ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ? តើនរណាជាអ្នកសរសេរគម្ពីរនេះ ? តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ? តើវាសរសេរទៅកាន់នរណា ? ហេតុអ្វី ? និងតើលក្ខណៈខុសប្លែកគ្នាមួយចំនួននៃគម្ពីរនេះមានអ្វីខ្លះ ? សេចក្តីផ្តើមទាំងឡាយក៏បង្ហាញដោយសង្ខេបនូវមាតិកានៃគម្ពីរនីមួយៗផងដែរ ។ ពួកគ្រូបង្រៀនគួរអានបញ្ចូលបរិបទ និងព័ត៌មានសាច់រឿងមកពីសេចក្តីផ្តើមនៃគម្ពីរទៅក្នុងមេរៀន ប្រសិនបើចាំបាច់ ។

មេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន

ទម្រង់នៃមេរៀន

មេរៀននីមួយៗនៅក្នុងសៀវភៅសិក្សានេះផ្តោតលើបណ្តុំបទគម្ពីរមួយ ជាជាងផ្តោតទៅលើគំនិត គោលលទ្ធិ ឬ គោលការណ៍ពិសេសណាមួយ ។ ទម្រង់នៃមេរៀននេះជួយអ្នក និង សិស្សរបស់អ្នកឲ្យសិក្សាព្រះគម្ពីរតាមលំដាប់លំដោយ ហើយពិភាក្សាពីគោលលទ្ធិ និង គោលការណ៍ដែលវាមាននៅក្នុងអត្ថបទព្រះគម្ពីរ ។ នៅពេលសិស្សរៀនមាតិកានៅក្នុងគោលលទ្ធិ ឬ គោលការណ៍ដែលរកឃើញ នោះការយល់ដឹងរបស់ពួកគេអំពីសេចក្តីពិតនោះនឹងកាន់តែជ្រាលជ្រៅ ។ លើសពីនេះទៅទៀត សិស្សនឹងមើលឃើញ ហើយយល់កាន់តែប្រសើរឡើងអំពីវិសាលភាពទាំងមូលនៃសារលិខិតដែលបំផុសគំនិតដល់អ្នកសរសេរគម្ពីរ ដែលមានបំណងចង់បង្ហាញ ។ ការបង្រៀនព្រះគម្ពីរតាមរបៀបនេះក៏នឹងជួយសិស្សឲ្យរៀនផងដែរ ពីរបៀបស្វែងរក និង អនុវត្តសេចក្តីពិតដ៏អស់កល្បនានានៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

នៅក្នុងមេរៀននីមួយៗគ្រប់ផ្នែកទាំងអស់នៃបណ្តុំបទគម្ពីរពុំត្រូវបានសង្កត់ធ្ងន់ឡើយ ។ ផ្នែកមួយចំនួនត្រូវបានផ្តោតលើតិចតួច ដោយសារវាពុំសូវផ្តោតសំខាន់លើសារលិខិតទាំងមូល នូវការបំផុសគំនិតរបស់អ្នកសរសេរ ឬ ដោយសារវាពុំសូវពាក់ព័ន្ធចំពោះយុវវ័យទេ ។ អ្នកមានទំនួលខុសត្រូវដើម្បីកែសម្រួលមេរៀនទាំងនេះទៅតាមតម្រូវការ និង ការចាប់អារម្មណ៍របស់សិស្សដែលអ្នកបង្រៀន ។ អ្នកអាចសម្របសម្រួលគំនិតនៃមេរៀននៅក្នុងសៀវភៅសិក្សានេះ ដោយជ្រើសយកការសង្កត់ធ្ងន់កាន់តែខ្លាំងចំពោះគោលលទ្ធិ ឬ គោលការណ៍ពិសេសៗ ជាជាងគំនិតនានាដែលត្រូវបានផ្តល់ឲ្យក្នុងមេរៀន ឬ ដោយជ្រើសយកការសង្កត់ធ្ងន់តែបន្តិចបន្តួចលើផ្នែកមួយនៃបណ្តុំបទគម្ពីរ ដែលត្រូវបានបង្កើតឡើងឲ្យយល់កាន់តែច្បាស់នៅក្នុងសៀវភៅសិក្សានេះ ។ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយអ្នកឲ្យធ្វើការកែសម្រួលនេះ នៅពេលអ្នករៀបចំ និង បង្រៀន ។

គោលលទ្ធិ និង គោលការណ៍ទាំងឡាយ

នៅក្នុងតួសេចក្តីនៃមេរៀននីមួយៗ អ្នកនឹងរកឃើញថា គោលលទ្ធិ និង គោលការណ៍គន្លឹះមួយចំនួននោះត្រូវបានគូសបញ្ជាក់ជាអក្សរដិតខ្មៅ ។ គោលលទ្ធិ និង គោលការណ៍ទាំងនេះត្រូវបានរកឃើញនៅក្នុងកម្មវិធីសិក្សាដោយសារ (១) វាឆ្លុះបញ្ចាំងពីសារលិខិតសំខាន់នៃបណ្តុំបទគម្ពីរ (២) ជាពិសេស វាអាចអនុវត្តបានចំពោះសេចក្តីត្រូវការ និង ស្ថានភាពនានារបស់សិស្ស (៣) វាគឺជាសេចក្តីពិតដ៏សំខាន់ ដែលអាចជួយសិស្សឲ្យមានទំនាក់ទំនងកាន់តែខ្លាំងឡើងជាមួយព្រះអម្ចាស់ ។ សូមដឹងថា ព្រះគម្ពីរសញ្ញាថ្មីបង្រៀនសេចក្តីពិតមួយចំនួនច្រើនជាងសេចក្តីពិតទាំងអស់ដែលមាននៅក្នុងកម្មវិធីសិក្សា ។ ប្រធាន ប៊ិច ជ៊ី ឃេ ផាកគី ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ព្រះគម្ពីរមាននូវ « បណ្តុំនៃសេចក្តីពិតដ៏អស់កល្ប ដែលនឹងបំពេញនូវសេចក្តីត្រូវការនៃជនគ្រប់រូបនៅក្នុងគ្រប់ស្ថានភាពទាំងអស់ » (« The Great Plan of Happiness » [CES Symposium on the Doctrine and Covenants/Church History, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣] គេហទំព័រ si.lds.org, សូមមើលផងដែរ *Teaching Seminary: Preservice Readings* [ឆ្នាំ ២០០៤] ទំព័រ៦៩ , គេហទំព័រ LDS.org) ។

នៅពេលអ្នកបង្រៀន សូមផ្តល់ឱកាសឲ្យសិស្សជានិច្ចដើម្បីស្វែងរកគោលលទ្ធិ និង គោលការណ៍នានានៅក្នុងព្រះគម្ពីរ ។ នៅពេលសិស្សបង្ហាញសេចក្តីពិតដែលពួកគេរកឃើញ នោះជាញឹកញាប់ពួកគេអាចប្រើពាក្យ ដែលខុសគ្នាអំពីរបៀបដែលគោលលទ្ធិ ឬ គោលការណ៍នោះបានថ្លែងនៅក្នុងសៀវភៅសិក្សានោះ ។ ពួកគេក៏អាចរកឃើញផងដែរ នូវសេចក្តីពិតដែលពុំមាននៅក្នុងគម្រោងមេរៀន ។ សូមប្រុងប្រយ័ត្ន កុំផ្តល់យោបល់ដោយងាយៗថា ចម្លើយរបស់សិស្សគឺខុស ដោយសារតែពាក្យដែលពួកគេប្រើដើម្បីបង្ហាញពីសេចក្តីពិត ខុសពីអ្វីដែលបានប្រើនៅក្នុងសៀវភៅសិក្សា ឬ ដោយសារពួកគេបានរកឃើញសេចក្តីពិតមួយ ដែលពុំបានលើកឡើងនៅក្នុងកម្មវិធីសិក្សានោះ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើប្រយោគរបស់សិស្សម្នាក់ខុសពីគោលលទ្ធិ នោះវាជាទំនួលខុសត្រូវរបស់អ្នកដើម្បីជួយសិស្សដោយឥរិយាបទទន់ភ្លន់ ដើម្បីជួយកែតម្រូវសេចក្តីថ្លែងការណ៍របស់គាត់ ដោយធ្វើការនេះដោយសេចក្តីស្រឡាញ់ និង ការទុកចិត្ត ។ ការធ្វើដូច្នោះអាចផ្តល់នូវបទពិសោធន៍រៀនសូត្រយ៉ាងសំខាន់ដល់សិស្សក្នុងថ្នាក់របស់អ្នក ។

ល្បឿនបង្រៀន

សៀវភៅសិក្សានេះមានមេរៀនថ្នាក់សិក្ខាសាលាប្រចាំថ្ងៃចំនួន ១៦០ មេរៀន ។ អ្នកអាចសម្របសម្រួលមេរៀននេះ និង ល្បឿននៃការបង្រៀនទៅតាមតម្រូវការនៃរយៈពេលវែងដែលអ្នកមាន ដើម្បីបង្រៀនវគ្គសិក្សានេះ ។ សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ សម្រាប់សេចក្តីណែនាំគំរូនៃល្បឿនបង្រៀន ។ សេចក្តីណែនាំនៃល្បឿនបង្រៀនផ្អែកទៅលើឆ្នាំសិក្សាដែលមានរយៈពេល ៣៦ សប្តាហ៍ ឬ ១៨០ ថ្ងៃ និងរួមបញ្ចូលនូវ ២០ ថ្ងៃ « ដែលអាចផ្លាស់ប្តូរបាន » ដែលអ្នកអាចប្រើដើម្បីសម្រួលមេរៀនប្រចាំថ្ងៃ ជួយសិស្សឲ្យសូត្រចាំវគ្គចំណេះចំណានខគម្ពីរស្ទាត់ និង គោលលទ្ធិគ្រឹះ រឭកមេរៀនពីមុនៗ ចាត់ចែង ហើយពិនិត្យការវាយតម្លៃលើការរៀនសូត្រដែលចាំបាច់ ហើយទុកពេលសម្រាប់កាលវិភាគដែលអាក់ខាននានា ។

កិច្ចការជំនួសអវត្តមាន

សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ: អាចត្រូវបានប្រើប្រាស់ក្នុងកម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃជាធនធាន ដើម្បីផ្តល់កិច្ចការដែលសិស្សមិនទាន់បានបំពេញនៅឡើយ ។ មេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សដែលសិក្សានៅផ្ទះ: ស្របនឹងមេរៀនដែលមាននៅក្នុងសៀវភៅសិក្សានេះ ។ សិស្សដែលអវត្តមានច្រើនលើសលុបអាចត្រូវបានចាត់ឲ្យបំពេញនូវកិច្ចការនានានៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សា ដែលត្រូវគ្នានឹងមាតិកាដែលពួកគេពុំបានធ្វើ ព្រោះមិនបានមករៀន ។ កិច្ចការនោះអាចបោះពុម្ពចេញពីគេហទំព័រLDS.org ដូច្នេះអ្នកពុំចាំបាច់ត្រូវផ្តល់សៀវភៅសិក្សាទាំងមូលនេះដល់សិស្ស ដែលត្រូវធ្វើកិច្ចការជំនួសពេលដែលអវត្តមានឡើយ ។ ព័ត៌មានបន្ថែមទាក់ទងនឹង *សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ:* គឺត្រូវបានផ្តល់ឲ្យនៅក្នុងវគ្គចំណងជើង « កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ: » នៅក្នុងសៀវភៅសិក្សានេះ ។

ជំនួយក្នុងការបង្រៀន

ជំនួយក្នុងការបង្រៀនមាននៅគែមទំព័រនៃសៀវភៅសិក្សានេះ ។ ការបង្រៀនទាំងនេះជួយពន្យល់ និង បង្ហាញអំពីរបៀបដែលអ្នក និង សិស្សដែលអ្នកបង្រៀន អាចអនុវត្តការបង្រៀន និងការរៀនសូត្រមូលដ្ឋានគ្រឹះនៃដំណឹងល្អនៅក្នុងការសិក្សារបស់អ្នកអំពីព្រះគម្ពីរសញ្ញាថ្មី ។ វាក៏ផ្តល់ផងដែរនូវយោបល់នានាស្តីអំពីរបៀបដ៏មានប្រសិទ្ធភាព ដើម្បីប្រើវិធីសាស្ត្រ ជំនាញ និង យុទ្ធសាស្ត្របង្រៀនផ្សេងៗ ។ នៅពេលអ្នកយល់គោលការណ៍ដែលមាននៅក្នុងជំនួយក្នុងការបង្រៀន សូមរកមើលរបៀបនានាដើម្បីអនុវត្តហើយប្រើវាឲ្យបានជាប់លាប់នៅក្នុងការបង្រៀនរបស់អ្នក ។





ចំណេះចំណានខគម្ពីរ និង គោលលទ្ធិគ្រឹះ

ដើម្បីជួយសិស្សឲ្យរក្សាទុកនូវសេចក្តីពិតដ៏អស់កល្បជានិច្ច និង ដើម្បីបង្កើនទំនុកចិត្តរបស់ពួកគេលើការរៀនសូត្រ និង ការបង្រៀនចេញពីព្រះគម្ពីរ នោះថ្នាក់សិក្ខាសាលា និង វិទ្យាស្ថានសាសនា (សសវ) បានជ្រើសរើសវគ្គបទគម្ពីរជាច្រើនសម្រាប់សិស្សឲ្យសូត្រចាំស្ទាត់ក្នុងអំឡុងពេលនៃវគ្គសិក្សានីមួយៗ ។ លើសពីនេះទៀតបញ្ជី គោលលទ្ធិគ្រឹះ ត្រូវបានដាក់បញ្ចូលដើម្បីបង្ហាញនូវគោលលទ្ធិគន្លឹះដែលសិស្សគួរតែយល់ ជឿ ហើយរស់នៅតាមពេញបួនឆ្នាំនៃថ្នាក់សិក្ខាសាលា និង ពេញមួយជីវិតរបស់ពួកគេ ។ សៀវភៅសិក្សាសម្រាប់វគ្គសិក្សានីមួយៗ ក្នុងថ្នាក់សិក្ខាសាលា ត្រូវបានរៀបចំដើម្បីបង្ហាញអំពីគោលលទ្ធិគ្រឹះនៅពេលវាលេចឡើងអំឡុងពេលសិស្សសិក្សាព្រះគម្ពីរតាមលំដាប់លំដោយរបស់វគ្គគម្ពីរ ។ មានវគ្គចំណេះចំណានខគម្ពីរជាច្រើនត្រូវបានជ្រើសរើសជាមួយនឹងគោលលទ្ធិគ្រឹះនៅក្នុងចិត្ត ដូច្នេះហើយ នៅពេលអ្នកបង្រៀនវគ្គចំណេះចំណានខគម្ពីរដល់សិស្ស នោះអ្នកនឹងបង្រៀនគោលលទ្ធិគ្រឹះផងដែរ ។

នៅពេលសិស្សបានរក្សាទុកនូវសេចក្តីពិតដ៏អស់កល្បជានិច្ចនៅក្នុងគំនិត និង ដួងចិត្តរបស់ខ្លួន នោះព្រះវិញ្ញាណបរិសុទ្ធនឹងនាំសេចក្តីពិតទាំងនេះ ទៅដល់ការចងចាំនៅពេលដែលចាំបាច់ និង ផ្តល់ភាពក្លាហានដល់គេដើម្បីធ្វើសកម្មភាពដោយសេចក្តីជំនឿ (សូមមើល យ៉ូហាន ១៤:២៦) ។ ប្រធានហាវីដ ឌបុលយូ ហឺនធើរ បានបង្រៀន ៖

« ខ្ញុំសុំលើកទឹកចិត្តអ្នកយ៉ាងម៉ឺងមាត់ ឲ្យប្រើប្រាស់ព្រះគម្ពីរនៅក្នុងការបង្រៀនរបស់អ្នក និង ធ្វើអ្វីៗគ្រប់យ៉ាងក្នុងអំណាចរបស់អ្នក ដើម្បីជួយសិស្សឲ្យប្រើប្រាស់ និង មានអារម្មណ៍កាន់តែកក់ក្តៅចំពោះព្រះគម្ពីរ ។ ខ្ញុំចង់ឲ្យមនុស្សវ័យក្មេងរបស់យើងមានទំនុកចិត្តលើព្រះគម្ពីរ ។ . . .

« . . . យើងចង់ឲ្យសិស្សមានទំនុកចិត្តលើអានុភាព និង សេចក្តីពិតនៃព្រះគម្ពីរ មានទំនុកចិត្តថា ព្រះវរបិតាសួគ៌របស់ពួកគេ ពិតជាកំពុងមានព្រះបន្ទូលទៅកាន់ពួកគេតាមរយៈព្រះគម្ពីរមែន ហើយទំនុកចិត្តថាពួកគេអាចងាកទៅអានព្រះគម្ពីរ ហើយរកចម្លើយចំពោះបញ្ហា និង ការអធិស្ឋានរបស់ពួកគេ ។ . . .

« . . .យើងសង្ឃឹមថា គ្មានសិស្សណាម្នាក់របស់អ្នកនឹងចាកចេញពីថ្នាក់របស់អ្នកដោយការភ័យខ្លាច ឬអៀនខ្មាស់ ឬ អាម៉ាស់មុខ ដែលពួកគេមិនអាចរកជំនួយដែលពួកគេត្រូវការ ដោយសារពួកគេមិនចេះព្រះគម្ពីរច្បាស់គ្រប់គ្រាន់ ក្នុងការរកវគ្គបទគម្ពីរត្រឹមត្រូវនោះឡើយ » (« Eternal Investments » [address to CES religious educators, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៩] ទំព័រ ២ si.lds.org, សូមមើលផងដែរ *Teaching Seminary: Preservice Readings* [ឆ្នាំ ២០០៤] ទំព័រ ២០,LDS.org) ។

សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ សម្រាប់ព័ត៌មានបន្ថែមអំពីចំណេះចំណានខគម្ពីរ និង គោលលទ្ធិគ្រឹះ ។

ការប្រើប្រាស់មេរៀនដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនរបស់សិស្ស

សេចក្តីសង្ខេបនេះនឹងជួយអ្នកឲ្យស្គាល់បរិបទ និង គោលលទ្ធិ ព្រមទាំងគោលការណ៍នានាដែលសិស្សបានសិក្សាក្នុងមួយសប្តាហ៍ នៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ។

សេចក្តីផ្តើមនៃមេរៀន

សេចក្តីផ្តើមនៃមេរៀននេះនឹងជួយអ្នកឲ្យស្គាល់ពីផ្នែកខ្លះៗនៃបណ្តុំបទគម្ពីរណាមួយ ដែលនឹងត្រូវលើកយកមកបញ្ចាក់នៅក្នុងមេរៀននេះ ។

សេចក្តីសង្ខេបនៃក្រុមខគម្ពីរ និង បរិបទ

ខគម្ពីរត្រូវបានដាក់ជាក្រុម ស្របតាមទីតាំងដែលផ្លាស់ប្តូរនៅក្នុងបរិបទ ឬ មាតិកាដែលមានពាសពេញទាំងបណ្តុំបទគម្ពីរ ។ សេចក្តីយោងនៃក្រុមខគម្ពីរនីមួយៗ ត្រូវបានបន្តដោយសេចក្តីសង្ខេបខ្លីនៃហេតុការណ៍ ឬការបង្រៀននៅក្នុងក្រុមខគម្ពីរនោះ ។

គួរសេចក្តីនៃមេរៀន


គួរសេចក្តីនៃមេរៀនផ្តល់នូវសេចក្តីណែនាំសម្រាប់អ្នក នៅពេលអ្នកសិក្សា និង បង្រៀន ។ វាផ្តល់គំនិតបង្រៀន រួមមានសំណួរ សកម្មភាព ការដេកស្រង់ ដ្យាក្រម និង តារាងនានា ។

គោលលទ្ធិ និង គោលការណ៍ទាំងឡាយ

នៅពេលគោលលទ្ធិ និងគោលការណ៍ទាំងឡាយលេចឡើងនៅក្នុងការសិក្សាអត្ថបទព្រះគម្ពីរ នោះវាត្រូវបានគូសបញ្ជាក់ជាអក្សរខ្មៅជិត ដើម្បីជួយអ្នកឲ្យកេឃើញ និងផ្តោតយកចិត្តទុកដាក់លើវានៅក្នុងការពិភាក្សារបស់អ្នកជាមួយសិស្ស ។

សេចក្តីណែនាំនៃមេរៀនបន្ទាប់

កថាខណ្ឌចុងក្រោយនៃមេរៀននីមួយៗផ្តល់ការចង្អុលបង្ហាញមួយទៅមេរៀនបន្ទាប់ ។ សូមចែកចាយកថាខណ្ឌនេះជាមួយសិស្សរបស់អ្នកនៅពេលបញ្ចប់មេរៀននីមួយៗ ដើម្បីជួយពួកគេឲ្យខ្នះខ្នែងសិក្សាព្រះគម្ពីរអំឡុងពេលនៃសប្តាហ៍ក្រោយ ។



មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ៤-៩ (មេរៀនទី ៨)

ការរៀបចំសម្ភារៈសម្រាប់គ្រូបង្រៀនដល់សិស្ស ដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ាកុស ៤-៩ (មេរៀនទី ៨) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីម្ចាស់ការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាកុស ៤-៥)

សិស្សបានរៀនថា ប្រសិនបើយើងសែ្វងរកជំនួយរបស់ព្រះអម្ចាស់ នៅគ្រាមានបញ្ហា ឬ ភ័យខ្លាច នោះទ្រង់អាចនាំសេចក្តីសុខសាន្តកើតមានមកដល់យើង ។ ពួកគេក៏បានរៀនផងដែរថា នៅពេលយើងមានបទពិសោធន៍ព្រះចេស្តារបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង នោះយើងអាចថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃអំពីពរជ័យ និងក្តីមេត្តាករុណារបស់ទ្រង់ ។ ចេញមកពីរឿងនៃកូនស្រីរបស់ឃ្លីស និងស្ត្រីដែលមានឈាមហូរ នោះសិស្សបានរៀនថា ប្រសិនបើយើងបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ តាមរយៈកិច្ចខិតខំរបស់យើង ដើម្បីមករកទ្រង់ នោះទ្រង់អាចធ្វើឲ្យយើងបានជាសះស្បើយ ហើយថាការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ តម្រូវឲ្យយើងបន្តជឿលើទ្រង់ ទោះជានៅក្នុងគ្រាពិបាកព្រោកជក្តី ។

ថ្ងៃទី ២ (ម៉ាកុស ៦-៨)

ចេញមកពីអត្ថបទហេតុនៃការប្រទានចំណីអាហារដល់មនុស្ស ៥០០០ នាក់ នោះសិស្សអាចរៀនថា នៅពេលយើងថ្វាយព្រះអង្គសង្គ្រោះអ្វីៗទាំងអស់ដែលយើងមាន នោះទ្រង់អាចតម្លើងការថ្វាយរបស់យើង ឲ្យសម្រេចតាមព្រះហប័ណាទ្រង់ ។ សិស្សក៏រៀនផងដែរថា យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដោយការដឹងអំពីតម្រូវការរបស់អ្នកដទៃ រួចហើយជួយបំពេញតម្រូវការទាំងនោះ ។

ថ្ងៃទី ៣ (ម៉ាកុស ៩: ១-២៩)

ចេញមកពីដំណើររឿងរបស់ព្រះយេស៊ូវ បណ្តាញវិញ្ញាណអសោចចេញពីក្នុងប្រុសម្នាក់ នោះសិស្សអាចរៀនថា ប្រសិនបើយើងជឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះអ្វីៗគ្រប់បែប [illegible] ប្រសិនបើយើងកាន់ជាប់នូវអ្វីដែលយើងជឿ [illegible]

សេចក្តីផ្តើម

មេរៀននេះ អាចជួយសិស្សឲ្យយល់ថា ការព្យាយាមដើម្បីផ្លាស់ចិត្តអ្នកដទៃដាច់ដាងឲ្យការធ្វើនូវអ្វីដែលយើងដឹងថាត្រឹមត្រូវ អាចនាំទៅកេការជ្រើសរើសខុសឆ្គង ការសោកស្តាយ និងប្បាដិសារី ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៦:១-២៩

ព្រះយេស៊ូវត្រូវបានគេបដិសេធនៅស្រុកណាសារ៉ែត ហើយបានបញ្ជូនពួកដប់ពីរនាក់ឲ្យចេញទៅផ្សព្វផ្សាយ ការស្តាប់របស់យ៉ូហាន បាទីស្មត្រូវបានដំណាលប្រាប់

សូមចាប់ផ្តើមថ្នាក់រៀនដោយការអញ្ជើញសិស្ស ឲ្យគិតអំពីត្រាពីមុន ដែលពួកគេមានអារម្មណ៍ថាក្រោមសម្ពាធក្នុងការធ្វើអ្វីមួយ ដែលពួកគេដឹងថាវាពុំត្រឹមត្រូវ ។

សូមសរសេរនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម នៅលើក្តារខៀន (សេចក្តីថ្លែងការណ៍នេះត្រូវបានកេឃើញនៅក្នុង« *Making the Right Choices* » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៣៧) ។

- *« ប្អូនប្រុសម្នាក់ដែលធ្វើខុស ចង់ឲ្យអ្នកចូលរួមនឹងពួកគេ ដោយសារពួកគេនឹងមានអារម្មណ៍កាន់តែសុខស្រួលបំពេញអ្វីដែលគេកំពុងតែធ្វើនោះ៖ ប្រោះមានអ្នកដទៃធ្វើដែរ »* (*ណែលអើ រីឆាត ដឺ ស្តូត*) ។

- តើមានទេវាហេរណ៍ណាខ្លះអំពីរបៀប ដែលអ្នកដទៃអាចនឹងព្យាយាមដាក់សម្ពាធមកលើអ្នក ឲ្យធ្វើអ្វីមួយ ដែលអ្នកនឹងថាពុំសុខស្ងួន ?

សូមអញ្ជើញសិស្សឲ្យអានមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាម៉ាកុស ៦ដែលអាចជួយពួកគេបៀសវាងពីការចុះញ៉ូមនឹងសម្ពាធអវិជ្ជមានរបស់មិត្តភក្តិ ។

ចុះសូមឲ្យសិស្សម្នាក់អាន ម៉ាកុស ៦:១៧-១៨ ឮៗ ។ ចុះសូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម ភេមើលនូវអ្វីដែលហេរ៉ូឌបានធ្វើចំពោះយ៉ូហាន បាទីស្ម ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានភេឃើញ ។

- តើហេរ៉ូឌបានធ្វើអ្វីខ្លះដល់យ៉ូហាន ហើយហេតុអ្វី ?

ហេរ៉ូឌ បានលែងលះមហេរីបស់ទ្រង់ ហើយបានរៀបការនឹងហេរ៉ូឌាស ជាមហេរីបរបស់អនុជទ្រង់ គឺភីលីព ។ ១៨ខ្វែងគឺជាការល្មើសនឹងច្បាប់របស់សាសន៍យូដាយ៉ាងដាក់ច្បាស់ (សូមមើលលេវីនីយ ១៨:១៦) ហើយយ៉ូហាន បាទីស្មបានដាក់បណ្តាសារ ។ ការដំទាស់របស់យ៉ូហានបំពេញការរៀបការនេះ បានធ្វើឲ្យហេរ៉ូឌាសខ្ញាល់ជាខ្លាំង ដូច្នេះហេរ៉ូឌបានចាប់យ៉ូហានដាក់គុក ដើម្បីឲ្យស្ងប់ចិត្តនាង ។

ចុះសូមឲ្យសិស្សម្នាក់អាន ម៉ាកុស ៦:១៩-២០ [illegible] ហើយ [illegible]



- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ: បន្ទាប់ពីបានស៊ីបន្ទោសដល់ពួកផារិស៊ី និងពួកសាឌូស៊ី ?
- តើយើងអាចរៀនអ្វីខ្លះនៅក្នុងបទពិសោធន៍នេះ:ស៊ីពីពីតំរុំត្រូវត្រូវ ដើម្បីឲ្យសេចក្តីពិតខាងវិញ្ញាណ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោម: ៖ **យើងចុះបញ្ជីទទួលសេចក្តីពិតខាងវិញ្ញាណ ដោយការស្វែងរកទីសម្គាល់ឡើយ**) ។

សូមសង្ខេប ម៉ាថាយ ១៦:៥–១២ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានព្រមានពួកសិស្សរបស់ទ្រង់ពីការបង្រៀនខុសឆ្គងរបស់ពួកផារិស៊ី និង ពួកសាឌូស៊ី ។

ម៉ាថាយ ១៦:១៣-២០ ។

ពេត្រុសបានថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានសន្យាថាប្រគល់ឲ្យនូវកូនសោនៃនគរស្ថានសួគ៌

សូមពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានស្តីបន្ទោសដល់ពួកផារិស៊ី និង ពួកសាឌូស៊ីដោយការចង់ឯទីសម្គាល់មួយមក ទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ពីរបៀបទទួលបានទីបន្ទាល់មួយគឺសេចក្តីពិត ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៣-១៤ ឮៗ ។ ចុះសូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមការិយាល័យណា ដែលព្រះយេស៊ូវបានចោទសួរ និង ចម្លើយរបស់ពួកសិស្សរបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានសួរអ្វីខ្លះដែលពួកសិស្សរបស់ទ្រង់ ? តើពួកគេបានឆ្លើយយ៉ាងដូចម្តេច ? (អ្នកគួរតែពន្យល់ថា អេលីយ៉ាស និង យេរេមា គឺជាពួកព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះ អេលីយ៉ា និង យេមា) ។
- តើចម្លើយរបស់ពួកគាត់អាចប្រាប់អ្វីខ្លះដល់យើងថា មនុស្សចានួយល់ដឹងដល់កម្រិតណាដែរថា ព្រះយេស៊ូវគឺជានរណា មានដល់ពេលនេះនៅក្នុងការងារបម្រើរបស់ទ្រង់ ?

កំណត់ចំណាំ ៖ នៅក្នុងមេរៀនសម្រាប់ថ្ងៃទី ៨ សិស្សបានសិក្សាវគ្គចំណេះដឹងសញ្ញីរ ម៉ាថាយ ១៦:១៥–១៩ ។ សូមពិចារណាចំណាយពេលពីរបីនាទី មើលវគ្គនោះឡើងវិញជាមួយពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៥-១៧ ឮៗ ។ ចុះសូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមភេមើលសំណួរទីពីរដែលព្រះអង្គសង្គ្រោះបានចោទសួរ ។

- តើសំណួរទីពីរដែលព្រះអង្គសង្គ្រោះបានសួរនោះជាអ្វីទៅ ? តើពេត្រុសបានឆ្លើយបែបណាដែរ ?
- យោងតាម ទទី ១៧តើពេត្រុសបានដឹងថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះបានដោយរបៀបណា ? (សូមចង្អុលបង្ហាញថា ព្រះវរបិតាសួគ៌បានបើកសម្តែងសេចក្តីពិតនេះដល់លោកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ) ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ: នៅក្នុងខគម្ពីរទាំងនេះអំពីរបៀបដែលយើងអាចទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ: ៖ **យើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈវិញ្ញាណមកពីព្រះវិញ្ញាណបរិសុទ្ធ**) ។
- ហេតុអ្វីអ្នកគិតថា ការទទួលបានទីបន្ទាល់មួយតាមរយៈវិញ្ញាណពីព្រះវិញ្ញាណបរិសុទ្ធជាជាងតាមវិធីផ្សេងទៀត គឺជារឿងដ៏សំខាន់សម្រាប់យើង ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងការជួយយើងឲ្យទទួលបានទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ ៖

«ការមានបន្ទូលរបស់ព្រះវិញ្ញាណព្រះ:ទៅកាន់វិញ្ញាណរបស់មនុស្សមានន្យព្រះចេស្តា ដើម្បីប្រទានសេចក្តីពិតដ៏មានតម្លៃ និង ការយល់ដឹងច្រើនជាងសេចក្តីពិតដែលអាចបានផ្តល់ឲ្យដោយទំនាក់ទំនងផ្ទាល់ខ្លួន ទោះជាជាមួយនឹងអ្នកស្ងាត់ក្តី ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ សេចក្តីពិតត្រូវដាក់បញ្ចូលទៅក្នុងគ្រប់ចរន្តសម្ងួនៃនសរីរាង្គ និង សរសៃឈាមសាច់ដុំនៃរូបកាយ ដើម្បីវាត្រូវបានចងាប់ជាប់ជាមួយហឫត » (*Teachings of Presidents of the Church: Joseph Fielding Smith* [ឆ្នាំ២០១៣] ទំព័រ ១៩៣–៨៤) ។

- តើអ្វីខ្លះដែលយើងអាចធ្វើ ដើម្បីរៀបចំខ្លួនយើងទទួលវិញ្ញាណ:តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?
- តើអ្នកបានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ និង ជាព្រះអង្គសង្គ្រោះរបស់អ្នកតាមរបៀបណាដែរ ? តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីទទួលបានសាក្សីនោះមកពីព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចពង្រឹងទីបន្ទាល់របស់ខ្លួន ឬអ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលបានទីបន្ទាល់មួយតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតដែលពួកគេបានទទួល ។

មេរៀនបន្ទាប់ (ម៉ាថាយ ១៨:១-២២:២៦)

ចុះសូមឲ្យសិស្សពិចារណាពីត្រាមួយដែល ពួកគេមានការលំបាកក្នុងការអភ័យទោសឲ្យមនុស្សម្នាក់ទៀត ។ សូមអញ្ជើញពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖ តើអ្វីបានជាអ្នកមានអារម្មណ៍ថា ពាជាងណាក្រសាយសមហេតុផល ដោយពុំចាំបាច់អភ័យទោសដល់បុគ្គលនេះ ? ហេតុអ្វីបានជាយើងគួរអភ័យទោសឲ្យអ្នកដទៃចំពោះការបំពានរបស់ពួកគេ សូម្បីតែយើងមានអារម្មណ៍ថាមិនចង់អភ័យទោសដល់ពួកគេក៏ដោយនោះ ? សូមអញ្ជើញសិស្សរកមើលចម្លើយចំពោះសំណួរទាំងនេះ នៅពេលពួកគេបន្តការសិក្សារបស់ខ្លួននៅសប្តាហ៍ក្រោយ ។

កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ

ក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំបព្វជិតភាពក្នុងមូលដ្ឋាន និង អ្នកតំណាង ស&វ នោះថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះអាចត្រូវបានរៀបចំឡើងនៅកន្លែងណា ដែលសិស្សពុំអាចចូលរួមរៀននៅក្នុងថ្នាក់ជារៀងរាល់ថ្ងៃបាន ដោយសារតែចម្ងាយផ្លូវឬ កត្តាផ្សេងៗទៀត (ដូចជាពិការភាពជាដើម) ។ ជាទូទៅ ថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះពុំដូចថ្នាក់រៀនដែលបង្រៀនរៀងរាល់ថ្ងៃ (ថ្ងៃនៃសប្តាហ៍) នៅពេលព្រឹកព្រលឹម ឬ ម៉ោងសិក្សាអំពីសាសនាសម្រាប់ថ្នាក់សិក្ខាសាលាឡើយ ។

កម្មវិធីសិក្សានៅផ្ទះអនុញ្ញាតឲ្យសិស្សទទួលបានក្រេឌីតនៅក្នុងថ្នាក់សិក្ខាសាលា តាមរយៈការបំពេញមេរៀននីមួយៗនៅផ្ទះជាជាងចូលរួមរៀននៅក្នុងថ្នាក់រៀងរាល់ថ្ងៃនៃសប្តាហ៍ ។ មេរៀនទាំងនេះមាននៅក្នុងសៀវភៅសិក្សាផ្សេងមួយទៀត *សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ:* ។ មួយសប្តាហ៍ម្តង សិស្សនឹងជួបជាមួយនឹងគ្រូបង្រៀនថ្នាក់សិក្ខាសាលា ដើម្បីប្រគល់កិច្ចការរបស់ពួកគេ និង ចូលរួមក្នុងមេរៀនប្រចាំសប្តាហ៍ ។ សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស និង មេរៀនប្រចាំសប្តាហ៍ ត្រូវបានពន្យល់បន្ថែមទៀតនៅខាងក្រោមនេះ: ។

សៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សសិក្សានៅផ្ទះ

សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ: ត្រូវបានរៀបចំឡើងដើម្បីជួយសិស្សដែលសិក្សានៅផ្ទះ: ឲ្យទទួលនូវបទពិសោធន៍នៅក្នុងការសិក្សាព្រះគម្ពីរសញ្ញាថ្មី ស្រដៀងនឹងសិស្សដែលចូលរៀននៅក្នុងថ្នាក់រៀន រៀងរាល់ថ្ងៃនៃសប្តាហ៍ដែរ ។ ហេតុដូច្នោះហើយ ល្បឿនបង្រៀននៃសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ព្រមទាំងគោលលទ្ធិ និង គោលការណ៍ដែលវាបញ្ជាក់អត្ថន័យនោះ: វាស្របទៅនឹងមេរៀននៅក្នុងសៀវភៅសិក្សានេះ: ។ សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ក៏រួមមាននូវសេចក្តីណែនាំអំពីចំណេះចំណានខគម្ពីរផងដែរ ។ វគ្គចំណេះចំណានខគម្ពីរត្រូវបានរៀបរាប់នៅក្នុងបរិបទ ដូចដែលវាមាននៅក្នុងអត្ថបទព្រះគម្ពីរ ហើយជាញឹកញាប់សកម្មភាពសរសេរនានា ត្រូវបានផ្តល់ឲ្យនៅក្នុងមេរៀននានាដែលមានវគ្គបទគម្ពីរនោះ: ។

រៀងរាល់សប្តាហ៍ សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ: ត្រូវបញ្ចប់មេរៀនបួនមកពីសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ហើយចូលរួមនៅក្នុងមេរៀនប្រចាំសប្តាហ៍មួយ ដែលបង្រៀនដោយគ្រូថ្នាក់សិក្ខាសាលារបស់ពួកគេ ។ សិស្សបំពេញកិច្ចការមួយចំនួនពីសៀវភៅមគ្គុទេសន៍ការសិក្សា នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សិស្សគួរតែមានសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរពីរក្បាល ដូច្នេះពួកគេអាចទុកមួយនៅជាមួយគ្រូ ហើយទុកមួយទៀតសម្រាប់សរសេរខ្លួនឯង ។ នៅពេលសិស្សជួបជាមួយគ្រូរបស់ខ្លួនរាល់សប្តាហ៍ សៀវភៅកំណត់ហេតុមួយដែលសិក្សានៅផ្ទះត្រូវឲ្យទៅគ្រូ ហើយសៀវភៅមួយក្បាលទៀតត្រូវប្រគល់ឲ្យសិស្សវិញ ដើម្បីប្រើសរសេរមេរៀនបន្ទាប់ ។ (ឧទាហរណ៍ អំឡុងមួយសប្តាហ៍ សិស្សបញ្ចប់កិច្ចការនៅក្នុងសៀវភៅកំណត់ហេតុទីមួយ ។ បន្ទាប់មក សិស្សយកសៀវភៅកំណត់ហេតុនោះទៅថ្នាក់រៀន ហើយប្រគល់វាទៅឲ្យគ្រូបង្រៀន ។ អំឡុងសប្តាហ៍បន្ទាប់ សិស្សបញ្ចប់កិច្ចការនៅក្នុងសៀវភៅកំណត់ហេតុទីពីរ ។ នៅពេលសិស្សប្រគល់សៀវភៅកំណត់ហេតុទីពីរឲ្យគ្រូ នោះគ្រូនឹងឲ្យសៀវភៅកំណត់ហេតុទីមួយមកសិស្សវិញ ។ បន្ទាប់មក សិស្សប្រើសៀវភៅកំណត់ហេតុទីមួយដើម្បីបំពេញកិច្ចការនៅសប្តាហ៍បន្ទាប់) ។

សិស្សថ្នាក់សិក្ខាសាលាទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ហើយអានមេរៀននានា ប៉ុន្តែសិស្សសិក្សានៅផ្ទះគួរយល់ថា ពួកគេត្រូវបានពឹងឲ្យចំណាយពេលពី ៣០ ទៅ ៤០ នាទីបន្ថែមទៀតសម្រាប់មេរៀននីមួយៗនៅក្នុងមេរៀនទាំងបួននៃមេរៀនការសិក្សានៅផ្ទះនៅក្នុងមេរៀននីមួយៗ ហើយចូលរួមនៅក្នុងថ្នាក់សិក្សានៅផ្ទះប្រចាំសប្តាហ៍ ។

មេរៀនប្រចាំសប្តាហ៍សម្រាប់គ្រូបង្រៀនដែលបង្រៀនសិស្សនៅផ្ទះ

មេរៀននីមួយៗនៅក្នុង *សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ:* ត្រូវគ្នានឹងមេរៀនចំនួនប្រាំ នៅក្នុងសៀវភៅសិក្សាប្រចាំថ្ងៃរបស់គ្រូបង្រៀន ។ បន្ទាប់ពីមេរៀនទីប្រាំនៅក្នុងសៀវភៅសិក្សានេះ អ្នកនឹងឃើញមានមេរៀនប្រចាំសប្តាហ៍មួយ សម្រាប់គ្រូបង្រៀនដែលបង្រៀនសិស្សនៅផ្ទះ: ។ មេរៀនសិក្សានៅផ្ទះនឹងជួយសិស្សឲ្យរឭក ពង្រីកការយល់ដឹងរបស់ពួកគេ និង អនុវត្តគោលលទ្ធិ និង គោលការណ៍ដែលពួកគេបានរៀន នៅពេលពួកគេបញ្ចប់មេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សអំឡុងសប្តាហ៍នោះ: ។ មេរៀនទាំងនេះអាចបង្ហាញនូវសេចក្តីពិតបន្ថែម ដែលពុំមាននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ។ (សម្រាប់ជំនួយនៅក្នុងការរៀបចំកាលវិភាគមេរៀនរបស់អ្នក សូមមើលសេចក្តីណែនាំពីល្បឿននៃការបង្រៀនសម្រាប់គ្រូបង្រៀនសិស្សដែលសិក្សានៅផ្ទះ: នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ:) ។

ក្នុងនាមជាគ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះម្នាក់ អ្នកអាចមានការយល់ដឹងទាំងស្រុងអំពីអ្វី ដែលសិស្សរបស់អ្នកកំពុងសិក្សានៅផ្ទះរាល់សប្តាហ៍ ដូច្នេះអ្នកអាចឆ្លើយសំណួរ និង បង្កើតការពិភាក្សានានាដ៏មានអត្ថន័យ នៅពេលអ្នកជួបជាមួយនឹងពួកគេ ។ សូមឲ្យសិស្សយកព្រះគម្ពីរ សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ និង សៀវភៅមគ្គុទេសន៍ការសិក្សាសិស្ស របស់ពួកគេមកថ្នាក់រៀនរាល់សប្តាហ៍ ដូច្នេះពួកគេអាចប្រើប្រាស់វាពេលកំពុងរៀន ។ សូមសម្របសម្រួលមេរៀននានាស្របទៅតាមតម្រូវការរបស់សិស្ស នៅពេលអ្នកបង្រៀន និង ស្របទៅតាមការណែនាំនៃព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកក៏អាចប្រើប្រាស់មេរៀនប្រចាំថ្ងៃរបស់គ្រូបង្រៀននៅក្នុងសៀវភៅសិក្សានេះ: នៅពេលអ្នករៀបចំ និង បង្រៀនផងដែរ ។ ការសិក្សាពីជំនួយក្នុងការបង្រៀន និង វិធីសាស្ត្រនានា ដែលបានប្រើនៅក្នុងមេរៀនប្រចាំថ្ងៃ អាចជួយពង្រីកការបង្រៀនប្រចាំសប្តាហ៍របស់អ្នក ។ សូមតម្រូវទៅតាមសេចក្តីត្រូវការពិសេសនានានៃសិស្សដែលអ្នកបង្រៀន ។ ឧទាហរណ៍ ប្រសិនបើសិស្សម្នាក់មានការលំបាកក្នុងការសរសេរ សូមឲ្យគាត់ប្រើម៉ាស៊ីនថតសំឡេង ឬ និយាយគំនិតនោះទៅសមាជិកគ្រួសារ ឬ មិត្តភក្តិ ដែលអាចសរសេរចម្លើយរបស់គាត់ទុក ។

នៅចុងបញ្ចប់នៃមេរៀនរាល់សប្តាហ៍ សូមប្រមូលសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់សិស្ស ហើយលើកទឹកចិត្តពួកគេឲ្យបន្តការសិក្សារបស់ពួកគេ ។ សូមផ្តល់សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ សម្រាប់កិច្ចការសប្តាហ៍បន្ទាប់ ដូចដែលបានពន្យល់ពីខាងលើនៅក្នុងវគ្គដែលហៅថា « សៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សដែលសិក្សានៅផ្ទះ: » ។ (ក្រោមការដឹកនាំថ្នាក់ដឹកនាំបព្វជិតភាព និង ឪពុកម្តាយ នោះគ្រូបង្រៀនថ្នាក់សិក្ខាសាលាប្រចាំស្តេក [ដែលបានហៅ] អាចទាក់ទងសិស្សថ្នាក់សិក្ខាសាលាតាមប្រព័ន្ធអេឡិចត្រូនិច ជាមួយសិស្សដែលចុះឈ្មោះចូលរៀនថ្នាក់សិក្ខាសាលានៅផ្ទះបាន) ។

នៅពេលអ្នកអានកិច្ចការរបស់សិស្ស នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់សិស្សចប់ហើយ សូមឆ្លើយតបចំពោះកិច្ចការរបស់ពួកគេម្តងម្កាល ដោយសរសេរកំណត់ចំណាំ ឬ មូលវាចារណ៍ខ្លីមួយ នៅពេលអ្នកជួបពួកគេលើកក្រោយ ។ អ្នកក៏អាចស្វែងរកវិធីនានាដើម្បីផ្តល់ការគាំទ្រ និង ផ្តល់មតិកែលម្អដ៏មានអត្ថន័យផងដែរ ។ ការណ៍នេះនឹងជួយសិស្សឲ្យដឹងថា អ្នកខ្វល់អំពីកិច្ចការរបស់ពួកគេ និង ជួយជំរុញទឹកចិត្តពួកគេឲ្យធ្វើកិច្ចការរបស់ពួកគេបានកាន់តែហ្មត់ចត់ ។

កិច្ចខិតខំភាគច្រើនរបស់សិស្ស ដើម្បីសូត្រវគ្គបទគម្ពីរគេខ្លឹះឲ្យចាំស្ទាត់នឹងអាចធ្វើបាន នៅពេលពួកគេបំពេញមេរៀនសិក្សានៅផ្ទះរបស់ខ្លួន។ គ្រូបង្រៀនដែលបង្រៀនសិស្សនៅផ្ទះ: អាចតាមដានកិច្ចខិតខំរបស់សិស្ស អំឡុងពេលមេរៀនសិក្សានៅផ្ទះ: ដោយអញ្ជើញសិស្សឲ្យសូត្រ ឬ រឭកវគ្គចំណេះចំណានខគម្ពីរដែលមាននៅក្នុងអត្ថបទសម្រាប់មេរៀនសិក្សានៅសប្តាហ៍នោះ: ។

ធនធានផ្សេងទៀត

LDS.org

ព្រះគម្ពីរសញ្ញាថ្មី សៀវភៅសិក្សាសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលា (nttm.lds.org) និង *សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ:* មាននៅលើគេហទំព័រ LDS.org និងនៅក្នុងកម្មវិធីបណ្ណាល័យដំណឹងល្អសម្រាប់ឧបករណ៍ចល័ត ។ កំណែឌីជីថលនៃសៀវភៅសិក្សាសម្រាប់គ្រូបង្រៀននេះមាននូវសេចក្តីពន្យល់ និង ព័ត៌មានសាច់រឿងបន្ថែម គំនិតបន្ថែមសម្រាប់ការបង្រៀន និងធនធានសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ដែលពុំបានដាក់បញ្ចូលនៅក្នុងសៀវភៅសិក្សាដែលបានបោះពុម្ព ដោយសារតែទំហំមានកំណត់ ។

si.lds.org

គ្រូបង្រៀនអាចមើលគេហទំព័រនៃថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនា (si.lds.org) សម្រាប់ជំនួយនៅក្នុងការរៀបចំមេរៀន និង ស្វែងរកគំនិតបន្ថែមសម្រាប់ការបង្រៀន ។

Notes and Journal Tools (ឧបករណ៍កំណត់ចំណាំ និង កំណត់ហេតុ)

គ្រូបង្រៀន និង សិស្សអាចប្រើ Notes and Journal tools (ឧបករណ៍កំណត់ចំណាំ និង កំណត់ហេតុ) តាមអ៊ីនធើរណែត និង ឧបករណ៍ចល័តដើម្បីគូសចំណាំ និង បន្ថែមកំណត់ចំណាំក្នុងកំណែឌីជីថលនៃសៀវភៅសិក្សាទាំងនេះ នៅពេលពួកគេរៀបចំមេរៀន និង សិក្សាព្រះគម្ពីរ ។ សៀវភៅសិក្សារបស់គ្រូបង្រៀន និង សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សក៏មាននៅ LDS.org ដើម្បីទាញយកជាទម្រង់នានា (ដូចជាឯកសារ PDF, ePub, និង mobi [Kindle]) ។

សម្ភារបន្ថែម

ធនធានខាងក្រោមនេះមាននៅលើអ៊ីនធើរណែត តាមរយៈអ្នកគ្រប់គ្រងរបស់អ្នក តាមរយៈមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រនៅក្នុងមូលដ្ឋាន និង តាមរយៈហាងទំនិញតាមអ៊ីនធើរណែតរបស់សាសនាចក្រនៅគេហទំព័រ (store.lds.org) ៖



New Testament DVD Presentations ១–២៥
(ទំនិញ ល.រ. ៥៤០១៤)




Media Library នៅលើគេហទំព័រ LDS.org



Gospel Art Book
(ទំនិញល.រ. ០៦០៤៨)



Scripture Study Journal
(ទំនិញ ល.រ. ០៩៥៩១)




New Testament Bookmark
(ទំនិញ ល.រ. ១០៤៦០)



New Testament Scripture Mastery Cards and Scripture Reading Charts
(ទំនិញ ល.រ. ១០៤៨០)



ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងដំណឹងល្អ
(ទំនិញ ល.រ. ៣៦៨៦៣)



ប្រធានបទដំណឹងល្អនៅលើគេហទំព័រ LDS.org



ដើម្បីកម្លាំងនៃយុវជន កូនសៀវភៅ
(ទំនិញ ល.រ. ០៩៤០៣)



New Testament Student Manual (Church Educational System manual ឆ្នាំ ២០១៤)
(ទំនិញ ល.រ. ១០៧៣៤)



ថង់ដាក់ឯកសារថ្នាក់សិក្ខាសាលា (សម្រាប់សិស្សរក្សាទុកក្រដាសចែក និង ឯកសារដែលបាត់ផ្សេងៗទៀត) (ទំនិញលេខ. ០៩៨២៧, មានតែជាភាសាអង់គ្លេសប៉ុណ្ណោះ)





មេរៀន ១

សេចក្តីផ្តើមអំពីព្រះគម្ពីរសញ្ញាថ្មី

សេចក្តីផ្តើម

ព្រះគម្ពីរសញ្ញាថ្មី គឺជាកំណត់ត្រាដ៏សំខាន់មួយអំពីជីវិតរមែងស្លាប់ ការបង្រៀន និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ការស្តាបនាសាសនាចក្ររបស់ទ្រង់ ហើយនិងការបម្រើនៃពួកសិស្សរបស់ទ្រង់កាលពីបុរាណ នៅពេលទ្រង់បានបន្តដឹកនាំពួកគេ បន្ទាប់ពីការយាងត្រឡប់ទៅស្ថានសួគ៌វិញរបស់ទ្រង់ ។ មេរៀននេះមានគោលបំណងរៀបចំខ្លួន ហើយលើកទឹកចិត្តសិស្សឲ្យសិក្សាព្រះគម្ពីរសញ្ញាថ្មី ដោយណែនាំពួកគេឲ្យស្គាល់ពីមូលបទសំខាន់ពីរដែលមាននៅក្នុងការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ និងពួកសាវករបស់ទ្រង់កាលពីបុរាណ ៖ ការអញ្ជើញម្តងហើយម្តងទៀតរបស់ព្រះអង្គសង្គ្រោះឲ្យមករកទ្រង់ និង ទំនួលខុសត្រូវនៃពួកសិស្សរបស់ទ្រង់ដើម្បីជួយមនុស្សដទៃទៀតឲ្យធ្វើរឿងដូចគ្នា ។

យោបល់សម្រាប់ការបង្រៀន

ព្រះគម្ពីរសញ្ញាថ្មីជួយយើងឲ្យមករកព្រះយេស៊ូវគ្រីស្ទ

សូមសរសេរសំណួរខាងក្រោមនេះ នៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ *តើបន្ទុកដ៏លំបាកមួយចំនួនដែលយុវវ័យជួបនៅក្នុងសម័យយើងនេះមានអ្វីខ្លះ ?*

សូមយកប្រអប់ទទេរ ឬកាបូបស្ពាយមួយ ព្រមទាំងរបស់ធ្ងន់ៗដើម្បីដាក់នៅក្នុងប្រអប់ ឬកាបូបនោះដូចជា ដុំថ្ម ឬសៀវភៅទៅថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខក្តារខៀន ហើយឲ្យគាត់កាន់ប្រអប់ទទេរ ឬស្ពាយកាបូបនោះ ។ ចូរសុំឲ្យសិស្សផ្សេងទៀតឆ្លើយនឹងសំណួរដែលមាននៅលើក្តារខៀន ហើយសុំឲ្យសិស្សម្នាក់ទៀតឡើងមកសរសេរចម្លើយរបស់សិស្សនោះ នៅលើក្តារខៀន ។ បន្ទាប់ពីទទួលបានចម្លើយនីមួយៗ សូមដាក់របស់ធ្ងន់មួយនៅក្នុងប្រអប់ ឬកាបូបនោះរហូតដល់វាពេញ ។

- **តើអ្នកមានអារម្មណ៍បែបណាដែរ ប្រសិនបើអ្នកត្រូវទ្រាំបន្ទុកនេះពេញមួយថ្ងៃ ?**

សុំឲ្យសិស្សពន្យល់ពីការប្រឈម ឬការលំបាកនានាដែលបន្ទុកមួយចំនួន ដែលបានសរសេរនៅលើក្តារខៀនអាចបង្កដល់មនុស្សម្នាក់ ។

សូមពន្យល់ថា ព្រះគម្ពីរសញ្ញាថ្មីបង្រៀនយើងអំពីការបម្រើនៅក្នុងជីវិតរមែងស្លាប់ និង ក្រោយការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ រួមបញ្ចូលទាំងការបង្រៀន អព្ភូតហេតុ ពលិកម្មធួន និងការយាងរបស់ទ្រង់ទៅជួបនឹងពួកសិស្សនៃសាសនាចក្រកាលពីបុរាណ ។ តាមរយៈការបង្រៀនទាំងឡាយ និងទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្សដទៃទៀតនោះវាគឺជាសេចក្តីពិតមួយដែលបានលើកឡើងម្តងហើយម្តងទៀត ដែលអាចជួយយើងសម្រាលបន្ទុកដែលយើងមាន ។


សូមពន្យល់ថា ម៉ាថាយ ១១ មានដាក់បញ្ចូលនូវឧទាហរណ៍មួយនៃបាវចនាដ៏សំខាន់នេះដែលសិស្សនឹងឃើញជារឿយៗនៅក្នុងការសិក្សារបស់ពួកគេអំពីព្រះគម្ពីរសញ្ញាថ្មីនាឆ្នាំនេះ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១១:២៨ ឲ្យឮៗ ។ សុំឲ្យសិស្សផ្សេងទៀតផ្លាស់តាម ដោយរកមើលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះទៅកាន់អស់អ្នកដែលទ្រទ្រង់បន្ទុកធ្ងន់ ។

- **តើអ្នកគិតថា ការនឿយព្រួយ ហើយមានផ្ទុកធ្ងន់ មានន័យដូចម្តេច ?**
- **តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានសេចក្តីសម្រាករបស់ទ្រង់ ? (សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ រួមជាមួយនឹងបន្ទុករបស់យើងនោះទ្រង់នឹងឲ្យយើងបានសម្រាក**) ។**
- **តើអ្នកគិតថា ការមករកព្រះយេស៊ូគ្រីស្ទមានន័យដូចម្តេច ?**

ដើម្បីជួយសិស្សឲ្យយល់ដឹងពីអត្ថន័យនៃការមករកព្រះគ្រីស្ទ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១១:២៩–៣០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្លាស់តាម ហើយស្វែងរកបន្ទូលណែនាំរបស់ព្រះអង្គសង្គ្រោះទៅកាន់អស់អ្នកដែលមានបំណងប្រាថ្នាចង់មករកទ្រង់ ។

- **យោងតាមខគម្ពីរទាំងនេះ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមករកព្រះគ្រីស្ទ ?**

សូមគូរ រូប នឹមគោមួយនៅលើក្តារខៀន ឬបង្ហាញរូបនឹមមួយ ។



សូមពន្យល់ថា នឹមគឺជាធ្មឹម ឈើមួយ ដែលភ្ជាប់ ឬដាក់គោ ឬ សត្វដទៃទៀតមួយនឹម ដើម្បីឲ្យវាអាចទាញបន្ទុកមួយរួមគ្នា ។

- **តើអ្វីទៅជាគោលបំណង និង អត្ថប្រយោជន៍របស់នឹម ? (ទោះបីជា នឹមនោះគឺជាទម្ងន់ ឬបន្ទុកមួយក្តី ក៏វាអនុញ្ញាតឲ្យសត្វទាំងពីរក្បាលរួមថាមពល និង កម្លាំងរបស់វា ដើម្បីបង្កើននូវផលិតភាពរបស់វាដែរ) ។**
- **តើអ្នកគិតថា ការទទួលយកនឹមរបស់ព្រះអង្គសង្គ្រោះដាក់មកលើយើង មានន័យដូចម្តេច ?**

សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះមកពីអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ សុំឲ្យសិស្សស្តាប់ ហើយគិតពីរបៀបដែលយើងអាចយកនឹមរបស់ព្រះអង្គសង្គ្រោះមកដាក់លើយើង ហើយថាតើពរជ័យអ្វីខ្លះដែលយើងអាចទទួលបានតាមរយៈការធ្វើដូច្នេះ ។



« នីមមួយទីម សត្វឲ្យដើរទន្ទឹមគ្នា ដើម្បីវាអាចឈានទៅមុខទាំងអស់គ្នា ក្នុងការសម្រេចកិច្ចការមួយ។

« ចូរពិចារណាអំពីការអញ្ជើញដ៏ពិសេសរបស់ព្រះអម្ចាស់ដល់យើងម្នាក់ៗថា ‹ ចូរទទួលនីមខ្ញុំចុះ › ។ ការចុះនិងការរក្សាសេចក្តីសញ្ញាពិសិដ្ឋ គឺជាការទីមយើងជាមួយនឹងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ មានន័យថា ព្រះអង្គសង្គ្រោះកំពុងតែអញ្ជើញយើង ឲ្យពឹងផ្អែក ហើយទាញជាមួយនឹងទ្រង់ ទោះជាសមត្ថភាពល្អបំផុតរបស់យើង មិនស្មើ ឬមិនអាចប្រៀបនឹងទ្រង់ក៏ដោយ ។ កាលណាយើងទុកចិត្ត ហើយទាញបន្ទុកយើងជាមួយទ្រង់ ក្នុងដំណើរនៃជីវិតរមែងស្លាប់នេះ នោះនីមទ្រង់ពិតជាងាយ ហើយបន្ទុកទ្រង់ពិតជាស្រាល ។

« យើងនឹងពុំនៅម្នាក់ឯងឡើយ ។ យើងអាចឆ្ពោះទៅមុខក្នុង ជីវិតប្រចាំថ្ងៃរបស់យើង ដោយមានជំនួយពីស្ថានសួគ៌ ។ តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះយើងអាចទទួលបានសមត្ថភាព និង ‹ លើសកម្លាំង[របស់យើង] › (‹ ខ្ញុំនឹងដើរតាមព្រះអង្គ › *ទំនុកតម្កើង* លេខ ១៣៥) » (« Bear Up Their Burdens with Ease » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៨៨) ។

- តើអ្វីទៅដែល« ទីម »យើងនឹងព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ?
- យោងតាមអែលឌើរ បែដណា តើពរជ័យនៃការជាប់នឹមជាមួយព្រះអង្គសង្គ្រោះមានអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា ការសន្យារបស់ព្រះអង្គសង្គ្រោះអំពី « សេចក្តីសំរាក » នៅក្នុង ម៉ាថាយ ១១:២៨–២៩ ពុំមានន័យថា ទ្រង់នឹងដកយកបញ្ហា ឬការប្រឈមរបស់យើងជានិច្ចនោះទេ ។ ជារឿយៗ ព្រះអង្គសង្គ្រោះនឹងប្រទានសេចក្តីសុខសាន្ត និង កម្លាំងដែលយើងត្រូវការដល់យើងដើម្បីយកឈ្នះ ឬស៊ូទ្រាំនឹងការសាកល្បងរបស់យើង ហេតុដូច្នេះហើយទើបធ្វើឲ្យបន្ទុករបស់យើងបានស្រាល ។ ប្រសិនបើយើងស្មោះត្រង់នៅក្នុងការប្រឈមទាំងឡាយនៃជីវិតរមែងស្លាប់ សេចក្តីសំរាកដែលយើងនឹងទទួលបានគឺជាភាពតម្កើងឡើងជាមួយនឹងព្រះ (សូមមើល គ. និង ស. ៨៤:២៣–២៤) ។

សុំឲ្យសិស្សពិចារណាពីរបៀបដែលព្រះអង្គសង្គ្រោះបានប្រទានសេចក្តីសំរាកដល់ពួកគេ នៅពេលពួកគេមករកទ្រង់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សដទៃទៀតនៅក្នុងថ្នាក់ ។ អ្នកគួរពិចារណាចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយរបស់អ្នក ។

សូមអញ្ជើញសិស្សដាក់គោលដៅជាក់លាក់នានាអំពីរបៀបដែលពួកគេអាចមករកព្រះយេស៊ូវគ្រីស្ទពេញមួយឆ្នាំ ក្នុងការសិក្សាអំពីព្រះគម្ពីរសញ្ញាថ្មីនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់បញ្ចូលការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ និង ការអាន ព្រះគម្ពីរសញ្ញាថ្មី ទាំងមូលនៅឆ្នាំនេះក្នុងគោលដៅរបស់ពួកគេ ។

សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ

សូមលើកទឹកចិត្តសិស្ស ឲ្យញែកពេលវេលារៀងរាល់ថ្ងៃ សម្រាប់ការសិក្សាផ្ទាល់ខ្លួនអំពីព្រះគម្ពីរសញ្ញាថ្មី ។ អ្នកអាចជួយពួកគេឲ្យផ្តល់ព័ត៌មានលម្អិតពីការសិក្សាប្រចាំថ្ងៃរបស់ពួកគេ ដោយផ្តល់ប្រព័ន្ធតាមដានដ៏ត្រឹមត្រូវមួយ (សូមមើលតារាងការអាននៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ) ។ សូមផ្តល់ឲ្យសិស្សនូវឱកាសជាទៀងទាត់ ដើម្បីចែកចាយអ្វីដែលពួកគេកំពុងរៀន និងអារម្មណ៍ពេលពួកគេធ្វើការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ។ សូមប្រុងប្រយ័ត្ន កុំធ្វើឲ្យសិស្សដែលប្រឈមមុខនឹងបញ្ហាក្នុងការសិក្សាព្រះគម្ពីរដោយខ្លួនឯងអៀនខ្មាស់ ឬបាក់ទឹកចិត្ត ។

ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទមានទំនួលខុសត្រូវមួយដើម្បីជួយមនុស្សដទៃទៀតឲ្យមករកទ្រង់ ។

ចូរសុំឲ្យសិស្សគិតពីគ្រានានានៅក្នុងជីវិតរបស់ពួកគេ ដែលពួកគេមានបំណងចង់ប្រាប់នរណាម្នាក់ពីបទពិសោធន៍មួយដែលពួកគេមាន ឬអ្វីមួយដែលពួកគេបានឃើញ បានអាន ឬបានស្តាប់ឮដោយក្តីរំភើប ។ សូមអញ្ជើញសិស្សពីរបីនាក់រាយការណ៍ពីអ្វីមួយដែលពួកគេមានបំណងចង់ប្រាប់មនុស្សម្នាក់ដោយក្តីរំភើប ។

សូមពន្យល់ថា ព្រះគម្ពីរសញ្ញាថ្មីមានឧទាហរណ៍ជាច្រើនពីបុគ្គលដែលទទួលបានការពង្រឹង ការបង្រៀន ឬមានពរដោយសារព្រះអម្ចាស់រួចហើយមានបំណងចង់ប្រាប់មនុស្សដទៃទៀតអំពីទ្រង់ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ១:៣៧-៤២ ។ សុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ដោយស្វែងរកអ្វីដែលពួកសិស្សពីរនាក់របស់យ៉ូហាន បាទីស្ទ បានធ្វើ ក្រោយពីស្តាប់ឮទីបន្ទាល់របស់លោកអំពីព្រះយេស៊ូវ ។

- តើអនទ្រេបានរៀនអ្វីខ្លះអំពីព្រះយេស៊ូវ ពេលលោកនិយាយនឹងទ្រង់ ?
- តើអនទ្រេបានធ្វើអ្វីខ្លះក្រោយពីលោកបានដឹងថា ព្រះយេស៊ូវគឺជាព្រះមែស៊ី ?
- ហេតុអ្វីអ្នកគិតថាគាត់មានចិត្តត្រេកអរដើម្បីចែចាយដំណឹងនេះដល់ប្អូនប្រុសរបស់លោកឈ្មោះ ស៊ីម៉ូន-ពេត្រុស ?

សូមសង្ខេប យ៉ូហាន ១:៤៣–៤៤ ដោយប្រាប់សិស្សថា ព្រះអង្គសង្គ្រោះបានអញ្ជើញបុរសម្នាក់ឈ្មោះភីលីពឲ្យធ្វើជាសិស្សរបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១:៤៥–៤៦ ឲ្យឮៗ ។ សុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ដោយរកមើលថាតើភីលីព បានធ្វើអ្វីខ្លះក្រោយពីលោកបានដឹងថា ព្រះយេស៊ូវគឺជាព្រះមែស៊ី ។

- តើភីលីព បាននិយាយអ្វីខ្លះទៅកាន់ ណាថាណែលអំពីព្រះយេស៊ូវពីស្រុកណាសារ៉ែត ?
- តើណាថាណែល បានឆ្លើយតបយ៉ាងណាដែរចំពោះទីបន្ទាល់របស់ភីលីពដែលថ្លែងថា ព្រះយេស៊ូវគឺជាព្រះមែស៊ី ?
- តើការអញ្ជើញរបស់ភីលីពដល់ណាថាណែលគឺជាអ្វីទៅ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ . . .*

- យោងតាមឧទាហរណ៍ទាំងនេះនៅក្នុងព្រះគម្ពីរសញ្ញាថ្មី តើយើងនឹងមានបំណងប្រាថ្នាអ្វីខ្លះ នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ ? (នៅពេលសិស្សឆ្លើយ សូមបំពេញប្រយោគនៅលើក្តារខៀន ដើម្បីវាឆ្លុះបញ្ចាំងពីគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងមានបំណងប្រាថ្នាដ៏ធំធេងមួយដើម្បីអញ្ជើញមនុស្សដទៃទៀតឲ្យមករកទ្រង់**) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរពីគោលការណ៍នេះ សូមចម្លង តារាង ដែលភ្ជាប់មកជាមួយនេះ ដាក់លើក្តារខៀន ៖

- ហេតុអ្វីអ្នកគិតថាយើងនឹងមានបំណងប្រាថ្នាដ៏ធំធេងមួយដើម្បីអញ្ជើញមនុស្សដទៃទៀតឲ្យមករកព្រះគ្រីស្ទ នៅពេលយើងមករកទ្រង់ដោយខ្លួនឯងនោះ ?

សូមពន្យល់ថា ប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ បានបង្រៀនពីពរជ័យដ៏អស្ចារ្យមួយដែលយើងទទួលបាន នៅពេលយើងអញ្ជើញមនុស្សដទៃទៀតឲ្យមករកព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ៖

« នៅពេលអ្នកអញ្ជើញមនុស្សដទៃទៀត ឲ្យមករកព្រះគ្រីស្ទដោយអស់ពីចិត្ត នោះដួងចិត្តអ្នកនឹងមានការផ្លាស់ប្តូរ ។ . . . តាមរយៈការជួយមនុស្សដទៃទៀតឲ្យមករកព្រះគ្រីស្ទ អ្នកនឹងរកឃើញថា អ្នកបានមករកទ្រង់ដោយខ្លួនឯង » (« Come unto Christ » *Ensign,* ខែ មីនា ឆ្នាំ២០០៨ ទំព័រ ៤៩) ។

- នៅពេលយើងអញ្ជើញមនុស្សដទៃទៀតឲ្យមករកព្រះយេស៊ូវគ្រីស្ទ តើមានអ្វីអាចកើតឡើងនៅក្នុងជីវិតយើង ?

សូមបន្ថែមសញ្ញាព្រួញមួយក្នុងរូបគំនូរលើក្តារខៀន ដើម្បីឲ្យវាមានភាពស្រដៀងគ្នាទៅនឹង តារាង ដែលភ្ជាប់មកជាមួយនោះ ៖

- ហេតុអ្វីបានជាអ្នកគិតថា ការអញ្ជើញមនុស្សដទៃទៀតឲ្យមករកព្រះគ្រីស្ទអាចជួយយើងឲ្យខិតកាន់តែជិតនឹងទ្រង់ផងដែរ ?
- តើនរណាបានអញ្ជើញអ្នកឲ្យមករកព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ? តើជីវិតរបស់អ្នកមានពរជ័យយ៉ាងណាដែរដោយសារទង្វើនេះ ?

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាប្រកបដោយការអធិស្ឋានពីមនុស្ស ដែលពួកគេអាចអញ្ជើញឲ្យមករកព្រះយេស៊ូវគ្រីស្ទ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីអញ្ជើញមនុស្សដទៃទៀតឲ្យមករកទ្រង់ ?


សូមពន្យល់ថា ការអញ្ជើញមិត្តភក្តិ និង មិត្តរួមថ្នាក់ឲ្យចូលរួមថ្នាក់សិក្ខាសាលាគឺជាវិធីមួយដែលសិស្សអាចអញ្ជើញមនុស្សដទៃទៀតឲ្យ « មកឃើញ »ថាតើព្រះយេស៊ូវគ្រីស្ទគឺជានរណា និងឃើញពីរបៀបដែលដំណឹងល្អរបស់ទ្រង់អាចប្រទានពរដល់ជីវិតរបស់ពួកគេ ។


សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១:៤៧–៥០ ឲ្យឮៗ ។ សុំឲ្យសិស្សផ្សេងទៀតផ្លាស់តាម ដោយរកមើលអ្វីដែល ណាថាណែល បានដកពិសោធន៍នៅពេលលោកបានជួបនឹងព្រះអង្គសង្គ្រោះ (សូមពន្យល់ថា ឃ្លា « គ្មានកលឧបាយ »មានន័យថា គ្មានការបោកបញ្ឆោត) ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលអ្វីខ្លះទើបធ្វើឲ្យ ណាថាណែល ប្រកាសថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ?
- យោងតាម ខទី ៥០តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះ ដល់ណាថាណែល ដោយសារតែលោកបានជឿ ?

សូមពន្យល់ថា ណាថាណែល ព្រមជាមួយនឹង អនទ្រេ ពេត្រុស ភីលីព និង អ្នកផ្សេងទៀតបានក្លាយជាសិស្សរបស់ព្រះយេស៊ូវ ។ ដោយសារពួកសាវកទាំងនេះបានស្តាប់តាមការអញ្ជើញឲ្យមករកព្រះយេស៊ូវគ្រីស្ទ នោះពួកគេបានឃើញ « ការដ៏ធំវិសេស » (ខទី ៥០) រួមបញ្ចូលទាំងអព្ភូតហេតុ និង ការបង្រៀនទាំងឡាយរបស់ព្រះយេស៊ូវគ្រីស្ទ និងការមានព្រះជន្មឡើងវិញ ព្រមទាំងការយាងឡើងទៅស្ថានសួគ៌វិញរបស់ទ្រង់ ។

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ថា នៅពេលសិស្សសិក្សាព្រះគម្ពីរសញ្ញាថ្មីនាឆ្នាំនេះ នោះពួកគេនឹងមានអារម្មណ៍ពីការទូលអង្វរជាបន្តបន្ទាប់របស់ព្រះអង្គសង្គ្រោះឲ្យមករកទ្រង់ ។ នៅពេលពួកគេអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលពួកគេរៀននៅក្នុងឆ្នាំនេះ ពួកគេនឹងទទួលបានជំនួយរបស់ទ្រង់ដើម្បីសម្រាលបន្ទុករបស់ពួកគេ ហើយពោរពេញដោយបំណងប្រាថ្នាដើម្បីជួយដល់មនុស្សដទៃទៀតឲ្យមករកទ្រង់ដូចជាពួកសាវកពីបុរាណផងដែរ ។





សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាថាយ ១១:២៩–៣០ ។ « ចូរទទួលនឹមខ្ញុំ »

ប្រធាន ហាវីដ ជបុលយូ ហ៊ីនធើរ បានបង្រៀនពីពរជ័យដែលកើតមាននៅពេលយើងទទួលនឹមរបស់ព្រះគ្រីស្ទ ៖

« ក្នុងសម័យព្រះគម្ពីរប៊ីប នឹមគឺជាឧបករណ៍មួយដែលផ្តល់ជំនួយយ៉ាងខ្លាំងដល់អ្នកដែលភ្ជួររាស់ដី ។ វាបានអនុញ្ញាតឲ្យកម្លាំងរបស់សត្វពាហនៈទីពីរជួយគាំទ្រដល់ការខិតខំរបស់សត្វពាហនៈតែមួយ ដោយចែករំលែក ហើយកាត់បន្ថយការងារដ៏ធ្ងន់របស់ន័ង្គល ឬរទេះនោះ ។ បន្ទុកមួយដែលមានភាពលើសលុប ឬប្រហែលជាសត្វតែមួយក្បាលមិនអាចទ្រាំទ្របានតែឯងនោះវាអាចទ្រាំទ្របានយ៉ាងស្មើភាពគ្នា ហើយដោយភាព ស្រណុកចិត្តដោយសត្វពីរក្បាលដែលបានដាក់ក្នុងនឹមតែមួយ ។ នឹមរបស់ទ្រង់តម្រូវឲ្យមានការខិតខំមួយដ៏ធំអស្ចារ្យ ហើយស្មោះអស់ពីចិត្ត ប៉ុន្តែចំពោះជនដែលបានប្រែចិត្តជឿពិតប្រាកដ នោះនឹមនេះមានភាពងាយស្រួល ហើយបន្ទុកវាក៏ស្រាលដែរ ។

« ព្រះគ្រីស្ទទូលសួរថាហេតុអ្វីបានជាប្រឈមនឹងបន្ទុកជីវិតតែម្នាក់ឯង ឬហេតុអ្វីបានជាប្រឈមនឹងវាជាមួយនឹងជំនួយបណ្តោះអាសន្នដែលនឹងរលាយបាត់ទៅវិញដូច្នេះ ? ចំពោះជនដែលមានបន្ទុកធ្ងន់ មានតែនឹមរបស់ព្រះគ្រីស្ទ និងអំណាច និង សេចក្តីសុខសាន្តនៃការឈរក្បែរព្រះប៉ុណ្ណោះដែលនឹងផ្តល់ការគាំទ្រ តុល្យភាព និង កម្លាំងដើម្បីតតាំងនឹងការប្រឈមរបស់យើង ហើយស៊ូទ្រាំនឹងកិច្ចការរបស់យើងនៅក្នុង . . . ជីវិតរមែងស្លាប់នេះ » (« Come unto Me » *Ensign* ខែ វិច្ឆិកា ឆ្នាំ១៩៩០ ទំព័រ ១៨ សូមមើលផងដែរ « Take My Yoke upon You » [*Ensign* ខែ កញ្ញា ឆ្នាំ ២០១៣ ទំព័រ ២២–២៣] សម្រាប់រូបនឹម និង ការពន្យល់បន្ថែមទៀតអំពីការប្រើ និង មុខងាររបស់វា) ។

មេរៀន ២

ផែនការនៃសេចក្តីសង្គ្រោះ

សេចក្តីផ្តើម

ប្រធានបិយ យេ ផាកកឺក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានណែនាំដល់គ្រូបង្រៀនខាងសាសនាឲ្យបង្ហាញទិដ្ឋភាពទូទៅដោយសង្ខេបអំពីផែនការនៃសេចក្តីសង្គ្រោះ នៅពេលចាប់ផ្តើមថ្នាក់ក្នុងឆ្នាំនីមួយៗ ៖

« ទិដ្ឋភាពទូទៅដោយសង្ខេបអំពី ‹ ផែនការនៃសុភមង្គល › . . . ប្រសិនបើត្រូវបានផ្តល់ឲ្យនៅពេលចាប់ផ្តើម ហើយត្រឡប់ទៅមើលម្តងទៀតជាញឹកញាប់ នោះវានឹងក្លាយជាគុណធម៌ដែលចាក់ជ្រៅទៅក្នុងដួងចិត្តសិស្សរបស់អ្នក » (« The Great Plan of Happiness » [សុន្ទរកថាទៅកាន់គ្រូបង្រៀនសឺ.អឺ.អេសខាងសាសនា ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៣] si.lds.org សូមមើលផងដែរ Teaching Seminary: Preservice Readings [Church Educational System manual ឆ្នាំ២០០៤] ទំព័រ ៦៨–៧៤) ។

មេរៀននេះផ្តល់នូវទិដ្ឋភាពទូទៅដោយសង្ខេបអំពីផែនការនៃសេចក្តីសង្គ្រោះ ហើយផ្តោតលើតួនាទីដ៏សំខាន់របស់ព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់នៅក្នុងផែនការនោះ ។

អញ្ជើញព្រះវិញ្ញាណតាមរយៈការប្រជុំធម្មនិដ្ឋានប្រកបដោយប្រសិទ្ធភាព

ការប្រជុំធម្មនិដ្ឋានខ្លីមួយ នៅពេលចាប់ផ្តើមថ្នាក់អាចជួយគ្រូបង្រៀន និងសិស្សឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណ ហើយរៀបចំខ្លួនរៀនសូត្រ ។ ជាទូទៅ ការប្រជុំធម្មនិដ្ឋានមួយ រួមមានទំនុកតម្កើងមួយ ការអធិស្ឋានមួយ និង គំនិតមួយពីព្រះគម្ពីរ ។ ការប្រជុំធម្មនិដ្ឋាន មានប្រសិទ្ធភាពច្រើនបំផុតនៅពេលសិស្សទាំងឡាយ ថ្លែងទីបន្ទាល់ ហើយចែកចាយអារម្មណ៍ និង គំនិតដែលពួកគេមាននៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមពិចារណាពីរបៀបដែលអ្នកអាចរៀបចំការប្រជុំធម្មនិដ្ឋានដើម្បីឲ្យសិស្សមានឱកាសចូលរួមពេញមួយឆ្នាំ ។

យោបល់សម្រាប់ការបង្រៀន

តួនាទីរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតមុនឆាកជីវិតនេះ

ជាផ្នែកមួយនៃ ការប្រជុំធម្មនិដ្ឋាននេះ អ្នកគួរអញ្ជើញសិស្សឲ្យច្រៀងវគ្គទី ១ និងទី ៤នៃបទ « ខ្ញុំជឿលើព្រះគ្រីស្ទ » (*ទំនុកតម្កើង* ទំព័រ ៧៥) ឬទំនុកតម្កើងមួយទៀតអំពីព្រះអង្គសង្គ្រោះ ។ សូមចាប់ផ្តើមមេរៀននេះដោយសួរ ៖

- **តើអ្នកនឹងឆ្លើយបែបណាដែរ ប្រសិនបើមនុស្សម្នាក់សួរអ្នកថា ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្ទជាអង្គដ៏សំខាន់ចំពោះអ្នក ?**

សូមពន្យល់ដល់សិស្សថា នៅក្នុងមេរៀនថ្ងៃនេះពួកគេនឹងរៀនអំពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ។ ចូរសុំឲ្យពួកគេរកមើលសេចក្តីពិតទាំងឡាយ ដែលអាចជួយពង្រឹងសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេសិក្សាក្នុងថ្ងៃនេះ ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ។ អ្នកក៏គួររៀបចំវាជា ក្រដាសចែក ឲ្យសិស្សផងដែរ ។ (ប្រសិនបើចែកក្រដាសនោះ ចូរសុំឲ្យសិស្សបំពេញតារាងរបស់ពួកគេនៅពេលអ្នកបំពេញ តារាង នោះនៅលើក្តារខៀន) ។

ព្រះយេស៊ូវគ្រីស្ទ គឺជាកត្តាដ៏សំខាន់នៃផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌

ជីវិតមុនឆាកជីវិតនេះ	ជីវិតរមែងស្លាប់	ជីវិតក្រោយពីជីវិតនេះ

សូមចង្អុលបង្ហាញថា ផែនការរបស់ព្រះវរបិតាសួគ៌មានបីដំណាក់កាលសំខាន់ៗ ៖ (១) ជីវិតរបស់យើងមុនឆាកជីវិតនេះដែលបានដឹកនាំទៅរកការចាប់កំណើតរបស់យើងខាងសាច់ឈាម (២) ជីវិតរមែងស្លាប់របស់យើងនៅលើផែនដី និង (៣) ជីវិតរបស់យើងក្រោយពីជីវិតនេះ ដែលនឹងកើតឡើងបន្ទាប់ពីសេចក្តីស្លាប់ខាងរូបកាយរបស់យើង ។

ចូរសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗ ហើយសុំឲ្យសិស្សផ្សេងទៀតស្តាប់រកដែនកំណត់ដែលយើងបានដកពិសោធន៍នៅក្នុងជីវិតរបស់យើងមុនឆាកជីវិតនេះ ។

« យើងបានរស់នៅជាកូនចៅវិញ្ញាណរបស់ព្រះវរបិតារបស់យើងនៅក្នុងស្ថានសួគ៌ពីមុនយើងកើតលើផែនដីនេះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងមិនដូចព្រះវរបិតាសួគ៌របស់យើង ហើយក៏មិនអាចក្លាយដូចជាទ្រង់ ហើយរីករាយជាមួយពរជ័យដែលទ្រង់រីករាយដោយគ្មានបទពិសោធន៍នៃការរស់នៅជាមនុស្សភាពនៃរូបកាយដែរ ។

« ព្រះរាជបំណងទាំងមូលរបស់ព្រះ—កិច្ចការ និង សិរីល្អរបស់ទ្រង់—គឺអាចធ្វើឲ្យយើងម្នាក់ៗរីករាយជាមួយនឹងពរជ័យទាំងអស់របស់ទ្រង់ ។ ទ្រង់បានប្រទានផែនការមួយដ៏ល្អឥតខ្ចោះដើម្បីសម្រេចបានព្រះរាជបំណងរបស់ទ្រង់ ។ យើងបានយល់ ហើយបានទទួលយកផែនការនេះ មុនយើងមកផែនដីនេះ ។ . . .

« ដើម្បីរីកចម្រើន ហើយប្រែក្លាយដូចជាព្រះ យើងម្នាក់ៗត្រូវតែទទួលរូបកាយ ហើយទទួលការសាកល្បងនៅអំឡុងពេលនៃសេចក្តីសាកល្បងនៅលើផែនដី » (*ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា* | ឆ្នាំ ២០០៤ | ទំព័រ ៤៨, ៤៩) ។

- តើដែនកំណត់អ្វីខ្លះដែលយើងមាន នៅក្នុងជីវិតយើងមុនឆាកជីវិតនេះ ?

សូមពន្យល់ថា នៅពេលព្រះវរបិតាសួគ៌បានសំដែងពីផែនការនៃសុភមង្គលរបស់ទ្រង់ យើងបានដឹងថា នឹងមានព្រះអង្គសង្គ្រោះមួយអង្គ ដើម្បីអនុវត្តផែនការនេះ ។ លូស៊ីហ្វើរ ដែលជាកូនចៅវិញ្ញាណម្នាក់របស់ព្រះវរបិតាសួគ៌បានបះបោរប្រឆាំងនឹងផែនការរបស់ព្រះវរបិតាសួគ៌ ។ វាត្រូវបានគេស្គាល់ជា *សាតាំង* ភាសាហេព្រើរមានន័យថា « មារសត្រូវ » ។

សុំសិស្សម្នាក់អាន យ៉ូហាន ៨:១–៣ ឲ្យឮ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វីដែលសាតាំងបានទាមទារពីព្រះវរបិតាសួគ៌ ។

- តើសាតាំងបានទាមទារអ្វីខ្លះពីព្រះវរបិតាសួគ៌ ?
- យោងតាម ខទី ២តើព្រះវរបិតាសួគ៌បានមានបន្ទូលអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ?
- តើព្រះយេស៊ូវគ្រីស្ទត្រូវបានជ្រើសរើសឲ្យធ្វើអ្វី ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះលើក្តារខៀននៅក្រោមពាក្យ *ជីវិតមុនឆាកជីវិតនេះ ៖* **ព្រះយេស៊ូវគ្រីស្ទត្រូវបានជ្រើសរើសនៅក្នុងជីវិតមុនឆាកជីវិតនេះដើម្បី ធ្វើជាព្រះអង្គសង្គ្រោះរបស់មនុស្សលោក**) ។

សូមពន្យល់ថា ក្រោយពីព្រះយេស៊ូវគ្រីស្ទត្រូវបានជ្រើសរើសឲ្យអនុវត្តផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ទ្រង់បានបង្កើតផែនដីនេះដែលយើងម្នាក់ៗអាចទទួលបានរូបកាយ និង បទពិសោធន៍ ។

ចូរសុំឲ្យសិស្សម្នាក់អាន ហេព្រើរ ១:១–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម ដោយ រកមើលតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការបង្កបង្កើតផែនដី ។

- តើតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការបង្កបង្កើតផែនដីមានអ្វីខ្លះ ? (សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្តារខៀនក្រោមពាក្យ *ជីវិតមុនឆាកជីវិតនេះ ៖* **ក្រោមការដឹកនាំរបស់ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទបានបង្កើតផែនដី**) ។



សូមអញ្ជើញសិស្សគិតពីភាពស្រស់ស្អាតរបស់ផែនដី ។ អ្នកគ្រូបង្ហាញរូបភាពមួយ ឬច្រើនពីភាពស្រស់ស្អាតរបស់ផែនដី ។

- តើការដឹងថា ព្រះយេស៊ូវគ្រីស្ទបានបង្កើតផែនដីនេះ និងភពរាប់លានទៀតដូចគ្នានេះដែរ វាជះឥទ្ធិពលដល់អារម្មណ៍របស់អ្នកទៅលើទ្រង់យ៉ាងណាដែរ ?

តួនាទីរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរមែងស្លាប់

សូមពន្យល់ថា នៅក្នុងជីវិតរមែងស្លាប់យើងដកពិសោធន៍ដែនកំណត់ ឬឧបសគ្គបន្ថែមទៀតដែលរារាំងយើងមិនឲ្យក្លាយដូចជាព្រះវរបិតាសួគ៌ ហើយត្រឡប់ទៅវត្តមានរបស់ទ្រង់វិញ ។ ចូរសុំឲ្យសិស្សម្នាក់អានឲ្យឮ នូវសេចក្តីថ្លែងការណ៍ខាងក្រោម ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់ ហើយ ស្វែងរកឧបសគ្គពីរដែលយើងដកពិសោធន៍នៅក្នុងជីវិតរមែងស្លាប់ ។

« នៅក្នុងជីវិតរមែងស្លាប់ យើងរស់នៅក្នុងលក្ខខណ្ឌដែលសេចក្តីស្លាប់ទាំងខាងរូបកាយ និង ខាងវិញ្ញាណ ។ ព្រះមានសិរីល្អ និង អមតៈនៃសាច និង ឈាមយ៉ាងល្អឥតខ្ចោះ ។ ដើម្បីប្រែក្លាយដូចជាព្រះ និងត្រឡប់ទៅរស់នៅទីវត្តមានរបស់ទ្រង់ យើងក៏ត្រូវតែមានរូបកាយអមតៈនៃសាច និងឆ្អឹងយ៉ាងល្អឥតខ្ចោះដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រោះតែការធ្លាក់របស់អ័ដាម និង អេវ៉ា មនុស្សគ្រប់គ្នានៅលើផែនដីមានរូបកាយរមែងស្លាប់ដែលមិនល្អឥតខ្ចោះ ហើយនៅទីបំផុតនឹងស្លាប់ ។ ប្រសិនបើពុំមានព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ សេចក្តីស្លាប់អាចបញ្ចប់រាល់សេចក្តីសង្ឃឹមសម្រាប់ជីវិតនាពេលអនាគតរួមរបស់នឹងព្រះវរបិតាសួគ៌ ។



« រួមជាមួយនឹងសេចក្តីស្លាប់ខាងរូបកាយ អំពើបាបគឺជាឧបសគ្គចម្បងដែលធ្វើឲ្យយើងពុំអាចប្រែក្លាយដូចជាព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ហើយត្រឡប់ទៅត្រឡប់វត្តមានរបស់ទ្រង់វិញ ។ នៅក្នុងលក្ខខណ្ឌនៃជីវិតរមែងស្លាប់ យើងតែងតែធ្លាក់ក្នុងការល្បួងធ្វើខុសបញ្ញត្តិរបស់ព្រះ ហើយមានបាប ។ . . . ទោះបីពេលខ្លះអំពើបាបពុំមានជលរអាក្រក់ភ្លាមៗក៏ដោយ វាតែងតែនាំទៅរកភាពអព្យាមង្គល ។ អំពើបាបធ្វើឲ្យមានអារម្មណ៍ថា មានកំហុស និងការខ្មាស់អៀន ។ ដោយសារតែអំពើបាបរបស់យើង យើងពុំអាចត្រឡប់ទៅរស់នៅជាមួយព្រះវរបិតាសួគ៌បានទេ ដរាបណាយើងទទួលបានការអភ័យទោស ហើយស្អាតស្អំជាមុនសិន ។




« . . . ដូចគ្នានឹងសេចក្តីស្លាប់រូបកាយដែរ យើងមិនអាចឈ្នះលើឥទ្ធិពលនៃអំពើបាបដោយខ្លួនយើងបានទេ » (*ប្រកាសដំណឹងល្អរបស់យើងទំព័រ ៥០*) ។

សូមពន្យល់ថា ពីមុនព្រះយេស៊ូវប្រសូតមកលើផែនដី មានទេវតាមួយអង្គបានលេចមកឯយ៉ូសែបនៅក្នុងសុបិន កាលគាត់បានដឹងថា ម៉ារាកំពុងមានផ្ទៃពោះ ។ ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ១:២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វី ដែលទេវតាអង្គនោះបានប្រកាសប្រាប់ទៅ យ៉ូសែប ។

- តើទេវតាបានមានបន្ទូលថាព្រះយេស៊ូវនឹងធ្វើអ្វីខ្លះ ? (បន្ទាប់ពីសិស្សឆ្លើយ ចូរសរសេរគោលលទ្ធិខាងក្រោមនៅលើក្តារខៀនក្រោមពាក្យ *ជីវិតរមែងស្លាប់ ៖* **ព្រះយេស៊ូវគ្រីស្ទបានយាងមកសង្គ្រោះពួកយើងចេញពីអំពើបាបរបស់យើង**) ។
- តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះ ដើម្បីឲ្យយើងត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង ?

សូមបង្ហាញរូបភាព ព្រះយេស៊ូវកំពុងអធិស្ឋានក្នុងសួនច្បារគែតសាម៉ានី, ការឆ្កាងនិង ម៉ារា និង ព្រះយេស៊ូវគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ (*Gospel Art Book* | ឆ្នាំ ២០០៩ | ល.រ. ៥៦, ៥៧, ៥៩ សូមមើលផងដែរ LDS.org) ។ សូមរំឭកសិស្សថា ការរងទុក្ខ, សេចក្តីស្លាប់និង ការរស់ឡើងវិញ របស់ព្រះយេស៊ូវគ្រីស្ទត្រូវហៅថាជា ដង្វាយធួន ។

- តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានការសង្គ្រោះចេញពីអំពើបាបរបស់យើងតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ? (សូមមើល កិច្ចការ ២:៣៨) ។



ហេតុអ្វីបានជាងាយ ? © ២០១៥ ដោយ ស៊ីមិន ដេវី ។ ប្រើប្រាស់ដោយមានការអនុញ្ញាតពី Altus Fine Art altusfineart.com ។

គួនាទីរបស់ព្រះយេស៊ូវគ្រីស្តនៅក្នុងជីវិតក្រោយពីជីវិតនេះ

ចូរសុំឲ្យសិស្សគិតពីមនុស្សម្នាក់ដែលបានចែកឋានទៅ ។ លុះពីរបីនាទីក្រោយមក សូមសួរ ៖

- យោងតាមការយល់ដឹងរបស់អ្នកអំពីផែនការនៃសេចក្តីសង្គ្រោះ តើអ្នកដែលបានចែកឋានទៅរស់នៅទីណាដែរ ? (នៅពេលមនុស្សស្លាប់ វិញ្ញាណមនុស្សទាំងអស់ចូលទៅក្នុងពិភពវិញ្ញាណ) ។ ដើម្បីបន្ថែមដល់ការយល់ដឹងរបស់សិស្ស អ្នកគួរសុំឲ្យសិស្សម្នាក់អាន អាលម៉ា ៤០:១១–១៤ ឲ្យឮៗ) ។



ការបញ្ចុះសពរបស់ព្រះគ្រីស្ទ ដោយ ខា ហានរីច ប្លូច ។ ការតាំងពិពណ៌នៃសារមន្ទីរប្រវត្តិសាស្ត្រជាតិនៅមាន ហ្ស្រ៊ីនវីកស្បក នៅហ៊ីលលើត្រ ប្រទេស ដាណឺម៉ាក់ ។ ហាមចំតចម្លង

សូមបង្ហាញ រូបភាព ការតម្កល់ព្រះសពរបស់ព្រះយេស៊ូវ (*Gospel Art Book* ល.រ. ៥៨ សូមមើលផងដែរ LDS.org) ។ ចូរសុំឲ្យសិស្សម្នាក់ឲ្យអាន ពេត្រុសទី ១ ៣:១៨–២០, ៤:៦ ឲ្យឮៗ ។ បន្ទាប់មក សូមសួរ ៖

- តើព្រះយេស៊ូវគ្រីស្តបានធ្វើអ្វីខ្លះភ្លាមៗក្រោយពីការសុគតរបស់ទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:១៨–១៩, ៣០-៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវគ្រីស្តបានធ្វើ ដើម្បីអនុញ្ញាតឲ្យដំណឹងល្អត្រូវបានប្រកាសដល់មនុស្សគ្រប់គ្នាក្នុងពិភពវិញ្ញាណ ។

- តើព្រះយេស៊ូវគ្រីស្តបានធ្វើអ្វីខ្លះ ដើម្បីអនុញ្ញាតឲ្យដំណឹងល្អត្រូវបានប្រកាសដល់មនុស្សគ្រប់គ្នាក្នុងពិភពវិញ្ញាណ ?
- តើការខិតខំទាំងនេះឆ្លុះបញ្ចាំងពីសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្តចំពោះមនុស្សគ្រប់គ្នាយ៉ាងដូចម្តេចដែរ ?

សូមចង្អុលទៅរូបភាពម៉ារា និង ព្រះយេស៊ូវគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ (*Gospel Art Book* ល.រ. ៥៩ សូមមើលផងដែរ LDS.org) ហើយសួរសិស្ស ៖

- តើមានអ្វីកើតឡើងនៅថ្ងៃទីបី បន្ទាប់ពីការសុគតរបស់របស់ព្រះអង្គសង្គ្រោះ ? (ទ្រង់បានមានព្រះជន្មរស់ឡើងវិញ) ។
- តើការរស់ឡើងវិញមានន័យដូចម្តេច ? (វិញ្ញាណ និង រូបកាយរបស់មនុស្សម្នាក់ត្រូវជុំចូលគ្នាវិញ ហើយពុំបែកចេញពីគ្នាទៀតឡើយ [សូមមើល គ. និង ស. ១៣៨:១៧]) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១៥:២០–២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលការមានព្រះជន្មឡើងវិញរបស់ព្រះយេស៊ូវគ្រីស្តជះឥទ្ធិពលដល់យើងម្នាក់ៗ ។

- តើយើងបានរងឥទ្ធិពលយ៉ាងណាដែរ ដោយសារតែការមានព្រះជន្មឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ត ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្តារខៀនក្រោមពាក្យ *ជីវិតក្រោយពីជីវិតនេះ ៖* **ដោយសារការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ត នោះមនុស្សទាំងអស់នឹងបានរស់ឡើងវិញ**) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:១២ ឲ្យឮ ។ បន្ទាប់មក សូមសួរ ៖

- តើនឹងមានអ្វីកើតឡើងចំពោះយើងម្នាក់ៗ បន្ទាប់ពីយើងបានរស់ឡើងវិញ ?

សូមពន្យល់ថា បញ្ជីជីវិតអាចតំណាងឲ្យគំនិត និង ទង្វើរបស់មនុស្សម្នាក់នៅក្នុងជីវិតនេះ ក៏ដូចជាកំណត់ត្រាដែលបានរក្សានៅទុកស្ថានសួគ៌អំពីសេចក្តីសុចរិតដែរ (សូមមើល Bible Dictionary « Book of life ») ។ សូមគូសបញ្ជាក់ថា យើងត្រូវបានកាត់សេចក្តី ពុំមែនតែទៅលើកិច្ចការរបស់យើងប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ស្របទៅតាមគំនិត ពាក្យសម្តី និង បំណងប្រាថ្នារបស់យើងផងដែរ (សូមមើល ម៉ូសាយ ៤:៣០, អាលម៉ា ១២:១៤, ៤១:៣, គ. និង ស. ១៣៧:៩) ។

អ្នកគួរផ្តល់យោបល់ឲ្យសិស្សសរសេរ *យ៉ូហាន ៥:២២* នៅលើរឹមនៃព្រះគម្ពីររបស់ពួកគេក្បែរ វិវរណៈ ២០:១២ ។ ចូរសុំឲ្យសិស្សអានយ៉ូហាន ៥:២២ ដោយស្ងៀមស្ងាត់ ហើយរកមើលថាតើនរណានឹងកាត់សេចក្តីយើង ។

- តើនរណានឹងកាត់សេចក្តីយើង ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្តារខៀនក្រោមពាក្យ *ជីវិតក្រោយពីជីវិតនេះ ៖* **ព្រះយេស៊ូវគ្រីស្តនឹងកាត់សេចក្តីមនុស្សលោកទាំងអស់**) ។

សូមរំឭកសិស្សថា គោលបំណងដ៏សំខាន់បំផុតនៃផែនការរបស់ព្រះវរបិតាសួគ៌គឺ ដើម្បីផ្តល់ឱកាសឲ្យយើងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ឬភាពតម្កើងឡើង ដែលវាមានន័យថាជាការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ហើយរស់នៅជាមួយនឹងទ្រង់ក្នុងក្រុមគ្រួសារដ៏នៅអស់កល្បជានិច្ចជារៀងដរាបតទៅ ។ អ្នកគួរបង្ហាញរូបភាពមួយពីគ្រួសាររបស់អ្នក ហើយពន្យល់ថាហេតុអ្វីការដែលអ្នកអាចរស់នៅជាមួយនឹងព្រះវរបិតាសួគ៌ និងគ្រួសាររបស់អ្នកជារៀងរហូតនោះគឺជារឿងដ៏សំខាន់សម្រាប់អ្នក ។

ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ៣:១៦–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ហើយរកមើលអ្វីដែលយើងត្រូវធ្វើដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច (ឬអស់កល្បអស់កាលជានិច្ច) ។

- តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលជីវិតដ៏នៅអស់កល្បជានិច្ច ? (សូមពន្យល់ថា ការជឿលើព្រះរាជបុត្រាបង្កើតតែមួយ មានន័យថាការអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ត ហើយរស់នៅស្របតាមដំណឹងល្អរបស់ទ្រង់ ដែលរួមបញ្ចូលទាំងការទទួលពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធផងដែរ) ។
- តើអ្នកនឹងសង្ខេប យ៉ូហាន ៣:១៦ ឲ្យទៅជាគោលការណ៍មួយបានយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀនក្រោមពាក្យ *ជីវិតក្រោយពីជីវិតនេះ ៖* **ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ត ហើយរស់នៅស្របតាមដំណឹងល្អរបស់ទ្រង់ នោះទើបយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

សូមរំឭកសិស្សពីសំណួរដែលអ្នកបានសួរកាលពីចាប់ផ្តើមថ្នាក់ ៖ « តើអ្នកនឹងឆ្លើយបែបណាដែរ ប្រសិនបើមនុស្សម្នាក់សួរអ្នកថា ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្តជាអង្គដ៏សំខាន់ចំពោះអ្នក ? » ចូរសុំឲ្យសិស្សពន្យល់ពីរបៀបដែលពួកគេអភិវឌ្ឍបន្ថែមទៀតចំពោះចម្លើយរបស់ពួកគេ ទៅនឹងសំណួរនេះដោយផ្អែកលើអ្វី ដែលពួកគេបានរៀននៅថ្ងៃនេះ ។ អ្នកគួរឲ្យសិស្សពីរបីនាក់ចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ត និង តួនាទីរបស់ទ្រង់នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ។ អ្នកអាចបញ្ចប់មេរៀននេះដោយចែកទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកផងដែរ ។

មេរៀន ៣

តួនាទីរបស់សិស្ស

សេចក្តីផ្តើម

ព្រះវិញ្ញាណបរិសុទ្ធ គ្រូបង្រៀន និង សិស្សមានតួនាទីសំខាន់មួយនៅក្នុងការរៀនសូត្រពីដំណឹងល្អ ។ មេរៀននេះអាចជួយសិស្សឲ្យយល់ពីតួនាទីទាំងនេះ ដើម្បីពួកគេអាចទទួលបានជោគជ័យនៅក្នុងការខិតខំរៀនសូត្ររបស់ពួកគេ ។ អ្នកប្រហែលជាត្រូវរំឭកគោលការណ៍នានាដែលត្រូវបានបង្រៀននៅក្នុងមេរៀននេះជាទៀងទាត់ ដើម្បីរំឭកសិស្សអំពីតួនាទីរបស់ពួកគេក្នុងការរៀនសូត្រពីដំណឹងល្អ ។

យោបល់សម្រាប់ការបង្រៀន

តួនាទីរបស់ព្រះវិញ្ញាណ គ្រូបង្រៀន និងសិស្សនៅក្នុងការរៀនសូត្រពីដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់អានសាច់រឿងដូចខាងក្រោមឲ្យឮៗ ។

មានយុវនារីម្នាក់ទទួលបានការបំផុសគំនិត និង ការបំភ្លឺ នៅពេលនាងចូលរៀនថ្នាក់សិក្ខាសាលា ។ នាងទទួលអារម្មណ៍ពីព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនៅទីនោះ ហើយមានអំណរគុណចំពោះរឿងទាំងឡាយដែលនាងរៀន ។ ហើយក៏មានយុវនារីម្នាក់ទៀតនៅក្នុងថ្នាក់សិក្ខាសាលាដដែលនោះដែរ ។ ប៉ុន្តែជារឿយៗ នាងមានភាពធុញទ្រាន់ ហើយមានអារម្មណ៍ថានាងរៀនអ្វីមិនបានច្រើនទេនៅក្នុងថ្នាក់នោះ ។

- តើហេតុផលមួយចំនួនដែលអាចកើតមាន ហើយវាធ្វើឲ្យយុវនារីទាំងពីរនេះមានបទពិសោធន៍ផ្ទុយគ្នា ខណៈដែលពួកគេចូលរៀននៅក្នុងថ្នាក់សិក្ខាសាលាតែមួយនោះមានអ្វីខ្លះ ? (ចម្លើយអាចមានដូចតទៅនេះ ៖ យុវនារីទីមួយប្រហែលជាចូលរួមយ៉ាងក្លៀវក្លានៅក្នុងមេរៀន យុវនារីទីមួយប្រហែលជាធ្លាប់មានបទពិសោធន៍នៃការរៀនសូត្រខាងវិញ្ញាណច្រើនកាលពីមុន រីឯយុវនារីទីពីរវិញប្រហែលជាមិនមានស្មារតីមូលដោយសារតែកង្វល់ផ្សេងៗ) ។

សូមអញ្ជើញសិស្សឲ្យរកមើលគោលលទ្ធិ និង គោលការណ៍នានានៅក្នុងមេរៀនថ្ងៃនេះដែលអាចជួយពួកគេឲ្យបំពេញតួនាទីរបស់ខ្លួននៅក្នុងថ្នាក់សិក្ខាសាលា ហើយពង្រឹងទីបន្ទាល់របស់ពួកគេអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

សូមពន្យល់ថា មានបុគ្គលបីរូបដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងបរិយាកាសរៀនសូត្រមួយអំពីដំណឹងល្អដូចជាថ្នាក់សិក្ខាសាលា គឺ ៖ ព្រះវិញ្ញាណបរិសុទ្ធ គ្រូបង្រៀន និង សិស្ស ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៤:២៦ ហើយឲ្យសិស្សម្នាក់ទៀតអាន យ៉ូហាន ១៦:១៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមដោយ រកមើលពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ទាក់ទងនឹង តួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ? (សិស្សអាចនឹងឲ្យចម្លើយផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេដឹងពីគោលលទ្ធិនេះ ៖ **ព្រះវិញ្ញាណបរិសុទ្ធបង្រៀនពីសេចក្តីពិត**) ។
- តើយើងអាចដឹងបានដោយរបៀបណា នៅពេលព្រះវិញ្ញាណបរិសុទ្ធកំពុងបង្រៀនសេចក្តីពិតនោះដល់យើង? (អ្នកគួរឲ្យសិស្សបើកទៅ គោលលទ្ធិ និង សេចក្តីសញ្ញា ៨:២–៣) ។

ចូរសុំឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥០:១៣–១៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ដោយរកមើលពីតួនាទីរបស់គ្រូបង្រៀនដំណឹងល្អម្នាក់ ។ មុនពេលសិស្សអាន សូមពន្យល់ថា ខគម្ពីរទាំងនេះ បានផ្តល់ឲ្យទៅពួកបរិសុទ្ធជំនាន់មុនដែលទទួលបានការតែងតាំងឲ្យបង្រៀនដំណឹងល្អ ។

- តើតួនាទីរបស់គ្រូបង្រៀនដំណឹងល្អម្នាក់មានអ្វីខ្លះ ? (សូមមើលផងដែរ គ. និង ស. ៤២:១៤) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ៣៣:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមដោយ រកមើលអ្វីដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើចំពោះយើង នៅពេលសេចក្តីពិតត្រូវបានបង្រៀនដោយព្រះចេស្តារបស់ទ្រង់ ។

- យោងតាមខគម្ពីរនេះ តើព្រះវិញ្ញាណបរិសុទ្ធធ្វើអ្វីខ្លះសម្រាប់យើង ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដើម្បីយាងព្រះវិញ្ញាណបរិសុទ្ធឲ្យនាំយកសេចក្តីពិតចូលទៅក្នុងដួងចិត្តរបស់ពួកគេ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១១៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលពីរបៀបដែលយើងត្រូវខិតខំស្វែងរកការរៀនសូត្រ ។

- តើយើងត្រូវខិតខំស្វែងរកការរៀនសូត្រតាមរបៀបណា ? (ដោយការសិក្សា និងដោយសេចក្តីជំនឿ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សស្តាប់រកមើលអ្វីដែលយើងអាចធ្វើឲ្យកើតឡើងបាន នៅពេលយើងខិតខំរៀនសូត្រដោយសេចក្តីជំនឿ ៖

« គ្រូបង្រៀនម្នាក់អាចពន្យល់បង្ហាញ លួងលោម ហើយធ្វើទីបន្ទាល់ និង ធ្វើយ៉ាងដូច្នោះជាមួយនឹងអំណាចខាងវិញ្ញាណ និងដោយមានប្រសិទ្ធភាព ។ ទោះជាយ៉ាងនេះក៏ដោយ នៅទីបំផុតសារលិខិតមួយ និង សាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ អាចជាប្រចូលទៅក្នុងដួងចិត្តបាន ដរាបណាអ្នកទទួលម្នាក់អនុញ្ញតឲ្យវាចូលតែប៉ុណ្ណោះ ។ ការរៀនសូត្រដោយសេចក្តីជំនឿបើកផ្លូវ *ចូលទៅក្នុង* ដួងចិត្ត » (« Seek Learning by Faith » *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៦១) ។

សូមបង្កើតបរិយាកាសនៃក្តីស្រឡាញ់ និងការគោរព

នៅពេលវគ្គសិក្សានេះចាប់ផ្តើម សូមស្វែងរកវិធីនានាដើម្បីបង្កើតបរិយាកាសរៀនសូត្រមួយដែលប្រកបដោយសេចក្តីស្រឡាញ់ ការគោរព និងមានគោលបំណង ។ សូមជួយសិស្សឲ្យមានអារម្មណ៍ល្អជាមួយគ្នា និងជាមួយអ្នក តាមរយៈការស្គាល់ឈ្មោះគ្នាទៅវិញទៅមក និងដោយការស្គាល់ពីចំណាប់អារម្មណ៍ ទេពកោសល្យ ឧបសគ្គ និង សមត្ថភាពរបស់គ្នាទៅវិញទៅមក ។ វិធីមួយដើម្បីបង្កើតបរិយាកាសបែបនេះ បាន គឺការអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ និង ទស្សនៈដែលចេញមកពីការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេជាមួយគ្នា ។

- នៅក្នុងសេចក្តីថ្លែងការណ៍នេះ តើគោលការណ៍អ្វីខ្លះដែលអ្នករៀនពីអ្វីដែលអាចកើតឡើង ប្រសិនបើយើងខិតខំរៀនសូត្រដោយសេចក្តីជំនឿ ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **ប្រសិនបើយើងខិតខំរៀនសូត្រដោយសេចក្តីជំនឿ នោះទើបយើងយាងព្រះវិញ្ញាណបរិសុទ្ធឲ្យចូលមកក្នុងដួងចិត្តរបស់យើង ដើម្បីបង្រៀន ហើយថ្លែងទីបន្ទាល់ពីសេចក្តីពិតបាន ។** សូមពិចារណាសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។)

សូមចង្អុលបង្ហាញថា សេចក្តីជំនឿគឺលើសពីជំនឿអកម្មទៅទៀត ។ យើងបង្ហាញសេចក្តីជំនឿរបស់យើងតាមរយៈសកម្មភាព ។

- តើអ្នកគិតថា ការរៀនសូត្រដោយសេចក្តីជំនឿ មានន័យដូចម្តេច ?

ដើម្បីបង្ហាញថា ការរៀនសូត្រដោយសេចក្តីជំនឿ មានន័យដូចម្តេចនោះ សុំរកអ្នកស្ម័គ្រចិត្តម្នាក់ដែលពុំធ្លាប់លេងកីឡាបាល់ទាល់ពីមុន ។ (អ្នកអាចសម្របសកម្មភាពនេះដើម្បីធ្វើឲ្យសិស្សម្នាក់ដែលពុំធ្លាប់លេងកីឡាបាល់បោះ លេងឧបករណ៍តន្ត្រី លេងត្រែ ពុំចេះចងក្រវ៉ាត់-ក ។ល។ អាចចូលរួមបាន) ។ សូមប្រាប់សិស្សស្ម័គ្រចិត្តនោះថា អ្នកចង់បង្រៀនគាត់ពីរបៀបលេងកីឡាបាល់ទាត់ឲ្យល្អអាចលេងក្នុងក្រុមកីឡាបាល់ទាត់មួយបាន ។ សូមសួរសិស្សស្ម័គ្រចិត្តនោះថា តើគាត់មានសេចក្តីជំនឿលើសមត្ថភាពបង្រៀនរបស់អ្នក និងលើសមត្ថភាពរៀនសូត្ររបស់គាត់ដែរឬទេ ។ រួចពន្យល់ ហើយបង្ហាញពីរបៀបបណ្តើរបាល់ ប៉ុន្តែកុំឲ្យសិស្សនោះសាកល្បង ។ សូមពន្យល់ពីរបៀបបញ្ជូនបាល់ ។ រួចធ្វើការបង្ហាញដោយបញ្ជូនបាល់នោះទៅសិស្សស្ម័គ្រចិត្តនោះ ប៉ុន្តែទារបាល់មកវិញ ដោយមិនឲ្យសិស្សនោះសាកល្បងបញ្ជូនបាល់ត្រឡប់មកអ្នកវិញ ។ សូមធ្វើដូចគ្នាសម្រាប់ការបោះបាល់ បន្ទាប់ពីវាបានចេញទៅខាងក្រៅទីលាន ។ បន្ទាប់មក សូមសួរសិស្សនោះ ៖

- តើអ្នកមានអារម្មណ៍ថាត្រូវត្រៀមខ្លួនបែបណាដើម្បីសាកល្បងសម្រាប់ក្រុមបាល់ទាត់មួយ ? ហេតុអ្វី ?
- ទោះបីជាការរៀនសូត្រ និង ការមើលអ្នកដទៃលេងបាល់ទាត់អាចជួយបានក៏ដោយ ប្រសិនបើអ្នកចង់អភិវឌ្ឍជំនាញដែលចាំបាច់ដើម្បីមានភាពជោគជ័យក្នុងកីឡាបាល់ទាត់កាន់តែប្រសើរនោះ តើអ្នកត្រូវធ្វើអ្វីខ្លះ ?
- តើកិច្ចការនេះអាចទាក់ទិននឹងការរៀនសូត្រដោយសេចក្តីជំនឿបានដោយរបៀបណា ? (ការជឿ និង ការទុកចិត្តថា ព្រះវិញ្ញាណអាចបង្រៀនយើងតែម្យ៉ាងគឺពុំគ្រប់គ្រាន់ឡើយ) ។ ដើម្បីទទួលបានចំណេះដឹងពីសេចក្តីពិតរបស់ព្រះ យើងក៏ត្រូវខិតខំរៀនសូត្រ ហើយអនុវត្តអ្វីដែលយើងរៀនសូត្រដងដែរ) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមរបស់អែលឌើរ បែដណា ឲ្យឮៗ ៖ សូមឲ្យសិស្សស្តាប់រកមើលអ្វីដែលលោកបង្រៀនអំពីការរៀនសូត្រដោយសេចក្តីជំនឿ (អ្នកអាចពិចារណាថតចម្លងសេចក្តីថ្លែងការណ៍នេះចែកឲ្យសិស្ស ហើយឲ្យពួកគេគូសចំណាំអ្វីដែលពួកគេរកឃើញ) ។



« អ្នករៀនសូត្រ អនុវត្តសិទ្ធិជ្រើសរើសរបស់ពួកគេ តាមរយៈការធ្វើសកម្មភាពស្របទៅតាមគោលការណ៍ត្រឹមត្រូវ បើកដួងចិត្តពួកគេឲ្យព្រះវិញ្ញាណបរិសុទ្ធ ហើយយាងការបង្រៀនរបស់ទ្រង់ អំណាចនៃការថ្លែងទីបន្ទាល់ និងសាក្សីបញ្ជាក់របស់ទ្រង់ ។ ការរៀនសូត្រដោយសេចក្តីជំនឿ តម្រូវឲ្យមានកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និងខាងរូបកាយ ហើយពុំមែនគ្រាន់តែជាការទទួលភាពអកម្មនោះទេ ។ វាគឺនៅក្នុងសេចក្តីស្មោះត្រង់ និង ភាពខ្ជាប់ខួននៃសកម្មភាពដែលបានបំផុសគំនិតយើងឲ្យមានសេចក្តីជំនឿនោះហើយ ដែលយើងបង្ហាញចំពោះព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជាការស្ម័គ្រចិត្តរបស់យើងដើម្បីរៀន និង ទទួលយកការបង្ហាត់បង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។ . . .

« . . .ការរៀនសូត្រដោយសេចក្តីជំនឿ ពុំអាចត្រូវបានផ្ទេរពីគ្រូបង្រៀនម្នាក់ទៅសិស្សម្នាក់តាមរយៈការបង្រៀន ការបង្ហាញ ឬតាមសកម្មភាពក្នុងថ្នាក់រៀនតែមួយមុខទេ តែសិស្សម្នាក់ត្រូវតែអនុវត្តសេចក្តីជំនឿ និងធ្វើសកម្មភាព ដើម្បីទទួលបានចំណេះដឹងសម្រាប់ខ្លួនគាត់ » (« Seek Learning by Faith »ទំព័រ ៦៤) ។

- តើកិច្ចខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និងខាងរូបកាយមួយចំនួន ដែលយើងអាចធ្វើដើម្បីយាងព្រះវិញ្ញាណឲ្យបង្រៀន ហើយថ្លែងទីបន្ទាល់ដល់យើងអំពីសេចក្តីពិតមានអ្វីខ្លះ ?

កំណត់ចំណាំ ៖ ពេលនេះអាចជាពេលមួយដ៏សមរម្យដើម្បីអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១២២ ហើយពិភាក្សាពីសារៈសំខាន់នៃសណ្តាប់ធ្នាប់ និង គារវភាពនៅក្នុងថ្នាក់រៀន ។

- តើឥរិយាបថ ឬ អាកប្បកិរិយាមួយចំនួនដែលអាចរារាំងព្រះវិញ្ញាណមិនឲ្យបង្រៀនសេចក្តីពិតដល់យើងនៅក្នុងថ្នាក់សិក្ខាសាលាមួយមានអ្វីខ្លះ ?
- តើបទពិសោធន៍ក្នុងថ្នាក់សិក្ខាសាលាសម្រាប់សិស្សម្នាក់ដែលខិតខំរៀនសូត្រដោយសេចក្តីជំនឿនឹងមានភាពខុសគ្នាពីបទពិសោធន៍របស់សិស្សម្នាក់ទៀតដែលខ្ជិលច្រអូសដូចម្តេចដែរ ?

ចូរសុំឲ្យសិស្សបើកទៅ ម៉ាថាយ ៤ ។ សូមពន្យល់ថា នៅក្នុងបទពិសោធន៍របស់សាវកពេត្រុស យើងអាចឃើញពីគំរូមួយនៃរបៀបដែលការខិតខំរៀនសូត្រដោយសេចក្តីជំនឿយាងព្រះវិញ្ញាណបរិសុទ្ធចូលមកក្នុងដួងចិត្តយើងដើម្បីបង្រៀន ហើយថ្លែងទីបន្ទាល់ពីសេចក្តីពិតនោះ ។ ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៤:១៨–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ដោយរកមើលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះទៅកាន់ពេត្រុស និង អនទ្រេ ។

- តើព្រះអម្ចាស់បានហៅ ពេត្រុស និង អនទ្រេ ឲ្យធ្វើអ្វីខ្លះ ?
- តើចម្លើយរបស់ពួកលោកគឺជាគំរូមួយនៃការខិតខំរៀនសូត្រដោយសេចក្តីជំនឿបានយ៉ាងដូចម្តេច ?

សូមចង្អុលបង្ហាញថា ទង្វើរបស់ពេត្រុសក្នុងការធ្វើតាមព្រះយេស៊ូវគ្រីស្ទនោះបានអនុញ្ញាតឲ្យលោកបាននៅជិតនឹងព្រះអង្គសង្គ្រោះនៅក្នុងការបម្រើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ ។ ដោយការស្តាប់តាមពាក្យអំពាវនាវរបស់ព្រះអង្គសង្គ្រោះឲ្យមកតាមទ្រង់ ពេត្រុសបានមាន

អភ័យឯកសិទ្ធិស្តាប់ឮព្រះអង្គសង្គ្រោះបង្រៀនជារៀងរាល់ថ្ងៃ ហើយឃើញអព្ភូតហេតុជាច្រើន ។ ពេត្រុសថែមទាំងបានដើរនៅលើទឹកដោយការអញ្ជើញរបស់ព្រះអង្គសង្គ្រោះទៀតផង (សូមមើល ម៉ាថាយ ១៤:២៨–២៩) ។

សូមពន្យល់សិស្សថា នៅគ្រាមួយ ព្រះយេស៊ូវបានសួរសំណួរមួយដល់ពួកសិស្សរបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៣–១៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានសួរ ។

- តើព្រះអង្គសង្គ្រោះបានសួរអ្វីខ្លះដល់ពួកសិស្សរបស់ទ្រង់ ?
- តើពួកគេបានឆ្លើយយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៥–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលពេត្រុសបានឆ្លើយតបចំពោះសំណួរបន្ទាប់ទៀតរបស់ព្រះអង្គសង្គ្រោះ ។

- តើអ្វីទៅជាចម្លើយរបស់ពេត្រុសចំពោះសំណួររបស់ព្រះអង្គសង្គ្រោះ ?
- តើព្រះអង្គសង្គ្រោះបានពន្យល់អ្វីខ្លះ អំពីរបៀបដែលពេត្រុសបានទទួលចំណេះដឹងរបស់លោក ?
- តើបទពិសោធន៍របស់ពេត្រុស គឺជាការឆ្លុះបញ្ចាំងមួយពីសេចក្តីពិតដែលយើងដឹងនៅក្នុងមេរៀននេះបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ចំណាំ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ (អ្នកអាចពិចារណាសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖

- តើអ្នកធ្លាប់ខិតខំរៀនសូត្រដោយសេចក្តីជំនឿនៅពេលណាដែរ ? តើព្រះវិញ្ញាណបរិសុទ្ធបានបំពេញតួនាទីរបស់ទ្រង់ នៅក្នុងការរៀនសូត្រអំពីដំណឹងល្អយ៉ាងដូចម្តេច នៅពេលអ្នកបានធ្វើកិច្ចការនេះ ? (អ្នកអាចឲ្យសិស្សសញ្ជឹងគិតពីបទពិសោធន៍រៀនសូត្រកាលពីមុនដែលពួកគេធ្លាប់មាន នៅពេលពួកគេបានខិតខំរៀនសូត្របន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ) ។

ប្រសិនបើសិស្សរីករាយនឹងចែកចាយ ចូរសុំឲ្យពួកគេពីរបីនាក់ពិពណ៌នាពីបទពិសោធន៍ដែលពួកគេបានសរសេរ ។ អ្នកក៏គួរចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយរបស់អ្នកផងដែរ រួមទាំងទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត ដែលអ្នកបានពិភាក្សានោះ ។

ចូរសុំឲ្យសិស្សគិតពីរឿងមួយឬពីរដែលពួកគេនឹងធ្វើដើម្បីរៀនសូត្រដោយសេចក្តីជំនឿ ហើយយាងព្រះវិញ្ញាណបរិសុទ្ធឲ្យចូលទៅក្នុងដួងចិត្តពួកគេដើម្បីបង្រៀន ហើយថ្លែងទីបន្ទាល់ពីសេចក្តីពិត ។ សូមអញ្ជើញសិស្សសរសេរអ្វីដែលពួកគេនឹងធ្វើ ។

សូមបញ្ចប់ដោយចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមរបស់ ប្រធាន ថូម៉ាស អេស ម៉នសុន ៖

« យុវវ័យអើយ ! ខ្ញុំសុំឲ្យអ្នកចូលរួមរៀននៅក្នុងថ្នាក់សិក្ខាសាលា ។ ចូរសិក្សាព្រះគម្ពីរទាំងឡាយរបស់អ្នកជារៀងរាល់ថ្ងៃ ។ ចូរស្តាប់គ្រូបង្រៀនរបស់អ្នក ដោយប្រុងប្រយ័ត្ន ។ ចូរអនុវត្តអ្វីដែលអ្នករៀនប្រកបដោយការអធិស្ឋាន » (« Participate in Seminary » ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ seminary.lds.org) ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

គារវភាពធ្វើឲ្យមានវិវរណៈ

គរិយាបថ និង អាកប្បកិរិយាប្រកបដោយគារវភាពអាចជាផ្នែកមួយនៃការរៀនសូត្រដោយសេចក្តីជំនឿ ហើយអាចយាងព្រះវិញ្ញាណឲ្យបង្រៀន ហើយថ្លែងទីបន្ទាល់ពីសេចក្តីពិត ។ ប្រធាន ប៊ិយដ៏ ឃេ ផាកគី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីទំនាក់ទំនងរវាងគារវភាព និង វិវរណៈ ថា ៖

« អស់រយៈពេលពីរបីឆ្នាំនេះ យើងបានមើលគំរូនៃគារវភាព និង ការខ្វះគារវភាពនៅក្នុងសាសនាចក្រ ។ ខណៈពេលដែលមនុស្សជាច្រើនត្រូវបានគេកោតសរសើរជាខ្លាំង យើងកំពុងតែសោត្រាត់ ។ យើងមានហេតុផលដើម្បីត្រូវព្រួយបារម្ភជាខ្លាំង ។

« ពិភពលោកកាន់តែមានភាពទ្រហឹងអឺងកងឡើងៗ ។ . . .

« ទំនោរចំពោះសំឡេងកាន់តែខ្លាំង កាន់តែមានសេចក្តីរំភើប កាន់តែមានទំនាស់ ពុំសូវមានការអត់ធ្មត់ ពុំសូវមានសេចក្តីសេចក្តីថ្លៃថ្នូរ ពុំសូវមានរបៀបរបប គឺវាពុំមែនជារឿងចៃដន្យ ឬ គ្មានកំហុស ឬក៏គ្មានអន្តរាយនោះឡើយ ។

« ការចេញបញ្ហាលើកដំបូងត្រូវបានធ្វើឡើងដោយ មេបញ្ជាការម្នាក់ប្រើប្រាស់វិធានការវាយលុក ដោយការធ្វើឲ្យការស្ទះខ្សែរយៈទំនាក់ទំនងនៃពួកខ្មាំងសត្រូវ ដែលគាត់មានបំណងចង់យកជ័យជំនះលើ ។

« ការគ្មានគារវភាពនេះ បំពេញបំណងរបស់មារសត្រូវ ដោយសារតែការរាតាំងបណ្តាញដ៏ពិសិដ្ឋនៃវិវរណៈទាំងខាងគំនិត និង ខាងវិញ្ញាណ ។ . . .

« . . . ថ្នាក់ដឹកនាំគួរបង្រៀនថា គារវភាពធ្វើឲ្យមានវិវរណៈ » (« Reverence Invites Revelation » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ២២) ។

សិស្ទើរម៉ាហ្គារ៉ែត អេស លីហ្វើរ ក្នុងគណៈប្រធានអង្គបឋមសិក្សាទូទៅបានបង្រៀនអំពីគារវភាពនៅក្នុងការប្រជុំសាសនាចក្រ ហើយការណែនាំរបស់គាត់មានសម្រាប់ថ្នាក់សិក្ខាសាលាផងដែរ ៖

« មានតែនៅក្នុងគរិយាបថនៃគារវភាពមួយប៉ុណ្ណោះ ទើបព្រះវិញ្ញាណអាចបញ្ជាក់ពីសេចក្តីពិតនៃដំណឹងល្អតាមរយៈព្រះបន្ទូលរបស់ព្រះ តន្ត្រី ទីបន្ទាល់ និង ការអធិស្ឋាន ។ . . .

« . . . ការសរសេរសោរ ឬការអានអ៊ីម៉ែលនៅក្នុងការប្រជុំសាសនាចក្រពុំគ្រាន់តែជាការខ្វះគារវភាពមួយប៉ុណ្ណោះ ប៉ុន្តែវាកំពុងទាក់ទាញ ហើយបង្ហាញជាសញ្ញាពីការខ្វះការគោរពមួយចំពោះមនុស្សនៅជុំវិញខ្លួនយើង ។ ដូច្នេះយើងធ្វើគំរូពីគារវភាពដោយការចូលរួមនៅក្នុងការប្រជុំ ស្តាប់អ្នកឡើងនិយាយ ហើយច្រៀងទំនុកតម្កើងនៃស៊ីយ៉ូនជាមួយគ្នា » (« Respect and Reverence » *Ensign* ឬ Liahona ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ១៣) ។

ការអំពាវមួយរបស់ព្យាការីឲ្យចូលរួមនៅក្នុងថ្នាក់សិក្ខាសាលា

ប្រធានចូម៉ាស អេស ម៉នសុនបានផ្តល់សារលិខិតខាងក្រោមនេះអំពីការចូលរួមក្នុងថ្នាក់សិក្ខាសាលា ៖

« ថ្នាក់សិក្ខាសាលា បានប្រទានពរជ័យដល់ជីវិតរបស់យុវវ័យពួកបរិសុទ្ធថ្ងៃចុងក្រោយរាប់រយពាន់នាក់ ។ ខ្ញុំចង់ចាំនូវបទពិសោធន៍ ថ្នាក់សិក្ខាសាលាផ្ទាល់ខ្លួនរបស់ខ្ញុំ ។ សម្រាប់ខ្ញុំ ថ្នាក់សិក្ខាសាលា បានប្រព្រឹត្តទៅនៅពេលព្រឹកព្រលឹមស្រាងៗ ក្នុងផ្ទះដ៏តូចមួយទល់មុខវិទ្យាល័យរបស់ខ្ញុំ ។ ខ្ញុំបានគិតថា ប្រសិនបើគ្រូ របស់ ខ្ញុំ អាច ភ្ញាក់ ពី ព្រលឹម បែប នោះបាន នោះខ្ញុំក៏អាចភ្ញាក់ពីព្រលឹមដូចនោះបានដែរ ។

« ថ្នាក់សិក្ខាសាលា នឹងជួយអ្នកឲ្យយល់ និង ជឿជាក់លើការបង្រៀនទាំងឡាយ និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកនឹងទទួលអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះអម្ចាស់ កាលដែលអ្នករៀនដើម្បីស្រឡាញ់ព្រះគម្ពីរទាំងឡាយ ។ អ្នកនឹង រៀបចំ ខ្លួន អ្នក សម្រាប់ ព្រះវិហារ បរិសុទ្ធ និង សម្រាប់ បម្រើ ជា អ្នក ផ្សព្វផ្សាយ សាសនា ។

« យុវវ័យអើយ ! ខ្ញុំសុំឲ្យអ្នកចូលរួមរៀននៅក្នុងថ្នាក់សិក្ខាសាលា ។ ចូរសិក្សាព្រះគម្ពីរទាំងឡាយរបស់អ្នកជារៀងរាល់ថ្ងៃ ។ ចូរស្តាប់គ្រូបង្រៀនរបស់អ្នក ដោយប្រុងប្រយ័ត្ន ។ ចូរអនុវត្តអ្វីដែលអ្នករៀនប្រកបដោយការអធិស្ឋាន » (« Participate in Seminary » ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ seminary.lds.org) ។

មេរៀន ៤

ការសិក្សាព្រះគម្ពីរ

សេចក្តីផ្តើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ និង ការអានព្រះគម្ពីរសញ្ញាថ្មីទាំងស្រុងដែលជាផ្នែកមួយនៃវគ្គសិក្សានេះ ។ សិស្សក៏អាចរៀនពីវិធីកែលម្អការសិក្សាព្រះគម្ពីររបស់ពួកគេផងដែរ ។

យោបល់សម្រាប់ការបង្រៀន

សេចក្តីត្រូវការសម្រាប់ ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃឲ្យមានប្រសិទ្ធភាព

សូមឲ្យ សំណៅចម្លង មួយនៃ ការស្ទង់មតិខាងក្រោមនេះដល់សិស្សគ្រប់គ្នា ។ សូមអញ្ជើញ សិស្សពិចារណាពីសេចក្តីថ្លែងការណ៍នោះ ហើយគូសចំណាំចម្លើយរបស់ខ្លួនជាបន្តបន្ទាប់ ។ សូមបញ្ជាក់អះអាងដល់សិស្សថា អ្នកនឹងពុំសុំឲ្យពួកគេប្រាប់ពីចម្លើយរបស់ពួកគេឡើយ ។

	ជំទាស់	ជំទាស់ខ្លះៗ	យល់ស្របខ្លះៗ	យល់ស្រប
១. ព្រះគម្ពីរមានតម្លៃធំធេងណាស់ចំពោះខ្ញុំ	|----------|		
២. ពីរបីសប្តាហ៍មកនេះ ខ្ញុំបានសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ។	|----------|		
៣. ខ្ញុំមានអារម្មណ៍ថា មោងសម្រាប់សិក្សាព្រះគម្ពីររបស់ខ្ញុំមានប្រយោជន៍ខ្លាំង។	|----------|		
៤. ខ្ញុំអនុវត្តអ្វីដែលខ្ញុំរៀននៅក្នុងការសិក្សាព្រះគម្ពីររបស់ខ្ញុំជាទៀងទាត់ ។	|----------|		

បន្ទាប់ពីសិស្សបញ្ចប់ការស្ទង់មតិនេះហើយ សូមអញ្ជើញឲ្យពួកគេពិចារណាអំឡុងពេលរៀនមេរៀននេះពីរបៀបដែលពួកគេអាចធ្វើឲ្យការសិក្សាព្រះគម្ពីររបស់ពួកគេបានប្រសើរឡើង ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« ព្រះគម្ពីរមានន័យព្រះបន្ទូលរបស់ព្រះគ្រីស្ទ ហើយជាអាងនៃទឹករស់ដែលយើងមានសិទ្ធិប្រើបាន ហើយដែលយើងអាចផឹកបានយ៉ាងច្រើន ហើយយូរអង្វែង ។ . . .

« តាមរយៈសកម្មភាពធម្មតាជារៀងរាល់ថ្ងៃ អ្នក និង ខ្ញុំបាត់បង់សារជាតិទឹកយ៉ាងច្រើនដែលជាផ្នែកយ៉ាងសំខាន់ដល់រូបកាយរបស់យើង ។ ការស្រេកទឹកគឺជាការត្រូវការទឹកពីកោសិការាងកាយ ហើយសារជាតិទឹកនៅក្នុងរូបកាយយើងត្រូវតែបំពេញបន្ថែមជារៀងរាល់ថ្ងៃ ។ តាមពិតទៅ វាមិនសមឡើយដែលត្រូវ« បំពេញ » សារជាតិទឹកម្តងម្កាលខណៈដែលមានកង្វះទឹកក្នុងខ្លួនយ៉ាងច្រើននៅចន្លោះពេលដ៏យូរនោះ ។ វាគឺជារឿងពិតដូចគ្នាចំពោះតម្រូវការខាងវិញ្ញាណដែរ ។ ការស្រេកឃ្លានខាងវិញ្ញាណគឺជាសេចក្តីត្រូវការមួយសម្រាប់ទឹករស់ ។ លំហូរទៀងទាត់មួយនៃទឹករស់គឺមានភាពប្រសើរខ្លាំងណាស់ចំពោះការភ្លក់ម្តងម្កាល » (« A Reservoir of Living Water » | Church Educational System fireside ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៧ | ទំព័រ ១, ៧ broadcast.lds.org) ។

- **តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីអែលឌើរ បែដណាអំពីអ្វីដែលយើងអាចទទួលបានពីការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ? (សិស្សគួរឆ្លើយគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ នៅពេលយើងសិក្សាព្រះគម្ពីរប្រចាំ ថ្ងៃ យើងទទួលបាន« ទឹករស់ » ដែលយើងត្រូវការ ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។**

សូមលើកទឹកចិត្តសិស្សឲ្យសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ

មានកិច្ចការមួយចំនួន ដែលគ្រូបង្រៀនអាចធ្វើ ហើយដែលវានឹងមានឥទ្ធិពលដ៏ខ្លាំងក្លា ហើយដ៏យូរអង្វែងសម្រាប់សេចក្តីល្អ នៅក្នុងជីវិតសិស្សទាំងឡាយ ដែលលើសពីការជួយពួកគេឲ្យរៀន ហើយស្រឡាញ់ព្រះគម្ពីរ ព្រមទាំងសិក្សាប្រចាំថ្ងៃ ។ គ្រូបង្រៀនអាចធ្វើជាគំរូនៃការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ។ ពួកគេក៏អាចជួយសិស្សឲ្យទទួលខុសត្រូវចំពោះការសិក្សាប្រចាំថ្ងៃរបស់ខ្លួន ដោយប្រើប្រព័ន្ធតាមដានសមរម្យមួយដែលវាស់វែងពីភាពប្រាកដ និង ការរីកចម្រើនរបស់ពួកគេ ។

តម្លៃនៃព្រះគម្ពីរបរិសុទ្ធនៅសម័យរបស់យើង

ដើម្បីជួយសិស្សយល់ពីតម្លៃ និង សារៈសំខាន់នៃព្រះគម្ពីរនៅសម័យរបស់យើង អ្នកគួរបង្ហាញវីដេអូ « The Blessings of Scripture » (៣:០៤) ដែលមាននៅ LDS.org ។ នៅក្នុងវីដេអូនេះ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងក្តារ៉ុមនៃពួកសាវកដប់ពីរ នាក់ពណ៌នាពីការលះបង់ដែលបុរសម្នាក់បានធ្វើ ដើម្បីជួយឲ្យមនុស្សជាច្រើនឲ្យអានព្រះគម្ពីរបឹប ។ ប្រសិនបើអ្នកបង្ហាញវីដេអូនេះ សូមពិចារណាផ្អាកវីដេអូនោះបន្តិចក្រោយពីអែលឌើរ គ្រីស្តូហ្វឺសិនសួរថា « តើអ្វីទៅដែលពួកគេបានយល់ដឹង ហើយជាអ្វីដែលយើងគួរតែយល់ដឹងផងដែរ ? » (កូដពេលវេលា ១:៥៦) ដើម្បីសួរសិស្សថា តើពួកគេនឹងឆ្លើយចំពោះសំណួររបស់លោកដោយរបៀបណា ។ រួចបន្តបង្ហាញវីដេអូ ។ នៅចុងបញ្ចប់នៃវីដេអូនោះ សូមបន្តមេរៀននៅត្រង់ឃ្លាដែលចាប់ផ្តើមដោយ « បន្ទាប់ពីវីដេអូ . . . »

ប្រសិនបើអ្នកមិនបង្ហាញវីដេអូ ចូរសុំឲ្យសិស្សបួននាក់ឡើងមកមុខក្តារខៀន ហើយអានផ្នែកនៃសុន្ទរកថារបស់អែលឌើរ គ្រីស្តូហ្វឺសិន ខាងក្រោម។



១. « នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៥៣៦ មានបុរសកម្សត់ម្នាក់ត្រូវបាននាំខ្លួនទៅគុកងងឹតនៅប្រាសាទវិលវ័រឌេ ជិតប្រ៊ុចសេល បែលជីម ។ ប្រហែលជាជិតមួយឆ្នាំកន្លះ បុរសម្នាក់នេះបានរងទុក្ខដោយភាពឯកោនៅក្នុងគុកដ៏កខ្វក់មួយ ។ ឥឡូវនេះ នៅខាងក្រៅជញ្ជាំងប្រាសាទ អ្នកទោសនោះត្រូវគេចងភ្ជាប់នឹងបង្គោលមួយ ។ គាត់មានពេលបន្តិសំឡេងអធិស្ឋានខ្លាំងៗជាចុងក្រោយ ពីមុនគាត់ត្រូវគេប្រហារជីវិតដោយការព្យួរ-ក ដោយពោលថា ‹ ឱ! ព្រះអម្ចាស់អើយ សូមបើកព្រះនេត្រស្តេចប្រទេសអង់គ្លេសផង › រួចគាត់ត្រូវបានគេបង្ក្រាប ។ រំពេចនោះ រូបកាយគាត់ត្រូវគេដុតត្រង់បង្គោលនោះ ។ តើបុរសនេះជានរណា តើត្រូវគេដាក់ទោសដោយរឿងហេតុអ្វីដែរ . . . ? » (« The Blessing of Scripture» *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៣២) ។

២. « គាត់ឈ្មោះវិលៀម ធីនឌេល បទឧក្រិដ្ឋរបស់គាត់គឺដោយសារគាត់បានបកប្រែ ហើយបោះពុម្ពព្រះគម្ពីរបឹបជាភាសាអង់គ្លេស ។

« . . . នៅក្នុងការប្រកែកគ្នាមួយជាមួយនឹងអាចារ្យម្នាក់ដែលជំទាស់នឹងការយកព្រះគម្ពីរមកឲ្យមនុស្សសាមញ្ញ លោកធីនឌេលបានសុំថា ‹ ប្រសិនបើព្រះទុកឲ្យខ្ញុំមានជីវិតតែបន្តិចទៀត ខ្ញុំនឹងធ្វើឲ្យក្មេងប្រុសកសិករម្នាក់ ដែលប្រើនង្គ័ល ចេះដឹងព្រះគម្ពីរច្រើនជាងសម្តេចសង្ឃទៅទៀត ! › . . .

« លោកវិលៀម ធីនឌេល ពុំមែនជាមនុស្សដំបូង ឬក៏ចុងក្រោយគេនៃជនរស់នៅក្នុងប្រទេស និង ភាសាជាច្រើនដែលបានលះបង់ សូម្បីតែសេចក្តីស្លាប់ ដើម្បីនាំព្រះបន្ទូលនៃព្រះឲ្យចេញផុតពីភាពអាប់អួរឡើយ ។ . . . តើពួកគេបានដឹងអ្វីខ្លះអំពីសារៈសំខាន់នៃដំណឹងល្អដែលយើងក៏ត្រូវដឹងដែរនោះ ? តើមនុស្សដែលបានរស់នៅប្រទេសអង់គ្លេសក្នុងសវត្សរ៍ទី ១៦ ជាអ្នកដែលបានចំណាយប្រាក់យ៉ាងច្រើន ហើយបានប្រថុយប្រថានឥតគ្រោះថ្នាក់ដើម្បីមានព្រះគម្ពីរបឹបនោះបានយល់ដឹងអ្វីខ្លះ ជារឿងដែលយើងក៏គួរតែយល់ដឹងដែរនោះ ? (« The Blessing of Scripture »ទំព័រ ៣២) ។

សូមសួរសិស្ស ៖

- ហេតុអ្វីអ្នកគិតថា មនុស្សបានធ្វើការលះបង់ដ៏ធំបែបនេះដើម្បីមានព្រះគម្ពីរ ?

ចូរសុំឲ្យអ្នកអានទីបីបន្តអានសេចក្តីថ្លែងការណ៍របស់អែលឌើរ គ្រីស្តូហ្វឺសិន ។

៣. « ក្នុងសម័យលោកធីនឌេល ភាពអវិជ្ជមានខាងបទគម្ពីរកាន់តែកសាយភាយ ដោយសារមនុស្សគ្មានព្រះគម្ពីរបឹបប្រើច្រើន ។ សព្វថ្ងៃនេះព្រះគម្ពីរបឹប និង ព្រះគម្ពីរផ្សេងទៀតមានគ្រប់ទីកន្លែង ប៉ុន្តែមានការកើនឡើងនូវភាពអវិជ្ជាខាងបទគម្ពីរ ដោយសារមនុស្សពុំបើកវា ។ ជាលទ្ធផល ពួកគេបានបំភ្លេចអ្វីដែលជីដូនជីតាពួកគេដឹង » (« The Blessing of Scripture »ទំព័រ ៣៣) ។

សូមសួរសិស្ស ៖

- ហេតុអ្វីអ្នកគិតថាមនុស្សខ្លះនៅសម័យយើងនេះមិនអានព្រះគម្ពីរ ស្របតាមសមត្ថភាពរបស់ខ្លួន ?

ចូរសុំឲ្យអ្នកអានទីបួនបន្តអានសេចក្តីថ្លែងការណ៍របស់អែលឌើរ គ្រីស្តូហ្វឺសិន ។

៤. « សូមពិចារណាអំពីទំហំនៃពរជ័យរបស់យើងក្នុងការមានព្រះគម្ពីរបឹប និងព្រះគម្ពីរ ៩០០ ទំព័របន្ថែមទៀតរួមមាន ព្រះគម្ពីរមរមន គោលលទ្ធិ និង សេចក្តីសញ្ញា និង មុត្តាដ៏មានតម្លៃមហិមា ។ . . . ប្រាកដណាស់ តាមរយៈពរជ័យនេះ ព្រះអម្ចាស់កំពុងមានបន្ទូលប្រាប់យើងថា សេចក្តីត្រូវការរបស់យើងសម្រាប់ការប្រើព្រះគម្ពីរឲ្យបានញឹកញាប់គឺធំជាងជំនាន់ណាៗទាំងអស់ » (« The Blessing of Scripture »ទំព័រ ៣៥) ។

បន្ទាប់ពីវីដេអូនេះ (ឬបន្ទាប់ពីអ្នកអានទីបួនបញ្ចប់ការអានសេចក្តីថ្លែងការណ៍របស់អែលឌើរ គ្រីស្តូហ្វឺសិន) សូមអញ្ជើញសិស្សពន្យល់ពីអ្វីដែលពួកគេជឿថាអែលឌើរ គ្រីស្តូហ្វឺសិនកំពុងថ្លែងពីសេចក្តីត្រូវការរបស់យើងក្នុងការសិក្សាព្រះគម្ពីរ ។ បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **នៅសព្វថ្ងៃនេះយើងត្រូវការព្រះគម្ពីរជាងជំនាន់ណាៗទាំងអស់ ។**

- ហេតុអ្វីអ្នកគិតថានៅសព្វថ្ងៃនេះយើងត្រូវការព្រះគម្ពីរជាងជំនាន់ណាៗទាំងអស់ ?

ដើម្បីជួយសិស្សយល់ដឹងថាតើការសិក្សាព្រះគម្ពីរអាចផ្តល់អត្ថប្រយោជន៍ដល់យើងយ៉ាងណានោះ សូមពន្យល់ថា សាវកប៉ុលបានសរសេរលិខិតមួយដែលនៅក្នុងនោះលោកបានរៀបរាប់ពីស្ថានភាពមួយចំនួននៃពិភពលោកនៅថ្ងៃចុងក្រោយ ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី ២ ៣:១–៥, ១៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ហើយរកមើលអំពើបាប និង ឥរិយាបថមួយចំនួនដែលកើតមានទូទៅនៅក្នុងជំនាន់យើង ។ (អ្នកគួរប្រាប់សិស្សឲ្យមើលទៅលេខយោងដើម្បីទទួលបានជំនួយឲ្យយល់ន័យពាក្យ ឬឃ្លាពិបាកៗនៅក្នុងខគម្ពីរទាំងនេះ) ។

- តើអំពើបាប និង ឥរិយាបថមួយចំនួន ដែលមាននៅក្នុងខគម្ពីរទាំងនេះ ដែលអ្នកធ្លាប់ឃើញនៅក្នុងសង្គមយើងនាសព្វថ្ងៃមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី ២ ៣:១៤–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតរកមើលថា តើយើងអាចស្វែងរកសុវត្ថិភាពនៅក្នុងគ្រាដ៏គ្រោះថ្នាក់ទាំងនេះបានដោយរបៀបណា ។

- តើយើងអាចស្វែងរកសុវត្ថិភាពនៅក្នុងគ្រាដ៏គ្រោះថ្នាក់ទាំងនេះបានដោយរបៀបណា ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងសិក្សាព្រះគម្ពីរ យើងអាចទទួលបាន . . .*

- យោងតាម ធីម៉ូថេទី ២ ៣:១៥–១៧តើយើងទទួលបានពរជ័យអ្វីខ្លះ នៅពេលយើងសិក្សាព្រះគម្ពីរ ហើយរស់នៅតាមការបង្រៀនទាំងនោះ ? (បន្ទាប់ពីសិស្សឆ្លើយ សូមបំពេញប្រយោគនៅលើក្តារខៀន ដែលមានន័យដូចខាងក្រោមនេះ ៖ **នៅពេលយើងសិក្សាព្រះគម្ពីរ យើងអាចទទួលបានប្រាជ្ញា ការកែតម្រូវ និង ការណែនាំដែលនឹងដឹកនាំយើងទៅរកសេចក្តីសង្គ្រោះ**) ។

សូមពន្យល់ថា សេចក្តីថ្លែងការណ៍នៅលើក្តារខៀនគឺជាឧទាហរណ៍នៃគោលការណ៍មួយ ។ គោលការណ៍ និងគោលលទ្ធិទាំងឡាយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាសេចក្តីពិតគ្រឹះ ពុំផ្លាស់ប្តូរ ដែលផ្តល់ការដឹកនាំចំពោះជីវិតរស់នៅរបស់យើង ។ ចំណុចមួយនៃគោលបំណងសំខាន់របស់ព្រះគម្ពីរ គឺដើម្បីបង្រៀនគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ យើងអាចធ្វើឲ្យការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់យើងឲ្យកាន់តែមានអត្ថន័យដោយការស្រាវជ្រាវរកគោលលទ្ធិ និង គោលការណ៍នានា ការសញ្ជឹងគិតពីអត្ថន័យរបស់វា និង ការអនុវត្តវានៅក្នុងជីវិតរបស់យើង ។

សូមយោងទៅគោលការណ៍ដែលអ្នកបានសរសេរលើក្តារខៀនម្តងទៀត ។

- តើអ្នកគិតថា នៅពេលយើងសិក្សាព្រះគម្ពីរ យើងអាចទទួលបានប្រាជ្ញា ការកែតម្រូវ និង ការណែនាំមានន័យដូចម្តេចខ្លះ ?
- តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកបានទទួលប្រាជ្ញា ការកែតម្រូវ ឬ ការណែនាំ ដែលជាលទ្ធផលនៃការសិក្សាព្រះគម្ពីរនៅពេលណាដែរ ? (អ្នកគួរចែកចាយបទពិសោធន៍មួយផងដែរ) ។

ការអានព្រះគម្ពីរសញ្ញាថ្មីប្រចាំថ្ងៃ

សូមពន្យល់ថា ការរំពឹងទុកមួយសម្រាប់វគ្គសិក្សានេះក្នុងថ្នាក់សិក្ខាសាលា គឺឲ្យសិស្សអាន ព្រះគម្ពីរសញ្ញាថ្មីទាំងមូល ។ នេះគឺជាតម្រូវការមួយដើម្បីទទួលបានសញ្ញាបត្រថ្នាក់សិក្ខាសាលា ។

សូមពន្យល់ថា ការអានព្រះគម្ពីរសញ្ញាថ្មីទាំងមូលនឹងតម្រូវឲ្យមានការតាំងចិត្តដ៏មុតមាំ ប៉ុន្តែវាគឺជាការខិតខំដ៏មានតម្លៃ ។ ដើម្បីឆ្លុះបញ្ចាំងពីការណ៍នេះ សូមបង្ហាញកែវថ្លាពីរដែលមានទឹកពេញ (ឬក៏ភេសជ្ជៈ) ។ សូមអញ្ជើញសិស្សពីរនាក់ឈរនៅក្បែរកែវនីមួយៗ ។ សូមឲ្យបំពង់បឺតទៅសិស្សម្នាក់ ។ ឲ្យបំពង់បឺតប្រាំពីរដើម ចងជាបាច់មួយទៅសិស្សម្នាក់ទៀត ។ សូមប្រាប់ពួកគេឲ្យបឺតទឹកទាំងអស់ឲ្យបានលឿនបំផុតតាមដែលពួកគេអាចធ្វើបានដោយប្រើបំពង់បឺតនោះ ។ (សិស្សដែលមានបំពង់បឺតមួយគួរតែបឺតទឹកអស់មុន រីឯសិស្សម្នាក់ទៀតគួរមានការពិបាកក្នុងបឺតទឹកតាមបំពង់បឺតទាំងនោះ) ។ សូមអញ្ជើញសិស្សទាំងពីរនាក់នេះទៅអង្គុយវិញ រួចសួរសិស្សផ្សេងទៀត ៖

- តើសកម្មភាពនេះមានទំនាក់ទំនងយ៉ាងណាដែរទៅនឹងគោលដៅរបស់យើង ចំពោះការអានព្រះគម្ពីរសញ្ញាថ្មីទាំងមូលនៅក្នុងវគ្គសិក្សានេះ ? (សិស្សដែលមានបំពង់បឺតប្រាំពីរ ប្រៀបដូចជាមនុស្សម្នាក់ ដែលព្យាយាមអានផ្នែកដ៏ធំក្នុងព្រះគម្ពីរក្នុងពេលតែមួយ) ។ សិស្សដែលមានបំពង់បឺតមួយគឺដូចជាមនុស្សម្នាក់ ដែលអានមួយផ្នែកតូចជារៀងរាល់ថ្ងៃ) ។

ដើម្បីជួយសិស្សឲ្យឃើញថាតើពួកគេអាចអានព្រះគម្ពីរសញ្ញាថ្មីទាំងមូលដោយអានបន្តិចម្តងៗជារៀងទាត់តាមរបៀបណា ចូរសុំឲ្យពួកគេចែកទំព័រនៅក្នុងព្រះគម្ពីរសញ្ញាថ្មី (មាន៣៧៩ ទំព័រ នៅក្នុងព្រះគម្ពីរបឺប)និងចំនួនថ្ងៃសរុបរហូតដល់ថ្ងៃបញ្ចប់វគ្គសិក្សានេះ ។ ឧទាហរណ៍ ប្រសិនបើវគ្គសិក្សានេះត្រូវបង្រៀនក្នុងរយៈពេល ២៨០ ថ្ងៃ សិស្សត្រូវអានប្រហែលជា ១ ទំព័រក្នុងមួយថ្ងៃដើម្បីបញ្ចប់ព្រះគម្ពីរសញ្ញាថ្មីនៅចុងបញ្ចប់នៃវគ្គសិក្សានេះ ។

សូមថ្លែងទីបន្ទាល់អំពីពរជ័យដែលអាចកើតមានដល់សិស្ស នៅពេលពួកគេសិក្សាព្រះគម្ពីរសញ្ញាថ្មីដោយឧស្សាហ៍ ។ សិស្សនឹងទទួលបានប្រាជ្ញា ការកែតម្រូវ និង ការណែនាំពីព្រះគម្ពីរ ហើយមានពរជាមួយនឹងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមយោងទៅគោលការណ៍ដែលអ្នកបានសរសេរលើក្តារខៀនម្តងទៀត ហើយថ្លែងទីបន្ទាល់ថា តាមរយៈការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ សិស្សនឹងដកពិសោធន៍នូវពរជ័យដែលប៉ុលបានរៀបរាប់នៅក្នុង ធីម៉ូថេទី ២ ៣:១៥–១៧ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅដើម្បីញែកពេលវេលារាល់ថ្ងៃ សម្រាប់ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ហើយអានព្រះគម្ពីរសញ្ញាថ្មីទាំងមូល ។ សូមអញ្ជើញសិស្សសរសេរគោលដៅរបស់ខ្លួននៅក្នុងសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមលើកទឹកចិត្តសិស្សឲ្យអានអត្ថបទសម្រាប់វគ្គសិក្សានេះ ។

បទដ្ឋានព្រះគម្ពីរគឺជាការនិពន្ធដ៏បំផុសគំនិតដែលមាននូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ វាឆ្លុះបញ្ចាំងពីទំនាក់ទំនងរបស់ព្រះជាមួយនឹងមនុស្សលោក ហើយបង្រៀនអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ វាគឺសំខាន់ដោយឡែកពីគ្នា និងដោយរួមគ្នា វាផ្តល់នូវការយល់ដឹងដ៏អស្ចារ្យពីដំណឹងល្អនិងផែនការនៃសេចក្តីសង្គ្រោះដែលបានរៀបចំដោយព្រះវរបិតា ដែលគង់នៅស្ថានសួគ៌របស់យើង ។ សិស្ស និង គ្រូបង្រៀនគួរអាន ហើយសិក្សាព្រះគម្ពីរសញ្ញាថ្មីទាំងមូលនៅក្នុងវគ្គសិក្សានេះ ។

មេរៀន ៥

បរិបទ និង ទិដ្ឋភាពទូទៅនៃព្រះគម្ពីរសញ្ញាថ្មី

សេចក្តីផ្តើម

ក្នុងមេរៀននេះ សិស្សនឹងរៀនពីមាតិកាប្រវត្តិសាស្ត្រ និងវប្បធម៌នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដោយរួមបញ្ចូលទាំងកត្តានានាដែលធ្វើឲ្យសាសន៍យូដាជាច្រើនបានបដិសេធព្រះយេស៊ូវថាជាព្រះមែស៊ី និង ព្រះអង្គសង្គ្រោះ ។ សិស្សក៏នឹងរៀនពីរចនាសម្ព័ន្ធនៃព្រះគម្ពីរសញ្ញាថ្មីផងដែរ ។

សូមប្រើរូបភាព

វត្ថុ និង រូបភាព រួមមានផែនទី និង តារាងទាំងឡាយអាចជួយសិស្សយ៉ាងមានប្រសិទ្ធភាពឲ្យមើលឃើញផ្ទាល់ភ្នែក, វិភាគ ហើយយល់អំពីបទគម្ពីរជាពិសេស នៅពេលវាត្រូវបានប្រើប្រាស់ដើម្បីជម្រុញឲ្យមានការពិភាក្សាមួយ ។ ការមានវត្ថុ និង រូបភាពមួយដាក់តាំងបង្ហាញ នៅពេលសិស្សដើរចូលមកក្នុងថ្នាក់រៀន អាចជួយបង្កើនបរិយាកាស នៃការរៀនសូត្រ ហើយជំរុញឲ្យមានស្មារតីនៃការស្វែងរកដោយខ្ជាប់ខ្ជួនមួយ ។





យោបល់សម្រាប់ការបង្រៀន

បរិបទនៃព្រះគម្ពីរសញ្ញាថ្មី

សូមដាក់បង្ហាញចំណែកមួយនៃ រូបភាព ស្វែងានឃើញព្រះយេស៊ូវគង់ខាងស្តាំនៃព្រះ (*Gospel Art Book* [ឆ្នាំ២០០៩] ល.រ. ៦៣ សូមមើលផងដែរ LDS.org) ដោយប្រើក្រដាស ឬវត្ថុផ្សេងទៀតដាក់បាំងរូបភាពទាំងមូលលើកលែងតែរូប ស្វែងាន (បុរសដែលពាក់មកុពណ៌ខៀវ) ។

សូមអញ្ជើញសិស្សពិពណ៌នាពីអ្វីដែលកំពុងកើតឡើងនៅក្នុង រូបភាពនោះ ។ សូមសួរពួកគេហេតុអ្វីបានជាពួកគេគិតថាបុរសម្នាក់នោះដួលទៅលើដី ហើយលាតដៃរបស់គាត់សន្ធឹង ។ បន្ទាប់ពីសិស្សឆ្លើយ សូមបើកបង្ហាញរូបភាពទាំងអស់ ។

- តើការឃើញរូបភាពទាំងមូលជួយអ្នកឲ្យយល់ពីអ្វី ដែលកំពុងកើតឡើងដោយរបៀបណា ?

សូមអញ្ជើញសិស្សអានក្បាលជំពូកក្នុង កិច្ចការ ៧ ដើម្បីយល់ថារូបភាពនេះបង្ហាញពីស្វែងានដែលជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទត្រូវបានគេចោលនឹងថ្មរហូតដល់ស្លាប់ ហើយឃើញព្រះយេស៊ូវកំពុងគង់នៅខាងស្តាំនៃព្រះ ។

- តើយើងអាចប្រដូចការបើករូបភាពនេះ ទៅនឹងការយល់ដឹងពីព្រះគម្ពីរបានដោយរបៀបណា ?

សូមពន្យល់ថា សកម្មភាពនេះឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការយល់ដឹងពីបរិបទនៃព្រះគម្ពីរ ។ ពាក្យ *បរិបទ* សំដៅទៅលើកាលៈទេសៈដែលកើតមាន ឬផ្តល់ជាប្រវត្តិផ្ទៃរឿងដល់វគ្គបទគម្ពីរ ព្រឹត្តិការណ៍ ឬដំណើររឿង ។ សូមចង្អុលបង្ហាញថា នៅពេលសិស្សដឹងច្បាស់នូវបរិបទខាងប្រវត្តិសាស្ត្រ និង ខាងវប្បធម៌ក្នុងព្រះគម្ពីរសញ្ញាថ្មី ពួកគេអាចយល់ដឹងកាន់តែប្រសើរ ហើយអនុវត្តការបង្រៀនរបស់វា ។

ពួកអ្នកដឹកនាំសាសនាសាសន៍យូដានៅក្នុងការបម្រើរបស់ព្រះអង្គសង្គ្រោះ

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១០:៣–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ហើយស្វែងរកពាក្យ ឬឃ្លាដែលព្យាការីយ៉ាកុបបានប្រើដើម្បីពិពណ៌នាពីស្ថានភាពខាងវិញ្ញាណ នៅក្នុងចំណោមពួកសាសន៍យូដាមួយចំនួនអំឡុងពេលនៃការបម្រើរបស់ព្រះអង្គសង្គ្រោះ ។

- តើពាក្យ ឬឃ្លាអ្វីទៅដែលយ៉ាកុបបានប្រើដើម្បីពិពណ៌នាស្ថានភាពខាងវិញ្ញាណនៅក្នុងចំណោមពួកសាសន៍យូដាមួយចំនួន ? (សូមពន្យល់ថាពាក្យ *ឧបាយកលផ្នែកសង្ឃ* ក្នុង ខទី ៥ សំដៅលើការប្រកាសដើម្បីរក « កម្រៃ និង ការសរសើរតម្កើងពីមនុស្សលោក » ជាជាងសុខុមាលភាពនៃរាស្ត្ររបស់ព្រះ [នីហ្វៃទី ២ ២៦:២៩] ។ ជនដែលមានកំហុសនៃឧបាយកលផ្នែកសង្ឃគឺជាពួកអ្នកដឹកនាំសាសនាដ៏ទុច្ចរិត នៅក្នុងចំណោមពួកសាសន៍យូដាដែលកំពុងដឹកនាំប្រជាជនទៅរកភាពវិនាស) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៣:១៦, ២៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្វែងរករបៀបដែលព្រះអង្គសង្គ្រោះបានពិពណ៌នាពីពួកអ្នកដឹកនាំសាសនាសាសន៍យូដាទាំងនេះនៅក្នុងការបម្រើរបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានពិពណ៌នាបែបណាពីពួកអ្នកដឹកនាំសាសនាសាសន៍យូដាទាំងនេះ ?
- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះពីអ្នកដឹកនាំទាំងនេះដោយហៅពួកគេថា « ពួកមនុស្សខ្វាក់ដែលនាំផ្លូវគេ » ?

សេចក្តីបន្ថែមទៅនឹងក្រឹត្យវិន័យរបស់ម៉ូសេ និងទស្សនវិជ្ជាភ្លែងភ្លាយផ្សេងទៀត

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតពីរបៀបដែលពួកអ្នកដឹកនាំសាសនាបានដឹកនាំប្រជាជនឲ្យវង្វេង សូមគូរវង្វង់មួយនៅលើក្តារខៀន ហើយសរសេរ *ក្រឹត្យវិន័យរបស់ម៉ូសេ* នៅចំកណ្តាល ។ សូមគូរវង្វង់មួយទៀតព័ទ្ធជុំវិញវង្វង់ទីមួយ ហើយសរសេរថា *ក្រឹត្យវិន័យតាមអាត់* ។

សូមពន្យល់ថា ដោយគ្មានពួកព្យាការី ពួកគ្រូបង្រៀន និង ពួកអ្នកដឹកនាំ នោះសាសន៍យូដាបានបន្ថែមច្បាប់ផ្ទាល់ខ្លួន និងការបកប្រែក្រឹត្យវិន័យនោះ ។ ដោយត្រូវបានគេឲ្យឈ្មោះផ្សេងៗគ្នាថាជាក្រឹត្យវិន័យតាមអាត់ ទំនៀមទម្លាប់តាមអាត់ ឬទំនៀមទម្លាប់ចាស់បុរាណ ច្បាប់ និង ការបកប្រែបន្ថែមទាំងនេះមានគោលបំណង ដើម្បីការពារកុំឲ្យមានការបំពានទៅលើក្រឹត្យវិន័យរបស់ព្រះ ។ ដើម្បីបង្ហាញពីច្បាប់មួយក្នុងចំណោមច្បាប់ទាំងនេះ ចូរសុំឲ្យសិស្សពីរនាក់ឡើងមកខាងមុខក្តារខៀន ។ ចូរសុំឲ្យខ្សែពួរដែលបានចងគូចទៅឲ្យពួកគេ

ម្នាក់មួយខ្សែ ។ សុំឲ្យសិស្សម្នាក់ស្រាយចំណងនោះដោយប្រើដៃតែម្ខាង រួចឲ្យសិស្សម្នាក់ទៀតស្រាយចំណងដោយប្រើដៃទាំងពីរ ។ បន្ទាប់ពីពួកគេបានសាកល្បងធ្វើដូច្នេះហើយ ចូរសុំឲ្យពួកគេត្រឡប់ទៅកន្លែងអង្គុយវិញ ។

សូមពន្យល់ថា ស្របតាមក្រឹត្យវិន័យតាមមាត់នោះ ការស្រាយចំណងមួយដោយដៃទាំងពីរនៅថ្ងៃឈប់សម្រាកត្រូវបានហាមឃាត់ ។ ការធ្វើបែបនេះ ត្រូវគេគិតថាជាការធ្វើការ ហេតុដូច្នេះហើយវាគឺជាការរំលោភបំពានមួយចំពោះថ្ងៃឈប់សម្រាក ។ ទោះជាយ៉ាងណាក៏ដោយ ការស្រាយចំណងដោយប្រើដៃតែម្ខាងត្រូវបានគេអនុញ្ញាតឲ្យ ។

- តើការបន្ថែមច្បាប់ដែលមនុស្សបង្កើតទៅលើបញ្ញត្តិរបស់ព្រះអាចនាំឲ្យមានគ្រោះថ្នាក់អ្វីខ្លះ ?

ចូរសុំឲ្យសិស្សម្នាក់អានឲ្យឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ស្តីពីពួកអ្នកដឹកនាំសាសនាសាសន៍យូដាដ៏ជាក់លាក់ ដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ពួកគេបានយករឿងដែលច្បាស់លាស់ ហើយសាមញ្ញនៃសាសនាដ៏បរិសុទ្ធ ហើយបានបន្ថែមនៅក្នុងនោះនូវការបកស្រាយយ៉ាងច្រើនរបស់ខ្លួន ពួកគេបានបញ្ចេញបញ្ចូលដោយបន្ថែមពិធីសាសនា និង ការអនុវត្តនានា ហើយពួកគេបានយកបរិយាកាសបង្គំដ៏រីករាយ ហើយមានក្តីអំណរ រួចបង្វែរវាឲ្យទៅជាប្រព័ន្ធនៃការធ្វើពិធីសាសនា និង ការអនុវត្តដ៏តឹងរឹង ហើយបង្ក្រួញយ៉ាងខ្លី និងធ្វើឲ្យស្រយុតចិត្ត ។ វិញ្ញាណដ៏រស់រវើកនៃក្រឹត្យវិន័យរបស់ព្រះអម្ចាស់បានក្លាយទៅជាលិខិតគ្មានន័យនៃពិធីសាសនារបស់សាសន៍យូដានៅក្នុងកណ្តាប់ដៃពួកគេ » (*The Mortal Messiah* វ៉ុល ៤ | ឆ្នាំ១៩៧៩–៨១ |, ១:២៣៨) ។

- យោងតាមអែលឌើរ ម៉ាក់ខនឃី តើពួកអ្នកដឹកនាំសាសនាសាសន៍យូដាបានធ្វើអ្វីខ្លះចំពោះក្រឹត្យវិន័យរបស់ព្រះជាមួយការបកប្រែបន្ថែមរបស់ពួកគនោះ ?

សូមចង្អុលបង្ហាញថា ពួកសាសន៍យូដាក្នុងសម័យព្រះយេស៊ូវបានស្ថិតនៅក្នុងស្ថានភាពនៃការក្បត់សាសនា ។ ទោះជាសិទ្ធិអំណាច និង ពិធីបរិសុទ្ធនៃបព្វជិតភាពអើរ៉ុន បានបន្តមាននៅក្នុងចំណោមពួកគេក៏ដោយ មានពួកសាសន៍យូដាជាច្រើនបានវង្វេងពីការអនុវត្តពិតនៃសាសនារបស់ខ្លួនដែលបានបើកសម្តែងតាមរយៈព្រះទៅកាន់ម៉ូសេ (សូមមើល គ. និង ស. ៨៤:២៥–២៨) ។ ទំនៀមទម្លាប់ចាស់បុរាណគឺមានអាទិភាពជាងសាសនាពិត និង បន្ទូលរបស់ព្រះដែលបានសរសេរទុក ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១២:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ហើយស្វែងរកអ្វីដែលពួកផារិស៊ីបានប៉ងធ្វើទៅលើព្រះយេស៊ូវគ្រីស្ទ ដោយសារទ្រង់បានបដិសេធសិទ្ធិអំណាច និង ទំនៀមទម្លាប់តាមមាត់មួយចំនួនរបស់ពួកគេ ។

- តើពួកអ្នកដឹកនាំសាសនាទាំងនេះបានរួមគំនិតគ្នាធ្វើអ្វីខ្លះទៅលើព្រះយេស៊ូវ ?

សូមពន្យល់ថា បន្ថែមពីលើទំនៀមទម្លាប់ក្បត់សាសនារបស់សាសន៍យូដា ទស្សនវិជ្ជាក្លែងក្លាយផ្សេងទៀត បានធ្វើឲ្យមានការបដិសេធពីសំណាក់ប្រជាជនចំពោះព្រះយេស៊ូវគ្រីស្ទ បន្ទាប់ពីការមានព្រះជន្មឡើងវិញរបស់ទ្រង់ ។ ឧទាហរណ៍ ការីកាសាយភាយនៃវប្បធម៌ក្រិកបានដឹកនាំមនុស្សជាច្រើនឲ្យបដិសេធធាតុពិតនៃការរស់ឡើងវិញខាងរូបកាយ (សូមមើល កូរិនថូសទី ១ ១៥:១២) ។ ហេតុដូច្នេះហើយ នៅពេលពួកសាវកបានថ្លែងទីបន្ទាល់ពីព្រះអង្គសង្គ្រោះ ដែលមានព្រះជន្មរស់ឡើងវិញ ក្រោយពីការឆ្កាងរបស់ទ្រង់ មានមនុស្សជាច្រើនបានបដិសេធទីបន្ទាល់របស់ពួកគេ ។

ច្បាប់បរទេស និង ការរំពឹងទុកឲ្យមានព្រះមែស៊ីមួយអង្គដើម្បីរំដោះអ៊ីស្រាអែល

សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖ *ក្រុងបាប៊ីឡូន ពើស៊ី ម៉ាសេដូន (ប្រទេសក្រិក) និង រ៉ូម* ។

- ទាក់ទងនឹងពួកសាសន៍យូដា តើអាណាចក្របុរាណទាំងនេះមានលក្ខណៈដូចគ្នាបែបណាខ្លះ ? (ពួកគេបានវាយជ្រាញ់ ហើយគ្រប់គ្រងលើពួកសាសន៍យូដា) ។

សូមបំបែកសិស្សជាក្រុម ហើយឲ្យ ក្រដាសចែក ខាងក្រោមនេះដល់ក្រុមនីមួយៗ ៖

ក្រៅពីគ្រានៃឯករាជ្យភាពតែម្តងគត់នោះ លុះមកត្រឹមសម័យព្រះគម្ពីរសញ្ញាថ្មី ពួកសាសន៍យូដាបានរស់នៅជាប្រជាជនស្ថិតនៅក្រោមអាណានិគមជាង ៥០០ ឆ្នាំ ។ មានការបះបោរមួយដែលដឹកនាំដោយពួកម៉ាកាប៊ី ជាពួកអ្នកស្រឡាញ់ជាតិមួយក្រុមដែលជាសាសន៍យូដា បានដឹកនាំទៅរកឯករាជ្យភាពប្រហែលជា ១៦០ ឆ្នាំពីមុនការប្រសូតរបស់ព្រះគ្រីស្ទ ។ ទោះជាយ៉ាងក៏ដោយ លុះដល់ពេលដែលព្រះគ្រីស្ទបានប្រសូតមក ពួករ៉ូមបានវាយយកបានអ៊ីស្រាអែល ។ ស្តេចហេរ៉ូឌ (គេស្គាល់ផងដែរជា ស្តេចហេរ៉ូឌដ៏មានឫទ្ធានុភាព) ដែលបានរៀបអភិសេកចូលទៅក្នុងត្រួសារម៉ាកាប៊ី ត្រូវបានពួករ៉ូមតែងតាំងឲ្យគ្រប់គ្រងលើអ៊ីស្រាអែល ។ ពួកសាសន៍យូដាបានអន់ចិត្តនឹងច្បាប់របស់ពួករ៉ូម ហើយបានទន្ទឹងរង់ចាំយ៉ាងអន្ទះសាចាំព្រះមែស៊ី ដែលបានសន្យាថានឹងយាងមកសង្គ្រោះពួកគេពីពួករ៉ូម ។ ដោយសារពួកសាសន៍យូដាជាច្រើនបានរំពឹងចង់ឲ្យព្រះមែស៊ីយាងមករំដោះពួកគេចេញពីច្បាប់បរទេស ពួកគេបានបដិសេធព្រះយេស៊ូវគ្រីស្ទថាជាព្រះអង្គសង្គ្រោះរបស់ពួកគេ ។

ចូរសុំឲ្យសិស្សអានក្រដាសនោះ ហើយពិភាក្សាសំណួរខាងក្រោមជាក្រុម (អ្នកគួរកត់សំណួរទាំងនេះលើក្តារខៀន) ៖

- តើពួកសាសន៍យូដាជាច្រើនបានរំពឹងអ្វីខ្លះពីព្រះមែស៊ីដែលនឹងយាងមក ?
- ហេតុអ្វីអ្នកគិតថាការរំពឹងទុកដ៏ខុសឆ្គងនេះបានដឹកនាំពួកសាសន៍យូដាជាច្រើនឲ្យបដិសេធព្រះយេស៊ូវ ថាជាព្រះមែស៊ី ?

សូមពន្យល់ថា កាលពួកសាសន៍យូដាមួយចំនួនបានបដិសេធព្រះគ្រីស្ទ មានពួកគេផ្សេងទៀតបានមានចិត្តរាបសា ហើយបានស្គាល់ទ្រង់ជាព្រះមែស៊ី និង ជាព្រះអង្គសង្គ្រោះ ។

ចូរសុំឲ្យសិស្សបីបួននាក់ប្ដូរវេនគ្នាអានឲ្យឮៗនៅក្នុង លូកា ២:២៥-៣៣ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ហើយស្វែងរកអ្វីដែល បុរសសុចរិតម្នាក់ឈ្មោះស៊ីម្មានបានធ្វើ ហើយថ្លែងកាលយ៉ូសែប និង ម៉ារាបាននាំព្រះយេស៊ូវទៅព្រះវិហារបរិសុទ្ធកាលពីនៅជាព្រះឱរស ។

- យោងតាម ខទី ៣០-៣២ហេតុអ្វីព្រះយេស៊ូវត្រូវបានបញ្ជូនមកផែនដី ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្មោលពីសេចក្ដីពិតខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទត្រូវបានបញ្ជូនមកដើម្បីនាំសេចក្ដីសង្គ្រោះដល់មនុស្សគ្រប់រូបគ្នា**) ។
- តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះ ដើម្បីអនុញ្ញាតឲ្យមនុស្សទាំងអស់បានសេចក្ដីសង្គ្រោះ ?

សូមដាក់បង្ហាញរូបភាពស្មេជាន ដែលបានបង្ហាញនៅពេលចាប់ផ្ដើមបង្រៀនមេរៀននេះ ។ សូមលើកទឹកចិត្តសិស្សឲ្យចងចាំបរិបទខាងវប្បធម៌ និង ខាងប្រវត្តិសាស្ត្រដែលអ្នកបានពិភាក្សា កាលពួកគេសិក្សាព្រះគម្ពីរសញ្ញាថ្មី ។ កាលពួកគេធ្វើដូច្នេះ ពួកគេនឹងយល់ពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ និង ពួកសាវករបស់ទ្រង់កាន់តែប្រសើរឡើង ។ (សម្រាប់ព័ត៌មានបន្ថែមស្ដីពីបរិបទខាងវប្បធម៌ និង ខាងប្រវត្តិសាស្ត្រនៃព្រះគម្ពីរសញ្ញាថ្មី សូមមើល « The Intertestamental Period » និង « The New Testament Setting » នៅក្នុង *New Testament Student Manual* (។ Church Educational System manual ឆ្នាំ ២០១៤ ។ ទំព័រ ១–៣) ។ ឯកសារនេះរួមបញ្ចូលសេចក្ដីពន្យល់ខ្លីៗស្ដីពីក្រុមនានាដូចជា ពួកសាម៉ារី ពួកផារិស៊ី ពួកសាឌូស៊ី ពួកសានហេឌ្រីន និងពួកអាចារ្យទាំងឡាយ) ។

ការមើលជាមុនដោយសង្ខេបពីព្រះគម្ពីរសញ្ញាថ្មី



សូមប្រាប់សិស្សថា អ្នកនឹងបង្ហាញ រូបភាព មួយដល់ពួកគេក្នុងពេល ១០ វិនាទី រួចចូរសុំឲ្យពួកគេសរសេរការពិពណ៌នាលម្អិតមួយអំពីអ្វីដែលពួកគេបានឃើញ ។ សូមបង្ហាញរូប ព្រះគ្រីស្ទព្យាបាលអ្នកឈឺនៅបេថែសដា (*Gospel Art Book* លេខ៨២ សូមមើលផងដែរ LDS.org) ។ ក្រោយពី ១០ វិនាទីកន្លងទៅ សូមយករូបភាពនោះទុក ហើយចូរសុំឲ្យសិស្សសរសេរការពិពណ៌នារបស់ខ្លួន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សពីរបីនាក់អានការពិពណ៌នារបស់ខ្លួនទៅកាន់សិស្សក្នុងថ្នាក់ ។

- ទោះបីជាអ្នកទាំងអស់គ្នាបានឃើញរូបភាពដូចគ្នាក៏ដោយ ហេតុអ្វីការពិពណ៌នារបស់អ្នកខុសគ្នា ?
- ហេតុអ្វីបានជាការមានសាក្សីនៃព្រឹត្តិការណ៍មួយលើសពីម្នាក់ វាគឺជារឿងមួយដ៏ល្អ ?

សូមសរសេរឈ្មោះអ្នកនិពន្ធនៃដំណឹងល្អទាំងបួននៅលើក្ដារខៀន ៖ *ម៉ាថាយ*, *ម៉ាកុស*, *លូកា* និង *យ៉ូហាន* ។ សូមពន្យល់ថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទទាំងនេះ ពួកគាត់ម្នាក់ៗបានកត់ត្រាព្រឹត្តិការណ៍ និង ការបង្រៀនទាំងឡាយចេញពីជីវប្រវត្តិរបស់ព្រះអង្គសង្គ្រោះ ។ កំណត់ត្រារបស់ពួកគាត់ត្រូវបានហៅថាដំណឹងល្អ ។ ពាក្យ *ដំណឹងល្អ* មានន័យថា « សេចក្ដីល្អដែលឲ្យដឹង » ។ សូមចង្អុលបង្ហាញថា ការបកប្រែរបស់ យ៉ូសែប ស៊្មីធ បានប្ដូរចំណងជើងនៃដំណឹងល្អនីមួយៗទៅជា *ទីបន្ទាល់* ដូចជានៅក្នុង « The Testimony of St. Matthew (ទីបន្ទាល់របស់ម៉ាថាយ » ។

- ហេតុអ្វីបានជាវាជាការល្អដើម្បីមានដំណឹងល្អ ឬទីបន្ទាល់នៃជីវប្រវត្តិ និង ការបង្រៀននៃព្រះយេស៊ូវគ្រីស្ទច្រើនជាងមួយ ?

សូមពន្យល់ថា ទោះបីជាដំណឹងល្អទាំងបួនមានភាពខុសគ្នាខ្លះៗនៅក្នុងសេចក្ដីលម្អិត និងទស្សនៈក្ដី ប៉ុន្តែវានិទានព្រឹត្តិការណ៍នៃជីវប្រវត្តិ និង ការបម្រើនៅលើផែនដីរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមសាសន៍យូដាដូចគ្នា ។ ដំណឹងល្អទាំងបួនថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះនៃពិភពលោក (សូមមើលសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ដំណឹងល្អ ») ។

អ្នកគួរឲ្យឯកសារកំណែសង្ខេបនៃតារាង « ជីវប្រវត្តិដ៏សំខាន់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរមែងស្លាប់ » ដល់សិស្សនៅចុងបញ្ចប់នៃមេរៀននេះ ។ កំណែពេញលេញនៃតារាងនេះមាននៅក្នុង លិបិក្រម នៃសៀវភៅសិក្សានេះ ។ សូមអញ្ជើញសិស្សប្រើតារាងនេះដើម្បីដឹងពីព្រឹត្តិការណ៍សំខាន់ៗមួយចំនួននៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ។

- យោងតាមតារាងនោះ តើការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះមានរយៈពេលប៉ុន្មាន ?
- នៅក្នុងការងារបម្រើរបស់ទ្រង់ តើព្រះអង្គសង្គ្រោះគង់នៅកន្លែងណាច្រើនជាងគេ ?

សូមអញ្ជើញសិស្សឲ្យប្រើតារាងនេះដើម្បីមានការយល់ដឹងកាន់តែប្រសើរទៅលើបរិបទនៃដំណឹងល្អទាំងបួន នៅពេលពួកគេសិក្សាព្រះគម្ពីរសញ្ញាថ្មី ។

ចូរសុំឲ្យសិស្សបើកទៅតារាងមាតិកានៃព្រះគម្ពីរប៊ីប ។ សូមពន្យល់ថា កាលដំណឹងល្អទាំងឡាយបានផ្ដល់នូវដំណើររឿងមួយអំពីការបម្រើរបស់ព្រះអង្គសង្គ្រោះ នោះគម្ពីរចាប់ពីគម្ពីរកិច្ចការរហូតដល់គម្ពីរវិវរណៈ បានកត់ត្រាពីការបម្រើនៃពួកសាវករបស់ព្រះគ្រីស្ទកាលពីបុរាណ បន្ទាប់ពីការឆ្លាង ការមានព្រះជន្មរស់ឡើងវិញ និង ការយាងឡើងទៅស្ថានសួគ៌វិញរបស់ទ្រង់ ។ ពួកសាវកទាំងនេះបានធ្វើដំណើរទូទាំងដែនដីអឺស្រាអែល និង អាណាចក្ររ៉ូម ដើម្បីផ្សព្វផ្សាយដំណឹងល្អ និង ស្ថាបនាសាខានានារបស់សាសនាចក្រ ។ ដោយសិក្សាពីសកម្មភាព និង ការសរសេររបស់ពួកសាវកទាំងនេះ យើងអាចពង្រឹងសេចក្ដីជំនឿរបស់យើងលើព្រះអង្គសង្គ្រោះ ហើយរៀនពីរបៀបដើម្បីទទួលបានពរជ័យនៃដង្វាយធួនរបស់ទ្រង់ ។ យើងក៏អាចឃើញពីភាពដូចគ្នានៃសាសនាចក្រនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ និងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទកាលពីបុរាណផងដែរ ។

សូមពិចារណាថ្លែងទីបន្ទាល់អំពីសេចក្ដីពិតនានាដែលអ្នកបានរកឃើញនៅក្នុងការសិក្សាព្រះគម្ពីរសញ្ញាថ្មី ។ សូមអញ្ជើញសិស្សស្វែងរកសេចក្ដីពិតដែលនឹងផ្ដល់ពរជ័យដល់ពួកគេ នៅពេលពួកគេសិក្សាព្រះគម្ពីរសញ្ញាថ្មីនាឆ្នាំនេះ ។

ព្រះរាជដីរប្រវត្តិសំខាន់ៗនៅក្នុងជីវិតរមែងស្លាប់នៃព្រះយេស៊ូវគ្រីស្ទ




ត្រាស់ហៅពួកសាវក


ធ្វើឲ្យសមុទ្រស្ងប់


យាងនៅលើទឹក


ធ្វើឲ្យទឹកក្លាយជាស្រាទំពាំងបាយជូរ


ទេសនកថានៅលើភ្នំ


ប្រទានអាហារដល់មនុស្សជាង ៥០០០ នាក់


មានព្រះជន្មធំដឹងក្តី


បង្រៀន ហើយព្យាបាលទូទាំងស្រុកកាលីឡេ


បង្រៀនរឿងប្រៀបប្រដូចអំពីនគរ



ភ្នំប្រែរូប


បង្រៀនស្ត្រីម្នាក់នៅឯអណ្តូងទឹក


បង្រៀន ហើយព្យាបាលនៅក្រុងសាម៉ារី និង ស្រុកពេរេ


ប្រសូត


ពិធីបុណ្យជ្រមុជទឹក


គៀសខ្លួនទៅប្រទេសអេស៊ីប


ការសម្អាតព្រះវិហារបរិសុទ្ធលើកទីមួយ


ប្រោសឡាសារឲ្យរស់ឡើងវិញ


ការឆ្កាង


ការយាងទៅស្ថានសូគ៌ាវិញ


អាហារចុងក្រោយ


ផ្លូវជោគជ័យ និង ការសម្អាតព្រះវិហារបរិសុទ្ធលើកទីពីរ


សួនច្បារគែតសេម៉ានី


ការមានព្រះជន្មរស់ឡើងវិញ

ឆ្នាំទីមួយនៃការងារបម្រើ | ឆ្នាំទីពីរនៃការងារបម្រើ | ឆ្នាំទីបីនៃការងារបម្រើ | សប្តាហ៍ចុងក្រោយ និង ដង្វាយធួន

© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។

មេរៀនសិក្សានៅផ្ទះ

ផែនការនៃសេចក្តីសង្គ្រោះ–សេចក្តីផ្តើម និង បរិបទនៃព្រះគម្ពីរសញ្ញាថ្មី(មេរៀនទី ១)

ការរៀបចំសម្ភារ សម្រាប់ គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សា នៅ ផ្ទះ

សេចក្តីសង្ខេប នៃ មេរៀន សិក្សា នៅ ផ្ទះប្រចាំថ្ងៃ

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបមួយអំពីព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេសិក្សាមេរៀនចំនួនបួនសម្រាប់សិស្សសិក្សានៅផ្ទះសម្រាប់ មេរៀនទី ១ ។ ការដឹងពីអ្វីដែលសិស្សនឹងត្រូវសិក្សា នឹងជួយអ្នកឲ្យរៀបចំខ្លួនដើម្បីបង្រៀន ។ សេចក្តីសង្ខេបនេះពុំមែនជាផ្នែកមួយនៃមេរៀនទេ ហើយពុំមានន័យថាត្រូវយកវាទៅចែកចាយជាមួយនឹងសិស្សដែរ ។ ដោយសារមេរៀនដែលអ្នកនឹងបង្រៀនសម្រាប់វគ្គទី ១ ផ្តោតសំខាន់ទៅលើគោលលទ្ធិ និង គោលការណ៍តែពីរបីដែលបានរៀបរាប់នៅក្នុងសេចក្តីសង្ខេបនេះ ពេលខ្លះអ្នកអាចមានអារម្មណ៍ត្រូវពិនិត្យមើល ឬពិភាក្សាគោលលទ្ធិ និង គោលការណ៍ផ្សេងទៀត ស្របតាមការបំផុសគំនិតនៃព្រះវិញ្ញាណ និង សេចក្តីត្រូវការនៃសិស្សរបស់អ្នក ។

ថ្ងៃទី ១ (ផែនការនៃសេចក្តីសង្គ្រោះ)

នៅក្នុងការសិក្សារបស់ពួកគេអំពីផែនការនៃសេចក្តីសង្គ្រោះ សិស្សទាំងឡាយបានរៀនថា ព្រះយេស៊ូវគ្រីស្តត្រូវបានជ្រើសរើសនៅក្នុងជីវិតមុនឆាកជីវិតនេះឲ្យធ្វើជាព្រះជ័ព្រោសលោះនៃមនុស្សលោក ហើយថានៅក្រោមការដឹកនាំរបស់ព្រះវរបិតាសួគ៌ទ្រង់បានបង្កើតផែនដីនេះ ។ ពួកគេក៏បានរៀនផងដែរពីសេចក្តីពិតដូចតទៅនេះ ៖ ព្រះយេស៊ូវគ្រីស្តបានយាងមកសង្គ្រោះពួកយើងពីអំពើបាបរបស់យើង ។ ដោយសារការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ត នោះមនុស្សទាំងអស់នឹងបានរស់ឡើងវិញ ។ ព្រះយេស៊ូវគ្រីស្តនឹងកាត់សេចក្តីមនុស្សលោកទាំងអស់ ។ ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ត ហើយរស់នៅស្របតាមដំណឹងល្អរបស់ទ្រង់ នោះទើបយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

ថ្ងៃទី ២ (តួនាទីរបស់សិស្ស)

សិស្សទាំងឡាយបានរៀនថា ព្រះវិញ្ញាណបរិសុទ្ធបង្រៀនអំពីសេចក្តីពិត ។ ពួកគេបានដឹងផងដែរថា ប្រសិនបើយើងខិតខំរៀនសូត្រដោយសេចក្តីជំនឿ នោះទើបយើងអាចយាងព្រះវិញ្ញាណបរិសុទ្ធឲ្យចូលមកក្នុងដួងចិត្តរបស់យើង ដើម្បីបង្រៀន ហើយថ្លែងទីបន្ទាល់ពីសេចក្តីពិត ។

ថ្ងៃទី ៣ (ការសិក្សាបទគម្ពីរ)

សិស្សទាំងឡាយបានរៀនពីសារៈសំខាន់នៃការអានទាំងស្រុងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី និង ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ។ លើសពីនេះទៀត សិស្សបានកត់សម្គាល់ឃើញថា សេចក្តីត្រូវការរបស់យើងចំពោះព្រះគម្ពីរនៅសព្វថ្ងៃនេះគឺធំជាងជំនាន់មុនៗទៅទៀត ហើយថានៅពេលយើងសិក្សាព្រះគម្ពីរ នោះយើងអាចទទួលបានប្រាជ្ញា ពន្លឺ សេចក្តីពិត ការកែតម្រូវ និង ការណែនាំដែលនឹងដឹកនាំយើងទៅរកសេចក្តីសង្គ្រោះ ។ ពួកគេក៏បានដឹងផងដែរថា នៅពេលយើងសិក្សាព្រះគម្ពីរប្រចាំថ្ងៃ យើងនឹងទទួលបាន « ទឹកស់ » ឬការចិញ្ចឹមបីបាច់ខាងវិញ្ញាណ ដែលយើងត្រូវការ ។

ថ្ងៃទី ៤ (សេចក្តីផ្តើម និង បរិបទនៃព្រះគម្ពីរសញ្ញាថ្មី)

សិស្សទាំងឡាយបានរៀនថា នៅពេលពួកគេដឹងច្បាស់ពីបរិបទខាងប្រវត្តិសាស្ត្រ និង ខាងប្បធម៌ក្នុងព្រះគម្ពីរសញ្ញាថ្មី នោះពួកគេអាចយល់ដឹងកាន់តែប្រសើរ ហើយអនុវត្តតាមការបង្រៀនរបស់វា ។ ពួកគេក៏បានរៀនដែរថា ព្រះយេស៊ូវគ្រីស្តត្រូវបានបញ្ជូនមក ដើម្បីនាំយកសេចក្តីសង្គ្រោះទៅឲ្យមនុស្សគ្រប់រូប ហើយថានៅពេលយើងមករកព្រះយេស៊ូវគ្រីស្ត យើងនឹងមានបំណងប្រាថ្នាដ៏ធំមួយដើម្បីអញ្ជើញមនុស្សដទៃទៀតឲ្យមករកទ្រង់ ។

សេចក្តីផ្តើម

មេរៀននេះមានគោលបំណងដើម្បីរៀបចំខ្លួន ហើយលើកទឹកចិត្តសិស្សឲ្យសិក្សាព្រះគម្ពីរសញ្ញាថ្មី ដោយណែនាំពួកគេឲ្យស្គាល់ប្រធានបទដ៏សំខាន់មួយដែលមាននៅក្នុងការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ត និង ពួកសាវករបស់ទ្រង់កាលពីជំនាន់បុរាណ ។ នៅពេលសិស្សសិក្សាព្រះគម្ពីរសញ្ញាថ្មី នោះពួកគេនឹងរៀនពីរបៀបឆ្លើយតបទៅនឹងការអញ្ជើញដដែលៗរបស់ព្រះអង្គសង្គ្រោះថាឲ្យមករកទ្រង់ ហើយទទួលបានជំនួយរបស់ទ្រង់ និង ព្រះបន្ទូលណែនាំរបស់ទ្រង់នៅក្នុងជីវិតរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

សេចក្តីផ្តើមអំពីព្រះគម្ពីរសញ្ញាថ្មី

ព្រះគម្ពីរសញ្ញាថ្មីជួយយើងឲ្យមករកព្រះយេស៊ូវគ្រីស្ត

សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀន មុនពេលចាប់ផ្តើមបង្រៀន ៖ *តើបន្ទុកដ៏លំបាកមួយចំនួនដែលយុវវ័យជួបនៅសម័យយើងនេះមានអ្វីខ្លះ ?*

សូមយកប្រអប់ទទេរ ឬកាបូបស្ពាយមួយ ហើយយករបស់ធ្ងន់ៗមកដាក់នៅក្នុងប្រអប់ ឬកាបូបនោះដូចជា ដុំថ្ម ឬសៀវភៅទៅថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខក្តារខៀន ហើយឲ្យគាត់កាន់ប្រអប់ទទេរ ឬស្ពាយកាបូបនោះ ។ ចូរសុំឲ្យសិស្សផ្សេងទៀតឆ្លើយនឹងសំណួរដែលមាននៅលើក្តារខៀន ហើយសុំឲ្យសិស្សម្នាក់ទៀតឡើងមកសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។ បន្ទាប់ពីទទួលបានចម្លើយនីមួយៗ សូមដាក់របស់ធ្ងន់មួយនៅក្នុងប្រអប់ ឬកាបូបនោះរហូតដល់វាពេញ ។

- តើអ្នកមានអារម្មណ៍បែបណាដែរ ប្រសិនបើអ្នកត្រូវទ្របន្ទុកនេះពេញមួយថ្ងៃ ?

សុំឲ្យសិស្សពន្យល់ពីការប្រឈម ឬការលំបាកនានាដែលបន្ទុកមួយចំនួនដែលបានសរសេរនៅលើក្តារខៀននេះ អាចបង្ករហេតុអ្វីដល់មនុស្សម្នាក់ ។

សូមពន្យល់ថា ព្រះគម្ពីរសញ្ញាថ្មីបង្រៀនយើងអំពីការបម្រើនៅក្នុងជីវិតរមែងស្លាប់ និង ក្រោយពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ត រួមបញ្ចូលទាំងការបង្រៀនទាំងឡាយអព្ភូតហេតុនានា ពលិកម្មធួន និងការយាងមករបស់ទ្រង់ទៅជួបនឹងពួកសិស្សនៃសាសនាចក្រកាលពីបុរាណ ។ តាមរយៈការបង្រៀនទាំងឡាយ និងទំនាក់ទំនងរបស់ទ្រង់ជាមួយមនុស្សដទៃទៀត វាគឺជាសេចក្តីពិតមួយដែលបានលើកឡើងម្តងហើយម្តងទៀត ដែលវាអាចជួយយើងសម្រាលបន្ទុកដែលយើងមាន ។


សូមពន្យល់ថា ម៉ាថាយ ១១ រួមបញ្ចូលនូវឧទាហរណ៍មួយនៃប្រធានបទដ៏សំខាន់នេះដែលសិស្សនឹងមើលឃើញជារឿយៗ នៅក្នុងការសិក្សារបស់ពួកគេអំពីព្រះគម្ពីរសញ្ញាថ្មីនៅឆ្នាំនេះ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១១:២៨ ឲ្យឮៗ ។ សុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ដោយរកមើលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះទៅកាន់អស់អ្នកដែលមានបន្ទុកធ្ងន់ ។

- តើអ្នកគិតថា ការនឿយព្រួយ ហើយមានផ្ទុកធ្ងន់ មានន័យដូចម្តេច ?
- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានការឈប់សម្រាករបស់ទ្រង់ ? (សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្តរួមជាមួយនឹងបន្ទុករបស់យើង នោះទ្រង់នឹងឲ្យយើងឈប់សម្រាក**) ។
- តើអ្នកគិតថា ការមករកព្រះយេស៊ូវគ្រីស្តមានន័យដូចម្តេច ?

ដើម្បីជួយសិស្សឲ្យយល់ដឹងពីអត្ថន័យនៃការមករកព្រះគ្រីស្ត សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ១១:២៩–៣០ ឲ្យឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលបន្ទូលណែនាំរបស់ព្រះអង្គសង្គ្រោះទៅកាន់អស់អ្នកដែលមានបំណងប្រាថ្នាចង់មករកទ្រង់ ។

- យោងតាមខគម្ពីរទាំងនេះ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមករកព្រះគ្រីស្ត ?

សូមគូរ រូប នឹមគោមួយនៅលើក្តារខៀន ឬបង្ហាញរូបនឹមមួយ ។



សូមពន្យល់ថា នឹម គឺជា ធ្នឹម ឈើមួយ ដែលភ្ជាប់ ឬដាក់គោ ឬសត្វជនិទៃទៀតមួយនឹម ដើម្បីឲ្យវាអាចទាញបន្ទុកមួយរួមគ្នា ។

- តើអ្វីទៅជាគោលបំណង និង អត្ថប្រយោជន៍របស់នឹម ? (ទោះបីជា នឹមនោះគឺជាទម្ងន់ ឬ បន្ទុកមួយក្តី ប៉ុន្តែវាអនុញ្ញាតឲ្យសត្វទាំងពីរក្បាលរួមថាមពល និង កម្លាំងរបស់វាជាមួយគ្នា ដើម្បីបង្កើននូវផលិតភាពរបស់វា) ។
- តើអ្នកគិតថា ការទទួលយកនឹមរបស់ព្រះអង្គសង្គ្រោះដាក់មកលើយើង មានន័យដូចម្តេច ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជាវឺ អេ បែឌណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សុំឲ្យសិស្សស្តាប់ ហើយគិតពីរបៀបដែលយើងអាចយកនឹមរបស់ព្រះអង្គសង្គ្រោះមកដាក់លើយើង ហើយថាតើពរជ័យអ្វីខ្លះដែលយើងអាចទទួលបានតាមរយៈការធ្វើដូច្នេះ ។

« នឹមមួយទឹមសត្វឲ្យដើរទន្ទឹមគ្នា ដើម្បីវាអាចសម្រេចកិច្ចការមួយបាន ។

« ចូរពិចារណាអំពីការអញ្ជើញដ៏ពិសេសរបស់ព្រះអម្ចាស់ដល់យើងម្នាក់ៗថា ‹ ចូរទទួលនឹមខ្ញុំ › ។ ការចុះ និង ការរក្សាសេចក្តីសញ្ញាពិសិដ្ឋ គឺជាការទឹមយើងជាមួយនឹងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ មានន័យថា ព្រះអង្គសង្គ្រោះ កំពុងតែអញ្ជើញយើង ឲ្យពឹងផ្អែក ហើយទាញជាមួយនឹងទ្រង់ ទោះជាសមត្ថភាពល្អបំផុតរបស់យើង មិនស្មើ ឬមិនអាចប្រៀបនឹងទ្រង់ក៏ដោយ ។ កាលណាយើងទុកចិត្ត ហើយទាញបន្ទុកយើងជាមួយទ្រង់ ក្នុងជំណើរនៃជីវិតរមែងស្លាប់នេះ នោះនឹមទ្រង់ពិតជាងាយ ហើយបន្ទុកទ្រង់ពិតជាស្រាល ។

« យើងនឹងពុំនៅម្នាក់ឯងឡើយ ។ យើងអាចឆ្ពោះទៅមុខ នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ដោយមានជំនួយមកពីស្ថានសួគ៌ ។ តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ នោះយើងអាចទទួលបានសមត្ថភាព និង ‹ លើសកម្លាំង[របស់យើង] › (‹ ខ្ញុំនឹងដើរតាមព្រះអង្គ › *ទំនុកតម្កើង* លេខ ១៣៥) » (« Bear Up Their Burdens with Ease » *Ensign* ឬ Liahona ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៨៨) ។

- តើអ្វីទៅ «ទឹម » យើងជាមួយនឹងព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ?
- យោងតាមអែលឌើរ បែឌណា តើពរជ័យនៃការដាប់នឹមជាមួយព្រះអង្គសង្គ្រោះមានអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា ការសន្យារបស់ព្រះអង្គសង្គ្រោះអំពី « ការឈប់សម្រាក » នៅក្នុង ម៉ាថាយ ១១:២៨–២៩ ពុំមែនមានន័យថា ទ្រង់នឹងដកយកបញ្ហា ឬការប្រឈមរបស់យើងចេញនោះឡើយ ។ ជារឿយៗ ព្រះអង្គសង្គ្រោះនឹងប្រទានសេចក្តីសុខសាន្តដល់យើង និង កម្លាំងដែលយើងត្រូវការដើម្បីយកឈ្នះ ឬស៊ូទ្រាំនឹងការសោកល្វងរបស់យើង ហេតុដូច្នេះហើយទើបធ្វើឲ្យបន្ទុករបស់យើងបានធូរស្រាល ។ ប្រសិនបើយើងស្មោះត្រង់នៅក្នុងការប្រឈមទាំងឡាយនៃជីវិតរមែងស្លាប់នេះ នោះការឈប់សម្រាកដែលយើងនឹងទទួលបានគឺជាភាពតម្កើងឡើងជាមួយនឹងព្រះ (សូមមើល គ. និង ស. ៨៤:២៣–២៤) ។

សុំឲ្យសិស្សពិចារណាពីរបៀបដែលព្រះអង្គសង្គ្រោះបានប្រទាននូវការឈប់សម្រាកដល់ពួកគេ នៅពេលពួកគេមករកទ្រង់ ។ សូមអញ្ជើញសិស្សពីរបីនាក់ ចែកចាយនូវបទពិសោធន៍របស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅដាក់លាក់នានាអំពីរបៀបដែលពួកគេអាចមករកព្រះយេស៊ូវគ្រីស្ទពេញមួយឆ្នាំ ក្នុងការសិក្សាអំពីព្រះគម្ពីរសញ្ញាថ្មីនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់បញ្ចូលការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ និង ការអានព្រះគម្ពីរសញ្ញាថ្មីទាំងស្រុងនៅឆ្នាំនេះក្នុងគោលដៅរបស់ពួកគេ ។

សេចក្តីសង្ខេបទិដ្ឋភាពទូទៅនៃព្រះគម្ពីរសញ្ញាថ្មី

គម្ពីរទាំងឡាយនៅក្នុងព្រះគម្ពីរសញ្ញាថ្មីធ្វើទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ និង ជាព្រះអង្គសង្គ្រោះរបស់យើង ។

សូមសរសេរឈ្មោះអ្នកនិពន្ធនៃដំណឹងល្អទាំងបួននៅលើក្តារខៀន ៖ *ម៉ាថាយ, ម៉ាកុស, លូកា* និង *យ៉ូហាន* ។ សូមពន្យល់ថា ក្នុងពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទទាំងនេះ ពួកគាត់ម្នាក់ៗបានកត់ត្រាព្រឹត្តិការណ៍ និង ការបង្រៀនទាំងឡាយចេញពីជីវប្រវត្តិរបស់ព្រះអង្គសង្គ្រោះ ។ កំណត់ត្រារបស់ពួកគាត់ត្រូវបានហៅថា ដំណឹងល្អ ។ ៣ក្យ *ដំណឹងល្អ* មានន័យថា « សេចក្តីល្អដែលត្រូវជឿង » ។ សូមចង្អុលបង្ហាញថា ការបកប្រែរបស់យ៉ូសែប ស្ម៊ីធបានប្តូរចំណងជើងនៃដំណឹងល្អនីមួយទៅជា *ទីបន្ទាល់* ដូចជានៅក្នុង « The Testimony of St. Matthew « ទីបន្ទាល់របស់ម៉ាថាយ » ។

- ហេតុអ្វីបានជាវាជាការល្អ ដើម្បីមានដំណឹងល្អ ឬទីបន្ទាល់អំពីជីវប្រវត្តិ និង ការបង្រៀននៃព្រះយេស៊ូវគ្រីស្ទច្រើនជាងមួយ ?

សូមពន្យល់ថា ទោះបីជាដំណឹងល្អទាំងបួនមានភាពខុសគ្នាខ្លះៗនៅក្នុងសេចក្តីលម្អិត និង ទស្សនៈក្តី ក៏វាទិទានព្រឹត្តិការណ៍នៃជីវប្រវត្តិ និង ការបម្រើនៅលើផែនដីរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមសាសន៍យូដាដូចគ្នា ។ ដំណឹងល្អទាំងបួនថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ សុំឲ្យសិស្សបើកទៅតារាង « ជីវប្រវត្តិដ៏សំខាន់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរមែងស្លាប់ » នៅចុងបញ្ចប់នៃវគ្គទី ១ ៖ មេរៀនថ្ងៃទី ៤ ។ សូមអញ្ជើញសិស្សឲ្យប្រើតារាងនេះដើម្បីដឹងពីព្រឹត្តិការណ៍សំខាន់ៗមួយចំនួននៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ។

- យោងតាមតារាងនេះ តើការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះមានរយៈពេលយូរប៉ុណ្ណា ?
- តើនៅក្នុងការបម្រើរបស់ទ្រង់ តើព្រះអង្គសង្គ្រោះគង់នៅកន្លែងណាច្រើនជាងគេ ?

សូមអញ្ជើញសិស្សឲ្យប្រើតារាងនេះដើម្បីមានការយល់ដឹងកាន់តែប្រសើរទៅលើបរិបទនៃដំណឹងល្អទាំងបួន នៅពេលពួកគេសិក្សាព្រះគម្ពីរសញ្ញាថ្មី ។

សូមអញ្ជើញសិស្សឲ្យបើកទៅតារាងមាតិកានៃព្រះគម្ពីរបឺប ។ សូមពន្យល់ថា កាលដំណឹងល្អទាំងឡាយនិទាននូវដំណើររឿងមួយអំពីការបម្រើរបស់ព្រះអង្គសង្គ្រោះ នោះគម្ពីរចាប់ពីគម្ពីរកិច្ចការរហូតដល់វិវរណៈ កត់ត្រាពីការបម្រើនៃពួកសាវករបស់ព្រះគ្រីស្ទកាលពីបុរាណ បន្ទាប់ពីការឆ្កាង ការមានព្រះជន្មរស់ឡើងវិញ និង ការយាងឡើងទៅស្ថានសួគ៌វិញរបស់ទ្រង់ ។ ពួកសាវកទាំងនេះបានធ្វើដំណើរទូទាំងដែនដីអ៊ីស្រាអែល និង ចក្រភពរ៉ូម ដើម្បីផ្សព្វផ្សាយដំណឹងល្អ និង ស្ថាបនាសាខាទាំងឡាយរបស់សាសនាចក្រ ។ ដោយសិក្សាពីសកម្មភាព និង ការសរសេររបស់ពួកសាវកទាំងនេះ យើងអាចពង្រឹងសេចក្តីជំនឿរបស់យើងលើព្រះអង្គសង្គ្រោះ ហើយរៀនពីរបៀបដើម្បីទទួលបានពរជ័យនានានៃដង្វាយធួនរបស់ទ្រង់ ។ យើងក៏អាចឃើញពីភាពដូចគ្នានៃសាសនាចក្រនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ និងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទកាលពីបុរាណ ។

សូមពិចារណាចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរសញ្ញាចាស់ ហើយអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនានាដែលនឹងផ្តល់ពរជ័យឲ្យពួកគេ នៅពេលពួកគេសិក្សាពីជីវប្រវត្តិ និង ការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ និង ពួកសាវករបស់ទ្រង់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

វគ្គបន្ទាប់ (ម៉ាថាយ ១–៥)

សូមពន្យល់ថា នៅក្នុងវគ្គបន្ទាប់ សិស្សនឹងសិក្សាពីសេចក្តីលម្អិតមួយចំនួនជុំវិញការប្រសូតរបស់ព្រះរាជបុត្រានៃព្រះ ។ ពួកគេក៏នឹងសិក្សាផងដែរនូវការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ អំពីរបៀបដើម្បីមានសុភមង្គលពិតនៅក្នុងជីវិតនេះ ហើយប្រែជាល្អតន្ធោះដូចជាព្រះវរបិតាសួគ៌ដែរ ។

សេចក្តីផ្តើមនៃ

ដំណឹងល្អយោងតាមម៉ាថាយ

ហេតុអ្វី ត្រូវសិក្សាគម្ពីរនេះ ?

វគ្គដែលពេញនិយមបំផុតមួយចំនួននៅក្នុងព្រះគម្ពីរប៊ីប គឺមាននៅក្នុងគម្ពីរម៉ាថាយ រួមបញ្ចូលទាំងទេសនកថានៅលើភ្នំ និងរឿងប្រៀបប្រដូច ការបង្រៀន និង អព្ភូតហេតុជាច្រើនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការសិក្សាគម្ពីរនេះអាចជួយសិស្សឲ្យស្គាល់ការងារបម្រើ និង ព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ហើយអាចពង្រឹងទីបន្ទាល់របស់ពួកគេថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះនៃលោកិយ និង ជាព្រះមែស៊ីដែលពួកព្យាការីបរិសុទ្ធទាំងអស់បានថ្លែងប្រកាសថានឹងយាងមក ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ម៉ាថាយ ដែលគេស្គាល់ថាជាលេវី និងជាកូនប្រុសរបស់អាល់ផាយគឺជាអ្នកនិពន្ធគម្ពីរនេះ ។ លោកគឺជាអ្នកយកផាសី ឬជាអ្នកយកពន្ធម្នាក់កាលពីមុន ហើយជីវិតរបស់លោកបានផ្លាស់ប្តូរដោយរៀងរហូត កាលលោកបានឆ្លើយតបទៅនឹងការអញ្ជើញរបស់ព្រះយេស៊ូវគ្រីស្ទឲ្យដើរតាមទ្រង់ ។ (សូមមើល ម៉ាថាយ ៩:៩, ម៉ាកុស ២:១៤, លូកា ៥:២៧–២៨សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ម៉ាថាយ ») ។ បន្ទាប់ពីការប្រែចិត្តជឿរបស់ខ្លួន ម៉ាថាយបានក្លាយជាសាវកម្នាក់ក្នុងចំណោមពួកសាវកទាំងដប់ពីរនាក់របស់ព្រះអង្គសង្គ្រោះ (សូមមើល ម៉ាថាយ ១០:២–៤) ។ ក្នុងនាមជាសាវកមួយរូប ម៉ាថាយគឺជាសាក្សីម្នាក់ចំពោះព្រឹត្តិការណ៍ជាច្រើនដែលលោកបានពិពណ៌នានៅក្នុងកំណត់ត្រារបស់លោក ។ ការណ៍នេះត្រូវបានគាំទ្រដោយការដាក់ចំណងជើងនៃដំណឹងល្អរបស់លោកនៅក្នុងការបកប្រែដោយ យ៉ូសែប ស្ម៊ីធ ៖ « ទីបន្ទាល់របស់ម៉ាថាយ » ។

តើនៅពេលណានិងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

យើងពុំបានដឹងច្បាស់ពីពេលវេលាដែលគម្ពីរម៉ាថាយត្រូវបានសរសេរឡើងឡើយ ប៉ុន្តែវាទំនងជាសរសេរឡើងនៅអំឡុង ៣ក់កណ្តាលសតវត្សទីមួយ នៃគ.ស. ។ យើងពុំដឹងពីទីកន្លែងដែលម៉ាថាយសរសេរគម្ពីរនេះទេ ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

ម៉ាថាយ ហាក់ដូចជាបានសរសេរទៅប្រជាជនសាសន៍យូដា ដើម្បីបង្ហាញថា ព្រះយេស៊ូវគ្រីស្ទបានបំពេញការព្យាករនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ស្តីពីការយាងមករបស់ព្រះមេស៊ី ។ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ« ម៉ាថាយ ») ។ ដូចដែល ម៉ាថាយ បាននិទានម្តងទៀត អំពីជីវប្រវត្តិ ព្រះបន្ទូល និង សកម្មភាពរបស់ព្រះយេស៊ូវគ្រីស្ទ ជាញឹកញាប់លោកបាននិយាយពីការព្យាករនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយបានប្រើឃ្លាថា « ដើម្បីឲ្យបានសម្រេច » (ឧទាហរណ៍ សូមមើល ម៉ាថាយ ៤:១៤, ៨:១៧, ១៣:៣៥, ២១:៤) ។

នៅក្នុងដំណឹងល្អរបស់លោក ម៉ាថាយបានប្រើ៣ក្យ « រ៉ាំ ហ្គូងដាវីឌ » ១២ ដង ជាទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគ្រងមរតកនៃបល្ល័ង្ករបស់ស្តេចដាវីឌដ៏ពេញច្បាប់ និង ជាការបំពេញនៃការព្យាករពីព្រះមែស៊ី ។ ពង្សាវតារបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងម៉ាថាយ បានគូសបង្ហាញពីតំណពូជពង្សរបស់ទ្រង់តាមរយៈដាវីឌ យូដា និង អ័ប្រាហាំ (សូមមើល ម៉ាថាយ ១:១–៣) ដោយបង្ហាញពីសិទ្ធិដ៏ត្រឹមត្រូវរបស់ព្រះយេស៊ូវដើម្បីគ្រប់គ្រង និង តួនាទីរបស់ទ្រង់នៅក្នុងការបំពេញការសន្យារបស់ព្រះចំពោះអ៊ីស្រាអែល ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

ទោះជាឯកសារមួយភាគធំរបស់ម៉ាថាយ ក៏មាននៅក្នុងម៉ាកុស និង លូកាក្តី ក៏ប្រហែលជា ៤២ ភាគរយនៃដំណឹងល្អរបស់ម៉ាថាយគឺជាគម្ពីរវិសេសវិសាលមួយដាច់ដោយឡែកដែរ ។ ប្រធានបទចម្បងមួយនៅក្នុងម៉ាថាយគឺថា ព្រះយេស៊ូវគ្រីស្ទបានយាងមកដើម្បីស្តាបនានគររបស់ទ្រង់នៅលើផែនដី ។ ម៉ាថាយ បាននិយាយអំពី « នគរស្ថានសួគ៌ »ជាច្រើនដង ហើយលោកគឺជាអ្នកនិពន្ធដំណឹងល្អតែម្នាក់គត់ដែលបានដាក់បញ្ចូលការបង្រៀនរបស់ព្រះយេស៊ូវអំពី« សាសនាចក្រ »(សូមមើល ម៉ាថាយ ១៦:១៨, ១៨:១៧) ។

ដំណឹងល្អរបស់ម៉ាថាយក៏ជួយយើងឲ្យឃើញពីភាពស្របគ្នារវាងការងារបម្រើរបស់លោកម៉ូសេ និង ព្រះយេស៊ូវគ្រីស្ទ ។ ឧទាហរណ៍ គួអង្គទាំងពីរត្រូវបានជួយសង្គ្រោះកាលនៅជាទារកពីការប៉ុនប៉ងសម្លាប់របស់ស្តេច (សូមមើល និក្ខមនំ ២:១–១០, ម៉ាថាយ ២:១៣–១៨) បានចេញពីស្រុកអេស៊ីព្ទ បាននាំមកនូវក្រឹត្យវិន័យរបស់ព្រះ ពីលើភ្នំ (សូមមើល និក្ខមនំ ១៩–២០, ម៉ាថាយ ៥–៧) ហើយបានទៅជួយរំដោះប្រជាជនរបស់ខ្លួន ។

គម្រោង

ម៉ាថាយ ១–៤ ម៉ាថាយ បង្ហាញពីពង្សាវតា និង ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកហោរាស្វែងរកស្តេចនៃពួកសាសន៍យូដា ។ ដោយទទួលបានការដឹកនាំនៅក្នុងសុបិន យ៉ូសែបបាននាំម៉ារា និង ព្រះយេស៊ូវទៅស្រុកអេស៊ីព្ទ ហើយក្រោយមកទៀតទៅស្រុកណាសារ៉ែត ។ យ៉ូហាន បាទីស្ទ ប្រកាសពីដំណឹងល្អនៃការប្រែចិត្ត ហើយបានជ្រមុជទឹកថ្វាយព្រះយេស៊ូវគ្រីស្ទ ។ ព្រះអង្គសង្គ្រោះបានទទួលការល្បួងនៅក្នុងទីរហោស្ថាន ។ ទ្រង់ចាប់ផ្តើមការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ដោយការបង្រៀន និងការព្យាបាល ។

ម៉ាថាយ ៥–៧ ព្រះយេស៊ូវគ្រីស្ទធ្វើទេសនកថានៅលើភ្នំ ។

ម៉ាថាយ ៨–១២ ព្រះអង្គសង្គ្រោះព្យាបាលមនុស្សកើតឃ្លង់ម្នាក់ ធ្វើឲ្យព្យុះស្ងប់ បណ្តេញអារក្ស ប្រោសកូនស្រីយ៉ៃរ៉ុសពីស្លាប់ ហើយព្យាបាលមនុស្សខ្វាក់ឲ្យមើលឃើញ ។ ព្រះយេស៊ូវគ្រីស្ទប្រទានសិទ្ធិអំណាចដើម្បីធ្វើកិច្ចការដូចជាទ្រង់ដល់ពួកសាវក ហើយបញ្ជូនពួកគាត់ចេញទៅប្រកាសដំណឹងល្អ ។ ព្រះយេស៊ូវប្រកាសថា យ៉ូហាន បាទីស្ទ គឺលើសពីព្យាការីមួយរូបទៅទៀត ។ ព្រះអង្គសង្គ្រោះព្យាបាលនៅថ្ងៃឈប់សម្រាក ។

ម៉ាថាយ ១៣–១៥ ព្រះយេស៊ូវបង្រៀនដោយប្រើរឿងប្រៀបប្រដូច ។ យ៉ូហាន បាទីស្ទ ត្រូវបានគេសម្លាប់ ។ បន្ទាប់ពីផ្តល់អាហារដល់មនុស្សប្រាំពាន់នាក់មក ព្រះយេស៊ូវ និង ពេត្រុស ដើរនៅលើសមុទ្រកាលីឡេ ។ ពួកអាចារ្យ និង ពួកផារិស៊ីចោទសួរព្រះយេស៊ូវ ។

ម៉ាថាយ ១៦–១៨ បន្ទាប់ពីពេត្រុសថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះមែស៊ី ព្រះអង្គសង្គ្រោះគូសបញ្ជាក់ថា ទ្រង់នឹងប្រទានកូនសោនៃនគរព្រះដល់ពេត្រុស និង ពួកដប់ពីរនាក់ ។ ព្រះយេស៊ូវគ្រីស្ទបានប្រែព្រះកាយនៅលើភ្នំជាទីកន្លែងដែល ពេត្រុស យ៉ាកុប និង យ៉ូហានបានទទួលកូនសោបព្វជិតភាព ។ ព្រះយេស៊ូវបង្គាប់ដល់ពួកសិស្សរបស់ទ្រង់ពីរបៀបដឹកនាំសាសនាចក្រ ហើយបង្រៀនថា ព្រះនឹងពុំអត់ឱនទោសឲ្យយើងឡើយ ប្រសិនបើយើងពុំអត់ឱនទោសដល់អ្នកដទៃ ។

ម៉ាថាយ ១៩–២៣ ព្រះអង្គសង្គ្រោះបង្រៀនពីលក្ខណៈដ៏នៅអស់កល្បជានិច្ចនៃអាពាហ៍ពិពាហ៍ ។ ទ្រង់យាងចូលទៅក្រុងយេរូសាឡិម ហើយបានសម្អាតព្រះវិហារបរិសុទ្ធ ។ តាមរយៈការប្រើរឿងប្រៀបប្រដូច ព្រះយេស៊ូវបានលាតត្រដាងពីចេតនាអាក្រក់របស់ពួកអ្នកដឹកនាំសាសន៍យូដាដែលបដិសេធទ្រង់ ។ ទ្រង់ព្រះកន្សែងចំពោះការបំផ្លិចបំផ្លាញនៃទីក្រុងយេរូសាឡិមនាពេលអនាគត ។

ម៉ាថាយ ២៤–២៥, យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ព្រះយេស៊ូវគ្រីស្ទព្យាករពីការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម ។ ទ្រង់បង្រៀនពីរបៀបដែលពួកអ្នកដើរតាមរបស់ទ្រង់អាចរៀបចំខ្លួនសម្រាប់ការយាងមកវិញរបស់ទ្រង់ ។

ម៉ាថាយ ២៦–២៧ ព្រះយេស៊ូវសោយព្រះស្ងោយសម្រាប់បុណ្យរំលងជាមួយនឹងពួកសិស្សរបស់ទ្រង់ ហើយណែនាំពីពិធីសាក្រាម៉ង់ ។ ទ្រង់រងទុក្ខនៅក្នុងសួនគែតសេម៉ានី ហើយត្រូវបានគេក្បត់ ចាប់ព្រះកាយ បាននាំទៅកាត់ទោសនៅមុខពួកមន្ត្រីយូដា និង រ៉ូម ហើយត្រូវបានគេឆ្កាង ។ ទ្រង់បានសុគត ហើយបានបញ្ចុះ ។

ម៉ាថាយ ២៨ ព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ បានលេចមកជួបនឹងពួកសិស្សរបស់ទ្រង់ ។ ព្រះយេស៊ូវតែងតាំងពួកសាវកឲ្យនាំយកដំណឹងល្អរបស់ទ្រង់ទៅដល់គ្រប់ជាតិសាសន៍ទាំងអស់ ។

មេរៀន ៦

ម៉ាថាយ ១–២

សេចក្តីផ្តើម

ម៉ាថាយបានផ្តល់ពង្សាវតារបស់ព្រះយេស៊ូវគ្រីស្ទ ហើយមានទេវតាមួយអង្គបានប្រកាសទៅកាន់យ៉ូសែបថា ព្រះយេស៊ូវពិតជាព្រះរាជបុត្រានៃព្រះ ។ ពួកអ្នកប្រាជ្ញមកពីទិសខាងកើតបានធ្វើដំណើរទៅរកព្រះយេស៊ូវ ដើម្បីបានថ្វាយបង្គំទ្រង់ ។ យ៉ូសែបត្រូវបានប្រាប់នៅក្នុងសុបិនឲ្យនាំគ្រួសាររបស់គាត់ទៅប្រទេសអេស៊ីប ដើម្បីចៀសផុតពីការសម្លាប់កុមារនៅភូមិបេថ្លេហិមរបស់ស្តេចហេរ៉ូឌ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១:១–១៧

ពង្សាវតារបស់ព្រះយេស៊ូវ

សូមដាក់បង្ហាញរូបថតឪពុកម្តាយរបស់អ្នក រួចសួរសិស្សថាតើពួកគេអាចប្រាប់ពីលក្ខណៈនិស្ស័យណាមួយដែលអ្នកទទួលបានពីឪពុកម្តាយដែរឬទេ ។ អ្នកក៏អាចឲ្យសិស្សពីរបីនាក់យករូបថតឪពុកម្តាយរបស់ពួកគេមក រួចសួរដល់សិស្សដទៃទៀតក្នុងថ្នាក់ឲ្យទស្សន៍ទាយថា តើរូបក្នុងរូបថតនោះគឺជាឪពុកម្តាយរបស់នរណា ។ សុំឲ្យសិស្សពិភាក្សាគ្នាពីលក្ខណៈនិស្ស័យនានាដែលពួកគេបានទទួលពីឪពុកម្តាយខ្លួន (ដូចជា ពណ៌ភ្នែក ពណ៌សក់ ឬកម្ពស់) ។

នៅពេលពួកគេសិក្សា ម៉ាថាយ ១–២ សុំឲ្យសិស្សរកមើលសេចក្តីពិតអំពីមាតាបិតា និង លក្ខណៈនិស្ស័យរបស់ព្រះអង្គសង្គ្រោះដែលទ្រង់បានទទួលមកពីពួកគាត់ ។ សកម្មភាពនេះនឹងរៀបចំសិស្សឲ្យយល់ឮវសេចក្តីពិតថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រាដ៏ទេវភាពរបស់ព្រះវរបិតាសួគ៌ និង ម៉ារា ហើយថាទ្រង់គឺជាបុត្រសំណព្វតែមួយគត់របស់ព្រះវរបិតានៅក្នុងសាច់ឈាម ។

សូមពន្យល់ថា ម៉ាថាយ ១:១–១៧ សរសេរពីដូនតារបស់ព្រះអង្គសង្គ្រោះ ។ សូមចង្អុលបង្ហាញថា ខទី ១ ចែងថា ព្រះយេស៊ូវគ្រីស្ទគឺជាពូជហ្លួងដាវីឌ និង អ័ប្រាហាំ ។

សូមពន្យល់ថា ព្រះគម្ពីរសញ្ញាចាស់បានប្រកាសថា ព្រះមែស៊ីនឹងជាពូជហ្លួងដាវីឌ (សូមមើល សាំយូអែលទី ២ ៧:១២–១៣, អេសាយ ៩:៦–៧, យេរេមា ២៣:៥–៦) ហើយថាពូជពង្សរបស់អ័ប្រាហាំនឹងឲ្យពរ « អស់ទាំងនគរនៅផែនដី » (លោកុប្បត្តិ ២២:១៨, សូមមើលផងដែរ អ័ប្រាហាំ ២:១១) ។ ម៉ាថាយចង់ឲ្យពួកអ្នកអានដឹងថា ព្រះយេស៊ូវបានបំពេញការព្យាករទាំងឡាយក្នុងព្រះគម្ពីរសញ្ញាចាស់ទាក់ទងនឹងព្រះមែស៊ី (សូមមើល ម៉ាថាយ ១:២២–២៣, ២:៥, ១៥, ២៣, ២៦:៥៥–៥៦) ។ ពង្សាវតានៅក្នុង ម៉ាថាយ ១:១–១៧ បង្ហាញថា ព្រះយេស៊ូវគឺជាព្រះមែស៊ីដែលបានសន្យា និងជាអ្នកគ្រងមរតដ៏ពេញសិទ្ធិនៃបល្ល័ង្ករបស់ដាវីឌ ។

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ១:១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលងារដែលព្រះយេស៊ូវបានទទួល ហើយរាយការណ៍អ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថាពាក្យ *ព្រះគ្រីស្ទ* ជាភាសាទម្រង់ភាសាអាវ៉ាម ប្រែថា *ព្រះមែស៊ី* ដែលមានន័យថា « អង្គដែលឆ្ងួន » ។

- នៅក្នុងជីវិតមុនផែនដី តើព្រះយេស៊ូវគ្រីស្ទត្រូវបានចាក់ប្រេងតាំង ឬជ្រើសឲ្យធ្វើអ្វីដែរ ? (ព្រះវរបិតាសួគ៌បានចាក់ប្រេងតាំងទ្រង់ឲ្យធ្វើជា « ព្យាការី សង្ឃ ស្តេច និងជាអ្នករំដោះ » [សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះមែស៊ី », scriptures.lds.org) ។

ម៉ាថាយ ១:១៨–២៥

ទេវតាមួយអង្គបានប្រកាសទៅកាន់យ៉ូសែបថា ព្រះយេស៊ូវពិតជាព្រះរាជបុត្រានៃព្រះ

សូមចង្អុលបង្ហាញថា ម៉ាថាយ ១:១៦ ក៏ចែងផងដែរថា ម៉ារាគឺជាប្រពន្ធរបស់ យ៉ូសែប ។ យោងតាម ម៉ាថាយ ១:១៨យ៉ូសែប និង ម៉ារាបាន *រៀបការជាប្តីប្រពន្ធ* ។ ការណ៍នេះមានន័យថា ពួកគេបានភ្ជាប់ពាក្យ ឬស្តីដណ្តឹង ហើយត្រូវបានភ្ជាប់ជាមួយគ្នាស្របច្បាប់ ប៉ុន្តែពុំទាន់បានរួមរស់នឹងគ្នាជាលក្ខណៈប្តីប្រពន្ធនៅឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ពីមុនអាពាហ៍ពិពាហ៍នេះកើតឡើង យ៉ូសែបបានដឹងថា ម៉ារាបានមានគភ៌ ។ សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ១:១៩ ឲ្យឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលយ៉ូសែបមានបំណងចង់ធ្វើ ។

- តើយ៉ូសែបមានបំណងចង់ធ្វើដូចម្តេច នៅពេលគាត់បានដឹងថា ម៉ារាមានគភ៌នោះ ? (សូមពន្យល់ថា « លែងនាងចេញ ដោយសម្ងាត់ » មានន័យថា យ៉ូសែបមានគម្រោងលុបចោលការភ្ជាប់ពាក្យនោះដោយសម្ងាត់ ដើម្បីកុំឲ្យម៉ារាត្រូវប្រឈមនឹងអាម៉ាសមុខ ឬក៏ត្រូវបង្កើលទោសដោយការចោលនឹងដុំថ្ម) ។
- តើខគម្ពីរនេះបង្រៀនអ្នកអ្វីខ្លះ អំពីបុគ្គលិកលក្ខណៈរបស់យ៉ូសែប ?

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ១:២០ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើងចំពោះ យ៉ូសែប កាលគាត់កំពុងសម្រេចចិត្តបញ្ចប់ការភ្ជាប់ពាក្យនឹងម៉ារា ។

- ហេតុអ្វីទេវតាប្រាប់កុំឲ្យយ៉ូសែបខ្លាចនឹងរៀបការជាមួយម៉ារា ?

ការប្រើប្រាស់កម្មវិធីសិក្សា

នៅពេលអ្នករៀបចំមេរៀនមួយ ចូរមើលកម្មវិធីសិក្សាប្រកបដោយការអធិស្ឋាន ព្រមជាមួយនឹងការសិក្សារបស់អ្នកអំពីបណ្តុំខគម្ពីរ ។ នៅពេលអ្នកធ្វើដូច្នេះ នោះព្រះវិញ្ញាណបរិសុទ្ធអាចជួយអ្នកឲ្យរៀបចំមេរៀនឲ្យស្របតាមសេចក្តីត្រូវការរបស់សិស្ស ។ អ្នកអាចជ្រើសរើសប្រើប្រាស់យោបល់ណែនាំក្នុងការបង្រៀនសម្រាប់បណ្តុំបទគម្ពីរ ឬអ្នកអាចកែសម្រួលគំនិតដែលបានណែនាំទៅតាមតម្រូវការ និងស្ថានភាពក្នុងថ្នាក់រៀនរបស់អ្នក ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃឃ្លា « ដោយព្រះវិញ្ញាណបរិសុទ្ធ » (ម៉ាថាយ ១:១៨, ២០) សុំឲ្យសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« តាមរបៀបដូចគ្នាដែលថា ព្រះយេស៊ូវគឺពិតជាបុត្រារបស់ម៉ារា នោះទ្រង់ក៏ជាបុត្រាផ្ទាល់ ហើយពិតរបស់ព្រះវរបិតាដ៏អស់កល្បជានិច្ចដែរ ។ . . . ការថ្លែងប្រាប់របស់ម៉ាថាយថា ‹ នាងមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ › ប្រសិនជាបកប្រែឲ្យត្រឹមត្រូវត្រូវតែនិយាយថា ‹ នាងមានគភ៌ *ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ* › ។ (ម៉ាថាយ ១:១៨) ។ . . . អាលម៉ាអត្តាធិប្បាយយ៉ាងល្អឥតខ្ចោះពីការចាប់បដិសន្ធិ និង ការប្រសូតរបស់ព្រះអម្ចាស់ដោយការព្យាករ ៖ ព្រះគ្រីស្ទ ‹ នឹងប្រសូតមកពីនាងម៉ារា . . . នាងជាស្ត្រីព្រហ្មចារី គឺជាប្រដាប់ដ៏ជម្រើស ហើយពិសេសមួយដែលនឹងត្រូវគ្របដណ្តប់ ហើយ *ចាប់ទំនៃដ្ឋដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ* ហើយនឹងប្រសូតបានបុត្រមួយ មែនហើយ គឺជា *ព្រះរាជបុត្រានៃព្រះ* › ។ (អាលម៉ា ៧:១០) »។ (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ទំ. ៨២) ។

- តើយើងបានរៀនអ្វីខ្លះពីអត្ថសញ្ញានៃមាតាបិតារបស់ព្រះយេស៊ូវនៅក្នុងការបង្រៀនទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រារបស់ព្រះវរបិតាសួគ៌និងម៉ារា ។** អ្នកគួរណែនាំសិស្សឲ្យសរសេរគោលលទ្ធិនេះ នៅរឹមទំព័រព្រះគម្ពីររបស់ពួកគេក្បែរ ម៉ាថាយ ១:១៨–២៥) ។

សូមនិយាយពីរូបថតឪពុកម្តាយអ្នក រួចនិយាយបញ្ចាក់ឡើងវិញពីលក្ខណៈនិស្ស័យខ្លះៗដែលអ្នកបានទទួលពីពួកគាត់ ។ សុំឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេម អ៊ី ថាលម៉ែហ្គុក្នុង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ សុំឲ្យសិស្សស្តាប់រកហេតុផលដ៏សំខាន់ដើម្បីយល់ដឹងថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះវរបិតាសួគ៌ និង ម៉ារា ។



« បុត្រនោះម៉ារានឹងប្រសូតមកគឺជាព្រះរាជបុត្រានៃអេឡូហីម ព្រះវរបិតាដ៏អស់កល្បជានិច្ច ។ . . . នៅក្នុងលក្ខណៈសម្បត្តិរបស់ទ្រង់ វានឹងរួមផ្សំបញ្ចូលអំណាចជាភាពជាព្រះជាមួយនឹងសមត្ថភាព និង លទ្ធភាពនៃជីវិតរមែងស្លាប់ ។ បុត្រាយេស៊ូវ ត្រូវទទួលមរតកបន្តខាងសាច់ឈាម សតិអារម្មណ៍ និងលក្ខណៈខាងវិញ្ញាណ និង្ឋាការ និងព្រះចេស្តាដែលកាត់តាមឪពុកម្តាយរបស់ទ្រង់—ដែលម្នាងជាអង្គដ៏អមតៈ និងមានសិរីល្អ—គឺព្រះ និងម្នាងទៀតជាមនុស្ស—ស្ត្រី » (*Jesus the Christ*, ការបោះពុម្ពលើកទី ៣ | ឆ្នាំ ១៩១៦ | ទំព័រ ៨១) ។

- តើលក្ខណៈនិស្ស័យអ្វីទៅដែលព្រះយេស៊ូវទទួលបានពីព្រះវរបិតារបស់ទ្រង់ ? តើលក្ខណៈនិស្ស័យអ្វីទៅដែលទ្រង់ទទួលបានពីព្រះមាតារបស់ទ្រង់ ?

សូមពន្យល់ថា ដោយសារព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះវរបិតាដ៏អតមៈ និងព្រះមាតាដែលជាស្ត្រីមានជីវិតរមែងស្លាប់ នោះទ្រង់មានសមត្ថភាពរស់នៅដ៏នៅអស់កល្ប ឬក៏សុគតប្រសិនបើទ្រង់ជ្រើសធ្វើដូច្នោះ ។ និស្ស័យនៃព្រះនេះធ្វើឲ្យទ្រង់មានលក្ខណៈសម្បត្តិវិសេសដាច់ដោយឡែក ដែលអាចរងទុក្ខសម្រាប់អំពើបាបរបស់យើង សុគតលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ។

ម៉ាថាយ ២:១–១២

ពួកហោរាត្រូវបានដឹកនាំឲ្យទៅរកព្រះយេស៊ូវ



សូមដាក់បង្ហាញអំណោយរុំជិតចំនួនបីនៅខាងមុខសិស្ស ឬគូរ រូប អំណោយចំនួនបីនៅលើក្តារខៀន ។

- តើនរណាទៅដែលបានទិញអំណោយថ្វាយព្រះអង្គសង្គ្រោះ បន្ទាប់ពីទ្រង់បានប្រសូតមក ?

សូមពន្យល់ថា ដំណឹងល្អរបស់ម៉ាថាយគឺជាដំណឹងល្អតែមួយគត់ដែលបានដាក់បញ្ចូលដំណើររឿងរបស់ពួកហោរា ។ សូមចែក ក្រដាសលំហាត់ខាងក្រោមនេះ ឬសរសេរសំណួរទាំងនោះលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ។ សូមទុកពេលឲ្យសិស្សពីរបីនាទីដើម្បីអានសំណួរ ហើយសរសេរចម្លើយរបស់ខ្លួន ។

តើអ្នកស្គាល់ពួកហោរាទាំងនោះដល់កម្រិតណាដែរ ?

១. តើពួកហោរាបានដឹងថា ព្រះមែស៊ីបានប្រសូតដោយរបៀបណា ?

២. ហេតុអ្វីពួកហោរាចង់ស្វែងរកព្រះមែស៊ី ?

៣. តើពួកសង្ឃរាជ និង ពួកអាចារ្យបានដឹងពីទីកន្លែង ដែលព្រះមែស៊ីបានប្រសូតដោយរបៀបណា ?

៤. តើស្តេចហេរ៉ូឌចង់ឲ្យពួកហោរាធ្វើអ្វីខ្លះ ក្រោយពីពួកគេបានរកឃើញព្រះយេស៊ូវ ?

៥. តើពួកហោរាបានធ្វើអ្វីជំនួសវិញ ?

លុះដល់ពេលកំណត់ហើយ សុំឲ្យសិស្សអាន ម៉ាថាយ ២:១–១២ ដោយស្ងៀមស្ងាត់ ដោយរកមើលចម្លើយទៅនឹងសំណួររបស់លំហាត់ ។

សុំឲ្យសិស្សពីរបីនាក់ចែកចាយពីរឿងថ្មីៗ ដែលពួកគេបានរៀនអំពីពួកហោរា ។ សេចក្តីលម្អិតនៅក្នុង ខទី ១១ និង ១៦ ណែនាំថា ប្រហែលជាពីរឆ្នាំបន្ទាប់ពីព្រះយេស៊ូវបានប្រសូតមកទើបពួកហោរាត្រូវបានដឹកនាំទៅកាន់គ្រួសារដ៏បរិសុទ្ធនេះ: (ពួកហោរាបានរកឃើញព្រះយេស៊ូវនៅក្នុងផ្ទះមួយ ពុំមែននៅក្នុងស្នូកទេ ហើយទ្រង់ជា « ព្រះកុមារ » គឺពុំមែនជាព្រះឱរសឡើយ) ។ សូមចង្អុលបង្ហាញថា ហេតុផលដែលស្តេចហេរ៉ូឌចង់ឲ្យពួកហោរារាយការណ៍ពីទីកន្លែងដែលពួកគាត់រកឃើញព្រះមែស៊ីគង់នៅ ដើម្បីនឹងទៅធ្វើគត់ទ្រង់ (សូមមើល ម៉ាថាយ ២:១៣) ។

- តើពួកហោរាបានដឹងពីទីកន្លែងទៅរកព្រះមែស៊ីយើញដោយរបៀបណា ?
- តើយើងអាចរៀនអ្វីខ្លះ: ពីគំរូរបស់ពួកហោរាក្នុងការស្វែងរកព្រះអង្គសង្គ្រោះ: ? (ចម្លើយរបស់សិស្សអាចផ្សេងៗគ្នា ប៉ុន្តែសូមជួយពួកគេឲ្យរកឃើញពីគោលការណ៍ខាងក្រោមនេះ: ៖ **ប្រសិនបើយើងស្វែងរកព្រះអង្គសង្គ្រោះដោយស្មោះត្រង់ និង ដោយឧស្សាហ៍ នោះយើងនឹងត្រូវបានដឹកនាំទៅរកទ្រង់**) ។
- តើយើងអាចស្វែងរកព្រះអង្គសង្គ្រោះដោយឧស្សាហ៍តាមរបៀបណា ?
- តើពួកហោរាបានធ្វើអ្វីខ្លះ: នៅពេលពួកគាត់បានរកឃើញព្រះអង្គសង្គ្រោះ: ? ហេតុអ្វី ? (គោលបំណងមួយសម្រាប់ការថ្វាយអំណោយដល់ព្រះអង្គសង្គ្រោះ: គឺដើម្បីថ្វាយបង្គំទ្រង់) ។
- តើយើងអាចរៀនអ្វីខ្លះ:ពីគំរូរបស់ពួកហោរា ក្នុងការថ្វាយអំណោយដល់ព្រះអង្គសង្គ្រោះ: ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ: ៖ **យើងអាចថ្វាយបង្គំព្រះអម្ចាស់ដោយថ្វាយអំណោយដ៏មានន័យដល់ទ្រង់**) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលយើងអាចថ្វាយអំណោយដ៏មានអត្ថន័យដល់ព្រះអង្គសង្គ្រោះ: សុំឲ្យសិស្សអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅក្នុងសម័យបុរាណ ពេលដែលប្រជាជនចង់ថ្វាយបង្គំព្រះអម្ចាស់ និង ស្វែងរកពរជ័យរបស់ទ្រង់ នោះជាញឹកញាប់ពួកគេបាននាំមកនូវអំណោយមួយ ។ . . .

« តើមានអ្វីមួយនៅក្នុងអ្នក ឬ នៅក្នុងជីវិតអ្នក ដែលមិនបរិសុទ្ធ ឬ មិនសក្តិសមទេ ? ពេលអ្នកលះបង់វាចោល នោះហើយជាអំណោយដល់ព្រះអង្គសង្គ្រោះ: ។ តើមានទម្លាប់ល្អ ឬ គុណសម្បត្តិណាមួយ ដែលអ្នកខ្វះខាតនៅក្នុងជីវិតអ្នកទេ ? នៅពេលអ្នកជ្រើសយក ហើយធ្វើឲ្យវាជាផ្នែកមួយនៃបុគ្គលិកលក្ខណៈរបស់អ្នក នោះអ្នកកំពុងថ្វាយអំណោយមួយដល់ព្រះអម្ចាស់ ។ ពេលខ្លះ ការណ៍នេះពិបាកធ្វើ ចុះតើអំណោយនៃការប្រែចិត្ត និង ការគោរពប្រតិបត្តិរបស់អ្នកនឹងជាអំណោយដ៏សក្តិសមដែរឬទេ ប្រសិនបើអ្នកពុំបានបង់ថ្លៃអ្វីសោះ ? » (« When Thou Art Converted » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១២) ។

- តើយើងអាចថ្វាយអ្វីខ្លះ: ធ្វើជាអំណោយដ៏មានន័យដល់ព្រះអង្គសង្គ្រោះ: ?

សុំឲ្យសិស្សសញ្ជឹងគិតពីសេចក្តីថ្លែងការណ៍របស់អែលឌើរ គ្រីស្តូហ្វឺសិន ហើយពិចារណាថាតើអំណោយអ្វីខ្លះ: ដែលពួកគេមានអារម្មណ៍ថាពួកគេគួរថ្វាយដល់ព្រះអង្គសង្គ្រោះ: ។ សុំឲ្យក្រដាសមួយសន្លឹកទៅសិស្សម្នាក់ៗ ដើម្បីសរសេរពីគំនិតរបស់ពួកគេ ។ សុំឲ្យពួកគេរៀបគម្រោងពីរបៀប ដែលពួកគេនឹងថ្វាយអំណោយទាំងនេះដល់ព្រះយេស៊ូវគ្រីស្ទ ។

ម៉ាថាយ ២:១៣–២៣ ។

យ៉ូសែប ម៉ារា និង ព្រះយេស៊ូវ គៀសខ្លួនទៅស្រុកអេស៊ីព្ទ

សូមពន្យល់ថា យោងតាម ម៉ាថាយ ២:១២–២៣ស្តេចហេរ៉ូឌបានក្រោធខឹងបន្ទាប់ពីពួកហោរា « វិលទៅស្រុកគេវិញ » (ម៉ាថាយ ២:១២) ដោយពុំបានប្រាប់ទ្រង់ពីទីកន្លែងដែលព្រះមែស៊ីគង់នៅ ។ ដោយមានសង្ឃឹមថាអាចធ្វើឲ្យព្រះមែស៊ីសុគតបាន ទ្រង់បានបង្គាប់ថា ក្មេងអាយុពីរឆ្នាំចុះក្រោមនៅភូមិបេថ្លេហិម និងតំបន់ជុំវិញនោះត្រូវតែសម្លាប់ចោលទាំងអស់ ។

សូមអាន ម៉ាថាយ ២:១៣–១៤ ឮៗ ។ សុំឲ្យសិស្សផ្ទៀងតាម ដោយរកមើលពីរបៀបដែល យ៉ូសែប បានដឹងពីអ្វីដែលត្រូវធ្វើដើម្បីរក្សាគ្រួសារគាត់ឲ្យមានសុវត្ថិភាព ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើយ៉ូសែបបាននាំម៉ារា និង ព្រះយេស៊ូវ ទៅទីណា ?

សូមសង្ខេប ម៉ាថាយ ២:១៥–២៣ ដោយពន្យល់ថា យ៉ូសែប ម៉ារា និង ព្រះយេស៊ូវ បានស្នាក់នៅស្រុកអេស៊ីព្ទរហូតដល់ស្តេចហេរ៉ូឌសុគត ។ ព្រះបានបង្គាប់យ៉ូសែបក្នុងសុបិនឲ្យនាំគ្រួសារគាត់ត្រឡប់ទៅអ៊ីស្រាអែលវិញ ហើយពួកគាត់បានតាំងលំនៅក្នុងស្រុកណាសារ៉ែត ។

- តើការយកចិត្តទុកដាក់ខ្ពស់របស់យ៉ូសែបទៅនឹងរឿងខាងវិញ្ញាណ បានប្រទានពរដល់ជីវិតរបស់មនុស្សដទៃទៀតដោយរបៀបណា ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីយ៉ូសែប ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ: ៖ **ប្រសិនបើយើងយកចិត្តទុកដាក់ខ្ពស់ទៅនឹងព្រះវិញ្ញាណ នោះយើងអាចទទួលបាននិរន្តរ: និង ការដឹកនាំ**) ។

សុំឲ្យសិស្សសញ្ជឹងគិតពីអ្វីដែលពួកគេអាចធ្វើ ដើម្បីមានការយកចិត្តទុកដាក់ខ្ពស់ទៅព្រះវិញ្ញាណ ។ សូមលើកទឹកចិត្តឲ្យពួកគេដាក់គោលដៅមួយធ្វើតាមការបំផុសគំនិតដែលពួកគេបានទទួល ។

ម៉ាថាយ ៣

សេចក្តីផ្តើម

យ៉ូហាន បាទីស្នបានប្រកាសដំណឹងល្អ ហើយបានធ្វើបុណ្យជ្រមុជទឹកនៅស្រុកយូដា ។ ព្រះយេស៊ូវគ្រីស្ទបានយាងពីស្រុកកាលីឡេទៅទន្លេយ័រដាន់ ជាកន្លែងដែលយ៉ូហានបានធ្វើបុណ្យជ្រមុជទឹកឲ្យទ្រង់ ។ ព្រះជាព្រះវរបិតាបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាបុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ ។

គោលបំណងថ្នាក់សិក្ខាសាលា

គោលបំណងថ្នាក់សិក្ខាសាលា « គឺដើម្បីជួយយុវវ័យ . . . ឲ្យយល់ ហើយពឹងផ្អែកលើការបង្រៀន និងលើជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ឲ្យមានភាពសក្តិសមសម្រាប់ពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួនពួកគេ ក្រុមគ្រួសារពួកគេ និងអ្នកដទៃទៀត សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ជាមួយនឹងព្រះវរបិតារបស់ពួកគេដែលគង់នៅស្ថានសួគ៌ » (« The Objective of Seminaries and Institutes of Religion » [ឆ្នាំ ២០១២] si.lds.org) ។ នៅពេលអ្នករៀបចំមេរៀន សូមសម្រេចប្រកបដោយការអធិស្ឋានពីរបៀបដែលអ្នកជួយសម្រេចគោលដៅនៃជារៀងរាល់ថ្ងៃ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៣:១–១២

យ៉ូហាន បាទីស្នប្រកាសដំណឹងល្អនៅស្រុកយូដា

សុំឲ្យសិស្សនីកស្រមៃពីអារម្មណ៍ដែលពួកគេអាចនឹងមាន ប្រសិនបើសិស្សម្នាក់នៅក្នុងថ្នាក់ក្រោកឡើង ហើយចាប់ផ្តើមយករបស់របរផ្ទាល់ខ្លួនរបស់សិស្សផ្សេងទៀត ។ រួចសុំឲ្យពួកគេនីកស្រមៃថា បន្ទាប់ពីយករបស់របរនីមួយៗរួចហើយ សិស្សនោះបានសុំអភ័យទោស ប៉ុន្តែនៅបន្តយករបស់របរពីសិស្សផ្សេងទៀត ។ សូមសួរ ៖

- តើអ្នកគិតយ៉ាងណាដែរ ចំពោះការសុំអភ័យទោសរបស់សិស្សម្នាក់នេះ ?
- តើទង្វើរបស់សិស្សនេះអាចស្រដៀងគ្នានឹងការព្យាយាមប្រែចិត្ត ដោយចិត្តមិនស្មោះយ៉ាងដូចម្តេចដែរ ?

នៅពេលសិស្សសិក្សា ម៉ាថាយ ៣ សុំឲ្យពួកគេរកមើលសេចក្តីពិតដែលជួយយើង ឲ្យយល់ដឹងពីអ្វីដែលយើងត្រូវធ្វើដើម្បីប្រែចិត្តដ៏ពិតប្រាកដ ។

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៣:១–៤ ឮៗ ។ សុំឲ្យសិស្សរកមើលថាតើមានអ្វីបានកើតឡើង ដែលអាចជួយរៀបចំមនុស្សសម្រាប់ការងារបម្រើរបស់ព្រះអង្គសង្គ្រោះ ។

- តើយ៉ូហាន បាទីស្នជានរណា ? (លោកគឺជាកូនប្រុសរបស់សាការី និង អេលីសាបិតដែលត្រូវជាសាច់ញាតិនឹងម៉ារា ។ លោកកាន់កូនសោនៃបព្វជិតភាពអើរ៉ុន [សូមមើល គ. និង ស. ១៣, ៨៤:២៧–២៨]) ។
- តើយ៉ូហានបានកំពុងធ្វើអ្វី ?
- តើយ៉ូហានបានដាស់តឿនពួកអ្នកស្តាប់របស់លោកឲ្យធ្វើខ្លះ ?

សូមពន្យល់ថា បេសកកម្មរបស់យ៉ូហានត្រូវបានព្យាករទុកជាមុនដោយអេសាយ និងព្យាការីផ្សេងទៀត (សូមមើល អេសាយ ៤០:៣, ម៉ាឡាគី ៣:១, នីហ្វៃទី ១ ១០:៧–១០) ។ យ៉ូហានត្រូវរៀបចំផ្លូវឲ្យព្រះមែស៊ី (ព្រះយេស៊ូវគ្រីស្ទ) ដោយប្រកាសអំពីការប្រែចិត្ត និងបុណ្យជ្រមុជទឹកដោយទឹក ។

- តើអ្នកគិតថាការប្រកាសពីការប្រែចិត្ត និង បុណ្យជ្រមុជទឹកដោយទឹកបានជួយរៀបចំផ្លូវសម្រាប់ព្រះអម្ចាស់ដោយរបៀបណា ?

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៣:៥–៦ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលប្រជាជនបានឆ្លើយតបចំពោះសារលិខិតរបស់យ៉ូហាន ។

- តើប្រជាជន បានឆ្លើយតបនឹងសារលិខិតរបស់យ៉ូហានយ៉ាងដូចម្តេច ? (ពួកគេបានសារភាពពីអំពើបាបខ្លួន ហើយបានជ្រមុជទឹក ។ សូមពន្យល់ថា ការយល់ព្រមសារភាពអំពើបាបរបស់បុគ្គលម្នាក់ដល់ព្រះវរបិតាសួគ៌ ហើយប្រសិនបើចាំបាច់ទៅដល់ថ្នាក់ដឹកនាំបព្វជិតភាពដែលបានចាត់ គឺជារឿងដ៏សំខាន់ចាំបាច់ចំពោះការប្រែចិត្ត [សូមមើល *ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* (ឆ្នាំ ២០០៤) ទំព័រ ១៣៤]) ។

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៣:៧ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើយ៉ូហានបាននិយាយជាមួយនឹងនរណា ។

- យោងតាមខគម្ពីរនេះ តើយ៉ូហានបាននិយាយនឹងនរណា ?



ពស់វែកប៉ាលេស្ទីន

© taviphoto/Shutterstock.com

សូមពន្យល់ថា ពួកផារិស៊ីគឺជាមនុស្សមួយក្រុមខាងសាសនានៅក្នុងចំណោមពួកសាសន៍យូដាដែលឈ្មោះមានន័យថា ព្រាត់ ឬបែកពីគ្នា ។ ពួកគេបានតម្កើងខ្លួនដោយសារការគោរពយ៉ាងម៉ឺងម៉ាត់ តាមក្រឹត្យវិន័យលោកម៉ូសេ ហើយជឿថាសេចក្តីបន្ថែមទៅនឹងក្រឹត្យវិន័យនេះ ដែលបង្កើតដោយមនុស្ស ដែលហៅថាជាច្បាប់តាមមាត់ សំខាន់ដូចគ្នានឹងក្រឹត្យវិន័យរបស់លោកម៉ូសេដែរ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ពួកផារិស៊ី ») ។ ពួកសាឌូស៊ីជាក្រុមតូចមួយ តែមានអំណាចខាងការត្រួតត្រាយ៉ាងខ្លាំងនៅក្នុងចំណោមពួកសាសន៍យូដា ដែលជឿលើការកាន់តាមតួអក្សរនៃក្រឹត្យវិន័យរបស់លោកម៉ូសេ ។ ពួកគេពុំជឿលើគោលលទ្ធិនៃការរស់ឡើងវិញ ឬជីវិតដ៏នៅអស់កល្បជានិច្ចឡើយ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ពួកសាឌូស៊ី ») ។

- តើយ៉ូហានបានហៅពួកផារិស៊ី និង ពួកសាឌូស៊ីយ៉ាងដូចម្តេច ?

ប្រសិនបើអាចធ្វើបាន សូមដាក់បង្ហាញ រូប ពស់វែកប៉ាលេស្ទីន ហើយពន្យល់ថា វាគឺជាពស់ដែលមានពិសខ្លាំងបំផុតនៅអឺស្រាអែល ។ ពស់វែកចេញធ្វើសកម្មភាពនៅពេលយប់ ហើយជាធម្មតាលាក់ខ្លួនចាំប្រមាញ់ចំណីរបស់វា ។ កាលពួកវាដួបនឹងការគម្រាមកំហែង ពស់វែកនឹងព័ទ្ធពេនខ្លួន បន្លឺសូរស៊ីៗៗ ហើយវាយប្រហារទៅលើសត្រូវរបស់វា ។

- ហេតុអ្វីអ្នកគិតថាយ៉ូហានហៅពួកផារិស៊ី និងពួកសាឌូស៊ីជាពួកពស់វែក ? (អ្នកគួរចង្អុលបង្ហាញថា ពួកផារិស៊ី និងពួកសាឌូស៊ីគិតថា យ៉ូហានគម្រាមកំហែងដល់ពួកគេ កាលលោកអូសទាញមនុស្សជាច្រើនចេញពីឥទ្ធិពលអាក្រក់ និងការបង្រៀនខុសឆ្គងរបស់ពួកគេ) ។

សូមពន្យល់ថាការបកប្រែដោយយ៉ូសែប ស៊្មីធ មានពាក្យពេចន៍បន្ថែមថា យ៉ូហានបាននិយាយទៅកាន់ពួកផារិស៊ី និង ពួកសាឌូស៊ី ។ សុំឲ្យសិស្សម្នាក់បើកទៅ ការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ៣:៣៤–៣៦ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ (អ្នកគួរពន្យល់ថាខគម្ពីរទាំងនេះគឺជាការបកប្រែនៃ ម៉ាថាយ ៣:៨–៩) ។ សុំឲ្យសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។

- យោងតាម យ៉ូហាន ប្រសិនបើពួកផារិស៊ី និង ពួកសាឌូស៊ីបដិសេធការបង្រៀនរបស់លោក តើពួកគេនឹងបដិសេធនរណាផងដែរ ?
- តើអ្នកនឹងសង្ខេបសារលិខិតរបស់យ៉ូហានដល់ពួកគេដោយរបៀបណា ?

សូមសរសេរឃ្លា *បង្កើតផលឲ្យសំណាំនឹងការប្រែចិត្ត* នៅលើក្តារខៀន ។

ដើម្បីជួយសិស្សឲ្យយល់ឃ្លានេះ សូមចង្អុលបង្ហាញថា នៅក្នុងព្រះគម្ពីរមនុស្សពេលខ្លះត្រូវបានតំណាងដោយដើមឈើដែលឲ្យផលល្អ ឬអាក្រក់ ។ សូមដាក់បង្ហាញ ឬគូរផ្លែឈើមួយចំណិត ហើយពន្យល់ថាវាតំណាងឲ្យបំណងប្រាថ្នា និង ទង្វើរបស់យើង ។ អ្នកគួរពន្យល់ថាឃ្លា « សំណាំនឹង » មានន័យថា « សក្តិសមនឹង ») ។

សូមរំឭកសិស្សពីសាច់រឿងដែលអ្នកបានសុំឲ្យពួកគេនឹកស្រមៃកាលពីដើមមេរៀន (សិស្សម្នាក់យករបស់របរផ្ទាល់ខ្លួនរបស់សិស្សផ្សេងទៀត រួចបន្តធ្វើដូច្នេះសូម្បីតែធ្វើការសុំទោសហើយក្តី) ។

- តើសិស្សនោះបានបង្ហាញគោលការណ៍នៃការប្រែចិត្តដោយសមមម្យតាមរយៈបំណងប្រាថ្នា ឬទង្វើរបស់ខ្លួនដែរឬទេ ? ហេតុអ្វីមិនមែន ? (សិស្សនេះបានបន្តយកសម្ភារពីសិស្សដទៃ សូម្បីតែធ្វើការសុំអភ័យទោសហើយក្តី) ។
- តើអ្នកនឹងសង្ខេបពីអត្ថន័យនៃ « បង្កើត . . . ផលឲ្យសំណាំនឹងការប្រែចិត្ត » យ៉ាងដូចម្តេច ? (ម៉ាថាយ ៣:៨) ។ (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងបង្ហាញការប្រែចិត្តពិតចំពោះព្រះអម្ចាស់ នៅពេលយើងផ្លាស់ប្តូរបំណងប្រាថ្នា និង ទង្វើរបស់យើងដើម្បីធ្វើតាមការបង្រៀនរបស់ទ្រង់**) ។
- តើបំណងប្រាថ្នា និងទង្វើបែបណាទៅដែលបង្ហាញថា យើងបានប្រែចិត្តពិតពីអំពើបាបរបស់យើង ?

ដើម្បីជួយសិស្សយល់ពីសេចក្តីពិតនេះ ចូរសរសេរឧទាហរណ៍ខាងក្រោមនៅលើក្តារខៀន ៖ *ការលួចចម្លងបន្ទំនៅសាលារៀន ចរិតកាចដាក់បងប្អូន ការខ្វះសេចក្តីសប្បុរស ឬការឆាឆៅសិស្សដទៃ ការប្រើពាក្យសម្តីមិនល្អ* និង *ការមើលរូបអាសគ្រាម* ។ សុំឲ្យសិស្សពន្យល់ពីរបៀប ដែលមនុស្សណាម្នាក់ដែលបានប្រែចិត្តពីអំពើបាបទាំងនេះ អាចគិតហើយប្រព្រឹត្ត ។

សូមអាន ម៉ាថាយ ៣:១០ ឮៗ ។ សុំឲ្យសិស្សផ្ទៀងតាម ហើយរកមើលផលវិបាកនៃការពុំប្រែចិត្តយ៉ាងពិតប្រាកដ ។ សុំឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមពន្យល់ថាការ « កាប់ចោះចោលទៅក្នុងភ្លើង » បញ្ជាក់ថា បុគ្គលដែលពុំប្រែចិត្តបាត់បង់ព្រះចេស្តានៃព្រះវិញ្ញាណនៃព្រះ ហើយនៅទីបំផុតចោះបង់ចោលពរជ័យនៃនគរសេឡេស្ទាល ។

សុំឲ្យសិស្សសញ្ជឹងគិតពីបំណងប្រាថ្នា ឬទង្វើនានាដែលពួកគេត្រូវផ្លាស់ប្តូរ ដើម្បីប្រែចិត្តយ៉ាងពិតប្រាកដ ។ សូមលើកទឹកចិត្តពួកគេឲ្យបង្ហាញការប្រែចិត្តពិតដោយផ្លាស់ប្តូរបំណងប្រាថ្នា និងទង្វើនានាដែលពុំស្របតាមការបង្រៀនរបស់ព្រះ ។

សុំឲ្យសិស្សអាន ម៉ាថាយ៣:១១ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលយ៉ូហានថ្លែងថា ព្រះអង្គសង្គ្រោះនឹងធ្វើ ។

- យោងតាម ខទី ១១តើព្រះយេស៊ូវអាចធ្វើអ្វីខ្លះដែលយ៉ូហានពុំអាចធ្វើបាន ? (ព្រះយេស៊ូវនឹងធ្វើបុណ្យជ្រមុជទឹក « ដោយព្រះវិញ្ញាណបរិសុទ្ធ និង ដោយភ្លើង » ។ សូមពន្យល់ថា យ៉ូហានកំពុងហៅការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ជាសេចក្តីសញ្ញាពាក់កណ្តាលទៀតនៃសេចក្តីសញ្ញា និង ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក ។ ព្រះវិញ្ញាណបរិសុទ្ធញែក ហើយបន្សុទ្ធព្រលឹងយើងដូចជាភ្លើងដែរ [សូមមើល នីហ្វៃទី ២ ៣១:១៣–១៤, ១៧]) ។

សូមសង្ខេប ខទី ១២ ដោយពន្យល់ថា វាពិពណ៌នាដោយតំណាងឲ្យអ្វីដែលនឹងកើតឡើងចំពោះមនុស្សសុចរិតដែលទទួលយកព្រះយេស៊ូវគ្រីស្ទ (ស្រូវសាលី) និងចំពោះមនុស្សទុច្ចរិតដែលបដិសេធទ្រង់ (អង្កាម) ។

ម៉ាថាយ ៣:១៣–១៧

ព្រះយេស៊ូវគ្រីស្ទបានជ្រមុជទឹក ហើយព្រះវរបិតាបានប្រកាសថា ទ្រង់ជាបុត្រាដ៏ជាទីស្រលាញ់

សុំឲ្យសិស្សបានជ្រមុជទឹកសូចសញ្ជឹងគិតពីពិធីបុណ្យជ្រមុជទឹករបស់ខ្លួន ។ សុំឲ្យពួកគេពីរបីនាក់ចែកចាយអ្វី ដែលពួកគេចងចាំ ។

សូមពន្យល់ថា ម៉ាថាយ ៣:១៣–១៧ និទានពីពិធីបុណ្យជ្រមុជទឹករបស់ព្រះអង្គសង្គ្រោះ ។ សុំឲ្យសិស្សរកមើលភាពស្រដៀងគ្នារវាងពិធីបុណ្យជ្រមុជទឹករបស់ពួកគេ និង របស់ព្រះអង្គសង្គ្រោះ កាលពួកគេសិក្សាខគម្ពីរទាំងនេះ ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

ដោយនរណា ?

ដោយរបៀបណា ?

ហេតុអ្វី ?

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សុំឲ្យដៃគូនីមួយៗប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ៣:១៣–១៧ហើយរកមើលចម្លើយចំពោះសំណួរទាំងបីនេះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយសូមសួរ ៖

- តើនរណាបានធ្វើបុណ្យជ្រមុជទឹកឲ្យព្រះយេស៊ូវ ? (សូមសរសេរ *យ៉ូហាន បាទីស្ទ* នៅលើក្តារខៀនក្បែរ *ដោយនរណា* ?)
- ហេតុអ្វីព្រះយេស៊ូវយាងពីស្រុកកាលីឡេទៅទន្លេយ័រដាន់ដើម្បីឲ្យ យ៉ូហាន បាទីស្ទ អាចជ្រមុជទឹកឲ្យទ្រង់ ? (សូមរំឭកសិស្សថា យ៉ូហានកាន់កូនសោនៃបព្វជិតភាពអើរ៉ុន ហើយជាបុរសតែម្នាក់គត់នៅពេលនោះដែលមានសិទ្ធិអំណាចដើម្បីធ្វើពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក ។ សូមសរសេរ *សិទ្ធិអំណាចត្រឹមត្រូវ* នៅលើក្តារខៀនក្បែរនឹង *យ៉ូហាន បាទីស្ទ*) ។
- នៅក្នុង ខទី ១៦ តើឃ្លាអ្វីទៅដែលបញ្ជាក់ពីរបៀបដែលព្រះយេស៊ូវបានទទួលបុណ្យជ្រមុជទឹក ? (សូមធ្វើឲ្យសិស្សយល់យ៉ាងច្បាស់ដូចថា ព្រះយេស៊ូវយាងឡើងឡើង « ចេញពីទឹក » ភ្លាមបង្ហាញថាទ្រង់បានទទួលបុណ្យជ្រមុជទឹកដោយការជ្រមុជក្នុងទឹក—មានន័យថាទ្រង់ត្រូវគ្របដណ្តប់ទាំងស្រុងដោយទឹក ។ សូមសរសេរ *ដោយការជ្រមុជក្នុងទឹក* លើក្តារខៀនក្បែរ *ដោយរបៀបណា* ?)

សុំឲ្យសិស្សនឹកស្រមៃថា ពួកគេស្ថិតនៅទន្លេយ័រដាន់ កាលព្រះយេស៊ូវបានយាងមកទទួលបុណ្យជ្រមុជទឹក ។

- ហេតុអ្វីបានជាយ៉ូហានដំបូងស្ទាក់ស្ទើរក្នុងការធ្វើពិធីបុណ្យជ្រមុជទឹកឲ្យព្រះអង្គសង្គ្រោះ ? (លោកបានដឹងថា តំណែង និងសិទ្ធិអំណាចរបស់ព្រះយេស៊ូវ គឺមហិមាជាងគាត់ទៅទៀត) ។
- យោងតាម ខទី ១៥ហេតុអ្វីបានជាព្រះយេស៊ូវមានបន្ទូលថាទ្រង់ត្រូវទទួលពិធីបុណ្យជ្រមុជទឹកយ៉ាងដូច្នេះ ? (« ដើម្បីបំពេញសេចក្តីសុចរិតគ្រប់យ៉ាង » ។ សូមសរសេរ ឃ្លានេះលើក្តារខៀនក្បែរ *ហេតុអ្វី* ?)
- តើអ្នកគិតថា ឃ្លានេះមានអត្ថន័យយ៉ាងណា ?

សូមពន្យល់ថា « ដើម្បីបំពេញសេចក្តីសុចរិតគ្រប់យ៉ាង » មានន័យថាការធ្វើគ្រប់កិច្ចការដែលព្រះវរបិតាសួគ៌តម្រូវឲ្យយើងធ្វើ ដើម្បីយើងអាចរស់នៅជាមួយនឹងទ្រង់ម្តងទៀត ។ ការណ៍នេះរួមបញ្ចូលនូវការទទួលពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ ដែលព្រះតម្រូវឲ្យកូនចៅទ្រង់គ្រប់រូបធ្វើ រួមទាំងព្រះយេស៊ូវផងដែរ ។ តាមរយៈការធ្វើពិធីបុណ្យជ្រមុជទឹក ព្រះយេស៊ូវបានទុកគំរូដ៏ល្អឥតខ្ចោះឲ្យយើងធ្វើតាម បានបង្ហាញពីសេចក្តីរាបសា បានគោរពតាមព្រះបញ្ញត្តិរបស់ព្រះវរបិតាទ្រង់ ហើយបានទទួលពិធីបរិសុទ្ធមួយដែលចាំបាច់ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច (សូមមើល នីហ្វៃទី ២ ៣១:៤–១១) ។

សុំឲ្យសិស្សប្រើចម្លើយសម្រាប់សំណួរទាំងបីនៅលើក្តារខៀន ដើម្បីបញ្ជាក់ពីគោលលទ្ធិមួយដែលយើងអាចរៀនពី ម៉ាថាយ ៣:១៣–១៧ ។ (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **បុណ្យជ្រមុជទឹកដោយការពន្លិចដោយមនុស្សម្នាក់ដែលកាន់សិទ្ធិអំណាច គឺជារឿងដ៏ចាំបាច់សម្រាប់សេចក្តីសង្គ្រោះ ។**

- តើបុណ្យជ្រមុជទឹករបស់អ្នក ប្រៀបដូចម្តេចគ្នានឹងគំរូដែលព្រះអង្គសង្គ្រោះបានបង្ហាញដល់យើងយ៉ាងដូចម្តេចដែរ ?

សូមពន្យល់ថា ម៉ាថាយ ៣:១៦–១៧ ក៏ជួយយើងឲ្យរៀននូវគោលលទ្ធិអំពីក្រុមព្រះដែរ ។ សុំឲ្យសិស្សអានខគម្ពីរទាំងនេះឡើងវិញដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលវាបង្រៀនអំពីព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ ។

- តើសមាជិកនៃក្រុមព្រះមួយអង្គៗគង់នៅឯណា អំឡុងពេលនៃបុណ្យជ្រមុជទឹករបស់ព្រះអង្គសង្គ្រោះ ? (ព្រះយេស៊ូវគ្រីស្ទគង់នៅក្នុងទន្លេយ័រដាន់ ព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើទ្រង់ដូចជាសត្វព្រាប ហើយព្រះវរបិតាបានមានបន្ទូលមកពីស្ថានសួគ៌ ។ អ្នកអាចពន្យល់ថា តាមពិតទៅព្រះវិញ្ញាណបរិសុទ្ធពុំបានប្រែជាសត្វព្រាបទេ ។ ផ្ទុយទៅវិញ សត្វព្រាបគឺជាសញ្ញា ឬជានិមិត្តរូបមួយថា ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកសណ្ឋិតលើព្រះយេស៊ូវ) ។
- តើខគម្ពីរទាំងនេះបង្រៀនគោលលទ្ធិអ្វីខ្លះដល់យើងអំពីក្រុមព្រះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ គឺជាតួអង្គបីអង្គដាច់ដោយឡែកពី គ្នា**) ។

សូមចង្អុលបង្ហាញថា មានមនុស្សជាច្រើនពុំមានចំណេះដឹងដ៏ត្រឹមត្រូវ ឬពេញលេញអំពីក្រុមព្រះឡើយ ។ កាលណាយើងយល់ពីលក្ខណៈពិតនៃក្រុមព្រះកាន់តែច្រើន នោះយើងនឹងមានសេចក្តីស្រឡាញ់កាន់តែធំឆេងចំពោះពួកទ្រង់ ហើយយើងនឹងរៀបចំខ្លួនបង្រៀន ហើយធ្វើទីបន្ទាល់អំពីពួកទ្រង់ដល់មនុស្សដទៃទៀតកាន់តែប្រសើរឡើង ។

ដើម្បីជួយសិស្សឲ្យទទួលចំណេះដឹងមួយកាន់តែប្រសើរឡើងអំពីអត្តសញ្ញាណនៃសមាជិកមួយអង្គៗរបស់ក្រុមព្រះ សូមបំបែកពួកគេជាក្រុមដែលមានគ្នាបីនាក់ ហើយសុំឲ្យពួកគេរកមើលពាក្យ « ព្រះ » នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។ សម្រាប់គ្រប់ក្រុមទាំងអស់ សូមចាត់តាំងសិស្សម្នាក់ៗក្នុងចំណោមសិស្សទាំងបីនាក់នោះធ្វើជាសមាជិកម្នាក់របស់ក្រុមព្រះ ។ សុំឲ្យសិស្សអានមេរៀនខាងដើម រកមើលព័ត៌មានអំពីសមាជិកដែលពួកគេបានទទួលការចាត់តាំង ។ លុះដល់ពេលកំណត់ហើយ សុំឲ្យសិស្សបង្រៀនដល់ក្រុមរបស់ខ្លួននូវអ្វីដែលពួកគេបានរៀន ហើយពន្យល់ពីហេតុផលដែលសេចក្តីពិតទាំងនោះគឺជារឿងដ៏សំខាន់ដែលយើងត្រូវដឹង ។

ដើម្បីបញ្ចប់មេរៀននេះ សូមពិចារណាអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធទៅដល់សិស្សដទៃទៀត ។

មេរៀន ៨

ម៉ាថាយ ៤

សេចក្តីផ្តើម

បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់ទ្រង់ ព្រះយេស៊ូវបានចំណាយពេល៤០ ថ្ងៃតមអាហារ ហើយទូលនឹងព្រះវរបិតាសួគ៌នៅក្នុងទីរហោស្ថាន ។ បន្ទាប់ពីបទពិសោធន៍នេះ អារក្ស បានល្បួងព្រះយេស៊ូវ ។ ព្រះយេស៊ូវបានតតាំងនឹងការល្បួងនីមួយៗដោយប្រើបទគម្ពីរ ។ ព្រះអង្គសង្គ្រោះបានយាងទៅស្រុកកាលីឡេ ជាទីកន្លែងដែលទ្រង់បានហៅពេត្រុស និង អ្នក ផ្សេងទៀតឲ្យដើរតាមទ្រង់ ហើយទ្រង់បានយាងទៅបង្រៀន ប្រកាស ហើយព្យាបាល ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៤:១–១១

ព្រះយេស៊ូវតតាំងនឹងការល្បួងរបស់អារក្ស

ចូរសុំសិស្សម្នាក់ឲ្យស្មគ្រចិត្តឡើងមកក្តារខៀន ។ ចូរសំណូមពរឲ្យសិស្សនោះផ្តោតលើវត្ថុមួយ នៅក្នុងបន្ទប់រយៈពេល ៣០ វិនាទី ដោយពុំសម្លឹងមើលអ្វីផ្សេង ។ នៅពេលសិស្សនោះចាប់ផ្តើមហើយ សូមល្បួងទាក់ទាញគាត់ឲ្យងាកចេញពីការសម្លឹងមើលវត្ថុនោះ: ។ ឧទាហរណ៍ អ្នកអាចដាក់បង្ហាញវត្ថុដែលមានពណ៌ភ្លឺ ធ្វើសំឡេងរំខានឮៗ ឬឲ្យអាហារដល់សិស្សនោះ: ។ ក្រោយពី ៣០ វិនាទីបាន បញ្ចប់ សូមសួរសិស្សនោះ: ៖

- តើប្អូនធ្វើបានយ៉ាងណាដែរ ? ហេតុអ្វីប្អូនអាច ឬ មិនអាចរក្សាការផ្តោតអារម្មណ៍របស់ប្អូនបាន ?
- តើប្អូនបានគិតអ្វីខ្លះនៅក្នុងពេល ៣០ វិនាទីនោះ: ?

សូមសួរសិស្សផ្សេងទៀត ៖

- តើបទពិសោធន៍នេះប្រៀបបានទៅនឹងការខិតខំរបស់យើង ដើម្បីយកចិត្តទុកដាក់លើការគោរពតាមព្រះបញ្ញត្តិរបស់ព្រះវរបិតាសួគ៌ ដូចម្តេចខ្លះ ? តើការល្បួងដែលរំខានដល់ម្នាក់នេះអាចតំណាងឲ្យអ្វីទៅ ? (ការខិតខំល្បួងយើងឲ្យធ្វើអំពើបាប) ។
- ហេតុអ្វីសាតាំងល្បួងយើងឲ្យធ្វើអំពើបាប ? (សូមមើល នីហ្វៃទី ២ ២:១៧–១៨, ២៧) ។

ចូរសុំឲ្យសិស្សគិតអំពីវិធីដែលសាតាំងល្បួងពួកគេឲ្យធ្វើអំពើបាប ។ នៅពេលពួកគេសិក្សា ម៉ាថាយ ៤ ចូរសុំឲ្យពួកគេរកមើលគោលការណ៍មួយដែលពួកគេអាចអនុវត្តតាម ដើម្បីជួយពួកគេឲ្យតតាំងនឹងការល្បួង ។

សូមពន្យល់ថា បន្ទាប់ពីពិធីបុណ្យជ្រមុជទឹករបស់ទ្រង់ ព្រះអង្គសង្គ្រោះមានបទពិសោធន៍មួយ ដែលបានជួយរៀបចំទ្រង់សម្រាប់ ការងារបម្រើរបស់ទ្រង់នៅលើផែនដី ។ សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស៊្មីធសម្រាប់ ម៉ាថាយ ៤:១–២ ឲ្យ ឮៗ ដោយផ្តោតលើភាពខុសគ្នានៅក្នុងការបកប្រែដោយយ៉ូសែប ស៊្មីធ និង អត្ថបទដើម ៖ « គ្រានោះព្រះយេស៊ូវត្រូវបាននាំទៅដោយ ព្រះវិញ្ញាណ ទៅឯទីរហោស្ថានដើម្បីទៅជួបព្រះ: ។ កាលទ្រង់បានតម ៤០ ថ្ងៃ ៤០ យប់ហើយបានទូលនឹងព្រះ: ក្រោយមកទ្រង់ឃ្លាន ហើយបានទុកដើម្បីឲ្យត្រូវអារក្សល្បួង » ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវ បានដកពិសោធន៍ នៅក្នុង ទីរហោស្ថាននោះ: ។ (អ្នកអាចនឹងត្រូវពន្យល់ថា នៅក្នុងបរិបទនេះ ពាក្យ *ទូលនឹង* មានន័យថា « គង់នឹង » ឬការមានទំនាក់ទំនងខាង វិញ្ញាណដ៏ជិតស្និទ្ធ) ។

- តើការតមអាហារ និង ការទូលនឹងព្រះវរបិតាសួគ៌បានជួយព្រះយេស៊ូវឲ្យរៀបចំខ្លួនសម្រាប់ការងារបម្រើរបស់ទ្រង់នៅលើផែនដីយ៉ាង ដូចម្តេច ?
- ក្រោយពីព្រះយេស៊ូវបានចំណាយពេលនេះធ្វើការតមអាហារ ហើយទូលនឹងព្រះវរបិតាទ្រង់ តើសាតាំងមានបំណងចង់ធ្វើអ្វីខ្លះ ?

សូមបំបែកសិស្សជាគូ ។ ចូរឲ្យសំណៅនៃ តារាង ខាងក្រោមនេះដល់ដៃគូនីមួយៗ ឬសុំឲ្យពួកគេចម្លងវាចូលក្នុងសៀវភៅកំណត់ចំណាំ ក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរបស់ពួកគេ ៖

ម៉ាថាយ ៤:១–១១

	រឿងដែលសាតាំងបានល្បួងឲ្យព្រះយេស៊ូវធ្វើ	របៀបដែលព្រះយេស៊ូវមានបន្ទូលតបនឹងការ ល្បួងនោះ:
ម៉ាថាយ ៤:៣–៤		
ម៉ាថាយ ៤:៥–៧		
ម៉ាថាយ ៤:៨–១១		

សូមកំណត់អំពីល្បឿន

សូមចៀសវាងពីកំហុសដោយចំណាយពេលច្រើនពេកទៅលើផ្នែកដំបូងនៃមេរៀននេះ: ហើយត្រូវបញ្ចប់ដោយប្រញាប់ប្រញាល់នូវផ្នែកដែលនៅសេសសល់ ។ នៅពេលអ្នករៀបចំខ្លួន សូមប៉ាន់ស្មានពីរយៈពេលដែលផ្នែកនីមួយៗនៅក្នុងមេរៀននេះត្រូវការ ដោយប្រើវិធីសាស្ត្របង្រៀនដែលអ្នកបានជ្រើសរើស ។ ស្ទើរតែជានិច្চកាល ដោយសារអ្នកមានឯកសារបង្រៀនដែលត្រូវការពេលច្រើនដើម្បីបង្រៀន សូមកំណត់ថាតើផ្នែកណាមួយនៃបណ្តុំបទគម្ពីរ ដែលត្រូវគូសបញ្ជាក់ និង ត្រូវសង្ខេប ។

សូមណែនាំសិស្សឲ្យអានខគម្ពីរ ដែលបានជ្រើសរើសជាមួយដៃគូពួកគេ ហើយបំពេញតារាងនោះ ។ ពីមុនពួកគេចាប់ផ្តើមសកម្មភាពនេះ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធកែតម្រូវសេចក្តីចែងនៅក្នុង ម៉ាថាយ ៤:៥, ៨ ដើម្បីបង្ហាញថា ព្រះវិញ្ញាណ បាននាំព្រះអង្គសង្គ្រោះទៅកន្លែងខុសៗគ្នាដូចដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ពុំមែនអារក្សទេ (សូមមើលផងដែរការបកប្រែដោយយ៉ូសែប ស៊្មីធ លូកា ៤:៥ ។

បន្ទាប់ពីសិស្សបានបំពេញតារាងចប់សព្វគ្រប់ហើយ ចូរសុំឲ្យសិស្សពីរបីគូប្រាប់ពីអ្វីដែលពួកគេបានសរសេរនៅក្នុងប្រអប់នីមួយៗ ។ អ្នកអាចសួរសំណួរដូចខាងក្រោម ៖

- តើសាតាំងមានបំណងអ្វីទៅកាលវាបានល្បួងព្រះយេស៊ូវ ដែលកំពុងតមអាហារឲ្យល្បួងធ្វើដុំថ្មក្លាយទៅជានំប៉័ង ? (វាបានល្បួងលួងលោមទាក់ទាញចិត្ត ដើម្បីបំពេញសេចក្តីស្រេកឃ្លានខាងរូបកាយ) ។
- តើមានរឿងខុសឆ្គងអ្វីខ្លះចំពោះសំណើរបស់សាតាំងថា នឹងថ្វាយនគរទាំងឡាយនៃលោកិយដល់ព្រះយេស៊ូវនោះ ? (សាតាំងបានសន្យានូវអ្វាន់ដែលពុំមែនជារបស់ខ្លួន ហើយដែលខ្លួនពុំអាចធ្វើបាន) ។
- តើដំណើររឿងនេះបង្ហាញអ្វីខ្លះទៀតអំពីយុទ្ធសាស្ត្ររបស់អារក្ស ដើម្បីល្បួងយើងឲ្យធ្វើអំពើបាប ? (សាតាំងសំដៅរកចំណុចខ្សោយឬឈឺចាប់បំផុតរបស់យើង ហើយល្បួងយើងម្តងហើយម្តងទៀត) ។

សូមចង្អុលបង្ហាញថា នៅទីបំផុតព្រះយេស៊ូវបានបំពេញសេចក្តីស្រេកឃ្លានរបស់ទ្រង់ ហើយថែមទាំងបានធ្វើសារធាតុមួយនៅលើផែនដី ឲ្យក្លាយទៅជាអាហារ (សូមមើល យ៉ូហាន ២:១–១១) ។ ទ្រង់ក៏បានទទួលការបញ្ជាក់ដ៏ទេវភាព និង ជំនួយសម្រាប់ការងារបម្រើរបស់ទ្រង់ផងដែរ (សូមមើល ម៉ាថាយ ១៧:១–៥, លូកា ២២:៤១–៤៤) ហើយនៅថ្ងៃមួយទ្រង់នឹងគ្រងលោកិយនេះ (សាការី ១៤:៩, វិវរណៈ ១១:១៥) ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើព្រះយេស៊ូវទទួលរបស់ទាំងនេះតាមរបៀបដែលសាតាំងបានល្បួងទ្រង់—ជំនួសឲ្យការរង់ចាំរហូតដល់ពេលវេលាត្រឹមត្រូវ និងតាមរបៀបត្រឹមត្រូវនោះ—វាគឺជាការរំលោភបំពានដ៏អត្ថានិយមមួយចំពោះព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ។ ព្រះយេស៊ូវបានស្តាប់នាអត្តសញ្ញាណដ៏ទេវភាពរបស់ទ្រង់ជាព្រះរាជបុត្រានៃព្រះតាមរបៀបដែលស្របតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ពុំមែនតាមបំណងរបស់សាតាំងឡើយ ។ (សូមមើល ដៃហ្វ្រី អ័រ ហូឡិន « The Inconvenient Messiah » *Ensign* ខែ កុម្ភៈ ឆ្នាំ១៩៨៤ ទំព័រ ៦៨–៧៣) ។

- តើចម្លើយរបស់ព្រះអង្គសង្គ្រោះចំពោះការល្បួងនីមួយៗមានអ្វីខ្លះដែលស្រដៀងគ្នា ? (ព្រះយេស៊ូវបានមានបន្ទូលតបទៅការល្បួងនីមួយៗរបស់សាតាំងដោយដកស្រង់ចេញពីបទគម្ពីរ) ។

សូមអញ្ជើញសិស្សធ្វើការជាគូ សរសេរគោលការណ៍មួយ ដែលយើងអាចរៀនពីគំរូនៃការតតាំងរបស់ព្រះអង្គសង្គ្រោះទៅនឹងការល្បួងរបស់អារក្ស ។ ចូរសុំឲ្យសិស្សពីរបីនាក់សរសេរគោលការណ៍ ដែលពួកគេបានរកឃើញនៅលើក្តារខៀន ។ នៅពេលសិស្សចែកចាយគោលការណ៍ទាំងឡាយ ដែលពួកគេបានរកឃើញ សូមគូសបញ្ជាក់គោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងនឹកចាំ ហើយអនុវត្តសេចក្តីពិតដែលបានបង្រៀននៅក្នុងព្រះគម្ពីរ យើងអាចតតាំងនឹងការល្បួងរបស់អារក្សបាន ។** ប្រសិនបើសេចក្តីពិតនេះពុំបានដាក់បង្ហាញឲ្យបានច្បាស់លាស់នៅក្នុងចំណោមគោលការណ៍របស់សិស្ស សូមបន្ថែមវាទៅលើក្តារខៀន ។

សូមចង្អុលបង្ហាញថា ព្រះអង្គសង្គ្រោះពុំគ្រាន់តែនឹកចាំបទគម្ពីរដែលបញ្ជាក់ពីជម្រើសដ៏ត្រឹមត្រូវសម្រាប់ការល្បួងនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានអនុវត្តសេចក្តីពិតដែលបានបង្រៀននៅក្នុងបទគម្ពីរទាំងនោះដែរ ។

- ដោយពិចារណានូវគោលការណ៍ដែលយើងបានរកឃើញអំពីអំណាចនៃការនឹកចាំ និង ការអនុវត្តសេចក្តីពិតដែលបានបង្រៀននៅក្នុងបទគម្ពីរ ហេតុអ្វីការសិក្សាព្រះគម្ពីរជាទៀងទាត់គឺជារឿងដ៏សំខាន់ ?

ចូរឲ្យក្រដាសមួយសន្លឹកដល់ដៃគូនីមួយៗ ហើយសុំឲ្យពួកគេគូសគូឡោនចំនួនបីនៅលើវា ។ សូមណែនាំពួកគេឲ្យសរសេរនៅក្នុងគូឡោនដំបូងនូវអំពើបាបបីយ៉ាង ដែលយុវវ័យស្របាលនឹងពួកគេអាចនឹងល្បួងឲ្យធ្វើ ។ ចូរសុំឲ្យពួកគេសរសេរនៅគូឡោនទីពីរអំពីវិធីមួយដែលសាតាំងព្យាយាមអូសទាញមនុស្សម្នាក់ឲ្យធ្វើអំពើបាបនីមួយៗ ដែលពួកគេបានសរសេរនៅក្នុងគូឡោនទីមួយ ។ សូមដឹកនាំសិស្សឲ្យប្តូរក្រដាសគ្នាទៅវិញទៅមក ។ រួចណែនាំពួកគេឲ្យស្វែងរកសេចក្តីយោងបទគម្ពីរដ៏ជាក់លាក់មួយ ដែលបង្រៀនសេចក្តីពិតដែលមនុស្សម្នាក់អាចនឹងនឹកចាំ ហើយអនុវត្តពេលទទួលការល្បួងឲ្យធ្វើអំពើបាបនីមួយៗ ដែលបានសរសេរនៅលើក្រដាសដែលពួកគេបានទទួល ។ (អ្នកអាចសុំឲ្យសិស្សយោងទៅលើចំណេះចំណានខគម្ពីរដូចជា លោកុប្បត្តិ ៣៩:៩, យ៉ូហាន ១៤:១៥ឬ គោលលទ្ធិ និង សេចក្តីសញ្ញា ១០:៥) ។ ចូរសុំឲ្យសិស្សសរសេរសេចក្តីយោងបទគម្ពីរនៅក្នុងគូឡោនទីបី ។

បន្ទាប់ពីពីរបីនាទីក្រោយមក សុំឲ្យសិស្សម្នាក់ពីដៃគូនីមួយៗប្រាប់ពីសេចក្តីយោងបទគម្ពីរដែលពួកគេបានរកឃើញ សម្រាប់ការល្បួងមួយនៅលើក្រដាសរបស់ពួកគេ ។ ចូរសុំឲ្យពួកគេពន្យល់ពីរបៀបដែលបទគម្ពីរនោះអាច ជួយយើងនៅពេលយើងជួបនឹងការល្បួងនោះ ។

- តើអ្នកទទួលបានការពង្រឹង ហើយអាចតតាំងនឹងការល្បួងមួយដោយសារអ្នកបាននឹកចាំ ហើយអនុវត្តសេចក្តីពិតដែលបានបង្រៀននៅក្នុងបទគម្ពីរទាំងនោះនៅពេលណាដែរ ? (សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ឬ រឿងផ្ទាល់ខ្លួនខ្លាំងពេកនោះទេ ។)

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរបស់ពួកគេ នូវសេចក្តីយោងបទគម្ពីរមួយដែលពួកគេនឹងនឹកចាំ ហើយអនុវត្តនៅពេលក្រោយកាលពួកគេត្រូវបានល្បួងឲ្យធ្វើអំពើបាប ។ សូមលើកទឹកចិត្តពួកគេឲ្យទន្ទេញចាំបទគម្ពីរដែលពួកគេបានជ្រើសរើសនោះ ។

ម៉ាថាយ ៤:១២–១៧

ព្រះយេស៊ូវគង់នៅស្រុកកាលីឡេ

សូមសង្ខេប ម៉ាថាយ ៤:១២–១៥ ដោយពន្យល់ថា បន្ទាប់ពីបទពិសោធន៍របស់ទ្រង់នៅក្នុងទីរហោស្ថាន ព្រះអង្គសង្គ្រោះបានយាងទៅស្រុកកាលីឡេ ហើយបានគង់នៅក្រុងកាពើណិម ។ ម៉ាថាយបានកត់ចំណាំថា ការងារបម្រើរបស់ព្រះអង្គសង្គ្រោះនៅស្រុកកាលីឡេបានបំពេញការព្យាករមួយរបស់អេសាយ (សូមមើល អេសាយ ៩:១–២) ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៤:១៦ ឲ្យឮៗ ។ អ្នកគួរណែនាំពួកគេឲ្យគូសចំណាំអ្វីដែលអេសាយបានព្យាករថានឹងកើតឡើង ។ សូមចង្អុលបង្ហាញថា នៅក្នុងការព្យាករនេះយើងបានរៀនថា **ព្រះយេស៊ូវគ្រីស្ទនាំពន្លឺមកក្នុងជីវិតអស់អ្នកដែលស្ថិតក្នុងទីងងឹត** ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលថាតើព្រះអង្គសង្គ្រោះបានធ្វើការណ៍នេះនៅក្នុងការងារបម្រើរបស់ទ្រង់តាមរបៀបណា ។

សូមសង្ខេប ម៉ាថាយ ៤:១៧ ដោយពន្យល់ថាព្រះអង្គសង្គ្រោះបានចាប់ផ្តើមប្រកាសពីការប្រែចិត្ត ដើម្បីរៀបចំស្ថាបនានគរស្ថានសួគ៌នៅក្នុងចំណោមមនុស្ស ។

ម៉ាថាយ ៤:១៨–២២

ព្រះយេស៊ូវហៅពេត្រុស និង អ្នកផ្សេងទៀតឲ្យដើរតាមទ្រង់



សូមដាក់ រូប Calling of the Fishermen (*Gospel Art Book* | ឆ្នាំ ២០០៩| ល.រ. ៣៧, សូមមើលផងដែរ LDS.org) ។ សូមចង្អុលបង្ហាញថា បុរសពីរនាក់នៅពីមុខទូកនោះគឺជា ពេត្រុស និង បងប្រុសរបស់គាត់ អនទ្រេ ។

- តើពួកគេកំពុងប្រើសំណាញ់ធ្វើអ្វី ?

សូមពន្យល់ថា កាលដែលមនុស្សដទៃមើលឃើញពេត្រុស និង អនទ្រេ គ្រាន់តែជាអ្នកនេសាទដ៏សាមញ្ញ នោះព្រះយេស៊ូវគ្រីស្ទបានមើលឃើញពីសក្តានុពលដ៏អស្ចារ្យរបស់ពួកគេ ហើយជ្រាបពីអ្វីដែលពួកគេអាចប្រែក្លាយបាន ។

- តើយើងប្រៀបបាននឹង ពេត្រុស និង អនទ្រេ យ៉ាងដូចម្តេចដែរ ?

នៅពេលសិស្សបន្តសិក្សា ម៉ាថាយ ៤សុំឲ្យពួកគេរកមើលអ្វីដែលយើងត្រូវធ្វើដើម្បីប្រែក្លាយដូចជាអ្វីៗទាំងអស់ ដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងប្រែក្លាយ ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង ម៉ាថាយ ៤:១៨–២២ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលទំនាក់ទំនងរវាងព្រះអង្គសង្គ្រោះ និង ពួកអ្នកនេសាទមួយចំនួន ។

- តើព្រះអម្ចាស់បានហៅ ពេត្រុស អនទ្រេ យ៉ាកុប និងយ៉ូហាន ឲ្យធ្វើអ្វី ? តើ« [អ្នកនេសាទ] មនុស្សជាអ្វីទៅ » ? (ខទី ១៩) ។
- តើអ្វីទៅដែលធ្វើឲ្យបុរសទាំងនេះបានបរិសុទ្ធដើម្បីដើរតាមព្រះអង្គសង្គ្រោះ ហើយជួយនៅក្នុងការងាររបស់ទ្រង់ ? ហេតុអ្វីការលះបង់បែប នេះអាចជារឿងពិបាកសម្រាប់ពួកគេ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីរបៀបដែលពួកគេបានប្រព្រឹត្ត ប្រសិនបើពួកគេជាមនុស្សម្នាក់ក្នុងចំណោមបុរសទាំងនេះ ។

- តើអ្នកបានកត់សម្គាល់ឃើញអ្វីខ្លះអំពីចម្លើយរបស់បុរសទាំងនេះ ? តើចម្លើយភ្លាមៗរបស់ពួកគាត់ចំពោះការអញ្ជើញរបស់ព្រះអង្គសង្គ្រោះបង្ហាញអ្វីខ្លះពីបុគ្គលិកលក្ខណៈរបស់ពួកគាត់ ។
- តើបុរសទាំងនេះនឹងធ្វើអំពើល្អច្រើននៅក្នុងជីវិតពួកគាត់ក្នុងនាមជាអ្នកនេសាទ ឬជា « ពួកអ្នកនេសាទមនុស្ស »ដែរឬទេ ? ហេតុអ្វី ?
- ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងដំណើររឿងនេះ តើអាចមានអ្វីខ្លះកើតឡើង ប្រសិនបើយើងឆ្លើយតបភ្លាមៗចំពោះការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យដើរតាមទ្រង់ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងឆ្លើយតបភ្លាមៗចំពោះការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យដើរតាមទ្រង់ ទ្រង់អាចធ្វើឲ្យជីវិតយើងបានប្រសើរជាង**) ។

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖ ចូរសុំឲ្យសិស្សស្តាប់រកថាតើព្រះអម្ចាស់អាចធ្វើឲ្យជីវិតយើងបានប្រសើរជាងយ៉ាងដូចម្តេចខ្លះ ប្រសិនបើយើងដើរតាមទ្រង់ ។



« បុរស និង ស្ត្រីដែលបង្វែរជីវិតខ្លួនមករកព្រះនឹងរកឃើញថា ទ្រង់អាចធ្វើឲ្យជីវិតរបស់ពួកគេបានប្រសើរជាង ។ ទ្រង់នឹងធ្វើឲ្យអំណរចាក់ចូលយ៉ាងជ្រៅក្នុងចិត្តពួកគេ ពង្រីកទស្សនវិស័យរបស់ពួកគេ ពង្រឹងនិងពង្រឹងកម្លាំងពួកគេ លើកវិញ្ញាណពួកគេឡើង ចម្រើនពរជ័យពួកគេ បង្កើនឱកាសដល់ពួកគេ ល្អលោមព្រលឹងពួកគេ បង្កើតមិត្តភាព ហើយចាក់ស្រោចនូវសេចក្តីសុខសាន្ត ។ នរណាក៏ដោយដែលបានលះបង់ជីវិតនៅក្នុងការបម្រើរបស់ព្រះ នឹងរកឃើញជីវិតដ៏នៅអស់កល្បជានិច្ច » (« Jesus Christ—Gifts and Expectations » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៨៨ ទំព័រ ៤) ។

- តើអ្នក ឬមនុស្សដែលអ្នកស្គាល់ ធ្លាប់បានដកពិសោធន៍ពរជ័យស្រដៀងគ្នានេះសម្រាប់ការលះបង់ចោលនូវកង្វល់ខាងលោកិយដើម្បីដើរតាមព្រះអង្គសង្គ្រោះនៅពេលណាដែរ ?
- នៅពេលពិចារណាពីពរជ័យដែលយើងទទួលបានដោយការដើរតាមព្រះអង្គសង្គ្រោះ ហេតុអ្វីអ្នកគិតថាវាគឺជារឿងដ៏សំខាន់ដើម្បីឆ្លើយតប *ភ្លាមៗ* ទៅនឹងការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យដើរតាមទ្រង់ ?

សូមអញ្ជើញសិស្សឲ្យសរសេរចម្លើយចំពោះសំណួរខាងក្រោមនេះក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើអ្នកអាចឆ្លើយតបនឹងការអញ្ជើញរបស់ព្រះអង្គសង្គ្រោះ ឲ្យដើរតាមទ្រង់បានយ៉ាងល្អប្រសើរតាមរបៀបណាដែរ ?

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។

ម៉ាថាយ ៤:២៣–២៥

ព្រះយេស៊ូវយាងទៅបង្រៀន ប្រកាស ហើយព្យាបាលនៅស្រុកកាលីឡេ

ចូរសុំឲ្យសិស្សអាន ម៉ាថាយ ៤:២៣–២៥ ដោយស្ងៀមស្ងាត់ រកមើលសកម្មភាពរបស់ព្រះអង្គសង្គ្រោះ ។ អ្នកគួរតែណែនាំឲ្យ សិស្សគួរចំណាំអ្វីដែលពួកគេរកឃើញ ។ សូមពន្យល់ថា ឧទាហរណ៍ជាក់លាក់នៃការបង្រៀន ការប្រកាស និង ការព្យាបាលរបស់ព្រះអង្គសង្គ្រោះនឹងត្រូវបានសិក្សានៅក្នុងដំណើរឆ្ពោះទាំងឡាយ ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលសិស្សបានស្គាល់នៅក្នុងមេរៀននេះ ។

មេរៀន ៩

ម៉ាថាយ ៥:១–១៦

សេចក្តីផ្តើម

ម៉ាថាយ ៥–៧ កត់ត្រាការបង្រៀនមួយដែលព្រះអង្គសង្គ្រោះបានធ្វើនៅឯការចាប់ផ្តើមការងារបម្រើរបស់ទ្រង់ ។ វាត្រូវបានគេស្គាល់ថាជាទេសនកថានៅលើភ្នំ ។ ម៉ាថាយ ៥:១–១៦ កត់ត្រាការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីគោលការណ៍ដែលនាំទៅរកសុភមង្គល ។ ព្រះអង្គសង្គ្រោះក៏បានបង្គាប់ពួកសិស្សរបស់ទ្រង់ឲ្យធ្វើគំរូសុចរិតមួយ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៥:១–១២

ព្រះអង្គសង្គ្រោះចាប់ផ្តើមទេសនកថានៅលើភ្នំដោយបង្រៀនពីក្រឹត្យវិន័យមាស ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *តើអ្នកសប្បាយចិត្តទេ ? ហេតុអ្វីសប្បាយចិត្ត ឬ ហេតុអ្វីមិនសប្បាយ ?*

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិត (ឬសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរបស់ពួកគេ) ថាតើពួកគេនឹងឆ្លើយតបសំណួរទាំងនេះយ៉ាងដូចម្តេច ។ (អ្នកគួរប្រាប់សិស្សថា ពួកគេនឹងត្រូវចែកចាយចម្លើយពួកគេជាមួយនឹងសិស្សដទៃទៀត) ។

ចូរសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយឲ្យឮៗ ៖



« ជាញឹកញាប់ណាស់ យើងត្រូវជាប់ក្នុងការបំភាន់ថា មានអ្វីមួយដែលនឹងនាំយើងឲ្យមានសុភមង្គល ប៉ុន្តែយើងមិនអាចយោងចាប់វាបានឡើយ រួមមាន ៖ ស្ថានភាពគ្រួសារដ៏ល្អជាងមុន , ស្ថានភាពហិរញ្ញវត្ថុកាន់តែល្អប្រសើរជាងមុន ឬទីបញ្ចប់នៃឧបសគ្គ ។

« . . . ស្ថានភាពដ៏នៅអស់កល្បជានិច្ចពុំសំខាន់ ឬកំណត់សុភមង្គលរបស់យើងឡើយ ។

« . . . *យើង* កំណត់សុភមង្គលរបស់យើង » (« Of Regrets and Resolutions » *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ២០១២ ទំព័រ ២៣) ។

- **តើអ្នកគិតថាឃ្លា « យើងកំណត់សុភមង្គលរបស់យើង » មានន័យដូចម្តេច ? ហេតុអ្វីវាសំខាន់ដើម្បីដឹងពីរឿងនេះ ?**

សូមពន្យល់ថា កាលព្រះអង្គសង្គ្រោះបានចាប់ផ្តើមការងារបម្រើរបស់ទ្រង់ ទ្រង់បានធ្វើការបង្រៀនមួយនៅក្បែរសមុទ្រកាលីឡេ ។ ជារឿយៗ ការបង្រៀននេះត្រូវបានគេហៅថា ទេសនកថានៅលើភ្នំ ហើយបានកត់ត្រាទុកនៅក្នុង ម៉ាថាយ ៥–៧ ។ នៅក្នុងទេសនកថានេះ ព្រះអង្គសង្គ្រោះបានពន្យល់ពីអ្វីដែលយើងអាចធ្វើដើម្បីមានសុភមង្គលពិត មិនថាស្ថានភាពដ៏នៅអស់កល្បជានិច្ចរបស់យើងទៅជាយ៉ាងណានោះទេ ។

សូមអញ្ជើញសិស្សមើល ម៉ាថាយ ៥:៣–១១ ដោយស្ងៀមស្ងាត់ រកមើលពាក្យដដែលដែលបានលើកឡើងនៅខាងដើមនៃខគម្ពីរនីមួយៗ ។ ចូរសុំឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអត្ថន័យនៃពាក្យ *មានពរ* ។

- **តើពាក្យ *មានពរ* មានន័យដូចម្តេច ?**

សូមពន្យល់ថា ដោយសារពាក្យ *មានពរ* បកប្រែមកពីពាក្យឡាតាំង *beatus* ដែលមានន័យថា មានសំណាង ឬរីករាយ ខគម្ពីរទាំងនេះត្រូវបានហៅជាទូទៅថាក្រឹត្យវិន័យមាស ។

ចូរឲ្យសំណៅនៃ តារាងខាងក្រោមដល់សិស្សម្នាក់ៗ ។ សូមចង្អុលបង្ហាញថា បន្ថែមពីលើខគម្ពីរដែលមានន្ទរក្រឹត្យវិន័យមាសនៅក្នុង ម៉ាថាយ ៥តារាងនេះមានសេចក្តីយោងចំនួនពីរទៅនឹង នីហ្វៃទី ៣ ។ សេចក្តីយោងទាំងនេះគឺជាផ្នែកនៃការបង្រៀនមួយ ដែលព្រះយេស៊ូវគ្រីស្ទបានធ្វើពេលទ្រង់បំពេញការងារបម្រើរបស់ទ្រង់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ដែលស្រដៀងគ្នាទៅនឹងទេសនកថានៅលើភ្នំដែរ ។ សេចក្តីយោងនៅក្នុង នីហ្វៃទី ៣ ផ្តល់នូវការយល់ដឹងយ៉ាងអស្ចារ្យពីវគ្គបទគម្ពីរដែលពាក់ព័ន្ធនៅក្នុង ម៉ាថាយ ៥ ។

ក្រឹត្យវិន័យមាស

ម៉ាថាយ ៥:៣, នីហ្វៃទី ៣ ១២:៣	ការមានសេចក្តីកម្សត់ខាងវិញ្ញាណមានន័យថា ការបន្ទាបខ្លួន និង « ការទទួលស្គាល់ដោយដឹងគុណចំពោះការពឹងផ្អែក [របស់យើង] លើព្រះអម្ចាស់—យល់ថា [យើង] មានសេចក្តីត្រូវការការផ្តត់ផ្តង់ពីទ្រង់ជាប់ជានិច្ច ។ ការបន្ទាបខ្លួនគឺជាការទទួលស្គាល់ថា ទេពកោសល្យ និង សមត្ថភាព [របស់យើង] គឺជាអំណោយទានមកពី ព្រះ » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ឆ្នាំ ២០០៤] ទំព័រ ២៥) ។

មូលដ្ឋានគ្រឹះនៃការបង្រៀន និង ការរៀនសូត្រដ៏ណឹងល្អ

មូលដ្ឋានបទគម្ពីរនៃមេរៀននីមួយៗក្នុងថ្នាក់សិក្ខាសាលាផ្តោតលើបណ្តុំបទគម្ពីរមួយជាជាងផ្តោតទៅលើគំនិតបាវចនា គោលលទ្ធិ ឬ គោលការណ៍ពិសេសណាមួយ ។ នៅពេលគ្រូបង្រៀន និង សិស្សសិក្សាបណ្តុំបទគម្ពីរទាំងនេះជាទៀងទាត់ ពួកគេនឹងអាចអនុវត្តមូលដ្ឋានគ្រឹះនៃការបង្រៀន និង ការរៀនសូត្រដ៏ណឹងល្អបានច្រើនដូចជា ការយល់ដឹងពីបរិបទ និង មាតិកា ការស្គាល់ ការយល់ដឹង និង ការទទួលអារម្មណ៍ពីសេចក្តីពិត និង សារៈសំខាន់ស្តីពីគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អ និងការអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ។

ម៉ាថាយ ៥:៤	ការយំសោកគឺជាអារម្មណ៍ ឬការបង្ហាញអារម្មណ៍សោកសៅ ។ មនុស្សម្នាក់អាចយំសោកដោយសារការលំបាក និង ការសោកល្វងនៃជីវិតរមែងស្លាប់ រួមទាំងសេចក្តីស្លាប់នៃមនុស្សជាទីស្រឡាញ់ផងដែរ ។ ដូចគ្នានេះដែរ មនុស្សម្នាក់ក៏អាចយំសោកដោយសារតែកាពសោកសៅនៃអំពើបាប ។
ម៉ាថាយ ៥:៥	« “កាពស្លូតត្រង់ ដូចដែលបានឲ្យនិយមន័យនៅក្នុងវចនានុក្រម Webster គឺជា ‹ ការបង្ហាញកាព អត់ធ្មត់ និង ការអត់ទ្រាំដ៏ឃ្យរ ដោយស៊ូទ្រាំរងបួសដោយគ្មានការសោកស្តាយ › [*Webster's Third New International Dictionary* (ឆ្នាំ១៩៧៦) ‹ meek › ទំព័រ ១៤០៣] ។ កាពស្លូតត្រង់ពុំមែនជាកាពទន់ខ្សោយនោះទេ ។ វាគឺជាស្លាកឈ្មោះនៃកាពក្លាហានរបស់ពួកគ្រីស្ទាន » (រ៉ូប៊ឺត ឌី ហៃល « Christian Courage: The Price of Discipleship », *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧៣) ។
ម៉ាថាយ ៥:៦, នីហ្វៃទី ៣ ១២:៦	ការស្រេកឃ្លាននូវសេចក្តីសុចរិតបញ្ជាក់ពីបំណងប្រាថ្នាដ៏ធំធេងមួយដើម្បីដឹង ហើយធ្វើតាមព្រះទ័យនៃព្រះ ។
ម៉ាថាយ ៥:៧	« ចិត្តមេត្តាករុណា គឺជាការព្យាបាលមនុស្សម្នាក់ដោយចិត្តអាណិតអាសូរលើសពីអ្វីដែលបុគ្គលនោះសមនឹងទទួលបាន » (« Mercy » Gospel Topics lds.org/topics) ។ យើងអាចទទួលបានសេចក្តីមេត្តាករុណាពីព្រះវរបិតាសួគ៌ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ (សូមមើល អាលម៉ា ៣៣:១១) ។
ម៉ាថាយ ៥:៨	« អ្នកដែលមានចិត្តបរិសុទ្ធគឺជាជនដែលស្រឡាញ់ព្រះអម្ចាស់ ខិតខំធ្វើតាមទ្រង់ ហើយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ជាជនដែលកំពុងព្យាយាមរស់នៅក្នុងជីវិតប្រកបដោយគុណធម៌ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុតដោយស្មោះត្រង់ ។ អ្នកដែលមានចិត្តបរិសុទ្ធគឺជាជនដែលគ្រប់គ្រងគំនិតខ្លួន ដើម្បីធ្វើឲ្យខ្លួនឯងមានសេរីភាពពីចំណង់ប្លែកៗ និង ទង្វើអសីលធម៌នានា » (សែលដុន អែហ្វ ឆាល « Words of Jesus: Chastity » *Ensign* ខែមករា ឆ្នាំ ២០០៣ ទំព័រ ៤៤) ។
ម៉ាថាយ ៥:៩	« [ការផ្សះផ្សា] គឺជាអំណោយទានដើម្បីជួយមនុស្ស ឲ្យរកឃើញចំណុចរួម ពេលមនុស្សដទៃទៀតកំពុងមើលឃើញពីភាពខុសគ្នា » (ហិនរី ប៊ី អាវរិង « Learning in the Priesthood » *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ ២០១១ ទំព័រ ៦៣) ។
ម៉ាថាយ ៥:១០–១២	ការត្រូវបានគេ « បៀតបៀនដោយព្រោះសេចក្តីសុចរិត » មានន័យថា ការយល់ព្រមគោរពតាម ហើយការពារព្រះយេស៊ូវគ្រីស្ទ និង ការបង្រៀនរបស់ទ្រង់ សូម្បីតែពេលយើងត្រូវបានគេសើចចំអកឲ្យ ឬធ្វើបាបដោយសារតែការធ្វើដូច្នោះក្តី ។

សូមបំបែកសិស្សជាប្រាំបីក្រុម ហើយចាត់ឲ្យក្រុមនីមួយៗនូវក្រឹត្យវិន័យមាសមួយដែលមាននៅក្នុងតារាង (ប្រសិនបើអ្នកគ្មានសិស្សគ្រប់គ្រាន់ដើម្បីបង្កើតជាប្រាំបីក្រុមទេ សូមពិចារណាចាត់ក្រឹត្យវិន័យមាសលើសពីមួយដល់ក្រុមនីមួយៗ) ។ សូមអញ្ជើញសិស្សរៀបចំបទឧទ្ទេសនាមខ្លីមួយអំពីក្រឹត្យវិន័យមាសដែលពួកគេបានទទួល ។ ពួកគេគួរដាក់បញ្ចូលសកម្មភាពខាងក្រោមនេះនៅក្នុងបទឧទ្ទេសនាមរបស់ពួកគេ (អ្នកគួរសរសេរសេចក្តីណែនាំទាំងនេះនៅលើ ក្តារខៀន ឬបង្កើតជាឯកសារយោងមួយ) ៖

១. សូមអញ្ជើញមិត្តរួមថ្នាក់ម្នាក់អានខគម្ពីរឮៗ ហើយរៀបរាប់ពីពរជ័យដែលយើងទទួលបានតាមរយៈការរស់នៅតាមក្រឹត្យវិន័យមាសនោះ ។

២. ដោយប្រើខគម្ពីរនេះ និងព័ត៌មាននៅក្នុងតារាង សូមពន្យល់ពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យដែលបានសន្យា ។

៣. សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យណែនាំពីវិធីជាក់លាក់ដែលយើងអាចរស់នៅឲ្យស្របនឹងក្រឹត្យវិន័យមាសនេះ ។

៤. សូមពន្យល់ពីរបៀបដែលការរស់នៅស្របតាមបទប្រទានពរនេះអាចនាំសុភមង្គលដល់យើង ។ អ្នកក៏គួរចែកចាយបទពិសោធន៍មួយដែលឆ្លុះបញ្ចាំងពីសេចក្តីពិតដែលអ្នកបានបង្រៀន រួមទាំងទីបន្ទាល់ពីសេចក្តីពិតនោះផងដែរ ។

លុះដល់ពេលកំណត់ហើយ សុំឲ្យក្រុមនីមួយៗធ្វើបទឧទ្ទេសនាមដល់សិស្សក្នុងថ្នាក់ពីបទប្រទានពរដែលពួកគេទទួលបាន ។

ក្រោយពីសិស្សបានបញ្ចប់បទឧទ្ទេសនាម សូមចង្អុលបង្ហាញថា បទប្រទានពរបង្រៀនអំពីលក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ ហើយថាតាមរយៈការរស់នៅតាមក្រឹត្យវិន័យទាំងនេះ នោះយើងអាចប្រែក្លាយកាន់តែដូចជាទ្រង់ ។

- **យោងតាមអ្វីដែលអ្នកបានរៀននៅក្នុង ម៉ាថាយ ៥តើអ្វីនឹងកើតឡើងចំពោះយើង កាលយើងអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទទាំងនេះ និងលក្ខណៈផ្សេងទៀត ? (ទោះបីជាពួកគេអាចនឹងប្រើពាក្យខុសគ្នាក៏ដោយ សិស្សទាំងឡាយគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ យើងឃើញថាសុភមង្គលនឹងកើនឡើង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។**

សូមពិចារណាចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍នេះ ។ សូមរំពុកសិស្សអំពី សំណួរទាក់ទងនឹងសុភមង្គល ដែលពួកគេបានសញ្ជឹងគិតនៅដើមមេរៀននេះ ។ សូមអញ្ជើញសិស្សស្វែងរកសុភមង្គលដ៏ធំធេងដោយជ្រើសរើសបទប្រទានពរមួយដែលមាននៅក្នុងក្រឹត្យវិន័យមាសដែលមានរាយក្នុងបញ្ជី រួចដាក់គោលដៅមួយដើម្បីអភិវឌ្ឍលក្ខណៈនោះ ។

ម៉ាថាយ ៥:១៣–១៦

ព្រះយេស៊ូវគ្រីស្ទណែនាំពួកសិស្សរបស់ទ្រង់ឲ្យធ្វើគំរូសុចរិត

ចូរសុំឲ្យសិស្សគិតពីមនុស្សម្នាក់ដែលពួកគេស្គាល់ ដូចជាសមាជិកគ្រួសារ ឬមិត្តម្នាក់ ដែលអាចទទួលពរដោយការខិតទៅជិតព្រះវរបិតាសួគ៌ ។ នៅពេលសិស្សបន្តសិក្សា ម៉ាថាយ ៥សុំឲ្យពួកគេរកមើលគោលការណ៍ដែលអាចដឹកនាំពួកគេ នៅពេលពួកគេព្យាយាមជួយមនុស្សម្នាក់នេះ ។

សូមដាក់បង្ហាញកំប៉ុងអំបិលមួយ ហើយចាក់អំបិលបន្តិចទៅក្នុងចាន ។

- តើអំបិលមានប្រយោជន៍យ៉ាងណាដែរ ?

សូមអញ្ជើញសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះរបស់អែលឌើរ ខាឡូស អ៊ី អេសេ នៃពួកចិតសិបនាក់ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលកិច្ចការមួយចំនួនដែលប្រើប្រាស់អំបិល ៖

« [អំបិលល្អ] . . . ស្អាត សុទ្ធ គ្មានសារជាតិពុល ហើយមានប្រយោជន៍ ។ នៅក្នុងស្ថានភាព ឬលក្ខខណ្ឌនេះ អំបិលនឹងការពារ ផ្តល់រសជាតិ ព្យាបាល ហើយធ្វើមុខងារដ៏មានប្រយោជន៍ផ្សេងទៀត » (« Salt of the Earth: Savor of Men and Saviors of Men » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨០ ទំព័រ ៤២) ។

សូមអញ្ជើញសិស្សអាន ម៉ាថាយ ៥:១៣ ដោយស្ងៀមស្ងាត់ ហើយរកមើលថាតើព្រះអង្គសង្គ្រោះប្រៀបធ្មឹមអំបិលទៅនរណា ។

- តើព្រះអង្គសង្គ្រោះបានប្រៀបប្រដូចអំបិលទៅនរណាដែរ ? (ពួកសិស្សរបស់ទ្រង់) ។
- តើពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបង្ហាញលក្ខណៈសម្បត្តិដូចគ្នានឹងអំបិលល្អតាមរបៀបណា ?
- យោងតាម ខទី ១៣តើមានអ្វីកើតឡើង កាលអំបិលបាត់បង់រសជាតិប្រៃ ?

សូមពន្យល់ថា ពាក្យ *ជាតិប្រៃ* ពុំមែនសំដៅតែលើរសជាតិរបស់អំបិលប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅទៅលើគុណសម្បត្តិដាច់ដោយឡែកដែលធ្វើឲ្យវាក្លាយទៅជាភ្នាក់ងារព្យាបាល និង ការពារផងដែរ ។

- តើអ្វីទៅដែលធ្វើឲ្យអំបិលបាត់បង់រសជាតិប្រៃ ? (អំបិលបាត់បង់ជាតិប្រៃ ពេលវាលាយនឹងសារធាតុផ្សេងទៀត ហើយទៅជាកខ្វក់) ។

សូមចាក់សារធាតុផ្សេងទៀត ដូចជាដី ចូលទៅក្នុងចាន ហើយលាយអំបិល និង សារធាតុផ្សេងទៀតបញ្ចូលគ្នា ។

- តើមានអ្វីកើតឡើងចំពោះប្រយោជន៍របស់អំបិល កាលវាលាយបញ្ចូលគ្នានឹងសារធាតុផ្សេងទៀត ?
- ក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ តើអ្វីទៅដែលអាចធ្វើឲ្យយើងបាត់បង់ជាតិប្រៃរបស់យើង ឬគុណសម្បត្តិដូចជាព្រះគ្រីស្ទដែលអនុញ្ញាតឲ្យយើងក្លាយជាទៅពរជ័យមួយសម្រាប់មនុស្សដទៃទៀត ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ការមានភាពកខ្វក់ដោយអំពើបាបនៃលោកិយ អាចរារាំងយើងមិនឲ្យធ្វើជាពរជ័យមួយសម្រាប់មនុស្សដទៃទៀត ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីរក្សាទុក ឬទទួលបានជាតិប្រៃរបស់យើងមកវិញ ?

សូមដាក់បង្ហាញចង្កៀងមួយ (កុំបញ្ឆេះវា) ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:១៤–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើព្រះអង្គសង្គ្រោះប្រៀបធ្មឹមពួកសិស្សរបស់ទ្រង់ទៅនឹងចង្កៀងតាមរបៀបណា ។

- តើពួកសិស្សរបស់ព្រះគ្រីស្ទត្រូវបានស្នើសុំឲ្យធ្វើអ្វីខ្លះជាមួយនឹងពន្លឺរបស់ពួកគេ ?
- តើឃ្លាដែលចែងថា ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺ មានន័យដូចម្តេច ? (សូមមើល នីហ្វៃទី ៣ ១៨:២៤) ។
- តើកិច្ចការល្អៗរបស់យើងនឹងដឹកនាំមនុស្សដទៃទៀតឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា នៅក្នុងចំណោមរឿងផ្សេងទៀតឃ្លា « សរសើរតម្កើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ » (ខទី ១៦) មានន័យថា ការថ្វាយការសរសើរ និង ការគោរពដល់ព្រះតាមរយៈពាក្យសម្តី ឬទង្វើ ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុង ខទី ១៤–១៦អំពីរបៀបដែលគំរូសុចរិតរបស់យើងអាចជះឥទ្ធិពលដល់មនុស្សដទៃទៀត ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញគោលការណ៍ដូចតទៅនេះ ៖ **គំរូសុចរិតរបស់យើងអាចលើកទឹកចិត្តមនុស្សដទៃទៀតឲ្យខិតទៅជិតព្រះវរបិតាសួគ៌ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើថ្មីៗនេះមានមនុស្សម្នាក់បានធ្វើគំរូសុចរិតមួយ ហើយវាបានជួយអ្នកឲ្យខិតទៅជិតនឹងព្រះវរបិតាសួគ៌នៅពេលណាដែរ ?

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីអ្វី ដែលពួកគេអាចធ្វើដើម្បីមានគំរូមួយដ៏ល្អប្រសើរដល់គ្រួសារ និង មិត្តរបស់ពួកគេ ។

សូមរំឭកឡើងវិញនូវគោលការណ៍ដែលបានរកឃើញ ហើយសរសេរនៅលើក្តារខៀននៅក្នុងមេរៀននេះ ។ សូមសរសេរពាក្យ *ចាប់ផ្តើម ឈប់* និង *បន្ត* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សវាយតម្លៃពីជីវិតរបស់ពួកគេ ហើយជ្រើសរើសយករឿងមួយដែលពួកគេអាចចាប់ផ្តើមធ្វើ រឿងមួយដែលពួកគេអាចឈប់ធ្វើវា និងរឿងមួយដែលពួកគេអាចបន្តធ្វើដើម្បីអនុវត្តគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

ម៉ាថាយ ៥:១៤–១៦

វគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រីស្ទ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកគួរតែណែនាំ សិស្សឲ្យគួរគូសចំណាំចំណេះចំណានខគម្ពីរនេះតាមរបៀបជាក់លាក់មួយ ដើម្បីឲ្យពួកគេងាយស្រួលរក ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សម្រាប់ការពន្យល់អំពី ចំណេះចំណានខគម្ពីរ និងបញ្ជីនៃសកម្មភាពបន្ថែមដើម្បីជួយសិស្សឲ្យចេះចាំវគ្គបទគម្ពីរជម្រើសទាំងនេះ សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ ។

ចំណេះចំណានខគម្ពីរ—ម៉ាថាយ ៥:១៤–១៦

សូមពន្យល់ថា ពេញមួយឆ្នាំសិស្សផ្តោតលើវគ្គចំណេះចំណានខគម្ពីរទាំង ២៥ រួមបញ្ចូលទាំង ម៉ាថាយ ៥:១៤–១៦ ។ វគ្គទាំងនេះនឹងជួយពួកគេឲ្យយល់ ហើយពន្យល់ពីគោលលទ្ធិគ្រឹះទាំងឡាយនៃដំណឹងល្អ ។ សេចក្តីយោងនៃចំណេះចំណានខគម្ពីរទាំង ២៥ មាននៅលើផ្នែកខ្នងនៃប្រដាប់សៀតសៀវភៅនៃថ្នាក់សិក្ខាសាលាសម្រាប់ព្រះគម្ពីរសញ្ញាថ្មី ។ សូមពន្យល់ថា « វគ្គចំណេះចំណានខគម្ពីរ រួមបញ្ចូលទាំងការអានយល់ដឹង ការអនុវត្ត និងការទន្ទេញវាឲ្យចាំ ។

ដើម្បីជួយសិស្សឲ្យទន្ទេញចាំវគ្គនេះ សុំឲ្យពួកគេសូត្រវាពីរបីដងនៅក្នុងចិត្តពួកគេ រួចសូត្រឮៗឲ្យមិត្តរួមថ្នាក់ម្នាក់ស្តាប់ ។ អ្នកគួរឲ្យសិស្សទាំងអស់សូត្រវគ្គនេះឮៗ នៅពេលចាប់ផ្តើម ឬបញ្ចប់ថ្នាក់ម្តងៗនៅសប្តាហ៍ក្រោយ ។

មេរៀន ១០

ម៉ាថាយ ៥:១៧–៤៨

សេចក្តីផ្តើម

នៅពេលព្រះអង្គសង្គ្រោះបន្តទេសនកថារបស់ទ្រង់នៅលើភ្នំក្នុងស្រុកកាលីឡេ ទ្រង់បានពន្យល់ថា ទ្រង់ពុំបានយាងមកដើម្បីបំផ្លាញក្រឹត្យវិន័យរបស់លោកម៉ូសេទេ ប៉ុន្តែយាងមកដើម្បីបំពេញវិញ ។ ព្រះអង្គសង្គ្រោះក៏បានប្រទានព្រះបញ្ញត្តិដែលពួកសិស្សរបស់ទ្រង់ត្រូវធ្វើតាមដើម្បីឲ្យបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតាសួគ៌ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៥:១៧–៤៨

ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់ពីរបៀបឲ្យបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតាសួគ៌

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀន ពីមុនចាប់ផ្តើមបង្រៀន ៖ *តើព្រះបញ្ញត្តិមួយណា ដែលអ្នកគិតថាមនុស្សពិបាកគោរពតាមជាងគេបំផុត* ? នៅពេលថ្នាក់ចាប់ផ្តើមសុំឲ្យសិស្សឆ្លើយតបទៅនឹងសំណួរនេះ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៤៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រះបញ្ញត្តិមួយដែលពិបាកគោរពតាម ។ អ្នកគួរអានការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ ម៉ាថាយ ៥:៤៨ដែលចែងថា « ដូច្នេះអ្នករាល់គ្នាត្រូវបានបង្គាប់ឲ្យគ្រប់លក្ខណ៍ ដូចព្រះវរបិតានៃអ្នកដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍ដែរ » ។

- តើព្រះបញ្ញត្តិឲ្យបានគ្រប់លក្ខណ៍ធ្វើឲ្យយើងមានអារម្មណ៍បែបណាដែរ ?
- តើអ្នកគិតថា ភាពគ្រប់លក្ខណ៍មានន័យដូចម្តេច ?

សូមពន្យល់ថា ពាក្យ « គ្រប់លក្ខណ៍ » ត្រូវបានបកប្រែចេញពីពាក្យក្រិកដែលមានន័យថា « ពេញលេញ »« *បញ្ចប់* » ឬ « *បានអភិវឌ្ឍយ៉ាងពេញលេញ* » ។ សូមសួរសិស្សថាតើសេចក្តីពន្យល់នេះជួយពួកគេឲ្យយល់ពីខគម្ពីរនេះកាន់តែប្រសើរឡើងបានដោយរបៀបណា ។ សូមពន្យល់ថាភាពបានពេញលេញ ឬបានអភិវឌ្ឍយ៉ាងពេញលេញនោះមានន័យថាការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ។

នៅពេលសិស្សបន្តការសិក្សារបស់ខ្លួនអំពីទេសនកថានៅលើភ្នំរបស់ព្រះអង្គសង្គ្រោះក្នុង ម៉ាថាយ ៥សុំឲ្យពួកគេរកមើលគោលការណ៍ដែលពួកគេត្រូវធ្វើតាមដើម្បីបានចម្រើនឡើងឆ្ពោះទៅកាន់ភាពបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ផងដែរ ។

សូមសង្ខេប ម៉ាថាយ ៥:១៧–២០ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនថា ទ្រង់បានយាងមកដើម្បីបំពេញក្រឹត្យវិន័យរបស់លោកម៉ូសេ ពុំមែនយាងមកដើម្បីបំផ្លាញ ឬលុបបំបាត់ចោលសេចក្តីពិតដ៏នៅអស់កល្បជានិច្ចណាមួយនៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ ។ ព្រះយេស៊ូវគ្រីស្ទបានស្តារឡើងវិញនូវភាពពោរពេញនៃដំណឹងល្អដែលបានបាត់បង់ដោយសារតែអំពើទុច្ចរិត និង ការក្បត់សាសនា ទ្រង់បានកែតម្រូវការការបង្រៀនខុសឆ្គង ហើយបានបំពេញការព្យាករដែលបានធ្វើឡើងដោយពួកព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ នៅទីបំផុត ដោយសារជាផ្នែកមួយនៃការស្តារភាពពោរពេញនៃដំណឹងល្អឡើងវិញ កត្តាមួយចំនួននៃក្រឹត្យវិន័យរបស់លោកម៉ូសេត្រូវបានបញ្ឈប់ ដូចជាការកាត់ស្បែក និងការបូជាសត្វ ។

សូមពន្យល់ថា ម៉ាថាយ ៥:២១–៤៨ រួមបញ្ចូលទាំងការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីក្រឹត្យវិន័យ និង ទំនៀមទំលាប់នានាដែលពួកសាសន៍យូដាបានបង្កើត ឬបន្ថែមទៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ។ នៅពេលព្រះយេស៊ូវគ្រីស្ទបានពន្យល់ពីអត្ថន័យពិតនៃក្រឹត្យវិន័យនោះ ទ្រង់បានបង្រៀនរបៀបដ៏ខ្ពង់ខ្ពស់មួយនៃសេចក្តីសុចរិត ។ សមាជិកនៃនគររបស់ទ្រង់ត្រូវរស់នៅតាមក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់នេះ ។ ក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់ទាំងនេះបានផ្តល់ការដឹកនាំ ដើម្បីជួយពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទចៀសវាងពីការបំពានព្រះបញ្ញត្តិរបស់ព្រះ ។

ដើម្បីរៀបចំសិស្សសិក្សាការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីកំហឹង សុំឲ្យពួកគេគិតពីគ្រាមួយដែលពួកគេបានខឹងនឹងនរណាម្នាក់ ។

- តើគ្រោះថ្នាក់មួយចំនួននៃការពុំអាចគ្រប់គ្រងកំហឹងរបស់យើងបាន មានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:២១–២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលក្រឹត្យវិន័យរបស់លោកម៉ូសេបានបង្រៀនអំពីអំពើហឹង្សា និង កំហឹង ព្រមទាំងសេចក្តីពិតបន្ថែមទៀតដែលព្រះអម្ចាស់បានបង្រៀនអំពីកំហឹងជាផ្នែកមួយនៃក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់ ។

- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះអំពីអំពើហឹង្សា និង កំហឹង ? (សូមពន្យល់ថា ពាក្យ *អារោលអម្បៅត* ក្នុង ខទី ២២ មានន័យថា មនុស្សល្ងីល្ងើ មនុស្សភ្លីភ្លើ ឬមនុស្សមិនចេះគិត) ។
- យោងតាមខគម្ពីរទាំងនេះ តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងពុំរៀនគ្រប់គ្រងកំហឹងរបស់យើងទេនោះ ?

សូមពន្យល់ថាការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ ម៉ាថាយ ៥:២២បានដកយកឃ្លា « ដោយគ្មានហេតុផល » ពីខគម្ពីរនេះ ដោយធ្វើវាឲ្យទៅជា « តែខ្ញុំប្រាប់អ្នករាល់គ្នាដូច្នេះវិញ ថា សូម្បីតែអ្នកណាដែលខឹងនឹងបងប្អូន នោះត្រែងត្រូវជាប់ជំនុំជំរះដែរ ហើយអ្នកណា

យល់ដឹងពីបរិបទ និង មាតិកា

គ្រឹះមួយនៃការបង្រៀន និង រៀនសូត្រពីដំណឹងល្អគឺការយល់ដឹងពីបរិបទ និង មាតិកានៃព្រះគម្ពីរ ។ បរិបទរួមមានទាំងកាលៈទេសៈ ដែលនៅជុំវិញ ឬផ្តល់ជាផ្ទៃរឿងអំពីវគ្គបទគម្ពីរ ព្រឹត្តការណ៍ និង ដំណើររឿងជាក់លាក់មួយ។ មាតិការួមបញ្ចូលទាំងខ្សែរឿង មនុស្ស ព្រឹត្តិការណ៍ ទេសនកថា និង ការពន្យល់ដែលបានបំផុសគំនិត ដែលបង្កើតអត្ថបទគម្ពីរ ។ នៅពេលអ្នកជួយសិស្សឲ្យយល់ពីបរិបទ និង មាតិកានៃព្រះគម្ពីរ ពួកគេនឹងរៀបចំខ្លួនដើម្បីស្គាល់សារលិខិតមូលដ្ឋានចាំបាច់របស់ពួកអ្នកនិពន្ធដ៏បំផុតគំនិត ។

ដែលស្តីឲ្យបងប្អូនថា អាចោលម្សៀត នោះក្រែងពួកក្រុមជំនុំធ្វើទោស តែចំណែកអ្នកណាដែលថា អាឆ្កួត នោះក្រែងធ្លាក់ទៅក្នុងភ្លើងនរក » ។

- ហេតុអ្វីបានជាការដកឃ្លា « ដោយគ្មានហេតុផល » ចេញពីខគម្ពីរនេះគឺជារឿងដ៏សំខាន់ ?
- តើការគ្រប់គ្រងកំហឹងរបស់យើងជួយយើងឲ្យរីកចម្រើនឆ្ពោះទៅរកភាពគ្រប់លក្ខណ៍បានយ៉ាងដូចម្តេច ?

សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន ៖ *ដូច្នេះ ប្រសិនបើអ្នករាល់គ្នាមករកយើង ឬមានបំណងចង់មករកយើង . . .*

សូមពន្យល់ថាការបកប្រែដោយ យ៉ូសែប ស៊្មីធ បានបន្ថែមឃ្លាថា « ប្រសិនបើអ្នករាល់គ្នាមករកយើង ឬមានបំណងចង់មករកយើង » នៅដើម ខទី ២៣ ដូច្នេះវាអានថា « ដូច្នេះ ប្រសិនបើអ្នករាល់គ្នាមករកយើង ឬមានបំណងចង់មករកយើង ឬបើកាលណាអ្នកនាំយកដង្វាយមកដល់អាសនា ហើយនៅទីនោះអ្នកនឹកឃើញថាបងប្អូនណាមានហេតុអ្វីទាស់នឹងអ្នក » (Joseph Smith Translation, Matthew ៥:២៥) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:២៣–២៤ ឲ្យឮៗ ដោយដាក់បញ្ចូលឃ្លាបន្ថែមពីការបកប្រែដោយយ៉ូសែប ស៊្មីធ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើព្រះអង្គសង្គ្រោះបានបង្រៀនយើងឲ្យធ្វើអ្វីខ្លះ ដើម្បីគ្រប់គ្រងកំហឹងរបស់យើងចំពោះមនុស្សដទៃ ប្រសិនបើយើងមានបំណងចង់មករកទ្រង់ ។

- តើឃ្លា « នោះត្រូវទុកដង្វាយរបស់អ្នកនៅមុខអាសនា ហើយទៅរកជានឹងបងប្អូន » មានន័យដូចម្តេច ? (ពីមុនប្រជាជនថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ ពួកគេត្រូវផ្សះផ្សារទំនាក់ទំនងរបស់ពួកគេជាមួយនឹងមនុស្សដទៃទៀតជាមុនសិន) ។
- យោងតាម ខទី ២៤តើយើងត្រូវធ្វើអ្វីខ្លះ ប្រសិនបើយើងមានបំណងចង់មករកព្រះគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ប្រសិនបើយើងមានបំណងចង់មករកព្រះយេស៊ូវគ្រីស្ទ យើងត្រូវតែធ្វើផ្មែករបស់យើងដើម្បីផ្សះផ្សារជាមួយនឹងមនុស្សដទៃទៀតជាមុនសិន**) ។
- តើការផ្សះផ្សារនឹងនរណាម្នាក់មានន័យដូចម្តេច ? (ការដោះស្រាយជម្លោះ ឬការស្តារឡើងវិញនូវភាពសុខដុមក្នុងទំនាក់ទំនង ។ ការណ៍នេះរួមបញ្ចូលទាំងជនដែលគ្មានអារម្មណ៍ល្អចំពោះយើង និង ជនដែលយើងមានអារម្មណ៍មិនល្អជាមួយ) ។
- ហេតុអ្វីអ្នកគិតថាយើងត្រូវដោះស្រាយជម្លោះរបស់យើងជាមួយនឹងមនុស្សដទៃ ដើម្បីមករកព្រះគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:២៥–២៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះមានបន្ទូលថាយើងអាចធ្វើដើម្បីផ្សះផ្សារនឹងអ្នកដទៃ ។

- តើអ្នកគិតថា ការស្រុះស្រួលភ្លាមៗនឹងមារសត្រូវរបស់អ្នកមានន័យដូចម្តេច ? សូមពន្យល់ថា ឃ្លា « ស្រុះស្រួល »ត្រូវបានបកប្រែចេញពីភាសាក្រិកដែលមានន័យថា « មានគំនិតល្អភ្លាមៗ ឬបានកម្ចាត់ចោលយ៉ាងល្អចំពោះ)
- តើការជ្រើសយកការមានគំនិតល្អទៅកាន់នរណាម្នាក់អាចជួយយើងឲ្យដោះស្រាយជម្លោះ ឬស្តារឡើងវិញនូវទំនាក់ទំនងដែលប្រេះស្រាំជាមួយនឹងគាត់បានយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សគិតពីគ្រាមួយដែលពួកគេបានដោះស្រាយជម្លោះជាមួយនឹងមនុស្សម្នាក់ទៀត ហើយជាលទ្ធផលបានខិតចូលកាន់តែជិតទៅរកព្រះគ្រីស្ទ ។ អ្នកគួរឲ្យសិស្សម្នាក់ ឬ ពីរនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ប្រសិនបើវាពុំមានលក្ខណៈផ្ទាល់ខ្លួនពេក ។ សូមលើកទឹកចិត្តសិស្សឲ្យដោះស្រាយជម្លោះរបស់ពួកគេជាមួយនឹងអ្នកដទៃ ដើម្បីពួកគេអាចរីកចម្រើនឆ្ពោះទៅរកការបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ។



សូមបង្ហាញស្មៅ (ឬ រូបភាព ស្មៅ) ។

- តើអាចនឹងមានអ្វីកើតឡើង ប្រសិនបើស្មៅពុំត្រូវបានគេដកចេញពីសួនដំណាំ ?
- តើស្មៅអាចប្រៀបទៅនឹងអំពើបាបបានដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:២៧–២៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអំពើបាបមួយដែលព្រះអង្គសង្គ្រោះបានព្រមាន និង ក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់ដែលទ្រង់រំពឹងឲ្យពួកសិស្សរបស់ទ្រង់រស់នៅតាម ។

- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះអំពីគំនិតដែលអសិលធម៌ ឬបំណងដែលពោរពេញដោយតណ្ហា ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដបញ្ជាក់ឲ្យច្បាស់ថា **ប្រសិនបើយើងជ្រើសយកគំនិតអសិលធម៌ ឬបំណងដែលពោរពេញដោយតណ្ហា វាប្រៀបបាននឹងយើងប្រព្រឹត្តអំពើកំផិតនៅក្នុងដួងចិត្តរបស់យើង**) ។

សូមពន្យល់ថា ទោះជាយើងពុំអាចវារាំងគំនិតឥតបរិសុទ្ធ ពុំឲ្យចូលមកក្នុងគំនិតរបស់យើងបានជានិច្ចក៏ដោយ ប៉ុន្តែយើងអាចវារាំងវាពុំឲ្យនៅទីនោះបាន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:២៩–៣០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីការដកយកគំនិតឥតបរិសុទ្ធចេញ ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាយើងត្រូវធ្វើអ្វីខ្លះ ដើម្បីដកយកគំនិតឥតបរិសុទ្ធចេញ ?
- តើអ្នកគិតថាការខ្វេះភ្នែកមនុស្សម្នាក់ចេញ និង ការកាត់ដៃមនុស្សម្នាក់ចោលនៅក្នុងខគម្ពីរទាំងនេះមានន័យដូចម្តេច ?

សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធសម្រាប់ ម៉ាថាយ ៥:៣០ បន្ថែមប្រយោគថា « ហេតុដូច្នេះហើយឥឡូវយើងមានបន្ទូលពីរឿងប្រៀបប្រដូចមួយទាក់ទងនឹងអំពើបាបអ្នករាល់គ្នាដែលបណ្តេញពួកគេចេញពីអ្នក ដើម្បីកុំឲ្យអ្នករាល់គ្នាត្រូវកាប់បោះចោលទៅក្នុងភ្លើង ។ ចូរសុំឲ្យសិស្សរកមើលថាតើការបកប្រែដោយយ៉ូសែប ស៊្មីធ ជួយយើងឲ្យយល់ពីអត្ថន័យនៃការខ្វេះភ្នែកមនុស្សម្នាក់ចេញ និង ការកាត់ដៃមនុស្សម្នាក់ចោលនៅក្នុងខគម្ពីរទាំងនេះបានយ៉ាងដូចម្តេច ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាមអ្វីដែលព្រះអម្ចាស់បានបង្រៀននៅក្នុង ម៉ាថាយ ៥:២៩–៣០តើអ្វីខ្លះអាចនឹងកើតឡើង ប្រសិនបើយើងពុំដកអំពើបាបចេញពីជីវិតយើង ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងជ្រើសពុំដកអំពើបាបចេញពីជីវិតរបស់យើង វានឹងបំផ្លាញយើងខាងវិញ្ញាណ**) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីដកអំពើបាបចេញពីជីវិតរបស់យើង ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីដកអំពើបាបចេញពីជីវិតរបស់យើង ហើយធ្វើឲ្យប្រាកដថាយើងពុំធ្វើអំពើបាបទាំងនោះម្តងទៀត ?

សូមលើកទឹកចិត្តសិស្សឲ្យគិតពីអំពើបាប ដែលពួកគេចង់ដកចេញពីជីវិតរបស់ពួកគេ រួចដាក់គោលដៅមួយ ដើម្បីធ្វើកិច្ចការនោះ ដោយការប្រែចិត្ត និង ការផ្លាស់ប្តូរវាជាមួយនឹងទង្វើរសុចរិត ។

សូមសង្ខេប ម៉ាថាយ ៥:៣១–៣៧ ដោយពន្យល់ថា ព្រះអម្ចាស់បានបង្រៀនអំពីការលែងលះ អាពាហ៍ពិពាហ៍ និង ការធ្វើសម្បថ ។

សូមអញ្ជើញសិស្សនឹកស្រមៃថា មានមិត្តម្នាក់នៅសាលាបាននិយាយរឿងដ៏អាក្រក់អំពីពួកគេ ។ សូមសួរទៅសិស្សថាតើពួកគេនឹងឆ្លើយតបយ៉ាងណា ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៣៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើក្រឹត្យវិន័យរបស់លោកម៉ូសេបានបង្រៀនអ្វីខ្លះអំពីការដាក់ទោសចំពោះបុគ្គលដែលប្រព្រឹត្តអំពើបាប ឬកំហុស ។ សូមអញ្ជើញពួកគេឲ្យប្រាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមពន្យល់ថាឃ្លា « ភ្នែកឲ្យជួនភ្នែក ហើយធ្មេញឲ្យជួនធ្មេញ » មានន័យថា នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ការដាក់ទោសត្រូវតែសក្តិសមនឹងទម្ងន់ទោសនោះ ។

សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញដៃគូម្នាក់អាន ម៉ាថាយ ៥:៣៩–៤២ ហើយដៃគូម្នាក់ទៀតអាន ម៉ាថាយ ៥:៤៣–៤៧ ។ ចូរសុំឲ្យពួកគេរកមើលក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់ ។ លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូខ្លួន (អ្នកគួរសរសេរសំណួរទាំងនេះនៅលើ ក្តារខៀន ឬចែកឯកសារឲ្យពួកគេ) ៖

យោងតាមព្រះអង្គសង្គ្រោះ តើក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់គឺជាអ្វីទៅ ?

តើក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់នេះបង្រៀនយើងអ្វីខ្លះពីរបៀបដែលយើងឆ្លើយតបនឹងជនដែលធ្វើឲ្យយើងអាក់អន់ចិត្ត ?

លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សដទៃ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៤៥ ឲ្យឮៗឡើងវិញ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើអ្វីនឹងកើតឡើង ប្រសិនបើយើងស្រឡាញ់សត្រូវរបស់យើង ហើយធ្វើល្អដាក់ជនដែលស្អប់យើង ។

- តើនឹងមានអ្វីខ្លះកើតឡើង ប្រសិនបើយើងស្រឡាញ់សត្រូវរបស់យើង ហើយធ្វើល្អដាក់ជនដែលស្អប់យើង ។
- ដោយដឹងថា យើងទាំងអស់គ្នាគឺជាកូនចៅវិញ្ញាណរបស់ព្រះ តើអ្នកគិតថាការធ្វើជាកូនចៅនៃព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ នៅក្នុងខគម្ពីរនេះមានន័យដូចម្តេច ? (វាមានន័យថា ការក្លាយដូចជាទ្រង់ ហើយក្លាយជាអ្នកគ្រងនគររបស់ទ្រង់) ។
- តើព្រះអង្គសង្គ្រោះបានបង្ហាញគំរូនៃការស្រឡាញ់របស់ទ្រង់ ចំពោះពួកសត្រូវ និងការធ្វើល្អដល់អ្នកដទៃនៅក្នុងព្រះជន្មរបស់ទ្រង់ដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថាតើពួកគេបានរៀនអ្វីខ្លះនៅក្នុង ម៉ាថាយ ៥ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតាសួគ៌ ។

- តើកិច្ចការមួយចំនួនដែលយើងត្រូវធ្វើ ដើម្បីបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌មានអ្វីខ្លះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់គោលការណ៍មួយដែលស្រដៀងនឹងគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងធ្វើតាមការបង្រៀន និង ព្រះបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះ យើងអាចបានគ្រប់លក្ខណ៍ ដូចជាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌**) ។

សូមរំឭកសិស្សថា មានតែតាមរយៈព្រះយេស៊ូវគ្រីស្ទ និង ព្រះគុណរបស់ទ្រង់ប៉ុណ្ណោះទើបយើងអាចបានគ្រប់លក្ខណ៍ (សូមមើល ម៉ូរ៉ូណៃ ១០:៣២) ។

ដើម្បីជួយសិស្សឲ្យយល់ពីដំណើរការនៃការបានគ្រប់លក្ខណ៍ សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ វ៉ាសុល អិម ណាំលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ឲ្យឮៗ ៖

« យើងពុំចាំបាច់ស្រងាកចិត្តទេ បើកិច្ចខិតខំដ៏ខ្លាំងបំផុតរបស់យើងទៅកាន់ភាពល្អឥតខ្ចោះ ក្នុងពេលនេះមើលទៅហាក់ដូចជា [ពិបាក] ក្រៃលែង ឬគ្មានទីបញ្ចប់នោះ ។ ភាពឥតខ្ចោះគឺនៅរង់ចាំការសម្រេច ។ វាអាចបានមកពេញលេញ មានតែបន្ទាប់ពីដំណើរការឡើងវិញ និង តាមរយៈព្រះអម្ចាស់ប៉ុណ្ណោះ ។ វាកំពុងរង់ចាំពួកអ្នកទាំងអស់ណាដែលស្រឡាញ់ទ្រង់ និង រក្សាបទបញ្ញត្តិរបស់ទ្រង់ » (« Perfection Pending » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៨៨) ។

- យោងតាមអែលឌើរ ណាំលសុន តើយើងនឹងបានគ្រប់លក្ខណ៍នៅពេលណា ?
- តើសេចក្តីថ្លែងការណ៍នេះអាចជួយមនុស្សម្នាក់ ដែលមានអារម្មណ៍ថាលើសលុប ហើយបាក់ទឹកចិត្ត ដោយសារតែភាពមិនគ្រប់លក្ខណ៍របស់ខ្លួនដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យបន្តគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ដើម្បីនៅទីបំផុតពួកគេអាចបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ១–៥ (មេរៀនទី ២)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ាថាយ ១– ៥ (មេរៀនទី ២) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាថាយ ១–២)

នៅពេលសិស្សបានសិក្សាអំពីពង្សាវតាររបស់ព្រះអង្គសង្គ្រោះ នោះពួកគេបានរៀន ថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះវរបិតាសួគ៌ និង ម៉ារា ។ នៅក្នុងគំរូរបស់ ពួកហោរាដែលបានមកថ្វាយបង្គំព្រះយេស៊ូវ សិស្សបានរៀនថា ប្រសិនបើយើងស្វែងរក ព្រះអង្គសង្គ្រោះដោយស្មោះ និង ដោយឧស្សាហ៍ នោះយើងនឹងត្រូវបានដឹកនាំទៅរកទ្រង់ ។ ការអានអំពីរបៀបដែលយ៉ូសែប ត្រូវបានបំផុសឲ្យនាំគ្រួសារគាត់ភៀសខ្លួន ចេញទៅស្រុកអេស៊ីព្ទដើម្បីមានសុវត្ថិភាព សិស្សបានរកឃើញថា ប្រសិនបើយើងបន្ទន់ចិត្តយើងទៅតាមព្រះវិញ្ញាណ នោះយើងអាចទទួលបននវិវរណៈ និង ការដឹកនាំ ។

ថ្ងៃទី ២ (ម៉ាថាយ ៣)

នៅពេលសិស្សអានអំពី យ៉ូហាន បាទីស្ទ និង ពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវគ្រីស្ទ ពួកគេបានរៀនពីសេចក្តីពិតដូចខាងក្រោម ។ យើងបង្ហាញការប្រែចិត្តពិតចំពោះ ព្រះអម្ចាស់ នៅពេលយើងផ្លាស់ប្តូរបំណងប្រាថ្នា និង ទង្វើរបស់យើងដើម្បីធ្វើតាមការ បង្រៀនរបស់ទ្រង់ ។ បុណ្យជ្រមុជទឹកដោយការពន្លិចដោយបុគ្គលម្នាក់ដែលកាន់សិទ្ធិ អំណាច គឺជារឿងដ៏ចាំបាច់សម្រាប់សេចក្តីសង្គ្រោះ ។ ព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ គឺជាតួអង្គបីអង្គដាច់ដោយឡែកពីគ្នា ។

ថ្ងៃទី ៣ (ម៉ាថាយ ៤)

នៅពេលសិស្សអានពីបន្ទូលឆ្លើយតបរបស់ព្រះអង្គសង្គ្រោះទៅនឹងការល្បួងរបស់អារក្ស ពួកគេបានរៀនថា នៅពេលយើងនឹកចាំ ហើយអនុវត្តសេចក្តីពិតដែលបានបង្រៀននៅ ក្នុងព្រះគម្ពីរ យើងអាចតតាំងនឹងការល្បួងរបស់អារក្សបាន ។ ពួកគេក៏បានរៀនដែរថា ព្រះយេស៊ូវគ្រីស្ទនាំយកពន្លឺចូលទៅក្នុងជីវិតរបស់ជនដែលស្ថិតនៅក្នុងសេចក្តីងងឹត ។ នៅពេលសិស្សអានពី ពេត្រុស អនទ្រេ យ៉ាកុប និងយ៉ូហាន ពួកគេបានរកឃើញសេចក្តី ពិតដូចខាងក្រោមនេះ ៖ ប្រសិនបើយើងឆ្លើយតបភ្លាមៗចំពោះការអញ្ជើញរបស់ ព្រះអង្គសង្គ្រោះឲ្យដើរតាមទ្រង់ ទ្រង់អាចធ្វើឲ្យជីវិតយើងបានប្រសើរជាង ។

ថ្ងៃទី ៤ (ម៉ាថាយ ៥)

នៅក្នុងមេរៀននេះសិស្សអានផ្នែកមួយនៃទេសនកថារបស់ព្រះអង្គសង្គ្រោះនៅលើភ្នំ ។ នៅក្នុងទេសនកថានេះ ពួកគេបានរៀនពីសេចក្តីពិតដូចខាងក្រោម ៖ នៅពេលយើង អភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ នោះយើងនឹងកាន់តែកេរឃើញសុភមង្គល ។ ការមាន ភាពកខ្វក់ដោយអំពើបាបនៃលោកិយអាចរារាំងយើងពីការធ្វើជាពរជ័យមួយសម្រាប់ មនុស្សដទៃទៀត ។ គំរូសុចរិតរបស់យើងអាចលើកទឹកចិត្តមនុស្សដទៃទៀតឲ្យខិតទៅ ជិតព្រះវរបិតាសួគ៌ ។ សិស្សក៏បានរៀនផងដែរពីក្រឹត្យវិន័យខ្ពង់ខ្ពស់ដែលព្រះយេស៊ូវ គ្រីស្ទបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់ពីអ្វីដែលយើងត្រូវធ្វើ ដើម្បីបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតា យើងដែលគង់នៅស្ថានសួគ៌ ។ លើសពីនេះទៀត នៅពេលសិស្សមើលក្រឹត្យវិន័យខ្ពង់ខ្ពស់របស់ ព្រះអម្ចាស់ឡើងវិញ ពួកគេអាចត្រិះរិះពីរបៀបដើម្បីកែលម្អរបៀបដែលពួកគេគោរពតាមព្រះបញ្ញត្តិ របស់ព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៥:១៧–៤៨

ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់ពីរបៀបឲ្យបានគ្រប់លក្ខណ៍ដូចជា ព្រះវរបិតាសួគ៌

សូមសរសេរសំណួរខាងក្រោមនេះ នៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ *តើព្រះបញ្ញត្តិមួយ ណាដែលអ្នកគិតថាមនុស្សពិបាកគោរពតាមជាងគេបំផុត ?* នៅពេលថ្នាក់ចាប់ផ្តើម សុំឲ្យសិស្ស ឆ្លើយតបទៅនឹងសំណួរនេះ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៤៨ ឲ្យឮៗ ។ ចុះសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល ព្រះបញ្ញត្តិមួយដែលពិបាកគោរពតាម ។ អ្នកគួរអានការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ ម៉ាថាយ ៥:៤៨ *ដែលចែងថា* « ដូច្នេះអ្នករាល់គ្នាត្រូវបានបង្គាប់ឲ្យគ្រប់លក្ខណ៍ ដូចព្រះវរបិតា នៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍ដែរ » ។

- តើព្រះបញ្ញត្តិឲ្យបានគ្រប់លក្ខណ៍ធ្វើឲ្យយើងមានអារម្មណ៍បែបណាដែរ ?
- តើអ្នកគិតថា ភាពគ្រប់លក្ខណ៍មានន័យដូចម្តេច ?

សូមពន្យល់ថា ពាក្យ « គ្រប់លក្ខណ៍ » ត្រូវបានបកប្រែចេញពីពាក្យក្រិកមួយពាក្យដែលមានន័យ ថា ឬ សុំឲ្យសិស្សអាន « បង្គើយ »« *បញ្ចប់* » ឬ « *បានអភិវឌ្ឍយ៉ាងពេញលេញ* » ។ សូមសួរ សិស្សពីរបៀបដែលសេចក្តីពន្យល់នេះជួយពួកគេឲ្យយល់ពីខគម្ពីរនេះកាន់តែប្រសើរឡើង ។ សូម ពន្យល់ថាដើម្បីឲ្យក្លាយទៅជាពេញលេញ ឬត្រូវបានបានអភិវឌ្ឍយ៉ាងពេញលេញនោះមានន័យថា ការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ។

នៅពេលសិស្សបន្តការសិក្សាអំពីទេសនកថានៅលើភ្នំរបស់ព្រះអង្គសង្គ្រោះក្នុង ម៉ាថាយ ៥សុំឲ្យ ពួកគេរកមើលគោលការណ៍ដែលពួកគេត្រូវធ្វើតាម ដើម្បីបានចម្រើនឡើងឆ្ពោះទៅកាន់ភាពបាន គ្រប់លក្ខណ៍ដូចជាព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ។

សូមសង្ខេប ម៉ាថាយ ៥:១៧–២០ ដោយពន្យល់ថាព្រះអង្គសង្គ្រោះបានបង្រៀនថា ទ្រង់បាន យាងមកដើម្បីបំពេញក្រឹត្យវិន័យរបស់លោកម៉ូសេ ពុំមែនយាងមកដើម្បីបំផ្លាញ ឬលុបបំបាត់ ចោលសេចក្តីពិតដ៏នៅអស់កល្បជានិច្ចណាមួយ នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ ។ ព្រះយេស៊ូវគ្រីស្ទបានស្តារឡើងវិញនូវភាពពោរពេញនៃដំណឹងល្អដែលបានបាត់បង់ដោយសារតែ អំពើទុច្ចរិត និង ការក្បត់សាសនា ទ្រង់បានកែតម្រូវការការបង្រៀនខុសឆ្គង ហើយបានបំពេញការ ព្យាការដែលបានធ្វើឡើងដោយពួកព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ នៅទីបំផុត ដោយសារជា ផ្នែកមួយនៃការស្តារភាពពោរពេញនៃដំណឹងល្អឡើងវិញ កត្តាមួយចំនួននៃក្រឹត្យវិន័យរបស់លោក ម៉ូសេត្រូវបានបញ្ឈប់ ដូចជាការកាត់ស្បែក និង ការបូជាសត្វ ។

សូមពន្យល់ថា ម៉ាថាយ ៥:២១–៤៨ រួមបញ្ចូលទាំងការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពី ក្រឹត្យវិន័យ និង ទំនៀមទម្លាប់នានាដែលពួកសាសន៍យូដាបានបង្កើត ឬបន្ថែមទៅក្នុងក្រឹត្យវិន័យ របស់លោកម៉ូសេ ។ នៅពេលព្រះយេស៊ូវគ្រីស្ទបានពន្យល់ពីអត្ថន័យពិតនៃក្រឹត្យវិន័យនោះ ទ្រង់ បានបង្រៀនពីរបៀបដ៏ខ្ពង់ខ្ពស់មួយនៃសេចក្តីសុចរិត ។ សមាជិកនៃនគររបស់ទ្រង់ត្រូវរស់នៅតាម ក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់នេះ ។ ក្រឹត្យវិន័យដ៏ខ្ពស់ទាំងនេះបានផ្តល់ការដឹកនាំដើម្បីជួយពួកសិស្ស របស់ព្រះយេស៊ូវគ្រីស្ទឲ្យចៀសវាងពីការបំពានព្រះបញ្ញត្តិរបស់ព្រះ ។

ដើម្បីជួយសិស្សឲ្យនឹកចាំពីរឿងមួយចំនួន ដែលពួកគេបានរៀនពីក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់នៅក្នុង មេរៀនសិក្សានៅផ្ទះរបស់ពួកគេ អ្នកគួរសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖ *កុំឲ្យសម្លាប់ មនុស្សឲ្យសោះ។ កុំឲ្យផិតគ្នាឲ្យសោះ។*

សុំឲ្យសិស្សពន្យល់ពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ពីក្រឹត្យវិន័យទាំងនេះ ។ (ប្រសិនបើសិស្សមិនចាំ សុំឲ្យពួកគេបើកទៅ ម៉ាថាយ ៥:២១–២៦ និង ម៉ាថាយ ៥:២៧–៣០តាមលំដាប់លំដោយ) ។

- តើគ្រោះថ្នាក់ណាខ្លះដែលអាចកើតមានឡើង ដោយសារតែការពុំអាចគ្រប់គ្រងកំហឹងរបស់យើងបាន ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីគ្រប់គ្រងគំនិតរបស់យើង ?

សូមសង្ខេប ម៉ាថាយ ៥:៣១–៣៧ ដោយពន្យល់ថា ព្រះអម្ចាស់បានបង្រៀនអំពីការលែងលះ អាពាហ៍ពិពាហ៍ និង ការធ្វើសម្បថ ។

សូមអញ្ជើញសិស្សនឹកស្រមៃថា មានមិត្តម្នាក់នៅសាលាបាននិយាយរឿងដ៏អាក្រក់អំពីពួកគេ ។ សូមសួរទៅសិស្សថាតើពួកគេនឹងឆ្លើយតបយ៉ាងណា ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៣៨ ឲ្យឮៗ ។ ចុះសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលក្រឹត្យវិន័យរបស់លោកម៉ូសេបានបង្រៀនអំពីការដាក់ទោសចំពោះបុគ្គលដែលប្រព្រឹត្តអំពើបាប ឬកំហុស ។ សូមអញ្ជើញឲ្យពួកគេប្រាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមពន្យល់ថាឃ្លា « ភ្នែកឲ្យធួននឹងភ្នែក ហើយធ្មេញឲ្យធួននឹងធ្មេញ » មានន័យថា នៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ការដាក់ទោសត្រូវតែសក្តិសមនឹងទម្ងន់ទោសនោះ ។

សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញដៃគូម្នាក់អាន ម៉ាថាយ ៥:៣៩–៤២ ហើយឲ្យដៃគូម្នាក់ទៀតអាន ម៉ាថាយ ៥:៤៣–៤៧ ។ ចុះសុំឲ្យពួកគេរកមើលក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់ ។ លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូខ្លួន (អ្នកគួរសរសេរសំណួរទាំងនេះនៅលើ ក្តារខៀន ឬចែកឯកសារឲ្យពួកគេ) ៖

យោងតាមព្រះអង្គសង្គ្រោះ តើក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់គឺជាអ្វីទៅ ?

តើក្រឹត្យវិន័យដ៏ខ្ពង់ខ្ពស់នេះបង្រៀនយើងអ្វីខ្លះ ពីរបៀបដែលយើងគួរធ្វើដាក់ជនដែលធ្វើឲ្យយើងអាក់អន់ចិត្ត ?

លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សដទៃ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៥:៤៥ ឲ្យឮៗ ។ ចុះសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាតើអ្វីនឹងកើតឡើង ប្រសិនបើយើងស្រឡាញ់សត្រូវរបស់យើង ហើយធ្វើល្អដាក់ជនដែលស្អប់យើង ។

- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងស្រឡាញ់សត្រូវរបស់យើង ហើយធ្វើល្អដាក់ជនដែលស្អប់យើង ?
- ដោយដឹងថា យើងទាំងអស់គ្នាគឺជាកូនចៅវិញ្ញាណរបស់ព្រះ តើអ្នកគិតថាការធ្វើជាកូនចៅនៃព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌នៅក្នុងខគម្ពីរនេះមានន័យដូចម្តេច ? (វាមានន័យថាការក្លាយដូចជាទ្រង់ ហើយក្លាយជាអ្នកគ្រងនគររបស់ទ្រង់) ។

- តើព្រះអង្គសង្គ្រោះបានបង្ហាញគំរូពីការស្រឡាញ់ពួកសត្រូវរបស់ទ្រង់ និង ការធ្វើល្អដល់អ្នកដទៃនៅក្នុងជីវិតរមែងស្លាប់របស់ទ្រង់ដោយរបៀបណា ?

សូមអញ្ជើញពួកសិស្សសញ្ជឹងគិតពីអ្វីដែលពួកគេបានរៀននៅក្នុង ម៉ាថាយ ៥ អំពីអ្វីដែលយើងត្រូវធ្វើ ដើម្បីបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតាសួគ៌ ។

- តើកិច្ចការមួយចំនួនដែលយើងត្រូវធ្វើដើម្បីបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌មានអ្វីខ្លះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរស្គាល់គោលការណ៍មួយដែលស្រដៀងនឹងគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងធ្វើតាមការបង្រៀន និងព្រះបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះ យើងអាចបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌**) ។

សូមរំឭកសិស្សថា មានតែតាមរយៈព្រះយេស៊ូវគ្រីស្ទ និង ព្រះគុណរបស់ទ្រង់ប៉ុណ្ណោះទេ ទើបយើងអាចបានគ្រប់លក្ខណ៍ (សូមមើល មរ៊ូណៃ ១០:៣២) ។

ដើម្បីជួយសិស្សឲ្យយល់ពីដំណើរការនៃការបានគ្រប់លក្ខណ៍ សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ វ៉ែសុល អិម ណិលសុន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« យើងពុំចាំបាច់ស្រងាកចិត្តទេ បើកិច្ចខិតខំដ៏ស្មោះបំផុតរបស់យើងទៅកាន់ភាពល្អឥតខ្ចោះ ក្នុងពេលនេះមើលទៅហាក់ដូចជា [ពិបាក] ក្រៃលែង ឬគ្មានទីបញ្ចប់នោះ ។ ភាពឥតខ្ចោះគឺកំពុងនៅរង់ចាំ ។ វាអាចបានពេញលេញ មានតែបន្ទាប់ពីដំណើរការរស់ឡើងវិញ និង តាមរយៈព្រះអម្ចាស់ប៉ុណ្ណោះ ។ វាកំពុងរង់ចាំពួកអ្នកទាំងអស់ណាដែលស្រឡាញ់ទ្រង់ និង រក្សាបទបញ្ញត្តិរបស់ទ្រង់ » (« Perfection Pending » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៨៨) ។

- យោងតាមអែលឌើរ ណិលសុន តើយើងនឹងបានគ្រប់លក្ខណ៍នៅពេលណា ?
- តើសេចក្តីថ្លែងការណ៍នេះអាចជួយមនុស្សម្នាក់ដែលមានអារម្មណ៍ថាលើសលុប ហើយបាក់ទឹកចិត្តដោយសារតែភាពមិនគ្រប់លក្ខណ៍របស់ខ្លួនដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យបន្តគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ដើម្បីនៅទីបំផុតពួកគេអាចបានគ្រប់លក្ខណ៍ដូចជាព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ។

មេរៀនបន្ទាប់ (ម៉ាថាយ ៦:១–១៣:២៣)

ដើម្បីជួយរៀបចំខ្លួនសិស្សសម្រាប់មេរៀនបន្ទាប់ សុំឲ្យពួកគេត្រិះរិះពីសំណួរដូចតទៅ ៖ តើក្រឹត្យវិន័យមាសគឺជាអ្វី ? តើព្រះអម្ចាស់បានបង្រៀនអ្វីខ្លះ ស្តីពីការថ្កោលទោសអ្នកដទៃ ? តើមានអ្វីកើតឡើងចំពោះជនដែលបម្រើចៅហ្វាយពីរ ? តើមនុស្សត្រូវធ្វើអ្វីខ្លះដើម្បីឲ្យព្រះអង្គសង្គ្រោះព្យាបាល ? សូមពន្យល់ថានៅក្នុងមេរៀនបន្ទាប់ សិស្សនឹងមានឱកាសរៀនពីចម្លើយចំពោះសំណួរទាំងនេះ ហើយរៀនអំពីការៈរបស់ព្រះអង្គសង្គ្រោះចំពោះពួកសាវករបស់ទ្រង់ ។

មេរៀន ១១

ម៉ាថាយ ៦

សេចក្តីផ្តើម

ព្រះយេស៊ូវបានបន្តទេសនាកថានៅលើភ្នំ ។ ទ្រង់បានបង្រៀនថាទង្វើសុចរិតនៃការលះបង់គួរធ្វើឡើងសម្រាប់ហេតុផលត្រឹមត្រូវ ហើយបានគូសបញ្ជាក់ថា វាគួរត្រូវបានធ្វើឡើង ដើម្បីបំពេញតាមព្រះហឫទ័យព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ។ ទ្រង់ក៏បានបង្គាប់ពួកសិស្សរបស់ទ្រង់ឲ្យខិតខំស្តាប់បនានគព្រះជាមុនសិន ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៦:១–១៨

ព្រះអង្គសង្គ្រោះបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យធ្វើកិច្ចការសុចរិត

សូមយករង្វាន់តូចមួយមកកាន់ថ្នាក់ (ដូចជាស្ករគ្រាប់) ។ នៅពេលសិស្សបានមកដល់ ហើយអ្នកឃើញពួកគេធ្វើអ្វីមួយដែលល្អ(ដូចជា ការដកព្រះគម្ពីរពួកគេចេញមក ការនិយាយរាក់ទាក់ទៅកាន់មនុស្សម្នាក់ ឬជួយរៀបចំការប្រជុំធម្មនិដ្ឋាន) សូមឲ្យរង្វាន់ពួកគេ ហើយប្រកាសពីទង្វើល្អរបស់ពួកគេចំពោះសិស្សក្នុងថ្នាក់ ។ សិស្សមួយចំនួនអាចធ្វើតាមទង្វើល្អរបស់មិត្តខ្លួន ដើម្បីទទួលបានរង្វាន់របស់ពួកគេ ។ សូមបន្តឲ្យរង្វាន់សិស្សរហូតដល់ពេលថ្នាក់ចាប់ផ្តើម ។

ដើម្បីចាប់ផ្តើមថ្នាក់ សូមសួរសិស្សពីហេតុផលដែលអ្នកបានផ្តល់រង្វាន់ដល់ពួកគេដោយសារទង្វើល្អដែលពួកគេបានធ្វើ ។ សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង ម៉ាថាយ ៦ព្រះអង្គសង្គ្រោះបានបន្តធ្វើទេសនកថារបស់ទ្រង់នៅលើភ្នំ ហើយបានបង្រៀនពីការជំរុញចិត្តខុសៗគ្នាដែលបុគ្គលម្នាក់អាចមានសម្រាប់ការធ្វើទង្វើសុចរិត ។ នៅពេលសិស្សសិក្សា ម៉ាថាយ ៦សុំឲ្យពួកគេរកមើលគោលការណ៍ដែលអាចជួយពួកគេ ឲ្យធ្វើទង្វើសុចរិតសម្រាប់មូលហេតុដ៏ត្រឹមត្រូវ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៦:១–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះមានបន្ទូលថាជាពុំត្រឹមត្រូវសម្រាប់ការធ្វើទង្វើដ៏សុចរិតនានា ។ (សូមចង្អុលបង្ហាញថា ការធ្វើទានគឺជាទង្វើនៃការលះបង់ខាងសាសនា ដូចជាការធ្វើទានដល់អ្នកក្រីក្រ) ។

- យោងតាមខគម្ពីរទាំងនេះ ហេតុអ្វីមនុស្សមួយចំនួនធ្វើទាន ?
- តើព្រះអង្គសង្គ្រោះបានហៅមនុស្សទាំងនេះជាអ្វីទៅ ? (អ្នកគួរចង្អុលបង្ហាញថា ពាក្យក្រិកដែលបកប្រែមកថាជា « ពួកមនុស្សលាក់ពុត » សំដៅទៅលើជនដែលក្លែងបន្លំ ។
- តើអ្នកគិតថាឃ្លា « គេបានរង្វាន់គេហើយ » មានអត្ថន័យដូចម្តេចដែរ ?

សូមសិស្សម្នាក់អាន ម៉ាថាយ ៦:៣–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនពីរបៀបដែលពួកសិស្សរបស់ទ្រង់គួរធ្វើទង្វើសុចរិត ។

- ហេតុអ្វីអ្នកគិតថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកសិស្សរបស់ទ្រង់ធ្វើការបម្រើ « ដោយសម្ងាត់ » ?
- តើការធ្វើទង្វើសុចរិតដោយសម្ងាត់បង្ហាញអ្វីខ្លះពីការលើកទឹកចិត្តរបស់បុគ្គលម្នាក់ក្នុងការធ្វើកិច្ចការទាំងនោះ ? (គាត់ចង់ធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ ហើយបម្រើដល់អ្នកដទៃជាជាងការទាមទារចំណាប់អារម្មណ៍ពីមនុស្សដទៃ) ។
- តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះ ដល់ជនដែលបានធ្វើទង្វើសុចរិតសម្រាប់ហេតុផលត្រឹមត្រូវ ?
- តើយើងអាចរៀន គោលការណ៍ អ្វីខ្លះមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការធ្វើទង្វើនៃការលះបង់ ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **ប្រសិនបើយើងធ្វើទង្វើនៃការលះបង់ ដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យជាជាងទាមទារចង់បានចំណាប់អារម្មណ៍ពីមនុស្សដទៃ នោះទ្រង់នឹងប្រទានរង្វាន់ដល់យើងយ៉ាងធំធេង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើការដែលព្រះវរបិតាសួគ៌នឹងប្រទានរង្វាន់ដល់យើងយ៉ាងធំធេងមានន័យយ៉ាងណាដែរចំពោះយើង ?

សូមចាត់តាំងឲ្យសិស្សធ្វើការជាគូៗ ។ សូមអញ្ជើញសិស្សម្នាក់នៅក្នុងក្រុមនីមួយៗអានម៉ាថាយ ៦:៥–៦ ហើយសិស្សម្នាក់ទៀតអានម៉ាថាយ ៦:១៦–១៨ ។ ចូរសុំឲ្យសិស្សម្នាក់រកមើលឧទាហរណ៍មួយដែលព្រះអង្គសង្គ្រោះបានប្រើ ដើម្បីបង្ហាញពីគោលការណ៍នៃការធ្វើទង្វើសុចរិតដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ ។ ចូរសុំឲ្យពួកគេចែកចាយជាមួយនឹងគ្នាពីអ្វីដែលពួកគេបានរកឃើញ ។ បន្ទាប់មក សូមសួរសិស្ស ៖

- នៅក្នុងបទគម្ពីរវគ្គនេះ តើការអនុវត្តខាងសាសនាមួយណាដែលព្រះយេស៊ូវបានគូសបញ្ជាក់ថាវាគួរធ្វើឡើងដោយសម្ងាត់ ?

សូមធ្វើឲ្យប្រាកដថាសិស្សយល់ថា ការអធិស្ឋានជាសាធារណៈពុំមែនជារឿងខុសឆ្គងនោះទេ ប៉ុន្តែគ្រាន់តែវាពុំបានធ្វើឡើងដោយសម្ងាត់ប៉ុណ្ណោះ ។ ការអធិស្ឋាន និង ការអនុវត្តខាងសាសនាផ្សេងទៀតអាចធ្វើឡើងជាសាធារណៈ ប្រសិនបើវាត្រូវបានធ្វើឡើងដោយភាពស្មោះត្រង់ និងការលះបង់ ។

- យោងទៅតាមខគម្ពីរដែលអ្នកបានសិក្សា តើហេតុអ្វីបានជាពួកមនុស្សលាក់ពុតអធិស្ឋាន ហើយតមអាហារ ?

សូមជួយសិស្សឲ្យរៀនស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

គោលបំណងដ៏សំខាន់មួយនៃការសិក្សាព្រះគម្ពីរ គឺដើម្បីរៀនពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ការស្គាល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៅក្នុងព្រះគម្ពីរ គឺជាមូលដ្ឋានគ្រឹះនៃការបង្រៀន និង ការរៀនសូត្រពីដំណឹងល្អ ។ ការរៀនសូត្រពីរបៀបដើម្បីស្គាល់ វាតម្រូវឲ្យមានការខិតខំ និង ការអនុវត្តយ៉ាងខ្លាំង ។ នៅពេលអ្នកជួយសិស្សឲ្យស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ សូមធ្វើឲ្យប្រាកដថា ត្រូវជួយពួកគេឲ្យថ្លែងពីសេចក្តីពិតទាំងនេះឲ្យច្បាស់ ហើយសាមញ្ញ ដើម្បីឲ្យប្រាកដថាពួកគេយល់ពីវា ។

អ្នកគួរពន្យល់ថាឃ្លា « ធ្វើទឹកមុខក្រៀម » ហើយ « គេកែលទឹកមុខស្រងូត » ក្នុង ខទី ១៦ បានសំដៅទៅលើបុគ្គលដែលបង្ហាញទិដ្ឋភាពខាងក្រៅនៃការតមអាហាររបស់ពួកគេ ដើម្បីទាមទារចំណាប់អារម្មណ៍របស់អ្នកដទៃ ។

សូមយោងទៅគោលការណ៍នៅលើក្តារខៀនម្តងទៀត ។ សូមអញ្ជើញសិស្សគិតពីគ្រាមួយដែលពួកគេបានធ្វើទង្វើនៃការលះបង់—ដូចជាការអធិស្ឋាន ឬការតមអាហារ—ដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ ។ ចូរសុំឲ្យពួកគេសញ្ជឹងគិតពីអារម្មណ៍ថាមានពរដែលពួកគេធ្លាប់ដោយសារតែការថ្វាយបង្គំដោយស្មោះត្រង់របស់ពួកគេ ។ អ្នកអាចសុំសិស្សពីរបីនាក់ឲ្យចែកចាយពរជ័យដែលពួកគេបានទទួលប្រសិនបើពួកគេគិតថាអាចចែកចាយបាន ។

សូមសង្ខេប ម៉ាថាយ ៦:៧–១៥ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រទានសេចក្តីបង្គាប់ និង គំរូមួយពីរបៀបអធិស្ឋានដ៏ត្រឹមត្រូវ ។ គំរូរបស់ទ្រង់ផ្តាល់ពីការអធិស្ឋានត្រូវបានរាប់ទុកថាជាការអធិស្ឋានរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សមើលខគម្ពីរទាំងនេះឡើងវិញដោយសង្ខេប រកមើលអ្វីដែលយើងអាច រៀនពីការអធិស្ឋានតាមរយៈគំរូរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ (ជាផ្នែកមួយនៃការពិភាក្សានេះ អ្នកគួរពន្យល់ថាការព្រមានរបស់ព្រះអម្ចាស់ទាស់នឹង « ភាពច្រំដែលៗ » ពុំសំដៅទាំងស្រុងលើការទន្ទានទាស់នឹងការប្រើពាក្យដូចគ្នា ឬស្រដៀងគ្នារាល់ពេលដែលយើងអធិស្ឋាននោះឡើយ ។ ព្រះអម្ចាស់ក៏ព្រមានទាស់នឹងការអធិស្ឋានដែលចេះតែពោលដោយគ្មានការគិត ពោលរឿងមិនសំខាន់ ឬគ្មានន័យដែរ ។ ការអធិស្ឋានរបស់យើងគួរមានការបន្ទាបខ្លួនចេញពីចិត្ត ហើយបង្ហាញសេចក្តីជំនឿ) ។

ម៉ាថាយ៦ :១៩–២៤

ព្រះយេស៊ូវគ្រីស្ទបង្រៀនហ្វូងមនុស្សឲ្យទុកទ្រព្យសម្បត្តិខ្លួនឯងនៅឯស្ថានសួគ៌វិញ



សូមបង្ហាញរូបភាបទ្រព្យសម្បត្តិមួយ ។ សូមពន្យល់ថា ទ្រព្យសម្បត្តិគឺជាអ្វីៗដែលយើងឲ្យតម្លៃយ៉ាងធំធេង ។

- តើអ្វីមួយដែលអ្នកគិតថាជាទ្រព្យសម្បត្តិនោះវាគឺជាអ្វីទៅ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៦:១៩–២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីទ្រព្យសម្បត្តិ ។

- តើទ្រព្យសម្បត្តិប្រភេទណាខ្លះ ដែលព្រះអង្គសង្គ្រោះបានបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យស្វែងរក ?
- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាទ្រព្យសម្បត្តិ ដែលទុកនៅលើផែនដី និង ទ្រព្យសម្បត្តិដែលទុកនៅស្ថានសួគ៌ខុសគ្នាដូចម្តេចខ្លះ ?

សូមសរសេរប្រយោគខាងក្រោមនេះនៅលើ ក្តារខៀន ៖

ទ្រព្យសម្បត្តិនៅលើផែនដី *ទ្រព្យសម្បត្តិនៅស្ថានសួគ៌*

សូមអញ្ជើញសិស្សឲ្យឡើងមកក្តារខៀន ហើយសរសេរឧទាហរណ៍ពីទ្រព្យសម្បត្តិនៅលើផែនដី និង ទ្រព្យសម្បត្តិនៅស្ថានសួគ៌ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៦:២២–២៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀន ដែលវាអាចជួយយើងឲ្យទុកទ្រព្យសម្បត្តិនៅស្ថានសួគ៌ ។

- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះនៅក្នុង ខទី ២២–២៣ ដែលអាចជួយយើងឲ្យរក្សាទុកទ្រព្យសម្បត្តិនៅស្ថានសួគ៌ ? (សូមចង្អុលបង្ហាញថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ ខទី ២២ អានថា « បើសិនជាភ្នែករបស់អ្នកស្មោះស្ម័គ្រទាំងស្រុងទៅចំពោះសិរីល្អនៃព្រះ » ។ អ្នកគួរពន្យល់សិស្សថា កិច្ចការ និងសិរីល្អរបស់ព្រះគឺដើម្បី « នាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » [ម៉ូសេ ១:៣៩]) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីឲ្យភ្នែករបស់យើងស្មោះស្ម័គ្រទាំងស្រុងទៅចំពោះសិរីល្អនៃព្រះ ?
- តើព្រះអង្គសង្គ្រោះបានបង្រៀនសេចក្តីពិតអ្វីខ្លះនៅចុងបញ្ចប់នៃ ខទី ២៤ ដែលអាចជួយយើងឲ្យចងចាំដើម្បីរក្សាទុកទ្រព្យសម្បត្តិនៅស្ថានសួគ៌ ? (សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **យើងពុំអាចបម្រើទាំងព្រះ និង ទ្រព្យសម្បត្តិក្នុងពេលតែមួយបានទេ ។** សូមពន្យល់ថាពាក្យ *ទ្រព្យសម្បត្តិ* សំដៅលើការទ្រព្យធន) ។
- តើអ្នកគិតថា ការ« បម្រើ » ទ្រព្យសម្បត្តិ វាមានន័យដូចម្តេច ? (ការដាក់ដួងចិត្តយើងលើទ្រព្យខាងលោកិយ តាមរបៀបដែលដឹកនាំយើងឲ្យឃ្លាតឆ្ងាយពីព្រះ) ។

ដើម្បីឆ្លុះបញ្ចាំងពីសេចក្តីពិតដែលសិស្សបានស្គាល់នៅក្នុង ម៉ាថាយ ៦:២៤សូមបិទបំពង់បឺតពីរតជាប់គ្នា ។ សូមដាក់បង្ហាញពែងទឹកមួយដែលមានទឹកពាក់កណ្តាល ហើយដាក់បំពង់បឺតមួយចូលទៅក្នុងពែងនោះ ហើយមួយទៀតនៅក្រៅពែង ។ សូមអញ្ជើញសិស្សម្នាក់សាកល្បងបឺតទឹកដោយប្រើបំពង់បឺតទាំងពីរ ។ (សូមធ្វើឲ្យប្រាកដថា សិស្សបឺតដំណាលគ្នាចេញ ពីបំពង់បឺតទាំងពីរដើម្បីគោលបំណងរបស់មេរៀនអាចសម្រេចបាន) ។ បន្ទាប់មក សូមសួរសិស្សនោះ ៖

- ហេតុអ្វីបួនពិបាកបឺតទឹកម្ល៉ះ ?

សូមសួរសិស្ស ៖

- ប្រសិនបើបំពង់បឺតតំណាងឲ្យយើង តើទឹកតំណាងឲ្យអ្វីទៅ ? (ការខិតខំរបស់យើងដើម្បីបម្រើព្រះ) ។
- ហេតុអ្វីអ្នកគិតថា យើងពុំអាចបម្រើព្រះ និង ទ្រព្យសម្បត្តិក្នុងពេលតែមួយបាន ? (សូមមើលផងដែរ យ៉ាកុប ១:៨) ។
- តើយើងត្រូវធ្វើអ្វីខ្លះជាមួយនឹងបំពង់បឺតដើម្បីអាចបឺតទឹកបាន ? តើវាពាក់ព័ន្ធនឹងការខិតខំរបស់យើងដើម្បីបម្រើព្រះយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីចម្លើយរបស់ពួកគេចំពោះសំណួរខាងក្រោមនេះ ។ អ្នកគួរឲ្យសិស្សកត់ត្រាចម្លើយរបស់ពួកគេ នៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

- នៅក្នុងជីវិតរបស់អ្នក តើឧទាហរណ៍មួយនៃរបៀបដាក់ដួងចិត្តអ្នកលើរឿងលោកិយអាចអូសទាញអ្នកចេញពីការបម្រើព្រះ និងការរក្សាទុកទ្រព្យសម្បត្តិនៅស្ថានសួគ៌គឺជាអ្វីទៅ ?

ម៉ាថាយ ៦:២៥–៣៤

ព្រះអង្គសង្គ្រោះបានបង្គាប់ពួកសិស្សរបស់ទ្រង់ឲ្យស្វែងរកនគរព្រះជាមុនសិន

សូមសង្ខេប ម៉ាថាយ ៦:២៥–៣៤ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្គាប់ពួកសិស្សរបស់ទ្រង់ កុំឲ្យព្រួយបារម្ភពេកពីការផ្គត់ផ្គង់សម្រាប់សេចក្តីត្រូវការមូលដ្ឋានរបស់ពួកគេ ។ ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ ម៉ាថាយ ៦:២៥–២៧ ជួយយើងឲ្យយល់ថាព្រះអង្គសង្គ្រោះកំពុងមានបន្ទូលជាក់លាក់ដល់ជនដែលនឹងចេញទៅប្រកាសដំណឹងល្អរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៦:៣១–៣៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើព្រះអង្គសង្គ្រោះបានបង្រៀនឲ្យពួកសិស្សរបស់ទ្រង់ស្វែងរកអ្វីជាមុនសិននៅ ក្នុងជីវិតរបស់ពួកគាត់ ។ (សូមចង្អុលបង្ហាញពាក្យមកពីការបកប្រែដោយ យ៉ូសែប ស៊្មីធ នៅក្នុង ខ ៣៣) ។

- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះដល់ពួកសិស្សទ្រង់ឲ្យស្វែងរកជាមុនសិន ក្នុងជីវិតរបស់ពួកគាត់ ?
- តើព្រះយេស៊ូវគ្រីស្ទបានសន្យាអ្វីខ្លះដល់ជន ដែលកំពុងស្វែងរកស្ថាបនានគរព្រះ (ឬសាសនាចក្ររបស់ទ្រង់) ជាជាងការស្វែងរកទទួលបានរបស់ខាងលោកិយ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងស្វែងរកស្ថាបនានគរព្រះជាមុនសិន នោះទ្រង់នឹងប្រទានពរដល់យើង ជាមួយនឹងអ្វីដែលទ្រង់ជ្រាបថាយើងត្រូវការ**) ។

ដើម្បីជួយសិស្សឲ្យយល់គោលការណ៍នេះ សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន ឲ្យឮៗ ៖



« យើងត្រូវដាក់ព្រះពីមុខអ្វីៗទាំងអស់នៅក្នុងជីវិតរបស់យើង ។ . . .

« ពេលយើងទុកព្រះជាមុន នោះអ្វីៗទាំងអស់ផ្សេងទៀតចូលទៅក្នុងកន្លែងត្រឹមត្រូវរបស់វា ឬ ក៏ចេញពីជីវិតយើង ។ សេចក្តីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់ត្រូវបានបង្ហាញដោយមនោសញ្ចេតនារបស់យើង ដោយរបៀបដែលយើងចំណាយពេលវេលារបស់យើង ចំណូលចិត្តដែលយើងតាមរក និង លំដាប់លំដោយនៃអាទិភាពរបស់យើង ។

« យើងគួរដាក់ព្រះមុន *មនុស្សទាំងអស់* ក្នុងជីវិតយើង » (« The Great Commandment—Love the Lord » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៨ ទំព័រ ៤) ។

- តើអ្នកធ្លាប់ដកពិសោធន៍ពីពរជ័យរបស់ព្រះវរបិតាសួគ៌នៅពេលណាដែរ កាលអ្នកបានស្វែងរកដើម្បីដាក់ទ្រង់ដំបូងគេនៅក្នុងជីវិតរបស់អ្នក ?

សូមត្រិះរិះចែកចាយទីបន្ទាល់របស់អ្នកពីពរជ័យដែលកើតមានតាមរយៈការដាក់ព្រះវរបិតាសួគ៌ដំបូងគេនៅក្នុងជីវិតយើង ។

ជាថ្មីម្តងទៀត សូមអញ្ជើញសិស្សឲ្យពិចារណាដោយសង្ខេបពីរបៀបដែលពួកគេប្រហែលជាត្រូវបានល្បួងឲ្យដាក់ដួងចិត្តរបស់ពួកគេទៅលើទ្រព្យខាងលោកិយ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅមួយ ដើម្បីយកឈ្នះលើការល្បួងនេះដោយសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវវិធីមួយដែលពួកគេនឹងខិតខំដាក់ព្រះវរបិតាសួគ៌ដំបូងគេនៅក្នុងជីវិតរបស់ខ្លួន ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាថាយ ៦:២២ ។ « ដូច្នេះ បើភ្នែកអ្នកល្អ »

«ពាក្យ *ល្អ* ដែលប្រើនៅក្នុងខគម្ពីរនេះ ចេញមកពីពាក្យក្រិកមួយដែលមានន័យថា ‹ សំឡេងល្អ សុខភាពល្អ សាមញ្ញ ស្មោះត្រង់ › ។ ការដឹងពីនិយមន័យនេះជួយយើងឲ្យយល់ពី សេចក្តីបង្គាប់របស់ព្រះអង្គសង្គ្រោះស្តីពីការធ្វើទាន ការអធិស្ឋាន និង ការតមអាហារ ។ ការណ៍ទាំងនេះគួរធ្វើឡើងដោយការផ្តោតចិត្តជំសាមញ្ញ ហើយស្មោះត្រង់មួយទៅលើព្រះវរបិតាយើង ដែលគង់នៅស្ថានសួគ៌ ឬលើអ្នកទទួល ។ យើងអាចត្រិះរិះចំពោះសំណួរទាំងនេះដូចជា ៖

នៅពេលធ្វើទានដល់អ្នកក្រីក្រ តើខ្ញុំសង្ឃឹមថានឹងបាននាំយកសិរីល្អថ្វាយព្រះ ឬ សម្រាប់ខ្លួនឯង ? នៅពេលខ្ញុំបម្រើព្រះអម្ចាស់ តើខ្ញុំកំពុងធ្វើកិច្ចការនេះដើម្បីទទួលបានការអនុញ្ញាតពីព្រះអម្ចាស់ ឬពីមនុស្ស ? នៅពេលខ្ញុំអធិស្ឋានជាសាធារណៈ តើខ្ញុំកំពុងទូលទៅកាន់ព្រះ ឬទៅអង្គដំនុំ ? (សូមមើល នីហ្វៃទី ២ ២:៣០, គ. និង ស. ៨៨:៦៧–៦៨, ម៉ូសេ ៤:២, យ៉ូសែប ស៊្មីធ–ប្រវត្តិ ១:៤៦) » (New Testament Student Manual [Church Educational System manual ឆ្នាំ២០១៤] ទំព័រ ២៩) ។

មេរៀន ១២

ម៉ាថាយ ៧

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានបន្តទេសនកថារបស់ទ្រង់នៅលើភ្នំដោយបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យកាត់សេចក្តីដោយសុចរិត ។ ទ្រង់ក៏បង្រៀនពីការទទួលវិវរណៈផ្ទាល់ខ្លួន និង ការធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ផងដែរ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៧:១–៥

ជាផ្នែកមួយនៃទេសនកថារបស់ទ្រង់នៅលើភ្នំ ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យកាត់សេចក្តីដោយសុចរិត ។

សូមសរសេរសំណួរខាងក្រោមនេះ នៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ *តើយើងគួរ ឬក៏មិនគួរកាត់សេចក្តីអ្នកដទៃ ?* នៅពេលចាប់ផ្តើមថ្នាក់រៀន សុំឲ្យសិស្សឆ្លើយនឹងសំណួរនេះ ។

សូមដាក់តាំង រូបភាព The Sermon on the Mount (*Gospel Art Book* | **ឆ្នាំ ២០០៩** | **ល.រ. ៣៩ សូមមើលផងដែរ** LDS.org) **។ សូមពន្យល់ថា នៅពេលព្រះយេស៊ូវបានបន្តទេសនកថារបស់ទ្រង់នៅលើភ្នំ ទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ពីការកាត់សេចក្តី ។**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីការកាត់សេចក្តី ។ សូមចង្អុលបង្ហាញថា ខទី ១ ជារឿយៗត្រូវបានយល់ច្រឡំថាមានន័យថាយើងពុំគួរកាត់សេចក្តី ។ ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៧:១ឲ្យឮៗ ។

- **តើព្រះអង្គសង្គ្រោះបង្រៀនអ្វីខ្លះអំពីការកាត់សេចក្តី ?**
- **តើអ្នកគិតថា ការការកាត់សេចក្តីដោយសុចរិតមានន័យដូចម្តេច ?**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វីដែលនឹងកើតឡើងផ្អែកតាមរបៀបដែលយើងកាត់សេចក្តីអ្នកដទៃ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- **តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងកាត់សេចក្តីអ្នកដទៃដោយសុចរិត ?** (**បន្ទាប់ពីសិស្សឆ្លើយ សូមជួយពួកគេឲ្យស្គាល់គោលការណ៍ខាងក្រោម ៖ *ប្រសិនបើយើងកាត់សេចក្តីអ្នកដទៃដោយសុចរិត នោះព្រះនឹងប្រទានសេចក្តីមេត្តាករុណា និង ភាពស្មើភាពគ្នាដូចគ្នាដល់យើង***) **។**

ប្រសិនបើអាចធ្វើទៅបាន សូមចែកសំណៅនៃ សេចក្តីថ្លែងការណ៍ ខាងក្រោមក្នុង *ពិតចំពោះសេចក្តីជំនឿ* ដល់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សម្នាក់អានវាឮៗ ។ ចូរសុំឲ្យសិស្សពាក់កណ្តាលថ្នាក់ផ្សេងតាមរកមើលប្រភេទនៃការកាត់សេចក្តីដែលយើងគួរ និងពុំគួរធ្វើ ។ ចូរសុំឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលរបៀបដែលយើងអាចកាត់សេចក្តីដោយសុចរិត ។

« ពេលខ្លះមនុស្សមានអារម្មណ៍ថា វាខុសក្នុងការវិនិច្ឆ័យអ្នកដទៃ ទោះជាតាមវិធីណាក៏ដោយ ។ ខណៈវាត្រឹមត្រូវដែល អ្នកមិនគួរកាត់ទោសអ្នកដ៏ទៃ ឬ វិនិច្ឆ័យពួកគេដោយមិនយុត្តិធម៌ នោះអ្នកនឹងត្រូវធ្វើការវិនិច្ឆ័យពីគំនិត ពីស្ថានភាព និង ពីមនុស្ស ដែលនៅក្នុងឆាកជីវិតរបស់អ្នក ។ . . .

« ការវិនិច្ឆ័យគឺជាការប្រើសេរីភាពយ៉ាងសំខាន់របស់អ្នក ហើយតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ជាពិសេស ពេលដែលអ្នកធ្វើការវិនិច្ឆ័យអំពីមនុស្សដទៃទៀត ។ ការវិនិច្ឆ័យទាំងអស់របស់អ្នកត្រូវតែបានដឹកនាំដោយបទដ្ឋានសុចរិត ។ សូមចងចាំថាមានតែព្រះប៉ុណ្ណោះ ដែលដឹងពីចិត្តរបស់បុគ្គលម្នាក់ៗ ហើយដែលអាចធ្វើការវិនិច្ឆ័យចុងក្រោយបង្អស់ដល់បុគ្គលម្នាក់ៗ (សូមមើល វិវរណៈ ២០:១២, នីហ្វៃទី៣ ២៧:១៤, គ. និង ស. ១៣៧:៩) ។ . . .

« . . . ធ្វើឲ្យអស់ពីសមត្ថភាពរបស់អ្នក វិនិច្ឆ័យពីស្ថានភាពរបស់មនុស្សជាជាងវិនិច្ឆ័យពីខ្លួនរបស់មនុស្ស ។ ពេលណាដ៏ដោយដែលអាចធ្វើទៅបាន ចូរជៀសវាងធ្វើការវិនិច្ឆ័យរហូតដល់អ្នកមានចំណេះដឹងគ្រប់គ្រាន់ល្មមនៃការពិតនោះ ។ ចូរស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធ ដែលជាអង្គដឹកនាំការសម្រេចចិត្តរបស់អ្នក » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* | ឆ្នាំ ២០០៤ | ទំព័រ ៥៣–៥៥) ។

- **តើការកាត់សេចក្តីប្រភេទណាខ្លះដែលយើងគួរធ្វើ ?**
- **តើយើងអាចកាត់សេចក្តីដោយសុចរិតតាមរបៀបណា ?**



ទេសនកថានៅលើភ្នំ ដោយ ខាល ហេនរីក ប្លុច ។ ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាមរមន ហ្វ្រីវើកស្បក នៅ ហីលលើរុត ប្រទេស ដាណឺម៉ាក់ ។ ហាមថតចម្លង ។

សូមដាក់បង្ហាញបំណែកឈើតូចមួយ និង ឈើមួយដើមវែងដែលក្រាស់ ។ សូមពន្យល់ថា កាលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សទ្រង់ពីការកាត់សេចក្តី ទ្រង់បានហៅបំណែកឈើតូចមួយជា *ភរម្ញ* និង ឈើមួយដើមធំជា *ឆ្អឹម* ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ៧:៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនពីការកាត់សេចក្តីអ្នកដទៃ ។

- តើកម្ទេច និង ធ្មឹមតំណាងឲ្យអ្វី ក្នុងការរៀបរាប់ពីភាពស្រដៀងគ្នារបស់ព្រះអង្គសង្គ្រោះ ?
- តើអ្នកអាចនិយាយឡើងវិញនូវការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង ខទី ៣យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរនាក់ឡើងមកខាងមុខក្តារខៀន ។ សូមណែនាំសិស្សម្នាក់ឲ្យកាត់ធ្មឹមដាក់ពីមុខភ្នែកខ្លួន ។ សូមសួរសិស្សទីពីរ ៖

- តើប្អូនចង់ឲ្យមិត្តរួមថ្នាក់ប្អូន ដែលកាន់ធ្មឹមដកយកកម្ទេចចេញពីភ្នែកប្អូនដែរឬទេ ? ហេតុអ្វីមិនបាច់ ?

សូមសួរសិស្សដែលកាន់ធ្មឹម ៖

- តើប្អូនត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យបានឃើញច្បាស់ពីមុនដកយកកម្ទេចចេញពីភ្នែករបស់មិត្តរួមថ្នាក់ប្អូន ?

សូមអញ្ជើញសិស្សដែលកាន់ធ្មឹមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ ក្នុងគណៈប្រធានទីមួយ ៖

« រឿងពីធ្មឹម និងកម្ទេចនេះ ហាក់ដូចជាទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការខ្វះសមត្ថភាពរបស់យើង ក្នុងការមើលខ្លួនឯងឲ្យបានច្បាស់ ។ ខ្ញុំមិនប្រាកដទេថា ហេតុអ្វីបានជាយើងអាចវិនិច្ឆ័យរោគ ហើយចេញបញ្ហាព្យាបាលជំងឺរបស់អ្នកដទៃបានយ៉ាងល្អ កាលដែលយើងមានការពិបាកក្នុងការមើលឃើញពីជំងឺរបស់យើងផ្ទាល់ជារឿយៗនោះ » (« Lord, Is It I? » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៥៦) ។

សូមអញ្ជើញសិស្សទាំងពីនាក់នោះត្រឡប់ទៅអង្គុយវិញ ។ ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៧:៤–៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថា តើព្រះអង្គសង្គ្រោះបានមានបន្ទូលថា យើងគួរព្រួយបារម្ភពីកំហុសរបស់នរណាទៅ ។

- តើកង្វល់ និង ការកែតម្រូវរបស់យើងគួរផ្តោតលើកំហុសអ្នកដទៃ ឬលើកំហុសខ្លួនឯង ? ហេតុអ្វី ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីខគម្ពីរទាំងនេះដែលអាចជួយយើងឲ្យចៀសវាងពីការកាត់សេចក្តីអ្នកដទៃដោយឥតសុចរិត ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងផ្តោតយកចិត្តទុកដាក់ទៅលើការដកយកអំពើបាបផ្ទាល់ខ្លួន នោះនឹងពុំសូវមានចិត្តកាត់សេចក្តីអ្នកដទៃដោយឥតសុចរិតទេ**) ។
- តើគោលការណ៍នេះអាចជួយយើងបែបណាដែរ ពេលយើងឃើញកម្ទេចនៅក្នុងភ្នែករបស់អ្នកផ្សេង ?

អ្នកអាចឲ្យបំណែកឈើតូចមួយទៅសិស្ស ដើម្បីទុកជាការរំឭកចាំពីគោលការណ៍នេះ ។ សុំឲ្យសិស្សសញ្ជឹងគិតពីអំពើបាប ឬភាពទន់ខ្សោយដែលពួកគេអាចដកចេញពីភ្នែករបស់ខ្លួន ។ សូមលើកទឹកចិត្តពួកគេឲ្យទូលសូមជំនួយពីព្រះអម្ចាស់ ដើម្បីដកយកគុណវិបត្តិរបស់ខ្លួនជាជាងការកាត់សេចក្តីអ្នកដទៃដោយឥតសុចរិត ។

ម៉ាថាយ ៧:៦–១៤

ព្រះអង្គសង្គ្រោះបង្រៀនពីការស្វែងរកវិវរណៈផ្ទាល់ខ្លួន

សូមសង្ខេប ម៉ាថាយ ៧:៦ ដោយពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធសម្រាប់ខគម្ពីរនេះជួយយើងឲ្យយល់ថា ព្រះយេស៊ូវគ្រីស្ទបានហៅពួកសិស្សទ្រង់ឲ្យប្រកាសដំណឹងល្អដល់ពិភពលោក ។ ពួកគាត់ត្រូវបង្រៀនពីការប្រែចិត្ត ប៉ុន្តែត្រូវរក្សាភាពអាថ៌កំបាំងនៃនគរទុកជារឿងសម្ងាត់ ។ និយាយម្យ៉ាងទៀត គឺពួកគាត់ពុំត្រូវពិភាក្សាប្រធានបទដែលពិសិដ្ឋជាមួយនឹងមនុស្សដែលពុំទាន់ត្រៀមខ្លួនទទួលវា ។ (សូមមើល ការបកប្រែដោយ យ៉ូសែប ស៊្មីធ ម៉ាថាយ ៧:៩–១១ | នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ |) ។

សូមពន្យល់ថា យោងតាមការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ៧:៧ (សូមមើល ការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ៧:១២ | ក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ |) ចាប់ផ្តើមជាមួយនឹងឃ្លា « និយាយទៅកាន់ពួកគេទូលសូមដល់ព្រះ » ។ សូមអញ្ជើញសិស្សម្នាក់អាន ខទី ៧ឮៗ ចាប់ផ្តើមជាមួយឃ្លានេះ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ឆ្លៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ឲ្យពួកសិស្សរបស់ទ្រង់បង្រៀន ។

- តើពួកសិស្សបានប្រាប់ឲ្យនិយាយអ្វីខ្លះទៅមនុស្ស ដែលចង់ទទួលបានចំណេះដឹងពីព្រះ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះក្នុង ខទី ៧ អំពីរបៀបដែលយើងអាចយល់ដឹងពីចំណេះដឹងពិសិដ្ឋមកពីព្រះ ? (បន្ទាប់ពីសិស្សឆ្លើយសូមជួយពួកគេឲ្យស្គាល់គោលការណ៍ខាងក្រោម ៖ **នៅពេលយើងទូលសូម ស្វែងរក ហើយគោះនៅក្នុងការស្រាវជ្រាវរបស់យើងរកសេចក្តីពិត ព្រះវរបិតាសួគ៌នឹងឆ្លើយ ហើយប្រទានវិវរណៈផ្ទាល់ខ្លួនដល់យើង**) ។
- តើពាក្យ *ទូលសូម ស្វែងរក* ហើយ *គោះ* បញ្ជាក់ពីអ្វីខ្លះដែលយើងត្រូវធ្វើដើម្បីទទួលបានវិវរណៈផ្ទាល់ខ្លួន ?

សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយពីគ្រាមួយដែលការទូលសូម ការស្វែងរក និង ការគោះរបស់ពួកគេ បានអញ្ជើញឲ្យមានវិវរណៈផ្ទាល់ខ្លួន ។

សូមសង្ខេប ម៉ាថាយ ៧:៩–១១ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនថា ដូចជាឪពុកម្នាក់ពុំឲ្យដុំថ្ម ឬពស់ ពេលកូនខ្លួនសូមនំប៉័ង ឬត្រីដែរ ព្រះវរបិតាសួគ៌នឹងពុំបដិសេធអំណោយទាននៃវិវរណៈផ្ទាល់ខ្លួនដល់កូនចៅទ្រង់ដែលទូលសូមវាឡើយ ។

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តសេចក្តីជំនឿដោយទូលសូម ស្វែងរក ហើយគោះដើម្បីអញ្ជើញឲ្យមានវិវរណៈ និង ការយល់ដឹងផ្ទាល់ខ្លួននៃដំណឹងល្អ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលពួកគេធ្វើកិច្ចការដោយសេចក្តីជំនឿ និង សេចក្តីអត់ធ្មត់ ព្រះវរបិតាសួគ៌នឹងឆ្លើយតប ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:១២–១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសេចក្តីពិតបន្ថែមទៀតដែលព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ឲ្យពួកសិស្សរបស់ទ្រង់បង្រៀន ។ សូមអញ្ជើញសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

ម៉ាថាយ ៧:១៥–២៧

ព្រះអង្គសង្គ្រោះសន្យានឹងប្រទានសេចក្តីសង្គ្រោះដល់ជន ដែលធ្វើតាមព្រះទ័យរបស់ព្រះវរបិតា ។

សុំឲ្យសិស្សសរសេរនៅលើក្តារខៀននូវគំនិតមួយចំនួន ដែលពិភពលោកទទួលយកជាទូទៅ ប៉ុន្តែដែលផ្ទុយនឹងផែនការរបស់ព្រះវរបិតាសួគ៌ ។

- **ហេតុអ្វីការអាចដឹងថាបុគ្គលម្នាក់ ឬមនុស្សមួយក្រុមកំពុងផ្តល់គំនិតមួយ ដែលផ្ទុយពីផែនការរបស់ព្រះវរបិតាសួគ៌គឺជារឿងដ៏សំខាន់ ?**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:១៥ ឲ្យឮៗ ។ បន្ទាប់មក សូមសួរ ៖

- **តើព្រះអម្ចាស់បានព្រមានដល់ពួកសិស្សអំពីអ្វីខ្លះ ? តើទ្រង់បានមានបន្ទូលថា ពួកព្យាការីក្លែងក្លាយទាំងនេះនឹងដឹកនាំឲ្យវង្វេងផ្លូវបានយ៉ាងដូចម្តេច ?**



សូមពន្យល់ថា អែលឌើរ អិម រ័សុល បាឡឺដ ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បានព្រមានពីពួកព្យាការីក្លែងក្លាយក្នុងជំនាន់របស់យើងដោយរួមបញ្ចូលទាំង « បុរសស្ត្រីដែលជាពួកអ្នកប្រកាសដោយឯកឯងពីគោលលទ្ធិនៃសាសនាចក្រ » ក៏ដូចជា « ជនដែលនិយាយ ហើយបោះពុម្ពប្រឆាំងនឹងពួកព្យាការីពិតរបស់ព្រះ និងអ្នកដែលខិតខំផ្សព្វផ្សាយដល់អ្នកដទៃដោយពុំគិតពីសុខុមាលភាពដ៏នៅអស់កល្បជានិច្ចនៃមនុស្សដែលពួកគេទាក់ទាញ » (« Beware of False Prophets and False Teachers » *Ensign* ខែ វិច្ឆិកា ឆ្នាំ១៩៩៩ ទំព័រ ៦៣) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:១៦–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលវិធីមួយដែលយើងអាចដឹងថាតើមនុស្សម្នាក់គឺជាព្យាការីក្លែងក្លាយ ឬគ្រូបង្រៀនក្លែងក្លាយ ។

- **តើវិធីមួយដែលយើងអាចដឹងថាមនុស្សម្នាក់គឺជាព្យាការីក្លែងក្លាយ ឬគ្រូបង្រៀនក្លែងក្លាយបានដោយរបៀបណា ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរ សេចក្តីពិត ខាងក្រោមនៅលើក្តារខៀន ៖ <u>**យើងអាចដឹងពួកព្យាការីក្លែងក្លាយដោយផលរបស់ពួកគេ**</u>) ។**

សូមបង្ហាញសិស្សពីផលផ្លែពីរប្រភេទ ។ សូមសួរសិស្សថាតើដំណាំប្រភេទណាដែលឲ្យផល ។ សូមពន្យល់ថា ស្រដៀងគ្នានឹងការស្គាល់ដំណាំតាមរយៈផលរបស់វាដែរ យើងអាចស្គាល់ពួកព្យាការីក្លែងក្លាយ និង គ្រូបង្រៀនក្លែងក្លាយតាមរយៈការបង្រៀន សកម្មភាព និងគំនិតរបស់ពួកគេ ។

- **ដោយផ្អែកតាមសេចក្តីពិតនេះ តើយើងអាចស្គាល់បុគ្គល ឬក្រុមដែលយើងគួរចៀសវាងបានយ៉ាងដូចម្តេច ?**
- **តើបញ្ជីគំនិតនៅលើក្តារខៀនទាក់ទងគ្នានឹងសេចក្តីពិតនេះយ៉ាងដូចម្តេចដែរ ?**

សូមសង្ខេប ម៉ាថាយ ៧:២១–២៣ ដោយពន្យល់ថា ពុំមែនមនុស្សគ្រប់គ្នាដែលប្រកាសអំពីជំនឿជឿលើព្រះយេស៊ូវគ្រីស្ទនឹងចូលនគរទ្រង់បានទេ ប៉ុន្តែជនដែលធ្វើតាមព្រះទ័យនៃព្រះវរបិតាសួគ៌ ហើយមកស្គាល់ទ្រង់ទើបនឹងចូលទៅក្នុងនគរស្ថានសួគ៌ ។

សូមដាក់បង្ហាញដុំថ្មមួយ និង ខ្សាច់មួយថាស ។ សូមសួរសិស្សថាតើពួកគេចង់សង់ផ្ទះរបស់ខ្លួនលើខ្សាច់ ឬលើថ្ម ។ សូមអញ្ជើញពួកគេពន្យល់ពីមូលហេតុ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៧:២៤–២៧ ឮៗ ។

- **យោងតាម ខទី ២៤តើព្រះអង្គសង្គ្រោះមានបន្ទូលថាសកម្មភាពអ្វីខ្លះដែលនឹងធ្វើឲ្យមនុស្សប្រៀបបាននឹងមនុស្សឆ្លាតដែលសង់ផ្ទះនៅលើថ្ម ?**
- **យោងតាម ខទី ២៦តើព្រះអង្គសង្គ្រោះមានបន្ទូលថាសកម្មភាពអ្វីខ្លះដែលនឹងធ្វើឲ្យមនុស្សប្រៀបបាននឹងមនុស្សល្ងង់ខ្លៅដែលសង់ផ្ទះនៅលើខ្សាច់ ?**
- **តើអ្នកគិតថា ភ្លៀង ទឹកជំនន់ និង ខ្យល់តំណាងឲ្យអ្វីនៅ រឿងប្រៀបប្រដូចទាំងនេះ(សូមមើល ខទី ២៧ សូមមើលផងដែរ ហេលេមិន ៥:១២) ?**
- **តើគោលការណ៍អ្វីខ្លះ ស្តីពីការធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ ដែលយើងអាចរៀនពីរឿងប្រៀបប្រដូចទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ <u>**ប្រសិនបើយើងស្តាប់ ហើយធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ នោះទ្រង់នឹងពង្រឹងកម្លាំងដល់យើងឲ្យស៊ូទ្រាំ នឹងការសាកល្បងរបស់យើង ។ ប្រសិនបើយើងស្តាប់តាមការបង្រៀនរបស់ព្រះអម្ចាស់ ប៉ុន្តែពុំបានធ្វើតាម នោះយើងនឹងពុំទទួលបានការគាំទ្រ ដែលយើងត្រូវការ នៅពេលការសាកល្បងបានមកដល់ឡើយ**</u>) ។**

សូមអញ្ជើញសិស្សពិចារណាពីអ្វីដែលព្រះអម្ចាស់បានបង្រៀន នៅក្នុងទេសនកថានៅលើភ្នំ (សូមមើល ម៉ាថាយ ៥–៧) ។ សូមអញ្ជើញពួកគេធ្វើដូចជាមនុស្សឆ្លាតនោះដោយសម្រេចចិត្តធ្វើតាមគោលការណ៍ដែលព្រះអង្គសង្គ្រោះបានបង្រៀន ។ អ្នកគួរឲ្យពេលសិស្សសរសេរពីរបៀបដែលពួកគេនឹងអនុវត្តគោលការណ៍មួយ ឬច្រើននៅក្នុងមេរៀននេះ ឬនៅក្នុងមេរៀនទាំងបី លើកមុន ។

ការយល់ដឹង ពីអត្ថន័យនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

នៅពេលសិស្សស្គាល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ អ្នកអាចដឹកនាំពួកគេ តាមរយៈការពិភាក្សានានាដែលនឹងជួយពួកគេឲ្យវិភាគ ហើយយល់ដឹងកាន់តែប្រសើរពីអត្ថន័យនៃសេចក្តីពិតទាំងនេះ ។ នៅពេលសិស្សយល់ពីគោលលទ្ធិ ឬគោលការណ៍មួយ នៃ ជំណឹងល្អ វាមានន័យថា ពួកគេយល់នូវសេចក្តីពិតដែលបានស្គាល់ទំនាក់ទំនងរបស់វាជាមួយនឹង គោលលទ្ធិ និង គោលការណ៍ផ្សេងៗទៀត នៅក្នុងផែនការរបស់ព្រះអម្ចាស់ និងស្ថានភាពដែលអាចអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។

ម៉ាថាយ ៨–១០

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទយាងឆ្លងកាត់ស្រុកកាលីឡេ ទ្រង់បានធ្វើអព្ភូតហេតុជាច្រើន ។ ទ្រង់ក៏បានហៅពួកសាវកដប់ពីរនាក់ បានប្រគល់អំណាច ហើយបានបង្គាប់ពួកគាត់ ហើយបានបញ្ជូនពួកគាត់ទៅបម្រើដល់ប្រជាជន ។

ការសិក្សាដំណឹងល្អតាមលំដាប់លំដោយ

ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន ពួកគាត់ម្នាក់ៗបានកត់ត្រាព្រឹត្តិការណ៍ និងព័ត៌មានលម្អិតនៃព្រះជន្មរបស់ព្រះអង្គសង្គ្រោះ ដែលមានលក្ខណៈពិសេសខុស ៗគ្នា ។ ទោះជាយ៉ាងក៏ដោយ ដំណឹងល្អរបស់ម៉ាថាយ ម៉ាកុស និងលូកា មានមាតិកាស្រដៀងគ្នាដែរ ។ កំណត់ចំណាំសម្រាប់គ្រូបង្រៀនត្រូវបានផ្តល់ឲ្យនៅទីកន្លែងខុសៗគ្នាក្នុងសៀវភៅសិក្សានេះដើម្បីជួយអ្នកឲ្យស្គាល់ពីទីកន្លែងដែលព្រឹត្តិការណ៍ជាក់លាក់នានា ដែលនឹងត្រូវបានលើកយកមកបង្រៀនជាព័ត៌មានលម្អិត ។ ឧទាហរណ៍ អព្ភូតហេតុដែលបានកត់ត្រានៅក្នុង ម៉ាថាយ ៨ និង ៩ នឹងត្រូវបានលើកឡើងយ៉ាងសឹងជាម្រាំនៅក្នុងមេរៀនសម្រាប់ ម៉ាកុស ១–៥ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ៨:១–៩:៣៤

ព្រះយេស៊ូវធ្វើអព្ភូតហេតុជាច្រើន

នៅពេលចាប់ផ្តើមថ្នាក់រៀន ចូរអញ្ជើញសិស្សឲ្យឆ្លើយសំណួរខាងក្រោមនេះ ៖

- ប្រសិនបើអ្នកបានដឹងថា ព្រះអង្គសង្គ្រោះនឹងយាងមកក្រុងរបស់អ្នកនៅថ្ងៃនេះ តើអ្នកនឹងនាំនរណាទៅឲ្យទ្រង់ព្យាបាល ? ហេតុអ្វី ?

សូមចម្លងសេចក្តីយោងបទគម្ពីរដូចខាងក្រោមនៅលើក្តារខៀន ៖ *ម៉ាថាយ ៨:១–៤*, *ម៉ាថាយ ៨:៥–១៣*, *ម៉ាថាយ ៨:១៤–១៥*, *ម៉ាថាយ ៨:២៣–២៧*, *ម៉ាថាយ ៨:២៨–៣២*, *ម៉ាថាយ ៩:១–៨*, *ម៉ាថាយ ៩:១៨–១៩*, *២៣–២៦*, *ម៉ាថាយ ៩:២០–២២*, *ម៉ាថាយ ៩:២៧–៣១*, និង *ម៉ាថាយ ៩:៣២–៣៣* ។ ចូរចាត់សេចក្តីយោងបទគម្ពីរមួយដល់សិស្សម្នាក់មួយៗ ។ (ប្រសិនបើអ្នកមានថ្នាក់តូច សិស្សមួយចំនួនអាចអានវគ្គបទគម្ពីរច្រើនជាងមួយ) ។

សូមអញ្ជើញសិស្សអានវគ្គបទគម្ពីរដែលពួកគេបានទទួល ហើយរកមើលអព្ភូតហេតុដែលព្រះយេស៊ូវបានធ្វើ ។ លុះដល់ពេលកំណត់ហើយ ចូរសុំឲ្យសិស្សរៀបរាប់ខ្លីៗពីអ្វីដែលពួកគេបានរៀន ។ (កំណត់ចំណាំ ៖ សិស្សនឹង សិក្សា អព្ភូតហេតុទាំងនេះកាន់តែសឹងជម្រៅថែមទៀតនៅក្នុង ម៉ាកុស ១–៥) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៨:១៦–១៧ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីការព្យាករមួយដែលព្រះយេស៊ូវគ្រីស្ទបានបំពេញ នៅពេលទ្រង់បានធ្វើអព្ភូតហេតុទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើសេចក្តីពិតអ្វីខ្លះ អំពីព្រះយេស៊ូវគ្រីស្ទដែលយើងអាចរៀនពីដំណើររឿងនៃអព្ភូតហេតុទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះយេស៊ូវអាចព្យាបាលយើងពីពិការភាព និងជំងឺនានារបស់យើង ។** អ្នកអាចនឹងត្រូវពន្យល់ថា *ពិការភាព* គឺជាជំងឺ គុណវិបត្តិ ឬភាពទន់ខ្សោយ) ។
- តើព្រះអង្គសង្គ្រោះអាចព្យាបាលយើង ឬពង្រឹងភាពទន់ខ្សោយរបស់យើងដោយរបៀបណា ប្រសិនបើទ្រង់ពុំបានយាងមកក្នុងចំណោមយើងសព្វថ្ងៃនេះ ? (តាមរយៈដង្វាយធួនរបស់ទ្រង់ ។ សូមមើល អាលម៉ា ៧:១១–១៣) ។

ម៉ាថាយ ៩:៣៥–១០:៨

ព្រះយេស៊ូវហៅពួកសាវកដប់ពីរនាក់

សូមដាក់បង្ហាញរូបភាពមួយ ឬរូបភាពជាច្រើននៃពួកសាវកបច្ចុប្បន្នរបស់សាសនាចក្រ រួមទាំងគណៈប្រធានទីមួយផងដែរ ។ (រូបភាពទាំងនោះអាចរកបាននៅ LDS.org ¦ សូមមើល Meet Today's Prophets and Apostles ¦ និង នៅក្នុងការចេញផ្សាយទស្សនាវដ្តី *Ensign* ឬ *Liahona* សម្រាប់សន្និសីទទូទៅ) ។

- តើអ្វីទៅដែលធ្វើឲ្យបុគ្គលទាំងនេះ មានភាពពិសេសខុសគ្នានៅក្នុងចំណោមមនុស្សទាំងអស់នៅលើផែនដីសព្វថ្ងៃនេះ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនានា នៅពេលពួកគេសិក្សា ម៉ាថាយ ៩–១០ អំពីតួនាទីរបស់ពួកសាវក និងពរជ័យដែលពួកគាត់អាចនាំមកក្នុងជីវិតរបស់យើង ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ៩:៣៥ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវគ្រីស្ទ បានធ្វើបន្តែមពីលើការព្យាបាលដល់មនុស្សដទៃ ។

- លើសពីការព្យាបាលដល់មនុស្សដទៃ តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ នៅក្នុងការងារបម្រើរបស់ទ្រង់ ?

សូមពន្យល់ថា នៅពេលព្រះយេស៊ូវបានប្រកាសដំណឹងល្អ ហើយបានធ្វើអព្ភូតហេតុពេញក្នុងស្រុកយូដា ចំនួនមនុស្សដែលបានដើរតាមទ្រង់ និងស្វែងរកទ្រង់ បានកើនឡើង ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៩:៣៦–៣៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើនរណាទៅដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា គាត់ត្រូវជួយទ្រង់ធ្វើការងារបម្រើដល់មនុស្សទាំងអស់ដែលបានដើរតាមទ្រង់ ។

- យោងតាម ខទី ៣៧–៣៨ថាតើនរណាទៅ ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា គាត់ត្រូវជួយទ្រង់មើលថែមនុស្សដែលបានដើរតាមទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១០:១–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវ បានធ្វើដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សទាំងនោះ ។

- តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ ដើម្បីជួយហ្វូងមនុស្សដែលបានដើរតាមទ្រង់ ?
- តើយើងអានរៀនគោលលទ្ធិអ្វីខ្លះ ពីខគម្ពីរទាំងនេះស្តីពីរបៀបមួយដែលព្រះយេស៊ូវគ្រីស្ទធ្វើការងារបម្រើដល់មនុស្សនៅលើផែនដី ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទហៅពួកសាវក ហើយប្រគល់សិទ្ធិអំណាចដល់ពួកគាត់ ។** អ្នកគួរផ្តល់យោបល់ឲ្យសិស្សសរសេរគោលលទ្ធិនេះនៅក្បែរ ម៉ាថាយ ១០:១–៤) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១០:៥–៨ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវគ្រីស្ទបានបង្គាប់ឲ្យពួកសាវករបស់ទ្រង់ទាំងអស់ធ្វើ ។

- តើព្រះយេស៊ូវបានបង្គាប់ពួកសាវករបស់ទ្រង់ឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថាពាក្យ *សាវក* ចេញមកពីពាក្យមួយរបស់ក្រិកដែលមានន័យថា « មនុស្សម្នាក់ដែលត្រូវបានបញ្ជូនទៅ » ។ ដំបូងឡើយ ពួកសាវកត្រូវបានបញ្ជូនតែនៅក្នុងចំណោមពួកសាសន៍អ៊ីស្រាអែលប៉ុណ្ណោះ ។ ក្រោយមកទៀត ព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញបានបង្គាប់ថា ដំណឹងល្អក៏ត្រូវប្រកាសនៅក្នុងចំណោមពួជសាសន៍ដទៃ ឬជនដែលពុំមែនជាពួកសាសន៍អ៊ីស្រាអែលផងដែរ ។

- តើអ្នកបានសង្កេតឃើញភាពស្រដៀងគ្នាអ្វីខ្លះ រវាងកិច្ចការដែលព្រះយេស៊ូវបានធ្វើ និងកិច្ចការដែលទ្រង់បានបង្គាប់ឲ្យពួកសាវករបស់ទ្រង់ធ្វើ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ មកពីខគម្ពីរទាំងនេះ អំពីអ្វីដែលព្រះអម្ចាស់ហៅឲ្យពួកសាវករបស់ទ្រង់ធ្វើ ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ព្រះអម្ចាស់ហៅពួកសាវកឲ្យប្រកាសដំណឹងល្អរបស់ទ្រង់ ហើយធ្វើកិច្ចការរបស់ទ្រង់ ។** សូមពិចារណាពីការសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។

សូមយោងទៅរូបពួកសាវកបច្ចុប្បន្នម្តងទៀត ។ ចូរសុំឲ្យសិស្សផ្តល់ជាឧទាហរណ៍ អំពីរបៀបដែលពួកសាវកបច្ចុប្បន្នប្រកាស ហើយធ្វើការងារបម្រើដូចជាព្រះយេស៊ូវគ្រីស្ទធ្វើ ប្រសិនបើទ្រង់បានគង់នៅទីនេះ ។

ដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍ពី សារៈសំខាន់ នៃសេចក្តីពិតដែលពួកគេបានស្គាល់ខាងលើ សូមអាន ឬបង្ហាញផ្ទៃកមួយនៃសន្ទរកថាថ្មីៗមួយដែលធ្វើឡើងដោយសាវកបច្ចុប្បន្នមួយរូបដែលពាក់ព័ន្ធនឹងយុវវ័យ ។ បន្ទាប់ពីអានសេចក្តីថ្លែងការណ៍នោះ ឬបង្ហាញជាវីដេអូរួចហើយ សូមសួរ ៖

- តើការយល់ដឹងថា ពួកសាវកត្រូវបានហៅដោយព្រះយេស៊ូវគ្រីស្ទឲ្យធ្វើកិច្ចការរបស់ទ្រង់ អាចជះឥទ្ធិពលដល់របៀបដែលយើងឆ្លើយតបនឹងអ្វីដែលពួកគាត់បានបង្រៀន ហើយប្រឹក្សាឲ្យយើងធ្វើយ៉ាងដូចម្តេចដែរ ?
- តើការងារបម្រើ និង សារលិខិតនៃពួកសាវកបច្ចុប្បន្នបានជះឥទ្ធិពលដល់ជីវិតរបស់អ្នកតាមរបៀបណាដែរ ?

សូមអញ្ជើញសិស្សឲ្យស្វែងរកដោយស្មោះនូវឱកាសដើម្បីស្តាប់ សិក្សា ហើយអនុវត្តប្រសាសន៍នៃពួកសាវករបស់ព្រះអម្ចាស់ ។

សូមជួយសិស្សឲ្យទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

បន្ទាប់ពីសិស្សស្គាល់ ហើយយល់ពីគោលការណ៍ និងគោលលទ្ធិទាំងឡាយនៃដំណឹងល្អ ដែលមាននៅក្នុងព្រះគម្ពីរ ពួកគេអាចនឹងមិនអនុវត្តវាឡើយ លុះត្រាពួកគេទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់របស់វា តាមរយៈព្រះវិញ្ញាណ ហើយមានអារម្មណ៍ពីកម្រិត នៃភាពចាំបាច់ ដើម្បីបញ្ចូលគោលការណ៍នៅក្នុងជីវិតផ្ទាល់របស់ពួកគេ ។ វិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីជួយសិស្សឲ្យធ្វើកិច្ចការនេះ គឺលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិត ហើយចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនដែលទាក់ទងនឹងសេចក្តីពិតទាំងនោះ ។

ម៉ាថាយ ១០:៥–៤២

ព្រះយេស៊ូវណែនាំពួកសាវកទាំងដប់ពីរនាក់ពីមុនពួកលោកចេញទៅប្រកាស ហើយធ្វើការងារបម្រើ

សូមសង្ខេប ម៉ាថាយ ១០:៥–១៦ ដោយពន្យល់ថា ព្រះអម្ចាស់បានណែនាំពួកសាវកឲ្យទុកចិត្តលើព្រះវរបិតាសួគ៌ ដើម្បីផ្តល់ដល់សេចក្តីត្រូវការរបស់ពួកគាត់ នៅពេលពួកលោកបានធ្វើដំណើរទៅប្រកាសដំណឹងល្អ ។ ព្រះអង្គសង្គ្រោះក៏បានបង្រៀនដល់ពួកគាត់ឲ្យប្រសិទ្ធពរដល់មនុស្ស ដែលបានទទួលពួកគាត់ ហើយផ្តល់ផ្ទះឲ្យពួកគាត់ស្នាក់នៅផងដែរ ។

ចូរសុំឲ្យសិស្សគិតពីគ្រាមួយដែលមានមនុស្សម្នាក់ ដែលមានសាសនាខុសពីពួកគេបានមកសួរពួកគេនូវសំណួរដ៏ពិបាកមួយអំពីដំណឹងល្អ ឬបានសួរពួកគេអំពីអ្វីមួយដែលបង្កហេតុពាក់ព័ន្ធនឹងសាសនាចក្រ ។

- តើអ្នកមានជំនឿចិត្តយ៉ាងណាដែរ ដោយដឹងពីអ្វីដែលអ្នកគួរនិយាយនៅក្នុងស្ថានភាពនោះ ? ហេតុអ្វី ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយ នៅក្នុងការបង្រៀនរបស់ព្រះយេស៊ូវទៅកាន់ពួកសាវករបស់ទ្រង់នៅផ្នែក សេសសល់ក្នុង ម៉ាថាយ ១០ ដែលអាចជួយយើងនៅពេលយើងត្រូវពន្យល់ដំណឹងល្អ ឬចែកចាយទីបន្ទាល់របស់យើង ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង ម៉ាថាយ ១០:១៦–២០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការសាកល្បងដែលព្រះយេស៊ូវបានមានបន្ទូលថា ពួកសាវកនឹងជួបនៅពេលពួកគេបានធ្វើដំណើរទៅប្រកាសដំណឹងល្អ ។

- តើការសាកល្បងអ្វីខ្លះ ដែលព្រះយេស៊ូវបានមានបន្ទូលថា ពួកសាវករបស់ទ្រង់នឹងជួបនៅពេលពួកគាត់ចេញទៅប្រកាសដំណឹងល្អ ?
- យោងតាម ខទី ១៩–២០តើពួកសាវកដឹងពីអ្វីដែលត្រូវនិយាយនៅក្នុងស្ថានភាពដ៏លំបាកទាំងនេះបានដោយរបៀបណា ? (អ្នកអាចនឹងត្រូវពន្យល់ថា ឃ្លា « កុំប់ព្រួយ » មានន័យថា « កុំឲ្យបារម្ភខ្លាំងពេក ») ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ មកពីខគម្ពីរទាំងនេះ អំពីការនិយាយទៅកាន់មនុស្សដទៃ នៅពេលយើងស្ថិតនៅក្នុងការបម្រើរបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យខុស ៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងស្ថិតនៅក្នុងការបម្រើរបស់ព្រះអម្ចាស់ ទ្រង់នឹងបំផុសគំនិតយើងពីអ្វីដែលត្រូវនិយាយ នៅពេលដែលចាំបាច់**) ។
- តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះអម្ចាស់បានបំផុតគំនិតអ្នកឲ្យដឹងពីអ្វីដែលត្រូវនិយាយទៅកាន់មនុស្សម្នាក់ទៀតនៅពេលណាដែរ ? (អ្នកគួរទុកពេលឲ្យសិស្សគិត ពីមុនសុំឲ្យពួកគេឆ្លើយនឹងសំណួរនេះ) ។

សូមសង្ខេប ម៉ាថាយ ១០:២១–៤២ ដោយពន្យល់ថា ព្រះយេស៊ូវគ្រីស្ទបានបន្តប្រទានការណែនាំ ការព្រមាន និងការលួងលោមដល់ពួកសាវករបស់ទ្រង់ពីការសោកល្វងដែលពួកគាត់នឹងជួប ។ ដើម្បីជួយសិស្សសិក្សាព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុង ម៉ាថាយ ១០:៣៧–៣៩សូមបំបែកពួកគេជាគូ ឬជាក្រុមតូចៗ ហើយឲ្យដៃគូ ឬក្រុមនីមួយៗនូវសំណៅនៃ ឯកសារដែលភ្ជាប់មកជាមួយ ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមសេចក្តីណែនាំនៅលើឯកសារនោះដោយសិក្សារួមគ្នានូវខគម្ពីរដែលបានចាត់ឲ្យ ហើយពិភាក្សាចម្លើយរបស់ពួកគេចំពោះសំណួរនានា ។

ម៉ាថាយ ១០:៣៧–៣៩

សូមសិក្សារួមគ្នាជាដៃគូ ឬជាក្រុមតូចៗនូវខគម្ពីរដែលបានចាត់ឲ្យ ហើយពិភាក្សាពីចម្លើយរបស់អ្នកចំពោះសំណួរនានា ។

សូមអាន ម៉ាថាយ ១០:៣៧–៣៨ដោយរកមើលការលះបង់ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា យើងត្រូវព្រមធ្វើដូចជាពួកសាវករបស់ទ្រង់ដែរ ។ ឃ្លាថា « គួរនឹងខ្ញុំ » នៅក្នុងខគម្ពីរទាំងនេះមានន័យថា អ្នកតំណាងដ៏សក្តិសមមួយរូបរបស់ព្រះអម្ចាស់ ហើយសក្តិសមនឹងពរជ័យរបស់ទ្រង់ ។

- ហេតុអ្វីអ្នកគិតថា វាជាការចាំបាច់សម្រាប់ពួកសាវករបស់ព្រះយេស៊ូវគ្រីស្ទត្រូវស្រឡាញ់ទ្រង់លើសអ្វីៗផ្សេងទៀត—រួមបញ្ចូលទាំងសមាជិកគ្រួសាររបស់ពួកគេផងដែរ ?



ពាក្យ ឈើឆ្កាង ដែលបានលើកឡើងក្នុង ខទី ៣៨ និយាយទៅដល់ឈើឆ្កាងដែលព្រះយេស៊ូវគ្រីស្ទបានលី ហើយត្រូវបានលើកឡើងដើម្បីបំពេញតាមព្រះទ័យរបស់ព្រះវរបិតាទ្រង់ ។ ក្នុងន័យធៀបព្រះយេស៊ូវគ្រីស្ទបានអំពាវនាវឲ្យពួកអ្នកដើរតាមទ្រង់ « ផ្ទុកឈើឆ្កាងខ្លួនមកតាម [ទ្រង់] » (ម៉ាថាយ ១៦:២៤) ។

សូមអានការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ១៦:២៦ (នៅក្នុង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ហើយរកមើលអត្ថន័យរបស់វាចំពោះយើងក្នុងការផ្ទុកឈើឆ្កាងរបស់យើង ហើយដើរតាមព្រះយេស៊ូវគ្រីស្ទ ។

សូមអាន ម៉ាថាយ ១០:៣៩ដោយរកមើលគោលការណ៍ ដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនអំពីការលះបង់ ។ ការបកប្រែដោយយ៉ូសែប ស៊្មីធ បញ្ជាក់ពីការចាប់ផ្តើមនៃខគម្ពីរនេះថា « អ្នកដែលចង់ឲ្យរួចជីវិត . . . ») ។ នៅក្នុងបរិបទនេះ ឃ្លាថា « រួចជីវិត » មានន័យថាការរស់នៅដោយកំណាញ់ជាជាងខិតខំបម្រើព្រះ និងកូនចៅរបស់ទ្រង់ ។

- តើអ្នកគិតថា មនុស្សដែលផ្តោតលើបំណង និងក្តីប្រាថ្នាដ៏កំណាញ់របស់ខ្លួន នៅទីបំផុតនឹង « បាត់ » ជីវិតទៅដោយរបៀបណា ?

យោងតាមអ្វីដែលអ្នកបានអាន សូមបំពេញគោលការណ៍ខាងក្រោម ៖

ប្រសិនបើយើងខិតខំដើម្បីបានរួចជីវិតនោះ _____ ។

សូមពិចារណាគូសចំណាំនៅក្នុង ខទី ៣៩ នូវសន្យាដែលព្រះអង្គសង្គ្រោះបានធ្វើដល់អស់អ្នកដែលបានបាត់ជីវិតសម្រាប់កិច្ចការរបស់ទ្រង់ ។ ការបាត់ជីវិតសម្រាប់កិច្ចការរបស់ទ្រង់ គឺលើសពីការសុខចិត្តស្លាប់ដើម្បីទ្រង់ទៅទៀត ។ វាមានន័យថា ការយល់ព្រមថ្វាយខ្លួនយើងរាល់ថ្ងៃដើម្បីបម្រើទ្រង់ និងមនុស្សដែលនៅជុំវិញយើង ។

- តើអ្នកគិតថា កាលដែលយើងរកឃើញជីវិតមកវិញ នៅពេលយើងបាត់ជីវិតសម្រាប់ទ្រង់នោះមានន័យដូចម្តេច ?

យោងតាមអ្វីដែលអ្នកបានអាន សូមបំពេញគោលការណ៍ខាងក្រោម ៖

ប្រសិនបើយើងបាត់ជីវិតសម្រាប់ព្រះយេស៊ូវគ្រីស្ទ នោះ _____ ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន រួចពិភាក្សាចម្លើយរបស់អ្នកសម្រាប់សំណួរបន្ទាប់ពីនោះ ។



« ខ្ញុំជឿថា ព្រះអង្គសង្គ្រោះកំពុងតែប្រាប់យើងថា លើកលែងតែយើងលះបង់ខ្លួនយើង ដើម្បីបម្រើដល់អ្នកដទៃ នោះទើបជីវិតរបស់យើងថ្កាល់នឹងមានគោលបំណងបន្តិចបន្តួចវិញ ។ អ្នកទាំងឡាយណាដែលរស់នៅសម្រាប់តែខ្លួនឯងទីបំផុតនឹងហួតហែង ហើយមាននិមិត្តរូបជា ការបាត់ជីវិតរបស់ខ្លួន ខណៈដែលមនុស្សដែលបាត់បង់ខ្លួនពួកគេដើម្បីបម្រើអ្នកដទៃ នឹងរីកចម្រើន ហើយលូតលាស់—និងជាប្រយោជន៍សំរាប់សង្គ្រោះ ជីវិតរបស់ពួកគេវិញ » (« What Have I Done for Someone Today ? » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៨៥) ។

- តើមនុស្សដែលអ្នកស្គាល់ដែលបានជ្រើសរើសបាត់បង់ជីវិតសម្រាប់ព្រះយេស៊ូវគ្រីស្ទជានរណា ? តើការសម្រេចចិត្តនេះមានផលប៉ះពាល់អ្វីខ្លះចំពោះបុគ្គលនេះ ?

បន្ទាប់ពីសិស្សបានបំពេញឯកសារនោះរួច អ្នកអាចសុំឲ្យពួកគេពីរបីនាក់សង្ខេបប្រាប់សិស្សផ្សេងទៀតពី អ្វីដែលពួកគេបានរៀន ។

អ្នកគួរចែកចាយទីបន្ទាល់របស់អ្នកពីគោលការណ៍ ដែលសិស្សបានស្គាល់ពាក់ព័ន្ធនឹងការបាត់ជីវិតរបស់យើងសម្រាប់ព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅ ក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេពីរឿងមួយចំនួនដែលពួកគេអាចធ្វើនៅសព្វថ្ងៃនេះ ឬនៅអនាគតដើម្បីបាត់ជីវិតខ្លួននៅក្នុងការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ និង អ្នកដទៃ ។ សូមអញ្ជើញពួកគេកំណត់គោលដៅមួយ ហើយអនុវត្តតាមគោលដៅនោះ ។

មេរៀន ១៤

ម៉ាថាយ ១១–១២

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានថ្លែងទីបន្ទាល់ថា យ៉ូហាន បាទីស្ទ ត្រូវបានបញ្ជូនមកដើម្បីរៀបចំផ្លូវពីមុនទ្រង់ ហើយទ្រង់បានសន្យាដល់អស់អ្នកណាដែលមករកទ្រង់ឲ្យបានសម្រាក ។ ព្រះយេស៊ូវបានតបនឹងការចោទប្រកាន់របស់ពួកផារិស៊ីថា ព្រះចេស្តារបស់ទ្រង់បានមកពីអារក្ស ។ ទ្រង់បានព្រមានពួកគេចំពោះការធ្វើការចោទប្រកាន់ខុសឆ្គង និងស្វែងរកទីសម្គាល់ ហើយទ្រង់បានបង្រៀនរឿងប្រៀបប្រដូចពីផ្ទះនៅទំនេរ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១១

ព្រះយេស៊ូវគ្រីស្ទបានថ្លែងទីបន្ទាល់ថា យ៉ូហាន បាទីស្ទ ត្រូវបានបញ្ជូនមកដើម្បីរៀបចំផ្លូវពីមុនទ្រង់

សូមបង្ហាញរូបភាពមន្ត្រីនគរបាល វេជ្ជបណ្ឌិត និងព្រះយេស៊ូវគ្រីស្ទដល់សិស្ស ។

- **ហេតុអ្វីការដឹងថាមនុស្សទាំងនេះ ពិតជាបង្ហាញខ្លួនថាពួកគេជានរណាគឺជារឿងដ៏សំខាន់ ? តើអ្នកអាចដឹងថា ពួកគេពិតជាបានបង្ហាញខ្លួនថាពួកគេជានរណាបានដោយរបៀបណា ?**

សូមពន្យល់ថា នៅក្នុងការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះយេស៊ូវគ្រីស្ទ មានមនុស្សជាច្រើនបានព្យាយាមចង់ដឹងថា តើអត្តសញ្ញាណពិតរបស់ទ្រង់ពិតដូចជាការបង្ហាញរបស់ទ្រង់មែនទេ ។ ចូរសុំឲ្យសិស្សរកមើលសេចក្តីពិតនានា នៅពេលពួកគេសិក្សាម៉ាថាយ ១១ ដែលអាចជួយពួកគេឲ្យអភិវឌ្ឍទីបន្ទាល់របស់ពួកគេថា តើព្រះយេស៊ូវគ្រីស្ទគឺជានរណា ។

សូមពន្យល់ថា ស្តេចហេរ៉ូឌបានចាប់ខ្លួន យ៉ូហាន បាទីស្ទ ទៅឃុំឃាំង ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១១: ២–៣ ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួរដែល យ៉ូហាន បានឲ្យសិស្សរបស់គាត់ឲ្យទៅទូលសួរព្រះយេស៊ូវ ។

- **តើយ៉ូហានបានបញ្ជូនសិស្សគាត់ឲ្យទូលសួរព្រះយេស៊ូវអំពីអ្វី ?**

សូមចង្អុលបង្ហាញថា ជាមួយនឹងសំណួរនេះក្នុង ខទី ៣សិស្សរបស់យ៉ូហានបានទូលសួរព្រះយេស៊ូវថា តើទ្រង់ជាព្រះមេស៊ីមែនទេ ។ សូមរំឭកសិស្សថា យ៉ូហាន បាទីស្ទ បានដឹងថា ព្រះយេស៊ូវគឺជាព្រះមេស៊ីរួចទៅហើយ (សូមមើល ម៉ាថាយ ៣:១១, ១៣–១៤; យ៉ូហាន ១:២៩–៣៤) ។

- **ហេតុអ្វីអ្នកគិតថាយ៉ូហាន បាទីស្ទ បានបញ្ជូនពួកសិស្សរបស់គាត់ឲ្យទៅសួរមើលថាតើព្រះយេស៊ូវគឺជាព្រះមេស៊ីមែនទេ កាលយ៉ូហានបានដឹងថាព្រះយេស៊ូវជានរណាហើយនោះ ? (គាត់ចង់ឲ្យពួកសិស្សរបស់គាត់ ទទួលបានសាក្សីផ្ទាល់ខ្លួនពីព្រះយេស៊ូវគ្រីស្ទ) ។**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១១:៤–៥ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះយេស៊ូវបានឆ្លើយនឹងសំណួររបស់ពួកគេ ។

- **ជាជាងគ្រាន់តែបញ្ជាក់ថា ទ្រង់គឺជាព្រះមេស៊ី តើព្រះយេស៊ូវបានឲ្យសិស្សរបស់យ៉ូហាន បាទីស្ទធ្វើអ្វីខ្លះ ?**

អ្នកគួរពន្យល់ថា ព្រះយេស៊ូវអាចមានបន្ទូលប្រាប់ទៅពួកសិស្សរបស់យ៉ូហានដោយងាយថា ទ្រង់គឺជាព្រះមេស៊ី ។ ផ្ទុយទៅវិញ ទ្រង់បានឲ្យពួកគេ « ឮ ហើយឃើញ » (ខទី ៤) ឬពិចារណាពីកិច្ចការរបស់ទ្រង់ រួចត្រឡប់ទៅរកយ៉ូហាន បាទីស្ទ ហើយថ្លែងទីបន្ទាល់ពីរឿងដែលពួកគេបានឮ ហើយឃើញព្រះយេស៊ូវធ្វើ ។

- **តើចម្លើយរបស់ព្រះយេស៊ូវអាចជួយពួកសិស្សរបស់យ៉ូហានឲ្យទទួលបានសាក្សីកាន់តែខ្លាំងក្លាមួយ អំពីព្រះអង្គសង្គ្រោះគ្រាន់តែមានបន្ទូលប្រាប់ពួកគេថាទ្រង់ជានរណាដោយរបៀបណា ?**
- **តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីដំណើររឿងនេះ អំពីរបៀបដែលយើងអាចពង្រឹងសាក្សីរបស់យើងពីព្រះអង្គសង្គ្រោះ ? (ទោះបីជាពួកគេអាចនឹងប្រើពាក្យខុសគ្នាក៏ដោយ សិស្សទាំងឡាយគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **នៅពេលយើងខិតខំរៀនសូត្រពីព្រះយេស៊ូវគ្រីស្ទ ហើយនៅពេលយើងថ្លែងទីបន្ទាល់ពីទ្រង់ នោះយើងអាចពង្រឹងទីបន្ទាល់របស់យើងពីទ្រង់ផងដែរ**) ។**

សូមអញ្ជើញសិស្សឲ្យសរសេរពីរបៀបដែលពួកគេបានស្គាល់ដោយខ្លួនឯងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ។ អ្នកគួរអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វី ដែលពួកគេបានសរសេរ ។

សូមសង្ខេប ម៉ាថាយ ១១:៧–២៧ ដោយពន្យល់ថា ក្រោយពីសិស្សទាំងពីរនាក់នោះបានចេញទៅ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ហ្វូងមនុស្សថា យ៉ូហាន បាទីស្ទ គឺជាព្យាការីដែលបានជ្រើសដើម្បីរៀបចំផ្លូវថ្វាយព្រះមេស៊ី ។ ព្រះយេស៊ូវបានដាក់ទោសដល់ជនដែលបានបដិសេធ យ៉ូហាន បាទីស្ទ ក៏ដូចជាជនដែលបានឃើញយ៉ាងច្បាស់ពីភស្តុតាងនៃទេវភាពរបស់ព្រះអម្ចាស់ ប៉ុន្តែនៅតែបដិសេធទ្រង់ផងដែរ ។ (*កំណត់ចំណាំ ៖* ការបង្រៀនរបស់ព្រះយេស៊ូវអំពីយ៉ូហាន បាទីស្ទ នៅក្នុងខគម្ពីរទាំងនេះនឹងត្រូវបានពិភាក្សាលម្អិតនៅក្នុងមេរៀន លូកា ៧:១៨–៣៥) ។

ម៉ាថាយ ១១:២៨–៣០ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

សម្រាប់ការពន្យល់អំពីចំណេះចំណានខគម្ពីរ និងបញ្ជីនៃសកម្មភាពបន្ថែម ដើម្បីជួយសិស្សឲ្យចេះចាំវគ្គបទគម្ពីរជាម្រើសទាំងនេះ សូមមើល ឧបសម្ព័ន្ធ នៃសៀវភៅសិក្សានេះ។

បន្ទាប់មក ព្រះយេស៊ូវបានប្រទានការសន្យាមួយដល់ជនទាំងអស់ដែលទទួលយកទ្រង់ជាព្រះមែស៊ី ។ ដើម្បីជួយសិស្សឲ្យមើល ម៉ាថាយ ១១:២៨–៣០ឡើងវិញដែលបានបង្រៀននៅក្នុងមេរៀនទី ១ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានអញ្ជើញឲ្យយើងធ្វើ ។

- តើព្រះអម្ចាស់បានអញ្ជើញយើងឲ្យធ្វើអ្វីខ្លះ ? តើទ្រង់សន្យានឹងប្រទានអ្វីខ្លះឲ្យយើងវិញ ? (បន្ទាប់ពីសិស្សបានចែកចាយចម្លើយរបស់ពួកគេហើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងសម្រាលបន្ទុករបស់យើង ហើយឲ្យយើងបានសម្រាក**) ។
- តើការយល់ដឹងពីសេចក្តីពិតនៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ អាចជួយអ្នកនៅក្នុងឆ្នាំនេះបានដោយរបៀបណា ?

ម៉ាថាយ ១២:១–៤២

ព្រះយេស៊ូវគ្រីស្ទស្តីបន្ទោសពួកផារិស៊ីអំពីការចោទប្រកាន់ក្លែងក្លាយ និងការព្យាយាមរកទីសម្គាល់របស់ពួកគេ ។

(កំណត់ចំណាំ ៖ ព្រឹត្តិការណ៍នៅក្នុងនៅក្នុង ម៉ាថាយ ១២:១–២១ នឹងត្រូវបង្រៀនយ៉ាងសឹងជម្រៅនៅក្នុងមេរៀន ម៉ាកុស ២–៣) ។

សូមសង្ខេប ម៉ាថាយ ១២:១–៣០ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានព្យាបាលបុរសម្នាក់នៅថ្ងៃឈប់សម្រាកមក មានពួកផារិស៊ីមួយចំនួនបានចាប់ផ្តើមព្យាយាមចង់កម្ចាត់ទ្រង់ចោល ។ នៅពេលទ្រង់បានព្យាបាលមនុស្សម្នាក់ដែលត្រូវអារក្សចូល ពួកគេប៉ុនប៉ងបង្ខូចទ្រង់នៅចំពោះមុខមនុស្សទូទៅដោយចោទប្រកាន់ទ្រង់ ពីការធ្វើកិច្চការទាំងនោះដោយអំណាចរបស់អារក្ស ។ ព្រះយេស៊ូវបានជ្រាបពីគំនិតរបស់ពួកគេ ហើយបានអះអាងផ្ទុយទៅវិញថា តាមរយៈការបណ្តេញអារក្សចេញនេះ ទ្រង់កំពុងបង្ហាញថា ទ្រង់គឺជាព្រះមែស៊ី ហើយកំពុងស្ថាបនានគរព្រះ ។ ចូរសុំឲ្យសិស្សអាន ម៉ាថាយ ១២:៣០ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលព្រះយេស៊ូវបានបង្រៀនពីជនដែលពុំចូលរួមនឹងទ្រង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខទី ៣០ប្រសិនបើយើងមានបំណងចង់រួមចំណែកក្នុងនគរព្រះ តើយើងត្រូវធ្វើអ្វីខ្លះ ? (នៅពេលសិស្សចែកចាយចម្លើយរបស់ពួកគេ សូមប្រាកដថា មានការគូសបញ្ជាក់ពីសេចក្តីពិតនេះ ៖ **ប្រសិនបើមានបំណងចង់ក្លាយជាផ្នែកមួយនៃនគរព្រះ យើងត្រូវតាំងចិត្តទាំងស្រុងស្មោះត្រង់នឹងព្រះយេស៊ូវគ្រីស្ទ**) ។
- តើវិធីដែលយើងអាចបង្ហាញការតាំងចិត្តទាំងស្រុងរបស់យើងស្មោះត្រង់នឹងព្រះយេស៊ូវគ្រីស្ទមានអ្វីខ្លះ ?

សូមសង្ខេប ម៉ាថាយ ១២:៣១–៤២ ដោយពន្យល់ថា ព្រះយេស៊ូវបានបញ្ជាក់ជាថ្មីម្តងទៀតថា កិច្চការល្អរបស់ទ្រង់គឺជាភស្តុតាងថា ទ្រង់មកពីព្រះ ហើយពុំមែនមកពីអារក្សឡើយ ។ ទ្រង់ក៏បានព្រមានពួកផារិស៊ីផងដែរថា ព្រះនឹងធ្វើឲ្យពួកគេទទួលខុសត្រូវចំពោះពាក្យចោទប្រកាន់របស់ពួកគេ ។ បន្ទាប់មកមានពួកអាចារ្យ និងពួកផារិស៊ីខ្លះបានសូរកកទីសម្គាល់ ហើយព្រះយេស៊ូវបានស្តីបន្ទោសពួកគេចំពោះការកទីសម្គាល់ និងការមើលពុំឃើញថា ទ្រង់ធំជាងព្យាការី មុនៗ ឬស្តេចណាៗទាំងអស់ក្នុងអ៊ីស្រាអែល ។

ម៉ាថាយ ១២:៤៣–៥០

ព្រះយេស៊ូវបង្រៀនរឿងប្រៀបប្រដូចពីផ្ទះនៅទំនេរ ហើយថាជនដែលធ្វើតាមព្រះទ័យរបស់ព្រះបិតាទ្រង់នឹងត្រូវបានរាប់បញ្ចូលនៅក្នុងចំណោមគ្រួសាររបស់ទ្រង់

ចូរសុំសិស្សឲ្យនឹកស្រមៃថា មានមិត្តរបស់ពួកគេម្នាក់បានសុំការប្រឹក្សាពីរបៀបចៀសវាងការត្រឡប់ទៅធ្វើអំពើបាប ដែលគាត់កំពុងព្យាយាមលះបង់ចោល ។

- តើអ្នកនឹងផ្តល់ការទុទ្ទានអ្វីខ្លះទៅមិត្តរបស់អ្នក ដើម្បីជួយគាត់ឲ្យតតាំងនឹងការល្បួងនោះ ?

សូមពន្យល់ថា ម៉ាថាយ ១២:៤៣–៤៥ មាននូវរឿងប្រៀបប្រដូចមួយពីវិញ្ញាណអាក្រក់មួយ ដែលត្រូវបានបណ្តេញចេញពីខ្លួនរបស់បុរសម្នាក់ ។ សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយនៅក្នុងរឿងប្រៀបប្រដូចនេះដែលអាចជួយមិត្តរបស់ខ្លួនឲ្យយកឈ្នះការល្បួង ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១២:៤៣–៤៤ ឲ្យ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលវិញ្ញាណអាក្រក់នោះបានធ្វើ បន្ទាប់ពីបានបណ្តេញចេញពីខ្លួនបុរសនោះ ។

- តើវិញ្ញាណអាក្រក់នោះ បានធ្វើអ្វីខ្លះបន្ទាប់ពីគ្មានកន្លែងជ្រកកោន ?
- តើពាក្យអ្វីទៅ ដែលពិពណ៌នាពីស្ថានភាពនៃ « ផ្ទះ » ឬបុរសនោះ ពេលដែលវិញ្ញាណមិនស្អាតត្រឡប់មកវិញ ?

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យអាន ម៉ាថាយ ១២:៤៥ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលវិញ្ញាណអាក្រក់នោះបានធ្វើបន្ទាប់ពីស្វែងរក « ផ្ទះ » ឬបុរសដែលនៅទទេស្អាត ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើបុរសនៅក្នុងរឿងប្រៀបប្រដូចនេះពុំបានធ្វើអ្វីខ្លះ ដែលអនុញ្ញាតឲ្យវិញ្ញាណអាក្រក់ត្រឡប់ចូលខ្លួនវិញ បន្ទាប់ពីអារក្សត្រូវបានបណ្តេញចេញពីខ្លួនគាត់នោះ ? (គាត់ពុំបានដាក់ជំនួសគំនិតអាក្រក់ ជាមួយគំនិត អារម្មណ៍ ពាក្យសម្តី និងទង្វើសុចរិតនោះទេ) ។
- តើបទពិសោធន៍របស់បុរសនៅក្នុងរឿបប្រៀបប្រដូចនេះ អាចតំណាងឲ្យមនុស្សម្នាក់ដែលកំពុងប្រែចិត្តពីអំពើបាប ហើយព្យាយាមតតាំងនឹងការល្បួងដោយរបៀបណា ?

បន្ទាប់ពីសិស្សបានឆ្លើយរួចហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ស្តែនសើរ ដបុលយូ ឃីមបឹល ៖



« នៅក្នុងការលះបង់ចោលអំពើបាប មនុស្សម្នាក់ពុំអាចគ្រាន់តែមាន *បំណងល្អ* ចង់ឲ្យស្ថានភាពបានប្រសើរឡើង ប៉ុណ្ណោះទេ ។ ប៉ុន្តែគាត់ត្រូវតែ *ធ្វើ* វា ។ . . .

« . . . រឿងដែលបានទាក់ទាញគាត់ ដែលបានចាប់យកគំនិតរវើរវាយរបស់គាត់ ហើយបានវាយលុកគំនិតរបស់គាត់ បានរលុតបាត់ទៅ ហើយការជំនួសដ៏ប្រសើរពុំទាន់បានបំពេញទីចំហនោះនៅឡើយ ។ នេះគឺជាឱកាសរបស់សាតាំង » (*The Miracle of Forgiveness* ⁄ ឆ្នាំ ១៩៦៩ ⁄ ទំព័រ ១៧១–៧២, ការគូសបញ្ជាក់បានបន្ថែម) ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ពីរឿងប្រៀបប្រដូចនេះដែលអាចជួយយើងឲ្យដឹងពីរបៀបដើម្បីបន្តរុញច្រានឥទ្ធិពលអាក្រក់បន្ទាប់ពីយើងបានដកវាចេញពីជីវិតរបស់យើង ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **យើងអាចរុញច្រានឥទ្ធិពលអាក្រក់ចេញ បន្ទាប់ពីយើងបានដកវាចេញពីជីវិតរបស់យើងដោយការដាក់ជំនួសវាដោយសេចក្តីសុចរិតវិញ**) ។

ដើម្បីជួយសិស្សយល់សេចក្តីពិតនេះ ចូរសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមឮៗ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលពីហេតុដលដែលថាវាពុំគ្រប់គ្រាន់ទេ បើគ្រាន់តែកម្ចាត់អំពើបាបចេញពី ជីវិតរបស់យើងតែប៉ុណ្ណោះនោះ ។

« ការព្យាយាមតតាំងនឹងអំពើបាប ឬធ្វើឲ្យជីវិតរបស់អ្នកជ្រះស្រឡះពីអំពើបាបតែម្យ៉ាងនោះគឺវាពុំគ្រប់គ្រាន់ទេ ។ អ្នកត្រូវបំពេញជីវិតរបស់អ្នកជាមួយនឹងសេចក្តីសុចរិត និងចូលរួមនៅក្នុងសកម្មភាពដែលនាំមកនូវអំណាចខាងវិញ្ញាណ ។ . . .

« ការគោរពប្រតិបត្តិដ៏ពេញលេញ នាំអំណាចដ៏ពេញលេញនៃដំណឹងល្អចូលទៅក្នុងជីវិតរបស់អ្នក រួមបញ្ចូលទាំងមានកម្លាំងកើនឡើងដើម្បីយកឈ្នះភាពទន់ខ្សោយរបស់អ្នក ។ ការគោរពនេះ រួមមានសកម្មភាពដែលអ្នកមិនអាចគិតដល់ពីដំបូងនៃផ្នែកនៃការប្រែចិត្ត ដូចជា ការចូលរួមការប្រជុំ ការបង់ដង្វាយមួយភាគដប់ ការផ្តល់ការបម្រើ និងការអភ័យទោសដល់អ្នកដទៃ » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* (ឆ្នាំ ២០០៤) ទំព័រ ១៣៥) ។

- នៅពេលយើងប្រែចិត្ត តើរឿងមួយចំនួនដែលយើងអាចធ្វើដើម្បីបំពេញជីវិតរបស់យើងដោយសេចក្តីសុចរិតដើម្បីយើងពុំត្រឡប់ទៅរកអំពើបាបវិញ មានអ្វីខ្លះ ? (អ្នកគួរអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយនៅលើក្តារខៀន) ។
- តើការធ្វើរឿងទាំងនេះ អាចនាំអំណាចខាងវិញ្ញាណដ៏ធំធេងចូលទៅក្នុងជីវិតរបស់យើង ហើយអាចជួយយើងឲ្យយកឈ្នះលើឥទ្ធិពលអាក្រក់បានដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ថា ការបំពេញជីវិតរបស់យើងដោយសេចក្តីសុចរិតនឹងផ្តល់អំណាចដ៏ធំធេងដល់យើងដើម្បីរុញច្រានអំពើអាក្រក់ ។ សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីរបៀបដែលពួកគេអាចបំពេញជីវិតរបស់ពួកគេដោយសេចក្តីសុចរិតកាន់តែច្រើនឡើង ហើយធ្វើតាមការបំផុតគំនិតដែលពួកគេទទួលបាននៅពេលពួកគេសញ្ជឹងគិត ។

សូមសង្កេតផ្នែកដែលនៅសល់នៃ ម៉ាថាយ ១២ ដោយពន្យល់ថា កាលព្រះយេស៊ូវកំពុងបង្រៀន មានមនុស្សម្នាក់បានទូលប្រាប់ទ្រង់ថា មានសមាជិកគ្រួសារមួយចំនួនរបស់ទ្រង់ចង់ជួបទ្រង់ ។ រួចព្រះអម្ចាស់បានបង្រៀនថា ជនទាំងអស់ណាដែលធ្វើតាមព្រះទ័យរបស់ព្រះវរបិតា ត្រូវបានរាប់បញ្ចូលនៅក្នុងចំណោមគ្រួសាររបស់ទ្រង់ ។

ចំណេះចំណានខគម្ពីរ—ម៉ាថាយ ១១:២៨–៣០

ដើម្បីជួយសិស្សឲ្យទន្ទេញចាំ ម៉ាថាយ ១១:២៨–៣០សូមអញ្ជើញសិស្សឲ្យបង្កើតសកម្មភាពនានាដែលអាចតំណាងឲ្យពាក្យ ឬឃ្លាទាំងឡាយនៅក្នុងខគម្ពីរនីមួយៗ រួចសូត្រវគ្គនោះកាលធ្វើសកម្មភាពទាំងនោះ ។ ចូរសុំឲ្យសិស្សអនុវត្តសូត្រវគ្គនោះ នៅពេលចាប់ផ្តើមថ្នាក់រយៈពេលពីរបីថ្ងៃរហូតដល់ពួកគេអាចសូត្រវាដោយការចងចាំ ។

មេរៀន ១៥

ម៉ាថាយ ១៣:១–២៣

សេចក្តីផ្តើម

កាលព្រះយេស៊ូវគង់នៅស្រុកកាលីឡេ មានហ្វូងមនុស្សច្រើនសន្ធឹកបានមករកទ្រង់ ។ ព្រះអង្គសង្គ្រោះបានបង្រៀនមនុស្សទាំងនោះដោយប្រើរឿងប្រៀបប្រដូចនានា ដោយចាប់ផ្តើមជាមួយនឹងរឿងប្រៀបប្រដូចអំពីអ្នកព្រួសគ្រាប់ពូជ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៣:១–១៧

ព្រះអង្គសង្គ្រោះចាប់ផ្តើមបង្រៀនជារឿងប្រៀបប្រដូច

សូមបង្ហាញសិស្សនូវកំប៉ុងតូចមួយដែលមានដីពេញ ។

- **តើដីដែលមានជីវជាតិមានលក្ខណៈអ្វីខ្លះ ? ចុះដែលគ្មានជីវជាតិវិញ ?**

សូមពន្យល់ថានៅក្នុង ម៉ាថាយ ១៣:១–២៣យើងអានថា ព្រះអង្គសង្គ្រោះបានប្រៀបធៀបប្រភេទដីខុសគ្នាទៅនឹងកម្រិតនៃការបើកចំហ ឬការទទួលយកខាងវិញ្ញាណនៃដួងចិត្តរបស់មនុស្សម្នាក់ៗ ។ នៅពេលសិស្សសិក្សាខគម្ពីរទាំងនេះ សូមអញ្ជើញពួកគេឲ្យពិចារណាថា តើប្រភេទដីមួយណាដែលទំនងជាស្តានភាពនៃដួងចិត្តរបស់ពួកគេសព្វថ្ងៃ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ១៣:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះយេស៊ូវបានបង្រៀនដល់ហ្វូងមនុស្សនៅស្រុកកាលីឡេ ។

- **តើព្រះយេស៊ូវបានបង្រៀនដល់ហ្វូងមនុស្សទាំងនោះតាមរបៀបណា ? (ជារឿងប្រៀបប្រដូច) ។**

សូមអញ្ជើញសិស្សឲ្យអានឃ្លាពីរដំបូងក្រោមពាក្យ « រឿងប្រៀបប្រដូច » ក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។


- **តើរឿងប្រៀបប្រដូចគឺជាអ្វី ?**

សូមពន្យល់ថា រឿងប្រៀបប្រដូចគឺជា « រឿងសាមញ្ញមួយដែលត្រូវបានប្រើ ដើម្បីបង្ហាញ និងបង្រៀន សេចក្តីពិតខាងវិញ្ញាណ ឬពីគោលការណ៍ ។ រឿងប្រដូចយោងទៅលើការប្រៀបធៀបវត្ថុបំណងធម្មតា ឬ ព្រឹត្តិការណ៍មួយ ទៅនឹងសេចក្តីពិត » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « រឿងប្រៀបប្រដូច » scriptures.lds.org) ។

- **យោងតាម ម៉ាថាយ ១៣:៣តើរឿងប្រៀបប្រដូចរបស់ព្រះអង្គសង្គ្រោះថ្លែងពីអ្វីទៅ ? (សូមពន្យល់ថា *ការព្រួសគ្រាប់ពូជ* មានន័យថា ការពង្រាយ ឬដាំគ្រាប់ពូជ) ។**

ចូរសុំឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ១៣:៤–៩ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលដីបួនប្រភេទដែលគ្រាប់ពូជរបស់អ្នកព្រួសគ្រាប់ពូជបានធ្លាក់លើ ។

- **តើដីប្រភេទណាខ្លះ ដែលគ្រាប់ពូជរបស់អ្នកព្រួសគ្រាប់ពូជបានធ្លាក់លើ ?**



សូមគូរ រូបភាព នៅលើក្តារខៀនដែលបរិយាយពីដីទាំងបួនប្រភេទ ហើយអញ្ជើញសិស្សឲ្យគូររូបស្រដៀងគ្នានេះ នៅក្នុងសៀវភៅកំណត់ចំណាំ ឬលើក្រដាសដែលអ្នកផ្តល់ឲ្យពួកគេ ។

សូមពន្យល់ថា ភ្លឺស្រែគឺជាគន្លងមួយនៅក្បែរទីវាលដែលមានភាពកាន់តែរឹងហាប់ ដោយសារតែមានមនុស្សដើរជាន់វា ។ ភាពរឹងហាប់ណែននៃភ្លឺស្រែ រារាំងគ្រាប់ពូជមិនឲ្យដុះឫសចាក់ចូលទៅក្នុងដីនោះ ។ កន្លែងថ្ម គឺជាថ្មែថ្មដែលគ្របដណ្តប់ដោយស្រទាប់ដីស្តើង ។ ហេតុដូច្នេះហើយ គ្រាប់ពូជអាចមានឫសរាក ថ្មដែលនៅពីក្រោមស្រទាប់ដីនោះរារាំងឫសកុំឲ្យចាក់ចូលទៅជ្រៅបាន ។ ដីដែលមានបន្លា គឺជាដីមានជីវជាតិ ប៉ុន្តែបន្លាបានដុះព័ទ្ធរុក្ខជាតិទាំងឡាយធ្វើឲ្យវាពុំអាចទទួលពន្លឺ ទឹក និងសារធាតុចិញ្ចឹមដែលចាំបាច់បានឡើយ ។ ដីល្អគឺជាដីមានជីវភាពដែលឫសអាចដុះចាក់ចូលយ៉ាងជ្រៅបាន ។

សូមសង្ខេប ម៉ាថាយ ១៣:១០–១៣ ដោយពន្យល់ថា ពួកសិស្សរបស់ព្រះអង្គសង្គ្រោះបានទូលសួរទ្រង់ពីហេតុផលដែលទ្រង់បង្រៀនជារឿងប្រៀបប្រដូច ។ ព្រះអង្គសង្គ្រោះបានពន្យល់ថា រឿងប្រៀបប្រដូចទាំងឡាយបានបើកសម្តែងពីអាថ៌កំបាំង ឬសេចក្តីពិតនៃនគរស្ថានសួគ៌ ដោយលាក់កំបាំងអត្ថន័យពីជនដែលពុំបានរៀបចំខ្លួនខាងវិញ្ញាណ (សូមមើល *New Testament Student Manual* | Church Educational System manual ឆ្នាំ ២០១៤ | ទំព័រ ៤៥) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៣:១៤–១៥ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលរារាំងមនុស្សពីការយល់ដឹងសេចក្តីពិតដែលព្រះអង្គសង្គ្រោះបានបង្រៀន ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថា អ្វីទៅដែលបានរារាំងមនុស្សពីការមើលឃើញ ការស្តាប់ឮ និងការយល់ដឹងពីសេចក្តីពិតដែលទ្រង់បានបង្រៀន ។ (សូមពន្យល់ថា ឃ្លា « ចិត្តរបស់ជនជាតិនេះបានត្រឡប់ជាស្ពឹកវិញ » មានន័យថា មនុស្សនោះមានចិត្តរឹងរូសហើយស្ពឹក) ។

នៅលើក្តារខៀនក្បែរគំនូរភ្លឺស្រែ សូមសរសេរសេចក្តីថ្លែងការណ៍មិនពេញលេញដូចតទៅ ៖ *ប្រសិនបើយើងមានចិត្តរឹងរូស នោះ* . . .

- យោងតាម ខទី ១៥តើយើងអាចបាត់បង់ពរជ័យអ្វីខ្លះ ប្រសិនបើយើងមានចិត្តរឹងរូស ? (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមបំពេញប្រយោគនៅលើក្តារខៀនដើម្បីនាំទៅរកគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងមានចិត្តរឹងរូស នោះយើងនឹងពុំយល់ពីព្រះបន្ទូលព្រះ ពុំបានប្រែចិត្តជឿចំពោះព្រះអង្គសង្គ្រោះ ហើយនឹងបានព្យាបាលដោយទ្រង់ឡើយ**) ។
- តើការប្រែចិត្តជឿចំពោះព្រះអង្គសង្គ្រោះ ហើយត្រូវបានព្យាបាលមានន័យដូចម្តេច ? (ការបានផ្លាស់ប្តូរ ហើយបានបរិសុទ្ធតាមរយៈដង្វាយធួនរបស់ទ្រង់ គឺដើម្បីឲ្យជំនឿ ដួងចិត្ត និងជីវិតរបស់យើង បានស្របទៅតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ហើយយើងបានរួចផុតពីបន្ទុកនៃអំពើបាប) ។

សូមសង្ខេប ម៉ាថាយ ១៣:១៦–១៧ ដោយពន្យល់ថា ព្រះយេស៊ូវបានមានព្រះបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់ថា ពួកគេមានពរដោយសារពួកគេមានភ្នែកដែលអាចមើលឃើញ និងត្រចៀកដែលអាចស្តាប់ឮ ។

ម៉ាថាយ ១៣:១៨–២៣

ព្រះអង្គសង្គ្រោះប្រទានការបកស្រាយរឿងប្រៀបប្រដូចស្តីពីអ្នកព្រួសគ្រាប់ពូជ

សូមយោងម្តងទៀតទៅគំនូររបស់ភ្លឺស្រែនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៣:១៨–១៩ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានប្រៀបធៀបទៅនឹងគ្រាប់ពូជ លើភ្លឺស្រែ និងបក្សីដែលបានលើកឡើងនៅក្នុង ម៉ាថាយ ១៣:៤ ។

- តើគ្រាប់ពូជតំណាងឲ្យអ្វី ? (សូមសរសេរឃ្លា *ព្រះបន្ទូលព្រះ* សម្រាប់គំនូរគ្រាប់ ពូជ) ។
- តើភ្លឺស្រែតំណាងឲ្យដួងចិត្តប្រភេទណាដែរ ? (សូមសរសេរឃ្លា *ពុំយល់ពីសេចក្តីពិត / ចិត្តរឹងរូស* សម្រាប់គំនូរផ្លូវ) ។
- តើសត្វស្លាបតំណាងឲ្យអ្វី ? តើនរណាជា « ជនទុច្ចរិត » ? (សូមសរសេរឃ្លា *សាតាំង និងពួកបរិវាររបស់វា* សម្រាប់គំនូរសត្វស្លាប) ។
- តើការបង្រៀនរបស់ព្រះអង្គសង្គ្រោះស្តីពីភ្លឺស្រែនោះ អាចជួយយើងឲ្យយល់ដឹងបន្ថែមទៀតពីគោលការណ៍ថា ប្រសិនបើយើងមានចិត្តរឹងរូស នោះយើងពុំយល់ពីព្រះបន្ទូលព្រះ ពុំបានប្រែចិត្តជឿចំពោះព្រះអង្គសង្គ្រោះ ហើយពុំបានព្យាបាលដោយទ្រង់ដោយរបៀបណា ?

សូមយោងទៅគំនូរដីមានថ្មនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង ម៉ាថាយ ១៣:២០–២១ និង លូកា ៨:១៣ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការបកស្រាយរបស់ព្រះអង្គសង្គ្រោះចំពោះកន្លែងដែលមានថ្ម ។

- តើរុក្ខជាតិដែលបានដុះនៅលើដីមានថ្មនោះតំណាងឲ្យអ្វី ? (សូមសរសេរឃ្លា *ទីបន្ទាល់ដែលគ្មានឫសចាក់ជ្រៅ* សម្រាប់គំនូររុក្ខជាតិនៅលើដីមានថ្ម) ។
- តើកំដៅព្រះអាទិត្យតំណាងឲ្យអ្វី ? (នៅលើគំនូររុក្ខជាតិដែលមានឫសរាក់ សូមសរសេរ *ការឈឺចាប់យ៉ាងខ្លាំង ការបៀតបៀន និងការល្បួង*) ។

សូមសរសេរសេចក្តីថ្លែងការណ៍មិនពេញលេញខាងក្រោម នៅលើក្តារខៀនក្បែរគំនូរដីដែលមានថ្ម ៖ *លុះត្រាយើងខិតខំធ្វើឲ្យទីបន្ទាល់របស់យើងកាន់តែជ្រៅឡើង* . . .

- យោងតាមអ្វីដែលអ្នកបានរៀននៅក្នុង ម៉ាថាយ ១៣:២០–២១ និង លូកា ៨:១៣តើអ្នកនឹងបំពេញសេចក្តីថ្លែងការណ៍នោះយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀនដើម្បីនាំទៅរកគោលការណ៍ខាងក្រោមនេះ ៖ **លុះត្រាយើងខិតខំធ្វើឲ្យទីបន្ទាល់របស់យើងកាន់តែខ្លាំងឡើង នោះយើងប្រហែលជាខ្វះកម្លាំងចាំបាច់ដើម្បីស៊ូទ្រាំនឹងការឈឺចាប់ដ៏ខ្លាំង ការបៀតបៀន និងការល្បួងទាំងឡាយ**) ។

សូមយោងទៅគំនូរដីមានបន្លានៅលើក្តារខៀន ។ សូមអញ្ជើញសិស្សអាន ម៉ាថាយ ១៣:២២ ដោយស្ងៀមស្ងាត់ ហើយរកមើលថា តើបន្លាតំណាងឲ្យអ្វី ។

- តើបន្លាតំណាងឲ្យអ្វី ? (សូមសរសេរឃ្លា *ការខ្វល់ខ្វាយពីលោកិយ* សម្រាប់គំនូរបន្លា) ។
- តើឧទាហរណ៍មួយចំនួនពី « ការខ្វល់ខ្វាយពីលោកិយ » មានអ្វីខ្លះ ? (ភាពរីករាយក្នុងលោកិយ ភាពលោភលន់ ឬការអូសទាញខាងសាច់ឈាមដែលនាំយើងឲ្យឃ្លាតឆ្ងាយពីព្រះ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ពីខគម្ពីរនេះអំពីអ្វីដែលការខ្វល់ខ្វាយពីលោកិយអាចប៉ះពាល់ដល់សេចក្តីជំនឿ និងទីបន្ទាល់របស់យើង ។ (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀនក្បែរនឹងគំនូរដីដែលមានបន្លា) ។ **ការខ្វល់ខ្វាយពីលោកិយអាចរំខានយើង ដកយកការផ្តោតយកចិត្តទុកដាក់របស់យើងចេញពីព្រះអម្ចាស់ ហើយពន្លិចសេចក្តីជំនឿ និងទីបន្ទាល់របស់យើងពីព្រះបន្ទូលព្រះ**) ។

សូមយោងទៅគំនូរដីល្អនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ១៣:២៣ ឲ្យឮៗនិងផ្អែកនៃការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់ខគម្ពីរនេះបានបញ្ជាក់ថា ៣ក្យ « យល់ » ប្រសិនបើបកប្រែឲ្យត្រឹមត្រូវនោះគឺថា « យល់ ហើយស៊ូទ្រាំ » ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើដីល្អតំណាងឲ្យអ្វី ។

ដើម្បីជួយសិស្សយល់ដឹងពីសារៈសំខាន់ពាក្យ *ស៊ូទ្រាំ* នៅក្នុងការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ ១៣:២១ សូមចង្អុលបង្ហាញថារុក្ខជាតិដុះនៅលើដីល្អបានទទួលរងកំដៅថ្ងៃដូចគ្នា (តំណាងឲ្យការឈឺចាប់ដ៏ខ្លាំង ការបៀតបៀន និងការល្បួងទាំងឡាយ) នឹងរុក្ខជាតិស្រពោនដុះនៅលើដី ដែលមានបន្លាដែរ ។

- តើអ្នកនឹងសន្និដ្ឋានថា ដីល្អតំណាងអ្វីតាមរបៀបណា ? (សូមសរសេរឃ្លា *មនុស្សម្នាក់ដែលស្តាប់ ហើយយល់ព្រះបន្ទូលព្រះ ហើយស៊ូទ្រាំនឹងការឈឺចាប់ដ៏ខ្លាំង ការបៀតបៀន និងការល្បួងទាំងឡាយ*) ។
- យោងតាម អ្វីដែលយើងបានរៀននៅក្នុង ម៉ាថាយ ១៣:១៥តើផលផ្លែដែលបានលើកឡើងនៅក្នុង ខទី ២៣ អាចតំណាងឲ្យអ្វីទៅ ? (ការប្រែចិត្តជឿចំពោះព្រះយេស៊ូវគ្រីស្ទ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ មកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីដីល្អ ? (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀនក្បែរនឹងគំនូរដីល្អ) ។ **នៅពេលយើងទទួលព្រះបន្ទូលព្រះ យល់ពីព្រះបន្ទូលនោះ ហើយស៊ូទ្រាំនឹងការឈឺចាប់ដ៏ខ្លាំង ការបៀតបៀន និងការល្បួងទាំងឡាយ យើងនឹងត្រូវបានប្រែចិត្តជឿចំពោះព្រះអង្គសង្គ្រោះ**) ។

ដើម្បីជួយសិស្សយល់ដឹងបន្ថែមទៀតពីគោលការណ៍ដែលពួកគេបានស្តាល់ សូមអញ្ជើញសិស្សប្អូននាក់ ឲ្យគេម្នាក់ៗអានសាច់រឿងមួយដូចខាងក្រោមនេះឲ្យឮៗ ។ បន្ទាប់ពីសិស្សម្នាក់ៗបានអានរួចហើយ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យពន្យល់ពីគោលការណ៍នីមួយៗដែលសាច់រឿងគួរបង្ហាញ ៖

១. មានយុវជនម្នាក់ចំណាយពេលស្ទើរតែរាល់ថ្ងៃខំសិក្សារៀនសូត្រ ដើម្បីទទួលបានការចូលរៀននៅសាកលវិទ្យាល័យដ៏ល្បីល្បាញមួយ ។ នៅពេលគាត់មិនរវល់ក្នុងការសិក្សា គាត់ខិតខំធ្វើការ ។ គាត់ប្រាប់ខ្លួនឯងថា គាត់គ្មានពេលអានព្រះគម្ពីរ អធិស្ឋាន ឬទៅព្រះវិហារនោះទេ ។

២. មានយុវនារីម្នាក់ផ្តាប់ចូលចិត្តទៅព្រះវិហាររាល់ថ្ងៃអាទិត្យ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលនាងចម្រើនវ័យធំឡើង មានមិត្តខ្លះបានចាប់ផ្តើមសើចចំអកដាក់នាងដោយសារបទដ្ឋានរបស់នាង ។ នាងបានចាប់ផ្តើមធ្វើខុសនឹងព្រះបញ្ញត្តិមួយចំនួន ។ នាងគ្មានអារម្មណ៍សុខស្រួលនៅឯព្រះវិហារទៀតឡើយ ហើយបានបាត់បង់បំណងប្រាថ្នាចង់ទៅចូលរួម ។

៣. មានយុវជនម្នាក់បានទៅព្រះវិហារជាទៀងទាត់ ប៉ុន្តែគាត់គ្រាន់តែទៅចូលរួម ហើយពុំបានបើកដួងចិត្តរបស់គាត់ចំពោះព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធឡើយ ។ គាត់បានអានព័ត៌មានតាមអ៊ិនធើរណែត ដែលបដិសេធគោលលទ្ធិដ៏សំខាន់របស់សាសនាចក្រ ហើយគាត់សួរខ្លួនឯងថាតើគាត់នៅជឿលើសេចក្តីពិតដ៏ពេញលេញនៃដំណឹងល្អទៀតដែរឬទេ ។

៤. មានយុវនារីម្នាក់ទៅព្រះវិហារ ហើយអធិស្ឋានដោយស្ងៀមស្ងាត់ដើម្បីនាងអាចទទួលបានការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលនាងទទួលបានការបំផុសគំនិត នោះនាងបានធ្វើតាមវា ។ នាងមានអារម្មណ៍នៅជិតនឹងព្រះអម្ចាស់ ហើយមានអំណរគុណចំពោះវិធីដែលនាងបានទទួលការបំផុសគំនិតដើម្បីយកឈ្នះលើការល្បួង ។

សូមពន្យល់សិស្សថា ដួងចិត្តប្រៀបដូចជាដីដែរ វាអាចផ្លាស់ប្តូរ ហើយប្រសើរឡើង ។ សូមសរសេរសំណួរខាងក្រោមដាក់លើ ក្តារខៀន ឬ ផ្តល់ជាឯកសារចែកឲ្យសិស្ស ៖ សូមអញ្ជើញសិស្សអាន ហើយពិភាក្សាសំណួរនោះជាមួយនឹងដៃគូ ៖

តើត្រូវធ្វើអ្វីខ្លះដើម្បីផ្លាស់ប្តូរ ឬថែទាំប្រភេទដីនីមួយៗដើម្បីឲ្យវាក្លាយជាកន្លែងគាប់ចិត្តមួយ ដើម្បីនឹងដាំដុះរុក្ខជាតិដែលល្អតម្លាស់ផ្តល់ផ្លែផ្កា ?

តើយើងអាចប្រដូចការធ្វើឲ្យដីនីមួយៗបានប្រសើរឡើងទៅនឹងអ្វីដែលយើងអាចធ្វើដើម្បីកាន់តែ ងាយទទួលព្រះបន្ទូលព្រះដោយរបៀបណា ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ចម្លើយរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

- តើការខិតខំទទួលបាន ហើយយល់ព្រះបន្ទូលព្រះធ្លាប់ជួយអ្នកឲ្យក្លាយជាប្រែចិត្តជឿយ៉ាងខ្លាំងទៅលើព្រះអង្គសង្គ្រោះបានដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថាតើដីប្រភេទ ណាដែលតំណាងឲ្យស្ថានភាពដួងចិត្តរបស់ពួកគេ នៅពេលនេះបានយ៉ាងល្អបំផុត ។ សូមអញ្ជើញសិស្សដាក់គោលដៅមួយពាក់ព័ន្ធនឹងអ្វីដែលពួកគេធ្វើ ដើម្បីទទួលបាន ហើយយល់ពីព្រះបន្ទូលព្រះកាន់តែប្រសើរឡើង ហើយស៊ូទ្រាំនឹងការឈឺចាប់ដ៏ខ្លាំង ការបៀតបៀន និងការល្បួងទាំងឡាយ ។ ប្រសិនបើមានពេល សូមអញ្ជើញសិស្សឲ្យ សរសេរគោលដៅរបស់ខ្លួននៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញឲ្យសិស្សឆ្លើយដោយសរសេរ ។

ការអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយដោយការសរសេរមុនពេលចែកចាយពីគំនិតរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់រៀន គឺផ្តល់ពេលវេលាឲ្យពួកគេដើម្បីរៀបចំគំនិត និង ទទួលការបើកបង្ហាញពីព្រះវិញ្ញាណបរិសុទ្ធ ។ សិស្សអាចមិនហ៊ានចែកចាយគំនិតរបស់ពួកគេនៅពេលពួកគេបានសរសេរដាលើកដំបូងនោះ ហើយអ្វីដែលពួកគេចែកចាយ ជាញឹកញាប់ វានឹងមានន័យកាន់តែខ្លាំងក្លា ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ៦:១–១៣:២៣ (មេរៀនទី ៣)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ៦:១–១៣:២៣ (មេរៀនទី ៣) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាថាយ ៦–៧)

នៅពេលសិស្សបន្តការសិក្សារបស់ពួកគេស្តីពីទេសនកថានៅលើភ្នំ ពួកគេបានរៀនដូចតទៅ ៖ ប្រសិនបើយើងធ្វើការលះបង់ ដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យជាដាច់ខាតមុនចង់បានចំណាប់អារម្មណ៍ពីមនុស្សដទៃ នោះទ្រង់នឹងប្រទានរង្វាន់ដល់យើងយ៉ាងធំធេង ។ យើងពុំអាចបម្រើទាំងព្រះ និង ទ្រព្យសម្បត្តិក្នុងពេលតែមួយបានទេ ។ នៅពេលយើងទូលសូមស្វែងរក ហើយគោះនៅក្នុងការស្វែងរកសេចក្តីពិត ព្រះវរបិតាសួគ៌នឹងឆ្លើយតប ហើយប្រទានវិវរណៈផ្ទាល់ខ្លួនដល់យើង ។ យើងអាចដឹងពីពួកព្យាការីក្លែងក្លាយដោយផលរបស់ពួកគេ ។

ថ្ងៃទី ២ (ម៉ាថាយ ៨–១០)

នៅក្នុងមេរៀននេះ សិស្សបានរៀនថា ព្រះយេស៊ូវអាចព្យាបាលពិការភាព និង ជំងឺរបស់យើង ហើយថាទ្រង់បានហៅ ពួកសាវកព្រមទាំងប្រទានសិទ្ធិអំណាចរបស់ទ្រង់ដល់ពួកគាត់ ។ សិស្សក៏រកឃើញផងដែរថា នៅពេលយើងស្ថិតនៅក្នុងការបម្រើរបស់ព្រះអម្ចាស់ ទ្រង់នឹងបំផុសចិត្តយើងឲ្យដឹងពីអ្វីដែលត្រូវនិយាយពេលត្រូវការ ហើយប្រសិនបើយើងលះបង់ជីវិតរបស់យើង (លះបង់ពេលវេលារបស់យើង) សម្រាប់បុព្វហេតុរបស់ព្រះគ្រីស្ទ នោះយើងនឹងរកឃើញគោលបំណងនៅក្នុងជីវិត ។

ថ្ងៃទី ៣ (ម៉ាថាយ ១១–១២)

សិស្សបានរៀនថា នៅពេលយើងខិតខំរៀនពីព្រះយេស៊ូវគ្រីស្ទ ហើយនៅពេលយើងថ្លែងទីបន្ទាល់ពីទ្រង់ ទីបន្ទាល់របស់យើងពីទ្រង់អាចត្រូវបានពង្រឹង ហើយប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងសម្រាលបន្ទុកយើង ហើយឲ្យយើងបានសម្រាក ។ លើសពីនេះទៀត សិស្សបានរៀនពីការប្តេជ្ញាចិត្តទាំងស្រុងចំពោះព្រះ និង ការជំនួសឥទ្ធិពលអាក្រក់នៅក្នុងជីវិតពួកគេដោយរឿងល្អៗ ។

ថ្ងៃទី ៤ (ម៉ាថាយ ១–២៣)

នៅពេលសិស្សបានសិក្សាពីរឿងប្រៀបប្រដូចនៃអ្នកព្រួសគ្រាប់ពូជ ពួកគេបានរៀនថា កង្វល់ពីលោកិយអាចរំខានយើង ធ្វើឲ្យយើងដកការផ្តោតយកចិត្តទុកដាក់ យើងចេញពីព្រះអម្ចាស់ ហើយជាន់ពន្លិចសេចក្តីជំនឿ និង ទីបន្ទាល់របស់យើងពីព្រះបន្ទូលរបស់ព្រះ ។ ដើម្បីការពាររឿងនេះកុំឲ្យកើតឡើង ហើយក្លាយជាប្រៃចិត្តជឿចំពោះព្រះអង្គសង្គ្រោះ យើងត្រូវទទួលព្រះបន្ទូលព្រះ ហើយព្យាយាមធ្វើឲ្យទីបន្ទាល់យើងបានចាក់ឫសយ៉ាងជ្រៅ ។

សេចក្តីផ្តើម

ដូចដែលបានកត់ត្រានៅក្នុង ម៉ាថាយ ៧ព្រះយេស៊ូវគ្រីស្ទបានបន្តទេសនកថារបស់ទ្រង់នៅលើភ្នំ ដោយបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យកាត់សេចក្តីដោយសុចរិត ។ ទ្រង់ក៏បង្រៀនពីការទទួលវិវរណៈផ្ទាល់ខ្លួន និងការធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ផងដែរ ។

យោបល់សម្រាប់ការបង្រៀន

កំណត់ចំណាំ ៖ នៅក្នុងមេរៀនសិក្សានៅផ្ទះសម្រាប់មេរៀនទី ១ និងមេរៀនថ្ងៃទី ៣ សម្រាប់សប្តាហ៍នេះ សិស្សបានសិក្សាវគ្គចំណេះចំណានខគម្ពីរក្នុង ម៉ាថាយ ១១:២៨–៣០ ។ សូមពិចារណាចំណាយពេលពីរបីនាទីមើលវគ្គនោះឡើងវិញជាមួយសិស្ស ។

ម៉ាថាយ ៧: ១–៥

ជាផ្នែកមួយនៃទេសនកថារបស់ទ្រង់នៅលើភ្នំ ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យកាត់សេចក្តីដោយសុចរិត ។

សូមសរសេរសំណួរខាងក្រោមនេះ នៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ *តើយើងគួរ ឬមិនគួរកាត់សេចក្តីអ្នកដទៃ ?* នៅពេលចាប់ផ្តើមថ្នាក់រៀន សុំឲ្យសិស្សឆ្លើយនឹងសំណួរនេះ ។

សូមដាក់រូប The Sermon on the Mount (*Gospel Art Book* [ឆ្នាំ២០០៩] ល.រ. ៣៩ សូមមើលផងដែរ LDS.org) ។ សូមពន្យល់ថា នៅពេលព្រះយេស៊ូវបានបន្តទេសនកថារបស់ទ្រង់នៅលើភ្នំ ទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ពីការកាត់សេចក្តី ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីការកាត់សេចក្តី ។ សូមចង្អុលបង្ហាញថា ខទី ១ ជារឿយៗត្រូវបានគេយល់ខុសដោយគិតថាយើងពុំគួរកាត់សេចក្តីនោះទេ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:១ –២ ឲ្យឮៗ ។

- តើព្រះអង្គសង្គ្រោះបង្រៀនអ្វីខ្លះអំពីការកាត់សេចក្តី ?
- តើអ្នកគិតថា ការការកាត់សេចក្តីដោយសុចរិតមានន័យដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលនឹងកើតឡើងចំពោះយើង ផ្អែកតាមរបៀបដែលយើងកាត់សេចក្តីអ្នកដទៃ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ (អ្នកគួរពន្យល់ថា ឃ្លា « គេនឹងវាល់ឲ្យអ្នករាល់គ្នា » មានន័យថា របៀបដែលអ្នករាល់គ្នាវាស់ ឬថ្កោលទោស) ។

- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងកាត់សេចក្តីអ្នកដទៃដោយសុចរិត ? (បន្ទាប់ពីសិស្សឆ្លើយ សូមជួយពួកគេឲ្យស្គាល់គោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងកាត់សេចក្តីអ្នកដទៃដោយសុចរិត នោះព្រះនឹងប្រទានសេចក្តីមេត្តាករុណា និង ភាពស្មើភាពគ្នាដូចគ្នាដល់យើង**) ។

ប្រសិនបើអាចធ្វើទៅបាន សូមចែកសំណៅនៃសេចក្តីថ្លែងការណ៍ខាងក្រោមក្នុង *ពិតចំពោះសេចក្តីជំនឿ* ដល់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សម្នាក់អានវាឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលប្រភេទនៃការកាត់សេចក្តីដែលយើងគួរ និង ពុំគួរធ្វើ ព្រមទាំង របៀបដែលយើងអាចកាត់សេចក្តីដោយសុចរិត ។

« ពេលខ្លះមនុស្សមានអារម្មណ៍ថា វាខុសក្នុងការវិនិច្ឆ័យអ្នកដទៃ ទោះជាតាមវិធីណាក៏ដោយ ។ ខណៈដែលថា អ្នកពិតជាមិនគួរថ្កោលទោសអ្នកដទៃ ឬ វិនិច្ឆ័យពួកគេដោយអយុត្តិធម៌ នោះអ្នកនឹងត្រូវធ្វើការវិនិច្ឆ័យពីគំនិត ពីស្ថានភាព និង ពីមនុស្ស នៅក្នុងឆាកជីវិតរបស់អ្នក ។ . . .

« ការវិនិច្ឆ័យគឺជាការប្រើសេរីភាពយ៉ាងសំខាន់របស់អ្នក ហើយតម្រូវឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ជាពិសេស ពេលអ្នកធ្វើការវិនិច្ឆ័យមនុស្សដទៃទៀត ។ ការវិនិច្ឆ័យទាំងអស់របស់អ្នកត្រូវតែបានដឹកនាំដោយមាត្រដ្ឋានសុចរិត ។ សូមចងចាំថាមានតែព្រះប៉ុណ្ណោះដែលដឹងពីចិត្តរបស់បុគ្គលម្នាក់ៗ ហើយដែលអាចធ្វើការវិនិច្ឆ័យចុងក្រោយបង្អស់ពីបុគ្គលម្នាក់ៗ (សូមមើល វិវរណៈ ២០:១២, នីហ្វៃទី៣ ២៧:១៤, គ. និង ស. ១៣៧:៩) ។ . . .

« . . . ធ្វើឲ្យអស់ពីសមត្ថភាពរបស់អ្នក វិនិច្ឆ័យពីស្ថានភាពរបស់មនុស្សជាជាងទៅលើបុគ្គលនោះផ្ទាល់ ។ ពេលណាក៏ដោយដែលអាចធ្វើទៅបាន ចូរជឿសាងធ្វើការវិនិច្ឆ័យរហូតទាល់តែអ្នកមានចំណេះដឹងគ្រប់គ្រាន់ល្មមនៃការពិតនោះ ។ ចូរស្តាប់តាមព្រះវិញ្ញាណបរិសុទ្ធដែលជាអង្គដឹកនាំការសម្រេចចិត្តរបស់អ្នក » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ឆ្នាំ២០០៤] ទំព័រ ៩០–៩១) ។

- តើការកាត់សេចក្តីប្រភេទណាខ្លះដែលយើងគួរធ្វើ ?
- តើយើងអាចកាត់សេចក្តីដោយសុចរិតតាមរបៀបណា ?
- តើឧទាហរណ៍មួយចំនួនពីគ្រាដែលមនុស្សម្នាក់នឹងត្រូវធ្វើការកាត់សេចក្តីសុចរិតមួយមានអ្វីខ្លះ ?

សូមដាក់បង្ហាញបំណែកឈើតូចមួយ និង ឈើមួយដើមវែង ហើយក្រាស់ ។ សូមពន្យល់ថា កាលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សទ្រង់ពីការកាត់សេចក្តី ទ្រង់បានហៅបំណែកឈើតូចមួយជា *ករម្ចុច* និង ឈើមួយដើមធំជា *ធ្នឹម* ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៧:៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីការកាត់សេចក្តីអ្នកដទៃ ។

- តើករម្ចុច និង ធ្នឹមតំណាងឲ្យអ្វីដែរ នៅក្នុងវិធីរៀបរាប់ភាពស្រដៀងគ្នារបស់ព្រះអង្គសង្គ្រោះ ។ (វាតំណាងឲ្យកំហុស ភាពទន់ខ្សោយ ឬអំពើបាបទោះតូចឬធំក្តី) ។
- តើអ្នកអាចនិយាយឡើងវិញនូវការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង ខទី ៣យ៉ាងដូចម្តេច ?

សូមអញ្ជើញឲ្យសិស្សពីរនាក់ឡើងមកក្តារខៀន ។ សូមណែនាំសិស្សម្នាក់ឲ្យកាត់ធ្នឹមដាក់ពីមុខភ្នែកខ្លួន ។ សូមសួរសិស្សទីពីរ ៖

- តើប្អូនចង់ឲ្យមិត្តរួមថ្នាក់ប្អូនដែលកាន់ធ្នឹមដកយកកម្ទេចចេញពីភ្នែកប្អូនដែរឬទេ ? ហេតុអ្វីមិនចង់ ?

សូមសួរសិស្សដែលកាន់ធ្នឹម ៖

- តើប្អូនត្រូវធ្វើអ្វីខ្លះដើម្បីឲ្យបានមើលឃើញច្បាស់ពីមុនយកកម្ទេចចេញពីភ្នែករបស់មិត្តរួមថ្នាក់ប្អូន ?

សូមអញ្ជើញសិស្សទាំងពីរនាក់នោះត្រឡប់ទៅអង្គុយវិញ ។ ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៧:៤–៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់រកមើលថាតើព្រះអង្គសង្គ្រោះបានមានបន្ទូលថាយើងគួរព្រួយបារម្ភពីកំហុសរបស់នរណាទៅ ។

- តើកង្វល់ និង ការកែតម្រូវរបស់យើងគួរផ្តោតលើកំហុសអ្នកដទៃ ឬលើកំហុសខ្លួនឯង ? ហេតុអ្វី ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីខគម្ពីរទាំងនេះ ដែលអាចជួយយើងឲ្យចៀសវាងពីការកាត់សេចក្តីអ្នកដទៃដោយឥតសុចរិត ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងផ្តោតលើការដកយកអំពើបាប និងភាពទន់ខ្សោយផ្ទាល់ខ្លួន នោះយើងនឹងពុំសូវកាត់សេចក្តីអ្នកដទៃដោយមិនសុចរិតឡើយ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

- តើគោលការណ៍នេះអាចជួយយើងបែបណាដែរ ពេលយើងឃើញកម្ទេចនៅក្នុងភ្នែករបស់អ្នកផ្សេង ?

អ្នកអាចឲ្យបំណែកឈើតូចមួយទៅសិស្សដើម្បីទុកជាការរំឭកចាំពីគោលការណ៍នេះ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអំពើបាប ឬភាពទន់ខ្សោយដែលពួកគេអាចដកចេញពីជីវិតរបស់ខ្លួន ។ សូមលើកទឹកចិត្តពួកគេឲ្យទូលសូមជំនួយពីព្រះអម្ចាស់ ដើម្បីដកយកគុណវិបត្តិរបស់ខ្លួនជាជាងការកាត់សេចក្តីអ្នកដទៃដោយមិនសុចរិត ។

ម៉ាថាយ ៧:២៤–២៧

ព្រះអង្គសង្គ្រោះសន្យានឹងប្រទានសេចក្តីសង្គ្រោះដល់ជនណាដែលធ្វើតាមព្រះទ័យរបស់ព្រះវរបិតា ។

សូមដាក់បង្ហាញដុំថ្មមួយ និង ខ្សាច់មួយថាស ។ សូមសួរសិស្សថាតើពួកគេចង់សង់ផ្ទះរបស់ខ្លួនលើខ្សាច់ ឬលើថ្ម ។ សូមអញ្ជើញពួកគេពន្យល់ពីមូលហេតុ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ៧:២៤–២៧ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះយេស៊ូវបានមានបន្ទូលថាប្រៀបបាននឹងការសង់ផ្ទះលើថ្ម និង អ្វីដែលប្រៀបបាននឹងការសង់ផ្ទះលើខ្សាច់ ។

- យោងតាម ខទី ២៤តើព្រះអង្គសង្គ្រោះមានបន្ទូលថាសកម្មភាពអ្វីខ្លះដែលនឹងធ្វើឲ្យមនុស្សប្រៀបបាននឹងមនុស្សឆ្លាតដែលសង់ផ្ទះនៅលើថ្ម ?
- យោងតាម ខទី ២៦តើព្រះអង្គសង្គ្រោះមានបន្ទូលថាសកម្មភាពអ្វីខ្លះដែលនឹងធ្វើឲ្យមនុស្សម្នាក់ប្រៀបបាននឹងមនុស្សល្ងង់ខ្លៅដែលសង់ផ្ទះនៅលើខ្សាច់ ?
- តើអ្នកគិតថា ភ្លៀង ទឹកជំនន់ និង ខ្យល់ (សូមមើល ខទី ២៧ សូមមើលផងដែរ ហេលេមិន ៥:១២) តំណាងឲ្យអ្វីនៅក្នុងការរៀបរាប់ភាពស្រដៀងគ្នាទាំងនេះ ?
- តើការអនុវត្តតាមការបង្រៀនរបស់ព្រះអម្ចាស់ បង្ហាញដល់យើងនូវគោលការណ៍អ្វីខ្លះចំពោះរឿងប្រៀបធៀបទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនយើងស្តាប់ ហើយធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ នោះទ្រង់នឹងពង្រឹងយើងឲ្យស៊ូទ្រាំនឹងការសាកល្បងរបស់យើង ។ ប្រសិនបើយើងស្តាប់តាមការបង្រៀនរបស់ព្រះអម្ចាស់ ប៉ុន្តែពុំបានធ្វើតាម នោះយើងនឹងពុំទទួលបានការគាំទ្រដែលយើងត្រូវការ នៅពេលការសាកល្បងបានមកដល់ឡើយ**) ។

សូមអញ្ជើញសិស្សធ្វើដូចជាមនុស្សឆ្លាតនោះ ដោយសម្រេចចិត្តធ្វើតាមគោលការណ៍ដែលព្រះអង្គសង្គ្រោះបានបង្រៀន ។ អ្នកគួរឲ្យពេលសិស្សសរសេរពីរបៀបដែលពួកគេនឹងអនុវត្តគោលការណ៍មួយ ឬច្រើននៅក្នុងមេរៀននេះ ឬនៅក្នុងការសិក្សារបស់ពួកគេពីការបង្រៀនដែលនៅសេសសល់នៃទេសនកថានៅលើភ្នំ ។

មេរៀនបន្ទាប់ (ម៉ាថាយ ១៣:២៤–១៧:២៧)

សូមប្រាប់សិស្សថា នៅសប្តាហ៍ក្រោយពួកគេនឹងអានពីផែនការអាក្រក់ដែលបានដឹកនាំឲ្យមានការសម្លាប់ យ៉ូហាន បាទីស្ទ ។ ពួកគេក៏នឹងរៀនផងដែរ ពីចម្លើយចំពោះសំណួរខាងក្រោមនេះ ៖ ហេតុអ្វីបានជាស្តេចហេរ៉ូឌ បង្គាប់ឲ្យកាត់ក្បាលយ៉ូហាន ? ហេតុអ្វីពេត្រុសលិចចុលទៅក្នុងទឹកបន្ទាប់ពីបានដើរលើទឹកប្រកបដោយជោគជ័យ ? ចូរសុំឲ្យសិស្សពិចារណាថា តើពួកគេមានអារម្មណ៍បែបណាប្រសិនបើមានមិត្តជិតស្និទ្ធ ឬសមាជិកគ្រួសារម្នាក់ស្លាប់ ។ នៅពេលពួកគេសិក្សាមេរៀនបន្ទាប់ សុំឲ្យពួកគេរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានធ្វើចំពោះសេចក្តីស្លាប់របស់មនុស្សជាទីស្រឡាញ់ និង អ្វីដែលបានកើតឡើងនៅលើភ្នំប្រែរូបនោះ ។

មេរៀន ១៦

ម៉ាថាយ ១៣:២៤–៥៨

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះបានប្រទានរឿងប្រៀបប្រដូច ដើម្បីបង្រៀនពីនគរស្ថានសួគ៌ ការស្តារឡើងវិញ និងការរីកចម្រើននៃសាសនាចក្ររបស់ទ្រង់នៅថ្ងៃចុងក្រោយ ការប្រមូលផ្តុំពួកសុចរិត និងការបំផ្លិចបំផ្លាញពួកទុច្ចរិត នៅពេលនៃការយាងមកជាលើកទីពីររបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៣:២៤–៣០, ៣៦–៤៣

ព្រះអង្គសង្គ្រោះបង្រៀន ហើយពន្យល់ពីរឿងប្រៀបប្រដូចនៃស្រូវសាលី និង ស្រងែ

មុនចាប់ផ្តើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើ ក្តារខៀន ៖


តើអ្នកធ្លាប់មានចិត្តតប់ប្រមល់ ឬ អន់ចិត្តដោយសារតែមានអំពើអាក្រក់ច្រើនពេកនៅក្នុងពិភពលោកនេះដែរឬទេ ?

ហេតុអ្វីព្រះអម្ចាស់មិនដកយកអំពើអាក្រក់នៅជុំវិញខ្លួនយើងតែម្តងទៅ ?

ហេតុអ្វីខ្ញុំគួរជ្រើសរើសធ្វើជាមនុស្សសុចរិត កាលមនុស្សមួយចំនួនជុំវិញខ្លួនខ្ញុំហាក់ដូចជាពុំបានដកពិសោធន៍ជួបនឹងផលអវិជ្ជមាននៃការជ្រើសរើសទុច្ចរិតរបស់ពួកគេជាងនោះ ?

នៅពេលចាប់ផ្តើមមេរៀននេះ ចូរសុំឲ្យសិស្សសញ្ជឹងគិតពីសំណួរនៅលើក្តារខៀន រួចអញ្ជើញពួកគេឲ្យចែកចាយគំនិតរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ នៅពេលសិស្សសិក្សា ម៉ាថាយ ១៣:២៤–៣០, ៣៦–៤៣សូមអញ្ជើញពួកគេរកមើលសេចក្តីពិតមួយដែលនឹងជួយលួងលោមចិត្តពួកគេ កាលកំពុងខិតខំរស់នៅដោយសុចរិតនៅក្នុងពិភពលោកទុច្ចរិតមួយ ។

សូមដាក់តាំង រូបភាព ស្រូវសាលី និងស្រងែ ឬគូរវានៅលើក្តារខៀន ។ ចូរពន្យល់ថា ស្រងែជាប្រភេទស្មៅពុល ។ ស្រូវ និងស្រងែ គឺមើលទៅស្ទើរតែដូចគ្នា នៅពេលវាដុះពន្លកចេញមក ប៉ុន្តែវាអាចមើលទៅខុសគ្នាពេលវាទំ ។



សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនរឿងប្រៀបប្រដូចមួយពីស្រូវសាលី និងស្រងែ ។ សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នាអាននៅក្នុង ម៉ាថាយ ១៣:២៤–៣០ ឲ្យឮៗ និងនៅក្នុងផ្ទៃក្នុមួយនៃការបកប្រែដោយ យ៉ូសែប ស៊្មីធ ម៉ាថាយ ១៣:២៩ ដែលបានកែប្រែផ្នែកខ្លះៗនៃខទី ២៩ ទៅជា « ចូរអ្នកប្រមូលស្រូវសាលីរួមគ្នាដាក់ក្នុងជង្រុករបស់យើងជាមុនសិន ហើយស្រងែត្រូវឃើញឆេះទាំងបាច់ៗ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើមានអ្វីបានកើតឡើងចំពោះស្រូវសាលី និង ស្រងែ ។

- តើមានអ្វីកើតឡើងចំពោះស្រូវសាលី និងស្រងែ ? (វាត្រូវបានព្រោះ [បានដាំ] ហើយអនុញ្ញាតឲ្យលូតលាស់រួមគ្នា ។ រួចស្រូវសាលីត្រូវបានប្រមូលដាក់ជង្រុក រីឯស្រងែត្រូវបានយកទៅដុតចោល) ។
- ហេតុអ្វីអ្នកគិតថាអ្នកព្រោះគ្រាប់ពូជបានប្រាប់ពួកអ្នកបម្រើរបស់គាត់ឲ្យទុកស្រូវសាលី និង ស្រងែ « ឲ្យវាដុះជាមួយគ្នា ដរាបដល់ពេលច្រូត »ដូច្នេះ ? (ប្រសិនបើអ្នកច្រូតកាត់ ព្យាយាមដកស្រងែចេញមុនពេលស្រូវ និងស្រងែទំ នោះហាក់ដូចជាគាត់បំផ្លាញស្រូវសាលីអស់ច្រើនជាងដែរ) ។
- យោងតាម ការបកប្រែដោយ យ៉ូសែប ស៊្មីធ ម៉ាថាយ ១៣:២៩រវាងស្រូវសាលី និងស្រងែ—តើមួយណាត្រូវបានប្រមូលជាមុន ?

សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានប្រទានរឿងប្រៀបប្រដូចអំពីស្រូវសាលី និងស្រងែមក ពួកសិស្សរបស់ទ្រង់បានទូលសួរទ្រង់ឲ្យពន្យល់ពីអត្ថន័យរបស់វា ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង ម៉ាថាយ ១៣:៣៦–៤៣ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការពន្យល់របស់ព្រះអង្គសង្គ្រោះអំពីរឿងប្រៀបប្រដូចនេះ ។

- តើនរណាទៅដែលបានព្រោះ ឬដាំគ្រាប់ពូជល្អនោះ ? (ព្រះអង្គសង្គ្រោះ) ។
- តើនរណាទៅដែលបានព្រោះ ឬដាំស្រងែនោះ ? (អារក្ស) ។
- តើស្រូវសាលី និង ស្រងែតំណាងឲ្យអ្វី ? (មនុស្សសុចរិត និង មនុស្សទុច្ចរិត ។ សូមពន្យល់ថា មនុស្សទុច្ចរិតគឺជាមនុស្សដែលមិនព្រមប្រែចិត្ត [សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ២៩:១៧]) ។

ជួយសិស្សឲ្យយល់ពីមាតិកានៃខគម្ពីរ

សូមសួរសំណួរដែលនឹងជួយសិស្សឲ្យវិភាគ ហើយយល់ពីមាតិកានៃខគម្ពីរ ។ ឧទាហរណ៍ អ្នកអាចសួរសំណួរដែលជួយពួកគេឲ្យ (១) ពិនិត្យមើលពីវគ្គបទព្រះគម្ពីរមួយដោយទទួលពន្លឺពីបទគម្ពីរផ្សេងទៀត ឬគោលការណ៍នៃដំណឹងល្អ (២) ពន្យល់ឲ្យច្បាស់ពីអត្ថន័យនៃពាក្យឬឃ្លា ឬ (៣) វិភាគព័ត៌មានលម្អិតនៃខ្សែរឿងឲ្យកាន់តែយល់បានសឹងតែម្រាំ ។ នៅពេលសិស្សឆ្លើយសំណួរទាំងនេះរួចហើយ ពួកគេនឹងត្រៀមខ្លួនជាស្រេចរកគោលលទ្ធិ និង គោលការណ៍នានា ។







សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ បញ្ជាក់ប្រាប់ថា « ពេលច្រូត » ឬ « ចុងបញ្ចប់នៃលោកិយ » ដែលបានចែងក្នុង ខទី ៣៩ សំដៅទៅលើការបំផ្លិចបំផ្លាញពួកទុច្ចរិត នៅឯការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ ការបកប្រែដោយ យ៉ូសែប ស៊្មីធ ក៏ជួយយើងឲ្យយល់ថា នៅថ្ងៃចុងក្រោយព្រះអម្ចាស់នឹងបញ្ជូនពួកទេវតា និង ពួកសារទូតដើម្បីមកជួយញែកពួកសុចរិតចេញពីពួកទុច្ចរិត (សូមមើល ការបកប្រែដោយ យ៉ូសែប ស៊្មីធ ម៉ាថាយ ១៣:៣៩–៤៤ ។ នៅក្នុងវចនានុក្រមព្រះគម្ពីរបរិបូរ នៃកំណែព្រះគម្ពីរបរិបូរ ជាភាសាអង់គ្លេសរបស់ អិល.ឌី.អែស. ។) ។

- យោងតាមរឿងប៉ៅបប្រដូចនេះ តើនឹងមានអ្វីកើតឡើងដល់ពួកសុចរិត និង ពួកទុច្ចរិតនៅថ្ងៃចុងក្រោយ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់នឹងប្រមូលពួកសុចរិតអំឡុងថ្ងៃចុងក្រោយ រួចហើយបំផ្លាញពួកទុច្ចរិតពេលទ្រង់យាងមក ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើសេចក្តីពិតនេះអាចនាំមក ហើយផ្តល់ការលួងលោមចិត្តដល់យើង កាលយើងរស់នៅក្នុងពិភពលោកមួយដ៏អាក្រក់បានដោយរបៀបណា ? (នៅទីបំផុត ព្រះអម្ចាស់នឹងដកយកសេចក្តីទុច្ចរិតចេញពីផែនដី ហើយប្រទានរង្វាន់ដល់ពួកស្មោះត្រង់) ។

សូមពន្យល់សិស្សថា ដោយសារសិទ្ធិជ្រើសរើសរបស់យើង យើងកំណត់ការជ្រើសរើសរបស់យើងថាតើយើងនឹងចង់ឲ្យបានប្រមូលផ្តុំជាមួយនឹងពួកសុចរិត ឬត្រូវរងទុក្ខជាមួយនឹងពួកគេទុច្ចរិត ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យព្រះអម្ចាស់បានប្រមូលផ្តុំយើង ?

ដើម្បីជួយឲ្យសិស្សយល់អំពីអ្វី ដែលយើងត្រូវធ្វើដើម្បីឲ្យព្រះអម្ចាស់ប្រមូលផ្តុំយើង សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« ព្រះអម្ចាស់ ប្រមូលរាស្ត្រទ្រង់ នៅពេលពួកគេទទួលទ្រង់ ហើយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ . . .

« . . . ព្រះអម្ចាស់ប្រមូលរាស្ត្ររបស់ទ្រង់ដើម្បីថ្វាយបង្គំ ស្ថាបនាសាសនាចក្រ ទុកជាការការពារមួយ ហើយទទួលការប្រឹក្សា និង ការណែនាំ ។ . . .

« ព្យាការីយ៉ូសែប ស៊្មីធ បានប្រកាសថា នៅគ្រប់ជំនាន់ទាំងអស់ ព្រះរាជបំណងនៃការប្រមូលផ្តុំ គឺជាការសង់ព្រះវិហារបរិសុទ្ធដើម្បីឲ្យកូនចៅរបស់ព្រះអម្ចាស់អាចទទួលពិធីបរិសុទ្ធដ៏ខ្ពស់បំផុត ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមមើល *Teachings of Presidents of the Church: Joseph Smith* ។ ឆ្នាំ២០០៧ ។ ទំព័រ៤១៦–១៧ ។ » (« The Spirit and Purposes of Gathering » ។ Brigham Young University–Idaho devotional ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០៦ ។ byui.edu) ។

- យោងតាមអែលឌើរ បែដណា តើយើងត្រូវធ្វើអ្វីខ្លះដើម្បីឲ្យព្រះអម្ចាស់ប្រមូលផ្តុំយើង ?
- តើមានពរជ័យអ្វីខ្លះបានកើតមានក្នុងជីវិតរបស់អ្នក នៅពេលព្រះអម្ចាស់បានប្រមូលផ្តុំអ្នក ?

សូមដាក់បង្ហាញ រូបភាព ពួកអ្នកផ្សព្វផ្សាយសាសនា ៖ អែលឌើរ, ពួកអ្នកផ្សព្វផ្សាយសាសនា ៖ សិស្ទើរនិង ព្រះវិហារបរិសុទ្ធសលត៍លេក (*Gospel Art Book* ។ ឆ្នាំ ២០០៩ ។ ល.រ. ១០៩, ១១០, ១១៩ សូមមើលផងដែរ LDS.org) ។


- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយព្រះអង្គសង្គ្រោះក្នុងការប្រមូលផ្តុំកូនចៅរបស់ព្រះវរបិតាសួគ៌ ?
- តើអ្នកបានទទួលពរជ័យអ្វីខ្លះ នៅពេលអ្នកជួយព្រះអម្ចាស់ប្រមូលផ្តុំពួកសុចរិតតាមរយៈកិច្ចការផ្សព្វផ្សាយសាសនា ឬកិច្ចការព្រះវិហារបរិសុទ្ធ ?

សូមបញ្ជាក់ប្រាប់សិស្សថា ដោយសារយើងទាំងអស់គ្នាធ្វើខុស ព្រះអង្គសង្គ្រោះអញ្ជើញយើងឲ្យប្រែចិត្ត ដើម្បីយើងអាចត្រូវបានប្រមូលផ្តុំជាមួយនឹងពួកសុចរិត ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអ្វីដែលពួកគេអាចធ្វើ ដើម្បីប្រមូលខ្លួនឯង ក្រុមគ្រួសាររបស់ពួកគេ និងមនុស្សដទៃទៀតទៅរកព្រះអង្គសង្គ្រោះ និងសាសនាចក្ររបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេបានទទួល ។

ម៉ាថាយ ១៣:៣១–៣៥, ៤៤–៥២

ព្រះយេស៊ូវប្រើរឿងប្រៀបប្រដូចដើម្បីបង្រៀនអំពីនគស្ថានសួគ៌

សូមដាក់បង្ហាញ រូបភាព នៃវត្ថុខាងក្រោម ឬគូររាវនៅលើក្តារខៀន ៖ គ្រាប់ពូជម្យ៉ាង, ដំបែ (ឬមេនំប៉័ង—សូមពន្យល់ថាដំបែត្រូវបានគេប្រើនៅក្នុងការចំអិនអាហារ ឬដាក់ជាមួយម្សៅធ្វើនំប៉័ងដើម្បីឲ្យវាឡើងពីមុនយកទៅដុត) កែវមុក្តា, ហិបកំណប់តូច និងសំណាញ់ ។




គ្រាប់ពូជម្យ៉ាង


ដំបែ



កែវមុក្តា



ហិបកំណប់



សំណាញ់

សូមពន្យល់ថា នៅក្នុងរឿងប្រៀបប្រដូចខុសៗគ្នាព្រះអង្គសង្គ្រោះបានប្រៀបធៀបវត្ថុទាំងនេះនីមួយៗទៅនឹងនគរស្ថានសួគ៌ ។ សូមពន្យល់សិស្សថា នគរស្ថានសួគ៌តំណាងឲ្យសាសនាចក្រ និងដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ ។ សូមសរសេរបទគម្ពីរយោងខាងក្រោមនេះនៅលើក្តារខៀន ៖ *ម៉ាថាយ ១៣:៣១–៣២, ម៉ាថាយ ១៣:៣៣, ម៉ាថាយ ១៣:៤៤, ម៉ាថាយ ១៣:៤៥–៤៦, ម៉ាថាយ ១៣:៤៧–៥០* ។ សូមចែកសិស្សជាដៃគូ ឬជាក្រុមតូចៗ ហើយចាត់តាំងសេចក្តីយោងមួយដែលមានសរសេរនៅលើ ក្តារខៀនដល់ដៃគូ ឬក្រុមនីមួយៗ ។ សូមអញ្ជើញដៃគូ ឬក្រុមនីមួយៗឲ្យបំពេញសកម្មភាពខាងក្រោមនេះ (អ្នកអាចនឹងផ្តល់បញ្ជីនេះនៅលើឯកសារចែកឲ្យ) ៖

១. ចូរអានរួមគ្នានូវខគម្ពីរដែលបានចាត់ឲ្យអ្នក ។

២. ចូរពិភាក្សាតើវត្ថុអ្វីទៅដែលព្រះអង្គសង្គ្រោះបានប្រៀបប្រដូចទៅនឹងសាសនាចក្រ និង ដំណឹងល្អរបស់ទ្រង់ ។

៣. ចូរពិភាក្សាតើសេចក្តីពិតអ្វីទៅដែលអ្នកគិតថា ព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងរឿងប្រៀបប្រដូចនេះអំពីសាសនាចក្រ និងដំណឹងល្អរបស់ទ្រង់ ។ សូមសរសេរសេចក្តីពិតនោះ នៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ដែលបានចាត់ឲ្យអានរឿងប្រៀបប្រដូចអំពីដំបែ និងសិស្សម្នាក់ទៀតដែលបានចាត់ឲ្យអានរឿងប្រៀបប្រដូចអំពីគ្រាប់ពូជម្ស៉ាង ឲ្យអានរឿងនោះឮៗឲ្យសិស្សដទៃទៀតស្តាប់ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យអាន សេចក្តីពិតនានាដែលពួកគេបានកត់ទុកដល់សិស្សក្នុងថ្នាក់ ។ (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតមួយដែលស្រដៀងនឹងសេចក្តីពិតខាងក្រោមនេះ ៖ **សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ នឹងរីកចម្រើនពីការចាប់ផ្តើមដ៏តូចរហូតដល់បានបំពេញផែនដីទាំងមូល ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប អេហ្វ ស៊្មីធ ដែលលោកបានបង្រៀនពីរបៀបដែលពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្តត្រូវបានប្រៀបប្រដូចទៅនឹងដំបែ ៖

« ទោះជានិយាយថា យើងមានចំនួនតិច បើប្រៀបធៀបនឹងពិភពលោកក្តី ប៉ុន្តែយើងអាចប្រៀបធៀបនឹងមេដំបែដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថានៅទីបំផុត វានឹងឡើងមានពាសពេញពិភពលោក » (*Gospel Doctrine* កំណែទី ៥ | ឆ្នាំ១៩៣៩ | ទំព័រ ៧៤) ។

- ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយសាសនាចក្ររបស់ព្រះអង្គសង្គ្រោះឲ្យរីកចម្រើន ?

សូមអញ្ជើញសិស្សម្នាក់ដែលបានចាត់ឲ្យអានរឿងប្រៀបប្រដូច ពីទ្រព្យសម្បត្តិនៅទីវាល សិស្សម្នាក់ដែលចាត់ឲ្យអានរឿងប្រៀបប្រដូចអំពីកែវមុក្តាដ៏មានតម្លៃមហិមា និងសិស្សម្នាក់ទៀតដែលបានចាត់ឲ្យអានរឿងប្រៀបប្រដូចអំពីសំណាញ់ឲ្យអានឮៗដល់សិស្សក្នុងថ្នាក់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យអាន សេចក្តីពិតនានាដែលពួកគេបានកត់ទុកដល់សិស្សក្នុងថ្នាក់ ។ (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីគោលការណ៍មួយ ដែលស្រដៀងនឹងសេចក្តីពិតខាងក្រោមនេះ ៖ **ដោយសារពរជ័យនៃដំណឹងល្អគឺជាតម្លៃដ៏អស់កល្បជានិច្ច នោះវាមានតម្លៃសក្តិសមសម្រាប់រាល់ការលះបង់ទាំងអស់ ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សយល់ពីគោលការណ៍នេះ ចូរសរសេរចំណងជើងខាងក្រោមនៅលើ ក្តារខៀន ៖

ពរជ័យទាំងឡាយនៃដំណឹងល្អ	*ពលិកម្មដើម្បីទទួលបានពរជ័យ*

ចូរសុំឲ្យសិស្សសរសេរពរជ័យមួយចំនួននៃដំណឹងល្អ (ឧទាហរណ៍ អាចរួមបញ្ចូលចំណេះដឹងនៅក្នុងបទគម្ពីរ ការដឹកនាំពីពួកព្យាការីនៅរស់ ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ និងអាពាហ៍ពិពាហ៍ដ៏នៅអស់កល្បជានិច្ច) ។ ចំពោះពរជ័យនីមួយៗដែលបានសរសេរ ចូរសុំឲ្យសិស្សពន្យល់ពីពលិកម្មអ្វីខ្លះ ដែលពួកគេត្រូវធ្វើដើម្បីទទួលបានពរជ័យនោះ ។ សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។

ចូរសុំឲ្យសិស្សជ្រើសយកពរជ័យមួយដែលបានសរសេរនៅលើក្តារខៀន ហើយពន្យល់ពីហេតុផលដែលថា ការទទួលបានពរជ័យនោះមានតម្លៃសក្តិសមចំពោះរាល់ពលិកម្មទាំងអស់ ។

- តើអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់ធ្លាប់លះបង់អ្វីមួយ ដើម្បីទទួលបានពរជ័យមួយនៃដំណឹងល្អនៅពេលណាដែរ ?

ចូរសរសេរសំណួរដូចខាងក្រោមនៅលើ ក្តារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយ ក្នុងសៀវភៅកំណត់ចំណាំ ក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

តើពរជ័យអ្វីនៃដំណឹងល្អ ដែលអ្នកប្រាថ្នាចង់បាន ?

ហេតុអ្វីអ្នកប្រាថ្នាចង់បានពរជ័យនោះ ?

តើអ្នកត្រូវពលិកម្មដោយរបៀបណា ដើម្បីទទួលបានពរជ័យនោះ ?

ម៉ាថាយ ១៣:៥៣–៥៨

ព្រះយេស៊ូវបង្រៀននៅស្រុកណាសារ៉ែត ហើយត្រូវបានបដិសេធដោយវាស្ត្រារបស់ទ្រង់

សូមសង្ខេប ម៉ាថាយ ១៣:៥៣–៥៨ ដោយពន្យល់ថាប្រជាជននៅស្រុកណាសារ៉ែតបានបដិសេធព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់ ។ ដោយសារតែការឥតជំនឿរបស់ពួកគេ ព្រះអង្គសង្គ្រោះពុំបានបង្កើតអព្ភូតហេតុជាច្រើននៅក្នុងចំណោមពួកគេទេ (សូមមើលផងដែរ ម៉ាកុស ៦:៣៧) ។

ម៉ាថាយ ១៤

សេចក្តីផ្តើម

បន្ទាប់ពីបានជ្រាបពីការស្លាប់របស់ យ៉ូហាន បាទីស្ទ ព្រះយេស៊ូវបានចង់គង់នៅតែឯកឯង ប៉ុន្តែមានមនុស្សជាច្រើនបានដើរតាមទ្រង់ ។ ទ្រង់មានព្រះទ័យមេត្តាដល់ពួកគេ បានព្យាបាលអ្នកឈឺ ហើយបានប្រទានអាហារដោយអព្ភូតហេតុដល់មនុស្សច្រើនជាងប្រាំពាន់នាក់ ។ នៅយប់នោះ ព្រះយេស៊ូវបានយាងដើរនៅលើសមុទ្រទៅរកពួកសិស្សរបស់ទ្រង់ដែលកំពុងជួបប្រទះនឹងព្យុះភ្លៀងធ្ងន់ធ្ងរនៅលើផ្ទៃសមុទ្រកាលីឡេ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៤:១–២១

ព្រះយេស៊ូវចង់គង់នៅតែអង្គឯង រួចបានប្រទានអាហារដល់មនុស្សច្រើនជាងប្រាំពាន់នាក់

ចូរសុំឲ្យសិស្សគិតពីគ្រាមួយ ដែលពួកគេមានភាពសោកសៅយ៉ាងខ្លាំង ។ សូមអញ្ជើញពួកគេឲ្យសញ្ជឹងគិតពីអ្វីដែលពួកគេបានធ្វើដើម្បីស៊ូទ្រាំ ហើយយកឈ្នះលើភាពសោកសៅរបស់ពួកគេ ។

- **តើរបៀបខុសគ្នាមួយចំនួនដែលមនុស្សព្យាយាមស៊ូទ្រាំហើយយកឈ្នះលើភាពសោកសៅមានអ្វីខ្លះ ?**

នៅពេលសិស្សសិក្សា ម៉ាថាយ ១៤ សូមអញ្ជើញពួកគេឲ្យរកមើលវិធីដែលពួកគេអាចស៊ូទ្រាំ ហើយយកឈ្នះលើទុក្ខព្រួយ ការសោកល្បួង និង ការសង្ស័យ ។

សូមសង្ខេប ម៉ាថាយ ១៤:១–១១ ដោយពន្យល់ថា តាមការញុះញង់របស់មហេសីថ្មីរបស់ខ្លួន (ហេរ៉ូឌាស) ស្តេចហេរ៉ូឌបានឃុំខ្លួនយ៉ូហាន បាទីស្ទ ទាំងអយុត្តិធម៌ ។ បន្ទាប់ពីបុត្រីរបស់មហេសីទ្រង់ (សាឡូមេ) បានរាំថ្វាយទ្រង់ទត ហេរ៉ូឌបានសន្យាជាសាធារណៈថានាងអាចមាន « គ្រប់របស់អ្វីដែលនាងនឹងសូម »(ម៉ាថាយ ១៤:៧) ។ បុត្រីនោះបានប្រឹក្សាជាមួយមាតានាង ហើយទូលសូមឲ្យកាត់ក្បាល យ៉ូហាន បាទីស្ទ ហើយជាលទ្ធផល ហេរ៉ូឌបានកាត់ក្បាលរបស់យ៉ូហាន ។

សូមរំឭកសិស្សថា យ៉ូហាន បាទីស្ទ គឺជាមិត្តនិងជាសាច់ញាតិម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ហើយព្រះបានជ្រើសគាត់ធ្វើជាព្យាការីដើម្បីរៀបចំផ្លូវសម្រាប់ព្រះមែស៊ី ។

- **សូមនឹកស្រមៃពីការធ្វើជាមិត្តដ៏ជិតស្និទ្ធម្នាក់នឹង យ៉ូហាន បាទីស្ទ ។ តើអ្នកនឹងមានអារម្មណ៍យ៉ាងណាដែរ នៅពេលឮពីការស្លាប់ដោយអយុត្តិធម៌របស់គាត់នោះ ?**

សូមអញ្ជើញឲ្យសិស្សម្នាក់ឲ្យអាន ម៉ាថាយ ១៤:១២–១៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះយេស៊ូវបានធ្វើនៅពេលទ្រង់ឮពីការស្លាប់របស់យ៉ូហាន ។

- **តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ នៅពេលទ្រង់ឮពីការស្លាប់របស់យ៉ូហាន ? (អ្នកគួរពន្យល់ថា « ទីស្ងាត់ដោយឡែក » សំដៅទៅលើទីកន្លែងមួយស្ងាត់) ។**
- **តើមានអ្វីបានកើតឡើងនៅពេលព្រះយេស៊ូវព្យាយាមគង់នៅតែអង្គឯង ?**
- **តើអ្នកមានអារម្មណ៍បែបណា ប្រសិនបើអ្នកសោកសៅហើយចង់នៅម្នាក់ឯង ប៉ុន្តែមានមនុស្សដទៃចង់បានចំណាប់អារម្មណ៍ពីអ្នក ?**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៤:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះយេស៊ូវបានឆ្លើយតបនៅពេលទ្រង់បានទតឃើញហ្វូងមនុស្សបានដើរតាមទ្រង់ ។

- **តើព្រះអង្គសង្គ្រោះបានបង្ហាញគំរូអ្វីខ្លះឲ្យយើងធ្វើតាម នៅពេលយើងជួបនឹងភាពសោកសៅ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ តាមរយៈការបង្ហាញសេចក្តីមេត្តាករុណាចំពោះអ្នកដទៃ សូម្បីតែពេលយើងកំពុងជួបប្រទះភាពសោកសៅក្តី នោះយើងកំពុងតែធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទហើយ) ។**
- **ហេតុអ្វីវាមានការលំបាកក្នុងការបង្ហាញសេចក្តីមេត្តាករុណាដល់មនុស្សដទៃទៀត នៅពេលយើងកំពុងតែរងទុក្ខនោះ ?**
- **តើការបង្ហាញសេចក្តីមេត្តាករុណាចំពោះមនុស្សដទៃអាចជួយយើង នៅពេលយើងកំពុងរងទុក្ខបានដោយរបៀបណា ?**
- **តើអ្នកឬមនុស្សម្នាក់ដែលអ្នកស្គាល់ធ្លាប់ជួបប្រទះភាពសោកសៅដ៏ធំ ប៉ុន្តែនៅតែបង្ហាញសេចក្តីមេត្តាករុណាដល់មនុស្សដទៃនៅពេលណាដែរ ? តើការបម្រើដល់អ្នកដទៃអាចជួយដោយរបៀបណា ?**

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង ម៉ាថាយ ១៤:១៥–២១ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានបន្តបង្ហាញសេចក្តីមេត្តាករុណាដល់ហ្វូងមនុស្ស ។ (*កំណត់ចំណាំ ៖ អព្ភូតហេតុដែលបានកត់ត្រានៅក្នុង ម៉ាថាយ ១៤:១៥–២១ នឹងត្រូវបង្រៀនយ៉ាងសឹងជម្រៅនៅក្នុងមេរៀនសម្រាប់ ម៉ាកុស ៦:៣៥–៤៤*) ។

- **តើព្រះយេស៊ូវបានបន្តបង្ហាញសេចក្តីមេត្តាករុណាដល់មនុស្ស ដែលបានដើរតាមទ្រង់ដោយរបៀបណា ?**

ចូរសួរសំណួរដែលជួយសិស្សឲ្យរកឃើញគោលលទ្ធិ និងគោលការណ៍នានា ។

នៅពេលសិស្សអភិវឌ្ឍការយល់ដឹងរបស់ពួកគេអំពីបរិបទ និងមាតិកានៃបទគម្ពីរ នោះពួកគេអាចស្គាល់គោលការណ៍ និងគោលលទ្ធិទាំងឡាយដែលវាមានកាន់តែល្អប្រសើរ ។ សំណួរដែលតម្រូវឲ្យមានការវិភាគអាចជួយសិស្សឲ្យធ្វើការសន្និដ្ឋាន ហើយលើកឡើងពីគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងអត្ថបទដែលពួកគេកំពុងសិក្សា ។

ម៉ាថាយ ១៤:២២–៣៦

ព្រះយេស៊ូវបានយាងដើរលើសមុទ្រ កាលកំពុងមានព្យុះភ្លៀង

ដើម្បីជួយសិស្សឲ្យពិចារណាពី ស្ថានភាពដែលពួកគេអាចជួបការសង្ស័យ និងការភ័យខ្លាច នៅពេលពួកគេដើរតាមព្រះយេស៊ូវគ្រីស្ទ ចូរសុំឲ្យសិស្សពីរនាក់អានសាច់រឿងដូចតទៅនេះឲ្យឮ ៖

១. ឃ្លាំងរីម្នាក់មានអារម្មណ៍តែលតោល នៅពេលនាងមើលឃើញម្តាយនាងរងទុក្ខជំងឺមួយនៅដំណាក់កាលចុងក្រោយ ។ នាងចាប់ផ្តើមសួរថា តើព្រះវរបិតាសួគ៌បានជ្រាបពីការឈឺចាប់របស់ម្តាយនាងដែរឬទេ ។ នាងចង់ជឿលើព្រះយ៉ាងខ្លាំង ប៉ុន្តែការសង្ស័យរបស់នាងកំពុងតែគ្របដណ្តប់មកលើនាង ។

២. មានយុវជនម្នាក់ទើបចូលក្នុងសាសនាចក្រថ្មីៗ ។ មិត្តភក្តិចាស់របស់គាត់ជាច្រើន បានធ្វើការរិះគន់ ដោយបើកចំហ ចំពោះការសម្រេចចិត្តរបស់គាត់ចូលក្នុងសាសនាចក្រ ។ គាត់កំពុងងឿងឆ្ងល់ថា តើគាត់គួរបន្តធ្វើជាសមាជិកសាសនាចក្រដ៏សកម្ម ហើយស្មោះត្រង់ដែរឬអត់ ។

- តើមានវិធីណាផ្សេងទៀត ដែលមនុស្សអាចជួបប្រទះនឹងការសង្ស័យ ឬ ការភ័យខ្លាច នៅពេលពួកគេស្វែងរកដើរតាមព្រះយេស៊ូវគ្រីស្ទ ?

ចូរសុំឲ្យសិស្សរកមើលសេចក្តីពិតនានា នៅពេលពួកគេសិក្សាផ្នែកនៅសល់ក្នុង ម៉ាថាយ ១៤ ដែលអាចជួយពួកគេឲ្យយកឈ្នះការភ័យខ្លាច ការសង្ស័យ និងការបាក់ទឹកចិត្ត ។

សូមសង្ខេប ម៉ាថាយ ១៤:២២ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្គាប់ពួកសិស្សរបស់ទ្រង់ ឲ្យធ្វើដំណើរតាមទូកទៅច្រាំងម្ខាងទៀតនៃសមុទ្រកាលីឡេ កាលទ្រង់ប្រាប់ឲ្យហ្វូងមនុស្សត្រឡប់ទៅវិញ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៤:២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីទីកន្លែងដែលព្រះយេស៊ូវបានយាងទៅ នៅពេលទ្រង់បានប្រាប់ឲ្យហ្វូងមនុស្សត្រឡប់ទៅវិញ ។ សូមអញ្ជើញពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៤:២៤–២៥ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលបានកើតឡើងកាលពួកសិស្សឆ្លងសមុទ្រកាលីឡេ ។

- តើមានអ្វីខ្លះបានកើតឡើងចំពោះពួកសិស្សកាលពួកគេកំពុងឆ្លងសមុទ្រកាលីឡេ ?
- តើឃ្លាថា « ដោយព្រោះត្រាសខ្យល់ » មានន័យដូចម្តេច ? (ខទី ២៤) ។ (វាកំពុងបក់បញ្ច្រាសទិសដែលពួកគេកំពុងធ្វើដំណើរ) ។

យោងតាម ខទី ២៣លុះលាចឡើង កាលព្រះយេស៊ូវគង់នៅតែអង្គឯងនៅលើភ្នំ ហើយពួកសិស្សកំពុងជិះទូកឆ្លងសមុទ្រកាលីឡេ ។ ចម្ងាយឆ្លងកាត់សមុទ្រនោះប្រមាណជាប្រាំបីគីឡូម៉ែត្រ ហើយចំណាយពេលឆ្លងពីពីរទៅបីម៉ោង ប្រសិនបើមានអាកាសធាតុល្អ ។

- យោងតាម ខទី ២៥តើព្រះអង្គសង្គ្រោះបានយាងដើរលើទឹកទៅរកពួកសិស្សនៅពេលណា ? (យាមបួនគឺ ពីម៉ោង ៣:០០ ព្រឹក ដល់ ៦:០០ ព្រឹក) ។
- តើពួកសិស្សទំនងជាជួបប្រទះនឹងខ្យល់ព្យុះរយៈពេលយូរប៉ុណ្ណាដែរ កាលឆ្លងកាត់សមុទ្រនោះ ? (ប្រមាណជា ៩ ទៅ ១២ ម៉ោង) ។

សូមអញ្ជើញសិស្សអាន ម៉ាកុស ៦:៤៧–៤៨ ដោយស្ងៀមស្ងាត់រកមើលរឿងលម្អិតបន្ថែមទៀត ដែលម៉ាកុសបានផ្តល់ឲ្យស្តីពីព្រឹត្តិការណ៍នេះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះយេស៊ូវអាចជួយពួកសិស្សឲ្យរួចផុត ពីបញ្ហារបស់ពួកគេបានភ្លាមៗដែរឬទេ ? តើចេតនាទុកឲ្យពួកសិស្សជួបបញ្ហាមួយគ្រា ពីមុនពួកគេទទួលការជួយសង្គ្រោះជាអ្វីទៅ ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀន នៅក្នុងដំណើររឿងទាំងនេះស្តីពីពួកសិស្សព្យាយាមឆ្លងកាត់សមុទ្រ ដែលទាក់ទងនឹងបញ្ហាផ្ទាល់ខ្លួនរបស់យើង ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ទោះបីជាព្រះអាចនឹងមិនជួយយើងឲ្យរួចផុតពីបញ្ហានានាជានិច្ចក្តី ប៉ុន្តែទ្រង់ជ្រាបថា យើងកំពុងជួបបញ្ហា ហើយទ្រង់នឹងយាងមកជួយក្នុងកាលកំណត់របស់ទ្រង់ផ្ទាល់**) ។
- តើរឿងល្អអ្វីខ្លះ ដែលអាចកើតចេញពីការជួបបញ្ហាមួយគ្រា ជាជាងឲ្យព្រះអម្ចាស់ជួយសង្គ្រោះយើងភ្លាមៗចេញពីការសោកល្បួង ?
- តើការដឹងថាព្រះអម្ចាស់ជ្រាបពីបញ្ហារបស់យើង អាចពង្រឹងសេចក្តីជំនឿយើងលើទ្រង់ ទាំងពេលទ្រង់មិនបានជួយសង្គ្រោះយើងភ្លាមៗក៏ដោយតាមរបៀបណា ?

ចូរសុំឲ្យសិស្ស ស្រមើស្រមៃ ថាពួកគេកំពុងជិះលើទូកនេសាទត្រីមួយនៅពាក់កណ្តាលអាគ្រាត្រ ដែលកំពុងជួបព្យុះភ្លៀង និងរលកធំៗអស់រយៈពេលជាច្រើនម៉ោង រួចក៏ឃើញមនុស្សម្នាក់ដើរនៅលើទឹក ។

- តើអ្នកអាចគិត ឬមានអារម្មណ៍បែបណាទៅ ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពនេះ ?

សូមជួយសិស្សឲ្យស្រមើស្រមៃពីដំណើររឿងនានា នៅក្នុងបទគម្ពីទាំងឡាយ

ការគិតនៅក្នុងចិត្តកើតមាននៅពេលសិស្សគិតពីរូបភាព នៅក្នុងគំនិតរបស់គេនូវអ្វីដែលកំពុងកើតឡើងនៅក្នុងដំណើររឿងខាងបទគម្ពីរ ។ ការគិតនៅក្នុងចិត្តអាចជួយបង្កើតដំណើររឿងខាងបទគម្ពីរឲ្យមានរូបភាពកាន់រស់រវើក និងពិតប្រាកដសម្រាប់សិស្សទាំងឡាយ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៤:២៦–២៧ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀប ដែលពួកសិស្សមានប្រតិកម្ម នៅពេលពួកគេបានឃើញព្រះយេស៊ូវ ។

- តើពួកសិស្សមានប្រតិកម្មបែបណាដែរ នៅពេលពួកគេបានឃើញព្រះយេស៊ូវ ?
- តើព្រះយេស៊ូវបានឆ្លើយតបនឹងការភ័យខ្លាចរបស់ពួកគេយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សម្នាក់ទៀតអាន ម៉ាថាយ ១៤:២៨ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលពេត្រុសប៉ងចង់ធ្វើ នៅពេលគាត់ឮព្រះសុរសៀងរបស់ព្រះអម្ចាស់ ។

- តើពេត្រុសចង់ធ្វើអ្វី នៅពេលគាត់បានឮព្រះសុរសៀងរបស់ព្រះអម្ចាស់ ?

សូមលើករូបភាពព្រះយេស៊ូវឡើងឲ្យសិស្សមើល រួចសុំឲ្យសិស្សស្រមៃថាពួកគេគឺជាពេត្រុសដែរ នៅក្នុងទូក ។ ចូរសុំឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ១៤:២៩–៣០ ។ បន្ទាប់ពីអានខនីមួយៗរួចហើយ ចូរសួរសិស្សថាតើពួកគេអាចគិត ឬមានអារម្មណ៍បែបណាទៅ ប្រសិនបើបានពួកគេជាពេត្រុសនោះ ។

- ហេតុអ្វីបានជាពេត្រុសចាប់ផ្តើមលិចចុះក្នុងទឹក ?
- តើព្យុះភ្លៀង និង រលកនៅក្នុងដំណើររឿងនេះអាចតំណាងឲ្យអ្វីខ្លះ នៅក្នុងជីវិតរបស់យើងដែលអាចដឹកនាំយើងឲ្យជួបនឹងការភ័យខ្លាច ឬការសង្ស័យ ?
- តើយើងអាចរៀនអ្វីខ្លះ ចេញពីបទពិសោធន៍របស់ពេត្រុសអំពីរបៀបចៀសវាងពីការហ៊ុមព័ទ្ធដោយដោយភាពភ័យខ្លាច និងការសង្ស័យរបស់យើង ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវធ្វើប្រាកដថា **ប្រសិនបើយើងសម្លឹងមើលទៅព្រះយេស៊ូវឲ្យខ្ជាប់ខ្ជួន ហើយថែរក្សាសេចក្តីជំនឿយើងលើទ្រង់ នោះយើងនឹងមិនគ្របដណ្តប់ដោយភាពភ័យខ្លាច និងការសង្ស័យរបស់យើងឡើយ**) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវភាពគ្រោះថ្នាក់នៃការបរាជ័យក្នុងការថែរក្សាសេចក្តីជំនឿយើងលើព្រះអម្ចាស់ ៖



« ខ្ញុំមានជំនឿដ៏មុតមាំថា ទោះជាបុគ្គលម្នាក់ៗ ជាគ្រួសារ សហគមន៍ និងប្រជាជាតិក្តី ប្រសិនបើយើងអាចសម្លឹងមើលទៅព្រះយេស៊ូវឲ្យខ្ជាប់ខ្ជួនដូចជាពេត្រុស នោះយើងក៏អាចដើរដោយមានជោគជ័យនៅលើ ‹ រលកសមុទ្រធំៗ នៃការឥតជំនឿ › ហើយបន្តដោយ ‹ មិនភ័យខ្លាចនៅកណ្តាលព្យុះភ្លៀងនៃភាពសង្ស័យ ដែលកំពុងបោកបក់យ៉ាងខ្លាំង › ។ ប៉ុន្តែប្រសិនបើយើងងាកចេញពីទ្រង់ ជាអង្គដែលយើងត្រូវជឿ កាលដែលវាងាយស្រួលនឹងធ្វើ ហើយកាលពិភពលោកនេះបានល្បួងយ៉ាងខ្លាំង ប្រសិនបើយើងសម្លឹងមើលទៅអំណាច និងកំហឹងនៃកត្តានានាដែលបំផ្លិចបំផ្លាញ ហើយគួរឲ្យខ្លាចទាំងនោះនៅជុំវិញយើង ជាជាងមើលទៅទ្រង់ដែលអាចជួយសង្គ្រោះយើង នោះយើងនឹងលិចទៅក្នុងសមុទ្រនៃវិបត្តិ និងទុក្ខវេទនា ព្រមទាំងភាពអស់សង្ឃឹមដោយចៀសមិនផុតឡើយ » (« The Beacon in the Harbor of Peace » *Ensign* ខែ វិច្ឆិកា ឆ្នាំ១៩៩២ ទំព័រ ១៩) ។

- តើអ្នកគិតថាយើងអាច« ផ្គោត » លើព្រះយេស៊ូវគ្រីស្ទ ដូចជាពេត្រុសបានធ្វើបានយ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់បានឃើញសេចក្តីជំនឿរបស់បុគ្គលម្នាក់លើព្រះយេស៊ូវគ្រីស្ទ អាចជួយគាត់ឲ្យចៀសវាងពីការហ៊ុមព័ទ្ធដោយការភ័យខ្លាច ឬការសង្ស័យនៅពេលណា ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើង « ផ្គោត » លើព្រះយេស៊ូវគ្រីស្ទ ហើយថែរក្សាសេចក្តីជំនឿរបស់យើងលើទ្រង់ យើងនឹងរកឃើញសេចក្តីសង្ឃឹម និងភាពក្លាហានដើម្បីប្រឈមនឹងឧបសគ្គរបស់យើង ។ សូមអញ្ជើញសិស្សឲ្យពិចារណាពីការផ្លាស់ប្តូរដែលពួកគេអាចធ្វើ នៅក្នុងជីវិតដើម្បីផ្គោត ហើយថែរក្សាសេចក្តីជំនឿរបស់ខ្លួនលើព្រះយេស៊ូវគ្រីស្ទកាន់តែប្រសើរឡើង ហើយដាក់គោលដៅមួយដើម្បីធ្វើការផ្លាស់ប្តូរទាំងនោះ ។

សូមពន្យល់ថា ដូចជាពេត្រុសដែរ ពេលខ្លះយើងអាចបរាជ័យក្នុងការថែរក្សាសេចក្តីជំនឿយើងលើព្រះយេស៊ូវគ្រីស្ទ ហើយអាចនឹងបន្ទន់ចិត្តទៅតាមការភ័យខ្លាច ការសង្ស័យ និងការបាក់ទឹកចិត្ត ។



សូមបង្ហាញ រូបភាព ព្រះយេស៊ូវគ្រីស្ទយាងដើរលើទឹក (សូមមើល *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៤៣ សូមមើលផងដែរ LDS.org) ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៤:៣០–៣២ ឲ្យឮៗ ។

- យោងតាម ខទី ៣០តើពេត្រុសបានធ្វើអ្វីខ្លះ នៅពេលគាត់ដឹងថាគាត់កំពុងតែលិចទៅក្នុងទឹកនោះ ?
- តើយើងអាចរៀនអ្វីខ្លះពីដំណើររឿងនេះស្តីពីអ្វីដែលព្រះអម្ចាស់នឹងធ្វើ ប្រសិនបើយើងស្វែងរកជំនួយរបស់ទ្រង់នៅពេលសេចក្តីជំនឿរបស់យើងធ្លាក់ចុះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងស្វែងរកជំនួយរបស់ព្រះ ពេលសេចក្តីជំនឿរបស់យើងធ្លាក់ចុះ នោះទ្រង់អាចលើកយើងឡើងចេញពីការភ័យខ្លាច និងការសង្ស័យរបស់យើងបាន**) ។
- តើព្រះលើកយើងឡើងចេញពីការភ័យខ្លាច និងការសង្ស័យរបស់យើងតាមរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៤:៣៣ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀប ដែលពួកសិស្សកំពុងនៅក្នុងទូក បានឆ្លើយតបបន្ទាប់ពីព្រះយេស៊ូវ និងពេត្រុសបានចូលមកក្នុងទូក ។

សូមសង្ខេប ម៉ាថាយ ១៤:៣៣–៣៦ ដោយពន្យល់ថា បន្ទាប់ពីព្រឹត្តិការណ៍នេះ ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បានបន្តដំណើរ របស់ខ្លួន ហើយបានទៅដល់ឆ្នេរកាលីឡេនោះ ។ នៅពេលមនុស្សម្នាបានដឹងថា ព្រះយេស៊ូវគង់នៅទីនោះ ពួកគេបាននាំមនុស្សដែល មានជំងឺទៅរកទ្រង់ ។ មានមនុស្សជាច្រើនបានជាសះស្បើយដោយគ្រាន់តែពាល់ជាយព្រះពស្ត្ររបស់ទ្រង់ ។

សូមបញ្ចប់ដោយលើកទឹកចិត្តសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀននៅក្នុងមេរៀននេះ តាមរយៈការធ្វើតាមអារម្មណ៍នានាដែលពួកគេ បានទទួល ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

ម៉ាថាយ ១៤:២៨–៣១ ។ បទបង្ហាញជាវីដេអូ—« Mountains to Climb (ភ្នំដែលត្រូវឡើង) »

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃការអំពាវនាវដល់ព្រះអម្ចាស់ ពេលពួកគេជួប ប្រទះបញ្ហា សូមពិចារណាចែកចាយវីដេអូ « ភ្នំដែលត្រូវឡើង » (៥:០៥) ។ វីដេអូនេះ មាននៅក្នុង LDS.org ។ ចូរសុំឲ្យសិស្សមើលរករបៀប ដែលព្រះអម្ចាស់អាចលើកយើង ឡើងចេញពីបញ្ហាទាំងឡាយរបស់យើង ។

មេរៀន ១៨

ម៉ាថាយ ១៥

សេចក្តីផ្តើម

កាលគង់នៅស្រុកកាលីឡេ ព្រះយេស៊ូវបានពន្យល់ពីហេតុផលដែលពួកសិស្សរបស់ទ្រង់មិនបានធ្វើតាមទំនៀមទម្លាប់ នៃការលាងសម្អាតខ្លួនឲ្យស្អាតពីមុនពួកគេបរិភោគអាហារ ។ បន្ទាប់មក ទ្រង់បានធ្វើដំណើរទៅឈូងសមុទ្រមេឌីទែរ៉ាណេ ជាកន្លែងដែលទ្រង់បានព្យាបាលកូនស្រីរបស់ស្ត្រីសាសន៍ដទៃម្នាក់ ។ ក្រោយមក ព្រះយេស៊ូវបានយាងត្រឡប់ទៅស្រុកកាលីឡេវិញ ជាកន្លែងដែលទ្រង់បានព្យាបាលមនុស្សជាច្រើន ហើយបានប្រទានចំណីដោយអព្ភូតហេតុដល់មនុស្សច្រើនជាងបួនពាន់នាក់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៥:១–២០

ពួកអាចារ្យ និង ពួកផារិស៊ីទូលសួរហេតុអ្វីបានជាពួកសិស្សរបស់ព្រះយេស៊ូវមិនលាងដៃពីមុនពួកគេបរិភោគអាហារ ។

សូមអញ្ជើញសិស្សបីនាក់ឲ្យអានសាច់រឿងដូចខាងក្រោមឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកចំណុចដូចគ្នាដែលសាច់រឿងទាំងនោះមាន ។

១. មានយុវនារីម្នាក់ត្រូវមិត្តភក្តិនាងលើកទឹកចិត្តឲ្យស្លៀកសំលៀកបំពាក់មិនសមរម្យទៅកម្មវិធីរាំនៅសាលា ។ យុវនារីនេះដឹងថាសំលៀកបំពាក់នោះមិនសក្តិសមនឹងបទដ្ឋាននៃភាពរមទមរម្យរបស់ព្រះអម្ចាស់ទេ ទោះជាវាពេញនិយមនៅក្នុងវប្បធម៌របស់នាងឲ្យស្លៀកសំលៀកបំពាក់បែបនោះក្តី ។

២. យុវជនម្នាក់មានគ្រួសារជាពួកបរិសុទ្ធថ្ងៃចុងក្រោយដែលស្រឡាញ់ព្រឹត្តិការណ៍កីឡា ។ នៅពេលព្រឹត្តិការណ៍ល្បីៗបានដាក់បញ្ចាំងតាមទូរទស្សន៍ គ្រួសារនេះទម្លាប់ចោលការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរ រាត្រីជួបជុំក្រុមគ្រួសារ និងការប្រជុំថ្ងៃអាទិត្យនៅព្រះវិហារមួយអន្លើរសិន ដើម្បីបានមើលព្រឹត្តិការណ៍ទាំងនោះ ។

៣. មានដៃគូវ័យក្មេងមួយគូកំពុងរៀបចំខ្លួនរៀបការ ។ ពួកគេរស់នៅក្នុងទីកន្លែងមួយ ដែលទទួលស្គាល់ការមានទំនាក់ទំនងផ្លូវភេទពីមុនពេលរៀបការយ៉ាងទូលំទូលាយ ។ មានមនុស្សមួយចំនួនបានប្រាប់ពួកគេថា ពួកគេចាស់គម្រិលពេកហើយ ដោយពួកគេរង់ចាំពេលរៀបការរួចសិន ទើបមានអាចមានភាពស្និទ្ធស្នាលខាងផ្លូវភេទបាន ។

- តើសាច់រឿងទាំងនេះមានចំណុចអ្វីខ្លះដូចគ្នា ? (សាច់រឿងនីមួយៗតំណាងឲ្យវិបត្តិរវាងការគោរពតាមព្រះបញ្ញត្តិរបស់ព្រះ និងការធ្វើតាមប្រពៃណី ឬទំនៀមទម្លាប់) ។

សូមពន្យល់ថា ប្រពៃណី ឬទំនៀមទម្លាប់រួមបញ្ចូលទាំងជំនឿ និងការអនុវត្តនានារបស់វប្បធម៌ សហគមន៍ គ្រួសារ ឬក្រុមមិត្តភក្តិផងដែរ ។

ចូរសុំឲ្យសិស្សប្រាប់ពីប្រពៃណី ឬទំនៀមទម្លាប់មួយ ឬច្រើនដែលអាចរារាំងពួកគេមិនឲ្យគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅក្នុង ម៉ាថាយ ១៥ ដែលអាចជួយពួកគេនៅពេលពួកគេត្រូវជ្រើសរើសរវាងការគោរពតាមព្រះបញ្ញត្តិរបស់ព្រះ និងការចូលរួមនៅក្នុងប្រពៃណី ឬទំនៀមទម្លាប់នានា ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៥:១–២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលប្រពៃណីដែលពួកអាចារ្យ និងពួកផារិស៊ីបានទូលសួរដល់ព្រះយេស៊ូវ ។

- តើប្រពៃណីអ្វីទៅដែលពួកសិស្សរបស់ព្រះយេស៊ូវមិនបានធ្វើតាម ?

សូមពន្យល់ថា ការលាងសម្អាតដៃដែលពួកអាចារ្យ និង ពួកផារិស៊ីបានលើកឡើងសំដៅទៅលើពិធីលាងដៃមួយសម្រាប់ឲ្យបានស្អាតបរិសុទ្ធ ហើយមិនសំដៅទៅលើការលាងដៃឲ្យមានអនាម័យនោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៥:៣ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលចម្លើយរបស់ព្រះយេស៊ូវ ចំពោះសំណួររបស់ពួកអាចារ្យ និង ពួកផារិស៊ី ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាពួកអាចារ្យ និងពួកផារិស៊ីកំពុងធ្វើអ្វី ដោយការចូលរួមនៅក្នុងប្រពៃណីរបស់ពួកគេនោះ ?

សូមសង្ខេប ម៉ាថាយ ១៥:៤–៦ ដោយពន្យល់ថា ព្រះយេស៊ូវបានបង្ហាញឧទាហរណ៍មួយពីរបៀបដែលពួកអាចារ្យ និងពួកផារិស៊ីប្រព្រឹត្តរំលងព្រះបញ្ញត្តិមួយរបស់ព្រះដោយការចូលរួមនៅក្នុងប្រពៃណីរបស់ពួកគេ ។ ពួកគេបានបង្រៀនថា មនុស្ស « នឹងមានសេរីភាព » (ខទី ៦) ចំពោះកាតព្វកិច្ចរបស់ពួកគេដើម្បីមើលថែឪពុកម្តាយចាស់ជរាខ្លួនដោយប្រកាសថា ប្រាក់របស់ពួកគេបានរក្សាទុកជាដង្វាយថ្វាយដល់ព្រះ ឬ *គ័របាន់* (សូមមើល ម៉ាកុស ៧:១០–១២) ។ ទោះជាយ៉ាងក៏ដោយ ព្រះយេស៊ូវបានបង្រៀនថាដោយធ្វើរឿងបែបនេះ ពួកគេបានបំពានព្រះបញ្ញត្តិឲ្យគោរពដល់ឪពុកម្តាយខ្លួន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៥:៧–៩ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលពួកអាចារ្យ និងពួកផារិស៊ីបានដឹកនាំមនុស្សឲ្យធ្វើដោយប្រើប្រពៃណីរបស់ពួកគេជាការដោះសាមួយ ដើម្បីមិនគោរពដល់ព្រះបញ្ញត្តិរបស់ព្រះ: ។

- តើពួកអាចារ្យ និងពួកផារិស៊ីបានដឹកនាំមនុស្សឲ្យធ្វើអ្វីខ្លះ: ?
- តើគោលការណ៍អ្វីខ្លះដែលយើងរៀនមកពីខគម្ពីរទាំងនេះ: អំពីអ្វីដែលយើងត្រូវធ្វើ ប្រសិនបើយើងមានបំណងប្រាថ្នាចង់ខិតទៅជិតព្រះ: ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់គោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **ប្រសិនបើយើងមានបំណងប្រាថ្នាចង់ខិតទៅជិតព្រះ: យើងត្រូវដាក់ព្រះបញ្ញត្តិរបស់ទ្រង់ឲ្យខ្ពស់ជាងប្រពៃណី ឬទំនៀមទម្លាប់នានាដែលយើងមាន**) ។

សូមអញ្ជើញអានឡើងវិញនូវសាច់រឿងពីដើមមេរៀនឲ្យឮៗ ។ បន្ទាប់ពីអានសាច់រឿងនីមួយៗរួច សូមសួរ ៖

- តើបុគ្គលម្នាក់ ឬបុគ្គលទាំងឡាយនៅក្នុងសាច់រឿងនេះអាចធ្វើអ្វីខ្លះ: ដើម្បីគោរពតាមព្រះបញ្ញត្តិរបស់ព្រះ: ?
- តើការធ្វើបែបនេះនឹងជួយបុគ្គលម្នាក់ ឬបុគ្គលទាំងឡាយឲ្យខិតទៅកាន់តែជិតព្រះបានដោយរបៀបណា ?

ក្រោយពីអ្នកបានពិភាក្សាអំពីសាច់រឿងនីមួយៗហើយ សូមសួរសិស្សក្នុងថ្នាក់ ៖

- តើអ្នកធ្លាប់ជ្រើសគោរពតាមព្រះបញ្ញត្តិរបស់ព្រះ: ជាជាងចូលរួមនៅក្នុងប្រពៃណី ឬទំនៀមទម្លាប់ដែលទទួលយកជាទូទៅនៅពេលណាដែរ ? តើការណ៍នេះបានជួយអ្នក ឲ្យខិតទៅកាន់តែជិតព្រះវរបិតាសួគ៌បានដោយរបៀបណា ? (អ្នកក៏គួរចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយផងដែរ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីប្រពៃណី និងទំនៀមទម្លាប់ដែលពួកគេប្រាប់កាលពីដើមមេរៀន ។ សូមលើកទឹកចិត្តពួកគេឲ្យជ្រើសគោរពតាមព្រះបញ្ញត្តិរបស់ព្រះ: ជាជាងធ្វើតាមប្រពៃណី ឬទំនៀមទម្លាប់នានាដើម្បីពួកគេអាចខិតទៅកាន់តែជិតនឹងព្រះ: ។

សូមរំឭកសិស្សថា ពួកអាចារ្យ និងពួកផារិស៊ីបានជឿថា ការបរិភោគអាហារដោយមិនបានលាងដៃនឹងធ្វើឲ្យមនុស្សម្នាក់ស្មោគគ្រោក ឬធ្វើឲ្យបុគ្គលនោះមិនស្អាតស្អំខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៥:១០–១១ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនថា វានឹងធ្វើឲ្យយើងស្មោគគ្រោកពិតប្រាកដនោះ: ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាអ្វីទៅដែលធ្វើឲ្យយើងស្មោគគ្រោកនោះ: ?

សូមចង្អុលបង្ហាញថា ព្រះអង្គសង្គ្រោះមានបន្ទូលថា « របស់ដែលធ្វើឲ្យស្មោកគ្រោក . . . គឺជាសេចក្តីដែលចេញពីមាត់វិញទេតើ » (ខទី ១១) ។ បន្ទាប់ពីមានបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់កុំឲ្យបារម្ភនឹងពួកផារិស៊ីដែលបានអាក់អន់ចិត្តដោយសារបន្ទូលទ្រង់ (សូមមើល ម៉ាថាយ ១៥:១២–១៦) នោះទ្រង់បានពន្យល់បន្ថែមទៀតអំពីអ្វី ដែលធ្វើឲ្យយើងស្មោកគ្រោកពិតនោះ: ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង ម៉ាថាយ ១៥:១៧–២០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះចង់ចង្អុលបង្ហាញ នៅពេលទ្រង់បានមានបន្ទូលថា « របស់ដែលធ្វើឲ្យស្មោកគ្រោក . . . គឺជាសេចក្តីដែលចេញពីមាត់វិញទេតើ »(ខទី ១១) ។

- តើព្រះអង្គសង្គ្រោះចង់មានបន្ទូលពីអ្វីទៅ កាលទ្រង់បានមានបន្ទូលថា « របស់ដែលធ្វើឲ្យស្មោកគ្រោក . . . គឺជាសេចក្តីដែលចេញពីមាត់វិញទេតើ » ?

សូមចង្អុលបង្ហាញថានៅក្នុងបទគម្ពីរ ជារឿយៗពាក្យដូងចិត្តតំណាងឲ្យគំនិត និងបំណងប្រាថ្នារបស់យើង ។ សូមសរសេរសេចក្តីថ្លែងការណ៍នេះនៅលើក្តារខៀន ៖ *ប្រសិនបើយើងជ្រើសបណ្តែតបណ្តោយតាមគំនិត និងបំណងប្រាថ្នាអាក្រក់ នោះ: . . .*

- តើអ្នកនឹងបំពេញតាមគោលការណ៍នេះ: ដោយផ្អែកលើការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខទី ១៩–២០បានយ៉ាងដូចម្តេច ? (សូមប្រើពាក្យសម្តីរបស់សិស្សដើម្បីបំពេញគោលការណ៍នេះ: ដើម្បីឲ្យវានាំទៅរកសេចក្តីពិតដូចតទៅនេះ: ៖ **ប្រសិនបើយើងជ្រើសអរសប្បាយនឹងគំនិត និងបំណងប្រាថ្នាអាក្រក់ ឬមិនសមរម្យ នោះគំនិត និងបំណងប្រាថ្នាទាំងនោះនឹងធ្វើឲ្យយើងកខ្វក់**) ។
- តើយើងមានភាពស្មោកគ្រោក ឬមិនស្អាតស្អំខាងវិញ្ញាណតាមរបៀបណាដែរ ប្រសិនបើយើងជ្រើសបណ្តែតបណ្តោយទៅតាមគំនិត និងបំណងប្រាថ្នាអាក្រក់ ឬមិនសមរម្យនោះ: ?
- តើពាក្យសម្តីចេញពីមាត់របស់យើង រួមទាំងទង្វើរបស់យើងផងដែរ ឆ្លុះបញ្ចាំងពីគំនិត និងបំណងប្រាថ្នានៅក្នុងដូងចិត្តរបស់យើងយ៉ាងដូចម្តេចដែរ ?

អ្នកគួរថ្លែងទីបន្ទាល់ពីគោលការណ៍នេះ: ហើយអញ្ជើញសិស្សជ្រើសរក្សាគំនិត និងបំណងប្រាថ្នាឲ្យបរិសុទ្ធ ។

ម៉ាថាយ ១៥:២១–២៨

ព្រះអង្គសង្គ្រោះព្យាបាលកូនស្រីស្ត្រីសាសន៍ដទៃម្នាក់

ចូរសុំឲ្យសិស្សឡើងមកក្តារខៀន សរសេរពីបំណងប្រាថ្នាសុចរិតរបស់ពួកគេមួយ ឬច្រើន ។

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍ទាំងឡាយនៅក្នុងម៉ាថាយ ១៥ដែលអាចជួយពួកគេឲ្យយល់ពីអ្វីដែលពួកគេត្រូវធ្វើ ដើម្បីទទួលបានបំណងប្រាថ្នាសុចរិតរបស់ពួកគេ ។

ចូរសុំឲ្យសិស្សបើកទៅផែនទីព្រះគម្ពីរប៊ីប ទី ១១ « ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរសញ្ញាថ្មី » ។ ចូរសុំឲ្យពួកគេរកមើលទីតាំងស្រុកទីរ៉ុស និង ស៊ីដូននៅលើផែនទីនោះ: ។ សូមពន្យល់ថា កាលព្រះយេស៊ូវយាងចេញពីស្រុកកាលីឡេទៅឈ្លងសមុទ្រទីរ៉ុស និងស៊ីដូន នោះទ្រង់បានជួបនឹងស្ត្រីសាសន៍កាណានម្នាក់ ។ ដូចជាមនុស្សផ្សេងទៀតជាច្រើននៅក្នុងភូមិភាគនោះដែរ ស្ត្រីម្នាក់នេះគឺជាសាសន៍ដទៃ—មានន័យថានាងពុំមែនជាសាសន៍យូដាទេ ។ នៅពេលនោះ: ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បានប្រកាសដំណឹងល្អទៅដល់តែ

ពួកសាសន៍យូដាប៉ុណ្ណោះ ហើយពុំទាន់ទៅដល់ពួកសាសន៍ដទៃនៅឡើយទេ (សូមមើល ម៉ាថាយ ១០:៥–៦) ។ ក្រោយមកទៀត ទ្វារនឹងបានបើកឡើងដល់ពួកសាសន៍ដទៃដើម្បីទទួលសារលិខិតនៃសេចក្តីសង្គ្រោះ (សូមមើល កិច្ចការ ១០) ។

សូមអញ្ជើញសិស្សប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង ម៉ាថាយ ១៥:២១–២៧ជាមួយនឹងដៃគូ ។ ចូរសុំឲ្យពួកគេរកមើលចម្លើយចំពោះសំណួរដូចខាងក្រោម (អ្នកគួរសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖

- តើបំណងប្រាថ្នាសុចរិតអ្វីខ្លះ ដែលស្ត្រីសាសន៍កាណានានោះមាន ?
- តើស្ត្រីរូបនេះបាននិយាយហើយធ្វើអ្វីខ្លះ ដែលបង្ហាញសេចក្តីជំនឿរបស់នាងលើព្រះយេស៊ូវគ្រីស្ទ ?

ចូរសុំឲ្យសិស្សរាយការណ៍ អំពីចម្លើយរបស់ពួកគេ ។

- តើចម្លើយរបស់ស្ត្រីរូបនេះចំពោះរឿងប្រៀបប្រដូចនេះបានបង្ហាញបន្ថែមទៀត ចំពោះសេចក្តីជំនឿរបស់នាងលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៥:២៨ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់ស្ត្រីម្នាក់នេះ ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីដល់ស្ត្រីម្នាក់នេះ ? ហេតុអ្វី ?
- តើមានគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពីដំណើររឿងនេះ ៖ អំពីអ្វីដែលអាចកើតឡើង នៅពេលយើងអនុវត្តសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់គោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលបានពរជ័យស្របតាមបំណងប្រាថ្នាសុចរិតរបស់យើង**) ។
- បន្ថែមលើការទូលសូមព្រះអម្ចាស់ឲ្យប្រទានពរយើង ដោយស្មោះត្រង់ស្របតាមបំណងប្រាថ្នាសុចរិតរបស់យើងតើ យើងអាចធ្វើអ្វីផ្សេងទៀតដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ?

សូមសួរសំណួរដែលជួយសិស្សយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

បន្ទាប់ពីបង្ហាញគោលលទ្ធិ និងគោលការណ៍ទាំងឡាយ នោះសិស្សត្រូវយល់ដឹងអំពីវាមុនពេលពួកគេអាចអនុវត្តវាប្រកបដោយអត្ថន័យ ។ ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិ ឬគោលការណ៍មួយ ចូរសួរសំណួរដែលនាំទៅរកការយល់ដឹងជ៏ ច្បាស់លាស់មួយអំពីអត្ថន័យរបស់វា ដែលលើកទឹកចិត្តសិស្សឲ្យគិតពីវាតាមបរិបទបែបទំនើបមួយ ឬដែលអញ្ជើញសិស្សឲ្យពន្យល់ពីការយល់ដឹងពួកគេអំពីវា ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមអំពីអ្វី ដែលពួកគេអាចធ្វើដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ចូរសុំសិស្សម្នាក់ឲ្យអានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អ៊ូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅពេលយើងមានសេចក្តីជំនឿលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ យើងត្រូវតែមានទំនុកចិត្តលើទ្រង់ ។ យើងត្រូវទុកចិត្តលើទ្រង់ឲ្យល្មមគ្រប់គ្រាន់ រហូតដល់យើងពេញចិត្តទទួលយកព្រះឆន្ទៈរបស់ទ្រង់ ដោយដឹងថាទ្រង់ជ្រាបដឹងនូវអ្វីដែលល្អបំផុតសម្រាប់យើង ។ . . .

« . . . មិនថាវាខ្លាំងយ៉ាងណាទេ សេចក្តីជំនឿមិនអាចបង្កើតលទ្ធផលដែលផ្ទុយទៅនឹងព្រះឆន្ទៈនៃទ្រង់ដែលជាអង្គមានព្រះចេស្តាបង្កើតវាបានឡើយ ។ . . . យើងពុំអាចមានសេចក្តីជំនឿដ៏ពិតលើព្រះអម្ចាស់ ដោយគ្មានការទុកចិត្តទាំងស្រុងលើព្រះរាជបំណងរបស់ព្រះអម្ចាស់ និង ទៅលើពេលវេលារបស់ព្រះអម្ចាស់បាននោះទេ » (« Faith in the Lord Jesus Christ » *Ensign* ខែ ឧសភា ឆ្នាំ១៩៩៤ ទំព័រ ៩៩, ១០០) ។

- តើការពន្យល់របស់អែលឌើរ អ៊ូក អំពីអត្ថន័យនៃការអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទអាចជួយយើងតាមរបៀបណា នៅពេលព្រះអម្ចាស់ពុំបានប្រទានពរភ្លាមៗដល់យើងស្របតាមបំណងប្រាថ្នាសុចរិតរបស់យើងនោះ ?

សូមអញ្ជើញសិស្សឲ្យមើលឡើងវិញនូវបញ្ជីនៃបំណងប្រាថ្នាសុចរិតនៅលើក្តារខៀន ហើយពន្យល់ពីអ្វី ដែលពួកគេអាចធ្វើដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេស្វែងរកដើម្បីទទួលបានបំណងប្រាថ្នាទាំងនោះ ។

- តើអ្នក (ឬមនុស្សម្នាក់ដែលអ្នកស្គាល់) ធ្លាប់ទទួលបានបំណងប្រាថ្នាសុចរិត (ស្របតាមឆន្ទៈ និងកាលវេលារបស់ព្រះអម្ចាស់) នៅពេលអ្នកបានអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទនោះនៅពេលណាដែរ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេស្វែងរកទទួលបានបំណងប្រាថ្នាដ៏សុចរិតរបស់ពួកគេពីទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមអ្វីដែលពួកគេបានសរសេរ ។

ម៉ាថាយ ១៥:២៩–៣៩

ព្រះយេស៊ូវបានប្រទានអាហារដល់ពួកអ្នកដើរតាម ច្រើនជាងបួនពាន់នាក់ចេញពីនំបុ័ងប្រាំពីរដុំ និងត្រីខ្លះៗ

សូមសង្ខេបម៉ាថាយ ១៥:២៩–៣៩ដោយពន្យល់ថា ព្រះយេស៊ូវបានយាងត្រឡប់ទៅស្រុកកាលីឡេវិញ ។ កាលទ្រង់គង់នៅទីនោះ មានមនុស្សជាងបួនពាន់នាក់បានប្រមូលផ្តុំគ្នាមករកទ្រង់ ដោយនាំយកមនុស្សដែលមានជំងឺ និងពិការភាពជាច្រើនមកជាមួយពួកគេ ។ ព្រះអង្គសង្គ្រោះបានព្យាបាលពួកគេ ហើយបន្ទាប់ពីប្រជាជនទាំងនោះបានចំណាយពេលបីថ្ងៃនៅជាមួយនឹងទ្រង់ នោះទ្រង់បានធ្វើអព្ភូតហេតុមួយទៀតដោយប្រទានអាហារដល់ពួកគេទាំងអស់គ្នាជាមួយនឹងនំបុ័ងប្រាំពីរដុំ និងត្រីតូចៗខ្លះប៉ុណ្ណោះ ។ (*កំណត់ចំណាំ ៖* អព្ភូតហេតុនៃការប្រទានអាហារដល់មនុស្សបួនពាន់នាក់នឹងពិភាក្សាកាន់តែល្អិតល្អន់នៅក្នុងមេរៀនសម្រាប់ម៉ាកុស ៨) ។

អ្នកគួរបញ្ចប់មេរៀននេះដោយចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត និងគោលការណ៍ទាំងឡាយដែលសិស្សបានស្គាល់នៅក្នុងម៉ាថាយ ១៥ ។

មេរៀន ១៩

ម៉ាថាយ ១៦

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានស្តីបន្ទោសពួកផារិស៊ី និង ពួកសាឌូស៊ីដែលចង់បានទីសម្គាល់មួយនៃទេវភាពរបស់ទ្រង់ ។ ពេត្រុសបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយត្រូវបានប្រគល់ឲ្យនូវកូនសោនៃនគរ ។ ព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ឲ្យលើឈើឆ្កាងរបស់ពួកគេ ហើយដើរតាមទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៦:១–១២

ពួកផារិស៊ី និង ពួកសាឌូស៊ីចង់បានទីសម្គាល់មួយមកពីព្រះអង្គសង្គ្រោះ

សូមសរសេរឃ្លាខាងក្រោមនៅលើ ក្តារខៀន ពីមុនចាប់ផ្តើមបង្រៀន ៖

តាមរយៈការលេចចេញមករបស់ទេវតាមួយអង្គ

តាមរយៈព្រះវិញ្ញាណបរិសុទ្ធ

តាមរយៈការជឿលើពាក្យមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់

តាមរយៈការឃើញអព្ភូតហេតុមួយ

ដើម្បីចាប់ផ្តើមមេរៀននេះ សុំឲ្យសិស្សជ្រើសរើសឃ្លានៅលើក្តារខៀនដែលវាពិពណ៌នាល្អបំផុតពីរបៀប ដែលពួកគេចង់ទទួលបានទីបន្ទាល់មួយអំពីដំណឹងល្អ ។ សុំឲ្យសិស្សពីរបីនាក់ប្រាប់ពីឃ្លាដែលពួកគេបានជ្រើស ហើយពន្យល់ពីហេតុផលដែលពួកគេជ្រើសយកវា ។

នៅពេលពួកគេសិក្សា ម៉ាថាយ ១៦ សុំឲ្យសិស្សរកមើលសេចក្តីពិតដែលទាក់ទងនឹងរបៀបដែលព្រះអម្ចាស់ជួយយើងឲ្យទទួល ហើយពង្រឹងទីបន្ទាល់របស់យើងអំពីដំណឹងល្អ ។

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ១៦:១ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលពួកផារិស៊ី និង ពួកសាឌូស៊ីចង់បានពីព្រះយេស៊ូវ ។

- តើពួកផារិស៊ី និង ពួកសាឌូស៊ីចង់បានអ្វីខ្លះពីព្រះយេស៊ូវ ?
- តើអ្នកគិតថា វាមានន័យដូចម្តេចកាលពួកផារិស៊ី និងពួកសាឌូស៊ីបាន « ល្បង » ព្រះយេស៊ូវកាលពួកគេទូលសុំឲ្យបង្ហាញទីសម្គាល់មួយនោះ ? (អត្ថន័យមួយនៃកិរិយាសព្ទ*ល្បង*គឺការព្យាយាម ឬសាកល្បង) ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង ម៉ាថាយ ១៦:២–៤ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកផារិស៊ី និង ពួកសាឌូស៊ី ។

- តើព្រះអម្ចាស់បានមានបន្ទូលថា ទីសម្គាល់អ្វីទៅដែលទ្រង់នឹងប្រទានឲ្យ ?

សូមពន្យល់ថា ព្រះយេស៊ូវបានមានបន្ទូលពីព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះ យ៉ូណាស ដែលត្រូវលេបចូលក្នុងពោះ « ត្រីមួយយ៉ាងធំ » (យ៉ូណាស ១:១៧) ។ « ការបញ្ចុះ » របស់យ៉ូណាស រួចបានចេញមកពីពោះត្រីក្រោយពីបានបីថ្ងៃមក គឺតំណាងឲ្យការសុគត ការបញ្ចុះ និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទពីផ្នូរនៅថ្ងៃទីបី ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ បន្ទាប់ពីបានស្តីបន្ទោសដល់ពួកផារិស៊ី និងពួកសាឌូស៊ី ?
- តើយើងអាចរៀនអ្វីខ្លះ ចេញពីបទពិសោធន៍នេះ:ស្តីពីវិធីពុំត្រឹមត្រូវដើម្បីស្វែងរកសេចក្តីពិតខាងវិញ្ញាណ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងពុំបានទទួលសេចក្តីពិតខាងវិញ្ញាណ ដោយការស្វែងរកទីសម្គាល់ឡើយ**) ។

សូមសង្ខេប ម៉ាថាយ ១៦:៥–១២ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានព្រមានពួកសិស្សរបស់ទ្រង់ ពីការបង្រៀនខុសរបស់ពួកផារិស៊ី និងពួកសាឌូស៊ី ។ (*កំណត់ចំណាំ ៖* ព្រឹត្តិការណ៍ទាំងនេះនឹងត្រូវបានលើកឡើងយ៉ាងលម្អិតនៅក្នុងមេរៀនម៉ាកុស ១០) ។

ម៉ាថាយ ១៦:១៣–២០ ។

ពេត្រុសបានថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានប្រគល់ឲ្យនូវកូនសោនៃនគរស្ថានសួគ៌

សូមពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានស្តីបន្ទោសដល់ពួកផារិស៊ី និងពួកសាឌូស៊ីដោយការចង់បានទីសម្គាល់មួយ នោះទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ពីរបៀបទទួលបានទីបន្ទាល់មួយពីសេចក្តីពិត ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៣–១៤ ឲ្យឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសំណួរដែលព្រះយេស៊ូវបានចោទសួរ និងចម្លើយរបស់ពួកសិស្សរបស់ទ្រង់ ។

ម៉ាថាយ ១៦:១៥–១៩

គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

- តើព្រះអង្គសង្គ្រោះបានសួរអ្វីខ្លះដល់ពួកសិស្សរបស់ទ្រង់ ? តើពួកគេបានឆ្លើយយ៉ាងដូចម្តេច ? (អ្នកអាចនឹងត្រូវពន្យល់ថា អេលីយ៉ាស និង យេរេមា គឺជាពួកព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះ អេលីយ៉ា និងយេរេមា) ។
- តើចម្លើយរបស់ពួកគាត់អាចប្រាប់អ្វីខ្លះដល់យើងថា មកដល់ពេលនេះនៅក្នុងការងារបម្រើរបស់ទ្រង់ តើមនុស្សបានយល់ដឹងដល់កម្រិតណាដែរ ថាព្រះយេស៊ូវគឺជានរណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៥–១៧ ឲ្យឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួរទីពីរដែលព្រះអង្គសង្គ្រោះបានចោទសួរ ។

- តើសំណួរទីពីរដែលព្រះអង្គសង្គ្រោះបានចោទនោះជាអ្វីទៅ ? តើពេត្រុសបានឆ្លើយបែបណាដែរ ?
- យោងតាម ខទី ១៧តើពេត្រុសបានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះបានដោយរបៀបណា ? (សូមចង្អុលបង្ហាញថា ព្រះវរបិតាសួគ៌បានបើកសម្តែងសេចក្តីពិតនេះដល់លោកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះ អំពីរបៀបដែលយើងអាចទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងពីសេចក្តីពិតថា **យើងទទួលបានទីបន្ទាល់មួយពីព្រះយេស៊ូវគ្រីស្ទតាមរយៈវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធ**) ។
- ហេតុអ្វីអ្នកគិតថា ការទទួលបានទីបន្ទាល់មួយតាមរយៈវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធជាជាងតាមវិធីផ្សេងទៀត ជារឿងសំខាន់សម្រាប់យើង ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធ ក្នុងការជួយយើងឲ្យទទួលបានទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ សុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖



« ការមានបន្ទូលរបស់ព្រះវិញ្ញាណនៃព្រះទៅកាន់វិញ្ញាណរបស់មនុស្ស មានន័យព្រះចេស្តាដើម្បីប្រទានសេចក្តីពិតដ៏មានឥទ្ធិពល និង ការយល់ដឹងច្រើនជាងសេចក្តីពិតដែលអាចបានផ្តល់ឲ្យដោយទំនាក់ទំនងផ្ទាល់ខ្លួន ទោះជាជាមួយនឹងអង្គនៅស្ងៀមក្តី ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ សេចក្តីពិតត្រូវត្បាញបញ្ចូលទៅក្នុងគ្រប់សរសៃរចនាសម្ពន្ធនៃសរីរាង្គ និងសរសៃពួរសាច់ដុំនៃរូបកាយ ដើម្បីវាត្រូវបានចងចាំជារៀងរហូត » (*Teachings of Presidents of the Church: Joseph Fielding Smith* | ឆ្នាំ ២០១៣ | ទំព័រ ១៨៣–៨៤) ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរៀបចំខ្លួនយើងដើម្បីទទួលវិវរណៈតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?
- តើអ្នកបានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះរបស់អ្នកតាមរបៀបណាដែរ ? តើអ្នកបានធ្វើអ្វីខ្លះដើម្បីទទួលបានសាក្សីនោះមកពីព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។ សូមលើកទឹកចិត្តពួកគេឲ្យកត់ត្រាពីរបៀប ដែលពួកគេអាចពង្រឹងទីបន្ទាល់របស់ខ្លួន ឬអ្វីដែលពួកគេត្រូវធ្វើ ដើម្បីទទួលបានទីបន្ទាល់មួយតាមរយៈព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សពីរនាក់ឡើងមកខាងមុខក្តារខៀន ហើយចូលរួមក្នុងការសម្តែងមួយ ។ សូមចាត់សិស្សម្នាក់ជាតំណាងឲ្យខ្លួនឯង ហើយសិស្សម្នាក់ទៀតជាតំណាងឲ្យមិត្តម្នាក់ដែលពុំមែនជាសមាជិកសាសនាចក្រ ។ សូមឲ្យក្រុមដែលមានសំណួរពីរដូចខាងក្រោមនេះ ដល់សិស្សដែលតំណាងឲ្យមិត្តដែលពុំមែនជាសមាជិក ។ សូមអញ្ជើញសិស្សនោះអានម្តងមួយសំណួរឲ្យឮៗ ហើយសុំឲ្យសិស្សម្នាក់ទៀតឆ្លើយ ។ (អ្នកគួរលើកទឹកចិត្តឲ្យសិស្សក្នុងថ្នាក់ឲ្យផ្តល់ជាចម្លើយ ដែលអាចកើតមានដល់សិស្សដែលត្រូវឆ្លើយនឹងសំណួរទាំងនោះ) ។



សេសារា ភីលីព

១. ខ្ញុំឮថា ព្រះវិហាររបស់ឯងប្រកាសថា ជាព្រះវិហារពិតតែមួយគត់របស់ព្រះយេស៊ូវគ្រីស្ទ ។ តើនោះជាអ្វីដែលឯងជឿមែនទេ ?

២. ព្រះវិហារខ្ញុំក៏ជឿលើព្រះយេស៊ូវគ្រីស្ទដែរ អញ្ចឹងហេតុអ្វីឯងគិតថា ព្រះវិហាររបស់ឯងគឺជាព្រះវិហារពិតតែមួយគត់នោះ ?

សូមអរគុណដល់សិស្សសម្រាប់ការចូលរួម ហើយអញ្ជើញពួកគេឲ្យត្រឡប់ទៅកន្លែងអង្គុយវិញ ។

នៅពេលសិស្សបន្តសិក្សាម៉ាថាយ ១៦សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតនានាដែលអាចជួយយើងឲ្យយល់ ហើយពន្យល់ដល់អ្នកដទៃពីភាពខុសគ្នាថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាសាសនាចក្ររបស់ព្រះអម្ចាស់នៅលើផែនដី ។

សូមរំឭកសិស្សថា នៅពេលព្រះយេស៊ូវបានសួរសំណួរអំពីអត្តសញ្ញាណរបស់ទ្រង់ដល់ពួកសិស្ស ពួកគេស្ថិតនៅក្នុងភូមិភាគមួយដែលហៅថា សេសារា ភីលីព (សូមមើល ម៉ាថាយ ១៦:១៣) ។ ប្រសិនបើអាចធ្វើទៅបាន សូមដាក់បង្ហាញ រូបភាព សេសារា ភីលីព (សូមមើលរូបថតទាំងឡាយអំពីព្រះគម្ពីរបឹបទី ២៦ « សេសារា ភីលីព ») ។ ចូរសុំឲ្យសិស្សបង្ហាញអ្វីដែលនៅពីក្រោយទន្លេ និងដើមឈើនៅក្នុងរូបថតនេះ ។ សូមពន្យល់ថា ថ្មភ្នំដ៏ធំនោះនៅសេសារា ភីលីពបានផ្តល់បរិយាកាសដ៏មានន័យមួយ ខណៈដែលព្រះអង្គសង្គ្រោះបានបន្តការពិភាក្សារបស់ទ្រង់ជាមួយនឹងពួកសិស្សរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦: ១៨–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអង្គសង្គ្រោះបានប្រើថ្មដាមួយដើម្បីពិពណ៌នាពីគ្រឹះនៃសាសនាចក្រ ។

- តើអ្នកគិតថា ព្រះអង្គសង្គ្រោះចង់មានបន្ទូលយ៉ាងដូចម្តេចដែរ កាលទ្រង់មានបន្ទូលថា ទ្រង់នឹងសង់សាសនាចក្ររបស់ទ្រង់ « នៅលើថ្មដានេះ » ? (ខទី ១៨) ។

ដើម្បីជួយសិស្សឲ្យយល់ឃ្លានេះ៖ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដោយព្យាការី យ៉ូសែប ស៊្មីធ ឲ្យឮៗ ៖



« នៅក្នុងការបង្រៀនរបស់ទ្រង់ ព្រះយេស៊ូវបានមានបន្ទូលថា ‹ ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មីដានេះ ។ . . . › [ម៉ាថាយ ១៦:១៨] ។ តើថ្មដាជាអ្វី ? វិវរណៈ » (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ១៩៥) ។

« សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវបានស្តាបនាឡើងដោយវិវរណៈដោយផ្ទាល់ ជាសាសនាចក្រពិតរបស់ព្រះដែលធ្លាប់មានពីមុនមកយោងតាមព្រះគម្ពីរ (អេម៉ុស ៣:៧និង កិច្ចការ ១:២) » (*Teachings: Joseph Smith* ទំព័រ ១៩៥) ។

- តើអ្នកអាចសង្ខេបនូវការបង្រៀនរបស់ព្រះអង្គសង្គ្រោះ អំពីសាសនាចក្ររបស់ទ្រង់ដែលបានកត់ត្រានៅក្នុង ខទី ១៨បានយ៉ាងដូចម្តេច ? (សិស្សគួរឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **សាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ គឺសង់ឡើងនៅលើវិវរណៈមកពីព្រះ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើការដឹងថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺសង់ឡើងនៅលើវិវរណៈមកពីព្រះ អាចពង្រឹងទីបន្ទាល់របស់អ្នកអំពីដំណឹងល្អយ៉ាងណាដែរ ?
- យោងតាម ខទី ១៩តើព្រះអង្គសង្គ្រោះបានសន្យានឹងប្រទានអ្វីខ្លះដល់ពេត្រុស ?
- តើមានគោលលទ្ធិអ្វីខ្លះដែលយើងអាចរៀនចេញពីការសន្យា ដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពេត្រុស ? (សូមប្រាកដថា សិស្សស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទប្រទានកូនសោនៃនគររបស់ទ្រង់ដល់ពួកព្យាការី និងពួកសាវកជម្រើសរបស់ទ្រង់**) ។
- តើកូនសោនៃនគរគឺជាអ្វីទៅ ? (អំណាច សិទ្ធិ និងសិទ្ធិអំណាចដោយផ្ទាល់ដែលចាំបាច់ ដើម្បីធ្វើជាអធិបតីនៅលើនគរព្រះនៅលើផែនដី ឬសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ) ។

ដើម្បីជួយសិស្សឲ្យយល់ពីអ្វីទៅជាកូនសោបព្វជិតភាពនោះ៖ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ ដាល្លិន អេក អូក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« ‹ កូនសោបព្វជិតភាពគឺជាសិទ្ធិអំណាចពីព្រះ ដែលបានប្រទានដល់ [ពួកអ្នកកាន់] បព្វជិតភាពដើម្បីដឹកនាំ គ្រប់គ្រង និងត្រួតត្រាការប្រើប្រាស់បព្វជិតភាពរបស់ទ្រង់នៅលើផែនដី › [*ក្បួនខ្ចាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ* [ឆ្នាំ ២០១០] ចំណុច ២.១.១) ។ រាល់សកម្មភាព ឬពិធីបរិសុទ្ធដែលធ្វើឡើងនៅក្នុងសាសនាចក្រ ត្រូវធ្វើឡើងនៅក្រោមការប្រគល់សិទ្ធិអំណាចដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់បុគ្គលម្នាក់ដែលកាន់កូនសោសម្រាប់ការងារនោះ » (« The Keys and Authority of the Priesthood » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៤៩) ។

- តើព្រះយេស៊ូវមានបន្ទូលថាពេត្រុសអាចធ្វើអ្វីខ្លះ ដោយសារកូនសោដែលគាត់នឹងទទួល ?

សូមពន្យល់ថា នៅក្នុងចំណោមកូនសោដែលព្រះអង្គសង្គ្រោះបានសន្យាប្រទានឲ្យដល់ពេត្រុស គឺជាកូនសោនៃអំណាចផ្សារភ្ជាប់ ។ អំណាចនេះអនុញ្ញាតឲ្យពិធីបរិសុទ្ធនានា ត្រូវបានធ្វើឡើងនៅក្រោមសិទ្ធិអំណាចនៃថ្នាក់ដឹកនាំសាសនាចក្រ ដើម្បីមានសុពលភាពនៅស្ថានសួគ៌ ។ វាក៏ត្រូវបានប្រើដើម្បីចងគ្រួសារឲ្យរួបរួមគ្នាសម្រាប់ភាពអស់កល្បជានិច្ចផងដែរ ។ នៅក្នុងសម័យរបស់យើង អំណាចផ្សារភ្ជាប់គឺត្រូវបានកាន់ដោយគណៈប្រធានទីមួយ និងក្រុមនៃពួកសាវកដប់ពីរនាក់ ។

- តើអ្នកនឹងសង្ខេបពីហេតុផលដែលព្រះអម្ចាស់ ប្រទានកូនសោបព្វជិតភាពដល់ពួកព្យាការី និងពួកសាវករបស់ទ្រង់យ៉ាងដូចម្តេចដែរ ? (សិស្សគួរឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **កូនសោបព្វជិតភាពគឺចាំបាច់ ដើម្បីគ្រប់គ្រងសាសនាចក្ររបស់ព្រះអម្ចាស់នៅលើផែនដី**) ។

ចូរសុំសិស្សម្នាក់អានសំណួរនៅក្នុងការសម្តែងឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យពន្យល់ពីរបៀប ដែលពួកគេនឹងឆ្លើយតបនឹងសំណួរទាំងនេះដោយប្រើសេចក្តីពិតដែលពួកគេបានរកឃើញនៅក្នុងម៉ាថាយ ១៦:១៨–១៩ ។ អ្នកក៏គួរអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីសេចក្តីពិតទាំងនេះផងដែរ ។

សូមពិចារណាដាក់បង្ហាញរូបភាពនៃគណៈប្រធានទីមួយ និងក្រុមនៃពួកសាវកដប់ពីរនាក់នាពេលបច្ចុប្បន្ន (សូមមើល LDS.org [ឧទាហរណ៍ Meet Today's Prophets and Apostles] និងច្បាប់ទាំងឡាយនៃសន្និសីទទូទៅរបស់ *Ensign* ឬ *Liahona*) ហើយដោយថ្លែងទីបន្ទាល់ថា កូនសោដូចគ្នាដែលបានប្រទានឲ្យពេត្រុស និងពួកសាវកផ្សេងទៀតកាលពីបុរាណគឺត្រូវបានកាន់ ហើយប្រើប្រាស់នៅសព្វថ្ងៃនេះដោយពួកព្យាការី និងពួកសាវកទាំងឡាយដែលនៅរស់របស់ព្រះអម្ចាស់ ។

ម៉ាថាយ ១៦:២១–២៨

ព្រះយេស៊ូវបង្រៀនពីអត្ថន័យនៃការដើរតាមទ្រង់

សូមសង្ខេប ម៉ាថាយ ១៦:២១–២៨ ដោយពន្យល់ថា ព្រះយេស៊ូវបានមានបន្ទូលពីពលិកម្មដ៏ធ្ងន់របស់ទ្រង់ ។ ទ្រង់ក៏បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ផងដែរថា ពួកគេត្រូវមានឆន្ទៈលះបង់ចោលនូវមនុស្សខាងសាច់ឈាម (សូមមើល ម៉ូសាយ ៣:១៩) ត្រូវគោរពប្រតិបត្តិ ហើយមានការលះបង់ ដើម្បីដើរតាមទ្រង់ដោយចិត្តរីករាយ ។

ចំណេះចំណានខគម្ពីរ—ម៉ាថាយ ១៦:១៥–១៩

សូមលើកទឹកចិត្តសិស្សឲ្យចែកចាយនឹងគ្រួសាររបស់ពួកគេ នូវអ្វីដែលពួកគេបានរៀននៅក្នុង ម៉ាថាយ ១៦ ។ សូមពិចារណាជ្រើសផ្នែកមួយនៃ ម៉ាថាយ ១៦:១៥–១៩ ដើម្បីឲ្យសិស្សទន្ទេញចាំនៅប៉ុន្មានថ្ងៃខាងមុខ ។ អ្នកក៏អាចរកឃើញគំនិតសម្រាប់ការទន្ទេញចាំ នៅក្នុងសេចក្តីបន្ថែមនៃសៀវភៅសិក្សានេះផងដែរ ។

មេរៀន ២០

ម៉ាថាយ ១៧

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទ ម៉ូសេ និងអេលីយ៉ា បានប្រគល់កូនសោបព្វជិតភាពឲ្យ ពេត្រុស យ៉ាកុប និង យ៉ូហាន នៅលើភ្នំប្រែរូប ។ បន្ទាប់ពីយាងចុះពីភ្នំវិញ ព្រះយេស៊ូវបានបណ្តេញអារក្សចេញពីក្មេងប្រុសម្នាក់ ។ នៅក្រុងកាពើណិម ព្រះយេស៊ូវបានបង់ពន្ធព្រះវិហារសម្រាប់អង្គទ្រង់ និង ពេត្រុសដោយភាពអស្ចារ្យ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៧:១–១៣

ម៉ូសេ និងអេលីយ៉ាសបានលេចមកឯ ពេត្រុស យ៉ាកុប និងយ៉ូហាន

សូមលើកប័ណ្ណបើកបរមួយឡើង ឬសូមអញ្ជើញសិស្សម្នាក់ដែលមានប័ណ្ណបើកបរឲ្យបង្ហាញវាដល់សិស្សក្នុងថ្នាក់ ។

- តើការមានប័ណ្ណបើកបរមួយផ្តល់សិទ្ធិឲ្យមនុស្សម្នាក់ធ្វើអ្វីបានខ្លះ ?

ចូរដាក់បង្ហាញ ឬបង្ហាញរូបភាពសោរថយន្ត ។

- ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីមានសិទ្ធិចំពោះកូនសោរថយន្ត បន្ថែមពីលើការមានប័ណ្ណបើកបរ ?
- តើការមានប័ណ្ណបើកបរ និងកូនសោរថយន្តត្រូវអាចប្រៀបបាននឹងសិទ្ធិអំណាច និងកូនសោនៃបព្វជិតភាពដែលចាំបាច់ដើម្បី ដឹកនាំកិច្ចការរបស់ព្រះបានយ៉ាងដូចម្តេច ? (ដូចជាជនដែលមានប័ណ្ណបើកបរត្រូវបានផ្តល់សិទ្ធិឲ្យបើកបរដូច្នេះដែរ នោះក៏មាន បុរសជាច្រើនដែលមានសិទ្ធិអំណាចបព្វជិតភាព ។ ប៉ុន្តែដូចជាកូនសោរថយន្តដែលអនុញ្ញាតឲ្យអ្នកបើកបរម្នាក់ អាចប្រើប្រាស់ រថយន្តមួយជាក់លាក់បានដែរ កូនសោបព្វជិតភាពផ្តល់សិទ្ធិអំណាចដល់បុគ្គលម្នាក់ឲ្យដំណើរការ ឬដឹកនាំកិច្ចការរបស់ព្រះនៅក្នុង ដែនជាក់លាក់មួយ ។ ប្រធានសាសនាចក្រកាន់ និងប្រើប្រាស់កូនសោបព្វជិតភាព ដើម្បីធ្វើជាអធិបតី ហើយដឹកនាំរាល់កិច្ចការរបស់ ព្រះអម្ចាស់នៅលើផែនដី) ។

សូមរំឭកសិស្សថា នៅក្នុង ម៉ាថាយ ១៦:១៩ យើងអានថា ព្រះអម្ចាស់បានសន្យានឹងប្រទានដល់ពេត្រុសនូវកូនសោនៃនគរ ឬសិទ្ធិ អំណាចដើម្បីដឹកនាំកិច្ចការរបស់ព្រះនៅលើផែនដី ។ នៅពេលនោះ ពេត្រុស និងសាវកផ្សេងទៀត បានទទួលសិទ្ធិអំណាចបព្វជិភាពរួច ហើយ ប៉ុន្តែពួកគេពុំទាន់បានទទួលកូនសោនៃនគរនៅឡើយទេ ។

នៅសិស្សសិក្សាព្រះគម្ពីរនៅថ្ងៃនេះ សូមអញ្ជើញពួកគេឲ្យរកមើលរបៀបដែលពេត្រុសបានទទួលកូនសោនគរ និងរបៀបដែលកូនសោ ទាំងនេះត្រូវបានប្រគល់ដល់ យ៉ូសែប ស៊្មីធ នៅពេលក្រោយមកទៀត និងអ្នកដឹកនាំផ្សេងទៀតនៅក្នុងជំនាន់របស់យើង ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៧:១–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីទីកន្លែងដែលព្រះអង្គសង្គ្រោះ បាននាំពេត្រុស យ៉ាកុប និងយ៉ូហានទៅ ដើម្បីរៀបចំខ្លួនពួកគេទទួលកូនសោបព្វជិតភាព ។ អ្នកគួរចង្អុលបង្ហាញថា ព្រះអង្គសង្គ្រោះ ប្រហែលជាបានជ្រើស ពេត្រុស យ៉ាកុប និងយ៉ូហាន ឲ្យយាងទៅជាមួយនឹងទ្រង់ ដោយសារពួកគេនឹងបម្រើជាគណៈប្រធានទីមួយ នៃសាសនាចក្រ បន្ទាប់ពីការមានព្រះជន្មឡើងវិញ និងការយាងទៅស្ថានសួគ៌វិញរបស់ព្រះអង្គសង្គ្រោះ (សូមមើល យ៉ូសែប ហ៊ីលឌីង ស្មីធ *Doctrines of Salvation* ចងក្រងដោយ ប្រ៊ូស អ័រ ម៉ាក់ខនឃី វ៉ុលទី ៣ | ឆ្នាំ ១៩៥៤–៥៦ | ៣:១៥២) ។

- តើព្រះយេស៊ូវបាននាំ ពេត្រុស យ៉ាកុប និងយ៉ូហាន ទៅកន្លែងណា ?
- តើមានអ្វីកើតឡើងចំពោះព្រះអង្គសង្គ្រោះនៅលើភ្នំនោះ ?
- តើការប្រែរូបមានន័យដូចម្តេច ?

សូមជួយសិស្សឲ្យយល់ថា *ប្រែរូប* សំដៅទៅលើ « លក្ខណៈនៃជនទាំងឡាយណា ដែលបានប្រែរាងកាយ និងសភាពមួយរយៈ—គឺថា បានលើកឡើងទៅកាន់កម្រិតកាន់តែខ្ពង់ខ្ពស់ខាងវិញ្ញាណដែលខ្ពស់ជាង—ដើម្បីឲ្យពួកគេអាចទ្រាំទ្រវត្តមាន និងសិរីល្អនៃពួកពលសួគ៌ទាំងឡាយបាន » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ប្រែរូប » ,scriptures.lds.org) ។ ពេត្រុស យ៉ាកុប និងយ៉ូហាន ក៏ បានប្រែរូបនៅពេលនេះដែរ (សូមមើល គ. និង ស. ៦៧:១១–១២) ។

ចូរសរសេរក្បាលរឿងដូចខាងក្រោមនៅលើក្តារខៀន ៖ *បុគ្គលទាំងឡាយដែលមានវត្តមាននៅលើភ្នំប្រែរូប* ។ នៅក្រោមក្បាលរឿងនេះ សូមសរសេរ *ព្រះយេស៊ូវគ្រីស្ទ ពេត្រុស យ៉ាកុប* និង *យ៉ូហាន* ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៧:៣ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់ ឲ្យរកមើលអ្នកដែលបានលេចមកឯព្រះយេស៊ូវ និង ពួកសាវកនៅលើភ្នំនោះ ។

- តើនរណាបានលេចចេញមកនៅលើភ្នំនោះ ? (សូមពន្យល់ថា *អេលីយ៉ាស* សំដៅទៅលើអេលីយ៉ា ព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ | សូមមើល ម៉ាថាយ ១៧:៣ |) ។



ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះកាយដល់ យ៉ូសែប ស៊្មីធ



យ៉ូហាន បាទីស្ទ បានស្តារបព្វជិតភាពអើរ៉ុនឡើងវិញ



ពេត្រុស យ៉ាកុប និង យ៉ូហាន បានស្តារបព្វជិតភាពមិលគីស្សាដែកឡើងវិញ



អេលីយ៉ា បានស្តារកូនសោនៃការផ្សារភ្ជាប់ឡើងវិញនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់

*សូមបន្តែម **ម៉ូសេ** និង **អេលីយ៉ា** នៅក្នុងបញ្ជីនៅលើក្តារខៀន ។*

ដើម្បីជួយសិស្សឲ្យយល់ពីហេតុផលដែលម៉ូសេ និងអេលីយ៉ាបានលេចមកនៅលើភ្នំនោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ឲ្យឮៗ ៖

« ព្រះអង្គសង្គ្រោះ ម៉ូសេ និងអេលីយ៉ាស | អេលីយ៉ា | បានប្រទានកូនសោទាំងឡាយ | នៃបព្វជិតភាព | ដល់ពេត្រុស យ៉ាកុប និង យ៉ូហាន នៅលើភ្នំនោះ នៅពេលពួកលោកបានប្រែរូបនៅចំពោះលោក » (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ | ទំព័រ ១០៥) ។

- យោងតាម យ៉ូសែប ស៊្មីធ ហេតុអ្វីបានជា អេលីយ៉ា និងម៉ូសេ បានលេចមកនៅលើភ្នំនោះ ? (ដើម្បីឲ្យកូនសោបព្វជិតភាពដល់ពេត្រុស យ៉ាកុប និងយ៉ូហាន ។ អ្នកក៏គួរពន្យល់ផងដែរថា ម៉ូសេ និងអេលីយ៉ា បានលេចមកនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៨៣៦ ដើម្បីស្តារឡើងវិញនូវកូនសោបព្វជិតភាព ៖ ម៉ូសេបានស្តារឡើងវិញនូវកូនសៅនៃការប្រមូលផ្តុំសាសន៍អ៊ីស្រាអែល | សូមមើល គ. និង ស. ១១០:១១ | ហើយអេលីយ៉ាបានស្តារឡើងវិញនូវកូនសៅដែលទាក់ទងនឹងអំណាចនៃការផ្សារភ្ជាប់ | សូមមើល គ. និង ស. ១១០:១៣–១៦ | ។ ការបង្ហាញខ្លួនទាំងនេះនៅទីក្រុងខឺតឡង់ ផ្តល់ជាគំរូមួយចំពោះការយល់ដឹងពីអ្វីដែលបានកើតឡើងនៅលើភ្នំប្រែរូប) ។

សូមពន្យល់ថា ការបកប្រែព្រះគម្ពីរបរិសុទ្ធដោយយ៉ូសែប ស៊្មីធ បញ្ជាក់ថា យ៉ូហាន បាទីស្ទ—ដែលស្តេចហេរ៉ូឌបានសម្លាប់—ក៏បានលេចមកនៅលើភ្នំនោះដែរ (សូមមើលការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាកុស ៩:៣ | នៅក្នុង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ | សូមមើលផងដែរនៅក្នុងសេចក្តីណែនាំដល់បទគម្ពីរ « អេលីយ៉ាស ») ។ សូមបន្តែម ***យ៉ូហាន បាទីស្ទ*** ចូលទៅក្នុងបញ្ជីនៅលើក្តារខៀន ។

សុំឲ្យសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ១៧:៤–៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមនុស្សផ្សេងទៀតដែលមានវត្តមាននៅលើភ្នំប្រែរូប ។

- តើនរណាផ្សេងទៀត ដែលជាបុគ្គលមានវត្តមាននៅលើភ្នំប្រែរូបនោះ ? (សូមបន្តែម ***ព្រះជាព្រះវរបិតា*** ចូលទៅក្នុងបញ្ជីនៅលើក្តារខៀន) ។

សូមរំឭកសិស្សដោយសង្ខេបថា គ្រាកាន់កាប់ត្រួតត្រាមួយនៅក្នុងដំណឹងល្អគឺជាគ្រាមួយ ដែលព្រះវរបិតាសួគ៌ប្រទានសិទ្ធិអំណាចបព្វជិតភាព ពិធីបរិសុទ្ធនានា និងចំណេះដឹងអំពីផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់ដល់មនុស្សនៅលើផែនដីតាមរយៈពួកអ្នកបម្រើដែលមានសិទ្ធិអំណាចរបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀន ហើយដាក់ផ្កាយមួយនៅក្បែរឈ្មោះបុគ្គលម្នាក់ៗដែលបានមាននៅលើក្តារខៀន ជាអ្នកដែលបានលេចមកឯព្យាការី យ៉ូសែប ស៊្មីធ នៅក្នុងជំនាន់របស់យើង ។ (សិស្សនោះគួរដាក់ផ្កាយមួយនៅក្នុងក្បែរឈ្មោះបុគ្គលនីមួយៗ ដែលមាននៅលើក្តារខៀន) ។

ចូរសុំសិស្សឲ្យពន្យល់ពីពេលដែលការមកជួបនីមួយៗបានកើតឡើង និងគោលបំណងរបស់វា ។ (នៅពេលសិស្សពន្យល់ អ្នកគួរបង្ហាញរូបភាពដូចខាងក្រោមនេះ ៖ ការនិមិត្តដំបូង យ៉ូហាន បាទីស្ទ ប្រគល់បព្វជិតភាពអើរ៉ុន ការស្តារបព្វជិតភាពមិលគីស្សាដែកឡើងវិញ និង អេលីយ៉ា បានលេចមកនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ | *សៀវភៅសិល្បៈដំណឹងល្អ* (ឆ្នាំ ២០០៩) ល.រ. ៩០, ៩៣, ៩៤, ៩៥សូមមើលផងដែរ LDS.org |) ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ចេញពីព្រឹត្តិការណ៍ទាំងនេះ ពាក់ព័ន្ធនឹងការប្រគល់កូនសោបព្វជិតភាពនៅក្នុងគ្រាកាន់កាប់ត្រួតត្រានីមួយៗ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្នើលពីសេចក្តីពិតខាងក្រោមនេះ ៖ **នៅក្នុងគ្រាកាន់កាប់ត្រួតត្រានីមួយៗ ព្រះប្រគល់កូនសោបព្វជិតភាពដល់ពួកអ្នកបម្រើជម្រើសរបស់ទ្រង់ ដើម្បីពួកគេអាចដឹកនាំកិច្ចការរបស់ទ្រង់នៅលើផែនដី**) ។
- ហេតុអ្វីវាគឺជារឿងដ៏សំខាន់ដើម្បីដឹងថា គំរូដូចគ្នាដដែលនៃការប្រគល់កូនសោបព្វជិតភាព ដែលបានកើតឡើងនៅសម័យព្រះយេស៊ូវគ្រីស្ទបានកើតឡើងដូចគ្នា នៅជំនាន់របស់យើងជាមួយនឹងព្យាការី យ៉ូសែប ស៊្មីធ ?
- តើពួកព្យាការី និងពួកសាវកនាពេលបច្ចុប្បន្នកាន់កូនសោដូចគ្នានឹងកូនសៅដែល យ៉ូសែប ស៊្មីធ បានទទួលដែរឬទេ ? (មែនហើយ) ។ តើពួកលោកបានទទួលកូនសោទាំងនោះតាមរបៀបណា ? (កូនសោទាំងនោះត្រូវបានប្រគល់បន្តពី យ៉ូសែប ស៊្មីធ ដល់ ព្រិកហាំ យ៉ង់ និងពួកព្យាការីបន្តបន្ទាប់ទៀត) ។

សូមពិចារណាអញ្ជើញសិស្សឲ្យចែកចាយអារម្មណ៍របស់ពួកគេផ្ទាល់អំពីសិទ្ធិអំណាចបព្វជិតភាព និងពរជ័យនៃការមានកូនសោដែលបានប្រគល់ឲ្យនៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់យើង ដូចជានៅក្នុងការងារបម្រើនៅក្នុងជីវិតរមែងស្លាប់របស់ព្រះយេស៊ូវគ្រីស្ទដែរ ។

ម៉ាថាយ ១៧:១៤–២៣

ព្រះយេស៊ូវបណ្តេញអារក្សចេញពីក្មេងប្រុសម្នាក់

សូមសង្ខេប ម៉ាថាយ ១៧:១៤–២៣ ដោយពន្យល់ថា មានឪពុកម្នាក់បាននាំកូនប្រុសខ្លួនមកជួបនឹងព្រះអង្គសង្គ្រោះដើម្បីឲ្យទ្រង់ជួយព្យាបាល ។ បន្ទាប់ពីព្រះយេស៊ូវបានព្យាបាលកុមារនោះ ទ្រង់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ថា ពរជ័យមួយចំនួនត្រូវអាចទទួលបានតែតាមរយៈការអធិស្ឋាន និងការតមអាហារប៉ុណ្ណោះ ។ ទ្រង់ក៏បានព្យាករពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ផងដែរ ។ (*កំណត់ចំណាំ ៖* ការបង្រៀនទាំងនេះនឹងពិភាក្សាកាន់តែសឹងជម្រៅបន្ថែមទៀត នៅក្នុងគំនិតសម្រាប់ការបង្រៀននៃម៉ាកុស ៩:១៤–២៩) ។

ម៉ាថាយ ១៧:២៤–២៧

ព្រះយេស៊ូវបានបង់ពន្ធព្រះវិហារឲ្យអង្គទ្រង់ និងពេត្រុសយ៉ាងអស្ចារ្យ ។

នៅពេលសិស្សសិក្សាម៉ាថាយ ១៧:២៤–២៧សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយយើងឲ្យយល់ដឹងពីរបៀបដែលគំរូរបស់យើងជះឥទ្ធិពលដល់មនុស្សដទៃទៀត ។

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនៃសារលិខិតនេះ សូមពន្យល់ថានៅក្រោមក្រឹត្យវិន័យរបស់ម៉ូសេ បុរសសាសន៍អ៊ីស្រាអែលគ្រប់រូបដែលមានអាយុលើសពី២០ឆ្នាំ គឺតម្រូវឲ្យបង់ពន្ធប្រចាំឆ្នាំដល់ព្រះវិហារបរិសុទ្ធ ដែលហៅថា *ប្រាក់ពន្ធ* (សូមមើលនិក្ខមនំ ៣០:១៣–១៦) ។ ប្រាក់នេះត្រូវបានប្រើដើម្បីជួត់ជ្ដង់ពាក់ព័ន្ធនឹងថ្លៃដំណើរការព្រះវិហារបរិសុទ្ធ ។ មានពួកសង្ឃ និងពួកអាចារ្យមួយចំនួននៅក្នុងចំណោមប្រជាជនត្រូវបានរួចពីពន្ធនេះដោយសារការកំណត់ពីក្រុមប្រឹក្សាដែលកាន់អំណាច ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៧:២៤–២៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរកមើលសំណួរដែលពួកអ្នកយកពន្ធ និងព្រះយេស៊ូវបានសួរដល់ពេត្រុស ។

- តើអ្នកយកពន្ធបានសួរអ្វីខ្លះដល់ពេត្រុស ? តើអ្វីទៅជាចម្លើយរបស់ពេត្រុស ?
- តើព្រះយេស៊ូវបានសួរអ្វីខ្លះដល់ពេត្រុស ? តើអ្វីទៅជាចម្លើយរបស់ពេត្រុស ?

សូមពន្យល់ថាពាក្យ *ពួកមនុស្សចម្លែក* នៅក្នុងបទគម្ពីរនេះសំដៅទៅលើមនុស្សគ្រប់គ្នានៅក្នុងនគរមួយ ដែលពុំមែនជាបុត្ររបស់ស្តេច ។ « ពួកមនុស្សចម្លែក » ត្រូវតែបង់ពន្ធ កាលបុត្ររបស់ស្តេចត្រូវបានលើកលែងពន្ធ ។ ព្រះយេស៊ូវបានបង្រៀនពេត្រុសថាដោយសារទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ហើយព្រះវិហារបរិសុទ្ធគឺជាដំណាក់របស់ព្រះវរបិតាទ្រង់ (សូមមើល ម៉ាថាយ ១៧:២៥–២៦, យ៉ូហាន ២:១៦) នោះទ្រង់ពុំចាំបាច់ត្រូវបង់ពន្ធនេះទេ ហើយអាចជ្រើសមិនធ្វើដូច្នេះបានដែរ ។ ប៉ុន្តែ ពួកអ្នកយកពន្ធបានរំពឹងទុកឲ្យព្រះយេស៊ូវបង់ពន្ធ ដោយសារពួកគេមិនបានដឹងថាទ្រង់គឺជានរណា ។

សូមអញ្ជើញសិស្សអាន ម៉ាថាយ ១៧:២៧ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលព្រះយេស៊ូវបានណែនាំឲ្យពេត្រុសធ្វើបន្ទាប់ទៀត ។

- តើព្រះអង្គសង្គ្រោះបានណែនាំពេត្រុសឲ្យធ្វើអ្វីខ្លះ ?
- ហេតុអ្វីបានជាព្រះយេស៊ូវមានបន្ទូលថា ទ្រង់នឹងបង់ពន្ធនោះ ?

សូមសរសេរពាក្យ *អាក់អន់ចិត្ត* នៅលើក្តារខៀន ហើយពន្យល់ថា នៅក្នុងបរិបទនេះ ឃ្លាថា « ដើម្បីកុំឲ្យយើងបានជាទីអាក់អន់ចិត្តដល់គេ » គឺទំនងជាសំដៅទៅលើធាតុពិតដែលព្រះអង្គសង្គ្រោះពុំចង់ធ្វើអ្វី ដែលអាចបណ្តាលឲ្យមនុស្សដទៃមានឧបសគ្គខាងវិញ្ញាណនោះទេ ។ (ប្រសិនបើទ្រង់មិនបង់ពន្ធនោះ ពួកសាសន៍យូដាមួយចំនួនអាចនឹងមិនពេញចិត្តចំពោះទ្រង់ និងពួកអ្នកដើរតាមរបស់ទ្រង់ ហើយលែងចង់ស្តាប់ដល់សារលិខិតនៃដំណឹងល្អ) ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះចេញពីគំរូរបស់ព្រះអង្គសង្គ្រោះ ? (ទោះបីជាសិស្សអាចនឹងឆ្លើយខុសៗគ្នាក្តី ពួកគេគួរតែស្គាល់នូវគោលការណ៍ខាងក្រោមនេះ ៖ **យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះដោយចៀសវាងនូវទង្វើដែលអាចធ្វើឲ្យមនុស្សដទៃមានឧបសគ្គខាងវិញ្ញាណ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើស្ថានភាពផ្សេងទៀតមួយចំនួនមានអ្វីខ្លះ ដែលគោលការណ៍នេះអាចដឹកនាំយើងឲ្យធ្វើការជ្រើសរើសដ៏ត្រឹមត្រូវ ?
- តើអ្នកធ្លាប់បានប្រទានឲ្យតាមរបៀបណាដែរ នៅពេលអ្នកព្យាយាមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ហើយចៀសវាងទង្វើដែលអាចបណ្តាលឲ្យមនុស្សដទៃទៀតជំពប់ដួលខាងវិញ្ញាណ ?

សូមបញ្ចប់មេរៀននេះដោយអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀនរបស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីមួយដែលពួកគេនឹងធ្វើ ដើម្បីឲ្យពួកគេរស់នៅតាមគោលការណ៍ដែលពួកគេបានស្គាល់ខាងលើកាន់តែប្រសើរឡើង ។

សួរសំណួរដែលញ៉ាំងឲ្យមានអារម្មណ៍បំផុសគំនិត និង ទីបន្ទាល់

បន្ទាប់ពីសិស្សយល់ពីគោលលទ្ធិ ឬគោលការណ៍មួយដែលបានបង្រៀននៅក្នុងបទគម្ពីរនេះ ចូរសួរសំណួរដែលជួយសិស្សឲ្យញឹងគិតពីបទពិសោធន៍ខាងវិញ្ញាណកាលពីអតីតកាលដែលទាក់ទងនឹងគោលលទ្ធិ ឬគោលការណ៍នោះ ។ សំណួរទាំងនេះអាចជួយសិស្សឲ្យមានអារម្មណ៍កាន់តែជ្រាលជ្រៅពីសេចក្តីពិតដ៏ពេញលេញ និងសារៈសំខាន់នៃសេចក្តីពិតនៃដំណឹងល្អនោះនៅក្នុងជីវិតរបស់ពួកគេ ។ ជារឿយៗ អារម្មណ៍ទាំងនោះនឹងបង្កើតបំណងប្រាថ្នាដ៏ខ្លាំងមួយ ដើម្បីរស់នៅតាមគោលការណ៍នៃដំណឹងល្អមួយកាន់តែស្មោះត្រង់ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

នៅពេលសិស្សអាចរកវគ្គចំណេះចំណានខគម្ពីរដោយងាយស្រួល នោះពួកគេនឹងកាន់តែមានទំនុកចិត្តលើការសិក្សា អនុវត្តដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេហើយបង្រៀនចេញពីព្រះគម្ពីរ ។

សកម្មភាពរំឭកពីចំណេះចំណានខគម្ពីរមានពាសពេញមេរៀននៅក្នុងសៀវភៅសិក្សានេះ ដើម្បីណែនាំឲ្យស្គាល់នូវវិធីសាស្ត្រខុសៗគ្នាដើម្បីជួយសិស្សរំឭកពីចំណេះចំណានខគម្ពីរជាទៀងទាត់ ។ សកម្មភាពរំឭកបន្ថែមទៀតត្រូវអាចរកបាននៅក្នុងលិបិក្រមនៃសៀវភៅសិក្សានេះ ។

ការធ្វើលំហាត់អាចជួយសិស្សឲ្យចាំនូវអ្វីដែលពួកគេបានរៀន និង វាស់ប្រមាណបាននូវការចេះដឹងរបស់ពួកគេ ។ សូមអញ្ជើញសិស្សអានវគ្គចំណេះចំណានខគម្ពីរចំនួនបី ដែលបានណែនាំឲ្យស្គាល់រួមមកហើយនៅក្នុងសៀវភៅសិក្សានេះ ។ អ្នកក៏អាចដាក់បញ្ចូលនូវវគ្គថ្មីៗពីរបីទៀតបានដែរ ។ (អ្នកគួរតែផ្តល់យោបល់ឲ្យសិស្សគូសចំណាំវគ្គទាំងនេះ នៅក្នុងព្រះគម្ពីររបស់ពួកគេ) ។ បន្ទាប់ពីសិស្សអានរួច ចូរចោទសួរពួកគេដោយឲ្យនូវពាក្យគន្លឹះមួយនៅក្នុងវគ្គនោះ ឬដោយអានឃ្លាមួយចេញពី វត្ថុដាក់ចំណាំក្នុងសៀវភៅថ្នាក់សិក្ខាសាលា ។ បន្ទាប់មក សុំឲ្យសិស្សរកវគ្គដែលត្រឹមត្រូវនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ១៣:២៤–១៧:២៧ (មេរៀនទី ៤)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ាថាយ ១៣:២៤–១៧:២៧ (មេរៀនទី ៤) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (១៣:២៤–៥៨)

នៅក្នុងរឿងប្រៀបប្រដូចស្តីពីស្រូវសាលី និង ស្រងែ សិស្សបានរៀនថា ព្រះអម្ចាស់នឹងប្រមូលពួកសុចរិតនៅថ្ងៃចុងក្រោយ រួចបំផ្លាញពួកទុច្ចរិតនៅឯការយោងមករបស់ទ្រង់ ។ ក្នុងរឿងប្រៀបប្រដូចបន្ថែមទៀត ដែលពួកគេបានរៀនពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ កំពុងបំពេញផែនដីទាំងមូល និងពរជ័យដ៏នៅអស់កល្បជានិច្ចដែលកើតមានដល់ជនដែលលះបង់ដើម្បីទទួលបានដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ២ (ម៉ាថាយ ១៤)

នៅក្នុង ម៉ាថាយ ១៤ សិស្សបានយល់ដឹងថា តាមរយៈការបង្ហាញសេចក្តីមេត្តាករុណាចំពោះអ្នកដទៃ សូម្បីតែពេលយើងកំពុងជួបប្រទះភាពសោកសៅក្តី ក៏យើងនៅតែធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទដែរ ។ ពួកគេក៏រៀនផងដែរថា ប្រសិនបើយើងស្វែងរកជំនួយរបស់ព្រះ ពេលសេចក្តីជំនឿយើងទន់ខ្សោយ ទ្រង់អាចលើកយើងឡើងចេញពីសេចក្តីភ័យខ្លាច និងការសង្ស័យរបស់យើងបាន ។

ថ្ងៃទី ៣ (ម៉ាថាយ ១៥)

នៅក្នុងសេចក្តីបង្គាប់របស់ព្រះអង្គសង្គ្រោះដល់ពួកអាចារ្យ និង ពួកផារិស៊ី សិស្សបានរៀនថា ប្រសិនបើយើងមានបំណងចង់ខិតជិតនឹងព្រះ យើងត្រូវដាក់ព្រះបញ្ញត្តិរបស់ទ្រង់លើទំនៀមទំលាប់ និងប្រពៃណីទាំងឡាយដែលយើងមាន ។ ពួកគេក៏រៀនផងដែរថា ប្រសិនបើយើងជ្រើសបណ្តែតបណ្តោយចិត្តទៅតាមអំពើអាក្រក់ ឬគំនិត និង បំណងប្រាថ្នាមិនសមរម្យនានា នោះគំនិត និងបំណងប្រាថ្នាទាំងនោះនឹងធ្វើឲ្យយើងខូចកេរ្តិ៍ឈ្មោះ ហើយថានៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលពរជ័យស្របតាមបំណងប្រាថ្នាដ៏សុចរិតរបស់យើង ។

ថ្ងៃទី ៤ (ម៉ាថាយ ១៦–១៧)

នៅក្នុងការសិក្សារបស់ពួកគេពី ម៉ាថាយ ១៦–១៧សិស្សបានរៀនថា សាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានស្តាបនានៅលើវិវរណៈមកពីព្រះ ។ ពួកគេក៏រៀនផងដែរពីកូនសោនៃបព្វជិតភាព ដែលបានប្រគល់ឲ្យកាលពីបុរាណ និង ក្នុងសម័យរបស់យើង ដែលអនុញ្ញាតឲ្យពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ដើម្បីគ្រប់គ្រងសាសនាចក្ររបស់ទ្រង់នៅលើផែនដី ។

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានស្តីបន្ទោសពួកផារិស៊ី និង ពួកសាឌូស៊ីដែលចង់បានទីសម្គាល់មួយនៃភាពជាព្រះរបស់ទ្រង់ ។ ពេត្រុសបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយត្រូវបានប្រគល់ឲ្យនូវកូនសោនៃនគរស្ថានសួគ៌ ។ គំនិតសម្រាប់ការបង្រៀនខាងក្រោមនេះអាចជួយសិស្សឲ្យយល់ពីរបៀបដើម្បីពង្រឹងទីបន្ទាល់របស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៦:១–១២

ពួកផារិស៊ី និង ពួកសាឌូស៊ីចង់បានទីសម្គាល់មួយមកពីព្រះអង្គសង្គ្រោះ:

សូមសរសេរឃ្លា ខាងក្រោម នេះនៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖

តាមរយៈការលេចចេញមករបស់ទេវតាមួយអង្គ

តាមរយៈព្រះវិញ្ញាណបរិសុទ្ធ

តាមរយៈការជឿលើពាក្យមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់

តាមរយៈការឃើញអព្ភូតហេតុមួយ

ដើម្បីចាប់ផ្តើមមេរៀននេះ ចូរសុំឲ្យសិស្សជ្រើសឃ្លានៅលើក្តារខៀន ដែលវាពិពណ៌នាល្អបំផុតពីរបៀប ដែលពួកគេចង់ទទួលបានទីបន្ទាល់មួយអំពីដំណឹងល្អ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីឃ្លាដែលពួកគេបានជ្រើស ហើយពន្យល់ពីហេតុផលដែលពួកគេបានជ្រើសយកវា ។

នៅពេលពួកគេសិក្សា ម៉ាថាយ ១៦ សុំឲ្យសិស្សរកមើលសេចក្តីពិតដែលទាក់ទងនឹងរបៀបដែលព្រះអម្ចាស់ជួយយើងឲ្យទទួលបាន ហើយពង្រឹងទីបន្ទាល់របស់យើងអំពីដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលពួកផារិស៊ី និង ពួកសាឌូស៊ីចង់បានពីព្រះយេស៊ូវ ។

- តើពួកផារិស៊ី និង ពួកសាឌូស៊ីចង់បានអ្វីខ្លះពីព្រះយេស៊ូវ ?

សូមអញ្ជើញសិស្សបីឬនាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង ម៉ាថាយ ១៦:២–៤ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកផារិស៊ី និង ពួកសាឌូស៊ី ។

- តើព្រះអម្ចាស់បានមានបន្ទូលថាទីសម្គាល់ណាខ្លះ ដែលទ្រង់នឹងប្រទានឲ្យ ?

សូមពន្យល់ថា ព្រះយេស៊ូវបានមានបន្ទូលពីព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះ យ៉ូណាស ដែលត្រូវលេបចូលក្នុងពោះ« ត្រីមួយយ៉ាងធំ » (យ៉ូណាស ១:១៧) ។ « ការបញ្ចុះ » របស់យ៉ូណាស រួចបានចេញមកពីពោះត្រី ក្រោយពីបានបីថ្ងៃមក គឺតំណាងឲ្យការសុគត ការបញ្ចុះ និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទពីផ្នូរនៅថ្ងៃទីបី ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីទីសម្គាល់របស់ព្យាការី យ៉ូណាស ៖ « ការបញ្ចុះ » របស់យ៉ូណាស រួចបានចេញមកពីពោះ ‹ ត្រីមួយយ៉ាងធំ › (យ៉ូណាស ១:១៥–១៧, ២) តំណាងឲ្យការសុគត ការបញ្ចុះ និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ (*Mormon Doctrine* ការបោះពុម្ពលើកទី ២ [ឆ្នាំ១៩៦៦] ទំព័រ ៧១១–១២) ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ បន្ទាប់ពីបានស្តីបន្ទោសដល់ពួកផារិស៊ី និងពួកសាឌូស៊ី ?
- តើយើងអាចរៀនអ្វីខ្លះនៅក្នុងបទពិសោធន៍នេះស្តីពីវិធីពុំត្រឹមត្រូវ ដើម្បីស្វែងរកសេចក្តីពិតខាងវិញ្ញាណ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងពុំបានទទួលសេចក្តីពិតខាងវិញ្ញាណ ដោយការស្វែងរកទីសម្គាល់ឡើយ**) ។

សូមសង្ខេប ម៉ាថាយ ១៦:៥–១២ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានព្រមានពួកសិស្សរបស់ទ្រង់ពីការបង្រៀនខុសឆ្គងរបស់ពួកផារិស៊ី និង ពួកសាឌូស៊ី ។

ម៉ាថាយ ១៦:១៣–២០ ។

ពេត្រុសបានថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានសន្យាថាប្រគល់ឲ្យនូវកូនសោនៃនគរស្ថានសួគ៌

សូមពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានស្តីបន្ទោសដល់ពួកផារិស៊ី និង ពួកសាឌូស៊ីដោយការចង់បានទីសម្គាល់មួយមក ទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ពីរបៀបទទួលបានទីបន្ទាល់មួយពីសេចក្តីពិត ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៣–១៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលសំណួរ ដែលព្រះយេស៊ូវបានចោទសួរ និង ចម្លើយរបស់ពួកសិស្សរបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានសួរអ្វីខ្លះដល់ពួកសិស្សរបស់ទ្រង់ ? តើពួកគេបានឆ្លើយយ៉ាងដូចម្តេច ? (អ្នកគួរតែពន្យល់ថា អេលីយ៉ាស និង យេរេមា គឺជាពួកព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ឈ្មោះអេលីយ៉ា និង យេរេមា) ។
- តើចម្លើយរបស់ពួកគាត់អាចប្រាប់អ្វីខ្លះដល់យើងថា មនុស្សបានយល់ដឹងដល់កម្រិតណាដែរថាព្រះយេស៊ូវគឺជានរណា មកដល់ពេលនេះនៅក្នុងការងារបម្រើរបស់ទ្រង់ ?

កំណត់ចំណាំ ៖ នៅក្នុងមេរៀនសម្រាប់ថ្ងៃទី ៤ សិស្សបានសិក្សាវគ្គចំណេះចំណានខគម្ពីរ ម៉ាថាយ ១៦:១៥–១៩ ។ សូមពិចារណាចំណាយពេលពីរបីនាទី មើលវគ្គនោះឡើងវិញជាមួយពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៦:១៥–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលសំណួរទីពីរដែលព្រះអង្គសង្គ្រោះបានចោទសួរ ។

- តើសំណួរទីពីរដែលព្រះអង្គសង្គ្រោះបានសួរនោះជាអ្វីទៅ ? តើពេត្រុសបានឆ្លើយបែបណាដែរ ?
- យោងតាម ខទី ១៧តើពេត្រុសបានដឹងថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះបានដោយរបៀបណា ? (សូមចង្អុលបង្ហាញថា ព្រះវរបិតាសួគ៌បានបើកសម្តែងសេចក្តីពិតនេះដល់លោកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះអំពីរបៀបដែលយើងអាចទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្តតាមរយៈវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធ**) ។
- ហេតុអ្វីអ្នកគិតថា ការទទួលបានទីបន្ទាល់មួយតាមរយៈវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធជាជាងតាមវិធីផ្សេងទៀត គឺជារឿងដ៏សំខាន់សម្រាប់យើង ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធក្នុងការជួយយើងឲ្យទទួលបានទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ សុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖



«ការមានបន្ទូលរបស់ព្រះវិញ្ញាណព្រះទៅកាន់វិញ្ញាណរបស់មនុស្សមាននូវព្រះចេស្តា ដើម្បីប្រទានសេចក្តីពិតដ៏មានតម្លៃពុល និង ការយល់ដឹងច្រើនជាងសេចក្តីពិតដែលអាចបានផ្តល់ឲ្យដោយទំនាក់ទំនងផ្ទាល់ខ្លួន ទោះជាជាមួយនឹងអង្គសួគ៌ាក្តី ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ សេចក្តីពិតត្រូវដោក់បញ្ចូលទៅក្នុងគ្រប់រចនាសម្ព័ន្ធនៃសារីរាង្គ និង សរសៃពួរសាច់ដុំនៃរូបកាយ ដើម្បីវាត្រូវបានចងចាំជារៀងរហូត » (*Teachings of Presidents of the Church: Joseph Fielding Smith* [ឆ្នាំ២០១៣] ទំព័រ ១៨៣–៨៤) ។

- តើអ្វីខ្លះដែលយើងអាចធ្វើ ដើម្បីរៀបចំខ្លួនយើងទទួលវិវរណៈតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?
- តើអ្នកបានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ និង ជាព្រះអង្គសង្គ្រោះរបស់អ្នកតាមរបៀបណាដែរ ? តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីទទួលបានសាក្សីនោះមកពីព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចពង្រឹងទីបន្ទាល់របស់ខ្លួន ឬអ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលបានទីបន្ទាល់មួយតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតដែលពួកគេបានទទួល ។

មេរៀនបន្ទាប់ (ម៉ាថាយ ១៨:១–២២:២៦)

ចូរសុំឲ្យសិស្សពិចារណាពីគ្រាមួយដែល ពួកគេមានការលំបាកក្នុងការអភ័យទោសឲ្យមនុស្សម្នាក់ទៀត ។ សូមអញ្ជើញពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖ ហេតុអ្វីបានជាអ្នកមានអារម្មណ៍ថា វាជាដំណោះស្រាយសមហេតុផល ដោយពុំចាំបាច់អភ័យទោសដល់បុគ្គលនេះ ? ហេតុអ្វីបានជាយើងគួរអភ័យទោសឲ្យអ្នកដទៃចំពោះការបំពានរបស់ពួកគេ សូម្បីតែយើងមានអារម្មណ៍ថាមិនចង់អភ័យទោសដល់ពួកគេក៏ដោយនោះ ? សូមអញ្ជើញសិស្សរកមើលចម្លើយចំពោះសំណួរទាំងនេះ នៅពេលពួកគេបន្តការសិក្សារបស់ខ្លួននៅសប្តាហ៍ក្រោយ ។

មេរៀន ២១

ម៉ាថាយ ១៨

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានបង្រៀនពួកសិស្សរបស់ទ្រង់ នូវគោលការណ៍ដែលនឹងជួយពួកគេដឹកនាំសាសនាចក្ររបស់ទ្រង់ បន្ទាប់ពីការយាងឡើងទៅស្ថានសួគ៌របស់ទ្រង់ ។ ព្រះអម្ចាស់ក៏បានប្រទានរឿងប្រៀបប្រដូចអំពីអ្នកបម្រើ ដែលគ្មានចិត្តមេត្តាដោយមានបន្ទូលតបទៅនឹងសំណួររបស់ពេត្រុសអំពីការអភ័យទោស ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៨:១–២០

ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់នូវគោលការណ៍ដែលនឹងជួយពួកគេឲ្យដឹកនាំសាសនាចក្រ

សូមសរសេរទង្វើខុសឆ្គងខាងក្រោមនេះនៅលើក្តារខៀន ៖ *ការកុហក ការមានគេលួចរបស់អ្វីមួយ ការមានមិត្តម្នាក់ក្បត់* ។ ចូរសុំឲ្យសិស្សដាក់ពិន្ទុដល់ទង្វើខុសឆ្គងនីមួយៗពីលេខ ១ ដល់លេខ ១០ ដោយលេខ ១ គឺសម្រាប់រឿងដែលងាយអភ័យទោសឲ្យ ហើយលេខ ១០ គឺរឿងពិបាកអភ័យទោសឲ្យបំផុត ។ សូមអញ្ជើញសិស្សស្ម័គ្រចិត្តពីរបីនាក់ឲ្យប្រាប់ពីរបៀបដែលពួកគេដាក់ពិន្ទុដល់ទង្វើខុសឆ្គងនីមួយៗ ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីហេតុផល ដែលយើងគួរអភ័យទោសដល់អ្នកដទៃ សូម្បីតែពេលវាពិបាកធ្វើក៏ដោយ ។

នៅពេលសិស្សសិក្សា ម៉ាថាយ ១៨ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលអាចជួយពួកគេឲ្យយល់ដឹងពីហេតុផលដែលយើងគួរអភ័យទោសដល់អ្នកដទៃ ។

សូមសង្ខេប ម៉ាថាយ ១៨:១–១៤ ដោយពន្យល់ថា ព្រះយេស៊ូវបានណែនាំពួកសិស្សរបស់ទ្រង់ឲ្យបន្ទាបខ្លួន ហើយក្លាយដូចជាក្មេងតូច ។ ទ្រង់ក៏បានពន្យល់ផងដែរថាអស់អ្នកដែល ធ្វើឲ្យកុមារតូចៗ « វាតចិត្ត » ដឹកនាំឲ្យពួកគេវង្វេង ឬបណ្តាលឲ្យពួកគេស្ងាក់ស្ទើរក្នុងសេចក្តីជំនឿ នឹងទទួលនូវការកាត់សេចក្តីរបស់ព្រះ (សូមមើល ខទី ៦–៧) ។ បន្ទាប់មក ព្រះអង្គសង្គ្រោះបានទូន្មានពួកសិស្សរបស់ទ្រង់ឲ្យដកចេញពីជីវិតរបស់គេ នូវរឿងដែលជំទាស់នឹងពួកគេ ឬដែលអាចធ្វើឲ្យពួកគេវាតចិត្ត (សូមមើល ខទី ៩) ។ (*កំណត់ចំណាំ ៖* ការបង្រៀនរបស់ព្រះអង្គសង្គ្រោះមាននៅក្នុង ម៉ាថាយ ១៨:១–១៤ នឹងត្រូវបានពិភាក្សាយ៉ាងសឹងជាម្រៅនៅក្នុងមេរៀនសម្រាប់ ម៉ាកុស ៩និង លូកា ១៥) ។

សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានទូន្មានពួកសិស្សរបស់ទ្រង់ឲ្យដកចេញពីជីវិតរបស់គេ នូវរឿងដែលអាចធ្វើឲ្យពួកគេវាតចិត្ត នោះទ្រង់បានប្រាប់ពួកគេពីអ្វីដែលមនុស្សម្នាក់គួរធ្វើប្រសិនបើមាននរណាម្នាក់ធ្វើខុស ឬធ្វើបាបទាស់នឹងគាត់ ។ ទ្រង់ក៏បានបង្រៀនដល់ពួកសាវកពីគោលការណ៍នៃវិន័យរបស់សាសនាចក្រផងដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៨:១៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះយេស៊ូវបានប្រាប់ពួកសិស្សរបស់ទ្រង់ឲ្យធ្វើ ប្រសិនបើនរណាម្នាក់ធ្វើខុសនឹងពួកគេ ។

- **តើយើងអាចរៀនអ្វីខ្លះ នៅក្នុងខគម្ពីរនេះស្តីពីអ្វីដែលយើងគួរធ្វើប្រសិនបើនរណាម្នាក់ធ្វើខុសនឹងយើង ?**

សូមសង្ខេប ម៉ាថាយ ១៨:១៦–១៧ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រាប់ពួកសាវករបស់ទ្រង់ថា ប្រសិនបើមនុស្សម្នាក់បដិសេធមិនទទួលស្គាល់កំហុសរបស់ខ្លួន ហើយមិនសារភាពពីអំពើបាបរបស់ខ្លួន ហើយមានសាក្សីពីរ ឬច្រើននាក់បានថ្លែងទាស់នឹងគាត់ បុគ្គលនោះនឹងត្រូវកាត់ចេញពីសាសនាចក្រ ។ អ្នកក៏គួរពន្យល់ផងដែរថា អ្នកដែលធ្វើជាអធិបតីលើក្រុមប្រឹក្សាវិន័យរបស់សាសនាចក្រជាកន្លែងដែលការសម្រេចចិត្តនានាបែបនេះតែងត្រូវបានធ្វើឡើង ដោយការស្វែងយល់ពីព្រះទ័យរបស់ព្រះអម្ចាស់ថា តើបុគ្គលម្នាក់គួរត្រូវកាត់ចេញពីសាសនាចក្រ ឬកាត់កាលចេញដែរឬអត់ ។


សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ១៨:១៨–២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើសិទ្ធិអំណាចអ្វីដែលពួកសាវកបានទទួល ។

- **តើសិទ្ធិអំណាចអ្វីដែលពួកគេសាវកបានទទួល ? (សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រទានកូនសោបព្វជិតភាពដល់ពួកសាវក ដោយប្រទានសិទ្ធិអំណាចដល់ពួកគេ ដើម្បីធ្វើពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ ហើយធ្វើការសម្រេចចិត្តទាក់ទងនឹងសាសនាចក្ររួមបញ្ចូលថាតើអ្នកមានបាបម្នាក់អាចបន្តធ្វើជាសមាជិក ដោយស្ថិតនៅក្រោមការដឹកនាំរបស់ពេត្រុស [សូមមើល ម៉ាថាយ ១៦:១៩]) ។**
- **តើព្រះអម្ចាស់បានសន្យាអ្វីខ្លះ ដល់ពួកសាវករបស់ទ្រង់នៅក្នុង ខទី ១៩–២០ ? (អ្នកគួរផ្តល់យោបល់ឲ្យសិស្សគូសចំណាំការសន្យានោះនៅក្នុង ខទី ២០) ។**

ម៉ាថាយ ១៨:២១–៣៥ ។

ព្រះអម្ចាស់ប្រទានរឿងប្រៀបប្រដូចស្តីពីអ្នកបម្រើដែលគ្មានចិត្តមេត្តា

សូមអញ្ជើញសិស្សម្នាក់អានដំណើររឿងខាងក្រោមឲ្យឮៗ ដែលលើកឡើងដោយប្រធាន ថូម៉ាស អេស ម៉ុនសុន អំពីគ្រួសារមួយដែលមានទារកអាយុពីរខែបានស្លាប់ ៖



« ឪពុកជាជាងធ្វើទូរ ក៏បានធ្វើក្តារមឈូសដ៏ស្អាតមួយសម្រាប់ដាក់សពកូនសំណព្វរបស់គាត់ ។ ថ្ងៃនៃពិធីបុណ្យសព គឺស្រងេះស្រងោចណាស់ ដែលបង្ហាញអំពីភាពសោកសៅដែលពួកគេមានក្នុងការបាត់បង់កូនរបស់ពួកគេ ។ នៅពេលគ្រួសារនោះ បានដើរទៅដល់សាលាប្រជុំ រួមជាមួយឪពុកជាអ្នកលីក្តារមឈូសតូចនោះ នោះមានមនុស្សតែបន្តិចមកចូលរួម ។ តែ ទ្វារសាលាប្រជុំជាប់សោរ ។ ប៊ីស្សពដ៏រវល់នោះ បានភ្លេចអំពីពិធីបុណ្យសព ។ គាត់ពុំអាចទាក់ទងទៅប៊ីស្សពម្នាក់នោះបានសោះ ។ ដោយមិនដឹងថាត្រូវធ្វើយ៉ាងណា នោះឪពុកូបនោះ បានលើកក្តាមឈូសកូនដាក់លើដៃគាត់លើទៅផ្ទះវិញជាមួយនឹងគ្រួសារគាត់ ទាំងដើរកាត់ភ្លៀងទទឹកខ្លួនជោគ »(« Hidden Wedges » *Ensign* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ១៩) ។

- ប្រសិនបើអ្នកជាសមាជិកម្នាក់ក្នុងគ្រួសារនោះ តើអ្នកមានអារម្មណ៍បែបណាកាលប៊ីស្សពមិនបានមកពិធីបុណ្យសពនោះ ?
- ហេតុអ្វីវាពិបាកនឹងអភ័យទោសឲ្យប៊ីស្សពូបនោះ ?

សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានណែនាំដល់ពួកសាវករបស់ទ្រង់ ពេត្រុសបានទូលសួរព្រះអម្ចាស់នូវសំណួរមួយអំពីការអភ័យទោស ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ១៨:២១ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលសំណួររបស់ពេត្រុស ។

- តើពេត្រុសបានទូលសួរអ្វីខ្លះដល់ព្រះអង្គសង្គ្រោះ ?

សូមពន្យល់ថា ពួកអ្នកដឹកនាំសាសនាមួយចំនួននៅជំនាន់ពេត្រុសបានបង្រៀនថា បុគ្គលម្នាក់មិនត្រូវអភ័យទោសដល់មនុស្សម្នាក់ទៀតឲ្យលើសពីបីដងទេ ។ ដោយទូសសួរព្រះអម្ចាស់ថាតើគាត់គួរអភ័យទោសដល់មនុស្សម្នាក់ដល់ទៅប្រាំពីរដង ពេត្រុសប្រហែលជាគិតថាគាត់គឺជាមនុស្សដែលមានចិត្តសប្បុរសហើយ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *The Mortal Messiah* វ៉ុលទី ៤ | ឆ្នាំ ១៩៧៩–៨១ | ៣:៩១) ។ សូមអញ្ជើញសិស្សអាន ម៉ាថាយ ១៨:២២ ដោយស្ងៀមស្ងាត់ ហើយរកមើលចម្លើយតបរបស់ព្រះអង្គសង្គ្រោះទៅពេត្រុស ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថា យើងគួរអភ័យទោសដល់ជនដែលធ្វើឲ្យយើងរវាតចិត្ត ឬធ្វើបាបទាស់នឹងយើងដល់ទៅប៉ុន្មានដង ? (សូមពន្យល់ថា « ប្រាំពីរចិតសិបដង » គឺជាការលើកឡើងមួយថា យើងមិនគួរកំណត់ថាយើងគួរអភ័យទោសដល់អ្នកដទៃទៀតប៉ុន្មានដងនោះទេ) ។
- តើយើងអាចរៀនការពិតអ្វីខ្លះពីព្រះអង្គសង្គ្រោះស្តីពីការអភ័យទោសដល់មនុស្សដទៃ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់បានបង្គាប់យើងឲ្យអភ័យទោសដល់ជនដែលធ្វើឲ្យយើងរវាតចិត្ត ឬធ្វើបាបទាស់នឹងយើង**) ។
- តើការអភ័យទោសដល់អ្នកដទៃមានន័យដូចម្តេច ? (សូមពន្យល់ថា ការអភ័យទោសដល់អ្នកដទៃគឺការប្រព្រឹត្តចំពោះមនុស្សដែលធ្វើឲ្យយើងរវាតចិត្ត ឬធ្វើឲ្យយើងឈឺចាប់ ដោយសេចក្តីស្រឡាញ់ ហើយមានអារម្មណ៍ល្អចំពោះគាត់ | សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « អភ័យទោស » scriptures.lds.org, គ. និង ស. ៦៤:៩–១១ | ។ ការអភ័យទោសពុំមែនមានន័យថាយើងបន្តអនុញ្ញាតឲ្យអ្នកដទៃធ្វើទុក្ខទោសយើង ឬថាអ្នកធ្វើខុសមិនគួរធ្វើឲ្យទទួលខុសត្រូវសម្រាប់ទង្វើរបស់ខ្លួនតាមច្បាប់ ឬដោយប្រការណាមួយឡើយ) ។

សូមពន្យល់ថា បន្ទាប់ពីឆ្លើយនឹងសំណួររបស់ពេត្រុស ព្រះអង្គសង្គ្រោះបានបង្រៀនពួកសិស្សរបស់ទ្រង់នូវរឿងប្រៀបប្រដូចមួយ ដែលអាចជួយយើងឲ្យយល់ពីហេតុផលដែលយើងគួរអភ័យទោសដល់អ្នកដទៃ ។

សូមបំបែកសិស្សជាគូ ហើយអញ្ជើញដៃគូនីមួយៗអាន ម៉ាថាយ ១៨:២៣–៣៥ រួមគ្នារកមើលហេតុផលដែលយើងគួរអភ័យទោសដល់អ្នកដទៃ ។ ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរៀន ។

ជំនួសការសុំឲ្យសិស្សអាន ម៉ាថាយ ១៨:២៣–៣៥ សូមពិចារណាបង្ហាញវីដេអូ « Forgive Every One Their Trespasses:The Parable of the Unmerciful Servant » |៦:០៦ | ។ នៅពេលសិស្សមើលវីដេអូនេះ សូមអញ្ជើញពួកគេរកមើលហេតុផលដែលយើងគួរអភ័យទោសអ្នកដទៃ ។ ក្រោយពីវីដេអូនេះ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។ វីដេអូនេះមាននៅក្នុង LDS.org ។

ដើម្បីជួយសិស្សឲ្យយល់ដឹងកាន់តែសឹងជម្រៅពីរឿងប្រៀបប្រដូចនេះ សូមសរសេរពាក្យខាងក្រោមនៅលើ ក្តារខៀន ៖

ស្តេច	បាវបម្រើ	គូកន

- តើបាវនោះជំពាក់ប្រាក់ស្តេចប៉ុន្មាន ? (*សូមសរសេរ បានជំពាក់ប្រាក់២ភោដិ* នៅក្រោមពាក្យ *អ្នកបម្រើ*)

**សូមពន្យល់ថា នៅក្នុងជំនាន់ព្រះយេស៊ូវ « ២ កោដិស្មើនឹង ១០០,០០០,០០០ កាក់ | រូបិយប័ណ្ណរ៉ូម | ។ មួយកាក់គឺជាប្រាក់កម្រៃធម្មតាក្នុងមួយថ្ងៃសម្រាប់កម្មករទូទៅ » (Jay A. Parry and Donald W. Parry *Understanding the Parables of*

Jesus Christ (ឆ្នាំ២០០៦) ទំព័រ ៩៥) ។ ចូរសុំឲ្យសិស្សគណនា ចំនួនឆ្នាំដែលកម្មករត្រូវធ្វើការដើម្បីសងបំណុលនេះអស់ដោយចែក ១០០,០០០,០០០ កាក់ នឹង ៣៦៥ ថ្ងៃ (១០០,០០០,០០០/៣៦៥=២៧៣.៩៧៣) ។ សូមសរសេរ *២៧៣.៩៧៣ ឆ្នាំ* នៅលើក្តារខៀនក្រោម *បានជំពាក់ស្តេច ២ កោដិ ។*

- តើអ្នកបម្រើផ្សេងទៀតបានជំពាក់ប្រាក់អ្នកបម្រើនោះប៉ុន្មាន ? (*សូមសរសេរ បានជំពាក់ ប្រាក់ ២០ រៀល* នៅក្រោមពាក្យ *គូកន*) ។

សូមពន្យល់ថា ២០ រៀលស្មើនឹង ១០០កាក់ ។ ដូច្នេះហើយគូកននោះបានជំពាក់បាវបម្រើនោះ ប្រមាណប្រាក់កម្រៃធ្វើការ ១០០ថ្ងៃ ឬក្បែរនឹងមួយភាគបីនៃប្រាក់ប្រចាំឆ្នាំរបស់ខ្លួន ។ សូមសរសេរ *១០០ថ្ងៃ* នៅលើក្តារខៀនក្រោម *បានជំពាក់បាវនោះ ២០រៀល ។*

- ហេតុអ្វីអ្នកគិតថា ស្តេចមានបន្ទូលហៅបាវបម្រើនោះថាជាមនុស្សទុច្ចរិតដោយសារគាត់មិនបានអភ័យទោសដល់គូកនខ្លួនសម្រាប់បំណុលនេះ ?

ចូរស្រង់សិស្សថាក្នុងចំណោមអ្នកទាំងបីក្នុងរឿងប្រៀបប្រដូចនេះតើតួអង្គនីមួយៗតំណាងឲ្យនរណា ។ ក្រោយពីពួកគេឆ្លើយតបហើយ សូមសរសេរតំណាងដែលមានដូចខាងក្រោមនៅលើក្តារខៀន ៖ *ស្តេច=ព្រះវរបិតាសួគ៌, បាវបម្រើ=យើង, គូកន=ជនដែលធ្វើឲ្យយើងរវាតចិត្ត ។*

- តើអ្នកគិតថាគោលការណ៍អ្វីខ្លះដែលព្រះអង្គសង្គ្រោះកំពុងព្យាយាមបង្រៀនដល់ពួកសិស្សរបស់ទ្រង់ស្តីពីហេតុផលដែលយើងគួរអភ័យទោសដល់អ្នកដទៃ ? (សិស្សគួរកត់ឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងចង់ឲ្យព្រះអភ័យទោសដល់យើង នោះយើងត្រូវតែមានឆន្ទៈនឹងអភ័យទោសដល់អ្នកដទៃ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

- តើមនុស្សម្នាក់អាចធ្វើអ្វីខ្លះ ប្រសិនបើគាត់កំពុងមានចិត្តស្មុគស្មាញក្នុងការអភ័យទោសដល់មនុស្សម្នាក់ទៀត ?

ដើម្បីជួយសិស្សស្គាល់នូវអ្វីដែលយើងអាចធ្វើ ដើម្បីមានឲ្យកាន់តែឆន្ទៈអភ័យទោសកាន់តែច្រើន សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងដូចខាងក្រោម ដោយប្រធាន ដែមស៍ អឺ ហ្វោស្ត នៃគណៈប្រធានទីមួយ ។ ប្រសិនបើអាចធ្វើបាន សូមចែកច្រាដាសឯកសារដល់សិស្សម្នាក់ៗ ។



« យើងត្រូវដឹងហើយទទួលស្គាល់នូវកំហឹងទាំងឡាយក្នុងដួងចិត្ត ។ វាត្រូវការការបន្ទាបខ្លួន ដើម្បីធ្វើបែបនេះ ប៉ុន្តែបើសិនយើងនឹងលុត ជង្គង់ចុះ ហើយសុំព្រះវរបិតាសួគ៌ប្រទានអារម្មណ៍ នៃការអភ័យទោស នោះទ្រង់នឹងជួយយើង ។ ព្រះអម្ចាស់តម្រូវយើងទាំងអស់គ្នាឲ្យ ‹ អត់ទោសដល់មនុស្ស ទាំងអស់ ›| គ. និង ស. ៦៤:១០ | សម្រាប់សេចក្តីល្អរបស់យើងផ្ទាល់ដោយសារ ‹ ការស្អប់ពន្យឺតដល់ការលូតលាស់ខាងវិញ្ញាណ › | Orson F. Whitney *Gospel Themes* (ឆ្នាំ ១៩១៤) ទំព័រ ១៤៤ | ។

លើកលែងតែយើងកំចាត់ចោលនូវការស្អប់ និងភាពល្ងីល្ងើរួចចេញពី ខ្លួនយើង ទើបព្រះអម្ចាស់អាចដាក់ការលួងលោម ចូលក្នុងដួងចិត្តរបស់ យើងបាន ។ . . .

« . . . ពេលសោកនាដកម្ម សង្គ្រប់ មកលើយើង យើងមិនគួរ ឆ្លើយតបដោយការស្វែងរកការសងសឹកផ្ទាល់ខ្លួននោះទេ ប៉ុន្តែគួរទុកឲ្យយុត្តិធម៌តបតនឹងវា ហើយបំភ្លេចវាចោលទៅ ។ វាមិនងាយស្រួលនឹងបំភ្លេចវាចោល ហើយកំចាត់ចេញពីដួងចិត្តរបស់យើងពីការអន់ចិត្តដែល កំពុងតែកកកួលឡើងនោះទេ ។ ព្រះអង្គសង្គ្រោះបានប្រទានដល់យើងទាំងអស់គ្នា នូវសេចក្តីសុខសាន្ត ដ៏ មានតម្លៃតាមរយៈដង្វាយធួនរបស់ទ្រង់ ប៉ុន្តែវាអាចមានដល់យើង ពេលដែលយើងមានឆន្ទៈលះបង់នូវអារម្មណ៍អវិជ្ជមាន នៃកំហឹងគំនុំឬការសងសឹកប៉ុណ្ណោះ ។ សម្រាប់យើងទាំងអស់គ្នាដែលអត់ទោសដល់ ‹ ពួកអ្នកដែលបំពានដល់ យើង › | ការបកប្រែ ដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ៦:១៣ | សូម្បីតែពួកអ្នក ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរក្តី ដង្វាយធួននាំមកនូវរង្វាស់នៃ សេចក្តីសុខសាន្ត និងការលួងលោម » (James E. Faust « The Healing Power of Forgiveness » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៦៩) ។

- តើប្រធាន ហ្វោស បានប្រាប់យើងឲ្យធ្វើអ្វីខ្លះ ដែលនឹងជួយយើងឲ្យអភ័យទោសដល់អ្នកដទៃ ?
- យោងតាមប្រធាន ហ្វោស តើមានអ្វីអាចកើតឡើងនៅពេលយើងអភ័យទោសដល់អ្នកដទៃ ?

ចូររំឭកសិស្សអំពីដំណើររឿងរបស់ប្រធាន ម៉ន សុន ដែលបានចែកចាយកាលពីដើមមេរៀននេះ ហើយសុំឲ្យសិស្សម្នាក់អានសេចក្តីសន្និដ្ឋាននៃដំណើររឿងនោះ ៖

« ប្រសិនបើគ្រួសារនោះមានចរិតមិនស្ងប់សមម្យ ពួកគេអាចនឹងបន្ទោសប៊ីស្សព និងបញ្ចេញនូវអារម្មណ៍ដ៏ឈឺចាប់នោះ ។ តែពេលដែលប៊ីស្សព បានដឹងពីសោកនាដកម្មនេះ គាត់បានទៅជួបនឹងគ្រួសារនោះ ហើយបានសុំអភ័យទោស ។ ដោយឃើញពីការឈឺចាប់នៅលើទឹកមុខ ឪពុកនោះបានទទួលយកការសុំអភ័យទោស ទាំងទឹកភ្នែក រួចហើយអ្នកទាំងពីរ បានឱបគ្នាដោយអារម្មណ៍នៃការយោគយល់គ្នា » (« Hidden Wedges » *Ensign* ខែឧសភា ឆ្នាំ ២០០២ ទំព័រ ១៩) ។

- តើព្រះអម្ចាស់ធ្លាប់ជួយអ្នកឲ្យអភ័យទោសដល់មនុស្សម្នាក់ ដែលបានធ្វើបាបទាស់នឹងអ្នក ឬធ្វើឲ្យអ្នករវាតចិត្តបានដោយរបៀបណា ?
- តើអ្វីទៅដែលធ្លាប់ជួយអ្នកឲ្យអភ័យទោសអ្នកដទៃ ? (សូមពិចារណាអញ្ជើញសិស្សឲ្យឆ្លើយសំណួរនេះ ក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីមនុស្ស ដែលពួកគេអាចនឹងមិនព្រមផ្តល់នូវការអភ័យទោសឲ្យ ។ សូមអញ្ជើញពួកគេឲ្យអធិស្ឋានសូមឲ្យមានបំណងប្រាថ្នាមួយ ដើម្បីអភ័យទោស និងសមត្ថភាពបំភ្លេចការឈឺចាប់ និងកំហឹងដើម្បីព្រះយេស៊ូវគ្រីស្ទអាចជួយពួកគេឲ្យមានអារម្មណ៍សុខសាន្ត និងការលួងលោមចិត្តតាមរយៈដង្វាយធួនរបស់ទ្រង់ ។

ការស្តែសំណួរ និងការអញ្ជើញដែលលើកទឹកចិត្តឲ្យមានការអនុវត្ត

គោលដៅនៃការបង្រៀនដ៏ណឹងល្អ គឺដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍ និង គោលលទ្ធិទាំងឡាយដែលមាននៅក្នុងបទគម្ពីរប្រែចិត្តជឿ ហើយទទួលពរជ័យដែលបានសន្យាដល់អស់អ្នកណា ដែលស្មោះត្រង់ និងគោរពប្រតិបត្តិ ។ សំណួរ និងការអញ្ជើញទាំងឡាយដែលលើកទឹកចិត្តឲ្យមានការអនុវត្តអាចជួយសិស្ស ឲ្យមើលឃើញពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍ និងគោលលទ្ធិទាំងនេះនៅក្នុងស្ថានភាពបច្ចុប្បន្នរបស់ពួកគេ និងនៅពេលអនាគត ។

មេរៀន ២២

ម៉ាថាយ ១៩–២០

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្តបានបង្រៀនអំពីភាពបរិសុទ្ធនៃអាពាហ៍ពិពាហ៍ ។ ទ្រង់បានគូសបញ្ជាក់ពីសារៈសំខាន់នៃការជ្រើសយកជីវិតអស់កល្បជានិច្ចជាជាងទ្រព្យសម្បត្តិខាងលោកិយ ហើយបានបង្រៀនរឿងប្រៀបប្រដូចអំពីពួកអ្នកធ្វើការនៅក្នុងចម្ការទំពាំងបាយជូរ ។ ព្រះយេស៊ូវក៏បានមានបន្ទូលប្រាប់ជាមុនពីអំការសុគតរបស់ទ្រង់ ហើយបានបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យបម្រើមនុស្សដទៃ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៩:១–១២

ព្រះអង្គសង្គ្រោះបង្រៀនអំពីភាពបរិសុទ្ធនៃអាពាហ៍ពិពាហ៍

សូមដាក់បង្ហាញ រូបភាព គូស្វាមីភរិយាដែលបានរៀបការហើយមានសុភមង្គល ហើយបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមចង្អុលបង្ហាញថា គោលលទ្ធិរបស់ព្រះអម្ចាស់ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងការលែងលះគ្នាគឺខុសពីជំនឿជាច្រើនរបស់លោកិយ ។

- តើជំនឿមួយចំនួនរបស់លោកិយអំពីអាពាហ៍ពិពាហ៍ ឬការលែងលះគ្នាមានអ្វីខ្លះ ? (*បម្រាម ៖* សូមចៀសវាងចំណាយពេលច្រើនពេកទៅលើប្រធានបទពុំសូវមានប្រយោជន៍នានា ដូចជាអាពាហ៍ពិពាហ៍ភេទដូចគ្នា ដែលអាចឲ្យទាញយកពេលវេលាចេញឆ្ងាយពីគោលការណ៍ដ៏សំខាន់ផ្សេងទៀតនៅក្នុងមេរៀនថ្ងៃនេះ) ។

នៅពេលសិស្សសិក្សា ម៉ាថាយ ១៩:១–១២ សូមអញ្ជើញពួកគេឲ្យរកមើលការបង្រៀនរបស់ព្រះអម្ចាស់អំពី អាពាហ៍ពិពាហ៍ និងការលែងលះគ្នា ហើយពិចារណាពីសារៈសំខាន់នៃការបង្រៀនទាំងនេះចំពោះពួកគេ ។

ចូរសុំសិស្សម្នាក់អាន ម៉ាថាយ ១៩:១–៣ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលសំណួរដែលពួកផារិស៊ីបានទូលសួរទៅព្រះយេស៊ូវ ។ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វី ដែលពួកគេរកឃើញ ។

សូមពន្យល់ថា ឃ្លា « នឹងលែងប្រពន្ធ ដោយហេតុណាក៏ដោយ » (ម៉ាថាយ ១៩:៣) សំដៅលើបុរសម្នាក់ដែលនឹងលែងលះប្រពន្ធខ្លួនឲ្យខានតែបាន សូម្បីតែវាជារឿងតូចតាច ឬជាភាពអត្មានិយមក៏ដោយ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៩:៤–៦ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនពីអាពាហ៍ពិពាហ៍ និងការលែងលះគ្នា ។

- តើសេចក្តីពិតទាំងឡាយណាខ្លះ អំពីអាពាហ៍ពិពាហ៍ដែលយើងរៀនពីព្រះបន្ទូលតបរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកផារិស៊ី ? (សិស្សអាចនឹងរកឃើញសេចក្តីពិតពីរបី ប៉ុន្តែត្រូវប្រាកដថាអ្នកបានគូសបញ្ជាក់ថា **អាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់គឺជាទំនាក់ទំនងដ៏ពិសិដ្ឋមួយដែលព្រះបានរៀបចំ ហើយបង្កើតឡើង**) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន ម៉ាថាយ ១៩:៧ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលសំណួរមួយទៀត ដែលពួកផារិស៊ីបានទូលសួរដល់ព្រះអង្គសង្គ្រោះ ។

- តើពួកផារិស៊ីបានទូលសួរអ្វីខ្លះដល់ព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៩:៨–៩ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលព្រះបន្ទូលតបរបស់ព្រះអង្គសង្គ្រោះ ។

- យោងតាមព្រះអង្គសង្គ្រោះ ហេតុអ្វីម៉ូសេបានអនុញ្ញាតឲ្យមានការលែងលះនៅក្នុងចំណោមពួកអ៊ីស្រាអែល ? (ដោយសារចិត្តរឹងរូសរបស់ប្រជាជន) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលការបង្រៀននេះពាក់ព័ន្ធនឹងសម័យរបស់យើង សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ ៖



« ប្រភេទអាពាហ៍ពិពាហ៍ដែលទាមទារឲ្យមានភាពតម្កើងឡើង—មានរយៈពេលអស់កល្ប ហើយមានគុណសម្បត្តិដូចជាព្រះ—ពុំសញ្ជឹងគិតពីការលែងលះឡើយ ។ នៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះអម្ចាស់ ស្វាមីភរិយាត្រូវបានរៀបការសម្រាប់ភាពអស់កល្បជានិច្ច ។ ប៉ុន្តែអាពាហ៍ពិពាហ៍ខ្លះមិនរីកចម្រើនឆ្ពោះទៅរកឧត្តមគតិនោះទេ ។ ដោយសារ ‹ ចិត្ត | របស់យើង | រឹងរូស | ម៉ាថាយ ១៩:៨ | នៅបច្ចុប្បន្ននេះ ព្រះអម្ចាស់ពុំបានបង្ខំឲ្យទូទាត់ជលវិបាកនៃបទដ្ឋានសេឡេស្ទាលឡើយ ។ ទ្រង់អនុញ្ញាតឲ្យបុគ្គលដែលលែងលះគ្នារៀបការម្តងទៀត ដោយគ្មានស្មាមប្រឡាក់នៃអមតៈភាពដែលបានបញ្ជាក់នៅក្នុងក្រឹត្យវិន័យស្ងួត » (« Divorce » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៧០) ។

សូមពិចារណាអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេថា ព្រះបានរៀបចំ ហើយបានបង្កើតអាពាហ៍ពិពាហ៍ជាទំនាក់ទំនងដ៏ពិសិដ្ឋមួយរវាងបុរសម្នាក់ និងស្ត្រីម្នាក់ ។

ចូរឆាប់ដឹងពីសេចក្តីត្រូវការ និងអារម្មណ៍របស់សិស្ស

នៅពេលអ្នកពិភាក្សាពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីអាពាហ៍ពិពាហ៍ និងការលែងលះគ្នា ចូរមានចិត្តសន្តោសចំពោះសិស្សដែលធ្លាប់ជួបប្រទះការឈឺចាប់ ឬការព្រួយបារម្ភដោយសារតែការចែកផ្លូវ ឬការលែងលះរបស់ឪពុកម្តាយ ឬសមាជិកគ្រួសារផ្សេងទៀត ។ សូមស្វែងរក ហើយធ្វើតាមការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ប្រកបដោយការអធិស្ឋាន នៅពេលអ្នករៀបចំមេរៀន ហើយបង្រៀន ។ ចូរចងចាំ ស្តាប់ដោយយកចិត្តទុកដាក់នៅពេលសិស្សទាំងឡាយសួរសំណួរ ឬចែកចាយពីគំនិត ឬអារម្មណ៍របស់ពួកគេ ។



ម៉ាថាយ ១៩:១៣–៣០, ២០:១–១៦

ព្រះយេស៊ូវបង្រៀនអំពីជីវិតដ៏នៅអស់កល្បជានិច្ច ហើយប្រទានរឿងប្រៀបប្រដូចស្តីពីពួកអ្នកធ្វើការក្នុងចម្ការ

សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកមុខថ្នាក់ ។ សូមប្រាប់សិស្សថា ប្រសិនបើគាត់អាចអាវ៉ាំងបាន ១០ គាត់នឹងទទួលបានរង្វាន់តូចមួយ (ដូចជា ស្ករគ្រាប់ ១០ គ្រាប់) ។ បន្ទាប់ពីសិស្សអាវ៉ាំងបាន ១០ ដងហើយ សូមឲ្យរង្វាន់ដល់គាត់ រួចសុំអ្នកស្ម័គ្រចិត្តម្នាក់ទៀត ។ ចូរសុំឲ្យសិស្សទីពីរអាវ៉ាំងម្តង រួចសួរដល់សិស្សក្នុងថ្នាក់ តើពួកគេគិតថាសិស្សម្នាក់នេះគួរទទួលបានរង្វាន់អ្វីដែរ និងហេតុអ្វី ។ សូមអញ្ជើញសិស្សទាំងពីរនាក់ឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយវិញ ។ សូមប្រាប់សិស្សក្នុងថ្នាក់ថា នៅពេលក្រោយទៀតក្នុងមេរៀននេះ: សិស្សទីពីរនឹងទទួលរង្វាន់មួយអាស្រ័យទៅលើអ្វី ដែលសិស្សរៀននៅក្នុងព្រះគម្ពីរ ។

សូមសង្ខេប ម៉ាថាយ ១៩:១៣–២៧ ដោយពន្យល់ថា ព្រះយេស៊ូវបានលើកទឹកចិត្តពួកសិស្សរបស់ទ្រង់ ឲ្យស្វែងរកជីវិតដ៏នៅអស់កល្បជានិច្ចជាជាងទ្រព្យសម្បត្តិខាងលោកិយ ។ ពេត្រុសបានទូលសួរពីអ្វីដែលពួកសិស្សនឹងទទួលបាន ដោយសារពួកគេបានលះបង់ទ្រព្យសម្បត្តិខាងលោកិយរបស់ខ្លួនមកដើរតាមព្រះអង្គសង្គ្រោះ ។ (*កំណត់ចំណាំ ៖* ព្រឹត្តិការណ៍ដែលបានពិភាក្សានៅក្នុងខគម្ពីរទាំងនេះ នឹងត្រូវបានបង្រៀនយ៉ាងសឹងជម្រៅនៅក្នុងមេរៀន ម៉ាកុស ១០) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៩:២៨–៣០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅកាន់ពេត្រុស ។

- យោងតាម ខទី ២៩តើមនុស្សគ្រប់គ្នាដែលលះបង់អ្វីទាំងអស់មកដើរតាមព្រះអង្គសង្គ្រោះនឹងត្រងអ្វីជាមរតក ?

សូមពន្យល់ថា បន្ទាប់មកព្រះអង្គសង្គ្រោះបានបង្រៀនពួកសិស្សរបស់ទ្រង់នូវរឿងប្រៀបប្រដូចមួយ ដើម្បីជួយពួកគេឲ្យយល់ពីព្រះរាជបំណងរបស់ព្រះវរបិតាសួគ៌ដើម្បីប្រទានឱកាសទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដល់កូនចៅរបស់ទ្រង់ទាំងអស់ ។ នៅក្នុងរឿងប្រៀបប្រដូចនេះ: មានបុរសម្នាក់បានជួលពួកអ្នកធ្វើការនៅពេលខុសគ្នាពេញមួយថ្ងៃ ដើម្បីធ្វើការនៅក្នុងចម្ការគាត់ ។ ថ្ងៃធ្វើការធម្មតាមួយនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មី ចាប់ផ្តើមប្រហែលពីម៉ោង ៦:០០ ព្រឹករហូតដល់ ៦:០០ ល្ងាច ដោយមានការផ្លាស់ប្តូរបន្តិចបន្តួចតាមរដូវកាលខុសៗគ្នានៃឆ្នាំ ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬ ចែកចាយឯកសារឲ្យសិស្ស ៖

ពួកអ្នកធ្វើការ (ម៉ោងចាប់ផ្តើម)	ប្រាក់បៀវត្សរ៍ដែលបានព្រមព្រៀង	ចំនួនម៉ោងដែលបានធ្វើការ	ចំនួនប្រាក់ដែលត្រូវបង់
ព្រឹកព្រលឹម (៦:០០ ព្រឹក)			
ម៉ោងទី ៣ (៩:០០ ព្រឹក)			
ម៉ោងទី ៦ (១២:០០ ថ្ងៃត្រង់)			
ម៉ោងទី ៩ (៣:០០ រ សៀល)			
ម៉ោងទី ១១ (៥:០០ ល្ងាច)			

សូមអញ្ជើញសិស្សឲ្យធ្វើការជាក្រុមតូចៗ ។ ចូរសុំឲ្យពួកគេអាន ម៉ាថាយ ២០:១–៧ នៅក្នុងក្រុមរបស់ខ្លួន រកមើលរយៈពេលធ្វើការដែលពួកអ្នកធ្វើការមួយក្រុមៗបានធ្វើ និងប្រាក់បៀវត្សរ៍ដែលពួកគេបានព្រមព្រៀង ។ (« ១កាក់ » សំដៅលើប្រាក់មួយកាក់ដែលជាប្រាក់មួយកាក់របស់រ៉ូម ហើយវាប្រហាក់ប្រហែលនឹងថ្លៃមួយថ្ងៃសម្រាប់ពួកអ្នកធ្វើការម្នាក់) ។

លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សពីរបីនាក់ឡើងមកក្តារខៀន ហើយបំពេញជួរឈរទីមួយក្នុងតារាង (ឬ សូមអញ្ជើញពួកគេឲ្យបំពេញវានៅលើសំណៅដែលអ្នកបានផ្តល់ឲ្យ) ។

- តើអ្នកគិតថានរណាទៅ ដែលគួរទទួលបានកម្រៃច្រើនជាងគេ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២០:៨–១០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលប្រាក់កម្រៃ ដែលក្រុមអ្នកធ្វើការនីមួយៗបានទទួល ។

- តើប្រាក់កម្រៃអ្វីទៅ ដែលពួកអ្នកធ្វើការមួយក្រុមៗទទួលបាន ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរ *១ កាក់* នៅក្នុងប្រអប់នីមួយៗក្នុងជួរឈរដែលសរសេរថា « ចំនួនប្រាក់ដែលត្រូវបង់ ») ។
- ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមពួកអ្នកធ្វើការទាំងនោះ ដែលបានធ្វើការពេញមួយថ្ងៃ តើអ្នកមានគំនិត ឬអារម្មណ៍បែបណា ពេលអ្នកទទួលបានរង្វាន់ដូចគ្នានឹងអ្នកដែលបានធ្វើការតែមួយម៉ោងនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២០:១១–១៤ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលថាតើជនដែលបានធ្វើពេញមួយថ្ងៃនិយាយអ្វីខ្លះទៅម្ចាស់ចម្ការ និងអ្វីដែលគាត់បាននិយាយមកពួកគេវិញ ។

- តើការឆ្លុះញញែរបស់ជនដែលបានធ្វើការពេញមួយថ្ងៃជាអ្វីទៅ ?
- តើម្ចាស់ចម្ការបាននិយាយដូចម្តេច ក្នុងការឆ្លើយតបអ្វី ?
- តើម្ចាស់ចម្ការមានភាពយុត្តិធម៌ (ភាពស្មើគ្នា) ចំពោះជនដែលបានធ្វើការពេញមួយថ្ងៃយ៉ាងដូចម្តេចដែរ ?

ដើម្បីជួយសិស្សឲ្យស្គាល់សេចក្តីពិតមួយនៅក្នុងរឿងប្រៀបប្រដូចនេះ សូមពន្យល់ថា ប្រាក់កម្រៃមួយកាក់នោះអាចតំណាងឲ្យជីវិតដ៏នៅអស់កល្បជានិច្ច ដូចដែលបានចែងនៅក្នុង ម៉ាថាយ ១៩:២៩ ។ សូមសរសេរសេចក្តីថ្លែងការណ៍មិនពេញលេញនៅលើក្តារខៀន ៖ *ព្រះប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សទាំងអស់ដែល* . . .

- ប្រសិនបើរង្វាន់នៅក្នុងរឿងប្រៀបប្រដូចនេះ តំណាងឲ្យជីវិតដ៏នៅអស់កល្បជានិច្ច តើអ្នកធ្វើការតំណាងឲ្យអ្វីទៅ ? (សិស្សអាចមានចម្លើយខុសៗគ្នា ប៉ុន្តែត្រូវសង្ខេបថា អ្នកធ្វើការក្នុងរឿងប្រៀបប្រដូចនេះអាចតំណាងឲ្យការធ្វើ និងការរក្សាសេចក្តីសញ្ញាពិសិដ្ឋជាមួយព្រះ ។ (បន្ទាប់ពីសិស្សឆ្លើយ សូមបំពេញសេចក្តីពិតនៅលើក្តារខៀនដូចខាងក្រោមនេះ ៖ **ព្រះប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សគ្រប់រូបដែលបានជ្រើសរើសធ្វើ និងរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋជាមួយទ្រង់**) ។

សូមចង្អុលបង្ហាញថា សេចក្តីពិតនេះជួយយើងឲ្យយល់ពីសេចក្តីមេត្តាករុណារបស់ព្រះវរបិតាសួគ៌សម្រាប់បុគ្គលទាំងឡាយដែលពុំបានធ្វើ ឬរក្សាសេចក្តីសញ្ញាកាលពីក្មេង និងសម្រាប់ជនដែលគ្មានឱកាសធ្វើកិច្ចការនេះរហូតក្រោយពីពួកគេស្លាប់ (សូមមើល គ. និង ស. ១៣៧:៧–៨) ។

- ហេតុអ្វីអ្នកគិតថា ការដឹងថាព្រះប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សគ្រប់រូបដែលជ្រើសធ្វើ ហើយរក្សាសេចក្តីសញ្ញាពិសិដ្ឋជាមួយទ្រង់ជារឿងសំខាន់សម្រាប់យើង មិនថាវាកើតអាចកើតឡើងនៅពេលណានោះទេ ?

សូមរំឭកសិស្សទីពីរដែលបានអាវ៉ាំងតែម្តង រួចសួរ ៖

- តើអ្នកគិតថាសិស្សម្នាក់នេះគួរទទួលបានរង្វាន់អ្វីទៅសម្រាប់ការអាវ៉ាំងម្តង ? (សូមឲ្យសិស្សនោះនូវរង្វាន់ដូចគ្នាដែលបានឲ្យទៅសិស្សដែលបានអាវ៉ាំង ១០ ដងដែរ) ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ២០:១៥–១៦ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលរបៀប ដែលម្ចាស់ចម្ការបានតបទៅកាន់ជនដែលឆ្លុះញញែរពីសេចក្តីសប្បុរសរបស់លោក ចំពោះពួកអ្នកធ្វើការផ្សេងទៀត ។

- តើអ្នកគិតថាម្ចាស់ចម្ការចង់មានន័យយ៉ាងដូចម្តេច នៅពេលលោកបានសួរថា « តើភ្នែកអ្នកឃើញអាក្រក់ ពីព្រោះខ្ញុំល្អឬអី ? » (ខទី ១៥) ។

សូមពន្យល់ថាអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បកស្រាយសំណួរនេះដូចខាងក្រោម ៖ « ហេតុអ្វីបានជា *អ្នក* ច្រណែនគ្នាដោយសារ *យើង* ជ្រើសរើសមានចិត្តល្អ ? » (« The Laborers in the Vineyard » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៣១) ។

- តើឃ្លាថា « បានហៅមនុស្សជាច្រើន តែរើសបានតិចទេ » ដែលចែងក្នុងខទី ១៦ មានន័យដូចម្តេច ? (ការបាន *ហៅ* មានន័យថា ការអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចការរបស់ព្រះវរបិតាសួគ៌ ។ ការ *រើស* មានន័យថា ការទទួលបានពរជ័យរបស់ទ្រង់—រួមបញ្ចូលទាំងពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច) ។
- តើគោលការណ៍អ្វីដែលយើងរៀនមកពី ខ ១៦នេះ ? (សិស្សអាចនឹងរកឃើញគោលការណ៍ជាច្រើន រួមបញ្ចូលទាំងគោលការណ៍ខាងក្រោមផងដែរ ៖ **ប្រសិនបើយើងជ្រើសរើសមានចិត្តច្រណែនចំពោះពរជ័យរបស់ព្រះវរបិតាសួគ៌ដល់មនុស្សដទៃទៀត នោះយើងអាចនឹងបាត់បង់ពរជ័យដែលទ្រង់សព្វព្រះទ័យប្រទានឲ្យយើង**) ។

សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ហើយអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីរបៀប ដែលពួកគេអាចល្បងឲ្យច្រណែននឹងពរជ័យដែលព្រះវរបិតាសួគ៌ប្រទានដល់អ្នកដទៃ ៖



« មានពេលខ្លះនៅក្នុងជីវិតរបស់យើង ពេលដែលមាននរណាម្នាក់ទៀតទទួលបានពរជ័យដែលមិនបានស្មានទុកមុន ឬទទួលបានការទទួលស្គាល់ជាពិសេសខ្លះ ។ តើខ្ញុំអាចសុំអង្វរយើងកុំឲ្យឈឺចាប់—ហើយមានអារម្មណ៍ថា ពុំមានចិត្តច្រណែនបានទេ—នៅពេលដែលពរជ័យបានឲ្យទៅអ្នកផ្សេង ? យើងមិនបានអន់ថយនោះទេ នៅពេលអ្នកផ្សេងត្រូវបានផ្តល់ពរបន្ថែមនោះ ។ យើងពុំស្ថិតនៅក្នុងការប្រណាំងគ្នា តើម្បីនឹងមើលឃើញថាតើនរណាមានជាងគេ ឬមានទេពកោសល្យជាងគេបំផុត ឬស្អាតជាងគេបំផុត ឬបានពរជ័យជាងគេបំផុតនោះឡើយ ។ ការប្រកួតដែលយើងកំពុងធ្វើនោះ *ភាមពិតទៅ* គឺជាការប្រកួតទាស់នឹងអំពើបាប ។ . . .

« . . . ការចង់បានរបស់អ្នកដទៃ ការខឹងតប់ប្រមល់ ឬការបំបាក់បំបែកអ្នកដទៃ *មិន*បានលើកកំពស់*មុខមាត់អ្នក*ឲ្យខ្ពស់ជាងមុនទេ ហើយការធ្វើឲ្យអ្នកដទៃខ្មាស់គេ ក៏មិនបានជួយអ្នកឲ្យបានល្អដែរ ។ ដូច្នេះសូមមានចិត្តល្អ នឹងមានអំណរគុណដោយព្រះមានព្រះហឫទ័យល្អ ។ វាជារបៀបមួយដែលសប្បាយក្នុងការរស់នៅ » (« Laborers in the Vineyard » ទំព័រ ៣១, ៣២) ។

សូមចែកចាយទីបន្ទាល់របស់អ្នកពីសេចក្តីពិត ដែលសិស្សបានស្គាល់ នៅពេលពួកគេបានសិក្សារឿងប្រៀបប្រដូចស្តីពីពួកអ្នកធ្វើការនៅក្នុងចម្ការ ។

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ សូមទុកពេលឲ្យសិស្សបំពេញសេចក្តីថ្លែងការណ៍នោះ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖ *ផ្អែកលើអ្វីដែលខ្ញុំបានរៀននៅក្នុងរឿងប្រៀបប្រដូចនេះ ខ្ញុំនឹង . . .*

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ដែលឥតភ័យបារម្ភឲ្យ ចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានសរសេរ ។

ម៉ាថាយ ២០:១៧–៣៤

ព្រះយេស៊ូវបានមានបន្ទូលប្រាប់ជាមុនអំពីការសុគតរបស់ទ្រង់ ហើយបានបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យបម្រើអ្នកដទៃ ។

សូមសង្ខេប ម៉ាថាយ ២០:១៧–៣៤ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ជាមុនថានឹងមានមនុស្សក្បត់ទ្រង់ ហើយទ្រង់ត្រូវបានគេដាក់ទោសរហូតដល់សុគត កាលទ្រង់ត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ។ ទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ថា ជាជាងការស្វែងរកមុខតំណែង និងសិទ្ធិអំណាច នោះពួកគេគួរតែធ្វើតាមគំរូរបស់ទ្រង់ ហើយបម្រើដល់មនុស្សដទៃវិញ ។

ម៉ាថាយ ២១:១–១៦

សេចក្តីផ្តើម

ព្រះយេស៊ូវបានយាងដោយជោគជ័យចូលទៅក្នុងយេរូសាឡិម នៅដើមសប្តាហ៍ចុងក្រោយនៃ
ព្រះជន្មរបស់ទ្រង់ ។ កាលគង់នៅទីនោះ ទ្រង់បានបោសសម្អាតព្រះវិហារបរិសុទ្ធជាលើកទីពីរ
ហើយបានព្យាបាលមនុស្សខ្វាក់ និងមនុស្សខ្វិនដែលបានមករកទ្រង់ ។

យោបល់សម្រាប់ការបង្រៀន


កំណត់ចំណាំ ៖ នៅចុងបញ្ចប់នៃមេរៀននេះគឺជាទំព័រមួយដែលមានចំណងជើងថា « សប្តាហ៍ចុងក្រោយ ដង្វាយធួន និងការមាន
ព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ » ។ ទិដ្ឋភាពទូទៅសង្ខេបនេះស្តីពីសប្តាហ៍ចុងក្រោយនៃព្រះជន្មរបស់ព្រះអង្គសង្គ្រោះនៅក្នុង
ជីវិតរមែងស្លាប់អាចជួយអ្នក និងសិស្សរបស់អ្នកយល់ពីព្រឹត្តិការណ៍នានាដែលបានដឹកនាំទៅរកការសុគត និងការមានព្រះជន្មរស់ឡើង
វិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកក៏គួរប្រើទិដ្ឋភាពទូទៅនេះនៅក្នុង ម៉ាកុស លូកា និងយ៉ូហាន ផងដែរ ។

ម៉ាថាយ ២១:១–១១

ព្រះយេស៊ូវគ្រីស្ទបានយាងដោយជោគជ័យចូលទៅក្នុងយេរូសាឡិម

ចូរដាក់បង្ហាញអាហារមួយមុខ ឬសរសេរឈ្មោះអាហារមួយនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សចង្អុលបង្ហាញថា តើពួកគេធ្លាប់ភ្លក់
អាហារនេះ ហើយចង់ឲ្យមនុស្សដទៃទៀតភ្លក់ដែរឬទេ ។ សូមអញ្ជើញសិស្សម្នាក់ដែលចង់ឲ្យគេភ្លក់អាហារនេះ ឲ្យឡើងមកខាងមុខ
ក្តារខៀន ។ ចូរសុំឲ្យគាត់ស្រមើស្រមៃថា គ្មាននរណាម្នាក់បានភ្លក់អាហារនេះឡើយ ។ ចូរណែនាំសិស្សនោះឲ្យប្រាប់ថា តើគាត់នឹង
និយាយ ឬធ្វើអ្វីខ្លះដើម្បីជួយមនុស្សម្នាក់ឲ្យអភិវឌ្ឍបំណងប្រាថ្នាចង់ភ្លក់អាហារនេះ ។ សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅកន្លែងអង្គុយ
របស់ពួកគេវិញ នៅពេលធ្វើចប់ ។ បន្ទាប់មក សូមសួរសិស្ស ៖

- ប្រសិនបើអ្នកពុំធ្លាប់ភ្លក់អាហារនោះពីមុនមកទេ តើអ្នកទំនងជាចង់ភ្លក់វាឥឡូវនេះទេ ? ហេតុអ្វី ?



សូមដាក់បង្ហាញរូបភាពមួយនៃព្រះអង្គសង្គ្រោះ ។ សូមពន្យល់ថា មានមនុស្សជាច្រើនស្គាល់ព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់តែ
បន្តិចបន្តួចប៉ុណ្ណោះ ហើយថាយើងមានទំនួលខុសត្រូវ ដើម្បីជួយមនុស្សដទៃទៀតឲ្យរៀនអំពីទ្រង់ ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតពីអ្វី ដែលពួកគេអាចធ្វើដើម្បីជួយដល់នរណាម្នាក់ដែលចង់ដឹងបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។ សូម
អញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សា ម៉ាថាយ ២១:១–១១ ដែលអាចជួយពួកគេ នៅពេលពួកគេលើកទឹក
ចិត្តមនុស្សដទៃទៀតឲ្យរៀនបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។

សូមពន្យល់ថា ម៉ាថាយ ២១ កត់ត្រាពីព្រឹត្តិការណ៍ដែលកើតឡើងរយៈពេលប្រាំថ្ងៃ មុនការឆ្កាងរបស់ព្រះអង្គសង្គ្រោះ ។ ចូររំឭកសិស្ស
ថា មានហ្វូងមនុស្សមួយក្រុមបានដើរតាមព្រះយេស៊ូវ និងពួកសាវករបស់ទ្រង់ កាលទ្រង់បានយាងចេញពីស្រុកយេរីខូ ធ្វើដំណើរ
ទៅទីក្រុងយេរូសាឡិម (សូមមើល ម៉ាថាយ ២០:១៧–១៨, ២៩) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:១–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវគ្រីស្ទបានបង្គាប់
ឲ្យពួកសិស្សរបស់ទ្រង់ពីរនាក់ឲ្យធ្វើ ។

- តើព្រះយេស៊ូវបានបង្គាប់ពួកសិស្សទាំងនេះឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា ការព្យាករដែលបានលើកឡើងនៅក្នុង ម៉ាថាយ ២១:៤–៥ មាននៅក្នុង សាការី ៩:៩–១០ ។ (សូមអញ្ជើញសិស្សឲ្យ
ពិចារណាសរសេរសេចក្តីយោងនេះនៅក្បែរ ខទី ៥) ។ ការព្យាករនេះគឺអំពីព្រះមេស៊ីដែលបានសន្យា ឬ « ព្យាការី សង្ឃ ស្តេច និងជា
អ្នករំដោះដែលចាក់ប្រេងតាំង ដែលពួកសាសន៍យូដាទន្ទឹងចាំយ៉ាងអន្ទះអន្ទែងឲ្យយាងមក » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ
« ព្រះមេស៊ី » scriptures.lds.org) ។ ចូរចង្អុលបង្ហាញថា នៅសម័យព្រះគម្ពីរប៊ីប សត្វលា « គឺជានិមិត្តសញ្ញាមួយនៃភាព
ជាស្តេចរបស់សាសន៍យូដា ។ . . . ការគង់លើសត្វលា . . . បានបង្ហាញថា ព្រះយេស៊ូវបានយាងមកជាព្រះអង្គសង្គ្រោះនៃភាពសុខសាន្ត
ហើយ ‹ រាបទាប › ពុំមែនជាអ្នកឈ្លានពានគង់លើសេះចម្បាំងទេ » (*New Testament Student Manual* [Church
Educational System manual ឆ្នាំ ២០១៤ [ទំព័រ៦៤) ។

- តើសកម្មភាពមួយចំនួននៅក្នុងវប្បធម៌ខុសគ្នា ដែលបង្ហាញពីការទទួលស្គាល់ដោយក្តីគោរពចំពោះភាពជាស្តេចមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:៦–៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែល « ហ្វូងមនុស្សស្ទើរតែ
ទាំងអស់ »(ខទី ៨) បានធ្វើកាលព្រះយេស៊ូវគង់លើសត្វលា ហើយយាងចូលទៅក្នុងទីក្រុងយេរូសាឡិម ។ (អ្នកគួរចង្អុលបង្ហាញដល់
សិស្សថា ការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ២១:៥ បញ្ជាក់ថា មានតែសត្វមួយក្បាលប៉ុណ្ណោះបានយកមកជិះ) ។

- តើហ្វូងមនុស្សបានធ្វើអ្វីខ្លះ ដើម្បីទទួលស្គាល់ដោយក្តីគោរពដល់ព្រះយេស៊ូវថាជាព្រះមេស៊ី ? (អ្នកអាចចង្អុលបង្ហាញថា ដំណឹងល្អ
របស់យ៉ូហានបញ្ជាក់យ៉ាងល្អិតល្អន់ថា ហ្វូងមនុស្សបានប្រើ « ធាងចាក » [យ៉ូហាន ១២:១៣] ។ ធាងចាកគឺជានិមិត្តសញ្ញាមួយ
នៃជោគជ័យ និងជ័យជំនះលើពួកសត្រូវ ។ ការក្រាលជាកម្រាលនៅលើផ្លូវ ដូចជាអ្វីដែលបណ្តាជនបានធ្វើដោយប្រើធាង និង

ការគូសចំណាំ និងការកត់កំណត់ហេតុអំពីសេចក្តីពន្យល់បទគម្ពីរ

ការកត់ចំណាំ ឬការកត់កំណត់ហេតុក្នុងព្រះគម្ពីរគឺជាវិធីមួយដ៏មានប្រយោជន៍បំផុតសម្រាប់សិស្ស ដើម្បីនៅចាំពីអ្វីដែលពួកគេបានរៀន ។ សិស្សអាចធ្វើដូចនេះដោយការគូសបន្ទាត់ពីខាងក្រោម ផ្ទាត់ពណ៌ ឬសង្ខេបពាក្យ ឬឃ្លាសំខាន់ៗ ។ ពួកគេក៏អាចសរសេរគោលការណ៍ ប្រសាសន៍ព្យាករ ឬការយល់ដឹងជ្រៅជ្រះផ្ទាល់ខ្លួន និងចំណាប់អារម្មណ៍ទាំងឡាយនៅក្នុងរឹមនៃខគម្ពីររបស់ពួកគេ ។

សម្លៀកបំពាក់គឺជាកាយវិការមួយគោរពដល់ភាពជាស្តេច ឬអ្នកចម្បាំង ។ ការធ្វើដូច្នេះ នោះហ្វូងមនុស្សបានទទួលស្គាល់ ហើយស្វាគមន៍ដល់ព្រះយេស៊ូវជាអ្នករំដោះ និងជាស្តេចរបស់ពួកគេ) ។

ចូរដាក់បង្ហាញរូបភាពការយាងចូលមកដ៏ជោគជ័យ (*Gospel Art Book* ២០០៩ | ល.រ.៥០ សូមមើលផងដែរ LDS.org) ។ ចូរសុំឲ្យសិស្សស្រមើស្រមៃថា ពួកគេគឺជាមនុស្សមួយក្រុមនៅក្នុងរូបភាពនេះ ។ សូមអានផ្នែកទីមួយនៃ ម៉ាថាយ ២១:៩ ឲ្យឮៗ ហើយអញ្ជើញសិស្សឲ្យអានឮៗរួមគ្នា នូវសម្រែករបស់ហ្វូងមនុស្សនៅក្នុងផ្នែកបញ្ចប់នៃខគម្ពីរនោះ ដូចជាពួកគេបាននៅជាមួយនឹងហ្វូងមនុស្សនោះដូច្នោះដែរ ។

- តើពាក្យអ្វីទៅ ដែលមនុស្សបានពោលឡើងម្តងហើយម្តងទៀត ? (*ហូសាណា*) ។

សូមពន្យល់ថា *ហូសាណា* មានន័យថា « សង្គ្រោះឥឡូវនេះ » (Bible Dictionary « Hosanna ») ។ សូមអញ្ជើញសិស្សឲ្យពិចារណាសរសេរនិយមន័យនៅក្នុងព្រះគម្ពីររបស់ពួកគេគឺនៅក្បែរ ខទី ៩ ។

សូមពន្យល់ថា ផ្នែកនៃសម្រែករបស់បណ្តាជនបានបំពេញការព្យាករបស់ព្រះមែស៊ីដែលមាននៅក្នុង ទំនុកដំកើង ១១៨:២៥–២៦ ។ អ្នកគួរផ្តល់យោបល់ឲ្យ សិស្សសរសេរសេចក្តីយោងនេះនៅក្បែរ ម៉ាថាយ ២១:៩ ។ សូមពន្យល់ថា ងារជាក្សត្រ និងជាព្រះមែស៊ី « បុត្រានៃហ្លួងដាវីដ » (ខទី ៩ខ) ត្រូវបានរក្សាទុកសម្រាប់អ្នកដែលទទួលមរតកនូវបល្ល័ង្ករបស់ស្តេចដាវីដ ។

- ដោយសម្រែកនេះ តើមនុស្សទាំងនោះកំពុងប្រកាសថាព្រះយេស៊ូវជានរណាទៅ ?
- ប្រសិនបើអ្នកកំពុងរស់នៅក្នុងទីក្រុងយេរូសាឡិមនៅពេលនេះ តើអ្នកមានគំនិត ឬអារម្មណ៍បែបណាដែរ កាលអ្នកបានឃើញការយាងចូលមកដ៏ជោគជ័យរបស់ព្រះអង្គសង្គ្រោះ ?

ចូរចង្អុលបង្ហាញថា មានមនុស្សរាប់ពាន់នាក់បន្ថែមទៀតនៅក្នុងទីក្រុងយេរូសាឡិមនៅពេលនោះ បានអបអរដល់បុណ្យរំលង ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:១០–១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលឥទ្ធិពលនៃឥរិយាបថរបស់ហ្វូងមនុស្សនោះទៅលើមនុស្សដទៃទៀតនៅក្នុងទីក្រុងយេរូសាឡិម ។



- តើមនុស្សដទៃទៀតបានសួរសំណួរអ្វីខ្លះ ដោយសារតែឥរិយាបថរបស់ហ្វូងមនុស្សនោះ ?
- ដូចដែលបានបង្ហាញនៅក្នុងដំណើររឿងនេះ តើមានអ្វីអាចកើតឡើងកាលយើងទទួលស្គាល់ ហើយនិយាយពីព្រះយេស៊ូវគ្រីស្ទជាសាធារណៈ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងទទួលស្គាល់ ហើយនិយាយពីព្រះយេស៊ូវគ្រីស្ទជាសាធារណៈ យើងអាចជួយមនុស្សដទៃទៀតឲ្យអភិវឌ្ឍនូវបំណងប្រាថ្នាមួយ ដើម្បីចង់ដឹងបន្ថែមទៀតអំពីទ្រង់ ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើបរិយាកាសនៅខាងក្រៅការប្រជុំសាសនាចក្រមួយចំនួន ដែលយើងអាចទទួលស្គាល់ហើយនិយាយអំពីព្រះយេស៊ូវគ្រីស្ទជាសាធារណៈមានអ្វីខ្លះ ? (សូមជួយសិស្សឲ្យយល់ដឹងថា នៅពេលត្រឹមត្រូវ យើងអាចធ្វើកិច្ចការនៅក្នុងមជ្ឈដ្ឋានជាផ្លូវការ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងនៅអំឡុងការសន្ទនាជាមួយមិត្តភក្តិ សមាជិកគ្រួសារ និងអ្នកជិតខាង) ។
- តើយើងអាចទទួលស្គាល់ ហើយនិយាយាពីព្រះយេស៊ូវគ្រីស្ទជាសាធារណៈតាមរបៀបមួយ ដែលនឹងជួយមនុស្សដទៃទៀតឲ្យចង់ដឹងបន្ថែមទៀតអំពីទ្រង់បានដោយរបៀបណា ?
- តើអ្នកនឹងឆ្លើយយ៉ាងណាដែរ ប្រសិនបើអ្នកត្រូវបានគេសួរថា តើព្រះយេស៊ូវគឺជានរណានោះ ?

ចូរសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀនហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

តើភ្លាប់មានការខិតខំរបស់មនុស្សម្នាក់ទៀតដើម្បីទទួលស្គាល់ ហើយនិយាយអំពី ព្រះយេស៊ូវគ្រីស្ទជាសាធារណៈ បាននាំអ្នកឲ្យចង់ដឹងបន្ថែមទៀតអំពីទ្រង់នៅពេលណាដែរ ?


តើអ្នក (ឬ មនុស្សម្នាក់ដែលអ្នកស្គាល់) ភ្លាប់ជួយមនុស្សម្នាក់ឲ្យចង់ដឹងបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ដោយសារអ្នកបានទទួលស្គាល់ ហើយបាននិយាយអំពីទ្រង់ជាសាធារណៈនៅពេលណាដែរ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សពីរបីនាក់ដែលស្ម័គ្រចិត្តចែកចាយអ្វីដែលពួកគេបានសរសេរ ។

សូមលើកទឹកចិត្តសិស្សឲ្យរកមើល ហើយឆ្លៀតឱកាសដើម្បីទទួលស្គាល់ ហើយនិយាយដោយសមរម្យអំពីព្រះយេស៊ូវគ្រីស្ទ ។

ម៉ាថាយ ២១:១២–១៦

ព្រះយេស៊ូវបានបោសសម្អាតព្រះវិហារបរិសុទ្ធ ហើយបានព្យាបាលមនុស្សខ្វាក់ និងមនុស្សខ្ញិន



សូមដាក់បង្ហាញរូបភាពមួយនៃព្រះវិហារបរិសុទ្ធនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលនៅជិតនឹងកន្លែងដែលអ្នករស់នៅ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិត ហើយពិពណ៌នាអំពីគំនិត និងអារម្មណ៍ដែលពួកគេមាននៅពេលចុងក្រោយ ដែលពួកគេបានទៅលេងព្រះវិហារបរិសុទ្ធ ។ ប្រសិនបើសិស្សពុំធ្លាប់ទៅព្រះវិហារបរិសុទ្ធ ចូរសុំឲ្យពួកគេពិពណ៌នាថា តើពួកគេនឹងមានអារម្មណ៍បែបណាដែរ ប្រសិនបើពួកគេបាននៅក្នុងព្រះវិហារបរិសុទ្ធ ។

- តើមានអ្វីកើតឡើងនៅក្នុងព្រះវិហារបរិសុទ្ធ ដែលអាចឲ្យយើងដកពិសោធន៍នូវអារម្មណ៍ទាំងនេះ ?

ចូរដាក់បង្ហាញរូបភាពដំណាក់របស់បិតាខ្ញុំ (*Gospel Art Book* ឆ្នាំ ២០០៩ | ល.រ.៥២សូមមើលផងដែរ LDS.org) ។ សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានយាងចូលទៅក្នុងទីក្រុងយេរូសាឡិម នោះទ្រង់បានយាងទៅទីធ្លាមួយនៅបរិវេណព្រះវិហារ

បរិសុទ្ធ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:១២–១៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលមនុស្សមួយចំនួនកំពុងធ្វើ ដែលជំទាស់នឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវ ។

- តើមនុស្សមួយចំនួនប្រព្រឹត្តដាក់ដំណាក់របស់ព្រះយ៉ាងដូចម្តេច ?

សូមពន្យល់ថាភ្ញៀវដែលមកទីក្រុងយេរូសាឡិមដើម្បីជប់លៀងបុណ្យរំលង ត្រូវការទិញសត្វដើម្បីថ្វាយជាគ្រឿងបូជានៅក្នុងព្រះវិហារបរិសុទ្ធ ដែលជាផ្នែកមួយនៃការថ្វាយបង្គំរបស់ពួកគេ ។ អ្នកប្តូរប្រាក់បានដោះដូរប្រាក់បណ្តាលរបស់ខ្លួន និង រូបិយប័ណ្ណផ្សេងទៀតជារូបិយប័ណ្ណព្រះវិហារបរិសុទ្ធ ដើម្បីទិញសត្វ ហើយពាណិជ្ជករផ្សេងទៀតបានលក់សត្វទាំងនោះ ។

- តើការធ្វើអាជីវកម្មបែបនេះនៅលើបរិវេណព្រះវិហារបរិសុទ្ធ វាខុសឆ្គងអ្វីទៅ ?

អ្នកគ្រូចង្អុលបង្ហាញថា ទោះជាអាជីវកម្មនេះគឺជារឿងចាំបាច់ ហើយបម្រើក្នុងគោលបំណងល្អយ៉ាងណាក្តី ប៉ុន្តែការធ្វើវានៅកន្លែងនោះ និងរបៀបដែលពាណិជ្ជករធ្វើ គឺខ្វះការគោរព កោតខ្លាច ។ ខទី ១៣ ណែនាំថា ពួកអ្នកប្តូរប្រាក់ និងពាណិជ្ជករគិតតែពីចង់បានប្រាក់ចំណូលជាជាងការថ្វាយបង្គំព្រះ និងការជួយមនុស្សដទៃទៀតឲ្យធ្វើដូចគ្នា ។

- តើសេចក្តីពិតអ្វីខ្លះ អំពីព្រះវិហារបរិសុទ្ធដែលយើងអាចរៀនពីបន្ទូល និងទង្វើរបស់ព្រះអង្គសង្គ្រោះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ដំណាក់របស់ព្រះអម្ចាស់គឺជាកន្លែងពិសិដ្ឋ ហើយទ្រង់មានព្រះទំរង់ចង់ឲ្យយើងប្រព្រឹត្តចំពោះដំណាក់នោះដោយគារវភាព**) ។
- តើយើងអាចបង្ហាញគារវភាពចំពោះដំណាក់របស់ព្រះអម្ចាស់បានដោយរបៀបណា ?
- តើការចូលរួមដោយភាពសក្តិសម អាចបង្ហាញគារវភាពចំពោះដំណាក់នេះដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធនោះ បន្ទាប់ពីបានបោសសម្អាតវារួចមក ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះចំពោះមនុស្សខ្វាក់ និងមនុស្សខ្ញើនដែលបានមករកទ្រង់នៅក្នុងព្រះវិហារបរិសុទ្ធ ?
- តើយើងអាចរៀនអ្វីខ្លះពីដំណើររឿងនេះ អំពីអ្វីដែលព្រះអម្ចាស់អាចធ្វើចំពោះយើង កាលយើងចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធ ? (សូមធ្វើឲ្យប្រាកដថាសិស្សស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **នៅពេលយើងចូលរួមក្នុងព្រះវិហារបរិសុទ្ធ ព្រះអម្ចាស់អាចព្យាបាលយើងបាន**) ។
- បន្ថែមពីលើជំងឺខាងរូបកាយ តើជំងឺ និងការប្រឈមអ្វីផ្សេងទៀតដែលព្រះអម្ចាស់អាចព្យាបាលបាន នៅពេលយើងចូលរួមនៅក្នុងព្រះវិហារបរិសុទ្ធ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន សេចក្តីថ្លែងការណ៍ខាងក្រោម ដែលបានថ្លែងដោយប្រធាន ជែមស៍ អ៊ី ហ្វោស្ត នៃគណៈប្រធានទីមួយឲ្យឮៗ ។ ចូរសុំឲ្យសិស្សស្តាប់រកទីបន្ទាល់របស់ប្រធាន ហ្វោស្ត អំពីសេចក្តីពិតដែលពួកគេបានស្គាល់ ។



« ព្រះអម្ចាស់បានប្រទានផ្លូវជាច្រើន ដែលដោយសារផ្លូវទាំងនេះ នោះយើងអាចទទួលបាន ឥទ្ធិពលនៃការព្យាបាល [របស់ទ្រង់] ។ ខ្ញុំមានអំណរគុណដែលព្រះអម្ចាស់បានស្ថាបនាកិច្ចការព្រះវិហារបរិសុទ្ធមកលើផែនដីវិញ ។ វាគឺជាផ្នែកមួយដ៏សំខាន់ចំពោះកិច្ចការនៃសេចក្តីសង្គ្រោះសម្រាប់មនុស្សរស់ផង និង មរណៈជនមនុស្សផងដែរ ។ ព្រះវិហារបរិសុទ្ធរបស់យើងផ្តល់កន្លែងមួយដ៏បរិសុទ្ធដែលយើងអាចទុកចោលមួយអន្លើរ នូវកង្វល់នៃលោកិយ ។ ព្រះវិហារបរិសុទ្ធរបស់យើងគឺជាទីកន្លែងនៃភាពសុខសាន្ត និង ភាពស្ងប់ស្ងាត់ ។ នៅក្នុងកន្លែងដ៏បរិសុទ្ធទាំងនេះ ព្រះ ‹ ប្រោសអស់អ្នកដែលមានចិត្តសង្រេងឲ្យបានជា ក៏រុំរបួសឲ្យគេផង › ។ (ទំនុក.១៤៧:៣) » ។
(« Spiritual Healing » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩២ ទំព័រ ៧) ។

- ហេតុអ្វីការថ្វាយបង្គំនៅក្នុងដំណាក់របស់ព្រះអម្ចាស់ ជួយយើងឲ្យដកពិសោធន៍នូវឥទ្ធិពលនៃការព្យាបាលរបស់ទ្រង់ ?

សូមពន្យល់ថា ការព្យាបាលដែលយើងដកពិសោធន៍ កាលយើងថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធអាចកើតមានភ្លាមៗ ដូចជាវាបានកើតឡើងចំពោះមនុស្សខ្វាក់ និងមនុស្សខ្ញើនដែលបានពិពណ៌នានៅក្នុងដំណើររឿងនេះ ឬវាអាចកើតឡើងនៅពេលក្រោយទៀត ។

- តើអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់ធ្លាប់ដកពិសោធន៍ឥទ្ធិពលព្យាបាលរបស់ព្រះអម្ចាស់ដោយការថ្វាយបង្គំនៅក្នុងព្រះវិហារបរិសុទ្ធនៅពេលណាដែរ ? (អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយរបស់អ្នកដែរ) ។

សូមសង្ខេប ម៉ាថាយ ២១:១៥–១៦ ដោយពន្យល់ថា ពួកមេសង្ឃ និងពួកអាចារ្យមិនរីករាយជាមួយនឹងអ្វី ដែលព្រះយេស៊ូវបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ និងជាមួយសម្រែកហ៊ោរបស់មនុស្សទៅកាន់ទ្រង់ថា « ហូសាណា » នៅទីនោះឡើយ ។ ព្រះយេស៊ូវបានចង្អុលបង្ហាញថា ទទួលស្គាល់ទ្រង់ពីសំណាក់មនុស្សទូទៅជាសាធារណៈបានបំពេញការព្យាករមួយ (សូមមើល ទំនុកដំកើង ៨:២) ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយ ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

Հիսուս Քրիստոսի Վերջին Շաբաթը, Քավությունը և Հարությունը





Պատմում է տասը կույսերի, քանքարների և ոչխարների ու այծերի առակները



Տառապում է Գեթսեմանում




Հրեա ղեկավարները Հիսուսին ձերբակալելու համար համաձայնության են գալիս Հուդայի հետ



Ասում է Բարեխոսական Աղոթքը



Ձերբակալությունը, չարչարանքները և խարազանումը



Խաչելությունը և մահը



Հայտնվում է Առաքյալներին և այլոց



Կանխագուշակում է Իր Երկրորդ Գալուստի նշանները



Ուսուցանում է այրի կնոջ լումայի առակը



Զատիկի նախապատրաստությունը



Սպասավորում է հաղորդությունը



Հուղարկավորությունը



Հարությունը և Մարիամ Մագդաղենացուն հայտնվելը




Հանդիմանում է փարիսեցիներին և ուսուցանում է տաճարում



Լվանում է Տասներկու աշակերտների ոտքերը



Վերջին Ընթրիքը



Ծառայում է հոգևոր աշխարհում



Հաղթական մուտքը



Մաքրագործում է տաճարը

Զատիկին նախորդող հինգերորդ օրը

Զատիկին նախորդող չորրորդ օրը

Զատիկին նախորդող երրորդ օրը

Զատիկին նախորդող վերջին օրը

Զատիկ

Հրեական շաբաթը

Կիրակի

(Զատիկին նախորդող երկրորդ օրվա իրադարձությունները հայտնի չեն:)

(Հրեաները օրը չափում էին մայրամուտիցմայրամուտ: Այդ օրվա իրադարձություններից շատերը տեղի ունեցան գիշերը:)

© 2015 by Intellectual Reserve, Inc. Բոլոր իրավունքները վերապահված են:

មេរៀន ២៤

ម៉ាថាយ ២១:១៣–២២:៤៤

សេចក្តីផ្តើម

បន្ទាប់ពីគង់នៅមួយយប់ក្នុងភូមិបេថានី ព្រះយេស៊ូវបានត្រឡប់ទៅព្រះវិហារបរិសុទ្ធ ។ នៅតាមផ្លូវ ទ្រង់បានដាក់បណ្តាសាដល់ដើមល្វាមួយ ។ ពួកអ្នកដឹកនាំសាសន៍យូដាបានមកឯទ្រង់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយចោទសួរពីសិទ្ធិអំណាចរបស់ទ្រង់ ។ ព្រះយេស៊ូវបានស្តីបន្ទោសដល់ពួកគេ ហើយបានបង្រៀននូវរឿងប្រៀបប្រដូចមួយចំនួន ដែលបង្ហាញពីផលនៃការបដិសេធ ឬការទទួលយកទ្រង់ និងដំណឹងល្អរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២១:១៧–៣២

ព្រះយេស៊ូវដាក់បណ្តាសាដើមល្វាមួយដើម ហើយស្តីបន្ទោសដល់ពួកអ្នកដឹកនាំសាសន៍យូដា

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ ***តើពេលណាខ្លះ ដែលអ្នកបានរកឃើញអ្វីមួយ ដែលមិនស្រស់ល្អ ដូចជាទ្រង់ទ្រាយពិតរបស់វា ?***

ដើម្បីចាប់ផ្តើមមេរៀននេះ សូមអញ្ជើញសិស្សម្នាក់ ឬច្រើននាក់ឲ្យចែកចាយចម្លើយរបស់ខ្លួនចំពោះសំណួរនៅលើក្តារខៀន ។

សូមពន្យល់ថា ម៉ាថាយ ២១ បង្ហាញពីដំណើររឿងមួយអំពីគ្រាមួយកាលព្រះយេស៊ូវគ្រីស្ទបានជួបប្រទះនឹងអ្វីមួយដែលមិនស្រស់ល្អ ដូចជាទ្រង់ទ្រាយពិតរបស់វា ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅក្នុង ម៉ាថាយ ២១ ដែលអាចដឹកនាំយើងមិនត្រឹមតែមានអាការៈទ្រង់ទ្រាយសុចរិតចំពោះអ្នកដទៃប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវរស់នៅដោយសុចរិតផងដែរ ។

ដើម្បីផ្តល់បរិបទសម្រាប់ ម៉ាថាយ ២១សូមពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានយាងដោយជោគជ័យចូលទៅក្នុងយេរូសាឡិម ហើយបានសម្អាតព្រះវិហារបរិសុទ្ធ ទ្រង់បានគង់នៅភូមិបេថានី ជាភូមិតូចមួយនៅក្បែរយេរូសាឡិម ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:១៨–២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើនៅថ្ងៃបន្ទាប់ នៅពេលទ្រង់បានធ្វើដំណើរចេញពីភូមិបេថានីត្រឡប់ទៅព្រះវិហារបរិសុទ្ធនៅយេរូសាឡិម ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះចំពោះដើមល្វានោះ ?



ដើមល្វា

© Jose Ramiro Laguna/ Shutterstock.com

សូមដាក់បង្ហាញរូបភាពដើមល្វាដែលមានស្លឹក ។ សូមពន្យល់ថា ស្លឹកនៅលើដើមល្វាជាធម្មតាបង្ហាញថា ដើមនោះមានផលផ្លែ ។ នៅនិទាឃរដូវ (កាលព្រះអង្គសង្គ្រោះបានឃើញដើមល្វាមួយដែលគ្មានផ្លែ) ជាធម្មតាដើមល្វាមានផ្លែមុនរដូវ ។ ប្រសិនបើវាគ្មានផ្លែទេ នោះមានន័យថាវានឹងគ្មានផ្លែនៅក្នុងឆ្នាំនោះទេ ។ ដើមឈើដែលបានរៀបរាប់នៅក្នុងដំណើររឿងនេះ មានទ្រង់ទ្រាយជាដើមឈើមានផលផ្លែ ប៉ុន្តែវាគ្មានផ្លែសោះ ។ ហេតុផលមួយដែលព្រះអង្គសង្គ្រោះប្រហែលជាបានដាក់បណ្តាសាដើមល្វានោះ គឺដើម្បីបង្រៀនដល់ពួកសិស្សរបស់ទ្រង់អំពីពួកអ្នកដឹកនាំសាសនាពុករលួយរបស់សាសន៍យូដា ។

- ដោយផ្អែកតាមអ្វីដែលអ្នកបានរៀនអំពីពួកអ្នកដឹកនាំសាសនាសាសន៍យូដានៅក្នុងជំនាន់របស់ព្រះអង្គសង្គ្រោះ តើពួកគេជាច្រើនដូចជាដើមល្វាដែលបានពណ៌នានៅក្នុងដំណើររឿងនោះយ៉ាងដូចម្តេចទៅ ? (ពួកគេខំបង្ហាញថាពួកគេដើរតាមព្រះ ប៉ុន្តែមិនបានបង្កើតផលផ្លែ ឬកិច្ចការនៃសេចក្តីសុចរិតទេ) ។

សូមសង្ខេប ម៉ាថាយ ២១:២៣–២៧ ដោយពន្យល់ថា ពួកអ្នកដឹកនាំសាសន៍យូដាមួយចំនួនបានដើរសំដៅទៅរកព្រះអង្គសង្គ្រោះនៅក្នុងព្រះវិហារបរិសុទ្ធ ហើយបានទូលសួរពីសិទ្ធិអំណាច ដែលទ្រង់បានធ្វើការយាងចូលក្នុងក្រុងយេរូសាឡិមដោយជោគជ័យរបស់ទ្រង់ ហើយបានសម្អាតព្រះវិហារបរិសុទ្ធ ។ ព្រះអង្គសង្គ្រោះបានតបដោយសួរពួកគេថា តើពិធីបុណ្យជ្រមុជទឹក (ឬការងារបម្រើ) របស់យ៉ូហាន បាទីស្ទ បានអនុញ្ញាតមកពីព្រះ ឬក៏មនុស្ស ។ ពួកអ្នកដឹកនាំទាំងនោះមិនបានឆ្លើយតបនឹងសំណួររបស់ព្រះអង្គសង្គ្រោះទេ ដោយភ័យខ្លាចពីការប្តោលទោសខ្លួនឯង ឬធ្វើឲ្យមនុស្សដែលបានទទួលស្គាល់យ៉ូហានថា ជាព្យាការីម្នាក់នោះត្រូវរវាទចិត្ត ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់ក៏មិនឆ្លើយនឹងសំណួររបស់ពួកគេដែរ ហើយបន្ទាប់មកបានលើកឡើងនូវរឿងប្រៀបប្រដូចបីដែលបង្ហាញពីទង្វើរបស់ពួកអ្នកដឹកនាំពុករលួយរបស់សាសន៍យូដាទាំងនោះ ។ រឿងប្រៀបប្រដូចទីមួយរៀបរាប់ពីរបៀបខុសគ្នា ដែលកូនប្រុសពីរនាក់បានធ្វើដាក់ឪពុករបស់ខ្លួន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:២៨–៣០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលថាតើកូនប្រុសណាដែលពិតជាស្រដៀងនឹងពួកអ្នកដឹកនាំសាសន៍យូដា ។

- តើកូនប្រុសម្នាក់ណាទៅដែលពិតជាស្រដៀងនឹងពួកអ្នកដឹកនាំសាសន៍យូដា ? ដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:៣១–៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកអ្នកដឹកនាំពុករលួយរបស់សាសន៍យូដាទាំងនោះតាមរយៈរឿងប្រៀបប្រដូចនេះ ។ (អ្នកគួរត្រូវពន្យល់ថា ពួកអ្នកយកពន្ធគឺជាពួកជនដើរប្រមូលពន្ធ ហើយពួកសំផឹងគឺជាពួកស្រីពេស្យា ។ ពួកអ្នកដឹកនាំសាសន៍យូដាបានប្រមាថមើលងាយមនុស្សទាំងពីរក្រុមនេះ ដោយចាត់ទុកថាពួកគេជាអ្នកមានបាប) ។

- តើពួកយកពន្ធ និងពួកស្រីសំផឹងដូចគ្នានឹងកូនប្រុសទីមួយដោយរបៀបណា ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីជនដែលនឹងចូលទៅក្នុងនគរព្រះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **ដើម្បីចូលក្នុងនគរព្រះបាន យើងត្រូវគោរពតាមព្រះវរបិតាសួគ៌យើង ហើយប្រែចិត្តពីអំពើបាបរបស់យើង ជាជាងគ្រាន់តែនិយាយ ឬធ្វើពុតថាយើងគោរពតាមទ្រង់**) ។

ដើម្បីជួយសិស្សយល់អំពីរឿងទាក់ទងនឹងសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗអំពីសាច់រឿងដូចខាងក្រោមនេះ ៖

ជារឿយៗ មានយុវជនម្នាក់ប្រាប់ឪពុកម្តាយខ្លួនថា គាត់ទៅចូលរួមសកម្មភាពរបស់សាសនាចក្រ ប៉ុន្តែតាមពិត គាត់បានទៅផ្ទះមិត្តម្នាក់របស់គាត់ ។ នៅពេលគាត់នៅក្បែរពួកថ្នាក់ដឹកនាំ និងពួកគ្រូបង្រៀនក្នុងសាសនាចក្រ គាត់និយាយ ហើយធ្វើដូចជាគាត់ជាអ្នកដែលគោរពតាមព្រះបញ្ញត្តិរបស់ព្រះវរបិតាសួគ៌ ប៉ុន្តែនៅខាងក្រៅវិញ គាត់បានបំពានព្រះបញ្ញត្តិជាច្រើន ។

- តើការជ្រើសរើសរបស់យុវជនម្នាក់នេះ រវាងគាត់ពីការចូលទៅក្នុងនគរព្រះតាមរបៀបណា ?
- ប្រសិនបើ អ្នកជាមិត្តរបស់យុវជនម្នាក់នេះ តើអាចនឹងនិយាយពាក្យអ្វីខ្លះទៅកាន់គាត់ដើម្បីជួយគាត់ឲ្យផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន ?

សូមអញ្ជើញសិស្សម្នាក់ទៀតអានសាច់រឿងដូចខាងក្រោមឲ្យឮៗ ៖

មានយុវនារីម្នាក់ចូលចិត្តនិយាយខ្សឹបខ្សៀវនឹងមិត្តៗរបស់នាង អំពីក្មេងស្រីមួយចំនួននៅសាលារៀនរបស់នាង ប៉ុន្តែធ្វើជារាក់ទាក់នឹងក្មេងស្រីទាំងនេះនៅពេលពួកគេនៅជិត ។ នាងទៅព្រះវិហារ ហើយទទួលទានសាក្រាម៉ង់ជាទៀងទាត់ ប៉ុន្តែនៅក្នុងការប្រជុំ ជារឿយៗ នាងបានផ្ញើសារទៅមិត្តនាងដោសរសេរអ៊ីមែលដល់អស់អ្នកដែលនៅជុំវិញនាង ។

- តើយុវនារីនេះធ្វើពុតជាគោរពតាមព្រះបញ្ញត្តិរបស់ព្រះវរបិតាសួគ៌បានដោយរបៀបណា ?
- ក្រៅពីឧទាហរណ៍នៅក្នុងសាច់រឿងទាំងនេះ តើរបៀបផ្សេងទៀតដែលយើងអាចនឹងល្បួងឲ្យធ្វើពើជាគោរពតាមព្រះវរបិតាសួគ៌ជាជាងគោរពទ្រង់ដោយពិតប្រាកដនោះមានអ្វីខ្លះ ?

នៅពេលសិស្សបន្តសិក្សា ម៉ាថាយ ២១ សូមអញ្ជើញពួកគេឲ្យរកមើលអ្វី ដែលពួកគេអាចធ្វើដើម្បីចៀសវាងមិនដូចជាដើមល្វាដែលគ្មានផលផ្លែនោះ ។

ម៉ាថាយ ២១:៣៣–២២:១៤

ព្រះយេស៊ូវបង្រៀនរឿងប្រៀបប្រដូចអំពីពួកអ្នកធ្វើចម្ការទុច្ចរិត និងអាពាហ៍ពិពាហ៍របស់ព្រះរាជបុត្រាស្តេច

សូមបំបែកសិស្សជាគូ ។ ប្រសិនបើអាចធ្វើទៅបាន សូមឲ្យសំណៅនៃ តារាងដូចខាងក្រោមនេះដល់ដៃគូនីមួយៗ ។ សូមអញ្ជើញសិស្សអាន ម៉ាថាយ ២១:៣៣–៤១ រួមគ្នាឲ្យឮៗជាមួយនឹងដៃគូខ្លួន ហើយបំពេញតារាងនោះដោយសរសេរអ្វី ដែលពួកគេគិតថា និមិត្តសញ្ញាបីចុងក្រោយនោះតំណាងឲ្យអ្វី ។

រឿងប្រៀបប្រដូចអំពីពួកអ្នកធ្វើចម្ការទុច្ចរិត

ម៉ាថាយ ២១:៣៣–៤១	
និមិត្តរូប	អត្ថន័យ
ថៅកែ	ព្រះវរបិតាសួគ៌
ពួកអ្នកធ្វើចម្ការ	
អ្នកបម្រើ	
កូនប្រុសរបស់ថៅកែ	

បន្ទាប់ពីសិស្សបានបំពេញតារាងចប់សព្វគ្រប់ហើយ សុំឲ្យសិស្សពីរបីគូប្រាប់ពីអ្វីដែលពួកគេបានសរសេរ ។ ប្រសិនបើត្រូវការ សូមបញ្ជាក់ថា ពួកអ្នកធ្វើចម្ការតំណាងឲ្យពួកអ្នកដឹកនាំពុករលួយរបស់សាសន៍អ៊ីស្រាអែល ពួកអ្នកបម្រើតំណាងឲ្យពួកព្យាការីរបស់ព្រះ ហើយកូនប្រុសថៅកែតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ។

- តើព្រះយេស៊ូវបានបង្ហាញអ្វីខ្លះតាមរយៈរឿងប្រៀបប្រដូចនេះ ? (ជាច្រើនសតវត្សរ៍ មានពួកអ្នកដឹកនាំអ៊ីស្រាអែលមួយចំនួនបានបដិសេធពួកព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយពួកអ្នកដឹកនាំសាសន៍យូដាបច្ចុប្បន្នមានចេតនាចង់ធ្វើគុតព្រះយេស៊ូវ [សូមមើល *New Testament Student Manual* (Church Educational System manual ឆ្នាំ ២០១៤) ទំព័រ ៦៥]) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២១:៤៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលជនដែលនឹងបានទទួលនគរព្រះ (មានន័យថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ និងពរជ័យនៃដំណឹងល្អ) បន្ទាប់ពីពួកអ្នកដឹកនាំសាសន៍យូដាបានបដិសេធវា ។

- តើនរណាទៅដែលនឹងទទួលបាននគរព្រះ ?

សូមពន្យល់ថា ការបកប្រែរបស់ យ៉ូសែប ស៊្មីធ ម៉ាថាយ ២១:៥៣បង្ហាញប្រាប់ថា ពួកសាសន៍ដទៃគឺជាប្រជាជាតិដែលនឹងទទួលបានន្តគរព្រះ ។ អ្នកគួរពន្យល់ថា ពាក្យ *សាសន៍ដទៃ* អាចសំដៅទៅលើ « មនុស្សក្រៅពីពូជអ៊ីស្រាអែល . . . ឬ ក្រៅពីពូជយូដា » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ពួកសាសន៍ដទៃ » scriptures.lds.org) ឬជាប្រជាជាតិដែលគ្មានភាពពេញលេញនៃសិទ្ធិអំណាច ពិធីបរិសុទ្ធ ក្រឹត្យវិន័យ និងការបង្រៀនទាំងឡាយរបស់ព្រះ ។ ការផ្លេងន្តគរនោះទៅឲ្យពួកសាសន៍ដទៃបានចាប់ផ្តើមនៅពេលពួកសាវកបាននាំយកដំណឹងល្អជាលើកដំបូងទៅដល់ពួកសាសន៍ដទៃ បន្ទាប់ពីការមានព្រះជន្មឡើងវិញរបស់ព្រះអង្គសង្គ្រោះ(សូមមើល កិច្ចការ ១០–១១, សូមមើលផងដែរ ម៉ាថាយ ២០:១៦) ។ វាបានបន្តនៅថ្ងៃចុងក្រោយជាមួយនឹងការស្តារឡើងវិញនៃដំណឹងល្អតាមរយៈព្យាការី យ៉ូសែប ស៊្មីធ ដែលបានរស់នៅក្នុងសាសន៍ដទៃ ។ ក្នុងនាមជាសមាជិកសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ យើងស្ថិតនៅក្នុងចំណោមអស់អ្នកដែលព្រះបានប្រទានន្តគរទ្រង់ឲ្យ ។

- យោងតាម ខទី ៤៣តើយើងមានទំនួលខុសត្រូវធ្វើអ្វីខ្លះ: ក្នុងនាមជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ? (សូមធ្វើឲ្យប្រាកដថាសិស្សរកឃើញអ្វីមួយស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ: ៖ **ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យើងមានទំនួលខុសត្រូវដើម្បីបង្កើតជលផ្លែនៃសេចក្តីសុចរិត ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឡើងមកក្តារខៀនគូររូបផ្លែនៅលើដើមល្វា ។ ចូរសុំឲ្យពួកគេសរសេរដាក់ពាក្យឲ្យផ្លែនោះ ដែលវាពណ៌នាពីកិច្ចការសុចរិតដែលយើងគួរធ្វើ ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សឲ្យពន្យល់ពីអ្វីដែលពួកគេបានសរសេរ ដោយសួរ ៖

- តើអ្នកគិតថា ហេតុអ្វីវាសំខាន់សម្រាប់យើង ដើម្បីបង្កើតជាជលផ្លែ ?
- តើអ្នកធ្លាប់បានប្រទានឲ្យតាមរបៀបណាដែរ នៅពេលអ្នកបានព្យាយាមនាំមកនូវផ្លែមួយនៃជលផ្លែនៃសេចក្តីសុចរិតទាំងនេះឬទេ ?

សូមសង្ខេប ម៉ាថាយ ២១:៤៥–៤៦ ដោយពន្យល់ថា ពួកសង្គ្រាជ និង ពួកផារិស៊ីបានខឹងសម្បារ នៅពេលពួកគេបានដឹងថា ពួកអ្នកធ្វើចម្ការទុច្ចរិតនៅក្នុងរឿងប្រៀបប្រដូចនោះតំណាងឲ្យពួកគេ ។ ប៉ុន្តែ ពួកគេបានទប់ចិត្តពីការលើកដៃទាស់នឹងព្រះអង្គសង្គ្រោះដោយសារពួកគេខ្លាចមានប្រតិកម្មពីប្រជាជន ប្រសិនបើពួកគេធ្វើដូច្នោះ ។

សូមពន្យល់ថា នៅក្នុង ម៉ាថាយ ២២:១–១០ យើងអានថា ព្រះយេស៊ូវគ្រីស្ទបាននិទានរឿងប្រៀបប្រដូចមួយ ដែលទ្រង់បានប្រៀបធៀបពរជ័យនៃដំណឹងល្អ ទៅនឹងពិធីជប់លៀងមង្គលការដែលស្តេចមួយអង្គប្រទានឲ្យបុត្រាទ្រង់ ។ មនុស្សដែលបានអញ្ជើញដំបូងគេទៅពិធីជប់លៀងនោះ (ជាតំណាងឲ្យពួកសាសន៍យូដា រួមទាំងពួកអ្នកដឹកនាំសាសន៍នោះដែរ) បានបដិសេធមិនចូលរួម ។ មនុស្សបន្ទាប់ទៀតដែលបានអញ្ជើញឲ្យចូលរួម (តំណាងឲ្យពួកសាសន៍ដទៃ) បានជ្រើសរើសមកចូលរួម ហើយបានបរិភោគអាហារនៅក្នុងពិធីជប់លៀងនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:១១–១៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើងនៅឯពិធីជប់លៀងមង្គលការនោះ ។

- ហេតុអ្វីក៏ភ្ញៀវម្នាក់នេះ ត្រូវបណ្តេញចេញពីពិធីជប់លៀងនោះដូច្នេះ ?

សូមពន្យល់ថា ស្តេចអង្គនោះបានបំពេញតាមប្រពៃណីពីបុរាណមួយ ដោយឲ្យពួកភ្ញៀវរបស់ទ្រង់នូវសំលៀកបំពាក់ស្អាតសមរម្យ ដើម្បីពាក់ចូលរួមក្នុងពិធីមង្គលការ ។ ប៉ុន្តែបុរសនេះមិនព្រមពាក់សំលៀកបំពាក់ដែលស្តេចបានប្រទានឲ្យទេ ។

- នៅក្នុងរឿងប្រៀបប្រដូចនេះ តើសំលៀកបំពាក់មង្គលការអាចតំណាងឲ្យអ្វីទៅ ? (អ្នកគួរពន្យល់ថា នៅក្នុងព្រះគម្ពីរសំលៀកបំពាក់ស្អាត និងអាវជាយ ជារឿយៗតំណាងឲ្យសេចក្តីសុចរិត និងបរិសុទ្ធភាពនៃជនដែលបានជ្រះស្អាតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ | សូមមើល *New Testament Student Manual* (Church Educational System manual ឆ្នាំ ២០១៤) ទំព័រ ៦៦, សូមមើលផងដែរ នីហ្វៃទី ៣ ២៧:១៩ |) ។

ចូរចង្អុលបង្ហាញ ការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ ម៉ាថាយ ២២:១៤ បន្ថែមថា ពុំមែនមនុស្សគ្រប់គ្នានៅឯពិធីជប់លៀងនឹងពាក់សំលៀកបំពាក់មង្គលការទាំងអស់គ្នានោះទេ) ។ និយាយម្យ៉ាងទៀត គឺពុំមែនមនុស្សគ្រប់រូបដែលទទួលស្គាល់ព្រះអង្គសង្គ្រោះត្រូវបានហៅ ហើយទទួលយកការអញ្ជើញឲ្យធ្វើជាផ្នែកមួយនៃនន្តគរនោះនឹងបានត្រៀមខ្លួន ហើយមានភាពសក្តិសម ដើម្បីរស់នៅដោយអស់កល្បជាមួយនឹងទ្រង់ និងព្រះវរបិតាសួគ៌នោះទេ ។ មនុស្សខ្លះនឹងបាត់បង់សិទ្ធិពរជ័យដ៏ច្រើន ដោយសារពួកគេមិនបានស្លៀកពាក់សំលៀកបំពាក់នៃសេចក្តីសុចរិតនោះ ។

- តើរឿងប្រៀបប្រដូចនេះ បង្ហាញបន្ថែមទៀតពីគោលការណ៍ដែលបានសរសេរនៅលើក្តារខៀនដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ពីសារៈសំខាន់នៃពរជ័យដ៏នៅអស់កល្បជានិច្ច ដែលយើងបានអញ្ជើញឲ្យទទួលយក ។ ចូរឲ្យសិស្សសញ្ជឹងគិតពីអ្វីដែលពួកគេកំពុងធ្វើ ដើម្បីទទួលយកការអញ្ជើញរបស់ព្រះវរបិតាសួគ៌ឲ្យទទួលយករាល់ពរជ័យនៃដំណឹងល្អ ។ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តអ្វី ដែលពួកគេបានរៀនដោយត្រៀមខ្លួនទទួលយកពរជ័យទាំងនោះ ។

ការចែកចាយគំនិត អារម្មណ៍ និងបទពិសោធន៍នានា

ការចែកចាយគំនិត និងបទពិសោធន៍ដែលទាក់ទងអាចជួយដល់សិស្សយល់កាន់តែច្បាស់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ។ នៅពេលសិស្សចែកចាយបទពិសោធន៍ទាំងឡាយរបស់ពួកគេ ជាញឹកញាប់ព្រះវិញ្ញាណបរិសុទ្ធដឹកនាំពួកគេឲ្យយល់កាន់តែជ្រៅជ្រះ ហើយមានទីបន្ទាល់អំពីគំនិតទាំងឡាយដែលពួកគេកំពុងចែកចាយនោះ ។ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះគំនិត និងអារម្មណ៍ និងបទពិសោធន៍ទាំងឡាយដែលសិស្សចែកចាយ ក៏អាចមានឥទ្ធិពលដ៏សំខាន់ទៅលើជួងចិត្ត និងគំនិតរបស់សិស្សផ្សេងទៀតផងដែរ ។

ម៉ាថាយ ២២:១៥–៤៦

សេចក្តីផ្តើម

កាលព្រះយេស៊ូវបានបន្តបង្រៀននៅឯព្រះវិហារបរិសុទ្ធ នោះពួកផារិស៊ី និងពួកសាឌូស៊ីបានព្យាយាមប្រើល្បិចបញ្ឆោតទ្រង់ដោយទូលសួរសំណួរពិបាកៗដល់ទ្រង់ ។ ទ្រង់បានឆ្លើយតបសំណួរពួកគេយ៉ាងជោគជ័យ ហើយបានបង្រៀនពួកគេឲ្យគោរពដល់ច្បាប់ដែនដី និងច្បាប់បញ្ញត្តិធំពីរ ។

ចូរដឹកនាំសិស្សតាមរយៈជំណើរការរៀនសូត្រ

សូមជួយសិស្សឲ្យមានការយល់ដឹង និងក្រេបជញ្ជក់រសជាតិគោលការណ៍នៃជំណឿឯកាន់តែប្រសើរឡើងដោយដឹកនាំពួកគេតាមរយៈជំណើរការរៀនសូត្រ ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកបទគម្ពីរដើម្បីយល់ដឹង ហើយជួយពួកគេឲ្យរកឃើញនូវសេចក្តីពិតនៃជំណឿឯសម្រាប់ខ្លួនឯង ។ ក៏សូមផ្តល់ឱកាសឲ្យសិស្ស ដើម្បីពន្យល់ពីជំណឿឯរបស់គេ និងដើម្បីចែកចាយ និងធ្វើទីបន្ទាល់ពីអ្វី ដែលពួកគេដឹង និងទទួលអារម្មណ៍ ។ ការណ៍នេះនឹងជួយឲ្យសិស្សមិនគ្រាន់តែយល់ដឹងពីជំណឿឯល្អប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ទទួលអារម្មណ៍ពីសេចក្តីពិតដ៏ពេញលេញរបស់វានៅក្នុងជួងចិត្តរបស់ពួកគេផងដែរ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២២:១៥–២២

ពួកផារិស៊ីព្យាយាមប្រើល្បិតបញ្ឆោតព្រះអង្គសង្គ្រោះដោយទូលសួរទ្រង់ថា តើមានច្បាប់នឹងបង់ពន្ធឬទេ

- តើច្បាប់សំខាន់ៗមួយចំនួនដែលរដ្ឋាភិបាលបានបង្កើត នៅក្នុងសង្គមរបស់យើងមានអ្វីខ្លះ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់អ្វីម្ល៉ះ ?

ចូរសុំឲ្យសិស្សពិចារណាដោយស្ងៀមស្ងាត់ ប្រសិនបើមានច្បាប់ណាមួយដែលពួកគេគួរតែគោរពតាម ប៉ុន្តែពួកគេមិនបានធ្វើ ។ កាលសិស្សសិក្សា ម៉ាថាយ ២២:១៥–២២សូមអញ្ជើញពួកគេឲ្យរកមើលអ្វី ដែលព្រះយេស៊ូវបានបង្រៀនអំពីការគោរពតាមច្បាប់ដែនដី ។

ចូររំឭកសិស្សថា នៅសប្តាហ៍ចុងក្រោយនៃព្រះជន្មរបស់ព្រះអង្គសង្គ្រោះ ទ្រង់បានបង្រៀនជារៀងរាល់ថ្ងៃក្នុងព្រះវិហារបរិសុទ្ធនៅក្រុងយេរូសាឡិម (សូមមើល លូកា ១៩:៤៧, ២២:៥៣) ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:១៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលពួកផារិស៊ីបានព្យាយាមធ្វើចំពោះព្រះអង្គសង្គ្រោះ ។

- តើឃ្លា « ចាប់ទ្រង់ដោយនូវព្រះបន្ទូល » មានន័យយ៉ាងណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:១៦–១៧ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលពួកផារិស៊ីព្យាយាមប្រើកលល្បិចដាក់ព្រះអង្គសង្គ្រោះ ។ សូមពន្យល់ថា ពាក្យ *ពន្ធ* នៅក្នុង ខទី ១៧ មានន័យថា ពន្ធអាករ ហើយដែលសេសារ ជាស្តេចអាណាចក្រ៉ូម ដែលគ្រប់គ្រងអ៊ីស្រាអែលនៅគ្រានោះ ។

- តើសំណួរដែលពួកគេបានទូលសួរព្រះយេស៊ូវគ្រីស្ទជាអន្ទាក់យ៉ាងដូចម្តេច ? (ប្រសិនបើព្រះអង្គសង្គ្រោះមានបន្ទូលថា វាគឺជារឿងត្រឹមត្រូវដើម្បីបង់ពន្ធដល់អាណាចក្រ៉ូម នោះពួកសាសន៍យូដានឹងគិតថា ទ្រង់ជាអ្នកគាំទ្រពួករ៉ូម ហើយមិនស្មោះត្រង់ចំពោះរាស្ត្ររបស់ទ្រង់ ។ ប្រសិនបើព្រះអង្គសង្គ្រោះមានបន្ទូលប្រាប់ពួកគេថា វាមិនត្រូវនឹងច្បាប់ទេ ដើម្បីបង់ពន្ធ នោះពួកផារិស៊ីអាចចោទប្រកាន់ព្រះយេស៊ូវថាជាជនក្បត់ជាតិ ហើយរាយការណ៍ប្រាប់មន្ត្រីរ៉ូមអំពីទ្រង់) ។

សូមអញ្ជើញសិស្សម្នាក់អានម៉ាថាយ ២២:១៨–២១ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀប ដែលព្រះអង្គសង្គ្រោះបានឆ្លើយតបទៅកាន់ពួកផារិស៊ី ។ សូមពន្យល់ថា ឃ្លា « ដូច្នេះ ចូរថ្វាយរបស់សេសារ ទៅសេសារទៅ » នៅក្នុង ខទី ២១ សំដៅទៅលើកាតព្វកិច្ចរបស់យើងដើម្បីគោរពតាមច្បាប់រដ្ឋ ដូចជាច្បាប់បង់ពន្ធ ។ ចូរលើកកាក់មួយឡើង ហើយសួរ ៖

- ហេតុអ្វីចម្លើយរបស់ព្រះអង្គសង្គ្រោះ គឺជាការឆ្លើយតបមួយដ៏ល្អឥតខ្ចោះចំពោះសំណួររបស់ពួកផារិស៊ី ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះថា យើងគួរដូច្នេះ « ចូរថ្វាយរបស់សេសារ ទៅសេសារទៅ » ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់រំពឹងឲ្យយើងធ្វើជាពលរដ្ឋល្អ ហើយគោរពតាមច្បាប់ដែនដី** [សូមមើលផងដែរ មាត្រានៃសេចក្តីជំនឿ ១:១២]) ។
- ហេតុអ្វីអ្នកគិតថា វាគឺជារឿងដ៏សំខាន់ចំពោះយើង ក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើជាពលរដ្ឋល្អ ហើយគោរពតាមច្បាប់ដែនដី ? (សូមមើល គ. និង ស. ៥៨:២១) ។

សូមអញ្ជើញសិស្សឲ្យអានម៉ាថាយ ២២:២២ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបដែលពួកផារិស៊ីបានមានប្រតិកម្មបែបណាចំពោះចម្លើយតបរបស់ព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សរាយការណ៍ពី អ្វីដែលពួកគេរកឃើញ ។

ម៉ាថាយ ២២:២៣–៣៤

ព្រះអង្គសង្គ្រោះបង្រៀនដល់ពួកសាឌូស៊ីអំពីអាពាហ៍ពិពាហ៍ និងការរស់ឡើងវិញ

សូមពន្យល់ថា ដោយបន្ថែមពីលើពួកផារិស៊ី នោះពួកសាឌូស៊ីក៏បានព្យាយាមប្រើល្បិចចាប់កំហុសព្រះបន្ទូលរបស់ទ្រង់ កាលទ្រង់បានបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ ។ ដើម្បីជួយសិស្សឲ្យយល់ដឹងពីជំនឿរបស់ពួកសាឌូស៊ី សូមអញ្ជើញពួកគេអានអត្ថន័យពាក្យ « សាឌូស៊ី » នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។ ចូរសុំឲ្យសិស្សរកមើលអ្វីដែលពួកសាឌូស៊ីជឿ និងមិនជឿ ។

- តើជំនឿអ្វីដែលពួកសាឌូស៊ីបានបដិសេធ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:២៣–២៨ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀប ដែលពួកសាឌូស៊ីបានព្យាយាមប្រើកលល្បិចដាក់ព្រះអង្គសង្គ្រោះ ។

- តើអ្នកនឹងសង្ខេបសំណួរ ដែលពួកសាឌូស៊ីបានទូលសួរដល់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?

សូមពន្យល់ថា ពួកសាឌូស៊ីមានចេតនាអនុវត្តផ្អុយពីទំនៀមទំលាប់នៃព្រះគម្ពីរសញ្ញាចាស់ដែលត្រូវបានរៀបចំឡើង ដើម្បីផ្តល់ផ្តង់ដល់ស្ត្រីមេម៉ាយ (សូមមើល ចោទិយកថា ២៥:៥–៦ Bible Dictionary, « Levirate marriage ») ។ ពួកគេបានប៉ុនប៉ងបំផ្លើសទំនៀមទម្លាប់នេះ ដើម្បីបង្ខូចគោលលទ្ធិនៃការរស់ឡើងវិញ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:២៩–៣០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើល ចម្លើយតបរបស់ព្រះអង្គសង្គ្រោះទៅនឹងសំណួររបស់ពួកសាឌូស៊ី ។

- តើព្រះអង្គសង្គ្រោះបានឆ្លើយតបទៅនឹងសំណួរនោះយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សឲ្យយល់ការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការដូចខាងក្រោម ដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនម៉ី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« [ព្រះយេស៊ូវគ្រីស្ទ] ពុំបាន *បដិសេធ* ទេប៉ុន្តែ *បានកំណត់* គំនិតទូទៅថា នឹងមានការរៀបការយកគ្នាជាប្តីប្រពន្ធនៅឯស្ថានសួគ៌ ។ ទ្រង់កំពុងតែមានបន្ទូលថា បើតាមទស្សនៈរបស់ ‹ ពួកគេ › (ពួកសាឌូស៊ី) បើតាមទស្សនៈរបស់ ‹ ពួកគេ › (‹ កូនចៅនៃលោកិយនេះ ›) នោះក្រុមគ្រួសារមិន ហើយនឹងមិនបន្តនៅក្នុងការរស់ឡើងវិញឡើយ ។ . . .

« ‹ ហេតុដូច្នេះហើយ កាលណាពួកគេ [អស់អ្នកដែលនឹងមិន មិន ឬមិនអាចរស់នៅតាមក្រឹត្យវិន័យនៃអាថាហ៍ពិថាហ៍ដ៏នៅអស់កល្បជានិច្ច] ចាកចេញពីលោកិយទៅ នោះពួកគេពុំមែនរៀបការយកគ្នាជាប្តីប្រពន្ធទៀតទេ › [គ. និង ស. ១៣២:១៦] ។

« នោះគឺសម្រាប់ជនដែលមិនជឿលើការរស់ឡើងវិញ នោះនឹងគ្មានការរៀបការយកគ្នាជាប្តីប្រពន្ធនៅឯស្ថានសួគ៌ចំពោះជន ដែលព្រះយេស៊ូវបានមានបន្ទូល គឺសូម្បីតែរាល់សេចក្តីពិតនៃការសង្គ្រោះផ្សេងទៀតក៏ដោយ » (*Doctrinal New Testament Commentary* រំលែទី ៣ [ឆ្នាំ ១៩៦៥–៧៣] ១:៦០៦) ។

ដើម្បីជួយសិស្សឲ្យយល់ដឹងបន្ថែមទៀត ពីសារលិខិតរបស់ព្រះអង្គសង្គ្រោះ នៅក្នុង ម៉ាថាយ ២២:២៩–៣០សូមពន្យល់ថា ព្រះអម្ចាស់បានបើកសម្តែងសេចក្តីពិតដ៏សំខាន់ជាច្រើន ស្តីពីអាថាហ៍ពិថាហ៍ដ៏នៅអស់កល្បជានិច្ចដល់ព្យាការីយ៉ូសែប ស៊្មីធ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:១៥–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអម្ចាស់បានបើកសម្តែងដល់ យ៉ូសែប ស៊្មីធ ស្តីពីអាថាហ៍ពិថាហ៍ ។

- តើព្រះអម្ចាស់បានមានបន្ទូលថាជនណាទៅដែលនឹងគ្មាន « ការរៀបការយកគ្នាជាប្តីប្រពន្ធ » (ខទី ១៦) នៅក្នុងការរស់ឡើងវិញ ?
- តើសេចក្តីពិតអ្វីខ្លះដែលព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុង ម៉ាថាយ ២២:៣០ និង គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:១៥–១៧ អំពីអាថាហ៍ពិថាហ៍ និងជីវិតក្រោយពីជីវិតនេះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ជនដែលពុំបានផ្សារភ្ជាប់នឹងស្វាមី ឬភរិយារបស់ខ្លួនដោយសិទ្ធិអំណាចនៃបព្វជិតភាពនោះទេ នៅក្នុងជីវិតរមែងស្លាប់ ឬតាមរយៈពិធីបរិសុទ្ធជំនួសក្នុងព្រះវិហារបរិសុទ្ធ នោះពួកគេនឹងពុំបានរៀបអាថាហ៍ពិថាហ៍នៅក្នុងជីវិតខាងមុខឡើយ**)

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ២២:៣១–៣៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីទៅជាសេចក្តីពិតផ្សេងទៀត ដែលព្រះអង្គសង្គ្រោះបានបង្រៀនពួកសាឌូស៊ីអំពីការរស់ឡើងវិញ ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលអ្វីខ្លះនៅក្នុង ខទី ៣២ ដែលចង្អុលបង្ហាញថា ការរស់ឡើងវិញគឺជារឿងពិត ?
- តើមនុស្សឆ្លើយតបយ៉ាងដូចម្តេច កាលពួកគេស្តាប់ឮព្រះអង្គសង្គ្រោះបង្រៀនគោលលទ្ធិទាំងនេះ ?

ម៉ាថាយ ២២:៣៤–៤០

ព្រះអង្គសង្គ្រោះបង្រៀនអំពីព្រះបញ្ញត្តិធំពីរ

សូមអញ្ជើញសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវព្រះបញ្ញត្តិឲ្យបានច្រើនតាមដែលអាចធ្វើបានក្នុងរយៈពេលមួយនាទី ។ ចូរសុំឲ្យសិស្សប្រាប់ពីចំនួនព្រះបញ្ញត្តិ ដែលពួកគេបានសរសេរ ។

សូមពន្យល់ថា សាសនាយូដាបង្រៀនថា ក្រឹត្យវិន័យរបស់ម៉ូសេមាន ៦១៣ ព្រះបញ្ញត្តិ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:៣៥–៣៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសំណួរ ដែលពួកផារិស៊ីម្នាក់បានទូលសួរព្រះអង្គសង្គ្រោះទាក់ទងនឹងព្រះបញ្ញត្តិទាំងនេះ ។

- តើសំណួរអ្វីទៅដែលពួកផារិស៊ីបានទូលសួរដល់ព្រះអង្គសង្គ្រោះ ?

ពីមុនសិស្សមើលទៅចម្លើយរបស់ព្រះអង្គសង្គ្រោះ សូមអញ្ជើញពួកគេឲ្យគូសរង្វង់លើព្រះបញ្ញត្តិមួយនៅក្នុងបញ្ជីរបស់ពួកគេ ដែលពួកគេគិតថាជាព្រះបញ្ញត្តិ « ដ៏ធំ » ឬសំខាន់បំផុត ។ ចូរសុំឲ្យសិស្សពីរបីនាក់ប្រាប់ថាតើព្រះបញ្ញត្តិមួយណា ដែលពួកគេបានគូសរង្វង់ ហើយពន្យល់ពីហេតុផលដែលពួកគេជ្រើសវា ។

ម៉ាថាយ ២២:៣៦–៣៩ គឺជាវគ្គ ចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរនឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថាសិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:៣៧–៤០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអង្គសង្គ្រោះបានឆ្លើយតបនឹងសំណួររបស់ពួកផារិស៊ី ។

- តើព្រះបញ្ញត្តិធំជាងគេបំផុតគឺជាអ្វីទៅ ? តើព្រះបញ្ញត្តិធំជាងគេបំផុតទីពីរគឺជាអ្វីទៅ ? (សូមពន្យល់ថា ព្រះបញ្ញត្តិទាំងពីរនេះមាននៅក្នុងក្រឹត្យវិន័យរបស់ម៉ូសេ | សូមមើល ចោទិយកថា ៦:៥, លេវីវិន័យ ១៩:១៨ | ។ ក៏សូមពន្យល់ផងដែរថា ការណែនាំរបស់ព្រះអង្គសង្គ្រោះឲ្យ « ស្រឡាញ់អ្នកជិតខាង » សំដៅទៅលើរបៀបដែលយើងប្រព្រឹត្តចំពោះមនុស្សដទៃទៀត) ។
- ហេតុអ្វីអ្នកគិតថាព្រះបញ្ញត្តិទាំងនេះចាត់ទុកថា ជាព្រះបញ្ញត្តិធំជាងគេបំផុត ?
- តើឃ្លា « បណ្តាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សំរេចនៅបទបញ្ញត្តទាំង ២ ប្រការនេះឯង » តើនៅក្នុង ខទី ៤០ មានន័យដូចម្តេច ? (សូមជួយសិស្សឲ្យយល់ដឹងថា រាល់ព្រះបញ្ញត្តិដែលបានបើកសម្តែងនៅក្នុងក្រឹត្យវិន័យរបស់ម៉ូសេ ហើយតាមរយៈព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ត្រូវបានបង្កើតឡើងដើម្បីជួយមនុស្សឲ្យបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះ និងចំពោះអ្នកជិតខាងរបស់ពួកគេ) ។
- ប្រសិនបើរាល់ព្រះបញ្ញត្តិត្រូវបានបង្កើតឡើង ដើម្បីជួយយើងឲ្យគោរពតាមព្រះបញ្ញត្តិធំទាំងពីរនេះ តើយើងអាចរៀនគោលការណ៍អ្វីខ្លះពី ខទី ៤០ អំពីសារៈសំខាន់នៃការគោរពតាមទង្វាយរាល់ព្រះបញ្ញត្តិរបស់ព្រះ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងពិតជាស្រឡាញ់ព្រះពិត ហើយស្រឡាញ់អ្នកជិតខាងដូចជាខ្លួនយើង នោះយើងនឹងខំព្យាយាមគោរពតាមបញ្ញត្តិទាំងអស់របស់ព្រះ**) ។

ដើម្បីបង្ហាញពីគោលការណ៍នេះ សូមអញ្ជើញសិស្សឲ្យមើលបញ្ជីនៃព្រះបញ្ញត្តិដែលពួកគេបានបង្កើតនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ចូរសុំឲ្យពួកគេគូសផ្តាយមួយនៅក្បែរព្រះបញ្ញត្តិ ដែលបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះ និងគូសប្រអប់បួនជ្រុងនៅក្បែរព្រះបញ្ញត្តិទាំងនោះដែលបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកជិតខាងយើង ។ (ព្រះបញ្ញត្តិមួយចំនួនអាចដាក់ទាំងផ្តាយ និងប្រអប់បួនជ្រុង) ។ ចូរសុំឲ្យសិស្សជ្រើសយកព្រះបញ្ញត្តិមួយ ក្នុងបញ្ជីរបស់ពួកគេ ហើយពន្យល់ថាតើការគោរពតាមព្រះបញ្ញត្តិនោះអនុញ្ញាតឲ្យយើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះ ចំពោះអ្នកជិតខាង ឬទាំងពីរបានដោយរបៀបណា ។

- តើអ្នកធ្លាប់មានអារម្មណ៍យ៉ាងណាដែរ កាលអ្នកបានជ្រើសគោរពតាមព្រះបញ្ញត្តិដាក់លាក់មួយ ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះ ឬចំពោះមនុស្សម្នាក់ទៀត ?

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍នោះថា ប្រសិនបើយើងពិតជាស្រឡាញ់ព្រះនិងអ្នកជិតខាងដូចជាខ្លួនឯងមែន នោះយើងនឹងគោរពតាមនៅរាល់ព្រះបញ្ញត្តិរបស់ព្រះ ។ សូមអញ្ជើញសិស្សឲ្យគិតពីព្រះបញ្ញត្តិមួយ ដែលពួកគេអាចគោរពតាមកាន់តែស្មោះត្រង់ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះព្រះវរបិតាសួគ៌ ឬចំពោះមនុស្សម្នាក់ទៀត ហើយលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅដើម្បីធ្វើដូច្នោះ ។ សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅនេះ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

ម៉ាថាយ ២២:៤១–៤៦

ព្រះអង្គសង្គ្រោះសួរពួកផារិស៊ី តើពួកគេគិតដូចម្តេចអំពីព្រះយេស៊ូវ

សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានឆ្លើយតបដោយជោគជ័យ ចំពោះសំណួររបស់ពួកផារិស៊ី និងពួកសាឌូស៊ីមក នោះទ្រង់បានសួរពួកផារិស៊ីនូវសំណួរមួយចំនួន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២២:៤១–៤២ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានសួរទៅពួកផារិស៊ី ។

- តើព្រះយេស៊ូវគ្រីស្ទបានសួរសំណួរអ្វីទៅពួកផារិស៊ី ?
- តើពួកផារិស៊ីបានឆ្លើយតបយ៉ាងដូចម្តេច ?

សូមពន្យល់ថា ពួកយូដាភាគច្រើនបានស្គាល់ថា ព្រះគ្រីស្ទ ឬព្រះមែស៊ីជាពូជពង្សនៃហ្លួងដាវីដ ។ ពួកផារិស៊ីបានជឿថាព្រះមែស៊ីនឹងក្លាយជាស្តេចនៃអ៊ីស្រាអែលដែលត្រូវបានអភិសេក ហើយជួយពួកគេមានជ័យជំនះលើសត្រូវបរទេស (ដូចជាពួករ៉ូម) ហើយទទួលបានសេរីភាពរបស់ពួកគេ ដូចជាស្តេចដាវីឌបានធ្វើកាលពីមុន ។ សូមសង្ខេប ម៉ាថាយ ២២:៤៣–៤៦ ដោយពន្យល់ថា ព្រះយេស៊ូវបានបង្រៀនពួកផារិស៊ីថា យោងតាមព្រះគម្ពីររបស់ពួកគេ ព្រះគ្រីស្ទគឺ *ជាជាងតែកូន* បុត្ររបស់ដាវីឌទៅទៀត—ទ្រង់ក៏ជាព្រះបុត្រានៃព្រះផងដែរ ។ ឬដូចដែលក្រោយមកទៀតបានបើកសម្តែងទៅកាន់ យ៉ូហាន បាទីស្ទ ថា ព្រះគ្រីស្ទគឺជា « ជាឫស ហើយជាពូជហ្លួងដាវីឌ » (វិវរណៈ ២២:១៦) ទ្រង់គឺជាព្រះអម្ចាស់របស់ដាវីដ និងជាពូជពង្សរបស់ទ្រង់ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលពួកគេនឹងឆ្លើយសំណួរថា « តើអ្នករាល់គ្នាគិតយ៉ាងណាដែរពីព្រះគ្រីស្ទ ? » សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះអង្គសង្គ្រោះ ។

ចំណេះចំណានខគម្ពីរ—ម៉ាថាយ ២២:៣៦–៣៩

ចូរផ្តល់ពេលឲ្យសិស្សសរសេរពាក្យសម្តីដកស្រង់ចេញមកពី ម៉ាថាយ ២២:៣៦–៣៩ នៅលើប័ណ្ណកត់ចំណាំ ឬក្រដាសតូចមួយ ។ សូមអញ្ជើញសិស្សឲ្យដាក់ប័ណ្ណរបស់ពួកគេតាមខ្លួន ហើយមើលវាម្តងម្កាល ពេញមួយថ្ងៃដើម្បីជួយពួកគេចងចាំនៅក្នុងគោរពតាមព្រះបញ្ញត្តិទីមួយ និងទីពីរ ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ១៨:១–២២:២៦ (មេរៀនទី ៥)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ១៨:១–២២:២៦ (មេរៀនទី ៥) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាថាយ ១៨–២០)

នៅក្នុងរឿងប្រៀបប្រដូចស្តីពីអ្នកបម្រើដែលគ្មានក្តីមេត្តា សិស្សបានរៀនថា ប្រសិនបើយើងចង់ឲ្យព្រះអភ័យទោសដល់យើង នោះយើងត្រូវមានឆន្ទៈអភ័យទោសឲ្យអ្នកដទៃជាមុនសិន ។ ពួកគេក៏បានរៀនផងដែរពីបរិសុទ្ធភាពនៃអាពាហ៍ពិពាហ៍ ។

ថ្ងៃទី ២ (ម៉ាថាយ ២១:១–១៦)

នៅពេលសិស្សបានសិក្សាពីការយាងចូលក្នុងទីក្រុងយេរូសាឡិមដ៏ជោគជ័យរបស់ព្រះអម្ចាស់ ពួកគេបានរៀនថា នៅពេលយើងទទួលស្គាល់ ហើយនិយាយជាសាធារណៈអំពីព្រះយេស៊ូវគ្រីស្ទ យើងអាចជួយអ្នកដទៃឲ្យអភិវឌ្ឍបំណងប្រាថ្នាមួយចង់ដឹងបន្ថែមទៀតអំពីទ្រង់ ។ នៅក្នុងការសម្អាតព្រះវិហារបរិសុទ្ធរបស់ព្រះអង្គសង្គ្រោះ សិស្សបានរៀនថា ជំណាក់របស់ព្រះអម្ចាស់គឺជាទីកន្លែងដ៏ពិសិដ្ឋមួយ ហើយទ្រង់មានព្រះរាជបំណងចង់ឲ្យយើងមានគាវភាពចំពោះវា ។ ពួកគេក៏បានរៀនផងដែរថា នៅពេលយើងចូលរួមក្នុងព្រះវិហារបរិសុទ្ធ ព្រះអម្ចាស់អាចព្យាបាលយើងបាន ។

ថ្ងៃទី ៣ (ម៉ាថាយ ២១:១៧–២២:១៤)

សិស្សបានសិក្សាពីរបៀបដែលព្រះអង្គសង្គ្រោះបានដាក់បណ្តាសាដល់ដើមល្វាមួយដើម រួចបានប្រើរឿងប្រៀបប្រដូចមួយចំនួនកាលទ្រង់បានបង្រៀននៅឯព្រះវិហារបរិសុទ្ធ ។ ពួកគេបានរៀនថា ដើម្បីចូលក្នុងនគរព្រះបាន យើងត្រូវគោរពតាមព្រះវរបិតាសួគ៌យើង ហើយប្រែចិត្តពីអំពើបាបរបស់យើង ជាជាងគ្រាន់តែនិយាយ ឬធ្វើពុតថាយើងគោរពទ្រង់ ។ សេចក្តីពិតមួយទៀតដែលសិស្សបានរៀនគឺថា ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ យើងមានទំនួលខុសត្រូវ ដើម្បីបង្កើតផលផ្លែនៃសេចក្តីសុចរិត ។

ថ្ងៃទី ៤ (ម៉ាថាយ ២២:១៥–៤៦)

សិស្សបានរៀនថា ព្រះយេស៊ូវបានបន្តសេចក្តីបង្គាប់របស់ទ្រង់នៅឯព្រះវិហារបរិសុទ្ធ ហើយបានបង្រៀនប្រជាជនថា ព្រះអម្ចាស់រំពឹងឲ្យយើងធ្វើជាពលរដ្ឋល្អ ហើយគោរពតាមច្បាប់ទាំងឡាយនៃដែនដី ។ ព្រះអង្គសង្គ្រោះបានបង្រៀនថា ដែលពុំបានផ្សារភ្ជាប់នឹងស្វាមី ឬភរិយារបស់ខ្លួននៅក្នុងជីវិតរមែងស្លាប់ ឬតាមរយៈពិធីបរិសុទ្ធដ៏និរន្តរ ក្នុងព្រះវិហារបរិសុទ្ធដោយសិទ្ធិអំណាចនៃបព្វជិតភាពនោះទេ ពួកគេនឹងពុំបានរៀបអាពាហ៍ពិពាហ៍នៅក្នុងជីវិតខាងមុខឡើយ ។ សិស្សក៏បានរៀនផងដែរថា ប្រសិនបើយើងស្រឡាញ់ព្រះពិត ហើយស្រឡាញ់អ្នកជិតខាងដូចជាខ្លួនយើង នោះយើងនឹងខំព្យាយាមគោរពតាមអាល់បញ្ញត្តិរបស់ព្រះ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់ពី សារៈសំខាន់នៃការធ្វើ និង ការរក្សាសេចក្តីសញ្ញាពិសិដ្ឋជាមួយនឹងព្រះ ។ ពួកគេក៏បានរៀនផងដែរពីសារៈសំខាន់នៃការមានចិត្តរីករាយ នៅពេលអ្នកដទៃត្រូវបានព្រះប្រទានពរឲ្យ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ១៩:២៨–២០:១៦ ។

ព្រះយេស៊ូវបង្រៀនអំពីជីវិតដ៏នៅអស់កល្បជានិច្ច ហើយប្រទានរឿងប្រៀបប្រដូចស្តីពីពួកអ្នកធ្វើការក្នុងចម្ការ

សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកខាងមុខក្តារខៀន ។ សូមប្រាប់សិស្សថា ប្រសិនបើគាត់អាចអាវ៉ាំងបាន ១០ ដង គាត់នឹងទទួលបានរង្វាន់តូចមួយ (ដូចជាស្តុកគ្រាប់ ១០ គ្រាប់) ។ បន្ទាប់ពីសិស្សអាវ៉ាំងបាន ១០ ដងហើយ សូមឲ្យរង្វាន់ដល់គាត់ រួចសួរអ្នកស្មើគ្រូចិត្តម្នាក់ទៀត ។ ចូរសុំឲ្យសិស្សទីពីរអាវ៉ាំងតែ រួចសួរដល់សិស្សក្នុងថ្នាក់តើពួកគេគិតថាសិស្សម្នាក់នេះគួរទទួលបានរង្វាន់អ្វីដែរ និងហេតុអ្វី ។ សូមអញ្ជើញសិស្សទាំងពីរនាក់ឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយវិញ ។ សូមប្រាប់សិស្សក្នុងថ្នាក់ថា នៅពេលក្រោយទៀតក្នុងមេរៀននេះ សិស្សទីពីរនឹងទទួលរង្វាន់មួយអាស្រ័យទៅលើអ្វី ដែលសិស្សរៀននៅក្នុងព្រះគម្ពីរ ។

សូមពន្យល់ថា នៅពេលព្រះយេស៊ូវកំពុងបង្រៀននៅលើឆ្នេរយូដា ពេត្រុសបានទូលសួរពីអ្វីដែលពួកសិស្សនឹងទទួលបាន ដោយសារពួកគេបានលះបង់ទ្រព្យសម្បត្តិខាងលោកិយរបស់ខ្លួនមកដើរតាមទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ១៩:២៨–៣០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅកាន់ពេត្រុស ។

- យោងតាម ខទី ២៩តើមនុស្សគ្រប់គ្នាដែលលះបង់អ្វីទាំងអស់មកដើរតាមព្រះអង្គសង្គ្រោះនឹងគ្រង់អ្វីជាមរតក ?

សូមពន្យល់ថា បន្ទាប់មកព្រះអង្គសង្គ្រោះបានបង្រៀនពួកសិស្សរបស់ទ្រង់នូវរឿងប្រៀបប្រដូចមួយដើម្បីជួយពួកគេឲ្យយល់ពីព្រះរាជបំណងរបស់ព្រះវរបិតាសួគ៌ដើម្បីប្រទានឱកាសទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដល់កូនចៅរបស់ទ្រង់ទាំងអស់គ្នា ។ នៅក្នុងរឿងប្រៀបប្រដូចនេះ មានបុរសម្នាក់បានជួលពួកអ្នកធ្វើការនៅពេលវេលាខុសគ្នាពេញមួយថ្ងៃ ដើម្បីធ្វើការនៅក្នុងចម្ការគាត់ ។ អ្នកគួរពន្យល់ថា ថ្ងៃធ្វើការធម្មតាមួយនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មីគឺប្រហែលពីម៉ោង ៦:០០ ព្រឹករហូតដល់ ៦:០០ យប់ ដោយមានការផ្លាស់ប្តូរបន្តិចបន្តួចតាមរដូវកាលខុសៗគ្នានៃឆ្នាំនោះ ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬ រៀបចំវាជាឯកសារចែកឲ្យសិស្ស ៖

ពួកអ្នកធ្វើការ (ម៉ោងចាប់ផ្តើម)	ប្រាក់បៀវត្សរ៍ដែលបានព្រមព្រៀង	ចំនួនម៉ោងដែលបានធ្វើការ	ចំនួនប្រាក់ដែលត្រូវបង់
ព្រឹកព្រលឹម (៦:០០ ព្រឹក)			
ម៉ោងទី ៣ (៩:០០ ព្រឹក)			
ម៉ោងទី ៦ (១២:០០ ថ្ងៃត្រង់)			
ម៉ោងទី ៩ (៣:០០ រសៀល)			

ពួកអ្នកធ្វើការ (ម៉ោងចាប់ផ្តើម)	ប្រាក់បៀវត្សរ៍ដែលបានព្រមព្រៀង	ចំនួនម៉ោងដែលបានធ្វើការ	ចំនួនប្រាក់ដែលត្រូវបង់
ម៉ោងទី ១១ (៥:00 ល្ងាច)			

សូមអញ្ជើញសិស្សឲ្យធ្វើការជាក្រុមតូចៗ ។ ចូរសុំឲ្យពួកគេអាន ម៉ាថាយ ២០:១–៧ នៅក្នុងក្រុមរបស់ខ្លួន រកមើលរយៈពេលធ្វើការដែលក្រុមនីមួយៗបានធ្វើ និងប្រាក់បៀវត្សរ៍ដែលពួកគេបានព្រមព្រៀង ។ (សូមពន្យល់ថា « ១ កាក់ » សំដៅលើប្រាក់មួយកាក់ ដែលជាប្រាក់មួយកាក់របស់រ៉ូម ហើយវាប្រហាក់ប្រហែលនឹងថ្លៃធ្វើការមួយថ្ងៃសម្រាប់អ្នកធ្វើការម្នាក់) ។

លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សពីរបីនាក់ឡើងមកក្តារខៀន ហើយបំពេញជួរឈរទីមួយក្នុងតារាង (ឬសូមអញ្ជើញពួកគេឲ្យបំពេញវានៅលើសំណៅដែលអ្នកបានផ្តល់ឲ្យ) ។

- តើអ្នកគិតថានរណាទៅដែលគួរទទួលបានកម្រៃច្រើនជាងគេ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២០:៨–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីប្រាក់កម្រៃដែលពួកអ្នកធ្វើការមួយក្រុមៗទទួលបាន ។

- តើប្រាក់កម្រៃអ្វីដែលពួកអ្នកធ្វើការមួយក្រុមៗទទួលបាន ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរ *១ កាក់* នៅក្នុងប្រអប់នីមួយៗក្នុងជួរឈរដែលសរសេរថា « ចំនួនប្រាក់ដែលត្រូវបង់ ») ។
- ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមពួកអ្នកធ្វើការទាំងនោះ ដែលបានធ្វើការពេញមួយថ្ងៃ តើអ្នកមានគំនិត ឬអារម្មណ៍បែបណាដែរ ពេលអ្នកទទួលបានវង្វាន់ដូចគ្នានឹងអ្នកដែលបានធ្វើការតែមួយម៉ោងនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២០:១១–១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាតើជន ដែលបានធ្វើពេញមួយថ្ងៃនិយាយអ្វីខ្លះទៅម្ចាស់ចម្ការ និង អ្វីដែលគាត់បាននិយាយមកពួកគេវិញ ។

- តើអ្វីទៅជាការត្អូញត្អែររបស់ជនដែលបានធ្វើការពេញមួយថ្ងៃ ?
- តើម្ចាស់ចម្ការបាននិយាយតបមកវិញយ៉ាងម៉េចខ្លះ ?
- តើម្ចាស់ចម្ការមានភាពយុត្តិធម៌ (ភាពស្មើគ្នា) ចំពោះជនដែលបានធ្វើការពេញមួយថ្ងៃយ៉ាងដូចម្តេចដែរ ?

ដើម្បីជួយសិស្សឲ្យស្គាល់សេចក្តីពិតមួយនៅក្នុងរឿងប្រៀបប្រដូចនេះសូមពន្យល់ថា ប្រាក់កម្រៃមួយកាក់នោះអាចតំណាងឲ្យជីវិតដ៏នៅអស់កល្បជានិច្ច ដូចដែលបានចែងនៅក្នុង ម៉ាថាយ ១៩:២៩ ។ សូមសរសេរប្រយោគមិនពេញលេញខាងក្រោម នៅលើក្តារខៀន ៖ *ព្រះប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សទាំងអស់ដែល . . .*

- ប្រសិនបើវង្វាន់នៅក្នុងរឿងប្រៀបប្រដូចនេះតំណាងឲ្យជីវិតដ៏នៅអស់កល្បជានិច្ច តើអ្នកធ្វើការតំណាងឲ្យអ្វី ? (សិស្សអាចមានចម្លើយខុសៗគ្នា ប៉ុន្តែត្រូវគូសបញ្ជាក់ថា អ្នកធ្វើការក្នុងរឿងប្រៀបប្រដូចនេះអាចតំណាងឲ្យការធ្វើ និង ការរក្សាសេចក្តីសញ្ញាជំពិសិដ្ឋជាមួយព្រះ ។ (បន្ទាប់ពីសិស្សឆ្លើយ សូមបំពេញសេចក្តីពិតនៅលើក្តារខៀនដូចខាងក្រោមនេះ ៖ **ព្រះប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សគ្រប់រូបដែលជ្រើសរើសធ្វើ ហើយ រក្សាសេចក្តីសញ្ញាជាមួយទ្រង់**) ។

សូមចង្អុលបង្ហាញថា សេចក្តីពិតនេះជួយយើងឲ្យយល់ពីសេចក្តីមេត្តាករុណារបស់ព្រះវរបិតាសួគ៌សម្រាប់បុគ្គលទាំងឡាយ ដែលពុំបានធ្វើ ឬរក្សាសេចក្តីសញ្ញាកាលពីក្មេង និង សម្រាប់ជនដែលគ្មានឱកាសធ្វើកិច្ចការនេះហួតក្រោយពីពួកគេស្លាប់ (សូមមើល គ. និង ស. ១៣៧:៧–៨) ។

- ហេតុអ្វីអ្នកគិតថា ការដឹងថាព្រះប្រទានជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សគ្រប់រូបដែលជ្រើសធ្វើ ហើយរក្សាសេចក្តីសញ្ញាពិសិដ្ឋជាមួយនឹងទ្រង់ ជារឿងសំខាន់សម្រាប់យើង មិនថាវាអាចកើតឡើងនៅពេលណានោះទេ ?

សូមរំឭកសិស្សពីសិស្សទីពីរដែលបានអាវ៉ៃតែម្តង រួចសួរ ៖

- តើអ្នកគិតថាសិស្សម្នាក់នេះគួរទទួលបានវង្វាន់អ្វីទៅសម្រាប់ការធ្វើអាវ៉ៃតែម្តងនោះ? (សូមឲ្យសិស្សនោះនូវវង្វាន់ដូចគ្នា ដែលអ្នកបានឲ្យទៅសិស្សដែលបានអាវ៉ៃ ១០ ដង) ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ២០:១៥–១៦ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាម្ចាស់ចម្ការបានតបទៅកាន់ជនដែលត្អូញត្អែរពីសេចក្តីសប្បុរសរបស់លោកចំពោះពួកអ្នកធ្វើការផ្សេងទៀតយ៉ាងដូចម្តេចដែរ ។

- តើអ្នកគិតថាម្ចាស់ចម្ការចង់មានន័យយ៉ាងដូចម្តេច នៅពេលលោកបានសួរថា « តើភ្នែកអ្នកឃើញអាក្រក់ ពីព្រោះខ្ញុំល្អឬអី ? » (ខទី ១៥) ។

សូមពន្យល់ថា អែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បកស្រាយសំណួរនេះដូចខាងក្រោម ៖ « ហេតុអ្វីបានជា *អ្នក* មានចិត្តច្រណែនដោយសារ *យើង* ជ្រើសរើសដើម្បីមានចិត្តល្អ ? » (« The Laborers in the Vineyard » *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ២០១២ ទំព័រ ៣១) ។

- តើឃ្លាថា « បានហៅមនុស្សជាច្រើន តែពីរសបានតិចទេ » ដែលចែងក្នុងខទី ១៦ មានន័យដូចម្តេច ? (ការបាន *ហៅ* មានន័យថា ការអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចការរបស់ព្រះវរបិតាសួគ៌ ។ ការ *រើស* មានន័យថាការទទួលបានពរជ័យរបស់ទ្រង់—រួមបញ្ចូលទាំងពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមមើលផងដែរ គ. និង ស. ១២១:៣៤–៤០) ។
- តើគោលការណ៍អ្វីខ្លះដែលយើងរៀនក្នុង ខទី ១៦ ? (សិស្សអាចនឹងរកឃើញគោលការណ៍ជាច្រើន រួមបញ្ចូលទាំងគោលការណ៍ខាងក្រោមផងដែរ ៖ **ប្រសិនបើយើងជ្រើសមានចិត្តច្រណែនចំពោះពរជ័យរបស់ព្រះវរបិតាសួគ៌ដល់មនុស្សដទៃទៀត នោះយើងប្រហែលជាបាត់បង់ពរជ័យដែលទ្រង់សព្វព្រះទ័យប្រទានឲ្យយើង**) ។

សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ហើយអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីរបៀប ដែលពួកគេអាចល្បងឲ្យច្រណែននឹងពរជ័យដែលព្រះវរបិតាសួគ៌ប្រទានដល់អ្នកដទៃ ៖



« មានពេលខ្លះនៅក្នុងជីវិតរបស់យើង ពេលដែលមាននរណាម្នាក់ទៀតទទួលបានពរជ័យ ដែលនឹកស្មានមិនដល់ ឬទទួលបានការទទួលស្គាល់ជាពិសេសខ្លះ ។ តើខ្ញុំអាចសុំអង្វរយើងកុំឲ្យឈឺចាប់—ហើយកុំឲ្យមានចិត្តច្រណែនបានទេ—នៅពេលសំណាងល្អបានឲ្យទៅអ្នកផ្សេងនោះ ? យើងមិនត្រូវអន់ចិត្តនោះទេ នៅពេលអ្នកផ្សេងត្រូវបានផ្តល់ពរបន្ថែមនោះ ។ យើងពុំមែនរស់នៅក្នុងការប្រកួតគ្នា ដើម្បីមើល ឃើញ ថា តើនរណាគឺជាអ្នកមានជាងគេបំផុត ឬមានទេពកោសល្យជាងគេបំផុត ឬស្អាតជាងគេបំផុតឬក៏មានពរជ័យជាងគេបំផុតនោះទេ ។ ការប្រកួតដែលយើងកំពុងធ្វើនោះ *ភាមពិតទៅ* គឺជាការប្រកួតទាស់នឹងអំពើបាប ។ . . .

« . . . ការមានចិត្តលោភលន់ ការត្អូញត្អែរ ការបំបាក់បំបែកសុភមង្គល របស់គេ *មិន*បានជួយ *អ្នក*ឲ្យឈរខ្ពស់ជាងមុនទេ ឬការធ្វើឲ្យអ្នកដទៃខ្មាស់គេក៏មិនបានធ្វើឲ្យមុខមាត់របស់អ្នកបានល្អប្រសើរដែរ ។ ដូច្នេះសូមមានចិត្តល្អ និងមានអំណរគុណដែលព្រះមានព្រះទ័យល្អ ។ វាជារបៀបមួយសប្បាយក្នុងការរស់នៅ » (« Laborers in the Vineyard » ទំព័រ ៣១, ៣២) ។

សូមចែកចាយទីបន្ទាល់របស់អ្នកពី សេចក្តីពិតដែលសិស្សបានស្គាល់ នៅពេលពួកគេបានសិក្សារឿងប្រៀបប្រដូចស្តីពីពួកអ្នកធ្វើការនៅក្នុងចម្ការ ។

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនេះនៅលើក្តារខៀន ។ សូមទុកពេលឲ្យសិស្សបំពេញសេចក្តីថ្លែងការណ៍នោះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖ *ផ្អែកលើអ្វីដែលខ្ញុំបានរៀននៅក្នុងរឿងប្រៀបប្រដូចនេះ ខ្ញុំនឹង . . .*

លុះដល់ពេលកំណត់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ដែលឥតគ័យបារម្ភឲ្យចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានសរសេរ ។

មេរៀនបន្ទាប់ (ម៉ាថាយ ២៣:១–២៦:៣០)

ដើម្បីជួយរៀបចំសិស្សសម្រាប់មេរៀនបន្ទាប់ សូមអញ្ជើញពួកគេឲ្យពិចារណាថា ពួកគេអាចរៀបចំខ្លួនយ៉ាងណា ឲ្យបានល្អបំផុតសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។ តើសេចក្តីពិតអ្វីខ្លះ ដែលត្រូវបានបង្រៀននៅពេលព្រះយេស៊ូវគ្រីស្ទប្រទានរឿងប្រៀបប្រដូចស្តីពីស្ត្រីព្រហ្មចារីទាំងដប់នាក់ ទេពកោសល្យ និងសត្វចៀម និងសត្វពពែ ? តើពិធីបរិសុទ្ធអ្វីខ្លះ ដែលព្រះអង្គសង្គ្រោះបានបង្កើតដើម្បីជំនួសឲ្យបុណ្យរំលង ? សូមអញ្ជើញសិស្សឲ្យរកមើលបន្ថែមនៅក្នុងការសិក្សានៅសប្តាហ៍ក្រោយ ។

មេរៀន ២៦

ម៉ាថាយ ២៣

សេចក្តីផ្តើម

នៅសប្តាហ៍ចុងក្រោយនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ទ្រង់បានប្តោលទោសដល់ការលាក់ពុតរបស់ពួកអាចារ្យ និងពួកផារិស៊ី ហើយបានទួញសោកដោយសារប្រជាជននៃយេរូសាឡិមមិនបានទទួលយកសេចក្តីស្រឡាញ់ និងការការពាររបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៣:១–១២

ព្រះអង្គសង្គ្រោះប្តោលទោសដល់ការលាក់ពុតរបស់ពួកអាចារ្យ និងពួកផារិស៊ី

សូមអញ្ជើញសិស្សឲ្យបង្ហាញព្រះគម្ពីររបស់ពួកគេដល់គ្នាទៅវិញទៅមក ហើយរកមើលថាតើនរណាមានព្រះគម្ពីរច្រើនជាងគេ ។

- តើអ្នកនឹងឆ្លើយតបបែបណាដែរ ប្រសិនបើមានមនុស្សម្នាក់បានប្រកាសថា បុគ្គលដែលមានព្រះគម្ពីរច្រើនជាងគេ គឺជាមនុស្សសុចរិតជាងគេបំផុតនោះ ?
- ហេតុអ្វីវិធីនេះ គឺជាវិធីមួយដែលគ្មានប្រសិទ្ធភាព ដើម្បីកំណត់ពីភាពសុចរិតរបស់បុគ្គលម្នាក់ ?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងបានកំណត់ភាពសុចរិតរបស់មនុស្សដទៃដោយរូបរាងខាងក្រៅនោះ ? (នៅក្នុងចំណោមបញ្ហាផ្សេងទៀត វាអាចជីកនាំមនុស្សមួយចំនួនឲ្យធ្វើរឿងលាក់ពុត) ។
- តើការលាក់ពុតគឺជាអ្វី ? (« ជាទូទៅពាក្យនេះចង្អុលបង្ហាញពីបុគ្គលម្នាក់ ដែលធ្វើពុតជាអ្នកជឿសាសនា តែតាមពិតពុំមែនទេ » [Bible Dictionary « Hypocrite »] ។ វាក៏អាចសំដៅទៅលើមនុស្សម្នាក់ដែលធ្វើពុតជាមិនជឿលើសាសនា តែតាមពិតគាត់ជឿ) ។

សូមពន្យល់ថា ជាផ្នែកមួយនៃសារលិខិតជាសាធារណៈចុងក្រោយរបស់ព្រះអង្គសង្គ្រោះ បានធ្វើឡើងនៅឯព្រះវិហារបរិសុទ្ធក្នុងក្រុងយេរូសាឡិមនៅសប្តាហ៍ចុងក្រោយនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ នោះទ្រង់ត្រូវបានប្តោលទោសដល់ការលាក់ពុតរបស់ពួកអាចារ្យ និងពួកផារិស៊ី ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅក្នុង ម៉ាថាយ ២៣ ដែលនឹងជួយពួកគេឲ្យដឹងពីរបៀបឆ្លើយតបនៅពេលពួកគេមើលឃើញមនុស្សដទៃមានការលាក់ពុត និងអ្វីដែលពួកគេអាចធ្វើដើម្បីយកឈ្នះការលាក់ពុតនៅក្នុងជីវិតរបស់ពួកគេផ្ទាល់ ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ២៣:១–៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលអំពីរបៀបដែលពួកអាចារ្យ និងពួកផារិស៊ីជាមនុស្សលាក់ពុត ។ សូមពន្យល់ថា ឃ្លា « អង្គុយនៅទីបង្រៀនរបស់លោកម៉ូសេ » (ខទី ២) មានន័យថា ពួកអាចារ្យ និងពួកផារិស៊ីមានតួនាទីជាអ្នកមានសិទ្ធិអំណាចដើម្បីបង្រៀនគោលលទ្ធិ ហើយបកប្រែ ហើយចាត់ចែងច្បាប់ ។ ឃ្លានោះក៏អាចសំដៅទៅលើកៅអីយ៉ាងពិតប្រាកដមួយ ដែលមាននៅក្នុងសាលាប្រជុំពីបុរាណ ដែលបានរក្សាទុកសម្រាប់ជនដែលជឿថាខ្លួនឯងសក្តិសមជាងមនុស្សផ្សេងទៀតនៅក្នុងសាលាប្រជុំ ។

- តើពួកអាចារ្យ និងពួកផារិស៊ីជាមនុស្សលាក់ពុតដោយរបៀបណា ?

ប្រសិនបើមាន សូមដាក់បង្ហាញរូបភាពមនុស្សម្នាក់ពាក់ស្លាកកត់ក្រឹត្យវិន័យ ដែលហៅផងដែរថា*ហឺបព្រះគម្ពីរ* ។ សូមពន្យល់ថា វាគឺជាទំនៀមទំលាប់សម្រាប់ពួកសាសន៍យូដា ដើម្បីពាក់ស្លាកកត់ក្រឹត្យវិន័យដែលជាប្រអប់តូចធ្វើពីស្បែកដែលពាក់ជាប់នឹងថ្ងាស និងដើមដៃ ។ នៅក្នុងស្លាកកត់ក្រឹត្យវិន័យនោះមាននូវខ្លាំស្បែកសម្រាប់សរសេរអក្សរមួយដុំតូចដែលមានពាក្យដកស្រង់ចេញពីបទគម្ពីរហេព្រើរ ។ ពួកសាសន៍យូដាបានពាក់ស្លាកកត់ក្រឹត្យវិន័យនោះដើម្បីជួយពួកគេឲ្យចងចាំក្នុងការធ្វើតាមព្រះបញ្ញត្តិរបស់ព្រះ (សូមមើលចោទិយកថា ៦:៤–៩, ១១:១៣–២១, និក្ខមនំ ១៣:៥–១០, ១៤–១៦) ។ ព្រះអម្ចាស់មិនបានប្តោលទោសជនដែលបានពាក់ស្លាកកត់ក្រឹត្យវិន័យនោះទេ ប៉ុន្តែទ្រង់បានប្តោលទោសដល់ជនដែលប្រើវាដោយលាក់ពុត ឬពង្រីកវាឲ្យធំ ដើម្បីឲ្យមនុស្សដទៃទៀតមើលឃើញវា ឬបង្ហាញខ្លួនសំខាន់ជាង ។



បុរសសាសន៍យូដាម្នាក់ពាក់ស្លាកកត់ក្រឹត្យវិន័យ

- យោងតាម ម៉ាថាយ ២៣:៥ហេតុអ្វីពួកអាចារ្យ និងពួកផារិស៊ីពង្រីកស្លាកកត់ក្រឹត្យវិន័យរបស់ខ្លួន ហើយ « រំយោលអាវគេឲ្យវែងៗ » ?
- តើពួកគេខំ « ធ្វើឲ្យមនុស្សមើលឃើញ » (ខទី ៥) ឬ ទទួលគោរពខាងលោកិយតាមរបៀបណាផ្សេងទៀត ?
- យោងតាមបន្ទូលទូន្មានរបស់ព្រះអម្ចាស់ទៅពួកសិស្សរបស់ទ្រង់នៅក្នុង ម៉ាថាយ ២៣:៣តើយើងអាចធ្វើអ្វីខ្លះ នៅពេលយើងឃើញមនុស្សដទៃមានភាពលាក់ពុត ឬធ្វើពុតជាមនុស្សសុចរិត តែធាតុពិតគឺមិនដូច្នោះនោះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **យើងអាចត្រើសគោរពតាមក្រឹត្យវិន័យរបស់ព្រះ ទោះបីយើងឃើញមនុស្សដទៃមានភាពលាក់ពុតក្តី**) ។
- ហេតុអ្វីសេចក្តីពិតនេះមានសារៈសំខាន់ចំពោះយើង ដើម្បីធ្វើតាមនៅក្នុងជំនាន់របស់យើង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ២៣:៨ ឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទូន្មានប្រជាជនមិនឲ្យធ្វើ ។ សូមឲ្យសិស្សរាយការណ៍ ពីអ្វីដែលពួកគេរកឃើញ ។

ចូរចង្អុលបង្ហាញថា ឃ្លា « អ្នករាល់គ្នាជាបងប្អូននឹងគ្នាទាំងអស់ » (ខទី ៨) ហើយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនប្រជាជនកុំឲ្យជឿថាខ្លួនឯងល្អជាងមនុស្សដទៃ ដោយសារពួកគេទាំងអស់គ្នាជាកូនចៅរបស់ព្រះ ហើយមានភាពស្មើគ្នានៅចំពោះព្រះនេត្រទ្រង់ ។

សូមសង្ខេប ម៉ាថាយ ២៣:៩–១០ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានថ្លែងទីបន្ទាល់ថា ព្រះវរបិតាសួគ៌គឺជាអង្គបង្កបង្កើតរបស់យើង ហើយថាទ្រង់ ព្រះគ្រីស្ទត្រូវបានព្រះវរបិតាបញ្ជូនមក ហើយគឺជាលោកចៅហ្វាយដ៏ពិតរបស់យើងដែលបានលះបង់ព្រះជន្មរបស់យើង (សូមមើលការបកប្រែរបស់ យ៉ូសែប ស៊្មីធ ម៉ាថាយ ២៣:៦ , ម៉ាថាយ ២៣:៧) ។

សូមពន្យល់ថា ពួកអាចារ្យ និងពួកផារិស៊ីបានជឿថាតួនាទី និងឋានៈនឹងធ្វើឲ្យពួកគេក្លាយមនុស្សអស្ចារ្យ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៣:១១–១២ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលថាតើនរណាទៅដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់នឹងជឿថាអស្ចារ្យនៅក្នុងនគរព្រះ ។

- យោងតាម ខទី ១១តើនរណាទៅដែលចាត់ទុកថាធំជាងគេនៅក្នុងនគរព្រះ ?
- យោងតាម ខទី ១២តើនឹងមានអ្វីកើតឡើងប្រសិនបើយើងដូចជាពួកផារិស៊ី ព្យាយាម « ដំកើង » (ឬលើក)ខ្លួនឲ្យខ្ពស់ជាងអ្នកដទៃ ? (បន្ទាប់ពីសិស្សឆ្លើយតប សូមឲ្យប្រាកដថាពួកគេយល់នូវគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងព្យាយាមដំកើងខ្លួនឲ្យខ្ពស់ជាងអ្នកដទៃ នោះយើងនឹងត្រូវបន្ទាបចុះវិញ ។** សូមពន្យល់ថាការ*បន្ទាបចុះវិញ*មានន័យថា ការដាក់ចុះ ឬការបំបាក់មុខ ឬការពុំសូវមានគេឯងគោរព) ។
- យោងតាមខទី ១១–១២តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងបន្ទាបខ្លួន ហើយបម្រើមនុស្សដទៃទៀត ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងបន្ទាបខ្លួន ហើយបម្រើមនុស្សដទៃ នោះព្រះអម្ចាស់នឹងដំកើងយើងឡើង**) ។

សូមពន្យល់ថា ឃ្លា « នឹងបានដំកើងឡើង » (ខទី ១២) មានន័យថា ព្រះអម្ចាស់នឹងលើកយើងឡើង ហើយជួយយើងឲ្យប្រែក្លាយកាន់តែដូចទ្រង់ ។

ផ្អែកតាមអ្វីដែលអ្នកបានរៀននៅក្នុង ម៉ាថាយ ២៣តើការបន្ទាបខ្លួនមានន័យដូចម្តេច ?

ចូរគូរ កម្រិតមាត្រដ្ឋាន ដូចខាងក្រោមនេះនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីកិច្ចការយ៉ាងល្អរបស់ពួកគេនៅឯសាលារៀន នៅផ្ទះនិងនៅព្រះវិហារ ។ ចូរសុំឲ្យពួកគេពិចារណាថាតើពួកគេផ្ទុកខ្លួនត្រង់ណាលើកម្រិតមាត្រដ្ឋាននេះ ដោយផ្អែកលើហេតុផលជម្រុញចិត្តរបស់ពួកគេសម្រាប់ការធ្វើកិច្ចការល្អ និងការខិតខំរបស់ពួកគេដើម្បីមានការបន្ទាបខ្លួន ។



សូមលើកទឹកចិត្តសិស្សឲ្យចងចាំថា យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះវរបិតាសួគ៌ ។ អ្នកក៏អាចលើកទឹកចិត្តពួកគេផងដែរ ឲ្យដាក់គោលដៅមួយដើម្បីបម្រើមនុស្សម្នាក់រាល់ថ្ងៃពេញមួយខែក្រោយ ។ ចូរពិចារណាអញ្ជើញពួកគេឲ្យសរសេរអំពីបទពិសោធន៍នេះនៅក្នុងសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់ពួកគេ ។

ម៉ាថាយ ២៣:១៣–៣៦

ព្រះយេស៊ូវគ្រីស្ទប្រកាសប្រាប់ថាវេទនាហើយ ដល់ពួកអាចារ្យ និងពួកផារិស៊ី

ពីមុនថ្នាក់ចាប់ផ្តើម សូមរៀបចំពែងបីដែលមិនថ្លា ។ សូមប្រឡាក់ភក់ ឬលាបខ្លាញ់នៅផ្នែកខាងក្រៅនៃពែងទីមួយ ហើយលាបផ្នែកខាងក្នុងនៃពែងទីពីរ ហើយទុកឲ្យពែងទីបីនោះទទេរស្អាត ។ ចូរដាក់បង្ហាញពែងទាំងនោះ ហើយសួរដល់សិស្សថាតើពួកគេចង់បានពែងមួយណា ដើម្បីផឹកទឹក ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកពិនិត្យមើលផ្នែកខាងក្នុងពែងទាំងនោះ ហើយពន្យល់ថាតើពែងមួយណាដែលគាត់ចង់បាន ដើម្បីផឹកទឹក ហើយហេតុអ្វី ។

- តើពែងកខ្វក់ទាំងនោះតំណាងឲ្យការលាក់ពុតយ៉ាងដូចម្តេចដែរ ?

សូមសង្ខេប ម៉ាថាយ ២៣:១៣–៣៦ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះប្រកាសថ្កោលទោសដល់ពួកអាចារ្យ និងពួកផារិស៊ីចំពោះការលាក់ពុត ។ សូមអញ្ជើញសិស្សឲ្យមើលខគម្ពីរទាំងនេះ ដោយរកមើលពាក្យមួយដែលព្រះអង្គសង្គ្រោះបានមានបន្ទូលម្តងហើយម្តងទៀតនៅដើមនៃខគម្ពីរទាំងនោះ ។ ចូរសុំពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំពាក្យ *វេទនា* នៅក្នុងខគម្ពីរទាំងនេះ ។ សូមពន្យល់ថា *វេទនា* សំដៅទៅលើទុក្ខវេទនា ការរងទុក្ខលំបាក និងទុក្ខសោក ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរ និង សំណួរខាងក្រោមនៅលើក្តារខៀន ៖

ម៉ាថាយ ២៣:២៣–២៤
ម៉ាថាយ ២៣:២៥–២៦ ។
ម៉ាថាយ ២៣:២៧–២៨ ។
ម៉ាថាយ ២៣:២៩–៣៦
តើពួកអាចារ្យ និងពួកផារិស៊ីជាមនុស្សលាក់ពុតដោយរបៀបណា ?
តើគំរូអ្វីខ្លះនៃការលាក់ពុតបែបនេះដែលយើងឃើញនៅក្នុងជំនាន់របស់យើង ?

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអានសេចក្តីយោងនីមួយៗនៅលើក្តារខៀនឮៗ ហើយពិភាក្សាសំណួរនៅលើក្តារខៀន បន្ទាប់ពួកគេបានអានសេចក្តីយោងនីមួយៗ ។ (Encourage students to read the Joseph Smith Translation excerpts in the footnotes for their assigned passages.)

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សប្រាប់ពីចម្លើយរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៣:២៦ ឲ្យឮៗ ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ទៅពួកផារិស៊ីឲ្យធ្វើដើម្បីយកឈ្នះលើការលាក់ពុត ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ពួកផារិស៊ីឲ្យធ្វើអ្វីខ្លះ ?
- ដោយផ្អែកលើអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកផារិស៊ី តើអ្វីនឹងកើតឡើងចំពោះយើង នៅពេលយើងខិតខំប្រែក្លាយជាមានភាពស្អាតស្អំខាងវិញ្ញាណនៅក្នុងចិត្តនោះ ? (បន្ទាប់ពីសិស្សឆ្លើយតប សូមឲ្យប្រាកដថាពួកគេយល់នូវគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងខិតខំប្រែក្លាយដើម្បីមានភាពស្អាតស្អំខាងវិញ្ញាណនៅក្នុងចិត្ត នោះវានឹងបង្ហាញនៅក្នុងការជ្រើសរើសខាងក្រៅរបស់យើង**) ។
- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីប្រែទៅជាស្អាតស្អំខាងវិញ្ញាណនៅក្នុងចិត្ត ?
- តើសេចក្តីសុចរិតនៅក្នុងចិត្តរបស់យើង អាចបង្ហាញឲ្យឃើញតាមរយៈការជ្រើសរើសរបស់យើងដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា តើពេងមួយណាដែលតំណាងឲ្យល្អបំផុតចំពោះស្ថានភាពខាងវិញ្ញាណបច្ចុប្បន្នរបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់ពីគោលការណ៍ពីមុន ហើយលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅមួយដែលនឹងជួយពួកគេឲ្យបានស្អាតស្អំខាងវិញ្ញាណ ។

> *សូមជួយសិស្សបំពេញតួនាទីរបស់ពួកគេនៅក្នុងដំណើរការរៀនសូត្រ*
>
> ការរៀនសូត្រខាងព្រលឹងវិញ្ញាណតម្រូវឲ្យមានកិច្ចខិតខំ និងការអនុវត្តនៃសិទ្ធិជ្រើសរើសដោយអ្នករៀន ។ សម្រាប់សិស្សជាច្រើនការខិតខំរៀនសូត្រចេញពីព្រះគម្ពីរទំនងហាក់ដូចជាមិនបានដឹងច្បាស់ ហើយអាចនឹងមានការលំបាក ។ ទោះបីយ៉ាងណាអ្នកអាចជួយពួកគេឲ្យយល់ព្រមទទួលយក និងបំពេញតួនាទីរបស់គេនៅក្នុងការរៀនសូត្រពីដំណឹងល្អ ។ នៅពេលសិស្សបំពេញតួនាទីខ្លួនយ៉ាងសកម្មនៅក្នុងការរៀនសូត្រអំពីដំណឹងល្អ នោះពួកគេបើកដួងចិត្តរបស់ពួកគេចំពោះព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

ម៉ាថាយ ២៣:៣៧–៣៩

ព្រះអង្គសង្គ្រោះបានទួញសោកដែលប្រជាជនយេរូសាឡិមមិនបានមករកទ្រង់

ចូរដាក់បង្ហាញ ឬគូររូបភាពមេមាន់ការពារកូន ។



- ហេតុអ្វីមេមាន់ប្រមូលកូននៅក្រោមស្លាបវា ? (ដើម្បីការពារវាពីគ្រោះថ្នាក់ ។ ចូរចង្អុលបង្ហាញថា មេមាន់ស៊ូលះបង់ជីវិតខ្លួនដើម្បីការពារកូន) ។


សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៣:៣៧–៣៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថាទ្រង់ប្រៀបបាននឹងមេមាន់ ។

- តើព្រះអង្គសង្គ្រោះប្រៀបបាននឹងមេមាន់ដែលក្រុងការពារកូនវាយ៉ាងដូចម្តេច ?
- តើការត្រូវបានប្រមូលផ្តុំដោយព្រះអង្គសង្គ្រោះមានន័យដូចម្តេច ?

ចូរចង្អុលបង្ហាញឃ្លា « ផ្ទះឯងនឹងត្រូវចោលស្ងាត់ទុកឲ្យឯង » (ខទី ៣៨) ហើយពន្យល់ថាពាក្យ *ចោលស្ងាត់* មានន័យថា ទទេរ ឬ បោះបង់ចោល ។ ដោយសារប្រជាជនមិនព្រមឲ្យព្រះអង្គសង្គ្រោះប្រមូលផ្តុំ នោះពួកគេត្រូវបានទុកចោលដោយគ្មានការការពារឡើយ ។ ឃ្លានេះអាចសំដៅទៅលើស្ថានភាពខាងវិញ្ញាណរបស់ប្រជាជន នៅសម័យព្រះ យេស៊ូវ ក៏ដូចជានាពេលអនាគតដែរ កាលក្រុងយេរូសាឡិមត្រូវបានបំផ្លាញចោល ។

- ដោយផ្អែកលើអ្វីដែលព្រះយេស៊ូវបានបង្រៀនអំពីមេមាន់ និងកូនមាន់ តើយើងអាចទទួលបានអ្វីខ្លះ ប្រសិនបើយើងយល់ព្រមឲ្យព្រះអង្គសង្គ្រោះប្រមូលផ្តុំ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងយល់ព្រមឲ្យព្រះអង្គសង្គ្រោះប្រមូលផ្តុំ នោះយើងនឹងទទួលបានការថែទាំ និងការការពាររបស់ទ្រង់**) ។
- តើយើងអាចបង្ហាញដល់ព្រះអង្គសង្គ្រោះថាយើងយល់ព្រមឲ្យទ្រង់ប្រមូលផ្តុំយ៉ាងដូចម្តេច ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សយល់អំពីរបៀបមួយដែលពួកគេអាចប្រមូលផ្តុំគ្នាទៅរកព្រះអង្គសង្គ្រោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ ៖



« [ព្រះអង្គសង្គ្រោះ] បានមានបន្ទូលជាច្រើនដងថា ទ្រង់នឹងប្រមូលយើងទៅរកទ្រង់ ដូចជាមេមាន់ប្រមូលកូនវានៅក្រោមស្លាបដូច្នោះដែរ ។ ទ្រង់មានបន្ទូលថា យើងត្រូវតែជ្រើសរើសមករកទ្រង់ ។ . . .

« របៀបមួយដើម្បីធ្វើដូច្នោះ គឺការប្រមូលផ្តុំជាមួយនឹងពួកបរិសុទ្ធនៅក្នុងសាសនាចក្ររបស់ទ្រង់ ។ សូមទៅការប្រជុំរបស់អ្នក សូម្បីតែវាមានភាពលំបាកក្តី ។ ប្រសិនបើអ្នកតាំងចិត្ត នោះទ្រង់នឹងជួយអ្នករកឃើញកម្លាំងដើម្បីធ្វើកិច្ចការនេះ » (« In the Strength of the Lord » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១៨) ។

- តើប្រធានអាវរិងបានថ្លែងថាយើងអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញឆន្ទៈរបស់យើងដើម្បីឲ្យព្រះអង្គសង្គ្រោះប្រមូលផ្តុំ ?

ចូរសុំឲ្យសិស្សមើលបញ្ជីនៅលើក្តារខៀនពីរបៀប ដែលយើងអាចបង្ហាញឆន្ទៈរបស់យើងដើម្បីឲ្យព្រះគ្រីស្ទប្រមូលផ្តុំ ។ សូមអញ្ជើញពួកគេឲ្យចែកចាយពីរបៀប ដែលពួកគេបានទទួលការថែទាំ និងការការពារតាមរយៈការប្រមូលផ្តុំទៅរកព្រះអង្គសង្គ្រោះតាមរបៀបមួយនៅក្នុងចំណោមរបៀបទាំងនោះ ។

សូមអញ្ជើញសិស្សឲ្យសម្រេចចិត្តពីអ្វី ដែលពួកគេនឹងធ្វើដើម្បីប្រមូលផ្តុំទៅរកព្រះអង្គសង្គ្រោះ ដើម្បីពួកគេអាចបន្តទទួលការមើលថែ និងការការពាររបស់ទ្រង់ ។

យ៉ូសែប ស្ម៊ីធ—ម៉ាថាយ, ម៉ាថាយ ២៤

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្តបានព្យាករពីការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម និងព្រះវិហារបរិសុទ្ធ ។ ទ្រង់បានបើកសម្តែងទីសម្គាល់ពីការយាងមកជាលើកទីពីររបស់ទ្រង់ ហើយបានបង្គាប់ពួកអ្នកស្មោះត្រង់ឲ្យរង់ចាំមើល ហើយរៀបចំខ្លួនសម្រាប់ថ្ងៃនោះ ។

ការកែលម្អក្នុងនាមជាគ្រូបង្រៀនម្នាក់

នៅពេលអ្នកមានបំណងចង់ធ្វើឲ្យកិច្ចការបង្រៀនល្អប្រសើរ ហើយខ្ជាប់ខ្ជួនតាមរបៀបដែលគាប់ព្រះទ័យដល់ព្រះវរបិតាសួគ៌ នោះទ្រង់នឹងបំផុសគំនិតអ្នកនៅក្នុងការរៀបចំរបស់អ្នក ពង្រឹងទំនាក់ទំនងរបស់អ្នកជាមួយសិស្ស តម្កើងកិច្ចខិតខំរបស់អ្នក ហើយប្រទានពរដល់អ្នកដោយព្រះវិញ្ញាណរបស់ទ្រង់ ។ ទ្រង់នឹងជួយអ្នកឲ្យមើលឃើញពីរបៀប ដែលអ្នកអាចរីកចម្រើននៅពេលអ្នកព្យាយាមដើម្បីបង្រៀនតាមរបៀបមួយដែលនាំសិស្សឲ្យយល់ និងពឹងផ្អែកទៅលើការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត ។



យោបល់សម្រាប់ការបង្រៀន

យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:១–២០

ព្រះយេស៊ូវព្យាករពីការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម និងព្រះវិហារបរិសុទ្ធ

ចូរដាក់បង្ហាញរូបភាព ការយាងមកជាលើកទីពីរ (*Gospel Art Book* ៖ ឆ្នាំ ២០០៩ ៖ ទំព័រ ៦៦សូមមើលផងដែរ LDS.org) ។ ចូរសុំឲ្យសិស្សសញ្ជឹងគិតពីសំណួរដែលពួកគេមានអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ត ហើយសរសេរសំណួរទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមកុំព្យាយាមឆ្លើយសំណួរទាំងនេះនៅពេលនេះឡើយ ។ សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយនៅពេលពួកគេសិក្សាយ៉ូសែប ស្ម៊ីធ—ម៉ាថាយ ។

សូមចង្អុលបង្ហាញថាយ៉ូសែប ស្ម៊ីធ—ម៉ាថាយគឺការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់ ម៉ាថាយ ២៣:៣៩ និងម៉ាថាយ ២៤ ។ សូមសង្ខេបយ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:១–៣ដោយពន្យល់ថាកាលព្រះយេស៊ូវគ្រីស្តបានបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធក្នុងទីក្រុងយេរូសាឡិម ពួកសិស្សរបស់ទ្រង់បានយល់ដឹងថា ទ្រង់នឹងយាងត្រឡប់មកផែនដីម្តងទៀត ។ បន្ទាប់មកព្រះយេស៊ូវបានយាងចេញពីព្រះវិហារបរិសុទ្ធនោះ ហើយពួកសិស្សរបស់ទ្រង់បានមករកទ្រង់ដោយចង់ដឹងបន្ថែមទៀត អំពីពេលវេលាដែលព្រះវិហារបរិសុទ្ធនឹងត្រូវបានបំផ្លាញចោល ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូសែប ស្ម៊ីធ —ម៉ាថាយ ១:៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួរពីរដែលពួកសិស្សបានសួរដល់ព្រះយេស៊ូវនៅលើភ្នំអូលីវ ។ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ហើយសរសេរសំណួរដូចខាងក្រោមនេះនៅលើក្តារខៀន ៖

១. តើទីក្រុងយេរូសាឡិម និងព្រះវិហារបរិសុទ្ធនឹងត្រូវបំផ្លាញចោលនៅពេលណា ?

២. តើទីសម្គាល់នៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ត និងការបំផ្លិចបំផ្លាញជនទុច្ចរិតគឺជាអ្វី ?

សូមពន្យល់ថា ព្រះយេស៊ូវគ្រីស្តបានលើកឡើងនូវសំណួរទីមួយនៅក្នុង ខទី ៥–២១ហើយសំណួរទីពីរត្រូវបានឆ្លើយនៅក្នុង ខទី ២១–៥៥ ។ សូមបែងចែកសិស្សជាដៃគូៗ ។ សូមណែនាំឲ្យពួកគេអាន យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:៥–១២ ឲ្យឮៗជាមួយនឹងដៃគូ ដោយរកមើលទីសម្គាល់ដែលទាក់ទងនឹងការបំផ្លិចបំផ្លាញទីក្រុងយេរូសាឡិម និងព្រះវិហារបរិសុទ្ធ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ទោះជាព្រះយេស៊ូវបានមានបន្ទូលថា ពួកសិស្សរបស់ទ្រង់នឹងត្រូវរងទុក្ខនៅពេលនេះក្តី តើទ្រង់បានមានបន្ទូលអ្វីខ្លះពីជនដែល « បន្តខ្ជាប់ខ្ជួន ហើយពុះពារ » ? (ខទី ១១) ។
- តើគោលការណ៍អ្វីដែលយើងអាចរៀនមកពី ខទី ១១នេះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្ទាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងបន្តខ្ជាប់ខ្ជួន ហើយមិនចុះចាញ់ នោះយើងនឹងត្រូវបានសង្គ្រោះ ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើការខ្ជាប់ខ្ជួន ហើយពុះពារមានន័យដូចម្តេច ? (*ខ្ជាប់ខ្ជួន* គឺការរឹងប៉ឹង មុតមាំ មិនងាករេ ហើយមិនចុះញ៉ែម) ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យពាក្យ *បានសង្គ្រោះ* នៅក្នុង ខទី ១១ សូមពន្យល់ថា នៅពេលយើងមានភាពខ្ជាប់ខ្ជួន នោះយើងអាចនឹងមិនត្រូវជួយសង្គ្រោះឲ្យរួចផុតពីការលំបាកទេ ប៉ុន្តែនៅទីបំផុតយើងនឹងបានសង្គ្រោះនៅក្នុងនគរព្រះវិញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលរបៀប ដែលជនបានបន្តខ្ជាប់ខ្ជួននៅក្នុងការគោរពតាមការប្រឹក្សារបស់ព្រះអង្គសង្គ្រោះត្រូវបានសង្គ្រោះឲ្យរួចពីការបំផ្លិចបំផ្លាញ ៖

នៅក្នុង យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:១៣–១៨ យើងរៀនថា ព្រះយេស៊ូវបានព្រមានពួកសិស្សរបស់ទ្រង់ ឲ្យត្រៀមខ្លួនរៀងខ្លួនឡើងទៅលើភ្នំ ហើយកុំត្រឡប់មកផ្ទះរបស់ពួកគេវិញ ដោយសារទីក្រុងយេរូសាឡិមនឹងមានការវាយប្រហារ ហើយបំផ្លាញចោល ។ ទ្រង់បានព្យាករថា សេចក្តីឈឺចាប់នៃថ្ងៃទាំងនោះគឺអាក្រក់ហួសពីអ្វី ដែលអ៊ីស្រាអែលធ្លាប់ឃើញទៅទៀត ។ នៅគ.ស. ៧០ ប្រមាណជា ៤០ ឆ្នាំក្រោយពីព្រះយេស៊ូវបានមានបន្ទូលពីរឿងទាំងនេះ ពួករ៉ូមបានឡោមព័ទ្ធទីក្រុងយេរូសាឡិម ហើយបានសំឡាប់ពួកយូដាជាងមួយលាននាក់ ។ ព្រះវិហារបរិសុទ្ធនោះត្រូវបានបំផ្លាញចោលសូម្បីតែថ្មមួយដុំត្រួតលើគ្នាក៏គ្មាននៅសេសសល់ដែរ—គឺដូចជាអ្វីដែលព្រះអង្គសង្គ្រោះបានព្យាករ (សូមមើល ម៉ាថាយ ២៤:២) ។ ប៉ុន្តែជនដែលបានស្តាប់តាមការព្រមានរបស់ព្រះយេស៊ូវ បានរត់គេចដោយ

សុវត្ថិភាពទៅកាន់ប៉ែលឡា ជាក្រុងមួយមានចម្ងាយប្រហែលជា ៨០ គីឡូម៉ែត្រនៅទិសឦសានៃទីក្រុងយេរូសាឡិម (សូមមើល Bible Dictionary « Pella ») ។

- តើបទពិសោធន៍របស់ពួកយូដា គួរបង្ហាញពីសារៈសំខាន់នៃការបន្តខ្ជាប់ខ្ជួននៅក្នុងការគោរពតាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- តើពេលណាដែលអ្នកធ្លាប់ទទួលបានពរជ័យដោយការបន្តខ្ជាប់ខ្ជួន នៅក្នុងការគោរពតាមព្រះបញ្ញត្តិ?

សូមសង្ខេប យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:១៩–២០ ដោយពន្យល់ថា ព្រះយេស៊ូវបានព្យាករថា ទោះបីជាពួកយូដានឹងរងទុក្ខនូវការសាកល្បងដ៏ធំក្តី ពួកគេនឹងត្រូវបានរក្សាឲ្យគង់វង្សដោយសារសេចក្តីសញ្ញារបស់ព្រះអម្ចាស់ជាមួយនឹងពួកគេ ។

យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:២១–៣៧

ព្រះយេស៊ូវព្យាករពីទីសម្គាល់នៃការយាងមកជាលើកទីពីររបស់ទ្រង់

សូមពន្យល់ថា បន្ថែមទៅលើការពន្យល់ពីទីសម្គាល់ដែលនឹងព្រមានពីការបំផ្លាញទីក្រុងយេរូសាឡិម ព្រះអង្គសង្គ្រោះបានមានបន្ទូលឆ្លើយនឹងសំណួរទីពីររបស់ពួកសិស្ស ដោយព្យាករពីទីសម្គាល់ទាក់ទិននឹងការយាងមកជាលើទីពីររបស់ទ្រង់ ។

ចូរសុំសិស្សម្នាក់អានយ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:២១–២៣ ឲ្យឮៗ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលព្រះអម្ចាស់បានបើកសម្តែងទីសម្គាល់នៃការយាងមកជាលើកទីពីររបស់ទ្រង់ ។

- ហេតុអ្វីវាមានប្រយោជន៍ដល់ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីដឹងពីទីសម្គាល់ដែលបង្ហាញពីការយាងមកជាលើកទីពីររបស់ទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូសែប ស្ម៊ីធ — ម៉ាថាយ ១:២៤–២៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលព្រះអង្គសង្គ្រោះនឹងលេចមកនៅឯការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះ នឹងលេចមកនៅឯការយាងមកជាលើកទីពីរតាមរបៀបណា ?
- តើការដឹងរឿងនេះ អាចជួយអ្នករើសតាំងឲ្យចៀសជុតពីការបោកបញ្ឆោតដោយរបៀបណា ?

សូមអញ្ជើញសិស្សអាន យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:២៧–៣១ ដោយស្ងាត់ស្ងៀម រកមើលទីសម្គាល់ដែលនឹងកើតឡើង ពីមុនការយាងមកជាលើកទីពីរ ។

- តើមនុស្សនឹងជួបប្រទះការលំបាកអ្វីខ្លះពីមុនការយាងមកជាលើកទីពីរ ?
- ផ្អែកលើ ខទី ២៧ និង ៣១តើទីសម្គាល់សំខាន់ៗអ្វីខ្លះ ដែលនឹងកើតមានពីមុនការយាងមកជាលើកទីពីរ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូគ្រីស្ទ អ្នករើសតាំងរបស់ព្រះអម្ចាស់នឹងត្រូវបានប្រមូលផ្តុំ ហើយដំណឹងល្អនឹងត្រូវប្រកាសទៅកាន់ពិភពលោកទាំងមូល**) ។
- តើយើងឃើញការព្យាករនេះត្រូវបានបំពេញដោយរបៀបណា ?

សូមពន្យល់ថា យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:៣២–៣៦ ពិពណ៌នាពីទីសម្គាល់បន្ថែមទៀតដែលទាក់ទងនឹងការយាងមកជាលើកទីពីរ ។

សូមរំឭកសិស្សពីការព្រមានរបស់ព្រះអង្គសង្គ្រោះថា នៅថ្ងៃចុងក្រោយព្រះគ្រីស្ទត្លែងភ្លាយ និងពួកព្យាការីក្លែងក្លាយនឹង « បោកបញ្ឆោតរាល់អ្នករើសតាំង » (ខទី ២២) ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូសែប ស្ម៊ីធ—ម៉ាថាយ ១:៣៧ ឲ្យឮៗ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលអ្នករើសតាំងអាចចៀសជុតពីការត្រូវបានគេបោកបញ្ឆោត ។

- តើអ្នករើសតាំងអាចចៀសជុតពីការបោកបញ្ឆោតតាមរបៀបណា ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីខនេះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងសង្ឃឹមទុកព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះយើងនឹងមិនត្រូវបានបោកបញ្ឆោតឡើយ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោម ដែលត្រូវបានចែករំលែកដោយអែលឌើរ អិម រ័សុល បាឡឺដ ក្នុងក្តារ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« អ្នកផ្សព្វផ្សាយសាសនាដ៏ល្អរបស់ខ្ញុំម្នាក់ដែលបានបម្រើជាមួយខ្ញុំ កាលខ្ញុំជាប្រធានបេសកកម្មនៅតូរ៉ង់តូ | ប្រទេសកាណាដា | បានមកជួបខ្ញុំនៅប៉ុន្មានឆ្នាំក្រោយមក ។ ខ្ញុំបានសួរគាត់ថា ‹ អែលឌើរ តើអ្នកមានអ្វីដែលខ្ញុំអាចជួយបាន ? ›

« គាត់បានពោលថា ‹ ប្រធាន ខ្ញុំគិតថាខ្ញុំបានបាត់បង់ទីបន្ទាល់របស់ខ្ញុំហើយ › ។

« ខ្ញុំមិនអាចជឿទេ ។ ខ្ញុំបានសួរគាត់ថា រឿងនេះអាចកើតឡើងយ៉ាងដូចម្តេចបាន ។

« គាត់បានពោលថា ‹ ខ្ញុំបានអានសៀវភៅមួយចំនួនដែលប្រឆាំងនឹងពួកមរមន › ។ ‹ ខ្ញុំមានសំណួរមួយចំនួន ហើយគ្មាននរណាម្នាក់ឆ្លើយនឹងសំណួរទាំងនោះឡើយ ។ ខ្ញុំមានអារម្មណ៍ច្របូកច្របល់ ហើយខ្ញុំគិតថាខ្ញុំកំពុងបាត់បង់ទីបន្ទាល់របស់ខ្ញុំហើយ › »
(« When Shall These Things Be? » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រ ៦០) ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថាតើពួកគេ ឬមនុស្សដែលពួកគេស្គាល់ធ្លាប់ជួបប្រទះរឿងស្រដៀងគ្នាទៅនឹងអ្វីដែលអតីតអ្នកផ្សព្វផ្សាយសាសនាម្នាក់នេះបានជួបដែរឬទេ ។

- តើការប្រឹក្សាអ្វីខ្លះ ដែលអ្នកនឹងផ្តល់ទៅឲ្យមនុស្សម្នាក់ដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ ? ហេតុអ្វី ?

សូមអញ្ជើញសិស្សម្នាក់ឲ្យបន្តអានដំណើររឿងរបស់អែលឌើរ បាឡឺដ ឲ្យឮៗ ៖

« ខ្ញុំបានសួរគាត់ថា តើគាត់មានសំណួរអ្វីខ្លះ ហើយគាត់ក៏បានប្រាប់ខ្ញុំ ។ វាគឺជាបញ្ហាបទដ្ឋានដែលប្រឆាំងនឹងសាសនាចក្រ ប៉ុន្តែខ្ញុំត្រូវការពេលវេលាខ្លះប៉ុណ្ណោះដើម្បីប្រមូលឯកសារ ដើម្បីខ្ញុំអាចផ្តល់នូវចម្លើយដែលមានអត្ថប្រយោជន៍ ។ ដូច្នេះយើងបានធ្វើការណាត់ជួបមួយនៅ ១០ ថ្ងៃក្រោយដោយខ្ញុំបានប្រាប់គាត់ថា ខ្ញុំនឹងឆ្លើយរាល់សំណួរទាំងអស់របស់គាត់ ។ នៅពេលគាត់បានចាប់ផ្តើមចាកចេញទៅ ខ្ញុំប្រាប់ឲ្យគាត់ឈប់ ។

« ខ្ញុំបានពោលថា ‹ អែលឌើរ ថ្ងៃនេះអ្នកបានសួរខ្ញុំនូវសំណួរមួយចំនួន › ។ ‹ ឥឡូវខ្ញុំមានសំណួរមួយសម្រាប់អ្នក › ។

« ‹ តើអ្វីទៅប្រធាន ? ›

« ‹ តើវាមានពេលយូរប៉ុណ្ណាហើយ ចាប់តាំងពីអ្នកបានអានព្រះគម្ពីរមរមន ? › ខ្ញុំបានសួរ ។

« គាត់បានឈោងមុខចុះ ។ មើលទៅឥដ្ឋមួយសន្ទុះ ។ រួចក៏មើលមុខខ្ញុំ ។ គាត់បានសារភាពថា ‹ ប្រធានខ្ញុំខានអានយូរហើយ › ។

« ខ្ញុំបានពោលថា ‹ មិនអីទេ › ។ ‹ អ្នកបានដាក់កិច្ចការឲ្យខ្ញុំធ្វើ ។ ដើម្បីឲ្យយុត្តិធម៌ ខ្ញុំក៏មានកិច្ចការសម្រាប់អ្នកដែរ ។ ខ្ញុំចង់ឲ្យអ្នកសន្យានឹងខ្ញុំថា អ្នកនឹងអានព្រះគម្ពីរមរមនយ៉ាងហោចណាស់ឲ្យបានមួយម៉ោងជារៀងរាល់ថ្ងៃចាប់ពីពេលនេះ រហូតដល់ការណាត់ជួបរបស់យើងនៅពេលក្រោយ › ។ គាត់បានយល់ព្រមថាគាត់នឹងធ្វើវា ។

« ដប់ថ្ងៃក្រោយមក គាត់បានត្រឡប់មកការិយាល័យរបស់ខ្ញុំ ហើយខ្ញុំបានត្រៀមខ្លួនជាស្រេច ។ ខ្ញុំបានដកយកក្រដាសខ្ញុំចេញមកដើម្បីចាប់ផ្តើមឆ្លើយសំណួររបស់គាត់ ប៉ុន្តែគាត់បានបញ្ឈប់ខ្ញុំ ។

« គាត់បានពោលថា ‹ ប្រធាន វាពុំចាំបាច់ទៀតទេ › ។ បន្ទាប់មក គាត់បានពន្យល់ ៖ ‹ ខ្ញុំដឹងថា ព្រះគម្ពីរមរមន ពិត ! ខ្ញុំដឹងថា យ៉ូសែប ស៊្មីធ ជាព្យាការីរបស់ព្រះ ។

« ខ្ញុំបានពោលថា ‹ វាជាការល្អណាស់ › ។ ‹ ប៉ុន្តែទោះជាយ៉ាងណា អ្នកនៅតែត្រូវស្តាប់ចម្លើយចំពោះសំណួររបស់អ្នកដដែល ។ ខ្ញុំបានចំណាយពេលយ៉ាងច្រើនចំពោះរឿងនេះ ដូច្នេះអ្នកគ្រាន់តែអង្គុយចុះនៅត្រង់នោះ ហើយស្តាប់ទៅបានហើយ › ។

« ហេតុដូច្នេះហើយខ្ញុំបានឆ្លើយរាល់សំណួររបស់គាត់ រួចសួរថា ‹ អែលឌើរ តើអ្នកបានរៀនអ្វីខ្លះពីការណ៍នេះ ? ›

« ហើយគាត់បានពោលថា ‹ ថ្វាយពេលវេលាស្មើគ្នាដល់ព្រះអម្ចាស់ › » (« When Shall These Things Be ? » ទំព័រ ៦០) ។

- តើបទពិសោធន៍នេះគួរបង្ហាញពីគោលការណ៍ដែលយើងបានរកឃើញនៅក្នុង ខទី ៣៧ យ៉ាងដូចម្តេច?
- តើអ្នកធ្លាប់បានទទួលពរជ័យយ៉ាងណាដែរ ពេលអ្នកឲ្យតម្លៃដល់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ?

យ៉ូសែប ស៊្មីធ—ម៉ាថាយ ១:៣៨–៥៥

ព្រះយេស៊ូវណែនាំពួកសិស្សរបស់ទ្រង់ អំពីការត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ

សូមពន្យល់ថា ដោយប្រើរឿងប្រៀបប្រដូច ព្រះយេស៊ូវបានណែនាំពួកសិស្សរបស់ទ្រង់ពីរបៀបរក្សាព្រះបន្ទូលរបស់ទ្រង់ ហើយត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

សូមបែងចែកសិស្សជាដៃគូៗ ។ ចូរចាត់សិស្សម្នាក់ពីដៃគូនីមួយៗសិក្សាយ៉ូសែប ស៊្មីធ—ម៉ាថាយ ១:៣៨–៤៦ ហើយសិស្សម្នាក់ទៀតសិក្សាយ៉ូសែប ស៊្មីធ—ម៉ាថាយ ១:៤៧–៥៤ ។ សូមអញ្ជើញសិស្សឲ្យរកមើលគោលលទ្ធិ និងគោលការណ៍នានានៅក្នុងខគម្ពីរដែលពួកគេត្រូវបានចាត់តាំង ហើយសរសេរវាទុក ។

លុះដល់ពេលកំណត់ហើយ សូមឲ្យសិស្សសង្ខេបរឿងប្រៀបប្រដូចដែលពួកគេបានអានដល់ដៃគូខ្លួន ហើយពិភាក្សាសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកបានរកឃើញសេចក្តីពិតអ្វីខ្លះ ?
- តើព្រះអង្គសង្គ្រោះបានបង្ហាញសេចក្តីពិតទាំងនេះ នៅក្នុងខគម្ពីរដែលអ្នកបានសិក្សាដោយរបៀបណា ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីសេចក្តីពិតដែលពួកគេបានរកឃើញ ដែលវាអាចរួមបញ្ចូលដូចខាងក្រោមនេះ ៖ **មានតែព្រះវរបិតាសួគ៌ប៉ុណ្ណោះ ដែលគ្រាបពីពេលវេលានៃការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះនឹងកើតឡើងពេលណា ។ ប្រសិនបើយើងរកមើលសញ្ញា ហើយគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងនឹងត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។**

សូមរំឭកឡើងវិញពីសេចក្តីពិតដែលបានរកឃើញនៅក្នុង យ៉ូសែប ស៊្មីធ—ម៉ាថាយហើយសុំឲ្យសិស្សពិចារណាពីរបៀបដែលសេចក្តីពិតទាំងនេះជួយឆ្លើយសំណួរដែលពួកគេបានសរសេរនៅដើមមេរៀននេះ ។ សូមអញ្ជើញពួកគេឲ្យថ្លែងទីបន្ទាល់ពីសេចក្តីពិតដែលពួកគេបានរៀន ។

ចូរសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ (ប្រសិនបើអាចសូមចែកសំណៅថតចម្លងដល់សិស្ស) ៖



« ចុះបើថ្ងៃនៃការយាងមករបស់ទ្រង់ជាថ្ងៃស្អែកវិញ ? ប្រសិនបើយើងបានដឹងថា យើងត្រូវជួបនឹងព្រះអម្ចាស់នៅថ្ងៃស្អែក — តាមរយៈការស្លាប់មុនអាយុ ឬតាមរយៈការយាងមកដែលមិនអាចរំពឹងទុកបានមុនរបស់ទ្រង់ — តើយើងនឹងធ្វើអ្វីនៅថ្ងៃនេះ ? តើយើងនឹងសារភាពអ្វីខ្លះ ? តើយើងនឹងបញ្ឈប់ការអនុវត្តអ្វី ? តើយើងនឹងយកដំណើរឿងណាមួយមកដោះស្រាយ ? តើការអត់ទោសណាខ្លះដែលយើងនឹងសំដែង ? តើយើងនឹងថ្លែងទីបន្ទាល់ណាមួយ ?

« ចុះបើយើងនឹងត្រូវធ្វើការណ៍ទាំងនោះនៅពេលនោះ ហេតុអ្វីយើងមិនធ្វើឥឡូវនេះ ? » (« Preparation for the Second Coming » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៩) ។

សូមអញ្ជើញសិស្សឲ្យសរសេរចម្លើយមួយ ឆ្លើយនឹងសំណួរខាងក្រោមនេះ ៖ ប្រសិនបើខ្ញុំបានដឹងថា ខ្ញុំនឹងជួបព្រះអង្គសង្គ្រោះនៅថ្ងៃស្អែក តើខ្ញុំនឹងផ្លាស់ប្តូរអ្វីខ្លះនៅថ្ងៃនេះ ? សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។

មេរៀន ២៨

ម៉ាថាយ ២៥:១–១៣

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានបង្រៀនតែពួកសិស្សរបស់ទ្រង់នៅលើភ្នំអូលីវ អំពីការយាងមក
ជាលើកទីពីររបស់ទ្រង់ ទ្រង់បានបង្រៀនរឿងប្រៀបប្រដូចមួយស្តីពីស្ត្រីព្រហ្មចារីដប់នាក់ ។

សូមប្រើដំណើររឿងដើម្បី ទាញយកចំណាប់អារម្មណ៍ ហើយបង្កើតការយល់ដឹង

ដំណើររឿងអាចធ្វើឲ្យសិស្ស មានចំណាប់អារម្មណ៍ និង ជួយពួកគេឲ្យយល់ពីដំណឹងល្អតាមរយៈបទពិសោធន៍ផ្សេងៗគ្នា ។ តាមរយៈការបង្ហាញអំពីគោលការណ៍ នៃដំណឹងល្អនៅក្នុងបរិបទទំនើបមួយ ឬ នៅក្នុងបរិបទនៃបទគម្ពីរ នោះដំណើររឿងទាំងឡាយអាចជួយសិស្សឲ្យយល់អំពីរបៀប ដែលគោលការណ៍ទាំងនេះមានទំនាក់ទំនងទៅនឹងជីវិតរបស់ពួកគេ ហើយជួយពួកគេឲ្យមានបំណងចង់អនុវត្តតាម ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៥:១–១៣

ព្រះយេស៊ូវគ្រីស្ទបង្រៀនរឿងប្រៀបប្រដូចមួយស្តីពីស្ត្រីព្រហ្មចារីដប់នាក់

សុំឲ្យសិស្សម្នាក់អានឮៗពីដំណើររឿងខាងក្រោមដែលអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់បានប្រាប់ពីយុវជនម្នាក់ដែលបានត្រឡប់មកពីបេសកកម្មវិញដែលបានចែកចាយបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងការប្រជុំថ្លែងទីបន្ទាល់ ។ សុំឲ្យសិស្សនឹកស្រមៃពីអារម្មណ៍ដែលពួកគេមាន ប្រសិនបើពួកគេគឺជាយុវជននៅក្នុង រឿងនេះ ។



« គាត់ . . . បានប្រាប់ពីពេលដែលគាត់ត្រឡប់មកផ្ទះវិញ បន្ទាប់ពីដើរលេងជាគូ ដែលមិនយូរប៉ុន្មានក្រោយពីគាត់ត្រូវបានតែងតាំងជាអែលឌើរនៅអាយុ ១៨ ឆ្នាំ ។ មានអ្វីមួយបានកើតឡើងនៅក្នុងការដើរលេងជាគូនេះ ដែលធ្វើឲ្យគាត់ពុំមានមោទនភាពសោះ ។ គាត់ពុំបានអធិប្បាយយ៉ាងល្អិតល្អន់ ហើយគាត់ក៏មិនគួរនិយាយអ្វីៗបែបនោះនៅមុខមនុស្សជាច្រើនឡើយ ។ រហូតមកដល់ថ្ងៃនេះ ខ្ញុំមិនបានដឹងពីរឿងពិតនៃហេតុការណ៍ដែលបានកើតឡើងនោះទេ ប៉ុន្តែវាពិតជាសំខាន់ចំពោះគាត់ ដែលបានប៉ះពាល់ដល់វិញ្ញាណរបស់គាត់ និង ការឲ្យតម្លៃលើខ្លួនឯង ។

« ខណៈដែលគាត់កំពុងអង្គុយនៅក្នុងឡានមួយសន្ទុះ លើច្រកផ្លូវចូលផ្ទះរបស់គាត់ ដោយគិតអំពីរឿងរ៉ាវនានា និង មានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងចំពោះអ្វីដែលបានកើតឡើង នោះម្តាយរបស់គាត់ដែលមិនមែនសមាជិក បានរត់ចេញមកពីផ្ទះតម្រង់ទៅកាន់ឡានរបស់គាត់ទាំងក្តីបារម្ភ ។ រំពេចនោះ ម្តាយរូបនេះ បាននិយាយប្រាប់ថា ប្អូនប្រុសរបស់យុវជនម្នាក់នោះ ទើបតែបានដួលនៅក្នុងផ្ទះ បានប៉ះទង្គិចក្បាលយ៉ាងខ្លាំង ហើយបានប្រកាច់ ឬកន្ត្រាក់ផងដែរ ។ ឪពុកដែលមិនមែនជាសមាជិកនោះ បានទូរស័ព្ទហៅឡានសង្គ្រោះបន្ទាន់ ប៉ុន្តែវាចំណាយពេលច្រើនទម្រាំមកដល់ដើម្បីជួយសង្គ្រោះ ។

« ម្តាយរូបនោះបានស្រែកយំថា ‹ សូមមកនេះ ហើយធ្វើអ្វីមួយដើម្បីជួយ › ។ ‹ តើពុំមានអ្វីដែលកូនធ្វើនៅក្នុងព្រះវិហាររបស់កូននៅចំពេលបែបនេះទេឬ ? កូនមានបព្វជិតភាពរបស់ពួកគេ ។ សូមមកនេះ ហើយធ្វើអ្វីមួយដើម្បីជួយ › ។ . . .

« . . . នៅពេលយប់នេះ នៅពេលមនុស្សម្នាក់ដែលគាត់ស្រឡាញ់យ៉ាងខ្លាំងត្រូវការសេចក្តីជំនឿ និង កម្លាំងរបស់គាត់ នោះយុវជនរូបនេះពុំអាចឆ្លើយតបបានឡើយ ។ ដោយបានមានអារម្មណ៍ដែលគាត់ទើបតែបានពុះពារ និង អារម្មណ៍រវើរវាយចំពោះអ្វីដែលគាត់ទើបតែបានធ្វើ—មិនថាជាអ្វីនោះទេ—គាត់មិនអាចចូលខ្លួនរបស់គាត់ ទៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ហើយអំពាវនាវសម្រាប់ពរជ័យដែលត្រូវការបានឡើយ(« The Confidence of Worthiness » *Liahona* ខែ មេសា ឆ្នាំ ២០១៤ ទំព័រ ៥៨–៥៩) ។

- តើអ្នកប្រហែលនឹងគិតអ្វីខ្លះ ប្រសិនបើអ្នកជាយុវជននោះ ហើយស្ថិតនៅក្នុងស្ថានភាពនេះ ? ហេតុអ្វីបានជាវាសំខាន់ដើម្បីត្រៀមខ្លួនជានិច្ច ?



សូមដាក់បង្ហាញរូប រឿងប្រៀបប្រដូចពីស្ត្រីព្រហ្មចារីដប់នាក់ (*Gospel Art Book* ⁄ ឆ្នាំ២០០៩⁄ ល.រ. ៥៣សូមមើលផងដែរ LDS.org) ។ សូមរំឭកសិស្សថា កាលព្រះយេស៊ូវគ្រីស្ទគង់នៅលើភ្នំអូលីវជាមួយនឹងពួកសិស្សរបស់ទ្រង់ ទ្រង់បានបង្រៀនពួកគេពីការយាងមកជាលើកទីពីរ (សូមមើល ម៉ាថាយ ២៤) ។ រួចទ្រង់បាននិទានរឿងប្រៀបប្រដូចពីស្ត្រីព្រហ្មចារីដប់នាក់ ដើម្បីចង្អុលបង្ហាញពីរបៀបដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:១–៤ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលធាតុដ៏សំខាន់នៃរឿងប្រៀបប្រដូចនេះ ។ សូមអញ្ជើញពួកគេឲ្យប្រាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរឃ្លាខាងក្រោមនេះនៅលើ ក្តារខៀន ៖

កូនកម្លោះ

ស្ត្រីព្រហ្មចារីឆ្លាតវៃ និង ល្ងង់ខ្លៅ

ចង្កៀង និង ប្រេង

សូមពន្យល់ថា យោងតាមទំនៀមទម្លាប់នៃអាពាហ៍ពិពាហ៍របស់សាសន៍យូដា កូនប្រុស ឬកូនកម្លោះ ត្រូវបានអមដំណើរដោយមិត្តជិតស្និទ្ធរបស់ខ្លួន នឹងទៅផ្ទះកូនក្រមុំនៅពេលយប់សម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍ ។ បន្ទាប់ពីពិធីនោះ ពិធីជប់លៀងទទួលអាហារសម្រាប់អាពាហ៍ពិពាហ៍បានធ្វើឡើងនៅផ្ទះកូនប្រុស ។ ភ្ញៀវដែលមកចូលរួមត្រូវបានតម្រូវឲ្យកាន់ចង្កៀងរបស់ខ្ទង ឬចន្លុះដើម្បីបង្ហាញថាពួកគេជាផ្នែកមួយនៃពិធីជប់លៀងសម្រាប់អាពាហ៍ពិពាហ៍នេះ ហើយដើម្បីបន្តែមពន្លឺ និង ភាពស្រស់បំព្រងដល់ឱកាសនោះ ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ២៥:៥–១៣ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើល អ្វីដែលស្ត្រីព្រហ្មចារីដ៏ឆ្លាតវៃប្រាំនាក់បានធ្វើ និង អ្វីដែលស្ត្រីព្រហ្មចារីដ៏ល្ងង់ខ្លៅប្រាំនាក់បានធ្វើ ។

ជំនួសការសុំឲ្យសិស្សអាន ម៉ាថាយ ២៥:៥–១៣ ឮៗ អ្នកអាចបង្ហាញសិស្សនូវផ្នែកមួយនៃវីដេអូ « They That Are Wise » (ក្នុងពេលវេលា ០:០០–៥:៤៦) ដែលបង្ហាញពីរឿងប្រៀបប្រដូចនៃស្ត្រីព្រហ្មចារីទាំងដប់នាក់ ។ វីដេអូនេះ មាននៅក្នុង *Doctrine and Covenants and Church History Visual Resource DVDs* និង នៅក្នុង LDS.org។ ពីមុនចាប់ផ្តើមវីដេអូនេះ សុំឲ្យសិស្ស រកមើល អ្វីដែលស្ត្រីព្រហ្មចារីដ៏ឆ្លាតវៃប្រាំនាក់បានធ្វើ និង អ្វីដែលស្ត្រីព្រហ្មចារីដ៏ល្ងង់ខ្លៅប្រាំនាក់បានធ្វើ ។

- តើស្ត្រីព្រហ្មចារីឆ្លាតវៃប្រាំនាក់បានធ្វើអ្វីខ្លះ ? តើស្ត្រីព្រហ្មចារីល្ងង់ខ្លៅប្រាំនាក់បានធ្វើអ្វីខ្លះ ?

សូមយោងទៅលើកត្តានានានៃរឿងប្រៀបប្រដូចនេះ ដែលបានសរសេរនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សផ្តល់ជាយោបល់ តើពួកគេគិតថាកត្តានីមួយៗតំណាងឲ្យអ្វីដែរ ។

សូមសរសេរពាក្យ *ព្រះយេស៊ូវគ្រីស្ទ* នៅក្បែរ *កូនកម្លោះ* លើក្តារខៀន ។ សូមពន្យល់ថា ឃ្លា « តែដោយព្រោះប្តីក្រមកពេក »(ខទី ៥) និង « លុះដល់កណ្តាលអធ្រាត្រ ស្រាប់តែឮសូរសម្រែក » (ខទី ៦) សំដៅទៅលើការយាងមកជាលើកទីពីរបស់ព្រះយេស៊ូវគ្រីស្ទ ។

- តើយើងអាចរៀនអ្វីខ្លះពីការយាងមកជាលើកទីពីរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងឃ្លាទាំងនេះ ?

សូមពន្យល់ថា ទាំងស្ត្រីព្រហ្មចារីឆ្លាតវៃ និង ល្ងង់ខ្លៅដែលត្រូវបានអញ្ជើញឲ្យមកបរិភោគអាហារ តំណាងឲ្យសមាជិកនៃសាសនាចក្រនេះ (សូមមើល ដាល្លិន អេក អូក « Preparation for the Second Coming » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៨) ។ សូមសរសេរ *សមាជិកនៃសាសនាចក្រ* នៅក្បែរ *ស្ត្រីព្រហ្មចារីឆ្លាតវៃ និង ល្ងង់ខ្លៅ* លើក្តារខៀន ។

សូមអញ្ជើញសិស្សឲ្យរំឭក ម៉ាថាយ ២៥:៨–៩ ឡើងវិញ ហើយសញ្ជឹងគិតពីហេតុផលដែលស្ត្រីព្រហ្មចារីឆ្លាតវៃពុំឲ្យប្រេងរបស់ខ្លួនទៅស្ត្រីព្រហ្មចារីដែលល្ងង់ខ្លៅ ។ ចូរសុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន ស្តែនសើរ ដបុលយូ យីមប៊ីល ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្តាប់រកមើលថាតើប្រេងតំណាងឲ្យអ្វីទៅ ហើយថាហេតុអ្វីបានជាវាពុំអាចចែកបាន ។



« ទង្វើបែបនេះពុំមែនជាភាពអត្ថានិមិយ ឬការខ្វះសណ្តានចិត្តល្អនោះទេ ។ ប្រេងដែលយើងត្រូវការដើម្បីស្វែងរកការដឹកនាំ និង បង្កើនចំណេះដឹង មិនអាចចែកចាយបានឡើយ ។ តើយើងអាចចែកចាយការគោរពប្រតិបត្តិចំពោះគោលការណ៍នៃដង្វាយមួយភាគក្នុងដប់ ចិត្តគំនិតដ៏សុខសាន្តដែលកើតចេញពីការរស់នៅដោយសុចរិតភាព ឬ ចែកចាយភាពរីកចម្រើននៃចំណេះដឹង បានយ៉ាងដូចម្តេចទៅ ? តើបុគ្គលម្នាក់អាចចែកចាយសេចក្តីជំនឿ ឬ ទីបន្ទាល់បានយ៉ាងដូចម្តេចទៅ ? តើបុគ្គលម្នាក់អាចចែកចាយឥរិយាបថ ឬ បរិសុទ្ធភាព ឬ ចែកចាយបទពិសោធន៍ក្នុងបេសកកម្ម បានយ៉ាងដូចម្តេចទៅ ? តើបុគ្គលម្នាក់អាចចែកចាយអាទិភាព ដើម្បីចូលក្នុងព្រះវិហារបរិសុទ្ធបានយ៉ាងដូចម្តេចទៅ ? បុគ្គលម្នាក់ៗត្រូវតែមានប្រេងនោះផ្ទាល់ខ្លួន ។ . . .

« ក្នុងរឿងប្រៀបប្រដូចនោះ ប្រេងអាចរកទិញបាននៅឯផ្សារ ។ នៅក្នុងជីវិតយើង ប្រេងនៃការត្រៀមខ្លួនជាស្រេច ប្រមូលសន្សំមួយតំណក់ម្តងៗ តាមរយៈការរស់នៅដោយសុចរិត ។ . . . រាល់ទង្វើនៃការលះបង់ និង ការគោរពប្រតិបត្តិគឺជាតំណក់ប្រេងមួយតំណក់ដែលបានបន្ថែមនៅក្នុងចង្កៀងរបស់យើង » (*Faith Precedes the Miracle* | ឆ្នាំ១៩៧២ | ទំព័រ ២៥៥–៥៦) ។

- តើប្រេងតំណាងឲ្យអ្វីដែរនៅក្នុងរឿងប្រៀបប្រដូចនេះ ? (សូមសរសេរចម្លើយរបស់សិស្ស ដូចជា *ការរៀបចំខ្លួនខាងវិញ្ញាណ ទីបន្ទាល់ សេចក្តីជំនឿ ការប្រែចិត្តជឿ* និង *បទពិសោធន៍* នៅក្បែរ *ចង្កៀង និង ប្រេង* លើក្តារខៀន ។ ដើម្បីជាគំនិតបន្ថែមចំពោះនិមិត្តរូបរបស់ប្រេង អ្នកគួរណែនាំឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៤៥:៥៦–៥៧ ហើយយោងឆ្លងវាទៅ ម៉ាថាយ ២៥:៨) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងរឿងប្រៀបប្រដូចនេះ និង មកពីសេចក្តីអធិប្បាយរបស់ប្រធាន យីមប៊ីល អំពីការខ្វីនូវការរៀបចំខ្លួនខាងវិញ្ញាណ ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **យើងពុំអាចខ្វីការរៀបចំខាងវិញ្ញាណពីអ្នកដទៃបានឡើយ**) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងរឿងប្រៀបប្រដូចនេះ អំពីរបៀបត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរដោយការបង្កើនទីបន្ទាល់ និង ការប្រែចិត្តជឿរបស់យើងតាមរយៈសេចក្តីសុចរិតប្រចាំថ្ងៃ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ចូរឲ្យសំណៅ ឯកសារដែលភ្ជាប់មកជាមួយដល់សិស្សម្នាក់ៗ ។ សុំឲ្យពួកគេសរសេរនៅលើក្រដាសនោះពីរបៀបដែលពួកគេអាចទទួលបាន « ប្រេង » នៃការត្រៀមខ្លួនខាងវិញ្ញាណ ។

ការត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់

ដើម្បីត្រៀមខ្លួនសម្រាប់យាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ខ្ញុំនឹងបន្ថែម« ប្រេង » នៅក្នុង « ចង្កៀង »របស់ខ្ញុំដោយ ៖



ក្រោយពីមានពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សពីរបីនាក់ចែកចាយគំនិតមួយចំនួនរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបផ្សេងទៀតដែលពួកគេអាចប្រមូលប្រេងមួយដំណក់ម្តងៗ តាមរយៈការរស់នៅដោយសុចរិត សូមត្រិះរិះនូវការបង្ហាញវគ្គនៃវីដេអូដែលនៅសល់ « They That Are Wise » (កូដពេលវេលា ៥:៤៦–៨:៤៤) ។ សូមអញ្ជើញសិស្សបន្ថែមគំនិតនានាទៅក្នុងបញ្ជីរបស់ពួកគេ នៅពេលពួកគេមើលវីដេអូនេះ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ២៥:១០–១២ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលកូនកម្លោះបានថ្លែងទៅស្ត្រីព្រហ្មចារីដែលល្ងង់ខ្លៅ ។ សុំឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ២៥:១១ បញ្ជាក់ថាកូនកម្លោះបានថ្លែងថា « ខ្ញុំមិនស្គាល់នាងទេ » ។

- តើសេចក្តីថ្លែងថា « ខ្ញុំមិនស្គាល់នាងទេ » ប្រាប់យើងអ្វីខ្លះពីស្ត្រីព្រហ្មចារីដ៏ល្ងង់ខ្លៅ ? តើការស្គាល់ព្រះអម្ចាស់ ខុសពីការគ្រាន់តែដឹងពីទ្រង់ដោយរបៀបណា ?
- តើយើងអាចរៀនអ្វីខ្លះចេញពីខគម្ពីរនេះ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីត្រៀមខ្លួនជាស្រេច សម្រាប់ការយាងមករបស់ព្រះអម្ចាស់ ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមករបស់ព្រះអម្ចាស់ ហើយមានភាពសក្តិសមឈរនៅក្នុងវត្តមានរបស់ទ្រង់ យើងត្រូវស្គាល់ទ្រង់**) ។
- តើអ្នកបានមកស្គាល់ព្រះអង្គសង្គ្រោះ ឲ្យប្រសើរជាងមុនក្នុងពេលថ្មីៗនេះតាមរបៀបណាដែរ ?

សូមរំឭកសិស្សពីដំណើររឿងនៅដើមមេរៀននេះ:ស្តីពីអ្នកកាន់បព្វជិតភាពវ័យក្មេងម្នាក់ ដែលពុំបានត្រៀមខ្លួននៅក្នុងគ្រាដ៏ចាំបាច់មួយ ។ សូមពន្យល់ថា យុវជននោះបានប្រញាប់ប្រញាល់ទៅផ្ទះរបស់បុរសចំណាស់ម្នាក់នៅក្នុងរួសរបស់ខ្លួនដែលរស់នៅក្បែរផ្ទះរបស់គាត់ ។ បុរសចំណាស់នោះបានប្រសិទ្ធពរឲ្យប្អូនប្រុសយុវជននោះ ដើម្បីធ្វើឲ្យស្ថានភាពគាត់មានភាពនឹងធឹង រហូតដល់វេជ្ជបណ្ឌិតជំនួយបានមកដល់ ។ សុំឲ្យសិស្សម្នាក់អានឮៗនូវទីបន្ទាល់របស់យុវជននោះ ដែលអែលឌើរ ហូឡិន បានលើកឡើង ៖



« គ្មាននរណាម្នាក់ដែលមិនធ្លាប់ប្រឈមមុខ ដូចអ្វីដែលខ្ញុំប្រឈមមុខនៅយប់នោះ ដែលនឹងដឹងពីក្តីអាម៉ាសដែលខ្ញុំបានទទួលអារម្មណ៍ និង ក្តីសោកសៅដែលខ្ញុំទ្រាំទ្រចំពោះអារម្មណ៍ ដែលគ្មានភាពសក្តិសមដើម្បីប្រើបព្វជិតភាពដែលខ្ញុំកាន់នោះទេ ។ នេះគឺជាអនុស្សាវរីយ៍ដែលកាន់តែយឺចាប់សម្រាប់ខ្ញុំ ដោយសារវាគឺជាប្អូនប្រុសរបស់ខ្ញុំផ្ទាល់ ដែលត្រូវការខ្ញុំ និង ឪពុកម្តាយជាទីស្រឡាញ់ដែលមិនមែនជាសមាជិករបស់ខ្ញុំដែលមានការភ័យខ្លាចយ៉ាងខ្លាំង ហើយដែលមានសិទ្ធរំពឹងចង់បានច្រើនជាងនេះពីរូបខ្ញុំ ។ គាត់បាននិយាយថា ប៉ុន្តែនៅពេលខ្ញុំឈរនៅពីមុខអ្នកទាំងអស់គ្នាថ្ងៃនេះ នោះខ្ញុំអាចសន្យានឹងអ្នកបែបនេះ ។ ‹ ខ្ញុំមិនល្អឥតខ្ចោះនោះទេ ប៉ុន្តែចាប់តាំងពីយប់នោះមក ខ្ញុំមិនធ្លាប់ធ្វើអ្វីដែលធ្វើឲ្យខ្លួនខ្ញុំចាកចេញពីការទៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ជាមួយនឹងទំនុកចិត្ត ហើយអធិស្ឋានសម្រាប់ជំនួយរបស់ទ្រង់នៅពេលចាំបាច់ឡើយ ។ គាត់ទទួលស្គាល់ថា ‹ ភាពសក្តិសមផ្ទាល់ខ្លួន គឺជាសង្គ្រាមមួយនៅក្នុងពិភពលោកនេះ ដែលយើងរស់នៅ ប៉ុន្តែវាគឺសង្គ្រាមមួយដែលខ្ញុំមានជ័យជំនះ › ។ ខ្ញុំបានទទួលអារម្មណ៍ដឹងថាមានព្រមានដៃនៃការកាត់ទោសចង្អុលមកកាន់ខ្ញុំម្តងនៅក្នុងជីវិតខ្ញុំ ហើយបើសិនខ្ញុំអាចធ្វើអ្វីបាននោះ ខ្ញុំគ្មានបំណងទទួលអារម្មណ៍បែបនេះម្តងទៀតឡើយ ។ គាត់បានបញ្ចប់ថា ‹ ហើយប្រាកដណាស់ ខ្ញុំអាចធ្វើកិច្ចការទាំងនោះបាន *គ្រប់យ៉ាង* › » (« The Confidence of Worthiness » ទំព័រ ៥៩) ។

ចូរសុំឲ្យសិស្សពិចារណាពីអ្វីដែលពួកគេត្រូវធ្វើដើម្បី ត្រៀមខ្លួនខាងវិញ្ញាណសម្រាប់ការយាងមករបស់ព្រះអម្ចាស់ និង ដើម្បីមានភាពសក្តិសមឈរនៅក្នុងវត្តមានរបស់ទ្រង់ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យគូសរង្វង់ត្រង់ទង្វើមួយ ឬពីរដែលពួកគេបានសរសេរនៅលើក្រដាស ហើយដាក់គោលដៅមួយ ដើម្បីធ្វើតាមរបៀបដែលនឹងបង្កើនការត្រៀមខ្លួនខាងវិញ្ញាណរបស់ពួកគេ ។ សូមអញ្ជើញពួកគេយកក្រដាសរបស់ពួកគេទៅផ្ទះ: ទុកជាការរំឭកមួយពីគោលដៅរបស់ពួកគេ ។

មេរៀន ២៩

ម៉ាថាយ ២៥:១៤–៤៦

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានបង្រៀនពួកសិស្សរបស់ទ្រង់អំពីការយាងមកជាលើកទីពីររបស់ទ្រង់កាលគង់នៅលើភ្នំអូលីវ ទ្រង់បានលើកឡើងពីរឿងប្រៀបប្រដូចស្តីពីទេពកោសល្យ ។ ទ្រង់ក៏បានពន្យល់ផងដែរថា ទ្រង់នឹងញែកមនុស្សសុចរិតចេញពីមនុស្សទុច្ចរិតកាលទ្រង់យាងមកម្តងទៀត ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៥:១៤–៣០

ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់នូវរឿងប្រៀបប្រដូចស្តីពីទេពកោសល្យ

ពីមុនចាប់ផ្តើមថ្នាក់ សូមដាក់កាក់ប្រាំនៅផ្នែកម្ខាងនៃបន្ទប់ ហើយកាក់ពីរនៅផ្នែកម្ខាងទៀត ។ សូមដាក់កាក់ប្រាំបីទៀតនៅក្នុងហោប៉ៅរបស់អ្នក ។

ដើម្បីចាប់ផ្តើមមេរៀននេះ សូមអញ្ជើញសិស្សបីនាក់ឲ្យឡើងមកក្តារខៀន ដើម្បីជួយអ្នកសម្តែងរឿងប្រៀបប្រដូចមួយដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ ជាផ្នែកមួយនៃសេចក្តីបង្គាប់របស់ទ្រង់ទាក់ទិននឹងការយាងមកជាលើកទីពីររបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:១៤–១៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលអ្នកបម្រើម្នាក់ៗបានទទួល និងអ្វីដែលពួកគេបានធ្វើជាមួយនឹងវត្ថុនោះ: ។

- តើចៅហ្វាយបានឲ្យអ្វីខ្លះ: ទៅពួកអ្នកបម្រើរបស់គាត់ម្នាក់ៗ ? (សូមពន្យល់ថា ទេពកោសល្យនៅក្នុងរឿងប្រៀបប្រដូចនេះ: គឺជាចំនួនសរុបនៃទឹកប្រាក់ ។ សូមយកកាក់ប្រាំបីចេញពីហោប៉ៅរបស់អ្នក ហើយឲ្យសិស្សទីមួយកាក់ប្រាំ សិស្សទីពីរកាក់ពីរ និងសិស្សទីបីកាក់មួយ ។

- តើអ្នកបម្រើម្នាក់ៗបានធ្វើអ្វីខ្លះ: ជាមួយនឹងប្រាក់ដែលគាត់បានទទួលនោះ: ?

សូមអញ្ជើញសិស្សដែលមានកាក់ប្រាំទៅយកកាក់ប្រាំបន្ថែមទៀតពីផ្នែកម្ខាងនៃថ្នាក់ ។ ចូរសុំឲ្យសិស្សដែលមានកាក់ពីរទៅយកកាក់ពីរបន្ថែមទៀតពីផ្នែកម្ខាងទៀតនៃថ្នាក់ ។ សូមអញ្ជើញសិស្សដែលមានកាក់មួយយកកាក់របស់ខ្លួនលាក់ ឬធ្វើហាក់ដូចជាកប់កាក់នោះ: ។

ចូរសុំឲ្យសិស្សប្រគល់កាក់ទាំងនោះមកឲ្យអ្នកវិញ ហើយចូលទៅកន្លែងអង្គុយវិញ ។ សូមសរសេរកត្តាខាងក្រោមនេះនៃរឿងប្រៀបប្រដូចនៅលើ ក្តារខៀន (ដោយគ្មានការពន្យល់ន័យនៅក្នុងវង់ក្រចក) ៖

ចៅហ្វាយរបស់ពួកអ្នកបម្រើ (ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ)

ពួកអ្នកបម្រើ (ពួកសិស្សរបស់ព្រះអម្ចាស់)

ទេពកោសល្យ (អំណោយទាន និង សមត្ថភាពដែលព្រះអម្ចាស់ប្រទានឲ្យពួកសិស្សរបស់ទ្រង់)

- តើអ្វីអាចតំណាងឲ្យវត្ថុធាតុនៃរឿងប្រៀបប្រដូចនេះ: ? (សូមពន្យល់ថា អំណោយទាន និងសមត្ថភាពខ្លះដែលយើងមាននៅក្នុងជីវិតរមែងស្លាប់ត្រូវបានទទួល ហើយអភិវឌ្ឍនៅក្នុងជីវិតមុនឆាកជីវិតនេះ: ។ យើងអាចជ្រើសបន្តអភិវឌ្ឍអំណោយទានទាំងនោះ: និងអំណោយទានផ្សេងទៀតនៅក្នុងជីវិតរមែងស្លាប់) ។

- យោងតាម ម៉ាថាយ ២៥:១៥ហេតុអ្វីចៅហ្វាយឲ្យចំនួនប្រាក់ខុសៗគ្នាដល់អ្នកបម្រើម្នាក់ៗ ? (បន្ទាប់ពីសិស្សឆ្លើយ សូមចង្អុលបង្ហាញថា ឃ្លា « តាមដំរិះគេរៀងខ្លួន » គួរសបញ្ជាក់ថា ព្រះប្រទានដល់យើងម្នាក់ៗនូវអំណោយទាន និង សមត្ថភាពដែលត្រូវយើងត្រូវការស្របតាមកាលៈទេសៈរបស់យើង) ។

សូមអានឮៗនូវសំណួរខាងក្រោម ហើយសូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីវា ៖

- តើអ្នកគិតថា អ្នកបម្រើណាមួយដែលអ្នកនឹងឲ្យទេពកោសល្យប្រាំ ទេពកោសល្យពីរ ឬទេពកោសល្យមួយ ? ហេតុអ្វី ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:១៩–២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលលោកចៅហ្វាយបានមានបន្ទូលទៅកាន់អ្នកបម្រើដែលបានទទួលទេពកោសល្យប្រាំ ។

- តើចៅហ្វាយបាននិយាយអ្វីខ្លះទៅអ្នកបម្រើទីមួយ ?

សូមពន្យល់ថា ការតាំងឲ្យ « ត្រួតលើរបស់ជាច្រើនទៅទៀត » និង ការ « ប្រកបដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ » (ម៉ាថាយ ២៥:២១) សំដៅទៅលើការបំពេញសក្តានុពលដ៏ទេវភាពរបស់យើង និងការទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចជាមួយព្រះវរបិតាសួគ៌ ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីបទពិសោធន៍របស់អ្នកបម្រើទីមួយ ? (គោលការណ៍ខាងក្រោមនេះ: គឺជាគោលការណ៍មួយដែលសិស្សអាចរកឃើញ ៖ **ប្រសិនបើយើងប្រើអំណោយទាន និងសមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើងដោយស្មោះត្រង់នោះយើងអាចបំពេញសក្តានុពលដ៏ទេវភាពរបស់យើង ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

- តើគំរូមួយចំនួនស្តីពីរបៀបដែលយើងអាចប្រើអំណោយទាន និង សមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើងមានអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា អ្នកបម្រើទីពីរអាចត្អូញត្អែរនៅពេលគាត់បានឃើញថា អ្នកបម្រើទីមួយបានទទួលទេពកោសល្យច្រាំ ហើយគាត់បានទទួលតែពីរនាក់ ។ ផ្ទុយទៅវិញ គាត់បានប្រើទេពកោសល្យដែលគាត់បានទទួលនោះដោយស្មោះត្រង់ ។

សុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ២៥:២២–២៣ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលលោកចៅហ្វាយបានថ្លែងទៅកាន់អ្នកបម្រើដែលបានទទួលទេពកោសល្យពីរនោះ ។

- តើចៅហ្វាយបាននិយាយអ្វីខ្លះ ទៅអ្នកបម្រើដែលបានទទួលទេពកោសល្យពីរ ?
- ទោះបីជាលោកចៅហ្វាយនោះបានឲ្យចំនួនប្រាក់ខុសគ្នាដល់អ្នកបម្រើពីរនាក់ដំបូងក៏ដោយ ហេតុអ្វីក៏អ្នកគិតថាពួកគេទាំងពីរនាក់បានទទួលចម្លើយដូចគ្នាមកពីចៅហ្វាយរបស់ពួកគេ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ មកពីបទពិសោធន៍របស់បុរសដែលបានទទួលទេពកោសល្យពីរនោះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ព្រះអម្ចាស់នឹងប្រទានពរយើង ប្រសិនបើយើងប្រើអំណោយទាន និង សមត្ថភាពទាំងឡាយដែលបានប្រទានឲ្យដោយស្មោះត្រង់ ដោយពុំគិតថាយើងទទួលបានប៉ុន្មាន ឬជាអ្វីនោះទេ ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ចូរសុំឲ្យសិស្សសញ្ជឹងគិត ប្រសិនបើពួកគេធ្លាប់មានអារម្មណ៍ថា នរណាម្នាក់មានអំណោយទាន ឬសមត្ថភាពច្រើន ហើយប្រសើរជាងពួកគេ ។ សូមចង្អុលបង្ហាញគោលការណ៍ដែលអ្នកទើបតែសរសេរនៅលើក្តារខៀន ។

- តើការចងចាំគោលការណ៍នេះអាចជួយយើងបែបណាខ្លះ នៅពេលយើងមានអារម្មណ៍ថា នរណាម្នាក់បានទទួលអំណោយទានច្រើន ឬប្រសើរជាងអ្វីដែលយើងមាននោះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដោយអែលឌើរ ឡឺនចិន អិល ឃុក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖

« ការរីកចម្រើននៅក្នុងទេពកោសល្យរបស់យើង គឺជាការវាស់វែងដ៏ល្អបំផុតនៃការរីកចម្រើនផ្ទាល់ខ្លួន ។ . . . ការប្រៀបធៀបពរជ័យគឺជាការដកយកសេចក្តីអំណរយ៉ាងពិតប្រាកដ ។ យើងពុំអាចមានការដឹងគុណ និងការច្រណែនក្នុងពេលតែមួយបានឡើយ ។ ប្រសិនបើយើងពិតជាចង់មានព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយដកពិសោធន៍នូវអំណរ និងសុភមង្គល យើងគួរតែរកយកនៅក្នុងពរជ័យរបស់យើង ហើយមានអំណរគុណ » (« Rejoice! » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ២៩, ៣០) ។

- តើយើងអាចរកឃើញអំណោយទាន និងសមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើងដោយរបៀបណា ?

សូមឲ្យក្រដាសមួយសន្លឹកដល់សិស្សម្នាក់ៗ ហើយចូរសុំឲ្យពួកគេសរសេរឈ្មោះរបស់ខ្លួននៅផ្នែកខាងលើ ។ សូមអញ្ជើញពួកគេឲ្យហុចក្រដាសរបស់ខ្លួនទៅឲ្យសិស្ស ដែលអង្គុយនៅក្បែរពួកគេ ។ ចូរសុំឲ្យសិស្ស សរសេរ អំណោយទាន ឬសមត្ថភាពមួយដែលពួកគេមើលឃើញនៅក្នុងបុគ្គលដែលមានឈ្មោះនៅលើក្រដាសនោះ ។ សូមណែនាំពួកគេឲ្យបន្តហុចក្រដាសរបស់ពួកគេដល់សិស្សដទៃទៀត ហើយសរសេរពីអំណោយទាន និងសមត្ថភាពដែលពួកគេបានសង្កេតឃើញ ។

បន្ទាប់ពីពីរបីនាទីក្រោយមក ចូរសុំឲ្យសិស្សប្រគល់ប្រកាសនោះទៅម្ចាស់ដើមវិញ ។ ចូរឲ្យពេលសិស្សអានអំពីអំណោយទាន និងសមត្ថភាពដែលអ្នកផ្សេងមើលឃើញពួកគេមាន ។ រួចសុំឲ្យពួកគេសរសេរចម្លើយឆ្លើយនឹងសំណួរខាងក្រោមនេះ នៅលើក្រដាសរបស់ខ្លួន ៖

- តើវិធីមួយដែលអ្នកអាចប្រើអំណោយទានមួយរបស់អ្នក ដើម្បីជួយការងារបន្ថែមទៀតរបស់ព្រះអម្ចាស់គឺជាអ្វីទៅ ?

សូមចង្អុលបង្ហាញថា រឿងប្រៀបប្រដូចពីទេពកោសល្យ រួមបញ្ចូលទាំងការព្រមានអំពីអំណោយទាន និង សមត្ថភាពដែលយើងបានទទួល ។ សុំឲ្យសិស្សបីឬនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ២៥:២៤–៣០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលចៅហ្វាយឆ្លើយតបនឹងអ្នកបម្រើដែលបានលាក់ទេពកោសល្យ ។ បន្ទាប់ពីអាន ខទី ២៧ សូមពន្យល់ថាពាក្យ *ទាំងដើម ទាំងការ* មានន័យថាការប្រាក់ (ប្រាក់ចំណូលបានមកពីការវិនិយោគ ឬការឲ្យខ្ចីប្រាក់) ។

- ហេតុអ្វីបានជាអ្នកបម្រើចុងក្រោយលាក់ទេពកោសល្យរបស់គាត់ ? តើចៅហ្វាយបានឆ្លើយបែបណា ចំពោះការជ្រើសរើសរបស់អ្នកបម្រើម្នាក់នេះ ?
- ទោះបីជា អ្នកបម្រើនេះបានរក្សាប្រាក់ចៅហ្វាយខ្លួនមិនឲ្យបាត់ក៏ដោយ តើទង្វើខុសឆ្គងរបស់អ្នកបម្រើរូបនេះជាអ្វីទៅ ?
- តើអ្នកគិតថា ចៅហ្វាយនឹងតបទៅអ្នកបម្រើនេះយ៉ាងដូចម្តេច ប្រសិនបើគាត់បានយកទេពកោសល្យពីរត្រឡប់មកឲ្យវិញ ?
- តើមានអ្វីកើតឡើងចំពោះទេពកោសល្យ ដែលចៅហ្វាយបានផ្តល់ទៅឲ្យអ្នកបម្រើនោះ ? (វាត្រូវបានដកចេញពីគាត់ ហើយយកទៅឲ្យអ្នកបម្រើម្នាក់ទៀត) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ស្តើរលីង ដំបុលយូ សីល នៃពួកចិតសិបនាក់ ៖ ចូរសុំឲ្យសិស្សស្តាប់រកមើលហេតុផល ដែលយើងបានបាត់បង់អំណោយ និងលទ្ធភាពទាំងឡាយ ប្រសិនបើយើងមិនប្រើវាសម្រាប់សេចក្តីល្អនោះ ។



« ការបាត់បង់របស់ | អ្នកបម្រើទីបី | ពុំមែនដោយសារគាត់បានធ្វើរឿងខុសឆ្គងនោះទេ ប៉ុន្តែដោយសារការភ័យខ្លាចរបស់គាត់បានរារាំងគាត់ | ពី | ការធ្វើកិច្ចការទាំងឡាយ ។ ប៉ុន្តែនេះគឺជាដំណើរការ ដែលពរជ័យរបស់យើងភាគច្រើនត្រូវបានបាត់បង់ ។ . . .

« . . . កាលមនុស្សម្នាក់មិនបានប្រើសាច់ដុំរបស់គាត់ នោះគាត់នឹងបាត់បង់កម្លាំង ។ . . . កាលយើងមិនអភិវឌ្ឍសមត្ថភាពរបស់យើង នោះយើងបាត់បង់សមត្ថភាពរបស់យើង ។ កាលមនុស្សពីបុរាណពុំបានគោរពបព្វជិតភាព វា

បណ្តុះបរិយាកាសសិក្សារៀនសូត្រដោយសេចក្តីស្រឡាញ់ ការគោរព និងគោលបំណង

នៅពេលសិស្សទាំងឡាយដឹងថាពួកគេត្រូវបានស្រឡាញ់ និងគោរពដោយគ្រូនិងសិស្សផ្សេងទៀត នោះពួកគេកាន់តែចូលចិត្តមកកាន់ថ្នាក់ដោយត្រៀមខ្លួនជាស្រេចដើម្បីរៀន ។ ការទទួលយក និងសេចក្តីស្រឡាញ់ដែលពួកគេទទួលបានអាចបន្ធន់ចិត្តរបស់ពួកគេ ងាប់ការភ័យខ្លាចរបស់ពួកគេ ហើយបណ្តុះបំណងប្រាថ្នា និងទំនុកចិត្តដែលចាំបាច់ ដើម្បីចែកចាយគំនិតបទពិសោធន៍ និងអារម្មណ៍របស់ពួកគេនៅក្នុងថ្នាក់ ។


ត្រូវបានដកយកចេញពីពួកគេ ។ . . . គ្មានទេពកោសល្យខាងវិញ្ញាណ ខាងផ្លូវចិត្ត ឬផ្លូវកាយណាមួយអាចរីកចម្រើនបានឡើយកាលវាត្រូវបានយកទៅកប់នៅក្នុងដីនោះ » (*The Law of the Harvest* ⏐ ឆ្នាំ ១៩៦៣ ⏐ ទំព័រ ៣៧៥) ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីអ្នកបម្រើដែលបានលាក់ទុកទេពកោសល្យនោះ ? (ទោះជាសិស្សប្រហែលជាផ្តល់យោបល់ អំពីគោលការណ៍ខុសៗគ្នាក្តី សូមធ្វើឲ្យប្រាកដថាពួកគេរកឃើញសេចក្តីពិតដូចខាងក្រោម ៖ **ការភ័យខ្លាចអាចរារាំងយើងមិនឲ្យប្រើអំណោយទាន និងសមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យ ។ ប្រសិនបើយើងមិនអភិវឌ្ឍ ហើយប្រើអំណោយទានខាងវិញ្ញាណរបស់យើងសម្រាប់សេចក្តីល្អទេ នោះយើងនឹងបាត់បង់វា**) ។
- តើការភ័យខ្លាចអាចរារាំងយើងមិនឲ្យធ្វើកិច្ចការល្អដោយប្រើអំណោយទាន និងសមត្ថភាពរបស់យើងបានដោយរបៀបណា ?

សូមអញ្ជើញសិស្សថ្លែងទីបន្ទាល់ អំពីគោលការណ៍ដែលពួកគេបានពិភាក្សា ។ សូមលើកទឹកចិត្តពួកគេឲ្យប្រើអំណោយទាន និងសមត្ថភាពរបស់ពួកគេដើម្បីពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។

ម៉ាថាយ ២៥:៣១–៤៦

ព្រះអង្គសង្គ្រោះមានបន្ទូលប្រាប់ទុកជាមុន អំពីការញែកមនុស្សទុច្ចរិតចេញពីមនុស្សសុចរិតនៅពេលនៃការយាងមកជាលើកទីពីររបស់ទ្រង់ ។



ចូរដាក់បង្ហាញរូបភាព ការយាងមកជាលើកទីពីរ (*Gospel Art Book* ⏐ ឆ្នាំ ២០០៩ ⏐ ទំព័រ ៦៦សូមមើលផងដែរ LDS.org) ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:៣១–៣៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអម្ចាស់ នឹងធ្វើជាមួយនឹងមនុស្សនៅលើផែនដី បន្ទាប់ពីការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើព្រះអម្ចាស់នឹងដូចម្តេចខ្លះជាមួយនឹងមនុស្សនៅលើផែនដីបន្ទាប់ពីការយាងមកជាលើកទីពីររបស់ទ្រង់ ?
- តើព្រះអម្ចាស់បានប្រើសត្វណាខ្លះ ដើម្បីតំណាងឲ្យមនុស្សទុច្ចរិត ? ចុះមនុស្សសុចរិតវិញ ?

សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញដៃគូពាក់កណ្តាលអាន ម៉ាថាយ ២៥:៣៤–៤០ ឲ្យឮៗរួមគ្នា ដោយរកមើលរបៀបដែលព្រះអម្ចាស់នឹងកំណត់ថាជា « កូនចៀម » (ម៉ាថាយ ២៥:៣២–៣៣) ។ សូមអញ្ជើញដៃគូពាក់កណ្តាលទៀតអាន ម៉ាថាយ ២៥:៤១–៤៦ ឲ្យឮៗរួមគ្នា ដោយរកមើលរបៀបដែលព្រះអម្ចាស់នឹងកំណត់ថាជា « សត្វពពែ » (ម៉ាថាយ ២៥:៣២–៣៣) ។

លុះដល់ពេលកំណត់ហើយ សូមឲ្យដៃគូនីមួយៗធ្វើការជាមួយដៃគូដែលអានខគម្ពីរខុសៗគ្នា ។ ចូរសុំឲ្យសិស្សសង្ខេបពីអ្វីដែលពួកគេបានអាន ហើយពិភាក្សាសំណួរខាងក្រោមនៅក្នុងក្រុមរបស់ខ្លួន ៖

- តើព្រះអម្ចាស់សម្គាល់បែងចែករវាងជនដែលស្រឡាញ់ទ្រង់ (កូនចៀម) និងជនដែលមិនស្រឡាញ់ទ្រង់ (សត្វពពែ) ដោយរបៀបណា ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ?

សូមអញ្ជើញមនុស្សម្នាក់ពីក្រុមនីមួយៗឲ្យសរសេរគោលការណ៍ ដែលក្រុមខ្លួនបានរកឃើញនៅលើក្តារខៀន ។ សិស្សគួររកឃើញគោលការណ៍ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងស្រឡាញ់ ហើយបម្រើមនុស្សដទៃ នោះយើងបង្ហាញសេចក្តីស្រឡាញ់យើងចំពោះព្រះអម្ចាស់ ។ នៅពេលយើងមិនយកចិត្តទុកដាក់ពីសេចក្តីត្រូវការរបស់មនុស្សដទៃ នោះយើងមិនយកចិត្តទុកដាក់នឹងព្រះអម្ចាស់ដែរ ។**

ដើម្បីជួយសិស្សយល់ដឹងពីគោលការណ៍ទាំងនេះ ចូរសួរសំណួរស្រដៀងគ្នានឹងសំណួរខាងក្រោមនេះ ៖

- តើមនុស្សដែលនៅខាងស្តាំព្រះហស្តនៃព្រះអម្ចាស់ប្រព្រឹត្តចំពោះប្អូនស្រីខ្លួន ដែលកំពុងសូមឲ្យជួយធ្វើកិច្ចការសាលារបស់នាងយ៉ាងដូចម្តេច ?
- តើមនុស្សដែលនៅព្រះហស្តខាងឆ្វេងរបស់ព្រះអម្ចាស់ អាចប្រព្រឹត្តចំពោះមិត្តក្នុងថ្នាក់ម្នាក់ដែលជ្រុះសៀវភៅនាងនៅតាមសាលសាលារៀនយ៉ាងដូចម្តេចដែរ ?
- តើការយល់ដឹងគោលការណ៍ទាំងនេះ អាចជួយយើងឲ្យកែលម្អទំនាក់ទំនងរបស់យើងជាមួយនឹងអ្នកដទៃយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេធ្លាប់ប្រព្រឹត្តចំពោះមនុស្សដទៃក្នុងអំឡុងពេល ២៤ ម៉ោងកន្លងមកនេះ ។ សូមអញ្ជើញពួកគេពិចារណាថា តើពួកគេនឹងជ្រើសធ្វើខុសពីមុនទេ ប្រសិនបើពួកគេស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នានៅពេលអនាគតនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតពីរបៀបដែលពួកគេអាចស្រឡាញ់ ហើយបម្រើដល់មនុស្សដទៃជានិច្ច ហើយអញ្ជើញពួកគេឲ្យធ្វើតាមដែនការរបស់ខ្លួន ។ អ្នកគួរតាមដានសិស្សនៅពេលក្រោយពេលបានជួបនឹងពួកគេ ហើយអញ្ជើញពួកគេឲ្យប្រាប់ពីបទពិសោធន៍ដែលមានមួយចំនួនរបស់ពួកគេ ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

ម៉ាថាយ ២៥:៣៥–៤០ ។ បទបង្ហាញជាវីដេអូ— « អាវក្រៅ »

ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈនៃការជួយដល់មនុស្សដទៃដែលខ្វះខាតដូចបានរៀបរាប់នៅក្នុង ម៉ាថាយ ២៥:៣៥–៤០សូមពិចារណាបង្ហាញវីដេអូ « The Coat (អាវក្រៅ) » (២:០៨) ដែលបង្ហាញពីព្រឹត្តិការណ៍មួយនៅក្នុងកុមារភាពរបស់ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត ។ វីដេអូនេះមាននៅក្នុង LDS.org ។ សូមអញ្ជើញសិស្សឲ្យមើលវីដេអូនេះ រកមើលថាតើក្មេងប្រុសនោះបានបម្រើដល់នរណា ។

ម៉ាថាយ ២៦:១–៣០

សេចក្តីផ្តើម

ពីរថ្ងៃមុនថ្ងៃបុណ្យរំលង យូដាសបានផ្សំគំនិតជាមួយពួកអ្នកដឹកនាំយូដាដែលមានបំណងចង់ធ្វើគុតព្រះយេស៊ូវ ។ នៅយប់នៃបុណ្យរំលង ព្រះយេស៊ូវបានតាំងពិធីសាក្រាម៉ង់ឡើង ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៦:១–១៦

យូដាសរួមគំនិតនឹងពួកអ្នកដឹកនាំយូដា ដែលមានបំណងចង់ធ្វើគុតព្រះយេស៊ូវ

មុនពេលបង្រៀន ចូររៀបចំតុមួយដែលមានកម្រាល ហើយដាក់បន្ទះនំប៉័ងពីរបីបន្ទះ (ឬ នំប្រៃ) និងពែងមួយនៅលើតុនោះ ។ បន្ទាប់ពីការប្រជុំធម្មនិដ្ឋាន សូមពន្យល់ថានៅសម័យព្រះគ្រីស្ទ នៅក្នុងចំណោមវត្ថុទាំងនេះគឺមានដាក់នៅលើតុរបស់សាសន៍យូដានៅក្នុងបុណ្យរំលង ។

- តើអ្វីទៅជាគោលបំណងនៃអាហារសម្រាប់បុណ្យរំលង ? (បុណ្យរំលងត្រូវបានធ្វើឡើងនៅសម័យម៉ូសេ ដើម្បីរំឭកកូនចៅអ៊ីស្រាអែលថា ពួកទេវតាបំផ្លាញបានដើររំលងផ្ទះរបស់ពួកគេ ហើយបានសម្លាប់កូនច្បងនៅស្រុកអេស៊ីព្ទ | សូមមើល និក្ខមនំ ១២:២១–២៨, ១៣:១៤–១៥ | ។ ជាផ្នែកនៃបុណ្យរំលង ពួកអ៊ីស្រាអែលបានបូជាចៀមមួយក្បាល ហើយយកឈាមវាទៅលាបនៅលើមាត់ទ្វាររបស់ពួកគេ ។ ចៀមនេះតំណាងឲ្យព្រះមែស៊ីដែលនឹងយាងមក ដែលពលិកម្មធួនរបស់ទ្រង់នឹងសង្គ្រោះដល់មនុស្សលោកពីសេចក្តីស្លាប់ និងអំពើបាប | សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « បុណ្យរំលង » scriptures.lds.org |) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:១–២ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវ បានមានបន្ទូលថានឹងកើតឡើងក្រោយពីបុណ្យរំលង ។

- តើព្រះយេស៊ូវបានមានបន្ទូលថានឹងមានអ្វីកើតឡើងក្រោយពីបុណ្យរំលង ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:៣–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម និងរកមើលថាតើនរណាទៅដែលបានរៀបផែនការធ្វើគុតព្រះយេស៊ូវនៅពេលនេះ ។

- ហេតុអ្វីពួកអាចារ្យ និងពួកមេសង្ឃបានសម្រេចចិត្តរង់ចាំរហូតដល់ក្រោយបុណ្យរំលងដើម្បីធ្វើគុតព្រះយេស៊ូវ ?

សូមសង្ខេប ម៉ាថាយ ២៦:៦–១៣ ដោយពន្យល់ថា កាលព្រះយេស៊ូវគង់នៅភូមិបេថានី មានស្ត្រីម្នាក់បានមករកទ្រង់ហើយចាក់ប្រេងលាបទ្រង់ជាមួយនឹងប្រេងដ៏ថ្លៃបំផុត ដើម្បីទទួលស្គាល់នូវការសុគត និងការបញ្ចុះសពរបស់ទ្រង់ដែលនឹងមកដល់ ។ ពួកសិស្សរបស់ទ្រង់មួយចំនួន រួមទាំងយូដាស ដែលជាសាវកម្នាក់ក្នុងចំណោមពួកសាវកដប់ពីរនាក់ និងជាអ្នកក្សាទ្រព្យរបស់ក្រុមនេះ បានត្អូញត្អែរថា ប្រេងនោះគួរយកទៅលក់ដើម្បីជួយដល់អ្នកក្រីក្រវិញ ។ ទោះជាយ៉ាងណាក៏ដោយ យូដាស ពុំបានខ្វល់ខ្វាយនឹងពួកអ្នកក្រីក្រទេ ប៉ុន្តែគាត់ជាចោរម្នាក់ដែលចង់បានប្រាក់សម្រាប់តែខ្លួនឯងវិញ (សូមមើល យ៉ូហាន ១២:៤–៦) ។ (*កំណត់ចំណាំ ៖* ការលាបប្រេងលើរបស់ព្រះយេស៊ូវ នៅភូមិបេថានីត្រូវបានលើកយកមកពិភាក្សាយ៉ាងពេញលេញនៅក្នុងមេរៀនម៉ាកុស ១១–១៤) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:១៤–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីយូដាសបានធ្វើបន្ទាប់ពីព្រះអង្គសង្គ្រោះ បានស្តីបន្ទោសគាត់ដោយសារការត្អូញត្អែរ ។

- តើយូដាសបានធ្វើអ្វីខ្លះ ? (គាត់បានផ្សំគំនិតជាមួយពួកមេសង្ឃ ដើម្បីជួយពួកគេតាមរក ហើយចាប់ព្រះយេស៊ូវ) ។
- តើពួកមេសង្ឃបានឲ្យប្រាក់ដល់យូដាសប៉ុន្មាន ដើម្បីប្រគល់ព្រះយេស៊ូវឲ្យពួកគេ ?

សូមពន្យល់ថា « យោងតាមក្រឹត្យវិន័យរបស់ម៉ូសេ ប្រាក់សាមសិបកាក់ត្រូវសងដល់ចៅហ្វាយសម្រាប់ការស្លាប់របស់បាវម្នាក់ (សូមមើល និក្ខមនំ ២១:៣២) ។ . . . ថ្លៃសម្រាប់ការក្បត់នោះ បង្ហាញពីសេចក្តីគោរពដ៏ស្តួចស្តើងដែលយូដាស និងពួកមេសង្ឃមានចំពោះព្រះអង្គសង្គ្រោះ » (*New Testament Student Manual* | Church Educational System manual ឆ្នាំ ២០១៤ | ទំព័រ ៨១) ។ វាក៏បានបំពេញការព្យាករក្នុងព្រះគម្ពីរសញ្ញាចាស់ ស្តីពីការក្បត់របស់យូដាសចំពោះព្រះអង្គសង្គ្រោះ (សូមមើល សាការី ១១:១២) ។

ម៉ាថាយ ២៦:១៧–២៥

ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ទទួលទានអាហារបុណ្យរំលង

ចូរដាក់បង្ហាញកញ្ចក់មួយ រួចសួរ ៖

- តើកញ្ចក់អាចមានប្រយោជន៍អ្វីខ្លះចំពោះយើង ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

ចូររៀបចំមេរៀននីមួយៗដោយគិតពីសិស្សរបស់អ្នក

នៅពេលអ្នករៀបចំបង្រៀន ចូរពិចារណាពីរបៀបដែលអ្នកសង្ឃឹមថា សិស្សនឹងអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងមេរៀននោះ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានរំឭកដល់គ្រូបង្រៀនដំណឹងល្អ ៖ « គោលដៅនៃការបង្រៀនដំណឹងល្អ. . .គឺពុំមែនដើម្បី ‹ ចាក់បញ្ចូលព័ត៌មាន › ទៅក្នុងគំនិត សិស្សនោះទេ ។ . . . *គោលដៅនោះគឺដើម្បីបំផុសគំនិតដល់បុគ្គលម្នាក់ៗឲ្យគិត ឲ្យមានអារម្មណ៍ដឹង ហើយបន្ទាប់មក ឲ្យបញ្ចេញសកម្មភាពបែបណាមួយអំពីការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ* » (នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៧០ ទំព័រ ១០៧) ។



« ជារឿយៗ យើងព្យាយាមចៀសវាងការមើលចូលយ៉ាងជ្រៅទៅក្នុងព្រលឹងយើង និងការប្រឈមនឹងភាពទន់ខ្សោយ ដែនកំណត់ និងភាពភ័យខ្លាចរបស់យើង ។ . . .

« ប៉ុន្តែការដែលយើងមើលឃើញខ្លួនឯងឲ្យច្បាស់ គឺជាកត្តាដ៏ចាំបាច់ចំពោះសុខុមាលភាព និងការរីកចម្រើនខាងវិញ្ញាណរបស់យើង ។ . . .

« ខ្ញុំសូមឲ្យយោបល់ថា ព្រះគម្ពីរបរិសុទ្ធនិង សុន្ទរកថាដែលផ្តល់ឲ្យក្នុង សន្និសីទទូទៅគឺជា កញ្ចក់ឆ្លុះបញ្ចាំងដ៏មានប្រសិទ្ធភាពមួយ ដែលយើងអាចយកមកឆ្លុះមើលខ្លួនឯងបាន » (« Lord, Is It I? » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៥៨) ។

- តើព្រះគម្ពីរ និងសុន្ទរកថាដែលបានលើកឡើងនៅឯសន្និសីទទូទៅ អាចប្រៀបបាននឹងកញ្ចក់ដូចម្តេចដែរ ?

នៅពេលសិស្សសិក្សា ម៉ាថាយ ២៦:១៧–២៥ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេឲ្យស្គាល់ពីភាពទន់ខ្សោយរបស់ពួកគេ ហើយខិតខំដើម្បីយកឈ្នះលើវា ។

សូមសង្ខេប ម៉ាថាយ ២៦:១៧–១៩ ដោយពន្យល់ថា ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកសិស្សរបស់ទ្រង់ ដើម្បីកក់បន្ទប់មួយនៅយេរូសាឡិមសម្រាប់អាហារបុណ្យរំលង ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:២០–២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវ បានមានបន្ទូលប្រាប់ពួកសាវករបស់ទ្រង់នៅក្នុងអាហារបុណ្យរំលង ។

- តើព្រះយេស៊ូវបានមានបន្ទូលពីអ្វីខ្លះទៅកាន់ពួកសាវករបស់ទ្រង់ ?
- ប្រសិនបើអ្នកជាសាវកម្នាក់ តើអ្នកប្រហែលនឹងគិតពីរឿងអ្វីខ្លះនៅគ្រានេះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:២២ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលចម្លើយរបស់ពួកសាវកតបនឹងបន្ទូលរបស់ព្រះយេស៊ូវ ។

- តើពួកសាវកបានទូលសួរសំណួរអ្វីខ្លះ ?
- តើសំណួរសួរថា « ព្រះអម្ចាស់អើយ តើទូលបង្គំឬអី? » បង្រៀនអ្វីខ្លះដល់យើងអំពីពួកសាវកដ៏ស្មោះត្រង់ទាំងដប់មួយនាក់នោះ ?
- យោងតាមដំណើររឿងនេះ តើយើងអាចរៀនគោលការណ៍អ្វីខ្លះអំពីរបៀបដែលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្តគួរឆ្លើយតប នៅពេលពួកគេស្តាប់បន្ទូលរបស់ព្រះអម្ចាស់នោះ ? (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្តស្តាប់ឮបន្ទូលរបស់ព្រះអម្ចាស់ ពួកគេត្រូវពិនិត្យពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីមើលថាតើបន្ទូលនោះអនុវត្តចំពោះពួកគេយ៉ាងដូចម្តេចដែរ**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន អុជដូហ្ស ឲ្យឮៗ ៖

« ពួកសិស្សមិនបានសង្ស័យអំពីសេចក្តីពិតនូវអ្វីដែល | ព្រះយេស៊ូវ |បានមានបន្ទូលឡើយ ។ ហើយក៏មិនបានមើលជុំវិញខ្លួនចង្អុលទៅមនុស្សម្នាក់ផ្សេងទៀត ហើយទូលសួរថា ‹ តើគាត់មែនទេ? › ។

« ផ្ទុយទៅវិញ ‹ ពួកគេមានសេចក្តីព្រួយជាខ្លាំង ហើយចាប់តាំងទូលសួរទ្រង់ថា *ព្រះអម្ចាស់អើយតើទូលបង្គំឬអី?* › | ម៉ាថាយ ២៦:២២ | ។

« ខ្ញុំចង់ដឹងថាតើពួកយើងម្នាក់ៗនឹងធ្វើអ្វីខ្លះ . . . តើយើងនឹងក្រឡេកមើលអ្នកនៅជុំវិញខ្លួនយើង ហើយគិតក្នុងចិត្តថា ‹ ទ្រង់ប្រហែលជាមានបន្ទូលពីបងប្រុស ចនសុន ហើយមើលទៅ ។ ខ្ញុំតែងងឿងឆ្ងល់អំពីគាត់ › ឬ ‹ ខ្ញុំរីករាយណាស់ដែលបងប្រុស ប្រោន នៅទីនេះ ។ គាត់ពិតជាត្រូវការឮសារលិខិតនេះ › ? ឬតើយើងនឹងមើលមកខ្លួនឯង ហើយទូលសួរសំណួរដ៏សំខាន់នោះ ដូចជាពួកសាវកពីបុរាណ ៖ ‹ តើខ្ញុំឬអី? › (« *Lord, Is It I?* » ទំព័រ ៥៦) ។

- តើឧទាហរណ៍មួយចំនួនណាខ្លះ ស្តីពីរបៀបដែលយើងនឹងត្រូវបានល្បួងឲ្យបដិសេធព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយសន្និដ្ឋានថាវាសំដៅទៅលើអ្នកផ្សេងម្នាក់ទៀត ?

សូមអញ្ជើញសិស្សម្នាក់ទៀតអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អុជដូហ្ស ឲ្យឮៗ ហើយសុំឲ្យក្នុងថ្នាក់ស្តាប់រកអ្វីដែលប្រធាន អុជដូហ្ស អញ្ជើញយើងឲ្យធ្វើ នៅពេលយើងស្តាប់ឮព្រះបន្ទូលរបស់ព្រះអម្ចាស់ ៖

ក្នុងឃ្លាដ៏សាមញ្ញនេះ ‹ *ព្រះអម្ចាស់អើយ តើទូលបង្គំឬអី?* › គឺការចាប់ផ្តើមនៃប្រាជ្ញា និង មាគ៌ាឆ្ពោះទៅកាន់ការប្រែចិត្តជឿផ្ទាល់ខ្លួន និងការផ្លាស់ប្តូរដ៏អស់កល្ប។ . . .

បងប្អូនប្រុស យើងត្រូវតែដាក់ភាពឆ្មើងឆ្មៃយើងមួយអន្លើរ មើលឲ្យហួសពីអំនួតយើង ហើយទូលសួរព្រះដោយចិត្តរាបទាបថា ‹ *ព្រះអម្ចាស់អើយ តើទូលបង្គំឬអី?* ›

« ហើយបើចម្លើយរបស់ព្រះអម្ចាស់ឆ្លើយតបថា ‹ ពិតណាស់ បុត្រា | ឬបុត្រី | យើងអើយ មានរឿងជាច្រើនដែលអ្នកត្រូវកែលម្អ ជារឿងដែលយើងអាចជួយអ្នកឲ្យយកឈ្នះបាន › ខ្ញុំសូមអធិស្ឋានថា យើងនឹងទទួលយកចម្លើយនេះ ទទួលស្គាល់អំពើបាប និង កំហុសយើងដោយចិត្តរាបទាប ហើយផ្លាស់ប្តូរមាគ៌ារបស់យើង ដោយក្លាយជាស្ងាមី ឪពុក និងកូនប្រុសកាន់តែល្អប្រសើរ » (« Lord, Is It I? » ទំព័រ ៥៦, ៥៨) ។

- តើអ្នកធ្លាប់ទទួលបានពរជ័យតាមរបៀបណាដែរ នៅពេលអ្នកបានអនុវត្តតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ហើយធ្វើការផ្លាស់ប្តូរនៅក្នុងជីវិតរបស់អ្នក ?

សូមថ្លែងទីបន្ទាល់អំពីគោលការណ៍ដែលសិស្សបានបង្ហាញពីមុន ។ សូមអញ្ជើញសិស្សឲ្យពិនិត្យមើលជីវិតរបស់ពួកគេនៅពេលណាដែលពួកគេស្តាប់ឮ ឬអានព្រះបន្ទូលរបស់ ព្រះអម្ចាស់ ហើយធ្វើតាមយ៉ាងឆាប់រហ័សតាមការបំផុសដែលពួកគេបានទទួល ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:២៣–២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះសំណួររបស់ពួកសាវក ។

សូមពន្យល់ថា មួយរំពេចបន្ទាប់ពីព្រះយេស៊ូវបានបង្ហាញថា យូដាសជាមនុស្សម្នាក់ដែលនឹងក្បត់ទ្រង់ យូដាសក៏ចេញទៅ (សូមមើល យ៉ូហាន ១៣:៣០) ។

ម៉ាថាយ ២៦:២៦–៣០

ព្រះយេស៊ូវគ្រីស្ទតាំងពិធីសាក្រាម៉ង់ឡើងអំឡុងបុណ្យរំលង ។



ចូរដាក់បង្ហាញរូបភាព អាហារយប់ថ្ងៃចុងក្រោយ (*Gospel Art Book* ⁄ ២០០៩ ⁄ ល.រ. ៥៤សូមមើលផងដែរ LDS.org) ។ សូមប្រាប់សិស្សថា កាលព្រះអង្គសង្គ្រោះសោយអាហារបុណ្យរំលងជាមួយនឹងពួកសាវកទ្រង់រួចហើយ នោះទ្រង់បានតាំងពិធីបរិសុទ្ធនៃសាក្រាម៉ង់ឡើង ។

សូមអញ្ជើញសិស្សឲ្យសរសេរចម្លើយរបស់ពួកគេឆ្លើយនិងសំណួរខាងក្រោមនេះ: នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ (អ្នកគួរសរសេរសំណួរទាំងនេះនៅលើក្តារខៀនពីមុនថ្នាក់ចាប់ផ្តើម) ៖

នៅពេលចុងក្រោយបង្អស់ ដែលអ្នកបានទទួលទានសាក្រាម៉ង់ តើអ្នកកំពុងធ្វើអ្វីខ្លះ ? តើអ្នកគិតអ្វីខ្លះ ? តើអ្នកមានអារម្មណ៍យ៉ាងណាដែរ ?

សូមលើកពែង និងនំប៉័ងដែលបានដាក់បង្ហាញនៅលើតុឡើង ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:២៦–២៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអម្ចាស់បានធ្វើជាមួយនឹងនំប៉័ង និងធាតុក្នុងពែងនោះ: ។

- តើព្រះអម្ចាស់បានធ្វើ អ្វីខ្លះជាមួយនឹងនំប៉័ង និងធាតុក្នុងពែងនោះ: ?
- យោងតាមខគម្ពីរទាំងនេះ: តើនិមិត្តរូបនៃសាក្រាម៉ង់តំណាងឲ្យអ្វី ? (សិស្សគួរតែរកឃើញគោលលទ្ធិដូចតទៅនេះ: ៖ **និមិត្តរូបនៃសាក្រាម៉ង់តំណាងឲ្យព្រះកាយ និងព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ដែលបានទ្រង់បានបូជាជំនួសយើង**) ។

សូមពន្យល់ថាសិស្សថា ការបកប្រែដោយយ៉ូសែប ស្ម៊ីធ ផ្តល់នូវគំនិតបន្ថែមទៀតសម្រាប់ខគម្ពីរទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យអានស្ងាត់ៗពីសេចក្តីដកស្រង់ចេញពីការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ ២៦:២២ ដែលមាននៅក្នុង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។ ក៏សូមអញ្ជើញពួកគេឲ្យអាន ការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ ២៦:២៤–២៥ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ផងដែរ ។ ចូរសុំឲ្យសិស្សរកមើលការផ្លាស់ប្តូរដ៏បំផុសគំនិតអ្វី ខ្លះដែលត្រូវបានធ្វើឡើងចំពោះខគម្ពីរទាំងនេះ ដែលអាចជួយយើងឲ្យយល់ដឹងពីគោលបំណងដ៏សំខាន់មួយនៃសាក្រាម៉ង់ ។

- ហេតុអ្វីព្រះយេស៊ូវគ្រីស្ទបានតាំងពិធីសាក្រាម៉ង់ឡើង ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ព្រះយេស៊ូវគ្រីស្ទបានតាំងពិធីសាក្រាម៉ង់ឡើង ដើម្បីឲ្យយើងចងចាំទ្រង់ និងដង្វាយធួនរបស់ទ្រង់សម្រាប់អំពើបាបរបស់យើង**) ។
- តើរឿងមួយចំនួនណាខ្លះ ដែលយើងអាចធ្វើដើម្បីធ្វើឲ្យប្រាកដថា សាក្រាម៉ង់ជួយយើងឲ្យចងចាំដល់ព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់សម្រាប់អំពើបាបរបស់យើង ?
- តើការព្យាយាមចងចាំដល់ព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់បានជះឥទ្ធិពលដល់អារម្មណ៍ និងបទពិសោធន៍របស់អ្នក កាលកំពុងទទួលទានសាក្រាម៉ង់យ៉ាងដូចម្តេចដែរ ?

ដើម្បីជួយសិស្សឲ្យរកឃើញគោលការណ៍មួយទៀត សូមសួរ ៖

- យោងតាមខទី ២៧–២៨តើការបង្ហូរព្រះលោហិតរបស់ព្រះគ្រីស្ទអនុញ្ញាតឲ្យយើងទទួលអ្វីខ្លះ: នៅពេលយើងទទួលទានសាក្រាម៉ង់ ? (ការផ្តាច់បាបរបស់យើង) ។

ចូរចង្អុលបង្ហាញថា ការដែលទទួលទាននំប៉័ង និងទឹកតែម្យ៉ាងនៅក្នុងពេលសាក្រាម៉ង់ពុំបានធ្វើឲ្យយើងមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការផ្តាច់បាប ឬការអភ័យទោសពីអំពើបាបរបស់យើងដោយស្វ័យប្រវត្តិឡើយ ។ យើងត្រូវតែអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ហើយទទួលទានសាក្រាម៉ង់ដោយស្មោះអស់ពីចិត្តដោយចងចាំដល់ទ្រង់ជានិច្ច ហើយព្យាយាមគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ដោយទទួលទានសាក្រាម៉ង់យ៉ាងសក្តិសម យើងរំឭកចាំសេចក្តីសញ្ញាបុណ្យជ្រមុជទឹករបស់យើង ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ៖ **នៅពេលយើងប្រែចិត្ត ហើយទទួលទានសាក្រាម៉ង់ដោយស្មោះអស់ពីចិត្ត យើងអាចទទួលការផ្តាច់បាបរបស់យើងបាន ។**

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេពី របៀបដែលពួកគេនឹងអនុវត្តសេចក្តីពិតទាក់ទងនឹងពិធីសាក្រាម៉ង់ដែលពួកគេបានរកឃើញ នៅក្នុង ម៉ាថាយ ២៦ ។ សូមអញ្ជើញសិស្សពីរបីនាក់ដែលចង់ចែកចាយអារម្មណ៍របស់ខ្លួន ឲ្យចែកចាយចម្លើយរបស់ពួកគេដល់សិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:២៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពេលណា ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់នឹងទទួលទានសាក្រាម៉ង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា « សាក្រាម៉ង់ពុំមែនគ្រាន់តែជានិមិត្តរូបពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការទន្ទឹងរង់ចាំដល់គ្រាដែលទ្រង់នឹងត្រឡប់មកផែនដីក្នុងសិរីល្អផងដែរ (សូមមើល ភូរិនថូសទី ១ ១១:២៦) » (*New Testament Student Manual* ទំព័រ ៨៣) ។ ប្រសិនបើយើងរក្សាសេចក្តីសញ្ញារបស់យើង ហើយកាន់ខ្ជាប់ដរាបដល់ទីបញ្ចប់ នោះយើងអាចស្ថិតនៅក្នុងចំណោមអស់អ្នកដែលទទួលទានសាក្រាម៉ង់ជាមួយនឹងព្រះអង្គសង្គ្រោះនាពេលអនាគត (សូមមើល គ. និង ស. ២៧:៤–១៤) ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយ ដែលបានប្រាប់នៅក្នុងមេរៀនថ្ងៃនេះ ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ២៣:១–២៦:៣០ (មេរៀនទី ៦)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និង គោលការណ៍ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា ២៣:១–២៦:៣០ (មេរៀនទី ៦) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាថាយ ២៣)

សិស្សបានសិក្សាពីការស្តីបន្ទោសរបស់ព្រះយេស៊ូវដល់ពួកអ្នកដឹកនាំសាសន៍យូដា ហើយបានរៀនថា យើងអាចជ្រើសគោរពតាមក្រឹត្យវិន័យរបស់ព្រះ សូម្បីតែយើងឃើញអ្នកដទៃធ្វើដោយលាក់ពុតក្តី ។ ពួកគេបានរៀនថា ប្រសិនបើយើងព្យាយាមលើកតម្កើងខ្លួនឯងខ្ពស់ជាងអ្នកដទៃ នោះយើងនឹងត្រូវធ្លាក់ចុះ ហើយប្រសិនបើយើងបន្ទាបខ្លួន ហើយបម្រើដល់អ្នកដទៃ នោះព្រះអម្ចាស់នឹងលើកតម្កើងយើងវិញ ។ ពួកគេក៏រៀនផងដែរថា នៅពេលយើងខិតខំឲ្យបានស្អាតស្អំខាងវិញ្ញាណនៅក្នុងចិត្ត វានឹងបានឆ្លុះបញ្ចាំងនៅក្នុងការជ្រើសរើសផ្នែកខាងក្រៅរបស់យើង ហើយប្រសិនបើយើងនឹងយល់ព្រមឲ្យព្រះអង្គសង្គ្រោះប្រមូលផ្តុំ នោះយើងនឹងទទួលបានការមើលថែទាំ និង ការការពាររបស់ទ្រង់ ។

ថ្ងៃទី ២ (ម៉ាថាយ ២៤)

នៅក្នុងការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការយាងមកជាលើកទីពីររបស់ទ្រង់ សិស្សបានរៀនដូចតទៅ ៖ ប្រសិនបើយើងបន្តខ្ជាប់ខ្ជួន ហើយមិនចុះចាញ់ នោះយើងនឹងត្រូវបានសង្គ្រោះ ។ ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូគ្រីស្ទ អ្នកវិសតាំងរបស់ព្រះអម្ចាស់នឹងត្រូវបានប្រមូលផ្តុំ ហើយដំណឹងល្អនឹងត្រូវប្រកាសទៅកាន់ពិភពលោកទាំងមូល ។ ប្រសិនបើយើងរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ទុក នោះយើងនឹងមិនត្រូវបានបោកបញ្ឆោតឡើយ ។ មានតែព្រះវរបិតាសួគ៌ប៉ុណ្ណោះ ទើបជ្រាបដឹងថា ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះនឹងកើតឡើងពេលណា ។ ប្រសិនបើយើងរកមើលទីសម្គាល់ ហើយគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងនឹងត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

ថ្ងៃទី ៣ (ម៉ាថាយ ២៥)

នៅពេលសិស្សសិក្សារឿងប្រៀបប្រដូចស្តីពីស្ត្រីព្រហ្មចារីទាំងដប់នាក់ ពួកគេបានរៀនថា យើងពុំអាចខ្ចីការត្រៀមខ្លួនខាងវិញ្ញាណពីអ្នកដទៃបានទេ ប៉ុន្តែផ្ទុយទៅវិញយើងត្រូវត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរដោយការបង្កើនទីបន្ទាល់ និងការប្រែចិត្តជឿរបស់យើងតាមរយៈសេចក្តីសុចរិតប្រចាំថ្ងៃ ។ ពួកគេក៏បានរៀនផងដែរថា ការត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមករបស់ព្រះអម្ចាស់ ហើយមានភាពសក្តិសម ដើម្បីឈរនៅក្នុងវត្តមានរបស់ទ្រង់ យើងត្រូវតែមកស្គាល់ទ្រង់ ។ សិស្សបានសិក្សាដោយសង្ខេបពីរឿងប្រៀបប្រដូចស្តីពីទេពកោសល្យ ហើយបានរៀនថា ការភ័យខ្លាចរារាំងយើងមិនឲ្យប្រើអំណោយទាន និង សមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើង ហើយប្រសិនបើយើងពុំអភិវឌ្ឍ ហើយប្រើអំណោយទានខាងវិញ្ញាណរបស់យើងសម្រាប់សេចក្តីល្អនោះទេ យើងនឹងបាត់បង់វា ។

ថ្ងៃទី ៤ (ម៉ាថាយ ២៦:១–៣០)

នៅពេលសិស្សបានសិក្សាពីថ្ងៃចុងក្រោយនៃការងារបម្រើ ក្នុងជីវិតរមែងស្លាប់របស់ព្រះយេស៊ូវគ្រីស្ទ ពួកគេបានរៀនថា នៅពេលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទឮព្រះបន្ទូលរបស់ព្រះអម្ចាស់ ពួកគេបានសាកល្បងជីវិតខ្លួនឯង ដើម្បីមើលឃើញថាវាអនុវត្តចំពោះពួកគេយ៉ាងដូចម្តេច ។ ពួកគេបានរៀនថា និមិត្តសញ្ញានៃពិធីសាក្រាម៉ង់តំណាងឲ្យព្រះកាយ និង ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានលះបង់សម្រាប់យើង ហើយថាព្រះយេស៊ូវគ្រីស្ទបានបង្កើតពិធីសាក្រាម៉ង់ ដើម្បីឲ្យយើងចងចាំទ្រង់ និងដង្វាយធួនរបស់ទ្រង់សម្រាប់អំពើបាបទាំងឡាយរបស់យើង ។ ពួកគេក៏បានរៀនថា នៅពេលយើងប្រែចិត្ត ហើយទទួលទានសាក្រាម៉ង់ដោយស្មោះអស់ពីចិត្ត នោះយើងអាចទទួលការផ្តាច់បាបរបស់យើង ។

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានបង្រៀនពួកសិស្សរបស់ទ្រង់អំពីការយាងមកជាលើកទីពីររបស់ទ្រង់ កាលគង់នៅលើភ្នំអូលីវ ទ្រង់បានលើកឡើងពីរឿងប្រៀបប្រដូចស្តីពីទេពកោសល្យ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៥:១៤–៣០

ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសិស្សរបស់ទ្រង់នូវរឿងប្រៀបប្រដូចស្តីពីទេពកោសល្យ

ពីមុនចាប់ផ្តើមថ្នាក់ សូមដាក់កាក់ប្រាំនៅផ្នែកម្ខាងនៃបន្ទប់ ហើយកាក់ពីរនៅផ្នែកម្ខាងទៀត ។ សូមដាក់កាក់ប្រាំបីទៀតនៅក្នុងហោប៉ៅរបស់អ្នក ។

ដើម្បីចាប់ផ្តើមមេរៀននេះ សូមអញ្ជើញសិស្សបីនាក់ឲ្យឡើងមកក្តារខៀន ដើម្បីជួយអ្នកសម្តែងរឿងប្រៀបប្រដូចមួយ ដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ ជាផ្នែកមួយនៃសេចក្តីបង្គាប់របស់ទ្រង់ទាក់ទិននឹងការយាងមកជាលើកទីពីររបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:១៤–១៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលអ្នកបម្រើម្នាក់ៗបានទទួល និងអ្វីដែលពួកគេបានធ្វើជាមួយនឹងវត្ថុនោះ ។

- តើចៅហ្វាយបានឲ្យអ្វីខ្លះទៅពួកអ្នកបម្រើរបស់គាត់ម្នាក់ៗ ? (សូមពន្យល់ថា ទេពកោសល្យ នៅក្នុងដំណើររឿងនេះគឺជាចំនួនសរុបនៃទឹកប្រាក់ ។ សូមយកកាក់ប្រាំបីចេញពីហោប៉ៅរបស់អ្នក ហើយឲ្យសិស្សទីមួយកាក់ប្រាំ សិស្សទីពីរកាក់ពីរ និងសិស្សទីបីកាក់មួយ ។
- តើអ្នកបម្រើម្នាក់ៗបានធ្វើអ្វីខ្លះជាមួយនឹងប្រាក់ដែលគាត់បានទទួល ?

សូមអញ្ជើញសិស្សដែលមានកាក់ប្រាំ ទៅយកកាក់ប្រាំបន្ថែមទៀតពីផ្នែកម្ខាងនៃបន្ទប់ ។ ចូរសុំឲ្យសិស្សដែលមានកាក់ពីរទៅយកកាក់ពីរបន្ថែមទៀតពីផ្នែកម្ខាងទៀតនៃបន្ទប់ ។ សូមអញ្ជើញសិស្សដែលមានកាក់មួយ យកកាក់របស់ខ្លួនទៅលាក់ទុក ឬធ្វើពុតជាកប់កាក់នោះ ។

ចូរសុំឲ្យសិស្សប្រគល់កាក់ទាំងនោះមកឲ្យអ្នកវិញ ហើយចូលទៅកន្លែងអង្គុយវិញ ។ សូមសរសេរកត្តាខាងក្រោមនៃរឿងប្រៀបប្រដូចនៅលើ ក្តារខៀន (ដោយគ្មានការបកប្រែនៅក្នុងវង់ក្រចក) ៖

ចៅហ្វាយរបស់ពួកអ្នកបម្រើ (ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ)

ពួកអ្នកបម្រើ (ពួកសិស្សរបស់ព្រះអម្ចាស់)

ទេពកោសល្យ (អំណោយទាន និង សមត្ថភាពដែលព្រះអម្ចាស់ប្រទានឲ្យពួកសិស្សរបស់ទ្រង់)

- តើតើធាតុនៃរឿងប្រៀបប្រដូចនេះអាចតំណាងឲ្យអ្វីទៅ ? (ប្រសិនបើចាំបាច់ សូមជួយសិស្សឲ្យស្គាល់បុគ្គល ឬអ្វីដែលធាតុទាំងនោះតំណាងឲ្យ ។ សូមសរសេរការបកប្រែនៅក្បែរចំណុចទាំងឡាយ លើក្តារខៀន ។ សូមពន្យល់ថា អំណោយទាន និង សមត្ថភាពខ្លះដែលយើងមាននៅក្នុងជីវិតមែងស្លាប់ត្រូវបានទទួល ហើយអភិវឌ្ឍនៅក្នុងជីវិតមុនឆាកជីវិតនេះ ។ យើងអាចជ្រើសបន្តអភិវឌ្ឍអំណោយទានទាំងនោះ និង អំណោយទានផ្សេងទៀតនៅក្នុងជីវិតមែងស្លាប់បាន) ។
- យោងតាម ម៉ាថាយ ២៥:១៥ហេតុអ្វីចៅហ្វាយឲ្យចំនួនប្រាក់ខុសៗគ្នាដល់អ្នកបម្រើម្នាក់ៗ ? (បន្ទាប់ពីសិស្សឆ្លើយ សូមចង្អុលបង្ហាញថាឃ្លា « តាមដំរិះគេរៀងខ្លួន » គួសបញ្ជាក់ថា ព្រះប្រទានអំណោយទាន និង សមត្ថភាពដល់យើងម្នាក់ៗ ដែលយើងត្រូវការស្របតាមកាលៈទេសៈរបស់យើង ។ មនុស្សគ្រប់រូបត្រូវបានទទួលអំណោយទានខាងវិញ្ញាណមួយមកពីព្រះ [សូមមើល គ. និង ស. ៤៦:១១] ។ សូមពន្យល់ថា ចំនួនទេពកោសល្យដែលយើងទទួលបាន ពុំមែនជាការគួសបង្ហាញមួយអំពីតម្លៃខ្លួនរបស់យើងនោះទេ) ។

សូមអានឮៗនូវសំណួរខាងក្រោម ហើយសូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីវា ៖

- តើអ្នកគិតថាអ្នកដូចជាអ្នកបម្រើណាមួយច្រើនជាងគេ ៖ អ្នកបម្រើដែលមានទេពកោសល្យប្រាំ ទេពកោសល្យពីរ ឬទេពកោសល្យមួយ ? ហេតុអ្វី ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:១៩–២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលលោកចៅហ្វាបានមានបន្ទូលទៅកាន់អ្នកបម្រើដែលបានទទួលទេពកោសល្យប្រាំ ។

- តើចៅហ្វាយបាននិយាយអ្វីខ្លះទៅអ្នកបម្រើទីមួយ ?

សូមពន្យល់ថា ការតាំងឲ្យ« ត្រួតលើរបស់ជាច្រើនទៅទៀត » និង ការ « ប្រកបដោយសេចក្តីអំណររបស់ចៅហ្វាយឯងចុះ » (ម៉ាថាយ ២៥:២១)មានន័យថាការបំពេញនូវសក្តានុពលដ៏ទេវភាពរបស់យើង និងការទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចជាមួយព្រះវរបិតាសួគ៌ ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ មកពីបទពិសោធន៍របស់អ្នកបម្រើទីមួយ ? (គោលការណ៍ខាងក្រោមនេះគឺជាគោលការណ៍មួយដែលសិស្សអាចរកឃើញ ៖ **ប្រសិនបើយើងប្រើអំណោយទាន និង សមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើង ដោយស្មោះត្រង់នោះយើងអាចបំពេញសក្តានុពលដ៏ទេវភាពរបស់យើង ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។
- តើគំរូមួយចំនួនស្តីពីរបៀបដែលយើងអាចប្រើអំណោយទាន និង សមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើងមានអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា អ្នកបម្រើទីពីរអាចត្អូញត្អែរនៅពេលគាត់បានឃើញថា អ្នកបម្រើទីមួយបានទទួលទេពកោសល្យប្រាំ ហើយគាត់បានទទួលតែពីរនោះ ។ ផ្ទុយទៅវិញ គាត់បានប្រើទេពកោសល្យដែលគាត់បានទទួលដោយស្មោះត្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៥:២២–២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលលោកចៅហ្វាយបានមានបន្ទូលទៅកាន់អ្នកបម្រើដែលបានទទួលទេពកោសល្យពីរ ។

- តើចៅហ្វាយបាននិយាយអ្វីខ្លះទៅអ្នកបម្រើដែលបានទទួលទេពកោសល្យពីរ ?
- ទោះបីជាលោកចៅហ្វាយនោះបានឲ្យប្រាក់ខុសគ្នាដល់អ្នកបម្រើពីរនាក់ដំបូងក៏ដោយ ហេតុអ្វីអ្នកគិតថាពួកគេទាំងពីរនាក់បានទទួលចម្លើយដូចគ្នាមកពីចៅហ្វាយរបស់ពួកគេ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីបទពិសោធន៍របស់បុរសដែលបានទទួលទេពកោសល្យពីរនោះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ព្រះអម្ចាស់នឹងប្រទានពរដល់យើង ប្រសិនបើយើងប្រើអំណោយទាន និង សមត្ថភាពដែលបានប្រទានឲ្យដោយស្មោះត្រង់ ដោយពុំគិតថាយើងទទួលបានប៉ុន្មាន ឬជាអ្វីនោះឡើយ ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ចូរសុំឲ្យសិស្សសញ្ជឹងគិត ប្រសិនបើពួកគេខ្លាប់មានអារម្មណ៍ថា នរណាម្នាក់មានអំណោយទាន ឬសមត្ថភាពច្រើនជាង ហើយប្រសើរជាងខ្លួន ។ សូមចង្អុលបង្ហាញគោលការណ៍ដែលអ្នកទើបសរសេរនៅលើក្តារខៀន ។

- តើការចងចាំគោលការណ៍នេះអាចជួយយើងបែបណាខ្លះ នៅពេលយើងមានអារម្មណ៍ថានរណាម្នាក់បានទទួលអំណោយទានច្រើនជាង ឬប្រសើរជាងយើង ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដោយអែលឌើរ ឃ្វីនថិន អិល ឃុក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖

« ការរីកចម្រើននៅក្នុងទេពកោសល្យរបស់យើងគឺជាង្វាស់ដ៏ល្អ បំផុតនៃការរីកចម្រើនផ្ទាល់ខ្លួន ។ . . .ការប្រៀបធៀបពេលដែលគឺជាការដកយកសេចក្តីអំណរចេញយ៉ាងពិតប្រាកដ ។ យើងពុំអាចមានអំណរគុណ និង ការច្រណែនក្នុងពេលតែមួយបានឡើយ ។ ប្រសិនបើយើងពិតជាចង់បានព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយទទួលពិសោធន៍នូវសេចក្តីអំណរ និង សុភមង្គល យើងគួររីករាយនៅក្នុងពរជ័យរបស់យើង ហើយចូរមានអំណរគុណ » (« Rejoice! » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ២៩, ៣០) ។

- តើយើងអាចរកឃើញអំណោយទាន និងសមត្ថភាពដែលព្រះអម្ចាស់បានប្រទានឲ្យយើងដោយរបៀបណា ?

សូមឲ្យក្រដាសមួយសន្លឹកដល់សិស្សម្នាក់ៗ ហើយចូរសុំឲ្យពួកគេសរសេរឈ្មោះរបស់ខ្លួននៅផ្នែកខាងលើគេបង្អស់ ។ សូមអញ្ជើញពួកគេឲ្យហុចក្រដាសរបស់ខ្លួនទៅឲ្យសិស្សដែលអង្គុយនៅក្បែរពួកគេ ។ ចូរសុំឲ្យសិស្សសរសេរអំណោយទាន ឬសមត្ថភាពមួយដែលពួកគេមើលឃើញនៅក្នុងបុគ្គលដែលមានឈ្មោះនៅលើក្រដាសនោះ ។ សូមណែនាំពួកគេឲ្យបន្តហុចក្រដាសនោះដល់សិស្សដទៃទៀត ហើយសរសេរពីអំណោយទាន និង សមត្ថភាពដែលពួកគេបានសង្កេតឃើញ ។

ក្រោយពីរបីនាទីមក ចូរសុំឲ្យសិស្សប្រគល់ក្រដាសនោះទៅម្ចាស់ដើមវិញ ។ ចូរឲ្យពេលសិស្សអានអំពីអំណោយទាន និងសមត្ថភាពដែលអ្នកផ្សេងមើលឃើញថាពួកគេមាន ។ រួចសុំឲ្យពួកគេសរសេរនៅលើក្រដាសរបស់ខ្លួនពីចម្លើយចំពោះសំណួរខាងក្រោមនេះ ៖

- តើវិធីមួយដែលអ្នកអាចប្រើអំណោយទានមួយរបស់អ្នក ដើម្បីជួយការងារបន្ថែមទៀតរបស់ព្រះអម្ចាស់គឺជាអ្វី ?

សូមចង្អុលបង្ហាញថា រឿងប្រៀបប្រដូចពីទេពកោសល្យរួមបញ្ចូលទាំងការព្រមានអំពីអំណោយទាន និង សមត្ថភាពដែលយើងបានទទួល ។ សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗ ពី ម៉ាថាយ ២៥:២៤–៣០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលចៅហ្វាយបានឆ្លើយតបទៅនឹងអ្នកបម្រើដែលបានលាក់ទេពកោសល្យ ។ បន្ទាប់ពីអាន ខទី ២៧ សូមពន្យល់ថាពាក្យ *ទាំងដើម ទាំងការ* មានន័យថាការប្រាក់ (ប្រាក់ចំណូលបានមកពីការវិនិយោគ ឬប្រាក់កម្ចី) ។

- ហេតុអ្វីបានជាអ្នកបម្រើចុងក្រោយលាក់ទេពកោសល្យរបស់គាត់ ? តើចៅហ្វាយបានឆ្លើយបែបណា ចំពោះការជ្រើសរើសរបស់អ្នកបម្រើម្នាក់នេះ ?
- ទោះបីជា អ្នកបម្រើនេះបានរក្សាប្រាក់ចៅហ្វាយខ្លួនមិនឲ្យបាត់ក៏ដោយ តើទង្វើខុសឆ្គងរបស់អ្នកបម្រើរូបនេះជាអ្វី ?
- តើអ្នកគិតថា ចៅហ្វាយនឹងធ្វើដូចម្តេចទៅអ្នកបម្រើនេះ ប្រសិនបើគាត់បានយកទេពកោសល្យពីរត្រឡប់មកឲ្យវិញ ?

សូមអញ្ជើញសិស្សចែកចាយទីបន្ទាល់របស់ពួកគេ អំពីគោលការណ៍ដែលពួកគេបានពិភាក្សា ។ សូមលើកទឹកចិត្តពួកគេឲ្យប្រើអំណោយទាន និង សមត្ថភាពរបស់ពួកគេដើម្បីជួយពន្លឿនកិច្ចការរបស់ព្រះអម្ចាស់ ។

មេរៀនបន្ទាប់ (ម៉ាថាយ ២៦:៣១–ម៉ាកុស ៣)

សូមពន្យល់ថា នៅសប្តាហ៍ក្រោយសិស្សនឹងសិក្សាលម្អិតពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានចាប់ផ្តើមដោយការរងទុក្ខរបស់ទ្រង់នៅសួនច្បារគែតសេមានី ហើយបានបន្តទៅការកាត់ទោសដោយខុសច្បាប់ ការប្រមាថ ការវាយដំ និង ការសុគតរបស់ទ្រង់លើឈើឆ្កាង ហើយនៅទីបំផុតបានបញ្ចប់ដោយការមានព្រះជន្មរស់ឡើងវិញដ៏រុងរឿងរបស់ទ្រង់ ។

ម៉ាថាយ ២៦:៣១–៣៥

សេចក្តីផ្តើម

នៅក្នុងសួនច្បារគែតសេម៉ានី ព្រះយេស៊ូវគ្រីស្ទបានចាប់ផ្តើមលើកដាក់មកលើអង្គទ្រង់ នូវអំពើបាបរបស់មនុស្សទាំងអស់ជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ ។ យូដាសបានចូលដៃនឹងពួកអ្នកដឹកនាំសាសន៍យូដាក្បត់នឹងព្រះយេស៊ូវ ។ បន្ទាប់មក ព្រះយេស៊ូវត្រូវបានកាត់ទោសនៅចំពោះមុខលោកកៃផា ជាសង្ឃជាន់ខ្ពស់ដោយអយុត្តិធម៌ ជាពេលដែលការកាត់ទោសដ៏ខុសឆ្គងដែលត្រូវបានលើកឡើងទាស់នឹងទ្រង់ ។ ខណៈពេលនោះ ពេត្រុសបានបដិសេធមិនស្គាល់ព្រះអង្គសង្គ្រោះចំនួនបីលើកទៅកាន់ជនដែលបានស្គាល់គាត់ថា ជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៦:៣១–៤៦

ព្រះយេស៊ូវគ្រីស្ទរងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី

ចូរសុំឲ្យសិស្សគិតពិចារណាអំពីសាច់រឿងខាងក្រោមនេះ ៖ មានយុវជនម្នាក់ត្រូវបានគេប្រាប់នៅក្នុងយុវវ័យរបស់គាត់ថា វាគឺជាកាតព្វកិច្ចរបស់គាត់ដើម្បីបម្រើបេសកកម្មពេញម៉ោង ។ ក្នុងនាមជាក្មេងជំទង់ម្នាក់ គាត់នៅតែដឹងថា គាត់គួរបម្រើបេសកកម្ម ប៉ុន្តែខ្វះនូវការតាំងចិត្តទៅបម្រើ ។ គាត់ចាប់អារម្មណ៍នឹងឱកាសផ្សេងទៀត ហើយបារម្ភថា បេសកកម្មនឹងរារាំងគាត់មិនឲ្យមានបទពិសោធន៍ទាំងនោះ ។

- តើនៅក្នុងស្ថានភាពផ្សេងទៀតណា ដែលបំណងប្រាថ្នារបស់យុវជនយុវនារីប្រហែលជាខុសពីអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យពួកគេធ្វើ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។
- ហេតុអ្វីពេលខ្លះ វាពិបាកធ្វើអ្វីដែលយើងដឹងថា ព្រះវរបិតាសួគ៌សព្វព្រះទ័យចង់ឲ្យយើងធ្វើ ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍ទាំងឡាយនៅក្នុងម៉ាថាយ ២៦:៣១–៤៦ដែលអាចជួយពួកគេ នៅពេលពួកគេមានបញ្ហាក្នុងការគោរពតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ។

ចូររំឭកសិស្សថា ដូចដែលបានកត់ត្រាទុកនៅក្នុង ម៉ាថាយ ២៦:១–៣០ព្រះអម្ចាស់បានសោយអាហារបុណ្យរំលងជាមួយនឹងពួកសាវករបស់ទ្រង់ ហើយបានស្ថាបនាពិធីសាក្រាម៉ង់ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី ម៉ាថាយ ២៦:៣១–៣៥ ។ ចូរឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអម្ចាស់បានព្យាករថា នឹងកើតឡើងដល់ពួកសាវករបស់ទ្រង់ ។

- តើព្រះយេស៊ូវបានមានបន្ទូលថាអ្វីខ្លះ នឹងកើតឡើងចំពោះពួកសាវករបស់ទ្រង់នាយប់នោះ ?

សូមពន្យល់ថា នៅក្នុងបរិបទនេះ ពាក្យថា *មានចិត្តរវាតរចេញ* មានន័យថា ការធ្លាក់ ឬការងាកចេញ ឬការបោះបង់ចោល ។

- តើពេត្រុស និងពួកសាវកផ្សេងទៀតបានឆ្លើយតបដូចម្តេច ចំពោះអ្វីដែលព្រះយេស៊ូវបានមានបន្ទូល ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ២៦:៣៦–៣៨ ឲ្យឮៗ ។ ចូរឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីទីកន្លែងដែលព្រះយេស៊ូវ និងពួកសាវកបានទៅបន្ទាប់ពីអាហារបុណ្យរំលង ។ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

ចូរឲ្យសិស្សបើកទៅរូបថតអំពីព្រះគម្ពីរបឹប ទី ១១, « ភ្នំដើមអូលីវ » និង ទី ១២, « សួនច្បារគែតសេម៉ានី » នៅក្នុងផ្នែកផែនទី និងរូបថតទាំងឡាយពីព្រះគម្ពីរបឹប ។ សូមពន្យល់ថា សួនច្បារគែតសេម៉ានីគឺជាសួនដើមអូលីវនៅលើភ្នំដើមអូលីវនៅខាងក្រៅកំផែងក្រុងយេរូសាឡិម ហើយឈ្មោះ *គែតសេម៉ានី* មានន័យថា « ច្របាច់យករប្រេង » ។

- តើឃ្លានៅក្នុង ខទី ៣៦–៣៨ បានពិពណ៌នាពីអារម្មណ៍របស់ព្រះយេស៊ូវអ្វីខ្លះកាលទ្រង់បានយាងចូលទៅក្នុងសួនច្បារគែតសេម៉ានី ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:៣៩ ឲ្យឮៗ ហើយសុំឲ្យសិស្ស ក្នុងថ្នាក់រកមើលអ្វីដែលព្រះយេស៊ូវបានធ្វើ បន្ទាប់ពីយាង« ចូលកាន់តែជ្រៅបន្តិចទៀត » ចូលទៅក្នុងសួនច្បារនោះ ។

- តើពាក្យ ឬឃ្លានៅក្នុង ខទី ៣៧–៣៩ ពិពណ៌នាអ្វីខ្លះ ពីបន្ទុកដ៏ធ្ងន់ដែលព្រះយេស៊ូវកំពុងជួបប្រទះ ?
- តើព្រះយេស៊ូវបានទូលសូមព្រះវរបិតាឲ្យដកយកអ្វីចេញពីទ្រង់ ?

សូមលើកពែងមួយឡើង ។ សូមពន្យល់ថា ពែងដែលព្រះយេស៊ូវបានមានបន្ទូល គឺជានិមិត្តសញ្ញាមួយចំពោះការរងទុក្ខដ៏ល្វីងជូរចត់ដែលទ្រង់បានដកពិសោធន៍ជាផ្នែកមួយនៃដង្វាយធួន ។ នៅក្នុង សួនច្បារគែតសេម៉ានីព្រះយេស៊ូវបានចាប់ផ្តើមលើកដាក់មកលើអង្គទ្រង់នូវអំពើបាប និងការរងទុក្ខរបស់មនុស្សទាំងអស់ជាផ្នែកនៃពលិកម្មធួនដ៏អស្ចារ្យរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ដែលបានពន្យល់ពីអ្វី ដែលព្រះយេស៊ូវកំពុងទូលសូមព្រះវរបិតា កាលទ្រង់បានទូលសូមឲ្យដកយកពែងនោះចេញពីទ្រង់ ៖

« ព្រះអម្ចាស់បានមានបន្ទូលថា ‹ ប្រសិនបើមានផ្លូវផ្សេង ទូលបង្គំស៊ូដើរលើផ្លូវនោះ ។ ប្រសិនបើមានផ្លូវណាមួយផ្សេងទៀត—ផ្លូវមួយណាក៏ដោយ—ទូលបង្គំនឹងដើរលើផ្លូវនោះដោយរីករាយ › ។ . . . ប៉ុន្តែនៅទីបំផុត ពែងនោះពុំត្រូវបានដកចេញឡើយ »
(« Teaching, Preaching, Healing » *Ensign* ខែ មករា ឆ្នាំ ២០០៣ ទំព័រ ៤១) ។



ភ្នំដើមអូលីវ



សួនច្បារគែតសេម៉ានី

ការបង្រៀនអំពីការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងសួនច្បារគែតសេម៉ានី

មានដំណើររឿងបីអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសួនច្បារគែតសេម៉ានី ។ នៅក្នុងសៀវភៅសិក្សានេះមេរៀនសម្រាប់ម៉ាថាយ ២៦ ផ្តោតទៅលើការចុះសម្រុងរបស់ព្រះអង្គសង្គ្រោះទៅតាមព្រះទ័យរបស់ព្រះបិតា ។ មេរៀនសម្រាប់ម៉ាកុស ១៤លើកឡើងអំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានរងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី ។ មេរៀនសម្រាប់លូកា ២២គូសបញ្ជាក់អំពីភាពតានតឹងនៃការរងទុក្ខរបស់ទ្រង់ ។ ការបង្រៀនសិស្សពីទិដ្ឋភាពដ៏វិសេសអស្ចារ្យទាំងនេះនៃដង្វាយធួន អាចជួយពួកគេឲ្យមានបទពិសោធន៍ខុសប្លែកគ្នា កាលពួកគេសិក្សាដំណើររឿងនីមួយៗ ។

អ្នកគួរផ្តល់យោបល់ឲ្យសិស្សគួសចំណាំឃ្លា « ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ » (ខទី ៣៩) ។

- ទោះបីជាព្រះយេស៊ូវបានទូលសូមផ្លូវមួយផ្សេងទៀតដើម្បីសម្រេចនូវព្រះទ័យរបស់ព្រះវរបិតាក្តី តើទ្រង់បានធ្វើអ្វីខ្លះដើម្បីធ្វើឲ្យដង្វាយធួនបានសម្រេច ? (សិស្សគួរឃើញសេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទបានដាក់ព្រះទ័យទ្រង់ចុះស្របតាមព្រះទ័យរបស់ព្រះវរបិតាដើម្បីសម្រេចបាននូវដង្វាយធួន**) ។
- តើយើងអាចរៀនអ្វីខ្លះ អំពីព្រះយេស៊ូវនៅក្នុងការដាក់ព្រះទ័យទ្រង់ចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ទោះជាវាមានន័យថាទ្រង់នឹងត្រូវស៊ូទ្រាំការរងទុក្ខដ៏ខ្លាំង ហើយនៅទីបំផុតគឺត្រូវសុគតក៏ដោយ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *យើងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទនៅពេលយើង . . .*

- តើអ្នកនឹងបំពេញសេចក្តីថ្លែងការណ៍នេះ ដោយផ្អែកលើអ្វីដែលយើងបានរៀននៅក្នុងម៉ាថាយ ២៦:៣៩យ៉ាងដូចម្តេច ? (សូមប្រើពាក្យសម្តីរបស់សិស្សដើម្បីបំពេញសេចក្តីថ្លែងការណ៍នេះដើម្បីឲ្យវានាំទៅរកសេចក្តីពិតដូចតទៅនេះ ៖ **យើងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងជ្រើសរើសដាក់ឆន្ទៈរបស់យើងឲ្យចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌**) ។

ចូររំឭកសិស្សនូវសាច់រឿងស្តីពីយុវជន ដែលបានមានចិត្តស្ញាក់ស្ញើរក្នុងការបម្រើបេសកកម្ម រួមទាំងស្ថានភាពផ្សេងទៀត ដែលបានសរសេរនៅលើក្តារខៀនផងដែរ ។

- តើគំរូរបស់ព្រះអង្គសង្គ្រោះអាចពង្រឹងយើង នៅក្នុងស្ថានភាពទាំងនេះបានដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យគិតពីគ្រាដែលពួកគេបានតាំងចិត្តជ្រើសធ្វើតាមព្រះទ័យរបស់ព្រះវរបិតា ទោះជាបំណងប្រាថ្នារបស់ពួកគេខុសពីព្រះទ័យរបស់ទ្រង់ក្តី ។ ចូរសុំឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ខ្លួន ហើយពន្យល់ពីហេតុផលដែលពួកគេបានធ្វើការជ្រើសរើសនោះ និងអារម្មណ៍ដែលពួកគេមានចំពោះវា ។

សូមលើកទឹកចិត្តសិស្សឲ្យបង្ហាញពីវិធីជាក់លាក់មួយដែលពួកគេនឹងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដោយការដាក់ឆន្ទៈរបស់ពួកគេឲ្យចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ។

សូមអញ្ជើញសិស្សឲ្យមើល ម៉ាថាយ ២៦:៣៧–៣៨ឡើងវិញ ដោយរកមើលការណែនាំរបស់ព្រះអង្គសង្គ្រោះទៅកាន់ពេត្រុស យ៉ាកុប និងយ៉ូហាន នៅក្នុងសួនច្បារគែតសេម៉ានី ។

- តើការណែនាំអ្វីខ្លះដែលព្រះយេស៊ូវបានប្រទានដល់ពេត្រុស យ៉ាកុប និងយ៉ូហាន ?
- តើអ្នកគិតថា ការណែនាំឲ្យ « ចាំយាមជាមួយនឹងខ្ញុំសិន » មានន័យដូចម្តេច ? (ខទី ៣៨) ។

ដើម្បីជួយសិស្សឲ្យយល់ពីហេតុផលដែលពួកសិស្សអាចនឹងត្រូវការការណែនាំរបស់ព្រះអង្គសង្គ្រោះឲ្យចាំយាមនឹងទ្រង់ សូមពន្យល់ថា កាលពួកសិស្សបានមកដល់សួនច្បារ ពួកគេ « បានចាប់ផ្តើមមានចិត្តភាំងជាខ្លាំង ហើយតប់ប្រមល់ណាស់ ហើយចាប់ផ្តើមងឿងឆ្ងល់ក្នុងចិត្តគេដោយគិតថា តើនេះជាព្រះមេស៊ីឬអី »(ការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាកុស ១៤:៣៦ | នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ |) ។ ដោយណែនាំពួកសិស្សទ្រង់ឲ្យចាំយាមនឹងទ្រង់ ព្រះយេស៊ូវកំពុងព្រមានពួកគេឲ្យប្រុងប្រយ័ត្នដោយសារសេចក្តីជំនឿរបស់ពួកគេលើទ្រង់នឹងត្រូវបានសាកល្បង ។

- ហេតុអ្វីពួកសិស្សងឿងឆ្ងល់ថា ព្រះយេស៊ូវពិតជាព្រះមែស៊ីមែនឬអត់ ? (មានពួកយូដាជាច្រើនពុំបានយល់ដឹងថាព្រះមែស៊ីនឹងត្រូវរងទុក្ខ ហើយសុគតនោះទេ ប៉ុន្តែពួកគេបានរំពឹងរង់ចាំថា ព្រះមែស៊ីនឹងផ្តល់សេរីភាពដល់ពួកយូដាដោយផ្តួលរំលំពួករ៉ូម) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:៤០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះយេស៊ូវបានរកឃើញថា ពួកសាវកទាំងបីនាក់នេះកំពុងធ្វើ កាលទ្រង់កំពុងអធិស្ឋាននោះ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស្ម៊ីធសម្រាប់លូកា ២២:៤៥បង្ហាញថា ពួកសិស្សទាំងនោះកំពុងដេកលក់ « ដ្បិតពួកគេពោរពេញដោយទុក្ខព្រួយ » ។

- ហេតុអ្វីពួកសាវកអាចពោរពេញដោយទុក្ខព្រួយ ?
- តើអ្នកមានអារម្មណ៍បែបណា ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពពួកគាត់ ហើយបានដឹងថាខ្លួនបានដេកលក់ ជាជាងចាំយាមជាមួយនឹងព្រះអង្គសង្គ្រោះនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ាថាយ ២៦:៤១ ឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើល អ្វីដែលព្រះយេស៊ូវបានមានបន្ទូលប្រាប់ដល់ពួកសិស្សរបស់ទ្រង់ឲ្យធ្វើ ។ សូមអញ្ជើញសិស្សឲ្យប្រាប់នូវអ្វីដែលពួកគេរកឃើញ ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការណែនាំរបស់ព្រះអង្គសង្គ្រោះដល់ពួកសាវកទាំងនេះ ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងចាំយាម ហើយអធិស្ឋានជាបន្តបន្ទាប់ យើងនឹងមានកម្លាំងដើម្បីតតាំងនឹងការល្បួង**) ។
- តើអ្នកគិតថាឃ្លា « ឯវិញ្ញាណក៏ប្រុងជាស្រេចមែន តែសាច់ឈាមខ្សោយទេ » (ខទី ៤១) មានន័យយ៉ាងណាដែរ ? តើឃ្លានេះទាក់ទងនឹងការតតាំងនឹងការល្បួងយ៉ាងដូចម្តេច ?
- ចូររំឭកឡើងវិញថា « ចាំយាម » មានន័យនៅដឹងខ្លួន រហ័សរហួន ឬប្រុងប្រយ័ត្ន ។ តើការចាំយាម និងការអធិស្ឋានខាងវិញ្ញាណអាចជួយយើងឲ្យយកឈ្នះលើភាពទន់ខ្សោយរបស់យើង ហើយតតាំងនឹងការល្បួងបានដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា តើពួកគេធ្លាប់ចុះញ៊ូមនឹងការល្បួងដោយសារតែពួកគេមិនបានអធិស្ឋាន ហើយនៅចាំយាម ដូចជាពួកគេសាវកនៅក្នុងសួនច្បារគែតសេម៉ានីដែរឬទេ ។ ចូរសុំឲ្យពួកគេពិចារណាពីរបៀបដែលការជ្រើសរើសនោះ បានជះឥទ្ធិពលដល់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីគ្រាដែលពួកគេបានតតាំងនឹងការល្បួងដោយការអធិស្ឋាន និងការចាំយាម ។

- តើអ្វីទៅធ្លាប់ជួយអ្នកឲ្យមានភាពទៀងទាត់នៅក្នុងការចាំយាម និងការអធិស្ឋានខាងវិញ្ញាណ ?

សូមថ្លែងទីបន្ទាល់ថា យើងអាចតតាំងនឹងការល្បួងបាន នៅពេលយើងចាំយាម ហើយអធិស្ឋានជាបន្តបន្ទាប់ ។ សូមអញ្ជើញសិស្សឲ្យសរសេរលើក្រដាសមួយសន្លឹក នូវកិច្ចការមួយដែលពួកគេនឹងធ្វើដើម្បីនៅចាំយាម ហើយអធិស្ឋានជាបន្តបន្ទាប់កាន់តែប្រសើរឡើង ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់ក្រដាសនោះតាមខ្លួន ដើម្បីរំឭកពួកគេពីគោលដៅរបស់ពួកគេ ។

សូមសង្ខេបម៉ាថាយ ២៦:៤២–៤៦ដោយពន្យល់ថា ព្រះយេស៊ូវបានអធិស្ឋានបីដងនៅក្នុងសួនច្បារគែតសេម៉ានី ។ រាល់លើកទ្រង់បានបង្ហាញថា ទ្រង់មានព្រះឆន្ទៈគោរពតាមព្រះទ័យរបស់ព្រះវរបិតាទ្រង់ ។

ម៉ាថាយ ២៦:៤៧–៧៥

ព្រះយេស៊ូវគ្រីស្ទត្រូវគេចាប់ព្រះកាយ ហើយកាត់ទោសនៅចំពោះមុខលោកកៃផា

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ជើរិល អិន ឡាន នៃពួកចិតសិបនាក់ ៖



« សូមនឹកស្រមៃថា ! ព្រះយេស៊ូវគ្រីស្ទ ! ជាអង្គដែលមានព្រះចេស្តា ពន្លឺ និងសិរីល្អធ្វើឲ្យចក្រវាឡមានរបៀបរៀបរយ ជាអង្គដែលមានបន្ទូល ហើយប្រព័ន្ធព្រះអាទិត្យ បណ្តុំផ្កាយ និងតារាកើតមានឡើង—ទ្រង់យាងឈរនៅចំពោះមុខមនុស្សទុច្ចរិត ហើយត្រូវបានពួកគេកាត់ទោសថាជាអង្គដែលគ្មានប្រយោជន៍ ឬគ្មានតម្លៃ ! » (« Knowest Thou the Condescension of God? » នៅក្នុង *Doctrines of the Book of Mormon: The 1991 Sperry Symposium*, ed. Bruce A. Van Orden and Brent L. Top ! ឆ្នាំ ១៩៩២ ! ទំព័រ ៨៦) ។

សូមសរសេរ *ម៉ាថាយ ២៦:៤៧–៦៨* នៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សស្វែងរកខគម្ពីរទាំងនេះ ដោយរកមើលរបៀបដែលព្រះយេស៊ូវគ្រីស្ទបានបន្តចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាទ្រង់ សូម្បីពេលទ្រង់ត្រូវបានមនុស្សទុច្ចរិតធ្វើបាប ហើយកាត់ទោសក្តី ។ ដោយផ្អែកទៅលើសេចក្តីត្រូវការរបស់សិស្ស អ្នកអាចអានខគម្ពីរទាំងនេះឲ្យឮៗជាមួយសិស្ស សូមចែកសិស្សជាគូដើម្បីអានខគម្ពីរទាំងនេះឲ្យឮៗ ឬណែនាំសិស្សឲ្យអានវាដោយស្ងៀមស្ងាត់ ។

ជំនួសឲ្យការណែនាំឲ្យសិស្សអាន ម៉ាថាយ ២៦:៤៧–៦៨អ្នកអាចបង្ហាញផ្នែកនៃវីដេអូខាងក្រោមនេះនៅក្នុង *The Life of Jesus Christ Bible Videos*(វីដេអូព្រះគម្ពីរបីបអំពីជីវប្រវត្តិរបស់ព្រះយេស៊ូវគ្រីស្ទ) ៖ (១) « The Savior Suffers in Gethsemane (ព្រះអង្គសង្គ្រោះរងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី) » (កូដពេលវេលា ៥:៥៣–៨:៣០) ដែលពិពណ៌នាអំពីព្រះយេស៊ូវគ្រីស្ទត្រូវយ៉ូដាសក្បត់ ហើយត្រូវចាប់ព្រះកាយ និង (២) « Jesus Is Tried by Caiaphas, Peter Denies Knowing Him (កៃផាសបានកាត់ទោសព្រះយេស៊ូវ ពេត្រុសបដិសេធថាមិនស្គាល់ទ្រង់) » (កូដពេលវេលា ០:០០–១:៤០) ដែលពិពណ៌នាថាកៃផាសបានកាត់ទោសព្រះយេស៊ូវ ហើយទ្រង់ត្រូវបានគេវាយដំ ព្រមទាំងបានគេស្អប់ខ្ពើម ។ វីដេអូទាំងនេះមាននៅក្នុង LDS.org ។

ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើព្រះយេស៊ូវបានចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ សូម្បីតែពេលទ្រង់ត្រូវបានពួកទុច្ចរិតធ្វើបាប ហើយកាត់ទោសដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:៥៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់គួរធ្វើនៅក្នុងព្រឹត្តិការណ៍ទាំងនេះ ។

- តើព្រះអង្គសង្គ្រោះគួរធ្វើអ្វី ?
- ជំនួសឲ្យការទូលសូមពួកទេវតាដប់ពីរកង ឬព្រះចេស្តានៃព្រះណាមួយផ្សេងទៀតឲ្យរំដោះទ្រង់ តើព្រះយេស៊ូវបានធ្វើអ្វី ?
- តើការណ៍នេះបង្រៀនអ្វីខ្លះ ដល់អ្នកអំពីព្រះទ័យរបស់ព្រះអង្គសង្គ្រោះដើម្បីធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក្តី ?

ទោះបីជាព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាដើម្បីបំផ្លាញមនុស្សដែលវាយទ្រង់ ហើយស្តោះដាក់ទ្រង់ក្តី ក៏ទ្រង់នៅតែស៊ូទ្រាំរងទុក្ខ (សូមមើល នីហ្វៃទី ១ ១៩:៩) ។ ពួកអ្នកដឹកនាំ និងពួកកងទ័ពពុំបានដឹងអំពីព្រះចេស្តាដ៏មហិមា ដែលព្រះយេស៊ូវបានអំពាវនាវរកជាព្រះទ័យនៃព្រះវរបិតាដែលឲ្យទ្រង់ធ្វើរឿងនេះឡើយ ។

ចូរចង្អុលបង្ហាញថា ដូចដែលបានកត់ត្រានៅក្នុងខទី ៥៦ការព្យាករបស់ព្រះអង្គសង្គ្រោះថា ពួកសាវកនឹងងាកចេញពីទ្រង់ត្រូវបានបំពេញ ។ ប៉ុន្តែ ការងាកចេញនេះគឺជារឿងបណ្តោះអាសន្នប៉ុណ្ណោះ ។

សូមសង្ខេបម៉ាថាយ ២៦:៦៩–៧៥ ដោយពន្យល់ថា កាលព្រះយេស៊ូវកំពុងត្រូវគេកាត់ទោស ក្រោយពីចាប់ព្រះកាយទ្រង់មក ពេត្រុសបានបដិសេធមិនស្គាល់ទ្រង់ដល់ទៅបីដង ។ (*កំណត់ចំណាំ ៖* ការបដិសេធរបស់ពេត្រុសនឹងពិភាក្សាលម្អិតនៅក្នុងមេរៀនលូកា ២២) ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលបានបង្ហាញនៅក្នុងមេរៀននេះ ។

ម៉ាថាយ ២៧:១–៥០

សេចក្តីផ្តើម

ជាផ្នែកមួយនៃការស្វែងគំនិតដើម្បីធ្វើគុតព្រះយេស៊ូវគ្រីស្ទ ពួកអ្នកដឹកនាំសាសន៍យូដាបាននាំព្រះយេស៊ូវទៅជួប ប៉ុនទាស–ពីឡាត់ ជាអភិបាលរ៉ូម ។ ពីឡាត់បាននាំព្រះយេស៊ូវទៅឲ្យគេធ្វើទុក្ខទោស ហើយត្រូវឆ្កាង ។ ព្រះយេស៊ូវបានព្រមទទួលការរងទុក្ខ និងសេចក្តីស្លាប់ដើម្បីបំពេញព្រះទ័យរបស់ព្រះវរបិតាទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៧:១–២៥

ព្រះយេស៊ូវត្រូវបាននាំទៅជួបពីឡាត់ដើម្បីឲ្យគេដាក់ទោសដោយការឆ្កាង

ចូរសុំឲ្យសិស្សគិតពិចារណាអំពីសំណួរខាងក្រោម ៖

- ប្រសិនបើអ្នកអាចក្លាយជាសាក្សីម្នាក់ ចំពោះព្រឹត្តិការណ៍ខាងវិញ្ញាណមួយ តើអ្នកនឹងជ្រើសយកព្រឹត្តិការណ៍មួយណា ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេ ។ សូមពន្យល់ថា នៅក្នុងមេរៀននេះ សិស្សនឹងសិក្សានូវព្រឹត្តិការណ៍ដ៏សំខាន់បំផុតមួយនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ។ សូមអញ្ជើញសិស្សឲ្យស្រមៃថា កំពុងឃើញផ្ទាល់នឹងភ្នែកនូវអ្វីដែលបានកើតឡើង ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *នៅថ្ងៃនេះខ្ញុំបានឃើញ ហើយបានទទួលអារម្មណ៍ . . .*

សូមយោងទៅសេចក្តីថ្លែងការណ៍មិនពេញលេញនៅលើក្តារខៀន ហើយពន្យល់ថា សិស្សនឹងមានឱកាសមួយ ដើម្បីបំពេញសេចក្តីថ្លែងការណ៍នោះនៅចុងបញ្ចប់នៃមេរៀននេះ ដោយផ្អែកលើអ្វីដែលពួកគេជួបនៅក្នុងការសិក្សារបស់ពួកគេអំពី ម៉ាថាយ ២៧:១–៥០ ។

សូមរំឭកសិស្សថា កាលព្រះយេស៊ូវត្រូវបានគេចាប់ព្រះកាយ « នោះពួកសិស្សទាំងអស់ក៏រត់ចោលទ្រង់ទៅ » (ម៉ាថាយ ២៦:៥៦) ។ សម្តេចសង្ឃពួកកែផា និង ពួកសានហេឌ្រីនបានចោទថាព្រះយេស៊ូវបានប្រើពាក្យប្រមាថ—តាមច្បាប់របស់សាសន៍យូដា វាគឺជាបទឧក្រិដ្ឋមួយត្រូវផ្តន្ទាទោសដល់ស្លាប់ ប៉ុន្តែតាមច្បាប់រ៉ូម ពួកយូដាគ្មានអំណាចដាក់ទោសមនុស្សម្នាក់ដល់ស្លាប់ដោយសារការប្រើពាក្យប្រមាថឡើយ ។ ហេតុដូច្នេះហើយ ពួកអ្នកដឹកនាំសាសន៍យូដាខំស្វែងរកបទល្មើសមួយតាមច្បាប់រ៉ូម ដែលថានៅក្រៅច្បាប់នោះ ដើម្បីព្រះយេស៊ូវត្រូវជាប់ទោសដល់សុគត ។

សូមសង្ខេប ម៉ាថាយ ២៧:១–១០ ដោយពន្យល់ថា ពួកអ្នកដឹកនាំសាសន៍យូដាបាននាំព្រះយេស៊ូវទៅជួប ប៉ុនទាស–ពីឡាត់ ជាអភិបាលរ៉ូមនៅស្រុកយូដា ។ កាលយូដាសបានឃើញព្រឹត្តិការណ៍នេះ គាត់បានសោកស្តាយចំពោះការជ្រើសរើសរបស់គាត់ក្នុងការក្បត់នឹងព្រះយេស៊ូវ គាត់បានខំយកប្រាក់ដែលគាត់បានទទួលទៅឲ្យពួកអ្នកដឹកនាំសាសន៍យូដា ហើយក្រោយមកទៀតបានបញ្ចប់ជីវិតខ្លួនឯង ។ ដោយសារប្រាក់នោះគឺជា « ថ្លៃឈាម » (ម៉ាថាយ ២៧:៦) វាមិនត្រូវតាមច្បាប់ដើម្បីដាក់វាបញ្ចូលទៅក្នុងរតនាគារវិញឡើយ ហេតុដូច្នេះហើយពួកអ្នកដឹកនាំសាសន៍យូដាបានប្រើប្រាក់នោះ ទិញដីវាលរបស់ជាងស្មូនសម្រាប់ជាទីកប់ខ្មោចមនុស្សចម្លែក (ជនបរទេស) ។ ម៉ាថាយបានយោងទៅព្រឹត្តិការណ៍នេះជាការបំពេញមួយនៃការព្យាករដែលមាននៅក្នុង សាការី ១១:១២–១៣ ។

សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាថាយ ២៧:១១–១៤ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរកមើលការចោទប្រកាន់ដែលពួកអ្នកដឹកនាំសាសន៍យូដាបានធ្វើឡើងចំពោះព្រះយេស៊ូវនៅមុខលោកពីឡាត់ ។

- យោងតាមខទី ១១ តើពីឡាត់បានសួរអ្វីខ្លះដល់ព្រះយេស៊ូវ ?

សូមពន្យល់ថា ពួកអ្នកដឹកនាំសាសន៍យូដាបានចោទប្រកាន់ព្រះយេស៊ូវអំពីអំពើក្បត់ ឬព្យាយាមផ្តួលរំលំរដ្ឋាភិបាលរ៉ូម ហើយបានប្រកាសថា ព្រះយេស៊ូវបានប្រកាសថាទ្រង់ជាស្តេច ហើយមានព្រះទ័យចង់ស្តាបនានគររបស់ទ្រង់ ។

- យោងតាមខទី ១៤ហេតុអ្វីបានជា ពីឡាត់ មានការសូប៉ស្វែងយ៉ាងខ្លាំង ?

ចូរសុំឲ្យសិស្សសញ្ជឹងគិតពីអ្វីដែលពួកគេអាចនឹងនិយាយទៅកាន់ពីឡាត់ ដើម្បីការពារព្រះអង្គសង្គ្រោះ ប្រសិនបើពួកគេមានឱកាសនិយាយនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមសង្ខេប ម៉ាថាយ ២៧:១៥–១៦ ដោយពន្យល់ថា រៀងរាល់ឆ្នាំអំឡុងពិធីជប់លៀងនៃបុណ្យរំលង វាគឺជាទំនៀមទម្លាប់របស់អភិបាលរ៉ូមដើម្បីអត់ទោសដល់អ្នកទោសព្រហ្មទណ្ឌម្នាក់ ។ ប្រជាជនបានអនុញ្ញាតឲ្យជ្រើសរើសអ្នកទោសម្នាក់ដើម្បីធ្វើការដោះលែង ។ អ្នកទោសម្នាក់ដែលនៅគ្រានៃការកាត់សេចក្តីដល់ព្រះយេស៊ូវ គឺជាបុរសម្នាក់ដែលមានឈ្មោះថា បារ៉ាបាស ដែលបានជាប់ទោសជាចោរ ជាអ្នកបះបោរប្រឆាំងនឹងមន្ត្រីរ៉ូម និងជាឃាតករ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី ម៉ាថាយ ២៧:១៧–២៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលពីឡាត់បានសួរដល់ហ្វូងមនុស្សដែលបានប្រមូលផ្តុំគ្នានៅវិមានរបស់លោកអភិបាល ។

> ***អានព្រះគម្ពីរជួបគ្នានៅក្នុងថ្នាក់រៀន***
>
> ការអានព្រះគម្ពីរជួបគ្នានៅក្នុងថ្នាក់រៀនអាចជួយសិស្សឲ្យស្គាល់ ហើយយល់កាន់តែប្រសើរនូវខគម្ពីរដែលពួកគេកំពុងសិក្សា ហើយជួយពួកគេឲ្យអានព្រះគម្ពីរបស់ពួកគេដោយមានទំនុកចិត្តកាន់តែខ្លាំងឡើង ។ សូមលើកទឹកចិត្តឲ្យមានការអានព្រះគម្ពីរនៅក្នុងថ្នាក់រៀន ដោយសុំឲ្យសិស្សបើកខគម្ពីរដែលបានចាត់ឲ្យឮៗ ។ សូមកុំបង្កើតឧបសគ្គដល់សិស្សដែលមិនស្ម័គ្រចិត្តអាន ឬអៀនខ្មាស់ឡើយ ។ ចំពោះសិស្សដែលមិនស្ម័គ្រចិត្តអានឮៗ សូមកុំបង្ខំពួកគេ ។

- យោងតាម ខទី ១៧ និងទី ២១ តើពីឡាត់បានសួរអ្វីខ្លះដល់ហ្វូងមនុស្ស ?
- តើមូលហេតុអ្វីទៅដែលពីឡាត់មាន ចំពោះការដោះលែងព្រះយេស៊ូវជាជាងដោះលែងបារ៉ាបាសនោះ ?
- ហេតុអ្វីនៅទីបំផុតពីឡាត់បានដោះលែងបារ៉ាបាស ហើយប្រគល់ព្រះយេស៊ូវឲ្យគេឆ្កាងទៅវិញ ?

ម៉ាថាយ ២៧:២៦–៥០

ព្រះយេស៊ូវត្រូវបានធ្វើទុក្ខទោស ប្រមាថ ហើយឆ្កាង

ចូរសុំឲ្យសិស្សម្នាក់អានម៉ាកុស ២៧:២៦ឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលពួកគេបានធ្វើទៅលើព្រះយេស៊ូវពីមុនទ្រង់ត្រូវគេបញ្ជូនទៅឆ្កាង ។

- តើការធ្វើទុក្ខទោសមានន័យដូចម្តេច ? (ការវាយនឹង ខ្សែតីម្តងហើយម្តងទៀត) ។

អ្នកគួរដាក់បង្ហាញដុំថ្មតូចមួយរាងស្រួចចុង ហើយពន្យល់ថា ខ្សែតី មួយត្រូវបានប្រើសម្រាប់ការធ្វើទុក្ខទោសជារឿយៗមានវត្ថុស្រួចៗ (ដូចជាបំបែកដុំថ្ម ដែក ឬឆ្អឹង) ចងភ្ជាប់នឹងខ្សែច្រើនសរសៃ ។ ការដាក់ទោសបែបនេះ ជាធម្មតាគឺសម្រាប់ជនដែលជាពួកអ្នកបម្រើកាលបុគ្គលដែលមានខ្សែលោហិតថ្លៃថ្នូរ ឬ ពួកជនសើរីនៃសាសន៍រ៉ូមត្រូវបានគេវាយនឹងដំបង ។ មានមនុស្សជាច្រើនមិនអាចទ្រាំទ្រនឹងការធ្វើទុក្ខទោសឡើយ ដោយសារវាធ្វើឲ្យមានរបួសរាងកាយយ៉ាងធ្ងន់ធ្ងរ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី ម៉ាថាយ ២៧:២៧–៣២ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលពួកទាហានរ៉ូមបានធ្វើចំពោះព្រះយេស៊ូវ ។

- តើពួកទាហានរ៉ូមបានធ្វើអ្វីខ្លះ ដើម្បីចំអកដល់ព្រះយេស៊ូវ ?
- ហេតុអ្វីអ្នកគិតថា ពួកទាហានបានរកឃើញមនុស្សម្នាក់ឲ្យជួយលីឈើឆ្កាងរបស់ព្រះយេស៊ូវជំនួសទ្រង់ ? (ព្រះយេស៊ូវប្រហែលជាមានព្រះកាយទ្រុឌទ្រោមបន្ទាប់ពីរងការឈឺចាប់ដែលមិនអាចប្រៀបផ្ទឹមបាន ហើយបាត់បង់លោហិតយ៉ាងច្រើនកាលរងទុក្ខនៅសួនច្បារគែតសេម៉ានី ហើយកាលត្រូវគេធ្វើទុក្ខទោស) ។
- ដោយដឹងថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ និងជាព្រះអង្គសង្គ្រោះនៃលោកិយ តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចដែរ ប្រសិនបើអ្នកត្រូវបានបង្ខំឲ្យលីឈើឆ្កាងរបស់ព្រះយេស៊ូវនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៧:៣៣–៣៤ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះយេស៊ូវមិនព្រមធ្វើពីមុនត្រូវបានគេឆ្កាងនោះ ។

- តើព្រះយេស៊ូវបានបដិសេធមិនធ្វើអ្វី ? (សោយវត្ថុធាតុដែលបានថ្វាយដល់ទ្រង់) ។

ការថ្វាយទឹកនេះគឺជាការបំពេញការព្យាករដែលមាននៅក្នុង ទំនុកដំកើង ៦៩:២១ ។ អ្នកគួរពន្យល់ថា ទឹកខ្មេះ « លាយនឹងប្រមាត់ » (ម៉ាថាយ ២៧:៣៤) ឬដូចជាម៉ាកុសបានកត់ត្រាថា « ស្រាទំពាំងបាយជូរលាយនឹងជ័រល្វីង » (ម៉ាកុស ១៥:២៣) គឺជាការផ្តល់ឲ្យតាមទំនៀមទំលាប់ជាថ្នាំស្ពឹកបន្ថយការរងទុក្ខរបស់បុគ្គលម្នាក់ ដែលរៀបនឹងស្លាប់ ។ ដោយបដិសេធមិនសោយវា ព្រះយេស៊ូវមានចេតនាពុំបណ្តោយឲ្យសាតិអារម្មណ៍ទ្រង់ស្ពឹកឥតវាងវៃឡើយ ហើយបានបង្ហាញពីការតាំងចិត្តដើម្បីបន្តមានស្មារតីនៅគ្រាដែលនៅសេសសល់នៃការរងទុក្ខដ៏ធ្ងន់ធ្ងរបស់ទ្រង់ ។

ចូរសុំឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង ម៉ាថាយ ២៧:៣៥–៤៥ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលរឿងបន្ថែមទៀតដែលប្រជាជនបានសើចចំអក ឬល្បួងព្រះយេស៊ូវ ។

- តើប្រជាជនបានសើចចំអក ឬល្បួងព្រះយេស៊ូវតាមរបៀបណា ?
- ដោយដឹងថា ព្រះយេស៊ូវមានព្រះចេស្តាដើម្បីរំដោះអង្គទ្រង់ ហេតុអ្វីអ្នកគិតថាទ្រង់មិនយាងចុះពីលើឈើឆ្កាងនោះមក ?

សូមអញ្ជើញសិស្សអាន ម៉ាថាយ ២៧:៤៦ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វីដែលព្រះយេស៊ូវបានមានបន្ទូលកាលនៅលើឈើឆ្កាងនោះ ។

- តើព្រះយេស៊ូវបានមានបន្ទូលអ្វីខ្លះ ? (« ឱ ព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ ? »)

ដើម្បីជួយសិស្សឲ្យយល់ពីអ្វីដែលបានកើតឡើងនៅគ្រានេះ សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដៃប្រ្វី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« ខ្ញុំសូមថ្លែងទីបន្ទាល់ដោយអស់ពីជំនឿនៃព្រលឹងរបស់ខ្ញុំថា . . . ព្រះវរបិតាដ៏ល្អឥតខ្ចោះមួយអង្គពុំបានបោះបង់ចោលព្រះរាជបុត្រារបស់ទ្រង់នៅគ្រានោះឡើយ ។ ពិតណាស់ វាគឺជាជំនឿផ្ទាល់ខ្លួនរបស់ខ្ញុំថា នៅរាល់ការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះគ្រីស្ទ ព្រះវរបិតាពុំដែលឆ្ងាយពីគង់នៅកាន់តែជិតនឹងព្រះរាជបុត្រារបស់ទ្រង់ជាងនៅគ្រាចុងក្រោយនៃការរងទុក្ខដ៏ឈឺចាប់ទាំងនេះឡើយ ។ យ៉ាងណាក៏ដោយ . . . ព្រះវរបិតាបានដកយកការលួងលោមនៃព្រះវិញ្ញាណរបស់ទ្រង់ចេញពីព្រះយេស៊ូវមួយរយៈខ្លី ដែលជាការគាំទ្រដល់វត្តមានរបស់ទ្រង់ » (« None Were with Him » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៨៧–៨៨) ។

- ហេតុអ្វីអ្នកគិតថា ព្រះវរបិតាសួគ៌បានដកយកព្រះវិញ្ញាណរបស់ទ្រង់ចេញពីព្រះយេស៊ូវនៅគ្រានោះ ?

ដើម្បីជួយសិស្សឲ្យរកឃើញសេចក្តីពិតមួយនៅក្នុងខទី ៤៦សូមអានសេចក្តីថ្លែងការណ៍បន្តទៀតរបស់អែលឌើរ ហូឡិន ៖

« វាតម្រូវឲ្យមាន ពិតណាស់វាគឺជាកត្តាដ៏សំខាន់ចំពោះសារៈសំខាន់នៃដង្វាយធួន ដែលព្រះរាជបុត្រាដ៏ល្អឥតខ្ចោះអង្គនេះដែលពុំធ្លាប់មានបន្ទុលអាក្រក់ ឬធ្វើខុស ឬប៉ះអ្វីដែលមិនស្អាតត្រូវតែស្គាល់ពីអារម្មណ៍ដែល មនុស្សដទៃ—គឺយើង គឺយើងទាំងអស់គ្នា—មាន នៅ

ពេលយើងបានធ្វើអំពើបាបបែបនោះ ។ ដើម្បីឲ្យដង្វាយធួនរបស់ទ្រង់គ្មានទីបញ្ចប់ ហើយមានភាពអស់កល្ប ទ្រង់ត្រូវទទួលអារម្មណ៍ថាដកពិសោធន៍ទាំងខាងសាច់ឈាម និងខាងវិញ្ញាណថាតើសេចក្តីស្លាប់មានសភាពបែបណា ដើម្បីញាណដឹងថាតើការបាត់ព្រះវិញ្ញាណនៃព្រះមានសភាពបែបណា ដោយបន្សល់ទុកនូវអារម្មណ៍ឯកោទាំងស្រុង ហើយអស់សង្ឃឹមនោះ » (« None Were with Him »ទំព័រ ៨៨) ។

- យោងតាម ម៉ាថាយ ២៧:៤៦ និងសេចក្តីថ្លែងការណ៍របស់អែលឌើរ ហូឡិន តើអ្នកអាចសង្ខេបអ្វីដែលព្រះអង្គសង្គ្រោះបានជួបជាផ្នែកមួយនៃដង្វាយធួនបានដោយរបៀបណា ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ជាផ្នែកមួយនៃដង្វាយធួន ព្រះយេស៊ូវគ្រីស្ទបានញាណដឹងការដកយកព្រះវិញ្ញាណរបស់ព្រះវរបិតាសួគ៌**) ។
- យោងតាមអែលឌើរ ហូឡិន ហេតុអ្វីព្រះយេស៊ូវបានជួបការដកយកនូវព្រះវិញ្ញាណ ? (ដើម្បីស្គាល់ថា តើសេចក្តីស្លាប់ខាងវិញ្ញាណមានសភាពបែបណា) ។

សូមពន្យល់ថា យើងដកពិសោធន៍នូវសេចក្តីស្លាប់ខាងវិញ្ញាណ ឬការដកយកចេញនូវព្រះវិញ្ញាណរបស់ព្រះវរបិតាសួគ៌ នៅពេលយើងមានបាប ។ សូមថ្លែងទីបន្ទាល់ថា ដោយសារព្រះយេស៊ូវគ្រីស្ទបានដកពិសោធន៍នូវសេចក្តីស្លាប់ខាងវិញ្ញាណនៅក្នុងសួនច្បារគែតសេម៉ានី និងនៅលើឈើឆ្កាង នោះទ្រង់អាចជួយយើង នៅពេលយើងត្រូវបានបំបែកចេញពីព្រះវិញ្ញាណរបស់ព្រះវរបិតាសួគ៌ ដោយសារការជ្រើសរើសមិនល្អរបស់យើង ។ ទ្រង់ក៏អាចជួយយើង នៅពេលយើងមានអារម្មណ៍ឯកោផងដែរ ។

សូមអញ្ជើញសិស្សឲ្យអាន ម៉ាថាយ ២៧:៥០ដោយស្ងៀមស្ងាត់ និងការដកស្រង់ពីការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាថាយ ២៧:៥៤ រកមើលអ្វីផ្សេងទៀតដែលព្រះអង្គសង្គ្រោះបានមានបន្ទូលកាលនៅលើឈើឆ្កាង ។

- យោងតាមការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ខគម្ពីរនេះ ហេតុអ្វីបានជាព្រះយេស៊ូវត្រូវរងទុក្ខចំពោះរឿងទាំងអស់ដែលទ្រង់បានធ្វើ ? (សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខដើម្បីបំពេញតាមព្រះហឫទ័យរបស់ព្រះវរបិតាសួគ៌**) ។

ចូររំឭកសិស្សពីមេរៀនលើកមុនដែលពួកគេបានសិក្សាអំពី ម៉ាថាយ ២៦ ហើយបានរៀនអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅសួនច្បារគែតសេម៉ានី និងព្រះឆន្ទៈរបស់ទ្រង់ដើម្បីដាក់ព្រះទ័យរបស់ទ្រង់ធ្វើតាមព្រះទ័យរបស់ព្រះវរបិតា ។ អ្នកគួរណែនាំសិស្សឲ្យសរសេរ ម៉ាថាយ ២៦:៣៩ ជាសេចក្តីយោងបទគម្ពីរនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ម៉ាថាយ ២៧:៥០ ដើម្បីជួយពួកគេឲ្យចងចាំថាព្រះយេស៊ូវបានធ្វើអ្វីដែលទ្រង់បានសន្យានឹងធ្វើ ។

- ហេតុអ្វីព្រះទ័យរបស់ព្រះវរបិតាទុកព្រះយេស៊ូវដកពិសោធន៍ការរងទុក្ខ ដែលទ្រង់បានធ្វើ ដោយចាប់ផ្តើមនៅក្នុងសួនច្បារគែតសេម៉ានី ហើយបានបញ្ចប់នៅលើឈើឆ្កាងដូច្នេះ ?

ដើម្បីរំឭកឡើងវិញ ហើយជួយសិស្សឲ្យទទួលអារម្មណ៍នូវសេចក្តីពិត និងសារៈសំខាន់នៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលពួកគេបានរៀននៅក្នុង ម៉ាថាយ ២៧អ្នកគួរបង្ហាញវីដេអូ *Mormon Messages* « None Were with Him » (៤:២៥) ។ វីដេអូនេះមានទូរដំណើររឿងនៃការឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ និងការដកស្រង់មួយចេញពី « None Were with Him » (*Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៨៦–៨៨) ជាសុន្ទរកថាក្នុងសន្និសីទទូទៅខែមេសា ឆ្នាំ២០០៩ ដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ ។ វីដេអូនេះអា–ចរកបាននៅក្នុង LDS.org ។

សូមពន្យល់ថា របៀបមួយដ៏ល្អបំផុតដើម្បីបង្ហាញការដឹងគុណរបស់យើងចំពោះព្រះអម្ចាស់សម្រាប់អ្វីដែលទ្រង់បានរងទុក្ខសម្រាប់យើង គឺដោយរស់នៅដោយសុចរិត ។ សូមយោងទៅសេចក្តីថ្លែងការណ៍មិនពេញលេញដែលអ្នកបានសរសេរលើក្តារខៀន នៅពេលចាប់ផ្តើមបង្រៀន ។ « ថ្ងៃនេះ ខ្ញុំបានឃើញ ហើយទទួលអារម្មណ៍ . . . » សូមអញ្ជើញពួកគេឲ្យបំពេញឃ្លានេះនៅក្នុងសៀវភៅកំណាត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ អ្នកគួរអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាថាយ ២៧:២៦ ។ តើការធ្វើទុក្ខទោសមានន័យដូចម្តេច ?

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បានពន្យល់ពីអត្ថន័យនៃ ការធ្វើទុក្ខទោស ៖

« ការអនុវត្តដ៏ឃោរឃៅនេះ ជាការត្រៀមខ្លួនសម្រាប់ការឆ្កាង មាននូវការសម្រាតខោអាវរបស់ជនរងគ្រោះ ការចងគាត់ជាប់នឹងបង្គោល ឬគ្រោងមួយ និងការវាយគាត់នឹងខ្សែតីដោយមានបន្ទះសំណ និងឆ្អឹងស្រួចៗ ។ វាបណ្តាលឲ្យអ្នកដែលត្រូវគេធ្វើបាបហូរឈាមទន់ខ្សោយ ហើយពេលខ្លះហូតដល់ស្លាប់ » (Doctrinal New Testament Commentary វ៉ុលទី ៣ [ឆ្នាំ១៩៦៥–៧៣] ១:៨០៧) ។

នៅគ្រាមួយទៀត អែលឌើរ ម៉ាក់ខន់ឃី បានថ្លែងម្តងទៀតថា « មានមនុស្សជាច្រើនបានស្លាប់ដោយការធ្វើទុក្ខទោសនោះ ប៉ុន្តែ [ព្រះយេស៊ូវគ្រីស្ទ] បានយាងក្រោកឡើងពីការរងទុក្ខនៃការធ្វើទុក្ខទោសនោះ ដើម្បីទ្រង់បានអាចសុគតយ៉ាងអាណោចអាធមនៅលើឈើឆ្កាងត្រង់កាលវ៉ារី » (« The Purifying Power of Gethsemane » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៥ ទំព័រ៩–១០) ។

ម៉ាថាយ ២៧:៥១–២៨:២០

សេចក្តីផ្តើម

នៅពេលព្រះគ្រីស្ទសុគត វាំងននៃព្រះវិហារបរិសុទ្ធត្រូវបានរហែកជាពីរ ។ ពួកអ្នកដឹកនាំសាសន៍យូដា បានប្តឹងលោកពីឡាត់ឲ្យការពារផ្នូរដែលទុកព្រះសពរបស់ព្រះយេស៊ូវ ។ ព្រះយេស៊ូវគ្រីស្ទបានរស់ឡើងវិញ ហើយបានបង្ហាញព្រះកាយដល់បុគ្គលជាច្រើន រួមទាំងពួកសាវករបស់ទ្រង់ផងដែរ ។ ទ្រង់បានបង្គាប់ពួកសាវករបស់ទ្រង់ឲ្យនាំយកដំណឹងល្អទៅទូទាំងផែនដី ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៧:៥១–៥៦

បន្ទាប់ពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ នោះវាំងននៃព្រះវិហារបរិសុទ្ធបានរហែក ហើយផែនដីក៏ញ័រ

ចូរសុំឲ្យសិស្សគិត ប្រសិនបើពួកគេ ឬនរណាម្នាក់ដែលពួកគេស្គាល់ មានមនុស្សម្នាក់ដែលជិតជិតនឹងពួកគេបានស្លាប់ ។ បន្ទាប់មក សូមសួរសិស្ស ៖

- ហេតុអ្វីការបាត់បង់អ្នកជាទីស្រឡាញ់ម្នាក់ អាចរឿងមួយដ៏ពិបាក ?

ចូរសុំឲ្យសិស្សស្វែងរកសេចក្តីពិត នៅពេលពួកគេសិក្សាម៉ាថាយ ២៧:៥១–២៨:២០ដែលនឹងជួយពួកគេរកបាននូវការលួងលោមចិត្ត នៅពេលមនុស្សជាទីស្រឡាញ់ម្នាក់បានស្លាប់ ។ ដើម្បីផ្តល់បរិបទសម្រាប់មេរៀននៅថ្ងៃនេះ អ្នកអាចសុំឲ្យសិស្សសង្ខេបដោយខ្លីៗពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានដកពិសោធន៍នៅចន្លោះគ្រាដែលទ្រង់ត្រូវគេចាប់ខ្លួន និងគ្រាទ្រង់ត្រូវបានគេឆ្កាង ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៧:៥១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើងនៅក្នុងព្រះវិហារបរិសុទ្ធ កាលព្រះយេស៊ូវបានសុគត ។

- តើមានអ្វីបានកើតឡើង កាលព្រះយេស៊ូវបានសុគត ? (Invite students to look at Matthew 27:51, footnote *b*, to understand that "rent in twain" means "torn into two pieces.")

សូមពិចារណាចម្លង តារាង នៃផ្ទៃកខាងក្នុងនៃព្រះវិហារបរិសុទ្ធនៅលើក្តារខៀន ។

សូមពន្យល់ថា នៅក្នុងសម័យព្រះយេស៊ូវ ព្រះវិហារបរិសុទ្ធមានបន្ទប់ពីរ ៖ ទីបរិសុទ្ធ និង ទីបរិសុទ្ធដ៏ពិសិដ្ឋ ។ ទីបរិសុទ្ធដ៏ពិសិដ្ឋតំណាងឲ្យវត្តមានរបស់ព្រះ ។ បន្ទប់ទាំងពីរនេះ ត្រូវខណ្ឌដាច់ពីគ្នាដោយវាំងនន ឬរនាំងមួយ ។ មួយឆ្នាំម្តង នៅថ្ងៃបុណ្យយញ្ញបូជា សង្ឃជាន់ខ្ពស់បានដើរកាត់ពីទីបរិសុទ្ធតាមវាំងននៃព្រះវិហារបរិសុទ្ធ ហើយចូលទៅក្នុងទីបរិសុទ្ធនៃអស់ទាំងទីបរិសុទ្ធ ជាកន្លែងដែលគាត់បានបង្ហូរឈាមនៃដង្វាយលោះបាបមួយ ដើម្បីឲ្យធួនសម្រាប់អំពើបាបនៃក្រុមជំនុំទាំងអស់របស់អ៊ីស្រាអែល (សូមមើល លេវីវិន័យ ១៦) ។ កាលវាំងននព្រះវិហារបរិសុទ្ធបានរហែកជាពីរ នៅពេលព្រះយេស៊ូវគ្រីស្ទបានសុគត វាគឺជានិមិត្តសញ្ញាដ៏អស្ចារ្យមួយថា ព្រះយេស៊ូវគ្រីស្ទ សង្ឃជាន់ខ្ពស់ដ៏អស្ចារ្យ បានឆ្លងកាត់តាមវាំងននៃសេចក្តីស្លាប់ ហើយមិនយូរប៉ុន្មាននឹងយាងចូលទៅក្នុងទីវត្តមាននៃព្រះជាព្រះវរបិតា ។

ដើម្បីជួយសិស្សឲ្យយល់ដឹងកាន់តែប្រសើរអំពីសារៈសំខាន់នៃការរហែកវាំងននេះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖




« ឥឡូវនេះទីបរិសុទ្ធដ៏ពិសិដ្ឋបានបើកសម្រាប់មនុស្សគ្រប់រូប តាមរយៈព្រះលោហិតដ៏ធួននៃកូនចៀម ឥឡូវនេះមនុស្សទាំងអស់អាចចូលទៅក្នុងទីដ៏ខ្ពស់បំផុត ហើយបរិសុទ្ធជាងទីណាៗទាំងអស់ ជានគរដែលរកឃើញនូវជីវិតដ៏នៅអស់កល្បជានិច្ច ។ . . . ពិធីបរិសុទ្ធនានាដែលបានធ្វើឡើងតាមវាំងននៃព្រះវិហារបរិសុទ្ធបុរាណនោះ គឺតំណាងឲ្យអ្វីដែលព្រះគ្រីស្ទត្រូវធ្វើ ដែលឥឡូវនេះទ្រង់កំពុងធ្វើ ដើម្បីឲ្យមនុស្សទាំងអស់មានសិទ្ធិឆ្លងកាត់វាំងននេះចូលទៅក្នុងវត្តមានរបស់ព្រះ អម្ចាស់ដើម្បីត្រងភាពតម្កើងឡើងដ៏ពេញលេញទុកជាមរតក » (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ១៩៦៥–៧៣ | ១:៨៣០) ។

- តើសេចក្តីពិតដ៏សំខាន់អ្វីខ្លះ ដែលអ្នកអាចរៀនពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទចេញពីការរហែកវាំងននេះ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទយើងទាំងអស់គ្នាអាចចូលទៅក្នុងទីវត្តមានរបស់ព្រះបាន ប្រសិនបើយើងប្រែចិត្ត ហើយរក្សាសេចក្តីសញ្ញារបស់យើង**) ។
- តើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ អាចធ្វើឲ្យយើងត្រឡប់ទៅទីវត្តមានរបស់ព្រះវិញបានដោយរបៀបណា ?

ចូរចង្អុលបង្ហាញថា ទោះជាដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទធ្វើឲ្យយើងអាចត្រឡប់ទៅវត្តមានរបស់ព្រះវិញក្តី ក៏យើងត្រូវធ្វើផ្នែករបស់យើងដើម្បីមានភាពសក្តិសមរស់នៅជាមួយនឹងព្រះវរបិតាសួគ៌របស់យើងដ៏អស់កល្បជានិច្ច ។

- តើ *យើង* ត្រូវធ្វើអ្វីខ្លះដើម្បី ឲ្យបានសក្តិសមរស់នៅជាមួយនឹងព្រះវរបិតាសួគ៌ដ៏អស់កល្បជានិច្ច ?



សូមសង្ខេប ម៉ាថាយ ២៧:៥២–៥៦ ដោយពន្យល់ថា បន្ទាប់ពីការមានព្រះជន្មឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ មានមនុស្សសុចរិតជាច្រើនដែលបានស្លាប់ហើយក៏បានរស់ឡើងវិញ ហើយបានបង្ហាញខ្លួនដល់មនុស្សជាច្រើននៅយេរូសាឡិមផងដែរ ។ ខគម្ពីរទាំងនេះក៏លើកឡើងផងដែរថា នៅក្នុងចំណោមជនដែលបានឃើញការសុគតរបស់ព្រះយេស៊ូវគឺមេបញ្ជាការរ៉ូមម្នាក់ និងស្ត្រីជាច្រើន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៧:៥៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សរកមើលរបៀបដែលមេបញ្ជាការរ៉ូម និងអ្នកដែលបាននៅជាមួយនឹងទ្រង់បានធ្វើ កាលពួកគេបានឃើញព្រឹត្តិការណ៍ដូចតទៅនេះពីការឆ្លងរបស់ព្រះអង្គសង្គ្រោះ ៖

- តើអ្វីទៅជាការឆ្លើយតបរបស់មេបញ្ជាការនោះ និងជនដែលបាននៅជាមួយទ្រង់ ?
- តើពួកគេបានឃើញអ្វីដែលប្រហែលជាបានធ្វើឲ្យពួកគេប្រកាសថា « [ព្រះយេស៊ូវ] ពិតជាព្រះរាជបុត្រានៃព្រះ ?

ម៉ាថាយ ២៧:៥៧–៦៦

ពួកអ្នកដឹកនាំសាសន៍យូដារួមផ្សំគំនិតជាមួយនឹងពីឡាត់ ដើម្បីការពារផ្នូររបស់ព្រះយេស៊ូវ ។

សូមសង្ខេប ម៉ាថាយ ២៧:៥៧–៦១ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវសុគត មានសិស្សម្នាក់ដែលមានសម្បត្តិស្តុកស្តុមឈ្មោះ យ៉ូសែប ដែលនៅភូមិអើរីម៉ាថេបាន « សូម [យក] ព្រះសពព្រះយេស៊ូវ » (ខទី ៥៨) ។ គាត់បានរុំព្រះសពព្រះយេស៊ូវនឹងក្រណាត់យ៉ាងស្អាត រួចតម្កល់ទុកនៅក្នុងផ្នូរមួយ (ឬក្នុងកន្លែងបញ្ចុះសព) ដែលជារបស់គាត់ ហើយបន្ទាប់មកបានបាំងច្រកចូលផ្នូរនោះដោយថ្មមួយផ្ទាំងធំ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី ម៉ាថាយ ២៧:៦២–៦៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលពួកមេសង្ឃ និងពួកផារិស៊ីបានដាក់ស្នើដល់ពីឡាត់ ។

- តើពួកមេសង្ឃ និងពួកផារិស៊ីបានស្នើអ្វីខ្លះដល់ពីឡាត់ ?
- ហេតុអ្វីបានជាពួកគេចង់បានការណ៍នេះ ?

ម៉ាថាយ ២៨:១–២០

ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ឡើងវិញ ហើយបានបង្ហាញព្រះកាយដល់មនុស្សជាច្រើន

ចូរពន្យល់ថា នៅព្រឹកព្រលឹមនាថ្ងៃដំបូងនៃសប្តាហ៍នោះ ឬថ្ងៃអាទិត្យ ម៉ារា ម៉ាក់ដាឡា និងស្ត្រីម្នាក់ទៀតឈ្មោះថា ម៉ារា បានទៅផ្នូរនោះ ដើម្បីចាក់ប្រេងលាបព្រះកាយរបស់ព្រះយេស៊ូវជាការបង្ហាញសេចក្តីស្រឡាញ់ និង កោតសរសើររបស់ពួកគេ ។ ចូរសុំឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអាននៅក្នុង ម៉ាថាយ ២៨:១–៦ ឲ្យឮៗ ។

- តើស្ត្រីទាំងនោះបានរកឃើញអ្វីខ្លះ ពេលពួកគេបានទៅដល់ផ្នូរខ្មោច ? (សូមពន្យល់ថា ការបកប្រែរបស់យ៉ូសែប ស៊្មីធ បញ្ជាក់ថា ស្ត្រីពីរនាក់នោះបានឃើញទេវតាពីរអង្គ ពុំមែនមួយអង្គទេ)។
- តើអ្នកនឹងមានប្រតិកម្មយ៉ាងណាដែរ ប្រសិនបើអ្នកបានឃើញទេវតាពីរអង្គ ? តើពួកអ្នកយាមមានប្រតិកម្មយ៉ាងណា ?
- យោងតាម ខទី ៥–៦ តើពួកទេវតាបានប្រាប់អ្វីខ្លះដល់ស្ត្រីទាំងនោះ ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងរៀននៅក្នុងបន្ទូលទាំងនេះ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ព្រះយេស៊ូវបានរស់ឡើងវិញពីការសុគត**)។

ដើម្បីជួយសិស្សយល់គោលលទ្ធិនៃការរស់ឡើងវិញ សូមបំបែកពួកគេជាក្រុមៗមានគ្នាពីរនាក់ ឬបីនាក់ ហើយអញ្ជើញពួកគេឲ្យបំពេញឯកសារចែកចាយខាងក្រោម នៅក្នុងក្រុមរបស់ពួកគេ ៖

« ទ្រង់រស់ឡើងវិញ » (ម៉ាថាយ ២៨:៦)

សូមសិក្សាចំណងជើង« Resurrection » នៅក្នុង Bible Dictionary ។ បន្ទាប់មកពីភាក្យាអំពីសំណួរដូចខាងក្រោម ហើយកត់ត្រាចម្លើយរបស់អ្នកនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ ។

តើមានភាពខុសគ្នាអ្វីខ្លះ រវាងការត្រូវបានប្រោសពីសេចក្តីស្លាប់ និងការត្រូវបានរស់ឡើងវិញ ?	
តើនឹងមានអ្វីកើតឡើងខ្លះចំពោះមនុស្សលោកគ្រប់រូប ដែលជាលទ្ធផលមួយមកពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ?	
តើការយល់ដឹងអំពីគោលលទ្ធិនៃការរស់ឡើងវិញអាចផ្តល់នូវការលួងលោមចិត្តដល់អ្នកទាំងឡាយដែលបានបាត់បង់មនុស្សជាទីស្រឡាញ់យ៉ាងដូចម្តេច ?	

ចូរសុំឲ្យសិស្សពីរបីនាក់ចែកចាយនឹងសិស្ស ក្នុងថ្នាក់អំពីអ្វីដែលពួកគេបានរៀន តាមរយៈការបំពេញឯកសារចែកចាយ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងក្លី ៖



« អព្ភូតហេតុនៅព្រឹកនៃការរស់ឡើងវិញនោះ ជាថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរដំបូង គឺជាអព្ភូតហេតុមួយសម្រាប់មនុស្សលោកគ្រប់រូប ។ វាគឺជាអព្ភូតហេតុនៃព្រះចេស្តារបស់ព្រះ ជាព្រះរាជបុត្រាសំណព្វ បានប្រទានជីវិតរបស់ទ្រង់ដើម្បីធ្វើឲ្យឆ្ងនចំពោះអំពើបាបនៃមនុស្សទាំងអស់ ជាពលិកម្មនៃក្តីស្រឡាញ់សម្រាប់បុត្រា និងបុត្រីគ្រប់រូបរបស់ព្រះ ។ នៅក្នុងការធ្វើដូច្នោះ ទ្រង់បានបំបាក់ចំណងនៃសេចក្តីស្លាប់ ។ . . .

« ហើយដូចជាទ្រង់បានយកព្រះកាយរបស់ទ្រង់មកវិញ ហើយយាងចេញពីផ្នូរដែរ នោះយើងទាំងអស់គ្នានឹងរីករាយចំពោះការរួបរួមនៃរូបកាយ និងវិញ្ញាណដើម្បីក្លាយជាមនុស្សរស់នៅថ្ងៃនៃការរស់ឡើងវិញផ្ទាល់ខ្លួនរបស់យើងផងដែរ ។

« ហេតុដូច្នោះហើយ យើងរីករាយ ដូចជាមនុស្សជាច្រើនផងដែរ ហើយក៏ដូចជាមនុស្សគ្រប់រូបផងដែរ នៅពេលយើងចងចាំអំពីព្រឹត្តការណ៍ដ៏រុងរឿងបំផុត ដ៏លួងលោមចិត្តបំផុត ដ៏បញ្ជាក់អះអាងបំផុតនៃគ្រប់ព្រឹត្តិការណ៍ទាំងអស់ក្នុងប្រវត្តិសាស្ត្រមនុស្ស—គឺជាជោគជ័យឈ្នះលើសេចក្តីស្លាប់ » (« The Victory over Death » *Ensign* ខែ មេសា ឆ្នាំ ១៩៩៧ ទំព័រ ៤) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៨:៧–១០ ឲ្យឮៗ ។

- យោងតាម ខទី ៧តើពួកទេវតាបញ្ជាឲ្យស្ត្រីទាំងនោះធ្វើអ្វីខ្លះ ?
- ហេតុអ្វីក៏អ្នកគិតថា ស្ត្រីទាំងនោះបានចាកចេញ « ទាំងភ័យ ហើយមានសេចក្តីអំណរជាខ្លាំងផង » ដូច្នេះ ?
- តើមានអ្វីកើតឡើងចំពោះស្ត្រីទាំងនោះ នៅពេលពួកគេបានទៅប្រាប់ដល់ពួកសិស្សអំពីបទពិសោធន៍របស់ពួកគេ ?

ចូរសង្កេតម៉ាថាយ ២៨:១១–១ ៥ដោយពន្យល់ថា ខណៈដែលស្ត្រីទាំងនោះប្រញាប់ទៅប្រាប់ដំណឹងដល់ពួកសិស្សអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ នោះពួកមេសង្ឃទាំងឡាយបានស្តាប់ព្រឹត្តិការណ៍អំពីអ្វីដែលបានកើតឡើងមកពីពួកទាហានដែលបានចាំយាមផ្នូរ ។ ពួកអ្នកដឹកនាំសាសន៍យូដាបានភ័យខ្លាចថាមនុស្សអាចដឹងអំពីសេចក្តីពិត នោះពួកគេបានឲ្យប្រាក់ដល់អ្នកយាមឲ្យនិយាយរឿងកុហកថា ពួកសិស្សរបស់ព្រះអង្គសង្គ្រោះបានយកព្រះសពរបស់ទ្រង់ចេញពីផ្នូរ ខណៈដែលអ្នកយាមកំពុងដេកលក់ ។

ចូរសុំសិស្សម្នាក់អាន ម៉ាថាយ ២៨:១៦–១៨ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម ហើយរកមើលនូវពរជ័យដែលកើតមានដល់សាវកដប់មួយនាក់ ពេលពួកគេបានគោរពតាមពាក្យសម្តីដែលស្ត្រីទាំងឡាយបានប្រាប់ពួកគេ ហើយបានចេញទៅស្រុកកាលីឡេ ។

- តើមានពរជ័យអ្វីខ្លះ កើតមានដល់ពួកសិស្សដប់មួយនាក់ ដោយសារតែពួកគេបានគោរពតាមពាក្យសម្តីរបស់ស្ត្រីទាំងនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៨:១៩–២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្គាប់ដល់ពួកសាវករបស់ទ្រង់ឲ្យធ្វើបន្ទាប់ពីពួកគេបានឃើញទ្រង់ ។

- តើពួកសិស្សត្រូវបានបញ្ជាឲ្យធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេបានមើលឃើញព្រះអង្គសង្គ្រោះ?
- តើយើងអាចរៀនអ្វីខ្លះពីបទពិសោធន៍របស់ពួកគេ អំពីទំនួលខុសត្រូវដែលយើងមាន នៅពេលយើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលយើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ នោះយើងមានទំនួលខុសត្រូវដើម្បីថ្លែងទីបន្ទាល់អំពីទ្រង់ដល់អ្នកដទៃ**) ។

សូមអញ្ជើញសិស្សឡើងមកក្តារខៀន សរសេរពីរបៀបដែលយើងអាចថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទដល់មនុស្សដទៃ ។ អ្នកគួរអញ្ជើញសិស្សឲ្យពន្យល់ ឬផ្តល់ឧទាហរណ៍ពីគំនិតដែលពួកគេសរសេរ ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- យោងតាមខទី ២០តើមានការសន្យាអ្វីខ្លះ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពួកសាវករបស់ទ្រង់ ?
- តើព្រះអម្ចាស់បាន « គង់នៅនឹងអ្នក » ឬបានជួយអ្នកនៅក្នុងកិច្ចខិតខំដើម្បីចែកចាយដំណឹងល្អតាមរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេ អំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងមនុស្សដទៃ ។ ដើម្បីជួយពួកគេឲ្យធ្វើកិច្ចការនេះ ចូរសុំឲ្យសិស្សប្រើគំនិតមួយ ដែលបានសរសេរនៅលើក្តារខៀន ដើម្បីបង្កើតជាគោលដៅផ្ទាល់ខ្លួនមួយ នៅក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងទីបន្ទាល់របស់ទ្រង់ដល់សមាជិកគ្រួសារ មិត្ត និងមនុស្សដទៃ ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅរបស់ពួកគេនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

ចំណេះចំណានខគម្ពីរ—ម៉ាថាយ ២៨:១៩–២០

ដើម្បីជួយសិស្សទន្ទេញចាំវគ្គចំណេះចំណានខគម្ពីរនេះ សូមបំបែកសិស្សជាគូ ហើយអញ្ជើញសិស្សម្នាក់ពីដៃគូនីមួយៗឲ្យសរសេរវគ្គនោះនៅលើក្រដាស ។ ចូរសុំឲ្យសិស្សកាត់ក្រដាសនោះជាបន្ទះៗ ដោយទុកឃ្លានៅក្នុងវគ្គបទគម្ពីរនោះនៅដដែល ។ ចូរសុំឲ្យសិស្សច្របល់បន្ទះក្រដាសទាំងនោះចូលគ្នា ហើយបន្ទាប់មកតម្រៀបវាឡើងវិញតាមលំដាប់លំដោយ (ដោយយោងទៅលើព្រះគម្ពីររបស់ពួកគេ ប្រសិនបើចាំបាច់) ។ ចូរសំណូមពរឲ្យសិស្សបន្តអនុវត្តតាមរបៀបនេះ រហូតដល់ពួកគេឈប់ត្រូវការប្រើព្រះគម្ពីររបស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យដកយកបន្ទះក្រដាសមួយចេញ ហើយសូត្រឃ្លាដែលបាត់ដោយការចងចាំ ។ បន្ទាប់ពីសិស្សបានទន្ទេញចាំមួយឃ្លាហើយ សូមលើកទឹកចិត្តពួកគេឲ្យដកឃ្លាមួយទៀត ហើយសូត្រឃ្លាទាំងពីរឡើងវិញពីការចងចាំ ។ ចូរអនុញ្ញាតឲ្យពួកគេបន្តដំណើរការនេះរហូតពួកគេអាចសូត្រវគ្គខគម្ពីរទាំងស្រុងដោយការចងចាំ ។

ម៉ាថាយ ២៨:១៩–២០

គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សម្រាប់ការពន្យល់អំពីចំណេះចំណានខគម្ពីរ និងបញ្ជីនៃសកម្មភាពបន្ថែមដើម្បីជួយសិស្សឲ្យចេះចាំវគ្គបទគម្ពីរជម្រើសទាំងនេះ សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ ។

សេចក្តីណែនាំ

ទៅកាន់ដំណឹងល្អស្របតាមលូកា

ហេតុអ្វី ត្រូវសិក្សាគម្ពីរនេះ ?

គម្ពីរម៉ាកុស រៀបរាប់អំពីការបម្រើ ការសុគត និង ការ
រស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងដំណើររឿងដ៏រំជួល
ចិត្តមួយ ដែលជាញឹកញាប់ផ្តោតទៅលើទង្វើដ៏ប្រកបដោយ
ព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ។ រឿងដែលសំខាន់បំផុត
នៅក្នុងរឿងទាំងនេះ គឺជង្វាយធួនដែល ម៉ាកុស បានគូស
បញ្ជាក់ថាជាជំណាក់កាលដ៏សំខាន់ចំពោះបេសកកម្ម
របស់ព្រះយេស៊ូវ ជាព្រះមែស៊ីដែលបានសន្យាជាយូរមក
នោះ ។ តាមរយៈការសិក្សាអំពីដំណើររឿង និង ទីបន្ទាល់របស់
ម៉ាកុស អំពីរបៀបដែលព្រះអង្គសង្គ្រោះបានបំពេញបេសកកម្ម
ជង្វាយធួនរបស់ទ្រង់ ពួកសិស្សអាចប្រែចិត្តជឿ កាន់តែខ្លាំង
ទៅក្នុងដំណឹងល្អ ហើយមានចិត្តក្លាហានដើម្បីធ្វើតាមព្រះអង្គ
សង្គ្រោះ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ម៉ាកុស (ក៏ហៅថាជា យ៉ូហាន ម៉ាកុស ផងដែរ) គឺជាអ្នក
សរសេរគម្ពីរនេះ ។ ថ្វីបើ ម៉ាកុស ពុំស្ថិតនៅក្នុងចំណោមពួក
សិស្សដប់ពីរបស់ព្រះយេស៊ូវគ្រីស្ទក្តី ក៏ក្រោយមកលោកបាន
ប្រែចិត្តជឿ ហើយបានក្លាយទៅជាជំនួយការរបស់សាវក
ពេត្រុស ហើយលោកប្រហែលជាបានសរសេរដំណឹងល្អ
របស់លោក ផ្អែកទៅលើអ្វីដែលលោកបានរៀនមកពីពេត្រុស
(សូមមើល *Bible Dictionary* « ម៉ាកុស ») ។

ម៉ាកុស និងម្តាយរបស់លោកឈ្មោះ ម៉ារា បានរស់នៅក្នុង
ទីក្រុងយេរូសាឡិម ដែលគេហៅជាន្លរបស់ពួកគេគឺជាកន្លែង
ជួបជុំសម្រាប់ពួកគ្រីស្ទានជំនាន់ដំបូងបំផុត (សូមមើលកិច្ចការ
១២:១២) ។ ម៉ាកុស បានចាកចេញពីទីក្រុងយេរូសាឡិម
ដើម្បីជួយដល់ បាណាបាស និង សូល (ប៉ុល) នៅក្នុងដំណើរ
ផ្សព្វផ្សាយសាសនាលើកដំបូងរបស់ពួកគេ (សូមមើលកិច្ចការ
១២:២៥, ១៣:៤–៦, ៤២–៤៨) ។ ក្រោយមក ប៉ុល
បានសរសេរថា ម៉ាកុស គឺនៅជាមួយលោកនៅទីក្រុង រ៉ូម (សូម
មើលកូល៉ុស ៤:១០, ភីលេម៉ូន ១:២៤) ហើយបានសរសេរដល់
ម៉ាកុស ក្នុងនាមជាដៃគូម្នាក់ដែល « ជា [អ្នក] មានប្រយោជន៍
ក្នុងការងារ (ធីម៉ូថេទី ២ ៤:១១) ។ ពេត្រុស បានហៅគាត់
ថាជា « ម៉ាកុស ជាកូនខ្ញុំ » (ពេត្រុសទី ១ ៥:១៣) ដោយផ្តល់
យោបល់អំពីភាពជិតស្និទ្ធនៃទំនាក់ទំនងរបស់ពួកគេ ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរ នេះត្រូវបានសរសេរ ?

យើងពុំដឹងពីទីកន្លែងច្បាស់លាស់ដែលដំណឹងល្អរបស់ម៉ាកុស
ត្រូវបានសរសេរឡើងឡើយ ។ ម៉ាកុស ទំនងជាបានសរសេរ
ដំណឹងល្អរបស់លោកនៅទីក្រុង រ៉ូម ចន្លោះគ.ស. ៦៤
និងគ.ស. ៧០ ប្រហែលជានៅមិនយូរប៉ុន្មានបន្ទាប់ពីសាវក
ពេត្រុស បានរងទុក្ខទុក្ករកម្មប្រមាណជាក្នុង គ.ស. ៦៤ ។

តើគម្ពីរនេះត្រូវបានសរសេរចំពោះនរណា ហើយ តើហេតុអ្វី ?

ដំណឹងល្អរបស់ម៉ាកុស មានព័ត៌មានលម្អិត—ដូចជាបាន
បកប្រែពាក្យដកស្រង់តាមទម្រង់ភាសាអារ៉ាម ឃ្លាឡេជាភាសា
ឡាតាំង និង ការពន្យល់អំពីទំនៀមទម្លាប់យូដា—ដែល
ហាក់ដូចជាចង់ផ្តល់សម្រាប់ដែលជាចម្បងសម្រាប់ជនជាតិរ៉ូម
និង មនុស្សមកពីសាសន៍ដទៃ ក៏ដូចជាអ្នកទាំងឡាយដែលបាន
ផ្លាស់ប្រែចិត្តជឿជាគ្រីស្ទាន ដែលភាគច្រើននៅក្នុងទីក្រុងរ៉ូម និង
នៅទូទាំងអាណាចក្ររ៉ូម ។ មនុស្សជាច្រើនបានជឿថា ម៉ាកុស
ប្រហែលជាបាននៅជាមួយពេត្រុសនៅក្នុងទីក្រុងរ៉ូម អំឡុង
គ្រាមួយដែលបានប៉ះទង្គិចទៅដោយការសោកល្វងដ៏ធ្ងន់ធ្ងរទៅ
លើសេចក្តីជំនឿសមាជិកនៃសាសនាចក្រគ្រប់កន្លែងពាសពេញ
អាណាចក្ររ៉ូម ។

មួយភាគបីនៃដំណើររឿងក្នុងដំណឹងល្អរបស់ ម៉ាកុស
រៀបរាប់អំពីការបង្រៀន និង បទពិសោធន៍ទាំងឡាយ
របស់ព្រះអង្គសង្គ្រោះ អំឡុងសប្តាហ៍ចុងក្រោយនៃជីវិត
របស់ទ្រង់ ។ ម៉ាកុស បានថ្លែងជាសាក្សីថានៅទីបំផុត ការ
រងទុក្ខរបស់ព្រះរាជបុត្រានៃព្រះ បានយកឈ្នះលើអំពើអាក្រក់
អំពើបាប និង សេចក្តីស្លាប់ ។ ទីបន្ទាល់នេះ មានន័យ
ថា អ្នកដើរតាមព្រះអង្គសង្គ្រោះទាំងឡាយពុំចាំបាច់ភ័យ
ខ្លាចឡើយ នៅពេលពួកគេប្រឈមមុខនឹងការបៀតបៀន
ការសោកល្វង ឬទោះជាត្រូវស្លាប់ក្តី ពួកគេកំពុងតែដើរតាម
លោកចៅហ្វាយរបស់ពួកគេហើយ ។ ពួកគេអាចស៊ូទ្រាំដោយ
មានទំនុកចិត្តដោយដឹងថា ព្រះអម្ចាស់នឹងជួយពួកគេ ហើយ
ថារាល់ការសន្យាទាំងអស់របស់ទ្រង់ នឹងត្រូវបានបំពេញ
នៅទីបំផុត ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ដំណឹងល្អរបស់ម៉ាកុស ចាប់ផ្តើមក្នុងដំហានដ៏លឿនមួយរំពេច
និង ដោយក្តីរំភើប ហើយរក្សាបាននូវល្បឿនដ៏លឿនដែល
បានដំណាលប្រាប់សារឡើងវិញអំពីព្រឹត្តការណ៍ទាំងឡាយ
នៅក្នុងដំណើរតៗគ្នាយ៉ាងហ៊ាស ។ ជាញឹកញាប់ ម៉ាកុសបាន
ប្រើពាក្យ*ស្រាប់តែ*និង*មួយរំពេច* ដែលផ្តល់នូវឥទ្ធិពលនៃដំហាន
និងសកម្មភាពលឿនៗ ។

ទោះបីមានច្រើនជាង ៩០ ភាគរយនៃឯកសារនៅក្នុងគម្ពីរ
ម៉ាកុស ត្រូវអាចរកឃើញមាននៅក្នុងគម្ពីរម៉ាថាយ និង លូកាក្តី
ក៏ដំណើររឿងរបស់ម៉ាកុស ជាញឹកញាប់មានបញ្ចូលនូវព័ត៌មាន
លម្អិតបន្ថែមទៀត ដែលជួយយើងឲ្យមានអំណរគុណកាន់តែ
ពេញលេញចំពោះសេចក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ
និង ការឆ្លើយតបរបស់ទ្រង់ចំពោះមនុស្សដែលនៅជុំវិញទ្រង់
(ប្រៀបធៀបម៉ាកុស ៩:៤–២៧ ជាមួយនឹងម៉ាថាយ ១៧:១៤–
១៨) ។ ឧទាហរណ៍ ម៉ាកុសរៀបរាប់អំពីការទទួលស្វាគមន៍ដល់
ព្រះអង្គសង្គ្រោះយ៉ាងក្លៀវក្លាពីសំណាក់អ្នកទាំងឡាយដែល
នៅស្រុកកាលីឡេ និងកន្លែងផ្សេងទៀតក្នុងការងារបម្រើពី
ដំបូងរបស់ទ្រង់(សូមមើលម៉ាកុស ១:៣២–៣៣, ៤៥, ២:២,
៣:៧–៩,៤:១) ។ ម៉ាកុស ក៏បានរៀបរាប់ដោយប្រុងប្រយ័ត្ន
ផងដែរអំពីការឆ្លើយតបអវិជ្ជមានពីពួកសង្ឃ និង ពួក
ផារិស៊ី ដែលជំទាស់កាន់តែខ្លាំងភ្លាមៗមកពីការមានគំនិត
សង្ស័យ (សូមមើលម៉ាកុស ២:៦–៧) ទៅជាគ្រោងបំផ្លាញ
ព្រះយេស៊ូវ (សូមមើលម៉ាកុស ៣:៦) ។

នៅក្នុងចំណោមបាវចនាដ៏សំខាន់ៗក្នុងគម្ពីរម៉ាកុស ក៏មាន
សំណួរជាច្រើនអំពីព្រះយេស៊ូវជានរណា ហើយនរណា
បានយល់អំពីអត្តសញ្ញាណរបស់ទ្រង់ ក៏ដូចជាតួនាទីរបស់សិស្ស
ដែលជាអ្នកត្រូវ « ផ្ទុកឈើឆ្កាងខ្លួនមកតាម [ព្រះយេស៊ូវ] »
(ម៉ាកុស ៨:៣៤) ។ បន្ថែមពីលើនោះ ម៉ាកុស គឺជាដំណឹងល្អ
តែមួយគត់ដែលរៀបរាប់អំពីរឿងប្រៀបធៀបនៃគ្រាប់ពូជដែល
ដុះដោយខ្លួនវា (សូមមើលម៉ាកុស ៤:២៦–២៧) ការព្យាបាល
មនុស្សថ្លង់នៅស្រុកដេកាប៉ូល (សូមមើលម៉ាកុស ៧:៣១–
៣៧) និង ការព្យាបាលបន្តិចម្តងៗដល់មនុស្សខ្វាក់ម្នាក់នៅភូមិ
បេតសៃដា (សូមមើលម៉ាកុស ៨:២២–២៦) ។

គម្រោង

ម៉ាកុស ១–៤ ព្រះយេស៊ូវបានទទួលបុណ្យ
ជ្រមុជទឹកដោយ យ៉ូហាន បាទីស្ទ ហើយចាប់ផ្តើម
ការផ្សាយ ការហៅពួកសិស្ស និងការធ្វើអព្ភូតហេតុ
ជាច្រើន ។ នៅពេលមានការប្រឆាំងជំទាស់នឹង
ទ្រង់កាន់តែខ្លាំងឡើង នោះទ្រង់បង្រៀនជារឿង
ប្រៀបធៀប ។

ម៉ាកុស ៥–៧ ព្រះអង្គសង្គ្រោះបន្តធ្វើ
អព្ភូតហេតុជាច្រើន បង្ហាញពីក្តីមេត្តាករុណា
របស់ទ្រង់ចំពោះអ្នកដទៃ ។ បន្ទាប់ពី យ៉ូហាន បាទីស្ទ
ត្រូវបានគេសម្លាប់ ព្រះយេស៊ូវបានប្រទានអាហារ
ដល់មនុស្សច្រើនដងជាច្រើនដង ហើយបានយាង
លើទឹក ។ ព្រះយេស៊ូវបង្រៀនទាស់នឹងទំនៀមទម្លាប់
ខុសឆ្គង ។

ម៉ាកុស ៨–១០ ព្រះយេស៊ូវគ្រីស្ទបន្តធ្វើអព្ភូតហេតុ ។
ពេត្រុសថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវជាព្រះគ្រីស្ទ ។
ព្រះអង្គសង្គ្រោះព្យាករបីដងអំពីការរងទុក្ខការសុគត និង
ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ប៉ុន្តែពួកសិស្ស
របស់ទ្រង់ពុំទាន់បានយល់ដឹងពេញលេញអំពីអត្ថន័យ
របស់ទ្រង់ឡើយ ។ ទ្រង់បង្រៀនពួកគេអំពីភាពរាបសារ
និង ការបម្រើដែលតម្រូវឲ្យពួកសាវកធ្វើ ។

ម៉ាកុស ១១–១៦ អំឡុងសប្តាហ៍ចុងក្រោយនៃព្រះជន្ម
របស់ទ្រង់ ព្រះអង្គសង្គ្រោះបានយាងចូលទីក្រុង
យេរូសាឡិម បង្រៀនពួកសិស្សរបស់ទ្រង់ ពីការរងទុក្ខ
នៅក្នុងសួនច្បារគេតសេម៉ានី ហើយត្រូវបានគេឆ្កាង ។
ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ។

ម៉ាកុស ១

សេចក្តីផ្តើម

យ៉ូហាន បាទីស្ទ បានផ្សាយអំពី « បុណ្យជ្រមុជទឹក ខាងឯការប្រែចិត្ត ប្រយោជន៍ឲ្យបានរួចពីបាប » (ម៉ាកុស ១:៤) ។ បន្ទាប់ពីយ៉ូហានបានជ្រមុជទឹកឲ្យព្រះយេស៊ូវ នោះព្រះអង្គសង្គ្រោះបានចាប់ផ្តើមផ្សាយដំណឹងល្អ ហើយធ្វើអព្ភូតហេតុដោយព្រះចេស្តា និង សិទ្ធិអំណាច ដ៏ទេវភាព ។ ទ្រង់បានបណ្តេញវិញ្ញាណអាក្រក់ ហើយបានព្យាបាលមនុស្សឃ្លង់ ។ ព្រះនាមរបស់ទ្រង់បានឮល្បីខ្ចរពេញស្រុកកាលីឡេ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ១:១–២០

ព្រះយេស៊ូវចាប់ផ្តើមការបម្រើរបស់ទ្រង់

ក្នុងរយៈពេលពីរបីថ្ងៃពីមុនថ្នាក់រៀន ចូរសួរដល់សិស្សពីរនាក់ប្រសិនបើពួកគេអាចនឹងចែកចាយទីបន្ទាល់របស់ពួកគេដោយសង្ខេបអំពីព្រះយេស៊ូវគ្រីស្ទនៅក្នុងថ្នាក់ ។ បន្ទាប់ពីការប្រជុំ សូមអញ្ជើញសិស្សពីរនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។ បន្ទាប់មក សួរដល់សិស្សក្នុងថ្នាក់ ៖

- តើការស្តាប់ឮទីបន្ទាល់មកពីបុគ្គលជាច្រើនរូប ជាជាងឮមកពីបុគ្គលតែម្នាក់មានតម្លៃបែបណាខ្លះ ?
- តើអ្នកគិតថា ការសិក្សាទីបន្ទាល់របស់ម៉ាកុស ក្នុងពេលឥឡូវនេះ បន្ទាប់ពីអ្នកបានសិក្សាអំពីទីបន្ទាល់របស់ម៉ាថាយមានតម្លៃបែបណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗនូវម៉ាកុស ១:១–៤, ៩–១១ ដោយស្ងាត់ស្ងៀម រកមើលព្រឹត្តការណ៍ដែលម៉ាកុស បានចាប់ផ្តើមដំណើររឿងរបស់លោកអំពីជីវិតរបស់ព្រះអង្គសង្គ្រោះ ។

- តើក្នុងព្រឹត្តការណ៍អ្វី ដែលម៉ាកុសបានចាប់ផ្តើមដំណើររឿងរបស់លោក ?

ចូរពន្យល់ថា ដំណើររឿងរបស់ម៉ាកុសអំពីជីវិតរបស់ព្រះអង្គសង្គ្រោះ គឺខុសប្លែកពីដំណើររឿងរបស់ម៉ាថាយ ។ វាចាប់ផ្តើមភ្លាមមួយរំពេច ហើយយ៉ាងលឿន ដោយគូសបញ្ជាក់អំពីភាពជាព្រះរបស់ព្រះអង្គសង្គ្រោះ តាមរយៈការផ្តោតទៅលើកិច្ចការ និង អព្ភូតហេតុទាំងឡាយរបស់ទ្រង់ ។ ម៉ាកុស ទំនងជាបានសរសេរដំណើររឿងរបស់លោកផ្តោតទៅលើអ្វីដែលលោកបានរៀនមកពីសាវកពេត្រុស ។

ចូរសង្ខេបម៉ាកុស១:១២–២០ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានតមអាហារអស់រយៈពេល ៤០ ថ្ងៃ នោះទ្រង់ត្រូវបានល្បួងដោយអារក្ស ។ ទ្រង់ក៏បានផ្សាយពីការប្រែចិត្តនៅស្រុកកាលីឡេ ហើយបានហៅពួកសិស្សឲ្យដើរតាមទ្រង់ផងដែរ ។ (*កំណត់ចំណាំ ៖* ដំណើររឿងទាំងនេះ ត្រូវបានបង្រៀនជ្រៅជ្រះនៅក្នុងមេរៀនទាំងឡាយក្នុងម៉ាថាយ ៤) ។

ម៉ាកុស ១:២១–៣៩

ព្រះយេស៊ូវបានបណ្តេញអារក្សចេញ ហើយបានព្យាបាលអ្នកឈឺ

ចូរសរសេរឃ្លា*ទឹកដីរបស់មារសត្រូវ*នៅលើក្តារខៀន ហើយសួរសិស្សថាតើមានគ្រោះថ្នាក់អ្វីខ្លះ ដែលទាហានទាំងជួប ពេលនៅក្នុងទឹកដីរបស់មារសត្រូវនោះ ។

សូមឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ថិយដ៍ ឃេ ជាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« អ្នករាល់គ្នាដែលជាមនុស្សវ័យក្មេង ត្រូវបានចិញ្ចឹមបីបាច់ធំឡើងនៅក្នុងទឹកដីរបស់មារសត្រូវ ។

« យើងបានដឹងមកពីខគម្ពីរថា មានសង្គ្រាមមួយនៅឯស្ថានសួគ៌ ហើយថាលូស៊ីហ្វើរបានបះបោរ ហើយ ‹ ត្រូវបោះទំលាក់ទៅផែនដីវិញ › ជាមួយអ្នកដើរតាមវា (វិវរណៈ ១២:៩) ។ វាបានតាំងចិត្តថាត្រូវរំខានផែនការរបស់ព្រះវរបិតាសួគ៌របស់យើង ហើយព្យាយាមគ្រប់គ្រងលើគំនិត និង ទង្វើរបស់មនុស្សទាំងអស់ » (« Counsel to Youth »*Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១៦) ។

- តើជីវិតរបស់យើងនៅលើផែនដីនេះ ទំនងដូចជាស្ថិតនៅក្នុងទឹកដីរបស់មារសត្រូវតាមរបៀបណា ?

ចូរសុំឲ្យសិស្សលើកដៃរបស់ពួកគេ បើពួកគេធ្លាប់មានអារម្មណ៍លើសលប់ ដោយសារតែឥទ្ធិពលអារក្ស និង ការល្បួងដែលហ៊ឺព័ទ្ធជុំវិញពួកគេ ។ នៅពេលសិស្សសិក្សាម៉ាកុស ១:២១–៣៩សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយដែលនឹងជួយពួកគេ ពេលពួកគេប្រឈមមុខនឹងឥទ្ធិពលអារក្ស និង ការល្បួង ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស១:២១–២២ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវបានធ្វើនៅក្នុងស្រុកកាពើណិម និង របៀបដែលពួកយូដាបានឆ្លើយតប ។

- ហេតុអ្វីក៏ពួកយូដាមានចិត្តភ្ញាក់ផ្អើលអស្ចារ្យចំពោះការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលព្រះយេស៊ូវបានបង្រៀន « ដូចជាមានអំណាច » ? (ម៉ាកុស ១:២២) ។

ចូរពន្យល់ថា ពួកអាចារ្យត្រូវបានគេចាត់ទុកថាជាអ្នកជំនាញខាងច្បាប់របស់ម៉ូសេ ។ នៅពេលពួកគេផ្សាយ ជាញឹកញាប់ពួកគេដកស្រង់ពីអ្នកមានសិទ្ធិអំណាចពីអតីតកាលនៅក្នុងក្រឹត្យវិន័យ (សូមមើល *New Testament Student Manual* [Church Educational System manual, ២០១៤]ទំព័រ ១០៣) ។ ផ្ទុយទៅវិញ ព្រះយេស៊ូវបានមានបន្ទូលដោយព្រះចេស្តា និង សិទ្ធិអំណាចមកពីព្រះវរបិតាទ្រង់ ហើយជាព្រះយេហូវ៉ាដ៏មហិមា ដែលបានប្រទានក្រឹត្យវិន័យម៉ូសេ (សូមមើល ការបកប្រែរបស់ យ៉ូសែប ស៊្មីធ ម៉ាថាយ ៧:៣៧ [នៅក្នុងម៉ាថាយ ៧:២៩ លេខយោង*ក*]) ។

សូមអញ្ជើញសិស្សឲ្យអានម៉ាកុស ១:២៣–២៦ ដោយស្ងាត់ស្ងៀម ឬបង្ហាញដល់សិស្សក្នុងថ្នាក់នូវវីដេអូ« Jesus Heals a Possessed Man »(១:៤៨ *វីដេអូព្រះគម្ពីរប៊ឺបអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ*មាននៅក្នុង LDS.org។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលបានកើតឡើង នៅពេលព្រះយេស៊ូវបង្រៀននៅក្នុងពោងជំនុំ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ចូរពន្យល់ថា « វិញ្ញាណអសោច » សំដៅទៅលើវិញ្ញាណអាក្រក់ ។

- តើវិញ្ញាណអសោចបានដឹងអ្វីខ្លះអំពីព្រះយេស៊ូវ ?
- តើវិញ្ញាណអសោចស្គាល់ព្រះយេស៊ូវយ៉ាងដូចម្តេច ? (វិញ្ញាណអសោច ដែលព្យាយាមមានរូបកាយសាច់ឈាម គឺជាអ្នកតើរតាមរបស់លូស៊ីហ្វើរ ។ ពួកគេរស់នៅក្នុងវត្តមានរបស់ព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ មុននឹងត្រូវបានបណ្តេញចេញពីស្ថានសួគ៌) ។
- ប្រសិនបើអ្នកនៅក្នុងពោងជំនុំនោះ តើអ្នកនឹងគិតយ៉ាងណា អំពីព្រះយេស៊ូវ ?

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាកុស១: ២៧–២៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវរបៀបដែលប្រជាជនឆ្លើយតបបន្ទាប់ពីបានឃើញព្រះយេស៊ូវបណ្តេញវិញ្ញាណអសោចចេញពីមនុស្ស ។

- តើមនុស្សបានឆ្លើយតបយ៉ាងដូចម្តេច ?
- តើដំណើររឿងនេះបង្រៀនយើងអ្វីខ្លះ អំពីព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ? (សិស្សគួរប្រាប់ពីសេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតដូចខាងក្រោម ៖ **ព្រះអង្គសង្គ្រោះមានព្រះចេស្តាលើអារក្ស និង ពួកអ្នកដើរតាមវា**)។
- តើការដឹងអំពីសេចក្តីពិតនេះ អាចជួយយើងនៅពេលយើងមានអារម្មណ៍លើសលប់ដោយសារតែឥទ្ធិពលអាក្រក់ និងការល្បួងដែលហ៊ឺព័ទ្ធជុំវិញយើងយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ដែមស៍ អឺ ហ្វោស្ត នៃគណៈប្រធានទីមួយ ៖



« [យ៉ូសែប ស៊្មីធ] បានថ្លែងថា ‹ វិញ្ញាណអាក្រក់មានកំហិត ដៃនកំណត់ និងក្រឹត្យវិន័យទាំងឡាយ ដែលពួកគេត្រូវបានគ្រប់គ្រងលើ › [នៅក្នុង *History of the Church* ៤:៥៧៦] ។ ដូច្នេះ សាតាំង និង ពួកទេវតារបស់វាពុំមានអំណាចអ្វីនោះទេ ។ . . .

« . . . ការខិតខំរបស់សាតាំងអាចត្រូវបានរារាំងដោយមនុស្សទាំងអស់ដែលមករកព្រះគ្រីស្ទតាមរយៈការគោរពប្រតិបត្តិតាមសេចក្តីសញ្ញា និង ពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ » (« Serving the Lord and Resisting the Devil »*Ensign* ខែ កញ្ញា ឆ្នាំ ១៩៩៥ ទំព័រ ៦, ៧) ។

- ស្របតាមប្រធាន ហ្វោស្ត តើយើងអាចធ្វើអ្វីខ្លះ ដើម្បីទទួលបានអំណាចកាន់តែខ្លាំងដើម្បីទប់ទល់នឹងអារក្ស ?
- ស្របតាមខ ២៨តើអ្វីខ្លះបានកើតឡើង បន្ទាប់ពីព្រះអង្គសង្គ្រោះបានបណ្តេញវិញ្ញាណអសោចនោះចេញ ?

សូមសង្ខេបម៉ាកុស ១:២៩–៣៩ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានព្យាបាលម្តាយក្មេករបស់ស៊ីម៉ូន ពេត្រុសពីជំងឺគ្រុនក្តៅ បានព្យាបាលមនុស្សជទៃទៀតជាច្រើនដែលឈឺ ហើយបានបណ្តេញអារក្សជាច្រើនចេញផងដែរ ។ ព្រះយេស៊ូវ បានបន្តផ្សព្វផ្សាយនៅក្នុងស្រុកកាលីឡេ ។

ម៉ាកុស ១:៤០–៤៥

ព្រះយេស៊ូវ បានប្រោសមនុស្សឃ្លង់ម្នាក់ឲ្យជា

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗនូវម៉ាកុស ១:៤០ដោយស្ងាត់ស្ងៀម រកមើលថានរណាមករកព្រះអង្គសង្គ្រោះ នៅពេលទ្រង់បានបន្តផ្សាយនៅក្នុងស្រុកកាលីឡេ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀន ។ ចូរសុំឲ្យសិស្សនឹកស្រមៃថា សិស្សដែលឡើងមកក្តារខៀន ជាមនុស្សកើតឃ្លង់ម្នាក់ ។

ចូរពន្យល់ថា ជំងឺឃ្លង់គឺជាជំងឺរ៉ាំរ៉ៃដែលសឹងនៅលើស្បែក សសៃប្រសាទ ភ្នែក ឆ្អឹង និង សន្លាក់ ។ បើពុំព្យាបាលទេ នោះវានឹងនាំឲ្យស្លាប់យ៉ាងឈឺចាប់ ។ នៅជំនាន់បុរាណ គេមានជំនឿថា បើនរណាម្នាក់ប៉ះពាល់នឹងអ្នកជំងឺឃ្លង់ នោះគេនឹងឆ្លងជំងឺនោះ ។ ចូរចង្អុលទៅសិស្សឈរនៅក្តារខៀន ហើយសួរ ៖

- ប្រសិនបើ (ឈ្មោះសិស្ស) គឺជាមនុស្សឃ្លង់ម្នាក់ដែលរស់នៅកាលពីជំនាន់បុរាណ តើគេប្រព្រឹត្តចំពោះ (គាត់ ឬនាង) យ៉ាងដូចម្តេច ?

ចូរពន្យល់ថា ដើម្បីការពារដល់សុខភាព និង សុខុមាលភាពរបស់សហគមន៍មួយ នោះពួកអ្នកមានជំងឺឃ្លង់ត្រូវបានបណ្តេញចេញឲ្យទៅរស់នៅខាងក្រៅទីក្រុង ។ ច្បាប់តម្រូវឲ្យពួកគេស្រែកថា « អសោច ! » ដើម្បីជាការព្រមានដល់នរណាដែលទៅរកពួកគេ (សូមមើល Bible Dictionary« Leper »,លេវីវិន័យ ១៣:៤៤–៤៦) ។ ចូរសុំឲ្យសិស្សមួយចំនួនសម្តែងពីទិដ្ឋភាពនេះ ដោយការដើរឆ្លងកាត់សិស្សដែលតំណាងឲ្យមនុស្សឃ្លង់ ។ នៅពេលពួកគេដើរជិត ចូរសុំឲ្យសិស្សដែលធ្វើតំណាងឲ្យមនុស្សឃ្លង់ស្រែកប្រាប់

ថា « អសោច ! អសោច ! » ចូរសួរដល់សិស្សដែលដើរនោះ ថាតើពួកគេនឹងមានប្រតិកម្មយ៉ាងណាចំពោះស្ថានភាពនេះ ។ បន្ទាប់មកអញ្ជើញសិស្សឲ្យអង្គុយចុះវិញ ។

- តើការមានរោគឃ្លង់ជះឥទ្ធិពលដល់ជីវិតរបស់អ្នកយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថាខ្លួនជាមនុស្សឃ្លង់ក្នុងជំនាន់របស់ព្រះយេស៊ូវគ្រីស្ទ ។ ចូរសួរពួកគេអំពីអ្វីដែលពួកគេនឹងធ្វើ ប្រសិនបើពួកគេបានឃើញព្រះអង្គសង្គ្រោះយាងមកនោះ ។

- ស្របតាមម៉ាកុស ១:៤០ តើមនុស្សឃ្លង់បានធ្វើអ្វីខ្លះ នៅពេលគាត់ឃើញព្រះអង្គសង្គ្រោះ ? (ចូរពន្យល់ថា ពាក្យ*មកដល់*មានន័យថា អង្វរសូម ឬអង្វរ) ។
- តើមនុស្សឃ្លង់បង្ហាញពីសេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ? តើឃ្លា « បើទ្រង់សព្វព្រះហឫទ័យ » បញ្ជាក់ពីជំនឿរបស់មនុស្សឃ្លង់នោះដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យអានម៉ាកុស ១:៤១–៤២ ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបដែលព្រះអង្គសង្គ្រោះឆ្លើយតបចំពោះការទូលអង្វររបស់បុរសនេះ ។

- តើមានអ្វីខ្លះដែលធ្វើឲ្យអ្នកចាប់អារម្មណ៍អំពីរបៀបដែលព្រះអង្គសង្គ្រោះឆ្លើយតបចំពោះការអង្វររបស់បុរសនោះ ?
- បើអ្នកជាមនុស្សឃ្លង់ តើវាមានន័យយ៉ាងណាចំពោះអ្នក ដែលត្រូវបានពាល់ដោយព្រះអង្គសង្គ្រោះនោះ ? ហេតុអ្វី ?
- តើជីវិតរបស់អ្នកនឹងបានផ្លាស់ប្តូរយ៉ាងដូចម្តេច បើព្រះយេស៊ូវគ្រីស្ទបានព្យាបាលរោគឃ្លង់របស់អ្នក ?

សូមសរសេរប្រយោគខាងក្រោមនេះនៅលើក្តារខៀន ៖ *រោគឃ្លង់ អាចប្រៀបដូចទៅនឹងអំពើបាប ។*

ដើម្បីជួយសិស្សឲ្យយល់ថា រោគឃ្លង់អាចប្រៀបដូចទៅនឹងអំពើបាប (សូមមើល លេវីវិន័យ ១៤) សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ប្រូស អរ ម៉ាក់ខនឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖

« រោគឃ្លង់នៅក្នុងជំនាន់ព្រះគម្ពីរប៊ីប បន្ថែមពីលើការនៅដាច់ស្រយាលពីឥទ្ធិពលខាងរូបកាយ នោះវាត្រូវបានគេចាត់ទុកថាជានិមិត្តសញ្ញានៃអំពើបាប និង ភាពពុំស្អាតស្អំ ដែលមានន័យថា ជំងឺអាក្រក់នេះ សឹបំផ្លាញរូបកាយសាច់ឈាម ដូច្នេះអំពើបាបវាសឹបំផ្លាញខាងវិញ្ញាណរបស់មនុស្ស » (*The Mortal Messiah* វ៉ុល ៤ | ១៩៧៩–៨១ |, ២:៤៥) ។

- តើរោគឃ្លង់ប្រៀបប្រដូចទៅនឹងអំពើបាបតាមរបៀបណា ? (នៅក្នុងការប្រៀបប្រដូចរោគឃ្លង់ទៅនឹងអំពើបាប ចូរប្រាកដថា សិស្សយល់ថា ជំងឺទាំងឡាយគឺពុំចាំបាច់បណ្តាលមកពីអំពើបាបនោះទេ) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសាឡើងវិញនូវម៉ាកុស ១:៤០–៤២ ឮៗ ដែលពេលនេះត្រូវជំនួសពាក្យ *មនុស្សមានអំពើបាប*ជំនួសឲ្យពាក្យ*មនុស្សឃ្លង់*ហើយដាក់ពាក្យ*អំពើបាប*ជំនួសឲ្យពាក្យ*រោគឃ្លង់* ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលយើងអាចប្រៀបប្រដូចការព្យាបាលមនុស្សឃ្លង់នេះទៅនឹងការត្រូវបានសម្អាតពីអំពើបាប ។

- នៅពេលអ្នកអានខគម្ពីរទាំងឡាយតាមរបៀបនេះ តើពាក្យអ្វីខ្លះដែលផ្តល់យោបល់អំពីការទទួលបាននូវការអភ័យទោស ?
- តើយើងអាចប្រៀបប្រដូច អ្វីដែលមនុស្សឃ្លង់បានធ្វើដើម្បីត្រូវបានជាស្អាតពីរោគឃ្លង់ ទៅនឹងអ្វីដែលយើងចាំបាច់ត្រូវធ្វើដើម្បីបានស្អាតពីអំពើបាបយ៉ាងដូចម្តេច ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀន តាមរយៈការប្រៀបប្រដូចការព្យាបាលមនុស្សឃ្លង់ទៅនឹងការស្អាតពីអំពើបាប ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគូរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿ ហើយមករកព្រះអង្គសង្គ្រោះ នោះទ្រង់នឹងមានក្តីមេត្តាចំពោះយើង ហើយសម្អាតយើងពីអំពើបាប ។** ដោយប្រើពាក្យរបស់សិស្ស ចូរសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើយើងត្រូវតែអនុវត្តសេចក្តីជំនឿ ហើយមករកព្រះអង្គសង្គ្រោះ ដើម្បីទ្រង់អាចអភ័យទោសដល់យើងពីអំពើបាបរបស់យើងតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យពិចារណាម្តងទៀតអំពីស្ថានភាពជីវិតរបស់មនុស្សឃ្លង់ពីមុន និង ក្រោយពេលដែលគាត់ត្រូវបានជាសះស្បើយ ។

- តើការមករកព្រះយេស៊ូវគ្រីស្ទដើម្បីត្រូវបានសម្អាតពីអំពើបាប អាចផ្លាស់ប្តូរជីវិតរបស់មនុស្សម្នាក់យ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់បានឃើញជីវិតរបស់មនុស្សម្នាក់ផ្លាស់ប្តូរ បន្ទាប់ពីត្រូវបានសម្អាតពីអំពើបាប តាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទនៅពេលណា ? (សូមប្រាប់ដល់សិស្សឲ្យប្រុងប្រយ័ត្នកុំបញ្ចេញឈ្មោះបុគ្គលណាម្នាក់ ឬរៀបរាប់ប្រាប់ពីអំពើបាបពីអតីតរបស់ពួកគេឡើយ) ។

ចូរសុំឲ្យសិស្សពិចារណាអំពីអំពើបាបអ្វីខ្លះដែលពួកគេចាំបាច់ត្រូវសម្អាតចោល ។ សូមអញ្ជើញសិស្សឲ្យមករកព្រះអង្គសង្គ្រោះតាមរយៈការអនុវត្តសេចក្តីជំនឿទៅលើទ្រង់ តាមរយៈការអធិស្ឋាន ការប្រែចិត្ត និង ការគោរពប្រតិបត្តិ ដើម្បីទ្រង់អាចធ្វើឲ្យពួកគេស្អាតបាន ។ សូមពិចារណាធ្វើការចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះចេស្តាលាងសម្អាតនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗចេញពី ម៉ាកុស ១:៤៣–៤៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលការណែនាំ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់មនុស្សឃ្លង់ដែលបានជាស្អាត ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ចូរពន្យល់ថា ក្រិត្យវិន័យរបស់ម៉ូសេ តម្រូវឲ្យអ្នកទាំងឡាយដែលបានជាស្អាតពីរោគឃ្លង់ បង្ហាញខ្លួនដល់សង្ឃនៅព្រះវិហារបរិសុទ្ធ ហើយថ្វាយនូវការបូជាមួយ ។

- តើបុរសនោះបានធ្វើអ្វីខ្លះ បន្ទាប់ពីព្រះអង្គសង្គ្រោះបានព្រមានគាត់កុំឲ្យប្រាប់ដល់អ្នកដទៃ ?
- តើមានអ្វីបានកើតឡើង ពេលបុរសនោះបានផ្សាយដំណឹងអំពីការជាស្អាតរបស់គាត់ ?

ចូរពិចារណាធ្វើការបញ្ចប់មេរៀនដោយការសួរដល់សិស្សអំពីអ្វីដែលបានធ្វើឲ្យពួកគេចាប់អារម្មណ៍បំផុតអំពីសកម្មភាពរបស់ព្រះយេស៊ូវគ្រីស្ទដែលបានកត់ត្រានៅក្នុងម៉ាកុសទី ១ ។

ការប្រៀបប្រដូចបទគម្ពីរទៅនឹងខ្លួនយើង

ការប្រៀបប្រដូចបទគម្ពីរទៅនឹងខ្លួនយើង មានន័យថាប្រៀបធៀបបទគម្ពីរទាំងឡាយទៅនឹងជីវិតផ្ទាល់ខ្លួនរបស់យើង ។ នៅពេលសិស្សមើលឃើញពីភាពដូចគ្នា រវាងបទពិសោធន៍របស់គេផ្ទាល់ជាមួយនឹងអ្នកទាំងឡាយដែលបានរៀបរាប់នៅក្នុងព្រះគម្ពីរ នោះពួកគេនឹងអាចស្គាល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អកាន់តែប្រសើរឡើង ។ សិស្សនឹងមើលឃើញកាន់តែល្អប្រសើរផងដែរអំពីរបៀបដែលពួកគេអាចអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

មេរៀន ៣៥

ម៉ាកុស ២–៣

សេចក្តីផ្តើម

ព្រះយេស៊ូវបានអភ័យទោស និង បានព្យាបាលដល់មនុស្សខ្វិនម្នាក់ រួចហើយបានហៅម៉ាថាយ ឲ្យដើរតាមទ្រង់ ។ ទ្រង់បានបង្រៀនពួកអាចារ្យ និង ពួកផារិស៊ីអំពីថ្ងៃឈប់សម្រាក ។

ព្រះអង្គសង្គ្រោះបានបន្តព្យាបាលមនុស្សជាច្រើន បានបញ្ជូនពួកសាវករបស់ទ្រង់ទៅផ្សាយដំណឹងល្អ ហើយព្រមានអំពីការនិយាយប្រមាថទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ២: ១–១២

ព្រះយេស៊ូវអភ័យទោស និង ព្យាបាលបុរសខ្វិនម្នាក់

សូមអញ្ជើញសិស្សឲ្យសញ្ជឹងស្រមៃថា មាននរណាម្នាក់ដែលពួកគេស្រឡាញ់កំពុងរងទុក្ខដោយសារឧបសគ្គខាងរូបកាយដែលគំរាមគំហែងដល់ជីវិត តម្រូវឲ្យមានការព្យាបាលជាពិសេស ។

- តើនរណាដែលអ្នកនឹងបែរទៅរកជំនួយ ដើម្បីជួយដល់មនុស្សជាទីស្រឡាញ់របស់អ្នក ? ហេតុអ្វី ?
- តើអ្នកនឹងស្ម័គ្រចិត្តធ្វើអ្វីខ្លះ ប្រសិនបើមានតែវេជ្ជបណ្ឌិតម្នាក់ដែលអាចជួយបាន ប៉ុន្តែវាមានការពិបាកណាស់ ដើម្បីនឹងណាត់ជួបជាមួយវេជ្ជបណ្ឌិតនោះ ?

សូមសង្ខេបម៉ាកុស ២:១–៤ ដោយពន្យល់ថា នៅក្នុងភូមិនៃស្រុកកាពើណិម ក្នុងស្រុកកាលីឡេ នោះមានបុរសម្នាក់ « មានជំងឺស្លាប់ដៃជើង » (ខទី ៣) ដែលមានន័យថាគាត់ខ្វិន ។ មនុស្សបួននាក់ទៀតបានសែងបុរសនេះទៅផ្ទះដែលព្រះយេស៊ូវគង់នៅ ។ នៅពេលពួកគេបានឃើញថា ផ្ទះនោះមានមនុស្សច្រើនកុះករដែលពួកគេពុំអាចចូលទៅក្នុងបាន នោះពួកគេក៏បានបើកផ្ទៃកន្ទែងដំបូលផ្ទះ ហើយបានសម្រូតបុរសខ្វិនមកនៅក្នុងវត្តមានរបស់ព្រះអង្គសង្គ្រោះ ។

ចូរសុំសិស្សម្នាក់អានម៉ាកុស ២:៥ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់បុរសដែលខ្វិននោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ាកុស ២:៦–១២ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលអ្វីដែលបានកើតឡើងបន្ទាប់ទៀត។

- យោងតាមខទី ៦–៧តើ « មានពួកអាចារ្យខ្លះ » បានឆ្លើយតបនឹងព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ? (ពួកគេបានខឹងដោយសារការប្រកាសរបស់ទ្រង់ចំពោះការអភ័យទោសនឹងអំពើបាបទាំងឡាយ) ។
- តើព្រះយេស៊ូវបានសួរដល់ពួកអាចារ្យអ្វីខ្លះ ?
- តើព្រះអង្គសង្គ្រោះបានបង្ហាញ និង បង្រៀនអ្វីខ្លះ តាមរយៈការព្យាបាលដល់បុរសនេះ ? (បន្ទាប់ពីសិស្សឆ្លើយតប សូមជួយពួកគេឲ្យស្គាល់នូវសេចក្តីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទ មានព្រះចេស្តាដើម្បីព្យាបាលយើងខាងវិញ្ញាណ និង ខាងសាច់ឈាម**)។

សូមចង្អុលបង្ហាញថា នៅពេលពួកអាចារ្យបានមើលឃើញបុរសខ្វិនក្រោកឡើងពីគ្រែដើរទៅ នោះពួកគេបានទទួលកស្តុតាងដែលពុំអាចបដិសេធបានថា ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាដើម្បីព្យាបាលអ្នកឈឺ ហើយពួកគេបានស្តាប់ឮទ្រង់ថ្លែងទីបន្ទាល់ថា ទ្រង់អាចអភ័យទោសអំពើបាបទាំងឡាយ ។ ទោះជាយ៉ាងណាក៏ដោយ វាពុំមានន័យការចង្អុលបង្ហាញថា បុរសទាំងនេះបានមករកព្រះយេស៊ូវបន្ទាប់ពីនោះ ហើយស្វែងរកនូវការអភ័យទោសចំពោះអំពើបាបផ្ទាល់ខ្លួនរបស់គេទេ ។

(កំណត់ចំណាំ ៖ ព្រឹត្តការណ៍ទាំងឡាយ បានកត់ត្រានៅក្នុងម៉ាកុស ២:១–១២ នឹងត្រូវបានពិភាក្សាកាន់តែសឹងជម្រៅនៅក្នុងមេរៀនសម្រាប់ល្ងាច ៥) ។

ម៉ាកុស ២:១៣–២២

ព្រះយេស៊ូវហៅម៉ាថាយឲ្យទៅតាមទ្រង់ ហើយសោយអាហារជាមួយនឹងអ្នកយកពន្ធ និង មនុស្សមានបាប

សូមបំបែកសិស្សជាដៃគូ ហើយឲ្យក្រដាសមួយសន្លឹកដល់ដៃគូនីមួយៗ ។ សូមអញ្ជើញសិស្សឲ្យពិភាក្សាអំពីសំណួរដូចខាងក្រោមជាមួយនឹងដៃគូរបស់ពួកគេ ហើយឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្រដាស ។

- តើមានមូលហេតុអ្វីខ្លះដែលបុគ្គលម្នាក់ៗប្រហែលជាមិនស្វែងរកការអភ័យទោសរបស់ព្រះអម្ចាស់ចំពោះអំពើបាបរបស់ពួកគេ ?

ចូរសុំឲ្យសិស្សពីរបីនាក់រៀបរាប់ពីចម្លើយរបស់ពួកគេ ដែលអាចនឹងមានបញ្ជូលនូវអ្វីដូចតទៅនេះ ៖ បុគ្គលខ្លះពុំចង់ឈប់មានអំពើបាបទេ ខ្លះទៀងពុំចង់ទទួលស្គាល់ ឬសារភាពអំពើបាបរបស់ពួកគេទេដោយសារតែភាពឆ្មើងឆ្មៃ ឬការខ្មាស់អៀន ឯអ្នកដទៃទៀតអាច

នឹងសង្ឃឹមថាព្រះអម្ចាស់នឹងអភ័យទោសដល់ពួកគេទោះជាពួកគេពុំប្រែចិត្តក្តី ហើយមួយចំនួនទៀតអាចនឹងជឿថា ព្រះអម្ចាស់មានព្រះចេស្តាដើម្បីអភ័យទោស ប៉ុន្តែពួកគេខ្វះសេចក្តីជំនឿថា ទ្រង់នឹងអភ័យទោសចំពោះអំពើបាបជាក់លាក់របស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតទាំងឡាយក្នុងម៉ាកុស ២:១៣–២២ដែលអាចលើកទឹកចិត្តយើងឲ្យស្វែងរកការអភ័យទោសរបស់ព្រះអម្ចាស់ ។

ចូរសុំសិស្សម្នាក់អាន ម៉ាកុស ២: ១៣–១៥ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ បន្ទាប់ពីការព្យាបាលដល់បុរសខ្ចិន ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ បន្ទាប់ពីការព្យាបាលដល់បុរសនេះ ?
- តើលេវីបានឆ្លើយតបយ៉ាងដូចម្តេច ចំពោះការអញ្ជើញរបស់ព្រះអង្គសង្គ្រោះ ?

ចូរពន្យល់ថា លេវី ក៏មានឈ្មោះថាម៉ាថាយផងដែរ ហើយគឺជាម៉ាថាយដែលបានសរសេរដំណឹងល្អរបស់ម៉ាថាយ ។ ឃ្លាថា« អង្គុយនៅត្រង់កន្លែងយកពន្ធ » (ខ ១៤) មានន័យថា ម៉ាថាយគឺជាអ្នកយកពន្ធ ហើយ « ជាអ្នកប្រមូលពន្ធនៅស្រុកកាពើណិម ប្រហែលជាធ្វើការបម្រើឲ្យ ហេរ៉ូឌ អាន់ទីប៉ាស » (Bible Dictionary« Matthew ») ។ មានពួកសាសន៍យូដាជាច្រើនបានស្អប់អ្នកយកពន្ធដោយសារពួកគេមើលទៅពួកយកពន្ធជាមនុស្សក្បត់ជាតិ ដែលប្រមូលប្រាក់ពីប្រជាជនរបស់ខ្លួនសម្រាប់ពួកជនជាតិរ៉ូម ។

- យោងតាមខទី ១៥តើម៉ាថាយបានធ្វើអ្វីខ្លះសម្រាប់ព្រះអង្គសង្គ្រោះ និង ពួកសាវករបស់ទ្រង់ ?
- តើនរណាបានចូលរួមនៅក្នុងពិធីជប់លៀងនេះ ?

ចូរពន្យល់ថា អំឡុងពេលនៃការបម្រើរបស់ព្រះអង្គសង្គ្រោះក្នុងជីវិតរមែងស្លាប់ ការចែកចាយអាហារមានន័យច្រើនជាងការគ្រាន់តែទទួលទាន និង ជីកជាមួយគ្នា ។ វាបញ្ជាក់ថា មានចំណងមិត្តភាព និង ភាពសុខសាន្តនៅក្នុងចំណោមមនុស្សទាំងអស់ដែលបានមកចូលរួម ។

សូមអញ្ជើញសិស្សម្នាក់អានម៉ាកុស ២:១៦ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលពួកអាចារ្យ និងពួកផារិស៊ីបានមានប្រតិកម្ម ពេលពួកគេបានមើលឃើញព្រះអង្គសង្គ្រោះទទួលទានជាមួយនឹងអ្នកយកពន្ធនោះ ។

- តើពួកអាចារ្យ និង ពួកផារិស៊ីបាននិយាយអ្វីខ្លះ ?
- ហេតុអ្វីក៏អ្នកគិតថា ពួកគេបានរិះគន់ដល់ព្រះយេស៊ូវចំពោះការទទួលទានអាហារជាមួយនឹងពួកយកពន្ធ និង មនុស្សមានបាបដូច្នេះ ?

ចូរសុំសិស្សម្នាក់អានម៉ាកុស ២:១៧ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះ ចំពោះការរិះគន់របស់ពួកអាចារ្យ និង ពួកផារិស៊ី ។

- តើព្រះអង្គសង្គ្រោះបានប្រើបន្ទូលអ្វីខ្លះពិពណ៌នាអំពីព្រះអង្គទ្រង់ ? (សូមចង្អុលបង្ហាញថា តាមរយៈការប្រើពាក្យ*ត្រូវហៅ*ព្រះអង្គសង្គ្រោះបានបញ្ជាក់សាជាថ្មីអំពីព្រះចេស្តារបស់ទ្រង់ដើម្បីព្យាបាលទាំងខាងវិញ្ញាណ និង ខាងសាច់ឈាម) ។
- តើការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះអាចប្រហែលជាជួយដល់ពួកអាចារ្យ និង ពួកផារិស៊ីឲ្យយល់ពីមូលហេតុដែលទ្រង់បានទំនាក់ទំនងនឹងពួកអ្នកយកពន្ធ និង មនុស្សមានបាបយ៉ាងដូចម្តេច ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខទី ១៧ អំពីរបៀបដែលព្រះអង្គសង្គ្រោះឆ្លើយតបចំពោះអំពើបាបរបស់យើង ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ព្រះអង្គសង្គ្រោះមានព្រះទ័យចង់ជួយយើងឲ្យប្រែចិត្តពីអំពើបាបរបស់យើង ហើយបានជាសះស្បើយ**) ។
- ហេតុអ្វីក៏វាសំខាន់ដើម្បីជឿថា ព្រះយេស៊ូវមានព្រះទ័យចង់ជួយយើងឲ្យប្រែចិត្ត ហើយត្រូវបានព្យាបាលឲ្យជាសះស្បើយ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ក្រេហ្គ អេ ខារដុន នៃក្រុមចិតសិបនាក់ ៖



« ព្រះអម្ចាស់ស្រឡាញ់យើង ហើយចង់ឲ្យយើងយល់ពីព្រះឆន្ទៈអភ័យទោសរបស់ទ្រង់ ។ . . .

«. . . យើងទាំងអស់គ្នា រួមទាំងអស់អ្នកដែលកំពុងពុះពារយកឈ្នះលើឥរិយាបទញៀន ដូចជាការបំពានលើសារធាតុប្រឆូបអាសគ្រាម និង អស់អ្នកដែលជិតស្និតនឹងពួកគេ អាចដឹងថា ព្រះអង្គសង្គ្រោះនឹងទទួលស្គាល់នូវការខិតខំដោយសុចរិតរបស់យើង ហើយនឹងអភ័យទោសដោយក្តីស្រឡាញ់នៅពេលការប្រែចិត្តត្រូវបានធ្វើឡើងចប់សព្វគ្រប់នោះ » (« The Savior Wants to Forgive »*Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ១៦) ។

- តើយើងអាចដឹងថា ព្រះអម្ចាស់មានព្រះទ័យចង់ជួយយើងឲ្យប្រែចិត្ត ហើយទទួលការអភ័យទោសរបស់ទ្រង់របៀបណា ?

សូមអញ្ជើញសិស្សឲ្យគិតពិចារណាថា តើពួកគេដូចជាពួកអ្នកយកពន្ធ និង មនុស្សមានបាប (ដែលទទួលស្គាល់នូវសេចក្តីត្រូវការចំពោះព្រះអង្គសង្គ្រោះរបស់ពួកគេ ហើយបានមករកទ្រង់) ឬក៏ពួកគេដូចជាពួកអាចារ្យ និង ពួកផារិស៊ី (ដែលពុំមករកព្រះអង្គសង្គ្រោះដើម្បីសុំការអភ័យទោស និង ព្រះចេស្តារព្យាបាលរបស់ទ្រង់ឡើយ) ។

សូមថ្លែងទីបន្ទាល់អំពីព្រះចេស្តា និង ព្រះរាជបំណងរបស់ព្រះអង្គសង្គ្រោះដើម្បីព្យាបាលយើង ហើយលើកទឹកចិត្តសិស្សឲ្យស្វែងរកការអភ័យទោសពីទ្រង់ តាមរយៈការកែប្រែចិត្ត នៅពេលចាំបាច់ ។

សូមសង្ខេបម៉ាកុស២:១៨–២២ដោយពន្យល់ថា ព្រះយេស៊ូវបានបង្រៀនថាហេតុអ្វីក៏ពួកសាវករបស់ទ្រង់ពុំបានតមអាហារ ខណៈដែលទ្រង់គង់នៅជាមួយនឹងពួកគេ ។ ទ្រង់ក៏បានបង្រៀនផងដែរថា ហេតុអ្វីក៏វាពិបាកសម្រាប់មនុស្សមួយចំនួនដើម្បីទទួលយកដំណឹងល្អរបស់ទ្រង់ ។ (*កំណត់ចំណាំ ៖* ការបង្រៀនទាំងនេះនឹងគ្របដណ្តប់កាន់តែជ្រៅជ្រះនៅក្នុងមេរៀនសម្រាប់ល្ងាច ៥) ។

ម៉ាកុស ២:២៣–៣:៦

ព្រះយេស៊ូវបង្រៀនអំពីថ្ងៃឈប់សម្រាក

ចូរស្នើសិស្សប្រសិនបើពួកគេធ្លាប់ជ្រើសរើសមិនចូលរួមក្នុងសកម្មភាពមួយ ដើម្បីរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

ចូរសរសេរសំណួរដូចខាងក្រោមនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យគិតពិចារណាអំពីសំណួរនោះ៖ នៅពេលពួកគេបន្តសិក្សានៅក្នុងម៉ាកុស ២–៣ ៖ *តើអ្នកដឹងថាសកម្មភាពមួយត្រឹមត្រូវឬអត់ ដើម្បីធ្វើនៅថ្ងៃឈប់សម្រាកយ៉ាងដូចម្តេច ?*

សូមបែងចែកថ្នាក់ជាពីរក្រុម ។ សូមអញ្ជើញមួយក្រុមអានម៉ាកុស ២:២៣–២៨ដោយស្ងាត់ស្ងៀម ។ (សូមលើកទឹកចិត្តសិស្សទាំងនេះឲ្យអានការបកប្រែរបស់ យ៉ូសែប ស្ម៊ីធ ម៉ាកុស ២:២៦–២៧ ផងដែរ [នៅក្នុងសេចក្តីបន្ថែមព្រះគម្ពីរប៊ីប]) ។ ចូរសុំសិស្សពាក់កណ្តាលថ្នាក់ទៀតអានម៉ាកុស ៣:១–៦ ដោយស្ងាត់ស្ងៀម ។ សូមណែនាំដល់សិស្សឲ្យស្វែងរកអ្វីដែលព្រះអង្គសង្គ្រោះ និងពួកសាវករបស់ទ្រង់បានធ្វើ ដែលពួកសាឌូស៊ីបានជឿថា ជាការបំពានល្មើសនឹងបទបញ្ញត្តិនៃការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើពួកផារិស៊ីបានជឿអ្វីខ្លះថាជាការធ្វើខុសច្បាស់ ដែលព្រះអង្គសង្គ្រោះ និង ពួកសិស្សរបស់ទ្រង់បានធ្វើនៅថ្ងៃឈប់សម្រាក ? (ការបេះពោត និង ការព្យាបាលមនុស្សណាម្នាក់) ។
- ហេតុអ្វីក៏ពួកផារ៉ាស៊ីគិតថាការបេះពោត ឬព្យាបាលមនុស្សណាម្នាក់ នៅថ្ងៃឈប់សម្រាកនោះ ជាការល្មើសនឹងច្បាប់របស់ព្រះ ?

ប្រសិនបើចាំបាច់ សូមរំឭកសិស្សថា ពួកគ្រូបង្រៀនសាសន៍យូដាបានបន្ថែមច្បាប់ និង ការបកប្រែផ្ទាល់ខ្លួនរបស់ពួកគេចូលទៅ ដែលហៅថាជាច្បាប់តាមមាត់ ឬទំនៀមទំលាប់ ចំពោះក្រិត្យវិន័យរបស់ម៉ូសេ ។ ច្បាប់ដែលបានបន្ថែមទាំងនេះ មានបំណងដើម្បីរាំងរាំងដល់ការល្មើសច្បាប់របស់ព្រះ ប៉ុន្តែវាក៏បានរារាំងមនុស្សមួយចំនួន មិនឲ្យយល់ពីគោលបំណងពិតនៃបទបញ្ញត្តិជាក់លាក់ រួមមានទាំងការបង្គាប់ឲ្យរក្សាថ្ងៃឈប់សម្រាកទុកជាបរិសុទ្ធផងដែរ ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *យើងអាចរក្សាថ្ងៃឈប់សម្រាកឲ្យបានបរិសុទ្ធដោយ . . .*

- តើអ្នកបញ្ចប់សេចក្តីថ្លែងការណ៍នេះ ដោយផ្អែកលើការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងម៉ាកុស ២–៣យ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតប សូមបំពេញប្រយោគនៅលើក្តារខៀនដើម្បីវានាំទៅរកសេចក្តីពិតដូចខាងក្រោមនេះ ៖ **យើងអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ដោយការថ្វាយសិរីល្អដល់ព្រះ និងការធ្វើការងារល្អ**)។
- តើយើងអាចថ្វាយសិរីល្អដល់ព្រះ នៅថ្ងៃបរិសុទ្ធរបស់ទ្រង់ដោយរបៀបណា ?
- តើគំរូមួយចំនួននៃការធ្វើការងារល្អនៅថ្ងៃបរិសុទ្ធមានអ្វីខ្លះ ?

សូមសួរសំណួរដែលជួយសិស្សយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

បន្ទាប់ពីសិស្សប្រាប់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ នោះពួកគេត្រូវយល់ដឹងអំពីវាមុនពេលពួកគេអាចយកវាមកអនុវត្តប្រកបដោយអត្ថន័យ ។ សូមសួរសំណួរដែលនឹងនាំសិស្សឲ្យយល់កាន់តែច្បាស់អំពីគោលលទ្ធិ ឬគោលការណ៍ជាក់លាក់ ឬដែលនឹងលើកទឹកចិត្តពួកគេឲ្យពិចារណានូវគោលការណ៍មួយនៅក្នុងបរិបទទំនើប ។ សូមអញ្ជើញសិស្សឲ្យពន្យល់អំពីការយល់ដឹងរបស់ពួកគេទៅលើគោលលទ្ធិ ឬគោលការណ៍ជាក់លាក់ផងដែរ ។

ដើម្បីជួយសិស្សយល់អំពីរបៀបដែលពួកគេអាចសម្រេចអំពីសកម្មភាព ដែលសមរម្យសម្រាប់ថ្ងៃឈប់សម្រាក ចូរសុំឲ្យសិស្សអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយប្រធាន ជេមស៍ អ៊ី ហ្វោស្ត នៃគណៈប្រធានទីមួយ ៖



« តើបទដ្ឋានយ៉ាងជាក់ច្បាស់ណា ដែលត្រូវអាចទទួលយកបាន និង មិនអាចទទួលយកបាននៅថ្ងៃឈប់សម្រាក ? នៅក្នុងសេចក្តីណែនាំ យើងម្នាក់ៗត្រូវតែឆ្លើយសំណួរនេះសម្រាប់ខ្លួនយើង ។ ខណៈដែលសេចក្តីណែនាំទាំងនេះមាននៅក្នុងខគម្ពីរ និង ពាក្យសម្តីរបស់ពួកព្យាការីសម័យទំនើប នោះសេចក្តីណែនាំទាំងនេះក៏ត្រូវបានសរសេរនៅក្នុងដួងចិត្តរបស់យើង ហើយគ្រប់គ្រងដោយមនសិការរបស់យើងផងដែរ ។ . . . វាមិនទំនងថានឹងមានការបំពានល្មើសដ៏ធ្ងន់ធ្ងរណាមួយ ក្នុងការថ្វាយបង្គំថ្ងៃឈប់សម្រាកទេ ប្រសិនបើយើងមកដោយមានដួងចិត្តរាបទាបនៅចំពោះព្រះអម្ចាស់ ហើយថ្វាយដួងចិត្ត ព្រលឹង និង គំនិតរបស់យើងទាំងអស់ទៅទ្រង់នោះ ។ (សូមមើល ម៉ាថាយ ២២:៣៧) ។

« អ្វីដែលសក្តិសម ឬ មិនសក្តិសមស្តីពីថ្ងៃឈប់សម្រាកនឹងត្រូវបានវិនិច្ឆ័យដោយយើងម្នាក់ៗ តាមរយៈការព្យាយាមស្មោះត្រង់ ជាមួយព្រះអម្ចាស់ ។ នៅថ្ងៃឈប់សម្រាក យើងគួរតែធ្វើអ្វីដែលយើងត្រូវតែធ្វើ និង អ្វីដែលយើងគួរតែធ្វើក្នុងតរិយាបថនៃការថ្វាយបង្គំ ហើយបន្ទាប់មកដាក់កំហិតលើសកម្មភាពដទៃផ្សេងទៀតរបស់យើង » (« The Lord’s Day » *Ensign* ខែវិច្ឆិកា ឆ្នាំ ១៩៩១, ៣៥) ។

- តើអ្នកមានអារម្មណ៍ថាជាពរជ័យយ៉ាងណា ពេលអ្នកបានព្យាយាមដើម្បីថ្វាយបង្គំព្រះ ហើយធ្វើការងារល្អនៅថ្ងៃឈប់សម្រាកនោះ ?

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីរបៀបមួយ ដែលពួកគេអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធបានកាន់តែល្អប្រសើរ ហើយសរសេរគោលដៅមួយដើម្បីធ្វើដូច្នោះ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

ម៉ាកុស ៣:៧–៣៥

ព្រះយេស៊ូវព្យាបាលមនុស្សជាច្រើន ទ្រង់បញ្ជូនពួកសាវករបស់ទ្រង់ឲ្យទៅផ្សព្វផ្សាយ និង ព្រមានអ្នកដទៃអំពីការប្រមាថ ។

សូមសង្កេបម៉ាកុស ៣:៧–៣៥ ដោយពន្យល់ថា ព្រះយេស៊ូវបានយាងចេញទៅសមុទ្រកាលីឡេ ហើយបានព្យាបាលមនុស្សជាច្រើនដែលបានដើរតាមទ្រង់នៅទីនោះ រួមមានទាំងមនុស្សមួយចំនួនដែលមានវិញ្ញាណអសោចផងដែរ ។ បន្ទាប់ពីការជ្រើសរើសពួកសាវកដប់ពីរនាក់ ព្រះយេស៊ូវបានតែងតាំងពួកគេ ហើយបានបញ្ជូនពួកគេឲ្យចេញទៅផ្សាយ ព្យាបាល និងបណ្តេញអារក្ស ។ បន្ទាប់មក ទ្រង់បានព្រមានពួកអាចារ្យអំពីការនិយាយប្រមាថទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ ហើយបានបង្រៀនថា គ្រួសាររបស់ទ្រង់គឺជាមនុស្សដែលធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ។

(*កំណត់ចំណាំ ៖* ព្រឹត្តការណ៍មួយចំនួន បានកត់ត្រានៅក្នុងម៉ាកុស ៣:៧–៣៥នឹងត្រូវបានពិភាក្សាកាន់តែសឹងជម្រៅនៅក្នុងមេរៀនសម្រាប់ម៉ាថាយ ១២:២២–៣៥) ។

ដើម្បីបញ្ចប់ អ្នកអាចនឹងចង់ថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលបានរៀបរាប់ច្រាប់នៅក្នុងមេរៀន ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ២៦:៣១– ម៉ាកុស ៣:៣៥ (មេរៀនទី ៧)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន សម្រាប់ការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ាថាយ ២៦:៣១–ម៉ាកុស ៣ (មេរៀនទី ៧) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកមួយនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅ ពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាថាយ ២៦:៣១–៧៥)

នៅពេលសិស្សសិក្សាអំពីការរងទុក្ខរបស់ព្រះយេស៊ូវនៅក្នុងសួនច្បារគែតសេម៉ានី ពួកគេបានរៀនថា ព្រះយេស៊ូវគ្រីស្ទ បានដាក់ព្រះឆន្ទៈរបស់ទ្រង់ចុះចូលតាមព្រះទ័យរបស់ព្រះបិតា ដើម្បីសម្រេចនូវដង្វាយធួន ហើយថាយើងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលយើងជ្រើសរើសដើម្បីដាក់ឆន្ទៈរបស់យើងចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ។ ចេញមកពីការណែនាំរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកសាវកនៅក្នុងសួនគែតសេម៉ានី សិស្សបានរៀនថាប្រសិនបើយើងមើល និងអធិស្ឋានជានិច្ច ដែលយើងនឹងមានកម្លាំង ដើម្បីទប់ទល់នឹងការល្បួង ។

ថ្ងៃទី ២ (ម៉ាថាយ ២៧–២៨)

ចេញមកពីដំណើររឿងការឆ្កាងរបស់ព្រះអង្គសង្គ្រោះ នោះសិស្សបានរៀនថា ជាចំណែកនៃដង្វាយធួន នោះព្រះយេស៊ូវគ្រីស្ទបានញាណដឹង អំពីការយោងចេញនៃព្រះវិញ្ញាណរបស់ព្រះវរបិតាសួគ៌ ។ ពួកគេក៏បានរៀនផងដែរថា ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ដើម្បីបំពេញតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ដូចដែលទ្រង់បានសន្យានៅក្នុងម៉ាថាយ ២៦ ។ ហើយនៅពេលសិស្សសិក្សាដំណើររឿងអំពីរ៉ាំងនន់របស់ព្រះវិហារបរិសុទ្ធរំហែកជាពីរ នៅពេលព្រះអង្គសង្គ្រោះសុគត នោះពួកគេបានរៀនថា វាជាន័មិត្តសញ្ញាអំពីសេចក្តីពិតថា ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះយើងទាំងអស់គ្នាអាចចូលទៅក្នុងវត្តមានរបស់ព្រះ ប្រសិនបើយើងប្រែចិត្ត ហើយរក្សាសេចក្តីសញ្ញាទាំងឡាយរបស់យើង ។

ថ្ងៃទី ៣ (ម៉ាកុស ១)

ចេញមកពីដំណើររឿងរបស់ព្រះយេស៊ូវបណ្តេញវិញ្ញាណអសោច នោះសិស្សបានរៀនថា ព្រះអង្គសង្គ្រោះមានព្រះចេស្តាលើអារក្ស និងអ្នកដើរតាមរបស់វា ។ សិស្សក៏បានរៀនផងដែរថា កិច្ចដ៏ជាព្រះយេស៊ូវមានក្តីមេត្តាករុណា និងបានព្យាបាលមនុស្សឃ្លង់ នៅពេលយើងអនុវត្តសេចក្តីជំនឿ ហើយមករកព្រះអង្គសង្គ្រោះ នោះទ្រង់នឹងមានក្តីមេត្តាចំពោះយើង ហើយសម្អាតយើងពីអំពើបាប ។

ថ្ងៃទី ៤ (ម៉ាកុស ២–៣)

នៅពេលសិស្សសិក្សាអំពីការអភ័យទោស និងការព្យាបាលអំពីបុរសខ្វិន នោះពួកគេបានរៀនថា ព្រះយេស៊ូវគ្រីស្ទ មានព្រះចេស្តាដើម្បីព្យាបាលយើងខាងវិញ្ញាណ និងខាងរូបកាយ ។ នៅពេលពួកគេបានសិក្សាអំពីព្រះយេស៊ូវបានសោយអាហារជាមួយនឹងអ្នកយកពន្ធ និងមនុស្សមានបាប នោះពួកគេបានរៀនថា ព្រះអង្គសង្គ្រោះមានក្តីប្រាថ្នាចង់ជួយយើងប្រែចិត្តពីអំពើបាបរបស់យើង ហើយត្រូវបានជាសះស្បើយ ។ នៅពេលពួកគេអានអំពីគ្រាដែលពួកផារិស៊ី បានដាក់ទោសដល់ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ចំពោះការមិនគោរពថ្ងៃឈប់សម្រាក នោះសិស្សបានរៀនថា យើងអាចរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធតាមរយៈការសរសើរតម្កើងដល់ព្រះ និងការធ្វើកិច្ចការល្អ ។

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានរស់ឡើងវិញ ហើយបានបង្ហាញព្រះកាយដល់បុគ្គលជាច្រើន រួមទាំងពួកសាវករបស់ទ្រង់ ។ ទ្រង់បានបញ្ជាដល់ពួកសាវករបស់ទ្រង់ឲ្យនាំយកដំណឹងល្អរបស់ទ្រង់ដល់គ្រប់ជាតិសាសន៍ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាថាយ ២៨

ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ហើយបានបង្ហាញព្រះកាយដល់មនុស្សជាច្រើន

ចូរសុំឲ្យសិស្សគិតថាតើពួកគេ ឬនរណាម្នាក់ដែលពួកគេស្គាល់ មាននរណាម្នាក់ដែលជិតជិតនឹងពួកគេបានស្លាប់ ។ បន្ទាប់មក សូមសួរសិស្ស ៖

- ហេតុអ្វីសេចក្តីស្លាប់របស់មនុស្សជាទីស្រឡាញ់ម្នាក់ ជាការលំបាកសម្រាប់យើង ?

ចូរសុំឲ្យសិស្សស្វែងរកសេចក្តីពិត នៅពេលពួកគេសិក្សាម៉ាថាយ ២៨ដែលនឹងជួយពួកគេរកបានភាពលួងលោមចិត្ត នៅពេលមនុស្សជាទីស្រឡាញ់ម្នាក់បានស្លាប់ ។

ចូរពន្យល់ថា នៅព្រឹកថ្ងៃដំបូងនៃសប្តាហ៍—ថ្ងៃអាទិត្យ—ម៉ារា ម៉ាក់ដាឡា និងស្ត្រីម្នាក់ទៀតដែលមានឈ្មោះថា ម៉ារា បានទៅផ្នូរ ជាកន្លែងដែលដាក់ព្រះសពរបស់ព្រះយេស៊ូវ ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ាថាយ ២៨:១–៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ហើយរកមើលអ្វីដែលស្ត្រីបានរកឃើញ នៅពេលពួកគេបានទៅដល់ផ្នូរនោះ ។

- តើស្ត្រីទាំងនោះបានរកឃើញអ្វីខ្លះ ពេលពួកគេបានទៅដល់ផ្នូរ ? (សូមពន្យល់ថា ការបកប្រែរបស់យ៉ូសែប ស៊្មីធ សម្រាប់ខគម្ពីរទាំងនេះ បញ្ជាក់ថា ពួកស្ត្រីបានឃើញទេវតា*ពីរអង្គ* ពុំមែនមួយអង្គទេ [សូមមើល យ៉ូហាន ២០:១២]) ។
- តើអ្នកគិតថាអ្នកនឹងមានប្រតិកម្មយ៉ាងណា ប្រសិនបើអ្នកបានឃើញទេវតាពីរអង្គនោះ ?
- យោងតាមខទី ៤តើពួកអ្នកយាមមានប្រតិកម្មយ៉ាងដូចម្តេច ?
- យោងតាម ខទី ៥–៦តើពួកទេវតាបានប្រាប់អ្វីខ្លះដល់ស្ត្រីទាំងនោះ ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីពាក្យទាំងនេះ ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ព្រះយេស៊ូវបានរស់ឡើងវិញពីការសុគត**)។

ដើម្បីជួយសិស្សយល់គោលលទ្ធិនៃការរស់ឡើងវិញ សូមបំបែកពួកគេជាក្រុមៗមានគ្នាពីរនាក់ ឬបីនាក់ ហើយអញ្ជើញពួកគេឲ្យបំពេញឯកសារចែកចាយដែលដាក់អមបន្ថែម នៅក្នុងក្រុមរបស់ពួកគេ ។

« ទ្រង់រស់ឡើងវិញ » (ម៉ាថាយ ២៨:៦)

សូមសិក្សាចំណងជើង« ការរស់ឡើងវិញ » នៅក្នុងវិនានុក្រមគម្ពីរបឺប ។ បន្ទាប់មកពីការសិក្សាអំពីសំណួរដូចខាងក្រោម ហើយកត់ត្រាចម្លើយរបស់អ្នកនៅក្នុងចន្លោះដែលបានផ្តល់ឲ្យ ។

តើមានភាពខុសគ្នាអ្វីខ្លះរវាងការត្រូវបានប្រោសឲ្យរស់ពីសេចក្តីស្លាប់ និងការត្រូវបានរស់ឡើងវិញ ?	
តើនឹងមានអ្វីកើតឡើងចំពោះមនុស្សលោកគ្រប់រូប ដែលជាលទ្ធផលមួយមកពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ?	
តើការយល់ដឹងអំពីគោលលទ្ធិនៃការរស់ឡើងវិញអាចផ្តល់នូវការលួងលោមចិត្តដល់អ្នកទាំងឡាយដែលបានបាត់បង់មនុស្សជាទីស្រឡាញ់យ៉ាងដូចម្តេច ?	

ចូរសុំឲ្យសិស្សពីរបីនាក់រាយការណ៍ទៅសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានរៀន តាមរយៈការបំពេញឯកសារចែកចាយ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហិងគ្លី ៖



« អត្ថន័យហេតុនៅព្រឹកនៃការរស់ឡើងវិញនោះ ជាថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរដំបូង គឺជាអត្ថន័យហេតុមួយសម្រាប់មនុស្សលោកគ្រប់រូប ។ វាគឺជាអត្ថន័យហេតុនៃព្រះចេស្តារបស់ព្រះ ជាព្រះរាជបុត្រាសំណប់ បានប្រទានជីវិតរបស់ទ្រង់ដើម្បីធ្វើឲ្យធួនចំពោះអំពើបាបនៃមនុស្សទាំងអស់ ជាពលិកម្មនៃក្តីស្រឡាញ់សម្រាប់បុត្រា និងបុត្រីគ្រប់រូបរបស់ព្រះ ។ នៅក្នុងការធ្វើដូច្នោះ ទ្រង់បានបំបាក់ចំណងនៃសេចក្តីស្លាប់ ។ . . .

« ហើយក៏ដូចជាទ្រង់បានយកព្រះកាយរបស់ទ្រង់មកវិញ ហើយយាងចេញពីផ្នូរ នោះយើងទាំងអស់គ្នានឹងរីករាយចំពោះការរួបរួមនៃរូបកាយ និងវិញ្ញាណដើម្បីក្លាយជាមនុស្សរស់នៅក្នុងថ្ងៃនៃការរស់ឡើងវិញផ្ទាល់ខ្លួនរបស់យើងផងដែរ ។

« ហេតុដូច្នោះហើយ យើងរីករាយ ដូចជាមនុស្សជាច្រើនផងដែរ ហើយក៏ដូចជាមនុស្សគ្រប់រូបផងដែរ នៅពេលយើងចងចាំអំពីព្រឹត្តិការណ៍ដ៏រុងរឿងបំផុត ដ៏លួងលោមចិត្តបំផុត ដ៏អះអាងបំផុតនៃគ្រប់ព្រឹត្តការណ៍ទាំងអស់ក្នុងប្រវត្តិសាស្ត្រមនុស្ស—គឺជាជោគជ័យឈ្នះលើសេចក្តីស្លាប់ » (« *The Victory over Death* »*Ensign,* ខែ មេសា ឆ្នាំ ១៩៩៧ ទំព័រ ៤) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៨:៧–១០ ឲ្យឮៗ ។ ចូរឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលស្ត្រីៗនៅឯផ្នូររបស់ព្រះយេស៊ូវត្រូវបានប្រាប់ឲ្យធ្វើ ។

- យោងតាម ខទី ៧តើពួកទេវតាបញ្ជាឲ្យស្ត្រីទាំងនោះធ្វើអ្វីខ្លះ ?
- ហេតុអ្វីក៏អ្នកគិតថា ស្ត្រីទាំងនោះបានចាកចេញ « ទាំងភ័យ ហើយមានសេចក្តីអំណរជាខ្លាំងផង » ដូច្នេះ ? (ម៉ាថាយ ២៨:៨) ។
- តើមានអ្វីកើតឡើងចំពោះស្ត្រីទាំងនោះ នៅពេលពួកគេបានទៅប្រាប់ដល់ពួកសិស្សអំពីបទពិសោធន៍របស់ពួកគេ ?

ចូរសង្កេតម៉ាថាយ ២៨:១១–១៥ ដោយពន្យល់ថា ខណៈដែលស្ត្រីទាំងនោះប្រញាប់ទៅប្រាប់ដំណឹងដល់ពួកសិស្សអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ នោះពួកមេសង្ឃបានស្តាប់ឮអំពីអ្វីដែលបានកើតឡើងមកពីពួកទាហានដែលបានចាំយាមផ្នូរ ។ ពួកអ្នកដឹកនាំសាសន៍យូដាបានភ័យខ្លាចថាមនុស្សអាចដឹងអំពីសេចក្តីពិត នោះពួកគេបានឲ្យប្រាក់ដល់អ្នកយាមឲ្យនិយាយរឿងកុហកថា ពួកសិស្សរបស់ព្រះអង្គសង្គ្រោះបានយកព្រះសពរបស់ទ្រង់ចេញពីផ្នូរខណៈដែលអ្នកយាមកំពុងដេកលក់ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាថាយ ២៨:១៦–១៨ ឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាមហើយរកមើលនូវពរជ័យដែលកើតមានដល់សាវកដប់មួយនាក់ ពេលពួកគេបានគោរពតាមសារដែលស្ត្រីទាំងឡាយបានប្រាប់ពួកគេ ហើយបានចេញទៅស្រុកកាលីឡេ ។

- តើមានពរជ័យអ្វីខ្លះកើតមានដល់ពួកសាវកដប់មួយនាក់ ដោយសារតែពួកគេបានគោរពតាមសារឲ្យចេញទៅស្រុកកាលីឡេនោះ ? (ពួកគេបានមើលឃើញព្រះអម្ចាស់ដែលរស់ឡើងវិញ) ។

សូមអញ្ជើញសិស្សឲ្យក្រោកឈរ ហើយអានម៉ាថាយ ២៨:១៩–២០ ឮៗជាមួយគ្នា ។ សូមរំឭកពួកគេថា នេះគឺជាចំណុះចំណានបទគម្ពីរមួយ ។

ចូរសុំឲ្យសិស្សក្នុងថ្នាក់រំឭកខទី ១៩–២០ ស្វែងរកនូវអ្វីដែលព្រះអង្គសង្គ្រោះបានបញ្ជាដល់ពួកសាវករបស់ទ្រង់ឲ្យធ្វើ បន្ទាប់ពីពួកគេបានឃើញទ្រង់ ។

- តើពួកសិស្សត្រូវបានបញ្ជាឲ្យធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេបានមើលឃើញព្រះអង្គសង្គ្រោះ?
- តើយើងអាចរៀនអ្វីខ្លះមកពីបទពិសោធន៍របស់ពួកគេអំពីទំនួលខុសត្រូវដែលយើងមាននៅពេលយើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលយើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ នោះយើងមានទំនួលខុសត្រូវដើម្បីថ្លែងទីបន្ទាល់អំពីទ្រង់ចំពោះអ្នកដទៃ)**។

សូមរំឭកសិស្សថា ជាផ្នែកនៃមេរៀនសិក្សានៅផ្ទះរបស់ពួកគេនៅក្នុងម៉ាថាយ ២៧–២៨នោះពួកគេបានសរសេររបៀបដែលពួកគេអាចថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទដល់អ្នកដទៃ (កិច្ចការទី ៣ នៅក្នុងមេរៀនទី ៧ ៖ មេរៀនថ្ងៃទី ២) ។ សូមអញ្ជើញសិស្សឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរ ហើយពន្យល់ និងផ្តល់ឧទាហរណ៍អំពីគំនិតរបស់ពួកគេ ។ អ្នកអាចកត់ត្រាគំនិតទាំងឡាយរបស់ពួកគេនៅលើក្តារខៀន ។

- ស្របតាមម៉ាថាយ ២៨:២០តើមានការសន្យាអ្វីខ្លះដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពួកសិស្សរបស់ទ្រង់ ?
- តើតាមរបៀបណាខ្លះដែលព្រះអម្ចាស់បាន « គង់នៅនឹងអ្នក » ឬបានជួយអ្នកនៅក្នុងកិច្ចខិតខំដើម្បីចែកចាយដំណឹងល្អ ?

សូមពិចារណាធ្វើការអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងសិស្សនៅក្នុងថ្នាក់ ជាក្រុមតូចៗ ឬជាដៃគូ ។ អ្នកក៏គួរតែចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងសិស្សក្នុងថ្នាក់ផងដែរ ។ សូមរំឭកសិស្សថា ពួកគេក៏បានសរសេរគោលដៅមួយនៅក្នុងកិច្ចការសរសេរកំណត់ហេតុការសិក្សាព្រះគម្ពីរ ស្តីអំពីរបៀបដែលពួកគេនឹងថ្លែងទីបន្ទាល់ចំពោះអ្នកដទៃអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគោលដៅរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

មេរៀនបន្ទាប់ (ម៉ាកុស ៤–៩)

សូមពន្យល់ដល់សិស្សថា នៅក្នុងមេរៀនបន្ទាប់ នោះពួកគេនឹងរៀនបន្ថែមអំពីអត្ថន័យហេតុដែលព្រះយេស៊ូវគ្រីស្ទបានធ្វើ ដូចជាការយាងដើរនៅលើទឹក ការបណ្តេញអារក្សចេញពីបុរសម្នាក់ និងការប្រោសក្មេងស្រីម្នាក់ពីសេចក្តីស្លាប់ ។ ចូរសួរដល់សិស្សប្រសិនបើពួកគេធ្លាប់ស្ថិតនៅក្នុងព្យុះដ៏ខ្លាំងមួយ ហើយតើពួកគេនឹងមានអារម្មណ៍យ៉ាងណាក្នុងពេលនោះ ។ សូមអញ្ជើញពួកគេឲ្យពិចារណាថាតើពួកគេធ្លាប់មានអារម្មណ៍ដូចជាពួកគេស្ថិតនៅក្នុងព្យុះដ៏ខ្លាំង ឬឧបសគ្គធ្ងន់ធ្ងរក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគេឬទេ ។ នៅពេលពួកគេសិក្សាម៉ាកុស ៤–៩អំឡុងសប្តាហ៍បន្ទាប់ សូមអញ្ជើញពួកគេឲ្យរកមើលនូវរបៀបដើម្បីរកបានសេចក្តីសុខសាន្តនៅក្នុងគ្រាលំបាកទាំងឡាយ ។

មេរៀន ៣៦

ម៉ាកុស ៤–៥

សេចក្តីផ្តើម

នៅឆ្នេរសមុទ្រកាលីឡេ ព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ដោយប្រើរឿងប្រៀបធៀប ។ ខណៈពេលនៅលើសមុទ្រ ព្រះអង្គសង្គ្រោះបានអម្ចាប់ព្យុះមួយ ។ ព្រះយេស៊ូវបានសម្តែងនូវភាពឧត្តុង្គឧត្តមរបស់ទ្រង់ឈ្នះលើពួកអារក្សដោយការបណ្តេញវាចេញពីបុរសម្នាក់ ។ ខណៈពេលកំពុងបម្រើនៅស្រុកកាពើណិម ទ្រង់បានព្យាបាលស្ត្រីម្នាក់ដែលធ្លាក់ឈាមហើយបានប្រោសកូនស្រីរបស់យ៉ៃរុសពីសេចក្តីស្លាប់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៤

ព្រះយេស៊ូវបានប្រើរឿងប្រៀបធៀបបង្រៀនអំពីនគរព្រះ បន្ទាប់មកអម្ចាប់ខ្យល់ព្យុះ

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីព្យុះដ៏អាក្រក់បំផុត ដែលពួកគេស្ថិតនៅក្នុងនោះ ។ ចូរសុំឲ្យសិស្សពីរបីនាក់ពិពណ៌នាសង្ខេបអំពីបទពិសោធន៍របស់ពួកគេ ។

- **តើឧបសគ្គទាំងឡាយនៃជីវិតដូចជាព្យុះមួយយ៉ាងដូចម្តេច ?**

ចូរសរសេរពាក្យដូចខាងក្រោមនៅលើក្តារខៀន (សូមទុកចន្លោះនៅក្រោមពាក្យនីមួយៗ) ៖ *ខាងរូបកាយ ខាងវិញ្ញាណ ខាងសតិអារម្មណ៍ ខាងសង្គម* ។ ចូរសួរសំណួរដូចខាងក្រោម ដែលវាអនុវត្តចំពោះពាក្យនីមួយៗនៅលើក្តារខៀន ៖

- **តើឧទាហរណ៍មួយចំនួនអំពីព្យុះខាងរូបកាយ (ឬខាងវិញ្ញាណ ខាងសតិអារម្មណ៍ ឬខាងសង្គម) អ្វីខ្លះ ដែលយុវវ័យជួបប្រទះ ? (សូមសរសេរចម្លើយរបស់សិស្សនៅក្រោមពាក្យដែលផ្គូផ្គងគ្នានៅលើក្តារខៀន) ។**

សូមអញ្ជើញសិស្សនៅពេលពួកគេសិក្សាម៉ាកុស ៤–៥ឲ្យរកមើលគោលការណ៍ទាំងឡាយដែលអាចជួយពួកគេ នៅពេលពួកគេជួបនឹងព្យុះនៃជីវិត ។

សូមសង្ខេបម៉ាកុស ៤:១–៣៤ ដោយការពន្យល់ថា ខណៈដែលស្ថិតនៅលើឆ្នេរសមុទ្រកាលីឡេ នោះព្រះអង្គសង្គ្រោះបានបង្រៀនន្ូវរឿងប្រៀបធៀបជាច្រើនដល់ហ្វូងមនុស្ស ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗមកពី ម៉ាកុស ៤:៣៥–៣៨ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឧបសគ្គដែលពួកសិស្សបានជួបប្រទះ នៅពេលពួកគេឆ្លងកាត់សមុទ្រកាលីឡេ ។

- **តើមានបញ្ហាអ្វីខ្លះបានកើតឡើង នៅពេលព្រះអង្គសង្គ្រោះ និងពួកសិស្សរបស់ទ្រង់ឆ្លងកាត់សមុទ្រកាលីឡេ ?**

ចូរពន្យល់ថា សមុទ្រកាលីឡេគឺមានជម្រៅ ២១៣ ម៉ែត្រ ទាបជាងកម្រិតទឹកសមុទ្រ ហើយមានភ្នំនៅព័ទ្ធជុំវិញនៃជ្រុងទាំងបី ។ ជួនកាលមានខ្យល់ត្រជាក់ ស្ងួត សម្រុកចុះមកពីលើភ្នំ ហើយមកប៉ះនឹងខ្យល់ក្តៅ សើម នៅលើសមុទ្រកាលីឡេ បង្កើតបានជាព្យុះមួយយ៉ាងខ្លាំងមួយរំពេច—ពេលខ្លះនៅក្នុងរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ—នឹងមានរលកធំៗនៅលើផ្ទៃទឹកដ៏តូចនេះ ។



សមុទ្រកាលីឡេនិងភ្នំអាបែល

- **តើព្យុះមានឥទ្ធិពលយ៉ាងណាទៅលើទូក ?**
- **ប្រសិនបើអ្នកស្ថិតនៅលើទូកមួយក្នុងស្ថានភាពទាំងនេះ តើអ្នកមានគំនិត និង អារម្មណ៍យ៉ាងណាដែរ ?**
- **តើពួកសិស្សស្វែងរកជំនួយមកពីនរណានៅគ្រាដ៏ភ័យរន្ធត់នេះ ? តើពួកគេបានសួរព្រះអង្គសង្គ្រោះអ្វីខ្លះ ?**
- **តើយើងត្រូវបានល្បួងឲ្យឆ្លើយដូចជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបានឆ្លើយ អំឡុងពេលមានព្យុះនៃជីវិតរបស់យើងតាមរបៀបណា ?**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៤:៣៩ឲ្យ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះអង្គសង្គ្រោះបានឆ្លើយតបទៅនឹងការអង្វរបស់ពួកសិស្សឲ្យទ្រង់ជួយ ។ ចូរសុំពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកក៏អាចនឹងចង់ឲ្យយោបល់ដល់សិស្សគួសចំណាំឃ្លា« ចូរស្ងៀមទៅ » និង « ហើយឈប់ចុះ » (ខទី ៣៩) ផងដែរ ។

- **ប្រសិនបើយើងស្វែងរកជំនួយរបស់ព្រះអម្ចាស់នៅគ្រាមានបញ្ហា ឬភ័យខ្លាច តើទ្រង់អាចធ្វើអ្វីខ្លះសម្រាប់យើង ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងស្វែងរកជំនួយរបស់ព្រះអម្ចាស់នៅគ្រាមានបញ្ហា ឬភ័យខ្លាច ទ្រង់អាចនាំសេចក្តីសុខសាន្តមកដល់យើង**)។**
- **តើយើងអាចស្វែងរកជំនួយរបស់ព្រះអម្ចាស់ក្នុងគ្រាមានបញ្ហា និង ភ័យខ្លាចដោយរបៀបណា ? (យើងអាចអធិស្ឋានទៅព្រះវរបិតាសួគ៌ក្នុងព្រះនាមនៃព្រះគ្រីស្ទ ។ ការអធិស្ឋានរបស់យើងអាចនឹងមិនត្រូវបានឆ្លើយតបតាមរបៀបដែលយើងរំពឹងទុកនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ យើងនឹងត្រូវបានប្រទានពរនូវសេចក្តីសុខសាន្ត នៅពេលយើងស្វែងរកជំនួយរបស់ព្រះអម្ចាស់) ។**

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៤:៤០–៤១ ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលពួកសិស្សបានសួរគ្នាអំពីព្រះយេស៊ូវ ។

- ប្រសិនបើអ្នកនៅជាមួយនឹងពួកសិស្ស តើអ្នកអាចឆ្លើយនឹងសំណួររបស់ពួកគេនៅក្នុងខទី ៤១ដោយរបៀបណា ?
- តើការយល់ដឹងថា « តើលោកនេះជាអ្វី » (ខទី ៤១) ព្រះយេស៊ូវអាចជួយពង្រឹងដល់សេចក្តីជំនឿរបស់យើង ហើយបំផុសយើងឲ្យស្វែងរកជំនួយរបស់ទ្រង់ក្នុងគ្រាដែលមានបញ្ហា ឬការភ័យខ្លាចដោយរបៀបណា ?

បើអាចធ្វើទៅបាន សូមអញ្ជើញសិស្សឲ្យអានទំនុកនៃទំនុកតម្កើង « លោកគ្រូ ខ្យល់ព្យុះកំពុងបោកបក់ » (*ទំនុកតម្កើង* លេខ ៥៤) ។ សូមគូសបញ្ជាក់ថា ព្រះយេស៊ូវមានព្រះចេស្តាដើម្បីរម្ងាប់ព្យុះ ពុំគ្រាន់តែព្យុះខាងរូបកាយទេ ប៉ុន្តែក៏អាចរម្ងាប់ព្យុះផ្ទាល់ខ្លួននៅក្នុងដួងចិត្តរបស់យើងផងដែរ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីគ្រាមួយដែលពួកគេបានស្វែងរកភាពសុខសាន្តរបស់ព្រះអម្ចាស់ អំឡុងពេលមានព្យុះនៃជីវិត ហើយទ្រង់បានសម្រាលភាពភ័យខ្លាចរបស់ពួកគេ ហើយលួងលោមចិត្តពួកគេ ។

សូមគិតពិចារណាធ្វើការអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេនូវអ្វីដែលពួកគេអាចធ្វើដើម្បីស្វែងរកជំនួយរបស់ព្រះអម្ចាស់ អំឡុងពេលគេមានឧបសគ្គ ។

ម៉ាកុស ៥:១–២០

ព្រះយេស៊ូវព្យាបាលបុរសម្នាក់ដោយការបណ្តេញអារក្សចេញពីគាត់

សូមសង្ខេបម៉ាកុស ៥:១–១៨ដោយការពន្យល់ថា ព្រះយេស៊ូវបានព្យាបាលបុរសម្នាក់ដែលមានពេញដោយវិញ្ញាណ « អសោច » ឬវិញ្ញាណអារក្ស ។ បន្ទាប់ពីវិញ្ញាណអសោចទាំងនោះបានត្រូវបណ្តេញចេញពីបុរសនោះ នោះពួកវាបានចូលទៅក្នុងហ្វូងជ្រូក បន្ទាប់មកវត់បោលយ៉ាងលឿនធ្លាក់ច្រាំងចូលសមុទ្រអស់ទៅ ។ បន្ទាប់មកបុរសនោះបានសូមចូលទៅក្នុងទូកដែលព្រះយេស៊ូវគង់នៅ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាកុស ៥: ១៩–២០ ឮៗ ។ ចូរអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានណែនាំបុរសនេះឲ្យធ្វើ ។

- តើព្រះអង្គសង្គ្រោះបានណែនាំបុរសនេះឲ្យធ្វើអ្វីខ្លះ ?
- តើបុរសនោះឆ្លើយតបយ៉ាងដូចម្តេច ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីរឿងនេះ អំពីអ្វីដែលយើងអាចធ្វើ នៅពេលយើងទទួលបទពិសោធន៍ព្រះចេស្តារបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **នៅពេលយើងមានបទពិសោធន៍ព្រះចេស្តារបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង នោះយើងអាចថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃអំពីពរជ័យ និងក្តីមេត្តាករុណារបស់ទ្រង់**) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចជួយអ្នកដទៃទៀត តាមរយៈការថ្លែងទីបន្ទាល់អំពីពរជ័យ និង ក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ ។

ការកំណត់ល្បឿន

សូមចៀសវាងកុំចំណាយពេលច្រើនពេកនៅផ្នែកទីមួយនៃមេរៀននេះ ហើយត្រូវប្រញាប់ប្រញាល់ដើម្បីបញ្ចប់មេរៀនដែលនៅសេសសល់ ។ នៅពេលអ្នករៀបចំមេរៀន សូមប៉ាន់ស្មានអំពីរយៈពេលដែលវគ្គនីមួយៗនៃមេរៀននឹងត្រូវចំណាយដោយប្រើវិធីសាស្ត្របង្រៀនដែលអ្នកបានជ្រើសរើស ។ ស្ទើរតែជានិច្চকាល ដោយសារតែអ្នកមានឯកសារត្រូវបង្រៀនច្រើនជាងពេលវេលាបង្រៀននោះ សូមកំណត់ថា តើផ្នែកណានៃបទគម្ពីរដែលត្រូវគូសបញ្ជាក់ និង ផ្នែកណាត្រូវសង្ខេប ។

ម៉ាកុស ៥:២១–៤៣

ព្រះយេស៊ូវបានព្យាបាលស្ត្រីម្នាក់ដែលធ្លាក់ឈាម ហើយបានប្រោសកូនស្រីរបស់យ៉ៃរ៉ុសពីសេចក្តីស្លាប់

ចូរសុំសិស្សម្នាក់ឲ្យអានឮៗនូវដំណើររឿងដូចខាងក្រោម ដែលបានប្រាប់ដោយអែលឌើរ ស្យាយអិន អិម ប៊ូរិន នៃពួកចិតសិបនាក់ ៖



« នៅថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ១៩៩០ កូនប្រុសទីបី និង ត្រូវជាកូនទីប្រាំមួយរបស់យើងបានកើតមក ។ យើងបានដាក់ឈ្មោះគាត់ថា ថៃសុន ។ . . .

« ពេល ថៃសុន មានអាយុប្រាំបីខែ គាត់បានលេបដីសមួយដុំដែលគាត់បានឃើញនៅលើកម្រាលព្រំ ។ ដីសនោះបានស្ទះនៅបំពង់ក ថៃសុន ហើយគាត់លែងដកដង្ហើម ។ បងប្រុសរបស់គាត់បាននាំ ថៃសុន ឡើងលើផ្ទះ ស្រែកដោយរំញ័រចិត្តថា ‹ អារអ្នន៎តតដកដង្ហើមទេ អារអ្នន៎តតដកដង្ហើមទេ ។ អារអ្នន៎តតដកដង្ហើមទេ › ។ យើងបានចាប់ផ្តើមធ្វើចលនា ហើយទូរស័ព្ទទៅលេខ ៩១១ ។

« វេជ្ជបណ្ឌិតជំនួយបានមកដល់ ហើយបានប្រញាប់នាំ ថៃសុន ទៅមន្ទីរពេទ្យ ។ នៅបន្ទប់រង់ចាំ យើងបានបន្តអធិស្ឋានយ៉ាងខ្លាំងនៅពេលយើងទូលអង្វរដល់ព្រះសុំឲ្យមានអព្ភូតហេតុ ។ បន្ទាប់ពីមួយសន្ទុះធំមក វេជ្ជបណ្ឌិតបានមកក្នុងបន្ទប់ ហើយនិយាយថា ‹ ខ្ញុំសូមចូលរួមសោកស្តាយ ។ គ្មានអ្វីផ្សេងទៀតដែលយើងអាចធ្វើបាននោះទេ ។ សូមចំណាយពេលតាមដែលអ្នកត្រូវការចុះ › ។ បន្ទាប់មកគាត់ក៏ចាកចេញទៅ » (« Because I Live, Ye Shall Live Also » *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១៦) ។

- ប្រសិនបើ ថៃសុន ជាប្អូនរបស់អ្នក តើអ្នកគិត ឬធ្វើអ្វីខ្លះនៅគ្រានោះ ?
- តើបទពិសោធន៍មួយដូច្នេះ សាកល្បងដល់សេចក្តីជំនឿរបស់មនុស្សម្នាក់យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៥:២១–២៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម រកមើលរបៀបដែលអ្នកគ្រប់គ្រងម្នាក់ឈ្មោះ យ៉ៃរ៉ុស បានជួបនឹងឧបសគ្គស្រដៀងគ្នានេះ ដែលអាចនឹងសាកល្បងសេចក្តីជំនឿរបស់លោក ។

- ហេតុអ្វីក៏យ៉ៃរ៉ុសស្វែងរកជំនួយរបស់ព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សម្នាក់អានម៉ាកុស ៥:២៥–២៦ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថានរណាផ្សេងទៀតដែលត្រូវការជំនួយរបស់ព្រះអង្គសង្គ្រោះ ។

សូមពន្យល់ថា ទោះបីជាដំណើររឿងទាំងឡាយក្នុងគម្ពីរសញ្ញាថ្មី ពុំកំណត់ពីលក្ខណៈនៃ « ការធ្លាក់ឈាម » របស់ស្ត្រីនោះក្តី (ខទី ២៥) ក៏យើងដឹងថាវាគឺជាបញ្ហាផ្ទាល់ខ្លួនរបស់ស្ត្រីនោះដែរ ។ បន្ថែមពីលើនោះ នៅក្រោមក្រិត្យវិន័យរបស់ម៉ូសេ មនុស្សម្នាក់ដែលមានជំងឺធ្លាក់ឈាម គឺត្រូវបានចាត់ទុកថាពុំស្អាតស្អំតាមតម្រា (សូមមើលលេវីវិន័យ ១៥:១៩–៣៣) ។ រឿងនេះទំនងជាមានន័យថា ស្ត្រីម្នាក់នេះត្រូវបានគេស្អប់ ហើយពុំមានគេរាប់រកអំឡុងពេល ១២ ឆ្នាំដែលគាត់ឈឺ ។ ភាពអស់សង្ឃឹមដែលគាត់បានមានអំពីស្ថានភាពរបស់គាត់ គឺជាភស្តុតាងនៅក្នុងភាពពិតដែលថា គាត់ «បានចំណាយទ្រព្យសម្បត្តិទាំងប៉ុន្មាន » (ម៉ាកុស ៥:២៦) ស្វែងរកការព្យាបាលពីគ្រូពេទ្យ ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ៥:២៧–៣៤ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ហើយរកមើលនូវអ្វីដែលស្ត្រីម្នាក់នេះបានធ្វើដើម្បីទទួលបានជំនួយរបស់ព្រះអង្គសង្គ្រោះ ។

- តើស្ត្រីរូបនេះ បានធ្វើអ្វី ដើម្បីបង្ហាញពីសេចក្តីជំនឿរបស់គាត់លើព្រះយេស៊ូវគ្រីស្ទ ? (អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « ចូលមកក្នុងហ្វូងមនុស្សពីក្រោយ » [ខទី ២៧] សំដៅថា គាត់បានពុះពារឆ្លងកាត់ហ្វូងមនុស្សដែលនៅជុំវិញព្រះអង្គសង្គ្រោះ) ។
- តើយើងអាចរៀនអ្វីខ្លះមកពីដំណើររឿងនេះ អំពីអ្វីដែលយើងត្រូវធ្វើ បើសិនជាយើងមានបំណងប្រាថ្នាដើម្បីបានជាសះស្បើយនោះ ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **ប្រសិនបើយើងបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទតាមរយៈការខិតខំរបស់យើងដើម្បីមករកទ្រង់ នោះទ្រង់នឹងធ្វើឲ្យយើងបានជាសះស្បើយ**) ។

សូមចង្អុលបង្ហាញថា ការបានជាសះស្បើយពីជំងឺនានា តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ គឺពុំអាស្រ័យតែលើការខិតខំរបស់យើងដើម្បីមករកទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែក៏តាមពេលវេលា និង ព្រះទ័យរបស់ព្រះផងដែរ ។

សូមអញ្ជើញសិស្សឲ្យអានម៉ាកុស ៥:៣៥ដោយស្ងាត់ស្ងៀម ហើយរកមើលនូវសារលិខិតដែលត្រូវបាននាំទៅដល់យ៉ៃរុស នៅពេលព្រះអង្គសង្គ្រោះបានឈប់ដើម្បីជួយដល់ស្ត្រីរូបនេះ ។

- តើយ៉ៃរុសបានទទួលដំណឹងអ្វីខ្លះ ?
- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពយ៉ៃរុស តើអ្នកអាចមានគំនិត និងអារម្មណ៍អ្វីខ្លះ នៅគ្រានោះ ?

ចូរសុំឲ្យសិស្សម្នាក់អានម៉ាកុស ៥:៣៦ឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលទៅយ៉ៃរុស ។

- តើព្រះអង្គសង្គ្រោះមានបន្ទូលអ្វីខ្លះ ដែលបានគាំទ្រដល់សេចក្តីជំនឿរបស់យ៉ៃរុស ?

ដើម្បីគូសបញ្ជាក់ពីអ្វីដែលយើងរៀនអំពីសេចក្តីជំនឿមកពីរឿងនេះ សូមសរសេរសេចក្តីពិតដូចខាងក្រោមនៅលើក្តារខៀន ៖ **ការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ តម្រូវឲ្យយើងបន្តជឿទៅលើទ្រង់ទោះជានៅគ្រាដែលគ្មានភាពពិតប្រាកដក្តី ។**

- តើយើងអាចអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់យើងតាមរបៀបណា ?

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ៥: ៣៧– ៤៣ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យធ្វើតាម រកមើលអ្វីដែលបានកើតឡើងចំពោះកូនស្រីរបស់យ៉ៃរុស ។

- តើព្រះអង្គសង្គ្រោះសម្តែងអព្ភូតហេតុអ្វីខ្លះ ?

អ្នកអាចនឹងចង់ថ្លែងទីបន្ទាល់អំពីព្រះចេស្តារបស់ព្រះអង្គសង្គ្រោះក្នុងការប្រទានពរ និង ព្យាបាលយើង ។ ចូរចង្អុលបង្ហាញថា ពេលខ្លះព្រះអង្គសង្គ្រោះរម្ងាប់ព្យុះនៅក្នុងជីវិតរបស់យើងតាមរយៈការដកយកនូវការលំបាក ឬការភ័យខ្លាចដែលយើងជួបប្រទះនោះចេញ ។ នៅគ្រាខ្លះទៀត ទ្រង់អាចនឹងមិនដកការសោកល្វងរបស់យើងចេញទេ ដូចបានបង្ហាញនៅក្នុងដំណើររឿងរបស់អែលឌើរ ហ្វូនិន អំពីការស្លាប់កូនប្រុសរបស់គាត់ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងប្រទានភាពសុខសាន្តដល់យើង ក្នុងគ្រាដែលយើងមានឧបសគ្គ ។

ដើម្បីជួយសិស្សយល់អំពីរបៀបដែលយើងអាចរក្សាសេចក្តីជំនឿ ទោះជាលទ្ធផលនៃព្យុះផ្ទាល់ខ្លួនរបស់យើងមានយ៉ាងណាក្តី សូមអានទីបន្ទាល់របស់អែលឌើរ ហ្វូនិន ដូចខាងក្រោម ។ សូមអញ្ជើញសិស្សឲ្យស្តាប់មើលរបៀបដែលគាត់អាចរក្សាសេចក្តីជំនឿរបស់គាត់ ទោះជាបន្ទាប់ពីការស្លាប់របស់កូនប្រុសគាត់ក្តី ។



« នៅពេលខ្ញុំមានអារម្មណ៍ដឹងថា កំហុស កំហឹង និង ការអាណិតខ្លួន កំពុងព្យាយាមគ្របដណ្តប់មកលើខ្ញុំ នោះខ្ញុំបានអធិស្ឋានសុំឲ្យដួងចិត្តរបស់ខ្ញុំឲ្យបានផ្លាស់ប្តូរ ។ តាមរយៈបទពិសោធន៍ដ៏ពិសិដ្ឋផ្ទាល់ខ្លួននេះ ព្រះអម្ចាស់បានប្រទានដួងចិត្តថ្មីដល់ខ្ញុំ ហើយទោះជាវានៅតែមានភាពឯកកោ និង ឈឺចាប់ក្តី ក៏ទស្សនៈរបស់ខ្ញុំទាំងមូលបានផ្លាស់ប្តូរ ។ ខ្ញុំបានឲ្យដឹងថា ខ្ញុំពុំត្រូវបានបាត់បង់ទេ ប៉ុន្តែមាននូវពរជ័យដ៏អស្ចារ្យមួយ កំពុងរង់ចាំខ្ញុំ បើខ្ញុំបង្ហាញថា ខ្លួនខ្ញុំស្មោះត្រង់ ។ . . .

« ខ្ញុំថ្លែងទីបន្ទាល់ដូចបានថ្លែងក្នុងសៀវភៅប្រកាសដំណឹងល្អរបស់យើងថា ‹ នៅពេលយើងពឹងផ្អែកទៅលើដង្វាយធួន នៃព្រះយេស៊ូវគ្រីស្ទ នោះទ្រង់អាចជួយយើងឲ្យស៊ូទ្រាំការសោកល្បួង ជម្ងឺ និង ការឈឺចាប់របស់យើង ។ យើងអាចពេញដោយក្តីអំណរ ភាពសុខសាន្ត និង ការលួងលោមចិត្ត ។ អ្វីៗទាំងអស់ដែលអយុត្តិធម៌នៅក្នុងជីវិតនេះ អាចត្រូវបានធ្វើឲ្យយុត្តិធម៌តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ › (*ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* (ឆ្នាំ ២០០៤) ទំព័រ ៥២) (« Because I Live » ទំព័រ ១៧) ។

- ដូចជាយ៉ៃរ៉ុស តើអ្នកឬនរណាម្នាក់ដែលអ្នកស្គាល់ បានរក្សាសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទអំឡុងពេលនៃភាពពុំពិតប្រាកដនៅពេលណា ? តើជាលទ្ធផលមានពរជ័យអ្វីខ្លះបានកើតឡើង ?

សូមគិតពិចារណាធ្វើការអញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលបានបង្រៀននៅក្នុងមេរៀននេះ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាកុស ៥:៣០ ។ « មានព្រះចេស្តាចេញពីទ្រង់ »

មានការបកប្រែមួយចំនួននៃម៉ាកុស ៥:៣០ថ្លែងថា « ព្រះចេស្តា » បានចេញពីព្រះយេស៊ូវគ្រីស្ទទៅ នៅពេលស្ត្រីនោះត្រូវបានព្យាបាលឲ្យជាសះស្បើយ ។ នៅក្នុងអត្ថបទដើមនៃគម្ពីរសញ្ញាថ្មីក្នុងភាសាក្រិក ពាក្យដែលឆ្លើយតបទៅនឹង *ព្រះចេស្តាគឺជាមពល*ដែលមានន័យថាជា « ព្រះចេស្តា » ឬ « កម្លាំង » ។

ម៉ាកុស ៦

សេចក្តីផ្តើម

ព្រះយេស៊ូវត្រូវបានគេបដិសេធនៅក្នុងស្រុកកំណើតរបស់ទ្រង់ ស្រុកណាសារ៉ែត ។ ទ្រង់បានបញ្ជូនពួកសាវកដប់ពីរនាក់ឲ្យផ្សាយដំណឹងល្អ ។ យ៉ូហាន បាទីស្ទ ត្រូវបានសម្លាប់ដោយបញ្ជារបស់ ហេរ៉ូឌ អាន់ទីប៉ាស ។ ព្រះយេស៊ូវបានប្រទានចំណីអាហារដល់ប្រជាជនច្រើនជាងប្រាំពាន់នាក់ដោយអព្ភូតហេតុ បានដើរលើទឹក បានអោប់ព្យុះ ហើយបានព្យាបាលអ្នកឈឺ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៦:១–២៩

ព្រះយេស៊ូវត្រូវបានគេបដិសេធនៅស្រុកណាសារ៉ែត ហើយទ្រង់បានបញ្ជូនពួកដប់ពីរនាក់ឲ្យចេញទៅផ្សព្វផ្សាយការស្លាប់របស់ យ៉ូហាន បាទីស្ទ ត្រូវបានតំណាលប្រាប់ ។

សូមចាប់ផ្តើមថ្នាក់រៀនដោយការអញ្ជើញសិស្សឲ្យគិតអំពីគ្រាចុងក្រោយបំផុត ដែលពួកគេបានមានអារម្មណ៍ថាត្រូវបានបង្ខំឲ្យធ្វើអ្វីមួយដែលពួកគេដឹងថាវាពុំត្រឹមត្រូវ ។

សូមសរសេរនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមនៅលើក្តារខៀន (សេចក្តីថ្លែងការណ៍នេះអាចរកបាននៅក្នុង« Making the Right Choices » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៣៧) ។

> ***« បុគ្គលម្នាក់ៗដែលធ្វើខុស ចង់ឲ្យអ្នកចូលរួមនឹងពួកគេ ដោយសារពួកគេនឹងមានអារម្មណ៍កាន់តែកក់ក្តៅ បើអ្វីដែលគេកំពុងតែធ្វើនោះ មានអ្នកដទៃធ្វើវាដែរ » (រីឆាត ជី ស្កុត) ។***

- **តើមានឧទាហរណ៍ណាខ្លះបង្ហាញអំពីរបៀបដែលអ្នកដទៃអាចនឹងព្យាយាមដាក់សម្ពាធមកលើអ្នកឲ្យធ្វើអ្វីមួយដែលអ្នកដឹងថាវាខុសឆ្គង ?**

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាម៉ាកុស ៦ដែលអាចជួយពួកគេចៀសវាងពីការចុះចាញ់នឹងសម្ពាធអវិជ្ជមានរបស់មិត្តភក្តិ ។

សូមសង្ខេបម៉ាកុស ៦:១–១៦ ដោយការពន្យល់ថា ព្រះយេស៊ូវបានផ្សាយនៅក្នុងស្រុកកំណើតរបស់ទ្រង់នៅស្រុកណាសារ៉ែត ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែការមិនជឿរបស់ប្រជាជន នោះទ្រង់មិនធ្វើអព្ភូតហេតុច្រើននៅក្នុងចំណោមពួកគេទេ ។ ខណៈដែលនៅទីនោះ ព្រះយេស៊ូវគ្រីស្ទបានបញ្ជូនពួកសាវកដប់ពីរនាក់ឲ្យចេញទៅពីរៗនាក់ ដើម្បីផ្សាយដំណឹងល្អ ។ ខណៈពេលកំពុងផ្សាយដំណឹងល្អ នោះពួកគេក៏បានបណ្តេញអារក្ស ហើយព្យាបាលអ្នកឈឺផងដែរ ។ នៅពេលហេរ៉ូឌស្តាប់ឮអំពីអព្ភូតហេតុជាច្រើនដែលព្រះយេស៊ូវបានធ្វើ នោះទ្រង់ភ័យខ្លាចថាយ៉ូហាន បាទីស្ទ នឹងបានរស់ឡើងវិញពីការស្លាប់ ហើយធ្វើអព្ភូតហេតុទាំងនេះ ។

សូមពន្យល់ថាម៉ាកុស ៦:១៧–២៩ ផ្តល់នូវដំណើររឿងមួយអំពីអ្វីដែលបានកើតឡើងចំពោះ យ៉ូហាន បាទីស្ទ ។ ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាកុស ៦:១៧–១៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលហេរ៉ូឌបានធ្វើចំពោះ យ៉ូហាន បាទីស្ទ ។

- **យោងតាមខគម្ពីរទាំងនេះ តើហេរ៉ូឌបានធ្វើអ្វីខ្លះដល់យ៉ូហាន ហើយហេតុអ្វី ?**

សូមពន្យល់ថា ហេរ៉ូឌដែលបានដំណាលប្រាប់នៅក្នុងខគម្ពីរទាំងនេះ គឺជា ហេរ៉ូឌ អាន់ទីប៉ាស ដែលគ្រប់គ្រងលើតំបន់កាលីឡេ ស្រុកពេរៀ បន្ទាប់ពីឪពុករបស់ទ្រង់សុគត គឺស្តេចហេរ៉ូឌ ។ ហេរ៉ូឌ អាន់ទីប៉ាស បានលែងលះមហេសីរបស់ទ្រង់ ហើយបានរៀបការនឹងហេរ៉ូឌាស ជាមហេសីរបស់អនុជទ្រង់ គឺកីលើព ។ ទង្វើនេះគឺជាការល្មើសនឹងច្បាប់របស់សាសន៍យូដាដាក់ស្តែង (សូមមើលលេវីវិន័យ ១៨:១៦) ហើយ យ៉ូហាន បាទីស្ទ បានដាក់បណ្តាសារ ។ ការជំទាស់របស់យ៉ូហានចំពោះការរៀបការនេះ បានធ្វើឲ្យហេរ៉ូឌាសខឹងជាខ្លាំង ដូច្នេះហេរ៉ូឌបានចាប់យ៉ូហានដាក់គុកដើម្បីឲ្យស្កប់ចិត្តនាង ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៦:១៩–២០ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលហេរ៉ូឌាសបានធ្វើចំពោះ យ៉ូហាន បាទីស្ទ ។

- **តើហេរ៉ូឌាសចង់ធ្វើអ្វីខ្លះចំពោះ យ៉ូហាន បាទីស្ទ ?**
- **ហេតុអ្វីក៏នាងមិនអាចសម្លាប់គាត់បាន ? (ដោយសារតែហេរ៉ូឌខ្លាចយ៉ូហាន ហើយបានដឹងថាគាត់ជាមនុស្សរបស់ព្រះ សូមមើលផងដែរការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាកុស ៦:២១ សម្រាប់ព័ត៌មានបន្ថែមអំពីការភ័យខ្លាចរបស់ ហេរ៉ូឌ ចំពោះយ៉ូហាន បាទីស្ទ ដោយរបៀបណា) ។**

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ៦:២១–២៩ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលនូវអ្វីដែលហេរ៉ូឌបានធ្វើចំពោះ យ៉ូហាន បាទីស្ទ ។

- **យោងតាមខទី ២៦តើហេរ៉ូឌមានអារម្មណ៍យ៉ាងណា អំពីការសំឡាប់យ៉ូហានបាទីស្ទ ?**

- ហេតុអ្វីក៏ហេរ៉ូឌត្រូវកាត់ក្បាលយ៉ូហាន បើគាត់ដឹងថាវាខុស ហើយពុំចង់ធ្វើវាផងនោះ ? (អ្នកអាចនឹងចង់ផ្តល់យោបល់ឲ្យសិស្សគូសចំណាំឃ្លា « ដោយព្រោះសម្បថរបស់ទ្រង់ ហើយនិងពួកភ្ញៀវ » ដែលបង្ហាញថា ហេរ៉ូឌមានកង្វល់អំពីមតិរបស់អ្នកទាំងឡាយដែលជាភ្ញៀវនៅជាមួយទ្រង់) ។
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការជ្រើសរើសរបស់ហេរ៉ូឌអំពីអ្វីដែលបានកើតឡើង នៅពេលយើងព្យាយាមដើម្បីផ្គាប់ចិត្តអ្នកដទៃ ជំនួសឲ្យធ្វើនូវអ្វីដែលត្រឹមត្រូវនោះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគូរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ការព្យាយាមដើម្បីផ្គាប់ចិត្តអ្នកដទៃជំនួសឲ្យការធ្វើនូវអ្វីដែលយើងដឹងថាត្រឹមត្រូវ អាចនាំទៅរកការជ្រើសរើសខុសឆ្គង ការសោកស្តាយ និង វិប្បដិសារី**)។

ដើម្បីជួយសិស្សយល់បន្ថែមទៀតអំពីសេចក្តីពិតនេះ សូមចាត់ពួកគេជាក្រុមដែលមានគ្នាពីរទៅបួននាក់ក្នុងមួយក្រុម ហើយសុំឲ្យពួកគេប្រាប់នូវឧទាហរណ៍អំពី ស្ថានភាពជាច្រើនដែលយុវវ័យត្រូវតែជ្រើសរើស រវាងការព្យាយាមដើម្បីផ្គាប់ចិត្តអ្នកដទៃ និងការធ្វើអ្វីដែលពួកគេដឹងថាត្រឹមត្រូវ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យក្រុមនិមួយៗរាយការណ៍ ។ នៅពេលពួកគេរាយការណ៍ ចូរសរសេរឧទាហរណ៍មួយចំនួនរបស់ពួកគេនៅលើក្តារខៀន ។

- តើអ្នកធ្លាប់ឃើញថាការចុះញ៊ីមចំពោះសម្ពាធទាំងឡាយដូចនៅក្នុងឧទាហរណ៍ទាំងនេះ នាំមកនូវការសោកស្តាយ និង វិប្បដិសារីតាមរបៀបណាខ្លះ ?
- តើអ្នកធ្លាប់បានឃើញនរណាម្នាក់ជ្រើសរើសធ្វើនូវអ្វី ដែលត្រឹមត្រូវជំនួសឲ្យការព្យាយាមផ្គាប់ចិត្តដល់អ្នកដទៃ នៅពេលណា ?
- តើអ្វីខ្លះអាចជួយយើងឲ្យជ្រើសរើសធ្វើអ្វី ដែលយើងដឹងថាត្រឹមត្រូវ ជំនួសឲ្យការព្យាយាមផ្គាប់ចិត្តអ្នកដទៃ ?

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីសប្តាហ៍ក្រោយ ហើយប្រាប់អំពីស្ថានភាពដែលអាចកើតមាន ដែលពួកគេអាចនឹងចាំបាច់ត្រូវជ្រើសរើសរវាងការផ្គាប់ចិត្តអ្នកដទៃ និង ការធ្វើអ្វីដែលត្រឹមត្រូវ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់ផែនការ អំពីរបៀបដែលពួកគេនឹងឆ្លើយតបចំពោះសម្ពាធនេះ ដែលពួកគេនឹងជួបប្រទះនោះ ។

ម៉ាកុស ៦:៣០–៤៤

ព្រះយេស៊ូវបានប្រទានចំណីអាហារដល់ប្រជាជនច្រើនជាងប្រាំពាន់នាក់ដោយអព្ភូតហេតុ

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីស្ថានភាពដូចខាងក្រោមនេះ ៖ អ្នកផ្សព្វផ្សាយសាសនាដែលទើបត្រូវបានហៅឲ្យបម្រើថ្មីម្នាក់មានអារម្មណ៍ភ័យយ៉ាងខ្លាំងដើម្បីចេញដំណើរទៅបេសកកម្មរបស់គាត់ ឬនាង ។ បុគ្គលនេះពុំសូវពូកែនិយាយបានល្អ ហើយមានការលំបាកក្នុងការរស់នៅចូលគេចុះក្នុងសង្គម ។

- តើអ្នកនឹងប្រាប់អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងរូបនេះអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សាម៉ាកុស ៦:៣០–៤៤ ដែលអាចជួយដល់អ្នកផ្សព្វផ្សាយសាសនាវ័យក្មេងរូបនេះ និង យើងទាំងអស់គ្នា ពេលយើងមានអារម្មណ៍ថាមិនល្អគ្រប់គ្រាន់ ដើម្បីធ្វើនូវអ្វីដែលព្រះអម្ចាស់បានសុំឲ្យយើងធ្វើនោះ ។

សូមសង្ខេបម៉ាកុស ៦:៣០–៣៣ ដោយពន្យល់ថា ពួកសាវកដប់ពីរនាក់ បានត្រឡប់មកពីផ្សាយដំណឹងល្អវិញ ហើយបានរាយការណ៍ដល់ព្រះយេស៊ូវអំពីអ្វីដែលពួកគេបានធ្វើ និង បានបង្រៀន ។ ព្រះយេស៊ូវ និង ពួកសាវកដប់ពីរនាក់ បានជិះទូកមួយធ្វើដំណើរទៅកន្លែងមួយ ដែលពួកគេអាចនៅតែឯង ហើយសម្រាក ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនមកពីស្រុកជិតខាងជាច្រើន បានទៅកន្លែងដែលព្រះយេស៊ូវនឹងចុះចត ហើយរង់ចាំពេលទ្រង់យាងមកដល់ ។

សូមអញ្ជើញសិស្សម្នាក់អានម៉ាកុស ៦:៣៤ ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះ បានឆ្លើយតបទៅកាន់ហ្វូងមនុស្ស ។

- តើអ្នកគិតថាឃ្លា « គេធៀបដូចជាចៀមដែលគ្មានអ្នកគង្វាល » មានន័យយ៉ាងណា ?

សូមពន្យល់ថា បន្ទាប់ពីការបង្រៀនដល់ហ្វូងមនុស្សពេញមួយថ្ងៃមក ព្រះអង្គសង្គ្រោះបានសម្តែងអព្ភូតហេតុដ៏អស្ចារ្យមួយ ។ ដើម្បីជួយសិស្សយល់អំពីអព្ភូតហេតុនេះ សូមចាត់ពួកគេជាដៃគូ ហើយឲ្យដៃគូនីមួយៗនូវច្បាប់ចម្លងនៃឯកសារចែកឲ្យដូចតទៅ ។ សូមអញ្ជើញឲ្យដៃគូនីមួយៗអានជាមួយគ្នាម៉ាកុស ៦:៣៥–៤៤ និងម៉ាថាយ ១៤:១៨ ហើយបន្ទាប់មកដាក់លេខព្រឹត្តការណ៍នៅលើឯកសារដែលចែកឲ្យនោះជាលំដាប់កាលប្បវត្តិ ។

ជំនួសឲ្យសិស្សអានដំណើររឿងនេះនៅក្នុងព្រះគម្ពីរ អ្នកអាចបង្ហាញវីដេអូ« The Feeding of the 5,000 »(២:៥២) ចេញមកពី*វីដេអូគម្ពីរបឹប អំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ*ហើយសុំឲ្យសិស្សដាក់លេខនៃព្រឹត្តការណ៍នៅលើឯកសារ ដែលចែកឲ្យនោះជាលំដាប់កាលប្បវត្តិ ដោយផ្អែកទៅលើអ្វីដែលពួកគេបានមើលឃើញនៅក្នុងវីដេអូ ។ វីដេអូនេះមាននៅក្នុង LDS.org ។

ការប្រទានអាហារដល់មនុស្ស ៥០០០ នាក់

___ ព្រះអង្គសង្គ្រោះចម្រើនឲ្យកាន់តែច្រើនឡើងនូវអ្វី ដែលពួកសិស្សបានយកមក បានបំពេញតម្រូវការ ហើយនៅសល់ហួសពីអ្វីដែលត្រូវការទៀតផង ។

___ ពួកសិស្សបាននិយាយថា ពួកគេមាននំប៉័ងប្រាំដុំ និង ត្រីពីរ ។

___ ពួកសិស្សបានស្នើសុំថាឲ្យមនុស្សចេញទៅរកទិញអាហារ ។

____ ព្រះអង្គសង្គ្រោះបានសួរថាតើពួកសិស្សអាចផ្គត់ផ្គង់អ្វីខ្លះ ។

____ ព្រះអង្គសង្គ្រោះបានប្រាប់ពួកសិស្សឲ្យផ្តល់អាហារដល់ប្រជាជន ។

____ ហ្វូងមនុស្សទាំងនោះ ពុំមានអ្វីបរិភោគទេ ។

____ ព្រះអង្គសង្គ្រោះបានសុំឲ្យពួកសិស្សផ្តល់ឲ្យទ្រង់នូវអ្វីដែលពួកគេមាន ។

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីបំពេញសកម្មភាពនេះ សូមរំឭកមើលចម្លើយទាំងអស់គ្នា ។ (លំដាប់ចម្លើយត្រឹមត្រូវ គឺ ៧, ៥, ២, ៤, ៣, ១, ៦) ។

- តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបានផ្តល់ចំណីអាហារឲ្យ ? (សូមពន្យល់ថា អត្ថបទជាភាសាក្រិកនៃម៉ាកុស ៦:៤៤បានប្រាប់យ៉ាងច្បាស់នូវឃ្លាថា « ប្រុស ៥ពាន់នាក់ » មានន័យថាជាបុរសពេញវ័យចំនួនប្រាំពាន់នាក់ ។ ដូច្នេះ ចំនួនដែលបានផ្តល់ចំណីអាហារទៅឲ្យ គឺទំនងជាមានច្រើនជាងនោះ ដោយគិតទាំងស្ត្រី និង កុមារ ដែលមានវត្តមាននៅទៅជាងដៃរនោះ [សូមមើលផងដែរម៉ាថាយ ១៤:២១]) ។

សូមចង្អុលបង្ហាញថា ពីមុនធ្វើអព្ភូតហេតុនេះ ដំបូងឡើយព្រះអង្គសង្គ្រោះបានសុំឲ្យពួកសិស្សរបស់ទ្រង់ផ្តល់នំប៉័ងប្រាំដុំ និងត្រីពីរ—ដែលជាអ្វីដែលពួកគេមាន—ដើម្បីថ្វាយទ្រង់ ។

- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពីអព្ភូតហេតុនេះ អំពីអ្វីដែលព្រះអង្គសង្គ្រោះអាចធ្វើ នៅពេលយើងថ្វាយដល់ទ្រង់នូវអ្វីៗទាំងអស់ដែលយើងមាន ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងថ្វាយព្រះអង្គសង្គ្រោះនូវអ្វីៗទាំងអស់ដែលយើងមាន នោះទ្រង់អាចតម្កើងការថ្វាយរបស់យើងដើម្បីសម្រេចនូវព្រះរាជបំណងរបស់ទ្រង់ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ការសរសេរនៅលើក្តារខៀន

តាមរយៈការប្រើក្តារខៀនឲ្យមានប្រសិទ្ធភាពអំឡុងពេលបង្រៀន អ្នកអាចរៀបចំសិស្សឲ្យរៀន និង អញ្ជើញឲ្យមានការចូលរួមប្រកបដោយអត្ថន័យ ជាពិសេសសម្រាប់អ្នកទាំងឡាយណា ដែលចង់រៀនដោយការមើលរូបភាព ។ នៅលើក្តារខៀន អ្នកអាចសង្ខេបចំណុចសំខាន់ឬគោលការណ៍ទាំងឡាយនៃមេរៀន គូសតារាងគោលលទ្ធិមួយ គូសផែនទីបង្កើតតារាង ដាក់តាំង ឬគូររូបនៃវត្ថុដែលមាននៅក្នុង២គម្ពីរ ឬធ្វើសកម្មភាពជាទៃទៀតជាច្រើន ដែលនឹងអភិវឌ្ឍន៍ការរៀនសូត្រ ។

ដើម្បីជួយសិស្សយល់អំពីគោលការណ៍នេះ សូមរំឭកពួកគេអំពីស្ថានភាពនៃអ្នកផ្សព្វផ្សាយសាសនាដែលបានហៅបម្រើថ្មីដែលភិតភ័យនោះ ដូចបានប្រាប់ពីខាងដើម ។

- ដោយពុំគិតអំពីភាពទន់ខ្សោយរបស់យុវជន ឬយុវនារីរូបនេះ តើព្រះអង្គសង្គ្រោះអាចនឹងសុំឲ្យអ្នកផ្សព្វផ្សាយរូបនេះយកអ្វីមកថ្វាយទ្រង់ ? (ព្រះអង្គសង្គ្រោះអញ្ជើញមនុស្សទាំងអស់ដែលព្យាយាម ដើម្បីសម្រេចនូវព្រះរាជបំណងរបស់ទ្រង់ ឲ្យថ្វាយទ្រង់នូវអស់ទាំងបំណងប្រាថ្នា លទ្ធភាព ទេពកោសល្យ ជំនាញ កម្លាំង អំណោយទាន និង កិច្ចខិតខំទាំងអស់របស់ពួកគេ [សូមមើលរោមណែ ១:២៦,នីហ្វៃទី ២ ២៥:២៩]) ។
- តើលទ្ធផលអ្វីខ្លះនឹងកើតមាន ប្រសិនបើអ្នកផ្សព្វផ្សាយសាសនានេះ ថ្វាយអ្វីៗទាំងអស់ដែលគាត់ ឬនាងមានទៅព្រះអង្គសង្គ្រោះ ?
- តើស្ថានភាពមួយចំនួនផ្សេងទៀតអ្វីខ្លះ ដែលសមាជិកវ័យក្មេងនៃសាសនាចក្រម្នាក់អាចជួប ដែលការដឹងអំពីគោលការណ៍នេះនឹងមានប្រយោជន៍ដល់គាត់ ?

សូមអញ្ជើញសិស្សឲ្យគិតពិចារណា ហើយសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបដែលព្រះអម្ចាស់បានតម្កើងការខិតខំរបស់ពួកគេ ដើម្បីឲ្យពួកគេអាចធ្វើនូវអ្វីដែលទ្រង់បានបញ្ជាឲ្យពួកគេធ្វើ ។ ចូរគិតពិចារណាធ្វើការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់នូវអ្វីដែលពួកគេបានសរសេរ ប្រសិនបើពួកគេមានអារម្មណ៍សុខស្រួលនឹងធ្វើដូច្នោះ ។

សូមចែកចាយទីបន្ទាល់របស់អ្នកថានៅពេលយើងថ្វាយព្រះអង្គសង្គ្រោះនូវអ្វីៗទាំងអស់ដែលយើងមាន នោះទ្រង់អាចតម្កើងការថ្វាយរបស់យើងដើម្បីសម្រេចនូវព្រះរាជបំណងរបស់ទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ ។

ម៉ាកុស ៦:៤៥–៥៦

ព្រះយេស៊ូវយាងដើរនៅលើទឹក ហើយបានព្យាបាលអ្នកឈឺ

សូមសង្ខេបម៉ាកុស ៦:៤៥–៥៦ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានប្រទានចំណីអាហារដល់មនុស្សប្រាំពាន់នាក់រួចហើយ ទ្រង់បានណែនាំពួកសិស្សរបស់ទ្រង់ឲ្យចូលទៅក្នុងទូក ហើយបានជិះទៅផ្នែកផ្សេងទៀតនៃសមុទ្រកាលីឡេ ។ បន្ទាប់មក ទ្រង់ឲ្យហ្វូងមនុស្សត្រឡប់ទៅវិញ ។ អំឡុងពេលយប់នោះមានព្យុះមួយកើតឡើង ហើយព្រះអង្គសង្គ្រោះបានទតមើលមកពីលើភ្នំមួយ ខណៈដែលពួកសិស្សរបស់ទ្រង់កំពុងពុះពារ ប៉ុន្តែពុំមានការរីកចម្រើននៅក្នុងការធ្វើដំណើររបស់ពួកគេទេ ។ បន្ទាប់មក ទ្រង់បានយាងដើរនៅលើទឹកទៅរកពួកគេ ព្យុះបានស្ងប់ទៅ ហើយពួកគេបានធ្វើដំណើរទៅដល់ផ្នែកម្ខាងទៀតនៃសមុទ្រកាលីឡេដោយសុវត្ថិភាព ។

- នៅក្នុងករណីនេះ តើព្រះចេស្តារបស់ព្រះអម្ចាស់អាចជួយឲ្យសិស្សសម្រេចនូវអ្វីដែលទ្រង់បានណែនាំដល់ពួកគេឲ្យធ្វើយ៉ាងដូចម្តេច ?

សូមគិតពិចារណាដើម្បីបញ្ចប់មេរៀននេះដោយការអញ្ជើញសិស្ស ដែលមានឆន្ទៈចង់ចែកចាយពីអារម្មណ៍ ឬទីបន្ទាល់របស់ពួកគេអំពីសេចក្តីពិត ដែលពួកគេបានពិភាក្សានៅថ្ងៃនេះ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាកុស ៦:៣៥–៤៤ ។ ការប្រទានចំណីអាហារដល់មនុស្សប្រាំពាន់នាក់

ប្រធាន ដេមស៍ អ៊ី ហ្វោស្ត នៃគណៈប្រធានទីមួយបានបង្រៀនថា កាលដែលព្រះចេស្តារបស់ព្រះអង្គសង្គ្រោះដើម្បីចម្រើនទំប៉ុង និងត្រីកាន់តែច្រើនឡើងបង្ហាញថា ទ្រង់នឹងតម្តើងការខិតខំដោយស្មោះត្រង់របស់យើង ដើម្បីបម្រើនៅក្នុងសាសនាចក្ររបស់ទ្រង់ ទោះជាយើងមានអារម្មណ៍ថា ការខិតខំរបស់យើងគឺស្មើនឹងនំប៉ុង និង ត្រីពីរបីក៏ដោយ ៖

« មានមនុស្សជាច្រើនរាប់មិនអស់ ដែលមានអំណោយទានស្មើនឹងនំប៉ុងប្រាំដុំ និង ត្រីតូចៗពីរ បានតម្តើងការហៅរបស់ពួកគេ [នៅក្នុងសាសនាចក្រ] ហើយបានបម្រើដោយគ្មានចង់ឲ្យគេចាប់អារម្មណ៍ ឬការទទួលស្គាល់ទេ ជាក់ស្តែងគាត់បានផ្តល់ចំណីអាហារដល់មនុស្សរាប់ពាន់នាក់ ។ . . . អ្នកទាំងនេះ គឺជាអ្នកដឹកនាំ និង គ្រូបង្រៀនរាប់រយពាន់នាក់នៅក្នុងគ្រប់អង្គការជំនួយ និង ក្លុំមបព្វជិតភាព គ្រូបង្រៀនតាមផ្ទះ គ្រូបង្រៀនសួរសុខទុក្ខតាមផ្ទះរបស់សមាគមសង្គ្រោះ ។ អ្នកទាំងនេះ គឺជាប៊ីស្សពជាំរាបសារជាច្រើនរូបនៅក្នុងសាសនាចក្រ ដែលមួយចំនួនពុំមានការបំពាក់បំប៉នជាផ្លូវការ ប៉ុន្តែបានតម្តើងការហៅដ៏អស្ចារ្យ តែងតែរៀនសូត្រដោយបំណងប្រាថ្នាដ៏រាបសារ ដើម្បីបម្រើព្រះអម្ចាស់ និង មនុស្សក្នុងវួដរបស់ពួកគេ ។ . . .

« មូលហេតុដ៏ចម្បងមួយដែលសាសនាចក្រនេះរីកចម្រើនចាប់តាំងពីការចាប់ផ្តើមដំបូងដោយរាបសារទៅដល់កាពីរឹងមាំដូចសព្វថ្ងៃនេះ គឺជាភាពស្មោះត្រង់ និង ការលះបង់របស់មនុស្សរាបសារ និងលះបង់រាប់លាននាក់ ដែលមានតែនំប៉ុងប្រាំដុំ និង ត្រីតូចៗពីរ ដើម្បីថ្វាយនៅក្នុងការបម្រើនៃលោកចៅហ្វាយប៉ុណ្ណោះ » (« *Five Loaves and Two Fishes* » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៤, ៥, ៦) ។

ម៉ាកុស ៧–៨

សេចក្តីផ្តើម

ព្រះយេស៊ូវស្តីបន្ទោសដល់ពួកផារិស៊ីចំពោះទំនៀមទម្លាប់ខុសឆ្គងរបស់ពួកគេ ។ បន្ទាប់មក ទ្រង់បានព្យាបាលកុមារម្នាក់ដែលមានអារក្សចូលដោយក្តីមេត្តាករុណា ក៏ដូចជាបុរសម្នាក់ដែលថ្លង់ ហើយពុំអាចនិយាយបានផងដែរ ។ ទ្រង់បានប្រទានចំណីអាហារដល់ប្រជាជនចំនួនបួនពាន់នៅជិតនឹងសមុទ្រកាលីឡេ ហើយបានធ្វើដំណើរទៅភូមិបេតសៃដា ជាកន្លែងដែលទ្រង់បានព្យាបាលបុរសខ្វាក់ជាយូរមកហើយម្នាក់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៧

ព្រះយេស៊ូវបានបន្ទោសដល់ពួកផារិស៊ី ព្យាបាលកុមារដែលមានអារក្សចូល ហើយព្យាបាលបុរសថ្លង់ម្នាក់

មុនពេលចាប់ផ្តើមថ្នាក់ សូមឲ្យសេចក្តីណែនាំដូចខាងក្រោមទៅដល់សិស្សបីនាក់ ។ សិស្សទី ១ ៖ « នៅពេលបានណែនាំឲ្យធ្វើដូច្នោះ ចូរដើរជុំវិញថ្នាក់រៀនដោយគ្មានអាវរងា ហើយធ្វើជារងាញ័រញាក់ ។ សិស្សទី ២ ៖ « នៅពេលបានណែនាំឲ្យធ្វើដូច្នោះ ចូរដើរទៅជុំវិញបន្ទប់ ហើយស្ងរនរណាម្នាក់ ប្រសិនបើបានឃើញសត្វចិញ្ចឹមរបស់គ្រួសារអ្នកដែលបានបាត់ដែរឬទេ » ។ សិស្សទី ៣ ៖ « នៅពេលបានណែនាំឲ្យធ្វើដូច្នោះ ចូរឈរបើកកាបូបស្ពាយរបស់អ្នក ដើម្បីឲ្យវត្ថុដែលដាក់ក្នុងកាបូបនោះជ្រុះពេលអ្នកដើរ » ។ (អ្នកអាចសម្របសម្រួលសកម្មភាពនេះដោយប្រើស្ថានភាពផ្សេងទៀត ដែលបង្ហាញសិស្សដែលខ្វះខាត ប៉ុន្តែសូមប្រយ័ត្នកុំប្រើពេលច្រើនពេក) ។

នៅពេលថ្នាក់រៀនចាប់ផ្តើម សូមណែនាំសិស្សឲ្យបំពេញការណែនាំទាំងនេះមួយម្តងៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលស្ថានភាពទាំងបីនេះមានទូទៅ ។

- តើស្ថានភាពទាំងនេះមានជាទូទៅដូចគ្នារបៀបណា ? (ស្ថានភាពនីមួយៗទាំងនេះ តំណាងឲ្យនរណាម្នាក់ដែលមានតម្រូវការ) ។
- តើយើងមានឱកាសដើម្បីជួយអ្នកដទៃដែលមានតម្រូវការញឹកញាប់ប៉ុណ្ណា ? តើមានឱកាសមួយចំនួនណាខ្លះ ដែលអ្នកបានធ្លាប់ឃើញថ្មីៗនេះ ?

សូមលើកទឹកចិត្តដល់សិស្សនៅពេលពួកគេសិក្សាម៉ាកុស ៧–៨ដើម្បីស្វែងរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបង្រៀនយើងឲ្យធ្វើ នៅពេលយើងកត់សម្គាល់ឃើញនរណាម្នាក់មានតម្រូវការ ។

សូមសង្ខេបម៉ាកុស ៧:១–៣០ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានស្តីបន្ទោសដល់ពួកផារិស៊ី ចំពោះការធ្វើតាមទំនៀមទម្លាប់មិនត្រឹមត្រូវ ។ ទ្រង់ក៏បានព្យាបាលកូនស្រីរបស់ស្ត្រីជនជាតិក្រិកម្នាក់ ដែលមានអារក្សចូលផងដែរ ។ សូមរំឭកសិស្សថានៅគ្រានេះ បេសកកម្មរបស់ព្រះអង្គសង្គ្រោះគឺចំពោះកូនចៅអ៊ីស្រាអែល ពុំមែនពួកសាសន៍ដទៃទេ ប៉ុន្តែទ្រង់បានជួយដល់ស្ត្រីសាសន៍ដទៃនេះដោយក្តីមេត្តាករុណា ព្រោះនាងបានទូលសូមឲ្យទ្រង់ជួយ ។

សូមអញ្ជើញសិស្សឲ្យរកមើលស្រុកទីរ៉ុស និង ស៊ីដូន និង សមុទ្រកាលីឡេនៅក្នុងផែនទីព្រះគម្ពីរបឺប លេខ ១១ « ទឹកដីបរិសុទ្ធនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មី » ។ សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានចាកចេញពីស្រុកទីរ៉ុស និង ស៊ីដូន នោះទ្រង់បានធ្វើដំណើរទៅកាន់ប៉ែកខាងកើតនៃសមុទ្រកាលីឡេ ទៅតំបន់ស្រុកដេកាប៉ូល ។

សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញពួកគេអានម៉ាកុស ៧:៣១–៣៧ឲ្យឮៗជាមួយគ្នា រកមើលរបៀបដែលព្រះអង្គសង្គ្រោះបានបង្ហាញក្តីមេត្តាករុណាដល់បុរសម្នាក់នៅក្នុងស្រុកដេកាប៉ូល ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរសុំសិស្សឲ្យពិភាក្សាអំពីសំណួរដូចខាងក្រោមជាមួយនឹងដៃគូរបស់ពួកគេ ៖

- តើបុរសដែលស្វែងរកការព្យាបាលនេះស្ថិតនៅក្នុងស្ថានភាពណា ?
- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ ពីមុនទ្រង់ព្យាបាលដល់បុរសនេះ ?

ដើម្បីជួយសិស្សឲ្យយល់សកម្មភាពរបស់ព្រះអង្គសង្គ្រោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ ប្រូស អរ ម៉ាក់ខនគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ព្រះអម្ចាស់កំពុងទំនាក់ទំនងនឹងព្រលឹងដែលមានជំនឿ ដែលពុំអាចស្តាប់ឮព្រះបន្ទូលទ្រង់ ឬមានបន្ទូលឆ្លើយឆ្លងពួកគេ ។ ដូច្នេះតើមានអ្វីដែលសាមញ្ញជាង ដើម្បីប្រើសញ្ញាសម្គាល់ជាទូទៅ ដើម្បីឲ្យបុរសថ្លង់ ហើយពុំអាចនិយាយនេះស្តាប់ និងយល់ នូវអ្វីដែលលោកចៅហ្វាយអាចធ្វើ ហើយនឹងធ្វើនោះ. . . ? » (*Doctrinal New Testament Commentary* រ៉ូលទី ៣ [ឆ្នាំ ១៩៦៥—៧៣], ១:៣៧៣) ។

- តើសកម្មភាពរបស់ព្រះអង្គសង្គ្រោះនៅក្នុងស្ថានភាពនេះបង្រៀនយើងអំពីចរិតលក្ខណៈរបស់ទ្រង់របៀបណា ?

ចូរពន្យល់ថាទោះជាព្រះអង្គសង្គ្រោះព្រមានដល់អ្នកទាំងឡាយ ដែលទ្រង់បានព្យាបាលឲ្យជា កុំឲ្យប្រាប់ដល់អ្នកដទៃអំពីអព្ភូតហេតុរបស់ទ្រង់ក្តី ក៏ប្រជាជននៅស្រុកដេកាប៉ូល នៅតែស្តាប់ឮអំពីរឿងអស្ចារ្យៗដែលព្រះអង្គសង្គ្រោះបានធ្វើដែរ ហើយមានមនុស្សយ៉ាងច្រើនកុះករមករកទ្រង់ (សូមមើល ម៉ាកុស ៧:៣៦–៣៧) ។

ម៉ាកុស ៨:១–២១

ព្រះយេស៊ូវបានប្រទានចំណីអាហារដល់ប្រជាជនបួនពាន់នាក់

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរដូចខាងក្រោម ក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើពេលណា ដែលមានមនុស្សម្នាក់សម្គាល់ឃើញថាអ្នកត្រូវការជំនួយ ហើយបានធ្វើអ្វីមួយដើម្បីជួយដល់អ្នក ?

ចូរពន្យល់ថាក្រោយមកក្នុងមេរៀននេះ សិស្សដែលចង់ចែកចាយបទពិសោធន៍របស់ពួកគេ នឹងមានឱកាសដើម្បីចែកចាយ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៨:១–៣ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលបញ្ហាដែលបានកើតឡើង ដោយសារតែហ្វូងមនុស្សដែលមកតាមព្រះយេស៊ូវ ។

- តើមានបញ្ហាអ្វីដែលបានកើតឡើងចំពោះហ្វូងមនុស្សនោះ ? តើនរណាដែលបានដឹងអំពីសេចក្តីត្រូវការរបស់ហ្វូងមនុស្ស ?
- តើព្រះអង្គសង្គ្រោះបារម្ភថាមានអ្វីអាចនឹងកើតឡើង បើមនុស្សព្យាយាមត្រឡប់ទៅផ្ទះរបស់ពួកគេវិញដោយគ្មានទទួលទានអ្វីបន្តិចជាមុនសិននោះ ?
- យោងតាមខទី ២តើព្រះអង្គសង្គ្រោះមានព្រះទ័យយ៉ាងណាចំពោះហ្វូងមនុស្ស ? (អ្នកគ្រូតែផ្តល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លា « ខ្ញុំមានចិត្តក្តួលអាណិតដល់មនុស្សទាំងអស់នេះណាស់ » ដែលបង្ហាញពីអារម្មណ៍អាណិតអាសូរ និង កង្វល់ដែលព្រះអង្គសង្គ្រោះមានចំពោះប្រជាជន) ។

សូមអញ្ជើញឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗចេញពី ម៉ាកុស ៨:៤–៩ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលជាលទ្ធផលមកពីក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ ។


- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះសម្រាប់ហ្វូងមនុស្ស ?
- តើមានមនុស្សប៉ុន្មាននាក់បានទទួលទានចំណីអាហារ ?
- តើយើងអាចរៀនអ្វីខ្លះមកពីគំរូរបស់ព្រះអង្គសង្គ្រោះ នៅក្នុងដំណើររឿងនេះ ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដោយការមើលឃើញពីតម្រូវការរបស់អ្នកដទៃ រួចហើយជួយបំពេញតាមតម្រូវការទាំងនោះ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់អំពីគោលការណ៍នេះ ចូរពន្យល់ថាបងស្រី លីនដា ខេ ប៊ើតុន ជាប្រធានសមាគមសង្គ្រោះទូទៅ បានបង្រៀនថា ដើម្បីដើរតាមគំរូរបស់ព្រះអង្គសង្គ្រោះនៅក្នុងការបម្រើដល់កូនចៅរបស់ព្រះ នោះយើងចាំបាច់ត្រូវ « ដំបូងសង្កេត បន្ទាប់មកបម្រើ » (« First Observe, Then Serve » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៧៨) ។ ចូរសរសេរឃ្លានេះនៅលើក្តារខៀន នៅខាងក្រោមគោលការណ៍ ។

- តើយើងអាចរៀនកាន់តែចេះយកចិត្តទុកដាក់ចំពោះតម្រូវការរបស់អ្នកដទៃបានយ៉ាងដូចម្តេច ? (ចូរគិតពិចារណាធ្វើការចង្អុលបង្ហាញថា មានតម្រូវការខ្លះអាចនឹងពុំត្រូវបានមើលឃើញភ្លាមៗនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចអធិស្ឋាន ហើយសុំជំនួយដើម្បីកត់សម្គាល់ឃើញពីតម្រូវការរបស់អ្នកដទៃ ហើយជ្រោតគំនិតរបស់យើងទៅលើអ្នកដទៃជាជាងមកលើខ្លួនយើង) ។
- តើមានអ្វីខ្លះអាចនឹងមកវាំងផ្លូវមិនឲ្យយើងអាចសម្គាល់ឃើញតម្រូវការរបស់អ្នកដទៃ ហើយជួយបំពេញវានោះ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍ទាំងឡាយដែលពួកគេបានសរសេរអំពីគ្រាមួយ ដែលមនុស្សម្នាក់បានសម្គាល់ឃើញពីតម្រូវការដែលពួកគេត្រូវការ ហើយបានផ្តល់ជំនួយ ។

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖



« តើបេះដូងរបស់អ្នកត្រូវបានប៉ះប៉ុន្មានដង នៅពេលអ្នកបានធ្វើជាសាក្សីពីតម្រូវការរបស់អ្នកដទៃ ? តើអ្នកធ្លាប់មាន*បំណង*ដើម្បីធ្វើជាមនុស្សឲ្យគេជួយញឹកញាប់ប៉ុណ្ណាដែរ ? ហើយជីវភាពប្រចាំថ្ងៃត្រូវបានបង្អាក់ញឹកញាប់ប៉ុណ្ណា រួចហើយអ្នកបានបន្សល់វាទុកឲ្យអ្នកផ្សេងជួយ ដោយមានអារម្មណ៍ថា ‹ អ៊ូ ក្រោកដណាស់ នឹងមាននរណាម្នាក់ជួយមើលថែតម្រូវការនោះហើយ › ។

« យើងត្រូវបានជាប់ជំពាក់យ៉ាងខ្លាំងនៅក្នុងភាពរវល់នៃជីវិតរបស់យើង ។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវបោះជំហានថយក្រោយបន្តិច ហើយសម្លឹងមើលនូវអ្វីដែលយើងកំពុងធ្វើ នោះយើងអាចរកឃើញថា យើងបានជ្រមុជខ្លួនយើងនៅក្នុង ‹ រឿងរ៉ាវគ្រប់បែបយ៉ាង › ។ ឬម្យ៉ាងទៀត ជាញឹកញាប់យើងបានចំណាយពេលច្រើនបំផុត ដោយយកចិត្តទុកដាក់ទៅអ្វីដែលពុំសូវសំខាន់នៅគ្រប់រឿងរ៉ាវគ្រប់បែបយ៉ាង ដោយមិនយកចិត្តទុកដាក់ទៅលើបព្វហេតុដែលកាន់តែសំខាន់ទៅវិញ » (« What Have I Done for Someone Today? » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៨៥) ។

ចូរសុំឲ្យសិស្សនឹកស្រមៃនៅក្នុងគំនិតរបស់ពួកគេ អំពីព្រឹត្តការណ៍ទាំងឡាយនៅក្នុងថ្ងៃណាមួយសម្រាប់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យគិតអំពីមនុស្សដែលពួកគេបានជួយ ដែលអាចនឹងត្រូវការជំនួយរបស់ពួកគេ ដូចជាឪពុកម្តាយ បងប្អូន និង មិត្តភក្តិ ។ សូមលើកទឹកចិត្តសិស្សឲ្យតាំងចិត្តដើម្បីធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះតាមរយៈការផ្តល់ជំនួយ នៅពេលពួកគេឃើញនរណាម្នាក់ត្រូវការជំនួយ ។

> ***ការចែកចាយគំនិត អារម្មណ៍ និងបទពិសោធន៍នានា***
>
> ការចែកចាយគំនិត និង បទពិសោធន៍ដែលទាក់ទង អាចជួយដល់ការយល់កាន់តែច្បាស់អំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ។ នៅពេលសិស្សចែកចាយបទពិសោធន៍ទាំងឡាយរបស់ពួកគេ ជាញឹកញាប់ព្រះវិញ្ញាណបរិសុទ្ធដឹកនាំពួកគេឲ្យយល់កាន់តែជ្រៅជ្រះ ហើយមានទីបន្ទាល់អំពីគំនិតទាំងឡាយដែលពួកគេកំពុងចែកចាយនោះ ។ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះគំនិតនិងអារម្មណ៍ និងបទពិសោធន៍ទាំងឡាយដែលសិស្សចែកចាយ ក៏អាចមានឥទ្ធិពលដ៏សំខាន់ទៅលើដួងចិត្ត និង គំនិតរបស់មិត្តភក្តិពួកគេផងដែរ ។

សូមសង្ខេបម៉ាកុស ៨:១០–២១ ដោយការពន្យល់ថា បន្ទាប់ពីបានប្រទានចំណីអាហារដល់មនុស្ស ៤០០០ នាក់ប្រកប ដោយអព្ភូតហេតុមក ព្រះយេស៊ូវ និង ពួកសិស្សរបស់ទ្រង់ បានជិះទូកទៅកន្លែងមួយដែលហៅថា ស្រុកដាលម៉ានូថា ។ នៅទីនោះពួកផារិស៊ីបានសុំឲ្យទ្រង់បង្ហាញទីសម្គាល់មួយដល់ពួកគេ ។ ព្រះយេស៊ូវបានបដិសេធ ហើយបានបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យប្រយ័ត្ននឹងគោលលទ្ធិរបស់ពួកផារិស៊ី ដែលគោលលទ្ធិនោះចេញមកពីភាពល្ងិតល្ងង់ខាងវិញ្ញាណ ។

ម៉ាកុស ៦:២២–២៦

ព្រះយេស៊ូវព្យាបាលបុរសខ្វាក់សន្សឹមៗ

ចូរពន្យល់ថាព្រះយេស៊ូវ និង ពួកសិស្សរបស់ទ្រង់បានចាកចេញពីតំបន់ស្រុកដេកាប៉ូល ហើយបានមកដល់កន្លែងមួយដែលហៅថា ភូមិបេតសៃដា ។ នៅពេលពួកលោកបានមកដល់ទីនោះ មានបុរសខ្វាក់ម្នាក់ត្រូវបានគេនាំទៅកាន់ព្រះអង្គសង្គ្រោះដើម្បីព្យាបាល ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ៨:២២–២៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះព្យាបាលដល់បុរសខ្វាក់ ។

- តើមានអ្វីបានកើតឡើង បន្ទាប់ពីគ្រាដំបូងដែលព្រះអង្គសង្គ្រោះបានដាក់ព្រះហស្តរបស់ទ្រង់ទៅលើបុរសខ្វាក់ភ្នែកនោះ ? (អ្នកគួរតែត្រូវពន្យល់ឃ្លា « ខ្ញុំឃើញមនុស្សដើរ មើលទៅដូចជាដើមឈើ » [ខទី ២៤] ចង្អុលបង្ហាញថា បុរសខ្វាក់អាចមើលឃើញ ប៉ុន្តែពុំច្បាស់) ។
- តើមានអ្វីខ្លះកើតឡើង បន្ទាប់ពីព្រះអង្គសង្គ្រោះបានដាក់ព្រះហស្តរបស់ទ្រង់ទៅលើបុរសនោះជាលើកទីពីរ ?

សូមចែកដល់សិស្សនូវច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ប្រូស អរ ម៉ាក់ខនគី ក្នុងក្លូ៉មនៃពួកសាវកដប់ពីរនាក់ ហើយសូមអញ្ជើញសិស្សម្នាក់អានវាឮៗ ។ សូមលើកទឹកចិត្តឲ្យសិស្សផ្ទៀងតាម ហើយរកមើលមូលហេតុនានាដែលព្រះយេស៊ូវប្រហែលជាបានព្យាបាលបុរសនោះបន្តិចម្តងៗ ឬនៅក្នុងដំណាក់កាលនានា។



« អព្ភូតហេតុនេះគឺពិសេស វាត្រូវបានកត់ត្រាតែគ្រាដែលព្រះយេស៊ូវបានព្យាបាលបុរសម្នាក់បន្តិចម្តងៗ ។ ប្រហែលជាព្រះអម្ចាស់របស់យើងបានធ្វើតាមរបៀបនេះ ដើម្បីពង្រឹងដល់ភាពទន់ខ្សោយ ប៉ុន្តែបណ្តុះសេចក្តីជំនឿរបស់បុរសខ្វាក់វិញ ។ វាហាក់ដូចជាបង្ហាញឲ្យឃើញថា គំរូជាលំដាប់លំដោយនៃការប៉ះព្រះកាយព្រះយេស៊ូវមានឥទ្ធិពលបន្ថែមជាសេចក្តីសង្ឃឹម ការអះអាង និងសេចក្តីជំនឿទៅដល់បុរសខ្វាក់ភ្នែក ។ ព្រះយេស៊ូវផ្ទាល់ (១) បានដឹកដៃរបស់បុរសខ្វាក់ចេញពីក្រុង (២) បានដាក់ទឹកមាត់របស់ទ្រង់ផ្ទាល់ទៅលើភ្នែករបស់បុរសខ្វាក់នោះ (៣) បានធ្វើពិធីបរិសុទ្ធនៃការដាក់ដៃលើ ហើយ (៤) បានដាក់ព្រះហស្តរបស់ទ្រង់ជាលើកទីពីរនៅលើភ្នែករបស់បុរសនោះ ។

« ប្រាកដណាស់ របៀបដែលការព្យាបាលនេះធ្វើឡើង បង្រៀនថា មនុស្សគប្បីស្វែងរកព្រះគុណព្យាបាលរបស់ព្រះអម្ចាស់ដោយអស់ពីពលំ និងអស់ពីសេចក្តីជំនឿរបស់ ពួកគេ ដ្បិតរឿងដូច្នេះគឺគ្រប់គ្រាន់ល្មមសម្រាប់តែការព្យាបាលខ្លះៗប៉ុណ្ណោះ បន្ទាប់ពីទទួលបានការណ៍ដូច្នោះហើយ ទោះជាយ៉ាងណាក៏ដោយ ពួកគេអាចនឹងទទួលបាននូវការការបញ្ជាក់ និងសេចក្តីជំនឿបន្ថែមដើម្បីធ្វើឲ្យជាសះស្បើយ និងបានល្អគ្រប់ផ្នែក ។ ជាញឹកញាប់មនុស្សក៏ត្រូវបានព្យាបាលពីជំងឺខាងវិញ្ញាណរបស់ពួកគេតាមកម្រិត មួយដំណាក់កាលម្តងៗផងដែរ នៅពេលពួកគេដាក់ជីវិតរបស់ពួកគេឲ្យស្របទៅតាមផែនការ និងគោលបំណងរបស់ព្រះ » (*Doctrinal New Testament Commentary* ១:៣៧៩–៨០) ។

- តើការត្រូវបានព្យាបាលបន្តិចម្តងៗ បង្កើនសេចក្តីជំនឿរបស់នរណាម្នាក់ទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីយល់ថា ពរជ័យមួយចំនួន ដូចជាការទទួលបានទីបន្ទាល់នៃដំណឹងល្អ ឬការទទួលបានការព្យាបាលខាងរូបកាយ ឬខាងវិញ្ញាណ ជាញឹកញាប់កើតមានបន្តិចម្តងៗ ឬក្នុងពេលយូរ ជាជាងក្នុងពេលភ្លាមៗ ឬទាំងស្រុងដូច្នេះ ?

ម៉ាកុស ៨:២៧–៣៨

ពេត្រុសថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវជាព្រះគ្រីស្ទ

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៨:២៨ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសំណួរដែលព្រះអង្គសង្គ្រោះសួរដល់ពួកសិស្សរបស់ទ្រង់ ។ សុំឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់នឹកគិតឡើងវិញអំពីរបៀបដែលពេត្រុសឆ្លើយតបចំពោះសំណួរនេះ ដូចបានកត់ត្រានៅក្នុងម៉ាថាយ ១៦:១៦(ខគម្ពីរនេះគឺជាចំណែកនៃចំណោះចំណានខគម្ពីរ) ។ បើពួកគេពុំចាំទេ សូមអញ្ជើញឲ្យសិស្សម្នាក់អានម៉ាកុស ៨:២៩ឮៗ (ខគម្ពីរនេះមាននូវការឆ្លើយតបរបស់ពេត្រុស) ។

សូមសង្ខេបម៉ាកុស ៨:៣០–៣៨ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ដល់ពួកសិស្សរបស់ទ្រង់ កុំឲ្យប្រាប់ពីអត្តសញ្ញាណរបស់ទ្រង់ ថាជាព្រះគ្រីស្ទ ឬជាព្រះមែស៊ី ទៅកាន់សាធារណៈជនឡើយ ។ ទ្រង់ក៏បានចាប់ផ្តើមបង្រៀនពួកគេអំពីការរងទុក្ខ និងការសុគតរបស់ទ្រង់នាពេលខាងមុខផងដែរ ។

សូមបញ្ចប់មេរៀនដោយការអញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលពួកគេបានរៀនមកពីខគម្ពីរ ដែលពួកគេបានសិក្សាក្នុងអំឡុងពេលរៀនមេរៀន ។

មេរៀន ៣៩

ម៉ាកុស ៩:១–២៩

សេចក្តីផ្តើម

ព្រះយេស៊ូវត្រូវបានប្រែរូបនៅក្នុងវត្តមានរបស់ ពេត្រុស យ៉ាកុប និង យ៉ូហាន ។ បន្ទាប់មក ទ្រង់បានបង្រៀនពួកគេអំពីតួនាទីរបស់ យ៉ូហាន បាទីស្ទ ជាអេលីយ៉ាមួយរូប ដែលបានរៀបចំផ្លូវថ្វាយព្រះមែស៊ី ។ បន្ទាប់ពីព្រះយេស៊ូវត្រឡប់ទៅកាន់ពួកសិស្សដទៃទៀតវិញ មានបុរសម្នាក់បានទូលអង្វរទ្រង់ឲ្យបណ្តេញវិញ្ញាណអសោចចេញពីកូនប្រុសរបស់គាត់ ។ ព្រះយេស៊ូវបានបណ្តេញវិញ្ញាណអសោច ហើយបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់អំពីតម្រូវការសម្រាប់ការអធិស្ឋាន និង ការតមអាហារ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៩:១–១៣

ព្រះយេស៊ូវត្រូវបានប្រែរូបនៅក្នុងវត្តមានរបស់ពេត្រុស យ៉ាកុប និងយ៉ូហាន ហើយបង្រៀនអំពីអេលីយ៉ា

សូមអញ្ជើញអ្នកស្ម័គ្រចិត្តច្រើនរូបមកខាងមុខក្តារខៀន ហើយសម្តែងសកម្មភាពមួយដោយសង្ខេប ដែលវាជួយបង្កើនកម្លាំងខាងរាងកាយ ។

- ហេតុអ្វីក៏មនុស្សម្នាក់ចង់ ឬចាំបាច់ត្រូវបង្កើនកម្លាំងខាងរូបកាយរបស់គេ ?
- តើកម្លាំងខាងរូបកាយត្រូវបានប្រៀបទៅនឹងកម្លាំងខាងវិញ្ញាណ ឬសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?
- តើស្ថានភាពមួយចំនួនណាខ្លះ ដែលសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទត្រូវបានសាកល្បង ហើយមានតម្រូវការជាពិសេសដើម្បីត្រូវបានពង្រឹងនោះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សនៅពេលពួកគេសិក្សាម៉ាកុស ៩:១–២៩ ឲ្យរកមើលសេចក្តីពិតទាំងឡាយ ដែលអាចជួយពួកគេពង្រឹងសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។

សូមសង្ខេបម៉ាកុស ១:១–១៣ ដោយការពន្យល់ថា វាមានន័យដំណើររឿងអំពីការប្រែរូបរបស់ព្រះយេស៊ូវនៅក្នុងវត្តមានរបស់ ពេត្រុស យ៉ាកុប និងយ៉ូហាន នៅលើភ្នំប្រែរូប ។ វគ្គគម្ពីរនេះ ក៏មានរៀបរាប់ថា ព្រះយេស៊ូវបានបង្រៀនដល់ពួកសាវកទាំងនេះថា យ៉ូហាន បាទីស្ទ បានបំពេញតាមតួនាទីដែលបានព្យាការអំពីអេលីយ៉ា ឬមនុស្សម្នាក់ដែលមករៀបចំផ្លូវថ្វាយការយាងមករបស់ព្រះអង្គសង្គ្រោះ (សូមមើល ការបកប្រែដោយ យ៉ូសែប ស៊្មីធ ម៉ាកុស ៩:១០) ។

ម៉ាកុស ៩:១៤–២៩

ព្រះយេស៊ូវបណ្តេញវិញ្ញាណអសោចចេញពីកូនប្រុសរបស់បុរសម្នាក់

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៩:១៤–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវស្ថានភាពដែលព្រះអង្គសង្គ្រោះបានជួប នៅពេលទ្រង់ត្រឡប់មកពីភ្នំ ទៅជួបនឹងពួកសិស្សដទៃទៀត ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ហើយឲ្យសិស្សម្នាក់ទៀតអានពាក្យរបស់ឪពុកនៅក្នុងដំណើររឿងដែលមាននៅក្នុងម៉ាកុស ៩:១៦–២៤ (អ្នកអាចនឹងចាត់ចែងផ្នែកទាំងនេះមុនពេលថ្នាក់រៀន ហើយអញ្ជើញឲ្យសិស្សទាំងនេះស្តាប់បន្ទាត់របស់ពួកគេ) ។ ចូរពិចារណាធ្វើការសម្តែងតួរបស់អ្នកអត្តាធិប្បាយ ឬអញ្ជើញសិស្សទីបីឲ្យធ្វើដូច្នោះ ។ ចូរសុំឲ្យសិស្សដែលបានចាត់តាំងនោះ អានផ្នែករបស់ពួកគេនៅក្នុងម៉ាកុស ៩:១៦–១៨ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលនូវអ្វីដែលឪពុកបានស្វែងរកពីពួកសិស្សរបស់ព្រះអង្គសង្គ្រោះ ។

- តើឪពុកូបនេះស្វែងរកអ្វីសម្រាប់កូនប្រុសរបស់គាត់ ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា កូនប្រុសនោះមានវិញ្ញាណអសោច ដែលបណ្តាលឲ្យគ ហើយថ្លង់ | សូមមើលម៉ាកុស ៩:១៧, ២៥| និងជំងឺផ្សេងទៀត ។ នៅពេលណាវិញ្ញាណអសោចចូលក្នុងកូនប្រុសនោះ កូននោះនឹងប្រកាច់ បែកពពុះមាត់ សង្កៀតធ្មេញ ហើយរឹងឆ្អឹង) ។

ចូរសុំឲ្យសិស្សនឹកស្រមៃថាធ្វើជាឪពុកូបនេះ ហើយពិចារណាអំពីរបៀប ដែលសេចក្តីជំនឿរបស់ពួកគេទៅលើព្រះអង្គសង្គ្រោះ និងព្រះចេស្តារបស់ទ្រង់អាចនឹងប៉ះទង្គិច នៅពេលពួកសិស្សពុំអាចព្យាបាលដល់កូនប្រុសរបស់ពួកគេ ។

សូមអញ្ជើញសិស្សដែលបានចាត់តាំងនោះឲ្យបន្តអានផ្នែករបស់ពួកគេនៅក្នុងម៉ាកុស ៩:១៩–២២ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយនឹកស្រមៃអំពីរបៀបដែលឪពុកូបនេះ អាចនឹងមានអារម្មណ៍បែបណា នៅពេលគាត់សន្ទនាជាមួយនឹងព្រះអង្គសង្គ្រោះ ។

- តើអ្នកគិតថាឪពុកូបនេះមានអារម្មណ៍យ៉ាងណា នៅពេលគាត់សន្ទនាជាមួយនឹងព្រះអង្គសង្គ្រោះ ?

ជៀសវាងចំណាយពេលក្នុងថ្នាក់រៀនឥតប្រយោជន៍

នៅពេលចាប់ផ្តើមថ្នាក់ទាន់ពេល ហើយសិស្សដឹងថាគ្មានពេលចំណាយដោយឥតប្រយោជន៍ នោះពួកគេនឹងទទួលអារម្មណ៍ដឹងពីគោលបំណងមួយ ។ បន្ទាប់ពីការចាប់ផ្តើមថ្នាក់ដោយមានប្រសិទ្ធភាព និង គុណភាព នោះថ្នាក់រៀនអាចជួយសិស្សឲ្យមានបទពិសោធន៍រៀនសូត្ររបស់ពួកគេនៅក្នុងបទគម្ពីរកាន់តែច្រើន ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ ខាងក្រោមនេះឮៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលនូវអ្វីដែលអែលឌើរ ហូឡិន បានបន្ថែមទៅលើការយល់ដឹងរបស់យើងអំពីអារម្មណ៍ និង ការអង្វររបស់ឪពុកកូបនេះ ។



« ដោយគ្មានសល់ក្តីសង្ឃឹមអ្វីសោះ ឪពុកកូបនេះបានដាក់នូវសេចក្តីជំនឿទាំងអស់ដែលគាត់មាន ហើយទូលអង្វរដល់ព្រះអង្គសង្គ្រោះនៃពិភពលោក ‹ *បើរ៉ោហកអាចនឹងជួយបាន នោះ*សូមអាណិតមេត្តាជួយ*យើង*ខ្ញុំផង › [ម៉ាកុស ៩:២២បានបន្ថែមអក្សរទ្រេត] ។ ខ្ញុំពិបាកអានពាក្យទាំងនោះដោយមិនយំណាស់ ។ ពហុសព្វនាម*យើងខ្ញុំ* គឺត្រូវបានប្រើដោយចេតនាពិត ។ បុរសនេះកំពុងនិយាយ ‹ គ្រួសារយើងខ្ញុំទាំងមូលកំពុងទូលអង្វរ › ។ បញ្ហារបស់យើងនឹងពុំដែលឈប់មានឡើយ ។ យើងនឿយហត់ណាស់ ។ កូនប្រុសរបស់យើងបានធ្លាក់ទៅក្នុងទឹក ។ គាត់ធ្លាក់ចូលភ្លើង ។ គាត់បន្តស្ថិតនៅក្នុងគ្រោះថ្នាក់ ហើយយើងបន្តភ័យខ្លាច ។ យើងពុំដឹងថាត្រូវទៅរកនរណាទៀតទេ ។ តើ*រ៉ោហក*អាចជួយយើងខ្ញុំបានទេ ? យើងនឹងមានអំណរគុណចំពោះ*អ្វីគ្រប់យ៉ាង*ជាពរជ័យមួយផ្នែក ជាក្តីសង្ឃឹមមួយភ្លែត ជាការលើកបន្ទុកតូចៗខ្លះចេញពីអំរែករបស់ម្តាយក្មេងប្រុសនេះដែលមានប្រចាំថ្ងៃក្នុងជីវិតរបស់គាត់ » (« Lord, I Believe »*Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៣) ។

សូមអញ្ជើញសិស្សដែលបានចាត់តាំងខាងផ្នែកព្រះអង្គសង្គ្រោះឲ្យអានម៉ាកុស ៩:២៣ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ឪពុកកូបនេះ ។

- តើឪពុកកូបនេះចាំបាច់ត្រូវជឿទៅលើនរណា ?
- តើគោលការណ៍អ្វីខ្លះដែលព្រះអង្គសង្គ្រោះបង្រៀនដល់ឪពុកកូបនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងជឿទៅលើព្រះយេស៊ូវគ្រីស្ទ រឿងគ្រប់យ៉ាងនឹងអាចធ្វើទៅបានសម្រាប់យើង ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំពាក្យនៅក្នុងខទី ២៣ដែលបង្រៀនពីគោលការណ៍នេះ) ។


ចូរចង្អុលបង្ហាញថា « រឿងគ្រប់យ៉ាង » ទាក់ទងទៅនឹងពរជ័យសុចរិតទាំងអស់ ដែលស្របទៅនឹងព្រះឆន្ទៈ គោលបំណង និងពេលវេលារបស់ព្រះ ។

- តើការជឿទៅលើគោលការណ៍នេះអាចជួយនរណាម្នាក់ ដែលប្រឈមមុខនឹងការលំបាកដែលហាក់ដូចជាមិនអាចយកឈ្នះដោយរបៀបណា ?

សូមអញ្ជើញសិស្សដែលបានចាត់ ឲ្យដើរតួផ្នែកឪពុកឲ្យអានម៉ាកុស ៩:២៤ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលការឆ្លើយតបរបស់ឪពុកចំពោះគោលការណ៍ដែលព្រះអង្គសង្គ្រោះបានបង្រៀន ។

- តើអ្នកនឹងពិពណ៌នាយ៉ាងដូចម្តេច អំពីសេចក្តីជំនឿរបស់ឪពុកកូបនេះនៅក្នុងគ្រានោះ ?

ចូរសុំឲ្យសិស្សកត់ចំណាំចម្លើយពីផ្នែករបស់ឪពុកកូបនេះ ។ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលនូវអ្វីដែលជាការប្រកាសរបស់ឪពុក ដែលគួរបង្ហាញអំពីអ្វីដែលយើងអាចធ្វើនៅក្នុងគ្រានៃ « ការមិនជឿ » ឬគ្រានៃការសង្ស័យ ឬភ័យខ្លាច ។



« នៅពេលប្រឈមមុខនឹងឧបសគ្គនៃសេចក្តីជំនឿ ឪពុកកូបនេះបានដាក់អស់នូវកម្លាំងរបស់គាត់ទទួលស្គាល់ពី ដៃនកំណាត់របស់គាត់ដំបូងគេ និង តែមួយគត់ ។ ការប្រកាសដំបូងបំផុតរបស់គាត់ គឺវិជ្ជមាន ហើយឥតស្ទាក់ស្ទើរថា ៖ « ខ្ញុំជឿហើយ លោកម្ចាស់អើយ » ។ ខ្ញុំចង់និយាយទៅបងប្អូនទាំងអស់គ្នា ដែលចង់មានជំនឿខ្លាំងឡើង ឲ្យចងចាំបុរសកូបនេះ ! ក្នុងវេលានៃការភ័យខ្លាច ឬការសង្ស័យ ឬពេលដែលមានបញ្ហា សូមកាន់ខ្ជាប់ទៅនឹងទីតាំងដែលអ្នកបានដណ្តើមយកមកវិញ បើទោះបីជាទីតាំងនោះមានកំណត់ក្តី ។ ក្នុងការលូតលាស់ដែលយើងទាំងអស់គ្នាមានបទពិសោធន៍ ក្នុងជីវិតរមែងស្លាប់ ភាពស្មើគ្នាខាងវិញ្ញាណទៅនឹងការវេទនារបស់ក្មេងប្រុសនេះ ឬការអស់សង្ឃឹមរបស់ឪពុកម្តាយ គឺនឹងមកដល់យើងទាំងអស់គ្នា ។ ពេលគ្រាទាំងនោះមកដល់ ហើយបញ្ហាផុសចេញមក នោះដំណោះស្រាយមិនកើតភ្លាមទេ *សូមកាន់ខ្ជាប់ទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយ ហើយឈរយ៉ាងរឹងមាំ រហូតដល់ចំណេះដឹងបន្ថែមទៀតមកដល់*» (« Lord, I Believe » ទំព័រ ៩៣–៩៤) ។

- តើយើងអាចរៀនអ្វីខ្លះមកពីឪពុកកូបនេះ អំពីអ្វីដែលយើងអាចធ្វើនៅក្នុងគ្រានៃការឥតជំនឿ ? (ក្រោយពីសិស្សឆ្លើយតបហើយ សូមសរសេរឃ្លាដែលមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *បើយើងកាន់ឲ្យជាប់នូវអ្វីដែលយើងជឿ. . .*)
- តើយើងអាចរៀនអ្វីខ្លះអំពីដំណោះស្រាយចំពោះការមិនជឿដែលចេញមកពីសេចក្តីថ្លែងការណ៍របស់ឪពុកកូបនេះ ត្រង់ផ្នែកផ្សេងទៀតនៅក្នុងខ ២៤ ? (ក្រោយពីសិស្សឆ្លើយតបហើយ សូមបន្ថែមឃ្លាខាងក្រោមទៅនឹងឃ្លាលើក្តារខៀន ៖ *ហើយស្វែងរកជំនួយរបស់ព្រះអម្ចាស់. . .*)

ចូរសុំសិស្សម្នាក់អាន ម៉ាកុស ៩:២៥–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានឆ្លើយតបចំពោះការទូលអង្វររបស់ឪពុកកូបនេះ ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ នៅក្នុងការឆ្លើយតបចំពោះការទូលអង្វររបស់ឪពុកកូបនេះ ?
- តើអ្នកនឹងបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដោយផ្អែកទៅលើអ្វីដែលអ្នកបានរៀនមកពីដំណើររឿងនេះយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតប សូមបំពេញប្រយោគនៅលើក្តារខៀនដើម្បីវានាំទៅរកគោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងកាន់ជាប់នូវអ្វីដែលយើងជឿ ហើយស្វែងរកជំនួយរបស់ព្រះអម្ចាស់ នោះទ្រង់នឹងជួយយើងពង្រឹងសេចក្តីជំនឿរបស់យើង) ។**

សូមយោងទៅលើស្ថានភាពដែលបានរៀបរាប់នៅលើក្តារខៀន ដែលអ្នកបានពិភាក្សានៅដើមមេរៀន ។

- តើគោលការណ៍នេះអាចត្រូវបានប្រើនៅក្នុងស្ថានភាពដូច្នេះយ៉ាងដូចម្តេច ?

- តើនៅពេលណាដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ បានទទួលជំនួយរបស់ព្រះអម្ចាស់នៅក្នុងពេលឥតជំនឿដោយសារតែការក្រសោបសេចក្តីជំនឿ ហើយស្វែងរកជំនួយរបស់ទ្រង់ ? (អ្នកគួរតែចែកចាយបទពិសោធន៍មួយផងដែរ) ។

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តគោលការណ៍នេះ៖ អំឡុងពេលឥតជំនឿ ។

ចូររំឭកសិស្សថា ឪពុកក្មេងនេះ៖ ដំបូងឡើយ បាននាំកូនប្រុសរបស់គាត់ទៅជួបនឹងពួកសិស្សមួយចំនួនរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីត្រូវបានព្យាបាល ។ សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេគឺជាពួកសិស្សទាំងនេះ៖ ។

- តើអ្នកនឹងគិត ឬមានអារម្មណ៍យ៉ាងណា ពេលអ្នកមិនអាចបណ្តេញវិញ្ញាណអសោចចេញពីក្មេងប្រុសនេះ ?

សូមអញ្ជើញសិស្សម្នាក់អានម៉ាកុស ៩:២៨ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវសំណួរដែលពួកសិស្សសួរទៅព្រះយេស៊ូវ ។

- តើពួកសិស្សបានសួរសំណួរព្រះយេស៊ូវអ្វីខ្លះ ?

សូមសុំឲ្យសិស្សរំឭកម៉ាកុស ៩:១៩ហើយរកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះបានពិពណ៌នាអំពីមនុស្ស រួមទាំងពួកសិស្សរបស់ទ្រង់ដែលមានវត្តមាននៅទីនោះ ។ (ពួកគេ « មិនជឿ » នោះទេ) ។ ចូរពន្យល់ថា*ការមិនជឿ*នៅទីនេះ៖ សំដៅទៅលើការខ្វះសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ សេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទគឺចាំបាច់ ដើម្បីឲ្យការប្រសិទ្ធពរបព្វជិតភាពមានប្រសិទ្ធភាព ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៩:២៩ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាម រកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះសំណួររបស់ពួកសិស្ស ។

- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះ ដល់ពួកសិស្សរបស់ទ្រង់ ?
- តើការអធិស្ឋាន និង ការតមអាហារ អាចមានឥទ្ធិពលទៅលើសេចក្តីជំនឿរបស់មនុស្សម្នាក់យ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតប សូមជួយពួកគេយល់នូវសេចក្តីពិតដូចខាងក្រោម ៖ **យើងអាចបង្កើនសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទតាមរយៈការអធិស្ឋាន និង ការតមអាហារ**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះ៖ ដែលដកស្រង់ពីសៀវភៅ *ពិតចំពោះសេចក្តីជំនឿ* ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលស្ថានភាពខុស ៗគ្នាដែលសេចក្តីពិតអាចអនុវត្ត ៖

« ដំណើររឿងនេះ | អំពីព្រះយេស៊ូវបណ្តេញវិញ្ញាណអសោចចេញពីកូនប្រុសរបស់បុរសនោះ | បង្រៀនថា ការអធិស្ឋាន និងការតមអាហារអាចផ្តល់នូវកម្លាំងបន្ថែមដល់អ្នកទាំងឡាយដែលនឹងផ្តល់ និង ទទួលការប្រសិទ្ធពរបព្វជិតភាព ។ ដំណើររឿងក៏អាចអនុវត្តចំពោះការខិតខំផ្ទាល់ខ្លួន ដើម្បីរស់នៅតាមដំណឹងល្អរបស់អ្នកផងដែរ ។ ប្រសិនបើអ្នកមានភាពទន់ខ្សោយ ឬអំពើបាបមួយដែលអ្នកបានពុះពារដើម្បីយកឈ្នះ នោះអ្នកគួរតែចាំបាច់ត្រូវតមអាហារ ហើយអធិស្ឋានដើម្បីទទួលបានជំនួយ ឬការអភ័យទោសដែលអ្នកប៉ងប្រាថ្នា ។ ដូចជាអារក្សអសោចដែលព្រះគ្រីស្ទបានបណ្តេញចេញ នោះការលំបាករបស់អ្នកអាចនឹងជាប្រភេទការលំបាកដែលនឹងបណ្តេញចេញតែតាមរយៈការអធិស្ឋាន និង ការតមអាហារ » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* | ឆ្នាំ ២០០៤ | ទំព័រ ៦៧ |) ។

- យោងតាមសេចក្តីថ្លែងការណ៍នេះ៖ តើស្ថានភាពមួយចំនួនដែលសេចក្តីពិតនេះអាចអនុវត្តមានអ្វីខ្លះ ?
- តើពេលណាដែលការអធិស្ឋាន និង ការតមអាហារបានជួយបង្កើនសេចក្តីជំនឿរបស់អ្នកទៅលើព្រះគ្រីស្ទ ហើយអនុញ្ញាតឲ្យអ្នកទទួលបានពរជ័យសុចរិតដែលអ្នកស្វែងរកនោះ ?

ចូរសុំឲ្យសិស្សនឹកគិតអំពីពរជ័យទាំងឡាយ ដែលពួកគេស្វែងរកសម្រាប់ខ្លួនគេ ឬអ្នកដទៃ ដែលអាចនឹងត្រូវបានទទួលតាមរយៈការបង្កើនសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ តាមរយៈការអធិស្ឋាន និង ការតមអាហារ ។ សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅមួយដើម្បីអធិស្ឋាន និងតមអាហារចំពោះពរជ័យទាំងនេះនៅថ្ងៃអាទិត្យតមអាហារក្រោយ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

សូមពិចារណាធ្វើការស្វែងរកជាមុននូវវគ្គចំណេះចំណានខគម្ពីរមួយចំនួនដែលសិស្សអាចនឹងមិនទាន់ស្គាល់នៅឡើយ ។ សូមអញ្ជើញពួកគេឲ្យអាន ហើយគូសចំណាំវា ។ អ្នកអាចនឹងចាត់តាំងវគ្គចំណេះចំណានខគម្ពីរថ្មីមួយដល់សិស្សម្នាក់ៗ ឬឲ្យសិស្សដែលចាប់ដៃគូៗ ហើយសុំឲ្យពួកគេគូសរូបនៅលើក្រដាសមួយ ដែលពិពណ៌នាអំពីសេចក្តីពិតដែលបានបង្រៀននៅក្នុងវគ្គបទគម្ពីររបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យពន្យល់អំពីរូបភាពរបស់ពួកគេទៅដល់សិស្សក្នុងថ្នាក់ ។ អ្នកអាចនឹងបង្ហាញរូបភាពសម្រាប់ជាសេចក្តីយោងពេលក្រោយ ។

(*កំណត់ចំណាំ* ៖ អ្នកអាចប្រើសកម្មភាពនេះនៅពេលចាប់ផ្តើម ឬពេលបញ្ចប់មេរៀនណាមួយ តាមពេលអនុញ្ញាត) ។

ម៉ាកុស ៩:៣០–៥០

សេចក្តីផ្តើម

ព្រះយេស៊ូវបានប្រាប់ដល់ពួកសិស្សរបស់ទ្រង់អំពីការចូលមកដល់នៃការសុគត និងការរស់ឡើងវិញរបស់ទ្រង់ ហើយបានបង្រៀនពួកគេអំពីនរណានឹងធំជាងគេបំផុតនៅក្នុងនគរនៃព្រះ ។ ទ្រង់បានព្រមានអំពីផលវិបាកនៃការដឹកនាំអ្នកដទៃទៅកាន់អំពើបាប ហើយបានណែនាំដល់ពួកសិស្សរបស់ទ្រង់ដើម្បីញែកខ្លួនពួកគេចេញពីឥទ្ធិពលដែលនឹងដឹកនាំពួកគេទៅរកអំពើបាប ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៩:៣០–៣៧

ព្រះយេស៊ូវបានប្រាប់ទុកជាមុនអំពីការចូលមកដល់នៃការសុគត និង ការរស់ឡើងវិញរបស់ទ្រង់ ហើយបានបង្រៀនអំពីនរណានឹងក្លាយជាធំជាងគេបំផុតនៅក្នុងនគរនៃព្រះ

សូមនាំយកវត្ថុមួយទៅថ្នាក់រៀន ដែលមានក្លិនខ្លាំង ដែលសិស្សនឹងស្គាល់ (ដូចជា ក្លិនក្រូចដែលពុះថ្មីៗ ឬក្លិនខ្ទឹមបារាំង ឬក្លិននំប៉័ងដុតថ្មី) ។ មុនពេលចាប់ផ្តើមថ្នាក់រៀន សូមដាក់វត្ថុនោះនៅក្នុងបន្ទប់រៀនកុំឲ្យសិស្សមើលឃើញ ។

សូមចាប់ផ្តើមមេរៀនដោយការសួរដល់សិស្សថាតើពួកគេមានសម្គាល់ដឹងអំពីក្លិនថ្មីមួយ ពេលពួកគេចូលមកក្នុងថ្នាក់រៀនឬទេ ។

- បើមាន តើក្លិននេះមានឥទ្ធិពលឲ្យអ្នកគិតអំពីអ្វី ឬធ្វើអ្វីពេលអ្នកស្គាល់វា ?

សូមចង្អុលបង្ហាញថា ក្លិនអាចមានឥទ្ធិពលលើយើង យើងអាចមានឥទ្ធិពលក្នុងគំនិត និង អាកប្បកិរិយារបស់អ្នកដទៃស្រដៀងនឹងក្លិននេះផងដែរ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីពិតនៅក្នុងម៉ាកុស ៩:៣០–៥០ដែលអាចជួយពួកគេឲ្យគិតពិចារណាអំពីឥទ្ធិពលរបស់ពួកគេទៅលើការខិតខំរបស់អ្នកដទៃដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ក៏ដូចជាឥទ្ធិពលរបស់អ្នកដទៃមានមកលើពួកគេផងដែរ ។

សូមពន្យល់ថា បន្ទាប់ពីការបណ្តេញវិញ្ញាណអសោចចេញពីយុវជនម្នាក់ (សូមមើលម៉ាកុស ៩:១៧–២៩) នោះព្រះអង្គសង្គ្រោះបានធ្វើដំណើរឆ្លងកាត់ស្រុកកាលីឡេជាមួយនឹងពួកសិស្សរបស់ទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៩: ៣១– ៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព្រឹត្តការណ៍ដែលព្រះអង្គសង្គ្រោះបានព្យាករ ។

- តើមានព្រឹត្តការណ៍អ្វីខ្លះដែលព្រះយេស៊ូវគ្រីស្ទបានព្យាករ ?

សូមសង្ខេបម៉ាកុស ៩:៣៣–៣៧ដោយពន្យល់ថា នៅពេលព្រះយេស៊ូវបានយាងមកស្រុកកាពើណិម នោះទ្រង់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់អំពីនរណាដែលជាអ្នកធំជាងគេបង្អស់នៅក្នុងនគរនៃព្រះ ។ ទ្រង់ក៏បានណែនាំពួកគេឲ្យទទួលអស់អ្នកដែលបន្ទាបខ្លួនដូចជាកុមារតូចៗ និងអ្នកដែលទទួលទ្រង់មកក្នុងសាសនាចក្រ (សូមមើល ការបកប្រែរបស់យ៉ូសែប ស៊្មីធ ម៉ាកុស ៩:៣៤–៣៥ ។ (*កំណត់ចំណាំ ៖* ការបង្រៀនទាំងនេះនឹងពិភាក្សាកាន់តែជ្រៅជ្រះនៅក្នុងមេរៀនសម្រាប់ម៉ាកុស ១០) ។

ម៉ាកុស ៩:៣៨–៥០

ព្រះយេស៊ូវព្រមានទាស់នឹងការមានឥទ្ធិពលលើអ្នកដទៃឲ្យធ្វើអំពើបាប ហើយនឹងអំពីការមិនញែកខ្លួនចេញពីឥទ្ធិពលអាក្រក់

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៩:៣៨ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលស្ថានភាពដែលសាវកយ៉ូហាន បានប្រាប់ដល់ព្រះអង្គសង្គ្រោះ ។

- តើយ៉ូហានបានរាយការណ៍អ្វីខ្លះទៅព្រះអង្គសង្គ្រោះ ?

សូមពន្យល់ថា ពួកសាវកបានហាមបុរសម្នាក់នេះមិនឲ្យបណ្តេញអារក្សចេញ ដោយសារគាត់ពុំមែនជាដៃគូធ្វើដំណើរបស់ពួកសាវកដប់ពីរនាក់ ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គសង្គ្រោះបានប្រាប់ដល់ពួកគេកុំឲ្យហាមដល់បុរសនេះឡើយ (ដោយចង្អុលបង្ហាញថាគាត់គឺជាបុរសសុចរិតម្នាក់ ដែលមានសិទ្ធិអំណាច) ហើយបានបង្រៀនថា អស់អ្នកដែលជួយដល់អ្នកតំណាងរបស់ទ្រង់ នឹងត្រូវបានទទួលរង្វាន់ (សូមមើលម៉ាកុស ៩:៣៩–៤១) ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៩:៤២ ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានព្រមាន ។ សូមពន្យល់ថានៅក្នុងបរិបទនេះ ពាក្យ*វរភាគចិត្ត*មានន័យថាមានឥទ្ធិពលលើអ្នកដទៃឲ្យជំពប់ដួល នាំឲ្យវង្វេង ឬមានឥទ្ធិពលលើនរណាម្នាក់ឲ្យមានបាប ឬបោះបង់ជំនឿរបស់ពួកគេ ។

- តើក្រុមមនុស្សណាខ្លះ ដែលព្រះអង្គសង្គ្រោះព្រមានទាស់នឹងការមានឥទ្ធិពលឲ្យធ្វើបាប ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា « កូនណាមួយដែលជឿដល់ [ព្រះយេស៊ូវ] » រួមទាំងអ្នកដែលក្មេងខ្ចីនៅក្នុងសេចក្តីជំនឿ ដូចជាយុវវ័យ ឬអ្នកថ្លាស់ប្រែចិត្តជឿថ្មី ក៏ដូចជាពួកសិស្សរាបសារ ទុកចិត្តគ្រប់វ័យ) ។

- តើអ្វីខ្លះគឺជាការព្រមានរបស់ព្រះយេស៊ូវទាស់ នឹងការមានឥទ្ធិពលរបស់សិស្សទ្រង់ឲ្យធ្វើអំពើបាប ? (ទ្រង់បានចង្អុលបង្ហាញថា វាល្អប្រសើរដើម្បីស្លាប់ ជាជាងទទួលបទពិសោធន៍នៃការរងទុក្ខដ៏ខ្លាំង និង ការបែកចេញពីព្រះ ដែលយើងនឹងជួបប្រទះ ប្រសិនបើយើងមានឥទ្ធិពលទៅលើអ្នកដទៃឲ្យធ្វើអំពើបាបនោះ) ។
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀន ពីការព្រមានរបស់ព្រះអង្គសង្គ្រោះនៅក្នុង ខទី ៤២ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងមានឥទ្ធិពលលើអ្នកដទៃដែលជឿលើព្រះយេស៊ូវគ្រីស្ទឲ្យប្រព្រឹត្តអំពើបាប នោះយើងនឹងទទួលខុសត្រូវនៅចំពោះមុខព្រះ**)។
- តើជនម្នាក់អាចធ្វើឲ្យខ្លួនមានឥទ្ធិពលលើអស់អ្នក ដែលជឿលើព្រះយេស៊ូវឲ្យប្រព្រឹត្តអំពើបាបតាមរបៀបណា ?

សូមរំឭកសិស្សអំពីភ្លើងនៅក្នុងថ្នាក់ និង អំពីភាពពិតដែលដូចជាភ្លើងនោះ គឺយើងមានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានទៅលើអ្នកដទៃ ។ ចូរសុំឲ្យសិស្សពិចារណាអំពីឥទ្ធិពលរបស់ពួកគេ ទៅលើអស់អ្នកដែលជឿទៅលើព្រះយេស៊ូវគ្រីស្ទ ។

ដើម្បីរៀបចំសិស្សឲ្យប្រាប់អំពីគោលការណ៍ផ្សេងទៀតដែលបានបង្រៀនដោយព្រះអង្គសង្គ្រោះ ចូរសុំអ្នកស្ម័គ្រចិត្តម្នាក់ដែលពាក់ស្បែកជើងចងខ្សែឲ្យឡើងមកក្តារខៀន ។ សូមណែនាំសិស្សឲ្យស្រាយខ្សែស្បែកជើង ហើយចងវាឡើងវិញដោយប្រើដៃតែមួយ ។ ខណៈដែលសិស្សព្យាយាមដើម្បីធ្វើដូចនេះ ចូរសួរដល់សិស្សក្នុងថ្នាក់ ៖

- តើឧបសគ្គអ្វីខ្លះដែលអ្នកនឹងជួបពិសោធន៍ ប្រសិនបើអ្នកបាត់បង់ដៃម្ខាង ?
- បើកើតមានមែន តើអ្វីដែលសក្តិសមនឹងឲ្យអ្នកបាត់បង់ដៃរបស់ដៃ ?

ចូរពន្យល់ថា ការដកផ្នែកមួយនៃរូបកាយចេញដោយសេរី គឺត្រូវបានស្គាល់ថា កាត់ដៃកាត់ជើង ហើយប្រហែលជាវាត្រូវកាត់ចេញ បើផ្នែកណាមួយនៃរូបកាយ ត្រូវបានខូចខាត បាក់បែកយ៉ាងធ្ងន់ធ្ងរ ឬស្លាប់នោះ ។ ទោះបីជាការកាត់ចេញ និង ការជាសះស្បើយតាមក្រោយអាចនឹងឈឺចាប់ ហើយមានដំបៅក្តី ក៏ដំណើរការនៃការកាត់ចេញនេះអាចជួយការពារកុំឲ្យឆ្លងមកពីការឆ្លងទៅផ្នែកផ្សេងទៀតនៃរូបកាយ ហើយបណ្តាលឲ្យខូចខាតបន្ថែមទៀត ឬរហូតដល់ស្លាប់ឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៩:៤៣ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀននៅពេលវានឹងល្អប្រសើរជាងដើម្បីបាត់បង់ដៃម្ខាងជាជាងទុកដៃទាំងពីរ ។

- តើពេលណាវានឹងល្អប្រសើរជាងដើម្បីបាត់បង់ដៃម្ខាងជាជាងទុកដៃទាំងពីរនៅ ?
- តើអ្នកគិតថាយើងគប្បីទទួលយកការបង្រៀននេះដោយន័យត្រង់ ហើយកាត់ដៃម្ខាងដែលធ្វើ « ឲ្យវាតចិត្ត » យើង ឬមានឥទ្ធិពលលើយើងឲ្យធ្វើបាបចោលឬ ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ព្រះអង្គសង្គ្រោះពុំមានបន្ទូលថា អស់អ្នកគ្រាន់តែកាត់ដៃរបស់ពួកគេមែនទែននោះទេ ។ តែទ្រង់ប្រើការប្រៀបធៀបដើម្បីគូសបញ្ជាក់អំពីសារៈសំខាន់នៃអ្វីដែលទ្រង់កំពុងបង្រៀន) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យគ្រួបមនស្សម្នាក់នៅលើក្តារខៀន ។ ខណៈដែលសិស្សកំពុងគ្រួប សូមពន្យល់ថា ការបកប្រែរបស់យ៉ូសែប ស៊្មីធ អំពីម៉ាកុស ៩:៤៣–៤៨ អាចបង្កើនការយល់ដឹងរបស់យើងអំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងវគ្គគម្ពីរនេះ ។ នៅក្នុងខគម្ពីរទាំងនេះ យើងរៀនថា ព្រះអង្គសង្គ្រោះបានប្រើដៃ ជើង និង ភ្នែកជានិមិត្តរូបនៃឥទ្ធិពលនានានៅក្នុងជីវិតរបស់យើង ដែលអាចនាំយើងឲ្យធ្វើបាប ។ សូមណែនាំសិស្សដែលកំពុងគ្រួបនៅលើក្តារខៀន គ្រួងង់ជុំវិញដៃ ជើង និង ភ្នែកមួយនៅលើរូបភាពដែលគាត់បានគូរនោះ ។ បន្ទាប់មកអញ្ជើញសិស្សឲ្យត្រឡប់ទៅកន្លែងអង្គុយរបស់ពួកគេវិញ ។

សូមអញ្ជើញសិស្សផ្សេងទៀតឲ្យជ្រើសវេណគ្នាអានឮៗចេញពីការបកប្រែដោយយ៉ូសែប ស៊្មីធ ម៉ាកុស ៩:៤០–៤៨ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះប្រៀបប្រដូចទៅនឹងដៃ ជើង និងភ្នែក ដែលបាន « ធ្វើឲ្យវាតចិត្ត » នរណាម្នាក់ ឬមានឥទ្ធិពលលើនរណាម្នាក់ឲ្យធ្វើបាប ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ*ជីវិត*នៅក្នុងការបកប្រែរបស់យ៉ូសែប ស៊្មីធ ម៉ាកុស ៩:៤០–៤១, ៤៣សំដៅទៅលើជីវិតអស់កល្បជានិច្ច ។

- យោងតាមការបកប្រែនេះ តើដៃ ជើង និង ភ្នែកដែលធ្វើឲ្យវាតចិត្តនោះតំណាងឲ្យអ្វី ? (ដៃតំណាងឲ្យសមាជិកគ្រួសារ និង មិត្តភក្តិរបស់យើង ជើងតំណាងឲ្យអស់អ្នកដែលយើងមើលជាគំរូអំពីរបៀបគិត និងធ្វើសកម្មភាព ហើយភ្នែកជាតំណាងឲ្យអ្នកដឹកនាំរបស់យើង) ។

សូមសរសេរដាក់ស្លាកផ្នែកទាំងនេះជាមួយនឹងការបកប្រែរបស់វានៅលើរូបភាព ដែលសិស្សបានគូរនៅលើក្តារខៀន ។

- តើព្រះអង្គសង្គ្រោះបង្រៀនយើងឲ្យធ្វើអ្វីខ្លះជាមួយនឹងឥទ្ធិពលមិនសុចរិត ឬឥទ្ធិពលដែលនាំឲ្យយើងធ្វើបាប ?
- តើការញែកខ្លួនយើងចេញពីឥទ្ធិពលមិនសុចរិត អាចស្រដៀងគ្នាទៅនឹងការកាត់ដៃ ឬជើងចោលតាមរបៀបណា ?
- តើមានអ្វីខ្លះអាចកើតឡើង បើយើងមិនញែកខ្លួនយើងចេញពីឥទ្ធិពលមិនសុចរិត ? ហេតុអ្វី ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ នៅក្នុងខទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **វាប្រសើរជាងដើម្បីញែកខ្លួនយើងចេញពីឥទ្ធិពលមិនសុចរិត ជាជាងយើងត្រូវញែកចេញពីព្រះនៅថ្ងៃចុងក្រោយ ។** ចូរប្រើពាក្យរបស់សិស្ស សរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះដោយអែលឌើរ វ៉ែលធើរ អែហ្វ ហ្គុងស្សាឡែស្ស នៃពួកចិតសិបនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលឥទ្ធិពលផ្សេងៗទៀតដែលយើងគប្បីញែកខ្លួនយើងចេញពីវា ។

« ដូច្នេះ ការកាត់ចេញមិនគ្រាន់តែសំដៅទៅលើមិត្តភក្តិប៉ុណ្ណោះទេ ប៉ុន្តែចំពោះគ្រប់ឥទ្ធិពលអាក្រក់ ដូចជាកម្មវិធីទូរទស្សន៍មិនត្រឹមត្រូវ គេហទំព័រអ៊ិនធើរណិត ខ្សែភាពយន្ត សៀវភៅ ល្បែងវីដេអូ ឬតន្ត្រីជាដើម ។ ការឆ្លាក់នៅក្នុងព្រលឹងរបស់យើងនូវគោលការណ៍នេះនឹងជួយយើងឲ្យទប់ទល់នឹងការល្បួងដែលនាំទៅរកឥទ្ធិពលមិនល្អនានា » (« Today Is the Time »*Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៥៥) ។

ការចាប់យក និង ការរក្សាចំណាប់អារម្មណ៍របស់សិស្សទាំងឡាយ

ដោយសារតែសិស្សមួយចំនួនការផ្តោតអារម្មណ៍របស់ពួកគេមានកំណត់ នោះសូមរកមើលរបៀបនានាដើម្បីទាក់ចំណាប់អារម្មណ៍របស់ពួកគេ និង អារម្មណ៍រីករាយរបស់ពួកគេសារជាថ្មីនៅក្នុងមេរៀន ។ ការណ៍នេះគួរតែត្រូវបានធ្វើឡើងតាមរបៀបមួយដែលទាញយកចំណាប់អារម្មណ៍របស់សិស្សផ្តោតលើបទគម្ពីរ ដែលពួកគេនឹងសិក្សា ។

- តើឧបសគ្គអ្វីខ្លះដែលយើងអាចជួបដោយការញែកយើងចេញពីឥទ្ធិពលមិនសុចរិត ?
- តើយើងអាចដឹងថារបៀបត្រឹមត្រូវ ដើម្បីញែកខ្លួនយើងចេញពីឥទ្ធិពលមិនសុចរិតបានយ៉ាងដូចម្តេច ?

សូមពន្យល់ថា ការញែកខ្លួនយើងចេញពីឥទ្ធិពលមិនសុចរិត ពុំមានន័យថាជាការប្រព្រឹត្តនឹងអ្នកដទៃដោយឈ្លើយ កាត់ទោសអ្នកដទៃ ឬបដិសេធមិនទំនាក់ទំនងនឹងអស់អ្នកដែលមិនមែនជាសមាជិកសាសនាចក្រស្មោះត្រង់នោះទេ ។ ផ្ទុយទៅវិញ យើងគប្បីញែកខ្លួនយើងពីអស់អ្នកដែលនឹងដឹកនាំយើងទៅធ្វើអំពើបាប ឬចៀសវាងពីការប្រាស្រ័យទាក់ទងស្និតស្នាលអស់អ្នកដែលនឹងដឹកនាំយើងទៅធ្វើអំពើបាប ។ ទោះជាយើងពុំអាចដកចេញ ឬចៀសវាងពីគ្រប់ឥទ្ធិពលទាំងអស់ ដែលនាំយើងឲ្យធ្វើបាបក្តី ក៏ព្រះអម្ចាស់នឹងប្រទានពរដល់យើង នៅពេលយើងព្យាយាមញែកខ្លួនយើងចេញពីឥទ្ធិពលអាក្រក់នានា តាមដែលយើងអាច ហើយនៅពេលយើងព្យាយាមអភិវឌ្ឍការលត់ដំខ្លួន ដើម្បីចៀសវាងពីឥទ្ធិពលទាំងឡាយ ដែលយើងមិនអាចដកចេញទាំងស្រុងបាន ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមអំពីសេចក្តីពិតនេះ ចូរអញ្ជើញសិស្សពីរនាក់ឲ្យឡើងមកខាងមុខក្តារខៀន ។ សូមណែនាំសិស្សម្នាក់ៗឲ្យអានឮៗនូវស្ថានភាពមួយដូចខាងក្រោម ហើយសួរសំណួរពាក់ព័ន្ធជាមួយនោះទៅដល់សិស្សក្នុងថ្នាក់ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឆ្លើយតបចំពោះសំណួរ ដោយផ្អែកទៅលើសេចក្តីពិតដែលបានប្រាប់នៅក្នុងម៉ាកុស ៩:៤៣–៤៨។

ស្ថានភាពទី ១ ។ ខ្ញុំមានមិត្តដែលលើកទឹកចិត្តខ្ញុំជារឿយៗ ឲ្យចូលរួមនៅក្នុងសកម្មភាពដែលមិនគោរពបទបញ្ញត្តិរបស់ព្រះ ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថា ខ្ញុំអាចមានឥទ្ធិពលល្អចំពោះពួកគេ បើខ្ញុំបន្តចំណាយពេលនៅជាមួយពួកគេ ។

- តើខ្ញុំនឹងមិនបាត់បង់លទ្ធភាពរបស់ខ្ញុំ ដើម្បីមានឥទ្ធិពលល្អលើមិត្តភក្តិទាំងឡាយទេឬ បើខ្ញុំញែកខ្លួនខ្ញុំពីពួកគេនោះ ? តើខ្ញុំគួរមានទំនាក់ទំនងប្រភេទណា ជាមួយពួកគេ?
- តើខ្ញុំគួរនិយាយ ហើយធ្វើអ្វីខ្លះ ដើម្បីញែកខ្លួនខ្ញុំពីមិត្តទាំងនោះដោយសមរម្យ ?

ស្ថានភាពទី ២ ។ ខ្ញុំចូលចិត្តក្រុមភ្លេងដ៏ល្បីមួយអស់ជាច្រើនឆ្នាំ ។ នៅក្នុងចម្រៀងតន្ត្រី និង ការសម្ភាសថ្មីៗមួយចំនួនរបស់ពួកគេ ពួកគេបានលើកទឹកចិត្តដល់ឥរិយាបថ និង គំនិតដែលផ្ទុយពីបទដ្ឋាន និង ការបង្រៀនរបស់ព្រះអម្ចាស់ ។

- តើវាគ្រាន់តែជាចម្រៀង និងទំនុកច្រៀងប៉ុណ្ណោះ មែនទេ ? ដូច្នេះតើវាមានគ្រោះថ្នាក់អ្វី ពេលបន្តស្តាប់ចម្រៀងរបស់ពួកគេ ហើយធ្វើតាមពួកគេនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមនោះ ?

សូមអរគុណអ្នកស្ម័គ្រចិត្តសម្រាប់ជំនួយរបស់ពួកគេ ហើយសូមអញ្ជើញពួកគេឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយរបស់ពួកគេវិញ ។ សូមសួរសិស្ស ៖

- ទោះជាការញែកខ្លួនយើងចេញពីឥទ្ធិពលទាំងឡាយ ដែលដឹកនាំយើងឲ្យធ្វើ អំពើបាប ដែលពេលខ្លះ អាចនឹងពិបាកធ្វើក្តី តើយើងអាចទទួលបានអ្វីខ្លះតាមរយៈការពលិកម្មនេះ ? (ពរជ័យជាច្រើន រួមមានទាំងជីវិតអស់កល្បជានិច្ច) ។ ហេតុអ្វីក៏រង្វាន់នេះមានតម្លៃចំពោះការពលិកម្មនានា ?
- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានជ្រើសរើសញែកខ្លួនចេញពីឥទ្ធិពលមិនសុចរិតនៅពេលណា ? (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។ តើមានការលំបាកអ្វីខ្លះចំពោះការញែកខ្លួនចេញពីឥទ្ធិពលនោះ ? តើពរជ័យអ្វីខ្លះអាចកើតមានមកពីការធ្វើដូច្នោះ ?

ចូរសុំសិស្សឲ្យពិចារណាថាតើមានឥទ្ធិពលអ្វីខ្លះ នៅក្នុងជីវិតរបស់ពួកគេដែលអាចនឹងនាំពួកគេឲ្យធ្វើបាប ។ សូមអញ្ជើញពួកគេឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបដែលពួកគេនឹងញែកខ្លួនចេញពីឥទ្ធិពលទាំងនេះ ។

សូមសង្ខេបម៉ាកុស ៩:៤៩–៥០ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានណែនាំដល់ពួកសិស្សរបស់ទ្រង់ឲ្យមានទំនាក់ទំនងសុខសាន្តជាមួយគ្នាទៅវិញទៅមក ។

សូមបញ្ចប់ដោយការលើកទឹកចិត្តដល់សិស្សឲ្យធ្វើសកម្មភាពតាមការបំផុសគំនិតនានា ដែលពួកគេបានទទួលក្នុងមេរៀននេះ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាកុស ៩:៣១ ។ « កូនមនុស្ស »

« កូនមនុស្ស » គឺជា « នាមមួយទៀតដែលព្រះយេស៊ូវបានប្រើនៅពេលទ្រង់មានបន្ទូលអំពីព្រះអង្គទ្រង់ (លូកា ៩:២២,២១:៣៦) ។ វាមានន័យថា កូនមនុស្សនៃបរិសុទ្ធភាព ។ បុរសនៃបរិសុទ្ធភាព គឺជាព្រះនាមមួយនៃព្រះជាព្រះវរបិតា ។ នៅពេលព្រះយេស៊ូវបានហៅព្រះអង្គទ្រង់ថាជា កូនមនុស្ស វាគឺជាការប្រកាសដោយឥតលាក់លាមអំពីទំនាក់ទំងដ៏ទេវភាពរបស់ទ្រង់ជាមួយនឹងព្រះបិតា ។ នាមនេះ ត្រូវបានរកឃើញជាញឹកញាប់នៅក្នុងដំណឹងល្អ ។ វិវរណៈថ្ងៃចុងក្រោយ បញ្ជាក់អំពីអត្ថន័យពិសេស និង ភាពពិសិដ្ឋនៃព្រះនាមរបស់ព្រះអង្គសង្គ្រោះ (គ និង ស ៤៥:៣៩,៤៩:៦, ២២,៥៨:៦៥,ម៉ូសេ ៦:៥៧) » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ« កូនមនុស្ស »*scriptures.lds.org*) ។

មេរៀនសិក្សានៅផ្ទះ

ម៉ាថាយ ៤–៩ (មេរៀនទី ៨)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់សិស្ស ដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ាកុស ៤–៩ (មេរៀនទី ៨) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាកុស ៤–៥)

សិស្សបានរៀនថា ប្រសិនបើយើងស្វែងរកជំនួយរបស់ព្រះអម្ចាស់ នៅគ្រាមានបញ្ហា ឬភ័យខ្លាច នោះទ្រង់អាចនាំសេចក្តីសុខសាន្តកើតមានមកដល់យើង ។ ពួកគេក៏បានរៀនផងដែរថា នៅពេលយើងមានបទពិសោធន៍ព្រះចេស្តារបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង នោះយើងអាចថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃអំពីពរជ័យ និងក្តីមេត្តាករុណារបស់ទ្រង់ ។ ចេញមកពីរឿងនៃកូនស្រីរបស់ជៃរ៉ុស និងស្ត្រីដែលមានធ្លាក់ឈាម នោះសិស្សបានរៀនថា ប្រសិនបើយើងបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ តាមរយៈកិច្ចខិតខំរបស់យើង ដើម្បីមករកទ្រង់ នោះទ្រង់អាចធ្វើឲ្យយើងបានជាសះស្បើយ ហើយថាការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ តម្រូវឲ្យយើងបន្តជឿលើទ្រង់ ទោះជានៅក្នុងគ្រាពុំពិតប្រាកដក្តី ។

ថ្ងៃទី ២ (ម៉ាកុស ៦–៨)

ចេញមកពីអត្ថហេតុនៃការប្រទានចំណីអាហារដល់មនុស្ស ៥០០០ នាក់ នោះសិស្សអាចរៀនថា នៅពេលយើងថ្វាយព្រះអង្គសង្គ្រោះអ្វីៗទាំងអស់ដែលយើងមាន នោះទ្រង់អាចតម្កើងការថ្វាយរបស់យើង ឲ្យសម្រេចតាមព្រះរាជបំណងទ្រង់ ។ សិស្សក៏រៀនផងដែរថា យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដោយការដឹងអំពីតម្រូវការរបស់អ្នកដទៃ រួចហើយជួយបំពេញតម្រូវការទាំងនោះ ។

ថ្ងៃទី ៣ (ម៉ាកុស ៩: ១–២៩)

ចេញមកពីដំណើររឿងរបស់ព្រះយេស៊ូវ បណ្តេញវិញ្ញាណអសោចចេញពីក្មេងប្រុសម្នាក់ នោះសិស្សអាចរៀនថា ប្រសិនបើយើងជឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះអ្វីៗគ្រប់បែបយ៉ាងអាចទៅរួចសម្រាប់យើង ។ គោលការណ៍ផ្សេងទៀតមកពីមេរៀននេះ រួមមានដូចខាងក្រោម ៖ ប្រសិនបើយើងកាន់ជាប់នូវអ្វីដែលយើងជឿ ហើយស្វែងរកជំនួយរបស់ព្រះអម្ចាស់ នោះទ្រង់នឹងជួយយើងពង្រឹងសេចក្តីជំនឿរបស់យើង ។ យើងអាចបង្កើនសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ តាមរយៈការអធិស្ឋាន និងការតមអាហារ ។

ថ្ងៃទី ៤ (ម៉ាកុស ៩:៣០–៥០)

នៅពេលសិស្សបានសិក្សាម៉ាកុស ៩:៣០–៥០ ពួកគេបានរៀនថា ប្រសិនបើយើងមានឥទ្ធិពលលើអ្នក ដែលជឿលើព្រះយេស៊ូវគ្រីស្ទឲ្យធ្វើអំពើបាប នោះយើងនឹងទទួលខុសត្រូវនៅចំពោះមុខព្រះ ។ ចេញមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរទាំងនេះ នោះសិស្សបានរៀនថា វាល្អប្រសើរ ដើម្បីញែកខ្លួនយើងពីឥទ្ធិពលមិនសុចរិត ជាជាងយើងត្រូវបានបំបែកចេញពីព្រះនៅទីបំផុតនោះ ។

សេចក្តីផ្តើម

មេរៀននេះ អាចជួយសិស្សឲ្យយល់ថា ការព្យាយាមដើម្បីផ្គាប់ចិត្តអ្នកដទៃជាជាងឲ្យការធ្វើនូវអ្វីដែលយើងដឹងថាត្រឹមត្រូវ អាចនាំទៅរកការជ្រើសរើសខុសឆ្គង ការសោកស្តាយ និងវិប្បដិសារី ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ៦:១–២៩

ព្រះយេស៊ូវត្រូវបានគេបដិសេធនៅស្រុកណាសារ៉ែត ហើយបានបញ្ជូនពួកដប់ពីរនាក់ឲ្យចេញទៅផ្សព្វផ្សាយ ការស្លាប់របស់យ៉ូហាន បាទីស្ទត្រូវបានដំណាលប្រាប់

សូមចាប់ផ្តើមថ្នាក់រៀនដោយការអញ្ជើញសិស្ស ឲ្យគិតអំពីគ្រាពីមុន ដែលពួកគេមានអារម្មណ៍ថាក្រោមសម្ពាធក្នុងការធ្វើអ្វីមួយ ដែលពួកគេដឹងថាវាពុំត្រឹមត្រូវ ។

សូមសរសេរនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម នៅលើក្តារខៀន (សេចក្តីថ្លែងការណ៍នេះត្រូវបានកេរឃើញនៅក្នុង« *Making the Right Choices* » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៣៧) ។

> *« បុគ្គលម្នាក់ៗដែលធ្វើខុស ចង់ឲ្យអ្នកចូលរួមនឹងពួកគេ ដោយសារពួកគេនឹងមានអារម្មណ៍កាន់តែសុខស្រួលចំពោះអ្វីដែលគេកំពុងតែធ្វើនោះ ព្រោះមានអ្នកដទៃធ្វើវាដែរ »* (*អែលឌើរ រីឆាត ជី ស្កត*) ។

- តើមានឧទាហរណ៍ណាខ្លះអំពីរបៀប ដែលអ្នកដទៃអាចនឹងព្យាយាមដាក់សម្ពាធមកលើអ្នកឲ្យធ្វើអ្វីមួយ ដែលអ្នកដឹងថាវាខុសឆ្គង ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាម៉ាកុស ៦ដែលអាចជួយពួកគេចៀសវាងពីការចុះញ៉ូមនឹងសម្ពាធអវិជ្ជមានរបស់មិត្តភក្តិ ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាកុស ៦:១៧–១៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលហេរ៉ូឌបានធ្វើចំពោះយ៉ូហាន បាទីស្ទ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- តើហេរ៉ូឌបានធ្វើអ្វីខ្លះដល់យ៉ូហាន ហើយហេតុអ្វី ?

ហេរ៉ូឌ បានលែងលះមហេសីរបស់ទ្រង់ ហើយបានរៀបការនឹងហេរ៉ូឌាស ជាមហេសីរបស់អនុជទ្រង់ គឺភីលីព ។ ទង្វើនេះគឺជាការល្មើសនឹងច្បាប់របស់សាសន៍យូដាយ៉ាងជាក់ច្បាស់ (សូមមើលលេវីនិយម ១៨:១៦) ហើយយ៉ូហាន បាទីស្ទបានដាក់បណ្តាសារ ។ ការជំទាស់របស់យ៉ូហានចំពោះការរៀបការនេះ បានធ្វើឲ្យហេរ៉ូឌាសខ្ញាល់ជាខ្លាំង ដូច្នេះហេរ៉ូឌបានចាប់យ៉ូហានដាក់គុក ដើម្បីឲ្យស្កប់ចិត្តនាង ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាកុស ៦:១៩–២០ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលហេរ៉ូឌាសបានធ្វើចំពោះយ៉ូហាន បាទីស្ទ ។

- តើហេរ៉ូឌាសចង់ធ្វើអ្វីខ្លះចំពោះយ៉ូហាន បាទីស្ទ ?
- ហេតុអ្វីក៏នាងមិនអាចសម្លាប់គាត់បាន ? (ដោយសារតែហេរ៉ូឌខ្លាចយ៉ូហាន ហើយបានដឹងថាគាត់ជាមនុស្សរបស់ព្រះ) ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាឲ្យអានឮៗនៅក្នុង ម៉ាកុស ៦:២១–២៩ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវអ្វីដែលហេរ៉ូឌបានធ្វើចំពោះយ៉ូហាន បាទីស្ទ ។

- យោងតាមខ ២៦តើហេរ៉ូឌមានអារម្មណ៍យ៉ាងណា អំពីការសម្លាប់យ៉ូហាន បាទីស្ទ ?
- ហេតុអ្វីក៏ហេរ៉ូឌត្រូវកាត់ក្បាលយ៉ូហាន បើទ្រង់ដឹងថាទង្វើនេះខុស ហើយពុំចង់ធ្វើវាផងនោះ ? (ហេរ៉ូឌមានកង្វល់អំពីមតិរបស់អ្នកទាំងឡាយដែលជាភ្ញៀវនៅជាមួយទ្រង់) ។
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការជ្រើសរើសរបស់ហេរ៉ូឌអំពីអ្វីដែលបានកើតឡើង នៅពេលយើងព្យាយាមផ្គាប់ចិត្តអ្នកដទៃ ជំនួសឲ្យធ្វើនូវអ្វីដែលត្រឹមត្រូវនោះ ?

(សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគួរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ការព្យាយាមដើម្បីផ្គាប់ចិត្តអ្នកដទៃ ជាជាងការធ្វើនូវអ្វីដែលយើងដឹងថាត្រឹមត្រូវ អាចនាំទៅរកការជ្រើសរើសខុសឆ្គង ការសោកស្តាយ និងវិប្បដិសារី**)។

ដើម្បីជួយសិស្សយល់បន្ថែមទៀតអំពីសេចក្តីពិតនេះ សូមចាត់ពួកគេជាក្រុមដែលមានគ្នាពីរទៅបួននាក់ក្នុងមួយក្រុម ហើយសុំឲ្យពួកគេប្រាប់នូវឧទាហរណ៍អំពីស្ថានភាពជាច្រើន ដែលយុវវ័យត្រូវតែជ្រើសរើស រវាងការព្យាយាមដើម្បីផ្គាប់ចិត្តអ្នកដទៃ និងការធ្វើអ្វីដែលពួកគេដឹងថាត្រឹមត្រូវ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យក្រុមនិមួយៗឲ្យរាយការណ៍ ។ នៅពេលពួកគេរាយការណ៍ ចូរសរសេរឧទាហរណ៍មួយចំនួនរបស់ពួកគេនៅលើក្តារខៀន ។

- តើអ្នកធ្លាប់ឃើញថាការចុះញ៊ែមចំពោះសម្ពាធទាំងឡាយដូចនៅក្នុងឧទាហរណ៍ទាំងនេះ នាំមកនូវការសោកស្តាយ និងវិប្បដិសារីតាមរបៀបណាខ្លះ ?
- តើអ្នកធ្លាប់បានឃើញនរណាម្នាក់ជ្រើសរើសធ្វើនូវអ្វី ដែលត្រឹមត្រូវជំនួសឲ្យការព្យាយាមផ្គាប់ចិត្តដល់អ្នកដទៃ នៅពេលណា ?
- តើអ្វីខ្លះអាចជួយយើងឲ្យជ្រើសរើសធ្វើអ្វី ដែលយើងដឹងថាត្រឹមត្រូវ ជំនួសឲ្យការព្យាយាមផ្គាប់ចិត្តអ្នកដទៃ ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយប្រធាន ស្ពែនសើរ ដប់លយ៉ូ ឃីមប៊ឹល អំពីការធ្វើការសម្រេចចិត្តត្រឹមត្រូវ ៖



« ការសម្រេចចិត្តត្រឹមត្រូវ គឺងាយធ្វើណាស់ នៅពេលយើងធ្វើវាទុកជាមុនយ៉ាងយូរមកហើយនោះ . . . ការណ៍នេះវាជួយមិនឲ្យមាននូវការឈឺចាប់នៅពេលត្រូវសម្រេចចិត្ត [ពេលធ្វើការសម្រេចចិត្ត] ពេលយើងធុញទ្រាន់ ឬត្រូវល្បួងយ៉ាងខ្លាំងនោះ » (*Teachings of Presidents of the Church: Spencer W. Kimball* [ឆ្នាំ ២០០៦] ទំព័រ ១០៨)។

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីសប្តាហ៍ក្រោយ ហើយប្រាប់អំពីស្ថានភាពដែលអាចកើតមាន ដែលពួកគេអាចនឹងចាំបាច់ត្រូវជ្រើសរើសរវាងការផ្គាប់ចិត្តអ្នកដទៃ និងការធ្វើអ្វីដែលត្រឹមត្រូវ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់ផែនការអំពីរបៀបដែលពួកគេនឹងតបតចំពោះសម្ពាធនេះ ខណៈពេលដែលពួកគេនឹងជួបប្រទះនោះ ។

ចូរពន្យល់ថា នៅពេលហេរ៉ូឌស្តាប់ឮអំពីអព្ភូតហេតុជាច្រើន ដែលព្រះយេស៊ូវបានធ្វើនៅស្រុកកាលីឡេ នោះទ្រង់ភ័យខ្លាចថាយ៉ូហាន បាទីស្មបានរស់ឡើងវិញពីស្លាប់ ហើយធ្វើអព្ភូតហេតុទាំងនេះ (សូមមើល ម៉ាកុស ៦:១៤–១៦) ។

ម៉ាកុស ៧–៨


ព្រះយេស៊ូវបានព្យាបាលមនុស្សពីរនាក់ ហើយបង្រៀនដល់ពួកសិស្សរបស់ទ្រង់

ចូរពន្យល់ថាម៉ាកុស ៧–៨មាននូវដំណើររឿងចំនួនពីរអំពីព្រះអង្គសង្គ្រោះព្យាបាលនរណាម្នាក់ ។ សូមចែកសិស្សជាគូៗ ។ សូមចាត់សិស្សម្នាក់នៅក្នុងក្រុមនីមួយៗឲ្យអានម៉ាកុស ៧:៣១–៣៥ ហើយសិស្សម្នាក់ទៀតអានម៉ាកុស ៨:២២–២៥ ។ បន្ទាប់មកអញ្ជើញសិស្សឲ្យពិពណ៌នាទៅដៃគូរបស់ពួកគេអំពីអព្ភូតហេតុនៃការព្យាបាល នៅក្នុងខគម្ពីរទាំងឡាយដែលពួកគេអាននោះ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យពន្យល់អំពីរបៀប ដែលព្រះអង្គសង្គ្រោះយាងទៅធ្វើការព្យាបាលដល់មនុស្សទាំងពីរបូននេះ ។

- តើមេរៀនអ្វីខ្លះដែលយើងអាចរៀនមកពីភាពពិត ដែលបុរសខ្វាក់ពុំបានជាទាំងស្រុងនៅលើកដំបូង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរប្រ៊ូស អ័រ ម៉ាក់ខនឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សផ្សេងតាម ហើយស្តាប់មើលនូវមូលហេតុនានាដែលព្រះយេស៊ូវអាចនឹងបានព្យាបាលបុរសនោះបន្តិចម្តងៗ ឬនៅក្នុងដំណាក់ការផ្សេងៗ ។



« អព្ភូតហេតុនេះគឺខុសពីគេ វាត្រូវបានកត់ត្រាតែក្នុងគ្រាដែលព្រះយេស៊ូវបានព្យាបាលបុរសម្នាក់បន្តិចម្តងៗ ។ វាអាចថា ព្រះអម្ចាស់របស់យើងបានធ្វើតាមរបៀបនេះ ដើម្បីពង្រឹងសេចក្តីជំនឿដែលទន់ខ្សោយតែកំពុងតែរីកចម្រើនរបស់បុរសខ្វាក់ភ្នែកនោះ ។ វានឹងបង្ហាញឲ្យឃើញថា គំរូនៃហេតុការណ៍ជាលំដាប់លំដោយ នៃការការប៉ះព្រះកាយជាមួយនឹងព្រះយេស៊ូវមានឥទ្ធិពលបន្ថែមជាសេចក្តីសង្ឃឹម ការអះអាង និងសេចក្តីជំនឿទៅដល់បុរសខ្វាក់ភ្នែក ។ ព្រះយេស៊ូវផ្ទាល់ (១) បានដឹកដៃរបស់បុរសខ្វាក់ចេញពីក្រុង (២) បានដាក់ទឹកមាត់របស់ទ្រង់ផ្ទាល់ទៅលើភ្នែករបស់បុរសខ្វាក់នោះ (៣) បានធ្វើពិធីបរិសុទ្ធនៃការដាក់ដៃលើ ហើយ (៤) បានដាក់ព្រះហស្តរបស់ទ្រង់ជាលើកទីពីរនៅលើភ្នែករបស់បុរសនោះ ។

« ប្រាកដណាស់ របៀបដែលការព្យាបាលនេះធ្វើឡើង បង្រៀនថាមនុស្សគប្បីស្វែងរកព្រះគុណព្យាបាលរបស់ព្រះអម្ចាស់ដោយអស់ពីកម្លាំង និងអស់ពីសេចក្តីជំនឿរបស់ពួកគេ ដ្បិតរឿងដូច្នេះគឺគ្រប់គ្រាន់លួមសម្រាប់តែការព្យាបាលខ្លះៗប៉ុណ្ណោះ បន្ទាប់ពីទទួលបានការណ៍ដូច្នោះហើយ ទោះជាយ៉ាងណាក៏ដោយ ពួកគេនឹងប្រហែលជាអាចទទួលបាននូវការអះអាង និងសេចក្តីជំនឿបន្ថែមនៅពេលនោះ ដើម្បីធ្វើឲ្យជាសះស្បើយ និងបានល្អគ្រប់ផ្នែក ។ ជាញឹកញាប់មនុស្សក៏ត្រូវបានព្យាបាលពីជំងឺខាងវិញ្ញាណរបស់ពួកគេតាមកម្រិត មួយដំណាក់កាលម្តងៗផងដែរ នៅពេលពួកគេរៀបចំជីវិតរបស់ពួកគេឲ្យស្របទៅតាមផែនការ និងគោលបំណងរបស់ព្រះ » (*Doctrinal New Testament Commentary* ដែលទី ៣ [ឆ្នាំ ១៩៦៥–៧៣] ១:៣៧៩–៨០) ។

- តើការត្រូវបានព្យាបាលបន្តិចម្តងៗ បង្កើនសេចក្តីជំនឿបន្តិចម្តងៗរបស់នរណាម្នាក់ទៅលើព្រះយេស៊ូវគ្រីស្តយ៉ាងដូចម្តេច ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីយល់ថា ពរជ័យមួយចំនួនដូចជាការទទួលបានទីបន្ទាល់នៃជំណឹងល្អ ឬការទទួលបានការព្យាបាលខាងរូបកាយ ឬខាងវិញ្ញាណ ជាញឹកញាប់កើតមានបន្តិចម្តងៗ ឬមួយដំណាក់កាលម្តងៗជាជាងក្នុងពេលភ្លាមៗ ឬទាំងស្រុងដូច្នេះ ?

សូមសង្កេតម៉ាកុស ៨:២៧–២៨ដោយពន្យល់ថា ព្រះយេស៊ូវបានសួរដល់ពួកសិស្សរបស់ទ្រង់ថា តើអ្នកដទៃបាននិយាយថាទ្រង់ជានរណា ។ ពួកគេបានតបថា អ្នកខ្លះនិយាយថា ទ្រង់គឺជាយ៉ូហាន បាទីស្ម ឬព្យាការីផ្សេងទៀត ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ៨:២៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលនូវអ្វី ដែលពេត្រុសបានប្រកាសអំពីព្រះយេស៊ូវ ។

- តើពេត្រុសនិយាយថា ព្រះយេស៊ូវជានរណា ? (ពាក្យ*ព្រះគ្រីស្ទ*ជាភាសាក្រិកស្មើនឹង៣ក្យថា*ព្រះមេស៊ី*)។

សូមសង្កេតម៉ាកុស ៨:៣០–៣១ ដោយពន្យល់ថា ព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សថា ទ្រង់នឹងត្រូវបានពួកសាសន៍យូដាបដិសេធ និងសម្លាប់ ។ សូមអញ្ជើញសិស្សម្នាក់អានម៉ាកុស ៨:៣២–៣៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀប ដែលពេត្រុសបានមានប្រតិកម្មចំពោះដំណឹងនេះ ។

ចូរពន្យល់ថា ដោយសារតែការរំពឹងទុករបស់ប្រជាជនសាសន៍យូដាអំពីព្រះមែស៊ីដ៏មានជ័យជំនះដូច្នេះវាពិបាកចំពោះពេត្រុស ក៏ដូចជាពួកសាសន៍យូដាជាច្រើនទៀតនាពេលនោះដើម្បីយល់ហើយទទួលយកគំនិតអំពីព្រះមែស៊ី ដែលនឹងរងទុក្ខ ហើយត្រូវសុគតនោះ។

- តើពេត្រុសដូចជាមនុស្សខ្លាក់ដែលពិពណ៌នានៅក្នុងម៉ាកុស ៨:២២–២៥យ៉ាងដូចម្តេច ? (ពេត្រុសបាន « មើលឃើញ » សេចក្តីពិតបន្តិចម្តងៗ ។ គាត់មានជំនឿទៅលើព្រះអង្គសង្គ្រោះ ប៉ុន្តែការយល់ដឹងរបស់គាត់អំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះ បានអភិវឌ្ឍមួយដំហានម្តងៗ) ។
- តើព្រះអម្ចាស់បានជួយអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ឲ្យមើលឃើញសេចក្តីពិតកាន់តែច្បាស់បន្តិចម្តងៗយ៉ាងដូចម្តេច ?

សូមបញ្ចប់មេរៀនថ្ងៃនេះដោយការអញ្ជើញសិស្សឲ្យអានម៉ាកុស ៨:៣៤–៣៨ដោយស្ងាត់ស្ងៀមហើយពិចារណាថាតើមេរៀនថ្ងៃនេះ អាចជួយពួកគេឲ្យដាក់ព្រះអម្ចាស់ជាមុន នៅក្នុងជីវិតរបស់ពួកគេយ៉ាងដូចម្តេច ។

មេរៀនបន្ទាប់ (ម៉ាកុស ១០–លូកា ៤)

ចូរពន្យល់ថា សិស្សនឹងបញ្ចប់ការសិក្សាជំណឹងល្អរបស់ម៉ាកុស ហើយចាប់ផ្តើមសិក្សាការសរសេររបស់លូកា ។ សូមអញ្ជើញពួកគេឲ្យរកមើលនូវរឿងលម្អិតថ្មី នៅពេលពួកគេអានម្តងទៀតអំពីព្រឹត្តិការណ៍ចុងក្រោយនៃជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ហើយគូសចំណាំនូវការនិយាយចំអកដែលមានចំពោះព្រះយេស៊ូវ ខណៈដែលទ្រង់ជាប់នៅលើឈើឆ្កាង ។ នៅក្នុងជំណឹងល្អរបស់លូកា ពួកគេនឹងអានដំណូកដ៏ល្បីបំផុតមួយនៅក្នុងគម្ពីរបឺប—លូកា ២—និងដំណើររឿងអំពីអ្នកស្រុកដុនដាបយ៉ាងខ្លាំង ពួកបំបរបង់ និងអ្នកមានបាបទាំងឡាយ ។

មេរៀន ៤១

ម៉ាកុស ១០

សេចក្តីផ្តើម

នៅជិតចុងបញ្ចប់នៃការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះអង្គសង្គ្រោះបានបម្រើទៅដល់អ្នកទាំងឡាយដែលនៅស្រុកពេរៀ ។ ខណៈនៅទីនោះ ទ្រង់បានបង្រៀនអំពីគោលលទ្ធិនៃអាពាហ៍ពិពាហ៍ ហើយបានហៅកុមារតូចៗមករកទ្រង់ ។ ព្រះអង្គសង្គ្រោះក៏បានជាស់គឿនដល់កម្លោះអ្នកមានម្នាក់ ឲ្យលក់ទ្រព្យសម្បត្តិទាំងអស់ដែលគាត់មាន ហើយដើរតាមទ្រង់ ។ នៅពេលព្រះអង្គសង្គ្រោះបានយាងចេញពីស្រុកពេរៀ ហើយទ្រង់បានយាងធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ជាលើកចុងក្រោយនៅក្នុងជីវិតរមែងស្លាប់ នោះទ្រង់បានមានបន្ទូលប្រាប់ទុកជាមុនអំពីការសុគត និង ការរស់ឡើងវិញរបស់ទ្រង់ ហើយបានទូន្មានដល់ពួកសាវករបស់ទ្រង់ឲ្យបម្រើអ្នកដទៃ ។ ទ្រង់ក៏បានព្យាបាលដល់បុរសខ្វាក់ភ្នែកនៅទីក្រុងយេរីខូផងដែរ ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ១០:១–១៦

ព្រះយេស៊ូវបង្រៀនអំពីគោលលទ្ធិ នៃអាពាហ៍ពិពាហ៍ ហើយហៅកុមារតូចៗមករកទ្រង់ ។

សូមបង្ហាញរូបភាពមួយចំនួនអំពីកុមារតូចៗទៅដល់សិស្ស ។

- តើគុណសម្បត្តិ ឬចរិតលក្ខណៈអ្វីខ្លះដែលអ្នកកោតសរសើរចំពោះបងប្អូនប្រុសស្រីវ័យក្មេងរបស់អ្នក ឬកុមារតូចៗផ្សេងទៀតដែលអ្នកស្គាល់ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាម៉ាកុស ១០:១–១៦ ដែលបង្រៀនយើងពីមូលហេតុដែលយើងគប្បីប្រែក្លាយដូចជាកុមារតូចៗ ។

សូមពន្យល់ថា នៅជិតចុងបញ្ចប់នៃការងារបម្រើរបស់ព្រះអង្គសង្គ្រោះ ទ្រង់បានយាងចេញពីស្រុកកាលីឡេ ហើយយាងទៅតំបន់មួយដែលហៅថា ស្រុកពេរៀ ។ (អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យរកមើលស្រុកពេរៀ នៅលើឯកសារចែកឲ្យ« ជីវប្រវត្តិដ៏សំខាន់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរមែងស្លាប់ » | សូមមើល មេរៀនទី ៥ | ឬផែនទី និងរូបថតទាំងឡាយអំពីព្រះគម្ពីរបឺប លេខ ១១, « ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរសញ្ញាថ្មី ») ។ សូមសង្កេបម៉ាកុស ១០:១–១២ ដោយពន្យល់ថា ខណៈដែលនៅក្នុងស្រុកពេរៀ នោះព្រះអង្គសង្គ្រោះបានបង្រៀនដល់ប្រជាជនអំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ១០: ១៣– ១៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលបានកើតឡើង ខណៈដែលព្រះអង្គសង្គ្រោះគង់នៅស្រុក ពេរៀ ។

- តើពួកសិស្សមានប្រតិកម្មយ៉ាងណា នៅពេលប្រជាជនបាននាំកុមារតូចៗមករកព្រះអង្គសង្គ្រោះ ? (សូមពន្យល់ថា ពាក្យ*ស្តីបន្ទោស*នៅក្នុងខទី ១៣ចង្អុលបង្ហាញថា ពួកសិស្សបានប្រាប់ដល់ប្រជាជនថា ពួកគេធ្វើខុសដែលនាំកូនមករកព្រះអង្គសង្គ្រោះ) ។
- តើព្រះអង្គសង្គ្រោះបានឆ្លើយតបទៅពួកសិស្សយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ១០:១៥–១៦ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ នៅពេលក្មេងតូចៗមករកទ្រង់ ។ សូមពន្យល់ថា ឃ្លា « ទទួលនគរព្រះ » នៅក្នុងខទី ១៥សំដៅទៅលើការទទួលដំណឹងល្អ ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីទទួលដំណឹងល្អ « ដូចកូនក្មេងមួយនេះ » ? (ខទី ១៥) ។ (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ហើយប្រៀបធៀបវានឹងចំណុចដែលបានសរសេរនៅលើក្តារខៀនហើយនោះ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីខគម្ពីរទាំងនេះ អំពីអ្វីដែលនឹងកើតឡើង នៅពេលយើងទទួលដំណឹងល្អដូចជាកូនក្មេងតូចៗនោះ ? (សិស្សអាចនឹងប្រាប់ពីសេចក្តីពិតជាច្រើន ប៉ុន្តែត្រូវប្រាកដដើម្បីបញ្ជាក់ថា**នៅពេលយើងទទួលដំណឹងល្អដូចជាកុមារតូចៗ នោះយើងនឹងបានរៀបចំខ្លួនចូលក្នុងនគរព្រះ**) ។
- តើការទទួលដំណឹងល្អដូចជាកុមារតូចៗ ជួយរៀបចំខ្លួនយើងឲ្យចូលទៅក្នុងនគររបស់ព្រះតាមរបៀបណាខ្លះ ? (ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកអាចឲ្យពួកគេអាន ម៉ូសាយ ៣:១៩) ។

ម៉ាកុស ១០:១៧–៣៤

ព្រះអង្គសង្គ្រោះក៏បានជាស់តឿនដល់កម្លោះអ្នកមានម្នាក់ឲ្យលក់ទ្រព្យសម្បត្តិទាំងអស់ដែលគាត់មាន ហើយដើរតាមទ្រង់

សូមអញ្ជើញសិស្សម្នាក់ឲ្យអានម៉ាកុស ១០:១៧–២០ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថាតើមានអ្វីខ្លះបានកើតឡើង បន្ទាប់ពីព្រះអង្គសង្គ្រោះបានប្រទានពរដល់កុមារតូចៗ ។

- តើអ្នកនឹងពិពណ៌នាអំពីបុរសដែលមករកព្រះយេស៊ូវយ៉ាងដូចម្តេច ? ហេតុអ្វី ?
- តើកម្លោះនោះបានទូលសួរអ្វីដល់ព្រះអង្គសង្គ្រោះ ? តើព្រះយេស៊ូវបានឆ្លើយតបដោយរបៀបណា ?

សូមពន្យល់ថាម៉ាថាយ ១៩ក៏មានខ្លឹមសំណើររឿងអំពីកម្លោះម្នាក់នេះមករកព្រះអង្គសង្គ្រោះដែរ ។ សូមអញ្ជើញសិស្សម្នាក់អានម៉ាថាយ ១៩:២០ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថាតើបុរសនោះបានឆ្លើយតបយ៉ាងដូចម្តេច បន្ទាប់ពីព្រះអង្គសង្គ្រោះបានរៀបរាប់អំពីបទបញ្ញត្តិមួយចំនួន ។

- បន្ទាប់ពីបានទទួលស្គាល់ថា គាត់បានរក្សាបទបញ្ញត្តិទាំងអស់ តើសំណួរអ្វីខ្លះដែលកម្លោះនោះបានទូលសួរដល់ព្រះអង្គសង្គ្រោះ ? (អ្នកគួរណែនាំសិស្សឲ្យគូសចំណាំសំណួររបស់កម្លោះនោះ) ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀន ៖ *តើខ្ញុំនៅខ្វះអ្វីទៀត ?*

សូមអញ្ជើញសិស្សអានម៉ាកុស ១០:២១ដោយស្ងាត់ស្ងៀម ហើយរកមើលថាតើព្រះអង្គសង្គ្រោះឆ្លើយតបចំពោះកម្លោះនេះដូចម្តេច ។

- តើព្រះអង្គសង្គ្រោះបានប្រាប់ដល់កម្លោះនោះថាគាត់នៅខ្វះអ្វីខ្លះ ?

សូមចង្អុលបង្ហាញឃ្លា « ព្រះយេស៊ូវទ្រង់ទតទៅគាត់ ដោយស្រឡាញ់ » នៅក្នុង ខទី២១ ។ អ្នកគួរណែនាំសិស្សឲ្យគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីដឹងថា ព្រះយេស៊ូវស្រឡាញ់កម្លោះម្នាក់នេះ មុនពេលទ្រង់ប្រាប់ថាគាត់នៅខ្វះអ្វីទៀតនោះ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីដំណើររឿងនេះ ? (សិស្សអាចរកឃើញគោលការណ៍មួយចំនួន រួមទាំងគោលការណ៍ដូចខាងក្រោមផងដែរ ៖ **ដោយសារទ្រង់ស្រឡាញ់យើង នោះព្រះអម្ចាស់ជួយយើងឲ្យដឹងថាយើងខ្វះខាតអ្វីខ្លះនៅក្នុងការខិតខំយើងដើរតាមទ្រង់ ។ ប្រសិនបើយើងទូលសួរដល់ព្រះអម្ចាស់ នោះទ្រង់នឹងប្រាប់យើងពីអ្វីដែលយើងត្រូវធ្វើជាចាំបាច់ដើម្បីគ្រងជីវិតអស់កល្បជានិច្ច**) ។

សូមអញ្ជើញសិស្សអានម៉ាកុស ១០:២២ដោយស្ងាត់ស្ងៀម រកមើលថាតើកម្លោះនោះមានប្រតិកម្មបែបណា នៅពេលព្រះអង្គសង្គ្រោះបានប្រឹក្សាឲ្យគាត់លក់ទ្រព្យសម្បត្តិទាំងអស់ដែលគាត់មាននោះ ។

- តើកម្លោះនោះមានប្រតិកម្មបែបណា ?
- យោងតាមខទី ២២ហេតុអ្វីបានជាគាត់មានប្រតិកម្មរបែបនោះ ?

សូមចង្អុលបង្ហាញថា ខណៈដែលយើងប្រហែលជាមិនត្រូវបានសុំឲ្យបោះបង់ចោលទ្រព្យដ៏ច្រើនរបស់យើង មករកព្រះអម្ចាស់ នោះទ្រង់បានសុំឲ្យយើងធ្វើការលះបង់ផ្សេងទៀត ដើម្បីបម្រើទ្រង់ ហើយគោរពតាមបទបញ្ញត្តិរបស់ទ្រង់ ។

- តើការលះបង់មួយចំនួន ដែលព្រះអម្ចាស់បានសុំឲ្យយើងលះបង់ ដែលប្រហែលជាពិបាកធ្វើនោះមានអ្វីខ្លះ ?
- តើពរជ័យអ្វីខ្លះដែលយើងប្រហែលជាមិនបានទទួល បើយើងជ្រើសរើសមិនធ្វើតាមព្រះអម្ចាស់នៅគ្រប់រឿងនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ១០: ២៣–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សជំនួសផ្ទៃកនៃខទី ២៧ដោយត្រឹមត្រូវជាមួយនឹងការដកស្រង់នៃការបកប្រែរបស់យ៉ូសែប ស៊្មីធ ដែលមាននៅក្នុង « ព្រះយេស៊ូវទ្រង់ទតទៅគេ មានបន្ទូលថា ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន » ចូរសុំឲ្យសិស្សផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវបានបង្រៀនអំពីការទុកចោលអ្វីៗទាំងអស់ដើម្បីប្រយោជន៍ទ្រង់ ។

- ហេតុអ្វីអ្នកគិតថា វាជារឿងពិបាកដើម្បីឲ្យអ្នកទាំងឡាយដែលទុកចិត្តទៅលើទ្រព្យ ឬរបស់ខាងលោកិយដទៃទៀតចូលទៅក្នុងនគរព្រះ ?
- តើអ្នកគិតថា ជនដែលទុកចិត្តលើព្រះអាចរឿងគ្រប់យ៉ាងនោះ មានន័យដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ១០:២៨–៣១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សអានការបកប្រែដោយយ៉ូសែប ស៊្មីធសម្រាប់ម៉ាកុស ១០:៣១ *ទ្រង់បានមានបន្ទូលស្តីបន្ទោស ពេត្រុស ថា « តែនឹងមានមនុស្សមុន ទៅជាក្រោយជាច្រើន ហើយមនុស្សក្រោយទៅជាមុនវិញ »* ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើពេត្រុសបាននិយាយអ្វីខ្លះ បន្ទាប់ពីព្រះអង្គសង្គ្រោះបានបង្រៀនថា យើងគប្បីមានឆន្ទៈលះបង់អ្វីដែលទ្រង់តម្រូវពីយើង ។

- យោងតាមខទី ២៨តើពេត្រុសបាននិយាយអ្វីខ្លះ ?
- តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះ ចំពោះអ្នកទាំងឡាយដែលស្ម័គ្រចិត្តដើម្បីលះបង់អ្វីៗគ្រប់យ៉ាងដើម្បីដើរតាមទ្រង់ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ អំពីកិច្ចការដែលយើងត្រូវធ្វើដើម្បីទទួលជីវិតអស់កល្បជានិច្ច ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេរកឃើញគោលការណ៍ដូចខាងក្រោមនេះ ៖ **ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច យើងត្រូវតែមានឆន្ទៈលះបង់ចោលអ្វីៗដែលព្រះអម្ចាស់ត្រូវការពីយើង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

- ហេតុអ្វីជីវិតអស់កល្បជានិច្ចមានតម្លៃសមនឹងការលះបង់ ដែលយើងត្រូវបានសុំឲ្យធ្វើនៅលើផែនដីនេះ ? (អ្នកគួរអំពុក«សិស្សថា ជីវិតអស់កល្បជានិច្ច រួមមានទាំងការរស់នៅជារៀងរហូតនៅក្នុងវត្តមានរបស់ព្រះជាមួយនឹងសមាជិកគ្រួសារសុចរិតរបស់យើង) ។

សូមសង្ខេប ម៉ាកុស ១០:៣២–៣៤ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រាប់ដល់ពួកសិស្សរបស់ទ្រង់ថា បន្ទាប់ពីពួកគេបានមកដល់ទីក្រុងយេរូសាឡិម នោះទ្រង់ត្រូវបានគេចំអកដាក់ វាយនឹងរំពាត់ ស្តោះដាក់ ហើយសម្លាប់ទ្រង់ រួចទ្រង់នឹងរស់ឡើងវិញនៅថ្ងៃទីបី ។

- តើព្រះអង្គសង្គ្រោះគឺជាគំរូដ៏ឥតខ្ចោះនៃការមានឆន្ទៈដើម្បីលះបង់នូវអ្វីៗដែលព្រះតម្រូវឲ្យធ្វើយ៉ាងដូចម្តេច ?

ចូរ ថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលត្រូវបានបង្រៀននៅក្នុងមេរៀននេះ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យពិចារណាប្រកបដោយការអធិស្ឋានទៅលើសំណួរថា « តើខ្ញុំនៅខ្វះអ្វីទៀត ? » ហើយគោរពតាមការបំផុសគំនិតនានា ដែលពួកគេអាចទទួលបានទាក់ទងនឹងការលះបង់ ដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកគេលះបង់ ។

ចែកចាយទីបន្ទាល់របស់អ្នក

ចុងបញ្ចប់មេរៀន គឺពុំមែនជាពេលតែមួយគត់ដើម្បីថ្លែងទីបន្ទាល់របស់អ្នកទេ ។ សូមឆ្លៀតឱកាសអំឡុងមេរៀនចែកចាយទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៅពេលពួកគេបានកេរឃើញ និង បានពិភាក្សាហើយ ។ សូមអញ្ជើញសិស្សឲ្យធ្វើដូចគ្នានេះ ។ បន្ទាប់ពីចែកចាយទីបន្ទាល់ នោះព្រះវិញ្ញាណបរិសុទ្ធ អាចថ្លែងជាសាក្សីអំពីសេចក្តីពិតពេញលេញនៃទីបន្ទាល់នៅក្នុងដួងចិត្ត និងគំនិតរបស់សិស្ស ។

ម៉ាកុស ១០:៣៥–៥២

ព្រះអង្គសង្គ្រោះប្រាប់ទុកជាមុនអំពីការសុគត និង ការរស់ឡើងវិញរបស់ទ្រង់ ហើយបានប្រឹក្សាដល់ពួកសាវកឲ្យបម្រើគ្នាទៅវិញទៅមក

សូមបំបែកក្រុមតូចៗ ។ សូមផ្តល់ដល់ក្រុមនីមួយៗនូវច្បាប់ចម្លងអំពីឯកសារចែកចាយដូចខាងក្រោម ហើយអញ្ជើញពួកគេឲ្យបំពេញវា ៖

តើអ្នកណាធំជាងគេក្នុងនគរស្ថានសួគ៌ ?

សូមបំពេញឯកសារចែកចាយនេះជាក្រុម ហើយពិភាក្សាចម្លើយចំពោះសំណួររបស់អ្នក ។

សូមសរសេរសកម្មភាពមួយចំនួនដែលអ្នកពេញចិត្ត ៖ _____

- សូមរៀបរាប់ឈ្មោះបុគ្គលមួយចំនួន ដែលបានធ្វើយ៉ាងល្អក្នុងសកម្មភាពដែលអ្នកបានរៀបរាប់ខាងលើ ។ តើអ្វីដែលធ្វើឲ្យពួកគេធំជាងគេ ?

នៅពេលអ្នកបន្តសិក្សាព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុងម៉ាកុស ១០សូមរកមើលនូវអ្វីដែលទ្រង់បង្រៀន ដែលធ្វើឲ្យមនុស្សម្នាក់ធំជាងគេពិតប្រាកដ ។

សូមអានម៉ាកុស ១០:៣៥–៣៧ ហើយរកមើលនូវអ្វីដែលយ៉ាកុប និង យ៉ូហាន បានទូលសូមពីព្រះអង្គសង្គ្រោះ នៅពេលពួកគេបានធ្វើដំណើរឆ្ពោះទៅទីក្រុងយេរូសាឡិម ។

សំណើររបស់យ៉ាកុប និង យ៉ូហានចង់អង្គុយនៅខាងស្តាំ និង ខាងឆ្វេងព្រះហស្តរបស់ព្រះអង្គសង្គ្រោះមានន័យថា ពួកគាត់ចង់បានទទួលសិរីល្អ និង កិត្តិយសកាន់តែខ្ពស់នៅក្នុងនគររបស់ព្រះ ជាងពួកសាវកដទៃៗទៀត ។ ម៉ាកុស ១០:៣៨–៤០ កត់ត្រាថា ព្រះអង្គសង្គ្រោះបានពន្យល់ដល់យ៉ាកុប និង យ៉ូហានថា ពរជ័យនេះនឹងត្រូវបានប្រទានដល់អ្នកទាំងឡាយដែលត្រៀមខ្លួនដើម្បីទទួលវា ។

សូមអានម៉ាកុស ១០:៤១ ហើយរកមើលរបៀបដែលសិស្សផ្សេងទៀតបានឆ្លើយតបចំពោះសំណើររបស់យ៉ាកុប និងយ៉ូហាន ។

- ហេតុអ្វីអ្នកគិតថា សិស្សដទៃទៀតមិនរីករាយជាមួយយ៉ាកុប និងយ៉ូហាន ?

សូមអានម៉ាកុស ១០:៤២–៤៥ រកមើលថាព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះដល់ពួកសាវករបស់ទ្រង់អំពីភាពធំជាងគេ ។

សូមបំពេញសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយផ្អែកទៅលើអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីភាពធំជាងគេពិតប្រាកដ ៖

ដើម្បីធំជាងគេពិតប្រាកដយើងត្រូវតែ _____.

នៅក្នុងខ ៤៥ពាក្យ*បម្រើ*មានន័យថា ផ្តល់ការមើលថែ ការលួងលោមចិត្ត ជួយ និងការគាំទ្រដល់អ្នកដទៃ ។

- ហេតុអ្វីក៏មនុស្សម្នាក់ដែលបម្រើ ហើយធ្វើការងារបម្រើដល់អ្នកដទៃ (ដូចព្រះអង្គសង្គ្រោះ) ត្រូវបានចាត់ទុកថាធំជាងគេពិតប្រាកដ ?
- តើពេលណា ដែលនរណាម្នាក់បម្រើ និងមើលថែអ្នក ឬគ្រួសារអ្នក? ហេតុអ្វីក៏អ្នកគិតថា មនុស្សម្នាក់នោះធំជាងគេពិតប្រាកដ ?

បន្ទាប់ពីសិស្សបានបំពេញឯកសារចែកចាយរួចហើយ ចូរអញ្ជើញពួកគេមួយចំនួនរាយការណ៍អំពីរបៀបដែលពួកគេបានបំពេញសេចក្តីថ្លែងការណ៍នោះដោយផ្អែកទៅលើម៉ាកុស ១០:៤២–៤៥។ សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្តាប់ពីគោលការណ៍ខាងក្រោមនេះ ៖ **ដើម្បីបានធំជាងគេពិតប្រាកដ យើងត្រូវតែធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះដោយបម្រើអ្នកដទៃ ។**

សូមសង្ខេបម៉ាកុស ១០:៤៦–៥២ ដោយពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះ និង ពួកសាវករបស់ទ្រង់ ចាកចេញពីស្រុកយេរីខូ ធ្វើដំណើរទៅទីក្រុងយេរូសាឡិម នោះមានបុរសខ្វាក់ម្នាក់ឈ្មោះ បារទីមេ បានស្រែករកព្រះអម្ចាស់ព្យាបាលគាត់ ។ ហ្វូងមនុស្សបានប្រាប់ បារទីមេ ឲ្យស្ងាត់ ប៉ុន្តែគាត់ស្រែករកកាន់តែខ្លាំង ។ ព្រះអង្គសង្គ្រោះបានស្តាប់ឮការស្រែករករបស់គាត់ ហើយមានក្តីមេត្តាចំពោះគាត់ រួចហើយបានព្យាបាលដល់គាត់ ។ (*កំណាត់ចំណាំ* ៖ ដំណើររឿងនៃការព្យាបាលរបស់ បារទីមេ នឹងត្រូវបានបង្រៀនកាន់តែលម្អិតនៅក្នុងមេរៀនសម្រាប់ល្ងាច ១៨) ។

- តើព្រះអង្គសង្គ្រោះគឺជាគំរូដ៏ឥតខ្ចោះអំពីគោលការណ៍ ដែលទ្រង់បានបង្រៀនអំពីការបម្រើដល់អ្នកដទៃយ៉ាងដូចម្តេច ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះអង្គសង្គ្រោះគឺពិតជាអស្ចារ្យ ដោយសារតែទ្រង់បានបម្រើដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ។ សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលពួកគេអាចធ្វើបាន ដើម្បីបម្រើ និងមើលថែដល់អ្នកទាំងឡាយដែលនៅជុំវិញពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅមួយ ដែលនឹងជួយពួកគេឲ្យបម្រើ ហើយធ្វើការងារបម្រើដល់អ្នកដទៃ ។

មេរៀន ៤២

ម៉ាកុស ១១–១៦

សេចក្តីផ្តើម

នៅជិតចុងបញ្ចប់នៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះអង្គសង្គ្រោះបានសង្កេតឃើញស្ត្រីមេម៉ាយក្រីក្រម្នាក់ ដែលបានដាក់ប្រាក់ពីរស្លឹងនៅក្នុងហឹបព្រះវិហារបរិសុទ្ធ ។ ក្រោយមក ខណៈដែលនៅពេលទទួលទានអាហារពេលល្ងាចនៅភូមិបេថានី ម៉ារាបានចាក់ប្រេងឲ្យព្រះយេស៊ូវជាទីសម្គាល់នៃការសុគតរបស់ទ្រង់ ។ ព្រះអង្គសង្គ្រោះបានរងទុក្ខនៅសួនច្បារគែតសេម៉ានី ។ ទ្រង់ត្រូវបានគេកាត់ទោស ហើយដាក់ទោសរហូតដល់សុគត ។ បន្ទាប់ពីទ្រង់បានសុគតនៅលើឈើឆ្កាង ហើយបានរស់ឡើងវិញ នោះព្រះអម្ចាស់បានលេចព្រះកាយមកឲ្យពួកសាវករបស់ទ្រង់ឃើញ ហើយបានបញ្ជាពួកគេឲ្យនាំដំណឹងល្អទៅកាន់ពិភពលោក ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ១១–១៣

ព្រះអង្គសង្គ្រោះបង្រៀននៅព្រះវិហារបរិសុទ្ធ ហើយសង្កេតឃើញស្ត្រីមេម៉ាយម្នាក់បានដាក់ប្រាក់ពីរស្លឹងទៅក្នុងហឹបព្រះវិហារបរិសុទ្ធ ។

សូមអានស្ថានភាពដូចតទៅនេះឲ្យឮៗ ហើយសុំឲ្យសិស្សស្តាប់រកមើលភាពផ្សេងគ្នារវាងដង្វាយនានា ដែលថ្វាយទៅព្រះអម្ចាស់នៅក្នុងស្ថានភាពនីមួយៗ ។

១. ស្ត្រីម្នាក់បានឲ្យដល់ប៊ីស្សពនូវចំនួនប្រាក់ដ៏ច្រើនជាដង្វាយតមអាហារ ។ ស្ត្រីម្នាក់ទៀតបានរស់នៅក្នុងវួដដូចគ្នា បានឲ្យប្រាក់ដល់ប៊ីស្សពក្នុងចំនួនតិចបំផុតមួយជាដង្វាយតមអាហាររបស់គាត់ ។

២. បុរសម្នាក់បម្រើជាប្រធានស្តេក ។ បុរសម្នាក់ទៀតនៅក្នុងស្តេកដូចគ្នា បម្រើជាគ្រូបង្រៀនថ្នាក់អង្គការបឋមសិក្សា ។

- តើអ្នកសម្គាល់ឃើញមានភាពខុសគ្នាអ្វីខ្លះ នៅក្នុងការថ្វាយដង្វាយតាមស្ថានភាពនីមួយៗ ?
- តើមនុស្សម្នាក់អាចមានអារម្មណ៍យ៉ាងដូចម្តេច បើដង្វាយរបស់ពួកគាត់ថ្វាយទៅព្រះអម្ចាស់មានចំនួនតិចតួច នៅពេលប្រៀបធៀបនឹងការថ្វាយដង្វាយរបស់អ្នកដទៃ ?

សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីពិតនៅពេលពួកគេសិក្សាម៉ាកុស ១១–១៤ដែលនឹងជួយពួកគេដឹងពីរបៀប ដែលព្រះអម្ចាស់ទតមើលទៅលើដង្វាយរបស់ពួកគេដល់ទ្រង់ ។

ចូរដាក់បង្ហាញរូបភាពការយាងចូលដ៏ជោគជ័យ (*Gospel Art Book* [២០០៩] ទំព័រ ៥០,សូមមើលផងដែរ LDS.org) ។ សូមសង្ខេបម៉ាកុស ១១:១–១២:៤០ ដោយពន្យល់ថា នៅពេលជិតដល់ទីបញ្ចប់នៃការបម្រើរបស់ព្រះអង្គសង្គ្រោះក្នុងជីវិតរមែងស្លាប់ នោះទ្រង់បានជិះចូលទៅក្នុងទីក្រុងយេរូសាឡិមដោយជោគជ័យ បានសម្អាតព្រះវិហារបរិសុទ្ធ ហើយបានបង្រៀនមនុស្សនៅទីនោះ ។ សូមរំឭកសិស្សថា នៅក្នុងការប៉ុនប៉ងដើម្បីបង្ខូចកេរ្តិ៍ឈ្មោះរបស់ព្រះអង្គសង្គ្រោះ នោះពួកផារិស៊ី និងពួកអាចារ្យ បានសួរដល់ទ្រង់នូវសំណួរលំបាកៗ ខណៈដែលទ្រង់បានបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ ។ បន្ទាប់ពីព្រះអង្គសង្គ្រោះបានឆ្លើយតបចំពោះសំណួររបស់ពួកគេ ទ្រង់បានប្រកាសបដិសេធពីភាពលាក់ពុតរបស់ពួកផារិស៊ី និង ពួកអាចារ្យ (សូមមើលម៉ាថាយ ២៣) ។

សូមពន្យល់ថា ខណៈដែលព្រះយេស៊ូវគង់នៅព្រះវិហារបរិសុទ្ធ នោះទ្រង់បានទតឃើញបុគ្គលទាំងឡាយដែលបានដាក់ប្រាក់ទៅក្នុងហឹបព្រះវិហារបរិសុទ្ធ ជាការថ្វាយដល់ព្រះ ។ សូមអញ្ជើញសិស្សម្នាក់អានម៉ាកុស ១២:៤១–៤៤ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះបានទតឃើញនៅត្រង់ហឹបនោះ ។

- តើព្រះអង្គសង្គ្រោះបានទតឃើញអ្វីនៅត្រង់ហឹបនោះ ?

សូមបង្ហាញកាក់ដែលមានតម្លៃតិចបំផុត ជាឬបិយបណ្ណប្រទេសអ្នក ហើយពន្យល់ថា *ប្រាក់មួយស្លឹង* គឺជា« កាក់ស្ពាន់ដ៏តិចបំផុតដែលបានប្រើដោយពួកសាសន៍យូដា » (Bible Dictionary, « Money ») ។

- តើមនុស្សម្នាក់មានអារម្មណ៍យ៉ាងណា បើពួកគេអាចដាក់ប្រាក់តែពីរស្លឹងជាដង្វាយថ្វាយព្រះនោះ ?
- តើព្រះអង្គសង្គ្រោះបានមានបន្ទូលដូចម្តេច អំពីដង្វាយរបស់ស្ត្រីមេម៉ាយ បើប្រៀបធៀបទៅនឹងដង្វាយរបស់អ្នកផ្សេងទៀត ?
- ហេតុអ្វីក៏អ្នកគិតថា ព្រះអង្គសង្គ្រោះចាត់ទុកដង្វាយរបស់គាត់ « ច្រើន » ជាងដង្វាយផ្សេងៗ ?
- ផ្អែកទៅលើអ្វីដែលព្រះអម្ចាស់បានមានបន្ទូលអំពីស្ត្រីមេម៉ាយ តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនអំពីការថ្វាយដល់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **បើយើងស៊ូត្រចិត្តដើម្បីផ្តល់អស់នូវអ្វីដែលយើងមានថ្វាយព្រះអម្ចាស់ នោះទ្រង់នឹងទទួលយកដង្វាយរបស់យើង ទោះបើវាមានចំនួនតិច បើប្រៀបទៅនឹងអ្នកដទៃក្តី**)។

សូមសង្ខេបម៉ាកុស ១៣ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសាវករបស់ទ្រង់អំពីការយាងមកជាលើកទីពីរ ។ សូមរំឭកសិស្សថា ពួកគេបានសិក្សាអំពីការបង្រៀនទាំងនេះនៅក្នុង យ៉ូសែប ស៊្មីធ–ម៉ាថាយ ។

ការបង្រៀនអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅសួនច្បារគែតសេម៉ានី

មានដំណើររឿងបីអំពីព្រឹត្តការណ៍ដែលបានកើតឡើងនៅក្នុងសួនច្បារគែតសេម៉ានី ។ មេរៀនសម្រាប់ម៉ាថាយ ២៦ផ្តោតទៅលើការចុះចូលរបស់ព្រះអង្គសង្គ្រោះទៅតាមព្រះទ័យរបស់ព្រះបិតាទ្រង់ ។ មេរៀនម៉ាកុស ១៤ថ្លែងអំពីការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងសួនច្បារគែតសេម៉ានី ។ មេរៀនលូកា ២២គូសបញ្ជាក់អំពីការរងទុក្ខដ៏ខ្លាំងហួសប្រមាណរបស់ទ្រង់ ។ ការផ្តោតទៅលើទិដ្ឋភាពពិសេសៗនៃដំណើររឿងទាំងបីនេះ អំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះ អាចផ្តល់ឲ្យសិស្សនូវបទពិសោធន៍ជាក់លាក់ នៅពេលពួកគេសិក្សាដំណើររឿងនីមួយៗ ។



ម៉ាកុស ១៤:១–៩

ម៉ារាបានចាក់ប្រេងឲ្យព្រះអង្គសង្គ្រោះ

ចូរពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ អំពីទីសម្គាល់នៃការយាងមកជាលើកទីពីរ នោះទ្រង់បានយាងចេញពីទីក្រុងយេរូសាឡិម ហើយបានចេញទៅភូមិបេថានី ទៅផ្ទះបុរសម្នាក់ឈ្មោះ សឺម៉ូន ដែលពីមុនបានរងទុក្ខដោយជំងឺឃ្លង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានម៉ាកុស ១៤:៣ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតឲ្យអានយ៉ូហាន ១២:៣ឮៗ ។ ចូរសូមឲ្យសិស្សក្នុងថ្នាក់ស្តាប់នូវអ្វីដែលបានកើតឡើងដល់ព្រះអង្គសង្គ្រោះ នៅពេលទ្រង់គង់ចុះទទួលទានអាហារពេលល្ងាច ។

- តើមានអ្វីខ្លះកើតឡើងចំពោះព្រះអង្គសង្គ្រោះ នៅពេលទ្រង់គង់ចុះនៅពេលទទួលទានអាហារពេលល្ងាចនៅផ្ទះរបស់សឺម៉ូន ? (ចូរពន្យល់ថា ស្ត្រីដែលចាក់ប្រេងឲ្យព្រះអង្គសង្គ្រោះ គឺជាម៉ារាបងស្រីរបស់ម៉ាថា និង ឡាសា [សូមមើលយ៉ូហាន ១២:១–៣]) ។
- តើម៉ារាបានបង្ហាញដល់ព្រះអង្គសង្គ្រោះនូវក្តីស្រឡាញ់ និង ការលះបង់របស់នាងយ៉ាងដូចម្តេចខ្លះ ?

ចូរពន្យល់ថា ទង្វើរបស់ម៉ារាក្នុងការចាក់ប្រេងលើសិរសារបស់ព្រះអង្គសង្គ្រោះ និង ព្រះបាទទ្រង់ ជាមួយនឹងប្រេងទេព្យ (ប្រេងដែលមានតម្លៃថ្លៃ) គឺជាទង្វើនៃគារវភាពដែលសូម្បីតែស្តេចកម្រនឹងបានទទួល (សូមមើល James E. Talmage, *Jesus the Christ* បោះពុម្ពជាលើកទី ៣ [ឆ្នាំ ១៩១៦] ទំព័រ ៥១២) ។

សូមអញ្ជើញឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ១៤:៤–៩ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលរបៀបដែលមនុស្សមួយចំនួននៅពេលទទួលទានអាហារពេលល្ងាច បានមានប្រតិកម្មយ៉ាងណាចំពោះអ្វីដែលម៉ារាបានធ្វើ ។ សូមពន្យល់ថា យើងរៀនមកពីយ៉ូហាន ១២:៤–៥ថា យូដាស អេស្ការីយ៉ុត គឺជាមនុស្សម្នាក់ដែលបានរអ៊ូរទាំអំពីទង្វើរបស់ម៉ារា ។

- តើយូដាស អេស្ការីយ៉ុត មានប្រតិកម្មយ៉ាងដូចម្តេចចំពោះការចាក់ប្រេងរបស់ម៉ារាដល់ព្រះអង្គសង្គ្រោះដោយប្រេងដែលមានតម្លៃថ្លៃនោះ ?
- យោងតាមខទី ៥តើប្រេងដ៏មានតម្លៃនោះថ្លៃប៉ុន្មាន ? (សូមពន្យល់ថា បីរយកាក់ គឺប្រហែលជាស្មើនឹងចំនួនប្រាក់ដែលអ្នកធ្វើការជាទូទៅអាចរកបានក្នុងមួយឆ្នាំ) ។
- តើព្រះអង្គសង្គ្រោះបានឆ្លើយតបយ៉ាងដូចម្តេច ចំពោះការរិះគន់របស់យូដាសអំពីម៉ារា ?

សូមចង្អុលបង្ហាញឃ្លា « នាងបានធ្វើការនេះ ជាការល្អដល់ខ្ញុំណាស់ » នៅក្នុងខទី ៦ហើយពន្យល់ថា វាចង្អុលបង្ហាញថា ព្រះអង្គសង្គ្រោះសព្វព្រះទ័យនឹងអ្វីដែលម៉ារាបានធ្វើ ។ ក៏សូមចង្អុលបង្ហាញឃ្លា « នាងបានធ្វើការអ្វីដែលនាងធ្វើបាន » នៅក្នុងខទី ៨ហើយពន្យល់ថា ការបញ្ជាក់នេះថា ម៉ារាបានថ្វាយអស់ពីលទ្ធភាពរបស់នាងទៅព្រះអម្ចាស់ ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ចេញមកពីខគម្ពីរទាំងនេះ អំពីរបៀបដែលព្រះអង្គសង្គ្រោះមានព្រះទ័យ នៅពេលយើងថ្វាយអស់ពីលទ្ធភាពរបស់យើងទៅទ្រង់ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ព្រះអង្គសង្គ្រោះ សព្វព្រះទ័យនៅពេលយើងថ្វាយដល់ទ្រង់ នូវលទ្ធភាពរបស់យើងទាំងអស់**) ។

សូមយោងទៅស្ថានភាពពីរដែលបានបង្ហាញនៅខាងដើមមេរៀន ។ ចូរសុំឲ្យសិស្សប្រើសេចក្តីពិតដែលពួកគេបានប្រាប់នៅក្នុងម៉ាកុស ១២និងម៉ាកុស ១៤ដើម្បីពន្យល់អំពីរបៀបដែលបុគ្គលម្នាក់នៅក្នុងស្ថានភាពនេះ អាចនឹងសព្វព្រះទ័យដល់ព្រះអម្ចាស់ ។

- តើការជឿទៅលើសេចក្តីពិតទាំងនេះ អាចជួយនរណាម្នាក់ដែលមានអារម្មណ៍ថាពួកគេពុំបានថ្វាយច្រើនដល់ព្រះអម្ចាស់យ៉ាងដូចម្តេច ?
- តើនៅពេលណា ដែលអ្នកបានឃើញនរណាម្នាក់បានថ្វាយអស់ពីលទ្ធភាពរបស់ពួកគេដល់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សឲ្យគិតពិចារណាថា តើថ្មីៗនេះពួកគេបានថ្វាយអស់ពីលទ្ធភាពរបស់ពួកគេដល់ព្រះអម្ចាស់ឬទេ ។ សូមលើកទឹកចិត្តពួកគេឲ្យជ្រើសរើសទិដ្ឋភាពមួយនៃជីវិតរបស់ខ្លួនគេ ដែលពួកគេអាចកែលម្អ ហើយដាក់គោលដៅ ដែលនឹងជួយពួកគេឲ្យថ្វាយអស់ពីលទ្ធភាពដល់ព្រះអម្ចាស់ ។

ម៉ាកុស ១៤:១០–១៦:២០

ព្រះយេស៊ូវ បានចាប់ផ្តើមជង្វាយធួនរបស់ទ្រង់ នៅពេលទ្រង់រងទុក្ខនៅសួនច្បារគែតសេម៉ានីដើម្បីអំពើបាបរបស់យើង ទ្រង់ត្រូវបាន យូដាស អេស្ការីយ៉ុត ក្បត់ ហើយបាននាំទៅឈរចំពោះមុខពួកអ្នកដឹកនាំយូដា

សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងាត់ៗនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្លាប់មានអារម្មណ៍ថា គ្មាននរណាយល់ចិត្តអ្នក ឬយល់ពីអ្វីដែលអ្នកកំពុងឆ្លងកាត់ដែរឬទេ ?
- តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកមិនអាចត្រូវបានអភ័យទោសពីអំពើបាបកាលពីអតីតកាលរបស់អ្នកឬទេ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាម៉ាកុស ១៤ដែលអាចជួយនរណាម្នាក់ដែលអាចនឹងមានអារម្មណ៍ទាំងនេះ ។

សូមសង្ខេបម៉ាកុស ១៤:១០–៣១ ដោយពន្យល់ថា ប៉ុន្មានពីរបីថ្ងៃបន្ទាប់ពីម៉ារាបានចាក់ប្រេងដល់ព្រះយេស៊ូវ នោះព្រះយេស៊ូវ និងពួកសាវកបានធ្វើបុណ្យរំលង ។ បន្ទាប់មក ព្រះអង្គសង្គ្រោះបានចេញទៅសួនច្បារគែតសេម៉ានី ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ១៤:៣២–៣៤ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះមានព្រះទ័យយ៉ាងណា នៅក្នុងសួនច្បារគែតសេម៉ានី ។

- តើព្រះអង្គសង្គ្រោះមានព្រះទ័យយ៉ាងណា នៅក្នុងសួនច្បារគែតសេម៉ានី ?

បន្ទាប់ពីសិស្សបានឆ្លើយសូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ឈឺចាប់ខ្លាំងបំផុត ធ្ងន់ធ្ងរបំផុត សោកសៅដ៏លើសលប់ ។*

សូមពន្យល់ថា ឃ្លាទាំងនេះ សំដៅទៅលើការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទដែលបានទទួលពិសោធន៍ ជាចំណែកនៃដង្វាយធួនរបស់ទ្រង់ ។

- តើឃ្លាទាំងនេះបង្រៀនយើងអ្វីខ្លះអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយបានសោកសៅនៅក្នុងសួនច្បារគែតសេម៉ានី**) ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ១៤:៣៥–៤២ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានធ្វើ ដោយសារការរងទុក្ខដ៏ខ្លាំងរបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ ដោយសារតែការរងទុក្ខដ៏ខ្លាំងរបស់ទ្រង់នោះ ? (សូមជួយសិស្សឲ្យយល់ថា ការរងទុក្ខរបស់ព្រះយេស៊ូវគឺធ្ងន់ធ្ងរហួសហេតុ ដែលទ្រង់បានទូលសូមថា បើអាចធ្វើទៅបានចំពោះទ្រង់ នោះសូមកុំឲ្យទូលបង្គំទទួលបទពិសោធន៍នេះអី) ។

សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន ៖ *ព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខ . . . ដើម្បីទ្រង់ . . .*

សូមពន្យល់ថា វគ្គបទគម្ពីរផ្សេងទៀតអាចជួយយើងយល់អំពីការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទ និង មូលហេតុដែលទ្រង់ស្ម័គ្រព្រះទ័យដើម្បីរងទុក្ខសម្រាប់យើង ។

សូមសរសេរសេចក្តីយោងដូចខាងក្រោមនេះនៅលើក្តារខៀន ៖ *អេសាយ ៥៣:៣–៥*និង*អាលម៉ា ៧:១១–១៣* ។ សូមបំបែកសិស្សជាគូៗ ហើយអញ្ជើញពួកគេឲ្យអានខគម្ពីរជាមួយគ្នា ដោយស្វែងរកនូវបព្វហេតុ និងមូលហេតុដែលព្រះអង្គសង្គ្រោះបានរងទុក្ខ ។ ចូរសូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេថា ពួកគេនឹងបំពេញឃ្លាដែលបានសរសេរនៅលើក្តារខៀនដោយប្រើនូវអ្វីដែលពួកគេបានរៀននៅក្នុងអេសាយ ៥៣:៣–៥អាលម៉ា ៧:១១–១៣យ៉ាងដូចម្តេច ។ (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ*ជួយ*នៅក្នុងអាលម៉ា ៧:១២មានន័យថា ប្រញាប់ដើម្បីផ្តល់នូវការសង្គ្រោះ ឬទៅផ្តល់ជំនួយដល់នរណាម្នាក់ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបួនប្រាំនាក់ចែកចាយរបៀបដែលពួកគេបានបំពេញឃ្លានោះ ។ ចម្លើយរបស់ពួកគេនឹងស្រដៀងគ្នាដូចខាងក្រោម ៖ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខនូវការឈឺចាប់ ក្តីទុក្ខលំបាក ការល្បួង ជំងឺ រោគ និងការសោកសៅរបស់យើង ដើម្បីទ្រង់នឹងដឹងរបៀបដើម្បីជួយយើង ។ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខសម្រាប់អំពើបាបរបស់យើង ដើម្បីទ្រង់នឹងលុបចោលអំពើរំលងរបស់យើងចេញ ។ សូមរំឭកសិស្សថា ការរងទុក្ខរបស់ព្រះអង្គសង្គ្រោះសម្រាប់អំពើបាបរបស់មនុស្សលោក បានចាប់ផ្តើមនៅក្នុងសួនច្បារគែតសេម៉ានី ហើយបានបន្ត និង ទីបំផុតឈានទៅដល់ការឆ្កាងរបស់ទ្រង់នៅលើឈើឆ្កាង ។

ដើម្បីជួយសិស្សដឹងពីសារៈសំខាន់នៃសេចក្តីពិតដែលជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយបានសោកសៅនៅក្នុងសួនច្បារគែតសេម៉ានី សូមពិចារណាធ្វើការបង្ហាញវីដេអូ « Special Witness—Elder Holland (សាក្សីពិសេស–អែលឌើរ ហូឡិន) »(២:៣៨) ដែលអែលឌើរ ដៃវ្រ៊ី អរ ហូឡិន នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ថ្លែងទីបន្ទាល់អំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី ។ វីដេអូនេះមាននៅក្នុង LDS.org ។

- តើការដឹងនូវអ្វីដែលព្រះអង្គសង្គ្រោះបានរងទុក្ខ និងមូលហេតុដែលទ្រង់បានរងទុក្ខ អាចជួយដល់អ្នក នៅពេលអ្នកជួបប្រទះនឹងការសាកល្បង ការឈឺចាប់ និង ក្តីលំបាកយ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់មានអារម្មណ៍ថាព្រះអង្គសង្គ្រោះជួយអ្នកនៅក្នុងគ្រាឈឺចាប់ ជំងឺ ឬការសោកសៅនៅពេលណា ?
- តើអារម្មណ៍អ្វីខ្លះដែលអ្នកបានដកពិសោធន៍ នៅពេលអ្នកបានប្រែចិត្ត ហើយមានអារម្មណ៍ថា អំពើបាបរបស់អ្នកត្រូវបានលុបចោល (ឬបំបាត់ចោល) តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?

សូមសង្ខេបម៉ាកុស ១៤:៤៣–១៦:២០ ដោយការពន្យល់ថា ព្រះយេស៊ូវ ត្រូវបាននាំយកទៅកាត់ទោសដោយមិនស្របច្បាប់ នៅចំពោះមុខពួកសានហេឌ្រីន ហើយផ្តន្ទាទោសដល់ស្លាប់ ។ បន្ទាប់ពីព្រះអង្គសង្គ្រោះបានសុគតនៅលើឈើឆ្កាង ហើយបានរស់ឡើងវិញ នោះទ្រង់បានលេចព្រះកាយមកឲ្យពួកសាវករបស់ទ្រង់ឃើញ ហើយបានបញ្ជាពួកគេឲ្យនាំដំណឹងល្អទៅកាន់ពិភពលោក ។

អ្នកគួរតែបញ្ចប់ ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលអ្នកបានពិភាក្សានៅថ្ងៃនេះ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ម៉ាកុស ១៤:៣–៩ ។ ម៉ារាចាក់ប្រេងលើព្រះយេស៊ូវ

អែលឌើរ ជេម អ៊ី ថាលម៉េហ្គ បានពន្យល់ថា ទង្វើរបស់ម៉ារាបង្ហាញនូវក្តីស្រឡាញ់ដ៏មហិមារបស់នាងចំពោះព្រះយេស៊ូវ ៖

« ដើម្បីចាក់ប្រេងលើក្បាលរបស់ភ្ញៀវម្នាក់ដោយប្រេងធម្មតា គឺធ្វើដើម្បី ផ្តល់ កិត្តិយសដល់ទ្រង់ ដើម្បីចាក់ប្រេងនៅលើព្រះបាទាទ្រង់ក៏បង្ហាញពីទីសម្គាល់នៃការគោរពខុសពីធម្មតា ប៉ុន្តែការចាក់ប្រេងលើសិរីសារ និង ព្រះបាទាដោយប្រេងទេព្វិរ ហើយដោយច្រើនដូច្នេះ គឺជាទង្វើនៃការគោរពបូជាដោយកម្រសូម្បីតែចំពោះស្តេច ។ ទង្វើរបស់ម៉ារា គឺជាការបង្ហាញនូវការគោរពបូជា វាគឺជាក្លិនក្រអូបដែលចេញមកពីក្នុងដួងចិត្តពោរពេញដោយការថ្វាយបង្គំ និងសុច្ឆន្ទៈ » (*Jesus the Christ,* បានបោះពុម្ពជាលើកទី ៣ [ឆ្នាំ ១៩១៦] ទំព័រ ៥១២) ។

សេចក្តីណែនាំ

ទៅកាន់ដំណឹងល្អស្របតាមលូកា

ហេតុអ្វី ត្រូវសិក្សាគម្ពីរនេះ ?

គម្ពីរលូកា ផ្តល់នូវសាក្សីបន្ថែមមួយអំពីសេចក្តីពិតជាច្រើន ដែលបានកត់ត្រាដោយ ម៉ាថាយ និង ម៉ាកុស ហើយក៏មាននូវមាតិកាពិសេសផងដែរ ។ ដំណឹងល្អរបស់លូកា អាចជួយឲ្យសិស្សយល់ដឹងជ្រៅជ្រះអំពីការបង្រៀនទាំងឡាយរបស់ព្រះយេស៊ូវគ្រីស្ទ ហើយជួយពួកគេឲ្យមានអំណរគុណកាន់តែពេញលេញចំពោះសេចក្តីស្រឡាញ់ និង ក្តីមេត្តាករុណារបស់ទ្រង់ចំពោះមនុស្សលោកទាំងអស់ ដូចបានបើកសម្តែងអំឡុងពេលការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ និងតាមរយៈដង្វាយធួនដ៏និរន្តរបស់ទ្រង់ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

លូកា គឺជាអ្នកសរសេរដំណឹងល្អនេះ ។ លោកគឺជាគ្រូពេទ្យមួយរូប (សូមមើលកូល៉ុស ៤:១៤) និង ជា « សាវ័កបរទេសរបស់ព្រះយេស៊ូវគ្រីស្ទ » ។ លូកា គឺជា « គូកនធ្វើការម្នាក់ » របស់ប៉ុល (ភីលេម៉ូន ១:២៤) និងជាដៃគូផ្សព្វផ្សាយសាសនារបស់ ប៉ុល (សូមមើលធីម៉ូថេទី ២ ៤:១១) ។ លូកា ក៏ជាអ្នកសរសេរគម្ពីរកិច្ចការផងដែរ (សូមមើល *Bible Dictionary*« *Luke* ») ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ទោះបីជាវាពុំត្រូវបានគេដឹងច្បាស់លាស់ថា ពេលណាដែលលូកាសរសេរដំណឹងល្អរបស់លោកក្តី ក៏វាទំនងជាត្រូវបានសរសេរនៅពាក់កណ្តាលសតវត្សទីមួយនៃគ.ស. ។ ប្រភពរបស់លូកា គឺជាប្រជាជនដែល « បានឃើញការទាំងនោះជាក់នឹងភ្នែក តាំងពីដើមរៀងមក » (លូកា ១:២) អំពីការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ យើងពុំដឹងពីទីកន្លែងដែលដំណឹងល្អរបស់លូកាត្រូវបានសរសេរឡើងឡើយ ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយតើហេតុអ្វី ?

លូកា មានបំណងចង់ឲ្យដំណឹងល្អរបស់លោកត្រូវបានអានជាចម្បងដោយអ្នកស្តាប់ជាសាសន៍ដទៃ ហើយលោកបានបង្ហាញថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះ ទាំងរបស់ពួកសាសន៍យូដា និង ពួកសាសន៍ដទៃ ។ លូកាបានថ្លែងជាពិសេសអំពីដំណឹងល្អរបស់ទ្រង់ទៅកាន់ « លោកថេអ៊ីល » (លូកា ១:៣) ដែលជាភាសាក្រិកមានន័យថា « មិត្តរបស់ព្រះ » ឬ « មនុស្សជាទីស្រឡាញ់របស់ព្រះ » ។ វាបង្ហាញថា ថេអ៊ីល បានទទួលការណែនាំពីមុនមកទាក់ទងទៅនឹងជីវិត និង ការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើលលូកា ១:៤) ។ លូកា បានសង្ឃឹមថានឹងផ្តល់ការណែនាំបន្ថែមទៀត ដោយការផ្តល់នូវដំណើររឿងត្រឹមត្រូវអំពីបេសកកម្ម និង ការបម្រើរបស់ព្រះអង្គសង្គ្រោះ ។ លោកចង់ឲ្យអ្នកទាំងឡាយដែលអានទីបន្ទាល់របស់លោក « ជ្រាបពីសេចក្តីពិត » (លូកា ១:៤) អំពីព្រះរាជបុត្រារបស់ព្រះ—ក្តីមេត្តារបស់ទ្រង់ ដង្វាយធួនរបស់ទ្រង់ និងការរស់ឡើងវិញរបស់ទ្រង់ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

គម្ពីរលូកា គឺជាដំណឹងល្អដែលវែងជាងគេក្នុងចំណោមដំណឹងល្អទាំងបួន ហើយជាគម្ពីរវែងជាងគេបំផុតនៅក្នុងគម្ពីរសញ្ញាថ្មី ។ ដំណើររឿងដ៏ល្បីបំផុតមួយចំនួនអំពីគ្រីស្ទអាណាចក្រ គឺពិសេសជាច់ដោយឡែកចំពោះដំណឹងល្អរបស់លូកា ៖ ជាស្ថានភាពទាំងឡាយអំពីកំណើតរបស់ យ៉ូហានបាទីស្ទ (សូមមើលលូកា ១:៥–២៥, ៥៧–៨០) និទានកថាទំនៀមទម្លាប់បុណ្យគ្រីស្ទម៉ាស់ (សូមមើលលូកា ២:១–២០) ដំណើររឿងរបស់ព្រះយេស៊ូវកាលជាកុមារវ័យ ១២ ឆ្នាំនៅក្នុងព្រះវិហារបរិសុទ្ធ (សូមមើលលូកា ២:៤១–៥២) ដំណើររឿងប្រៀបធៀបអំពីសាសន៍សាម៉ារីល្អ (សូមមើលលូកា ១០:៣០–៣៧) កូនប្រុសខ្ជះខ្ជាយ (សូមមើលលូកា ១៥:១១–៣២) និង បុរសអ្នកមាន និងឡាសារ (សូមមើលលូកា ១៦:១៩–៣១) ដំណើររឿងអំពីមនុស្សឃ្លង់ដប់នាក់ (សូមមើលលូកា ១៧:១១–១៩) និង ដំណើររឿងនៃព្រះអម្ចាស់ដែលរស់ឡើងវិញយាងទៅជាមួយនឹងពួកសិស្សនៅតាមផ្លូវទៅកាន់ទីក្រុងអេម៉ោស (សូមមើលលូកា ២៤:១៣–៣២) ។

លក្ខណៈពិសេសផ្សេងៗទៀត គឺជាការដាក់បញ្ចូលរបស់លូកាអំពីការបង្រៀនរបស់ យ៉ូហានបាទីស្ទ ដែលពុំមាននៅក្នុងដំណឹងល្អផ្សេងទៀតឡើយ (សូមមើលលូកា ៣:១០–១៤) ការគូសបញ្ជាក់របស់លោកអំពីភាពពេញលេញនៃការអធិស្ឋានរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើលលូកា ៣:២១,៥:១៦,៩:១៨, ២៨–២៩,១១:១) និងការដាក់បញ្ចូលរបស់លោកអំពីការហៅបម្រើ ការបំពាក់បំប៉ន និង កិច្ចការផ្សព្វផ្សាយសាសនារបស់ពួកចិតសិបនាក់ (សូមមើលលូកា ១០:១–២២) ។ លើលពីនោះទៀត លូកា គឺជាអ្នកសរសេរដំណឹងល្អតែម្នាក់គត់ ដែលបានកត់ត្រាថា ព្រះអង្គសង្គ្រោះបានបង្ហូរលោហិតនៅក្នុងសួនច្បារគេតសេម៉ានី ហើយថាមានទេវតាមួយអង្គបានមកបម្រើទ្រង់ (សូមមើលលូកា ២២:៤៣–៤៤) ។

ដោយសារតែដំណឹងល្អរបស់លូកាចាប់ផ្តើម និង បញ្ចប់ទៅវិញនៅក្នុងព្រះវិហារបរិសុទ្ធ នោះវាក៏ជាសញ្ញាផងដែរអំពីសារៈសំខាន់របស់ព្រះវិហារបរិសុទ្ធថា ជាកន្លែងសំខាន់មួយនៃការទំនាក់ទំនងរបស់ព្រះជាមួយមនុស្សលោក (សូមមើលលូកា ១:៩,២៤:៥៣) ។

គម្រោង

លូកា ១–៣កំណើត និង បេសកកម្មរបស់យ៉ូហាន បាទីស្ទ និង ព្រះយេស៊ូវគ្រីស្ទត្រូវបានព្យាករពីមុនមក ។ សាក្សីជាច្រើនបានថ្លែងទីបន្ទាល់ថា ទារកយេស៊ូវគឺជាព្រះមែស៊ី ។ នៅព្រះជន្មាយុ ១២ វស្សា ព្រះយេស៊ូវគ្រីស្ទបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ ។ យ៉ូហាន បាទីស្ទ ផ្សាយអំពីការប្រែចិត្ត ហើយធ្វើបុណ្យជ្រមុជទឹកដល់ព្រះយេស៊ូវគ្រីស្ទ ។ លូកា កត់ត្រាអំពីពង្សាវតារបស់ព្រះយេស៊ូវគ្រីស្ទ ។

លូកា ៤–៨ព្រះយេស៊ូវគ្រីស្ទ ត្រូវបានល្បួងនៅទីរហោស្ថាន ។ នៅណាសារ៉ែត ទ្រង់បានប្រកាសអំពីខ្លួនព្រះអង្គថាជាព្រះមែស៊ី ហើយត្រូវបានគេបដិសេធ ។ ព្រះយេស៊ូវគ្រីស្ទជ្រើសរើសពួកសាវកដប់ពីរនាក់ ហើយបង្រៀនដល់ពួកសិស្សរបស់ទ្រង់ ។ ទ្រង់អភ័យទោសដល់អំពើបាប ហើយធ្វើអព្ភូតហេតុជាច្រើន ។

លូកា ៩–១៤ពួកសាវកដប់ពីរនាក់ ត្រូវបានបញ្ជូនឲ្យទៅផ្សាយ និងព្យាបាល ។ ព្រះយេស៊ូវគ្រីស្ទប្រទានអាហារដល់មនុស្សប្រាំពាន់នាក់ ហើយបានប្រែរូបនៅលើភ្នំមួយ ។ ទ្រង់ហៅពួកចិតសិបនាក់ ហើយបញ្ជូនពួកគេឲ្យចេញទៅបង្រៀន ។ ព្រះយេស៊ូវគ្រីស្ទបង្រៀនអំពីភាពជាសិស្ស អំពើពុតត្បុត និងការជំនុំជំរះ ។ ទ្រង់រៀបរាប់អំពីរឿងប្រៀបធៀបអំពីសាសន៍សាម៉ារីល្អ ។

លូកា ១៥–១៧ព្រះយេស៊ូវបង្រៀនរឿងប្រៀបធៀប ។ ទ្រង់បង្រៀនអំពីទង្វើបំពាន សេចក្តីជំនឿ និង ការអភ័យទោស ។ ទ្រង់ព្យាបាលដល់មនុស្សឃ្លង់ដប់នាក់ ហើយបង្រៀនអំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។

លូកា ១៨–២២ព្រះយេស៊ូវបន្តបង្រៀនរឿងប្រៀបធៀប ។ ទ្រង់ព្យាបាលបុរសខ្វាក់ម្នាក់ ហើយបង្រៀន សាខេ ។ ទ្រង់ជិះចូលទៅទីក្រុងយេរូសាឡិមដោយជោគជ័យ ទ្រង់ព្រះកន្សែងចំពោះទីក្រុង ហើយសម្អាតព្រះវិហារបរិសុទ្ធ ។ ព្រះយេស៊ូវបានព្យាករជាមុនអំពីការបំផ្លិចបំផ្លាញនៃទីក្រុងយេរូសាឡិម ហើយមានបន្ទូលអំពីទីសម្គាល់ដែលនឹងកើតមានមុនការយាងមកជាលើកទីពីររបស់ទ្រង់ ។ ទ្រង់តាំងពិធីសាក្រាម៉ង់ឡើង បង្រៀនដល់ពួកសាវករបស់ទ្រង់ ហើយរងទុក្ខនៅសួនច្បារគេតសេម៉ានី ។ ទ្រង់ត្រូវបានគេក្បត់ចាប់ចង ចំអក វាយដំ និង សួរចម្លើយ ។

លូកា ២៣–២៤ព្រះយេស៊ូវត្រូវបានសួរចម្លើយនៅពីមុខលោកពីឡាត់ ហើយស្តេចហេរ៉ូឌ ទ្រង់ត្រូវបានគេឆ្កាង និងបញ្ចុះព្រះសពទ្រង់ ។ ពួកទេវតានៅឯទីផ្នូរ ហើយពួកសាវកពីរនាក់ដើរនៅតាមផ្លូវទៅកាន់ទីក្រុងអេម៉ោស ថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទត្រូវបានរស់ឡើងវិញ ។ ព្រះអង្គសង្គ្រោះបានលេចព្រះកាយរបស់ទ្រង់មកជូបពួកសិស្សនៅទីក្រុងយេរូសាឡិម សន្យានឹងពួកសាវករបស់ទ្រង់ថា ពួកគេនឹងត្រូវបានប្រទានឲ្យនូវព្រះចេស្តាមកពីព្រះ ហើយទ្រង់ក៏យាងត្រឡប់ទៅស្ថានសួគ៌វិញ ។

លូកា ១

សេចក្តីផ្តើម

ទេវតា កាព្រីយ៉ែល បានបង្ហាញព្រះកាយដល់សាការី ហើយបានប្រាប់ថា សាការី និង ករិយា គាត់ អេលីសាបិត នឹងមានកូនប្រុសម្នាក់ ដែលពួកគេគួរដាក់ឈ្មោះថា យ៉ូហាន ។ ប្រាំមួយ ខែក្រោយមក ទេវតាដដែលនោះបានបង្ហាញព្រះកាយដល់ម៉ារា ហើយបានប្រាប់ថា នាង នឹងធ្វើជាមាតារបស់ព្រះរាជបុត្រានៃព្រះ ។ ម៉ារាបានទៅលេងអេលីសាបិត ហើយពួកគេ បានមានចិត្តរីករាយនឹងការយាងមករបស់ព្រះអង្គសង្គ្រោះ ។ បីខែក្រោយមក អេលីសាបិត បានបង្កើតយ៉ូហាន ។

យោបល់សម្រាប់ការបង្រៀន

លូកា ១:១–៤

លូកាពន្យល់ពីមូលហេតុសម្រាប់ការសរសេរដំណឹងល្អរបស់លោក

សូមដាក់តាំងរូបភាពដូចខាងក្រោម ហើយសុំឲ្យសិស្សពន្យល់អំពីអ្វី ដែលកំពុងកើតឡើងនៅក្នុងរូបនីមួយៗ ៖ យ៉ូសែប និង ម៉ារា ធ្វើដំណើរទៅភូមិបេថ្លេហិម (*Gospel Art Book* ¦ ឆ្នាំ ២០០៩ ¦ លេខ ២៩ សូមមើលផងដែរ LDS.org), ទេវតា បង្ហាញព្រះកាយដល់ពួកអ្នកគង្វាល (លេខ ៣១), សិម្មូនគោរពដល់ទារកព្រះគ្រីស្ទ (លេខ ៣២), ក្មេងប្រុសយេស៊ូវនៅក្នុង ព្រះវិហារបរិសុទ្ធ (លេខ ៣៨), សាសន៍សាម៉ារីល្អ (លេខ ៤៨), ម៉ារា និងម៉ាថា (លេខ ៤៥) និង មនុស្សឃ្លង់ដប់នាក់ (លេខ ៤៦) ។ ចូរចង្អុលបង្ហាញថា ព្រឹត្តការណ៍ទាំងនេះ និង ព្រឹត្តការណ៍ដទៃជាច្រើនទៀត និង ការបង្រៀនមកពីការបម្រើក្នុងជីវិត រមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ត្រូវបានកត់ត្រាដោយលូកា ប៉ុន្តែពុំមាននៅក្នុងដំណឹងល្អរបស់ម៉ាថាយ ម៉ាកុស និង យ៉ូហានទេ ។



សូមណែនាំដោយសង្ខេបអំពីដំណឹងល្អរបស់លូកា ដោយពន្យល់ថា លូកាបានចាប់ផ្តើមដំណឹងល្អរបស់លោកដោយថ្លែងអំពីមនុស្សម្នាក់ ឈ្មោះ « ថេវភីល » (ខទី ៣) ហើយបានពន្យល់អំពីមូលហេតុរបស់គាត់ចំពោះការសរសេរនោះ ។ *ថេវភីល* មាននំយថា « មិត្តរបស់ ព្រះ » (Bible Dictionary« Theophilus ») ។ សូមអញ្ជើញសិស្សម្នាក់អាន លូកា ១:១–៤ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុង ថ្នាក់ផ្ទៀងតាមរកមើលមូលហេតុរបស់លូកាចំពោះការសរសេរនោះ ។

- តើលូកាមានមូលហេតុអ្វីខ្លះចំពោះការសរសេរដំណើររឿងនេះ ?
- ផ្អែកទៅលើលូកា ១:៤ តើការសិក្សាដំណឹងល្អរបស់លូកាអាចមានអត្ថ ប្រយោជន៍ចំពោះអ្វីខ្លះចំពោះយើង ?

ចូរអះអាងនឹងសិស្សថា នៅពេលពួកគេសិក្សាដំណឹងល្អរបស់លូកា នោះពួកគេអាចបាន « ដឹងច្បាស់ » (ខទី ៤) អំពីសេចក្តីពិត ទាំងឡាយដែលបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ។

> ***បំណងរបស់អ្នកនិពន្ធ***
>
> នៅពេលអ្នកបង្រៀនមកពីបទគម្ពីរ ចូរព្យាយាមកំណត់នូវអ្វីជាការព្យាករដែលអ្នកនិពន្ធចង់ទំនាក់ទំនង ។ ដើម្បីរៀនបន្ថែមអំពីបំណងរបស់លូកាចំពោះការសរសេរដំណឹងល្អរបស់លោក សូមអាន « ការណែនាំទៅកាន់ដំណឹងល្អស្របតាមលូកា » ដែលផ្តើមមេរៀននេះ ។

លូកា ១:៥–២៥

ទេវតា កាព្រីយ៉ែល ប្រកាសអំពីការចាប់កំណើតរបស់យ៉ូហាន ដល់សាការី ហើយអេលីសាបិតមានផ្ទៃពោះ

ចូរសុំឲ្យសិស្សពិចារណាអំពីពរជ័យ ឬចម្លើយមួយមកពីព្រះ ដែលពួកគេកំពុងរង់ចាំ ឬសង្ឃឹមនោះ ។ សូមអញ្ជើញសិស្សឲ្យរកមើល សេចក្តីពិត នៅពេលពួកគេសិក្សាលូកា ១ដែលអាចជួយពួកគេនៅពេលពួកគេកំពុងរង់ចាំពរជ័យ ឬចម្លើយមួយមកពីព្រះ ។

ចូរសុំសិស្សម្នាក់អានលូកា ១:៥–៧ ឲ្យឮៗ ហើយអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលថា នរណាកំពុងរង់ចាំពរជ័យជាក់លាក់យ៉ាងខ្លាំង ក្នុងជីវិតរបស់ពួកគេ ។

- តើព័ត៌មានលម្អិតអ្វីខ្លះដែលយើងបានរៀនអំពីសាការី និងអេលីសាបិត ចេញមកពីខគម្ពីរទាំងនេះ ?

សូមសង្ខេបលូកា ១:៨–១០ ដោយការពន្យល់ថា សាការី ត្រូវបានតែងតាំងឲ្យដុតកំញានក្នុងព្រះវិហារបរិសុទ្ធយេរូសាឡិម ជាកិត្តិយសដែលមានចំពោះសង្ឃម្នាក់ ដែលមានប្រហែលជាម្តងក្នុងមួយជីវិតរបស់គាត់ប៉ុណ្ណោះ ។

ចូរសុំឲ្យសិស្សអានលូកា ១:១១–១៣ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលបានកើតឡើង ខណៈដែលសាការីស្ថិត នៅក្នុងព្រះវិហារបរិសុទ្ធ ។

- យោងតាមខទី ១៣ តើការអធិស្ឋាននឹងត្រូវបានឆ្លើយតបចំពោះសាការី និងអេលីសាបិតយ៉ាងណា ? (សូមចង្អុលបង្ហាញថា សាការី និង អេលីសាបិត ទំនងជាបានអធិស្ឋានអស់ជាច្រើនឆ្នាំមកហើយ ដើម្បីសុំមានកូនម្នាក់នោះ ។ អ្នកអាចនឹងចង់ផ្តល់យោបល់សិស្ស ឲ្យគូសចំណាំឃ្លា « ព្រះបានទទួលសេចក្តីអធិស្ឋានរបស់អ្នកហើយ » នៅក្នុងខគម្ពីរនេះ) ។
- តើសាការីមានអារម្មណ៍យ៉ាងណាដែរ ពេលគាត់បានស្តាប់ឮថា គាត់ និង អេលីសាបិតនឹងមានកូនប្រុសម្នាក់ ទោះជាពួកគេ « ចាស់ណាស់ » ក៏ដោយនោះ ? (ខទី ៧) ។

សូមសង្ខេបលូកា ១:១៤–១៧ ដោយពន្យល់ថា ទេវតាកាព្រីយ៉ែល បានប្រាប់ដល់សាការីថា លោក និង អេលីសាបិត នឹង « មានសេចក្តីអំណរ និងសេចក្តីរីករាយ » (ខទី ១៤) ហើយថាកូនប្រុសរបស់ពួកគេនឹងរៀបចំមនុស្សជាច្រើនសម្រាប់ព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ១:១៨–២០ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀបដែលសាការីបានឆ្លើយតបទៅកាន់ទេវតា ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- តើមានអ្វីកើតឡើងដល់សាការី ដោយសារតែគាត់សង្ស័យចំពោះបន្ទូលរបស់ទេវតា ?
- យោងតាមខទី ២០តើទេវតាបានមានបន្ទូលថា អ្វីនឹងកើតឡើងចំពោះពាក្យដែលទ្រង់ថ្លែងទៅសាការី ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ព្រះបន្ទូលរបស់ព្រះអម្ចាស់ថ្លែងតាមរយៈពួកអ្នកបម្រើរបស់ទ្រង់ នឹងត្រូវបានបំពេញនៅពេលកំណត់មកដល់ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើឃ្លា « នៅពេលកំណត់ » មានន័យយ៉ាងណា ? (ស្របតាមកាលកំណត់របស់ព្រះអម្ចាស់) ។

សូមយោងទៅសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ហើយសួរថា ៖

- តើការដឹងពីសេចក្តីពិតនេះ ជះឥទ្ធិពលទៅលើរបៀបដែលយើងឆ្លើយតបចំពោះការសន្យារបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតប សូមធ្វើកំណែថ្មីទៅលើសេចក្តីពិតនៅលើក្តារខៀន ដើម្បីបង្កើតជាសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះ ៖ **យើងអាចទុកចិត្តទៅលើការសន្យារបស់ព្រះ ដោយសារព្រះបន្ទូលរបស់ទ្រង់ នឹងត្រូវបានបំពេញនៅពេលកំណត់**) ។
- តើសេចក្តីពិតនេះអាចជួយនរណាម្នាក់ ដែលទន្ទឹងចាំការសន្យារបស់ព្រះដើម្បីបំពេញយ៉ាងដូចម្តេច ?

សូមសង្ខេបលូកា ១:២១–២៤ ដោយពន្យល់ថា នៅពេលសាការីបានចាកចេញពីព្រះវិហារបរិសុទ្ធមក គាត់ពុំអាចនិយាយបានទេ ។ ក្រោយមកអេលីសាបិតបានមានផ្ទៃពោះ ដូចដែលទេវតាបានសន្យា ។

ចូរសួរដល់សិស្សម្នាក់ (តម្រូវទៅលើយុវនារី) ឲ្យអានឮៗនូវពាក្យរបស់អេលីសាបិតនៅក្នុងលូកា ១:២៥។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ពិចារណាអំពីរបៀប ដែលអេលីសាបិតអាចមានអារម្មណ៍យ៉ាងណា នៅពេលគាត់ហៀបនឹងមានកូនម្នាក់នោះ ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថាសេចក្តីថ្លែងការណ៍របស់អេលីសាបិតថា ព្រះអម្ចាស់បាន « ដោះសេចក្តីខ្មាស [របស់គាត់] នៅកណ្តាលមនុស្សចេញ » អាចនឹងសំដៅទៅលើការខ្មាស់អៀនដែលនាងមាន ដោយសារតែទស្សនៈមិនត្រឹមត្រូវជាទូទៅនៅក្នុងវប្បធម៌ពីបុរាណថា ការគ្មានកូនគឺជាទណ្ឌកម្មមួយមកពីព្រះ ។

លូកា ១:២៦–៣៨

ទេវតាកាព្រីយ៉ែលប្រកាសអំពីការចាប់កំណើតរបស់ព្រះយេស៊ូវគ្រីស្ទនឹងនាងម៉ារា



ទេវតាកាព្រីយ៉ែលបានបង្ហាញព្រះកាយដល់ម៉ារា

សូមបង្ហាញរូបភាពការប្រាប់ ៖ ទេវតាកាព្រីយ៉ែលបង្ហាញព្រះកាយដល់ម៉ារា (*Gospel Art Book* លេខ ២៨, សូមមើលផងដែរ LDS.org), ហើយសុំសិស្សឲ្យនឹកស្រមៃថា តើពួកគេនឹងមានអារម្មណ៍យ៉ាងណា ដែលទេវតាបានបង្ហាញព្រះកាយមកដល់ពួកគេដោយពុំបានរំពឹងទុកជាមុននោះ ។ សូមសង្ខេបលូកា ១:២៦–២៧ដោយពន្យល់ថា នៅក្នុងប្រាំមួយខែនៃការមានផ្ទៃពោះរបស់អេលីសាបិត នោះទេវតាកាព្រីយ៉ែល ត្រូវបានបញ្ជូនឲ្យទៅជួបម៉ារា ជាស្ត្រីវ័យក្មេងម្នាក់នៅភូមិណាសារ៉ែត ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១:២៨–៣៣ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវឃ្លាដែលអាចនឹងជួយម៉ារាឲ្យយល់អំពីសារៈសំខាន់នៃកិច្ចការដែលព្រះបានប្រទានដល់នាង ។

- តើឃ្លាអ្វីខ្លះដែលអាចឲ្យម៉ារាយល់អំពីសារៈសំខាន់នៃកិច្ចការដែលព្រះបានប្រទានដល់នាង ?
- តើនាមថា « ព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត » (ខទី ៣២) មានន័យយ៉ាងណា ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ជាព្រះវរបិតា**) ។

ចូរសុំឲ្យសិស្សអានលូកា ១:៣៤ដោយស្ងាត់ស្ងៀម រកមើលនូវសំណួររបស់ម៉ារា ។ សុំឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ ចូរពន្យល់ថាសេចក្តីថ្លែងរបស់ម៉ារាដែលថា « ខ្ញុំមិនស្គាល់ប្រុសណាផង » មានន័យថា នាងគឺជាស្ត្រីព្រហ្មចារី ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ១:៣៥–៣៧ឮៗ ហើយសុំឲ្យសិស្សរកមើលចម្លើយរបស់ទេវតាចំពោះសំណួររបស់ម៉ារា ។

ចូរពន្យល់ថាយើងពុំដឹងលើសពីដំណើររឿងនៅក្នុងបទគម្ពីរ អំពីរបៀបដែលអព្ភូតហេតុអំពីការចាប់ទុំផ្ទៃរបស់ព្រះយេស៊ូវគ្រីស្ទកើតឡើងយ៉ាងណាទេ យើងអាចប្រាប់ដោយសាមញ្ញថា វាគឺជាអព្ភូតហេតុ ហើយថាទារកដែលចាប់កំណើតនោះនឹងជាព្រះរាជបុត្រានៃព្រះ ។

- ដូចបានកត់ត្រានៅក្នុងលូកា ១:៣៧តើសេចក្តីពិតអ្វីខ្លះ ដែលទេវតាបានថ្លែង ដែលជួយពន្យល់អំពីព្រឹត្តការណ៍ដ៏អព្ភូតហេតុនេះ ? (សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **ត្បិតការអ្វីដែលព្រះទ្រង់ធ្វើពុំបាន នោះគ្មានសោះឡើយ ។** អ្នកអាចនឹងចង់ផ្តល់យោបល់ដល់សិស្សឲ្យគូសចំណាំសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។
- តើអ្នកគិតថា ម៉ារា ឬអេលីសាបិត អាចនឹងនិយាយដូចម្តេច ដើម្បីលើកទឹកចិត្តយើង ប្រសិនបើយើងមានអារម្មណ៍ថា អ្វីដែលយើងសង្ឃឹមចង់បាននោះវាមិនអាចកើតឡើងសោះនោះ ?
- តើបទពិសោធន៍មួយណា ដែលបានពង្រឹងដល់ជំនឿរបស់អ្នកថា ការណ៍អ្វីដែលព្រះទ្រង់ធ្វើពុំបាន នោះគ្មានសោះឡើយ ?

សូមអញ្ជើញសិស្សឲ្យអានលូកា ១:៣៨ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបដែលម៉ារាបានឆ្លើយតបចំពោះទេវតា ។

- តើភស្តុតាងអ្វីខ្លះដែលអ្នកបានឃើញនៅក្នុងខគម្ពីរនេះ ដែលម៉ារា បានជឿថាជាព្រះបន្ទូលរបស់ទេវតា ?
- តើការទទួលយកពាក្យរបស់ម៉ារា មានភាពខុសគ្នាពីការឆ្លើយតបរបស់សាការីចំពោះការប្រកាសរបស់ទេវតានៅក្នុងព្រះវិហារបរិសុទ្ធយ៉ាងដូចម្តេច ?

ចៀសវាងការប៉ាន់ស្មាន

សូមកុំស្មានអំពីប្រធានបទពិសិដ្ឋ ថា ព្រះអង្គសង្គ្រោះត្រូវបានចាប់ទុំផ្ទៃយ៉ាងណានោះឡើយ ។ ផ្ទុយទៅវិញ សូមផ្តោតទៅលើការបង្រៀននៅក្នុងបទគម្ពីរ ចាំក្នុងគំនិតអំពីទីបន្ទាល់ដែលមាននៅក្នុងព្រះគម្ពីរថា កំណើតរបស់ព្រះគ្រីស្ទគឺជាអព្ភូតហេតុមួយ ហើយថាម៉ារា « ហៅថាជាស្ត្រីព្រហ្មចារីទាំងមុន និង ក្រោយពេលនាងប្រសូត្របុត្រ » (អែសរ៉ា ថាហ្វ ប៊ែនសឹន « *Joy in Christ* »*Ensign*ខែ មិនា ឆ្នាំ ១៩៨៦, ៤ សូមមើលផងដែរ នីហ្វៃទី ១ ១១:១៣–២០, អាលម៉ា ៧:១០) ។

សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូរបស់ម៉ារា និង អេលីសាបិត ដោយការជឿថានៅក្នុងជីវិតរបស់ពួកគេផ្ទាល់ គ្មានអ្វីដែលព្រះអម្ចាស់បញ្ជាដល់ពួកគេហើយ នឹងពុំអាចធ្វើបានដោយមានជំនួយទ្រង់នោះឡើយ ។

លូកា ១:៣៩–៥៦

ម៉ារីទៅលេងអេលីសាបិត ហើយស្ត្រីទាំងពីរបានថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ



ម៉ារីទៅលេងអេលីសាបិត

បើអាចធ្វើទៅបាន សូមបង្ហាញរូបមួយអំពីម៉ារា ទៅលេងអេលីសាបិត អំឡុងពេលដែលអេលីសាបិតមានផ្ទៃពោះ ។ ចូរសួរសិស្សប្រសិនបើពួកគេអាចស្គាល់រូបថតនេះជានរណា ហើយអ្វីកំពុងតែកើតឡើងនៅក្នុងរូបនេះ: ។

- ម៉ារា និង អេលីសាបិត មើលទៅហាក់ដូចជាស្ត្រីសាមញ្ញ ប៉ុន្តែតើពួកគាត់បានបំពេញតួនាទីដ៏សំខាន់ដែលនឹងផ្លាស់ប្តូរពិភពលោកតាមរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១:៤១–៤៥ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលទីបន្ទាល់របស់អេលីសាបិតទៅកាន់ម៉ារា ។

- តើអេលីសាបិតបានយល់អំពីម៉ារាអ្វីខ្លះហើយ ?

សូមអញ្ជើញសិស្សម្នាក់ (ជាយុវនារី) ឲ្យអានលូកា ១:៤៦–៤៩ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀបដែលម៉ារាបានសរសើរដល់ព្រះអម្ចាស់ ។

- តើឃ្លាអ្វីខ្លះដែលបានកត់ត្រានៅក្នុងខទី ៤៩ដែលម៉ារាបានប្រើដើម្បីពិពណ៌នាអំពីអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់នាង ? (« រឿងអស្ចារ្យ ») ។

សូមអញ្ជើញសិស្សឲ្យអានលូកា ១:៣៨, ៤៥–៤៦សារឡើងវិញដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីដែលម៉ារាបានធ្វើ ដែលអនុញ្ញាតឲ្យព្រះអម្ចាស់ធ្វើ « រឿងអស្ចារ្យ » សម្រាប់នាង ។

- តើម៉ារាបានធ្វើអ្វីខ្លះ ដែលអនុញ្ញាតឲ្យព្រះអម្ចាស់ធ្វើនូវ « រឿងអស្ចារ្យ » សម្រាប់នាង ?

សូមចង្អុលបង្ហាញថា ដូចជាសាការី អេលីសាបិត និង ម៉ារា មានតួនាទីផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងផែនការរបស់ព្រះ: នោះយើងក៏មានតួនាទីសំខាន់ដែលបានចាត់តាំងដោយព្រះអម្ចាស់ផងដែរ ។

- ផ្អែកទៅលើគំរូរបស់ម៉ារា តើអ្វីខ្លះនឹងកើតឡើងនៅក្នុងជីវិតរបស់យើង បើយើងព្យាយាមបំពេញតួនាទីដែលព្រះអម្ចាស់មានសម្រាប់យើងដោយស្មោះត្រង់នោះ: ? (សូមជួយសិស្សឲ្យស្គាល់ពីគោលការណ៍នេះ ៖ **ប្រសិនបើយើងព្យាយាមបំពេញតួនាទីដែលព្រះអម្ចាស់មានសម្រាប់យើងដោយស្មោះត្រង់ នោះទ្រង់អាចធ្វើរឿងអស្ចារ្យជាច្រើននៅក្នុងជីវិតរបស់យើង**) ។
- តើតួនាទីមួយចំនួនដែលព្រះអម្ចាស់ចង់ឲ្យអ្នកបំពេញនៅក្នុងផែនការទ្រង់មានអ្វីខ្លះ ?
- តើរឿងអ្វីខ្លះអាចកើតឡើងនៅក្នុងជីវិតរបស់អ្នក ប្រសិនបើអ្នកឆ្លើយតបចំពោះព្រះអម្ចាស់ដូចជាម៉ារាបានធ្វើនោះ: ?

លូកា ១:៥៧–៨០

យ៉ូហាន បាទីស្ទ បានចាប់កំណើត

សូមសង្ខេបលូកា ១:៥៧–៨០ ដោយពន្យល់ថា បន្ទាប់ពីអេលីសាបិតបានប្រសូត្របុត្រ នោះសាការីបានបញ្ជាក់ថា កូននោះគួរដាក់ឈ្មោះថា យ៉ូហាន ។ នៅពេលគាត់បានធ្វើដូច្នោះ: រំពេចនោះ គាត់អាចមានលទ្ធភាពនិយាយបានវិញ ហើយគាត់បានព្យាករអំពីបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ និង យ៉ូហាន ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងបំពេញតួនាទីដែលបានផ្តល់ឲ្យយើងពីព្រះដោយស្មោះត្រង់ដូចជា សាការី អេលីសាបិត និង ម៉ារាបានធ្វើ នោះព្រះអម្ចាស់អាចធ្វើនូវរឿងអស្ចារ្យទាំងឡាយសម្រាប់យើង និង តាមរយៈយើង ។ សូមលើកទឹកចិត្តសិស្សឲ្យបំពេញតួនាទីផ្ទាល់ខ្លួនរបស់ពួកគេនៅក្នុងផែនការរបស់ព្រះអម្ចាស់ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

លូកា ១:៣៨ ។ « សូមឲ្យបានសំរេចដូចពាក្យលោកចុះ »

ជាភាសាក្រិករបស់លូកា បានបង្ហាញថាពាក្យសម្តីរបស់ម៉ារា ឆ្លុះបញ្ចាំងពីភាពរឹងមាំនៃការសម្រេចចិត្តរបស់នាង ។ នាងពុំស្នាក់ស្ទើរចំពោះសំណើនោះទេ ប៉ុន្តែបានទទួលយកទាំងស្រុងនូវតួនាទីរបស់នាងនៅក្នុងផែនការនៃសេចក្តីសង្គ្រោះ ដូចនិយាយថា « យល់ព្រមទាំងស្រុង ។ ខ្ញុំនឹងធ្វើជាអ្នកបម្រើរបស់ព្រះអម្ចាស់ ដូចលោកប្រាប់ចុះ: » ។ (សម្រាប់ការយល់ដឹងបន្ថែមចំពោះការឆ្លើយតបរបស់ម៉ារា សូមមើលវគ្គលូកា ១:៣៨នៅក្នុង *New Testament Student Manual [Church Educational System manual* ឆ្នាំ ២០១៤] ទំព័រ ១៤២) ។

លូកា ២

សេចក្តីផ្តើម

យ៉ូសែប និង ម៉ារាបានធ្វើដំណើរទៅកាន់ភូមិបេថ្លេហិម ជាកន្លែងដែលព្រះយេស៊ូវបានប្រសូត្រ ។ ពួកអ្នកគង្វាលបានគោរពតាមការណែនាំរបស់ទេវតាដើម្បីទៅរកមើលទារកយេស៊ូវដែលទើបនឹងប្រសូត្រ បន្ទាប់មកពួកគេបានប្រកាសអំពីការប្រសូត្ររបស់ព្រះយេស៊ូវទៅដល់អ្នកដទៃទៀត ។ ស៊ីម៉ូន បានប្រទានពរដល់ព្រះយេស៊ូវនៅព្រះវិហារបរិសុទ្ធ ហើយ នាង អាណ បានចែកចាយជាសាក្សីថា ព្រះប្រោសលោះបានប្រសូត្រមកហើយ ។ ព្រះយេស៊ូវបានលូតលាស់ « ប្រកបដោយប្រាជ្ញាវិតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » (លូកា ២:៥២) ។

យោបល់សម្រាប់ការបង្រៀន

លូកា ២:១–២០

ព្រះយេស៊ូវប្រសូតក្នុងភូមិបេថ្លេហិម

សូមពិចារណាឲ្យសិស្សក្នុងថ្នាក់ច្រៀងបទ « អំណរដល់លោក » (*ទំនុកតម្កើង* ទំព័រ ១២៤) ឬទំនុកតម្កើងបុណ្យគ្រីស្តម៉ាសផ្សេងទៀតជាផ្នែកនៃការប្រជុំធម្មនិដ្ឋាន ។



ចូរដាក់បង្ហាញរូបភាពយ៉ូសែប និង ម៉ារា ធ្វើដំណើរទៅកាន់ភូមិបេថ្លេហិម (*Gospel Art Book* ២០០៩ | ទំព័រ ២៩ សូមមើលផងដែរ LDS.org) ។ ចូរសុំឲ្យសិស្សពិចារណាថា តើពួកគេដឹងច្រើនប៉ុណ្ណាអំពីព្រឹត្តការណ៍ដែលកើតមាននៅជុំវិញការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ ។

ដើម្បីរៀបចំសិស្សឲ្យសិក្សាលូកា ២:១–២០អញ្ជើញសិស្សឲ្យធ្វើនូវលំហាត់ពិត ឬមិនពិតដូចខាងក្រោម ។ (មុនពេលថ្នាក់រៀន សូមរៀបចំច្បាប់ចម្លង នៃលំហាត់សម្រាប់សិស្សម្នាក់ៗ) ។

លំហាត់ពិត–មិនពិត (លូកា ២:១–២០)

___ ១. ម៉ារា និង យ៉ូសែប បានចេញទៅបេថ្លេហិមដើម្បីបង់ពន្ធ ។

___ ២. ម៉ារា និង យ៉ូសែប ត្រូវធ្វើដំណើរ ២៧ ម៉ៃល (៤៤ គីឡូម៉ែត្រ) ពីស្រុកណាសារ៉ែត ទៅភូមិបេថ្លេហិម ។

___ ៣. ម៉ារា បានដាក់ទារកយេស៊ូវផ្ទុំនៅក្នុងស្នូកមួយ ដោយសារតែផ្ទះសំណាក់គ្មានកន្លែងសម្រាក ។

___ ៤. ពួកអ្នកគង្វាលបានដើរតាមផ្កាយទៅកាន់ទីស្នូកដែលព្រះយេស៊ូវផ្ទុំ ។

___ ៥. ក្រៅពីម៉ារា និង យ៉ូសែប មនុស្សដំបូងនៅក្នុងកំណត់ត្រាដែលបានឃើញព្រះយេស៊ូវគ្រីស្ទ គឺពួកអ្នកគង្វាល ។

___ ៦. ទេវតាបានប្រាប់ពួកអ្នកគង្វាលកុំឲ្យប្រាប់នរណាអំពីអ្វីដែលពួកគេបានឃើញឡើយ ។

សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយចំពោះលំហាត់នៅពេលពួកគេសិក្សាលូកា ២។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២:១–៥ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីមូលហេតុដែលយ៉ូសែប និង ម៉ារាធ្វើដំណើរទៅភូមិបេថ្លេហិម ។

- ហេតុអ្វីយ៉ូសែប និង ម៉ារាធ្វើដំណើរទៅភូមិបេថ្លេហិម ? (សូមចង្អុលបង្ហាញថាលូកា ២:១ បានបញ្ជាក់ថា សេសា ចង់ឲ្យប្រជាជនចុះបញ្ជី ឬជំរឿនប្រជាជន ។ រឿងនេះ ធ្វើឡើងក្នុងគោលបំណងដាក់ឲ្យបង់ពន្ធ)។

សូមអញ្ជើញសិស្សឲ្យបើកទៅផែនទី និងលិបិក្រមនៃឈ្មោះកន្លែងទាំងឡាយ ផែនទី លេខ ១១« ដែនដីបរិសុទ្ធនៅសម័យព្រះគម្ពីរសញ្ញាថ្មី » នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។ ចូរសុំឲ្យសិស្សរកមើលស្រុកណាសារ៉ែត និង ភូមិបេថ្លេហិម នៅលើផែនទីហើយប្រើនូវគន្លឹះ គណនាអំពីរយៈចម្ងាយប្រហាក់ប្រហែលដែលយ៉ូសែប និង ម៉ារាបានធ្វើដំណើរ ។ បន្ទាប់ពីសិស្សឆ្លើយតប សូមពន្យល់ថាចម្ងាយ ៨៥–៩០ ម៉ៃល (១៣៧–១៤៥ គីឡូម៉ែត្រ) រវាងស្រុកណាសារ៉ែត និង បេថ្លេហិម នឹងចំណាយពេលបួនទៅប្រាំថ្ងៃដើម្បីដើរ ហើយប្រហែលជាឆ្ងាយជាងនេះសម្រាប់យ៉ូសែប និង ម៉ារា តាមស្ថានភាពរបស់ម៉ារានោះ ។

ចូរសុំឲ្យសិស្សពិចារណាអំពីអ្វីដែលពួកគេគិតថា ជាស្ថានភាពសមរម្យសម្រាប់ការប្រសូត្រនៃព្រះអង្គបង្កបង្កើត និង ជាព្រះអង្គសង្គ្រោះនៃពិភពលោក ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២:៦–៧ ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលស្ថានភាពនៃការប្រសូត្ររបស់ព្រះយេស៊ូវ ។

ប្រើជំនួយសិក្សាព្រះគម្ពីរ

សាសនាចក្របានរៀបចំដាក់ជំនួយការសិក្សាព្រះគម្ពីរមួយចំនួន ហើយបានបញ្ចូលវានៅក្នុងបទដ្ឋានព្រះគម្ពីរសម្រាប់ភាសាមួយចំនួន ។ ជំនួយការសិក្សាទាំងនេះរួមមានឯកសារយោងដូចជាលេខយោង លិបិក្រម រូបភាព និង ផែនទី ។ វាគឺជាឧបករណ៍ជំនួយដ៏មានតម្លៃបំផុតមួយចំនួនដែលគ្រូ និង សិស្សទាំងឡាយអាចប្រើ នៅពេលពួកគេសិក្សាព្រះគម្ពីរ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើជំនួយការសិក្សាដែលមាន នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

- មិនថាស្ថានភាពរបស់ព្រះយេស៊ូវសំខាន់ជាពិសេសប៉ុណ្ណា ក្នុងនាមជាព្រះរាជបុត្រាសំណព្វតែមួយគត់របស់ព្រះខាងសាច់ឈាមទេ តើស្ថានភាពនៃការប្រសូត្ររបស់ទ្រង់យ៉ាងណាដែរ ?

សូមអញ្ជើញឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ២:៨–១៤ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីរបៀបដែលការប្រសូត្ររបស់ព្រះអង្គសង្គ្រោះត្រូវបានប្រកាស ។ ចូរសុំឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមដាក់តាំងរូបភាពទេវតាបង្ហាញព្រះកាយដល់ពួកអ្នកគង្វាល (*Gospel Art Book* លេខ៣១សូមមើលផងដែរ LDS.org) ។

- យោងតាមខទី ១០តើយើងអាចមានបទពិសោធន៍អ្វីខ្លះ ដោយសារតែព្រះអង្គសង្គ្រោះបានប្រសូត្រមកនោះ ? (បន្ទាប់ពីសិស្សបានឆ្លើយសូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ដោយសារតែព្រះអង្គសង្គ្រោះបានប្រសូត្រមកលើផែនដី នោះយើងអាចទទួលបទពិសោធន៍នៃក្តីអំណរដ៏មហិមា**) ។



នៅពេលសិស្សបន្តសិក្សាលូកា ២សូមអញ្ជើញពួកគេឲ្យមើលគំរូនៃរបៀប ដែលចំណេះដឹងអំពីការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទបាននាំមកនូវក្តីអំណរដល់អ្នកដទៃយ៉ាងដូចម្តេច ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ២:១៥–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលពួកអ្នកគង្វាលបានឆ្លើយតបចំពោះសារលិខិតរបស់ទេវតា ។

- តើឃ្លាអ្វីខ្លះ ដែលបង្ហាញអំពីរបៀបដែលពួកអ្នកគង្វាលបានឆ្លើយតបចំពោះសារលិខិតរបស់ទេវតា ? (អ្នកអាចនឹងចង់ផ្តល់យោបល់ឲ្យសិស្សគូសចំណាំឃ្លា « ចូរយើងទៅ » នៅក្នុងខទី ១៥និង « គេក៏ទៅជាប្រញាប់ » នៅក្នុងខទី ១៦) ។
- តើពួកអ្នកគង្វាលទទួលបានសាក្សី ឬទីបន្ទាល់អ្វីខ្លះដោយសារតែពួកគេអនុវត្តតាមសារលិខិតនេះ ?
- តើពួកអ្នកគង្វាលធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេបានទទួលសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ ?
- ហេតុអ្វីក៏អ្នកគិតថា ពួកអ្នកគង្វាលបានចែកចាយជាមួយអ្នកដទៃអំពីអ្វីដែលពួកគេបានជួបដូច្នេះ ?
- តើមានគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីដំណើររឿងនេះ អំពីអ្វីដែលបានកើតឡើង នៅពេលយើងទទួលទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើងអំពីព្រះយេស៊ូវគ្រីស្ទ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្តាប់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **នៅពេលយើងទទួលទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើងអំពីព្រះយេស៊ូវគ្រីស្ទ នោះយើងមានបំណងចែកចាយទីបន្ទាល់របស់យើងជាមួយអ្នកដទៃ**) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពួកគេមានអារម្មណ៍នៃបំណងប្រាថ្នាមួយ ដើម្បីចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ជាមួយអ្នកដទៃ ។ សូមលើកទឹកចិត្តពួកគេឲ្យគិតពិចារណាអំពីអ្វីដែលបានលើកទឹកចិត្តពួកគេឲ្យមានបំណងប្រាថ្នានោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

លូកា ២:២១–៣៩

សិម្មាន និង នាងអាណា ប្រកាសអំពីព្រះយេស៊ូវថាជាព្រះអង្គសង្គ្រោះនៃពិភពលោក

សូមសង្ខេបលូកា ២:២១–២៤ដោយពន្យល់ថា បន្ទាប់ពីការប្រសូត្ររបស់ព្រះយេស៊ូវ នោះម៉ារា និង យ៉ូសែបបាននាំទ្រង់ទៅព្រះវិហារបរិសុទ្ធស្របតាមច្បាប់របស់ យូដា (សូមមើលនិក្ខមនំ ១៣:២) ។ មនុស្សពីរនាក់នៅព្រះវិហារបរិសុទ្ធនាថ្ងៃនោះបានទទួលស្គាល់ទារកយេស៊ូវជាព្រះមែស៊ី ។ សូមអញ្ជើញយុវជននៅក្នុងថ្នាក់ឲ្យអានដំណើររឿងអំពីសិម្មូននៅក្នុងលូកា ២:២៥–៣២ ដោយស្ងាត់ស្ងៀម ។ (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ឃ្លា « រង់ចាំសេចក្តីដោះទុក្ខ របស់សាសន៍អ៊ីស្រាអែល » នៅក្នុងខទី ២៥សំដៅទៅលើការរង់ចាំព្រះមែស៊ីយ៉ាងមក) ។ សូមអញ្ជើញយុវនារីឲ្យអានដំណើររឿងអំពីអាណានៅក្នុងលូកា ២:៣៦–៣៨ដោយស្ងាត់ស្ងៀម (ហើយបើចាំបាច់ សូមពន្យល់ថា «៨០ នាក់ » នៅក្នុងខទី ៣៧មានន័យថា ៨០) ។ នៅពេលសិស្សអានខគម្ពីរដែលបានចាត់តាំងរបស់ពួកគេហើយ សូមអញ្ជើញពួកគេឲ្យរកមើលចម្លើយចំពោះសំណួរដូចខាងក្រោម ៖

- តើចំណេះដឹងអំពីការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ នាំអំណរដល់មនុស្សម្នាក់នេះយ៉ាងដូចម្តេច ?
- តើគាត់ ឬនាងថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ?



ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញយុវជនម្នាក់ឲ្យក្រោកឈរឡើង ហើយសង្ខេបដំណើររឿងដែលបានអាន រួចរៀបរាប់អំពីចម្លើយរបស់គាត់ចំពោះសំណួរដូចតទៅ ។ សូមដាក់តាំងរូបភាព សិម្មាន គោរពដល់ព្រះគ្រីស្ទ (*Gospel Art Book* លេខ៣២សូមមើលផងដែរ LDS.org) ។

សូមសង្ខេបលូកា ២:៣៣–៣៥ដោយពន្យល់ថា សិម្មាន ក៏បានប្រទានពរដល់ម៉ារា និង យ៉ូសែបផងដែរ ។

សូមអញ្ជើញយុវនារីម្នាក់ឲ្យក្រោកឈរឡើង ហើយសង្ខេបដំណើររឿងដែលនាងបានអានរួចរៀបរាប់អំពីចម្លើយរបស់នាងចំពោះសំណួរដូចតទៅ ។

សូមអញ្ជើញសិស្សឲ្យពន្យល់អំពីរបៀប ដែលការដឹងថា ព្រះអង្គសង្គ្រោះបានប្រសូត្រមក អាចនាំក្តីអំណរដល់យើងយ៉ាងដូចម្តេច ។ សូមអញ្ជើញអ្នកទាំងឡាយ ដែលមានអារម្មណ៍ថាអាចធ្វើដូច្នោះបាន ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមសង្ខេបលូកា ២:៣៩ដោយពន្យល់ថា ព្រឹត្តការណ៍ដូចខាងក្រោមទាំងនេះ ម៉ារា យ៉ូសែប និង ព្រះយេស៊ូវ បានត្រឡប់មកស្រុកណាសារ៉ែតវិញ ។

លូកា ២:៤០–៥២

ព្រះរាជកុមារយេស៊ូវ បង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេអំពីចំណុចមួយ ដែលពួកគេនឹងកែលម្អ ។ សូមអញ្ជើញសិស្សពីរបីនាក់ដែលមានអារម្មណ៍ថាអាចធ្វើដូច្នោះបានឲ្យចែកចាយអំពីអ្វីដែលពួកគេបានសរសេរជាមួយនឹងសិស្សក្នុងថ្នាក់ ។ (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។

- តើការស្គាល់ថាព្រះយេស៊ូវយ៉ាងណា ពេលទ្រង់នៅជាកុមារភាព អាចជួយអ្នកដែលជាយុវវ័យម្នាក់យ៉ាងដូចម្តេច ?

សូមពន្យល់ថា យើងមានព័ត៌មានលម្អិតបន្តិចបន្តួចអំពីកុមារភាពរបស់ព្រះយេស៊ូវ ប៉ុន្តែរឿងទាំងនោះដែលបានកត់ត្រា អាចនឹងជាពរជ័យដ៏អស្ចារ្យមួយ ហើយដឹកនាំយើង នៅពេលយើងព្យាយាមកែលម្អខ្លួនយើង ។ នៅពេលសិស្សសិក្សាផ្នែកដែលនៅសល់ក្នុងលូកា ២ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយយើងដឹង អំពីផ្នែកនានាដែលយើងគប្បីផ្តោតអារម្មណ៍ទៅលើ នៅពេលយើងព្យាយាមកែលម្អខ្លួនយើង ។



សូមដាក់តាំងរូបភាពព្រះយេស៊ូវ អធិស្ឋានជាមួយនឹងមាតាទ្រង់ (*Gospel Art Book* លេខ៣៣ សូមមើលផងដែរ LDS.org) ។ សូមអញ្ជើញសិស្សម្នាក់អានលូកា ២:៤០ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលរបៀបដែលលូកាបានពិពណ៌នាអំពីកុមារភាពរបស់ព្រះយេស៊ូវ ។ ចូរពន្យល់ថា*រំរឿង*មានន័យថា ធំឡើង ឬចម្រើនឡើង ។ ចូរសុំឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗមកពី លូកា ២:៤១–៤៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវបានធ្វើ ពេលទ្រង់មានវ័យ ១២ វស្សា ។

- ហេតុអ្វីព្រះយេស៊ូវគង់នៅពីក្រោយក្នុងព្រះវិហារបរិសុទ្ធ ? (សូមអញ្ជើញសិស្សឲ្យអានដកស្រង់ចេញមកពីការបកប្រែដោយយ៉ូសែប ស៊្មីធ លូកា ២:៤៦ ដែលមាននៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយរកមើលថាការបកប្រែដោយយ៉ូសែប ស៊្មីធ គួសបញ្ជាក់អំពីអ្វីដែលព្រះយេស៊ូវកំពុងធ្វើនៅព្រះវិហារបរិសុទ្ធ ហើយថាការបញ្ជាក់នេះពិពណ៌នាកាន់តែល្អអំពីព្រឹត្តការណ៍នៅក្នុងលូកា ២:៤៧យ៉ាងដូចម្តេច) ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២:៤៨–៥០ ឲ្យឮៗ ។ សូមសុំឲ្យសិស្សផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់ម៉ារា និង យ៉ូសែប នៅពេលពួកគេបានរកឃើញទ្រង់ ។

ជំនួសឲ្យការសុំឲ្យសិស្សអានលូកា ២:៤៨–៥០អ្នកអាចនឹងចង់បង្ហាញវីដេអូ « Young Jesus Teaches in the Temple (ព្រះ រាជកុមារយេស៊ូវបង្រៀននៅក្នុងព្រះវិហារបរិសុទ្ធ) » (២:៣០) ចេញមកពី *The Life of Jesus Christ Bible Videos* ដែលមាននៅក្នុង LDS.org។

- តើព្រះយេស៊ូវមានបន្ទូលអ្វីខ្លះទៅកាន់ម៉ារា និង យ៉ូសែប ពេលពួកគេរកឃើញទ្រង់ ?
- តើដំណើររឿងនេះបើកសម្តែងអំពីចំណេះដឹងរបស់ព្រះយេស៊ូវអំពីអត្តសញ្ញាណពិតរបស់ទ្រង់ និង អំពីចរិកលក្ខណៈរបស់ទ្រង់នៅក្នុងយុវវ័យរបស់ទ្រង់អ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២:៥១–៥២ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាព្រះយេស៊ូវធំឡើងយ៉ាងដូចម្តេច ។

- តើវាមានន័យយ៉ាងណាដើម្បី « [ចម្រើន] ប្រាជ្ញា » ? (អភិវឌ្ឍប្រាជ្ញា) ។ ដើម្បីចម្រើន « ពេញវ័យ » ? (អភិវឌ្ឍខាងរូបកាយ) ។ ដើម្បីចម្រើន« ជាទីគាប់ព្រះហឫទ័យដល់ព្រះ » ? (អភិវឌ្ឍខាងវិញ្ញាណ) ។ ដើម្បីចម្រើន « ជាទីគាប់ព្រះហឫទ័យដល់មនុស្ស. . . » ? (អភិវឌ្ឍខាងសង្គម) ។
- ផ្អែកទៅលើខទី ៥២តើអ្នកអាចថ្លែងគោលការណ៍មួយដែលអាចដឹកនាំយើងនៅក្នុងការដើរតាមគំរូរបស់ព្រះយេស៊ូវយ៉ាងដូចម្តេច ? (សិស្សគួរឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវតាមរយៈការទទួលប្រាជ្ញា និង ការរីកចម្រើនខាងរូបកាយ ខាងវិញ្ញាណ និង ខាងសង្គម**)។
- ហេតុអ្វីក៏វាសំខាន់សម្រាប់យើងដើម្បីអភិវឌ្ឍនៅក្នុងចំនុចទាំងបួន*នីមួយៗ*នេះ ? (ដើម្បីយើងប្រែក្លាយទៅជាមនុស្ស ដែលមានតុល្យភាពល្អ) ។
- តើអ្នកត្រូវបានប្រទានពរ នៅពេលអ្នកបានព្យាយាមធ្វើតាមគំរូរបស់ព្រះយេស៊ូវ ដោយការអភិវឌ្ឍខ្លួនអ្នកក្នុងចំណុចទាំងនេះយ៉ាងដូចម្តេច ?

ចូរសរសេរក្បាលរឿងដូចខាងក្រោមនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យចម្លងវាដាក់ទៅក្នុងសៀវភៅកំណាត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុនៃការសិក្សាព្រះគម្ពីរ ៖ *បញ្ញា ខាងរូបកាយ ខាងវិញ្ញាណ*និង*ខាងសង្គម* ។ ចូរសុំឲ្យសិស្សសរសេរនៅក្រោមផ្នែកនីមួយៗទាំងនេះនូវគោលដៅមួយសម្រាប់ការអភិវឌ្ឍថ្នាល់ខ្លួនរបស់ពួកគេ ។ ចូរលើកទឹកចិត្តសិស្សឲ្យធ្វើតាមគោលដៅទាំងនេះ ។ សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ទាំងឡាយ ដែលបានប្រាប់នៅក្នុងមេរៀនថ្ងៃនេះ ។

(ចម្លើយ ឆ្លើយនឹងលំហាត់មានដូចខាងក្រោម ៖ ១. ពិត, ២. ខុស, ៣. ពិត, ៤. ខុស, ៥. ពិត, ៦. ខុស) ។

ការរំឭកពីចំណេះចំណានខគម្ពីរ

ការធ្វើដដែលៗជួយសិស្សឲ្យចាំនូវទីតាំងនៃវគ្គចំណេះចំណានខគម្ពីរ ។ សូមប្រើកាតចំណេះចំណានបទគម្ពីរ ឬឲ្យសិស្សបង្កើតជាកាតផ្ទាល់ខ្លួនរបស់ពួកគេ ដោយសរសេរពាក្យគន្លឹះ ឬអត្ថន័យនៅផ្នែកដែលគ្មានការកត់ចំណាំ ឬសន្លឹកក្រដាស ហើយសរសេរសេចក្តីយោងនានានៅផ្នែកម្ខាងទៀត ។ សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ ចូរសុំពួកគេឲ្យធ្វើសួរគ្នាទៅវិញទៅមកដោយប្រើកាតនោះ ។ សូមអញ្ជើញសិស្សឲ្យប្រើកាតទាំងនេះញឹកញាប់ ដើម្បីសួរខ្លួនគេ និងសួរគ្នាទៅវិញទៅមក ។ អ្នកអាចនឹងប្រើតម្រុយនៅលើកាត ដើម្បីធ្វើជាសកម្មភាពប្រណាំងបទគម្ពីរជាមួយនឹងសិស្សក្នុងថ្នាក់ (សូមមើល « ប្រណាំងខគម្ពីរ » នៅក្នុងសេចក្តីបន្ថែមនៃសៀវភៅសិក្សានេះ) ។

លូកា ៣–៤

សេចក្តីផ្តើម

យ៉ូហាន បាទីស្ទ បានផ្សាយអំពីការប្រែចិត្ត ហើយបានថ្លែងទីបន្ទាល់អំពីការយាងមករបស់ព្រះមែស៊ី ។ ព្រះយេស៊ូវគ្រីស្ទ បានទទួលបុណ្យជ្រមុជទឹកដោយយ៉ូហាន រួចហើយបានតមអាហារនៅក្នុងទីរហោស្ថានអស់រយៈពេល ៤០ ថ្ងៃ ។ បន្ទាប់ពីធ្វើដំណើរទៅកាន់ស្រុកកាលីឡេ ព្រះយេស៊ូវបានប្រកាសនៅស្រុកណាសារ៉ែតថា ទ្រង់គឺជាព្រះមែស៊ី ។ មនុស្សនៅស្រុកណាសារ៉ែត បានបដិសេធទ្រង់ ហើយទ្រង់បានទៅស្រុកកាពើណិម ជាកន្លែងដែលទ្រង់បានព្យាបាលមនុស្សឈឺ និងបណ្តេញអារក្សចេញ ។

យោបល់សម្រាប់ការបង្រៀន

លូកា ៣:១–២២

យ៉ូហាន បាទីស្ទ ព្យាករអំពីព្រះយេស៊ូវគ្រីស្ទ

ពីមុនថ្នាក់រៀន ចូរសុំឲ្យសិស្សម្នាក់សិក្សាដំណើររឿងរបស់អេលីយ៉ា និងស្ត្រីមេម៉ាយនៅឯ សារិបតា នៅក្នុងពង្សាវតាក្សត្រទី ១ ១៧:១–១៦ ហើយសិស្សផ្សេងទៀតសិក្សាដំណើររឿងរបស់ ណាម៉ាន់ និង អេលីសេ នៅក្នុងពង្សាវតាក្សត្រទី ២ ៥:១–១៥។ ចូរពន្យល់ថា ពួកគេនឹងផ្តល់នូវសេចក្តីសង្ខេបមួយអំពីដំណើររឿងទាំងនេះនៅក្នុងមេរៀននាពេលក្រោយ ។ ចូរសុំឲ្យពួកគេគូសបញ្ជាក់អំពីអ្វីដែល ណាម៉ាន់ និង ស្ត្រីមេម៉ាយនៅឯសារិបតា បានធ្វើ ដើម្បីបង្ហាញពីសេចក្តីជំនឿរបស់ពួកគេ និងដើម្បីចង្អុលបង្ហាញថា ពួកគាត់ទាំងពីរគឺជាពួកសាសន៍ដទៃ (ពុំមែនជាវង្សអ៊ីស្រាអែលទេ) ។

ដើម្បីចាប់ផ្តើមមេរៀន ចូរសុំឲ្យសិស្សសរសេរនៅលើក្រដាសមួយអំពីគ្រាមួយ ដែលពួកគេមានអារម្មណ៍ថាបែកចេញ ឬនៅដាច់ដោយឡែកពីអ្នកទាំងឡាយដែលនៅជុំវិញពួកគេ ជាលទ្ធផលមកពីការរស់នៅតាមដំណឹងល្អ ដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ (ចូរប្រាកដថា សិស្សមិនត្រូវសរសេរឈ្មោះរបស់ពួកគេនៅលើក្រដាសពួកគេឡើយ) ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សឲ្យក្រដាសរបស់ពួកគេមកអ្នក ។ សូមអានន្ទរបទពិសោធន៍ពីរបីឲ្យឮៗដល់សិស្សក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាលូកា ៣:១–២២ ដើម្បីអាចពន្យល់ពីមូលហេតុ ដែលអ្នកទាំងឡាយដែលរស់នៅតាមដំណឹងល្អ ជួនកាលអាចនឹងមានអារម្មណ៍ថាបែកចេញពីអ្នកដទៃ ។

សូមពន្យល់ថា នៅក្រោមក្រឹត្យវិន័យរបស់ម៉ូសេ សង្ឃជាន់ខ្ពស់ ធ្វើកិច្ចការដូចជាអ្នកកាន់តំណែងជាអធិបតីនៃបព្វជិតភាពអើរ៉ុន និងអ្នកដឹកនាំនយោបាយនៃជាតិសាសន៍អ៊ីស្រាអែល ។ ទោះជាយ៉ាងណាក៏ដោយ មកដល់ជំនាន់នៃការបម្រើរបស់ព្រះអង្គសង្គ្រោះ តំណែងនៃសង្ឃជាន់ខ្ពស់បានក្លាយទៅជាពុករលួយ ។ ជាជាងត្រូវបានជ្រើសរើសដោយព្រះ នោះសង្ឃជាន់ខ្ពស់ត្រូវបានជ្រើសរើសដោយមនុស្ស ដូចជា ហេរ៉ូឌ និងមន្ត្រីជនជាតិរ៉ូមផ្សេងទៀត (សូមមើល Bible Dictionary« High Priest ») ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ៣:២–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាតើព្រះបានមានបន្ទូលទៅកាន់នរណាជំនួសឲ្យពួកសង្ឃជាន់ខ្ពស់ ។

- តើព្រះបន្ទូលនៃព្រះអម្ចាស់មានមកតាមរយៈនរណា ជាជាងមកតាមពួកសង្ឃជាន់ខ្ពស់ ? (« យ៉ូហាន ជាកូនប្រុសរបស់សាការី » ក៏ត្រូវបានគេស្គាល់ថាជា យ៉ូហាន បាទីស្ទ ដែរ) ។
- តើយ៉ូហាន បាទីស្ទ បានបង្រៀនអំពីអ្វីខ្លះ ?

ចូរពន្យល់ថា នៅក្នុងជំនាន់របស់យ៉ូហាន មនុស្សមួយចំនួនបានជឿថា ដោយសារតែពួកគេជាកូនចៅរបស់អ័ប្រាហាំ នោះពួកគេត្រូវបានព្រះស្រឡាញ់ច្រើនជាង ឬល្អជាងពួកសាសន៍ដទៃ ដែលពុំមែនជាពួកសាសន៍អ៊ីស្រាអែល ។ សូមអញ្ជើញសិស្សម្នាក់អានលូកា ៣:៧–៩ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលយ៉ូហាន បាទីស្ទ បានបង្រៀនថា ពួកសាសន៍យូដាចាំបាច់ត្រូវធ្វើកិច្ចការដែលសព្វព្រះទ័យដល់ព្រះ ។

- តើយ៉ូហានបានបង្រៀនដល់ពួកយូដាអ្វីខ្លះ ដែលពួកគេចាំបាច់ត្រូវធ្វើដើម្បីសរសើរដល់ព្រះ ? (ចូរពន្យល់ថា « ផលផ្លែ » គឺជានិមិត្តរូបមួយនៃលទ្ធផលដែលយើងជ្រើសរើស) ។
- យោងតាមខ ទី ៩តើអ្វីខ្លះនឹងកើតឡើងចំពោះអ្នកទាំងឡាយ ដែលពុំនាំមកនូវ «ផលល្អ» ឬរស់នៅដោយសុចរិតនោះ ?

សូមសង្ខេបលូកា ៣:១០–១៥ ដោយពន្យល់ថា យ៉ូហាន បានបង្រៀនដល់ក្រុមយូដាជាក់លាក់ អំពីរបៀបដែលពួកគេអាចនាំមកនូវផលល្អនោះ ។ ការបម្រើរបស់យ៉ូហាន គឺគួរឲ្យសរសើរណាស់ ហើយមនុស្សមួយចំនួនបានគិតថា គាត់ប្រហែលជាព្រះមែស៊ី ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានម៉ាកុស ១០:១៦–១៧ឮៗ ហើយសុំឲ្យសិស្សរកមើលនូវអ្វីដែលយ៉ូហានបានថ្លែងអំពីព្រះមែស៊ីនឹងធ្វើពេលទ្រង់យាងមក ។

- តើយ៉ូហានបាននិយាយថា ការយាងមករបស់ព្រះមែស៊ីនឹងធ្វើអ្វីខ្លះ ?

ចូរពន្យល់ថាឃ្លា « នឹងធ្វើបុណ្យជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនិងភ្លើងវិញ » (ខទី ១៦) សំដៅទៅលើឥទ្ធិពលក្នុងការទទួលយកអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធឲ្យបានទៅជាបរិសុទ្ធ និងព្រៃកចេញជាបរិសុទ្ធ ។

ដើម្បីជួយសិស្សយល់ខទី ១៧បន្ថែមទៀត សូមដាក់បង្ហាញនូវគ្រាប់ស្រូវ ឬគ្រាប់ធ្ញូសតូចៗ និងកំទេចរណារ ឬកំទេចក្រដាសតូចៗពេញមួយក្បាំដៃ ។ សូមដាក់លាយគ្រាប់ស្រូវ និងកំទេចរណារជាមួយគ្នា ហើយដាក់វានៅក្នុងថាសសំប៉ែតមួយ ។

- តើមនុស្សម្នាក់អាចព្រៃកគ្រាប់ស្រូវចេញពីកំទេចរណារបានយ៉ាងដូចម្តេច ?

សូមពន្យល់ថា បន្ទាប់ពីស្រូវត្រូវបានច្រូតកាត់ និងបោកបែនរួចហើយ (នៅពេលដែលគ្រាប់ស្រូវបំបែកចេញពីកណ្តាប់) នោះគ្រាប់ស្រូវនឹងត្រូវបានអុំចេញ ។ ការអុំស្រូវគឺជាវិធីពីបុរាណ ដែលប្រើដើម្បីព្រៃកគ្រាប់ស្រូវចេញពីអង្កាម (សំបកខាងក្រៅ) និងសំបកស្រូវ ។ ការអុំស្រូវនឹងប្រើនូវប៉ែល ឬរនាស់ឈើ (បកប្រែនៅក្នុងគម្ពីរថា « អុំ ») ដើម្បីបោះស្រូវដែលបែនហើយទៅលើខ្យល់ ។ បន្ទាប់មកខ្យល់នឹងបក់ជាត់អ្វីដែលស្រាល អង្កាមដែលមិនចង់បាននោះចេញ ហើយគ្រាប់ស្រូវដែលធ្ងន់នឹងធ្លាក់ចុះនៅក្នុងគំនរមួយនៅលើកន្លែងដែលបែននោះ ។

ដើម្បីបង្ហាញគំនិតនេះ សូមដាក់បង្ហាញនូវផ្លិតដៃមួយ (អ្នកអាចប្រើក្រដាសរឹង ក្រដាសកាតុង ឬក្រដាសបត់មកបក់បើចាំបាច់) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្តារខៀន ហើយសុំឲ្យគាត់ឬនាង បកផ្លិតទៅលើគ្រាប់ស្រូវ និងកំទេចរណារ ។ នៅពេលសិស្សបកផ្លិត សូមអុំគ្រាប់ស្រូវ និងកំទេចរណារដែលដាក់លាយគ្នានោះដោយថ្នមៗ ដើម្បីឲ្យខ្យល់ដែលកំពុងតែមានចលនា បក់នូវកំទេចរណារចេញខណៈដែលគ្រាប់ស្រូវធ្លាក់ចុះទៅលើថាសវិញ ។ សូមអញ្ជើញឲ្យសិស្សទៅកាន់កន្លែងអង្គុយវិញ ។

- តើស្រូវ និងអង្កាមតំណាងឲ្យអ្វីខ្លះ ? (ស្រូវតំណាងឲ្យមនុស្សសុចរិត ហើយអង្កាមតំណាងឲ្យមនុស្សអាក្រក់) ។
- យោងតាមខទី ១៦–១៧តើនរណាព្រៃកមនុស្សសុចរិតចេញពីមនុស្សអាក្រក់ ? (បន្ទាប់ពីសិស្សបានឆ្លើយសូមសរសេរសេចក្តីពិតខាង ក្រោមនៅលើក្តារខៀន ៖ **ព្រះយេស៊ូវគ្រីស្ទ ព្រៃកមនុស្សល្អចេញពីមនុស្សអាក្រក់**) ។
- ទោះបីជាមានការព្រៃកមនុស្សល្អចេញពីមនុស្សអាក្រក់នៅទីបំផុត នឹងកើតមាននៅថ្ងៃជំនុំជំរះក្តី តើការធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងការរស់នៅតាមដំណឹងល្អរបស់ទ្រង់ ធ្វើឲ្យពួកសិស្សរបស់ទ្រង់ត្រូវបានព្រៃកចេញពីអ្នកដទៃក្នុងពេលនេះតាមរបៀបណា ?
- ហេតុអ្វីក៏យើងចាំបាច់ត្រូវយល់ថា ការព្យាយាមធ្វើតាមព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅតាមដំណឹងល្អរបស់ទ្រង់ អាចធ្វើឲ្យយើងត្រូវបាន ឬមានអារម្មណ៍ថាព្រៃកចេញពីអ្នកដទៃ ?

សូមសង្ខេបលូកា ៣:១៨–២២ដោយការពន្យល់ថា ព្រះយេស៊ូវបានយាងមកទទួលបុណ្យជ្រមុជទឹកដោយយ៉ូហាន បាទីស្ទ ។ ក្រោយមកទៀត យ៉ូហាន បាទីស្ទ ត្រូវចាប់ដាក់ក្នុងគុកដោយស្តេចហេរ៉ូឌ ។

លូកា ៣:២៣–៣៨

តំណពូជពង្សរបស់ព្រះយេស៊ូវត្រូវបានកើតមានឡើង

សូមសង្ខេបលូកា ៣:២៣–៣៨ដោយពន្យល់ថា លូកាបានដាក់បញ្ចូលពង្សាវតារបស់ព្រះយេស៊ូវ ហើយថ្លែងទីបន្ទាល់ថា យ៉ូសែបគឺត្រូវបាន « ជាប់ជា » ឪពុក (ពុំពិត) របស់ព្រះយេស៊ូវ ដែលជាព្រះរាជបុត្រានៃព្រះ ។

លូកា ៤:១–១៣

ព្រះយេស៊ូវត្រូវបានល្បួងដោយសាតាំងនៅក្នុងទីរហោស្ថាន

ចូរពន្យល់ថាលូកា ៤:១–១៣ មានន័យដំណើររឿងមួយអំពីការតមអាហាររបស់ព្រះយេស៊ូវអស់រយៈពេល ៤០ ថ្ងៃនៅក្នុងទីរហោស្ថាន និងការបដិសេធនឹងការល្បួងរបស់សាតាំង ។

លូកា ៤:១៤–៣០

ព្រះយេស៊ូវគ្រីស្ទប្រកាសថា ទ្រង់គឺជាព្រះមែស៊ី

*សូមសរសេរពាក្យ**សរសើរ** **វាយដំរណ្តើយ** **ក្រីក្រ*** និង***ខ្វាក់***នៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សពិចារណាអំពីគ្រាមួយ ពេលពាក្យមួយ ឬច្រើនទាំងនេះ អាចនឹងពិពណ៌នាអំពីរបៀបដែលពួកគេមានអារម្មណ៍អំពីខ្លួនពួកគេ ។ សូមអញ្ជើញពួកគេនៅពេលពួកគេសិក្សាលូកា ៤:១៤–៣០រកមើលរបៀប ដែលពួកគេអាចនឹងរកបាននូវការសម្រាលអារម្មណ៍ទាំងនេះ ។

សូមសង្ខេបលូកា ៤:១៤–១៧ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវត្រឡប់មកពីទីរហោស្ថាន ទ្រង់បានចាប់ផ្តើមផ្សាយ នៅក្នុងសាលាជំនុំនៅស្រុកកាលីឡេ ។ មិនយូរប៉ុន្មាន ទ្រង់ត្រឡប់ទៅកាន់ស្រុកកំណើតរបស់ទ្រង់វិញ គឺណាសារ៉ែត ។ ខណៈពេលនៅទីនោះ ទ្រង់បានគង់ នៅក្នុងសាលាជំនុំមួយ ហើយអានចេញពីគម្ពីរអេសាយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានលូកា ៤:១៨–២១ ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលលោកអេសាយបានបង្រៀនអំពីបេសកកម្មដ៏ទេវភាពរបស់ព្រះមែស៊ី ។

- តើព្រះយេស៊ូវបានថ្លែងទីបន្ទាល់អ្វីខ្លះ ទៅកាន់ប្រជាជននៅក្នុងស្រុកកំណើតរបស់ទ្រង់ គឺស្រុកណាសារ៉ែត ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ព្រះយេស៊ូវ គឺជាព្រះមែស៊ីដែលត្រូវបានបញ្ជូនឲ្យមកព្យាបាលចិត្តសង្រេង ហើយរំដោះអ្នកទាំងឡាយដែលស្ថិតនៅក្នុងការចាប់ជាឈ្លើយខាងវិញ្ញាណ**) ។
- តើបទពិសោធន៍អ្វីខ្លះដែលអ្នកមាន ដែលបង្ហាញអ្នកថា ព្រះយេស៊ូវគ្រីស្ទ បន្តព្យាបាល និងរំដោះយើងនៅក្នុងសម័យរបស់យើង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានលូកា ៤:២២ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលមនុស្សនៅស្រុកណាសារ៉ែត បានឆ្លើយតបចំពោះការប្រកាសដ៏ឥតញញើតរបស់ទ្រង់ថា ទ្រង់គឺជាព្រះមែស៊ីដែលគេបានទន្ទឹងរង់ចាំនោះ ។

- តើប្រជាជនបានមានប្រតិកម្មចំពោះការប្រកាសរបស់ព្រះយេស៊ូវយ៉ាងដូចម្តេច ?
- ផ្អែកទៅលើខទី ២២តើហេតុអ្វីក៏អ្នកគិតថាប្រជាជននៃស្រុកណាសារ៉ែត មានការលំបាកមួយដើម្បីជឿថា ព្រះយេស៊ូវ គឺជាព្រះមែស៊ី ?

សូមសង្ខេបលូកា ៤:៣៣ដោយពន្យល់ថា ព្រះយេស៊ូវ បានដឹងថាប្រជាជននៅស្រុកណាសារ៉ែត នឹងល្បងទ្រង់ដើម្បីឲ្យទ្រង់បង្ហាញដល់គេថាទ្រង់គឺជាព្រះមែស៊ី ដោយការធ្វើអព្ភូតហេតុទាំងឡាយ ដែលទ្រង់បានធ្វើនៅស្រុកកាពើណិមឡើងវិញ ។

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗលូកា ៤:២៤–២៧ ដោយស្ងប់ស្ងាត់ រក មើលដំណើររឿងព្រះគម្ពីរសញ្ញាចាស់ពីរ ដែលព្រះអង្គសង្គ្រោះបានយោងទៅ នៅពេលទ្រង់បានតបនឹងប្រជាជននៃស្រុកណាសារ៉ែត ។ (អ្នកអាចនឹងចាំបាច់ត្រូវបញ្ជាក់ថា អេលីយ៉ា សំដៅទៅលើអេលីយ៉ា ហើយអេលីសេ សំដៅទៅលើអេលីសេ) ។ ចូរសុំឲ្យសិស្សរៀបរាប់ពីអ្វី ដែលពួកគេរកឃើញ ។

ចូរសុំឲ្យសិស្សពីរនាក់ដែលអ្នកបានអញ្ជើញកាលពីមុនឲ្យសិក្សាដំណើររឿងទាំងនេះ ធ្វើបទបង្ហាញពីការសង្ខេបរបស់ពួកគេ ។ បន្ទាប់មក ចូរពន្យល់ថា ព្រះយេស៊ូវបានបង្រៀនដល់អ្នកទាំងឡាយនៅស្រុកណាសារ៉ែតថា ទោះជាមានស្ត្រីមេម៉ាយ និងមនុស្សឃ្លង់ជាច្រើនជាពួកអ៊ីស្រាអែលក្តី ក៏មានអ្នកពុំមែនជាពួកអ៊ីស្រាអែលពីរូប (ជាសាសន៍ដទៃ) ដែលបានជូបនឹងអព្ភូតហេតុផងដែរ ។

- តើណាម៉ាន និងស្ត្រីមេម៉ាយនៃសារិបតា បានបង្ហាញពីសេចក្តីជំនឿដោយរបៀបណា ?
- តើសេចក្តីជំនឿរបស់ណាម៉ាន និងស្ត្រីមេម៉ាយ ខុសពីជំនឿនៃមនុស្សនៅស្រុកណាសារ៉ែតយ៉ាងដូចម្តេច ?

សូមចង្អុលបង្ហាញថា ព្រះយេស៊ូវបានធ្វើអព្ភូតហេតុមួយចំនួននៅស្រុកណាសារ៉ែត ដោយសារមនុស្សជាទូទៅពុំមានជំនឿទៅលើទ្រង់ (សូមមើលម៉ាថាយ ១៣:៥៤–៥៨,ម៉ាកុស ៦:១–៦) ។

- តើមានគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនអំពីសេចក្តីជំនឿ នៅពេលយើងមានភាពផ្ទុយគ្នា ជាមួយមនុស្សនៅស្រុកណាសារ៉ែត ជាមួយនឹងស្ត្រីមេម៉ាយ និងណាម៉ាន់ ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចមើលឃើញអព្ភូតហេតុជាច្រើនកើតឡើង**) ។

> *ប្រៀបធៀបគ្នា និង ភាពផ្ទុយ*
>
> សារលិខិតមួយនៃបទគម្ពីរ ត្រូវបានបញ្ជាក់ជាញឹកញាប់ នៅពេលវាត្រូវបានប្រៀបធៀបគ្នា និង ភាពផ្ទុយគ្នាជាមួយអ្វីផ្សេងទៀត ។ សូមជួយសិស្សកត់ចំណាំពីភាពដូចគ្នា ឬ ខុសគ្នារវាងការបង្រៀនមនុស្ស ឬ ព្រឹត្តិការណ៍ ដែលអាចនាំសេចក្តីពិតនៃដំណឹងល្អ ចូលទៅក្នុងដួងចិត្តពួកគេដ៏ជ្រៅជ្រះ ។

ចូរសុំឲ្យសិស្សឡើងមកក្តារខៀន ហើយសរសេររបៀបដែលយើងអាចបង្ហាញសេចក្តីជំនឿរបស់យើងថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះរបស់យើង ។ ក្រោយពីសិស្សបានបំពេញបញ្ចប់ការសរសេរ រួចហើយសូមសួរ ៖

- តើមានឧទាហរណ៍នៃពរជ័យ ឬអព្ភូតហេតុអ្វីខ្លះ ដែលកើតមានឡើង តែនៅពេលយើងធ្វើសកម្មភាពប្រកបដោយសេចក្តីជំនឿជាមុននោះតែប៉ុណ្ណោះ ?

សូមអញ្ជើញសិស្សម្នាក់អានលូកា ៤:២៨–៣០ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀបដែលក្រុមជំនុំឆ្លើយតបនឹងព្រះយេស៊ូវ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើដំណើររឿងនេះបង្ហាញអំពីរបៀប ដែលព្រះយេស៊ូវបានព្យែកពួកមនុស្សអាក្រក់ចេញពីមនុស្សសុចរិតដោយរបៀបណា ? (សូមមើល លូកា ៣:១៧) ។

លូកា ៤:៣១–៤៤

ព្រះយេស៊ូវបានបណ្តេញអារក្សចេញ ហើយបានព្យាបាលអ្នកឈឺ

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញពួកគេឲ្យអានលូកា ៤:៣១–៤៤ឮៗជាមួយនឹងដៃគូរបស់ពួកគេ ហើយរកមើលពរជ័យ ដែលមនុស្សនៅស្រុកកាពើណិម បានទទួល ប្រៀបធៀបនឹងពរជ័យនៃមនុស្សនៅស្រុកណាសារ៉ែតបានទទួល ។ បន្ទាប់ពីពួកគេបានអាន សូមអញ្ជើញពួកគេឲ្យពិភាក្សាអំពីចម្លើយរបស់ពួកគេចំពោះសំណួរដូចខាងក្រោម ជាមួយនឹងដៃគូរបស់ពួកគេ (អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖

- តើមនុស្សនៅស្រុកកាពើណិមបានឆ្លើយតបចំពោះព្រះយេស៊ូវផ្សេងគ្នាយ៉ាងដូចម្តេច បើប្រៀបធៀបនឹងអ្នកទាំងឡាយនៅស្រុកណាសារ៉ែត ?
- តើមនុស្សនៅស្រុកកាពើណិម បានទទួលពរជ័យអ្វីខ្លះ បើប្រៀបធៀបនឹងពរជ័យដែលមនុស្សនៅស្រុកណាសារ៉ែតបានទទួល ?
- តើដំណើររឿងទាំងនេះបង្ហាញអំពីគោលការណ៍ដែលថា នៅពេលយើងបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវ នោះយើងអាចមើលឃើញអព្ភូតហេតុជាច្រើនកើតឡើងយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរពីរចុងក្រោយជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមបញ្ចប់មេរៀនដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ និងអំពីដំណឹងល្អដែលអ្នកបានទទួល នៅពេលអ្នកបានបង្ហាញសេចក្តីជំនឿទៅលើទ្រង់ ។ ចូរសុំឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវរបៀបជាច្រើនដែលពួកគេអាចបង្ហាញសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញពួកគេឲ្យដាក់គោលដៅមួយ ដើម្បីធ្វើរឿងដែលពួកគេសរសេរចុះនោះ ។

មេរៀនសិក្សានៅផ្ទះ

ម៉ាកុស ១០–លូកា ៤ (មេរៀនទី ៩)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ាកុស ១០–លូកា ៤ (មេរៀនទី ៩) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ាកុស ១០–១៦)

នៅពេលសិស្សសិក្សាអំពីការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យនាំកុមារតូចៗមករកទ្រង់ នោះពួកគេបានរៀនថា នៅពេលយើងទទួលដំណឹងល្អដូចជាកុមារតូចៗ នោះយើងនឹងត្រូវបានរៀបចំខ្លួន ដើម្បីចូលក្នុងនគរព្រះ ។ នៅពេលពួកគេអានអំពីការដាស់តឿនរបស់ព្រះយេស៊ូវគ្រីស្ទទៅដល់កម្លោះអ្នកមាន នោះពួកគេបានរៀនថា ដោយសារទ្រង់ស្រឡាញ់យើង នោះព្រះអម្ចាស់នឹងជួយយើងឲ្យដឹងនូវអ្វី ដែលយើងខ្វះខាតនៅក្នុងកិច្ចខិតខំរបស់យើង ដើរតាមទ្រង់ ហើយបើយើងទូលសូមដល់ព្រះអម្ចាស់ នោះទ្រង់នឹងបង្រៀនយើងអំពីអ្វីដែលយើងចាំបាច់ត្រូវធ្វើដើម្បីទទួលគ្រងជីវិតដ៏នៅអស់កល្បជានិច្ច ។ ដំណើររឿងរបស់ស្ត្រីមេម៉ាយដែលថ្វាយប្រាក់ស្លឹង និងអំពីម៉ារាចាក់ប្រេងតាំងថ្វាយព្រះអង្គសង្គ្រោះ បានជួយសិស្សឲ្យរៀនថា ប្រសិនបើយើងមានឆន្ទៈដើម្បីផ្តល់នូវអ្វីៗទាំងអស់ ដែលយើងមានថ្វាយព្រះអម្ចាស់ នោះទ្រង់នឹងទទួលយកដង្វាយរបស់យើង ទោះជាវាមើលទៅតិចតួច បើប្រៀបទៅនឹងអ្នកដទៃក្តី ហើយថាព្រះអង្គសង្គ្រោះសព្វព្រះទ័យ នៅពេលយើងថ្វាយអស់ពីលទ្ធភាពទៅទ្រង់ ។

ថ្ងៃទី ២ (លូកា ១)

នៅក្នុងមេរៀននេះ សិស្សបានសិក្សាអំពីការសន្យារបស់ទេវតាកាព្រីយ៉ែលថា សាការី និងអេលីសាបិត នឹងមានកូនប្រុសម្នាក់ ។ ពួកគេក៏បានរៀនផងដែរថា កាព្រីយ៉ែលបានប្រាប់ម៉ារាថា នាងនឹងធ្វើជាមាតានៃព្រះរាជបុត្រារបស់ព្រះ ។ ចេញមកពីបទគម្ពីរទាំងនេះ សិស្សបានរៀនពីសេចក្តីពិតដូចខាងក្រោម ៖ ព្រះបន្ទូលរបស់ព្រះអម្ចាស់ថ្លែងតាមរយៈពួកអ្នកបម្រើរបស់ទ្រង់ នឹងត្រូវបានបំពេញនៅពេលកំណត់ ។ ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ជាព្រះបិតា ។ ការអ្វីដែលព្រះទ្រង់ធ្វើពុំបាន នោះគ្មានសោះឡើយ ។ ប្រសិនបើយើងព្យាយាមបំពេញតួនាទីដែលព្រះអម្ចាស់មានសម្រាប់យើងដោយស្មោះត្រង់ នោះទ្រង់អាចធ្វើរឿងអស្ចារ្យជាច្រើននៅក្នុងជីវិតរបស់យើង ។

ថ្ងៃទី ៣ (លូកា ២)

នៅពេលសិស្សបានសិក្សាអំពីការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ នោះពួកគេបានរៀនថា ដោយសារតែព្រះអង្គសង្គ្រោះបានប្រសូត្រមកលើផែនដី នោះយើងអាចទទួលបទពិសោធន៍សេចក្តីអំណរដ៏មហិមា ។ ពួកគេនឹងរៀនថា នៅពេលយើងស្តាប់តាមការណែនាំរបស់ព្រះ នោះយើងអាចទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនយើង អំពីព្រះយេស៊ូវគ្រីស្ទ ហើយនៅពេលយើងទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើង អំពីព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងចង់ចែកចាយទីបន្ទាល់របស់យើងជាមួយអ្នកដទៃផងដែរ ។ នៅពេលសិស្សសិក្សាអំពីឃុវីយរបស់ព្រះយេស៊ូវ នោះពួកគេបានរៀនថា យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវ តាមរយៈការទទួលបានប្រាជ្ញា និងការរីកចម្រើនខាងរូបកាយ ខាងវិញ្ញាណ និងខាងសង្គម ។

ថ្ងៃទី ៤ (ម៉ាថាយ ៣–៤)

នៅក្នុងមេរៀននេះ សិស្សបានរៀនអំពីយ៉ូហាន បាទីស្ទ និងអំពីពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេក៏បានរៀនផងដែរ អំពីការប្រកាសរបស់ព្រះយេស៊ូវនៅក្នុងស្រុកណាសារ៉ែតថា ទ្រង់គឺជាព្រះមែស៊ី ។ ចេញមកពីដំណើររឿងទាំងនេះ សិស្សបានរៀនពីសេចក្តីពិតដូចខាងក្រោម ៖ ព្រះយេស៊ូវគ្រីស្ទ ញែកមនុស្សសុចរិតចេញពីមនុស្សទុច្ចរិត ។ ព្រះយេស៊ូវ គឺជាព្រះមែស៊ីដែលត្រូវបានបញ្ជូនឲ្យមកព្យាបាលចិត្តសង្រេង ហើយរំដោះអ្នកទាំងឡាយដែលស្ថិតនៅក្នុងការចាប់ជាឈ្លើយខាងវិញ្ញាណ ។ នៅពេលយើងបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចមើលឃើញអព្ភូតហេតុកើតឡើងជាច្រើន ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់អំពីការរងទុក្ខមួយចំនួន ដែលព្រះយេស៊ូវបានទទួលរងជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ ។ បន្ថែមពីលើនោះ សិស្សនឹងបានយល់នូវមូលហេតុមួយចំនួនថា ហេតុអ្វីព្រះអង្គសង្គ្រោះរងទុក្ខសម្រាប់យើង ។

យោបល់សម្រាប់ការបង្រៀន

ម៉ាកុស ១៤:១០–១៦:២០

ព្រះយេស៊ូវ បានចាប់ផ្តើមដង្វាយធួនរបស់ទ្រង់ នៅពេលទ្រង់រងទុក្ខនៅសួនច្បារគែតសេម៉ានី សម្រាប់អំពើបាបរបស់យើង ទ្រង់បានត្រូវយូដាស អេស្ការីយ៉ុតក្បត់ ហើយបាននាំទៅឈរចំពោះមុខពួកអ្នកដឹកនាំសាសន៍យូដា

សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងាត់ៗនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្លាប់មានអារម្មណ៍ថា គ្មាននរណាយល់ពីអ្នក ឬយល់ពីអ្វីដែលអ្នកកំពុងតែឆ្លងកាត់ដែរឬទេ ?
- តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកមិនអាចត្រូវបានអភ័យទោសពីអំពើបាបពីអតីតកាលរបស់អ្នកឬទេ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាម៉ាកុស ១៤ដែលអាចជួយនរណាម្នាក់ដែលប្រហែលជាមានអារម្មណ៍ទាំងនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាកុស ១៤:៣២–៣៤ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលនូវរបៀបដែលព្រះអង្គសង្គ្រោះមានព្រះទ័យយ៉ាងណានៅក្នុងសួនច្បារគែតសេម៉ានី ។

- តើព្រះអង្គសង្គ្រោះមានព្រះទ័យយ៉ាងណានៅក្នុងសួនច្បារគែតសេម៉ានី ?

បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ឈឺចាប់ខ្លាំងបំផុត ធ្ងន់ធ្ងរបំផុត សោកសៅដ៏លើសលប់ ។*

សូមពន្យល់ថា ឃ្លាទាំងនេះ សំដៅទៅលើការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានទទួលពិសោធន៍ ជាចំណែកនៃដង្វាយធួនរបស់ទ្រង់ ។

- តើឃ្លាទាំងនេះបង្រៀនយើងអ្វីខ្លះអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ? (បន្ទាប់ពីសិស្សឆ្លើយតប សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយបានសោកសៅនៅក្នុងសួនច្បារគែតសេម៉ានី**) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ នែល អិល អាន់ឌឺរសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។



« នៅក្នុងសួនច្បារគែតសេម៉ានី ការរងទុក្ខរបស់ព្រះយេស៊ូវ បានចាប់ផ្តើម ‹ ឈឺចាប់ខ្លាំងបំផុត › (ម៉ាកុស ១៤:៣៣) ឬនៅកាសាក្រិក ‹ លើសលប់ › និង ‹ ជិញ្ជ៉ូរន្ធត់ › ។

« សូមស្រមៃមើល ព្រះយេហូវ៉ា ដែលជាព្រះបង្កបង្កើតនៃពិភពលោកនេះ និងពិភពដទៃ ‹ បានញ័ររន្ធត់ › ! ។ . . . ទ្រង់ពុំបានដឹងដោយផ្ទាល់ អំពីដំណើរការនៃដង្វាយធួនថាឈឺចាប់ប៉ុណ្ណាពីមុននោះទេ ។ ដូច្នេះ នៅពេលការឈឺចាប់បានដល់កម្រិតពេញលេញរបស់វា វាធ្ងន់ធ្ងរពេកក្រៃ មានភាពដុនដាបយ៉ាងខ្លាំង សូម្បីតែទ្រង់ដែលមានប្រាជ្ញាវាងវៃល្អឯក មិនអាចនឹកស្រមៃដល់ឡើយ ! វាពុំគួរឲ្យងឿងឆ្ងល់ទេ ថា ហេតុអ្វីទេវតាមួយអង្គលេចមកដើម្បីចម្រើនកម្លាំងដល់ទ្រង់ ! (សូមមើល លូកា ២២:៤៣) ។

« ទម្ងន់សរុបនៃអំពើបាបខាងសាច់ឈាមទាំងអស់—ពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល —បានសង្កត់សង្កិនលើព្រលឹងដ៏ឥតខ្ចោះ គ្មានអំពើបាបសោះ និងញាណដឹងនោះ ! ទុក្ខវេទនា និងដំណឹងទាំងឡាយរបស់យើងក៏ជាផ្នែកមួយនៃការគុណតម្កើងដ៏ច្រើនពន់ពេកនៃដង្វាយធួននេះដែរ ។ (សូមមើល អាលម៉ា ៧:១១–១២, អេសាយ ៥៣:៣–៥, ម៉ាថាយ ៨:១៧) ។ . . .

« នៅក្នុងគ្រាដ៏លំបាកនេះ តើទ្រង់ប្រហែលជាសង្ឃឹមថានឹងមានការសង្គ្រោះចៀមឈ្មោលពីព្រៃឬទេ ? ខ្ញុំមិនដឹងទេ ។ ការរងទុក្ខរបស់ទ្រង់—តាមដែលវាកើតឡើង វាត្រូវបានគុណធ្វើដង*អនន្ត*ដោយ*និរន្តរភាព*—បានបួងសួងដល់ព្រលឹងដ៏ឥតប្រៀបរបស់ទ្រង់នៅលើឈើឆ្កាង ហើយវាគឺជាសម្រែកយំនៃការលះបង់ ។ (សូមមើល ម៉ាថាយ ២៧:៤៦) ។ . . .

« ដង្វាយធួនដ៏រុងរឿង និងអស្ចារ្យ គឺជាទង្វើដ៏សំខាន់បំផុត នៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោកទាំងអស់ ។ វាគឺជាត្រចៀកទ្វារដែលអ្វីៗទាំងអស់ផ្សេងទៀត ដែលសំខាន់ត្រូវបានបើកឡើងនៅទីបំផុត ។ ប៉ុន្តែវាងាកទៅរកការចុះចូលដោយរាបសារ ខាងវិញ្ញាណរបស់ព្រះយេស៊ូវ ! » (« *Willing to Submit* »*Ensign* ខែ ឧសភា ឆ្នាំ ១៩៨៥ ទំព័រ ៧២–៧៣) ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង ម៉ាកុស ១៤:៣៥–៤២ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ ដោយសារការរងទុក្ខដ៏ខ្លាំងរបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានធ្វើដូចម្តេច ដោយសារតែការរងទុក្ខដ៏ខ្លាំងរបស់ទ្រង់នោះ ? (សូមជួយសិស្សឲ្យយល់ថា ការរងទុក្ខរបស់ព្រះយេស៊ូវគឺធ្ងន់ធ្ងរក្រៃលែង ដែលទ្រង់បានទូលអង្វរ បើអាចធ្វើទៅបានចំពោះទ្រង់ នោះសូមកុំឲ្យទទួលបទពិសោធន៍នេះអី) ។

សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន ៖ *ព្រះយេស៊ូវគ្រីស្ទ បានរងទុក្ខ . . .ដើម្បីទ្រង់ . . .*

សូមពន្យល់ថា វគ្គបទគម្ពីរផ្សេងទៀតអាចជួយយើងយល់អំពីការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទ និងមូលហេតុដែលទ្រង់ស្ម័គ្រព្រះទ័យ ដើម្បីរងទុក្ខសម្រាប់យើង ។

សូមសរសេរសេចក្តីយោងដូចខាងក្រោមនេះនៅលើ ក្តារខៀន ៖ *អេសាយ ៥៣:៣–៥*និង*អាលម៉ា ៧:១១–១៣* ។ សូមបំបែកសិស្សទៅជាគូៗ ហើយអញ្ជើញពួកគេឲ្យអានខគម្ពីរដោយម្នាក់ម្តងៗ ដោយរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានរងទុក្ខ និងហេតុអ្វីក៏ទ្រង់បានរងទុក្ខ ។ ចូរសូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរបស់ពួកគេថា តើពួកគេនឹងបំពេញឃ្លា ដែលបានសរសេរនៅលើក្តារខៀន ដោយប្រើនូវអ្វីដែលពួកគេបានរៀននៅក្នុងអេសាយ ៥៣:៣–៥ និងអាលម៉ា ៧:១១–១៣យ៉ាងដូចម្តេច ។ (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យដ្ឋ*យ*នៅក្នុងអាលម៉ា ៧:១២មានន័យថា ប្រញាប់ដើម្បីផ្តល់នូវការសង្គ្រោះ ឬទៅកេជំនួយរបស់នរណាម្នាក់ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបួនប្រាំនាក់ ចែកចាយរបៀបដែលពួកគេបានបំពេញឃ្លានោះ ។ ចម្លើយរបស់ពួកគេគួរតែស្រដៀងគ្នាដូចខាងក្រោម ៖ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខនូវការឈឺចាប់ ក្តីទុក្ខលំបាក ការល្បួង ជំងឺ រោគា និងការសោកសៅរបស់យើង ដើម្បីទ្រង់អាចនឹងដឹងរបៀបដើម្បីជួយយើង ។ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខសម្រាប់អំពើបាបរបស់យើង ដើម្បីទ្រង់អាចនឹងលុបអំពើរំលងរបស់យើងចេញ ។ សូមរំឭកសិស្សថា ការរងទុក្ខរបស់ព្រះអង្គសង្គ្រោះសម្រាប់អំពើបាបរបស់មនុស្សលោក បានចាប់ផ្តើមនៅក្នុងសួនច្បារគែតសេម៉ានី ហើយបានបន្ត និងទៅដល់នៅក្នុងការឆ្កាងរបស់ទ្រង់នៅលើឈើឆ្កាង ។

ដើម្បីជួយសិស្សដឹងពីសំខាន់នៃសេចក្តីពិតដែលជាផ្នែកមួយនៃដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយបានសោកសៅនៅក្នុងសួនច្បារគែតសេម៉ានី សូមពិចារណាធ្វើការបង្ហាញវីដេអូ « *Special Witness—Elder Holland* » **(សាក្សីពិសេស—អែលឌើរ ហូឡិន) »(២:៣៨) ដែលអែលឌើរ ដៃហ្វ្រី អរ ហូឡិន នៃក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ ថ្លែងទីបន្ទាល់អំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី ។ វីដេអូនឹងមាននៅក្នុង *LDS.org* ។**

- តើការដឹងនូវអ្វីដែលព្រះអង្គសង្គ្រោះបានរងទុក្ខ និងមូលហេតុដែលទ្រង់បានរងទុក្ខ អាចជួយដល់អ្នក នៅពេលអ្នកជួបនឹងការសោកល្បង ការឈឺចាប់ និងក្តីលំបាកយ៉ាងដូចម្តេច ? (សូមមើល គ. និង ស. ៤៥:៣–៥) ។
- តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះអង្គសង្គ្រោះជួយអ្នកនៅក្នុងគ្រាឈឺចាប់ ជំងឺ ឬការសោកសៅនៅពេលណា ?
- តើអារម្មណ៍អ្វីខ្លះដែលអ្នកបានមានពិសោធន៍ នៅពេលអ្នកបានប្រែចិត្ត ហើយមានអារម្មណ៍ថា អំពើបាបរបស់អ្នកត្រូវបានលុបចោល (ឬ បំបាត់ចោល) តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?

សូមសង្ខេបម៉ាកុស ១៤:៤៣–១៦:២០ដោយការពន្យល់ថា ព្រះយេស៊ូវ ត្រូវបាននាំយកទៅកាត់ទោសដោយមិនស្របច្បាប់ នៅចំពោះមុខពួកសានហេឌ្រីន (អ្នកដឹកនាំសាសន៍យូដា) ហើយផ្តន្ទាទោសដល់ស្លាប់ ។ បន្ទាប់ពីព្រះអង្គសង្គ្រោះសុគតនៅលើឈើឆ្កាង ហើយត្រូវបានរស់ឡើងវិញ នោះទ្រង់បានយាងមកជួបនឹងពួកសាវករបស់ទ្រង់ ហើយបានបញ្ជូនពួកគេឲ្យចេញទៅផ្សព្វផ្សាយ ដោយសន្យានឹងពួកគេថា ទីសម្គាល់នានានឹងកើតមានតាមក្រោយដល់អ្នកទាំងឡាយដែលជឿ ។ (*កំណត់ចំណាំ* ៖ សេចក្តីស្លាប់ ការបញ្ចុះ និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានពិភាក្សាដោយលំអិត ខណៈពេលសិស្សបានសិក្សាម៉ាថាយ ២៧–២៨) ។

ចូរសុំឲ្យសិស្សម្នាក់អាន ម៉ាកុស ១៦:១៥ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវសេចក្តីបង្គាប់ ដែលព្រះអម្ចាស់បានប្រទានដល់ពួកសាវករបស់ទ្រង់ ។

- តើអ្នកអាចជួយបំពេញនូវសេចក្តីបង្គាប់ឲ្យចេញទៅផ្សាយដំណឹងល្អទៅដល់ « លោកិយទាំងមូល » នាសព្វថ្ងៃនេះ និងនៅពេលអនាគតបានយ៉ាងដូចម្តេច ?

អ្នកអាចនឹងចង់បញ្ចប់ ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលអ្នកបានពិភាក្សានៅថ្ងៃនេះ ។

មេរៀនបន្ទាប់ (ម៉ាថាយ ៥:១–១០:៣៧)

ចូរសុំឲ្យសិស្សគិតពិចារណា ប្រសិនបើពួកគេធ្លាប់រៀងឆ្ងល់ថា ពួកគេអាចត្រូវបានអភ័យទោសចំពោះអំពើបាបរបស់ពួកគេដោយរបៀបណា ។ ចូរពន្យល់ថា នៅពេលពួកគេសិក្សាលូកា ៥:១–១០:៣៧ នៅក្នុងសប្តាហ៍ខាងមុខ នោះពួកគេនឹងអានអំពីការស្ម័គ្រព្រះទ័យរបស់ព្រះអង្គសង្គ្រោះដើម្បីអភ័យទោសដល់អំពើបាបរបស់ពួកគេ និងអ្វីដែលពួកគេអាចធ្វើដើម្បីទទួលបានការអភ័យទោស ។

លូកា ៥

សេចក្តីផ្តើម

បន្ទាប់ពីការចាប់បានត្រីដ៏ច្រើនសន្ធឹកដោយអព្ភូតហេតុដែលមានជំនួយរបស់ព្រះអង្គសង្គ្រោះ នោះពេត្រុស យ៉ាកុប និង យ៉ូហាន បានបោះបង់ចោលអ្វីៗទាំងអស់ ដើរតាមព្រះអង្គសង្គ្រោះ ហើយក្លាយជាអ្នកនេសាទមនុស្សវិញ ។ ព្រះយេស៊ូវបានព្យាបាលមនុស្សឃ្លង់ម្នាក់ និងមនុស្សខ្វិនម្នាក់ ។ ទ្រង់បានហៅម៉ាថាយឲ្យធ្វើជាសិស្សមួយរូប ហើយបានបង្រៀនថា ទ្រង់យាងមកដើម្បីហៅអ្នកមានបាបឲ្យប្រែចិត្ត ។ ព្រះយេស៊ូវក៏បានបង្រៀនរឿងប្រៀបប្រដូចពីស្រាទំពាំងបាយជូរថ្មីដាក់ក្នុងដបចាស់ ។

យោបល់សម្រាប់ការបង្រៀន

លូកា ៥:១–១១

ព្រះអម្ចាស់បានហៅពេត្រុស យ៉ាកុប និង យ៉ូហាន ឲ្យក្លាយជាអ្នកនេសាទមនុស្ស

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀន ៖ *តើអ្នកគ្លាប់ត្រូវបានសុំឲ្យធ្វើអ្វីមួយ ដោយមិនដឹងពីមូលហេតុចំពោះការធ្វើការងារនោះនៅពេលណា* ? ចូរសុំឲ្យសិស្សគិតពិចារណាអំពីសំណួរ ហើយអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។

- ហេតុអ្វីក៏វាជាការលំបាក ដើម្បីធ្វើតាមការណែនាំដោយពុំយល់ពីមូលហេតុនោះ ?
- តើបទបញ្ញត្តិ ឬការទូន្មានអ្វីខ្លះមកពីអ្នកដឹកនាំសាសនាចក្រ ដែលយុវវ័យមួយចំនួនអាចនឹងឃើញថាមានការលំបាកដើម្បីគោរពតាម បើពួកគេពុំយល់ដឹងពេញលេញពីមូលហេតុនោះ ? (សូមពិចារណាពីការសរសេរចម្លើយរបស់សិស្សលើក្តារខៀន ។)

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយនៅក្នុងលូកា ៥:១–១១ ដែលអាចជួយពួកគេ នៅពេលពួកគេពុំយល់ដឹងពេញលេញពីមូលហេតុដែលពួកគេត្រូវបានសុំឲ្យធ្វើតាមដំបូន្មាន ឬបទបញ្ញត្តិរបស់ព្រះអម្ចាស់ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ៥:១–៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានសុំឲ្យស៊ីម៉ូន (ពេត្រុស) ធ្វើ បន្ទាប់ពីទ្រង់បានបញ្ចប់ការផ្សាយ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើស៊ីម៉ូនបានប្រាប់ព្រះអង្គសង្គ្រោះអ្វីខ្លះ អំពីការខិតខំកាលពីមុនរបស់គាត់ ដើម្បីចាប់ត្រី ?
- តើបទពិសោធន៍នេសាទត្រីរបស់ស៊ីម៉ូន អាចបាននាំគាត់ឲ្យគិតដូចម្តេច ពេលដែលព្រះអង្គសង្គ្រោះបានប្រាប់ដល់ គាត់ឲ្យទម្លាក់អួនម្តងទៀតយ៉ាងណា ?
- តើស៊ីម៉ូនបាននិយាយដូចម្តេច ដែលបង្ហាញថា គាត់ទុកចិត្តព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានលូកា ៥:៦–៩ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថាអ្វីខ្លះបានកើតឡើង បន្ទាប់ពីស៊ីម៉ូនបានធ្វើតាមអ្វីដែលព្រះអម្ចាស់បានសុំ ។

- តើមានអ្វីខ្លះកើតឡើង នៅពេលស៊ីម៉ូនបានធ្វើតាមអ្វីដែលព្រះអម្ចាស់បានសុំ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពីឆន្ទៈរបស់ស៊ីម៉ូន ដើម្បីធ្វើនូវអ្វីដែលព្រះអម្ចាស់បានសុំ ទោះជាគាត់មិនយល់ពីមូលហេតុក្តី ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគូរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងធ្វើអ្វីដែលព្រះអម្ចាស់សុំ ទោះជាយើងពុំយល់ពីមូលហេតុក៏ដោយ នោះទ្រង់អាចផ្តល់ពរដ៏មហិមាជាង ដែលយើងអាចរំពឹងទុក** ។ ចូរប្រើពាក្យរបស់សិស្ស សរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើការរស់នៅតាមដំណឹងល្អតម្រូវឲ្យយើងទុកចិត្តលើព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដោយអែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរពិចារណាធ្វើការផ្តល់ច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍មួយច្បាប់ដល់សិស្ស ។



« ជីវិតនេះជាបទពិសោធន៍មួយ នៅក្នុងការទុកចិត្តយ៉ាងជ្រាលជ្រៅ—ជាការទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ការទុកចិត្តលើការបង្រៀនរបស់ទ្រង់ ការទុកចិត្តលើសមត្ថភាពរបស់យើង ដូចដែលបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីគោរពប្រតិបត្តិដល់ការបង្រៀនទាំងនោះ ដើម្បីបានសុភមង្គលនាពេលឥឡូវនេះ និង នៅជីវិតដ៏ពោរពេញដោយគោលបំណង ជាជីវិតដ៏នៅអស់កល្បជានិច្ចដ៏រីករាយបំផុត ។ ដើម្បីទុកចិត្តមានន័យថា គោរពដោយស្ម័គ្រចិត្ត ដោយពុំដឹងពីទីបញ្ចប់ តាំងពីដំបូងមក (សូមមើល សុភា. ៣:៥–៧) ។ ដើម្បីបង្កើតជលផ្លែ នោះការទុកចិត្តរបស់អ្នកលើព្រះអម្ចាស់ ត្រូវតែមានកាន់តែខ្លាំងក្លា និង កាន់តែបិតបេះ ជាងទំនុកចិត្តរបស់អ្នកលើអារម្មណ៍ និង បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក » («Trust in the Lord» *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១៧) ។

- តើយើងអាចបង្កើតការទុកចិត្តដូចគ្នានេះ ទៅលើព្រះអង្គសង្គ្រោះយ៉ាងដូចម្តេចដែរ ?

សូមជួយសិស្សឲ្យ ប្រាប់ពីគោលការណ៍ ដែលបានបង្កប់ន័យ ។

គោលការណ៍ជាច្រើន ពុំបានថ្លែងដោយផ្ទាល់នៅក្នុងព្រះគម្ពីរទេ ប៉ុន្តែវាជាអត្ថន័យប្រយោលវិញ ។ គោលការណ៍ដែលបង្កប់ន័យជាញឹកញាប់អាចត្រូវបានរកឃើញដោយការសួរថា « តើអ្វីជាគំនិតអប់រំ ឬជាចំនុចសំខាន់នៃរឿងនេះ ? សូមជួយសិស្សភៀតលើសកម្មភាព តំរិយាបទ និង អាកប្បកិរិយាមនុស្សម្នាក់ៗ ឬជាក្រុមនៅក្នុងដំណើររឿងខាងបទគម្ពីរ ហើយប្រាប់ពីពរដ៏ទាំងឡាយ ឬ ផលវិបាកដែលជាលទ្ធផល ។ ការសិក្សាដំណើររឿងបទគម្ពីរតាមរបៀបនេះ អាចជួយធ្វើឲ្យគោលការណ៍នៃដំណឹងល្អដែលបង្កន់ន័យបង្ហាញកាន់តែច្បាស់ ។

- តើអ្នក ឬគ្រួសារអ្នកធ្លាប់ទទួលបានពរជ័យដ៏មហិមាជាង អ្វីដែលអ្នកបានរំពឹងទុកដោយការធ្វើតាមការដឹកនាំរបស់ព្រះអម្ចាស់ ទោះជាពេលដែលអ្នកពុំយល់ពេញលេញពីមូលហេតុវាយ៉ាងដូចម្តេច ? (ចម្លើយអាចរួមមានទាំងបទពិសោធន៍ ដែលបានជួយសិស្សនៅទីបំផុត បានយល់ពីមូលហេតុដែលព្រះអម្ចាស់បានប្រទានការដឹកនាំដូច្នេះ) ។

នៅលើសន្លឹកក្រដាសមួយ ដែលពួកគេអាចយកទៅផ្ទះ ចូរអញ្ជើញសិស្សឲ្យសរសេរការប្រឹក្សា ឬ បទបញ្ញត្តិមកពីព្រះអម្ចាស់ ដែលពួកគេអាចធ្វើតាមកាន់តែស្មោះត្រង់ ទោះជាពួកគេមិនយល់ពីមូលហេតុពេញលេញក្នុងការធ្វើដូច្នោះក្តី ។ (បើមានពេល អ្នកអាចអញ្ជើញសិស្សឲ្យមើលយោបល់នានានៅក្នុងកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន* [កូនសៀវភៅ ឆ្នាំ ២០១១] ដើម្បីជាគំនិត) ។

សូមសង្ខេបលូកា ៥:១០–១១ ដោយការពន្យល់ថា ពេត្រុស យ៉ាកុប និង យ៉ូហាន បានទុកចោលទូកនេសាទ និងសំណាញ់របស់ពួកគេចោលហើយទៅតាមព្រះយេស៊ូវ ។

លូកា ៥:១២–២៦

ព្រះយេស៊ូវព្យាបាលមនុស្សឃ្លង់ និងបុរសខ្វិន

សូមបង្ហាញសិស្សនូវវត្ថុដូចខាងក្រោម (ឬគូរបំវត្ថុនោះនៅលើក្តារខៀន) ៖ សារាង បង់រុំរបួស សាប៊ូ និង ប្រដាប់ដាក់ទឹកកកស្ពឹ ។

- តើវត្ថុទាំងនេះអាចជួយព្យាបាលមនុស្សឈឺ ឬមានរបួសយ៉ាងដូចម្តេច ?
- ក្រៅពីជំងឺ និងរបួសខាងរូបកាយ តើមានអ្វីផ្សេងទៀតដែលមនុស្សម្នាក់ចាំបាច់ត្រូវបានព្យាបាលនោះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។ ចម្លើយអាចរួមមាន អំពើបាប ការញៀន ការអស់សង្ឃឹម និងបទពិសោធន៍ល្វីងជូរចត់) ។

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍ទាំងឡាយ នៅពេលពួកគេសិក្សាលូកា ៥:១២–២៥ដែលបង្រៀនយើងអំពីអ្វីដែលយើងអាចធ្វើ ដើម្បីជួយខ្លួនយើង និងអ្នកដទៃឲ្យទទួលបាននូវការព្យាបាលដែលចាំបាច់ ។

សូមគូស តារាងដូចខាងក្រោម នៅលើក្តារខៀន ហើយអញ្ជើញឲ្យសិស្សចម្លងវាចូលទៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

តាពស្រដៀងគ្នា	តាពខុសគ្នា

សូមសរសេរសេចក្តីយោង ដូចខាងក្រោមនេះនៅលើ ក្តារខៀន ៖ *លូកា ៥:១២–១៥* និង *លូកា ៥:១៧–២៥* ។ ចូរពន្យល់ថា ខគម្ពីរទាំងនេះរៀបរាប់ថា ព្រះអង្គសង្គ្រោះបានព្យាបាលបុរសពីរនាក់ ។ បុរសម្នាក់មានរោគឃ្លង់ ហើយបុរសម្នាក់ទៀតខ្វិន មានន័យថាគាត់ពុំអាចដើរបាន ។ សូមចែកសិស្សជាគូ ។ ចូរសុំឲ្យពួកគេអានដំណើររឿងនីមួយៗជាមួយនឹងដៃគូពួកគេ ហើយពិភាក្សាអំពីសំណួរដូចខាងក្រោម ៖

- តើការព្យាបាលទាំងពីរនេះស្រដៀងគ្នាយ៉ាងដូចម្តេច ? តើវាខុសគ្នាយ៉ាងដូចម្តេច?
- តើសេចក្តីជំនឿដើរតួនាទីអ្វីខ្លះ នៅក្នុងដំណើររឿងនីមួយៗ ?

ចូរសុំឲ្យសិស្សកត់ត្រានៅក្នុងតារាងរបស់ពួកគេពីអ្វីដែលពួកគេរកឃើញ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។ ចូរពិចារណាធ្វើការអញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « ទ្រង់បានឃើញសេចក្តីជំនឿរបស់គេ » នៅក្នុង ខទី ២០ ។ ចូរប្រាកដថា សិស្សយល់ដឹងថា សេចក្តីជំនឿនៃអ្នកទាំងឡាយ ដែលបាននាំបុរសខ្វិនមកព្រះអង្គសង្គ្រោះ បាននាំឲ្យបុរសនេះត្រូវបានព្យាបាលជាសះស្បើយ ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីដំណើររឿងទាំងនេះអំពីរបៀប ដែលយើងអាចត្រូវបានព្យាបាល និងអ្វីដែលយើងអាចធ្វើដើម្បីជួយអ្នកដទៃឲ្យបានជាសះស្បើយ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគូរស្ទាល់គោលការណ៍ទាំងឡាយដូចខាងក្រោមនេះ ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿ ហើយមករកព្រះអង្គសង្គ្រោះ នោះទ្រង់អាចព្យាបាលយើង ។ យើងអាចជួយអ្នកដទៃឲ្យមករកព្រះអង្គសង្គ្រោះ ដើម្បីពួកគេអាចត្រូវបានព្យាបាល ។** សូមគោលការណ៍ទាំងនេះនៅលើក្តារខៀន) ។
- តើយើងអាចទទួលបានការព្យាបាលមកពីព្រះអង្គសង្គ្រោះតាមរបៀបណា ? (សូមជួយសិស្សឲ្យយល់ថា ព្រះអង្គសង្គ្រោះអាចដកយកជំងឺចេញពីយើងបាន ឬទ្រង់អាចប្រទានដល់យើងនូវភាពក្លាហាន សេចក្តីជំនឿ ការកំសាន្តចិត្ត និងសេចក្តីសុខសាន្ត ដែលយើងត្រូវការដើម្បីស៊ូទ្រាំ ឬយកឈ្នះលើជំងឺទាំងឡាយរបស់យើង) ។

ចូរសុំឲ្យសិស្សគិតពិចារណាអំពីជំងឺទាំងឡាយ ដែលបានសរសេរនៅលើក្តារខៀន ដែលមនុស្សប្រហែលជាត្រូវការដើម្បីនឹងត្រូវបានព្យាបាល ។

- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីជួយនាំមនុស្សមករកព្រះអង្គសង្គ្រោះ ដើម្បីទទួលនូវព្រះចេស្តាព្យាបាលរបស់ទ្រង់ ?
- តើអ្នក ឬនរណាម្នាក់ធ្លាប់ដឹងថា ត្រូវបានព្យាបាលតាមរយៈការអនុវត្តសេចក្តីជំនឿទៅលើព្រះអង្គសង្គ្រោះនៅពេលណា ? (សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ឬ រឿងផ្ទាល់ខ្លួនខ្លាំងពេកនោះទេ) ។

- តើអ្នកធ្លាប់ឃើញមនុស្សម្នាក់បាននាំមនុស្សផ្សេងទៀតទៅរកព្រះអម្ចាស់ ដើម្បីទទួលបានព្រះចេស្តាព្យាបាលរបស់ព្រះអង្គសង្គ្រោះ នៅពេលណា ?

ចូរសុំឲ្យសិស្សពិចារណាអំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីអនុវត្តសេចក្តីជំនឿកាន់តែខ្លាំងឡើង ទៅលើព្រះយេស៊ូវគ្រីស្ទ ដើម្បីត្រូវបានព្យាបាល អភ័យទោស ឬលួងលោមចិត្ត ឬអ្វីដែលពួកគេអាចធ្វើដើម្បីនាំមិត្តម្នាក់ ឬនរណាម្នាក់ទៀតមករកព្រះអង្គសង្គ្រោះ ។ សូមលើកទឹកចិត្តពួកគេធ្វើសកម្មភាព តាមការបំផុសគំនិតដែលពួកគេបានទទួល ។

លូកា ៥:២៧–៣៥

ពួកអាចារ្យ និងពួកផារិស៊ី ចោទសួរថាហេតុអ្វីក៏ព្រះយេស៊ូវទទួលទានជាមួយនឹងពួកអ្នកយកពន្ធ និងពួកមនុស្សមានបាប ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានលូកា ៥:២៧–២៨ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះ ទៅដល់លោកលេវី ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្វីទៅដែលធ្វើឲ្យអ្នកស៊ើចសសើរ អំពីរបៀបដែលលោកលេវី ឆ្លើយតបចំពោះការអញ្ជើញរបស់ព្រះអង្គសង្គ្រោះ ?

ចូរអំពាវសិស្សថា លេវី ក៏ត្រូវបានហៅថាជា ម៉ាថាយផងដែរ (សូមមើលម៉ាថាយ ៩:៩) ។ គាត់គឺជាអ្នកយកពន្ធ មានន័យថា គាត់ប្រមូលពន្ធមកពីបងប្អូនសាសន៍យូដារបស់គាត់សម្រាប់រដ្ឋាភិបាលរ៉ូម ។ ជាទូទៅពួកសាសន៍យូដាស្អប់ពួកអ្នកយកពន្ធ ហើយមើលទៅពួកគេដូចជា ពួកបំបរបង់ និងអ្នកមានបាប និងជាមនុស្សក្បត់ជាតិចំពោះជាតិសាសន៍អ៊ីស្រាអែល ។ សូមសង្កេតលូកា ៥:២៩–៣៥ ដោយពន្យល់ថា ខណៈដែលព្រះយេស៊ូវកំពុងទទួលទានជាមួយនឹងលេវី និងអ្នកផ្សេងទៀត នោះពួកអាចារ្យ និងពួកផារិស៊ីបានបន្ទោសទ្រង់ចំពោះការទទួលទានជាមួយពួកមានបាប ។ ព្រះយេស៊ូវបានបង្រៀនពួកគេថា ទ្រង់មកដើម្បីហៅពួកមានបាបឲ្យប្រែចិត្ត ។

លូកា ៥:៣៦–៣៩

ព្រះយេស៊ូវប្រាប់រឿងប្រៀបប្រដូចពីស្រាទំពាំងបាយជូរថ្មីដាក់ក្នុងដបចាស់

ចូរពន្យល់ថា ព្រះអង្គសង្គ្រោះ បានប្រើរឿងប្រៀបប្រដូចដើម្បីបង្រៀនដល់ពួកអាចារ្យ និងពួកផារិស៊ី ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ៥:៣៦–៣៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានប្រើនៅក្នុងរឿងប្រៀបប្រដូចរបស់ទ្រង់ ។

- តើអ្វីដែលព្រះអង្គសង្គ្រោះបានប្រើ ដើម្បីបង្រៀនអំពីរឿងប្រៀបប្រដូចរបស់ទ្រង់ ?

ចូរបង្ហាញសិស្សនូវក្រណាត់ថ្មី និងក្រណាត់ចាស់ដែលមានដាច់ប្រហោង ។ ចូរពន្យល់ថា « ក្រណាត់ថ្មី » នៅខ ៣៦សំដៅទៅលើក្រណាត់ដែលមិនទាន់រួញ ។ មនុស្សម្នាក់ពុំអាចប៉ះក្រណាត់ចាស់ជាមួយនឹងក្រណាត់ថ្មីបានទេ ដោយសារតែក្រណាត់ថ្មី នឹងធ្វើឲ្យរួញ ដែលធ្វើឲ្យកន្លែងដាច់កាន់តែដាច់ធំជាងមុនទៀត ។ តាមរបៀបស្រដៀងគ្នានេះ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ពុំគ្រាន់តែជាការប៉ះប៉ូវទៅលើជំនឿចាស់ និងការអនុវត្តចាស់ៗនោះទេ ប៉ុន្តែជាការស្តារឡើងវិញនូវសេចក្តីពិតទាំងស្រុង ។

សូមពន្យល់ថា*ដប*សំដៅទៅលើ « ថង់ស្បែក ឬស្បោងដាក់ស្រា » ហើយបើអាចធ្វើទៅបាន ចូរបង្ហាញសិស្សនូវចំរៀកស្បែកចាស់ និងស្បែកថ្មី ។

- តើស្បែកចាស់ និង ស្បែកថ្មី ខុសគ្នាយ៉ាងណា? (ស្បែកថ្មីគឺទន់ ហើយងាយបត់ ឯស្បែកចាស់រឹង ហើយជុំយស្រួយ) ។

ចូរពន្យល់ថា ស្រាថ្មីកាច់មេនៅក្នុងថង់ស្បែក ហើយឧស្ម័ននឹងដោរឡើងនៅខាងក្នុង ហើយធ្វើឲ្យថង់ស្បែកយឺតឡើង ។ នៅពេលស្បោងដាក់ស្រាបានយឺតអស់ហើយតាមរបៀបនេះ នោះការព្យាយាមដើម្បីបិទស្រាថ្មីនៅក្នុងវាម្តងទៀត នឹងប្រថុយក្នុងការផ្ទុះស្បោងនោះ ។

នៅក្នុងរឿងប្រៀបប្រដូចស្រាថ្មី តំណាងឲ្យការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ហើយនឹងភាពពេញលេញនៃដំណឹងល្អដ៏អស់កល្ប ឯស្រាចាស់តំណាងឲ្យការអនុវត្ត ទំនៀមទំលាប់ និងជំនឿរបស់ពួកផារិស៊ីនៅក្រោមច្បាប់ម៉ូសេ ។

- តើ « ដបចាស់ » តំណាងឲ្យពួកអាចារ្យ និងពួកផារិស៊ីរបៀបណា ? (ក៏ដូចជាដបចាស់ដែលរឹងខ្លាំងពេកដើម្បីដាក់ស្រាថ្មី នោះពួកអាចារ្យ និងពួកផារិស៊ី ក៏មានដួងចិត្តរឹងរូស ហើយពុំចង់ផ្លាស់ប្តូរ ដើម្បីទទួលយកព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់ផងដែរ) ។
- តើ « ដបថ្មី » អាចតំណាងឲ្យនរណា ? (អ្នកទាំងឡាយដែលរាបសារ និងមានឆន្ទៈដើម្បីផ្លាស់ប្តូរ ទទួលយកព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់) ។
- តើយើងអាចរៀនអ្វីខ្លះ មកពីរឿងប្រៀបប្រដូចនេះអំពីអ្វី ដែលយើងចាំបាច់ត្រូវធ្វើ ដើម្បីទទួលព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់ ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ដើម្បីទទួលយកព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់ យើងត្រូវតែរាបសារ ហើយមានឆន្ទៈដើម្បីផ្លាស់ប្តូរ ។** សូមអញ្ជើញសិស្សឲ្យពិចារណាសរសេរគោលការណ៍នេះនៅលើទំព័រគម្ពីររបស់ពួកគេនៅក្បែរលូកា ៥:៣៦–៣៩) ។

ដើម្បីជួយសិស្សឲ្យយល់អំពីគោលការណ៍នេះ ចូរអញ្ជើញពួកគេឲ្យរំពឹកលូកា ៥ហើយរកមើលឧទាហរណ៍អំពីរបៀប ដែលបុគ្គលម្នាក់ៗមានឥរិយាបថរឹងរូស ហើយរឹងទទឹងចំពោះព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់ ក៏ដូចជាឧទាហរណ៍អំពីរបៀប ដែលបុគ្គលម្នាក់ៗរាបសារ និងមានឆន្ទៈដើម្បីផ្លាស់ប្តូរ និងរីកចម្រើនតាមរយៈការធ្វើតាមព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សពីរបីនាក់រៀបរាប់ពីអ្វី ដែលពួកគេរកឃើញ ។

សូមបញ្ចប់មេរៀនដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដែលបានបង្រៀននៅក្នុងលូកា ៥។

លូកា ៦:១–៧:១៨

សេចក្តីផ្តើម

ព្រះយេស៊ូវបានបង្រៀនអំពីសារៈសំខាន់នៃការធ្វើល្អចំពោះអ្នកដទៃ រួមទាំងនៅក្នុងថ្ងៃឈប់សម្រាក ។ បន្ទាប់ពីបានចំណាយពេលមួយយប់នៅក្នុងការអធិស្ឋាន ទ្រង់បានហៅពួកសាវកដប់ពីរនាក់មក រួចហើយបង្រៀនពួកគេ និងបណ្តាជនកកកុញ ។ ទ្រង់ក៏បានព្យាបាលដល់បាវសំណព្វរបស់មេទ័ពម្នាក់ ហើយបានប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់ឲ្យរស់ពីស្លាប់ឡើងវិញ ។

យោបល់សម្រាប់ការបង្រៀន

លូកា ៦

ព្រះយេស៊ូវព្យាបាលនៅថ្ងៃឈប់សម្រាក រើសរើសសាវកដប់ពីរនាក់ ហើយបង្រៀនដល់ហ្វូងមនុស្ស ។

(កំណត់ចំណាំ ៖ រឿងជាច្រើននៅក្នុងលូកា ៦ ត្រូវបានរៀននៅក្នុងមេរៀនទាំងឡាយសម្រាប់ម៉ាថាយ ៥–៧,១០:១–៤និងម៉ាកុស ៣:១–៦។ ផ្នែកនេះនៃមេរៀន នឹងផ្តោតទៅលើលូកា ៦:៣១–៣៨) ។

ចូរសុំឲ្យសិស្សនីកស្រមៃថា នៅក្នុងការប្រជុំនៅព្រះវិហាររបស់ពួកគេ នៅថ្ងៃអាទិត្យ ពួកគេស្តាប់ឮការប្រកាសមួយអំពីគម្រោងការបម្រើដល់គ្រួសារមួយ ដែលរស់នៅក្បែរជិតខាង ។ បន្ទាប់ពីការប្រកាសត្រូវបានធ្វើឡើង ពួកគេបានស្តាប់ឮការឆ្លើយតបផ្សេងៗគ្នាចំនួនបួន ។ សូមអញ្ជើញសិស្សបួននាក់ឲ្យអានឮៗ នូវការឆ្លើយតបដោយជាសម្មតិកម្មដូចខាងក្រោម ៖

១. « គ្រួសារនោះមានរឿងជាច្រើនក្នុងពេលថ្មីៗនេះ ។ ខ្ញុំរីករាយនឹងជួយឲ្យអស់ពីលទ្ធភាពដែលខ្ញុំអាចធ្វើទៅបាន » ។

២. « វាគួរតែមានអាហារសំរាន់បន្ទាប់ពីនោះ ប្រសិនបើគ្មានទេ នោះខ្ញុំនឹងមិនទៅទេ » ។

៣. « ខ្ញុំពិតជាមិនចង់ទៅទេ ប៉ុន្តែខ្ញុំអាចជួយខ្លះៗនៅសប្តាហ៍ក្រោយ ជាមួយនឹងគម្រោងមួយដែលខ្ញុំកំពុងរៀបចំ ដូច្នេះប្រហែលជាខ្ញុំគប្បីជួយឥឡូវនេះ » ។

៤. « បើមិត្តរបស់ខ្ញុំទៅ នោះខ្ញុំនឹងទៅដែរ » ។

- តើឧទាហរណ៍ទាំងនេះផ្តល់ជាយោបល់យ៉ាងណាខ្លះ អំពីមូលហេតុជាច្រើន ដែលពេលខ្លះមនុស្សធ្វើការបម្រើ ?

ចូរសុំឲ្យសិស្សពិចារណាអំពីឱកាសនានា ដែលពួកគេត្រូវបម្រើ និងរបៀបដែលពួកគេមានអារម្មណ៍អំពីការបម្រើ ។ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍ជាច្រើនខណៈពេលពួកគេសិក្សាលូកា ៦–៧ ដែលអាចជួយពួកគេផ្តល់ការបម្រើតាមរបៀបមួយដែលប្រកបដោយអត្ថន័យ ។

សូមសង្ខេបលូកា ៦ដោយការពន្យល់ថា ខណៈដែលព្រះយេស៊ូវស្ថិតនៅក្នុងស្រុកកាលីឡេ ក្នុងការបម្រើដំបូងរបស់ទ្រង់ ទ្រង់បានព្យាបាលបុរសដែលមានជម្ងឺស្ងួតដៃនៅថ្ងៃឈប់សម្រាក បានចំណាយពេលមួយយប់ធ្វើការអធិស្ឋាន ហើយបានហៅពួកសាវកដប់ពីរនាក់ ។ បន្ទាប់មក ព្រះយេស៊ូវ បានចាប់ផ្តើមបង្រៀនពួកគេ និង « បណ្តាជនកកកុញ » (ខទី ១៧) ពីរបៀបដើម្បីទទួលបានរង្វាន់ពីស្ថានសួគ៌ ។

សូមអញ្ជើញសិស្សឲ្យអានលូកា ៦:១៩ ដោយស្ងាត់ស្ងៀម រកមើលនូវអ្វីដែលព្រះយេស៊ូវបានធ្វើសម្រាប់បណ្តាជន មុនពេលទ្រង់ចាប់ផ្តើមបង្រៀនដល់ពួកគេ ។ ចូរសុំឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ៦:៣១–៣៥ ។ ចូរសូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលព្រះឱវាទដែលព្រះអម្ចាស់បានប្រទានដល់ពួកសិស្សរបស់ទ្រង់ ។

- តើព្រះឱវាទអ្វីខ្លះ ដែលព្រះយេស៊ូវបានប្រទានដល់ពួកសិស្សរបស់ទ្រង់ ?
- ស្របតាមខ ៣៥តើយើងគប្បីរំពឹងចង់បានអ្វីខ្លះ ពីការធ្វើល្អនឹងអ្នកដទៃ ? (អ្នកគួរតែអញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « ឥតសង្ឃឹមនឹងបានអ្វីមកវិញទេ ») ។
- តើរង្វាន់ខាងសាច់ឈាមអ្វីខ្លះដែលមនុស្សប្រហែលជាសង្ឃឹមចង់បាន ពេលពួកគេផ្តល់ការបម្រើដល់អ្នកដទៃ ?
- ប្រសិនបើយើងធ្វើល្អនឹងអ្នកដទៃដោយឥតសង្ឃឹមចង់បានអ្វីមកវិញនោះ តើព្រះអម្ចាស់សន្យាថានឹងមានអ្វីកើតឡើង ? (សិស្សគួរកត់ឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងធ្វើល្អនឹងអ្នកដទៃដោយឥតសង្ឃឹមចង់បានអ្វីមកវិញ នោះ រង្វាន់របស់យើងនឹងមហិមា ហើយយើងនឹងក្លាយជាកូនចៅនៃព្រះដ៏ខ្ពស់បំផុត**)។

សូមពន្យល់ថាទោះបីជាយើងទាំងអស់គ្នាជាកូនចៅនៃព្រះក្តី ក៏អ្នកទាំងឡាយដែលធ្វើល្អនឹងអ្នកដទៃ គឺបានបំពេញនូវសក្តានុពលដ៏ទេវភាពរបស់ពួកគេ តាមរយៈការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ។

- ហេតុអ្វីក៏ការសន្យានេះជារង្វាន់ដ៏វិសេសបំផុតសម្រាប់ការស្រឡាញ់ និងការធ្វើល្អចំពោះអ្នកដទៃដូច្នេះ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ៦:៣៦–៣៨ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវឧទាហរណ៍នានា ដែលព្រះយេស៊ូវបានប្រទានឲ្យក្នុងរបៀបមួយដែលយើងអាចធ្វើល្អចំពោះអ្នកដទៃ ។

- ស្របតាមខ ៣៦–៣៧តើឧទាហរណ៍អ្វីខ្លះ ដែលព្រះយេស៊ូវបានប្រទានឲ្យក្នុងរបៀបមួយដែលយើងអាចធ្វើល្អចំពោះអ្នកដទៃ ? (អ្នកគួរតែពន្យល់ថា អ្នកទាំងឡាយដែលធ្វើល្អតាមរបៀបទាំងនេះ នឹងទទួលបានព្រះគុណ និងការអភ័យទោសរបស់ព្រះ) ។

ដើម្បីជួយសិស្សយល់ខ ៣៨សូមយកធុង កន្ត្រក ឬប្រអប់ និងវត្ថុមួយចំនួនទៀត ដូចជាសំលៀកបំពាក់ អាហារ ដបទឹកមកថ្នាក់រៀន ។ ត្រូវប្រាកដថា យកវត្ថុមកឲ្យច្រើនទៀត ដែលអាចដាក់នៅក្នុងប្រអប់ដែលអ្នកយកមកនោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្តារខៀន ហើយសុំឲ្យគាត់ឬនាង ព្យាយាមដាក់វត្ថុក្នុងប្រអប់ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ នៅពេលសិស្សបានបញ្ចប់ ចូរសួរដល់ពួកគេ ៖

- តើឃ្លា « គេនឹងវាល់ឲ្យអ្នកយ៉ាងល្អ ទាំងញាត់ ទាំងរលាក់ ហើយដាក់ឲ្យហៀរ » (ខ ៣៨) ពិពណ៌នាអំពីកិច្ចខិតខំរបស់អ្នកដើម្បីដាក់បំពេញនៅក្នុងប្រអប់នេះដូចម្តេចខ្លះ ? (អរគុណដល់សិស្ស ហើយអញ្ជើញឲ្យពួកគេទៅកន្លែងអង្គុយវិញ) ។
- តើឃ្លាទាំងនេះពិពណ៌នាពីរបៀបដែលព្រះវរបិតាសួគ៌ប្រទានរង្វាន់ដល់យើង នៅពេលយើងផ្តល់ទៅឲ្យអ្នកដទៃយ៉ាងដូចម្តេច ? (សិស្សប្រហែលជាប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **នៅពេលយើងផ្តល់ទៅដល់អ្នកដទៃដោយសប្បុរស នោះព្រះវរបិតាសួគ៌ប្រទានពរដល់យើងកាន់តែសប្បុរសផងដែរ**) ។
- តើយើងអាចកាន់តែមានចិត្តសប្បុរសក្នុងការផ្តល់ទៅឲ្យអ្នកដទៃតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីគ្រាមួយដែលពួកគេ ឬនរណាម្នាក់ដែលគេស្គាល់ បានផ្តល់ឲ្យដោយសប្បុរសទៅដល់អ្នកដទៃ ។ សូមបង្ហាញសំណួរដូចខាងក្រោម (ឬផ្តល់ដល់សិស្សនូវច្បាប់ចម្លងនៃសំណួរទាំងនោះ) ហើយអញ្ជើញសិស្សឲ្យឆ្លើយតបចំពោះសំណួរនោះ ក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ (ឬនៅក្នុងឯកសារចែកឲ្យដែលអ្នកបានឲ្យនោះ) ។

- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ត្រូវបានប្រទានពរពីព្រះអម្ចាស់យ៉ាងដូចម្តេច សម្រាប់ការផ្តល់ឲ្យដោយសប្បុរសនោះ ?
- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីកាន់តែមានចិត្តសប្បុរសដល់អ្នកដទៃ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ ចូរពិចារណាធ្វើការអញ្ជើញដល់សិស្សណាដែលស្ម័គ្រចិត្តចែកចាយអ្វីដែលពួកគេបានសរសេរនោះ ។ សូមលើកទឹកចិត្តដល់សិស្សឲ្យអធិស្ឋានសូមជំនួយរបស់ព្រះអម្ចាស់ នៅពេលពួកគេព្យាយាមកាន់តែមានចិត្តសប្បុរសចំពោះអ្នកដទៃ ។

លូកា ៧:១–១០

ព្រះយេស៊ូវព្យាបាលបាវសំណព្វរបស់មេទ័ពម្នាក់

ចូរពន្យល់ថា បន្ទាប់ពីការបង្រៀនដល់មហាជន ព្រះយេស៊ូវបានចូលទៅក្រុងមួយដែលហៅថា កាពើណិម ។

សូមអញ្ជើញឲ្យសិស្សពីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ៧:២–៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវនរណាដែលស្វែងរកជំនួយរបស់ព្រះយេស៊ូវ បន្ទាប់ពីការស្តាប់ឮថា ទ្រង់បានចូលមកដល់ទីក្រុង ។

- តើនរណាស្វែងរកជំនួយរបស់ព្រះយេស៊ូវ ?

ចូរពន្យល់ថា មេទ័ពម្នាក់ គឺជាមន្ត្រីកងទ័ពពួករ៉ូម ដែលគ្រប់គ្រងពួកទាហាន ៥០ ទៅ ១០០ នាក់ ។

- តើអ្វីដែលធ្វើឲ្យមេទ័ពមានបញ្ហាសុគស្មាញ ?

ចូរចង្អុលបង្ហាញថា ជាទូទៅ ពួកយូដាពុំចូលចិត្តមេទ័ពទេ ដោយសារតែពួកគេតំណាងឲ្យអំណាចខាងនយោបាយ និងកងទ័ពរបស់ពួករ៉ូមគ្រប់គ្រងលើពួកយូដា និងទឹកដីរបស់ពួកគេ (សូមមើល*New Testament Student Manual* | Church Educational System manual, **ឆ្នាំ ២០១៤** | **ទំព័រ ១៥៣**) ។

- តើមេទ័ពនេះជាមនុស្សប្រភេទណា ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ៧:៦–៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលមេទ័ពបានបង្ហាញពីសេចក្តីជំនឿដ៏ខ្លាំងទៅលើព្រះយេស៊ូវគ្រីស្ទ ។

- តើមេទ័ពបង្ហាញពីសេចក្តីជំនឿដ៏ខ្លាំងរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

ចូរសុំឲ្យសិស្សម្នាក់អាន លូកា ៧:៩–១០ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលមេទ័ពបានទទួលរង្វាន់ដោយព្រោះតែសេចក្តីជំនឿរបស់គាត់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីដំណើររឿងនេះ ? (សិស្សអាចប្រាប់អំពីគោលការណ៍ជាច្រើន រួមមានដូចខាងក្រោម ៖ **តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចជួយនាំមកនូវពរជ័យជាច្រើនចូលទៅក្នុងជីវិតរបស់អ្នកដទៃ**) ។

លូកា ៧:១១–១៨

ព្រះយេស៊ូវបានប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយម្នាក់ពីស្លាប់

ចូរពន្យល់ថានៅថ្ងៃបន្ទាប់ពីព្រះអង្គសង្គ្រោះបានព្យាបាលដល់បាវរបស់មេទ័ព នោះទ្រង់បានធ្វើនូវអព្ភូតហេតុមួយផ្សេងទៀត ។

បទបង្ហាញជាសោតទស្សន៍

បទបង្ហាញជាសោតទស្សន៍ ជួយដល់សិស្សល្អបំផុតនៅក្នុងការរៀនសូត្រ និងការអនុវត្តគោលការណ៍នៃដំណឹងល្អ នៅពេលពួកគេជួយសិស្សឲ្យយល់ព្រឹត្តការណ៍ ឬគោលការណ៍ដែលបានកត់ត្រានៅក្នុងបទគម្ពីរបានល្អប្រសើរ ។ វាអាចជាជំនួយដើម្បីសរសេរនៅលើក្តារខៀននូវរឿងជាក់លាក់ទាំងឡាយ ដែលសិស្សអាចរកមើល ឬសំណួរដែលពួកគេអាចពិចារណា នៅពេលពួកគេមើល ឬ ស្តាប់ បទបង្ហាញ ។ អ្នកក៏អាចផ្អាកបទបង្ហាញមួយសន្ទុះ ដើម្បីសួរសំណួរ ឬ ប្រាប់អំពីព័ត៌មានដែលនឹងជួយដល់សិស្ស ។

សូមអញ្ជើញឲ្យសិស្សម្នាក់ឲ្យអាន លូកា ៧:១១–១២ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់បានជួបប្រទះ នៅពេលពួកគេបានមកដល់ទីក្រុងមួយ ដែលហៅថា ណាអ៊ីន ។

ជាជាងឲ្យសិស្សម្នាក់អានលូកា ៧:១១–១២ ឮៗ នោះអ្នកអាចបង្ហាញនូវផ្នែកមួយនៃវីដេអូ« The Widow of Nain » (0:00–0:45) ចេញមកពី *The Life of Jesus Christ Bible Videos* ដែលមាននៅក្នុង LDS.org ។

- តើព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់មើលឃើញអ្វីខ្លះ នៅពេលពួកគាត់បានចូលទៅដល់ច្រកទ្វារទីក្រុង ?
- យោងតាមខទី ១២ហេតុអ្វីក៏សេចក្តីស្លាប់របស់បុរសក្មេងនេះ ជាសោកនាដកម្មជាពិសេសចំពោះស្ត្រីរូបនេះដូច្នេះ ?


ចូរចង្អុលបង្ហាញថា ស្ត្រីរូបនេះពុំត្រាន់តែបាត់បង់កូនដោយសេចក្តីស្លាប់ទេ ប៉ុន្តែកាលពីមុននោះ គាត់ក៏បានបាត់បង់ប្តីរបស់គាត់ផងដែរ ។ បន្ថែមពីលើការសោកសៅដ៏ខ្លាំងដែលគាត់មាន គាត់ប្រហែលជាគ្មាននរណានឹងផ្គត់ផ្គង់ហិរញ្ញវត្ថុដល់គាត់ផងដែរ ។

ចូរសុំឲ្យសិស្សម្នាក់អានលូកា ៧:១៣–១៥ ឮៗ ឬបង្ហាញវីដេអូដែលនៅសល់ទាំងប៉ុន្មាន (០:៤៥–២:២៣) ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ នៅពេលទ្រង់ទតឃើញស្ត្រីរូបនេះកំពុងទួញសោក ។ (អ្នកគួរតែពន្យល់ថា ក្តារមឈូសគឺជាមឈូសមួយ ឬជើងទម្រដែលដាក់ក្តារមឈូស) ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះចំពោះស្ត្រីរូបនេះ ?
- ស្របតាមខទី ១៣ហេតុអ្វីក៏ព្រះយេស៊ូវព្យាបាលកូនប្រុសរបស់ស្ត្រីរូបនេះ ? (អ្នកគួរតែចង្អុលបង្ហាញថា ស្ត្រីមេម៉ាយ ពុំបានសុំទ្រង់ឲ្យព្យាបាលដល់កូនប្រុសគាត់ទេ ប៉ុន្តែទ្រង់បានសង្កេតឃើញពីតម្រូវការគាត់ រួចហើយក៏ជួយបំពេញតម្រូវការនោះ) ។
- តើអ្នកអាចនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពស្ត្រីមេម៉ាយរូបនេះ ហើយបានឃើញព្រះអង្គសង្គ្រោះប្រោសកូនប្រុសតែមួយគត់របស់អ្នកពីស្លាប់នោះ ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីដំណើររឿងនេះ អំពីរបៀបដែលយើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។ (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នាបាន ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទដោយការបង្ហាញនូវក្តីមេត្តាករុណាដល់អ្នកដទៃ ហើយបម្រើដល់តម្រូវការដែលពុំថ្លែងបានរបស់ពួកគេ**) ។
- តើយើងអាចញាណដឹងពីតម្រូវការរបស់អ្នកដទៃ នៅពេលពួកគេពុំចែកចាយជាមួយនឹងយើងដោយរបៀបណា ?

ចូរពន្យល់ថា នៅពេលសិស្សស្វែងរកភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេអាចនឹងទទួលបានការបំផុសគំនិតអំពីរបៀបដើម្បីឆ្លើយតបចំពោះតម្រូវការដែលលាក់ទុករបស់អ្នកដទៃ ។ បន្ថែមពីលើនោះ សិស្សអាចនឹងពិចារណាអំពីដំបូន្មានដែលប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានទទួលម្តងនោះថា ៖ « នៅពេលអ្នកជួបនឹងនរណាម្នាក់ សូមប្រព្រឹត្តនឹងពួកគេ ដូចជាពួកគេស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ ហើយអ្នកនឹងធ្វើត្រូវច្រើនជាងពាក់កណ្តាល » (« In the Strength of the Lord » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១៦) ។

ដើម្បីជួយសិស្សយល់អំពីសេចក្តីពិត និងសារៈសំខាន់នៃគោលការណ៍ដែលពួកគេបានប្រាប់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ឲ្យឮៗ ៖



« ដំណើររឿងមួយចំនួននៃការបម្រើរបស់លោកចៅហ្វាយ បានប៉ះដល់អារម្មណ៍របស់ខ្ញុំច្រើនជាងគេគឺគំរូរបស់ទ្រង់អំពីក្តីមេត្តាករុណា ដែលបានបង្ហាញដល់ស្ត្រីមេម៉ាយសោកសៅនៅណាអ៊ីន ។ . . .

« វាមានអានុភាព ភាពទន់ភ្លន់ និងក្តីមេត្តាខ្លាំងណាស់ ដែលលោកចៅហ្វាយរបស់យើងបានបង្ហាញនោះ ! យើងក៏អាចប្រទានពរផងដែរ ប្រសិនបើយើងនឹងធ្វើតាមគំរូដ៏ខ្ពង់ខ្ពស់របស់ទ្រង់នេះ ។ ឱកាសមាននៅគ្រប់ទីកន្លែង អ្វីដែលត្រូវការនោះគឺជាភ្នែកដើម្បីមើលមើញនូវស្ថានភាពគួរសង្វេគ និងត្រចៀកដើម្បីស្តាប់នូវការអង្វរករដោយស្ងាត់ស្ងៀមនៃដួងចិត្តខ្ទេចខ្ទាំ ។ មែនហើយ ជាព្រលឹងមួយដែលមានពេញទៅដោយក្តីមេត្តាករុណា ដែលយើងនឹងមិនត្រឹមតែទំនាក់ទំនងភ្នែកនឹងភ្នែក ឬស្តាប់នឹងត្រចៀកទេ ប៉ុន្តែតាមរបៀបដ៏អស្ចារ្យរបស់ព្រះអង្គសង្គ្រោះ គឺដោយចិត្តនឹងចិត្ត » (« Meeting Life's Challenges, » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៧១) ។

- តើនៅពេលណា ដែលអ្នក ឬគ្រួសារអ្នកទទួលបានក្តីមេត្តាករុណា ឬការបម្រើមកពីអ្នកដទៃ ទោះជាអ្នកពុំបានសុំជំនួយក្តីនោះ ?
- តើការធ្វើតាមគំរូរបស់ព្រះគ្រីស្ទ អាចជួយយើងបង្កើតលទ្ធភាព ដើម្បីញាណដឹងពីតម្រូវការដែលពុំបានថ្លែងរបស់អ្នកដទៃយ៉ាងដូចម្តេច ?

ប្រសិនបើអ្នកពុំបង្ហាញវីដេអូទេ សូមអញ្ជើញសិស្សអានលូកា ៧:១៦–១៧ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវរបៀបដែលបណ្តាជនមានប្រតិកម្មចំពោះអព្ភូតហេតុនៃការប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយឲ្យរស់ឡើងវិញ ។

- តើបណ្តាជនមានប្រតិកម្មយ៉ាងដូចម្តេច បន្ទាប់ពីព្រះយេស៊ូវបានប្រោសកូនប្រុសរបស់ស្ត្រីមេម៉ាយឲ្យរស់ឡើងវិញ ?

ចូរពន្យល់ថា មនុស្សអាចនឹងបានប្រកាសថា « មានហោរា១ ធំបានកើតឡើងក្នុងពួកយើង » (ខទី ១៦) ដោយសារតែការព្យាបាលកូនប្រុសនៃស្ត្រីមេម៉ាយឲ្យរស់ឡើងវិញនៃស្រុកណាអ៊ីន និងឱកាសជាច្រើនទៀត និងអំឡុងពេលព្យាការីគម្ពីរសញ្ញាចាស់អេលីយ៉ា និងអេលីសេ បានប្រោសដល់ក្មេងប្រុសជាច្រើនពីស្លាប់ (សូមមើលពង្សាវតារក្យត្រទី ១ ១៧:១៧–២៤,ពង្សាវតារក្យត្រទី ២ ៤:៣២–៣៧, *New Testament Student Manual* ទំព័រ ១៥៤) ។

សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យរកមើលឱកាសជាច្រើន ដើម្បីបំពេញតាមតម្រូវការដែលពុំបានថ្លែងរបស់អ្នកដទៃ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យបម្រើដោយសប្បុរស និងដោយឥតសង្ឃឹមថាចង់បានអ្វីតបវិញ ។

លូកា ៧:១៨–៥០

សេចក្តីផ្តើម

ព្រះយេស៊ូវបានសរសើរដល់យ៉ូហានបាទីស្ទ ហើយបានថ្លែងទីបន្ទាល់ថា យ៉ូហានបានរៀបចំផ្លូវថ្វាយការបម្រើរបស់ទ្រង់ ។ ខណៈដែលព្រះយេស៊ូវកំពុងសោយអាហារជាមួយស៊ីម៉ូន ជាពួកផារិស៊ី នោះមានស្ត្រីដែលបានប្រែចិត្តម្នាក់មកបង្ហាញសេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់នាងទៅលើព្រះអង្គសង្គ្រោះ ។

យោបល់សម្រាប់ការបង្រៀន

លូកា ៧:១៨–៣៥

ព្រះយេស៊ូវបានសរសើរដល់យ៉ូហាន បាទីស្ទ ហើយថ្លែងទីបន្ទាល់អំពីបេសកកម្មរបស់យ៉ូហាន

សូមអញ្ជើញសិស្សធ្វើការជាដៃគូ ហើយឲ្យក្រដាសមួយសន្លឹកដល់ដៃគូនីមួយៗ ។ ចូរសុំឲ្យដៃគូនោះសរសេរហេតុការណ៍ជាច្រើនអំពីយ៉ូហាន បាទីស្ទ ចេញមកពីការចងចាំរបស់ពួកគេ បើពួកគេអាចក្នុងរយៈពេលមួយនាទី ។ បន្ទាប់ពីរយៈពេលមួយនាទី ចូរសុំឲ្យសិស្សរាប់ចំនួននៃហេតុការណ៍ទាំងនោះនៅលើក្រដាសរបស់ពួកគេ ។

- តើមានហេតុការណ៍អ្វីខ្លះអំពីយ៉ូហានបាទីស្ទ ដែលអ្នកអាចរៀបរាប់ ?

ចូរអញ្ជើញសិស្សឲ្យប្រាប់ដល់សិស្ស ក្នុងថ្នាក់អំពីហេតុការណ៍មួយចំនួនដែលពួកគេបានសរសេរ ។

បើអាចធ្វើទៅបាន ចូរដាក់តាំងដើមត្រែងខ្ពស់មួយ ហើយនឹងក្រណាត់ទន់មួយបំណែក ។ ចូរពន្យល់ថា ព្រះយេស៊ូវបានប្រើវត្ថុទាំងនេះដើម្បីបង្រៀនមនុស្សអំពីចរិកលក្ខណៈរបស់យ៉ូហានបាទីស្ទ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ៧:២៤–២៦ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវបានបង្រៀនអំពីយ៉ូហាន បាទីស្ទ ខណៈដែលសំដៅទៅលើដើមត្រែង និងក្រណាត់មួយបំណែក ។

- តើយ៉ូហានបាទីស្ទខុសគ្នាពីដើមត្រែង ឬស្លឹកស្មៅយ៉ាងដូចម្តេច ? (មិនដូចជាដើមត្រែងទេ ដែលត្រូវបានបោកបក់ ឬរញ្ជួយដោយខ្យល់នោះ តែយ៉ូហានបាទីស្ទ គឺមានភាពរឹងមាំ និងពុំងាករេនៅក្នុងដំណឹងល្អរបស់ទ្រង់ និងនៅ ក្នុង ការបំពេញបេសកកម្មរបស់លោកឡើយ) ។

សូមបង្ហាញរូបភាពអំពីយ៉ូហាន បាទីស្ទ ហើយសួរ ៖

- តើយ៉ូហាន បាទីស្ទខុសគ្នាពីអ្នកទាំងឡាយ « ដែលស្លៀកពាក់អាវទន់ភ្លន់ » ហើយរស់នៅដោយប្រណិត « នៅក្នុងដំណាក់ស្តេច » យ៉ាងដូចម្តេច (ខទី ២៥) ? (យ៉ូហាន បាទីស្ទ បានរស់នៅតាមទីវាល ហើយស្លៀកពាក់រោមអូដ្ឋ ដែលតូចទាប ។ ជាជាងការស្វែងរកភាពសុខស្រួលខាងសាច់ឈាម យ៉ូហាន បាទីស្ទ បានព្យាយាមធ្វើតាមព្រះទ័យរបស់ព្រះតែប៉ុណ្ណោះ) ។
- តើព្រះយេស៊ូវបានមានបន្ទូលអ្វីខ្លះអំពី យ៉ូហាន បាទីស្ទនៅក្នុងខទី ២៦ ?

ដើម្បីជួយសិស្សយល់អំពីតួនាទីពិសេសរបស់យ៉ូហាន បាទីស្ទ ចូរពន្យល់ថា ព្រះយេស៊ូវបានដកស្រង់ការព្យាករណ៍មួយ ដែលបានសរសេររាប់រយឆ្នាំពីមុន ដែលបានថ្លែងអំពី « សារទូត » ដែលនឹង «រៀបចំផ្លូវនៅមុខ [ព្រះមែស៊ី] » (ម៉ាឡាគី ៣:១) ។ សូមអញ្ជើញសិស្សម្នាក់អានលូកា ៧:២៧–២៨ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវមូលហេតុដែលយ៉ូហាន បាទីស្ទដែលជាព្យាការីពិសេសនៅក្នុងចំណោមពួកព្យាការី ។

- តើតួនាទីពិសេស និងសំខាន់អ្វីខ្លះ ដែលយ៉ូហាន បាទីស្ទត្រូវបានតែងតាំងមុនកំណើតលោកិយដើម្បីធ្វើកិច្ចការ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យ៉ូហាន បាទីស្ទ គឺជាព្យាការីដែលបានតែងតាំងពីមុនកំណើតលោកិយ ដើម្បីរៀបចំផ្លូវ និងធ្វើបុណ្យជ្រមុជទឹកថ្វាយព្រះរាជបុត្រានៃព្រះ**) ។
- តើ យ៉ូហាន បាទីស្ទបានរៀបចំផ្លូវសម្រាប់ការយាងមករបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

ចូរពន្យល់ថា ព្យាការីយ៉ូសែប ស៊្មីធ បានមានប្រសាសន៍ដូចខាងក្រោមទាក់ទងនឹងលូកា ៧:២៨ ៖

« ព្រះយេស៊ូវត្រូវបានគេមើលទៅថាជាអ្នក ដែលតូចជាងគេនៅក្នុងនគរព្រះ ហើយ [ហាក់ដូចជា] ត្រូវបានឲ្យឈ្មោះតូចជាងគេ ចំពោះការជឿរបស់ពួកគេទៅលើទ្រង់ ដែលថាជាព្យាការីមួយរូប គឺដូចជាអ្វីដែលទ្រង់បានមានបន្ទូលថា— ‹ អ្នកដែលចាត់ទុកខ្លួនតូចជាងគេក្នុងចំណោមអ្នករាល់គ្នា គឺធំជាងយ៉ូហាន—នោះគឺជារូបយើងនេះហើយ › » (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ៨២) ។

ចូរសង្កេតលូកា ៧:២៩–៣៥ដោយពន្យល់ថា មានមនុស្សជាច្រើនបានជឿលើការបង្រៀនរបស់ព្រះយេស៊ូវ ប៉ុន្តែពួកផារិស៊ី និងអ្នកច្បាប់ជាច្រើន ដែលមានវត្តមាននៅទីនោះបានបដិសេធចំពោះការបង្រៀនរបស់ទ្រង់ ។ ព្រះយេស៊ូវបានបង្រៀនថា ពួកគេបានបដិសេធសេចក្តីពិត មិនថាជាទ្រង់ ឬយ៉ូហានបាទីស្ទបានបង្រៀនសេចក្តីពិតក្តីនោះទេ ។



ការផ្សាយដំណឹងល្អរបស់ យ៉ូហាន បាទីស្ទ

លូកា ៧: ៣៦–៥០

ខណៈដែលព្រះយេស៊ូវបានទទួលទានអាហារពេលល្ងាចជាមួយនឹងស៊ីម៉ូន ពេត្រុសរួចហើយ នោះមានស្ត្រីម្នាក់មកលាងព្រះបាទទ្រង់ដោយទឹកភ្នែករបស់នាង ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀន ៖ ***តើខ្ញុំអាចត្រូវបានអភ័យទោសឬទេ*** *?*

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគ្រាដែលពួកគេបានងើបឆ្ងល់ ប្រសិនបើជាពួកគេអាចត្រូវបានអភ័យទោសឬយ៉ាងណា ។ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលឆ្លើយនឹងសំណួរនេះ នៅពេលពួកគេបន្តសិក្សាអំពីលូកា ៧របស់ពួកគេ ។

ដើម្បីជួយសិស្សយល់អំពីបរិបទ និងមាតិកានៃលូកា ៧:៣៦–៥០សូមអញ្ជើញសិស្សម្នាក់ឲ្យអានអំពីសេចក្តីសង្ខេប និងការពន្យល់ដូចខាងក្រោម ៖

ពួកផារិស៊ីម្នាក់មានឈ្មោះថា ស៊ីម៉ូន បានអញ្ជើញព្រះយេស៊ូវមកពិធីលៀងអាហារនៅផ្ទះរបស់ខ្លួន ។ នៅក្នុងពិធីលៀងអាហារប្រភេទនេះ ភ្ញៀវតែងតែទម្រេតខ្លួននៅលើខ្នើយដែលដាក់នៅជុំវិញតុ ហើយសណ្តូកជើងរបស់ពួកគេចេញពីតុ ។ ទំនៀមទម្លាប់ក្នុងសង្គមនៃជំនាន់នោះ អនុញ្ញាតឲ្យមនុស្សដែលខ្វះខាតដើរប្រមូលអាហារដែលនៅសេសសល់ពីពិធីជប់លៀង ។ ដូច្នេះ វាពុំមែនជារឿងចម្លែក ដែលមនុស្សមិនបានអញ្ជើញ ចូលមកក្នុងផ្ទះអំឡុងពេល ពិធីជប់លៀងមួយឡើយ (សូមមើល James E. Talmage, *Jesus the Christ* បោះពុម្ពលើកទី ៣ | ឆ្នាំ ១៩១៦ | ទំព័រ ២៦១) ។

ដើម្បីជួយសិស្សយល់ដឹងបន្ថែមអំពីមាតិកានៅក្នុងលូកា ៧:៣៦–៥០ សូមពិចារណាចាក់បង្ហាញវីដេអូ « Come unto Me » (១១:៣៤) មាននៅលើ LDS.org ។ អ្នកក៏អាចចង់ចាក់វគ្គនៃវីដេអូ ដែលបង្ហាញអំពីព្រះយេស៊ូវកំពុងសោយអាហារជាមួយនឹងស៊ីម៉ូន ជាពួកផារិស៊ី (ចាប់ផ្តើមនៅលេខកូនដង្កាង ៤:១៧) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម នៅក្នុងគម្ពីររបស់ពួកគេ ហើយរកមើលទង្វើអ្វី ដែលបានកើតឡើងនៅពេលមនុស្សដែលគេពុំបានអញ្ជើញម្នាក់ បានដើរចូលមកក្នុងផ្ទះរបស់ស៊ីម៉ូន អំឡុងពេលទទួលទានអាហារនោះ ។ សូមផ្អាកវីដេអូ បន្ទាប់ពីព្រះយេស៊ូវមានបន្ទូលថា « អ្នកស្មានត្រូវ » (លូកា ៧:៤៣) (លេខកូដង្កាង ៧:២៤) ។

- តើលូកាបានពិពណ៌នាអំពីស្ត្រីដែលនៅក្នុងលូកា ៧:៣៧យ៉ាងដូចម្តេច ?
- តើស្ត្រីនោះបង្ហាញសេចក្តីស្រឡាញ់របស់នាងចំពោះព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ? (អ្នកអាចនឹងចង់ពន្យល់ថា « ប្រេងទេព្ឋិរសទ្ធ » គឺជាដបមួយដែលពេញទៅដោយប្រេងក្រអូបដ៏មានតម្លៃ) ។
- តើស៊ីម៉ូនបានគិតយ៉ាងណា ពេលគាត់បានមើលឃើញអ្វីដែលស្ត្រីនោះកំពុងធ្វើ ?

ដើម្បីមើលរឿងប្រៀបធៀបដែលព្រះយេស៊ូវបានបង្រៀន ចូរសុំឲ្យសិស្សម្នាក់អានលូកា ៧:៤០–៤៣

.ឮៗ ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់ ឲ្យធ្វើងតាម រកមើលអ្វី ដែលព្រះយេស៊ូវបានបង្រៀនដល់សឺម៉ូន ។ សូមចម្លង តារាងខាងក្រោមដាក់លើក្តារខៀន ។

ម្ចាស់បំណុល= _____	
កូនបំណុល ដែលខ្ចីប្រាក់ ៥០ សេន= _____	កូនបំណុល ដែលខ្ចីប្រាក់ ៥០០ សេន= _____

ចូរពន្យល់ថាម្ចាស់បំណុលគឺជាមនុស្សម្នាក់ ដែលឲ្យប្រាក់គេខ្ចី មនុស្សដែលខ្ចីប្រាក់គេ គឺជាកូនបំណុល ។ កូនបំណុលយល់ព្រមបង់សងទៅម្ចាស់បំណុល ឬត្រូវជាប់គុក ។ ចូរសួរដល់សិស្សម្នាក់ឲ្យសង្ខេបរឿងប្រៀបធៀបតាមសម្តីរបស់ពួកគេ ។

- **តើម្ចាស់បំណុលតំណាងឲ្យនរណា ? (*សូមសរសេរ ព្រះយេស៊ូវគ្រីស្ទ* នៅលើក្តារខៀនជិតនឹង៣ក្យ « ម្ចាស់បំណុល ») ។**
- **តើម្ចាស់បំណុលណាម្នាក់ ដែលអាចតំណាងឲ្យស្ត្រីនោះ ហើយនរណា ដែលអាចតំណាងឲ្យសឺម៉ូន ជាពួកផារិស៊ី ? ហេតុអ្វី ? (*ចូរសរសេរសឺម៉ូន ជាពួកផារិស៊ី*នៅក្រោម៣ក្យ « កូនបំណុល ដែលខ្ចីប្រាក់ ៥០ សេន » និង *ស្ត្រី*នៅក្រោម៣ក្យ « កូនបំណុល ដែលខ្ចីប្រាក់ ៥០០ សេន ») ។**

ចូរពន្យល់ថា អំឡុងជំនាន់របស់ព្រះយេស៊ូវ វាគឺជាទំនៀមទម្លាប់សម្រាប់អ្នកទទួលភ្ញៀវ ដើម្បីគោរពដល់ភ្ញៀវល្អៗរបស់គាត់ ដោយការធ្វើទង្វើចិត្តល្អ ដូចជាការថើបពួកគេពេលស្វាគមន៍ ផ្តល់ទឹកសម្រាប់ពួកគេលាងជើង និងចាក់តាំងប្រេងនៅលើក្បាលពួកគេជាដើម (សូមមើល James E. Talmage *Jesus the Christ* ទំព័រ ២៦១) ។

សូមចាក់វីដេអូនៅលេខកូដម៉ោង ៧:២៥ ហើយបញ្ឈប់វាបន្ទាប់ពីព្រះយេស៊ូវមានបន្ទូលថា « អញ្ជើញទៅដោយសុខសាន្តចុះ » (លូកា ៧:៥០) (លេខកូដពេលវេលា ៨:៥២) ។ ឬ អញ្ជើញឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗចេញមកពី លូកា ៧:៤៤–៤៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលពីរបៀប ដែលសឺម៉ូនបានប្រព្រឹត្តនឹងព្រះយេស៊ូវ ដោយប្រៀបធៀបទៅនឹងរបៀបដែលស្ត្រីបានប្រព្រឹត្តចំពោះទ្រង់ និងរបៀបដែលពួកគេអាចនឹងមានអារម្មណ៍យ៉ាងណាអំពីព្រះយេស៊ូវ ។

- **យោងតាមខទី ៤៤–៤៧ តើភាពខុសគ្នាមួយចំនួនអ្វីខ្លះរវាងរបៀប ដែលសឺម៉ូនបានប្រព្រឹត្តនឹងព្រះយេស៊ូវ និងរបៀបដែលស្ត្រីបានប្រព្រឹត្តចំពោះទ្រង់ ហើយតើពួកគេម្នាក់ៗអាចនឹងមានអារម្មណ៍យ៉ាងណាអំពីព្រះយេស៊ូវ ? (សូមសរសេរចម្លើយរបស់សិស្សនៅក្នុងតារាងនៅលើក្តារខៀន) ។**

នៅពេលសិស្សបានបញ្ចប់ការរាយការណ៍អំពីអ្វី ដែលពួកគេបានរកឃើញហើយនោះ តារាងគួរតែមានសណ្ឋានស្រដៀងខាងក្រោម ៖

ម្ចាស់បំណុល=លើព្រះយេស៊ូវគ្រីស្ទ	
កូនបំណុល ដែលខ្ចីប្រាក់ ៥០ សេន = សឺម៉ូនជាពួកផារិស៊ី ពុំបានឲ្យទឹកដល់ព្រះយេស៊ូវដើម្បីលាងព្រះបាទាទ្រង់ទេ ពុំបានថើបទ្រង់ទេ ពុំបានចាក់ប្រេងតាំងទ្រង់ទេ ស្រឡាញ់ទ្រង់បន្តិចបន្តួច	កូនបំណុល ដែលខ្ចីប្រាក់ ៥០០ សេន = ស្ត្រី បានលាងព្រះបាទាទ្រង់ដោយទឹកភ្នែករបស់នាង ហើយ បានជូតសម្អាតដោយសក់របស់នាង បានថើបព្រះបាទារបស់ទ្រង់ បានចាក់ប្រេងតាំងលើព្រះបាទាទ្រង់ បានស្រឡាញ់ទ្រង់យ៉ាងខ្លាំង

- **តើមានពរជ័យអ្វីខ្លះ ដែលស្ត្រីម្នាក់នេះបានទទួលមកពីព្រះអង្គសង្គ្រោះ ?**

ចូរចង្អុលបង្ហាញថា តាមរយៈការប្រៀបធៀបដោយពុំថ្លែងជាវាចា សឺម៉ូនប្រៀបបានទៅនឹងកូនបំណុលដែលខ្ចីប្រាក់ ៥០ សេន ឯព្រះអង្គសង្គ្រោះបានផ្តល់យោបល់ថា សឺម៉ូនត្រូវការនូវការអភ័យទោសពីបាបរបស់ខ្លួនផងដែរ ។

សូមអញ្ជើញសិស្សឲ្យអានលូកា ៧:៤៥–៥០ ដោយស្ងាត់ស្ងៀម ហើយសុំពួកគេឲ្យរកមើលនូវអ្វី ដែលបានធ្វើឲ្យស្ត្រីម្នាក់នេះអាចទទួលបានការអភ័យទោស ។

- **តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីដំណើររឿងនេះ ? (*សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន* ដោយប្រើ៣ក្យរបស់សិស្ស ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿរបស់យើង តាមរយៈការបង្ហាញសេចក្តីស្រឡាញ់របស់យើង និងការលះបង់ថ្វាយព្រះអម្ចាស់ នោះយើងអាចទទួលបទពិសោធន៍នៃការអភ័យទោសរបស់ទ្រង់ ។ នៅពេលយើងទទួលបានការអភ័យទោសរបស់ព្រះអម្ចាស់ នោះយើងត្រូវបានពេញដោយបំណងប្រាថ្នាដើម្បីស្រឡាញ់ និងបម្រើទ្រង់កាន់តែច្រើន**) ។**

សូមជួយសិស្សឲ្យ ប្រាប់ពីគោលការណ៍ទាំងឡាយ ។

ពេលខ្លះអ្នកនឹងចង្អុលបង្ហាញអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយទៅដល់សិស្ស ។ នៅពេលផ្សេងទៀតអ្នកនឹងដឹកនាំ លើកទឹកចិត្ត និងអនុញ្ញាតឲ្យសិស្សស្វែងរកគោលលទ្ធិ និងគោលការណ៍ទាំងនេះដោយខ្លួនឯង ។ នៅក្នុងគោលលទ្ធិ និងគោលការណ៍ដែលបានប្រាប់នោះ វាសំខាន់ដើម្បីថ្លែងវាឲ្យច្បាស់លាស់ និងសមញ្ញ ។ ចូរសរសេរគោលលទ្ធិ ឬគោលការណ៍ដែលបានប្រាប់នោះនៅលើក្តារខៀន ឬអញ្ជើញសិស្សឲ្យសរសេរ ឬគូសចំណាំវានៅក្នុងព្រះគម្ពីររបស់ពួកគេ ដែលអាចជួយបញ្ជាក់ពីសេចក្តីពិតទាំងនេះនៅក្នុងគំនិតរបស់សិស្ស ។

- ហេតុអ្វីក៏យើងអាចនឹងមានបំណងប្រាថ្នាស្រឡាញ់ និងបម្រើព្រះអង្គសង្គ្រោះកាន់តែច្រើន នៅពេលយើងទទួលបទពិសោធន៍នៃការអភ័យទោសពីទ្រង់ ?

សូមឲ្យសិស្សបីនាក់អានម្តងម្នាក់ៗ នូវកថាកណ្ដមួយចេញមកពីសេចក្ដីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« មានកម្រិតជាច្រើននៃភាពសក្តិសម និងសេចក្ដីសុចរិតផ្ទាល់ខ្លួន ។ ប៉ុន្តែការប្រែចិត្តគឺជាពរជ័យមួយចំពោះយើងទាំងអស់គ្នា ។ យើងម្នាក់ៗចាំបាច់ត្រូវទទួលអារម្មណ៍ដឹងអំពីព្រះហស្តឱបក្រសោបដោយក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ តាមរយៈការអភ័យទោសអំពើបាបរបស់យើង ។

« ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំត្រូវបានសុំឲ្យជួបនឹងបុរសម្នាក់ដែល កាលពីមុនបានមានជីវិតរស់នៅដ៏វឹកវរ ។ ជាលទ្ធផលនៃជម្រើសមិនល្អរបស់គាត់ នោះគាត់បានបាត់បង់សមាជិកភាពរបស់គាត់នៅក្នុងសាសនាចក្រ ។ គាត់ចង់ត្រឡប់មកសាសនាចក្រវិញ ហើយបានរក្សាបទបញ្ញត្តិដោយស្មោះត្រង់ ប៉ុន្តែទង្វើកាលពីមុនរបស់គាត់បានមកមកអុកឡុកអំខានគាត់មិនចេះឈប់ឈរ ។ ពេលជួបជាមួយគាត់ ខ្ញុំមានអារម្មណ៍ដឹងពីការខ្មាស់អៀន និងវិប្បដិសារីដ៏ខ្លាំងរបស់គាត់ដែលបានបោះបង់ចោលសេចក្ដីសញ្ញារបស់គាត់ ។ បន្ទាប់ពីការសម្ភាសរបស់យើង ខ្ញុំបានដាក់ដៃរបស់ខ្ញុំលើក្បាលរបស់គាត់ ដើម្បីប្រទានពរជ័យបព្វជិតភាពមួយដល់គាត់ ។ មុនពេលថ្លែង ខ្ញុំបានទទួលអារម្មណ៍ដឹងពីក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះមានដល់គាត់ ហើយអភ័យទោសដល់គាត់ ។ បន្ទាប់ពីការប្រសិទ្ធពរ នោះយើងបានឱបគ្នា ហើយបុរសនោះបានទ្រហោយំ ។

« ខ្ញុំមានភាពអស្ចារ្យណាស់ចំពោះព្រះហស្តឱបក្រសោប ដោយក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ និងក្តីស្រឡាញ់របស់ទ្រង់ចំពោះជនដែលប្រែចិត្ត មិនថាអ្នកដែលបានលះបង់អំពើបាបនោះមានភាពអត្ថានិយមប៉ុណ្ណាទេ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះអាច ហើយចង់អភ័យទោសចំពោះអំពើបាបរបស់យើង ។ លើកលែងតែអំពើបាបរបស់មនុស្សមួយចំនួន ដែលជ្រើសរើសយកសេចក្ដីហិនហោច ក្រោយពីបានដឹងដ៏ពេញលេញហើយនោះ ក្រៅពីនោះពុំមានអំពើបាបណា ដែលពុំអាចអត់ទោសឲ្យបាននោះឡើយ ។ វាជាឯកសិទ្ធិដ៏អស្ចារ្យក្រៃលែងសម្រាប់យើងម្នាក់ៗ ក្នុងការងាកបែរចេញពីអំពើបាបរបស់យើង ហើយមករកព្រះគ្រីស្ទ ។ ការអភ័យទោសដ៏ទេវភាព គឺជាផលផ្លែដ៏ផ្អែមល្ហែមបំផុតមួយ នៃដំណឹងល្អដែលដកចេញនូវទោសកំហុស និង ការឈឺចាប់ចេញពីដួងចិត្តយើង ហើយជំនួសមកវិញដោយនូវអំណរ និង សេចក្ដីសុខសាន្តក្នុងសតិសម្បជញ្ញៈ » (« Repent . . . That I May Heal You » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤០–៤១) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពួកគេបានទទួលបទពិសោធន៍នៃការអភ័យទោសមកពីព្រះអម្ចាស់ ។ ចូរសុំឲ្យពួកគេពិចារណាអំពីអ្វីដែលពួកគេបានគិត និងរបៀបដែលពួកគេបានទទួលអារម្មណ៍ដឹងអំពីព្រះអង្គសង្គ្រោះ ។

សូមយោងទៅសំណួរនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សពន្យល់អំពីរបៀបដែលពួកគេនឹងឆ្លើយនឹងសំណួរ ប្រសិនបើនរណាម្នាក់បានសួរដល់ពួកគេថា « តើខ្ញុំអាចត្រូវបានអភ័យទោសឬទេ ? »

សូមបញ្ចប់មេរៀនដោយការថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាអភ័យទោសដល់យើង ប្រសិនបើយើងអនុវត្តសេចក្ដីជំនឿទៅលើទ្រង់ ហើយប្រែចិត្តពីអំពើបាបរបស់យើង ។

ការរំឭកពីចំណេះចំណានខគម្ពីរ

ដើម្បីជួយសិស្សរំឭកចំណេះចំណានខគម្ពីរទាំងប្រាំដែលពួកគេបានសិក្សាឡើងវិញ អំឡុងវគ្គសិក្សានេះ អ្នកគប្បីដាក់លំហាត់ខ្លីមួយដល់ពួកគេ ។ សូមផ្តល់ពាក្យគន្លឹះមកពីវត្ថុសិក្សាចំណាំក្នុងសៀវភៅថ្នាក់សិក្ខាសាលា ហើយសុំឲ្យសិស្សរសេរនូវសេចក្ដីយោងបទគម្ពីរដែលទាក់ទង ។ សូមមើល សេចក្ដីបន្ថែមនៃសៀវភៅសិក្សានេះសម្រាប់យោបល់បន្ថែម ។

លូកា ៨–៩

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះបានបន្តបម្រើនៅក្នុងស្រុកកាលីឡេ ជាកន្លែងដែលទ្រង់បានព្យាករអំពីការសុគត និងការរស់ឡើងវិញរបស់ទ្រង់ ។ ពេលចាកចេញពីកាលីឡេ ព្រះយេស៊ូវ បានធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិមដើម្បីបញ្ចប់បេសកកម្មក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ។ នៅក្នុងស្រុកសាម៉ារី យ៉ាកុប និង យ៉ូហាន បានហៅឲ្យភ្លើងធ្លាក់ចុះពីលើមេឃដើម្បីឆេះភូមិសាសន៍សាម៉ារី ដែលបានបដិសេធព្រះយេស៊ូវ ប៉ុន្តែទ្រង់បានបង្រៀនពួកសិស្សរបស់ទ្រង់ថាទ្រង់បានយាងមកដើម្បីសង្គ្រោះប្រជាជន ពុំមែនដើម្បីបំផ្លាញពួកគេទេ ។ ព្រះយេស៊ូវក៏បានបង្រៀនអំពីភាពជាសិស្សពិតផងដែរ ។

យោបល់សម្រាប់ការបង្រៀន

លូកា ៨:១–៩:៥៦

ព្រះអង្គសង្គ្រោះធ្វើអព្ភូតហេតុ បង្រៀនដោយប្រើរឿងប្រៀបធៀប ហើយធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម

ចូរសរសេរស្ថានភាពដូចខាងក្រោមនៅលើក្តារខៀន ឬសរសេរស្ថានភាពនីមួយៗនៅលើសន្លឹកក្រដាសផ្សេងៗគ្នាមួយ ។ សូមឲ្យសិស្សបីនាក់អានវាឮៗ ។

១. នៅពេលអ្នកសុំឲ្យបងប្រុសរបស់អ្នកជួយសម្អាតភាពរញ៉េរញ៉ៃរបស់អ្នកដោយទន់ភ្លន់ គាត់បែជាប្រាប់មកវិញទាំងទ្រគោះបោះបោកថា ធ្វើខ្លួនឯងទៅ ។

២. ខណៈពេលកំពុងរៀបចំសកម្មភាពសាលាមួយ នោះសិស្សរួមថ្នាក់ពីរបីនាក់បានរិះគន់ ហើយបានសើចចំអកចំពោះគំនិតដែលអ្នកចែកចាយ ។

៣. នៅពេលអ្នកចែកចាយដំណឹងល្អជាមួយមិត្តម្នាក់ នាងប្រាប់អ្នកថាជំនឿរបស់អ្នកចម្លែកណាស់ ។

- តើអ្នកនឹងមានអារម្មណ៍យ៉ាងណាចំពោះស្ថានភាពនីមួយៗនេះ ? តើអ្នកនឹងមានប្រតិកម្មយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីពិត នៅពេលពួកគេសិក្សាអំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងលូកា ៨–៩ ដែលអាចដឹកនាំពួកគេនៅពេលពួកគេមានអារម្មណ៍អាក់អន់ចិត្តដោយសកម្មភាព ឬពាក្យសម្តីរបស់អ្នកដទៃ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការសង្ខេបជំពូកលូកា ៨–៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលព្រឹត្តការណ៍ដែលត្រូវបានកត់ត្រានៅក្នុងជំពូកទាំងនេះ ។ សូមពន្យល់ថា ដោយសារតែពួកគេបានសិក្សាពីព្រឹត្តការណ៍ទាំងនេះយ៉ាងលម្អិតនៅក្នុងមេរៀននៅម៉ាថាយ និងម៉ាកុស នោះមេរៀននេះនឹងផ្តោតទៅលើលូកា ៩:៥១–៦២ ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ៩:៥១ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវកន្លែងដែលព្រះអង្គសង្គ្រោះបានសម្រេចចិត្តថាទៅ ។ សូមពន្យល់ថា ឃ្លា « ត្រូវឡើងទៅស្ថានសួគ៌ » សំដៅទៅលើការយាងឡើងទៅស្ថានសួគ៌វិញរបស់ព្រះអង្គសង្គ្រោះ ។

- តើព្រះអង្គសង្គ្រោះសម្រេចថាទៅកន្លែងណា ?

ចូរពន្យល់ថា ការធ្វើអ្វីមួយដោយខ្ជាប់ខ្ជួនមានន័យថា ធ្វើវានៅក្នុងការប្តេជ្ញាចិត្ត ឬក្នុងរបៀបមួយដែលពុំងាករេ ។ កាលពីដើម ព្រះអង្គសង្គ្រោះបានព្យាករដល់ពួកសិស្សរបស់ទ្រង់ថា ទ្រង់នឹងត្រូវគេក្បត់ វាយនឹងរំពាត់ ហើយឆ្កាងនៅក្នុងទីក្រុងយេរូសាឡិម (សូមមើលម៉ាថាយ ២០:១៧–១៩,លូកា ៩:៤៤) ។

- តើការប្តេជ្ញាចិត្តរបស់ព្រះអង្គសង្គ្រោះដើម្បីទៅកាន់ទីក្រុងយេរូសាឡិមមានអ្វីខ្លះទោះជាមានបញ្ហាទាំងនេះបើកបង្ហាញអំពីចរិតលក្ខណៈរបស់ទ្រង់នោះ ?

ចូរចង្អុលបង្ហាញថា ខណៈដែលកំពុងធ្វើដំណើរទៅទីក្រុងយេរូសាឡិម ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ បានទៅកាន់ភូមិសាម៉ារី ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេណគ្នាអានអំពីលូកា ៩:៥២–៥៤ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលប្រតិកម្មរបស់សាសន៍សាម៉ារីពេលពួកគេបានដឹងថា ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ចង់ចូលមកក្នុងភូមិរបស់ពួកគេ

- តើសាសន៍សាម៉ារីបានមានប្រតិកម្មអ្វីខ្លះ នៅពេលពួកគេបានដឹងថា ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ ចង់ចូលទៅក្នុងភូមិរបស់ពួកគេនោះ ?
- តើយ៉ាកុប និងយ៉ូហាន បានមានប្រតិកម្មចំពោះការមិនរាក់ទាក់របស់ពួកសាសន៍សាម៉ារី និងការបដិសេធព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- តើមនុស្សនៅសព្វថ្ងៃមានប្រតិកម្មយ៉ាងខ្លាំងចំពោះការប្រមាថ និងការធ្វើឲ្យអាក់អន់ចិត្តមកពីអ្នកដទៃតាមរបៀបណា ? (សូមយោងទៅលើស្ថានភាពទាំងឡាយចាប់តាំងពីចាប់ផ្តើមមេរៀនមក ហើយសុំឲ្យសិស្សពិចារណាអំពីរបៀបនានាដែលនរណាម្នាក់អាចនឹងមានប្រតិកម្មយ៉ាងខ្លាំងចំពោះស្ថានភាពទាំងនេះ) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ៩:៥៥–៥៦ ឮៗ ។ ចូរសុំឲ្យសិស្សផ្សេងទៀតផ្ទៀងតាម ហើយរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅកាន់ យ៉ាកុប និង យ៉ូហាន ។ ចូរសុំឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

ចូរពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះបានមានបន្ទូលថា « អ្នករាល់គ្នាមិនដឹងជាមានវិញ្ញាណបែបយ៉ាងណាទេ » (ខទី ៥៥) នោះទ្រង់កំពុងផ្តល់យោបល់ថា សំណើររបស់យ៉ាកុប និងយ៉ូហាន គឺពុំសមស្របទៅនឹងព្រះវិញ្ញាណនៃព្រះឡើយ ប៉ុន្តែវាមានភាពសមស្របទៅនឹងវិញ្ញាណរបស់សាតាំងច្រើនជាង ដែលចាក់រុកចិត្តមនុស្សឲ្យមានកំហឹង (សូមមើលនីហ្វៃទី ៣ ១១:២៩–៣០) ។

- តើប្រតិកម្មរបស់ព្រះអង្គសង្គ្រោះចំពោះការបដិសេធរបស់ពួកសាសន៍សាម៉ារីខុសគ្នាពីប្រតិកម្មរបស់យ៉ាកុប និងយ៉ូហានយ៉ាងដូចម្តេចខ្លះ ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីគំរូរបស់ព្រះអង្គសង្គ្រោះដែលអាចដឹកនាំយើងនៅពេលយើងប្រឈមមុខនឹងការធ្វើឲ្យអាក់អន់ចិត្តនោះ ? (ដោយប្រើពាក្យសម្តីរបស់សិស្ស ចូរសរសេរនៅលើក្តារខៀនអំពីសេចក្តីពិតមួយ ដែលស្រដៀងគ្នាដូចខាងក្រោម ៖ **យើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នៅពេលយើងជ្រើសរើសឆ្លើយតបចំពោះការធ្វើឲ្យអាក់អន់ចិត្ត ដោយភាពអត់ធ្មត់ និងការស៊ូទ្រាំ**) ។

សូមអញ្ជើញសិស្សឲ្យនឹកគិតអំពីស្ថានភាពនានា នៅដើមមេរៀន ។

- តើគ្រោះថ្នាក់ដ៏ខ្លាំងនៃការជ្រើសរើសទទួលការអាក់អន់ចិត្តនៅក្នុងស្ថានភាពនីមួយៗទាំងនេះមានអ្វីខ្លះ ?
- នៅក្នុងស្ថានភាពនីមួយៗ តើយើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- តើយើងអាចត្រូវបានប្រទានពរ នៅពេលយើងជ្រើសរើសឆ្លើយតបចំពោះការធ្វើឲ្យអាក់អន់ចិត្ត ដោយការអត់ធ្មត់ និងការស៊ូទ្រាំយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សនឹកគិតអំពីស្ថានភាពមួយ ពេលដែលពួកគេបានជ្រើសរើសទទួលការអាក់អន់ចិត្ត ដោយពាក្យសម្តី ឬទង្វើរបស់នរណាម្នាក់ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នៅពេលយើងជ្រើសរើសឆ្លើយតបចំពោះការធ្វើឲ្យអាក់អន់ចិត្តដោយភាពអត់ធ្មត់ និងការស៊ូទ្រាំ)។

ការរំលោភបំពានគឺពុំត្រូវបានអនុវិនឲ្យទេ

នៅពេលអ្នកសុំឲ្យសិស្សគិតពិចារណាអំពីការប្រព្រឹត្តខុសទាស់នឹងពួកគេ ឬការឆ្លើយតបដោយការអត់ធ្មត់ និងការស៊ូទ្រាំ សូមបង្ហាញឲ្យច្បាស់ថា សិស្សពុំគួរអនុញ្ញាតឲ្យមានការបំពានណាមួយបន្តមានទាស់នឹងពួកគេនោះទេ ។ ប្រសិនបើសិស្សជាជនរងគ្រោះនៃការបំពានមួយ នោះពួកគេគួរតែស្វែងរកជំនួយពីឪពុកម្តាយ ថ្នាក់ដឹកនាំបព្វជិតភាព និងអ្នកមានសិទ្ធិអំណាចដទៃទៀតរបស់ពួកគេក្លាមតាមដែលអាចធ្វើទៅបាន ។

លូកា ៩:៥៧–៦២

ព្រះយេស៊ូវបង្រៀនអំពីភាពជាសិស្សពិត

សូមអញ្ជើញសិស្សម្នាក់ឲ្យមកកាន់ក្តារខៀន ហើយបង្ហាញគាត់ ឬនាងនូវវត្ថុតូចៗចំនួន ២០–៣០ ដុំ (ដូចជាអង្កាំ) ។ សូមណែនាំសិស្សឲ្យរាប់វត្ថុនោះដោយស្ងៀមស្ងាត់ ។ ខណៈដែលគាត់ ឬនាងកំពុងរាប់នោះ ចូរសុំឲ្យសិស្សក្នុងថ្នាក់រាប់ឮៗរំខានដល់សិស្សនោះ ។ សូមប្រាកដថា សិស្សពុំប្រែទៅជាមានឥរិយាបទរញ៉ៃរញ៉ៃក្នុងការព្យាយាមដើម្បីរំខានដល់សិស្សម្នាក់នោះឡើយ ។ សូមណែនាំពួកគេឲ្យបន្តនៅអង្គុយចុះ ហើយប្រាប់ដល់ពួកគេកុំឲ្យចោទអ្វី ឬប៉ះពាល់ដល់សិស្សដែលកំពុងរាប់ឡើយ ។

- តើការរាប់វត្ថុនោះដោយមានការរំខាន វាស្រដៀងគ្នាទៅនឹងការព្យាយាមធ្វើតាមព្រះយេស៊ូវគ្រីស្តតាមរបៀបណាដែរ ?

អរគុណដល់សិស្សដែលបានរាប់វត្ថុនោះ ហើយអញ្ជើញឲ្យពួកគេទៅកន្លែងអង្គុយវិញ ។ នៅពេលសិស្សបន្តសិក្សានៅក្នុងលូកា ៩សូមអញ្ជើញពួកគេឲ្យពិចារណាអំពីរបៀបដែលយើងអាចយកឈ្នះលើឥទ្ធិពលដែលអាចនឹងរំខាន ឬរារាំងយើងមិនឲ្យធ្វើតាមព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ៩:៥៧ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលបុរសម្នាក់បាននិយាយទៅកាន់ព្រះយេស៊ូវ នៅពេលទ្រង់ និងពួកសិស្សរបស់ទ្រង់បានធ្វើដំណើរទៅទីក្រុងយេរូសាឡិម ។

- តើបុរសនេះប្រាប់ព្រះអង្គសង្គ្រោះ ថាគាត់កំពុងមានឆន្ទៈដើម្បីធ្វើអ្វីខ្លះ ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ដើម្បីធ្វើជាសិស្សពិតរបស់ព្រះយេស៊ូវគ្រីស្ទ . . .*

សូមអញ្ជើញសិស្សម្នាក់អានលូកា ៩:៥៨ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះបុរសដែលមានបំណងប្រាថ្នាធ្វើតាមទ្រង់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើឃ្លា « កូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ » ចង្អុលបង្ហាញអំពីរបៀបរស់នៅរបស់ព្រះអង្គសង្គ្រោះយ៉ាងណាដែរ ? (ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ ត្រូវធ្វើការផ្លាស់ប្តូរជាប្រចាំ ។ ការបម្រើរបស់ពួកលោក ពុំមានភាពសុខស្រួល ឬដោយរលូននោះទេ) ។

សូមអញ្ជើញសិស្សឲ្យអានលូកា ៩:៥៩–៦០ដោយស្ងាត់ស្ងៀម រកមើលចម្លើយទីពីររបស់បុរសនោះចំពោះការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យដើរតាមទ្រង់ ។

- តើបុរសនេះចង់ធ្វើអ្វី មុនពេលដើរតាមព្រះអង្គសង្គ្រោះ ?
- តើពាក្យ*សិន*(ខ ៥៩) បង្ហាញអំពីបុរសនេះថាជាមនុស្សយ៉ាងណាដែរ ?

ចូរពន្យល់ថា ព្រះយេស៊ូវគ្រីស្ទ ពុំបានចង្អុលបង្ហាញថា វាខុសឆ្គងដើម្បីទួញយំចំពោះការស្លាប់របស់មនុស្សជាទីស្រឡាញ់ ឬផ្តល់ការគោរពរបស់យើងនៅឯពិធីបុណ្យសពនោះទេ (សូមមើលគ. និង ស. ៤២:៤៥) ។ ផ្ទុយទៅវិញ ទ្រង់កំពុងបង្រៀនបុរសនេះនូវមេរៀនសំខាន់មួយអំពីភាពជាសិស្ស ។

- តើយើងអាចរៀនអ្វីខ្លះមកពីការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះដែលបានកត់ត្រានៅក្នុងខទី ៦០អំពីអាទិភាពនៃសិស្សពិតមួយរូបនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ៩:៦១–៦២ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលបុរសទីបីប្រាថ្នាចង់ធ្វើ ពីមុនដើរតាមព្រះអង្គសង្គ្រោះ ។

- តើបុរសនេះចង់ធ្វើអ្វី មុនពេលដើរតាមព្រះអង្គសង្គ្រោះ ?
- តើព្រះអង្គសង្គ្រោះបានឆ្លើយតបចំពោះបុរសនេះយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សឲ្យយល់អំពីសទិសន័យនៃការដាក់ដៃរបស់យើងទៅកាន់នង្គ័ល ហើយកុំមើលក្រោយឡើយនោះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ឲ្យឮៗ ៖



« ដើម្បីភ្ជួរដីបានត្រង់ [ឬមានជ្រួ] នោះអ្នកភ្ជួរដីចាំបាច់ត្រូវតម្រង់ភ្នែកមើលឲ្យត្រង់ទៅមុខ។ វាក្បាគាត់ឲ្យស្ថិតនៅលើផ្លូវពិតមួយ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគាត់ងាកមើលក្រោយ ហើយឃើញកន្លែងដែលគាត់បានភ្ជួរនោះ:ឱកាសនៃការវៀចវេរនឹងមានច្រើន ។ លទ្ធផលគឺមានភាពវៀចវេ ហើយពុំភ្ជួរដីបានល្អទេ ។ . . . ប្រសិនបើថាមពលរបស់យើងត្រូវបានផ្តោតទៅមុខ មិនផ្តោតទៅក្រោយ—ទៅលើជីវិតអស់កល្បជានិច្ច និងអំណរនៃសេចក្តីសង្គ្រោះ—នោះយើងនឹងទទួលបានវាដោយពិតប្រាកដ » (« Ω » *Ensign* ខែ ឧសភា ឆ្នាំ ១៩ ៨៧ ទំព័រ ១៧) ។

- តើការធ្វើជាសិស្សម្នាក់នៃព្រះយេស៊ូវគ្រីស្ទគឺដូចជាការដាក់ដៃរបស់យើងកាន់នង្គ័ល ហើយមិនក្រឡេកមើលក្រោយយ៉ាងដូចម្តេច ?
- តើព្រះអង្គសង្គ្រោះគឺជាគំរូនៃអ្វីដែលទ្រង់បានបង្រៀនដូចបានកត់ត្រានៅក្នុងខទី ៦២យ៉ាងដូចម្តេច ? (« ទ្រង់តម្រង់ព្រះភក្ត្រ យាងឆ្ពោះត្រង់ទៅក្រុងយេរូសាឡិមតែម្តង » [លូកា ៩:៥១] ដើម្បីបំពេញនូវបេសកកម្មដែលព្រះវរបិតាបានប្រទានដល់ទ្រង់ ហើយទ្រង់ពុំងាកក្រោយឡើយ) ។

សូមយោងទៅលើប្រយោគពុំពេញលេញនៅលើតារាងខ្យែង ។

- ផ្អែកទៅលើអ្វីដែលយើងបានរៀនមកពីលូកា ៩:៥៧–៦២ តើអ្នកនឹងសង្ខេបសេចក្តីពិតមួយដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីអ្វីដែលទ្រង់តម្រូវពីពួកសិស្សរបស់ទ្រង់ដោយរបៀបណា ? (សិស្សអាចនឹងប្រាប់អំពីគោលការណ៍ផ្សេងៗ ។ បន្ទាប់ពីពួកគេឆ្លើយតប សូមបំពេញប្រយោគនៅលើតារាងខ្យែងដើម្បីវានាំទៅរកសេចក្តីពិតដូចខាងក្រោមនេះ ៖ **ដើម្បីធ្វើជាសិស្សពិតរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងមិនត្រូវឲ្យអ្វីមួយមកមានអាទិភាពច្រើនជាងការធ្វើតាមទ្រង់នោះឡើយ**)។
- ហេតុអ្វីក៏ពេលខ្លះយើងដាក់អាទិភាពផ្សេងលើទំនួលខុសត្រូវរបស់យើងក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« សាតាំងមានឧបករណ៍ដ៏មានអានុភាពមួយដើម្បីប្រើទាស់នឹងមនុស្សល្អ ។ វាគឺជាការរំខាន ។ វានឹងនាំឲ្យមនុស្សល្អបំពេញនៅក្នុងជីវិតដោយ ‹ របស់ល្អៗ › ដើម្បីកុំឲ្យមានកន្លែងណាគិតពីរឿងសំខាន់ផ្សេងទៀត » («First Things First » *Ensign* ខែ ឧសភា ឆ្នាំ ២០០១ ទំព័រ ៧) ។

ដើម្បីជួយសិស្សពិចារណាអំពីអ្វីដែលអាចរារាំងពួកគេពីការធ្វើតាមព្រះយេស៊ូវគ្រីស្ទដោយពេញលេញ សូមគូសតារាងដូចខាងក្រោមនៅលើតារាងខ្យែង ហើយសុំឲ្យសិស្សចម្លងវាចូលទៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

ការទទួលខុសត្រូវទាំងឡាយរបស់សិស្សនៃព្រះយេស៊ូវគ្រីស្ទ	អាទិភាពផ្សេងៗ

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ ចូរសុំឲ្យពួកគេធ្វើការជាដៃគូដើម្បីសរសេរនៅក្នុងតារាងទំនួលខុសត្រូវនៃសិស្សពិតរបស់ព្រះយេស៊ូវគ្រីស្ទ (ដែលអាចនឹងបញ្ចូលទាំងភាពស្មោះត្រង់ ការបម្រើអ្នកដទៃ ការចែកចាយដំណឹងល្អ ការធ្វើពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធ និងការចិញ្ចឹមបីបាច់គ្រួសារ) ។ សម្រាប់ទំនួលខុសត្រូវនីមួយៗដែលបានសរសេរនៅក្នុងតារាងរបស់ពួកគេ ចូរសុំឲ្យសិស្សសរសេរឧទាហរណ៍មួយចំនួនដែលជាអាទិភាពដទៃទៀតដែលនរណាម្នាក់អាចដាក់ពីលើទំនួលខុសត្រូវនោះ ។

សូមអញ្ជើញឲ្យសិស្សមួយចំនួនរៀបរាប់ពីអ្វីដែលពួកគេបានសរសេរ ។

សូមលើកទឹកចិត្តសិស្សឲ្យចែកចាយគំរូវិជ្ជមាននានានៃសិស្សរបស់ព្រះយេស៊ូវគ្រីស្ទដោយសួរ ៖

- តើអ្នកបានមើលឃើញនរណាម្នាក់បានជ្រើសរើសដាក់គោលដៅ ឬអាទិភាពដាច់ដោយឡែកពីការធ្វើតាមព្រះអង្គសង្គ្រោះនៅពេលណា ?

ចូរសុំឲ្យសិស្សគិតពិចារណាអំពីអ្វីដែលពួកគេអាចអនុញ្ញាតឲ្យដាក់អាទិភាពលើការធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់ ។ សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេសម្រាប់អ្វីដែលពួកគេនឹងធ្វើដើម្បីដាក់ឲ្យព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់មានអាទិភាពខ្ពស់ជាង ។

អ្នកអាចនឹងចង់បញ្ចប់មេរៀនដោយការអញ្ជើញសិស្សឲ្យច្រៀងទំនុកតម្កើងបទ« ខ្ញុំនឹងដើរតាមព្រះអង្គ » (*ទំនុកតម្កើង*លេខ ១៣៥) ឬទំនុកតម្កើងផ្សេងទៀតអំពីការធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់ ។

ការប្រើប្រាស់ទំនុកតម្កើង

តន្ត្រី ជាពិសេសទំនុកតម្កើងរបស់សាសនាចក្រ អាចដើរតួយ៉ាងសំខាន់មួយ នៅក្នុងការជួយដល់សិស្សឲ្យទទួលអារម្មណ៍ដឹងអំពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងបទពិសោធន៍នៃការរៀនសូត្រដំណឹងល្អរបស់ពួកគេ ។ ដើម្បីជួយផ្តល់នូវគំនិតបន្ថែមអំឡុងមេរៀន នោះអ្នកអាចសុំឲ្យសិស្សច្រៀងមួយវគ្គ ឬច្រើនវគ្គ ដែលទាក់ទងដោយផ្ទាល់នឹងមេរៀន ។

លូកា ១០:១–៣៧

សេចក្តីផ្តើម

ព្រះយេស៊ូវបានហៅ បង្រៀន និងបញ្ជូនពួកចិតសិបនាក់ឲ្យចេញទៅ ។ ពួកគាត់បានផ្សាយដំណឹងល្អ ព្យាបាលអ្នកឈឺ បណ្តេញអារក្សអាសោច ហើយត្រឡប់មករាយការណ៍អំពីដំណើរការរបស់ពួកគេ ។ ព្រះយេស៊ូវបានបង្រៀនដល់អ្នកប្រាជ្ញខាងច្បាប់ម្នាក់អំពីរឿងប្រៀបធៀបនៃសាសន៍សាម៉ារីល្អ ។

យោបល់សម្រាប់ការបង្រៀន

លូកា ១០:១–២៤

ព្រះអម្ចាស់ហៅ ប្រទានអំណាច និងណែនាំដល់ពួកចិតសិបនាក់

សូមយកប្រអប់មួយដែលមានដាក់ពេញទៅដោយវត្ថុ (ដូចជា បាល់ដែលមានទំហំផ្សេងៗគ្នា) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកខាងមុខថ្នាក់ ។ ចូរសុំឲ្យសិស្សកាន់វត្ថុដែលអ្នកផ្តល់ឲ្យពួកគេមិនត្រូវឲ្យវាធ្លាក់ ឬដាក់វាចុះឡើយ ។ សូមផ្តល់វត្ថុទាំងឡាយដល់សិស្សម្នាក់ រហូតដល់គេពុំអាចកាន់វាអស់ ហើយមានវត្ថុខ្លះធ្លាក់ចុះ ។ បន្ទាប់មកសួរដល់សិស្ស ៖

- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីការពារកុំឲ្យវត្ថុទាំងនេះធ្លាក់ចុះ ?

បើចាំបាច់ សូមផ្តល់យោបល់ឲ្យសិស្សសុំជំនួយពីអ្នកដទៃនៅក្នុងថ្នាក់ ។ សូមបន្តផ្តល់វត្ថុទាំងឡាយទៅដល់សិស្ស ហើយអនុញ្ញាតឲ្យគេហុចវាខ្លះទៅសិស្សផ្សេងទៀត ។ បន្ទាប់មកអញ្ជើញសិស្សឲ្យអង្គុយចុះវិញ ។

- តើអ្នកអាចប្រៀបធៀបសកម្មភាពនេះទៅនឹងរបៀបដែលអ្នកដឹកនាំសាសនាចក្រគ្រប់គ្រងការទទួលខុសត្រូវរបស់ពួកគេយ៉ាងដូចម្តេច ?

សូមរំឭកសិស្សថា ព្រះអង្គសង្គ្រោះបានហៅពួកសាវកដប់ពីរនាក់ ហើយបានបញ្ជូនពួកគេឲ្យចេញទៅដើម្បីជួយនៅក្នុងកិច្ចការរបស់ទ្រង់ ។ ទោះជាយ៉ាងណាក៏ដោយ ពួកសាវកនឹងត្រូវការអ្នកដទៃទៀតឲ្យជួយពួកគេបង្រៀន និងបម្រើ ដើម្បីឲ្យពរជ័យនៃដំណឹងល្អអាចត្រូវបាននាំទៅដល់មនុស្សទាំងអស់ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១០:១–២ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សផ្សេងតាមរកមើលអ្នកដែលព្រះអម្ចាស់បានតែងតាំង ដើម្បីជួយពួកសាវកឲ្យធ្វើកិច្ចការរបស់ពួកលោក ។

- តើនរណាដែលព្រះអម្ចាស់តែងតាំងដើម្បីជួយទ្រង់នៅក្នុងកិច្ចការរបស់ទ្រង់ ? តើតួនាទីរបស់ពួកលោកមានអ្វីខ្លះ ?

ចូរពន្យល់ថា ពាក្យ*ពួកចិតសិបនាក់*នៅក្នុងលូកា ១០:១ សំដៅទៅលើតំណែងមួយនៅក្នុងបព្វជិតភាពមិលគីស្សាដែក ។ តំណែងដូចគ្នានេះមាននៅក្នុងសាសនាចក្រដែលបានស្តារឡើងវិញសព្វថ្ងៃនេះ ។ (បើអាចធ្វើទៅបាន ចូរបង្ហាញទំព័រដែលមានចំណងជើង « អ្នកមានសិទ្ធិអំណាចទូទៅ និងអ្នកកាន់តំណែងទូទៅនៃ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ » នៅក្នុងទស្សនាវដ្តីសន្និសីទថ្មីៗបំផុតនៃទស្សនាវដ្តី *Ensign* ឬ *Liahona*) ។ ឥឡូវមានក្លុំមនៃពួកចិតសិបនាក់ជាច្រើន ប៉ុន្តែមានតែសមាជិកនៃក្លុំមពីរដំបូងប៉ុណ្ណោះ ដែលត្រូវបានហៅជាអ្នកមានសិទ្ធិអំណាចទូទៅ ។ ក្លុំមនីមួយៗ អាចមានចំនួនសមាជិកដល់ទៅ ៧០ នាក់ ។ កិច្ចការរបស់ពួកគាត់ដើម្បីផ្សាយដំណឹងល្អ និងដើម្បីជួយគ្រប់គ្រងសាសនាចក្រ គឺត្រូវបានដឹកនាំដោយក្លុំមនៃពួកសាវកដប់ពីរនាក់ និងគណៈប្រធាននៃពួកចិតសិបនាក់ (សូមមើលគ. និង ស. ១០៧:២៥–២៦, ៣៨សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ« ពួកចិតសិបនាក់ »,scriptures.lds.org) ។

- យោងតាម ខទី ២តើព្រះអម្ចាស់មានបន្ទូលថាអ្វីដែលតិចតួចសម្រាប់ចម្រូតនៃព្រលឹង ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនអំពីកិច្ចការរបស់ព្រះអម្ចាស់មកពីខគម្ពីរទាំងនេះ ? (សិស្សគួរប្រាប់ពីសេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតដូចខាងក្រោម ៖ **ព្រះអម្ចាស់ហៅអ្នកធ្វើការបន្ថែមពីលើពួកសាវកដប់ពីរនាក់ដើម្បីតំណាងឲ្យទ្រង់ ហើយដើម្បីជួយទ្រង់នៅក្នុងកិច្ចការរបស់ទ្រង់**)។
- បន្ថែមពីលើពួកសាវក និងពួកចិតសិបនាក់ តើនរណាផ្សេងទៀតដែលមានទំនួលខុសត្រូវដើម្បីជួយព្រះអម្ចាស់ក្នុងកិច្ចការរបស់ទ្រង់សព្វថ្ងៃនេះ ? (សមាជិកសាសនាចក្រទាំងអស់) ។

ចូរពន្យល់ថា ដូចដែលព្រះអង្គសង្គ្រោះបានប្រកាសអំពីតម្រូវការអ្នកធ្វើការបន្ថែមដើម្បីច្រូតយកសេចក្តីសង្គ្រោះ ពួកព្យាការីថ្ងៃចុងក្រោយក៏អំពាវនាវរកអ្នកផ្សព្វផ្សាយសាសនាបន្ថែមដោយខ្លាប់ខ្លួនដងដែរ ។ សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉ុនសុន ៖



« ខ្ញុំរំឭកឡើងវិញនូវអ្វីដែលពួកព្យាការីបានបង្រៀនជាយូរលង់មកហើយ—ថារាល់យុវជនដែលមានលក្ខណៈសម្បត្តិសក្តិសម និងមានសមត្ថភាពគ្រប់ឫប គួរតែត្រៀមខ្លួនបម្រើបេសកកម្ម ។ ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា គឺជាកាតព្វកិច្ច របស់បព្វជិតភាព —ជាកាតព្វកិច្ច ដែលព្រះអម្ចាស់រំពឹងចង់បានពីយើង ជាអ្នកដែលត្រូវបានប្រទានឲ្យនូវអ្វីៗជាច្រើន ។ យុវជនទាំងឡាយ ខ្ញុំសូមដាស់តឿនដល់អ្នកឲ្យត្រៀមខ្លួនសម្រាប់ការបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ . . .

« ៣ក្យសម្តីទៅកាន់យុវនារីទាំងឡាយ ៖ ខណៈដែលអ្នកពុំមានន័យទំនួលខុសត្រូវបព្វជិតភាព ដូចគ្នានឹងយុវជនដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងក្តី ក៏អ្នកអាចធ្វើការចូលរួមចំណែកដ៏មានតម្លៃជាអ្នកផ្សព្វផ្សាយសាសនាបានផងដែរ ហើយយើងស្វាគមន៍ចំពោះការបម្រើរបស់អ្នក » (« As We Meet Together Again » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៥–៦) ។

- ក្រៅពីការបម្រើបេសកកម្មពេញម៉ោង តើយើងអាចជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់យ៉ាងដូចម្តេច ?
- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់មានបទពិសោធន៍អ្វីខ្លះ ដែលបានរីករាយនៅក្នុងការជួយកិច្ចការរបស់ព្រះអម្ចាស់នោះ ?

សូមសង្ខេបលូកា ១០:៣–២៤ ដោយពន្យល់ថា ព្រះអម្ចាស់បានប្រទានសេចក្តីណែនាំដល់ពួកចិតសិបនាក់អំពី របៀបដើម្បីបំពេញទំនួលខុសត្រូវរបស់ពួកគេ ។ ទ្រង់ក៏បានវាយផ្ចាលមនុស្សនៅក្នុងទីក្រុងផ្សេងៗ ដែលបានបដិសេធកិច្ចការរបស់ទ្រង់ផងដែរ ។ ពួកចិតសិបនាក់ ក្រោយមកបានរាយការណ៍អំពីកិច្ចការរបស់ពួកគេថ្វាយព្រះយេស៊ូវ ហើយទ្រង់បានប្រទានសេចក្តីណែនាំបន្ថែមដល់ពួកគេ ហើយរីករាយនឹងពួកគេផងដែរ ។

លូកា ១០:២៥–៣៧

ព្រះយេស៊ូវរៀបរាប់រឿងប្រៀបធៀបអំពីសាសន៍សាម៉ារីល្អ ។

សូមសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយប្រធាន ឌៀថើរ អេស អុបដូហ្វ នៃគណៈប្រធានទីមួយ ៖

« មនុស្សនៅជុំវិញយើងពុំល្អឥតខ្ចោះនោះទេ ។ មនុស្សធ្វើនូវរឿងដែលខុស អន់ចិត្ត និងខឹង ។ នៅក្នុងជីវិតរមែងស្លាប់នេះ វានឹងតែងតែរបៀបនោះជានិច្ច » (« The Merciful Obtain Mercy » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៧៧) ។

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យពិចារណាថាតើពួកគេស្គាល់នរណាម្នាក់ដែលធ្វើរឿងដែលខុស អន់ចិត្ត ឬខឹងពួកគេឬទេ ។

- ហេតុអ្វីក៏វាពិបាកដើម្បីស្រឡាញ់នរណាម្នាក់ ដែលប្រព្រឹត្តនូវរឿងទាំងនេះ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅពេលពួកគេសិក្សាលូកា ១០:២៥–៣៧ ដែលអាចដឹកនាំពួកគេនៅពេលពួកគេប្រាស្រ័យទាក់ទងនឹងបុគ្គលម្នាក់ៗ ដែលអាចនឹងពិបាក ដើម្បីស្រឡាញ់នោះ ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ១០:២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសំណួរដែលអ្នកច្បាជ្ញខាងច្បាប់បានសួរដល់ព្រះអង្គសង្គ្រោះ ។

- តើអ្នកច្បាជ្ញខាងច្បាប់នោះបានសួរអ្វីខ្លះដល់ព្រះអង្គ សង្គ្រោះ ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១០:២៦–២៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានឆ្លើយតប ។ បន្ទាប់មកចូរអញ្ជើញសិស្សឲ្យរាយការណ៍នូវអ្វីដែលពួកគេរកឃើញ ។

- តើគោលការណ៍អ្វីខ្លះដែលយើងបានរៀនពីខគម្ពីរទាំងនេះ ដែលស្តីពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានជីវិតដ៏អស់កល្បជានិច្ច ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **ដើម្បីទទួលបានជីវិតដ៏អស់កល្បជានិច្ច យើងត្រូវស្រឡាញ់ព្រះ ហើយស្រឡាញ់អ្នកជិតខាងយើងឲ្យដូចខ្លួនយើង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- យោងតាមខទី ២៧តើយើងត្រូវស្រឡាញ់ព្រះយ៉ាងដូចម្តេច ?
- តើដើម្បីស្រឡាញ់ព្រះដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់អ្នកមានន័យយ៉ាងណា ?

សូមចង្អុលបង្ហាញឃ្លា « ស្រឡាញ់អ្នកជិតខាងយើងឲ្យដូចខ្លួនយើង » នៅលើក្តារខៀន ។ ដើម្បីជួយសិស្សយល់នូវអត្ថន័យដើម្បីស្រឡាញ់អ្នកជិតខាងយើងឲ្យដូចខ្លួនយើង សូមអញ្ជើញពួកគេឲ្យសរសេរនៅលើក្តារខៀន នូវអ្វីៗដែលពួកគេធ្វើអំឡុងថ្ងៃធម្មតាមួយ ។ (ចំនុចទាំងនោះអាចរួមមាន ការរៀបចំខ្លួនសម្រាប់ថ្ងៃនោះ ការទទួលទានអាហារ ការដេក ការធ្វើកិច្ចការសាលា ជាដើម) ។

បន្ទាប់ពីការសរសេរបញ្ជីមួយនៅលើក្តារខៀនរួចហើយ សូមអញ្ជើញសិស្សឲ្យពិចារណាថាតើសកម្មភាពរបស់ពួកគេប៉ុន្មានដែលផ្តោតទៅលើខ្លួនពួកគេ ។

- តើយើងអាចរៀនអ្វីខ្លះចេញមកពីលំហាត់នេះ ?
- តើវិធីមួយចំនួនណាខ្លះ ដែលយើងអាចយកចិត្ត ទុកដាក់កាន់តែញឹកញាប់ទៅលើសុខុមាលភាពរបស់អ្នកដទៃ ហើយព្យាយាមស្រឡាញ់ពួកគេឲ្យច្រើនដូចដែលយើងស្រឡាញ់ខ្លួនយើង ?
- តើវិធីមួយចំនួនណាខ្លះ ដែលយើងអាចធ្វើការណ៍នេះទោះជាអំឡុងសកម្មភាពទាំងឡាយដែលយើងធ្វើសម្រាប់ខ្លួនយើង ? (ឧទាហរណ៍អាចរួមមាន ការទទួលទានអាហារជាមួយនឹងអ្នកទាំងឡាយដែលហាក់ដូចជាឯកោ ឬសរសើរអ្នកដទៃអំឡុងសកម្មភាពនៅសាលារបស់យើង) ។

- តើអ្នកគិតថា ការស្រឡាញ់ព្រះ និងអ្នកជិតខាងរបស់យើង ឲ្យច្រើនដូចជាយើងស្រឡាញ់ខ្លួនយើង អាចជួយយើងរីកចម្រើនឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ចយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានលូកា ១០:២៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលសំណួរទីពីរដែលអ្នកច្រាជូខាងច្បាប់បានសួរដល់ព្រះយេស៊ូវ ។

- តើសំណួរទីពីររបស់អ្នកច្រាជូខាងច្បាប់ជាអ្វី ?

សូមរៀបចំសិស្សមួយចំនួនឲ្យសម្តែងរឿងប្រៀបធៀបអំពីសាសន៍សាម៉ារីដ៏ល្អនៅក្នុងលូកា ១០:៣០–៣៥។ សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាអ្នកអត្ថាធិប្បាយ ហើយសិស្សដទៃទៀតសម្តែងតួជាបុរសសាសន៍យូដាដែលត្រូវរបួស ចោរពីរនាក់ សង្ឃ សាសន៍លេវី និងសាសន៍សាម៉ារី ។ (បើអ្នកមានសិស្សតិចតួចនៅក្នុងថ្នាក់ ពួកគេអាចដើរតួជាច្រើនប្រភេទ) ។ អ្នកអាចនឹងចង់ផ្តល់នូវវត្ថុខ្លះ ដែលមានដូចជា ស្លាកឈ្មោះ សំលៀកបំពាក់បន្ថែមដើម្បីយកមកពីបុរសសាសន៍យូដា ប្រអប់ពីរដែលតំណាងឲ្យប្រេង និងស្រា កៅអីរុញតំណាងឲ្យសត្វព្រៃ និងកាក់ពីរដើម្បីតំណាងឲ្យប្រាក់បួនកាក់ ។ (*កំណត់ចំណាំ ៖* អ្នកអាចនឹងចង់ជ្រើសរើសអ្នកចូលរួម ហើយផ្តល់ការណែនាំជាក់លាក់ដល់ពួកគេ មុនថ្នាក់រៀនចាប់ផ្តើមដើម្បីប្រាកដថា ការសម្តែងមានប្រសិទ្ធភាព សមរម្យ និងសុវត្ថិភាព) ។

សូមអញ្ជើញអ្នកអត្ថាធិប្បាយឲ្យអានលូកា ១០:៣០–៣៥ ឮៗ ហើយសុំឲ្យអ្នកទាំងឡាយដែលចូលរួមសម្តែងរឿងប្រៀបធៀប ។ ចូរសុំឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីនរណាជាអ្នកជិតខាងរបស់យើង ។ បន្ទាប់ពីការសម្តែងរឿង សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយពួកគេវិញ ។

- តើសកម្មភាពណារបស់សាសន៍សាម៉ារីធ្វើឲ្យអ្នកចាប់អារម្មណ៍បំផុត ?

ដើម្បីជួយសិស្សឲ្យយល់ដឹងកាន់តែល្អប្រសើរ អំពីអ្វីដែលអាចរំពឹងទុកមកពីសង្ឃម្នាក់ សាសន៍លេវី និងសាសន៍សាម៉ារី សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការពន្យល់ដូចខាងក្រោម ៖

ពួកសង្ឃ និងពួកលេវី បានកាន់បព្វជិតភាពអើរ៉ុន ហើយត្រូវបានចាត់តាំងឲ្យបម្រើព្រះ និងបងប្អូនរបស់ពួកគេ ទាំងពីរក្រុមនៅក្នុងព្រះវិហារបរិសុទ្ធ ហើយជាគ្រូបង្រៀន និងជាគំរូនៃក្រឹត្យវិន័យរបស់ព្រះ ។ អ្នកកាន់បព្វជិតភាពទាំងនេះបានដឹងដោយពេញលេញអំពីបញ្ញត្តិឲ្យ « ស្រឡាញ់អ្នកជិតខាងដូចជាខ្លួនឯង » (លេវីវិន័យ ១៩:១៨) ហើយយកចិត្តទុកដាក់នឹងមនុស្សចម្លែក និងអ្នកធ្វើដំណើរ (សូមមើលលេវីវិន័យ ១៩:៣៤,២៥:៣៥) ។ ផ្ទុយទៅវិញ « ពួកសាសន៍សាម៉ារីគឺជាពួកអ៊ីស្រាអែលខ្លះ និងពួកសាសន៍ដទៃខ្លះ ។ សាសនារបស់ពួកគេគឺមានភាពចម្រុះរបស់សាសនាយូដា និងជាមនុស្សដែលគ្មានជំនឿ និងការអនុវត្តខាងសាសនាទេ ។ . . . ពួកយូដាបានកើតមាន [ការស្តប់] ចំពោះពួកសាសន៍សាម៉ារី ដោយសារសាសន៍សាម៉ារី បានក្បត់ពីសាសនាអ៊ីស្រាអែល » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សាសន៍សាម៉ារី » ,scriptures.lds.org) ។ ទាំងសាសន៍យូដា និងសាសន៍សាម៉ារី បានចេញទៅតាមផ្លូវរបស់ពួកគេដើម្បីចៀសពីគ្នា ។

- នៅក្នុងរឿងប្រៀបធៀប ហេតុអ្វីក៏ទង្វើរបស់សង្ឃ លេវី និងសាសន៍សាម៉ារីមានភាពភ្ញាក់ផ្អើលដូច្នេះ ?
- តើមូលហេតុអ្វីខ្លះដែលសាសន៍សាម៉ារីអាចនឹងមិនត្រូវជួយដល់សាសន៍យូដាដែលរបួសនោះ ?
- យោងតាមខទី ៣៣តើអ្វីដែលបានបណ្តាលឲ្យសាសន៍សាម៉ារីត្រូវធ្វើទង្វើនោះ នៅពេលគាត់បានមើលឃើញបុរសដែលរបួសនោះ ?

ចូរចង្អុលបង្ហាញថា ការមានចិត្តមេត្តាករុណា មានន័យថាសម្គាល់ឃើញតម្រូវការ ឬឧបសគ្គរបស់មនុស្សម្នាក់ទៀត ហើយមានអារម្មណ៍នូវបំណងប្រាថ្នាមួយដើម្បីធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីជួយមនុស្សនោះ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១០:៣៦–៣៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់អ្នកច្រាជូខាងច្បាប់នោះ ។

- តើរឿងប្រៀបធៀបនេះឆ្លើយតបនឹងសំណួរនៅក្នុងខទី ២៩ថា « នរណាជាអ្នកជិតខាងខ្ញុំ » យ៉ាងដូចម្តេច ?

សូមជួយសិស្សឲ្យយល់ថា ការប្រើសាសន៍សាម៉ារីនៅក្នុងរឿងប្រៀបធៀបនេះរបស់ព្រះអង្គសង្គ្រោះ ឲ្យយោបល់ថា អ្នកជិតខាងរបស់យើង គឺមិនគ្រាន់តែជាមនុស្សដែលរស់នៅជិតយើងប៉ុណ្ណោះទេ ប៉ុន្តែគឺជាកូនចៅរបស់ព្រះវរបិតាសួគ៌គ្រប់រូប—រួមទាំងអ្នកទាំងឡាយដែលយើងពិបាកស្រឡាញ់បំផុតផងដែរ ។

ចូរសុំសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហាវើដ ដបុលយូ ហ៊ីនធើរ ៖

« យើងចាំបាច់ត្រូវចងចាំសុភាសិតមួយថា យើងបង្កើតមិត្តរបស់យើង នោះព្រះបានបង្កើតអ្នកជិតខាងរបស់យើង—គ្រប់ទីកន្លែង ។ ក្តីស្រឡាញ់ពុំគួរមានព្រំដែននោះទេ ។ . . . ព្រះគ្រីស្ទមានបន្ទូលថា ‹ ដ្បិតបើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកណា ដែលស្រឡាញ់ដល់ខ្លួន នោះតើបានបំណាច់អ្វី ? ឯពួកអ្នកយកពន្ធ តើគេមិនប្រព្រឹត្តដូច្នេះដែរទេឬអី › ? (ម៉ាថាយ ៥:៤៦) » (« The Lord's Touchstone » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៣៥) ។

- យោងតាម ខទី ៣៧តើព្រះអង្គសង្គ្រោះបានបង្រៀនដល់អ្នកច្រាជូខាងច្បាប់ឲ្យធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាម្តងទៀតអំពីបុគ្គលម្នាក់ៗដែលពួកគេបានគិតពីមុន ដែលអាចនឹងពិបាកក្នុងការស្រឡាញ់ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីស្រឡាញ់ និងមានចិត្តមេត្តាករុណាចំពោះអ្នកទាំងឡាយដែលយើងពិបាកស្រឡាញ់ ?
- ចូរពិចារណាអំពីគ្រាមួយ ដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ បានធ្វើតាមការទូន្មានរបស់ព្រះអង្គសង្គ្រោះឲ្យ « ស្រឡាញ់ . . . អ្នកជិតខាងដូចជាខ្លួនឯង » (លូកា ១០:២៧) ។ តើលទ្ធផលគឺជាអ្វី ?

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលបានបង្រៀននៅក្នុងមេរៀនថ្ងៃនេះ ។ ចូរសរសេរសេចក្តីថ្លែងពុំពេញលេញដូចខាងក្រោមនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យបំពេញវាក្នុងសៀវភៅកំណាត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណាត់ហេតុការសិក្សាព្រះគម្ពីរ ៖ *ខ្ញុំនឹងធ្វើតាមគំរូរបស់សាសន៍សាម៉ារីដ៏ល្អដោយ . . .*

ការសួរសំណួរ និងធ្វើការអញ្ជើញដែលលើកទឹកចិត្តឲ្យអនុវត្ត

គោលដៅនៃការបង្រៀនដ៏ណឹងល្អ គឺដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍ និងគោលលទ្ធិទាំងឡាយ ដែលមាននៅក្នុងបទគម្ពីរ ហើយបានផ្លាស់ប្រែចិត្តជឿ និងទទួលពរជ័យដែលបានសន្យាដល់អស់អ្នកណាដែលស្មោះត្រង់ និងគោរពប្រតិបត្តិតាម ។ ការសួរសំណួរ និងការអញ្ជើញដែលលើកទឹកចិត្តឲ្យអនុវត្ត អាចជួយសិស្សឲ្យមើលឃើញពីរបៀប ដែលពួកគេអាចអនុវត្តគោលការណ៍ទាំងនេះនៅក្នុងស្ថានភាពបច្ចុប្បន្នរបស់គេ និងគិតពិចារណាអំពីរបៀប ដែលពួកគេអាចអនុវត្តតាមនាពេលអនាគត ។

មេរៀនសិក្សានៅផ្ទះ

លូកា ៥:១–១០:៣៧ (មេរៀនទី ១០)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់សិស្សដែលសិក្សា នៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា លូកា ៥:១–១០:៣៧ (មេរៀនទី ១០) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍មួយចំនួនទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (លូកា ៥)

ចេញមកពីដំណើររឿងរបស់ព្រះអង្គសង្គ្រោះអញ្ជើញពេត្រុស យ៉ាកុប និង យ៉ូហាន ឲ្យទៅនេសាទមនុស្ស នោះសិស្សបានរៀនថា ប្រសិនបើយើងធ្វើអ្វីដែលព្រះអម្ចាស់បញ្ជាប្រាប់ ទោះជាពេលយើងពុំយល់ពីមូលហេតុក្តី នោះទ្រង់អាចផ្តល់ពរជ័យកាន់តែធំជាងដែលយើងអាចទទួលបានទៅទៀត ។ ហើយចេញមកពីការព្យាបាលមនុស្សឃ្លង់ និងមនុស្សខ្វិន នោះសិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿ ហើយមករកព្រះអង្គសង្គ្រោះ នោះទ្រង់អាចព្យាបាលយើង ហើយយើងអាចជួយអ្នកដទៃឲ្យមករកព្រះអង្គសង្គ្រោះ ដើម្បីពួកគេអាចត្រូវបានព្យាបាល ។ សិស្សក៏បានរៀនផងដែរថា ដើម្បីទទួលយកព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់ យើងត្រូវតែរាបសារ ហើយមានឆន្ទៈដើម្បីផ្លាស់ប្តូរ ។

ថ្ងៃទី ២ (លូកា ៦:១–៧:១៧)

សិស្សបានរកឃើញថា ប្រសិនបើយើងធ្វើល្អនឹងអ្នកដទៃដោយពុំរំពឹងចង់បានអ្វីត្រឡប់មកវិញ នោះរង្វាន់របស់យើងនឹងមានដ៏មហិមា ហើយយើងនឹងក្លាយជាកូននៃព្រះដ៏ខ្ពស់បំផុត ហើយថាព្រះវរបិតាសួគ៌ប្រទានពរដល់យើងប្រកបដោយសប្បុរស នៅពេលយើងផ្តល់ទៅឲ្យអ្នកដទៃដោយសប្បុរសនោះ ។ ពួកគេក៏បានរៀនផងដែរពីសេចក្តីពិតដូចតទៅនេះ ៖ តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចជួយនាំមកនូវពរជ័យជាច្រើនចូលទៅក្នុងជីវិតរបស់អ្នកដទៃ ។ យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទដោយការបង្ហាញនូវក្តីមេត្តាករុណាដល់អ្នកដទៃ ហើយបម្រើដល់តម្រូវការដែលពុំបានថ្លែងរបស់ពួកគេ ។

ថ្ងៃទី ៣ (លូកា ៧:១៨–៥០)

នៅក្នុងមេរៀននេះ សិស្សបានរៀនថា យ៉ូហាន បាទីស្ទ គឺជាព្យាការីដែលបានតែងតាំងពីមុនកំណើតលោកិយ ដើម្បីរៀបចំផ្លូវ និងធ្វើបុណ្យជ្រមុជទឹកថ្វាយព្រះរាជបុត្រានៃព្រះ ។ ចេញមកពីរឿងរបស់ស្ត្រីដែលលាងព្រះបាទារបស់ព្រះអង្គសង្គ្រោះដោយទឹកភ្នែករបស់នាង នោះសិស្សបានរៀនដូចខាងក្រោម ៖ នៅពេលយើងអនុវត្តសេចក្តីជំនឿរបស់យើង តាមរយៈការបង្ហាញសេចក្តីស្រឡាញ់របស់យើង និងលះបង់ថ្វាយព្រះអម្ចាស់ នោះយើងអាចទទួលបានការអភ័យទោសរបស់ទ្រង់ ។ នៅពេលយើងទទួលបានការអភ័យទោសរបស់ព្រះអម្ចាស់ នោះយើងត្រូវបានពេញដោយបំណងប្រាថ្នាដើម្បីស្រឡាញ់ និងបម្រើទ្រង់កាន់តែច្រើន ។

ថ្ងៃទី ៤ (លូកា ៨:១–១០:៣៧)

ចេញមកពីមេរៀននេះ សិស្សត្រូវបានលើកទឹកចិត្តឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ តាមរយៈការជ្រើសរើសឆ្លើយតបចំពោះស្ថានភាពប្រមាថ ឬអាក់អន់ចិត្តដោយការអត់ធ្មត់ និងការស៊ូទ្រាំ ។ បន្ថែមពីលើនោះទៅទៀត ពួកគេបានរៀនថា ដើម្បីធ្វើជាសិស្សពិតរបស់ព្រះអង្គសង្គ្រោះ នោះយើងត្រូវតែកុំបណ្តោយឲ្យអ្វី មានអាទិភាពខ្ពស់ជាងការធ្វើតាមទ្រង់ ហើយថាដើម្បីទទួលបានជីវិតអស់កល្បជានិច្ច យើងត្រូវតែស្រឡាញ់ព្រះ និងស្រឡាញ់អ្នកជិតខាងយើងដូចជាខ្លួនយើង ។

សេចក្តីផ្តើម

អ្នកប្រាជ្ញខាងច្បាប់ម្នាក់បានសួរព្រះអង្គសង្គ្រោះថា « តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីឲ្យបានជីវិតអស់កល្បជានិច្ច ? » (លូកា ១០:២៥) ។ ការធ្វើតាមគំនិតសម្រាប់ការបង្រៀន អាចជួយសិស្សឲ្យរៀនអំពីអត្ថន័យដើម្បីស្រឡាញ់ព្រះ និងស្រឡាញ់អ្នកជិតខាងដូចជាខ្លួនយើង ។

យោបល់សម្រាប់ការបង្រៀន

លូកា ១០:២៥–៣៧

ព្រះយេស៊ូវបង្រៀនរឿងប្រៀបធៀបអំពីសាសន៍សាម៉ារីល្អ ។

សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ឌៀថើរ អេស្វ អុដដូហ្វ នៃគណៈប្រធានទីមួយឲ្យឮៗ ៖

« មនុស្សនៅជុំវិញយើងពុំល្អឥតខ្ចោះនោះទេ ។ មនុស្សធ្វើនូវរឿងដែលរំខាន អន់ចិត្ត និងធ្វើឲ្យខឹង ។ នៅក្នុងជីវិតរមែងស្លាប់នេះ វានឹងតែងតែរបៀបនោះជានិច្ច » (« The Merciful Obtain Mercy »*Ensign* ឬ*Liahona*ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៧៧) ។

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យពិចារណាថាតើពួកគេស្គាល់នរណាម្នាក់ដែលធ្វើខ្វះធ្វើដែលរំខានអន់ចិត្ត ឬធ្វើឲ្យពួកគេខឹងឬទេ ។

- ហេតុអ្វីក៏វាពិបាកដើម្បីស្រឡាញ់នរណាម្នាក់ ដែលធ្វើនូវរឿងទាំងនេះ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅពេលពួកគេសិក្សាលូកា ១០:២៥–៣៧ដែលអាចដឹកនាំពួកគេនៅពេលពួកគេប្រាស្រ័យទាក់ទងនឹងបុគ្គលម្នាក់ៗ ដែលអាចនឹងពិបាកដើម្បីស្រឡាញ់នោះ ។

សូមរំឭកសិស្សថា នៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេអំពីលូកា ១០ពួកគេបានរៀនអំពីអ្នកប្រាជ្ញខាងច្បាប់ម្នាក់ដែលបានសួរព្រះអង្គសង្គ្រោះអំពីរបៀបដើម្បីទទួលបានជីវិតដ៏អស់កល្បជានិច្ច ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១០:២៦–២៨ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះ ។ បន្ទាប់មក ចូរអញ្ជើញសិស្សឲ្យរាយការណ៍នូវអ្វីដែលពួកគេរកឃើញ ។

- តើគោលការណ៍អ្វីខ្លះដែលយើងបានរៀនមកពីខគម្ពីរទាំងនេះពាក់ព័ន្ធទៅនឹងអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានជីវិតដ៏អស់កល្បជានិច្ច ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **ដើម្បីទទួលបានជីវិតដ៏អស់កល្បជានិច្ច យើងត្រូវស្រឡាញ់ព្រះ ហើយស្រឡាញ់អ្នកជិតខាងយើងឲ្យដូចខ្លួនយើង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើដើម្បីស្រឡាញ់ព្រះដោយអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំងរបស់អ្នកមានន័យយ៉ាងណា ?

សូមបង្ហាញឃ្លា « ស្រឡាញ់អ្នកជិតខាងយើងឲ្យដូចខ្លួនយើង » នៅលើក្តារខៀន ។ ដើម្បីជួយសិស្សយល់នូវអត្ថន័យដើម្បីស្រឡាញ់អ្នកជិតខាងយើងឲ្យដូចខ្លួនយើង សូមអញ្ជើញពួកគេឲ្យសរសេរនៅលើក្តារខៀននូវអ្វីៗ ដែលពួកគេធ្វើអំឡុងថ្ងៃធម្មតាមួយ ។ (ចំនុចទាំងនោះអាចរួមមាន ការរៀបចំខ្លួនសម្រាប់ថ្ងៃនោះ ការទទួលទានអាហារ ការដេក ការធ្វើកិច្ចការសាលា ជាដើម) ។

បន្ទាប់ពីប្រមូលបញ្ជីមួយនៅលើក្តារខៀនរួចហើយ សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេមានសកម្មភាពប៉ុន្មានដែលផ្តោតទៅលើខ្លួនពួកគេ ។ (អ្នកអាចនឹងសុំឲ្យពួកគេប្រាប់ថា តើចំនុចនីមួយៗនៅក្នុងបញ្ជីនេះ គឺសម្រាប់ខ្លួនគេ សម្រាប់អ្នកដទៃ ឬសម្រាប់ព្រះ) ។

- តើយើងអាចរៀនអ្វីខ្លះ ចេញមកពីលំហាត់នេះ ?
- តើវិធីមួយចំនួនអ្វីខ្លះ ដែលយើងអាចផ្តោតកាន់តែច្រើនទៅលើសុខុមាលភាពរបស់អ្នកដទៃ ហើយព្យាយាមស្រឡាញ់ពួកគេឲ្យច្រើនដូចដែលយើងស្រឡាញ់ខ្លួនយើង ?
- តើវិធីមួយចំនួនដែលយើងអាចធ្វើការណ៍នេះទោះជាអំឡុងសកម្មភាពទាំងឡាយដែលយើងធ្វើសម្រាប់ខ្លួនយើងនោះមានអ្វីខ្លះ ? (ឧទាហរណ៍អាចរួមមាន ការទទួលទានអាហារជាមួយនឹងអ្នកទាំងឡាយដែលហាក់ដូចជាឯកោ ឬសរសើរអ្នកដទៃ ក្នុងអំឡុងសកម្មភាពនៅសាលារបស់យើង) ។
- តើអ្នកគិតថា ការស្រឡាញ់ព្រះ និងអ្នកជិតខាងយើងឲ្យច្រើនដូចជាយើងស្រឡាញ់ខ្លួនយើង អាចជួយយើងឲ្យរីកចម្រើនឆ្ពោះទៅកាន់ជីវិតអស់កល្បជានិច្ចយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានលូកា ១០:២៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលសំណួរទីពីរដែលអ្នកប្រាជ្ញខាងច្បាប់បានសួរដល់ព្រះយេស៊ូវ ។

- តើអ្វីជាសំណួរទីពីររបស់អ្នកប្រាជ្ញខាងច្បាប់ ?

សូមរៀបចំសិស្សមួយចំនួនឲ្យសម្តែងរឿងប្រៀបធៀបអំពីសាសន៍សាម៉ារីដ៏ល្អនៅក្នុងលូកា ១០:៣០–៣៥ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើជាអ្នកអត្ថាធិប្បាយ ហើយសិស្សដទៃទៀតដើរតួជាបុរសសាសន៍យូដា ដែលត្រូវរបួស ចោរពីរនាក់ សង្ឃ សាសន៍លេវី និងសាសន៍សាម៉ារី ។ (បើអ្នកមានសិស្សតិចតួចនៅក្នុងថ្នាក់ ពួកគេអាចដើរតួច្រើន) ។ អ្នកគួរតែផ្តល់នូវវត្ថុខ្លះ ដែលមានដូចជា ស្លាកឈ្មោះ សំលៀកបំពាក់បន្ថែម ដែលយកមកពីបុរសសាសន៍យូដា ប្រអប់ពីរដែលតំណាងឲ្យប្រេង និងស្រា កៅអីរុញតំណាងឲ្យសត្វព្រៃ និងកាក់ពីរដើម្បីតំណាងឲ្យប្រាក់ពីរកាក់ ។ (*កំណត់ចំណាំ* ៖ អ្នកគួរតែជ្រើសរើសអ្នកចូលរួម ហើយផ្តល់ការណែនាំជាក់លាក់ដល់ពួកគេពីមុនថ្នាក់រៀនដើម្បីប្រាកដថា ការសម្តែងមានប្រសិទ្ធភាព សមរម្យ និងមានសុវត្ថិភាព) ។

សូមអញ្ជើញអ្នកអត្ថាធិប្បាយអានលូកា ១០:៣០–៣៥ ឲ្យឮៗ ហើយសុំឲ្យអ្នកទាំងឡាយដែលចូលរួមសម្តែងរឿងប្រៀបធៀប ។ ចូរសុំឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីនរណាជាអ្នកជិតខាងរបស់យើង ។ បន្ទាប់ពីការដើរតួសម្តែងរឿង សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយពួកគេវិញ ។

- តើសកម្មភាពណារបស់សាសន៍សាម៉ារីដែលធ្វើឲ្យអ្នកចាប់អារម្មណ៍បំផុត ?

ដើម្បីជួយសិស្សឲ្យយល់ដឹងកាន់តែល្អប្រសើរ អំពីអ្វីដែលប្រហែលជាត្រូវបានរំពឹងទុកមកពីសង្ឃម្នាក់ សាសន៍លេវី និងសាសន៍សាម៉ារី សូមអញ្ជើញសិស្សម្នាក់ឲ្យអាននូវការពន្យល់ដូចខាងក្រោម ៖

នៅក្នុងក្រឹត្យវិន័យដែលបានចារទុករបស់ម៉ូសេ ពួកសង្ឃ និងពួកលេវី ត្រូវបានចាត់តាំង [និងត្រូវបានតម្រូវ] ឲ្យបម្រើព្រះ និងបងប្អូនរបស់ពួកគេ ទាំងនៅក្នុងព្រះវិហារបរិសុទ្ធ ទាំងជាគ្រូបង្រៀន និងជាគំរូនៃក្រឹត្យវិន័យរបស់ព្រះ ។ អ្នកកាន់បព្វជិតភាពទាំងនេះ គឺបានដឹងអំពីបទបញ្ញត្តិឲ្យ « ស្រឡាញ់អ្នកដទៃដូចខ្លួនឯង » យ៉ាងច្បាស់ (លេវីវិន័យ ១៩:១៨) ។ តាមពិត លេវីវិន័យគឺមានកាតព្វកិច្ចជាក់លាក់ជាមួយនឹងការជួយដល់អ្នកធ្វើដំណើរខាងអាជីវកម្ម និងតាមរបៀបផ្សេងៗទៀត (សូមមើលលេវីវិន័យ ២៥:៣៥–៣៦) ។ ផ្ទុយទៅវិញ « ពួកសាសន៍សាម៉ារីគឺជាពួកអ៊ីស្រាអែលខ្លះ និងពួកសាសន៍ដទៃខ្លះ ។ សាសនារបស់ពួកគេគឺមានភាពចម្រុះរបស់សាសន៍យូដា និងជាមនុស្សដែលគ្មានជំនឿ និងការអនុវត្តខាងសាសនានោះទេ ។ . . . ពួកយូដាបានកើតមាន [ការស្អប់] ចំពោះពួកសាសន៍សាម៉ារី ដោយសារសាសន៍សាម៉ារីបានក្បត់ពីសាសនាអ៊ីស្រាអែល » (*Guide to the Scriptures* « សាសន៍សាម៉ារី » *scriptures.lds.org*) ។ ទាំងសាសន៍យូដា និងសាសន៍សាម៉ារី បានចេញទៅតាមផ្លូវរបស់ពួកគេដើម្បីចៀសកុំឲ្យជួបគ្នា ។

- នៅក្នុងរឿងប្រៀបធៀប ហេតុអ្វីក៏ទង្វើរបស់សង្ឃ លេវី និងសាសន៍សាម៉ារី គឺជាទង្វើគួរឲ្យភ្ញាក់ផ្អើលដូច្នេះ ?
- តើមូលហេតុអ្វីខ្លះ ដែលសាសន៍សាម៉ារីអាចនឹងមិនត្រូវជួយដល់សាសន៍យូដាដែលបួសនោះ ?
- ស្របតាមលូកា ១០:៣៣តើអ្វីដែលបានបណ្តាលឲ្យសាសន៍សាម៉ារីត្រូវធ្វើទង្វើនោះ នៅពេលគាត់បានមើលឃើញបុរសដែលបួសនោះ ?

ចូរចង្អុលបង្ហាញថា ការមានចិត្តមេត្តាករុណា មានន័យថាសម្លាប់ឃើញតម្រូវការ ឬឧបសគ្គរបស់មនុស្សម្នាក់ទៀត ហើយមានបំណងប្រាថ្នាមួយដើម្បីធ្វើអ្វីដែលយើងអាចធ្វើបានដើម្បីជួយមនុស្សនោះ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១០:៣៦–៣៧ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមហើយរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់អ្នកប្រាជ្ញខាងច្បាប់នោះ ។

- តើរឿងប្រៀបធៀបនេះឆ្លើយសំណួរនៅក្នុង ខ ២៩ថា « នរណាជាអ្នកជិតខាងខ្ញុំ » យ៉ាងដូចម្តេច ?

សូមជួយសិស្សឲ្យយល់ថា ការប្រើសាសន៍សាម៉ារីនៅក្នុងរឿងប្រៀបធៀបនេះរបស់ព្រះអង្គសង្គ្រោះឲ្យយោបល់ថា អ្នកជិតខាងរបស់យើង គឺមិនគ្រាន់តែជាមនុស្សដែលរស់នៅជិតយើងទេ ប៉ុន្តែគឺជាកូនចៅរបស់ព្រះ:រាបិតាសួគ៌គ្រប់រូប—រួមទាំងអ្នកទាំងឡាយដែលយើងពិបាកស្រឡាញ់បំផុតក្តី ។

ចូរសុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហារីង ដបុលយូ ហ៊ីនធើរ ៖



« យើងចាំបាច់ត្រូវចងចាំសុភាសិតមួយថា យើងបង្កើតមិត្តរបស់យើងនោះព្រះបានបង្កើតអ្នកជិតខាងរបស់យើង—គ្រប់ទីកន្លែង ។ ក្តីស្រឡាញ់ពុំគួរមានព្រំដែននោះទេ ។ . . . ព្រះគ្រីស្ទមានបន្ទូលថា ‹ ដ្បិតបើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកណា ដែលស្រឡាញ់ដល់ខ្លួន នោះតើបានបំណាច់អ្វី ឯពួកអ្នកយកពន្ធ តើគេមិនប្រព្រឹត្តដូច្នេះដែរទេឬអី ? › (ម៉ាថាយ ៥:៤៦) » (« *The Touchstone* » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៣៥) ។

- យោងតាម លូកា ១០:៣៧តើព្រះអង្គសង្គ្រោះបានបង្រៀនដល់អ្នកប្រាជ្ញខាងច្បាប់ឲ្យធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាម្តងទៀតអំពីបុគ្គលម្នាក់ៗដែលពួកគេបានគិតពីមុន ដែលអាចនឹងពិបាកក្នុងការស្រឡាញ់ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីស្រឡាញ់ និងមានចិត្តមេត្តាករុណាចំពោះអ្នកទាំងឡាយដែលយើងពិបាកស្រឡាញ់ ?
- ចូរពិចារណាអំពីគ្រាមួយ ដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ បានធ្វើតាមការទូន្មានរបស់ព្រះអង្គសង្គ្រោះឲ្យ « ស្រឡាញ់ . . . អ្នកជិតខាងដូចជាខ្លួនឯង » (លូកា ១០:២៧) ។ តើលទ្ធផលគឺជាអ្វី ?

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលបានបង្រៀននៅក្នុងមេរៀនថ្ងៃនេះ ។ ចូរសរសេរសេចក្តីថ្លែងពុំពេញលេញដូចខាងក្រោមនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យបំពេញវាក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖ *ខ្ញុំនឹងធ្វើតាមគំរូរបស់សាសន៍សាម៉ារីដ៏ល្អដោយ . . .*

មេរៀនបន្ទាប់ (លូកា ១០:៣៨–១៧:៣៧)

សូមពន្យល់សិស្សថានៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងសិក្សាអំពីរបៀបដែលព្រះយេស៊ូវស្តីបន្ទោសម្តងហើយម្តងទៀតដល់ពួកផារិស៊ី ដែលព្យាយាមធ្វើខ្លួនជាសុចរិត ប៉ុន្តែខាងក្នុងខ្លួនពេញដោយភាពអត្មានិយម ។ ចូរសុំឲ្យពួកគេពិចារណាអំពីរបៀប ដែលពួកគេអាចនឹងមិនធ្វើដូចពួកផារិស៊ី ហើយផ្ទុយទៅវិញកាន់តែដូចជាអ្នកដើរតាមដោយពរបសាររបស់ព្រះគ្រីស្ទ ។ ពួកគេក៏សិក្សារឿងប្រៀបធៀបជាច្រើនទៀតដែលព្រះយេស៊ូវបានប្រទានឲ្យផងដែរ រួមមានទាំងរឿងប្រៀបធៀបអំពីកូនប្រុសខ្ជះខ្ជាយផងដែរ ។ ចូរសុំឲ្យពួកគេកត់សម្គាល់ពី អ្វីដែលបានកើតឡើងចំពោះបុរសអ្នកមាន ដែលបានលះបង់ជីវិតរបស់គាត់ដើម្បីទទួលបានទ្រព្យសម្បត្តិ ហើយព្រងើយកន្តើយនឹងអ្នកក្រីក្រនោះ ។

លូកា ១០:៣៨ –លូកា ១២:៥៩

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះបានបង្រៀនម៉ារា និងម៉ាថានៅក្នុងផ្ទះរបស់ម៉ាថា ។ ក្រោយមក ទ្រង់បានបង្រៀនសេចក្តីពិតជាច្រើន ទៅដល់ពួកសិស្សរបស់ទ្រង់អំពីការអធិស្ឋាន ហើយបានព្រមានទាស់នឹងការលាក់ពុត និងសេចក្តីលោភលន់ ។

យោបល់សម្រាប់ការបង្រៀន

លូកា ១០:៣៨–៤២

ព្រះយេស៊ូវបង្រៀនម៉ារា និងម៉ាថា

ចូរសុំឲ្យសិស្សគិតអំពីជម្រើសដែលពួកគេបានធ្វើកាលពីម្សិលមិញ ។ សូមអញ្ជើញពួកគេឲ្យចំណាយពេលមួយនាទី ដើម្បីសរសេរការជ្រើសរើសនោះឲ្យបានច្រើនតាមដែលពួកគេអាចធ្វើទៅបាន នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ចូរសុំឲ្យសិស្សមួយចំនួនប្រាប់អំពីការជ្រើសរើសល្អៗរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

- តើស្ថានភាពមួយចំនួនណាខ្លះ ដែលយើងអាចត្រូវធ្វើការសម្រេចចិត្តរវាងការជ្រើសរើសល្អៗចំនួនពីរ ?

នៅពេលសិស្សសិក្សាលូកា ១០:៣៨–៤២ សូមអញ្ជើញពួកគេរកមើលគោលការណ៍មួយដែលព្រះអង្គសង្គ្រោះបានបង្រៀន ដែលអាចដឹកនាំយើងនៅក្នុងការសម្រេចចិត្ត—ជាពិសេសនៅពេលមានការជ្រើសរើសល្អៗច្រើនជាងមួយមានសម្រាប់យើងនោះ ។

សូមពន្យល់ថា បន្ទាប់ពីការបង្រៀនរឿងប្រៀបធៀបអំពីសាសន៍សាម៉ារីល្អ នោះព្រះអង្គសង្គ្រោះបានធ្វើដំណើរទៅកាន់ភូមិបេថានី ហើយបានទៅលេងផ្ទះស្ត្រីម្នាក់ឈ្មោះ ម៉ាថា ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១០:៣៨–៤០ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលម៉ាថា និងប្អូនស្រីនាងម៉ារា បានជ្រើសរើសធ្វើ ខណៈដែលព្រះអង្គសង្គ្រោះគង់នៅក្នុងផ្ទះពួកគេនោះ ។

- តើម៉ារាបានធ្វើអ្វីខ្លះ ខណៈដែលព្រះអង្គសង្គ្រោះគង់នៅក្នុងផ្ទះរបស់ពួកគេ ?
- តើម៉ាថាបានធ្វើអ្វីខ្លះ ? (សូមចង្អុលបង្ហាញថា ពាក្យ*ការរវល់ជាច្រើន*នៅក្នុងខទី ៤០សំដៅទៅលើបន្ទុក) ។

ចូរដាក់បង្ហាញរូបភាពម៉ារា និងម៉ាថា (*Gospel Art Book* ⁄ ឆ្នាំ ២០០៩ ⁄ ទំព័រ៤៥ សូមមើលផងដែរ LDS.org) ។ ចូរពន្យល់ថា បដិសណ្ឋារកិច្ចគឺសំខាន់ណាស់នៅក្នុងជំនាន់របស់ព្រះយេស៊ូវ ។ ម៉ាថា កំពុងព្យាយាមធ្វើអ្វីដែលធម្មតានាងត្រូវរំពឹងឲ្យធ្វើក្នុងនាមជាម្ចាស់ផ្ទះ ។ នាងបានដើរទៅលើកង្វល់ខាងសាច់ឈាម ដូចជាការរៀបចំ និងការចំអិនម្ហូបអាហារ ។

- យោងតាមខទី ៤០តើម៉ាថាបានសួរទៅដល់ព្រះអង្គសង្គ្រោះអ្វីខ្លះ ដែលបង្ហាញថា នាងបានខ្វល់ខ្វាយអំពីរឿងខាងសាច់ឈាម ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១០:៤១–៤២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានឆ្លើយតបនឹងម៉ាថា ។

- តើព្រះអង្គសង្គ្រោះមានន័យយ៉ាងណា នៅពេលទ្រង់មានបន្ទូលថា « មានសេចក្តីតែ១ទេ ដែលចាំបាច់ ឯម៉ារា នាងបានរើសចំណែកយ៉ាងល្អ » ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាលីន អេក អ្នក នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖

« វាគួរឲ្យគោរពចំពោះម៉ាថាដែល ‹ នាងព្រួយចិត្តខំប្រឹងរៀបចំធ្វើអីច្រើនម្ល៉េះ › (ខទី ៤១) ប៉ុន្តែដំណឹងល្អមកពីលោកគ្រូគឺកាន់តែ ‹ ចាំបាច់ › ជាង » (« Good, Better, Best » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ១០៤) ។

- តើព្រះអង្គសង្គ្រោះមានន័យយ៉ាងណា ពេលទ្រង់មានបន្ទូលថា « ចំណែកយ៉ាងល្អ » ដែលម៉ារាបានជ្រើសរើសនឹង « មិនត្រូវយកចេញពីនាងឡើយ » (លូកា ១០:៤២) ? (តាមរយៈការជ្រើសរើសស្តាប់តាមព្រះអង្គសង្គ្រោះ ជាជាងដើរទៅលើកង្វល់ខាងសាច់ឈាម ម៉ារានឹងទទួលបានពរជ័យខាងវិញ្ញាណដែលនឹងមានជារៀងរហូត) ។
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីការព្រមានរបស់ព្រះអង្គសង្គ្រោះទៅកាន់ម៉ាថា ? (សិស្សអាចថ្លែងវាផ្សេងៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងជ្រើសរើសលះបង់ខ្លួនយើងចំពោះរឿងខាងវិញ្ញាណ ជាងកង្វល់ខាងសាច់ឈាម នោះយើងនឹងទទួលបានពរជ័យជារៀងរហូត**) ។
- តើយើងអាចលះបង់ខ្លួនយើងចំពោះរឿងខាងវិញ្ញាណ ហើយនៅតែយកចិត្តទុកដាក់នឹងរឿងផ្សេងៗដែល « ចាំបាច់ » (លូកា ១០:៤២) ប៉ុន្តែមិនសូវសំខាន់យ៉ាងដូចម្តេច ?

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តសេចក្តីពិតដែលពួកគេរៀន

ប្រសិនបើគោលការណ៍នៃដំណឹងល្អមួយត្រូវបានសិក្សា ប៉ុន្តែមិនបានអនុវត្តការសិក្សានោះមិនបានពេញលេញឡើយ ។ ការអនុវត្តកើតមាន នៅពេលមនុស្សម្នាក់បានទទួលយកសេចក្តីពិតមួយនៅក្នុងដួងចិត្ត គំនិតរបស់គាត់ ឬនាង បន្ទាប់មកធ្វើសកម្មភាពស្របតាមសេចក្តីពិតនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសនៃព្រះវិញ្ញាណដែលពួកគេទទួលបាន ដើម្បីអនុវត្តសេចក្តីពិតទាំងឡាយនៃដំណឹងល្អដែលពួកគេរៀន ។



សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ អ្វកស៍ ឲ្យឮៗ ៖



« ពេលយើងពិចារណាពីជម្រើសជាច្រើន យើងគួរចងចាំថាវាពុំគ្រាន់ទេដែលអ្វីមួយនោះមានលក្ខណៈល្អប្រសើរ ។ ជម្រើសផ្សេងៗគឺល្អប្រសើរជាង ហើយនៅតែមានជម្រើសផ្សេងទៀតដែលល្អបំផុត ។ . . .

« ចូរពិចារណាអំពីរបៀបដែលយើងប្រើពេលវេលារបស់យើង នៅក្នុងការជ្រើសរើសដែលយើងធ្វើក្នុងការមើលទូរទស្សន៍ ការលេងវីដេអូហ្គេម ការលេងអ៊ិនធើរណិត ឬ ការអានសៀវភៅ ឬការអានទស្សនាវដ្តី ។ ប្រាកដណាស់វាល្អដើម្បីមើលកម្មវិធីកំសាន្តល្អៗ ឬដើម្បីទទួលបានព័ត៌មានដ៏គួរឲ្យចាប់អារម្មណ៍ ។ ប៉ុន្តែពុំមែនអ្វីៗទាំងអស់នោះមានតម្លៃក្នុងចំណែកជីវិតរបស់យើង ដែលយើងត្រូវលះបង់ដើម្បីទទួលបានវាទេ ។ រឿងមួយចំនួនវាល្អប្រសើរ ប៉ុន្តែរឿងផ្សេងទៀតគឺល្អបំផុត («Good, Better, Best » ទំព័រ ១០៤–៥) ។

ចូរសុំសិស្សឲ្យមើលបញ្ជីនៃការជ្រើសរើសដែលពួកគេបានធ្វើកាលពីម្សិលមិញ ហើយដាក់ស្លាកការជ្រើសរើសវិជ្ជមានមួយៗថា « ល្អ » « ល្អប្រសើរជាង » ឬ « ល្អបំផុត » ។ សូមអញ្ជើញសិស្សម្នាក់ ឬពីរនាក់ឲ្យថ្លែងទីបន្ទាល់អំពីរបៀបដែលពួកគេទទួលបានពរជ័យចំពោះការដាក់រឿងខាងវិញ្ញាណ មុនកង្វល់ខាងសាច់ឈាម ។

លូកា ១១

ព្រះយេស៊ូវបង្រៀនពួកសិស្សរបស់ទ្រង់អំពីការអធិស្ឋាន

សូមអញ្ជើញសិស្សឲ្យស្រមៃថា ពួកគេជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង ដែលកំពុងបង្រៀនអ្នករៀនដែលព្យាយាមអធិស្ឋានជាច្រើនដង ហើយមានអារម្មណ៍ថាព្រះពុំឆ្លើយតបសោះ ។ អ្នករៀននោះគិតថានឹងឈប់ធ្វើការអធិស្ឋាន ។

- ដោយផ្អែកទៅលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក តើអ្នកអាចនឹងឆ្លើយតបចំពោះកង្វល់នេះយ៉ាងដូចម្តេច ?

នៅពេលសិស្សសិក្សាលូកា ១១ សូមអញ្ជើញពួកគេឲ្យស្វែងរកសេចក្តីពិតដែលអាចជួយនរណាម្នាក់ ដែលមានអារម្មណ៍ថាព្រះពុំឆ្លើយតបការអធិស្ឋានរបស់ពួកគាត់ ។

សូមសង្ខេបលូកា ១១:១–៤ ដោយការពន្យល់ថា បន្ទាប់ពីការស្តាប់ព្រះអង្គសង្គ្រោះអធិស្ឋាន មានសិស្សម្នាក់របស់ទ្រង់បានសួរថា តើទ្រង់នឹងបង្រៀនពួកគេអំពីរបៀបអធិស្ឋានបានឬទេ ហើយព្រះអង្គសង្គ្រោះបានបង្រៀន ។

ចូរពន្យល់ថា បន្ទាប់ពីព្រះអម្ចាស់បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់អំពីរបៀបអធិស្ឋាន ទ្រង់បានប្រើរឿងប្រៀបធៀប ដើម្បីបង្រៀនសេចក្តីពិតបន្ថែមអំពីការអធិស្ឋាន រួមមានទាំងការមានឆន្ទៈរបស់ព្រះ ដើម្បីឆ្លើយតបនឹងការអធិស្ឋាន ។

សូមអញ្ជើញសិស្សឲ្យសិក្សាលូកា ១១:៥–១៣ ជាដៃគូ ហើយរកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនអំពីការអធិស្ឋាន ។ សូមចង្អុលបង្ហាញថា ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ មានបន្ថែមទៅលើ ខ ៥និង១៣ ។ សេចក្តីបន្ថែមទាំងនេះគឺមាននៅក្នុងការបកប្រែដោយយ៉ូសែប ស្ម៊ីធ លូកា ១១:៥–៦ (និង ការបកប្រែដោយយ៉ូសែប ស្ម៊ីធ លូកា ១១:១៤ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរសិស្សក្នុងថ្នាក់ ៖

- នៅក្នុងរឿងប្រៀបធៀបដែលអ្នកបានអាននៅក្នុងខទី ៥–៨ តើមិត្តម្នាក់បានសុំអ្វីពីមិត្តម្នាក់ទៀត ? ហេតុអ្វី ?
- ហេតុអ្វីអ្នកគិតថា មិត្តទីពីរបានគោរពតាមសំណើររបស់មិត្តទីមួយ ? (អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ*ទទូចអង្វរ*នៅក្នុងខទី ៨សំដៅទៅលើការទទូចរបស់បុរសនោះនៅក្នុងការសុំ ទោះជាមិត្តរបស់គាត់បានបដិសេធសំណើររបស់គាត់ពីដំបូងក្តី) ។
- ប្រសិនបើបុរសដែលត្រូវការនោះតំណាងឲ្យយើង ហើយមិត្តរបស់គាត់ដែលមាននំប៉័ងតំណាងឲ្យព្រះវរបិតាសួគ៌ តើព្រះអង្គសង្គ្រោះបានផ្តល់យោបល់អ្វីខ្លះ ដែលយើងត្រូវធ្វើក្នុងគ្រាចាំបាច់នោះ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងអធិស្ឋាន ហើយស្វែងរកដោយខ្ជាប់ខ្ជួន នូវពរជ័យរបស់ព្រះអម្ចាស់នៅក្នុងគ្រាចាំបាច់* . . .

- យោងតាមខទី ១៣តើព្រះវរបិតាសួគ៌នឹងប្រទានអ្វីខ្លះ ដល់អ្នកទាំងឡាយដែលអធិស្ឋានទទូចអង្វរ ហើយស្វែងរកពរជ័យរបស់ទ្រង់នោះ ?
- ដោយផ្អែកលើការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងលូកា ១១:៥–១៣ តើអ្នកនឹងបញ្ចប់សេចក្តីថ្លែងការណ៍នៅលើក្តារខៀនយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតប សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដើម្បីវានាំទៅរកសេចក្តីពិតដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងអធិស្ឋានដោយខ្ជាប់ខ្ជួន ហើយស្វែងរកពរជ័យរបស់ព្រះវរបិតាសួគ៌នៅក្នុងគ្រាចាំបាច់ នោះទ្រង់នឹងឆ្លើយការអធិស្ឋានរបស់យើង ដែលប្រទានពរយើងច្រើនបំផុតនោះ**) ។

ចូរពិចារណាធ្វើការអញ្ជើញសិស្សឲ្យចែកចាយឧទាហរណ៍ អំពីពេលដែលពួកគេបានទទួលចម្លើយចំពោះការអធិស្ឋានរបស់ពួកគេ នៅពេលពួកគេស្វែងរកពរជ័យរបស់ព្រះវរបិតាសួគ៌ដោយទទូចអង្វរនោះ ។

សូមសង្ខេបលូកា ១១:១៤–៥៤ ដោយការពន្យល់ថា ព្រះយេស៊ូវបានបណ្តេញអារក្សចេញពីបុរសម្នាក់ បានប្រឹក្សាដល់ប្រជាជនឲ្យស្តាប់ព្រះបន្ទូលព្រះ ហើយបានវាយផ្ចាលពួកផារិស៊ី និងពួកអាចារ្យសម្រាប់ភាពលួងលោភ និងភាពទុច្ចរិតរបស់ពួកគេ ។

លូកា ១២

ព្រះអង្គសង្គ្រោះព្រមានអំពីការលាក់ពុត និងភាពលោកលន់

សូមអានសំណួរដូចខាងក្រោមដល់សិស្សក្នុងថ្នាក់ ហើយអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីចម្លើយរបស់ពួកគេដោយស្ងាត់ស្ងៀម ៖

- តើអ្នកធ្លាប់ចង់បានអ្វីមួយខ្លាំងពេក ដែលអ្នកបានគិតអំពីវាគ្រប់ពេលឬទេ ?

- តើឥទ្ធិពលអវិជ្ជមានអ្វីខ្លះអាចកើតមានមកលើយើងចំពោះការគិតប្រភេទនេះ ?

សូមសង្ខេបលូកា ១២:១–១៣ ដោយពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះគង់នៅខាងមុខហ្វូងមនុស្សដ៏ច្រើន នោះទ្រង់បានបង្រៀនដល់ពួកសិស្សឲ្យប្រយ័ត្ននឹងភាពលាក់ពុត ។ ទ្រង់ក៏បានរំឭកពួកគេផងដែរថា គ្រប់រឿងដែលបានលាក់កំបាំងនឹងត្រូវបើកបង្ហាញឡើងនៅថ្ងៃមួយ ហើយថាព្រះដឹង ហើយមើលថែទាំកូនចៅរបស់ទ្រង់ទាំងអស់ ។ បុរសនោះបានសួរដល់ព្រះអង្គសង្គ្រោះ ប្រសិនបើទ្រង់នឹងមានបន្ទូលទៅបងប្រុសរបស់គាត់ ហើយបញ្ចុះបញ្ចូលបងប្រុសឲ្យចែកមរតកជាមួយនឹងគាត់នោះ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១២:១៤–១៥ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះសំណើររបស់បុរសនោះ ។

- តើមានការព្រមានអ្វីខ្លះ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់មនុស្សដែលនៅជាមួយនឹងទ្រង់ ?

ចូរពន្យល់ថា*ភាពលោភលន់*មានន័យថាមានបំណងប្រាថ្នាលើអ្វីមួយដ៏លើសលប់ ។ ចូរសរសេរនៅលើក្តារខៀននូវសេចក្តីពិតដូចខាងក្រោម ៖ **ព្រះអម្ចាស់បញ្ជាយើងកុំឲ្យលោភលន់ចង់បានទ្រព្យសម្បត្តិខាងលោកិយ ។**

- ហេតុអ្វីក៏មនុស្សម្នាក់គួរចៀសវាងពីការលោភលន់ ? តើសេចក្តីពិតនេះអាចជួយយើងរស់នៅក្នុងជីវិត ឲ្យកាន់តែរីករាយយ៉ាងដូចម្តេច ?

ចូរពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានប្រាប់ដល់សិស្សរបស់ទ្រង់ឲ្យចៀសវាងពីការលោភលន់ នោះទ្រង់បានប្រទានរឿងប្រៀបធៀបដើម្បីបង្ហាញអំពីសារៈសំខាន់នៃបទបញ្ញត្តិនេះ ។ សូមអញ្ជើញសិស្សអានលូកា ១២:១៦–១៩ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវចំនួនដងដែលបុរសនៅក្នុងរឿងប្រៀបធៀបនេះប្រើពាក្យខ្ញុំនិង*របស់ខ្ញុំ* ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើពេលបុរសនោះប្រើពាក្យខ្ញុំនិង*របស់ខ្ញុំ*ញឹកញាប់ប៉ុណ្ណា ដើម្បីបង្រៀនយើងអំពីកង្វល់របស់គាត់?
- តើយើងអាចត្រូវបានល្បួងដូចជាបុរសនេះតាមរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១២:២០–២១ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះបានមានបន្ទូលអំពីភាពកំណាញ់ និងភាពលោភលន់របស់បុរសនោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ខាងក្រោម ដោយ អែលឌើរ អិម រ័សុល បាឡឺដ ក្នុងកម្រងនៃពួកសាវកដប់ពីរនាក់ ។ (សេចក្តីថ្លែងការណ៍នេះ មាននៅក្នុង « What Matters Most Is What Lasts Longest » *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៤៤) ៖

« អ្វីដែលសំខាន់បំផុត គឺជាអ្វីដែលយូរអង្វែងបំផុត » (អែលឌើរ អិម រ័សុល បាឡឺដ) ។

- តើបុរសអ្នកមាននៅក្នុងរឿងប្រៀបធៀបបានភ្លេចផ្តោតទៅលើ « រឿងសំខាន់បំផុត » តាមរបៀបណា ?
- ហេតុអ្វីក៏សកម្មភាពរបស់បុរសនេះត្រូវបានចាត់ទុកថាល្ងង់ខ្លៅ ?

សូមសង្ខេបលូកា ១២:២២–៣០ ដោយពន្យល់ថា ព្រះអម្ចាស់បានគូសបញ្ជាក់ថា ពួកសិស្សរបស់ទ្រង់ពុំចាំបាច់ត្រូវខ្វល់ហួសហេតុអំពីតម្រូវការខាងសាច់ឈាមរបស់ពួកគេនោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១២:៣១–៣៤ ឲ្យឮៗ ។ សូមអញ្ជើញពួកគេឲ្យអាន ការបកប្រែដោយយ៉ូសែបស្ម៊ីធ លូកា ១២:៣៤ ផងដែរ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានប្រឹក្សាដល់ពួកសិស្សរបស់ទ្រង់ឲ្យស្វែងរកជាជាងផ្តោតទៅលើបំណងប្រាថ្នាកំណាញ់ផ្ទាល់ខ្លួនរបស់ពួកគេ ។

- តើព្រះយេស៊ូវបានប្រឹក្សាដល់ពួកសិស្សរបស់ទ្រង់ឲ្យស្វែងរកអ្វីខ្លះ ?
- តើពួកគេត្រូវបានសន្យាអ្វីខ្លះ ប្រសិនបើពួកគេព្យាយាមស្វែងរកនូវនគរព្រះនោះ ?
- តើអ្នកនឹងសង្ខេបការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងលូកា ១២:៣១–៣៤ ជាគោលការណ៍មួយយ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើសម្តីរបស់ពួកគេផ្ទាល់ ប៉ុន្តែពួកគេគួរប្រាប់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងស្វែងរកនគររបស់ព្រះ និងសេចក្តីសុចរិតរបស់ទ្រង់ នោះទ្រង់នឹងជួយផ្គត់ផ្គង់ចំពោះសេចក្តីត្រូវការរបស់យើង ហើយរៀបចំកន្លែងមួយសម្រាប់យើងនៅក្នុងនគររបស់ទ្រង់**) ។

- តើយើងអាចស្វែងរកនគរព្រះតាមរបៀបណា ? (នៅពេលសិស្សឆ្លើយតប អ្នកអាចនឹងចង់យោងទៅលើគោលការណ៍ដែលពួកគេបានស្គាល់ពីខាងដើមអំពីការលះបង់ខ្លួនយើង ចំពោះរឿងខាងវិញ្ញាណជាងកង្វល់ខាងសាច់ឈាម) ។

សូមថ្លែងទីបន្ទាល់អំពីរបៀបដែលអ្នកត្រូវបានប្រទានពរ នៅពេលអ្នកព្យាយាមដាក់អាទិភាពទៅលើរឿងខាងវិញ្ញាណជាជាងលើរឿងខាងសាច់ឈាម ហើយនាំមកនូវនគររបស់ព្រះនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតថាតើពួកគេត្រូវបានផ្តោតកាន់តែខ្លាំងទៅលើរឿងខាងវិញ្ញាណឬកង្វល់ខាងសាច់ឈាម ។ សូមអញ្ជើញពួកគេឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីដែលពួកគេនឹងធ្វើដើម្បីដាក់អាទិភាពរឿងខាងវិញ្ញាណពីលើកង្វល់ខាងសាច់ឈាម ហើយនាំមកនូវនគររបស់ព្រះនោះ ។

សូមសង្ខេបលូកា ១២:៣៥–៥៩ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនដល់អ្នកដើរតាមរបស់ទ្រង់ ដើម្បីរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ ទ្រង់បានជួយពួកគេយល់ថានៅកន្លែងណា « ដែលប្រគល់ទុកជាច្រើនឲ្យ. . . នោះទារជាច្រើនមកវិញ » (ខ ៤៨) ហើយទ្រង់បានពន្យល់ថា ដំណឹងល្អរបស់ទ្រង់នឹងបណ្តាលឲ្យមានការបែងចែកដ៏ធំនៅក្នុងចំណោមប្រជាជន ។

លូកា ១៣–១៤

សេចក្តីផ្តើម

ព្រះយេស៊ូវបានបង្រៀនអំពីការប្រែចិត្ត និងនគរនៃព្រះ ហើយទ្រង់បានព្យាបាលនៅថ្ងៃឈប់សម្រាក ។ ទ្រង់ក៏បានប្រើរឿងប្រៀបធៀបដើម្បីបង្រៀនអំពីភាពរាបសារ និងតម្លៃនៃភាពជាសិស្សផងដែរ ។

យោបល់សម្រាប់ការបង្រៀន

លូកា ១៣:១–១៤:១៤

ព្រះយេស៊ូវព្យាបាលនៅថ្ងៃឈប់សម្រាក ហើយបង្រៀនអំពីភាពរាបសារ និងការមើលថែដល់មនុស្សដែលមិនសូវមានសំណាង

សូមអានស្ថានភាពខាងក្រោមនេះឮៗ ៖ អ្នកកំពុងអង្គុយទទួលទានអាហារជាមួយនឹងមិត្តភក្តិបីបួននាក់ ហើយពួកគេបានសង្កេតឃើញសិស្សម្នាក់ស្លៀកពាក់ពុំសូវសមរម្យអង្គុយតែម្នាក់ឯង ។ មនុស្សម្នាក់ក្នុងក្រុមរបស់អ្នកបាននិយាយត្រគោះបោះបោកអំពីរូបរាយរបស់សិស្សនោះ ហើយមិត្តភក្តិរបស់អ្នកសើច ។

ចូរអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលពួកគេនឹងមានអារម្មណ៍ចំពោះស្ថានភាពនេះ ។

- តើអ្នកអាចមានប្រតិកម្មដោយរបៀបផ្សេងៗជាច្រើនអ្វីខ្លះ នៅក្នុងស្ថានភាពនេះ ?

សូមអញ្ជើញសិស្សឲ្យរកមើលលូកា ១៣–១៤ អំពីអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀន អំពីការប្រាស្រ័យទាក់ទងនឹងមនុស្សដែលពុំសូវមានសំណាងដូចយើង ។

សូមសង្ខេបលូកា ១៣:១–១៤:៦ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះ បានរៀបរាប់រឿងប្រៀបធៀបអំពីដើមល្វាដែលនឹងត្រូវកាប់រំលំ ប្រសិនបើវាពុំផ្តល់ផលផ្លែ ដែលរឿងនេះបង្រៀនដល់យើងថា យើងនឹងត្រូវស្លាប់ ប្រសិនបើយើងពុំប្រែចិត្តទេនោះ ។ ទ្រង់បានព្យាបាលស្ត្រីម្នាក់នៅថ្ងៃឈប់សម្រាក ហើយបានបង្រៀនអំពីនគរនៃព្រះ និងអ្នកទាំងឡាយដែលនឹងត្រូវបានអនុញ្ញាតឲ្យចូលក្នុងនគរ ។ ទ្រង់ក៏បានទួញសោកផងដែរ ចំពោះការបំផ្លិចបំផ្លាញនៃទីក្រុងយេរូសាឡិមដែលនឹងកើតមាន ។ នៅក្នុងលូកា ១៤:១–៦ យើងអានថា ព្រះអង្គសង្គ្រោះត្រូវបានអញ្ជើញឲ្យទៅសោយព្រះស្ងោយពេលល្ងាច នៅផ្ទះរបស់ចៅហ្វាយនៃពួកផារិស៊ីម្នាក់នៅថ្ងៃឈប់សម្រាក ។ មុនពេលទទួលទានអាហារ ព្រះអង្គសង្គ្រោះបានព្យាបាលបុរសម្នាក់ដែលបានរងទុក្ខដោយជំងឺទាចទឹក ដែលជាជំងឺម្យ៉ាងដែលបណ្តាលឲ្យរូបកាយរបស់មនុស្សនោះហើមមានពេញដោយទឹក ។

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមចាត់សិស្សម្នាក់ពីដៃគូនីមួយៗអានលូកា ១៣:១៥–១៦ ហើយសិស្សម្នាក់ទៀតអានលូកា ១៤:៥–៦ ដោយស្ងាត់ស្ងៀម ។ ចូរសុំឲ្យសិស្សរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកផារិស៊ី ដែលបានចោទប្រកាន់ទ្រង់អំពីការមិនគោរពថ្ងៃឈប់សម្រាក ដោយការព្យាបាលបុគ្គលទាំងនេះ ។ សុំឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញទៅដល់ដៃគូរបស់ពួកគេ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរសិស្សក្នុងថ្នាក់ ៖

- តើឃ្លាអ្វីខ្លះ ដែលពិពណ៌នាអំពីរឿងទាំងឡាយដែលពួកផារិស៊ីនឹងធ្វើចំពោះសត្វចិញ្ចឹមរបស់ពួកគេនៅថ្ងៃឈប់សម្រាក ? (ស្រាយចំណងវា ហើយទាញពួកវាចេញពីរណ្តៅ) ។
- តើយើងអាចរៀនអ្វីខ្លះ មកពីគំរូរបស់ព្រះអង្គសង្គ្រោះអំពីការគោរពថ្ងៃឈប់សម្រាក និងការរក្សាវាឲ្យបរិសុទ្ធ ? (ការបម្រើមនុស្សដែលខ្វះខាត គឺជារឿងសមហេតុផល ដើម្បីធ្វើនៅថ្ងៃឈប់សម្រាក) ។ គំរូសុចរិតរបស់ព្រះអង្គសង្គ្រោះផ្ទុយពីអាកប្បកិរិយារបស់ពួកផារិស៊ីមួយចំនួនដែលមានបព្វហេតុត្រឹមត្រូវក្នុងការជួយសត្វ ប៉ុន្តែមិនជួយមនុស្សនៅថ្ងៃឈប់សម្រាកនោះទេ) ។

សូមសង្ខេបលូកា ១៤:៧–១១ ដោយពន្យល់ថា បន្ទាប់ពីការព្យាបាលមនុស្សដែលរងទុក្ខដោយជំងឺទាចទឹក នោះព្រះអង្គសង្គ្រោះបានវាយផ្ចាលនឹងភ្ញៀវដែលមកទទួលទានអាហារពេលល្ងាចដទៃទៀត ដែលព្យាយាមលើកខ្លួនពួកគេឡើងដោយអង្គុយនៅកៅអីមានកិត្តិយសបំផុត ដែលនៅកៀកបំផុតនឹងម្ចាស់ផ្ទះ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១៤:១២–១៤ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកផារិស៊ីដែលបានអញ្ជើញទ្រង់ទៅសោយព្រះស្ងោយនាពេលល្ងាច ។

- តើព្រះអង្គសង្គ្រោះបានប្រទានការប្រឹក្សាអ្វីខ្លះ ដល់ពួកផារិស៊ីរូបនេះ ?
- តើមូលហេតុបែបណាខ្លះ ដែលជាបព្វហេតុមនុស្សអញ្ជើញមិត្តភក្តិរបស់ពួកគេ និងអ្នកជិតខាង ដែលមានទ្រព្យសម្បត្តិរបស់ពួកគេទៅទទួលទានអាហារពេលល្ងាចនោះ ?

ចូរពន្យល់ថា នៅក្នុងជំនាន់របស់ព្រះអង្គសង្គ្រោះ អ្នកទាំងឡាយដែលកំបុតដៃជើង ខ្វិន ឬខ្វាក់ ជាញឹកញាប់មានការលំបាកក្នុងការផ្គត់ផ្គង់ខ្លួនពួកគេ ហើយបានធ្លាក់ខ្លួនក្រីក្រ ។ ពួកជាអ៊ីសីមួយចំនួនបានមើលងាយដល់មនុស្សទាំងនេះ (សូមមើលលូកា ១៦:១៤–៣១) ។

- តើមូលហេតុមួយចំនួនណាខ្លះ ដែលមនុស្សនៅសព្វថ្ងៃអាចមើលងាយអ្នកដទៃ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពីលូកា ១៤:១៤ អំពីការព្យាយាមជួយមនុស្សដែលមិនស្ងួមានសំណាងដូចជាយើង ? (នៅខាងក្រោមនេះ គឺជាគោលការណ៍មួយដែលសិស្សអាចប្រាប់ ៖ **ប្រសិនបើយើងព្យាយាមជួយមនុស្សដែលមិនស្ងួមានសំណាងដូចជាយើង នោះព្រះអម្ចាស់នឹងប្រទានរង្វាន់ដល់យើង នៅពេលនៃការរស់ឡើងវិញ**) ។

សូមចង្អុលបង្ហាញថា បន្ថែមពីលើការផ្តល់រង្វាន់ដល់យើងនៅឯការរស់ឡើងវិញ នោះព្រះអម្ចាស់នឹងប្រទានពរយើងនៅក្នុងជីវិតនេះផងដែរ នៅពេលយើងព្យាយាមជួយអ្នកដទៃ ដែលពុំស្ងួមានសំណាងដូចជាយើង ។

- តើយើងអាចជួយអ្នកដទៃ ដែលពុំស្ងួមានសំណាងដូចជាយើងដោយរបៀបណា ?
- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ ត្រូវបានប្រទានពរដោយការព្យាយាមជួយដល់អ្នក ដែលពុំស្ងួមានសំណាងដូចជាយើងនៅពេលណា ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលពួកគេអាចជួយមនុស្សដែលពុំស្ងួមានសំណាងដូចជាពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវគោលដៅមួយដើម្បីបម្រើអ្នកទាំងឡាយដែលមិនស្ងួមានសំណាងដូចជាពួកគេ ។

លូកា ១៤:១៥–៣៥

ព្រះយេស៊ូវប្រទានរឿងប្រៀបធៀបអំពីការជប់លៀងដ៏ធំ ហើយបង្រៀនអំពីតម្លៃនៃភាពជាសិស្ស

សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្តារខៀនរឿងមួយចំនួន ដែលពួកគេអាចត្រូវបានសុំឲ្យពលិកម្ម ឬលះបង់ក្នុងនាមជាពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទ ។

- តើការដោះសារមួយចំនួនណាខ្លះ ដែលមនុស្សអាចនឹងត្រូវបានល្បួងឲ្យប្រើ ដើម្បីចៀសវាងពីការលះបង់ទាំងនេះ ?

ពេលសិស្សបន្តសិក្សា លូកា ១៤សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍ទាំងឡាយ ដែលបង្រៀនអំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទតម្រូវពីពួកសិស្សរបស់ទ្រង់ ។

សូមពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានប្រឹក្សានឹងពួកផារិស៊ី ឲ្យអញ្ជើញមនុស្សដែលមិនស្ងួមានសំណាងដូចពួកគេ ឲ្យទទួលទានអាហារ នោះមនុស្សម្នាក់ នៅក្នុងបន្ទប់បាននិយាយទៅទ្រង់ថា « មានពរហើយ អ្នកណាដែលនឹងបរិភោគក្នុងនគរព្រះ » (លូកា ១៤:១៥) ។ ជាការឆ្លើយតបចំពោះសេចក្តីថ្លែងការណ៍នេះ ព្រះអង្គសង្គ្រោះបានរៀបរាប់រឿងប្រៀបធៀបអំពីអាហារពេលល្ងាចដ៏ធំ ។

សូមអញ្ជើញសិស្សឲ្យអានលូកា ១៤:១៦–២៤ ឮៗជាមួយនឹងដៃគូរបស់ពួកគេពីផ្នែកខាងដើមនៃមេរៀន ។ ចូរសុំឲ្យសិស្សម្នាក់ពីដៃគូនីមួយៗឲ្យរកមើលការអញ្ជើញ ដែលមនុស្សនៅក្នុងរឿងប្រៀបធៀបបានទទួល ។ សូមអញ្ជើញសិស្សផ្សេងទៀតនៅក្នុងដៃគូនីមួយៗឲ្យរកមើលការដោះសារដែលមនុស្សបានធ្វើ ដែលបដិសេធនូវការផ្តល់ឲ្យនោះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរសិស្សក្នុងថ្នាក់ ៖

- តើដំណឹងល្អព្រះយេស៊ូវគ្រីស្ទ ប្រៀបបានទៅនឹងការជប់លៀងដ៏ធំមួយយ៉ាងដូចម្តេច ? (ចម្លើយអាចរួមមានដូចខាងក្រោម ៖ ដំណឹងល្អគឺជាអំណោយទានមួយ ដែលបានរៀបចំសម្រាប់យើង វាអាចបំពេញក្នុងខ្លួនយើង ហើយបំពេញតម្រូវការរបស់យើង យើងត្រូវបានអញ្ជើញឲ្យទទួលទាន ហើយយើងអាចទទួលយក ឬបដិសេធការអញ្ជើញឲ្យទទួលទាននោះ) ។
- តើការដោះសារអ្វីខ្លះដែលមនុស្ស ដែលពុំទទួលយកការអញ្ជើញទៅចូលរួមក្នុងពិធីជប់លៀងដ៏ធំនោះ ?
- តើការដោះសារទាំងនេះអ្វីខ្លះ ដែលបង្ហាញអំពីអាទិភាពរបស់មនុស្សទាំងនេះ ?

ស្របតាមខ ២៤តើទទួលនៃការដាក់អាទិភាពផ្សេងៗខ្ពស់ជាងព្រះអម្ចាស់ និងដំណឹងល្អរបស់ទ្រង់មានអ្វីខ្លះ ? (សិស្សអាចប្រាប់ពីគោលការណ៍មួយដូចខាងក្រោម ៖ **ប្រសិនបើយើងដាក់អាទិភាពផ្សេងខ្ពស់ជាងព្រះអម្ចាស់ និងដំណឹងល្អរបស់ទ្រង់ នោះយើងនឹងបាត់បង់ពរជ័យដែលយើងប្រហែលជាបានទទួល**) ។

សូមអញ្ជើញសិស្សឲ្យរកមើលអ្វីដែលបានសរសេរនៅលើកក្តារខៀនអំពីការលះបង់ដែលពួកគេអាចនឹងសុំឲ្យធ្វើ នៅពេលពួកគេជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។

- តើពរជ័យអ្វីខ្លះដែលយើងអាចបាត់បង់ ប្រសិនបើយើងពុំព្រមធ្វើការលះបង់ទាំងនេះទេនោះ ?

ចូរពន្យល់ថា បន្ទាប់ពីការបង្រៀនរឿងប្រៀបធៀបនេះ ព្រះអង្គសង្គ្រោះបានមានបន្ទូលទៅហ្វូងមនុស្សអំពីអ្វីដែលទ្រង់តម្រូវពីពួកសិស្សរបស់ទ្រង់ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១៤:២៥–២៧ ឮៗ ។

សូមពន្យល់ថា ការបកប្រែដោយបានបញ្ជាក់យ៉ាងច្បាស់ពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ នៅក្នុងលូកា ១៤:២៥–២៧ ។ « មានមនុស្សសន្ធឹកណាស់ ដើរទៅជាមួយនឹងទ្រង់ នោះទ្រង់បែរទៅមានព្រះបន្ទូលនឹងគេថា បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី ឬស្វាមី និងជីវិតខ្លួនឯងផង ឬម្យ៉ាងទៀត ខ្លាចលះបង់ជីវិតដើម្បីខ្ញុំ អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ ។ ហើយអ្នកណាដែលមិនផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំ នោះក៏ធ្វើជាសិស្សខ្ញុំមិនបានដែរ ។ ហេតុដូច្នោះហើយ ចូរដោះស្រាយរឿងនេះក្នុងដួងចិត្តរបស់អ្នក ដើម្បីអ្នករាល់គ្នាអាចធ្វើរឿងដែលខ្ញុំនឹងបង្រៀន ហើយបង្គាប់ដល់អ្នក » ។

- តើព្រះអង្គសង្គ្រោះមានបន្ទូលថា ពួកសិស្សរបស់ទ្រង់ត្រូវមានឆន្ទៈធ្វើអ្វីខ្លះ ?

> ***ប្រើជំនួយសិក្សាព្រះគម្ពីរ***
>
> សាសនាចក្របានរៀបចំជាក់ជំនួយការសិក្សាមួយចំនួននៃព្រះគម្ពីរ ហើយបានបញ្ចូលវានៅក្នុងបទដ្ឋានព្រះគម្ពីរសម្រាប់ភាសាមួយចំនួន ។ ជំនួយការសិក្សាទាំងនេះរួមមាន លេខរយោង មាតិកាតាមប្រធានបទ រូបភាព និងផែនទី ។ ទាំងនេះគឺជាធនធានដ៏មានតម្លៃសម្រាប់ប្រើប្រាស់ ខណៈពេលសិក្សាបទគម្ពីរទាំងឡាយ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើជំនួយការសិក្សាទាំងនេះ នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

ចូរពន្យល់ថា និយមន័យមួយនៃភាសាក្រិច ពាក្យដែលបានបកប្រែថា*ស្អប់*គឺ « មិនស្ងួរស្រឡាញ់ » (ដេម ស្ត្រុង *The Exhaustive Concordance of the Bible* [ឆ្នាំ ១៨៩០] « misĕō » ទំព័រ ៤៨) ។ ព្រះអង្គសង្គ្រោះបានពន្យល់ថា សម្រាប់ពួកសិស្សរបស់ទ្រង់ ការលះបង់ចំពោះគ្រួសារ ឬសូម្បីតែជីវិតផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ ត្រូវតែកើតមានបន្ទាប់ពីការលះបង់ថ្វាយទ្រង់ (សូមមើលផងដែរម៉ាថាយ ១០:៣៧) ។ ដើម្បីលើឈើឆ្កាងរបស់មនុស្សម្នាក់ សំដៅទៅលើការឆ្កាង និងតំណាងឲ្យការស្ម័គ្រចិត្តដែលបានតម្រូវឲ្យមាន ដើម្បីប្រគល់ជីវិតរបស់មនុស្សម្នាក់ថ្វាយព្រះគ្រីស្ទ ដែលបានលះបង់ជីវិតរបស់ទ្រង់ដល់យើង (សូមមើលផងដែរ ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ ម៉ាថាយ ១៦:២៦ ។

- តើសេចក្តីពិតអំពីការធ្វើជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? (សិស្សអាចបាប់រអំពីភាពផ្សេងៗ នៃសេចក្តីពិត ប៉ុន្តែចូរប្រាកដថា ពួកគេប្រាប់សេចក្តីពិតដែលស្រដៀងគ្នាដូចខាងក្រោមនេះ ៖ **ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទត្រូវតែមានឆន្ទៈលះបង់អ្វីៗគ្រប់យ៉ាង ដើម្បីដើរតាមទ្រង់ ។** អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរសេចក្តីពិតនេះនៅក្រមទំព័រក្បែរ លូកា ១៤:២៥–២៧) ។
- ហេតុអ្វីក៏អ្នកគិតថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទចាំបាច់ត្រូវមានឆន្ទៈ ដើម្បីដាក់ទ្រង់ពីមុនអ្វីៗទាំងអស់ រួមទាំងសមាជិកគ្រួសារ និងជីវិតផ្ទាល់ខ្លួនរបស់ពួកគេនោះ ?

ចូរសរសេរឃ្លា*ដោះស្រាយរឿងនេះនៅក្នុងដួងចិត្តរបស់អ្នក* (នៅលើក្តារខៀន ។

- តើអ្នកគិតថាឃ្លា « ដោះស្រាយរឿងនេះនៅក្នុងដួងចិត្តរបស់អ្នក » មានអត្ថន័យដូចម្តេចដែរ ? (សូមពន្យល់ថានៅក្នុងបរិបទនេះពាក្យ*ដោះស្រាយ*មានន័យថាសម្រុះសម្រួល ឬសម្រេចចិត្តដោយម៉ឺងម៉ាត់) ។
- តើព្រះអង្គសង្គ្រោះចង់ឲ្យយើងដោះស្រាយអ្វីនៅក្នុងចិត្តរបស់យើង ?
- តើគោលការណ៍អ្វីដែលយើងអាចរៀនមកពីការបកប្រែរបស់យ៉ូសែប ស្ម៊ីធ អំពីលូកា ១៤:១៧? (សិស្សគួរអាចឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងដោះស្រាយនៅក្នុងខ្លួនយើងអំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបង្រៀន និងបញ្ជាដល់យើង នោះយើងនឹងក្លាយទៅជាសិស្សរបស់ទ្រង់) ។

សូមផ្តល់ដល់សិស្សនូវច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍ដូចខាងក្រោយដោយអែលឌើរ ឌ្យាវី ដំបុលយូ ហ្គើបបុននៃពួកចិតសិបនាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ហើយរកមើលអ្វីដែលយើងត្រូវធ្វើដើម្បីរស់នៅតាមគោលការណ៍នេះ ។



« នៅពេលអ្នកចាប់ផ្តើមដាក់អាទិភាពរបស់អ្នក នៅក្នុងជីវិត សូមចងចាំថា សុវត្ថិភាពពិតនៅក្នុងជីវិតមានតែតាមរយៈការរស់នៅតាមបទបញ្ជាត្តិតែប៉ុណ្ណោះ ។ . . .

« . . . ហើយក្នុងវ័យក្មេងខ្លីរបស់អ្នក តើវាជារឿងអស្ចារ្យប៉ុណ្ណា ដើម្បីសម្រេចចិត្តតែម្តងអំពីអ្វីដែលអ្នកនឹងធ្វើ និងអ្វីដែលអ្នកនឹងមិនធ្វើនោះ ទាក់ទងនឹងភាពស្មោះត្រង់ ភាពមទម្យ ព្រហ្មចារីភាព ពាក្យសម្តីប្រាជ្ញាវាងវៃ និងអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ។

« បងប្អូនប្រុសស្រី សូមបន្តនៅលើផ្លូវត្រង់ ហើយចង្អៀតនេះចុះ ។ ទេ សូមនៅ*ចំកណ្តាល*នៃផ្លូវត្រង់ ហើយចង្អៀតនេះ ។ ចូរកុំរសាត់ឡើយ កុំដើរវង្វេងឡើយ កុំឲ្យទទឹកឡើយ សូមប្រុងប្រយ័ត្ន ។

«. . . ការរស់នៅតាមព្រះបញ្ញត្តិទាំងឡាយ នឹងនាំឲ្យអ្នកមានសុភមង្គលដែលមនុស្សជាច្រើនស្វែងរកនៅកន្លែងផ្សេងៗ »
(« Wherefore, Settle This in Your Hearts »*Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ១០៣,១០៤) ។

- តើបទបញ្ជាត្តិមួយណា ដែលអ្នកបានតាំងចិត្តគោរពតាមដោយម៉ឺងម៉ាត់នោះ ? តើអ្នកត្រូវបានប្រទានពរដោយការសម្រេចចិត្តដើម្បីគោរពបទបញ្ជាត្តិនោះយ៉ាងដូចម្តេច ?

សូមលើកទឹកចិត្តសិស្សឲ្យដោះស្រាយ នៅក្នុងដួងចិត្តរបស់ពួកគេអំពី« អ្វីដែល[ពួកគេ] នឹង. . . និង. . . នឹងមិនធ្វើនោះ ទាក់ទងនឹងភាពស្មោះត្រង់ ភាពមទម្យ ព្រហ្មចារីភាព ពាក្យសម្តីប្រាជ្ញាវាងវៃ និងអាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ » ។ អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសរសេរការសម្រេចចិត្តរបស់ពួកគេ នៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬក្នុងសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីរ ។

សូមពន្យល់ថា បន្ទាប់ពីការបង្រៀនគោលការណ៍ទាំងនេះអំពីភាពជាសិស្ស នោះព្រះអង្គសង្គ្រោះបានប្រទានន្ទូវរឿងប្រៀបធៀបចំនួនពីរ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានលូកា ១៤:២៨–៣០ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតអានលូកា ១៤:៣១–៣៣ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ហើយពិចារណាអំពីអ្វីដែលរឿងប្រៀបធៀបទាំងពីរនេះបង្ហាញ ។

- តើអ្នកគិតថា រឿងប្រៀបធៀបទាំងពីរនេះបង្ហាញពីអ្វីខ្លះ ?

ចូរពន្យល់ថារឿងប្រៀបធៀបទាំងពីរនេះ បង្ហាញអំពីសារៈសំខាន់នៃការរាប់ ឬការប្តេជ្ញាចិត្ត តម្លៃនៃបុព្វហេតុនៃសេកម្មភាពមុនពេលចាប់ផ្តើមវា ដើម្បីកំណត់ថាតើអ្នកនឹងអាចបញ្ចប់វាឬទេ ។ ព្រះអង្គសង្គ្រោះចង់ឲ្យអ្នកដើរតាមរបស់ទ្រង់ពិចារណាដោយប្រុងប្រយ័ត្នថា តើពួកគេមានឆន្ទៈដើម្បីលះបង់នូវអ្វីៗចាំបាច់ ដើម្បីពួកគេអាចបន្តរហូតដល់ទីបំផុតក្នុងនាមជាសិស្សរបស់ទ្រង់ឬទេ ។ (សូមមើលផងដែរ ការបកប្រែរបស់យ៉ូសែប ស្ម៊ីធ លូកា ១៤:៣១ ។

ចូរសុំឲ្យសិស្សពិចារណាអំពីបញ្ហីនៃការលះបង់នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់ថា ហេតុអ្វីពួកគេមានឆន្ទៈដើម្បីធ្វើការលះបង់ទាំងនេះក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមពិចារណាអំពីការអញ្ជើញសិស្សឲ្យគូសចំណាំខទី ៣៣ ដែលផ្តល់ន្ទូវសេចក្តីសង្ឃឹមដ៏សាមញ្ញមួយ អំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងជំពូកនេះ ។ ចូរថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានពិភាក្សា ។

លូកា ១៥

សេចក្តីផ្តើម

ពួកផារិស៊ី និង ពួកអាចារ្យបានរអ៊ូរទាំអំពីទំនាក់ទំនងរបស់ព្រះអង្គសង្គ្រោះនឹងពួកអ្នកយកពន្ធ និង មនុស្សមានបាប ។ ព្រះអង្គសង្គ្រោះបានឆ្លើយតបដោយការប្រទាននូវរឿងប្រៀបធៀបអំពីចៀមដែលបាត់ ការបាត់កាក់ និង រឿងកូនប្រុសខ្ជះខ្ជាយ ។

យោបល់សម្រាប់ការបង្រៀន

លូកា ១៥:១–១០

ព្រះយេស៊ូវបានប្រទានរឿងប្រៀបធៀបអំពីចៀមដែលបាត់ ការបាត់កាក់

សូមចាប់ផ្តើមថ្នាក់ដោយការសួរដល់សិស្សប្រសិនបើពួកគេធ្លាប់បាត់វត្ថុមួយ ដែលមានតម្លៃចំពោះពួកគេ ។

- តើអ្នកមានឆន្ទៈធ្វើអ្វីខ្លះដើម្បីស្វែងរកវា ? ហេតុអ្វី ?
- តើអ្នកគិតថាវាមានន័យយ៉ាងណាចំពោះមនុស្សដែលបាន « វង្វេង » ខាងវិញ្ញាណ ? (សូមជួយសិស្សយល់ដឹងថា រឿងនេះអាចសំដៅទៅលើអ្នកទាំងឡាយដែលពុំទាន់បានទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ឬដែលពុំរស់នៅស្របតាមការបង្រៀននៃដំណឹងល្អបច្ចុប្បន្ននេះ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលអាចនឹងវង្វេងខាងវិញ្ញាណ ។ ចូរសុំឲ្យពួកគេពិចារណា អំពីរបៀបដែលពួកគេមានអារម្មណ៍យ៉ាងណាអំពីមនុស្សម្នាក់នេះ ។

សូមពន្យល់ថាលូកា ១៥មាននូវការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីអ្នកទាំងឡាយ ដែលវង្វេងខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីពិតនៅក្នុងលូកា ១៥ស្តីអំពីរបៀបដែលព្រះវរបិតាសួគ៌មានព្រះទ័យ អំពីអ្នកទាំងឡាយដែលវង្វេងខាងវិញ្ញាណ និងទំនួលខុសត្រូវដែលយើងមានចំពោះពួកគេ ។

ចូរសុំឲ្យសិស្សម្នាក់អាន លូកា ១៥:១–២ ឮៗ ។ ចូរអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលថានរណាបានខិតមកជិតនឹងព្រះយេស៊ូវ ហើយនឹងអ្វីដែលពួកផារិស៊ី និងពួកអាចារ្យបានរអ៊ូរទាំ ។

- តើនរណាបានខិតមកជិតនឹងព្រះអង្គសង្គ្រោះ ? ហេតុអ្វីក៏ពួកផារិស៊ី និង ពួកអាចារ្យរអ៊ូរទាំ ?
- តើការរអ៊ូរទាំនេះ បង្ហាញអំពីពួកផារ៉ាស៊ី និង ពួកអាចារ្យយ៉ាងណា ?

ចូរពន្យល់ថា ព្រះអង្គសង្គ្រោះ បានឆ្លើយតបដោយការប្រទាននូវរឿងប្រៀបធៀបចំនួនបី ៖ ចៀមមួយដែលបាត់ កាក់មួយដែលបាត់ និង កូនប្រុសម្នាក់ដែលវង្វេង ។ រឿងប្រៀបធៀបទាំងនេះមានន័យទាំងផ្តល់ក្តីសង្ឃឹមដល់មនុស្សមានបាប ក៏ដូចជាស្តីបន្ទោសដល់ភាពលាក់ពុត និងការលើកតំកើងខ្លួនឯងរបស់ពួកអាចារ្យ និង ពួកផារិស៊ី ។ ចូរលើកទឹកចិត្តដល់សិស្សឲ្យយកចិត្តទុកដាក់ទៅលើប្រធានបទនៃរឿងប្រៀបធៀបនីមួយៗ ថាហេតុអ្វីបានជាវាបាត់ និង របៀបដែលវារកឃើញវិញ ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬឲ្យវាទៅសិស្សទុកជាក្រដាសសម្រាប់ចែកឲ្យ។ សូមចាត់សិស្សជាគូៗ ហើយចាត់ឲ្យសិស្សម្នាក់សិក្សាលូកា ១៥:៣–៧ ហើយសិស្សផ្សេងទៀតឲ្យសិក្សាលូកា ១៥:៨–១០។ សូមអញ្ជើញសិស្សឲ្យអានរឿងប្រៀបធៀបដែលចាត់ទៅឲ្យពួកគេ ហើយរកមើលចម្លើយចំពោះសំណួរនៅក្នុងកូឡោនខាងឆ្វេង ។ (រឿងប្រៀបធៀបទីបី នឹងត្រូវប្រើនៅពេលក្រោយក្នុងមេរៀន) ។

រឿងប្រៀបធៀបអំពីចៀមដែលបាត់ កាក់ និង កូនប្រុស

	លូកា ១៥:៣–៧ ។	លូកា ១៥:៨–១០	លូកា ១៥:១១–៣២
តើបាត់អ្វី ?			
ហេតុអ្វីក៏វាបាត់ ?			
តើវារកឃើញដោយរបៀបណា ?			

	លូកា ១៥:៣–៧ ។	លូកា ១៥:៨–១០	លូកា ១៥:១១–៣២
តើពាក្យ ឬឃ្លាអ្វីខ្លះ ដែលពិពណ៌នាអំពីប្រតិកម្ម ដែលវាត្រូវបានរកឃើញវិញ ?			

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សពន្យល់អំពីរឿងប្រៀបធៀបដែលត្រូវបានចាត់ទៅឲ្យពួកគេ ហើយរាយការណ៍អំពីចម្លើយចំពោះសំណួរនៅក្នុងតារាងទៅដល់ដៃគូរបស់ពួកគេ ។ បន្ទាប់ពីសិស្សទាំងពីរនៅក្នុងក្រុមនីមួយៗបានបញ្ចប់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យមកឯក្តារខៀន ហើយបំពេញនៅក្នុងតារាងនូវចម្លើយរបស់ពួកគេ ឬ (ប្រសិនបើអ្នកពុំគូសតារាងនៅលើក្តារខៀន) ចែកចាយចម្លើយរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

- តើ ការបាត់ចៀម និងការបាត់កាក់មានភាពខុសគ្នាអ្វីខ្លះ ? (ចៀមបានវង្វេងចេញពីផ្លូវពុំមែនជាកំហុសរបស់វាទេ ខណៈដែលកាក់ត្រូវបានបាត់ ដោយសារតែភាពធ្វេសប្រហែស ឬការមិនយកចិត្តទុកដាក់របស់ម្ចាស់វាផ្ទាល់ [សូមមើល ដេវីឌ អូ មិកឃៃ នៅក្នុង Conference Report ខែ មេសា ឆ្នាំ ១៩៤៥ ទំព័រ ១២០, ១២១–២២]) ។
- យោងតាមខទី ៧និង១០តើកាក់ និង ចៀមដែលត្រូវបានរកឃើញតំណាងឲ្យអ្វី ? (វាតំណាងឲ្យមនុស្សមានបាបដែលបានប្រែចិត្ត ហើយបានត្រឡប់មករកព្រះវិញ) ។
- តើទំនួលខុសត្រូវរបស់យើងមានអ្វីខ្លះចំពោះអ្នកទាំងឡាយដែលវង្វេង ទោះជាពួកគេវង្វេងដោយរបៀបណាក្តីនោះ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងជួយអ្នកដទៃឲ្យមានបំណងប្រាថ្នាប្រែចិត្ត . . .*

- ផ្អែកទៅលើចម្លើយនៃអ្នកទាំងឡាយដែលបានរកឃើញនូវអ្វីដែលបានបាត់ តើអ្នកនឹងបញ្ចប់សេចក្តីថ្លែងការណ៍នៅលើក្តារខៀនយ៉ាងដូចម្តេច ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងជួយអ្នកដទៃឲ្យប្រាថ្នាចង់ប្រែចិត្ត នោះយើងនឹងទទួលអារម្មណ៍នៃក្តីអំណរ និងសេចក្តីអំណរនៃស្ថានសួគ៌ ។** ចូរបំពេញគោលការណ៍ដែលបានសរសេរនៅលើក្តារខៀន។ អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យពិចារណាធ្វើការសរសេរគោលការណ៍នេះ នៅក្នុងគម្ពីររបស់ពួកគេជិតនឹងលូកា ១៥:១–១០) ។
- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានជួយមនុស្សម្នាក់ដែលបានវង្វេងខាងវិញ្ញាណឲ្យមានបំណងប្រាថ្នាប្រែចិត្ត ឬខិតទៅកាន់តែជិតព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ? តើនរណាម្នាក់បានជួយដល់អ្នកនៅពេលណា ? (សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ឬ រឿងផ្ទាល់ខ្លួនខ្លាំងពេកនោះទេ ។)

លូកា ១៥:១១–៣២

ព្រះយេស៊ូវបានប្រទានរឿងប្រៀបធៀបអំពីកូនប្រុសខ្ជះខ្ជាយ

សូមអញ្ជើញសិស្សក្នុងថ្នាក់គិតពិចារណាអំពីស្ថានភាពដូចខាងក្រោម ៖ យុវនារីម្នាក់ បានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ ហើយបានឈប់អធិស្ឋាន និង ឈប់ចូលរួមក្នុងព្រះវិហារ ។ នាងមានប្រាថ្នាចង់ចាប់ផ្តើមអធិស្ឋាន និង រស់នៅតាមបទដ្ឋានរបស់ព្រះអម្ចាស់វិញ ប៉ុន្តែនាងបារម្ភថា ទ្រង់មិនចង់ឲ្យនាងត្រឡប់មកវិញ ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថាតើពួកគេស្គាល់នរណាម្នាក់ ដែលអាចនឹងមានអារម្មណ៍ដូចជាបុគ្គលនៅក្នុងស្ថានភាពនេះឬទេ ។ សូមពន្យល់ថា រឿងប្រៀបធៀបទីបីនៅក្នុងលូកា ១៥គឺជារឿងអំពីកូនប្រុសខ្ជះខ្ជាយ (មានន័យថា ជាមនុស្សម្នាក់ដែលបានចាយវាយយ៉ាងខ្ជះខ្ជាយ ហើយដោយឥតបើគិត) បងប្រុសរបស់គាត់ និង ឪពុករបស់ពួកគេ ។ ចូរអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅពេលពួកគេសិក្សារឿងប្រៀបធៀបនេះដែលអាចជួយបុគ្គលម្នាក់ៗដែលអាចមានអារម្មណ៍ថាពួកគេបានវង្វេងហើយគ្មានសង្ឃឹមថាអាចត្រឡប់មកវិញ ។

សូមពិចារណាបែងចែកសិស្សជាក្រុមដែលមានសមាជិកបីនាក់ ។ សូមឲ្យក្រុមនិមួយៗនូវច្បាប់ចម្លងមួយនូវឯកសារចែកចាយដូចខាងក្រោម ។ សូមអញ្ជើញពួកគេអានលូកា ១៥:១១–៣២ឲ្យឮៗនៅក្នុងក្រុមរបស់ពួកគេ ។ សូមចាត់សិស្សម្នាក់ឲ្យពិចារណាអំពីរឿងប្រៀបធៀបអំពីទស្សនវិស័យរបស់កូនប្រុសខ្ជះខ្ជាយ ហើយឲ្យសិស្សទីពីរពិចារណាអំពីទស្សនៈវិស័យរបស់ឪពុក និង សិស្សទីបីពិចារណាអំពីទស្សនៈវិស័យរបស់បងប្រុស ។

បន្ទាប់ពីសិស្សបានបញ្ចប់ការអាន ចូរសុំឲ្យពួកគេពិភាក្សាអំពីសំណួរនៅលើឯកសារដែលចែកឲ្យនៅក្នុងក្រុមរបស់ពួកគេ ។

ជំនួសឲ្យការសុំឲ្យសិស្សអាន និង ពិភាក្សាអំពីរឿងប្រៀបធៀប អ្នកអាចបង្ហាញវីដេអូ « The Prodigal Son » (៥:៣៥) ចេញមកពី *The Life of Jesus Christ Bible Videos* ។ សូមផ្តល់ដល់សិស្សម្នាក់ៗនូវឯកសារចែកចាយដូចខាងក្រោមមួយច្បាប់ ហើយសុំឲ្យសិស្សរកមើលចម្លើយនឹងសំណួរទាំងឡាយ នៅពេលពួកគេមើលវីដេអូ ។ វីដេអូនេះមាននៅក្នុង LDS.org ។

កិច្ចការក្រុមតូចៗ

អំឡុងពេលធ្វើកិច្ចការជាក្រុមតូចៗ សិស្សអាចត្រូវបាននាំខាងបង្ហែរចេញពីគោលបំណងរបស់សកម្មភាព ពីបញ្ហាផ្ទាល់ខ្លួន ឬ ក្លាយទៅជាមិនសូវយកចិត្តទុកដាក់ក្នុងកិច្ចខិតខំរបស់ពួកគេដើម្បីរៀន ។ សូមបន្តចូលរួមយ៉ាងសកម្ម ដោយការផ្លាស់ពីក្រុមមួយទៅក្រុមមួយទៀត ហើយពិនិត្យមើលសកម្មភាពនៃការរៀនសូត្រ ដើម្បីជួយសិស្សឲ្យផ្តោតយកចិត្តទុកដាក់ទៅលើកិច្ចការ និងទទួលបានលទ្ធផលច្រើនបំផុតមកពីកិច្ចការនោះ ។

រឿងប្រៀបធៀបអំពីកូនប្រុសខ្ជះខ្ជាយ

រឿងកូនប្រុសខ្ជះខ្ជាយ

- តើមានអ្វីខ្លះដែលបានជួយអ្នកភ្ញាក់ដឹងខ្លួន ឬទទួលស្គាល់ស្ថានភាពអាក្រក់ដែលអ្នកកំពុងស្ថិតនៅ ?
- តើអ្នករំពឹងឲ្យឪពុករបស់អ្នកធ្វើដូចម្តេចចំពោះការត្រឡប់មកផ្ទះវិញរបស់អ្នក ?
- តើអ្នកអាចនឹងគិត ហើយមានអារម្មណ៍យ៉ាងណា នៅពេលឪពុករបស់អ្នកប្រព្រឹត្តនឹងអ្នក ដូចជាគាត់បានធ្វើ ?

ឪពុក

- តើអ្នកអាចនឹងគិត ហើយមានអារម្មណ៍យ៉ាងណា ខណៈដែលកូនពៅរបស់អ្នកបានវង្វេងបាត់នោះ ?
- ហេតុអ្វីក៏អ្នកស្វាគមន៍កូនប្រុសខ្ជះខ្ជាយរបស់អ្នកត្រឡប់មកផ្ទះ តាមរបៀបដែលអ្នកធ្វើនោះ ?
- នៅពេលដែលកូនច្បងរបស់អ្នក អន់ចិត្តចំពោះរបៀបដែលអ្នកប្រព្រឹត្តនឹងប្អូនប្រុសរបស់គាត់ តើអ្នកបានជួយគាត់ឲ្យយល់អំពីសកម្មភាពរបស់អ្នកយ៉ាងដូចម្តេច ?

បងប្រុស

- តើអ្នកអាចនឹងគិត ហើយមានអារម្មណ៍យ៉ាងណា ខណៈដែលប្អូនប្រុសរបស់អ្នកបានវង្វេងបាត់នោះ ?
- ហេតុអ្វីក៏វាលំបាកចំពោះអ្នកដើម្បីរីករាយចំពោះការត្រឡប់មកវិញរបស់ប្អូនប្រុសអ្នក?
- តើមានពរជ័យអ្វីខ្លះ ដែលអ្នកបានទទួលចំពោះការមានភាពស្មោះត្រង់ចំពោះឪពុករបស់អ្នក ?

ចូរសួរសិស្សអំពីរបៀបដែលពួកគេនឹងបំពេញនៅក្នុងកូឡោនទីបី (លូកា ១៥:១១–៣២) នៃតារាងនៅលើក្តារខៀន ឬនៅលើក្រដាសចែកចាយដំបូងគេ ។ សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ឬអញ្ជើញសិស្សឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្រដាសចែកចាយរបស់ពួកគេ ។

- ហេតុអ្វីក៏កូនប្រុសខ្ជះខ្ជាយបានវង្វេង ? (ផ្ទុយគ្នាចំពោះរឿងចៀម និងកាក់ ពីរឿងកូនប្រុសខ្ជះខ្ជាយដែលបានវង្វេងដោយសារតែការបះបោររបស់គាត់ផ្ទាល់) ។
- កាលបានយល់ដឹងថាឪពុកនៅក្នុងរឿងប្រៀបធៀបនេះតំណាងឲ្យព្រះវរបិតាសួគ៌ តើយើងអាចរៀនអ្វីខ្លះអំពីរបៀបដែលព្រះវរបិតាសួគ៌បានឆ្លើយតបចំពោះអ្នកទាំងឡាយដែលត្រឡប់មករកទ្រង់ដោយការប្រែចិត្តនោះ ? (សិស្សគួររកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងត្រឡប់ទៅរកព្រះវរបិតាសួគ៌តាមរយៈការប្រែចិត្ត និងការស្វែងរកការអត់ទោសរបស់ទ្រង់ នោះទ្រង់នឹងរីករាយ ហើយស្វាគមន៍យើងឲ្យត្រឡប់មកក្នុងព្រះហស្តលាតត្រដាងរបស់ទ្រង់វិញ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើគោលការណ៍នេះអាចជួយអ្នកទាំងឡាយដែលមានអារម្មណ៍ថាបានវង្វេងខាងវិញ្ញាណយ៉ាងដូចម្តេច ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« នៅក្នុងរូបភាពដ៏ទន់ភ្លន់នៃភាពអន្ទះសារបស់ក្មេងប្រុសនេះ ឪពុកស្មោះត្រង់បានរត់ទៅជួបនឹងគាត់ ហើយការឱបថើបគាត់ គឺជាទិដ្ឋភាពដ៏រំជួលចិត្ត និង មានក្តីករុណាបំផុតមួយនៅក្នុងបទគម្ពីរទាំងអស់ ។ រឿងនេះប្រាប់ថា កូនទាំងអស់របស់ព្រះ ទាំងកូនដែលវង្វេងផ្លូវ ឬអ្វីផ្សេងទៀត ថាព្រះចង់ឲ្យយើងត្រឡប់ទៅរកព្រះហស្តការពាររបស់ទ្រង់ខ្លាំងប៉ុណ្ណា » («The Other Prodigal » *Ensign* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ៦២) ។

សូមរំឭកសិស្សអំពីបងច្បងនៅក្នុងរឿងប្រៀបធៀប ។

- ហេតុអ្វីក៏អ្នកគិតថាបងច្បងខឹង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលពីយោបល់ស្តីអំពីមូលហេតុដែលបងច្បងខឹង ៖



« កូនប្រុសរូបនេះពុំខឹងខ្លាំងដែលប្អូនប្រុសដែលបានមកផ្ទះវិញ ដូចជាគាត់ខឹងនឹងឪពុកម្តាយគាត់ដែលរីករាយយ៉ាងខ្លាំងអំពីរឿងនោះ ។ ចំពោះអារម្មណ៍ដែលថាគេពុំដឹងគុណ ហើយប្រហែលជាអាណិតខ្លួនឯងច្រើនបន្តិចនេះ កូនប្រុសដែលធ្វើកាតព្វកិច្ចរបស់គាត់នេះ—ហើយគាត់គឺជាអ្នកធ្វើកាតព្វកិច្ច*ដ៏អស្ចារ្យ*—បានភ្លេចអំពីគ្រាមួយ ដែលគាត់ពុំធ្លាប់ដឹងពីភាពអាក្រក់ ឬភាពអស់សង្ឃឹម ភាពភ័យខ្លាច ឬការស្អប់ខ្ពើមខ្លួនឯង ។ គាត់បានភ្លេចនូវគ្រាមួយដែលថាគោគ្រប់ក្បាលនៅក្នុងក្រោល ហើយក៏ដូចជាខោអាវក្នុងទូ និងចិញ្ចៀននៅក្នុងថតតុទាំងអស់ផងដែរ គឺជារបស់ផងគាត់ត្រូចទៅហើយនោះ ។ គាត់បានភ្លេចគ្រាមួយដែលភាពស្មោះត្រង់របស់គាត់បាន ហើយនឹងត្រូវបានផ្តល់រង្វាន់ជានិច្ច ។ . . .

គាត់ពុំទាន់មានចិត្តករុណា និង ក្តីមេត្តានៅឡើយទេ ដែលវាជាដង្ហើមនៃក្តីសប្បុរសធម៌នៃចក្ខុវិស័យដើម្បីមើលឃើញថា*នេះពុំមែនជាការត្រឡប់មកវិញដើម្បីប្រកួតប្រជែងនោះទេ* ។ នោះគឺជាប្អូនប្រុសរបស់គាត់ ។ . . .

« ច្បាស់ណាស់ ប្អូនប្រុសនេះ ធ្លាប់ជាអ្នកមានទោស—ជាអ្នកទោសនៃអំពើបាប ភាពល្ងិតល្ងង់ និង នៅក្នុងទ្រុងជ្រូក ។ ប៉ុន្តែបងប្រុសបានរស់ នៅក្នុងការជាប់ឃុំខ្លួនៗផងដែរ ។ ពីព្រោះ គាត់ពុំទាន់អាចដោះលែងខ្លួនគាត់ពីការជាប់ឃុំឃាំង ។ គាត់ត្រូវបានលងបន្លាច ដោយអស្ងរកាយក្អែកបៃតងនៃភាពច្រណែន » (« The Other Prodigal » ទំព័រ ៦៣) ។

- ស្របតាមអែលឌើរ ហូឡិន ហេតុអ្វីក៏បងប្រុសច្បងខឹង ?
- តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីចងចាំគ្រាដែលយើងមើលឃើញព្រះប្រកបដោយក្តីមេត្តាករុណា ហើយបានប្រទានពរដល់អ្នកទាំងឡាយដែលប្រែចិត្ត ហើយត្រឡប់មកទ្រង់វិញនោះ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីរឿងប្រៀបធៀបនេះ អំពីការប្រែក្លាយឲ្យកាន់តែដូចជាព្រះវរបិតាសួគ៌របស់យើង ? (សិស្សគួរឆកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **យើងអាចប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌របស់យើង ដោយការឆ្លើយតបដោយក្តីមេត្តាករុណា និង ក្តីអំណរ នៅពេលអ្នកដទៃប្រែចិត្ត**) ។

ចូរពិភាក្សាគោលការណ៍ដែលសិស្សបានរៀនមកពីរឿងប្រៀបធៀបនៅក្នុងលូកា ១៥ ។ ចូរសុំឲ្យសិស្សពន្យល់អំពីរបៀបដែលពួកគេអាចនឹងប្រើគោលការណ៍ទាំងនេះដើម្បីឆ្លើយតបចំពោះពួកផារិស៊ី និង ពួកអាចារ្យដែលបានរអ៊ូរទាំ នៅពេលព្រះយេស៊ូវបានទទួលទានជាមួយនឹង ពួកមនុស្សមានបាប ។

ចូរពិភាក្សាអំពីមនុស្សដែលពួកគេបានគិតដល់ នៅពេលចាប់ផ្តើមថ្នាក់ ដែលអាចនឹងវង្វេងខាងវិញ្ញាណ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យពិចារណាប្រកបដោយការអធិស្ឋានអំពីរបៀបដែលពួកគេអាចជួយមនុស្សនោះប្រែចិត្ត ហើយខិតមកកាន់តែជិតព្រះវរបិតាសួគ៌ ។ សូមអញ្ជើញពួកគេឲ្យសរសេរចម្លើយ ឆ្លើយនឹងសំណួរនេះចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើវិធីមួយដែលអ្នកនឹងអនុវត្តន៍នូវអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ គឺជាអ្វី ?

មេរៀន ៥៤

លូកា ១៦

សេចក្តីផ្តើម

ព្រះយេស៊ូវបានបង្រៀនពីរឿងប្រៀបធៀបនៃអ្នកត្រួតត្រាទុច្ចរិត ។ ពួកផារិស៊ី បានស្តាប់ឮការបង្រៀនរបស់ព្រះយេស៊ូវ ហើយបាននិះគន់ដល់ទ្រង់ ។ រួចមកព្រះយេស៊ូវបានស្តីបន្ទោសពួកផារិស៊ី ហើយបានបង្រៀនពួកគេអំពីរឿងប្រៀបធៀបនៃអ្នកមាន និង សាឡា ។

យោបល់សម្រាប់ការបង្រៀន

លូកា ១៦:១–១២

ព្រះយេស៊ូវបង្រៀនរឿងប្រៀបធៀបនៃអ្នកត្រួតត្រាទុច្ចរិត ។

ចូរពិចារណាធ្វើការនាំយកវត្ថុខ្លះមកថ្នាក់រៀន ដែលអាចតំណាងឲ្យទ្រព្យសម្បត្តិ និង អំណាចខាងលោកិយ ដូចជាលុយ ឧបករណ៍អេឡិចត្រូនិច សញ្ញាបត្រ ឡានជិះ ឬរូបភាពផ្ទះមួយខ្នង ។

សូមចាប់ផ្តើមមេរៀននេះដោយសួរ ៖

- តើវត្ថុមួយចំនួនណាខ្លះ ដែលមនុស្សជាញឹកញាប់បានដាក់ដួងចិត្តរបស់ខ្លួនទៅលើវានោះ ហើយព្យាយាមចង់បានវានោះ ? (ប្រសិនបើអ្នកនាំយកវត្ថុទាំងឡាយមកថ្នាក់រៀន សូមដាក់តាំងវាពេលសិស្សប្រាប់អំពីវត្ថុទាំងនោះ ។ បើមិនដូច្នោះទេ ចូរសុំឲ្យសិស្សម្នាក់សរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន) ។
- តើទ្រព្យមួយចំនួនដែលព្រះវរបិតាសួគ៌ចង់ឲ្យយើងស្វែងរក មានអ្វីខ្លះ ? (សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរនៅលើក្តារខៀននូវចម្លើយរបស់សមាជិកក្នុងថ្នាក់ ដែលអាចនឹងរួមមាន គ្រួសារអស់កល្បជានិច្ច ភាពសុខសាន្ត សេចក្តីអំណរ និងសិរីល្អសេឡេស្ទាល ។ សូមណែនាំសិស្សឲ្យសរសេរក្បាលរឿង*ទ្រព្យដ៏អស់កល្បជានិច្ច*នៅខាងលើបញ្ជី) ។

សូមចង្អុលបង្ហាញថា យើងអាចរីករាយនឹងទ្រព្យទាំងនេះអស់កល្បជានិច្ច មួយចំនួនទាំងនេះនៅក្នុងជីវិតនេះ ។ ចូរសុំឲ្យសិស្សពិចារណាអំពីទ្រព្យអស់កល្បជានិច្ចណាមួយ ដែលពិតជាសំខាន់ចំពោះពួកគេ ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតទាំងឡាយនៅពេលពួកគេសិក្សាលូកា ១៦ដែលអាចជួយពួកគេទទួលបានទ្រព្យដ៏អស់កល្បជានិច្ច ។

សូមពន្យល់ថា បន្ទាប់ពីការបង្រៀនរឿងប្រៀបធៀបអំពីចៀមដែលបាត់ កាក់ដែលបាត់ និង កូនប្រុសខ្លះខ្លាយ នោះព្រះអង្គសង្គ្រោះបានបង្រៀនរឿងប្រៀបធៀបអំពីអ្នកត្រួតត្រាទុច្ចរិត ។ អ្នកអាចនឹងចង់ពន្យល់ថា អ្នកត្រួតត្រាម្នាក់ គឺជាមនុស្សម្នាក់ដែលគ្រប់គ្រងលើកិច្ចការអាជីវកម្ម ប្រាក់ ឬទ្រព្យសម្បត្តិរបស់មនុស្សម្នាក់ទៀត ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១៦:១–២ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលបុរសអ្នកមាននៅក្នុងរឿងប្រៀបធៀបនេះបានរៀនអំពីការត្រួតត្រារបស់គាត់ ។

- តើអ្នកត្រួតត្រាបានធ្វើអ្វីខ្លះ ជាមួយនឹងទ្រព្យរបស់បុរសអ្នកមាន ?
- តើលទ្ធផលនៃភាពខ្ជះខ្ជាយរបស់អ្នកត្រួតត្រាគឺជាអ្វី ? (គាត់នឹងបាត់បង់ការងារ) ។

សូមសង្ខេបលូកា ១៦:៣–៧ដោយពន្យល់ថា អ្នកត្រួតត្រាបារម្ភអំពីអ្វីដែលគាត់នឹងធ្វើ នៅពេលគាត់បាត់បង់ការងាររបស់គាត់ ដោយសារតែគាត់ពុំមានអារម្មណ៍ថា គាត់អាចធ្វើការដោយកម្លាំងដៃ ហើយខ្ចាស់រៀនខ្លាំងដើម្បីសុំទានគេ ។ គាត់បានរៀបចំផែនការមួយ ដែលគាត់បានគិតថា វាអាចនាំទៅរកឱកាសការងារក្នុងផ្ទះផ្សេងទៀត ។ គាត់បានទៅជួបនឹងអ្នកជំពាក់បំណុលពីរនាក់របស់អ្នកមាន ហើយបានបញ្ចុះថ្លៃបំណុលរបស់ពួកគេនោះយ៉ាងច្រើន ដែលគាត់សង្ឃឹមថា នឹងទទួលបានការពេញចិត្តពីពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១៦:៨ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវរបៀបដែលបុរសអ្នកមានបានឆ្លើយតប នៅពេលគាត់បានដឹងអំពីទង្វើរបស់អ្នកត្រួតត្រាខ្លួននោះ ។ ចូរពន្យល់ថា «មនុស្សរបស់ផងលោកីយ៍នេះ » គឺជាមនុស្សចេះតែគិតអំពីទ្រព្យខាងលោកិយ ហើយថា « មនុស្សរបស់ផងពន្លឺ » គឺជាអ្នកដើរតាមព្រះ ឬចេះតែគិតអំពីទង្វើខាងវិញ្ញាណ ។

- តើបុរសអ្នកមានឆ្លើយតបយ៉ាងដូចម្តេច ពេលគាត់បានដឹងអំពីសកម្មភាពរបស់អ្នកត្រួតត្រា ? តើអ្វីខ្លះ ដែលបុរសអ្នកមានបានសរសើរ? (បុរសអ្នកមានបានសរសើរអំពីភាពវៃឆ្លាតរបស់អ្នកត្រួតត្រា នៅក្នុងការទទួលយកការពេញចិត្តរបស់កូនបំណុលរបស់បុរសអ្នកមាន) ។ គាត់ពុំបានសរសើរដល់ភាពមិនស្មោះត្រង់របស់អ្នកត្រួតត្រានោះទេ) ។

ចូរផ្តល់ឲ្យសិស្សនូវច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដេម អឹ ថាលម៉ែហ្គុង ក្នុរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍នេះឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះកំពុងតែបានបង្រៀន តាមរយៈរឿងប្រៀបធៀបអំពីអ្នកត្រួតត្រាទុច្ចរិត ។



« ព្រះរាជបំណងរបស់ព្រះអម្ចាស់យើង គឺដើម្បីបង្ហាញពីភាពផ្ទុយគ្នារវាងការយកចិត្តទុកដាក់ ការចេះគិតគូ និង ការលះបង់របស់មនុស្ស ដែលជាប់ទាក់ទងនៅក្នុងកិច្ចការរកប្រាក់កាសចូលនៃលោកិយ ហើយមនុស្សជាច្រើនដែលមានដួងចិត្តស្ងាត់ស្ងើរកំពុងអះអាងថាខ្លួន កំពុងតែព្យាយាមស្វែងរកទ្រព្យខាងវិញ្ញាណវិញ ។ . . .

« . . . ការរៀនមេរៀនមួយមកពីមនុស្សមិនស្មោះត្រង់ និងមនុស្សអាក្រក់ ប្រសិនបើពួកគេឆ្លាតវៃខ្លាំង ក្នុងការផ្តល់តែនូវអ្វីដែលពួកគេគិតនាពេលអនាគត នោះតើអ្នកដែលជាអ្នកជឿទៅលើអនាគតដ៏អស់កល្បជានិច្ច គប្បីត្រៀមខ្លួនកាន់តែច្រើនប្រសើរជាងនេះប៉ុណ្ណាទៀតទៅ ! . . . លើកតម្កើងអ្នកត្រួតត្រាទុច្ចរិត និងអ្នកស្រឡាញ់ទ្រព្យសម្បត្តិ ពុំមែនប្រដូចនឹងភាពមិនស្មោះត្រង់ ការលោភលន់ [ការលោភលន់អត្មានិយម] និងការចង់បានទ្រព្យរបស់ពួកគេយ៉ាងហោចណាស់គ្រាន់តែជាទង្វើដែលនឹងផ្លាស់ប្តូរ [ជាបណ្តោះអាសន្ន] ប្រដូចនៅក្នុងថាមពល ការគិតទុកជាមុន ហើយការផ្គត់ផ្គង់សម្រាប់អនាគតរបស់ពួកគេវិញទេតើ » (*Jesus the Christ,* កំណែទី៣. [ឆ្នាំ ១៩១៦] ទំព័រ ៤៦៣, ៤៦៤) ។

- តើព្រះអង្គសង្គ្រោះចង់ឲ្យពួកសិស្សរបស់ទ្រង់រៀនអ្វីខ្លះ មកពីមនុស្សដែលចេះតែគិតអំពីទ្រព្យខាងលោកិយដែលប្រៀបប្រដូចទៅនឹងអ្នកត្រួតត្រាទុច្ចរិតនោះ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងរៀបចំខ្លួនដោយឈ្លាសវៃសម្រាប់អនាគតដ៏អស់កល្បជានិច្ចរបស់យើង . . .*

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១៦:១០–១២ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា យើងត្រូវតែធ្វើ ដើម្បីត្រូវបានប្រទានពរនូវជីវិតអស់កល្បជានិច្ចដ៏បរិបូរណ៍ ។ សូមពន្យល់ថា*ទ្រព្យសម្បត្តិ*សំដៅទៅលើទ្រព្យសម្បត្តិខាងលោកិយ រួមមានទាំង ប្រាក់ ទ្រព្យធន និងទំនាក់ទំនង ។

- តើអ្នកគិតថាវាមានន័យយ៉ាងណាដើម្បី « ស្មោះត្រង់ក្នុងការតូចបំផុត » (ខទី ១០) ? (ក្រោយពីសិស្សឆ្លើយតបហើយ សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្តារខៀន ៖ *ហើយប្រើទ្រព្យលើដែនដីដោយសុចរិត. . .*)

សូមបង្ហៀរចំណាប់អារម្មណ៍របស់សិស្សលើបញ្ជីនៃទ្រព្យសម្បត្តិដ៏អស់កល្បជានិច្ចនៅលើក្តារខៀន ។

- តើអ្វីដែលធ្វើឲ្យអ្វីទាំងនេះជា « សម្បត្តិដ៏ពិត » (ខទី ១១) ?

ចូរសុំឲ្យសិស្សបញ្ចប់សេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដើម្បីវាបង្កើតគោលការណ៍មួយអំពីរបៀបដែលយើងអាចទទួលបានទ្រព្យសម្បត្តិដ៏អស់កល្បជានិច្ច ។ (សិស្សគួរតែរកឃើញគោលលទ្ធិដូចតទៅនេះ ៖ **ប្រសិនបើយើងរៀបចំខ្លួនដោយឈ្លាសវៃសម្រាប់អនាគតដ៏អស់កល្បជានិច្ចរបស់យើង ហើយប្រើទ្រព្យខាងលោកិយដោយសុចរិត នោះយើងអាចត្រូវបានប្រទានពរនូវទ្រព្យសម្បត្តិខាងលោកិយ**) ។

- ហេតុអ្វីក៏ពេលខ្លះវាពិបាកដើម្បីរៀបចំខ្លួនសម្រាប់អនាគតដ៏អស់កល្បជានិច្ចរបស់យើងដោយឈ្លាសវៃ និង ឧស្សាហ៍ព្យាយាមដូច្នេះ ?
- តើយើងអាចប្រើទ្រព្យសម្បត្តិខាងលោកិយដោយសេចក្តីសុចរិតយ៉ាងដូចម្តេច ?
- តើការប្រើទ្រព្យខាងលោកិយដោយសុចរិតរបស់យើង ឆ្លុះបញ្ចាំងអំពីភាពសក្តិសមរបស់យើងដើម្បីត្រូវបានទុកចិត្តជាមួយនឹងទ្រព្យដ៏អស់កល្បជានិច្ចយ៉ាងដូចម្តេច ?

សូមទទួលស្គាល់ចម្លើយរបស់សិស្សដោយវិជ្ជមាន

សូមប្រាកដថាទទួលស្គាល់ដោយវិជ្ជមានចំពោះចម្លើយរបស់សិស្សតាមរបៀបផ្សេងៗ ដោយអរគុណ ឬសរសើរចំពោះចម្លើយរបស់ពួកគេ ។ ការធ្វើដូច្នេះនឹងជួយសិស្សឲ្យមានអារម្មណ៍ថាពួកគេត្រូវបានស្តាប់ ហើយបានបញ្ជាក់ និង អាចជួយពួកគេមានអារម្មណ៍កាន់តែកក់ក្តៅក្នុងការចែកចាយចម្លើយ គំនិត និង បទពិសោធន៍នៅពេលខាងមុខៗ ។

លូកា ១៦:១៣–៣១

ព្រះយេស៊ូវស្តីបន្ទោសពួកផារិស៊ី ហើយបង្រៀនអំពីរឿងប្រៀបធៀបនៃអ្នកមាន និង សាឡា ។

សូមនាំសិស្សឲ្យចាប់អារម្មណ៍ទៅលើបញ្ជីនៅលើក្តារខៀន (ឬ ប្រសិនបើអ្នកនាំពួកគេឲ្យចាប់អារម្មណ៍នឹងវត្ថុ ដែលតំណាងឲ្យទ្រព្យខាងលោកិយ) ហើយសុំពួកគេឲ្យពិចារណាអំពីរបៀបដែលការលោភលន់ចង់បានទ្រព្យខាងលោកិយ អាចរារាំងយើងមិនឲ្យទទួលបានទ្រព្យដ៏អស់កល្បជានិច្ច ។ សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយចំពោះសំណួរនេះនៅពេលពួកគេសិក្សាលូកា ១៦:១៣–២៦ ។

សូមសង្ខេបលូកា ១៦:១៣–១៤ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនថា យើង « មិនអាចបម្រើព្រះផងទ្រព្យសម្បត្តិផងបានទេ » (ខទី ១៣) ។ ពួកផារិស៊ីបានស្តាប់ពាក្យបង្រៀនរបស់ព្រះអង្គសង្គ្រោះ ហើយ « បានចំអក » (ខទី ១៤) ឬរិះគន់ដល់ទ្រង់ ។ ចូរសុំឲ្យសិស្សស្វែងរកនៅក្នុងលូកា ១៦:១៤ នូវពាក្យដែលពិពណ៌នាអំពីពួកផារិស៊ី ហើយផ្តល់នូវការពន្យល់មួយ អំពីមូលហេតុពួកគេបានរិះគន់ដល់ព្រះអង្គសង្គ្រោះចំពោះការបង្រៀនរបស់ទ្រង់ ។

- ចេញមកពីអ្វីដែលអ្នកបានរៀនអំពីពួកផារិស៊ី តើពួកគេលោភលន់ចង់បានអ្វី ? (ទ្រព្យសម្បត្តិ និង អំណាចខាងលោកិយ [សូមមើលម៉ាថាយ ២៣:២–៦, ១៤]) ។
- ហេតុអ្វីក៏អ្នកគិតថា ភាពលោភលន់របស់ពួកផារិស៊ី បានបណ្តាលឲ្យពួកគេរិះគន់ដល់ព្រះអង្គសង្គ្រោះដូច្នេះ ?

ចូរពន្យល់ថា ការបកប្រែរបស់យ៉ូសែប ស៊្មីធ អំពីលូកា ១៦:១៦–២៣ (នៅក្នុងសេចក្តីបន្ថែមក្នុងព្រះគម្ពីរប៊ីប) ផ្តល់នូវគំនិតសឺីជម្រៅបន្ថែមទៅលើការផ្ទាស់ប្តូររវាងពួកផារិស៊ី និង ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីសង្ខេបនៃការបកប្រែនេះដូចខាងក្រោម ៖

ពួកផារិស៊ីបានប្រកាសថា ក្រឹត្យវិន័យរបស់ម៉ូសេ និងបទគម្ពីរដែលបានព្យាករដទៃទៀត (គម្ពីរសញ្ញាចាស់) បានបម្រើជាច្បាប់របស់ពួកគេ ហើយពួកគេបានបដិសេធព្រះយេស៊ូវថាជាចៅក្រមរបស់ពួកគេឡើយ ។ ព្រះយេស៊ូវបានពន្យល់ថា ក្រឹត្យវិន័យរបស់ម៉ូសេ និងពួកព្យាការី បានថ្លែងទីបន្ទាល់អំពីទ្រង់ ។ ទ្រង់បានចោទសួរដល់ពួកផារិស៊ីចំពោះការបដិសេធនូវអ្វីដែលបានសរសេរទុក ហើយបានបន្ទោសពួកគេចំពោះ « បង្ខូចផ្លូវត្រង់ » (ការបកប្រែរបស់យ៉ូសែប ស៊្មីធ លូកា ១៦:២១) ។ ដើម្បីជួយពួកផារិស៊ី ដែលបានដាក់ដួងចិត្ត

របស់ពួកគេលើទ្រព្យខាងលោកិយ និង អំណាច ឲ្យយល់ពីឥរិយាបថ និង ផលវិបាករបស់ពួកគេចំពោះរឿងនោះ៖ នោះព្រះអង្គសង្គ្រោះបានប្រៀបប្រដូចពួកគេទៅនឹងមនុស្សអ្នកមាន នៅក្នុងរឿងប្រៀបធៀបដែលបានកត់ត្រានៅក្នុងលូកា ១៦:១៩–៣១។

ចូរសុំឲ្យអ្នកស្ម័គ្រចិត្តបីនាក់ចូលរួមនៅក្នុងការអានរឿង ។ សូមចាត់អ្នកស្ម័គ្រចិត្តម្នាក់ឲ្យអានព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ (លូកា ១៦:១៩–២៣) អ្នកស្ម័គ្រចិត្តទីពីរឲ្យអានពាក្យសម្តីរបស់បុរសអ្នកមាន (លូកា ១៦:២៤, ២៧, ២៨, ៣០) ហើយអ្នកស្ម័គ្រចិត្តទីបីដើម្បីអានពាក្យសម្តីរបស់អ័ប្រាហាំ (លូកា ១៦:២៥, ២៦, ២៩, ៣១) ។ សូមណែនាំដល់សិស្សទាំងនេះ ឲ្យអានឮៗនូវចំណែករបស់ពួកគេនៅក្នុងលូកា ១៦:១៩–២៦។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សំៀងតាម រកមើលនូវអ្វីដែលបុរសក្រីក្រម្នាក់ឈ្មោះ ឡាសា និង បុរសអ្នកមានម្នាក់បានជួបប្រទះ ។

- តើជីវិតរមែងស្លាប់នៃបុរសអ្នកមាន និង ឡាសាមានភាពខុសគ្នាយ៉ាងដូចម្តេច ?
- តើជីវិតបន្ទាប់ពីជីវិតរមែងស្លាប់របស់ពួកគេខុសគ្នាយ៉ាងដូចម្តេច ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា « ដើមទ្រូងរបស់អ័ប្រាហាំ » [ខទី ២២] តំណាងឲ្យស្ថានបរមសុខ នៅក្នុងពិភពវិញ្ញាណ ហើយថា « ស្ថាននរក » [ខទី ២៣] សំដៅទៅលើស្ថានឃុំព្រលឹង [សូមមើល Bible Dictionary« Abraham's Bosom » « Hell »]) ។
- តើតាមរបៀបណា ដែលបុរសអ្នកមានបរាជ័យក្នុងការប្រើទ្រព្យសម្បត្តិខាងលោកិយរបស់គាត់ដោយសុចរិត ?

សូមរំឭកសិស្សថា បុរសអ្នកមាននៅក្នុងរឿងប្រៀបធៀបនេះ តំណាងឲ្យពួកផារិស៊ីដែលមានចិត្តលោភលន់ ។

- តើយើងអាចរៀនអ្វីខ្លះមករឿងប្រៀបធៀបនេះ អំពីអ្វីដែលនឹងកើតឡើង ប្រសិនបើយើងមានចិត្តលោភលន់ ហើយពុំប្រើទ្រព្យសម្បត្តិខាងលោកិយរបស់យើងដោយសុចរិតនោះ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងលោភលន់ ហើយពុំប្រើទ្រព្យលើផែនដីរបស់យើងដោយសុចរិត នោះទីបំផុតយើងនឹងទទួលបទពិសោធន៍ការរងទុក្ខ និង វិប្បដិសារី** [សូមមើលផងដែរ គ និង ស ១០៤:១៨]) ។

ដើម្បីរៀបចំសិស្សឲ្យសំគាល់រកនូវសេចក្តីពិតបន្ថែមមកពីរឿងប្រៀបធៀបនេះ៖ សូមអញ្ជើញពួកគេឲ្យគិតអំពីនរណាម្នាក់ ដែលគេយកចិត្តទុកដាក់ ដែលកំពុងតែរស់នៅដោយមិនគោរពតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ។

- តើអ្នកគិតថាអ្វីខ្លះ ដែលអាចបញ្ចុះបញ្ចូលមនុស្សនោះឲ្យប្រែចិត្ត ហើយផ្លាស់ប្តូរជីវិតរស់នៅរបស់គេបាន ?

សូមអញ្ជើញសិស្សដែលបានចាត់តាំងនោះឲ្យអានផ្នែករបស់ពួកគេនៅក្នុងលូកា ១៦:២៧–៣១ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្សំៀងតាមរកមើលសំណើររបស់បុរសអ្នកមាន ។

- តើបុរសអ្នកមានចង់ធ្វើដូចម្តេចសម្រាប់បុរសទាំងប្រាំនេះ ? ហេតុអ្វី ?
- តើបុរសអ្នកមានជឿថា អ្វីខ្លះនឹងកើតឡើង បើឡាសាបានលេចមកបងប្អូនប្រុសរបស់អ្នកមាន ?

ចូរពន្យល់ថា បុរសអ្នកមានបានជឿថា បងប្អូនរបស់គាត់នឹងប្រែចិត្ត ហើយបានផ្លាស់ប្រែចិត្តចំពោះសេចក្តីពិត ប្រសិនបើឡាសាបានលេចមកឯពួកគេ ។ ការប្រែចិត្តជឿ គឺ « ជាការប្រែជំនឿ ចិត្ត និងជីវិតរបស់មនុស្សម្នាក់ ដើម្បីទទួលយក ហើយធ្វើឲ្យបានស្របតាមព្រះហឫទ័យនៃព្រះ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ប្រែចិត្តជឿ, ការប្រែចិត្តជឿ, អ្នកប្រែចិត្តជឿ » ,scriptures.lds.org) ។

- ស្របតាមរឿងប្រៀបធៀប ហេតុអ្វីក៏អ័ប្រាហាំមិនបញ្ជូនឡាសាឲ្យទៅបងប្អូនប្រុសរបស់អ្នកមាន ?

ចូរចង្អុលបង្ហាញថា ដោយការប្រាប់ថា « ម៉ូសេ និង ពួកព្យាការី » (លូកា ១៦:២៩, ៣១) ព្រះអង្គសង្គ្រោះបានយោងបទគម្ពីរម្តងទៀតថា ពួកផារិស៊ីបានប្រកាសអះអាងថាជឿ ហើយរស់នៅតាម តែតាមពិតបានបដិសេធ ។ ចូរពន្យល់ថា មានមនុស្សម្នាក់ ដែលមានឈ្មោះ ឡាសា ពិតដែលក្រោយមកបានក្លាយទៅជា « មនុស្សម្នាក់ [ដែល] រស់ពីស្លាប់ឡើងវិញ » (ខទី ៣១) នៅពេលព្រះអង្គសង្គ្រោះបានប្រោសជីវិតដល់គាត់ឲ្យរស់ឡើងវិញ (សូមមើលយ៉ូហាន ១១) ។ ក្រោយមក ព្រះយេស៊ូវបានក្លាយទៅជាអង្គដែលបានរស់ឡើងវិញពីការសុគត ពេលទ្រង់ត្រូវបានរស់ឡើងវិញ ។ នៅក្នុងឧទាហរណ៍ទាំងពីរ ទោះជាយ៉ាងណាក៏ដោយ ពួកផារិស៊ី និង អ្នកដទៃទៀត បានបដិសេធភស្តុតាងដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ ហើយពុំបានបញ្ចុះបញ្ចូលឲ្យប្រែចិត្តទេ ។

- តើសេចក្តីពិតអំពីការផ្លាស់ប្រែចិត្តជឿអ្វីខ្លះ ដែលយើងអាចរៀនពីអ្វីដែលអ័ប្រាហាំបានបង្រៀនអំពីបុរសអ្នកមាន នៅក្នុងរឿងប្រៀបធៀបនេះ ? (សិស្សអាចនឹងប្រាប់ពីសេចក្តីពិតផ្សេង ៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេស្គាល់គោលលទ្ធិដូចខាងក្រោមនេះ ៖ **ការផ្លាស់ប្រែចិត្តជឿកើតមានតាមរយៈការជឿ និង ការស្តាប់តាមពាក្យសម្តីរបស់ពួកព្យាការី ពុំមែនតាមរយៈការមើលឃើញអព្ភូតហេតុ ឬមើលឃើញពួកទេវតានោះទេ**) ។
- ហេតុអ្វីក៏អ្នកគិតថា ការផ្លាស់ប្រែចិត្តជឿកើតមានតាមរយៈការជឿ និង ការស្តាប់តាមពាក្យសម្តីរបស់ពួកព្យាការី ជាជាងតាមរយៈការមើលឃើញអព្ភូតហេតុ ឬការមើលឃើញពួកទេវតាដូច្នេះ ?
- តើយើងអាចជួយដល់មនុស្សដែលជឿ ហើយស្តាប់តាមពាក្យសម្តីរបស់ពួកព្យាការីយ៉ាងដូចម្តេច ?
- តើការបង្រៀនជាក់លាក់មកពីពួកព្យាការីអ្វីខ្លះ មានឥទ្ធិពលលើការផ្លាស់ប្រែចិត្តជឿរបស់អ្នក ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបដែលពួកគេអាចជឿ ឬស្តាប់នូវការបង្រៀន ឬដំបូន្មានជាក់លាក់មកពីពួកព្យាការីបានកាន់តែល្អប្រសើរ ដែលបានជួយពង្រឹងដល់ការផ្លាស់ប្រែចិត្តជឿរបស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តតាមអ្វីដែលពួកគេបានសរសេរ ។

លូកា ១៧

សេចក្តីផ្តើម

ព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់អំពីតម្រូវការដើម្បីអភ័យទោសអ្នកដទៃ ។ បន្ទាប់មក ពួកសាវកបានសូមឲ្យព្រះយេស៊ូវបង្កើនសេចក្តីជំនឿរបស់ពួកគេ ។ ក្នុងការឆ្លើយតប ព្រះអង្គសង្គ្រោះបានបង្រៀនពួកគេនូវរឿងប្រៀបធៀបអំពីបាវត់គប្រយោជន៍ ។ ក្រោយមក ព្រះយេស៊ូវបានព្យាបាលមនុស្សឃ្លង់ដប់នាក់ ប៉ុន្តែមានតែម្នាក់គត់ដែលបានត្រឡប់មកថ្លែងអំណរគុណទ្រង់ ។ ព្រះអង្គសង្គ្រោះបានប្រឈមនឹងពួកផារិស៊ី ហើយទ្រង់បានបង្រៀនអំពីការមកដល់នៃនគររបស់ព្រះ ។

សូមផ្តោតទៅលើការជួយសិស្សឲ្យបំពេញតួនាទីរបស់ពួកគេ

នៅពេលអ្នករៀបចំមេរៀននីមួយៗ សូមបន្តផ្តោតទៅលើតួនាទីរបស់សិស្សនៅក្នុងថ្នាក់ ហើយពុំត្រឹមតែផ្តោតលើអ្វីដែលអ្នកនឹងធ្វើនៅក្នុងថ្នាក់ឡើយ ។ ជាជាងគ្រាន់តែសួរថា « តើខ្ញុំនឹងធ្វើអ្វីខ្លះនៅក្នុងថ្នាក់ថ្ងៃនេះ ? » ឬ « តើខ្ញុំនឹងបង្រៀនសិស្សរបស់ខ្ញុំអ្វីខ្លះ? » អ្នកគប្បីគិតផងដែរពេលរៀបចំមេរៀនថា « តើសិស្សរបស់ខ្ញុំនឹងធ្វើអ្វីខ្លះនៅក្នុងថ្នាក់ថ្ងៃនេះ ? » « តើខ្ញុំនឹងជួយសិស្សរបស់ខ្ញុំឲ្យរកឃើញនូវអ្វី ដែលពួកគេត្រូវដឹងបានយ៉ាងដូចម្តេច ? »

យោបល់សម្រាប់ការបង្រៀន

លូកា ១៧:១–១០

ពួកសាវកបានសូមឲ្យព្រះយេស៊ូវបង្កើនសេចក្តីជំនឿរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីស្ថានភាពជាក់លាក់ដែលអាចនឹងតម្រូវឲ្យពួកគេអនុវត្តសេចក្តីជំនឿ (ដូចជាការស្វែងរកពរជ័យបព្វជិតភាព បង់ដង្វាយមួយភាគក្នុងដប់ ឬផ្តល់ការឡើងនិយាយ ឬមេរៀននៅព្រះវិហារ) ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់រាយការណ៍ពីអ្វីដែលពួកគេបានគិតពិចារណា ហើយកត់ត្រាចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងាត់ៗនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្លាប់ចង់បានសេចក្តីជំនឿកាន់តែខ្លាំងឬទេ ? ប្រសិនបើដូច្នោះ តើបទពិសោធន៍អ្វីខ្លះដែលបានធ្វើឲ្យអ្នកមានអារម្មណ៍បែបនេះ ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍ទាំងឡាយ នៅពេលពួកគេសិក្សាលូកា ១៧ដែលអាចជួយពួកគេបង្កើនសេចក្តីជំនឿរបស់ពួកគេ ។

សូមសង្ខេបលូកា ១៧:១–២ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានព្រមានថា អ្នកទាំងឡាយណាដែលដឹកនាំអ្នកដទៃឲ្យវង្វេង ឬបញ្ឆះបញ្ឆូលពួកគេឲ្យធ្វើបាប នឹងទទួលខុសត្រូវ ។

សូមអញ្ជើញសិស្សឲ្យអានលូកា ១៧:៣–៤ដោយស្ងាត់ៗ រកមើលបញ្ញត្តិមួយ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់ពួកសិស្សរបស់ទ្រង់ដែលនឹងតម្រូវឲ្យមានសេចក្តីជំនឿ ។

- យោងតាមខទី ៣តើព្រះយេស៊ូវបញ្ជាដល់ពួកសិស្សរបស់ទ្រង់ឲ្យធ្វើអ្វីខ្លះ ប្រសិនបើមាននរណាម្នាក់បានធ្វើខុសនឹងពួកគេ ?
- យោងតាមខទី ៤តើពួកសិស្សត្រូវអភ័យទោសញឹកញាប់ប៉ុណ្ណា ? (សូមគិតធ្វើការពន្យល់ថា ចម្លើយរបស់ព្រះអង្គសង្គ្រោះ គឺជារបៀបមួយដែលយើងគប្បីអភ័យទោស មិនថាច្រើនដងប៉ុណ្ណា ដល់នរណាម្នាក់ធ្វើខុសនឹងយើង ដែលបានប្រែចិត្តនោះទេ) ។
- ហេតុអ្វីក៏វាពិបាកដើម្បីអភ័យទោសដល់នរណាម្នាក់ដែលបានធ្វើខុសនឹងយើងដដែលៗនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១៧:៥ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលពួកសាវកប្រាថ្នាចង់បានពីព្រះអង្គសង្គ្រោះ បន្ទាប់ពីទ្រង់បានប្រាប់ដល់ពួកសិស្សឲ្យអភ័យទោសដល់អ្នកទាំងឡាយដែលបានធ្វើឲ្យពួកគេអាក់អន់ចិត្ត ។

- តើពួកសាវកប្រាថ្នាចង់បានអ្វីខ្លះពីព្រះអង្គសង្គ្រោះ ? (អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « បង្កើនសេចក្តីជំនឿរបស់យើង » នៅក្នុងព្រះគម្ពីររបស់ពួកគេ ។
- តើការស្វែងរកសេចក្តីជំនឿកាន់តែខ្លាំងទៅលើព្រះអម្ចាស់ អាចនឹងជួយដល់ពួកសាវកឲ្យគោរពតាមបទបញ្ញត្តិដើម្បីអភ័យទោសដល់អ្នកដទៃយ៉ាងដូចម្តេច ?

សូមសង្ខេបលូកា ១៧:៦ដោយពន្យល់ថាក្រោយមក ព្រះអង្គសង្គ្រោះ បានបង្រៀនដល់ពួកសាវករបស់ទ្រង់ថា សេចក្តីជំនឿមានទំហំតូចប៉ុនគ្រាប់ពូជមួយគ្រាប់ អាចធ្វើឲ្យមានអព្ភូតហេតុ ។ ដើម្បីជួយពួកសាវកឲ្យដឹងអំពីរបៀបដើម្បីបង្កើនសេចក្តីជំនឿរបស់ពួកគេ នោះព្រះយេស៊ូវបានប្រទានរឿងប្រៀបធៀប ពិពណ៌នាអំពីទំនាក់ទំនងរបស់ចៅហ្វាយ និងអ្នកបម្រើម្នាក់ ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *សេចក្តីជំនឿរបស់យើងនឹងកើនឡើងនៅពេលយើង . . .*

សូមអញ្ជើញឲ្យសិស្សមួយចំនួនតូចប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ១៧:៧–១០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលចៅហ្វាយរំពឹងពីអ្នកបម្រើ ។

- តើចៅហ្វាយតម្រូវអ្វីខ្លះពីអ្នកបម្រើ ?

ចូរពន្យល់ថា នៅក្នុងជំនាន់ក្នុងព្រះគម្ពីរបើប មានចៅហ្វាយម្នាក់បានផ្តល់នូវអ្វីៗដែលចាំបាច់ទាំងអស់ក្នុងជីវិតទៅឲ្យអ្នកបម្រើរបស់គាត់ នៅពេលអ្នកបម្រើស្មោះត្រង់បានបំពេញកាតព្វកិច្ចដែលបានរំពឹងទុករបស់គាត់ ។ ដោយសារតែរឿងនេះ វាពុំចាំបាច់ឲ្យចៅហ្វាយត្រូវផ្តល់នូវការអរគុណជាពិសេសដល់អ្នកបម្រើ ឬមានអារម្មណ៍ថា ជំពាក់គុណគាត់ចំពោះការបំពេញកាតព្វកិច្ចរបស់គាត់នោះទេ ។

- តើព្រះវរបិតាសួគ៌យើងដូចគ្នានឹងលោកចៅហ្វាយនៅក្នុងរឿងប្រៀបធៀបនេះយ៉ាងដូចម្តេច ? តើទ្រង់តម្រូវអ្វីខ្លះពីយើង ? (ឲ្យ « ធ្វើតាមបង្គាប់គ្រប់ជំពូក ដែលបានប្រទានដល់ » យើង [ខ ១០]) ។

សូមបន្ថែមទៅលើសេចក្តីថ្លែងការណ៍នៅលើក្តារខៀន អានដូចតទៅ ៖ *សេចក្តីជំនឿរបស់យើងនឹងកើនឡើង នៅពេលយើងព្យាយាមធ្វើអ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌បញ្ជា ។*

ដើម្បីជួយសិស្សឲ្យមើលឃើញនូវអ្វីផ្សេងទៀតដែលអាចបង្កើនជំនឿរបស់ពួកគេ សូមសួរ ៖

- យោងតាមខទី ១០តើអ្នកបម្រើគួរនិយាយអ្វីខ្លះ បន្ទាប់ពីរក្សាបញ្ញត្តិរបស់ចៅហ្វាយរបស់ពួកគេហើយនោះ ?
- តើ« បាវឥតប្រយោជន៍ » មានន័យយ៉ាងណា ? (វាមានន័យថា មិនថាមនុស្សរក្សាបញ្ញត្តិបានល្អប៉ុណ្ណាទេ ពួកគេគឺនៅតែជំពាក់គុណព្រះជានិច្ច) ។
- ហេតុអ្វីក៏យើងជំពាក់គុណព្រះវរបិតាសួគ៌ជានិច្ច ទោះជាពេលយើងគោរពប្រតិបត្តិ ហើយរស់នៅដោយសុចរិតក៏ដោយក្តី ? (ដោយសារព្រះវរបិតាសួគ៌ប្រទានពរដល់យើងជានិច្ច យើងពុំអាចបង់សងដល់ទ្រង់ទាំងអស់វិញនោះទេ [សូមមើលម៉ូសាយ ២:២០–២៦]) ។

សូមបញ្ចប់សេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដើម្បីវានាំទៅគោលការណ៍ដូចខាងក្រោម ៖ **សេចក្តីជំនឿរបស់យើងនឹងបង្កើនឡើង នៅពេលយើងព្យាយាមដើម្បីធ្វើអ្វី ៗទាំងអស់ ដែលព្រះវរបិតាសួគ៌បញ្ជា និងនៅពេលយើងចងចាំថា យើងជំពាក់គុណទ្រង់ជានិច្ច ។** អ្នកអាចលើកទឹកចិត្តសិស្ស ឲ្យសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- តើការព្យាយាមធ្វើតាមអ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌បញ្ជា បង្កើនសេចក្តីជំនឿរបស់យើងយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគ្រាមួយ ដែលពួកគេបានរក្សាបទបញ្ញត្តិ ឬបានបំពេញកាតព្វកិច្ចរបស់ពួកគេដោយការគោរពប្រតិបត្តិ ហើយជាលទ្ធផលមានអារម្មណ៍ថា បានបង្កើនសេចក្តីជំនឿ ។ សូមអញ្ជើញពួកគេឲ្យសរសេរគំនិតរបស់ពួកគេចូលក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យចែកចាយជាមួយនឹងសិស្សម្នាក់ទៀតអំពីអ្វី ដែលពួកគេបានសរសេរ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

លូកា ១៧:១១–១៩

ព្រះយេស៊ូវព្យាបាលមនុស្សឃ្លង់ទាំងដប់នាក់

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *អំឡុងជំនាន់ក្នុងព្រះគម្ពីរបរីប វាជាបញ្ហាដ៏ធំមួយ ក្នុងការរងទុក្ខដោយសារតែជំងឺឃ្លង់. . .*

សូមជួយសិស្សឲ្យរំឭកមើលនូវអ្វីដែលពួកគេដឹងអំពីជំងឺឃ្លង់ តាមរយៈសុំឲ្យពួកគេប្រាប់ដល់សិស្សក្នុងថ្នាក់អំពីរបៀបដែលពួកគេនឹងបំពេញក្នុងសេចក្តីថ្លែងការណ៍ ។ ឧទាហរណ៍ សិស្សអាចនឹងប្រាប់ថា ជំងឺឃ្លង់អាចនាំឲ្យមានការខូចអវយវៈ និងសេចក្តីស្លាប់ ដែលមនុស្សឃ្លង់ត្រូវបំបែកចេញពីមនុស្សផ្សេងទៀតក្នុងសង្គម ដើម្បីការពារសុខភាពរបស់អ្នកដទៃ ហើយដែលពួកគេតម្រូវឲ្យស្រែកថា « អសោច ! » ដើម្បីព្រមានដល់អ្នកដទៃកុំឲ្យមករកពួកគេ (សូមមើល Bible Dictionary, « Leper ») ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១៧:១១–១២ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលនរណាដែលព្រះយេស៊ូវបានជួបនៅពេលទ្រង់បានឈប់នៅក្នុងភូមិមួយ ខណៈពេលកំពុងធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ប្រសិនបើអ្នកគឺជាមនុស្សឃ្លង់ម្នាក់នៃមនុស្សឃ្លង់ទាំងនោះ តើអ្នកប្រហែលជាមានអារម្មណ៍យ៉ាងណា ពេលអ្នកបានមើលឃើញព្រះយេស៊ូវ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន លូកា ១៧:១៣–១៤ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលអ្វីដែលមនុស្សឃ្លង់បានទូលទៅព្រះអង្គសង្គ្រោះ ហើយចម្លើយរបស់ទ្រង់ទៅកាន់ពួកគេមានអ្វីខ្លះ ។

- តើមនុស្សឃ្លង់បានសូមអ្វីខ្លះពីព្រះយេស៊ូវ ?
- តើព្រះយេស៊ូវបង្រៀនពួកគេឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា ក្រឹត្យវិន័យរបស់ម៉ូសេ បានពិពណ៌នាថា មនុស្សឃ្លង់បង្ហាញខ្លួនពួកគេដល់ពួកសង្ឃបន្ទាប់ ពីពួកគេបានជាសះស្បើយ ដើម្បីអាចចូលទៅក្នុងសង្គមវិញបាន (សូមមើលលេវីវិន័យ ១៤) ។

- តើមានអ្វីកើតឡើងនៅពេលមនុស្សឃ្លង់ទាំងឡាយចេញទៅ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះចេញមកពីខទី ១៤ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យពីព្រះអម្ចាស់ ? (សិស្សគួរសំគាល់ឃើញពីសេចក្តីពិតមួយ ដែលស្រដៀងគ្នានឹងសេចក្តីពិតដូចខាងក្រោម ៖ **យើងទទួលពរជ័យរបស់ព្រះអម្ចាស់នៅពេលយើងធ្វើនូវអ្វីដែលទ្រង់បានណែនាំឲ្យយើងធ្វើ**) ។

ចូរសុំឲ្យសិស្សគិតពិចារណាថា តើមានអារម្មណ៍យ៉ាងណាក្នុងនាមជាមនុស្សឃ្លង់ម្នាក់ដែលបានជាសះស្បើយនោះ ។

- តើអ្នកគិតថាអ្នកនឹងបានធ្វើអ្វីខ្លះ នៅពេលអ្នកបានដឹងថាអ្នកត្រូវបានជាសះស្បើយពីជំងឺឃ្លង់នោះ ?

សូមអញ្ជើញសិស្សបីឬបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ១៧:១៥–១៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវរបៀបដែលមនុស្សឃ្លង់ម្នាក់មានប្រតិកម្មផ្សេងៗពីអ្នកដទៃទៀត ។

- តើមនុស្សឃ្លង់សាសន៍សាម៉ារីបានធ្វើអ្វីខ្លះ ដែលបានបង្ហាញពីការដឹងគុណរបស់គាត់ចំពោះព្រះអង្គសង្គ្រោះ ?
- ហេតុអ្វីលូកាបានប្រាប់ថា មនុស្សឃ្លង់ដែលដឹងគុណនោះ គឺជាសាសន៍សាម៉ារីម្នាក់—ជាមនុស្សម្នាក់ដែលពួកយូដាមើលងាយបំផុតនោះ ? តើរឿងលម្អិតអ្វីខ្លះដែលបានជួយឲ្យយើងយល់ដឹងបន្ថែមអំពីដំណើររឿងនេះ ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនពីមនុស្សឃ្លង់ដែលត្រឡប់មកថ្លែងអំណរគុណដល់ព្រះអម្ចាស់វិញនោះ ? (សិស្សគួរសំគាល់ឃើញពីសេចក្តីពិតមួយ ដែលស្រដៀងគ្នានឹងសេចក្តីពិតដូចខាងក្រោម ៖ **វាសំខាន់ដើម្បីបង្ហាញនូវការដឹងគុណចំពោះពរជ័យទាំងឡាយដែលយើងទទួល**) ។
- ហេតុអ្វីក៏វាសំខាន់ ដើម្បីបង្ហាញនូវការដឹងគុណចំពោះពរជ័យទាំងឡាយដែលយើងទទួលនោះ ?
- តើពេលខ្លះយើងអាចប្រៀបដូចជាមនុស្សឃ្លង់ទាំងប្រាំបួនយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖

« បងប្អូនប្រុសស្រីរបស់ខ្ញុំអើយ តើយើងចងចាំថាត្រូវថ្លែងអំណរគុណចំពោះពរជ័យ ដែលយើងទទួលឬទេ ? ការថ្លែងអំណរគុណដោយស្មោះ ពុំគ្រាន់តែជួយយើងឲ្យទទួលស្គាល់ពរជ័យរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ចាក់សោរបើកទ្វារនៃស្ថានសួគ៌ ហើយជួយយើងទទួលអារម្មណ៍ដឹងពីក្តីស្រឡាញ់របស់ព្រះផងដែរ » (« The Divine Gift of Gratitude »*Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៨៧) ។

- យោងតាមខទី ១៩តើព្រះអង្គសង្គ្រោះមានបន្ទូលអ្វីខ្លះបានកើតឡើងចំពោះមនុស្សឃ្លង់រូបនេះ ដោយសារតែទង្វើរបស់គាត់ ? (គាត់បានជាសះស្បើយទាំងស្រុង) ។
- តើការថ្លែងអំណរគុណដល់ព្រះអម្ចាស់ចំពោះពរជ័យរបស់យើង អាចជួយយើងឲ្យបានជាសះស្បើយទាំងស្រុងតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាគម្ពីររបស់ពួកគេនូវពរជ័យជាក់លាក់មកពីព្រះវរបិតាសួគ៌ ដែលពួកគេមានអំណរគុណចំពោះនោះ ។ សូមអញ្ជើញពួកគេឲ្យសរសេរអំពីរបៀបដែលពួកគេអាចរស់នៅក្នុងការដឹងគុណចំពោះពរជ័យទាំងនោះ ។

លូកា ១៧:២០–៣៧

ព្រះយេស៊ូវបង្រៀនអំពីការមកដល់នៃនគររបស់ព្រះ

សូមសង្ខេបលូកា ១៧:២០–៣៧ ដោយពន្យល់ថា ព្រះយេស៊ូវបានបង្រៀនអំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។ (*កំណត់ចំណាំ ៖ ការបង្រៀនស្រដៀងគ្នា ត្រូវបានបង្រៀនក្នុងសម្ភារមេរៀនសម្រាប់ម៉ាថាយ ២៤និង យ៉ូសែប ស៊្មីធ—ម៉ាថាយ*) ។

អ្នកអាចបញ្ចប់មេរៀន ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត ដែលបានប្រាប់នៅក្នុងមេរៀននេះ ។ សូមអញ្ជើញសិស្សឲ្យអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

សកម្មភាពនេះអាចត្រូវបានប្រើដើម្បីជួយសិស្សទន្ទេញចាំចំណេះចំណានខគម្ពីរ ។

សូមបែងចែកសិស្សទាំងឡាយជាក្រុមដែលមានគ្នាបួន ឬប្រាំនាក់ ។ សូមឲ្យក្រុមនីមួយៗនូវគ្រាប់ឡុកឡាក់មួយ និងខ្មៅដៃមួយដើម ។ (ប្រសិនបើពុំមានគ្រាប់ឡុកឡាក់ទេ អ្នកអាចដាក់ចំរៀកក្រដាសតូចៗចំនួនប្រាំមួយ ចាប់ពីលេខ ១ ដល់ ៦ នៅក្នុងស្រោមសំបុត្រមួយ ឬប្រអប់មួយផ្សេងទៀត) ។ សិស្សម្នាក់ៗនឹងចាំបាច់ត្រូវមានចំរៀកក្រដាសទទេមួយ ។ ចូរសុំឲ្យក្រុមនីមួយៗអង្គុយតៀកគ្នានៅជុំវិញតុមួយ ឬអង្គុយជារង្វង់មួយ ។ សូមអញ្ជើញពួកគេឲ្យបើកគម្ពីររបស់ពួកគេទៅចំណេះចំណានខគម្ពីរដែលអ្នកចង់ឲ្យពួកគេទន្ទេញចាំនោះ ។ សូមពន្យល់ថា គោលបំណងរបស់សកម្មភាពនេះ គឺត្រូវធ្វើជាមនុស្សទីមួយ នៅក្នុងក្រុមដែលសរសេរពីវគ្គគម្ពីរទាំងមូល ។ ទោះជាយ៉ាងណាក៏ដោយ សិស្សទាំងឡាយត្រូវប្រើខ្មៅដៃមួយដែលបានផ្តល់ឲ្យក្រុមនីមួយៗនោះ ។ មនុស្សម្នាក់ដែលមានលទ្ធភាព ដើម្បីប្រើខ្មៅដៃ បោះគ្រាប់ឡុកឡាក់ចំលេខ ១ (ឬចាប់យកក្រដាសមួយ ដែលបានលេខ ១) ។ សូមអញ្ជើញសមាជិកក្នុងក្រុមនីមួយៗឲ្យដាក់វេនគ្នាបោះគ្រាប់ឡុកឡាក់ (ឬយកក្រដាសមួយឡើង ហើយដាក់វាចូលវិញ) ។ នៅពេលសិស្សម្នាក់បោះចំលេខ ១ នោះសិស្សរូបនោះ យកខ្មៅដៃ ហើយចាប់ផ្តើមសរសេរពាក្យខគម្ពីរនៅលើក្រដាសរបស់គាត់ ដោយនិយាយពាក្យនីមួយៗឮៗ ។ ខណៈពេលនោះ អ្នកផ្សេងទៀតនៅក្នុងក្រុម ផ្លាស់វេណគ្នាបោះគ្រាប់ឡុកឡាក់ ។ នៅពេលដែលសិស្សម្នាក់ទៀតនៅក្នុងក្រុមបោះចំលេខ ១ សិស្សនោះយកខ្មៅដៃពីអ្នកសរសេរមុនមក ហើយចាប់ផ្តើមសរសេរខគម្ពីរនៅក្នុងក្រដាសរបស់ខ្លួន ខណៈដែលនិយាយពាក្យឮៗ ។ អ្នកសរសេរពីមុន ចូលរួមនឹងក្រុមវិញដើម្បីធ្វើការបោះគ្រាប់ឡុកឡាក់ ។ នៅពេលសិស្សដែលមានលទ្ធភាពនឹងកាន់ខ្មៅដៃ ហើយបានសរសេរនូវផ្នែកមួយនៃខគម្ពីរហើយនោះ នោះពួកគេត្រូវតែអានវគ្គនោះឮៗមុនពេលសរសេរខគម្ពីរថែមទៀត ។ (ការណ៍នេះផ្តល់នូវចំនុចដដែលៗ ដែលនឹងជួយសិស្សឲ្យទន្ទេញចាំខគម្ពីរ) ។ សកម្មភាពអាចបញ្ចប់ពេលសិស្សម្នាក់មកពីក្រុមនីមួយៗបានសរសេរចំណេះចំណានខគម្ពីរបានទាំងអស់ហើយ ។

សូមឲ្យសិស្សក្នុងថ្នាក់អានខឡើងវិញទាំងអស់គ្នាក្រោយពីបញ្ចប់សកម្មភាពនេះ ។

មេរៀនសិក្សានៅផ្ទះ

លូកា ១០:៣៨–១៧:៣៧ (មេរៀនទី ១១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្ស ដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និង គោលការណ៍ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា លូកា ១០:៣៨–១៧:៣៧ (មេរៀនទី ១១) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (លូកា ១០:៣៨–១២:៥៩)

ចេញមកពីព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះទៅកាន់ម៉ាថា សិស្សបានរៀនថា ប្រសិនបើយើងជ្រើសរើសលះបង់ខ្លួនយើងចំពោះរឿងខាងវិញ្ញាណពី លើសពីកង្វល់ខាងសាច់ឈាម នោះយើងនឹងទទួលបានពរជ័យដ៏ឃ្លាំងអង្វែង ។ ព្រះយេស៊ូវក៏បានបង្រៀនផងដែរ ប្រសិនបើយើងអធិស្ឋានដោយខ្ជាប់ខ្ជួន ហើយស្វែងរកពរជ័យរបស់ព្រះវរបិតាសួគ៌ក្នុងគ្រាចាំបាច់ បន្ទាប់មកទ្រង់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់យើងតាមពេលវេលារបស់ទ្រង់ និង តាមរបៀបរបស់ទ្រង់ផ្ទាល់ ។ សេចក្តីពិតផ្សេងទៀតដែលសិស្សបានរៀនមានដូចជា ៖ ព្រះអម្ចាស់បញ្ជាយើងកុំឲ្យលោភចង់បានទ្រព្យសម្បត្តិខាងលោកិយ ។ ប្រសិនបើយើងស្វែងរកនគររបស់ព្រះ និង សេចក្តីសុចរិតរបស់ទ្រង់ នោះទ្រង់នឹងជួយផ្គត់ផ្គង់ចំពោះសេចក្តីត្រូវការរបស់យើង ហើយរៀបចំកន្លែងមួយសម្រាប់យើងនៅក្នុងនគររបស់ទ្រង់ ។

ថ្ងៃទី ២ (ម៉ាថាយ ១៣–១៥)

នៅក្នុងដំពូកនេះ សិស្សបានរៀនអំពីគោលការណ៍ដូចខាងក្រោម ៖ ប្រសិនបើយើងព្យាយាមជួយមនុស្សដែលមិនសូវមានភ័ព្វវាសនាដូចជាយើង នោះព្រះអម្ចាស់នឹងប្រទានឱ្យនៅជាប់ជាមួយយើង នៅពេលការរស់ឡើងវិញ ។ ប្រសិនបើយើងដាក់អាទិភាពផ្សេងខ្ពស់ជាងព្រះអម្ចាស់ និង ដំណឹងល្អរបស់ទ្រង់ នោះយើងនឹងបាត់បង់ពរជ័យនៃដំណឹងល្អដែលយើងអាចនឹងទទួល ។ ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទ ត្រូវតែមានឆន្ទៈលះបង់អ្វីៗគ្រប់យ៉ាងដើម្បីដើរតាមទ្រង់ ។ នៅពេលយើងជួយអ្នកដទៃមានបំណងប្រាថ្នាចង់ប្រែចិត្ត នោះយើងមានអារម្មណ៍អំណរ និងស្ថានសួគ៌ក៏មានអំណរផងដែរ ។

ថ្ងៃទី ៣ (លូកា ១៦)

ចេញមកពីរឿងប្រៀបធៀបរបស់អ្នកត្រួតគ្រាទុច្ចរិត និងអ្នកមាន និងឡាសារ នោះសិស្សបានរៀនថា ប្រសិនបើយើងបានរៀបចំខ្លួនដោយឈ្លាតសម្រាប់អនាគតដ៏អស់កល្បជានិច្ចរបស់យើង ហើយប្រើទ្រព្យលើផែនដីដោយសុចរិត នោះយើងអាចត្រូវបានប្រទានពរនូវទ្រព្យដ៏អស់កល្បជានិច្ច ។ ពួកគេក៏បានរៀនផងដែរអំពីគោលការណ៍ទាំងឡាយដូចតទៅនេះ ៖ ប្រសិនបើយើងលោភលន់ ហើយពុំប្រើទ្រព្យលើផែនដីរបស់យើងដោយសុចរិត នោះនៅទីបំផុតយើងនឹងទទួលបទពិសោធន៍នៃការរងទុក្ខ និងវិប្បដិសារី ។ ការផ្លាស់ប្រែចិត្តជឿកើតមានតាមរយៈការជឿ និងការស្តាប់តាមពាក្យសម្តីរបស់ពួកព្យាការី ពុំមែនតាមរយៈការមើលឃើញអព្ភូតហេតុ ឬមើលឃើញពួកទេវតានោះទេ ។

ថ្ងៃទី ៤ (លូកា ១៧)

នៅក្នុងលូកា ១៧ពួកសាវកបានសុំឲ្យព្រះយេស៊ូវបង្កើនសេចក្តីជំនឿរបស់ពួកគេ ។ ពួកសិស្សបានរៀនថា សេចក្តីជំនឿរបស់យើងនឹងកើនឡើង នៅពេលយើងព្យាយាមដើម្បីធ្វើអ្វីទាំងអស់ដែលព្រះវរបិតាសួគ៌បញ្ជា និង នៅពេលយើងចងចាំថា យើងជំពាក់គុណទ្រង់ជានិច្ច ។ ពួកសិស្សក៏បានរៀនផងដែរថា យើងទទួលពរជ័យរបស់ព្រះអម្ចាស់នៅពេលយើងធ្វើនូវអ្វីដែលទ្រង់បានបង្រៀនយើងឲ្យធ្វើ ហើយសំខាន់ក្រៃលែងដើម្បីបង្ហាញនូវការដឹងគុណចំពោះពរជ័យដែលយើងបានទទួល ។

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះបានឆ្លើយតបចំពោះការអ៊ូទាំរបស់ពួកផារិស៊ីអំពីការទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងអ្នកប្រមូលពន្ធ និង ពួកអ្នកមានបាប តាមរយៈការប្រទានឲ្យនូវរឿងប្រៀបធៀបអំពីចៀមដែលបាត់ ការបាត់កាក់ និង រឿងកូនប្រុសខ្ជះខ្ជាយ ។

យោបល់សម្រាប់ការបង្រៀន

លូកា ១៥

ព្រះយេស៊ូវប្រទានរឿងប្រៀបធៀបអំពីចៀមដែលបាត់ ការបាត់កាក់ និង រឿងកូនប្រុសខ្ជះខ្ជាយម្នាក់

សូមចាប់ផ្តើមថ្នាក់ដោយការសួរដល់សិស្សប្រសិនបើពួកគេធ្លាប់បាត់វត្ថុមួយ ដែលមានតម្លៃចំពោះពួកគេ ។

- តើអ្នកមានឆន្ទៈធ្វើអ្វីខ្លះដើម្បីស្វែងរកវា ? ហេតុអ្វី ?
- តើអ្នកគិតថាវាមានន័យយ៉ាងណាចំពោះមនុស្សដែលបាន « វង្វេង » ខាងវិញ្ញាណ ? (សូមជួយសិស្សយល់ដឹងថា រឿងនេះអាចសំដៅទៅលើអ្នកទាំងឡាយដែលពុំទាន់បានទទួលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញនៅឡើយ ឬដែលពុំរស់នៅស្របតាមការបង្រៀននៃដំណឹងល្អបច្ចុប្បន្ននេះ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលប្រហែលជាវង្វេងខាងវិញ្ញាណ ។ ចូរសុំឲ្យពួកគេពិចារណាអំពីអារម្មណ៍ដែលពួកគេមានអំពីមនុស្សម្នាក់នេះ ។

សូមពន្យល់ថាលូកា ១៥មាននូវការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីអ្នកទាំងឡាយដែលវង្វេងខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីពិតនៅក្នុងលូកា ១៥ស្តីពីរបៀបដែលព្រះវរបិតាសួគ៌មានព្រះទ័យអំពីអ្នកទាំងឡាយដែលវង្វេងខាងវិញ្ញាណ និង ទំនួលខុសត្រូវដែលយើងមានចំពោះពួកគេ ។

ចូរសុំឲ្យសិស្សម្នាក់អាន លូកា ១៥:១–២ ឮៗ ។ ចូរអញ្ជើញឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលពួកផារិស៊ី និង ពួកអាចារ្យបានអ៊ូរអំពីនោះ ។

- ហេតុអ្វីក៏ពួកផារិស៊ី និង ពួកអាចារ្យអ៊ូរទាំ ?
- តើការអ៊ូរទាំនេះ បង្ហាញអំពីពួកផារិស៊ី និងពួកអាចារ្យអ្វីខ្លះ ?

ចូរពន្យល់ថា ព្រះអង្គសង្គ្រោះបានឆ្លើយតបដោយការប្រទាននូវរឿងប្រៀបធៀបចំនួនបី ៖ ចៀមមួយដែលបាត់ កាក់មួយដែលបាត់ និងកូនប្រុសម្នាក់ដែលវង្វេង ។ ចូរសុំឲ្យពួកគេយកចិត្តទុកដាក់ថា ហេតុអ្វីក៏វត្ថុក្នុងរឿងប្រៀបធៀបនីមួយៗបានបាត់ និង របៀបដែលវាត្រូវបានរកឃើញវិញ ។

ចូរពន្យល់ថានៅក្នុងរឿងប្រៀបធៀបអំពីចៀមដែលបាត់ និងកាក់ដែលបាត់ នោះព្រះអង្គសង្គ្រោះបានពិពណ៌នាអំពីរបៀបដែលអ្នកគង្វាល និង ស្ត្រីដែលបាត់កាក់ បានខិតខំរកដោយឧស្សាហ៍ រហូតដល់ពួកគេបានរកឃើញវត្ថុដែលបាត់នោះវិញ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ១៥:៤–៦, ៨–៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាអ្នកគង្វាល និង ស្ត្រីមានអារម្មណ៍យ៉ាងណា នៅពេលពួកគេបានរកឃើញចៀម និង កាក់នោះ ។

- តើមានភាពខុសគ្នាអ្វីខ្លះ រវាងរបៀបដែលចៀមវង្វេង និង កាក់ដែលបានបាត់ ? (ចៀមបានវង្វេងចេញពីផ្លូវនៃជីវិតដែលវាធ្លាប់ដើរតាម និង ពុំមែនជាកំហុសរបស់វាទេ ខណៈដែលកាក់ត្រូវបានបាត់ ដោយសារតែភាពធ្វេសប្រហែស ឬការមិនយកចិត្តទុកដាក់របស់ម្ចាស់ផ្ទាល់ [សូមមើល ដេវីឌ អូ មិកឃេ នៅក្នុង *Conference Report* ខែ មេសា ឆ្នាំ ១៩៤៥ ទំព័រ ១២០– ២២]) ។
- តើមានពាក្យអ្វីខ្លះ ត្រូវបានប្រើដើម្បីពិពណ៌នាអំពីអារម្មណ៍ដែលអ្នកគង្វាល និងស្ត្រីនោះបានមាន ?

សូមអញ្ជើញសិស្សឲ្យអានលូកា ១៥:៧, ១០ដោយស្ងាត់ស្ងៀម ហើយស្វែងរកអ្វីដែលព្រះអង្គសង្គ្រោះបានប្រដូចទៅនឹងក្តីអំណររបស់អ្នកគង្វាល និងស្ត្រីនោះ ។ (សេចក្តីអំណរនៅក្នុងស្ថានសួគ៌មានចំពោះអ្នកមានបាបដែលប្រែចិត្ត) ។

សូមពន្យល់ថា រឿងប្រៀបធៀបទីបីនៅក្នុងលូកា ១៥គឺជារឿងអំពីកូនប្រុសខ្ជះខ្ជាយម្នាក់ (មានន័យថា ជាមនុស្សម្នាក់ដែលបានខ្ជះខ្ជាយចាយវាយហួសហេតុ) បងប្រុសរបស់គាត់ និង ឪពុករបស់ពួកគេ ។

សូមធ្វើការពិចារណាបែងចែកសិស្សជាក្រុមៗ ដែលមានសមាជិកបីនាក់ ។ សូមឲ្យក្រុមនិមួយៗនូវច្បាប់ចម្លងមួយនៃឯកសារចែកចាយដូចខាងក្រោម ។ សូមអញ្ជើញពួកគេឲ្យអានលូកា ១៥:១១–៣២ឮៗនៅក្នុងក្រុមរបស់ពួកគេ ។ សូមចាត់សិស្សម្នាក់ឲ្យពិចារណានូវរឿងប្រៀបធៀបអំពីទស្សនៈវិស័យរបស់កូនប្រុសខ្ជះខ្ជាយ ហើយឲ្យសិស្សទីពីរពិចារណាអំពីទស្សនៈវិស័យរបស់ឪពុក និង សិស្សទីបី ពិចារណាអំពីទស្សនៈវិស័យរបស់បងប្រុស ។

បន្ទាប់ពីសិស្សបានអានចប់ហើយ ចូរសុំឲ្យពួកគេពិភាក្សាអំពីសំណួរនៅលើឯកសារដែលចែកឲ្យនៅក្នុងក្រុមរបស់ពួកគេ ។

ជំនួសឲ្យការសុំឲ្យសិស្សអាន និង ពិភាក្សាអំពីរឿងប្រៀបធៀប អ្នកអាចបង្ហាញវីដេអូ « រឿងកូនខ្ជះខ្ជាយ » (៥:៣៥) ចេញមកពីវីដេអូ *ព្រះគម្ពីរបឺមអំពីជីវិតនៃព្រះយេស៊ូវគ្រីស្ទ* ។ សូមផ្តល់ដល់សិស្សម្នាក់ៗនូវសេចក្តីចម្លងចែកចាយមួយច្បាប់ដូចខាងក្រោម ហើយសុំឲ្យសិស្សរកមើលចម្លើយចំពោះសំណួរទាំងឡាយនៅពេលពួកគេមើលវីដេអូ ។ វីដេអូនេះមាននៅក្នុង *LDS.org*

រឿងប្រៀបប្រដូចអំពីកូនប្រុសខ្ជះខ្ជាយ

កូនប្រុសខ្ជះខ្ជាយ

- តើមានអ្វីខ្លះដែលបានជួយអ្នកឲ្យដឹងខ្លួន ឬទទួលស្គាល់ស្ថានភាពអាក្រក់ដែលអ្នកកំពុងស្ថិតនៅ ?
- តើអ្នកបានរំពឹងឲ្យឪពុករបស់អ្នកធ្វើដូចម្តេច ចំពោះការត្រឡប់មកផ្ទះរបស់អ្នកវិញ ?
- តើអ្នកប្រហែលជាគិត ហើយមានអារម្មណ៍យ៉ាងណា នៅពេលឪពុករបស់អ្នកប្រព្រឹត្តចំពោះអ្នកដូចជាគាត់បានធ្វើនោះ ?

ឪពុក

- តើអ្នកប្រហែលជាគិត ហើយមានអារម្មណ៍យ៉ាងណា ខណៈដែលកូនពៅរបស់អ្នកបានវង្វេងបាត់នោះ ?
- ហេតុអ្វីក៏អ្នកស្វាគមន៍កូនប្រុសខ្ជះខ្ជាយរបស់អ្នកត្រឡប់មកផ្ទះ តាមរបៀបដែលអ្នកធ្វើនោះ ?
- នៅពេលដែលកូនច្បងរបស់អ្នក អន់ចិត្តចំពោះរបៀបដែលអ្នកប្រព្រឹត្តនឹងប្អូនប្រុសរបស់អ្នក តើអ្នកបានជួយគាត់ដូចម្តេច ដើម្បីឲ្យយល់អំពីសកម្មភាពរបស់អ្នក ?

បងប្រុស

- តើអ្នកប្រហែលជាគិត ហើយមានអារម្មណ៍យ៉ាងណា ខណៈដែលប្អូនប្រុសរបស់អ្នកបានវង្វេងបាត់នោះ ?
- ហេតុអ្វីក៏វាលំបាកចំពោះអ្នកដើម្បីរីករាយចំពោះការត្រឡប់មកវិញរបស់ប្អូនប្រុសអ្នក?
- តើមានពរជ័យអ្វីខ្លះ ដែលអ្នកបានទទួលចំពោះការមានចិត្តស្មោះត្រង់ចំពោះឪពុករបស់អ្នក ?

- ហេតុអ្វីក៏កូនប្រុសខ្ជះខ្ជាយបានវង្វេង ? (ចំពោះរឿងចៀម និង កាក់ វាផ្ទុយពីរឿងកូនប្រុសខ្ជះខ្ជាយដែលបានវង្វេងដោយសារតែការបះបោររបស់គាត់ផ្ទាល់) ។
- កាលបានយល់ដឹងថាឪពុកនៅក្នុងរឿងប្រៀបធៀបនេះតំណាងឲ្យព្រះវរបិតាសួគ៌ តើយើងអាចរៀនអ្វីខ្លះ អំពីរបៀបដែលព្រះវរបិតាសួគ៌បានឆ្លើយតបចំពោះអ្នកទាំងឡាយ ដែលត្រឡប់មករកទ្រង់ដោយការប្រែចិត្តនោះ ? (សិស្សគួរឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងត្រឡប់ទៅរកព្រះវរបិតាសួគ៌តាមរយៈការប្រែចិត្ត និងការស្វែងរកការអភ័យទោសរបស់ទ្រង់ នោះទ្រង់នឹងរីករាយ ហើយស្វាគមន៍យើងឲ្យត្រឡប់មកក្នុងរង្វង់ព្រះហស្តរបស់ទ្រង់វិញ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើគោលការណ៍នេះប្រហែលជាជួយអ្នកទាំងឡាយដែលមានអារម្មណ៍ថាបានវង្វេងខាងវិញ្ញាណយ៉ាងដូចម្តេច ?

សូមរំឭកសិស្សអំពីបងប្អូននៅក្នុងរឿងប្រៀបធៀប ។

- ហេតុអ្វីក៏អ្នកគិតថាបងប្អូនខឹង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ដៃវ្រីអ័រ ហូឡិន ក្នុងកូរ៉ូមនៃពួកសាវកដប់ពីរនាក់ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលពីយោបល់ស្តីអំពីមូលហេតុដែលបងប្អូនខឹង ។



« ចំពោះអារម្មណ៍ដែលថាគេពុំសូវចេះដឹងគុណ ហើយប្រហែលជាអាណិតខ្លួនឯងច្រើនបន្តិចនេះ កូនប្រុសដែលបំពេញកាតព្វកិច្ចរបស់គាត់នេះ—ហើយគាត់គឺពិតជា*អស្ចារ្យ*—ពិតជាយកចិត្តទុកដាក់ការណើរកិច្ចខ្លួន—បានភ្លេចអំពីគ្រាមួយ ដែលគាត់ពុំធ្លាប់ដឹងពីភាពអាក្រក់ ឬភាពអស់សង្ឃឹមភាពត័យខ្លាច ឬការស្អប់ខ្ពើមខ្លួនឯង ។ គាត់បានភ្លេចនូវគ្រាមួយដែលថាគោគ្រប់ក្បាលនៅក្នុងក្រោល ហើយក៏ដូចជាខោអាវក្នុងទូ និងចិញ្ចៀននៅក្នុងថតតុទាំងអស់ផងដែរ គឺជារបស់ផងគាត់រួចទៅហើយនោះ ។ គាត់បានភ្លេចគ្រាមួយ ដែលភាពស្មោះត្រង់របស់គាត់បាន ហើយនឹងតែងតែត្រូវបានផ្តល់រង្វាន់ជានិច្ច ។ . . .

«. . . គាត់មានអ្វីៗគ្រប់បែបយ៉ាង ហើយដែលបានមកដោយការខិតខំធ្វើការរបស់គាត់ ដែលរកបានមកតាមរបៀបដ៏*អស្ចារ្យ* តែខ្វះខាតចំនុចមួយដែលអាចនឹងធ្វើឲ្យគាត់ក្លាយជាមនុស្សពេញលេញរបស់ព្រះអម្ចាស់ ដែលគាត់ហៀបនឹងធ្វើបានហើយនោះ ។ គាត់ពុំទាន់មានចិត្តអាណិតមេត្តា និងក្តីករុណានៅឡើយទេ ដែលវាជាដងផ្លែមនៃក្តីសប្បុរសធម៌នៃចក្ខុវិស័យដើម្បីមើលឃើញថា*នេះពុំមែនជាការត្រឡប់មកវិញដោយប្រក្រតីប្រដែងនោះទេ* ។ គឺជាប្អូនប្រុសរបស់គាត់ ។ . . .

« ពិតណាស់ ប្អូនប្រុសនេះ៖ ធ្លាប់ជាអ្នកមានទោស—ជាអ្នកទោសនៃអំពើបាប ភាពល្ងិតល្ងង់ និង នៅក្នុងទ្រុងជ្រូក ។ ប៉ុន្តែបងប្រុសបានរស់នៅក្នុងការដាប់ឃ្មុំខ្លះៗផងដែរ ។ ពីព្រោះគាត់ពុំទាន់អាចដោះលែងខ្លួនគាត់ ពីការដាប់ឃ្មុំ ។ គាត់ត្រូវបានលង់លក់ទៅក្នុងភាពច្រណែន ។ គាត់មានអារម្មណ៍ថាឪពុកគាត់ពុំឲ្យតម្លៃ ហើយត្រូវបានកាត់ចេញដោយប្អូនប្រុសរបស់គាត់ ខណៈដែលវានឹងគ្មានរឿងដូច្នោះកើតឡើយ » (« រឿងកូនខ្ជះខ្ជាយ »*Ensign*ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ៦៣) ។

- ស្របតាមអែលឌើរ ហូឡិន ហេតុអ្វីក៏បងប្រុសច្បងខឹង ? តើបងប្រុសច្បងក៏ត្រូវបានវង្វេងដោយរបៀបណា ?
- តើយើងចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីចងចាំគ្រាដែលយើងមើលឃើញព្រះប្រកបដោយក្តីមេត្តាករុណា ហើយបានប្រទានពរដល់អ្នកទាំងឡាយដែលប្រែចិត្ត ហើយត្រឡប់មកទ្រង់វិញនោះ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីរឿងប្រៀបធៀបនេះ៖ អំពីការប្រែក្លាយឲ្យកាន់តែដូចជាព្រះវរបិតាសួគ៌របស់យើង ? (សិស្សគួរករឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **យើងអាចប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌របស់យើងដោយការឆ្លើយតបដោយក្តីមេត្តាករុណា និង ក្តីអំណរ នៅពេលអ្នកដទៃប្រែចិត្ត**) ។

ចូររំឭកសិស្សអំពីមនុស្សដែលពួកគេបានគិត នៅពេលចាប់ផ្តើមថ្នាក់ដំបូង ដែលអាចនឹងវង្វេងខាងវិញ្ញាណ ។ សូមលើកទឹកចិត្តដល់ពួកគេ ឲ្យពិចារណាប្រកបដោយការអធិស្ឋានអំពីរបៀបដែលពួកគេអាចជួយមនុស្សនោះឲ្យប្រែចិត្ត ហើយខិតមកកាន់តែជិតព្រះវរបិតាសួគ៌វិញ ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំពីរបៀបដែលពួកគេផ្ទាល់អាចនឹងត្រូវវង្វេង ហើយត្រូវការនូវការប្រែចិត្ត និងត្រឡប់មករកព្រះអង្គសង្គ្រោះវិញ ។

មេរៀនបន្ទាប់ (លូកា ១៨–យ៉ូហានទី ១)

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគ្រាមួយដែលមនុស្សម្នាក់បានប្រព្រឹត្តមិនល្អនឹងពួកគេ ហើយតើមានអារម្មណ៍យ៉ាងណាដែរ ។ សូមពន្យល់ថា នៅពេលពួកគេសិក្សាមេរៀនបន្ទាប់ នោះពួកគេនឹងរៀនអំពីរបៀបដែលព្រះអង្គសង្គ្រោះជ្រើសរើសឆ្លើយតបចំពោះអ្នកទាំងឡាយដែលបានប្រព្រឹត្តមិនល្អនឹងពួកគេ ។ ចូរសុំឲ្យពួកគេកត់សម្គាល់សេចក្តីលម្អិតបន្ថែមនៅក្នុងដំណើររឿងរបស់លូកា អំពីការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងសួនច្បារគេតសេម៉ានី និង អ្វីដែលព្រះយេស៊ូវបានសោយ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់នោះ ។

លូកា ១៨–២១

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ជាលើកចុងក្រោយនៅក្នុងជីវិតរមែងស្លាប់ ទ្រង់បានបង្រៀនដំណឹងល្អរបស់ទ្រង់ ហើយបានធ្វើអព្ភូតហេតុនៅក្នុងចំណោមប្រជាជននោះ ។ ទ្រង់បានដឹះលាចូលទៅក្នុងទីក្រុងយេរូសាឡិមដោយជោគជ័យ បានសម្អាតព្រះវិហារបរិសុទ្ធម្តងទៀត ហើយបានបង្រៀនប្រជាជននៅទីនោះ ។

យោបល់សម្រាប់ការបង្រៀន

លូកា ១៨–២១

ព្រះអង្គសង្គ្រោះបង្រៀននៅតាមផ្លូវទៅកាន់ទីក្រុងយេរូសាឡិម

ចូរពន្យល់សិស្សថា ពួកគេបានរៀនរួចទៅហើយអំពីព្រឹត្តការណ៍ជាច្រើនដែលបានកត់ត្រានៅក្នុងលូកា ១៨–២១ពីការសិក្សារបស់ពួកគេអំពីម៉ាថាយ និងម៉ាកុស ។ ដើម្បីរំឭកអំពីព្រឹត្តការណ៍ទាំងពីរនេះ សូមបង្ហាញរូបភាពដូចខាងក្រោម ៖ ព្រះគ្រីស្ទ និងកម្លោះអ្នកមាន (*Gospel Art Book* | ឆ្នាំ ២០០៩ | ល.រ. ៤៨; សូមមើលផងដែរ LDS.org) និង Triumphal Entry (*Gospel Art Book* ល.រ. ៥០) ។ សូមអញ្ជើញសិស្សឲ្យសង្កេតរឿងទាំងនេះសម្រាប់សិស្សក្នុងថ្នាក់ ហើយពន្យល់អំពីអ្វីដែលពួកគេចងចាំអំពីការរៀនសូត្រពីដំណើររឿងទាំងឡាយ ។





អ្នកគួរប្រើការសង្កេតដូចខាងក្រោមអំពីលូកា ១៨–២១ប្រសិនបើសិស្សត្រូវការជំនួយសូមចងចាំអំពីដំណើររឿងទាំងនេះ ។ (*កំណត់ចំណាំ ៖* ដើម្បីជួយសិស្សយល់នៅពេលព្រឹត្តិការណ៍ទាំងឡាយនៃមេរៀននេះ បានកើតមានឡើងនៅក្នុងជីវិតរបស់ព្រះអង្គសង្គ្រោះ អ្នកគ្រូតែបង្ហាញដល់សិស្សអំពីក្រាហ្វិក*ការងារបម្រើនៅក្នុងជីវិតរមែងស្លាប់សំខាន់ៗនៃព្រះយេស៊ូវគ្រីស្ទ*នៅក្នុងសេចក្តីបន្ថែមអំពីសៀវភៅសិក្សានេះ) ។

នៅពេលព្រះយេស៊ូវគ្រីស្ទបានធ្វើដំណើរទៅកាន់ទីក្រុងយេរូសាឡិម ជាលើកចុងក្រោយនៅក្នុងជីវិតរមែងស្លាប់ ទ្រង់បានបង្រៀនរឿងប្រៀបធៀបជាច្រើន និងព្យាបាលមនុស្សជាច្រើន ។ ទ្រង់បានអញ្ជើញកម្លោះអ្នកមានឲ្យប្រគល់អ្វីទាំងអស់ទៅដល់ជនក្រីក្រ ហើយមកតាមទ្រង់ ។ ទ្រង់បានព្យាបាលមនុស្សខ្វាក់ ។ ដោយមិនគិតអំពីការរិះគន់ ទ្រង់បានសោយជាមួយនឹងមេលើពួកអ្នកយកពន្ធនៅទីក្រុងយេរីកូ ។

ទ្រង់បានមកដល់ទីក្រុងយេរូសាឡិម នៅក្នុងចំណោមមនុស្សស្រែកសសើរ ដោយជិះលើលានៅពេលទ្រង់យាងចូលទៅក្នុងទីក្រុង ។ ជាថ្មីម្តងទៀត ទ្រង់បានបណ្តេញពួកអ្នកប្តូរប្រាក់ចេញពីព្រះវិហារបរិសុទ្ធ បានបង្រៀនប្រជាជននៅទីនោះ ហើយបានឆ្លើយតបនិងសំណួររបស់ពួកសង្ឃរាជ និងពួកអាចារ្យទាំងឡាយ ។ ទ្រង់បានសរសើរដល់ស្ត្រីមេម៉ាយមួយរូប ដែលបានថ្វាយប្រាក់ពីរស្លឹងដាក់ក្នុងហឺបព្រះវិហារបរិសុទ្ធ ។ ទ្រង់ក៏បានបង្រៀនពួកសិស្សអំពីការយាងមកជាលើកទីពីររបស់ទ្រង់ ។

ចូរពន្យល់ថា ដំណើររឿងភាគច្រើនដែលសិស្សនឹងសិក្សានៅក្នុងមេរៀននេះ គឺផ្តោតពិសេសចំពោះដំណឹងល្អរបស់លូកា ។

ដើម្បីរៀបចំសិស្សឲ្យសិក្សាដំណើររឿងទាំងនេះ ចូរសរសេរសំណួរដូចខាងក្រោមនៅលើក្តារខៀន ៖

តើសកម្មភាពអ្វីខ្លះ ដែលអាចបង្ហាញថា មនុស្សពិតជាចង់ខិតទៅកាន់តែជិតនឹងព្រះអម្ចាស់ ?

តើមានឥរិយាបទអ្វីខ្លះ ដែលបង្ហាញថាពួកគេពិតជាចង់ទទួលបានការអភ័យទោស ឬមានចំណងជ្រាថ្នាចង់បានជំនួយរបស់ព្រះអម្ចាស់មែននោះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសំណួរទាំងនេះ នៅពេលពួកគេសិក្សាអំពីដំណើររឿងដូចខាងក្រោមចេញពីការសរសេររបស់លូកា ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរដូចខាងក្រោមនៅលើក្តារខៀន ៖ *លូកា ១៨:១–៨*, *លូកា ១៨:៩–១៤*, *លូកា ១៨:៣៥–៤៣*, *លូកា ១៩:១–១០* ។ ចូរពន្យល់ថាវគ្គបទគម្ពីរទាំងនេះរួមមានទាំងរឿងប្រៀបធៀប និងព្រឹត្តិការណ៍ពីការធ្វើដំណើរចុងក្រោយរបស់ព្រះអង្គសង្គ្រោះឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិមអំឡុងជីវិតរមែងស្លាប់របស់គាត់ ។

សូមចាត់សិស្សម្នាក់ៗនូវសេចក្តីយោងបទគម្ពីរមួយ ដែលបានសរសេរនៅលើក្តារខៀន ឬពិចារណាបំបែកសិស្សក្នុងថ្នាក់ជាបួនក្រុម ហើយចាត់ឲ្យក្រុមនីមួយៗនូវសេចក្តីយោងបទគម្ពីរមួយនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់ៗឬក្រុមដើម្បីអានន្ទវគ្គគម្ពីរដែលបានចាត់ ហើយរៀបចំដើម្បីសម្តែងដំណើររឿង ឬរឿងប្រៀបធៀបនោះ ។ (ប្រសិនបើអ្នកមិនបំបែកសិស្សជាក្រុមៗទេ សូមពិចារណាធ្វើការសម្តែងដំណើររឿងនីមួយៗជាមួយសិស្សទាំងអស់ ។ ប្រសិនបើអ្នកជ្រើសរើសមិនសម្តែងដំណើររឿងទាំងនេះ អ្នកអាចអញ្ជើញសិស្សឲ្យសិក្សាសេចក្តីយោងបទគម្ពីរដែលបានចាត់ឲ្យដាច់ដោយឡែកពីគ្នានោះ តាមរយៈការប្រើសំណួរដូចខាងក្រោមបន្ទាប់មកបង្រៀនគ្នាទៅវិញទៅមកនូវអ្វីដែលពួកគេបានរៀន) ។ សូមពន្យល់ថាសិស្សម្នាក់នៅក្នុងថ្នាក់ ឬក្នុងក្រុមនីមួយៗ គប្បីធ្វើជាអ្នកអត្ថាធិប្បាយ ហើយអានដំណើររឿងបទគម្ពីរ នៅពេលសិស្សផ្សេងទៀតក្នុងថ្នាក់ ឬក្នុងក្រុមសម្តែងរឿង ។ ដើម្បីមានគារវភាព ហើយការគោរពចំពោះព្រះអង្គសង្គ្រោះ សូមណែនាំដល់អ្នកទាំងឡាយដែលសម្តែងរឿងលូកា ១៨:៣៥–៤៣ និងលូកា ១៩:១–១០

សូមបង្ហាញគារវភាព និងការគោរពដល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។

ដើម្បីគោរពដល់សេចក្តីថ្លៃថ្នូរនៃព្រះយេស៊ូវគ្រីស្ទ នោះសាសនាចក្រជាក់តាំងរូបភាពរបស់ព្រះអង្គសង្គ្រោះក្នុងមន្ទីរសិល្បៈ និងរោងល្ខោនដោយប្រុងប្រយ័ត្នបំផុត ។ យើងត្រូវតែបង្ហាញគារវភាពចំពោះទ្រង់នៅក្នុងថ្នាក់រៀនរបស់យើងផងដែរ ។ សូមចៀសវាងពីការពិពណ៌នាអំពីព្រះអង្គសង្គ្រោះក្នុងរបៀបមួយដែលគ្មានគារវភាព ។ អ្នកទាំងឡាយដែលដើរតួធ្វើជាព្រះសូរសៀងរបស់ទ្រង់ គប្បីប្រើតែព្រះបន្ទូលរបស់ទ្រង់ដូចបានកត់ត្រានៅក្នុងបទគម្ពីរ ។

កុំឲ្យមាន នរណាដើរតួជាតំណាងព្រះអង្គសង្គ្រោះឡើយ ។ សូមណែនាំដល់អ្នកអត្ថាធិប្បាយឲ្យអានព្រះបន្ទូលរបស់ព្រះយេស៊ូវ ហើយសួរដល់អ្នកដើរតួឲ្យឆ្លើយតបដូចជាទ្រង់ស្ថិតនៅលើឆាកក្នុងរឿងនោះដែរ ។

នៅពេលក្រុមរៀបចំខ្លួន សូមអញ្ជើញពួកគេពិភាក្សាអំពីសំណួរដូចខាងក្រោមរួមគ្នា ហើយត្រៀមខ្លួនប្រាប់អំពីចម្លើយរបស់ពួកគេទៅដល់សិស្សក្នុងថ្នាក់ បន្ទាប់ពីពួកគេសម្តែងរឿង ។ (សូមពិចារណាធ្វើការសរសេរសំណួរទាំងនេះនៅលើក្តារខៀន ឬ ចែកជាក្រដាសដល់ពួកគេ) ។

- តើតួឯក (មេម៉ាយ ពួកអ្នកយកពន្ធ មនុស្សខ្វាក់ ឬសាការី) មានបំណងអ្វីខ្លះនៅក្នុងដំណើររឿងនេះ ?
- តើតួឯកបានធ្វើអ្វីខ្លះដែលបានបង្ហាញពីបំណងប្រាថ្នារបស់គាត់ថាស្មោះនោះ ?
- តើមានរឿងអ្វីខ្លះកើតឡើងដោយសារតែសកម្មភាពស្មោះត្រង់របស់តួឯកទាំងនោះ ?
- តើគោលការណ៍ ឬគោលលទ្ធិអ្វីខ្លះ ដែលអ្នកអាចរកឃើញនៅក្នុងរឿងនេះ ?

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សក្នុងថ្នាក់ ឬក្រុមនីមួយៗឲ្យសម្តែងដំណើររឿងរបស់ពួកគេ នៅពេលអ្នកអត្ថាធិប្បាយអានខគម្ពីរ ។ នៅពេលសិស្សក្នុងថ្នាក់មើល ឬផ្តៀងតាមនៅក្នុងគម្ពីររបស់ពួកគេ ចូរសុំសិស្សឲ្យពិចារណាអំពីអ្វីដែលដំណើររឿងនីមួយៗអាចបង្រៀនយើងអំពីការអនុវត្តសេចក្តីជំនឿនៅក្នុងព្រះអម្ចាស់ ។ បន្ទាប់ពីការសម្តែងនីមួយៗ ចូរសុំឲ្យសិស្សក្នុងថ្នាក់ ឬក្រុមរាយការណ៍ពីចម្លើយរបស់ពួកគេនឹងសំណួរមុនៗ ។ ចូរសុំឲ្យពួកគេសរសេរនៅលើក្តារខៀននូវគោលការណ៍ ឬគោលលទ្ធិទាំងឡាយដែលពួកគេបានស្គាល់ ។

បន្ទាប់មកក្រុមទាំងឡាយបានរាយការណ៍ចម្លើយរបស់ពួកគេនឹងសំណួរទាំងឡាយ រួចសួរសំណួរដូចខាងក្រោម ៖

- តើភាពស្រដៀងគ្នាអ្វីខ្លះដែលអ្នកកត់សម្គាល់ឃើញថាមាននៅក្នុងសកម្មភាពនៃតួឯកនីមួយៗ ? (ពួកគេម្នាក់ៗបង្ហាញពីភាពខ្លាប់ខ្លួន ឬភាពស្មោះស្ម័គ្រនៅពេលពួកគេព្យាយាមដើម្បីទទួលបានតាមបំណងប្រាថ្នារបស់ពួកគេ) ។
- តើសកម្មភាពទាំងនេះអាចបង្រៀនយើងអ្វីខ្លះ អំពីការអនុវត្តសេចក្តីជំនឿទៅលើព្រះអម្ចាស់ ?
- តើភាពស្រដៀងគ្នាអ្វីខ្លះដែលអ្នកបានកត់សម្គាល់ឃើញថាតួឯកម្នាក់ៗ បានទទួលដែលជាលទ្ធផលពីសកម្មភាពរបស់ពួកគេនោះ ? (ម្នាក់ៗបានទទួលជំនួយ ឬក្តីមេត្តាករុណា) ។

ចូរសុំឲ្យសិស្សប្រាប់គោលការណ៍មួយចេញពីភាពស្រដៀងគ្នាក្នុងដំណើររឿងទាំងឡាយ ។ សិស្សអាចនឹងប្រាប់អំពីគោលការណ៍ផ្សេងមួយ ប៉ុន្តែចូរធ្វើយ៉ាង ណាដើម្បីគូសបញ្ជាក់ថា**ប្រសិនបើយើងស្មោះត្រង់ និងខ្ជាប់ខ្ជួន នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះអម្ចាស់ នោះយើងអាចទទួលបានក្តីមេត្តាករុណារបស់ទ្រង់** ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់នូវអ្វីដែលបង្ហាញថាមនុស្សម្នាក់កំពុងអនុវត្តសេចក្តីជំនឿទៅលើព្រះអម្ចាស់ ។

« សេចក្តីជំនឿពិតគឺផ្តោតនៅក្នុង និងទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយតែងតែដឹកនាំទៅរកសកម្មភាពសុចរិត » (« Ask in Faith »*Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៩៥) ។

សូមនាំសិស្សទៅកាន់សំណួរដែលបានសរសេរនៅលើក្តារខៀនដែលបានសរសេរនៅពេលចាប់ផ្តើមមេរៀន ។ ចូរសុំឲ្យសិស្សងាកទៅរកដៃគូ ហើយពិភាក្សាចម្លើយចំពោះសំណួរទាំងឡាយ ។

- តើមានវិធីអ្វីខ្លះ ដែលយើងអាចអនុវត្តសេចក្តីជំនឿទៅលើព្រះនាសព្វថ្ងៃនេះ ?

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ឲ្យស្តាប់មើលអត្ថន័យចំពោះបទពិសោធន៍នៃសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ ៖

« សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ គឺជាពរជ័យផ្ទាល់ខ្លួន និង សម្រាប់បុគ្គលម្នាក់ៗ ជាកម្លាំង ជាការការពារ ជាការធានាអះអាង ជាការដឹកនាំ ដែលពោរពេញដោយសេចក្តីស្រឡាញ់ ជាការលួងលោមចិត្ត ជាការគាំទ្រ និង ជាអំណោយទានទាំងឡាយខាងវិញ្ញាណ ដែលយើងបានទទួល និង ក៏ដោយសារតែតាមរយៈព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ » (« The Tender Mercies of the Lord » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៩៩) ។

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរដូចខាងក្រោមក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ (អ្នកគួរតែសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ។

- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ? តើក្តីមេត្តាករុណាអ្វីខ្លះដែលអ្នកឬពួកគេទទួលបទពិសោធន៍ជាលទ្ធផលនោះ ?
- ចូរពិចារណាអំពីរបៀបដែលអ្នកប៉ងចង់បានជំនួយ ឬក្តីមេត្តាករុណារបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នក ។ តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីអនុវត្តសេចក្តីជំនឿរបស់អ្នកទៅលើព្រះអម្ចាស់ ដើម្បីទទួលបានក្តីមេត្តាករុណារបស់ទ្រង់ ?

សូមអញ្ជើញសិស្សពីរបីនាក់ដែលមានអារម្មណ៍ថា អាចចែកចាយឲ្យរាយការណ៍អំពីអ្វីដែលពួកគេបានសរសេរ ។ សូមរំឭកសិស្សថាពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួនពេកនោះទេ ។ អ្នកក៏អាចនឹងចង់ចែកចាយបទពិសោធន៍របស់អ្នកជាមួយនឹងគោលការណ៍ហើយថ្លែងទីបន្ទាល់អំពីសេចក្តីពិតពេញលេញផងដែរ ។

លូកា ២២

សេចក្តីផ្តើម

នៅពេលនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ខិតជិតមកដល់ទីបញ្ចប់ នោះព្រះយេស៊ូវបានតាំងពិធីសាក្រាម៉ង់ឡើង បានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ឲ្យបម្រើអ្នកដទៃ ហើយបានបញ្ជាដល់ពេត្រុសឲ្យពង្រឹងដល់បងប្អូនប្រុសរបស់គាត់ ។ ពលិកម្មធួនរបស់ព្រះអង្គសង្គ្រោះបានចាប់ផ្តើមនៅសួនច្បារគែតសេម៉ានី ។ ទ្រង់ត្រូវបានគេចាប់ព្រះកាយ ហើយបានកាត់ទោសនៅចំពោះមុខលោកកៃផាស ។ ខណៈដែលព្រះអង្គសង្គ្រោះត្រូវបានគេកាត់ទោស ពេត្រុសបានបដិសេធថាពុំស្គាល់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

លូកា ២២:១–៣៨

ព្រះអង្គសង្គ្រោះបានតាំងពិធីសាក្រាម៉ង់ឡើង ហើយបានណែនាំដល់ពួកសិស្សរបស់ទ្រង់

ចូរសុំឲ្យសិស្សម្នាក់ៗនឹកស្រមៃ (ឬអ្នកអាចអញ្ជើញសិស្សពីរនាក់ឲ្យសម្តែងសកម្មភាពនេះ) ដែលពួកគេនឹងសមាជិកគ្រួសារម្នាក់កំពុងអង្គុយនៅលើឥដ្ឋ ។ សមាជិកគ្រួសារចង់ក្រោកឈរ ហើយសុំជំនួយ ។

- តើអ្នកអាចជួយពួកគេបានល្អប៉ុណ្ណា ប្រសិនបើអ្នកបន្តអង្គុយនៅលើឥដ្ឋ ?
- តើវាមានភាពខុសគ្នាយ៉ាងណា ប្រសិនបើអ្នកក្រោកឈរមុនគេនោះ ?

ចូរពន្យល់ថា ការប្រៀបធៀបនេះអាចជួយយើងឲ្យយល់នូវអ្វីដែលយើងអាចធ្វើ ដើម្បីជួយលើកអ្នកដទៃខាងវិញ្ញាណ ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ ខណៈពេលពួកគេសិក្សាលូកា ២២ដែលនឹងជួយពួកគេឲ្យដឹងអំពីរបៀប ដើម្បីជួយលើកអ្នកដទៃខាងវិញ្ញាណ ។

សូមសង្ខេបលូកា ២២:១–៣០ដោយរំឭកសិស្សថា នៅជិតចុងបញ្ចប់នៃ ការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះអង្គសង្គ្រោះបានជួបនឹងពួកសិស្សរបស់ទ្រង់ដើម្បីគោរពតាមបុណ្យរំលង ។ អំឡុងគ្រានោះ ព្រះអង្គសង្គ្រោះបានប្រកាសថា សិស្សរបស់ទ្រង់ម្នាក់នឹងក្បត់ទ្រង់ ទ្រង់បានតាំងពិធីបរិសុទ្ធនៃសាក្រាម៉ង់ឡើង បានបញ្ជាឲ្យបន្តធ្វើវាក្នុងការរំឭកចាំអំពីទ្រង់ ហើយបានបង្រៀនពួកសាវករបស់ទ្រង់ថា អ្នកទាំងឡាយដែលបម្រើដល់អ្នកដទៃគឺជាមនុស្សល្អបំផុត ។ ព្រះអង្គសង្គ្រោះ ក៏បានសរសើរពួកសិស្សរបស់ទ្រង់ឲ្យបន្តនៅជាមួយទ្រង់ ហើយសន្យានឹងពួកគេថា ថ្ងៃមួយពួកគេនឹងអង្គុយនៅលើបល្ល័ង្ក ហើយកាត់ក្តីដល់ពូជអំបូរទាំងដប់ពីរនៃអ៊ីស្រាអែលផងដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២២:៣១–៣២ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្លៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលដល់ស៊ីម៉ូនពេត្រុស ។ សូមពន្យល់ទៅកាន់សិស្សថា ការបកប្រែរបស់ យ៉ូសែប ស៊្មីធ ខ ទី៣១ និយាយថា « ហើយព្រះអម្ចាស់ក៏មានព្រះបន្ទូលថា ស៊ីម៉ូនៗអើយ មើលសាតាំងបានសូមចង់បានអ្នករាល់គ្នា ប្រយោជន៍នឹងរែងអ្នករាល់គ្នា ដូចជារែងអង្ករ » ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថាសាតាំងប្រាថ្នាចង់ធ្វើអ្វី ? (សាតាំងចង់រែងពេត្រុស និងពួកបរិសុទ្ធដូចជាស្រូវសាលី) ។

ចូរពន្យល់ថា អង្ករត្រូវបានរែងបំបែកអង្កាមចេញពីស្រូវសាលី ។

- តើអ្នកបានរៀនអ្វីខ្លះអំពីពេត្រុស ដែលបង្ហាញថាគាត់បានមានទីបន្ទាល់រួចហើយនោះ ? (ប្រសិនបើចាំបាច់ សូមរំឭកសិស្សថា ពេត្រុសបានប្រកាសទីបន្ទាល់របស់គាត់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រារបស់ព្រះ [សូមមើលម៉ាថាយ ១៦:១៣–១៧]) ។
- យោងតាមខទី ៣២តើពេត្រុសនៅតែត្រូវការបទពិសោធន៍អ្វីខ្លះ ពីមុនគាត់អាចពង្រឹងដល់បងប្អូនប្រុសរបស់គាត់ ?
- តើមានភាពខុសគ្នាយ៉ាងណារវាងការមានទីបន្ទាល់អំពីដំណឹងល្អ និងការផ្លាស់ប្រែចិត្តជឿដំណឹងល្អ ? (ការមានទីបន្ទាល់អំពីដំណឹងល្អមានន័យថា យើងបានទទួលស្គាល់បន្ទាល់ខាងវិញ្ញាណអំពីសេចក្តីពិតតាមរយៈព្រះវិញ្ញាណបរិសុទ្ធ [សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ទីបន្ទាល់ » ,scriptures.lds.org] ។ ការប្រែចិត្តជឿចំពោះដំណឹងល្អមានន័យថា « ជាការប្រែជំនឿ ចិត្ត និងជីវិត[របស់យើង] ដើម្បីទទួលយក ហើយធ្វើឲ្យបានស្របតាមព្រះហឫទ័យនៃព្រះ (កិច្ចការ ៣:១៩) » [សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ប្រែចិត្តជឿ, ការប្រែចិត្តជឿ, អ្នកប្រែចិត្តជឿ » ,scriptures.lds.org]) ។
- ផ្អែកទៅលើអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់ពេត្រុស តើយើងអាចធ្វើអ្វីខ្លះ នៅពេលយើងបានផ្លាស់ប្រែចិត្តជឿទៅលើដំណឹងល្អ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **នៅពេលយើងត្រូវបានផ្លាស់ប្រែចិត្តជឿដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នោះយើងអាចពង្រឹងដល់អ្នកដទៃ ។** ចូរពិចារណាអញ្ជើញសិស្សឲ្យគូសចំណាំឃ្លាដែលបង្រៀនសេចក្តីពិតនេះនៅក្នុង ខទី ៣២ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២២:៣៣–៣៤ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាមសែ្វងរកមើលរបៀបដែលពេត្រុសបានឆ្លើយតបចំពោះការដាស់តឿនរបស់ព្រះអង្គសង្គ្រោះ ដើម្បីត្រូវបានផ្លាស់ប្រែចិត្តជឿ ហើយពង្រឹងដល់បងប្អូនប្រុសរបស់គាត់ ។

- តើពេត្រុសបានឆ្លើយតបចំពោះការដាស់តឿនរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- តើព្រះអង្គសង្គ្រោះបានព្យាករថាពេត្រុសនឹងធ្វើអ្វី ?

ចូរពន្យល់ថាកំណែថ្មីដោយលម្អិតបន្ថែមអំពីដំណើររឿងនេះត្រូវបានកត់ត្រានៅក្នុងម៉ាថាយ ២៦។ សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ២៦:៣៥–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើពេត្រុសបាននិយាយអ្វីទៅកាន់ព្រះអង្គសង្គ្រោះ បន្ទាប់ពីបានស្តាប់ឮការព្យាករ ។

- តើពេត្រុសបានឆ្លើយតបយ៉ាងណា បន្ទាប់ពីបានស្តាប់ឮការព្យាករនេះ ?
- តើចម្លើយរបស់ពេត្រុសអាចបង្រៀនយើង អំពីអ្វីដែលគាត់បានគិតអំពីភាពរឹងមាំនៃទីបន្ទាល់របស់គាត់យ៉ាងណា ?

ការបង្រៀនអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅសួនច្បារគែតសេម៉ានី

មានដំណើររឿងបីអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសួនច្បារគែតសេម៉ានី ។ នៅក្នុងសៀវភៅសិក្សានេះ មរៀនម៉ាថាយ ២៦ផ្តោតទៅលើការចុះចូលរបស់ព្រះអង្គសង្គ្រោះទៅតាមព្រះទ័យរបស់ព្រះបិតាទ្រង់ ។ មរៀនម៉ាកុស ១៤ថ្លែងអំពីការរងទុក្ខរបស់ព្រះយេស៊ូវនៅក្នុងសួនច្បារគែតសេម៉ានី ។ មរៀនលូកា ២២គូសបញ្ជាក់អំពីភាពធ្ងន់ធ្ងរនៃការរងទុក្ខរបស់ទ្រង់ ។ ការបង្រៀនសិស្សអំពីទិដ្ឋភាពដ៏ពិសេសទាំងនេះនៃដង្វាយធួនអាចជួយពួកគេឲ្យមានបទពិសោធន៍យ៉ាងច្បាស់ នៅពេលពួកគេសិក្សាដំណើររឿងនីមួយៗ ។

លូកា ២២:៣៩–៥៣

ព្រះអង្គសង្គ្រោះបានរងទុក្ខនៅសួនច្បារគែតសេម៉ានីបង្ហូរឈាមពីគ្រប់រន្ធញើស ហើយត្រូវបានយូដាក្បត់ ។

ចូរពន្យល់ថា បន្ទាប់ពីបុណ្យរំលង ព្រះអង្គសង្គ្រោះ និងពួកសិស្សរបស់ទ្រង់បានចេញទៅសួនច្បារគែតសេម៉ានី ។ សូមអញ្ជើញឲ្យសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ២២:៣៩–៤៣ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើពេលទ្រង់យាងទៅសួនច្បារគែតសេម៉ានី ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាមខទី ៤៣តើនរណាបានជួយព្រះអង្គសង្គ្រោះឲ្យមានកម្លាំងដើម្បីធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ?
- តើសេចក្តីពិតអ្វីដែលយើងអាចរៀនមកពីដំណើររឿងនេះ៖ អំពីអ្វីដែលព្រះវរបិតាសួគ៌នឹងធ្វើសម្រាប់យើង ប្រសិនបើយើងព្យាយាមធ្វើតាមព្រះទ័យរបស់ទ្រង់នោះ ? (សិស្សអាចស្គាល់សេចក្តីពិតខុសៗគ្នា ប៉ុន្តែត្រូវបញ្ជាក់ថា**ប្រសិនបើយើងយល់ព្រមគោរពតាមព្រះវរបិតាសួគ៌ នោះទ្រង់នឹងប្រទានដល់យើងនូវកម្លាំងដើម្បីធ្វើតាមព្រះទ័យរបស់ទ្រង់**)។
- តើរបៀបមួយចំនួនអ្វីខ្លះ ដែលព្រះវរបិតាសួគ៌ពង្រឹងដល់យើង ?

ចូរពន្យល់ថាភាគច្រើនបំផុត ជំនួយដែលយើងទទួលមកពីព្រះវរបិតាសួគ៌នឹងពុំកើតមានតាមការបង្ហាញព្រះកាយរបស់ពួកទេវតាទេ ប៉ុន្តែទ្រង់នឹងជួយយើងតាមរបៀបដែលទ្រង់ស្គាល់ច្បាស់ថានឹងល្អបំផុតសម្រាប់យើង ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគ្រាមួយដែលពួកគេមានអារម្មណ៍ត្រូវបានពង្រឹងដោយព្រះវរបិតាសួគ៌ នៅពេលពួកគេព្យាយាមធ្វើតាមព្រះទ័យរបស់ទ្រង់ ។

ចូរពន្យល់ថា ដំណើររឿងរបស់លូកាអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី រួមមាននូវព័ត៌មានលម្អិតដែលពុំបញ្ចូលនៅក្នុងដំណើររឿងដែលត្រូវបានផ្តល់ឲ្យដោយម៉ាថាយ និងម៉ាកុសទេ ។ សូមអញ្ជើញសិស្សម្នាក់អានលូកា ២២:៤៤ឲ្យឮៗ ។ ចូរអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលលូកាពិពណ៌នាអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី ។

- តើលូកាបានពិពណ៌នាអ្វីខ្លះ អំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី ? (អ្នកគួរអញ្ជើញសិស្សឲ្យគូសចំណាំ៣ក្យនៅក្នុងខទី ៤៤ដែលបង្រៀនពីសេចក្តីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទបានហូរឈាមចេញពីគ្រប់រន្ធញើសនៅពេលទ្រង់រងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី ។** អ្នកអាចនឹងចង់ចង្អុលបង្ហាញថា ទិដ្ឋភាពនៃការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនេះគឺត្រូវបានព្យាករអស់ជាច្រើនសតវត្សរ៍ មកហើយ [សូមមើលម៉ូសាយ ៣:៧]) ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមអំពីអ្វីដែល ព្រះអង្គសង្គ្រោះមានបទពិសោធន៍ ចូរពន្យល់ថាព្រះអង្គសង្គ្រោះបានពិពណ៌នាអំពីការរងទុក្ខរបស់ទ្រង់ផ្ទាល់នៅក្នុងវិវរណៈមួយដែលបានប្រទានតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ បានកត់ត្រានៅក្នុងគោលលទ្ធិ និង សេចក្តីសញ្ញា ១៩។ សូមពិចារណាធ្វើការអញ្ជើញសិស្សឲ្យធ្វើសេចក្តីយោងបទគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៨ជាមួយនឹងលូកា ២២:៤៤នៅក្នុងគម្ពីររបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានពិពណ៌នាអំពីការរងទុក្ខរបស់ទ្រង់ ។

- តើព័ត៌មានលម្អិតបន្ថែមអ្វីខ្លះដែលយើងរៀនអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះមកពីការពិពណ៌នារបស់ព្រះអង្គផ្ទាល់នៅក្នុងខទី ១៨ ? (ការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទបានបណ្តាលឲ្យទ្រង់ « ត្រូវញ័រដោយសារតែការឈឺចាប់ . . . ត្រូវច្រួចឈាមចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយ និងវិញ្ញាណផង ») ។
- តើអ្នកមានគំនិតអ្វីខ្លះ ពេលដឹងថាព្រះយេស៊ូវគ្រីស្ទបានរងទុក្ខយ៉ាងច្រើនដើម្បីអ្នកនោះ ?

សូមសង្ខេបលូកា ២២:៤៥–៤៨ដោយការពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះរងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី នោះទ្រង់បានត្រូវយូដាស អេស្ការីយ៉ុត ក្បត់ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២២:៤៩–៥១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលនូវអ្វីដែលពេត្រុសបានធ្វើ នៅពេលមេសង្ឃ និងជនដទៃទៀត បានមកចាប់ព្រះកាយព្រះយេស៊ូវនោះ (សូមមើលយ៉ូហាន ១៨:១០ដែលជាដំណើររឿងតែមួយគត់ដែលប្រាប់អំពីពេត្រុសជាសាវក បានកាត់ត្រចៀករបស់អ្នកបម្រើ) ។

- តើពេត្រុសបានធ្វើអ្វីខ្លះ ចំពោះអ្នកបម្រើរបស់សង្ឃជាន់ខ្ពស់ ?
- តើហេតុអស្ចារ្យអ្វី ដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់អ្នកបម្រើនោះ ?

សូមសង្ខេបលូកា ២២:៥២–៥៣ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានសួរថាហេតុអ្វីក៏មេសង្ឃ និងអ្នកដទៃទៀត មកចាប់ព្រះកាយទ្រង់អំឡុងពេលយប់ ជាជាងអំឡុងពេលថ្ងៃ នៅពេលទ្រង់គង់នៅព្រះវិហារបរិសុទ្ធទៅវិញដូច្នេះ ។

លូកា ២២:៥៤–៧១

ព្រះយេស៊ូវត្រូវបានកាត់ទោសនៅពីមុខពួកសានហេឌ្រីន ហើយពេត្រុសបានបដិសេធថាពុំស្គាល់ទ្រង់

សូមសង្ខេបលូកា ២២:៥៤ដោយពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះត្រូវបាននាំយកទៅដល់ផ្ទះរបស់មេសង្ឃដើម្បីកាត់ទោស ពេត្រុសបានដើរតាម ។

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ ចូរផ្តល់ដល់ដៃគូនីមួយៗនូវច្បាប់ចម្លងនៃតារាងដូចខាងក្រោមមួយច្បាប់ (ឬសរសេរបង្ហាញវានៅលើក្តារខៀន) ។ សូមអញ្ជើញសិស្សឲ្យអានបទគម្ពីរយោងនៅក្នុងតារាង ហើយបំពេញនៅក្នុងតារាងនោះជាមួយនឹងដៃគូពួកគេ ។

លូកា ២២:៥៤–៦០

	តើមានរឿងអ្វីបានកើតឡើងចំពោះពេត្រុស ?	តើពេត្រុសបាននិយាយអ្វី ?
លូកា ២២:៥៥–៥៧		
លូកា ២២:៥៨		
លូកា ២២:៥៩–៦០		

- **ហេតុអ្វីក៏អ្នកគិតថា ពេត្រុសប្រហែលជាត្រូវបានល្បួងឲ្យបដិសេធថាមិនស្គាល់ព្រះយេស៊ូវចំពោះមនុស្សទាំងនេះ ?**

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២២:៦២–៦២ឲ្យ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវអ្វីដែលបានកើតឡើង បន្ទាប់ពីពេត្រុសបានបដិសេធថាមិនស្គាល់ព្រះអង្គសង្គ្រោះ ។

- **តើអ្វីបានកើតឡើង បន្ទាប់ពីពេត្រុសបានបដិសេធថាមិនស្គាល់ព្រះអង្គសង្គ្រោះនោះ ?**

ប្រសិនបើអាចធ្វើបាន សូមបង្ហាញរូបភាព*ការបដិសេធរបស់ពេត្រុស*ដោយ ខាល ហេនរីក ប្លិច ។ រូបភាពនេះមាននៅលើ LDS.org ។


- **ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ពេត្រុស តើគំនិត ឬអារម្មណ៍អ្វីខ្លះដែលអ្នកគិតថាអ្នកនឹងមាន នៅពេលព្រះអង្គសង្គ្រោះបានទតមើលមកអ្នក ? ហេតុអ្វី ?**
- **តើបទពិសោធន៍របស់ពេត្រុសបង្ហាញពីភាពខុសគ្នា រវាងការមានទីបន្ទាល់នៃដំណឹងល្អ និងការផ្លាស់ប្រែចិត្តជឿដំណឹងល្អយ៉ាងដូចម្តេច ?**

ចូរពន្យល់ថា ទោះជាពេត្រុសមានទីបន្ទាល់អំពីដំណឹងល្អក្តី ក៏គាត់ពុំទាន់បានផ្លាស់ប្រែចិត្តជឿទាំងស្រុងនៅឡើយដែរ ។ ទោះជាយ៉ាងណាក៏ដោយ គាត់បានទទួលស្គាល់ភាពទន់ខ្សោយរបស់គាត់ ដោយបានផ្លាស់ប្រែចិត្តជឿពេញលេញ ហើយបានលះបង់ជីវិតរបស់គាត់ដើម្បីបម្រើព្រះ និងចែកចាយដំណឹងល្អ ។

- **តើមេរៀនអ្វីខ្លះ ដែលយើងអាចរៀនពីបទពិសោធន៍របស់ពេត្រុស ?**

សូមសង្ខេបលូកា ២២:៦៣–៧១ដោយពន្យល់ថា ព្រះអង្គសង្គ្រោះ ត្រូវបានគេចំអក ហើយវាយដោយពួកមេសង្ឃ ។

សូមបញ្ចប់មេរៀនដោយអញ្ជើញសិស្សសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវរឿងជាច្រើនដែលពួកគេអាចធ្វើដើម្បីអាចជួយពួកគេបានផ្លាស់ប្រែចិត្តជឿយ៉ាងពិតប្រាកដចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើរឿងមួយនៃរឿងទាំងឡាយ នៅក្នុងបញ្ជីរបស់ពួកគេនាសប្តាហ៍នេះ ។



ការបដិសេធរបស់ពេត្រុស ដោយ ខាល ហេនរីក ប្លិច ។ ការតាំងពិពណ៌នៃសារមន្ទីរប្រវត្តិសាស្ត្រជាតិនៅមិន ហ្ស្រិនវើកស្បក នៅហ៊ីលលើរ៉ត ប្រទេស ដាណឺម៉ាក់ ។ ហាមចំតចម្លង ។

លូកា ២៣

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះត្រូវបានកាត់ទោសពីមុខប៉ុនទាស–ពីឡាត់ និងហេរ៉ូឌ អាន់ទីប៉ាស ។ មនុស្សទាំងពីរនាក់នេះ៖ ពុំរកឃើញកំហុសរបស់ព្រះអង្គ សង្គ្រោះអំពីបទឧក្រិដ្ឋដែលពួកសាសន៍យូដាបានចោទប្រកាន់ទ្រង់នោះទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពីឡាត់ បានប្រគល់ទ្រង់ឲ្យគេឆ្កាង ។ ព្រះយេស៊ូវអែម៉ាយទោសដល់ពួកទ័ពរ៉ូម ដែលបានឆ្កាងទ្រង់ ហើយបានមានបន្ទូលទៅចោរម្នាក់ដែលត្រូវបានគេឆ្កាងនោះផងដែរ ។ បន្ទាប់ពីព្រះយេស៊ូវសុគត យ៉ូសែបជាអ្នកស្រុកអើរីម៉ាថេ បានដាក់ព្រះសពទ្រង់នៅក្នុងផ្នូរ ។

យោបល់សម្រាប់ការបង្រៀន

លូកា ២៣:១–២៥

ព្រះអង្គសង្គ្រោះត្រូវបានកាត់ទោសនៅចំពោះមុខ ពីឡាត់ និង ហេរ៉ូឌ

មុនចាប់ផ្តើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ថាគេប្រពឹត្តមិនល្អដាក់អ្នក ដោយសារតែពាក្យសម្តី ឬសកម្មភាពរបស់មនុស្សផ្សេងនោះ ?

តើអ្នកឆ្លើយតបនឹងស្ថានភាពនោះយ៉ាងដូចម្តេច ?

សូមចាប់ផ្តើមដោយការអញ្ជើញសិស្សឲ្យសញ្ជឹង គិតចំពោះសំណួរទាំងឡាយនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាលូកា ២៣ដែលនឹងជួយពួកគេឲ្យដឹងអំពីរបៀបដើម្បីឆ្លើយតបនៅពេលពួកគេមានអារម្មណ៍ថាអ្នកដទៃធ្វើមិនល្អដាក់ខ្លួន ។

សូមរំឭកសិស្សថា បន្ទាប់ពីព្រះយេស៊ូវបានរងទុក្ខនៅក្នុងសួនគែតសេម៉ានី នោះមេសង្ឃបានចាប់ព្រះកាយទ្រង់ ហើយដាក់ទោសទ្រង់រហូតសុគត ។ ចូរពន្យល់ថា ចាប់តាំងពីពេលនោះមករហូតដល់ការសុគតរបស់ទ្រង់ ព្រះយេស៊ូវ បានជួបនឹងមនុស្សដូចខាងក្រោម ៖ ប៉ុនទាស–ពីឡាត់, ហេរ៉ូឌ អាន់ទីប៉ាស ក្រុមស្ត្រីស្មោះត្រង់មួយក្រុម ពួកទាហានរ៉ូម និងចោរពីរនាក់ដែលត្រូវបានគេឆ្កាងនៅសងខាងទ្រង់ ។ ប៉ុនទាស–ពីឡាត់ គឺជាអ្នកគ្រប់គ្រងជនជាតិរ៉ូមនៅក្នុងទឹកដីស្រុកយូដា ដែលរួមមានទាំងរដ្ឋធានីទីក្រុងយេរូសាឡិម ហេរ៉ូឌ អាន់ទីប៉ាស(ដែលបានសម្លាប់យ៉ូហានបាទីស្ទ) បានគ្រប់គ្រងដែនដីនៃស្រុកកាលីឡេ និង ស្រុកពេរៀ ក្រោមសិទ្ធិអំណាចរបស់រ៉ូម (សូមមើល លូកា ៣:១) ។

សូមបំបែកសិស្សជាគូៗ ហើយអញ្ជើញដៃគូនីមួយៗឲ្យអានលូកា ២៣:១–១១ ជាមួយគ្នា ហើយរកមើលភាពខុសគ្នារវាងការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះ ប៉ុនទាស–ពីឡាត់ និង ការឆ្លើយរបស់ទ្រង់ចំពោះ ហេរ៉ូឌ អាន់ទីប៉ាស ។ ដើម្បីជួយពួកគេយល់អំពីការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះពីឡាត់ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ ម៉ាកុស ១៥:២ អានថា « . . .ទ្រង់មានបន្ទូលឆ្លើយថា ត្រូវដូចលោកមានប្រសាសន៍ហើយ »។) ។

សូមអញ្ជើញសិស្សឲ្យពិភាក្សាជាមួយនឹងដៃគូរបស់ពួកគេអំពីចម្លើយចំពោះសំណួរដូចខាងក្រោម ៖

- តើការឆ្លើយតបរបស់ព្រះយេស៊ូវចំពោះពីឡាត់ ខុសគ្នាពីការឆ្លើយតបរបស់ទ្រង់ចំពោះហេរ៉ូឌយ៉ាងដូចម្តេច ?
- ហេតុអ្វីក៏ពីឡាត់ភ្ញាក់ផ្អើលចំពោះការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះលោក ?
- ហេតុអ្វីក៏ហេរ៉ូឌបានខកព្រះទ័យនឹងការស្ងាត់ស្ងៀមរបស់ព្រះអង្គសង្គ្រោះ ?

សូមសង្ខេបលូកា ២៣:១២–២៥ដោយពន្យល់ថា ទាំងពីឡាត់ និង ហេរ៉ូឌ ពុំអាចរកឃើញកំហុសរបស់ព្រះយេស៊ូវទេ ដូច្នេះពីឡាត់បានប្រាប់ទៅហ្វូងមនុស្សថា លោកនឹងដាក់ទណ្ឌកម្មព្រះយេស៊ូវ រួចហើយដោះលែងទ្រង់ ។ មនុស្សបានស្រែកទៅពីឡាត់ឲ្យដោះលែងបារ៉ាបាសជំនួសវិញ ហើយបញ្ជាឲ្យគេឆ្កាងព្រះយេស៊ូវវិញ ។ ពីឡាត់បានដោះលែងបារ៉ាបាស ហើយបានប្រគល់ព្រះយេស៊ូវឲ្យគេឆ្កាង ។ *(កំណត់ចំណាំ ៖* ដំណើររឿងរបស់ព្រះយេស៊ូវនៅចំពោះមុខរបស់ពីឡាត់ នឹងត្រូវបានបង្រៀនកាន់តែលម្អិតនៅក្នុងមេរៀនសម្រាប់ យ៉ូហាន ១៨–១៩) ។

លូកា ២៣:២៦–៥៦

ព្រះយេស៊ូវត្រូវបានឆ្កាងនៅចន្លោះពួកចោរពីរនាក់

សូមសង្ខេបលូកា ២៣:២៦–៣១ ដោយពន្យល់ថា ស្ត្រីស្មោះត្រង់មួយក្រុម ដែលបាននៅជាមួយទ្រង់ ចាប់តាំងពីការបម្រើរបស់ទ្រង់នៅស្រុកកាលីឡេ បានយំ ពេលពួកគេបានដើរតាមព្រះយេស៊ូវ ខណៈដែលទ្រង់ត្រូវបានគេនាំទៅកន្លែងនៃការឆ្កាងរបស់ទ្រង់ ។ ព្រះយេស៊ូវ

បានប្រាប់ពួកគេថាកុំទួញសោកអំពីទ្រង់ឡើយ ប៉ុន្តែទួញយំចំពោះការបំផ្លិចបំផ្លាញដ៏ឆាប់រហ័សដែល នឹងកើតមានមកលើទីក្រុងយេរូសាឡិមវិញ ពីព្រោះពួកយូដាបានបដិសេធស្តេចរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៣:៣២–៣៤ ឲ្យឮៗ ។ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែបស៊្មីធ សម្រាប់លូកា ២៣:៣៥ អានថា « គ្រានោះ ព្រះយេស៊ូវទ្រង់បានមានព្រះបន្ទូលថា ឱព្រះវរបិតាអើយ សូមអត់ទោសដល់ពួកគេផង ដ្បិតពួកគេមិនដឹងជាគេធ្វើអ្វីទេ ។ (មានន័យដល់ពួកទាហានដែលឆ្កាងទ្រង់) ហើយពួកគេបានចែកព្រះពស្ត្រទ្រង់ ហើយចាប់ឆ្នោត ។) ។ សូមអញ្ជើញសិស្សឲ្យដើរតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើ នៅពេលទ្រង់កំពុងត្រូវបានគេដំដែកគោលទៅនឹងឈើឆ្កាង ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ នៅពេលទ្រង់ត្រូវបានគេដំដែកគោលទៅនឹងឈើឆ្កាង ? (អ្នកគួរតែប្រាប់សិស្សឲ្យគូសចំណាំព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ដែលបានកត់ត្រានៅក្នុង ខ ៣៤) ។
- ហេតុអ្វីក៏ការអធិស្ឋានរបស់ព្រះអង្គសង្គ្រោះនៅគ្រានោះមានភាពអស្ចារ្យម៉្លេះ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីគំរូរបស់ព្រះអង្គសង្គ្រោះ អំពីរបៀបដែលយើងគប្បីធ្វើតប នៅពេលអ្នកដទៃប្រព្រឹត្តមិនល្អនឹងយើង ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេគូរស្តាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទដោយការជ្រើសរើសអភ័យទោសដល់អ្នកទាំងឡាយ ដែលប្រព្រឹត្តមិនល្អនឹងយើង**) ។
- តើការការអភ័យទោសមានអត្ថន័យយ៉ាងណា ?

អ្នកគួរតែពន្យល់ថា ការអភ័យទោសអ្នកដទៃពុំមែនមានន័យថាអ្នកទាំងឡាយដែលធ្វើបាបទាស់នឹងយើង មិនគួរទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេនោះទេ ។ ទាំងពុំមានន័យថា យើងគប្បីដាក់ខ្លួនយើងទៅក្នុងស្ថានភាពដែលមនុស្សនោះអាចបន្តប្រព្រឹត្តខុសនឹងយើងដែរ ។ តែការអភ័យទោសមានន័យថា ប្រព្រឹត្តនឹងអ្នកទាំងឡាយដែលប្រព្រឹត្តមិនល្អនឹងយើងដោយក្តីស្រឡាញ់ ហើយពុំឱបក្រសោបការតូចចិត្ត ឬកំហឹងចំពោះពួកគេ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរ « អភ័យទោស »scriptures.lds.org) ។

ចូរសុំឲ្យសិស្សពិចារណាដោយស្ងាត់ស្ងៀមថា តើមាននរណាម្នាក់ដែលពួកគេចាំបាច់ត្រូវអភ័យទោសឲ្យឬទេ ។ ដោយទទួលស្គាល់ថាជួនកាលវាមានការលំបាកដើម្បីអភ័យទោសដល់នរណាម្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់នូវអ្វីដែលពួកគេអាចធ្វើ បើពួកគេកំពុងមានការលំបាកក្នុងអភ័យទោសដល់នរណាម្នាក់ ។

« ខ្ញុំសូមអង្វរអ្នកឲ្យទូលសុំកម្លាំងមកពីព្រះអម្ចាស់ដើម្បីអភ័យទោស ។ . . . វាប្រហែលជាពុំងាយស្រួលទេ ហើយវាអាចនឹងប្រហែលជាពុំកើតមានយ៉ាងឆាប់រហ័សផងដែរ ។ ប៉ុន្តែ បើអ្នកនឹងស្វែងរកវាដោយចិត្តស្មោះសរ ហើយបណ្តុះវាឡើង នោះវានឹងកើតមានឡើង » (« Of You It Is Required to Forgive » *Ensign* ខែ មិថុនា ឆ្នាំ ១៩៩១ ទំព័រ ៥) ។

- តើប្រធាន ហ៊ិងគ្លី បានប្រឹក្សាដល់យើងឲ្យធ្វើអ្វីខ្លះ បើយើងកំពុងពុះពារក្នុងការអភ័យទោសដល់នរណាម្នាក់នោះ ?
- តើអ្នកគិតថាការអធិស្ឋានសុំកម្លាំងអាចជួយយើងឲ្យអភ័យទោសបានយ៉ាងដូចម្តេច ?

សូមឲ្យសិស្សគិតអំពីពេលមួយ នៅពេលពួកគេបានអភ័យទោសដល់នរណាម្នាក់ ។ សូមឲ្យសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។ (ចូរកុំសុំពួកគេកុំឲ្យបញ្ចេញឈ្មោះអ្នកទាំងនោះជាមួយសិស្សក្នុងថ្នាក់ឡើយ ហើយរំឭកពួកគេកុំឲ្យចែកចាយអ្វីដែលផ្ទាល់ខ្លួនខ្លាំងពេក) ។

សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ហើយអភ័យទោសដល់អ្នកទាំងឡាយដែលបានប្រព្រឹត្តខុសនឹងពួកគេ ។ សូមអញ្ជើញពួកគេឲ្យអធិស្ឋានសុំកម្លាំង និងសមត្ថភាពដើម្បីធ្វើដូច្នោះ ។

សូមសង្ខេបលូកា ២៣:៣៥–៣៨ដោយពន្យល់ថា ពួកអ្នកគ្រប់គ្រងយូដា និងពួកទាហានរ៉ូម បានចំអកដល់ព្រះអង្គសង្គ្រោះ ពេលទ្រង់ត្រូវជាប់ឈើឆ្កាង ។



សូមដាក់តាំងបង្ហាញរូបភាព*ការឆ្កាង* (*Gospel Art Book* | ឆ្នាំ ២០០៩ |លេខ. ៥៧ សូមមើលផងដែរគេហទំព័រ LDS.org) ។ សូមអញ្ជើញសិស្សម្នាក់អានលូកា ២៣:៣៩–៤៣ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលចោរពីរនាក់ ដែលបានព្យួរនៅសងខាងព្រះអង្គសង្គ្រោះប្រព្រឹត្តចំពោះទ្រង់ ។

- តើចោរទាំងពីរនាក់នោះម្នាក់ៗបានប្រព្រឹត្តនឹងព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- តើចោរនោះចង់មានន័យយ៉ាងណា ពេលគាត់និយាយថា « យើងត្រូវទោសចំពោះការដែលយើងបានប្រព្រឹត្ត » (ខទី ៤១) ?
- តើព្រះអង្គសង្គ្រោះឆ្លើយតបចំពោះចោរនេះយ៉ាងដូចម្តេច នៅពេលគាត់បានសូមព្រះអង្គសង្គ្រោះឲ្យចងចាំគាត់នៅក្នុងនគរនៃព្រះ ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែល្អប្រសើរអំពីអត្ថន័យរបស់ព្រះអង្គសង្គ្រោះ ពេលទ្រង់មានបន្ទូលទៅចោរនោះ ដើម្បីគាត់នឹងបាននៅជាមួយទ្រង់ក្នុងស្ថានបរមសុខ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោម ៖

« នៅក្នុងខគម្ពីរ ពាក្យ*ស្ថានបរមសុខ*ត្រូវបានប្រើនៅក្នុងរបៀបផ្សេងៗ ។ ទីមួយ វាសម្គាល់ថាជាកន្លែងនៃភាពសុខសាន្ត និងសុភមង្គលនៅក្នុងពិភពវិញ្ញាណបន្ទាប់ពីជីវិតរមែងស្លាប់ ដែលរក្សាទុកសម្រាប់អ្នកទាំងឡាយដែលបានទទួលបុណ្យជ្រមុជទឹក ហើយដែលបានបន្តនៅស្មោះត្រង់ (សូមមើលអាលម៉ា ៤០:១២,មរ៉ូណៃ ១០:៣៤) ។ . . .

« ការប្រើទីពីរនៃពាក្យ*ស្ថានបរមសុខ*ត្រូវបានរកឃើញ នៅក្នុងដំណើររឿងរបស់លូកា អំពីការឆ្កាងរបស់ព្រះអង្គសង្គ្រោះ ។ . . . ព្យាការី យ៉ូសែប ស៊្មីធ បានពន្យល់ថា . . . ព្រះអម្ចាស់បានមានបន្ទូលពិតថា ចោរនឹងបាននៅជាមួយទ្រង់ក្នុងពិភពនៃពួកវិញ្ញាណ » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* |ឆ្នាំ ២០០៤ | ១១១; សូមមើលផងដែរ *History of the Church,* ៥:៤២៤–២៥) ។

សេចក្តីយោងបទគម្ពីរ

បទគម្ពីរយោង គឺជាសេចក្តីយោងបទគម្ពីរមួយ ដែលអាចផ្តល់ព័ត៌មានបន្ថែម និងផ្តល់ការយល់ដឹងទៅលើវគ្គព្រះគម្ពីរដែលបានសិក្សានោះ ។ សេចក្តីយោងបទគម្ពីរ ឬ ការភ្ជាប់ គឺជាការភ្ជាប់សេចក្តីយោង ព្រះគម្ពីរដែលជួយសិស្សយល់នូវព្រះគម្ពីរ ។ សេចក្តីយោងបទគម្ពីរដែលអ្នកចែកចាយជាផ្នែកនៃមេរៀនរបស់អ្នក គប្បីតែពង្រីកការយល់ដឹងរបស់សិស្សអំពីបទគម្ពីរ ហើយពុំគ្រាន់តែជាឡើងវិញនូវសេចក្តីពិតដែលពួកគេបានរៀនរួចហើយនោះឡើយ ។

- យោងតាមព្យាការី យ៉ូសែប ស៊្មីធ តើចោរនឹងទៅកន្លែងណាបន្ទាប់ពីគាត់ស្លាប់ទៅ ? (ពិភពវិញ្ញាណ | សូមមើល អាលម៉ា ៤០:១១–១៤ |) ។
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីសេចក្តីថ្លែងរបស់ព្រះអង្គសង្គ្រោះថា ចោរនឹងនៅជាមួយទ្រង់ក្នុងស្ថានបរមសុខ (លូកា ២៣:៤៣) ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **វិញ្ញាណនៃមនុស្សទាំងអស់ចូលទៅក្នុងពិភពវិញ្ញាណនៅពេលពួកគេស្លាប់**) ។

ចូរពន្យល់ថា បទគម្ពីរផ្សេងទៀតអាចជួយយើងឲ្យយល់បានកាន់តែល្អប្រសើរអំពីអ្វីដែលកើតឡើងចំពោះចោរ និងអ្នកផ្សេងទៀតដូចជាគាត់នៅក្នុងពិភពនៃពួកវិញ្ញាណ ។ អ្នកគ្រូតែប្រាប់ដល់សិស្សឲ្យសរសេរគោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:២៨–៣២, ៥៨–៥៩ជាសេចក្តីយោងបទគម្ពីរនៅក្នុងវិមទំព័រនៃបទគម្ពីររបស់ពួកគេជិតនឹងលូកា ២៣:៤៣ ។

ចូរពន្យល់ថាគោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨មានន័យវិវរណៈមួយ ដែលត្រូវបានប្រទានឲ្យដោយប្រធាន យ៉ូសែប អេហ្វ ស៊្មីធ ដែលព្រះអង្គសង្គ្រោះបានបើកសម្តែងសេចក្តីពិតអំពីពិភពវិញ្ញាណ ។ សេចក្តីពិតទាំងនេះអាចជួយយើងយល់អំពីអ្វីដែលព្រះអង្គសង្គ្រោះចង់ចង្អុលបង្ហាញពេលទ្រង់មានបន្ទូលថា « ថ្ងៃនេះ អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ » (លូកា ២៣:៤៣) ។

សូមឲ្យសិស្សបួនប្រាំនាក់ឆ្លាស់វេនគ្នាអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:១១, ១៦, ១៨, ២៨–៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានធ្វើ ពេលទ្រង់យាងទៅពិភពវិញ្ញាណ ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីខ្លះ នៅពេលទ្រង់យាងទៅពិភពវិញ្ញាណ ?
- យោងតាមខទី ២៩តើព្រះអង្គសង្គ្រោះពុំយាងទៅកន្លែងណា ពេលទ្រង់នៅក្នុងពិភពវិញ្ញាណ ?
- តើព្រះអង្គសង្គ្រោះបានរៀបចំសារទូតសុចរិតរបស់ទ្រង់ឲ្យធ្វើអ្វីខ្លះ ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **នៅក្រោមការដឹកនាំរបស់ព្រះយេស៊ូវគ្រីស្ទ សារទូតសុចរិតទាំងឡាយបង្រៀនអំពីដំណឹងល្អដល់អ្នកទាំងឡាយណាដែលនៅក្នុងស្ថានឃុំព្រលឹង**) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ អាឡេន អេ ភីសុន អតីតសមាជិកក្រុមចិតសិបនាក់ប្រចាំតំបន់ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកអ្វីជាសារលិខិតរបស់ព្រះអង្គសង្គ្រោះ ចំពោះជនឧក្រិដ្ឋនៅលើឈើឆ្កាង ។



« ព្រះអង្គសង្គ្រោះបានឆ្លើយតបប្រកបដោយព្រះគុណ ហើយបានផ្តល់ក្តីសង្ឃឹមដល់គាត់ ។ ជនឧក្រិដ្ឋនេះ ទំនងជាពុំយល់ថាដំណឹងល្អនឹងត្រូវបានផ្សាយទៅដល់គាត់នៅក្នុងពិភពវិញ្ញាណ ឬថាគាត់នឹងទទួលឱកាសមួយដើម្បីរស់នៅស្របតាមព្រះ ពេលជាវិញ្ញាណនោះទេ (សូមមើលពេត្រុសទី ១ ៤:៦.គ. និង ស. ១៣៨:១៨–៣៤) ។ ពិតណាស់ ព្រះអង្គសង្គ្រោះមានព្រះទ័យអាណិតដល់ចោរដែលបានព្យួរនៅសងខាងទ្រង់ ពិតណាស់ថាទ្រង់ខ្វល់ព្រះទ័យយ៉ាងខ្លាំងចំពោះអ្នកទាំងឡាយដែលស្រឡាញ់ទ្រង់ ហើយព្យាយាមរក្សាបទបញ្ញត្តិរបស់ទ្រង់ ! » (« Words of Jesus: On the Cross» *Ensign* ខែ មិថុនា ឆ្នាំ ២០០៣ ទំព័រ ៣៤) ។

- តើសេចក្តីសង្ឃឹមអ្វីខ្លះដែលពាក្យសម្តីនៅក្នុងគ. និង ស. ១៣៨:២៩–៣២បានផ្តល់ដល់យើង ទាក់ទងនឹងអ្នកទាំងឡាយដែលបានស្លាប់ទៅដោយគ្មានចំណេះដឹងអំពីដំណឹងល្អនោះ ?

ចូរពន្យល់ថា ទោះជាដំណឹងល្អនឹងត្រូវបានផ្សាយដល់ចោរក៏ដោយ ក៏គាត់ពុំអាចត្រូវបានសង្គ្រោះដោយស្វ័យប្រវត្តិនៅក្នុងនគរបស់ព្រះដែរ ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានគោលលទ្ធិ និង សេចក្តីសញ្ញា ១៣៨:៥៨–៥៩ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលចោរនោះ និងអ្នកដទៃទៀតនៅក្នុងស្ថានឃុំព្រលឹង នឹងត្រូវធ្វើដើម្បីត្រូវបានប្រោសលោះ ។

- តើចោរ ឬវិញ្ញាណផ្សេងទៀតនៅក្នុងស្ថានឃុំព្រលឹងនឹងចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីត្រូវបានប្រោសលោះ ?
- តើអ្វីខ្លះនឹងកើតមានឡើងដល់វិញ្ញាណទាំងឡាយដែលប្រែចិត្ត ហើយទទួលយកពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ដែលបានធ្វើឡើងជំនួសឲ្យពួកគេនោះ ? (ពួកវិញ្ញាណ « ដែលប្រែចិត្ត នោះនឹងបានប្រោសលោះតាមរយៈការគោរពតាមពិធីទាំងឡាយនៃ | ព្រះវិហារបរិសុទ្ធ | » ត្រូវបានសម្អាតឲ្យបានស្អាត នោះនឹងបានទទួលរង្វាន់ | របស់ពួកគេ | » | គ. និង ស. ១៣៨:៥៨–៥៩ |) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីជួយដល់វិញ្ញាណទាំងនោះដែលដូចជាចោររូបនោះ ដែលត្រូវការការប្រោសលោះនោះ ? (យើងអាចបញ្ចប់កិច្ចការពង្សប្រវត្តិ ហើយចូលរួមនៅក្នុងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធសម្រាប់មរណជន) ។

សូមសង្ខេបលូកា ២៣:៤៤–៥៦ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះ បានសុគតនៅលើឈើឆ្កាងបន្ទាប់ពីទ្រង់មានបន្ទូលថា « ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណដល់ព្រះហស្តទ្រង់វិញ » (ខទី ៤៦) ។ យ៉ូសែបជាអ្នកស្រុកអេរីម៉ាថេ បានអុំព្រះសពរបស់ព្រះអង្គសង្គ្រោះនៅក្នុងសំពត់ទេសឯក ហើយបានដាក់ទ្រង់នៅក្នុងផ្នូរ ។

សូមបញ្ចប់មេរៀនដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

លូកា ២៤

សេចក្តីផ្តើម

នៅថ្ងៃទីបីបន្ទាប់ពីការសុគតរបស់ព្រះយេស៊ូវ ពួកទេវតានៅឯផ្នូរបានប្រកាសអំពីការរស់ឡើងវិញរបស់ទ្រង់ដល់ស្ត្រីមួយក្រុម ។ ពេលស្តាប់ឮការរាយការណ៍របស់ស្ត្រីនោះ ពួកសិស្សមួយចំនួនបានសង្ស័យអំពីលទ្ធភាពនៃការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ។ ពួកសិស្សពីរនាក់បានធ្វើដំណើរទៅក្រុងអេម៉ោស ពួកគេបាននិយាយជាមួយទ្រង់នៅតាមផ្លូវ ដោយពុំបានស្គាល់ព្រះអម្ចាស់ដែលបានរស់ឡើងវិញឡើយ ។ ក្រោយមកព្រះយេស៊ូវបានលេចមកឯពួកសាវករបស់ទ្រង់ និងអ្នកដទៃទៀត បានបង្ហាញរូបកាយដែលបានរស់ឡើងវិញរបស់ទ្រង់ដល់ពួកគេ ហើយបានបង្គាប់ដល់ពួកគេឲ្យផ្សាយការប្រែចិត្ត និងធ្វើជាសាក្សីដល់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

លូកា ២៤:១–១២

ពួកទេវតាប្រកាសដល់ក្រុមស្ត្រីថា ព្រះយេស៊ូវគ្រីស្ទបានរស់ឡើងវិញ

សូមបង្ហាញវីដេអូ« Jesus Is Laid in a Tomb »ចេញមកពីវីដេអូ*គម្ពីរបរិបូរអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ*ចុចផ្អាកមុនពេលពួកទេវតាមានបន្ទូលទៅពួកស្ត្រី (លេខកូដម៉ោង ០:០០–២:២៧) ។ វីដេអូនេះមាននៅក្នុង LDS.org។

ប្រសិនបើអ្នកពុំអាចបង្ហាញវីដេអូ សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេបាននៅឯផ្នូរ ពេលព្រះយេស៊ូវត្រូវបានគេដាក់នៅទីនោះ ហើយបានមើលឃើញថ្មរមៀលចេញពីខាងមុខមាត់ទ្វារ ។ ចូរសុំឲ្យពួកគេនឹកស្រមៃអំពីគំនិត និងអារម្មណ៍ដែលពួកគេអាចមាននៅទីនោះ ។ សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៤:១–៤ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលស្ត្រីនោះបានរកឃើញពេលពួកគេត្រឡប់ទៅឯផ្នូរក្នុងរយៈពេលបីថ្ងៃក្រោយមក ។

បន្ទាប់ពីការបង្ហាញវីដេអូ ឬការអានខទី ១–៤ ចូរសួរ ៖

- តើស្ត្រីនោះបានរកឃើញអ្វីនៅឯផ្នូរ ?
- តើអ្នកប្រហែលជាមានប្រតិកម្មយ៉ាងដូចម្តេច ប្រសិនបើអ្នកបានឃើញពួកទេវតាគង់នៅឯផ្នូរដែលបើកនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៤:៥–៨ ឲ្យ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលពួកទេវតាបានប្រាប់ដល់ស្ត្រីនោះ ។ ចូរសុំឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេបលូកា ២៤:៩–១០ ដោយពន្យល់ថា ស្ត្រីនោះបានចាកចេញពីផ្នូរ ហើយបានប្រាប់ដល់ពួកសាវកអំពីអ្វីដែលពួកគេបានឃើញ និងស្តាប់ឮ ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ២៤:១១ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលប្រតិកម្មរបស់ ពួកសាវកចំពោះពាក្យសម្តីរបស់ស្ត្រីទាំងនោះ ។ ចូរសុំឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

ចូរពន្យល់ថា បន្ទាប់ពីស្តាប់ឮស្ត្រីរាយការណ៍ហើយ នោះពេត្រុស និងយ៉ូហានបានរត់ទៅផ្នូរ ហើយបានឃើញថា ព្រះសពរបស់ព្រះយេស៊ូវបានបាត់ (សូមមើលលូកា ២៤:១២,យ៉ូហាន ២០:៩–៤) ។

លូកា ២៤:១៣–៣២

ព្រះអម្ចាស់ដ៏មានព្រះជន្មរស់បានមានបន្ទូលទៅពួកសិស្សពីរនាក់នៅលើផ្លូវទៅទីក្រុងអេម៉ោស

ចូរសុំឲ្យសិស្សពិចារណាអំពីគ្រាមួយពេលដែលពួកគេ ដូចជាពួកសិស្សនៅក្នុងដំណើររឿងនេះ បានមានបញ្ហានឹងជឿទៅលើគោលគំនិតនៃដំណឹងល្អមួយ ។

សូមពន្យល់ថានៅក្នុងលូកា ២៤:១៣ យើងរៀនថា សិស្សពីរនាក់បានចាកចេញពីទីក្រុងយេរូសាឡិម « នៅថ្ងៃនោះ » ដោយកំពុងធ្វើដំណើរប្រហែលជា ៦–៧.៥ ម៉ៃល (១០–១២ គ.ម) « ភូមិអេម៉ោស » ។ ការសិក្សាអំពីបទពិសោធន៍របស់ពួកគាត់នៅតាមផ្លូវទៅភូមិអេម៉ោស អាចជួយយើងដឹងអំពីរបៀបដើម្បីពង្រឹងទីបន្ទាល់របស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អានលូកា ២៤:១៤–១៧ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថានរណាបានចូលរួមដំណើរនឹងពួកសិស្សទាំងពីរនាក់នោះ ខណៈពេលពួកគាត់កំពុងដើរ ។

- តើនរណាបានចូលរួមដំណើរនឹងពួកសិស្សពេលពួកគាត់ធ្វើដំណើរនោះ ?
- ហេតុអ្វីក៏ពួកសិស្សពុំស្គាល់ព្រះយេស៊ូវ ? (ចូរពន្យល់ថា ពាក្យ*ភ្ជាន* [ខទី ១៦] មានន័យថារារាំង ឬបិទបាំង) ។

សូមបង្ហាញវីដេអូ« Christ Appears on the Road to Emmaus »(៣:៣២) ចេញមកពី *The Life of Jesus Christ Bible Videos* ដែលមាននៅ LDS.org។ ចូរសុំឲ្យសិស្សមើលនូវអ្វីដែលពួកសិស្សបានរៀនមកពីព្រះយេស៊ូវនៅពេលពួកគាត់ដើរជាមួយទ្រង់ដោយពុំស្គាល់ថាទ្រង់ជានរណានោះ ។ មុនពេលបង្ហាញវីដេអូ ចូរពន្យល់ថា ការសន្យានៅក្នុងវីដេអូគឺ

ដកស្រង់ចេញមកពីលូកា ២៤:១៧–៣៣ដើម្បីសិស្សអាចរៀងតាមនៅក្នុងព្រះគម្ពីរ ប្រសិនបើពួកគេចង់រៀងតាមនោះ ។ (ប្រសិនបើអ្នកពុំអាចបង្ហាញវីដេអូបាន សូមអញ្ជើញសិស្សឲ្យផ្លាស់វេណគ្នាអានឮៗចេញមកពីខគម្ពីរទាំងនេះ) ។

សូមចង្អុលបង្ហាញថា នៅក្នុងវីដេអូនេះ យើងពុំស្តាប់ឮអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្ស នៅពេលពួកគាត់ដើរនោះទេ ។ សូមអញ្ជើញសិស្សម្នាក់អានលូកា ២៤:២៧ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលថា តើព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សអ្វីខ្លះ: ។

- តើព្រះយេស៊ូវបានសួរដល់ពួកសិស្សអ្វីខ្លះ: ? តើទ្រង់បានប្រើឧបករណ៍អ្វី ដើម្បីបង្រៀនអំពីព្រះអង្គទ្រង់នោះ: ?
- យោងតាមលូកា ២៤:៣២តើការបង្រៀនរបស់ព្រះអង្គសង្គ្រោះចេញមកពីបទគម្ពីរនានាជះឥទ្ធិពលដល់ពួកសិស្សពីរនាក់នោះយ៉ាងដូចម្តេច ?
- តើវាមានន័យយ៉ាងណាដែលពួកសិស្ស ‹ មានសេចក្តីខ្ជួលខ្ចាញ់នៅក្នុងចិត្ត › ពួកគេនោះ: ? (ព្រះវិញ្ញាណបរិសុទ្ធបានថ្លែងទីបន្ទាល់ថាការបង្រៀនអំពីព្រះយេស៊ូវនៅក្នុងបទគម្ពីរគឺជាការពិត) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកសិស្សប្រហែលជាបានរៀនមកពីការប្រើបទគម្ពីររបស់ព្រះយេស៊ូវដើម្បីបង្រៀនពួកគេជាជាងគ្រាន់តែការបង្ហាញនូវ អត្តសញ្ញាណរបស់ព្រះអង្គ ។ អ្នកអាចនឹងសុំឲ្យសិស្សពីរបីនាក់ចែកចាយផ្តត់គំនិតរបស់ពួកគេ ។

- តើយើងអាចរៀនអ្វីបានខ្លះពីខគម្ពីរទាំងនេះ: អំពីឥទ្ធិពលនៃការសិក្សាគម្ពីរផ្ទាល់ខ្លួនរបស់យើង ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **នៅពេលយើងសិក្សាខគម្ពីរ សូមយើងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យបង្រៀនយើងអំពីព្រះយេស៊ូវគ្រីស្ទ**)។
- ក្រៅពីការខ្ជួលខ្ចាញ់នៅក្នុងចិត្តរបស់យើង តើអ្នកអាចពិពណ៌នាអំពីអ្វីដែលយើងអាចនឹងមានបទពិសោធន៍ពេលព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

ចូរសុំសិស្សឲ្យរកមើលខគម្ពីរមួយដែលបានជួយពួកគេមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធបង្រៀនពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញពួកគេឲ្យចែកចាយបទគម្ពីររបស់ពួកគេ ហើយនិងឥទ្ធិពលអ្វីដែលពួកគេបានទទួលអារម្មណ៍ ។ អ្នកក៏អាចនឹងចង់ចែកចាយខគម្ពីរមួយដែលបានជួយអ្នកដោយផ្ទាល់ផងដែរ ។

សូមរំឭកសិស្សថា ទោះជាវាសំខាន់ដើម្បីអានគម្ពីរសញ្ញាថ្មីសម្រាប់ពិន្ទុថ្នាក់សិក្ខាសាលាក្តី តែក៏វាកាន់តែសំខាន់ដើម្បីសិក្សាគម្ពីរតាមរបៀបមួយដែលព្រះវិញ្ញាណបរិសុទ្ធអាចពង្រឹងដល់ទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ: ។

សូមផ្តល់ច្បាប់ចម្លងនៃវត្ថុសិក្ខចំណាំក្នុងសៀវភៅដែលមានន្ទវសេចក្តីថ្លែងការដូចខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ (ឬអញ្ជើញសិស្សឲ្យសរសេរសេចក្តីថ្លែងការណ៍នៅលើវត្ថុសិក្ខចំណាំក្នុងសៀវភៅដែលនៅទំនេរ) ៖



« គោលបំណងដ៏ចម្បងនៃព្រះគម្ពីរទាំងឡាយ គឺដើម្បីបំពេញដល់ព្រលឹងយើងដោយសេចក្តីជំនឿទៅលើព្រះ: ជាព្រះវរបិតា និងទៅលើព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។ . . .

«. . . សេចក្តីជំនឿ កើតមានតាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ មកកាន់ព្រលឹងរបស់យើង ព្រះវិញ្ញាណមកកាន់វិញ្ញាណរបស់យើង នៅពេលយើងស្តាប់ ឬ អានព្រះបន្ទូលរបស់ព្រះ: ។ ហើយសេចក្តីជំនឿបានចាស់ទុំ នៅពេលយើងបន្តទទួលទានព្រះបន្ទូល ។ . . .

« . . . ចូរសិក្សាព្រះគម្ពីរដោយយកចិត្តទុកដាក់ ដោយមានចេតនា ។ សូមពិចារណា ព្រមទាំងអធិស្ឋានអំពីវា ។ ខគម្ពីរគឺជាវិវរណៈ: ហើយវានឹងនាំមកនូវវិវរណៈបន្ថែម » (ឌី ថត គ្រីស្តូហ្វឺសិន «The Blessing of Scripture» *Ensign ឬលីអាហ្គណាខែ* ឧសភា ឆ្នាំ ២០១០ ទំព័រ ៣៤, ៣៥) ។

សូមប្រាប់ឲ្យសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដោយអែលឌើរ គ្រីស្តូហ្វឺសិន នោះឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរៀងតាមរកមើលនូវរបៀបដែលពួកគេអាចកែលម្អការសិក្សាគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយ ដើម្បីសិក្សាបទគម្ពីររបស់ពួកគេតាមរបៀបដែលអញ្ជើញព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្កើនជំនឿ និងចំណេះដឹងរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចនឹងផ្តល់យោបល់ថា ពួកគេសរសេរគោលដៅនេះនៅលើខ្នងនៃវត្ថុសិក្ខចំណាំក្នុងសៀវភៅ ដើម្បីពួកគេអាចប្រើវាជាការរំឭកមួយ អំឡុងការសិក្សាបទគម្ពីររបស់ពួកគេ ។

លូកា ២៤:៣៣–៥៣

ព្រះយេស៊ូវបានលេចមកឯពួកសិស្សរបស់ទ្រង់ ហើយបង្ហាញរូបកាយដែលបានរស់ឡើងវិញរបស់ទ្រង់ដល់ពួកគេ

សូមអញ្ជើញសិស្សពីរនាក់ឲ្យយកគម្ពីររបស់ពួកគេមកខាងមុខថ្នាក់ ដើម្បីជួយដើរតួធ្វើជាទិដ្ឋភាពមួយ ដែលបង្ហាញពីអ្នកផ្សព្វផ្សាយសាសនាដើរទៅមាត់ទ្វារផ្ទះរបស់មនុស្សម្នាក់ ។ សូមប្រាប់ពួកគេឲ្យគោះទ្វារ ។ ធ្វើជាបើកទ្វារ ហើយស្វាគមន៍ពួកគេ ។ សូមប្រាប់ពួកគេឲ្យណែនាំខ្លួន ។ បន្ទាប់ពីពួកគេណែនាំខ្លួនហើយ ចូរនិយាយអ្វីខ្លះដូចខាងក្រោម ៖

« ខ្ញុំមានសំណួរមួយ ។ មនុស្សជាច្រើនដែលពុំជឿទៅលើជីវិតបន្ទាប់ពីការស្លាប់ ។ ពួកគេខ្លះបាននិយាយថា ពួកគេជឿទៅលើព្រះយេស៊ូវ ប៉ុន្តែពុំជឿថាទ្រង់បានរស់ឡើងវិញដោយមានរូបកាយទេ ។ ពួកគេនិយាយថា ទ្រង់បន្តរស់នៅតែជាវិញ្ញាណប៉ុណ្ណោះ: ។ តើអ្នកជឿអំពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទឬទេ ?

សូមផ្តល់ពេលដល់សិស្សទាំងពីរនាក់ដើម្បីឆ្លើយសំណួរ ។


សូមចង្អុលបង្ហាញថាលូកា ២៤:៣៦–៣៩គឺជាចំណេះចំណានខគម្ពីរមួយ ហើយអាចជួយបង្រៀនអំពីការរស់ឡើងវិញដោយពិតប្រាកដរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមផ្តល់នូវបរិបទសម្រាប់វគ្គគម្ពីរនេះ ដោយពន្យល់ថា ពួកសិស្សដែលនៅជាមួយព្រះយេស៊ូវនៅតាមផ្លូវទៅភូមិអេម៉ោស រំពេចនោះបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ ហើយបានរៀបរាប់ពីបទពិសោធន៍របស់ពួកគេទៅដល់ពួកសាវក និងពួកសិស្សដទៃទៀត (សូមមើលលូកា ២៤:៣៣–៣៥) ។ ខណៈដែលពួកគេកំពុងដើរ នោះព្រះអង្គសង្គ្រោះបានបង្ហាញព្រះកាយ (សូមមើលខ ៣៦) ។

សូមអញ្ជើញសិស្សម្នាក់ដែលបានជួយដើរតួឲ្យអានលូកា ២៤:៣៦–៣៩ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវភស្តុតាង ដែលព្រះយេស៊ូវពិតជាបានរស់ឡើងវិញ ហើយមានរូបកាយសាច់ និងឆ្អឹង ។

- តើព្រះយេស៊ូវបានអញ្ជើញពួកសិស្សរបស់ទ្រង់ឲ្យធ្វើអ្វី ដើម្បីជួយពួកគេឲ្យយល់ថា ទ្រង់គឺពុំមែនជាវិញ្ញាណ តែមានរូបកាយសាច់ឈាមនោះ ? (ចូរពិចារណាធ្វើការដាក់បង្ហាញរូបភាពព្រះយេស៊ូវបង្ហាញស្នាមរបួសទាំងឡាយរបស់ទ្រង់ [*Gospel Art Book* [ឆ្នាំ ២០០៩ [ទំព័រ ៦០, សូមមើលផងដែរ LDS.org]) ។
- តើអ្នកគិតថាអ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកមានវត្តមាន អំឡុងពេលដែលព្រះគ្រីស្ទបង្ហាញព្រះអង្គទ្រង់ដល់ពួកសិស្សរបស់ទ្រង់នោះ ?

អរគុណដល់សិស្សដែលបានជួយដើរតួ ហើយសុំឲ្យពួកគេទៅកាន់កន្លែងអង្គុយវិញ ។ សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៤:៤០–៤៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលនូវអ្វីផ្សេងទៀតដែលព្រះយេស៊ូវបានធ្វើ ដើម្បីបង្ហាញថា ទ្រង់មានរូបកាយដែលរស់ឡើងវិញ (ឬរាងកាយ) ។

- តើព្រះអង្គសង្គ្រោះបានធ្វើអ្វីផ្សេងទៀត ដើម្បីបង្ហាញថាទ្រង់មានរូបកាយរស់ឡើងវិញនោះ ?
- តើគោលលទ្ធិអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? (សិស្សអាចប្រាប់អំពីគោលលទ្ធិផ្សេងមួយ ប៉ុន្តែចូរប្រាកដថាអ្នកគូសបញ្ជាក់ថា**ព្រះយេស៊ូវគ្រីស្ទមានរូបកាយសាច់ និងឆ្អឹង ដែលបានរស់ឡើងវិញ ។** សូមសរសេរគោលលទ្ធិនេះនៅលើក្តារខៀន) ។
- ហេតុអ្វីគោលលទ្ធិនេះសំខាន់ដើម្បីយល់ និងជឿ ?



សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗ ៖

« តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ—បានសង្គ្រោះពីការស្លាប់ខាងរូបកាយ (សូមមើលកូរិនថូសទី១ ១៥:២២) ។ ការរស់ឡើងវិញ គឺជាការរួបរួមឡើងវិញនៃវិញ្ញាណនឹងរូបកាយនៅក្នុងស្ថានភាពអមតភាពល្អឥតខ្ចោះមួយ ឈប់ស្ថិតក្រោមឥទ្ធិពលនៃជំងឺ ឬសេចក្តីស្លាប់ទៀតឡើយ (សូមមើលអាលម៉ា ១១:៤២–៤៥) ។ . . .

« ការយល់ដឹង និងទីបន្ទាល់អំពីការរស់ឡើងវិញ អាចផ្តល់ដល់អ្នកនូវក្តីសង្ឃឹម និងទស្សនវិស័យ ពេលអ្នកជួបនឹងការលំបាក ការសោកល្បួងនានា ហើយយកឈ្នះលើជីវិត ។ អ្នកអាចរកបានភាពលួងលោមនៅក្នុងការអះអាងថា ព្រះអង្គសង្គ្រោះមានព្រះជន្មរស់ ហើយថាតាមរយៈដង្វាយធួនរបស់ទ្រង់ ‹ ទ្រង់ផ្តាច់ចំណងទាំងឡាយនៃសេចក្តីស្លាប់ ដើម្បីកុំឲ្យផ្លូវមានជ័យជំនះ ហើយដើម្បីឲ្យទ្រនិចនៃសេចក្តីស្លាប់ត្រូវបានលេបទៅក្នុងសេចក្តីសង្ឃឹមនៃសិរីល្អ › (អាលម៉ា ២២:១៤) » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* [ឆ្នាំ ២០០៤ [ទំព័រ ១៣៩, ១៤០) ។

- តើឧទាហរណ៍មួយចំនួននៃការសាកល្បងអ្វីខ្លះ ដែលសេចក្តីសង្ឃឹមនៃការរស់ឡើងវិញផ្តាល់ខ្លួនរបស់យើង អាចជួយយើងឲ្យស៊ូទ្រាំ ?

ចូរសុំឲ្យសិស្សខ្លះថ្លែងទីបន្ទាល់អំពីការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ហើយពន្យល់ពីមូលហេតុដែលគោលលទ្ធិនៃការរស់ឡើងវិញសំខាន់ចំពោះពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៤:៤៤–៥៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ដូចជាពួកគេមានចំណែកនៅក្នុងក្រុមពួកសិស្សដែលនៅជាមួយទ្រង់ ហើយពិចារណាអំពីការបង្រៀនណាមួយ ដែលមានអត្ថន័យបំផុតចំពោះពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេអំពីការបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានពិភាក្សា ។

ចំណេះចំណានខគម្ពីរ—លូកា ២៤:៣៦–៣៩

ដើម្បីជួយសិស្សទន្ទេញចាំលូកា ២៤:៣៦–៣៩សូមបំបែកថ្នាក់ជាបួនក្រុម ។ សូមចាត់ខផ្សេងមួយចេញមកពីវគ្គគម្ពីរនេះដល់ក្រុមនីមួយៗ ហើយណែនាំសិស្សក្នុងក្រុមនីមួយៗធ្វើការរួមគ្នាដើម្បីទន្ទេញចាំខគម្ពីរដែលបានចាត់ឲ្យពួកគេ ។ បន្ទាប់ពីពីរបីនាទីមក ចូរសុំឲ្យក្រុមនីមួយៗសូត្រខគម្ពីរដែលចាត់ឲ្យពួកគេនោះ តាមលំដាប់នៃខ ។ អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យសូត្រខគម្ពីររបស់ពួកគេម្តងទៀតសម្រាប់ថ្នាក់ក្រោយៗ រហូតដល់វគ្គគម្ពីរទាំងមូលត្រូវបានស្គាល់គ្រប់គ្នា ។

លូកា២៤:៣៦–៣៩ គឺជាចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះ ដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

សេចក្តីផ្តើមនៃ

ដំណឹងល្អយោងតាមយ៉ូហាន

ហេតុអ្វី ត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងគ្រាមួយដែលមានការបៀតបៀនទាស់នឹងពួកគ្រីស្ទាន ការក្បត់សាសនា និងជម្លោះអំពីលក្ខណៈសម្បត្តិនៃព្រះយេស៊ូវគ្រីស្ទចេះតែកើនឡើង នោះសាវកយ៉ូហានបានកត់ត្រាទីបន្ទាល់របស់លោកអំពីព្រះអង្គសង្គ្រោះ ។ ការសិក្សាដំណឹងល្អរបស់យ៉ូហានអាចជួយសិស្សឲ្យស្គាល់ព្រះវរបិតាសួគ៌តាមរយៈការងារបម្រើរបស់ព្រះរាជបុត្រាទ្រង់គឺ ព្រះយេស៊ូវគ្រីស្ទ ។ ដំណើររឿងរបស់យ៉ូហានបង្រៀនយើងថា ជនដែលរស់នៅស្របតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទអាចទទួលបានពរដ៏ធំធេង រួមបញ្ចូលទាំងជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

សាវកយ៉ូហានបានសរសេរគម្ពីរនេះ ។ នៅក្នុងគម្ពីរនេះគាត់បានហៅខ្លួនឯងថាជា « សិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់ » (សូមមើល យ៉ូហាន ១៣:២៣, ១៩:២៦, ២០:២, ២១:៧, ២០) ។

យ៉ូហាន និងបងប្រុសរបស់គាត់ឈ្មោះ យ៉ាកុប គឺជាអ្នកនេសាទគ្រី (សូមមើល ម៉ាថាយ ៤:២១) ។ ពីមុនភ្លាយជាសិស្ស និងជាសាវកម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ តាមពិតទៅ យ៉ូហានគឺជាអ្នកដើរតាមយ៉ូហាន បាទីស្ទ (សូមមើល យ៉ូហាន ១:៣៥–៤០ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « យ៉ូហាន កូនប្រុសរបស់សេបេដេ » scriptures.lds.org) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

យើងពុំដឹងពីពេលវេលាជាក់លាក់ដែលយ៉ូហានបានសរសេរគម្ពីរនេះទេ ។ កាលបរិច្ឆេទដែលបានដាក់ស្នើសម្រាប់ការសរសេររបស់គម្ពីរនេះគឺ នៅចន្លោះពីគ.ស.ទី ៦០ និង គ.ស.ទី ១០០ ។ ពួកអ្នកសរសេរគ្រីស្ទានកាលពីបុរាណនៅសតវត្សទីពីរនៃគ.ស.បានណែនាំថា យ៉ូហានបានសរសេរគម្ពីរនេះនៅអេភេសូរក្នុងតំបន់អាស៊ីតូច (ប្រទេសតួកគីសព្វថ្ងៃ) ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយតើហេតុអ្វី ?

ទោះបីជាការសរសេររបស់យ៉ូហានគឺសម្រាប់មនុស្សគ្រប់គ្នាក្តី ប៉ុន្តែសារលិខិតរបស់គាត់ក៏មានសម្រាប់ក្រុមអ្នកអានជាក់លាក់មួយចំនួនផងដែរ ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងក្រុមមួយនៃពួកសាវកដប់ពីរនាក់បានសរសេរថា ៖ « ដំណឹងល្អរបស់យ៉ូហានគឺជាដំណើររឿងសម្រាប់ពួកបរិសុទ្ធ វាគឺជាដំណឹងល្អដ៏ឧត្តមសម្រាប់សាសនាចក្រ » (*Doctrinal New Testament Commentary* វ៉ុល ៣ [ឆ្នាំ ១៩៦៥–៧៣] ១:៦៥) ។ យ៉ូហានបានថ្លែងថា គោលបំណងរបស់គាត់ក្នុងការសរសេរគម្ពីរនេះគឺដើម្បីទាក់ទាញមនុស្សដទៃទៀតឲ្យ « ជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ » (យ៉ូហាន ២០:៣១) ។ « ទិដ្ឋភាពនៃជីវប្រវត្តិរបស់ព្រះយេស៊ូវដែល [យ៉ូហាន] ពិពណ៌នាគឺត្រូវបានជ្រើសរើស ហើយរៀបចំយ៉ាងផ្ទៃផ្ទង់ដោយមានគោលបំណងនេះ នៅក្នុងគំនិត » (Bible Dictionary « John, Gospel of ») ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ប្រហែលជា ៩២ ភាគរយនៃឯកសារនៅក្នុងដំណឹងល្អរបស់យ៉ូហាន គឺគ្មាននៅក្នុងដំណើររឿងនៃដំណឹងល្អផ្សេងទៀតឡើយ ។ ប្រហែលដោយសារយ៉ូហានមានបំណងចង់សរសេរទៅកាន់ប្រជាជននោះ—ជាសមាជិកសាសនាចក្រដែលមានការយល់ដឹងពីព្រះយេស៊ូវគ្រីស្ទរួចហើយ—គឺខុសពីពួកអ្នកអានរបស់ម៉ាថាយ ម៉ាកុស និងលូកា ។ នៅក្នុងចំណោមអត្ថហេតុទាំងប្រាំពីរដែលយ៉ូហានបានលើកឡើង មានអត្ថហេតុប្រាំពុំត្រូវបានកត់ត្រានៅក្នុងដំណឹងល្អផ្សេងទៀតនោះទេ ។ កាលម៉ាថាយ ម៉ាកុស និងលូកា បានបង្ហាញនូវព័ត៌មានដែលគួរឲ្យពិចារណាស្តីពីការងារបម្រើរបស់ព្រះយេស៊ូវនៅក្នុងស្រុកកាលីឡេ យ៉ូហានបានកត់ត្រាពីព្រឹត្តិការណ៍ជាច្រើនដែលបានកើតឡើងនៅក្នុងស្រុកយូដា ។ ដំណឹងល្អរបស់យ៉ូហានគឺជាគោលលទ្ធិដ៏វិសេសវិសាល ដោយមាននូវប្រធានបទដ៏សំខាន់មួយចំនួនរបស់វា ដែលលើកឡើងពីទេវភាពរបស់ព្រះយេស៊ូវថាជាព្រះរាជបុត្រានៃព្រះ ជង្វាយធួននៃព្រះគ្រីស្ទ ជីវិតដ៏នៅអស់កល្បជានិច្ច ព្រះវិញ្ញាណបរិសុទ្ធ សេចក្តីត្រូវការដើម្បីកើតជាថ្មី សារៈសំខាន់នៃការស្រឡាញ់មនុស្សដទៃ និងសារៈសំខាន់នៃការជឿលើព្រះអង្គសង្គ្រោះ ។

យ៉ូហានបានគូសបញ្ជាក់អំពីទេវភាពរបស់ព្រះយេស៊ូវថាជាព្រះរាជបុត្រានៃព្រះ ។ យ៉ូហានបានកត់ត្រាសេចក្តីយោងរបស់ព្រះយេស៊ូវចំពោះព្រះវរបិតាទ្រង់ជាង ១០០ ដោយមានសេចក្តីយោងជាង ២០ នៅក្នុងយ៉ូហាន ១៤ តែឯង។ ការចូលរួមចំណែកដ៏ធំមួយរបស់យ៉ូហាន គឺជាការដាក់បញ្ចូលរបស់គាត់អំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកសិស្សរបស់ទ្រង់មុនទ្រង់ត្រូវបានគេចាប់ព្រះកាយ រួមមានការអធិស្ឋានជំនួសដ៏អស្ចារ្យ ដែលបានធ្វើឡើងនៅយប់ដែលទ្រង់បានរងទុក្ខនៅក្នុងសួនច្បារគែតសេម៉ានី ។ ផ្នែកនេះនៅក្នុងដំណើររឿងរបស់យ៉ូហាន (យ៉ូហាន ១៣–១៧) ជាតំណាងដែលលើសពី ១៨ ភាគរយនៃទំព័រទាំងឡាយនៅក្នុងយ៉ូហានទៅទៀត ដោយផ្តល់ឲ្យយើងនូវការយល់ដឹងជាច្រើនទៀតអំពីគោលលទ្ធិរបស់ព្រះអង្គសង្គ្រោះ និងអ្វីដែលទ្រង់ពេញចង់បានពីពួកសិស្សរបស់ទ្រង់ ។

គម្រោង

យ៉ូហាន ១ យ៉ូហានថ្លែងទីបន្ទាល់ពីទេវភាពនៃជីវិតមុនផែនដី និងបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទដើម្បីផ្តល់សេចក្តីសង្គ្រោះដល់មនុស្សលោកគ្រប់រូប ។ យ៉ូហានកត់ត្រាពិធីបុណ្យជ្រមុជទឹករបស់ព្រះយេស៊ូវ និងការហៅរបស់ពួកសិស្សមួយចំនួន ។

យ៉ូហាន ២–៤ ព្រះយេស៊ូវគ្រីស្ទធ្វើទឹកឲ្យក្លាយទៅជាស្រា ។ ទ្រង់បង្រៀននីកូដេមអំពីការកើតជាថ្មីខាងវិញ្ញាណ ហើយថ្លែងទីបន្ទាល់ទៅកាន់ស្ត្រីនៅអណ្តូងទឹកថា ទ្រង់គឺជាព្រះគ្រីស្ទ ។ ទ្រង់ព្យាបាលកូនប្រុសរបស់បុរសត្រកូលខ្ពស់ម្នាក់ ។

យ៉ូហាន ៥–៧ ព្រះអង្គសង្គ្រោះព្យាបាលបុរសខ្វិនជើងម្នាក់នៅឯស្រះបេថែសដា ហើយប្រកាសពីព្រះចេស្តា និងសិទ្ធិអំណាចនៃព្រះបស់ទ្រង់ ។ ទ្រង់ប្រទានអាហារដល់មនុស្សប្រាំពាន់នាក់នៅក្នុងការរៀបចំសម្រាប់ការបង្រៀនរបស់ទ្រង់អំពីនំប៉័ងជីវិត ទ្រង់ប្រកាសថា ទ្រង់គឺជាព្រះមែស៊ី ហើយប្រកាសនៅក្នុងបុណ្យបារាំថា មានតែជនដែលទទួលយកទ្រង់ប៉ុណ្ណោះ ដែលអាចមានជីវិតដ៏នៅអស់កល្បជានិច្ចបាន ។

យ៉ូហាន ៨–១០ តាមរយៈបទពិសោធន៍នៃស្ត្រីដែលបាននាំមក ដោយសារបានប្រព្រឹត្តអំពើកំផិត ព្រះយេស៊ូវបង្រៀនអំពីសេចក្តីមេត្តាករុណា និងការប្រែចិត្ត ។ ទ្រង់ប្រកាសថា ទ្រង់គឺជាព្រះយេហូវ៉ា ជាព្រះដ៏ជាព្រះ ។ ទ្រង់ព្យាបាលបុរសម្នាក់ដែលកើតមកខ្វាក់ភ្នែក ហើយរៀបរាប់ថាទ្រង់គឺជាអ្នកគង្វាលល្អ ដែលស្រឡាញ់ ហើយលះបង់ព្រះជន្មរបស់ទ្រង់ការពារចៀមរបស់ទ្រង់ ។

យ៉ូហាន ១១–១៣ ព្រះយេស៊ូវគ្រីស្ទបានប្រោសឡាសារឲ្យរស់ពីស្លាប់ ដោយបង្ហាញពីព្រះចេស្តារបស់ទ្រង់លើសេចក្តីស្លាប់ ។ ទ្រង់យាងចូលក្រុងយេរូសាឡិមដោយជោគជ័យ ។ នៅក្នុងអាហារយប់ថ្ងៃចុងក្រោយ ព្រះយេស៊ូវលាងជើងពួកសិស្សរបស់ទ្រង់ ហើយបង្រៀនពួកគេឲ្យចេះស្រឡាញ់គ្នា ។

យ៉ូហាន ១៤–១៦ ព្រះយេស៊ូវណែនាំពួកសិស្សទ្រង់ស្តីពីទំនាក់ទំនងរវាងសេចក្តីស្រឡាញ់ និងការគោរពប្រតិបត្តិ ។ ទ្រង់សន្យានឹងបញ្ជូនព្រះដ៏ជាជំនួយ (ព្រះវិញ្ញាណបរិសុទ្ធ) ហើយបម្រើពួកសិស្សរបស់ទ្រង់ដោយផ្ទាល់ ។ ទ្រង់ប្រកាសថា ទ្រង់គឺជាដើមទំពាំងបាយជូរដ៏ពិត ហើយថាទ្រង់បានយកឈ្នះលើលោកិយហើយ ។

យ៉ូហាន ១៧–១៩ ព្រះយេស៊ូវបានធ្វើការអធិស្ឋានជំនួសសម្រាប់ពួកសិស្សរបស់ទ្រង់ និងជនដែលនឹងជឿលើការបង្រៀនរបស់ពួកគេ ។ ទ្រង់ត្រូវបានគេក្បត់ ចាប់ព្រះកាយកាត់ទោស ហើយផ្តន្ទាទោស ។ បន្ទាប់ពីការរងទុក្ខនៅលើឈើឆ្កាង ទ្រង់បានសុគត ហើយត្រូវបានគេបញ្ចុះក្នុងផ្នូរ ។

យ៉ូហាន ២០–២១ ព្រះយេស៊ូវគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញបានបង្ហាញអង្គទ្រង់ដល់ម៉ារា ម៉ាក់ដាឡានៅសួនផ្នូរ ហើយបន្ទាប់មកដល់ពួកសិស្សមួយចំនួននៅក្រុងយេរូសាឡិម ។ ទ្រង់បង្ហាញអង្គទ្រង់ដល់ពួកសិស្សប្រាំពីរនាក់នៅឯសមុទ្រកាលីឡេ ហើយអនុញ្ញាតឲ្យពេត្រុសដឹកនាំពួកសិស្សទាំងឡាយនៅក្នុងការងារបម្រើដល់មនុស្សដទៃទៀត ។

មេរៀន ៦០

យ៉ូហាន ១


សេចក្តីផ្តើម

យ៉ូហានសិស្សជាទីស្រឡាញ់ បានកត់ត្រាគោលលទ្ធិសំខាន់ៗដែលទាក់ទងនឹងតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតមុនផែនដីនេះ ។ យ៉ូហាន បាទីស្ទ ក៏បានថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ហើយបានជ្រមុជទឹកឲ្យទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទបានអញ្ជើញមនុស្សជាទៃទៀតឲ្យរៀនអំពីទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន១:១–១៨, ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ យ៉ូហាន១:១–១៩

យ៉ូហានថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទថា ជាព្រះរាជបុត្រានៃព្រះ



សូមចែកសិស្សជាគូៗ ។ សូមដាក់តាំង រូបភាព ព្រះយេស៊ូវគ្រីស្ទនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សនីកស្រមៃថា ពួកគេកំពុងនិយាយនឹងមនុស្សម្នាក់ ដែលដឹងបន្តិចបន្តួចអំពីព្រះយេស៊ូវគ្រីស្ទ ។ ចូរអញ្ជើញឲ្យសិស្សម្នាក់ក្នុងចំណោមដៃគូនីមួយៗ ចំណាយពេលមួយនាទី បង្រៀនសិស្សផ្សេងទៀតអំពីព្រះយេស៊ូវ សម្តែងដូចជាសិស្សដទៃស្គាល់ពីទ្រង់បន្តិចបន្តួច ។ ក្រោយពីសកម្មភាពនេះ សូមអញ្ជើញសិស្សពីរបីនាក់ដែលត្រូវបានបង្រៀនពីព្រះគ្រីស្ទឲ្យចែកចាយជាមួយសិស្សដទៃទៀត អំពីអ្វីដែលពួកគេបានរៀនពីដៃគូរបស់ពួកគេ ។

សូមណែនាំខ្លីៗពីគម្ពីរយ៉ូហានដោយពន្យល់ថា សាវ័កយ៉ូហានបានកត់ត្រាអ្វីដែលគាត់ចង់ឲ្យពួកបរិសុទ្ធដឹងអំពីព្រះយេស៊ូវគ្រីស្ទ ។ យ៉ូហានគឺជាសាក្សីម្នាក់ចំពោះដំណើររឿងជាច្រើនដែលលោកបានសរសេរ ។ ឯកសារភាគច្រើននៅក្នុងដំណឹងល្អរបស់យ៉ូហានគ្មាននៅក្នុងដំណឹងល្អរបស់ម៉ាថាយ ម៉ាកុស និងលូកា ដែលសរសេរដើម្បីជួយពួកយូដា និងពួកសាសន៍ដទៃឲ្យជឿថា ព្រះយេស៊ូវគឺជាព្រះមែស៊ី និងព្រះអង្គសង្គ្រោះនៃមនុស្សលោកនោះទេ ។ ផ្ទុយទៅវិញ យ៉ូហានបានសរសេរយ៉ាងជាក់លាក់ទៅកាន់ជនដែលបានដឹងរួចហើយថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។

នៅពេលសិស្សសិក្សា យ៉ូហាន ១សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតអំពីព្រះអង្គសង្គ្រោះ ដែលអាចពង្រឹងសេចក្តីជំនឿ និងទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។

សូមឲ្យសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:១–២(នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ។ ចូរសុំពួកគេឲ្យរកមើលសេចក្តីពិត ដែលយ៉ូហានបានបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ។

- តើសេចក្តីពិតអ្វីខ្លះ ដែលយើងរៀនអំពីព្រះយេស៊ូវគ្រីស្ទ នៅក្នុងខគម្ពីរទាំងនេះ ? (សេចក្តីពិតមួយដែលសិស្សគួរកត់សម្គាល់គឺថា **ព្រះយេស៊ូវគ្រីស្ទគង់នៅជាមួយនឹងព្រះតាំងពីដំបូង ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ក្បែររូបភាពព្រះអង្គសង្គ្រោះ) ។
- តើ កាលដែលព្រះយេស៊ូវគ្រីស្ទបានគង់នៅជាមួយនឹងព្រះ តាំងពីដើមដំបូងមានន័យដូចម្តេច ? (សូមពន្យល់ថា ឃ្លា « តាំងពីដើមដំបូង » សំដៅទៅលើជីវិតមុនផែនដីនេះ ។ ព្រះយេស៊ូវគ្រីស្ទគឺជាបុត្រវិញ្ញាណច្បងរបស់ព្រះវរបិតា [សូមមើល គ. និង ស. ៩៣:២១] ទ្រង់មើលទៅ « ដូចជាព្រះ » នៅក្នុងចំណោមវិញ្ញាណដែលជុំគ្នានៅទីនោះ « មុនកំណើតលោកិយមកម្ល៉ះ » [សូមមើល អ័ប្រាហាំ ៣:២២–២៤] ហើយទ្រង់ត្រូវបានរើសតាំងដោយព្រះបិតាតាំងតែពីដំបូងមក [សូមមើល ម៉ូសេ ៤:២] ។

សូមអញ្ជើញសិស្សម្នាក់អាន ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ យ៉ូហាន ១:៣ឲ្យឮៗ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលសេចក្តីពិតមួយបន្ថែមទៀត ដែលយ៉ូហានបានបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ។

- តើយ៉ូហានបានបង្រៀនអ្វីខ្លះទៀតអំពីព្រះយេស៊ូវគ្រីស្ទ ? (សិស្សគួរអាចឃើញគោលលទ្ធិមួយដែលស្រដៀងគ្នានឹងគោលលទ្ធិខាងក្រោម ៖ **វត្ថុសព្វសារពើត្រូវបានបង្កើតឡើងដោយព្រះយេស៊ូវគ្រីស្ទ ។** ចូរសរសេរសេចក្តីពិតនេះនៅក្បែររូបភាពរបស់ព្រះអង្គសង្គ្រោះនៅលើក្តារខៀន) ។

សូមពន្យល់ថា ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និងផែនដីក្រោមការដឹកនាំរបស់ព្រះវរបិតា ហើយថាព្រះយេស៊ូវគ្រីស្ទបានបង្កើតពិភពលោកជាច្រើនរាប់មិនអស់ (សូមមើល ម៉ូសេ ១:៣៣) ។ ប៉ុន្តែ ព្រះវរបិតាសួគ៌បានទុក « ព្រឹត្តិការណ៍បង្កបង្កើតពីរ » សម្រាប់ទ្រង់ផ្ទាល់គឺ ៖ ការបង្កបង្កើតវិញ្ញាណទាំងអស់ (រួមទាំងវិញ្ញាណរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ) និងការបង្កបង្កើតរូបកាយរបស់អ័ដាម និងអេវ៉ា (Bruce R. McConkie *A New Witness for the Articles of Faith* [ឆ្នាំ ១៩៨៥] ទំព័រ ៦៣ សូមមើលផងដែរ ម៉ូសេ ២:២៧) ។

សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:៤–៥ ឲ្យឮៗ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលយ៉ូហានបានពិពណ៌នាពីព្រះយេស៊ូវ និងដំណឹងល្អរបស់ទ្រង់ ។

- តើយ៉ូហានបានពិពណ៌នាអំពីព្រះយេស៊ូវ និងដំណឹងល្អរបស់ទ្រង់របៀបណា ?
- តើឃ្លាថា « នៅក្នុងទ្រង់មានដំណឹងល្អ » មានន័យដូចម្តេច ? (ព្រះយេស៊ូវគ្រីស្ទគឺជាដំណឹងល្អ ជាតំណាងនៃដំណឹងល្អ) ។

ជួយសិស្សឲ្យយល់ពីគោលលទ្ធិគ្រឹះ

សិស្សនឹងរៀននូវគោលលទ្ធិគ្រឹះ នៅពេលពួកគេសិក្សា និងពិភាក្សាអំពីបទគម្ពីរនិងនៅពេលពួកគេចាំវគ្គចំណេះចំណានបទគម្ពីរគន្លឹះ ។ អ្នកពុំគួរបង្ខំរចេញពីការសិក្សាបទគម្ពីរតាមលំដាប់លំដោយ ដើម្បីផ្តោតទៅលើគោលលទ្ធិគ្រឹះនោះទេ ។ ផ្ទុយទៅវិញ ចូរបង្ហាញ ហើយជួយសិស្សឲ្យយល់ពីគោលលទ្ធិគ្រឹះ នៅពេលពួកគេនៅក្នុងវគ្គនៃការសិក្សា ។ ឧទាហរណ៍ នៅក្នុងមេរៀននេះ អ្នកអាចគូសបញ្ជាក់ពីគោលលទ្ធិនៃក្រុមព្រះដែលទាក់ទងនឹងអ្វីដែលបានបង្រៀននៅក្នុង យ៉ូហាន ១ ។

- តើអ្នកគិតថាការមានពន្លឺដែល « ភ្លឺមកក្នុងពិភពលោក ហើយពិភពលោកយល់មិនដល់ពន្លឺទេ » មានន័យដូចម្តេច ? (ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:៥) ។

សូមពន្យល់ថា ក្រោយមកសាវកយ៉ូហានបានបង្រៀនអំពី យ៉ូហាន បាទីស្ទ ។ សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:៦–១០ ឲ្យឮៗ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វី ដែលយ៉ូហាន បាទីស្ទ បានប្រកាសអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- នៅក្នុង ខទី ៩–១០តើគោលលទ្ធិអ្វីខ្លះ ដែលសាវកយ៉ូហាន បានបង្រៀនអំពីព្រះយេស៊ូវ ? (សិស្សគួររកឃើញគោលលទ្ធិមួយដែលស្រដៀងគ្នានឹងគោលលទ្ធិខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាពន្លឺនៃពិភពលោក ។** ចូរសរសេរសេចក្តីពិតនេះនៅក្បែររូបភាពរបស់ព្រះអង្គសង្គ្រោះនៅលើក្តារខៀន)។
- តើព្រះយេស៊ូវគ្រីស្ទជាពន្លឺនៃពិភពលោករបៀបណា ? (សូមមើល គ. និង ស. ៨៨:៥–១៣) ។

សូមសង្ខេបការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:១១–១៨ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ដោយពន្យល់ថា យ៉ូហាន បាទីស្ទ បានថ្លែងទីបន្ទាល់ថា ជនទាំងអស់ណាដែលជឿលើព្រះយេស៊ូវគ្រីស្ទនឹងទទួលបានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ។

ចូរចង្អុលបង្ហាញថានៅក្នុង ខទី ១៤និង១៦ យ៉ូហាន បានហៅព្រះយេស៊ូវគ្រីស្ទថាជា « ព្រះបន្ទូល » ។ សូមពន្យល់ថា នេះគឺជាងារមួយរបស់ព្រះយេស៊ូវគ្រីស្ទដែលមានច្រើនកន្លែងនៅក្នុងព្រះគម្ពីរ (សូមមើល យ៉ូហាន ១:១, ១៤, យ៉ូហានទី ១ ១:១, វិវរណៈ ១៩:១៣, គ. និង ស. ៩៣:៨–១០, ម៉ូសេ ១:៣២) ។

ចូរចង្អុលបង្ហាញថា យើងប្រើពាក្យសម្តីដើម្បីប្រាស្រ័យទាក់ទង ហើយបង្ហាញពីគំនិត អារម្មណ៍ និងយោបល់ដល់មនុស្សដទៃទៀត ។

- តើពាក្យ « ព្រះបន្ទូល » ជាងារមួយដ៏សមរម្យរបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

ក៏សូមពន្យល់ផងដែរថា ប្រសិនបើគ្មានការបកប្រែដោយយ៉ូសែប ស្ម៊ីធ ទេ យ៉ូហាន ១:១៨ អាចនឹងមានការយល់ខុស ដោយសារបានចែងថា គ្មានអ្នកណាដែលឃើញព្រះជាព្រះវរបិតាឡើយ ។ សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:១៩ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។

- តើ ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:១៩ បញ្ជាក់ពី យ៉ូហាន ១:១៨ដោយរបៀបណា ?

សូមបែងចែកសិស្សជាគូដដែល កាលពួកគេបានធ្វើសកម្មភាពនៅដើមមេរៀន ។ ចូរសុំឲ្យសិស្សម្នាក់ពីដៃគូនីមួយៗចំណាយពេលមួយនាទីបង្រៀនដៃគូខ្លួនអំពីព្រះយេស៊ូវគ្រីស្ទ ដោយប្រើគោលលទ្ធិដែលសិស្សក្នុងថ្នាក់បានរកឃើញនៅក្នុង ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:១–១៩ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- ហេតុអ្វីវាជារឿងដ៏សំខាន់ សម្រាប់មនុស្សម្នាក់ដើម្បីដឹងគោលលទ្ធិទាំងនេះអំពីព្រះយេស៊ូវគ្រីស្ទ ?

យ៉ូហាន ១:១៩–៣៤, ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:២០–៣៤

យ៉ូហាន បាទីស្ទ បានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង បានជ្រមុជទឹកថ្វាយទ្រង់

សូមសង្ខេប ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:២០–២៨ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ដោយពន្យល់ថា សាសន៍យូដាបានបញ្ជូនពួកសង្ឃទៅរកយ៉ូហាន បាទីស្ទ ដើម្បីសួរលោកថាតើលោកជាព្រះមែស៊ីឬ ។ យ៉ូហានបានពន្យល់ថា តួនាទីរបស់គាត់គឺដើម្បីថ្លែងទីបន្ទាល់អំពីព្រះមែស៊ី ដែលនឹងត្រូវជ្រមុជដោយភ្លើង និង ជាមួយព្រះវិញ្ញាណបរិសុទ្ធ ។ នៅថ្ងៃបន្ទាប់មក យ៉ូហាន បាទីស្ទ បានឃើញព្រះយេស៊ូវដែលលោកបានជ្រមុជទឹកកាលពីមុន ។

សូមអញ្ជើញសិស្សម្នាក់ឲ្យក្រោកឈរអានពាក្យសម្តីរបស់យ៉ូហាន បាទីស្ទ នៅក្នុង ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:២៩–៣៣ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ឲ្យឮៗ ហាក់ដូចជាសិស្សម្នាក់នោះជាយ៉ូហាន បាទីស្ទ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលយ៉ូហាន បាទីស្ទ ចង់ឲ្យមនុស្សស្គាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

ចូរចង្អុលបង្ហាញទៅរូបភាពរបស់ព្រះយេស៊ូវគ្រីស្ទ និងសេចក្តីពិតដែលបានសរសេរនៅលើក្តារខៀន ហើយសួរ ៖

- តើសេចក្តីពិត ឬ ការពិពណ៌នាអ្វីផ្សេងទៀតអំពីព្រះយេស៊ូវគ្រីស្ទដែលយើងអាចបន្ថែមមកពី ការបកប្រែដោយយ៉ូសែប ស្ម៊ីធ យ៉ូហាន ១:២៩–៣៣? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។
- ហេតុអ្វីអ្នកគិតថា យ៉ូហាន បាទីស្ទ ហៅព្រះយេស៊ូវថាជា « កូនចៀមរបស់ព្រះ » ?

យ៉ូហាន ១:៣៥–៥១

ព្រះយេស៊ូវអញ្ជើញអ្នកដើរតាមទ្រង់ឲ្យរៀនបន្ថែមទៀតពីទ្រង់

ចូរសុំឲ្យសិស្សស្រមៃថា យុវវ័យម្នាក់ចូលរួមការប្រជុំតមអាហារ និង ថ្លែងទីបន្ទាល់ ស្តាប់ឮមិត្តភក្តិជាច្រើនថ្លែងទីបន្ទាល់ថា ពួកគេដឹងថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់ខ្លួន ។ យុវវ័យម្នាក់នេះឆ្ងល់ពីរបៀបដែលមិត្តភក្តិទាំងនោះ « ដឹង » រឿងទាំងនោះ ។

- តើអ្នកនឹងឆ្លើយតបចំពោះសំណួរនេះយ៉ាងណាដែរ ?

នៅពេលសិស្សសិក្សា យ៉ូហាន ១:៣៥–៥១សូមអញ្ជើញសិស្ស ឲ្យរកមើលអ្វីដែលយើងអាចធ្វើដើម្បីទទួលបាន (ឬពង្រឹង) សាក្សីរបស់យើងពីព្រះយេស៊ូវគ្រីស្ទថាជាព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ១:៣៥–៣៧ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលយ៉ូហាន បាទីស្ទ បានធ្វើមួយថ្ងៃបន្ទាប់ពីគាត់បានជ្រមុជទឹកឲ្យព្រះយេស៊ូវ ។

- តើយ៉ូហានបានធ្វើអ្វីខ្លះ នៅពេលគាត់បានឃើញព្រះយេស៊ូវ ?

ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ១:៣៨–៣៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលទៅកាន់ពួកសិស្សទាំងពីរនាក់នោះ ។

- តើព្រះយេស៊ូវបានមានបន្ទូលសួរអ្វីខ្លះ ដល់សិស្សសិស្សទាំងពីរនាក់នោះ ?
- តើពួកគេឆ្លើយយ៉ាងម៉េចដែរ ?
- តើព្រះយេស៊ូវបានអញ្ជើញសិស្សទាំងពីរនាក់នោះឲ្យធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ១:៤០–៤២ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអន់ឌ្រេបានរៀន បន្ទាប់ពីគាត់បានទទួលយកការអញ្ជើញរបស់ព្រះអង្គសង្គ្រោះថា « ចូរតាមខ្ញុំទៅមើល » ។

- តើអន់ឌ្រេបានរៀនអ្វីខ្លះ ដោយទទួលយកការអញ្ជើញរបស់ព្រះអង្គសង្គ្រោះថា « ចូរតាមខ្ញុំទៅមើល » ? (ថាព្រះយេស៊ូវគឺជាព្រះមែស៊ី ឬព្រះគ្រីស្ទ ។ អ្នកក៏គួរចង្អុលបង្ហាញថា យើងរៀនចេញពីការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ យ៉ូហាន ១:៤២ ថា ពេត្រុសនឹងត្រូវបានហៅ « កេផាសគឺប្រែថា *អ្នករមើលឃុត* ឬថ្ម » ដោយបង្ហាញថា ពេត្រុសនឹងក្លាយជាអ្នករមើលឃុតនៅក្នុងសាសនាចក្រ) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១:៤៣–៤៦ ឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានអញ្ជើញភីលីពឲ្យធ្វើ ។ ចូរសុំឲ្យសិស្សចែកចាយអ្វីដែលពួកគេរកឃើញ ។

- តើពាក្យណាមួយនៅក្នុង ខទី ៤៥ ដែលបង្ហាញថាភីលីពបានទទួលទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ បន្ទាប់ពីលោកបានទទួលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យតាមទ្រង់ ?
- តើការអញ្ជើញអ្វីខ្លះ ដែលភីលីពក្រោយមកបានផ្តល់ដល់ ណាថាណែល ?

សូមអញ្ជើញសិស្សបីនាក់អាន យ៉ូហាន ១:៤៧–៥១ ឲ្យឮៗ ។ ចូរចាត់ម្នាក់ធ្វើជាអ្នកពោល ម្នាក់ទៀតអានព្រះបន្ទូលរបស់ព្រះយេស៊ូវ ហើយម្នាក់ទៀតអានពាក្យសម្តីរបស់ ណាថាណែល ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់រកមើលអ្វីដែលបានកើតឡើង នៅពេលណាថាណែលបានទទួលយកការអញ្ជើញឲ្យរៀនអំពីព្រះយេស៊ូវ ។

- តើមានអ្វីបានកើតឡើង បន្ទាប់ពីណាថាណែលបានទទួលយកការអញ្ជើញឲ្យរៀនអំពីព្រះយេស៊ូវ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីដំណើររឿងទាំងនេះ ? (សិស្សគួរអាចឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងទទួលយកការអញ្ជើញឲ្យរៀន និង ធ្វើតាមព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងទទួលបានសាក្សីផ្ទាល់ខ្លួនពីទ្រង់**) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។



« វាទំនងថា អត្ថន័យដ៏សំខាន់បំផុតនៃដំណើរជីវិតរមែងស្លាប់របស់យើង និង ចម្លើយនានាចំពោះសំណួរសំខាន់ៗបំផុតនៅក្នុងជីវិត គឺត្រូវបានមើលឃើញនៅក្នុងកត្តាដ៏សង្ខេបក្តីទាំងពីរនេះ៖ ក្នុងឆាកចាប់ផ្តើមនៃការបម្រើក្នុងជីវិតលើផែនដីរបស់ព្រះអង្គសង្គ្រោះ ។ កត្តាទីមួយ គឺជាសំណួរមួយឃ្លាដែលមានចំពោះយើងនៅលើផែនដីនេះ ៖ ‹ តើអ្នកស្វែងរកអី ? តើអ្នកចង់បានអ្វី ? › ទីពីរ គឺជាចម្លើយរបស់ទ្រង់ឆ្លើយនឹងចម្លើយរបស់យើង *ទោះបីជាចម្លើយនោះវាជាអ្វីក៏ដោយ* ។ មិនថាយើងជានរណា ហើយយើងឆ្លើយតបដោយរបៀបណានោះទេ ចម្លើយរបស់ទ្រង់គឺ *តែងតែ* ដូចគ្នាជដែលជានិច្ច ៖ ‹ ចូរមកចុះ › ទ្រង់មានបន្ទូលដោយក្តីស្រឡាញ់ ។ ‹ ចូរមកតាមខ្ញុំ › ។ ទីណាក៏ដោយដែលអ្នកនឹងទៅ រឿងដំបូងនោះ៖ សូមមក ហើយមើលអ្វីដែលយើងធ្វើ និង ពីរបៀបដែលយើងចំណាយពេលវេលារបស់យើង ។ ចូររៀនពីខ្ញុំ ចូរដើរជាមួយនឹងយើងចុះ៖ ចូរនិយាយជាមួយយើងចុះ៖ សូមជឿចុះ ។ សូមស្តាប់ខ្ញុំអធិស្ឋាន ។ ជាផលតបស្នងមកវិញ អ្នកនឹងរកឃើញចម្លើយចំពោះការអធិស្ឋានរបស់អ្នក ។ ព្រះនឹងនាំមកនូវការសង្គ្រោះដល់ព្រលឹងអ្នក » (« He Hath Filled the Hungry with Good Things » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៦៥) ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីកិច្ចខិតខំផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីរៀនពីព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមទ្រង់ ។

- តើទីបន្ទាល់របស់អ្នកអ្នកអំពីព្រះយេស៊ូវគ្រីស្ទបានកើនឡើងតាមរបៀបណាខ្លះ ខណៈដែលអ្នកបានរៀន និង បានធ្វើតាមទ្រង់នោះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវពាក្យពីរបីប្រយោគអំពីអ្វី ដែលពួកគេនឹងធ្វើដើម្បីទទួលយកកាន់តែពេញលេញ នូវការអញ្ជើញរបស់ព្រះអង្គសង្គ្រោះថា « ចូរតាមខ្ញុំទៅមើល » ហើយរៀនពីទ្រង់ ហើយដើរតាមទ្រង់ ។

សូមបញ្ចប់ដោយការចែកចាយនូវទីបន្ទាល់របស់អ្នក អំពីគោលការណ៍ទាំងឡាយដែលបានរកឃើញនៅក្នុងថ្នាក់ថ្ងៃនេះ ។

មេរៀនសិក្សានៅផ្ទះ

លូកា ១៨–យ៉ូហាន ១ (មេរៀនទី ១២)

ការរៀបចំសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែល សិស្សបានរៀន នៅពេលពួកគេបានសិក្សា លូកា ១៨–យ៉ូហាន ១ (មេរៀនទី ១២) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និងគោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពី ព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (លូកា ១៨–២១)

នៅក្នុងមេរៀននេះសិស្សបានសិក្សារឿងប្រៀបប្រដូចអំពីការកាត់សេចក្តីអយុត្តិធម៌ និង អំពីពួកផារិស៊ី និងអ្នកយកពន្ធ ។ ពួកគេក៏បានអានអំពីបុរសខ្វាក់ម្នាក់ ដែលបានស្វែង រកជំនួយរបស់ព្រះអម្ចាស់ និងអំពីសាខេផងដែរ ។ នៅក្នុងជំណើររឿងទាំងនេះ សិស្ស បានរៀនថា ប្រសិនបើយើងមានចិត្តស្មោះ ហើយស៊ូទ្រាំ នៅពេលយើងអនុវត្តសេចក្តី ជំនឿលើព្រះអម្ចាស់ នោះយើងអាចទទួលបានសេចក្តីមេត្តាករុណារបស់ទ្រង់ ។

ថ្ងៃទី ២ (លូកា ២២)

នៅពេលសិស្សអានអំពីការទូន្មានរបស់ព្រះអម្ចាស់ទៅកាន់ពេត្រុស ពួកគេបានរៀន ថា នៅពេលយើងបានប្រែចិត្តជឿលើជំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នោះយើងអាច ពង្រឹងដល់មនុស្សជាទៃ ។ សិស្សក៏បានរៀននូវសេចក្តីពិតខាងក្រោមនេះផងដែរ កាល ណាពួកគេអានអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី ៖ ប្រសិនបើយើងមានឆន្ទៈធ្វើតាមព្រះវរបិតាសួគ៌ នោះទ្រង់នឹងប្រទានកម្លាំងដល់យើង ដើម្បីធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទបានបង្ហូរញើសទ្រង់ដូចជាដំណក់ ឈាមដ៏ធំៗ នៅពេលទ្រង់រងទុក្ខនៅក្នុងច្បារគែតសេម៉ានី ។

ថ្ងៃទី ៣ (លូកា ២៣–២៤)

នៅក្នុងមេរៀននេះ សិស្សអានអំពីការឆ្កាង ការបញ្ចេះព្រះសព និងការមានព្រះជន្ម ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេបានរៀនពីសេចក្តីពិតដូចតទៅនេះ ៖ យើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ដោយការជ្រើសរើសអភ័យទោស ដល់អ្នកទាំងឡាយ ដែលប្រព្រឹត្តមិនល្អដាក់យើង ។ វិញ្ញាណនៃមនុស្សទាំងអស់ចូល ទៅក្នុងពិភពវិញ្ញាណនៅពេលពួកគេស្លាប់ ។ ព្រះយេស៊ូវគ្រីស្ទមានព្រះកាយដាសាច់ និងឆ្អឹងដែលបានរស់ឡើងវិញ ។

ថ្ងៃទី ៤ (យ៉ូហាន ១)

នៅពេលសិស្សសិក្សាពាក្យសម្តីរបស់យ៉ូហានសំណព្វ និងយ៉ូហាន បាទីស្ទ ពួកគេ បានរៀនថា ព្រះយេស៊ូវគ្រីស្ទគង់នៅជាមួយនឹងព្រះតាំងពីដំបូងម្ល៉ះ ថាវត្ថុសព្វសារពើ ត្រូវបានបង្កើតឡើងដោយសារទ្រង់ ហើយថាទ្រង់គឺជាពន្លឺនៃលោកិយនេះ ។ នៅពេល សិស្សអានអំពីរបៀបដែលពួកសិស្សមួយចំនួនបានស្គាល់ព្រះយេស៊ូវគ្រីស្ទ ពួកគេបាន រៀនថា នៅពេលយើងទទួលយកការអញ្ជើញឲ្យរៀន ហើយដើរតាមព្រះយេស៊ូវគ្រីស្ទ យើងនឹងទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនអំពីទ្រង់ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់ពីរបៀបដើម្បីអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យបង្រៀនពួកគេអំពី ព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះទៅទៀត ពួកគេនឹងរៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាអង្គដែលមាន ព្រះជន្មរស់ឡើងវិញ ដោយមានរូបកាយជាសាច់ និង ឆ្អឹង ។

យោបល់សម្រាប់ការបង្រៀន

លូកា ២៤:១៣–៣២

ព្រះអម្ចាស់ដ៏មានព្រះជន្មរស់ បានមានបន្ទូលទៅពួកសិស្សពីរនាក់នៅលើផ្លូវទៅទីក្រុង អេម៉ោស

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា តើពួកគេធ្លាប់មានបញ្ហាស្មុគស្មាញក្នុងការដឹងថាទស្សនៈមួយអំពី មនោភាពនៃជំណឹងល្អគឺជាការពិតដែរឬទេ ។

សូមពន្យល់ថានៅក្នុង លូកា ២៤:១៣ យើងរៀនថា មានពួកសិស្សពីរនាក់បានចាកចេញពី យេរូសាឡិមនៅក្នុងថ្ងៃតែមួយដែលស្ត្រីមួយក្រុមបានរកឃើញថា ផ្នូរបស់ព្រះយេស៊ូវនៅទទេ ស្អាត ។ ពួកគេបានធ្វើដំណើរប្រមាណជា ១០–១២ គីឡូម៉ែត្រ « ទៅឯភូមិអេម៉ាស » ។ ការសិក្សាអំពីបទពិសោធន៍របស់ពួកគាត់នៅតាមផ្លូវទៅភូមិអេម៉ោស អាចជួយយើងដឹងអំពីរបៀប ដើម្បីពង្រឹងទីបន្ទាល់របស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ និងជំណឹងល្អរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៤:១៤–១៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្នក ដែលបានចូលរួមនឹងពួកសិស្សទាំងពីរនាក់នោះ៖ កាលពួកគាត់កំពុងដើរ ។

- តើនរណាបានចូលរួមដំណើរនឹងពួកសិស្ស ខណៈពេលពួកគាត់ធ្វើដំណើរទៅភូមិអេម៉ាស ?
- ហេតុអ្វីក៏ពួកសិស្សពុំស្គាល់ព្រះយេស៊ូវ ? (ចូរពន្យល់ថា ពាក្យថ្លឹង នៅក្នុងលូកា ២៤:១៦] មានន័យថា រារាំង ឬបិទបាំង) ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង លូកា ២៤:១៧–៣៣ ។ ចូរសុំឲ្យសិស្ស ក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលពួកសិស្សបានរៀនមកពីព្រះយេស៊ូវ នៅពេលពួកគាត់ដើរជាមួយ ទ្រង់ដោយពុំស្គាល់ថា ទ្រង់ជានរណាឡើយ ។

ប្រសិនបើវីដេអូជាភាសារបស់អ្នក នោះជំនួសឲ្យការអាន លូកា ២៤:១៧–៣៣ អ្នកអាច ចាក់វីដេអូ « Christ Appears on the Road to Emmaus (ព្រះគ្រីស្ទបង្ហាញអង្គ ទ្រង់នៅលើផ្លូវទៅកាន់ភូមិអេម៉ាស » (៣:៣២) នៅក្នុង *The Life of Jesus Christ Bible Videos(វីដេអូព្រះគម្ពីរបីបអំពីជីវប្រវត្តិរបស់ព្រះយេស៊ូវគ្រីស្ទ)* ដែលមាននៅក្នុង LDS.org ។ ចូរសុំឲ្យសិស្សមើលនូវអ្វីដែលពួកសិស្សបានរៀនមកពីព្រះយេស៊ូវ នៅពេលពួក គេដើរជាមួយទ្រង់ដោយពុំស្គាល់ថាទ្រង់ជានរណានោះ ។ មុនពេលបង្ហាញវីដេអូ ចូរពន្យល់ថា ការសន្ទនានៅក្នុងវីដេអូគឺដកស្រង់ចេញពីលូកា ២៤:១៧–៣៣ដើម្បីសិស្សអាចផ្ទៀងតាមនៅក្នុង ព្រះគម្ពីររបស់ពួកគេ ប្រសិនបើពួកគេចង់ធ្វើដូច្នោះ ។

សូមចង្អុលបង្ហាញថា នៅក្នុងវីដេអូនេះ យើងស្តាប់មិនឮពីអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួក សិស្ស នៅពេលពួកលោកធ្វើដំណើរមួយគ្នានោះឡើយ ។ សូមអញ្ជើញសិស្សម្នាក់អាន លូកា ២៤:២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវបានបង្រៀន ដល់ពួកសិស្សទាំងនោះ ។

- តើព្រះយេស៊ូវបានសួរពួកសិស្សអ្វីខ្លះ ?
- តើទ្រង់បានប្រើឧបករណ៍អ្វី ដើម្បីបង្រៀនអំពីព្រះអង្គទ្រង់នោះ ? (ព្រះគម្ពីរ) ។
- នៅក្នុង ខទី ៣២កាលដែលពួកសិស្ស ‹ មានសេចក្តីខ្ពស់ខ្ពាន់នៅក្នុងចិត្ត › តើវាមានន័យ យ៉ាងណាដែរ ? (ព្រះវិញ្ញាណបរិសុទ្ធបានថ្លែងទីបន្ទាល់ថា ការបង្រៀនអំពីព្រះយេស៊ូវនៅក្នុង បទគម្ពីរគឺជាការពិត) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកសិស្សអាចនឹងបានរៀនមកពីការប្រើបទគម្ពីរ របស់ព្រះយេស៊ូវ ដើម្បីបង្រៀនពួកគេជាជាងការបង្ហាញព្រះអង្គទ្រង់ថាជានរណាដោយសាមញ្ញ នោះ ។ អ្នកអាចនឹងសុំឲ្យសិស្សពីរបីនាក់ចែកចាយគំនិតរបស់ពួកគេ ។

- តើគោលការណ៍អ្វីខ្លះ ដែលខគម្ពីរទាំងនេះបង្រៀនអំពីឥទ្ធិពលនៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់យើង ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលយើងសិក្សាខគម្ពីរ នោះយើងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យបង្រៀនយើងអំពីព្រះយេស៊ូវគ្រីស្ទ**)។
- ក្រៅពីអារម្មណ៍ខ្លួនខ្មាញ់នៅក្នុងចិត្តរបស់យើង តើអ្នកអាចពិពណ៌នាអំពីអ្វីដែលយើងអាចនឹងជួបពិសោធន៍ ពេលព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

ចូរសុំសិស្សឲ្យរកមើលខគម្ពីរមួយ ដែលបានជួយពួកគេមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធបង្រៀនពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញពួកគេឲ្យចែកចាយបទគម្ពីររបស់ពួកគេ ហើយនិងឥទ្ធិពល ដែលពួកគេបានទទួលអារម្មណ៍ ។ អ្នកក៏គួរចង់ចែកចាយខគម្ពីរមួយ ដែលបានជួយអ្នកដោយផ្ទាល់ផងដែរ ។

សូមរំឭកសិស្សថា ទោះជាវាសំខាន់ដើម្បីអានគម្ពីរសញ្ញាថ្មីសម្រាប់ពិន្ទុថ្នាក់សិក្ខាសាលាក្តី តែអ្វីដែលកាន់តែសំខាន់នោះ គឺដើម្បីសិក្សាព្រះគម្ពីរតាមរបៀបមួយដែលយាងព្រះវិញ្ញាណបរិសុទ្ធឲ្យមកពង្រឹងដល់ទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។

ប្រសិនបើអាចធ្វើទៅបាន សូមផ្តល់ច្បាប់ចម្លងនៃវគ្គសិក្សាចំណាំក្នុងសៀវភៅមួយដែលមាននូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ឬអញ្ជើញសិស្សឲ្យសរសេរសេចក្តីថ្លែងការណ៍នោះនៅលើក្រដាសមួយសន្លឹក ឬបណ្ណដែលអាចប្រើវគ្គសិក្សាចំណាំក្នុងសៀវភៅបាន ។ (ឯកសារ PDF ដែលអាចបោះពុម្ពបានដោយមានវគ្គសិក្សាចំណាំក្នុងសៀវភៅច្រើនមាននៅក្នុងកំណែលើអ៊ីនធើណែតនៃមេរៀននេះ) ។



« គោលបំណងដ៏ចម្បងនៃព្រះគម្ពីរទាំងឡាយ គឺដើម្បីបំពេញដល់ព្រលឹងយើងដោយសេចក្តីជំនឿទៅលើព្រះ ជាព្រះវរបិតា និងទៅលើព្រះរាជបុត្រារបស់ទ្រង់គឺ ព្រះយេស៊ូវគ្រីស្ទ ។ . . .

«. . . សេចក្តីជំនឿ កើតមកតាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធមកកាន់ព្រលឹងរបស់យើង ព្រះវិញ្ញាណមកកាន់វិញ្ញាណរបស់យើង នៅពេលយើងស្តាប់ ឬ អានព្រះបន្ទូលរបស់ព្រះ ។ ហើយសេចក្តីជំនឿបានចាស់ទុំ នៅពេលយើងបន្តទទួលទានព្រះបន្ទូល ។ . . .

« . . . ចូរសិក្សាព្រះគម្ពីរដោយយកចិត្តទុកដាក់ ដោយមានចេតនា ។ សូមពិចារណា ព្រមទាំងអធិស្ឋានអំពីវា ។ ខគម្ពីរគឺជាវិវរណៈ ហើយវានឹងនាំមកនូវវិវរណៈបន្ថែម » (ឌី ថត គ្រីស្តូហ្វឺសិន «The Blessing of Scripture» *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៣៨–៣៥) ។

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដោយអែលឌើរ គ្រីស្តូហ្វឺសិន ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវរបៀបដែលពួកគេអាចកែលម្អការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យជាក់គោលដៅមួយសិក្សាបទគម្ពីររបស់ពួកគេតាមរបៀបដែលអញ្ជើញព្រះវិញ្ញាណបរិសុទ្ធដើម្បីបង្កើនសេចក្តីជំនឿ និងចំណេះដឹងរបស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចនឹងផ្តល់យោបល់ថា ពួកគេសរសេរគោលដៅនេះនៅលើខ្នងនៃវគ្គសិក្សាចំណាំក្នុងសៀវភៅ ដើម្បីពួកគេអាចប្រើវាជាការរំឭកមួយ អំឡុងការសិក្សាបទគម្ពីរបស់ពួកគេ ។

លូកា ២៤:៣៦–៣៩

ព្រះយេស៊ូវបានលេចមកឯពួកសិស្សរបស់ទ្រង់ ហើយបង្ហាញព្រះកាយដែលបានរស់ឡើងវិញរបស់ទ្រង់ដល់ពួកគេ

សូមពន្យល់ថា ពួកសិស្សដែលនៅជាមួយព្រះយេស៊ូវនៅតាមផ្លូវទៅភូមិអេម៉ោស រំពេចនោះបានត្រឡប់ទៅក្រុងយេរូសាឡិមវិញ ហើយបានរៀបរាប់ពីបទពិសោធន៍របស់ពួកគេទៅដល់ពួកសាវក និងពួកសិស្សដទៃទៀត (សូមមើលលូកា ២៤:៣៣–៣៥) ។

សូមអញ្ជើញសិស្សអានវគ្គចំណេះចំណានខគម្ពីរនៅក្នុង លូកា ២៤:៣៦–៣៩ឲ្យឮៗរួមគ្នា ដោយរកមើលអ្វីដែលបានកើតឡើងកាលពួកសិស្សបានប្រាប់ពីបទពិសោធន៍របស់ពួកគេដល់ពួកសិស្សដទៃទៀត ។

- តើមានអ្វីបានកើតឡើង កាលពួកសិស្សបានប្រាប់ពីបទពិសោធន៍របស់ពួកគេ ?

ចូរបង្ហាញរូបភាពព្រះយេស៊ូវបង្ហាញស្នាមរបួសរបស់ទ្រង់(*Gospel Art Book* [ឆ្នាំ ២០០៩] ល.រ ទី ៦០, សូមមើលផងដែរ LDS.org) ។

- តើព្រះយេស៊ូវបានអញ្ជើញពួកសិស្សរបស់ទ្រង់ឲ្យធ្វើអ្វីខ្លះ ដើម្បីជួយពួកគេយល់ថា ទ្រង់គឺពុំមែនជាវិញ្ញាណ តែមានរូបកាយជាសាច់ឈាមនោះ ?
- តើគោលលទ្ធិអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? (សិស្សអាចរកឃើញគោលលទ្ធិខុសៗគ្នា ប៉ុន្តែចូរប្រាកដថាអ្នកគូសបញ្ជាក់ថា**ព្រះយេស៊ូវគ្រីស្ទមានព្រះកាយជាសាច់ និងឆ្អឹងដែលបានរស់ឡើងវិញ** ។ សូមសរសេរគោលលទ្ធិនេះលើក្តារខៀន សូមមើលផងដែរ គ. និង ស. ១៣០:២២) ។

សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយទីបន្ទាល់របស់ខ្លួន អំពីការព្រះជន្មឡើងវិញរបស់ព្រះអង្គសង្គ្រោះ ហើយពន្យល់ពីហេតុផលដែលគោលលទ្ធិនេះមានសារៈសំខាន់ចំពោះពួកគេ ឬសូមអញ្ជើញពួកគេឲ្យចែកចាយអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេសម្រាប់កិច្ចការទី៣ ពីមេរៀនទី ១២ ៖ មេរៀនថ្ងៃទី ៣ ។ សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ពីធាតុពិតនៃការមានព្រះជន្មឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

មេរៀនបន្ទាប់ (យ៉ូហាន ២–៦)

សូមពន្យល់ដល់សិស្សថា នៅពេលពួកគេសិក្សា យ៉ូហាន ២–៦ ពួកគេនឹងរៀនពីចម្លើយសម្រាប់សំណួរដូចខាងក្រោមនេះ ៖ តើអព្ភូតហេតុដាសាធារណៈលើកដំបូងរបស់ព្រះយេស៊ូវគឺជាអ្វីទៅ ? តើវាបានជួយមាតារបស់ទ្រង់យ៉ាងដូចម្តេច ? ហេតុអ្វីបានជាទ្រង់បានបោសសម្អាតព្រះវិហារបរិសុទ្ធ ? តើព្រះយេស៊ូវបានប្រកាសជាលើកដំបូងថា ទ្រង់ជាព្រះមែស៊ីទៅដល់នរណា ? តើអ្វីទៅដែលទ្រង់បានបើកសម្តែងដល់ស្ត្រីម្នាក់នេះអំពីជីវិតរបស់នាងដែលមានតែទ្រង់មួយអង្គគត់ដែលដឹង ? ហេតុអ្វីបានជាព្រះអង្គសង្គ្រោះបានហៅអង្គទ្រង់ថាជាទឹករស់ និងជានំបុ័ងនៃជីវិត ? សិស្សក៏នឹងអានអំពីព្រះយេស៊ូវគ្រីស្ទ ដែលបានធ្វើការងារបម្រើដោយមហិទ្ធិឫទ្ធិ និងដោយព្រះចេស្តាផងដែរ ។

យ៉ូហាន ២

សេចក្តីផ្តើម

នៅក្នុងស្រុកកាណា ព្រះអង្គសង្គ្រោះបានសម្តែងអព្ភូតហេតុជាសាធារណៈដំបូងគេនៃការបម្រើលើផែនដីរបស់ទ្រង់ នៅពេលទ្រង់បានធ្វើឲ្យទឹកក្លាយទៅជាស្រា ។ ព្រះយេស៊ូវគ្រីស្ទបានយាងទៅក្រុងយេរូសាឡិមសម្រាប់បុណ្យរំលែង ។ ទ្រង់បានបោសសម្អាតព្រះវិហារបរិសុទ្ធ ដោយបណ្តេញពួកអ្នកប្តូរប្រាក់ ដែលបានប្រមាថដល់ដំណាក់របស់ព្រះវរបិតាទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ២:១–១១

ព្រះយេស៊ូវធ្វើឲ្យទឹកក្លាយទៅជាស្រា

សូមអញ្ជើញសិស្សគិតពីរឿង « ដំបូងៗ » ដែលធ្លាប់កើតឡើងក្នុងជីវិតរបស់ពួកគេ ៖ ថ្ងៃចូលរៀនដំបូង ថ្ងៃធ្វើការដំបូង ឬ គ្រាដំបូងដែលពួកគេចងចាំពីអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធ ។

- ហេតុអ្វីពេលខ្លះអ្នកបានចាត់ទុក « រឿងដំបូង » ទាំងនេះ និងរឿងផ្សេងៗទៀតនៅក្នុងជីវិតរបស់អ្នកជាការណ៍សំខាន់ ?

សូមពន្យល់សិស្សថា នៅពេលពួកគេសិក្សា យ៉ូហាន ២:១–១១ ពួកគេនឹងរៀនអំពីអព្ភូតហេតុដំបូងដែលត្រូវបានកត់ត្រា ដែលព្រះយេស៊ូវបានធ្វើនៅក្នុងការងារបម្រើនៅលើផែនដីរបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យរកមើលហេតុផលដែលអព្ភូតហេតុដំបូងដែលកត់ត្រាទុកជារឿងដ៏សំខាន់ ។

សូមពន្យល់ថា មិនយូរប៉ុន្មានបន្ទាប់ពីព្រះយេស៊ូវបានជ្រមុជទឹក នោះទ្រង់និងពួកសិស្សទ្រង់បានចូលរួមពិធីជប់លៀងមង្គលការមួយនៅស្រុកកាណា ជាភូមិមួយនៅក្បែរស្រុកណាសារ៉ែតដែលជាស្រុកកំណើតរបស់ព្រះយេស៊ូវ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២:១–៣ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលបញ្ហាអ្វីខ្លះដែលបានកើតឡើងអំឡុងពិធីជប់លៀងមង្គលការនោះ ។

- តើបញ្ហាអ្វីខ្លះ ដែលបានកើតឡើងអំឡុងពិធីជប់លៀងមង្គលការនោះ ?

សូមពន្យល់ថា ស្រាគឺជាភេជ្ជៈប្រពៃណីនៅក្នុងពិធីជប់លៀងមង្គលការ ។ ពេលខ្លះ ពិធីជប់លៀងមង្គលការបន្តអស់ជាច្រើនថ្ងៃ ។ ការអស់ស្រាទទួលភ្ញៀវ គឺជារឿងគួរឲ្យអាម៉ាស់មួយសម្រាប់ម្ចាស់កម្មវិធីជប់លៀងនោះ ។ ម៉ារាទំនងជាមានអារម្មណ៍ពីទំនួលខុសត្រូវមួយចំនួនចំពោះពិធីជប់លៀងនោះ ដូច្នេះនៅពេលអស់ស្រា នាងបានដើរសំដៅទៅរកបុត្រារបស់នាង ហើយទូលសូមជំនួយពីទ្រង់ដើម្បីជួយសង្គ្រោះគ្រួសារពីភាពអាម៉ាស់នោះ ។ ការឆ្លើយតបរបស់ព្រះយេស៊ូវបានបង្ហាញការគោរព និងក្តីមេត្តាចំពោះបំណងរបស់មាតាទ្រង់ដើម្បីជួយដល់ពិធីរៀបការនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២:៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការឆ្លើយតបរបស់ព្រះយេស៊ូវទៅកាន់មាតារបស់ទ្រង់ ។

- តើព្រះយេស៊ូវបានមានបន្ទូលដូចម្តេចទៅកាន់មាតារបស់ទ្រង់ ?
- តើការឆ្លើយតបរបស់ព្រះយេស៊ូវបង្ហាញពីការគោរពចំពោះមាតារបស់ទ្រង់យ៉ាងដូចម្តេច ? (ព្រះយេស៊ូវពុំគ្រាន់តែសួរដល់មាតាទ្រង់នូវអ្វីដែលគាត់ចង់ឲ្យទ្រង់ធ្វើប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏បានបង្ហាញព្រះឆន្ទៈដើម្បីធ្វើវាផងដែរ) ។ អ្នកអាចនឹងត្រូវពន្យល់ថា នៅសម័យព្រះយេស៊ូវ ពាក្យ « មាតាអើយ » គឺជាវិធីមួយដែលបង្ហាញការគោរពដល់ម្តាយ) ។
- តើព្រះយេស៊ូវមានបន្ទូលសំដៅទៅលើអ្វី កាលទ្រង់បានមានបន្ទូលថា « ពេលវេលាខ្ញុំមិនទាន់មកដល់នៅឡើយ » ?



ពាងថ្មដាក់ស្រាពីសម័យកាលព្រះគម្ពីរសញ្ញាថ្មីនៅក្នុងស្រុកអ៊ីស្រាអែល

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២:៥ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វីដែលម៉ារាបាននិយាទៅកាន់ពួកអ្នកបម្រើ ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើការណែនាំរបស់ម៉ារាទៅពួកអ្នកបម្រើបង្រៀនយើងអ្វីខ្លះ អំពីសេចក្តីជំនឿរបស់នាងលើព្រះយេស៊ូវ ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ២:៦–៧ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលថា តើព្រះយេស៊ូវបានបង្គាប់ពួកអ្នកបម្រើឲ្យធ្វើអ្វីខ្លះ ។

- តើព្រះយេស៊ូវបានបង្គាប់ពួកសិស្សទាំងនេះឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា នៅសម័យព្រះយេស៊ូវពាងថ្មដែលធ្វើពីថ្មត្រូវបានគេចាត់ទុកថាបរិសុទ្ធ សម្រាប់ប្រើនៅក្នុងពិធីសាសនា ។ វាគឺជាទំនៀមទម្លាប់របស់ពួកសាសន៍យូដា ដើម្បីធ្វើខ្លួនឲ្យបានបរិសុទ្ធពីមុនបរិភោគអាហារ ដោយលាងដៃនឹងទឹកមកពីពាងថ្មទាំងនេះ ។

- តើពួកអ្នកបម្រើបានដាក់ទឹកក្នុងពាងថ្មទាំងនោះដល់កម្រិតណា ?

ដើម្បីជួយសិស្សឲ្យយល់ដឹងពីចំណុះទឹកដែលបានមាននៅក្នុងពាងថ្មទាំងនោះ សូមដាក់បង្ហាញធុងបើកចំហមួយដែលមានចំណុះមួយលីត្រ ។ សូមពន្យល់ដល់សិស្សថា « អំរែក » គឺប្រមាណ (៣៤ លីត្រ) ដូច្នេះប្រាំមួយពាងមានចំណុះប្រមាណពី ៣៨០ លីត្រ ទៅ ៦០០ លីត្រ) ។ សូមយកទឹកចាក់បំពេញធុងនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២:៨ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់រកមើលថា តើព្រះយេស៊ូវបានបង្គាប់ពួកបម្រើឲ្យធ្វើអ្វីបន្ទាប់ទៀត ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ នៅពេលសិស្សរាយការណ៍ សូមយកពែងទៅដួសទឹកក្នុងធុងនោះ ហើយលើកពែងនោះឡើង ។

- ប្រសិនបើអ្នកជាម្នាក់ក្នុងចំណោមអ្នកបម្រើទាំងនោះ តើអ្នកអាចមានគំនិត ឬមានអារម្មណ៍យ៉ាងណា នៅពេលអ្នកយកពែងមួយទៅជូនអភិបាល ឬថ្នាក់ដឹកនាំនៅក្នុងពិធីជប់លៀងនោះ ?

ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ២:៩–១០ ឲ្យឮៗ ហើយសូមអញ្ជើញសិស្សក្នុងថ្នាក់រកមើលថា តើលោកអភិបាលបានថ្លែងអ្វីខ្លះបន្ទាប់ពីភ្លក់រស់ជាតិភេសជ្ជៈដែលយកមកជូនលោកនោះ ។

- តើព្រះយេស៊ូវបានធ្វើអ្វីខ្លះចំពោះទឹកនោះ ?
- តើលោកអភិបាលនៅក្នុងពិធីនោះបាននិយាយដូចម្តេចអំពីស្រាថ្មីនោះ ? (សូមពន្យល់ថា ជាធម្មតាស្រាល្អបំផុតត្រូវយកទៅប្រើនៅពេលចាប់ផ្តើមកម្មវិធី ហើយស្រាដែលមានគុណភាពអន់ជាងយកទៅប្រើនៅពេលក្រោយនៃពិធីនោះ) ។

សូមពន្យល់ថា ព្រះយេស៊ូវពុំដែលផ្តល់ការបកស្រាយជាក់លាក់ពីអត្ថន័យ ឬ និមិត្តសញ្ញានៃអព្ភូតហេតុដំបូង ដែលបានកត់ត្រានៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់នេះឡើយ ។ ទោះជាយ៉ាងណា មានសេចក្តីពិតសំខាន់ៗជាច្រើន ដែលយើងអាចរៀនពីដំណើររឿងនៃអព្ភូតហេតុដំបូងរបស់ព្រះយេស៊ូវដែលបានកត់ត្រា ។

សូមចែកសិស្សជាក្រុម ដែលមួយក្រុមតូចៗមានគ្នាពីរ ឬបីនាក់ ។ សូមអញ្ជើញក្រុមនីមួយៗឲ្យសរសេរសេចក្តីពិតឲ្យបានច្រើនដែលអាចរៀនចេញពី យ៉ូហាន ២:១–១១ តាមដែលពួកគេអាចធ្វើទៅបាននៅលើក្រដាសមួយសន្លឹក ។ បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់នៅក្នុងក្រុមនីមួយៗឲ្យចែកចាយដល់សិស្សដទៃទៀត នូវសេចក្តីពិតដែលក្រុមរបស់ខ្លួនបានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ធ្វើជាអ្នកសរសេរ ។ ចូរសុំឲ្យអ្នកសរសេរនោះសរសេរនៅលើក្តារខៀននូវសេចក្តីពិតនីមួយៗដែលបានចែកចាយ ។ សេចក្តីពិតមួយចំនួនដែលសិស្សអាចរកឃើញមានដូចខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាលើវត្ថុសព្វសារពើ ។ ព្រះអង្គសង្គ្រោះបានជ្រាបថាទ្រង់មានបេសកកម្មដ៏ទេវភាពមួយដែលត្រូវបំពេញ ។ ព្រះមែស៊ីបានបង្ហាញព្រះចេស្តាដ៏ទេវភាពរបស់ទ្រង់តាមរយៈអព្ភូតហេតុនានា ។ ព្រះរាជបុត្រានៃព្រះស្រឡាញ់ ហើយគោរពដល់មាតារបស់ទ្រង់ ។**

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ២:១១ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់រកមើលថា តើអព្ភូតហេតុនេះមានប្រសិទ្ធភាពយ៉ាងណាខ្លះដល់ពួកសិស្សរបស់ព្រះយេស៊ូវ ។

- តើអព្ភូតហេតុនេះមានប្រសិទ្ធភាពយ៉ាងណាខ្លះ ដល់ពួកសិស្សរបស់ព្រះយេស៊ូវ ?

សូមគូសរង្វង់លើសេចក្តីពិតខាងក្រោម នៅលើក្តារខៀនដកស្រង់ចេញពីបញ្ជីនៃសេចក្តីពិតដែលសិស្សបានបង្ហាញ ។ **ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាលើវត្ថុសព្វសារពើ ។** (*កំណត់ចំណាំ ៖* ប្រសិនបើសិស្សមិនបានសរសេរពីសេចក្តីពិតនេះទេ សូមដាក់បញ្ចូលវាទៅក្នុងបញ្ជីនោះ) ។

- តើការយល់ដឹងថា ព្រះយេស៊ូវមានព្រះចេស្តាលើវត្ថុសព្វសារពើបានពង្រឹងសេចក្តីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?
- តើមានដំណើររឿងផ្សេងណាទៀត ដែលយើងបានសិក្សានៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានបង្ហាញផងដែរថា ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាលើវត្ថុសព្វសារពើនោះ ? (ចម្លើយអាចរួមមានដូចតទៅនេះ ៖ អព្ភូតហេតុពីរស្តីពីដុំនំបុ័ង និងត្រី [ប្រាំពាន់នាក់ ៖ ម៉ាកុស ៦:៣៣–៤៤ឬ៣ន់នាក់ ៖ ម៉ាកុស ៨:១–៩] ការធ្វើឲ្យព្យុះភ្លៀងស្ងប់ [ម៉ាកុស ៤:៣៥–៤១] ឬការយាងដើរនៅលើទឹក [ម៉ាថាយ ១៤:២២–៣៣]) ។

យ៉ូហាន ២:១២–២៥

ព្រះយេស៊ូវគ្រីស្ទសម្អាតព្រះវិហារបរិសុទ្ធ

សូមអញ្ជើញសិស្សឲ្យប្រាប់ឈ្មោះល្បែងកម្សាន្តលេងនៅទីវាលខាងក្រៅ ដែលពួកគេធ្លាប់លេងកាលពីក្មេង ។ បន្ទាប់ពីពួកគេបានគិតពីល្បែងកម្សាន្តមួយចំនួនមក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- ទោះបីជាល្បែងកម្សាន្តទាំងនេះវាមិនអាក្រក់ ហើយសប្បាយនឹងលេងក្តី តើអ្នកមានអារម្មណ៍ស្រណុកក្នុងចិត្តដើម្បីលេងវានៅលើទីធ្លានៃព្រះវិហារបរិសុទ្ធដែរឬទេ ?

សូមចែកសិស្សជាក្រុមដែលមានគ្នាពីរនាក់ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២:១២–១៧ ។ នៅពេលពួកគេអាន ចូរសុំឲ្យក្រុមរកមើល ហើយពិភាក្សាពីចម្លើយចំពោះសំណួរដូចខាងក្រោម (សូមសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖



១. តើព្រះយេស៊ូវបានរកឃើញនរណានៅក្នុងព្រះវិហារបរិសុទ្ធ ?

២. ហេតុអ្វីអ្នកគិតថាព្រះយេស៊ូវអាក់អន់ព្រះទ័យ ?

៣. តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ ដើម្បីកែតម្រូវបញ្ហានោះ ?

លុះដល់ពេលកំណត់ហើយ សូមដាក់បង្ហាញរូបភាព ព្រះយេស៊ូវបោសសម្អាតព្រះវិហារបរិសុទ្ធ (*Gospel Art Book* [ឆ្នាំ ២០០៩] ល.រ. ៥១ សូមមើលផងដែរ LDS.org) ហើយសុំឲ្យសិស្សពីរបីក្រុមប្រាប់ពីចម្លើយរបស់ពួកគេ ។ អ្នកអាចនឹងត្រូវពន្យល់ថា ទស្សនិកជនរាប់ពាន់នាក់ដែលមកទីក្រុងយេរូសាឡិមសម្រាប់ការអបអរសាទរបុណ្យរំលង ត្រូវការទិញសត្វដើម្បីថ្វាយជាគ្រឿងបូជា

នៅក្នុងព្រះវិហារបរិសុទ្ធ ដែលជាផ្នែកមួយនៃការថ្វាយបង្គំរបស់ពួកគេ ។ អ្នកប្តូរប្រាក់បានលក់ដូរប៊ិចប៊ិចប័ណ្ណរបស់រ៉ូម និង រូបិយប័ណ្ណផ្សេងទៀតជារូបិយប័ណ្ណព្រះវិហារបរិសុទ្ធ ដើម្បីទិញសត្វធ្វើជាគ្រឿងបូជា ហើយពាណិជ្ជករផ្សេងទៀតបានលក់សត្វដែលពួកគេត្រូវការនោះ ។ កាលការលក់ដូរត្រូវតែកើតឡើង នោះការធ្វើអាជីវកម្មបែបនេះនៅព្រះវិហារបរិសុទ្ធគឺជាការខ្វះគារវភាព និងខ្វះការគោរពក្តី ។

- តើសេចក្តីពិតអ្វីខ្លះអំពីព្រះវិហារបរិសុទ្ធ ដែលយើងអាចរៀនចេញពីការពិពណ៌នារបស់ព្រះយេស៊ូវអំពីព្រះវិហារបរិសុទ្ធនៅក្នុង ខ ទី ១៦ ? (សិស្សគួរកត់ឃើញសេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម ៖ **ព្រះវិហារបរិសុទ្ធគឺជាដំណាក់នៃព្រះ**) ។
- តើព្រះវិហារបរិសុទ្ធគឺជាដំណាក់របស់ព្រះតាម របៀប ណា ? (ចម្លើយរបស់សិស្សអាចផ្សេងៗគ្នា ប៉ុន្តែអាចរួមមាននូវគំនិតខាងក្រោមនេះ ៖ ព្រះវិហារបរិសុទ្ធគឺជាទីកន្លែងដែលព្រះអាចយាងមក ជាកន្លែងដែលទ្រង់មានវត្តមាន ឬអាចទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយជាកន្លែងដែលពិធីបរិសុទ្ធនានាទាក់ទងនឹងកិច្ចការនៃសេចក្តីសង្គ្រោះរបស់ទ្រង់ត្រូវបានធ្វើឡើង ។ ព្រះវិហារបរិសុទ្ធ គឺជាទីកន្លែងដ៏បរិសុទ្ធបំផុតនៃការថ្វាយបង្គំនៅលើផែនដីនេះ) ។

សូមជួយសិស្សឲ្យយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

សូមជួយសិស្សឲ្យយល់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដោយសួរសំណួរដែលដឹកនាំសិស្សទៅរកការវិភាគពីអត្ថន័យរបស់វា ឬប្រដូចវាទៅនឹងស្ថានភាពបច្ចុប្បន្ននានា ។ ការយល់ដឹងពីគោលលទ្ធិ និងគោលការណ៍មានន័យថា សិស្សយល់ពីគោលលទ្ធិ និងគោលការណ៍ដែលបានស្គាល់ និងស្ថានភាពដែលពួកគេអាចអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។ ការដឹងពីគោលលទ្ធិ និងគោលការណ៍មួយគឺជាតម្រូវការជាមុនមួយដើម្បីទទួលបានអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់របស់វា ហើយស្គាល់ពីរបៀបយកវាមកអនុវត្ត ។

ចូរសុំសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ។ ចូរសុំឲ្យសិស្សស្តាប់រករបៀបដែលការយល់ដឹងពីភាពបរិសុទ្ធនៃព្រះវិហារបរិសុទ្ធរបស់ព្រះយេស៊ូវបានជួយដល់ការសម្រេចចិត្តរបស់ទ្រង់ ដើម្បីបណ្តេញពួកអ្នកប្តូរប្រាក់ និងពួកអាជីវករចេញពីព្រះវិហារបរិសុទ្ធ ។



« ហេតុផលសម្រាប់កំហឹងនោះគឺគ្រាន់តែព្រះបន្ទូលចំនួនបីម៉ាត់ប៉ុណ្ណោះគឺ ៖ ‹ ព្រះដំណាក់នៃព្រះវរបិតារបស់ខ្ញុំ › ។ វាពុំមែនជាដំណាក់សាមញ្ញទេ វាគឺជាដំណាក់នៃព្រះ ។ វាត្រូវបានសាងសង់ឡើងសម្រាប់ថ្វាយបង្គំព្រះ ។ វាគឺជាដំណាក់សម្រាប់ដួងចិត្តដ៏មានគារវភាព ។ វាជាកន្លែងដែលមានបំណងសម្រាប់ការលួងលោមចំពោះទុក្ខលំបាក និងបញ្ហានៃមនុស្ស គឺជាទ្វារនៃស្ថានសួគ៌ ។ . . . ពលិកម្ម [របស់ព្រះយេស៊ូវ] ចំពោះព្រះដ៏ខ្ពស់បំផុតបង្កាត់ភ្លើងនៅក្នុងព្រលឹងទ្រង់ ហើយប្រទានព្រះបន្ទូលរបស់ទ្រង់នូវកម្លាំង ដែលចាក់ទំលុះអ្នកប្រមាថទាំងនោះដូចជាកាំបិតស្ងៀត » (« Hallowed Be Thy Name » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ ទំព័រ ៥៣) ។

- តើសកម្មភាពរបស់ព្រះយេស៊ូវ បានបង្ហាញគារវភាពរបស់ទ្រង់ចំពោះដំណាក់នៃព្រះវរបិតាទ្រង់ដោយរបៀបណា ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *យើងបង្ហាញគារវភាពចំពោះព្រះវិហារបរិសុទ្ធតាមរយៈ . . .*

សូមចែកសិស្សជាក្រុម ដែលមួយក្រុមៗមានគ្នាពីរ ឬបីនាក់ ។ សូមអញ្ជើញក្រុមទាំងឡាយឲ្យសរសេរនៅលើក្រដាស នូវរបៀបជាច្រើនដែលពួកគេអាចគិតឃើញដើម្បីបំពេញឃ្លានេះ ។ បន្ទាប់ពីមួយ ឬពីរនាទីក្រោយមក ចូរសុំឲ្យក្រុមមួយចែកចាយបញ្ជីរបស់ខ្លួនដល់សិស្សផ្សេងទៀត ។ ខណៈពេលក្រុមទីមួយចែកចាយ ចូរសុំឲ្យក្រុមផ្សេងទៀតគូសសញ្ញាកែងនៅក្បែរចំណុចនីមួយៗដែលបានលើកឡើង ហើយដែលមាននៅក្នុងបញ្ជីរបស់ពួកគេ ។ ក្រោយមកទៀត សុំឲ្យក្រុមមួយទៀតចែកចាយចំណុចទាំងឡាយនៅលើបញ្ជីរបស់ខ្លួន ដែលក្រុមទីមួយមិនបានលើកឡើង ។ សូមធ្វើដំណើរការនេះម្តងហើយម្តងទៀត រហូតក្រុមទាំងអស់បានចែកចាយបញ្ជីរបស់ខ្លួន ។

- តើយើងអាចបង្ហាញគារវភាពរបស់យើងចំពោះព្រះវិហារបរិសុទ្ធបានដោយរបៀបណា កាលយើងមិនបាននៅក្នុងព្រះវិហារបរិសុទ្ធនោះ ?

សូមអញ្ជើញសិស្សម្នាក់ៗឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេពីហេតុដល ដែលពួកគេគិតថាវាជារឿងដ៏សំខាន់ ដែលពួកគេត្រូវធ្វើឲ្យអស់ពីលទ្ធភាពដើម្បីបង្ហាញគារវភាពចំពោះព្រះវិហារបរិសុទ្ធ ។ ក៏សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយ ដើម្បីធ្វើកិច្ចការមួយដែលបង្ហាញគារវភាពចំពោះព្រះវិហារបរិសុទ្ធ ។ ចូរលើកទឹកចិត្តពួកគេឲ្យធ្វើតាមគោលដៅនេះ ។

ចូរចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ទាំងឡាយ ដែលបានបង្ហាញនៅក្នុងមេរៀនថ្ងៃនេះ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

សកម្មភាពនេះអាចត្រូវបានប្រើប្រាស់ដើម្បីណែនាំ ឬរំឭកឈុតនៃវគ្គចំណេះចំណានខគម្ពីរ ។ សូមជ្រើសរើសប័ណ្ណចំណេះចំណានខគម្ពីរមួយចំនួន ហើយរៀបចំចែកវាឲ្យដល់សិស្សរបស់អ្នក ។ (សូមប្រាកដថាមានកាតនីមួយៗឲ្យច្រើន ដូច្នេះមានសិស្សច្រើនអាចបានវគ្គចំណេះចំណានខគម្ពីរដែលដូចគ្នា ។ អ្នកគួរមានប័ណ្ណគ្រប់គ្រាន់សម្រាប់សិស្សម្នាក់ៗ ដើម្បីមានវគ្គបទខគម្ពីរពីរ ឬ បីផ្សេងៗគ្នា) ។ សូមចែកប័ណ្ណនោះដល់សិស្ស ។ សូមទុកពេលឲ្យសិស្សសិក្សាវគ្គចំណេះចំណានខគម្ពីរ សេចក្តីយោង ពាក្យគន្លឹះ សេចក្តីថ្លែងការណ៍នៃបរិបទ គោលលទ្ធិ និងគោលការណ៍ និង គំនិតអនុវត្តនានានៅលើប័ណ្ណនីមួយៗ ។ សូមនិយាយតម្រុយចេញពីប័ណ្ណ (ឧទាហរណ៍ ពាក្យនានាមកពីវគ្គចំណេះចំណានខគម្ពីរ ឬ ពាក្យគន្លឹះ បរិបទ គោលលទ្ធិ ឬ គោលការណ៍ ឬ ការអនុវត្ត) ។ សិស្សដែលមានកាតដែលទាក់ទងនឹងតម្រុយនោះគួរតែក្រោកឈរឡើង ហើយនិយាយសេចក្តីយោងនៃចំណេះចំណានខគម្ពីរនោះឲ្យឮៗ ។

មេរៀន ៦២

យ៉ូហាន ៣

សេចក្តីផ្តើម

នារាត្រីមួយពួកផារិស៊ីម្នាក់ឈ្មោះ នីកូដេម បានមកឯព្រះយេស៊ូវ ហើយបានសន្ទនាជាមួយនឹងទ្រង់ ។ ព្រះយេស៊ូវបានបង្រៀននីកូដេមថា មនុស្សទាំងអស់ត្រូវតែកើតជាថ្មី ដើម្បីចូលទៅក្នុងនគរនៃព្រះបាន ។ ក្រោយមក យ៉ូហាន បាទីស្ទ បានពន្យល់ដល់ពួកសិស្សរបស់ទ្រង់ថា គួនាទីរបស់លោកគឺរៀបចំផ្លូវថ្វាយព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៣:១–២១

ព្រះយេស៊ូវបង្រៀននីកូដេមពីសេចក្តីពិតខាងវិញ្ញាណ

សូមអញ្ជើញសិស្សឲ្យស្រមៃថា នៅថ្ងៃណាមួយ កាលពួកគេកំពុងពិភាក្សាអំពីសាសនាជាមួយមិត្តភក្តិមួយចំនួន នោះមានម្នាក់និយាយថា « ដរាបណាខ្ញុំជាមនុស្សល្អ នោះខ្ញុំអាចទៅនគរស្ថានសួគ៌ » ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលពួកគេនឹងឆ្លើយតបទៅមិត្តម្នាក់នេះ ។

សូមលើកទឹកចិត្តសិស្សឲ្យមើលនៅក្នុងយ៉ូហាន ៣រកមើលអ្វីដែលយើងត្រូវធ្វើដើម្បីចូលទៅក្នុងនគរព្រះ ។

សូមពន្យល់ថា នៅជិតការចាប់ផ្តើមនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ នោះព្រះអង្គសង្គ្រោះបានយាងទៅក្រុងយេរូសាឡិម ដើម្បីប្រារព្ធពិធីបុណ្យរំលង ។ មនុស្សជាច្រើននៅក្នុងក្រុងយេរូសាឡិមបានជឿលើព្រះយេស៊ូវ បន្ទាប់ពីពួកគេបានឃើញអព្ភូតហេតុដែលទ្រង់បានសម្តែង (សូមមើល យ៉ូហាន ២:២៣–២៥) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៣:១–២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើង ខណៈដែលព្រះអង្គសង្គ្រោះគង់នៅក្រុងយេរូសាឡិម ។

- តើព្រះយេស៊ូវបានយាងទៅជួបនរណា ?

សូមពន្យល់ថាក្នុងនាមជា « ចៅហ្វាយសាសន៍យូដាម្នាក់ » (យ៉ូហាន ៣:១) នីកូដេម ជាសមាជិកម្នាក់នៃពួកសានហេឌ្រីន ។ ពួកសាសន៍ហេឌ្រីនគឺជាក្រុមប្រឹក្សាភិបាល ដែលបានបង្កើតឡើងដោយពួកផារិស៊ី និង ពួកសាឌូស៊ី ដែលដឹកនាំកិច្ចការរដ្ឋការ និង សាសនានៃពួកប្រជាជនសាសន៍យូដា ។

- ហេតុអ្វីអ្នកគិតថា នីកូដេមមកជួបព្រះយេស៊ូវនៅយប់នោះ ?
- យោងតាម ខទី ២តើនីកូដេមបានទទួលស្គាល់អ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ?

សូមពន្យល់ថា ការទទួលស្គាល់របស់នីកូដេមថាព្រះយេស៊ូវគឺជា « គ្រូមកពីព្រះពិត » (ខទី ២) ជាចំណុចមួយដែលលោកចង់រៀនពីព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៣:៣–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់នីកូដេម ។

- យោងតាម ខទី ៣តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះដល់នីកូដេម ?
- តើនីកូដេមបានគិតថា ព្រះអង្គសង្គ្រោះចង់មានបន្ទូលយ៉ាងដូចម្តេចទាក់ទងនឹងការ « កើតជាថ្មី » (ខទី ៣) នោះ ?

សូមពន្យល់ថា ដើម្បីបានកើតជាថ្មីគឺ « ដើម្បីមានព្រះវិញ្ញាណនៃព្រះអម្ចាស់បណ្តាលឲ្យមានការផ្លាស់ប្តូរយ៉ាងធំក្នុងដួងចិត្តរបស់មនុស្សម្នាក់ ដើម្បី [គាត់]ពុំមានបំណងប្រាថ្នាធ្វើអាក្រក់ទៀតឡើយ ប៉ុន្តែមានបំណងស្វែងរកការណ៍នៃព្រះវិញ (សេចក្តីណែនាំដល់បទគម្ពីរ ទាំងឡាយ « កើតម្តងទៀត កើតពីព្រះ » scriptures.lds.org សូមមើលផងដែរ ម៉ូសាយ ៥:២, អាលម៉ា ៥: ១៤–១៥ , ម៉ូសេ ៦:៥៩) ។

- យោងតាម ខទី ៥តើរឿងពីរយ៉ាងដែលព្រះយេស៊ូវបានបង្រៀននីកូដេមដែលចាំបាច់ដើម្បីចូលទៅក្នុងនគរព្រះជាអ្វី ? តើអ្នកគិតថាការ « កើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ » មានន័យដូចម្តេច ?
- តើអ្នកនឹងសង្ខេបអ្វីដែលខគម្ពីរទាំងនេះបង្រៀន អំពីរឿងដែលចាំបាច់សម្រាប់ការកើតជាថ្មីខាងវិញ្ញាណ និងការចូលទៅក្នុងនគរសេឡេស្ទាលដោយរបៀបណា ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖ **ការទទួលបុណ្យជ្រមុជទឹក និងការទទួលអំណោយទាននៃព្រះវិញ្ញាណគឺចាំបាច់ចំពោះការកើតជាថ្មីខាងវិញ្ញាណ និងការទទួលភាពតម្កើងឡើងនៅក្នុងនគរសេឡេស្ទាល**) ។

សូមរំឭកសិស្សពីសាច់រឿងនេះជាមួយនឹងមិត្តភក្តិ ។ សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញសិស្សម្នាក់ពីដៃគូនីមួយៗ ឲ្យសម្តែងជាមិត្តដែលគិតថារឿងដែលចាំបាច់ ដើម្បីចូលទៅក្នុងនគរព្រះគឺ ត្រូវធ្វើជាមនុស្សល្អម្នាក់ ។ សូមអញ្ជើញសិស្សម្នាក់ទៀតនៅក្នុងក្រុមនីមួយៗ ឲ្យហាត់បញ្ជាក់ដោះស្រាយការយល់ខុសឆ្គងនោះដោយប្រើ យ៉ូហាន ៣:៥ ។



នីកូដេម ទៅជួបនឹងព្រះយេស៊ូវ

យ៉ូហាន ៣:៥ គឺជាចំណេះ: ចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រីះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សូមសង្ខេប យ៉ូហាន ៣:៦–១២ ដោយពន្យល់ថា នីកូដេមបានទូលសួរព្រះយេស៊ូវថា តើអ្វីទៅដែលអាចធ្វើឲ្យមនុស្សអាចកើតជាថ្មីបាន ។ ព្រះយេស៊ូវបានតបដោយចោទសួរថា តើនីកូដេមអាចក្លាយជាអ្នកដឹកនាំ និងជាគ្រូបង្រៀនសាសនាម្នាក់យ៉ាងដូចម្តេចបានទៅបើមិនដឹងថាការកើតជាថ្មីខាងវិញ្ញាណពិតជាចាំបាច់ និងអ្វីដែលអាចធ្វើឲ្យកើតមានការកើតជាថ្មីខាងវិញ្ញាណផងនោះ ។

នៅក្នុង យ៉ូហាន ៣:១៣–២១ យើងអានថា ព្រះអង្គសង្គ្រោះបានពន្យល់ដល់នីកូដេម ពីរបៀបដែលមនុស្សអាចកើតជាថ្មីបាន ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗ នៅក្នុង យ៉ូហាន ៣:១៣–១៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីរបៀបដែលព្រះយេស៊ូវបានឆ្លើយនឹងសំណួររបស់នីកូដេម ។

ជំនួសឲ្យការអញ្ជើញសិស្សឲ្យអាន យ៉ូហាន ៣:១៣–១៥ ឮៗ អ្នកគួរបង្ហាញវីដេអូ « Heavenly Things » (៨:៥៥) ត្រង់លេខកូដពេលវេលា ៥:៣០ រហូតដល់ចប់ ។ វីដេអូនេះបរិយាយពីព្រះអង្គសង្គ្រោះបង្រៀនដល់នីកូដេម ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមនៅក្នុងព្រះគម្ពីររបស់ពួកគេ ដោយរកមើលរបៀបដែលព្រះយេស៊ូវបានឆ្លើយតបនឹងសំណួររបស់នីកូដេម ។ វីដេអូនេះមាននៅក្នុង LDS.org ។



- តើព្រះអង្គសង្គ្រោះបានមានបន្ទូលអ្វីខ្លះ អំពីព្រះអង្គទ្រង់នៅក្នុងយ៉ូហាន ៣:១៣ ? (ទ្រង់បានថ្លែងទីបន្ទាល់ថា ព្រះអង្គទ្រង់គឺជាព្រះរាជបុត្រានៃព្រះដែលយាងចុះមកពីស្ថានសួគ៌) ។

សូមដាក់បង្ហាញរូបភាព ម៉ូសេ និងសត្វពស់លង្ហិន (*Gospel Art Book* | ឆ្នាំ២០០៩| ល.រ. ១៦សូមមើលផងដែរ LDS.org) ។ ចូរសុំឲ្យសិស្សពន្យល់ដំណើររឿងចេញពីបទគម្ពីរដែលមាននៅក្នុងរូបភាពនេះ ។ ប្រសិនបើចាំបាច់ សូមពន្យល់ថា នៅសម័យម៉ូសេ ព្រះអម្ចាស់បានបញ្ជូនពស់ពិសដោយសារតែពួកសាសន៍អ៊ីស្រាអែលធ្វើអំពើបាបទាស់នឹងព្រះ ។ ពួកសាសន៍អ៊ីស្រាអែលបានត្រូវពិស នៅពេលសត្វពស់បានចឹកពួកគេ ។ ព្រះអម្ចាស់បានដឹកនាំម៉ូសេ ឲ្យដាក់រូបពស់ស្ពាន់មួយលើបង្គោលដោយសន្យាថា សាសន៍អ៊ីស្រាអែលណាម្នាក់ ដែលមើលរូបពស់នៅលើបង្គោលនោះនឹងបានជាសះស្បើយ ។ (សូមមើល ជនគណនា ២១:៨–៩) ។

- យោងតាម យ៉ូហាន ៣:១៤តើព្រះយេស៊ូវបានមានបន្ទូលថាសត្វពស់ស្ពាន់នោះតំណាងឲ្យអ្វីទៅ ?

សូមដាក់បង្ហាញរូបភាព ការឆ្កាង *(Gospel Art Book* | ឆ្នាំ ២០០៩ | ល.រ. ៥៧, សូមមើលផងដែរ LDS.org) ។



- យោងតាម ខទី ១៥តើពរជ័យអ្វីទៅ ដែលកើតមានចំពោះជនដែលមើលទៅព្រះអង្គសង្គ្រោះ ?
- តើយើងអាចរៀនគោលលទ្ធិអ្វីខ្លះ ចេញពីខគម្ពីរទាំងនេះ អំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នាប៉ុន្តែចូរប្រាកដថាត្រូវគូសបញ្ជាក់សេចក្តីពិតដូចខាងក្រោមនេះ ៖ **មនុស្សលោកអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ៣:១៦–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលគោលលទ្ធិដែលយើងអាចរៀនអំពីព្រះវរបិតាសួគ៌ ។

- តើព្រះវរបិតាសួគ៌បានបញ្ជូនព្រះរាជបុត្រាទ្រង់ឲ្យធ្វើអ្វី ?
- តើយើងអាចរៀនគោលលទ្ធិអ្វីខ្លះមកពីខគម្ពីរទាំងនេះអំពីព្រះវរបិតាសួគ៌ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា តើម្បីបង្ហាញពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះវរបិតាសួគ៌ស្រឡាញ់កូនចៅរបស់ទ្រង់ដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ឲ្យរងទុក្ខសម្រាប់អំពើបាបរបស់ពួកគេ ។** សូមបន្ថែមគោលលទ្ធិនេះទៅលើគោលលទ្ធិដែលមាននៅលើក្តារខៀន) ។
- តើព្រះវរបិតាសួគ៌បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទមកកាន់ផែនដីដើម្បីបង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ ចំពោះយើងម្នាក់ៗតាមរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សពិចារណាថា តើការដឹងអំពីសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះពួកគេធ្វើឲ្យពួកគេមានអារម្មណ៍បែបណាដែរ ។

« គ្មានភស្តុតាងណាមួយប្រសើរជាងព្រះចេស្តា និង ភាពឥតខ្ចោះដ៏ពុំអាចប្រៀបផ្ទឹមនៃសេចក្តីស្រឡាញ់របស់ព្រះជាងជាងការប្រកាសដោយសាវកយ៉ូហានឡើយ | នៅក្នុង យ៉ូហាន ៣:១៦ | ។ . . . សូមគិតមើលចុះ ថាតើព្រះវរបិតាសួគ៌របស់យើងឈឺចាប់ក្នុងព្រះទ័យខ្លាំងប៉ុណ្ណា ដែលបានបញ្ជូនបុត្រាតែមួយរបស់ទ្រង់ឲ្យស៊ូទ្រាំនឹងការរងទុក្ខ ដែលពុំអាចយល់បាន សម្រាប់អំពើបាបរបស់យើងនោះ ។ នោះគឺជាភស្តុតាងដ៏អស្ចារ្យបំផុតនៃសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះពួកយើងម្នាក់ៗ ! » (« Love and Law » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ២៦) ។

- តើអ្នកមានអារម្មណ៍បែបណា ដោយដឹងថាព្រះវរបិតាសួគ៌ស្រឡាញ់អ្នកយ៉ាងខ្លាំង រហូតដល់ទ្រង់បានបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយឲ្យរងទុក្ខ ហើយសុគតសម្រាប់អ្នកនោះ ?
- យោងតាម យ៉ូហាន ៣:១៦–១៧តើយើងអាចទទួលបានការសង្គ្រោះតាមរយៈដង្វាយធួនដោយរបៀបណា ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងជឿលើព្រះយេស៊ូវគ្រីស្ទ ដែលរួមបញ្ចូលទាំងការប្រែចិត្តពីអំពើបាបរបស់យើង ព្រមទាំងគោរពតាមព្រះបន្ទូលរបស់ទ្រង់ នោះយើងអាចមានជីវិតអស់កល្បជានិច្ច តាមរយៈដង្វាយធួនរបស់ទ្រង់ ។**

សូមអញ្ជើញសិស្សឲ្យរំឭកសេចក្តីពិតដែលលព្រះយេស៊ូវបានបង្រៀនដល់នីកូដេម ដែលមាននៅលើក្តារខៀនឡើងវិញ ។

- តើសេចក្តីពិតទាំងនេះជាប់ទាក់ទងគ្នាយ៉ាងដូចម្តេច ?
- តើវិធីមួយចំនួនដែលយើងអាចបង្ហាញជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទមានអ្វីខ្លះ ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងបង្ហាញជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទដោយប្រែចិត្ត ហើយដើរតាមទ្រង់ នោះយើងអាចបានការសង្គ្រោះ ហើយទទួលជីវិតដ៏នៅអស់កល្បជានិច្ចតាមរយៈដង្វាយធួន ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ខ្ញុំនឹងបង្ហាញសេចក្តីជំនឿរបស់ខ្ញុំលើព្រះយេស៊ូវគ្រីស្ទតាមរយៈ. . .* ចូរសុំសិស្សឲ្យបញ្ចប់ឃ្លានេះ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេដោយការសរសេរពីអ្វីដែលអ្នកនឹងធ្វើ ដើម្បីបង្ហាញសេចក្តីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ ។

យ៉ូហាន ៣:២២–៣៦

យ៉ូហាន បាទីស្ទ បង្រៀនថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ

ចូរដាក់បង្ហាញធុងថ្លាមួយដែលមានទឹកពេញ ។ ចូរដាក់លាក់មួយ ឬពីរតំណក់ទៅក្នុងទឹកនោះ ។

- តើពណ៌នោះអាចប្រៀបបាននឹងឥទ្ធិពលរបស់យើងទៅលើមនុស្សដទៃទៀតបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ដេវីឌ អូ មិកឃេ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវអ្វី ដែលយើងអាចរៀនអំពីឥទ្ធិពលរបស់យើងនៅក្នុងជីវិតរបស់អ្នកដទៃ ។



« មនុស្សគ្រប់រូបដែលរស់ នៅក្នុងពិភពលោកនេះមាននូវឥទ្ធិពលមួយ មិនថាវាជាឥទ្ធិពលល្អ ឬ អាក្រក់នោះទេ (*Teachings of Presidents of the Church: David O. McKay* | ឆ្នាំ ២០០៣ | ទំព័រ ២២៧) ។

« ផលប៉ះពាល់នៃពាក្យសម្តី និង ទង្វើរបស់យើងគឺធំធេងណាស់នៅលើពិភពលោកនេះ ។ រៀងរាល់វិនាទីនៃជីវិត អ្នកកំពុងផ្លាស់ប្តូរទៅរកកម្រិតមួយនៃជីវិតមនុស្សទូទាំងពិភពលោក » (*Teachings: David O. McKay* ទំព័រ ២២៧) ។

ចូរសុំឲ្យសិស្សរកមើលគោលការណ៍មួយនៅក្នុង យ៉ូហាន ៣:២២–៣៦ ដែលបង្រៀនយើងពីរបៀប ដែលយើងអាចជះឥទ្ធិពលល្អដល់មនុស្សដទៃទៀត ។

សូមសង្ខេប យ៉ូហាន ៣:២២–២៦ ដោយពន្យល់ថា ពួកសិស្សមួយចំនួនរបស់យ៉ូហាន បាទីស្ទ មានកង្វល់ដោយសារប្រជាជនបានដើរតាមព្រះយេស៊ូវគ្រីស្ទជាជាងដើរតាម យ៉ូហាន បាទីស្ទ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៣:២៧–៣០ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលយ៉ូហាន បាទីស្ទ បានយល់អំពីតួនាទីរបស់ខ្លួនដែលទាក់ទងនឹងព្រះយេស៊ូវគ្រីស្ទ ។

- តើយ៉ូហាន បាទីស្ទ ចង់ឲ្យពួកសិស្សរបស់គាត់យល់អ្វីខ្លះអំពីតួនាទីរបស់ខ្លួន ? (គាត់បានត្រូវបញ្ជូនមកពីមុនព្រះយេស៊ូវគ្រីស្ទ ដើម្បីរៀបចំមនុស្សសម្រាប់ទ្រង់) ។
- តើវិធីរៀបរាប់ភាពស្រដៀងគ្នាអ្វីទៅដែលយ៉ូហាន បាទីស្ទ បានប្រើ (ខទី ២៩) ?

សូមពន្យល់ថា កូនកម្លោះតំណាងឲ្យព្រះយេស៊ូវ ហើយកូនក្រមុំអាចតំណាងឲ្យអស់អ្នកដែលមកឯព្រះគ្រីស្ទ ហើយមិត្តភក្តិរបស់កូនកម្លោះតំណាងឲ្យយ៉ូហាន បាទីស្ទ ។

- តើអ្នកគិតថាយ៉ូហាន បាទីស្ទ ចង់មានន័យដូចម្តេច កាលគាត់ថ្លែងថា « ត្រូវឲ្យព្រះអង្គនោះបានចំរើនឡើង ហើយខ្ញុំត្រូវថយវិញចុះ » (ខទី ៣០) ? តើការណ៍នេះបង្ហាញអ្វីខ្លះ អំពីបុគ្គលិកលក្ខណៈរបស់យ៉ូហាន បាទីស្ទ ?
- តើព្រះយេស៊ូវគ្រីស្ទអាចធ្វើអ្វីខ្លះ ដែល យ៉ូហាន បាទីស្ទ មិនអាចធ្វើបានសម្រាប់ប្រជាជន ?
- តើយើងអាចរៀនអ្វីខ្លះចេញពីគំរូរបស់យ៉ូហាន បាទីស្ទ អំពីអ្វីដែលយើងអាចធ្វើដើម្បីជះឥទ្ធិពលល្អដល់មនុស្សដទៃ ? (សិស្សអាចបង្ហាញនូវសេចក្តីពិតខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា វាបញ្ជាក់យ៉ាងច្បាស់ថា **យើងអាចជះឥទ្ធិពលល្អដោយដឹកនាំពួកគេទៅរកព្រះយេស៊ូវគ្រីស្ទ**) ។
- ហេតុអ្វីការប្រើឥទ្ធិពលរបស់យើង ដើម្បីដឹកនាំមនុស្សដទៃឲ្យទៅឯព្រះគ្រីស្ទវាសំខាន់ ?
- តើអ្នកធ្លាប់ឃើញមនុស្សម្នាក់ដឹកនាំមនុស្សដទៃទៀតទៅរកព្រះអង្គសង្គ្រោះនៅពេលណាដែរ ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីរបៀប ដែលពួកគេអាចដឹកនាំមនុស្សដទៃទៅរកព្រះអង្គសង្គ្រោះ ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ក្នុងការខិតខំរបស់ពួកគេដើម្បីធ្វើកិច្ចការនោះ ។

សូមសង្ខេប យ៉ូហាន ៣:៣១–៣៦ យ៉ូហាន បាទីស្ទ បានប្រកាសថាព្រះយេស៊ូវបានបញ្ជូនពីព្រះ ហើយថាអស់អ្នកណាដែលជឿលើទ្រង់អាចទទួលជីវិតអស់កល្បជានិច្ច ។

ចំណេះចំណានខគម្ពីរ—យ៉ូហាន ៣:៥

ដើម្បីជួយសិស្សឲ្យទន្ទេញចាំ យ៉ូហាន ៣:៥សូមអញ្ជើញសិស្សឲ្យសរសេរតួអក្សរដំបូងនៃពាក្យនៅក្នុងខគម្ពីរនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យហាត់និយាយខគម្ពីរនេះឮៗ ដោយប្រើតួអក្សរដំបូង ហើយមើលខគម្ពីរនោះប្រសិនបើចាំបាច់ ។ នៅពេលសិស្សអាចនិយាយខគម្ពីរនោះទាំងស្រុង ដោយប្រើតួអក្សរដំបូង សូមអញ្ជើញពួកគេឲ្យហាត់សូត្រខគម្ពីរនោះដោយការចងចាំ ។ អ្នកអាចអញ្ជើញពួកគេឲ្យហាត់ប្រើខគម្ពីរនេះនៅដើម ឬចុងបញ្ចប់ថ្នាក់សម្រាប់រយៈពេលពីរបីថ្ងៃ ។

យ៉ូហាន ៤

សេចក្តីផ្តើម

ខណៈកំពុងយាងធ្វើដំណើរទៅស្រុកកាលីឡេ ព្រះយេស៊ូវបានឆ្លងកាត់ស្រុកសាម៉ារី ហើយ
បង្រៀនស្ត្រីម្នាក់នៅឯអណ្តូងទឹក ។ ស្ត្រីនោះបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។
ក្រោយមក ព្រះយេស៊ូវបានព្យាបាលកូនប្រុសបុរសត្រកូលខ្ពង់ខ្ពស់ម្នាក់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៤:១–៤២

ព្រះយេស៊ូវបង្រៀនស្ត្រីសាសន៍សាម៉ារីម្នាក់

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើធនធានធម្មជាតិអ្វី ដែលមានតម្លៃបំផុតនៅលើផែនដីនេះ ?

បន្ទាប់មក សូមឲ្យសិស្សឆ្លើយសំណួរនៅលើក្តារខៀន ។ ចូរពិចារណាដាក់បង្ហាញរូបភាពអំពីធនធានធម្មជាតិដូចជា ដី ដែក ធ្យូងថ្ម ប្រេង មាស ឬពេជ្រ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា ក្នុងក្លុំមនៃពួកសាវក ដប់ពីរនាក់ ៖

« យើងអាចគិតជាមុនថា មាស ប្រេង ឬ ពេជ្រមានតម្លៃខ្លាំងបំផុត ។ ប៉ុន្តែក្រៅពីជាតិខនិច ដែក ត្បូងច្នៃហើយ និង ធាតុរំលាយ នានាដែលមាននៅលើដី និង ក្នុងដី នោះទឹកគឺមានតម្លៃខ្លាំងបំផុត » (« A Reservoir of Living Water » ‖ Church Educational System fireside for young adults ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៧ ‖ ទំព័រ ១, lds.org/broadcasts) ។

ចូរដាក់បង្ហាញកែវថ្លាមួយដែលមានទឹកពេញ ។

- **ហេតុអ្វីទឹកស្អាតមានតម្លៃ ? (អ្នកអាចអញ្ជើញសិស្សម្នាក់ ឬពីរនាក់ឲ្យចែកចាយបទពិសោធន៍មួយដែលបានជួយពួកគេឲ្យមានអំណរគុណដល់សារៈសំខាន់នៃទឹក) ។**

សូមអញ្ជើញសិស្សឲ្យរកមើល តើព្រះយេស៊ូវបានប្រៀបធៀបទឹកទៅនឹងអ្វី កាលពួកគេសិក្សា យ៉ូហាន ៤ ។

សូមសង្ខេប យ៉ូហាន ៤:១–៣ ដោយពន្យល់ថា ព្រះយេស៊ូវបានយាងចេញពីស្រុកយូដាទៅស្រុកកាលីឡេ ។

ចូរសុំសិស្សម្នាក់អានយ៉ូហាន ៤:៤ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់រកមើលតំបន់ដែលព្រះយេស៊ូវបានយាងដើរកាត់ កាលទ្រង់យាងធ្វើដំណើរទៅស្រុកកាលីឡេ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សរកមើលស្រុកយូដា ស្រុកសាម៉ារី និងស្រុកកាលីឡេនៅលើតារាង « ជីវប្រវត្តិដ៏សំខាន់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរមែងស្លាប់ » (មាននៅក្នុង មេរៀនទី ៥) ឬអញ្ជើញពួកគេឲ្យមើលផែនទីព្រះគម្ពីរបឺប លេខ ១១ « ទឹកដីបរិសុទ្ធនៅក្នុងជំនាន់គម្ពីរសញ្ញាថ្មី » ដើម្បីរកមើលភូមិភាគទាំងបីនោះ ។

- **ហេតុអ្វីក៏កាលដែលព្រះយេស៊ូវបានយាងឆ្លង *ភាគ* ស្រុកសាម៉ារីជំនួសឲ្យការយាងដើរវាងស្រុកនោះ គឺជារឿងដ៏សំខាន់ ? (ជាទូទៅពួកសាសន៍យូដាធ្វើដំណើរវាងស្រុកសាម៉ារី ជាជាងធ្វើដំណើរឆ្លងកាត់ស្រុកនោះដោយសារភាពជាសត្រូវដែលមានរវាងសាសន៍យូដា និង សាសន៍សាម៉ារី ‖ សូមមើល James E. Talmage *Jesus the Christ* កំណែទី ៣ (ឆ្នាំ ១៩១៦) ទំព័រ ១៧២ ‖) ។**

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៤:៦–៩ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវបានសួរដល់ស្ត្រីម្នាក់កាលទ្រង់បានយាងឈប់នៅក្នុងស្រុកសាម៉ារី ។



- **តើព្រះយេស៊ូវបានសួរស្ត្រីម្នាក់នេះអ្វីខ្លះ ?**
- **ហេតុអ្វីនាងមានការភ្ញាក់ផ្អើលកាលព្រះយេស៊ូវបានសុំទឹកនាងផឹក ?**

ចូរដាក់បង្ហាញរូបភាព ព្រះយេស៊ូវ និងស្ត្រីសាសន៍សាម៉ារី (*Gospel Art Book* ‖ ឆ្នាំ ២០០៩ ‖ ល.រ. ៣៦សូមមើលផងដែរ LDS.org) ។

ចូរសុំសិស្សម្នាក់អាន យ៉ូហាន ៤:១០–១២ ឲ្យ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលចម្លើយរបស់ព្រះយេស៊ូវទៅកាន់ស្ត្រីនោះ ។

- យោងតាម ខទី ១០តើព្រះអង្គសង្គ្រោះបានប្រទានដល់ស្ត្រីនោះអ្វីខ្លះ ? (សូមពន្យល់ថាឃ្លា « អំណោយទាននៃព្រះ » សំដៅទៅលើព្រះយេស៊ូវថាជាព្រះអង្គសង្គ្រោះនៃពិភពលោក) ។
- យោងតាមខទី ១១តើស្ត្រីនោះបានទូលសួរអ្វីខ្លះដល់ព្រះយេស៊ូវ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៤:១៣–១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវ បានមានបន្ទូលអំពីទឹកដែលទ្រង់បានប្រទានឲ្យ ។

- តើព្រះយេស៊ូវបានមានបន្ទូលអ្វីខ្លះ អំពីទឹកដែលទ្រង់បានប្រទានឲ្យនោះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមរបស់អែលឌើរ ដេវីឌ អេ បែដណា ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ស្តាប់រកមើលថាតើទឹករស់តំណាងឲ្យអ្វី ។



« ទឹករស់ដែលបាននិយាយនៅក្នុងរឿងនេះ គឺតំណាងឲ្យព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ ។ ហើយដោយសារទឹកចាំបាច់សម្រាប់ទ្រទ្រង់ជីវិតឲ្យរស់នៅបាន នោះព្រះអង្គសង្គ្រោះ និង គោលលទ្ធិ គោលការណ៍ ព្រមទាំងពិធីបរិសុទ្ធទាំងឡាយរបស់ទ្រង់គឺចាំបាច់សម្រាប់ជីវិតអស់កល្បជានិច្ច ។ អ្នក និង រូបខ្ញុំត្រូវការទឹករស់របស់ទ្រង់រាល់ថ្ងៃ ហើយវាផ្គត់ផ្គង់គ្រប់គ្រាន់ដើម្បីទ្រទ្រង់ការរីកចម្រើន និង ការអភិវឌ្ឍជាបន្តបន្ទាប់ខាងវិញ្ញាណរបស់យើង » (« A Reservoir of Living Water »ទំព័រ ២) ។

- យោងតាមអែលឌើរ បែដណា តើទឹករស់តំណាងឲ្យអ្វី ?

នៅលើកែវទឹកដែលអ្នកបានដាក់បង្ហាញ សូមបិទស្លាកឈ្មោះថា *ព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ។*

- ហេតុអ្វីទឹកគឺជានិមិត្តសញ្ញាដ៏សមរម្យមួយនៃព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ?
- តើអ្នកអាចសង្ខេបព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុង ខទី ១៤ទៅជាគោលការណ៍មួយបានយ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលយកដំណឹងល្អរបស់ទ្រង់ដោយស្មោះត្រង់ នោះយើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

ចូរសុំសិស្សម្នាក់អាន យ៉ូហាន ៤:១៥–១៨ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលស្ត្រីនោះបានទូលសូមពីព្រះយេស៊ូវ ហើយថាតើព្រះអង្គសង្គ្រោះបានឆ្លើយតបយ៉ាងដូចម្តេច ។

- ស្របតាមខទី ១៥តើស្ត្រីនោះបានទូលសូមអ្វីខ្លះពីព្រះយេស៊ូវ ?

សូមពន្យល់ថា ចម្លើយតបរបស់ព្រះយេស៊ូវបានជួយស្ត្រីនោះឲ្យយល់ពីសេចក្តីត្រូវការរបស់នាង សម្រាប់ទឹករស់ដែលទ្រង់ប្រទានឲ្យ ។

- យោងតាម ខទី ១៧–១៨តើព្រះយេស៊ូវបានបើកសម្តែងអ្វីខ្លះអំពីស្ត្រីនោះ ? (សូមចង្អុលបង្ហាញថា ចម្លើយរបស់ព្រះយេស៊ូវបង្ហាញថា ទ្រង់បានជ្រាបថាស្ត្រីនោះមានបញ្ហានៅក្នុងការស្វែងរកទំនាក់ទំនងអាពាហ៍ពិពាហ៍ដ៏មានអត្ថន័យ ហើយយូរអង្វែងមួយ ប៉ុន្តែដោយការរួមរស់នឹងបុរសម្នាក់ដែលពុំមែនជាប្តីរបស់នាង នោះពុំបានគោរពតាមច្បាប់ព្រហ្មចារីភាពទេ) ។
- តើគំនិត ឬ អារម្មណ៍បែបណាដែលស្ត្រីម្នាក់នេះអាចមាន នៅពេលព្រះយេស៊ូវគ្រីស្ទបានបើកសម្តែងព័ត៌មានលម្អិតអំពីនាង ដែលជាជនចម្លែកដែលនាងមិនដែលស្គាល់ ?
- តើព្រះបន្ទូលរបស់ព្រះយេស៊ូវបានជួយស្ត្រីនោះឲ្យយល់ពីសេចក្តីត្រូវការរបស់នាង សម្រាប់ទឹករស់ដែលទ្រង់ប្រទានឲ្យដោយរបៀបណា ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ អំពីព្រះអង្គសង្គ្រោះចេញពីខគម្ពីរទាំងនេះ ? (បន្ទាប់ពីសិស្សបានឆ្លើយរួចហើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ព្រះយេស៊ូវគ្រីស្ទជ្រាបពីអំពើចាបរបស់យើង ហើយប្រទានដំណឹងល្អរបស់ទ្រង់ ដើម្បីជួយយើងឲ្យយកឈ្នះវា**) ។
- ហេតុអ្វីវាសំខាន់ដើម្បីយល់ពីសេចក្តីពិតនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៤:១៩–២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលដែលស្ត្រីនោះបានពោលទៅកាន់ព្រះយេស៊ូវ ។

- តើស្ត្រីនោះបាននិយាយដូចម្តេច ដែលបានបង្ហាញថា ទស្សនៈរបស់នាងអំពីព្រះយេស៊ូវត្រូវបានផ្លាស់ប្តូរ ?

សូមពន្យល់ថា នៅស្រុកសាម៉ារីមានភ្នំមួយឈ្មោះថាហ្គើរីស៊ីម ។ ជាច្រើនសតវត្សរ៍ពីមុនការបម្រើនៃជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ នោះសាសន៍សាម៉ារីបានសាងសង់ព្រះវិហារបរិសុទ្ធនៅទីនោះ ដើម្បីទុកជាទីកន្លែងថ្វាយបង្គំ ។ ប៉ុន្តែមិនដូចជាសាសន៍យូដាឡើយ សាសន៍សាម៉ារីពុំមានសិទ្ធិអំណាចបព្វជិតភាពដើម្បីធ្វើពិធីបរិសុទ្ធនានាឡើយ ហើយពួកគេបានបដិសេធការបង្រៀនជាច្រើនពីព្យាការីនៃព្រះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហាន ៤:២១–២៣ ដែលមាននៅក្នុងការបកប្រែដោយ យ៉ូសែប ស៊្មីធ យ៉ូហាន ៤:២៦ (នៅក្នុង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ស្ត្រីនោះអំពីការថ្វាយបង្គំព្រះ ។

- តើពួកអ្នកថ្វាយបង្គំព្រះដ៏ពិតថ្វាយបង្គំដល់ព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ?
- យោងតាមការបកប្រែដោយ យ៉ូសែប ស៊្មីធ តើពរជ័យអ្វីខ្លះនឹងទទួលបាន នៅពេលយើងថ្វាយបង្គំព្រះនៅក្នុង « វិញ្ញាណ និង សេចក្តីពិត » ?

- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងថ្វាយបង្គំព្រះវរបិតានៅក្នុងវិញ្ញាណ និង សេចក្តីពិត នោះទ្រង់នឹងប្រទានពរដល់ពួកយើងនៅក្នុងវិញ្ញាណរបស់ទ្រង់**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើល ហើយគូសចំណាំពីអត្ថន័យនៃការថ្វាយបង្គំព្រះវរបិតានៅក្នុងវិញ្ញាណ និង សេចក្តីពិត ។



« គោលបំណងរបស់យើងគឺថ្វាយបង្គំព្រះដ៏ពិត និង មានព្រះជន្មរស់ ហើយដើម្បីធ្វើបែបនោះ ដោយព្រះចេស្តានៃព្រះវិញ្ញាណ និង តាមរបៀបដែលទ្រង់បានតាំងឡើង ។ ការយល់ព្រមថ្វាយបង្គំព្រះដ៏ពិតនោះបានដឹកនាំទៅរកសេចក្តីសង្គ្រោះ ភក្តីភាពដែលបានផ្តល់ឲ្យដល់ព្រះត្លែងក្លាយ និង មិនបានស្ថាបនានៅលើសេចក្តីពិតអស់កល្បពុំមានន័យការធានាអះអាងបែបនេះឡើយ ។

« ចំណេះដឹងនៃសេចក្តីពិតមួយ គឺចាំបាច់ចំពោះការថ្វាយបង្គំដ៏ពិត ។ . . .

« . . .សេចក្តីពិត និង ការថ្វាយបង្គំដ៏ឥតខ្ចោះ រួមមាននៅក្នុងការដើរតាមជំហាននានានៃព្រះរាជបុត្រានៃព្រះ វាមាននៅក្នុងការរក្សាព្រះបញ្ញត្តិ ព្រមទាំងការគោរពតាមព្រះឆន្ទៈនៃព្រះវរបិតា ទៅនឹងកម្រិតនោះ ដែលយើងរីកចម្រើនពីព្រះគុណថែមលើព្រះគុណរហូតដល់យើងបានសិរីរុងរឿងនៅក្នុងព្រះគ្រីស្ទ ដូចដែលទ្រង់នៅក្នុងព្រះវរបិតាទ្រង់ដែរ ។ វាលើសពីការគ្រាន់តែការអធិស្ឋាន និងទេសនកថា ព្រមទាំងច្រៀងទៅទៀត ។ វាគឺជាការរស់នៅតាម ហើយធ្វើតាម និង គោរពតាម ។ វាគឺជាការប្រឹងធ្វើតាមជីវិតនៃអង្គជាគំរូដ៏អស្ចារ្យ | ព្រះយេស៊ូវគ្រីស្ទ | » (« How to Worship » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៧១ ទំព័រ ១២៩, ១៣០) ។

សូមកុំខ្លាចចំពោះការស្ងៀមស្ងាត់

សិស្សអាចនឹងមិនឆ្លើយសំណួរភ្លាមៗទេ ប៉ុន្តែសូមកុំបារម្ភចំពោះការស្ងៀមស្ងាត់នេះ ។ ពេលខ្លះសិស្សគ្រាន់តែត្រូវការឱកាសមួយ ដើម្បីសញ្ជឹងគិតពីសំណួរនោះ និងរបៀបដើម្បីឆ្លើយតប ។ ការសញ្ជឹងគិតនេះអាចជួយ ឲ្យមានការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។

- យោងតាមអែលឌើរ ម៉ាក់ខនឃី តើការថ្វាយបង្គំព្រះវរបិតានៅក្នុងវិញ្ញាណ និង សេចក្តីពិតមានន័យយ៉ាងណា?
- តើអ្នកធ្លាប់មានពរដោយសារអ្នកបានស្វែងរកដើម្បីថ្វាយបង្គំព្រះវរបិតានៅក្នុងវិញ្ញាណ និងសេចក្តីពិតនៅពេលណា ?

សូមអញ្ជើញសិស្សឲ្យពិចារណានូវអ្វីដែលពួកគេអាចធ្វើ ដើម្បីថ្វាយបង្គំព្រះវរបិតានៅក្នុងវិញ្ញាណ និងសេចក្តីពិតកាន់តែប្រសើរឡើង ។

- ចូរសុំសិស្សម្នាក់អាន យ៉ូហាន ៤:២៥–២៦ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វីដែលព្រះយេស៊ូវ បានបើកសម្តែងអំពីអង្គទ្រង់ទៅកាន់ស្ត្រីនោះ ។
- តើព្រះយេស៊ូវបានបើកសម្តែងអ្វីខ្លះ អំពីអង្គទ្រង់ទៅកាន់ស្ត្រីនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៤:២៧–៣០ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វី ដែលស្ត្រីម្នាក់នោះបានធ្វើបន្ទាប់ពីបានជជែកជាមួយព្រះអង្គសង្គ្រោះ ។

- តើស្ត្រីម្នាក់នោះបានធ្វើដូចម្តេច បន្ទាប់ពីបានជជែកជាមួយព្រះអង្គសង្គ្រោះ ?
- តើគាត់បាននិយាយអ្វីខ្លះ ដែលបង្ហាញថាគាត់បានទទួលទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីដំណើររឿងនេះ អំពីអ្វីដែលនឹងកើតឡើង នៅពេលយើងទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **នៅពេលយើងទទួលបានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ នោះយើងត្រូវបានពោរពេញដោយបំណងប្រាថ្នា ដើម្បីចែកចាយវាដល់មនុស្សដទៃទៀត**) ។

សូមសង្ខេប ខទី ៣១–៣៧ ដោយពន្យល់ថា ពួកសិស្សរបស់ព្រះយេស៊ូវបានត្រឡប់មកវិញដោយមានអាហារ ។ នៅពេលពួកគេបានអញ្ជើញឲ្យទ្រង់សោយអាហារ នោះទ្រង់បានបង្រៀនពួកគេថា ទ្រង់ត្រូវបានទ្រទ្រង់ឲ្យរស់ ពុំមែនដោយការសោយអាហារនោះទេ ប៉ុន្តែដោយការធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាទ្រង់ទៅវិញ ។ ក្រោយមកទ្រង់បានអញ្ជើញពួកគេឲ្យឃើញថា ឱកាសនានាដើម្បីផ្សាយដំណឹងល្អវាមានច្រើនណាស់ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៤:៣៩–៤២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលឥទ្ធិពលនៃទីបន្ទាល់របស់ស្ត្រីម្នាក់នោះទៅលើប្រជាជននៅក្នុងទីក្រុងរបស់នាង ។

- តើទីបន្ទាល់របស់ស្ត្រីម្នាក់នោះមានឥទ្ធិពលអ្វីខ្លះទៅលើប្រជាជននៅក្នុងទីក្រុងរបស់នាង ?
- យោងតាម ខទី ៤២ តើប្រជាជនបាននិយាយដូចម្តេចទៅស្ត្រីនោះ ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងបានស្គាល់ព្រះអង្គសង្គ្រោះ ហើយទទួលទានទឹករស់របស់ទ្រង់ យើងនឹងត្រូវបានពោរពេញដោយបំណងប្រាថ្នាមួយដើម្បីចែកចាយទីបន្ទាល់របស់យើងអំពីទ្រង់ជាមួយនឹងមនុស្សដទៃ ។

យ៉ូហាន ៤:៤៣–៥៤

ព្រះយេស៊ូវព្យាបាលកូនប្រុសរបស់បុរសត្រកូលខ្ពង់ខ្ពស់ម្នាក់

សូមសង្ខេប យ៉ូហាន ៤:៤៣–៤៥ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានបង្រៀនដល់ស្ត្រីនោះ នៅក្នុងស្រុកសាម៉ារីមក ទ្រង់បានយាងចូលទៅស្រុកកាលីឡេ ជាទីកន្លែងដែលប្រជាជនបានទទួលទ្រង់ ។

សូមផ្តល់ ឯកសារខាងក្រោមនេះដល់សិស្ស ។ សូមអញ្ជើញពួកគេអាន យ៉ូហាន ៤:៤៦–៥៤ ដោយស្ងៀមស្ងាត់ ហើយឆ្លើយសំណួរទាំងឡាយដែលមាននៅលើឯកសារនោះ ។

យ៉ូហាន ៤:៤៦–៥៤

១. តើនរណាបានជួបនឹងព្រះយេស៊ូវ ហើយតើគាត់ចង់បានពរជ័យអ្វីពីព្រះអង្គសង្គ្រោះ ?

២. ដោយផ្អែកលើអ្វីដែលព្រះយេស៊ូវបានបន្ទូល ហេតុអ្វីបានជាទ្រង់បានពន្យាពេលក្នុងការប្រទានពរដល់ការស្វែងរករបស់បុរសម្នាក់នេះ ?

៣. តើបុរសម្នាក់នេះបានបង្ហាញថា គាត់ពុំត្រូវការទីសម្គាល់មួយ ដើម្បីជឿដោយរបៀបណា ?

៤. យោងតាម ខទី ៥១–៥៣តើជំនឿរបស់បុរសម្នាក់នេះលើព្រះយេស៊ូវគ្រីស្ទបានបញ្ជាក់ដោយរបៀបណា ?

៥. តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីបទពិសោធន៍របស់បុរសម្នាក់នេះ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យចែកចាយចម្លើយរបស់ពួកគេ ។ នៅពេលពួកគេប្រាប់ពីគោលការណ៍ ដែលពួកគេបានរៀនពីបទពិសោធន៍របស់បុរសត្រកូលខ្ពស់ម្នាក់នោះ សូមជួយពួកគេឲ្យបង្ហាញនូវសេចក្តីពិតដូចខាងក្រោមនេះ ៖ **នៅពេលយើងជឿលើព្រះយេស៊ូវគ្រីស្ទដោយពុំត្រូវការទីសម្គាល់ នោះព្រះអម្ចាស់នឹងបញ្ជាក់ពីសេចក្តីជំនឿរបស់យើង ។**

- ហេតុអ្វីវាសំខាន់ដើម្បីជឿលើព្រះយេស៊ូវគ្រីស្ទដោយពុំចាំបាច់ត្រូវការទីសម្គាល់ ?
- តើរបៀបមួយចំនួនដែលព្រះអម្ចាស់បានបញ្ជាក់សេចក្តីជំនឿរបស់យើង នៅពេលយើងអនុវត្តសេចក្តីជំនឿលើទ្រង់នោះមានអ្វីខ្លះ ?

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ថា នៅពេលយើងស្វែងរកព្រះអម្ចាស់ដោយសេចក្តីជំនឿ នោះទ្រង់នឹងប្រទានពរដល់យើងនូវភស្តុតាងដើម្បីគាំទ្រដល់ជំនឿរបស់យើង ។

មេរៀន ៦៤


យ៉ូហាន ៥

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះបានចូលរួមពិធីជប់លៀងមួយ (ស្រដៀងនឹងបុណ្យរំលង) នៅក្រុងយេរូសាឡិម ហើយបានព្យាបាលបុរសពិការជើងម្នាក់នៅឯស្រះបេថែសដា ។ ព្រះយេស៊ូវគ្រីស្ទបានបង្រៀនថា ទ្រង់តំណាងឲ្យព្រះវរបិតាសួគ៌ ហើយបានពន្យល់ពីហេតុផលដែលប្រជាជនត្រូវគោរពដល់ព្រះរាជបុត្រានៃព្រះ ។ ទ្រង់ក៏បានពិពណ៌នាផងដែរពីសាក្សីផ្សេងទៀត ដែលបានថ្លែងទីបន្ទាល់អំពីភាពជាព្រះរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៥:១–៣០



ព្រះយេស៊ូវព្យាបាលបុរសពិការម្នាក់នៅថ្ងៃឈប់សម្រាក ហើយបង្រៀនអំពីទំនាក់ទំនងរបស់ទ្រង់នឹងព្រះវរបិតា

សូមដាក់បង្ហាញ រូបភាព បំណែកជើង ឬចាន (ឬអ្នកអាចគូររូបភាពចានបែកមួយនៅលើក្តារខៀន) ។

ចូរសុំឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេធ្លាប់ធ្វើឲ្យវត្ថុដែលមានតម្លៃ ឬសំខាន់ឲ្យបែកបាក់ ។ សូមពន្យល់ថាក្នុងនាមជាកូនចៅរបស់ព្រះវរបិតាសួគ៌ យើងរាល់គ្នាសំខាន់ និង មានតម្លៃខ្លាំងបំផុត ។ ប៉ុន្តែដោយសារការជ្រើសរើសរបស់យើង ឬ ឧបសគ្គនានាដែលយើងជួបប្រទះ មានគ្រានានាដែលយើងអាចមានអារម្មណ៍ថាខ្ទេចខ្ទាំ ឬ ដូចជាមានតម្លៃតិចតួច ។

- តើមនុស្សម្នាក់អាចនឹងមានអារម្មណ៍ខ្ទេចខ្ទាំខាងវិញ្ញាណ ខាងសាច់ឈាម ឬ ខាងសតិអារម្មណ៍តាមរបៀបណាខ្លះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ កាលពួកគេសិក្សា យ៉ូហាន ៥:១–៩ ដែលអាចជួយលួងលោមយើង ហើយផ្តល់សេចក្តីសង្ឃឹមដល់យើង នៅពេលយើងមានអារម្មណ៍ខ្ទេចខ្ទាំ ។

សូមសង្ខេប យ៉ូហាន ៥:១ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទបានបម្រើនៅក្នុងស្រុកកាលីឡេ នោះទ្រង់បានយាងទៅក្រុងយេរូសាឡិម ដើម្បីប្រតិបត្តិតាមពិធីជប់លៀងរបស់ពួកសាសន៍យូដា ដែលស្រដៀងនឹងបុណ្យរំលង ។ កាលគង់នៅក្រុងយេរូសាឡិម ទ្រង់បានយាងទៅស្រះទឹកនៅក្បែរព្រះវិហារបរិសុទ្ធ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូហាន ៥:២–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើនរណាខ្លះដែលបានប្រមូលផ្តុំគ្នានៅក្បែរស្រះទឹកនោះ ។

- តើមនុស្សប្រភេទណា ដែលបានប្រមូលផ្តុំគ្នានៅក្បែរស្រះទឹក បេថែសដា ? (សូមចង្អុលបង្ហាញថាពាក្យ *ខ្វះឈឺ ខ្វះខ្វាក់ ខ្វះខ្វិន* និង *ខ្វះស្វិត* នៅក្នុង ។ ខទី ៣ ។ ពិពណ៌នាអំពីមនុស្សដែលឈឺ ទន់ខ្សោយ ឬ ពិការតាមរបៀបផ្សេងៗ) ។
- តើមនុស្សរងទុក្ខទាំងនេះកំពុងរង់ចាំអ្វី ? (សូមពន្យល់ថា អាចមានក្បាលទឹកមួយដែលយូរៗម្តងបានហូរចូលទៅក្នុងស្រះ ហើយធ្វើឲ្យផ្ទៃខាងលើនៃទឹកនោះឡើងពពុះ ដែលអាចនឹងផ្តល់ការព្យាបាលដល់មនុស្សទាំងនេះ (សូមមើល Bible Dictionary « Bethesda ») ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« គ្មានចម្ងល់សោះឡើយថា ស្រះទឹកបេថែសដាគឺជាប្រភពទឹក ដែលវាជាទឹកមានន័យអំណាចដែលអាចព្យាបាលមនុស្សឲ្យជាបាន ។ ប៉ុន្តែការកត់សម្គាល់មួយថា ទេវតាបានយាងចុះមកហើយកូរទឹកនោះ ប្រយោជន៍ឲ្យមនុស្សដំបូងគេ ដែលបានចុះទៅក្នុងទឹកនោះនឹងបានជាសះស្បើយ គឺពិតជាគំនិតរឹតវាយមួយ ។ អព្ភូតហេតុនៃការព្យាបាលវាពុំកើតឡើងតាមរបៀបនេះឡើយ » (*Doctrinal New Testament Commentary* វ៉ុលទី ៣ ។ ឆ្នាំ ១៩៦៥–៧៣ ។ ១:១៨៨) ។

- តើអែលឌើរ ម៉ាក់ខន់ឃី បានបង្រៀនអ្វីខ្លះ អំពីជំនឿដែលមានទេវតាមួយអង្គបានបណ្តាលឲ្យទឹកអាចព្យាបាលដល់មនុស្សដំបូងដែលចូលទៅក្នុងស្រះនោះ ?



- តើអ្នកគិតថាទិដ្ឋភាពនៅឯស្រះទឹកនោះមានសភាពបែបណាដែរ ដោយមានមនុស្សជាច្រើនសង្ឃឹមថានឹងបានជាសះស្បើយ ដោយត្រូវធ្វើជាមនុស្សដំបូងគេដើម្បីឈានជើងចូលទៅក្នុងស្រះនោះ ?

សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហាន ៥:៥–៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអង្គសង្គ្រោះបានទតឃើញនរណាដេកនៅក្បែរស្រះទឹកនោះ ។

សូមដាក់បង្ហាញរូប ព្រះគ្រីស្ទព្យាបាលអ្នកឈឺនៅបេថែសដា (*Gospel Art Book* ។ ឆ្នាំ ២០០៩ ។ ល.រ.៤២ សូមមើលផងដែរ LDS.org) ។

- តើខគម្ពីរទាំងនេះពិពណ៌នាអំពីបុរសម្នាក់នេះ ដែលព្រះអង្គសង្គ្រោះបានទតឃើញយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សអាន យ៉ូហាន ៥:៨–៩ ដោយស្ងៀមស្ងាត់ ហើយរកមើលចម្លើយរបស់ព្រះអង្គសង្គ្រោះឆ្លើយតបទៅបុរសម្នាក់នោះ ។ ចូរសុំពួកគេឲ្យប្រាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមអញ្ជើញពួកគេឲ្យពិចារណាគូសចំណាំឃ្លា « អ្នកនោះបានជាភ្លាម » (ខទី ៩) ។

សូមសរសេរពាក្យ *បេថែសដា* នៅលើក្តារខៀន ។ សូមពន្យល់ថាពាក្យ *បេថែសដា* អាចត្រូវបានបកប្រែថាជា « ដំណាក់នៃសេចក្តីមេត្តាករុណា » (Bible Dictionary « Bethesda ») ។ សូមសរសេរនិយមន័យនេះនៅលើក្តារខៀនក្បែរពាក្យ*បេថែសដា* ។ សូមពន្យល់ថា សេចក្តីមេត្តាករុណាគឺជាសេចក្តីអាណិតអាសូរ ឬ សេចក្តីសប្បុរស ។ ទង្វើដ៏អស្ចារ្យបំផុតនៃសេចក្តីមេត្តាករុណា ដែលបានធ្វើឡើងនោះគឺ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

- ហេតុអ្វីបានជា *បេថែសដា* គឺជាឈ្មោះសមរម្យមួយសម្រាប់ទីកន្លែងនេះ ជាពិសេសបន្ទាប់ពីព្រះអង្គសង្គ្រោះបានព្យាបាលបុរសម្នាក់នេះ ?
- តើយើងអាចក្លាយជាបុរសម្នាក់នេះ ដែលនៅតែមាត់ស្រះបេថែសដាតាមរបៀបណាខ្លះ ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនចេញពីការព្យាបាលរបស់ព្រះអង្គសង្គ្រោះដល់បុរសម្នាក់នេះ ? (ទោះបីជាសិស្សអាចនឹងឆ្លើយខុសៗគ្នាក្តី ចូរធ្វើឲ្យប្រាកដដើម្បីគូសបញ្ជាក់ថា **តាមរយៈព្រះចេស្តា និងសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចជាសះស្បើយ**) ។

ដើម្បីជួយសិស្សឲ្យយល់ពីសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ មើរិល ជេ ប៊ែតមែន ដែលបានផ្តល់នូវគំរិះដ៏ជ្រៅនេះ កាលនៅបម្រើជាប៊ីស្សពជាអធិបតី ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកវិធីដែលព្រះអង្គសង្គ្រោះអាចព្យាបាលយើង ៖

« គឺដូចជាបុរសខ្វិនជើងនៅឯស្រះបេថែសដា ដែលត្រូវការឲ្យមនុស្សរឹងមាំជាងខ្លួនគាត់ ដើម្បីព្យាបាលគាត់ឲ្យជាដែរ (សូមមើល យ៉ូហាន ៥:១–៩) ដូច្នេះយើងត្រូវពឹងផ្អែកលើអព្ភូតហេតុនានានៃដង្វាយធួនរបស់ព្រះគ្រីស្ទ ដើម្បីឲ្យព្រលឹងរបស់យើងត្រូវបានព្យាបាលឲ្យជាពីសេចក្តីសោកសៅ ទុក្ខព្រួយ និង អំពើបាប ។ . . . តាមរយៈព្រះគ្រីស្ទ នោះដួងចិត្តដែលខ្ទេចខ្ទាំត្រូវបានជួសជុល ហើយភាពសុខសាន្តត្រូវបានជំនួសដោយភាពចប់អារម្ម និង ក្តីទុក្ខព្រួយ » (« The Power to Heal from Within » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៥ ទំព័រ ១៣) ។

- តើវិធីមួយចំនួនដែលយើងអាចជាសះស្បើយបានតាមរយៈសេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់មានអ្វីខ្លះ ? (អ្នកគួរពន្យល់ថា យើងអាចនឹងជៈសះស្បើយនៅក្នុងជីវិតនេះ ឬ នៅក្នុងជីវិតក្រោយ) ។
- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានសេចក្តីមេត្តាករុណា និងការព្យាបាលតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ?

សូមឲ្យសិស្សពិចារណាពីគ្រានានា នៅពេលអ្នកបានឃើញ ឬ បានទទួលអារម្មណ៍នៃព្រះចេស្តា សេចក្តីមេត្តាករុណា ឬ សេចក្តីអាណិតអាសូររបស់ព្រះយេស៊ូវគ្រីស្ទ ជួយពួកគេ ឬ នរណាម្នាក់ផ្សេងទៀតដែលមានអារម្មណ៍ថាខ្ទេចខ្ទាំចិត្ត ទាំងខាងវិញ្ញាណ ខាងសាច់ឈាម ឬ សតិអារម្មណ៍ ។ សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ខ្ញុំដឹងថាព្រះអង្គសង្គ្រោះពោរពេញដោយសេចក្តីមេត្តាករុណា និង សេចក្តីអាណិតអាសូរដោយសារ. . .*

ចូរសុំឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេនឹងបំពេញនូវប្រយោគខាងក្រោម ៖ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេ ។

សូមសង្ខេប យ៉ូហាន ៥:១០–១៦ ដោយពន្យល់ថា ក្រោយមកព្រះអង្គសង្គ្រោះបានទតឃើញបុរសម្នាក់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយទ្រង់បានប្រទានព្រះឱវាទដល់គាត់ « កុំឲ្យធ្វើបាបទៀតឡើយ » (យ៉ូហាន ៥:១៤) ។ នៅពេលអ្នកដឹកនាំសាសន៍យូដាបានដឹងថា បុរសម្នាក់នោះត្រូវបានប្រោសឲ្យជាដោយសារព្រះយេស៊ូវនៅថ្ងៃឈប់សម្រាក នោះពួកគេបានបៀតបៀន ហើយបានព្យាយាមចង់សម្លាប់ព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៥:១៧–១៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលហេតុផលមួយទៀតដែលពួកអ្នកដឹកនាំសាសន៍យូដាខឹងនឹងព្រះយេស៊ូវ ។

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង ខទី ១៧ព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកអ្នកដឹកនាំសាសន៍យូដាថា ដោយការព្យាបាលបុរសនោះ ទ្រង់កំពុងធ្វើកិច្ចការរបស់ព្រះវរបិតាសួគ៌ ។ ក្រោយមកព្រះអង្គសង្គ្រោះបានបង្រៀនអំពីទំនាក់ទំនងរបស់ទ្រង់ និង ព្រះវរបិតា ។

- យោងតាម ខទី ១៨តើអ្វីទៅជាហេតុផលមួយទៀត ដែលពួកអ្នកដឹកនាំសាសន៍យូដាខឹងនឹងព្រះយេស៊ូវ ? (ពួកគេបានជឿថាព្រះយេស៊ូវមានទោសនៃការប្រមាថព្រះ ពីព្រោះទ្រង់បានមានបន្ទូលថា ព្រះគឺជាព្រះវរបិតាទ្រង់ ហេតុដូច្នេះហើយបានប្រកាសខ្លួនស្មើនឹងព្រះ) ។

សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀន ៖ *តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះ អំពីទំនាក់ទំនងរបស់ទ្រង់នឹងព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ?* សូមបំបែកសិស្សជាគូៗ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអាន យ៉ូហាន ៥:១៩–២២, ២៦–២៧, ៣០ ឮៗរួមគ្នា ។ សូមឲ្យពួកគេរកមើលចម្លើយចំពោះសំណួរនេះ ។

ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរៀន ។ សូមសង្ខេបចម្លើយរបស់ពួកគេចំពោះសំណួរនេះ ដោយសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **រាល់កិច្ចការដែលទ្រង់បានធ្វើ ព្រះយេស៊ូវគ្រីស្ទតំណាងឲ្យព្រះវរបិតាសួគ៌ ហើយខិតខំគោរពតាមព្រះទ័យរបស់ទ្រង់ ។** សូមពន្យល់ថា ព្រះអង្គសង្គ្រោះអញ្ជើញយើងឲ្យធ្វើដូចគ្នា) ។

- ហេតុអ្វីវាសំខាន់ដើម្បីយល់ថា រាល់កិច្ចការដែលទ្រង់ធ្វើ ព្រះយេស៊ូវគ្រីស្ទឈរជាអង្គតំណាងដ៏ល្អឥតខ្ចោះនៃព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ?

យ៉ូហាន ៥:៣១–៤៧

ព្រះយេស៊ូវបានបង្រៀនពីសាក្សីជាច្រើននាក់ ដែលថ្លែងទីបន្ទាល់ពីភាពជាព្រះរបស់ទ្រង់

សូមយកសណ្តែកមួយក្តារដែលមិនទាន់បកសំបកមកថ្នាក់រៀន (សណ្តែកបារាំងមួយក្តារតូចក៏បាន) ។ សូមក្តាប់សណ្តែកមួយក្តារនោះក្នុងដៃដើម្បីកុំឲ្យសិស្សមើលឃើញ ។ សូមពន្យល់ថា អ្នកកំពុងកាន់វត្ថុមួយដែលមនុស្សមិនធ្លាប់ឃើញពីមុនមកឡើយ ។ ចូរសុំឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេជឿអ្នក ។ សូមអញ្ជើញសិស្សម្នាក់ដែលមិនទាន់ប្រាកដថា តើរឿងនេះពិតឬអត់នោះឲ្យជ្រើសមិត្តរួមថ្នាក់ពីរបីនាក់ដើម្បីមើលវត្ថុនោះ ។ សូមបង្ហាញវត្ថុនោះដល់សិស្សទាំងនេះ ហើយអញ្ជើញពួកគេឲ្យប្រាប់សិស្សដទៃទៀតថា តើអ្នកកំពុងប្រាប់ពីការពិតមែនដែរឬទេ ។

- តើការអះអាងពីភាពពោរពេញនៃសេចក្តីពិតណាមួយ ត្រូវបានពង្រឹងដោយរបៀបណា នៅពេលមានសាក្សីច្រើនជាងម្នាក់នោះ ?

សូមបង្ហាញសណ្តែកនោះដល់សិស្ស ហើយពន្យល់ពីរបៀប ដែលផ្នែកខាងក្នុងរបស់វាពុំធ្លាប់មានមនុស្សណាម្នាក់បានមើលឃើញឡើយ ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៥:៣១ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលអំពីសាក្សីរបស់ទ្រង់ផ្ទាល់ អំពីទំនាក់ទំនងរបស់ទ្រង់នឹងព្រះវរបិតាសួគ៌ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមចង្អុលបង្ហាញថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ បានបញ្ជាក់ ខទី ៣១ និង ៣២ ៖ « ប្រសិនបើខ្ញុំធ្វើបន្ទាល់ពីខ្លួនខ្ញុំ នោះសេចក្តីបន្ទាល់របស់ខ្ញុំគឺពិត ។ ដ្បិតខ្ញុំមិនបាននៅម្នាក់ឯងឡើយ » (ការបកប្រែដោយ យ៉ូសែ ស៊្មីធ យ៉ូហាន ៥:៣២–៣៣) ។ សូមពន្យល់ថា ព្រះអង្គសង្គ្រោះកំពុងបង្រៀនពួកសាសន៍យូដាថា ពួកគេមានសាក្សីម្នាក់ផ្សេងទៀតក្រៅពីទ្រង់ ។

ធ្វើបញ្ជី

បញ្ជីមួយគឺជាបណ្តុំនៃគំនិត ឬសេចក្តីណែនាំ ។ ការស្វែងរកបញ្ជីទាំងឡាយនៅក្នុងព្រះគម្ពីរអាចជួយអ្នក និងសិស្សរបស់អ្នកឲ្យបង្ហាញគន្លឹះសំខាន់ដែលបានគូសបញ្ជាក់នៅក្នុងខគម្ពីរទាំងនោះ ។

សូមសរសេរបទគម្ពីរយោងខាងក្រោមនេះនៅលើក្តារខៀន ៖ *យ៉ូហាន ៥:៣២–៣៥*, *យ៉ូហាន ៥:៣៦*, *យ៉ូហាន ៥:៣៧–៣៨*, *យ៉ូហាន ៥:៣៩*, *យ៉ូហាន ៥:៤៥–៤៧* ។ សូមឲ្យសេចក្តីយោងខគម្ពីរនីមួយៗដល់សិស្សម្នាក់ ឬច្រើននាក់ ។ ចូរសុំឲ្យពួកគេអានខគម្ពីរទាំងនេះ ហើយរកមើលសាក្សីផ្សេង ៗទៀតនៃទេវភាពរបស់ព្រះយេស៊ូវ ។ សូមជួយសិស្សធ្វើ បញ្ជី មួយអំពីសាក្សីទាំងនេះដោយអញ្ជើញពួកគេសរសេរអ្វីដែលពួកគេរកឃើញនៅលើក្តារខៀន ក្បែរនឹងសេចក្តីយោងខគម្ពីររបស់ពួកគេ ។

សូមពន្យល់ថា ទោះបីជាមានសាក្សីច្រើនអំពីព្រះយេស៊ូវគ្រីស្ទក្តី ក៏ពួកអ្នកដឹកនាំសាសន៍យូដាពុំជឿលើភាពជាព្រះរបស់ព្រះយេស៊ូវឡើយ ។ សូមចង្អុលបង្ហាញថានៅក្នុង ខទី ៣៩ ថានៅពេលព្រះយេស៊ូវបានមានបន្ទូលអំពីព្រះគម្ពីរ នោះទ្រង់មានបន្ទូលថា « ដោយស្មានថា បានជីវិតដ៏នៅអស់កល្បជានិច្ចអំពីគម្ពីរនោះមក » ។

- តើមានជំនឿខុសឆ្គងអ្វីខ្លះ ដែលព្រះយេស៊ូវបានចង្អុលបង្ហាញដល់ពួកសាសន៍យូដា ? (សូមបង្ហាញថា ពួកសាសន៍យូដាជាច្រើនបានជឿថា គ្រាន់តែការសិក្សាព្រះគម្ពីរមួយមុខ វានឹងអនុញ្ញាតឲ្យពួកគេទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ពួកគេមិនបានយល់ថា គោលបំណងនៃព្រះគម្ពីរ គឺដើម្បីចង្អុលបង្ហាញពួកគេទៅកាន់ព្រះយេស៊ូវគ្រីស្ទនោះទេ ។ ក្នុងន័យនេះ ទ្រង់បានមានបន្ទូលថា « អ្នករាល់គ្នាគិតថាអ្នកបានជីវិតដ៏នៅអស់កល្បជានិច្ច ដោយការស្វែងរកបទគម្ពីរ ដ្បិតវាថ្លែងទីបន្ទាល់ពីខ្ញុំ) ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៥:៤០ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល អ្វីដែលពួកសាសន៍យូដាត្រូវធ្វើ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

- ទោះបីជាពួកសាសន៍យូដាបានសិក្សាព្រះគម្ពីរក្តី តើពួកគេបានបដិសេធធ្វើអ្វីខ្លះដែលប្រហែលជាបានជួយពួកគេឲ្យមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច ?
- យោងតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង ខ ទី ៣៩ និង ៤០តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ? (សូមជួយសិស្សឲ្យបង្ហាញគោលការណ៍ស្រដៀងគ្នាមួយដូចនឹងគោលការណ៍ខាងក្រោម ៖ **មានតែតាមរយៈការមករកព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ទើបយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ចូរពួកសិស្សថាជីវិតដ៏នៅអស់កល្បជានិច្ច គឺរួមមានការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ហើយរស់នៅជារៀងរហូតជាមួយនឹងសមាជិកសក្តិសមនៃក្រុមគ្រួសាររបស់យើងនៅក្នុងវត្តមានរបស់ទ្រង់ ។

- តើការ « មកឯព្រះគ្រីស្ទ » មានន័យដូចម្តេច ? (ការមកឯព្រះគ្រីស្ទគឺជាការអនុវត្តសេចក្តីជំនឿលើទ្រង់ ប្រែចិត្តពីអំពើបាប ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់) ។
- ហេតុអ្វីការមកឯព្រះយេស៊ូវគ្រីស្ទគឺចាំបាច់ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីវិធីដែលទីបន្ទាល់ទាំងឡាយ ដែលមាននៅលើក្តារខៀនអាចជួយមនុស្សម្នាក់ឲ្យមកឯព្រះអង្គសង្គ្រោះ ។

- តើទីបន្ទាល់មួយក្នុងចំណោមទីបន្ទាល់ទាំងនេះ បានជួយអ្នកឲ្យមកឯព្រះគ្រីស្ទនៅពេលណា ?

សូមឲ្យសិស្សពិចារណាពី អ្វីដែលពួកគេនឹងធ្វើដើម្បីមកឯព្រះអង្គសង្គ្រោះឲ្យកាន់តែពេញលេញ ដើម្បីឲ្យពួកគេអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ពីសេចក្តីពិតដែលបានបង្រៀននៅក្នុង យ៉ូហាន ៥ ។

មេរៀន ៦៥

យ៉ូហាន ៦

សេចក្តីផ្តើម

នៅថ្ងៃបន្ទាប់ពីទ្រង់បានប្រទានអាហារប្រកបដោយអព្ភូតហេតុដល់ហ្វូងមនុស្ស ដែលមានចំនួនច្រើនជាង ៥០០០ នាក់ នោះព្រះយេស៊ូវបានបង្រៀនថា ទ្រង់គឺជានំបុ័ងជីវិត ។ អ្នកដើរតាមទ្រង់មួយចំនួនបានបដិសេធការបង្រៀនរបស់ទ្រង់ ហើយបានបែរចេញពីទ្រង់ ។ ផ្ទុយទៅវិញ ពេត្រុសបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវបង្រៀនព្រះបន្ទូលនៃជីវិតដ៏នៅអស់កល្បជានិច្ច ហើយទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៦:១–២១

ព្រះយេស៊ូវបានប្រទានអាហារដល់មនុស្សច្រើនជាង ៥០០០ នាក់ ប្រកបដោយអព្ភូតហេតុ ហើយយាងដើរនៅលើសមុទ្រ ។

ចូរពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានថ្លែងទីបន្ទាល់អំពីភាពជាព្រះរបស់ទ្រង់នៅទីក្រុងយេរូសាឡិមហើយ (សូមមើលយ៉ូហាន ៥) នោះទ្រង់បានត្រឡប់ទៅស្រុកកាលីឡេវិញ ជាកន្លែងដែលទ្រង់ និងពួកសិស្សរបស់ទ្រង់បានបង្រៀនដំណឹងល្អ ហើយបានព្យាបាលមនុស្សជាច្រើន (សូមមើលម៉ាថាយ ៤–១៣) ។ បន្ទាប់មកព្រះយេស៊ូវបានយាងឆ្លងសមុទ្រកាលីឡេជាមួយនឹងសិស្សរបស់ទ្រង់ ហើយបានប្រទានអាហារដល់ហ្វូងមនុស្សច្រើនជាង ៥០០០ នាក់ប្រកបដោយអព្ភូតហេតុ (សូមមើលយ៉ូហាន ៦:១–១៣) ។

សូមបង្ហាញដុំនំបុ័ង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសង្ខេបដំណើររឿងព្រះអង្គសង្គ្រោះ ប្រទានអាហារដល់មនុស្សច្រើនជាង ៥០០០ នាក់ជាមួយនឹងនំបុ័ងប្រាំដុំ និងត្រីតូច ២ពីរ ។

- តើអ្នកអាចគិតយ៉ាងណា បើអ្នកមានវត្តមាននៅក្នុងអព្ភូតហេតុនេះ ហើយដឹងថា ព្រះយេស៊ូវមានលទ្ធភាពប្រទានអាហារប្រកបដោយអព្ភូហេតុដូច្នេះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៦:១៤–១៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលនូវអ្វីដែលមនុស្សចង់ធ្វើបន្ទាប់ពីព្រះយេស៊ូវបានប្រទានអាហារដល់ពួកគេប្រកបដោយអព្ភូហេតុនោះ ។

- តើប្រជាជនចង់ធ្វើអ្វីខ្លះ ?

សូមពន្យល់ថា មានទំនៀមទម្លាប់មួយ នៅក្នុងចំណោមពួកយូដានៅជំនាន់របស់ព្រះយេស៊ូវ បានឲ្យយោបល់ថា នៅពេលព្រះមែស៊ី ឬស្តេចនៃអ៊ីស្រាអែលយាងមក នោះទ្រង់នឹងប្រទាននំបុ័ងជាអាហារដល់ប្រជាជនមកពីស្ថានសួគ៌ ។

- យោងតាមខទី ១៥តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ ជាជាងអនុញ្ញាតឲ្យមនុស្សបំពាក់មកុដដល់ទ្រង់ឲ្យធ្វើជាស្តេចរបស់ពួកគេនោះ ?
- ហេតុអ្វីព្រះយេស៊ូវមិនចង់ឲ្យគេទទួលស្គាល់ទ្រង់ ថាជាស្តេចនៃសាសន៍យូដា ?

សូមសង្ខេបយ៉ូហាន ៦:១៦–២១ដោយរំឭកដល់សិស្សថា ព្រះអង្គសង្គ្រោះបានបញ្ជូនសិស្សរបស់ទ្រង់ឆ្លងកាត់សមុទ្រកាលីឡេ ហើយក្រោយមកនៅពេលយប់ នៅពេលដែលពួកសិស្សកំពុងមានបញ្ហាក្នុងការអុំទូកបញ្ច្រាស់ទឹករលក និងខ្យល់ នោះទ្រង់បានយាងដើរឆ្លងកាត់ទឹកសមុទ្រមកជួបនឹងពួកគេ ។ សូមចង្អុលបង្ហាញថា ដំណើររឿងរបស់យ៉ូហានអំពីព្រឹត្តិការណ៍នេះគួរសបញ្ជាក់ថា នៅពេលពួកសិស្សបានទទួលព្រះយេស៊ូវចូលមកលើទូក « ដោយស្ម័គ្រចិត្ត » នោះពួកគេ (ខទី ២១) បានចូលចតដោយសុវត្ថិភាពនៅទិសដៅរបស់ពួកគេ « មួយរំពេច » ។ ចូរពន្យល់ថា នៅពេលយើងទទួលយកព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់ដោយស្ម័គ្រចិត្ត នោះទ្រង់អាចជួយដឹកនាំយើងដោយសុវត្ថិភាពឆ្លងកាត់បញ្ហានៃជីវិតរមែងស្លាប់នេះ ។

យ៉ូហាន ៦:២២–៥៩

ព្រះយេស៊ូវបង្រៀនថា ទ្រង់គឺជានំបុ័ងជីវិត

ចូរពន្យល់ថាយ៉ូហាន ៦:២២–២៥កត់ត្រាថា មានមនុស្សជាច្រើនដែលព្រះយេស៊ូវបានប្រទានអាហារឲ្យប្រកបដោយអព្ភូតហេតុ បានធ្វើដំណើរទៅកាន់ស្រុក កាពើណិម ដើម្បីស្វែងរកទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៦:២៦–២៧ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវមានបន្ទូលទៅកាន់ប្រជាជន ។ ចូរពន្យល់ថាពាក្យ*អាហារ*នៅក្នុងខទី ២៧សំដៅទៅលើម្ហូបអាហារ ។

- យោងតាមព្រះអង្គសង្គ្រោះ ហេតុអ្វីមនុស្សទាំងនេះស្វែងរកទ្រង់ ? (ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ផ្តល់យោបល់ថា ពួកគេបានដើរតាមទ្រង់ដើម្បីទទួលបានអាហារបន្ថែមមកពីទ្រង់) ។
- តើព្រះអង្គសង្គ្រោះប្រាប់ពួកគេថា ពួកគេគួរស្វែងរកអ្វីខ្លះ ?

ចូរពន្យល់ថា « អាហារ | ឬ ម្ហូបអាហារ | ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ច » (ខទី ២៧) អាចសំដៅទៅលើសេចក្តីពិតដ៏អស់កល្បជានិច្ចនៃដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ ។

- តើខគម្ពីរទាំងនេះអាចជួយយើងឲ្យយល់ពីមូលហេតុ ដែលព្រះយេស៊ូវមិនអនុញ្ញាតឲ្យក្រុមមនុស្សទាំងនេះមកបំពាក់មកុដទ្រង់ធ្វើជាស្តេចរបស់ពួកគេយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៦:២៨–៣១ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វី ដែលមនុស្សប្រាថ្នាចង់បានពីព្រះយេស៊ូវ ដើម្បីបង្ហាញបន្ថែមទៀតដល់ពួកគេថា ទ្រង់គឺជាព្រះមែស៊ី ។

- តើប្រជាជនចង់ឲ្យព្រះយេស៊ូវធ្វើអ្វីខ្លះសម្រាប់ពួកគេ ? (សូមពន្យល់ថា នំម៉ាន៉ាគឺជា « នំប៉័ងពីស្ថានសួគ៌ » [ខទី ៣១] ដែលព្រះបានប្រទានដល់កូនចៅនៃអ៊ីស្រាអែល នៅពេលពួកគេដើរនៅក្នុងទីរហោស្ថាន) ។
- សូមពិចារណាអំពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើនៅថ្ងៃមុននោះ តើសំណើរនេះអាចចង្អុលបង្ហាញអំពីហ្វូងមនុស្សយ៉ាងណាខ្លះ ?
- ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទសព្វថ្ងៃនេះ តើវិធីមួយចំនួនដែលយើងប្រហែលជាត្រូវបានល្បួងឲ្យមានឥរិយាបទដូចជាហ្វូងមនុស្សទាំងនោះ មានអ្វីខ្លះ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យគូសចំណាំ និងកត់ចំណាំក្នុងគម្ពីររបស់ពួកគេ ។

អ្នកអាចជួយសិស្សឲ្យយល់ និងរក្សានូវរឿងដែលពួកគេបានរៀន ដោយការលើកទឹកចិត្តដល់ពួកគេឲ្យគូសចំណាំ និងកត់ចំណាំក្នុងគម្ពីររបស់ពួកគេ ។ ការគូសចំណាំមានន័យថាគូសសម្គាល់ បង្ហាញភាពខុសគ្នា ញែកចេញពីគ្នា ឬឲ្យយកចិត្តទុកដាក់ ដែលអាចបានធ្វើឡើងដោយការគូសបន្ទាត់ពីខាងក្រោម ផាត់ពណ៌ ឬគូសពាក្យ ឬវគ្គគម្ពីរគន្លឹះនានា ។ ការធ្វើកំណត់ចំណាំមានន័យថាត្រូវកត់ចំណាំ និងអត្ថាធិប្បាយពន្យល់បន្ថែម ។ សូមអនុញ្ញាតឲ្យសិស្សជ្រើសរើសថា តើពួកគេនឹងគូសចំណាំ ហើយកត់ចំណាំគម្ពីររបស់ពួកគេយ៉ាងណា និងដោយរបៀបណា ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេណគ្នាឲ្យអានយ៉ូហាន ៦:៣២–៣៥ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ប្រជាជន ជាការឆ្លើយតបចំពោះសំណើររកទីសម្គាល់មួយរបស់ពួកគេ ។

- តើព្រះអង្គសង្គ្រោះបង្រៀនអំពីព្រះអង្គទ្រង់អ្វីខ្លះ នៅពេលទ្រង់សំដៅទៅលើនំម៉ាន៉ា ឬនំប៉័ងពីស្ថានសួគ៌នោះ ?

អ្នកអាចនឹងចង់ផ្តល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លាថា « ខ្ញុំជានំប៉័ងជីវិត » នៅក្នុងខទី ៣៥ ។

- តើយើងអាចប្រៀបប្រដូចព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់ទៅនឹងនំប៉័ងតាមរបៀបណា ?
- តើអ្នកគិតថាវាមានន័យយ៉ាងណា ដែលមនុស្សដែលមករកព្រះយេស៊ូវគ្រីស្ទ « នឹងមិនឃ្លានទៀតឡើយ » នោះ ? (ខទី ៣៥) ។
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខទី ៣៥ ? (ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗក្តី ក៏ពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **បើសិនជាយើងមករកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងចិញ្ចឹមបីបាច់យើងខាងវិញ្ញាណ ។** អ្នកគួរតែស្នើឲ្យសិស្សសរសេរគោលការណ៍នេះ នៅគែមទំព័រនៃបទគម្ពីររបស់ពួកគេ នៅជិតនឹងយ៉ូហាន ៦:៣៥) ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖

យើងមករកព្រះយេស៊ូវគ្រីស្ទតាមរយៈ . . . ទ្រង់នឹងចិញ្ចឹមបីបាច់យើងតាមរយៈ . . .

សូមបែងចែកសិស្សជាគូៗ ។ ចូរសុំពួកគេឲ្យធ្វើការរួមគ្នា ដើម្បីបង្កើតបញ្ជីមួយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេអំពីអ្វីៗមួយចំនួន ដែលយើងអាចធ្វើដើម្បីមករកព្រះយេស៊ូវគ្រីស្ទ និងរបៀបដែលទ្រង់នឹងចិញ្ចឹមបីបាច់យើងខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យរាយការណ៍ពីចម្លើយរបស់ពួកគេដល់សិស្សនៅក្នុងថ្នាក់ ។

ដើម្បីជួយសិស្សក្នុងថ្នាក់មានអារម្មណ៍ដឹងសេចក្តីពិត និងសារៈសំខាន់នៃគោលការណ៍ ដែលពួកគេបានប្រាប់នៅក្នុងខទី ៣៥ចូរពិចារណាធ្វើការអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយពីរបៀបដែលពួកគេទទួលអារម្មណ៍ នៅពេលពួកគេបានទទួលការចិញ្ចឹមបីបាច់ខាងវិញ្ញាណ នៅពេលពួកគេមករកព្រះអង្គសង្គ្រោះ ។

សូមសង្កេបយ៉ូហាន ៦:៣៦–៤៧ដោយពន្យល់ថា មនុស្សមួយចំនួនបានរអ៊ូរទាំទាស់នឹងព្រះអង្គសង្គ្រោះ ដោយសារតែទ្រង់បានបង្រៀនថា ទ្រង់គឺជានំប៉័ងដែលចុះមកពីស្ថានសួគ៌ ។

ដើម្បីរៀបចំសិស្សឲ្យស្គាល់គោលការណ៍បន្ថែមមួយទៀត ដែលព្រះអង្គសង្គ្រោះបានបង្រៀន សូមអញ្ជើញសិស្សពីរបីនាក់ឲ្យមកខាងមុខក្តារខៀន ហើយផ្តល់នំប៉័ងមួយចំណិតដល់ពួកគេម្នាក់ៗ ។ សូមអញ្ជើញពួកគេឲ្យស្រង់ភ្លិននំប៉័ង ហើយនឹកគិតអំពីរសជាតិរបស់វា ។

- តើនំប៉័ងនឹងចិញ្ចឹមបីបាច់អ្នកបានល្អប្រសើរឬទេ បើអ្នកគ្រាន់តែបានស្រង់ភ្លិន នឹកស្រមៃអំពីរសជាតិ ហើយកាន់ជាមួយអ្នករាល់ថ្ងៃនោះ ?
- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានប្រយោជន៍មកពីនំប៉័ងនោះ ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗមកពីយ៉ូហាន ៦:៤៥–៥៤ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើបទពិសោធន៍មិត្តក្នុងថ្នាក់របស់ពួកគេមានជាមួយនឹងនំប៉័ង អាចទាក់ទងទៅនឹងអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងខគម្ពីរទាំងនេះយ៉ាងដូចម្តេច ។

- តើនំប៉័ងជីវិតខុសពីនំប៉័ងធម្មតាយ៉ាងដូចម្តេច ? (មិនដូចជានំប៉័ងដែលអាចចំអែតយើងតែមួយរយៈដ៏ខ្លីនោះទេ ព្រះអង្គសង្គ្រោះប្រទានពរដល់យើងដែលនឹងមានជារៀងរហូត) ។

សូមចង្អុលបង្ហាញឃ្លាដូចខាងក្រោមនៅក្នុងខទី ៥១ ៖ « នំប៉័ងដែលខ្ញុំឲ្យ គឺជាសាច់ឈាមខ្ញុំ ដែលខ្ញុំនឹងលះបង់ជំនួសជីវិតមនុស្សលោក » ។

- តើព្រះអង្គសង្គ្រោះប្រទានព្រះកាយ និងលោហិតរបស់ទ្រង់សម្រាប់ជីវិតមនុស្សលោកយ៉ាងដូចម្តេច ?
- យោងតាម ខទី ៥៣–៥៤តើព្រះអង្គសង្គ្រោះបានបង្រៀនដល់ប្រជាជនឲ្យធ្វើអ្វីខ្លះ ?

ចូរពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រើពាក្យ*ពិសារ*និង*ផឹក*ជានិមិត្តរូប ។ ដើម្បីជួយសិស្សឲ្យយល់ការបង្រៀនរបស់ព្រះអង្គសង្គ្រោះ សូមអញ្ជើញសិស្សឲ្យស្ម័គ្រចិត្តបរិភោគនំប៉័ង ។ រួចហើយអញ្ជើញពួកគេឲ្យត្រឡប់ទៅកន្លែងអង្គុយវិញ ។

- តើអ្វីនឹងកើតឡើងចំពោះនំប៉័ង និងជីវជាតិចិញ្ចឹមបីបាច់របស់វា នៅពេលទទួលទាន ? (វីតាមីន និងជីវជាតិបានក្លាយទៅជាផ្នែកនៃរូបកាយ វាផ្តល់កម្លាំង និងសុខភាពល្អ) ។
- តើអ្នកគិតថាវាមានន័យយ៉ាងណា ដើម្បីទទួលទានព្រះកាយ និងផឹកលោហិតរបស់ព្រះអង្គសង្គ្រោះនោះ ? (វាអាចមានន័យដើម្បីធ្វើឲ្យការបង្រៀន និងដង្វាយធួនរបស់ទ្រង់ចាក់ឫសជ្រៅចូលក្នុងខ្លួន) ។ វាក៏អាចជាការតំណាងឲ្យការទទួលទានសាក្រាម៉ង់ ដែលព្រះអង្គសង្គ្រោះនឹងបង្កើតឡើងនៅពេលក្រោយផងដែរ) ។
- យោងតាមខ ៥៤តើពរជ័យអ្វីខ្លះ ដែលយើងអាចទទួល ប្រសិនបើយើងធ្វើឲ្យការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទចាក់ឫសជ្រៅចូលទៅក្នុងខ្លួនយើង ឬអនុវត្តវានោះ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងក្រេបជញ្ជក់ការបង្រៀន និងអនុវត្តនោះ ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទចាក់ជ្រៅចូលទៅក្នុងខ្លួនយើង នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

ចូរសុំឲ្យសិស្សគិតពិចារណាអំពីសំណួរដូចខាងក្រោម រួចហើយអញ្ជើញពួកគេជាច្រើនរូបឲ្យចែកចាយចម្លើយរបស់ពួកគេ ៖

- តើយើងធ្វើឲ្យការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទចាក់ឫសជ្រៅចូលទៅក្នុងខ្លួនយើង យ៉ាងដូចម្តេច ? (ចម្លើយដែលអាចអាចរួមមាន ការទទួលយកព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាពិតរបស់ព្រះ ការទទួលទានសាក្រាម៉ង់រាល់សប្តាហ៍ ការរក្សាបទបញ្ញត្តិ និងការកាន់ខ្ជាប់ដល់ចុងបំផុតនៅក្នុងសេចក្តីសុចរិត ។ សូមមើលប្រ៊ូស អ័រ ម៉ាក់ខនឃី *Doctrinal New Testament Commentary,* វ៉ុល ៣ (ឆ្នាំ ១៩៦៥–៧៣), ១:៣៥៨។) ។

ចូរពន្យល់ថា ជីវិតអស់កល្បជានិច្ចគឺត្រូវរស់នៅគ្មានទីបញ្ចប់ ហើយប្រែក្លាយដូចជាព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជារៀងរហូត ។ សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៦:៥៦–៥៧ ឲ្យឮៗ ហើយសួរសិស្សក្នុងថ្នាក់ឲ្យរកមើលរបៀបដែលយើងអាចប្រែក្លាយដូចជាពួកទ្រង់ នៅពេលយើងក្រេកជញ្ជក់ការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទចាក់ឫសជ្រៅក្នុងខ្លួនយើង ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា ព្រះអង្គសង្គ្រោះនឹងមិនគង់នៅជាមួយយើងជាសាច់និងឆ្អឹងទេ ប៉ុន្តែឥទ្ធិពលដ៏ទេវភាពរបស់ទ្រង់ នឹងនៅជាមួយយើង ដើម្បីជួយយើងឲ្យប្រែក្លាយកាន់តែដូចជាទ្រង់ និងព្រះវរបិតាសួគ៌ ។

សូមថ្លែងទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតដែលសិស្សបានប្រាប់ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវគោលដៅមួយអំពីរបៀបដែលពួកគេនឹងឱបក្រសោបដង្វាយធួន ឬការបង្រៀនមួយរបស់ទ្រង់កាន់តែជ្រៅក្នុងខ្លួនពួកគេ ។

យ៉ូហាន ៦:៦០–៧១

ពេត្រុស ថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវមានព្រះបន្ទូលអំពីជីវិតដ៏នៅអស់កល្បជានិច្ច

សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀន ៖ *បន្ត ឬឈប់ ?*

ចូរសុំឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេត្រូវជ្រើសរើសរវាងការបន្តធ្វើអ្វីមួយដែលពិបាក ឬក៏ឈប់ធ្វើវា ។ អ្នកអាចសុំឲ្យសិស្សម្នាក់ ឬពីរនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេ ។

ចូរពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានប្រទានទេសនកថាដូចបានកត់ត្រានៅក្នុងយ៉ូហាន ៦នោះពួកសិស្សរបស់ទ្រង់បានជួបនឹងការសម្រេចចិត្តស្រដៀងគ្នា ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៦:៦០–៦៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលចម្លើយរបស់ពួកសិស្សជាច្រើនរបស់ព្រះយេស៊ូវ ចំពោះការបង្រៀនរបស់ទ្រង់ ។

- ហេតុអ្វីក៏ពួកសិស្សរបស់ព្រះយេស៊ូវជាច្រើនជ្រើសរើសឈប់ដើរតាមទ្រង់ ? (ចូរពន្យល់ថា ឃ្លា « ពិបាកស្តាប់ណាស់ » [ខទី ៦០] មានន័យថា ពួកគេមានអារម្មណ៍ថា ការបង្រៀនរបស់ព្រះយេស៊ូវគឺពិបាកធ្វើតាមខ្លាំងណាស់) ។
- ហេតុអ្វីមនុស្សមួយចំនួនឃើញថាវាពិបាក ដើម្បីរក្សាបទបញ្ញត្តិរបស់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៦:៦៧ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវសំណួរដែលព្រះយេស៊ូវគ្រីស្ទ បានសួរដល់ពួកសាវករបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានសួរអ្វីខ្លះដល់ពួកសាវករបស់ទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៦:៦៨–៦៩ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀបដែលស៊ីម៉ូន ពេត្រុស បានឆ្លើយតបនឹងព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- ចេញមកពីចម្លើយរបស់ពេត្រុស តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ដែលនឹងជួយយើងបន្តនៅស្មោះត្រង់ អំឡុងគ្រាដែលលំបាក ដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ឬរស់នៅតាមការបង្រៀនរបស់ទ្រង់ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ទីបន្ទាល់រឹងមាំអំពីព្រះយេស៊ូវគ្រីស្ទ នឹងជួយយើងឲ្យមានចិត្តស្មោះត្រង់ជានិច្ច អំឡុងគ្រាដែលលំបាក ដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ឬរស់នៅតាមការបង្រៀនរបស់ទ្រង់**) ។
- តើទីបន្ទាល់រឹងមាំអំពីព្រះអង្គសង្គ្រោះ បានជួយអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ បន្តមានចិត្តស្មោះត្រង់ជានិច្ច ទោះជាការបង្រៀននៃដំណឹងល្អហាក់ដូចជាពិបាកធ្វើតាមក៏ដោយនោះ យ៉ាងដូចម្តេច ?

សូមលើកទឹកចិត្តសិស្សឲ្យពឹងផ្អែកទីបន្ទាល់របស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទនៅពេលដែលការបង្រៀនអំពីដំណឹងល្អអាចនឹងពិបាកដើម្បីពួកគេរស់នៅតាមក្តី ។ សូមអញ្ជើញសិស្សដែលអាចមានអារម្មណ៍ថា ពួកគេខ្វះទីបន្ទាល់រឹងមាំអំពីព្រះយេស៊ូវគ្រីស្ទ ឲ្យពង្រឹងទីបន្ទាល់របស់ខ្លួន តាមរយៈការព្យាយាមធ្វើឲ្យការបង្រៀន និងដង្វាយធួនរបស់ទ្រង់ចាក់ចូលជ្រៅទៅក្នុងខ្លួនពួកគេ ។

មេរៀនសិក្សានៅផ្ទះ

យ៉ូហាន ២–៦ (មេរៀនទី ១៣)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា យ៉ូហាន ២–៦ (មេរៀនទី ១៣) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (យ៉ូហាន ២)

នៅពេលសិស្សអានអំពីអព្ភូតហេតុដំបូងរបស់ព្រះអង្គសង្គ្រោះ អំពីការប្រែទឹកឲ្យទៅជាស្រា ពួកគេបានរៀនថា ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាលើធាតុទាំងឡាយ ។ ពួកគេក៏រៀនផងដែរថា ព្រះអង្គសង្គ្រោះស្រឡាញ់ ហើយគោរពដល់ព្រះមាតាទ្រង់ ។ នៅពេលពួកគេបានសិក្សាដំណើររឿងអំពីព្រះយេស៊ូវដែលបានបោសសម្អាតព្រះវិហារបរិសុទ្ធ នោះសិស្សបានរៀនថា ព្រះវិហារបរិសុទ្ធគឺជាដំណាក់របស់ព្រះ ។

ថ្ងៃទី ២ (យ៉ូហាន ៣)

សិស្សបានរៀននូវសេចក្តីពិតខាងក្រោមនេះចេញពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះទៅកាន់នីកូដេម ។ ការទទួលបុណ្យជ្រមុជទឹក និងការទទួលអំណោយទាននៃព្រះវិញ្ញាណគឺចាំបាច់ចំពោះការកើតមកម្តងទៀតខាងវិញ្ញាណ និងការទទួលភាពតម្កើងឡើងនៅក្នុងនគរសេឡេស្ទាល ។ មនុស្សលោកអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ព្រះវរបិតាសួគ៌ស្រឡាញ់កូនចៅរបស់ទ្រង់ដល់ម្ល៉ះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ឲ្យរងទុក្ខសម្រាប់អំពើបាបរបស់ពួកគេ ។ ប្រសិនបើយើងជឿលើព្រះយេស៊ូវគ្រីស្ទ ដែលរួមបញ្ចូលទាំងការប្រែចិត្តចេញពីអំពើបាបរបស់យើង ព្រមទាំងគោរពតាមព្រះបន្ទូលរបស់ទ្រង់ផងនោះ យើងអាចមានជីវិតអស់កល្បជានិច្ច តាមរយៈដង្វាយធួនរបស់ទ្រង់ ។ ចេញពីគំរូរបស់យ៉ូហាន បាទីស្ទ ដែលសិស្សបានរៀនថា យើងអាចជៈឥទ្ធិពលដល់មនុស្សដទៃសម្រាប់ការណ៍ល្អ តាមរយៈការនាំពួកគេទៅរកព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ៣ (យ៉ូហាន ៤)

នៅពេលសិស្សអានអំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះដល់ស្ត្រីសាសន៍សាម៉ារីនៅអណ្តូងទឹក នោះពួកគេបានរៀននូវសេចក្តីពិតដូចខាងក្រោមនេះ ៖ ប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលយកដំណឹងល្អរបស់ទ្រង់ដោយស្មោះស្ម័គ្រ នោះយើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ព្រះយេស៊ូវគ្រីស្ទជ្រាបពីអំពើបាបរបស់យើង ហើយប្រទានដំណឹងល្អរបស់ទ្រង់ដើម្បីជួយយើងឲ្យមកឈ្នះវាបាន ។ ប្រសិនបើយើងថ្វាយបង្គំព្រះវរបិតានៅក្នុងវិញ្ញាណ និងសេចក្តីពិត នោះទ្រង់នឹងប្រទានវិញ្ញាណរបស់ទ្រង់ដល់ពួកយើង ។ នៅពេលយើងទទួលបានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងពោរពេញដោយបំណងប្រាថ្នាដើម្បីចែកចាយវាដល់មនុស្សដទៃទៀត ។

ថ្ងៃទី ៤ (យ៉ូហាន ៥–៦)

នៅពេលសិស្សអានអំពីការព្យាបាលរបស់ព្រះអង្គសង្គ្រោះដល់បុរសទន់ខ្សោយម្នាក់ ពួកគេបានរៀនថា តាមរយៈព្រះចេស្តា និង សេចក្តីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចជាសះស្បើយបាន ។ ពួកគេក៏បានរៀនផងដែរថា មានតែតាមរយៈការមករកព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ទើបយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ចេញពីទេសនកថារបស់ព្រះអង្គសង្គ្រោះស្តីពីនំប៉័ងជីវិត សិស្សបានរៀនថា ទីបន្ទាល់មួយដ៏រឹងមាំអំពីព្រះយេស៊ូវគ្រីស្ទនឹងជួយយើងឲ្យបន្តមានចិត្តស្មោះត្រង់ អំឡុងពេលដែលវាអាចមានការលំបាកដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ ឬក៏ដើម្បីរស់នៅតាមការបង្រៀនទាំងឡាយរបស់ទ្រង់ ។

សេចក្តីផ្តើម

នៅថ្ងៃបន្ទាប់មកទៀត ក្រោយពីទ្រង់បានប្រទានអាហារដល់ហ្វូងមនុស្សជាង ៥០០០នាក់ ដោយអព្ភូតហេតុមក ទ្រង់បានបង្រៀនថាទ្រង់គឺជានំប៉័ងជីវិត ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៦:២២–៥៩

ព្រះយេស៊ូវបង្រៀនថា ទ្រង់គឺជានំប៉័ងជីវិត

ចូរដាក់បង្ហាញនំប៉័ងមួយដុំ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសង្ខេបពីដំណើររឿងរបស់ព្រះអង្គសង្គ្រោះប្រទានអាហារដល់មនុស្សច្រើនជាង ៥០០០ នាក់ ជាមួយនឹងនំប៉័ងប្រាំដុំ និងត្រីតូចពីរ ។

- តើអ្នកប្រហែលជាគិតដូចម្តេចខ្លះ ប្រសិនបើអ្នកបានឃើញអព្ភូតហេតុនេះ ហើយបានដឹងថាព្រះយេស៊ូវមានសមត្ថភាពដើម្បីប្រទានអាហារដោយអព្ភូតហេតុនោះ ។

សូមពន្យល់ថាយ៉ូហាន ៦:២២–២៥ កត់ត្រាថាមានមនុស្សជាច្រើន ដែលព្រះយេស៊ូវបានប្រទានអាហារដោយអព្ភូតហេតុ បានធ្វើដំណើរទៅក្រុងកាពើណិម ដើម្បីស្វែងរកទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៦:២៦–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់ហ្វូងមនុស្សនោះ ។

សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់ យ៉ូហាន ៦:២៦ បញ្ជាក់ថា « ព្រះយេស៊ូវបានឆ្លើយនឹងពួកគេដោយមានបន្ទូលថា ប្រាកដមែន យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នករាល់គ្នាស្វែងរកយើងពុំមែនដោយសារអ្នករាល់គ្នាចង់គោរពតាមព្រះបន្ទូលរបស់យើងឡើយ ប៉ុន្តែដោយសារអ្នករាល់គ្នាបានឃើញអព្ភូតហេតុ ប៉ុន្តែដោយសារអ្នករាល់គ្នាបានបរិភោគនំប៉័ងឆ្អែតប៉ុណ្ណោះ » (ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ—យ៉ូហាន ៦:២៦) ។ ក៏សូមពន្យល់ផងដែរថា ពាក្យ *អាហារ* នៅក្នុង យ៉ូហាន ៦:២៧ និងនៅក្នុងព្រះគម្ពីរបឺមទាំងមូលគឺសំដៅទៅលើគ្រឿងបរិភោគ ។ *សាច់* ត្រូវបានប្រើដើម្បីសំដៅទៅលើអ្វីដែលយើងហៅថាអាហារ ។

- យោងតាមព្រះអង្គសង្គ្រោះ ហេតុអ្វីបានមនុស្សទាំងនេះស្វែងរកទ្រង់ ? (ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះណែនាំថា ពួកគេបានដើរតាមទ្រង់ដើម្បីទទួលបានអាហារច្រើនទៀតពីទ្រង់) ។
- តើអ្វីទៅដែលព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ពួកគេថា ពួកគេគួរស្វែងរកនោះ ?

សូមពន្យល់ថា « អាហារ [ឬ គ្រឿងបរិភោគ] ដែលនៅស្ថិតស្ថេរដរាបដល់ជីវិតអស់កល្បជានិច្ច » (យ៉ូហាន ៦:២៧) អាចសំដៅទៅលើសេចក្តីពិតដ៏នៅអស់កល្បជានិច្ចនៃដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៦:២៨–៣១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលមនុស្សទាំងនោះចង់ឲ្យព្រះយេស៊ូវបង្ហាញដល់ពួកគេបន្ថែមទៀតថា ទ្រង់គឺជាព្រះមែស៊ី ។

- តើមនុស្សទាំងនោះចង់ឲ្យព្រះយេស៊ូវធ្វើអ្វីខ្លះ សម្រាប់ពួកគេ ? (សូមពន្យល់ថា នំម៉ាណាគឺជា « នំបុ័ងពីស្ថានសួគ៌ » [យ៉ូហាន ៦:៣១] ដែលព្រះបានប្រទានដល់កូនចៅអ៊ីស្រាអែល កាលពួកគេបានវង្វេងនៅក្នុងទីរហោស្ថាន សូមមើល និក្ខមនំ ១៦:១៤–១៥, ៣៥) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង យ៉ូហាន ៦:៣២–៣៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនមនុស្សទាំងនោះ ក្នុងការឆ្លើយតបទៅនឹងសំណើររបស់ពួកគេចង់ឃើញទីសម្គាល់ ។

- តើព្រះអង្គសង្គ្រោះបានបង្រៀនអ្វីខ្លះអំពីអង្គទ្រង់ កាលទ្រង់មានបន្ទូលអំពីនំម៉ាណា ឬនំបុ័ងពីស្ថានសួគ៌នោះ ?

អ្នកគួរផ្តល់យោបល់សិស្សឲ្យគូសចំណាំឃ្លា « ខ្ញុំជានំបុ័ងជីវិត » នៅក្នុងយ៉ូហាន ៦:៣៥ ។

- តើយើងអាចប្រៀបប្រដូចព្រះអង្គសង្គ្រោះ និងការបង្រៀនរបស់ទ្រង់ទៅនឹងនំបុ័ងបានដោយរបៀបណា ?
- តើអ្នកគិតថាវាមានន័យដូចម្តេចដែរថា អស់អ្នកដែលមករកព្រះយេស៊ូវគ្រីស្ទ « នឹងមិនឃ្លានទៀតឡើយ »? (យ៉ូហាន ៦:៣៥) ។ (ចម្លើយមួយដែលអាចមានគឺថា ទ្រង់នឹងចិញ្ចឹមបីបាច់ពួកគេខាងវិញ្ញាណ) ។
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខទី ៣៥ ? (ទោះជាសិស្សអាចនឹងប្រើពាក្យផ្សេងៗក្តី ក៏ពួកគេគួរតែប្រាប់នូវគោលការណ៍មួយដែលស្រដៀងគ្នាដូចគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងចិញ្ចឹមបីបាច់យើងខាងវិញ្ញាណ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖

យើងមករកព្រះយេស៊ូវគ្រីស្ទតាមរយៈ . . . *ទ្រង់នឹងចិញ្ចឹមបីបាច់យើងដោយ . . .*

សូមបំបែកសិស្សជាគូ ។ ចូរសុំឲ្យពួកគេធ្វើការរួមគ្នាបង្កើតជាបញ្ជីមួយ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេពីរឿងមួយចំនួនដែលយើងអាចធ្វើដើម្បីមករកព្រះយេស៊ូវគ្រីស្ទ និងពីរបៀបដែលទ្រង់នឹងចិញ្ចឹមបីបាច់យើងខាងវិញ្ញាណ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីចម្លើយរបស់ពួកគេដល់សិស្សផ្សេងទៀត ។

ចូរពិចារណាអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីរបៀបដែលពួកគេបានទទួលការចិញ្ចឹមបីបាច់ខាងវិញ្ញាណ នៅពេលពួកគេបានមករកព្រះអង្គសង្គ្រោះ ។

ដើម្បីរៀបចំខ្លួនសិស្សឲ្យរកឃើញពីគោលការណ៍មួយបន្ថែមទៀត ដែលព្រះអង្គសង្គ្រោះបានបង្រៀន សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឡើងមកខាងមុខក្តារខៀន ហើយឲ្យនំបុ័ងមួយចំណិតដល់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យស្រង់ក្លិននំបុ័ងនោះ ហើយស្រមៃពីរស់ជាតិរបស់វា ។

- តើនំបុ័ងនេះនឹងចិញ្ចឹមបីបាច់អ្នកបានល្អដល់កម្រិតណា ប្រសិនបើអ្នកគ្រាន់តែស្រង់ក្លិនវា ស្រមៃស្រមៃពីរស់ជាតិ ហើយកាន់វាពេញមួយថ្ងៃនោះ ?
- តើយើងត្រូវតែធ្វើអ្វីខ្លះ ដើម្បីទទួលបានអត្ថប្រយោជន៍ពីអ្វីដែលនំបុ័ងអាចផ្តល់ឲ្យបាន ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង យ៉ូហាន ៦:៤៩–៥៤ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលបទពិសោធន៍របស់មិត្តរួមថ្នាក់របស់ពួកគេជាមួយនឹងនំបុ័ងអាចទាក់ទងនឹងអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។

- តើនំបុ័ងជីវិតខុសពីនំបុ័ងធម្មតាដូចម្តេច ? (មិនដូចជានំបុ័ងដែលអាចបំពេញសេចក្តីស្រេកឃ្លានរបស់យើងតែក្នុងរយៈពេលមួយដ៏ខ្លីឡើយ ព្រះយេស៊ូវគ្រីស្ទប្រទានពរដ៏ជាយដល់យើងដែលមានជារៀងរហូត)។
- យោងតាម ខទី ៥៣–៥៤តើព្រះអង្គសង្គ្រោះបានបង្រៀនមនុស្សទាំងនោះឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រើពាក្យ*ពិសា* និង*ផឹក* ជានិមិត្តរូប ។ ដើម្បីជួយសិស្សឲ្យយល់ដឹងពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ សូមអញ្ជើញសិស្សនោះទទួលទាននំបុ័ង ។ បន្ទាប់មក សូមអញ្ជើញពួកគេត្រឡប់ទៅកន្លែងអង្គុយវិញ ។

- តើមានអ្វីកើតឡើងចំពោះនំបុ័ង និងសារធាតុចិញ្ចឹមរបស់វា នៅពេលវាត្រូវបានគេបរិភោគនោះ ? (រំតាមីន និងសារធាតុចិញ្ចឹមបានក្លាយជាផ្នែកនៃរូបកាយ ដោយផ្តល់ឲ្យរូបកាយនូវកម្លាំង និងសុខភាពល្អ) ។
- តើអ្នកគិតថា ការបរិភោគសាច់ ហើយផឹកព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ មាន ន័យដូចម្តេច ? (វាអាចមានន័យថា ជាការបញ្ចូលការបង្រៀន និងជង្វាយធួនរបស់ទ្រង់នៅក្នុងចិត្ត ។ វាក៏អាចតំណាងឲ្យការទទួលទានសាក្រាម៉ង់ ដែលព្រះអង្គសង្គ្រោះនឹងធ្វើនៅពេលក្រោយផងដែរ) ។
- យោងតាម យ៉ូហាន ៦:៥៤តើយើងអាចទទួលបានពរជ័យអ្វីខ្លះ ប្រសិនបើយើងបញ្ចូលនៅក្នុងចិត្ត ឬអនុវត្តការបង្រៀន និងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងបញ្ចូលនៅក្នុងចិត្ត ឬអនុវត្ត ការបង្រៀន និងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ករបៀបដែលលោកបានមានប្រសាសន៍ថា យើងអាចបញ្ចូលនៅក្នុងចិត្តយើងនូវការបង្រៀន និងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។



« ដើម្បីពិសា ហើយផឹកព្រះលោហិតរបស់ព្រះរាជបុត្រានៃព្រះ ដំបូងត្រូវទទួលយកទ្រង់យ៉ាងពេញលេញថាជាបុត្រផ្ទាល់ខាងសាច់ឈាមរបស់ព្រះវរបិតាដ៏អស់កល្បជានិច្ច ហើយទីពីរ ត្រូវគោរពតាមព្រះបញ្ញត្តិរបស់ព្រះរាជបុត្រា ដោយទទួលយកជំណឹងល្អរបស់ទ្រង់ ចូលរួមក្នុងសាសនាចក្ររបស់ទ្រង់ ហើយស៊ូទ្រាំក្នុងការគោរពប្រតិបត្តិ និងសេចក្តីសុចរិតដរាបដល់ចុងបំផុត ។ អស់អ្នកណាដែលពិសាសាច់របស់ទ្រង់ ហើយផឹកព្រះលោហិតរបស់ទ្រង់តាមរបៀបនេះនឹងមានជីវិតដ៏នៅអស់កល្បជានិច្ច មានន័យថាទទួលបានភាពតម្កើងឡើងនៅក្នុងស្ថានសួគ៌ដ៏ខ្ពស់នៃពិភពសេឡេស្ទាល » (*Doctrinal New Testament Commentary* រំលៃ ៣ [ឆ្នាំ១៩៦៥–៧៣] ១:៣៥៨) ។

- តើអែលឌើរ ម៉ាក់ខន់ឃី បានណែនាំអ្វីខ្លះ ដល់យើងឲ្យបញ្ចូលការបង្រៀន និងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងចិត្ត ?

សូមពន្យល់ថា ជីវិតដ៏នៅអស់កល្បជានិច្ចគឺដើម្បីរស់នៅ ហើយប្រែក្លាយដូចជាព្រះវរបិតាសួគ៌របស់យើង និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទជារៀងរហូត ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៦:៥៦–៥៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលយើងអាចប្រែក្លាយដូចជាពួកទ្រង់ នៅពេលបញ្ចូលនៅក្នុងចិត្តនូវការបង្រៀន និងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វី ដែលពួកគេរកឃើញ ។

សូមពន្យល់ថា ព្រះអង្គសង្គ្រោះនឹងពុំគង់នៅក្នុងខ្លួនយើងជារូបកាយនោះទេ ប៉ុន្តែព្រះចេស្តាដ៏ទេវភាពរបស់ទ្រង់នឹងនៅជាមួយនឹងយើង ដើម្បីជួយយើងឲ្យប្រែក្លាយកាន់តែដូចជាទ្រង់ និងព្រះវរបិតាសួគ៌ ។

សូមសង្ខេប យ៉ូហាន ៦:៥៩–៦៦ ដោយពន្យល់ថា ពួកសិស្សមួយចំនួនរបស់ព្រះយេស៊ូវបានបដិសេធការបង្រៀនរបស់ទ្រង់ ហើយងាកចេញពីការដើរតាមទ្រង់ ។

សូមថ្លែងទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត ដែលសិស្សបានបង្ហាញ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវគោលដៅមួយសម្រាប់របៀប ដែលពួកគេនឹងបញ្ចូលដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ឬការបង្រៀនមួយរបស់ទ្រង់នៅក្នុងចិត្តឲ្យកាន់តែប្រសើរឡើង ។

មេរៀនបន្ទាប់ (យ៉ូហាន ៧–១០)

សូមប្រាប់សិស្សថា នៅមេរៀនបន្ទាប់ ពួកគេនឹងរៀនពីរបៀបដែលព្រះយេស៊ូវគ្រីស្ទប្រព្រឹត្តចំពោះស្ត្រីម្នាក់ដែលគេចាប់បានថាប្រព្រឹត្តអំពើកំផិត និងអ្វីដែលទ្រង់បានមានបន្ទូល ដើម្បីបំបែកហ្វូងមនុស្សដែលចង់សម្លាប់នាង ។ អ្នកអាចសុំឲ្យសិស្សបិទភ្នែក ហើយស្រមៃថាតើការខ្វាក់ភ្នែកមានសភាពបែបណា ។ បន្ទាប់មកសួរថា តើពួកគេនឹងមានអារម្មណ៍បែបណាដែរ ប្រសិនបើបានព្យាបាលឲ្យជាពីការខ្វាក់នោះ ហើយមើលឃើញជាលើកដំបូង ។ សិស្សនឹងអានអំពីបុរសខ្វាក់ភ្នែកម្នាក់ដែលគាត់មិនថែមទាំងបានភ្លឺខាងរូបកាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានខ្លឹខាងវិញ្ញាណទៀតផង ហើយបានទទួលនូវសាក្សីមួយថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ។ ពួកគេក៏នឹងរៀនពីហេតុផលដែលព្រះអង្គសង្គ្រោះហៅអង្គទ្រង់ថា ជាអ្នកគង្វាលល្អ និងពីព្រះចេស្តាដែលទ្រង់បានមានបន្ទូលថា ទ្រង់បានទទួលពីព្រះវរបិតា ។

មេរៀន ៦៦

យ៉ូហាន ៧

សេចក្តីផ្តើម

ព្រះយេស៊ូវបានចូលរួមពិធីបុណ្យបារាំនៅយេរូសាឡិម ។ ទ្រង់បានយាងទៅព្រះវិហារបរិសុទ្ធ ហើយបានបង្រៀនមនុស្សម្នាក់នៅទីនោះ ពីរបៀបដែលពួកគេអាចទទួលបានទីបន្ទាល់មួយ ថា ការបង្រៀនរបស់ទ្រង់គឺមកពីព្រះជាព្រះវរបិតា ។ ដោយសារមនុស្សច្រឡំថា តើព្រះយេស៊ូវ គឺជានរណា នោះទ្រង់បានប្រើរូបភាពនៃទឹក និង ពន្លឺដើម្បីថ្លែងទីបន្ទាល់អំពីភាពជាព្រះរបស់ ទ្រង់ ។ ទ្រង់ក៏បានបង្រៀនពួកគេអំពីព្រះវិញ្ញាណបរិសុទ្ធផងដែរ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៧:១–១៣

ព្រះយេស៊ូវចូលរួមពិធីបុណ្យបារាំ

សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀន ៖ *តើព្រះយេស៊ូវមានបងប្អូនប្រុសស្រីដែរទេ ?*

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរនេះ ។ ប្រសិនបើចាំបាច់ សូមជួយសិស្សឲ្យយល់ថា យ៉ូសែប និង ម៉ារា មានកូនដែលបានកើតបន្ទាប់ ពីព្រះយេស៊ូវ ហើយដែលបានចិញ្ចឹមបីបាច់នៅក្នុងផ្ទះជាមួយនឹងទ្រង់ដែរ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារព្រះយេស៊ូវគ្រីស្ទ គឺជាបុត្រារបស់ម៉ារី និង ព្រះជាព្រះវរបិតា ទ្រង់ពុំមែនជាកូនរបស់យ៉ូសែបទេ នោះបុគ្គលទាំងនោះគឺជាបងប្អូនប្រុសស្រីម្តាយតែមួយ ឪពុកទីទៃរបស់ព្រះយេស៊ូវ (សូមមើល ម៉ាថាយ ១៣:៥៥–៥៦) ។

- **តើអ្នកគិតថា ការធំឡើងដឹងក្តីនៅក្នុងផ្ទះតែមួយជាមួយព្រះយេស៊ូវមានសភាពបែបណាដែរ ?**
- **តើអ្នកគិតថា វានឹងស្រួលជាងដើម្បីជឿលើទ្រង់ទេ ប្រសិនបើអ្នកបានធំឡើងជាមួយទ្រង់នៅក្នុងផ្ទះតែមួយនោះ ? ហេតុអ្វីងាយជឿ ឬ ហេតុអ្វីមិនងាយជឿ ?**

សូមចង្អុលបង្ហាញថា នៅក្នុង យ៉ូហាន ៧ យើងរៀនពីរបៀបដែល « ប្អូនប្រុស » របស់ព្រះយេស៊ូវ (យ៉ូហាន ៧:៣, ៥) គិតអំពីទ្រង់ ។ ពាក្យ *ប្អូនទ្រង់* ប្រហែលជាសំដៅលើប្អូនប្រុសម្តាយតែមួយរបស់ព្រះយេស៊ូវ ប៉ុន្តែវាក៏អាចរួមបញ្ចូលនូវសាច់ញាតិជិតស្និទ្ធផ្សេងទៀតផងដែរ ។

សូមអញ្ជើញសិស្សបួនប្រាំនាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង យ៉ូហាន ៧:១–៥ ។

- **តើយើងរៀនអ្វីខ្លះនៅក្នុងខទី ៥អំពីបងប្អូនរបស់ព្រះយេស៊ូវគ្រីស្ទ ?**

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្រុមនៃពួកសាវកដប់ពីរ នាក់ ៖



« ទីបន្ទាល់មួយអំពីភាពជាព្រះរបស់ព្រះគ្រីស្ទ និង ព្រះចេស្តានៃការសង្គ្រោះនៃដំណឹងល្អរបស់ទ្រង់ គឺពុំត្រូវបានប្រទានឲ្យដោយស្ងួយប្រវត្តិ ដោយសារតែទំនាក់ទំនងនៃគ្រួសារនោះទេ ។

« . . . ទោះជាយ៉ាងណា ពួកគេត្រូវបានចិញ្ចឹមបីបាច់នៅក្នុងផ្ទះតែមួយ ហើយចេញមកពីផ្ទះដែលមានឥទ្ធិពល | ការថែរក្សា | ដ៏ទន់ភ្លន់របស់ យ៉ូសែប និង ម៉ារា ទោះបីជាពួកគេបានដឹងពីការបង្រៀន ការបម្រើ និង អព្ភូតហេតុអំពីព្រះយេស៊ូវក្តី តែសាច់ញាតិដ៏ជិតស្និទ្ធរបស់ទ្រង់ពុំបានទទួលស្គាល់ថា ទ្រង់គឺជាព្រះមែស៊ីឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេទាំងអស់គ្នាបានផ្លាស់ប្រែចិត្តជឿនៅពេលក្រោយមក (កិច្ចការ ១:១៤) » (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ១:៤៣៧) ។

- **តើសមាជិកផ្ទាល់មួយចំនួននៃគ្រួសាររបស់ព្រះយេស៊ូវ ពុំជឿលើទ្រង់បានដោយរបៀបណា ថ្វីបើពួកគេបានដឹងពីការបង្រៀន និង អព្ភូតហេតុរបស់ទ្រង់ហើយនោះ ?**

សូមចង្អុលបង្ហាញថា យ៉ូហាន ៧ កត់ត្រា ព្រឹត្តិការណ៍ ដែលបានកើតឡើងនៅពេលពិធីបុណ្យបារាំត្រូវបានប្រារព្ធធ្វើឡើងនៅយេរូសាឡិម (សូមមើល យ៉ូហាន ៧:២) ។ អំឡុងពេលពិធីជប់លៀងប្រាំបីថ្ងៃនេះ ដែល « បានចាត់ទុកថាជាពិធីដ៏រីករាយខ្លាំង និង អស្ចារ្យបំផុត » (Bible Dictionary, « Feasts ») ពួកសាសន៍ យូដាជាច្រើនបានធ្វើដំណើរទៅក្រុងយេរូសាឡិម ដើម្បីប្រារព្ធរំពួកដល់ពរជ័យរបស់ព្រះដែលប្រទានមកលើកូនចៅនៃសាសន៍អ៊ីស្រាអែល នៅពេលពួកគេធ្វើដំណើរនៅក្នុងទីរហោស្ថាន ដោយរស់នៅក្នុងខ្ទម ឬរោងឱបោសថបណ្តោះអាសន្ន បន្ទាប់ពីការរំដោះឲ្យរួចពីទាសភាពនៅក្នុងប្រទេសអេស៊ីព្ទ (សូមមើល លេវីវិន័យ ២៣:៣៩–៤៣) ។ ពួកសាសន៍យូដាក៏បានប្រារព្ធ ហើយថ្លែងអំណរគុណផងដែរសម្រាប់ការច្រូតកាត់ប្រចាំឆ្នាំនៃជលានុផល និង គ្រាប់ធញ្ញជាតិ (សូមមើល និក្ខមនំ ២៣:១៦) ។

- **យោងតាម ខទី ៣–៤តើបងប្អូនរបស់ព្រះយេស៊ូវបានទូលសុំឲ្យទ្រង់ធ្វើអ្វីខ្លះ ?**

ការយល់ពីបរិបទ និង មាតិកា

គ្រឹះមួយនៃការបង្រៀន និង រៀនសូត្រពីដំណឹងល្អ គឺការយល់ដឹងពីបរិបទ និងមាតិកានៃបណ្តុំព្រះគម្ពីរ ។ បរិបទ រួមមានទាំងស្ថានភាព ឬ ផ្ទៃរឿងអំពីវគ្គបទគម្ពីរព្រឹត្តិការណ៍ និង ដំណើររឿងជាក់លាក់មួយ។ មាតិកាគឺជាខ្សែរឿងអំពីមនុស្ស ព្រឹត្តិការណ៍ ទេសនកថា និង ការពន្យល់ដ៏បំផុសគំនិតនៅក្នុងអត្ថបទនោះ ។ នៅពេលអ្នកជួយសិស្សរបស់អ្នកឲ្យយល់ពីបរិបទ និង មាតិកានៃព្រះគម្ពីរ នោះពួកគេនឹងរៀបចំខ្លួនដើម្បីស្គាល់សារលិខិតរបស់ពួកអ្នកនិពន្ធដ៏បំផុសគំនិត ។

សូមសង្កេប យ៉ូហាន ៧:៦–១០ដោយពន្យល់ថា ព្រះយេស៊ូវបានសម្រេចព្រះទ័យពន្យាការទៅពិធីបុណ្យនោះ ប៉ុន្តែទ្រង់បានលើកទឹកចិត្តបងប្អូនរបស់ទ្រង់ឲ្យទៅ ។ ក្រោយមកបន្ទាប់ពីពិធីបុណ្យនោះបានចាប់ផ្តើម នោះព្រះយេស៊ូវបានយាងចេញទៅដោយសម្ងាត់—ដោយដឹងថាអ្នកដឹកនាំសាសន៍យូដាមួយចំនួននៅក្នុងក្រុងយេរូសាឡិមចង់ធ្វើគុតទ្រង់ ប៉ុន្តែថាពេលវេលានៃការសុគតរបស់ទ្រង់ពុំទាន់មកដល់នៅឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៧:១១–១៣ ឲ្យឮៗ ។

- តើប្រជាជននៅយេរូសាឡិមបាននិយាយអ្វីខ្លះអំពីព្រះយេស៊ូវ ?

សូមចង្អុលបង្ហាញគឺដូចនៅសម័យរបស់ព្រះយេស៊ូវដែរ មានគំនិតផ្សេងៗគ្នាអំពីព្រះយេស៊ូវគ្រីស្ទនៅក្នុងជំនាន់របស់យើងនេះ: ។ មនុស្សមួយចំនួនដឹង ហើយថ្លែងទីបន្ទាល់ថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះ: និងជាព្រះអង្គសង្គ្រោះនៃមនុស្សលោកទាំងអស់ ។ មនុស្សផ្សេងទៀតជឿលើទ្រង់ ហើយសង្ឃឹមថាដំណឹងល្អរបស់ទ្រង់គឺជាការពិត ។ ប៉ុន្តែ ក៏មានមនុស្សដែលសង្ស័យពីទេវភាពរបស់ព្រះយេស៊ូវ និងសេចក្តីពិតដ៏ពេញលេញនៃការបង្រៀនរបស់ទ្រង់ដែរ ។ សូមអញ្ជើញសិស្សឲ្យរកមើល នៅពេលពួកគេបន្តសិក្សា យ៉ូហាន ៧នូវរបៀបដែលយើងអាចដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់យើង ហើយថាការបង្រៀនរបស់ទ្រង់គឺជាការពិត ។

យ៉ូហាន ៧:១៤–៣៦

ព្រះយេស៊ូវគ្រីស្ទបង្រៀនពួកសាសន៍យូដានៅឯព្រះវិហារបរិសុទ្ធ

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៧:១៤–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវបានធ្វើនៅឯព្រះវិហារបរិសុទ្ធ ។ វាអាចមានប្រយោជន៍ដើម្បីពន្យល់ថា ព្រះវិហារបរិសុទ្ធគឺជាកន្លែងដ៏សំខាន់នៃការប្រារព្ធនានាដែលធ្វើឡើង អំឡុងពេលនៃបុណ្យបាវ៉ា ។

- តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ ?
- ហេតុអ្វីពួកសាសន៍យូដាមានភាពស្ងប់ស្ងែង ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៧:១៦–១៨ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្ទៀងតាមរកមើល អ្វីដែលព្រះយេស៊ូវបានមានបន្ទូលថាមនុស្សអាចធ្វើ ដើម្បីដឹងថា តើគោលលទ្ធិ ឬ ការបង្រៀនរបស់ទ្រង់នោះពិតឬអត់ ។

- យោងតាម ខទី ១៦តើព្រះយេស៊ូវបានទទួលគោលលទ្ធិដែលទ្រង់បានបង្រៀនពីនរណា ?
- តើមនុស្សម្នាក់អាចដឹងថា គោលលទ្ធិដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀន គឺពិតជាមកពីព្រះមែនដោយរបៀបណា ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ: អំពីរបៀបដែលយើងអាចទទួលបាននូវទីបន្ទាល់មួយអំពីការបង្រៀនរបស់ព្រះវរបិតាសួគ៌ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីបង្ហាញគោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ខាងក្រោមនេះ: ៖ **ប្រសិនបើយើងធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ នោះយើងនឹងទទួលបានទីបន្ទាល់មួយអំពីគោលលទ្ធិរបស់ទ្រង់ ។** អ្នកគួរអញ្ជើញសិស្សឲ្យគូសចំណាំពាក្យនៅក្នុងខទី ១៧ដែលបង្រៀនពីគោលការណ៍នេះ:) ។

ដើម្បីជួយសិស្សស្គាល់ពីរបៀបដែលគោលការណ៍នេះអាចយកមកអនុវត្តនៅក្នុងជីវិតរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ដៃមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ៖

« យើងទទួលបានទីបន្ទាល់មួយនៃគោលការណ៍នៃដំណឹងល្អ តាមរយៈការគោរពប្រតិបត្តិដោយការព្យាយាមរស់នៅតាមវា ។ . . . ទីបន្ទាល់មួយអំពីការអធិស្ឋានដ៏មានប្រសិទ្ធិភាពកើតឡើង តាមរយៈការអធិស្ឋានដោយបន្ទាបខ្លួន និង ដោយចិត្តស្មោះសរ ។ ទីបន្ទាល់នៃដង្វាយមួយភាគក្នុងដប់ កើតមកពីការបង់ដង្វាយមួយភាគក្នុងដប់ » (« Lord, I Believe; Help Thou Mine Unbelief » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ២២) ។

ទោះជាបងប្អូនរបស់ទ្រង់ពុំបានជឿលើទ្រង់ភ្លាមៗក្តី ប៉ុន្តែក្រោយមកពួកគេបានទទួលទីបន្ទាល់មួយ ហើយបានប្រែចិត្តជឿ (សូមមើល កិច្ចការ ១:១៤) ។

- តើគោលការណ៍នេះដែលបានបង្ហាញនៅក្នុង យ៉ូហាន ៧:១៧ បានជួយបងប្អូនរបស់ព្រះយេស៊ូវឲ្យទទួលបានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់បានដោយរបៀបណា ?

ចូរសុំឲ្យសិស្សស្រមៃថា ពួកគេមានមិត្តម្នាក់ដែលកំពុងជួបបញ្ហាជាមួយទីបន្ទាល់របស់គាត់អំពីដំណឹងល្អ ។

- តើអ្នកអាចប្រើគោលការណ៍ដែលបានបង្ហាញនៅក្នុង យ៉ូហាន ៧:១៧ ដើម្បីជួយមិត្តម្នាក់នេះតាមរបៀបណា ?

ដើម្បីជួយសិស្សឲ្យថ្លែងទីបន្ទាល់អំពីលការណ៍ដែលពួកគេបានបង្ហាញខាងលើ ហើយទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់របស់វា សូមដាក់បង្ហាញឃ្លាខាងក្រោមនេះ: ៖

ខ្ញុំដឹង _____ *គឺជាការពិត ដោយសារនៅពេលខ្ញុំបានរស់នៅតាមវា ខ្ញុំ* _____ ។

សូមលើកទឹកចិត្តសិស្សឲ្យបំពេញឃ្លានោះ: នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេដោយការសរសេរអំពីព្រះបញ្ញត្តិ ឬ គោលការណ៍នៃដំណឹងល្អ ដែលពួកគេបានដឹងថាវាពិត តាមរយៈកិច្ចខិតខំរស់នៅតាមវា ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានសរសេរជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យសរសេរសេចក្តីពិតនៃដំណឹងល្អ ព្រះបញ្ញត្តិ ឬការបង្រៀនមួយដែលពួកគេចង់ទទួលបានទីបន្ទាល់មួយដ៏រឹងមាំ ។ ក៏សូមអញ្ជើញពួកគេឲ្យសរសេរអ្វី ដែលពួកគេនឹងធ្វើដើម្បីទទួលបាននូវទីបន្ទាល់កាន់តែខ្លាំងឡើងអំពីសេចក្តីពិត ព្រះបញ្ញត្តិ ឬការបង្រៀននេះ តាមរយៈការអនុវត្តគោលការណ៍ដែលពួកគេបានរៀននៅក្នុង យ៉ូហាន ៧:១៧ ។

សូមសង្ខេបយ៉ូហាន ៧:១៩–៣៦ ដោយពន្យល់ថាព្រះយេស៊ូវបានស្តីបន្ទោសអ្នកដឹកនាំសាសន៍យូដា ចំពោះការបដិសេធសេចក្តីបង្រៀន និង អព្ភូតហេតុរបស់ទ្រង់ ព្រមទាំងព្យាយាមចង់ធ្វើគុតទ្រង់ ។ មនុស្សជាច្រើនបានឆ្ងល់ថា តើទ្រង់គឺជាព្រះមែស៊ីឬ ហើយថាពួកសង្ឃរាជ និង ពួកផារិស៊ីបានបញ្ជូនពួកទាហានឲ្យទៅចាប់ទ្រង់ ។

យ៉ូហាន ៧:៣៧–៥៣

ព្រះយេស៊ូវគ្រីស្ទបង្រៀនអំពីអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

ចូរសុំឲ្យសិស្សម្នាក់ដែលស្រេកទឹក ស្ម័គ្រចិត្តឡើងមកក្តារខៀន ។ ចូរឲ្យពែងទទេមួយដល់សិស្សម្នាក់នោះ ហើយសួរគាត់ ៖

- តើពែងទឹកទទេនេះនឹងបំពេញការស្រេកទឹករបស់អ្នកឬទេ ?
- តើអ្នកត្រូវការអ្វីទៀត ?

សូមដាក់បង្ហាញប្រភពទឹកមួយដូចជា ទឹកមួយដប ឬទឹកមួយថូ ។ ចូរយកទឹកមកចាក់ក្នុងពែងនោះ ហើយអញ្ជើញសិស្សឲ្យជីកវា ។ បន្ទាប់មក អញ្ជើញសិស្សឲ្យត្រឡប់ទៅកន្លែងអង្គុយខ្លួនវិញ ។

ចូរលើកក្តម ឬដបទឹកដែលអ្នកប្រើដើម្បីចាក់ទឹកឲ្យសិស្សនោះឡើង ។ សូមពន្យល់ថា ជារៀងរាល់ថ្ងៃ ក្នុងអំឡុងពេលប្រាំបីថ្ងៃនៃបុណ្យបាវ៉ា សង្ឃម្នាក់ដែលបានតែងតាំងបានដងទឹកពីស្រះទឹកស៊ីឡោមដោយប្រើក្តមមាសមួយ ហើយចាក់ទឹកនោះចូលទៅក្នុងអាងប្រាក់នៅត្រង់ជើងនៃអាសនាក្នុងព្រះវិហារបរិសុទ្ធ ។ នៅថ្ងៃចុងក្រោយនៃបុណ្យបាវ៉ា នៅពេលសង្ឃនោះបានធ្វើដូច្នោះហើយ ព្រះយេស៊ូវបានឈរ ហើយធ្វើការអញ្ជើញទៅដល់ប្រជាជន ។ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខនឃី *Doctrinal New Testament Commentary,* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣| ១:៤៤៦) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៧:៣៧ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល អ្វីដែលព្រះអង្គសង្គ្រោះបានអញ្ជើញប្រជាជនឲ្យធ្វើ បន្ទាប់ពីទ្រង់បានបង្ហាញអង្គទ្រង់នៅឯព្រះវិហារបរិសុទ្ធនៅថ្ងៃទីប្រាំបី និងជាថ្ងៃចុងក្រោយបង្អស់នៃពិធីបុណ្យនោះ ។

- តើព្រះអង្គសង្គ្រោះបានអញ្ជើញប្រជាជនឲ្យធ្វើអ្វីខ្លះ ?
- ដោយពិចារណាពីការដង និងការចាក់ទឹកដែលសង្ឃនោះបានធ្វើឡើងនៅក្នុងបុណ្យនេះ ហេតុអ្វីអ្នកគិតថា ព្រះយេស៊ូវធ្វើការអញ្ជើញនេះនៅពេលនេះ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងមកឯព្រះយេស៊ូវគ្រីស្ទ ហើយជឿលើទ្រង់* . . .

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៧:៣៨–៣៩ ឲ្យ ឮៗ ហើយក្រោយមកពន្យល់ថា ការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់យ៉ូហាន ៧:៣៩ បញ្ជាក់ពីផ្នែកចុងក្រោយនៃខគម្ពីរនេះថា « ដ្បិតព្រះវិញ្ញាណបរិសុទ្ធត្រូវបានសន្យាដល់អស់អ្នកណាដែលជឿ បន្ទាប់ពីព្រះយេស៊ូវបានតម្កើងឡើង » ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីសន្យាដែលព្រះយេស៊ូវបានធ្វើដល់អស់អ្នកណាដែលមករកទ្រង់ ហើយជឿលើទ្រង់ ។

សូមពន្យល់ថា ឃ្លា « ហូរចេញពីពោះខ្លួនមក » បង្ហាញថា ទឹករស់នឹងមាននៅក្នុងខ្លួន ហើយចេញពីអ្នកជឿ ជាជាងចេញមកពីប្រភពខាងក្រៅ ។

- យោងតាមខទី ៣៩តើទឹករស់ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលតំណាងឲ្យអ្វី ?

សូមពន្យល់ថា « ដោយហេតុផលមួយចំនួនពុំត្រូវបានពន្យល់ពេញលេញនៅក្នុងព្រះគម្ពីរ នោះព្រះវិញ្ញាណបរិសុទ្ធពុំដំណើរការពេញទាំងស្រុងនៅក្នុងចំណោមពួកសាសន៍យូដាឡើយ អំឡុងឆ្នាំនៃការបម្រើនៃជីវិតរមែងស្លាប់របស់ព្រះយេស៊ូវ (យ៉ូហាន ៧:៣៩, ១៦:៧) (Bible Dictionary, « Holy Ghost ») ។ កាល *អំណោយទាន* នៃព្រះវិញ្ញាណបរិសុទ្ធមិនត្រូវបានប្រទានឲ្យនៅគ្រាកាន់កាប់ត្រួតត្រានោះ រហូតក្រោយព្រះអង្គសង្គ្រោះបានតម្កើងឡើងដោយសម្រេចបានបេសកកម្មរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ នោះ *ព្រះចេស្តា* នៃព្រះវិញ្ញាណបរិសុទ្ធត្រូវបានប្រទានឲ្យដើម្បីជួយមនុស្សឲ្យទទួលបានទីបន្ទាល់មួយអំពីសេចក្តីពិតដែលព្រះអង្គសង្គ្រោះ និងពួកសិស្សរបស់ទ្រង់បានបង្រៀន ។

- ផ្អែកលើការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងយ៉ូហាន ៧:៣៧–៣៩ តើអ្នកនឹងបញ្ចប់សេចក្តីថ្លែងការណ៍នៅលើក្តារខៀនយ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងមកឯព្រះយេស៊ូវគ្រីស្ទ ហើយជឿលើទ្រង់ នោះយើងនឹងពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ**) ។

សូមពន្យល់ថា អស់អ្នកដែលពោរពេញដោយព្រះវិញ្ញាណ អាចជះឥទ្ធិពលលើមនុស្សដទៃឲ្យធ្វើការល្អ ។ សូមអញ្ជើញសិស្សឲ្យគិតពីគ្រាមួយនៅពេលពួកគេពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ហើយជាលទ្ធផល អាចមានលទ្ធិពលលើមនុស្សដទៃទៀតឲ្យធ្វើការល្អ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។

សូមសង្ខេប យ៉ូហាន ៧:៤០–៥៣ ដោយពន្យល់ថា ពួកសង្ឃរាជ និងពួកផារិស៊ីមានបំណងចាប់ព្រះកាយព្រះយេស៊ូវម្តងទៀត ។ នីកូដេម ជាពួកផារិស៊ីដែលបានមករកព្រះយេស៊ូវទាំងយប់ (សូមមើល យ៉ូហាន ៣:១–២) បានមកការពារព្រះអង្គសង្គ្រោះ ហើយបានរំឭកពួកផារិស៊ី និង ពួកសង្ឃរាជថា ក្រឹត្យវិន័យផ្តាល់ខ្លួនរបស់ពួកគេ មិនអនុញ្ញាតឲ្យបុគ្គលណាម្នាក់ត្រូវបានកាត់ទោសឡើយ ទាល់តែបុគ្គលនោះត្រូវបានផ្តល់ឱកាសឲ្យនិយាយសិន ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលសិស្សបានស្គាល់នៅក្នុងការសិក្សារបស់ពួកគេអំពីយ៉ូហាន ៧ ។

យ៉ូហាន ៨:១–៣០

សេចក្តីផ្តើម

អំឡុងពេលព្រះអង្គសង្គ្រោះនៅក្នុងទីក្រុងយេរូសាឡិមសម្រាប់បុណ្យបារាំ ពួកអាចារ្យ និង ពួកផារិស៊ីមួយចំនួន បាននាំស្ត្រីម្នាក់មកឯទ្រង់ ដែលត្រូវបានចោទថាបានប្រព្រឹត្តសហាយស្មន់ ហើយពួកគេបានសួរទ្រង់ថា តើនាងគួរតែត្រូវចោលនឹងដុំថ្មដែរឬទេ ។ ទ្រង់បានធ្វើឲ្យអ្នកចោទប្រកាន់ទាំងនោះស្រឡាំងកាំង ហើយបានបង្ហាញក្តីមេត្តាដល់ស្ត្រីនោះ ។ ព្រះយេស៊ូវក៏បានបង្រៀនថា ព្រះវរបិតាថ្លែងទីបន្ទាល់អំពីទ្រង់ដែរ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៨:១–១១

ស្ត្រីម្នាក់ប្រព្រឹត្តសហាយស្មន់ ត្រូវបានគេនាំមកចំពោះមុខព្រះអង្គសង្គ្រោះ

សូមអញ្ជើញសិស្សឲ្យគិតពីគ្រាដែលពួកគេធ្លាប់ជួប ឬមានទំនាក់ទំនងជាមួយនឹងមនុស្សដែលមានអាការៈ ឬឥរិយាបថមិនសមស្របនឹងបទដ្ឋានរបស់ព្រះអម្ចាស់ ។

- តើយើងអាចនឹងជួបឧបសគ្គអ្វីខ្លះ នៅពេលយើងនៅជាមួយនឹងមនុស្សដទៃទៀតដែលមានអាការៈ និងឥរិយាបថមិនសមស្របតាមបទដ្ឋានរបស់ព្រះអម្ចាស់នោះ ? (សិស្សអាចនឹងឆ្លើយថា យើងប្រហែលជាត្រូវបានល្បួងឲ្យវិនិច្ឆ័យបុគ្គលបែបនេះថាមិនសុចរិត ឬខ្វះក្តីមេត្តាចំពោះពួកគេ) ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើយើងគួរធ្វើអ្វីខ្លះនៅក្នុងស្ថានភាពនេះ កាលយើងនៅជាមួយនឹងមនុស្សដទៃដែលមានអាការៈ និងឥរិយាបថមិនសមស្របតាមបទដ្ឋានរបស់ព្រះអម្ចាស់ ?

នៅពេលសិស្សសិក្សា យ៉ូហាន ៨:១–១១ សូមលើកទឹកចិត្តសិស្សឲ្យរកមើលសេចក្តីពិតនានា ដែលអាចជួយពួកគេឆ្លើយនឹងសំណួរនេះ ។

សូមពន្យល់ថា បន្ទាប់ពីបុណ្យបារាំ ព្រះយេស៊ូវគ្រីស្ទបានបន្តគង់នៅក្រុងយេរូសាឡិមមួយរយៈទៀត ហើយបានបង្រៀនប្រជាជននៅឯព្រះវិហារបរិសុទ្ធ (សូមមើល យ៉ូហាន ៨:១–២) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:៣–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើង នៅពេលព្រះយេស៊ូវបានបង្រៀនដល់ប្រជាជន ។

- តើមានអ្វីបានកើតឡើង នៅពេលព្រះយេស៊ូវបានបង្រៀនដល់ប្រជាជននោះ ?
- តើពួកអាចារ្យ និងពួកផារិស៊ីបានទូលសួរដល់ព្រះអង្គសង្គ្រោះនូវសំណួរអ្វីខ្លះ ?
- យោងតាម ខទី ៦តើពួកអាចារ្យ និងពួកផារិស៊ីមានចេតនាអ្វី ? (ពួកគេចង់បង្ខូចកិត្តិយសរបស់ព្រះយេស៊ូវនៅចំពោះមុខបណ្តាជន ហើយបង្កើតលេសមួយដើម្បីចោទប្រកាន់ទ្រង់ ដោយសារពួកគេចង់បានមូលហេតុមួយដើម្បីចាប់ព្រះកាយទ្រង់ ហើយកាត់ទោសទ្រង់ដល់ជីវិត (សូមមើល យ៉ូហាន ៧:១, ៣២)) ។

សូមពន្យល់ថា ប្រសិនបើព្រះយេស៊ូវមានបន្ទូលឲ្យចោលស្ត្រីនោះនឹងដុំថ្ម គឺទ្រង់កំពុងតែអនុញ្ញាតឲ្យមានការដាក់ទោសមួយ ដែលមិននិយមប្រើនៅក្នុងចំណោមប្រជាជនយូដា ហើយបំពានច្បាប់របស់រ៉ូមទៀត ។ ប្រសិនបើព្រះយេស៊ូវមានបន្ទូលកុំឲ្យចោលស្ត្រីនោះនឹងដុំថ្ម នោះទ្រង់នឹងមិនគោរពដល់ក្រឹត្យវិន័យរបស់ម៉ូសេ ឬប្រព្រឹត្តចំពោះទំនៀមទំលាប់ពីបុរាណ ដែលពួកគេទទួលស្គាល់ដោយខ្វះការគោរព ។ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Doctrinal New Testament Commentary* វ៉ុលទី ៣ (ឆ្នាំ ១៩៦៥–៧៣) ១:៤៥០–៥១) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:៧–៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ថាតើព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលតបទៅវិញយ៉ាងដូចម្តេចដែរ ។

- យោងតាមខទី ៧តើព្រះយេស៊ូវមានបន្ទូលតបទៅវិញយ៉ាងដូចម្តេច ?
- តើអ្នកគិតថា ព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យបុរសទាំងនេះដឹងពីអ្វី កាលទ្រង់បានមានបន្ទូលថា « អ្នកណាដែលគ្មានបាបសោះ ចូរឲ្យអ្នកនោះចោលនាងនឹងថ្មជាមុនគេចុះ » ? (ខទី ៧) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើង នៅពេលពួកផារិស៊ី និងពួកអាចារ្យបានពិចារណាពីព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ។

- តើអ្នកគិតថាឃ្លា « បញ្ញាចិត្តគេ បានចោទប្រកាន់ទោសខ្លួន » មានន័យយ៉ាងណា ?
- ដោយជ្រើសដើរចេញទៅ តើពួកបុរសទាំងនេះបានទទួលស្គាល់អ្វី ?

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ មកពីដំណើរឿងនេះ អំពីរបៀបចៀសវាងពីការថ្កោលទោសមនុស្សដទៃ ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ការទទួលស្គាល់ភាពមិនល្អឥតខ្ចោះរបស់យើង អាចជួយយើងឲ្យចៀសវាងពីការថ្កោលទោសមនុស្សដទៃទៀត ។** ចូរសរសេរគោលការណ៍នេះនៅក្រោមសំណួរនៅលើក្តារខៀន) ។
- តើអ្នកគិតថា ការទទួលស្គាល់ភាពមិនល្អឥតខ្ចោះរបស់យើង អាចជួយយើងឲ្យចៀសវាងពីការថ្កោលទោសមនុស្សដទៃទៀតបានដោយរបៀបណា ?

សូមរំឭកសិស្សថា ស្ត្រីម្នាក់នេះត្រូវបានគេចោទថាបានប្រព្រឹត្តអំពើសាហាវស្មន់ ដែលជាអំពើបាបដ៏ធ្ងន់ធ្ងរបំផុត (សូមមើល អាលម៉ា ៣៩:៣–៥) ។

- តើអ្នកគិតថាស្ត្រីនោះមានអារម្មណ៍បែបណា នៅពេលអំពើបាបរបស់គាត់ត្រូវបានលាតត្រដាងនៅចំពោះព្រះយេស៊ូវ និង ហ្វូងមនុស្សដ៏ធំដូចនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:១០–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សអានឲ្យឮៗផងដែរនូវឃ្លាខាងក្រោមនៅក្នុងការបកប្រែដោយយ៉ូសែប ស៊្មីធ ខទី ១១ « *ហើយស្ត្រីនោះបានសរសើរតម្កើងព្រះចាប់ពីពេលនោះមក ហើយបានជឿដល់ព្រះនាមទ្រង់* » ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យធ្វើតាម ថាតើព្រះអង្គសង្គ្រោះបានមានបន្ទូលតបទៅស្ត្រីនេះយ៉ាងដូចម្តេច ។

- តើព្រះអង្គសង្គ្រោះបានបង្ហាញសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាដល់ស្ត្រីរូបនេះយ៉ាងដូចម្តេច ?
- តើព្រះអង្គសង្គ្រោះបានបង្គាប់ស្ត្រីនោះអ្វីខ្លះ ?

ដើម្បីជួយសិស្សយល់ថា ព្រះអង្គសង្គ្រោះពុំបានមានចិត្តអាណិតដល់អំពើបាបរបស់ស្ត្រីនេះទេ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ដោយប្រធាន ស្ពែនសើរ ដបុលយូ ឃីមបឺលដូចតទៅនេះ ៖

« ការបង្គាប់របស់ទ្រង់ដល់នាងគឺ ‹ អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ › ។ ទ្រង់កំពុងតែណែនាំស្ត្រីដែលមានអំពើបាបនោះឲ្យទៅតាមផ្លូវរបស់នាង *លះបង់ចោលជីវិតអាក្រក់របស់នាង ឈប់ប្រព្រឹត្តអំពើបាបទៀត ផ្លាស់ប្រែជីវិតនាងជាថ្មី* ។ ទ្រង់កំពុងមានបន្ទូលថា នាងអើយ ចូរទៅចុះ ហើយចាប់ផ្តើមការប្រែចិត្តរបស់នាងចុះ ហើយទ្រង់កំពុងចង្អុលបង្ហាញនាងពីជំហានចាប់ផ្តើម—ដើម្បី *លះបង់អំពើរំលងរបស់នាង* » (*The Miracle of Forgiveness* | ឆ្នាំ១៩៦៩ | ទំព័រ ១៦៥) ។

- តើយើងរៀនសេចក្តីពិតអ្វីខ្លះ អំពីព្រះអង្គសង្គ្រោះនៅក្នុងខទី ១០–១១ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអង្គសង្គ្រោះបង្ហាញសេចក្តីមេត្តាករុណាដល់យើង ដោយផ្តល់ដល់យើងនូវឱកាសដើម្បីប្រែចិត្ត ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើការយល់ដឹងពីសេចក្តីពិតនេះអាចជួយយើង នៅពេលយើងមានបាបបានយ៉ាងដូចម្តេច ?
- តើសេចក្តីពិតពីដែលយើងបានរកឃើញ អាចជួយយើងឲ្យឆ្លើយតបនឹងស្ថានភាពនានា កាលយើងនៅជាមួយនឹងមនុស្សដទៃដែលមានអាការៈ និងឥរិយាបថមិនសមស្របតាមបទដ្ឋានរបស់ព្រះអម្ចាស់បានយ៉ាងដូចម្តេច ?
- យោងតាមការបកប្រែដោយយ៉ូសែប ស៊្មីធ ក្នុង ខទី ១១តើសេចក្តីមេត្តារបស់ព្រះអង្គសង្គ្រោះមានប្រសិទ្ធភាពអ្វីខ្លះទៅលើស្ត្រីនោះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ពីអារម្មណ៍ដែលពួកគេមានចំពោះព្រះអង្គសង្គ្រោះ ដោយសារការព្រមស៊ូគ្រារបស់ទ្រង់ដើម្បីបង្ហាញសេចក្តីមេត្តាដល់យើង ហើយប្រទានឱកាសឲ្យយើងប្រែចិត្ត ។

យ៉ូហាន ៨:១២–៣០

ព្រះយេស៊ូវបង្រៀនថា ព្រះវរបិតាទ្រង់ផ្តល់ទីបន្ទាល់អំពីទ្រង់

សូមអញ្ជើញសិស្សឲ្យបិទភ្នែក ហើយព្យាយាមគូររូបសាមញ្ញមួយអំពីវត្ថុជាក់លាក់មួយ ។ បន្ទាប់មក ចូរសុំសិស្សឲ្យបើកភ្នែកវិញ ហើយប្រៀបធៀបគំនូររបស់ពួកគេជាមួយនឹងគំនូររបស់សិស្សនៅក្បែរខ្លួន ។

- តើរឿងមួយចំនួនណាខ្លះ ដែលអ្នកអាចធ្វើបានល្អប្រសើរ បើមានពន្លឺនោះ ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៨:១២ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យធ្វើតាមអកមើលអ្វី ដែលព្រះយេស៊ូវបានប្រកាសអំពីអង្គទ្រង់ផ្ទាល់ ។

- តើព្រះយេស៊ូវបានមានបន្ទូលហៅអង្គទ្រង់ថាជាអ្វី ? (សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្តារខៀន ៖ **ព្រះយេស៊ូវគ្រីស្ទ គឺជាពន្លឺនៃពិភពលោក**) ។

សូមរំឭកសិស្សថា ព្រះយេស៊ូវបានធ្វើការប្រកាសនេះនៅឯបុណ្យចានំ ។ នៅរៀងរាល់ល្ងាច នៃពិធីបុណ្យជប់លៀងប្រាំបីថ្ងៃនេះ មានជើងចង្កៀងធំៗ ឬជើងចង្កៀងត្រូវគេដុតបំភ្លឺនៅតាមទីធ្លាព្រះវិហារបរិសុទ្ធ ដើម្បីបំភ្លឺដល់មនុស្សជាច្រើនដែលនៅក្នុងក្រុងយេរូសាឡិម ដើម្បីអបអរដល់ពិធីបុណ្យនេះ ។

- តើព្រះយេស៊ូវគ្រីស្ទបានប្រទានពន្លឺដល់ស្ត្រី ដែលនាំមកដោយចោទថាបានប្រព្រឹត្តសាហាយស្មន់ និងពួកបុរសដែលចោទប្រកាន់នាងយ៉ាងដូចម្តេច ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុង ខទី ១២ ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងដើរតាមព្រះអង្គសង្គ្រោះ យើងនឹងចៀសវាងផុតពីសេចក្តីងងឹតខាងវិញ្ញាណ ហើយពោរពេញដោយពន្លឺរបស់ទ្រង់**) ។
- តើអ្នកមានអារម្មណ៍បែបណាដែរ នៅពេលព្រះអង្គសង្គ្រោះជួយអ្នកឲ្យចៀសផុតពីការដើរនៅក្នុងភាពងងឹតខាងវិញ្ញាណនោះ ?

ការព្យាករមួយចំនួននៅក្នុងព្រះគម្ពីរសញ្ញាចាស់ បង្ហាញថាព្រះមែស៊ីនឹងក្លាយជាពន្លឺដល់គ្រប់សាសន៍ទាំងអស់ (សូមមើល អេសាយ ៤៩:៦, ៦០:១–៣) ។ ហេតុដូច្នោះហើយ នៅក្នុងការប្រកាសអំពីអង្គទ្រង់ថាជាពន្លឺនៃលោកិយ នោះព្រះយេស៊ូវកំពុងប្រកាសថា ទ្រង់គឺជាព្រះមែស៊ី ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៨:១៣ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលពួកផារិស៊ីបានឆ្លើយតបទៅនឹងការប្រកាសរបស់ព្រះអង្គសង្គ្រោះ ។

- តើពួកផារិស៊ីបានឆ្លើយតបនឹងការប្រកាសរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- ហេតុអ្វីបានជាពួកគេពោលថាកំណត់ត្រា ឬទីបន្ទាល់របស់ព្រះយេស៊ូវមិនពិត ? (ដោយសារទ្រង់បានថ្លែងទីបន្ទាល់ពីអង្គឯង) ។

សូមពន្យល់ថា ព្រះយេស៊ូវបានរំឭកដល់ពួកផារិស៊ីថា ក្រឹត្យវិន័យរបស់ម៉ូសេតម្រូវឲ្យមានទីបន្ទាល់យ៉ាងហោចណាស់ពីរនាក់ ដើម្បីបង្កើតសេចក្តីពិត (សូមមើល យ៉ូហាន ៨:១៧, ចោទិយកថា ១៧:៦) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៨:១៨ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមនុស្សផ្សេងទៀតដែលបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះមែស៊ីដែលបានសន្យាទុក ។

- យោងតាម ខទី ១៨តើព្រះអង្គសង្គ្រោះបានមានបន្ទូលថានរណាទៅ ដែលជាសាក្សីទីពីរចំពោះភាពជាព្រះរបស់ទ្រង់ ? (អ្នកគួរគូសបញ្ជាក់ថា តាមរយៈព្រះបន្ទូលនេះព្រះយេស៊ូវបានបញ្ជាក់ថាទ្រង់ និងព្រះវរបិតាត្រង់គឺជាតួអង្គពីរដាច់ដោយឡែកពីគ្នា) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៨:១៩ឲ្យឮៗ ។ ចូរសុំឲ្យសិស្សរកមើលអ្វី ដែលពួកផារិស៊ីពុំបានយល់ដឹងអំពីព្រះយេស៊ូវ និងព្រះវរបិតារបស់ទ្រង់ ។

- យោងតាម ខទី ១៩ហេតុអ្វីបានជាពួកផារិស៊ីមិនស្គាល់ព្រះវរបិតា ? (ពួកផារិស៊ីមិនស្គាល់ព្រះវរបិតា ដោយសារពួកគេមិនស្គាល់ព្រះយេស៊ូវ ហើយមិនបានដឹងថាទ្រង់គឺជានរណាពិតប្រាកដ) ។
- ផ្អែកលើបន្ទូលដែលព្រះអង្គសង្គ្រោះប្រាប់ទៅពួកផារិស៊ី តើយើងអាចធ្វើអ្វីខ្លះ ដើម្បីស្គាល់ព្រះវរបិតាសួគ៌ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដដើម្បីបញ្ជាក់ថា **នៅពេលយើងរៀនពីព្រះយេស៊ូវគ្រីស្ទ នោះយើងបានស្គាល់ព្រះវរបិតា ។** ដោយប្រើពាក្យរបស់សិស្ស សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅគ្រប់អ្វីៗទាំងអស់ដែលព្រះយេស៊ូវ យាងមកមានបន្ទូល និងធ្វើរួមមាន និងជាពិសេស នៅក្នុងការរងទុក្ខនៃដង្វាយធួន និងការពលិកម្មរបស់ទ្រង់ នោះទ្រង់កំពុងបង្ហាញដល់យើងថា តើព្រះវរបិតាសួគ៌ដ៏អស់កល្បជានិច្ចរបស់យើង មានលក្ខណៈបែបណា និងយ៉ាងដូចម្តេចហើយថា តើទ្រង់បានលះបង់ គ្រប់យ៉ាងអ្វីខ្លះសម្រាប់កូនចៅរបស់ទ្រង់គ្រប់វ័យ និងគ្រប់ជាតិសាសន៍នោះ ។ ព្រះយេស៊ូវគ្រីស្ទបានព្យាយាមបើកសម្តែងគ្រប់ព្រះបន្ទូល និងទង្វើ ហើយធ្វើឲ្យយើងដឹងដោយផ្ទាល់អំពីលក្ខណៈពិតរបស់ព្រះបិតារបស់ទ្រង់ ថាគឺជាព្រះវរបិតា ដែលនៅស្ថានសួគ៌របស់យើង ។ . . .

« ដូច្នេះ ការឲ្យអាហារដល់អ្នកស្រេកឃ្លាន ការព្យាបាលអ្នកឈឺ ការវាយផ្ចាលដល់មនុស្សលាក់ពុត ការទូលអង្វរសុំសេចក្តីជំនឿ—គឺជារបៀបដែលព្រះគ្រីស្ទបានបង្ហាញយើងពីមាគ៌ានៃព្រះបិតាទ្រង់គឺ ‹ ប្រកបដោយក្តីមេត្តាករុណា និង ព្រះគុណ កម្រនឹងព្រះពិរោធ អត់ធ្មត់ និងពោរពេញដោយសេចក្តីល្អ › ។ នៅក្នុងជីវិតរបស់ទ្រង់ និងជាពិសេសនៅក្នុងការសុគតរបស់ទ្រង់ នោះព្រះគ្រីស្ទកំពុងប្រកាសថា ‹ នេះគឺជាសេចក្តីមេត្តាករុណា *របស់ព្រះ* ដែលយើងកំពុងបង្ហាញដល់អ្នក ព្រមទាំងវាក៏ជាសេចក្តីមេត្តាករុណារបស់យើងផ្ទាល់ផងដែរ › » (« The Grandeur of God » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ៧០, ៧២) ។

- យោងតាមអែលឌើរ ហូឡិន តើយើងអាចរៀនអ្វីខ្លះអំពីព្រះវរបិតារបស់យើង កាលយើងរៀនអំពីព្រះយេស៊ូវគ្រីស្ទ ?

សូមសង្ខេប យ៉ូហាន ៨:២១–២៤ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានព្រមានពួកផារិស៊ីថា ប្រសិនបើពួកគេពុំជឿទ្រង់ទេ នោះពួកគេនឹងស្លាប់ក្នុងអំពើបាបរបស់ខ្លួន ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:២៥–៣០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យរកមើលសេចក្តីពិតបន្ថែមទៀត ដែលព្រះយេស៊ូវបានបង្រៀនដល់ពួកផារិស៊ីអំពីអង្គទ្រង់ និងព្រះវរបិតាសួគ៌ ។ អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំអ្វី ដែលពួកគេបានរកឃើញ ។

- តើសេចក្តីពិតបន្ថែមទៀតអ្វីខ្លះ ដែលព្រះយេស៊ូវបានបង្រៀនអំពីអង្គទ្រង់ និងព្រះវរបិតាសួគ៌ ?
- តើការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរទាំងនេះ ជួយយើងឲ្យយល់បន្ថែមទៀតអំពីទំនាក់ទំនងរវាងព្រះអង្គសង្គ្រោះ និងព្រះវរបិតាសួគ៌យ៉ាងដូចម្តេចដែរ ?

សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទី ដើម្បីពិនិត្យមើលឡើងវិញ ហើយសញ្ជឹងគិតពីដំណើររឿងដែលពួកគេបានសិក្សាពាក់ព័ន្ធនឹងបន្ទូល និងទង្វើរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាថ្មីឆ្នាំនេះ (ឧទាហរណ៍ រួមមានដំណើររឿងអំពីស្ត្រី ដែលនាំមកដោយចោទថាបានប្រព្រឹត្តសាហាយស្មន់) ។ អ្នកគួរដាក់បង្ហាញរូបភាពនៅក្នុង *Gospel Art Book* (ឆ្នាំ ២០០៩) សូមមើលផងដែរ LDS.org) ដែលបង្ហាញពីព្រឹត្តិការណ៍នៅក្នុងការងារបម្រើនៅក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យសង្ខេបដំណើររឿងមួយ ដែលពួកគេម្នាក់ៗបានគិតឃើញ ហើយពន្យល់ដល់សិស្សក្នុងថ្នាក់អំពីអ្វី ដែលវាបង្រៀនអំពីព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ។

មេរៀន ៦៨

យ៉ូហាន ៨:៣១–៥៩

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះ បានបន្តបង្រៀននៅព្រះវិហារបរិសុទ្ធបន្ទាប់ពីបុណ្យបារាំ ។ ទ្រង់បានបង្រៀនអំពីសេរីភាពពីអំពើបាប ។ នៅពេលព្រះយេស៊ូវបានប្រកាសថា ទ្រង់គឺជាព្រះយេហូវ៉ាដ៏មហិមា នោះពួកយូដាបានព្យាយាមចោលដុំថ្មលើទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

សូមសម្របវិធីសាស្ត្របង្រៀនដើម្បីបំពេញតាមតម្រូវការរបស់សិស្ស

វិធីសាស្ត្របង្រៀន និងជំនាញគឺគ្រាន់តែជាឧបករណ៍ដើម្បីជួយសិស្សឲ្យរៀន ប៉ុណ្ណោះ តែវាពុំមែនជាគោលបំណងក្នុងថ្នាក់រៀនទេ ។ សូមជ្រើសរើសវិធីសាស្ត្រដែលនឹងជួយសិស្សរបស់អ្នកយល់មាតិកា គោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃបណ្តុំបទគម្ពីរដោក់លាក់ ហើយអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងនោះនៅក្នុងជីវិតរបស់ពួកគេ ។ សូមចងចាំថា បើគ្មានព្រះវិញ្ញាណទេ ទោះជាវិធីសាស្ត្របង្រៀនមានប្រសិទ្ធភាពបំផុតក្តី ក៏វានឹងគ្មានជោគជ័យពេញលេញដែរ ។

យ៉ូហាន ៨:៣១–៣៦

ព្រះយេស៊ូវបង្រៀនអំពីសេរីភាពពីអំពើបាប ។

ដើម្បីជួយសិស្សចងចាំពីអ្វីដែលពួកគេរៀននៅក្នុងមេរៀនមុនៗ សូមលើកដុំថ្មតូចមួយឡើង ។ សូមអញ្ជើញសិស្សឲ្យសង្ខេបខ្លីៗអំពីរបៀបដែលព្រះអង្គសង្គ្រោះឆ្លើយតប នៅពេលពួកអាចារ្យ និងពួកផារិស៊ីមួយចំនួន បាននាំស្ត្រីម្នាក់ដែលប្រព្រឹត្តអំពើកំផិតមករកទ្រង់ និងអ្វីដែលទ្រង់បានបង្រៀនបន្ទាប់ពីនោះ (សូមមើលយ៉ូហាន ៨:១–៣០) ។ (ព្រះអង្គសង្គ្រោះពុំបានផ្តន្ទាទោសដល់ស្ត្រីនោះទេ ហើយបានប្រាប់ទៅនាងថា « កុំឲ្យធ្វើបាបទៀតឡើយ » [ខទី ១១] ។ បន្ទាប់មកព្រះយេស៊ូវបានបង្រៀនថា ទ្រង់គឺជា « ពន្លឺលោកីយ៍ » [ខ ១២] ហើយថានៅពេលណាយើងជឿទៅលើទ្រង់ ហើយគោរពតាមការបង្រៀនរបស់ទ្រង់ នោះយើងបានស្គាល់ព្រះវរបិតា) ។

- ស្របតាមយ៉ូហាន ៨:៣០តើសកម្មភាព និងព្រះបន្ទូលរបស់ព្រះយេស៊ូវជះឥទ្ធិពលដល់ពួកសាសន៍យូដាយ៉ាងដូចម្តេច ?


សូមចង្អុលបង្ហាញថា ទោះជាពួកសាសន៍យូដាជាច្រើនជឿទៅលើព្រះយេស៊ូវ ក៏មានពួកយូដាមួយចំនួនបានបន្តថ្កោលទ្រង់ នៅពេលទ្រង់បង្រៀនប្រជាជនអំពីភាពជាសិស្ស សេចក្តីពិត និងសេរីភាពជុំយពីទាសភាព ។

សូមគូររូបខាងក្រោមនេះដាក់នៅលើក្តារខៀន ៖



ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ៨:៣១–៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលព្រះយេស៊ូវបានមានបន្ទូល ដែលយើងចាំបាច់ត្រូវធ្វើដើម្បីទទួលបានសេរីភាព ។

សូមអញ្ជើញសិស្សឲ្យឡើងមកក្តារខៀន ហើយបំពេញក្នុងប្រឡោះទាំងឡាយ ដោយផ្អែកទៅលើអ្វីដែលព្រះយេស៊ូវបានមានបន្ទូលថា យើងចាំបាច់ត្រូវធ្វើ ដើម្បីទទួលបានសេរីភាព ។ រូបដែលបានបំពេញគួរតែមើលទៅស្រដៀងគ្នានឹងរូបដូចខាងក្រោម ៖



- តើវាមានន័យយ៉ាងណា ដើម្បី « នៅជាប់ក្នុងព្រះបន្ទូល [របស់ព្រះគ្រីស្ទ] » ? (ខទី ៣១) ។
- តើអ្នកនឹងសង្ខេបជាសេចក្តីថ្លែងការណ៍អំពីគោលការណ៍ការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលបានកត់ត្រានៅក្នុងខទី ៣១–៣២យ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថាវាច្បាស់លាស់ថា **ប្រសិនបើយើងនៅជាប់ក្នុងព្រះបន្ទូលរបស់ព្រះគ្រីស្ទ នោះយើងនឹងជាពួកសិស្សរបស់ទ្រង់ ហើយស្គាល់សេចក្តីពិត ដែលនឹងធ្វើឲ្យយើងមានសេរីភាព ។** សូមពិចារណាសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ អ្នកគប្បីចង្អុលបង្ហាញថាយ៉ូហាន ៨:៣៦គួរសបញ្ជាក់ថា ដោយសារព្រះយេស៊ូវគ្រីស្ទ ទើបយើងអាចបានមានសេរីភាព) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលថា តើយើងអាចមានសេរីភាពពីអ្វី ប្រសិនបើយើងរស់នៅស្របតាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ៖

« មានសេរីភាពពីអំណាចដ៏អាក្រក់នៃគោលលទ្ធិក្លែងក្លាយ មានសេរីភាពពីទាសភាពនៃការលោភលន់ និងតណ្ហា មានសេរីភាពពីច្រវាក់នៃអំពើបាប មានសេរីភាពពីឥទ្ធិពលអាក្រក់ និងពុករលួយគ្រប់យ៉ាង ហើយនិងមានសេរីភាពពីអំណាចគាបសង្កត់ និងចុះអន់ថយគ្រប់យ៉ាង មានសេរីភាពបន្តនៅក្នុងសេរីភាពគ្មានព្រំដែន ដែលកើតរាយនៅក្នុងភាពពេញលេញតែតាមរយៈតួអង្គដ៏លើកតម្កើងតែប៉ុណ្ណោះ » (*Doctrinal New Testament Commentary,* វ៉ុលទី ៣ [ឆ្នាំ ១៩៦៥–៧៣], ១:៤៥៦–៥៧) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៨:៣៣ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលពួកយូដាជឿថាពួកគេទទួលបានសេរីភាព ។

- តើពួកយូដាជឿថាអ្វីខ្លះ ដែលនឹងធ្វើឲ្យពួកគេមានសេរីភាព ? (ពួកគេបានជឿដោយខុសឆ្គងថា ការធ្វើជាកូនចៅរបស់អ័ប្រាហាំ និងជាអ្នកគ្រងសេចក្តីសញ្ញាអ័ប្រាហាំ នោះពួកគេនឹងទទួលបានសេរីភាពខាងវិញ្ញាណដោយងាយ) ។


ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ៨:៣៤–៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាព្រះយេស៊ូវបានបង្ហាញពីអ្វីដែលប្រជាជនចាំបាច់ត្រូវមានសេរីភាពពីវា ។

- យោងតាមខទី ៣៤តើព្រះអង្គសង្គ្រោះបានបង្ហាញថា ប្រជាជនចាំបាច់ត្រូវមានសេរីភាពពីអ្វី ?

សូមចង្អុលបង្ហាញថា ភាសាក្រិក បកប្រែជាកិរិយាសព្ទថាជា « បានប្រព្រឹត្ត » នៅក្នុងខទី ៣៤ដែលផ្តល់គំនិតអំពីការបន្តនៅក្នុងបាបជាជាងការប្រែចិត្ត ។


- តើគោលការណ៍អ្វីដែលយើងរៀនមកពី ខទី ៣៤នេះ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងប្រព្រឹត្តអំពើបាប ហើយពុំប្រែចិត្ត នោះយើងនឹងក្លាយទៅជាបាវបម្រើនៃអំពើបាប**) ។
- តើ « បាវបម្រើនៃអំពើបាប » មានន័យយ៉ាងណា ? (អ្នកគប្បីចង្អុលបង្ហាញថា ៣ក្យដែលបានបកប្រែថាជា « បាវបម្រើ » អាចនឹងគិតថាជា « ទាសករ ») ។

ដើម្បីជួយសិស្សមើលឃើញពីទំនាក់ទំនងរវាងគោលការណ៍ពីរ ដែលពួកគេបានស្គាល់ សូមគូររូបដូចខាងក្រោមនៅលើក្តារខៀន ៖



- ហេតុអ្វីមនុស្សមួយចំនួននាសព្វថ្ងៃនេះ បដិសេធសេចក្តីពិតទាំងនេះដោយជឿថា ការដើរតាមព្រះអង្គសង្គ្រោះដាក់យើងនៅក្នុងទាសភាព ខណៈដែលការប្រព្រឹត្តអំពើបាបនាំឲ្យមានសេរីភាពដូច្នេះទៅវិញ ?

ដើម្បីជួយឲ្យសិស្សយល់ដឹងបន្ថែមអំពីគោលការណ៍ពីរដែលពួកគេបានប្រាប់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« ការធ្វើតាមការល្បួងរបស់ [សាតាំង] នាំទៅរកជម្រើសកាន់តែតូចចង្អៀតទៅៗរហូតដល់គ្មានសល់ជម្រើសសោះ ហើយនាំទៅរកការញៀនដែលយើងគ្មានអំណាចដើម្បីទប់ទល់សោះ ។ . . .

«. . . ពិភពលោកមើលទៅអ្វីៗតាមរយៈកែវភ្នែករបស់ក្រឹហ្វរ ដោយគិតថាការគោរពប្រតិបត្តិចំពោះក្រិត្យវិន័យរបស់ព្រះ និងពិធីបរិសុទ្ធរបស់ព្រះ គឺជា ‹ ទាសភាព › (អាលម៉ា ៣០:២៤, ២៧) ។ . . .

«. . . តើមាននរណាម្នាក់សង្ស័យទេថា លទ្ធផលមួយនៃ ការមានពន្លឺ និងសេចក្តីពិតទាំងអស់ ហើយព្រះជាម្ចាស់លើសេរីភាពដ៏ខ្ពស់បំផុតដើម្បីឲ្យប្រែក្លាយ និងធ្វើនោះ ?

« ក៏ដូចគ្នាផងដែរថា នៅពេលការយល់ដឹងរបស់យើងអំពីគោលលទ្ធិ និងគោលការណ៍នានានៃដំណឹងល្អកើនឡើង នោះសិទ្ធិសេរីភាពរបស់យើងនឹងរីកកាន់តែធំ ។ ដំបូងឡើយ យើងមានជម្រើសជ្រើស ហើយអាចសម្រេចបានកាន់តែច្រើន និងទទួលបានពរជ័យកាន់តែច្រើន ដោយសារយើងមានក្រិត្យវិន័យកាន់តែច្រើនដែលយើងអាចគោរពតាម ។ . . . ទីពីរ ដោយមានការយល់ដឹងបន្ថែម នោះយើងអាចមានជម្រើសល្អៗកាន់តែឈ្លាសវៃ ដោយសារតែយើងមើលឃើញកាន់តែច្បាស់ មិនគ្រាន់តែជាជម្រើស ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាលទ្ធផលប្រកបដោយសក្តានុពលផងដែរ » (« Moral Agency » *Ensign* ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤៩, ៥០–៥១) ។

សូមចែកសិស្សជាគូ ។ សូមអញ្ជើញដៃគូសិស្សនីមួយៗដែលបានចាត់ឲ្យទទួលវគ្គនៃកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន*(កូនសៀវភៅឆ្នាំ ២០១១) ។ ចូរសុំឲ្យសិស្សគូរតារាងដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ (អ្នកគប្បីគូរវានៅលើក្តារខៀន) ។ សូមអញ្ជើញដៃគូនីមួយៗអានជាមួយគ្នា នូវវគ្គដែលបានចាត់ឲ្យក្នុងកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន* ហើយបំពេញវានៅក្នុងតារាង ។

បទដ្ឋានដែលបានពិភាក្សានៅក្នុងកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន* ៖	តើការរស់នៅតាមបទដ្ឋាននេះ អាចនាំមកនូវសេរីភាពតាមរបៀបណា ?	តើការមិនរស់នៅតាមបទដ្ឋាននេះ អាចនាំមកនូវទាសភាពតាមរបៀបណា ?

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញដៃគូសិស្សនីមួយៗប្តូរដៃគូគ្នាជាមួយនឹងដៃគូផ្សេង ហើយបង្រៀនអំពីអ្វីដែលពួកគេបានរៀនអំពីបទដ្ឋានដែលពួកគេបានសិក្សា ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ប្រាប់ចម្លើយដែលពួកគេបានរៀនដល់សិស្សក្នុងថ្នាក់ ។

- តើសេរីភាពអ្វីខ្លះ ដែលបានសន្យានៅក្នុងកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន*ដែលអ្នកបានទទួលបទពិសោធន៍ផ្ទាល់ខ្លួន ?

សូមអញ្ជើញសិស្សឲ្យសរសេរពីរបៀបជាក់លាក់មួយ ដែលពួកគេនឹងស្វែងរកសេរីភាព ក្នុងការរស់នៅស្របតាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ ។

យ៉ូហាន ៨:៣៧–៥៩

ព្រះយេស៊ូវបានថ្លែងទីបន្ទាល់អំពីភាពជាព្រះរបស់ទ្រង់

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរខាងក្រោមដោយសង្ខេប ៖

- តើនរណាដែលអ្នកស្គាល់ ដែលមានចរិតលក្ខណៈស្រដៀងគ្នា ស្ទើរតែបេះបទនឹងឪពុករបស់ខ្លួន ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗចេញមកពី យ៉ូហាន ៨:៣៧–៤០, ៤៤–៤៥។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលពីរបៀបដែលពួកអ្នកដឹកនាំយូដា ជំទាស់នឹងព្រះអម្ចាស់ ខុសពីព្យាការីអ័ប្រាហាំដ៏អស្ចារ្យក្នុងគម្ពីរសញ្ញាចាស់ ដែលពួកគេអះអាងថាជាឪពុករបស់ពួកគេនោះ ។

- យោងតាមខទី ៣៩តើព្រះអង្គសង្គ្រោះមានបន្ទូលដូចម្តេចខ្លះ ដែលថាពួកគេនឹងធ្វើ ប្រសើនបើពួកគេគឺជាកូនចៅរបស់អ័ប្រាហាំ ?
- យោងតាមខទី ៤០តើពួកគេព្យាយាមធ្វើអ្វីខ្លះ ដែលអ័ប្រាហាំនឹងមិនធ្វើនោះ ?
- យោងតាមខទី ៤៤–៤៥តើនរណាដែលព្រះយេស៊ូវមានបន្ទូលថាជាឪពុករបស់ពួកគេ ? (អារក្ស) ។ តើពួកគេធ្វើតាមអារក្សតាមរបៀបណា ?

សូមសង្ខេបយ៉ូហាន ៨:៤៦–៥០ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនថា អ្នកទាំងឡាយដែលជារបស់ផងព្រះ ទទួលយកព្រះបន្ទូលទ្រង់ ។ ពួកអ្នកដឹកនាំយូដាបានព្យាយាមប្រមាថព្រះយេស៊ូវដោយហៅទ្រង់ថាជា សាសន៍សាម៉ារី (ជាសាសន៍សាម៉ារីដែលត្រូវបានពួកសាសន៍យូដាស្អប់ជាទូទៅនោះ) ហើយបានប្រកាសថាទ្រង់មានវិញ្ញាណអារក្ស ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ៨:៥១–៥៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួរដែលអ្នកដឹកនាំយូដាបានសួរព្រះយេស៊ូវ ។

- តើពួកគេបានសួរសំណួរព្រះយេស៊ូវអ្វីខ្លះ ? (អ្នកគប្បីអញ្ជើញសិស្សឲ្យគូសចំណាំសំណួរ « តើអ្នកធំជាងលោកអ័ប្រាហាំ ជាឰយុកោយើង និងពួកហោរា ដែលស្លាប់ទៅហើយនោះឬអី ?» នៅក្នុងខទី ៥៣) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ៨:៥៦–៥៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះសំណួររបស់ពួកយូដា ។

- តើព្រះយេស៊ូវឆ្លើយយ៉ាងណា ចំពោះសំណួរថា « តើអ្នកធំជាងលោកអ័ប្រាហាំ ជាឰយុកោយើង និងពួកហោរា ដែលស្លាប់ទៅហើយនោះឬអី » នោះ ? (អ្នកគប្បីអញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « មុនដែលលោកអ័ប្រាហាំកើតមក នោះមានខ្ញុំហើយ » នៅក្នុងខទី ៥៨) ។

សូមអញ្ជើញសិស្សឲ្យអានយ៉ូហាន ៨:៥៨ លេខយោងខដោយស្ងាត់ស្ងៀម ហើយរកមើលអត្ថន័យនៃពាក្យ « ខ្ញុំ » ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- តើពាក្យ « ខ្ញុំ » មានន័យយ៉ាងណា ? (ពាក្យនោះប្រាប់អំពីព្រះយេហូវ៉ា ព្រះនៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា Septuagint គឺជាការបកប្រែភាសាក្រិកនៃគម្ពីរសញ្ញាចាស់ ។ អ្នកគប្បីអញ្ជើញសិស្សឲ្យសរសេរនៅក្នុងគម្ពីររបស់ពួកគេនូវសេចក្តីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះយេហូវ៉ា ជាព្រះនៃគម្ពីរសញ្ញាចាស់**) ។
- ផ្អែកទៅលើការសិក្សារបស់អ្នកអំពីខទី ៥៨តើចម្លើយរបស់ព្រះយេស៊ូវគឺជាអ្វី ចំពោះសំណួរថាតើទ្រង់ធំជាងអ័ប្រាហាំទេឬអីនោះ ?



សូមដាក់តាំងរូបភាពជាច្រើនមកពី*សៀវភៅសិល្បៈដំណឹងល្អ*(| ឆ្នាំ ២០០៩ | សូមមើលផងដែរ LDS.org) ដែលបង្ហាញពីអព្ភូតហេតុដែលបានកត់ត្រានៅក្នុងគម្ពីរសញ្ញាចាស់ (ដូចជាបុរសបីនាក់នៅក្នុងគុកភ្លើងលេខ២៥ឬដានីយ៉ែលនៅក្នុងរូងសិង្ហលេខ២៦) ។

- ប្រសិនបើអ្នកឈរនៅចំពោះមុខព្រះយេស៊ូវ ហើយបានស្តាប់ឮទ្រង់ប្រកាសថា ទ្រង់គឺជាអង្គដែលបាននាំឲ្យមានអព្ភូតហេតុដែលបានកត់ត្រានៅក្នុងគម្ពីរសញ្ញាចាស់ តើអ្នកនឹងឆ្លើយតបចំពោះទ្រង់យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ៨:៥៩ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលអ្នកដឹកនាំពួកយូដាបានឆ្លើយតបចំពោះការប្រកាសរបស់ព្រះយេស៊ូវថា ទ្រង់ជាព្រះយេហូវ៉ា ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វីអ្នកមានអារម្មណ៍ថា វាសំខាន់សម្រាប់យើងដើម្បីដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះយេហូវ៉ា ជាព្រះនៃគម្ពីរសញ្ញាចាស់ ?

សូមពិចារណាធ្វើការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងសិស្សក្នុងថ្នាក់ ។ អ្នកអាចបញ្ចប់មេរៀននេះដោយការចែកទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកផងដែរ ។

ការរំឭកពីចំណេះចំណានខគម្ពីរ



សំណួរ និង ការប្រលងផ្តល់ឱកាសឲ្យសិស្សសាកល្បងការចងចាំអំពីចំណេះចំណានខគម្ពីររបស់ពួកគេ ។ តម្រូវអាចរួមមាន ពាក្យគន្លឹះ ឬ សេចក្តីយោងព្រះគម្ពីរ ការដកស្រង់ពីវគ្គបទគម្ពីរ ឬ រឿងប្រឌិតដែលគូសបង្ហាញពីសេចក្តីពិតដែលបានបង្រៀននៅក្នុងវគ្គបទគម្ពីរទាំងនោះ ។ សំណួរ និង ការប្រលងនានាអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ នៅលើក្តារខៀន ឬនៅលើក្រដាស ។ បន្ទាប់ពីសិស្សបានធ្វើសំណួរ ឬការសាកល្បងរួចហើយ ចូរពិចារណាធ្វើការចាប់ដៃគូសិស្ស ដែលមានបញ្ហាក្នុងការទន្ទេញចាំចំណេះចំណានខគម្ពីរ ធ្វើការជាមួយនឹងអ្នកដែលទទួលបានពិន្ទុខ្ពស់ ។ សិស្សដែលបានពិន្ទុខ្ពស់អាចដើរតួធ្វើជាអ្នកបង្ហាត់ ដើម្បីជួយសិស្សដែលមានពិន្ទុទាបឲ្យសិក្សា និង កែលម្អឲ្យបានល្អប្រសើរឡើង ។ (ប្រសិនបើអ្នកធ្វើដូចនេះ ចូរប្រាកដថា ធ្វើវាក្នុងរបៀបមួយដែលពុំធ្វើឲ្យសិស្សដែលកំពុងមានបញ្ហាមានការខ្មាស់អៀនឡើយ) ។

មេរៀន ៦៩

យ៉ូហាន ៩

សេចក្តីផ្តើម

ព្រះយេស៊ូវបានព្យាបាលបុរសម្នាក់ដែលខ្វាក់ភ្នែកពីកំណើត ។ ពួកផារិស៊ីបានចោទសួរបុរសនេះ ហើយបានបណ្តេញគាត់ចេញពីសាលាប្រជុំ ដោយសារតែគាត់បានបដិសេធមិនផ្តន្ទាទោសដល់ព្រះយេស៊ូវ ដែលជាមនុស្សមានបាបចំពោះការព្យាបាលនៅថ្ងៃឈប់សម្រាក ។ ព្រះអង្គសង្គ្រោះបានស្វែងរកបុរសនោះ ហើយបុរសនោះបានថ្វាយបង្គំព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៩:១–៧

ព្រះយេស៊ូវបានព្យាបាលបុរសម្នាក់ដែលខ្វាក់ភ្នែកពីកំណើត

សូមនាំនូវអត្ថបទព័ត៌មានមួយមកថ្នាក់រៀន ដែលពិពណ៌នាអំពីមនុស្សម្នាក់ដែលជួបនឹងឧបសគ្គមួយ ។ សូមសង្កេបអត្ថបទនោះដល់សិស្ស ឬសរសេរក្បាលរឿងនៅលើក្តារខៀន ។

- តើមានឧទាហរណ៍អ្វីផ្សេងទៀត ដែលអ្នកបានមើលឃើញមនុស្សដែលជួបបទពិសោធន៍នូវរឿងអាក្រក់ៗ ?

សូមចង្អុលបង្ហាញថា មនុស្សខ្លះងឿងឆ្ងល់ថា ហេតុអ្វីព្រះអនុញ្ញាតឲ្យរឿងអាក្រក់កើតមានដល់ជីវិតរបស់ពួកគេយ៉ាងខ្លាំងដូច្នេះ ។

ចូរសុំឲ្យសិស្សរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាយ៉ូហាន ៩:១–៥ដែលអាចជួយយើងឲ្យយល់កាន់តែប្រសើរថា ហេតុអ្វីព្រះអនុញ្ញាតឲ្យរឿងអាក្រក់មានឥទ្ធិពលលើជីវិតរបស់យើង ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៩:១–២ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរឿងអាក្រក់ដែលបុរសម្នាក់បានជួប ។ សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- ស្របតាមខ ២តើពួកសិស្សបានសួរអ្វីខ្លះ អំពីបុព្វហេតុនៃរឿងអាក្រក់របស់បុរសនេះ ?

ចូរពន្យល់ថា មនុស្សជាច្រើននៅក្នុងជំនាន់របស់ព្រះអង្គសង្គ្រោះបានជឿ ដូចជាមនុស្សមួយចំនួនក្នុងសម័យយើងជឿថា រឿងអាក្រក់ដែលមនុស្សជួបប្រទះ គឺជាលទ្ធផលនៃអំពើបាបដែលពួកគេ ឬឪពុកម្តាយរបស់ពួកគេបានប្រព្រឹត្ត ។ (អ្នកក៏គប្បីចង្អុលបង្ហាញផងដែរថា ចម្ងល់របស់ពួកសិស្សសន្មតពីភាពពិតនៃជីវិតមុនជីវិតនៅលើផែនដី) ។

- តើអ្នកគិតថាជំនឿនេះត្រឹមត្រូវឬទេ ? ហេតុអ្វីត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៩:៣–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការខ្វាក់ភ្នែករបស់បុរសនោះ ។

- តើអ្នកគិតថាវាមានន័យយ៉ាងណា ដែលថា « ការរបស់ព្រះបានសំដែងមកក្នុងខ្លួនគាត់វិញ » នោះ ? (ខ ៣) ។
- ចេញមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរទាំងនេះ តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនអំពីរឿងអាក្រក់របស់យើង ? (សិស្សអាចនឹងប្រើ៣ក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដូចខាងក្រោមនេះ ៖ **ព្រះអាចប្រើរឿងអាក្រក់របស់យើង ដើម្បីបង្ហាញពីកិច្ចការ និងព្រះចេស្តារបស់ទ្រង់**) ។

សូមពន្យល់ថា ខណៈដែលមានបុព្វហេតុផ្សេងៗជាច្រើនអំពីរឿងអាក្រក់នៅក្នុងជីវិតរបស់យើង នោះព្រះអាចប្រើឧបសគ្គរបស់យើងដើម្បីជួយយើងឲ្យសម្រេចគោលបំណងដ៏សុចរិតរបស់ទ្រង់ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីរឿងអាក្រក់ដែលពួកគេបានជួប ឬកំពុងជួបក្នុងពេលថ្មីៗនេះ ។ នៅពេលសិស្សបន្តសិក្សាយ៉ូហាន ៩ចូរសុំឲ្យពួកគេពិចារណាអំពីរបៀបដែលព្រះអាចបង្ហាញកិច្ចការ និងព្រះចេស្តារបស់ទ្រង់តាមរយៈពួកគេ ដោយសារតែរឿងអាក្រក់ទាំងនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៩:៦–៧ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀបដែលព្រះបើកសម្តែងកិច្ចការ និងព្រះចេស្តារបស់ទ្រង់តាមរយៈបទពិសោធន៍របស់បុរសខ្វាក់ភ្នែក ។

អ្នកក៏អាចបង្ហាញផ្នែកមួយនៃវីដេអូ*គម្ពីរបឺរអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ* « ព្រះយេស៊ូវព្យាបាលបុរសខ្វាក់ភ្នែកពីកំណើត »| លេខកូដម៉ោង ០:០០ ដល់ ៣:៣៧ | ។ វីដេអូនេះមាននៅក្នុង LDS.org ។

- តើអ្នកស្រមៃថាវាយ៉ាងណា ដែលបុរសនេះបានមើលឃើញជាលើកទីមួយនោះ ?
- តើរឿងអាក្រក់របស់បុរសនេះ អនុញ្ញាតឲ្យអ្នកដទៃធ្វើជាសាក្សីអំពីព្រះចេស្តារបស់ព្រះយ៉ាងដូចម្តេច ?
- នៅក្នុងដំណើររឿងនេះ បុរសនោះចាំបាច់ត្រូវលាងភ្នែកនៅក្នុងស្រះស៊ីឡោម ដើម្បីទទួលបានការមើលឃើញរបស់គាត់ ។ តើអ្នកចាំបាច់ត្រូវធ្វើអ្វីខ្លះ ដើម្បីព្រះអាចបើកសម្តែងកិច្ចការ និងព្រះចេស្តាទ្រង់នៅក្នុងជីវិតរបស់អ្នក ?

យ៉ូហាន ៩:៨–៤១

ព្រះអង្គសង្គ្រោះបានស្វែងរកបុរសដែលទ្រង់បានព្យាបាលនោះ បន្ទាប់ពីពួកផារិស៊ីបានបណ្តេញបុរសនោះចេញ ។

ចូរសង្កេតយ៉ូហាន ៩:៨–១៥ដោយពន្យល់ថា បន្ទាប់ពីបុរសខ្វាក់ភ្នែកត្រូវបានព្យាបាល នោះមនុស្សមួយចំនួនបានប្រកែកគ្នាថា តើគាត់នោះគឺជាបុរសដែលខ្វាក់ភ្នែកពីកំណើតឬអី ។ អ្នកផ្សេងទៀតបានងឿងឆ្ងល់ពីរបៀប ដែលគាត់ត្រូវបានព្យាបាល ហើយបាននាំគាត់ទៅជួបនឹងពួកផារិស៊ី ដែលបានចាប់ផ្តើមចោទសួរដល់គាត់ ។

សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវយ៉ូហាន ៩:១៨រកមើលថ្ងៃដែលព្រះអង្គសង្គ្រោះបានព្យាបាលបុរសខ្វាក់ភ្នែក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា ពួកផារិស៊ីបានមានប្រតិកម្មយ៉ាងណាចំពោះព្រះយេស៊ូវដែលបានព្យាបាលបុរសនោះនៅថ្ងៃឈប់សម្រាក ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ៩:១៦–៣៨ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរឿងអាក្រក់ផ្សេងទៀត ដែលបុរសបានទទួលការព្យាបាលនោះបានជួប ។

ជំនួសឲ្យសិស្សអាន អ្នកអាចបង្ហាញវីដេអូ« ព្រះយេស៊ូវព្យាបាលបុរសខ្វាក់ភ្នែកពីកំណើត »បន្ត (លេខកូដម៉ោង ៣:៣៧–៧:៤៧) ។ សូមណែនាំសិស្សឲ្យរកមើលរឿងអាក្រក់ផ្សេងទៀត ដែលបុរសបានទទួលការព្យាបាលនោះបានជួប ។

សូមជួយរៀបចំសិស្សឲ្យប្រាប់នូវគោលការណ៍មួយមកពីដំណើររឿងនេះ ដោយរំឭកពួកគេថា ឪពុកម្តាយរបស់បុរសខ្វាក់ភ្នែកនេះ ត្រូវបានគេនាំទៅខាងមុខពួកផារិស៊ីដើម្បីចោទសួរ ។

- ស្របតាមខ ២២ហេតុអ្វីក៏ឪពុកម្តាយរបស់បុរសខ្វាក់ភ្នែកនេះ ទុកឲ្យកូនប្រុសរបស់ពួកគេពន្យល់អំពីរបៀបដែលគាត់អាចមើលឃើញវិញដូច្នេះ ?

ចូរពន្យល់ថា « សាលាជំនុំប្រើជាមណ្ឌលសាសនា និងសង្គមសម្រាប់សហគមន៍យូដាជាច្រើន ។ សាលាជំនុំផ្តល់នូវលទ្ធភាពទទួលបានការណែនាំខាងវិញ្ញាណ និងការថ្វាយបង្គំ ក៏ដូចជាឱកាសខាងការអប់រំ និងខាងសង្គមផងដែរ ។ ដោយសារតែសាលាជំនុំសំខាន់យ៉ាងខ្លាំងចំពោះសង្គមសាសន៍យូដា ដូច្នេះការបណ្តេញចេញពីសាលាជំនុំ . . . គឺលើសពីការកាត់កាល និងការបាត់បង់ការរាប់អានជាមួយនឹងសហគមន៍សាសនាទៅទៀត ។ វាមានន័យថា ជាការនិរទេសចេញពីកិច្ចការខាងវប្បធម៌ និងខាងសង្គមផងដែរ ។ ការគម្រាមគំហែងនេះ បានបង្ហាញនូវភាពធ្ងន់ធ្ងរលួមគ្រប់គ្រាន់ ដែលនឹងធ្វើឲ្យឪពុកម្តាយរបស់បុរសដែលខ្វាក់ភ្នែកពីកំណើតនោះ មិនចង់ទាក់ទងនៅក្នុងការសើបអង្កេតអំពី ‖ រឿងការព្យាបាលរបស់កូនប្រុសពួកគាត់ ‖ » (*New Testament Student Manual* ‖ Church Educational System manual, ឆ្នាំ ២០១៤ ‖ ទំព័រ ២៣០) ។

- ស្របតាមខ ២៤តើសម្តែងអ្វីខ្លះ ដែលអ្នកគិតថាបុរសដែលបានទទួលការព្យាបាលនោះបានជួបប្រទះ ?

សូមអញ្ជើញសិស្សឲ្យអានខទី ៣០–៣៣ដោយស្ងាត់ស្ងៀម រួមទាំងការស្រង់ចេញមកពីការបកប្រែរបស់ យ៉ូសែប ស៊្មីធ យ៉ូហាន ៩:៣២ ហើយរកមើលចម្លើយរបស់បុរសនោះចំពោះពួកផារិស៊ី ។

- តើមូលហេតុអ្វីខ្លះ ដែលបុរសនោះប្រើដើម្បីការពារព្រះយេស៊ូវ ? (អ្នកអាចនឹងចង់ឲ្យយោបល់សិស្សគូសចំណាំពាក្យរបស់គាត់នៅក្នុង ខទី ៣៣) ។
- តើបុរសនេះដឹងអ្វីខ្លះ អំពីព្រះយេស៊ូវគ្រីស្ទ ?

សូមចង្អុលបង្ហាញថាបុរសនេះត្រូវបានបណ្តេញចេញពីសាលាជំនុំ ពីព្រោះតែការពារដល់មនុស្សដែលបានព្យាបាលគាត់ដោយពុំខ្លាច (សូមមើលខទី ៣៨) ។

- ហេតុអ្វីអ្នកគិតថា បុរសនេះមានឆន្ទៈស្មោះត្រង់ចំពោះអ្វីដែលគាត់បានដឹងអំពីព្រះយេស៊ូវគ្រីស្ទ ទោះជានឹងត្រូវបានបណ្តេញចេញពីសាលាជំនុំក៏ដោយនោះ ?

សូមរំឭកសិស្សថា បន្ទាប់ពីបុរសនោះត្រូវបានបណ្តេញចេញពីសាលាជំនុំ ព្រះអង្គសង្គ្រោះបានរកឃើញគាត់ ហើយបានសួរគាត់ថា « តើអ្នកជឿដល់ព្រះរាជបុត្រានៃព្រះឬទេ » (ខ ទី ៣៥) ។ សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ៩:៣៦–៣៨ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលការឆ្លើយតបរបស់បុរសនោះ ។

- តើមានអ្វីកើតឡើង ចំពោះទីបន្ទាល់របស់បុរសនេះអំពីព្រះយេស៊ូវគ្រីស្ទ ? (គាត់បានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ) ។
- តើមានគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីបុរសនេះ អំពីការបន្តស្មោះត្រង់ចំពោះអ្វីដែលយើងដឹងនោះ ? (សិស្សអាចនឹងប្រាប់ពីគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថា ពួកគេយល់គោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងបន្តនៅស្មោះត្រង់ចំពោះអ្វីដែលយើងដឹង ដោយពុំគិតពីការផ្ទុយ នោះទីបន្ទាល់របស់យើងនឹងត្រូវបានពង្រឹង ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សយល់កាន់តែល្អប្រសើរអំពីរឿងនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានអេធើរ ១២:៦ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលបានកើតឡើង បន្ទាប់ពីយើងបន្តនៅតែមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ នៅពេលយើងជួបនឹងការផ្ទុយចំពោះសេចក្តីជំនឿរបស់យើងនោះ ។

- ហេតុអ្វីអ្នកគិតថាទីបន្ទាល់របស់យើងត្រូវបានពង្រឹង បន្ទាប់ពីទប់ទល់នឹងដំណើរការផ្ទុយ ឬការសាកល្បងនៃសេចក្តីជំនឿនោះ ?
- តើទីបន្ទាល់របស់អ្នកត្រូវបានពង្រឹង ដោយសារតែការផ្ទុយយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សស្គាល់គោលការណ៍ផ្សេងទៀតមកពីដំណើររឿងនេះ ចូរសួរថាតើមានសិស្សប៉ុន្មាននាក់ដែលប្រើកញ្ចក់កែវភ្នែកត្រឹមត្រូវ (ដូចជាវ៉ែនតា ឬកញ្ចក់កែវភ្នែក) ។

- តើកញ្ចក់កែវភ្នែកទាំងនេះធ្វើអ្វីខ្លះ ចំពោះការមើលឃើញរបស់អ្នក ?
- តើការមើលឃើញដោយភ្នែកខាងសាច់ឈាមរបស់បុរសនេះដូចម្តេច បន្ទាប់ពីព្រះយេស៊ូវបានព្យាបាលគាត់ ?
- តើការមើលឃើញ ឬការយល់ដឹងខាងវិញ្ញាណរបស់បុរសនេះអំពីព្រះអង្គសង្គ្រោះ ត្រូវបានកែតម្រូវ និងកែលម្អយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យអានយ៉ូហាន ៩:១១, ១៧, ៣៣ដោយស្ងាត់ស្ងៀម ហើយរកមើលឃ្លាដែលពិពណ៌នាអំពីការមើលឃើញ ឬការយល់ដឹងរបស់បុរសនេះអំពីព្រះយេស៊ូវជានរណា ។ ចូរសុំពួកគេឲ្យរាយការណ៍ពីអ្វី ដែលពួកគេរកឃើញ ។ (ចម្លើយរបស់ពួកគេគួរតែរួមមាន « បុរសនេះដែលត្រូវបានហៅនាមថា ព្រះយេស៊ូវ » « ជាព្យាការីម្នាក់ » និងជាមនុស្ស « របស់ព្រះ » ។ សូមសរសេរឃ្លាទាំងនេះនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យគូសចំណាំវានៅលើគម្ពីររបស់ពួកគេ)។

- ស្របតាមឃ្លាទាំងនេះ តើមានអ្វីកើតឡើងចំពោះការមើលឃើញខាងវិញ្ញាណរបស់បុរសនេះ ? (វាត្រូវបានកែតម្រូវ ហើយកែលម្អ ។ ឃ្លាទាំងនេះឆ្លុះបញ្ចាំងអំពីការរីកចម្រើននៃភាពចាស់ទុំខាងវិញ្ញាណរបស់បុរសនេះ និងការយល់ពីអត្តសញ្ញាណពិតរបស់ព្រះយេស៊ូវ) ។
- ហេតុអ្វីអ្នកគិតថា ការមើលឃើញ និងការយល់ដឹងរបស់គាត់អំពីព្រះយេស៊ូវបានឃើញកាន់តែច្បាស់ដូច្នេះ? (គាត់បានអនុវត្តសេចក្តីជំនឿដោយការនៅតែមានចិត្តស្មោះត្រង់ចំពោះអ្វីដែលគាត់បានដឹង) ។

ចូរសុំឲ្យសិស្សមើលត្រួសៗយ៉ូហាន ៩:៣៦–៣៨ ដោយរកមើលរបៀប ដែលបុរសនេះបានមើលឃើញព្រះអង្គសង្គ្រោះនៅទីបំផុត ។

- តើបុរសនេះបានមើលឃើញព្រះអង្គសង្គ្រោះដូចម្តេច នៅទីបំផុតនោះ ? (គាត់បានដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ) ។
- តើការមើលឃើញរបស់បុរសនេះបានភ្លឺច្បាស់យ៉ាងណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលនូវអ្វីដែលប្រធាន ហ៊ីនធើរ បានមានប្រសាសន៍ថាបានកើតឡើងចំពោះបុរសនេះ ។

« ឥឡូវការមើលឃើញត្រូវបានផ្តល់ឲ្យ*ពីរដង*—ម្តងគឺដើម្បីព្យាបាលភាពពិការពីកំណើត (ភាពពិការខាងសាច់ឈាមពីកំណើត) និងម្តងទៀត ដើម្បីមើលឃើញស្តេចអស់ទាំងស្តេចពីមុនទ្រង់យាងទៅបល្ល័ង្កដ៏អស់កល្បជានិច្ចរបស់ទ្រង់ ។ ព្រះយេស៊ូវបានប្រោសការមើលឃើញទាំងខាងសាច់ឈាម *និង*ខាងវិញ្ញាណ » (« The God That Doest Wonders »*Ensign* **ខែ ឧសភា ឆ្នាំ ១៩៨៩** ទំព័រ ១៦–១៧) ។

- តើការព្យាបាលរបស់បុរសនោះពីការខ្វាក់ភ្នែកខាងសាច់ឈាម តំណាងឲ្យការព្យាបាលពីការខ្វាក់ភ្នែកខាងវិញ្ញាណយ៉ាងដូចម្តេច ?
- តើមានគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីដំណើររឿងនេះ អំពីអ្វីដែលអាចកើតមានឡើងចំពោះយើង នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះភែវភ្នែកខាងវិញ្ញាណ និងការយល់ដឹងរបស់យើងមើលឃើញកាន់តែច្បាស់ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- ហេតុអ្វីក៏អ្នកគិតថាការអនុវត្តសេចក្តីជំនឿ ចាំបាច់ដើម្បីមើលឃើញ និងយល់ពីសេចក្តីពិតខាងវិញ្ញាណកាន់តែច្បាស់ ?

ចូរពន្យល់ថា ពួកជាវ៉ាស៊ីមួយចំនួនបានឈរនៅជិតនោះ នៅពេលបុរសនោះបានជួប ហើយបានថ្វាយបង្គំព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ៩:៣៩–៤១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនអំពីភាពខ្វាក់ ។

- តើអ្នកនឹងសង្ខេបអំពីអ្វី ដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកជាវ៉ាស៊ីយ៉ាងដូចម្តេច ?

ចូរពន្យល់ថានៅក្នុងការឆ្លើយតបចំពោះសំណួររបស់ពួកជាវ៉ាស៊ី « តើយើងរាល់គ្នាខ្វាក់ដែរឬអី ? » (ខ ៤០) « ព្រះអង្គសង្គ្រោះបានប្រើការប្រៀបធៀបមួយ ដែលបង្រៀនថាបុគ្គលម្នាក់ៗដែល ‹ ខ្វាក់ › —ជាអ្នកទាំងឡាយដែលពុំដឹងថាទ្រង់—‹ ឥតមានបាប › (យ៉ូហាន ៩:៤១) ។ ផ្ទុយទៅវិញ បុគ្គលម្នាក់ៗដែលអាច ‹ មើលឃើញ ›—ជាអ្នកទាំងឡាយដែលបានទទួលសាក្សីគ្រប់គ្រាន់អំពីព្រះអង្គសង្គ្រោះ និងបេសកកម្មដ៏ទេវភាពរបស់ទ្រង់ដែលពួកគេបានស្គាល់ថាទ្រង់ជានរណា—នឹងទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ ។ ពួកជាវ៉ាស៊ីនៅក្នុងចំណោមអស់អ្នកដែលអាច ‹ មើលឃើញ › ហើយ ‹ នៅតែមានអំពើបាប › របស់ពួកគេ ។ និយាយពីខាងវិញ្ញាណ ពួកគេបានជ្រើសរើសធ្វើជាខ្វាក់ ដោយសារតែពួកគេបដិសេធមិនទទួលស្គាល់ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ទោះជាពួកគេបានទទួលសាក្សីជាច្រើនក្តី » (New Testament Student Manual ទំព័រ ២៣១) ។

ដើម្បីបញ្ចប់ សូមអញ្ជើញសិស្សឲ្យមើលគោលការណ៍ពីរនៅលើក្តារខៀន ហើយពិចារណាថាមួយណាដែលពួកគេមានអារម្មណ៍ថាពួកគេគួរតែអនុវត្តតាមនៅក្នុងជីវិតរបស់ពួកគេ (ពួកគេអាចមានអារម្មណ៍ចាំបាច់ត្រូវអនុវត្តគោលការណ៍ទាំងពីរផងដែរ) ។ សូមផ្តល់ពេលដល់សិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបដែលពួកគេនឹងអនុវត្តគោលការណ៍នេះ ។ សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានសុំការណែនាំអំពីរបៀបដើម្បីធ្វើការណ៍នេះ ។

ជួយសិស្សឲ្យអនុវត្តគោលទ្ធិ និងគោលការណ៍ទាំងឡាយ

នៅពេលសិស្សអនុវត្តគោលការណ៍ទាំងឡាយនៃដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេ នោះពួកគេនឹងទទួលបានពរជ័យដែលបានសន្យាទាំងឡាយ ។ សូមផ្តល់ពេលដល់សិស្សនៅក្នុងថ្នាក់ដើម្បីពិចារណា ឬ សរសេរអំពីអ្វីដែលពួកគេបានយល់ និងមានអារម្មណ៍ ហើយពិចារណាទៅលើសកម្មភាពជាក់លាក់ ដែលពួកគេគួរតែធ្វើដើម្បីអនុវត្តគោលការណ៍មួយ ។ នៅពេលវេលាដូច្នេះ សូមលើកទឹកចិត្តសិស្សឲ្យសុំការណែនាំមកពីព្រះអម្ចាស់ ។

មេរៀន ៧០

យ៉ូហាន ១០

សេចក្តីផ្តើម

ព្រះយេស៊ូវបានបង្រៀនថា ទ្រង់គឺជាអ្នកគង្វាលល្អ ហើយថាទ្រង់នឹងលះបង់ជីវិតរបស់ទ្រង់ដើម្បីចៀមរបស់ទ្រង់ ។ ទ្រង់ក៏បានថ្លែងទីបន្ទាល់ថា ព្រះវរបិតាសួគ៌បានប្រទានអំណាចឲ្យយកឈ្នះលើសេចក្តីស្លាប់ដល់ទ្រង់ផងដែរ ។ មនុស្សមួយចំនួនបានចោទព្រះយេស៊ូវអំពីថាទ្រង់ប្រមាថព្រះ ដោយសារតែការប្រកាសថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១០:១–២៤

ព្រះយេស៊ូវបានបង្រៀនថា ទ្រង់គឺជាអ្នកគង្វាលល្អ ហើយថាទ្រង់នឹងលះបង់ជីវិតរបស់ទ្រង់ដើម្បីប្រជារាស្ត្ររបស់ទ្រង់

សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកខាងមុខក្តារខៀន ។ ចូរយកកន្សែងបិទមុខសិស្ស រួចប្រមូលព្រះគម្ពីរបឹបូនក្បាល រួមទាំងព្រះគម្ពីររបស់សិស្សដែលបានបិទមុខនោះផងដែរ ។ ចូរសុំឲ្យសិស្សដែលបានបិទមុខជិតនោះស្ទាបព្រះគម្ពីរនីមួយៗ ហើយសាកល្បងសម្រេចថាតើព្រះគម្ពីរមួយណាជារបស់ខ្លួន ។ បន្ទាប់ពីសិស្សនោះបានសាកល្បងធ្វើកិច្ចការនោះមក ចូរសួរ ៖

- ហេតុអ្វីអ្នកអាច (ឬមិនអាច) សម្រេចថា ព្រះគម្ពីរមួយណាជារបស់ខ្លួន ?
- ប្រសិនបើខ្ញុំឲ្យអ្នកស្ទាបមុខមិត្តរួមថ្នាក់ម្នាក់ៗ តើអ្នកគិតថា អ្នកអាចស្មានដឹងត្រូវបានប៉ុន្មាននាក់ ? (ចូរកុំសុំឲ្យសិស្សធ្វើរឿងនេះ) ។

សូមអញ្ជើញសិស្សឲ្យដោះកន្សែងចេញ ហើយត្រឡប់ទៅកន្លែងអង្គុយរបស់ខ្លួនវិញ ។ សូមពន្យល់ថា មានគ្រាមួយអ្នកគង្វាលនៅក្នុងបញ្ជីមប្រទេសត្រូវបានគេទទួលថា តើគាត់ស្គាល់ចៀមរបស់គាត់ច្បាស់ប៉ុណ្ណា ។ គាត់បានឆ្លើយថា « ប្រសិនបើអ្នកយកក្រណាត់មកបិទភ្នែករបស់ខ្ញុំ ហើយយកចៀមណាមួយក៏បាន ហើយគ្រាន់តែឲ្យខ្ញុំដាក់ដៃលើមុខរបស់វា នោះខ្ញុំអាចប្រាប់ភ្លាមថាវាជាចៀមរបស់ខ្ញុំ ឬមិនមែនជាចៀមរបស់ខ្ញុំ (ជី អិម ម៉ាក់គី *Bible Manners and Customs* | គ្មានកាលបរិច្ឆេទ | ទំព័រ ៣៥) ។

- ប្រសិនបើអ្នកគឺជាអ្នកគង្វាល តើអ្នកគិតថា អ្នកធ្វើអ្វីដើម្បីស្គាល់ចៀមនៅក្នុងហ្វូងចៀមរបស់អ្នក ដូចដែលអ្នកគង្វាលចៀមម្នាក់នេះបានធ្វើ ?

សូមអញ្ជើញសិស្សអាន យ៉ូហាន ១០:១៤ ដោយស្ងៀមស្ងាត់ ហើយរកមើលអ្វី ដែលព្រះយេស៊ូវបានហៅដល់អង្គទ្រង់ ។ ចូរសុំពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរសេចក្តីថ្លែងការណ៍នេះនៅលើក្តារខៀន ៖ *ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគង្វាលល្អ* ។

- ហេតុអ្វីអ្នកគិតថា « អ្នកគង្វាលល្អ » គឺជាងារមួយដ៏សមត្រឹមត្រូវសម្រាប់ព្រះអង្គសង្គ្រោះ ?

កាលសិស្សសិក្សា យ៉ូហាន ១០ សូមលើកទឹកចិត្តពួកគេឲ្យរកមើលសេចក្តីពិត ដែលបង្រៀនយើងពីរបៀបដែលព្រះអង្គសង្គ្រោះគឺជាអ្នកគង្វាលដ៏ល្អរបស់យើង ។

ដើម្បីជួយសិស្សឲ្យយល់ពី មជ្ឈដ្ឋាន វប្បធម៌នៅក្នុង យ៉ូហាន ១០:១–៥សូមពន្យល់ថា នៅសម័យព្រះអង្គសង្គ្រោះ ពួកអ្នកគង្វាលបាននាំហ្វូងសត្វរបស់ខ្លួនទៅរកស៊ី ជីកទឹក ហើយសម្រាកនៅពេលថ្ងៃ ។ នៅពេលយប់ អ្នកគង្វាលមួយចំនួនកៀងហ្វូងចៀមរបស់ខ្លួនទៅក្រោលរួមគ្នាមួយ ។ ក្រោលចៀមគឺជារូងមួយ ឬបរិវេណដែលមានជញ្ជាំងថ្មបិទជុំជិត ដែលមានបន្លាមុតស្រួចដាក់នៅខាងលើចុងចម្រឹងជញ្ជាំងនោះ ដើម្បីការពារសត្វព្រៃចូលមកក្នុងក្រោល ។

សូមចែកសិស្សជាគូ ។ សូមអញ្ជើញដៃគូនីមួយៗអាន យ៉ូហាន ១០:១–៥ ឲ្យឮៗរួមគ្នា ហើយរកមើលអ្វីដែលអ្នកគង្វាលល្អធ្វើ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីអ្វី ដែលពួកគេបានរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ក្រោមឃ្លា *ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគង្វាលល្អ* ។ (ចម្លើយអាចរួមមានដូចខាងក្រោម ៖ ទ្រង់យាងចូលតាមទ្វារ ទ្រង់ហៅចៀមរបស់ទ្រង់តាមឈ្មោះ ហើយទ្រង់នៅពីមុខចៀមរបស់ទ្រង់) ។

- យោងតាម ខទី ៣តើអ្នកគង្វាលនាំចៀមខ្លួនចេញពីក្រោលតាមរបៀបណា ?
- យោងតាម ខទី ៤–៥ហេតុអ្វីបានជាចៀមធ្វើតាមតែអ្នកគង្វាលនេះប៉ុណ្ណោះ ?
- តើព្រះអង្គសង្គ្រោះបានហៅ អស់អ្នកដែលព្យាយាមចូលទៅក្នុងក្រោលតាមផ្លូវផ្សេងក្រៅពីទ្វារចូលនោះ ថាដូចម្តេច ?

សូមពន្យល់ថា ពួកផារិស៊ីស្ថិតនៅក្នុងចំណោមក្រុមមនុស្សដែលព្រះយេស៊ូវកំពុងមានបន្ទូល (សូមមើល យ៉ូហាន ៩:៤១) ។

- តើពួកផារិស៊ីប្រៀបបាននឹងពួកចោរឆក់ ពួកចោរប្លន់ និងពួកមនុស្សចំឡែកនៅក្នុងក្រោលបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សអានយ៉ូហាន ១០:៦ដោយស្ងាត់ស្ងៀម ហើយរកមើលការឆ្លើយតបរបស់ពួកផារិស៊ី ទៅនឹងការបង្រៀនព្រះអង្គសង្គ្រោះ ។ ចូរសុំពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ជួយសិស្សឲ្យយល់អំពីមជ្ឈដ្ឋានវប្បធម៌

ពួកអ្នកនិពន្ធព្រះគម្ពីរបានសរសេរដោយមានការដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ប៉ុន្តែពាក្យពេចន៍ និងរូបភាព ដែលពួកគេម្នាក់ៗប្រើបានរងឥទ្ធិពលពីវប្បធម៌របស់ពួកគេ ។ ការជួយសិស្សឲ្យយល់ពីវប្បធម៌នេះអាចបញ្ជាក់យ៉ាងច្បាស់ ហើយធ្វើឲ្យការយល់ដឹងរបស់ពួកគេអំពីរូបភាព ដំណើររឿង ការបង្រៀន គោលលទ្ធិ និងគោលការណ៍នានានៅក្នុងព្រះគម្ពីរកាន់តែមានភាពសម្បើម ។

ដូចដែលបានកត់ត្រានៅក្នុង យ៉ូហាន ១០:៧–១៦ ចូរពន្យល់ថា ព្រះអង្គសង្គ្រោះបានបន្តបង្រៀនអំពីភាពខុសគ្នារវាងទ្រង់ និងពួកផារិស៊ី ។ សូមអញ្ជើញសិស្សម្នាក់អាន ខទី ៧–១០ ឲ្យឮៗ រួមទាំងការបកប្រែដោយយ៉ូសែប ស៊្មីធនៅក្នុងខទី ៨ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការបង្រៀនរបស់ព្រះយេស៊ូវនៅក្នុងខគម្ពីរទាំងនេះ ។

- តើគំនិតសឹងជម្រៅបន្ថែមទៀតអ្វីខ្លះ ដែលការបកប្រែដោយយ៉ូសែប ស៊្មីធ នៅក្នុង ខទី ៨ បានផ្តល់ឲ្យ ?
- តើអ្នកគិតថា ព្រះអង្គសង្គ្រោះមានន័យយ៉ាងណា នៅពេលទ្រង់មានបន្ទូលថា « ខ្ញុំគឺជាទ្វារ » (ខទី ៧, ៩) ?

សូមពន្យល់ថា « អ្នកគង្វាលនៅអឺស្រាអែលឈរនៅច្រកចូលនៃក្រោលចៀម ហើយត្រួតពិនិត្យមើលចៀមនីមួយៗ នៅពេលវាដើរចូលក្រោល ហើយព្យាបាលរបួសតាមការចាំបាច់ ។ បន្ទាប់ពីចៀមត្រូវបានកៀងចូលក្រោលនៅពេលយប់រួចហើយ នោះអ្នកគង្វាលនឹងដេកនៅច្រកទ្វារ ជារបាំងការពារផ្លូវប្រយោជន៍កុំឲ្យសត្វសាហាវ ឬ ចោរលួចអាចធ្វើបាបចៀមខ្លួន » (*New Testament Student Manual* | Church Educational System manual ឆ្នាំ ២០១៤ | ទំព័រ ២៣១–៣២) ។

- តើសកម្មភាពរបស់អ្នកគង្វាលទាំងនេះស្រដៀងគ្នាទៅនឹងអ្វី ដែលព្រះអង្គសង្គ្រោះបានធ្វើចំពោះយើងដូចម្តេចទៅ ?
- តើអ្នកគិតថា ព្រះអង្គសង្គ្រោះប្រទានព្រះជន្មទ្រង់ « ពេញបរិបូរណ៍ » (យ៉ូហាន ១០:១០) ដល់អស់អ្នកដែលធ្វើតាមទ្រង់ដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១០:១១–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីផ្សេងទៀត ដែលព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលពីអ្នកគង្វាលល្អធ្វើ ។ ចូរចង្អុលបង្ហាញថា អ្នកសឹឈ្នួលម្នាក់ គឺជាមនុស្សដែលជំរុញចិត្តខ្លួនឲ្យធ្វើការងារដើម្បីទទួលបានប្រាក់កម្រៃតែប៉ុណ្ណោះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឡើងមកក្តារខៀន ហើយសរសេរនូវអ្វីផ្សេងទៀតដែលពួកគេបានរកឃើញអំពីអ្នកគង្វាលល្អ នៅក្រោម *ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគង្វាលល្អ* ។ (ចម្លើយអាចរួមមានដូចខាងក្រោម ៖ ទ្រង់លះបង់ជីវិតសម្រាប់ចៀមរបស់ទ្រង់ ទ្រង់ស្គាល់ចៀមរបស់ទ្រង់ ហើយចៀមរបស់ទ្រង់ស្គាល់ទ្រង់) ។

- តើអ្វីទៅដែលអ្នកគង្វាលម្នាក់សុខចិត្តធ្វើ ប៉ុន្តែអ្នកសឹឈ្នួលពុំព្រមធ្វើ ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀន អំពីព្រះអង្គសង្គ្រោះមកពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ក្នុងនាមជាអ្នកគង្វាលល្អមួយរូប ព្រះយេស៊ូវគ្រីស្ទស្គាល់ពួកយើងម្នាក់ៗ ហើយថ្វាយព្រះជន្មរបស់ទ្រង់សម្រាប់ពួកយើង ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ក្រោមឃ្លា *ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគង្វាលល្អ*) ។

សូមអំពាវនាវសិស្សពីអ្នកគង្វាលនៅបញ្ជឹមប្រទេស ដែលបានស្គាល់កូនចៀមនីមួយៗរបស់ខ្លួនផងដែរ ។

- តើអ្នកគិតថា ព្រះអង្គសង្គ្រោះស្គាល់អ្នកច្បាស់ប៉ុណ្ណា ?
- តើរបៀបដែលអ្នករស់នៅសព្វថ្ងៃអាចត្រូវបានប្រែប្រួលយ៉ាងណាខ្លះ ដោយដឹងថាព្រះអង្គសង្គ្រោះស្គាល់អ្នក ហើយមានព្រះឆន្ទៈថ្វាយព្រះជន្មទ្រង់សម្រាប់អ្នកដូច្នេះ ?

សូមពន្យល់ថា បន្ទាប់ពីទ្រង់បានបង្រៀនថា ទ្រង់នឹងលះបង់ព្រះជន្មរបស់ទ្រង់សម្រាប់យើង នោះព្រះអង្គសង្គ្រោះបានចង្អុលបង្ហាញពីរឿងមួយផ្សេងទៀតដែលទ្រង់នឹងធ្វើ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១០:១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីផ្សេងទៀត ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់នឹងធ្វើសម្រាប់ចៀមរបស់ទ្រង់ (មានន័យថា រាស្ត្ររបស់ទ្រង់) ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់នឹងធ្វើអ្វីខ្លះសម្រាប់ចៀមរបស់ទ្រង់ ?
- តើខគម្ពីរនេះចង្អុលបង្ហាញអ្វីខ្លះអំពីទីតាំងរបស់ចៀមទ្រង់ ?

សូមពន្យល់ថា ព្រះអង្គសង្គ្រោះកំពុងបង្រៀនពួកសាសន៍យូដានៅក្នុងក្រុងយេរូសាឡិមថា ទ្រង់នឹងជួបកូនចៅរបស់ព្រះនៅទឹកដីផ្សេងទៀត បង្រៀនពួកគេអំពីដំណឹងល្អទ្រង់ ហើយនាំពួកគេចូលមកឯហ្វូងចៀមទ្រង់ (សាសនាចក្រទ្រង់) ។ សូមពន្យល់ថា ព្រះគម្ពីរមរមនបានពន្យល់អំពីខគម្ពីរនេះ ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានខគម្ពីរនៅក្នុង នីហ្វៃទី ៣ ១៥:១៥–១៧, ២១, ១៦:១–៣ ។ អ្នកគួរស្នើឲ្យសិស្សសរសេរសេចក្តីយោងនេះនៅក្បែរ ឬ នៅក្បែរ យ៉ូហាន ១០:១៦ ។

- តើខគម្ពីរទាំងនេះជួយយើងយល់កាន់តែច្បាស់ពី យ៉ូហាន ១០:១៦បានដោយរបៀបណា ? (ពាក្យ « ចៀមផ្សេងទៀត » សំដៅទៅលើពួកសាសន៍នីហ្វៃ និងពួកអំបូរដែលវង្វេង ពុំមែនពួកសាសន៍ដទៃទេ) ។

ចូរសុំឲ្យសិស្សអាន យ៉ូហាន ១០:១៧–១៨ ដោយរកមើលគោលលទ្ធិមួយអំពីព្រះអង្គសង្គ្រោះ ។ សុំឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ក្នុងនាមជាព្រះរាជបុត្រានៃព្រះ ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាដើម្បីដាក់ព្រះជន្មទ្រង់ចុះ ហើយយកមកវិញបាន ។** សូមលើកទឹកចិត្តសិស្សឲ្យគូសចំណាំពាក្យទាំងឡាយ ដែលបង្រៀនអំពីគោលការណ៍នេះនៅក្នុងខគម្ពីរទាំងនេះ) ។

- ហេតុអ្វីព្រះអង្គសង្គ្រោះមានទាំងលទ្ធភាពដើម្បីសុគត និងលទ្ធភាពដើម្បីមានព្រះជន្មរស់ឡើងវិញបន្ទាប់ពីសុគតដូច្នេះ ? (មកពីមាតាទ្រង់ ម៉ារា ជាស្ត្រីដែលជីវិតរមែងស្លាប់ នោះព្រះយេស៊ូវគ្រងមរតកនៃមតភាពរួមមាននូវសមត្ថភាពដែលអាចស្លាប់ ។ មកពីអេឡូហិម ជាព្រះវរបិតារបស់ទ្រង់ នោះទ្រង់គ្រងមរតកនៃអមតៈភាព និង ព្រះចេស្តាដើម្បីរស់នៅជារៀងរហូត ។ ហេតុដូច្នេះហើយទ្រង់បានគ្រងមរតកនូវលទ្ធភាពដើម្បីសុគត ហើយមានព្រះជន្មឡើងវិញ ដែលជាកត្តាចាំបាច់ដើម្បីឲ្យព្រះយេស៊ូវអាចមានលទ្ធភាពធ្វើដង្វាយធួនបាន ។ | សូមមើលមេរៀនស្តីពី ម៉ាថាយ ១–២ |) ។

សូមសង្ខេប យ៉ូហាន ១០:១៩–២៤ ដោយពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានបង្រៀនការណ៍ទាំងនេះហើយ នោះមនុស្សបានខ្វែងគំនិតគ្នា ថាតើព្រះយេស៊ូវគឺជានរណា ។ ពួកគេបានមកអរព្រះយេស៊ូវនៅឯព្រះវិហារបរិសុទ្ធ ហើយបានបង្ខំទ្រង់ឲ្យប្រាប់ពីអត្តសញ្ញាណពិតរបស់ទ្រង់ថាជាព្រះគ្រីស្ទ ។

យ៉ូហាន ១០:២៥–៤២

ព្រះយេស៊ូវប្រកាសថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ

សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យឡើងមកខាងមុខក្តារខៀន ។ ចូរយកកន្សែងបិទមុខសិស្សម្នាក់នោះ រួចប្រាប់ឲ្យសិស្សបីបួននាក់ផ្សេងទៀតប្តូរវេនគ្នានិយាយពាក្យមួយជាក់លាក់ (ឧទាហរណ៍ « អ្នកគង្វាល ») ។ ចូរសុំឲ្យសិស្សដែលបិទមុខជិតស្តាប់ទៅសិស្សម្នាក់ៗ ដែលនិយាយពាក្យនោះ ហើយសម្រេចថាតើគាត់អាចស្គាល់សិស្សដែលនិយាយពាក្យនោះបានដែរឬអត់ តាមរយៈសំឡេងរបស់ពួកគេ ។

- ហេតុអ្វីមានសំឡេងខ្លះ ងាយនឹងស្គាល់ជាងសំឡេងដទៃទៀត ?

សូមប្រាប់សិស្សនោះឲ្យដោះកន្សែងចេញ ហើយត្រឡប់ទៅកន្លែងអង្គុយវិញ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១០:២៥–៣០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការឆ្លើយតបរបស់ព្រះអង្គសង្គ្រោះចំពោះសំណួររបស់ប្រជាជន ឲ្យប្រាប់ពួកគេថាតើទ្រង់គឺជាព្រះគ្រីស្ទមែន ឬ មិនមែន ។

- តើព្រះអង្គសង្គ្រោះបានពិពណ៌នាយ៉ាងដូចម្តេចខ្លះអំពីចៀមរបស់ទ្រង់ ? (ចៀមរបស់ព្រះអង្គសង្គ្រោះស្តាប់សំឡេងទ្រង់ ហើយដើរតាមទ្រង់) ។
- យោងតាម ខទី ២៨តើអ្នកដែលស្តាប់តាមសំឡេងរបស់ព្រះអង្គសង្គ្រោះ ហើយដើរតាមទ្រង់នឹងទទួលបានអ្វី ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងរកឃើញគោលការណ៍ខុសៗគ្នា ប៉ុន្តែត្រូវប្រាកដដើម្បីគូសបញ្ជាក់ថា **ប្រសិនបើយើងស្តាប់សំឡេងនៃអ្នកគង្វាលល្អ ហើយធ្វើតាមទ្រង់ នោះទ្រង់នឹងដឹកនាំយើងឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ក្រោមឃ្លា *ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគង្វាលល្អ* ។ អ្នកគួរណែនាំសិស្សឲ្យសរសេរគោលការណ៍នេះ នៅរឹមទំព័រព្រះគម្ពីររបស់ពួកគេក្បែរ យ៉ូហាន ១០:២៧–២៨) ។

សូមរំឭកសិស្សពីសិស្សទីពីរដែលបានបិទមុខ និងលទ្ធភាពរបស់គាត់ក្នុងការស្គាល់សំឡេងមិត្តរួមថ្នាក់របស់ខ្លួន ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីស្គាល់សំឡេងរបស់ព្រះអង្គសង្គ្រោះ ? (សូមមើលផងដែរ គ. និង ស. ១៨:៣៤–៣៦) ។
- តើអ្នកបានធ្វើអ្វីខ្លះដើម្បីឲ្យកាន់តែស្គាល់សំឡេងរបស់ព្រះអង្គសង្គ្រោះ ?
- តើយើងអាចបង្ហាញថា យើងដើរតាមព្រះអង្គសង្គ្រោះតាមរបៀបណា ?

សូមទុកពេលឲ្យសិស្សសញ្ជឹងគិតអំពីរបៀប ដែលពួកគេអាចស្តាប់ឮសំឡេងរបស់ព្រះអង្គសង្គ្រោះហើយដើរតាមទ្រង់កាន់តែប្រសើរឡើង ។ សូមអញ្ជើញឲ្យសរសេរចំណុចមួយណាក៏បានក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ (១) គោលដៅមួយដើម្បីយកចិត្តទុកដាក់ស្តាប់កាន់តែច្រើនដល់សំឡេងរបស់ព្រះអង្គសង្គ្រោះ និង របៀបជាក់លាក់នានាដែលពួកគេអាចធ្វើបែបនោះបាន ឬ (២) គោលដៅ មួយដើម្បីធ្វើតាមសំឡេងរបស់ទ្រង់ឲ្យបានកាន់តែប្រសើរឡើង និង របៀបដែលពួកគេដាក់ផែនការដើម្បីធ្វើវា ។

សូមសង្ខេប យ៉ូហាន ១០:៣១–៤២ ដោយពន្យល់ថា បន្ទាប់ពីព្រះអង្គសង្គ្រោះបានថ្លែងទីបន្ទាល់ថាទ្រង់ និងព្រះវរបិតារបស់ទ្រង់គឺតែមួយ នោះពួកអ្នកដឹកនាំសាសន៍យូដាចង់យកដុំថ្មចោលដាក់ទ្រង់ ដោយសារការប្រើប្រមាថព្រះ ។ ប៉ុន្តែ ទ្រង់បានឆ្លើយតបចំពោះការចោទប្រកាន់របស់ពួកគេ ទំនុកដំកើង ៨២:៦ដែលអានថា « យើងបាននិយាយថា ឯងរាល់គ្នាជាព្រះ ហើយជាកូននៃព្រះដ៏ខ្ពស់បំផុតទាំងអស់គ្នា » ។ ក្រោយមកព្រះអង្គសង្គ្រោះបានសួរពួកសាសន៍យូដាថា ហេតុអ្វីពួកគេចោទទ្រង់អំពីការប្រើពាក្យប្រមាថដល់ព្រះ កាលទ្រង់មានព្រះបន្ទូលថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះនៅពេលដែលព្រះគម្ពីរចែងថា ពួកយើងគឺជាកូនចៅនៃព្រះ ហើយខ្លួនយើងអាចក្លាយដូចជាព្រះ ។

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ពីសេចក្តីពិត និងគោលការណ៍ដែលបានបង្រៀននៅក្នុង យ៉ូហាន ១០ ហើយលើកទឹកចិត្តសិស្សឲ្យអនុវត្តវា ។

មេរៀនសិក្សានៅផ្ទះ

យ៉ូហាន ៧–១០ (មេរៀនទី ១៤)

ការរៀបចំសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា យ៉ូហាន ៧–១០ (មេរៀនទី ១៤) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (យ៉ូហាន ៧)

ចេញពីការបង្រៀនរបស់ព្រះយេស៊ូវនៅយេរូសាឡិមអំឡុងពេលបុណ្យបារាំ នោះសិស្សបានរៀនថា ប្រសិនបើយើងធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ នោះយើងនឹងទទួលបាននូវទីបន្ទាល់ស្តីពីគោលលទ្ធិរបស់ទ្រង់ ។ ពួកគេក៏បានរកឃើញគោលការណ៍ផងដែរថា ប្រសិនបើយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយជឿលើទ្រង់ នោះយើងនឹងបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ។

ថ្ងៃទី ២ (យ៉ូហាន ៨)

នៅក្នុងដំណើររឿងអំពីស្ត្រីម្នាក់ដែលត្រូវបានគេនាំខ្លួនមកដោយធ្វើអំពើកំផិត សិស្សបានរៀនថា ការទទួលស្គាល់ភាពមិនល្អឥតខ្ចោះផ្ទាល់ខ្លួនអាចជួយយើងឲ្យចៀសផុតពីការថ្កោលទោសអ្នកដទៃ ហើយថាព្រះអង្គសង្គ្រោះបង្ហាញសេចក្តីមេត្តាដល់យើងតាមរយៈការប្រទានឱកាសឲ្យយើងប្រែចិត្ត ។ បន្ទាប់មកសិស្សបានរៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាពន្លឺនៃលោកិយ ហើយថាប្រសិនបើយើងដើរតាមព្រះអង្គសង្គ្រោះ យើងនឹងចៀសផុតពីភាពងងឹតខាងវិញ្ញាណ ហើយពោរពេញដោយពន្លឺរបស់ទ្រង់ ។ ពួកគេក៏បានរៀនផងដែរ អំពីគោលការណ៍ទាំងឡាយដូចតទៅនេះ ៖ នៅពេលយើងរៀនពីព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងស្គាល់ព្រះវរបិតា ។ ប្រសិនបើយើងបន្តនៅក្នុងបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងក្លាយជាសិស្សរបស់ទ្រង់ ហើយស្គាល់សេចក្តីពិត ដែលធ្វើឲ្យយើងមានសេរីភាព ។ ប្រសិនបើយើងប្រព្រឹត្តអំពើបាប ហើយពុំប្រែចិត្ត នោះយើងក្លាយជាបាវបម្រើរបស់អំពើបាបហើយ ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះយេហូវ៉ា ជាព្រះនៃព្រះគម្ពីរសញ្ញាចាស់ ។

ថ្ងៃទី ៣ (យ៉ូហាន ៩)

នៅក្នុង យ៉ូហាន ៩ សិស្សបានអានអំពីព្រះយេស៊ូវព្យាបាលបុរសម្នាក់ ដែលកើតមកងងឹតភ្នែក ។ នៅក្នុងដំណើររឿងនេះ ពួកគេបានរៀនពីសេចក្តីពិតដូចខាងក្រោម ៖ ព្រះអាចប្រើទុក្ខលំបាករបស់យើងដើម្បីបង្ហាញពីកិច្ចការ និងព្រះចេស្តារបស់ទ្រង់ ។ នៅពេលយើងបន្តមានចិត្តស្មោះត្រង់ ចំពោះអ្វីដែលយើងដឹងជាជាងបដិសេធវា នោះទីបន្ទាល់របស់យើងនឹងរឹងមាំ ។ នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះគ្រីស្ទ នោះការមើលឃើញ និង ការយល់ដឹងខាងវិញ្ញាណរបស់យើងប្រែកាន់តែច្បាស់ឡើង ។

ថ្ងៃទី ៤ (យ៉ូហាន ១០)

នៅក្នុងមេរៀននេះ សិស្សបានរៀនថា ក្នុងនាមជាអ្នកគង្វាលល្អ ព្រះយេស៊ូវគ្រីស្ទស្គាល់ពួកយើងម្នាក់ៗ ហើយថ្វាយព្រះជន្មរបស់ទ្រង់សម្រាប់ពួកយើង ។ ក្នុងនាមជាព្រះរាជបុត្រានៃព្រះ ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាដាក់ព្រះជន្មទ្រង់ចុះ ហើយលើកវាឡើងជាថ្មីវិញបាន ។ សិស្សក៏ស្គាល់ពីគោលការណ៍ថា ប្រសិនបើយើងស្គាល់សំឡេងនៃអ្នកគង្វាលល្អ ហើយធ្វើតាមទ្រង់ នោះទ្រង់នឹងដឹកនាំយើងឆ្ពោះទៅរកជីវិតអស់កល្បជានិច្ច ។

សេចក្តីផ្តើម

អំឡុងពេលព្រះអង្គសង្គ្រោះនៅក្នុងទីក្រុងយេរូសាឡិមសម្រាប់បុណ្យបារាំ ពួកអាចារ្យ និង ពួកផារិស៊ីមួយចំនួន បាននាំស្ត្រីម្នាក់ដែលត្រូវបានចោទថាបានប្រព្រឹត្តអំពើកំផិតមកឯទ្រង់ ហើយបានសួរថាតើនាងគួរតែត្រូវគេចោលនឹងដុំថ្មឬ ។ ទ្រង់បានធ្វើឲ្យអ្នកចោទប្រកាន់ទាំងនោះស្រឡាំងកាំង ហើយបានបង្ហាញក្តីមេត្តាដល់ស្ត្រីនោះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ៨:១–១១

ស្ត្រីម្នាក់ ដែលបានប្រព្រឹត្តអំពើកំផិត ត្រូវបាននាំមកចំពោះមុខព្រះអង្គសង្គ្រោះ:

សូមអញ្ជើញសិស្សឲ្យគិតពីគ្រាដែលពួកគេធ្លាប់ជួប ឬស្គាល់មនុស្សដែលមានរូបរាង ឬឥរិយាបថមិនសក្តិសមនឹងបទដ្ឋានរបស់ព្រះអម្ចាស់ ។

- តើយើងអាចប្រឈមមុខនឹងអ្វី នៅពេលយើងនៅជាមួយនឹងមនុស្សដទៃទៀតដែលមានរូបរាង ឬឥរិយាបថមិនសក្តិសមនឹងបទដ្ឋានរបស់ព្រះអម្ចាស់នោះ ? (សិស្សអាចនឹងឆ្លើយថាយើងអាចល្បួងឲ្យកាត់សេចក្តីបុគ្គលទាំងនោះដោយមិនសុចរិត ឬប្រព្រឹត្តចំពោះពួកគេដោយអសប្បុរសធម៌) ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើយើងគួរធ្វើអ្វីខ្លះ នៅក្នុងស្ថានភាពដែលយើងនៅជាមួយនឹងអ្នកដទៃដោយមានអាការៈ ឬឥរិយាបថមិនសក្តិសមនឹងបទដ្ឋានរបស់ព្រះអម្ចាស់ ?

សូមលើកទឹកចិត្តសិស្សឲ្យរកមើលសេចក្តីពិតនានា នៅពេលពួកគេសិក្សា យ៉ូហាន ៨:១–១១ ដែលអាចជួយឆ្លើយសំណួរនេះ ។

សូមពន្យល់ថា បន្ទាប់ពីបុណ្យបារាំ ព្រះយេស៊ូវគ្រីស្ទបានបន្តគង់នៅយេរូសាឡិមមួយរយៈ ហើយបានបង្រៀនមនុស្សនៅព្រះវិហារបរិសុទ្ធ (សូមមើល យ៉ូហាន ៨:១–២) ។

សូមសិស្សម្នាក់អាន យ៉ូហាន ៨:៣–៦ ឲ្យឮៗ ។ ចុះសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើង នៅពេលព្រះយេស៊ូវបង្រៀនមនុស្សទាំងនោះ ។

- តើមានអ្វីបានកើតឡើង នៅពេលព្រះយេស៊ូវបានបង្រៀនមនុស្សទាំងនោះ ?
- តើពួកអាចារ្យ និងពួកផារិស៊ីបានទូលសួរសំណួរអ្វីខ្លះ ដល់ព្រះអង្គសង្គ្រោះ ?
- យោងតាម ខទី ៦តើអ្វីទៅជាចេតនារបស់ពួកអាចារ្យ និងពួកផារិស៊ីទាំងនោះ ? (ពួកគេចង់បង្ខូចកិត្តិយសរបស់ព្រះយេស៊ូវនៅចំពោះមុខមហាជន ហើយបង្កើតមូលហេតុមួយដើម្បីចោទប្រកាន់ទ្រង់ ដោយសារពួកគេចង់មានមូលហេតុចាប់ព្រះកាយទ្រង់ ហើយកាត់ទោសទ្រង់ដល់ជីវិត [សូមមើល យ៉ូហាន ៧:១, ៣២]) ។

សូមពន្យល់ថា ប្រសិនបើព្រះយេស៊ូវបានមានបន្ទូលឲ្យចោលស្ត្រីនោះនឹងដុំថ្ម នោះបានន័យថាទ្រង់យល់ព្រមនឹងការដាក់ទណ្ឌកម្មមួយដែលមិនសូវពេញនិយម នៅក្នុងចំណោមប្រជាជនយូដា ហើយដែលត្រូវបានហាមឃាត់ដោយច្បាប់របស់រ៉ូម ។ ប្រសិនបើព្រះយេស៊ូវបានមានបន្ទូលកុំឲ្យចោលស្ត្រីនោះនឹងដុំថ្ម ទ្រង់នឹងត្រូវគេចោទប្រកាន់ថាមិនគោរពដល់ក្រឹត្យវិន័យរបស់ម៉ូសេ ឬប្រព្រឹត្តចំពោះការអនុវត្តពីបុរាណដោយការខ្វះក្តីគោរព ។ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខនឃី *Doctrinal New Testament Commentary* រំលទី ៣ ឆ្នាំ ១៩៦៥—៧៣] ១:៤៥០– ៥១) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:៧–៨ ឲ្យឮៗ ។ ចុះសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានឆ្លើយតប ។

- យោងតាម ខទី ៧តើអ្វីទៅជាចម្លើយរបស់ព្រះយេស៊ូវ ?
- តើអ្នកគិតថាព្រះអង្គសង្គ្រោះចង់ឲ្យបុរសទាំងនេះយល់ដឹងពីអ្វីទៅ នៅពេលទ្រង់បានមានបន្ទូលថា « អ្នកណាដែលគ្មានបាបសោះ ចូរឲ្យអ្នកនោះចោលនាងនឹងថ្មដាមុនគេចុះ » ? (យ៉ូហាន ៨:៧) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលនូវអ្វីដែលបានកើតឡើង កាលពួកផារិស៊ី និងពួកអាចារ្យបានពិចារណាពីបន្ទូលរបស់ព្រះអង្គសង្គ្រោះ ។

- តើអ្នកគិតថាឃ្លា « ស្វែងរកដំបូន្មានតាមអំពើចិត្តរបស់ខ្លួន » មានន័យដូចម្តេច ?
- តើវាមានន័យដូម្តេចដែលបុរសទាំងនេះបានទទួលស្គាល់ដោយជ្រើសដើរចេញទៅ ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីដំណើររឿងនេះ អំពីរបៀបចៀសវាងការផ្តន្ទាទោសដល់មនុស្សដទៃ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគួរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ការទទួលស្គាល់ភាពមិនល្អឥតខ្ចោះផ្ទាល់ខ្លួន អាចជួយយើងឲ្យចៀសផុតពីការថ្កោលទោសអ្នកដទៃ** ។ ចូរសរសេរគោលការណ៍នេះនៅក្រោមសំណួរនៅលើក្តារខៀន) ។
- តើអ្នកគិតថា ការទទួលស្គាល់ភាពមិនល្អឥតខ្ចោះផ្ទាល់ខ្លួន អាចជួយយើងឲ្យចៀសផុតពីការថ្កោលទោសអ្នកដទៃបានដោយរបៀបណា ?

ចូរព្រមានសិស្សថា ស្ត្រីនេះមានទោសដោយអំពើសាហាយស្មន់ដែលជាអំពើបាបមួយធ្ងន់ធ្ងរបំផុត (សូមមើល អាលម៉ា ៣៩:៣–៥) ។

- តើអ្នកគិតថាស្ត្រីនោះមានអារម្មណ៍បែបណា នៅពេលអំពើបាបរបស់គាត់ត្រូវបានយកមកលាតត្រដាងនៅចំពោះព្រះយេស៊ូវ និង ហ្វូងមនុស្សដ៏ធំដូចនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ៨:១០–១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានឆ្លើយតបទៅស្ត្រីនេះ ។

- តើព្រះអង្គសង្គ្រោះបានបង្ហាញសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាដល់ស្ត្រីនេះតាមរបៀបណាខ្លះ ?
- តើការណែនាំអ្វីខ្លះដែលព្រះអង្គសង្គ្រោះបានប្រទានដល់ស្ត្រីនេះ ?

ដើម្បីជួយសិស្សយល់ដឹងថា ព្រះអង្គសង្គ្រោះមិនបានចុះសម្រុងចំពោះអំពើបាបរបស់ស្ត្រីនោះទេ ចូរសុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះដោយប្រធាន ស្ពែនសើរ ជបុលយូ ឃីមប៊ីល ៖



« ការបង្គាប់របស់ទ្រង់ដល់នាងគឺ អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ ។ ទ្រង់បានណែនាំស្ត្រីដែលមានបាបនោះឲ្យចេញទៅ*លះបង់ជីវិតដ៏អាក្រក់របស់នាង ឈប់ធ្វើបាបទៀត ផ្លាស់ប្តូរជីវិតរបស់នាង* ។ ទ្រង់បានមានបន្ទូលថា នាងអើយ អញ្ជើញទៅចុះ ហើយចាប់ផ្តើមការប្រែចិត្តរបស់អ្នក ហើយទ្រង់បានបង្ហាញដល់យើងពីដំហានចាប់ផ្តើម—ដើម្បី *លះបង់អំពើរំលងរបស់នាង* » (The Miracle of Forgiveness [ឆ្នាំ ១៩៦៩] ទំព័រ ១៦៥) ។

- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនពីព្រះអង្គសង្គ្រោះនៅក្នុង យ៉ូហាន ៨:១០–១១ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអង្គសង្គ្រោះបង្ហាញសេចក្តីមេត្តាករុណាដល់យើងដោយផ្តល់ដល់យើងនូវឱកាសដើម្បីប្រែចិត្ត** ។ ចូរសរសេរសេចក្តីពិតនេះនៅក្រោមសំណួរទីពីរនៅលើក្តារខៀន) ។
- តើការយល់ដឹងពីសេចក្តីពិតនេះ អាចជួយយើងនៅពេលយើងមានបាបបានយ៉ាងដូចម្តេច ?
- តើសេចក្តីពិតទាំងពីរដែលយើងបានរកឃើញនៅក្នុងមេរៀននេះ អាចជួយយើងឲ្យឆ្លើយតបនៅក្នុងស្ថានភាពដែលយើងនៅជាមួយនឹងមនុស្សដទៃដែលមានរូបរាង ឬតរិយោបថមិនសក្តិសមនឹងព្រះបញ្ញត្តិ និងបទដ្ឋានរបស់ព្រះអម្ចាស់បានដោយរបៀបណា ?

ចូរចែកចាយការបន្តែមទៅចុងបញ្ចប់នៃយ៉ូហាន ៨:១១ដូចខាងក្រោមនេះមកការបកប្រែដោយ យ៉ូសែប ស្ម៊ីធ ៖ « ហើយស្ត្រីនោះបានសរសេរតម្កើងដល់ព្រះចាប់តាំងពីពេលនោះមក ហើយបានជឿលើព្រះនាមទ្រង់ » ។

- យោងតាមការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ យ៉ូហាន ៨:១១តើឥទ្ធិពលអ្វីខ្លះ ដែលសេចក្តីមេត្តារបស់ព្រះអង្គសង្គ្រោះបានមានទៅលើស្ត្រីនោះ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេពីអារម្មណ៍ដែលពួកគេមានចំពោះព្រះអង្គសង្គ្រោះដោយសារព្រះឆន្ទៈរបស់ទ្រង់ ដើម្បីបង្ហាញសេចក្តីមេត្តាដល់យើង ហើយប្រទានឱកាសឲ្យយើងប្រែចិត្ត ។ អ្នកគួរទុកពេលឲ្យសិស្សចែកចាយអ្វីដែលពួកគេបានសរសេរ ។ ក៏សូមពិចារណាចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ទាំងឡាយ ដែលបានបង្ហាញនៅក្នុងមេរៀននេះ ។

មេរៀនបន្ទាប់ (យ៉ូហាន ១១–១៥)

សូមលើកទឹកចិត្តសិស្សឲ្យរកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ នៅពេលពួកគេសិក្សា យ៉ូហាន ១១–១៥ ៖ តើការមើលឃើញមនុស្សម្នាក់រស់ពីស្លាប់មានអារម្មណ៍បែបណាដែរ ? ហេតុអ្វីព្រះគម្ពីរបានកត់ត្រាថា « ព្រះយេស៊ូវព្រះកន្សែង » (យ៉ូហាន ១១:៣៥) ? តើព្រះយេស៊ូវបានធ្វើអ្វីខ្លះ សម្រាប់ពួកសាវករបស់ទ្រង់ ដែលធម្មតាជាកិច្ចការរបស់ពួកអ្នកបម្រើវិញនោះ ? តើព្រះអង្គសង្គ្រោះបានសន្យាដល់ពួកសិស្សរបស់ទ្រង់ថា ពួកគេនឹងទទួលបានអ្វីទៅ ដើម្បីលួងលោមពួកគេបន្ទាប់ពីទ្រង់បានយាងចេញទៅ ?

យ៉ូហាន ១១

សេចក្តីផ្តើម

ម៉ារា និង ម៉ាថាបានឲ្យគេទៅប្រាប់ព្រះយេស៊ូវថា ប្អូនប្រុសរបស់ពួកគេ ឡាសារ បានឈឺ ។ ព្រះយេស៊ូវបានពន្យារការយាងដំណើររបស់ទ្រង់ ហើយបានយាងមកដល់ក្រោយឡាសារស្លាប់បានបួនថ្ងៃ ។ ដោយមានសេចក្តីស្រឡាញ់ និងក្តីអាណិតអាសូរ ព្រះយេស៊ូវបានប្រោសឡាសារឲ្យរស់ពីស្លាប់ឡើងវិញ ។ ការណ៍នេះបង្ហាញពីអំណាចដ៏ទេវភាពអស្ចារ្យ ដែលគួរសបញ្ជាក់ថា ព្រះយេស៊ូវគឺជាព្រះមែស៊ីដែលបានជ្រើស ហើយមានព្រះចេស្តាលើសេចក្តីស្លាប់ ។ បន្ទាប់ពីបានដឹងពីអព្ភូតហេតុនេះហើយ ពួកសង្ឃរាជ និង ពួកផារិស៊ីរៀបផែនការសម្លាប់ដើម្បីធ្វើគត ព្រះយេស៊ូវ និង ឡាសារ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១១:១–៤៦

ព្រះយេស៊ូវបានប្រោសឡាសារឲ្យរស់ពីស្លាប់

សូមឲ្យក្រដាសមួយបំបែកតូចដល់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្រដាសនោះនូវការសោកល្បួងមួយដែលពួកគេ ឬមនុស្សម្នាក់ដែលពួកគេស្គាល់បានជួប ។ កាលសិស្សសរសេរ សូមប្រាប់ពួកគេថា អ្វីដែលពួកគេសរសេរនឹងត្រូវចែកចាយដោយ អនាមិកជាមួយនឹងសិស្សក្នុងថ្នាក់ ដើម្បីកុំឲ្យពួកគេសរសេរឈ្មោះរបស់ពួកគេនៅលើក្រដាសនោះ: ។ សូមប្រមូលក្រដាស ហើយអាន ការសោកល្បួងមួយចំនួនឲ្យឮៗ ។ (ដើម្បីចៀសវាងកុំឲ្យគេស្គាល់ឈ្មោះសិស្សជាមួយនឹងការសោកល្បួងជាក់លាក់ ប្រសិនបើអ្នកមានសិស្សតែពីរបីនាក់ ចូរសុំឲ្យសិស្សសរសេរការសោកល្បួងបីបួនដែលពួកគេធ្លាប់ឃើញអ្នកដទៃជួបពិសោធន៍នោះ:) ។

- តើវិធីមួយដែលជំនឿរបស់មនុស្សជឿលើព្រះយេស៊ូវគ្រីស្ទអាចរងឥទ្ធិពលមានអ្វីខ្លះ: កាលពួកគេជួបប្រទះនឹងការល្បួងនានា ?

សូមអញ្ជើញសិស្សរកមើលសេចក្តីពិត កាលពួកគេសិក្សា យ៉ូហាន ១១ ដែលអាចជួយយើងបង្កើនសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេជួបប្រទះនឹងការសោកល្បួងនានា ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១១:១–៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលការសោកល្បួងមួយដែលមិត្តមួយចំនួនរបស់ព្រះយេស៊ូវបានជួបប្រទះ: ។

- យោងតាមខទី ១តើការសោកល្បួងអ្វីដែលឡាសារបានជួប ? តើរឿងនេះអាចជាការសោកល្បួងសម្រាប់ ម៉ារា និងម៉ាថា បានយ៉ាងដូចម្តេច ?
- តើម៉ារា និងម៉ាថា បានធ្វើអ្វីខ្លះដោយសារតែជំងឺរបស់ឡាសារ ? តើការឆ្លើយតបនេះចង្អុលបង្ហាញអ្វីពីពួកគេ ?

សូមចង្អុលបង្ហាញថា ព្រះយេស៊ូវបានគង់នៅភូមិបេថានីជាប់នៅស្រុកពេរៀ (សូមមើល យ៉ូហាន ១:២៨, ១០:៤០) ដែលត្រូវចំណាយពេលធ្វើដំណើរប្រហែលមួយថ្ងៃពីភូមិបេថានី ។ ហេតុដូច្នោះហើយ យ៉ាងហោចណាស់ វាត្រូវចំណាយពេលមួយថ្ងៃដើម្បីឲ្យមនុស្សម្នាក់នាំសារទៅដល់ព្រះយេស៊ូវ ហើយមួយថ្ងៃទៀតដើម្បីធ្វើដំណើរទៅបេថានីវិញ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១១:៤–៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលវិធី ដែលព្រះយេស៊ូវបានឆ្លើយតបបន្ទាប់ពីឮពីជំងឺរបស់ឡាសារ ។

- ការដឹងថា ព្រះយេស៊ូវស្រឡាញ់ម៉ាថា ម៉ារា និងឡាសារ តើពួកសិស្សប្រហែលជាបានរំពឹងឲ្យព្រះយេស៊ូវធ្វើអ្វី កាលទ្រង់ស្តាប់ឮពីជំងឺរបស់ឡាសារនោះ ? (យាងទៅភូមិបេថានីព្យាបាលឡាសារភ្លាម ឬប្រហែលព្រះយេស៊ូវអាចមានបន្ទូល ហើយព្យាបាលគាត់ពីចម្ងាយ ដូចដែលព្រះយេស៊ូវបានធ្វើដល់កូនប្រុសរបស់អ្នកមានត្រកូលខ្ពស់ម្នាក់នោះ [សូមមើល យ៉ូហាន ៤:៤៦–៥៣]) ។
- តើព្រះយេស៊ូវបានធ្វើអ្វីជំនួសវិញ ?
- យោងតាម ខទី ៤តើព្រះយេស៊ូវបានមានបន្ទូលដូចម្តេច នឹងបានសម្រេចតាមរយៈជំងឺរបស់ឡាសារនោះ ?

សូមរំឭកសិស្សថា ភូមិបេថានីមានចម្ងាយតិចជាងប៊ីតឡូម៉ែត្រពីក្រុងយេរូសាឡិមនៅដែនដីស្រុកយូដា (សូមមើល យ៉ូហាន ១១:១៨) ។ សូមសង្ខេប យ៉ូហាន ១១:៨–១០ ដោយពន្យល់ថា ពួកសិស្សមួយចំនួនបានណែនាំឲ្យព្រះយេស៊ូវកុំឲ្យត្រឡប់ទៅស្រុកយូដាវិញ ដោយសារពួកអ្នកដឹកនាំសាសន៍យូដានៅភូមិភាគនោះចង់ធ្វើគុតទ្រង់ (សូមមើល យ៉ូហាន ១០:៣១–៣៩ និងការបកប្រែដោយយ៉ូសែប ស៊្មីធ ដែលអានថា « បន្ទាប់មក ថូម៉ាស ដែលហៅថាឌីឌីម បាននិយាយទៅពួកសិស្សផ្សេងទៀតថា ចូរយើងទៅដើម្បីយើងអាចស្លាប់ជាមួយនឹងទ្រង់ ពីព្រោះពួកគេខ្លាចក្រែងពួកយូដាចាប់ព្រះយេស៊ូវ ហើយធ្វើគុតទ្រង់ ប៉ុន្តែពួកគេពុំទាន់យល់ពីព្រះចេស្តានៃព្រះនៅឡើយទេ]) ។ ព្រះយេស៊ូវបានមានបន្ទូលតបវិញដោយបញ្ជាក់ថា ទ្រង់នឹងប្រើពេលវេលាដែលទ្រង់នៅសល់ ដើម្បីធ្វើកិច្ចការរបស់ទ្រង់ដោយគ្មានការស្ទាក់ស្ទើរឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១១:១១–១៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វី ដែលព្រះយេស៊ូវបានមានបន្ទូលអំពីស្ថានភាពរបស់ឡាសារ ។

- តើពួកសិស្សភាន់ច្រឡំថាព្រះយេស៊ូវមានបន្ទូលអ្វីអំពីស្ថានភាពរបស់ឡាសារ ?

ការអានបទគម្ពីរវែងៗនៅក្នុងថ្នាក់

នៅពេលសុំឲ្យសិស្សអានបទគម្ពីរវែងៗ សូមពិចារណាអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរមួយ រួចសុំឲ្យសិស្សម្នាក់នោះហៅសិស្សម្នាក់ទៀតឲ្យអានខគម្ពីរបន្ទាប់ទៀត ។ សកម្មភាពនេះអាចបន្តនៅក្នុងមេរៀនទាំងមូល ។ ត្រូវប្រុងប្រយ័ត្នមិនត្រូវធ្វើឲ្យអ្នកទាំងឡាយដែលពុំសូវចេះអាន ឬដែលអៀនខ្មាស់ក្នុងការអានអាម៉ាស់មុខឡើយ ។ សិស្សដែលមិនស្ម័គ្រចិត្តអានឮៗ សូមកុំបង្ខំឡើយ ។

- យោងតាម ខទី ១៥ហេតុអ្វីព្រះយេស៊ូវត្រេកអរ ដែលទ្រង់ពុំបានគង់នៅទីនោះព្យាបាលជំងឺរបស់ឡាសារ ? (សូមអញ្ជើញសិស្សឲ្យពិចារណាគូសចំណាំឃ្លា « ដើម្បីឲ្យអ្នករាល់គ្នាបានជឿ » នៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

សូមចង្អុលបង្ហាញថា ព្រះអង្គសង្គ្រោះបានបង្ហាញថា អ្វីដែលទ្រង់នឹងធ្វើនៅបេថានី គឺជួយពួកសិស្សរបស់ទ្រង់ឲ្យបង្កើនសេចក្តីជំនឿរបស់ខ្លួនលើទ្រង់ ។

សូមសង្ខេប យ៉ូហាន ១១:១៦ដោយពន្យល់ថា សាវក ថូម៉ាស បានលើកទឹកចិត្តដល់ពួកសិស្ស ដែលជាសម្លាញ់របស់ខ្លួនឲ្យចូលរួមនឹងលោក ដើម្បីទៅជាមួយព្រះយេស៊ូវទៅស្រុកយូដា បើទោះបីជាមានន័យថាត្រូវស្លាប់ជាមួយទ្រង់ក្តី ។

សូមអញ្ជើញសិស្សអាន យ៉ូហាន ១១:១៧ដោយស្ងៀមស្ងាត់រកមើលរយៈពេលដែលឡាសារបានស្លាប់ ពេលព្រះយេស៊ូវបានយាងមកដល់ភូមិ បេថានី ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកកត្តាសំខាន់នៃការស្លាប់របស់ឡាសារអស់រយៈពេលបួនថ្ងៃនោះ ។

« ភាពស្មុគស្មាញនៃសពកំពុងដំណើរការ ដោយសារសេចក្តីស្លាប់មានរយៈពេលយូរដែលធ្វើឲ្យវិវត្តទៅរកដំណើរការនេះជាជាច់ខាត ។ . . . ចំពោះពួកសាសន៍យូដាពាក្យថាបួនថ្ងៃមានសារៈសំខាន់ណាស់ចំពោះពួកគេ វាគឺជាជំនឿដ៏មានប្រជាប្រិយភាពនៅក្នុងចំណោមពួកគេថា នៅថ្ងៃទីបួនវិញ្ញាណបានចាកចេញ និង ពុំត្រឡប់មកសាច់ញាតិជិតស្និទ្ធនៃសពវិញឡើយ » (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ១:៥៣៣) ។

- ចំពោះពួកសាសន៍យូដា តើអ្វីទៅជាកត្តាដ៏សំខាន់នៃមនុស្សម្នាក់ដែលស្លាប់ទៅអស់រយៈពេលបួនថ្ងៃ ?
- ប្រសិនបើអ្នកគឺជាម៉ាថា ឬ ម៉ារាវិញ តើអ្នកកំពុងគិត ឬ មានអារម្មណ៍បែបណា នៅពេលព្រះយេស៊ូវពុំបានមក រហូតដល់ឡាសារបានស្លាប់អស់បួនថ្ងៃដូច្នោះ ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហាន ១១:១៨–២៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលថា តើម៉ាថាបានទូលអ្វីខ្លះទៅព្រះយេស៊ូវអំពីការសោកល្បងនេះ ។

ជំនួសការសុំឲ្យសិស្សអាន អ្នកអាចបង្ហាញរូបភាពពីការសន្ទនារវាងព្រះអង្គសង្គ្រោះ និងម៉ាថានៅក្នុងវីដេអូ « Lazarus Is Raised from the Dead » ដកស្រង់ពី *The Life of Jesus Christ Bible Videos* | ក្នុងពេលវេលា ២:០២–៣:៣៥ | ដល់ពួកគេ ។ វីដេអូនេះមាននៅក្នុង LDS.org ។

- តើឃ្លាណាមួយនៅក្នុង ខទី ២១–២៧ បង្ហាញថា ម៉ាថាបានជ្រើសអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទនៅក្នុងការសោកល្បងនេះ ? (ប្រសិនបើអ្នកបង្ហាញវីដេអូ អ្នកគួរឲ្យពេលសិស្សមួយនាទីដើម្បីមើលខគម្ពីរទាំងនេះឡើងវិញ) ។
- តើឃ្លាណាមួយរបស់ម៉ាថា ដែលធ្វើឲ្យអ្នកចាប់អារម្មណ៍ជាងគេ ? ហេតុអ្វី ?
- តើយើងអាចរៀនអ្វីខ្លះចេញពីគំរូរបស់ម៉ាថា អំពីអ្វីដែលយើងអាចធ្វើនៅក្នុងការសោកល្បងដែលយើងជួប ? (សិស្សគួរអាចឃើញគោលការណ៍មួយដូចតទៅនេះ ៖ **យើងអាចជ្រើសរើសដើម្បី អនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទអំឡុងពេលនៃការសោកល្បងរបស់យើង**) ។

សូមនាំចំណាប់អារម្មណ៍របស់សិស្សទៅរក យ៉ូហាន ១១:២៥–២៦ ។ សូមពន្យល់ថា ឃ្លា « មិនត្រូវស្លាប់ឡើយ » (យ៉ូហាន ១១:២៦) សំដៅទៅលើសេចក្តីស្លាប់ទីពីរ ឬសេចក្តីស្លាប់ខាងវិញ្ញាណ ឬការបែកចេញពីវត្តមាន និងនគរព្រះ ។

- តើយើងរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងបន្ទូលរបស់ព្រះអង្គសង្គ្រោះទៅម៉ាថា ? (សិស្សគួរអាចឃើញសេចក្តីពិតមួយ ដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាការរស់ឡើងវិញ និងជាជីវិត ។ ប្រសិនបើយើងមឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហាន ១១:២៨–៣៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលម៉ារាបានទូលទៅកាន់ព្រះយេស៊ូវ និងរបៀបដែលទ្រង់បានឆ្លើយតប ។ អ្នកអាចនឹងត្រូវពន្យល់ថា ៣ក្យ « ក្តាប់ » នៅក្នុងខគម្ពីរទាំងនេះមានន័យថាការសោកសង្រេង ឬទុក្ខព្រួយ ។

ជំនួសការសុំឲ្យសិស្សអាន អ្នកគួរបង្ហាញទិដ្ឋភាពនៃខគម្ពីរទាំងនេះនៅក្នុងវីដេអូ « Lazarus Is Raised from the Dead » | ក្នុងពេលវេលា ៣:៣៦–៤:៥០ | ។

- តើការថ្លែងរបស់ម៉ារានៅក្នុង ខ ៣២ ឆ្លុះបញ្ចាំងពីសេចក្តីជំនឿរបស់នាងលើព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?
- តើព្រះយេស៊ូវបានមានបន្ទូលតបយ៉ាងដូចម្តេច កាលទ្រង់បានទតឃើញការទួញយំរបស់ម៉ារា និងអ្នកដែលនៅជាមួយនឹងនាងនោះ ?
- ហេតុអ្វីអ្នកគិតថា ព្រះយេស៊ូវព្រះកន្សែង ?

សូមអញ្ជើញសិស្សអាន យ៉ូហាន ១១:៣៧ ដោយស្ងៀមស្ងាត់រកមើលអ្វីដែលមនុស្សមួយចំនួនងឿងឆ្ងល់ ទាក់ទងនឹងអ្វីដែលព្រះយេស៊ូវបានធ្វើសម្រាប់ឡាសារ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហាន ១១:៣៨–៤៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វី ដែលព្រះអង្គសង្គ្រោះបានធ្វើបន្ទាប់ទៀត ។

ជំនួសការសុំឲ្យសិស្សអាន អ្នកគួរបង្ហាញទិដ្ឋភាពនៃខគម្ពីរទាំងនេះនៅក្នុងវីដេអូ « Lazarus Is Raised from the Dead » | ក្នុងពេលវេលា ៤:៥១–៧:៥១ | ។

- នៅក្នុង ខទី ៤០តើព្រះយេស៊ូវបានរំឭកម៉ាថាអំពីអ្វីខ្លះ ក្រោយពីនាងបានទូលសូរពីការយកថ្មចេញពីផ្នូររបស់ឡាសារ ?

- តើការសន្យានេះបានបំពេញយ៉ាងដូចម្តេច ? (អ្នកគួរតែពន្យល់ថា ឡាសារមិនបានរស់ឡើងវិញពីស្លាប់ទេ ហើយក៏គ្មានជីវិតអមតៈដែរ វិញ្ញាណរបស់គាត់ត្រូវបាននាំត្រឡប់មកចូលក្នុងរូបកាយគាត់វិញ ប៉ុន្តែរូបកាយគាត់នៅតែជារូបកាយរមែងស្លាប់) ។

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកគោលបំណងសំខាន់មួយ ដែលព្រះអង្គសង្គ្រោះសម្រេចបាន តាមរយៈការប្រោសឲ្យឡាសារស្លាប់ហើយរស់ឡើងវិញ ។

« ទ្រង់បានរៀបចំស្ថានភាពនេះ ប្រយោជន៍ឲ្យគ្រប់សម័យទាំងអស់បានជឿលើការបង្រៀនដ៏អស្ចារ្យរបស់ទ្រង់ ៖ ថាទ្រង់គឺជាការរស់ឡើងវិញ និងជាជីវិត ថាអមតៈភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចបានកើតឡើងតាមរយៈទ្រង់ ហើយថាអស់អ្នកដែលជឿ និងធ្វើតាមព្រះបន្ទូលរបស់ទ្រង់នឹងពុំត្រូវស្លាប់ខាងវិញ្ញាណឡើយ » (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ១:៥៣១) ។

- តើអព្ភូតហេតុនេះបានចង្អុលប្រាប់ទុកជាមុន ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះតាមរបៀបណា ?
- តើអព្ភូតហេតុនេះបានបង្ហាញព្រះចេស្តារបស់ទ្រង់ដើម្បីប្រទានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចយ៉ាងដូចម្តេច ?
- តើយើងអាចទទួលបានពរជ័យយ៉ាងដូចម្តេច តាមរយៈការយល់ដឹងពីព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ដើម្បីផ្តល់នូវជីវិតអមតៈភាព និងជីវិតដ៏នៅអស់កល្បជានិច្ច ?

សូមរំឭកសិស្សថា ម៉ាថា និងម៉ារា បានចាប់ផ្តើមបង្ហាញសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ តាមរយៈការឲ្យគេទៅប្រាប់ទ្រង់នៅពេលឡាសារឈឺ ហើយបានបន្តជឿ និង ទុកចិត្តលើទ្រង់ងសូម្បីតែបន្ទាប់ពីឡាសារស្លាប់ក៏ដោយ ។ សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងជ្រើសរើសអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទនៅក្នុងការសោកល្បងរបស់យើងនោះ . . .*

- តើអ្នកនឹងបំពេញគោលការណ៍នេះ ដោយផ្អែកលើអ្វីដែលយើងបានរៀននៅក្នុងយ៉ូហាន ១១យ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយ សូមបំពេញប្រយោគនៅលើក្តារខៀន ដែលមានន័យដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងជ្រើសរើសអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទអំឡុងពេលនៃការសោកល្បងរបស់យើង នោះសេចក្តីជំនឿរបស់យើងលើទ្រង់នឹងត្រូវបានបញ្ជាក់ ព្រមទាំងកាន់តែសីជម្រៅ**) ។

សូមរំឭកសិស្សថា មនុស្សមួយចំនួនបានងឿងឆ្ងល់ថា ព្រះយេស៊ូវអាចការពារឡាសារកុំឲ្យស្លាប់បាន (សូមមើល ខទី ៣៧) ប៉ុន្តែព្រះយេស៊ូវបានរង់ចាំយាងមកដល់ភូមិបេថេនី រហូតដល់ឡាសារស្លាប់បានបួនថ្ងៃ (សូមមើល ខទី ១៧) ។

- តើការប្រោសឲ្យឡាសារស់ឡើងវិញ បន្ទាប់ពីគាត់ស្លាប់បានបួនថ្ងៃបានបញ្ជាក់ ហើយបានពង្រឹងដល់សេចក្តីជំនឿនៃពួកសិស្សរបស់ព្រះយេស៊ូវ ព្រមទាំងម៉ាថា និង ម៉ារាលើព្រះអង្គសង្គ្រោះរបៀបណា ? (នៅក្នុងការប្រោសឡាសារឲ្យរស់ឡើងវិញ បន្ទាប់ពីស្លាប់បានបួនថ្ងៃ ព្រះយេស៊ូវបានបង្ហាញថា ទ្រង់មានព្រះចេស្តាលើសេចក្តីស្លាប់ តាមរបៀបមួយដែលពួកសាសន៍យូដាមិនអាចបដិសេធ ឬបកស្រាយខុសបាន) ។
- តើអ្នកបានជ្រើសរើសដើម្បី អនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទអំឡុងពេលនៃការសោកល្បង ហើយជាលទ្ធផលសេចក្តីជំនឿរបស់អ្នកលើទ្រង់ត្រូវបានបញ្ជាក់ ឬ ពង្រឹងនោះនៅពេលណាដែរ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវរឿង ដែលពួកគេនឹងធ្វើដើម្បីជួយពួកគេជ្រើសអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នៅក្នុងការសោកល្បងដែលពួកគេកំពុងជួប ឬអាចនឹងជួប ។

យ៉ូហាន ១១:៤៧–៥៧

ពួកសង្ឃរាជ និង ពួកផារិស៊ីពិគ្រោះគ្នាដើម្បីធ្វើគុតព្រះយេស៊ូវ

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១១:៤៧–៤៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលរបៀបដែលពួកពួកសង្ឃរាជ និង ពួកផារិស៊ីបានឆ្លើយតបចំពោះការរាយការណ៍អំពីការប្រោសឡាសារឲ្យរស់ពីស្លាប់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេប យ៉ូហាន ១១:៤៩–៥៧ ដោយពន្យល់ថា កៃផា ជាសង្ឃជាន់ខ្ពស់ បាននិយាយគាំទ្រថា ព្រះយេស៊ូវគួរតែធ្វើគុតដើម្បីការពារពួករ៉ូមកុំឲ្យបំផ្លិចបំផ្លាញដល់ជាតិសាសន៍របស់ខ្លួន ។ គាត់ក៏បានព្យាករដោយពុំដឹងខ្លួនអំពីលទ្ធផល ដែលការសុគតរបស់ព្រះយេស៊ូវនឹងកើតមានទៅលើកូនចៅនៃព្រះ ។ ពួកអ្នកដឹកនាំសាសន៍យូដាបានសម្រេចចិត្តដើម្បីធ្វើគុតព្រះយេស៊ូវ ហើយបានបញ្ជាថាអស់អ្នកណាដែលដឹងពីកន្លែងដែលទ្រង់យាងទៅ គួរតែជូនដំណឹងដល់ពួកគេ ប្រយោជន៍ឲ្យពួកគេអាចចាប់បញ្ជូនទ្រង់ទៅ ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ អំពីសេចក្តីពិតដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

មេរៀន ៧២

យ៉ូហាន ១២

សេចក្តីផ្តើម

ម៉ារាមកពីភូមិបេថានី ជាបងស្រីរបស់ម៉ាថា និង ឡាសារបានលាបប្រេងលើព្រះបាទារបស់ព្រះយេស៊ូវ ដែលជានិមិត្តសញ្ញានៃការបញ្ចុះសពរបស់ទ្រង់ដែលនឹងខិតចូលមកដល់ ។ នៅថ្ងៃស្អែកឡើងព្រះយេស៊ូវបានយាងចូលទៅក្នុងទីក្រុងយេរូសាឡិមដោយជោគជ័យ ហើយបានព្យាករពីការសុគតរបស់ទ្រង់ ។ ថ្វីបើព្រះយេស៊ូវបានធ្វើអព្ភូតហេតុជាច្រើនក្តី ប៉ុន្តែមានមនុស្សមួយចំនួននៅតែពុំជឿលើទ្រង់ ។ ទ្រង់បានបង្រៀនពីលទ្ធផលនៃការជឿ និងពុំជឿលើទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១២:១–១៩

ម៉ារាបានលាបប្រេងលើព្រះបាទារបស់ព្រះយេស៊ូវ ហើយព្រះយេស៊ូវធ្វើការយាងចូលទៅក្នុងក្រុងយេរូសាឡិមដោយជោគជ័យ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យគូរប្រមគំនូរមួយ ស្តីពីអព្ភូតហេតុមួយរបស់ព្រះអង្គសង្គ្រោះដែលបានកត់ត្រានៅក្នុងព្រះគម្ពីរសញ្ញាថ្មីនៅលើក្តារខៀន ។ បន្ទាប់ពីសិស្សម្នាក់ៗបញ្ចប់ការគូរ សូមសិស្សក្នុងថ្នាក់ឲ្យទស្សន៍ទាយអព្ភូតហេតុដែលបានគូរបង្ហាញនោះ ។ ចូរសុំឲ្យសិស្សដែលគូរគំនូរនោះ ពន្យល់ពីហេតុផលដែលគាត់ជ្រើសគូរអព្ភូតហេតុនេះ ។

ចូរសុំសិស្សឲ្យសញ្ជឹងគិតថា តើការបានឃើញអព្ភូតហេតុមួយបែបនេះអាចជះឥទ្ធិពលដល់ជំនឿរបស់ពួកគេលើព្រះអង្គសង្គ្រោះយ៉ាងណាដែរ ។ នៅពេលពួកគេសិក្សា យ៉ូហាន ១២សូមអញ្ជើញពួកគេឲ្យរកមើលរបៀបផ្សេងៗគ្នា ដែលមនុស្សបានឆ្លើយតបចំពោះអព្ភូតហេតុរបស់ព្រះអង្គសង្គ្រោះ ព្រមទាំងរកមើលសេចក្តីពិត ដែលអាចជួយយើងឲ្យយល់ពីការឆ្លើយតបទាំងនេះ ។

សូមសង្ខេប យ៉ូហាន ១២:១–៩ ដោយពន្យល់ថា ប្រាំមួយថ្ងៃបន្ទាប់ពីបុណ្យរំលង នោះព្រះយេស៊ូវបានសោយអាហារពេលយប់ជាមួយមិត្តភក្តិមួយចំនួននៅភូមិ បេថានី ។ ម៉ារាជាបងស្រីរបស់ម៉ាថា និង ឡាសារបានលាបប្រេងលើព្រះបាទារបស់ព្រះយេស៊ូវជាមួយនឹងប្រេងទេព្យដ៏មានតម្លៃ ។ មនុស្សជាច្រើនបានឮថាព្រះយេស៊ូវគង់នៅភូមិ បេថានី ហើយបានមកជួបទ្រង់ និង ឡាសារ ដែលព្រះយេស៊ូវបានប្រោសឲ្យគាត់រស់ពីស្លាប់កាលពីពេលមុននោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១២:១០–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលពួកសង្ឃរាជចង់ធ្វើដល់ឡាសារ ។ អ្នកគួរចង្អុលបង្ហាញថា ការប្រោសឡាសារឲ្យរស់វិញគឺជាភស្តុតាងដែលមិនអាចប្រកែកបានថា ព្រះយេស៊ូវគ្រីស្ទមានព្រះចេស្តាលើសេចក្តីស្លាប់ ។

- តើពួកសង្ឃរាជចង់ធ្វើអ្វីដល់ឡាសារ ? ហេតុអ្វី ?
- តើខគម្ពីរទាំងនេះជួយយើងឲ្យយល់ពីអំពើទុច្ចរិតរបស់ពួកសង្ឃរាជ និងពួកផារិស៊ីបានដោយរបៀបណា ? (អ្នកគួរអំពាវនាវសិស្សថា ពួកអ្នកដឹកនាំសាសន៍យូដាក៏ចង់ធ្វើគុតព្រះអង្គសង្គ្រោះដែរ (សូមមើល យ៉ូហាន ១១:៤៧–៤៨, ៥៣)) ។

សូមសង្ខេប យ៉ូហាន ១២:១២–១៦ ដោយពន្យល់ថា នៅថ្ងៃបន្ទាប់ពីម៉ារាបានលាបប្រេងលើព្រះបាទារបស់ព្រះយេស៊ូវ នោះទ្រង់បានយាងចូលក្នុងក្រុងយេរូសាឡិមដោយជោគជ័យ ។ (ព័ត៌មានលម្អិតដែលសំខាន់បំផុតស្តីពីការយាងចូលដោយជោគជ័យត្រូវបានបង្រៀននៅក្នុង ម៉ាថាយ ២១:១–១១) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១២:១៧–១៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលមនុស្សបានឮពីព្រះយេស៊ូវបានប្រោសឲ្យឡាសាររស់ពីស្លាប់ឡើងវិញ អំឡុងពេលការយាងចូលមកដោយជោគជ័យ ក្នុងក្រុងយេរូសាឡិមនោះ ។

- តើមនុស្សទាំងនេះបានធ្វើអ្វីខ្លះ កាលព្រះអង្គសង្គ្រោះបានយាងចូលមកដោយជោគជ័យទៅក្នុងក្រុងយេរូសាឡិម ?
- យោងតាម ខទី ១៩ តើពួកផារិស៊ីបានឆ្លើយតប ចំពោះអ្វីដែលកំពុងកើតឡើងយ៉ាងដូចម្តេច ?

យ៉ូហាន ១២:២០–៣៦

ព្រះយេស៊ូវបានមាននបន្ទូលប្រាប់ទុកជាមុនពីការសុគតរបស់ទ្រង់

សូមសង្ខេប យ៉ូហាន ១២:២០–២២ ដោយពន្យល់ថា « សាសន៍ក្រេក » (ខទី ២០)—អាចជាពួកអ្នកប្រែចិត្តជឿដល់សាសនាយូដា—បានមកទីក្រុងយេរូសាឡិមដើម្បីប្រតិបត្តិតាមបុណ្យរំលង ហើយបានស្នើសុំជួបជាមួយព្រះយេស៊ូវ ។ នៅពេលព្រះយេស៊ូវបានជ្រាបដឹងពីសំណើរបស់ពួកគេ នោះទ្រង់បានបង្រៀនអំពីការរងទុក្ខ ការសុគត និង ការរស់ឡើងវិញរបស់ទ្រង់ដែលនឹងកើតឡើង ។ សូមអញ្ជើញសិស្សអាន យ៉ូហាន ១២:២៧–៣៣ដោយស្ងៀមស្ងាត់រកមើលអ្វី ដែលព្រះយេស៊ូវបានបង្រៀនអំពីដង្វាយធួនរបស់ទ្រង់ ។ អ្នកគួរតែអញ្ជើញសិស្សឲ្យគូសចំណាំអ្វី ដែលពួកគេបានរកឃើញ ។

- យោងតាម ខទី ២៧តើព្រះយេស៊ូវព្រមធ្វើអ្វីខ្លះ: ទោះបីទ្រង់ « មានចិត្តតប់ប្រមល់ » ក្តី ? (ទោះបីទ្រង់ជ្រាបពីទម្ងន់នៃការរងទុក្ខដ៏ធំរបស់ទ្រង់ក្តី ក៏ព្រះយេស៊ូវបានសម្រេចព្រះទ័យបន្តស៊ូទ្រាំទៅមុខ ដើម្បីសម្រេចឲ្យបាននូវព្រះរាជបំណងរបស់ទ្រង់ដែរ) ។
- យោងតាមខទី ២៨តើព្រះយេស៊ូវបានអធិស្ឋានទូលសូមអ្វីខ្លះ ? តើព្រះវរបិតាសួគ៌បានឆ្លើយតបបែបណាដែរ ? (សូមពន្យល់ថា « យើង . . . ក៏នឹងដំកើងឡើងទៀតដែរ » ឆ្លុះបញ្ចាំងពីការទុកព្រះទ័យទាំងស្រុងរបស់ព្រះវរបិតាសួគ៌លើព្រះរាជបុត្រាទ្រង់ថា ទ្រង់នឹងបំពេញដង្វាយធួននោះ) ។
- តើព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលបានកត់ត្រានៅក្នុង ខទី ៣២ ទាក់ទងនឹងដង្វាយធួនរបស់ទ្រង់យ៉ាងដូចម្តេច ?

សូមពន្យល់ថា បន្ទាប់ពីស្តាប់ឮការបង្រៀនរបស់ព្រះយេស៊ូវ ហ្វូងមនុស្សបានពោលថា ពួកគេបានរៀនពីព្រះគម្ពីរថា ព្រះមែស៊ីនឹងមិនសុគតទេ ហើយពួកគេបានទូលសួរថាតើ « កូនមនុស្ស » ដែលនឹង « ត្រូវលើកឡើង » ជានរណា (យ៉ូហាន ១២:៣៤) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១២:៣៥–៣៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលពីរបៀបដែលព្រះយេស៊ូវបានឆ្លើយនឹងសំណួររបស់ពួកគេ ។

- តើព្រះយេស៊ូវបានមានបន្ទូលអ្វីខ្លះ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់ប្រជាជន ? (ព្រះអង្គសង្គ្រោះបានមានបន្ទូលប្រាប់ថា ទ្រង់គឺជា « ពន្លឺ ») ។

យ៉ូហាន ១២:៣៧–៥០

ព្រះយេស៊ូវបង្រៀនពីលទ្ធផលនៃការជឿ និងការពុំជឿលើទ្រង់

សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅលើគំនូរនៅលើក្តារខៀន ស្តីពីអព្ភូតហេតុមួយចំនួនរបស់ព្រះយេស៊ូវ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១២:១១ ហើយឲ្យសិស្សម្នាក់ទៀតអាន យ៉ូហាន ១២:៣៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលរបៀបខុសៗគ្នាដែលប្រជាជនបានឆ្លើយតបទៅនឹងអព្ភូតហេតុ ដែលព្រះយេស៊ូវបានធ្វើឡើង ។

- តើប្រជាជន បានឆ្លើយតបនឹងអព្ភូតហេតុរបស់ព្រះយេស៊ូវយ៉ាងដូចម្តេច ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ចេញពីប្រតិកម្មផ្សេងៗគ្នាទាំងនេះស្តីពីទំនាក់ទំនងរវាងអព្ភូតហេតុ និងការជឿលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែចូរប្រាកដដើម្បីបញ្ជាក់ឲ្យច្បាស់ថា **អព្ភូតហេតុតែម្យ៉ាងពុំបានធ្វើឲ្យយើងជឿលើព្រះយេស៊ូវគ្រីស្ទបានឡើយ**) ។
- ទោះបីជាអព្ភូតហេតុតែមួយមុខគត់នោះ ពុំបណ្តាលឲ្យយើងជឿលើព្រះយេស៊ូវគ្រីស្ទក្តី តើវាអាចជះឥទ្ធិពលដល់សេចក្តីជំនឿរបស់យើងទៅលើទ្រង់បានយ៉ាងដូចម្តេច ?
- ហេតុអ្វីអ្នកគិតថា មនុស្សមួយចំនួនជឿទៅលើព្រះយេស៊ូវគ្រីស្ទបន្ទាប់ពីបានឃើញ ឬរៀនពីអព្ភូតហេតុរបស់ទ្រង់ ខណៈដែលមនុស្សដទៃទៀតពុំបានជឿទៅវិញ ?

សូមសង្ខេប យ៉ូហាន ១២:៣៨–៤១ ដោយពន្យល់ថា ធាតុពិតដែលមនុស្សមួយចំនួនបានជ្រើសរើសជឿលើព្រះយេស៊ូវនោះ វាបានបំពេញការព្យាករដែលបានធ្វើឡើងដោយព្យាការីអេសាយ (សូមមើល អេសាយ ៦:៩–១០, ៥៣:១–៣) ។ ទោះបីជាមានកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គសង្គ្រោះក្តី ក៏មនុស្សមួយចំនួនជ្រើសរើសយកការបិទភ្នែកខ្លួនឲ្យខ្ជាក់ ហើយធ្វើចិត្តរបស់ខ្លួនឲ្យរឹងរូសប្រឆាំងនឹងទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១២:៤២–៤៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលមូលហេតុដែលពួកអ្នកដឹកនាំសាសន៍យូដាមួយចំនួន ដែលបានជឿលើព្រះយេស៊ូវ ប៉ុន្តែពុំបាន « សារភាព » (ខទី ៤២) ឬពុំបានទទួលស្គាល់ជំនឿរបស់ពួកគេដោយបើកចំហឡើយ ។

- ហេតុអ្វីមេដឹកនាំធំៗមួយចំនួនពុំបានទទួលស្គាល់ ដោយបើកចំហពីជំនឿរបស់ពួកគេលើព្រះយេស៊ូវ ?
- តើការចូលចិត្តនឹង « សេចក្តីសរសើររបស់មនុស្ស ជាជាងសេចក្តីសរសើររបស់ព្រះវិញ » មានន័យដូចម្តេច ? (ខទី ៤៣) ។
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (សូមជួយសិស្សឲ្យរកឃើញគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ការខ្វល់ខ្វាយកាន់តែច្រើនពីការបំពេញចិត្តរបស់មនុស្សដទៃ ជាជាងការបំពេញព្រះទ័យដល់ព្រះ អាចរារាំងយើងពីការទទួលស្គាល់ដោយឥតលាក់លាមពីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់**) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមសួរ ៖

- តើគំរូមួយចំនួននៃគោលការណ៍នេះ នៅក្នុងជំនាន់របស់យើងមានអ្វីខ្លះ ?
- តើរបៀបសមរម្យមួយចំនួន ដើម្បីបង្ហាញថាយើងជឿលើព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់មានអ្វីខ្លះ ?
- តើលទ្ធផលវិជ្ជមានអ្វីខ្លះ ដែលអាចកើតមានឡើងពីការបង្ហាញថាយើងជឿលើព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ ?

ដើម្បីរៀបចំសិស្សឲ្យរកឃើញគោលការណ៍មួយ ដែលបានបង្រៀននៅក្នុង យ៉ូហាន ១២:៤៤–៤៦ ចូរសុំឲ្យពួកគេគិតពីគ្រាមួយ ដែលពួកគេពុំបានមើលឃើញ ដោយសារសេចក្តីងងឹត (ឧទាហរណ៍ គ្រាមួយដែលពួកគេស្ថិតនៅក្នុងបន្ទប់ងងឹតមួយ ឬនៅខាងក្រៅនាពេលយប់) ។ សូមអញ្ជើញសិស្សពីបីនាក់ឲ្យពិពណ៌នាពីបទពិសោធន៍របស់ពួកគេ ដោយដាក់បញ្ចូលពីអារម្មណ៍របស់ពួកគេ ថាតើពួកគេស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ដែលអាចអាចកើតមានដោយប្រការណាមួយដែរទេ ហើយការមានពន្លឺនឹងជួយពួកគេបានដោយរបៀបណា ។

ប្រសិនបើសមហេតុផល ចូរបិទភ្លើងនៅក្នុងបន្ទប់ ប៉ុន្តែផ្តល់ពន្លឺខ្លះៗ ។ ចូរចង្អុលបង្ហាញថា ភាពងងឹតអាចជួយយើងឲ្យយល់ពីសភាពនៃសេចក្តីងងឹតខាងវិញ្ញាណ ។

- តើការនៅក្នុងស្ថានភាពងងឹតនៃរូបកាស្រដៀងគ្នាទៅនឹងស ភាពងងឹតខាងវិញ្ញាណយ៉ាងដូចម្តេច ?
- តើគ្រោះថ្នាក់អ្វីខ្លះអាចកើតឡើងមកពីការរស់ នៅក្នុងភាពងងឹតខាងវិញ្ញាណនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១២:៤៤–៤៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀប ដែលអស់អ្នកដែលជឿលើព្រះយេស៊ូវគ្រីស្ទបានទទួលពរ ។

- យោងតាម យ៉ូហាន ១២:៤៦តើអស់អ្នកដែលជឿលើព្រះយេស៊ូវគ្រីស្ទបានទទួលពរដោយរបៀបណា ? (បន្ទាប់ពីសិស្សបានឆ្លើយ ចូរបើកភ្លើងក្នុងបន្ទប់វិញ ប្រសិនបើអ្នកបានបិទវា ។ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖ **ប្រសិនបើយើងជឿលើព្រះយេស៊ូវគ្រីស្ទ យើងនឹងមិនត្រូវរស់នៅក្នុងភាពងងឹតខាងវិញ្ញាណឡើយ**) ។
- តើព្រះយេស៊ូវគ្រីស្ទជាពន្លឺបានយ៉ាងដូចម្តេច ? តើការជឿលើទ្រង់ ដកយកភាពងងឹតខាងវិញ្ញាណចេញពីជីវិតរបស់មនុស្សម្នាក់បានយ៉ាងដូចម្តេច ? (សូមមើលផងដែរ គ. និង ស. ៥០:២៣–២៥, ៩៣:៣៦–៣៩) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀប ដែលព្រះយេស៊ូវគ្រីស្ទបណ្តេញសេចក្តីងងឹតខាងវិញ្ញាណដោយប្រទានន្លឺវត្តន្លឺ (ឬទិសដៅ និងភាពច្បាស់លាស់) នៅក្នុងជីវិតរបស់យើង សូមបំបែកសិស្សជាក្រុមដោយមានមនុស្សពីរ ឬបីនាក់ ។ សូមចែក ឯកសារខាងក្រោមនេះដល់ក្រុមនីមួយ ៖

ការពិភាក្សា និងការដាក់កិច្ចការជាក្រុមតូចៗ

សកម្មភាពជាក្រុមតូចៗជាញឹកញាប់អាចអនុញ្ញាតឲ្យមានសិស្សច្រើនចូលរួមនៅក្នុងមេរៀននេះ ហើយអាចផ្តល់បរិយាកាសល្អមួយដែលសិស្សអាចចែកចាយអារម្មណ៍គំនិត និងទីបន្ទាល់របស់ពួកគេជាមួយនឹងគ្នា ។ សិស្សអាចត្រៀមខ្លួនយ៉ាងល្អប្រសើរដើម្បីធ្វើសកម្មភាពមួយចំនួនជាក្រុម ប្រសិនបើអ្នក ដំបូងឡើយណែនាំពួកគេតាមរយៈឧទាហរណ៍ពីកិច្ចការមួយ ដែលពួកគេគួរធ្វើនៅក្នុងក្រុមរបស់ខ្លួន ។

ព្រះយេស៊ូវគ្រីស្ទបណ្តេញភាពងងឹតដោយការប្រទានពន្លឺ

ចំពោះប្រធានបទនីមួយៗដូចមានខាងក្រោមនេះ សូមពិភាក្សាសំណួរដូចតទៅ ៖

- តើមនុស្សដែលមានភាពងងឹតខាងវិញ្ញាណ អាចជឿលើប្រធានបទនេះឬទេ ?
- តើពន្លឺអ្វីដែលព្រះយេស៊ូវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់បានប្រទានឲ្យអំពីប្រធានបទនេះ ?

ប្រធានបទ ៖

- គោលបំណងនៃរូបកាយរបស់យើង
- ការកម្សាន្ត និង ប្រព័ន្ធផ្សព្វផ្សាយ
- ការទទួលបានភាពសុខសាន្ត និងសុភមង្គល
- អាពាហ៍ពិពាហ៍ និង គ្រួសារ
- ជីវិតក្រោយការស្លាប់

សូមឲ្យសិស្សពិភាក្សាគ្នាពីប្រធានបទមួយ ដែលមាននៅលើក្តារខៀនដោយប្រើសំណួរដែលភ្ជាប់មកជាមួយ ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទីពិភាក្សាពីប្រធានបទដែលនៅសេសសល់ដោយប្រើសំណួរទាំងនេះ ។ (អ្នកគួរដាក់ជំនួសប្រធានបទមួយចំនួន ក្នុងចំណោមប្រធានបទទាំងនេះជាមួយនឹងប្រធានបទមួយដែលទាក់ទងនឹងសិស្សរបស់អ្នក) ។

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ពីក្រុមនីមួយៗឲ្យជ្រើសយកប្រធានបទមួយនៅក្នុងឯកសារនោះ ហើយប្រាប់ពីការពិភាក្សាជាក្រុមស្តីពីប្រធានបទនេះ ។ បន្ទាប់មក សូមសួរសិស្ស ៖

- តើគោលការណ៍ដែលយើងរកឃើញនៅក្នុង ខទី ៤៦ អាចជួយយើងឲ្យយល់ពីមូលហេតុ ដែលយើងអាចឃើញថាប្រធានបទជាក់លាក់ និង បញ្ហានានាមានផ្សេងគ្នាជាងចំពោះមនុស្សដទៃបានដោយរបៀបណា ?
- តើពន្លឺដែលព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់បានប្រទានមកបានជួយអ្នកនៅក្នុងស្ថានភាពណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងខាងក្រោមនេះដោយអែលឌើរ ហ្គែរីឌ ដំបុលយូ ហ្កង នៃពួកចិតសិបនាក់ បានថ្លែងទីបន្ទាល់ពីពរជ័យដែលកើតមានឡើងតាមរយៈការជ្រើសរើសជឿ និង ធ្វើតាមព្រះយេស៊ូវគ្រីស្ទ ៖

« ជំនឿគឺជាជម្រើសមួយ [សូមមើល ម៉ូសាយ ៤:៩] ។ . . .

« នៅពេលយើងជ្រើសដើម្បីជឿ នោះយើងយល់ ហើយឃើញកិច្ចការនានាក្នុងរបៀបជាច្រើន ។ នៅពេលយើងឃើញ និង រស់នៅតាមរបៀបនោះ យើងនឹងរីករាយ ហើយមានអំណរ នៅក្នុងរបៀបមួយដែលមានតែដំណឹងល្អតែប៉ុណ្ណោះ ដែលអាចធ្វើឲ្យវាកើតមានឡើង » (« Choose Goodness and Joy » New Era ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៤៤) ។

សូមសង្ខេប យ៉ូហាន ១២:៤៧–៥០ដោយពន្យល់ថា ព្រះយេស៊ូវបានបង្រៀនអស់អ្នក ដែលពុំជឿលើព្រះបន្ទូលរបស់ទ្រង់ ហើយបដិសេធទ្រង់នឹងត្រូវបានជំនុំជម្រះ ដោយព្រះបន្ទូលដែលទ្រង់បានមានព្រះបន្ទូល ដែលជាព្រះបន្ទូលដែលព្រះវរបិតាសួគ៌បានប្រទានឲ្យទ្រង់ ។

ចូរចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យ ដែលអ្នកបានទទួល ដោយសារការជ្រើសរើសជឿលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីរបៀបដែលពួកគេនឹងអនុវត្តគោលការណ៍មួយដែលពួកគេបានរៀន ។ សូមលើកទឹកចិត្តសិស្សឲ្យជ្រើសរើសជឿលើព្រះយេស៊ូវគ្រីស្ទ ។

យ៉ូហាន ១៣

សេចក្តីផ្តើម

បន្ទាប់ពីការទទួលទានអាហារបុណ្យរំលង ព្រះយេស៊ូវបានលាងជើងឲ្យពួកសាវករបស់ទ្រង់ ហើយបានប្រាប់ថា យូដាស គឺជាអ្នកក្បត់ទ្រង់ ។ ដោយពុំគិតអំពីភាពភ័ន្តវន្តនៃសប្តាហ៍ចុងក្រោយនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ព្រះយេស៊ូវបានផ្តោតការបង្រៀនរបស់ទ្រង់ទៅលើ ការគោរពប្រតិបត្តិ ការបម្រើ និងសេចក្តីស្រឡាញ់—ជាឥរិយាបថដែលកំណត់អំពីជីវិតទ្រង់ ហើយគួរតែកំណត់ជីវិតរបស់ពួកសិស្សរបស់ទ្រង់នៅគ្រប់ជំនាន់ផងដែរ ។

មានទំនុកចិត្តលើព្រះចេស្តារនៃព្រះបន្ទូល


អ្នកអាចត្រូវបានល្បួងឲ្យជឿថា សិស្សនឹងមិនចូលចិត្តការសិក្សាព្រះគម្ពីរ ឬ ថាពួកគាត់មិនអាចបង្រៀនព្រះគម្ពីរពីមួយថ្ងៃទៅមួយថ្ងៃ និងទទួលបានការចាប់អារម្មណ៍របស់សិស្សរហូតឡើយ ។ ទោះជាយ៉ាងណា សូមចងចាំថា ព្រះគម្ពីរមាននូវ « ព្រះបន្ទូលទាំងឡាយខាងជីវិត » (គ. និង ស. ៨៤:៨៥) និងថាព្រះបន្ទូលមាន « ប្រសិទ្ធភាពលើ [គំនិត]. . .ជាងផ្លែដារ ឬ អ្វីផ្សេងៗទៀត » (អាលម៉ា ៣១:៥) ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៣:១–១៧

ព្រះយេស៊ូវលាងជើងឲ្យពួកសាវករបស់ទ្រង់

មុនចាប់ផ្តើមថ្នាក់ សូមថតចម្លង រូប ដូចខាងក្រោមនៅលើក្តារខៀន ៖



សូមអានសំណួរដូចខាងក្រោមឮៗ ហើយអញ្ជើញសិស្សឲ្យពិចារណា អំពីរបៀបដែលពួកគេនឹងឆ្លើយ (ពន្យល់ថា ពួកគេពុំចាំបាច់ត្រូវឆ្លើយឮៗទេ) ៖

- តើអ្នកនឹងដាក់ខ្លួនរបស់អ្នក នៅកន្លែងណានៅលើរង្វាស់ទំហំនេះ ?
- តើអ្នកចង់រីករាយជាងក្នុងពេលឥឡូវនេះឬទេ ?
- តើអ្នកអាចគិតអំពីនរណាម្នាក់ ដែលអ្នកចង់ជួយឲ្យបានកាន់តែសប្បាយរីករាយឬទេ ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយនៅពេលពួកគេសិក្សាយ៉ូហាន ១៣ដែលនឹងជួយពួកគេដឹងនូវអ្វី ដែលពួកគេអាចធ្វើដើម្បីបានកាន់តែសប្បាយរីករាយ ។

ដើម្បីជួយសិស្សយល់បរិបទនៃយ៉ូហាន ១៣សូមរំឭកពួកគេថា ព្រះយេស៊ូវបានប្រារព្ធពិធីលៀងអាហារ សម្រាប់បុណ្យរំលងជាមួយនឹងពួកសាវករបស់ទ្រង់ ។ សូមសង្ខេបយ៉ូហាន ១៣:១–៣ ដោយពន្យល់ថា នៅពេលព្រះយេស៊ូវចែកចាយអាហារពេលយប់ចុងក្រោយនេះជាមួយនឹងពួកសាវករបស់ទ្រង់ពីមុនការឆ្កាងរបស់ទ្រង់ នោះទ្រង់បានដឹងថាទ្រង់នឹងត្រូវគេសម្លាប់ក្នុងពេលឆាប់ៗ ហើយត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌ទ្រង់វិញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ១៣:៤–៥ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វី ដែលព្រះយេស៊ូវបានធ្វើបន្ទាប់ពីទ្រង់ និងពួកសាវករបស់ទ្រង់បញ្ចប់ការទទួលទានអាហារបុណ្យរំលង ។ ចូរពន្យល់ថា ឃ្លា « ដោះព្រះពស្ត្រពេញ » នៅក្នុងខ ៤ មានន័យថា ព្រះយេស៊ូវបានដោះព្រះពស្ត្រក្រៅចេញ ស្រដៀងគ្នានឹងនរណាម្នាក់ដោះអាវធំចេញក្នុងជំនាន់របស់យើងផងដែរ ។

- តើការបម្រើអ្វីខ្លះដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់ពួកសិស្សរបស់ទ្រង់ ?

ចូរពន្យល់ថា « នៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មី មនុស្សពាក់ស្បែកជើងសម្រែក ដើរលើថ្នល់ដីភាគច្រើន ដែលសត្វធ្វើឲ្យក្រខ្វក់ ហើយមានតែត្រូវលាងទឹកជាប្រចាំប៉ុណ្ណោះ ។ ជើងរបស់ពួកគេក្រខ្វក់ខ្លាំងណាស់ ហើយការលាងជើងរបស់មនុស្សម្នាក់ផ្សេងទៀតអាចជាកិច្ចការថោកទាបមួយ ។ . . . ទំនៀមទម្លាប់នៃការទទួលរាក់ទាក់នេះ ជាធម្មតាត្រូវធ្វើឡើងដោយពួកបាវបម្រើទាបបំផុត » (*New Testament Student Manual* [Church Educational System manual, ឆ្នាំ ២០១៤] ទំព័រ ២៤២) ។ អំឡុងអាហារយប់ចុងក្រោយនេះ « ព្រះគ្រីស្ទបានក្រោកឡើងយ៉ាងស្ងៀមស្ងាត់ ប្រដាប់ព្រះអង្គទ្រង់ដូចជាទាសករ ឬបាវបម្រើម្នាក់ ហើយលុតជង្គង់ចុះលាងជើងរបស់ពួកសាវក » (ដៃហ្វ្រី អ័រ ហូឡិន« He Loved Them unto the End » Ensign, ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ ទំព័រ ២៥) ។



សូមបង្ហាញរូបភាពព្រះយេស៊ូវលាងជើងឲ្យពួកសាវករបស់ទ្រង់ (*Gospel Art Book* [ឆ្នាំ ២០០៩] លេខ៥៥សូមមើលផងដែរ LDS.org) ។

- ប្រសិនបើអ្នកបាននៅទីនោះ ពេលព្រះយេស៊ូវលាងជើងពួកសាវករបស់ទ្រង់ តើអ្នកអាចនឹងមានប្រតិកម្មយ៉ាងណា ប្រសិនបើព្រះយេស៊ូវចាប់ផ្តើមលាងជើងរបស់អ្នក ?
- តើទង្វើនៃការលាងជើងឲ្យពួកសាវករបស់ទ្រង់ បង្ហាញអំពីចរិកលក្ខណៈរបស់ព្រះយេស៊ូវយ៉ាងណា ?

សូមអញ្ជើញសិស្សឲ្យអានការបកប្រែដោយ យ៉ូសែប ស៊្មីធ យ៉ូហាន ១៣:៨ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាពេត្រុសបាននិយាយអ្វីពេលព្រះអង្គសង្គ្រោះ ចាប់ផ្តើមលាងជើងរបស់គាត់ ។

- ស្របតាមការបកប្រែរបស់ យ៉ូសែប ស៊្មីធ យ៉ូហាន ១៣:៨តើពេត្រុសនិយាយអ្វីខ្លះ នៅពេលព្រះអង្គសង្គ្រោះបានចាប់ផ្តើមលាងជើងរបស់គាត់ ?

សូមអញ្ជើញសិស្សឲ្យអានការបកប្រែដោយយ៉ូសែប ស៊្មីធ យ៉ូហាន ១៣:៩–១០ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការឆ្លើយតបរបស់ពេត្រុសចំពោះអ្វីដែលព្រះអម្ចាស់បានប្រាប់គាត់ ។

- តើយើងរៀនអ្វីខ្លះអំពីពេត្រុសចេញមកពីចម្លើយរបស់គាត់ ដែលបានកត់ត្រានៅក្នុងខទី ៩អំពីអ្វីដែលព្រះអម្ចាស់បានប្រាប់ដល់គាត់ ? (ពេត្រុសគោរពព្រះអម្ចាស់ ហើយចង់ធ្វើតាមទ្រង់ទាំងស្រុង) ។

ចូរពន្យល់ថា តាមរយៈការលាងជើងរបស់ពួកសាវករបស់ទ្រង់ ព្រះអង្គសង្គ្រោះពុំគ្រាន់តែធ្វើការបម្រើដ៏ល្អមួយប៉ុណ្ណោះនោះទេ តែទ្រង់ក៏បានបំពេញតាមក្រឹត្យវិន័យរបស់ម៉ូសេ ហើយបានបង្កើតពិធីបរិសុទ្ធដ៏ពិសិដ្ឋមួយ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខនឃី *Doctrinal New Testament Commentary* វ៉ុល ៣ | ឆ្នាំ ១៩៦៥–៧៣ | ១:៧០៨–៩) ។ ពិធីបរិសុទ្ធនេះ ត្រូវបានស្តារឡើងវិញនៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់យើង តាមរយៈព្យាការី យ៉ូសែប ស៊្មីធ (សូមមើលគ. និង ស. ៨៨:៧៤–៧៥, ១៣៧–៤១) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ១៣:១១ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាហេតុអ្វីព្រះយេស៊ូវមានបន្ទូលទៅសាវកថា « អ្នករាល់គ្នាមិនមែនស្អាតគ្រប់គ្នាទេ » ។

- តើព្រះអង្គសង្គ្រោះសំដៅទៅលើនរណា នៅពេលទ្រង់មានបន្ទូលថា « អ្នករាល់គ្នាមិនមែនស្អាតគ្រប់គ្នាទេ » ? (យូដា អេស្ការីយ៉ុត ដែលនឹងក្បត់ទ្រង់ក្នុងពេលដ៏ខ្លីខាងមុខ) ។

សូមអញ្ជើញឲ្យសិស្សច្រើននាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ១៣:១២–១៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលទង្វើអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសាវករបស់ទ្រង់ បន្ទាប់ពីទ្រង់បានលាងជើងរបស់ពួកគេ ។

- យោងតាមខទី ១៣–១៦តើព្រះអង្គសង្គ្រោះបានធ្វើគំរូ ហើយអញ្ជើញពួកសាវករបស់ទ្រង់ឲ្យធ្វើតាមអ្វីខ្លះ ? (ទោះជាព្រះអង្គសង្គ្រោះគឺជា « លោកគ្រូ ហើយជាព្រះអម្ចាស់ » [ខទី ១៣] ហើយជាអង្គដែលធំបំផុត ទ្រង់បានបម្រើអ្នកដទៃ) ។

- ផ្អែកទៅលើការសន្យារបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកសាវករបស់ទ្រង់ ដែលបានកត់ត្រានៅក្នុងខទី ១៧តើពរជ័យអ្វីខ្លះ ដែលយើងនឹងទទួលនៅពេលយើងធ្វើតាមគំរូរបស់ទ្រង់តាមរយៈការបម្រើអ្នកដទៃ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្គាល់ទង្វើគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **នៅពេលយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ដោយការបម្រើអ្នកដទៃ នោះយើងនឹងកាន់តែសប្បាយរីករាយ**) ។

- ហេតុអ្វីអ្នកគិតថា យើងនឹងកាន់តែសប្បាយរីករាយ ប្រសិនបើយើងបម្រើអ្នកដទៃដូចជាព្រះអង្គសង្គ្រោះបានធ្វើ ?

ចូរសុំឲ្យសិស្សគិតអំពីគ្រាមួយ ដែលពួកគេកាន់តែរីករាយដោយសារតែពួកគេធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ តាមរយៈការបម្រើអ្នកដទៃ ។ សូមឲ្យសិស្សបីបួននាក់ចែកចាយនូវបទពិសោធន៍នានារបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។ អ្នកក៏អាចចង់ចែកចាយពីបទពិសោធន៍មួយរបស់អ្នកផងដែរ ។

ដើម្បីជួយសិស្សរៀនវិធីមួយដែលពួកគេអាចអនុវត្តគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ការអធិស្ឋានពេលព្រឹករៀងរាល់ថ្ងៃថ្មីរបស់អ្នក ទូលសុំព្រះវរបិតាសួគ៌ឲ្យដឹកនាំអ្នក ដើម្បីឲ្យស្គាល់ឱកាសបម្រើដល់កូនចៅដ៏មានតម្លៃណាម្នាក់របស់ទ្រង់ ។ រួចហើយសូមឲ្យដួងចិត្តអ្នកពេញទៅដោយសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ពេញក្នុងមួយថ្ងៃ ហើយស្វែងរកជួយដល់នរណាម្នាក់ ។ ប្រសិនបើអ្នកធ្វើដូចនេះ ការញាណដឹងខាងវិញ្ញាណរបស់អ្នក នឹងត្រូវបានពង្រីកឡើង ហើយអ្នកនឹងរកឃើញឱកាសបម្រើដែលអ្នកពុំដែលដឹងពីមុនសោះឡើយ » (« Be Anxiously Engaged » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៣១) ។

- ស្របតាមអែលឌើរ បាឡឺត តើយើងអាចស្វែងរកឱកាសដើម្បីបម្រើអ្នកដទៃយ៉ាងដូចម្តេច ?

សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ តាមរយៈការបម្រើអ្នកដទៃ ។ សូមធ្វើការពិចារណាអញ្ជើញសិស្សឲ្យរៀបចំខ្លួនអំឡុងពេលរៀនពីរបីថ្នាក់ក្រោយៗឲ្យរាយការណ៍ពីបទពិសោធន៍របស់ពួកគេក្នុងការបម្រើអ្នកដទៃ ។

យ៉ូហាន ១៣:១៨–៣០

ព្រះយេស៊ូវបានប្រាប់ពីអ្នកក្បត់ទ្រង់

សូមសង្ខេបយ៉ូហាន ១៣:១៨–៣០ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានបង្រៀនដល់ពួកសាវករបស់ទ្រង់ថា ពួកគេនឹងបានរីករាយប្រសិនបើពួកគេបម្រើអ្នកដទៃ នោះទ្រង់បានមានបន្ទូលថា ម្នាក់ក្នុងចំណោមពួកគេនឹងក្បត់ទ្រង់ ។ នៅពេលយ៉ូហានបានសួរព្រះយេស៊ូវថានរណានឹងក្បត់ទ្រង់ នោះព្រះយេស៊ូវបានបញ្ជាក់ថា ម្នាក់ក្នុងចំណោមពួកសាវករបស់ទ្រង់ (យូដាស) នឹងក្បត់ទ្រង់ ។

យ៉ូហាន ១៣:៣១–៣៨

ព្រះយេស៊ូវបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យស្រឡាញ់គ្នាទៅវិញទៅមក

ចូរសួរដល់សិស្ស ប្រសិនបើមាននរណាម្នាក់ធ្លាប់ចោទប្រកាន់ពួកគេថា មិនប្រព្រឹត្តដូចជាគ្រីស្ទាន ឬសិស្សពិតរបស់ព្រះយេស៊ូវគ្រីស្ទដោយសារតែពួកគេជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយឬទេ ។ ប្រសិនបើមានសិស្សណាម្នាក់

លើកដៃ ចូរសួរពួកគេថាតើពួកគេឆ្លើយតបចំពោះការចោទប្រកាន់ដែលថា ពួកគេមិនមែនជាគ្រីស្ទានដោយរបៀបណា ។ ប្រសិនបើគ្មាននរណាម្នាក់មានបទពិសោធន៍នេះទេ ចូរសួរ ៖

- តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្តេច ប្រសិនបើនរណាម្នាក់ប្រាប់អ្នកថា អ្នកពុំមែនជាគ្រីស្ទាននោះ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ១៣:៣៤–៣៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាតើព្រះអង្គសង្គ្រោះមានបន្ទូលអ្វីខ្លះ ដែលនឹងជួយអ្នកដទៃឲ្យដឹងថា ពួកសាវករបស់ទ្រង់ គឺជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។

- យោងតាមខទី ៣៤តើបទបញ្ញត្តិអ្វីខ្លះ ដែលព្រះយេស៊ូវបានប្រទានដល់ពួកសាវករបស់ទ្រង់ ?
- យោងតាមខទី ៣៥តើអ្នកដទៃនឹងដឹងឬទេ ប្រសិនបើពួកសាវកស្រឡាញ់គ្នាទៅវិញទៅមក ដូចជាព្រះយេស៊ូវស្រឡាញ់ពួកគេនោះ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកសាវករបស់ទ្រង់ ? (ដោយប្រើ៣ក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្គាល់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **នៅពេលយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូវគ្រីស្ទស្រឡាញ់យើង នោះអ្នកដទៃនឹងដឹងថា យើងគឺជាពួកសិស្សរបស់ទ្រង់**)។
- ស្របតាមអ្វីដែលអ្នកបានសិក្សាក្នុងឆ្នាំនេះអំពីព្រះយេស៊ូវគ្រីស្ទ តើទ្រង់បង្ហាញថាទ្រង់ស្រឡាញ់ប្រជាជនតាមរបៀបណា ?

ដើម្បីជួយសិស្សយល់អំពីសេចក្តីពិត និងសារៈសំខាន់នៃគោលការណ៍ដែលពួកគេបានប្រាប់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោម ដែលរៀបរាប់ដោយអែលឌើរ ប៉ុល អ៊ី ខូអែលឡែកយើរ នៃពួកចិតសិបនាក់ ៖



« អ្នកផ្សព្វផ្សាយវ័យក្មេងពីរនាក់ បានគោះទ្វារមួយ ដោយសង្ឃឹមថា រកឃើញនរណាម្នាក់ ដែលនឹងទទួលយកសាររបស់ពួកគេ ។ ទ្វាបើកឡើង ហើយបុរសមានធ្ងន់ម្នាក់បានទទួលពួកគេ ដោយសំឡេងដែលមិនសូវរួសរាយប៉ុន្មាន ៖ ‹ ខ្ញុំគិតថា ខ្ញុំបានប្រាប់អ្នកហើយថា កុំឲ្យគោះទ្វារខ្ញុំទៀត ។ ខ្ញុំបានព្រមានអ្នកពីមុនហើយ ថាបើអ្នកមកម្តងទៀត វានឹងមិនមែនជា បទពិសោធន៍ដ៏រីករាយនោះទេ ។ ឥឡូវថយចេញទៅ › ។ គាត់បានបិទទ្វារយ៉ាងលឿន ។

« ពេលដែលពួកអែលឌើរបានដើរចេញ អ្នកផ្សព្វផ្សាយដែលបម្រើយូរជាង ហើយមានបទពិសោធន៍ជាង បានដាក់ដៃលើស្មា អ្នកផ្សព្វផ្សាយដែលថ្មីជាងដើម្បីលួងលោម និង លើកទឹកចិត្តគាត់ ។ ពួកអ្នកផ្សព្វផ្សាយមិនបានដឹងទេថាបុរសនោះបានមើលពួកគេតាមមាត់បង្អួច ដើម្បីប្រាកដថា ពួកគេយល់អំពីសាររបស់គាត់ ។ គាត់ពិតជាវិលវិញថា នឹងឃើញពួកគេចំអកដល់ការឆ្លើយតបដ៏គំហកគំរើយរបស់គាត់ ពេលពួកគេព្យាយាមជួបជាមួយគាត់ ។ ទោះជាយ៉ាងណា ពេលគាត់បានឃើញអ្នកផ្សព្វផ្សាយទាំងពីរូប ដែលបានបង្ហាញចិត្តសប្បុរសចំពោះគ្នា នោះដួងចិត្តរបស់គាត់ត្រូវបានបន្ទន់មួយរំពេច ។ គាត់បានបើកទ្វារ ហើយហៅពួកអ្នកផ្សព្វផ្សាយឲ្យត្រឡប់មកវិញ និង ចែកចាយសារលិខិតរបស់ពួកគេជាមួយគាត់ ។

« . . . គោលការណ៍នៃការស្រឡាញ់គ្នាទៅវិញទៅមកនេះ និងការអភិវឌ្ឍសមត្ថភាពរបស់យើងឲ្យផ្តោតទៅលើព្រះគ្រីស្ទនៅក្នុងរបៀបដែលយើងគិត និយាយ និងប្រព្រឹត្តិ គឺជាគ្រឹះនៃការក្លាយទៅជាពួកសិស្សរបស់ព្រះគ្រីស្ទ » (« He Truly Loves Us» *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ១៧) ។

- តើអ្នកផ្សព្វផ្សាយសាសនាដែលបានពិពណ៌នានៅក្នុងដំណើររឿងនេះ បានធ្វើតាមការប្រឹក្សារបស់ព្រះអង្គសង្គ្រោះឲ្យស្រឡាញ់គ្នាទៅវិញទៅមកយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យច្រៀងបទ« ចូរអ្នកស្រឡាញ់គ្នា »(*ទំនុកតម្កើង*លេខ ៣០៨) ហើយសុំឲ្យពួកគេគិតអំពីនរណាម្នាក់ ដែលពួកគេស្គាល់ដែលងាយស្គាល់ថាជាសិស្សមួយរូបរបស់ព្រះយេស៊ូវគ្រីស្ទ ដោយសារតែក្តីស្រឡាញ់របស់ពួកគាត់បង្ហាញចំពោះអ្នកដទៃ ។ បន្ទាប់ពីការច្រៀងទំនុកតម្កើង សូមអញ្ជើញសិស្សឲ្យចែកចាយឈ្មោះ បុគ្គលទាំងឡាយដែលពួកគេបានគិត ហើយពន្យល់អំពីរបៀបជាក់លាក់ដែលមនុស្សទាំងនោះបានបង្ហាញក្តីស្រឡាញ់របស់ពួកគេដល់អ្នកដទៃ ។ សូមពិចារណាធ្វើការប្រាប់ដល់សិស្សក្នុងថ្នាក់អំពីនរណាម្នាក់ដែលអ្នកបានគិតផងដែរ ។

សូមលើកទឹកចិត្តដល់សិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីប្រែក្លាយកាន់តែស្រឡាញ់អ្នកដទៃដូចជាព្រះអង្គសង្គ្រោះស្រឡាញ់ពួកគេ ។

សូមសង្ខេបយ៉ូហាន ១៣:៣៦–៣៨ដោយពន្យល់ថា បន្ទាប់ពីពេត្រុសបានប្រកាសថា គាត់នឹងដាក់ជីវិតដើម្បីព្រះយេស៊ូវគ្រីស្ទ នោះព្រះយេស៊ូវបានប្រាប់ពេត្រុសថា គាត់នឹងបដិសេធព្រះយេស៊ូវបីដងពីមុនមាត់រងាវ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

សូមដឹកនាំសិស្សនៅក្នុងការប្រកួតគ្នាបើករកបទគម្ពីរ ដោយការប្រើតម្រុយដើម្បីជួយពួកគេហាត់រកវគ្គបទគម្ពីរ ក្នុងគម្ពីររបស់ពួកគេឲ្យបានឆាប់ ។ សម្រាប់តម្រុយ អ្នកអាចប្រើ៣ក្យគន្លឹះ សេចក្តីថ្លែងការណ៍នៃបរិបទ គោលលទ្ធិ និង គោលការណ៍ និង គំនិតអនុវត្តនានា មកពីកាតចំណេះចំណានខគម្ពីរ ។ អ្នកក៏អាចបង្កើតតម្រុយនោះបានដោយខ្លួនឯងផងដែរ ។ សកម្មភាពសូរដេញរកខគម្ពីរដែលសិស្សដណ្តើមគ្នារកទីតាំងនៃវគ្គបទគម្ពីរ អាចជួយពួកគេឲ្យចូលរួមយ៉ាងសកម្ម នៅក្នុងការរៀនវគ្គចំណេះចំណានខគម្ពីរ ។ នៅពេលប្រើសកម្មភាពសូរដេញរកខគម្ពីរ សូមធ្វើវាតាមរបៀបមួយដែលពុំធ្វើឲ្យមានអារម្មណ៍ឈឺចាប់ ឬ ប៉ះទង្គិចព្រះវិញ្ញាណឡើយ ។ សូមជួយសិស្សឲ្យចៀសវាងពីការប្រព្រឹត្តចំពោះព្រះគម្ពីររបស់ខ្លួនដោយគ្មានគោរវភាព ឬ ប្រកួតប្រជែងជ្រុលហួសហេតុពេក ។ សូមគិតអញ្ជើញសិស្សប្រកួតប្រជែងនឹងបទដ្ឋានមួយជាជាងប្រកួតប្រជែងតតាំងនឹងគ្នា ។ ឧទាហរណ៍ សិស្សអាចប្រកួតជាមួយគ្រូបង្រៀន ឬ ពួកគេអាចប្រកួតដើម្បីមើលថា ប្រសិនបើភាគរយជាក់លាក់មួយនៃសិស្សក្នុងថ្នាក់ អាចរកឃើញវគ្គបទគម្ពីរជាក់លាក់មួយនៅក្នុងពេលកំណត់មួយ ។

យ៉ូហាន ១៤

សេចក្តីផ្តើម

បន្ទាប់ពីអាហារបុណ្យរំលងហើយ ព្រះយេស៊ូវបានបង្រៀនដល់ពួកសាវកអំពីរបៀបដើម្បីត្រឡប់ទៅព្រះវរបិតាសួគ៌វិញ និងរបៀបដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះអង្គសង្គ្រោះ ។ បន្ទាប់មក ព្រះយេស៊ូវបានសន្យានឹងពួកសាវករបស់ទ្រង់ថា ទ្រង់នឹងបញ្ជូនព្រះជ័យជំនួយមួយអង្គទៀតដល់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៤:១–១៤

ព្រះអង្គសង្គ្រោះបង្រៀនដល់ពួកសិស្សរបស់ទ្រង់ អំពីរបៀបដើម្បីត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌

បើអាចធ្វើទៅបាន សូមបង្ហាញផែនទីមួយអំពីទីក្រុងអ្នក ហើយអញ្ជើញសិស្សឲ្យប្រាប់ពីទីតាំងបច្ចុប្បន្នរបស់ពួកគេនៅលើផែនទីនោះ ។ នៅលើផែនទី សូមប្រាប់ពីកន្លែងមួយទៀតដែលសិស្សស្គាល់ ។ សូមឲ្យពួកគេសរសេរនៅលើក្រដាសមួយសន្លឹក អំពីរបៀបដើម្បីធ្វើដំណើរពីកន្លែងបច្ចុប្បន្នរបស់ពួកគេទៅកាន់កន្លែងនោះ ។ សូមអញ្ជើញសិស្សម្នាក់ ឬពីរនាក់ឲ្យរាយការណ៍ពីអ្វីដែលពួកគេសរសេរ ។

សូមសរសេរ*នគរសេរេឡស្ទាល* នៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សពិចារណាអំពីការដឹកនាំដែលនឹងផ្តល់ទៅ ឲ្យនរណាម្នាក់ដែលចង់ដឹងអំពីរបៀបដើម្បីទៅដល់នគរសេឡេស្ទាល ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ ពេលសិស្សសិក្សាយ៉ូហាន ១៤ដែលអាចជួយពួកគេស្គាល់ពីរបៀបដើម្បីត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌ ហើយចូលទៅនគរសេឡេស្ទាល ។

ដើម្បីជួយសិស្សឲ្យយល់បរិបទអំពីយ៉ូហាន ១៤សូមរំឭកពួកគេថា ព្រះអង្គសង្គ្រោះបានគោរពតាមបុណ្យរំលងជាមួយនឹងពួកសាវករបស់ទ្រង់ នៅបន្ទប់ខាងលើក្នុងទីក្រុងយេរូសាឡិម ។ បន្ទាប់ពីអាហារបុណ្យរំលង ព្រះយេស៊ូវបានប្រាប់ដល់ពួកសិស្សរបស់ទ្រង់ថា ទ្រង់នឹងចាកចេញពីពួកគេ ក្នុងពេលឆាប់ៗ (សូមមើលយ៉ូហាន ១៣:៣៣) ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗពី យ៉ូហាន ១៤:១–៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួកសាវករបស់ទ្រង់ដើម្បីជួយលួងលោមដល់ពួកគេ ។

- តើព្រះយេស៊ូវបង្រៀនអ្វីខ្លះ ដល់ពួកសាវករបស់ទ្រង់ដើម្បីជួយលួងលោមចិត្តពួកគេ ?
- តើអ្នកគិតថាឃ្លា « នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន » នៅក្នុងខទី ២មានន័យយ៉ាងណា ?

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ៖



« [សេចក្តីថ្លែងការណ៍] ‹ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន › . . . គួរតែជា— ‹ នៅក្នុងនគររបស់ព្រះបិតាខ្ញុំ គឺមាននគរជាច្រើន › ដើម្បីអ្នកអាចជាអ្នកគ្រងមរតករបស់ព្រះ ហើយជាអ្នកគ្រងមរតកនៃព្រះជាមួយនឹងខ្ញុំផង ។ . . . មាននគរជាច្រើនសម្រាប់អ្នកទាំងឡាយណា ដែលគោរពតាមច្បាប់សេឡេស្ទាល ហើយមាននគរជាច្រើនទៀតសម្រាប់អ្នកទាំងឡាយដែលមិនគោរពច្បាប់ មនុស្សគ្រប់រូបតាមលំដាប់របស់ពួកគេ » (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ២១៩) ។

អ្នកគួរតែផ្តល់យោបល់ឲ្យសិស្សសរសេរពាក្យ*នគរ*និង*នគរជាច្រើន*នៅក្នុងគម្ពីររបស់ពួកគេខាងលើពាក្យ*ដំណាក់*និង*ទីលំនៅ*នៅក្នុងយ៉ូហាន ១៤:២ ។

- តើការបង្រៀនមួយណានៅក្នុងយ៉ូហាន ១៤:១–៤ដែលអាចលួងលោមចិត្តដល់ពួកសាវក ?
- យោងតាមខទី ៥តើថូម៉ាសបានឆ្លើយតបចំពោះការបង្រៀនរបស់ព្រះអង្គសង្គ្រោះថា ពួកសាវករបស់ទ្រង់បានស្គាល់ផ្លូវទៅកាន់នគររបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ១៤:៦ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលការឆ្លើយតបរបស់ព្រះយេស៊ូវចំពោះសំណួររបស់ថូម៉ាស ។

- តើព្រះយេស៊ូវឆ្លើយតបចំពោះសំណួររបស់ថូម៉ាសយ៉ាងដូចម្តេច ?

សូមគូសរូបផ្លូវមួយនៅលើក្តារខៀន ។ នៅចុងម្ខាងនៃផ្លូវ សូមសរសេរពាក្យ*យើង*ហើយនៅចុងម្ខាងទៀតសរសេរពាក្យ*នគររបស់ព្រះវរបិតាសួគ៌* ។ សូមសរសេរពាក្យ*មាគ៌ា*នៅក្រោមពាក្យផ្លូវ ហើយចង្អុលបង្ហាញថា ឃ្លានេះសំដៅទៅលើផ្លូវដែលដឹកនាំពីកន្លែងមួយទៅកន្លែងមួយ ។

- តើព្រះអង្គសង្គ្រោះគឺជាផ្លូវយ៉ាងដូចម្តេច ? (សិស្សអាចឆ្លើយតបថា ព្រះអង្គសង្គ្រោះបង្ហាញយើងពីរបៀបរស់នៅដើម្បីប្រែក្លាយដូចជាព្រះ និងរបៀបដើម្បីឲ្យមានភាពសក្តិសម ទៅរស់នៅក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌) ។

លូកា ១៤:៦ គឺជាចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រីស្ទ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

ចូរសរសេរពាក្យ*សេចក្តីពិត*និង*ជីវិត*នៅលើក្តារខៀនក្រោមពាក្យ « មាគ៌ា » ។

- តើព្រះយេស៊ូវគ្រីស្ទជាសេចក្តីពិតតាមរបៀបណាខ្លះ ? (ទ្រង់គឺជាប្រភពនៃសេចក្តីពិតទាំងអស់ ហើយបានរស់នៅស្របតាមទាំងសេចក្តីពិតដោយល្អឥតខ្ចោះ ទាំងអស់) ។
- តើព្រះយេស៊ូវគ្រីស្ទជាជីវិតតាមរបៀបណាខ្លះ ? (ទ្រង់ធ្វើឲ្យការយកឈ្នះលើសេចក្តីស្លាប់ អាចកើតមានឡើងសម្រាប់យើងខាងរូបកាយ ហើយត្រូវបានរស់ឡើងវិញជាមួយនឹងរូបកាយខាងសាច់ឈាមអមតៈ ហើយយកឈ្នះលើសេចក្តីស្លាប់ខាងវិញ្ញាណដើម្បីទទួលបានជីវិតអស់កល្បជានិច្ច ។ ទ្រង់គឺជា « ពន្លឺដែលនៅក្នុងគ្រប់ទាំងអស់ ដែលផ្តល់ជីវិតដល់គ្រប់ទាំងអស់ » [គ. និង ស. ៨៨:១៣]) ។

នៅក្រោមគំនូរផ្លូវនៅលើក្តារខៀន ចូរសរសេរពាក្យ*ព្រះយេស៊ូវគ្រីស្ទគឺជា*នៅជិតនឹងពាក្យ « មាគ៌ា » ។

- ផ្អែកទៅលើអ្វីដែលយើងបានពិភាក្សា តើអ្នកនឹងសង្ខេបអត្ថន័យនៃសេចក្តីថ្លែងការណ៍របស់ព្រះអង្គសង្គ្រោះថា « បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ » យ៉ាងដូចម្តេច ? (យ៉ូហាន ១៤:៦) ។ (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែស្តាប់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **មានតែតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងតាមរយៈការធ្វើតាមមាគ៌ារបស់ទ្រង់ប៉ុណ្ណោះ ទើបយើងអាចចូលក្នុងនគររបស់ព្រះវរបិតាសួគ៌បាន**) ។
- តើមានអ្វីនឹងកើតឡើង បើយើងព្យាយាមធ្វើតាមផ្លូវមួយដែលពុំមែនជាមាគ៌ារបស់ព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចតទៅនេះដោយអែលឌើរ លូរែន អឺ ខូប្រ៊ីតហ្គ នៃពួកចិតសិបនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលអ្វីនឹងកើតឡើង ប្រសិនបើយើងព្យាយាមធ្វើតាមផ្លូវមួយ ដែលពុំមែនជាមាគ៌ារបស់ព្រះអង្គសង្គ្រោះ ។



« មានផ្លូវតែមួយគត់ទៅកាន់សុភមង្គល និងភាពពេញលេញ ។ ទ្រង់គឺជាផ្លូវ ។ គ្រប់ផ្លូវផ្សេងៗ រាល់ផ្លូវណាមួយផ្សេង មិនថាផ្លូវណាទេ គឺជាភាពល្ងីល្ងើ ។ . . .

« . . . យើងអាចធ្វើតាមព្រះ ហើយទទួលបានព្រះចេស្តារបស់ទ្រង់ និងមានសន្តិភាព ពន្លឺ កម្លាំង ចំណេះដឹង ទំនុកចិត្ត ក្តីស្រឡាញ់ និងក្តីអំណរ ឬយើងអាចទៅផ្លូវផ្សេង រាល់ផ្លូវផ្សេង មិនថាផ្លូវផ្សេងណាទេ នឹងទៅតែម្នាក់ឯង—ដោយគ្មានការទ្រទ្រង់របស់ទ្រង់ គ្មានព្រះចេស្តារបស់ទ្រង់ គ្មានការដឹកនាំទេ នោះយើងនឹងស្ថិតនៅក្នុងភាពងងឹត ភាពច្របូកច្របល់ ការសង្ស័យ ទួញសោក និងអស់សង្ឃឹម ។ ហើយខ្ញុំបានសួរថា តើផ្លូវណាដែលងាយស្រួលជាង ? . . .

« មានផ្លូវតែមួយគត់ទៅកាន់សុភមង្គល និងភាពពេញលេញ ។ ព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវ » (« The Way »*Ensign* ឬ*លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ៣៤, ៣៦) ។

- ស្របតាមអែលឌើរ ខូប្រ៊ីតហ្គ តើមានអ្វីនឹងកើតឡើង ប្រសិនបើយើងពុំធ្វើតាមមាគ៌ារបស់ព្រះអង្គសង្គ្រោះនោះ ?
- តើអ្វីនឹងកើតឡើង ប្រសិនបើយើងធ្វើតាមមាគ៌ារបស់ព្រះអង្គសង្គ្រោះ ?

ចូរសុំឲ្យសិស្សគិតពិចារណាអំពីបទពិសោធន៍នានា ដែលពួកគេមាន ដែលពួកគេត្រូវបានប្រទានពរតាមរយៈការធ្វើតាមមាគ៌ារបស់ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

ចូរសង្ខេបយ៉ូហាន ១៤:៧–១៤ដោយពន្យល់ថា ព្រះអង្គសង្គ្រោះ បានបង្រៀនដល់ពួកសាវករបស់ទ្រង់ថា គោលបំណងមួយរបស់ទ្រង់នៅក្នុងការយាងមកលើផែនដី គឺដើម្បីបើកសម្តែងតាមរយៈព្រះបន្ទូល និងទង្វើរបស់ទ្រង់អំពីលក្ខណៈពិតរបស់ព្រះវរបិតាសួគ៌ ។ ទ្រង់ក៏បានសន្យាដល់ពួកសាវករបស់ទ្រង់ផងដែរថា ពួកគេនឹងមានព្រះចេស្តាដើម្បីធ្វើកិច្ចការអស្ចារ្យៗ ។

យ៉ូហាន ១៤:១៥–៣១

ព្រះយេស៊ូវបង្រៀនពួកសាវករបស់ទ្រង់អំពីរបៀបដើម្បីបង្ហាញអំពីក្តីស្រឡាញ់របស់ពួកគេចំពោះទ្រង់

ចូរសុំឲ្យសិស្សគិតអំពីនរណាម្នាក់ដែលពួកគេស្រឡាញ់ ។

- តើអ្នកបង្ហាញសេចក្តីស្រឡាញ់របស់អ្នកចំពោះមនុស្សម្នាក់នេះរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ១៤:១៥ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលព្រះយេស៊ូវប្រាប់ដល់ពួកសាវករបស់ទ្រង់ ឲ្យធ្វើដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ពួកគេចំពោះទ្រង់ ។

- ផ្អែកទៅលើអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួកសាវករបស់ទ្រង់ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវគ្រីស្ទ ? (សិស្សគួរឲ្យរកឃើញសេចក្តីពិតដូចតទៅនេះ ៖ **យើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវគ្រីស្ទ ដោយការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់**) ។

សូមយកក្រដាសដែលមានសរសេរបទបញ្ញត្តិទាំងឡាយ នៅលើនោះជាច្រើនសន្លឹកមកថ្នាក់រៀន (ដូចជាការគោរពពាក្យសម្តីនៃប្រាជ្ញាវាងវៃ ការថ្វាយដង្វាយមួយភាគក្នុងដប់ និងការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ) ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យឡើងមកខាងមុខថ្នាក់ ។ សូមណែនាំដល់សិស្សម្នាក់ៗឲ្យយកក្រដាសមក អានបទបញ្ញត្តិនោះឲ្យឮៗ ហើយពន្យល់ពីរបៀបដែលការរក្សាបទបញ្ញត្តិនោះ អនុញ្ញាតឲ្យយើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវគ្រីស្ទយ៉ាងណាខ្លះ ។ រួចហើយ អញ្ជើញពួកគេឲ្យត្រឡប់ទៅកន្លែងអង្គុយវិញ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេបង្ហាញសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះអង្គសង្គ្រោះ តាមរយៈការរក្សាបទបញ្ញត្តិរបស់ទ្រង់ល្អយ៉ាងណា ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅមួយ ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះអង្គសង្គ្រោះដោយការរក្សាឲ្យបានកាន់តែល្អប្រសើរឡើងចំពោះបទបញ្ញត្តិមួយ ឬច្រើនដែលប្រហែលជាពិបាកសម្រាប់ពួកគេ ។

លូកា ១៤:១៥ គឺជាចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

ចូរសុំឲ្យសិស្សម្នាក់អាន យ៉ូហាន ១៤:១៦–១៧, ២៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការសន្យារបស់ព្រះអង្គសង្គ្រោះចំពោះពួកសាវករបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះបានសូរអ្វីខ្លះដល់ពួកសាវករបស់ទ្រង់ ?

ចូរពន្យល់ថា ឃ្លា « ព្រះដ៏ជាជំនួយមួយអង្គទៀត » នៅក្នុងខទី ១៦សំដៅទៅលើព្រះវិញ្ញាណបរិសុទ្ធ ។ ដោយសារព្រះអង្គសង្គ្រោះជាព្រះដ៏ជាជំនួយមួយចំពោះពួកសាវករបស់ទ្រង់អំឡុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ នោះទ្រង់ហៅព្រះវិញ្ញាណបរិសុទ្ធថាជាព្រះដ៏ជាជំនួយ*មួយអង្គទៀត* ។

- យោងតាម យ៉ូហាន ១៤:១៦–១៧, ២៦តើព្រះវិញ្ញាណបរិសុទ្ធអាចធ្វើអ្វីសម្រាប់យើង ? (ដោយការប្រើពាក្យផ្ទាល់របស់ពួកគេ សិស្សគួរតែប្រាប់នូវសេចក្តីពិតដូចខាងក្រោម ៖ **ព្រះវិញ្ញាណបរិសុទ្ធអាចលួងលោមយើង បង្រៀនយើងនូវការណ៍គ្រប់យ៉ាង ហើយក៏នឹងរំឭកពីគ្រប់ទាំងសេចក្តី**) ។

សូមអញ្ជើញសិស្សឲ្យកត់ត្រាចម្លើយចំពោះសំណួរនេះ: ចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើអ្នកទទួលអារម្មណ៍ដឹងថា ព្រះវិញ្ញាណបរិសុទ្ធលួងលោមចិត្តអ្នកនៅពេលណា ? តើនៅពេលណា ដែលអ្នកមានអារម្មណ៍ដឹងថាទ្រង់បង្រៀនអ្នក ? តើទ្រង់ជួយអ្នកចងចាំរឿងទាំងឡាយនោះពេលណា ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញអ្នកស្ម័គ្រចិត្តពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

សូមអញ្ជើញឲ្យសិស្សច្រើននាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ១៤:១៨–២៣ ។

- យោងតាមខទី ២១និង២៣តើយើងនឹងត្រូវបានប្រទានពរយ៉ាងដូចម្តេច ប្រសិនបើយើងរក្សាបទបញ្ញត្តិទាំងឡាយ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **ប្រសិនបើយើងរក្សាបទបញ្ញត្តិទាំងឡាយ នោះព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នឹងគង់នៅជាមួយនឹងយើង**) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ នឹងគង់នៅជាមួយយើង ? (ការណ៍នេះសំដៅទៅលើការបង្ហាញតួអង្គព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ [គ. និង ស. ១៣០:៣]) ។

សូមពន្យល់ថាព្យាការី យ៉ូសែប ស៊្មីធ បានបង្រៀនថា ខណៈដែលព្រះវិញ្ញាណបរិសុទ្ធ សំដៅទៅថាជាព្រះដ៏ជាជំនួយទីមួយ នោះព្រះយេស៊ូវគ្រីស្ទ គឺជាព្រះដ៏ជាជំនួយទីពីរ ។ ដើម្បីទទួលបានទ្រង់ជាព្រះដ៏ជាជំនួយទីពីរ នោះដំបូងឡើយ យើងត្រូវអភិវឌ្ឍសេចក្តីជំនឿទៅលើទ្រង់ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយព្យាយាមរស់នៅដោយសុចរិត ហើយបម្រើព្រះ ។ ប្រសិនបើយើងធ្វើនូវរឿងទាំងនោះ ទីបំផុត យើង « នឹងមានតួអង្គព្រះយេស៊ូវគ្រីស្ទចូលរួមនឹង [យើង] ឬលេចមកឯ [យើង] ពីមួយគ្រាទៅមួយគ្រា . . . ហើយការនិមិត្តទាំងឡាយនៃស្ថានសួគ៌នឹងបើកចំហឲ្យ [យើង] ហើយព្រះអម្ចាស់នឹងបង្រៀន [យើង] ដោយផ្ទាល់ » (នៅក្នុង *History of the Church* ៣:៣៨០–៨១) ។ ការសន្យានេះនឹងត្រូវបានបំពេញស្របតាមព្រះទ័យ និងពេលវេលាកំណត់របស់ព្រះអម្ចាស់ (សូមមើលគ. និង ស. ៨៨:៦៨) ។

សូមអញ្ជើញសិស្សឲ្យអានយ៉ូហាន ១៤:២៧ដោយស្ងាត់ស្ងៀម ហើយរកមើលសារលិខិតរបស់ព្រះអង្គសង្គ្រោះទៅកាន់ពួកសាវករបស់ទ្រង់ ។

- តើសារលិខិតរបស់ព្រះអង្គសង្គ្រោះនៅក្នុងខទី ២៧ទាក់ទងទៅនឹងគោលការណ៍នានា ដែលយើងត្រូវបានប្រាប់នៅក្នុងមេរៀននេះយ៉ាងដូចម្តេច ?
- តើមានភាពខុសគ្នាអ្វីខ្លះរវាងសេចក្តីសុខសាន្ត ដែលព្រះអង្គសង្គ្រោះប្រទានឲ្យ ហើយសេចក្តីសុខសាន្តដែលលោកិយផ្តល់ឲ្យ ?

សូមសង្ខេបយ៉ូហាន ១៤:២៨–៣០និងការបកប្រែដោយ យ៉ូសែប ស៊្មីធ យ៉ូហាន ១៤:៣០ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ដោយការពន្យល់ថា ព្រះយេស៊ូវបានប្រាប់ពួកសាវករបស់ទ្រង់ថា ពួកគេគួររីករាយ ដោយសារទ្រង់ហៀបនឹងចាកចេញពីពួកគេដើម្បីត្រឡប់ទៅស្ថានសួគ៌វិញហើយ ។ ទ្រង់ក៏បានប្រាប់ពួកគេថា សាតាំងពុំមានអំណាចលើទ្រង់ទេ ដោយសារទ្រង់បានយកឈ្នះលើលោកិយហើយ ។ ព្រះយេស៊ូវបានប្រាប់ពួកសាវកថា សាតាំងអាចនៅតែមានឥទ្ធិពលលើពួកគេ ដោយសារពួកគេពុំទាន់បំពេញកិច្চការរបស់ពួកគេ នៅលើផែនដីនៅឡើយទេ ។

សូមអញ្ជើញសិស្សឲ្យអានយ៉ូហាន ១៤:៣១ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វី ដែលព្រះអង្គសង្គ្រោះចង់ឲ្យពិភពលោកស្គាល់ ។

- តើព្រះអង្គសង្គ្រោះចង់ឲ្យពិភពលោកស្គាល់អ្វីខ្លះ ?
- តើព្រះអង្គសង្គ្រោះបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ?

ដើម្បីបញ្ចប់សូមអញ្ជើញសិស្សថ្លែងទីបន្ទាល់ អំពីរបៀបដែលគោលការណ៍ទាំងឡាយនៅក្នុងមេរៀននេះ អាចជួយពួកគេ នៅពេលពួកគេព្យាយាមត្រឡប់ទៅកាន់វត្តមានរបស់ព្រះនៅនគរសេឡេស្ទាលវិញ ។

ចំណេះចំណានខគម្ពីរ—យ៉ូហាន ១៤:៦

ដើម្បីជួយសិស្សទន្ទេញចាំយ៉ូហាន ១៤:៦ចូរពិចារណាធ្វើការប្រើប្រាស់គំនិតមួយនៃសេចក្តីបន្ថែម នៅក្នុងសៀវភៅសិក្សានេះ ។

ចំណេះចំណានខគម្ពីរ—យ៉ូហាន ១៤:១៥

ដើម្បីជួយសិស្សទន្ទេញចាំយ៉ូហាន ១៤:១៥សូមអញ្ជើញពួកគេសរសេរខនេះលើក្រដាសមួយសន្លឹក ។ ចូរសុំឲ្យពួកគេអានខនោះឡើងវិញ រហូតដល់ពួកគេទន្ទេញវាចាំ ។ បន្ទាប់មកអញ្ជើញឲ្យពួកគេដាក់តាំងក្រដាសនេះ នៅកន្លែងមួយដែលអាចរំឭកពួកគេឲ្យបង្ហាញសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះអម្ចាស់ តាមរយៈការរក្សាបទបញ្ញត្តិរបស់ទ្រង់ ។

យ៉ូហាន ១៥

សេចក្តីផ្តើម

នាល្ងាចចុងក្រោយនៃការបម្រើក្នុងជីវិតរមែងស្លាប់របស់ទ្រង់ ក្រោយពីអាហារយប់ថ្ងៃចុងក្រោយ នោះព្រះអង្គសង្គ្រោះបានបង្រៀនពួកសាវករបស់ទ្រង់ថា ទ្រង់គឺជាដើមទំពាំងបាយជូរពិត ហើយថាពួកសិស្សរបស់ទ្រង់គឺជាមែក ។ ទ្រង់បានបញ្ជាដល់ពួកសិស្សរបស់ទ្រង់ឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយបានព្រមានពួកគេពីការបៀតបៀនដែលពួកគេនឹងជួបដោយសារតែពួកគេទាក់ទងជាមួយទ្រង់ ។



យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៥:១–១១

ព្រះយេស៊ូវពន្យល់ថា ទ្រង់គឺជាដើមទំពាំងបាយជូរពិត

ពីមុនថ្នាក់ចាប់ផ្តើម ចូរសរសេរនៅលើក្តារខៀននូវពាក្យ *ជោគជ័យ កើតទុក្ខ សប្បាយ មនុស្សស្លាប់ មានប្រយោជន៍ គ្មានផលប្រកបដោយផ្លែផ្កា មានផល ផ្លែយ៉ាងច្រើន ច្រើនក្រៃលែង* និង *បរាជ័យ* ។

សូមអញ្ជើញសិស្សឲ្យស្រមៃថា ពួកគេកំពុងសម្លឹងមើលទៅជីវិតរបស់ខ្លួននៅ ៦០ ឆ្នាំក្រោយពីពេលឥឡូវនេះ ។

- តើពាក្យណាមួយ ដែលអ្នកចង់ប្រើដើម្បីពិពណ៌នាពីជីវិតរបស់អ្នក ? ហេតុអ្វី ?

ចូរគូររូបដើមទំពាំងបាយជូរមួយនៅលើក្តារខៀន ។ អ្នកអាចនឹងចង់ឲ្យយោបល់ដល់សិស្សឲ្យចម្លងគំនូរនោះ នៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ។ សូមពន្យល់ថា ព្រះយេស៊ូវបានប្រើរឿងប្រៀបប្រដូចអំពីដែនទំពាំងបាយជូរ ដើម្បីជួយពួកសិស្សរបស់ទ្រង់ឲ្យយល់ពីរបៀបដើម្បីមានជីវិតដែលបង្កើតផ្លែផ្កា មានគំនិតច្នៃប្រឌិត និង មានភាពបរិបូរ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៥:១–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើធាតុនៃពាក្យប្រៀបធៀបតំណាងឲ្យអ្វី ។

- តើដើមទំពាំងបាយជូរតំណាងឲ្យអ្វី ? (សូមសរសេរស្លាកសម្រាប់ដើមទំពាំងបាយជូរនៅលើក្តារខៀនថា *ព្រះយេស៊ូវគ្រីស្ទ*) ។
- តើមែកតំណាងឲ្យអ្វី ? (សូមសរសេរស្លាកសម្រាប់មែកថា *សិស្សរបស់ព្រះយេស៊ូវគ្រីស្ទ*) ។
- ប្រសិនបើព្រះយេស៊ូវគ្រីស្ទ គឺជាចម្ការទំពាំងបាយជូរ ហើយយើងគឺជាខ្នែងរបស់វានោះ តើផ្លែតំណាងឲ្យអ្វី ? (ផ្លែអាចតំណាងឲ្យកិច្ចការ និងទង្វើសុចរិតដែលសិស្សរបស់ព្រះយេស៊ូវគ្រីស្ទគួរតែបង្កបង្កើតឡើង ។ សូរសរសេរស្លាកសម្រាប់ផ្លែថា *កិច្ចការសុចរិត*) ។

សូមចង្អុលបង្ហាញពាក្យ *អ្នកដាំ* នៅក្នុង ខទី ១ ។

- តើអ្នកដាំជានរណា ? (មនុស្សម្នាក់ដែលថែទាំចម្ការទាំងបាយជូរ) ។
- យោងតាម ខទី ១–២តើព្រះវរបិតាសួគ៌ប្រៀបបាននឹងអ្នកដាំដោយរបៀបណា ? (សូមពន្យល់ថា ព្រះជាព្រះវរបិតាបានដាំដើមទំពាំងបាយជូរពិត [ព្រះយេស៊ូវគ្រីស្ទ]ដែលមនុស្សជទៃនឹងទទួលបានការចិញ្ចឹមបីបាច់) ។

សូមបង្ហាញដល់សិស្ស នូវមែកតូចមួយដែលអ្នកបានកាច់មកពីដើមឈើមួយ ហើយពន្យល់ថាតើអ្នកនឹងមានអារម្មណ៍រីករាយបែបណាសម្រាប់ពេលដែលអ្នកអាចបេះផលផ្លែមួយចំនួនពីមែកនេះមកទទួលទាន ។ ចូរសួរដល់សិស្សថា តើពួកគេគិតថាអ្នកនឹងអាចទទួលទានផលផ្លែនោះមកពីមែកនោះនៅពេលណាដែរ ។

- ហេតុអ្វីមែកនេះនឹងពុំផ្តល់ផលផ្លែអ្វីសោះឡើយ ? (ដោយសារវាបានកាច់ចេញពីដើម វាមិនអាចទទួលការចិញ្ចឹមបីបាច់ឲ្យបង្កើតផលផ្លែបានទេ) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៥:៤–៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យដើរតាម រកមើលថាតើព្រះអង្គសង្គ្រោះបានបន្ទូលថា អ្វីទៅដែលចាំបាច់ដើម្បីធ្វើឲ្យមែកមួយមានផលផ្លែ ។

- តើព្រះយេស៊ូវបានបន្ទូលថាអ្វីទៅ ដែលចាំបាច់ដើម្បីធ្វើឲ្យមែកមួយមានផលផ្លែ ? (មែកនោះត្រូវតែ « នៅជាប់ » នឹងដើមទំពាំងបាយជូរ) ។
- តើមែកនេះប្រៀបបាននឹងមនុស្សម្នាក់ដែលបានបែកចេញ ឬបានកាត់ចេញពីព្រះអង្គសង្គ្រោះដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យពិចារណាគូសចំណាំឧទាហរណ៍នីមួយៗនៃពាក្យ *នៅជាប់* ឬ *បានជាប់នឹង* នៅក្នុង ខទី ៤–៥ ។ សូមពន្យល់ថា ពាក្យ *នៅជាប់*ពេលប្រើនៅក្នុងខគម្ពីរទាំងនេះ មានន័យថា បន្តនៅយ៉ាងរឹងមាំ ហើយស្ថិតស្ថេរជានិច្ចជាប់នឹងព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់ (សូមមើល ដៃហ្រ្វី អ័រ ហូឡិន « Abide in Me » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៣២) ។

- យោងតាម ខទី ៥តើលទ្ធផលនៃការនៅជាប់ ឬការតភ្ជាប់យ៉ាងរឹងមាំនឹងព្រះអង្គសង្គ្រោះជាអ្វី ? (សិស្សរបស់ព្រះយេស៊ូវគ្រីស្ទនឹងនាំមកនូវផលផ្លែយ៉ាងច្រើន) ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះយើងនឹងនៅជាប់នឹងសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ហើយ . . .* ។

ដើម្បីជួយសិស្សឲ្យយល់ពីវិធីមួយ ដែលព្រះយេស៊ូវគ្រីស្ទជួយយើងឲ្យគោរពតាមព្រះបញ្ញត្តិ ហើយនៅជាប់នឹងសេចក្តីស្រឡាញ់របស់ទ្រង់ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ៖

« វាគឺ . . . តាមរយៈព្រះគុណរបស់ព្រះអម្ចាស់ តាមរយៈសេចក្តីជំនឿលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្តពីអំពើបាបទាំងឡាយរបស់ពួកគេ ដែលបុគ្គលទាំងឡាយនឹងទទួលបានកម្លាំង និងជំនួយដើម្បីធ្វើកិច្ចការល្អនានា បើពុំដូចនោះទេពួកគេនឹងមិនមានលទ្ធភាពដើម្បីបន្តឡើយ ប្រសិនបើត្រូវទុកឲ្យពួកគេធ្វើដោយខ្លួនឯងនោះ ។ ព្រះគុណនេះ គឺជាអំណាចមួយដែលអាចធ្វើអ្វីបានទាំងអស់ ដែលអនុញ្ញាតឲ្យបុរស និងស្ត្រីទទួលបានជីវិតអស់កល្បជានិច្ច និងការលើកតម្កើង បន្ទាប់ពីពួកគេបានពង្រីកការខិតខំរបស់ពួកគេឲ្យអស់ពីសមត្ថភាពរបស់ពួកគេផ្ទាល់ » (Bible Dictionary « Grace »)

- តើវិធីមួយចំនួន ដែលព្រះយេស៊ូវគ្រីស្ទពង្រឹងយើងឲ្យគោរពតាមព្រះបញ្ញត្តិមានអ្វីខ្លះ ?

សូមសង្ខេប យ៉ូហាន ១៥:៦–៨ដោយពន្យល់ថាព្រះអង្គសង្គ្រោះ បានបង្រៀនថា អស់អ្នកដែលពុំនៅជាប់នឹងទ្រង់ គឺដូចជាមែកដែលត្រូវបានកាត់ចេញ ។ វាស្ងិតស្ងោ ហើយងាប់ ប៉ុន្តែបុគ្គលម្នាក់ដែលនៅជាប់នៅក្នុងព្រះយេស៊ូវគ្រីស្ទបង្កើតកិច្ចការសុចរិតដែលសរសើរតម្កើងដល់ព្រះ ។

- តើយើងអាចធ្វើអ្វីខ្លះដើម្បីនៅជាប់ជាមួយ ឬ មានទំនាក់ទំនងយ៉ាងរឹងមាំចំពោះព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៥:៩–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ឲ្យធ្វើ និង ពរជ័យដែលពួកគេនឹងបានទទួល ។

- តើព្រះយេស៊ូវបានបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យធ្វើអ្វីខ្លះ ?
- តើការគោរពតាមព្រះបញ្ញត្តិអនុញ្ញាតឲ្យយើងនៅជាប់នឹងសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះបានដោយរបៀបណា ? (សូមពន្យល់ថា កាលព្រះវរបិតា និង ព្រះរាជបុត្រាស្រឡាញ់ពួកយើងដោយសេចក្តីស្រឡាញ់ដ៏ឥតខ្ចោះ និងអស់កល្បជានិច្ច ការរក្សាបទបញ្ញត្តិរបស់ពួកទ្រង់ធ្វើឲ្យយើងទទួលបាននូវពរជ័យដ៏ពេញលេញ ដែលពួកទ្រង់មានព្រះទ័យប្រទានដល់យើងដោយសេចក្តីស្រឡាញ់ | សូមមើល នីហ្វៃទី ១ ១៧:៣៥, គ. និង ស ៩៥:១២, ១៣០:២០–២១|) ។

- យោងតាម ខទី ១១ហេតុអ្វីបានជាព្រះយេស៊ូវបង្រៀនពួកសិស្សរបស់ទ្រង់ឲ្យនៅជាប់នឹងទ្រង់ ហើយនាំមកនូវកិច្ចការសុចរិត ?

ចូរសួរសិស្សថា តើពួកគេនឹងបំពេញឃ្លាមិនពេញលេញនៅលើក្តារខៀននោះយ៉ាងដូចម្តេច ដើម្បីឲ្យវាក្លាយជាគោលការណ៍មួយ ដោយផ្អែកលើអ្វីដែលពួកគេបានអាននៅក្នុង ខទី ១១ ។ (សូមបំពេញឃ្លានៅលើក្តារខៀន ដោយប្រើពាក្យរបស់សិស្សដើម្បីនាំទៅរកគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងគោរពព្រះបញ្ញត្តិទាំងឡាយ នោះយើងនឹងនៅជាប់ជាមួយសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ហើយទទួលអំណរពោរពេញ**) ។

- ហេតុអ្វីអ្នកគិតថា ការនៅជាប់ជាមួយព្រះអង្គសង្គ្រោះធ្វើឲ្យយើងទទួលបាននូវសេចក្តីអំណរពេញលេញ ?

ចូរសុំឲ្យសិស្សគិតពីមនុស្សម្នាក់ដែលពួកគេស្គាល់ដែលមានអំណរ ដោយសារគាត់នៅជាប់នឹងព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីមនុស្សម្នាក់ ដែលពួកគេគិតដល់ ហើយពន្យល់ពីហេតុផលដែលបុគ្គលម្នាក់នោះគឺជាគំរូមួយដ៏ល្អសម្រាប់គោលការណ៍នេះ ។ អ្នកក៏គួរពិចារណាអញ្ជើញសិស្សឲ្យចែកចាយពីរបៀប ដែលនៅជាប់នឹងព្រះអង្គសង្គ្រោះបាននាំយកអំណារឲ្យពួកគេ ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីវិធី ដែលពួកគេអាចបន្តនៅជាប់យ៉ាងរឹងមាំនឹងព្រះអង្គសង្គ្រោះ ហើយក្រោយមកទទួលបានអំណរកាន់តែប្រសើរឡើង ។

យ៉ូហាន ១៥:១២–១៧

ព្រះយេស៊ូវបញ្ជាពួកសិស្សរបស់ទ្រង់ឲ្យស្រឡាញ់គ្នាទៅវិញទៅមក

សូមសរសេរនៅលើ ក្តារខៀន នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន រ័សុល អិម ណិលសុន ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ។ (សេចក្តីថ្លែងការណ៍នេះមាននៅក្នុង « The Mission and Ministry of Jesus Christ » *Ensign* ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៣៨) ។

« ច្បាស់ណាស់ ភស្តុតាងដ៏ល្អបំផុតនៃការគោរពស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវ គឺការយកគំរូតាមទ្រង់របស់យើង » (ប្រធាន រ័សុល អិម ណិលសុន) ។

សូមគូសបន្ទាត់ក្រោមពាក្យ *សេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់* និង *ការធ្វើគំរូតាម* នៅក្នុងឃ្លាលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យពន្យល់ពីអត្ថន័យនៃពាក្យ ដែលបានគូសបន្ទាត់ពីក្រោម ។ (*សេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់* គឺជាសេចក្តីស្រឡាញ់ និង ការគោរពយ៉ាងខ្លាំង ហើយ *ការធ្វើគំរូតាមទ្រង់* មានន័យថា ត្រាប់តាម ឬ ចម្លងតាម) ។

- ហេតុអ្វីអ្នកគិតថា សេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់ចំពោះព្រះយេស៊ូវ គឺជាវិធីមួយដ៏ល្អបំផុតដើម្បីបង្ហាញថា យើងស្រឡាញ់ ហើយគោរពទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ១៥:១២ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើព្រះអង្គសង្គ្រោះបានសុំឲ្យយើងផ្តល់សេចក្តីស្រឡាញ់ដ៏ខ្ពង់ខ្ពស់ដល់ទ្រង់យ៉ាងដូចម្តេច ។

- តើព្រះយេស៊ូវបានបង្គាប់ឲ្យយើងធ្វើអ្វីខ្លះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអង្គសង្គ្រោះបានបង្គាប់ឲ្យយើងស្រឡាញ់គ្នា ដូចជាទ្រង់ស្រឡាញ់យើង ។** សូមលើកទឹកចិត្តសិស្សឲ្យពិចារណាគូសចំណាំសេចក្តីពិតនេះនៅក្នុង ខទី ១២) ។
- តើអ្នកគិតថា ដើម្បីស្រឡាញ់មនុស្សម្នាក់តាមរបៀបដែលព្រះយេស៊ូវគ្រីស្ទស្រឡាញ់អ្នក មានន័យយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សអាន យ៉ូហាន ១៥:១៣–១៧ដោយស្ងៀមស្ងាត់រកមើលរបៀបដែលព្រះអង្គសង្គ្រោះបានស្រឡាញ់យើង ។ បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមបំបែកពួកគេជាគូ ហើយសុំឲ្យពួកគេពិភាក្សាគ្នាពីអ្វីដែលពួកគេបានរកឃើញ ។ បន្ទាប់មក សួរសំណួរដូចខាងក្រោមនេះ ៖

- យោងតាម ខទី ១៣តើព្រះអង្គសង្គ្រោះបានមានបន្ទូលថា ការបង្ហាញសេចក្តីស្រឡាញ់ដ៏ធំបំផុតគឺជាអ្វី ?
- តើទ្រង់បានបង្ហាញសេចក្តីស្រឡាញ់បែបនេះតាមរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីអត្ថន័យនៃការលះបង់ជីវិតរបស់យើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដោយអែលឌើរ ក្លូឌីអូ អរ អែម កូស្តា នៃពួកចិតសិបនាក់ ៖



« [ព្រះយេស៊ូវគ្រីស្ទ] បានប្រទានដល់យើងពីគំរូដ៏អស្ចារ្យនៃសេចក្តីស្រឡាញ់ កាលទ្រង់បានប្រកាសថា ‹ គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិតជំនួសពួកសំឡាញ់របស់ខ្លួននោះទេ › [យ៉ូហាន ១៥:១៣] ។ ក្រោយមកទៀត ទ្រង់បានធ្វើឲ្យនសម្រាប់អំពើបាបរបស់យើងរាល់គ្នា ហើយនៅទីបំផុតបានលះបង់ជីវិតរបស់ទ្រង់សម្រាប់យើងគ្រប់គ្នា ។

« យើងអាចលះបង់ជីវិតរបស់យើងចំពោះអស់អ្នកដែលយើងស្រឡាញ់បានដោយពុំមែនដោយស្លាប់ខាងរូបកាយរបស់យើងសម្រាប់ពួកគេឡើយ ប៉ុន្តែដោយការរស់នៅសម្រាប់ពួកគេ—គឺផ្តល់ពេលវេលារបស់យើង មានវត្តមានជានិច្ចនៅក្នុងជីវិតរបស់ពួកគេ បម្រើពួកគេ មានភាពគួរសម មានសេចក្តីសប្បុរស ហើយបង្ហាញសេចក្តីស្រឡាញ់ពិតចំពោះអស់អ្នកដែលជាគ្រួសាររបស់យើង និង ដល់មនុស្សទាំងអស់ —ដូចដែលព្រះអង្គសង្គ្រោះបានបង្រៀន » (« Don't Leave for Tomorrow What You Can Do Today » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៧៤) ។

- យោងតាមអែលឌើរ កូស្តា តើវិធីមួយចំនួនដែលយើងអាចលះបង់ជីវិតរបស់យើងសម្រាប់មនុស្សដទៃទៀតមានអ្វីខ្លះ ?
- តើធ្លាប់មាននរណាម្នាក់បានលះបង់ជីវិតខ្លួនតាមរបៀបមួយបែបនេះសម្រាប់អ្នកនៅពេលណា ?

សូមអញ្ជើញសិស្សសញ្ជឹងគិតពីព្រះបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះឲ្យស្រឡាញ់គ្នាដូចជាទ្រង់ស្រឡាញ់យើង ។ សូមទុកពេលឲ្យពួកគេពីរបីនាទី ដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរបស់ពួកគេ អំពីមនុស្សម្នាក់ដែលពួកគេជឿថា ព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យពួកគេបង្ហាញសេចក្តីស្រឡាញ់ និងពីផែនការមួយពី របៀប ដែលពួកគេនឹងធ្វើរឿងនោះ ។

ជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ

សិស្សនឹងអនុវត្តគោលលទ្ធិ និង គោលការណ៍ដែលពួកគេបានរកឃើញ នៅក្នុងព្រះគម្ពីរ នៅពេលពួកគេទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់របស់វា តាមរយៈព្រះវិញ្ញាណ ហើយទទួលអារម្មណ៍ពីភាពបន្ទាន់មួយចំនួន ដើម្បីបញ្ចូលវានៅក្នុងជីវិតរបស់ពួកគេ ។ វិធីដ៏មានប្រសិទ្ធភាពមួយដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ទាំងឡាយ គឺត្រូវលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិត ហើយសរសេរអំពីវិធី ដែលពួកគេអាចអនុវត្ត ឬរស់នៅតាមសេចក្តីពិតដែលពួកគេបានរៀន ។

យ៉ូហាន ១៥:១៨–២៧

ព្រះយេស៊ូវព្រមានពួកសិស្សរបស់ទ្រង់អំពីការបៀតបៀន ដែលពួកគេនឹងជួបប្រទះចំពោះការថ្លែងទីបន្ទាល់អំពីទ្រង់

សូមពន្យល់ថាបន្ទាប់ពីព្រះអង្គសង្គ្រោះបានបង្រៀនអំពីការនៅជាប់នឹងទ្រង់ ហើយបង្ហាញសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក នោះទ្រង់បានបង្រៀនពួកគេអំពីអ្វីដែលបានកើតឡើងដល់ពួកគេ ដោយសារតែសាក្សីពិសេសដែលពួកគេមានអំពីទ្រង់ និងទំនួលខុសត្រូវដើម្បីចែកចាយ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ១៥:១៨–២០ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះយេស៊ូវបានបង្រៀនថា តើលោកិយនេះនឹងប្រព្រឹត្តចំពោះពួកសិស្សរបស់ទ្រង់យ៉ាងដូចម្តេច ។ (សូមពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះ ពាក្យ « លោកិយ » សំដៅទៅលើមនុស្សដែលប្រព្រឹត្តបាប ហើយបដិសេធព្រះ) ។

- តើព្រះយេស៊ូវបានមានបន្ទូលថា លោកិយនឹងប្រព្រឹត្តចំពោះពួកសិស្សរបស់ទ្រង់យ៉ាងដូចម្តេច ?

អ្នកគួរចង្អុលបង្ហាញដល់សិស្សថា ដោយសារ « លោកិយបានស្អប់ » ពួកសិស្សរបស់ព្រះអង្គសង្គ្រោះ នោះសិស្សនឹងទំនងជាជួបការប្រឆាំងនឹងពួកមរមន និងប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងវិបសាយដែលពេញដោយការស្អប់ ។ សិស្សមួយចំនួននឹងជួបនូវការបដិសេធ ការចំអក និងការបំភិតបំភ័យតាមរយៈឥរិយាបថខឹងសម្បារ រួមទាំងការធ្វើសារបំភ័យផងដែរ ។

ប្រសិនបើអាចធ្វើបាន អ្នកគួរពិចារណាណែនាំសិស្សពីរបៀប និងទីកន្លែងស្វែងរកចម្លើយសម្រាប់ការចោទប្រកាន់ ដែលពេញដោយការស្អប់ទាស់នឹងសាសនាចក្រ ។ បន្ថែមពីលើការស្វែងរកជំនួយពីពួកមជ្ឈិមវ័យ ដែលទុកចិត្ត សិស្សអាចស្វែងរកធនធានតាមអ៊ិនធើរណែត នៅ mormonnewsroom.org, lds.org/topics និង seektruth.lds.org ។

សូមសង្ខេប យ៉ូហាន ១៥:២១–២៥ ដោយពន្យល់ថាព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថា អស់អ្នកដែលស្អប់ទ្រង់ ក៏ស្អប់ព្រះវរបិតាដែរ ហើយថាពួកគេនឹងត្រូវទទួលខុសត្រូវចំពោះជម្រើសរបស់ពួកគេ ។

សូមពន្យល់ថា ទោះបីជាមានការស្អប់ខ្ពើម និង ការបៀតបៀនពីសំណាក់មនុស្សដទៃចំពោះពួកអ្នកដើរតាមព្រះអង្គសង្គ្រោះក្តី ក៏ព្រះយេស៊ូវគ្រីស្ទបានប្រទានរបៀបនានាសម្រាប់ពិភពលោក ដើម្បីទទួលនូវទីបន្ទាល់អំពីទ្រង់ ។ សូមអញ្ជើញសិស្សអាន យ៉ូហាន ១៥:២៦–២៧ដោយស្ងៀមស្ងាត់រកមើលសាក្សីដែលនឹងថ្លែងទីបន្ទាល់ អំពីព្រះយេស៊ូវគ្រីស្ទទៅកាន់ពិភពលោក ។

- តើនរណាដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា នឹងថ្លែងទីបន្ទាល់ពីទេវភាពរបស់ទ្រង់ ? (ព្រះវិញ្ញាណបរិសុទ្ធ និងពួកសិស្សរបស់ព្រះអង្គសង្គ្រោះ) ។

សូមអញ្ជើញសិស្សសញ្ជឹងគិតអំពីគោលការណ៍ និងសេចក្តីពិតនានា នៅក្នុងមេរៀននេះ ។ សូមលើកទឹកចិត្តពួកគេឲ្យពិនិត្យមើលឡើងវិញ នូវអារម្មណ៍ដែលពួកគេត្រូវបានបំផុសគំនិតឲ្យធ្វើ ហើយធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួលពីព្រះវិញ្ញាណបរិសុទ្ធ ។

មេរៀនសិក្សានៅផ្ទះ

យ៉ូហាន ១១–១៥ (មេរៀនទី ១៥)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា យ៉ូហាន ១១–១៥ (មេរៀនទី ១៥) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (យ៉ូហាន ១១)

នៅពេលសិស្សអានអំពីព្រះយេស៊ូវប្រោសឡាសារឲ្យរស់ពីស្លាប់ ពួកគេបានរៀនពីគោលការណ៍ខាងក្រោមនេះ ៖ យើងអាចជ្រើសរើសដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ អំឡុងពេលការសោកល្វងរបស់យើង ។ ព្រះយេស៊ូវគ្រីស្ទគឺជាអង្គរស់ឡើងវិញ និង ជាជីវិត ។ ប្រសិនបើយើងជឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ប្រសិនបើយើងជ្រើសរើសអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ អំឡុងពេលការសោកល្វងរបស់យើង នោះសេចក្តីជំនឿរបស់យើងទៅលើទ្រង់នឹងត្រូវបានបញ្ជាក់ ព្រមទាំងកាន់តែសឹងជម្រៅ ។

ថ្ងៃទី ២ (យ៉ូហាន ១២)

នៅក្នុងមេរៀននេះសិស្សបានសិក្សាអំពីម៉ារា ជាបងស្រីរបស់ម៉ាថា និងឡាសារ ការលាបប្រេងលើព្រះបាទារបស់ព្រះយេស៊ូវ និងការយាងចូលមកក្នុងទីក្រុងយេរូសាឡិមដោយជោគជ័យ ។ ពួកគេក៏បានសិក្សាអំពីការបង្រៀនរបស់ព្រះយេស៊ូវនៅក្រុងយេរូសាឡិមដែរ ។ ចេញពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ សិស្សបានរៀនសេចក្តីពិតដូចខាងក្រោមនេះ ៖ អព្ភូតហេតុតែម្យ៉ាងមិនបានបណ្តាលឲ្យយើងជឿលើព្រះយេស៊ូវគ្រីស្ទទេ ។ ការខ្វល់ខ្វាយកាន់តែច្រើនពីការបំពេញចិត្តរបស់មនុស្សដទៃ ជាជាងបំពេញតាមព្រះទ័យដល់ព្រះ អាចរាំងយើងពីការទទួលស្គាល់ដោយបើកចំហរពីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ និង ជំណឹងល្អរបស់ទ្រង់ ។ ប្រសិនបើយើងជឿលើព្រះយេស៊ូវគ្រីស្ទ យើងមិនត្រូវរស់នៅក្នុងសេចក្តីងងឹតខាងវិញ្ញាណឡើយ ។

ថ្ងៃទី ៣ (យ៉ូហាន ១៣)

នៅពេលសិស្សអានដំណើររឿងស្តីពីព្រះអង្គសង្គ្រោះលាងជើងឲ្យពួកសាវក នោះពួកគេបានរៀនពីសេចក្តីពិតដូចខាងក្រោម ៖ នៅពេលយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះដោយការបម្រើដល់អ្នកដទៃ នោះយើងនឹងកាន់តែមានសុមង្គល ។ នៅពេលយើងស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូវគ្រីស្ទស្រឡាញ់យើង នោះមនុស្សដទៃទៀតនឹងស្គាល់ថាយើងគឺជាសិស្សរបស់ទ្រង់ ។

ថ្ងៃទី ៤ (យ៉ូហាន ១៤–១៥)

នៅក្នុងមេរៀននេះ សិស្សបានសិក្សាការបង្រៀនដែលព្រះអង្គសង្គ្រោះបានបង្ហាញទៅកាន់ពួកសាវករបស់ទ្រង់ ពីមុនទ្រង់បានចាប់ផ្តើមពលិកម្មដ្ឋនរបស់ទ្រង់ ។ ពួកគេបានរៀនថា មានតែតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង តាមរយៈការធ្វើតាមមាគ៌ារបស់ទ្រង់ប៉ុណ្ណោះ ទើបយើងអាចចូលទៅក្នុងនគររបស់ព្រះវរបិតាសួគ៌បាន ។ ពួកគេក៏បានរៀនផងដែរថា យើងបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូវគ្រីស្ទដោយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ហើយថាព្រះវិញ្ញាណបរិសុទ្ធអាចលួងលោមយើង បង្រៀនយើងពីគ្រប់សេចក្តីទាំងអស់ ក៏នឹងរំឭកពីគ្រប់អ្វីគ្រប់យ៉ាងដែរ ។ នៅពេលសិស្សបានសិក្សាអំពីដើមទំពាំងបាយជូរ និងមែករបស់វា ពួកគេបានរៀនថា ប្រសិនបើយើងគោរពព្រះបញ្ញត្តិ យើងនឹងរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ហើយបានទទួលសេចក្តីអំណរយ៉ាងពេញលេញ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់ពីអ្វី ដែលពួកគេត្រូវធ្វើដើម្បីត្រឡប់ទៅកព្រះវរបិតាសួគ៌វិញ ។ លើសពីនេះទៀត នៅពេលសិស្សពិនិត្យឡើងវិញនូវការទូន្មានរបស់ព្រះអម្ចាស់ដូចដែលបានកត់ត្រាទុកនៅក្នុង យ៉ូហាន ១៤ពួកគេអាចពិចារណាពីរបៀប ដែលពួកគេអាចធ្វើតាមរបៀបរបស់ព្រះអង្គសង្គ្រោះឲ្យកាន់តែប្រសើរឡើង ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៤:១–១៤

ព្រះអង្គសង្គ្រោះបង្រៀនពួកសាវករបស់ទ្រង់ពីរបៀប ដើម្បីត្រឡប់ទៅកព្រះវរបិតាសួគ៌វិញ ។

បើអាចធ្វើទៅបាន ចូរដាក់បង្ហាញផែនទីទីក្រុងរបស់អ្នក ហើយអញ្ជើញសិស្សឲ្យប្រាប់ពីទីតាំងបច្ចុប្បន្នរបស់ពួកគេនៅលើនោះ ។ នៅលើផែនទីនោះ ចូរបង្ហាញពីទីកន្លែងមួយទៀតដែលសិស្សស្គាល់ ។ ចូរសុំឲ្យពួកគេសរសេរនៅលើក្រដាសមួយសន្លឹកពីរបៀបដំណើរពីទីតាំងបច្ចុប្បន្នរបស់ពួកគេទៅកាន់កន្លែងនោះ ។ សូមអញ្ជើញឲ្យសិស្សម្នាក់ ឬពីរនាក់ប្រាប់ពីអ្វីដែលពួកគេបានសរសេរ ។

ចូរសរសេរ *នគរសេឡេស្ទាល* នៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សពិចារណាពីទិសដៅដែលពួកគេនឹងប្រាប់ដល់មនុស្សម្នាក់ ដែលចង់ដឹងពីរបៀបទៅដល់នគរសេឡេស្ទាល ។

ចូររំឭកសិស្សថា នៅពេលពួកគេសិក្សា យ៉ូហាន ១៤ នៅក្នុងមេរៀនប្រចាំថ្ងៃរបស់ពួកគេ នោះពួកគេបានរៀនពីសេចក្តីពិតមួយដែលអាចជួយពួកគេឲ្យដឹងពីរបៀបត្រឡប់ទៅព្រះវរបិតាសួគ៌វិញ ហើយចូលទៅក្នុងនគរសេឡេស្ទាល ។ សូមពន្យល់ថា នៅក្នុងមេរៀននេះ ពួកគេនឹងរៀនបន្តែមទៀតអំពីសេចក្តីពិតនោះ ។

ដើម្បីជួយសិស្សឲ្យយល់ដឹងពីបរិបទនៃ យ៉ូហាន ១៤ ចូររំឭកពួកគេថា ព្រះអង្គសង្គ្រោះបានប្រារព្ធបុណ្យរំលងជាមួយនឹងពួកសាវករបស់ទ្រង់នៅបន្ទប់ខាងលើនៅក្រុងយេរូសាឡិម ។ បន្ទាប់ពីសោយអាហារបុណ្យរំលងហើយ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ទៅពួកសិស្សរបស់ទ្រង់ថា មិនយូរប៉ុន្មានទៀតទេ ទ្រង់នឹងចាកចេញពីពួកគេហើយ (សូមមើល យ៉ូហាន ១៣:៣៣) ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ១៤:១–៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះយេស៊ូវ បានបង្រៀនពួកសាវករបស់ទ្រង់ដើម្បីជួយលួងលោមពួកគេ ។

សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ យ៉ូហាន ១៤:៣ បានសរសេរថា « ហើយនៅពេលខ្ញុំទៅ ខ្ញុំនឹងរៀបកន្លែងឲ្យអ្នករាល់គ្នា ហើយត្រឡប់មកវិញ ហើយទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ » ។

- តើព្រះយេស៊ូវបានបង្រៀនអ្វីខ្លះ ដល់ពួកសាវករបស់ទ្រង់ដើម្បីជួយលួងលោមពួកគេ ?
- តើអ្នកគិតថាឃ្លា « នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន » (យ៉ូហាន ១៤:២) មានន័យដូចម្តេច ?

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយព្យាការី យ៉ូសែប ស្ម៊ីធ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវអត្ថន័យនៃឃ្លាដែលទ្រង់បានមានបន្ទូល ។



« [ឃ្លា]ថា ‹ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន › . . . គួរមានន័យថា—‹ នៅក្នុងនគរនៃព្រះវរបិតាខ្ញុំ មាននគរជាច្រើន › ដើម្បីឲ្យអ្នករាល់គ្នាអាចគ្រងមរតករបស់ព្រះ ហើយគ្រងមរតកជាមួយខ្ញុំ ។ . . . មានលំនៅសម្រាប់ជនដែលគោរពតាមក្រឹត្យវិន័យសេឡេស្ទាល ហើយមានលំនៅផ្សេងទៀតសម្រាប់ជនដែលមិនបានគោរពតាមក្រឹត្យវិន័យនោះ គឺមនុស្សគ្រប់រូបតាមលំដាប់របស់ខ្លួន » (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ២១៩) ។

អ្នកគួរផ្តល់ជាយោបល់ឲ្យសិស្សសរសេរពាក្យ *នគរ* និង *នគរទាំងឡាយ* នៅក្នុងព្រះគម្ពីររបស់ពួកគេនៅខាងលើពាក្យ *ដំណាក់* និង *លំនៅ* នៅក្នុង យ៉ូហាន ១៤:២ ។

- តើការបង្រៀនណាមួយនៅក្នុង យ៉ូហាន ១៤:១–៤ បានក្លាយជាការលួងចិត្តដល់ពួកសាវក ?
- យោងតាម ខទី ៥តើថូម៉ាសបានឆ្លើយតបយ៉ាងដូចម្តេចដែរ ចំពោះការបង្រៀនរបស់ព្រះអង្គសង្គ្រោះថា ពួកសាវករបស់ទ្រង់បានស្គាល់ផ្លូវទៅនគរព្រះវរបិតាសួគ៌ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៤:៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលចម្លើយរបស់ព្រះយេស៊ូវ ចំពោះសំណួររបស់ថូម៉ាស ។ សូមឮកពួកគេថា នេះគឺជាចំណុះចំណានបទគម្ពីរមួយ ។

- តើព្រះយេស៊ូវបានឆ្លើយតបនឹងសំណួររបស់ថូម៉ាសយ៉ាងដូចម្តេច ?

សូមគូរគន្លងផ្លូវមួយនៅលើក្តារខៀន ។ នៅចុងម្ខាងនៃគន្លងផ្លូវនោះ៖ សូមសរសេរថា*យើង*ហើយម្ខាងទៀតសរសេរថា*នគរព្រះវរបិតាសួគ៌* ។ សូមសរសេរ*ផ្លូវ*ពីក្រោយគន្លងផ្លូវ ហើយចង្អុលបង្ហាញថា ឃ្លានេះសំដៅលើគន្លងផ្លូវដែលដឹកនាំពីកន្លែងមួយទៅកន្លែងមួយទៀត ។

- តើព្រះអង្គសង្គ្រោះគឺជាផ្លូវយ៉ាងដូចម្តេច ? (សិស្សអាចនឹងឆ្លើយថា ព្រះអង្គសង្គ្រោះបង្ហាញពីរបៀបរស់នៅ ដើម្បីប្រែក្លាយដូចជាព្រះ និងរបៀបមានភាពសក្តិសម ដើម្បីរស់នៅក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌) ។

សូមសរសេរ *សេចក្តីពិត* និង *ជីវិត* នៅលើក្តារខៀនក្រោមពាក្យ « ផ្លូវ » ។

- តើព្រះយេស៊ូវគ្រីស្តជាសេចក្តីពិតតាមរបៀបណាខ្លះ ? (ទ្រង់គឺជាប្រភពនៃរាល់សេចក្តីពិត ហើយបានរស់នៅតាមរាល់សេចក្តីពិតយ៉ាងល្អឥតខ្ចោះ) ។
- តើព្រះយេស៊ូវគ្រីស្តជាជីវិតតាមរបៀបណាខ្លះ ? (ទ្រង់ធ្វើឲ្យយើងអាចយកឈ្នះលើសេចក្តីស្លាប់ខាងរូបកាយ ហើយរស់ឡើងវិញជាមួយរូបកាយអមតៈ ហើយយកឈ្នះលើសេចក្តីស្លាប់ខាងវិញ្ញាណ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ទ្រង់គឺជា « ពន្លឺដែលនៅក្នុងគ្រប់ទាំងអស់ ដែលផ្តល់ជីវិតដល់គ្រប់ទាំងអស់ » [គ. និង ស. ៨៨:១៣]) ។

នៅក្រោមរូបគំនូរអំពីគន្លងផ្លូវនៅលើក្តារខៀន សូមសរសេរ *ព្រះយេស៊ូវគ្រីស្ទគឺ* នៅក្បែរ « ផ្លូវ » ។

- យោងតាមអ្វីដែលយើងបានពិភាក្សា និងអ្វីដែលអ្នកបានរៀននៅក្នុងមេរៀនប្រចាំថ្ងៃរបស់អ្នក តើអ្នកនឹងសង្ខេបអត្ថន័យនៃព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះថា « បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ » យ៉ាងដូចម្តេចដែរ ? (យ៉ូហាន ១៤:៦) ។ (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ៖ ៖ **មានតែតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង តាមរយៈការធ្វើតាមរបៀបរបស់ទ្រង់ប៉ុណ្ណោះទើបយើងអាចចូលទៅក្នុងនគររបស់ព្រះវរបិតាសួគ៌បាន**) ។
- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងព្យាយាមធ្វើតាមរបៀបមួយដែលពុំមែនជារបៀបរបស់ព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍របស់អែលឌើរ លូរែន អ៊ី ឌូប្រីតហ្គ នៃពួកចិតសិបនាក់ដូចខាងក្រោមនេះ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលអ្វីដែលកើតឡើង ប្រសិនបើយើងព្យាយាមធ្វើតាមរបៀបមួយដែលពុំមែនជារបៀបរបស់ព្រះអម្ចាស់ ។

« ព្រះយេស៊ូវគ្រីស្ទ គឺជាផ្លូវ ។ ទ្រង់គឺជាពន្លឺ និងជីវិត ជានំបុ័ង និងទឹក ជាទីចាប់ផ្តើម និងទីបញ្ចប់ ជាការរស់ឡើងវិញ និងជីវិត ជាព្រះអង្គសង្គ្រោះនៃលោកិយ ជាសេចក្តីពិត និងជាផ្លូវ ។

« មានផ្លូវតែមួយគត់ដែលនាំទៅរកសុភមង្គល និងភាពពេញលេញ ។ ទ្រង់គឺជាផ្លូវនោះ ។ រាល់ផ្លូវផ្សេងទៀត ផ្លូវផ្សេងទៀតណាក្តី ទោះជាផ្លូវណាក៏ដោយ គឺជាភាពឆ្គួតលីលា ។ . . .

« ផ្លូវរបស់ព្រះអម្ចាស់មិនលំបាកទេ ។ ជីវិតគឺពិបាក ប៉ុន្តែជំណឹងល្អមិនដូច្នោះទេ ។ ‹ មានការផ្តួយចំពោះរឿងសព្វសារពើ › [នីហ្វៃទី ២ ២:១១] នៅគ្រប់ទីកន្លែងសម្រាប់មនុស្សគ្រប់គ្នា ។ ជីវិតធ្វើឲ្យយើងទាំងអស់គ្នាមានការលំបាក ប៉ុន្តែជីវិតក៏មានភាពសាមញ្ញផងដែរ ។ យើងមានការជ្រើសរើសតែពីប៉ុណ្ណោះ ។ យើងអាចដើរតាមព្រះអម្ចាស់ ហើយទទួលបាននូវព្រះចេស្តារបស់ទ្រង់ ហើយមានសេចក្តីសុខសាន្ត ពន្លឺ កម្លាំង ចំណេះដឹង ភាពជឿជាក់ សេចក្តីស្រឡាញ់ និងអំណរក៏បាន ឬក៏យើងអាចទៅផ្លូវមួយចំនួននានាទៀត ផ្លូវផ្សេងណាមួយ ផ្លូវផ្សេងណាក៏បានដែរ ហើយដើរលើផ្លូវនោះតែម្នាក់ឯង—ដោយគ្មានជំនួយរបស់ទ្រង់ គ្មានការគាំទ្ររបស់ទ្រង់ គ្មានព្រះចេស្តារបស់ទ្រង់ គ្មានការដឹកនាំរបស់ទ្រង់ នៅក្នុងសេចក្តីងងឹត ភាពចលាចល ការសង្ស័យ ទុក្ខសោក និងភាពអស់សង្ឃឹម ។ ហើយខ្ញុំសួរថា តើផ្លូវមួយណាងាយជាង ? . . .

« មានផ្លូវតែមួយគត់ដែលនាំទៅរកសុភមង្គល និងភាពពេញលេញ ។ ព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវ » (« The Way » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៣៤, ៣៦) ។

- យោងតាមអែលឌើរ ឌូប្រីតហ្គ តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងមិនធ្វើតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងធ្វើតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ?
- តើអ្វីទៅជារបៀបរបស់ព្រះអង្គសង្គ្រោះ ? (ប្រសិនបើចាំបាច់ ចូរឮកសិស្សថា របៀបរបស់ព្រះអម្ចាស់រួមមាន ការបង្កើនសេចក្តីជំនឿលើទ្រង់ និង ព្រះវរបិតាសួគ៌ ប្រែចិត្ត ទទួលពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ ដូចជាបុណ្យជ្រមុជទឹក និងពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ហើយស៊ូទ្រាំដរាបដល់ចុងបំផុត នៅក្នុងសេចក្តីជំនឿ និង ការគោរពប្រតិបត្តិ) ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតពីបទពិសោធន៍ដែលពួកគេធ្លាប់មាន ហើយដែលពួកគេត្រូវបានប្រទានឲ្យតាមរយៈការធ្វើតាមរបៀបរបស់ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេកំពុងធ្វើតាមរបៀបរបស់ព្រះអង្គសង្គ្រោះបានល្អកម្រិតណាដែរ ។ ចូរសុំឲ្យពួកគេគិតពីរបៀបមួយ ដែលពួកគេអាចធ្វើតាមព្រះអង្គសង្គ្រោះកាន់តែប្រសើរឡើង ហើយដាក់គោលដៅមួយដើម្បីអនុវត្តសកម្មភាពនោះ ។

សូមសង្ខេប យ៉ូហាន ១៤:៧–១៤ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនពួកសាវករបស់ទ្រង់ថា ព្រះរាជបំណងមួយរបស់ទ្រង់ក្នុងការយាងមកផែនដីគឺ ដើម្បីបើកសម្តែងតាមរយៈព្រះបន្ទូល និងទង្វើរបស់ទ្រង់នូវលក្ខណៈពិតរបស់ព្រះវរបិតាសួគ៌ ។ ទ្រង់ក៏បានសន្យាដល់ពួកសាវករបស់ទ្រង់ថា ពួកគេនឹងមានអំណាចដើម្បីធ្វើកិច្ចការដ៏អស្ចារ្យទាំងឡាយ ។

មេរៀនបន្ទាប់ (យ៉ូហាន ១៦–២១)

សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ នៅពេលពួកគេបញ្ចប់ការសិក្សារបស់ពួកគេនៅក្នុងដំណឹងល្អរបស់យ៉ូហាន ៖ តើព្រះយេស៊ូវបានមានបន្ទូលដូចម្តេចទៅមាតារបស់ទ្រង់ កាលទ្រង់ត្រូវបានគេឆ្កាងនៅលើឈើឆ្កាងនោះ ? តើនរណាជាមនុស្សដំបូង ដែលព្រះយេស៊ូវគ្រីស្តបានបង្ហាញអង្គទ្រង់ឲ្យឃើញ បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ ? តើនរណាទៅដែលបានបដិសេធមិនជឿទីបន្ទាល់របស់អ្នកឯទៀតថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញហើយ ? សូមអញ្ជើញសិស្សឲ្យស្រមៃពីអ្វី ដែលព្រះអង្គសង្គ្រោះនឹងមានបន្ទូលទៅកាន់ពួកសិស្សរបស់ទ្រង់ដែលបានឃើញទ្រង់ និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ប៉ុន្តែក្រោយមកបានសម្រេចចិត្តត្រឡប់ទៅធ្វើការងារចាស់របស់ខ្លួនវិញ ជាជាងការប្រកាសដំណឹងល្អនោះ ។ ចូរសុំឲ្យពួកគេមើលនៅក្នុងមេរៀនបន្ទាប់សម្រាប់អ្វី ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលទៅកាន់សិស្សទាំងនោះ ។

យ៉ូហាន ១៦

សេចក្តីផ្តើម

បន្ទាប់ពីសោយអាហារបុណ្យរំលងហើយ ព្រះយេស៊ូវគ្រីស្ទបានបន្តបង្រៀនដល់ពួកសិស្សរបស់ទ្រង់ ។ ទ្រង់បានបង្រៀនពួកគេថា មិនយូរប៉ុន្មានទេ ទ្រង់នឹងយាងទៅព្រះវរបិតា ហើយថាព្រះវិញ្ញាណបរិសុទ្ធ ឬព្រះដ៏ជាជំនួយនឹងយាងមក ហើយដឹកនាំពួកគេទៅរកាល សេចក្តីពិតទាំងអស់ ។ ព្រះយេស៊ូវបានព្យាករអំពីការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ព្រមទាំងបានប្រកាសថាទ្រង់នឹងមានជ័យជំនះលើពិភពលោក ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៦:១–១៥

ព្រះយេស៊ូវគ្រីស្ទអធិប្បាយអំពីតួនាទីនៃព្រះវិញ្ញាណបរិសុទ្ធ

សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកខាងមុខក្តារខៀន ។ សូមយកក្រណាត់បិទមុខសិស្សម្នាក់នោះ: ដើម្បីកុំឲ្យមើលឃើញ ។ បន្ទាប់ពីសិស្សនោះត្រូវបានបិទមុខហើយ សូមអញ្ជើញសិស្សផ្សេងទៀតដាក់ព្រះគម្ពីររបស់ពួកគេនៅកន្លែងណាមួយនៅក្នុងបន្ទប់រៀន ។ បន្ទាប់មក ចូរសួរសិស្សដែលត្រូវបានបិទមុខជិតនោះថា តើវាពិបាកយ៉ាងណាទៅដើម្បីស្វែងរកព្រះគម្ពីរជាក់លាក់មួយចំនួននៅក្នុងបន្ទប់រៀន ហើយបើកវាទៅទំព័រជាក់លាក់មួយនោះ: ។ ចូរសួរសិស្សនោះថា ប្រសិនបើមានមនុស្សស្ម័គ្រចិត្តជួយនាំគាត់ទៅរកព្រះគម្ពីរនោះ: តើវាជាការប្រសើរដែរទេ ។

សូមអញ្ជើញសិស្សដែលបានបិទមុខនោះឲ្យជ្រើសសិស្សម្នាក់ទៀតឲ្យដើរតួជាអ្នកនាំផ្លូវ ។ សូមអញ្ជើញសិស្សដែលត្រូវបានជ្រើសរើសឲ្យនាំសិស្សដែលបិទមុខជិតនោះ: ទៅរកព្រះគម្ពីរជាក់លាក់មួយចំនួន ហើយជួយគាត់ឲ្យស្វែងរកទំព័រជាក់លាក់ ។ បន្ទាប់ពីកិច្ចការទាំងនេះបានបញ្ចប់ហើយ សូមពន្យល់ថា កាលព្រះយេស៊ូវគ្រីស្ទគង់នៅលើផែនដី ទ្រង់បានបង្ហាត់បង្រៀនដល់ពួកសិស្សរបស់ទ្រង់ ។ ទ្រង់បាននាំពួកគេដោយផ្ទាល់ឲ្យយល់ដឹងពីសេចក្តីពិតដែលទ្រង់បានបង្រៀន ។

សូមសង្ខេប យ៉ូហាន ១៦:១–៤ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានសោយអាហារនៃបុណ្យរំលងជាមួយពួកសិស្សរបស់ទ្រង់ហើយ នោះទ្រង់បានប្រាប់ពួកគេថាពេលវេលានឹងមកដល់ នៅពេលមនុស្សនឹងស្អប់ពួកគេ ហើយថាមនុស្សទាំងនេះនឹងជឿថាអ្វី ដែលពួកគេកំពុងធ្វើគឺជាការបម្រើព្រះដោយសម្លាប់ពួកសិស្ស ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៦:៥–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលព្រះយេស៊ូវបានប្រាប់ពួកសិស្សរបស់ទ្រង់ និង របៀបដែលពួកគេមានអារម្មណ៍អំពីវា ។

- **តើពួកសិស្សមានអារម្មណ៍យ៉ាងណាដែរអំពីដំណឹងថា ព្រះយេស៊ូវនឹងយាងចេញពីពួកគេ ហើយថាពួកគេនឹងមានគេបៀតបៀននោះ: ?**

សូមអញ្ជើញសិស្សដែលកំពុងដើរតួជាអ្នកនាំផ្លូវដល់សិស្ស ដែលបានបិទភ្នែកជិតនោះឲ្យត្រឡប់ទៅកន្លែងអង្គុយវិញ ។ សូមសួរសិស្សបិទមុខនោះ: ៖

- **តើវាមានអារម្មណ៍បែបណាដែរ ដោយនៅម្នាក់ឯងម្តងទៀត គ្មានមិត្តចាំជួយអ្នកនោះ: ?**

ចូរឲ្យកៅអីមួយដល់សិស្សដែលបានបិទភ្នែកជិតនោះ: ហើយអញ្ជើញគាត់ឲ្យអង្គុយចុះ (ប៉ុន្តែកុំទាន់ស្រាយបើកភ្នែកឡើយ) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៦:៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល តើព្រះយេស៊ូវបានសន្យាថានរណាទៅដែលនឹងបានបញ្ជូនមក បន្ទាប់ពីទ្រង់បានយាងចេញទៅ ។

- **តើនរណាទៅដែលព្រះយេស៊ូវបានសន្យាថា នឹងបញ្ជូនមកបន្ទាប់ពីទ្រង់បានយាងចេញទៅ ? (ព្រះយេស៊ូវនឹងបញ្ជូនព្រះដ៏ជាជំនួយ ឬព្រះវិញ្ញាណបរិសុទ្ធ) ។**

សូមពន្យល់ថា ពាក្យ *ការចាំបាច់* ដែលប្រើនៅក្នុង ខទី ៧ មានន័យថាការចាត់ចែងដែលមានអត្ថប្រយោជន៍ ។ ចូរចង្អុលបង្ហាញថា « ព្រះវិញ្ញាណបរិសុទ្ធពុំបានដំណើរការពេញលេញនៅក្នុងចំណោមសាសន៍យូដានៅម៉ឺយរបស់ព្រះយេស៊ូវឡើយ (យ៉ូហាន ៧:៣៩, ១៦:៧) » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះវិញ្ញាណបរិសុទ្ធ ») ។ ដើម្បីជួយសិស្សឲ្យយល់ពីហេតុផលដែលព្រះវិញ្ញាណបរិសុទ្ធពុំបានដំណើរការពេញលេញ សូមអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ដរាបណាព្រះយេស៊ូវនៅជាមួយពួកសិស្សដោយផ្ទាល់ នោះវាពុំចាំបាច់ត្រូវការនូវភាពជាគ្រូកនដ៏ខ្ជាប់ខ្ជួនពេញលេញនៃព្រះវិញ្ញាណជាមួយពួកគេឡើយ ដូចបន្ទាប់ពីព្រះយេស៊ូវយាងទៅ » (*Doctrinal New Testament Commentary* រ៉ុល ៣ | ឆ្នាំ ១៩៦៥–៧៣ | ទំព័រ ៧៥៣) ។

សូមសង្ខេប យ៉ូហាន ១៦:៨–១២ ដោយពន្យល់ថា តួនាទីមួយរបស់ព្រះវិញ្ញាណបរិសុទ្ធគឺដើម្បីស្តីបន្ទោសពិភពនៃអំពើបាប ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៦:១៣ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលតួនាទីផ្សេងទៀតរបស់ព្រះដ៏ជាជំនួយនឹងបំពេញជីវិតរបស់ពួកសិស្សបន្ទាប់ពីទ្រង់បានយាងចាកចេញពីពួកគេទៅ ។

- តើតួនាទីអ្វីទៅដែលព្រះវិញ្ញាណបរិសុទ្ធនឹងបំពេញជីវិតរបស់ពួកសិស្សរបស់ព្រះអម្ចាស់ បន្ទាប់ពីទ្រង់បានយាងចេញទៅ ? តើពួកសិស្សអាចនឹងបានទទួលផលប្រយោជន៍ពីការជួយ និង ការដឹកនាំដែលព្រះវិញ្ញាណប្រទានឲ្យដោយរបៀបណា ?
- យោងតាមខទី ១៣តើអ្វីខ្លះដែលព្រះវិញ្ញាណបរិសុទ្ធក៏អាចធ្វើសម្រាប់យើងនៅជំនាន់របស់យើង ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ព្រះវិញ្ញាណបរិសុទ្ធអាចដឹកនាំយើងទៅរកការយល់សេចក្តីពិត ហើយបង្ហាញយើងនូវរឿងដែលនឹងកើតមាន**) ។
- តើព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងទៅរកសេចក្តីពិតតាមរបៀបណាខ្លះ ?
- តើព្រះវិញ្ញាណបរិសុទ្ធអាចបង្ហាញយើងនូវរឿង ដែលនឹងកើតឡើងតាមរយៈបៀបណាខ្លះ ? (ប្រសិនបើចាំបាច់ សូមពន្យល់ថា តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអាចប្រទាននូវការធានាអះអាង សេចក្តីសង្ឃឹម ការនិមិត្ត ការព្រមាន និង ការណែនាំសម្រាប់អនាគតរបស់យើង) ។

សូមដាក់វត្ថុមួយ (ជារង្វាន់) នៅលើថ្មើរមួយ ឬលើកៅអីមួយ ឬកន្លែងផ្សេងទៀតនៅក្នុងបន្ទប់រៀន ។ សូមអញ្ជើញសិស្សដែលបិទភ្នែកជិតស្វែងរកវត្ថុនោះ ។ សូមអញ្ជើញសិស្សម្នាក់ទៀតឲ្យខ្សឹបប្រាប់ទិសដៅដល់សិស្ស ដែលបិទភ្នែកនោះ ដើម្បីជួយគាត់សំដៅទៅរករង្វាន់នោះ ។ បន្ទាប់ពីសិស្សបានរកឃើញវត្ថុនោះហើយ សូមអញ្ជើញឲ្យស្រាយក្រណាត់ចេញ ។ សូមអញ្ជើញសិស្សទាំងពីរនាក់នោះ ឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយវិញ ។ សូមសួរសិស្ស ៖

- តើនៅពេលណា ដែលអ្នកធ្លាប់មានអារម្មណ៍ដឹងថា ព្រះវិញ្ញាណបរិសុទ្ធដឹកនាំអ្នកទៅរកសេចក្តីពិត ? តើអ្នកដឹងថា ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំអ្នកដោយរបៀបណា ?

អ្នកគ្រូចែកចាយបទពិសោធន៍មួយ កាលពួកគេត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់អ្នក ។ ដើម្បីជួយសិស្សឲ្យអនុវត្តសេចក្តីពិតដែលពួកគេបានរៀនសូត្រ សូមលើកទឹកចិត្តរបស់ពួកគេឲ្យរស់នៅតាមរបៀប ដែលអញ្ជើញការដឹកនាំនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេ ។

ចូរចង្អុលបង្ហាញថា យ៉ូហាន ១៦:១៣ បង្ហាញថា ព្រះវិញ្ញាណបរិសុទ្ធដែលមានតួនាទីថ្លែងសាក្សីពីព្រះវរបិតា និងព្រះរាជបុត្រានឹង « មានព្រះបន្ទូល មិនមែនដោយព្រះអង្គទ្រង់ទេ គឺនឹងមានព្រះបន្ទូលចំពោះតែសេចក្តីណាដែលទ្រង់ឮ ហើយនិងសំដែង » ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៦:១៤–១៥ ឲ្យឮៗ ហើយចូរសុំឲ្យសិស្ស ក្នុងថ្នាក់រកមើលថាតើសារលិខិតរបស់នរណាទៅដែលព្រះវិញ្ញាណបរិសុទ្ធនឹងមានបន្ទូលមកកាន់យើង ។

- តើសារលិខិតរបស់នរណាទៅ ដែលព្រះវិញ្ញាណបរិសុទ្ធនាំមកឲ្យយើង ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ព្រះវិញ្ញាណបរិសុទ្ធបើកសម្តែងសេចក្តីពិត និងសេចក្តីណែនាំដែលកើតចេញព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ**) ។
- តើហេតុអ្វីបានជាវាមានប្រយោជន៍ដើម្បីដឹងថា នៅពេលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់ពួកយើង នោះទ្រង់មានព្រះបន្ទូលជំនួសព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ ?

សូមពន្យល់ដល់សិស្សថាការសន្ទនារបស់ព្រះវិញ្ញាណបរិសុទ្ធទៅកាន់វិញ្ញាណរបស់អ្នក កាន់តែមានភាពជាក់ច្បាស់ ជាងការសន្ទនានានាដែលអ្នកអាចទទួលតាមរយៈញាណពីកំណើតរបស់អ្នកទៅទៀត » (*ព័តមំពោះសេចក្តីជំនឿ* | ឆ្នាំ ២០០៤ | ទំព័រ ៨២) ។ នេះមានន័យថា ព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកនាំផ្លូវដ៏មានតម្លៃបំផុតរបស់យើងនៅក្នុងការរៀនសូត្រពីសេចក្តីពិត ព្រះចេស្តារបស់ទ្រង់មានតម្លៃលើសជាងការបង្ហាញផ្ទាល់ភ្នែកពីទស្សនៈរបស់មនុស្សដទៃ ឬហេតុផលនៃពិភពលោកទៅទៀត ។ ដូចជាយើងដែរ សិស្សរបស់ព្រះអង្គសង្គ្រោះត្រូវរៀនពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធធ្វើជាអ្នកនាំផ្លូវនៅក្នុងការអវត្តមានរបស់ព្រះអម្ចាស់ ។

យ៉ូហាន ១៦:១៦–៣៣

ព្រះអង្គសង្គ្រោះពិគ្រោះអំពីការយាងចាកចេញពីជីវិតរមែងស្លាប់ ហើយប្រកាសថាទ្រង់បានយកឈ្នះពិភពលោកហើយ ។

សូមអញ្ជើញសិស្សឲ្យគិតពីគ្រាមួយ ដែលពួកគេត្រូវតែនិយាយលាដល់សមាជិកគ្រួសារម្នាក់ ឬមិត្តម្នាក់មួយរយៈ ។

- តើអ្នកនឹងនិយាយអ្វីខ្លះ ដើម្បីលួងលោមគ្នាទៅវិញទៅមកនៅពេលអ្នកនិយាយពាក្យថាលាគ្នា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានយ៉ូហាន ១៦:១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីផ្សេងទៀត ដែលព្រះយេស៊ូវបានប្រាប់ពួកសិស្សថានឹងលួងលោមចិត្តពួកគេ នៅពេលពួកគេបានគិតពីការយាងចេញរបស់ទ្រង់ ។ ចូរសុំឲ្យសិស្សប្រាប់អំពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា នៅក្នុង យ៉ូហាន ១៦:១៧–១៩ យើងអានថាពួកសិស្សពុំយល់ពី អ្វីដែលព្រះយេស៊ូវមានបន្ទូលនោះទេ នៅពេលទ្រង់មានបន្ទូលថា ទ្រង់កំពុងតែចាកចេញទៅ ប៉ុន្តែពួកគេនឹងឃើញទ្រង់ម្តងទៀត ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៦:២០–២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែល ព្រះអម្ចាស់មានបន្ទូលថាពួកសិស្សរបស់ទ្រង់នឹងមានអារម្មណ៍យ៉ាងណា នៅពេលទ្រង់ចាកចេញទៅ និង អ្វី ដែលពួកគេនឹងមានអារម្មណ៍ នៅពេលពួកគេបានឃើញទ្រង់ម្តងទៀត ។ អ្នកគ្រូតែពន្យល់ថា ឃ្លា « ស្ត្រីកាលណាហៀបនឹងសំរាលកូន » សំដៅលើម្តាយដែលហៀបនឹងសម្រាលកូន ។

ការចែកចាយបទពិសោធន៍ដែលពាក់ព័ន្ធ

ទាំងគ្រូនិងសិស្សគួរតែមានឱកាស ដើម្បីចែកចាយពីគំនិតនិង ការយល់ដឹងរបស់ពួកគេក៏ដូចជាបទពិសោធន៍ផ្ទាល់ខ្លួន ដែលពួកគេមានជាមួយនឹងគោលលទ្ធិឬគោលការណ៍មួយ ។ ពួកគេក៏អាចរៀបរាប់ពីបទពិសោធន៍ ដែលពួកគេបានឃើញនៅក្នុងជីវិតរបស់អ្នកដទៃផងដែរ ។ ប៉ុន្តែគ្រូបង្រៀនអាចជួយសិស្សឲ្យយល់ដឹងថា បទពិសោធន៍មួយចំនួនគឺពិសិដ្ឋក្រៃលែង ហើយមានលក្ខណៈយ៉ាងផ្ទាល់ខ្លួន ដើម្បីចែកចាយនឹងនៅក្នុងថ្នាក់រៀន (សូមមើល អាលម៉ា ១២:៩, គ. និង ស. ៦៣:៦៤) ។

- តើពួកសិស្សមានអារម្មណ៍យ៉ាងណា នៅពេលព្រះយេស៊ូវបានយាងចេញទៅ ? តើទ្រង់បានសន្យាថានឹងមានអ្វីកើតឡើងបន្ទាប់ពីនោះ ?

សូមពន្យល់ថា ពួកសិស្សរបស់ទ្រង់នឹងឃើញទ្រង់ម្តងទៀត បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ។ ទោះបីជាពួកគេកើតទុក្ខជាខ្លាំង ដោយសារការសុគតរបស់ទ្រង់ក្តី ក៏សេចក្តីអំណរដែលពួកគេនឹងទទួលបាននៅឯការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់នោះ នឹងនៅជារៀងរហូត ។

សូមសង្ខេប យ៉ូហាន ១៦:២៣–៣២ ដោយពន្យល់ថា ព្រះយេស៊ូវបានបង្រៀនពួកសិស្សរបស់ទ្រង់ ឲ្យអធិស្ឋានដោយផ្ទាល់ទៅរកព្រះវរបិតាសួគ៌នៅក្នុងព្រះនាមរបស់ (ព្រះគ្រីស្ទ) ហើយបានបញ្ជាក់ដល់ពួកគេអំពីសេចក្តីស្រឡាញ់របស់ព្រះវរបិតា ចំពោះពួកគេ និងទ្រង់ ។


សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ១៦:៣៣ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់រកមើលពាក្យ និងឃ្លាដែលព្រះអង្គសង្គ្រោះបានលួងលោមពួកសិស្សរបស់ទ្រង់ ។

- តើពាក្យ និងឃ្លាអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រើ ដើម្បីលួងលោមពួកសិស្សរបស់ទ្រង់ ?
- យោងតាម ខទី ៣៣ហេតុអ្វីយើងអាចមានសុភមង្គល និងសេចក្តីសុខសាន្ត សូម្បីរស់នៅក្នុងពិភពលោកមួយពោរពេញដោយទុក្ខសោក និងសេចក្តីស្លាប់ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ដោយសារព្រះយេស៊ូវគ្រីស្ទ បានយកឈ្នះលើពិភពលោក នោះយើងអាចមានសង្ឃឹមត្រេកអរ និង មានភាពសុខសាន្ត**) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែរថា ព្រះយេស៊ូវគ្រីស្ទឈ្នះលោកីយ៍ហើយ ?

សូមពន្យល់ថា ដោយសារបុត្រាបង្កើតតែមួយគត់របស់ព្រះវរបិតា ព្រះយេស៊ូវគ្រីស្ទបានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប យកឈ្នះលើរាល់គ្រប់ការល្បួងនៃលោកិយ ។ ទ្រង់ក៏មានបទពិសោធន៍ទ្រង់គ្រប់ការឈឺចាប់ និង រងទុក្ខវេទនាគ្រប់បែបយ៉ាង ហើយបានធ្វើឲ្យធួននឹងអំពើបាបរបស់យើងទាំងអស់គ្នា។ តាមរយៈព្រះជន្មទ្រង់ ការរងទុក្ខ និង សុគត ព្រមទាំងការរស់ឡើងវិញរបស់ទ្រង់ នោះទ្រង់យកឈ្នះលើគ្រប់អ្វីទាំងអស់ ដែលនឹងរារាំងយើងចេញពីភាពស្អាតស្អំ ស្វែងរកភាពសុខសាន្ត ហើយរស់នៅម្តងទៀតជាមួយព្រះវរបិតា ដែលគង់នៅឋានសួគ៌ និង អស់អ្នកដែលយើងស្រឡាញ់ ។

- តើការដឹងថា ព្រះយេស៊ូវគ្រីស្ទបានឈ្នះលើពិភពលោកនេះ អាចជួយឲ្យយើងមានសង្ឃឹម និង មានភាពសុខសាន្តរបៀបណាខ្លះ ?

សូមឲ្យក្រដាសអំពីសេចក្តីថ្លែងខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍នោះឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលការពន្យល់ថាអំពីហេតុដល ដែលយើងអាចមានភាពសុខសាន្ត ទោះបីស្ថិតនៅក្នុងការសោកល្បួង និងការលំបាកនៃពិភពលោកនេះក្តី ។



« សូមឲ្យយើងមានក្តីសង្ឃឹម ដើម្បីរស់នៅក្នុងជីវិតនេះចុះ ។ ទោះបីយើងរស់នៅក្នុងពេលដ៏រឹកវក់ក៏ដោយ ក៏ព្រះអម្ចាស់ស្រឡាញ់ ហើយគិតដល់យើងដែរ ។ ទ្រង់នៅខាងយើងជានិច្ច នៅពេលយើងធ្វើអ្វីដែលត្រូវ ។ ទ្រង់នឹងជួយយើង ពេលយើងមានអាសន្ន ។ . . .ជីវិតយើងអាចបានពេញទៅដោយក្តីអំណរបានផងដែរ នៅពេលយើងធ្វើតាមការបង្រៀននៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

« ព្រះអម្ចាស់បានក្រើនរំឭកថា ‹ ត្រូវសង្ឃឹមឡើង ត្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ › [យ៉ូហាន ១៦:៣៣] ។ នេះជាសុភមង្គលដ៏មហិមាដែលចំណេះដឹងនោះបានប្រទានដល់យើង ។ ទ្រង់រស់ដើម្បីយើង ហើយក៏សុគតដើម្បីយើងដែរ ។ ទ្រង់បានបង់ថ្លៃសម្រាប់អំពើបាបយើង ។ សូមឲ្យយើងធ្វើតាមគំរូទ្រង់ ។ សូមឲ្យយើងបង្ហាញអំណរគុណថ្វាយទ្រង់ ដោយទទួលពលិកម្មរបស់ទ្រង់ ហើយរស់នៅក្នុងជីវិតដែលសក្តិសមឲ្យយើងត្រឡប់ទៅរស់ជាមួយនឹងទ្រង់វិញនៅថ្ងៃណាមួយ » (« God Be with You Till We Meet Again » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១១០–១១) ។

- តើនៅពេលណាដែល ដែលការដឹងថា ព្រះយេស៊ូវគ្រីស្ទបានឈ្នះលើពិភពលោកនេះ អាចជួយឲ្យអ្នកមានសង្ឃឹមត្រេកអរ និង មានភាពសុខសាន្ត ?

សូមអញ្ជើញសិស្សឲ្យមានចិត្តរីករាយ ហើយរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលពួកគេធ្វើដូច្នោះ ពួកគេនឹងមានអារម្មណ៍នៃភាពសុខសាន្ត និង សេចក្តីសង្ឃឹមដែលកើតមានតាមរយៈពលិកម្មដ៏ធួន និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអម្ចាស់ ។

យ៉ូហាន ១៧

សេចក្តីផ្តើម

ពីមុនព្រះអង្គសង្គ្រោះបានរងទុក្ខនៅក្នុងសួនច្បារគេតសេម៉ានី ទ្រង់បានផ្តល់ការអធិស្ឋានទូលសូមជំនួសដ៏មហិមារបស់ទ្រង់ ។ ទ្រង់បានអធិស្ឋានសូមឲ្យពួកសិស្សរបស់ទ្រង់ និងអស់អ្នកដែលចូលមករកទ្រង់នឹងអាចស្គាល់ព្រះវរបិតាសួគ៌ ហើយទទួលបានជីវិតដ៏អស់កល្បជានិច្ច ហើយទ្រង់បានអធិស្ឋានសូមឲ្យពួកគេអាចនឹងបានក្លាយទៅជាតែមួយជាមួយនឹងទ្រង់ និងព្រះបិតាទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៧:១–៨

ព្រះយេស៊ូវគ្រីស្ទបានថ្លែងទៅកាន់ព្រះវរបិតាសួគ៌នៅក្នុងការអធិស្ឋាន

សូមអញ្ជើញសិស្សឲ្យប្រាប់ឈ្មោះមនុស្សដែលពួកគេស្គាល់ ។ បន្ទាប់មក សុំឲ្យពួកគេប្រាប់ឈ្មោះមនុស្សដែលពួកគេស្គាល់ជាងគេបំផុតនៅក្នុងជីវិតពួកគេ ។

- **តើការដឹង*អំពី*នរណាម្នាក់ និង*ការស្គាល់*ពិតអំពីបុគ្គលនោះមានភាពខុសគ្នាយ៉ាងណា ?**
- **តើត្រូវធ្វើអ្វីខ្លះដើម្បីស្គាល់មនុស្សម្នាក់ពិត ?**
- **តើបុគ្គលមួយចំនួនណាខ្លះ ដែលអ្នកមានអារម្មណ៍ថាសំខាន់ដើម្បីនឹងស្គាល់ពួកគេឲ្យបានល្អប្រសើរនោះ ? ហេតុអ្វី ?**

ចូរពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនអំពីសារៈសំខាន់នៃការមកស្គាល់ព្រះវរបិតាសួគ៌ និងទ្រង់ផ្ទាល់ ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាយ៉ូហាន ១៧ដែលនឹងជួយពួកគេឲ្យមកស្គាល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។

ដើម្បីជួយសិស្សឲ្យយល់បរិបទនៃយ៉ូហាន ១៧សូមចង្អុលបង្ហាញថា នៅពេលមួយ ចន្លោះពេលដែលព្រះអង្គសង្គ្រោះ និងពួកសិស្សរបស់ទ្រង់បានទទួលទានអាហារយប់ចុងក្រោយ និងពេលដែលពួកគេចូលទៅក្នុងសួនច្បារគេតសេម៉ានី ព្រះយេស៊ូវបានធ្វើការអធិស្ឋានមួយ ដែលតាមទំនៀមទម្លាប់ត្រូវបានគេស្គាល់ថា ជាការអធិស្ឋានទូលសូមជំនួស ។ អត្ថន័យមួយនៃពាក្យ*ជួយអង្វរ*គឺជាការនិយាយទៅនរណាម្នាក់ជំនួសឲ្យមនុស្សម្នាក់ផ្សេងទៀត ។ នៅក្នុងករណីនេះ ព្រះយេស៊ូវគ្រីស្ទ បានមានបន្ទូលទៅព្រះវរបិតាសួគ៌ជំនួសឲ្យពួកសិស្សរបស់ទ្រង់ ដែលទូលអង្វរសូមឲ្យពួកគេអាចទទួលបានជីវិតអស់កល្បជានិច្ច ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៧:១–៣ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានពិពណ៌នាអំពីជីវិតដ៏អស់កល្បជានិច្ច ។

- **តើព្រះអង្គសង្គ្រោះបានពិពណ៌នាពីអំពីជីវិតអស់កល្បជានិច្ចយ៉ាងដូចម្តេចខ្លះ ?**
- **ផ្អែកទៅលើខទី ៣តើអ្នកនឹងថ្លែងយ៉ាងដូចម្តេច អំពីគោលការណ៍មួយដែលបង្រៀនពីអ្វីដែលយើងត្រូវធ្វើ ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច ? (សិស្សអាចនឹងប្រើពាក្យសម្តីផ្សេងៗគ្នា ប៉ុន្តែចូរប្រាកដថា វាច្បាស់លាស់ថា**<u>**ដើម្បីទទួលបានជីវិតអស់កល្បជានិច្ច យើងត្រូវតែស្វែងស្គាល់ព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ**</u> **) ។**

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃការស្គាល់ព្រះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« វាគឺជារឿងមួយដើម្បីដឹងអំពីព្រះ និងជារឿងមួយទៀតដើម្បីស្គាល់ទ្រង់ ។ យើងនឹងដឹងអំពីទ្រង់ នៅពេលយើងរៀនថា ទ្រង់គឺជាតួអង្គមួយដែលរូបមនុស្សត្រូវបានបង្កើតឡើងតាម នៅពេលយើងដឹងថា ព្រះរាជបុត្រាមានរូបភាពនៃអង្គព្រះបិតារបស់ទ្រង់ នៅពេលយើងរៀនថា ទាំងព្រះបិតា និងព្រះរាជបុត្រាមានលក្ខណៈ និងអំណាចជាក់លាក់ ។ ប៉ុន្តែយើងស្គាល់ទ្រង់ នៅក្នុងន័យនៃការទទួលបានជីវិតអស់កល្បជានិច្ច នៅពេលយើងរីករាយ និងមានបទពិសោធន៍នូវរឿងដូចគ្នាដែលទ្រង់ទាំងពីរអង្គមាន ។ ដើម្បីស្គាល់ព្រះ គឺត្រូវគិតដូចជាទ្រង់គិត មានអារម្មណ៍ដូចជាទ្រង់មាន មានអំណាចដូចដែលទ្រង់មាន យល់សេចក្តីពិតដូចដែលទ្រង់យល់ ហើយធ្វើអ្វីដែលទ្រង់ធ្វើ ។ អ្នកទាំងឡាយដែលស្គាល់ព្រះប្រែក្លាយដូចជាទ្រង់ ហើយមានជីវិតដូចជាជីវិតទ្រង់ ដែលជាជីវិតអស់កល្បជានិច្ច » (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ១:៧៦២) ។

- **តើការស្គាល់ព្រះបិតា និងព្រះរាជបុត្រា ខុសពីការគ្រាន់តែដឹង*អំពី*ពួកទ្រង់យ៉ាងដូចម្តេច ?**
- **ហេតុអ្វីមនុស្សម្នាក់មិនអាចទទួលបានជីវិតដ៏អស់កល្បជានិច្ច បើគេពុំស្គាល់ព្រះជាព្រះបិតា និងព្រះយេស៊ូវគ្រីស្ទដូច្នេះ ?**
- **តើមានវិធីណាខ្លះដែលយើងអាចបានស្គាល់ព្រះបិតា និងព្រះរាជបុត្រា ?**

លូកា ១៧:៣ គឺជាចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រីស្ទ និងត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះ តាមរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

សម្រាប់ការពន្យល់អំពីចំណេះចំណានខគម្ពីរ និងបញ្ជីសកម្មភាពបន្ថែម ដើម្បីជួយសិស្សទន្ទេញចាំវគ្គបទគម្ពីរ ដែលបានជ្រើសរើសទាំងនេះ សូមមើលសេចក្តីបន្ថែមនៃសៀវភៅសិក្សានេះ។

សូមសង្ខេបយ៉ូហាន ១៧:៤–៥ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានរាយការណ៍ទៅកាន់ព្រះបិតាទ្រង់ថា ទ្រង់បានបញ្ចប់កិច្ចការដែលព្រះបិតារបស់ទ្រង់បានប្រទានឲ្យទ្រង់ធ្វើ ។ ទ្រង់បានទូលសូមព្រះបិតាទ្រង់ឲ្យប្រទានសិរីល្អទ្រង់ដូចគ្នានឹងសិរីល្អដែលទ្រង់មាននៅក្នុងជីវិតមុនជីវិតលើផែនដី ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៧:៦–៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលពួកសិស្សបានធ្វើដើម្បីបានស្គាល់ព្រះអង្គសង្គ្រោះ ។

- តើពួកសិស្សបានធ្វើអ្វីខ្លះដើម្បីបានស្គាល់ព្រះអង្គសង្គ្រោះ ? (អ្នកអាចនឹងចង់លើកទឹកចិត្តសិស្សឲ្យគូសចំណាំឃ្លា « គេក៏ទទួលយក » និង « ក៏ជឿ » នៅក្នុងខទី ៨) ។

យ៉ូហាន ១៧:៩–១៩

ព្រះអង្គសង្គ្រោះអធិស្ឋានសម្រាប់ពួកសិស្សរបស់ទ្រង់

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៧:៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថានរណាដែលព្រះអង្គសង្គ្រោះបានអធិស្ឋានឲ្យជាក់លាក់នោះ ។

- តើព្រះអង្គសង្គ្រោះអធិស្ឋានសម្រាប់នរណា ពេលទ្រង់ហៀបនឹងចាប់ផ្តើមធ្វើដង្វាយធួននោះ ?
- ហេតុអ្វីក៏អ្នកគិតថា ពួកសាវកអាចបានប្រយោជន៍មកពីការស្តាប់ព្រះអង្គសង្គ្រោះទូលអង្វរជំនួសពួកគេនោះ ?

ចូរសរសេរ*យ៉ូហាន ១៧:១១–១៨* នៅលើក្តារខៀន ។ សូមចែកសិស្សទៅជាគូ ។ សូមអញ្ជើញសិស្សឲ្យសិក្សាខគម្ពីរទាំងនេះជាមួយនឹងដៃគូរបស់ពួកគេ ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវទូលអង្វរជំនួសពួកសិស្សរបស់ទ្រង់ ។ អ្នកអាចគូរអញ្ជើញសិស្សឲ្យគូសចំណាំអ្វី ដែលពួកគេបានរកឃើញ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យពួកគេខ្លះរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញទៅដល់សិស្សក្នុងថ្នាក់ ។

សូមចង្អុលបង្ហាញថា ព្រះអង្គសង្គ្រោះបានប្រាប់ថា ពួកសិស្សរបស់ទ្រង់នឹងបន្តរស់នៅក្នុងពិភពលោកមួយដែលមានអំពើអាក្រក់ ហើយដែលស្អប់ពួកគេ ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីខទី ១៤–១៦អំពីការរស់នៅក្នុងពិភពលោក ដូចជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ យើងរស់នៅក្នុងលោកិយ ប៉ុន្តែពុំមែនជារបស់លោកិយឡើយ ។**
- តើអ្នកគិតថា ការរស់ *នៅក្នុង*លោកិយ ប៉ុន្តែពុំមែនជា*របស់*លោកិយ មានន័យយ៉ាងណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅក្នុងសាសនាចក្រ ជាញឹកញាប់យើងថ្លែងពាក្យកាព្យ ៖ ‹ នៅក្នុងលោកិយ ប៉ុន្តែពុំមែនជារបស់លោកិយឡើយ › ។ . . .

« ប្រហែលជាយើងគួរថ្លែងពាក្យកាព្យ. . . ជាការដាស់តឿនផ្សេងពីរ ។ ទីមួយ‹ *នៅក្នុងលោកិយ* ›។ ជាប់ទាក់ទងបានទទួលដំណឹង ។ សូមព្យាយាមយល់ ហើយអត់ធន់ និងថ្លែងអំណរគុណចំពោះភាពផ្សេង។ពីគ្នា ។ សូមធ្វើការចែកចាយដ៏មានអត្ថន័យចំពោះសង្គមតាមរយៈការបម្រើ និងការប្រឡូកចូលរួម ។ ទីពីរ‹ *ពុំមែនជារបស់លោកិយ* ›។ មិនធ្វើតាមផ្លូវខុស ឬបត់បែនដើម្បីសម្រប ឬទទួលយល់ព្រមនឹងអ្វីដែលមិនត្រឹមត្រូវឡើយ ។ . . .

« សមាជិកនៃសាសនាចក្រចាំបាច់ត្រូវដឹងឥទ្ធិពល ច្រើនជាងទទួលរងឥទ្ធិពល ។ យើងគួរតែកាត់បន្ថយនូវកំណើននៃអំពើបាប និងសេចក្តីអាក្រក់ ជំនួសឲ្យការអនុញ្ញាតឲ្យខ្លួនយើងរងឥទ្ធិពលនៃអំពើបាបនោះ ។ យើងម្នាក់ៗចាំបាច់ត្រូវដួងដោះស្រាយបញ្ហា ជាជាងចៀសវាង ឬបដិសេធវា » (« The Effects of Television » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៩ ទំព័រ ៨០) ។

- ហេតុអ្វីព្រះអម្ចាស់ចង់ឲ្យយើងបន្តរស់នៅក្នុងលោកិយ តែពុំមែនជារបស់លោកិយ ?

សូមអញ្ជើញសិស្សឲ្យធ្វើការជាមួយដៃគូពួកគេម្តងទៀត ហើយគិតពីគំរូមួយអំពីរបៀបដែលមនុស្សម្នាក់អាចនៅក្នុងលោកិយ ប៉ុន្តែពុំមែនជារបស់ផងលោកិយនៅក្នុងស្ថានភាពនីមួយៗដូចខាងក្រោម ៖

១. នៅសាលារៀន

២. ជាមួយមិត្តភក្តិ

៣. នៅលើអ៊ិនធើណិត

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់ដល់សិស្សក្នុងថ្នាក់អំពីគំរូដែលពួកគេគិតនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយបទពិសោធន៍នានា ដែលពួកគេមាន នៅពេលពួកគេ ឬនរណាម្នាក់ដែលពួកគេស្គាល់ បានបង្ហាញដោយត្រឹមត្រូវពីការនៅក្នុងលោកិយ ប៉ុន្តែពុំមែនជារបស់ផងលោកិយ ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរបស់ពួកគេអំពីវិធីជាក់លាក់មួយ ដែលពួកគេនឹងព្យាយាមដើម្បីធ្វើតាមព្រះអង្គសង្គ្រោះឲ្យបានកាន់តែល្អប្រសើរ តាមរយៈការរស់នៅក្នុងលោកិយ តែពុំមែនជារបស់ផងលោកិយ ។

យ៉ូហាន ១៧:២០–២៦

ព្រះអង្គសង្គ្រោះអធិស្ឋានសម្រាប់មនុស្សទាំងអស់ដែលទទួលដំណឹងល្អរបស់ទ្រង់

សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខថ្នាក់ ហើយធ្វើកិច្ចការមួយដែលនឹងធ្វើឲ្យដៃរបស់គាត់ប្រឡាក់ (ដូចជាលុបក្តារខៀនដោយប្រើដៃ ឬកកាយយកអ្វីមួយលាក់នៅដីល្បាប់មួយចាន) ។ សូមលើកទឹកចិត្តសិស្សឲ្យព្យាយាមរក្សាដៃរបស់គាត់បានស្អាត ខណៈដែលគេធ្វើកិច្ចការនោះ ។

បន្ទាប់ពីសិស្សបញ្ចប់កិច្ចការនោះ ចូរសុំឲ្យសិស្សបង្ហាញដៃរបស់គាត់ដល់សិស្សក្នុងថ្នាក់ ។

- តើសកម្មភាពនេះប្រៀបដូចជាការខិតខំរបស់យើង ដើម្បីរស់នៅក្នុងលោកិយ តែពុំមែនជារបស់ផងលោកិយយ៉ាងដូចម្តេច ? (ទោះជាយើងខិតខំអស់ពីលទ្ធភាពក្តី ក៏យើងនៅតែពុំស្អាតទាំងស្រុងពីអំពើបាប និងសេចក្តីអាក្រក់ដែលមាននៅក្នុងលោកិយនេះដែរ) ។
- ប្រសិនបើយើងពុំអាចបានស្អាតពីអំពើបាបរបស់យើង តើទីបញ្ចប់យើងនឹងដកពិសោធន៍នឹងផលវិបាកអ្វីខ្លះ ? ហេតុអ្វី ? (យើងនឹងបំបែកចេញពីវត្តមានរបស់ព្រះជារៀងរហូត ពីព្រោះគ្មានវត្ថុមិនស្អាតណា អាចរស់នៅក្នុងវត្តមានរបស់ទ្រង់បានឡើយ | សូមមើល នីហ្វៃទី ១ ១៥:៣៣–៣៤|) ។

អរគុណដល់សិស្ស ហើយសុំឲ្យគេអង្គុយចុះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៧:២០–២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាតើព្រះអង្គសង្គ្រោះបានអធិស្ឋានសម្រាប់អ្វីខ្លះ ។

- តើព្រះអង្គសង្គ្រោះបានអធិស្ឋានសម្រាប់អ្វី ? (អ្នកគួរផ្តល់យោបល់ឲ្យសិស្សគូសចំណាំពាក្យ*តែមួយ* ត្រង់កន្លែងណាដែលឃើញមានពាក្យនោះនៅក្នុងខទី ២០–២៣) ។
- តើអ្វីទៅ ដែលធ្វើឲ្យយើងអាចប្រែក្លាយទៅជាតែមួយជាមួយព្រះបិតា និងព្រះរាជបុត្រាបាន ? (ពរជ័យនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលយើងទទួលបានតាមរយៈការគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ) ។

សូមសរសេរសេចក្តីពិតដូចតទៅនេះនៅលើក្តារខៀន ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលពរជ័យទាំងឡាយនៃដង្វាយធួនរបស់ទ្រង់ នោះយើងអាចប្រែក្លាយទៅជាតែមួយជាមួយព្រះ និងព្រះរាជបុត្រា ។**

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« នំយពិតនៃពាក្យ*ដង្វាយធួន*ជាភាសាអង់គ្លេស គឺជាភស្តុតាងផ្ទាល់ ៖ at–one–ment ជាការនាំបញ្ចូលគ្នានូវរឿងទាំងឡាយដែលបានបំបែកចេញ ឬឃ្លាតឆ្ងាយនោះ » (« The Atonement of Jesus Christ » *Ensign* ខែ មិនា ឆ្នាំ ២០០៨ ទំព័រ ៣៤–៣៥) ។

- ចេញមកពីអ្វីដែលអ្នកដឹងអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហេតុអ្វីក៏អ្នកចង់ប្រែក្លាយទៅជាតែមួយជាមួយនឹងពួកទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ជែមស៍ អ៊ី ហ្វោស្ត នៃគណៈប្រធានទីមួយឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលពរជ័យដែលនឹងកើតមានចំពោះអស់អ្នកដែលព្យាយាមប្រែក្លាយទៅជាតែមួយជាមួយនឹងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។



« យើងគួរតែព្យាយាមដោយស្មោះ ពុំគ្រាន់តែដឹងអំពីលោកចៅហ្វាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីព្យាយាមដូចជាទ្រង់បានអញ្ជើញយើងឲ្យប្រែក្លាយទៅជាតែមួយជាមួយនឹងទ្រង់ (សូមមើលយ៉ូហាន ១៧:២១) ។ . . .

« . . . នៅថ្ងៃខាងមុខនឹងមានពេញដោយទុក្ខព្រួយ និងការលំបាក ។ ប៉ុន្តែដោយការអះអាងជាមួយនឹងការលួងលោមនៃទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះ នោះយើងនឹងត្រូវបានប្រទានន្ទរង្គំចិត្តដ៏ក្លាហានដោយស្ងប់ស្ងាត់មួយ » (« That We Might Know Thee » *Ensign* ខែ មករា ឆ្នាំ ១៩៩៩ ទំព័រ ២, ៥) ។

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការមកស្គាល់ព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាសួគ៌ ហើយនឹងអំពីការព្យាយាមដើម្បីប្រែក្លាយទៅជាតែមួយជាមួយនឹងទ្រង់ទាំងពីរអង្គ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វី ដែលពួកគេអាចធ្វើដើម្បីស្គាល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានកាន់តែច្បាស់ ហើយពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយពួកទ្រង់ ។

សូមអញ្ជើញសិស្សឲ្យកត់ត្រាគំនិតរបស់ពួកគេនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ដែលមានឆន្ទៈចែកចាយគំនិត និងអារម្មណ៍ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

ចំណេះចំណានខគម្ពីរ—យ៉ូហាន ១៧:៣

ដើម្បីជួយសិស្សទន្ទេញចាំយ៉ូហាន ១៧:៣សូមអញ្ជើញពួកគេឲ្យយកកាតចំណេះចំណានខគម្ពីរ ដែលមានវគ្គបទគម្ពីរនេះដាក់តាមខ្លួនអំឡុងសប្តាហ៍ក្រោយ ។ សូមលើកទឹកចិត្តពួកគេឲ្យរំឭកវគ្គបទគម្ពីរ ហើយហាត់សូត្រវាឡើងវិញនៅពេលមានឱកាស ។ អ្នកអាចនឹងចង់ផ្តល់យោបល់ឲ្យពួកគេព្យាយាមសូត្រវាចេញមកពីការចងចាំទៅកាន់សមាជិកគ្រួសារ ហើយពន្យល់អំពីអត្ថន័យរបស់វា ។ នៅពេលចាប់ផ្តើមថ្នាក់រៀននៅពីរបីថ្ងៃខាងមុខទៀត សូមអញ្ជើញសិស្សឲ្យរាយការណ៍អំពីការរីកចម្រើនរបស់ពួកគេ ក្នុងការទន្ទេញចាំវគ្គបទគម្ពីរនេះ ។

យ៉ូហាន ១៨–១៩

សេចក្តីផ្តើម

បន្ទាប់ពីពួកអ្នកដឹកនាំសាសន៍យូដាបានចាប់ព្រះកាយ និង ចោទសួរព្រះយេស៊ូវហើយ នោះពួកគេបាននាំទ្រង់ទៅចំពោះមុខលោកពីឡាត់ដើម្បីជំនុំជម្រះ និង កាត់ទោស ។ លោកពីឡាត់ព្រមឆ្កាងព្រះយេស៊ូវ បើទោះបីជាគាត់បានដឹងថា ព្រះយេស៊ូវគ្មានទោសក្តី ។ កាលនៅលើឈើឆ្កាង ព្រះអង្គសង្គ្រោះបានផ្តាំសាវកយ៉ូហានឲ្យមើលថែមាតាទ្រង់ ។ បន្ទាប់ពីព្រះយេស៊ូវត្រូវបានគេឆ្កាង ព្រះកាយរបស់ទ្រង់ត្រូវបានគេដាក់ទៅក្នុងផ្នូរ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ១៨:១–៣២

ព្រះយេស៊ូវត្រូវបានចាប់ព្រះកាយ ហើយចោទសួរដោយពួកអ្នកដឹកនាំសាសន៍យូដា ដែលក្រោយមកបាននាំទ្រង់ទៅជួបលោកពីឡាត់ ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើនៅពេលណាដែលជាគ្រាដ៏លំបាកបំផុត ដើម្បីមើលថែសុខុមាលភាពនៃមនុស្សដទៃនោះ ?

សូមអញ្ជើញសិស្សពីបីនាក់ឲ្យពន្យល់អំពីរបៀប ដែលពួកគេនឹងឆ្លើយសំណួរនៅលើក្តារខៀន ។

សូមពន្យល់ថា ព្រះយេស៊ូវគ្រីស្ទ និងលោកអភិបាលរ៉ូមឈ្មោះ ពីឡាត់ បានជ្រើសដាក់អាទិភាព ឬឲ្យតម្លៃរឿងខុសគ្នានៅក្នុងព្រឹត្តិការណ៍ដែលបានរៀបរាប់នៅក្នុង យ៉ូហាន ១៨–១៩ ។ សូមសរសេរឃ្លា *កង្វល់របស់ព្រះយេស៊ូវគ្រីស្ទ* និង *កង្វល់របស់ពីឡាត់* នៅជ្រុងម្ខាងពីគ្នានៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សា យ៉ូហាន ១៨–១៩ ដែលអាចជួយពួកគេឲ្យដឹងថា តើកង្វល់អ្វីខ្លះដែលគួរមានអាទិភាពនៅក្នុងជីវិតរបស់ពួកគេ ។

សូមសង្ខេប យ៉ូហាន ១៨:១–៣ ដោយពន្យល់ថាបន្ទាប់ពីព្រះយេស៊ូវបានរងទុក្ខនៅក្នុងច្បារគែតសេម៉ានី នោះយូដាស-អ៊ីស្ការីយ៉ុតបានមកដល់ រួមនឹងពួកមន្ត្រីដែលបានចាត់មកដោយពួកសង្ឃរាជ និងពួកផារិស៊ីដើម្បីមកចាប់ព្រះយេស៊ូវ ។

- ប្រសិនបើអ្នកដឹងថា កងទាហានមួយក្រុមកំពុងមកចាប់ខ្លួនអ្នក ហើយសម្លាប់អ្នក តើអ្នកនឹងមានប្រតិកម្មបែបណា ?

សូមអញ្ជើញសិស្សពីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហាន ១៨:៤–១១ និងលូកា ២២:៥០–៥១ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលព្រះយេស៊ូវបានឆ្លើយតបនៅពេលក្រុមនេះបានមកដល់ ។

- តើព្រះយេស៊ូវបានបន្ទូលអ្វីខ្លះ ទៅជនដែលបានមកចាប់ព្រះកាយទ្រង់ ? (អ្នកគួរពន្យល់ថា ពាក្យ *អ្នកទាំងនេះ:* នៅក្នុង យ៉ូហាន ១៨:៨ និង *ពួកអ្នក* នៅក្នុង យ៉ូហាន ១៨:៩ សំដៅលើពួកសាវកដែលនៅជាមួយព្រះយេស៊ូវ) ។
- យោងតាមខគម្ពីរទាំងនេះ តើព្រះយេស៊ូវមានកង្វល់អំពីអ្វី ? (នៅពេលសិស្សឆ្លើយ សូមសរសេរឃ្លាងខាងក្រោមនៅលើក្តារខៀននៅក្រោមឃ្លា « កង្វល់របស់ព្រះយេស៊ូវគ្រីស្ទ » ៖ *ការពារពួកសាវករបស់ទ្រង់ ព្យាបាលត្រចៀករបស់អ្នកបម្រើនោះ: ធ្វើតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌*) ។

ចូរសុំឲ្យសិស្សម្នាក់អានសេចក្តីសង្ខេបខាងក្រោមនេះអំពី យ៉ូហាន ១៨:១២–៣២ ឲ្យឮៗ ។

ព្រះយេស៊ូវបានអនុញ្ញាតឲ្យពួកមន្ត្រីនោះចាប់ទ្រង់ ។ ពួកគេបាននាំទ្រង់ទៅជួប អាណា ជាអ្នកដឹកនាំសាសន៍យូដាម្នាក់ រួចទៅជួបនឹងពួកកៃផា ជាសង្ឃជាន់ខ្ពស់ដែលព្យាយាមដាក់ទោសព្រះយេស៊ូវរហូតដល់ការសុគតនោះ ។ ពេត្រុស និងសិស្សដទៃទៀតបានដើរតាមព្រះយេស៊ូវ ។ នៅពេលមនុស្សបីនាក់ផ្សេងគ្នាបានសួរពេត្រុស ថាគាត់គឺជាកូនសិស្សម្នាក់របស់ព្រះយេស៊ូវឬ នោះពេត្រុសបានបដិសេធពុំស្គាល់រាល់ពេល ។ បន្ទាប់ពីកៃផាបានចោទសួរព្រះយេស៊ូវ នោះពួកអ្នកដឹកនាំសាសន៍យូដាបាននាំព្រះយេស៊ូវទៅជួបលោកពីឡាត់ ដែលជាអ្នកអភិបាលក្រុងសាសន៍រ៉ូមនៅស្រុកយូដា ដើម្បីទទួលការកាត់ទោស និង ដាក់ទណ្ឌកម្ម ។ មានតែសាសន៍រ៉ូមប៉ុណ្ណោះ ដែលមានសិទ្ធិអំណាចចេញច្បាប់ឲ្យកាត់ទោសដល់ជីវិតនៅក្នុងក្រុងយេរូសាឡិម ។

សូមពន្យល់ថា ការជំនុំជម្រះក្តីនេះអាចនឹងធ្វើឡើងនៅបន្ទាយអានតូនា នៅក្បែរព្រះវិហារបរិសុទ្ធ ។ (អ្នកគួរពិចារណាអញ្ជើញសិស្សឲ្យបើកទៅផែនទី ទី១២ « ក្រុងយេរូសាឡិមនៅសម័យព្រះយេស៊ូវ » នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ហើយរកមើលបន្ទាយអានតូនា [ជាទីតាំងលេខ ៣ នៅលើផែនដីនោះ]) ។

យ៉ូហាន ១៨:៣៣–១៩:១៦

ព្រះយេស៊ូវ គ្រីស្ទត្រូវបានកាត់ទោសនៅចំពោះមុខពីឡាត់

សូមអញ្ជើញសិស្សពីរនាក់ឲ្យអានឮៗនៅបន្ទូលរបស់ព្រះអង្គសង្គ្រោះ និងពាក្យរបស់ពីឡាត់ ដែលបានកត់ត្រានៅក្នុង យ៉ូហាន ១៨:៣៣–៣៧ ។ (អ្នកអាចនឹងអញ្ជើញសិស្សទាំងនេះពីមុនថ្នាក់ចាប់ផ្តើមឲ្យរកមើលឃ្លាដែលពួកគេនឹងត្រូវអាន) ។ ចូរពិចារណា

ធ្វើការសម្តែងតួរបស់អ្នកអត្តាធិប្បាយ ឬអញ្ជើញសិស្សម្នាក់ទៀតឲ្យធ្វើជាអ្នកអត្តាធិប្បាយ ។ នៅពេលសិស្សទាំងនេះអានផ្នែករបស់ខ្លួនរួចហើយ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលលោកពីឡាត់ចង់ដឹងពីព្រះយេស៊ូវ ។

- យោងតាម យ៉ូហាន ១៨:៣៣តើពីឡាត់ចង់ដឹងអ្វីខ្លះពីព្រះយេស៊ូវ ?

សូមពន្យល់ថា ពួកអ្នកដឹកនាំសាសន៍យូដាបានចោទប្រកាន់ព្រះយេស៊ូវពីការប្រកាសថា ទ្រង់គឺជាស្តេចនៃសាសន៍យូដា ដោយសារព្រះយេស៊ូវបានប្រកាសថាទ្រង់គឺជាស្តេច ទ្រង់អាចមានទោសពីការបំបះបំបោរ ឬ ក្បត់ជាតិ ប្រឆាំងនឹងរដ្ឋាភិបាលរ៉ូម (សូមមើល យ៉ូហាន ១៩:១២) ជាបទឧក្រិដ្ឋមួយដែលត្រូវជាប់ទោសដល់ស្លាប់ ។

- តើព្រះយេស៊ូវបានពន្យល់អ្វីខ្លះទៅពីឡាត់ ? (នគរទ្រង់ « មិនមែនត្រូវខាងលោកីយ៍នេះទេ » [យ៉ូហាន ១៨:៣៦] ហើយទ្រង់បានយាងមកផែនដីនេះ « ធ្វើទីបន្ទាល់ពីសេចក្តីពិត » [យ៉ូហាន ១៨:៣៧]) ។

ចូរសុំអាន យ៉ូហាន ១៨:៣៨–៤០ ដោយស្ងៀមស្ងាត់រកមើលអ្វី ដែលលោកពីឡាត់បានសន្និដ្ឋានអំពីព្រះយេស៊ូវ ។

- តើលោកពីឡាត់បានសន្និដ្ឋានអ្វីខ្លះអំពីព្រះយេស៊ូវ ? (លោកបានពោលថា លោកមិនឃើញ « ជាអ្នកនោះមានទោសខុសអ្វីសោះ » [ខទី ៣៨]) ។
- យោងតាម ខទី ៣៩តើលោកពីឡាត់បានព្យាយាមធ្វើអ្វីខ្លះ ដើម្បីដោះលែងព្រះយេស៊ូវ ?

សូមសង្ខេប យ៉ូហាន ១៩:១–៥ ដោយពន្យល់ថា ពួកទ័ពរ៉ូមបានធ្វើបាប ហើយសើចចំអកដល់ព្រះយេស៊ូវ ។ បន្ទាប់មក លោកពីឡាត់បានបង្ហាញព្រះយេស៊ូវដល់ប្រជាជន ។

សូមអញ្ជើញសិស្សអាន យ៉ូហាន ១៩:៤, ៦ ដោយស្ងៀមស្ងាត់រកមើលអ្វីដែលលោកពីឡាត់បានបង្ហាញដល់ពួកយូដា (« ខ្ញុំមិនឃើញជាអ្នកនោះមានទោសខុសអ្វីសោះ ») ។

- ដោយផ្អែកទៅលើការទទូចថា លោកមិនឃើញព្រះយេស៊ូវមានទោសខុសអ្វីសោះ តើលោកពីឡាត់ទំនងជាបានជឿលើបែបណាទៅថាជារឿងត្រឹមត្រូវដើម្បីធ្វើនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៩:៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វី ដែលពួកអ្នកដឹកនាំសាសន៍យូដាបានប្រាប់ទៅលោកពីឡាត់អំពីព្រះយេស៊ូវ ។

សូមអញ្ជើញសិស្សដែលអានសម្តីរបស់លោកពីឡាត់ បន្ទូលរបស់ព្រះយេស៊ូវ និងអ្នកនិទានដើម្បីដើរតួម្តងទៀត ហើយអាន យ៉ូហាន ១៩:៨–១១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលចម្លើយរបស់លោកពីឡាត់ កាលលោកបានស្តាប់ឮថា ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ: ។

- តើលោកពីឡាត់បានឆ្លើយតបយ៉ាងដូចម្តេច បន្ទាប់ពីពួកអ្នកដឹកនាំសាសន៍យូដាបានប្រាប់លោកថា ព្រះយេស៊ូវបានមានបន្ទូលថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះ: ?
- ប្រសិនបើអ្នកជាលោកពីឡាត់ តើអ្នកអាចនឹងមានអារម្មណ៍បែបណាដែរ បន្ទាប់ពីស្តាប់ឮអ្វីដែលព្រះយេស៊ូវបានមានបន្ទូល អំពីអំណាចរបស់អ្នកក្នុងនាមជាអភិបាលនោះ: ? ហេតុអ្វី ?

សូមពន្យល់ថាសេចក្តីថ្លែងការណ៍របស់ព្រះយេស៊ូវដែលបានកត់ត្រានៅក្នុង ខទី ១១ អំពីពួកអ្នកដឹកនាំរបស់ពួកសាសន៍យូដាថាមាននូវ « អំពើបាបធ្ងន់ » បានបង្ហាញថា ប្រសិនបើលោកពីឡាត់បន្ទន់ចិត្តទៅតាមការស្នើសុំរបស់ហ្វូងមនុស្ស ហើយបញ្ជាឲ្យឆ្កាងព្រះយេស៊ូវ នោះលោកពីឡាត់នឹងមានកំហុសប្រព្រឹត្តបាប ប៉ុន្តែពុំមានកម្រិតដូចគ្នាទៅនឹងអស់អ្នកដែលព្យាយាមយ៉ាងសកម្មចង់សម្លាប់ព្រះយេស៊ូវឡើយ ។

សូមអញ្ជើញសិស្សអាន ម៉ាថាយ ២៧:១៩ ដោយស្ងាត់ស្ងៀម រកមើលអ្វីដែលភរិយារបស់លោកពីឡាត់បានឲ្យដំបូន្មានពីកិច្ចការដែលលោកត្រូវធ្វើ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៩:១២–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលលោកពីឡាត់បានខិតខំធ្វើទាក់ទងនឹងរឿងរបស់ព្រះយេស៊ូវ និងរបៀបដែលពួកយូដាឆ្លើយតប ។

- យោងតាមខទី ១២តើលោកពីឡាត់បានខិតខំធ្វើអ្វីខ្លះ ?
- តើពួកអ្នកដឹកនាំសាសន៍យូដាបាននិយាយអ្វីខ្លះទៅកាន់លោកពីឡាត់ កាលពួកគេបានដឹងថា លោកចង់ដោះលែងព្រះយេស៊ូវនោះ ?

សូមរំឭកសិស្សថា សេសារ គឺជាស្តេចរ៉ូមដែលបានប្រទានតំណែងជាអភិបាលស្រុកយូដាដល់លោកពីឡាត់ ។ កាលពីប៉ុន្មានគ្រាមុន លោកពីឡាត់បានបញ្ជាឲ្យពួកទ័ពរ៉ូមឲ្យសម្លាប់ពួកសាសន៍យូដា ហើយលោកបានប្រមាថទំនៀមទំលាប់ខាងសាសនាដ៏ពិសិដ្ឋមួយចំនួនរបស់ពួកគេ ។ ទង្វើរបស់លោកពីឡាត់ត្រូវបានគេរាយការណ៍ទៅស្តេចសេសារ ហើយស្តេចសេសារស្តីបន្ទោសដល់លោកពីឡាត់ (សូមមើលជំពូក ៤៣ កំណត់ចំណាំ ៧ នៅក្នុង James E. Talmage *Jesus the Christ* កំណែទី ៣ [ឆ្នាំ ១៩១៦] ទំព័រ ៦៤៨–៤៩) ។

- តើនឹងអាចអ្វីកើតឡើងចំពោះលោកពីឡាត់ ប្រសិនបើពួកសាសន៍យូដាបានរាយការណ៍ថា លោកពុំមែនជា « មិត្ត » នឹងស្តេចសេសារនោះ (ខទី ១២) ? (ប្រសិនបើស្តេចសេសារបានសង្ស័យថា លោកពីឡាត់មិនស្មោះត្រង់នឹងទ្រង់ នោះស្តេចសេសារ អាចនឹងដកចេញនូវមុខតំណែង និងអំណាចរបស់លោកជាអភិបាល) ។

សូមចង្អុលបង្ហាញថា លោកពីឡាត់ត្រូវជ្រើសរវាងការការពារប្រយោជន៍ផ្ទាល់ខ្លួន និង ការដោះលែងព្រះអង្គសង្គ្រោះ ដែលលោកបានដឹងថាគ្មានទោសអ្វីនោះ ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ១៩:១៦ ឲ្យឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលលោកពីឡាត់បានជ្រើសរើសធ្វើ ។

- តើលោកពីឡាត់បានជ្រើសរើសធ្វើអ្វី ?
- តើការជ្រើសរើសនេះបង្ហាញថា តើរឿងដែលលោកពីឡាត់បារម្ភខ្លាំងបំផុតនោះគឺអ្វី ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀនក្រោមពាក្យ « កង្វល់របស់ពីឡាត់ » ៖ *ខ្លួនឯង មុខតំណែង និងអំណាចរបស់គាត់*) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ មកពីការសម្រេចចិត្តរបស់លោកពីឡាត់ដើម្បីដាក់ប្រយោជន៍ផ្ទាល់ខ្លួន ពីមុនការដោះលែងព្រះអង្គសង្គ្រោះ ដែលលោកបានដឹងថាគ្មានទោសអ្វីនោះ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ការដាក់ប្រយោជន៍ផ្ទាល់ខ្លួនរបស់យើង មុនការធ្វើអ្វីដែលត្រឹមត្រូវនឹងដឹកនាំយើងទៅរកអំពើបាប**) ។
- តើស្ថានភាពណាខ្លះដែលយើងអាចត្រូវបានល្បួងឲ្យដាក់ចំណាប់អារម្មណ៍ផ្ទាល់របស់យើងពីមុនការធ្វើអ្វីដែលត្រឹមត្រូវនោះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីយកឈ្នះលើការល្បួងឲ្យដាក់ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់យើងពីមុនការធ្វើរឿងដែលត្រឹមត្រូវនោះ ?

ប្រៀបធៀបគ្នា និង ភាពផ្ទុយ

ដោយកត់ចំណាំពីភាពដូចគ្នា ឬភាពខុសគ្នារវាងការបង្រៀនមនុស្ស ឬព្រឹត្តិការណ៍ដែលអាចបញ្ជាក់ពីគោលលទ្ធិ គោលការណ៍ ឬខគម្ពីរមួយ ហើយនាំសេចក្តីពិតនៃដំណឹងល្អចូលទៅក្នុងដួងចិត្តដ៏ជ្រៅ ។

សូមអញ្ជើញសិស្សឲ្យរកមើលអ្វី ដែលពួកគេអាចរៀនអំពីបុគ្គលិកលក្ខណៈរបស់ព្រះគ្រីស្ទដោយប្រៀបធៀបទៅនឹងបុគ្គលិកលក្ខណៈរបស់លោកពីឡាត់ កាលពួកគេសិក្សាគ្រាចុងក្រោយនៃជីវិតរមែងស្លាប់របស់ព្រះយេស៊ូវគ្រីស្ទ ។

យ៉ូហាន ១៩:១៧–៤២

ព្រះយេស៊ូវត្រូវបានឆ្កាង ហើយព្រះសពរបស់ទ្រង់ត្រូវបានដាក់នៅក្នុងផ្នូរ

សូមសង្ខេប យ៉ូហាន ១៩:១៧–២៤ ដោយពន្យល់ថា ព្រះយេស៊ូវបានលីឈើឆ្កាងរបស់ទ្រង់ទៅភ្នំគាល់កូថា ជាទីកន្លែងដែលទ្រង់ត្រូវបានគេឆ្កាង ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ១៩:២៥–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើនរណាខ្លះបានមានវត្តមាន កាលព្រះយេស៊ូវត្រូវបានគេឆ្កាង ។

- **តើនរណាបានឈរក្បែរឈើឆ្កាង កាលព្រះយេស៊ូវត្រូវបានគេឆ្កាង ? (បន្ទាប់ពីសិស្សបានឆ្លើយរួចហើយ សូមពន្យល់ថា ឃ្លាថា « សិស្សម្នាក់ . . . ដែល [ព្រះយេស៊ូវ] ស្រឡាញ់ » [ខទី ២៦] សំដៅលើសាវកយ៉ូហាន ក៏ស្គាល់ផងដែរថាជាយ៉ូហានដ៏ជាទីស្រឡាញ់) ។**
- **យោងតាម ខទី ២៦–២៧តើព្រះយេស៊ូវបានព្រួយបារម្ភពីនរណា កាលទ្រង់ត្រូវបានគេឆ្កាងនៅលើឈើឆ្កាង ? តើទ្រង់បានបង្គាប់យ៉ូហានឲ្យធ្វើអ្វី ? (មើលថែមាតារបស់ទ្រង់ ឲ្យដូចជាម្តាយរបស់ខ្លួន) ។ នៅលើក្តារខៀនក្រោមពាក្យ « កង្វល់របស់ព្រះយេស៊ូវ » សូមសរសេរ *សុខុមាលភាពរបស់មាតាទ្រង់*) ។**

ប្រសិនបើអាចធ្វើទៅបាន សូមឲ្យសំណៅនៃសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា ក្នុងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ដល់សិស្ស ។ សូមប្រាប់ឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍នោះឮៗ ។



« បុគ្គលិកលក្ខណៈត្រូវបានបើកសម្តែង . . . នៅក្នុងអំណាចដើម្បីញែកដឹងពីការរងទុក្ខរបស់មនុស្សផ្សេងទៀត នៅពេលយើងខ្លួនឯងផ្ទាល់កំពុងតែរងទុក្ខ នៅក្នុងលទ្ធភាពដើម្បីដឹងពីសេចក្តីស្រេកឃ្លានរបស់មនុស្សដទៃ នៅពេលយើងស្រេកឃ្លាន និង នៅក្នុងអំណាចដើម្បីឈោងទៅជួយ និង បង្ហាញសេចក្តីអាណិតអាសូរដល់សេចក្តីឈឺចាប់ខាងវិញ្ញាណរបស់មនុស្សដទៃ នៅពេលយើងកំពុងតែនៅកណ្តាលនៃភាពតានតឹងខាងវិញ្ញាណផ្ទាល់ខ្លួនរបស់យើងនោះ ។ ហេតុដូច្នោះហើយ បុគ្គលិកលក្ខណៈនេះត្រូវបានបង្ហាញដោយការមើល និង ឈោងទៅរកនៅពេលការឆ្លើយតបដោយឯកឯងត្រូវបានផ្តោតទាំងស្រុងទៅលើចំណង់ និងតម្រូវការផ្ទាល់ខ្លួន ។ ប្រសិនបើសម្ភាពបែបនេះ គឺជាទង្វើនៃបុគ្គលិកលក្ខណៈវិនិច្ឆ័យរបស់បុគ្គលិកលក្ខណៈខាងសីលធម៌ នោះព្រះអង្គសង្គ្រោះនៃពិភពលោកគឺជាគំរូដ៏ល្អឥតខ្ចោះនៃបុគ្គលិកលក្ខណៈដ៏ខ្ពាប់ខ្ពស់ និង សប្បុរសនេះ » (« The Character of Christ » [Brigham Young University–Idaho Religion Symposium ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៣] ទំព័រ ២–៣) ។

- **ដោយផ្អែកលើអ្វីដែលយើងបានរៀននៅក្នុង យ៉ូហាន ១៨–១៩ អំពីបុគ្គលិកលក្ខណៈរបស់ព្រះអង្គសង្គ្រោះ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើតាមគំរូរបស់ទ្រង់ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ *យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ តាមរយៈការជ្រើសរើសជួយមនុស្សដទៃ ទោះជានៅពេលយើងស្ថិតក្នុងតម្រូវការខ្លួនឯងក្តី*))**
- **តើយើងអាចយកឈ្នះបំណងប្រាថ្នា ដែលខ្វល់ខ្វាយតែពីខ្លួនឯងជាមុនសិន ហើយបែរទៅជ្រើសយកការជួយមនុស្សដទៃទៀត ទោះជាយើងអាចនឹងមានសេចក្តីត្រូវការផ្ទាល់ខ្លួនក្តីបានដោយរបៀបណា ?**
- **តើនៅពេលណាដែល ដែលអ្នកបានឃើញនរណាម្នាក់បានធ្វើតាមគំរូរបស់ព្រះយេស៊ូវ តាមរយៈការជ្រើសរើសជួយមនុស្សដទៃ បើទោះបីជានៅពេលដែលគាត់កំពុងត្រូវការជំនួយក្តី ?**

អ្នកគួរចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ និងគំរូដ៏ល្អឥតខ្ចោះដែលទ្រង់បានបង្ហាញស្តីពីការខ្វល់ខ្វាយពីសេចក្តីត្រូវការរបស់មនុស្សដទៃពីមុនសេចក្តីត្រូវការរបស់ទ្រង់ផ្ទាល់ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវរឿងដែលពួកគេនឹងធ្វើដើម្បីធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ។

សូមសង្ខេប យ៉ូហាន ១៩:២៨–៤២ ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានសុគត យ៉ូសែបដែលនៅភូមិអើរីម៉ាថេ បានសូមលោកពីឡាត់យកព្រះសពព្រះយេស៊ូវ ។ ក្រោយមកយ៉ូសែប និង នីកូដេម បានរៀបចំព្រះសពរបស់ព្រះអង្គសង្គ្រោះ ហើយដាក់ព្រះសពទ្រង់នៅក្នុងផ្នូរ ដែលយ៉ូសែបបានបរិច្ចាគនោះ ។

យ៉ូហាន ២០

សេចក្តីផ្តើម

នៅថ្ងៃអាទិត្យបន្ទាប់ពីការឆ្កាង ម៉ារា ម៉ាក់ដាឡា បានរកឃើញថាផ្នូរនៅទទេ ហើយបានប្រាប់ដល់យ៉ូហាន និងពេត្រុស ដែលក្រោយមកបានរត់ទៅមើលផ្នូរទទេនោះ ។ ព្រះគ្រីស្ទដែលបានរស់ឡើងវិញបានលេចមកឯ ម៉ារា ម៉ាក់ដាឡា ហើយក្រោយមកលេចមកឯពួកសិស្សរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ២០:១–១០

ម៉ារា ម៉ាក់ដាឡា បានរកឃើញផ្នូរទទេ ហើយប្រាប់ដល់ យ៉ូហាន និង ពេត្រុស ដែលក្រោយមកបានរត់ទៅមើលផ្នូរទទេនោះ:

ដើម្បីរៀបចំសិស្សឲ្យសិក្សាយ៉ូហាន ២០សូមអញ្ជើញពួកគេឲ្យគិតអំពីគ្រាមួយ ដែលមនុស្សជាទីស្រឡាញ់ម្នាក់របស់គេ ឬមនុស្សជាទីស្រឡាញ់របស់នរណាម្នាក់ដែលពួកគេស្គាល់បានស្លាប់ ។

- តើយើងអាចមានអារម្មណ៍យ៉ាងណា ពេលមនុស្សជាទីស្រឡាញ់ម្នាក់បានស្លាប់ទៅនោះ ?

ដើម្បីជួយសិស្សយល់អំពីបរិបទអំពីយ៉ូហាន ២០ចូរពន្យល់ពួកគេថា បន្ទាប់ពីព្រះយេស៊ូវបានសុគតប្រហែលជាម៉ោង ៣:០០ រសៀលថ្ងៃសុក្រ ក្រោយមកព្រះសពរបស់ទ្រង់ត្រូវបានគេដាក់នៅក្នុងផ្នូរមួយនាពេលល្ងាចនោះ ហើយបានដាក់ថ្មមួយធ្ងាំងយ៉ាងធំបិទនៅមាត់ផ្នូរ ។ ថ្ងៃឈប់សម្រាកបានចាប់ផ្តើមនៅពេលអស្តង្គត ។ (អ្នកគួរពន្យល់ថា ពីមុនការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ រាស្ត្រនៅក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់បានគោរពថ្ងៃឈប់សម្រាកចាប់ពីថ្ងៃលិចនៅថ្ងៃសុក្រ រហូតដល់ថ្ងៃលិចទៅវិញនៅថ្ងៃសៅរ៍) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ យ៉ូសែប ប៊ី វ៉ីតលីន នៃក្លុំមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់នឹកស្រមៃ ថាតើពួកសិស្សរបស់ព្រះយេស៊ូវមានអារម្មណ៍យ៉ាងណានៅថ្ងៃសុក្រដ៏អកុសលនោះ ។



« ខ្ញុំគិតអំពីភាពងងឹតនាថ្ងៃសុក្រ ដែលព្រះគ្រីស្ទត្រូវបានលើកឡើងឆ្កាងលើឈើឆ្កាង ។

« នៅថ្ងៃសុក្រដ៏អាក្រក់នោះ ផែនដីបានញ័រន្ធត់ ហើយកាន់តែងងឹតសូន្យសុង ។ ព្យុះភ្លៀងដ៏សាហាវបានមាននៅគ្រប់កន្លែងលើផ្ទៃផែនដី ។

« បុរសអាក្រក់ទាំងឡាយដែលស្វែងធ្វើគុតជីវិតទ្រង់បានរីករាយ ។ ព្រោះថាឈប់មានព្រះយេស៊ូវទៀតហើយ តែពួកអ្នកទាំងឡាយដែលដើរតាមទ្រង់នឹងរត់ខ្ចាត់ខ្ចាយ ។ នៅថ្ងៃនោះ ពួកគេបានឈរដោយជោគជ័យ ។

« នៅថ្ងៃនោះ វាំងននៃព្រះវិហារបរិសុទ្ធត្រូវបានហែកជាពីរចំរៀក ។

« ម៉ារា ម៉ាក់ដាឡា និង ម៉ារា ជាមាតាព្រះយេស៊ូវ ត្រូវបានពោរពេញទៅដោយទុក្ខសោក និងអស់សង្ឃឹម ។ បុរសដ៏អស្ចារ្យម្នាក់ដែលពួកគេបានស្រឡាញ់ និងគោរពត្រូវបានព្យួរដោយគ្មានជីវិត នៅលើឈើឆ្កាង ។

« នៅថ្ងៃសុក្រនោះ ពួកសាវកត្រូវបានខ្ទេចខ្ទាំក្នុងចិត្ត ។ ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់ពួកគេ—ជាមនុស្សដែលដើរលើទឹក ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ—គឺស្ថិតនៅក្នុងកណ្តាប់ដៃនៃមនុស្សទុច្ចរិតដោយផ្ទាល់ ។ ពួកគេបានសម្លឹងមើលដោយគ្មានសង្ឃឹម ខណៈដែលទ្រង់អនុញ្ញាតឲ្យមារសត្រូវធ្វើទុក្ខដល់ទ្រង់ ។

« នៅថ្ងៃសុក្រនោះ ព្រះអង្គសង្គ្រោះនៃមនុស្សលោក ត្រូវបានគេមើលងាយ វាយដំ បំពាន ហើយប្រមាថ ។

« វាគឺជាថ្ងៃសុក្រមួយដែលពោរពេញទៅដោយទុក្ខសោកយ៉ាងខ្លោចផ្សារ ឈឺចាប់យ៉ាងធ្ងន់ធ្ងរក្នុងព្រលឹងនៃអ្នកដែលស្រឡាញ់ និងគោរពដល់ព្រះរាជបុត្រានៃព្រះ ។

« ខ្ញុំគិតថាគ្រប់ជំនាន់ ចាប់តាំងពីការចាប់ផ្តើមនៃប្រវត្តិសាស្ត្ររបស់លោកិយនេះ ថ្ងៃសុក្រនោះគឺជាថ្ងៃដ៏ខ្មៅងងឹតបំផុត » (« Sunday Will Come, » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២៩–៣០) ។

- ប្រសិនបើអ្នកជាសិស្សម្នាក់ដែលនៅទីនោះក្នុងថ្ងៃសុក្រនោះ តើអ្នកប្រហែលនឹងមានអារម្មណ៍ ឬមានគំនិតយ៉ាងណាខ្លះ ?

បន្ទាប់ពីសិស្សឆ្លើយតប សូមអានអំពីសេចក្តីថ្លែងការណ៍បន្ថែមខាងក្រោមដោយអែលឌើរ វ៉ីតលីន ៖

« ប៉ុន្តែក្តីអស់សង្ឃឹមនៅថ្ងៃនោះពុំនៅយូរអង្វែងនោះទេ » (« Sunday Will Come » ទំព័រ ៣០) ។

សូមអញ្ជើញសិស្សឲ្យរកមើលរបៀបដែល « ក្តីអស់សង្ឃឹមនៅថ្ងៃនោះ ពុំនៅយូរអង្វែងនោះទេ » នៅពេលពួកគេសិក្សាយ៉ូហាន ២០ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានយ៉ូហាន ២០:១–២ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលម៉ារា ម៉ាក់ដាឡា បានមើលឃើញ ពេលនាងបានមកដល់ផ្នូរបស់ព្រះយេស៊ូវពីព្រឹកព្រលើមនៅថ្ងៃទីមួយនៃសប្តាហ៍ ឬថ្ងៃអាទិត្យ ។

សូមជួយសិស្សឲ្យយល់បរិបទនៃព្រះគម្ពីរ

បរិបទនៃព្រះគម្ពីរ រួមមាននូវស្ថានភាពទាំងឡាយជុំវិញព្រឹត្តិការណ៍មួយដែលបានកត់ត្រានៅក្នុងវគ្គបទគម្ពីរមួយ ។ ការយល់ដឹងអំពីមាតិកានេះនឹងរៀបចំសិស្សឲ្យទទួលស្គាល់សារលិខិតរបស់អ្នកនិពន្ធដ៏បំផុសគំនិតអំពីបទគម្ពីរទាំងឡាយ ។ វាក៏ជួយសិស្សឲ្យបោះជំហានចូលទៅក្នុងពិភពលោករបស់អ្នកនិពន្ធម្នាក់ៗខាងស្មារតីបានច្រើនតាមដែលអាចធ្វើទៅបានផងដែរ ហើយមើលឃើញពីព្រឹត្តិការណ៍ទាំងឡាយដូចដែលអ្នកនិពន្ធបានមើលឃើញ ។

- តើម៉ារាមើលឃើញអ្វី ?
- តើម៉ារាបានធ្វើដូចម្តេច នៅពេលគាត់បានឃើញថា ថ្មត្រូវបានរមៀលចេញពីមាត់ផ្នូរនោះ ? តើនាងបានសន្និដ្ឋានអ្វីខ្លះ ?

សូមអញ្ជើញសិស្សច្រើននាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ២០:៣–១០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលពេត្រុស និង យ៉ូហាន ដែលសំដៅថាជា « សិស្សមួយនោះ » (ខទី ៣) បានធ្វើអ្វីខ្លះ បន្ទាប់ពីបានស្តាប់ឮដំណឹងពីម៉ារា ។

- តើពេត្រុស និងយ៉ូហាន បានធ្វើអ្វីខ្លះ បន្ទាប់ពីស្តាប់ឮដំណឹងពីម៉ារា ?
- យោងតាមខទី ៨តើយ៉ូហានបានឆ្លើយតបយ៉ាងដូចម្តេចចំពោះការមើលឃើញផ្នូរទទេ ? តើគាត់ជឿអ្វី ?

អ្នកអាចនឹងចង់ពន្យល់ថា គាត់ពុំបានយល់ពេញលេញអំពីការប្រកាសរបស់ព្រះអង្គសង្គ្រោះដែលថាទ្រង់នឹងរស់ឡើងវិញពីសុគតនៅថ្ងៃទីបីទេ ទាល់តែយ៉ូហានបានមើលឃើញផ្នូរទទេនោះ ។ នៅពេលយ៉ូហានបានឃើញផ្នូរទទេ នោះគាត់បាននឹកចាំ ហើយជឿ (សូមមើល យ៉ូហាន ២០:៨–៩) ។

យ៉ូហាន ២០:១១–៣១

ព្រះអង្គសង្គ្រោះដ៏មានព្រះជន្មរស់បានលេចមកឯ ម៉ារា ម៉ាក់ដាឡា ហើយក្រោយមកលេចមកឯពួកសិស្សរបស់ទ្រង់

សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ២០:១១–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថានរណានិយាយទៅកាន់ម៉ារា បន្ទាប់ពីពេត្រុស និងយ៉ូហាន បានចាកចេញពីផ្នូរទៅនោះ ។

- នៅក្នុងខទី ១២–១៣តើនរណាបាននិយាយទៅកាន់ម៉ារា ?
- តើនរណាបាននិយាយទៅកាន់ម៉ារានៅក្នុងខទី ១៥ ? តើម៉ារាគិតថាព្រះយេស៊ូវគ្រីស្ទជានរណា ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ២០:១៦–១៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលព្រះយេស៊ូវបានណែនាំដល់ម៉ារា ឲ្យធ្វើនៅពេលនាងបានមើលស្គាល់ទ្រង់ ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃឃ្លា « កុំពាល់ខ្ញុំ » (ខទី ១៧) សុំឲ្យសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« កំណែស្តេចជេមស៍ បានដកស្រង់ព្រះយេស៊ូវមានបន្ទូលថា ‹ កុំពាល់ខ្ញុំ › ។ ការបកប្រែដោយយ៉ូសែប ស្ម៊ីធ បានអានថា ‹ កុំឱបខ្ញុំ › ។ ការបកប្រែផ្សេងៗចេញមកពីភាសាក្រេក ផ្សាយវគ្គគម្ពីរនេះថា ‹ កុំតោងខ្ញុំអី › ឬ ‹ កុំកាន់ខ្ញុំអី › ។ អ្នកខ្លះផ្តល់ន័យថា ‹ កុំតោងខ្ញុំទៀត › ឬ « កុំកាន់ខ្ញុំទៀត » ។ អ្នកខ្លះនិយាយអំពីការឈប់កាន់ទ្រង់ ឬតោងទ្រង់ ដោយបញ្ជាក់ថា ម៉ារាបានកាន់ទ្រង់រួចហើយ ។ មានមូលហេតុត្រឹមត្រូវចំពោះការគិតថា អ្វីដែលទំនាក់ទំនងទៅកាន់ម៉ារាដោយព្រះអម្ចាស់ដែលមានព្រះជន្មរស់គឺសំខាន់ ៖ ‹ អ្នកពុំអាចទុកឲ្យខ្ញុំនៅទីនេះបានទេ ឬតខ្ញុំនឹងយាងឡើងទៅជួបនឹងព្រះបិតាខ្ញុំ › » (*The Mortal Messiah* រ៉ូលទី ៤ | ឆ្នាំ ១៩៧៩–៨១ | ៤:២៦៤) ។

- យោងតាម ខទី ១៧តើព្រះយេស៊ូវបានណែនាំម៉ារាឲ្យធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេគឺជាសិស្សម្នាក់ដែលបានស្តាប់ឮសាក្សីរបស់ម៉ារា ។ សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើអ្នកគិតថាអ្នកនឹងមានអារម្មណ៍យ៉ាងណា នៅពេលអ្នកស្តាប់ម៉ារា ?
- តើអ្នកនឹងជឿគាត់ឬទេ ? ហេតុអ្វី ឬ ហេតុអ្វីមិនជឿ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ សូមរំឭកពួកគេថា សិស្សខ្លះមានបញ្ហាក្នុងការជឿលើសាក្សីរបស់ម៉ារា (សូមមើលម៉ាកុស ១៦:១១) ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហាន ២០:១៩–២០ ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វី ដែលបានកើតឡើងនាល្ងាចនោះ ។

- តើមានអ្វីខ្លះបានកើតឡើងនាល្ងាចនោះ ពេលពួកសាវកបានជួបជុំគ្នានោះ ?
- តើគោលលទ្ធិសំខាន់ដែលម៉ារា និងពួកសិស្សបានរៀនមានអ្វីខ្លះ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទបានយកឈ្នះសេចក្តីស្លាប់តាមរយៈការរស់ឡើងវិញ**)។
- យោងតាមខទី ២០តើពួកសិស្សមានអារម្មណ៍យ៉ាងណា នៅពេលពួកគេបានឃើញព្រះអម្ចាស់បានរស់ឡើងវិញ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ យ៉ូសែប ប៊ី វ៉ីតលីន ឮៗ ៖

« រំពេចនោះកែវភ្នែកទាំងឡាយដែលធ្លាប់ពោរពេញដោយទឹកភ្នែកហូរជានិច្ចនោះ ត្រូវបានស្ងួត ។ បបូរមាត់ដែលធ្លាប់ខ្សឹបការអធិស្ឋានអំពីការបាក់ទឹកចិត្ត និងទុក្ខព្រួយ ឥឡូវនេះ ពោរពេញដោយការសរសើរដំកើងដ៏អស្ចារ្យចំពោះព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់ដែលបានគង់នៅខាងមុខពួកគេ ជាផលផ្លែដំបូងនៃការរស់ឡើងវិញ ជាភស្តុតាងថា សេចក្តីស្លាប់ គឺគ្រាន់តែជាការចាប់ផ្តើមនៃដំណើរថ្មី និងការរស់នៅដ៏អស្ចារ្យតែប៉ុណ្ណោះ » (« Sunday Will Come » ទំព័រ ៣០) ។

- តើការដឹងថាព្រះយេស៊ូវគ្រីស្ទត្រូវបានរស់ឡើងវិញ បានជួយយើងយ៉ាងដូចម្តេចខ្លះ នៅពេលយើងមានទុក្ខព្រួយ ពេលនរណាម្នាក់ដែលយើងស្រឡាញ់បានបាត់បង់ជីវិតទៅនោះ ? (ដោយសារព្រះយេស៊ូវគ្រីស្ទត្រូវបានរស់ឡើងវិញ នោះមនុស្សគ្រប់រូបដែលបានរស់នៅលើផែនដីនេះ ក៏នឹងត្រូវបានរស់ឡើងវិញផងដែរ | សូមមើលកូរិនថូសទី ១ ១៥:២០–២២|) ។

សូមសង្ខេបយ៉ូហាន ២០:២១–២៣ដោយពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវបានបង្ហាញដល់ពួកសិស្សរបស់ទ្រង់នូវស្នាមរបួសនៅលើព្រះហស្តរបស់ទ្រង់ និងនៅចំហៀងព្រះកាយទ្រង់ នោះទ្រង់បានបញ្ជាពួកគេឲ្យធ្វើកិច្ចការទ្រង់ ហើយមានបន្ទូលទៅពួកគេថា « ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ » (ខទី ២២) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២០:២៤–២៥ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសាវកដែលពុំមានវត្តមាននៅឱកាសដ៏ពិសិដ្ឋនោះ ។

- តើសាវកមួយណាដែលពុំមានវត្តមាននៅពេលសិស្សដទៃទៀតបានឃើញព្រះអម្ចាស់ដែលមានព្រះជន្មរស់ ?
- យោងតាមខទី ២៥តើថូម៉ាសបាននិយាយថា គាត់ត្រូវការអ្វីខ្លះដើម្បីជឿ ?
- តើការឆ្លើយតបរបស់ថូម៉ាស បានកត់ត្រានៅក្នុងខនេះ ខុសពីការឆ្លើយតបរបស់យ៉ូហាន នៅពេលយ៉ូហានបានឃើញផ្សេងទេ ដូចដែលបានកត់ត្រានៅក្នុងយ៉ូហាន ២០:៨យ៉ាងដូចម្តេច ?
- ហេតុអ្វីក៏អ្នកគិតថា វាលំបាកសម្រាប់ថូម៉ាសក្នុងការជឿ ?

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី យ៉ូហាន ២០:២៦–២៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលថា ថូម៉ាសបានជួបនឹងបទពិសោធន៍អ្វីខ្លះក្នុងរយៈពេលប្រាំបីថ្ងៃ ដែលគាត់បាននិយាយថា គាត់មិនជឿថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញនោះ ។

ជំនួសការឲ្យសិស្សអាន អ្នកអាចបង្ហាញវីដេអូ « Blessed Are They That Have Not Seen, and Yet Have Believed »(២:២៩) ចេញមកពី*វីដេអូគម្ពីរប៊ីបអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ* ដើម្បីជួយសិស្សឲ្យមើលឃើញពីបទពិសោធន៍របស់ថូម៉ាស ដូចបានកត់ត្រានៅក្នុងខគម្ពីរទាំងនេះ ។ វីដេអូនេះមាននៅក្នុង LDS.org។

- បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទអនុញ្ញាតឲ្យថូម៉ាសពាល់ព្រះហស្ត និងចំហៀងព្រះកាយទ្រង់ តើជម្រើសអ្វីដែលទ្រង់អញ្ជើញឲ្យថូម៉ាសធ្វើការជ្រើសរើស ? (ជឿចុះ) ។
- យោងតាម ខទី ២៩តើព្រះយេស៊ូវចង់ឲ្យថូម៉ាសយល់ពីអ្វីខ្លះ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **យើងនឹងត្រូវបានប្រទានពរ ប្រសិនបើយើងជ្រើសរើសជឿទៅលើព្រះយេស៊ូវគ្រីស្ទ ទោះជាយើងពុំអាចមើលឃើញទ្រង់ក្តី**)។

សូមបំបែកសិស្សជាក្រុមពីរនាក់ ឬបីនាក់ ហើយផ្តល់ឲ្យក្រុមនីមួយៗនូវឯកសារចែកចាយមួយ ដែលមាននូវសំណួរដូចខាងក្រោម ។

យើងនឹងត្រូវបានប្រទានពរ ប្រសិនបើយើងជ្រើសរើសជឿទៅលើព្រះយេស៊ូវគ្រីស្ទ ទោះជាយើងពុំអាចមើលឃើញទ្រង់ក្តី

១. ហេតុអ្វីអ្នកជ្រើសរើសជឿទៅលើព្រះយេស៊ូវគ្រីស្ទ ទោះជាអ្នកពុំបានមើលឃើញទ្រង់ដោយភ្នែកខាងសាច់ឈាមរបស់អ្នកផ្ទាល់នោះដូច្នេះ ?

២. តើយើងអាចធ្វើអ្វីខ្លះដើម្បីបង្ហាញថា យើងបានជ្រើសរើសជឿទៅលើព្រះយេស៊ូវគ្រីស្ទ ?

៣. តើអ្នកត្រូវបានប្រទានពរយ៉ាងដូចម្តេច តាមរយៈការជ្រើសរើសជឿទៅលើព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញក្រុមនីមួយៗ ឲ្យពិភាក្សាសំណួរទាំងឡាយជាមួយគ្នា ហើយសរសេរចម្លើយរបស់ពួកគេនៅលើឯកសារចែកចាយ ឬនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាបទគម្ពីររបស់ពួកគេ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។

ចូរពន្យល់ថា ទោះជាព្រះយេស៊ូវបានបង្រៀនថាយើងនឹងត្រូវបានប្រទានពរ ប្រសិនបើយើងជ្រើសរើសជឿទៅលើទ្រង់ ទោះជាយើងពុំអាចមើលឃើញទ្រង់ក្តី ទ្រង់បានផ្តល់ជាសាក្សីជាច្រើនដើម្បីធ្វើជាមូលដ្ឋានគ្រឹះមួយនៃជំនឿរបស់យើង ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន យ៉ូហាន ២០:៣០–៣១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវមូលហេតុដែលយ៉ូហានបានកត់ត្រានៅក្នុងព្រឹត្តិការណ៍ទាំងនេះ ។

- ហេតុអ្វីយ៉ូហានកត់ត្រាព្រឹត្តិការណ៍ទាំងនេះ ? (អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ*ជីវិត* [ខទី ៣១] សំដៅទៅលើជីវិតអស់កល្បជានិច្ច)។
- តើមានសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីខទី ៣១អំពីទីបន្ទាល់អំពីពួកសាវក និងពួកព្យាការី ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរប្រាប់ពីសេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **ពួកសាវក និងពួកព្យាការីផ្តែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ដើម្បីយើងអាចជឿថា ទ្រង់គឺជាព្រះរាជបុត្រារបស់ព្រះ ។ តាមរយៈការជ្រើសរើសជឿទៅលើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានផ្តល់ឲ្យតាមរយៈពួកសាវក និងពួកព្យាការី នោះយើងអាចទទួលបានជីវិតអស់កល្បជានិច្ច ។** ការជឿនេះចង្អុលប្រាប់ថា មនុស្សម្នាក់នឹងព្យាយាមរក្សាបទបញ្ញត្តិរបស់ទ្រង់ ហើយរស់នៅស្មោះត្រង់ចំពោះទីបន្ទាល់នោះ) ។
- តើទីបន្ទាល់របស់ពួកសាវក និងពួកព្យាការីបានពង្រឹងដល់ជំនឿរបស់អ្នកទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តសេចក្តីពិត ដែលពួកគេបានប្រាប់នៅក្នុងយ៉ូហាន ២០ដោយការតាំងចិត្តអំពីរបៀបដែលពួកគេនឹងបង្ហាញជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។

យ៉ូហាន ២១

សេចក្តីផ្តើម

ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ បានបង្ហាញអង្គទ្រង់ដល់ពួកសិស្សរបស់ទ្រង់កាលពួកគេកំពុងនេសាទត្រី ។ នៅលើឆ្នេរ ព្រះយេស៊ូវបានសោយជាមួយនឹងពួកសិស្សរបស់ទ្រង់ ហើយបានអញ្ជើញពេត្រុសឲ្យបង្ហាញសេចក្តីស្រឡាញ់របស់គាត់ ដល់ព្រះអម្ចាស់ដោយឲ្យចំណីដល់ចៀមរបស់ទ្រង់ ។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ជាមុនពីការរងទុក្ខកេរម្មរបស់ពេត្រុស និង ការប្រែរូបរបស់យ៉ូហាន ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ២១:១–១៧

ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ បង្ហាញអង្គទ្រង់ដល់ពួកសិស្សមួយចំនួនរបស់ទ្រង់នៅសមុទ្រទីបេរាស (សមុទ្រកាលីឡេ)

សូមគូររូប បេះដូងមួយធំនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សឲ្យឡើងមកក្តារខៀនសរសេរ នៅក្នុងបេះដូងនោះរឿងពីរ ឬបីយ៉ាងដែលពួកគេចូលចិត្ត ។ សូមពន្យល់ថា រឿងទាំងនេះអាចរួមបញ្ចូលទាំងមនុស្ស ទ្រព្យសម្បត្តិ ឬសកម្មភាព ។

នៅពេលសិស្សបានបញ្ចប់ អ្នកក៏អាចសរសេរនូវរឿងមួយចំនួន ដែលអ្នកចូលចិត្តផងដែរ ។

សូមសង្ខេប យ៉ូហាន ២១:១–២ ដោយពន្យល់ថា បន្ទាប់ពីមើលឃើញព្រះអម្ចាស់ ដែលមានព្រះជន្មរស់ឡើងវិញពីរដង ពេត្រុស និងពួកសិស្សផ្សេងទៀតមួយចំនួនបាននៅលើឆ្នេរសមុទ្រកាលីឡេ (ក៏ត្រូវបានគេហៅថា សមុទ្រទីបេរាស ផងដែរ) ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមអកមើលអ្វី ដែលពេត្រុសបានសម្រេចចិត្តធ្វើ ។

- តើអ្នកគិតថាសកម្មភាពអ្វីខ្លះ ដែលពេត្រុសអាចនឹងបន្ថែមទៅក្នុងបញ្ជីរបស់យើងនៃរឿងដែលចូលចិត្តនៅលើក្តារខៀននោះ ? (ក្រោយពីសិស្សឆ្លើយតបហើយ សូមសរសេរ *ការស្ទុចត្រី* នៅក្នុងបេះដូងនៅលើក្តារខៀន) ។
- តើពេត្រុស និងពួកសិស្សដទៃទៀតបានទៅរកត្រីយូរប៉ុណ្ណាដែរ? តើពួកគេចាប់ត្រីបានប៉ុន្មានដែរ ?

ចូរសុំឲ្យសិស្សពិចារណា ហើយគិតពីអារម្មណ៍ដែលពេត្រុស និងពួកសិស្សផ្សេងទៀតអាចនឹងមាន ក្រោយពីចាប់ត្រីមិនបានសោះពេញមួយយប់នោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:៤–៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើងនៅព្រឹកស្អែក ។

- តើនរណានៅលើឆ្នេរនោះ ?
- តើដំបូងឡើយពួកសិស្សបានស្គាល់ព្រះយេស៊ូវដែរទេ ?
- តើព្រះយេស៊ូវបង្រៀនពួកគេឲ្យធ្វើអ្វីខ្លះ ?
- តើមានអ្វីបានកើតឡើង បន្ទាប់ពីពួកគេបានធ្វើតាមសេចក្តីណែនាំរបស់ព្រះយេស៊ូវ ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ដៃប្រ៊ី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« កាលពីបីឆ្នាំមុន បុរសទាំងនេះបាននេសាទនៅក្នុងសមុទ្រនេះ ។ ក្នុងស្ថានភាពដូចគ្នានេះដែរ តាមបទគម្ពីរបានចែងថា ពួកគេ ‹បានដឹកអ្នកទាល់តែ គ្មានបានអ្វីសោះ› (លូកា ៥:៥) ។ ប៉ុន្តែអ្នកស្រុកកាលីឡេនៅលើមាត់ច្រាំងនោះបានហៅពួកគេឲ្យទម្លាក់អួនពួកគេចុះ រួចពួកគេបានទម្លាក់ចុះទៅ ‹ នោះក៏ជាប់បានត្រីសន្ធឹក › (លូកា ៥:៦) រហូតដល់អួនពួកគេដាច់ ដោយសារត្រីដែលចាប់បាន មានចំនួនអាចដាក់បានបំពេញដល់ទៅពីរទូក នោះពួកគេក៏ចាប់ផ្តើមលិច ។

« ឥឡូវវាបានកើតឡើងម្តងទៀត » (« The First Great Commandment » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ២០១២ ទំព័រ ៨៤) ។

- តើការចាប់ត្រីបានដោយអព្ភូតហេតុជាលើកទីពីរ បានជួយពួកសិស្សឲ្យស្គាល់ជនដែលនៅលើឆ្នេរនោះដោយរបៀបណា ?
- ប្រសិនបើអ្នកមានវត្តមាននៅលើទូកនោះជាមួយនឹងពួកសិស្ស តើអ្នកប្រហែលជាគិត ឬ មានអារម្មណ៍យ៉ាងដូចម្តេចដែរ ?

សូមសង្ខេប យ៉ូហាន ២១:៧–១៤ ដោយពន្យល់ថា កាលសិស្សមិនអាចលើកសំណាញ់ដែលមានសុទ្ធតែត្រីចូលទៅក្នុងទូក យ៉ូហានបានប្រកាសថា បុរសដែលនៅលើឆ្នេរនោះគឺជាព្រះអម្ចាស់ ។ ពេត្រុសបានលោតចូលទៅក្នុងសមុទ្រភ្លាម ហើយហែលទៅរកព្រះយេស៊ូវ ខណៈសិស្សដទៃទៀតជិះទូកមកតាមក្រោយ ។ កាលពួកគេបានមកដល់ឆ្នេរវិញ ព្រះយេស៊ូវបានត្រៀមអាហារសម្រាប់ពួកគេ ។

សូមពន្យល់ថា អែលឌើរ ដៃប្រ៊ី អ័រ ហូឡិន បានបរិយាយយ៉ាងល្អិតល្អន់អំពីដំណើររឿងនេះដោយបង្រៀនថា បន្ទាប់ពីពេត្រុស និងពួកសិស្សដទៃទៀតបានបដិសេធព្រះអង្គសង្គ្រោះ ព្រះយេស៊ូវអាចនឹង « [ទតមើល] ទៅទូកតូចចំណាស់ អ្នកណ្តាចរបស់ពួកគេ និងគំនរត្រី ១៥៣ ក្បាល នោះព្រះយេស៊ូវ [បានមានបន្ទូល] ទៅកាន់សាវកវៀមច្បងរបស់ទ្រង់ » (« The First Great Commandment »ទំព័រ ៨៤) ហើយបន្ទាប់មកក៏មានបន្ទូលទៅពេត្រុស ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:១៥–១៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលសំណួរដែលព្រះយេស៊ូវបានសួរដល់ពេត្រុសម្តងហើយម្តងទៀត ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរតែគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើព្រះយេស៊ូវបានសួរសំណួរអ្វីទៅពេត្រុសរហូតដល់ទៅបីដង ?
- កាលព្រះយេស៊ូវបានសួរថា « តើអ្នកស្រឡាញ់ខ្ញុំជាជាងរបស់ទាំងនេះឬអី ? » (ខទី ១៥) តើអ្នកគិតថាពាក្យ *របស់ទាំងនេះ* សំដៅទៅលើអ្វី ? (ព្រះយេស៊ូវអាចនឹងសំដៅទៅលើគំនរត្រី ឬរឿងផ្សេងទៀតដែលទាក់ទងនឹងជីវិតរបស់អ្នកនេសាទត្រីម្នាក់ ។ សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀននៅក្បែររូបបេះដូង ៖ *តើអ្នកស្រឡាញ់ខ្ញុំជាជាងរបស់ទាំងនេះឬអី* ?)
- តើពេត្រុសបានឆ្លើយបែបណាដែរ ?
- តើអ្នកនឹងមានអារម្មណ៍បែបណាដែរ ប្រសិនបើអ្នកស្ថិតនៅក្នុងតួនាទីរបស់ពេត្រុស ហើយត្រូវបានព្រះយេស៊ូវសួរអ្នករហូតដល់បីដងថា តើអ្នកស្រឡាញ់ទ្រង់ដែរឬអត់ ?

ដើម្បីជួយសិស្សឲ្យយល់ពីហេតុផលដែល ព្រះយេស៊ូវបានសួរសំណួរនេះដល់ទៅបីដងនោះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ហូឡិន ៖



« (ហើយជាថ្មីម្តងទៀត ខ្ញុំទទួលស្គាល់ថា នេះជាចំណេះដឹងដែលពុំបានកត់ត្រានៅក្នុងគម្ពីរ) ប្រហែលជាព្រះយេស៊ូវបានឆ្លើយតបដោយមានបន្ទូលបែបនេះ ៖ ‹ ហេតុអ្វីអ្នកមកទីនេះ ពេត្រុស? ហេតុអ្វីក៏យើងមកឆ្នេរដដែលនេះ ដែលមានអ្នកដដែល និងមានការសន្ទនាដដែលនេះ ? តើវាមិនជាក់ស្តែងទេឬអីនៅពេលនោះ ហើយតើវាមិនជាក់ស្តែងទេឬអី នៅពេលនេះថាបើយើងចង់បានត្រី តើយើងនឹងបានត្រីទេឬអី ? ពេត្រុស អ្វីដែលយើងត្រូវការគឺជាពួកសិស្ស—ហើយយើងត្រូវការពួកគេជារៀងរហូត ។ យើងត្រូវការមនុស្សម្នាក់ដើម្បីឲ្យចំណីដល់ចៀមរបស់យើង ហើយជួយសង្គ្រោះកូនចៀមរបស់យើង ។ យើងត្រូវការមនុស្សម្នាក់ដើម្បីប្រកាសដំណឹងល្អរបស់យើង ហើយការពារសេចក្តីជំនឿរបស់យើង ។ យើងត្រូវការមនុស្សម្នាក់ដែលស្រឡាញ់យើង គឺស្រឡាញ់យើងដោយពិតប្រាកដ ហើយស្រឡាញ់អ្វីដែលព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌បានប្រទានសិទ្ធិឲ្យយើងធ្វើ ។. . .ហេតុដូច្នេះហើយពេត្រុស នេះជាលើកទីពីរ ហើយប្រហែលជាលើកចុងក្រោយ ដែលយើងសុំឲ្យអ្នកលះបង់របស់ទាំងនេះ ហើយទៅបង្រៀន ហើយថ្លែងទីបន្ទាល់ ធ្វើការ ហើយបម្រើដោយស្មោះត្រង់រហូតដល់ថ្ងៃដែលពួកគេនឹងធ្វើចំពោះអ្នកដូចជាពួកគេបានធ្វើដាក់យើងដែរ › » («The First Great Commandment» ទំព័រ ៨៤) ។

- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីបទពិសោធន៍របស់ពេត្រុស ? (បន្ទាប់ពីសិស្សឆ្លើយសូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងស្រឡាញ់ព្រះអង្គសង្គ្រោះ និងព្រះវរបិតាសួគ៌លើសអ្វីៗទាំងអស់ យើងនឹងឲ្យចំណីដល់ចៀមរបស់ពួកទ្រង់**) ។
- តើនរណាខ្លះជាកូនចៀមរបស់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ? តើយើងឲ្យចំណីវាដូចម្តេច?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗដោយអែលឌើរ រ៉ូបឺត ឌី ហៃល នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« នេះគឺជាការអំពាវនាវរបស់ព្រះគ្រីស្ទដល់ពួកគ្រីស្ទានគ្រប់រូបនាបច្ចុប្បន្ននេះ ៖ ‹ ចូរឲ្យចំណីដល់កូនចៀមខ្ញុំសឹងផង ។ . . . ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំសឹងផង › —គឺចែកចាយដំណឹងល្អរបស់យើងដល់មនុស្សទាំងចាស់ទាំងក្មេង ដោយលើកស្ទួយ ឲ្យពរ លួងលោម លើកទឹកចិត្ត ហើយពង្រឹងពួកគេ ជាពិសេសដល់ជនដែលគិត ហើយជឿខុសពីយើង » (« Being a More Christian Christian » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៩១) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលគោលការណ៍ដែលពួកគេទើបសំគាល់ឃើញអាចទាក់ទងនឹងយើង សូមអញ្ជើញសិស្សបីនាក់ឲ្យប្តូរវេនគ្នាអានសាច់រឿងខាងក្រោមនេះឲ្យឮៗ ។ អ្នកអាចសម្របសាច់រឿងទាំងនេះទៅតាមតម្រូវការ និងចំណាប់អារម្មណ៍នៃសិស្សរបស់អ្នក ។ បន្ទាប់ពីសាច់រឿងនីមួយៗត្រូវបានអានចប់ ចូរសួរសំណួរតាមក្រោយ ។

១. មានក្មេងប្រុសមួយក្រុម បានអញ្ជើញយុវជនម្នាក់ឲ្យអង្គុយជាមួយពួកគេនៅម៉ោងបាយថ្ងៃត្រង់ ហើយគាត់សង្ឃឹមថានឹងក្លាយជាមិត្តជាមួយនឹងពួកគេ ។ អំឡុងពេលនៃការសន្ទនារបស់ពួកគេ មានក្មេងប្រុសម្នាក់នៅក្នុងក្រុមនោះចាប់ផ្តើមចំអន់ឲ្យក្មេងប្រុសម្នាក់ទៀតជាសាធារណៈ ។

២. មានយុវនារីម្នាក់ចូលចិត្តលេងបាត់ទាត់ ។ នាងបានចំណាយពេលជាច្រើនម៉ោងក្នុងមួយសប្តាហ៍ ដើម្បីលេងបាល់ទាត់ ហើយមានពេលតិចតួចណាស់សម្រាប់រឿងផ្សេងទៀតដូចជា រាត្រីជួបជុំក្រុមគ្រួសារ និងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ។

៣. មានយុវជនម្នាក់មមាញឹកនឹងការសិក្សា ព្រមទាំងសកម្មភាពក្រៅម៉ោងសិក្សាផ្សេងទៀត ។ ពេញមួយសប្តាហ៍ គាត់បានទន្ទឹងរង់ចាំការមានពេលទំនេរដ៏កម្រមួយចំនួនជាមួយនឹងមិត្តភក្តិនៅយប់ថ្ងៃសុក្រ ។ មុនពេលគាត់ទូរសព្ទទៅមិត្តរបស់គាត់ ដៃគូបង្រៀនតាមផ្ទះរបស់គាត់បានទូរសព្ទមកសួរថា តើគាត់អាចចេញទៅជួយដល់គ្រួសារមួយដែលពួកគេបានចាត់តាំងឲ្យ ដែលមានសេចក្តីត្រូវការជាបន្ទាន់បានទេ ។

- តើមានការជ្រើសរើសអ្វីខ្លះសម្រាប់បុគ្គលនេះ ?
- តើបុគ្គលម្នាក់នេះអាចធ្វើបានដូចម្តេចខ្លះ ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះព្រះអម្ចាស់ ? តើទង្វើនោះបានបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះអម្ចាស់តាមរបៀបណា ?

លំហាត់សរសេរ

ការអញ្ជើញសិស្សឲ្យសរសេរនូវចម្លើយរបស់ខ្លួនចំពោះសំណួរដែលបំផុសគំនិតជួយធ្វើឲ្យពួកគេគិតបានចាក់ឫសយ៉ាងជ្រៅ ហើយច្បាស់លាស់ ។ នៅក្នុងចំណោមរឿងផ្សេងទៀត លំហាត់សរសេរផ្តល់ឱកាសឲ្យសិស្សចូលរួមដោយផ្ទាល់ ហើយទទួលបានការបំផុសគំនិតអំពីរបៀបអនុវត្តនូវអ្វីដែលពួកគេកំពុងរៀន ។

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ហូឡិន ៖

« បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំពុំដឹងច្បាស់ពីបទពិសោធន៍របស់យើងនឹងមានសភាពយ៉ាងណានៅថ្ងៃជំនុំជំរះនោះទេ ប៉ុន្តែខ្ញុំនឹងពិតជាភ្ញាក់ផ្អើលណាស់ បើនៅក្នុងការសន្ទនានោះ ព្រះពុំសួរយើងដូចគ្នានឹងអ្វីដែលព្រះគ្រីស្ទបានសួរដល់ពេត្រុសនោះ ៖ ‹ តើអ្នកស្រឡាញ់ខ្ញុំទេ ? › » (« The First Great Commandment » ទំព័រ ៨៤) ។

ចូរចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការជ្រើសស្រឡាញ់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទឲ្យលើសពីអ្វីៗទាំងអស់ និងការបង្ហាញសេចក្តីស្រឡាញ់នោះដោយឲ្យចំណីដល់ហ្វូងចៀមរបស់ទ្រង់ ។

ចូរលើកលើកឡើងពីអ្វីដែលបានសរសេរនៅក្នុងរូបបេះដូងនៅលើក្តារខៀន និងសំណួរដែលបានសរសេរនៅក្បែរវត្ថុទាំងនោះ ៖ « តើអ្នកស្រឡាញ់ខ្ញុំជាជាងរបស់ទាំងនេះឬអី ? » ចូរគូសបន្ទាត់ក្រោមពាក្យ *របស់ទាំងនេះ* ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរខាងក្រោមទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- ប្រសិនបើព្រះយេស៊ូវបានសួរសំណួរដូចគ្នានេះដល់អ្នក តើអ្នកគិតថាទ្រង់ចង់មានបន្ទូលអំពីអ្វីទៅ នៅក្នុងជីវិតរបស់អ្នកចំពោះពាក្យថា « របស់ទាំងនេះ » ?
- តើអ្នកនឹងឆ្លើយសំណួររបស់ទ្រង់យ៉ាងដូចម្តេច ?
- តើអ្នកនឹងបង្ហាញសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះអម្ចាស់តាមរបៀបណា ?

យ៉ូហាន ២១:១៨–២៥

ព្រះយេស៊ូវប្រាប់ពីការរងទុក្ខទុក្កកម្មរបស់ពេត្រុស និង ការបកប្រែរបស់យ៉ូហាន

សូមសង្ខេប យ៉ូហាន ២១:១៨–២១ ដោយពន្យល់ថា ព្រះយេស៊ូវបានព្យាករថា នៅពេលពេត្រុសមានអាយុចាស់ « នោះគាត់នឹងសន្ធឹងដៃ [របស់គាត់] ទៅ » (ខទី ១៨) ហើយត្រូវនាំទៅកន្លែងដែលគាត់មិនចង់ទៅ ។ វាជាទំនៀមទម្លាប់ដែលជឿថា ពេត្រុសបានស្លាប់ដោយសារការឆ្កាង ។ ប៉ុន្តែគេនិយាយថា ពេត្រុសបានស្នើសុំឲ្យគេឆ្កាងគាត់ដាំក្បាលចុះក្រោម ដោយព្រោះគាត់ចាត់ទុកខ្លួនឯងថាគាត់ពុំសក្តិសមនឹងស្លាប់តាមរបៀបដូចព្រះអង្គសង្គ្រោះឡើយ (សូមមើល យ៉ូសែប ហ្វីលឌីង ស្មីធ *Doctrines of Salvation* ចងក្រងដោយ ប្រ៊ូស អ័រ ម៉ាក់ខនយ៉ី វ៉ុលទី ៣ [ឆ្នាំ ១៩៥៤–៥៦] ៣:១៥១–៥២) ។

បន្ទាប់ពីឮអំពីការព្យាករណ៍នេះ ពេត្រុសបានទូលសួរថា តើនឹងមានអ្វីកើតឡើងចំពោះសាវកយ៉ូហាន ឬ យ៉ូហានដ៏ជាទីស្រឡាញ់ ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:២២–២៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យរៀងតាមរកមើលរបៀប ដែលព្រះអង្គសង្គ្រោះបានឆ្លើយតបនឹងពេត្រុស ។

- តើពេត្រុសបានដឹងអ្វីខ្លះអំពីយ៉ូហាន ?

សូមពន្យល់ថា ពាក្យ *នៅ* នៅក្នុង ខទី ២២ មានន័យថា បន្តរស់នៅលើផែនដីនេះ ។ ហេតុដូច្នេះហើយ យ៉ូហាននឹងបន្តរស់នៅលើផែនដីនេះ ជាតួអង្គប្រែរូប រហូតដល់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកអ្នកដែលបានផ្លាស់ប្រែរូបគឺជា « ជនទាំងឡាយណាដែលបានផ្លាស់ប្រែ ដើម្បីកុំឲ្យស្គាល់ការឈឺចាប់ ឬសេចក្តីស្លាប់ ដរាបដល់ការរស់ឡើងវិញទៅរកអមតភាព » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ពួកអ្នកដែលបានផ្លាស់ប្រែរូប » , scriptures.lds.org) ។

- យោងតាម ខទី ២២តើព្រះយេស៊ូវបានចង់ឲ្យពេត្រុសផ្តោតទៅលើអ្វី ជាជាងខ្វល់ខ្វាយអំពីខ្លួនឯងជាមួយនឹងអ្វីដែលនឹងកើតឡើងចំពោះយ៉ូហាននោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:២៤–២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ធ្វើតាមរកមើលអ្វី ដែលយ៉ូហានចង់ឲ្យមនុស្សគ្រប់គ្នាដឹង នៅពេលគាត់បានបញ្ចប់កំណត់ត្រារបស់គាត់ ។

- តើយ៉ូហានចង់ឲ្យមនុស្សគ្រប់គ្នាដឹងអ្វីខ្លះ នៅពេលគាត់បានបញ្ចប់កំណត់ត្រារបស់គាត់ ?

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

ចេញពីអ្វីៗទាំងអស់ដែលបានសរសេរនៅក្នុងកំណត់ត្រារបស់ម៉ាថាយ ម៉ាកុស លូកា និង យ៉ូហាន តើរឿង ព្រឹត្តិការណ៍ ឬការបង្រៀនអ្វីខ្លះ នៅក្នុងការបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះដែលមានឥទ្ធិពលយ៉ាងខ្លាំងអស្ចារ្យមកលើអ្នក ? ហេតុអ្វី ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីចម្លើយរបស់ពួកគេចំពោះសំណួរទាំងនេះ ។ អ្នកអាចចាក់ភ្លេងទំនុកតម្កើងដោយស្ងៀមស្ងាត់ ដូចជា « ចូរមកតាមខ្ញុំ » (*ទំនុកតម្កើង* ល.រ. ៦៣) ហើយអនុញ្ញាតឲ្យសិស្សមើលសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេដើម្បីឮពួកពីសេចក្តីពិតមួយចំនួនដែលពួកគេបានរៀន ។ បន្ទាប់ពីផ្តល់ពេលវេលាគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សពីរបីនាក់ឲ្យឡើងមកខាងមុខក្តារខៀន ហើយចែកចាយចម្លើយរបស់ពួកគេជាមួយសិស្សក្នុងថ្នាក់ ។

អ្នកគួរបញ្ចប់ដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិតដ៏ពេញលេញនៃដំណើររឿងអំពីការងារបម្រើក្នុងជីវិតរមែងស្លាប់ និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានសរសេរដោយ ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន ។

មេរៀនសិក្សានៅផ្ទះ

យ៉ូហាន ១៦–២១ (មេរៀនទី ១៦)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា យ៉ូហាន ១៦–២១ (មេរៀនទី ១៦) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (យ៉ូហាន ១៦)

ចេញពីអ្វីដែលព្រះយេស៊ូវបានបង្រៀនដល់ពួកសាវករបស់ទ្រង់ បន្ទាប់ពីអាហារយប់ថ្ងៃចុងក្រោយ ពួកសិស្សបានរៀនថា ព្រះវិញ្ញាណបរិសុទ្ធអាចដឹកនាំយើងទៅរកសេចក្តីពិតគ្រាប់យ៉ាង ហើយបង្ហាញដល់យើងនូវរឿងដែលនឹងកើតឡើង ។ ពួកសិស្សក៏រៀនផងដែរថា ព្រះយេស៊ូវគ្រីស្ទបើកសម្តែងសេចក្តីពិត និងសេចក្តីណែនាំដែលចេញមកពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ ដោយសារព្រះយេស៊ូវគ្រីស្ទបានឈ្នះលើពិភពលោក នោះយើងអាចមានសង្ឃឹម និង មានភាពសុខសាន្ត ។

ថ្ងៃទី ២ (យ៉ូហាន ១៧)

នៅពេលសិស្សបានសិក្សាពីការអធិស្ឋានជំនួសរបស់ព្រះយេស៊ូវគ្រីស្ទ ពួកគេបានរៀនថា ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច យើងត្រូវតែស្គាល់ព្រះវរបិតាសួគ៌ និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេក៏រៀនដែរថា ក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងគប្បីនៅក្នុងពិភពលោក ប៉ុន្តែពុំមែនជារបស់ពិភពលោកឡើយ ។ នៅពេលសិស្សអានអំពីរបៀប ដែលព្រះយេស៊ូវបានអធិស្ឋានឲ្យពួកសិស្សរបស់ទ្រង់អាចបានរួមតែមួយនឹងទ្រង់ និងព្រះវរបិតា នោះពួកគេបានរៀនថា នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលពរដោយនៃជង្វាយធួនរបស់ទ្រង់ នោះយើងអាចភ្ជាយទៅជាតែមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា ។

ថ្ងៃទី ៣ (យ៉ូហាន ១៨–១៩)

ចេញពីគំរូដ៏អាត្មានិយមរបស់ពីឡាត់ សិស្សបានរៀនថា ការដាក់ចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់យើងមុនធ្វើអ្វីដែលត្រឹមត្រូវនឹងនាំយើងទៅរកអំពើបាប ។ នៅពេលសិស្សបានសិក្សាដំណើររឿងរបស់យ៉ូហានអំពីការឆ្កាង នោះពួកគេបានរៀនថា យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះដោយជ្រើសជួយដល់មនុស្សដទៃ សូម្បីតែនៅពេលយើងមានសេចក្តីត្រូវការក្តី ។

ថ្ងៃទី ៤ (យ៉ូហាន ២០–២១)

នៅក្នុងមេរៀននេះ សិស្សបានសិក្សាដំណើររឿងរបស់យ៉ូហានអំពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេបានរៀនថា ព្រះយេស៊ូវគ្រីស្ទយកឈ្នះលើសេចក្តីស្លាប់តាមរយៈការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ ចេញពីបទពិសោធន៍របស់ថូម៉ាស ពួកគេបានរៀនថា យើងនឹងមានពរ ប្រសិនបើយើងជ្រើសជឿលើព្រះយេស៊ូវគ្រីស្ទ សូម្បីតែពេលយើងមិនអាចមើលឃើញទ្រង់ក្តី ។

សេចក្តីផ្តើម

ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ បានបង្ហាញអង្គទ្រង់ដល់ពួកសិស្សរបស់ទ្រង់ កាលពួកគេកំពុងនេសាទត្រី ។ នៅលើឆ្នេរ ព្រះយេស៊ូវបានសោយជាមួយនឹងពួកសិស្សរបស់ទ្រង់ ហើយបានអញ្ជើញពេត្រុសឲ្យបង្ហាញសេចក្តីស្រឡាញ់គាត់ដល់ទ្រង់ដោយឲ្យចំណីដល់ចៀមរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ២១:១–១៧

ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ បង្ហាញអង្គទ្រង់ដល់ពួកសិស្សមួយចំនួនរបស់ទ្រង់នៅសមុទ្រទីបេរាស (សមុទ្រកាលីឡេ)

សូមគូររូប បេះដូងមួយធំនៅលើក្តារខៀន ។



សូមអញ្ជើញសិស្សឲ្យឡើងមកក្តារខៀនសរសេរនៅក្នុងបេះដូងនោះរឿងពីរ ឬបីយ៉ាងដែលពួកគេចូលចិត្ត ។ សូមពន្យល់ថា រឿងទាំងនេះអាចរួមបញ្ចូលទាំងមនុស្ស ទ្រព្យសម្បត្តិ ឬសកម្មភាព ។

នៅពេលសិស្សបានបញ្ចប់ អ្នកក៏អាចសរសេរនូវរឿងមួយចំនួនដែលអ្នកចូលចិត្តផងដែរ ។

សូមសង្ខេប យ៉ូហាន ២១:១–២ ដោយពន្យល់ថា បន្ទាប់ពីមើលឃើញព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញពីរដង នោះពេត្រុស និងពួកសិស្សផ្សេងទៀតមួយចំនួនបាននៅលើឆ្នេរសមុទ្រកាលីឡេ (ក៏ត្រូវបានគេហៅថា សមុទ្រទីបេរាស ផងដែរ) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលពេត្រុសបានសម្រេចចិត្តធ្វើ ។

- តើអ្នកគិតថាសកម្មភាពអ្វីខ្លះ ដែលពេត្រុសអាចនឹងបន្ថែមទៅក្នុងបញ្ជីនៃរឿងដែលចូលចិត្តនៅលើក្តារខៀននោះ ? (ក្រោយពីសិស្សឆ្លើយតបហើយ សូមសរសេរ *ការស្ទុចត្រី* នៅក្នុងរូបបេះដូងនៅលើក្តារខៀន) ។
- តើពេត្រុស និងពួកសិស្សដទៃទៀតបានទៅរកត្រីរយៈពេលយូរប៉ុណ្ណា ? តើពួកគេចាប់ត្រីបានប៉ុន្មានដែរ ?

ចូរសុំឲ្យសិស្សពិចារណា ហើយគិតថាពេត្រុស និងពួកសិស្សផ្សេងទៀតអាចនឹងមានអារម្មណ៍បែបណាដែរ ក្រោយពីចាប់ត្រីមិនបានសោះពេញមួយយប់នោះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហាន ២១:៤–៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលអ្វីដែលបានកើតឡើងនៅព្រឹកស្អែក ។

- តើមានអ្វីបានកើតឡើង បន្ទាប់ពីពួកសិស្សចាប់ត្រីមិនបានសោះពេញមួយយប់ ?

សូមសង្ខេប យ៉ូហាន ២១:៧–១៤ ដោយពន្យល់ថា កាលសិស្សមិនអាចលើកសំណាញ់ដែលសុទ្តែត្រីចូលទៅក្នុងទូកបាន យ៉ូហានបានប្រកាសថា បុរសដែលនៅលើឆ្នេរនោះគឺជាព្រះអម្ចាស់ ។ ពេត្រុសបានលោតចូលទៅក្នុងសមុទ្រភ្លាម ហើយហែលទៅរកព្រះយេស៊ូវ កាលសិស្សដទៃទៀតជិះទូកមកតាមក្រោយ ។ កាលពួកគេបានមកដល់ឆ្នេរវិញ ព្រះយេស៊ូវបានត្រៀមអាហារសម្រាប់ពួកគេ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« បន្ទាប់ពីបានជួបជុំម្តងទៀតជាមួយនឹងព្រះយេស៊ូវដែលរស់ឡើងវិញដោយក្តីអំណរ នោះពេត្រុសបានសន្ទនាជាមួយនឹងព្រះអង្គសង្គ្រោះដែលខ្ញុំគិតថា វាគឺជាគ្រាដ៏សំខាន់នៅក្នុងការងារបម្រើជាសាវក ហើយជាពិសេសគឺសម្រាប់ពេត្រុសផ្ទាល់តែម្តង ដោយបានផ្លាស់ប្តូរបុរសដ៏អស្ចារ្យនេះទៅរកជីវិតដ៏វិសេសនៃការបម្រើ និងការដើរនាំដែលមានការលះបង់ខ្ពស់ ។ ដោយទតមើលទៅទូកតូចចំណាស់ អួនដាច់ដោចរបស់ពួកគេ និងគំនរត្រី ១៥៣ ក្បាល នោះព្រះយេស៊ូវ [បានមានបន្ទូល

] ទៅកាន់សាវកម្នាក់ទៀតបន្ទាប់ពីគាត់ ។ ចុងក្រោយ ចូរអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ហូប៊ិន ៖

« (ហើយជាថ្មីម្តងទៀត ខ្ញុំទុទ្ទូលស្តាល់ថា នេះជាការបរិយាយដែលពុំបានកត់ត្រានៅក្នុងគម្ពីរ) ប្រហែលជាព្រះយេស៊ូវបានតបដោយមានបន្ទូលបែបនេះ ៖ ‹ ហេតុអ្វីអ្នកមកទីនេះពេត្រុស ? ហេតុអ្វីក៏យើងមកឆ្នេរដែលនេះ ដែលមានអួនដែល និងមានការសន្ទនាដែលនេះ ? តើវាមិនដាក់ស្តែងទេឬអីនៅពេលនោះ ហើយតើវាមិនដាក់ស្តែងទេឬអីនៅពេលនេះថា បើយើងចង់បានត្រី តើយើងមិនបានត្រីទេឬអី ? ពេត្រុស អ្វីដែលយើងត្រូវការគឺជាពួកសិស្ស—ហើយយើងត្រូវការពួកគេជាវៀងហុត ។ យើងត្រូវការមនុស្សម្នាក់ដើម្បីឲ្យចំណីដល់ចៀមរបស់យើង ហើយជួយសង្គ្រោះកូនចៀមរបស់យើង ។ យើងត្រូវការនរណាម្នាក់ ដើម្បីប្រកាសដំណឹងល្អរបស់យើង ហើយការពារសេចក្តីជំនឿរបស់យើង ។ យើងត្រូវការនរណាម្នាក់ដែលស្រឡាញ់យើង គឺស្រឡាញ់យើងដោយពិតប្រាកដ ហើយស្រឡាញ់អ្វីដែលព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌បានប្រទានសិទ្ធិឲ្យយើងធ្វើ ។. . .ហេតុដូច្នេះហើយពេត្រុស នេះជាលើកទីពីរ ហើយប្រហែលជាលើកចុងក្រោយ ដែលយើងសុំឲ្យអ្នកលះបង់របស់ទាំងនេះ ហើយទៅបង្រៀន ហើយថែរក្សា ធ្វើការ ហើយបម្រើដោយស្មោះត្រង់រហូតដល់ថ្ងៃដែលពួកគេនឹងធ្វើចំពោះអ្នកដូចជាពួកគេបានធ្វើជាក់យើងដែរ › » («The First Great Commandment» ទំព័រ ៨៤) ។

- តើគោលការណ៍អ្វី ដែលយើងអាចរៀនមកពីការសន្ទនារបស់ព្រះអម្ចាស់ជាមួយនឹងពេត្រុស ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងស្រឡាញ់ព្រះអង្គសង្គ្រោះ និងព្រះវរបិតាសួគ៌លើសអ្វីៗទាំងអស់ នោះយើងនឹងឲ្យចំណីដល់ចៀមរបស់ទ្រង់**) ។
- តើនរណាខ្លះ ជាកូនចៀមរបស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ? តើយើងឲ្យចំណីវាតាមរបៀបណា?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលយើងអាចឲ្យចំណីដល់ចៀមរបស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ សូមឲ្យសិស្សម្នាក់អានឲ្យៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ រ៉ូប៊ឺត ឌី ហៃល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« នេះគឺជាការអំពាវនាវរបស់ព្រះគ្រីស្ទដល់ពួកគ្រីស្ទានគ្រប់រូបសព្វថ្ងៃនេះ ៖ ‹ ចូរឲ្យចំណីដល់កូនចៀមខ្ញុំសឺផង ។ . . . ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំសឺផង ›—គឺចែកចាយដំណឹងល្អរបស់យើងដល់មនុស្សទាំងចាស់ទាំងក្មេង ដោយចម្រើនកម្លាំង ប្រទានពរ លួងលោម លើកទឹកចិត្ត ហើយពង្រឹងពួកគេ ជាពិសេសដល់ជនដែលគិត ហើយជឿអ្វីខុសពីយើង » («Being a More Christian Christian» *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៩១) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលគោលការណ៍នៃការស្រឡាញ់ព្រះឲ្យលើសពីអ្វីៗទាំងអស់អាចអនុវត្តបាន សូមអញ្ជើញសិស្សបីនាក់ឲ្យប្តូរវេនគ្នាអានសាច់រឿងខាងក្រោមនេះឲ្យឮៗ ។ បន្ទាប់ពីសាច់រឿងនីមួយៗត្រូវបានអានចប់ ចូរសួរសំណួរដែលមានបន្ទាប់នោះ ។

១. មានក្មេងប្រុសមួយក្រុមបានអញ្ជើញយុវជនម្នាក់ឲ្យអង្គុយជាមួយពួកគេនៅម៉ោងបាយថ្ងៃត្រង់ ហើយគាត់សង្ឃឹមថានឹងក្លាយជាមិត្តជាមួយនឹងពួកគេ ។ អំឡុងពេលនៃការសន្ទនារបស់ពួកគេ មានក្មេងប្រុសម្នាក់នៅក្នុងក្រុមនោះចាប់ផ្តើមចំអន់ឲ្យក្មេងប្រុសម្នាក់ទៀតជាសាធារណៈ ។

២. មានយុវនារីម្នាក់ចូលចិត្តលេងបាត់ទាត់ ។ នាងបានចំណាយពេលជាច្រើនម៉ោងក្នុងមួយសប្តាហ៍ ដើម្បីលេងបាល់ទាត់ ហើយមានពេលតិចតួចណាស់សម្រាប់រឿងផ្សេងទៀតដូចជារាត្រីជួបជុំក្រុមគ្រួសារ និងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ។

៣. មានយុវជនម្នាក់មមាញឹកនឹងការសិក្សា និងកម្មវិធីក្រៅពីការសិក្សានានា។ ពេញមួយសប្តាហ៍គាត់បានទន្ទឹងរង់ចាំការមានពេលទំនេរដើម្បីមួយចំនួនជាមួយនឹងមិត្តភក្តិនៅយប់ថ្ងៃសុក្រ ។ ពីមុនពេលគាត់ទូរស័ព្ទទៅមិត្តរបស់គាត់បន្តិចនារាត្រីនោះ ដៃគូបង្រៀនតាមផ្ទះរបស់គាត់បានទូរស័ព្ទមកសួរថា តើគាត់អាចចេញទៅជួយដល់គ្រួសារមួយដែលពួកគេបានចាត់តាំងឲ្យ ដែលមានសេចក្តីត្រូវការបន្ទាន់បានទេ ។

- តើបុគ្គលនេះមានការជ្រើសរើសអ្វីខ្លះ ?
- តើបុគ្គលម្នាក់នេះអាចធ្វើអ្វីបានខ្លះ ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះព្រះអម្ចាស់ ? តើទង្វើនោះបានបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះអម្ចាស់តាមរបៀបណា ?

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ហូប៊ិន ៖

« បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ ខ្ញុំពុំដឹងច្បាស់ពីបទពិសោធន៍របស់យើងនឹងដាយ៉ាងណានៅថ្ងៃជំនុំជំរះនោះទេ ប៉ុន្តែខ្ញុំនឹងភ្ញាក់ផ្អើលណាស់ បើនៅក្នុងការសន្ទនានោះ ព្រះពុំបានសួរយើងដូចគ្នានឹងអ្វីដែលព្រះគ្រីស្ទបានសួរដល់ពេត្រុសនោះ ៖ ‹ តើអ្នកស្រឡាញ់ខ្ញុំទេ ? › » («The First Great Commandment» ទំព័រ ៨៤) ។

ចូរចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការជ្រើសស្រឡាញ់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទឲ្យលើសពីអ្វីៗទាំងអស់ និងការបង្ហាញសេចក្តីស្រឡាញ់នោះដោយឲ្យចំណីដល់ហ្វូងចៀមរបស់ទ្រង់ ។

ចូរលើកលើកឡើងពីអ្វី ដែលបានសរសេរនៅក្នុងរូបបេះដូងនៅលើក្តារខៀន និងសំណួរដែលបានសរសេរនៅក្បែរវត្ថុទាំងនោះ ៖ « តើអ្នកស្រឡាញ់ខ្ញុំដាជាងរបស់ទាំងនេះឬអី ? » ចូរគូសបន្ទាត់ក្រោមពាក្យ *របស់ទាំងនេះ:* ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរខាងក្រោមនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរបស់ពួកគេ ៖

- ប្រសិនបើព្រះយេស៊ូវបានសួរសំណួរដូចគ្នានេះដល់អ្នក តើអ្នកគិតថាទ្រង់ចង់មានបន្ទូលពីអ្វីទៅ ចំពោះពាក្យថា « របស់ទាំងនេះ: » នៅក្នុងជីវិតរបស់អ្នក ?
- តើអ្នកនឹងឆ្លើយសំណួររបស់ទ្រង់យ៉ាងដូចម្តេច ?

នៅពេលអ្នកបញ្ចប់ដំណឹងល្អទាំងឡាយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរក្នុងកិច្ចការសម្រាប់មេរៀនថ្ងៃទី ៤ នៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ អំពីដំណើររឿង ព្រឹត្តិការណ៍ ឬការបង្រៀនដកស្រង់ចេញពីការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះដែលបានជួយពួកគេឲ្យជឿ ឬបានពង្រឹងដល់ជំនឿរបស់ពួកគេថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ។

មេរៀនបន្ទាប់ (កិច្ចការ ១–៥)

សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ នៅពេលពួកគេសិក្សា កិច្ចការ ១–៥៖ តើនរណាបានដឹកនាំសាសនាចក្រ បន្ទាប់ព្រះអង្គសង្គ្រោះបានសុគត ហើយមានព្រះជន្មរស់ឡើងវិញ ? តើពួកសាវកផ្សេងទៀតត្រូវបានជ្រើសរើសតាមរបៀបណា ? តើមានអព្ភូតហេតុអ្វីខ្លះ បានកើតឡើងនៅថ្ងៃនៃបុណ្យថ្ងៃទី ៥០ ? តើព្រះវិញ្ញាណបរិសុទ្ធបានដៈតិទ្ធិពលដល់អព្ភូតហេតុនៅថ្ងៃនោះយ៉ាងដូចម្តេច ? តើអព្ភូតហេតុអ្វីខ្លះ ដែលពេត្រុសបានធ្វើនៅឯព្រះវិហារបរិសុទ្ធ ហើយតើមានអ្វីទៅបានកើតឡើងដល់ពេត្រុសដោយសារឬរឿងនេះ ? តើមានអ្វីខ្លះបានកើតឡើងចំពោះអាន៉ានាស និងសាភីរ៉ា ដោយសារការកុហកដល់ថ្នាក់ដឹកនាំបព្វជិតភាពរបស់ខ្លួននោះ ?

ចំពោះគម្ពីរកិច្ចការនៃពួកសាវក

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

គម្ពីរកិច្ចការនៃពួកសាវកបង្កើតជាស្ពានមួយរវាងកំណត់ត្រាអំពីជីវប្រវត្តិរបស់ព្រះយេស៊ូវគ្រីស្ទ និងការបង្រៀននៅក្នុងដំណឹងល្អទាំងបួន ហើយនិងការសរសេរ ព្រមទាំងកិច្ចការរបស់ពួកសាវកទាំងឡាយរបស់ទ្រង់ ។ គម្ពីរកិច្ចការបង្ហាញអំពីរបៀបដែលព្រះអង្គសង្គ្រោះបានបន្តដឹកនាំសាសនាចក្រទ្រង់ តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធដល់អ្នកទាំងឡាយណាដែលកាន់កូនសោបព្វជិតភាព ។ ព្រះវិញ្ញាណបរិសុទ្ធ បានបើកសម្តែងសេចក្តីពិតដល់ពួកសាវក ដែលក្រោយមកបានដឹកនាំ និងបង្រៀនដល់សាសនាចក្រ ។ ពួកសាវកក៏បានធ្វើអព្ភូតហេតុនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ ។ តាមរយៈការសិក្សារបស់ពួកគេក្នុងគម្ពីរនេះ សិស្សនឹងរៀនអំពីរបៀប ដែលសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទបានចាប់ផ្តើមរីកដុះដាលមកពីទីក្រុងយេរូសាឡិម « រហូតដល់ចុងផែនដីបំផុត » (កិច្ចការ ១:៨) ។ ការសិក្សាគម្ពីរនេះក៏អាចជួយសិស្សឲ្យមើលឃើញនូវប្រាជ្ញានៃការធ្វើតាមពួកព្យាការី និងពួកសាវកសម័យទំនើប ហើយអាចបំផុសគំនិតពួកគេឲ្យឈរធ្វើជាសាក្សីដ៏មុតមាំរបស់ព្រះយេស៊ូវគ្រីស្ទផងដែរ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

លូកា បានសរសេរគម្ពីរកិច្ចការនៃពួកសាវកជា « ផ្នែកទីពីរនៃកិច្ចការទាំងពីរផ្នែក ។ . . . ផ្នែកទីមួយត្រូវបានស្គាល់ថាជាដំណឹងល្អស្របតាមលូកា » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ« កិច្ចការនៃពួកសាវក »scriptures.lds.org, សូមមើលផងដែរ លូកា ១:១-៤,កិច្ចការ ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

គម្ពីរកិច្ចការត្រូវបានសរសេរបន្ទាប់ពីដំណឹងល្អរបស់លូកា (សូមមើលកិច្ចការ ១:១) ដែលទំនងជាត្រូវបានសរសេរឡើងនៅហាសិបឆ្នាំចុងក្រោយនៃសតវត្សទីមួយនៃគ.ស ។យើងពុំដឹងថា វាត្រូវបានសរសេរឡើងនៅកន្លែងណានោះទេ ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ? ហេតុអ្វី ?

លូកា បានថ្លែងអំពីគម្ពីរកិច្ចការទៅកាន់បុរសម្នាក់ឈ្មោះ ថេអ៊ែលូ (សូមមើល កិច្ចការ ១:១) ។

តើលក្ខណៈពិសេសមួយចំនួននៅក្នុងគម្ពីរនេះមានអ្វីខ្លះ ?

គម្ពីរកិច្ចការរៀបរាប់អំពីការកើតមាន និងការីកដុះដាលនៃពួកគ្រីស្ទាន ដោយចាប់ផ្តើមនៅក្នុងទីក្រុងយេរូសាឡិម ជាក្រុងមិនសូវជឿនលឿនរបស់ពួកសាសន៍យូដា ហើយបញ្ចប់ទៅនៅក្នុងទីក្រុងរ៉ូម ជាទីក្រុងដ៏ធំនៃអាណាចក្ររ៉ូម ។ ព្រឹត្តិការណ៍ទាំងឡាយដែលបានពិពណ៌នានៅក្នុងគម្ពីរកិច្ចការ បានកើតមានឡើងក្នុងរយៈកាលមួយប្រហែលជា ៣០ ឆ្នាំ (ប្រហែលជាក្នុងគ.ស.៣០-៦២) ហើយផ្តោតជាចម្បងទៅលើការបម្រើរបស់ពេត្រុស (សូមមើល កិច្ចការ ១–១២) និង ប៉ុល (សូមមើលកិច្ចការ ១៣–២៨) ។ ប្រសិនបើគ្មានគម្ពីរកិច្ចការទេ នោះចំណេះដឹងរបស់យើងអំពីប្រវត្តិសាសនាចក្រដំនាន់បុរាណដែលបានផ្តល់ឲ្យដោយសំបុត្រទាំងឡាយក្នុងគម្ពីរសញ្ញាថ្មីនឹងមានកម្រិតតិចតួចស្តួចស្តើងណាស់ ។ លើសពីនេះទៅទៀត គម្ពីរកិច្ចការផ្តល់នូវបរិបទខាងប្រវត្តិសាស្ត្រដ៏មានតម្លៃចំពោះសំបុត្ររបស់ប៉ុល ។

អ្វីដែលសំខាន់ក្នុងការីកចម្រើនរបស់សាសនាចក្រពីបុរាណ គឺការផ្លាស់ប្រែចិត្តជឿរបស់ប៉ុល (កិច្ចការ ៩) និងបេសកកម្មជាបន្តបន្ទាប់របស់លោក ការនិមិត្តដែលពេត្រុសបានទទួលស្តីពីការទទួលពួកសាសន៍ដទៃដែលពុំបានផ្លាស់ប្រែចិត្តជឿលើសាសនាយូដាកាលពីមុនឲ្យចូលមកក្នុងសាសនាចក្រ (កិច្ចការ ១០:៩-១៦, ៣៤-៣៥), និងគោលទិដ្ឋដែលបានបង្រៀននៅឯសន្និសីទក្នុងក្រុងយេរូសាឡិម (កិច្ចការ ១៥) ។

ដូចបានកត់ត្រានៅក្នុងលូកា ២៤:៤៩ព្រះអង្គសង្គ្រោះបានណែនាំដល់ពួកសាវកថា ពួកលោកត្រូវចាប់ផ្តើមធ្វើការបម្រើរបស់ខ្លួន ដរាបណាពួកលោកមាន « ព្រះចេស្តាពីស្ថានលើបានមកគ្រប់ដណ្តប់លើ » ។ គម្ពីរកិច្ចការកត់ត្រាអំពីការប្រទានឲ្យនៃអំណាចនេះដោយព្រះវិញ្ញាណបរិសុទ្ធ ហើយពិពណ៌នាអំពីលទ្ធផលដ៏អស្ចារ្យ ដែលបានចាប់ផ្តើមដាមួយនឹងការផ្លាស់ប្រែចិត្តជឿរបស់មនុស្សរាប់ពាន់នាក់ នៅក្នុងបុណ្យថ្ងៃទី ៥០ (សូមមើលកិច្ចការ ២) ។ ក្នុងគម្ពីរកិច្ចការ លូកាបានគូសបញ្ជាក់អំពីការធ្វើការរបស់ព្រះវិញ្ញាណបរិសុទ្ធមកលើបុគ្គលម្នាក់ៗ និងក្រុមដ៏នុំទាំងឡាយ ។ ឃ្លាថា « ព្រះចេស្តាពីស្ថានលើ បានមកគ្របដណ្តប់លើអ្នកណាគ្នា » ទំនងជាមានន័យថា សាវក « ទទួលបានចំណេះដឹង អំណាច និងពរជ័យជាពិសេសជាក់លាក់ ដែលតាមធម្មតាត្រូវបានប្រគល់ឲ្យតែនៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះអម្ចាស់តែប៉ុណ្ណោះ » (ប្រ៊ូស អ័រ ម៉ាក់ខនឃី *Doctrinal New Testament Commentary,* វ៉ុលទី ៣ [១៩៦៥–៧៣] ១:៨៥៩) ។

គម្រោង

កិច្ចការ ១-២ ព្រះយេស៊ូវគ្រីស្ទបម្រើដល់ពួកសិស្សរបស់ទ្រង់រយៈពេល ៤០ ថ្ងៃ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ រួចហើយយាងទៅស្ថានសួគ៌វិញ ។ តាមរយៈការបំផុសគំនិត ពួកសាវកបានហៅ ម៉ាធាស ឲ្យបំពេញកិច្ចការនៅក្នុងក្តារ៉ែមនៃពួកសាវកដប់ពីរនាក់ ។ ព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានចាក់ស្រោចមកលើថ្ងៃនៃបុណ្យថ្ងៃទី ៥០ ។ ពេត្រុសបានថ្លែងទីបន្ទាល់យ៉ាងមោះមុតអំពីព្រះអង្គសង្គ្រោះ ដែលបានរស់ឡើងវិញ ហើយមានប្រជាជនប្រហែលជាបីពាន់នាក់ត្រូវបានផ្លាស់ប្រែចិត្តជឿ ។

កិច្ចការ ៣-៨ ពេត្រុស និងយ៉ូហាន បានព្យាបាលបុរសម្នាក់ដែលខ្វិនតាំងពីកំណើត ។ ពេត្រុស និង យ៉ូហាន ត្រូវបានគេចាប់ខ្លួនដោយសារតែការផ្សាយ និងការព្យាបាល នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានរំដោះចេញពីគុក ។ ពួកសាវកបានហៅបុរសប្រាំពីរនាក់ឲ្យជួយពួកគេនៅក្នុងការបម្រើរបស់ពួកគេ ម្នាក់ក្នុងចំណោមអ្នកទាំងប្រាំពីរនេះ មានឈ្មោះថា ស្តេផាន បានថ្លែងទីបន្ទាល់ពីមុខក្រុមប្រឹក្សាពួកយូដា ហើយសមាជិកក្រុមប្រឹក្សានោះបានសំឡាប់គាត់ ។ ភីលីព ផ្សព្វផ្សាយនៅពេញដែនដីសាម៉ារី ។

កិច្ចការ ៩-១២ សូល បានផ្លាស់ប្រែចិត្ត ហើយបានចាប់ផ្តើមការបម្រើរបស់គាត់ ។ នៅក្នុងការនិមិត្តមួយ ពេត្រុសបានដឹងថា ដំណឹងល្អគួរតែត្រូវបានផ្សព្វផ្សាយដល់ពួកសាសន៍ដទៃ ។ ហេរ៉ូឌ អាគ្រីប៉ា ទី១ បានយកសាវកយ៉ាកុប (បងប្រុសរបស់យ៉ូហាន) ទៅសំឡាប់ ហើយចាប់ពេត្រុសដាក់គុក ។

កិច្ចការ ១៣-១៥ សូល និង បាណាបាស ត្រូវបានហៅឲ្យធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេបានជួបនឹងការប្រឆាំងដ៏ទាស់មកពីពួកយូដា ហើយត្រូវបានទទួលយកដោយពួកសាសន៍ដទៃមួយចំនួន ។ ពួកអ្នកដឹកនាំសាសនាចក្រជួបជុំគ្នានៅក្នុងទីក្រុងយេរូសាឡិម ហើយប្តេជ្ញាចិត្តថា អ្នកផ្លាស់ប្រែចិត្តជឿដែលជាសាសន៍ដទៃ ពុំចាំបាច់ត្រូវកាត់ស្បែកទេ (ឬបន្តប្រតិបត្តិតាមក្រឹត្យវិន័យលោកម៉ូសេ) នៅពេលពួកគេចូលរួមក្នុងសាសនាចក្រ ។ ប៉ុល (ដែលឥឡូវត្រូវបានហៅថា សូល) បានចេញដំណើរផ្សព្វផ្សាយសាសនាលើកទីពីររបស់គាត់ ទៅជាមួយនឹងសីឡាស ។

កិច្ចការ ១៦-២០ ប៉ុល និងសីឡាស បានពង្រឹងដល់ព្រះវិហារនានាជាច្រើន ដែលត្រូវបានស្ថាបនាឡើងពីមុនមក ។ នៅលើភ្នំម៉ាស ទីក្រុងអាថែន ប៉ុលបានផ្សាយថា « យើងរាល់គ្នា ជាពូជព្រះ » (កិច្ចការ ១៧:២៩) ។ ប៉ុលបានបញ្ចប់បេសកកម្មទីពីររបស់គាត់ ហើយបានចេញដំណើរបេសកកម្មទីបីទូទាំងអាស៊ី ។ ប៉ុលបានប្តេជ្ញាចិត្តត្រឡប់ទៅកាន់ទីក្រុងយេរូសាឡិមវិញ ។

កិច្ចការ ២១-២៨ នៅក្នុងទីក្រុងយេរូសាឡិម ប៉ុលត្រូវបានគេចាប់ខ្លួន ហើយលោកនៅបន្តថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទទៀត ។ ព្រះអម្ចាស់បានបង្ហាញព្រះកាយម្តងទៀតដល់ប៉ុល ។ ពួកយូដាជាច្រើន បានមានកលល្បិចរកសំឡាប់ប៉ុល ។ នៅក្នុងស្រុងសេសារ គាត់បានថ្លែងទីបន្ទាល់ចំពោះមុខ លោកភេលីច ភេស្ទុស និង អ័គ្រីប៉ា ។ ប៉ុលត្រូវបានជាប់គាំងនៅតាមផ្លូវទៅទីក្រុងរ៉ូម ។ ប៉ុលផ្សាយដំណឹងល្អ ខណៈដែលស្ថិតក្នុងការចាប់ខ្លួននៅក្នុងទីក្រុងរ៉ូម ។

កិច្ចការ ១:១-៨

សេចក្តីផ្តើម

បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ព្រះយេស៊ូវបានបម្រើដល់សាវករបស់ទ្រង់អស់រយៈពេល ៤០ ថ្ងៃ ។ ទ្រង់បានរៀបចំពួកគេដើម្បីធ្វើជាសាក្សីរបស់ទ្រង់នៅទូទាំងផែនដី ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១:១-៨

ព្រះយេស៊ូវបម្រើដល់ពួកសិស្សរបស់ទ្រង់អស់រយៈពេល ៤០ ថ្ងៃ

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា មានមិត្តដែលមានជំនឿផ្សេងម្នាក់ បានមកកាន់ពួកគេដោយមានបំណងចង់ដឹងអំពីសាសនាចក្ររបស់យើង ហើយបានសួរថា « តើនរណាជាដឹកនាំសាសនាចក្ររបស់អ្នក ? »

សូមឲ្យសិស្សសរសេរចម្លើយរបស់ពួកគេសម្រាប់សំណួរនេះ ចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

នៅពេលសិស្សសិក្សា កិច្ចការ ១:១-៨សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយដែលអាចជួយឆ្លើយសំណួរថា នរណាជាដឹកនាំសាសនាចក្រនេះ ។

សូមអញ្ជើញសិស្សឲ្យបើកទៅគម្ពីរកិច្ចការ ហើយប្រាប់អំពីចំណងជើងពេញលេញនៃគម្ពីរនេះ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

- ដោយផ្អែកទៅលើចំណងជើងពេញលេញនោះ តើអ្នកគិតថា យើងអាចរៀនអ្វីខ្លះអំពីគម្ពីរនេះ ?

ចូរពន្យល់ថា គម្ពីរកិច្ចការគូសចំណាំពីការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ គម្ពីរម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន ផ្តល់ដំណើររឿងអំពីការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះ រួមទាំងដង្វាយធួន និងមានព្រះជន្មឡើងវិញរបស់ទ្រង់ ។ គម្ពីរកិច្ចការរៀបរាប់អំពីការងារបម្រើរបស់ពួកសាវក បន្ទាប់ពីការយាងឡើងទៅស្ថានសួគ៌វិញរបស់ព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១:១-២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថា គម្ពីរនេះបានសរសេរឡើងសម្រាប់នរណា ។


- តើគម្ពីរនេះបានសរសេរឡើងសម្រាប់នរណា ?

ចូរពន្យល់ថា លូកា គឺជាអ្នកសរសេរគម្ពីរកិច្ចការ ហើយថា « រឿងមួយច្បាប់មុន » សំដៅទៅលើនៅក្នុងខទី ១គឺជាគម្ពីរលូកា ក៏បានសរសេរទៅកាន់លោកថេវភីលផងដែរ ។ គោលបំណងរបស់លូកានៅក្នុងការសរសេរនេះ គឺដើម្បីជួយថេវភីលឲ្យទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនអំពី ព្រះយេស៊ូវគ្រីស្ទ (សូមមើលលូកា ១:១-៤) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១:២-៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថា ព្រះយេស៊ូវគ្រីស្ទបានធ្វើការងារបម្រើដល់ពួកសាវករបស់ទ្រង់ដោយផ្ទាល់យ៉ាងប៉ុណ្ណាដែរ បន្ទាប់ពីការមានព្រះជន្មឡើងវិញរបស់ទ្រង់ ។ (អ្នកគួរពន្យល់ថា នៅក្នុងខទី ៣ពាក្យថា « បានរងទុក្ខ » សំដៅទៅលើពលិកម្មធួនរបស់ព្រះអង្គសង្គ្រោះ ហើយពាក្យ « ភស្តុតាងជាច្រើន » សំដៅទៅលើភស្តុតាងដែលពុំអាចបដិសេធបានដែលព្រះយេស៊ូវបានបង្ហាញថា ទ្រង់មានព្រះជន្មរស់ឡើង) ។

- តើព្រះយេស៊ូវគ្រីស្ទចំណាយពេលប៉ុន្មាន គង់នៅជាមួយពួកសិស្សរបស់ទ្រង់ បន្ទាប់ពីទ្រង់មានព្រះជន្មឡើងវិញ ?
- តើព្រះយេស៊ូវបានបង្រៀនអ្វីខ្លះដល់ពួកគេក្នុងរយៈពេល ៤០ ថ្ងៃនោះ ? (អស់ទាំងសេចក្តីខាងឯនគរព្រះ) ។

សូមចាប់ផ្តើមគូសពង្រាងនូវគ្រោងផ្ទះមួយលើក្តារខៀន ។ (ឬអ្នកអាចសង់ជាគំរូកូនផ្ទះតូចមួយដោយប្រើឈើ ឬដីឥដ្ឋ) ។



នៅពេលអ្នកបញ្ចប់បានពាក់កណ្តាល សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀន ហើយបញ្ចប់គំនូរនោះឲ្យអ្នក ។ សូមផ្តល់ការណែនាំជាក់លាក់ដល់សិស្សនោះ អំពីរបៀបបញ្ចប់ផ្ទះនោះ ។ អ្នកគួរសុំឲ្យគាត់បន្ថែមដំបូល បង្អួចខ្លះៗ និងទេសភាព ។ បន្ទាប់ពីធ្វើការជាមួយគ្នារយៈពេលខ្លី សូមដើរទៅជ្រុងម្ខាងទៀតនៃបន្ទប់ ហើយបន្តផ្តល់ការណែនាំដល់សិស្សនោះ ។ នៅពេលផ្ទះនោះបានចប់សព្វគ្រប់ សូមអរគុណដល់សិស្សនោះ ហើយសុំឲ្យគាត់អង្គុយចុះវិញ ។

ចូរសុំឲ្យសិស្សក្នុងថ្នាក់នឹកស្រមៃថា ការគូសរូបផ្ទះនោះតំណាងឲ្យនគរព្រះនៅលើផែនដី ដែលជាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។

- តើវិធីសាស្ត្រនៃការគូសរូបផ្ទះរបស់យើងនេះអាចបង្ហាញអំពីរបៀបដែលព្រះយេស៊ូវបានស្ថាបនាសាសនាចក្ររបស់ទ្រង់ នៅគ្រានៃការងារបម្រើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ និងបន្ទាប់ពីទ្រង់មានព្រះជន្មឡើងវិញយ៉ាងដូចម្តេច ? (នៅគ្រានៃការងារបម្រើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់ ព្រះអង្គសង្គ្រោះបានចាប់ផ្តើមស្ថាបនាសាសនាចក្ររបស់ទ្រង់ ។ ទ្រង់បានហៅមនុស្សដទៃទៀតឲ្យជួយ

ទ្រង់ស្តាបនាវាឡើង ហើយបន្ទាប់ពីទ្រង់មានព្រះជន្មឡើងវិញ ទ្រង់បានដឹកនាំកិច្ចខិតខំរបស់ពួកគេ ទោះជាទ្រង់គ្មានវត្តមានគង់នៅជាមួយនឹងពួកគេដោយផ្ទាល់ក្តី) ។

- យោងតាមខទី ២តើព្រះយេស៊ូវគ្រីស្ទដឹកនាំសាសនាចក្ររបស់ទ្រង់យ៉ាងដូចម្តេច ? (សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ដោយប្រើពាក្យរបស់សិស្សផ្ទាល់ ៖**ព្រះយេស៊ូវដឹកនាំសាសនាចក្ររបស់ទ្រង់ ដោយការបើកសម្តែងអំពីព្រះឆន្ទៈរបស់ទ្រង់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ**) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅក្នុងខទីមួយ [នៃគម្ពីរកិច្ចការ] ការប្រកាសនោះគឺថា សាសនាចក្រនឹងបន្តដឹកនាំដោយ*ព្រះ* ពុំមែនដឹកនាំដោយមនុស្សទេ ។ . . . ប្រាកដណាស់ ចំណងជើងពេញលេញនៃគម្ពីរកិច្ចការអាចនឹងសមរម្យ បើមានចំណងជើងដូចនេះថា ‹ កិច្ចការរបស់ព្រះគ្រីស្ទដែលមានព្រះជន្មឡើងវិញកំពុងធ្វើការតាមរយៈព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិត និងការងារបម្រើនៃពួកសាវករបស់ទ្រង់ដែលបានតែងតាំង › ។ . . .

« ការដឹកនាំរបស់សាសនាចក្រគឺនៅដដែល ។ ទីតាំងនៃព្រះអង្គសង្គ្រោះត្រូវបានផ្លាស់ប្តូរ ប៉ុន្តែការដឹកនាំ និងភាពដឹកនាំក្នុងសាសនាចក្រ គឺដូចគ្នាទាំងស្រុង » (« Therefore, What ? » [Church Educational System conference on the New Testament ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០០ [ទំព័រ ៦, si.lds.org) ។

- ហេតុអ្វីក៏វាសំខាន់ដើម្បីដឹងថា ព្រះយេស៊ូវគ្រីស្ទបន្តដឹកនាំសាសនាចក្រតាមរយៈវិវរណៈនាសព្វថ្ងៃនេះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីបទពិសោធន៍ទាំងឡាយ ដែលបានពង្រឹងដល់ទីបន្ទាល់របស់ពួកគេថា ព្រះយេស៊ូវបានដឹកនាំសាសនាចក្ររបស់ទ្រង់នាសព្វថ្ងៃនេះតាមរយៈវិវរណៈ ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។ អ្នកក៏អាចចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយផងដែរ ។


សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗក្នុង កិច្ចការ ១:៤-៨ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ព្រះយេស៊ូវបានបង្គាប់ឲ្យពួកសាវកធ្វើអ្វីខ្លះ ។

- យោងតាម ខទី ៤តើព្រះយេស៊ូវបានបង្គាប់ឲ្យពួកសាវកធ្វើអ្វីខ្លះ ?
- យោងតាមខទី ៥តើព្រះអង្គសង្គ្រោះសន្យាដល់ពួកសាវកថាពួកគេនឹងទទួលបានអ្វីខ្លះ ប្រសិនបើពួកគេបន្តនៅក្នុងទីក្រុងយេរូសាឡិម ?
- យោងតាមខទី ៨តើព្រះវិញ្ញាណបរិសុទ្ធនឹងប្រទានអំណាចដល់ពួកសាវកឲ្យធ្វើអ្វីខ្លះ ?
- តើយើងអាចរៀនអ្វីខ្លះ អំពីពួកសាវកនៅក្នុងអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងខទី ៨ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ ៖**ពួកសាវកគឺជាសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ ហើយថ្លែងទីបន្ទាល់អំពីទ្រង់នៅទូទាំងផែនដីនេះ**) ។

ដើម្បីជួយសិស្សឲ្យយល់សេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហ្គរដិន ប៊ី ហ៊ីងគ្លី ៖



« នៅជំនាន់របស់យើង ព្រះអម្ចាស់បានហៅសាក្សីពិសេសចំនួន ១៥ រូបដើម្បីថ្លែងទីបន្ទាល់ អំពីភាពជាព្រះរបស់ទ្រង់ទៅកាន់ពិភពលោកទាំងមូល ។ ការហៅរបស់ពួកលោក គឺជាការហៅពិសេសមួយ ពួកលោកគឺជាសាវករបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានជ្រើសរើស ហើយប្រទានសិទ្ធិអំណាចឲ្យ ។ ពួកលោកត្រូវបានបង្គាប់ឲ្យថ្លែងជាសាក្សី អំពីភាពពិតនៃការមានព្រះជន្មរបស់ទ្រង់ ដោយសិទ្ធិអំណាច និងអំណាចនៃភាពជាសាវកដ៏បរិសុទ្ធ ដែលបានប្រគល់ឲ្យនៅក្នុងខ្លួនពួកលោក » (« Special Witnesses of Christ »*Ensign*ខែ មេសា ឆ្នាំ ២០០១ ទំព័រ ៤) ។



ព្រះវរបិតាសួគ៌ដ៏មានព្រះជន្មរស់

ទីបន្ទាល់នៃពួកសាវក

ព្រះវិហារសាសនាព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធចុងក្រោយ

ដើម្បីថ្លែងទីបន្ទាល់ អំពីភាពជាព្រះរបស់ទ្រង់ទៅកាន់ពិភពលោកទាំងមូល ។ ការហៅរបស់ពួកលោក គឺជាការហៅពិសេសមួយ ពួកលោកគឺជាសាវករបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានជ្រើសរើស ហើយប្រទានសិទ្ធិអំណាចឲ្យ ។ ពួកលោកត្រូវបានបង្គាប់ឲ្យថ្លែងជាសាក្សី អំពីភាពពិតនៃការមានព្រះជន្មរបស់ទ្រង់ ដោយសិទ្ធិអំណាច និងអំណាចនៃភាពជាសាវកដ៏បរិសុទ្ធ ដែលបានប្រគល់ឲ្យនៅក្នុងខ្លួនពួកលោក ។

ថ្ងៃទី ១ ខែមករា ២០០០

គណៈប្រធានទីមួយ

ក្រុមប្រឹក្សាដប់ពីរនាក់

- តើយើងអាចរៀនអ្វីខ្លះ អំពីពួកសាវកនៅក្នុងអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងខទី ៨ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ ៖**ពួកសាវកគឺជាសាក្សីអំពីព្រះយេស៊ូវគ្រីស្ទ ហើយថ្លែងទីបន្ទាល់អំពីទ្រង់នៅទូទាំងផែនដីនេះ**) ។

ចូរសរសេរសេចក្តីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្តារខៀន ៖*ពួកសាវកនៅជំនាន់របស់យើងថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទ . . .*

ប្រសិនបើអាចធ្វើទៅបាន សូមផ្តល់ឯកសារអំពី« ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ ៖ ទីបន្ទាល់នៃពួកសាវក » (*Ensign* ខែ មេសា ឆ្នាំ ២០០០ ទំព័រ ២) ដល់សិស្សម្នាក់ៗ នៅក្នុងថ្នាក់ ។ អ្នកក៏អាចគិតផងដែរអំពីការយកច្បាប់ចម្លងមួយច្បាប់មក កាត់វាទៅជាវគ្គតូចៗ ហើយចែកវគ្គទាំងឡាយទៅឲ្យសិស្ស ។ សូមឲ្យសិស្សអានឯកសារឬវគ្គនោះដោយ ស្ងៀមស្ងាត់ ហើយរកមើលថាពួកគេអាចបំពេញប្រយោគនេះនៅលើក្តារខៀនតាមរបៀបណា ។ នៅពេលសិស្សបានបញ្ចប់ការអាន ចូរសុំឲ្យសិស្សម្នាក់ឡើងមក

ក្តារខៀន ហើយធ្វើជាអ្នកសរសេរ ។ ចូរអញ្ជើញសិស្សឲ្យប្រាប់ពីអ្វី ដែលពួកគេបានរកឃើញ ហើយសុំឲ្យសិស្សនៅឯក្តារខៀនសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

- តើនៅក្នុងសេចក្តីប្រកាសទាំងនេះសេចក្តីប្រកាសមួយណាសំខាន់ខ្លាំងបំផុតចំពោះអ្នក ?
- តើសាក្សីរបស់ពួកសាវកសម័យថ្មីមានឥទ្ធិពល ទៅលើសាក្សីផ្ទាល់ខ្លួនរបស់អ្នក ឬទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

ចូរពន្យល់ថា ទោះជាកិច្ចការ ១:៨សំដៅជាក់លាក់ទៅលើតួនាទីរបស់ពួកសាវក ថាជាសាក្សីពិសេសរបស់ព្រះអង្គសង្គ្រោះក្តី ក៏វាបានបង្រៀនយើងអំពីអ្វី ដែលអាចជួយយើងធ្វើជាសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទនៅទូទាំងពិភពលោកផងដែរ ។

- ផ្អែកទៅលើការសន្យារបស់ព្រះអម្ចាស់ចំពោះពួកសាវក នៅក្នុងកិច្ចការ ១:៨តើអ្វីទៅធ្វើឲ្យយើងអាចក្លាយជាសាក្សីរបស់ព្រះយេស៊ូវគ្រីស្ទបាន ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ ៖ **តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចក្លាយជាសាក្សីនៃព្រះយេស៊ូវគ្រីស្ទ**) ។
- តើព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងក្លាយជាសាក្សីរបស់ព្រះអង្គសង្គ្រោះតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីគ្រា ដែលពួកគេទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកដទៃបានចែកចាយទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ ពីរបីនាទីក្រោយមក សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ។ សូមរំឭកសិស្សថា ពួកគេមិនគួរចែកចាយពីបទពិសោធន៍ ឬ រឿងផ្ទាល់ខ្លួនច្រើនពេកនោះទេ) ។

- តើអ្នកបានទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយអ្នកថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទទៅកាន់អ្នកដទៃនៅពេលណាដែរ ?

សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកឱកាសចែកចាយទីបន្ទាល់របស់ពួកគេជាមួយអ្នកដទៃ ហើយទុកចិត្តថា ព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់សេចក្តីពិតអំពីអ្វីដែលពួកគេធ្វើជាសាក្សី ។

កិច្ចការ-វិវរណៈ

ទិដ្ឋភាពទូទៅនៃព្រះគម្ពីរសញ្ញាថ្មីពាក់កណ្តាលទីពីរ

ចូរពន្យល់ថាកិច្ចការ ១:៨ពុំគ្រាន់តែបង្រៀនសេចក្តីពិតទេ ប៉ុន្តែក៏ផ្តល់នូវទិដ្ឋភាពទូទៅនៃគម្ពីរសញ្ញាថ្មីពាក់កណ្តាលចុងក្រោយផងដែរ ។

- យោងតាមកិច្ចការ ១:៨តើព្រះអង្គសង្គ្រោះបានព្យាករថា ពួកសិស្សរបស់ទ្រង់នឹងធ្វើជាសាក្សីអំពីទ្រង់នៅកន្លែងណា ?

សូមសរសេរចំណុចដូចខាងក្រោមនេះនៅលើក្តារខៀន ៖ *កិច្ចការ ១–៥ = យេរូសាឡិម, កិច្ចការ ៦–៩ = ស្រុកយូដា និងសាម៉ារី , កិច្ចការ ១០–២៨= ចុងបំផុតនៃផែនដី* (សូមមើល Bible Dictionary « Acts of the Apostles ») ។

ចូរពន្យល់ថា ពួកសិស្សបានចាប់ផ្តើមធ្វើជាសាក្សីអំពីព្រះយេស៊ូវដូចបានដឹកនាំ ។ ទីមួយ ពួកសាវកបានផ្សាយនៅក្នុងទីក្រុងយេរូសាឡិម បន្ទាប់មក នៅស្រុកយូដា និងស្រុកសាម៉ារី រួចហើយទៅទីឆ្ងាយបំផុតនៃផែនដី ។

ចូរសុំឲ្យសិស្សបើក ទៅតារាងមាតិការបស់ ព្រះគម្ពីរប៊ីប ។ សូមអញ្ជើញសិស្សឲ្យរកក្នុងគម្ពីរសញ្ញាថ្មីនូវគម្ពីរ ដែលនៅបន្ទាប់នឹងគម្ពីរកិច្ចការ ។ សូមពន្យល់ថា គម្ពីរ៉ូមរហូតដល់គម្ពីរហេព្រើរ គឺជាសំបុត្រ (លិខិត) ដែលត្រូវបានសរសេរដោយសាវកប៉ុល ។ សិស្សនឹងរៀនអំពីការផ្លាស់ប្រែចិត្តជឿ និងការបម្រើរបស់ប៉ុល នៅពេលពួកគេសិក្សាកិច្ចការ ៩,១៣-២៨ ។

ចូរសុំឲ្យសិស្សបើកទៅកាន់ថៃស្សាឡូនីច ទី ១ ។ ចូរពន្យល់ថា ធីម៉ូថេ គឺជាប្រជាជនដែលរស់នៅក្នុងទីក្រុងថៃស្សាឡូនីច ។ សូមអញ្ជើញសិស្សឲ្យបើកទៅផែនទីគម្ពីរប៊ីបលេខ ១៣« ការធ្វើដំណើរផ្សព្វផ្សាយសាសនារបស់សាវកប៉ុល »និងទីតាំងទីក្រុងថៃស្សាឡូនីចនៅលើផែនទី ។ ចូរពន្យល់ថា សំបុត្រជាច្រើននៅក្នុងគម្ពីរសញ្ញាថ្មី ត្រូវបានសរសេរទៅកាន់ក្រុមជំនុំនៃសាសនាចក្រនៅទីក្រុងផ្សេងៗគ្នា ដើម្បីប្រាប់អំពីតម្រូវការជាក់លាក់របស់ពួកគេ ។ អ្នកក៏អាចនឹងចង់ពន្យល់ថា សំបុត្រទាំងនេះ គឺពុំបានរៀបចំតាមលំដាប់លំដោយនៃកាលប្រវត្តិវិទ្យា នៅក្នុងគម្ពីរសញ្ញាថ្មីទេ ។ គម្ពីរថៃស្សាឡូនីចទី ១គឺត្រូវបានជឿថាជាសំបុត្រទីមួយដែលប៉ុលបានសរសេរ ។

ចូរសុំសិស្សឲ្យរកមើលតារាងមាតិកា ហើយប្រាប់អំពីគម្ពីរផ្សេងៗមួយចំនួន ដែលបានសរសេរជាសំបុត្រទៅកាន់ក្រុមជំនុំនៃពួកបរិសុទ្ធ ។

ចូរពន្យល់ថា បន្ទែមពីលើការសរសេរទៅកាន់ក្រុមជំនុំនៃពួកបរិសុទ្ធ ប៉ុលបានសរសេរទៅកាន់បុគ្គលម្នាក់ៗដូចជា ធីម៉ូថេទី ទីតុស និង ភីលេម៉ូន ។

ចូរសុំឲ្យសិស្សរកមើលថា តើគម្ពីរអ្វីនៅបន្ទាប់ពីហេព្រើរនៅក្នុងតារាងមាតិកា ។

ចូរពន្យល់ថា បន្ទែមពីលើប៉ុល ពួកសាវក និងអ្នកដឹកនាំសាសនាចក្រដទៃទៀតបានសរសេរទៅកាន់សមាជិកនៃសាសនាចក្រ ។ យើងនៅតែមានសំបុត្រទាំងនេះមួយចំនួន ដែលជាគម្ពីរយ៉ាកុបទៅដល់គម្ពីរពួកចៅហ្វាយ ។ គម្ពីរវិវរណៈកត់ត្រាការនិមិត្តមួយ ដែលសាវកយ៉ូហានបានមើលឃើញ ។

សូមអញ្ជើញសិស្សឲ្យបន្តការអានទៅព្រះគម្ពីរសញ្ញាថ្មីពាក់កណ្តាលទីពីរដោយខ្លួនគេផ្ទាល់ ។ សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋាននៅពេលពួកគេសិក្សាដើម្បីឲ្យព្រះវិញ្ញាណបរិសុទ្ធអាចបំភ្លឺគំនិតពួកគេ ហើយជួយពួកគេទទួលបានការយល់ដឹងកាន់តែជ្រាលជ្រៅនៅពេលពួកគេសិក្សាការបង្រៀនទាំងឡាយរបស់ពួកសាវកក្នុងគម្ពីរសញ្ញាថ្មី ។

សូមលើកទឹកចិត្តសិស្សឲ្យអានអត្ថបទសម្រាប់វគ្គសិក្សានេះ ។

សូមលើកទឹកចិត្តសិស្សឲ្យអានគម្ពីរសញ្ញាថ្មីទាំងមូល ។ អែលឌើរ ដាវីឌ អេ បែឌណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា «ការអានគម្ពីរមួយក្នុងព្រះគម្ពីរពីដើមរហូតដល់ចប់. . . [ណែនាំ] ដល់យើងចំពោះរឿងសំខាន់ៗ គោលលទ្ធិនៃដំណឹងល្អ និងគោលការណ៍គ្មានទីបំផុត [ហើយ] អាចជួយយើងរៀនអំពីលក្ខណៈសំខាន់ៗ. . . និងលំដាប់ព្រឹត្តិការណ៍ ពេលវេលា និងបរិបទនៃព្រឹត្តិការណ៍ និងការបង្រៀនទាំងឡាយ » (« A Reservoir of Living Water » [Church Educational System fireside for young adults ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៧] ទំព័រ ២, lds.org/broadcasts) ។

កិច្ចការ ១:៩-២៦

សេចក្តីផ្តើម

បន្ទាប់ពីការណែនាំដល់ពួកសិស្សរបស់ទ្រង់អស់រយៈពេល ៤០ ថ្ងៃ នោះព្រះយេស៊ូវគ្រីស្ទ បានយាងត្រឡប់ទៅស្ថានសួគ៌វិញ ។ ពួកសាវក និងអ្នកដទៃទៀតបានរួបរួមគ្នានៅក្នុងការអធិស្ឋាន និងការទូលអង្វរ ។ តាមរយៈការបំផុសគំនិត ម៉ាត់ធាស ត្រូវបានហៅឲ្យបំពេញក្នុងតំណែងទំនេរ នៅក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ដែលបន្សល់ទុកពីការក្បត់ និងការស្លាប់របស់យូដាសអេស្ការីយ៉ុត ។

យោបល់សម្រាប់ការបង្រៀន

បង្កើតបរិយាកាសដែលពោរពេញដោយសេចក្តីស្រឡាញ់ ការគោរព និង គោលបំណង ។

សូមស្វែងរកវិធីនានាដើម្បីបង្កើតបរិយាកាសរៀនសូត្រមួយ ដែលប្រកបដោយសេចក្តីស្រឡាញ់ ការគោរព និងគោលបំណងដោយខ្ជាប់ខ្ជួន ។ សូមជួយសិស្សឲ្យមានអារម្មណ៍កក់ក្តៅនឹងគ្នាទៅវិញទៅមក ដោយការលើកទឹកចិត្តពួកគេឲ្យរៀនអំពីចំណាប់អារម្មណ៍ ទេពកោសល្យ ឧបសគ្គ និងលទ្ធភាពរបស់គ្នាទៅវិញទៅមក ។ វិធីមួយដើម្បីបង្កើតបរិយាកាសបែបនេះបាន គឺការអញ្ជើញសិស្សឲ្យចែកចាយពីបទពិសោធន៍ និង ទស្សនៈដែលចេញមកពីការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេជាមួយគ្នា ។

កិច្ចការ ១:៩-១២

ព្រះអង្គសង្គ្រោះយាងឡើងទៅស្ថានសួគ៌

សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្តារខៀន ៖ *ត្រូវ ឬខុស* ?

សូមអានសេចក្តីថ្លែងការណ៍ដូចខាងក្រោម អំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សឲ្យចង្អុលបង្ហាញថាតើសេចក្តីថ្លែងការណ៍នោះ ត្រូវ ឬខុស ។ (*កំណាត់ចំណាំ* ៖នៅក្នុងមេរៀនត្រង់ចំណុចនេះ សិស្សពុំចាំបាច់ស្គាល់ចម្លើយចំពោះសំណួរនីមួយៗ ឬចំណាយពេលច្រើនពេក ដើម្បីពិភាក្សាចម្លើយរបស់ពួកគេនោះទេ) ។

១. ព្រះយេស៊ូវគ្រីស្ទនឹងយាងត្រឡប់មកផែនដីនៅថ្ងៃចុងក្រោយ ។

២. នៅការយាងមកជាលើកទីពីររបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទនឹងលេចមកជួបតែពួកសុចរិតតែប៉ុណ្ណោះ ។

៣. ដោយសារតែព្រះយេស៊ូវនឹងលាក់អត្តសញ្ញាណមិនឲ្យនរណាដឹង នៅពេលទ្រង់យាងមកម្តងទៀត នោះមនុស្សស្ទើរតែទាំងអស់នឹងមិនដឹងថា ការយាងមកជាលើកទីពីរកើតឡើងទេ ។

អ្នកអាចនឹងចង់រំឭកដោយសង្ខេប អំពីចម្លើយចំពោះសេចក្តីថ្លែងការណ៍នីមួយៗ ៖ (១) ត្រូវ (សូមមើល ម៉ូសេ ៧:៦០); (២) ខុស (សូមមើល យ៉ូសែប ស៊្មីធ—ម៉ាថាយ ១:២៦; គ. និង ស. ១០១:២៣); (៣) ខុស (សូមមើល គ. និង ស. ៤៩:២២–២៣) ។

ចូរពន្យល់ថា អំឡុងការបម្រើនៃជីវិតរមែងស្លាប់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានព្យាករថា នៅក្នុងថ្ងៃចុងក្រោយ មានមនុស្សមួយចំនួននឹងប្រកាសផ្សាយនូវការបង្រៀនខុសឆ្គងអំពីការយាងមកជាលើកទីពីររបស់ទ្រង់ (សូមមើលយ៉ូសែប ស៊្មីធ—ម៉ាថាយ ១:២២-២៥) ។

- តើយើងអាចដឹងថា ការបង្រៀនជាក់លាក់មួយអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទគឺត្រូវ ឬខុសយ៉ាងដូចម្តេច ? (ប្រសិនបើយើងស្តាប់ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ និងពាក្យសម្តីរបស់ពួកព្យាការីរបស់ទ្រង់ នោះយើងអាចចៀសវាងពីការបោកបញ្ឆោត (សូមមើលយ៉ូសែប ស៊្មីធ—ម៉ាថាយ ១:៣៧)) ។

សូមអញ្ជើញសិស្សឲ្យរកមើល ពេលពួកគេបន្តសិក្សាកិច្ចការ ១រកមើលសេចក្តីពិតសំខាន់អំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមរំឭកពួកគេថា ព្រះអង្គសង្គ្រោះ បានណែនាំដល់សិស្សរបស់ទ្រង់អស់រយៈពេល ៤០ ថ្ងៃ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ (សូមមើលកិច្ចការ ១:៣) ។ សូមដាក់តាំងបង្ហាញរូបភាពការយាងឡើងទៅវិញ (*Gospel Art Book* (ឆ្នាំ ២០០៩)ទំព័រ ៦២ សូមមើលគេហទំព័រ LDS.org ផងដែរ) ។



សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១:៩-១២ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលនូវអ្វីដែលបានកើតឡើងបន្ទាប់ពីព្រះអង្គសង្គ្រោះបញ្ចប់ការបង្រៀនដល់ពួកសាវករបស់ទ្រង់ ។

- តើអ្វីខ្លះបានកើតឡើង បន្ទាប់ពីព្រះអង្គសង្គ្រោះបញ្ចប់ការបង្រៀនដល់ពួកសាវករបស់ទ្រង់ ?
- ប្រសិនបើអ្នកបានឃើញព្រះអង្គសង្គ្រោះយាងឡើងទៅស្ថានសួគ៌វិញ តើអ្នកមានគំនិត និងអារម្មណ៍យ៉ាងណា ?

ចូរពន្យល់ថា នៅក្នុងជំនាន់អ៊ីស្រាអែលពីបុរាណ ពេលខ្លះដុំពពកមួយដុំគឺជាការតំណាងអំពីវត្តមាន និងសិរីល្អនៃព្រះដែលមើលឃើញនឹងភ្នែក (សូមមើលនិក្ខមនំ ៤០:៣៤) ។ ពពកដែលប្រាប់នៅក្នុងកិច្ចការ ១:៩គឺជាពពកនៃសិរីល្អ (សូមមើល Bible Dictionary« Cloud ») ហើយបុរសពីរនាក់ដែលប្រាប់នៅក្នុងខទី ១០គឺជាពួកទេវតា ។

- តើពួកទេវតាប្រាប់ពួកសាវកអំពីអ្វីខ្លះ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលព្រះយេស៊ូវនឹងយាងមក « តាមបែបនោះ » (កិច្ចការ ១:១១) នៅពេលទ្រង់យាងឡើងទៅវិញ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖**នៅឯការយាងមកជាលើកទីពីររបស់ទ្រង់ ព្រះអង្គសង្គ្រោះនឹងយាងចុះមកពីស្ថានសួគ៌នៅក្នុងសិរីល្អ ។**

ចូរចង្អុលបង្ហាញថា ការយាងឡើងទៅវិញរបស់ព្រះអង្គសង្គ្រោះ បានកើតឡើងនៅលើភ្នំដើមអូលីវ (សូមមើលខទី ១២) ។ ចូរពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះយាងមកម្តងទៀត ការលេចមករបស់ទ្រង់ នឹងមាននៅពេលទ្រង់នឹងយាងឡើងទៅវិញ ហើយគង់នៅលើភ្នំដើមអូលីវ (សូមមើលសាការី ១៤:៤,គ. និង ស. ៤៥:៤៧-៥៣,គ. និង ស. ១៣៣:១៩-២០) ។ នេះនឹងកើតឡើងពីមុនការយាងមកដ៏អស្ចារ្យ និងមហិមារបស់ទ្រង់ចំពោះពិភពលោក (សូមមើលអេសាយ ៤០:៥) ។

- តើការស្គាល់លក្ខណៈនៃការយាងមកវិញរបស់ព្រះអង្គសង្គ្រោះ អាចជួយយើងចៀសផុតពីការបោកបញ្ឆោត ខណៈដែលយើងរង់ចាំការយាងមកជាលើកទីពីររបស់ទ្រង់យ៉ាងដូចម្តេច ?

កិច្ចការ ១:១៣-២៦

ម៉ាធាស ត្រូវបានជ្រើសរើសដើម្បីបំពេញកិច្ចការនៅក្នុងក្រុមនៃពួកសាវកដប់ពីរនាក់

ចូរពន្យល់ថា បន្ទាប់ពីពួកសាវកបានត្រឡប់មកដល់ទីក្រុងយេរូសាឡិមវិញ ពួកគេបានជួបជុំគ្នាជាមួយនឹងពួកបុរស និងស្ត្រីស្មោះត្រង់មួយចំនួន រួមទាំងម៉ារា ដែលជាមាតារបស់ព្រះយេស៊ូវដើម្បីអធិស្ឋាន និងថ្វាយបង្គំ ។ សូមអញ្ជើញសិស្សឲ្យអានកិច្ចការ ១:១៣ដោយស្ងាត់ស្ងៀម ហើយរាប់ចំនួនពួកសាវកដែលបានសរសេរនោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើហេតុអ្វីមានតែពួកសាវក ១១ នាក់នៅជំនាន់នោះ ? (យ៉ូដាស អេស្ការីយ៉ុត បានក្បត់ព្រះយេស៊ូវគ្រីស្ទ រួចហើយបានបញ្ចប់ជីវិតរបស់ខ្លួន [សូមមើល ម៉ាថាយ ២៧:៣-៥]) ។

សូមសង្ខេបកិច្ចការ ១:១៥-២០ដោយពន្យល់ថា ពេត្រុស បានឈរនៅចំពោះមុខពួកសិស្ស ១២០ នាក់ ហើយបានដំណាលអំពីការស្លាប់របស់ យ៉ូដាស អេស្ការីយ៉ុត ។ ដោយសារ យូដាស គឺជាសាវកម្នាក់ក្នុងចំណោមដប់ពីរនាក់ នោះពួកសាវកបានជួបជុំគ្នាដើម្បីជ្រើសរើសសាវកថ្មី ។

សូមអញ្ជើញសិស្សឲ្យពិពណ៌នាអំពីរបៀបផ្សេងៗ ដែលអ្នកដឹកនាំមួយចំនួនដូចខាងក្រោមត្រូវបានជ្រើសរើស ៖ ជាមេក្រុម អ្នកដឹកនាំក្នុងរដ្ឋាភិបាលមូលដ្ឋាន ជាស្តេច ឬម្ចាស់ក្សត្រី និងជាប្រធានក្រុមហ៊ុនជាដើម ។

- តើអ្វីខ្លះជាគុណសម្បត្តិមួយចំនួននៃតំណែងអ្នកដឹកនាំទាំងនេះ ?

សូមបង្ហាញរូបភាពមួយ ឬរូបថតរបស់គណៈប្រធានទីមួយបច្ចុប្បន្ន និងក្រុមនៃពួកសាវកដប់ពីរនាក់ ហើយថ្លែងទីបន្ទាល់ថា បុរសម្នាក់ៗទាំងនេះគឺជាសាវករបស់ព្រះយេស៊ូវគ្រីស្ទ ។ ចូរសុំឲ្យសិស្សពិចារណាអំពីរបៀប ដែលសាវកម្នាក់របស់ព្រះយេស៊ូវត្រូវបានជ្រើសរើស និងគុណសម្បត្តិអ្វីខ្លះដែលមនុស្សម្នាក់មាន ដើម្បីបម្រើជាសាវកមួយរូបនោះ ។

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញពួកគេអានកិច្ចការ ១:២១-២៦ឲ្យពួ ៗ ជាមួយនឹងឪពុកម្តាយរបស់ពួកគេ ហើយរកមើលរបៀបដែលសាវកថ្មីត្រូវបានជ្រើសរើសបន្ទាប់ពីការស្លាប់របស់ យូដាស អេស្ការីយ៉ុត ។

- តើការណ៍ដែល « ពួកគេចាប់ឆ្នោត » មានន័យយ៉ាងណា ? (ខទី ២៦) ។

អ្នកអាចនឹងចង់ពន្យល់ថា ការចាប់ឆ្នោតពីបុរាណមានន័យដោយស្មោះថា ជាការបង្កើតការសម្រេចចិត្តមួយ ដែលបានបង្ហាញនូវការទុកចិត្តទៅលើព្រះក្នុងការដឹកនាំលទ្ធផល (សូមមើលកិច្ចការ ១:២៦,សូមមើលផងដែរសុភាសិត ១៦:៣៣) ។ « ប្រសិនបើពួកគេចាប់ឆ្នោត វាគឺជាឧទាហរណ៍មួយដែលថា ព្រះអម្ចាស់បានជ្រើសរើសលទ្ធផល ។ ទោះជាយ៉ាងណាក៏ដោយ ប្រហែលជា ‹ ពួកគេចាប់ឆ្នោត › នោះដោយសន្មតថាជា ‹ ការគាំទ្រដល់ការបោះឆ្នោត › ដើម្បីលើកតម្កើងដល់អ្នកដែលព្រះបានជ្រើសរើសឲ្យបម្រើនៅក្នុងភាពជាសាវកដ៏ពិសិដ្ឋ » (Bruce R. McConkie, *Doctrinal New Testament Commentary* វ៉ុលទី ៣ [ឆ្នាំ ១៩៦៥–៧៣] ២:៣២) ។

- យោងតាមខទី ២១-២២តើគុណសម្បត្តិអ្វីខ្លះដែលពេត្រុសបាននិយាយថា សាវកថ្មីត្រូវតែមាន ? (គាត់ត្រូវតែជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ក៏ជាសាក្សីអំពីការបម្រើ និងការរស់ឡើងវិញរបស់ទ្រង់ផងដែរ) ។
- តើអ្វីខ្លះដែលធ្វើឲ្យអ្នកចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះការអធិស្ឋានរបស់ពួកសាវកដែលបានកត់ត្រានៅក្នុងខទី ២៤-២៥?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខទី ២៤អំពីរបៀបដែលសាវកម្នាក់របស់ព្រះយេស៊ូវគ្រីស្ទត្រូវបានហៅ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ត្រូវគូសបញ្ជាក់ថា**ពួកសាវករបស់ព្រះយេស៊ូវត្រូវបានហៅដោយព្រះតាមរយៈវិវរណៈ** ។ ចូរសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យពិចារណាអំពីការសរសេរវានៅក្នុងគម្ពីររបស់ពួកគេនៅជិតនឹងខទី ២៤) ។
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដែលសាវកម្នាក់ត្រូវបានហៅដោយព្រះ តាមរយៈវិវរណៈជំនួសឲ្យការជ្រើសរើសនៅក្នុងរបៀបមួយស្រដៀងទៅនឹងការជ្រើសរើសអ្នកដឹកនាំដទៃទៀតនៅក្នុងលោកិយនេះ ?

ដើម្បីបង្ហាញពីរបៀបដែលសាវកថ្មីម្នាក់ ត្រូវបានហៅដោយព្រះតាមរយៈវិវរណៈ សូមអញ្ជើញសិស្សម្នាក់ឲ្យអានអំពីដំណើររឿងដូចខាងក្រោមមកពីជីវិតរបស់ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត ៖



« ប្រធាន [ហ៊ីប៊ើរ ចេ] ក្រាន្ត បានទទួលវិវរណៈក្នុងនាមជាប្រធានសាសនាចក្រដើម្បីដឹកនាំសាសនាចក្រទាំងមូល ។ វិវរណៈដូច្នេះមានបន្ទាប់ពីលោកត្រូវបានលែកចេញជាប្រធាននៃសាសនាចក្រ នៅពេលលោកបានស្វែងយល់ពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ នៅក្នុងការតែងតាំងសមាជិកថ្មីនៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ នៅពេលលោកបានពិចារណាអំពីការទទួលខុសត្រូវនេះ គំនិតរបស់លោកបានគិតម្តងហើយម្តងទៀតអំពីមិត្តជិតស្និទ្ធម្នាក់ឈ្មោះ រីឆាដ ដំបុលយូ យ៉ង ជាពួកបរិសុទ្ធថ្ងៃចុងក្រោយស្មោះត្រង់ម្នាក់ និងជាអ្នកដឹកនាំល្អម្នាក់ ។ ប្រធាន ក្រាន្ត បានពិភាក្សាអំពីលទ្ធភាពនេះជាមួយនឹងទីប្រឹក្សារបស់លោក ដែលបានគាំទ្រដល់ការសម្រេចចិត្តរបស់លោក ។ នៅទីបំផុត ពេលលោកបានមានទំនុកចិត្តដើម្បីធ្វើកិច្ចការនេះ ដូច្នេះលោកក៏បានសរសេរឈ្មោះរបស់មិត្តលោកនៅលើក្រដាសមួយ

សន្លឹក ហើយបាននាំយកក្រដាសនោះទៅជាមួយលោកទៅក្នុងការប្រជុំក្នុងព្រះវិហារបរិសុទ្ធប្រចាំសប្តាហ៍ជាមួយគណៈប្រធានទីមួយ និងក្រុមនៃពួកដប់ពីរនាក់ ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលលោកហៀបនឹងបង្ហាញឈ្មោះ ដើម្បីទទួលបានការអនុម័តពីបងប្អូនប្រុសរបស់លោក លោកពុំអាចធ្វើដូច្នោះបានទេ ។ ផ្ទុយទៅវិញលោកបានបង្ហាញឈ្មោះរបស់ មែលវិន ជេ បាឡឺដ ដែលជាបុរសម្នាក់លោកពុំស្គាល់ជំនួសឲ្យឈ្មោះ រីឆាដ ដីបុលយូ យ៉ង់ ។ ក្រោយមកប្រធាន ក្រានត បានប្រាប់អំពីឥទ្ធិពលនៃបទពិសោធន៍នេះដែលមានមកលើលោក ៖

« ‹ ខ្ញុំបានដឹងពីការបំផុសគំនិតនៃការដឹកនាំរបស់ព្រះដ៏មានព្រះជន្មរស់នៅក្នុងកិច្ចការរបស់ខ្ញុំ ។ ចាប់តាំងពីថ្ងៃដែលខ្ញុំបានជ្រើសរើសមនុស្សម្នាក់ដែលប្រៀបធ្ងឹមបានជាមនុស្សចម្លែក ឲ្យធ្វើជាសាវក ជំនួសឲ្យមិត្តជិតស្និទ្ធ និងជាទីស្រឡាញ់របស់ខ្ញុំ នោះខ្ញុំបានដឹងថាដរាបណាខ្ញុំនៅរស់ នោះខ្ញុំត្រូវបានទទួលនូវពន្លឺ និងការបំផុសគំនិត និងការណែនាំរបស់ព្រះនៅក្នុងការដឹកនាំកិច្ចការរបស់ទ្រង់នៅលើផែនដីនេះ › » (*Teachings of Presidents of the Church: Heber J. Grant* | ឆ្នាំ ២០០២ |, ១៨១-៨២)។

- តើសេចក្តីពិតដែលបានបង្រៀននៅក្នុងកិច្ចការ ១:២៤បានគូសបង្ហាញនៅក្នុងដំណើររឿងនេះ ដែលពិពណ៌នាអំពីការហៅបម្រើរបស់ពួកសាវកសម័យទំនើបយ៉ាងដូចម្តេច ?
- តើការហៅបម្រើរបស់សាវកម្នាក់បង្ហាញថា ព្រះអង្គសង្គ្រោះបន្តដឹកនាំសាសនាចក្ររបស់ទ្រង់យ៉ាងដូចម្តេច ? (អ្នកអាចនឹងចង់រំឭកសិស្សអំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងកិច្ចការ ១:២—ថាព្រះយេស៊ូវដឹកនាំសាសនាចក្ររបស់ទ្រង់ ដោយការបើកសម្តែងអំពីព្រះឆន្ទៈរបស់ទ្រង់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ) ។

សូមយោងទៅរូបភាព ឬរូបថតដែលអ្នកដាក់បង្ហាញពីមុនអំពីពួកសាវកដែលនៅរស់ ។ អ្នកអាចនឹងចង់ចំណាយពេលដើម្បីជួយសិស្សរៀន ឬរំឭកឈ្មោះរបស់ពួកគេ ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើបទពិសោធន៍អ្វីខ្លះដែលបានជួយអ្នកស្គាល់ថា ពួកសាវកនៅរស់ត្រូវបានហៅដោយព្រះ ?

ហេតុអ្វីក៏វាសំខាន់ដែលអ្នកត្រូវមានទីបន្ទាល់មួយថា ពួកសាវកនៅរស់ត្រូវបានហៅដោយព្រះនោះ ?

សូមអញ្ជើញពួកគេឲ្យសរសេរចម្លើយ ឆ្លើយសំណួរមួយ ចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេនៅក្នុងថ្នាក់ ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ អំពីសេចក្តីពិតដែលសិស្សបានប្រាប់នៅក្នុងកិច្ចការ ១:៩-២៦ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

ដើម្បីជួយសិស្សរំឭកចំណេះចំណានខគម្ពីរចំនួន ១០ ដំបូង ចូរសរសេរនូវសេចក្តីយោងដូចខាងក្រោម និងពាក្យគន្លឹះឆ្លើយឆ្លងនៅលើក្តារខៀន (ប្រសិនបើអ្នកចង់បាន អ្នកអាចផ្តល់ដល់សិស្សនូវច្បាប់ចម្លងនៃតារាង) ៖

ម៉ាថាយ ៥:១៤-១៦	ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺ ។	លូកា ២៤:៣៦-៣៩	រូបកាយដែលបានរស់ឡើងវិញ គឺមាននូវសាច់ និងឆ្អឹង ។
ម៉ាថាយ ១១:២៨-៣០	ចូរមកឯខ្ញុំ ។	យ៉ូហាន ៣:៥	កើតអំពីទឹក និងអំពីព្រះវិញ្ញាណ
ម៉ាថាយ ១៦:១៥-១៩	កូនសោនៃនគរស្ថានសួគ៌	យ៉ូហាន ១៤:៦	ជាផ្លូវ ជាសេចក្តីពិត និងជាជីវិត
ម៉ាថាយ ២២:៣៦-៣៩	ស្រឡាញ់ព្រះអម្ចាស់ ស្រឡាញ់អ្នកជិតខាងខ្លួន ។	យ៉ូហាន ១៤:១៥	បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ
ម៉ាថាយ ២៨:១៩-២០	បង្រៀន និង ជ្រមុជទឹកឲ្យគ្រប់សាសន៍ទាំងអស់ ។	យ៉ូហាន ១៧:៣	ការស្គាល់ព្រះ និងព្រះយេស៊ូវគ្រីស្ទ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ ចូរសុំឲ្យសិស្សរំឭកជាមួយដៃគូរបស់ពួកគេអំពីចំណេះចំណានខគម្ពីរ ដែលបានសរសេរនៅលើក្តារខៀន ។ អ្នកអាចនឹងផ្តល់យោបល់ឲ្យដៃគូម្នាក់អានឮៗនូវពាក្យគន្លឹះមកពីចំណេះចំណានខគម្ពីរ ហើយដៃគូម្នាក់ទៀត ប្រាប់អំពីសេចក្តីយោងដែលឆ្លើយឆ្លងគ្នានោះ ។ សូមអញ្ជើញសិស្សឲ្យឆ្លាស់តួនាទីគ្នារហូតដល់ពួកគេបានរំឭកវគ្គបទគម្ពីរទាំង ១០ ។

ប្រសិនបើមានពេល សូមពិចារណាធ្វើការផ្តល់ចំណោទមួយដល់សិស្ស ។ សូមផ្តល់ក្រដាសមួយសន្លឹកដល់សិស្ស ដែលរួមមានទាំងពាក្យគន្លឹះសម្រាប់ចំណេះចំណានខគម្ពីរនីមួយៗ ដែលមាននូវបន្ទាត់ទទេមួយ ។ សូមអញ្ជើញសិស្សឲ្យសរសេរសេចក្តីយោងឆ្លើយឆ្លងគ្នានៅលើបន្ទាត់ទទេនោះ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមពិនិត្យមើលចំណោទនោះ ។

កិច្ចការ ២

សេចក្តីផ្តើម

ពួកសិស្សត្រូវបានពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃបុណ្យថ្ងៃទី ៥០ ហើយត្រូវបានប្រទានពរដោយនឹងអំណោយទានខាងភាសា នៅពេលពួកគេបានផ្សាយដំណឹងល្អ ។ ពេត្រុសបានប្រកាសថា ព្រះយេស៊ូវ គឺ « ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រីស្ទផង » (កិច្ចការ ២:៣៦) ហើយបានអញ្ជើញមនុស្សឲ្យប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ មនុស្សប្រហែលជាបីពាន់នាក់ ត្រូវបានផ្លាស់ប្រែចិត្តជឿ ហើយទទួលបុណ្យជ្រមុជទឹកនាថ្ងៃនោះ បន្ទាប់មកពួកគេបានបន្តស្មោះត្រង់នៅក្នុងសាសនាចក្រ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ២:១-១៣

ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទ បានពេញដោយព្រះវិញ្ញាណបរិសុទ្ធនៅថ្ងៃបុណ្យថ្ងៃទី ៥០ ។

ចូរសុំឲ្យសិស្សគិត អំពីឱកាសថ្មីៗបំផុតដែលពួកគេត្រូវនិយាយនៅក្នុងព្រះវិហារ បង្រៀនមេរៀន ឬចែកចាយដំណឹងល្អជាមួយនរណាម្នាក់ ។

- **តើអ្វីខ្លះអាចជាបញ្ហាក្នុងការនិយាយ ការបង្រៀន ឬថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?**

សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីពិតមួយ នៅពេលពួកគេសិក្សា កិច្ចការ ២:១-១៣ដែលនឹងជួយពួកគេ នៅពេលពួកគេមានអារម្មណ៍រន្ធត់ ឬភ័យខ្លាចក្នុងការបង្រៀន និងថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃអំពីដំណឹងល្អដែលបានស្តារឡើងវិញ ។


ចូរពន្យល់ថា ប្រហែលជាមួយសប្តាហ៍បន្ទាប់ពីព្រះអង្គសង្គ្រោះបានយាងទៅស្ថានសួគ៌វិញ នោះពួកយូដាមកពីជាតិសាសន៍ជាច្រើន បានមកទីក្រុងយេរូសាឡិមដើម្បីចូលរួមនៅក្នុងពិធីជប់លៀងបុណ្យថ្ងៃទី ៥០ និងដើម្បីថ្វាយបង្គំនៅព្រះវិហារបរិសុទ្ធ ហើយថ្លែងអំណរគុណដល់ព្រះអម្ចាស់ ។ ពិធីជប់លៀងនេះប្រារព្ធឡើងនៅថ្ងៃទី ៥០ បន្ទាប់ពីពិធីជប់លៀងបុណ្យរំលង ហើយប្រារព្ធនូវរដូវចម្រូតដំបូងគេ (សូមមើល Guide to the Scriptures« Pentecost »scriptures.lds.org) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២:១-៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីអ្វី ដែលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបានទទួលបទពិសោធន៍នៅថ្ងៃនៃបុណ្យថ្ងៃទី ៥០ ។

- **តើពួកសិស្សមានបទពិសោធន៍អ្វីខ្លះនៅថ្ងៃនៃបុណ្យថ្ងៃទី ៥០ ? (ការចាក់ស្រោចនៃព្រះវិញ្ញាណបរិសុទ្ធ) ។**
- **តើការចាក់ស្រោចនៃព្រះវិញ្ញាណបរិសុទ្ធនេះ ត្រូវបានពិពណ៌នាយ៉ាងដូចម្តេច ?**

ចូរពន្យល់ថា ឃ្លា « អណ្តាតបែកចេញពីគ្នា » (ខទី ៣) សំដៅទៅលើភាសា ដែលត្រូវបានបែកចេញជាពីរ ឬបំបែក ឬដែលបានលេចចេញជាអណ្តាតភ្លើង ។ កាលពីបុរាណ ជាញឹកញាប់ភ្លើងបានតំណាងឲ្យវត្តមាន ឬឥទ្ធិពលរបស់ព្រះ ។ នេះគឺជាទីសម្គាល់មួយថា ពួកសិស្សបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យាដោយព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២:៤-៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលបានកើតឡើង នៅពេលសិស្សត្រូវបានពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ។



- **យោងតាមខទី ៤តើអ្វីបានកើតឡើងខ្លះ នៅពេលពួកសិស្សត្រូវបានពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ? (ព្រះវិញ្ញាណ « ប្រទានឲ្យនិយាយភាសា » ហើយអាចឲ្យពួកគេនិយាយជាភាសាផ្សេងៗ) ។**
- **ហេតុអ្វីក៏ពួកសាសន៍យូដា ចេញមកពីជាតិសាសន៍ផ្សេងៗមានអារម្មណ៍អស្ចារ្យនឹងអ្វីដែលពួកគេបានស្តាប់ឮដូច្នេះ ?**

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗកិច្ចការ ២:៩-១១ហើយរាប់ចំនួនក្រុមមនុស្ស ឬជាតិសាសន៍ផ្សេងៗ ដែលបានស្តាប់ឮពួកសិស្សនិយាយភាសានានាដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ ចូរសុំពួកគេឲ្យរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ សូមពិចារណាអំពីការដាក់បង្ហាញផែនទីដែលអមជាមួយដល់សិស្ស ដើម្បីជួយសិស្សឲ្យមើលឃើញពីទីកន្លែងណា ដែលពួកយូដាទាំងនេះមក ។

សូមចង្អុលបង្ហាញថា យោងតាមខទី ១១ក្រុមនីមួយៗទាំងនេះបានស្តាប់ឮនៅក្នុងភាសាកំណើតរបស់ពួកគេ « កិច្ចការដ៏អស្ចារ្យរបស់ព្រះ » ត្រូវបានបង្រៀនដោយពួកសិស្ស ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា អ្នកចូលសាសនាគឺជាពួកសាសន៍ដទៃ ដែលបានចូលរួមនៅក្នុងជំនឿពួកយូដា ។


- ដូចបានបង្ហាញដោយបទពិសោធន៍របស់ពួកសិស្សនៅថ្ងៃនៃបុណ្យថ្ងៃទី ៥០ តើមានអ្វីខ្លះ ដែលអាចជួយយើងបង្រៀន និងថ្លែងទីបន្ទាល់អំពីអ្នកដទៃ ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលយើងពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ នោះទ្រង់នឹងជួយយើងបង្រៀន ហើយថ្លែងទីបន្ទាល់ដល់មនុស្សដទៃ**) ។

ដើម្បីជួយសិស្សយល់គោលការណ៍នេះ សូមនាំកែវទឹកពី ថូទឹកមួយ និងថាសមួយមកថ្នាក់រៀន ។ សូមដាក់កែវទឹកនៅលើថាស ដើម្បីថាសអាចទ្រទឹកដែលកំពប់ ។ បន្ទាប់មកបិទគំរបកែវដោយសន្លឹកក្រដាសមួយសន្លឹក ឬគម្របមួយ ដើម្បីកុំឲ្យទឹកកំពប់ចេញពីកែវ ហើយទម្លាក់វត្ថុមួយ (ដូចជាថ្មមួយដុំ) ទៅក្នុងកែវទឹកមួយទៀត ដើម្បីកែវនោះត្រូវបានបំពេញស្មើរតែទាំងអស់ដោយវត្ថុនោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យចាក់ទឹកពីក្នុងថូបំពេញក្នុងកែវទឹកទាំងពីរ ។

- ប្រសិនបើកែវទឹកជាតំណាងឲ្យយើង ហើយទឹកតំណាងឲ្យព្រះវិញ្ញាណបរិសុទ្ធ តើក្រដាស (ឬគម្រប) និងថ្មតំណាងឲ្យអ្វីទៅ ? តើឥរិយាបទ ឬអាកប្បកិរិយាណាខ្លះ ដែលអាចរារាំងយើងមិនឲ្យបានបំពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ?
- តើយើងអាចត្រូវបានបំពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីទ្រង់អាចជួយយើងបង្រៀន និងថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃយ៉ាងណាខ្លះ ?
- តើព្រះវិញ្ញាណបានជួយអ្នកបង្រៀនដំណឹងល្អ ឬចែកចាយទីបន្ទាល់របស់អ្នកជាមួយអ្នកដទៃតាមរបៀបណាខ្លះ ?

សូមថ្លែងទីបន្ទាល់អំពីគោលការណ៍ដែលបានសរសេរនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យអនុវត្តគោលការណ៍នេះ ដោយការស្វែងរកភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យពួកគេអាចបង្រៀន និងថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃ ។

សូមសង្ខេបកិច្ចការ ២:១២-១៣ដោយពន្យល់ថា ពួកសាសន៍យូដាមួយចំនួន ត្រូវបានស្ងើចអស្ចារ្យចំពោះអ្វីដែលពួកគេបានស្តាប់ឮ ខណៈដែលអ្នកដទៃបានចំអកដល់ពួកសិស្សដោយចោទប្រកាន់ពួកគេថា ត្រូវស្រវឹងស្រាជោគជាំនោះ ។



ការបដិសេធរបស់ពេត្រុស ដោយ ខាល ហេនរីក ប្លូច ។ ការតាំងពិពណ៌នៃសារមន្ទីរប្រវត្តិសាស្ត្រជាតិនៅមាន ហ្គ្រិនវិកស្បក នៅហ៊ីលលើត្រ ប្រទេស ដាណឺម៉ាក់ ។ ហាមចំតចម្លង ។

កិច្ចការ ២:១៤-៤៧

ពេត្រុសថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយបង្រៀនអំពីរបៀបដើម្បីទទួលបានសេចក្តីសង្គ្រោះ

សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ២:១៤ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលថា នរណាបានចាប់ផ្តើមបង្រៀនដល់ហ្វូងមនុស្ស ។ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

ចូរសុំឲ្យសិស្សនឹកស្រមៃថា ពួកគេស្ថិតនៅក្នុងស្ថានភាពរបស់ពេត្រុស ឈរនៅចំពោះមុខហ្វូងមនុស្ស ។

- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ពេត្រុស តើសេចក្តីពិតនៃដំណឹងល្អអ្វីខ្លះ ដែលអ្នកនឹងត្រូវបង្រៀន និងថ្លែងទីបន្ទាល់នោះ ? ហេតុអ្វី ?

សូមសង្ខេបកិច្ចការ ២:១៥-៣៥ដោយពន្យល់ថា ពេត្រុសបានប្រកាសថា ព្រឹត្តិការណ៍នៃអំណោយទានខាងភាសា និងការបើកសម្តែងផ្សេងៗទៀតពីព្រះវិញ្ញាណ នៅក្នុងចំណោមពួកសិស្ស គឺជាការបំពេញមួយនៃការព្យាករណ៍ និងអត្ថន័យអំពីការព្យាការណ៍របស់យ៉ូអែល (សូមមើលយ៉ូអែល ២:២៨-៣២) ។ បន្ទាប់មក ពេត្រុសបានបង្រៀន និងថ្លែងទីបន្ទាល់ទៅដល់មនុស្សដោយប្រើពាក្យសម្តី និងទំនុកតម្កើងមួយចំនួនរបស់ស្តេចដាវីឌ ។

សូមសរសេរបទគម្ពីរយោង និងសំណួរខាងក្រោមនៅលើក្តារខៀន ៖

កិច្ចការ ២:២២-២៤, ២៩-៣៣, ៣៦

តើអ្វីខ្លះជាសេចក្តីពិតសំខាន់មួយចំនួន ដែលពេត្រុសបានបង្រៀន និងថ្លែងទីបន្ទាល់?

តើអ្វីខ្លះដែលបានធ្វើឲ្យអ្នកចាប់អារម្មណ៍បំផុតអំពីទីបន្ទាល់របស់ពេត្រុសទៅកាន់ពួកសាសន៍យូដា ?

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមអញ្ជើញដៃគូនីមួយៗ សិក្សាសេចក្តីយោងបទគម្ពីរនៅលើក្តារខៀន ហើយពិភាក្សាចម្លើយរបស់ពួកគេចំពោះសំណួរក្នុងនោះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមដាក់តាំងរូបភាពមួយ ដែលបង្ហាញពីការបដិសេធអំពីព្រះអង្គសង្គ្រោះរបស់ពេត្រុស (ឧទាហរណ៍ ការបដិសេធរបស់ពេត្រុសដោយ ខាល ហេនរីក ប្លូច មាននៅលើគេហទំព័រ LDS.org) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសង្ខេបអំពីអ្វីដែលពេត្រុសបាននិយាយ និងធ្វើ នៅពេលគេសួរអំពីទំនាក់ទំនងរបស់លោកនឹងព្រះយេស៊ូវ នៅយប់ដែលព្រះអង្គសង្គ្រោះត្រូវបានគេចាប់ព្រះកាយ (សូមមើលលូកា ២២:៥៤-៦២) ។

- តើពាក្យសម្តី និងសកម្មភាពរបស់ពេត្រុសនៅថ្ងៃនៃបុណ្យថ្ងៃទី ៥០ ខុសពីឥរិយាបថរបស់លោកនៅយប់ដែលព្រះអង្គសង្គ្រោះត្រូវបានចាប់ព្រះកាយយ៉ាងដូចម្តេច ?
- តើអ្នកគិតថា មានអ្វីដែលមានឥទ្ធិពលដល់ការផ្លាស់ប្តូរនេះក្នុងខ្លួនពេត្រុស ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២:៣៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀប ដែលពាក្យសម្តីរបស់ពេត្រុសបានមានឥទ្ធិពលទៅលើហ្វូងមនុស្ស ។

- តើពាក្យសម្តីរបស់ពេត្រុស មានឥទ្ធិពលលើហ្វូងមនុស្សយ៉ាងដូចម្តេច ?

អ្នកអាចនឹងចង់អញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « មានសេចក្តីចាក់ចុចក្នុងចិត្ត » ។ ចូរពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធបានចាក់ទៅក្នុងចិត្តរបស់មនុស្ស នៅពេលពួកគេស្តាប់ឮទីបន្ទាល់របស់ពេត្រុស ។ ពាក្យ*ចាក់*នៅត្រង់នេះ មានន័យថា « ចាក់យ៉ាងជ្រៅ » ហើយផ្តល់ជាយោបល់ថា មនុស្សបានមានអារម្មណ៍សោកស្តាយដោយសារពួកសាសន៍យូដា ជាប្រជាជន និងជាតិសាសន៍មួយ ដែលបានឆ្កាង

កិច្ចការ ២:៣៦-៣៨

គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរនឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកគប្បីផ្តល់យោបល់ ឲ្យសិស្សគូសចំណាំចំណេះចំណានខគម្ពីរនេះ ដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងកេវាឃើញ ។ សូមបើកទៅយោបល់នៃការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ របស់ពួកគេ ។ ពេត្រុសពុំបញ្ជាក់ថា ក្រុមពួកសាសន៍យូដាដែលចេញមកពីជាតិសាសន៍ផ្សេងៗ ដែលលោកបានបង្រៀននៅថ្ងៃនៃបុណ្យថ្ងៃទី ៥០ គឺជាជាតិសាសន៍ដែលមានទំនួលខុសត្រូវចំពោះការឆ្កាងព្រះយេស៊ូវគ្រីស្ទនោះទេ ។

- យោងតាមខទី ៣៧តើប្រជាជននោះបានសួរសំណួរអ្វីខ្លះ ?
- តើសំណួរនេះបានបើកសម្តែងអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងដួងចិត្តមនុស្សយ៉ាងណា ? (មនុស្សបានចាប់ផ្តើមមានបទពិសោធន៍នៃការផ្លាស់ប្តូរដួងចិត្ត) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២:៣៨-៤១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វី ដែលពេត្រុសបានណែនាំដល់មនុស្សឲ្យធ្វើ ។ ចូរពន្យល់ថា*សំណារវៀច* មានន័យថា បះបោរ បង្ខូចផ្លូវ ឬបាក់បែក ។

- តើពេត្រុសណែនាំមនុស្សឲ្យធ្វើអ្វីខ្លះ ?
- យោងតាមខទី ៤១តើមនុស្សបានឆ្លើយតបចំពោះការបង្រៀន និងការអញ្ជើញរបស់ពេត្រុសឲ្យប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹកយ៉ាងដូចម្តេច ?

ចូរសរសេរសេចក្តីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងទទួលព្រះបន្ទូលនៃព្រះដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ . . .*

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗមកពីកិច្ចការ ២:៤២-៤៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលអ្នកផ្លាស់ប្រែចិត្តជឿថ្មីមកក្នុងសាសនាចក្របានធ្វើ បន្ទាប់ពីពួកគេបានទទួលសេចក្តីពិតដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ហើយបានទទួលបុណ្យជ្រមុជទឹកនោះ ។ ចូរពន្យល់ថា ឃ្លា « កាច់នំប៉័ង » (ខទី ៤២) សំដៅទៅលើការចូលរួមនៅក្នុងពិធីបរិសុទ្ធ នៃពិធីសាក្រាម៉ង់ និងដើម្បីមាន « របស់ទាំងអស់នៅមូលព្រមគ្នា) (ខទី ៤៤) សំដៅទៅលើពួកបរិសុទ្ធ ត្រូវបានសាមគ្គី និងរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ។

- ស្របតាមខគម្ពីរទាំងនេះ តើសកម្មភាពអ្វីខ្លះដែលបានបង្ហាញថា អ្នកទាំងឡាយដែលបានជ្រមុជទឹក ត្រូវបានផ្លាស់ប្រែចិត្តជឿដោយពិត (សូមមើលផងដែរនីហ្វៃទី៣ ២៦:១៧-២១) ? (សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់សិស្សក្នុងថ្នាក់នៅលើក្តារខៀន) ។

សូមរំឭកសិស្សថា មុនពេលពួកយូដាស្តាប់ឮ ហើយធ្វើតាមពាក្យរបស់ពេត្រុស នោះពួកគេពុំព្រមទទួលយកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់ពួកគេទេ ឬក៏ទាំងមិនធ្វើតាមការបង្រៀនរបស់ទ្រង់ផងដែរ ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំពីរបៀបដែលមនុស្សបានផ្លាស់ប្តូរ ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនមកពីកិច្ចការ ២:៣៧-៤៧អំពីអ្វីដែលអាចកើតឡើង នៅពេលយើងទទួលព្រះបន្ទូលរបស់ព្រះតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ? (សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដើម្បីវាំងនាំទៅរកសេចក្តីពិតដូចខាងក្រោមនេះដោយប្រើពាក្យរបស់សិស្ស **៖ នៅពេលយើងទទួលព្រះបន្ទូលព្រះតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះដួងចិត្តយើងនឹងផ្លាស់ប្តូរ ហើយយើងនឹងបានប្រែចិត្តជឿដល់ព្រះយេស៊ូវគ្រីស្ទ**)។
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីទទួលព្រះបន្ទូលនៃព្រះដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យរំឭកសកម្មភាព ដែលបានរៀបរាប់នៅលើក្តារខៀនអំពីអ្នកទាំងឡាយដែលត្រូវបានជ្រមុជទឹក និងបានផ្លាស់ប្រែចិត្តជឿ ។

- នៅពេលអ្នកខិតខំប្រឹងប្រែងរៀន និងរស់នៅតាមសេចក្តីពិតនៃដំណឹងល្អ តើព្រះវិញ្ញាណបានជួយអ្នកផ្លាស់ប្តូរ ហើយបានផ្លាស់ប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ? (អ្នកអាចនឹងចង់ចែកចាយបទពិសោធន៍មួយមកពីជីវិតផ្ទាល់ខ្លួនរបស់អ្នកផងដែរ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីទទួលបានព្រះបន្ទូល និងការបង្រៀនរបស់ព្រះ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធកាន់តែល្អប្រសើរ ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេទទួល ។

ចំណេះចំណានខគម្ពីរ—កិច្ចការ ២:៣៦-៣៨

សូមអញ្ជើញសិស្សឲ្យប្រៀបធៀបកិច្ចការ ២:៣៦-៣៨ទៅនឹងមាត្រានៃសេចក្តីជំនឿទីបួន។ ចូរសុំឲ្យសិស្សប្រាប់នៅក្នុងកិច្ចការ ២:៣៦-៣៨នូវព្រះបន្ទូលដែលបង្ហាញ ឬបង្រៀននូវគោលការណ៍ និងពិធីបរិសុទ្ធទីមួយនៃដំណឹងល្អ ។ បន្ទាប់មក ចូរបំបែកសិស្សជាគូៗ ហើយសុំឲ្យដៃគូនីមួយៗពិភាក្សាអំពីរបៀបដែលគោលការណ៍ និងពិធីបរិសុទ្ធនីមួយៗទាំងនេះ ជួយយើងទទួលបានពរជ័យពេញលេញនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- តើពរជ័យអ្វីខ្លះ ដែលពេត្រុសនិយាយថាមនុស្សនឹងទទួលបាន ដែលជាលទ្ធផលនៃការប្រែចិត្ត និងការទទួលបុណ្យជ្រមុជទឹកនោះ ?
- សូមផ្តោតការយល់ដឹងរបស់អ្នកអំពីកិច្ចការ ២:៣៨តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីរៀបចំខ្លួនទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ? (សិស្សគប្បីប្រាប់ពីសេចក្តីពិតមួយស្រដៀងគ្នាដូចខាងក្រោម ដោយប្រើពាក្យរបស់ពួកគេផ្ទាល់ **៖ នៅពេលយើងមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក នោះយើងនឹងត្រូវបានរៀបចំដើម្បីទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើសេចក្តីជំនឿ ការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹក រៀបចំមនុស្សម្នាក់ដើម្បីទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធយ៉ាងដូចម្តេច ?

មេរៀន ៨៤

កិច្ចការ ៣

សេចក្តីផ្តើម

នៅឯក្លោងទ្វារនៃព្រះវិហារបរិសុទ្ធ ពេត្រុស ដែលបានទៅអមដោយយ៉ូហាន បានព្យាបាលបុរសម្នាក់ដែលកើតមកពិការ ។ បន្ទាប់មក ពេត្រុសបានបង្រៀនដល់ប្រជាជនដែលបានធ្វើជាសាក្សីអំពីការព្យាបាលបុរសនេះ ។ គាត់បានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ បានអញ្ជើញពួកគេឲ្យប្រែចិត្ត ហើយព្យាករអំពីការស្តារឡើងវិញនៃដំណឹងល្អនៅថ្ងៃចុងក្រោយ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ៣:១-១១

ពេត្រុស និងយ៉ូហាន បានព្យាបាលបុរសម្នាក់ដែលកើតមកពិការ

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពួកគេបានសូមអ្វីមួយជាក់លាក់ (ប្រហែលជាអំណោយខួបកំណើត ឬអំណោយបុណ្យគ្រីស្ទម៉ាស់) ប៉ុន្តែបានទទួលអ្វីមួយផ្សេងជំនួសវិញ ។ ចូរសុំឲ្យពួកគេពីរបីនាក់ ចែកចាយបទពិសោធន៍របស់ពួកគេ ហើយពន្យល់ថាតើពួកគេមានអារម្មណ៍យ៉ាងណា នៅពេលពួកគេពុំបានទទួលនូវអ្វីដែលពួកគេចង់បាននោះ ។

- តើយើងអាចប្រៀបធៀបបទពិសោធន៍ទាំងនេះ ទៅនឹងការស្វែងរកពរជ័យមកពីព្រះវរបិតាសួគ៌តាមរយៈការអធិស្ឋានយ៉ាងដូចម្តេច ? (ពេលខ្លះ ព្រះវរបិតាសួគ៌ពុំឆ្លើយតបការអធិស្ឋានរបស់យើងតាមរបៀបដែលយើងបានរំពឹងទុក ឬប្រទានអ្វីដែលយើងទូលសូមនោះទេ) ។

ចូរសុំឲ្យសិស្សពិចារណាអំពីបទពិសោធន៍នានា ដែលនៅក្នុងនោះពួកគេពុំទទួលបានចម្លើយ ឬពរជ័យមកពីព្រះវរបិតាសួគ៌ ដូចដែលពួកគេរំពឹងទុកនោះ ។

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សាកិច្ចការ ៣ដែលនឹងជួយពួកគេ នៅពេលពួកគេមិនបានទទួលចម្លើយ ឬពរជ័យទាំងឡាយដែលពួកគេរំពឹងចង់បានមកពីព្រះអម្ចាស់នោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៣:១-៣ ឮៗ ។ ចូរសុំឲ្យសិស្សផ្សេងតាម ហើយរកមើលថានរណាដែលពេត្រុស និងយ៉ូហានបានជួបនៅឯក្លោងទ្វារនៃព្រះវិហារបរិសុទ្ធ ។

- តើពេត្រុស និងយ៉ូហាន បានជួបនឹងនរណានៅឯក្លោងទ្វារព្រះវិហារបរិសុទ្ធ ?
- តើវាមានន័យយ៉ាងណាដែលបុរសនេះ « គាត់សូមទាន » ? (ខទី ៣) ។ (អ្នកគម្ពីរពន្យល់ថា*ទាន*គឺជាវត្ថុដែលមនុស្សបរិច្ចាគដល់ជនក្រីក្រ) ។

សូមចង្អុលបង្ហាញថា យើងរៀនមកពីកិច្ចការ ៤:២២ថា បុរសពិការ គឺមានវ័យច្រើនជាង ៤០ ឆ្នាំហើយ ។

- ចូរពិចារណាថា បុរសនេះពុំអាចដើរបានអស់ ៤០ ឆ្នាំ តើជើងខ្វិនរបស់គាត់ស្ថិតនៅក្នុងស្ថានភាពបែបណាទៅ ?

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើគេនឹងមានអារម្មណ៍យ៉ាងណាដែលស្ថិតនៅក្នុងស្ថានភាពបុរសខ្វិននោះ ។

- តើរបៀបជាក់លាក់មួយចំនួនអ្វីខ្លះ ដែលមនុស្សអាចឆ្លើយតបចំពោះមនុស្សម្នាក់នៅក្នុងស្ថានភាពដូចបុរសនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៣:៤-៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលរបៀបដែលពេត្រុសបានធ្វើដល់បុរសម្នាក់នេះ ។

- តើពេត្រុសបានធ្វើអ្វីសម្រាប់បុរសម្នាក់នេះ ?
- តើអ្វីខ្លះដែលបានលេចធ្លោចំពោះអ្នកអំពីសកម្មភាព និងពាក្យសម្តីរបស់ពេត្រុស ?

សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ៣:៨ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវអ្វីដែលបុរសបានធ្វើ បន្ទាប់ពីពេត្រុស « លើកគាត់ឡើង » (ខទី ៧) ។

ដើម្បីជួយសិស្សមើលឃើញព្រឹត្តការណ៍ដែលបានកត់ត្រានៅក្នុងកិច្ចការ ៣:១-៨អ្នកគម្ពីរបង្ហាញវីដេអូ« Peter and John Heal a Man Crippled Since Birth »(៣:២១) ចេញមកពី*វីដេអូព្រះគម្ពីរបឹបអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ*មាននៅក្នុងLDS.org។

- តើបុរសនោះបានធ្វើអ្វីខ្លះ បន្ទាប់ពីពេត្រុស « បានលើកគាត់ឡើង » ?
- តើបុរសនេះបានទទួលពរជ័យតាមរបៀបណា ដែលវាអស្ចារ្យជាងទានដែលគាត់បានសូមតាំងពីដើមនោះ ?

សូមឲ្យសិស្សប្រើពាក្យផ្ទាល់ខ្លួនរបស់ពួកគេ

នៅពេលសិស្សបង្ហាញពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីរ សូមកុំនិយាយថា ចម្លើយរបស់ពួកគេខុសឡើយ ដោយសារតែពួកគេមានចម្លើយខុសពីពាក្យ ដែលបានប្រើនៅក្នុងសៀវភៅសិក្សានេះ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើប្រយោគរបស់សិស្សម្នាក់ខុសពីគោលលទ្ធិ វាជាការទទួលខុសត្រូវរបស់អ្នកដើម្បីជួយគេដោយទន់ភ្លន់ក្នុងការកែតម្រូវប្រយោគនោះ ។ ការធ្វើដូច្នោះអាចផ្តល់នូវបទពិសោធន៍ក្នុងការសិក្សាដ៏សំខាន់ ដោយសារយើងបានរក្សាបរិយាកាសប្រកបដោយក្តីស្រឡាញ់ និងការគោរព ។

សូមលើកទឹកចិត្តដល់សិស្សឲ្យនឹកគិតអំពីបទពិសោធន៍ដែលពួកគេបានទទួលចម្លើយ ឬពរជ័យមួយមកពីព្រះវរបិតាសួគ៌ ដែលខុសគ្នាពីចម្លើយ ឬពរជ័យដែលពួកគេបានរំពឹងទុកនោះ ។

- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីកិច្ចការ ៣:១-៨ដែលអាចជួយយើងនៅពេលយើងពុំទទួលបានចម្លើយ ឬពរជ័យដែលយើងរំពឹងទុកមកពីព្រះវរបិតាសួគ៌ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះវរបិតាសួគ៌ប្រហែលនឹងមិនឆ្លើយតប ចំពោះការអធិស្ឋានរបស់យើង តាមវិធីដែលយើងចង់បាន ឬរំពឹងចង់បានពីទ្រង់ឡើយ ប៉ុន្តែចម្លើយរបស់យើងតែងតែសម្រាប់សេចក្តីល្អបំផុតដល់យើងជានិច្ច ។** ចូរសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ហើយពិចារណាធ្វើការអញ្ជើញសិស្សឲ្យសរសេរវានៅរឹមគម្ពីររបស់ពួកគេជិតនឹងខទី ៦) ។
- តើព្រះវរបិតាសួគ៌អាចឆ្លើយតបការអធិស្ឋានរបស់យើង ខុសពីរបៀបដែលយើងចង់បាន ឬរំពឹងទុកពីទ្រង់យ៉ាងដូចម្តេច ? (ឧទាហរណ៍ ទ្រង់អាចប្រទានកម្លាំងដល់យើងដើម្បីស៊ូទ្រាំការសាកល្បងមួយ ជាជាងដកវាចេញ ឬទ្រង់អាចនឹងប្រទានប្រាជ្ញាដល់យើង ដើម្បីជួយយើងដោះស្រាយបញ្ហាមួយ ជាជាងដោះស្រាយបញ្ហាជំនួសយើង) ។

ចូរពន្យល់ថា នៅក្នុងដំណើររឿងដែលបានកត់ត្រានៅក្នុងកិច្ចការ ៣:១-៨វាបង្ហាញជាក់ស្តែងថា អ្វីដែលបុរសនេះបានទទួលគឺអស្ចារ្យជាងអ្វីដែលគាត់បានសុំទាន ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងករណីផ្សេងទៀត វាអាចនឹងមិនច្បាស់ថា អ្វីដែលយើងកំពុងទទួលបានគឺអស្ចារ្យជាងអ្វីដែលយើងសុំនោះទេ ។

- តើការចងចាំសេចក្តីពិតដែលបានសរសេរនៅលើក្តារខៀនអាចជួយយើង នៅពេលយើងទទួលចម្លើយចំពោះការអធិស្ឋានមួយ ដែលខុសពីចម្លើយដែលយើងរំពឹងទុកបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីបទពិសោធន៍ ដែលចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់ពួកគេខុសគ្នាពីចម្លើយដែលពួកគេចង់បាន ប៉ុន្តែត្រឡប់ទៅជាសម្រាប់សេចក្តីល្អកាន់តែប្រសើររបស់គេវិញ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៣:៩-១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមអកមើលរបៀប ដែលមនុស្សបានមានប្រតិកម្មចំពោះការព្យាបាលបុរសនេះ ។

- តើប្រជាជនបានមានប្រតិកម្មចំពោះការព្យាបាលបុរសនេះយ៉ាងដូចម្តេច ?

កិច្ចការ ៣:១២-២៦

ពេត្រុសថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយផ្សាយពីការប្រែចិត្ត

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យនឹកស្រមៃថា ពួកគេស្ថិតនៅក្នុងចំណោមមនុស្សនៅព្រះវិហារបរិសុទ្ធ ដែលបានធ្វើជាសាក្សីអំពីការព្យាបាលបុរសខ្វិននោះ ។ សូមចង្អុលបង្ហាញថា មនុស្សទាំងនេះបានឃើញបុរសខ្វិននេះសូមទានជាញឹកញាប់ នៅពេលពួកគេបានចូលតាមឯក្លោងទ្វារព្រះវិហារបរិសុទ្ធ ប៉ុន្តែបន្ទាប់ពីគាត់ត្រូវបានព្យាបាល នោះពួកគេបានឃើញគាត់លោត ហើយដើរ ។

- ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមមនុស្សនៅព្រះវិហារបរិសុទ្ធ តើអ្នកគិតថា ទស្សនៈរបស់អ្នកអំពីពេត្រុស និងយ៉ូហានប្រហែលជាអាចផ្លាស់ប្តូរយ៉ាងដូចម្តេច បន្ទាប់ពីបានឃើញអព្ភូតហេតុនេះ ?

សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញដៃគូនីមួយៗអានកិច្ចការ ៣:១២-១៦ឲ្យឮៗជាមួយគ្នា ហើយស្វែងរករបៀប ដែលពេត្រុសបានពន្យល់អំពីការព្យាបាលបុរសខ្វិនចំពោះហ្វូងមនុស្ស ។ បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយនោះ សូមសួរ ៖


- តើពេត្រុសបានយកការសរសើរដាក់ខ្លួនឯង ចំពោះការព្យាបាលបុរសនោះឬទេ ?
- តើពេត្រុសនិយាយថា បុរសនេះត្រូវបានព្យាបាលដោយអំណាចអ្វី ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ពួកអ្នកបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ អាចធ្វើអព្ភូតហេតុតាមរយៈសេចក្តីជំនឿទៅលើព្រះនាមរបស់ទ្រង់**) ។

ចូរពន្យល់ថា ពេត្រុសបានប្រើស្ថានភាពនេះ ដើម្បីបង្រៀនមនុស្សអំពីព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានកាត់ទោសដល់សុគត ដោយរាស្ត្ររបស់ទ្រង់ក្នុងពេលថ្មីៗនោះ ប៉ុន្តែបានយកឈ្នះលើសេចក្តីស្លាប់តាមរយៈការរស់ឡើងវិញរបស់ទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ៣:១៧-២១ឲ្យឮៗ រួមទាំងការផ្លាស់ប្តូរក្នុងការបកប្រែដោយ យ៉ូសែប ស៊្មីធ ចំពោះ ខទី ១៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលការអញ្ជើញរបស់ពេត្រុសដល់ប្រជាជន ។

- តើពេត្រុសអញ្ជើញមនុស្សឲ្យធ្វើអ្វីខ្លះ ?

ដើម្បីជួយសិស្សយល់អំពីសារលិខិតរបស់ពេត្រុស សូមចង្អុលបង្ហាញថា ពេត្រុស កំពុងនិយាយទៅកាន់ប្រជាជន ដែលត្រូវបានស្រែក ឬយល់ព្រមចំពោះ ការឆ្កាងព្រះយេស៊ូវគ្រីស្ទ (សូមមើលកិច្ចការ ៣:១៤-១៥) ។ ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ៖



« [ពេត្រុស] ពុំបាននិយាយទៅពួកគេ ‹ ប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក សម្រាប់ការផ្តាច់បាបរបស់អ្នកទេ › ប៉ុន្តែគាត់បាននិយាយថា ‹ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឲ្យមានពេលលំហើយ មកពីចំពោះព្រះអម្ចាស់ › ។ [កិច្ចការ ៣:១៩] ។

« . . . ពួកគេពុំអាចត្រូវបានទទួលបុណ្យជ្រមុជទឹក សម្រាប់ការផ្តាច់បាបបានទេ ដ្បិតពួកគេបានបង្ហូរឈាមជនឥតទោស » (នៅក្នុង*History of the Church*៦:២៥៣) ។

កិច្ចការ ៣:១៩-២១

គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរនឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះ ដោយរៀបដាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

ចូរចង្អុលបង្ហាញឃ្លា « ប្រយោជន៍ឲ្យមានពេលលំហើយ មកពីចំពោះព្រះអម្ចាស់ ហើយឲ្យទ្រង់បានចាត់ព្រះយេស៊ូវគ្រីស្ទ » (ខទី ១៩-២០) ។

- តើអ្នកគិតថា ឃ្លានេះសំដៅទៅលើអ្វី ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« នៅក្នុងគ្រាដែលកំណត់នេះ *ពេលលំហើយ*នេះ គឺនឹងកើតឡើងនៅការយាងមកជាលើកទីពីររបស់កូនមនុស្ស នៅក្នុងថ្ងៃដែលព្រះអម្ចាស់បានបញ្ជូនព្រះគ្រីស្ទមកកាន់ផែនដីម្តងទៀត ។

« . . . វាគឺជាថ្ងៃដែល ‹ ផែនដីនឹងបានផ្លាស់ប្តូរសារជាថ្មី ហើយនឹងទទួលសិរីល្អដ៏ប្រកបដោយភាពបរមសុខ › ។ (មាត្រានៃសេចក្តីជំនឿទីដប់) ។ វាគឺជាថ្ងៃនៃ ‹ ផែនដីថ្មី › ដែលអេសាយបានមើលឃើញ (អេសាយ ៦៥:១៧) ផែនដីនឹងមានជ័យជំនះ នៅពេលសេចក្តីទុច្ចរិតបញ្ឈប់ នៅពេលដែលសម័យសហស្សវត្សរ៍បានចូលមកដល់ » (នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៦៧ ទំព័រ ៤៣) ។

ចូរដាក់បង្ហាញរូបភាពការយាងមកជាលើកទីពីរនៅលើក្តារខៀន (*Gospel Art Book* | ឆ្នាំ ២០០៩ | ទំព័រ ៦៦, សូមមើលផងដែរLDS.org) ។ សូមដាក់ស្លាកវាដោយការសរសេរ*ពេលលំហើយ*នៅលើក្តារខៀនជិតនឹងរូបភាពនោះ ។



- តើផែនដីនឹងជាពេលលំហើយក្នុងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ? (វានឹងបោសសម្អាតសេចក្តីទុច្ចរិត) ។

សូមចង្អុលបង្ហាញឃ្លា « គ្រាតាំងរបស់ទាំងអស់ឡើងវិញ » (ខទី ២១) ។

- តើអ្នកគិតថា « គ្រាតាំងរបស់ទាំងអស់ឡើងវិញ » សំដៅទៅលើអ្វី ? (អ្នកគប្បីចង្អុលបង្ហាញថាកិច្ចការ ៣:២១ដើម្បីជួយសិស្សឲ្យយល់ថា រឿងនេះសំដៅទៅលើការស្តារឡើងវិញនៃដំណឹងល្អនៅក្នុងថ្ងៃចុងក្រោយ ។ ព្រះយេស៊ូវគ្រីស្ទ នឹងបន្តគង់នៅស្ថានសួគ៌អំឡុងគ្រានៃការក្បត់សាសនា ដែលនឹងមក ប៉ុន្តែទ្រង់នឹងយាងត្រឡប់មកកាន់ផែនដីវិញ ដើម្បីនាំមកនូវការស្តារឡើងវិញនៃគ្រប់របស់ទាំងអស់ដែលទាក់ទងនឹងដំណឹងល្អ ។ អ្នកគប្បីចង្អុលបង្ហាញថា ពេត្រុសបានប្រើឃ្លា « គ្រាតាំងរបស់ទាំងអស់ឡើងវិញ » ដើម្បីពិពណ៌នាអំពីឧទាហរណ៍នានា ពេលព្រះយេស៊ូវគ្រីស្ទនឹងយាងមកផែនដីមុនការយាងមកជាលើកទីពីររបស់ទ្រង់ ។



- តើព្រះយេស៊ូវគ្រីស្ទបានយាងមកផែនដីនៅពេលណា ដែលជាផ្នែកនៃការស្តារឡើងវិញនូវដំណឹងល្អនៅថ្ងៃចុងក្រោយ ? (សិស្សអាចនឹងប្រាប់អំពីការយាងមករបស់ព្រះអង្គសង្គ្រោះ នៅក្នុងការនិមិត្តទីមួយរបស់ យ៉ូសែប ស៊្មីធ | សូមមើលយ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១៧| និងនៅព្រះវិហារបរិសុទ្ធខឺតឡង់ | សូមមើលគ. និង ស. ១១០:២-៥|) ។

ចូរដាក់បង្ហាញរូបភាពការនិមិត្តដំបូងនៅលើក្តារខៀន (*Gospel Art Book* ទំព័រ ៩០, សូមមើលផងដែរLDS.org) ។ សូមដាក់ស្លាកវាដោយការសរសេរ*គ្រាតាំងរបស់ទាំងអស់ឡើងវិញ*នៅលើក្តារខៀនជិតនឹងរូបភាពនោះ ។

- យោងតាមខទី ២១តើនរណាបាននិយាយបន្ថែមពីលើការនិយាយរបស់ពេត្រុស អំពីការស្តារឡើងវិញនូវដំណឹងល្អនាថ្ងៃចុងក្រោយ ? (ដោយការប្រើពាក្យផ្ទាល់របស់ពួកគេ សិស្សគួរតែប្រាប់នូវគោលលទ្ធិដូចខាងក្រោម ៖**ពួកព្យាការីនៅគ្រប់សម័យកាលទាំងអស់បានប្រាប់ទុកជាមុនពីការស្តារឡើងវិញ នៃដំណឹងល្អ**) ។

សូមសង្ខេបកិច្ចការ ៣:២២-២៦ដោយការពន្យល់ថា ពេត្រុសបានថ្លែងទីបន្ទាល់ថា ម៉ូសេ « អស់ទាំងហោរា ចាប់តាំងពីលោកសាំយូអែល គឺអស់អ្នកដែលបានទាយតមក » (ខទី ២៤) បានប្រាប់អំពីព្រះយេស៊ូវគ្រីស្ទ ហើយបានព្រមានអំពីផលវិបាកនៃការបដិសេធទ្រង់ (ខទី ២៣) ។

អ្នកគប្បីបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកថា ព្រះយេស៊ូវគ្រីស្ទ បានយាងមកផែនដីជាផ្នែកនៃការស្តារឡើងវិញនៃដំណឹងល្អនៅថ្ងៃចុងក្រោយ ហើយថាទ្រង់នឹងយាងត្រឡប់មកវិញ នៅការយាងមកជាលើកទីពីររបស់ទ្រង់ដើម្បីសម្អាតសេចក្តីទុច្ចរិតពីផែនដី ។

ចំណេះចំណានខគម្ពីរ—កិច្ចការ ៣:១៩-២១

ដើម្បីជួយសិស្សយល់អំពីរបៀបដើម្បីប្រើកិច្ចការ ៣:១៩-២១នៅក្នុងការផ្សព្វផ្សាយសាសនា សូមបង្ហាញពីស្ថានភាពដូចខាងក្រោម ៖ ហើយអ្នករៀនថ្មីបានសួរថា « តើនៅកន្លែងណាក្នុងព្រះគម្ពីរបឹប ស្តីពីដំណឹងល្អនឹងត្រូវបានស្តារឡើងវិញនៅថ្ងៃចុងក្រោយ ? »

សូមឲ្យសិស្សធ្វើការជាដៃគូ ។ ចូរសុំឲ្យដៃគូនីមួយៗរៀបចំចម្លើយមួយចំពោះសំណួរនេះ ដោយប្រើកិច្ចការ ៣:៩-២១និងយ៉ាងហោចណាស់វគ្គបទគម្ពីរបឹបមួយទៀត ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យមើលនៅត្រង់« ការស្តារឡើងវិញនៃដំណឹងល្អ »នៅក្នុង Topical Guide ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យដើរតួជាអ្នករៀនថ្មី ហើយម្នាក់ទៀតដើរតួជាអ្នកផ្សព្វផ្សាយសាសនានៅខាងមុខសិស្សក្នុងថ្នាក់ ។ ចូរសុំឲ្យដៃគូដើរតួជាអ្នកផ្សព្វផ្សាយសាសនា ដើម្បីចែកចាយចម្លើយដែលបានរៀបចំរបស់ពួកគេជាមួយនឹងសិស្ស ដែលកំពុងដើរតួជាអ្នករៀនថ្មី ។

កិច្ចការ ៤-៥

សេចក្តីផ្តើម

បន្ទាប់ពីការព្យាបាលបុរសខ្វិននៅព្រះវិហារបរិសុទ្ធ (សូមមើលកិច្ចការ ៣) នោះពេត្រុស និងយ៉ូហាន ត្រូវបានគេចាប់ខ្លួន ។ ពួកសាសនាហេទ្រីន បានបញ្ជាឲ្យពួកគេឈប់បង្រៀននៅក្នុងព្រះនាមនៃព្រះយេស៊ូវ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពួកសាវកបានបន្តផ្សាយដំណឹងល្អ ហើយព្យាបាលនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវដែរ ។ ពួកគេត្រូវបានចាប់ខ្លួនម្តងទៀត ហើយបានត្រូវវាយចំពោះការបដិសេធ ដើម្បីអនុវត្តតាមបញ្ជារបស់ពួកអ្នកដឹកនាំសាសន៍យូដា ។ សមាជិកសាសនាចក្របានរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ប៉ុន្តែមានពីរនាក់ក្នុងចំណោមពួកគេបានស្លាប់ដោយសារតែកុហកពេត្រុស និងព្រះ ។

សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ

សូមលើកទឹកចិត្តសិស្ស ឲ្យឆ្លៀតពេលរៀងរាល់ថ្ងៃ សម្រាប់ការសិក្សាផ្ទាល់ខ្លួនអំពីព្រះគម្ពីរសញ្ញាថ្មី ។ សូមជួយពួកគេឲ្យផ្តល់ព័ត៌មានលម្អិត ចំពោះការសិក្សាប្រចាំថ្ងៃរបស់ពួកគេ ដោយផ្តល់ប្រព័ន្ធតាមដានដ៏ត្រឹមត្រូវមួយ (សូមមើលតារាងការអាននៅក្នុងឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ) ។ សូមផ្តល់ឲ្យសិស្សនូវឱកាសជាទៀងទាត់ ដើម្បីចែកចាយអ្វីដែលពួកគេកំពុងរៀន និងមានអារម្មណ៍ ខណៈដែលពួកគេធ្វើការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ។ សូមប្រុងប្រយ័ត្ន កុំធ្វើឲ្យសិស្សដែលប្រឈមមុខនឹងបញ្ហាក្នុងការសិក្សាព្រះគម្ពីរ អៀនខ្មាស ឬបាក់ទឹកចិត្តឡើយ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ៤:១-៣១

សមាជិកនៃពួកសាន់ហេឌ្រីនបានបញ្ជាឲ្យពេត្រុស និងយ៉ូហានបញ្ឈប់បង្រៀននៅក្នុងព្រះនាមនៃព្រះយេស៊ូវ ។

ចូរសួមឲ្យសិស្សពិចារណាអំពីអ្វី ដែលពួកគេនឹងធ្វើនៅក្នុងស្ថានភាពដូចខាងក្រោម ៖

១. មិត្តភក្តិម្នាក់បានបង្ហោះអ្វីមួយ ដែលមិនពិតអំពីសាសនាចក្រនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។

២. គ្រូបង្វឹកដាក់កាលវិភាគប្រកួត ដែលតម្រូវឲ្យក្រុមរបស់អ្នកលេងនៅថ្ងៃអាទិត្យ ។

៣. មិត្តរបស់អ្នកបានសួរយោបល់អ្នកអំពីបញ្ហាខាងសង្គមមួយ ដែលរឿងនោះមានប្រជាប្រិយភាព និងមានការគាំទ្រជាទូទៅ ប៉ុន្តែវាផ្ទុយទៅនឹងការបង្រៀនរបស់សាសនាចក្រ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- **តើស្ថានភាពមួយចំនួនណាផ្សេងទៀត ដែលយើងអាចនឹងចាំបាច់ត្រូវចែកចាយ ឬការពារជំនឿរបស់យើង ?**
- **តើវាជាឧបសគ្គឬទេ ក្នុងការចែកចាយ ឬការការពារសេចក្តីជំនឿរបស់យើងនោះ ?**

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាកិច្ចការ ៤-៥ដែលអាចនឹងដឹកនាំពួកគេនៅក្នុងស្ថានភាពប្រភេទនេះ ។

សូមអញ្ជើញសិស្សឲ្យសង្ខេបអំពីអ្វី ដែលពួកគេចងចាំអំពីព្រឹត្តការណ៍ និងការបង្រៀននានា ដែលបានកត់ត្រានៅក្នុងកិច្ចការ ៣។ បើចាំបាច់ សូមរំឭកពួកគេថា បន្ទាប់ពីការព្យាបាលបុរសខ្វិនម្នាក់ ពេត្រុស និងយ៉ូហាន បានបង្រៀនក្រុមមនុស្សមួយក្រុម ដែលបានមករុំព័ទ្ធជុំវិញពួកគេនៅឯព្រះវិហារបរិសុទ្ធ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៤:១-៤ ឮៗ ។ ចូរសុំឲ្យសិស្សផ្សេងតាមរកមើលថាមានអ្វីបានកើតឡើងចំពោះពេត្រុស និងយ៉ូហាន នៅពេលពួកគាត់បានបង្រៀនមនុស្សនៅព្រះវិហារបរិសុទ្ធ ។

- **តើមានអ្វីបានកើតឡើងចំពោះពេត្រុស និងយ៉ូហាន ?**

សូមសង្ខេបកិច្ចការ៤:៥-៦ដោយពន្យល់ថា ពេត្រុស និងយ៉ូហាន ត្រូវបានគេចាប់ខ្លួន ហើយនាំទៅចំពោះមុខក្រុមប្រឹក្សាគ្រប់គ្រងរបស់ពួកសាសន៍យូដា ដែលហៅថាពួកសាន់ហេឌ្រីន (សូមមើល Bible Dictionary« Sanhedrin ») ។ សូមរំឭកសិស្សថា សមាជិកជាច្រើនរបស់ពួកសាន់ហេឌ្រីន បានចូលរួមក្នុងការចាប់ខ្លួន និងឆ្កាងព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៤:៧ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលសំណួរដែលអ្នកដឹកនាំយូដាបានសួរដល់ពេត្រុស និងយ៉ូហាន ។

- **តើពួកអ្នកដឹកនាំយូដាបានសួរអ្វីខ្លះដល់ពេត្រុស និងយ៉ូហាន ?**
- **តើមានអ្វីអាចកើតឡើងចំពោះពេត្រុស និងយ៉ូហាន ប្រសិនបើពួកគាត់បានបង្ហាញប្រាប់ថា ពួកគេជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ?**

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី កិច្ចការ ៤:៨-២១ ។ សូមអញ្ជើញសិស្សឲ្យរកមើលនូវអ្វី ដែលពេត្រុសបានប្រកាសដល់ពួកក្រុមប្រឹក្សា ។

ជំនួសការឲ្យសិស្សអានកិច្ចការ ៤:៨-២១សូមពិចារណាធ្វើការចាក់បង្ហាញវីដេអូ« Peter and John Are Judged »(២:៥១) ចេញមកពី*វីដេអូគម្ពីរប៊ីបអំពីជីវិតរបស់ព្រះយេស៊ូវគ្រីស្ទ* ។ វីដេអូនេះមាននៅក្នុង LDS.org ។

- **យោងតាមកិច្ចការ ៤:១០-១២តើសេចក្តីពិតណាខ្លះដែលពេត្រុសបានបង្រៀនដល់ក្រុមប្រឹក្សា ? (សិស្សគប្បីប្រាប់អំពីសេចក្តីពិតជាច្រើន ប៉ុន្តែចូរប្រាកដថា បានគូសបញ្ជាក់**ព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ គឺជាព្រះនាមតែមួយគត់ ដែលយើងអាចទទួលបានសេចក្តីសង្គ្រោះ**)។**
- **យោងតាមខទី ១៣ហេតុអ្វីក្រុមប្រឹក្សាមានចិត្តអស្ចារ្យចំពោះពេត្រុស និងយ៉ូហាន ?**

សូមអញ្ជើញសិស្សឲ្យរំឭកកិច្ចការ ៤:៨ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលមានឥទ្ធិពលដល់ពេត្រុស ហើយបានជួយគាត់ឲ្យនិយាយដោយអង់អាចទៅកាន់ក្រុមប្រឹក្សា ។

- តើអ្នកគិតថា ការណ៍ដែលត្រូវបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ បានជះឥទ្ធិពលដល់សមត្ថភាពរបស់ពេត្រុស ដើម្បីបង្រៀនដោយក្លាហានយ៉ាងដូចម្តេច ?
- តើគោលការណ៍ណាខ្លះ ដែលយើងអាចរៀនមកពីគំរូរបស់ពេត្រុស ដូចបានកត់ត្រានៅក្នុងខទី ៨ និងទី ១៣ ? (សិស្សអាចនឹងប្រើពាក្យផ្ទាល់ខ្លួនផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេប្រាប់នូវគោលការណ៍ដូចតទៅនេះ: **នៅពេលយើងបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចចែកចាយដំណឹងល្អដោយភាពក្លាហាន ។**

ចូរអញ្ជើញសិស្សឲ្យស្វែងរកមើលគំរូបន្ថែមទៀតអំពីគោលការណ៍នេះ: នៅពេលពួកគេបន្តសិក្សាកិច្ចការ ៤–៥ ។

- យោងតាមខទី ១៨តើក្រុមប្រឹក្សាបានបញ្ជាអ្វីខ្លះដល់ពេត្រុស និងយ៉ូហាន ?
- យោងតាមខទី ១៩-២០ តើពេត្រុស និងយ៉ូហាន បានឆ្លើយតបចំពោះបញ្ជារបស់ក្រុមប្រឹក្សាយ៉ាងដូចម្តេច ?

សូមសង្ខេបកិច្ចការ ៤:២៣-២៨ដោយពន្យល់ថា បន្ទាប់ពីពេត្រុស និងយ៉ូហានត្រូវបានគេដោះលែង នោះពួកគេបានជួបជុំនឹងពួកអ្នកជឿផ្សេងទៀត ហើយបានអធិស្ឋានជាមួយនឹងពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ៤:២៩-៣០ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវអ្វីដែលពួកអ្នកជឿបានទូលសូមពីព្រះ: ។

- តើពួកអ្នកជឿបានទូលសូមអ្វីខ្លះពីព្រះ: ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកិច្ចការ ៤:៣១ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលបានកើតឡើងបន្ទាប់ពីការអធិស្ឋានរបស់ពួកគេ ។

- តើមានអ្វីកើតឡើង បន្ទាប់ពីមនុស្សបានអធិស្ឋាន ?
- អាស្រ័យទៅលើខគម្ពីរទាំងនោះ: តើយើងអាចធ្វើអ្វីខ្លះ: ដើម្បីអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យជួយយើងថ្លែងពីព្រះបន្ទូលនៃព្រះដោយក្លាហាន ?

សូមយោងទៅលើស្ថានភាពមួយចំនួនដែលបានប្រាប់នៅដើមមេរៀន ។

- តើយើងអាចក្លាហាននៅក្នុងការចែកចាយដំណឹងល្អនៅក្នុងស្ថានភាពនានា ដូចជាស្ថានភាពទាំងនេះតាមរបៀបណា ?
- តើយើងអាចចែកចាយ និងការពារដំណឹងល្អជាមួយអ្នកដទៃដោយក្លាហាន ខណៈដែលយើងនៅតែផ្តល់ការគោរព ហើយភាពរាបសារបានយ៉ាងដូចម្តេច ?
- តើនៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធ បានជួយអ្នកឲ្យថ្លែងពីព្រះបន្ទូលនៃព្រះដោយក្លាហាន ?

កិច្ចការ ៤:៣២-៥:១១

សមាជិកនៃសាសនាចក្រស្រស់នៅតាមក្រឹត្យវិន័យនៃការថ្វាយ ប៉ុន្តែអាន្នាសា និងសាភីរ៉ា កុហកពេត្រុស ។

ចូរសុំឲ្យសិស្សគិតពិចារណាអំពីស្ថានភាពដូចខាងក្រោម ៖

១. ក្រុមយុវវ័យមួយក្រុម កំពុងរៀបដែនការធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជននៅព្រះវិហារបរិសុទ្ធ ។ សមាជិកម្នាក់ក្នុងក្រុមដឹងថា គាត់ចាំបាច់ត្រូវជួបនឹងប៊ីស្សពសុំបណ្ណ ប៉ុន្តែនាងក៏បានដឹងថា នាងបានធ្វើអំពើបាបមួយចំនួនដែលពុំទាន់បានសារភាព ។

២. ក្មេងប្រុសម្នាក់កំពុងរៀបចំខ្លួនបម្រើបេសកកម្ម ។ គាត់ដឹងថា ប៊ីស្សពនឹងសួរសំណួរអំពីភាពសក្តិសមរបស់គាត់ ដើម្បីបម្រើបេសកកម្ម ។ គាត់បានព្យាយាមរិះរកវិធីដើម្បីឆ្លើយសំណួរទាំងនោះ: ដោយពុំប្រាប់ប៊ីស្សពអំពីកំហុសមួយចំនួនដែលគាត់បានធ្វើខុស ។

សូមអញ្ជើញសិស្សឲ្យស្វែងរកគោលការណ៍មួយ នៅពេលពួកគេសិក្សាកិច្ចការ ៤:៣២-៥:១១ដែលអាចជួយពួកគេយល់អំពីសារៈសំខាន់នៃការស្មោះត្រង់ជាមួយនឹងអ្នកបម្រើរបស់ព្រះ: ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៤:៣២-៣៥ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាសមាជិកសាសនាចក្របានប្រើទ្រព្យសម្បត្តិរបស់ពួកគេធ្វើអ្វីខ្លះ: ។

- តើសមាជិកសាសនាចក្របានប្រើទ្រព្យសម្បត្តិរបស់ពួកគេធ្វើអ្វីខ្លះ: ?
- យោងតាមខទី ៣៤–៣៥ តើដំណើរការរបស់ពួកគេក្នុងការចែកចាយទ្រព្យខាងរូបកាយរបស់ពួកគេមានអ្វីខ្លះ: ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៥:១-២ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាគូស្វាមីភរិយាដែលបានរៀបការឈ្មោះ អាន្នាសា និងសាភីរ៉ា បានយកប្រាក់ដែលពួកគេបានទទួលមកពីការលក់ដីនោះទៅធ្វើអ្វី ។

- តើអាន្នាសា និងសាភីរ៉ា បានធ្វើអ្វីដែលជារឿងដ៏ធ្ងន់ធ្ងរនោះ: ?

សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ៥:៣-៤ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលថា ពេត្រុសបាននិយាយអ្វីទៅកាន់អាន្នាសា ។

- យោងតាមខទី ៤ តើទីបំផុតអាន្នាសាបានកុហកដល់នរណា ?
- ចេញមកពីចម្លើយរបស់ពេត្រុស តើគោលការណ៍អ្វីខ្លះ: ដែលយើងអាចរៀនអំពីការកុហកដល់អ្នកបម្រើរបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើសម្តីរបស់ពួកគេផ្ទាល់ ដើម្បីប្រាប់ពីគោលការណ៍ខាងក្រោមនេះ: **ប្រសិនបើយើងកុហកដល់ពួកអ្នកបម្រើរបស់ព្រះ: នោះដូចជាយើងកុហកដល់ទ្រង់ដែរ**)។
- ហេតុអ្វីក៏អ្នកគិតថា ការកុហកដល់ពួកអ្នកបម្រើរបស់ទ្រង់ គឺដូចគ្នានឹងការកុហកទ្រង់ដូច្នេះ: ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី កិច្ចការ ៥:៥-១១ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលបានកើតឡើងដល់ អាន្នាំនាស និងសាភីរ៉ា ជាលទ្ធផលនៃការបំពានលើសេចក្តីសញ្ញារបស់ពួកគេ និងការកុហកពេត្រុស ។

- តើមានអ្វីបានកើតឡើងចំពោះអាន្នាំនាស និងសាភីរ៉ា ?
- ទោះជាយើង ឬអ្នកទាំងឡាយដែលយើងស្គាល់ពុំជួបប្រទះនឹងផលវិបាកដ៏ធ្ងន់ធ្ងរ ឬវិបត្តិភ្លាមៗក្នុងការកុហកក្តី តើផលវិបាកមួយចំនួនដែលយើងអាចជួបប្រទះមានអ្វីខ្លះ បើយើងកុហកព្រះអម្ចាស់ ឬបំពានលើសេចក្តីសញ្ញារបស់យើងនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សូមឲ្យសិស្សស្តាប់មើលផលវិបាកមួយចំនួនដែលកើតមកពីភាពមិនស្មោះត្រង់ ៖

« នៅក្នុងជំនាន់របស់យើង អ្នកទាំងឡាយដែលរកឃើញថា មានភាពមិនស្មោះត្រង់ពុំស្លាប់ដូចជាអាន្នាំនាស និងសាភីរ៉ាទេ ប៉ុន្តែមានអ្វីមួយនៅក្នុងខ្លួនគេបានស្លាប់ ។ មនសិការត្រូវរងគ្រោះ ឥរិយាបថចុះទន់ខ្សោយ ការគោរពខ្លួនឯងត្រូវអន្តរាយ សេចក្តីសុចរិតត្រូវស្លាប់ » (« We Believe in Being Honest » *Ensign* ខែ តុលា ឆ្នាំ ១៩៩០ ទំព័រ ៤) ។

- ស្របតាមប្រធាន ហ៊ិងគ្លី តើផលវិបាកមួយចំនួននៃការកុហកមានអ្វីខ្លះ ? សូមយោងទៅលើស្ថានភាពមកពីដើមវគ្គនៃមេរៀននេះ ។
- តើបុគ្គលម្នាក់ៗនៅក្នុងស្ថានភាពទាំងនេះចាំបាច់ត្រូវដឹងអ្វីខ្លះ ដែលនឹងកើតឡើងចំពោះយើង ប្រសិនបើយើងកុហកដល់អ្នកដឹកនាំបព្វជិតភាព ?
- តើមានពរជ័យអ្វីខ្លះ ដែលកើតចេញមកពីការស្មោះត្រង់ជាមួយនឹងអ្នកបម្រើរបស់ព្រះអម្ចាស់ ?

កិច្ចការ ៥:១២-៤២

ពួកសាវកគឺត្រូវបានគេដាក់ក្នុងគុក ដោយសារការព្យាបាលនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ

ចូរសុំឲ្យសិស្សនឹកស្រមៃថា ពួកគេកំពុងរស់នៅក្នុងជំនាន់របស់ពេត្រុស និងយ៉ូហាន ហើយគឺជាអ្នកយកសារព័ត៌មានសម្រាប់កាសែតមួយ ។ ចូរពន្យល់ថា ពួកគេនឹងត្រូវបានអញ្ជើញឲ្យសិក្សាផ្នែកនៃកិច្ចការ ៥:១២-៣២រួចហើយសរសេរដើមរឿងសង្ខេបអំពីអ្វីបានកើតឡើង ។ (ដើម្បីផ្តល់បរិបទសម្រាប់វគ្គសិក្សាទាំងឡាយ សូមរំឭកសិស្សថា ពួកសាន់ហេឌ្រីនបានបញ្ជាដល់ពេត្រុស និងយ៉ូហានឲ្យឈប់និយាយនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទទៀត) ។ សូមធ្វើតាមការណែនាំ ដែលបានផ្តល់ឲ្យជាមួយនឹងបណ្តុំបទគម្ពីរនីមួយៗ ។

១. កិច្ចការ ៥:១២-១៦(សូមអានវគ្គគម្ពីរនេះជាថ្នាក់ ហើយសរសេរដើមរឿងជាមួយគ្នា) ។

២. កិច្ចការ ៥:១៧-២៣(ចូរសុំឲ្យសិស្សអានវគ្គគម្ពីរនេះជាមួយនឹងដៃគូ ហើយសរសេរដើមរឿង ។ សូមឲ្យដៃគូមួយចំនួន ចែកចាយដើមរឿងរបស់ពួកគេដល់សិស្សក្នុងថ្នាក់) ។

៣. កិច្ចការ ៥:២៤-៣២(ចូរសុំឲ្យសិស្សក្នុងថ្នាក់អានផ្សេងៗពីគ្នា ហើយសរសេរដើមរឿង ។ សូមឲ្យសិស្សមួយចំនួន ចែកចាយដើមរឿងរបស់ពួកគេដល់សិស្សក្នុងថ្នាក់) ។

បន្ទាប់ពីសិស្សចែកចាយដើមរឿងរបស់ពួកគេហើយ ចូរសួរថា

- យោងតាមខទី ២៩ហេតុអ្វីក៏ពេត្រុស និងពួកសាវកផ្សេងទៀត និយាយថា ពួកគេបានបន្តផ្សាយនៅក្នុងព្រះនាមនៃព្រះយេស៊ូវថ្វីបើមានបញ្ជាពីក្រុមប្រឹក្សាក្តី ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖*ប្រសិនបើយើងជ្រើសគោរពតាមព្រះជាងមនុស្ស នោះ* . . .

- ចេញមកពីអ្វីដែលអ្នកបានអាននៅក្នុងកិច្ចការ ៤-៥តើវិធីមួយចំនួន ដែលយើងអាចបំពេញសេចក្តីថ្លែងការណ៍នេះមានអ្វីខ្លះ ? (បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដូចតទៅ ៖**ប្រសិនបើយើងជ្រើសរើសគោរពតាមព្រះជាជាងមនុស្សនោះទ្រង់នឹងគង់នៅជាមួយយើង**) ។
- តើព្រះគង់នៅជាមួយនឹងពេត្រុស និងពួកសាវកដទៃទៀតដោយរបៀបណា នៅពេលពួកគេបានគោរពទ្រង់ជាជាងពួកក្រុមប្រឹក្សានោះ ? (ព្រះបានបំពេញពួកគេដោយព្រះវិញ្ញាណបរិសុទ្ធ | សូមមើលកិច្ចការ ៤:៨, ៣១| បានជួយពួកគេធ្វើអព្ភូតហេតុ | សូមមើលកិច្ចការ ៥:១២-១៦| ហើយបានបញ្ជូនទេវតារបស់ទ្រង់ដើម្បីរំដោះពួកគេពីក្នុងគុក | សូមមើលកិច្ចការ ៥:១៧-២១|) ។
- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានជ្រើសរើសគោរពតាមព្រះជាជាងមនុស្សនៅពេលណា ? តើព្រះបង្ហាញថាទ្រង់គង់នៅជាមួយអ្នក ឬបុគ្គលម្នាក់នេះដោយរបៀបណា ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗមកពីកិច្ចការ៥:៣៣-៤២ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាមរកឃើញគំរូបន្ថែមទៀតអំពីរបៀបដែលព្រះអម្ចាស់គង់នៅជាមួយពេត្រុស និងពួកសាវកដទៃទៀត ។

ជំនួសឲ្យសិស្សអានកិច្ចការ ៥:៣៣-៤២អ្នកអាចរំឭក ហើយសង្ខេបមាតិកាកិច្ចការ ៥:១២-៤២ដោយបង្ហាញវីដេអូ« ពេត្រុស និងយ៉ូហានបន្តផ្សាយដំណឹងល្អ »(៥:៣៨) ។ វីដេអូនេះមាននៅក្នុង LDS.org ។

សូមចង្អុលបង្ហាញថា យើងរៀននៅក្នុងកិច្ចការ ៥:៣៣ ថាក្រុមប្រឹក្សាព្យាយាមសម្លាប់ពេត្រុស និងយ៉ូហាន ។

- យោងតាម ខទី ៤១-៤២តើពួកសាវកបន្តស្មោះត្រង់ចំពោះព្រះអម្ចាស់ ក្នុងពេលប្រឈមមុខនឹងគំរាមកំហែងនេះយ៉ាងដូចម្តេច ? តើព្រះអម្ចាស់គង់នៅជាមួយពួកគេក្នុងគ្រានេះយ៉ាងដូចម្តេច ?
- តើសេចក្តីពិតដែលយើងបានសម្គាល់ឃើញ នៅក្នុងមេរៀននេះអាចជួយយើងនៅពេលយើងរស់នៅតាមដំណឹងល្អ ហើយចែកចាយវាជាមួយនឹងអ្នកនៅជុំវិញយើងយ៉ាងដូចម្តេច ?

សូមចែកចាយទីបន្ទាល់របស់អ្នក អំពីសេចក្តីពិតទាំងឡាយដែលបានបង្រៀននៅក្នុងថ្ងៃនេះ ។

មេរៀនសិក្សានៅផ្ទះ

កិច្ចការ ១-៥ (មេរៀនទី ១៧)

ការរៀបចំមេរៀនសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សរបស់អ្នកបានរៀននៅពេលពួកគេបានសិក្សា កិច្ចការ ១-៥ (មេរៀនទី ១៧) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និងគោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (កិច្ចការ ១-៨)

សិស្សបានចាប់ផ្តើមការសិក្សាពួកគេអំពីគម្ពីរកិច្ចការដោយរៀនថា ព្រះយេស៊ូវគ្រីស្ទដឹកនាំសាសនាចក្រទ្រង់តាមរយៈការបើកសម្តែងព្រះឆន្ទៈទ្រង់ដល់ពួកសាវកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយថាពួកសាវកគឺជាសាក្សីនៃព្រះយេស៊ូវគ្រីស្ទ ហើយថ្លែងទីបន្ទាល់អំពីទ្រង់ទៅកាន់ផែនដីទាំងមូល ។ បន្ទាប់មក សិស្សបានរៀនថា តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ យើងក៏អាចក្លាយជាសាក្សីនៃព្រះយេស៊ូវគ្រីស្ទបានផងដែរ ។ ឯកសារនៅក្នុងមេរៀននេះក៏ផ្តល់ដល់សិស្សនូវទិដ្ឋភាពទូទៅមួយនៃផ្នែកពាក់កណ្តាលទៀតនៃព្រះគម្ពីរសញ្ញាថ្មីដែរ ។

ថ្ងៃទី ២ (កិច្ចការ ១:៩-២៦)

នៅពេលសិស្សបានសិក្សាដំណើររឿងអំពីការយាងទៅស្ថានសួគ៌វិញរបស់ព្រះយេស៊ូវគ្រីស្ទ ពួកគេបានរៀនថា ការយាងមកជាលើកទីពីររបស់ទ្រង់ ព្រះអង្គសង្គ្រោះនឹងយាងចុះមកពីស្ថានសួគ៌នៅក្នុងសិរីល្អ ។ នៅពេលពួកគេបានអានអំពីរបៀបជ្រើសសាវកជំនួសតំណែងរបស់យូដាស នោះសិស្សបានរៀនថា ពួកសាវករបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានហៅដោយព្រះតាមរយៈវិវរណៈ ។

ថ្ងៃទី ៣ (កិច្ចការ ២)

នៅពេលសិស្សបានសិក្សាពីព្រឹត្តិការណ៍នានា នៅបុណ្យថ្ងៃទីហាសិប ពួកគេបានរកឃើញសេចក្តីពិតដូចខាងក្រោមនេះ ៖ នៅពេលយើងត្រូវបានបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ ទ្រង់នឹងជួយយើងបង្រៀន និងថ្លែងទីបន្ទាល់ទៅដល់អ្នកដទៃ នៅពេលយើងទទួលព្រះបន្ទូលព្រះតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះដួងចិត្តយើងនឹងផ្លាស់ប្តូរ ហើយយើងនឹងបានប្រែចិត្តជឿដល់ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលយើងមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយបានជ្រមុជទឹក យើងបានត្រៀមខ្លួនទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

ថ្ងៃទី ៤ (កិច្ចការ ៣-៥)

នៅពេលពេត្រុស និងយ៉ូហានបានព្យាបាលបុរសខ្វិនម្នាក់នៅព្រះវិហារបរិសុទ្ធ សិស្សបានរៀនថា ព្រះវរបិតាសួគ៌ប្រហែលនឹងមិនឆ្លើយតប ចំពោះការអធិស្ឋានរបស់យើងតាមវិធីដែលយើងចង់បាន ឬពេលចង់បានពីទ្រង់ឡើយ ប៉ុន្តែចម្លើយរបស់យើងតែងតែសម្រាប់សេចក្តីល្អបំផុតដល់យើងជានិច្ច ។ គោលការណ៍ផ្សេងទៀតដែលបានរៀននៅក្នុងមេរៀននេះ រួមមានដូចតទៅនេះ ៖ ពួកអ្នកបម្រើរបស់ព្រះយេស៊ូវគ្រីស្ទអាចធ្វើអព្ភូតហេតុតាមរយៈសេចក្តីជំនឿទៅលើព្រះនាមរបស់ទ្រង់ ពួកព្យាការីនៅគ្រប់សម័យកាលទាំងអស់បានប្រាប់ទុកជាមុនពីការស្តារឡើងវិញនៃដំណឹងល្អ ។ ប្រសិនបើយើងកុហកដល់ពួកអ្នកបម្រើរបស់ព្រះ នោះដូចជាយើងកុហកដល់ទ្រង់ដែរ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យស្គាល់ពីរបៀបដែលពួកគេអាចឆ្លើយដោយក្លាហាន នៅពេលពួកគេមានឱកាសចែកចាយ ឬ គាំទ្រដំណឹងល្អ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ៤:១-៣១

សមាជិកនៃពួកសាសនហេត្រីនបង្គាប់ឲ្យពេត្រុស និងយ៉ូហានឈប់បង្រៀននៅក្នុងព្រះនាមនៃព្រះយេស៊ូវទៀត ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា ពួកគេនឹងធ្វើអ្វីខ្លះនៅក្នុងស្ថានភាពខាងក្រោមនេះ (សូមពិចារណាសរសេរសេចក្តីរឿងទាំងនេះនៅលើក្តារខៀនពីមុនថ្នាក់ចាប់ផ្តើម) ៖

១. មានមិត្តម្នាក់ចុះផ្សាយរឿងមិនពិតមួយអំពីសាសនាចក្រលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។

២. មានគ្រូបង្វឹកម្នាក់បានដាក់កាលវិភាគការប្រកួតយកពានរង្វាន់មួយ ដែលតម្រូវឲ្យក្រុមរបស់អ្នកលេងនៅថ្ងៃអាទិត្យ ។

៣. មិត្តរបស់អ្នកសាកសួរមតិអ្នកអំពីបញ្ហាសង្គមមួយដែលពេញនិយម ហើយមានមនុស្សទូទៅគាំទ្រ ប៉ុន្តែវាផ្ទុយទៅនឹងការបង្រៀនរបស់សាសនាចក្រ ។

បន្ទាប់ពីផ្តល់ពេលឲ្យសិស្សសញ្ជឹងគិតគ្រប់គ្រាន់ហើយ សូមសួរដូចតទៅនេះ ៖

- តើមានកាលៈទេសៈមួយចំនួនណាផ្សេងទៀតដែលយើងត្រូវចែកចាយ ឬគាំទ្រសេចក្តីជំនឿយើងនោះ ?

នៅពេលសិស្សសិក្សា កិច្ចការ ៤–៥ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតនានា ដែលអាចដឹកនាំពួកគេនៅក្នុងស្ថានភាពទាំងនេះ ។

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនៅក្នុង កិច្ចការ ៤សូមអញ្ជើញពួកគេឲ្យចងចាំពីព្រឹត្តិការណ៍ និងការបង្រៀនទាំងឡាយនៅក្នុង កិច្ចការ ៣ ។ (នៅឯព្រះវិហារបរិសុទ្ធ ពេត្រុស និងយ៉ូហានបានព្យាបាលបុរសខ្វិនម្នាក់តាំងពីកំណើត ហើយបានបង្រៀនអំពីព្រះយេស៊ូវ) ។

សូមសង្ខេប កិច្ចការ ៤:១–៦ ដោយពន្យល់ថា ពេត្រុស និងយ៉ូហានត្រូវបានគេចាប់ខ្លួនដោយសារទង្វើទាំងនេះ ហើយបាននាំទៅជួបនឹងពួកសានហេទ្រីន ដែលជាក្រុមប្រឹក្សាពួកសាសន៍យូដា ។ សូមរំឭកសិស្សថា មានសមាជិកជាច្រើនរបស់ពួកសានហេទ្រីនធ្លាប់ចូលរួមនឹងការចាប់ព្រះកាយ និងការឆ្កាងព្រះអង្គសង្គ្រោះកាលពីមុន ។

សូមអញ្ជើញសិស្សម្នាក់អាន ម៉ាថាយ ៤:៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលសំណួរដែលពួកអ្នកដឹកនាំសាសន៍យូដាបានចោទសួរដល់ពេត្រុស និងយ៉ូហាន ។

- តើពួកអ្នកដឹកនាំសាសន៍យូដាបានចោទសួរអ្វីខ្លះដល់ពេត្រុស និងយ៉ូហាន ?
- តើអាចមានអ្វីកើតឡើងដល់ពេត្រុស និងយ៉ូហាន ប្រសិនបើពួកគាត់បាននិយាយប្រាប់ថា ខ្លួនគឺជាពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទនោះ ?

ចូរសុំឲ្យសិស្សពិចារណាពីអារម្មណ៍ ដែលពួកគេអាចមាន ប្រសិនបើពួកគេស្ថិតនៅក្នុងស្ថានភាពរបស់ពេត្រុស និងយ៉ូហាន ហើយថាពួកគេនឹងនិយាយអ្វីខ្លះទៅក្រុមប្រឹក្សានោះ ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង កិច្ចការ ៤:៨-២១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ពេត្រុសបានប្រកាសអ្វីខ្លះដល់ក្រុមប្រឹក្សានោះ ។

ជំនួសឲ្យការអញ្ជើញសិស្សអាន កិច្ចការ ៤:៨-២១សូមពិចារណាបង្ហាញវីដេអូ « Peter and John Are Judged » (២:៥១) នៅក្នុង *The Life of Jesus Christ Bible Videos* ។ វីដេអូនេះបង្ហាញពីព្រឹត្តិការណ៍នៅក្នុងកិច្ចការ ៤:៨–២១ ។ វាមាននៅក្នុង LDS.org ។

- យោងតាម កិច្ចការ ៤:១៣ហេតុអ្វីក្រុមប្រឹក្សានោះមានចិត្តស្ងប់ស្ងែងដល់ពេត្រុស និងយ៉ូហាន ?

សូមអញ្ជើញសិស្សឲ្យរំឭក កិច្ចការ ៤:៨ ឡើងវិញដោយស្ងៀមស្ងាត់ រកមើលអ្វីដែលបានជះឥទ្ធិពលដល់ពេត្រុស ហើយបានជួយគាត់ឲ្យថ្លែងដោយភាពក្លាហានទៅកាន់ក្រុមប្រឹក្សានោះ ។

- តើអ្នកគិតថាការពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធបានជះឥទ្ធិពលដល់លទ្ធភាពរបស់ពេត្រុសក្នុងការបង្រៀនដំណឹងល្អដោយភាពក្លាហានយ៉ាងដូចម្តេចដែរ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីគំរូរបស់ពេត្រុស ដូចដែលបានកត់ត្រានៅក្នុង ខទី ៨ និង ១៣ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីគោលការណ៍មួយ ដែលស្រដៀងនឹងគោលការណ៍ដូចតទៅនេះនេះ ៖ **នៅពេលយើងបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចចែកចាយដំណឹងល្អដោយភាពក្លាហាន ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- យោងតាម កិច្ចការ ៤:១៨ហេតុអ្វីក្រុមប្រឹក្សានោះចេញសេចក្តីបង្គាប់អ្វីខ្លះដល់ពេត្រុស និងយ៉ូហាន ?
- យោងតាម ខទី ១៩–២០តើពេត្រុស និងយ៉ូហានបានឆ្លើយតបយ៉ាងដូចម្តេច ?

សូមសង្ខេប កិច្ចការ ៤:២៣–៣០ ដោយពន្យល់ថា បន្ទាប់ពីពេត្រុស និងយ៉ូហានបានដោះលែងខ្លួនមក ពួកគាត់បានប្រមូលផ្តុំនឹងពួកអ្នកជឿផ្សេងទៀត ហើយបានអធិស្ឋានជាមួយនឹងពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៤:៣១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា បន្ទាប់ពីការអធិស្ឋានរបស់ពួកគេ តើមានអ្វីបានកើតឡើង ។

- តើមានអ្វីកើតឡើង បន្ទាប់ពីមនុស្សបានអធិស្ឋាន ?
- ចំពោះរឿងដែលយើងបានរៀននៅក្នុងខគម្ពីរនេះ តើយើងអាចធ្វើអ្វីខ្លះដើម្បីអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យជួយយើង ថ្លែងព្រះបន្ទូលព្រះដោយភាពក្លាហាន ?

សូមលើកឡើងពីស្ថានភាពមួយចំនួននៅដើមមេរៀននេះ ។

- តើយើងអាចមានភាពក្លាហានក្នុងការចែកចាយដំណឹងល្អនៅក្នុងស្ថានភាពដូចជាស្ថានភាពទាំងនេះដោយនៅតែមានការគោរព និងតាមផ្លូវរដ្ឋបានដោយរបៀបណា ? (សូមមើល អាលម៉ា ៣៨:១២អ្នកគួរពន្យល់ថា ការមានភាពក្លាហានក្នុងការចែកចាយដំណឹងល្អមានន័យថា យើងចែកចាយអ្វីដែលយើងដឹងថាពិតដោយមានទំនុកចិត្ត ប៉ុន្តែយើងធ្វើវាដោយភាពរាបសា និងការគោរពដល់មនុស្សជាទៃ ដែលគិត ឬមានអារម្មណ៍ខុសពីយើង) ។
- តើព្រះវិញ្ញាណបរិសុទ្ធធ្លាប់ជួយអ្នកឲ្យថ្លែងពីព្រះបន្ទូលនៃព្រះ ដោយភាពក្លាហាននៅពេលណាដែរ ?
- តើអ្នកបានដឹងថា ព្រះវិញ្ញាណបរិសុទ្ធបានជួយអ្នកតាមរបៀបណា ?

កិច្ចការ ៥:១២-៤២

ពួកសាវកត្រូវបានគេចាប់ជាក់ឃុំឃាំង ដោយសារការព្យាបាលនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។

ចូរសុំឲ្យសិស្សនឹកស្រមៃថា ពួកគេកំពុងរស់នៅក្នុងសម័យរបស់ពេត្រុស និងយ៉ូហាន ហើយគឺជាអ្នករាយការណ៍សម្រាប់សារព័ត៌មាន *Jerusalem Times* ។ សូមពន្យល់ថា ពួកគេនឹងត្រូវបានអញ្ជើញឲ្យសិក្សាផ្នែកនៃ កិច្ចការ ៥:១២–៣២ រួចហើយសរសេរព័ត៌មានមួយដោយសង្ខេបរឿងដែលបានកើតឡើង ។ (ដើម្បីផ្តល់ជាបរិបទចំពោះសារលិខិតទាំងនេះ សូមរំឭកសិស្សថា ពួកសានហេឌ្រីនបានបង្គាប់ពេត្រុស និងយ៉ូហានឲ្យឈប់និយាយនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ) ។ សូមធ្វើតាមសេចក្តីណែនាំដែលបានផ្តល់ឲ្យ ជាមួយនឹងខគម្ពីរនីមួយៗ ។

១. កិច្ចការ ៥:១២–១៦ (សូមអានខគម្ពីរនេះទាំងអស់គ្នា ហើយសរសេរព័ត៌មានមួយរួមគ្នា) ។

២. កិច្ចការ ៥:១៧–២៣ (សុំឲ្យសិស្សអានខគម្ពីរនេះជាមួយនឹងដៃគូម្នាក់ ហើយសរសេរព័ត៌មានមួយ ។ សូមអញ្ជើញដៃគូមួយចំនួនឲ្យចែកចាយព័ត៌មានខ្លួនដល់សិស្សក្នុងថ្នាក់) ។

៣. កិច្ចការ ៥:២៤-៣២ (សុំឲ្យសិស្សអានខគម្ពីរនេះរៀង២ខ្លួន ហើយសរសេរព័ត៌មានមួយ ។ សូមអញ្ជើញសិស្សមួយចំនួនឲ្យ ចែកចាយព័ត៌មានខ្លួនដល់សិស្សក្នុងថ្នាក់) ។

បន្ទាប់ពីសិស្សចែកចាយព័ត៌មានខ្លួនរួចហើយ សូមសួរ ៖

- យោងតាម កិច្ចការ ៥:២៩ហេតុអ្វីពេត្រុស និងពួកសាវកផ្សេងទៀតបានពោលថា ពួកគាត់បានបន្តប្រកាសនៅក្នុងព្រះនាមរបស់ព្រះយេស៊ូវ ទោះជាមានសេចក្តីបង្គាប់មកពីក្រុមប្រឹក្សានោះយ៉ាងណាក៏ដោយ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *ប្រសិនបើយើងជ្រើសគោរពតាមព្រះជាងមនុស្ស នោះ . . .*

- ចំពោះរឿងដែលយើងបានអាននៅក្នុង កិច្ចការ ៤–៥តើវិធីមួយចំនួនដែលយើងអាចបំពេញឃ្លានេះមានអ្វីខ្លះ ? (បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដូចតទៅ ៖**ប្រសិនបើយើងជ្រើសរើសគោរពតាមព្រះជាជាងមនុស្សនោះទ្រង់នឹងគង់នៅជាមួយយើង) ។**
- តើព្រះបានគង់នៅជាមួយនឹងពេត្រុស និងពួកសាវកផ្សេងទៀត កាលពួកគាត់គោរពតាមទ្រង់ជាងក្រុមប្រឹក្សានោះតាមរបៀបណាខ្លះ? (ព្រះបានបំពេញពួកគាត់ដោយព្រះវិញ្ញាណបរិសុទ្ធ [សូមមើល កិច្ចការ ៤:៨, ៣១]ដោយផ្តល់លទ្ធភាពឲ្យពួកគាត់ធ្វើអត្ថុតហេតុនានា [សូមមើល កិច្ចការ ៥:១២–១៦] ហើយបានបញ្ជូនទេវតារបស់ ទ្រង់ឲ្យនាំពួកគាត់ចេញពីទីឃុំឃាំង [សូមមើល កិច្ចការ ៥:១៧–២០]) ។
- តើអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់ធ្លាប់ជ្រើសរើសគោរពតាមព្រះជាងមនុស្សនៅពេលណា ? តើព្រះបានបង្ហាញថា ទ្រង់បានគង់នៅជាមួយនឹងអ្នក ឬបុគ្គលនោះតាមរបៀបណា ?

ចូរសុំឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអាននៅក្នុង កិច្ចការ ៥:៣៣-៤២ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលគំរូបន្ថែមទៀតអំពីរបៀបដែលព្រះអម្ចាស់បានគង់នៅជាមួយនឹងពេត្រុស និងពួកសាវកផ្សេងទៀត ។

ជំនួសឲ្យការអញ្ជើញសិស្សអាន កិច្ចការ ៥:៣៣–៤២អ្នកអាចរំឭកឡើងវិញ ហើយសង្ខេបពីមាតិការបស់ កិច្ចការ ៥:១២–៤២ ដោយបង្ហាញវីដេអូ « Peter and John Continue Preaching the Gospel » (៥:៣៨) ។ វីដេអូនេះមាននៅក្នុង LDS.org ។

សូមចង្អុលបង្ហាញថា យើងបានរៀននៅក្នុង កិច្ចការ ៥:៣៣ ថា ក្រុមប្រឹក្សានោះបានចង់សម្លាប់ពេត្រុស និងយ៉ូហាន ។

- យោងតាម ខទី ៤១–៤២តើពួកសាវកបានបន្តស្មោះត្រង់ចំពោះព្រះអម្ចាស់ទោះជាមានការគម្រាមកំហែងនេះបានដោយរបៀបណា ? តើព្រះអម្ចាស់បានគង់នៅជាមួយនឹងពួកគាត់នៅគ្រានោះតាមរបៀបណា ?
- តើសេចក្តីពិតដែលយើងបានស្គាល់ នៅក្នុងមេរៀននេះអាចជួយយើង នៅពេលយើងខិតខំរស់នៅតាមដំណឹងល្អ ហើយចែកចាយវាជាមួយអស់អ្នក ដែលនៅជុំវិញយើងបានដោយរបៀបណា ?

សូមចែកចាយទីបន្ទាល់ពីសេចក្តីពិតដែលបានបង្រៀននៅថ្ងៃនេះ ហើយអញ្ជើញសិស្សឲ្យអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនបន្ទាប់ (កិច្ចការ ៦-១២)

ចូរសួរដល់សិស្សថា មនុស្សដែលបានស្លាប់ដោយត្រូវបានធ្វើឃាតដោយដំណឹងល្អមានប៉ុន្មាននាក់ដែលពួកគេគិតឃើញ ។ សូមពន្យល់ថា នៅពេលពួកគេសិក្សា កិច្ចការ ៦–១២ នៅសប្តាហ៍ក្រោយ ពួកគេនឹងរៀនអំពីទុក្ករបុគ្គលពីររូបដ៏ក្លាហានសម្រាប់ព្រះយេស៊ូវគ្រីស្ទ ៖បុគ្គលម្នាក់ជាពួកចិតសិបនាក់ ហើយម្នាក់ទៀតគឺជាសាវកម្នាក់ ។ ចូរសុំឲ្យសិស្សគិតពិចារណាអំពីសំណួរខាងក្រោម ៖ ហេតុអ្វីការនិមិត្តរបស់ពេត្រុសស្តីពីកូនលៀសមានសារៈសំខាន់ខ្លាំងម្ល៉េះដល់សាសនាចក្រ ? តើមានអ្វីបានកើតឡើងចំពោះសូល (ក៏ស្គាល់ថាជាប៉ុល) ដែលបានផ្លាស់ប្តូរជីវិតរបស់គាត់ ? តើគាត់ខ្វាក់ភ្នែកដោយរបៀបណា ហើយតើព្រះអម្ចាស់បានដឹកនាំនរណាឲ្យទៅធ្វើភ្នែកគាត់ឲ្យមើលឃើញវិញតាមរបៀបណា ?

កិច្ចការ ៦-៧

សេចក្តីផ្តើម

ពួកសាវកបានតែងតាំងពួកសិស្សប្រាំពីរនាក់ដើម្បីជួយក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ ស្តេផានជាសិស្សម្នាក់ដែលបានជ្រើសរើស បានសម្តែងអព្ភូតហេតុជាច្រើន ។ ពួកយូដាមួយចំនួនបានចោទលោកថាបានប្រមាថព្រះ ហើយបាននាំគាត់ទៅចំពោះមុខពួកសាសន៍ហេព្រើន ជាកន្លែងដែលគាត់បានប្រែរូប ។ បន្ទាប់ពីបានវាយផ្តាលដល់ពួកសាសន៍យូដាចំពោះការបដិសេធព្រះអង្គសង្គ្រោះមក ស្តេផានបានឃើញព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់មកគេបានបណ្តេញលោកចេញពីទីក្រុង ហើយចោលដុំថ្មដាក់លោកហូតដល់ស្លាប់ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ៦:១-៨

ពួកសិស្សប្រាំពីរនាក់ត្រូវបានជ្រើសរើសដើម្បីជួយពួកសាវកនៅក្នុងកិច្ចការ

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់នៅក្នុងគ្រួសារ វួដ ឬសហគមន៍របស់ពួកគេ ដែលមានបញ្ហាខាងសាច់ឈាមឬ តម្រូវការជាក់លាក់ ។

- **តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលអ្នកគិតអំពីបុគ្គលម្នាក់នេះ ឬគិតអំពីស្ថានភាពរបស់គាត់នោះ ?**
- **តើអ្នកគិតថា ព្រះវរបិតាសួគ៌មានព្រះទ័យបែបណាដែរ ចំពោះបុគ្គលទាំងនេះម្នាក់ៗ ?**

នៅពេលពួកគេសិក្សាកិច្ចការ ៦:១-៨សូមអញ្ជើញសិស្សឲ្យរកមើលរបៀបដែលព្រះអម្ចាស់បានប្រទានឲ្យ ដើម្បីបំពេញតាមតម្រូវការរបស់កូនចៅទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៦:១-២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវកង្វល់ដែលពួកសាសន៍ក្រិក បាននាំមកឲ្យពួកសាវកចាប់អារម្មណ៍ ។ ពួកសាសន៍ក្រិក « គឺជាពួកគ្រីស្ទានសាសន៍យូដាដែលនិយាយភាសាក្រិក » និងពួកហេព្រើរ « ជាពួកគ្រីស្ទានសាសន៍យូដាដែលមកពីប៉ាលេស្ទីន » (*New Testament Student Manual* | Church Educational System manual **ឆ្នាំ ២០១៤ | ទំព័រ ២៨៨) ។**

- **តើពួកបរិសុទ្ធសាសន៍ក្រិកមានកង្វល់អ្វីខ្លះ ?**

ចូរពន្យល់ថានៅគ្រានេះ សាសនាចក្រកំពុងរីកចម្រើនយ៉ាងលឿន ហើយតម្រូវការខាងសាច់ឈាមរបស់មនុស្សជាច្រើន រួមទាំងស្ត្រីមេម៉ាយក៏មានច្រើនផងដែរ ។ ដោយសារតែពួកសាវកមានការទទួលខុសត្រូវចំពោះការផ្សាយដំណឹងល្អទៅដល់ « គ្រប់ជាតិសាសន៍ » (ម៉ាថាយ ២៨:១៩) នោះពួកលោកពុំអាចយកចិត្តទុកដាក់ដោយផ្ទាល់ចំពោះតម្រូវការរបស់សមាជិកសាសនាចក្រគ្រប់រូបនោះបានទេ ។

សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី កិច្ចការ ៦:៣-៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀប ដែលពួកសិស្សបានដោះស្រាយបញ្ហានេះ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- **តើអស់អ្នកដែលត្រូវបានជ្រើសរើសគួរមានគុណសម្បត្តិអ្វីខ្លះ ដើម្បីជួយក្នុងពេលមានតម្រូវការកើនឡើងក្នុងសាសនាចក្រ ដើម្បីសក្តិសមក្នុងការហៅនេះ ? (អ្នកអាចនឹងចង់ផ្តល់យោបល់ឲ្យសិស្សគូសចំណាំឃ្លានៅក្នុងខទី ៣ និងទី ៥ដែលពិពណ៌នាអំពីគុណសម្បត្តិទាំងនេះ) ។**
- **តើដំណើរការនេះស្រដៀងគ្នានឹងអ្វី ដែលព្រះអម្ចាស់បានធ្វើនៅក្នុងសាសនាចក្រនាពេលសព្វថ្ងៃនេះដើម្បីប្រាកដថា បានបំពេញតាមតម្រូវការរបស់សមាជិកនោះដូចម្តេចខ្លះ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ សមាជិកសាសនាចក្រមានភាពសក្តិសម ត្រូវបានហៅឲ្យជួយក្នុងការបម្រើដើម្បីបំពេញតម្រូវការរបស់អ្នកដទៃ) ។**

សូមអញ្ជើញសិស្សប៉ុន្មាននាក់ឲ្យមកកាន់ក្តារខៀន ហើយសរសេរអំពីការហៅក្នុងសាសនាចក្រ ។ ចំពោះការហៅមួយចំនួនដែលពួកគេបានសរសេរ ចូរសួរ ៖

- **តើមនុស្សដែលបានបម្រើដោយស្មោះត្រង់នៅក្នុងការហៅនេះ បម្រើឲ្យតម្រូវការរបស់នរណា ?**
- **ហេតុអ្វីអ្នកគិតថា វាសំខាន់ចំពោះមនុស្ស ដែលត្រូវបានហៅឲ្យជួយបម្រើដល់សេចក្តីត្រូវការរបស់អ្នកដទៃ ត្រូវមានគុណសម្បត្តិដែលបានរៀបរាប់នៅក្នុងខទី ៣ និងទី ៥?**

សូមឲ្យសិស្សអាន កិច្ចការ ៦:៧-៨ ដោយស្ងៀមស្ងាត់ ។ អ្នកគប្បីផ្តល់យោបល់ឲ្យពួកគេគូសចំណាំលទ្ធផលវិជ្ជមាន ដែលកើតមកពីការហៅរបស់ពួកសិស្សទាំងប្រាំពីរនាក់បម្រើដល់អ្នកដទៃ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ប្រើប្រាស់កម្មវិធីសិក្សា

នៅពេលអ្នករៀបចំមេរៀនមួយ ចូរមើលកម្មវិធីសិក្សាប្រកបដោយការអធិស្ឋានព្រមជាមួយនឹងការសិក្សារបស់អ្នកអំពីបណ្តុំខគម្ពីរ ។ នៅពេលអ្នកធ្វើដូច្នេះ នោះព្រះវិញ្ញាណបរិសុទ្ធអាចជួយអ្នកឲ្យរៀបចំមេរៀនដែលស្របតាមសេចក្តីត្រូវការសិស្សរបស់អ្នក ។ អ្នកអាចជ្រើសរើសប្រើប្រាស់យោបល់ណែនាំក្នុងការបង្រៀន សម្រាប់បណ្តុំបទគម្ពីរ ឬអ្នកអាចកែសម្រួលគំនិតដែលបានណែនាំ ទៅតាមតម្រូវការក្នុងថ្នាក់រៀនរបស់អ្នក ។

កិច្ចការ ៦:៩-៧:៥៣

ស្ទេផានត្រូវបាននាំទៅមុខពួកសានហេទ្រិន ហើយថ្លែងទីបន្ទាល់ថាពួកគេបានបដិសេធព្រះវិមសិ៍ហើយ

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យក្រោកឈរ ហើយបង្ហាញថាវាដូចម្តេច ប្រសិនបើពួកគេព្យាយាមមិនព្រមទទួលជំនួយរបស់មនុស្សផ្សេងក្នុងស្ថានភាពដូចខាងក្រោម ទោះជាពួកគេត្រូវការជំនួយក្តីដូចជា ៖ ធ្វើកិច្ចការសាលា ចម្អិនអាហារ ដោះស្រាយបញ្ហាធំមួយនៅក្នុងជីវិតរបស់ពួកគេ ។

- ហេតុអ្វីក៏ពេលខ្លះយើងបដិសេធជំនួយរបស់អ្នកដទៃ ?
- តើលទ្ធផលអ្វីខ្លះអាចនឹងកើតមាន មកពីការមិនព្រមទទួលជំនួយរបស់អ្នកដទៃ ?

សូមចង្អុលបង្ហាញថា របៀបមួយដែលព្រះវរបិតាសួគ៌ជួយយើង គឺតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យរកមើលនៅពេលពួកគេសិក្សាកិច្ចការ ៦:៩-៧:៥៣អំពីលទ្ធផលនៃការបដិសេធព្រះវិញ្ញាណបរិសុទ្ធ ។

ចូរពន្យល់ថា ដូចបានកត់ត្រានៅក្នុងកិច្ចការ ៦:៩មនុស្សជាច្រើនដែលពុំជឿទៅលើព្រះយេស៊ូវគ្រីស្ទ បានជំទាស់នឹងស្ទេផាន នៅពេលគាត់បានបង្រៀនដំណឹងល្អ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៦:១០-១១ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាហេតុអ្វីបានជាអស់អ្នកដែលមានជម្លោះជាមួយនឹងស្ទេផាន បានរងឥទ្ធិពលពីគាត់ ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ពាក្យ *បានសូក*នៅក្នុង*ខ ១១*មានន័យថា សូកប៉ាន់ ។

- តើមនុស្សដែលមានជម្លោះនឹងស្ទេផាន បានរងឥទ្ធិពលដោយសារការបង្រៀនរបស់គាត់យ៉ាងដូចម្តេច ?
- តើស្ទេផានត្រូវបានគេចោទអំពីរឿងអ្វី ?

សូមសង្ខេបកិច្ចការ ៦:១២-១៤ដោយពន្យល់ថា ស្ទេផាន ត្រូវបាននាំមកខាងមុខពួកក្រុមប្រឹក្សាគ្រប់គ្រងសាសន៍យូដា ដែលហៅថាពួកសានហេទ្រិន ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៦:១៥ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលខុសប្រក្រតីអំពីរូបកាយរបស់ស្ទេផាន នៅពេលគាត់ឈរនៅចំពោះក្រុមប្រឹក្សា ។

- តើអ្នកគិតថាឃ្លា ស្ទេផានមាន « មុខដូចជាមុខទេវតា » មានន័យយ៉ាងណា ? (ខ ១៥) ។ (ស្ទេផានបានប្រែរូប ។ ការប្រែរូបដ៏បរិសុទ្ធនេះ គឺជារបៀបមួយដែលព្រះបានបង្ហាញដល់ប្រជាជនថា ទ្រង់បានអនុមតិដល់ស្ទេផាន និងសារលិខិតរបស់គាត់ ។ [សូមមើល ប្រ៊ូស អ័រ ម៉ាក់ខនំឃី *Doctrinal New Testament Commentary* វុំលទី ៣ [ស្តាំ ១៩៦៥–៧៣ [២:៦៧]) ។

សូមសង្ខេបកិច្ចការ ៧:១-៥០ដោយពន្យល់ថា នៅក្នុងការឆ្លើយតបចំពោះការចោទប្រកាន់ទាស់នឹងគាត់ នោះស្ទេផានបានរៀបរាប់អំពីប្រវត្តិរបស់អ៊ីស្រាអែលមួយចំនួន ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៧:៣៥-៣៩ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលស្ទេផានបាននិយាយអំពីការព្យាបាលរបស់ព្យាការីម៉ូសេដល់ពួកអ៊ីស្រាអែលជំនាន់បុរាណ ។

- ស្របតាមខ ៣៥តើកូនចៅនៃអ៊ីស្រាអែលបានឆ្លើយតបចំពោះម៉ូសេយ៉ាងដូចម្តេច នៅពេលគាត់មករំដោះពួកគេចេញពីអេស៊ីព្ទ ?
- តើពួកគេឆ្លើយតបចំពោះម៉ូសេយ៉ាងដូចម្តេច ថ្វីបើបន្ទាប់ពីគាត់បានរំដោះពួកគេឲ្យរួចហើយនោះ (សូមមើលខ ៣៩) ?

សូមរំឭកសិស្សថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្យាការីដែលម៉ូសេបានព្យាករ (សូមមើលខ ៣៧) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៧:៥១-៥៣ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលស្ទេផាន បានប្រៀបធៀបពួកអ្នកដឹកនាំយូដានៃជំនាន់របស់គាត់ ទៅនឹងពួកសាសន៍អ៊ីស្រាអែលជំនាន់ដើមដែលគាត់បានពិពណ៌នា ។

- ស្របតាមខ ៥១តើពួកអ្នកដឹកនាំយូដាក្នុងជំនាន់ស្ទេផាន ស្រដៀងគ្នានឹងពួកអ៊ីស្រាអែលពីបុរាណ ដែលគាត់បានពិពណ៌នាយ៉ាងដូចម្តេចខ្លះ ? (ពួកគេទាំងពីរ គឺបានទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ ។ សូមពន្យល់ថា « ពួកមនុស្សក្បាលរឹង ដែលមានចិត្តមានត្រចៀកមិនកាត់ស្បែកអើយ » សំដៅទៅលើដួងចិត្តទុច្ចរិត និងដែលមានអំនួតដែលពោរពេញដោយអំពើបាបរបស់ពួកសាសន៍យូដា ។
- ស្របតាមខ ៥២តើពួកយូដាពីជំនាន់បុរាណបដិសេធ ហើយបៀតបៀនដល់នរណា នៅពេលពួកគេបដិសេធព្រះវិញ្ញាណបរិសុទ្ធនោះ ? (ពួកព្យាការី រួមទាំងម៉ូសេ) ។
- តើស្ទេផាននិយាយថា ពួកក្រុមប្រឹក្សាសាសន៍យូដាបានបដិសេធដល់នរណា ? (« ព្រះដ៏សុចរិត » [ខ ៥២] មានន័យថា ព្រះអង្គសង្គ្រោះ) ។

ចូរពន្យល់ថា ស្ទេផាន បានបង្ហាញថា ក៏ដូចជាពួកអ៊ីស្រាអែលពីបុរាណដែលបានបដិសេធព្យាការីម៉ូសេដែរ គឺពួកអ្នកដឹកនាំសាសន៍យូដានៅជំនាន់របស់ស្ទេផាន បានបដិសេធព្រះអង្គសង្គ្រោះ ។

- តើសេចក្តីពិតអ្វី ដែលយើងអាចរៀនអំពីការជំទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **ការបដិសេធព្រះវិញ្ញាណបរិសុទ្ធអាចដឹកនាំទៅរកការបដិសេធព្រះអង្គសង្គ្រោះ និងពួកព្យាការីរបស់ទ្រង់**)។

- តើការជំទាស់នឹងព្រះវិញ្ញាណបរិសុទ្ធ អាចនាំយើងឲ្យបដិសេធការបង្រៀនរបស់ព្រះអង្គសង្គ្រោះ និងពួកព្យាការីរបស់ទ្រង់យ៉ាងដូចម្តេច ? (ព្រះវិញ្ញាណបរិសុទ្ធ ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងថ្លែងសាក្សីអំពីសេចក្តីពិតនៃព្រះបន្ទូលរបស់ទ្រង់ និងពាក្យសម្តីរបស់ពួកព្យាការីរបស់ទ្រង់) ។ ហេតុដូច្នេះហើយ ការជំទាស់នឹងព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើឲ្យទីបន្ទាល់របស់មនុស្សម្នាក់ទន់ខ្សោយ ហើយការតាំងចិត្តរបស់គាត់ ឬនាងដើម្បីដើរតាមព្រះអង្គសង្គ្រោះ និងពួកព្យាការីរបស់ទ្រង់ក៏ទន់ខ្សោយផងដែរ) ។

សូមអញ្ជើញសិស្សឲ្យពន្យល់អំពីរបៀបដែលមនុស្សម្នាក់អាចត្រូវបានល្បួង ឲ្យជំទាស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងស្ថានភាពដូចខាងក្រោម ៖ (១) ការជ្រើសរើសការកម្សាន្ត និងប្រព័ន្ធផ្សព្វផ្សាយ (២) ការជ្រើសរើសថាតើត្រូវធ្វើតាមការទូន្មានរបស់ពួកព្យាការីអំពីការដើរលេងជាគ្នាឬទេ និង (៣) ការសម្រេចចិត្តថាតើអនុវត្តគោលការណ៍ទាំងឡាយនៃការប្រែចិត្ត ដែលព្រះយេស៊ូវគ្រីស្ទ និងពួកព្យាការីរបស់ទ្រង់បានបង្រៀនឬទេ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីទទួលស្គាគមន៍ជាជាងជំទាស់ឥទ្ធិពលរបស់ព្រះវិញ្ញាណបរិសុទ្ធ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀប ដែលការទទួលយកឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ នាំពួកគេឲ្យទទួលយកព្រះអង្គសង្គ្រោះ និងពួកព្យាការីរបស់ទ្រង់ ហើយអនុវត្តការបង្រៀនរបស់ពួកគេ ។

សូមលើកទឹកចិត្តដល់សិស្សឲ្យពិចារណាអំពីរឿងមួយ ដែលពួកគេអាចធ្វើនៅសប្តាហ៍ក្រោយដើម្បីខំប្រឹងប្រែងអញ្ជើញឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ចូលក្នុងជីវិតរបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅមួយ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ហើយលើកទឹកចិត្តពួកគេឲ្យបំពេញគោលដៅនោះ ។

កិច្ចការ ៧:៥៤-៦០

ស្តេផានត្រូវបានចោលនឹងដុំថ្មរហូតដល់ស្លាប់

សូមសរសេរពាក្យ *សេចក្តីវេទនា* នៅលើក្តារខៀន ហើយសូមសួរសិស្សថា តើពួកគេស្គាល់ពីអត្ថន័យនៃពាក្យនេះឬទេ ។ បន្ទាប់ពីពួកគេឆ្លើយតបហើយ សូមសរសេរនិយមន័យដូចខាងក្រោមនៅជិតនឹងពាក្យនោះ ៖ *ជាការបណ្តាលឲ្យមានបញ្ហាដ៏ធំ ឬការរងទុក្ខដ៏ធំ ។*

- ហេតុអ្វីយើងគប្បីរំពឹងទុកថា មានសេចក្តីវេទនាក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ?

សូមលើកទឹកចិត្តសិស្សឲ្យរកមើល នៅពេលពួកគេសិក្សាកិច្ចការ ៧:៥៤-៦០អំពីគោលការណ៍មួយដែលអាចជួយយើងនៅពេលយើងជួបសេចក្តីវេទនា ។

សូមពន្យល់ថា បន្ទាប់ពីស្តេផាន បានស្តីបន្ទោសដល់ពួកអ្នកដឹកនាំសាសន៍យូដាទុច្ចរិតហើយ នោះពួកគេ « មានចិត្តក្តៅក្រហាយណាស់ » (ខ ៥៤) និងមានកំហឹង ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៧:៥៥-៥៦ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលរបៀបដែលស្តេផានបានជួប អំឡុងគ្រានៃការបៀតបៀននេះ ។

- តើស្តេផានបានមានពេញដោយឥទ្ធិពលអ្វី ?
- តើស្តេផានបានឃើញនរណា ?



សូមដាក់តាំងរូបភាពស្តេផានឃើញព្រះយេស៊ូវគង់ខាងស្តាំព្រះហស្តនៃព្រះ (*សៀវភៅសិល្បៈដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៦៣; សូមមើលផងដែរ LDS.org) ។

- តើយើងអាចរៀនអ្វីខ្លះ មកពីដំណើររឿងនៃការនិមិត្តរបស់ស្តេផាន អំពីគោលលទ្ធិគ្រិះអំពីក្រុមព្រះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងប៉ុន្តែចូរប្រាកដថាពួកគេគូរស្គាល់គោលលទ្ធិដូចខាងក្រោមនេះ ៖ **ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ជាតូរអង្គបីផ្សេងគ្នា និង ដាច់ដោយឡែកពីគ្នា ។** អ្នកគួរណែនាំសិស្សឲ្យសរសេរគោលលទ្ធិនេះ នៅទីមទំព័រព្រះគម្ពីររបស់ពួកគេក្បែរ កិច្ចការ ៧:៥៥-៥៦) ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗមកពីកិច្ចការ ៧:៥៧-៦០ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលអ្វី ដែលមនុស្សបានធ្វើចំពោះស្តេផាន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្វីទៅដែលធ្វើឲ្យអ្នកចាប់អារម្មណ៍យ៉ាងខ្លាំង អំពីការអធិស្ឋានរបស់ស្តេផាន ?
- ហេតុអ្វីអ្នកគិតថា លូកាបានពិពណ៌នាអំពីការស្លាប់ដ៏សោកនាដកម្មរបស់ស្តេផានជាមួយនឹងឃ្លាថា « គាត់ដេកលក់ទៅ » ? (ខ ៦០) ។ (ចូរចង្អុលបង្ហាញថា ឃ្លានេះអាចនឹងសំដៅទៅលើការសង្រ្គោះរបស់ព្រលឹងសុចរិតពីបញ្ហាខាងជីវិតរមែងស្លាប់ និងភាពសុខសាន្តដែលមនុស្សបានឆ្លាស់ប្រែចេញពីជីវិតនេះទៅជីវិតបន្ទាប់ | សូមមើលគ. និង ស. ៤២:៤៦|) ។

សូមអញ្ជើញសិស្សឲ្យនឹកគិតអំពីអ្វីដែលស្តេផានបានជួប ពីមុនគាត់ត្រូវបាននាំយកទៅ ហើយត្រូវបានសំឡាប់ចោលនោះ (សូមមើលកិច្ចការ ៧:៥៥-៥៦) ។

- តើព្រះបានពង្រឹងដល់ស្តេផាន តាមរយៈបទពិសោធន៍របស់គាត់ជាមួយនឹងពួកសាសនហេខ្មីនយ៉ាងដូចម្តេច ? (ស្តេផានបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយបានឃើញព្រះអង្គសង្គ្រោះគង់នៅខាងស្តាំព្រះហស្តរបស់ព្រះ) ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ចេញមកពីបទពិសោធន៍របស់ស្ទេផាន ដែលអាចជួយឲ្យយើងបន្តស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ អំឡុងសេចក្តីទុក្ខវេទនានោះ ? (សិស្សអាចនឹងប្រាប់ពីគោលការណ៍ផ្សេងៗ ប៉ុន្តែសូមប្រាកដថា ពួកគេយល់គោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងបន្តស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ អំឡុងការរងទុក្ខវេទនា នោះទ្រង់នឹងគង់នៅជាមួយយើង**) ។
- តើព្រះអម្ចាស់អាចគង់នៅជាមួយយើង នៅពេលយើងជួបនឹងការរងទុក្ខវេទនាតាមរបៀបណា ?
- ទោះជាស្ទេផានបាត់បង់ជីវិតគាត់ក្តី តើគាត់បានទទួលបានអ្វីខ្លះ ?

ចូរពន្យល់ថា ជាទូទៅស្ទេផាន ត្រូវបានរាប់ថាជាទុក្ករជនគ្រីស្ទានដំបូងគេ ។ បន្ថែមពីលើនោះ គាត់ត្រូវបានគេមើលឃើញជាតំណាងព្រះគ្រីស្ទ គាត់ និងព្រះអង្គសង្គ្រោះបានឈរនៅចំពោះក្រុមប្រឹក្សាដើម្បីត្រូវបានគេកាត់ទោស ដោយបានប្រកាសអំពីសេចក្តីពិតចំពោះមុខមារសត្រូវ ប្រគល់ជីវិតនៅក្នុងបុព្វហេតុសុចរិត ហើយបានថ្លែងដូចគ្នានៅពេលរងទុក្ខដល់ស្លាប់ (សូមមើលលូកា ២៣:៣៣-៣៤, ៤៦) ។ អ្នកគម្ពីចង្អុលបង្ហាញថា យុវបុរសម្នាក់ឈ្មោះ សូល—ដែលក្រោយមកបានក្លាយទៅជាសាវកប៉ុល—មានវត្តមាន ហើយធ្វើជាសាក្សីដល់ការធ្វើទុក្ករកម្មដល់ស្ទេផាន (សូមមើលខ ៥៨) ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

កិច្ចការ ៨

សេចក្តីផ្តើម

ការបៀតបៀនទាស់នឹងសាសនាចក្រនៅក្នុងទីក្រុងយេរូសាឡិម នាំឲ្យសមាជិកសាសនាចក្រត្រូវខ្ចាត់ព្រាត់ពាសពេញស្រុកយូដា និង ស្រុកសាម៉ារី ។ ភីលីព បានបម្រើនៅស្រុកសាម៉ារី ជាកន្លែងដែលមនុស្សជាច្រើនបានទទួលយកដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់ពី ពេត្រុស និងយ៉ូហាន បានប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធទៅដល់អ្នកផ្លាស់ប្រែចិត្តជឿថ្មីហើយ នោះគ្រូមន្តអាគមម្នាក់ឈ្មោះ សឺម៉ូន បានចង់ទិញបព្វជិតភាព ។ ក្រោយមក ព្រះបានដឹកនាំភីលីពទៅកាន់មន្ត្រីសាសន៍អេធីយ៉ូពីម្នាក់ ដែលភីលីពបានបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ហើយបានទទួលបុណ្យជ្រមុជទឹក ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ៨:១–២៥

ភីលីព បម្រើនៅក្នុងស្រុកសាម៉ារី នៅកន្លែងដែលស៊ីម៉ូន ជាគ្រូមន្តអាគម ប៉ុនប៉ងចង់ទិញបព្វជិតភាព ។

សូមបង្ហាញប្រាក់មួយចំនួន ។ ចូរសុំឲ្យសិស្សនឹកស្រមៃថា ពួកគេបានទទួលប្រាក់យ៉ាងច្រើន ។

- **តើមានអ្វីខ្លះដែលអ្នកនឹងទិញបានដោយប្រាក់ ?**

សូមចង្អុលបង្ហាញថា មនុស្សមួយចំនួនជឿថា ប្រាក់អាចទិញអ្វីៗគ្រប់យ៉ាង ។ ទោះជាយ៉ាងណាក៏ដោយ វត្ថុមានតម្លៃបំផុតមួយចំនួននៅក្នុងជីវិត គឺពុំអាចទិញដោយប្រាក់បាននោះទេ ។ ខណៈពេលសិស្សសិក្សាកិច្ចការ ៨សូមអញ្ជើញពួកគេឲ្យរកមើលអំណោយទានមួយមកពីព្រះ ដែលពុំអាចទិញដោយប្រាក់បាន ។

សូមរំឭកសិស្សថា នៅក្នុងកិច្ចការ ៧យើងរៀនអំពីការស្លាប់របស់សាវកស្ទេផាន នៅក្នុងកណ្តាប់ដៃរបស់ពួកអ្នកបៀតបៀន ។ សូមឲ្យសិស្សពីបួននាក់ប្តូរវេនគ្នាអានឮៗពី កិច្ចការ ៨:១-៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលសមាជិកសាសនាចក្របានធ្វើ ដែលជាលទ្ធផលនៃការបៀតបៀនទាស់នឹងសាសនាចក្រនៅក្នុងទីក្រុងយេរូសាឡិម ។ អ្នកគប្បីពន្យល់ថា *ចាប់ទាញអូស*(កិច្ចការ ៨:៣) មានន័យថា ការទាញ ឬការអូស ។

- **តើការបៀតបៀនបាននាំឲ្យសមាជិកសាសនាចក្រធ្វើអ្វីខ្លះ ?**

សូមបង្ហៀរចំណាប់អារម្មណ៍របស់សិស្សទៅកាន់ឈ្មោះ*ភីលីព*នៅក្នុងខទី ៥។ សូមរំឭកសិស្សថា ភីលីព គឺជាសិស្សម្នាក់ក្នុងចំណោមសិស្សប្រាំពីរនាក់ដែលត្រូវបានតែងតាំងឲ្យជួយដល់សាវកដប់ពីរនាក់នៅក្នុងការបម្រើតាមតម្រូវការរបស់សមាជិកសាសនាចក្រ (សូមមើលកិច្ចការ ៦:៥) ។ ចូរសុំឲ្យសិស្សយោងទៅលើឯកសារចែកចាយ « ទិដ្ឋភាពទូទៅនៃកិច្ចការនៃពួកសាវក » (សូមមើលសេចក្តីបន្ថែមនៃសៀវភៅសិក្សានេះ) ហើយរកមើលការបញ្ជារបស់ព្រះអង្គសង្គ្រោះដែលបានកត់ត្រានៅក្នុង កិច្ចការ ១:៨។

- **យោងតាមកិច្ចការ ៨:៥តើភីលីពបានចាប់ផ្តើមធ្វើយ៉ាងដូចម្តេច ដើម្បីបំពេញតាមការបញ្ជារបស់ព្រះអង្គសង្គ្រោះ ?**

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៨:៦-៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលពួកសាសន៍សាម៉ារីបានឆ្លើយតបចំពោះការផ្សាយដំណឹងល្អរបស់ភីលីព ។

- **តើសាសន៍សាម៉ារីទាំងនេះបានឆ្លើយតបយ៉ាងដូចម្តេច ចំពោះការផ្សាយដំណឹងល្អរបស់ភីលីព ?**
- **បន្ថែមពីលើការផ្សាយដំណឹងល្អ តើកិច្ចការងារផ្សេងៗទៀតដែលភីលីពបានធ្វើមានអ្វីខ្លះ ?**

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៨:៩-១១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការពិពណ៌នាអំពីសាសន៍សាម៉ារីម្នាក់ដែលមានឈ្មោះ សឺម៉ូន ។

- **តើយើងអាចរៀនអ្វីខ្លះអំពីសឺម៉ូនមកពីខគម្ពីរទាំងនេះ ? (ចូរពន្យល់ថា « ការប្រើអំណាចដើម្បីទទួលបានជំនួយ ឬគ្រង់គ្រងមកពីវិញ្ញាណអសោចគឺត្រូវបានហៅថា*គ្រូមន្តអាគម* » [Bruce R. McConkie, *Doctrinal New Testament Commentary,* វ៉ុលទី ៣ (ឆ្នាំ ១៩៦៥–៧៣) ២:៨២]) ។**
- **តើសឺម៉ូនមានឥទ្ធិពលអ្វីខ្លះទៅលើប្រជាជននេះ ?**

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៨:១២-១៣ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលសឺម៉ូនបានឆ្លើយតបចំពោះការប្រកាសដំណឹងល្អរបស់ភីលីព ។ សូមឲ្យសិស្សរាយការណ៍នូវអ្វីដែលពួកគេរកឃើញ ។

- **យោងតាម ខទី ១៣តើសឺម៉ូនបានទទួលឥទ្ធិពលដោយសារ « អព្ភូតហេតុ និង ទីសម្គាល់ » ដែលគាត់បានឃើញយ៉ាងដូចម្តេច ?**

សូមសង្ខេបកិច្ចការ ៨:១៤-១៦ដោយពន្យល់ថា ពេត្រុស និង យ៉ូហាន បានមកកាន់សាសន៍សាម៉ារី បន្ទាប់ពីស្តាប់ឮថា ប្រជាជននៅទីនោះបានទទួលយកព្រះបន្ទូលរបស់ព្រះ ។ ពួកគេបានអធិស្ឋានថា ពួកសាសន៍សាម៉ារីដែលបានផ្លាស់ប្រែចិត្តនឹងទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

មូលដ្ឋានគ្រឹះនៃការបង្រៀន និង ការរៀនសូត្រដំណឹងល្អ

មេរៀនដែលសំអាងទៅលើបទគម្ពីរនីមួយៗក្នុងថ្នាក់សិក្ខាសាលា ផ្តោតលើវគ្គបទគម្ពីរមួយជាជាងផ្តោតទៅលើគំនិតបាវចនា គោលលទ្ធិ ឬ គោលការណ៍ពិសេសណាមួយ ។ មេរៀនទាំងនេះដាក់បញ្ចូលមូលដ្ឋានគ្រឹះនៃការបង្រៀន និងការរៀនសូត្រដំណឹងល្អដែលជួយសិស្សឲ្យយល់ពីបរិបទ និងមាតិការៃបណ្តុំបទគម្ពីរមួយ ស្គាល់ យល់ ហើយដឹងពីសេចក្តីពិត និងសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ហើយអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ។

ចូរសុំឲ្យសិស្សអានកិច្ចការ ៨:១៧ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលពេត្រុស និងយ៉ូហាន បានធ្វើចំពោះសមាជិកសាសនាចក្រថ្មីនៅក្នុងសាសន៍សាម៉ារី ។

- តើយើងអាចរៀនអ្វីខ្លះមកពីដំណើររឿងនេះអំពីរបៀប ដែលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធត្រូវបានប្រទានឲ្យ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលលទ្ធិដូចខាងក្រោមនៅលើក្តារខៀន ៖ **អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធត្រូវបានប្រទានឲ្យ បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក តាមរយៈការដាក់ដៃលើដោយពួកអ្នកកាន់បព្វជិតភាព**) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៨:១៨-១៩ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវសំណើរបស់ស៊ីម៉ូនចំពោះពេត្រុស ។

- តើស៊ីម៉ូនបានដាក់សំណើអ្វីដល់ពេត្រុស ?

សូមបង្ហាញសិស្សនូវប្រាក់ ដែលអ្នកបានដាក់បង្ហាញ នៅពេលចាប់ផ្តើមមេរៀន ។ សូមអញ្ជើញពួកគេឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងឆ្លើយតបចំពោះស៊ីម៉ូន ប្រសិនបើពួកគេស្ថិតនៅក្នុងស្ថានភាពរបស់ពេត្រុស ។

សូមអញ្ជើញសិស្សបួនប្រាំនាក់ឲ្យផ្លាស់វេនគ្នាអានឮៗចេញមកពី កិច្ចការ ៨:២០–២៤ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលពេត្រុសបានបង្រៀនដល់ស៊ីម៉ូនអំពីការទទួលបព្វជិតភាព ។

- តើពេត្រុសបង្រៀនស៊ីម៉ូនអ្វីខ្លះអំពីបព្វជិតភាព ដូចបានកត់ត្រានៅក្នុងខទី ២០ ?
- នៅពេលគាត់បានផ្តល់ប្រាក់ដល់ពួកសាវកដើម្បីទទួលបានបព្វជិតភាព តើអ្វីដែលស៊ីម៉ូនមិនយល់អំពីបព្វជិតភាព ? (ដោយសារតែបព្វជិតភាពជារបស់ផងព្រះ នោះវាអាចត្រូវបានប្រទានឲ្យតែនៅពេលវាស្របទៅតាមព្រះទ័យរបស់ទ្រង់ប៉ុណ្ណោះ ។ ព្រះបង្កើតរបៀបដែលបព្វជិតភាពអាចត្រូវបានទទួល) ។
- យោងតាម ខទី ២១-២៣ ហេតុអ្វីស៊ីម៉ូនមិនទាន់អាចទទួលបព្វជិតភាពនៅឡើយ ? តើអ្នកគិតថាដួងចិត្តរបស់ស៊ីម៉ូន « ពុត្រឹមត្រូវនៅក្នុងព្រះនេត្ររបស់ព្រះ » តាមរបៀបណា ? (ខទី ២១) ។
- តើយើងអាចរៀនមកពីដំណើររឿងនេះអ្វីខ្លះ អំពីការទទួលបព្វជិតភាព ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ ៖ **បព្វជិតភាពបានប្រទានឲ្យស្របតាមព្រះឆន្ទៈ និងបទដ្ឋាននៃភាពសក្តិសមរបស់ព្រះ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីដឹងថា បព្វជិតភាពត្រូវបានប្រគល់ឲ្យដល់បុគ្គលណាដែលធ្វើទង្វើស្របតាមព្រះទ័យរបស់ព្រះ និងបទដ្ឋាននៃភាពសក្តិសមតែប៉ុណ្ណោះនោះ ?

សូមសង្ខេបកិច្ចការ ៨:២៥ដោយពន្យល់ថា ពេត្រុស និង យ៉ូហាន បានផ្សាយដំណឹងល្អនៅក្នុងភូមិសាសន៍សាម៉ារីជាច្រើន ។

កិច្ចការ ៨:២៦-៤០

ភីលីពបង្រៀន ហើយជ្រមុជទឹកដល់មន្ត្រីសាសន៍អេធីយ៉ូពីម្នាក់

ចូរសុំឲ្យសិស្សគិតអំពីស្ថានភាពនានាដែលពួកគេបានត្រូវការ ឬនឹងត្រូវការនរណាម្នាក់ដើម្បីដឹកនាំពួកគេ ។

- តើស្ថានភាពមួយចំនួនណាខ្លះ ដែលនៅក្នុងនោះ អ្នកអាចធ្វើជាអ្នកដឹកនាំដល់នរណាម្នាក់ផ្សេងទៀតនោះ ? (អ្នកអាចអញ្ជើញសិស្សឲ្យគិតអំពីជោគវាសនា ឬប្រធានបទ ដែលពួកគេមានតំរិះ ឬទេពកោសល្យដែលពួកគេបានអភិវឌ្ឍ) ។

នៅពេលសិស្សសិក្សាផ្នែកសេសសល់ទាំងប៉ុន្មាននៃកិច្ចការ ៨សូមអញ្ជើញពួកគេឲ្យរកមើលវិធីសំខាន់មួយ ដែលពួកគេអាចធ្វើជាអ្នកដឹកនាំសម្រាប់អ្នកដទៃ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ៨:២៦-២៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវមូលហេតុដែលភីលីពបានចេញទៅឯក្រុងកាសា ។

- ហេតុអ្វីភីលីពចេញទៅឯក្រុងកាសា ?
- តើនរណាកំពុងធ្វើដំណើរនៅក្នុងតំបន់ដែលភីលីពស្ថិតនៅនោះ ? (មេអេធីយ៉ូពីម្នាក់ ។ ចូរពន្យល់ថា មេគឺជាមន្ត្រីម្នាក់នៅក្នុងទីលានរបស់ស្តេច ឬម្ចាស់ក្សត្រី [សូមមើល Bible Dictionary« Eunuch »]) ។
- តើមន្ត្រីអេធីយ៉ូពីបានធ្វើអ្វីខ្លះ នៅក្នុងរទេះចំបាំងរបស់គាត់ ? (ការអានចេញមកពីអេសាយ ឬសម្តីរបស់អេសាយ) ។

សូមដាក់កៅអីពីរទល់មុខគ្នានៅខាងមុខថ្នាក់រៀន ។ ចូរស្នើសុំអ្នកស្ម័គ្រចិត្តពីរនាក់ឲ្យដើរតួជាមន្ត្រីអេធីយ៉ូពី និងភីលីពនៅក្នុងដំណើររឿងដូចតទៅនេះ ។ (អ្នកគប្បីចាត់តួទាំងនេះពីមុនថ្នាក់រៀន ហើយអញ្ជើញសិស្សទាំងនេះឲ្យត្រៀមខ្លួនដើរតួផ្ទៃករបស់ពួកគេ) ។ ចូរសុំឲ្យសិស្សដើរតួជាមន្ត្រីអេធីយ៉ូពីអង្គុយនៅកៅអីមួយ ហើយសិស្សដែលដើរតួជាភីលីពឲ្យឈរនៅក្បែរទ្វារ ។ សូមអញ្ជើញសិស្សទីបីឲ្យដើរតួជាអ្នកធ្វើអត្ថាធិប្បាយ ។

ចូរសុំឲ្យសិស្សទាំងនេះអានឮៗចេញមកពីកិច្ចការ ៨:២៩-៣៩ហើយដើរតួផ្ទៃករបស់ពួកគេតាមលំដាប់លំដោយ ។ ចូរសុំឲ្យសិស្សមើលនូវអ្វីដែលកើតឡើងរវាងភីលីព និងមន្ត្រីអេធីយ៉ូពី ។ នៅពេលសិស្សអាន ហើយដើរតួនូវផ្ទៃករបស់ពួកគេ ចូរធ្វើដូចខាងក្រោម ៖

១. បន្ទាប់ពីអ្នកធ្វើអត្ថាធិប្បាយអានខទី ៣២-៣៣សូមអញ្ជើញសិស្សឲ្យពិចារណាអំពីការសរសេរ*អេសាយ ៥៣:៧-៨*ជាសេចក្តីយោងខគម្ពីរនៅក្នុងគម្ពីររបស់ពួកគេនៅជិតនឹងកិច្ចការ ៨:៣២-៣៣ ។

២. បន្ទាប់ពីអ្នកធ្វើអត្ថាធិប្បាយអានខទី ៣៥ចូរសុំឲ្យសិស្សដែលដើរតួជាភីលីព ពន្យល់ដល់សិស្សក្នុងថ្នាក់អំពីអ្វីដែលគាត់ ឬនាងនឹងបង្រៀនអំពីព្រះអង្គសង្គ្រោះនៅក្នុងស្ថានភាពនេះ ។ (អ្នកគប្បីអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្តល់យោបល់ផងដែរ) ។

៣. នៅពេលអ្នកធ្វើអត្ថាធិប្បាយអានខទី ៣៨ចូរសុំឲ្យអ្នកស្ម័គ្រចិត្ត កុំសម្តែងអំពីពិធីបុណ្យជ្រមុជទឹក ។

បន្ទាប់ពីអ្នកស្ម័គ្រចិត្តបានបញ្ចប់សកម្មភាពនេះ សូមអរគុណដល់ពួកគេ ហើយអញ្ជើញពួកគេឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយរបស់ពួកគេវិញ ។

- យោងតាម ខទី ២៩ហេតុអ្វីភីលីពដើរទៅកាន់រទេះចម្បាំងរបស់មន្ត្រីអេធីយ៉ូពី ?
- យោងតាម ខទី ៣១តើមន្ត្រីនោះបាននិយាយថា គាត់បានត្រូវការអ្វីខ្លះ ដើម្បីយល់អំពីការសរសេររបស់អេសាយ ?
- យោងតាមខទី ៣៥-៣៨តើភីលីពធ្វើជាអ្នកនាំផ្លូវដល់មន្ត្រីនោះយ៉ាងដូចម្តេច ?
- តើយើងអាចរៀនអំពីគោលការណ៍អ្វីខ្លះ ចេញមកពីបទពិសោធន៍របស់ភីលីពអំពីលទ្ធផលនៃការស្តាប់តាមការបំផុសគំនិតមកពីព្រះ ? (សិស្សអាចនឹងប្រើពាក្យសម្តីផ្សេង ប៉ុន្តែចូរប្រាកដថាពួកគេយល់ច្បាស់លាស់ថា**នៅពេលយើងស្តាប់តាមការបំផុសគំនិតមកពីព្រះ នោះយើងអាចទទួលបានឱកាសនានាដើម្បីជួយដឹកនាំអ្នកដទៃទៅកាន់ព្រះយេស៊ូវគ្រីស្ទ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមឲ្យសិស្សនូវច្បាប់ចម្លងឯកសារចែកចាយដូចខាងក្រោម ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមការណែនាំនៅលើឯកសារចែកចាយឲ្យនោះ ហើយគិតអំពីរបៀប ដែលពួកគេអាចជួយដឹកនាំនរណាម្នាក់មកកាន់ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថា ពួកគេនឹងមានឱកាសដើម្បីចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេសរសេរ ។

ការដឹកនាំអ្នកដទៃមកកាន់ព្រះយេស៊ូវគ្រីស្ទ

ជ្រើសរើសស្ថានភាពមួយនៃស្ថានភាពនានាដូចខាងក្រោម ៖

- យុវជនម្នាក់ដែលជាមិត្តរបស់អ្នក ជាសមាជិកនៃព្រះវិហារគ្រីស្ទានផ្សេង ។ នៅថ្ងៃមួយអំឡុងពេលអាហារថ្ងៃត្រង់ អ្នកទទួលអារម្មណ៍បំផុសគំនិតឲ្យនិយាយនឹងគាត់អំពីសាសនាចក្រ ។
- ខណៈពេលកំពុងដើរទៅផ្ទះវិញចេញពីសាលារៀនវិញ អ្នកបានឃើញយុវនារីម្នាក់កំពុងយំ ។ អ្នកស្គាល់ថានាងជាសមាជិកម្នាក់ក្នុងវួដរបស់អ្នក ដែលពុំបានចូលរួមក្នុងការប្រជុំអស់បីបួនឆ្នាំហើយ ។ អ្នកមានអារម្មណ៍បំផុសគំនិតឲ្យនិយាយនឹងនាង ។ នៅពេលអ្នកព្យាយាមលួងលោមនាង នាងបានប្រាប់អំពីឧបសគ្គរបស់នាង ហើយបានសួរថា « ហេតុអ្វីក៏ខ្ញុំពុំអាចមានក្តីសប្បាយរីករាយ ? »
- ម្តាយរបស់យុវជនម្នាក់ ដែលអ្នកស្គាល់ក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គមថ្មីៗនេះបានទទួលមរណភាព ។ អ្នកមានអារម្មណ៍បំផុសគំនិតឲ្យឆ្លើយតបចំពោះការប្រកាសព័ត៌មាន ដែលគាត់បានបង្ហោះថ្មីៗដូចតទៅ ៖ « មានអារម្មណ៍ឯកោណាស់ឥឡូវនេះ ។ ចង់ឲ្យមានមនុស្សម្នាក់យល់ចិត្ត » ។

នៅខាងក្រោយនៃក្រដាសមួយសន្លឹកនេះ ឬនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរបស់អ្នក សូមសរសេរនូវអ្វីដែលអ្នកនឹងនិយាយ និងធ្វើដើម្បីជួយដឹកនាំបុគ្គលនេះឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងការពិពណ៌នារបស់អ្នក សូមបញ្ចូលនូវចម្លើយតបនឹងសំណួរដូចខាងក្រោម ៖

- តើសេចក្តីពិតអំពីដំណឹងល្អអ្វីខ្លះ ដែលអ្នកនឹងចែកចាយដើម្បីជួយដឹកនាំបុគ្គលនេះមកកាន់ព្រះយេស៊ូវគ្រីស្ទ ?
- តើខគម្ពីរអ្វីមួយដែលអ្នកអាចអញ្ជើញបុគ្គលនេះឲ្យសិក្សា ?
- តើអ្នកអញ្ជើញបុគ្គលនេះឲ្យធ្វើអ្វីខ្លះ ?

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមបំបែកសិស្សជាគូៗ ។ សូមអញ្ជើញសិស្សឲ្យពន្យល់ដល់ដៃគូរបស់ពួកគេអំពីអ្វីដែលពួកគេបានសរសេរ ហើយហេតុអ្វីក៏ពួកគេយកមធ្យោបាយនោះ ។ បន្ទាប់មកអញ្ជើញសិស្សបីបួននាក់ ពន្យល់ដល់សិស្សក្នុងថ្នាក់ទាំងមូលអំពីអ្វីដែលពួកគេបានសរសេរ ។ អ្នកអាចនឹងពិចារណាធ្វើការអញ្ជើញដល់សិស្សឲ្យជ្រើសរើសស្ថានភាពមួយនៃស្ថានភាពពីរដំបូងឲ្យសម្តែងអំពីអ្វី ដែលពួកគេនឹងនិយាយ ហើយធ្វើនៅក្នុងស្ថានភាពទាំងនេះ ដែលអ្នកដើរតួជាបុគ្គលម្នាក់ ដែលពួកគេព្យាយាមជួយ ។ (ប្រសិនបើអ្នកធ្វើដូច្នោះ សូមផ្តល់ពេលមួយនាទីដល់សិស្សដើម្បីរៀបចំខ្លួនពីមុនអញ្ជើញពួកគេឲ្យដើរតួក្នុងស្ថានភាពនោះជាមួយអ្នក) ។ បន្ទាប់មក សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកបានជួយណែនាំដល់នរណាម្នាក់ឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទនៅពេលណា និងដោយរបៀបណា ?
- តើនរណាម្នាក់បានជួយណែនាំដល់អ្នកឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទនៅពេលណា និងដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យស្តាប់តាមការបំផុសគំនិតមកពីព្រះ ដូច្នេះពួកគេអាចត្រូវបានដឹកនាំទៅកាន់នរណាម្នាក់ដែលពួកគេអាចជួយដឹកនាំឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេអាចធ្វើនៅក្នុងប៉ុន្មានថ្ងៃទៀត ដើម្បីណែនាំនរណាម្នាក់ដែលពួកគេស្គាល់ ឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តសិស្សឲ្យរាយការណ៍ដល់សិស្សក្នុងថ្នាក់ អំពីបទពិសោធន៍ដែលពួកគេមាន ។

កិច្ចការ ៩

សេចក្តីផ្តើម

ព្រះយេស៊ូវបានបង្ហាញព្រះកាយដល់សុល នៅពេលលោកធ្វើដំណើរទៅស្រុកដាម៉ាស បន្ទាប់មកសុលបានងងឹតភ្នែក ។ ក្រោយមក អាន៉ានាសបានព្យាបាលគាត់ សុលបានជ្រមុជទឹក ហើយបានចាប់ផ្តើមផ្សាយនៅក្នុងស្រុកដាម៉ាស ។ បីឆ្នាំក្រោយមក សុលបានធ្វើដំណើរទៅក្រុងយេរូសាឡិម ប៉ុន្តែកាលមានគេគំរាមកំហែងដល់ជីវិតរបស់លោក នោះពួកសាវកបានបញ្ជូនលោកទៅស្រុកតើសុសវិញ ។ ពេត្រុសបានធ្វើអព្ភូតហេតុនៅក្នុងភូមិលីដា និង ក្រុងយ៉ុបប៉េ ។

យោបល់សម្រាប់ការបង្រៀន

ជួយសិស្សឲ្យយល់ពីបរិបទ និងមាតិកា

គ្រឹះមួយនៃការបង្រៀន និងការរៀនសូត្រអំពីដំណឹងល្អ គឺការយល់ដឹងពីបរិបទ និងមាតិកានៃព្រះគម្ពីរ ។ បរិបទរួមមានទាំងកាល:ទេស: ដែលនៅជុំវិញ ឬផ្ទៃរឿង អំពីវគ្គបទគម្ពីរព្រឹត្តិការណ៍ និង ដំណើររឿងជាក់លាក់មួយ។ មាតិការួមបញ្ចូលនូវមនុស្ស ព្រឹត្តិការណ៍ ទេសនកថា និងការពន្យល់ដែលបានបំផុសគំនិត ដែលបង្កើតអត្ថបទនោះឡើង ។ នៅពេលអ្នកជួយសិស្សឲ្យយល់ពីបរិបទ និង មាតិកានៃព្រះគម្ពីរ ពួកគេនឹងរៀបចំខ្លួនដើម្បីស្គាល់សារលិខិតរបស់ពួកអ្នកនិពន្ធដ៏បំផុតគំនិតទាំងឡាយ ។

កិច្ចការ ៩:១-៩

ព្រះយេស៊ូវបានបង្ហាញព្រះកាយទ្រង់ដល់សុលនៅតាមផ្លូវទៅស្រុកដាម៉ាស

សូមសរសេរនៅលើ ក្តារខៀន នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ (សេចក្តីថ្លែងការណ៍នេះមាននៅក្នុង « The Best Is Yet to Be » *Ensign* ឬ *Liahona* ខែ មករា ឆ្នាំ ២០១០ ទំព័រ ២៥–២៦) ។

> *« មានអ្វីមួយនៅក្នុងខ្លួនពួកយើងគ្រប់គ្នា ដែលបរាជ័យក្នុងការអភ័យទោស និងបំភ្លេចនូវកំហុសពីមុនៗនៅក្នុងជីវិតនេះ—ទាំងកំហុសរបស់យើង ឬ កំហុសរបស់មនុស្សដទៃទៀត ។ . . .*
>
> *« ចូរឲ្យមនុស្សប្រែចិត្ត ។ ចរឲយមនសសរកចមរនឡង ចូរជឿថា មនុស្សអាចផ្លាស់ប្តូរ ហើយកែខ្លួនឲ្យប្រសើរឡើងបាន » (អែលឌើរ ដៃហ្វ្រី អ័រ ហូឡិន) ។*

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ។ បន្ទាប់មក សូមសួរសិស្ស ៖

- **តើស្ថានភាពណាខ្លះ ដែលវាសំខាន់ដើម្បីឲ្យអ្នកដទៃផ្លាស់ប្តូរ និងកែខ្លួនឲ្យប្រសើរឡើង ហើយជឿថាពួកគេអាចធ្វើបែបនោះបាន ?**
- **តើស្ថានភាពណាខ្លះ ដែលវាសំខាន់ដើម្បីជឿថា យើងអាចផ្លាស់ប្តូរ និងកែខ្លួនឲ្យប្រសើរឡើងបាន ?**

នៅពេលសិស្សសិក្សា កិច្ចការ ៩សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលយើងអាចរៀនអំពីបទពិសោធន៍របស់នរណាម្នាក់ដែលបានផ្លាស់ប្តូរ និងកែខ្លួនឲ្យប្រសើរឡើង ។

សូមពន្យល់ថា អត្ថបទភាគច្រើននៃ កិច្ចការ ៩ ផ្តោតអារម្មណ៍លើបទពិសោធន៍របស់បុរសម្នាក់ឈ្មោះសុល ។ សូមអញ្ជើញសិស្សម្នាក់អានការពិពណ៌នាអំពីសុលដូចខាងក្រោមឲ្យឮៗ ៖

សុលបានកើតនៅប្រទេសក្រិក ស្រុកតើសុស (សូមមើល កិច្ចការ ២១:៣៩) ហើយមានសញ្ជាតិរ៉ូម (សូមមើល កិច្ចការ ១៦:៣៧) ។ គាត់គឺជាសាសន៍យូដាមកពីតំណពូជពង្សរបស់បេនយ៉ាមីន (សូមមើល រ៉ូម ១១:១) ហើយបានទទួលការអប់រំនៅយេរូសាឡិមមកពីលោកកាម៉ាលាល (សូមមើល កិច្ចការ ២២:៣) ជាពួកជាវិសីម្នាក់ដ៏ល្បីល្បាញ និងជាគ្រូបង្រៀនក្រឹត្យវិន័យសាសន៍យូដាគួរឲ្យគោរព (សូមមើល កិច្ចការ ៥:៣៤) ។ សុលបានក្លាយជាពួកជាវិសីម្នាក់ (សូមមើល កិច្ចការ ២៣:៦) ហើយលោកបាននិយាយ « ភាសាហេព្រើរ » (ប្រហែលជាអារ៉ាម) និងភាសាក្រិក (សូមមើល កិច្ចការ ២១:៣៧, ៤០) ។ ក្រោយមក លោកត្រូវបានគេស្គាល់តាមឈ្មោះជាភាសាឡាតាំងរបស់លោកគឺ ប៉ុល (សូមមើល កិច្ចការ ១៣:៩) ។ (សូមមើល Bible Dictionary, « Paul ») ។

សូមរំឭកសិស្សថា សុលមានវត្តមាន នៅពេលប្រជាជនចោលដុំថ្មដាក់ស្តេផាន (សូមមើល កិច្ចការ ៧:៥៨–៥៩) ។ សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៨:១–៣ ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតអាន កិច្ចការ ៩:១–២ ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលពីរបៀបដែលសុលបានប្រព្រឹត្តដាក់ពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ។

- **តើសុលបានប្រព្រឹត្តចំពោះពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?**
- **យោងតាម កិច្ចការ ៩:១–២ ហេតុអ្វីសុលធ្វើដំណើរទៅស្រុកដាម៉ាស ?**

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៩:៣–៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើមានអ្វីបានកើតឡើង នៅពេលសុលបានធ្វើដំណើរទៅស្រុកដាម៉ាស ។

- **តើនរណាបានមកជួបនឹងសុល ?**

សូមចង្អុលបង្ហាញថាឃ្លា « ធាក់ជល់នឹងជន្លួញ » នៅក្នុង ខទី ៥ ។ សូមពន្យល់ថា *ជន្លួញ* សំដៅទៅឈើស្រួចមួយដែលប្រើចាក់សត្វពាហនៈឲ្យដើរទៅមុខ (ប្រសិនបើធ្វើទៅបាន សូមបង្ហាញឈើស្រួចមួយដល់សិស្ស) ។ នៅក្នុងករណីនេះ ការ « ធាក់ជល់នឹងជន្លួញ » មានន័យថា ការទាស់ប្រឆាំងនឹងព្រះ ។

សូមអញ្ជើញសិស្សឲ្យពិចារណាគូសចំណាំសំណួររបស់សុល ដែលបានកត់ត្រានៅក្នុង ខទី ៦ ។

- តើសំណួររបស់សុលបង្រៀនយើងអ្វីខ្លះអំពីលោក ? (លោកមានបំណងចុះចូលនឹងព្រះទ័យរបស់ព្រះអម្ចាស់) ។

សូមសង្ខេប កិច្ចការ ៩:៧–៩ដោយពន្យល់ថាយោងតាមការបកប្រែដោយយ៉ូសែប ស៊្មីធ កិច្ចការ ៩:៧ ជនដែលបានធ្វើដំណើរជាមួយនឹងសុលបានឮឮញញួរ ប៉ុន្តែពុំបានឮសំឡេងរបស់ព្រះយេស៊ូវឡើយ នៅពេលទ្រង់មានបន្ទូលទៅកាន់សុល (សូមមើល កិច្ចការ ២២:៩) ។ បន្ទាប់ពីការនិមិត្តនោះ សុលបានងងឹតភ្នែក ។ លោកត្រូវបានគេនាំទៅស្រុក ដាម៉ាស ហើយលោកពុំបានបរិភោគ ឬ ផឹកអ្វីឡើយអស់រយៈពេលបីថ្ងៃ ។

- សូមស្រមៃធ្វើជាសុល ។ ប្រសិនបើអ្នកបានបៀតបៀនយ៉ាងឃោរឃៅលើពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ តើអ្នកអាចគិត និង មានអារម្មណ៍បែបណាខ្លះអំឡុងគ្រាបែបនេះ ?

កិច្ចការ ៩:១០-២២

លោកអាន៉ានាសនៅស្រុកដាម៉ាសបានព្យាបាល ជ្រមុជទឹក ហើយបង្រៀនសុលអំពីព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៩:១០–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ព្រះអម្ចាស់បានបង្គាប់ឲ្យអាន៉ានាស ជាសមាជិកសាសនាចក្រម្នាក់នៅស្រុកដាម៉ាសឲ្យធ្វើអ្វីខ្លះ ។

- តើព្រះអម្ចាស់បានបង្គាប់ឲ្យអាន៉ានាសធ្វើអ្វីខ្លះ ?

សូមចង្អុលបង្ហាញថា គោលបំណងដំបូងរបស់សុលក្នុងការទៅស្រុកដាម៉ាស គឺដើម្បីចាប់មនុស្សដូចជាអាន៉ានាស ។

- ប្រសិនបើអ្នកជាអាន៉ានាសវិញ ហើយបានដឹងអំពីកិត្តិនាមរបស់សុល តើអ្នកគិតអំពីអ្វីខ្លះ បន្ទាប់ពីបានទទួលការណែនាំនេះមកពីព្រះអម្ចាស់នោះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៩:១៣–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើព្រះអម្ចាស់បានបង្រៀនអាន៉ានាសអ្វីខ្លះអំពីសុល ។

- តើការយល់ឃើញរបស់ព្រះអម្ចាស់ ខុសពីការយល់ឃើញរបស់អាន៉ានាសអំពីសុលយ៉ាងណាខ្លះ ?
- យោងតាម ខទី ១៥ តើព្រះអម្ចាស់បានជ្រើសរើសសុលឲ្យក្លាយជាអ្វី ហើយធ្វើអ្វី ? (អ្នកគួរចង្អុលបង្ហាញថា ឃ្លា « ប្រដាប់រើសតាំង » អាចសំដៅទៅលើភាពពិតដែលសុលត្រូវបានរើសតាំងពីមុនផែនដី ឲ្យធ្វើការងារបម្រើរបស់លោក) ។
- យោងតាម ខទី ១៦ ទោះបីជាសុលនឹងក្លាយជាប្រដាប់រើសតាំងមួយចំពោះព្រះអម្ចាស់ក្តី តើលោកនឹងជួបបទពិសោធន៍អ្វីខ្លះ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីខគម្ពីទាំងនេះ អំពីរបៀបដែលព្រះអម្ចាស់ទតមើលមកយើង ? (សិស្សអាចស្គាល់សេចក្តីពិតខុសគ្នាមួយ ប៉ុន្តែសូមកុំភ្លេចគូសបញ្ជាក់ថា **ព្រះអម្ចាស់ទតឃើញយើងថា យើងអាចក្លាយជាមនុស្សបែបណា** ហើយ **ព្រះអម្ចាស់ទតឃើញនូវសក្តានុពលរបស់យើង ក្នុងការជួយដល់ទ្រង់នៅក្នុងកិច្ចការរបស់ទ្រង់យ៉ាងដូចម្តេច ។** សូមសរសេរសេចក្តីពិតទាំងនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីរបៀបដែលប្រវត្តិផ្ទាល់ខ្លួន លក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈ និងសមត្ថភាពរបស់ពួកគេអាចយកមកប្រើដើម្បីជួយព្រះអម្ចាស់នៅក្នុងកិច្ចការរបស់ទ្រង់ ។ សូមឲ្យពួកគេឲ្យសរសេរគំនិតរបស់ពួកគេចូលក្នុងសៀវភៅសរសេរ ឬ សៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៩:១៧–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើអាន៉ានាសបានធ្វើអ្វីខ្លះ បន្ទាប់ពីព្រះអម្ចាស់បានជួយលោកឲ្យយល់ពីសក្តានុពលរបស់សុល និងបេសកកម្មនាពេលអនាគតរបស់លោក ។

- តើអាន៉ានាសបានធ្វើអ្វីខ្លះសម្រាប់ប៉ុល ?
- យោងតាម ខទី ២០ តើសុល « ស្រាប់តែ » ឬភ្លាមនោះបាន ធ្វើអ្វីខ្លះ បន្ទាប់ពីបានជ្រមុជទឹក ហើយបានទទួលកម្លាំង ?

សូមចង្អុលបង្ហាញថា ការប្រែចិត្ត បុណ្យជ្រមុជទឹក និងការបង្រៀនរបស់សុលបានបង្ហាញអំពីសេចក្តីជំនឿរបស់លោកទៅលើព្រះយេស៊ូវគ្រីស្ទ និងការចុះចូលរបស់លោកទៅតាមព្រះទ័យរបស់ព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ៩:២១–២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប្រជាជននោះមានប្រតិកម្មយ៉ាងដូចម្តេចចំពោះការបង្រៀនរបស់ប៉ុល ។

- តើប្រជាជននោះមានប្រតិកម្មយ៉ាងដូចម្តេចចំពោះការបង្រៀនរបស់ប៉ុល ?
- ហេតុអ្វីប្រជាជននោះមានការភ្ញាក់ផ្អើល នៅពេលពួកគេបានស្តាប់សុល ?

សូមរំឭកសិស្សថា សំណួរដែលសុលបានទូលសួរទៅព្រះយេស៊ូវដែលបានកត់ត្រានៅក្នុង កិច្ចការ ៩:៦ បានបង្ហាញពីការបន្ទាបខ្លួន និងបំណងប្រាថ្នារបស់លោកដើម្បីចុះចូលនឹងព្រះទ័យរបស់ព្រះអម្ចាស់ ។

- ដូចជាសុលដែរ តើយើងត្រូវធ្វើអ្វីខ្លះដើម្បីផ្លាស់ប្តូរ ហើយបំពេញសក្តានុពលដែលព្រះអម្ចាស់បានទតឃើញនៅក្នុងខ្លួនយើង ? (សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖ **ប្រសិនបើយើងចុះចូលតាមព្រះទ័យរបស់ព្រះអម្ចាស់ នោះយើងអាចផ្លាស់ប្តូរ ហើយអាចបំពេញសក្តានុពល ដែលទ្រង់ទតឃើញនៅក្នុងខ្លួនយើង**) ។

សូមអញ្ជើញសិស្សស្ម័គ្រចិត្តពីរនាក់ឲ្យឡើងមកខាងមុខក្តារខៀន ។ សូមឲ្យដីឥដ្ឋទន់ទៅសិស្សម្នាក់ ហើយឲ្យដីឥដ្ឋរឹងទៅសិស្សម្នាក់ទៀត ។ (ប្រសិនបើអ្នកគ្មានដីឥដ្ឋទន់ទេ សូមឲ្យសិស្សស្រមៃថាកំពុងធ្វើសកម្មភាពនេះ បន្ទាប់មកសួរពួកគេនូវសំណួរបន្ទាប់ពី

សកម្មភាពនេះ) ។ សូមឲ្យពេល ៣០ វិនាទីដល់សិស្សស្ម័គ្រចិត្ត ឬបង្កើតអ្វីមួយដែលពួកគេចង់ធ្វើចេញពីដីឥដ្ឋនោះ ។ ប្រសិនបើសិស្សដែលមានដីឥដ្ឋរឹងនិយាយថា វាពិតជាលំបាកខ្លាំងណាស់ សូមលើកទឹកចិត្តគាត់ឲ្យព្យាយាមបន្តែមទៀត ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សដែលស្ម័គ្រចិត្តឲ្យបង្ហាញអ្វីដែលពួកគេបានបង្កើត ។ សូមសួរទៅសិស្សដែលមានដីឥដ្ឋរឹង ៖

- ហេតុអ្វីវាមានការលំបាកដើម្បីសូនអ្វីមួយចេញពីដីឥដ្ឋរបស់អ្នក ?

សូមអរគុណដល់សិស្សស្ម័គ្រចិត្ត ហើយសូមអញ្ជើញពួកគេឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយរបស់ពួកគេវិញ ។ សូមសួរសិស្ស ៖

- តើដីឥដ្ឋរឹងអាចប្រៀបបាននឹងមនុស្សម្នាក់ ដែលពុំចុះចូលនឹងព្រះទ័យរបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ?
- តើដីឥដ្ឋទន់អាចប្រៀបបាននឹងមនុស្សម្នាក់ ដែលចុះចូលនឹងព្រះទ័យរបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ?
- តើការចុះចូលទៅនឹងព្រះអម្ចាស់បានជួយអ្នក ឬអ្នកដទៃឲ្យផ្លាស់ប្តូរ និង បំពេញសក្តានុពលដែលព្រះអម្ចាស់ទតឃើញនៅក្នុងខ្លួនអ្នក ឬ ពួកគេយ៉ាងដូចម្តេចខ្លះ ?

សូមអានឮៗនូវសុន្ទរកថាខាងក្រោមនេះ ដែលថ្លែងដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« [បុគ្គល] ម្នាក់មិនអាចសួរសំណួរដែលសំខាន់នៅក្នុងជីវិតរបស់ [ខ្លួន] គេខ្លាំងជាងសំណួរដែលប៉ុលបានសួរឡើយ ៖ ‹ . . . ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្តេច ? › » (« Listen to a Prophet's Voice » *Ensign* ខែ មករា ឆ្នាំ ១៩៧៣ ទំព័រ ៥៧) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរថា « ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យឲ្យទូលបង្គំធ្វើដូចម្តេច ? » សូមអញ្ជើញពួកគេឲ្យកត់ត្រាការបំផុសគំនិតទាំងឡាយ ដែលពួកគេទទួលបាន ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ប៊ែនសឺន ៖

« [បុគ្គល] ម្នាក់ពុំអាចធ្វើសកម្មភាពណាប្រសើរជាងការដើរតាមផ្លូវដែលនឹងនាំចម្លើយដល់ [ខ្លួន] ចំពោះសំណួរនោះ ហើយបន្ទាប់មកធ្វើតាមចម្លើយនោះឡើយ » (« Listen to a Prophet's Voice » ទំព័រ ៥៧) ។

សូមលើកទឹកចិត្តសិស្សឲ្យបន្តស្វែងរកចម្លើយចំពោះសំណួរនេះ ហើយធ្វើតាមការបំផុសគំនិតនានាដែលពួកគេបានទទួល ។

កិច្ចការ ៩:២៣-៣១

ជីវិតរបស់សុលត្រូវបានគេគំរាមកំហែងនៅក្រុងយេរូសាឡិម ហើយពួកសាវកបានបញ្ជូនលោកទៅស្រុកតើសុស

សូមចង្អុលបង្ហាញថា បន្ទាប់ពីការប្រែចិត្តជឿរបស់សុល លោកបានរស់នៅស្រុកអារ៉ាប់ ហើយក្រោយមកបានត្រឡប់ទៅក្រុងដាម៉ាស (សូមមើល កាឡាទី ១:១៧) ។ សូមមើល កិច្ចការ ៩:២៣–២៦ ដោយពន្យល់ថា សាសន៍យូដានៅក្នុងស្រុក ដាម៉ាសរួមគំនិតដើម្បីសម្លាប់សុល ប៉ុន្តែសមាជិកសាសនាចក្របានជួយលោកឲ្យរត់គេចចេញពីទីក្រុងនោះ ។ បីឆ្នាំបន្ទាប់ពីការប្រែចិត្តជឿរបស់លោក (សូមមើល កាឡាទី ១:១៨) សុលបានទៅក្រុងយេរូសាឡិម ជាកន្លែងដែលសមាជិកសាសនាចក្រមានការភ័យខ្លាចនឹងទទួលយកលោក ដោយសារពួកគេពុំជឿថា លោកបានក្លាយជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទឡើយ ។

- ហេតុអ្វីអ្នកគិតថា សមាជិកសាសនាចក្រមួយចំនួនមានចិត្តស្ងាក់ស្ងើរ ដើម្បីទទួលយកថាសុលបានក្លាយជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមសង្ខេប កិច្ចការ ៩:២៧–៣១ ដោយពន្យល់ថា បាណាបាស ដែលជាសមាជិកសាសនាចក្រម្នាក់ (សូមមើល កិច្ចការ ៤:៣៦–៣៧) បាននាំសុលទៅជួបសាវកទាំងឡាយ ហើយបានប្រាប់ពួកលោកអំពីការនិមិត្តរបស់សុល និងអំពីការប្រកាសដំណឹងល្អដ៏អង់អាចរបស់លោកនៅក្នុងស្រុក ដាម៉ាស ។ ក្រោយមកសមាជិកសាសនាចក្របានស្វាគមន៍សុលដោយក្តីរាប់អាន ។ នៅពេលពួកក្រិកកាន់សាសនាយូដា នៅក្រុងយេរូសាឡិមបានព្យាយាមសម្លាប់សុល នោះអ្នកដឹកនាំសាសនាចក្របានបញ្ជូនលោកទៅស្រុក តើសុស ។ សាសនាចក្របានជួបភាពសុខសាន្ត និងការរីកចម្រើននៅស្រុកយូដា ស្រុកកាលីឡេ និងសាម៉ារី ។

កិច្ចការ ៩:៣២-៤៣

ពេត្រុសសម្តែងអព្ភូតហេតុនៅក្នុងភូមិលីដា និង ក្រុងយ៉ុបប៉េ

សូមចែកសិស្សជាគូ ។ សូមឲ្យសិស្សម្នាក់នៅក្នុងដៃគូនីមួយៗអានកិច្ចការ ៩:៣២–៣៥ ហើយឲ្យសិស្សម្នាក់ទៀតអានកិច្ចការ ៩:៣៦–៤២ ។ សូមអញ្ជើញពួកគេឲ្យរកមើលអព្ភូតហេតុដែលពេត្រុសបានធ្វើ ហើយថាតើប្រជាជនមានប្រតិកម្មបែបណា ។ សូមពន្យល់ថា*ដាក់ទាន* (ខទី ៣៦) គឺជាទម្លាប់នៃការផ្តល់ទានដល់ជនក្រីក្រ ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យពិភាក្សាជាមួយនឹងដៃគូរបស់ពួកគេអំពីអព្ភូតហេតុ ដែលពេត្រុសបានធ្វើ ហើយថាតើប្រជាជនមានប្រតិកម្មបែបណា ។ បន្ទាប់មក សូមសួរសិស្ស ៖

- យោងតាម ខទី ៣៥ និង ៤២តើប្រជាជននៅក្នុងភូមិលីដា និង ប្រជាជននៅក្នុងក្រុងយ៉ុបប៉េ បានមានប្រតិកម្មបែបណាដែរចំពោះការងារបម្រើរបស់ពេត្រុស ?
- តើយើងអាចរៀនអ្វីខ្លះអំពីប្រតិកម្មរបស់ពួកគេចំពោះឥទ្ធិពល ដែលអាចកើតមានពីការងារបម្រើដល់មនុស្សដទៃ ? (សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖**តាមរយៈការបម្រើដល់មនុស្សដទៃ យើងអាចជួយមនុស្សទូទៅឲ្យងាកទៅរកព្រះអម្ចាស់ ហើយជឿលើទ្រង់បាន**) ។

សូមពន្យល់ថា ការប្រគល់បព្វជិតភាពគឺជាវិធីមួយនៃការបម្រើដល់មនុស្សដទៃ ។ ដើម្បីជួយសិស្សឲ្យស្គាល់វិធីបន្ថែមទៀត ដែលយើងអាចធ្វើការងារបម្រើដល់មនុស្សដទៃបាន សូមសួរ ៖

- យោងតាម ខទី ៣៦ និង ៣៩ តើតេប៊ីថាបានធ្វើការងារបម្រើដល់មនុស្សដទៃយ៉ាងដូចម្តេច ?
- តើមនុស្សម្នាក់ដែល « បានធ្វើគុណ » (ខទី ៣៦) ហើយដែលបម្រើដល់មនុស្សដទៃអាចជួយមនុស្សឲ្យងាកទៅរកព្រះអម្ចាស់ ហើយជឿលើទ្រង់បានយ៉ាងដូចម្តេច ?
- តើនៅពេលណាដែរ ដែលការធ្វើគុណរបស់មនុស្សម្នាក់ផ្សេងទៀតបានជួយអ្នក ឬអ្នកដទៃទៀតឲ្យត្រឡប់មករកព្រះអម្ចាស់ និងជឿលើទ្រង់វិញ ?

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយ ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

មេរៀន ៨៩

កិច្ចការ ១០-១១

សេចក្តីផ្តើម

ព្រះបានបើកសម្តែងដល់ពេត្រុសនៅក្នុងការនិមិត្តមួយថា ដំណឹងល្អគួរប្រកាសដល់ពួកសាសន៍ដទៃ ពេត្រុសបានបង្រៀនដំណឹងល្អដល់កូនេសាល និងគ្រួសារគាត់ ហើយក្រោយមកបានដោះស្រាយជម្លោះក្នុងចំណោមពួកបរិសុទ្ធសាសន៍យូដាអំពីការប្រកាសដំណឹងល្អដល់ពួកសាសន៍ដទៃ ។ កិច្ចការរបស់ព្រះអម្ចាស់បានបន្តឆ្ពោះទៅមុខទោះបីជាមានការបៀតបៀនយ៉ាងណាក្តី ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១០

ព្រះបើកសម្តែងដល់ពេត្រុសនៅក្នុងការនិមិត្តមួយថា ដំណឹងល្អគួរប្រកាសដល់ពួកសាសន៍ដទៃ

សូមអញ្ជើញសិស្សឲ្យស្រមៃថា មានមិត្តម្នាក់សួរថា ៖« ខ្ញុំបានឮថានៅឆ្នាំ ១៩៧៨ ព្រះវិហារឯងបានផ្លាស់ប្តូរជំហរខ្លួន ដើម្បីអនុញ្ញាតឲ្យបុរសទាំងអស់ទទួលបព្វជិតភាពដោយពុំគិតពីពូជសាសន៍ ។ ប្រសិនបើអ្នកឯងជឿថា ព្រះវិហារឯងដឹកនាំដោយព្រះ ហើយព្រះគឺជាអង្គដែលពុំចេះផ្លាស់ប្តូរ តើរឿងនោះកើតឡើងបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេពីរបៀបដែលពួកគេនឹងឆ្លើយតបទៅកាន់មិត្តនេះយ៉ាងដូចម្តេច ។ (*កំណត់ចំណាំ* ៖ត្រូវប្រាកដថាសិស្សឆ្លើយតបចំពោះសំណួរនៃការផ្លាស់ប្តូរការអនុវត្តរបស់សាសនាចក្រ ជាជាងគិតពីហេតុផលដែលអាចកើតមានចំពោះការដាក់កំហិតដល់បព្វជិតភាព ។ ហើយក៏កុំគិតពីហេតុផលដែលការដាក់កំហិតនៃបព្វជិតភាពបានកើតឡើងដែរ ដោយសារហេតុផលទាំងនេះពុំបានបើកសម្តែងឡើយ [សូមមើលសេចក្តីប្រកាសជាផ្លូវការទី ២]) ។

នៅពេលសិស្សសិក្សា កិច្ចការ ១០-១១ សូមអញ្ជើញពួកគេឲ្យរកមើលគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលអាចជួយពួកគេឲ្យឆ្លើយនូវសំណួរអំពីរបៀបដែលព្រះអម្ចាស់ដឹកនាំ ណែនាំ ផ្លាស់ប្តូរ ហើយគ្រប់គ្រងសាសនាចក្ររបស់ទ្រង់ ។

សូមពន្យល់ថា រហូតមកដល់ត្រង់នេះនៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ដំណឹងល្អត្រូវបានប្រកាសដល់ពួកសាសន៍យូដាភាគច្រើនដូចដែលបានណែនាំដោយព្រះអង្គសង្គ្រោះ (សូមមើល ម៉ាថាយ ១០:៥–៦) ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គសង្គ្រោះបានប្រាប់ពួកសិស្សរបស់ទ្រង់ផងដែរថា បន្ទាប់ពីព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើពួកគេ នោះពួកគេបានផ្សព្វផ្សាយដំណឹងល្អ « រហូតដល់ចុងផែនដីបំផុត » (កិច្ចការ ១:៨) ។ នៅក្នុង កិច្ចការ ១០ យើងអានអំពីការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងរបៀប ដែលសាសនាចក្របានធ្វើ ដែលនឹងជួយសម្រួលដល់ការណ៍នេះបាន ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:១-២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលព័ត៌មានលម្អិតអំពីសាសន៍ដទៃម្នាក់ឈ្មោះកូនេលាស ។ (អ្នកគ្រូចង្អុលបង្ហាញថា កូនេលាស « ខ្លាចដល់ព្រះ » (ខទី ២) ។ ពួកអ្នកកោតខ្លាចដល់ព្រះ គឺជាពួកសាសន៍ដទៃដែលបានថ្វាយបង្គំព្រះអម្ចាស់ ប៉ុន្តែមិនបានផ្សព្វផ្សាយ ឬប្រែចិត្តជឿដល់សាសនាយូដាទេ ហេតុដូច្នេះហើយពួកគេមិនបានរស់នៅតាមក្រឹត្យវិន័យរបស់ម៉ូសេទាំងស្រុងឡើយ) ។

- តើកូនេលាសធ្វើការអ្វី ? (គាត់ជាមេបញ្ជាការទ័ពរ៉ូម ហើយគ្រប់គ្រងទ័ពមួយរយនាក់) ។

សូមរំឭកសិស្សថា ពីមុនគ្រានេះ ពួកសាសន៍ដទៃម្នាក់មិនអាចចូលរួមក្នុងសាសនាចក្ររបស់ព្រះគ្រីស្ទដោយគ្មានការប្រែចិត្តជឿជាមុនដល់សាសនាយូដាបានឡើយ ដោយសារដំណឹងល្អត្រូវបានផ្សព្វផ្សាយទៅដល់តែពួកសាសន៍យូដាប៉ុណ្ណោះ ។

- ទោះជាកូនេសាលពុំអាចចូលរួមសាសនាចក្រក្នុងនាមជាសាសន៍ដទៃ តើគាត់អាចបង្ហាញសេចក្តីជំនឿរបស់គាត់ដល់ព្រះយ៉ាងដូចម្តេច ?

សូមអញ្ជើញឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង កិច្ចការ ១០:៣-៦ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើងចំពោះកូនេលាស ។ (សូមពន្យល់ថា « ម៉ោង ៣ រសៀល » [ខទី ៣] គឺប្រហែលជាម៉ោង៣:០០ រសៀល) ។

- យោងតាម ខទី ៤ តើទេវតាបានប្រាប់កូនេលាសអ្វីខ្លះ អំពីការអធិស្ឋាន និងការដាក់ទានរបស់គាត់ ?
- តើទេវតាបានប្រាប់កូនេលាសឲ្យធ្វើអ្វីខ្លះ ?

សូមសង្ខេប កិច្ចការ ១០:៧–៨ ដោយពន្យល់ថា កូនេលាសបានបញ្ជូនមនុស្សបីនាក់រកពេត្រុសនៅយ៉ុបប៉េ ។ (ដើម្បីជួយសិស្សឲ្យយល់ទំនាក់ទំនងរវាងសេសារា និងយ៉ុបប៉េ អ្នកគ្រូឲ្យសិស្សបើកទៅផែនទី « ទឹកដីបរិសុទ្ធនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាថ្មី » [ផែនទី ព្រះគម្ពីរប៊ីប លេខ ១១]) ។

សូមពន្យល់ថា កាលបុរសទាំងនេះបានធ្វើដំណើរទៅយ៉ុបប៉េ នោះពេត្រុសមានការនិមិត្តដ៏អស្ចារ្យមួយ ខណៈពេលស្នាក់នៅក្នុងផ្ទះបុរសម្នាក់ដែលមានឈ្មោះថា ស៊ីម៉ូន ។ សូមចែកក្រដាសមួយសន្លឹកដល់សិស្ស ។ សូមអញ្ជើញសិស្សឲ្យអាន កិច្ចការ ១០:៩–១៦ ដោយ

ស្ងៀមស្ងាត់ ហើយគូរូបនៃការនិមិត្តរបស់ពេត្រុស ដូចដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ: ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សុំឲ្យសិស្សប្រើរូបរបស់ពួកគេ ដើម្បីពន្យល់ដល់មិត្តរួមថ្នាក់ពីអ្វី ដែលបានកើតឡើងនៅក្នុងការនិមិត្តរបស់ពេត្រុស ។ ដោយធ្វើតាមសកម្មភាពនេះ សូមសួរ ៖

- នៅក្នុងការនិមិត្តនោះ តើពេត្រុសបានបង្គាប់ឲ្យបរិភោគអ្វី ?
- យោងតាម ខទី ១៤តើអ្វីជាប្រតិកម្មដំបូងគេបង្អស់របស់ពេត្រុស ចំពោះព្រះបញ្ញត្តិនេះ: ? (សូមពន្យល់ថា នៅក្រោមក្រឹត្យវិន័យរបស់លោកម៉ូសេ ពួកសាសន៍យូដាបានហាមមិនឲ្យបរិភោគសត្វដែលបានចាត់ទុកថាជាសត្វសាមញ្ញ ឬមិនស្អាតឡើយ (សូមមើលលេវីវិន័យ ១១)) ។
- យោងតាម ខទី ១៥តើព្រះអម្ចាស់បានមានបន្ទូលយ៉ាងណាដែរ អំពីសត្វមិនស្អាតដែលទ្រង់បានបង្គាប់ឲ្យពេត្រុសបរិភោគនោះ: ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:១៧-២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលបានកើតឡើង កាលពេត្រុសកំពុងសញ្ជឹងគិតអំពីអត្ថន័យនៃការនិមិត្តរបស់លោក ។

- តើឃ្លានៅក្នុង ខទី ១៧ បង្ហាញអ្វីខ្លះថា កាលដំបូងឡើយពេត្រុសពុំបានយល់ពីការនិមិត្តរបស់លោកនោះទេ ?
- កាលពេត្រុសកំពុងសញ្ជឹងគិតពីការនិមិត្តរបស់លោក តើនរណាបានមកដល់ ?
- តើព្រះវិញ្ញាណបានប្រាប់ឲ្យពេត្រុសធ្វើអ្វីខ្លះ: ?

សូមសង្ខេប កិច្ចការ ១០:២១-២៤ ដោយពន្យល់ថា បុរសទាំងបីនាក់នោះបានប្រាប់ពេត្រុសពីការនិមិត្តរបស់កូនេលាស ។ លុះស្អែកឡើង ពេត្រុស និងសិស្សផ្សេងទៀតបានអមដំណើរពួកគេទៅជួបនឹងកូនេលាស ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង កិច្ចការ ១០:២៥-២៨ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើពេត្រុសបានធ្វើអ្វីខ្លះ កាលលោកបានទៅដល់ផ្ទះរបស់កូនេលាស ។

- យោងតាម ខទី ២៨ តើពេត្រុសបាននិយាយអ្វីខ្លះអំពីការប្រាស្រ័យទាក់ទងរវាងពួកយូដា និងពួកសាសន៍ដទៃ ?
- តើឥឡូវនេះពេត្រុសបានយល់អ្វីខ្លះ: ?

សូមសង្ខេប កិច្ចការ ១០:២៩–៣៣ ដោយពន្យល់ថា កូនេសាលបានប្រាប់ពេត្រុសពីការនិមិត្តខ្លួន ។ កូនេសាលក៏បានប្រមូលគ្រួសារ និងមិត្តគាត់មកជុំគ្នាដើម្បីឲ្យពេត្រុសអាចបង្រៀនដល់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:៣៤-៣៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាពេត្រុសបានរៀនអ្វីខ្លះ: ។

- តើអ្នកនឹងសង្ខេបអំពីអ្វី ដែលពេត្រុសបានដឹងយ៉ាងដូចម្តេច ?

សូមសង្ខេប កិច្ចការ ១០:៣៦–៤៣ ដោយពន្យល់ថា ពេត្រុសបានបង្រៀនកូនេសាល និងគ្រួសារគាត់អំពីព្រះយេស៊ូវគ្រីស្ទ និងកិច្ចការល្អ ការឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ ពេត្រុសបានថ្លែងទីបន្ទាល់ថា ជនដែលជឿលើព្រះយេស៊ូវគ្រីស្ទនឹងទទួលបានការផ្តាច់បាបរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:៤៤-៤៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីប្រសិទ្ធភាពដែលការបង្រៀនរបស់ពេត្រុសបានមានចំពោះពួកសាសន៍ដទៃទាំងនេះ: ។ សូមពន្យល់ថា ឃ្លា « ពួកកាត់ស្បែក » ខទី ៤៥ សំដៅទៅលើពួកសិស្សសាសន៍យូដាដែលមកពីយ៉ុបប៉េជាមួយនឹងពេត្រុស ។

- យោងតាម ខទី ៤៤–៤៦តើការបង្រៀនរបស់ពេត្រុសមានឥទ្ធិពលអ្វីខ្លះទៅលើគ្រួសាររបស់កូនេលាស ?
- ហេតុអ្វីពួកយូដាដែលបានមានវត្តមាន នៅពេលនោះមានការភ្ញាក់ផ្អើល ?
- តាមរយៈបទពិសោធន៍របស់ពេត្រុសដែលបានកត់ត្រានៅក្នុង កិច្ចការ ១០តើព្រះអម្ចាស់បានបើកសម្តែងអ្វីខ្លះដល់លោក៣ក់ព័ន្ធនឹងពួកសាសន៍ដទៃ ? (ដំណឹងល្អគួរបានផ្សាយដល់ពួកសាសន៍យូដា ហើយពួកគេគួរបានជ្រមុជទឹកចូលទៅក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ) ។

ដើម្បីជួយសិស្សឲ្យស្គាល់គោលលទ្ធិ ដែលយើងអាចរៀននៅក្នុង កិច្ចការ ១០ សូមចែកពួកគេជាក្រុមដែលមានគ្នាពីរ ឬបីនាក់ ។ សូមផ្តល់ដល់ក្រុមនីមួយៗនូវសំណៅនៃ ឯកសារខាងក្រោមនេះ ឬសរសេរសំណួរទាំងនេះនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យធ្វើការជាមួយនឹងក្រុមខ្លួន ដើម្បីឆ្លើយសំណួរ ។

កិច្ចការ ១០

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងដំណើររឿងរបស់ពេត្រុស និងកូនេលាសស្តីពីរបៀបដែលព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងព្រឹត្តិការណ៍ ដែលព្រះអម្ចាស់បានបើកសម្តែងសេចក្តីពិតដល់ពេត្រុសម្តងបន្តិចៗ ជាជាងបើកសម្តែងទាំងអស់ក្នុងពេលតែមួយ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងដំណើររឿងនេះស្តីពីអ្វីដែលព្រះអាចនឹងធ្វើចំពោះសេចក្តីបង្គាប់ដែលទ្រង់បានប្រទានកាលពីមុន ?

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សបីបួននាក់ឡើងមកក្តារខៀន ដើម្បីសរសេរសេចក្តីពិតនានា ដែលក្រុមខ្លួនបានរកឃើញ ។ សូមប្រាកដថា សេចក្តីពិតខាងក្រោមនេះត្រូវបានបង្ហាញនៅក្នុងអ្វីដែលពួកគេសរសេរ ៖

ព្រះដឹកនាំសាសនាចក្ររបស់ទ្រង់ដោយប្រទានវិវរណៈដល់ព្យាការីរបស់ទ្រង់ ដែលជាសាវកម្នាក់ឯទៀត ។

យើងអាចទទួលបានវិវរណៈ និងការយល់ដឹងជាបន្តបន្ទាប់ នៅពេលយើងគោរពតាមព្រះអម្ចាស់ ។

ព្រះអាចនឹងផ្លាស់ប្តូរ ឬបន្ថែមទៅក្នុងសេចក្តីណែនាំ ដែលទ្រង់បានប្រទានកាលពីមុនស្របតាមព្រះប្រាជ្ញាញាណរបស់ទ្រង់ និងសេចក្តីត្រូវការរបស់កូនចៅទ្រង់ ។

សូមផ្តល់ឱកាសដល់សិស្សឲ្យពន្យល់ ចែកចាយ និងថ្លែងទីបន្ទាល់

ការអនុញ្ញាតឲ្យសិស្សបង្រៀនគ្នាទៅវិញទៅមក ផ្តល់ឱកាសដល់ពួកគេពន្យល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ចែកចាយគំនិត និងបទពិសោធន៍ ហើយថ្លែងទីបន្ទាល់អំពីសេចក្តីពិតដ៏ទេវភាព ។ ការណ៍នេះក៏អាចធ្វើឲ្យសិស្សយល់ដឹងកាន់តែសឹងជម្រៅអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ហើយបង្កើនសមត្ថភាពរបស់ពួកគេក្នុងការបង្រៀនដំណឹងល្អ ។ នៅពេលសិស្សពន្យល់ចែកចាយ ហើយថ្លែងទីបន្ទាល់ នោះព្រះវិញ្ញាណបរិសុទ្ធអាចពង្រឹងដល់ទីបន្ទាល់នៃសេចក្តីពិត ដែលពួកគេបានបង្ហាញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា សេចក្តីពិតទីបីនៅក្នុងបញ្ជីត្រូវបានឆ្លុះបញ្ចាំងយ៉ាងដូចម្តេចខ្លះ នៅក្នុងសេចក្តីថ្លែងការណ៍របស់អែលឌើរ គ្រីស្តូហ្វឺសិន ។

« តាមរយៈបទពិសោធន៍នេះ និង វិវរណៈទៅកាន់ពេត្រុស ព្រះអម្ចាស់បានកែទម្លាប់របស់សាសនាចក្រ ហើយបានបើកសម្តែងឲ្យមានការយល់ដឹងកាន់តែពេញលេញអំពីគោលលទ្ធិដល់ពួកសិស្សរបស់ទ្រង់ ។ ហេតុដូច្នេះហើយ ការប្រកាសដំណឹងល្អបានលាតសន្ធឹងដល់មនុស្សគ្រប់រូប » (« The Doctrine of Christ » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ២០១២ ទំព័រ ៨៨) ។

សូមទុកពេលឲ្យសិស្សរំឭកឡើងវិញនូវអ្វីដែលពួកគេបានសរសេរអំពីរបៀប ដែលពួកគេនឹងឆ្លើយសំណួររបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរគំនិតដែលពួកគេទទួលបានបន្ថែមទៀតពេលកំពុងសិក្សា កិច្ចការ ១០ហើយអនុញ្ញាតឲ្យពួកគេចែកចាយគំនិតទាំងនេះដល់សិស្សក្នុងថ្នាក់ ។

អ្នកនឹងត្រូវចង្អុលបង្ហាញថា ទោះបីជាព្រះអាចនឹងកែសម្រួលការអនុវត្តរបស់សាសនាចក្រ ហើយបន្ថែមដល់ការយល់ដឹងខាងគោលលទ្ធិរបស់យើងតាមរយៈវិវរណៈជាបន្តបន្ទាប់ក្តី (សូមមើល មាត្រានៃ សេចក្តីជំនឿ ១:៩) ក្តី ក៏និស្ស័យ លក្ខណៈ សេចក្តីសញ្ញា គោលលទ្ធិ និងផែនការរបស់ទ្រង់នឹងមិនផ្លាស់ប្តូរឡើយ ។ ការដឹងពីបញ្ហានេះអាចជួយយើងឲ្យមានសេចក្តីជំនឿលើព្រះ ហើយទុកចិត្តថា ទ្រង់នឹងដឹកនាំសាសនាចក្ររបស់ទ្រង់ស្របតាមព្រះឆន្ទៈរបស់ទ្រង់ និងសេចក្តីត្រូវការរបស់កូនចៅទ្រង់ ។

កិច្ចការ ១១:១-១៨

ពេត្រុសបានដោះស្រាយជម្លោះក្នុងចំណោមពួកបរិសុទ្ធសាសន៍យូដា អំពីការបង្រៀនដំណឹងល្អ ដល់ពួកសាសន៍ដទៃ ។

- តើអ្នកគិតថា សមាជិកសាសនាចក្រជាសាសន៍យូដាមួយចំនួនមានអារម្មណ៍បែបណា នៅពេលពួកគេស្តាប់ឮពីការប្រាស្រ័យទាក់ទងរបស់ពេត្រុសជាមួយនឹងសាសន៍ដទៃ ? (ការប្រាស្រ័យទាក់ទងរបស់ពេត្រុសជាមួយនឹងសាសន៍ដទៃគឺជាការផ្លាស់ប្តូរមួយដ៏ធំមួយពីទម្លាប់ចាស់ ហើយសមាជិកមួយចំនួនមានការលំបាកដើម្បីទទួលយកការផ្លាស់ប្តូរនេះ) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១១:១-៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ពួកសិស្សទាំងនោះបានឆ្លើយតបយ៉ាងដូចម្តេចចំពោះអ្វីដែលពេត្រុសបានធ្វើ ។

- តើពួកសិស្សទាំងនោះបានឆ្លើយតបយ៉ាងដូចម្តេច ចំពោះអ្វីដែលពេត្រុសបានធ្វើ ?

សូមសង្ខេប កិច្ចការ ១១:៤-១៥ដោយពន្យល់ថា ពេត្រុសបានពិពណ៌នាទៅពួកសិស្សពីការនិមិត្តដែលលោក និង កូនេលាសបានទទួល ។ លោកបានប្រាប់ពួកគេថា កូនេលាស និង គ្រួសាររបស់លោកបានទទួលការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយក្រោយមកបានទទួលបទពិសោធន៍នៃព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដូចគ្នាទៅនឹងពេត្រុស និងពួកសិស្សផ្សេងទៀតបានមានផងដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១១:១៦-១៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសុន្ទរកថាបញ្ចប់របស់ពេត្រុសទៅកាន់ពួកសិស្សទាំងនោះ ។

- តើអ្នកគិតថា ពេត្រុសចង់មានន័យយ៉ាងណាដែរ នៅពេលលោកបានមានប្រសាសន៍ថា « ចុះតើខ្ញុំជាអ្វីដែលអាចនឹងឃាត់ព្រះបាន » (ខទី ១៧) ? (ពេត្រុសពុំបានបដិសេធព្រះទ័យរបស់ព្រះអំពីការប្រទានឱកាសដល់ពួកសាសន៍ដទៃដើម្បីទទួលដំណឹងល្អប្រែចិត្ត ហើយជ្រមុជទឹកនោះឡើយ) ។

សូមអញ្ជើញសិស្សឲ្យអានកិច្ចការ ១១:១៨ដោយស្ងាត់ស្ងៀម ហើយរកមើលថា ពួកសិស្សបានឆ្លើយតបយ៉ាងដូចម្តេចដល់ការពន្យល់របស់ពេត្រុស ។

- តើពួកសិស្សបានឆ្លើយតបយ៉ាងដូចម្តេច នៅពេលពួកគេបានដឹងថា ពេត្រុសត្រូវបានដឹកនាំដោយព្រះនោះ ?
- តើដំណើររឿងនេះបង្រៀននូវគោលការណ៍អ្វីខ្លះ អំពីរបៀបដែលយើងអាចគាំទ្រ ហើយធ្វើតាមអ្នកដែលធ្វើជាអធិបតីនៅក្នុងសាសនាចក្រនោះ ? (សិស្សអាចរកឃើញគោលការណ៍ខុសៗគ្នា ប៉ុន្តែសូមធ្វើឲ្យប្រាកដថា ពួកគេយល់ថា**នៅពេលយើងដឹងថា ពួកអ្នកដែលធ្វើជាអធិបតីលើសាសនាចក្រត្រូវបានដឹកនាំដោយព្រះ នោះយើងអាចគាំទ្រដោយមានទំនុកចិត្ត ហើយធ្វើតាមពួកគាត់ ។** គោលការណ៍នេះត្រូវបានបញ្ជាក់នៅក្នុងព្រះគម្ពីរសម័យទំនើប ដែលបានកត់ត្រាថា ព្រះបានបើកសម្តែងព្រះឆន្ទៈរបស់ទ្រង់ដល់អស់អ្នក ដែលកាន់កូនសោបព្វជិតភាពជា អធិបតី [សូមមើល គ. និង ស. ២៨:២, ៧, ៤២:១១, ១០៧:៦៥–៦៦]) ។
- តើអ្នកបានដឹងថា អស់អ្នកដែលធ្វើជាអធិបតីលើសាសនាចក្រត្រូវបានដឹកនាំដោយព្រះយ៉ាងដូចម្តេច ?
- តើមានការទូន្មានអ្វីខ្លះ មកពីព្យាការីដែលអ្នកបានជ្រើសធ្វើតាម ដោយសារអ្នកដឹងថាព្យាការីត្រូវបានដឹកនាំដោយព្រះនោះ ?

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយដើម្បីទទួលបានទីបន្ទាល់មួយដ៏រឹងមាំថា អស់អ្នកដែលធ្វើជាអធិបតីលើសាសនាចក្រត្រូវបានដឹកនាំដោយព្រះ ។

កិច្ចការ ១១:១៩–៣០


កិច្ចការរបស់ព្រះអម្ចាស់ឆ្ពោះទៅមុខទោះបីជាមានការបៀតបៀនយ៉ាងណាក្តី ។

សូមសង្ខេបកិច្ចការ ១១:១៩-៣០ ដោយពន្យល់ថា ដោយសារការបៀតបៀន សិស្សមួយចំនួនត្រូវបានខ្ចាត់ខ្ចាយទៅទូទាំងតំបន់នានា ប៉ុន្តែពួកអ្នកស្មោះត្រង់នៅតែបន្តផ្សព្វផ្សាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទមិនថាទីណាដែលពួកគេបានទៅនោះទេ ។

កិច្ចការ ១២

សេចក្តីផ្តើម

ស្តេចហេរ៉ូឌបានសម្លាប់សាវកយ៉ាកុប រួចហើយបានចាប់ពេត្រុសដាក់គុក ។ នៅយប់ពីមុន ពេត្រុសត្រូវគេប្រហារជីវិត មានទេវតាមួយអង្គបានជួយលោកឲ្យគេចខ្លួនពីគុក ។ ទេវតាមួយ អង្គដែលបានចាត់មកពីព្រះបានវាយហេរ៉ូឌ ហើយដំណឹងល្អបានបន្តឆ្ពោះទៅមុខ ។



យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១២:១-១៧

ហេរ៉ូឌប្រហារជីវិតយ៉ាកុប ហើយចាប់ខ្លួនពេត្រុសបានគេចខ្លួនចេញពីគុកដោយអព្ភូតហេតុ

សូមដាក់តាំង ត្រីវិស័យ មួយ ឬគូរវានៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យពន្យល់ថា ត្រីវិស័យមួយដំណើរការយ៉ាងដូចម្តេច ហើយគេប្រើវាសម្រាប់ធ្វើអ្វី ។

- **ដោយសារត្រីវិស័យតែងចង្អុលទៅទិសខាងជើង តើការប្រើត្រីវិស័យអាចជួយយើងឲ្យធ្វើការសម្រេចចិត្តត្រឹមត្រូវអំពីទិសដៅលយើងគួរទៅបានយ៉ាងដូចម្តេច ?**

សូមគូរសញ្ញា X មួយនៅលើក្តារខៀននៅក្បែរត្រីវិស័យនោះ: (ប៉ុន្តែពុំមែននៅក្បែរចំណុចប្រាប់ទិសខាងជើងទេ) ហើយចូរសុំឲ្យសិស្សនឹកស្រមើស្រមៃថាសញ្ញា X តំណាងឲ្យមេដែកមួយដែលមានដៃយូរ ។

- **តើមេដែកនេះនឹងមានឥទ្ធិពលទៅលើទ្រនិចត្រីវិស័យនោះយ៉ាងណាដែរ ? (ទ្រនិចនោះនឹងចង្អុលទៅមេដែកដែលនៅក្បែរនោះ ដោយសារវាមានទំនាញម៉ាញ៉េទិចភាគខាងជើង) ។**
- **តើមេដែកនេះនឹងមានឥទ្ធិពលដល់លទ្ធភាពរបស់អ្នក ក្នុងការជ្រើសរើសទិសត្រឹមត្រូវដែលអ្នកគួរទៅបានយ៉ាងដូចម្តេច ?**

នៅពេលសិស្សសិក្សា កិច្ចការ ១២ សូមលើកទឹកចិត្តសិស្សឲ្យរកមើលឥទ្ធិពលមួយ ដែលអាចរារាំងលទ្ធភាពរបស់យើងនៅក្នុងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ។

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនៅក្នុង កិច្ចការ ១២សូមពន្យល់ថា ចាប់តាំងពីការធ្វើទុក្ករកម្មដល់ស្តេផាន ពួកគ្រីស្ទានបានរីករាលដាលនៅក្នុង និងនៅជុំវិញក្រុងយេរូសាឡិមបានជួបនឹងការបៀតបៀនកាន់តែច្រើនឡើង ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១២:១-៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលស្តេចហេរ៉ូឌ អ័គ្រីប៉ាបានរួមចំណែកដល់ការបៀតបៀននេះ: ។ (សូមពន្យល់ថា មួយសង្កាត់ស្មើនឹងទាហានបួននាក់) ។

- **តើស្តេចហេរ៉ូឌបានយកដាវសម្លាប់នរណា ?**
- **យោងតាម ខទី ៣តើនរណាពីរការយចំពោះការសំឡាប់យ៉ាកុប ?**

សូមពន្យល់ថា ឃ្លា « ពួកសាសន៍យូដា » នៅក្នុង ខទី ៣ សំដៅទៅលើពួកអ្នកដឹកនាំសាសន៍យូដាដ៏មានឥទ្ធិពលនៅក្នុងក្រុងយេរូសាឡិម ដែលបានលើកទឹកចិត្តឲ្យមានការបៀតបៀនដល់សាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ ។ ស្តេចហេរ៉ូឌបានខិតខំផ្គាប់ចិត្តពួកអ្នកដឹកនាំសាសន៍យូដាទាំងនេះ (សូមមើល Bible Dictionary, « Herod ») ។ សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនេះនៅក្បែរសញ្ញា X នៅលើក្តារខៀន *៖ប្រសិនបើយើងជ្រើសធ្វើឲ្យមនុស្សដទៃរីករាយលើសពីព្រះ នោះ* . . .

- **តើស្តេចហេរ៉ូឌបានធ្វើអ្វីខ្លះ: បន្ទាប់ពីទ្រង់បានទតឃើញថា ការសម្លាប់យ៉ាកុបបានធ្វើឲ្យពួកអ្នកដឹកនាំយូដាទាំងឡាយសប្បាយចិត្ត ? (ទ្រង់បានដាក់ផែនការចង់សម្លាប់ពេត្រុសជាសាធារណៈ) ។**

សូមចង្អុលទៅរូបភាពនៃត្រីវិស័យនៅលើក្តារខៀន ហើយសួរ ៖

- **តើបំណងប្រាថ្នារបស់ស្តេចហេរ៉ូឌដើម្បីធ្វើឲ្យមនុស្សដទៃរីករាយ ជាជាងព្រះនោះបានជះឥទ្ធិពលដល់ទិសដៅក្នុងជីវិតរបស់ហេរ៉ូឌយ៉ាងណាដែរ ?**
- **ដោយផ្អែកលើអ្វីដែលអ្នកបានរៀនមកពីគំរូរបស់ស្តេចហេរ៉ូឌ តើអ្នកនឹងបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀនយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដើម្បីវានាំទៅរកសេចក្តីពិតដូចតទៅនេះ: ៖ប្រសិនបើយើងចង់ធ្វើឲ្យមនុស្សដទៃរីករាយជាជាងព្រះ នោះយើងអាចនឹងបាននាំឲ្យធ្លាក់កាន់តែជ្រៅទៅក្នុងអំពើបាប) ។**
- **តើឧទាហរណ៍មួយចំនួនផ្សេងទៀតដែលបង្ហាញថា ការស្វែងរកដើម្បីផ្គាប់ចិត្តមនុស្សដទៃជាជាងការគាប់ព្រះទ័យព្រះ អាចដឹកនាំមនុស្សម្នាក់ឲ្យធ្វើអំពើបាបនោះមានអ្វីខ្លះ ?**

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីរបៀប ដែលពួកគេអាចនឹងកំពុងអនុញ្ញាតឲ្យបំណងប្រាថ្នាខ្លួនធ្វើឲ្យមនុស្សដទៃរីករាយ ដឹកនាំពួកគេឲ្យឃ្លាតឆ្ងាយចេញពីព្រះវរបិតារបស់ពួកគេដែលគង់នៅលើស្ថានសួគ៌ ។

សូមពន្យល់ថា សិស្សនឹងត្រូវអញ្ជើញឲ្យ ដើរតួសម្តែងពីព្រឹត្តិការណ៍ នៅក្នុង កិច្ចការ ១២:៥–១៧ ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យដើរតួជាពេត្រុស ទាហានពីរនាក់ ទេវតា រ៉ូដា និងសិស្សម្នាក់ ឬពីរនាក់នៅផ្ទះរបស់ម៉ារា ជាម្តាយរបស់ម៉ាកុស ។ អ្នក ឬសិស្សម្នាក់ទៀតអាចដើរតួជាអ្នកពោល ។

- ចូរសុំអ្នកពោលឲ្យអាន កិច្ចការ ១២:៥–៦ ឮៗ ហើយអញ្ជើញសិស្សដែលដើរតួដូចដែលបានលើកឡើងនៅក្នុងខគម្ពីរនេះ ឲ្យសម្តែងតាមអ្វីដែលបានអាន ។ ដើម្បីជួយសិស្សឲ្យយល់ពីមាតិកានេះ សូមផ្អាកបន្ទាប់ពីការអានន្ទវក្រុមនៃខគម្ពីរនីមួយៗ ហើយសម្តែង រួចហើយសួរសំណួរដែលទាក់ទង ។
- តើសមាជិកសាសនាចក្រកំពុងធ្វើអ្វីនៅពេលនេះ ?

ចូរសុំអ្នកពោលឲ្យអាន កិច្ចការ ១២:៧-១០ ឮៗ ខណៈសិស្សដែលបានចាត់តាំងសម្តែងនូវអ្វីដែលបានអាន ។

- តើការរារាំង ឬឧបសគ្គអ្វីដែលពេត្រុសបានឆ្លងកាត់នៅក្នុងការគេចខ្លួននេះ ?

ចូរសុំអ្នកពោលឲ្យអាន កិច្ចការ ១២:១១-១៥ ឮៗ ខណៈសិស្សដែលបានចាត់តាំងសម្តែងនូវអ្វីដែលគេបានអាន ។

- តើពេត្រុសបានដឹងពីអ្វីដែលកើតឡើងនៅពេលណា ?
- តើមានអ្វីបានកើតឡើង នៅពេលពេត្រុសបានគោះទ្វារផ្ទះរបស់ម៉ារា ?

ចូរសុំអ្នកពោលឲ្យអាន កិច្ចការ ១២:១៦-១៧ ឮៗ ហើយអញ្ជើញសិស្សដែលបានចាត់តាំងសម្តែងនូវអ្វីដែលគេបានអាន ។ បន្ទាប់ខគម្ពីរទាំងនេះត្រូវបានសិស្សអាន ហើយសម្តែងរួចហើយ សូមអញ្ជើញសិស្សឲ្យទៅអង្គុយវិញ ។

- យោងតាម ខទី ១៧តើពេត្រុសបានផ្តល់ការសរសើរដល់នរណា ដែលបានជួយគាត់ឲ្យគេចខ្លួនពីទីឃុំឃាំង ? (សូមចង្អុលបង្ហាញថា យ៉ាកុបដែលបានលើកឡើងនៅក្នុង ខទី ១៧ គឺជាប្អូនប្រុសម្នាក់របស់ព្រះយេស៊ូវ [សូមមើល ម៉ាថាយ ១៣:៥៥]) ។

សូមអញ្ជើញសិស្សឲ្យរំឭក កិច្ចការ ១២:៥ ឡើងវិញ ហើយរកមើលអំពីរបៀបដែលខគម្ពីរនេះទាក់ទងនឹងអ្វី ដែលបានកើតឡើងដល់ពេត្រុស ។

- តើអ្នកគិតថាឃ្លា « គេខំប្រឹងអធិស្ឋានដល់ព្រះឲ្យគាត់អស់ពីចិត្ត » (ខទី ៥) ប្រាប់អ្វីខ្លះ អំពីភាពស្មោះត្រង់ និងការលះបង់ក្នុងការអធិស្ឋានរបស់សមាជិកសាសនាចក្រ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងដំណើររឿងនេះស្តីពីប្រសិទ្ធភាពដែលការអធិស្ឋានរបស់យើងអាចជួយដល់ខ្លួនយើង និងមនុស្សដទៃបាន ? (សិស្សគួររកឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ការអធិស្ឋានដ៏ស្មោះ និង អស់ពីចិត្តរបស់យើង ញុាំងឲ្យមានអព្ភូតហេតុ និងពរជ័យពីព្រះចូលមកក្នុងជីវិតរបស់យើង និងជីវិតមនុស្សដទៃទៀត ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើការអធិស្ឋានដោយស្មោះ និងជាញឹកញាប់មានន័យដូចម្តេច ?

សូមពន្យល់ថា គោលការណ៍នេះពុំមែនមានន័យថា ប្រសិនបើការអធិស្ឋានរបស់យើងស្មោះត្រង់ ហើយស្ងាហាប់ នោះយើងនឹងទទួលអ្វីដែលយើងកំពុងអធិស្ឋានសូមដោយស្វ័យប្រវត្តិនោះទេ ។ កត្តាចូលរួមចំណែកផ្សេងទៀតចំពោះការទទួលបានអព្ភូតហេតុ និងពរជ័យមកពីព្រះ រួមបញ្ចូលទាំងព្រះទ័យ និងពេលវេលារបស់ព្រះ ក៏ដូចជាសិទ្ធិជ្រើសរើសរបស់បុគ្គលផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗ ។ ចូរសុំឲ្យសិស្សស្តាប់រកមើលថា ការអធិស្ឋានដែលស្មោះអស់ពីចិត្ត ហើយមានការលះបង់របស់យើងអាចជះឥទ្ធិពលដល់ព្រះទ័យរបស់ព្រះយ៉ាងដូចម្តេច ។

« ការអធិស្ឋានគឺជាទង្វើ ដែលព្រះហឫទ័យរបស់ព្រះវរបិតា និងឆន្ទៈរបស់កូន បាននាំឲ្យមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក ។ គោលបំណងនៃការអធិស្ឋាន គឺពុំមែនដើម្បីផ្លាស់ប្តូរព្រះហឫទ័យរបស់ព្រះឡើយ ប៉ុន្តែដើម្បីសូមនូវព្រះពរទាំងឡាយដែលព្រះទ្រង់ប្រណី នឹងប្រទានឲ្យដល់យើង និង ដល់អ្នកឯទៀត ប៉ុន្តែគឺយើងត្រូវតែសុំដើម្បីឲ្យបានទទួល ។ ព្រះពរតម្រូវឲ្យមានសកម្មភាព ឬការប្រឹងប្រែងខ្លះនៅក្នុងចំណែករបស់យើងមុននឹងអាចទទួលវាបាន ។ ការអធិស្ឋាន គឺជាទង្វើ និងជាធម្មោបាយដែលបានចាត់សម្រាប់ការទទួលនូវពរជ័យទាំងអស់ដ៏ខ្ពស់បំផុត » (សេចក្តីយោងដល់បទគម្ពីរទាំងឡាយ « ការអធិស្ឋាន ») ។

- យោងតាមឃ្លានេះ តើអ្វីទៅជាគោលបំណងដ៏សំខាន់នៃការអធិស្ឋាន ?
- ហេតុអ្វីការចងចាំថា គោលបំណងនៃការអធិស្ឋានពុំមែនដើម្បីផ្លាស់ប្តូរព្រះទ័យរបស់ព្រះគឺជារឿងដ៏សំខាន់ ?

សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរដូចខាងក្រោម ក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើការអធិស្ឋានបានញុាំងឲ្យមានអព្ភូតហេតុ និងពរជ័យមកពីព្រះនៅក្នុងជីវិតរបស់អ្នក ឬនៅក្នុងជីវិតរបស់មនុស្សដទៃទៀតដែលអ្នកបានអធិស្ឋានឲ្យនៅពេលណា ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមពិចារណាអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ ដោយធ្វើតាមយោបល់របស់សិស្ស សូមអញ្ជើញពួកគេឲ្យពិចារណាថា ពួកគេអាចអធិស្ឋានឲ្យកាន់តែស្មោះអស់ពីចិត្ត និងមានការលះបង់ដើម្បីញុាំងឲ្យកើតមានពរជ័យ និងអព្ភូតហេតុនានាដែលព្រះមានព្រះទ័យប្រទានដល់ពួកគេ និងមនុស្សដែលពួកគេអធិស្ឋានឲ្យ ។

ប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នា

គ្រូបង្រៀនដ៏មានប្រសិទ្ធភាពមានវិធីខុសៗគ្នា ដែលពួកគេបង្រៀននៅក្នុងមេរៀននេះ និងពីមួយថ្ងៃទៅមួយថ្ងៃ ។ មានឆន្ទៈដើម្បីដកពិសោធន៍នឹងវិធីសាស្ត្រ ឬការចាប់ផ្តើមថ្មី ។ សូមត្រៀមផ្លាស់ប្តូរវិធីសាស្ត្រក្នុងអំឡុងមេរៀននេះផងដែរ ប្រសិនបើសិស្សគ្មានចំណាប់អារម្មណ៍ ឬក៏អ្វីដែលពួកគាត់កំពុងធ្វើហាក់ដូចជាពុំបានសម្រេចស្របតាមលទ្ធផលដែលពួកគេចង់បាននោះ ។

កិច្ចការ ១២:១៨-២៥

ព្រះបានវាយស្តេចហេរ៉ូឌ ហើយដំណឹងល្អបានបន្តរីកចម្រើនទៅមុខ

សូមសង្ខេប កិច្ចការ ១២:១៨–២២ ដោយពន្យល់ថា លុះស្អែកឡើង ស្តេចហេរ៉ូឌបានដឹងពីការគេចខ្លួនរបស់ពេត្រុស ហើយបានសម្លាប់ទាហានដែលទ្រង់គិតថា ត្រូវទទួលខុសត្រូវចំពោះការអនុញ្ញាតឲ្យពេត្រុសគេចខ្លួន ។ ក្រោយមកទៀត ស្តេចហេរ៉ូឌបានថ្លែងទៅកាន់ប្រជាជនដែលបានសរសើរទ្រង់ចំពោះបន្ទូលទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១២:២៣-២៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលបានកើតឡើងចំពោះស្តេចហេរ៉ូឌ ។

- **តើមានរឿងអ្វីបានកើតឡើងចំពោះស្តេចហេរ៉ូឌ ? ហេតុអ្វី ?**
- **តើមានអ្វីបានកើតឡើងដល់កិច្ចការផ្សព្វផ្សាយសាសនារបស់សាសនាចក្រ ថ្វីបើសមាជិកសាសនាចក្ររងនូវការបៀតបៀនក្តី ?**

សូមបញ្ចប់ដោយអញ្ជើញសិស្សឲ្យរំឭកឡើងវិញនូវសេចក្តីពិតដែលពួកគេបានរៀន ហើយសញ្ជឹងគិតអំពីរបៀបដែលពួកគេនឹងអនុវត្តសេចក្តីពិតទាំងនោះនៅក្នុងជីវិតរបស់ពួកគេ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

កិច្ចការ ១២:១-១៧ ។ ពេត្រុស និងយ៉ាកុបទុកព្រះខ្ពស់ជាងគេបង្អស់

កិច្ចការ ១២បង្ហាញថា ពេត្រុស និងយ៉ាកុបបានដាក់ព្រះខ្ពស់ជាងជីវិតរបស់ពួកលោក ថ្វីបើពួកលោកទទួលការដាក់ទោសយ៉ាងណាក៏ដោយ ។ ហេតុអ្វីការស្រឡាញ់ព្រះ ហើយដាក់ទ្រង់ឲ្យខ្ពស់ជាងគេនៅក្នុងជីវិតរបស់យើងជារឿងសំខាន់ ? អែលឌើរ លីន ជី រ៉ូប៊ីន ក្នុងគណៈប្រធាននៃពួកចិតសិបនាក់ បានលើកឡើងនូវបទពិសោធន៍ដូចខាងក្រោមនេះ ដែលវាបានជួយលោកឲ្យយល់ពីសារៈសំខាន់នៃទិសដៅដែលយើងត្រូវដើរនៅក្នុងជីវិតរបស់យើង ៖

« ‹ តើបងប្អូនបែរមុខទៅផ្លូវមួយណា ? › ប្រធាន ប៊ិយដ៍ ឃេ ផាកគឺ បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលជាមួយនឹងសំណួរមួយ ពេលពួកយើងកំពុងធ្វើដំណើរទាំងអស់គ្នាក្នុងការចាត់តាំងដំបូងរបស់ខ្ញុំក្នុងនាមជាពួកចិតសិបនាក់ថ្មីមួយរូប ។ ដោយគ្មានការបកស្រាយពីសំណួរនេះ ខ្ញុំមានអារម្មណ៍ច្របូកច្របល់ ។ លោកបន្តថា ‹ ពួកចិតសិបនាក់ពុំធ្វើជាតំណាងរាស្ត្រថ្លែងទៅកាន់ព្យាការីឡើយ តែតំណាងព្យាការីថ្លែងទៅកាន់រាស្ត្រទៅវិញ › ។ សូមលោកកុំភ្លេចថាត្រូវផ្តោតអារម្មណ៍ទៅលើអ្វីឲ្យសោះ! › វាជាមេរៀនដ៏មានអានុភាពមួយ ។

« ការព្យាយាមផ្តាប់ចិត្តមនុស្សជាងធ្វើតាមព្រះហឫទ័យព្រះ គឺជាការប្រព្រឹត្តផ្ទុយទៅនឹង *ព្រះបញ្ញត្តិធំៗទីមួយ និង ទីពីរ* ។ (សូមមើល ម៉ាថាយ ២២:៣៧–៣៩) ។ វាជាការភ្លេចថាយើងបែរមុខរបស់យើងទៅកាន់ទិសណា ។ ហើយយើងឆ្លាប់បានធ្វើកំហុសនោះ ព្រោះយើងខ្លាចមនុស្ស ។ ព្រះអម្ចាស់បានព្រមានយើងក្នុងអេសាយថា ‹ កុំឲ្យខ្លាចសេចក្តីត្មះតិះដៀលរបស់មនុស្សឡើយ › (អេសាយ ៥១:៧ សូមមើលផងដែរ នីហ្វៃទី ២ ៨:៧) ។ ក្នុងការនិមិត្តរបស់លីហៃ ការភិតភ័យនេះផ្តើម*ដោយការចំអកពីអគារដ៏ធំ* ហើយទូលាយដែលបណ្តាលឲ្យមនុស្សជាច្រើនភ្លេចពីអ្វីដែលត្រូវផ្តោតអារម្មណ៍ ហើយដើរចេញពីដើមឈើដោយ ‹ មានការខ្មាស់អៀន › (សូមមើល នីហ្វៃទី ១ ៨:២៥–២៨) » (« Which Way Do You Face? » *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ២០១៤ ទំព័រ ៩) ។

កិច្ចការ ១២:៥ ។ « គេខំប្រឹងអធិស្ឋានដល់ព្រះឲ្យគាត់អស់ពីចិត្ត »

ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្ហាញការដឹងគុណរបស់លោកចំពោះមនុស្សដែលបានអធិស្ឋានឲ្យលោក និងថ្នាក់ដឹកនាំរបស់សាសនាចក្រ ៖

« ខ្ញុំសូមបង្ហាញអំណរគុណរបស់ខ្ញុំចំពោះ បងប្អូន សម្រាប់ការមានសណ្តានចិត្តល្អដល់ខ្ញុំនៅគ្រប់ទីកន្លែងដែលខ្ញុំទៅ ។ ខ្ញុំសូមអរគុណបងប្អូន សម្រាប់ការអធិស្ឋានឲ្យខ្ញុំ ។ ខ្ញុំទទួលអារម្មណ៍ពីការអធិស្ឋានទាំងនោះ ហើយខ្ញុំមានអំណរគុណចំពោះវាខ្លាំងណាស់ » (« As We Gather Once Again » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៥) ។

« ខ្ញុំស្រឡាញ់ហើយអធិស្ឋានសម្រាប់បងប្អូន » ។ ខ្ញុំសូមស្នើសុំម្តងទៀតឲ្យបងប្អូនចងចាំដល់ខ្ញុំ និងពួកអ្នកមានសិទ្ធិអំណាចទូទៅទាំងអស់នៅក្នុងការអធិស្ឋាន ។ យើងរួបរួមនឹងបងប្អូននៅក្នុងការដើរតាំការងារដ៏អស្ចារ្យនេះឲ្យឆ្ពោះទៅមុខ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ដល់បងប្អូនថាយើងនៅក្នុងកិច្ចការនេះរួមគ្នា ហើយថាបុរស ស្ត្រី និងកុមារគ្រប់រូបមានចំណែកមួយនៅក្នុងកិច្ចការនេះ ។ សូមឲ្យព្រះប្រទានកម្លាំង និងសមត្ថភាព ព្រមទាំងការតាំងចិត្តដល់យើង ដើម្បីយើងអាចបំពេញផ្នែករបស់យើងឲ្យបានល្អប្រសើរ » (« Until We Meet Again » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ១០៩) ។

ប្រធាន ហារ៉ុល ប៊ី លី បានផ្តល់ការយល់ដឹងទាក់ទងនឹងការអធិស្ឋានដ៏ខ្លាំងក្លា ៖

« បងប្អូនត្រូវមានបំណងប្រាថ្នាធ្វើវាឲ្យអស់ពីព្រលឹង ! បងប្អូនត្រូវធ្វើឲ្យអស់ពីកម្លាំងដែលបងប្អូនមាន ហើយមានបំណងប្រាថ្នាមួយថា ការណ៍នេះគឺជារឿងដ៏មានតម្លៃបំផុតនៅក្នុងពិភពលោកទាំងមូលនេះ ដែលបងប្អូនខិតខំស្វែងរក ! » (*Teachings of Harold B. Lee* និពន្ធដោយ Clyde J. Williams [ឆ្នាំ ១៩៩៦] ទំព័រ ១២៥) ។

កិច្ចការ ១២:២១–២៣ ។ ការសុគតរបស់ស្តេច ហេរ៉ូឌ អ័គ្រីប៉ា ទីមួយ

ស្តេច ហេរ៉ូឌ អ័គ្រីប៉ា ទីមួយ គឺជាក្មួយប្រុសរបស់ហេរ៉ូឌផងដែរ ។ ជាទូទៅ ទ្រង់មានភាពល្បីល្បាញនៅក្នុងចំណោមពួកផារិស៊ី ដោយសារទ្រង់គោរពប្រតិបត្តិតាមប្រពៃណីរបស់យូដាដោយប្រុងប្រយ័ត្ន ។ វាប្រហែលជាដោយសារតែហេតុផលនេះហើយ—ការល្បីឈ្មោះនៅក្នុងចំណោមពួកយូដា—ទើបទ្រង់បានបង្គាប់ឲ្យគេសម្លាប់យ៉ាកុប (សូមមើល កិច្ចការ ១២:១–២) ។ អ័គ្រីប៉ាបានសុគតនៅក្នុងព្រះជន្ម ៥៤ ព្រះវស្សា នៅក្នុង គ.ស.៤៤ ក្នុងឆ្នាំដាមួយគ្នាដែលយ៉ាកុបត្រូវបានគេធ្វើទុក្ករកម្ម ។ លូកាបានឃើញការសុគតភ្លាមៗរបស់អ័គ្រីប៉ា ដោយសារការដាក់ទោសមកពីព្រះ តាមរយៈទេវតាមួយអង្គរបស់ព្រះអម្ចាស់ » (*New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៤] ទំព័រ ៣០២, សូមមើលផងដែរ Bible Dictionary « Herod ») ។

មេរៀនសិក្សានៅផ្ទះ

កិច្ចការ ៦-១២ (មេរៀនទី ១៨)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា កិច្ចការ ៦-១២ (មេរៀនទី ១៨) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (កិច្ចការ ៦-៧)

សិស្សបានរៀនថា សមាជិកសាសនាចក្រដែលសក្តិសមត្រូវបានហៅឲ្យជួយបម្រើដល់សេចក្តីត្រូវការរបស់មនុស្សជាទៃ ។ ខណៈដែលកំពុងសិក្សាអំពីពាក្យសម្តី និងការធ្វើទុក្ករកម្មរបស់ស្វែផាន នោះពួកគេបានរកឃើញសេចក្តីពិតដូចដូចតទៅនេះ ៖ ការបដិសេធព្រះវិញ្ញាណបរិសុទ្ធអាចដឹកនាំទៅរកការបដិសេធព្រះអង្គសង្គ្រោះ និងពួកព្យាការីរបស់ទ្រង់ ។ ព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ ជាតួអង្គបីផ្សេងគ្នា ។ ប្រសិនបើយើងបន្តស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទនៅក្នុងគ្រាទុក្ខលំបាក នោះទ្រង់នឹងគង់នៅជាមួយនឹងយើង ។

ថ្ងៃទី ២ (កិច្ចការ ៨)

នៅក្នុងការសិក្សារបស់ពួកគេអំពី កិច្ចការ ៨ សិស្សបានរៀនដូចខាងក្រោមអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ៖ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធត្រូវបានប្រទានឲ្យបន្ទាប់ពីពិធីបុណ្យជ្រមុជទឹកតាមរយៈការដាក់ដៃលើដោយពួកអ្នកកាន់បព្វជិតភាព ។ បព្វជិតភាពបានប្រទានឲ្យស្របតាមព្រះឆន្ទៈ និងបទដ្ឋាននៃភាពសក្តិសមរបស់ព្រះ ។ នៅពេលយើងស្តាប់តាមការបំផុសគំនិតពីព្រះ យើងអាចទទួលបានឱកាសជួយដឹកនាំមនុស្សជាទៃទៅរកព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ៣ (កិច្ចការ ៩)

នៅក្នុង កិច្ចការ ៩សិស្សបានរៀនថា ព្រះអម្ចាស់ទតឃើញសក្តានុពល ដែលយើងអាចទទួលបាន ហើយថាទ្រង់ទតឃើញសក្តានុពលរបស់យើងសម្រាប់ការជួយទ្រង់នៅក្នុងកិច្ចការរបស់ទ្រង់ ។ ពួកគេក៏បានរៀនគោលការណ៍ទាំងឡាយដូចតទៅនេះផងដែរ ៖ ប្រសិនបើយើងចុះចូលតាមព្រះទំរាស់របស់ព្រះអម្ចាស់ នោះយើងអាចផ្លាស់ប្តូរ ហើយអាចបំពេញសក្តានុពល ដែលទ្រង់ទតឃើញនៅក្នុងខ្លួនយើង ។ តាមរយៈការបម្រើដល់មនុស្សជាទៃ យើងអាចជួយមនុស្សទូទៅឲ្យបែរទៅរកព្រះអម្ចាស់ ហើយជឿលើទ្រង់ ។

ថ្ងៃទី ៤ (កិច្ចការ ១០-១២)

សិស្សបានសិក្សាការនិមិត្តរបស់ពេត្រុសអំពីការប្រកាសដំណឹងល្អដល់ពួកសាសន៍ដទៃ ហើយបានរៀនថា នៅពេលយើងដឹងថា ពួកអ្នកដែលធ្វើជាអធិបតីលើសាសនាចក្របានដឹកនាំដោយព្រះ យើងអាចគាំទ្រដោយមានទំនុកចិត្ត ហើយធ្វើតាមពួកគាត់ ។ ពួកគេក៏បានរៀនសេចក្តីពិតទាំងឡាយដូចតទៅនេះផងដែរ ៖ ប្រសិនបើយើងចង់ធ្វើឲ្យមនុស្សជាទៃកែរាយជាជាងព្រះ នោះយើងអាចនឹងបាននាំឲ្យធ្លាក់កាន់តែជ្រៅទៅក្នុងអំពើបាប ។ ការអធិស្ឋានដ៏ស្មោះ ហើយស្វាហាប់របស់យើង ទូលសូមអត្ថហេតុ និងពរជ័យរបស់ព្រះចូលមកក្នុងជីវិតរបស់យើង និងជីវិតមនុស្សជាទៃទៀត ។

សេចក្តីផ្តើម

ព្រះបានបើកសម្តែងដល់ពេត្រុសតាមរយៈការនិមិត្តមួយថា ដំណឹងល្អគួរប្រកាសដល់ពួកសាសន៍ដទៃ ។ ពេត្រុសបានបង្រៀនដំណឹងល្អដល់កូនេសាល និងគ្រួសារគាត់ ហើយក្រោយមកបានដោះស្រាយដំឡោះក្នុងចំណោមពួកបរិសុទ្ធសាសន៍យូដាអំពីការប្រកាសដំណឹងល្អដល់ពួកសាសន៍ដទៃ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១០

ព្រះបើកសម្តែងដល់ពេត្រុសនៅក្នុងការនិមិត្តមួយថា ដំណឹងល្អគួរប្រកាសដល់ពួកសាសន៍ដទៃ

សូមអញ្ជើញសិស្សឲ្យស្រមៃថា មានមិត្តម្នាក់សួរ ៖« ខ្ញុំបានឮថានៅឆ្នាំ ១៩៧៨ ព្រះវិហារឯងបានផ្លាស់ប្តូរដំហរខ្លួន ដើម្បីអនុញ្ញាតឲ្យបុរសទាំងអស់ទទួលបព្វជិតភាពដោយពុំគិតពីពូជសាសន៍ ។ ប្រសិនបើឯងជឿថា ព្រះវិហារឯងដឹកនាំដោយព្រះ ហើយព្រះគឺជាអង្គដែលពុំចេះផ្លាស់ប្តូរ តើរឿងនោះកើតឡើងបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរបស់ពួកគេថាពួកគេនឹងឆ្លើយតបទៅកាន់មិត្តម្នាក់នេះយ៉ាងដូចម្តេច ។ *(កំណត់ចំណាំ ៖* ត្រូវប្រាកដថាសិស្សឆ្លើយចំពោះសំណួរនៃការផ្លាស់ប្តូរការអនុវត្តរបស់សាសនាចក្រ ជាជាងគិតពីហេតុផលដែលអាចកើតមានចំពោះការដាក់កំហិតដល់បព្វជិតភាព ។ នៅក្នុងការពិភាក្សារបស់អ្នក ក៏កុំគិតពីមូលហេតុនៃការដាក់កំហិតបព្វជិតភាពបានកើតឡើង ដោយសារហេតុផលទាំងនេះពុំបានបើកសម្តែងឡើយ [សូមមើល សេចក្តីប្រកាសជាផ្លូវការទី ២]) ។

នៅពេលសិស្សសិក្សា កិច្ចការ ១០ សូមអញ្ជើញពួកគេរកមើលសេចក្តីពិតដែលអាចជួយពួកគេឲ្យឆ្លើយនូវសំណួរអំពីរបៀបដែលព្រះអម្ចាស់ដឹកនាំ ណែនាំ ផ្លាស់ប្តូរ ហើយចាត់ចែងសាសនាចក្ររបស់ទ្រង់ ។

សូមពន្យល់ថា រហូតមកដល់ត្រង់នេះ នៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ដំណឹងល្អបានប្រកាសដល់ពួកសាសន៍យូដាភាគច្រើន ដោយមានករណីលើកលែងតែពីរបី ដូចដែលបានណែនាំដោយព្រះអង្គសង្គ្រោះ (សូមមើល ម៉ាថាយ ១០:៥–៦) ។ ប៉ុន្តែនៅក្នុង កិច្ចការ ១០ យើងបានអានអំពីការផ្លាស់ប្តូរដ៏សំខាន់មួយតាមរបៀបដែលសាសនាចក្របានធ្វើ ។

សូមអញ្ជើញសិស្សឲ្យសង្ខេបអ្វីដែលពួកគេបានរៀននៅក្នុងការសិក្សាពួកគេអំពីពួកសាសន៍ដទៃម្នាក់ ដែលមានឈ្មោះថា កូនេសាល ។ (គាត់គឺជាមន្ត្រីម្នាក់នៅ ក្នុងកងទ័ពរ៉ូម ។ គាត់ និងគ្រួសារគាត់គឺជាពួកអ្នកជឿ ហើយកោតខ្លាចដល់ព្រះ ។ ក្នុងនាមជាពួកសាសន៍ដទៃម្នាក់ គាត់ពុំអាចចូលរួមក្នុងសាសនាចក្ររបស់ព្រះគ្រីស្ទដោយគ្មានការប្រែចិត្តជឿដល់សាសនាយូដាបានឡើយ) ។

សូមសង្ខេប កិច្ចការ ១០:៣–៨ ដោយពន្យល់ថា ជាលទ្ធផលនៃភាពស្មោះត្រង់របស់កូនេសាល មានទេវតាមួយអង្គបានលេចមកជួបគាត់ ហើយណែនាំគាត់ឲ្យបញ្ជូនមនុស្សទៅយ៉ុបប៉េដើម្បីរកពេត្រុស ។ កាលពួកបាវបម្រើរបស់កូនេសាលបានធ្វើដំណើរទៅយ៉ុបប៉េ នោះពេត្រុសមានការនិមិត្តដ៏អស្ចារ្យមួយ កាលស្នាក់នៅក្នុងផ្ទះបុរសម្នាក់ដែលមានឈ្មោះថា ស៊ីម៉ូន ។

សូមអញ្ជើញសិស្សពីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង កិច្ចការ ១០:៩-១៦ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ពេត្រុសបានឃើញអ្វីនៅក្នុងការនិមិត្តនោះ ។ (សម្រាប់ភាពខុសពីគ្នា អ្នកគួរឲ្យក្រដាសមួយសន្លឹកដល់សិស្សទុកសម្រាប់សកម្មភាពគំនូរ ។ សូមអញ្ជើញសិស្សឲ្យអានកិច្ចការ ១០:៩–១៦ ដោយស្ងៀមស្ងាត់ ហើយគូររូបនៃការនិមិត្តរបស់ពេត្រុស ដូចដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សុំឲ្យសិស្សប្រើរូបរបស់ពួកគេដើម្បីពន្យល់ដល់មិត្តរួមថ្នាក់ពីអ្វី ដែលបានកើតឡើងនៅក្នុងការនិមិត្តរបស់ពេត្រុស) ។ បន្ទាប់ពីសកម្មភាពមួយណាក៏បាន នៅក្នុងចំណោមសកម្មភាពទាំងពីរនេះ សូមសួរ ៖

- នៅក្នុងការនិមិត្តនោះ តើពេត្រុសបានបង្គាប់ឲ្យបរិភោគអ្វី ?

- យោងតាម ខទី ១៨តើអ្វីជាប្រតិកម្មដំបូងគេបង្អស់របស់ពេត្រុសចំពោះព្រះបញ្ញត្តិនេះ ? (សូមពន្យល់ថា នៅក្រោមក្រឹត្យវិន័យរបស់លោកម៉ូសេ ពួកសាសន៍យូដាបានហាមមិនឲ្យបរិភោគសត្វដែលបានចាត់ទុកថាជាសត្វសាមញ្ញ ឬមិនស្អាតឡើយ [សូមមើល លេវីវិន័យ ១១]) ។
- យោងតាម កិច្ចការ ១០:១៥តើព្រះអម្ចាស់បានមានបន្ទូលយ៉ាងណាដែរ អំពីសត្វមិនស្អាតដែលទ្រង់បានបង្គាប់ឲ្យពេត្រុសបរិភោគ ?

សូមសង្ខេប កិច្ចការ ១០:១៧–២៨ ដោយពន្យល់ថា ដំបូងឡើយពេត្រុសពុំបានយល់ពីអត្ថន័យនៃការនិមិត្តរបស់គាត់នោះទេ ។ នៅពេលគាត់សញ្ជឹងគិតពីរឿងនោះ ពួកបាវបម្រើកូនេសាលបានមកដល់ ហើយបានប្រាប់ពេត្រុសពីការនិមិត្តរបស់កូនេសាល ។ លុះស្តែកឡើង ពេត្រុស និងសិស្សផ្សេងទៀតបានអមដំណើរពួកគេទៅជួបនឹងកូនេសាល ។ ថ្វីបើ ការពិតដែលថា ពួកសាសន៍យូដាភាគច្រើនបានគិតថាការរាប់អាន ឬការទៅជួបនឹងពួកសាសន៍ដទៃម្នាក់គឺជារឿងខុសច្បាប់យ៉ាងណាក្តី ក៏ពេត្រុសនៅតែចូលក្នុងផ្ទះរបស់កូនេសាល ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:២៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលមូលហេតុដែលពេត្រុសបានលើកឡើងទាក់ទងនឹងការរាប់អាន ឬទៅជួបនឹងពួកសាសន៍ដទៃម្នាក់ ។

- តើពេត្រុសបានផ្តល់ជាមូលហេតុអ្វីខ្លះទាក់ទងនឹងការរាប់អានឬទៅជួបនឹងពួកសាសន៍ដទៃម្នាក់ ?

សូមសង្ខេប កិច្ចការ ១០:២៩–៣៣ ដោយពន្យល់ថា កូនេសាលបានប្រាប់ពេត្រុសពីការនិមិត្តខ្លួន ។ កូនេសាលក៏បានប្រមូលគ្រួសារ និងមិត្តគាត់មកជុំគ្នាដើម្បីឲ្យពេត្រុសអាចបង្រៀនដល់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:៣៤-៣៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថាពេត្រុសបានរៀនអ្វីខ្លះ ។

- តើអ្នកនឹងសង្ខេបអំពីអ្វី ដែលពេត្រុសបានដឹងយ៉ាងដូចម្តេច ? (អ្នកគួរពន្យល់ថា កាលព្រះពុំបានសព្វព្រះទ័យចំពោះអស់អ្នកណា ដោយផ្អែកលើភាពខុសគ្នាដូចជា សញ្ជាតិ ឬតួនាទីក្នុងសង្គមនោះទេ ប៉ុន្តែទ្រង់កាត់សេចក្តីមនុស្សទាំងអស់ដោយកិច្ចការពួកគេ ហើយប្រទានពរដល់ជនណាដែលគោរពតាមទ្រង់ ។ អ្នកក៏អាចស្វែងរកបានអត្ថបទ « Race and the Church: All Are Alike unto God » [mormonnewsroom.org/article/race-church] មានប្រយោជន៍ផងដែរ) ។

សូមសង្ខេប កិច្ចការ ១០:៣៦–៤៣ ដោយពន្យល់ថា ពេត្រុសបានបង្រៀនកូនេសាល និងគ្រួសារគាត់អំពីព្រះយេស៊ូវគ្រីស្ទ និងកិច្ចការល្អ ការឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ ពេត្រុសបានថ្លែងទីបន្ទាល់ថា ជនដែលជឿលើព្រះយេស៊ូវគ្រីស្ទនឹងទទួលបានការផ្តាច់បាបរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១០:៤៤-៤៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីប្រសិទ្ធភាពដែលការបង្រៀនរបស់ពេត្រុសបានមានចំពោះពួកសាសន៍ដទៃទាំងនេះ ។ សូមពន្យល់ថា ឃ្លា « ពួកកាត់ស្បែក » នៅក្នុង ខទី ៤៥ សំដៅទៅលើពួកសិស្សសាសន៍យូដាដែលមកពីយ៉ុបប៉េជាមួយនឹងពេត្រុស ។

- យោងតាម ខទី ៤៤–៤៦តើការបង្រៀនរបស់ពេត្រុសមានឥទ្ធិពលអ្វីខ្លះទៅលើគ្រួសាររបស់កូនេលាស ? (អ្នកគួរពន្យល់ថា ឃ្លា « អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ » នៅក្នុង ខទី ៤៥ សំដៅលើ *ព្រះចស្តា* នៃព្រះវិញ្ញាណបរិសុទ្ធដែលមកសណ្ឋិតលើពួកសាសន៍ដទៃ ។ វាខុសពី *អំណោយទាន* នៃព្រះវិញ្ញាណបរិសុទ្ធ ដែលយើងទទួលតាមរយៈពិធីបរិសុទ្ធនៃពិធីបញ្ចាក់បន្ទាប់ពីពិធីបុណ្យជ្រមុជទឹក [សូមមើល កិច្ចការ ៨:១៤–១៧, *Teachings of Presidents of the Church: Joseph Smith* (ឆ្នាំ ២០០៧), ៩៧]) ។
- ហេតុអ្វីពួកយូដាដែលបានមានវត្តមាន នៅពេលនោះមានការភ្ញាក់ផ្អើល ?
- តាមរយៈបទពិសោធន៍របស់ពេត្រុសដែលបានកត់ត្រានៅក្នុង កិច្ចការ ១០តើព្រះអម្ចាស់បានបើកសម្តែងអ្វីខ្លះដល់លោកពាក់ព័ន្ធនឹងពួកសាសន៍ដទៃ ?

ដើម្បីជួយសិស្សឲ្យស្គាល់គោលលទ្ធិ ដែលយើងអាចរៀននៅក្នុង កិច្ចការ ១០ សូមចែកពួកគេជាក្រុមដែលមានគ្នាពីរ ឬបីនាក់ ។ សូមផ្តល់ដល់ក្រុមនីមួយៗនូវសំណៅនៃ ឯកសារខាងក្រោមនេះ ឬសរសេរសំណួរទាំងនេះនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យធ្វើការជាមួយនឹងក្រុមខ្លួនដើម្បីឆ្លើយសំណួរ ។

កិច្ចការ ១០

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងដំណើររឿងរបស់ពេត្រុស និងកូនេលាសស្តីពីរបៀបដែលព្រះអម្ចាស់ដឹកនាំសាសនាចក្ររបស់ទ្រង់ ? (ចូរចងចាំថា ពេត្រុសគឺជាប្រធាននៃសាសនាចក្រ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងព្រឹត្តិការណ៍ ដែលព្រះអម្ចាស់បានបើកសម្តែងសេចក្តីពិតដល់ពេត្រុសម្តងបន្តិចៗ ជាជាងបើកសម្តែងទាំងអស់ក្នុងពេលតែមួយ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងដំណើររឿងនេះស្តីពីអ្វីដែលព្រះអាចនឹងធ្វើចំពោះសេចក្តីបង្គាប់ដែលទ្រង់បានប្រទានកាលពីមុន ?

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សបីបួននាក់ឡើងមកក្តារខៀន ដើម្បីសរសេរសេចក្តីពិតនានា ដែលក្រុមខ្លួនបានរកឃើញ ។ សូមប្រាកដថា សេចក្តីពិតខាងក្រោមនេះត្រូវបានបង្ហាញនៅក្នុងអ្វីដែលពួកគេសរសេរ ៖

ព្រះដឹកនាំសាសនាចក្ររបស់ទ្រង់ដោយប្រទានវិវរណៈដល់ព្យាការីរបស់ទ្រង់ ដែលជាសាវកម្នាក់ ។

យើងអាចទទួលបានវិវរណៈ និងការយល់ដឹងជាបន្តបន្ទាប់ នៅពេលយើងគោរពតាមព្រះអម្ចាស់ ។

ព្រះអាចនឹងផ្លាស់ប្តូរ ឬបន្ថែមទៅក្នុងសេចក្តីណែនាំដែលទ្រង់បានប្រទានកាលពីមុន ស្របតាមព្រះប្រាជ្ញាញាណរបស់ទ្រង់ និងសេចក្តីត្រូវការរបស់កូនចៅទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងក្បាំមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា សេចក្តីពិតទីបីដែលពួកគេបានរកឃើញបានបញ្ជាក់យ៉ាងដូចម្តេចខ្លះ នៅក្នុងសេចក្តីថ្លែងការណ៍របស់អែលឌើរ គ្រីស្តូហ្វឺសិន ៖

« តាមរយៈបទពិសោធន៍នេះ និង វិវរណៈទៅកាន់ពេត្រុស ព្រះអម្ចាស់បានកែទម្លាប់របស់សាសនាចក្រ ហើយបានបើកសម្តែងឲ្យមានការយល់ដឹងកាន់តែពេញលេញអំពីគោលលទ្ធិដល់ពួកសិស្សរបស់ទ្រង់ ។ ហេតុដូច្នេះហើយ ការប្រកាសដំណឹងល្អបានលាតសន្ធឹងដល់មនុស្សគ្រប់រូប » (« The Doctrine of Christ » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៨៨) ។

សូមទុកពេលឲ្យសិស្សរំឭកឡើងវិញនូវអ្វីដែលពួកគេបានសរសេរ អំពីរបៀបដែលពួកគេនឹងឆ្លើយសំណួររបស់ពួកគេអំពីការផ្លាស់ប្តូរទម្លាប់នៅក្នុងសាសនាចក្រ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរគំនិតដែលពួកគេទទួលបានបន្ថែមទៀត កាលសិក្សា កិច្ចការ ១០ហើយអនុញ្ញាតឲ្យពួកគេចែកចាយគំនិតទាំងនេះដល់សិស្សក្នុងថ្នាក់ ។

អ្នកនឹងត្រូវចង្អុលបង្ហាញថា ទោះបីជាព្រះអាចនឹងកែសម្រួលការអនុវត្តរបស់សាសនាចក្រ ហើយបន្ថែមដល់ការយល់ដឹងខាងគោលលទ្ធិរបស់យើងតាមរយៈវិវរណៈដាបន្តបន្ទាប់ក្តី (សូមមើលមាត្រានៃសេចក្តីជំនឿ ១:៩) ក្តី ក៏និស្ស័យ លក្ខណៈ សេចក្តីសញ្ញា គោលលទ្ធិ និងផែនការរបស់ទ្រង់នឹងមិនផ្លាស់ប្តូរឡើយ ។ ការដឹងពីបញ្ហានេះអាចជួយយើងឲ្យមានសេចក្តីជំនឿលើព្រះ ហើយទុកចិត្តថា ទ្រង់នឹងដឹកនាំសាសនាចក្ររបស់ទ្រង់ស្របតាមព្រះឆន្ទៈរបស់ទ្រង់ និងសេចក្តីត្រូវការរបស់កូនចៅទ្រង់ ។

សូមបញ្ចប់មេរៀនដោយអញ្ជើញសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេ អំពីសេចក្តីពិតដែលពួកគេបានរៀន ។

មេរៀនបន្ទាប់ (កិច្ចការ ១៣-១៩)

សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយ ហើយពិចារណានូវសំណួរខាងក្រោមនេះ នៅពេលពួកគេសិក្សា កិច្ចការ ១៣-១៩ ៖ តើប៉ុលបានធ្វើអ្វីខ្លះដល់អេលីម៉ាស ជាគ្រូអាបធ្មប់ ? តើអ្នកគិតថា អ្នកនឹងមានប្រតិកម្មយ៉ាងណា ប្រសិនបើអ្នកត្រូវគេជឿថា អ្នកជាព្រះវិញនោះ ? ហេតុអ្វីប៉ុលនិងបាណាបាសត្រូវបានគេសាទរថាជាព្រះ? តើពេត្រុសបានឆ្លើយយ៉ាងណា ? តើអ្វីជាបញ្ហានៅក្នុងចំណោមសមាជិកសាសនាចក្រពាក់ព័ន្ធនឹងការកាត់ស្បែក ហើយហេតុអ្វីបញ្ហានោះត្រូវដោះស្រាយនៅចំពោះមុខពួកសាវក ? តើអ្វីជាការសម្រេចចិត្តរបស់ពួកគាត់ ? នៅពេលប៉ុលទៅលេងក្រុងអាថែន លោកបានប្រកាសដំណឹងល្អពីលើភ្នំអើយ៉ូសអំពីព្រះដ៏ពុំស្គាល់ ។ តើលោកបានបង្រៀនអ្វីខ្លះដល់ហ្វូងមនុស្សទាំងនេះ ?

កិច្ចការ ១៣-១៤

សេចក្តីផ្តើម

ប៉ុល (កាលពី មុនហៅថាសុល) បានចាប់ផ្តើមដំណើរផ្សព្វផ្សាយសាសនារបស់លោកលើកដំបូងជាមួយ បាណាបាសដៃលជាដៃគូរបស់លោក ។ ពួកលោកបានបង្រៀនដំណឹងល្អ ហើយបង្កើតសាខាសាសនាចក្រជាច្រើន ទោះបីជាការបៀតបៀនបន្តកើតមានក្តី ។ នៅពេលពួកសាសន៍យូដាបានបដិសេធមិនទទួលព្រះបន្ទូលព្រះ នោះប៉ុល និង បាណាបាសបានផ្តោតលើការបង្រៀនក្នុងចំណោមពួកសាសន៍ដទៃ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១៣:១-១៣

ប៉ុល និង បាណាបាសបានចាប់ផ្តើមដំណើរផ្សព្វផ្សាយសាសនា ហើយស្តីបន្ទោសដល់ព្យាការីក្លែងក្លាយ

ពីមុនថ្នាក់ចាប់ផ្តើម សូមរៀបចំស្លាកសញ្ញាមួយដៃលមានពាក្យថា « គ្មានការផ្ទុយ » ហើយស្លាកសញ្ញាមួយទៀតមានពាក្យថា « មានការផ្ទុយជានិច្ច » ។ សូមដាក់វានៅទល់មុខគ្នានៅលើជញ្ជាំងថ្នាក់រៀន ។

សូមឲ្យសិស្សនឹកស្រមៃអំពីចន្លោះរវាងស្លាកសញ្ញាទាំងពីរ ជាវង្វាល់មួយតំណាងឲ្យកម្រិតនៃការផ្ទុយដៃលមនុស្សម្នាក់ជួបប្រទះ នៅពេលគាត់ព្យាយាមរស់នៅតាមដំណឹងល្អ ។ សូមអញ្ជើញសិស្សឲ្យឈរនៅចន្លោះស្លាកសញ្ញាដៃលពួកគេគិតថា វាបង្ហាញអំពីកម្រិតនៃការផ្ទុយដៃលម៉ូសេបានជួបប្រទះ ។ ចូរសុំឲ្យសិស្សពីរបីនាក់ពន្យល់ពីការជ្រើសរើសទីតាំងរបស់ពួកគេ ។ សូមធ្វើលំហាត់នេះម្តងទៀត ដោយសូមឲ្យសិស្សឈរនៅកន្លែងមួយនៅលើវង្វាល់នៃការផ្ទុយនេះចំពោះយ៉ូសែប ស៊្មីធ ហើយបន្ទាប់មកចំពោះនីហ្វៃ ។ ចូរសុំឲ្យសិស្សពីរបីនាក់ពន្យល់ពីការជ្រើសរើសរបស់ពួកគេសម្រាប់ទីតាំងនីមួយៗ ។ សូមអញ្ជើញសិស្សឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយគេវិញ ។

សូមទទួលស្គាល់ថា សិស្សគ្រប់រូបរបស់ព្រះយេស៊ូវគ្រីស្ទនឹងជួបប្រទះការផ្ទុយនៅគ្រាខុសៗគ្នានៅក្នុងជីវិតរបស់ពួកគេ ។ សូមឲ្យសិស្សគិតពីទីកន្លែងដៃលពួកគេដាក់ខ្លួនឯង ឲ្យស្របតាមវង្វាល់នៃការផ្ទុយ នៅពេលពួកគេបានព្យាយាមរស់នៅតាមដំណឹងល្អ ។ នៅពេលសិស្សសិក្សា កិច្ចការ ១៣–១៤ សូមលើកទឹកចិត្តពួកគេឲ្យរកមើលគោលការណ៍ ដៃលអាចជួយដឹកនាំពួកគេ នៅពេលពួកគេជួបប្រទះការផ្ទុយនៅក្នុងការខិតខំរបស់ពួកគេដើម្បីរស់នៅដោយសុចរិត ។

សូមសង្ខេប កិច្ចការ ១៣:១–៦ ដោយពន្យល់ថា នៅពេលពួកព្យាការី និងពួកគ្រូបង្រៀនមួយចំនួនបានប្រមូលផ្តុំគ្នានៅក្រុងអាន់ទីយ៉ូក នៅស្រុកស៊ីរី ពួកគាត់បានទទួលការដឹកនាំមកពីព្រះវិញ្ញាណបរិសុទ្ធថា សុល (ក្រោយមកត្រូវបានស្គាល់ថាជា ប៉ុល) និងបាណាបាស គួរបានហៅឲ្យប្រកាសដំណឹងល្អរួមគ្នា ។ បន្ទាប់ពីពួកគាត់បានញែកចេញហើយ សុល និងបាណាបាសបានធ្វើដំណើរពីអាន់ទីយ៉ូក ទៅកោះគីប្រុស ហើយបានផ្សព្វផ្សាយដំណឹងល្អនៅក្នុងសាលាប្រជុំនៅក្នុងទីក្រុងសាឡាមីស ។ ពួកគាត់បានធ្វើដំណើរពីទីនោះទៅផ្នែកម្ខាងទៀតនៃកោះនោះទៅក្រុងប៉ាផុស ។ (អ្នកគួរឲ្យសិស្សស្វែងរកក្រុងអាន់ទីយ៉ូក និង គីប្រុស នៅលើផែនទីក្នុងព្រះគម្ពីរ ល.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា ») ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៣:៦-៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើមានអ្វីបានកើតឡើង នៅពេលសុល និងបាណាបាសបានមកដល់ក្រុងប៉ាផុស ។

- យោងតាម ខទី ៧តើនរណាចង់ស្តាប់ដំណឹងល្អពីសុល និងបាណាបាស ? (សើគាស-ប៉ូល៉ូស ដៃលជាអ្នកតំណាងជាតិរ៉ូមម្នាក់) ។
- តើការផ្ទុយអ្វីខ្លះដៃលពួកផ្សព្វផ្សាយសាសនា បានជួបប្រទះនៅក្នុងការបង្រៀនអំពីដំណឹងល្អទៅដល់សើគាស-ប៉ូល៉ូស ?

សូមពន្យល់ថា នៅដើមដំបូងក្នុង កិច្ចការ ១៣:៩សុលត្រូវបានហៅថាប៉ុល ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កិច្ចការ ១៣:៩-១២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា តើប៉ុលបានជួបនឹងការផ្ទុយអ្វីខ្លះមកពីព្យាការីក្លែងក្លាយឈ្មោះអេលីម៉ាសនោះ ។

- តើប៉ុលបាននិយាយអ្វីខ្លះអំពីអេលីម៉ាសនៅក្នុង ខទី ១០ ? (សូមពន្យល់ថា ប៉ុលបានប្រើពាក្យខ្លាំងៗ ដោយសារអេលីម៉ាសកំពុងប៉ុនប៉ងរារាំងមនុស្សម្នាក់មិនឲ្យទទួលសេចក្តីសង្គ្រោះ) ។
- យោងតាម ខទី ១១តើប៉ុលបានធ្វើអ្វីខ្លះ ចំពោះព្យាការីក្លែងក្លាយតាមរយៈព្រះចេស្តានៃព្រះ ?
- យោងតាម ខទី ១២តើការឃើញព្រះចេស្តារបស់ព្រះ បានជះឥទ្ធិពលដល់អ្នកតំណាងជាតិនោះយ៉ាងដូចម្តេច ?
- តើយើងអាចរៀនអ្វីខ្លះ មកពីដំណើររឿងនេះទាក់ទងនឹងព្រះចេស្តារបស់ព្រះប្រៀបធៀបនឹងអំណាចរបស់អារក្ស ? (ទោះបីជាសិស្សអាចនឹងប្រើពាក្យខុសៗគ្នាក្តី ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះចេស្តានៃព្រះគឺអស្ចារ្យជាងអំណាចរបស់អារក្ស ។** អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីរបស់ពួកគេក្បែរ កិច្ចការ ១៣:៩–១២) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា តើការយល់ដឹងថាព្រះចេស្តារបស់ព្រះគឺអស្ចារ្យជាងអំណាចរបស់អារក្សអាចជួយយើង នៅពេលយើងជួបប្រទះនឹងការផ្ទុយនៅក្នុងជីវិតយើងយ៉ាងដូចម្តេច ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

កិច្ចការ ១៣:១៤-៤៣

ប៉ុលតំណាលប្រាប់ប្រវត្តិរបស់ពួកសាសន៍អ៊ីស្រាអែល ហើយថ្លែងទីបន្ទាល់ថាព្រះយេស៊ូវគ្រីស្ទបានយាងមកដើម្បីបំពេញការសន្យារបស់ព្រះ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីកំហុសមួយដែលពួកគេបានធ្វើ ដែលពួកគេចង់ត្រឡប់ទៅក្រោយវិញ ហើយលុបបំបាត់វា ។ សូមពន្យល់ថា នៅពេលខ្លះការផ្ទុយដែលយើងជួបប្រទះកើតឡើង ដោយសារការជ្រើសរើសខុសរបស់យើងផ្ទាល់ ។ នៅពេលសិស្សសិក្សាកិច្ចការ ១៣:១៤–៤៣ សូមលើកទឹកចិត្តពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេឲ្យយកឈ្នះលើការផ្ទុយនេះ ។

សូមសង្ខេប កិច្ចការ ១៣:១៤–៣៧ ដោយពន្យល់ថា ប៉ុល និងបាណាបាសបានចាកចេញពីគីប្រុស ហើយជិះទូកទៅស្រុកប៉ាមភីលា (ជាប្រទេសតួគីនៅបច្ចុប្បន្ននេះ) បន្ទាប់ពីដៃគូរបស់ពួកលោកម្នាក់ យ៉ូហាន ម៉ាកុស បានសម្រេចចិត្តចេញពីពួកលោក ហើយត្រឡប់ទៅផ្ទះវិញ ។ ប៉ុល និងបាណាបាសបានបន្តដំណើរទៅកាន់ក្រុងអាន់ទីយ៉ូកក្នុងស្រុកពីស៊ីឌា (សូមកុំភាន់ច្រឡំនឹងអាន់ទីយ៉ូកនៅស្រុកស៊ីរី ជាកន្លែងដែលពួកលោកបានចាប់ផ្តើមបេសកកម្ម) ។ នាថ្ងៃឈប់សម្រាកនៅទីនោះ ប៉ុលបានឈរនៅចំពោះមុខមនុស្សនៅឯសាលាប្រជុំ ហើយបានរ៉ាប់រ៉ាប់ប្រាប់អំពីព្រឹត្តិការណ៍នៅក្នុងប្រវត្តិសាស្ត្ររបស់ពួកអ៊ីស្រាអែល ។ បន្ទាប់មក ប៉ុលបានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ថាជាព្រះអង្គសង្គ្រោះនៃអ៊ីស្រាអែលដែលបានសន្យា ។

សូមអញ្ជើញសិស្សអាន កិច្ចការ ១៣:២៦–៣៨ដោយស្ងៀមស្ងាត់រកមើលថាតើប៉ុលបានបង្រៀនអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ។

- តើប៉ុលចង់ឲ្យមនុស្សដែលនៅសាលាប្រជុំនោះយល់អ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៣:៣៨–៣៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប៉ុលបានបង្រៀនថាយើងអាចទទួលបានពរជ័យអ្វីខ្លះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

- តើយើងអាចទទួលបានពរជ័យអ្វីខ្លះ ដោយសារព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ? (សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ដោយប្រើពាក្យរបស់សិស្សផ្ទាល់ ៖ **យើងអាចត្រូវបានអភ័យទោសពីអំពើបាបយើង ហើយបានរាប់ជាសុចរិតវិញតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ**) ។

សូមពន្យល់ថាពាក្យ *បានរាប់ជាសុចរិត* ដែលបានប្រើនៅក្នុង ខទី ៣៩ មានន័យថា « ដើម្បីឲ្យបានលើកលែងពីការដាក់ទោសចំពោះអំពើបាប ហើយរាប់ថាឥតមានទោស » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « រាប់ជាសុចរិត, ការរាប់ជាសុចរិត » scriptures.lds.org) ។ នៅពេលមនុស្សម្នាក់បានរាប់ជាសុចរិតតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះទំនាក់ទំនងរបស់គាត់ជាមួយនឹងព្រះនឹងបានប្រសើរឡើងជាថ្មី ។

- តើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទអនុញ្ញាតឲ្យយើង ត្រូវបានរាប់ជាសុចរិតចេញពីអំពើបាបរបស់យើងដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វ័សិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ព្រះយេស៊ូវគ្រីស្ទ បានរងការឈឺចាប់ ហើយលះបង់ព្រះជន្មរបស់ទ្រង់ដើម្បីធ្វើឲ្យធួននឹងអំពើបាប ។ ព្រះចេស្តានៃដង្វាយធួនទ្រង់អាចលុបបំបាត់ចោលអំណាចនៃអំពើបាបដែលមានមកលើយើង ។ នៅពេលយើងប្រែចិត្ត នោះព្រះគុណដ៏ធួនរបស់ទ្រង់បង្រួប ហើយលាងសម្អាតយើង (សូមមើល នីហ្វៃទី៣ ២៧:១៦–២០) ។ នៅពេលយើងពុំបណ្តោយខ្លួនទៅតាមការល្បួង គឺដូចជាយើងពុំព្រមទៅស្លាប់ដូច្នេះដែរ » (« That They May Be One in Us » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ៧១) ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីបានទទួលបានការអភ័យទោសពីអំពើបាបយើង ហើយបានរាប់ជាសុចរិតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?
- តើមនុស្សមួយចំនួននៅក្នុងព្រះគម្ពីរដែលទទួលបានការអត់ទោសពីអំពើបាបរបស់ពួកគេ ហើយបានរាប់ជាសុចរិតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទមាននរណាខ្លះ ? (ឧទាហរណ៍មួយចំនួនអាចមានដូចជា ប៉ុល អាលម៉ាជាកូន និងអេណុស) ។

សូមអញ្ជើញសិស្សឲ្យច្រៀងពីវគ្គដំបូងនៃបទ« ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » (*ទំនុកតម្កើង* លេខ ១១៥) ។ នៅពេលពួកគេច្រៀង សូមលើកទឹកចិត្តឲ្យពួកគេរកមើលពីរបៀប ដែលអ្នកនិពន្ធទំនុកតម្កើងនេះបានបង្ហាញអំណរគុណរបស់គាត់ចំពោះដង្វាយធួន និងការអត់ទោសរបស់ព្រះអង្គសង្គ្រោះដោយរបៀបណា ។

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោម នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ឬនៅលើក្រដាសមួយសន្លឹក ។

- តើអ្នកមានអារម្មណ៍យ៉ាងណាដែរចំពោះព្រះយេស៊ូវគ្រីស្ទ នៅពេលអ្នកគិតអំពីរបៀបដែលដង្វាយធួនធ្វើឲ្យអ្នកអាចទទួលបានការអត់ទោសពីអំពើបាបនានារបស់អ្នក ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីអ្វីដែលពួកគេបានសរសេរ ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួលមកពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយពួកគេឲ្យទទួលបានការអត់ទោស និងការរាប់ជាសុចរិតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

សូមសង្ខេប កិច្ចការ ១៣:៤០–៤៣ ដោយពន្យល់ថា បន្ទាប់ពីការបង្រៀនរបស់ប៉ុលហើយ មានពួកសាសន៍ដទៃជាច្រើនបានសុំឲ្យប៉ុលបង្រៀនម្តងទៀតនៅថ្ងៃឈប់សម្រាកបន្ទាប់ ។

កិច្ចការ ១៣:៤៤-៥២

ប៉ុល និង បាណាបាស បង្រៀនយ៉ាងអង់អាច ទោះបីជាមានការបៀតបៀនជាខ្លាំងក្តី

សូមពន្យល់ថា លុះថ្ងៃសប្ដាហ៍បន្ទាប់បានមកដល់ ប្រជាជននៅក្រុងនោះស្ទើរតែទាំងអស់បានមកស្ដាប់ប៉ុល និងបាណាបាសបង្រៀនពីបន្ទូលរបស់ព្រះ (សូមមើល កិច្ចការ ១៣:៤៤) ។

សូមបំបែកសិស្សជាគូ ហើយអញ្ជើញពួកគេឲ្យអាន កិច្ចការ ១៣:៤៤–៥២ រួមគ្នា ។ សូមណែនាំសិស្សម្នាក់នៅក្នុងដៃគូនីមួយៗឲ្យរកមើលលក្ខណៈ និងសកម្មភាពរបស់ពួកសាសន៍យូដា ហើយសិស្សម្នាក់ទៀតរកមើលលក្ខណៈ និងសកម្មភាពរបស់ពួកសាសន៍ដទៃ នៅពេលមនុស្សបានប្រមូលផ្ដុំគ្នាស្ដាប់ប៉ុល និងបាណាបាស ។ ក៏សូមលើកទឹកចិត្តឲ្យសិស្សអានការបកប្រែដោយ យ៉ូសែប ស៊្មីធនៅក្នុង កិច្ចការ ១៣:៤៨ផងដែរ ដែលបានផ្លាស់ប្ដូរឃ្លាចុងក្រោយទៅជា « ចំណែកអស់អ្នកដែលត្រូវបានជីវិតអស់កល្បជានិច្ច នោះក៏បានជឿ » ។ នៅពេលសិស្សបានបញ្ចប់ការអានហើយ សូមឲ្យដៃគូនីមួយៗប្រៀបធៀប ហើយបង្ហាញអំពីភាពខុសគ្នារវាងសកម្មភាព និងលក្ខណៈរបស់ពួកសាសន៍យូដា និងពួកសាសន៍ដទៃ ។

- តើពរជ័យអ្វីខ្លះអាចកើតមានចំពោះជនដែលយល់ព្រមស្ដាប់ដល់ប៉ុល និងដៃគូលោក ?

កិច្ចការ ១៤

ប៉ុល និងបាណាបាសធ្វើអព្ភូតហេតុ នៅពេលពួកលោកប្រកាសដំណឹងល្អនៅកណ្ដាលការបៀតបៀនជាបន្តបន្ទាប់នោះ

សូមសរសេរសំណួរខាងក្រោមនេះដាក់លើក្ដារខៀន ***៖ហេតុអ្វីព្រះអម្ចាស់អនុញ្ញាតឲ្យមនុស្សល្អជួបនឹងការសាកល្បងពិបាកៗ ?***

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្ដីពិតមួយ នៅពេលពួកគេសិក្សាកិច្ចការ ១៤ដែលអាចជួយពួកគេឲ្យយល់ពីរបៀបមួយដើម្បីឆ្លើយសំណួរនេះ ។

សូមពន្យល់ថា កិច្ចការ ១៤:១–២១ រៀបរាប់អំពីការរងទុក្ខមួយចំនួន ដែលប៉ុល និងបាណាបាសបានស៊ូទ្រាំតស៊ូ កាលពួកលោកបានបន្តប្រកាសដំណឹងល្អ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យអានខគម្ពីរខាងក្រោមឮៗ ហើយសុំសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការរងទុក្ខដែលពួកអ្នកផ្សព្វផ្សាយទាំងពីរក្នុងរូបនេះបានជួបប្រទះ ។

១ កិច្ចការ ១៤:១–២ (ពួកសាសន៍យូដាដែលឥតជំនឿបានចាក់រុកពួកសាសន៍ដទៃឲ្យទាស់នឹងប៉ុល និងបាណាបាស) ។

២ កិច្ចការ ១៤:៨–១៨ (បន្ទាប់ពីប៉ុលព្យាបាលមនុស្សខ្វិនម្នាក់ហើយ ប្រជាជននៅក្រុងលីស្ត្រាគិតថាប៉ុល និងបាណាបាសគឺជាព្រះរបស់ក្រិក ហើយចង់ថ្វាយដង្វាយដល់ពួកលោក) ។

៣ កិច្ចការ ១៤:១៩–២០ (ប៉ុលត្រូវគេចោលនឹងដុំថ្ម ហើយបានធ្វើឲ្យដឹងខ្លួនវិញ) ។

- តើការរងទុក្ខអ្វីខ្លះដែលប៉ុល និងបាណាបាសត្រូវតែស៊ូទ្រាំ ?
- តើអ្នកអាចមានគំនិតអ្វីខ្លះ ប្រសិនបើអ្នកបាននៅជាមួយនឹងប៉ុល និងបាណាបាសអំឡុងពេលនៃការសាកល្បងទាំងនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៤:២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីការរងទុក្ខ ។

- តើប៉ុលបង្រៀនគោលការណ៍ អ្វីខ្លះនៅក្នុងខគម្ពីរនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងឆ្លងកាត់ការឈឺចាប់ដ៏ខ្លាំងដោយស្មោះត្រង់ នោះយើងនឹងបានត្រៀមខ្លួនចូលទៅក្នុងនគរសេឡេស្ទាល**) ។
- តើអ្នកគិតថា ការស៊ូទ្រាំការរងទុក្ខដោយស្មោះត្រង់អាចជួយយើងឲ្យរៀបចំខ្លួនសម្រាប់នគរសេឡេស្ទាលយ៉ាងដូចម្ដេច ?

សូមឲ្យសិស្សញ៉ែងគិតអំពីពរជ័យ ដែលបានកើតមានចំពោះពួកគេ ឬមនុស្សដែលពួកគេស្គាល់ នៅពេលពួកគេបានឆ្លងកាត់ការរងទុក្ខដោយស្មោះត្រង់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីបទពិសោធន៍របស់ខ្លួន ។ សូមរំឭកសិស្សថា ពួកគេពុំគ្រូវចែកចាយអំពីបទពិសោធន៍ផ្ទាល់ខ្លួនខ្លាំងពេកនោះទេ ។ សូមពិចារណាចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក ដែលអាចបង្ហាញបន្ថែមទៀតអំពីគោលការណ៍នេះ ហើយថ្លែងទីបន្ទាល់ពីសេចក្ដីពិតដ៏ពេញលេញរបស់វា ។

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីសេចក្ដីពិតដែលពួកគេបានស្គាល់នៅក្នុង កិច្ចការ ១៣ និង ១៤ ហើយជ្រើសសេចក្ដីពិតមួយដែលនឹងជួយពួកគេបានច្រើនបំផុតនៅក្នុងការសាកល្បង ។ សូមឲ្យប័ណ្ណកត់ចំណាំតូចមួយ ឬក្រដាសមួយសន្លឹកដល់សិស្សម្នាក់ៗ ហើយអញ្ជើញសិស្សសរសេរគោលការណ៍ដែលពួកគេជ្រើសនៅលើប័ណ្ណនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់វា នៅកន្លែងដែលពួកគេអាចមើលឃើញជាញឹកញាប់ (កញ្ចក់ ទូរនៅសាលារបស់ពួកគេ ។ល។) ដើម្បីផ្ដល់កម្លាំង និងការលើកទឹកចិត្ត នៅពេលពួកគេជួបនឹងការសាកល្បងនានា ។

ជួយសិស្សឲ្យស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

គោលបំណងមួយរបស់ព្រះគម្ពីរ គឺដើម្បីបង្រៀនគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ការស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយនៅក្នុងព្រះគម្ពីរ គឺជាមូលដ្ឋានគ្រឹះនៃការបង្រៀន និងការរៀនសូត្រដ៏ណឹងល្អ ។ ការរៀនសូត្រពីរបៀបដើម្បីស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយនេះ វាតម្រូវឲ្យមានការខិតខំ និងការអនុវត្តយ៉ាងខ្លាំង ។ កាលគោលទ្ធិ និងគោលការណ៍ទាំងឡាយត្រូវបានកេរឃើញ សូមធ្វើឲ្យប្រាកដថា វាត្រូវបានលើកឡើងយ៉ាងច្បាស់ ដើម្បីប្រាកដថា សេចក្ដីពិតទាំងនេះមានភាពច្បាស់លាស់នៅក្នុងគំនិតរបស់សិស្ស ។

កិច្ចការ ១៥

សេចក្តីផ្តើម

មានសមាជិកសាសនាចក្រមួយចំនួនមកពីស្រុកយូដាបានប្រាប់ដល់ពួកប្រែចិត្តនៅក្រុងអាន់ទីយ៉ូក ថា ពួកគេត្រូវកាត់ស្បែកដើម្បីទទួលបានសេចក្តីសង្គ្រោះ ។ ប៉ុល និងបាណាបាសបាននាំយកបញ្ហានោះទៅប្រាប់ដល់ពួកសាវកនៅឯក្រុងយេរូសាឡិម ។ នៅអំឡុងព្រឹត្តិការណ៍មួយដែលបានហៅថា សន្និសីទនៅយេរូសាឡិម (ប្រមាណ គ.ស.៤៩-៥០) ពេត្រុសបានថ្លែងទីបន្ទាល់ថា ព្រះនឹងសង្គ្រោះដល់ពួកយូដា និងពួកសាសន៍ដទៃ មិនថាពួកគេបានកាត់ស្បែក ឬក៏អត់នោះទេ ។ ពួកសាវកបានផ្ញើសំបុត្រទៅសមាជិកសាសនាចក្រដោយពន្យល់ថា ការកាត់ស្បែកពុំមែនជាទង្វើចាំបាច់សម្រាប់សេចក្តីសង្គ្រោះនោះទេ ។ ប៉ុលបានជ្រើសយកសិទ្ធាសជាដៃគូផ្សព្វផ្សាយសាសនារបស់លោក ហើយបានបម្រើបេសកកម្មជាលើកទីពីររបស់លោក ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១៥:១-២៩

តាមរយៈការទូន្មានដ៏បំផុសគំនិត ពេត្រុស និងពួកសាវកផ្សេងទៀតបានតាំងចិត្តថា ព្រះអម្ចាស់មិនតម្រូវឲ្យមានការកាត់ស្បែកទៀតឡើយ ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្តារខៀននូវការសម្រេចចិត្តដ៏សំខាន់ៗមួយចំនួន ដែលពួកគេត្រូវធ្វើនៅពេលនេះ និងនាពេលអនាគត ។

- **តើអ្នកនិយាយប្រាប់នរណា នៅពេលអ្នកត្រូវការធ្វើការសម្រេចចិត្តដ៏សំខាន់ៗនោះ ? ហេតុអ្វីអ្នកត្រូវនិយាយជាមួយពួកគេ ?**
- **ហេតុអ្វីវាជារឿងវៃឆ្លាតដើម្បីស្វែងរកជំនួយរបស់ព្រះ ពីមុនធ្វើការសម្រេចចិត្ត ?**

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត ខណៈពេលពួកគេសិក្សា កិច្ចការ ១៥ ដែលអាចណែនាំពួកគេ នៅពេលពួកគេព្យាយាមស្គាល់ព្រះទ័យរបស់ព្រះចំពោះពួកគេ ។

សូមពន្យល់ថា កាលប៉ុល និងបាណាបាសទៅជួបនឹងពួកបរិសុទ្ធនៅអាន់ទីយ៉ូក មានពួកសាសន៍យូដាមួយចំនួនមកពីស្រុកយូដាដែលបានប្រែចិត្តជឿចំពោះសាសនាគ្រីស្ទ បានធ្វើការអះអាងមួយចំនួនអំពីអ្វីដែលពួកអ្នកប្រែចិត្តសាសន៍ដទៃត្រូវធ្វើដើម្បីត្រូវបានសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៥:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា មនុស្សទាំងនេះដែលមកពីស្រុកយូដាបានប្រកាសថា តើពួកអ្នកប្រែចិត្តដែលជាសាសន៍ដទៃត្រូវធ្វើអ្វីខ្លះដើម្បីត្រូវបានសង្គ្រោះ ។

- **តើមនុស្សទាំងនេះបានប្រកាសថា ពួកអ្នកប្រែចិត្តជឿដែលជាសាសន៍ដទៃត្រូវធ្វើអ្វីខ្លះ ដើម្បីបានសង្គ្រោះ ?**

សូមពន្យល់ថា ជាផ្នែកមួយនៃសេចក្តីសញ្ញាដែលបានធ្វើជាមួយនឹងអ័ប្រាហាំ ព្រះបានបង្គាប់ថា បុរសទាំងអស់ដែលបានចូលទៅក្នុងសេចក្តីសញ្ញាជាមួយនឹងទ្រង់ត្រូវតែកាត់ស្បែក ។ « ការកាត់ស្បែក គឺធ្វើដោយកាត់ ‹ ស្បែកស្រោមចុងស្វាស › ពីទារក និងមនុស្សពេញវ័យប្រុសៗ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ« កាត់ស្បែក »scriptures.lds.org) ។ ការកាត់ស្បែកគឺជាតំណាង ឬការរំឭកមួយអំពីសេចក្តីសញ្ញាដែលមនុស្សបានធ្វើជាមួយនឹងព្រះ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៥:២-៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើមានអ្វីខ្លះបានកើតឡើងបន្ទាប់ពីប៉ុល និងបាណាបាសបានស្តាប់ឮមនុស្សទាំងនេះប្រកាសថា ពួកអ្នកប្រែចិត្តដែលជាសាសន៍ដទៃត្រូវតែកាត់ស្បែកនោះ ។

- **យោងតាម ខទី ២តើមានអ្វីខ្លះបានកើតឡើង នៅពេលមនុស្សទាំងនេះបាននិយាយថា ពួកអ្នកប្រែចិត្តចូលមកក្នុងសាសនាចក្រត្រូវតែកាត់ស្បែកនោះ ?**
- **តើសមាជិកសាសនាចក្រនៅអាន់ទីយ៉ូកបានតាំងចិត្តធ្វើអ្វីខ្លះ ?**

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៥:៤-៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើមានអ្វីបានកើតឡើងខ្លះ នៅពេលប៉ុល និងមនុស្សដទៃបានទៅដល់ក្រុងយេរូសាឡិម ។

- **បន្ទាប់ពីប៉ុល និងបាណាបាសបានលើកឡើងពីបទពិសោធន៍នៃការចែកចាយដំណឹងល្អជាមួយនឹងសាសន៍ដទៃហើយ តើពួកជាវិសុទ្ធដែលបានប្រែចិត្តជឿមួយចំនួនបានជឿថា ពួកអ្នកប្រែចិត្តជឿសាសន៍ដទៃត្រូវធ្វើអ្វីខ្លះដើម្បីបានសង្គ្រោះ ?**
- **យោងតាម ខទី ៦តើពួកសាវក និងពួកអែលឌើរបានមកជួបជុំគ្នាធ្វើអ្វីខ្លះ ?**

សូមសរសេរសំណួរខាងក្រោមដាក់លើក្តារខៀន ឬផ្តល់ ឯកសារដល់សិស្ស ៖

កិច្ចការ ១៥:៧-១១

១. តើនរណាបានក្រោកឡើងនិយាយ ?

២. តើអ្នកគិតថា ពេត្រុសចង់មានន័យដូចម្តេច នៅពេលលោកបានពោលថា ព្រះ « មិនបានរាប់ពួកយើង [ពួកយូដាដែលបានប្រែចិត្ត] និងពួកគេខុសពីគ្នាទេ [ពួកសាសន៍ដទៃដែលបានប្រែចិត្ត] » ?

៣. នៅក្នុង ខទី ៨, ៩ និង ១១ តើឃ្លាអ្វីទៅដែលបង្ហាញថាពួកអ្នកប្រែចិត្ត ដែលជឿជាសាសន៍ដទៃ មិនចាំបាច់ត្រូវកាត់ស្បែកដើម្បីបានសង្គ្រោះនោះទេ ?

សូមបំបែកសិស្សជាគូ ។ សូមអញ្ជើញសិស្សអាន កិច្ចការ ១៥:៧–១១ ជាមួយដៃគូខ្លួន ដោយរកមើលចម្លើយចំពោះសំណួរទាំងនោះ: ។ ពីមុនពួកគេអាន សូមពន្យល់ថា ឃ្លា « លុះ បានជជែកគ្នាជាយូរទៅ » នៅក្នុង ខទី ៧ មានន័យថា ពួកសាវកបានពិភាក្សាវែកញែកយ៉ាងខ្លាំងពីបញ្ហាកាត់ស្បែក ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ប្រាប់ចម្លើយរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។ បន្ទាប់ពីសិស្សបានឆ្លើយសំណួរទីមួយរួចហើយ សូមរំឭកពួកគេថា ពេត្រុសគឺជាសាវករៀមច្បងនៅលើផែនដី ហេតុដូច្នេះហើយលោកមានសិទ្ធិអំណាចដើម្បីនិយាយតំណាងឲ្យព្រះអម្ចាស់ ។

- តើអ្វីទៅជាផ្លូវមួយដែលយើងអាចស្គាល់ព្រះហឫទ័យរបស់ព្រះអម្ចាស់ ? (សិស្សគួរស្គាល់សេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម: **យើងអាចស្គាល់ព្រះហឫទ័យរបស់ព្រះអម្ចាស់តាមរយៈពួកព្យាការី និងពួកសាវកនៅរស់របស់ទ្រង់ទាំងឡាយ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើផ្លូវមួយចំនួនណាខ្លះ ដែលពួកសាវកនៅរស់ ជួយយើងឲ្យស្គាល់វិវរណៈដែលពួកគាត់បានទទួល ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៥:១២-១៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ហ្វូងមនុស្សបានឆ្លើយតបយ៉ាងណា ចំពោះការប្រកាសរបស់ពេត្រុសថា ការកាត់ស្បែកពុំមែនជារឿងចាំបាច់សម្រាប់សេចក្តីសង្គ្រោះនោះឡើយ ។

- តើហ្វូងមនុស្សបានឆ្លើយតបនឹងការប្រកាសរបស់ពេត្រុសយ៉ាងដូចម្តេច ?
- តើប៉ុល និងបាណាបាសបានធ្វើអ្វីខ្លះ ដើម្បីបញ្ជាក់ចំពោះការប្រកាសរបស់ពេត្រុសថា ពួកសាសន៍ដទៃពុំចាំបាច់ត្រូវកាត់ស្បែកនោះទេ ?
- យោងតាម ខទី ១៥តើយ៉ាកុបបាននិយាយថា ការប្រកាសរបស់ពេត្រុស (សីម្មាន) ស្របគ្នាជាមួយនឹងពាក្យរបស់នរណា ?

អ្នកអាចនឹងចង់ពន្យល់ថា ពេត្រុសបានធ្វើជាអធិបតីនៅឯសន្និសីទនោះ ហើយទំនងជា យ៉ាកុបក៏មានតួនាទីធំមួយនៅទីនោះផងដែរ ។ យ៉ាកុបគឺជាប្អូនរបស់ព្រះយេស៊ូវគ្រីស្ទដែលកើតមកពីពោះម្តាយតែមួយតែឪពុកផ្សេងគ្នា និងជាប៊ីស្សពដំបូងគេរបស់សាសនាចក្រនៅក្រុងយេរូសាឡិម ។ សូមសង្ខេប កិច្ចការ ១៥:១៦–១៨ ដោយពន្យល់ថា យ៉ាកុបបានដកស្រង់ អេម៉ុស ៩:១១–១២ ដើម្បីបង្ហាញថាការប្រកាសរបស់ពេត្រុសស្របគ្នាជាមួយនឹងប្រសាសន៍របស់ពួកព្យាការី ដែលបានកត់ត្រានៅក្នុងព្រះគម្ពីរនានា ។

- យោងតាមអ្វីដែលយ៉ាកុបបានបង្រៀន តើអ្វីទៅជាផ្លូវមួយទៀតដែលយើងអាចស្គាល់ព្រះហឫទ័យរបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ: **យើងអាចស្គាល់ព្រះហឫទ័យនៃព្រះអម្ចាស់តាមរយៈការសិក្សាព្រះគម្ពីរនានា ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៥:១៩-២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើល ពាក្យពេចន៍ដែលយ៉ាកុបបានទូន្មានឲ្យថ្នាក់ដឹកនាំសាសនាចក្រធ្វើ ។ សូមពន្យល់ថា ពាក្យ *គំនិត* នៅក្នុង ខទី ១៩ មានន័យថា សំណើ ឬអនុសាសន៍ (សូមមើល Bruce R. McConkie, *Doctrinal New Testament Commentary*, លុំ ៣ [ឆ្នាំ១៩៦៥–៧៣] ២:១៤៣) ។

- តើយ៉ាកុបបានទូន្មានឲ្យថ្នាក់ដឹកនាំសាសនាចក្រធ្វើអ្វីខ្លះសម្រាប់ពួកសាសន៍ដទៃ ? (យ៉ាកុបបានចេញអនុសាសន៍ថា ថ្នាក់ដឹកនាំសាសនាចក្រ « មិនត្រូវធ្វើឲ្យមានចិត្តខ្វល់ឡើយ » [ខទី ១៩] ឬកុំធ្វើឲ្យការរស់នៅតាមដំណឹងល្អកាន់តែមានភាពលំបាកដល់ពួកសាសន៍ដទៃដែលបានប្រែចិត្តជឿ ហើយមិនត្រូវតម្រូវឲ្យពួកគេធ្វើតាមទម្លាប់នៃក្រឹត្យវិន័យរបស់ម៉ូសេ ពីមុនក្លាយជាសមាជិកសាសនាចក្រនោះឡើយ ។ ដោយថ្លែងបែបនេះ: យ៉ាកុបកំពុងគាំទ្រដល់ការសម្រេចចិត្តដែលពេត្រុសបានធ្វើឡើងកាលពីមុន) ។
- យោងតាម ខទី ២០តើផ្នែកអ្វីខ្លះនៅក្នុងក្រឹត្យវិន័យរបស់ម៉ូសេដែលយ៉ាកុបគិតថា ពួកអ្នកប្រែចិត្តជឿដែលជាសាសន៍ដទៃនៅតែត្រូវគោរពតាម ? (ការហាមឃាត់កុំឲ្យធ្វើអំពើបាបខាងផ្លូវភេទ ការបរិភោគអាហារដែលថ្វាយជាដង្វាយទៅរូបព្រះ និងការបរិភោគឈាម) ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង កិច្ចការ ១៥:២២-២៧ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលការសម្រេចចិត្តរបស់ក្រុមប្រឹក្សានោះ: ។

- តើពួកសាវកបានសម្រេចចិត្តធ្វើអ្វី ? (ផ្ញើសំបុត្រមួយដល់សមាជិកសាសនាចក្រដោយប្រកាសថា ការកាត់ស្បែកពុំបានតម្រូវឲ្យធ្វើឡើងដើម្បីទទួលបានសេចក្តីសង្គ្រោះឡើយ) ។
- តើអ្នកគិតថា ហេតុអ្វីបានជាពួកសាវកបានសម្រេចចិត្តបញ្ជូនថ្នាក់ដឹកនាំដូចជាប៉ុល និងស៊ីឡាសឲ្យនាំយកសំបុត្រនោះទៅ ? (សិស្សអាចមានចម្លើយផ្សេងៗគ្នា ប៉ុន្តែហេតុផលមួយគឺដើម្បីបញ្ជាក់ថា ការប្រកាសនោះកើតចេញពីការសម្រេចចិត្តរួមគ្នារបស់ពួកសាវក ។ សូមចង្អុលបង្ហាញថា គណៈប្រធានទីមួយ និងក្រុមនៃពួកសាវកដប់ពីរនាក់ធ្វើតាមទំនៀមទម្លាប់ដូចគ្នានេះនៅក្នុងជំនាន់របស់យើង ដើម្បីផ្តល់ការណែនាំដ៏បំផុសគំនិតដល់សមាជិកសាសនាចក្រទាំងឡាយ) ។

ជួយសិស្សឲ្យយល់ដឹងពីអត្ថន័យនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

នៅពេលសិស្សបានរកឃើញគោលការណ៍ និងគោលលទ្ធិនៅក្នុងព្រះគម្ពីរ សូមឆ្លៀតពេលដើម្បីពិភាក្សាអំពីសេចក្តីពិតទាំងនេះ តាមរបៀបមួយដែលនឹងជួយសិស្សឲ្យយល់វាបានកាន់តែល្អប្រសើរ ។ នៅក្នុងការពិភាក្សាទាំងនេះ សូមលើកទឹកចិត្តសិស្សឲ្យត្រួតពិនិត្យមើលទំនាក់ទំនងរវាងសេចក្តីពិតដែលបានរកឃើញ និងគោលការណ៍នៃដំណឹងល្អផ្សេងទៀត ។ ពួកគេក៏គួររកឃើញរបៀបដើម្បីអនុវត្តសេចក្តីពិតទាំងនេះ នៅក្នុងជីវិតរបស់ពួកគេផងដែរ ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ មកពីដំណើរឿងនេះពីរបៀបដែលថ្នាក់ដឹកនាំសាសនាចក្រទទួលបានការបំផុសគំនិតអំពីបញ្ហាលំបាកនានា ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖**តាមរយៈការប្រឹក្សារួមគ្នា និងការស្វែងរកវិវរណៈមកពីព្រះ នោះថ្នាក់ដឹកនាំសាសនាចក្រទទួលបានការបំផុសគំនិតចំពោះបញ្ហាលំបាកនានា**) ។

ដើម្បីជួយសិស្សឲ្យ យល់ ថាសេចក្តីពិតនេះទាក់ទងនឹងសាសនាចក្រនៅសព្វថ្ងៃនេះតាមរបៀបណា សូមអញ្ជើញសិស្សឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះមកពីអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« គំរូដូចគ្នានេះត្រូវបានធ្វើតាមនាសព្វថ្ងៃនេះនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ដែលបានស្តារឡើងវិញ ។ ប្រធានសាសនាចក្រអាចប្រកាស ឬ បកស្រាយគោលលទ្ធិទាំងឡាយ ដោយផ្អែកលើវិវរណៈដែលប្រទានដល់លោក (សូមមើល ជាឧទាហរណ៍ គ. និង ស. ១៣៨) ។ ការពិពណ៌នាអំពីគោលលទ្ធិក៏អាចបានមកតាមរយៈការប្រឹក្សារួមគ្នារបស់គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ផងដែរ (សូមមើល ជាឧទាហរណ៍ សេចក្តីប្រកាសជាផ្លូវការទី២) ។ ជារឿយៗ ការពិភាក្សាក្នុងក្រុមប្រឹក្សានឹងរួមបញ្ចូលនូវបទដ្ឋានព្រះគម្ពីរ ការបង្រៀនរបស់ថ្នាក់ដឹកនាំសាសនាចក្រ និង អ្វីដែលបានធ្វើហើយពីមុន ។ ប៉ុន្តែ នៅទីបញ្ចប់គឺដូចជាសាសនាចក្រនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែរ ដែលជាធម្មតាគោលដៅរបស់វាពុំមែនជាការព្រមព្រៀងគ្នានៅក្នុងសមាជិកក្រុមប្រឹក្សានោះទេ ប៉ុន្តែវាជាវិវរណៈមកពីព្រះវិញ ។ វាគឺជាដំណើរការមួយដែលត្រូវតែមានទាំងហេតុផល និងសេចក្តីជំនឿដើម្បីទទួលបានព្រះតំរិះ និងព្រះទ័យរបស់ព្រះអម្ចាស់ » (« The Doctrine of Christ » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៨៨) ។

- ហេតុអ្វីអ្នកគិតថា វាជារឿងសំខាន់ដែលថ្នាក់ដឹកនាំសាសនាចក្រត្រូវប្រឹក្សារួមគ្នាជារឿយៗ ក្នុងពេលស្វែងរកវិវរណៈពីព្រះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៥:២៨-២៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ពួកសាវក និងពួកអែលឌើរបានសរសេរអ្វីខ្លះនៅក្នុងសំបុត្រផ្ញើទៅសមាជិកសាសនាចក្រនោះ ។

- តើពួកសាវក និងពួកអែលឌើរបានសរសេរអ្វីខ្លះ នៅក្នុងសំបុត្រផ្ញើទៅសមាជិកសាសនាចក្រនោះ ?
- នៅក្នុង ខទី ២៨តើឃ្លា « មិនគួរគប្បីនឹងដាក់បន្ទុកអ្វីទៀតលើអ្នករាល់គ្នា ក្រៅពីសេចក្តីទាំងនេះដែលត្រូវតែកាន់នោះឡើយ » មានន័យដូចម្តេច ? (មនុស្សមិនត្រូវគោរពតាមកិច្ចតម្រូវបន្ថែមណាមួយ ដែលកើតចេញមកពីមនុស្ស ដែលពុំមែនមកពីព្រះឡើយ) ។
- យោងតាម ខទី ២៨ តើពួកសាវកបានស្គាល់ព្រះទ័យរបស់ព្រះស្តីពីតម្រូវការសម្រាប់ពួកសាសន៍ដទៃ ដែលបានប្រែចិត្តជឿយ៉ាងដូចម្តេច ?

សូមចង្អុលបង្ហាញថា ព្រះវិញ្ញាណបរិសុទ្ធបានបំផុសគំនិតដល់ពួកសាវក កាលពួកគាត់បានប្រឹក្សារួមគ្នា ។ ទ្រង់ក៏បានប្រទានសាក្សីបញ្ជាក់មួយថា ការសម្រេចចិត្តរបស់ពួកលោកគឺត្រឹមត្រូវ ។

- ដោយផ្អែកលើរបៀបដែលថ្នាក់ដឹកនាំសាសនាចក្របានស្គាល់ព្រះទ័យរបស់ព្រះអម្ចាស់ ដូចដែលបានកត់ត្រានៅក្នុង ខទី ២៨តើយើងអាចស្គាល់ព្រះទ័យរបស់ព្រះអម្ចាស់តាមរបៀបណា ? (សិស្សអាចនឹងប្រើពាក្យពេចន៍ផ្សេងៗគ្នា ប៉ុន្តែចូរធ្វើយ៉ាងណាជួយពួកគេឲ្យយល់ថា **យើងអាចស្គាល់ព្រះទ័យរបស់ព្រះអម្ចាស់ តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ** ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ចូរអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅលើក្តារខៀន ។

- តើសេចក្តីពិតទាំងនេះអាចជួយយើង នៅពេលយើងត្រូវធ្វើការសម្រេចចិត្តដ៏សំខាន់មួយដោយរបៀបណា ?
- យោងតាមសេចក្តីពិតទាំងនេះ តើយើងត្រូវធ្វើអ្វីខ្លះដើម្បីស្គាល់ព្រះទ័យរបស់ព្រះអម្ចាស់ ?
- តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកពិតជាបានស្គាល់ព្រះទ័យរបស់ព្រះអម្ចាស់ នៅពេលអ្នកបានធ្វើតាមសេចក្តីពិតទាំងនេះនៅពេលណា ?

សូមលើកទឹកចិត្តសិស្សឲ្យសិក្សាប្រសាសន៍របស់ពួកព្យាការីបច្ចុប្បន្ន និងព្រះគម្ពីរទាំងឡាយ ។ សូមពន្យល់ថា នៅពេលពួកគេធ្វើដូច្នេះ នោះពួកគេអាចបានស្គាល់ព្រះទ័យរបស់ព្រះអម្ចាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នៅពេលកំពុងធ្វើការសម្រេចចិត្តដ៏សំខាន់នានា ។

កិច្ចការ ១៥:៣០-៤១

ប៉ុល និងអ្នកដទៃទៀតបាននាំយកសំបុត្ររបស់ពួកសាវកទៅដល់សមាជិកនៅអាន់ទីយ៉ូក

សូមសង្ខេប កិច្ចការ ១៥:៣០–៤១ ដោយពន្យល់ថា ថ្នាក់ដឹកនាំសាសនាចក្រមួយចំនួនបាននាំយកសំបុត្ររបស់ពួកសាវកដល់សមាជិកសាសនាចក្រនៅអាន់ទីយ៉ូក ។ បន្ទាប់ពីប្រកាសដំណឹងល្អនៅអាន់ទីយ៉ូកមក ប៉ុលបានសុំឲ្យបាណាបាស ទៅជាមួយលោកទៅកន្លែងដែលពួកគាត់ធ្លាប់បានប្រកាសដំណឹងល្អ ។ បាណាបាស ចង់នាំម៉ាកុសទៅជាមួយពួកគាត់ ប៉ុន្តែប៉ុលបានបដិសេធ ។ បន្ទាប់ពីការខ្វែងគំនិតគ្នាមួយចំនួនរវាងថ្នាក់ដឹកនាំសាសនាចក្រទាំងពីរមក បាណាបាសបានសម្រេចចិត្តនាំម៉ាកុសទៅជាមួយលោក ដូច្នេះប៉ុលបានជ្រើសសីឡាសជាដៃគូបេសកកម្ម ហើយបានចាប់ផ្តើមបេសកកម្មលើកទីពីររបស់លោក ។ សូមពន្យល់ថា ការមិនយល់ស្របគ្នាគឺពុំមែនចាត់ទុកថាជាអំពើបាបទេ ។ ប៉ុន្តែ ជំនួសឲ្យការទាស់ទែងគ្នា នោះយើងគួរខិតខំស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីកុំឲ្យមានការខ្វែងគំនិតគ្នា ។ (យើងរៀននៅក្នុង ធីម៉ូថេទី ២ ៤:១១ ថា បញ្ហារវាងប៉ុល និងម៉ាកុសក្រោយមកត្រូវបានសម្រុះសម្រួលគ្នាវិញ) ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលសិស្សបានស្គាល់នៅក្នុងកិច្ចការ ១៥ ។

មេរៀន ៩៣

កិច្ចការ ១៦

សេចក្តីផ្តើម

ព្រះវិញ្ញាណបរិសុទ្ធបានណែនាំ ប៉ុល និង ដៃគូរបស់លោកឲ្យផ្សាយដំណឹងល្អនៅក្នុងខេត្ត ម៉ាសេដូន (ប្រទេសក្រិកភាគខាងជើង) ។ មានស្ត្រីម្នាក់ឈ្មោះ លីឌា បានទទួលសារលិខិត របស់ពួកលោក ហើយបានជ្រមុជទឹក ។ បន្ទាប់ពីប៉ុលបានបណ្តេញវិញ្ញាណអាក្រក់ចេញពីបាវ បម្រើស្រីម្នាក់ លោក និងសីឡាសត្រូវបានគេវាយដំ ហើយត្រូវគេចាប់ដាក់គុក ។ នៅយប់នោះ ពួកលោកត្រូវបានដោះលែងចេញពីគុកដោយអព្ភូតហេតុ បន្ទាប់មកពួកលោកបានជ្រមុជទឹក ដល់អ្នកយាមគុក និងគ្រួសាររបស់គាត់ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១៦:១-១៥

ប៉ុល និង ដៃគូរបស់លោកផ្សាយដំណឹងល្អនៅខេត្តម៉ាសេដូន

សូមសរសេរឃ្លាខាងក្រោមមកពីប្រធាន ថូម៉ាស អេស ម៉នសុន នៅក្តារខៀន ។ (ឃ្លានេះ មាននៅក្នុង« The Spirit Giveth Life,»*Ensign*ខែ មិថុនា ឆ្នាំ ១៩៩៧ ទំព័រ ៥) ។

« សូមកុំពន្យារពេលចំពោះការបំផុសគំនិត » (ប្រធាន ថូម៉ាស អេស ម៉នសុន) ។

- *ការបំផុសគំនិត* សំដៅទៅលើអារម្មណ៍ ដែលបណ្តាលចិត្តឲ្យយើងនិយាយ ឬធ្វើអ្វីមួយមកពីព្រះវិញ្ញាណបរិសុទ្ធ ។ តើមានអ្វីអាចកើតឡើង ប្រសិនបើមនុស្សម្នាក់បានពន្យារពេលស្តាប់តាមការបំផុសគំនិតនោះ ?

នៅពេលសិស្សសិក្សា កិច្ចការ ១៦ សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេឲ្យយល់បន្ថែមទៀត អំពីសារៈសំខាន់នៃការស្តាប់តាមការបំផុសគំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធ ។

សូមសង្ខេប កិច្ចការ ១៦:១–៥ ដោយពន្យល់ថា ប៉ុល សីឡាស និងអ្នកប្រែចិត្តជឿម្នាក់ជាសាសន៍ដទៃឈ្មោះ ធីម៉ូថេធាស (ក៏ត្រូវបានគេស្គាល់ថាជា ធីម៉ូថេ) បានធ្វើដំណើរទៅសាខាសាសនាចក្រជាច្រើន ដើម្បីប្រកាសអំពីការសម្រេចចិត្តដែលថ្នាក់ដឹកនាំសាសនាចក្រ នៅយេរូសាឡិមបានធ្វើឡើង ដែលវាបានជះឥទ្ធិពលដល់សាសនាចក្រទាំងមូល ហើយពង្រឹងដល់សេចក្តីជំនឿរបស់សមាជិក សាសនាចក្រ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៦:៦-១០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុល និងពួកដៃគូរបស់លោក (ទំនងជាមានទាំង លូកា ផងដែរ) បានដឹងយ៉ាងដូចម្តេចថាត្រូវទៅទីណា កាលពួកលោកកំពុងធ្វើដំណើរ ។

- **តើប៉ុល និងដៃគូរបស់លោកបានដឹងអំពីកន្លែងដែលពុំត្រូវទៅយ៉ាងដូចម្តេច ? តើពួកលោកបានដឹងអំពីកន្លែងដែលត្រូវទៅយ៉ាងដូចម្តេច ?**
- **តើប៉ុលបានមើលឃើញអ្វីនៅក្នុងការនិមិត្តមួយ ?**
- **តើប៉ុល និងដៃគូរបស់លោកបានឆ្លើយតបនឹងការនិមិត្តរបស់ប៉ុលបានយ៉ាងដូចម្តេច ?**

សូមសង្ខេប កិច្ចការ ១៦:១១–១៣ ដោយពន្យល់ថា ប៉ុល និងសីឡាសបានធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ រហូតដល់ពួកលោក បានមកកាន់ក្រុងភីលីព ជាក្រុងមួយនៅស្រុកម៉ាសេដូន ។ (អ្នកគ្រូអញ្ជើញសិស្សឲ្យបើកទៅផែនទីក្នុងព្រះគម្ពីរបរិសុទ្ធ ឬ ស.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា » ហើយស្វែងរកក្រុងភីលីព) ។ នៅថ្ងៃឈប់សម្រាក ពួកលោកបានចេញពីក្រុងនោះទៅ អធិស្ឋាននៅក្បែរមាត់ទន្លេ ហើយបានចាប់ផ្តើមនិយាយនឹងពួកស្ត្រីដែលបានប្រមូលផ្តុំគ្នានៅទីនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៦:១៤-១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ស្ត្រីឈ្មោះលីឌា បានឆ្លើយ តបនឹងការបង្រៀនរបស់ប៉ុលយ៉ាងដូចម្តេច ។ (អ្នកគ្រូពន្យល់ថា ឃ្លា « អ្នកជំនួញលើខពណ៌ស្វាយ » [ខទី ១៤] សំដៅទៅលើ ធាតុពិតថា លីឌា លក់ថ្នាំជ្រលក់ពណ៌ស្វាយដែលមានតម្លៃថ្លៃ ហើយប្រហែលជាចង្អុលបង្ហាញថា លីឌា គឺជាស្ត្រីម្នាក់ដែលមានទ្រព្យ សម្បត្តិច្រើន និងឥទ្ធិពលខ្លាំង) ។

- **តើលីឌាបានឆ្លើយតបចំពោះការបង្រៀនរបស់ប៉ុលយ៉ាងដូចម្តេច ? (អ្នកអាចនឹងត្រូវពន្យល់ថា *យកចិត្តទុកដាក់* មានន័យថាផ្តោតអារម្មណ៍ ឬស្តាប់តាម) ។**
- **តើឃ្លានៅក្នុង កិច្ចការ ១៦:១៤ បង្ហាញអ្វីខ្លះថាលីឌាបានត្រៀមខ្លួនទទួលយកដំណឹងល្អ ?**
- **តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ចេញពីបទពិសោធន៍របស់ប៉ុលអំពីអ្វីដែលអាចកើតឡើងប្រសិនបើយើងធ្វើតាមវិវរណៈ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេយល់ថា ****នៅពេលយើងធ្វើតាមវិវរណៈមកពីព្រះ យើងអាចទទួលបានការគាំទ្រពីករអស់អ្នកដែលត្រៀមខ្លួនទទួលយកដំណឹងល្អ**** ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។**

សូមចង្អុលបង្ហាញថា តាមរយៈការធ្វើតាមវិវរណៈ យើងក៏អាចជួយមនុស្សដទៃឲ្យចាប់ផ្តើម ឬបន្តដំណើរការនៃការត្រៀមខ្លួនដើម្បីទទួលដំណឹងល្អផងដែរ ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតអំពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមមកពីអែលឌើរ ដាល្លិន អេក អ្នក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានការដឹកនាំទៅរកមនុស្សដែលត្រៀមខ្លួនទទួលយកដំណឹងល្អនោះ ។



« យើងត្រូវតែអធិស្ឋានទូលសូមជំនួយ និង ការណែនាំពីព្រះអម្ចាស់ ប្រយោជន៍ឲ្យយើងអាចក្លាយជាឧបករណ៍នៅក្នុងព្រះហស្តទ្រង់សម្រាប់បុគ្គលណាម្នាក់ដែលបានត្រៀមខ្លួនជាស្រេច—ជាបុគ្គលម្នាក់ដែលចង់ឲ្យយើងជួយគេនាថ្ងៃនេះ ។ បន្ទាប់មក យើងត្រូវស្តាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណអំពីរបៀបដែលយើងដំណើរការនោះ ។

« ការបំផុសគំនិតទាំងនោះនឹងកើតឡើង ។ យើងដឹងពីទីបន្ទាល់ផ្ទាល់ខ្លួនរាប់មិនអស់មកហើយថា ព្រះអម្ចាស់កំពុងរៀបចំមនុស្សទាំងឡាយឲ្យទទួលយកដំណឹងល្អរបស់ទ្រង់តាមវេលារបស់ទ្រង់ និងតាមរបៀបរបស់ទ្រង់ ។ មនុស្សទាំងនោះកំពុងស្រាវជ្រាវ ហើយនៅពេលយើងស្វែងរកពួកគេ នោះព្រះអម្ចាស់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេតាមរយៈការឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ។ ទ្រង់នឹងបំផុសគំនិត ហើយណែនាំដល់អស់អ្នកដែលមានបំណងនិង មានចិត្តស្មោះសរស្វែងរកការណែនាំពីរបៀប ទីកន្លែង ពេលវេលា និង មនុស្សដែលយើងត្រូវចែកចាយដំណឹងល្អរបស់ទ្រង់ » (« Sharing the Gospel » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០០១ ទំព័រ ៨) ។

- យោងតាមអែលឌើរ អ្នក តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានការដឹកនាំទៅរកអស់អ្នកដែលត្រៀមខ្លួនទទួលយកដំណឹងល្អ ?

សូមពិចារណាធ្វើការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយទាក់ទងនឹងរបៀបដែលការស្តាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណបានដឹកនាំអ្នកទៅរកមនុស្សម្នាក់ដែលបានត្រៀមខ្លួនទទួលយកដំណឹងល្អ ឬទាក់ទងនឹងរបៀបដែលការស្តាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណរបស់មនុស្សម្នាក់បានដឹកនាំគាត់ឲ្យរកឃើញអ្នក កាលអ្នកបានត្រៀមខ្លួនទទួលយកដំណឹងល្អ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍មួយដែលពួកគេ ឬមនុស្សម្នាក់ដែលពួកគេស្គាល់បានទទួលការដឹកនាំឲ្យទៅរកមនុស្សម្នាក់ ដែលត្រៀមខ្លួនទទួលយកដំណឹងល្អ ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីរបៀប ទីកន្លែង ពេលវេលា និងមនុស្សដែលពួកគេអាចចែកចាយដំណឹងល្អជាមួយបាន ។ សូមលើកទឹកចិត្តពួកគេឲ្យកត់ត្រាការបំផុសគំនិតនានាដែលពួកគេបានទទួល ហើយបន្តអធិស្ឋានទូលសូមការដឹកនាំ ។

កិច្ចការ ១៦:១៦-៤០

ប៉ុល និង សីឡាសត្រូវបានចាប់ដាក់គុក ហើយក្រោយមកត្រូវបានដោះលែងវិញ

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង កិច្ចការ ១៦:១៦-១៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើប៉ុលបានធ្វើអ្វីខ្លះ នៅពេលលោកបានជួបនឹង « បាវស្រី » ម្នាក់ (ខទី ១៦) ឬបាវបម្រើស្រីដែលមានវិញ្ញាណអាក្រក់ចូល ។ អ្នកគួរពន្យល់ថា *អារក្សភីថង់* គឺជាដំណើរការនៃការទស្សទាយ ឬការព្យាយាមប្រាប់ទុកជាមុនពីអនាគត ដោយប្រើមធ្យោបាយខាងអបិយជំនឿ ។

កិច្ចការសម្រាប់ក្រុមតូចៗ

ការបំបែកសិស្សជាក្រុមតូចៗ អាចអនុញ្ញាតឲ្យសិស្សកាន់តែច្រើនចូលរួមក្នុងសកម្មភាព ។ សូមផ្តល់ការណែនាំច្បាស់លាស់ថា សិស្សត្រូវធ្វើអ្វីខ្លះនៅក្នុងសកម្មភាពនេះ ។ ការកំណត់ពេលវេលាមួយ ក៏អាចជួយសិស្សឲ្យផ្តោតយកចិត្តទុកដាក់ផងដែរ ។ សកម្មភាពជាក្រុមដែលមានរយៈពេលឃ្លី ជាញឹកញាប់នាំឲ្យក្រុមបញ្ចប់ក្នុងពេលខុសៗគ្នា ហើយអាចធ្វើឲ្យមានភាពខ្វះសណ្តាប់ធ្នាប់ ។ សូមជួយសិស្សឲ្យផ្តោតយកចិត្តទុកដាក់ ហើយទទួលបានការយល់ដឹងច្រើនពីកិច្ចការនេះ ដោយដើរពិនិត្យមើលសកម្មភាពនេះពីក្រុមមួយទៅក្រុមមួយ ។

- តើនៅទីបំផុតប៉ុលបានធ្វើអ្វីខ្លះដល់វិញ្ញាណអាក្រក់ដែលចូលបាវបម្រើស្រីនោះ ?
- តើពួកចៅហ្វាយរបស់បាវបម្រើស្រីនេះនៅក្នុងក្រុងបានជួបបញ្ហាអ្វីខ្លះ បន្ទាប់ពីប៉ុលបានបណ្តេញវិញ្ញាណអាក្រក់នោះចេញពីនាង ?

សូមសង្កេប កិច្ចការ ១៦:២០–២៤ ដោយពន្យល់ថា ពួកបុរសដែលលែងបានទទួលប្រយោជន៍ពីបាវស្រីនោះ បាននាំយកប៉ុល និងសីឡាស់ទៅជួប « តម្រួតនគរបាល » (ខទី ២០) ឬអាជ្ញាធរក្នុងមូលដ្ឋាន ហើយបានអះអាងថាប៉ុល និងសីឡាសបានបង្រៀនដល់ប្រជាជនថា ពួកគេពុំគួរធ្វើតាមច្បាប់រ៉ូមឡើយ ។ ដោយមានការបង្គាប់របស់តម្រួតនគរបាល ក្រោយមកប៉ុល និងសីឡាសត្រូវបានគេវាយដំ ហើយយកទៅឃុំ ហើយជើងរបស់ពួកលោកត្រូវគេចង ដើម្បីកុំឲ្យដើរបាន ។

ដើម្បីជួយសិស្សឲ្យយល់អំពីមាតិកានៃ កិច្ចការ ១៦:២៥–៣៦ សូមបំបែកសិស្សជា គូ ហើយចែកក្រដាសមួយសន្លឹកដល់ដៃគូនីមួយៗ ។ សូមចម្លងតារាងខាងក្រោមដាក់នៅលើ ក្តារខៀន ហើយអញ្ជើញដៃគូនីមួយៗឲ្យចម្លងតារាងនេះដាក់ក្នុងក្រដាសរបស់ពួកគេ ។

កិច្ចការ ១៦:២៥	កិច្ចការ ១៦:២៦	កិច្ចការ ១៦:២៧–២៨
កិច្ចការ ១៦:២៩–៣០	កិច្ចការ ១៦:៣១–៣២	កិច្ចការ ១៦:៣៣–៣៤

សូមអញ្ជើញដៃគូនីមួយៗឲ្យអានឮៗនូវខគម្ពីរនៅលើតារាង រួចហើយប្តូរវេនគ្នាគូររូបសាមញ្ញដើម្បីតំណាងឲ្យក្រុមនីមួយៗនៃក្រុមខគម្ពីរទាំងប្រាំមួយនោះ (សិស្សម្នាក់មកពីដៃគូមួយអាចគូររូបដើម្បីតំណាងឲ្យក្រុមនៃខគម្ពីរបី ហើយសិស្សម្នាក់ទៀតនៅក្នុងដៃគូដដែលនោះអាចគូររូបដើម្បីតំណាងឲ្យក្រុមនៃខគម្ពីរបីផ្សេងទៀត) ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យដាក់បង្ហាញ ហើយពន្យល់ដោយសង្កេបអំពីរូបភាពរបស់ពួកគេទៅដៃគូផ្សេងទៀត ឬដល់សិស្សក្នុងថ្នាក់ទាំងមូល ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែសឹងជម្រៅអំពីកិច្ចការ ១៦:២៥–៣៦ សូមសួរសំណួរខាងក្រោមនេះ ៖

- តើប៉ុល និងស៊ីឡាសបានឆ្លើយយ៉ាងណាដែរ ទៅនឹងសំណួររបស់អ្នកយាមគុកអំពីរបៀបដែលគាត់អាចទទួលបានការសង្គ្រោះ ?
- តើអ្នកយាមគុកនោះបានធ្វើអ្វីខ្លះ ដើម្បីបង្ហាញពីជំនឿរបស់ខ្លួនលើព្រះយេស៊ូវគ្រីស្ទ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងកិច្ចការ ១៦:៣១–៣៣អំពីកិច្ចការដែលយើងត្រូវធ្វើដើម្បីទទួលបានសេចក្តីសង្គ្រោះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ ៖ **សេចក្តីសង្គ្រោះតម្រូវឲ្យមានការជឿលើព្រះយេស៊ូវគ្រីស្ទ ហើយយើងបង្ហាញជំនឿរបស់យើងលើទ្រង់តាមរយៈការទទួលបុណ្យជ្រមុជទឹក**) ។

សូមពន្យល់ថា *សេចក្តីសង្គ្រោះ* មានន័យថា « ដើម្បីឲ្យបានរួចផុតពីសេចក្តីស្លាប់ខាងសាច់ឈាម ព្រមទាំងពីសេចក្តីស្លាប់ខាងវិញ្ញាណផង » (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « Salvation » scriptures.lds.org) ។

- តើការទទួលបុណ្យជ្រមុជទឹកបង្ហាញពីសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?
- បន្ថែមពីលើការទទួលបុណ្យជ្រមុជទឹក តើអ្វីទៅជាវិធីផ្សេងទៀត ដែលយើងអាចបង្ហាញជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទបាន ?

សូមសង្ខេប កិច្ចការ ១៦:៣៥–៤០ ដោយពន្យល់ថា តម្រួតនគរបាលនោះបានបង្គាប់ឲ្យអ្នកយាមគុកដោះលែងប៉ុល និង ស៊ីឡាស ។ ប៉ុលបានបដិសេធពីការដោះលែងនោះ ដោយសារលោកបានដឹងពីសិទ្ធិរបស់លោកក្នុងនាមជាពលរដ្ឋសាសន៍រ៉ូម ហើយបានដឹងថាការប្រព្រឹត្តរបស់ពួកគេចំពោះលោកគឺអយុត្តិធម៌ ។ វាជារឿងខុសច្បាប់ដែលវាយដំពលរដ្ឋសាសន៍រ៉ូម ដោយពុំបានធ្វើការកាត់ទោសជាមុននោះ ។ នៅពេលពួកតម្រួតនគរបាលបានដឹងថា ប៉ុល និងស៊ីឡាសគឺជាសាសន៍រ៉ូម ពួកគេមានការភ័យខ្លាច ដោយសារពួកគេបានដឹងថា ប្រសិនបើមេរបស់ពួកគេបានដឹងថា ពួកគេបានប្រព្រឹត្តដាក់ពលរដ្ឋរ៉ូមបែបនេះ នោះពួកគេអាចនឹងត្រូវទទួលទណ្ឌកម្មរហូតដល់ស្លាប់ ។ ពួកតម្រួតនគរបាលនោះ បានមកទីឃុំឃាំង ដើម្បីដោះលែងប៉ុល និងស៊ីឡាស ហើយបានសូមឲ្យពួកលោកចាកចេញពីក្រុងនោះ ។

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុង កិច្ចការ ១៦ ។

ការរំឭកអំពីចំណេះចំណានខគម្ពីរ

សូមប្រើតារាងដែលភ្ជាប់មកជាមួយដើម្បីរំឭកឡើងវិញនូវគន្លឹះចំណេះចំណានខគម្ពីរ ដែលសិស្សបានសិក្សារួចមកហើយនៅក្នុងឆ្នាំនេះ ។ សូមអានឮៗនូវសំណួរ ឬកង្វល់នៅក្នុងជួរឈរខាងឆ្វេងនៃតារាង ហើយអញ្ជើញសិស្សឲ្យស្វែងរកវគ្គចំណេះចំណានខគម្ពីរដែលអាចផ្តល់ចម្លើយមួយ (ចម្លើយត្រូវបានផ្តល់ឲ្យនៅជួរឈរខាងស្តាំនៃតារាង) ។ អ្នកអាចចង់អានសំណួរ ឬកង្វល់ទាំងនេះឮៗ មិនតាមលំដាប់លំដោយបាន ។ បន្ទាប់ពីសិស្សរកឃើញបទគម្ពីរមួយហើយ សូមសួរពួកគេថា តើវគ្គចំណេះចំណានខគម្ពីរនោះអាចជួយមនុស្សម្នាក់ដែលមានកង្វល់នេះយ៉ាងដូចម្តេច ។

ខ្ញុំភ័យខ្លាចនឹងរស់នៅតាមជំនឿរបស់ខ្ញុំ ។ ខ្ញុំព្រួយចិត្តពីការគិតរបស់មនុស្សជុំវិញចំពោះខ្ញុំ ។	ម៉ាថាយ ៥:១៤–១៦
ខ្ញុំមានការថប់បារម្ភយ៉ាងលើសលុប ដោយសារតែការសោកល្បួង និងឧបសគ្គរបស់របស់ខ្ញុំ ។	ម៉ាថាយ ១១:២៨–៣០
ហេតុអ្វីព្យាការីអាចទទួលវិវរណៈសម្រាប់សាសនាក្រៅទាំងមូល ?	ម៉ាថាយ ១៦:១៥–១៩
ខ្ញុំស្រឡាញ់ព្រះវរបិតាសួគ៌ ប៉ុន្តែនៅពេលនេះខ្ញុំពិបាកក្នុងការផ្តល់ក្តីស្រឡាញ់ដល់មិត្តម្នាក់ ។ តើព្រះពិតជាចង់ឲ្យខ្ញុំស្រឡាញ់គាត់ដែរមែនទេ ?	ម៉ាថាយ ២២:៣៦–៣៩
ខ្ញុំដឹងថា ក្នុងនាមជាអ្នកកាន់បព្វជិតភាពម្នាក់ ខ្ញុំមានភារកិច្ចបម្រើបេសកកម្មនៅទីណាដែលព្រះអម្ចាស់ឲ្យខ្ញុំទៅ ប៉ុន្តែខ្ញុំព្រួយចិត្តអំពីការឃ្លាតឆ្ងាយពីមនុស្សគ្រប់គ្នាដែលខ្ញុំស្គាល់ និងត្រូវនៅឯកោ ។	ម៉ាថាយ ២៨:១៩–២០
តើយើងដឹងថា ព្រះយេស៊ូវគ្រីស្ទពិតជាមានព្រះជន្មរស់ឡើងវិញដោយមានព្រះកាយជាសាច់ និងឆ្អឹងតាមរបៀបណា ?	លូកា ២៤:៣៦–៣៩
តើបុណ្យជ្រមុជទឹកពិតជាចាំបាច់ដើម្បីរស់នៅជាមួយនឹងព្រះមែនឬ ?	យ៉ូហាន ៣:៥
មនុស្សមួយចំនួននិយាយថា វាមិនសំខាន់អ្វីទេដែលថា ខ្ញុំជ្រើសរើសដើរតាមព្រះយេស៊ូវគ្រីស្ទ ឬមនុស្សម្នាក់ផ្សេងទៀតនោះ ។ ដរាបណាខ្ញុំជាមនុស្សល្អ ខ្ញុំនឹងបានឡើងទៅស្ថានសួគ៌ ។	យ៉ូហាន ១៤:៦
តើអ្វីទៅជាវិធីដ៏ល្អបំផុតសម្រាប់ខ្ញុំ ដើម្បីបង្ហាញព្រះអម្ចាស់ថាខ្ញុំស្រឡាញ់ទ្រង់ ?	យ៉ូហាន ១៤:១៥
ហេតុអ្វីការស្គាល់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទគឺជារឿងសំខាន់ ?	យ៉ូហាន ១៧:៣
តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ?	កិច្ចការ ២:៣៦–៣៨
តើមនុស្សគ្រប់គ្នាដែលបានរស់នៅក្នុងជំនាន់ព្រះគម្ពីរបើបបានដឹង ហើយបានព្យាករថានឹងមានការស្តារឡើងវិញនៃដំណឹងល្អនៅថ្ងៃចុងក្រោយដែរឬទេ ?	កិច្ចការ ៣:១៩–២១

កិច្ចការ ១៧

សេចក្តីផ្តើម

ក្រោយពីចាកចេញពីភីលីព ប៉ុល និងស៊ីឡាសបានបង្រៀនដំណឹងល្អនៅថែស្សាឡូនីច និងក្រុងបេរា ។ ការបៀតបៀនមកពីពួកអ្នកឥតជំនឿនៅក្នុងទីក្រុងទាំងនេះ បានជម្រុញប៉ុលឲ្យកៀសខ្លួនទៅក្រុងអាថែន ជាកន្លែងដែលលោកបានបង្រៀនដល់ប្រជាជននៅទីនោះអំពីលក្ខណៈពិតរបស់ព្រះនៅលើភ្នំអើរីយ៉ូស ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១៧:១-១៥

មានពួកយូដាមួយចំនួននៅក្រុងថែស្សាឡូនីចព្យាយាមបញ្ឈប់ប៉ុលមិនឲ្យប្រកាសដំណឹងល្អ

សូមអញ្ជើញសិស្សឲ្យពន្យល់ថា ពួកគេនឹងឲ្យដំបូន្មានអ្វីខ្លះទៅមនុស្សដែលនៅក្នុងស្ថានភាពខាងក្រោមនេះ ៖

១. យុវជនម្នាក់ដែលជាសមាជិកសាសនាចក្របានស្តាប់សមាជិកមួយរូបនៅក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ថ្លែងអំពីសារសំខាន់នៃអាពាហ៍ពិពាហ៍ និងគ្រួសារនៅក្នុងវិធានការរបស់ព្រះវរបិតាសួគ៌ ។ មិត្តមួយចំនួនរបស់យុវជននោះបានសម្តែងការមិនពេញចិត្តជាមួយនឹងការបង្រៀនរបស់សាវកូរបនោះ ។ យុវជននោះចង់ដឹងដោយខ្លួនឯងថា តើការបង្រៀនរបស់សាវកូរបនោះជាការពិតដែរឬទេ ។

២. យុវនារីម្នាក់បានចោទសួរពីសារៈសំខាន់នៃការរក្សាថ្ងៃឈប់សម្រាកជាថ្ងៃបរិសុទ្ធ ។ មិត្តនាងភាគច្រើនបានចំណាយពេលនៅថ្ងៃអាទិត្យដើរផ្សារ និងដេក ហើយពួកគេមិនគិតចង់ទៅព្រះវិហារនោះទេ ។ ម្តាយនាងពន្យល់ពីពរជ័យដែលអាចកើតមានមកពីការគោរពដល់ព្រះអម្ចាស់នៅថ្ងៃអាទិត្យ ប៉ុន្តែយុវនារីម្នាក់នេះនៅតែពិបាកនឹងជឿថា ការរក្សាថ្ងៃឈប់សម្រាកជាថ្ងៃបរិសុទ្ធគឺជារឿងដ៏មានសារៈសំខាន់ ។

នៅពេលសិស្សសិក្សា កិច្ចការ ១៧ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍ ដែលនឹងជួយពួកគេឲ្យដឹងដោយខ្លួនឯងពីសេចក្តីពិតដ៏ពេញលេញនៃសារលិខិតដែលយើងទទួលពីពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ។

សូមពន្យល់ថា ប៉ុល និងស៊ីឡាសបានធ្វើដំណើរទៅថែស្សាឡូនីច ជាកន្លែងដែលពួកលោកបានបង្រៀននៅក្នុងសាលាប្រជុំរបស់ពួកយូដា ។ (អ្នកគួរអញ្ជើញសិស្សឲ្យស្វែងរកថែស្សាឡូនីច និងម៉ាសេដូនី នៅលើផែនទីក្នុងព្រះគម្ពីរ លវ. ១៣ « ដំណើរទាំងឡាយដែលសាវកប៉ុលទៅផ្សាយសាសនា ») ។ សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៧:១-៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រើអ្វីទៅដើម្បីបង្រៀនដល់ពួកយូដា ។

- តើប៉ុលបានប្រើអ្វីទៅដើម្បីបង្រៀនដល់ពួកយូដា ?

សូមពន្យល់ថា *បើកសម្តែង* (ខទី ៣) មានន័យថាបង្ហាញ ឬប្រកាស ។ ប៉ុលបានប្រើវគ្គបទគម្ពីរដើម្បីប្រកាស ឬបង្ហាញថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។

សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ១៧:៤-៥ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលរបៀប ដែលប្រជាជននៅថែស្សាឡូនីចបានឆ្លើយតបចំពោះការបង្រៀនរបស់ប៉ុល ។ អ្នកគួរពន្យល់ថា ពាក្យ *បានចូលខាង* មានន័យថាមកជួបជុំជាមួយ ឬចូលរួម ហើយថាពាក្យ *មនុស្សពាលអនាថា* មានន័យថា អារក្ស ។

- តើប្រជាជនបានឆ្លើយតបទៅនឹងការបង្រៀនរបស់ប៉ុលយ៉ាងដូចម្តេច ?

សូមសង្ខេប កិច្ចការ ១៧:៦–៩ ដោយពន្យល់ថា មានក្រុមពួកឥតជំនឿមួយក្រុមបានព្យាយាមស្វែងរកប៉ុល និងស៊ីឡាស ។ នៅពេលពួកគេរកមិនឃើញ ក្រុមមនុស្សកំណាចនេះបានទៅរកពួកដឹកនាំនៅថែស្សាឡូនីច ហើយបានចោទប្រកាន់ថាការបង្រៀនរបស់ប៉ុលបានគំរាមកំហែងដល់សិទ្ធិអំណាចរបស់ស្តេចសេសា ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៧:១០-១២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុល និងស៊ីឡាសបានគេចខ្លួនទៅទីណា ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម ខទី ១២ តើពួកយូដានៅក្រុងបេរាបានឆ្លើយតបនឹងការបង្រៀនរបស់ប៉ុលយ៉ាងដូចម្តេច ?

សូមចម្លងសមីការមិនពេញលេញខាងក្រោមនេះដាក់លើក្តារខៀន ៖

_____ + _____ = *ជន*

- យោងតាម ខទី ១១ តើដំបូងឡើយប្រជាជនបានធ្វើអ្វីខ្លះ ដែលបានដឹកនាំពួកគេឲ្យជឿលើការបង្រៀនរបស់ប៉ុល ? (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀនជាផ្នែកទីមួយនៃសមីការនោះ ៖ *ពួកគេបានរៀបចំចិត្តគំនិតសព្វគ្រប់នឹងទទួលយកពាក្យសម្តីរបស់ប៉ុល*)។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃការ « ប្រុងប្រៀបសព្វគ្រប់នឹង [ទទួល] ព្រះបន្ទូល » សូមយកបាល់មួយមកថ្មាក់ ហើយអញ្ជើញសិស្សពីរនាក់ឲ្យឡើងមកក្តារខៀន ។ ចូរសុំឲ្យសិស្សម្នាក់ត្រៀមខ្លួនចាប់បាល់នោះ ហើយប្រាប់សិស្សម្នាក់ទៀតឲ្យបោះបាល់ទៅសិស្សទីមួយ ។ ក្រោយមកទៀត ចូរសួរដល់សិស្សក្នុងថ្នាក់ថាតើពួកគេអាចប្រាប់ថា សិស្សទីមួយបានត្រៀមខ្លួនចាប់បាល់ដោយរបៀបណា ។

បន្ទាប់មក សូមអញ្ជើញសិស្សទីមួយឲ្យបង្ហាញពីការ *មិន* ត្រៀមខ្លួនចាប់បាល់នោះ ហើយបន្តធ្វើបែបនោះកាលដែលសិស្សម្នាក់ទៀតបោះបាល់ឲ្យម្តងទៀត ។ ចូរឲ្យសិស្សម្នាក់ទៀតបោះបាល់មក (ដោយប្រុងប្រយ័ត្នដើម្បីកុំឲ្យកើតមានការរងរបួស) ។ ចូរសួរដល់សិស្សក្នុងថ្នាក់ថា តើពួកគេអាចប្រាប់ថាសិស្សទីមួយមិនបានត្រៀមខ្លួនដើម្បីចាប់បាល់ដោយរបៀបណា ។ សូមអញ្ជើញសិស្សទាំងពីរនាក់ឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយវិញ ។

សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យបង្ហាញថា ការត្រៀមខ្លួនទទួលយកពាក្យសម្តីរបស់ពួកអ្នកបម្រើរបស់ព្រះមានលក្ខណៈបែបណាដែរ ។ បន្ទាប់មក ចូរសុំឲ្យពួកគេបង្ហាញថា ប្រសិនបើមនុស្សម្នាក់*មិន*បានត្រៀមខ្លួនទទួលយកពាក្យសម្តីរបស់ពួកអ្នកបម្រើរបស់ព្រះ តើវាមានលក្ខណៈបែបណាដែរ ។ (ឧទាហរណ៍ សិស្សអាចបិទព្រះគម្ពីរ និយាយជាមួយអ្នកជិតខាង ឬលេងតែជាមួយនឹងឧបករណ៍អេឡិចត្រូនិច) ។

- ក្រៅពីអាការៈខាងក្រៅរបស់គាត់ តើអ្វីទៅអាចនឹងកើតឡើងនៅក្នុងដួងចិត្ត និងគំនិតរបស់មនុស្សម្នាក់ ដែលត្រៀមខ្លួនទទួលយកសារលិខិតនៃដំណឹងល្អ ?

សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅលើចន្លោះទីពីរនៅក្នុងសមីការនៅលើក្តារខៀន ។

- យោងតាម ខទី ១១ តើប្រជាជនបានធ្វើអ្វីផ្សេងទៀត ដែលបានដឹកនាំពួកគេឲ្យជឿលើការបង្រៀនរបស់ប៉ុល ? (បន្ទាប់ពីសិស្សឆ្លើយរួចហើយ សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀនជាផ្នែកទីពីរនៃសមីការនោះ ៖ *ពួកគេបានស្រាវជ្រាវពីព្រះគម្ពីរារាល់ថ្ងៃ ដើម្បីយល់ពីពាក្យសម្តីរបស់ប៉ុល*)។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីកិច្ចការ ១៧:១០-១២ដែលអាចពង្រឹងជំនឿរបស់យើង លើពាក្យសម្តីនៃពួកអ្នកបម្រើរបស់ព្រះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគួរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងទទួលពាក្យសម្តីនៃពួកអ្នកបម្រើរបស់ព្រះអម្ចាស់ដោយត្រៀមគំនិតជាស្រេច ហើយស្រាវជ្រាវបទគម្ពីរប្រចាំថ្ងៃ នោះជំនឿរបស់យើងលើប្រសាសន៍របស់ពួកលោកនឹងមានភាពរឹងមាំ ។**

សូមមើលឡើងវិញពីស្ថានភាព ដែលបានពិពណ៌នានៅខាងដើមមេរៀន ។

- តើគោលការណ៍នេះអាចជួយមនុស្ស នៅក្នុងស្ថានភាពទាំងនេះបានយ៉ាងដូចម្តេច ?
- តើការសិក្សាព្រះគម្ពីរប្រចាំថ្ងៃអាចជៈឥទ្ធិពលដល់សមត្ថភាពរបស់យើង ដើម្បីនឹងជឿលើសេចក្តីពិតយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីពេលវេលា ដែលពួកគេបានធ្វើជាសាក្សីអំពីភាពពេញលេញនៃសេចក្តីពិតនៃគោលការណ៍នេះ ។ អ្នកគួរអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមលើកទឹកចិត្តសិស្សឲ្យទទួលយកពាក្យសម្តីរបស់ពួកព្យាការី ថ្នាក់ដឹកនាំ គ្រូបង្រៀន និងឪពុកម្តាយដោយ « ប្រុងប្រៀបសព្វគ្រប់ » ហើយអានព្រះគម្ពីរារាល់ថ្ងៃ ។

សូមសង្ខេប កិច្ចការ ១៧:១៣–១៥ ដោយពន្យល់ថា នៅពេលពួកយូដានៅក្នុងថែស្សាឡូនីចបានស្តាប់ឮថា ប៉ុលកំពុងប្រកាសដំណឹងល្អនៅក្រុងបេរា នោះពួកគេបានមកធ្វើឲ្យប្រជាជននៅក្រុងបេរាខឹង ។ ប៉ុលបានរត់ភៀសខ្លួនម្តងទៀត ដូច្នេះលោកបានធ្វើដំណើរទៅក្រុងអាថែន ។

កិច្ចការ ១៧:១៦-៣៤

ប៉ុលបង្រៀននៅភ្នំអើរីយ៉ូស

សូមអញ្ជើញសិស្សឲ្យបើកទៅរូបថតអំពីព្រះគម្ពីរប៊ីប ល.រ. ២៩ « អាថែន » នៅក្នុងផែនទី និងរូបថតទាំងឡាយអំពីព្រះគម្ពីរប៊ីប ។ សូមចង្អុលបង្ហាញថា រូបថតនេះបង្ហាញពីព្រះវិហារបរិសុទ្ធមួយនៃព្រះវិហារបរិសុទ្ធជាច្រើននៅក្រុងអាថែនដែលបានប្រើប្រាប់សម្រាប់ជាការថ្វាយបង្គំរូបព្រះក្លែងក្លាយ ។ នៅខាងក្នុងព្រះវិហារបរិសុទ្ធទាំងនេះ គឺជារូបសំណាកព្រះដែលបង្កើតដោយស្មាដៃមនុស្ស ។ នៅខាងក្រៅគឺជាអាសនាបូជាថ្វាយដល់ព្រះក្លែងក្លាយទាំងនេះត្រូវបានគេធ្វើឡើង ។

សូមសង្ខេប កិច្ចការ ១៧:១៦–២១ ដោយពន្យល់ថា ប៉ុលមានកង្វល់យ៉ាងខ្លាំងចំពោះការថ្វាយបង្គំព្រះក្លែងក្លាយនៅក្រុងអាថែន ហើយលោកបានបង្រៀននៅក្នុងសាលាប្រជុំ និងតាមផ្សារនៅទីនោះ ។ បន្ទាប់មក ពួកទស្សនវិទូបានអញ្ជើញប៉ុលឲ្យពន្យល់ពី « គោលលទ្ធិថ្មី » របស់លោក (ខទី១៩) ទៅដល់ក្រុមប្រឹក្សាច្បាប់ ដែលលោកបានជួបនៅលើភ្នំអើរីយ៉ូស ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៧:២២-២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានសង្កេតឃើញអ្វីនៅលើអាសនាមួយនៅអាថែន ។

- តើប៉ុលបានឃើញអ្វីនៅលើអាសនាមួយនៅអាថែន ?

សូមពន្យល់ថា ខទី ២២ កត់ត្រាថា ប៉ុលបានសរសើរដល់ពួកអាថែនដោយពោលថា ពួកគេ « ឧស្សាហ៍ខ្នះខ្នែង » មានន័យថាពួកគេ « កាន់សាសនាណាស់ » ឬ « ខ្វាល់ខ្វាយពីរឿងរបស់ព្រះ » ។ អាសនាសម្រាប់ « ព្រះដ៏ពុំស្គាល់ » (ខទី ២៣) គឺជាការប៉ុនប៉ងរបស់ពួកអាថែនដើម្បីចុះសម្រុងនឹងព្រះដែលខ្លួនពុំស្គាល់ ឬព្រះដែលពុំស្គាល់ពីនាមនោះទៀតផង ។ តាមមើលទៅ ពួកគេមិនចង់ធ្វើខុស ឬព្រងើយកន្តើយនឹងព្រះណាមួយរវាទចិត្ត ឬទទួលការប្រមាថ ។

សូមចង្អុលបង្ហាញថា ប្រយោគចុងក្រោយក្នុង កិច្ចការ ១៧:២៣ រួចសួរ ៖

- ហេតុអ្វីប៉ុលបានធ្វើសេចក្តីយោងទៅអាសនានេះ ទៅលើ « ព្រះដ៏ពុំស្គាល់ » នេះ ? (លោកបានប្រើវាដើម្បីឧទ្ទេសនាមនូវគំនិតពីព្រះដ៏ពិត ជាព្រះវរបិតាសួគ៌ ជាព្រះដែលពួកគេពុំស្គាល់) ។

សូមបំបែកសិស្សជាដៃគូ ឬ ជាក្រុមតូចៗ ។ សូមអញ្ជើញក្រុមនីមួយៗឲ្យស្វែងរក កិច្ចការ ១៧:២៤–៣១ នូវសេចក្តីពិតឲ្យបានច្រើនតាមដែលពួកគេអាចរកឃើញអំពីព្រះដែលប្រជាជនអាថែនមិនបានស្គាល់នោះ ។ កាលពួកគេកំពុងសិក្សា សូមសរសេរលេខខគម្ពីរនីមួយៗ (២៤-៣១) នៅលើក្តារខៀន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ឡើងមកក្តារខៀន សរសេរពីសេចក្តីពិតមួយ ដែលពួកគេបានរកឃើញ នៅក្បែរលេខនៃខគម្ពីរដែលពួកគេបានរកឃើញវា ។ (ដើម្បីជួយសិស្សឲ្យស្គាល់ពីសេចក្តីពិតមួយនៅក្នុង កិច្ចការ ១៧:២៧សូមពន្យល់ថាការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ខគម្ពីរនេះបានចែងថា « ពួកគេត្រូវស្វែងរកព្រះអម្ចាស់ ប្រសិនបើពួកគេមានឆន្ទៈរកទ្រង់ ដ្បិតទ្រង់គង់នៅមិនឆ្ងាយពីយើងរាល់គ្នាឡើយ ។

អ្នកក៏អាចណែនាំឲ្យសិស្សគូសចំណាំសេចក្តីពិតនីមួយៗនៅក្នុងព្រះគម្ពីររបស់ពួកគេផងដែរ ។ សេចក្តីពិតមួយចំនួនដែលពួកគេបានសរសេរនៅលើក្តារខៀន អាចរួមមានដូចខាងក្រោមនេះ ៖

ខទី ២៤ ៖ ព្រះបានបង្កើតពិភពលោក ។

ខទី ២៥ ៖ ព្រះបានប្រទានជីវិតដល់វត្ថុសព្វសារពើ ។

ខទី ២៦ ៖ ព្រះគ្រប់គ្រងលើជីវិតទាំងអស់ ។

ខទី ២៧ ៖ប្រសិនបើយើងមានឆន្ទៈស្វែងរកព្រះ យើងនឹងឃើញថា ទ្រង់គង់នៅមិនឆ្ងាយពីយើងឡើយ ។

ខទី ២៨ ៖យើងគឺជាកូនចៅរបស់ព្រះ ។

ខទី ២៩ ៖ យើងត្រូវបានបង្កើតឡើងតាមរូបរបស់ព្រះ ។

ខទី ៣០ ៖ ព្រះបង្គាប់មនុស្សគ្រប់គ្នាឲ្យប្រែចិត្ត ។

ខទី ៣១ ៖ព្រះនឹងកាត់សេចក្តីយើង ព្រះនឹងព្រោសមនុស្សទាំងអស់ឲ្យរស់ពីស្លាប់ ។

ការសម្រេចចិត្តពីអ្វីដែលត្រូវបង្រៀន

នៅពេលអ្នកសម្រេចចិត្តដើម្បីគូសបញ្ជាក់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុងមេរៀនមួយ ចូរស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ព្យាយាមកំណត់ពីបំណងរបស់អ្នកនិពន្ធដែលបានបំផុសគំនិត សញ្ជឹងគិតថាតើសេចក្តីពិតមួយណាដែលជាគោលលទ្ធិគ្រឹះ និងគោលការណ៍នាំមុខមានការប្រែចិត្តជឿ ហើយពិចារណាពីសេចក្តីត្រូវការរបស់សិស្ស ។

សូមអញ្ជើញសិស្សឲ្យជ្រើសយកសេចក្តីពិតមួយនៅលើក្តារខៀន ដែលវាមានន័យចំពោះពួកគេ ។ ចូរសុំឲ្យសិស្សពីរបីនាក់ចែកចាយពីសេចក្តីពិតដែលពួកគេបានជ្រើស ហើយហេតុអ្វីបានជាវាមានន័យចំពោះពួកគេ ។

សូមចង្អុលបង្ហាញពី គោលលទ្ធិ« យើងគឺជាកូនចៅរបស់ព្រះ » ។

- តើពាក្យថាជា « កូនចៅ » របស់ព្រះមានន័យដូចម្តេច ? (យើងគឺជាកូនខាងចៅវិញ្ញាណរបស់ព្រះវរបិតាសួគ៌) ។
- ហេតុអ្វីវាជារឿងដ៏សំខាន់ ដែលត្រូវយល់ដឹងពីសេចក្តីពិតនេះ ? (វាអាចជួយយើងឲ្យស្គាល់ពីតម្លៃគ្មានដែនកំណត់របស់យើងចំពោះព្រះវរបិតាសួគ៌ និងសក្តានុពលរបស់យើងដើម្បីប្រែក្លាយដូចជាទ្រង់ដែរ) ។
- តើបញ្ហា ឬការភាន់ច្រឡំអ្វីខ្លះ ដែលអាចកើតឡើងតាមរយៈការមិនយល់ពីគោលលទ្ធិនេះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ក្នុងក្លឹមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា ហេតុអ្វីយើងត្រូវចងចាំ ដើម្បីមើលឃើញខ្លួនឯងថាជាកូនចៅដ៏សំខាន់របស់ព្រះ ។



« ចូរប្រុងប្រយ័ត្នពីរបៀបដែលអ្នកសម្គាល់ចរិតខ្លួនឯង ។ ចូរកុំសម្គាល់ចរិត ឬកំណត់ខ្លួនឯងដោយគុណសម្បត្តិបណ្តោះអាសន្នមួយចំនួនឡើយ ។ គុណសម្បត្តិតែមួយ*គត់*ដែលចង្អុលបង្ហាញចរិតយើងគឺថា យើងគឺជាបុត្រាបុត្រីនៃព្រះ ។ ការពិតនោះមានគុណសម្បត្តិលើសពីបុគ្គលិកលក្ខណៈផ្សេងទៀតទាំងអស់ រួមទាំងជាតិសាសន៍ ការងារ បុគ្គលិកលក្ខណៈ កិត្តិយស ឬសូម្បីតែសាសនា » (« How to Define Yourself » *New Era* ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤៨) ។

សូមជួយសិស្សឲ្យទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

បន្ទាប់ពីសិស្សបានស្គាល់ ហើយយល់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃជំពូកដ៏ល្អនៅក្នុងព្រះគម្ពីរហើយ នោះពួកគេអាចទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់របស់វាតាមរយៈព្រះវិញ្ញាណ ។ វិធីមួយដើម្បីជួយសិស្សឲ្យធ្វើកិច្ចការនេះ គឺលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិត ហើយចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនដែលទាក់ទងនឹងគោលលទ្ធិ ឬគោលការណ៍នោះ ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីចងចាំថា យើងគឺជាកូនចៅនៃព្រះជាមុន ?

សូមយោងទៅគោលការណ៍ « ប្រសិនបើយើងមានឆន្ទៈស្វែងរកព្រះ យើងនឹងឃើញថា ទ្រង់គង់នៅមិនឆ្ងាយពីយើងឡើយ » ។

- តើយើងអាចខិតខំស្គាល់ ហើយខិតមកជិតព្រះតាមរបៀបណា ?
- តើការយល់ដឹងពីទំនាក់ទំនងយើងជាមួយនឹងព្រះ អាចជះឥទ្ធិពលដល់បំណងប្រាថ្នារបស់យើងដើម្បីស្វែងរកទ្រង់យ៉ាងដូចម្តេច ?
- តើអ្នកមានអារម្មណ៍ថាធ្លាប់នៅជិតនឹងព្រះវរបិតាសួគ៌នៅពេលណាដែរ ?

សូមសង្ខេប កិច្ចការ ១៧:៣២–៣៤ ដោយពន្យល់ថា ពួកអាថែនបានមានប្រតិកម្មលាយឡំគ្នានឹងការលើកឡើងរបស់ប៉ុលអំពី « មនុស្សស្លាប់រស់ឡើងវិញ » (ខទី ៣២) ។ មានពួកគេមួយចំនួនបានចំអកឲ្យប៉ុល រីឯអ្នកផ្សេងទៀតចង់ស្តាប់ថែមទៀត ហើយមានមនុស្សខ្លះបានជឿ ។

អ្នកគួរថ្លែងទីបន្ទាល់ថា សិស្សអាចស្គាល់ ហើយយល់ពីព្រះ ទោះជាមនុស្សជាច្រើនមិនបានស្គាល់ទ្រង់ក្តី ។ សូមអញ្ជើញសិស្សឲ្យសរសេរឃ្លា *ព្រះដែលអាចស្គាល់* នៅលើក្រដាសមួយសន្លឹក ឬបញ្ជីណាមួយ ហើយសរសេរពីវិធីដែលពួកគេនឹងខិតខំ ហើយអភិវឌ្ឍទំនាក់ទំនងមួយជាមួយនឹងព្រះ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់ក្រដាសនេះនៅត្រង់កន្លែង ដែលវាអាចជួយរំឭកពួកគេពីគោលដៅទាំងនោះ ។

មេរៀន ៩៥

កិច្ចការ ១៨-១៩

សេចក្តីផ្តើម

ប៉ុលត្រូវពួកសាសន៍យូដាជាច្រើននៅក្រុងកូរិនថូសបដិសេធ ប៉ុន្តែទទួលបានជោគជ័យជាមួយនឹងសាសន៍ដទៃដែលនៅទីនោះ ។ ស្វាមីភរិយារៀបការដ៏ស្មោះត្រង់មួយគូ គឺអ័គីឡា និងព្រីស៊ីល បានជួយអ័ប៉ុឡូសឲ្យយល់ពីផ្លូវរបស់ព្រះ ។ ប៉ុលបានប្រកាសពីព្រះវិញ្ញាណបរិសុទ្ធ បានធ្វើអព្ភូតហេតុ ហើយបានចេញពីក្រុមមនុស្សដ៏គ្មានសណ្តាប់ធ្នាប់ក្នុងសាលាប្រជុំនៅឯអេភេសូរ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១៨:១-១៧

ប៉ុលប្រកាសដំណឹងល្អនៅក្រុងកូរិនថូស

ចូរអានសំណួរដូចខាងក្រោមនេះឲ្យឮៗ ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ៖

- តើមានវិធីមួយចំនួនណាខ្លះ ដែលអ្នកអាចចូលរួមនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ?
- តើមានឧបសគ្គណាខ្លះ ដែលអ្នកធ្លាប់បានជួប នៅពេលអ្នកព្យាយាមធ្វើកិច្ចការរបស់ព្រះអម្ចាស់ ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេ ។ នៅពេលសិស្សសិក្សា កិច្ចការ ១៨ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេ នៅពេលពួកគេព្យាយាមធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។

សូមសង្ខេប កិច្ចការ ១៨:១–៤ ដោយពន្យល់ថា ប៉ុលបានចាកចេញពីទីក្រុងអាថែនទៅកូរិនថូស ជាទីកន្លែងដែលលោកបានបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទនៅក្នុងសាលាប្រជុំ ។ (អ្នកគួរអញ្ជើញសិស្សឲ្យបើកទៅផែនទីក្នុងព្រះគម្ពីរបរិសុទ្ធ ឬ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា » ហើយស្វែងរកក្រុងអាថែន និងកូរិនថូស) ។

សូមឲ្យសិស្សម្នាក់អានកិច្ចការ ១៨:៥-៦ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលឧបសគ្គនានា ដែលប៉ុលបានជួបប្រទះ នៅពេលលោកបានបង្រៀនពួកសាសន៍យូដាអំពីព្រះយេស៊ូវគ្រីស្ទនៅកូរិនថូស ។

- តើឧបសគ្គអ្វីខ្លះដែលប៉ុលបានជួបប្រទះ ?
- តើប៉ុលបានដាក់ផែនការធ្វើអ្វីខ្លះ ដោយសារពួកសាសន៍យូដានៅក្នុងសាលាប្រជុំនោះបានបដិសេធសារលិខិតរបស់លោក ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ១៨:៧-១០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលថាតើមានអ្វីបានកើតឡើង ដែលវាបានផ្តល់ជាការលើកទឹកចិត្តដល់ប៉ុល ។

- តើមានអ្វីបានកើតឡើងដែលវាបានផ្តល់ជាការលើកទឹកចិត្តដល់ប៉ុល ?
- យោងតាម ខទី ១០តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ប៉ុល ប្រសិនបើលោកបានប្រកាសដំណឹងល្អ ?
- តើយើងអាចរៀនពីគោលការណ៍អ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះ អំពីអ្វីដែលព្រះអម្ចាស់នឹងធ្វើសម្រាប់ជនដែលធ្វើកិច្ចការរបស់ទ្រង់ដោយសក្តិសម ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគ្រាស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងរស់នៅដោយសក្តិសម នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង កាលយើងធ្វើកិច្ចការរបស់ទ្រង់**)។
- ហេតុអ្វីវាជារឿងយ៉ាងសំខាន់ដើម្បីដឹងថា ព្រះអម្ចាស់នឹងគង់នៅជាមួយអ្នក កាលអ្នកធ្វើកិច្ចការរបស់ទ្រង់ ?

ចូរសុំសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖

« ឥឡូវនេះ អ្នកទាំងអស់គ្នាមួយចំនួនអាចមានការខ្មាស់អៀនពីធម្មជាតិ ឬគិតថាខ្លួនឯងគ្មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបដោយវិជ្ជមានទៅនឹងការហៅបម្រើ ។ សូមចងចាំថា នេះ . . . គឺជាកិច្ចការរបស់ព្រះអម្ចាស់ ហើយពេលយើងស្ថិតនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ នោះយើងនឹងទទួលបានជំនួយពីព្រះអម្ចាស់ ។ ចូរចាំថា ព្រះអម្ចាស់នឹងដុសខាត់ខ្នងដើម្បីរែកបន្ទុក ដែលនឹងដាក់មកលើខ្នងនោះ » (« To Learn, to Do, to Be » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៦២) ។

- តើនៅពេលណា ដែលព្រះអម្ចាស់បានគង់នៅជាមួយអ្នកនៅពេលអ្នកបានធ្វើកិច្ចការរបស់ទ្រង់ ? តើអ្នកបានដឹងថាទ្រង់គង់នៅជាមួយអ្នកដោយរបៀបណា ?

សូមសង្ខេប កិច្ចការ ១៨:១១–១៧ ដោយពន្យល់ថា ប៉ុលបានបន្តផ្សព្វផ្សាយនៅក្នុងកូរិនថូសអស់រយៈពេលមួយឆ្នាំកន្លះ (ហើយទំនងជាសរសេរសំបុត្ររបស់លោកទៅកាន់ពួកថែស្សាឡូនីចនៅគ្រានេះ) ។ កាលលោកនៅក្នុងកូរិនថូស មានពួកយូដាមួយក្រុមបានព្យាយាមធ្វើឲ្យប៉ុលមានទោស ចំពោះអ្វីដែលលោកកំពុងបង្រៀន ប៉ុន្តែអ្នកតំណាងផ្នែកច្បាប់បានបដិសេធករណីនេះ ។

កិច្ចការ ១៨:១៨-២៨

អ័គីឡា និង ព្រីស៊ីល បានជួយអ័ប៉ុឡូសឲ្យយល់ពីមាគ៌ារបស់ព្រះ

សូមសង្ខេប កិច្ចការ ១៨:១៨–២៣ ដោយពន្យល់ថា មានស្វាមីភរិយាមួយគូ គឺអ័គីឡា និងព្រីស៊ីល បានអមដំណើរប៉ុលទៅអេភេសូរ ។ ប៉ុលបានធ្វើដំណើរទៅយេរូសាឡិម រួចហើយទៅភាគខាងជើងអាន់ទីយ៉ូក ដោយទុកឲ្យស្វាមីភរិយាគូនេះនៅអេភេសូរ ។ នៅអាន់ទីយ៉ូក លោកបានបញ្ចប់ដំណើរផ្សាយសាសនាជាលើកទីពីររបស់លោក ដែលមានរយៈពេលបីខែ ហើយមានចម្ងាយផ្លូវប្រមាណជា ៤,៨២៨ គីឡូម៉ែត្រ ។ បន្ទាប់មកមិនយូរប៉ុន្មាន លោកបានចាកចេញពីអាន់ទីយ៉ូក ហើយបានចាប់ផ្តើមដំណើរផ្សាយសាសនាលើកទីបីរបស់លោក ដោយធ្វើដំណើរទៅតាមសាខាដែលលោកបានស្ថាបនាកាលពីមុន ហើយពង្រឹងដល់សមាជិកទាំងឡាយ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៨:២៤-២៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើមានអ្វីបានកើតឡើងនៅអេភេសូរ បន្ទាប់ពីប៉ុលបានចេញទៅ ។

- តើមានអ្វីបានកើតឡើងនៅអេភេសូរ បន្ទាប់ពីប៉ុលបានចាកចេញនោះ ?
- តើអ័ប៉ុឡូសបានយល់អ្វីរួចទៅហើយអំពី « សេចក្តីខាងឯព្រះអម្ចាស់ » ? (ខទី ២៥)
- តើអ័ប៉ុឡូសនៅខ្វះចំណេះដឹងអ្វីខ្លះ ? (ដោយបាន « ស្គាល់តែបុណ្យជ្រមុជទឹករបស់លោកយ៉ូហាន » [ខទី ២៥] ប៉ុន្តែអ័ប៉ុឡូសនៅខ្វះការយល់ដឹងពីភាពពេញលេញនៃដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៨:២៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែល អ័គីឡា និងព្រីស៊ីលបានធ្វើ កាលពួកគេបានស្តាប់ឮការបង្រៀនរបស់អ័ប៉ុឡូស ។

- តើអ័គីឡា និងព្រីស៊ីលបានធ្វើអ្វីខ្លះ កាលពួកគេបានស្តាប់ឮការបង្រៀនរបស់អ័ប៉ុឡូស ?
- តើឃ្លាដែលថាពួកគេ « ពន្យល់ពីផ្លូវព្រះឲ្យរឹតតែច្បាស់ទៅទៀត » មានន័យដូចម្តេច ? (ខទី ២៦) ។ (អ័គីឡា និងព្រីស៊ីលបានបង្រៀនអ័ប៉ុឡូសបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ដោយជួយបន្ថែមចំណេះ និងការយល់ដឹងដល់អ័ប៉ុឡូស) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កិច្ចការ ១៨:២៧-២៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលភស្តុតាងថា អ័គីឡា និងព្រីស៊ីលបានជួយអ័ប៉ុឡូសឲ្យយល់ដឹងពីផ្លូវព្រះរឹតតែច្បាស់ ។

- តើឃ្លាអ្វីនៅក្នុងខគម្ពីរទាំងនេះដែលចង្អុលបង្ហាញថា អ័គីឡា និងព្រីស៊ីលបានជួយអ័ប៉ុឡូសឲ្យយល់ដឹងពីផ្លូវរបស់ព្រះរឹតតែច្បាស់ ?

កិច្ចការ ១៩:១-២០

ប៉ុលផ្តល់អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ហើយធ្វើអព្ភូតហេតុ

សូមពន្យល់ថា បន្ទាប់ពីប៉ុលបានធ្វើដំណើរទៅកន្លែងជាច្រើន នោះលោកបានត្រឡប់មកអេភេសូរវិញ ។ សូមអញ្ជើញសិស្សម្នាក់អានកិច្ចការ ១៩:២-៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប៉ុលបានជួយប្រជាជននៅអេភេសូរឲ្យយល់ពីផ្លូវរបស់ព្រះរឹតតែច្បាស់តាមរបៀបណា ។

- តើគោលលទ្ធិអ្វីទៅ ដែលប៉ុលបានបង្រៀនដល់ពួកសិស្សនៅអេភេសូរឲ្យយល់រឹតតែច្បាស់នោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោម ដែលបានចោះពុម្ពឡើងក្រោមការដឹកនាំរបស់ព្យាការី យ៉ូសែប ស៊្មីធ ហើយឲ្យសិស្សក្នុងថ្នាក់ស្តាប់រកហេតុផល ដែលប្រជាជនទាំងនេះត្រូវការបុណ្យជ្រមុជទឹក ៖

« វាទំនងដូចជា . . . មានពួកនិកាយយូដាមួយចំនួនបានធ្វើបុណ្យជ្រមុជទឹកដូចជាយ៉ូហាន [បាទីស្ទ] ប៉ុន្តែភ្លេចប្រាប់ពួកគេថា នឹងមានមនុស្សម្នាក់ផ្សេងទៀតមកតាមក្រោយដោយព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីធ្វើបុណ្យជ្រមុជទឹកដោយភ្លើង និងព្រះវិញ្ញាណបរិសុទ្ធ ៖—ដែលវាបានបង្ហាញដល់ពួកអ្នកប្រែចិត្តជឿទាំងនេះថា បុណ្យជ្រមុជទឹកដំបូងរបស់ពួកគេជារឿងមិនស្របច្បាប់នោះទេ ហើយកាលពួកគេបានស្តាប់ឮរឿងនេះហើយ ពួកគេបានជ្រមុជទឹកដោយរីករាយ ហើយបន្ទាប់ពីមានដៃបានដាក់នៅលើក្បាលពួកគេ នោះពួកគេបានទទួលអំណោយទានស្របតាមការសន្យា » (« Baptism » ការចោះពុម្ពបានធ្វើឡើងនៅក្នុង *Times and Seasons* ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ១៨៤២ ទំព័រ ៩០៤, ការប្រកបពាក្យត្រូវបានកែសម្រួលឲ្យមានលក្ខណៈទំនើប, យ៉ូសែប ស៊្មីធជានិពន្ធនាយកនៅគ្រានោះ) ។

- ហេតុអ្វីបានជាមនុស្សមួយចំនួននៅអេភេសូរត្រូវជ្រមុជទឹកជាថ្មី ?
- តើយើងអាចរៀនពីការពិតណាខ្លះអំពីបុណ្យជ្រមុជទឹកកិច្ចការ ១៩:២–៦ ? (ទោះបីជាសិស្សអាចនឹងប្រើពាក្យខុសគ្នាក្តី សូមជួយពួកគេឲ្យស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖**ពិធីបុណ្យជ្រមុជទឹកត្រូវតែបានធ្វើឡើងដោយអ្នកបម្រើម្នាក់របស់ព្រះដែលមានសិទ្ធិអំណាច ។ ដើម្បីឲ្យពិធីបុណ្យជ្រមុជទឹកមានលក្ខណៈពេញលេញ វាត្រូវអមដោយការទទួលព្រះវិញ្ញាណបរិសុទ្ធ**) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ៖

« ប្រសិនបើអ្នកពុំបានទទួលពិធីបុណ្យជ្រមុជទឹកដោយការផ្តាច់បាប ហើយទទួលព្រះវិញ្ញាណបរិសុទ្ធទេនោះ អ្នកដូចជាជ្រមុជទឹកឲ្យបាវខ្សាច់ដូច្នោះដែរ ។ ពិធីបុណ្យជ្រមុជទឹកដោយទឹក គឺជាពិធីបុណ្យជ្រមុជទឹកពាក់កណ្តាល ហើយវាពុំល្អទេ បើគ្មានពាក់កណ្តាលទៀត--ដែលជាពិធីបុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ » (*Teachings of Presidents of the Church:Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ៩៥) ។

សូមសង្ខេប កិច្ចការ ១៩:៧–១០ ដោយពន្យល់ថា ប៉ុលបានបន្តផ្សព្វផ្សាយនៅអេភេសូរអស់រយៈពេលជាងពីរឆ្នាំ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៩:១១-១២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា មានអព្ភូតហេតុអ្វីខ្លះបានកើតឡើងនៅអេភេសូរ ខណៈពេលដែលប៉ុលនៅទីនោះ ។

- តើព្រះបានធ្វើអព្ភូតហេតុអ្វីខ្លះតាមរយៈប៉ុល ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងដំណើររឿងនេះអំពីអ្វីដែលព្រះធ្វើ តាមរយៈពួកអ្នកបម្រើដែលមានសិទ្ធិអំណាចរបស់ទ្រង់ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីបង្ហាញសេចក្តីពិតមួយស្រដៀងគ្នានឹងគោលការណ៍ខាងក្រោមនេះ: **វិធីមួយដែលព្រះបង្ហាញព្រះចេស្តាទ្រង់ គឺតាមរយៈពួកអ្នកបម្រើរបស់ទ្រង់ដែលមានសិទ្ធិអំណាច**) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៩:១៣-១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើមានអ្វីខ្លះបានកើតឡើងកាលពួកយូដាមួយចំនួនបានព្យាយាមបណ្តេញអារក្សចេញ ដូចជាប៉ុលបានធ្វើ ។

- តើមានអ្វីខ្លះបានកើតឡើង នៅពេលកូនប្រុសទាំងប្រាំពីររបស់សង្គ្រាជបានព្យាយាមបណ្តេញវិញ្ញាណអាក្រក់នោះ ?
- តើវិញ្ញាណអាក្រក់នោះបានស្គាល់នរណា ? តើវិញ្ញាណអាក្រក់នោះពុំបានស្គាល់នរណា ?
- ហេតុអ្វីវិញ្ញាណអាក្រក់នោះពុំស្គាល់ពួកកូនប្រុសរបស់ស្កេវ៉ា ? (ដោយសារពួកគេគ្មានសិទ្ធិអំណាចដើម្បីធ្វើការងារបម្រើនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៩:១៧-២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា មនុស្សជាច្រើនបានធ្វើអ្វីខ្លះបន្ទាប់ពីបានរៀនអំពីព្រឹត្តិការណ៍នេះហើយ ។ សូមពន្យល់ថា « ក្បួនដំរា » (ខទី ១៩) សំដៅទៅលើអំពើអាបធ្មប់ និងអំពើអាក្រក់ផ្សេងទៀត ។

- តើមនុស្សជាច្រើនបានធ្វើអ្វីខ្លះបន្ទាប់ពីព្រឹត្តិការណ៍នេះ ដើម្បីបង្ហាញថា ពួកគេមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ? (ពួកគេបានសារភាព ហើយបានលះបង់ទំនៀមទម្លាប់អាក្រក់របស់ខ្លួនដោយការដុតគម្ពីរដែលទាក់ទងនឹងទំនៀមទម្លាប់ទាំងនោះចោល) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ពីក្នុងខគម្ពីរទាំងនេះអំពីរបៀបបង្ហាញសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគូរស្គាល់គោលការណ៍ដូចតទៅនេះ: **តាមរយៈការសារភាព ហើយការបោះបង់ចោលការអនុវត្តអាក្រក់នានា នោះយើងបង្ហាញសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ**) ។
- តើយើងត្រូវមានការលះបង់អ្វីខ្លះ ដើម្បីបោះបង់ចោលអំពើបាបមួយដែលយើងបានសារភាព ?

សូមថ្លែងទីបន្ទាល់ពីសារៈសំខាន់នៃការបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ដោយពុំគ្រាន់តែសារភាពអំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវលះបង់អ្វីៗទាំងអស់ ដែលអាចដឹកនាំយើងត្រឡប់ទៅរកអំពើបាបទាំងនោះវិញដែរ ។

សូម អញ្ជើញ សិស្សឲ្យសញ្ជឹងគិតថា តើមានអ្វីខ្លះនៅក្នុងជីវិតរបស់ពួកគេ ដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យពួកគេលះបង់ចោល ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើសកម្មភាពតាមការបំផុសគំនិត ដែលពួកគេបានទទួលនៅក្នុងមេរៀននេះ ។

> ***សូមជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ***
>
> សូមផ្តល់ឱកាសឲ្យសិស្សសញ្ជឹងគិតពីស្ថានភាពផ្ទាល់ខ្លួនគេ និង គិតពីរបៀបជាក់លាក់នានាដែលពួកគេអាចអនុវត្តគោលការណ៍ ឬគោលលទ្ធិមួយ ។ កាលសិស្សមានពេលសញ្ជឹងគិត ហើយពិចារណាពីរបៀបធ្វើឲ្យគោលការណ៍មួយអនុវត្តចំពោះពួកគេ នោះព្រះវិញ្ញាណអាចដឹកនាំពួកគេ ។

កិច្ចការ ១៩:២១-៤១

អ្នកថ្វាយបង្គំព្រះ ឌីអានក្លែងក្លាយ និយាយជំទាស់នឹងប៉ុល ហើយបានបង្កឲ្យមានភាពចលាចលនៅក្នុងទីក្រុង

សូមសង្ខេប កិច្ចការ ១៩:២១–៤១ ដោយពន្យល់ថា ផ្នែកមួយនៃសេដ្ឋកិច្ចនៅក្រុងអេភេសូរត្រូវបានដឹកនាំដោយការថ្វាយបង្គំព្រះឌីអានដែលជាព្រះរបស់ពួករ៉ូម ។ ការផ្សព្វផ្សាយរបស់ប៉ុលជំទាស់ចំពោះការថ្វាយបង្គំព្រះក្លែងក្លាយនេះបានធ្វើឲ្យជាងចម្លាក់រូបសំណាកព្រះឌីអានដែលមានមន្តអាគម ធ្វើការដឹកនាំប្រជាជនឲ្យទាស់នឹងប៉ុល ។ ប្រជាជនបានប្រមូលផ្តុំគ្នានៅរោងល្ខោននៅក្រុងនោះ (ដែលអាចដាក់មនុស្សដល់ទៅ ២៤,០០០ នាក់) មានភាពច្របូកច្របល់ និងភាពចលាចល ។ ប៉ុលមានបំណងថ្លែងទៅក្រុមមនុស្សនេះ ប៉ុន្តែពួកសិស្ស និងពួកអ្នកដឹកនាំរដ្ឋាភិបាលមួយចំនួនបានបញ្ចុះបញ្ចូលលោកមិនឲ្យចូលទៅក្នុងរោងល្ខោននោះទេ ។ នៅទីបំផុត ស្មៀនក្រុងបាននិយាយនឹងក្រុមនេះ ហើយពួកគេបានបំបែកផ្លូវគ្នា ។ សូមចង្អុលបង្ហាញថា ការការពាររបស់ប៉ុលគឺជាឧទាហរណ៍មួយអំពីរបៀបដែលកិច្ចការរបស់ព្រះនឹងពុំត្រូវបានរារាំង ទោះជាមានការប្រឆាំងតវ៉ារបស់មនុស្សទុច្ចរិតក្តី ។ (នៅគ្រានេះហើយនៅអេភេសូរ [ប្រមាណ គ.ស៥៧] ដែលប៉ុលបានសរសេរកូរិនថូសទី ១) ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

មេរៀនសិក្សានៅផ្ទះ

កិច្ចការ ១៣-១៩ (មេរៀនទី ១៩)

ការរៀបចំសម្ភារមេរៀនសម្រាប់គ្រូបង្រៀនដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា កិច្ចការ ១៣-១៩ (មេរៀនទី ១៩) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និងគោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (កិច្ចការ ១៣-១៤)

នៅពេលសិស្សសិក្សាអំពីប៉ុល និងអន្តរកម្មរបស់ប៉ាណាបាសជាមួយនឹងគ្រួធ្មប់ម្នាក់ ពួកគេបានរៀនថា ព្រះចេស្តានៃព្រះគឺអស្ចារ្យជាងអំណាចរបស់អារក្ស ។ នៅពេលប៉ុលបង្រៀនអំពីព្រះអង្គសង្គ្រោះ និងអំពីការឈឺចាប់ដ៏ខ្លាំង នោះសិស្សសម្គាល់ឃើញពីគោលការណ៍ដូចតទៅនេះ ៖ យើងអាចទទួលបានការអភ័យទោសពីអំពើបាបយើង ហើយបានរាប់ថាជាសុចរិតវិញ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នៅពេលយើងឆ្លងកាត់ការឈឺចាប់ដ៏ខ្លាំងដោយស្មោះត្រង់ យើងនឹងបានត្រៀមខ្លួនចូលទៅក្នុងនគរសួគ៌ស្ថាល ។

ថ្ងៃទី ២ (កិច្ចការ ១៥)

នៅពេលសិស្សបានសិក្សាពីរបៀបដែលពួកថ្នាក់ដឹកនាំសាសនាចក្របានធ្វើការសម្រេចចិត្តរួមគ្នា នោះពួកគេបានរៀនថា យើងអាចស្គាល់ពីព្រះទ័យរបស់ព្រះអម្ចាស់តាមរយៈពួកព្យាការី និងពួកសាវកនៅសម័យរបស់ទ្រង់ តាមរយៈការសិក្សាព្រះគម្ពីរ និងតាមរយៈការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ពួកគេក៏បានរៀនផងដែរថា តាមរយៈការប្រឹក្សារួមគ្នា និងការស្វែងរកវិវរណៈពីព្រះ នោះថ្នាក់ដឹកនាំសាសនាចក្រទទួលបានការបំផុសគំនិតចំពោះបញ្ហាលំបាកៗ ។

ថ្ងៃទី ៣ (កិច្ចការ ១៦-១៧)

ចេញពីដំណើររឿងរបស់ប៉ុល យើងអាចរៀនថា នៅពេលយើងធ្វើតាមវិវរណៈដែលព្រះបានប្រទានឲ្យ នោះយើងអាចនឹងដឹកនាំឲ្យទៅកមនុស្សដែលត្រៀមខ្លួនទទួលយកដំណឹងល្អ ។ សេចក្តីសង្គ្រោះតម្រូវឲ្យមានការជឿលើព្រះយេស៊ូវគ្រីស្ទ ហើយយើងបង្ហាញជំនឿរបស់យើងលើទ្រង់តាមរយៈការទទួលបុណ្យជ្រមុជទឹក ។ ប្រសិនបើយើងទទួលពាក្យសម្តីនៃពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ដោយត្រៀមគំនិតជាស្រេច ហើយស្វែងរកបទគម្ពីរប្រចាំថ្ងៃ នោះជំនឿរបស់យើងលើពាក្យសម្តីរបស់ពួកគាត់នឹងមានភាពរឹងមាំ ។

ថ្ងៃទី ៤ (កិច្ចការ ១៨-១៩)

តាមរយៈការអះអាងរបស់ព្រះអម្ចាស់ទៅកាន់ប៉ុល នៅពេលលោកចប់បាវម្តជាមួយនឹងប្រជាជននៅក្រុងកូរិនថូស សិស្សបានរៀនថា ប្រសិនបើយើងរស់នៅដោយសក្តិសម នោះព្រះអម្ចាស់នឹងគង់នៅជាមួយយើង កាលយើងធ្វើកិច្ចការរបស់ទ្រង់ ។ នៅពេលពួកគេបានសិក្សាអំពីការបង្រៀន និងការព្យាបាលរបស់ប៉ុលនៅក្នុងអេភេសូរ នោះសិស្សបានរៀនដូចតទៅនេះ ៖ ដើម្បីមានសុពលភាព ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើឡើងដោយអ្នកបម្រើម្នាក់របស់ព្រះដែលមានសិទ្ធិអំណាច ។ ដើម្បីឲ្យពិធីបុណ្យជ្រមុជទឹកមានភាពពេញលេញ វាត្រូវអមដោយការទទួលព្រះវិញ្ញាណបរិសុទ្ធ ។ វិធីមួយដែលព្រះបង្ហាញព្រះចេស្តាទ្រង់ គឺតាមរយៈពួកអ្នកបម្រើរបស់ទ្រង់ដែលមានសិទ្ធិអំណាច ។ ដោយការសោរសាភ និងលះបង់ការអនុវត្តអាក្រក់ៗ យើងបង្ហាញសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ។

សេចក្តីផ្តើម

នៅភ្នំអើរីយ៉ូសនៅក្រុងអាថែន ប៉ុលបានបង្រៀនប្រជាជនអំពីនិស្ស័យនៃព្រះ ។ មេរៀននេះអាចជួយសិស្សឲ្យយល់ពីចរិតលក្ខណៈមួយចំនួនរបស់ព្រះវរបិតាសួគ៌ និងទំនាក់ទំនងរបស់ពួកគេជាមួយនឹងទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ១៧:១៦-៣៤

ប៉ុលបង្រៀននៅភ្នំអើរីយ៉ូស

សូមអញ្ជើញសិស្សឲ្យបើកទៅរូបថតអំពីព្រះគម្ពីរប៊ីប ល.រ. ២៩ « អាថែន » នៅក្នុងផែនទី និងរូបថតទាំងឡាយអំពីព្រះគម្ពីរប៊ីប ។ សូមចង្អុលបង្ហាញថា រូបថតនេះបង្ហាញពីព្រះវិហារបរិសុទ្ធមួយក្នុងចំណោមព្រះវិហារបរិសុទ្ធជាច្រើននៅក្រុងអាថែនដែលបានប្រើប្រាប់សម្រាប់ជាការថ្វាយបង្គំរូបព្រះក្លែងក្លាយ ។ នៅខាងក្នុងព្រះវិហារបរិសុទ្ធនោះ គឺមានរូបសំណាកព្រះដែលបង្កើតដោយមនុស្ស ។ នៅខាងក្រៅគឺមានអាសនាសម្រាប់ធ្វើការថ្វាយបូជាថ្វាយដល់ព្រះក្លែងក្លាយទាំងនេះ ។

សូមពន្យល់ថា ដើម្បីការពារប៉ុលពីក្រុមកាចសាហាវមួយក្រុមរបស់ពួកសាសន៍យូដានៅក្រុងថែស្សាឡូនីច សមាជិកសាសនាចក្របានបញ្ជូនលោកទៅក្រុងអាថែន (សូមមើល កិច្ចការ ១៧:១៣–១៥) ។ នៅក្នុង កិច្ចការ ១៧:១៦–២១ យើងអានថា ប៉ុលមានកង្វល់យ៉ាងខ្លាំងអំពីអបិយជំនឿនៅក្រុងអាថែន ហើយលោកបានបង្រៀននៅក្នុងសាលាប្រជុំ និងតាមផ្សារនៅទីនោះ ។ បន្ទាប់មក ពួកទស្សនវិទូបានអញ្ជើញប៉ុលឲ្យពន្យល់ពី « គោលលទ្ធិថ្មី » របស់លោក (កិច្ចការ ១៧:១៩) ទៅដល់ក្រុមប្រឹក្សាប្បាប់ដែលបានជួបនៅលើភ្នំអើរីយ៉ូស ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ១៧:២២-២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថាប៉ុលបានសង្កេតឃើញអ្វីខ្លះនៅលើអាសនាមួយនៅក្រុងអាថែន ។

- តើប៉ុលបានឃើញអ្វីខ្លះនៅលើអាសនាមួយនៅក្រុងអាថែន ?

សូមពន្យល់ថា កិច្ចការ ១៧:២២ កត់ត្រាថា ប៉ុលបានសរសើរដល់ពួកអាថែនដោយពោលថា ពួកគេ « ឧស្សាហ៍ខ្នះខ្នែង » មានន័យថា ពួកគេ « កាន់សាសនា » ឬ « ខ្ចល់ខ្ចាយពីរឿងរបស់ព្រះ » ។ អាសនាសម្រាប់ « ព្រះដ៏ពុំស្គាល់ » (កិច្ចការ ១៧:២៣) គឺជាការប៉ុនប៉ងរបស់ពួកអាថែនដើម្បីឲ្យព្រះដែលគេពុំស្គាល់ ឬព្រះផ្សេងណាមួយដែលមិនស្គាល់ឈ្មោះបានសព្វចិត្ត ។ ពួកគេទំនងជាមិនចង់ឲ្យមានការព្រងើយកន្តើយ ឬការវាតចិត្តចំពោះនឹងព្រះណាមួយឡើយ ។

សូមចង្អុលបង្ហាញពី ប្រយោគចុងក្រោយក្នុង កិច្ចការ ១៧:២៣ រួចសួរ ៖

- ហេតុអ្វីប៉ុលបានធ្វើសេចក្តីយោងពីអាសនានេះទៅនឹង « ព្រះដ៏ពុំស្គាល់ »នោះ ? (លោកបានប្រើវាដើម្បីឧទ្ទេសនាមនូវគំនិតពីព្រះដ៏ពិត ជាព្រះវរបិតាសួគ៌ ជាព្រះដែលពួកគេពុំស្គាល់) ។

សូមបំបែកសិស្សជាគូ ឬ ជាក្រុមតូចៗ ។ សូមអញ្ជើញក្រុមនីមួយៗឲ្យស្វែងរកនូវសេចក្តីពិតឲ្យបានច្រើនតាមដែលពួកគេអាចរកឃើញក្នុង កិច្ចការ ១៧:២៤–៣១ អំពីព្រះដែលប្រជាជនអាថែនមិនបានស្គាល់នោះ ។ កាលពួកគេកំពុងសិក្សា សូមសរសេរលេខខគម្ពីរនីមួយៗ (២៤-៣១) នៅលើក្តារខៀន ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ឡើងមកក្តារខៀន សរសេរពីសេចក្តីពិតមួយ ដែលពួកគេបានរកឃើញ នៅក្បែរលេខនៃខគម្ពីរដែលពួកគេបានរកឃើញវា ។ (ដើម្បីជួយសិស្សឲ្យស្គាល់ពីសេចក្តីពិតមួយនៅក្នុង កិច្ចការ ១៧:២៧សូមពន្យល់ថាការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ខគម្ពីរនេះបានចែងថា « ពួកគេត្រូវស្វែងរកព្រះអម្ចាស់ ប្រសិនបើពួកគេមានឆន្ទៈរកទ្រង់ ដ្បិតទ្រង់គង់នៅមិនឆ្ងាយពីយើងរាល់គ្នាឡើយ ។

អ្នកក៏គួរណែនាំឲ្យសិស្សគូសចំណាំសេចក្តីពិតនីមួយៗនៅក្នុងព្រះគម្ពីររបស់ពួកគេផងដែរ ។ សេចក្តីពិតមួយចំនួនដែលពួកគេបានសរសេរនៅលើក្តារខៀន អាចរួមមានដូចខាងក្រោមនេះ ៖

ខទី ២៤៖ ព្រះបានបង្កើតពិភពលោក ។

ខទី ២៥ ៖ ព្រះបានប្រទានជីវិតដល់វត្ថុសព្វសារពើ ។

ខទី ២៦ ៖ ព្រះគ្រប់គ្រងលើជីវិតទាំងអស់ ។

ខទី ២៧៖ប្រសិនបើយើងមានឆន្ទៈស្វែងរកព្រះ យើងនឹងឃើញថា ទ្រង់គង់នៅមិនឆ្ងាយពីយើងឡើយ ។

ខទី ២៨ ៖យើងគឺជាកូនចៅរបស់ព្រះ ។

ខទី ២៩ ៖ យើងត្រូវបានបង្កើតឡើងតាមរូបរបស់ព្រះ ។

ខទី ៣០៖ ព្រះបង្គាប់មនុស្សគ្រប់គ្នាឲ្យប្រែចិត្ត ។

ខទី ៣១៖ព្រះនឹងកាត់សេចក្តីយើង, ព្រះនឹងប្រោសមនុស្សទាំងអស់ឲ្យរស់ពីស្លាប់ ។

សូមអញ្ជើញសិស្សឲ្យជ្រើសយកសេចក្តីពិតមួយនៅលើក្តារខៀន ដែលវាមានន័យចំពោះពួកគេ ។ ចូរសុំឲ្យសិស្សពីរបីនាក់ចែកចាយពីសេចក្តីពិតដែលពួកគេបានជ្រើស ហើយហេតុអ្វីបានជាវាមានន័យចំពោះពួកគេ ។

សូមចង្អុលបង្ហាញសេចក្តីពិតនៅក្នុង កិច្ចការ ១៧:២៨« យើងគឺជាកូនចៅរបស់ព្រះ: » ។

- តើពាក្យថាជា « កូនចៅ » របស់ព្រះមានន័យដូចម្តេច ? (យើងគឺជាកូនខាងចៅញ្ញាណរបស់ព្រះវរបិតាសួគ៌) ។
- ហេតុអ្វីវាជារឿងដ៏សំខាន់ ដែលត្រូវយល់ដឹងពីសេចក្តីពិតនេះ: ? (វាអាចជួយយើងឲ្យស្គាល់ពីតម្លៃគ្មានដែនកំណត់របស់យើងចំពោះព្រះវរបិតាសួគ៌ និងសក្តានុពលរបស់យើងដើម្បីប្រែក្លាយដូចជាទ្រង់ដែរ) ។
- តើបញ្ហា ឬការភាន់ច្រឡំអ្វីខ្លះ: ដែលអាចកើតឡើងតាមរយៈការមិនយល់ពីគោលលទ្ធិនេះ: ?

ប្រសិនបើអាចធ្វើទៅបាន សូមចែកឲ្យសិស្សនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជាល្លិន អេក អ៊ុក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សម្នាក់អានវាឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់ ឬរកមើលថា ហេតុអ្វីយើងត្រូវចងចាំដើម្បីឃើញខ្លួនឯងថាជាកូនចៅនៃព្រះជំបូងគេបង្អស់ ។

« ចូរប្រុងប្រយ័ត្នពីរបៀបដែលអ្នកសម្គាល់ចរិតខ្លួនឯង ។ ចូរកុំសម្គាល់ចរិត ឬកំណត់ខ្លួនឯងដោយគុណសម្បត្តិបណ្តោះអាសន្នមួយចំនួនឡើយ ។ គុណសម្បត្តិតែមួយគត់ដែលចង្អុលបង្ហាញចរិតយើងគឺថា យើងគឺជាបុត្រាបុត្រីនៃព្រះ ។ ការពិតនោះមានគុណសម្បត្តិលើសពីបុគ្គលិកលក្ខណៈផ្សេងទៀតទាំងអស់ រួមទាំងជាតិសាសន៍ ការងារ បុគ្គលិកលក្ខណៈ កិត្តិយស ឬសូម្បីតែសាសនា » (« How to Define Yourself » *New Era* ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤៨) ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីចងចាំមុនបំផុងគេបង្អស់ថា យើងគឺជាកូនចៅនៃព្រះ ?

សូមយោងទៅសេចក្តីពិតនៅក្នុង កិច្ចការ ១៧:២៧« ប្រសិនបើយើងមានឆន្ទៈស្វែងរកព្រះ យើងនឹងឃើញថា ទ្រង់គង់នៅមិនឆ្ងាយពីយើងឡើយ » ។

- តើយើងអាចខិតខំស្គាល់ ហើយខិតមកជិតព្រះតាមរបៀបណា ?
- តើការយល់ដឹងអំពីទំនាក់ទំនងរបស់យើងជាមួយនឹងព្រះ: ជះឥទ្ធិពលដល់បំណងប្រាថ្នាយើងដើម្បីស្វែងរកទ្រង់យ៉ាងដូចម្តេច ?
- តើអ្នកមានអារម្មណ៍ថា ឆ្ងាប់នៅជិតនឹងព្រះវរបិតាសួគ៌នៅពេលណា ?

សូមសង្ខេប កិច្ចការ ១៧:៣២–៣៤ ដោយពន្យល់ថា ពួកអាថែនបានមានប្រតិកម្មនឹងការលើកឡើងរបស់ប៉ុលអំពី « មនុស្សស្លាប់រស់ឡើងវិញ » (កិច្ចការ ១៧:៣២) ។ មានពួកគេមួយចំនួនបានចំអកឲ្យប៉ុល រីឯអ្នកផ្សេងទៀតចង់ស្តាប់ថែមទៀត ហើយមានមនុស្សខ្លះបានជឿ ។

អ្នកគួរថ្លែងទីបន្ទាល់ថា សិស្សអាចស្គាល់ ហើយយល់ពីព្រះ: ទោះជាមនុស្សជាច្រើនមិនបានស្គាល់ទ្រង់ក្តី ។ សូមអញ្ជើញសិស្សឲ្យសរសេរឃ្លា *ព្រះដែលអាចស្គាល់* នៅលើក្រដាសមួយសន្លឹក ឬប័ណ្ណមួយ ហើយសរសេរពីវិធីដែលពួកគេនឹងខិតខំ ហើយអភិវឌ្ឍទំនាក់ទំនងមួយជាមួយនឹងព្រះ: ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់ក្រដាសនេះនៅត្រង់កន្លែង ដែលវាអាចជួយរំឭកពួកគេពីគោលដៅទាំងនោះ: ។

មេរៀនបន្ទាប់ (កិច្ចការ ២០-រ៉ូម ៧)

សូមពន្យល់សិស្សថា នៅមេរៀនបន្ទាប់ ពួកគេនឹងរកបានចម្លើយចំពោះសំណួរថា « តើប៉ុលបានប្រោសនរណាឲ្យរស់ពីស្លាប់ ? » និង « តើកាល:ទេសៈអ្វីខ្លះដែលនៅហ៊ឹមព័ទ្ធសេចក្តីស្លាប់របស់បុគ្គលម្នាក់នេះ: ? » សូមអញ្ជើញពួកគេឲ្យស្រមៃថា ពួកគេត្រូវបានគេចាប់ខ្លួនប្រឡំ ហើយកប៉ាល់ក៏លិចទៅទើរនៅលើកោះមួយ រួចក៏ត្រូវពស់ចឹក ។ ចូរសួរថា តើពួកគេអាចរៀនអ្វីខ្លះពីការសាកល្បងបែបនេះ: ។ ចូរសុំឲ្យសិស្សរកមើលស្តេចមួយអង្គ ដែលមានបន្ទូលទៅប៉ុលនៅក្នុងការសាកល្បងមួយថា « បន្តិចទៀត ឯងនឹងនាំឲ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទានដែរ » (កិច្ចការ ២៦:២៨) ។ នៅពេលពួកគេសិក្សានៅផ្នែកដែលនៅសល់នៃកិច្ចការរបស់ពួកសាវក សូមលើកទឹកចិត្តពួកគេឲ្យរកមើលថា ឧបសគ្គនានាអាចជួយយើងឲ្យខិតទៅជិតព្រះអង្គសង្គ្រោះបានយ៉ាងដូចម្តេច ។ សូមប្រាប់ពួកគេថា ពួកគេក៏នឹងអាននូវផ្នែកមួយនៃសំបុត្រ ដែលសាវកប៉ុលបានសរសេរទៅកាន់សមាជិកសាសនាចក្រនៅទីក្រុងរ៉ូមផងដែរ ។

មេរៀន ៩៦

កិច្ចការ ២០-២២

សេចក្តីផ្តើម

ប៉ុលបានប្រកាសដំណឹងល្អក្នុងតំបន់អាស៊ីតូច (ប្រទេសតួកគីសព្វថ្ងៃ) ហើយកាលលោកនៅឯក្រុងម៉ាលទុស ជាទីក្រុងមួយក្បែរក្រុងអេភេសូរ លោកបានព្រមានពីការក្បត់សាសនានាពេលអនាគត ហើយបានលើកទឹកចិត្តថ្នាក់ដឹកនាំបព្វជិតភាពឲ្យលើកតម្កើងសមាជិកសាសនាចក្រ ។ បន្ទាប់មក លោកបានធ្វើដំណើរទៅក្រុងយេរូសាឡិម ជាកន្លែងដែលលោកទទួលការបៀតបៀន ហើយចាប់ខ្លួន ។ កាលកំពុងឈរនៅលើកាំជណ្តើរនៃបន្ទាយអានតូនា (ជាបន្ទាយរបស់ទ័ពរ៉ូម) ប៉ុលបានចែកចាយដំណើររឿងនៃការប្រែចិត្តជឿរបស់លោក ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ២០:១-២១:៤០

ប៉ុលបានធ្វើការងារបម្រើនៅក្នុងតំបន់អាស៊ីតូច ហើយធ្វើដំណើរទៅក្រុងយេរូសាឡិម ជាទីកន្លែងដែលលោកត្រូវបានគេវាយដុំ ហើយចាប់ខ្លួន

ចូរសុំឲ្យសិស្សគិតពីគ្រាមួយដែលពួកគេត្រូវចាកចេញពីគ្រួសារ មិត្តភក្តិ ឬមនុស្សផ្សេងទៀត ដែលពួកគេយកចិត្តទុកដាក់រយៈពេលបីបួនថ្ងៃ បីបួនសប្តាហ៍ ឬបីបួនខែ ។

- **តើអ្នក ឬមនុស្សដែលអ្នកធ្លាប់នៅជាមួយបានមានអារម្មណ៍បែបណាពីមុនអ្នកចាកចេញទៅ ?**
- **តើអ្នកនិយាយអ្វីខ្លះប្រាប់គ្នាពីមុនចាកចេញទៅនោះ ?**

សូមពន្យល់ថា នៅក្នុងដំណើរផ្សព្វផ្សាយសាសនាជាលើកទីបីរបស់ប៉ុល លោកបានចំណាយពេលនៅម៉ាសេដូនី ក្រិក និងតំបន់អាស៊ីតូច ។ នៅក្នុងដំណើរនេះ លោកបានទទួលការបំផុសគំនិតឲ្យត្រឡប់ទៅក្រុងយេរូសាឡិមវិញ ។ នៅពេលលោកបានធ្វើដំណើរ លោកបានឈប់ដើម្បីប្រកាសដំណឹងល្អ ហើយបានលាសមាជិកសាសនាចក្រនៅតាមផ្លូវ ។ នៅវេលាយប់ពីមុនការចាកចេញរបស់លោកពីភូមិត្រូអាស នៅថ្ងៃឈប់សម្រាកថ្មី (ថ្ងៃអាទិត្យ) ប៉ុល និងពួកសិស្សបានជួបជុំគ្នាទទួលទានសាក្រាម៉ង់ (សូមមើល កិច្ចការ ២០:៧) ។ បន្ទាប់មក ប៉ុលបាននិយាយនឹងពួកបរិសុទ្ធរហូតដល់វេលាយប់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កិច្ចការ ២០:៩-១២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថាមានអ្វីបានកើតឡើងចំពោះយុវជនម្នាក់ដែលមានឈ្មោះ អឺទីកុស បន្ទាប់ពីគាត់បានដេកលង់លក់អំឡុងពេលប៉ុលកំពុងបង្រៀន ។

- **តើមានរឿងអ្វីបានកើតឡើងចំពោះអឺទីកុស ?**
- **តើប៉ុលបានធ្វើដូចម្តេច ដើម្បីបង្ហាញសេចក្តីស្រឡាញ់ និងកង្វល់ចំពោះយុវជនម្នាក់នេះ ?**
- **តើទង្វើរបស់ប៉ុលបានបង្ហាញពីការងារបម្រើរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ?**

សូមពន្យល់ថា ជាផ្នែកមួយនៃដំណើរផ្សព្វផ្សាយសាសនាជាលើកទីបីរបស់ប៉ុល នោះប៉ុលបានចំណាយពេលប្រមាណជាបីឆ្នាំនៅអេភេសូរធ្វើការនៅក្នុងចំណោមប្រជាជននៅទីនោះ ។ សូមសង្ខេប កិច្ចការ ២០:១៣–១៧ ដោយពន្យល់ថា នៅតាមផ្លូវដែលលោកធ្វើដំណើរទៅក្រុងយេរូសាឡិមនោះ ប៉ុលបានឈប់នៅក្រុងមីលេត ហួសអេភេសូរបន្តិច ហើយបានផ្ញើសំបុត្រទៅឲ្យថ្នាក់ដឹកនាំសាសនាចក្រនៅអេភេសូរឲ្យមកជួបនឹងលោក ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២០:១៨-២៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានពន្យល់អ្វីខ្លះអំពីការបម្រើរបស់លោក ។

- **តើប៉ុលបានពិពណ៌នាបែបណាអំពីការបម្រើរបស់លោកជាអ្នកផ្សព្វផ្សាយសាសនា ?**
- **តើសេចក្តីថ្លែងរបស់ប៉ុលដែលថាលោក « មិនបានខាននឹងប្រាប់សេចក្តីអ្វី » (ខទី ២០) ពីរឿងទាំងឡាយដែលលោកបានបង្រៀនអាចនឹងមានន័យយ៉ាងណា ?**
- **យោងតាម ខទី ២៣តើប៉ុលស្ម័គ្រចិត្តប្រឈមនឹងអ្វីខ្លះ ក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ ?**

សូមពន្យល់ថា ប៉ុលងាយនឹងរងនូវគ្រោះថ្នាក់នៅក្រុងយេរូសាឡិម កាលពួកអ្នកដឹកនាំសាសន៍យូដាបានចាត់ទុកលោកជាជនក្បត់ដោយសារការខិតខំរបស់លោកដើម្បីប្រកាសដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

- **យោងតាម ខទី ២២ ហេតុអ្វី ប៉ុលស្ម័គ្រចិត្តទៅកាន់ក្រុងយេរូសាឡិម ?**

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុងកិច្ចការ ២០:២៤-២៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានត្រៀមខ្លួនធ្វើអ្វីខ្លះក្នុងនាមជាអ្នកបម្រើម្នាក់របស់ព្រះអម្ចាស់ ។

- **យោងតាម ខទី ២៤តើប៉ុលបានត្រៀមខ្លួនធ្វើអ្វីខ្លះ ក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ ?**
- **តើប៉ុលបានប្រាប់ថា លោកមានអារម្មណ៍បែបណានៅពេលលោកធ្វើអ្វីដែលព្រះអម្ចាស់បានដឹកនាំនោះ ?**

ចូរសួរសំណួរដែលជួយសិស្សឲ្យយល់មាតិកានៃបទគម្ពីរ

ការសួរសំណួរដែលជួយសិស្សឲ្យវិភាគបទគម្ពីរអាចពង្រីកការយល់ដឹងរបស់សិស្សអំពីព្រះគម្ពីរ ។ សំណួរបែបនេះអាចជួយបញ្ជាក់ពីអត្ថន័យនៃពាក្យ ឬឃ្លានានា ហើយជួយសិស្សឲ្យរកឃើញអត្ថន័យកាន់តែមានខ្លឹមសារ នៅក្នុងព័ត៌មានលម្អិតនៃដំណើររឿងមួយ ។ បន្ទាប់មក សិស្សនឹងត្រៀមខ្លួនប្រាប់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ។

- តើយើងអាចរៀនអ្វីខ្លះមកពីគំរូនៃការបម្រើរបស់ប៉ុល ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចតទៅនេះ: **ៈពួកអ្នកបម្រើដ៏ពិតរបស់ព្រះអម្ចាស់បំពេញភារកិច្ចរបស់ខ្លួនដោយស្មោះត្រង់ ហើយដោយធ្វើបែបនេះ នោះពួកគេមានន្ទរអំណរ**) ។
- តើការបំពេញភារកិច្ចដោយស្មោះត្រង់មានន័យយ៉ាងណាចំពោះអ្នក ?
- តើយើងអាចអនុវត្តសេចក្តីពិតនេះនៅក្នុងជីវិតយើងផ្ទាល់បានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យចែកចាយពីគ្រាមួយដែលពួកគេ ឬមនុស្សម្នាក់ដែលពួកគេស្គាល់បានជ្រើសរើសបម្រើព្រះអម្ចាស់ដោយអស់ពីកម្លាំង និងពលំ ហើយទទួលបានន្ទរអំណរដ៏អស្ចារ្យ ។

សូមរំឭកសិស្សថា ប៉ុលបានទៅលេងពួកថ្នាក់ដឹកនាំសាសនាចក្រនៅអេភេសូរជាលើកចុងក្រោយ ពីមុនលោកចាកចេញទៅក្រុងយេរូសាឡិម ។

- ប្រសិនបើអ្នកជាប៉ុល ពេលដឹងថាអ្នកនឹងពុំបានឃើញថ្នាក់ដឹកនាំសាសនាចក្រនៅអេភេសូរម្តងទៀត តើពាក្យទូន្មានអ្វីខ្លះដែលអ្នកនឹងផ្តល់ទៅពួកគេពីមុនអ្នកចាកចេញទៅ ?

ចូរសុំឲ្យសិស្សអាន កិច្ចការ ២០:២៨–៣១ ដោយស្ងៀមស្ងាត់ ហើយរកមើលការព្រមានរបស់ប៉ុលទៅកាន់ពួកថ្នាក់ដឹកនាំសាសនាចក្រទាំងនេះ ។

- តើប៉ុលបានព្រមានដល់ថ្នាក់ដឹកនាំទាំងនេះអំពីអ្វីខ្លះ ?

សូមពន្យល់ថា ប៉ុលបានប្រើសត្វចចកជាតំណាងឲ្យមនុស្សមិនស្មោះត្រង់ដែលនឹងបោកបញ្ឆោតសមាជិកសាសនាចក្រស្មោះត្រង់ ។

- តើអ្នកនឹងប្រើពាក្យអ្វី ដើម្បីពិពណ៌នាពីស្ថានភាពរបស់ជនដែលងាកចេញពីសេចក្តីពិត ហើយព្យាយាមដឹកនាំមនុស្សដទៃទៀតឲ្យឃ្លាតចេញពីសេចក្តីពិតនោះ ? (ការក្បត់សាសនា ។ សូមពន្យល់ថា ប៉ុលកំពុងព្រមានថ្នាក់ដឹកនាំសាសនាចក្រអំពីការក្បត់សាសនានៅក្នុងសាសនាចក្រនាពេលអនាគត) ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២០:៣៦-៣៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ថ្នាក់ដឹកនាំសាសនាចក្របានឆ្លើយតបបែបណា កាលប៉ុលបានចាកចេញទៅ ។ សូមអញ្ជើញសិស្សឲ្យប្រាប់អំពីអ្វីដែលពួកគេបានរកឃើញ ។

សូមសង្ខេប កិច្ចការ ២១:១–១០ ដោយពន្យល់ថា ប៉ុលបានបន្តដំណើររបស់លោកឆ្ពោះទៅកាន់ក្រុងយេរូសាឡិម ហើយបានឈប់នៅតំបន់ផ្សេងៗដើម្បីចំណាយពេលនៅជាមួយនឹងសមាជិកសាសនាចក្រ ។ នៅពេលប៉ុលបានឈប់នៅទីក្រុងមួយដែលមានឈ្មោះថា ទីរ៉ុស នោះមានពួកសិស្សមួយចំនួន—ព្រួយបារម្ភពីសុវត្ថិភាពរបស់ប៉ុល—បានប្រាប់ប៉ុលកុំឲ្យទៅក្រុងយេរូសាឡិម (សូមមើល កិច្ចការ ២១:៤) ។

នៅឯសេសារា មានព្យាការីម្នាក់ឈ្មោះ អ័ក្កាបុស បានព្យាករទាក់ទងនឹងរឿងដែលនឹងកើតឡើងចំពោះប៉ុលនៅក្រុងយេរូសាឡិម ។ សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២១:១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលថា អ័ក្កាបុស បានព្យាករពីអ្វីខ្លះ ។ (អ្នកគួរពន្យល់ថាពាក្យ*ខ្សែក្រវាត់* សំដៅទៅលើខ្សែក្រវាត់ចង្កេះ) ។ សមអញ្ជញសសសឲយរបរបពអរដលពកគរកឃញ

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២១:១២-១៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុល និងពួកដៃគូរបស់លោកបានឆ្លើយតបបែបណាចំពោះការព្យាករនេះ ។

- តើប៉ុល និងពួកដៃគូរបស់លោកបានឆ្លើយតបបែបណាចំពោះការព្យាករនេះ ?
- តើប៉ុលមានប្រតិកម្មបែបណាចំពោះការព្យាករនេះ ? តើអ្នកចាប់អារម្មណ៍អ្វីខ្លះចំពោះការឆ្លើយតបរបស់ប៉ុល ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីគំរូរបស់ប៉ុលក្នុងការធ្វើជាអ្នកបម្រើដ៏ពិតរបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ: **ៈពួកអ្នកបម្រើដ៏ពិតរបស់ព្រះអម្ចាស់យល់ព្រមធ្វើតាមព្រះទ័យរបស់ព្រះ មិនថាត្រូវលះបង់អ្វីឡើយ**) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីប្រភេទនៃការលះបង់ ដែលយើងអាចនឹងត្រូវសុំឲ្យធ្វើ ក្នុងនាមជាពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ។

- តើអ្នកធ្លាប់យល់ព្រមធ្វើតាមព្រះទ័យរបស់ព្រះមិនថាអ្នកត្រូវលះបង់អ្វីក៏ដោយនៅពេលណា ? ហេតុអ្វីអ្នកយល់ព្រមធ្វើរឿងនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីសង្ខេបនៃកិច្ចការ ២១:១៧–៤០ដូចខាងក្រោម ។

ប៉ុលបានមកដល់ក្រុងយេរូសាឡិម ហើយបានរាយការណ៍ពីការងារផ្សព្វផ្សាយសាសនារបស់លោកទៅថ្នាក់ដឹកនាំសាសនាចក្រក្នុងមូលដ្ឋាន ។ ប៉ុលបានទៅព្រះវិហារបរិសុទ្ធ ហើយកាលពួកសាសន៍យូដាមួយក្រុមដែលស្គាល់ប៉ុលពេលធ្វើដំណើរផ្សព្វផ្សាយសាសនាបានឃើញលោក នោះពួកគេបានប្រកាសថា ប៉ុលគឺជាគ្រូបង្រៀនក្លែងក្លាយ ដែលបានបង្រៀនទាស់នឹងក្រឹត្យវិន័យរបស់ម៉ូសេ ហើយបាននាំពួកសាសន៍ដទៃឲ្យចូលទៅក្នុងព្រះវិហារបរិសុទ្ធដោយខុសច្បាប់ ។ ដោយសារការចោទប្រកាន់នេះ នោះមានមនុស្សកំណាចមួយក្រុមបានបណ្តេញប៉ុលចេញពីព្រះវិហារបរិសុទ្ធ ហើយបានចាប់ផ្តើមវាយដំលោក ។ ពួកទាហានរ៉ូមបានមកធ្វើអន្តរាគមន៍ ហើយបានចាប់លោកទៅកាត់ទោស ។ កាលនៅលើកាំជណ្តើរនៃបន្ទាយ អានតូនា (សូមមើល ផែនទីទាំងឡាយដែលទាក់ទងទៅនឹងព្រះគម្ពីរ ប៊ីប ផែនទី ទី ១២ « ក្រុងយេរូសាឡិមនៅសម័យព្រះយេស៊ូវ ») ប៉ុលបានសួរទៅពួកទាហាន ប្រសិនបើលោកអាចនិយាយទៅកាន់ប្រជាជនបានទេ ។

កិច្ចការ ២២:១-៣០

ប៉ុលប្រាប់ពីការប្រែចិត្តជឿរបស់លោក ហើយថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ

សូមសរសេរពាក្យ *ប្រែចិត្តជឿ* នៅលើក្តារខៀន ហើយពន្យល់ថា *ប្រែចិត្តជឿ* មានន័យថា ផ្លាស់ប្តូរ ។ ចូរសួរសិស្សថា ទឹកអាចប្រែ ឬផ្លាស់ប្តូរដើម្បីឲ្យវាអាចប្រើសម្រាប់គោលបំណងផ្សេងទៀតបានដោយរបៀបណា ។ (ឧទាហរណ៍ ទឹកអាចធ្វើឲ្យទៅជាទឹកកក) ។ ចូរសុំឲ្យសិស្សសញ្ជឹងគិតពីប្រភេទនៃការផ្លាស់ប្តូរដែលការប្រែចិត្តជឿចំពោះដំណឹងល្អតម្រូវឲ្យមាន ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២២:១-៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលថា តើប៉ុលបានពិពណ៌នាពីខ្លួនលោកដូចម្តេចខ្លះ កាលលោកថ្លែងទៅពួកយូដាពីលើកាំជណ្តើរបន្ទាយអានតូនានៅក្រុងយេរូសាឡិមនោះ ។

- តើប៉ុលមានលក្ខណៈបែបណា ពីមុនលោកបានប្រែចិត្តជឿ ហើយប្រែក្លាយជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ?

សូមចម្លងសំណួរ និងសេចក្តីយោងព្រះគម្ពីរខាងក្រោមដាក់លើក្តារខៀន ឬ រៀបចំវាជាក្រដាសចែកឲ្យសិស្ស ។ សូមបែងចែកសិស្សទៅជាប្រាំក្រុម ហើយចាត់សំណួរមួយដល់ក្រុមនីមួយៗ ។ ចូរសុំឲ្យសិស្សអានខគម្ពីរដែលទាក់ទងនឹងសំណួរ ដែលពួកគេបានចាត់ឲ្យដោយស្ងៀមស្ងាត់ ហើយបន្ទាប់មកឆ្លើយសំណួរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

១. តើប៉ុលបានពិពណ៌នាបែបណាពីការនិមិត្តដំបូងរបស់លោក ? (កិច្ចការ ២២:៦-៩)

២. តើប៉ុលបានណែនាំឲ្យធ្វើអ្វីខ្លះ ? (កិច្ចការ ២២:១០-១១)

៣. តើប៉ុលបានជួយនរណានៅស្រុកដាម៉ាស ហើយប៉ុលបានទទួលអ្វីម្តងទៀត ? (កិច្ចការ ២២:១២-១៣)


៤. តើអាន៉ានាសបានព្យាករអ្វីខ្លះអំពីប៉ុល ? (កិច្ចការ ២២:១៤-១៥)

៥. តើប៉ុលបានបង្ហាញពីសេចក្តីជំនឿរបស់លោកលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ? (កិច្ចការ ៩:១៨, ២២:១៦)

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ពីចម្លើយរបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យសង្ខេបពីអ្វី ដែលពួកគេបានរៀនពីដំណើរការនៃការប្រែចិត្តជឿរបស់ប៉ុល ។ (អ្នកក៏គួរតែពន្យល់ផងដែរថា នៅចន្លោះគ្រានៃការនិមិត្តដំបូងរបស់ប៉ុល និងគ្រាដែលលោកបានបម្រើជាអ្នកផ្សព្វផ្សាយសាសនា លោកបានចំណាយពេលបីឆ្នាំនៅស្រុកអារ៉ាប់ ដែលទំនងជាយៈពេលមួយនៃការរៀបចំខ្លួន និងការរីកចម្រើនខាងវិញ្ញាណ [សូមមើល កាឡាទី ១:១១–១៨]) ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកគិតថា ប៉ុលបានផ្លាស់ប្តូរបែបណាដែរ ជាលទ្ធផលនៃការប្រែចិត្តជឿរបស់លោកនោះ ?
- តើមានអ្វីបានកើតឡើង ដែលបណ្តាលឲ្យកើតមានការផ្លាស់ប្តូរទាំងនេះ ?
- ការប្រែចិត្តជឿរបស់ប៉ុលអាចបង្រៀនយើងអ្វីខ្លះ អំពីរបៀបដែលយើងអាចប្រែចិត្តជឿនោះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតខាងក្រោមនេះ ៖ **នៅពេលយើងគោរពតាមព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចកាន់តែប្រែចិត្តជឿបានពេញលេញ**) ។
- តើគោលការណ៍នេះអាចជួយមនុស្សម្នាក់ ដែលចង់ប្រែចិត្តជឿយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះមកពីសិស្ទើរ ប៊ូនី អិល អូស្ការសុន ប្រធានយុវនារីទូទៅ ដែលគាត់បានពន្យល់ពីភាពខុសប្លែកគ្នារវាងការមានទីបន្ទាល់នៃដំណឹងល្អ និងការប្រែចិត្តជឿដ៏ពិតចំពោះដំណឹងល្អ ៖



« ការប្រែចិត្តជឿពិត មានន័យច្រើនជាងការមានចំណេះដឹងពីគោលការណ៍ដំណឹងល្អ ហើយមានន័យច្រើនជាងការគ្រាន់តែមានទីបន្ទាល់អំពីគោលការណ៍ទាំងនោះទៅទៀត ។ វាអាចធ្វើទៅបានដើម្បីមានទីបន្ទាល់អំពីដំណឹងល្អដោយពុំរស់នៅតាមវានោះ ។ ការប្រែចិត្តជឿពិតមានន័យថា យើងធ្វើតាមអ្វីដែលយើងជឿ ។ . . .

« . . . ការផ្លាស់ប្រែចិត្តជឿ កើតមានពេលយើងធ្វើសកម្មភាពតាមគោលការណ៍សុចរិត ដែលយើងបានរៀនក្នុងផ្ទះ និងរៀននៅក្នុងថ្នាក់រៀនរបស់យើង ។ ការប្រែចិត្តជឿកើតមាន នៅពេលយើងរស់នៅតាមដំណឹងល្អ រីករាយនឹងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ » (« Be Ye Converted » *Ensign* ឬ *Liahona* ខែវិ ច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ៧៦, ៧៨) ។

សូមអានសំណួរខាងក្រោមនេះឲ្យឮៗ ឬសរសេរវានៅលើក្តារខៀន ៖ *តើខ្ញុំអាចប្រែចិត្តជឿដ៏ពិតចំពោះដំណឹងល្អយ៉ាងដូចម្តេច ?* សូមអញ្ជើញសិស្សឲ្យកត់ត្រាចម្លើយរបស់ពួកគេចូលក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមសង្ខេប កិច្ចការ ២២:១៧–៣០ ដោយពន្យល់ថា ប៉ុលបានប្រាប់ពួកអ្នកស្តាប់របស់លោកថា បន្ទាប់ពីការប្រែចិត្តជឿរបស់លោក ព្រះអម្ចាស់បានបញ្ជូនលោកចេញពីក្រុងយេរូសាឡិមឲ្យទៅធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នៅក្នុងចំណោមពួកសាសន៍ដទៃ ។ បន្ទាប់មកពួកអ្នកស្តាប់ទាំងនោះបានប្រកាសថា ប៉ុលគួរត្រូវយកទៅសម្លាប់ចោល ។ ប៉ុលត្រូវបាននាំទៅជួបនឹងមេទ័ពធំរបស់កងទ័ពរ៉ូមនៅយេរូសាឡិម ជាអ្នកដែលបានសម្រេចចិត្តថា ប៉ុលគួរត្រូវយកទៅធ្វើទុក្ខទោស ឬវាយនឹងរំពាត់ ជាការដាក់ទោសមួយដែលជាធម្មតាប្រើដើម្បីបំបាក់មុខ និងសួរចម្លើយឧក្រិដ្ឋជន ។ ប៉ុន្តែ នៅពេលពួកមន្ត្រីរ៉ូមបានដឹងថា ប៉ុលគឺជាពលរដ្ឋរ៉ូមម្នាក់ នោះពួកគេបានសម្រេចចិត្តមិនវាយដំលោកទេ ដោយសារអំពើនេះផ្ទុយនឹងច្បាប់របស់រ៉ូមនៅក្នុងចាប់ចង ឬវាយដំពលរដ្ឋរ៉ូមម្នាក់ដែលមិនទាន់បាន « កាត់ទោស » (ខទី ២៥) ។ ផ្ទុយទៅវិញ ពួកគេបាននាំលោកទៅកាន់ក្រុមប្រឹក្សាគ្រប់គ្រងរបស់សាសន៍យូដា ពួកសានហេឌ្រីន ។

សូមបញ្ចប់ដោយចែកចាយទីបន្ទាល់របស់អ្នក អំពីគោលការណ៍នានាដែលបានបង្រៀននៅក្នុងកិច្ចការ ២០–២២ ។

កិច្ចការ ២៣-២៦

សេចក្តីផ្តើម

ពួកអ្នកដឹកនាំសាសន៍យូដាបានចោទសួរទៅប៉ុល ហើយពួកសាសន៍យូដាមួយក្រុមបានរួមគំនិតគ្នាចង់សម្លាប់លោក ។ ប៉ុលត្រូវគេនាំខ្លួនទៅជួបស្តេចសេសារ ហើយលោកទទួលបានការការពារខ្លួនទាស់នឹងការចោទប្រកាន់ខុសឆ្គងនានានៅចំពោះមុខពួកអ្នកដឹកនាំរ៉ូមមួយចំនួន ។ លោកបានតំណាលអំពីការប្រែចិត្តជឿរបស់លោក ហើយបានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ២៣-២៥

ប៉ុលត្រូវបានគេបៀតបៀន, កាត់សេចក្តី ហើយត្រូវគេចាប់ជាក់គុក

ពីមុនថ្នាក់ចាប់ផ្តើម សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្រដាសមួយសន្លឹក ៖*បទបញ្ញត្តិ និងពរជ័យរបស់ព្រះ:* ។ សូមប្រើបង់ស្អិត ឬខ្សែដើម្បីកំណត់តំបន់មួយក្នុងថ្នាក់រៀន ហើយដាក់ក្រដាសនោះនៅលើកម្រាលឥដ្ឋត្រង់តំបន់កំណត់ទុកនេះ: ។ នៅពេលថ្នាក់ចាប់ផ្តើម សូមអញ្ជើញសិស្សម្នាក់ឲ្យឈរនៅក្នុងតំបន់នោះ: ដែលជាតំណាងឲ្យបទបញ្ញត្តិ និងពរជ័យរបស់ព្រះ: ។

- នៅពេលយើងខិតទៅជិតព្រះដោយធ្វើតាមបទបញ្ញត្តិ និងការបង្រៀនទាំងឡាយរបស់ទ្រង់ តើពរជ័យមួយចំនួន ដែលយើងអាចទទួលមានអ្វីខ្លះ: ?

សូមអញ្ជើញសិស្សឲ្យដើរនៅខាងក្រៅតំបន់ ដែលតំណាងឲ្យបទបញ្ញត្តិ និងពរជ័យរបស់ព្រះ: ។

- តើឥទ្ធិពលមួយចំនួនអ្វីខ្លះ: នៅក្នុងពិភពលោកនេះ: ដែលអាចអូសទាញមនុស្សម្នាក់ឲ្យងាកចេញ ហើយឈប់រស់នៅស្របតាមបទបញ្ញត្តិ និងការបង្រៀនរបស់ព្រះនោះ: ?
- តើមានអ្វីខ្លះអាចកើតឡើង នៅពេលមនុស្សដកខ្លួនចេញពីព្រះ: ?

សូមអរគុណដល់សិស្ស ហើយអញ្ជើញពួកគេទៅកន្លែងអង្គុយវិញ ។ សូមឲ្យសិស្សពិចារណាថា តើពួកគេកំពុងតែដើរទៅទិសដៅមួយណាឥឡូវនេះ: ហើយតើពួកគេមានអារម្មណ៍ថា ពួកគេនៅជិត ឬឆ្ងាយពីព្រះវរបិតាសួគ៌ប៉ុណ្ណាដែរ ។ នៅពេលសិស្សសិក្សា កិច្ចការ ២៣–២៦ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលនឹងជួយពួកគេ នៅពេលពួកគេបានឃ្លាតឆ្ងាយពីព្រះ: និងពរជ័យទាំងឡាយរបស់ទ្រង់ ។

សូមរំឭកសិស្សថា ប៉ុលត្រូវបានគេចាប់ខ្លួននៅខាងក្រៅព្រះវិហារបរិសុទ្ធនៅក្រុងយេរូសាឡិម ហើយបាននាំទៅជួបនឹងពួកអ្នកដឹកនាំសាសន៍យូដា (សូមមើល កិច្ចការ ២១:៣០–៣៣, ២២:២៣–៣០) ។ សូមសង្ខេប កិច្ចការ ២៣:១–១០ ដោយពន្យល់ថា ប៉ុលត្រូវពួកអ្នកដឹកនាំសាសន៍យូដាទាំងនេះចោទសួរ ហើយចាប់ដាក់គុក ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៣:១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើមានអ្វីបានកើតឡើងកាលប៉ុលនៅក្នុងគុក ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះអម្ចាស់បានប្រាប់អ្វីខ្លះដល់ប៉ុលនៅក្នុងគុក ?

សូមរំឭកសិស្សអំពីការសន្យាដែលបានកត់ត្រានៅក្នុង កិច្ចការ ១៨:៩–១០ ថាព្រះអម្ចាស់បានគង់នៅជាមួយប៉ុល ហើយការពារលោក កាលលោកបានធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សឲ្យពិចារណាធ្វើការគូសចំណាំឃ្លា « ព្រះអម្ចាស់បានគង់នៅជាមួយនឹងលោក » ហើយសរសេរ កិច្ចការ ១៨:៩–១០ ជាសេចក្តីយោងបទគម្ពីរនៅរឹមទំព័រក្បែរនឹង ខទី ១១ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីសង្ខេបខាងក្រោមឲ្យឮៗ ៖

នៅក្នុង កិច្ចការ ២៣:១២–២៥:២៧ យើងរៀនថា មេទ័ព្យមបានចាប់ខ្លួនប៉ុលបញ្ជូនទៅស្តេចសេសារ ដើម្បីការពារកុំឲ្យពួកសាសន៍យូដាមួយក្រុមមកសម្លាប់លោក ។ ប៉ុលបានប្រកាសអំពីភាពគ្មានទោសរបស់លោកនៅមុខចៅហ្វាយខេត្តម្នាក់ឈ្មោះ ភេលីច ។ ទោះបីដាដឹងថា ប៉ុលគ្មានទោសក្តី ក៏ភេលីចបានបន្តដាក់ប៉ុលឲ្យជាប់ឃុំនៅក្នុងផ្ទះរយៈពេលពីរឆ្នាំដែរ ។ ភេស្ទុសបានទទួលតំណែងជំនួសភេលីចជាចៅហ្វាយខេត្តម្នាក់នៅស្រុកយូដា ។ ស្តេចហេរ៉ូឌអ័គ្រីប៉ាដែលបានគ្រប់គ្រងក្នុងតំបន់មួយនៅទិសឦសានៃសមុទ្រកាលីឡេបានយាងមកជួបនឹងភេស្ទុស មានបំណងចង់ស្តាប់អំពីករណីរឿងក្តីរបស់ប៉ុល ។ ប៉ុលត្រូវគេនាំខ្លួនទៅជួបនឹងស្តេចហេរ៉ូឌអ័គ្រីប៉ា ។

កិច្ចការ ២៦

ប៉ុលតំណាលប្រាប់អំពីការប្រែចិត្តជឿរបស់លោក ហើយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទនៅមុខស្តេចហេរ៉ូឌអ័គ្រីប៉ា

សូមឲ្យសិស្សពីរបីនាក់ប្តូរវេណគ្នាអានឮៗនៅក្នុង កិច្ចការ ២៦:៤-១១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើប៉ុលបានពិពណ៌នាអំពីអតីតកាលរបស់លោកដល់ស្តេចអ័គ្រីប៉ាយ៉ាងដូចម្តេចដែរ ។

- តើប៉ុលបានពិពណ៌នារឿងរ៉ាវអតីតកាលរបស់លោកដល់ស្តេចអ័គ្រីប៉ាយ៉ាងដូចម្តេចដែរ ?

សូមពន្យល់ថា ក្រោយមកប៉ុលបានរៀបរាប់ប្រាប់អំពីការនិមិត្តរបស់លោកអំពីព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៦:១៦-១៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលបេសកកម្ម ដែលព្រះអម្ចាស់បានប្រទានដល់ប៉ុលនៅលើផ្លូវទៅស្រុកដាម៉ាស ។

- តើបេសកកម្មអ្វីដែលព្រះអម្ចាស់បានប្រទានដល់ប៉ុល ? (អ្នកគួរណែនាំសិស្សឲ្យគូសចំណាំឃ្លា ដែលពិពណ៌នាអំពីបេសកកម្ម ដែលព្រះអម្ចាស់បានប្រទានដល់ប៉ុល) ។

សូមពន្យល់ថា នៅក្នុងបរិបទនេះពាក្យថា *ទទួលមរតក* (ខទី ១៨) សំដៅទៅលើការចូលទៅក្នុងនគរសេឡេស្ទាលនៃព្រះ ។

- តើអ្វីខ្លះដែលអាចជួយនរណាម្នាក់ងាកចេញពីសេចក្តីងងឹត និងឥទ្ធិពលនៃសាតាំង ហើយបែរឆ្ពោះទៅរកពន្លឺ និងបទបញ្ញត្តិ និងពរជ័យនៃព្រះវិញនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៦:១៩-២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប៉ុលបាននិយាយអ្វីខ្លះដែលលោកបានបង្រៀនដល់ទាំងពួកសាសន៍យូដា និងពួកសាសន៍ដទៃត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានពរជ័យដែលបានលើកឡើងនៅក្នុង ខទី ១៨ ។ អ្នកអាចពន្យល់ថា ឃ្លា « ទាំងប្រព្រឹត្តបែបសំណំនឹងការប្រែចិត្តផង » នៅក្នុង ខទី ២០ អាចមានន័យថា រស់នៅដោយសុចរិតដើម្បីបង្ហាញថា អ្នកបានប្រែចិត្តពិតមែន ។

ស្ថរសំណួរដែលជួយសិស្ស ឲ្យរកឃើញគោលលទ្ធិ និង គោលការណ៍នានា

នៅពេលសិស្សអភិវឌ្ឍការយល់ដឹងរបស់ពួកគេអំពីបរិបទ និង អត្ថន័យនៃបទគម្ពីរ នោះពួកគេអាចស្គាល់គោលការណ៍ និងគោលលទ្ធិទាំងឡាយកាន់តែល្អប្រសើរ ។ សំណួរវិភាគអាចជួយសិស្សឲ្យធ្វើការសន្និដ្ឋាន ហើយលើកឡើងអំពីគោលការណ៍ ឬគោលលទ្ធិដែលមាននៅក្នុងអត្ថបទ ដែលពួកគេកំពុងសិក្សាយល់កាន់តែច្បាស់ ។

- យោងតាម ខទី ២០តើប៉ុលបានបង្រៀនដល់ពួកសាសន៍យូដា និងពួកសាសន៍ដទៃឲ្យធ្វើអ្វីខ្លះ ?

ចូរសរសេរសេចក្តីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោម នៅលើក្តារខៀន៖ *បើយើងប្រែចិត្ត ហើយងាកទៅរកព្រះ*. . .

- ផ្អែកលើអ្វីដែលយើងរៀននៅក្នុងខទី ១៨ តើអ្នកនឹងបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀនយ៉ាងដូចម្តេច ? (សូមសង្កេបចម្លើយរបស់សិស្សដោយបំពេញប្រយោគនៅលើក្តារខៀន ដែលមានន័យដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងប្រែចិត្ត ហើយងាកទៅរកព្រះ នោះយើងអាចយកឈ្នះលើអំណាចរបស់សាតាំងនៅក្នុងជីវិតរបស់យើង ទទួលការអត់ទោសពីអំពើបាបយើង ហើយសក្តិសមចូលក្នុងនគរសេឡេស្ទាល**) ។

ដើម្បីជួយសិស្សឲ្យយល់អំពីគោលការណ៍នេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ នែលអិល អាន់ឌើរសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ (សូមពិចារណាផ្តល់សំណៅនៃសេចក្តីថ្លែងការណ៍មួយច្បាប់ដល់សិស្ស) ៖



« នៅពេលយើងមានបាប យើងងាកចេញពីព្រះ ។ នៅពេលយើងប្រែចិត្ត យើងត្រឡប់មករកព្រះវិញ ។ ការអញ្ជើញឲ្យប្រែចិត្តគឺកម្រជាសំឡេងមួយនៃការដាក់ទណ្ឌកម្មណាស់ ផ្ទុយទៅវិញវាជាសំឡេងអង្វរឲ្យងាកក្រោយ និង ដើម្បី ‹ ត្រឡប់ › ទៅរកព្រះវិញ [សូមមើល ហេលេមិន ៧:១៧] ។ វាគឺជាការដង្ហោយហៅរបស់ព្រះវរបិតាដែលពេញដោយក្តីស្រឡាញ់ និង ព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់ ដើម្បីធ្វើឲ្យយើងក្លាយជាមនុស្សដែលលើសពីអ្វីដែលជាខ្លួនយើង ដើម្បីឈានជើងឡើងទៅផ្លូវមួយដែលខ្ពស់ជាងនេះនៃជីវិតនេះ ដើម្បីផ្លាស់ប្តូរ ហើយទទួលអារម្មណ៍នៃសុភមង្គលក្នុងការគោរពព្រះបញ្ញត្តិ » (« Repent . . . That I May Heal You » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤០) ។

- យោងតាមអែលឌើរ អាន់ឌើរសិន តើយើងទទួលបានអ្វីខ្លះ នៅពេលយើងប្រែចិត្ត ហើយត្រឡប់ទៅរកព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទវិញ ?

នៅពេលសិស្សបន្តសិក្សា កិច្ចការ ២៦ សូមអញ្ជើញសិស្សឲ្យរកមើលអ្វីដែលបានរារាំងភេស្ទុស និងស្តេចអ័គ្រីប៉ាពីការប្រែចិត្ត ពីការងាកទៅរកព្រះ និងការប្រែចិត្តជឿព្រះយេស៊ូវគ្រីស្ទនោះ។ ចូរសរសេរសេចក្តីថ្លែងការណ៍ពុំពេញលេញដូចខាងក្រោមនៅលើក្តារខៀន៖ *ដើម្បីប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទ* . . .

សូមចែកសិស្សជាគូ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កិច្ចការ ២៦:២៤-២៨ជាមួយដៃគូរបស់ពួកគេ ។ សូមឲ្យពួកគេប្រាប់ ហើយប្រៀបធៀបវិធីដែលភេស្ទុស និងស្តេចអ័គ្រីប៉ាបានមានប្រតិកម្មចំពោះការបង្រៀន និងទីបន្ទាល់របស់ប៉ុលអំពីព្រះយេស៊ូវគ្រីស្ទ ។ នៅពេលសិស្សអាន ហើយពិភាក្សាជាមួយដៃគូខ្លួន សូមចម្លង តារាង ខាងក្រោមនេះដាក់នៅលើក្តារខៀន (សូមកុំដាក់សេចក្តីថ្លែងនៅពីខាងក្រោមក្បាលចំណងជើងនីមួយៗឡើយ) ៖

ប្រតិកម្មចំពោះការបង្រៀនរបស់ប៉ុល	
ភេស្ទុស	ស្តេច អ័គ្រីប៉ា
និយាយក្នុងសំឡេងខ្លាំងមួយ បាននិយាយថាប៉ុលឆ្កួត បានចោទប្រកាន់ប៉ុលថាឆ្កួតលីលា	បានបញ្ចុះបញ្ចូលស្ទើរតែក្លាយជាពួកគ្រីស្ទានទៅហើយ

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ឡើងមកក្តារខៀន សរសេរចម្លើយដែលពួកគេបានរកឃើញ (ចម្លើយគួរស្រដៀងគ្នានឹងឃ្លានៅក្នុងតារាងខាងលើ) ។

- តើប្រតិកម្មរបស់ភេស្ទុសបង្ហាញឲ្យឃើញ អំពីទស្សនៈរបស់គាត់ទាក់ទងនឹងការបង្រៀនរបស់ប៉ុលយ៉ាងណាខ្លះ ? (សូមបន្ថែមពាក្ស *ឥតជំនឿ* ទៅនឹងចម្លើយរបស់សិស្សនៅក្រោមចំណងជើង « ភេស្ទុស ») ។

- យោងតាម ខទី ២៧ តើប៉ុលបាននិយាយថា លោកបានដឹងអ្វីខ្លះអំពីស្តេចអ័គ្រីប៉ា ? (សូមបន្តែមពាក្យ *បានជឿដល់ពួកព្យាការី* នៅក្រោមចំណងជើង « ស្តេចអ័គ្រីប៉ា ») ។
- តើយើងអាចរៀនអ្វីខ្លះ អំពីមតិរបស់ស្តេចអ័គ្រីប៉ាទៅកាន់ប៉ុលអំពីការតាំងចិត្តរបស់ស្តេចអ័គ្រីប៉ា ធ្វើជាគ្រីស្ទាន (សូមមើល ខទី ២៨) ? (សូមបន្តែមពាក្យ *គ្មានឆន្ទៈដើម្បីតាំងចិត្តពេញលេញ* នៅក្រោមក្បាលចំណងជើង« ស្តេចអ័គ្រីប៉ា ») ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៦:២៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើប៉ុលបានឆ្លើយតបនឹងមតិរបស់ស្តេចអ័គ្រីប៉ាយ៉ាងដូចម្តេច កាលទ្រង់មានបន្ទូលថា ឯងនឹងនាំឲ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទានដែរ ។

- តើប៉ុលមានបំណងចង់បានអ្វីសម្រាប់ស្តេចអង្គ និងអស់អ្នកដែលបានស្តាប់ឮការបង្រៀនរបស់លោក ?
- តើអ្នកគិតថា មានអ្វីខ្លះដែលបានរារាំងភេស្ទុសពីការប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទ ?
- តើអ្នកគិតថា មានអ្វីខ្លះដែលបានរារាំងស្តេចអ័គ្រីប៉ាពីការប្រែចិត្តជឿ ?
- តើយើងអាចរៀនអ្វីខ្លះមកពីភេស្ទុស និងស្តេចអ័គ្រីប៉ា អំពីអ្វីដែលយើងត្រូវធ្វើដើម្បីបានប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគួរស្គាល់គោលការណ៍ដូចខាងក្រោមនេះ៖ **ដើម្បីប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទ យើងត្រូវតែជ្រើសរើសជឿ ហើយតាំងចិត្តរស់នៅតាមដំណឹងល្អឲ្យបានពេញលេញ**) ។

ដើម្បីជួយឲ្យយល់គោលការណ៍នេះ ចូរសុំឲ្យសិស្សម្នាក់អានដំណើររឿងខាងក្រោមនេះមកពីប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ នៃគណៈប្រធានទីមួយឲ្យឮៗ ៖



« មានបងប្អូនប្រុសពីរនាក់ បានឈរនៅលើច្រាំងថ្មចោតតូចមួយ ដើម្បីគយគន់មើលទឹកដ៏ថ្លាឆ្វង់នៅក្នុងបឹងខៀវស្រងាត់មួយ ។ វាគឺជាកន្លែងមុជទឹកមួយដ៏ល្បីល្បាញ ហើយជារឿយៗបងប្អូនប្រុសទាំងពីរនាក់នេះ បាននិយាយគ្នាពីការលោតចុះទៅក្នុងបឹងនោះ—ជាអ្វីមួយដែលពួកគេបានឃើញអ្នកដទៃធ្វើ ។

ទោះបីពួកគេទាំងពីរនាក់ចង់លោតចុះទៅក្តី ប៉ុន្តែគ្មាននរណាម្នាក់ចង់លោតទៅមុនឡើយ ។ កម្ពស់នៅច្រាំងថ្មចោតនោះ គឺវាពុំសូវខ្ពស់ប៉ុន្មានទេ ប៉ុន្តែចំពោះក្មេងប្រុសទាំងពីរនាក់នេះ វាហាក់ដូចចម្ងាយនោះកាន់តែកើនឡើង ពេលណាពួកគេបានចាប់ផ្តើមឱនទេរទៅមុខ—ហើយសេចក្តីក្លាហានរបស់ពួកគេបានរសាយបាត់មួយរំពេច ។

នៅទីបំផុត មានម្នាក់បានដាក់ជើងម្ខាងរបស់ខ្លួននៅគែមច្រាំងថ្មចោតនោះ ហើយបានរំកិលទៅមុខបន្តិចម្តងៗ ។ នៅពេលនោះប្អូនប្រុសរបស់គាត់ម្នាក់ទៀតបានខ្សឹបថា ‹ ប្រហែលជាយើងត្រូវចាំរហូតដល់រដូវក្តៅឆ្នាំក្រោយ › ។

ប៉ុន្តែទម្ងន់របស់ក្មេងប្រុសទីមួយបានទាញគាត់ចុះទៅមុខរួចទៅហើយ ។ គាត់បានតបថា ‹ បងប្រុសខ្ញុំតាំងចិត្តរួចហើយ ! ›

គាត់បានលោតគ្រាំចូលទៅក្នុងបឹងនោះ ហើយបានងើបចេញពីទឹកមកវិញដោយសម្រែកនៃភាពជោគជ័យ ។ ក្មេងប្រុសទីពីរក៏បានលោតទៅតាមភ្លាមដែរ ។ ក្រោយមកទៀតពួកគេទាំងពីរបានអស់សំណើចពីពាក្យចុងក្រោយរបស់ក្មេងប្រុសទីមួយពីមុនលោតចូលទៅក្នុងទឹកថា ៖ « បងប្រុសខ្ញុំតាំងចិត្តហើយ » ។

ការតាំងចិត្តគឺដូចគ្នានឹងការលោតចូលទៅក្នុងបឹងនោះផងដែរ ។ អ្នកអាចតាំងចិត្តធ្វើវា ឬ ក៏ដកថយ ។ អ្នកអាចរំកិលទៅមុខ ឬ ឈរនៅស្ងៀម ។ វាពុំមែនបញ្ចប់ត្រឹមតែពាក់កណ្តាលផ្លូវនោះឡើយ ។ . . .

អស់អ្នកណាដែលមានការតាំងចិត្តបែបនេះ អាចរំពឹងទុកថានឹងទទួលបានពរជ័យនៃទីបន្ទាល់អំណរ និង សេចក្តីសុខសាន្ត ។ ទ្វារនៃស្ថានសួគ៌អាចនឹងបើកឡើងចំពោះពួកគេ ។ . . .

ភាគច្រើនយើងម្នាក់ៗឈរនៅត្រង់ចំណុចនៃការសម្រេចចិត្តមួយដែលឈរមើលពីលើផ្ទៃទឹកនោះ ។ នេះគឺជាការអធិស្ឋានរបស់ខ្ញុំថា យើងនឹងមានសេចក្តីជំនឿបោះជំហានទៅមុខ ប្រឈមមុខនឹងសេចក្តីភ័យខ្លាច និងការមន្ទិលសង្ស័យនានារបស់យើងដោយសេចក្តីក្លាហាន រួចហើយនិយាយមកខ្លួនឯងថា ‹ ខ្ញុំបានតាំងចិត្តហើយ ! › (« Brother, I'm Committed » *Ensign* ខែ កក្កដា ឆ្នាំ ២០១១ ទំព័រ ៤, ៥) ។

- តើការតាំងចិត្តដើម្បីរស់នៅតាមដំណឹងល្អដូចគ្នានឹងការលោតចូលទៅក្នុងទឹកដូចម្តេចដែរ ?
- យោងតាមប្រធាន អុជដូហ្វ ហេតុអ្វីវាជារឿងដ៏សំខាន់ដែលត្រូវមានការតាំងចិត្តទាំងស្រុង ជាជាង « មានការតាំងចិត្តតែមួយផ្នែក » ដើម្បីរស់នៅតាមដំណឹងល្អនោះ ?
- តើការតាំងចិត្តរបស់អ្នកដើម្បីរស់នៅតាមបទបញ្ញត្តិ ឬគោលការណ៍នៃដំណឹងល្អបានជួយពង្រឹងដល់ការប្រែចិត្តជឿរបស់អ្នកទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ? (សូមពិចារណាធ្វើការចែកចាយឧទាហរណ៍ផ្ទាល់ខ្លួនរបស់អ្នក) ។

សូមអញ្ជើញសិស្សឲ្យសរសេរជាបញ្ជីបទបញ្ញត្តិ ឬគោលការណ៍នៃដំណឹងល្អមួយ ដែលពួកគេបានគិតថា ពួកគេបានរស់នៅតាមយ៉ាងពេញលេញ ដាក់នៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យពួកគេពិចារណាពីគោលការណ៍នៃដំណឹងល្អនានា ដែលពួកគេគិតថា « នៅបន្តិចទៀត » ប៉ុន្តែពុំ « ឃ្លាទៀត » (កិច្ចការ ២៦:២៩) ពួកគេបានតាំងចិត្តរស់នៅតាម ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយអំពីកិច្ចការដែលពួកគេអាចធ្វើ ដើម្បីបង្កើនការយល់ដឹង និងការតាំងចិត្តរបស់ពួកគេចំពោះគោលការណ៍មួយនៅក្នុងចំណោមគោលការណ៍ទាំងនេះ ។ សូមលើកទឹកចិត្តសិស្សឲ្យអធិស្ឋានសូមជំនួយ នៅពេលពួកគេខិតខំប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទតាមរយៈការរស់នៅតាមដំណឹងល្អកាន់តែពេញលេញ ។

សូមសង្ខេប កិច្ចការ ២៦:៣០–៣២ ដោយពន្យល់ថា ភេស្ទុស និងស្តេចអ័គ្រីប៉ាបានដឹងថា ប៉ុលគ្មានកំហុស ហើយចង់ដោះលែងលោក ប៉ុន្តែដោយសារប៉ុលបានប្តឹងតវ៉ាការចោទប្រកាន់របស់លោកទៅស្តេចសេសារ នោះពួកគាត់ត្រូវតែបញ្ជូនលោកទៅកាន់ក្រុងរ៉ូម ។

សូមបញ្ចប់ដោយរំឭកឡើងវិញ ហើយថ្លែងទីបន្ទាល់អំពីគោលការណ៍ដែលបានបង្រៀននៅក្នុង កិច្ចការ ២៣-២៦ ។

កិច្ចការ ២៧-២៨

សេចក្តីផ្តើម

កាលកំពុងធ្វើដំណើរទៅក្រុងរ៉ូមក្នុងនាមជាអ្នកទោសម្នាក់ ប៉ុលត្រូវបានគេបញ្ជូនខ្លួនតាមសំពៅទៅកាន់កោះមួយ ។ នៅលើកោះនោះ លោកត្រូវបានពស់វែកចឹក ប៉ុន្តែគ្មានគ្រោះថ្នាក់អ្វីទេ ហើយលោកបានព្យាបាលអ្នកជំងឺជាច្រើន ។ នៅទីបំផុតប៉ុលត្រូវគេនាំខ្លួនទៅក្រុងរ៉ូម ជាកន្លែងដែលលោកបានជាប់ឃុំនៅក្នុងផ្ទះអស់រយៈពេលពីរឆ្នាំ ហើយបានបង្រៀន ព្រមទាំងថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ២៧

ប៉ុលត្រូវគេបញ្ជូនខ្លួនតាមសំពៅ នៅពេលលោកធ្វើដំណើរទៅក្រុងរ៉ូម

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនេះ៖ នៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ។ (សេចក្តីថ្លែងការណ៍ទាំងនេះមាននៅក្នុងសៀវភៅ *ដើម្បីកម្លាំងយុវជន* | កូនសៀវភៅ ឆ្នាំ ២០១១ | ទំព័រ ៤, ១១, ១៦) ។

- *« ចូរចៀសវាងពីការដើរលេងជាគ្នាញឹកញាប់ជាមួយនឹងដៃគូដដែលៗ » ។*
- *« កុំចូលរួមទស្សនា ឬចូលរួមក្នុងអ្វីដែលថោកទាប អសីលធម៌ ហិង្សា ឬ អាសគ្រាមតាមរូបភាពណាមួយឡើយ » ។*
- *« ប្រសិនបើមិត្តភ័ក្តិរបស់អ្នកទទូចឲ្យអ្នកធ្វើនូវអ្វីដែលប្រាសចាក ចូរធ្វើជាមនុស្សម្នាក់ដែលក្រោកឈរឡើងសម្រាប់ភាពត្រឹមត្រូវ ទោះបីជាអ្នកត្រូវឈរតែម្នាក់ឯងក៏ដោយ » ។*

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដែលបានសរសេរនៅលើក្តារខៀន ។

- ហេតុអ្វីយុវវ័យមួយចំនួនអាចនឹងជ្រើសរើសមិនស្តាប់តាមសេចក្តីថ្លែងការណ៍ព្រមាន និងការទូន្មានទាំងនេះ ?

នៅពេលសិស្សសិក្សា កិច្ចការ ២៧ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលនឹងជួយពង្រឹងដល់សេចក្តីជំនឿរបស់ពួកគេ ដើម្បីស្តាប់តាមការព្រមាន និងពាក្យទូន្មានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ។

សូមរំឭកសិស្សថា ប៉ុលត្រូវបានគេចោទប្រកាន់ថាក្បត់ជាតិ ហើយត្រូវឃុំខ្លួន ។ ប៉ុលបានដាក់បណ្តឹងរឿងក្តីរបស់លោកឡើងទៅស្តេចសេសានៅក្រុងរ៉ូម ដែលជាសិទ្ធិរបស់លោកក្នុងនាមជាពលរដ្ឋរ៉ូមម្នាក់ ។ សូមសង្ខេប កិច្ចការ ២៧:១–៨ ដោយពន្យល់ថា ប៉ុលបានធ្វើដំណើរជាមួយពួកអ្នកទោសផ្សេងទៀតតាមទូកឆ្ពោះទៅកាន់ក្រុងរ៉ូម ក្រោមការឃុំឃាំងរបស់មេបញ្ជាការរ៉ូមម្នាក់ (ជាមន្ត្រីទំព័រ៉ូមម្នាក់ដែលបញ្ជាទំព័រ ៥០ ទៅ ១០០ នាក់) ។ បន្ទាប់ពីធ្វើដំណើរតាមទូកអស់រយៈពេលជាច្រើនថ្ងៃ ពួកគេបានឈប់នៅផែមួយនៅកោះក្រេត ។ នៅពេលពួកគេចេញពីផែនោះ ប៉ុលបានព្រមានដល់មនុស្សនៅលើសំពៅនោះថា ពួកគេមិនគួរបន្តដំណើររបស់ពួកគេទៀតទេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:៩-១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានដឹងថានឹងមានអ្វីកើតឡើងខ្លះ ប្រសិនបើលោក និងមនុស្សផ្សេងទៀតនៅលើសំពៅនោះបន្តធ្វើដំណើរទៅរ៉ូមនោះ ។ អ្នកគួរពន្យល់ថា ពាក្យ *បុណ្យតម* នៅក្នុងបរិបទនេះមានន័យថា ការមិនបរិភោគអាហារដោយស្ម័គ្រចិត្ត ។ នៅក្នុងករណីនេះ « បុណ្យតម » ប្រហែលជាសំដៅទៅលើថ្ងៃបរិសុទ្ធរបស់ពួកសាសន៍យូដាដែលហៅថា ថ្ងៃនៃដង្វាយធួន ដែលបានកំណត់តាំងពីដើមរដូវនោះ ដែលជាទូទៅវាគ្មានសុវត្ថិភាពដើម្បីធ្វើដំណើរនៅលើសមុទ្រមេឌីទែរ៉ាណេឡើយ ដោយសារមានព្យុះធំៗ ។

- យោងតាម ខទី ១០តើប៉ុលបានព្រមាន និងព្យាករអ្វីខ្លះទាក់ទងនឹងអ្វីដែលនឹងកើតឡើង ប្រសិនបើពួកគេបន្តធ្វើដំណើរទៀត ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:១១-១២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា មេទ័ពរ៉ូមម្នាក់នោះ និងមនុស្សដទៃទៀតនៅលើសំពៅបានឆ្លើយតបយ៉ាងដូចម្តេចទៅនឹងការព្រមានរបស់ប៉ុល ។

- ផ្ទុយពីការស្តាប់តាមការព្រមានរបស់ប៉ុល តើមេបញ្ជាការនោះបានទុកចិត្តនរណាវិញ ?
- ហេតុអ្វីអ្នកគិតថាមេទ័ពនោះជឿលើម្ចាស់សំពៅច្រើនជាងប៉ុល ?
- យោងតាម ខទី ១២ ហេតុអ្វីមនុស្សភាគច្រើននៅលើសំពៅនោះបានបដិសេធការព្រមានរបស់ប៉ុល ? (សូមពន្យល់ថា ពាក្យ *ទ្វារ សមុទ្រ* សំដៅទៅលើផែ ហើយ *ស្រួល* មានន័យភាពសុខសាន្ត ឬងាយ) ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី កិច្ចការ ២៧:១៣-២១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាមានអ្វីបានកើតឡើងកាលសំពៅនោះបានបន្តដំណើរឆ្ពោះទៅក្រុងរ៉ូមនោះ ។

- តើមានអ្វីបានកើតឡើង កាលសំពៅនោះបានបន្តដំណើរឆ្ពោះទៅក្រុងរ៉ូមនោះ ?
- បន្ទាប់ពីឃើញថា « មានខ្យល់បក់រំភើយៗមកពីទិសខាងត្បូង » (ខទី ១៣) តើមនុស្សនៅលើសំពៅអាចនឹងគិតយ៉ាងណាអំពីប៉ុល និងការព្រមានដែលលោកបានផ្តល់ឲ្យនោះ ?

- យោងតាម ខទី ២០ តើមនុស្សនៅលើសំពៅនោះមានអារម្មណ៍យ៉ាងណា កាលដែលនៅក្នុងព្យុះភ្លៀងនោះ ?
- ដូចដែលបានបង្ហាញដោយពាក្យសម្តីរបស់ប៉ុល ដែលបានកត់ត្រានៅក្នុង ខទី ២១ តើយើងអាចរៀនគោលការណ៍អ្វីខ្លះ អំពីរឿងដែលអាចកើតឡើង ប្រសិនបើយើងបដិសេធការព្រមាន និងពាក្យទូន្មានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងបដិសេធការព្រមាន និងពាក្យទូន្មានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងធ្វើឲ្យខ្លួនឯងមានគ្រោះថ្នាក់ហើយ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន។ សូមពន្យល់ថា គ្រោះថ្នាក់នោះអាចរួមបញ្ចូលទាំង ការបាត់បង់សិទ្ធិទទួលបានពរជ័យដែលយើងនឹងទទួលបានផងដែរ) ។

សូមមើលឡើងវិញជាមួយនឹងសិស្សនូវហេតុផលដែលមេទ័ពនោះ និងមនុស្សដទៃទៀតនៅលើសំពៅបានបដិសេធការព្រមាន និងពាក្យទូន្មានរបស់ប៉ុល (សូមមើល កិច្ចការ ២៧:១១–១២) ។

- តើមនុស្សនៅសព្វថ្ងៃនេះអាចធ្វើការដោះសារស្រដៀងគ្នានេះ ដើម្បីបដិសេធចំពោះការព្រមាន និងពាក្យទូន្មានរបស់ពួកព្យាការីរបស់ព្រះអម្ចាស់តាមរបៀបណា ?

ដោយប្រើកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ឬសុន្ទរកថាក្នុងសន្និសីទថ្មីៗ សូមផ្តល់ជាឧទាហរណ៍បន្ថែមទៀតអំពីការព្រមាន និងពាក្យទូន្មានរបស់ពួកព្យាការី ដែលអ្នកមានអារម្មណ៍ថា វាទាក់ទងនឹងសិស្ស ។

- តើមនុស្សទាំងឡាយអាចនឹងបណ្តោយឲ្យខ្លួនស្ថិតក្នុងគ្រោះថ្នាក់បែបណាខ្លះ ដោយសារការបដិសេធចំពោះការព្រមាន និងពាក្យទូន្មានមកពីពួកព្យាការីនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:២២-២៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រាប់ដល់ពួកមនុស្សនៅលើសំពៅនោះអំពីអ្វីខ្លះ ។

- ប្រសិនបើអ្នកនៅលើសំពៅនោះកណ្តាលព្យុះភ្លៀងដ៏គួរឲ្យរន្ធត់ តើពាក្យរបស់ប៉ុលមួយណាដែលនឹងជួយលួងលោមចិត្តអ្នក ?
- តើប៉ុលបានព្យាករថា នឹងមានអ្វីខ្លះកើតឡើងចំពោះមនុស្ស និងសំពៅនោះ ?

សូមសង្ខេប កិច្ចការ ២៧:២៧–៣០ ដោយពន្យល់ថា នៅយប់ទី ១៤ នៃព្យុះនោះ ក្រុមនាវិកបានចោះយុថ្កាចំនួនបួនចូលទៅក្នុងសមុទ្រ ដើម្បីការពារសំពៅកុំឲ្យបោកទៅត្រូវនឹងថ្ម ។ បន្ទាប់មកក្រុមនាវិកនោះបានទៅខាងមុខសំពៅ ហើយធ្វើសកម្មភាពទំនងដូចជាពួកគេបានត្រៀមបោះយុថ្កាបន្ថែមទៀត ។ ប៉ុន្តែ តាមពិតពួកគេកំពុងត្រៀមបោះបង់សំពៅនោះចោល ហើយភៀសខ្លួនជាមួយនឹងទូកតូចមួយ ដោយសារពួកគេភ័យខ្លាចថា សំពៅនោះនឹងលិច ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:៣១-៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមានដែលប៉ុលបានផ្តល់ដល់មេទ័ព និងពួកទាហានទាំងនោះ ។ សូមពន្យល់ថា ពាក្យ *ពួកនោះ* នៅក្នុង ខទី ៣១ សំដៅទៅលើក្រុមនាវិកដែលព្យាយាមគេចខ្លួន ។

- តើការព្រមានអ្វីខ្លះដែលប៉ុលបានផ្តល់ទៅមេទ័ព និងពួកទាហាននោះ ?
- តើពួកទាហាននោះបានឆ្លើយតបចំពោះការព្រមាន និងពាក្យទូន្មានរបស់ប៉ុលយ៉ាងដូចម្តេច ? (ពួកគេបានស្តាប់តាមការព្រមានរបស់លោក ហើយបានរារាំងពួកនាវិកពីការគេចខ្លួន ដោយការកាត់ខ្សែពួរទូកតូចនោះ ហើយបណ្តោយឲ្យវាអណ្តែតទៅតែឯង) ។

សូមពន្យល់ថា លុះស្អែកឡើង ប៉ុលបានអង្វរដល់មនុស្សនៅលើសំពៅដែលបានតមអាហារឲ្យទទួលទានអាហារវិញ (សូមមើល កិច្ចការ ២៧:៣៣–៣៤) ។ លោកបានអះអាងនឹងពួកគេជាថ្មីថា នឹងគ្មាននរណាម្នាក់ស្លាប់ឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:៣៥-៣៦ ឲ្យឮៗ ។ សូមឲ្យសិស្សផ្ទៀងតាម ។

- តើក្រុមមនុស្សនោះបានឆ្លើយតបចំពោះការទូន្មានរបស់ប៉ុលយ៉ាងដូចម្តេច ?

សូមសង្ខេប កិច្ចការ ២៧:៣៧–៤១ ដោយពន្យល់ថា សំពៅនោះបានលិច កាលវាកំពុងធ្វើដំណើរទៅកាន់កោះម៉ាល់តា ។ សូមអញ្ជើញសិស្សឲ្យអាន កិច្ចការ ២៧:៤២-៤៤ ដោយស្ងៀមស្ងាត់ ហើយរកមើលនូវអ្វីដែលបានកើតឡើងដល់មនុស្សនៅលើសំពៅ ។

- តើមានអ្វីខ្លះកើតឡើងចំពោះមនុស្សនៅលើសំពៅ ?

សូមរំឭកសិស្សអំពីការព្យាករបស់ប៉ុលដែលបានកត់ត្រាទុកនៅក្នុងកិច្ចការ ២៧:២២–២៦ ថាគ្មាននរណាម្នាក់នឹងត្រូវស្លាប់ឡើយ ថ្វីបើសំពៅនោះត្រូវលិចក្តី ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះក្នុងដំណើរឿងនេះ អំពីអ្វីដែលអាចកើតឡើង ប្រសិនបើយើងបានស្តាប់តាមពាក្យទូន្មាន និងការព្រមានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ? (សិស្សអាចប្រាប់ពីគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងស្តាប់តាមពាក្យទូន្មាន និងការព្រមានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ចំពោះយើង ។ ប្រសិនបើយើងស្តាប់តាមពាក្យទូន្មាន និងការព្រមានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងអាចទប់ទល់នឹងគ្រោះថ្នាក់ដែលគំរាមកំហែងយើងបាន ។** សូមសរសេរគោលការណ៍ទាំងនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់អំពីគោលការណ៍ ដែលពួកគេបានរកឃើញនៅក្នុង កិច្ចការ ២៧ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ ៖

« គ្រប់ពេលនៅក្នុងជីវិតរបស់ខ្ញុំ នៅពេលខ្ញុំបានជ្រើសរើសពន្យារពេលធ្វើតាមពាក្យទូន្មានដ៏បំផុសគំនិត ឬសម្រេចចិត្តថា ខ្ញុំជាមនុស្សដែលត្រូវបានលើកលែង នោះខ្ញុំបានដឹងថា ខ្ញុំធ្វើឲ្យខ្លួនឯងស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ហើយ ។ គ្រប់ពេលដែលខ្ញុំបានស្តាប់តាមការទូន្មានរបស់ព្យាការី ខ្ញុំទទួលអារម្មណ៍បញ្ជាក់នៅក្នុងការអធិស្ឋាន ហើយពេលខ្ញុំបានធ្វើតាម នោះខ្ញុំបានរកឃើញថា ខ្ញុំបានឆ្ពោះទៅទីសុវត្ថិភាពហើយ » (« Finding Safety in Counsel » *Ensign* ខែឧសភា ឆ្នាំ ១៩៩៧ ទំព័រ ២៥) ។

- តើការស្តាប់តាមការព្រមាន និងពាក្យទូន្មានដែលត្រូវបានបំផុសគំនិតដោយពួកអ្នកបម្រើរបស់ព្រះអម្ចាស់បានជួយអ្នកឲ្យទប់ទល់នឹងគ្រោះថ្នាក់ ដែលគំរាមកំហែងដល់សុវត្ថិភាពខាងវិញ្ញាណ និងខាងសាច់ឈាមរបស់អ្នកយ៉ាងដូចម្តេច ? (សូមរំឭកសិស្សថា ពួកគេអាចសិក្សាអំពីការទូន្មានរបស់ពួកព្យាការីសម័យទំនើបរបស់ព្រះអម្ចាស់នៅក្នុងទស្សនាវដ្តីសាសនាចក្រ ព្រមទាំងនៅក្នុងសៀវភៅ *ដើម្បីកម្លាំងនៃយុវជន*ផងដែរ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេមានកំពុងតែបដិសេធការព្រមាន ឬពាក្យទូន្មានណាមួយមកពីពួកអ្នកបម្រើរបស់ព្រះអម្ចាស់ដែរឬទេ ឬឲ្យពួកគេគិតពិចារណាពីវិធីមួយដែលពួកគេអាចស្តាប់តាមការព្រមាន និងពាក្យទូន្មាន ដែលពួកគេបានទទួលឲ្យបានកាន់តែប្រសើរឡើង ។ សូមអញ្ជើញសិស្សឲ្យសរសេរពីគោលការណ៍មួយទាក់ទងនឹងរបៀប ដែលពួកគេនឹងស្តាប់តាមពាក្យទូន្មាននោះឲ្យបានកាន់តែប្រសើរឡើង ។

កិច្ចការ ២៨

ប៉ុលត្រូវគេនាំខ្លួនទៅក្រុងរ៉ូម ជាកន្លែងដែលលោកបង្រៀន ហើយថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ

ចូរបង្ហាញដល់សិស្សនូវរូបភាពខ្យល់ព្យុះសង្ឃរា ឬខ្យល់កួច (ឬគូរវានៅលើក្តារខៀន) ។



សូមពន្យល់ថា អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ូមនៃពួកសាវកដប់ពីរនាក់បានថ្លែងថា ឧបសគ្គ និងការសាកល្បងនៅក្នុងជីវិតគឺជា « ខ្យល់កួចខាងវិញ្ញាណ » (សូមមើល « Spiritual Whirlwinds » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ១៨–២១) ។

- តើឧទាហរណ៍មួយចំនួនអំពីការសាកល្បង និងការលំបាកដែលអាចប្រៀបបានទៅនឹងខ្យល់កួចនោះមានអ្វីខ្លះ ?

នៅពេលសិស្សសិក្សា កិច្ចការ ២៨ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេឲ្យស៊ូទ្រាំនឹង « ខ្យល់កួចខាងវិញ្ញាណ » ដែលពួកគេជួបដោយស្មោះត្រង់ ។

សូមពន្យល់ថា នៅក្នុង កិច្ចការ ២៨ យើងបានអានអំពីបទពិសោធន៍របស់ប៉ុលនៅលើកោះ៖ ការបន្តដំណើររបស់លោកទៅក្រុងរ៉ូម និងការជាប់ឃុំរបស់លោកនៅក្រុងរ៉ូម ។

សូមចែកសិស្សជាបី ឬច្រើនក្រុម អាស្រ័យទៅលើចំនួនសិស្សរបស់អ្នក ។ សូមចាត់តាំងបណ្តុំបទគម្ពីរខាងក្រោមនេះដល់ក្រុមនីមួយៗ ៖កិច្ចការ ២៨:១–៦, កិច្ចការ ២៨:៧–១៤ និង កិច្ចការ ២៨:១៦–២៤សូមឲ្យបណ្តុំបទគម្ពីរដូចគ្នាទៅក្រុមផ្សេងទៀត ប្រសិនបើចាំបាច់ ។ សូមអញ្ជើញក្រុមនីមួយៗ ឲ្យសិក្សាបណ្តុំបទគម្ពីររបស់ពួកគេ រួចហើយធ្វើដូចតទៅនេះ (សូមសរសេរសេចក្តីណែនាំទាំងនេះនៅលើ ក្តារខៀន) ៖

១. គូរូបភាពមួយ ឬសរសេរព័ត៌មានមួយដែលសង្ខេបពីព្រឹត្តិការណ៍ ដែលបានរៀបរាប់នៅក្នុងបណ្តុំបទគម្ពីររបស់អ្នក ។

២. បង្ហាញរូបភាពរបស់អ្នក ឬអានព័ត៌មាននោះទៅដល់សិស្សផ្សេងទៀត ហើយសង្ខេបព្រឹត្តិការណ៍ ដែលបានរៀបរាប់នៅក្នុងបណ្តុំបទគម្ពីររបស់អ្នក ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យក្រុមនីមួយៗប្រាប់ដល់សិស្សក្នុងថ្នាក់ ។ (ប្រសិនបើមានលើសពីបីក្រុម សូមអញ្ជើញក្រុមទាំងអស់ដែលមានបណ្តុំបទគម្ពីរដូចគ្នាចែកចាយរូបភាព ឬព័ត៌មានរបស់ពួកគេ និងគំនិតបន្ថែម ដែលពួកគេបានទទួលមកពីការអាននៅក្នុងខគម្ពីររបស់ពួកគេ) ។

- តើប៉ុលបានជួបការសាកល្បងអ្វីខ្លះ កាលលោកបានធ្វើដំណើរទៅក្រុងរ៉ូម ហើយស្នាក់នៅទីនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៨:៣០-៣១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ប៉ុលអាចធ្វើអ្វីបានខ្លះ ទោះជាលោកត្រូវបានឃុំខ្លួននៅក្នុងផ្ទះក្តី ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើប៉ុលបានធ្វើអ្វីខ្លះដើម្បីបង្ហាញថា លោកបានបន្តស្មោះត្រង់ចំពោះព្រះ ទោះជាលោកបានជួពនឹងការសាកល្បងជាច្រើនក្តី ?
- តើរឿងល្អអ្វីខ្លះបានកើតឡើងចេញពីការសាកល្បង ដែលប៉ុលបានជួបកាលនៅលើសមុទ្រ កាលត្រូវគេចាប់ខ្លួនបញ្ជូនតាមសំពៅ និងកាលជាប់ឃុំនៅក្រុងរ៉ូម ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន **៖ប្រសិនបើយើងស្មោះត្រង់ នោះព្រះអាចជួយយើងបង្វែរទុក្ខវេទនារបស់យើងទៅជាពរជ័យសម្រាប់ខ្លួនយើង និងមនុស្សផ្សេងទៀត**) ។
- តើឧទាហរណ៍នានានៃវិធីដែលព្រះអាចជួយមនុស្សឲ្យបង្វែរការសាកល្បងទៅជាពរជ័យសម្រាប់ខ្លួនពួកគេ និងមនុស្សផ្សេងទៀត នោះមានអ្វីខ្លះ ?
- តើព្រះធ្លាប់ជួយអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់បង្វែរការសាកល្បងទៅជាពរជ័យមួយសម្រាប់ខ្លួនអ្នក ឬមនុស្សដទៃនៅពេលណា ? (សូមពិចារណាធ្វើការចែកចាយឧទាហរណ៍ផ្ទាល់ខ្លួនរបស់អ្នក) ។

សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូរបស់ប៉ុល ហើយជ្រើសរើសបន្តស្មោះត្រង់ កាលពួកគេជួបនឹងការសាកល្បង ដើម្បីឲ្យព្រះអាចជួយពួកគេបង្វែរការសាកល្បងទាំងនោះទៅជាពរជ័យសម្រាប់ខ្លួនពួកគេ និងមនុស្សដទៃ ។

សូមសួរសំណួរដែលជួយសិស្សឲ្យយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

បន្ទាប់ពីប្រាប់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ នោះសិស្សចាំបាច់ត្រូវយល់ដឹងអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ពីមុនពេលពួកគេអាចអនុវត្តវាប្រកបដោយអត្ថន័យ ។ សូមសួរសំណួរដែលនឹងដឹកនាំទៅរកការយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃគោលការណ៍ ឬ គោលលទ្ធិជាក់លាក់មួយ ដែលលើកទឹកចិត្តសិស្សឲ្យគិតអំពីគោលលទ្ធិ ឬ គោលការណ៍មួយនៅក្នុងបរិបទសម័យទំនើប ឬអញ្ជើញសិស្សឲ្យពន្យល់អំពីការយល់ដឹងរបស់ពួកគេទាក់ទងនឹងគោលលទ្ធិ ឬគោលការណ៍នោះ ។

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់ពួករ៉ូម

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រដល់ពួករ៉ូមគឺជាសំបុត្រដ៏វែងបំផុតរបស់ប៉ុល ហើយត្រូវបានមនុស្សជាច្រើនរាប់ទុកថាជាសំបុត្រដ៏មានខ្លឹមសារបំផុតរបស់លោក ។ សំបុត្រនេះមាននូវការពន្យល់ដ៏ពេញលេញបំផុតរបស់លោក ស្តីពីគោលលទ្ធិនៃការរាប់ជាសុចរិតតាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ជាជាងតាមរយៈការប្រតិបត្តិតាមក្រឹត្យវិន័យរបស់លោកម៉ូសេ ។ វាមាននូវការបង្រៀនជាច្រើនអំពីគោលលទ្ធិនៃសេចក្តីសង្គ្រោះ និងការអនុវត្តតាមគោលលទ្ធិទាំងនោះជាក់ស្តែងនៅក្នុងជីវិតប្រចាំថ្ងៃ ។ តាមរយៈការសិក្សារបស់ពួកគេអំពីគម្ពីរនេះ សិស្សអាចទទួលបាននូវការយល់ដឹងកាន់តែជំជេងអំពីជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងអំពីសេចក្តីសង្ឃឹម និងសេចក្តីសុខសាន្តដែលមនុស្សទាំងអស់អាចរកឃើញនៅក្នុងព្រះគ្រីស្ទ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

សាវកប៉ុលគឺជាអ្នកនិពន្ធសំបុត្រដល់ពួករ៉ូម (សូមមើល រ៉ូម ១:១) ។ នៅក្នុងការសរសេរសំបុត្រនេះ ប៉ុលបានប្រើជំនួយរបស់អ្នកសរសេរម្នាក់ឈ្មោះ ទីទាស ដែលបានសរសេរ ៣ក្យស្វាគមន៍ផ្ទាល់ខ្លួនរបស់គាត់ទៅកាន់ពួកបរិសុទ្ធរ៉ូមនៅជិតសេចក្តីបញ្ចប់នៃសំបុត្រនេះ (សូមមើល រ៉ូម ១៦:២២) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ប៉ុលបានសរសេរសំបុត្ររបស់លោកដល់ពួករ៉ូមនៅក្រុងកូរិនថូសនៅជិតការបញ្ចប់ដំណើរផ្សព្វផ្សាយសាសនាជាលើកទីបីរបស់លោក ។ តម្រុយមួយចំនួនបានណែនាំថា ប៉ុលបានសរសេរសំបុត្រនេះអំឡុងពេលដែលលោកបានស្នាក់នៅក្នុងក្រុងកូរិនថូសរយៈពេលបីខែ (សូមមើល កិច្ចការ ២០:២–៣ ៣ក្យ *ស្រុករក្រក* នៅក្នុងខគម្ពីរទាំងនេះសំដៅលើក្រុងកូរិនថូស) អាចនៅចន្លោះ គ.ស. ៥៥ និង ៥៦ ។ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។

តើគម្ពីរនេះត្រូវបានសរសេរចំពោះនរណា ហើយតើហេតុអ្វី ?

សំបុត្រដល់ពួករ៉ូមនេះគឺសរសេរទៅកាន់សមាជិកសាសនាចក្រក្នុងក្រុងរ៉ូម (សូមមើល រ៉ូម ១:៧) ។ ដើមកំណើតសាសនាចក្រនៅក្រុងរ៉ូមពុំមាននរណាដឹងច្បាស់ទេ ប៉ុន្តែទំនងជាចាប់ផ្តើមនៅក្រោយបុណ្យថ្ងៃទីហាសិប កាលពួកសាសន៍យូដាដែលបានមកលេងក្រុងរ៉ូម បានស្តាប់ឮពេត្រុសប្រកាសពីដំណឹងល្អ (សូមមើល កិច្ចការ ២:១០) ។ ទោះបីជាប៉ុលពុំទាន់បានទៅដល់ក្រុងរ៉ូមក្តី ក៏លោកបានសរសេរ៣ក្យស្វាគមន៍ទៅកាន់ពួកបរិសុទ្ធជាក់លាក់ ដែលលោកបានស្គាល់តាមរយៈការស្គាល់គ្នាពីមុន ឬតាមរយៈមនុស្សដទៃទៀត ដែលធ្លាប់រស់នៅក្រុងរ៉ូម ដូចជា ព្រីស៊ីល និងអ័គីឡា (សូមមើល កិច្ចការ ១៨:១–២, ១៨, រ៉ូម ១៦:១–១៦, ២១) ។

វាមាននូវហេតុផលធំៗយ៉ាងហោចណាស់ចំនួនបី ដែលប៉ុលបានធ្វើសំបុត្រនេះទៅកាន់ពួករ៉ូម ៖

(១) *ដើម្បីរៀបចំការមកកាន់ក្រុងរ៉ូមរបស់លោកនាពេលខាងមុខ* ។ ប៉ុលបានចង់ទៅប្រកាសដំណឹងល្អនៅក្រុងរ៉ូមអស់រយៈពេលជាច្រើនឆ្នាំមកហើយ (សូមមើល កិច្ចការ ១៩:២១, រ៉ូម ១:១៥, ១៥:២៣) ។ លោកក៏បានសង្ឃឹមផងដែរថា សាសនាចក្រនៅក្រុងរ៉ូមនឹងមានភាពកិច្ចជាមូលដ្ឋានមួយដែលអាចជួយលោក ឲ្យទៅបម្រើបេសកកម្មនៅប្រទេសអេស្ប៉ាញបាន (សូមមើល រ៉ូម ១៥:២២–២៤, ២៨) ។

(២) *ដើម្បីបញ្ជាក់ ហើយការពារការបង្រៀនរបស់លោក* ។ ប៉ុលបានជួបប្រទះនឹងការជំទាស់ជាដែលៗមកពីសំណាក់បុគ្គលដែលយល់ខុស ឬមូលបង្កាច់ការបង្រៀនរបស់លោកអំពីក្រឹត្យវិន័យរបស់លោកម៉ូសេ និងសេចក្តីជំនឿទៅលើព្រះគ្រីស្ទ (សូមមើល កិច្ចការ ១៣:៤៥, ១៥:១–២, ២១:២៧–២៨, រ៉ូម ៣:៨, ពេត្រុសទី ២ ៣:១៥–១៦) ។ ប៉ុលមានហេតុផលជាក់ច្បាស់ក្នុងការសង្ស័យថា ការយល់ខុសបែបនេះបានកើតមាននៅក្នុងចំណោមសមាជិកសាសនាចក្រនៅក្រុងរ៉ូម ដូច្នេះទើបលោកបានសរសេរសំបុត្រដើម្បីសម្រាលអស់ទាំងកង្វល់នានាពីមុនលោកទៅដល់ ។

(៣) *ដើម្បីរំលឹកកម្មសំសាមគ្គីភាពរវាងសមាជិកសាសនាចក្រដែលជាពួកសាសន៍យូដា និងពួកសាសន៍ដទៃ* ។ មិនយូរប៉ុន្មានមុនពេលប៉ុលបានសរសេរសំបុត្រនេះ ពួកគ្រីស្ទានដែលជាសាសន៍យូដាដែលត្រូវមហារាជ ក្លូឌាស បណ្តេញចេញពីក្រុងរ៉ូម (សូមមើល កិច្ចការ ១៨:២) បានចាប់ផ្តើមត្រឡប់ទៅក្រុងរ៉ូមវិញ ហើយក៏ទៅកាន់ក្រុមជំនុំពួកគ្រីស្ទានដែលជាសាសន៍ដទៃយ៉ាងច្រើនលើសលុប ។ ស្ថានភាពនេះអាចធ្វើឲ្យកើតមានភាពតានតឹង និងបញ្ហាមួយចំនួនរវាងពួកគ្រីស្ទានដែលជាសាសន៍យូដា និងសាសន៍ដទៃ ។ ក្នុងនាមជា « សាវកដល់សាសន៍ដទៃ » (រ៉ូម ១១:១៣) ប៉ុលបានព្យាយាមជាក់បញ្ចូលពួកប្រែចិត្តជឿជាសាសន៍ដទៃ ចូលទៅក្នុងសាសនាចក្រ ប៉ុន្តែក្នុងនាមជាសាសន៍យូដាម្នាក់ (សូមមើល រ៉ូម ១១:១) ប៉ុលក៏មានបំណងប្រាថ្នាដ៏ធំធេងចង់ឲ្យប្រជាជនខ្លួនបានទទួលយកដំណឹងល្អផងដែរ ។ ប៉ុលបានលើកកម្ពស់សាមគ្គីភាពក្នុងសាសនាចក្រ ដោយបង្រៀនពីរបៀបដែលគោលលទ្ធិនៃដំណឹងល្អអនុវត្តចំពោះពួកបរិសុទ្ធគ្រប់រូប (សូមមើល រ៉ូម ៣:២១–៤:២៥, ១១:១៣–៣៦, ១៤:១–១៥:១៣) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

បន្ទាប់ពីចាប់ផ្តើម៣ក្យស្វាគមន៍មក សំបុត្រនេះបានចាប់ផ្តើមជាមួយនឹងឃ្លាមួយស្តីពីបាវចនារបស់វា ៖ « ដំណឹងល្អនៃព្រះគ្រីស្ទ . . . ជាព្រះចេស្តានៃព្រះសម្រាប់នឹងជួយសង្គ្រោះ » ដល់អស់អ្នកណាដែល « នឹងរស់នៅដោយអាងសេចក្តីជំនឿ » លើព្រះយេស៊ូវគ្រីស្ទ (រ៉ូម ១:១៦–១៧) ។

ទោះបីជាសំបុត្ររបស់ប៉ុលដល់ពួករ៉ូមបានដើរតួយ៉ាងសំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រគ្រីស្ទានក្តី ប៉ុន្តែជាអកុសល វាក៏ក្លាយជា « ប្រភពនៃការយល់ខុស ការបកស្រាយខុស និងការខូចខាតខាងគោលលទ្ធិច្រើនជាងគម្ពីរផ្សេងៗទៀតនៅក្នុងព្រះគម្ពីរបីបវែរ » យោងតាមអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនយ៉ី ក្នុងកូរ៉ូមនៃពួកសាវកដប់ពីរនាក់ (*Doctrinal New Testament Commentary* វ៉ុលទី ៣ [ឆ្នាំ១៩៦៥–៧៣] ២:២១១) ។ សូម្បីតែនៅក្នុងចំណោមពួកគ្រីស្ទានពីដំបូង ការសរសេររបស់ប៉ុលត្រូវបានចាត់ទុកថាជារឿង « ដែលពិបាកយល់ » ហើយពេលខ្លះ ការបង្រៀនរបស់លោកត្រូវបានគេបកស្រាយខុស ហើយមូលបង្កាច់ (ពេត្រុសទី ២ ៣:១៥–១៦) ។

គម្រោង

រ៉ូម ១–៣ ប៉ុលពន្យល់ពីគោលលទ្ធិនៃការរាប់ជាសុចរិតតាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ ប៉ុលឲ្យនិយមន័យចំពោះស្ថានភាពនៃអំពើបាបដែលមនុស្សលោកទាំងអស់មាន ហើយបង្រៀនថា ដំណោះស្រាយរបស់ព្រះដើម្បីដោះស្រាយបញ្ហានេះសម្រាប់មនុស្សទាំងអស់គឺជាជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈការទទួលយកជង្វាយធួននៃព្រះគ្រីស្ទដោយស្មោះត្រង់ នោះមនុស្សលោកទាំងអស់អាចបានរាប់ជាសុចរិត (ត្រូវបានអភ័យទោសឲ្យ) ហើយទទួលបានសេចក្តីសង្គ្រោះ ។

រ៉ូម ៤–៨ ប៉ុលដកស្រង់គំរូរបស់អ័ប្រាហាំ ដើម្បីបង្ហាញគោលលទ្ធិនៃការរាប់ជាសុចរិតតាមរយៈសេចក្តីជំនឿ ។ លោកបរិយាយពីគោលលទ្ធិនៃសេចក្តីសង្គ្រោះ ហើយបង្រៀនពីរបៀប ដែលគោលលទ្ធិទាំងនេះជះឥទ្ធិពលលើជីវិតរបស់មនុស្សទាំងអស់ ដែលមានសេចក្តីជំនឿលើព្រះគ្រីស្ទ ។

រ៉ូម ៩–១៦ ប៉ុលសរសេរអំពីងារជ័ដម្រើសរបស់អ៊ីស្រាអែល បង្ហាញពីការបដិសេធដំណឹងល្អ ព្រមទាំងសេចក្តីសង្គ្រោះរបស់ពួកគេ ។ ប៉ុលទុន្មានដល់សមាជិកសាសនាចក្រសាសន៍យូដា និងសាសន៍ដទៃឲ្យរស់នៅតាមដំណឹងល្អ ដើម្បីឲ្យមានសេចក្តីសុខសាន្ត និងសាមគ្គីភាពនៅក្នុងសាសនាចក្រ ។ លោកអង្វរដល់ពួកបរិសុទ្ធនៅក្រុងរ៉ូមឲ្យបន្តគោរពតាមព្រះបញ្ញត្តិទាំងឡាយ ។

មេរៀន ៩៩

រ៉ូម ១–៣

សេចក្តីផ្តើម

ប៉ុលបានសរសេរសំបុត្រមួយទៅពួកបរិសុទ្ធនៅទីក្រុងរ៉ូម ដោយប្រកាសថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្តគឺជាព្រះចេស្តានៃព្រះសម្រាប់សេចក្តីសង្គ្រោះ ។ សូមពន្យល់ថា គ្មាននរណាម្នាក់អាចត្រូវបានសង្គ្រោះដោយកិច្ចការរបស់ខ្លួនផ្ទាល់ឡើយ ពួកគេត្រូវតែបានសង្គ្រោះដោយព្រះគុណនៃព្រះយេស៊ូវគ្រីស្ត ដែលបានកើតមានតាមរយៈដង្វាយធួន ។

យោបល់សម្រាប់ការបង្រៀន

រ៉ូម ១:១–១៧

ប៉ុលប្រកាសថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្តគឺជាព្រះចេស្តានៃព្រះសម្រាប់សេចក្តីសង្គ្រោះ

សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ឡារី អិក្ង ហក នៃពួកចិតសិបនាក់ ។ សូមពន្យល់ថា កាលនៅជាយុវវ័យម្នាក់ អែលឌើរ អិក្ង ហក បានចុះឈ្មោះចូលធ្វើទាហាននៅក្នុងទ័ពជើងទឹករបស់សហរដ្ឋអាមេរិក ។



« ខ្ញុំបានជួបគ្រូបង្វឹករបស់ខ្ញុំ ដែលជាទាហានជើងចាស់ម្នាក់ ពេលដែលលោកធាក់បើកទ្វារចូលមកបន្ទាយទាំងស្រែកដោយពាក្យអាសគ្រាម ។

« បន្ទាប់ពីការណែនាំខ្លួនដ៏រន្ធត់នេះ គាត់បានចាប់ផ្តើមពីចុងម្ខាងនៃបន្ទាយ ហើយចោទសួរទាហានថ្មីម្នាក់ៗ ។ ដោយគ្មានការលើកលែង នោះគ្រូបង្វឹកព្យាយាមរកឃើញអ្វីមួយពីទាហានថ្មីម្នាក់ៗ ដើម្បីចំអកឲ្យជាមួយនឹងភាសាគ្រោតគ្រាតខ្លាំងៗ ។ គាត់បានដើរតាមជួរ ដោយឲ្យទាហានជើងទឹកម្នាក់ៗស្រែកឆ្លើយទៅវិញ ដូចដែលបានបញ្ជា ៖ ‹ បាទ ! › ឬ ‹ ទេ ! លោកពលបាលត្រី › ។ . . . ពេលដល់វេនខ្ញុំ ខ្ញុំអាចប្រាប់បានថា គាត់បានកញ្ឆក់យកកាបូបស្ពាយរបស់ខ្ញុំ ហើយចាក់ឥវ៉ាន់ចេញទៅលើពួកនៅពីក្រោយខ្ញុំ ។ គាត់បានមើលរបស់របរខ្ញុំ បន្ទាប់មកដើរត្រឡប់មកខាងមុខខ្ញុំវិញ ។ ខ្ញុំបានរៀបចំខ្លួនសម្រាប់ការស្រែកវាយប្រហាររបស់គាត់ ។ គាត់កាន់ព្រះគម្ពីរមរមនរបស់ខ្ញុំក្នុងដៃគាត់ » (« Come unto Me, O Ye House of Israel » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៣២) ។

- តើអ្នកមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកនៅក្នុងស្ថានភាពរបស់អែលឌើរ អិក្ង ហក ?
- តើអ្នកគិតថាគ្រូបង្វឹកនោះនឹងធ្វើអ្វី ?
- តើអ្នកធ្លាប់ស្ថិតនៅក្នុងស្ថានភាពដែលអ្នកព្រួយថា ជំនឿរបស់អ្នកត្រូវបានគេសើចចំអកដែរឬទេ ? (សូមគិតអំពីការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់) ។

នៅពេលសិស្សសិក្សារ៉ូម ១សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេ នៅពេលពួកគេជួបប្រទះនឹងការសើចចំអកដល់ជំនឿ និងបទដ្ឋានរបស់ពួកគេ ។

សូមណែនាំដោយសង្ខេបពីគម្ពីររ៉ូម ដោយអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវឃ្លាខាងក្រោមនេះ ៖

គម្ពីររ៉ូមគឺជាសំបុត្រមួយដែលប៉ុលបានសរសេរទៅពួកបរិសុទ្ធនៅក្រុងរ៉ូម កាលដំណើរផ្សព្វផ្សាយសាសនារបស់លោកជិតដល់ទីបញ្ចប់ ។ លោកបានសរសេរទៅពួកបរិសុទ្ធនៅក្រុងរ៉ូមឲ្យត្រៀមខ្លួនសម្រាប់ការមកដល់របស់លោក ដើម្បីបញ្ចាក់ ហើយការពារការបង្រៀនរបស់លោក និងដើម្បីលើកកម្ពស់សាមគ្គីភាពរវាងសមាជិកសាសនាចក្រសាសន៍យូដា និងសាសន៍ដទៃ ។ ក្រុងរ៉ូម—ជារាជធានីនៃអាណាចក្ររ៉ូម—ត្រូវបានដោគជាំទៅដោយទស្សនៈលោកិយ ហើយជាកន្លែងមួយដែលពិបាកក្នុងការប្រកាសដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ត ។

សូមសង្ខេប រ៉ូម ១:១–១៤ ដោយពន្យល់ថា ប៉ុលបានចាប់ផ្តើមសំបុត្ររបស់លោកដោយថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ត ហើយបង្ហាញពីចំណងក្រាបថ្វាយលោក ដើម្បីទៅជួបពួកបរិសុទ្ធនៅក្រុងរ៉ូម ។

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ១:១៥–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះ ដល់ពួកបរិសុទ្ធនៅក្រុងរ៉ូមអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ត ។

- តើប៉ុលបាននិយាយថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្តជាអ្វី ? (សិស្សគួរអាចឃើញសេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម ៖ **ដំណឹងល្អនៃព្រះគ្រីស្ត គឺជាព្រះចេស្តានៃព្រះសម្រាប់សេចក្តីសង្គ្រោះដល់អស់អ្នកណាដែលអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ត ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។ អ្នកអាចឲ្យយោបល់ដល់សិស្ស ឲ្យគូសចំណាំពាក្យ ឬ ឃ្លានានាដែលបង្រៀនពីសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។
- តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្តបណ្តាលឲ្យយើងត្រូវបានសង្គ្រោះពីអ្វី ? (សេចក្តីស្លាប់ខាងរូបកាយ និង ខាងវិញ្ញាណ) ។
- ហេតុអ្វីយើងត្រូវអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ត ដើម្បីទទួលបានពរជ័យនៃសេចក្តីសង្គ្រោះតាមរយៈដំណឹងល្អ ? (ព្រះយេស៊ូវគ្រីស្តបានធ្វើដង្វាយធួនដែលធ្វើឲ្យសេចក្តីសង្គ្រោះរបស់យើងអាចកើតមានឡើង) ។

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវការពន្យល់ខាងក្រោមនេះអំពីអត្ថន័យនៃពាក្យជឿលើព្រះយេស៊ូវគ្រីស្ទ ហើយអនុវត្តសេចក្តីជំនឿលើទ្រង់ ៖

ដូចដែលបានប្រើដោយប៉ុល ពាក្យ *ជំនឿ* និង *សេចក្តីជំនឿ* ពុំមានន័យគ្រាន់តែជាការព្រមព្រៀងខាងផ្លូវចិត្តថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះប៉ុណ្ណោះទេ ប៉ុន្តែជាការទទួលយកដោយពេញដួងចិត្ត ហើយទុកចិត្តលើទ្រង់ថា ទ្រង់ជាអង្គដែលលះបង់ព្រះអង្គទ្រង់នៅក្នុងដង្វាយធួនសម្រាប់អំពើបាបរបស់យើង ។ ការទុកចិត្តដ៏ជ្រាលជ្រៅនេះដឹកនាំទៅរកជីវិតនៃសេចក្តីស្មោះត្រង់ បង្ហាញដោយការប្រែចិត្តពីអំពើបាប ការទទួលបុណ្យជ្រមុជទឹក និងការព្យាយាមរស់នៅដូចអ្វីដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀន (សូមមើល កិច្ចការ ១៦:៣០–៣៣, រ៉ូម ៦:១–១១, កូរិនថូសទី ១ ៦:៩–១១) ។ « សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ . . . បង្ហាញនៅក្នុងជីវិតនៃការគោរពប្រតិបត្តិតាមក្រឹត្យវិន័យ និងពិធីបរិសុទ្ធនៃដំណឹងល្អ និងការបម្រើដល់ព្រះគ្រីស្ទ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សេចក្តីសង្គ្រោះ » scriptures.lds.org) ។

- ដោយសារប៉ុលបានដឹងថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺជាព្រះចេស្តានៃព្រះសម្រាប់សេចក្តីសង្គ្រោះដល់អស់អ្នកណាដែលជឿនោះ តើប៉ុលមានអារម្មណ៍បែបណាដែរចំពោះការប្រកាសពីដំណឹងល្អ ? (លោកគ្មានភាពអាម៉ាស់នោះទេ [សូមមើល រ៉ូម ១:១៦]) ។
- តើការមានទីបន្ទាល់មួយអំពីអំណាចនៃដំណឹងល្អ អាចមានឥទ្ធិពលដល់បំណងប្រាថ្នារបស់អ្នកដើម្បីចែកចាយដំណឹងល្អជាមួយនឹងមនុស្សដទៃយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលយើងទទួលទីបន្ទាល់មួយថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទមានអំណាចដើម្បីសង្គ្រោះយើង នោះយើងនឹងមិនខ្មាស់អៀនក្នុងការចែកចាយវាជាមួយនឹងមនុស្សដទៃឡើយ**) ។
- តើគោលការណ៍នេះអាចជួយអ្នក នៅពេលអ្នកជួបប្រទះនឹងការបៀតបៀន ឬការចំអកចំពោះជំនឿរបស់អ្នកដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អានឮៗនៅផ្នែកបន្ទាប់នៃរឿងរបស់អែលឌើរ អិក ហក ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់មើលថា តើលោកបានឆ្លើយតបនឹងគ្រូបង្វឹកនោះយ៉ាងដូចម្តេច ។



« ខ្ញុំគិតថា គាត់នឹងស្រែកឲ្យខ្ញុំ តែគាត់បានខិតមកជិតខ្ញុំ ហើយខ្សឹបថា ‹ តើអ្នកជាពួកមរមនឬ ? ›

« ដូចដែលបានបញ្ជា នោះខ្ញុំបានស្រែកថា ‹ បាទ ! លោកពលបាលត្រី › ។

« ជាថ្មីម្តងទៀត ខ្ញុំបានរំពឹងនូវរឿងអាក្រក់នឹងកើតឡើង ។ ផ្ទុយទៅវិញ គាត់បានឈប់មួយសន្ទុះ ហើយលើកដៃគាត់ដែលកាន់ព្រះគម្ពីរមរមនខ្ញុំនោះ ហើយបាននិយាយដោយសំឡេងតិចៗ ថា ‹ តើអ្នកជឿលើព្រះគម្ពីរនេះទេ ? ›

« ម្តងទៀត ខ្ញុំស្រែកថា ‹ បាទ ! លោកពលបាលត្រី › » (« Come unto Me, O Ye House of Israel » ទំព័រ ៣២) ។

- តើការឆ្លើយតបរបស់អែលឌើរ អិក ហក គឺជាគំរូដ៏ល្អមួយពីគោលការណ៍ដែលបានបង្រៀននៅក្នុង រ៉ូម ១:១៦ យ៉ាងដូចម្តេច ?

សូមពន្យល់ថា ផ្ទុយពីការចំអកដល់អែលឌើរ អិក ហក គ្រូបង្វឹកនោះបានដាក់ព្រះគម្ពីរមរមនចុះដោយថ្នម ហើយបានបន្តទៅឈ្មោះទាហានផ្សេងទៀត ។ សូមអានឮៗនូវពាក្យពេចន៍បន្ថែមទៀតរបស់អែលឌើរ អិក ហក ៖

« ជាញឹកញាប់ ខ្ញុំឆ្ងល់ថា ហេតុអ្វីពលបាលត្រីទាហានជើងទឹកដ៏កាចនោះបានលើកលែងឲ្យខ្ញុំនៅថ្ងៃនោះ ។ តែខ្ញុំមានអំណរគុណ ដែលខ្ញុំអាចនិយាយបានដោយគ្មានស្ទាក់ស្ទើរថា ‹ បាទ ! ខ្ញុំជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ › និងថា ‹ បាទ ! ខ្ញុំដឹងថា ព្រះគម្ពីរមរមនពិត › ។ ទីបន្ទាល់នេះជាអំណោយដ៏មានតម្លៃ ដែលបានប្រទានដល់ខ្ញុំតាមរយៈព្រះវិញ្ញាណបរិសុទ្ធ » (« Come unto Me, O Ye House of Israel » ទំព័រ ៣២) ។

- តើអ្នក (ឬ មនុស្សម្នាក់ដែលអ្នកស្គាល់) ធ្លាប់បង្ហាញថា អ្នកមិនខ្មាស់ដើម្បីចែកចាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នៅពេលណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា តើពួកគេមានអារម្មណ៍រឹងមាំដល់កម្រិតណា អំពីទីបន្ទាល់របស់ពួកគេចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយថាតើពួកគេអាចធ្វើអ្វីខ្លះដើម្បីពង្រឹងទីបន្ទាល់ទាំងនោះ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅមួយធ្វើរឿងនោះ ។

រ៉ូម ១:១៨–៣:២៣

ប៉ុលបង្រៀនថា មនុស្សលោកទាំងអស់ធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ

សូមពន្យល់ថា នៅក្នុងសម័យរបស់ប៉ុល មានពួកគ្រីស្ទានជាសាសន៍យូដាមួយចំនួនបានខិតខំរកពាក្យដោះសារចំពោះតរិយាបថអសីលធម៌ ឬតរិយាបថពេញដោយអំពើបាប ដោយគូសបញ្ជាក់ពីសេចក្តីមេត្តាករុណារបស់ព្រះ ហើយបដិសេធសេចក្តីយុត្តិធម៌ដ៏ល្អឥតខ្ចោះរបស់ទ្រង់ ។ ក៏មានពួកគ្រីស្ទានជាសាសន៍យូដាមួយចំនួនបានជឿដងដែរថា ការប្រតិបត្តិតាមក្រឹត្យវិន័យរបស់ម៉ូសេគឺចាំបាច់ចំពោះសេចក្តីសង្គ្រោះរបស់ពួកគេ ។ ប៉ុលបានខិតខំកែតម្រូវការយល់ខុសទាំងពីរនេះ ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង រ៉ូម ១: ១៨–៣២ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអំពើបាប ដែលប៉ុលបាននិយាយថានឹងមានពាសវាលពាសកាលនៅក្នុងជំនាន់របស់លោក ។ អ្នកគួរជួយសិស្សឲ្យកំណត់ន័យនៃពាក្យ និងឃ្លានៅក្នុង ខទី ១៨–៣២ ដើម្បីជួយពួកគេឲ្យយល់ពីការព្រមានដែលប៉ុលបានផ្តល់ទៅពួកបរិសុទ្ធនៅរ៉ូម ។ ឧទាហរណ៍ សូមពិចារណាសួរសំណួរខាងក្រោមនេះ ៖

- នៅក្នុង ខទី ២៥ តើអ្នកគិតថាឃ្លា « កោតខ្លាច ហើយគោរពបូជាដល់របស់ដែលកើតមក ជាជាងដល់ព្រះ » មានន័យដូចម្តេច ?

ចូរចង្អុលបង្ហាញថានៅក្នុង រ៉ូម ១:១៨–៣២ យើងរៀនថា **ពួកព្យាការី និងពួកសាវកទាំងឡាយបង្រៀនយើងអំពីតរិយាបថ និងអាកប្បកិរិយាដែលធ្វើខុសនឹងព្រះ ។**

សូមពន្យល់ថា ឃ្លា « ផ្លាស់ប្រែទំនៀមទំលាប់ពីបវេណីចេញ ឲ្យខុសពីធម្មតា » នៅក្នុង ខទី ២៦ និង « លះចោលទំនៀមទំលាប់របស់ស្ត្រីពីបវេណីចេញ » នៅក្នុង ខទី ២៧ សំដៅទៅលើឥរិយាបថមនុស្សរួមភេទដូចគ្នា ។ អ្នកគួរពន្យល់ថា តាំងពីដើម និងនៅក្នុងព្រះគម្ពីរទាំងមូល ព្រះអម្ចាស់ដាក់ទោសជាន់ធ្ងន់ដល់ការបំពានច្បាប់ព្រហ្មចារីភាព រួមទាំងឥរិយាបថមនុស្សរួមភេទដូចគ្នាផងដែរ ។

កំណត់ចំណាំ ៖ ប្រធានបទអំពីការទាក់ទាញភេទដូចគ្នាតម្រូវឲ្យមានចិត្តទូលាយទន់ភ្លន់ ។ នៅពេលសិស្សរបស់អ្នកពិភាក្សាពីបញ្ហានេះ សូមប្រាកដថា វាត្រូវបានធ្វើឡើងដោយចិត្តសប្បុរស មេត្តាករុណា និងដោយសេចក្តីគួរសម ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលជំហររបស់សាសនាចក្រស្តីពីឥរិយាបថនៃមនុស្សរួមភេទដូចគ្នា សូមអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមឲ្យពួក ៖

« អាកប្បកិរិយាស្រឡាញ់បុរស និងបុរសដូចគ្នា និង ស្ត្រី និងស្ត្រីគឺជាអំពើបាបដ៏ធ្ងន់ធ្ងរ ។ ប្រសិនបើអ្នកឃើញថា ខ្លួនអ្នកមានបញ្ហាជាមួយនឹងចំណាប់អារម្មណ៍លើភេទដូចគ្នា ឬ អ្នកកំពុងតែត្រូវបានទាក់ទាញឲ្យចូលរួមនៅក្នុងអាកប្បកិរិយាមិនសមរម្យ ចូរស្វែងរកការប្រឹក្សាពីឪពុកម្តាយ និង ប៊ីស្សពរបស់អ្នក ។ ពួកគេនឹងជួយអ្នក » (*For the Strength of Youth* [កូនសៀវភៅ ឆ្នាំ២០១១] ទំព័រ៣៦) ។

« គោលជំហរខាងគោលលទ្ធិរបស់សាសនាចក្រគឺច្បាស់លាស់ ៖ ការរួមភេទគួរតែកើតមានរវាងបុរសម្នាក់ និងស្ត្រីម្នាក់ដែលបានរៀបការប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនគួរប្រើប្រាស់វាជាហេតុផលចំពោះអំពើទុច្ចរិតឡើយ ។ ព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលយើងដើរតាម ប្រាកដជាដាក់ទោសចំពោះរឿងអសីលធម៌ខាងផ្លូវភេទ ប៉ុន្តែមិនឃោរឃៅនោះទេ ។ ព្រះទ័យរបស់ទ្រង់តែងតែលើកតម្កើងបុគ្គលម្នាក់ៗ តែពុំដែលទាញទម្លាក់ចុះឡើយ ។ . . .

« សាសនាចក្របានបង្ហាញពីលក្ខណៈខុសគ្នារវាងការប្រតិព័ទ្ធ និង ឥរិយាបថទាក់ទាញចិត្តចំពោះភេទដូចគ្នា ។ ខណៈដែលការមានអារម្មណ៍ និងទំនោរចិត្តស្រឡាញ់ភេទដូចគ្នាពុំមែនជាអំពើបាប តែការចូលរួមក្នុងទង្វើប្រតិព័ទ្ធភេទដូចគ្នាទេតើ ទើបខុសនឹង ‹ គោលការណ៍ខាងគោលលទ្ធិ ដែលផ្អែកលើព្រះគម្ពីរដ៏ពិសិដ្ឋ . . . ថាអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និង ស្ត្រីម្នាក់ គឺចាំបាច់ចំពោះផែនការនៃអង្គដ៏បង្កបង្កើត សម្រាប់ជោគវាសនាដ៏អស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់ › [« សេចក្តីថ្លែងការណ៍របស់គណៈប្រធានទីមួយ ស្តីពីអាពាហ៍ពិពាហ៍ភេទដូចគ្នាmormonnewsroom.org] » (« Same–Sex Attraction » Gospel Topics, lds.org/topics) ។

- ហេតុអ្វីវាជារឿងសំខាន់ដែលយើងត្រូវយល់ដឹងពីការបង្រៀនរបស់ពួកព្យាការី និងពួកសាវករបស់ព្រះអម្ចាស់ស្តីពីឥរិយាបថនៃមនុស្សរួមភេទដូចគ្នា ?
- តើយើងអាចបង្ហាញចិត្តសប្បុរស និងចិត្តមេត្តាដល់ជនដែលជួបនឹងភាពទាក់ទាញភេទដូចគ្នា កាលនៅតែគាំទ្រដល់ជំហររបស់សាសនាចក្រស្តីពីឥរិយាបទនៃមនុស្សរួមភេទដូចគ្នាតាមរបៀបណា ?

សូមសង្ខេប រ៉ូម ២:១–៣:៨ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា មនុស្សទាំងអស់នឹងត្រូវបានកាត់សេចក្តី ស្របតាមកិច្ចការរបស់ពួកគេ ហើយលោកបានបង្ហាញថា សេចក្តីទុច្ចរិតរបស់ពួកសាសន៍យូដាបានកើតមកពីការរស់នៅតាមក្រឹត្យវិន័យរបស់ម៉ូសេតែខាងក្រៅ ប៉ុន្តែពុំមែនចេញពីចិត្តរបស់ពួកគេទេ ។

សូមអញ្ជើញសិស្សម្នាក់អានរ៉ូម ៣:៩–១២, ២៣ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់រកមើលថា តើប៉ុលបាននិយាយថានរណាដែលរងឥទ្ធិពលពីអំពើបាប ។

- តើប៉ុលបាននិយាយថានរណាដែលរងឥទ្ធិពលពីអំពើបាប ? តើអំពើបាបរបស់យើងមានលទ្ធផលអ្វីខ្លះ ចំពោះយើង ? (បន្ទាប់ពីសិស្សបានឆ្លើយរួចហើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **រាល់មនុស្សដែលមានការទទួលខុសត្រូវទាំងអស់ប្រព្រឹត្តអំពើបាប ហើយត្រូវការការអភ័យទោសរបស់ព្រះ**) ។
- តើសេចក្តីពិតនេះជួយយើងឲ្យយល់ដឹងកាន់តែប្រសើរឡើង ពីហេតុផលដែលយើងត្រូវការព្រះយេស៊ូវគ្រីស្ទបានដោយរបៀបណា ?

រ៉ូម ៣:២៤–៣១

មនុស្សលោកទាំងអស់អាចបានរាប់ជាសុចរិតតាមរយៈការទទួលយកដង្វាយធួនរបស់ព្រះគ្រីស្ទដោយស្មោះត្រង់

សូមពន្យល់ថា ខគម្ពីរដែលនៅសេសសល់ក្នុង រ៉ូម ៣ ប៉ុលបានបង្រៀនពីរបៀបដែលព្រះយេស៊ូវគ្រីស្ទយកឈ្នះលើបញ្ហាដែលយើងជួបប្រទះ—ពោលគឺថា ព្រះមិនអាចទទួលយកអំពើបាបទាំងអស់ ឯមនុស្សគ្រប់រូបដែលមានការទទួលខុសត្រូវនៅតែប្រព្រឹត្តអំពើបាបនោះទេ ។ ដើម្បីយល់ពីខគម្ពីរទាំងនេះបាន សិស្សនឹងត្រូវយល់ពីអត្ថន័យនៃពាក្យដូចខាងក្រោមនេះ ៖ *ការរាប់ជាសុចរិត* (ការ « ឲ្យបានលើកលែងពីការដាក់ទោសចំពោះអំពើបាប ហើយរាប់ថាឥតមានទោស » [សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « រាប់ជាសុចរិត, ការរាប់ជាសុចរិត » scriptures.lds.org]) *ការប្រោសសង្គ្រោះ* (ពលិកម្មធួន និងប្រភពនៃសេចក្តីមេត្តាករុណា) និង *ព្រះគុណ* (« ជំនួយ និងកម្លាំងពីព្រះត្រូវបានប្រទានឲ្យដោយសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់នៃព្រះយេស៊ូវគ្រីស្ទ » [សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះគុណ »]) ។ សូមពិចារណាសរសេរនិយមន័យនៃពាក្យទាំងនេះលើក្តារខៀនពីមុនថ្នាក់ចាប់ផ្តើម ឬផ្តល់ជាឯកសារដែលមាន ពាក្យ ទាំងនេះដល់សិស្សម្នាក់ៗ ។

ចូរសុំសិស្សម្នាក់អាន រ៉ូម ៣:២៤–២៦ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យើងអាចមានភាពសក្តិសម ដើម្បីនៅក្នុងវត្តមានរបស់ព្រះបានតាមរបៀបណា ។

- យោងតាម រ៉ូម ៣:២៤ តើយើងត្រូវបានរាប់ជាសុចរិត ឬបានប្រកាសថាមានភាពសក្តិសមដើម្បីនៅក្នុងវត្តមានរបស់ព្រះតាមរបៀបណា ?

> ***និយមន័យពាក្យ និង ឃ្លាពិបាកៗ***
> ការឲ្យនិយមន័យពាក្យ និងឃ្លាពិបាកៗ អាចជាជំហានជំនួយសំខាន់មួយ នៅក្នុងការយល់ដឹងពីមាតិកានៃបទគម្ពីរ ហើយការស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ ។ ប្រសាសន៍របស់ពួកព្យាការីវចនានុក្រម សៀវភៅសិក្សារបស់សិស្ស លេខយោង និង ជំនួយសិក្សាព្រះគម្ពីរ អាចជួយសិស្សឲ្យយល់ពីពាក្យ ឬ ឃ្លាពិបាកៗ ។

សូមចង្អុលបង្ហាញថា ការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ រ៉ូម ៣:២៤ បានប្តូរពាក្យ *ទទេ* ទៅជា *តែ* ។ សូមពន្យល់ថា មិនថាយើងធ្វើល្អដល់កម្រិតណានៅក្នុងជីវិតនេះនោះទេ យើងមិនអាចទទួលបាន ឬសមនឹងទទួលសេចក្តីសង្គ្រោះដោយខ្លួនយើងបានឡើយ ដោយសារយើងទាំងអស់គ្នាធ្វើបាប ដូច្នោះហើយយើងខ្វះមិនដល់សិរីល្អនៃព្រះឡើយ គឺដូចដែលប៉ុលបានបង្រៀន (សូមមើល រ៉ូម ៣:២៣) ។ មានតែតាមរយៈព្រះគុណរបស់ព្រះប៉ុណ្ណោះ—កន្លាំង និងអំណាចដែលអាចធ្វើទៅបានរបស់ទ្រង់—ទើបយើងអាចត្រូវបានសង្គ្រោះ (សូមមើលផងដែរ ម៉ូរ៉ូណៃ ១០:៣២–៣៣) ។

- យោងតាម ខទី ២៦ តើព្រះរាប់នរណាខ្លះថាសុចរិតដោយព្រះគុណនោះ ? (ជនដែលជឿលើព្រះយេស៊ូវ) ។

សូមរំឭកសិស្សពីរបៀបដែលប៉ុលបានប្រើពាក្យ *ដឹ* និង *សេចក្តីជំនឿ* ដូចដែលបានប្រកាសកាលពីខាងដើមមេរៀន ។

- តើខគម្ពីរទាំងនេះបង្រៀនគោលការណ៍អ្វីខ្លះអំពីលទ្ធផលនៃការទទួលយកដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្តដោយស្មោះត្រង់នោះ ? (សិស្សអាចប្រាប់ពីគោលការណ៍មួយដូចខាងក្រោម ៖ **តាមរយៈការទទួលយកដ៏ស្មោះត្រង់នៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្តនោះមនុស្សលោកទាំងអស់នឹងបានរាប់ជាសុចរិត ហើយទទួលសេចក្តីសង្គ្រោះ**) ។
- តើយើងអាចបង្ហាញការទទួលយកនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះដោយស្មោះត្រង់ដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីសេចក្តីត្រូវការរបស់ខ្លួនចំពោះព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ត និងអ្វីដែលពួកគេអាចធ្វើ ដើម្បីទទួលយកដង្វាយធួនរបស់ទ្រង់កាន់តែស្មោះត្រង់ថែមទៀត ។ សូមអញ្ជើញពួកគេឲ្យកត់ត្រាអារម្មណ៍របស់ពួកគេចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអារម្មណ៍ និងទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។

សូមសង្ខេប រ៉ូម ៣:២៧–៣០ ដោយពន្យល់ថា ប៉ុលបានគូសបញ្ជាក់សារជាថ្មីថា បុគ្គលម្នាក់ត្រូវបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្តជាជាង ដោយសារការគោរពប្រតិបត្តិរបស់ខ្លួនតាមក្រឹត្យវិន័យរបស់ម៉ូសេ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

រ៉ូម ១:១ ។ « ដំណឹងល្អនៃព្រះ »

ជាការពិតណាស់ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ត ដំណឹងល្អនៃព្រះមានន័យថា ដំណឹងល្អរបស់ព្រះដែលជាព្រះវរបិតា ។ វាត្រូវគេស្គាល់ថាជា « ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ត » ដោយសារព្រះគ្រីស្តបានក្លាយជាព្រះអង្គគាំទ្រ និងជាអ្នកគាំទ្រដ៏ធំចំពោះផែនការរបស់ព្រះវរបិតា ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

ការយល់ដឹងពីពាក្យគន្លឹះនៅក្នុងសំបុត្ររបស់ប៉ុលដល់ពួករ៉ូម

ដើម្បីជួយសិស្សឲ្យយល់ពីពាក្យមួយចំនួនដែលប៉ុលបានប្រើ ដែលប្រហែលជាពាក្យដែលពួកគេពុំសូវស្គាល់ សូមពិចារណាផ្តល់ឯកសារដែលមាននិយមន័យដូចខាងក្រោមនេះដល់សិស្ស នៅពេលអ្នកចាប់ផ្តើមការសិក្សារបស់អ្នកអំពីរ៉ូម (លើកលែងតែកន្លែងដែលបានកត់ចំណាំ និយមន័យទាំងអស់គឺជកស្រង់មកពី សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ [scriptures.lds.org]) ៖

ដំណឹងល្អ ៖ ជាផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះ ដែលធ្វើទៅបានតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ត ។ ដំណឹងល្អមានរួមទាំងសេចក្តីពិតដ៏នៅអស់កល្បជានិច្ច ឬក្រឹត្យ សេចក្តីសញ្ញា និងពិធីបរិសុទ្ធទាំងប៉ុន្មានដែលត្រូវការ ដើម្បីឲ្យមនុស្សលោកចូលទៅឯវត្តមានព្រះវិញ ។

សេចក្តីសង្គ្រោះ ៖ ដើម្បីឲ្យបានរួចផុតពីសេចក្តីស្លាប់ខាងសាច់ឈាម ព្រមទាំងពីសេចក្តីស្លាប់ខាងវិញ្ញាណផង ។ នៅក្នុងន័យនេះ សេចក្តីសង្គ្រោះនៅក្នុងសម្តីរបស់ប៉ុលគឺដូចគ្នានឹងជីវិតដ៏នៅអស់កល្បជានិច្ចដែរ (សូមមើល អាលម៉ា ១១:៤០–៤១, គ. និង ស. ៦:១៣, ១៤:៧ Bruce R. McConkie, *The Promised Messiah: The First Coming of Christ* [ឆ្នាំ១៩៧៨] ទំព័រ ១២៩–៣០) ។

រាប់ជាសុចរិត, ការរាប់ជាសុចរិត ៖ ដើម្បីឲ្យបានលើកលែងពីការដាក់ទោសចំពោះអំពើបាប ហើយរាប់ថាឥតមានទោស ។ ជនម្នាក់ៗត្រូវបានរាប់ជាសុចរិត ដោយសារព្រះគុណនៃព្រះអង្គសង្គ្រោះ តាមរយៈសេចក្តីជំនឿជឿដល់ទ្រង់ ។ សេចក្តីជំនឿនេះគឺបានបង្ហាញ ដោយសារការប្រែចិត្ត និងការគោរពតាមក្រឹត្យវិន័យ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ ។ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ត អាចនាំឲ្យមនុស្សលោកប្រែចិត្ត ហើយបានរាប់ជាសុចរិត ឬលើកលែងពីការដាក់ទោស ដែលគេនឹងត្រូវទទួល ។

សេចក្តីជំនឿ ៖ សេចក្តីជំនឿគឺជាសេចក្តីទុកចិត្ត និងទីទុកចិត្តដល់ព្រះយេស៊ូវគ្រីស្ត ដែលនាំជនណាម្នាក់ឲ្យគោរពតាមទ្រង់ ។ សេចក្តីជំនឿត្រូវតែផ្តោតសំខាន់ទៅលើព្រះយេស៊ូវគ្រីស្ត ដើម្បីឲ្យបាននាំជនណាម្នាក់ទៅរកសេចក្តីសង្គ្រោះ ។

ការប្រោសសន្តោស ៖ « ពលិកម្មធួន » (*Merriam–Webster's Collegiate Dictionary* កំណែទី ១១ [ឆ្នាំ២០០៣] « propitiation ») ។ ប្រភពនៃសេចក្តីមេត្តាករុណា, ការធ្វើឲ្យធូរស្រាល ។

ព្រះគុណ ៖ « ព្រះគុណគឺជាអំណោយមួយមកពីព្រះវរបិតាសួគ៌ ដែលបានប្រទានតាមរយៈព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ត ។ ពាក្យ ព្រះគុណ ដូចដែលបានប្រើនៅក្នុងព្រះគម្ពីរ សំដៅជាចម្បងទៅលើអំណាចដែលអាចធ្វើអ្វីគ្រប់យ៉ាង និង ការព្យាបាលខាងវិញ្ញាណដែលបានផ្តល់ឲ្យតាមរយៈសេចក្តីមេត្តាករុណា និង សេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ត (« Grace » Gospel Topics, lds.org/topics) ។

កិច្ចការ ៖ ជាសកម្មភាពរបស់មនុស្សម្នាក់ មិនថាល្អ ឬអាក្រក់នោះទេ ។ មនុស្សម្នាក់ៗនឹងត្រូវកាត់សេចក្តីតាមរយៈកិច្ចការរបស់គាត់ ។

ក្រឹត្យវិន័យ ៖ ជាបញ្ញត្តិ ឬច្បាប់ទាំងឡាយនៃព្រះដែលព្រះពរ និងទោសទាំងអស់ផ្តែកទៅលើនៅលើស្ថានសួគ៌ ព្រមទាំងនៅលើផែនដីផង ។ អស់អ្នកណាដែលគោរពតាមក្រឹត្យវិន័យទាំងឡាយនៃព្រះ នោះនឹងបានទទួលព្រះពរ ដែលបានសន្យាទុក ។ . . . ក្រឹត្យវិន័យលោកម៉ូសេ [ឬ គ្រាន់តែជា « ក្រឹត្យវិន័យ » ដូចដែលប៉ុលបានប្រើ] គឺជាក្រឹត្យវិន័យដែលបានរៀបចំទុកដើម្បីនាំឲ្យមនុស្សប្រុសស្រីមកឯព្រះគ្រីស្ត ។

រ៉ូម ៤–៧

សេចក្តីផ្តើម

ប៉ុលបានពន្យល់អំពីរបៀបដែលអ័ប្រាហាំត្រូវបានរាប់ជាសុចរិតតាមរយៈព្រះគុណ ។ បន្ទាប់មក ប៉ុលបានពិពណ៌នាពីពរជ័យដែលកើតឡើងដល់ជនដែលត្រូវបានរាប់ជាសុចរិត ហើយបានបង្រៀនថា បុណ្យជ្រមុជទឹកតំណាងឲ្យការស្លាប់ក្នុងអំពើបាប ហើយមានជីវិតឡើងវិញនៅក្នុងព្រះគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

រ៉ូម ៤–៥

ប៉ុលពន្យល់អំពីរបៀបដែលអ័ប្រាហាំត្រូវបានរាប់ជាសុចរិតតាមរយៈព្រះគុណ

សូមចម្លងរូបភាព និងឃ្លាខាងក្រោមដាក់លើក្តារខៀន ៖

ក. ជំនឿរបស់អ្នកថា ទឹកនោះអាចសង្គ្រោះអ្នកបាន
ខ. ការខិតខំរបស់អ្នកដើម្បីបានទឹកនោះមកផឹក
គ. ទឹក



សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពួកគេកំពុងនៅលើវាលខ្សាច់ ហើយស្រេកទឹកហៀបនឹងស្លាប់ ហើយមានទឹកមួយដបនៅលើកំពូលភ្នំមួយក្បែរនោះ ។

- **នៅក្នុងចំណោមកិច្ចការខាងក្រោមនេះ តើកិច្ចការណាមួយនឹងសង្គ្រោះអ្នកបាន ៖ *(ក)* ជំនឿរបស់អ្នកថាទឹកនោះអាចសង្គ្រោះអ្នកបាន *(ខ)* ការខិតខំរបស់អ្នកដើម្បីបានទឹកនោះមកផឹក ឬ *(គ)* ទឹកនោះផ្ទាល់ ? (សូមកុំនិយាយថា ចម្លើយទាំងអស់របស់សិស្សគឺត្រឹមត្រូវឬអត់នោះ) ។**

សូមពន្យល់ថា សាច់រឿងនេះអាចជួយយើងឲ្យយល់ដឹងអំពីការបង្រៀនរបស់ប៉ុលនៅក្នុង រ៉ូម ៤–៧ ស្តីពីរបៀបដែលសេចក្តីជំនឿ កិច្ចការ និងព្រះគុណទាក់ទងទៅនឹងគោលលទ្ធិនៃការរាប់ជាសុចរិត ។ (សូមរំឭកសិស្សថា ការបង្រៀនរបស់ប៉ុលស្តីពីការរាប់ជាសុចរិតត្រូវបានណែនាំនៅក្នុង រ៉ូម ១–៣) ។

- **យោងតាមការបង្រៀនរបស់ប៉ុលនៅក្នុង រ៉ូម ១–៣តើការបានរាប់ជាសុចរិតមានន័យដូចម្តេច ? (ដើម្បីឲ្យបានលើកលែងពីការដាក់ទោសចំពោះអំពើបាប ហើយរាប់ថាឥតមានទោស ឬជាមនុស្សសុចរិត) ។**

សូមផ្តល់បរិបទសម្រាប់ រ៉ូម ៤ ដោយពន្យល់ថា មានពួកបរិសុទ្ធជាសាសន៍យូដាមួយចំនួននៅទីក្រុងរ៉ូមបានគូសបញ្ជាក់ហួសហេតុអំពីសារៈសំខាន់នៃការខិតខំរបស់ពួកគេ និងអំពីក្រឹត្យវិន័យរបស់លោកម៉ូសេនៅក្នុងការបានរាប់ជាសុចរិត ។

- **តើមនុស្សមួយចំនួននៅសព្វថ្ងៃនេះ អាចមានការយល់ខុសស្រដៀងគ្នានេះអំពីការរាប់ជាសុចរិតដោយរបៀបណា ?**
- **នៅក្នុងចំណោមជម្រើសដែលបានសរសេរនៅលើក្តារខៀន តើជម្រើសណាមួយអាចតំណាងឲ្យគំនិតថា យើងអាចត្រូវបានសង្គ្រោះតាមរយៈការប្រព្រឹត្តរបស់យើង ? (សូមសរសេរ *(ការប្រព្រឹត្ត)* នៅក្បែរជម្រើស ខ) ។**

សូមពន្យល់ថា ប៉ុលបានព្យាយាមកែតម្រូវការយល់ខុសដែលមាននៅក្នុងជំនាន់របស់លោក ដោយរំឭកពួកសាសន៍យូដាអំពីលោកអប្បកោពីបុរាណឈ្មោះអ័ប្រាហាំ ជាមនុស្សម្នាក់ដែលពួកសាសន៍យូដាជាច្រើនបានឃើញថាជាអ្នកត្រូវបានរាប់ថាជាសុចរិត ។

សូមឲ្យសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស៊្មីធ រ៉ូម ៤:២–៥ឲ្យឮៗ (នៅក្នុង Bible appendix) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលមូលហេតុដែលអ័ប្រាហាំត្រូវបានគេវិនិច្ឆ័យថា ជាមនុស្សសុចរិត ។

- **តើអ័ប្រាហាំ *ពុំ* ត្រូវបានរាប់ជាសុចរិតតាមរយៈអ្វីទៅ ? (« ច្បាប់នៃការប្រព្រឹត្ត ») ។**

- យោងតាមការបង្រៀនរបស់ប៉ុល ដែលបានកត់ត្រានៅក្នុង រ៉ូម ១–៣ ហេតុអ្វីយើងពុំអាចរាប់ជាសុចរិតតាមរយៈច្បាប់នៃការប្រព្រឹត្តបាន ? (ប៉ុលបានបង្រៀនថា « គ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ » [រ៉ូម ៣:២៣] ។ ការរាប់ជាសុចរិតតាមរយៈច្បាប់នៃការប្រព្រឹត្តនឹងតម្រូវឲ្យយើងឈប់ធ្វើអំពើបាប) ។

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង រ៉ូម ៤:៦–៨ ប៉ុលបានដកស្រង់ចេញពីស្តេចដាវីឌដើម្បីបង្ហាញបន្ថែមទៀតថា ការប្រព្រឹត្តរបស់យើងតែម្យ៉ាងពុំធ្វើឲ្យយើងបានរាប់ជាសុចរិត ឬធ្វើឲ្យយើងឥតទោសបានឡើយ ។

ដើម្បីសង្ខេប រ៉ូម ៤:៩–១៥ សូមអញ្ជើញសិស្សម្នាក់ឲ្យអានប្រយោគខាងក្រោមនេះឲ្យឮៗ ៖

ដើម្បីបង្ហាញពីភាពខុសឆ្គងនៃគំនិតថា មានតែជនដែលបានកាត់ស្បែក ហើយគោរពតាមក្រឹត្យវិន័យរបស់ម៉ូសេប៉ុណ្ណោះ ដែលអាចទទួលបានពរជ័យនៃការមានភាពស្មោះត្រង់បាន នោះប៉ុលបានបង្រៀនថា អ័ប្រាហាំបានទទួលពរជ័យនៃភាពស្មោះត្រង់របស់លោក *តាំងពីមុន* លោកបានកាត់ស្បែកមកម្ល៉េះ ហើយការកាត់ស្បែកនោះគឺជា *ទីសម្គាល់* មួយនៃភាពស្មោះត្រង់របស់លោក ។ អ័ប្រាហាំបានបន្តមានភាពស្មោះត្រង់ បន្ទាប់ពីចុះសេចក្តីសញ្ញានឹងព្រះ ហើយបានកាត់ស្បែក ។ តាមរបៀបនេះ អ័ប្រាហាំបានក្លាយជាឪពុកនៃមនុស្សស្មោះត្រង់ *ទាំងអស់* ទាំងអ្នកដែលពុំកាត់ស្បែក (ពួកសាសន៍ដទៃ) និងពួកអ្នកកាត់ស្បែក (ពួកសាសន៍យូដា) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវការបកប្រែដោយ យ៉ូសែប ស៊្មីធ នៅក្នុង រ៉ូម ៤:១៦ ហើយចូរឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការពន្យល់ដ៏ពេញលេញបន្ថែមទៀតថា យើងត្រូវបានរាប់ជាសុចរិតតាមរបៀបណា ។

- តើយើងត្រូវបានរាប់ជាសុចរិតតាមរបៀបណា ? (សិស្សគួរអាចឃើញគោលលទ្ធិមួយ ដែលស្រដៀងគ្នានឹងគោលលទ្ធិខាងក្រោម ៖ **យើងបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿ និងការប្រព្រឹត្តតាមរយៈព្រះគុណ**) ។

សូមរំឭកសិស្សថា *ព្រះគុណ*សំដៅទៅលើពរជ័យ សេចក្តីមេត្តាករុណា ជំនួយ និងកម្លាំងដែលមានចំពោះយើង ដោយសារតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

- តើជម្រើសណាមួយដែលបានសរសេរនៅលើក្តារខៀនអាចតំណាងឲ្យដង្វាយធួន និងព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ ? តើជម្រើសណាមួយអាចតំណាងឲ្យសេចក្តីជំនឿរបស់យើងលើទ្រង់ ? (បន្ទាប់ពីសិស្សឆ្លើយរួច សូមសរសេរ *(ដង្វាយធួន និងព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ)* នៅក្បែរជម្រើស គ និង *(សេចក្តីជំនឿ)* នៅក្បែរជម្រើស ក) ។
- ប្រសិនបើយើងស្ថិតនៅក្នុងស្ថានភាពនេះ តើយើងអាចបានសង្គ្រោះដោយសេចក្តីជំនឿ និងការខិតខំរបស់យើងដែរឬទេ ប្រសិនបើគ្មានទឹកនោះ ? (ទេ) ។ តើទឹកនៅក្នុងសាច់រឿងនេះប្រៀបបានទៅនឹងដង្វាយធួន និងព្រះគុណនៃព្រះយេស៊ូវគ្រីស្ទដោយរបៀបណាដែរ ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយប្រធាន ឌៀថើរ អេហ្វ អ៊ុជដូហ្វ នៃគណៈប្រធានទីមួយ ៖

« សេចក្តីសង្គ្រោះពុំអាចទិញបានដោយប្រាក់នៃការគោរពប្រតិបត្តិឡើយ តែអាចទិញបានដោយព្រះលោហិតនៃបុត្រានៃព្រះ [សូមមើល កិច្ចការ ២០:២៨] ។ . . .

« ព្រះគុណគឺជាអំណោយមកពីព្រះ ហើយបំណងប្រាថ្នារបស់យើងក្នុងការគោរពតាមបញ្ញត្តិនីមួយៗរបស់ព្រះ គឺជាការបង្ហាញដល់ព្រះវរបិតាសួគ៌ក្នុងជីវិតរមែងស្លាប់នេះថា យើងចង់ទទួលបានអំណោយដ៏ពិសិដ្ឋនេះ » (« The Gift of Grace » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១០៩, ១១០) ។

សូមចង្អុលបង្ហាញថា កាលសាច់រឿងដែលបានពិពណ៌នានៅលើក្តារខៀនជួយយើងឲ្យយល់ពីរបៀបដែលសេចក្តីជំនឿ ការប្រព្រឹត្ត និងព្រះគុណដែលធ្វើឲ្យយើងបានរាប់ជាសុចរិត នោះវាពុំបានបង្ហាញទាំងស្រុងនោះទេថា យើងបានទទួលព្រះគុណរបស់អង្គសង្គ្រោះនោះ ។ ព្រះយេស៊ូវគ្រីស្ទពុំគ្រាន់តែប្រទានទឹក ដែលសង្គ្រោះដល់ជីវិតដែលតំណាងឲ្យព្រះគុណរបស់ទ្រង់ប៉ុណ្ណោះទេ ដែលទឹកនេះធ្វើឲ្យយើងត្រូវបានរាប់ជាសុចរិត ហើយសម្អាតយើងពីអំពើបាប ប៉ុន្តែទ្រង់ក៏អាចធ្វើឲ្យយើងមានសេចក្តីជំនឿ និងកម្លាំងដែលយើងត្រូវការដើម្បីទទួលបានទឹកនោះ ឬបានព្រះគុណរបស់ទ្រង់ផងដែរ ។ យើងអាចមានពរជ័យ តាមរយៈព្រះគុណនេះពីមុន អំឡុងពេល និងក្រោយពីពេលដែលយើងអនុវត្តសេចក្តីជំនឿទៅលើទ្រង់ ហើយប្រព្រឹត្តការល្អ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« អំណាចនៃដង្វាយធួនអាចធ្វើឲ្យមានការប្រែចិត្តបាន . . . ហើយ វាក៏ពង្រឹងយើងឲ្យមើលឃើញ ធ្វើកិច្ចការ និង ប្រែខ្លួនល្អតាមរបៀបដែលយើងមិនអាចស្គាល់ ឬសម្រេចបានជាមួយនឹងសម្បត្តភាពដែលមានកំណត់នៃជីវិតរមែងស្លាប់នេះ » (« Therefore They Hushed Their Fears » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៤៧) ។

- តើព្រះគុណរបស់ព្រះអង្គសង្គ្រោះអាចជួយយើងឲ្យអនុវត្តសេចក្តីជំនឿទៅលើទ្រង់ ហើយប្រព្រឹត្តការល្អបានយ៉ាងដូចម្តេច ?
- តើការប្រព្រឹត្តមួយចំនួនណាខ្លះ ដែលយើងអាចធ្វើដើម្បីបង្ហាញសេចក្តីជំនឿរបស់យើងលើព្រះគ្រីស្ទ ហើយបានរាប់ជាសុចរិតតាមរយៈព្រះគុណរបស់ទ្រង់ ? (ប្រែចិត្ត ហើយគោរពបទបញ្ញត្តិទាំងឡាយ ព្រមទាំងទទួលពិធីបរិសុទ្ធនៃដំណឹងល្អ) ។

សូមអញ្ជើញសិស្សឲ្យបំបែកគ្នាជាក្រុមដែលមានគ្នាពីរ ឬបីនាក់ ហើយពន្យល់គ្នាទៅវិញទៅមកថា តើសេចក្តីជំនឿ និងការប្រព្រឹត្តសុចរិតជួយយើងឲ្យទទួលបានព្រះគុណរបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ដើម្បីយើងអាចត្រូវបានរាប់ជាសុចរិត ។ (សូមធ្វើឲ្យប្រាកដថា សិស្សយល់ថា សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងលើព្រះចេស្តារបស់ទ្រង់ដើម្បីសង្គ្រោះយើងនឹងលើកទឹកចិត្តយើងឲ្យទទួលយកពិធីបរិសុទ្ធចាំបាច់នានា ហើយគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ព្រះ ដែលអនុញ្ញាតឲ្យយើងបានរាប់ជាសុចរិតតាមរយៈព្រះគុណរបស់ព្រះអង្គសង្គ្រោះ) ។

សូមសង្ខេប រ៉ូម ៥ ដោយពន្យល់ថា ប៉ុលបានបង្រៀនអំពីភាពសុខសាន្តដែលកើតមានដល់ជន ដែលទទួលបានព្រះគុណរបស់ព្រះគ្រីស្ទ តាមរយៈសេចក្តីជំនឿ (សូមមើល ខទី ១–២) ។ លោកបានពន្យល់បន្ថែមទៀតថា ព្រះគុណមានសម្រាប់យើងដោយសារតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ គឺលើសពីការលួមគ្រប់គ្រាន់ដើម្បីយកឈ្នះលើឥទ្ធិពលនៃការធ្លាក់ទៅទៀត ។

រ៉ូម ៦–៧

ប៉ុលបង្រៀនអំពីរបៀបចៀសផុតពីអំពើបាប ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច

សូមសួរសិស្សថា តើពួកគេនឹងឆ្លើយតបយ៉ាងណាដែរចំពោះសាច់រឿងខាងក្រោមនេះ ៖

នៅទីបំផុត មិត្តរបស់អ្នកកំពុងដាក់ផែនការទៅបម្រើបេសកកម្ម ប៉ុន្តែនៅពេលនេះគាត់កំពុងធ្វើការជ្រើសរើសដែលផ្ទុយនឹងបទដ្ឋានរបស់ព្រះអម្ចាស់ ។ នៅពេលបង្ហាញនូវកង្វល់អំពីឥរិយាបថរបស់មិត្តអ្នក គាត់និយាយថា « វាពុំមែនជាបញ្ហាធំទេ ។ ដោយសារដង្វាយធួន ខ្ញុំអាចប្រែចិត្ត ពីមុនខ្ញុំទៅបេសកកម្មបានជានិច្ច » ។

សូមពន្យល់ថា មានមនុស្សមួយចំនួនល្មើសនឹងបទបញ្ញត្តិរបស់ព្រះទាំងបំពាន រួចដាក់ផែនការដើម្បីប្រែចិត្តតាមក្រោយ ដូចជាពីមុនពួកគេចូលព្រះវិហារបរិសុទ្ធ ឬ ចេញបម្រើបេសកកម្មជាដើម ។ នៅពេលសិស្សសិក្សា រ៉ូម ៦ សូមអញ្ជើញពួកគេឲ្យរកមើលហេតុផលដែលលក្ខណៈនេះបង្ហាញពីការយល់ខុសដ៏ធ្ងន់ធ្ងរមួយអំពីគោលលទ្ធិនៃព្រះគុណ ។

សូមចែកសិស្សជាគូ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអាន រ៉ូម៦:១–៦, ១១–១២ ឮៗរួមគ្នា ហើយពិភាក្សាថា តើការបង្រៀនរបស់ប៉ុលអាចកែតម្រូវការការគិតរបស់មិត្តពួកគេបានយ៉ាងដូចម្តេច ។ ក្រោយពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- តើប៉ុលបានឆ្លើយតបទៅនឹងការយល់ខុសថា ព្រះគុណរបស់ព្រះអង្គសង្គ្រោះនឹងធ្វើឲ្យយើងរួចផុតពីអំពើបាបរបស់យើងដោយឯកឯងបានយ៉ាងដូចម្តេច ?
- តើអ្នកគិតថា ការ « ស្លាប់ខាងឯអំពើបាប » (ខទី ២) និង ការ « បានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ » (ខទី ៤)មានន័យដូចម្តេច ?
- យោងតាមខគម្ពីរទាំងនេះ តើបុណ្យជ្រមុជទឹកដោយការពន្លិចតំណាងឲ្យអ្វី ? (នៅពេលសិស្សឆ្លើយរួច សូមជួយសិស្សឲ្យស្គាល់គោលលទ្ធិដូចតទៅនេះ ៖ **បុណ្យជ្រមុជទឹកដោយការផ្តាច់ចាប អាចតំណាងឲ្យសេចក្តីស្លាប់របស់យើងពីអំពើបាប និងជីវិតថ្មីខាងវិញ្ញាណ** ។

សូមពន្យល់ថា ជីវិតខាងវិញ្ញាណថ្មីដែលយើងចាប់ផ្តើម នៅពេលយើងបានជ្រមុជទឹក រួមបញ្ចូលទាំងការទទួលការផ្តាច់ចាបរបស់យើង និងការតាំងចិត្តដើម្បីគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ព្រះ ។

ដើម្បីរៀបចំសិស្សឲ្យស្គាល់គោលការណ៍បន្ថែមទៀតនៅក្នុង រ៉ូម ៦ សូមបង្ហាញក្រដាសប្រាក់មួយចំនួន ។

- តើនរណាបើកប្រាក់ខែឲ្យបុគ្គលិកម្នាក់ៗ ? ហេតុអ្វីនិយោជកម្នាក់ពុំបើកប្រាក់ខែឲ្យបុគ្គលិករបស់និយោជកម្នាក់ទៀត ?

សូមអញ្ជើញសិស្សឲ្យអាន រ៉ូម ៦:១៣ ដោយស្ងាត់ស្ងៀម ដោយរកមើល« និយោជក » ឬចៅហ្វាយពីរូប ជាមនុស្សម្នាក់ដែលអាចងាកទៅរក ហើយបម្រើ ។ (អ្នកគួរពន្យល់ថាពាក្យ *ប្រគល់* នៅក្នុងខគម្ពីរនេះចង់សំដៅទៅលើការថ្វាយ ឬប្រគល់ខ្លួន) ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមគូសតារាងខាងក្រោមដាក់លើ ក្តារខៀន ៖

ឈ្នួលរបស់អំពើបាប	ឈ្នួលរបស់ព្រះ

សូមឲ្យសិស្សអាន រ៉ូម ៦:១៤–២៣ដោយស្ងៀមស្ងាត់ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលពាក្យ « ឈ្នួល » (ខទី ២៣) ឬផលនៃអំពើបាប និងពាក់កណ្តាលទៀតរកមើលឈ្នួលរបស់ព្រះ ។ បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឡើងមកក្តារខៀនសរសេរអំពីអ្វីដែលពួកគេបានរកឃើញទៅក្នុងតារាង ។ (នៅក្រោមពាក្យ « ឈ្នួលរបស់អំពើបាប » សិស្សគួរសរសេរ *សេចក្តីស្លាប់* [សូមមើល ខទី ១៦, ២១, ២៣] ហើយនៅក្រោមពាក្យ « ឈ្នួលរបស់ព្រះ » ពួកគេគួរសរសេរ *សេចក្តីសុចរិត* [សូមមើល ខទី ១៦], *បរិសុទ្ធ* [សូមមើល ខទី ១៩, ២២], *ជីវិតអស់កល្បជានិច្ច* [សូមមើល ខទី ២៣] និង *ជីវិតដ៏នៅអស់កល្បជានិច្ច* [សូមមើល ខទី ២៣]) ។ សូមពន្យល់ថា សេចក្តីស្លាប់ដែលជាឈ្នួលនៃអំពើបាបសំដៅទៅលើ « ការបែកចេញពីព្រះ និងពីឥទ្ធិពលទ្រង់ » ហើយវាមានន័យថា « ស្លាប់ចំពោះអ្វីៗខាងសេចក្តីសុចរិត » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « Death, Spiritual » scriptures.lds.org) ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីក្នុង រ៉ូម ៦:១៦ អំពីផលនៃការប្រគល់ខ្លួនឲ្យអំពើបាប ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងប្រគល់ខ្លួនឲ្យអំពើបាប នោះយើងនឹងក្លាយជាពួកអ្នកបម្រើរបស់អំពើបាប**) ។
- តើការប្រគល់ខ្លួនឲ្យអំពើបាបធ្វើឲ្យយើងក្លាយជាបាវបម្រើនៃអំពើបាបនោះយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីឧទាហរណ៍នានា ពីគ្រាដែលការប្រគល់ខ្លួនឲ្យអំពើបាបរបស់មនុស្សម្នាក់បានដឹកនាំទៅរកការបាត់បង់សេរីភាព ។

សូមយោងទៅបញ្ជីក្រោមចំណងជើង « ឈ្នួលរបស់ព្រះ: » ។

- តើអ្វីទៅជាអត្ថប្រយោជន៍នៃការបម្រើសេចក្តីសុចរិត ជាជាងអំពើបាប ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ពីការបង្រៀនរបស់ប៉ុលអំពីរបៀបបានសេរីភាពផុតពីអំពើបាប ហើយទទួលបានអំណោយទាននៃជីវិតអស់កល្បជានិច្ច ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **ប្រសិនបើយើងងាកទៅរកព្រះ នោះយើងអាចរួចផុតពីអំពើបាប ហើយទទួលបានអំណោយទាននៃជីវិតដ៏នៅអស់កល្បជានិច្ច**) ។
- តើយើងអាចថ្វាយខ្លួនចំពោះព្រះតាមរបៀបណា ?
- តើអ្នកធ្លាប់ដកពិសោធន៍នូវសេរីភាពផុតពីអំពើបាប ដោយការថ្វាយខ្លួនចំពោះព្រះ តាមរបៀបណា ?

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការថ្វាយខ្លួនចំពោះព្រះ ។ សូមអញ្ជើញពួកគេឲ្យសរសេរពីគោលការណ៍មួយ ទាក់ទងនឹងរបៀបដែលពួកគេនឹងថ្វាយខ្លួនចំពោះព្រះកាន់តែប្រសើរឡើង ។

សូមសង្ខេប រ៉ូម ៧ ដោយពន្យល់ថា ប៉ុលបានប្រើពាក្យប្រៀបធៀបអំពីអាពាហ៍ពិពាហ៍ដើម្បីបង្រៀនថា សមាជិកសាសនាចក្រត្រូវបានរំដោះឲ្យផុតពីក្រឹត្យវិន័យរបស់ម៉ូសេ ហើយបានចូលរួមនឹងព្រះគ្រីស្ទ ។ លោកក៏បានសរសេរផងដែរអំពីឧបសគ្គរវាង « សាច់ឈាម » (ខទី ១៨) ឬសេចក្តីស្រេកឃ្លានខាងរូបកាយ និង « ប៉ែកខាងក្នុង » (ខទី ២២) ឬជីវភាពខាងវិញ្ញាណ ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិតនានា ដែលបានបង្រៀននៅក្នុងមេរៀននេះ: ។

សួរសំណួរដែលញ៉ាំងឲ្យមានអារម្មណ៍ និង ទីបន្ទាល់

បន្ទាប់ពីសិស្សយល់នូវគោលលទ្ធិ ឬគោលការណ៍មួយរួចហើយ អ្នកអាចសួរសំណួរដែលដឹកនាំសិស្សឲ្យសញ្ជឹងគិតពីបទពិសោធន៍ខាងវិញ្ញាណ ដែលទាក់ទងនឹងគោលលទ្ធិ ឬគោលការណ៍នោះ: ហើយមានអារម្មណ៍យ៉ាងជ្រាលជ្រៅបន្ថែមទៀតអំពីសេចក្តីពិតដ៏ពេញលេញ និងសារៈសំខាន់នៃសេចក្តីពិតនៃដំណឹងល្អនេះនៅក្នុងជីវិតរបស់ពួកគេ ។ ជាច្រើនគ្រា អារម្មណ៍ទាំងនោះបានបង្កើត នូវបំណងប្រាថ្នាកាន់តែខ្លាំងនៅក្នុងចិត្តរបស់សិស្ស ដើម្បីរស់នៅតាមគោលការណ៍នៃដំណឹងល្អមួយកាន់តែស្មោះស្ម័គ្រ ។

មេរៀនសិក្សានៅផ្ទះ

កិច្ចការ ២០–រ៉ូម ៧ (មេរៀនទី ២០)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា កិច្ចការ ២០–រ៉ូម ៧ (មេរៀនទី ២០) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីទាំងនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី១ (កិច្ចការ ២០–២២)

នៅក្នុងដំណើររបស់ប៉ុលជាអ្នកផ្សព្វផ្សាយសាសនា នោះសិស្សបានរៀនថា ពួកអ្នកបម្រើពិតរបស់ព្រះអម្ចាស់បំពេញកាតព្វកិច្ចរបស់ខ្លួនដោយស្មោះត្រង់ ហើយដោយការធ្វើដូច្នេះ ពួកគេមាននូវអំណរ ។ ពួកគេក៏រៀនផងដែរថា ពួកអ្នកបម្រើដ៏ពិតរបស់ព្រះអម្ចាស់យល់ព្រមធ្វើតាមព្រះទ័យរបស់ព្រះ មិនថាត្រូវលះបង់អ្វីឡើយ ។ នៅក្នុងដំណើររឿងរបស់ប៉ុលស្តីពីការប្រែចិត្តជឿរបស់លោក សិស្សបានរៀនថា នៅពេលយើងគោរពតាមព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចចាប់ផ្តើមប្រែចិត្តជឿកាន់តែពេញលេញ ។

ថ្ងៃទី២ (កិច្ចការ ២៣–២៨)

នៅពេលសិស្សបានសិក្សាទីបន្ទាល់របស់ប៉ុលនៅចំពោះស្តេចអ័គ្រីប៉ា ពួកគេបានរៀនថា ប្រសិនបើយើងប្រែចិត្ត ហើយងាកទៅរកព្រះ នោះយើងអាចយកឈ្នះលើអំណាចរបស់សាតាំងនៅក្នុងជីវិតរបស់យើង ទទួលការអភ័យទោសពីអំពើបាបយើង ហើយមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីត្រងនគរសេឡេស្ទាល ។ ពួកគេក៏បានរកឃើញសេចក្តីពិតថា ដើម្បីប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទបាន នោះយើងត្រូវតែជ្រើសពីសជឿ ហើយត្រូវតាំងចិត្តរស់នៅ តាមជំនឿឲ្យបានពេញលេញ ។ នៅក្នុងដំណើររឿងស្តីពីការធ្វើដំណើររបស់ប៉ុលទៅកាន់ទីក្រុងរ៉ូម សិស្សបានរៀនថា ប្រសិនបើយើងស្មោះត្រង់ នោះព្រះអាចជួយយើងឲ្យងែ្វកការសោកល្បួងក្លាយទៅជាពរជ័យសម្រាប់ខ្លួនយើង និងមនុស្សជុំវិញទៀត ។

ថ្ងៃទី ៣ (រ៉ូម ១–៣)

នៅក្នុងសំបុត្ររបស់ប៉ុលទៅពួករ៉ូម សិស្សបានរៀនពីសេចក្តីពិតដូចខាងក្រោមនេះ ៖ នៅពេលយើងទទួលទីបន្ទាល់មួយថា ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទមានអំណាចដើម្បីសង្គ្រោះយើង នោះយើងនឹងមិនខ្មាស់អៀនក្នុងការចែកចាយវាជាមួយនឹងមនុស្សជុំវិញឡើយ ។ រាល់មនុស្សដែលមានការទទួលខុសត្រូវធ្វើបាប ហើយត្រូវការការអភ័យទោសរបស់ព្រះ ។ តាមរយៈការទទួលយកដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទដ៏ស្មោះត្រង់ នោះមនុស្សលោកទាំងអស់នឹងត្រូវបានអនុគ្រោះឲ្យ ហើយទទួលនូវសេចក្តីសង្គ្រោះ ។

ថ្ងៃទី ៤ (រ៉ូម ៤–៧)

នៅក្នុងការបង្រៀនរបស់ប៉ុលដល់ពួកបរិសុទ្ធនៅរ៉ូម នោះសិស្សបានរៀនថា យើងត្រូវបានរាប់ថាសុចរិតដោយសេចក្តីជំនឿ និងកិច្ចការទាំងឡាយតាមរយៈព្រះគុណ ។ ពួកគេក៏បានសិក្សាផងដែរអំពីសេចក្តីពិតដូចតទៅនេះ ៖ ពិធីបុណ្យជ្រមុជទឹកដោយការផ្តាច់បាបអាចតំណាងឲ្យសេចក្តីស្លាប់ពីអំពើបាប និងជីវិតថ្មីខាងវិញ្ញាណរបស់យើង ។ ប្រសិនបើយើងងាកទៅរកអំពើបាប នោះយើងនឹងក្លាយជាពួកអ្នកបម្រើរបស់អំពើបាប ។ ប្រសិនបើយើងងាកទៅរកព្រះ នោះយើងអាចរួចផុតពីអំពើបាប ហើយទទួលបានអំណោយទាននៃជីវិតដ៏នៅអស់កល្បជានិច្ច ។

សេចក្តីផ្តើម

ប៉ុលត្រូវបានគេនាំខ្លួនទៅក្រុងរ៉ូមក្នុងនាមជាអ្នកទោសម្នាក់ឆ្លងកាត់សមុទ្រនៅរដូវរងារ ។ ពីមុនចាកចេញទៅ ប៉ុលត្រូវបានព្រមានថា ដំណើរនេះនឹងមាន « អន្តរាយ ហើយខូចខាតជាច្រើន » (កិច្ចការ ២៧:១០) ។ នៅក្នុងព្យុះមួយ ប៉ុលបានព្យាករថា ទោះបីសំពៅនោះត្រូវបានបំផ្លាញចោលក្តី ក៏មនុស្សលើសំពៅនោះនឹងមិននិវាសឡើយ ។ ការព្យាករបស់ប៉ុលត្រូវបានបំពេញ ។

យោបល់សម្រាប់ការបង្រៀន

កិច្ចការ ២៧

ប៉ុលត្រូវបានបញ្ជូនខ្លួនទៅតាមសំពៅ នៅពេលលោកត្រូវបាននាំខ្លួនទៅក្រុងរ៉ូម

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនេះនៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ (សេចក្តីថ្លែងការណ៍ទាំងនេះមាននៅក្នុង *កម្លាំងដើម្បីយុវជន* [កូនសៀវភៅ ឆ្នាំ ២០១១] ទំព័រ ៤, ១១, ១៦) ។

> *« ចូរចៀសវាងពីការដើរលេងជាគូញឹកញាប់ជាមួយនឹងដៃគូដដែលៗ » ។*
>
> *« កុំចូលរួមទស្សនា ឬចូលរួមក្នុងអ្វីដែលថោកទាប អសីលធម៌ ហិង្សា ឬ អាសគ្រាមតាមរូបភាពណាមួយឡើយ » ។*
>
> *« ប្រសិនបើមិត្តភ័ក្តិរបស់អ្នកទទូចឲ្យអ្នកធ្វើនូវអ្វីដែលប្រាសចាក ចូរធ្វើជាមនុស្សម្នាក់ដែលក្រោកឈរឡើងសម្រាប់ភាពត្រឹមត្រូវ ទោះបីជាអ្នកត្រូវឈរតែម្នាក់ឯងក៏ដោយ » ។*

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដែលបានសរសេរនៅលើក្តារខៀន ។

- ហេតុអ្វីយុវវ័យមួយចំនួនអាចមិនជ្រើសស្តាប់តាមការព្រមាន និងការទុន្មានទាំងនេះ ?

នៅពេលសិស្សសិក្សា កិច្ចការ ២៧ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលនឹងជួយពង្រឹងដល់សេចក្តីជំនឿរបស់ពួកគេ ដើម្បីស្តាប់តាមការព្រមាន និងពាក្យទុន្មានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ។

សូមរំឭកសិស្សថា ប៉ុលត្រូវបានគេចោទប្រកាន់ថាក្បត់ជាតិ ហើយត្រូវឃុំខ្លួន ។ លោកបានដាក់ពាក្យបណ្តឹងរបស់លោកឡើងទៅដល់ស្តេចសេសានៅក្រុងរ៉ូម ហើយវាជាសិទ្ធិរបស់លោកក្នុងនាមជាពលរដ្ឋរ៉ូមម្នាក់ ។ សូមសង្កេប កិច្ចការ ២៧:១–៨ ដោយពន្យល់ថា ប៉ុលបានធ្វើដំណើរជាមួយពួកអ្នកទោសផ្សេងទៀតតាមទូកឆ្ពោះទៅកាន់ក្រុងរ៉ូម ក្រោមការយាមកាមពីសំណាក់ឆ្មាំគុករ៉ូមម្នាក់ ។ បន្ទាប់ពីធ្វើដំណើរតាមទូកអស់រយៈពេលជាច្រើនថ្ងៃ ពួកគេបានឈប់នៅផែមួយនៅកោះក្រេត ។ នៅពេលពួកគេចេញពីផែនោះ ប៉ុលបានព្រមានដល់មនុស្សនៅលើសំពៅនោះថា ពួកគេមិនគួរបន្តដំណើររបស់ពួកគេទៀតទេ ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:៩–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ប៉ុលបានព្រមានថានឹងមានអ្វីកើតឡើងខ្លះ៖ ប្រសិនបើលោក និងមនុស្សផ្សេងទៀតនៅលើសំពៅនោះបន្តធ្វើដំណើរទៅរ៉ូមនោះ ។ អ្នកគួរពន្យល់ថា ពាក្យ *បុណ្យតម* ដែលប្រើនៅក្នុង ខ ទី ៩ សំដៅទៅលើការមិនបរិភោគអាហារដោយស្ម័គ្រចិត្ត ។ នៅក្នុងករណីនេះ « បុណ្យតម » ប្រហែលជាសំដៅទៅលើថ្ងៃបរិសុទ្ធរបស់ពួកសាសន៍យូដាដែលហៅថា ថ្ងៃនៃដង្វាយធួន ដែលបានកំណត់តាំងពីដើមរដូវនោះ៖ ដែលជាទូទៅវាគ្មានសុវត្ថិភាពដើម្បីធ្វើដំណើរនៅលើសមុទ្រមេឌីទែរ៉ាណេឡើយ ដោយសារមានព្យុះធំៗណាស់ ។ ជាធម្មតា ថ្ងៃនៃដង្វាយធួនចាប់ផ្តើមនៅចុងខែកញ្ញា ឬដើមខែតុលា ។ សូមពន្យល់ផងដែរថា ពាក្យ *ទំនិញ* នៅក្នុង ខទី ១០ សំដៅទៅលើទំនិញរបស់សំពៅ ។

- យោងតាម កិច្ចការ ២៧:១០តើប៉ុលបានព្រមាន ហើយបានព្យាករថានឹងមានអ្វីកើតឡើង ប្រសិនបើពួកគេបន្តធ្វើដំណើរទៀតនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:១១–១២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា មេទ័ពរ៉ូមម្នាក់នោះ៖ និងមនុស្សដទៃទៀតនៅលើសំពៅបានឆ្លើយតបយ៉ាងដូចម្តេចទៅនឹងការព្រមានរបស់ប៉ុល ។

- ហេតុអ្វីអ្នកគិតថាមេទ័ពនោះជឿលើម្ចាស់សំពៅច្រើនជាងប៉ុល ?
- យោងតាម ខទី ១២ ហេតុអ្វីមនុស្សនៅលើសំពៅនោះភាគច្រើនបានបដិសេធការព្រមានរបស់ប៉ុល ? (អ្នកគួរពន្យល់ថា ពាក្យ *ទ្វារសមុទ្រ* សំដៅទៅលើផៃ ហើយ *ស្រួល* មានន័យភាពកក់ក្តៅ ឬងាយ) ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី កិច្ចការ ២៧:១៣–២១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាមានអ្វីបានកើតឡើង កាលសំពៅនោះបានបន្តដំណើរឆ្ពោះទៅក្រុងរ៉ូមនោះ ។

- តើមានអ្វីបានកើតឡើង កាលសំពៅនោះបានបន្តដំណើរឆ្ពោះទៅក្រុងរ៉ូមនោះ ?
- យោងតាម ខទី ២០ តើមនុស្សនៅលើសំពៅនោះមានអារម្មណ៍យ៉ាងណាដែរ ចំពោះស្ថានភាពរបស់ពួកគេ កាលស្ថិតនៅក្នុងព្យុះភ្លៀងនោះ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពី ខទី ២១ អំពីអ្វីដែលអាចកើតឡើង ប្រសិនបើយើងបដិសេធការព្រមាន និងពាក្យទូន្មានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ៖ **ប្រសិនបើយើងបដិសេធការព្រមាន និងពាក្យទូន្មានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងធ្វើឲ្យខ្លួនឯងស្ថិតក្នុងគ្រោះថ្នាក់ហើយ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន។ សូមពន្យល់ថា គ្រោះថ្នាក់នោះអាចរួមបញ្ចូលទាំង ការបាត់បង់សិទ្ធិទទួលបានពរជ័យដែលយើងនឹងទទួលបានផងដែរ) ។

សូមមើលឡើងវិញជាមួយនឹងសិស្សនូវហេតុផលដែលមេទ័ពនោះ៖ និងមនុស្សដទៃទៀតនៅលើសំពៅបានបដិសេធការព្រមាន និងពាក្យទូន្មានរបស់ប៉ុល (សូមមើល កិច្ចការ ២៧:១១–១២) ។

- តើមនុស្សនៅសព្វថ្ងៃនេះអាចធ្វើការដោះសារស្រដៀងគ្នានេះ ដើម្បីបដិសេធចំពោះការព្រមាន និងពាក្យទូន្មានរបស់ពួកព្យាការីរបស់ព្រះអម្ចាស់តាមរបៀបណា ?

ដោយប្រើកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ឬសុន្ទរកថាក្នុងសន្និសីទថ្មីៗ សូមផ្តល់ជាឧទាហរណ៍បន្ថែមទៀតអំពីការព្រមាន និងពាក្យទូន្មានរបស់ពួកព្យាការីដែលអ្នកមានអារម្មណ៍ថា វាទាក់ទងនឹងសិស្សក្នុងថ្នាក់របស់អ្នក ។

- តើបុគ្គលទាំងឡាយអាចនឹងធ្វើឲ្យខ្លួនឯងជួបនឹងគ្រោះថ្នាក់អ្វីខ្លះ ដោយការបដិសេធការព្រមាន និងពាក្យទូន្មានបែបនេះមកពីពួកព្យាការី ?

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:២២–២៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលបានប្រាប់ដល់ពួកមនុស្សនៅលើសំពៅនោះអំពីអ្វីខ្លះ ។

- ប្រសិនបើអ្នកនៅលើសំពៅនោះកណ្តាលព្យុះភ្លៀងដ៏គួរឲ្យរន្ធត់ តើពាក្យរបស់ប៉ុលមួយណាដែលនឹងជួយលួងលោមចិត្តអ្នក ?
- តើប៉ុលបានព្យាករថានឹងមានអ្វីកើតឡើងដល់សំពៅនោះ ?

សូមសង្ខេប កិច្ចការ ២៧:២៧–៣០ ដោយពន្យល់ថា នៅយប់ទី ១៤ នៃព្យុះនោះ ក្រុមនាវិកបានបោះយុថ្កាចំនួនបួនចូលទៅក្នុងសមុទ្រ ដើម្បីការពារសំពៅកុំឲ្យបោកទៅត្រូវនឹងថ្ម ។ បន្ទាប់មក ក្រុមនាវិកនោះបានទៅខាងមុខសំពៅ ហើយធ្វើសកម្មភាពទំនងដូចជាពួកគេបានត្រៀមបោះយុថ្កាបន្ថែមទៀត ។ ប៉ុន្តែ តាមពិតពួកគេកំពុងត្រៀមបោះបង់សំពៅនោះចោល ហើយគៀសខ្លួនជាមួយនឹងទូកតូចមួយ ដោយសារពួកគេភ័យខ្លាចថា សំពៅនោះនឹងលិច ។

សូមអញ្ជើញសិស្សម្នាក់អាន កិច្ចការ ២៧:៣១–៣២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមានដែលប៉ុលបានផ្តល់ដល់មេទ័ព និងពួកទាហានទាំងនោះ៖ ។ សូមពន្យល់ថា ពាក្យ *ពួកនោះ* នៅក្នុង ខទី ៣១ សំដៅទៅលើក្រុមនាវិកដែលព្យាយាមគេចខ្លួន ។

- តើការព្រមានអ្វីខ្លះដែលប៉ុលបានផ្តល់ទៅមេទ័ព និងពួកទាហាននោះ៖ ?
- តើពួកទាហាននោះបានឆ្លើយតបចំពោះការព្រមាន និងពាក្យទូន្មានរបស់ប៉ុលយ៉ាងដូចម្តេច ? (ពួកគេបានស្តាប់តាមការព្រមានរបស់លោក ហើយបានរារាំងពួកនាវិកពីការគេចខ្លួន ដោយការកាត់ខ្សែព្យួរទូកតូចនោះ ហើយបណ្តោយឲ្យវាអណ្តែតទៅតែឯង) ។

សូមសង្ខេប កិច្ចការ ២៧:៣៣–៤៤ ដោយពន្យល់ថា ប៉ុលបានណែនាំថា មនុស្សគ្រប់គ្នានៅលើសំពៅនោះត្រូវបរិភោគអាហារខ្លះដើម្បីមានកម្លាំង ។ ក្រោយមកនៅថ្ងៃដដែលនោះ៖ សំពៅនោះបានបុកដីដោយសារវាបានបើកសំដៅទៅកាន់ដីគោក ប៉ុន្តែមនុស្សទាំងអស់បានគេចខ្លួនដោយសុវត្ថិភាព ។ សូមរំឭកសិស្សអំពីការព្យាករបស់ប៉ុលដែលបានកត់ត្រាទុកនៅក្នុងកិច្ចការ ២៧:២២–២៦ ថាគ្មាននរណាម្នាក់នឹងត្រូវស្លាប់ឡើយ ថ្វីបើសំពៅនោះត្រូវលិចក្តី ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះក្នុងដំណើររឿងនេះ៖ អំពីអ្វីដែលអាចកើតឡើង ប្រសិនបើយើងបានស្តាប់តាមពាក្យទូន្មាន និងការព្រមានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ ? (សិស្សអាចកេរឃើញគោលការណ៍ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោមនេះ៖ **ប្រសិនបើយើងស្តាប់តាមពាក្យទូន្មាន និងការព្រមានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងបំពេញការសន្យារបស់ទ្រង់ចំពោះយើង ។ ប្រសិនបើយើងស្តាប់តាមពាក្យទូន្មាន និងការព្រមានរបស់ពួកអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងអាចទប់ទល់នឹងគ្រោះថ្នាក់ដែលគំរាមកំហែងយើងបាន ។** សូមសរសេរគោលការណ៍ទាំងនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់អំពីគោលការណ៍ ដែលពួកគេបានរកឃើញនៅក្នុង កិច្ចការ ២៧ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយ ៖



« គ្រប់ពេលនៅក្នុងជីវិតរបស់ខ្ញុំ នៅពេលខ្ញុំបានជ្រើសរើសពន្យារពេលធ្វើតាមពាក្យទូន្មានដ៏បំផុសគំនិត ឬសម្រេចចិត្តថា ខ្ញុំដាមនុស្សដែលត្រូវបានលើកលែង នោះខ្ញុំបានដឹងថា ខ្ញុំធ្វើឲ្យខ្លួនឯងស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ហើយ ។ គ្រប់ពេលដែលខ្ញុំបានស្តាប់តាមការទូន្មានរបស់ព្យាការី ខ្ញុំទទួលអារម្មណ៍បញ្ជាក់នៅក្នុងការអធិស្ឋាន ហើយពេលខ្ញុំបានធ្វើតាម នោះខ្ញុំបានរកឃើញថា ខ្ញុំបានឆ្ពោះទៅទីសុវត្ថិភាពហើយ » (« Finding Safety in Counsel » *Ensign* ខែឧសភា ឆ្នាំ ១៩៩៧ ទំព័រ ២៥) ។

- តើការស្តាប់តាមការព្រមាន និងពាក្យទូន្មានរបស់ពួកអ្នកមប្រើរបស់ព្រះអម្ចាស់បានជួយអ្នកឲ្យទប់ទល់នឹងគ្រោះថ្នាក់ ដែលគំរាមកំហែងដល់សុវត្ថិភាពខាងវិញ្ញាណ និងខាងសាច់ឈាមរបស់អ្នកយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេកំពុងតែបដិសេធការព្រមាន ឬពាក្យទូន្មានណាមួយមកពីពួកអ្នកបម្រើរបស់ព្រះអម្ចាស់ដែរឬទេ ឬគិតពីវិធីមួយដែលពួកគេអាចស្តាប់តាមការព្រមាន និងពាក្យទូន្មានដែលពួកគេបានទទួលឲ្យកាន់តែប្រសើរឡើង ។ សូមអញ្ជើញពួកគេឲ្យសរសេរអំពីគោលការណ៍មួយទាក់ទងនឹងរបៀប ដែលពួកគេនឹងស្តាប់តាមពាក្យទូន្មាននោះឲ្យកាន់តែប្រសើរឡើង ។

មេរៀនបន្ទាប់ (រ៉ូម ៨–កូរិនថូសទី១ ៦)

សូមពន្យល់សិស្សថា នៅពេលពួកគេសិក្សា រ៉ូម ៨–១៦ និង កូរិនថូសទី១ ១–៦ នៅសប្តាហ៍ក្រោយ ពួកគេនឹងរៀនអំពីពាក្យទូន្មានដ៏ឆ្លាតវៃ ដែលសាវកប៉ុលបានផ្តល់ទៅសមាជិកសាសនាចក្រនៅរ៉ូម និងកូរិនថូស ដើម្បីជួយពួកគេឲ្យខិតចូលកាន់តែជិតព្រះ៖នៅក្នុងពិភពលោកដ៏ទុច្ចរិត ហើយពោរពេញដោយបញ្ហា ។ ចូរសុំពួកគេឲ្យរកមើលចម្លើយចំពោះសំណួរខាងក្រោម ៖ ហេតុអ្វីរូបកាយយើងប្រៀបបាននឹងព្រះវិហារបរិសុទ្ធ ? តើសមាជិកសាសនាចក្រគួរដោះស្រាយភាពខុសគ្នាជាមួយគ្នាយ៉ាងដូចម្តេច ?

រ៉ូម ៨–១១

សេចក្តីផ្តើម

ប៉ុលបានបង្រៀនអំពីពរជ័យនៃការកើតជាថ្មីខាងវិញ្ញាណ និងការចុះចូលតាមព្រះទ័យរបស់ព្រះវរបិតាសួគ៌ ។ លោកក៏បានបង្រៀនផងដែរអំពីការបដិសេធសេចក្តីសញ្ញានៃព្រះរបស់អ៊ីស្រាអែល និងអំពីការផ្សាយដំណឹងល្អនៅក្នុងចំណោមពួកសាសន៍ដទៃ ។

យោបល់សម្រាប់ការបង្រៀន

រ៉ូម ៨

ប៉ុលបានពិពណ៌នាអំពីពរជ័យនៃការកើតជាថ្មីខាងវិញ្ញាណ

សូមចាប់ផ្តើមមេរៀនដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើការគ្រងមរតកជាអ្វី ?
- ប្រសិនបើអ្នកអាចគ្រងទ្រព្យសម្បត្តិរបស់នរណាម្នាក់ តើអ្នកជ្រើសរើសគ្រងសម្បត្តិរបស់នរណា ? ហេតុអ្វី ?
- តើនរណាទៅដែលគ្រងមរតករបស់មនុស្សម្នាក់នោះ ?

ចូរសុំឲ្យសិស្សពិចារណាអំពីពរជ័យ ដែលមនុស្សម្នាក់អាចទទួល ក្នុងនាមជាអ្នកគ្រងមរតកម្នាក់នៅរាល់អ្វីៗដែលព្រះវរបិតាសួគ៌មាន ។ នៅពេលសិស្សសិក្សា រ៉ូម ៨:១–១៨ សូមអញ្ជើញពួកគេឲ្យរកមើលថា យើងត្រូវធ្វើអ្វីខ្លះដើម្បីគ្រងមរតកនៅរាល់អ្វីៗ ដែលព្រះវរបិតាសួគ៌មាន ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង រ៉ូម ៨:១, ៥–៧, ១៣ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីការដើរ « តាមសាច់ឈាម » ឬងាកទៅរកទំនោរធ្វើអំពើបាប និងការដើរតាម « ព្រះវិញ្ញាណ » (ខទី ៥) ។

- **តើ « គំនិតខាងសាច់ឈាម » មានន័យដូចម្តេច ? (ខទី ៦) ។ (ការផ្តោតលើការបំពេញភាពត្រេកត្រអាល និងតណ្ហានៃរូបកាយ) ។**
- **តើ « គំនិតនៃព្រះវិញ្ញាណ » មានន័យដូចម្តេច ? (ខទី ៦) ។**

សូមពន្យល់ថាការ « សម្លាប់អំពើរបស់រូបសាច់ចេញ » (ខទី ១៣) មានន័យថា ការសម្លាប់ ឬបង្ក្រាបភាពទន់ខ្សោយ ការល្បួង និងអំពើបាបដែលទាក់ទងនឹងរូបកាយយើង (សូមមើល . ម៉ូសាយ ៣:១៩) ។

- **តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុង ខទី ១៣ អំពីអ្វីដែលអាចជួយយើងឲ្យយកឈ្នះលើទំនោរនៃមនុស្សខាងសាច់ឈាមក្នុងការធ្វើអំពើបាប ? (សូមជួយសិស្សឲ្យរកឃើញនូវគោលការណ៍ដូចតទៅនេះ ៖ ប្រសិនបើយើងធ្វើតាមព្រះចេស្តានៃព្រះវិញ្ញាណ នោះយើងអាចយកឈ្នះលើទំនោរនៃការធ្វើអំពើបាបរបស់មនុស្សខាងសាច់ឈាមបាន ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។**

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ៨:១៤–១៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្សេងតាមរកមើលថា ប៉ុលបានលើកឡើងបែបណាចំពោះជនដែលធ្វើតាមព្រះវិញ្ញាណ ។

- **តើប៉ុលបានលើកឡើងបែបណាចំពោះជនដែលធ្វើតាមព្រះវិញ្ញាណ ? (សូមពន្យល់ថាពាក្យ *ពួកកូន* នៅក្នុងបរិបទនេះមានន័យថា ទាំងកូនប្រុស និងកូនស្រី [សូមមើល គ. និង ស. ២៥:១]) ។**

ចូរចង្អុលបង្ហាញថា ឃ្លា « និស្ស័យជាកូនចិញ្ចឹម » (ខទី ១៥) ។ សូមពន្យល់ថា ពាក្យ « វិញ្ញាណយើង » (ខទី ១៦) មានន័យថា រូបកាយវិញ្ញាណរបស់យើងត្រូវបានបង្កើតឡើងដោយព្រះវរបិតាសួគ៌ ហើយធ្វើឲ្យមនុស្សគ្រប់រូបក្លាយជាកូនវិញ្ញាណរបស់ព្រះវរបិតាសួគ៌ ។ ទោះជាយ៉ាងក៏ដោយ មានតែតាមរយៈការចុះសេចក្តីសញ្ញាជាមួយនឹងព្រះតាមរយៈពិធីបរិសុទ្ធនានា ហើយរក្សាសេចក្តីសញ្ញាទាំងនោះប៉ុណ្ណោះ ទើបមនុស្សមានការកើតជាថ្មីខាងវិញ្ញាណ ឬត្រូវបានទទួលចិញ្ចឹមជាបុត្រាបុត្រីរបស់ទ្រង់នៅក្នុងសេចក្តីសញ្ញានៃដំណឹងល្អ ។ ភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធចង្អុលបង្ហាញថា មនុស្សបែបនេះពុំមែនគ្រាន់តែជាកូនវិញ្ញាណរបស់ព្រះដោយគុណធម៌នៃការបង្កបង្កើតប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ជាកូនចៅនៃសេចក្តីសញ្ញារបស់ទ្រង់ផងដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ៨:១៧–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថា កូនចៅនៃសេចក្តីសញ្ញារបស់ព្រះអាចប្រែក្លាយជាអ្វី ។

- **តើកូនចៅនៃសេចក្តីសញ្ញារបស់ព្រះអាចប្រែក្លាយជាអ្វី ? (សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ដោយទុកចន្លោះត្រង់កន្លែងពាក្យ *ស្មោះត្រង់* ៖ ប្រសិនបើយើងជាកូនចៅដ៏ស្មោះត្រង់នៃសេចក្តីសញ្ញារបស់ព្រះ នោះយើងអាចគ្រងមរតកជាមួយនឹងព្រះយេស៊ូវគ្រីស្ទនូវអ្វីៗដែលព្រះវរបិតាសួគ៌មាន) ។**

- តើអ្នកត្រងមរតកជាមួយមានន័យដូចម្តេច ? (មនុស្សម្នាក់ដែលទទួលបានមរតកស្មើនឹងអ្នកត្រងមរតកផ្សេងទៀត) ។
- យោងតាម ខទី ១៧តើកូនចៅនៃសេចក្តីសញ្ញារបស់ព្រះត្រូវធ្វើអ្វីខ្លះ ដើម្បីក្លាយជាអ្នកត្រងមរតកជាមួយនឹងព្រះគ្រីស្ទ ?

សូមពន្យល់ថា « រងទុក្ខជាមួយនឹង [ព្រះយេស៊ូវគ្រីស្ទ] » (ខទី ១៧) ពុំមែនមានន័យថា យើងរងទុក្ខនូវអ្វីដែលព្រះអង្គសង្គ្រោះបានរងទុក្ខ ដែលជាផ្នែកមួយនៃពលិកម្មធួនរបស់ទ្រង់នោះទេ ។ ផ្ទុយទៅវិញ ដូចជាព្រះអង្គសង្គ្រោះដែរ យើងត្រូវបោះបង់ចោលនូវគ្រប់ទាំងអំពើដ៏ឥតបរិសុទ្ធ បែរមកគោរពព្រះបញ្ញត្តិ ហើយស៊ូទ្រាំនឹងការផ្ទុយដោយស្មោះត្រង់ (សូមមើល ម៉ាថាយ ១៦:២៤, ការបកប្រែដោយ យ៉ូសែប ស៊្មីធ, ម៉ាថាយ ១៦:២៦ [នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ]) ។ សូមបន្ថែមពាក្យ*ស្មោះត្រង់*ដើម្បីបំពេញគោលការណ៍នៅលើក្តារខៀន ។ សូមគូសតារាងមួយដែលមានជួរឈរបីនៅលើក្តារខៀន ។ សូមសរសេរចំណងជើងជួរឈរទីមួយថា *កិច្ចតម្រូវ* ជួរឈរកណ្តាល *ការផ្ទុយ* និងជួរឈរទីបីថា *មរតក* ។ ចូរសរសេរចម្លើយរបស់សិស្សចំពោះសំណួរខាងក្រោមនេះនៅក្នុងជួរឈរដែលសមរម្យ ។

- តើទង្វើអ្វីខ្លះ ដែលយើងត្រូវតម្រូវឲ្យធ្វើដើម្បីត្រូវបានចាត់ទុកថាជាកូនចៅនៃសេចក្តីសញ្ញាដ៏ស្មោះត្រង់របស់ព្រះ ?
- តើឧទាហរណ៍នៃការផ្ទុយដែលយើងអាចជួប នៅពេលយើងខិតខំរស់នៅធ្វើជាកូនចៅនៃសេចក្តីសញ្ញាដ៏ស្មោះត្រង់របស់ព្រះនោះមានអ្វីខ្លះ ?
- តើយើងអាចទទួលបានពរជ័យអ្វីខ្លះពីព្រះវរបិតាសួគ៌ ប្រសិនបើយើងខិតខំរស់នៅធ្វើជាកូនចៅនៃសេចក្តីសញ្ញាដ៏ស្មោះត្រង់របស់ព្រះនោះ ? (ចម្លើយមួយដែលអាចមានគឺថា យើងអាចប្រែក្លាយដូចជាព្រះវរបិតាសួគ៌) ។

ចូរសុំឲ្យសិស្សពិចារណាអំពីបញ្ជីនៅលើក្តារខៀន ។

- បន្ទាប់ពីអានការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ១៨រួចហើយ តើអ្នកគិតថាកិច្ចតម្រូវចំពោះការត្រងមរតកជាមួយនឹងព្រះគ្រីស្ទមានលក្ខណៈបែបណាដែរ ប្រសិនបើប្រៀបធៀបនឹងពរជ័យនានា ? ហេតុអ្វី ?

សូមពន្យល់ថា នៅក្នុង រ៉ូម ៨:១៩–៣០ យើងអានថា ប៉ុលបានបង្រៀនថា ព្រះវិញ្ញាណជួយយើងនៅក្នុងភាពទន់ខ្សោយរបស់យើង ហើយជួយយើងឲ្យស្គាល់អ្វីដែលត្រូវអធិស្ឋានទូលសូម ។ យើងក៏អានផងដែរថា ព្រះយេស៊ូវគ្រីស្ទត្រូវបានហៅមកនៅក្នុងជីវិតមុនផែនដីនេះ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះនៃកូនចៅរបស់ព្រះ (សូមមើល ការបកប្រែដោយ យ៉ូសែប ស៊្មីធ, រ៉ូម ៨:២៩–៣០) ។

កំណត់ចំណាំ ៖ នៅក្នុង រ៉ូម ៨:២៩–៣០ ពាក្យ *តម្រូវទុកជាមុន* មានន័យថាតែងតាំង ឬហៅពីមុន ។ សិស្សនឹងសិក្សាការបង្រៀនមួយចំនួនរបស់ប៉ុលស្តីពីការតែងតាំងពីមុន នៅក្នុងមេរៀនអំពី អេភេសូរ ១ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង រ៉ូម ៨:២៨, ៣១–៣៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះអំពីសេចក្តីស្រឡាញ់របស់ព្រះ ដែលពាក់ព័ន្ធនឹងការផ្ទុយ ការប្រឈមមុខ និងទុក្ខវេទនានៅក្នុងជីវិតរមែងស្លាប់ ។ ចូរចង្អុលបង្ហាញថា ការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ រ៉ូម ៨:៣១ បានប្តូរឃ្លា « ទាស់នឹង » ទៅជា « ឈ្នះ » ។

- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងរកឃើញសេចក្តីពិតផ្សេងៗគ្នា រួមបញ្ចូលទាំងគោលការណ៍ខាងក្រោមផងដែរ ៖ **ប្រសិនបើយើងស្រឡាញ់ព្រះ នោះគ្រប់ការណ៍ទាំងអស់នឹងរួមគ្នា សម្រាប់សេចក្តីល្អដល់យើង ។ យើងអាចយកឈ្នះលើការប្រឈមមុខ និង សេចក្តីឈឺចាប់ទាំងអស់នៅក្នុងជីវិតរមែងស្លាប់តាមរយៈព្រះយេស៊ូវគ្រីស្ទ ។ គ្មានអ្វីអាចបំបែកយើងពីសេចក្តីស្រឡាញ់របស់ព្រះ ដែលបានបង្ហាញឲ្យឃើញនៅក្នុងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបានឡើយ**) ។
- តើព្រះយេស៊ូវគ្រីស្ទ និងការបង្រៀនរបស់ទ្រង់អាចជួយយើងឲ្យយកឈ្នះលើការប្រឈមមុខ និងទុក្ខវេទនានៅក្នុងជីវិតរមែងស្លាប់នេះបានយ៉ាងដូចម្តេច ?
- ដោយពិចារណាអំពីការប្រឈម និងទុក្ខវេទនាក្នុងជីវិតរមែងស្លាប់ដែលអ្នកធ្លាប់ជួប តើប្រយោគណាមួយនៅក្នុងខគម្ពីរទាំងនេះដែលអ្នកគិតថាសំខាន់ ? ហេតុអ្វី ?
- តើអ្នកធ្លាប់ដកពិសោធន៍អំពីសេចក្តីស្រឡាញ់របស់ព្រះនៅក្នុងចំណោមការប្រឈមមុខ និងទុក្ខវេទនារបស់អ្នកយ៉ាងដូចម្តេចដែរ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកត់ចំណាំការរៀនសូត្ររបស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវអ្វីដែលពួកគេត្រូវបានបំផុសគំនិតឲ្យធ្វើ ដើម្បីពួកគេអាចយកឈ្នះលើការប្រឈម និងទុក្ខវេទនាទាំងឡាយរបស់ពួកគេតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។

ការសួរសំណួរ និងការអញ្ជើញដែលលើកទឹកចិត្តឲ្យមានការអនុវត្ត

នៅទីបំផុត គោលដៅនៃការបង្រៀនដ៏ណឹងល្អ គឺដើម្បីជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលមាននៅក្នុងបទគម្ពីរ ហើយបានផ្លាស់ប្តែរចិត្តជឿ និងទទួលពរជ័យដែលបានសន្យាដល់អស់អ្នកណាដែលស្មោះត្រង់ ហើយគោរពប្រតិបត្តិតាមព្រះ ។ សំណួរដែលលើកទឹកចិត្តឲ្យមានការអនុវត្តអាចដើរតួយ៉ាងសំខាន់មួយ នៅក្នុងការជួយសិស្សឲ្យមើលឃើញអំពីរបៀប ដែលពួកគេអាចអនុវត្តគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

រ៉ូម ៩–១១

ប៉ុលបង្រៀនផងដែរអំពីការបដិសេធសេចក្តីសញ្ញារបស់ព្រះ និងការផ្សាយដំណឹងល្អដល់ពួកសាសន៍ដទៃ

ចូរសុំសិស្សឲ្យពិចារណាថាពួកគេនឹងប្រព្រឹត្តតបចំពោះសាច់រឿងខាងក្រោមនេះដោយរបៀបណា ៖

១. អ្នកអមដំណើរជាមួយបីស្បូរបស់អ្នកទៅសួរសុខទុក្ខយុវជនម្នាក់ ដែលមានគ្រួសារសកម្មនៅក្នុងសាសនាចក្រ ប៉ុន្តែគាត់អសកម្ម ។ នៅពេលបីស្បូរបស់អ្នកព្យាយាមជួយយុវជននោះឲ្យយល់អំពីជំនឿជាក់នៃការមិនរស់នៅតាមដំណឹងល្អ យុវជននោះបានពោលថា « កុំបារម្ភអី ។ ខ្ញុំជ្រមុជទឹករួចហើយ ហើយឪពុកម្តាយខ្ញុំជាសមាជិកសកម្មទៀត ។ ព្រះនឹងមិនដកយកពរជ័យចេញពីខ្ញុំនោះទេ » ។

២. ថ្មីៗនេះអ្នកបានសេពគប់នឹងយុវនារីម្នាក់ដែលមានជំនឿផ្សេង ។ នាងសួរអំពីបទដ្ឋានដែលអ្នករស់នៅតាម ។ បន្ទាប់ពីអ្នករៀបរាប់អំពីបទដ្ឋានមួយចំនួនរបស់ព្រះអម្ចាស់ហើយ នាងពោលថា « ខ្ញុំមិនយល់ទេ ហេតុអ្វីអ្នកធ្វើរឿងទាំងអស់នេះ ។ អ្វីដែលអ្នកត្រូវធ្វើដើម្បីឲ្យបានសង្គ្រោះនោះ គឺជឿលើព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះជាការស្រេច » ។

នៅពេលសិស្សសិក្សា រ៉ូម ៩–១១ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត ដែលអាចជួយពួកគេឲ្យយល់ថា ការទទួលបានពរជ័យនៃដំណឹងល្អតម្រូវឲ្យមានអ្វីខ្លះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពន្យល់អំពីការបង្រៀនរបស់ប៉ុលនៅក្នុង រ៉ូម ៩–១១ដូចតទៅនេះ ៖

ដូចដែលបានកត់ត្រានៅក្នុង រ៉ូម ៩–១១ ប៉ុលបានប្រើពាក្យ *អ៊ីស្រាអែល* និង *សាសន៍អ៊ីស្រាអែល* ជំនួសឲ្យពាក្យ *សាសន៍យូដា* នៅក្នុងការពិភាក្សាអំពីការជ្រើសរើស ដែលពួកសាសន៍យូដាជាច្រើនបានធ្វើ ។ ពេលខ្លះ កូនចៅនៃសេចក្តីសញ្ញារបស់ព្រះគឺសំដៅទៅលើវង្សអ៊ីស្រាអែល ។ នៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ព្រះបានជ្រើសព្ងជពង្សយ៉ាកុប ឬអ៊ីស្រាអែល ជាផ្នែកមួយនៃសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងអ័ប្រាហាំ (សូមមើល រ៉ូម ៩:៤–៥) ដែលបានដាក់បញ្ចូលនូវពរជ័យដ៏អស្ចារ្យ ដូចជាដំណឹងល្អ សិទ្ធិអំណាចបព្ងជិតភាព ជីវិតដ៏នៅអស់កល្បជានិច្ច កូនចៅអស់កល្បជានិច្ច ដែនដីមរតក និងការទទួលខុសត្រូវក្នុងការផ្តល់ពរជ័យដល់ពិភពលោកជាមួយនឹងដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ៩:៦, ៨ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះ អំពីសមាជិកនៃវង្សអ៊ីស្រាអែល ។

- តើអ្នកគិតថា ប៉ុលចង់មានន័យយ៉ាងណាដោយពោលថា « មិនមែនអស់អ្នកដែលកើតក្នុងសាសន៍អ៊ីស្រាអែល ជាសាសន៍អ៊ីស្រាអែលពិតនោះឡើយ » ? (ខទី ៦) ។ (ពួកសាសន៍យូដាជាច្រើនបានទុកចិត្តទាំងខុសឆ្គងថា តំណពូជពង្សរបស់ពួកគេតាមអ័ប្រាហាំនឹងធានាអះអាងដល់ពួកគេចំពោះពរជ័យនៃសេចក្តីសញ្ញានោះ) ។

សូមពន្យល់ថា នៅក្នុង រ៉ូម ៩:២៥–៣០ យើងអានថា ប៉ុលបានបង្រៀនថា ពួកសាសន៍ដទៃដែលបានចូលក្នុងសាសនាចក្រអាចទទួលបានរាល់ពរជ័យនៃសេចក្តីសញ្ញា ហើយប្រែក្លាយទៅជាមនុស្សសុចរិតដោយអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។

ចូរសុំឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង រ៉ូម ៩:៣១–៣៣, ១០:១–៤ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអំពីរបៀបដែលពួកសាសន៍អ៊ីស្រាអែលមួយចំនួននៅក្នុងសម័យរបស់ប៉ុលបានខិតខំប្រែក្លាយទៅជាមនុស្សសុចរិតនៅចំពោះព្រះ ។ សូមពន្យល់ថា « ក្រឹត្យវិន័យដ៏សុចរិត » (រ៉ូម ៩:៣១) សំដៅទៅលើក្រឹត្យវិន័យរបស់ម៉ូសេ, « ថ្មជំពប់ » (រ៉ូម ៩:៣២, ៣៣) គឺជាព្រះយេស៊ូវគ្រីស្ទ និង « សេចក្តីសុចរិតនៃព្រះ » (រ៉ូម ១០:៣) សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ។

- យោងតាម រ៉ូម ៩:៣១–៣៣ តើពួកសាសន៍អ៊ីស្រាអែលមួយចំនួននៅក្នុងសម័យរបស់ប៉ុល បានខិតខំប្រែក្លាយជាមនុស្សសុចរិតនៅចំពោះព្រះតាមរបៀបណា ? (តាមរយៈការធ្វើកិច្ចការនៅក្នុងក្រឹត្យវិន័យរបស់ម៉ូសេដ៏តឹងរឹង) ។
- យោងតាម រ៉ូម ១០:៣–៤ តើពួកសាសន៍អ៊ីស្រាអែលបានបដិសេធអ្វី ? (ព្រះយេស៊ូវគ្រីស្ទ និងសេចក្តីសុចរិតអាចកើតមានឡើងតាមរយៈទ្រង់) ។

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង រ៉ូម ១០:៨–១៣ ប៉ុលបានពន្យល់ « សេចក្តីសុចរិត ដែលមកដោយសារសេចក្តីជំនឿ » (រ៉ូម ៩:៣០) អាចទទួលយកបាន ។ សូមអញ្ជើញសិស្សបួនប្រាំនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង រ៉ូម ១០:៨–១៣ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀប ដើម្បីទទួលបានសេចក្តីសុចរិតនេះ ។

- តើមនុស្សម្នាក់ត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានសេចក្តីសុចរិតដែលកើតចេញពីសេចក្តីជំនឿ ?

សូមពន្យល់ថា ពាក្យក្រិកដែលប្រែមកថា *សារភាព* នៅក្នុង ខទី ៩ ចង្អុលបង្ហាញអំពីការទទួលស្គាល់ដោយបើកចំហរមួយនៃការទទួលយក ឬមានន័យថាសេចក្តីសញ្ញា ហើយពាក្យក្រិក ដែលប្រែថា *ជឿ* ចង្អុលបង្ហាញអំពីការតាំងចិត្តដ៏ជឿជាក់មួយ ។ ទំនុកចិត្តដ៏ជ្រាលជ្រៅលើព្រះអង្គសង្គ្រោះនេះ បានដឹកនាំមនុស្សឲ្យទទួលស្គាល់ការទទួលយករបស់ពួកគេចំពោះទ្រង់ដោយឥតលាក់លាម តាមរបៀបដែលទ្រង់បានតាំងឡើង ។ របៀបដែលបានត្រូវតាំងឡើងទាំងនេះរួមបញ្ចូលទាំងការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ ការប្រែចិត្ត និងការទទួលយកពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ ដូចជាពិធីបុណ្យជ្រមុជទឹក និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

- យោងតាមការបង្រៀនរបស់ប៉ុល តើយើងត្រូវធ្វើអ្វីខ្លះ ប្រសិនបើយើងប្រាថ្នាចង់ទទួលបានពរជ័យនៃសេចក្តីសញ្ញារបស់ព្រះ រួមទាំងសេចក្តីសង្គ្រោះនោះផងដែរ ? (សូមជួយសិស្សឲ្យរកឃើញនូវគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងទទួល ហើយប្រតិបត្តិតាមព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ នោះយើងអាចទទួលបានពរជ័យនៃសេចក្តីសញ្ញារបស់ព្រះ ហើយត្រូវបានសង្គ្រោះ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ចូរចង្អុលបង្ហាញថា មានមនុស្សខ្លះធ្លាប់ប្រើ រ៉ូម ១០:៩, ១៣ ដើម្បីប្រកាសថា អ្វីទាំងអស់ដែលយើងត្រូវធ្វើដើម្បីបានសង្គ្រោះ គឺការសារភាពជាពាក្យសម្តីពីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ។ ចូរអំពុកសិស្សអំពីសាច់រឿង ដែលបានលើកឡើងខាងដើមនៃមេរៀននេះ ។

- តើសេចក្តីពិតនៅក្នុងមេរៀននេះអាចជួយយើងឲ្យឆ្លើយតបនឹងសាច់រឿងទាំងនេះបានយ៉ាងដូចម្តេច ?

សូមសង្ខេបផ្នែកនៅសល់ក្នុង រ៉ូម ១០–១១ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា ការស្តាប់ព្រះបន្ទូលព្រះ គឺជារឿងដ៏សំខាន់ចំពោះការអភិវឌ្ឍសេចក្តីជំនឿលើព្រះគ្រីស្ទ ។ លោកបានប្រើរឿងប្រៀបធៀបមួយអំពីការផ្សាំមែកដើមអូលីវព្រៃទៅនឹងដើមអូលីវស្រុក ដើម្បីតំណាងឲ្យការដាក់បញ្ចូលពួកសាសន៍ដទៃទៅក្នុងវង្សអ៊ីស្រាអែល (សូមមើល យ៉ាកុប ៥:៣–១៤) ។ លោកក៏បានបង្រៀនផងដែរថា ដំណឹងល្អនឹងផ្តល់ទៅឲ្យពួកសាសន៍យូដាម្តងទៀត ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

រ៉ូម ១២–១៦

សេចក្តីផ្តើម

ប៉ុលបានបង្រៀនសមាជិកសាសនាចក្រនៅរ៉ូម ឲ្យចាត់ទុករូបកាយរបស់ពួកគេជាយញ្ញបូជារស់ថ្វាយព្រះ ហើយគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ។ ប៉ុលក៏បានបង្រៀនពួកបរិសុទ្ធផង ដែរពីរបៀបលើកកម្ពស់ឲ្យមានសេចក្តីសុខសាន្ត នៅពេលការខ្វែងគំនិតគ្នាបានកើតឡើង ដោយសារតែចំណង់ចំណូលចិត្តផ្ទាល់ខ្លួន ។ នៅពេលបញ្ចប់សំបុត្រនេះ ប៉ុលបានព្រមានដល់ជនដែលចង់ធ្វើការបោកបញ្ឆោត ។

យោបល់សម្រាប់ការបង្រៀន

រ៉ូម ១២–១៣

ប៉ុលបង្រៀនសមាជិកសាសនាចក្រឲ្យចាត់ទុករូបកាយរបស់ពួកគេ ជាយញ្ញបូជារស់ថ្វាយព្រះ ហើយឲ្យគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ។

ចូរយកធុងទឹកពីរដែលមានរាងខុសគ្នា និងពែងទឹកមួយមកថ្នាក់រៀន ។ ចូរដាក់បង្ហាញទឹក និងធុងមួយ ។

- ប្រសិនបើខ្ញុំចាក់ទឹកចូលទៅក្នុងធុងនេះ តើរាងរបស់ទឹកនេះនឹងផ្លាស់ប្តូរយ៉ាងដូចម្តេច ? (វានឹងមានរាងទៅតាមរាងនៃធុងនោះ) ។

ចូរចាក់ទឹកចូលទៅក្នុងធុងនោះ ។ បន្ទាប់មក ចូរចាក់ទឹកចូលទៅក្នុងធុងទីពីរ ហើយចង្អុលបង្ហាញពីរបៀបដែលទឹកនោះមានរាងទៅតាមរាងនៃធុងនោះ ។

សូមពន្យល់ថា នៅក្នុងការបង្ហាញនេះ ទឹកតំណាងឲ្យមនុស្ស ហើយធុងតំណាងឲ្យជំនឿ និងទម្លាប់ខុសៗគ្នានៅក្នុងលោកិយ ។

- តើគ្រោះថ្នាក់អ្វីខ្លះដែលអាចកើតចេញពីការអនុលោមទៅតាមជំនឿ និងទម្លាប់ខាងលោកិយជាបន្តបន្ទាប់នោះ ?

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ១២:១–២ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធនៅរ៉ូមធ្វើអ្វីខ្លះ ។

- តើប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធនៅរ៉ូមធ្វើអ្វីខ្លះ ?

សូមពន្យល់ថា នៅក្នុងទម្ទូចអង្វរឲ្យសមាជិកសាសនាចក្រឲ្យថ្វាយរូបកាយរបស់ពួកគេជា « យញ្ញបូជារស់ » (ខទី ១) ប៉ុលកំពុងតែប្រៀបធៀបទៅនឹងទម្លាប់នៃការបូជាយញ្ញសត្វនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ។ សត្វទាំងនេះគឺជាដង្វាយថ្វាយដល់ព្រះ ។

- តើអ្នកគិតថា ប៉ុលបានមានន័យយ៉ាងណា នៅពេលលោកបានសរសេរថា « ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ . . . ដល់ព្រះ » ? (ខទី ១) ។ (សមាជិកសាសនាចក្រត្រូវថ្វាយខ្លួនទាំងស្រុងដល់ព្រះ ដោយការលះបង់បំណងប្រាថ្នាដែលមានបាប) ។
- យោងតាមការដាស់តឿនរបស់ប៉ុលនៅក្នុង ខទី ១–២ តើព្រះរំពឹងចង់បានអ្វីពីយើង ? (សូមជួយសិស្សឲ្យស្គាល់ពីសេចក្តីពិតដូចតទៅនេះ ៖ **ព្រះរំពឹងឲ្យយើងលះបង់ជីវិតរបស់យើងថ្វាយទ្រង់ ហើយកុំអនុលោមតាមពិភពលោក ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមពន្យល់ថា នៅក្នុង រ៉ូម ១២–១៣ ប៉ុលបានបង្រៀន សមាជិកសាសនាចក្រអំពីគោលការណ៍ជាច្រើនដែលនឹងជួយពួកគេឲ្យលះបង់ជីវិតរបស់ពួកគេថ្វាយព្រះ ហើយមិនអនុលោមតាមពិភពលោកនោះឡើយ ។ ដើម្បីជួយសិស្សឲ្យស្គាល់ពីគោលការណ៍ទាំងនេះមួយចំនួន សូមចែកសិស្សជាក្រុមដែលមានគ្នាបីនាក់ ។ ចូរផ្តល់ដល់សិស្សម្នាក់ៗនូវក្រដាសមួយសន្លឹកដែលមាន សេចក្តីណែនាំ ខាងក្រោមនេះនៅផ្នែកខាងលើ ។ (ពីមុនថ្នាក់ចាប់ផ្តើម សូមគូសរង្វង់លើសេចក្តីយោងបទគម្ពីរមួយ នៅក្នុងសេចក្តីយោងទាំងបីនៅលើក្រដាសនីមួយៗ ។ ចូរធ្វើឲ្យប្រាកដថា សិស្សម្នាក់ៗនៅក្នុងក្រុមនីមួយៗទទួលបានក្រដាសមួយសន្លឹក ដែលមានសេចក្តីយោងបទគម្ពីរមួយដែលបានគូសរង្វង់ ហើយខុសៗពីគ្នា) ។

រ៉ូម ១២:៩–១៦	រ៉ូម ១២:១៧–២១	រ៉ូម ១៣:៨–១៣

១. អានបទគម្ពីរដែលបានគូសរង្វង់នៅផ្នែកខាងលើនៃក្រដាសនេះ ។

២. ជ្រើសយកការបង្រៀនមួយរបស់ប៉ុលនៅក្នុងបទគម្ពីរដែលអ្នកអាន ហើយសរសេរវានៅក្នុងចន្លោះខាងក្រោម ។ ចូរសរសេរពីរបៀបដែល ការរស់នៅតាមការបង្រៀននេះអាចជួយយើងឲ្យលះបង់ជីវិតរបស់យើងថ្វាយព្រះ ហើយមិនអនុលោមតាមពិភពលោកនេះ ។ (ប្រសិនបើអ្នកពុំមែនជាមនុស្សដំបូងដែលបានទទួលក្រដាសនេះទេ អ្នកអាចបន្ថែមគំនិតរបស់អ្នកទៅលើអ្វីដែលពីមុនអ្នកបានសរសេរនៅខាងក្រោម ឬអ្នកអាចសរសេរអំពីការបង្រៀនមួយទៀតនៅក្នុងខគម្ពីរដែលបានគូសរង្វង់រួចនោះ) ។

គូសបញ្ជាក់មូលដ្ឋានគ្រឹះនៃការបង្រៀន និងការរៀនសូត្រដ៏ណែនាំល្អ

នៅពេលអ្នកបង្រៀន សូមគូសបញ្ជាក់ពីមូលដ្ឋានគ្រឹះនៃការបង្រៀន និងការរៀនសូត្រដ៏ណែនាំល្អ ដូចជាការយល់ដឹងពីបរិបទ និងមាតិការនៃបទគម្ពីរ ការស្គាល់ការយល់ដឹង និងការទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ព្រមទាំងការអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ។ មូលដ្ឋានគ្រឹះទាំងនេះពុំមែនជាវិធីសាស្ត្រដើម្បីយកទៅប្រើនោះទេ ប៉ុន្តែវាជាលទ្ធផលដែលគួរសម្រេចឲ្យបាន ។ វាបង្កើតជាគន្លងមួយឲ្យធ្វើតាមដើម្បីបណ្តុះដំណឹងល្អនៅក្នុងគំនិត និងដួងចិត្តរបស់សិស្ស ។

សូមពន្យល់សិស្សថា ពួកគេនឹងមានពេលបីនាទី ដើម្បីធ្វើសកម្មភាពនេះតាមការណែនាំនៅលើក្រដាសរបស់ពួកគេ ។ លុះអស់ពេលបីនាទីហើយ សូមអញ្ជើញពួកគេឲ្យហុចក្រដាសរបស់ខ្លួនទៅសិស្សម្នាក់ទៀតនៅក្នុងក្រុមរបស់ពួកគេ ។ សូមធ្វើសកម្មភាពម្តងទៀត ដើម្បីឲ្យសិស្សម្នាក់ៗអាន ហើយបញ្ចេញមតិយោបល់ដល់បទគម្ពីរទាំងបីនោះ ។ ចូរជ្រាកដថា សិស្សទទួលបានក្រដាសដើមរបស់ពួកគេត្រឡប់មកវិញ ។

ចូរទុកពេលឲ្យសិស្ស ដើម្បីពិនិត្យឡើងវិញនូវមតិយោបលនៅលើក្រដាសរបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីអ្វីមួយដែលពួកគេបានរៀនពីរបៀបដែលពួកគេអាចលះបង់ជីវិតរបស់ពួកគេថ្វាយព្រះ ហើយមិនអនុលោមតាមពិភពលោកនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ១៣:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានទូន្មានពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ។

- តើអ្នកគិតថា ប៉ុលចង់មានន័យដូចម្តេចដោយពោលឡើងថា « ត្រូវប្រដាប់ខ្លួន ដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទវិញ » ?
- តើការបង្រៀនដែលយើងបានសិក្សានៅក្នុង រ៉ូម ១២–១៣ ជួយយើងឲ្យប្រែក្លាយដូចជាព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមកែសម្រួលសេចក្តីពិតដែលបានសរសេរនៅលើក្តារខៀនកាលពីមុន ដើម្បីឲ្យវាមានសេចក្តីដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងលះបង់ជីវិតរបស់យើងថ្វាយព្រះ ហើយមិនអនុលោមតាមពិភពលោកនេះ នោះយើងអាចប្រែក្លាយកាន់តែដូចជាព្រះយេស៊ូវគ្រីស្ទ**) ។
- តើព្រះអង្គសង្គ្រោះគឺជាគំរូមួយនៃការលះបង់ជីវិតរបស់មនុស្សម្នាក់ថ្វាយព្រះ ហើយមិនអនុលោមតាមពិភពលោកនេះយ៉ាងដូចម្តេច ?
- តើយើងអាចមិនអនុលោមតាមបទដ្ឋានរបស់ពិភពលោកតាមរបៀបណា ? (អ្នកគួរផ្តល់ជាឧទាហរណ៍ជាក់លាក់មួយចំនួនដូចជាការប្រតិបត្តិថ្ងៃឈប់សម្រាក ម៉ូដសំលៀកបំពាក់ ឬប្រហែលជាលើកឡើងពីបញ្ហាខាងវប្បធម៌ ឬសង្គមដែលផ្ទុយនឹងគោលការណ៍នានានៃដំណឹងល្អ) ។

ចូរសុំឲ្យសិស្សគិតពីមនុស្សម្នាក់ដែលពួកគេស្គាល់ ហើយបុគ្គលនោះបានខិតខំលះបង់ជីវិតរបស់ខ្លួនថ្វាយព្រះ ហើយមិនអនុលោមតាមពិភពលោកនេះទេ ។

- តើអ្នកបានគិតអំពីនរណាដែរ ? ហេតុអ្វី ?
- តើបុគ្គលម្នាក់នេះបានក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេពីវិធីមួយ ដែលពួកគេអាចលះបង់ជីវិតរបស់ពួកគេថ្វាយដល់ព្រះ ហើយមិនអនុលោមតាមពិភពលោកនេះ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តតាមអ្វីដែលពួកគេបានសរសេរ ។

រ៉ូម ១៤:១–១៥:៣

ប៉ុលទូន្មានដល់សមាជិកសាសនាចក្រឲ្យចៀសវាងពីការទាស់ទែងគ្នានៅក្នុងបញ្ហាចំណង់ចំណូលចិត្តផ្ទាល់ខ្លួន

សូមឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេចង់ឆ្លើយថា បាទ/ចាសចំពោះសំណួរខាងក្រោមនេះ ។ អ្នកអាចកែប្រែសំណួរមួយចំនួនទាំងនេះ ដើម្បីឲ្យវាឆ្លុះបញ្ចាំងកាន់តែប្រសើរពីវប្បធម៌ដែលអ្នករស់នៅ ។ ប្រសិនបើអ្នកធ្វើដូច្នោះ សូមជ្រើសយកឧទាហរណ៍ដែលសំខាន់ចំពោះការជ្រើសរើសផ្ទាល់ខ្លួន ប៉ុន្តែមិនសំខាន់ចំពោះការគោរពប្រតិបត្តិ ដើម្បីបញ្ជាក់អត្ថន័យច្បាស់លាស់ពីព្រះបញ្ញត្តិ ។ ចម្លើយចំពោះសំណួរទាំងអស់នេះគួរតែជាចម្លើយបាទ/ចាស ។

- តើវាជាជម្រើស សមហេតុ ជលប្ទទេ កាលដែលពួកបរិសុទ្ធថ្ងៃចុងក្រោយម្នាក់ (១) អនុវត្តតាមរបបអាហារឫស ? (២) ហូប សូកូឡា ? (៣) ស្លៀកពាក់ខោខ្លីនៅទីសាធារណៈ ? (៤) ប្រើបច្ចេកវិទ្យានៅថ្ងៃឈប់សម្រាក ? (៥) ចូលរួមបរអរថ្ងៃបុណ្យទិវាជាតិដែលទាក់ទងនឹងសាសនា ឬប្រពៃណីដែល ជា វប្បធម៌ដទៃ ?

សូមពន្យល់ថា កាលតរិយាបថមួយចំនួនបានតម្រូវឲ្យមាន ឬបានហាមឃាត់យ៉ាងច្បាស់ដោយបទបញ្ញត្តិមកពីព្រះ នោះតរិយាបថផ្សេងទៀតធ្វើឡើងដោយសំអាងទៅលើចំណូលចិត្ត ឬការវិនិច្ឆ័យរបស់សមាជិកសាសនាចក្រម្នាក់ៗ ។ បញ្ហាទាំងនេះអាចរួមបញ្ចូលទាំងការជ្រើសរើសមួយចំនួន ដូចជាការកម្សាន្ត សម្លៀកបំពាក់ របបអាហារ ការប្រតិបត្តិថ្ងៃឈប់សម្រាក និងវិន័យរបស់ឪពុកម្តាយសម្រាប់កូនចៅ ។ ព្រះអម្ចាស់បានប្រទានបទដ្ឋាន និងព្រះបញ្ញត្តិដើម្បីដឹកនាំការជ្រើសរើសរបស់យើងនៅក្នុងបញ្ហាទាំងនេះមួយចំនួន ដូចជាការស្លៀកពាក់ខោជើងខ្លីដែលសមរម្យ ប៉ុន្តែការសម្រេចចិត្តមួយចំនួនអាស្រ័យលើការវិនិច្ឆ័យផ្ទាល់ខ្លួន ។ ពេលខ្លះសមាជិកអាចធ្វើការសម្រេចចិត្តបែបនេះ ដោយផ្អែកលើការបំផុសគំនិតសម្រាប់ស្ថានភាព ឬសេចក្តីត្រូវការជាក់លាក់ ។

នៅពេលសិស្សសិក្សា រ៉ូម ១៤:១–១៥:៣ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលប៉ុលបង្រៀនអំពីរបៀបដែលយើងគួរដោះស្រាយបញ្ហាតាមចំណូលចិត្តផ្ទាល់ខ្លួននៅក្នុងសាសនាចក្រ ។

សូមសង្ខេប រ៉ូម ១៤:១–៥ ដោយពន្យល់ថា បញ្ហាមួយនៃចំណូលចិត្តផ្ទាល់ខ្លួន ដែលសមាជិកសាសនាចក្រនៅក្នុងជំនាន់របស់ប៉ុលបានជួបប្រទះ គឺជារបបអាហាររបស់មនុស្សម្នាក់ ។ មនុស្សខ្លះមិនបានធ្វើតាមកម្រិតនៃរបបអាហារនោះទេ ។ មនុស្សផ្សេងទៀតបានតមសាច់ ហើយបរិភោគតែបន្លែប៉ុណ្ណោះ ជាការបន្តមួយនៃច្បាប់របបអាហារនៅក្រោមក្រឹត្យវិន័យរបស់ម៉ូសេ ទោះជាការរឹតបន្តឹងទាំងនេះមិនបានតម្រូវឲ្យធ្វើទៀតក៏ដោយ ។ បន្ថែមពីលើនេះទៀត មានសមាជិកសាសនាចក្រមួយចំនួនបានជ្រើសបន្តប្រតិបត្តិតាមប្រពៃណីទម្លាប់ និងទិវាបុណ្យជាតិពួកយូដា ។

- តើអ្នកគិតថា វានឹងមានបញ្ហាអ្វីដែលអាចកើតឡើងនៅក្នុងសាសនាចក្រ កាលសមាជិកធ្វើការសម្រេចចិត្តផ្សេងៗគ្នានៅក្នុងបញ្ហាទាំងនេះ ?

សូមអញ្ជើញសិស្សអាន រ៉ូម ១៤:៣ ដោយស្ងាត់ស្ងៀមរកមើលថា តើចំណង់ចំណូលចិត្តផ្ទាល់ខ្លួននៅក្នុងរបបអាហារអាចដឹកនាំសមាជិកសាសនាចក្រមួយចំនួនឲ្យធ្វើអ្វីខ្លះ ។

- តើសមាជិកសាសនាចក្រកំពុងប្រឈមមុខនឹងបញ្ហាអ្វីខ្លះ ? (សមាជិកសាសនាចក្រមួយចំនួនកំពុងតែស្អប់ ហើយវិនិច្ឆ័យសមាជិកផ្សេងទៀត ដែលមានការជ្រើសរើសខុសពីពួកគេ) ។
- ហេតុអ្វីអ្នកគិតថា រឿងនេះនឹងកើតឡើង ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរដូចខាងក្រោមនៅលើក្តារខៀន ៖ *រ៉ូម ១៤:១០–១៣, ១៥, ២១* ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានខគម្ពីរទាំងនេះឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានបង្រៀនសមាជិកសាសនាចក្រមិនឲ្យធ្វើអ្វីខ្លះ នៅក្នុងបញ្ហានៃចំណូលចិត្តផ្ទាល់ខ្លួននេះ ។ បន្ទាប់ពីសិស្សម្នាក់បានអាន ខទី ១៥ រួចហើយ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ខគម្ពីរនេះបានចែកថា « ប៉ុន្តែ បើអ្នកធ្វើឲ្យបងប្អូនអ្នកព្រួយចិត្ត ដោយព្រោះម្ហូបចំណីអ្វី នោះអ្នកប្រព្រឹត្តមិនមែនដោយស្រឡាញ់ទៀតទេ ប្រសិនបើអ្នកបរិភោគវា ហេតុដូច្នេះហើយ កុំធ្វើឲ្យអ្នកណាដែលព្រះគ្រីស្ទបានសុគតជំនួសត្រូវវិនាស ដោយសារម្ហូបរបស់អ្នកឡើយ »។

- ដោយផ្អែកទៅលើអ្វីដែលប៉ុលបានបង្រៀននៅក្នុង ខទី ១៣ តើយើងអាចរៀនពីសេចក្តីពិតអ្វីខ្លះ អំពីអ្វីដែលយើងមិនគួរធ្វើនៅក្នុងបញ្ហានានា ដែលបានមិនបានចែងជាក់លាក់នៅក្នុងព្រះបញ្ញត្តិ ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងពីសេចក្តីពិតដូចខាងក្រោម ៖ **នៅក្នុងបញ្ហានានាដែលបានមិនបានចែងជាក់លាក់នៅក្នុងព្រះបញ្ញត្តិ នោះយើងមិនត្រូវវិនិច្ឆ័យការជ្រើសរើសរបស់មនុស្សដទៃឡើយ**) ។
- ហេតុអ្វីវាជាបញ្ហាមួយ នៅពេលសមាជិកសាសនាចក្រមើលងាយ ឬដាក់ទោសដល់សមាជិកសាសនាចក្រផ្សេងទៀតដែលធ្វើការជ្រើសរើសផ្សេងគ្នា នៅក្នុងកត្តាទាំងឡាយដែលព្រះបញ្ញត្តិមិនបានតម្រូវ ឬហាមឃាត់មិនឲ្យមានឥរិយាបថជាក់លាក់មួយនោះ ?

ចូរចង្អុលបង្ហាញទៅឃ្លា « ធ្វើឲ្យជំពប់ដួល ឬរវាតចិត្តចេញ » នៅក្នុង ខទី ១៣ ។ សូមពន្យល់ថា ឃ្លានេះសំដៅទៅលើការធ្វើឲ្យមនុស្សម្នាក់ផ្សេងទៀតជំពប់ដួល ឬរវាតចិត្តខាងវិញ្ញាណចេញពីការខិតខំរបស់ពួកគេដើម្បីជឿលើព្រះគ្រីស្ទ ហើយរស់នៅតាមដំណឹងល្អរបស់ទ្រង់ ។

- តើការបរិភោគអាហារជាក់លាក់របស់សមាជិកសាសនាចក្រអាចធ្វើឲ្យមនុស្សដទៃទៀតជំពប់ដួល ឬរវាតចិត្តចេញបានយ៉ាងដូចម្តេច ?
- តើប៉ុលបានទូន្មានសមាជិកសាសនាចក្រឲ្យធ្វើអ្វីខ្លះ ប្រសិនបើការជ្រើសរើសរបបអាហាររបស់ពួកគេផ្ទាល់អាចបំផ្លាញដល់មនុស្សម្នាក់ទៀតខាងវិញ្ញាណនោះ ? (ប៉ុលបានប្រឹក្សាដល់ពួកបរិសុទ្ធឲ្យពិចារណាពីផលនៃទម្លាប់ផ្ទាល់ខ្លួនរបស់ពួកគេទៅលើមនុស្សដទៃ ហើយយល់ព្រមលះបង់ទង្វើដែលអាចធ្វើឲ្យមនុស្សដទៃទៀតជំពប់ដួលខាងវិញ្ញាណ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ មកពីការណែនាំរបស់ប៉ុលស្តីពីទង្វើរបស់យើងនៅក្នុងបញ្ហា ដែលបានចែងយ៉ាងជាក់លាក់នៅក្នុងព្រះបញ្ញត្តិ ? (សូមជួយសិស្សឲ្យស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **នៅក្នុងបញ្ហានានាដែលមិនបានចែងជាក់លាក់នៅក្នុងព្រះបញ្ញត្តិ យើងត្រូវពិចារណាថា តើការជ្រើសរើសរបស់យើងជះឥទ្ធិពលលើមនុស្សដទៃទៀតយ៉ាងដូចម្តេច** ។ *កំណត់ចំណាំ* ៖ សេចក្តីពិតស្រដៀងគ្នាមួយនឹងលើកឡើងយកមកពិភាក្សាយ៉ាងសិ៏ជម្រៅនៅក្នុងភ្ជុំនថ្ងៃសទី ១ ៨) ។

សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ១៤:១៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានទូន្មានឲ្យសមាជិកសាសនាចក្របន្តធ្វើអ្វីខ្លះ ។

- តើការធ្វើតាមពាក្យទូន្មានរបស់ប៉ុលស្តីពីបញ្ហានៃចំណូលចិត្តផ្ទាល់ខ្លួន អាចជះឥទ្ធិពលដល់សេចក្តីសុខសាន្ត និងការស្អាងឡើងដែលសមាជិកសាសនាចក្របានដកពិសោធន៍រួមគ្នាយ៉ាងដូចម្តេចដែរ ?

សូមរំឭកសិស្សពីបញ្ហានៃចំណង់ចំណូលចិត្តផ្ទាល់ខ្លួន ដែលបានសរសេរកាលពីដើម ។ សូមឲ្យសិស្សពិពណ៌នាពីរបៀបដែលសមាជិកសាសនាចក្រ អាចធ្វើតាមពាក្យទូន្មានរបស់ប៉ុលនៅក្នុងបញ្ហានានាដូចជាបញ្ហាទាំងនេះ ។

រ៉ូម ១៥:៤–១៦:២៧

ប៉ុលបញ្ចប់សំបុត្ររបស់លោកដល់ពួករ៉ូម

សូមពន្យល់ថា នៅពេលប៉ុលហៀបនឹងបញ្ចប់សំបុត្ររបស់លោក នោះលោកបានផ្តល់ពាក្យទូន្មានបន្ថែមទៀតដល់ពួកសមាជិកសាសនាចក្រនៅក្រុងរ៉ូម ។ សូមអញ្ជើញសិស្សម្នាក់អាន រ៉ូម ១៥:៤ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនថា ហេតុអ្វីបានជាបទគម្ពីរត្រូវបានសរសេរឡើង ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងខទី ៤ ហេតុផលដែលបទគម្ពីរត្រូវបានសរសេរឡើង ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងពីសេចក្តីពិតដូចខាងក្រោម ៖ **ព្រះគម្ពីរត្រូវបានសរសេរឡើងដើម្បីបង្រៀនយើង ហើយផ្តល់សេចក្តីសង្ឃឹមដល់យើង**) ។

សូមពន្យល់ថា បន្ទាប់មកប៉ុលបានបង្ហាញសេចក្តីពិតនេះដោយដកស្រង់បទគម្ពីរមួយចំនួនចេញពីព្រះគម្ពីរសញ្ញាចាស់ ដើម្បីអះអាងជាថ្មីដល់ពួកបរិសុទ្ធថា កិច្ចការផ្សព្វផ្សាយសាសនានៅក្នុងចំណោមពួកសាសន៍ដទៃ គឺស្របតាមផែនការរបស់ព្រះ (សូមមើល រ៉ូម ១៥:៩–១២) ។

សូមសង្កេតផ្នែកបន្តទៀតនៃ រ៉ូម ១៥–១៦ ដោយពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោក ដោយពិពណ៌នាអំពីការខិតខំរបស់លោកដើម្បីប្រកាសដំណឹងល្អ ។ លោកក៏បានព្រមានដល់ជនដែលបណ្តាលឲ្យមានការបែកបាក់គ្នា បង្រៀនគោលលទ្ធិក្លែងក្លាយ ហើយខិតខំបោកបញ្ឆោតមនុស្សដទៃទៀត (សូមមើល រ៉ូម ១៦:១៧–១៨) ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

សេចក្តីផ្តើមអំពី

សំបុត្រទីមួយរបស់ប៉ុលដល់ពួកកូរិនថូស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សមាជិកសាសនាចក្រពីបុរាណដែលរស់នៅក្រុងកូរិនថូស បានជួបប្រទះនឹងបញ្ហាជាច្រើនដែលកើតមាននៅក្នុងពិភពលោកសព្វថ្ងៃនេះ ដូចជាការមិនចុះសម្រុងគ្នា ការបង្រៀនក្លែងក្លាយ និងភាពអសីលធម៌ ។ នៅក្នុងកូរិនថូសទី ១ យើងរៀនថា ប៉ុលបានបង្រៀនពួកបរិសុទ្ធទាំងនេះអំពីរបៀបដើម្បីបង្កើនសាមគ្គីភាពនៅក្នុងសាសនាចក្រ របៀបរៀនរឿងរ៉ាវរបស់ព្រះ តួនាទីរបស់រូបកាយជាព្រះវិហារបរិសុទ្ធ លក្ខណៈនៃអំណោយទានខាងវិញ្ញាណ សារៈសំខាន់នៃការទទួលទានសាក្រាម៉ង់ដោយសក្តិសម និងភាពជាក់ស្តែងនៃការរស់ឡើងវិញ ។ នៅក្នុងការសិក្សារបស់ពួកគេអំពីការបង្រៀនរបស់ប៉ុល ដែលបានកត់ត្រានៅក្នុងកូរិនថូសទី ១ នោះសិស្សអាចរៀនពីគោលលទ្ធិ និងគោលការណ៍ដែលនឹងជួយពួកគេឲ្យរស់នៅដោយសុចរិត ទោះជាពួកគេហ៊ឺមព័ទ្ធដោយសេចក្តីទុច្ចរិតយ៉ាងណាក៏ដោយ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ខគម្ពីរដំបូងនៅក្នុងសំបុត្រទីមួយដល់ពួកកូរិនថូសចង្អុលបង្ហាញថា សាវកប៉ុលបានផ្ញើសំបុត្រនេះទៅ ហើយមានសិស្សម្នាក់ឈ្មោះសូស្ថេន បានបម្រើជាអ្នកសរសេររបស់ប៉ុល (សូមមើល កូរិនថូសទី ១ ១:១) ។ កាលគេមិនបានដឹងពីតួនាទីលម្អិតរបស់សូស្ថេន វាបញ្ជាក់យ៉ាងច្បាស់ថា ប៉ុលគឺជាអ្នកនិពន្ធមាតិការបស់សំបុត្រនេះ (សូមមើល កូរិនថូសទី ១ ១៦:២១–២៤) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះ ត្រូវបានសរសេរ ?

ប៉ុលបានសរសេរសំបុត្រនេះដែលត្រូវបានគេស្គាល់ថាជា កូរិនថូសទី ១ នៅជិតចុងបញ្ចប់នៃដំណើរទេស្សនៈកិច្ចនៅអេភេសូរយៈពេលបីឆ្នាំ របស់លោក (នៅក្នុងបេសកកម្មលើកទីបីរបស់លោក) ដែលទំនងជាបញ្ចប់នៅចន្លោះ គ.ស. ៥៥ និង ៥៦ (សូមមើល កិច្ចការ ១៩:១០, ២០:៣១,សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយតើហេតុអ្វី ?

សំបុត្រនេះបានសរសេរទៅសមាជិកសាសនាចក្រនៅក្រុងកូរិនថូស ។ ប៉ុលបានប្រកាសដំណឹងល្អនៅក្រុងកូរិនថូសរយៈពេលជិតពីរឆ្នាំ (សូមមើល កិច្ចការ ១៨:១–១៨) ហើយបានរៀបចំសាខាមួយរបស់សាសនាចក្រនៅទីនោះ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ ក្រោយមកទៀត កាលប៉ុលកំពុងប្រកាសដំណឹងល្អនៅអេភេសូរ ក្នុងដំណើរបេសកកម្មលើកទីបីរបស់លោក នោះលោកបានទទួលព័ត៌មានពីសមាជិកសាសនាចក្រនៅក្រុងកូរិនថូស ។ លោកបានសរសេរឆ្លើយតបមួយទៅសាខានោះ (សូមមើល កូរិនថូសទី ១ ៥:៩) ប៉ុន្តែជាអកុសលសំបុត្រនេះបានបាត់ ហេតុដូច្នេះហើយវាគ្មាននៅក្នុងព្រះគម្ពីររបស់យើងទេ ។ ក្រោយមកទៀត ប៉ុលបានទទួលបាយការណ៍មួយទៀតពីសមាជិកសាសនាចក្រនៅក្រុងកូរិនថូសស្តីពីបញ្ហានានា នៅក្នុងសាសនាចក្រនៅទីនោះ (សូមមើល កូរិនថូសទី ១ ១:១១) ដែលលោកបានឆ្លើយតបដោយសរសេរសំបុត្រមួយទៀតដែលត្រូវបានគេស្គាល់ថាជា កូរិនថូសទី ១ ។ ហេតុដូច្នេះហើយ កូរិនថូសទី ១ តាមពិតទៅជាសំបុត្រទីពីររបស់ប៉ុលទៅសមាជិកនៅក្រុងកូរិនថូស ។

នៅសម័យរបស់ប៉ុល ក្រុងកូរិនថូសគឺជារាជធានីរបស់អ៊ូម ស្រុកអាខៃដែលមានទំហំយ៉ាងធំគ្របដណ្តប់ស្ទើរតែមួយភាគយ៉ាងធំនៃប្រទេសក្រិកកាលពីបុរាណ នៅភាគខាងត្បូងនៃម៉ាសេដូន ។ ដោយសារវាជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយដ៏ធំ ក្រុងកូរិនថូសបានទាក់ទាញមនុស្សមកពីគ្រប់ទិសទីនៃអាណាចក្ររ៉ូម ដោយធ្វើឲ្យវាក្លាយជាទីក្រុងដ៏ប្លែកបំផុតមួយនៅក្នុងតំបន់ ។ ការថ្វាយបង្គំរូបព្រះជាទម្វើពេញនិយមយ៉ាងខ្លាំងក្នុងវប្បធម៌សាសនារបស់ពួកកូរិនថូស ហើយមានព្រះវិហារ និងទីធ្វើសក្ការបូជាជាច្រើននៅក្នុងទីក្រុងនេះ ។ នៅគ្រាដែលប៉ុលធ្វើការងារបម្រើនោះពួកកូរិនថូសល្បីខាងការធ្វើរឿងអសីលធម៌យ៉ាងកំរោល ។ ឧទាហរណ៍ ការធ្វើពេស្យាកម្មត្រូវបានគោរាយការណ៍ថាបានធ្វើឡើងនៅឯវិហារអាហ្វ្រូដៃ ។

សំបុត្រទីមួយរបស់ប៉ុលដល់ពួកកូរិនថូសបានបញ្ជាក់យ៉ាងច្បាស់ថា សមាជិកសាសនាចក្របានខ្វះសាមគ្គីភាព ហើយថាជំនឿ និងទំនៀមទម្លាប់ពួកឥតជំនឿមួយចំនួនបានចាប់ផ្តើមជះឥទ្ធិពលដល់ការប្រតិបត្តិតាមរបស់ខ្លួនមកលើគោលការណ៍និងពិធីបរិសុទ្ធនៃដំណឹងល្អ (សូមមើល កូរិនថូសទី ១ ១:១១, ៦:១–៨, ១០:២០–២២, ១១:១៨–២២) ។ ប៉ុលបានសរសេរទៅសមាជិកសាសនាចក្រនៅក្រុងកូរិនថូស ដើម្បីជួយពួកគេជាមួយបញ្ហា និងសំណួរដែលពួកគេមាន និងដើម្បីពង្រឹងពួកអ្នកប្រែចិត្តជឿដែលមានបញ្ហាជាមួយនឹងការបោះបង់ចោលជំនឿ និងទំនៀមទម្លាប់ពីអតីតកាលរបស់ខ្លួន ។

តើនៅក្នុងគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ព្រះគម្ពីរសញ្ញាថ្មីមានពាក្យទូន្មាន និងការបង្រៀនមកពីប៉ុលទៅកាន់សមាជិកសាសនាចក្រនៅក្រុងកូរិនថូស ច្រើនជាងសាខាផ្សេងៗទៀត ។ តាមពិត សំបុត្រទីពីររបស់ប៉ុលដល់ពួកកូរិនថូសបន្ថែមបង្រួមមួយភាគបួននៃរាល់ការសរសេររបស់ប៉ុលដែលមាន ។

នៅក្នុងកូរិនថូសទី ១ យើងរៀនថា ប៉ុលបានពន្យល់ថា ព្រះយេស៊ូវគ្រីស្តបានបំពេញក្រឹត្យវិន័យរបស់ម៉ូសេ ។ ប៉ុលបានគូសបញ្ជាក់ពីសារៈសំខាន់នៃការ « កាន់តាមបញ្ញត្តិរបស់ព្រះ » (កូរិនថូសទី ១ ៧:១៩)ការ « នៅក្នុងក្រឹត្យវិន័យព្រះគ្រីស្ទ » (កូរិនថូសទី ១ ៩:២១) ដើម្បីទទួលបានពរជ័យនៃសេចក្តីសង្គ្រោះតាមរយៈដំណឹងល្អ ។

គម្រោង

កូរិនថូសទី ១ ១–១១ ប៉ុលព្រមានទាស់នឹងការចែកបក្សពួកនៅក្នុងសាសនាចក្រ ហើយគូសបញ្ជាក់ពីសារៈសំខាន់នៃសាមគ្គីភាពនៅក្នុងចំណោមសមាជិកសាសនាចក្រ ។ លោកបានព្រមានសមាជិកទាស់នឹងរឿងអសីលធម៌ខាងផ្លូវភេទ លោកបង្រៀនថា រូបកាយគឺជាព្រះវិហារបរិសុទ្ធសម្រាប់វិញ្ញាណបរិសុទ្ធ ហើយលើកទឹកចិត្តការលះបង់ខ្លួន ។ លោកលើកឡើងពីសំណួរជាក់លាក់ស្តីពីអាពាហ៍ពិពាហ៍ និងការបម្រើជាអ្នកផ្សព្វផ្សាយសាសនា រួមទាំងពិធីបរិសុទ្ធនៃសាក្រាម៉ង់ ហើយថាតើគួរតែអនុញ្ញាតឲ្យបរិភោគសាច់សំណែន ដែលថ្វាយរូបសំណាក់ព្រះនៃពួកអ្នកឥតជំនឿដែរឬអត់ ។

កូរិនថូសទី ១ ១២–១៤ ប៉ុលបង្រៀនថា យើងត្រូវស្វែងរកអំណោយទាននៃព្រះវិញ្ញាណ ។ លោករំឭកដល់ពួកបរិសុទ្ធនៅក្រុងកូរិនថូសអំពីសារៈសំខាន់នៃពួកសាវក ពួកព្យាការី និងពួកគ្រូបង្រៀន និងការមើលថែ ដែលសមាជិកគួរមានចំពោះគ្នាទៅវិញទៅមក ។ លោកគូសបញ្ជាក់ពីសារៈសំខាន់នៃព្រហ្មចារីភាពលើសអំណោយទានខាងវិញ្ញាណផ្សេងទៀតទាំងអស់ ។

កូរិនថូសទី ១ ១៥–១៦ ប៉ុលថ្លែងទីបន្ទាល់ថា លោកឈរនៅក្នុងចំណោមមនុស្សជំទៃជាច្រើន ដែលជាសាក្សីពីព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ ។ លោកបង្រៀនថា មនុស្សគ្រប់រូបនឹងបានរស់ឡើងវិញ ហើយថាពិធីបុណ្យជ្រមុជទឹកសម្រាប់អ្នកស្លាប់បញ្ជាក់ពីសេចក្តីពិតនៃការរស់ឡើងវិញនាពេលអនាគត ។ ប៉ុលពន្យល់ថា រូបកាយដែលរស់ឡើងវិញនឹងស្ថិតនៅក្នុងកម្រិតនៃភាពរុងរឿងខុសៗគ្នា ហើយថាជ័យជំនះរបស់ព្រះយេស៊ូវគ្រីស្ទលើផ្នូរ បានកាត់ផ្តាច់ចំណងនៃសេចក្តីស្លាប់ ។ ប៉ុលរៀបចំការប្រមូលផ្តុំមួយសម្រាប់ពួកបរិសុទ្ធក្រីក្រនៅទីក្រុងយេរូសាឡិម ។

មេរៀន ១០៣

កូរិនថូសទី១ ១–២

សេចក្តីផ្តើម

បន្ទាប់ពីដឹងអំពីបញ្ហាដែលសមាជិកសាសនាចក្រនៅកូរិនថូសបានជួបប្រទះ ប៉ុលបានសរសេរសំបុត្រដល់សមាជិកទាំងនេះ ហើយបានជាស់តឿនពួកគេឲ្យបំបាត់ចោលនូវការឈ្លោះប្រកែកគ្នា ហើយចេះសាមគ្គីគ្នា ។ លោកក៏បានពន្យល់ផងដែរថា ព្រះហៅពួកទន់ខ្សោយ ហើយរាបសា ឲ្យប្រកាសដំណឹងល្អរបស់ទ្រង់ ហើយថារឿងនៃព្រះអាចដឹង ហើយយល់បានតែតាមរយៈព្រះវិញ្ញាណប៉ុណ្ណោះ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ១:១–១៦

ប៉ុលសរសេរសំបុត្រដល់ពួកបរិសុទ្ធនៅកូរិនថូស ហើយជាស់តឿនពួកគេឲ្យបំបាត់ចោលនូវការឈ្លោះប្រកែកគ្នា ហើយចេះសាមគ្គីគ្នា

សូមបង្ហាញរូបភាពមួយអំពីគ្រួសារ ក្រុមកីឡា និងមិត្តមួយក្រុមដល់សិស្សក្នុងថ្នាក់ (ឬសរសេរពាក្យ *គ្រួសារ ក្រុមកីឡា ក្រុមមិត្តភក្តិ* នៅលើក្តារខៀន) ។

- តើអ្វីទៅដែលបណ្តាលឲ្យមានការបែកបាក់ និងការឈ្លោះប្រកែកគ្នានៅក្នុងក្រុមទាំងនេះ ?
- តើការបែកបាក់ និងការឈ្លោះប្រកែកគ្នាបែបនេះអាចជះឥទ្ធិពលដល់គ្រួសារ ក្រុម ឬមិត្តភក្តិយ៉ាងដូចម្តេច ?
- តើការបែកបាក់ និងការឈ្លោះប្រកែកគ្នាបែបនេះនៅក្នុងចំណោមសមាជិកសាសនាចក្រ អាចជះឥទ្ធិពលដល់សាសនាចក្រយ៉ាងដូចម្តេចដែរ ?

នៅពេលសិស្សសិក្សា កូរិនថូសទី១ ១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយអំពីការបែកបាក់ និងការឈ្លោះប្រកែកគ្នា ដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធនៅកូរិនថូស ។

សូមអញ្ជើញសិស្សបើកទៅផែនទីក្នុងព្រះគម្ពីរ ល.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា » ដែលមាននៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ហើយរកកូរិនថូសនៅលើផែនទីនោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌខាងក្រោមនេះឲ្យឮៗ ៖

នៅក្នុងដំណើរទៅផ្សាយសាសនាទីពីររបស់លោក ប៉ុលបានធ្វើដំណើរទៅក្រុងមួយឈ្មោះថា កូរិនថូស ជាកន្លែងដែលលោកបានប្រកាសដំណឹងល្អ ។ មានមនុស្សជាច្រើនបានជ្រមុជទឹកនៅគ្រានោះ (សូមមើល កិច្ចការ ១៨:១–១៨) ។ ក្រោយមកទៀត កាលប៉ុលកំពុងប្រកាសដំណឹងល្អនៅអេភេសូរ លោកបានដឹងថា មានបញ្ហាបានកើតឡើងនៅក្នុងចំណោមសមាជិកសាសនាចក្រនៅកូរិនថូស ដោយសារមានពួកអ្នកប្រែចិត្តជឿមួយចំនួនបានត្រឡប់ទៅរកជំនឿដើមរបស់ពួកគេ ហើយអនុវត្តការថ្វាយបង្គំរូបព្រះវិញ ។ ប៉ុលបានសរសេរសំបុត្រដល់សមាជិកសាសនាចក្រនៅកូរិនថូសដើម្បីពង្រឹងពួកគេ ហើយរំឭកពួកគេអំពីការតាំងចិត្តរបស់ពួកគេដើម្បីបម្រើព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយទៅសមាជិកសាសនាចក្រនៅកូរិនថូសយ៉ាងដូចម្តេច ។

- តើប៉ុលបាននិយាយទៅសមាជិកសាសនាចក្រនៅកូរិនថូសយ៉ាងដូចម្តេច ?
- យោងតាម ខទី ១ តើប៉ុលមានតួនាទីអ្វីខ្លះនៅក្នុងសាសនាចក្រ ?

សូមសង្កេប កូរិនថូសទី ១ ១:៣–៩ ដោយពន្យល់ថា ប៉ុលបានប្រាប់ពួកបរិសុទ្ធនៅកូរិនថូសថា លោកមានអំណរគុណដល់ព្រះជំនួសពួកគេសម្រាប់ព្រះគុណ ដែលពួកគេបានទទួលតាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលបានប្រទានពរដល់ពួកគេតាមគ្រប់វិធី ។ សូមចង្អុលបង្ហាញថា នៅពេលប៉ុលបាននិយាយទៅកាន់ពួកបរិសុទ្ធ លោកបានប្រើភាសាដែលចង្អុលបង្ហាញថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទគឺជាតួអង្គពីរដាច់ដោយឡែកពីគ្នា (សូមមើល ខទី ៣) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១:១០–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានដាស់តឿនពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ។

- យោងតាម កូរិនថូសទី១ ១:១០ តើព្រះអម្ចាស់រំពឹងឲ្យយើងធ្វើអ្វីខ្លះ ក្នុងនាមជាសមាជិកសាសនាចក្រ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្គាល់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **ព្រះអម្ចាស់រំពឹងឲ្យយើងសាមគ្គីគ្នាក្នុងនាមជាពួកបរិសុទ្ធ ហើយបំបាត់ចោលនូវការបែកបាក់ និងការឈ្លោះប្រកែកគ្នា**) ។
- ក្នុងនាមជាសមាជិកសាសនាចក្រ តើយើងអាចធ្វើអ្វីខ្លះដើម្បីបំបាត់ចោលនូវការបែកបាក់ និងការឈ្លោះប្រកែកគ្នានៅក្នុងក្រុមគ្រួសាររបស់យើង ? នៅក្នុងវួដរបស់យើង ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

- តើយើងអាចទទួលពរជ័យអ្វីខ្លះមកពីការសាមគ្គីគ្នា ហើយបំបាត់ចោលនូវការឈ្លោះប្រកែកគ្នានោះ ?
- តើអ្នកធ្លាប់មានពរនៅពេលណាដែរដោយសារតែការសាមគ្គីគ្នានៅក្នុងថ្នាក់ ក្រុម ឬ្ជដ ឬ សាខា ?

សូមឲ្យសិស្សមើលទៅចម្លើយដែលបានសរសេរនៅលើក្តារខៀន ហើយលើកទឹកចិត្តពួកគេឲ្យជ្រើសយកវិធីមួយដែលពួកគេអាចបំបាត់ចោលនូវការបែកបាក់ និងការឈ្លោះប្រកែកគ្នា ហើយដាក់គោលដៅមួយដើម្បីអនុវត្តវា ។

សូមសង្ខេប កូរិនថូសទី១ ១:១២–១៦ ដោយពន្យល់ថា ពួកបរិសុទ្ធនៅកូរិនថូសបានបែងចែកជាក្រុមទៅតាមអ្នកដែលជ្រមុជទឹកឲ្យពួកគេ ។ ការទាស់ទែងគ្នាបានកើនឡើង ដោយសារពួកគេបានជឿថា ស្ថានភាពរបស់ពួកគេនៅក្នុងសាសនាចក្រគឺត្រូវបានកំណត់ថាសំខាន់តាមរយៈបុគ្គលដែលបានជ្រមុជទឹកឲ្យពួកគេប៉ុណ្ណោះ ។

កូរិនថូសទី១ ១:១៧–៣១

ប៉ុលបង្រៀនថា ព្រះហៅពួកទន់ខ្សោយឲ្យប្រកាសដំណឹងល្អរបស់ទ្រង់

សូមពន្យល់ថា នៅសម័យប៉ុល មានជនជាតិក្រិកជាច្រើនបានរស់នៅកូរិនថូស ។ ជនជាតិក្រិកទាំងនេះបានឲ្យតម្លៃយ៉ាងខ្លាំងទៅលើគំនិតខាងទស្សនវិជ្ជា និងប្រាជ្ញាខាងលោកិយ ។

- ហេតុអ្វីមនុស្សម្នាក់ ដែលឲ្យតម្លៃទៅលើទស្សនវិជ្ជាខាងលោកិយ អាចមានការពិបាកដើម្បីទទួលយកដំណឹងល្អ ? (អ្នកគួរអាន នីហ្វៃទី២ ៩:២៨) ។

នៅពេលសិស្សសិក្សាកូរិនថូសទី ១ ១:១៧–៣១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយពួកគេឲ្យយល់អំពីការបោកបញ្ឆោតតាមរយៈប្រាជ្ញាខាងលោកិយ ។

សូមបែងចែកសិស្សទាំងឡាយជាបួនក្រុមតូចៗ ។ ចូរចាត់សេចក្តីយោងបទគម្ពីរមួយដូចមានខាងក្រោមនេះដល់សិស្សក្នុងក្រុមនីមួយៗ ៖ កូរិនថូសទី១ ១:១៧–១៨, កូរិនថូសទី១ ១:១៩–២០, កូរិនថូសទី១ ១:២១–២២ និង កូរិនថូសទី១ ១:២៣–២៤ ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរទាំងនេះនៅក្នុងក្រុមរបស់ពួកគេ ដោយរកមើលថាប៉ុលបាននិយាយអ្វីខ្លះ អំពីភាពខុសគ្នានៃប្រាជ្ញារបស់លោកិយ និងព្រះបញ្ញាញាណរបស់ព្រះ ។ សូមពន្យល់ថា ឃ្លា « ដ្បិត ព្រះគ្រីស្ទមិនបានចាត់ខ្ញុំឲ្យមកធ្វើបុណ្យជ្រមុជទឹកទេ » នៅក្នុង ខ ទី ១៧ ណែនាំថា ប៉ុលមិនមែនត្រូវបានបញ្ជូនទៅ ដើម្បីបង្កើនកេរ្តិ៍ឈ្មោះដោយផ្អែកលើចំនួននៃពួកអ្នកប្រែចិត្តជឿ ដែលលោកបាននាំមកនោះទេ ។ អ្នកក៏គួរពន្យល់ផងដែរថា ឃ្លា « ប្រាជ្ញារបស់ពួកអ្នកប្រាជ្ញ »នៅក្នុង ខទី ១៩ និង « ប្រាជ្ញារបស់លោកីយ៍នេះ »នៅក្នុង ខ ទី ២០ សំដៅទៅលើទម្លាប់ខាងទស្សនវិជ្ជាដែលមិនបានធ្វើឲ្យខ្លួចនៅជំនាន់នោះ ។

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ពីក្រុមនីមួយៗឲ្យសង្ខេបប្រាប់ដល់សិស្សក្នុងថ្នាក់ថាប៉ុលបានបង្រៀនអ្វីខ្លះដល់ពួកបរិសុទ្ធនៅកូរិនថូសអំពីប្រាជ្ញា ។ បន្ទាប់ពីក្រុមទាំងអស់បានប្រាប់រួចហើយ សូមសួរ ៖

- ហេតុអ្វីអ្នកគិតថា ពួកឥតជំនឿបានគិតថា សារលិខិតអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទគឺជារឿងឆ្កួតលីលា ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន កូរិនថូសទី១ ១:២៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានបង្រៀនអ្វីខ្លះអំពីប្រាជ្ញាមនុស្សប្រៀបធ្ងឹមទៅនឹងព្រះបញ្ញាញាណរបស់ព្រះ ។ សូមពន្យល់ថា ប៉ុលបានប្រើឃ្លា « សេចក្តីល្ងង់ល្ងើរបស់ព្រះ នោះមានប្រាជ្ញាលើសជាងមនុស្ស » និង « សេចក្តីកំសោយរបស់ព្រះ ក៏មានកំឡាំងលើសជាងមនុស្សដែរ » ដើម្បីបង្ហាញអំពីព្រះបញ្ញាញាណ និងព្រះចេស្តារបស់ព្រះ ។ ព្រះពុំមានសេចក្តីល្ងង់ល្ងើ ឬភាពកំសោយណាមួយឡើយ ។

- តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះ អំពីប្រាជ្ញាមនុស្សប្រៀបធ្ងឹមនឹងព្រះបញ្ញាញាណរបស់ព្រះ ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ព្រះបញ្ញាញាណរបស់ព្រះគឺ ធំជាងប្រាជ្ញាមនុស្សទៅទៀត**) ។
- តើការយល់ដឹងអំពីសេចក្តីពិតនេះអាចជះឥទ្ធិពលយ៉ាងដូចម្តេច ទៅលើរបៀបដែលមនុស្សម្នាក់ស្វែងរកដំណោះស្រាយសម្រាប់បញ្ហារបស់គាត់ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១:២៦–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាព្រះបានជ្រើសយកនរណាដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ។

- តើព្រះបានជ្រើសយកនរណាដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ?
- ហេតុអ្វីអ្នកគិតថា ព្រះបានជ្រើសយកមនុស្សដែលលោកិយនេះរាប់ទុកថាជាមនុស្សល្ងង់ ហើយកំសោយដើម្បីប្រកាសដំណឹងល្អរបស់ទ្រង់ ?

កូរិនថូសទី១ ២

ប៉ុលពន្យល់អំពីរបៀបដែលយើងរៀនពីរឿងរបស់ព្រះ

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមដោយប្រធាន ប៊ិយដ៏ ឃេ ផាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ខ្ញុំអង្គុយនៅក្នុងយន្តហោះក្បែរអ្នកពុំជឿព្រះម្នាក់ ដែលបង្ហាញការពុំជឿព្រះរបស់គាត់យ៉ាងបន្ទាន់រហូតធ្វើឲ្យខ្ញុំបានថ្លែងទីបន្ទាល់របស់ខ្ញុំទៅកាន់គាត់ ។ ខ្ញុំបានថ្លែងថា ‹ លោកយល់ខុសហើយ តាមពិតគឺមានព្រះមួយអង្គ ។ ខ្ញុំ *ដឹង* ថាទ្រង់មានព្រះជន្មរស់ ! ›

« គាត់បានតវ៉ាថា ‹ លោកពុំ *ដឹង*ទេ ។ គ្មាននរណាម្នាក់ *ដឹង* អំពីរឿងនោះទេ ! លោកមិនអាច*ដឹង*រឿងនោះទេ ! › នៅពេលខ្ញុំឈប់តប បុរសឥតជឿលើព្រះរូបនោះដែលជាមេធាវី បានចោទសួរនូវសំណួរមួយដ៏ពិបាកបំផុតអំពី

ប្រធានបទទីបន្ទាល់ ។ គាត់ពោលពាក្យចំអក ហើយមានឫកអួតអាងថា ‹ មែនហើយ លោកនិយាយថា លោកដឹងរឿងនោះ ។ សូមប្រាប់ខ្ញុំបានទេ តើលោកដឹង *តាមរបៀបណា* › ។

« នៅពេលខ្ញុំព្យាយាមឆ្លើយ ទោះជាខ្ញុំមានចំណេះដឹងជ្រៅជ្រះក្តី ក៏ខ្ញុំពិបាកនឹងឆ្លើយខ្លាំងណាស់ ។ . . .

« នៅពេលខ្ញុំប្រើពាក្យ *ព្រះវិញ្ញាណ* និង *សាក្សី* បុរសនោះបានតបថា ‹ ខ្ញុំពុំយល់អ្វីដែលលោកចង់និយាយទេ › ។ ពាក្យ *ការអធិស្ឋាន ការចេះវិញ្ញកដឹង* និង *សេចក្តីជំនឿ* គឺគ្មានន័យចំពោះគាត់នោះទេ ។ គាត់បានពោលថា ‹ លោកឃើញទេ លោកពុំដឹងរឿងនោះទេ ។ ប្រសិនបើលោកដឹងមែន នោះលោកប្រាកដជាអាចប្រាប់ខ្ញុំបានហើយថា *លោកដឹងវាតាមរបៀបណា* › ។

« ខ្ញុំ . . . មិនដឹងថាត្រូវធ្វើអ្វីនោះទេ » (« The Candle of the Lord » *Ensign* ខែ មករា ឆ្នាំ១៩៨៣ ទំព័រ ៥១) ។

- តើអ្នកនឹងនិយាយអ្វីខ្លះ ទៅកាន់បុរសឥតជឿព្រះម្នាក់នោះ ?

នៅពេលសិស្សសិក្សា កូរិនថូសទី១ ២ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលនឹងជួយពួកគេឲ្យដឹងអំពីហេតុផល ដែលបុរសម្នាក់នេះពុំអាចយល់ប្រសាសន៍របស់ប្រធាន ជាកកី និងហេតុផលដែលពួកគេអាចមានភាពជឿជាក់នៅក្នុងចំណេះដឹងរបស់ពួកគេអំពីបញ្ហាខាងវិញ្ញាណ ។

សូមសង្ខេប កូរិនថូសទី១ ២:១–៨ ដោយពន្យល់ថា ប៉ុលបានប្រាប់ពួកបរិសុទ្ធនៅកូរិនថូសថា លោកពុំបានប្រើប្រាជ្ញាខាងលោកិយដើម្បីធ្វើឲ្យពួកគេជឿលើដំណឹងល្អឡើយ ។ លោកបានបង្រៀនពួកគេដោយព្រះវិញ្ញាណដើម្បីឲ្យពួកគេមានសេចក្តីជំនឿលើព្រះ ។ ប៉ុលក៏បានប្រាប់ពួកគេដែរថា ពួកអ្នកឥតជំនឿមិនអាចយល់អំពីអាថ៌កំបាំងរបស់ព្រះឡើយ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង កូរិនថូសទី១ ២:៩–១៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអំពីហេតុផលដែលប៉ុលបាននិយាយថា មនុស្សមួយចំនួនអាចស្គាល់ ហើយយល់ « សេចក្តីជ្រាលជ្រៅនៃព្រះ » (ខទី ១០) កាលមនុស្សផ្សេងទៀតពុំអាច ។

- យោងតាម ខទី ៩–១០ ហេតុអ្វីប៉ុល និងមនុស្សស្មោះត្រង់ផ្សេងទៀតអាចយល់អំពីការណ៍ទាំងឡាយនៃព្រះ ?
- យោងតាម ខទី ១៤ ហេតុអ្វីមនុស្សមួយចំនួនពុំអាចយល់អំពីការណ៍ទាំងឡាយនៃព្រះ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះ អំពីរបៀបដែលយើងអាចស្គាល់ ហើយយល់អំពីរឿងនៃព្រះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងអាចដឹង ហើយយល់អំពីរឿងរ៉ាវរបស់ព្រះបាន តែតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ប៉ុណ្ណោះ**) ។

សូមលើកឡើងពីដំណើររឿងរបស់ប្រធានជាកកី ហើយពន្យល់ថា ប្រធាន ជាកកី បានទទួលការបំផុសគំនិតឲ្យសរសេរបុរសដែលអង្គុយក្បែរលោកនៅលើយន្តហោះអំពីរសជាតិអំបិល ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវដំណើររឿងបន្តទៀតរបស់ប្រធាន ជាកកី ។



« ពិតណាស់ បន្ទាប់ពីបានព្យាយាមឆ្លើយពីរបីលើកមក លោកពុំអាចធ្វើឲ្យបុរសនោះយល់បានឡើយ ។ លោកពុំអាចប្រើតែពាក្យសម្តីម៉្យាងនោះទេ ដូច្នេះលោកក៏បានចែកចាយបទពិសោធន៍ដ៏សាមញ្ញមួយនៃការភ្លក់រសជាតិអំបិល ។ ខ្ញុំបានថ្លែងទីបន្ទាល់ទៅគាត់ម្តងទៀត ហើយពោលថា ‹ ខ្ញុំដឹងថា មានព្រះ ។ លោកបានចំអកដល់ទីបន្ទាល់នោះ ហើយពោលថា ប្រសិនបើខ្ញុំ *ពិតជា* ដឹងមែន នោះខ្ញុំនឹងអាចប្រាប់លោកពី *របៀប* ដ៏ជាក់លាក់ដែលខ្ញុំដឹងហើយ ។ សំឡាញ់អើយ ប្រសិនបើនិយាយខាងវិញ្ញាណ ខ្ញុំធ្លាប់ភ្លក់អំបិល ។ ខ្ញុំមិនអាចបង្រៀនលោកជាពាក្យសម្តីពីរបៀបដែលចំណេះដឹងនេះបានកើតឡើងលើសពីអ្វី ដែលលោកត្រូវប្រាប់ខ្ញុំពីរសជាតិអំបិលបានឡើយ ។ ប៉ុន្តែខ្ញុំសូមនិយាយទៅកាន់លោកថា មានព្រះពិតមែន ! ទ្រង់ពិតជាមានព្រះជន្មរស់ ! ហើយដោយសារតែ លោកពុំដឹង សូមកុំព្យាយាមប្រាប់ខ្ញុំថាខ្ញុំពុំដឹងអីពីព្រោះខ្ញុំដឹងពីរឿងនេះ ! ›

« កាលយើងបែកចេញពីគ្នា ខ្ញុំបានឮគាត់រអ៊ូថា ‹ ខ្ញុំពុំត្រូវការសាសនារបស់លោកស្អីនោះទេ ! ខ្ញុំពុំត្រូវការវាសោះឡើយ › ។

« ចាប់តាំងពីថ្ងៃមានបទពិសោធន៍នោះមក ខ្ញុំពុំដែលខ្ចាស់អៀន ឬអាម៉ាស់រហូតដល់ខ្ញុំពុំអាចពន្យល់ពីអ្វីៗដែលខ្ញុំដឹងខាងវិញ្ញាណ ដែលខ្ញុំពុំអាចពន្យល់ជាពាក្យសម្តីសោះឡើយ » (« The Candle of the Lord » ទំព័រ ៥២) ។

សូមសរសេរពាក្យ *ការណ៍ទាំងឡាយនៃព្រះ* នៅលើក្តារខៀន ហើយសួរសិស្សថា អ្វីទៅដែលពួកគេនឹងចាត់ទុកថាជាការណ៍នៃព្រះ ដែលគ្រាន់តែរកស្គាល់ ហើយយល់តែតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ប៉ុណ្ណោះ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

- ហេតុអ្វីវាជារឿងដ៏សំខាន់ដែលយើងត្រូវជឿថា យើងអាចដឹង ហើយយល់អំពីរឿងរ៉ាវរបស់ព្រះបាន តែតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ប៉ុណ្ណោះ ?

សូមឲ្យសិស្សមើលមកបញ្ជីលើក្តារខៀន ហើយអញ្ជើញពួកគេឲ្យ ចែកចាយ ពីបទពិសោធន៍មួយដែលពួកគេបានស្គាល់ ហើយយល់តាមរយៈព្រះវិញ្ញាណនូវរឿងមួយរបស់ព្រះក្នុងចំណោមរឿងទាំងនេះរបស់ព្រះ ។ សូមគិតពីការចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនអ្នក ។

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាថា ពួកគេអាចធ្វើអ្វីខ្លះ ដើម្បីស្វែងរកជំនួយពីព្រះវិញ្ញាណ នៅពេលពួកគេព្យាយាមចង់ស្គាល់ ហើយយល់អំពីការណ៍ទាំងឡាយនៃព្រះ ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

សូមអញ្ជើញសិស្សឲ្យចែកចាយ

ការចែកចាយគំនិត និងបទពិសោធន៍ដែលទាក់ទង បញ្ជាក់ពីការយល់ដឹងរបស់សិស្សអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ នៅពេលសិស្សចែកចាយបទពិសោធន៍ទាំងនេះ ជាញឹកញាប់ព្រះវិញ្ញាណបរិសុទ្ធដឹកនាំពួកគេឲ្យយល់កាន់តែជ្រៅជ្រះ ហើយមានទីបន្ទាល់អំពីរឿងទាំងឡាយដែលពួកគេកំពុងតែចែកចាយនោះ ។ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះពាក្យសម្តី និងបទពិសោធន៍ទាំងឡាយរបស់ពួកគេក៏អាចមានឥទ្ធិពលដ៏សំខាន់ទៅលើផ្លូងចិត្ត និង គំនិតរបស់មិត្តភក្តិពួកគេផងដែរ ។

កូរិនថូសទី ១ ៣–៤

សេចក្តីផ្តើម

ប៉ុលបានពន្យល់ទៅពួកបរិសុទ្ធនៅកូរិនថូសអំពីតួនាទីរបស់ពួកអ្នកផ្សព្វផ្សាយសាសនានៅក្នុងការស្ថាបនាគរព្រះ ។ លោកបានបង្រៀនថា សាលដំនុំរបស់ពួកគេគឺជាកន្លែងដែលព្រះវិញ្ញាណអាចគង់នៅ ហើយបានជាស់តឿនពួកគេកុំឲ្យគិតថា មានមនុស្សមួយចំនួនល្អជាងមនុស្សដទៃទៀតឲ្យសោះ ។ (កំណត់ចំណាំ ៖ គោលលទ្ធិដែលចែងថា រូបកាយយើងប្រៀបបាននឹងព្រះវិហារបរិសុទ្ធនឹងត្រូវលើកយកមកបង្រៀននៅក្នុងមេរៀនអំពីកូរិនថូសទី១ ៦) ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ៣

ប៉ុលបានពន្យល់ទៅពួកបរិសុទ្ធនៅកូរិនថូសអំពីតួនាទីរបស់ពួកផ្សព្វផ្សាយសាសនា និងសមាជិកសាសនាចក្រនៅក្នុងការស្ថាបនាគរព្រះ

សូមអញ្ជើញសិស្សឲ្យស្រមៃថា មានមិត្តម្នាក់បានចុះឈ្មោះចូលថ្នាក់គណិតវិទ្យាកម្រិតខ្ពស់ ប៉ុន្តែពុំបានចូលរៀនវគ្គត្រៀម ដូចជាថ្នាក់មូលដ្ឋានពិជគណិតនោះទេ ។

- **តើអ្នកគិតថា មិត្តរបស់អ្នកនឹងទទួលបានជោគជ័យដល់កម្រិតណានៅក្នុងថ្នាក់គណិតវិទ្យាកម្រិតខ្ពស់នេះ ? ហេតុអ្វី ?**
- **ហេតុអ្វីវាជារឿងចាំបាច់ ដើម្បីយល់ពីគំនិតមូលដ្ឋាននៃប្រធានបទមួយពីមុនអ្នកអាចចេះស្ទាត់នូវរឿងដែលមានកម្រិតខ្ពស់ជាងនោះ ?**

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៣:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរឿងប្រៀបធៀប ដែលប៉ុលបានប្រើដើម្បីបង្ហាញដល់ពួកបរិសុទ្ធនៅកូរិនថូសថា ពួកគេមិនទាន់ត្រៀមខ្លួនរួចរាល់សម្រាប់សេចក្តីពិតនៃដំណឹងល្អដែលមានកម្រិតខ្ពស់ជាងនៅឡើយទេ ។ សូមពន្យល់ថា ឃ្លា « ត្រូវតែនិយាយដូចនឹងមនុស្សខាងឯសាច់ឈាមវិញ » នៅក្នុង ខទី ១ សំដៅទៅលើមនុស្សខាងសាច់ឈាម ឬ « ជនណាមួយដែលជ្រើសរើសដើម្បីនៅក្រោមឥទ្ធិពលនៃតណ្ហា សេចក្តីប៉ងប្រាថ្នា សេចក្តីស្រេកឃ្លាន និងវិស័យខាងសាច់ឈាម ជាជាងនៅក្រោមការដាស់តឿននៃព្រះវិញ្ញាណបរិសុទ្ធ ។ ជនបែបនេះអាចយល់សេចក្តីខាងសាច់ឈាម ប៉ុន្តែមិនយល់សេចក្តីខាងវិញ្ញាណឡើយ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « មនុស្សខាងសាច់ឈាម » scriptures.lds.org) ។

សូមសរសេរពាក្យ *ទឹកដោះរាវ* និង *សាច់* នៅលើក្តារខៀន ។

- **នៅក្នុងចំណោមអាហារទាំងនេះ តើអាហារណាមួយដែលអ្នកនឹងយកមកបញ្ចុកទារក ? ហេតុអ្វី ?**
- **តើឃ្លាថា « កូនខ្ចីក្នុងព្រះគ្រីស្ទ » នៅក្នុង ខទី ១ ប្រាប់អ្វីខ្លះអំពីការធំដឹងក្តីខាងវិញ្ញាណរបស់ពួកបរិសុទ្ធនៅកូរិនថូស ?**

ដើម្បីជួយសិស្សឲ្យយល់ថា ពួកបរិសុទ្ធពុំទាន់ត្រៀមខ្លួនដើម្បីទទួលយកសេចក្តីពិតដែលកាន់តែអស្ចារ្យ សូមរំឭកពួកគេថា ពួកបរិសុទ្ធនៅកូរិនថូសខ្លះសាមគ្គីភាព ហើយថាពួកគេមួយចំនួនបានដាក់បញ្ចូលនូវជំនឿ និងទំនៀមទម្លាប់ឥតសាសនា (ទុច្ចរិត) ទៅក្នុងការគោរពប្រតិបត្តិតាមដំណឹងល្អ ។ សូមពន្យល់ថា ប៉ុលបានប្រើពាក្យប្រៀបធៀបមួយចំនួនដើម្បីបង្រៀនពួកបរិសុទ្ធទាំងនេះនូវសារៈសំខាន់នៃការមានសាមគ្គីភាព ដើម្បីកែតម្រូវជំនឿ និងទម្លាប់ខុសឆ្គង និងដើម្បីពង្រឹងសេចក្តីជំនឿរបស់ពួកគេលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមបំបែកសិស្សជាក្រុមដែលមានគ្នាបីនាក់ ។ សូមចាត់សិស្សម្នាក់ៗនៅក្នុងក្រុមឲ្យធ្វើ គម្រោងបង្រៀនដូចខាងក្រោមនេះ ។ សូមឲ្យឯកសារស្តីពីគម្រោងបង្រៀនដល់សិស្សម្នាក់ ហើយទុកពេលពីរបីនាទីឲ្យសិស្សអានវា ។ បន្ទាប់ពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ៗឲ្យប្រើគម្រោងនោះ ដើម្បីបង្រៀនសិស្សពីរនាក់ទៀតនៅក្នុងក្រុមខ្លួន ។ (ប្រសិនបើពុំអាចមានសិស្សបីនាក់ក្នុងមួយក្រុមទេ អ្នកគួរបំបែកសិស្សជាគូៗ ហើយចាត់គម្រោងបង្រៀនពីរដល់សិស្សម្នាក់ៗនៅក្នុងគូនីមួយៗ) ។

ពិនិត្យមើលកិច្ចការជាក្រុម

នៅក្នុងការពិភាក្សា និងលំហាត់ជាក្រុមតូចៗជាច្រើន សិស្សអាចនឹងងាកចេញពីគោលបំណងរបស់សកម្មភាព ចាប់ផ្តើមពិភាក្សាពីបញ្ហាផ្ទាល់ខ្លួន ឬមិនខិតខំចង់រៀនសូត្រ ។ សូមបន្តចូលរួមយ៉ាងសកម្មដោយដើរមើលពីក្រុមមួយទៅក្រុមមួយ ហើយពិនិត្យមើលសកម្មភាពនោះ ដើម្បីជួយសិស្សឲ្យផ្តោតយកចិត្តទុកដាក់ទៅលើកិច្ចការ ហើយទទួលបានលទ្ធផលច្រើនបំផុតមកពីកិច្ចការនោះ ។

សិស្សទី ១

សូមអញ្ជើញក្រុមរបស់អ្នកឲ្យនឹកស្រមៃថា ពួកគេបានចូលរួមក្នុងការប្រជុំសាក្រាម៉ង់មួយ ដែលមានអ្នកទើបតែត្រឡប់មកពីបេសកកម្មម្នាក់បានឡើងនិយាយអំពីបេសកកម្មរបស់គាត់ ។ ខណៈពេលគាត់កំពុងនិយាយ គាត់បានលើកឡើងថា គាត់បានជ្រមុជទឹកឲ្យមនុស្សពីរបីនាក់ ។ លុះមួយសប្តាហ៍ក្រោយមក មានអ្នកទើបត្រឡប់មកពីបេសកកម្មម្នាក់ទៀតបានឡើងនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់អំពីបេសកកម្មរបស់នាង ហើយបានលើកឡើងថា នាងបានបង្រៀនមនុស្សជាច្រើន ហើយនៅទីបំផុតមនុស្សទាំងនោះបានជ្រមុជទឹកបន្ទាប់ពីនាងបានឆ្លាស់ចេញទៅតំបន់ផ្សេង ។

- **តើអ្នកនឹងឆ្លើយតបបែបណា ប្រសិនបើមានមនុស្សម្នាក់និយាយថា អ្នកផ្សព្វផ្សាយសាសនាដែលជ្រមុជទឹកមនុស្សបានពីរបីនាក់នៅក្នុងបេសកកម្ម មានភាពជោគជ័យច្រើនជាងអ្នកផ្សព្វផ្សាយសាសនាដែលអ្នករៀនរបស់នាងមិនបានជ្រមុជទឹកសោះរហូតដល់នាងបានចាកចេញពីតំបន់នោះ ?**

សូមសរសេរពាក្យ *បានដាំដុះ* និង *បានស្រោចទឹក* នៅលើក្រដាសមួយសន្លឹក ហើយបង្រៀនវាដល់ក្រុមរបស់អ្នក ។ សូមពន្យល់ថា ប៉ុលបានប្រៀបធៀបពួកអ្នកផ្សព្វផ្សាយសាសនាទៅនឹងមនុស្សដែលបានដាំគ្រាប់ពូជ ហើយស្រោចទឹកវា ។ សូមរំឭកក្រុមរបស់អ្នកថា ពួកបរិសុទ្ធនៅកូរិនថូសបានចាប់ផ្តើមបំបែកខ្លួនជាក្រុមតាមអ្នកដែលបានជ្រមុជទឹកឲ្យពួកគេ ។ ពួកគេបានជឿថា ស្ថានភាពរបស់ពួកគេនៅក្នុងសាសនាចក្រគឺពឹងផ្អែកទៅលើសារៈសំខាន់នៃបុគ្គលដែលបានជ្រមុជទឹកឲ្យពួកគេនោះ ។ (សូមមើល កូរិនថូសទី ១ ១:១០–១៦) ។

សូមប្តូរវេនជាមួយនឹងមិត្តរួមក្រុមអ្នកអាននៅក្នុង កូរិនថូសទី ១ ៣:៤–៩ ឲ្យឮៗ ។ ចូរសុំឲ្យក្រុមអ្នកផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយអ្វីខ្លះ អំពីពួកអ្នកផ្សព្វផ្សាយសាសនាដែលធ្លាប់បង្រៀន ហើយបានជ្រមុជទឹកដល់ប្រជាជននៅកូរិនថូស ។

- យោងតាម ខទី ៥ តើប៉ុលបាននិយាយថាលោក និងអ័ប៉ុឡូសជានរណា ? (សូមពន្យល់ថា *អ្នកបម្រើ* មានន័យថា ពួកអ្នកបម្រើអ្នកទទួលភារៈកិច្ចតាមបង្គាប់អ្នកប្រើ) ។
- យោងតាម ខទី ៦–៧ តើប៉ុលបាននិយាយអ្វីខ្លះអំពីពួកអ្នកផ្សព្វផ្សាយសាសនា ដែលបានដាំដុះគ្រាប់ពូជនៃដំណឹងល្អ និងពួកអ្នកផ្សព្វផ្សាយសាសនាដែលជួយគ្រាប់ពូជទាំងនោះឲ្យលូតលាស់ ?

ប្រសិនបើចាំបាច់ សូមចង្អុលបង្ហាញឃ្លា « អ្នកសាបព្រោះ និងអ្នកដែលស្រោច នោះមិនមែនជាអ្វីទេ » នៅក្នុង ខទី ៧ ហើយពន្យល់ថា ប៉ុលបានប្រើឃ្លាទាំងនេះដើម្បីបង្រៀនថា តួនាទីទាំងនេះ គ្មានតួនាទីណាមួយសំខាន់ជាងតួនាទីរបស់ព្រះឡើយ ។

- តើ « ស្រេចហើយនឹងព្រះដែលធ្វើឲ្យដុះវិញទេតើ » (ខទី ៧) មានន័យដូចម្តេច ? (គឺជាព្រះទេតើដែលបណ្តាលចិត្តមនុស្សឲ្យផ្លាស់ប្តូរតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយដឹកនាំពួកគេទៅរកការប្រែចិត្តជឿ ពុំជាអស់អ្នកបង្រៀន ហើយជ្រមុជទឹកនោះឡើយ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង កូរិនថូសទី ១ ៣:៦–៧ អំពីតួនាទីរបស់យើង និងតួនាទីរបស់ព្រះនៅក្នុងការជួយមនុស្សដទៃឲ្យប្រែចិត្តជឿលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ? (បន្ទាប់ពីក្រុមរបស់អ្នកបានឆ្លើយហើយ សូមអញ្ជើញពួកគេឲ្យសរសេរសេចក្តីពិតខាងក្រោមនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ កូរិនថូសទី ១ ៣:៦–៧ ៖ **យើងអាចជួយមនុស្សដទៃទៀតឲ្យរៀនអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបាន ប៉ុន្តែមនុស្សបានប្រែចិត្តជឿតែតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ**) ។

សូមបញ្ជាក់ថា ដើម្បីឲ្យមនុស្សទទួលបានព្រះវិញ្ញាណបរិសុទ្ធ ហើយប្រែចិត្តជឿ ពួកគេត្រូវធ្វើផ្នែករបស់ខ្លួនដោយអនុវត្តសេចក្តីជំនឿ ហើយធ្វើតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

- តើអ្នកគិតថា ការដឹងសេចក្តីពិតនេះអាចជួយពួកបរិសុទ្ធនៅកូរិនថូសឲ្យកាន់តែមានសាមគ្គីភាពខ្លាំងឡើងយ៉ាងដូចម្តេច ?

ចូរសួរដល់ក្រុមរបស់អ្នកថា តើសេចក្តីពិតនេះអាចជួយពួកគេឲ្យឆ្លើយតបនៅក្នុងសាច់រឿងអំពីមនុស្សពីរនាក់ ដែលទើបត្រឡប់មកពីបេសកកម្មវិញបានយ៉ាងដូចម្តេច ?

- ហេតុអ្វីវាជារឿងសំខាន់ចំពោះយើងដើម្បីមានការយល់ដឹងថា ព្រះវិញ្ញាណបរិសុទ្ធជាអង្គដែលធ្វើឲ្យមានការប្រែចិត្តជឿពុំមែនជាអំណាចផ្ទាល់ខ្លួនរបស់យើងនោះទេ ?

សិស្សទី ២

សូមសរសេរពាក្យ *គ្រឹះ* នៅលើក្រដាសមួយសន្លឹក ហើយបង្រៀនវាដល់ក្រុមរបស់អ្នក ។

- ហេតុអ្វីគ្រឹះគឺជាផ្នែកមួយដ៏សំខាន់នៃអគារ ?
- តើមានអ្វីនឹងកើតឡើង ប្រសិនបើគ្រឹះនោះមានបញ្ហា ?

សូមអញ្ជើញសមាជិកក្រុមរបស់អ្នកម្នាក់ឲ្យអាន កូរិនថូសទី១ ៣:១០ ឮៗ ហើយសួរសមាជិកក្រុមផ្សេងទៀតឲ្យរកមើលថា ប៉ុលបាននិយាយអ្វីខ្លះអំពីកិច្ចការផ្សព្វផ្សាយសាសនារបស់លោកនៅក្នុងចំណោមពួកកូរិនថូស ។

- តើប៉ុលបាននិយាយថា លោកបានធ្វើអ្វីខ្លះ កាលធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នៅកូរិនថូស ?
- តើអ្នកគិតថា ប៉ុលចង់មានន័យដូចម្តេច នៅពេលលោកមានប្រសាសន៍ថា « មានម្នាក់ទៀតជាអ្នកសង់ពីលើ » ?

សូមអញ្ជើញសមាជិកក្រុមរបស់អ្នកម្នាក់ទៀតអាន កូរិនថូសទី១ ៣:១១ ឮៗ ហើយសួរសមាជិកក្រុមផ្សេងទៀតឲ្យរកមើលថា ប៉ុលបានសង់គ្រឹះអ្វីសម្រាប់ពួកបរិសុទ្ធនៅកូរិនថូស ។

- តើប៉ុលបានសង់គ្រឹះអ្វី កាលលោកបានបង្រៀននៅកូរិនថូស ?
- យោងតាម ខទី ១១ តើនរណាគប្បីធ្វើជាគ្រឹះនៃជីវិតរបស់យើង ? (សូមប្រាកដថា ក្រុមអ្នកស្គាល់ពីសេចក្តីពិតដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាគ្រឹះដែលយើងត្រូវសង់លើ** ។ សូមពិចារណាអញ្ជើញក្រុមរបស់អ្នកឲ្យគូសចំណាំសេចក្តីពិតនេះនៅក្នុង ខទី ១១) ។
- តើការសង់នៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយយើងឲ្យស៊ូទ្រាំនឹងការល្បួង និងការសាកល្បងបានដោយរបៀបណា ? (សូមមើល ហេលេមិន ៥:១២) ។
- តើយើងអាចធ្វើឲ្យប្រាកដថា ជីវិតរបស់យើងត្រូវបានសង់នៅលើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសមាជិកក្រុមម្នាក់ឲ្យចែកចាយអំពីមនុស្សម្នាក់ដែលគាត់ស្គាល់ ហើយមានជីវិតឆ្លុះបញ្ចាំងពីការសង់លើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទ ។ ចូរសុំឲ្យសិស្សម្នាក់នេះពន្យល់ពីរបៀបដែលការសង់គ្រឹះលើព្រះគ្រីស្ទបានប្រទានពរដល់បុគ្គលម្នាក់នេះ ។

សូមអញ្ជើញសមាជិកក្រុមឲ្យដាក់គោលដៅមួយ ដែលនឹងជួយគាត់ឲ្យសង់លើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទ ។

សិស្សទី ៣

សូមសរសេរពាក្យ ព្រះវិហារបរិសុទ្ធ នៅលើក្រដាសមួយសន្លឹក ហើយបង្រៀនវាដល់ក្រុមរបស់អ្នក ។ សូមពន្យល់ថា ប៉ុល ប្រៀបប្រដូចអំពីព្រះវិហារបរិសុទ្ធជារឿយៗ ។ ដូចដែលបានកត់ត្រានៅក្នុង កូរិនថូសទី ១ ៣:១៦–១៧ លោកបានប្រើពាក្យ *ព្រះវិហារបរិសុទ្ធ* ដើម្បីសំដៅទៅលើក្រុមជំនុំរបស់សាសនាចក្រ ។

ចូរអញ្ជើញសមាជិកក្រុមអ្នកម្នាក់ឲ្យអានកូរិនថូស ទី១ ៣:១៦–១៧ ឮៗ ។ សូមឲ្យសិស្សក្នុងក្រុមផ្សេងទៀតផ្ទៀងតាមរកមើលថា តើប៉ុលបាននិយាយថា សមាជិកសាសនាចក្រនៅកូរិនថូសត្រូវការយល់ដឹងពីអ្វីខ្លះ ។ សូមពន្យល់ថា *ខ្លួនអ្នករាល់គ្នា* (ខទី ១៦) សំដៅទៅលើក្រុមជំនុំរបស់សាសនាចក្រ ហើយថាឃ្លា « បើអ្នកណាបង្ខូចព្រះវិហារនៃព្រះ » (ខទី ១៧) សំដៅទៅលើមនុស្សគ្រប់គ្នាដែលព្យាយាមបំផ្លាញរាស្ត្ររបស់ព្រះ ។

- យោងតាមខទី ១៦ តើប៉ុលចង់ឲ្យសមាជិកសាសនាចក្រយល់អំពីអ្វីខ្លះ ទាក់ទងនឹងក្រុមជំនុំរបស់ពួកគេ ?

ទោះជាកូរិនថូស ទី១ ៣:១៦–១៧ ទំនងជាសំដៅទៅលើសាសនាចក្រទាំងមូលថាជាក្រុមជំនុំមួយក្តី ប៉ុន្តែខគម្ពីរទាំងនេះក៏អាចអនុវត្តទៅនឹងរូបកាយរបស់យើងបានដែរ ។

- តើកូរិនថូសទី១ ៣:១៦–១៧ អាចអនុវត្តចំពោះរូបកាយរបស់យើងបានយ៉ាងដូចម្តេច ? តើអ្វីជាលទ្ធផលនៃបង្ខូចរូបកាយរបស់យើង ?

សូមសង្ខេបកូរិនថូស ទី១ ៣:១៨–២៣ ដោយពន្យល់ទៅក្រុមរបស់អ្នកថា ប៉ុលបានបង្រៀនពួកបរិសុទ្ធថា ប្រាជ្ញាពិតគឺមាននៅក្នុងព្រះយេស៊ូវគ្រីស្ទ ហើយប្រាជ្ញាខាងលោកិយគឺ « ជាសេចក្តីល្ងង់ល្ងើនៅចំពោះព្រះ » (ខទី ១៩) ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីអ្វីដែលពួកគេបានរៀននៅក្នុងក្រុមរបស់ពួកគេ និងអ្វីដែលពួកគេនឹងធ្វើដោយសារតែអ្វីដែលពួកគេបានរៀន ។

កូរិនថូសទី ១ ៤

ប៉ុលប្រាប់ពួកបរិសុទ្ធនៅកូរិនថូសកុំឲ្យគិតថា មានមនុស្សខ្លះល្អជាងអ្នកដទៃផ្សេងទៀត

សូមពន្យល់ថា ដោយផ្អែកទៅលើពាក្យទូន្មានរបស់ប៉ុល ដែលបានកត់ត្រានៅក្នុងកូរិនថូសទី១ ៤:១–៣ វាបង្ហាញថា មានសមាជិកសាសនាចក្រមួយចំនួននៅកូរិនថូសបានកាត់សេចក្តីចំពោះការងាររបស់ប៉ុល ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនា និងជាថ្នាក់ដឹកនាំមួយរូបរបស់សាសនាចក្រ ។ ពួកគេអាចនឹងងឿងឆ្ងល់ពីការកាត់សេចក្តី ឬគំនិតរបស់លោកដែលថា ប្រហែលជាមានមនុស្សម្នាក់ទៀតអាចធ្វើកិច្ចការមួយបានប្រសើរជាង ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៤:៣–៥ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានឆ្លើយតបទៅនឹងការកាត់សេចក្តីរបស់ពួកគេយ៉ាងដូចម្តេច ។

- តើប៉ុលបានឆ្លើយតបទៅនឹងការកាត់សេចក្តីរបស់ពួកគេយ៉ាងដូចម្តេច ?
- ហេតុអ្វីប៉ុលពុំបានខ្វល់ខ្វាយអំពីការកាត់សេចក្តីរបស់អ្នកដទៃ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងខទី ៥ អំពីរបៀបដែលព្រះអម្ចាស់នឹងកាត់សេចក្តីយើង ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតមួយដែលស្រដៀងនឹងសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់នឹងកាត់សេចក្តីយើងដោយយុត្តិធម៌ ដោយសារទ្រង់ជ្រាបពីគ្រប់ការណ៍ទាំងអស់រួមទាំងគំនិត និងចេតនានៅក្នុងដួងចិត្តរបស់យើងទៀតផង**) ។
- តើការជឿលើសេចក្តីពិតនេះអាចជួយដល់មនុស្សម្នាក់ដែលត្រូវបានកាត់សេចក្តីដោយអយុត្តិធម៌បានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កូរិនថូស ទី១ ៤:៦–៧ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលថាប៉ុលបានបង្រៀនពួកបរិសុទ្ធអំពីអ្វីខ្លះទាក់ទងនឹងទំនាក់ទំនងរបស់ពួកគេជាមួយនឹងសមាជិកដទៃទៀត រួមទាំងថ្នាក់ដឹកនាំសាសនាចក្រផងដែរ ។

- យោងតាម ខទី ៦ តើប៉ុលបានប្រាប់ពួកបរិសុទ្ធកុំឲ្យធ្វើអ្វីខ្លះ នៅពេលពួកគេសង្កេតឃើញនូវភាពខុសគ្នានៅក្នុងពួកអ្នកផ្សព្វផ្សាយសាសនា និងថ្នាក់ដឹកនាំសាសនាចក្រ ? (ពួកគេពុំគួរ « មានសេចក្តីអំនួត » ហើយគិតថាមនុស្សខ្លះល្អជាងមនុស្សផ្សេងទៀតនោះទេ) ។
- ដោយផ្អែកលើសំណួររបស់ប៉ុលដែលបានកត់ត្រានៅក្នុងខទី ៧ តើនរណាដែលប្រទានឲ្យមនុស្សនូវទេពកោសល្យ និងសមត្ថភាពខុសៗគ្នាទាំងនោះ ?
- តើពាក្យទូន្មានរបស់ប៉ុលអាចជួយយើងយ៉ាងដូចម្តេច នៅពេលយើងគិតអំពីថ្នាក់ដឹកនាំ និងពួកគ្រូបង្រៀនក្នុងសាសនាចក្ររបស់យើង ?

សូមសង្ខេប កូរិនថូសទី១ ៤:៨–២១ ដោយពន្យល់ថា ប៉ុលបានប្រាប់ដល់ពួកបរិសុទ្ធនៅកូរិនថូសថា ពួកសាវករបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានហៅឲ្យរងទុក្ខ ដោយសារតែសេចក្តីទុច្ចរិតនៃលោកិយនេះ ។ លោកិយកាត់សេចក្តីពួកសាវក និងថ្នាក់ដឹកនាំផ្សេងទៀតក្នុងសាសនាចក្រថាជា « មនុស្សល្ងង់ល្ងើ » (ខទី ១០) ដោយសារការខិតខំដើរតាមព្រះគ្រីស្ទ ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

មេរៀន ១០៥

កូរិនថូសទី១ ៥–៦

សេចក្តីផ្តើម


សាវកប៉ុលបានព្រមានពួកបរិសុទ្ធទាស់នឹងការអនុញ្ញាត ឲ្យពួកទុច្ចរិតជះឥទ្ធិពលលើពួកគេ ។ លោកបានព្រមានពួកបរិសុទ្ធឲ្យចៀសវាងពីទស្សនៈ និងទម្លាប់អសីលធម៌ដែលបាននិយមនៅកូរិនថូស ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ៥

ប៉ុលព្រមានពួកបរិសុទ្ធទាស់នឹងការសេពគប់នឹងជនដែលជ្រើសដោយចេតនា នឹងធ្វើអំពើបាប

សូមគូរូបសាមញ្ញមួយអំពីផ្លែឈើរលួយមួយចាន ហើយមានតែផ្លែឈើស្រស់មួយបំណែកនៅក្នុងចាននោះ ។ អ្នកអាចដាក់បង្ហាញផ្លែឈើរលួយមួយចំណិតក៏បាន ។



- តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកបន្តដាក់ផ្លែឈើរលួយនោះឲ្យលាយឡំជាមួយផ្លែឈើស្រស់ៗផ្សេងទៀតនោះ ?
- តើផ្លែឈើរលួយមួយចំណិតនោះអាចតំណាងឲ្យអ្វីនៅក្នុងជីវិតយើង ? (ឥទ្ធិពលដែលអាចបំផ្លាញយើង) ។

នៅពេលសិស្សសិក្សា កូរិនថូសទី ១ ៥ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយពួកគេឲ្យតបតនឹងឥទ្ធិពលអាក្រក់នៅក្នុងជីវិតរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៥:១–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលទម្លាប់អាក្រក់មួយ នៅក្នុងចំណោមពួកបរិសុទ្ធនៅកូរិនថូស ។

- តើទម្លាប់អាក្រក់អ្វីទៅដែលមាននៅក្នុងចំណោមពួកបរិសុទ្ធនៅកូរិនថូស ? (សូមពន្យល់ថា អំពើកំផិត សំដៅទៅលើទំនាក់ទំនងផ្លូវភេទណាមួយក្រៅចំណងអាពាហ៍ពិពាហ៍ ។ មានសមាជិកម្នាក់នៅកូរិនថូសបានធ្វើអំពើបាបខាងផ្លូវភេទជាមួយនឹងម្តាយចុងរបស់ខ្លួន) ។
- យោងតាម ខទី ២តើប៉ុលបានប្រឹក្សាឲ្យថ្នាក់ដឹកនាំសាសនាចក្រធ្វើអ្វីខ្លះចំពោះបុរសម្នាក់នេះ ? (សូមពន្យល់ថា ឃ្លា « ឲ្យថយចេញពីចំណោមអ្នករាល់គ្នា » នៅក្នុង ខទី ២ មានន័យថា អ្នកធ្វើបាបនោះគួរត្រូវបានកាត់កាលចេញពីសាសនាចក្រ) ។

សូមចង្អុលបង្ហាញថា ថ្នាក់ដឹកនាំសាសនាចក្របានពិចារណាពីកត្តាជាច្រើន មុនធ្វើការកាត់កាលចេញ ឬធ្វើការដាក់វិន័យតាមទម្រង់ណាមួយនៅក្នុងសាសនាចក្រ ។ បន្ថែមពីលើការសម្រេចចិត្តថា អំពើរំលងនោះមានភាពធ្ងន់ធ្ងរដល់កម្រិតណា ថ្នាក់ដឹកនាំសាសនាចក្រពិចារណាពីគោលបំណងជាច្រើនសម្រាប់ការដាក់វិន័យរបស់សាសនាចក្រ ៖ ដើម្បីជួយបុគ្គលម្នាក់ឲ្យប្រែចិត្ត ដើម្បីការពារជនដែលអាចរងឥទ្ធិពលអវិជ្ជមានពីទង្វើនៃជននោះ ឬការបែកសាយនៃជំនឿរបស់បុគ្គលនោះ និងដើម្បីការពារសេចក្តីទៀងត្រង់នៃការបង្រៀនរបស់សាសនាចក្រ (សូមមើល « Church Discipline » mormonnewsroom.org/articles/church–discipline) ។

សូមអញ្ជើញសិស្សអាន កូរិនថូសទី១ ៥:៦–៧ ឲ្យឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលរឿបប្រៀបធៀបដែលប៉ុលបានប្រើដើម្បីពន្យល់ថា ហេតុអ្វីបុគ្គលនេះត្រូវដកចេញពីសាសនាចក្រ ។

- តើប៉ុលបានប្រៀបធៀបពួកអ្នកធ្វើបាបដែលមិនបានប្រែចិត្តទៅនឹងអ្វី ? (សូមពន្យល់ថាដំបែ ឬមេនំប៉័ង នៅទីបំផុតនឹងធ្វើឲ្យនំប៉័ងខូច ឬទៅជាដុះផ្សិត) ។
- តើត្រូវដាក់ដំបែប៉ុន្មានដើម្បីឲ្យមានប្រសិទ្ធិភាពចំពោះដុំម្សៅទាំងមូល ?
- តើម្សៅតំណាងឲ្យអ្វី ? (សាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ) ។
- តើអ្នកនឹងសង្ខេបពីអត្ថន័យនៃរឿងប្រៀបធៀបនេះ ទៅជាគោលការណ៍មួយយ៉ាងដូចម្តេច ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្គាល់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **ប្រសិនបើយើងជ្រើសរើសសេពគប់ជាមួយនឹងអស់អ្នកដែលឱបក្រសោបអំពើបាប នោះយើងអាចរងឥទ្ធិពលពីអំពើទុច្ចរិតរបស់ពួកគេ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៥:៩–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពាក្យទូន្មាន ដែលប៉ុលបានផ្តល់ឲ្យដល់ពួកបរិសុទ្ធនៅកូរិនថូស ។

- តើប៉ុលបានណែនាំពួកបរិសុទ្ធនៅកូរិនថូសឲ្យចៀសវាងអ្វី ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតពីការទូន្មានរបស់ប៉ុល កុំឲ្យសេពគប់នឹងពួកអ្នកប្រព្រឹត្តអំពើសាហាយស្មន់ ឬមនុស្សផ្សេងទៀតដែលឱបក្រសោបអំពើបាប សូមឲ្យសំណៅនៃសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ នែល អេ ម៉ាក់ស្វែល ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ដល់សិស្ស ។ សូមឲ្យសិស្សម្នាក់អានវាឮៗ ៖

« សូមកុំសេពគប់នឹងពួកអ្នកប្រព្រឹត្តអំពើសាហាយស្មន់—ពុំមែនដោយសារអ្នកជាមនុស្សល្អពេកសម្រាប់ពួកគេនោះទេ ប៉ុន្តែដូចជា [សិ. អែស.] ល្ងីសបានសរសេរថា ដោយសារអ្នកមិនទាន់ល្អគ្រប់គ្រាន់នៅឡើយ ។ សូមចងចាំថា ស្ថានភាពអាក្រក់នានាអាចបំផ្លិចបំផ្លាញ សូម្បីតែមនុស្សល្អ » (« The Stern but Sweet Seventh Commandment » *New Era* ខែ មិថុនា ឆ្នាំ ១៩៧៩ ទំព័រ ៤២) ។

- តើការសេពគប់យ៉ាងជិតស្និទ្ធជាមួយនឹងជនដែលឱបក្រសោបអំពើបាប អាចធ្វើឲ្យសមត្ថភាពរបស់យើងដើម្បីធ្វើការជ្រើសរើសត្រឹមត្រូវចុះខ្សោយដូចម្តេច ?
- តើគំរូមួយចំនួននៃស្ថានភាពអាក្រក់ ដែលអាចបំផ្លិចបំផ្លាញមនុស្សល្អមានអ្វីខ្លះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដោយមិនបង្ខូចដល់បទដ្ឋានរបស់យើងដើម្បីជួយបុគ្គលដែលបានឱបក្រសោបអំពើបាបទាំងនោះ ? (យើងអាចអធិស្ឋានឲ្យពួកគេ បង្ហាញចិត្តសប្បុរស ហើយគោរពពួកគេក្នុងនាមជាកូនចៅនៃព្រះ ហើយធ្វើគំរូល្អមួយក្នុងការគោរពតាមព្រះបញ្ញត្តិ) ។


សូមអញ្ជើញសិស្សឲ្យពិចារណាប្រកបដោយការអធិស្ឋាននូវអ្វីដែលពួកគេអាចធ្វើ ដើម្បីជៈឥទ្ធិពលទៅលើមនុស្សដទៃទៀតតាមរបៀបវិជ្ជមានមួយដោយមិនបង្ខូចដល់បទដ្ឋានរបស់ពួកគេ ។

សូមសង្ខេប កូរិនថូសទី ១ ៥:១២–១៣ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា សាសនាចក្រមានការទទួលខុសត្រូវមួយដើម្បីហៅសមាជិកឲ្យប្រែចិត្ត ហើយនៅក្នុងករណីមួយចំនួនគឺដើម្បី « បណ្តេញ [ចេញពីសាសនាចក្រ] » (ខទី ១៣) ចំពោះជនដែលប្រព្រឹត្តអំពើរំលងយ៉ាងធ្ងន់ធ្ងរ ។

កូរិនថូសទី១ ៦

ប៉ុលបង្រៀនដល់ពួកបរិសុទ្ធអំពីសាមគ្គីភាព និងច្បាប់ព្រហ្មចារីភាព ។

ចូរគូរ រូប សាមញ្ញមួយទៀតនៅលើក្តារខៀនអំពីផ្លែឈើរលួយមួយចាន ហើយមានតែផ្លែឈើស្រស់មួយបំណែកនៅក្នុងចាននោះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា ពួកគេគ្លាប់មានការងឿងឆ្ងល់ពីរបៀបចៀសវាងពីអំពើបាបដែរឬទេ កាលដែលវាហ៊ឹមព័ទ្ធពួកគេនោះ ។ ចូរចង្អុលបង្ហាញថា រឿងនេះគឺជាការប្រឈមមួយដែលពួកបរិសុទ្ធនៅកូរិនថូសបានជួប ។



នៅពេលសិស្សសិក្សា កូរិនថូសទី១ ៦សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលប៉ុលបានបង្រៀន ដែលវាអាចជួយពួកគេឲ្យរស់នៅដោយសុចរិត ទោះជាត្រូវបានហ៊ឹមព័ទ្ធដោយឥទ្ធិពលអាក្រក់ក្តី ។

សូមសង្ខេប កូរិនថូសទី ១ ៦:១–៨ ដោយពន្យល់ថា ប៉ុលបានទូន្មានដល់ពួកបរិសុទ្ធកូរិនថូសឲ្យដោះស្រាយជម្លោះដោយសុចរិតនៅក្នុងចំណោមពួកគេជាជាងសម្រេចចិត្តឡើងទៅតុលាការភ្លាមៗនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៦:៩–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការអនុវត្តអំពើបាបនៅក្នុងកូរិនថូស ដែលប៉ុលបានបង្រៀនឲ្យសមាជិកសាសនាចក្រចៀសវាង ។

- តើឥរិយាបថអាក្រក់ប្រភេទណាដែលប៉ុលបានបង្រៀន ឲ្យសមាជិកសាសនាចក្រចៀសវាង ?
- យោងតាម ខទី ១១ តើបានរំឭកពួកបរិសុទ្ធទាំងនេះអំពីខ្លួនពួកគេនូវអ្វីខ្លះ ? (ពួកអ្នកប្រែចិត្តជឿជាច្រើនមកពីកូរិនថូសបានចូលរួមនៅក្នុងឥរិយាបថអាក្រក់ទាំងនេះ មុននឹងចូលរួមក្នុងសាសនាចក្រ ប៉ុន្តែពួកគេបានប្រែចិត្ត ហើយបានជ្រះស្អាតពីអំពើបាបរបស់ពួកគេ) ។

សូមពន្យល់ថា កូរិនថូសកាលពីបុរាណល្បីឈ្មោះខាងរឿងអសីលធម៌ ហើយពួកកូរិនថូសជាច្រើនបានលើកកម្ពស់គំនិត ដែលថារូបកាយរបស់យើងបានបង្កើតឡើងសម្រាប់ភាពរីករាយ ។ សូមសង្ខេបការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ កូរិនថូសទី ១ ៦:១២ ដោយពន្យល់ថា ប៉ុលបានបង្រៀនទាស់នឹងទស្សនៈថា គ្មានរឿងត្រូវ ឬខុសនោះទេ ។

- តើគំនិត និងការអនុវត្តនៅក្នុងកូរិនថូសស្រដៀងគ្នានឹងទំនោរ ដែលយើងបានឃើញនៅក្នុងពិភពលោកសព្វថ្ងៃនេះយ៉ាងដូចម្តេចដែរ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៦:១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីគោលបំណងនៃរូបកាយរបស់យើង ។

- តើប៉ុលបានបង្រៀនអ្វីខ្លះពីរូបកាយរបស់យើង ? (កាលពួកកូរិនថូសជាច្រើនទំនងជាជឿថា រូបកាយត្រូវបានបង្កើតឡើងសម្រាប់ភាពត្រេកត្រអាលខាងរូបកាយប៉ុណ្ណោះ នោះប៉ុលបានកែតម្រូវទស្សនៈនោះដោយបង្រៀនថា រូបកាយយើងត្រូវបានបង្កើតឡើងដើម្បីបំពេញគោលបំណងរបស់ព្រះអម្ចាស់) ។

សូមសង្ខេប កូរិនថូសទី ១ ៦:១៤–១៧ ដោយពន្យល់ថា ជនដែលចូលរួមនឹងសាសនាចក្របានចូលរួមនឹងព្រះគ្រីស្តក្នុងនាមជា « សមាជិក » ខាងវិញ្ញាណនៃព្រះកាយរបស់ទ្រង់ ។ ប៉ុលក៏បានពន្យល់ផងដែរថា រឿងអសីលធម៌ខាងផ្លូវភេទគឺមិនដែលចុះសម្រុងជាមួយនឹងទំនាក់ទំនងខាងវិញ្ញាណមួយជាមួយនឹងព្រះយេស៊ូវគ្រីស្តឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៦:១៨ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ (អ្នកគួរចង្អុលបង្ហាញថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ កូរិនថូសទី១ ៦:១៨ ផ្លាស់ប្តូរឃ្លា « នៅខាងក្រៅរូបកាយ » ទៅជា « ទាស់នឹងព្រះកាយរបស់ព្រះគ្រីស្ទ ») ។

- តើប៉ុលបានបង្រៀនពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ?
- តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះ អំពីជនដែលប្រព្រឹត្តអំពើសហាយស្មន់ ? (អ្នកគួរអញ្ជើញសិស្សឲ្យគូសចំណាំពាក្យនៅក្នុងខទី ១៨ដែលបង្រៀនពីសេចក្តីពិតដូចខាងក្រោម ៖ **ជនដែលប្រព្រឹត្តអំពើសហាយស្មន់ នោះឈ្មោះថាធ្វើបាបដល់រូបកាយខ្លួនឯង**) ។

សូមពន្យល់ថា បន្ទាប់មកទៀត ប៉ុលបានបង្រៀនពីហេតុផលដែលការសហាយស្មន់ ឬភាពអសីលធម៌ខាងផ្លូវភេទ គឺជាអំពើបាបមួយដែលមាន « ឈ្មោះថា ធ្វើបាបទាស់នឹងរូបកាយខ្លួនឯង » ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៦:១៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រៀបធៀបរូបកាយយើងទៅនឹងអ្វី ។

- តើប៉ុលបានប្រៀបធៀបរូបកាយយើងនឹងអ្វី ?

សូមដាក់តាំងរូបភាពនៃព្រះវិហារបរិសុទ្ធមួយ ។

- តើព្រះវិហារបរិសុទ្ធ និងអគារផ្សេងទៀតខុសពីគ្នាដូចម្តេច ?
- តើអ្នកនឹងសង្ខេបសេចក្តីពិត ដែលប៉ុលបានបង្រៀននៅក្នុងខទី ១៩ យ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **រូបកាយយើងគឺជាព្រះវិហារបរិសុទ្ធរបស់ព្រះ ដែលព្រះវិញ្ញាណអាចគង់នៅបាន**) ។
- តើការយល់ដឹងថា រូបកាយរបស់យើងគឺជាព្រះវិហារបរិសុទ្ធ អាចជះឥទ្ធិពលដល់ការប្រព្រឹត្តរបស់យើងទៅលើរូបកាយរបស់យើង និងរូបកាយរបស់មនុស្សដទៃទៀតយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ ។ ចូរឲ្យសិស្សក្នុងថ្នាក់ស្តាប់រកការយល់ដឹងបន្ថែមទៀតថា ការយល់ដឹងពីសេចក្តីពិតនេះអាចជះឥទ្ធិពលដល់ការប្រព្រឹត្តរបស់យើងទៅលើរូបកាយរបស់យើងយ៉ាងដូចម្តេច ។



« ដោយទទួលស្គាល់សេចក្តីពិតទាំងនេះ [នៅក្នុង កូរិនថូសទី១ ៦:១៩–២០] . . . នោះយើងនឹងមិនបង្ខូចរូបកាយរបស់យើងដោយការសាក់ខ្លួន ឬធ្វើឲ្យចុះខ្សោយដោយសារការប្រើថ្នាំ ឬប្រមាថវាដោយអំពើសហាយស្មន់ អំពើកំផិត ឬរឿងអសីលធម៌ឡើយ ។ . . . ដោយសាររូបកាយយើងគឺជាឧបករណ៍សម្រាប់វិញ្ញាណយើង នោះវាជារឿងដ៏សំខាន់ដែលយើងត្រូវមើលថែវាឲ្យអស់ពីលទ្ធភាព ។ យើងគួរគិតឲ្យបានដិតដល់ពីអំណាចរបស់វា ដើម្បីបម្រើ ហើយជួយជម្រុញដល់កិច្ចការរបស់ព្រះគ្រីស្ទ » (« Reflections on a Consecrated Life » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១៧) ។

- តើអ្នកគិតថា ប៉ុលចង់មានន័យដូចម្តេចដោយពោលថា « អ្នករាល់គ្នាមិនមែនជាខ្លួនទេ » នៅក្នុង ខទី ១៩ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៦:២០ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីមូលហេតុដែលរូបកាយយើងពុំមែនជារបស់យើង ។

- តើឃ្លាអ្វីទៅដែលបង្ហាញពីហេតុផលថា រូបកាយយើងពុំមែនជារបស់យើង ? (សូមពន្យល់ថាឃ្លា « ចេញថ្លៃលោះ » មានន័យថា ការប្រោសលោះ ឬការនាំត្រឡប់មកវិញតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ) ។
- តើអ្នកនឹងសង្ខេបសេចក្តីពិតនៅក្នុងខទី ១៩–២០ យ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមពិចារណាអញ្ជើញពួកគេឲ្យសរសេរសេចក្តីពិតខាងក្រោមនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខទី ១៩–២០ ៖ **ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបានចេញថ្លៃលោះយើង នោះរូបកាយយើងពុំមែនជារបស់យើងឡើយ**) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖



« សូមកុំពោល ៖ ‹ តើវាធ្វើឲ្យនរណាឈឺចាប់ ? ហេតុអ្វីមានសេរីភាពបន្តិចក៏មិនបាន ? ខ្ញុំអាចធ្វើអំពើរំលងនៅពេលនេះ ហើយចាំប្រែចិត្តនៅពេលក្រោយ › ។ សូមកុំលួងលោមគ្មានមេត្តាបែបនេះឡើយ ។ បងប្អូនមិនអាចគ្មានទោសដោយ ‹ ឆ្គាងព្រះគ្រីស្ទ › បានទេ [សូមមើល ហេព្រើរ ៦:៦] ។ ‹ រត់ពីការសហាយស្មន់ › [កូរិនថូសទី១ ៦:១៨] ប៉ុលបានស្រែក ហើយរត់គេចខ្លួនដូចជាមិនបាន ‹ *ប្រព្រឹត្តអំពើអ្វីដូចនោះឲ្យសោះ* › [គ. និង ស. ៥៩:៦ការគូសបញ្ជាក់បានបន្ថែម] គោលលទ្ធិ និង សេចក្តីសញ្ញាបន្ថែម ។ ហេតុអ្វី ? ពិតណាស់ ដោយសារហេតុផលមួយ គឺដោយសារការរងទុក្ខទាំងខាងរូបកាយ និងខាងវិញ្ញាណដ៏មិនអាចគណនាបានដែលព្រះអង្គសង្គ្រោះនៃលោកិយបានស៊ូទ្រាំដើម្បីឲ្យយើង *អាច* រួចខ្លួន [សូមមើលជាពិសេស គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៥–២០] ។ យើងជំពាក់គុណទ្រង់ចំពោះរឿងនោះ ។ ពិតណាស់ យើងជំពាក់គុណទ្រង់គ្រប់យ៉ាងសម្រាប់រឿងនោះ » (« Personal Purity » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៧៦) ។

- តើការចងចាំថា រូបកាយយើងពុំមែនជារបស់យើង អាចជះឥទ្ធិពលដល់ការជ្រើសរើសរបស់យើងទាក់ទងនឹងរូបកាយរបស់យើងយ៉ាងដូចម្តេច ?

សូមឲ្យសិស្សមើលរូបភាពផ្លែឈើស្រស់មួយបំណែក ដែលហ៊ុមព័ទ្ធដោយផ្លែឈើរលួយនៅលើក្តារខៀន ។

- តើការយល់ដឹងសេចក្តីពិតទាំងនេះអំពីរូបកាយយើង អាចជួយយើងឲ្យបន្តមានភាពបរិសុទ្ធបានដោយរបៀបណា នៅពេលយើងត្រូវបានហ៊ុមព័ទ្ធទៅដោយអំពើទុច្ចរិតនោះ ?

កូរិនថូសទី១ ៦:១៩–២០

គឺជាចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះតាមរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

ចូរថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានពិភាក្សា ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអារម្មណ៍ ឬការបំផុសគំនិតដែលពួកគេបានទទួលនៅក្នុងមេរៀននេះ ហើយធ្វើតាមការបំផុសគំនិតទាំងនោះ ។

ចំណេះចំណានខគម្ពីរ—កូរិនថូសទី ១ ៦:១៩–២០

សូមអញ្ជើញសិស្សឲ្យសរសេរការឡើងនិយាយសង្ខេបមួយដោយផ្អែកលើ កូរិនថូសទី១ ៦:១៩–២០ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់បញ្ចូលចំណុចដូចខាងក្រោម ៖ (១) ព័ត៌មានផ្ទៃរឿងដែលទាក់ទងនឹងវគ្គគម្ពីរនេះ (ព័ត៌មានផ្ទៃរឿងដែលអាចរកបាននៅលើកាត ចំណេះចំណានខគម្ពីរ) (២) គោលការណ៍ដែលវាបង្រៀន និង (៣) បទពិសោធន៍ផ្ទាល់ខ្លួន ដែលបង្ហាញពីសេចក្តីពិត ដែលវគ្គគម្ពីរនេះបង្រៀន ។ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ធ្វើបទបង្ហាញការនិយាយរបស់ពួកគេក្នុងថ្នាក់ ។ សូមលើកទឹកចិត្តសិស្សឲ្យពិចារណាពីឱកាស ដែលពួកគេមានដើម្បីបង្ហាញការនិយាយរបស់ខ្លួនដល់គ្រួសារ ឬនៅឯសាសនាចក្រ ។

មេរៀនសិក្សានៅផ្ទះ

រ៉ូម ៨–កូរិនថូសទី១ ៦ (មេរៀនទី ២១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា រ៉ូម ៨–១៦ និងកូរិនថូសទី ១ ១–៦(មេរៀនទី ២១) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (រ៉ូម ៨–១១)

នៅក្នុងការបង្រៀនរបស់ប៉ុលដល់ពួកបរិសុទ្ធរ៉ូម អំពីការការផ្តោតគំនិតខាងវិញ្ញាណឬខាងកាមគុណ នោះសិស្សបានរៀនថា ប្រសិនបើយើងធ្វើតាមព្រះចេស្តានៃព្រះវិញ្ញាណ នោះយើងអាចយកឈ្នះលើទំនោររបស់មនុស្សខាងសាច់ឈាម ហើយមិនធ្វើអំពើបាប ។ សិស្សក៏រកឃើញសេចក្តីពិតដូចតទៅនេះដែរ ៖ ប្រសិនបើយើងជាកូនចៅនៃសេចក្តីសញ្ញាជំនោះត្រង់របស់ព្រះ នោះយើងអាចត្រងមតេកជាមួយនឹងព្រះយេស៊ូវគ្រីស្ទនូវអ្វីៗទាំងអស់ដែលព្រះវរបិតាសួគ៌មាន ។ ប្រសិនបើយើងស្រឡាញ់ព្រះ នោះគ្រប់ការណ៍ទាំងអស់នឹងផ្សំគ្នា សម្រាប់សេចក្តីល្អដល់យើង ។ យើងអាចយកឈ្នះអស់គ្រប់ទាំងឧបសគ្គ និងសេចក្តីឈឺចាប់ទាំងអស់នៅក្នុងជីវិតរមែងស្លាប់បាន តាមរយៈព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើយើងទទួល ហើយប្រតិបត្តិតាមព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ នោះយើងអាចទទួលបានពរជ័យនៃសេចក្តីសញ្ញារបស់ព្រះ ហើយត្រូវបានសង្គ្រោះ ។

ថ្ងៃទី ២ (រ៉ូម ១២–១៦)

នៅក្នុង រ៉ូម ១២–១៣សិស្សបានរកឃើញថា ព្រះវរិពីងឲ្យយើងលះបង់ជីវិតរបស់យើងថ្វាយដល់ទ្រង់ ហើយចៀសវាងពីការអនុលោមតាមលោកិយ ហើយប្រសិនបើយើងធ្វើដូច្នេះ នោះយើងអាចប្រែក្លាយកាន់តែដូចជាព្រះគ្រីស្ទ ។ នៅក្នុង រ៉ូម ១៤–១៥សិស្សបានរៀនថា ទោះជាពុំបានលើកឡើងនៅក្នុងបទបញ្ញត្តិជាក់លាក់ណាមួយក្តី ប៉ុន្តែយើងត្រូវចៀសវាងពីការកោតសេចក្តីចំពោះការជ្រើសរើសរបស់មនុស្សដទៃទៀត ហើយត្រូវពិចារណាពីរបៀបដែលការជ្រើសរើសរបស់យើងជះឥទ្ធិពលដល់អ្នកដទៃ ។ សិស្សក៏រៀនផងដែរថា ព្រះគម្ពីរត្រូវបានសរសេរឡើងដើម្បីបង្រៀនយើង ហើយផ្តល់សេចក្តីសង្ឃឹមដល់យើង ។

ថ្ងៃទី ៣ (កូរិនថូស ទី១ ១–២)

នៅក្នុងសំបុត្រមួយដល់ពួកបរិសុទ្ធកូរិនថូស ប៉ុលបានលើកឡើងនូវកែងល់ និងសំណួរមួយចំនួន ។ សិស្សបានរៀនចេញមកពីការសរសេររបស់លោកថា ព្រះអម្ចាស់ពីងឲ្យយើងដែលជាពួកបរិសុទ្ធ ឲ្យចេះសាមគ្គីគ្នា ហើយលុបបំបាត់ចោលការបែងចែកបក្សពួក និងការឈ្លោះទាស់ទែងគ្នា ហើយថាយើងអាចដឹង ហើយយល់ពីរឿងរបស់ព្រះតែតាមរយៈព្រះវិញ្ញាណប៉ុណ្ណោះ ។

ថ្ងៃទី ៤ (កូរិនថូស ទី១ ៣–៦) ។

នៅក្នុងមេរៀននេះ សិស្សបានបន្តសិក្សាសំបុត្ររបស់ប៉ុលដល់ពួកបរិសុទ្ធកូរិនថូស ។ សិស្សបានរៀនសេចក្តីពិតដូចខាងក្រោមនេះចេញពីពាក្យសម្តីរបស់ប៉ុល ៖ យើងអាចជួយមនុស្សដទៃទៀតឲ្យរៀនអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបាន ប៉ុន្តែមនុស្សអាចប្រែចិត្តជឿបានតែតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ។ ព្រះអម្ចាស់នឹងកាត់សេចក្តីយើងដោយយុត្តិធម៌ ដោយសារទ្រង់ជ្រាបគ្រប់ការណ៍ទាំងអស់ រួមទាំងគំនិត និងចេតនានៅក្នុងដួងចិត្តរបស់យើងទៀតផង ។ ប្រសិនបើយើងជ្រើសរើសសេពគប់ជាមួយនឹងជនដែលឱបក្រសោបអំពើបាប នោះយើងអាចរងឥទ្ធិពលអំពើទុច្ចរិតរបស់ពួកគេ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់ដឹងពីរបៀបចៀសវាងពីអំពើបាប កាលណាវាហ៊ុមព័ទ្ធពួកគេ ។ លើសពីនេះទៀត ពួកគេនឹងរៀនថា ហេតុអ្វីការការក្សាខ្លួនយើងឲ្យបានបរិសុទ្ធជារឿងសំខាន់ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ៦

ប៉ុលបង្រៀនដល់ពួកបរិសុទ្ធអំពីសាមគ្គីភាព និងច្បាប់ព្រហ្មចារីភាព ។

នៅលើក្តារខៀន ចូរគូរ រូប ផ្លែឈើលួយមួយចាន ដោយមានតែផ្លែឈើស្រស់មួយចំណិតនៅក្នុងចាននោះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពួកគេធ្លាប់មានការងឿងឆ្ងល់ពីរបៀបចៀសវាងពីអំពើបាបដែរឬទេ កាលណាដែលវាហ៊ុមព័ទ្ធពួកគេនោះ ។



នៅពេលសិស្សសិក្សា កូរិនថូសទី១ ៦ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលសាវកប៉ុលបានបង្រៀន ដែលវាអាចជួយពួកគេឲ្យរស់នៅដោយសុចរិត ទោះជាត្រូវបានហ៊ុមព័ទ្ធដោយឥទ្ធិពលអាក្រក់ក្តី ។

សូមសង្កេប កូរិនថូសទី ១ ៦:១–៨ ដោយពន្យល់ថា ប៉ុលបានទូន្មានដល់ពួកបរិសុទ្ធកូរិនថូស ឲ្យដោះស្រាយជម្លោះនៅក្នុងចំណោមពួកគេដោយសុចរិតភាពជាជាងសម្រេចចិត្តឡើងទៅតុលាការភ្លាមៗនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៦:៩–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការអនុវត្តអំពើបាបនៅក្នុងកូរិនថូស ដែលប៉ុលបានបង្រៀនឲ្យសមាជិកសាសនាចក្រចៀសវាង ។

- តើតរិយាបថអាក្រក់ប្រភេទណា ដែលប៉ុលបានបង្រៀនឲ្យសមាជិកសាសនាចក្រចៀសវាង ?
- យោងតាម កូរិនថូសទី ១ ៦:១១ តើប៉ុលបានរំឭកពួកបរិសុទ្ធទាំងនេះអំពីខ្លួនពួកគេអ្វីខ្លះ ? (ពួកអ្នកប្រែចិត្តជឿមកពីកូរិនថូសជាច្រើន បានចូលរួមនៅក្នុងតរិយាបថអាក្រក់ទាំងនេះពីមុនចូលរួមក្នុងសាសនាចក្រ ប៉ុន្តែពួកគេបានប្រែចិត្ត ហើយបានជ្រះស្អាតពីអំពើបាបទាំងឡាយរបស់ពួកគេ) ។

សូមពន្យល់ថា ក្រុងកូរិនថូសកាលពីបុរាណល្បីឈ្មោះខាងរឿងអសីលធម៌ ហើយពួកកូរិនថូសជាច្រើនបានលើកកម្ពស់គំនិត ដែលថារូបកាយរបស់យើងបានបង្កើតឡើងសម្រាប់តាពីរកាយ ។ សូមសង្ខេបការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ កូរិនថូសទី១ ៦:១២ ដោយពន្យល់ថា ប៉ុល បានបង្រៀនទាស់នឹងទស្សនៈថា គ្មានរឿងត្រូវ ឬខុសនោះទេ ។

- តើគំនិត និងការអនុវត្តនៅក្នុងកូរិនថូសស្រដៀងគ្នាទៅនឹងទំនោរដែលយើងបានឃើញនៅក្នុងពិភពលោកសព្វថ្ងៃនេះយ៉ាងដូចម្តេចដែរ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៦:១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប៉ុលបានបង្រៀនអ្វីខ្លះអំពីគោលបំណងនៃរូបកាយរបស់យើង ។ (អ្នកគួរពន្យល់ថា ពាក្យ *បំណី* មានន័យថាម្ហូបអាហារ) ។

- តើប៉ុលបានបង្រៀនអ្វីខ្លះពីរូបកាយរបស់យើង ? (កាលពួកកូរិនថូសជាច្រើនទំនងជាជឿថា រូបកាយត្រូវបានបង្កើតឡើងសម្រាប់តែភាពសប្បាយត្រេកត្រអាលខាងរូបកាយប៉ុណ្ណោះ នោះប៉ុលបានកែតម្រូវទស្សនៈនោះដោយបង្រៀនថា រូបកាយយើងត្រូវបានបង្កើតឡើងដើម្បីសម្រេចគោលបំណងរបស់ព្រះអម្ចាស់) ។

សូមសង្ខេប កូរិនថូសទី ១ ៦:១៤–១៧ ដោយពន្យល់ថា ជនដែលចូលរួមនឹងសាសនាចក្របានរួបរួមនឹងព្រះគ្រីស្តក្នុងនាមជា « សមាជិក » ខាងវិញ្ញាណនៃព្រះកាយរបស់ទ្រង់ ។ ប៉ុលក៏បានពន្យល់ផងដែរថា រឿងអសីលធម៌ខាងផ្លូវភេទគឺជារឿងមួយដែលមិនចុះសម្រុងជាមួយនឹងទំនាក់ទំនងខាងវិញ្ញាណ ជាមួយនឹងព្រះយេស៊ូវគ្រីស្តឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៦:១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ។ (អ្នកគួរចង្អុលបង្ហាញថា ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ កូរិនថូសទី១ ៦:១៨ ផ្លាស់ប្តូរឃ្លា « នៅខាងក្រៅរូបកាយ » ទៅជា « ទាស់នឹងព្រះកាយរបស់ព្រះគ្រីស្ត ») ។

- តើប៉ុលបានបង្រៀនពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ?
- តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះអំពីជនដែលប្រព្រឹត្តសហាយស្មន់ ? (អ្នកគួរអញ្ជើញសិស្សឲ្យគូសចំណាំពាក្យនៅក្នុងខទី ១៨ដែលបង្រៀនពីសេចក្តីពិតដូចខាងក្រោម ៖ **ជនដែលប្រព្រឹត្តសហាយស្មន់នឹងគ្នា នោះឈ្មោះថាធ្វើបាបដល់រូបកាយខ្លួនឯង**) ។

សូមពន្យល់ថា បន្ទាប់មកទៀត ប៉ុលបានបង្រៀនពីហេតុផលដែលការសហាយស្មន់ ឬភាពអសីលធម៌ខាងផ្លូវភេទ គឺជាអំពើបាបមួយដែលមាន « ឈ្មោះថា ធ្វើបាបដល់ [រូបកាយ] ខ្លួនឯង » ។

សូមរំឭកសិស្សថា កូរិនថូសទី ១ ៦:១៩–២០ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៦:១៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រៀបធៀបរូបកាយយើងទៅនឹងអ្វី ។

- តើប៉ុលបានប្រៀបធៀបរូបកាយយើងទៅនឹងអ្វី ?

សូមដាក់តាំងរូបភាពនៃព្រះវិហារបរិសុទ្ធមួយ ។

- តើព្រះវិហារបរិសុទ្ធ និងអគារផ្សេងទៀតខុសគ្នាយ៉ាងដូចម្តេច ?
- តើអ្នកនឹងសង្ខេបសេចក្តីពិត ដែលប៉ុលបានបង្រៀននៅក្នុងខទី ១៩ យ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **រូបកាយយើងគឺជាព្រះវិហារបរិសុទ្ធរបស់ព្រះ ដែលព្រះវិញ្ញាណអាចគង់នៅ**) ។
- តើការយល់ដឹងថា រូបកាយរបស់យើងគឺជាព្រះវិហារបរិសុទ្ធអាចជះឥទ្ធិពលដល់ការប្រព្រឹត្តរបស់យើងទៅលើរូបកាយរបស់យើង និងរូបកាយរបស់មនុស្សដទៃទៀតយ៉ាងដូចម្តេចដែរ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ចូរឲ្យសិស្សក្នុងថ្នាក់ស្តាប់រកគំនិតបន្ថែមទៀតអំពីរបៀបដែលការយល់ដឹងថា រូបកាយរបស់យើងគឺជាព្រះវិហារបរិសុទ្ធនៃព្រះ អាចជះឥទ្ធិពលទៅលើការប្រព្រឹត្តរបស់យើងទៅលើរូបកាយនេះយ៉ាងដូចម្តេច ។

« ដោយទទួលស្គាល់សេចក្តីពិតទាំងនេះ [នៅក្នុង កូរិនថូសទី ១ ៦:១៩–២០] . . . យើងនឹងមិនធ្វើឲ្យរូបកាយរបស់យើងខូចខាតដោយសារការសោក់ខ្លួន ឬធ្វើឲ្យចុះខ្សោយដោយសារការប្រើថ្នាំឬប្រមាថវាដោយសារការសហាយស្មន់ អំពើកំផិត ឬរឿងអសីលធម៌នោះឡើយ ។ . . . ដោយសាររូបកាយយើងគឺជាឧបករណ៍សម្រាប់វិញ្ញាណយើង នោះវាជារឿងដ៏សំខាន់ដែលយើងត្រូវថែរក្សាវាឲ្យអស់ពីលទ្ធភាព ។ យើងគួរគិតឲ្យបានជិតដល់ពីអំណាចរបស់វានៅក្នុងការបម្រើ ហើយជួយជម្រុញដល់កិច្ចការរបស់ព្រះគ្រីស្ត » (« Reflections on a Consecrated Life » *Ensign* ឬ *Liahona* ខែវិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១៧) ។

- តើអ្នកគិតថា ប៉ុលចង់មានន័យដូចម្តេច ពេលពោលថា « អ្នករាល់គ្នាមិនមែនផងខ្លួនទេ » នៅក្នុង កូរិនថូសទី ១ ៦:១៩ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៦:២០ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីមូលហេតុដែលរូបកាយយើងពុំមែនជារបស់ផងយើង ។

- តើឃ្លាអ្វីទៅដែលបង្ហាញពីហេតុផលថារូបកាយយើងពុំមែនជារបស់ផងយើង ? (សូមពន្យល់ថាឃ្លា « ចេញថ្លៃលោះ » មានន័យថា ការប្រោសលោះ ឬការនាំត្រឡប់មកវិញតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត) ។
- តើអ្នកនឹងសង្ខេបសេចក្តីពិតនៅក្នុងខទី ១៩–២០ យ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយតប សូមជួយពួកគេឲ្យស្គាល់នូវសេចក្តីពិតដូចខាងក្រោម ៖ **ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្តបានចេញថ្លៃលោះយើង នោះរូបកាយយើងពុំមែនជារបស់ផងយើងឡើយ**) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗមកពីអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« សូមកុំពោលថា ‹ តើវាធ្វើឲ្យនរណាឈឺចាប់ ? ហេតុអ្វីមានសេរីភាពបន្តិចក៏មិនបាន ? ខ្ញុំអាចធ្វើអំពើរំលងនៅពេលនេះ ហើយចាំប្រែចិត្តនៅពេលក្រោយ ។ សូមកុំឆោតល្ងង់ ហើយគ្មានមេត្តាបែបនេះ ។ បងប្អូនមិនអាចគ្មានទោស ដោយ ‹ ផ្តាំងព្រះគ្រីស្ត › បានទេ [សូមមើល ហេព្រើរ ៦:៦] ។ គោលលទ្ធិ និង សេចក្តីសញ្ញាបន្ថែមថា ‹ រត់ពីការសហាយស្មន់ › [កូរិនថូសទី ១ ៦:១៨] ប៉ុលបានយំ ហើយតេះគេចខ្លួនមិន ‹ *ប្រព្រឹត្តអំពើអ្វីដូចនោះឲ្យសោះ* › [គ. និង ស. ៥៩:៦ការគួសបញ្ជាក់បានបន្ថែម] ។ ហេតុអ្វី ? ពិតណាស់ ដោយសារហេតុផលមួយ គឺដោយសារការរងទុក្ខទាំងខាងរូបកាយ និងខាងវិញ្ញាណដ៏មិនអាចគណនាបាន ដែលព្រះអង្គសង្គ្រោះនៃលោកិយបានស៊ូទ្រាំដើម្បីឲ្យយើង *អាច* រួចខ្លួន [សូមមើលជាពិសេសក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៥–២០] ។ យើងជំពាក់គុណទ្រង់ចំពោះរឿងនោះ ។ ពិតណាស់ យើងជំពាក់គុណទ្រង់គ្រប់យ៉ាងសម្រាប់រឿងនោះ » (« Personal Purity » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៧៦) ។

- តើការចង់ចាំថា រូបកាយយើងពុំមែនជារបស់យើងអាចជះឥទ្ធិពលដល់ការជ្រើសរើសរបស់យើងទាក់ទងនឹងរូបកាយរបស់យើងយ៉ាងដូចម្តេច ?

សូមឲ្យសិស្សមើលរូបភាពផ្លែឈើស្រស់មួយចំណិត ដែលហ៊ឹមព័ទ្ធដោយផ្លែឈើរលួយនៅលើក្តារខៀន ។

- តើការយល់ដឹងសេចក្តីពិតទាំងនេះអំពីរូបកាយយើង អាចជួយយើងឲ្យបន្តមានភាពបរិសុទ្ធបានដោយរបៀបណា នៅពេលយើងត្រូវបានហ៊ឹមព័ទ្ធទៅដោយអំពើទុច្ចរិតនោះ ?

ចូរថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានពិភាក្សា ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអារម្មណ៍ ឬការបំផុសគំនិតដែលពួកគេបានទទួលនៅក្នុងមេរៀននេះ ហើយធ្វើតាមការបំផុសគំនិតទាំងនោះ ។

មេរៀនបន្ទាប់ (កូរិនថូសទី ១ ៧–១៤)

សូមពន្យល់ដល់សិស្សថា ព្រះវរបិតាសួគ៌បានប្រទានអំណោយទានខាងវិញ្ញាណដល់ពួកគេម្នាក់ៗយ៉ាងហោចណាស់មួយ ។ សូមអញ្ជើញពួកគេឲ្យសិក្សាមេរៀនបន្ទាប់ដោយរកមើលថា មានអំណោយទានវិញ្ញាណមួយចំនួនអ្វីខ្លះ ដែលព្រះវរបិតាសួគ៌បានប្រទានដល់កូនចៅរបស់ទ្រង់ ។ សូមប្រាប់ពួកគេថា សាវកប៉ុលបានបង្រៀនថា សូម្បីតែលោកក៏បានលះបង់នូវរាល់ទ្រព្យសម្បត្តិរបស់លោកដើម្បីជួយដល់ជនក្រីក្រ ហើយប្រគល់ខ្លួនលោកឲ្យគេដុតក៏ដោយ ប៉ុន្តែប្រសិនបើលោកគ្មានអំណោយទានជាក់លាក់មួយទេ នោះលោកគ្មានអ្វីទាំងអស់ ។ សូមអញ្ជើញសិស្សឲ្យគិតពីអំណោយទានដែលពួកគេមាន ។

កូរិនថូសទី១ ៧–៨

សេចក្តីផ្តើម


ប៉ុលបានណែនាំសមាជិកសាសនាចក្រនៅកូរិនថូសទាំងអ្នករៀបការរួច និងអ្នកនៅលីវអំពីអាពាហ៍ពិពាហ៍ និងកិច្ចការផ្សព្វផ្សាយសាសនា ។ ដោយឆ្លើយតបចំពោះសំណួរមួយអំពីការបរិភោគអាហារដែលថ្វាយដល់រូបព្រះ ប៉ុលបានបង្រៀនពួកបរិសុទ្ធឲ្យពិចារណាពីផលនៃទម្លាប់ផ្ទាល់ខ្លួនរបស់ពួកគេចំពោះមនុស្សដទៃទៀត ហើយព្រមបញ្ឈប់នូវទង្វើមួយចំនួន ប្រសិនបើទង្វើទាំងនោះអាចបណ្តាលឲ្យមនុស្សម្នាក់ទៀតជំពប់ដួលខាងវិញ្ញាណ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ៧

ប៉ុលទូន្មានដល់សមាជិកសាសនាចក្រដែលរៀបការរួច និងអ្នកនៅលីវអំពីអាពាហ៍ពិពាហ៍

សូមគូរតារាងខាងក្រោមនេះដាក់នៅលើក្តារខៀន ៖



ជំនឿខុសឆ្គង ៖ | សេចក្តីពិត ៖ | ជំនឿខុសឆ្គង ៖

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនៃ កូរិនថូសទី១ ៧ សូមរំឭកពួកគេថា ដូចជាយើងដែរ សមាជិកសាសនាចក្រនៅកូរិនថូសនៅបានរស់នៅក្នុងសង្គមមួយដែលពោរពេញទៅដោយការភ័ន្តច្រឡំ និងគំនិតស្មុគស្មាញអំពីអាពាហ៍ពិពាហ៍ និងភាពស្និទ្ធស្នាលខាងរូបកាយ ឬខាងផ្លូវភេទ ។

- ដោយផ្អែកទៅលើអ្វីដែលអ្នកបាននឹកចាំនៅក្នុងការសិក្សារបស់អ្នកអំពី កូរិនថូសទី១ ៥–៦ តើជំនឿខុសឆ្គងមួយចំនួន អំពីទំនាក់ទំនងផ្លូវភេទដែលមានការពេញនិយមនៅកូរិនថូសមានអ្វីខ្លះ ?

បន្ទាប់ពីសិស្សឆ្លើយតបរួច ចូរសរសេរឃ្លាខាងក្រោមនេះនៅផ្នែកខាងឆ្វេងនៃតារាងនៅក្រោមពាក្យ « ជំនឿខុសឆ្គង » ។ *ការចូលរួមនៅក្នុងភាពស្និទ្ធស្នាលខាងរូបកាយជាមួយនឹងមនុស្សម្នាក់ គឺជាទង្វើសមរម្យ ។*

សូមពន្យល់ថា សមាជិកសាសនាចក្រនៅកូរិនថូសបានសរសេរសំបុត្រទៅសាវកប៉ុល សូមការណែនាំអំពីបទដ្ឋានរបស់ព្រះអម្ចាស់ចំពោះភាពបរិសុទ្ធខាងផ្លូវភេទ ។

សូមអញ្ជើញសិស្សម្នាក់អានកូរិនថូសទី ១ ៧:១ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលសំណួរមួយដែលពួកបរិសុទ្ធនៅកូរិនថូសបានសួរទៅប៉ុល ។

- តើពួកបរិសុទ្ធនៅកូរិនថូសបានសួរអ្វីទៅប៉ុល ?

សូមពន្យល់ថា ឃ្លា « បើមនុស្សប្រុសមិនដែលប៉ះពាល់នឹងស្រីសោះ នោះល្អជាជាង » នៅក្នុង ខទី ១ បញ្ជាក់ថា ពួកបរិសុទ្ធនៅកូរិនថូសមានសំណួរថា ភាពស្និទ្ធស្នាលខាងរូបកាយមានភាពសមរម្យនៅពេលណា ។ មនុស្សខ្លះអាចនឹងសួរថា មនុស្សដែលរៀបការរួចគួរចូលរួមនៅក្នុងភាពស្និទ្ធស្នាលខាងរូបកាយដែរទេ ។ ចូរសរសេរឃ្លាខាងក្រោមនេះនៅផ្នែកខាងស្តាំនៃតារាងនៅក្រោមពាក្យ « ជំនឿខុសឆ្គង » ។ *ការមានភាពស្និទ្ធស្នាលខាងរូបកាយ គឺជារឿងជាមិនអាចទទួលយកបានឡើយ សូម្បីតែនៅក្នុងអាពាហ៍ពិពាហ៍ក្តី ។*

សូមចង្អុលបង្ហាញថា ផ្នែកទាំងពីរនៃជំនឿខុសឆ្គង ដែលបានសរសេរនៅលើតារាងតំណាងឲ្យទស្សនៈខុសឆ្គងនានានៅក្នុងបទដ្ឋានរបស់ព្រះចំពោះភាពស្និទ្ធស្នាលខាងរូបកាយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កូរិនថូសទី ១ ៧:២–៣ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានបង្រៀនអ្វីខ្លះដល់ពួកកូរិនថូសទាក់ទងភាពស្និទ្ធស្នាលខាងរូបកាយ ។ (អ្នកគួរជួយសិស្សឲ្យយល់ថា *អំពើសហាយស្មន់* សំដៅលើទំនាក់ទំនងផ្លូវភេទខាងក្រៅអាពាហ៍ពិពាហ៍ និង *ដោយចិត្តសប្បុរស* សំដៅទៅលើសេចក្តីស្រឡាញ់ និងភាពស្និទ្ធស្នាលដែលបង្ហាញឡើងរវាងស្វាមី និងភរិយា) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោម ដែលមាននៅក្នុង *ដើម្បីកម្លាំងនៃយុវជន* ៖

« ការស្និទ្ធស្នាលខាងរូបកាយរវាងប្តី និង ប្រពន្ធ គឺមានភាពស្រស់ស្អាត ហើយពិសិដ្ឋ ។ វាត្រូវបានតែងតាំងឡើងដោយព្រះសម្រាប់ការបង្កើតកូនចៅ និងសម្រាប់ ការបង្ហាញសេចក្តីស្រឡាញ់រវាងប្តី និងប្រពន្ធ ។ ព្រះបានបញ្ជាថា ភាពស្និទ្ធស្នាលខាងផ្លូវភេទគឺរក្សារទុកសម្រាប់អាពាហ៍ពិពាហ៍ » (*ដើម្បីកម្លាំងនៃយុវជន* | កូនសៀវភៅ ឆ្នាំ ២០១១ | ទំព័រ ២៦) ។

សូមជួយសិស្សបំពេញគ្នាទីរបស់ពួកគេនៅក្នុងដំណើរការរៀនសូត្រ

ការរៀនសូត្រខាងព្រលឹងវិញ្ញាណតម្រូវឲ្យមានកិច្ចខិតខំ និងការអនុវត្តនៃសិទ្ធិជ្រើសរើសដោយអ្នករៀន ។ សម្រាប់សិស្សមួយចំនួន ការដាក់កិច្ចខិតខំដើម្បីរៀនអំពីព្រះគម្ពីរមើលទៅហាក់ដូចជាមិនជិតស្និទ្ធ ហើយដូចជាអ្វីមួយដែលពិបាក ។ ទោះបីយ៉ាងណា អ្នកអាចជួយពួកគេឲ្យយល់ ព្រមទទួលយក និងបំពេញគ្នាទីរបស់គេនៅក្នុងការរៀនសូត្រពីដំណឹងល្អ ។ នៅពេលសិស្សបំពេញគ្នាទីខ្លួនយ៉ាងសកម្ម នៅក្នុងការរៀនសូត្រអំពីដំណឹងល្អ នោះពួកគេបើកដួងចិត្តរបស់ពួកគេចំពោះព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

- នៅក្នុងអ្វីដែលយើងទើបតែបានអាន តើយើងអាចរៀនអ្វីខ្លះអំពីភាពស្និទ្ធស្នាលខាងរូបកាយ ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះលើតារាងនៅក្រោមពាក្យ « សេចក្តីពិត » ៖ **ការស្និទ្ធស្នាលខាងរូបកាយរវាងប្តី និងប្រពន្ធគឺតាំងឡើងដោយព្រះ** ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៏ ឃេ ផាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកហេតុផល ដែលភាពស្និទ្ធស្នាលនៅក្នុងអាពាហ៍ពិពាហ៍ត្រូវបានតាំងឡើងដោយព្រះ ។



« អំណាចនៃការបង្កើតកូនពុំមែនជាផ្នែកចៃដន្យមួយនៃផែនការនេះទេ វាគឺជាផែនការនៃសុភមង្គល វាគឺជាគន្លឹះឆ្ពោះទៅរកសុភមង្គល ។

« បំណងប្រាថ្នាចង់បង្កើតជីវិតមនុស្សលោកនៅតែបន្ត ហើយរឹងមាំយ៉ាងខ្លាំង ។ សុភមង្គលនៅក្នុងជីវិតរមែងស្លាប់អំណរ និង ភាពតម្កើងឡើងរបស់យើងគឺផ្អែកលើរបៀប ដែលយើងឆ្លើយតបចំពោះចំណង់ទាក់ទាញអារម្មណ៍ខាងរូបកាយដែលមាននេះ » (« The Plan of Happiness » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ២៦) ។

- តើគោលបំណងនៃភាពស្និទ្ធស្នាលខាងរូបកាយរវាងប្តី និងប្រពន្ធជាអ្វី ?
- ហេតុអ្វីការបង្កបង្កើត—សមត្ថភាពបង្កើតជីវិតរមែងស្លាប់—មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ?

សូមសង្ខេប កូរិនថូសទី១ ៧:៤–២៤ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា ស្វាមីភរិយាមិនគួរឃាត់សេចក្តីស្រឡាញ់នៅក្នុងអាពាហ៍ពិពាហ៍ពីគ្នាឡើយ ហើយថាសមាជិកសាសនាចក្រដែលបានលែងលះគ្នា ហើយជាស្ត្រីមេម៉ាយបានអនុញ្ញាតឲ្យរៀបការជាថ្មីបាន ប្រសិនបើពួកគេជ្រើសរើស ហើយថាសមាជិកសាសនាចក្រគួរ « នៅជាប់នឹងព្រះ » ទោះពួកគេស្ថិតនៅក្នុងកាលៈទេសៈណាក្តី ។ ប៉ុលក៏មិនបានលើកទឹកចិត្តឲ្យមានការលែងលះគ្នាដែរ ។

ដើម្បីជួយសិស្សឲ្យស្គាល់សេចក្តីពិតមួយទៀត នៅក្នុងការសរសេររបស់ប៉ុលក្នុង កូរិនថូសទី១ ៧ សូមបំបែកសិស្សជាក្រុមដែលមានគ្នាពីរ ឬបីនាក់ ហើយចែក ឯកសារខាងក្រោមនេះដល់ក្រុមនីមួយៗ ៖

កូរិនថូសទី១ ៧:១២–១៧

មានសមាជិកសាសនាចក្រនៅកូរិនថូសដែលមានស្វាមីភរិយា ដែលពុំមែនជាពួកគ្រីស្ទាន ។

- តើការលំបាកណាខ្លះដែលស្វាមីភរិយាមានជំនឿខុសគ្នាជួបប្រទះ ?

សូមអានឮៗនូវពាក្យទូន្មានរបស់ប៉ុលទៅកាន់គ្រួសារទាំងនេះ ដែលមានសមាជិកគ្រួសារពុំមែនជាសមាជិកនៅក្នុង កូរិនថូសទី១ ៧:១២–១៧ដោយរកមើលសេចក្តីពិតដែលប៉ុលបានបង្រៀនថា អាចជួយគ្រួសារដែលមានសមាជិកគ្រួសារពុំមែនជាសមាជិកបាននៅសព្វថ្ងៃនេះ ។

នៅក្នុងចន្លោះខាងក្រោម សូមសង្ខេបអ្វីដែលប៉ុលបានបង្រៀនអំពីជល ដែលសមាជិកសាសនាចក្រដ៏ស្មោះត្រង់អាចមានចំពោះគ្រួសារខ្លួន ៖ _____.

- តើគំរូអ្វីដែលអ្នកធ្លាប់ឃើញថា សមាជិកសាសនាចក្រមានជលវិជ្ជមានមួយទៅលើសមាជិកគ្រួសារដែលមិនមែនជាសមាជិកសាសនាចក្រ ឬមិនសកម្មនៅក្នុងសាសនាចក្រនោះ ?

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សប្រាប់ពីសេចក្តីពិត ដែលពួកគេបានរកឃើញនៅក្នុង កូរិនថូសទី១ ៧:១២–១៧ ។ ចម្លើយរបស់សិស្សអាចផ្សេងៗពីគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញសេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតខាងក្រោមនេះ ៖ **ពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទដ៏ស្មោះត្រង់មានឥទ្ធិពលដ៏បរិសុទ្ធមួយទៅលើក្រុមគ្រួសាររបស់ខ្លួន** ។

អ្នកគួរអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីគំរូរបស់សមាជិកសាសនាចក្រ ដែលមានជលវិជ្ជមានមួយទៅលើសមាជិកគ្រួសារដែលមិនមែនជាសមាជិកសាសនាចក្រ ឬ ដែលមិនសកម្មនៅក្នុងសាសនាចក្រ ។

សូមសង្ខេប កូរិនថូសទី១ ៧:២៥–៤០ ដោយពន្យល់ថា ប៉ុលបានចែកចាយទស្សនៈរបស់លោកទាក់ទងនឹងសមាជិកនៅលីវដែល « ត្រូវបានហៅឲ្យធ្វើការងារបម្រើ » (ការបកប្រែដោយយ៉ូសែប ស៊្មីធ កូរិនថូសទី ១ ៧:២៩ | នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ |) ហើយពន្យល់ថា កាលៈទេសៈរបស់ពួកគេបានអនុញ្ញាតឲ្យពួកគេបម្រើព្រះអម្ចាស់ « ឥតមានសេចក្តីណែនាំឲ្យទាស់ចិត្តឡើយ » (ខទី ៣៥) ឬដោយគ្មានកង្វល់ខាងសាច់ឈាមទាក់ទងនឹងការផ្គត់ផ្គង់ដល់គ្រួសារ ។ ទោះជាយ៉ាងណាក្តី ទ្រង់ពុំបានហាមមិនឲ្យពួកគេរៀបការនោះទេ ។

កូរិនថូសទី១ ៨

ប៉ុលឆ្លើយនឹងសំណួរមួយអំពីការបរិភោគអាហារដែលបានថ្វាយដល់រូបព្រះ

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិល ថម គែរី ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖

« ខ្ញុំបានចំណាយពេលក្នុងអាជីពការងារខ្ញុំនៅក្នុងនាយកដ្ឋានហាងអាជីវកម្ម ។ ដោយសារខ្ញុំជាផ្នែកមួយនៃក្រុមគ្រប់គ្រងវាសំខាន់ណាស់ដែលខ្ញុំត្រូវមានទំនាក់ទំនងខាងសង្គមជាមួយនឹងអង្គភាពអាជីវកម្មក្នុងមូលដ្ឋាន ។ ភាគច្រើន ការប្រជុំជាមួយនឹងអង្គភាពទាំងនេះតែងតែចាប់ផ្តើមជាមួយការផឹកស្រាក្រឡុក | ជាពេលដែលគ្រឿងស្រវឹងត្រូវបានដាក់ជូនតាមទម្លាប់ | ។ វាជាពេលមួយដើម្បីធ្វើខ្លួនឲ្យចូលក្នុងចំណោមគេឯង ហើយស្គាល់មនុស្សដែលនៅក្នុងអង្គភាពនោះ ។ ខ្ញុំតែងតែមានអារម្មណ៍រសាប់រសល់នៅ

ក្នុងគ្រាជួបជុំទាំងនេះ ។ ដំបូងខ្ញុំបានចាប់ផ្តើមសុំយកសូដាលាយនឹងក្រូចឆ្មារ ។ មិនយូរប៉ុន្មាន ខ្ញុំបានឃើញថា សូដាលាយនឹងក្រូចឆ្មារនោះគឺស្រដៀងគ្នានឹងភេសជ្ជៈផ្សេងទៀតដែរ ។ ខ្ញុំអាចបង្កើតអារម្មណ៍ថា ខ្ញុំមិនចេះពីកគ្រឿងស្រវឹង ដោយកាន់កែវសូដាដ៏ថ្លាឆ្វង់នៅក្នុងដៃបានឡើយ » (« The Tradition of a Balanced, Righteous Life » *Ensign* ខែ សីហា ឆ្នាំ ២០១១ ទំព័រ ៤៨–៤៩) ។

- តើនឹងមានអ្វីកើតឡើង ប្រសិនបើអែលឌើរ ភែរី បានបន្តពិសារសូដានៅក្នុងគ្រាពិសារស្រាក្រឡុកនោះ ។
- តើស្ថានភាពផ្សេងទៀតណាខ្លះ ដែលគំរូរបស់យើងអាចជះឥទ្ធិពលអវិជ្ជមានដល់មនុស្សដទៃទៀត ទោះជាយើងមិនបានធ្វើអ្វីខុសក្តី ?

សូមពន្យល់ថា សមាជិកសាសនាចក្រនៅកូរិនថូសងឿងឆ្ងល់ថា កាលដែលពួកគេបរិភោគអាហារដែលបានថ្វាយដល់រូបព្រះ ឬព្រះជាហ្គានជារឿងត្រឹមត្រូវដែរទេ ។

សូមចង្អុលបង្ហាញថា ប៉ុលបានទទួលស្គាល់ថា សមាជិកសាសនាចក្រអាចនឹងថារឿងនេះគឺជារឿងត្រឹមត្រូវ ដោយសារពួកគេបានដឹងថាគ្មានព្រះជាហ្គាននោះទេ (សូមមើល កូរិនថូសទី១ ៨:៤–៦) ។

សូមអញ្ជើញសិស្សម្នាក់អានកូរិនថូសទី១ ៨:១ ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះដល់ពួកបរិសុទ្ធនៅកូរិនថូស ។

- ទោះជាមនុស្សទូទៅបានដឹងថា រូបព្រះមិនពិតក្តី តើប៉ុលបាននិយាយអ្វីខ្លះដែលកាន់តែសំខាន់ជាងអ្វីដែលពួកគេបានដឹងទៅទៀតនោះ ? (សេចក្តីសប្បុរស ឬសេចក្តីស្រឡាញ់ដោយគ្មានលក្ខខណ្ឌដល់មនុស្សដទៃ) ។
- យោងតាមខគម្ពីរនេះ តើអ្វីទៅជាលទ្ធផលដែលកើតចេញពីចំណេះដឹង ? (ការមានសេចក្តីអំនួត ឬក្រអឺតក្រទម) ។ តើអ្វីទៅជាលទ្ធផលដែលកើតចេញពីសេចក្តីសប្បុរស ? (ការស្អាង ឬការពង្រឹងខ្លួនឯង ឬមនុស្សដទៃទៀត) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៨:៧–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ពួកបរិសុទ្ធនៅកូរិនថូសមិនគួរបរិភោគអាហារដែលបានថ្វាយដល់រូបព្រះនៅពេលណា ។ (អ្នកគួរជួយសិស្សឲ្យយល់ដឹងថា ពាក្យ*ខ្សោយ* នៅក្នុងខគម្ពីរទាំងនេះប្រហែលជាសំដៅទៅលើភាពទន់ខ្សោយនៅក្នុងការយល់ដឹង ហើយថាពាក្យ *អំណាច* [ខទី ៩] សំដៅទៅលើសេរីភាពរបស់សមាជិកសាសនាចក្រដើម្បីទទួលទានអាហារដែលបានថ្វាយដល់រូបព្រះ) ។

- យោងតាមខទី ៩ តើនៅក្រោមលក្ខខណ្ឌណាខ្លះ ដែលប៉ុលបានលើកឡើងថាពួកគេមិនគួរបរិភោគអាហារដែលថ្វាយដល់រូបព្រះ ? (ប្រសិនបើវាបានក្លាយជាថ្មជំពប់មួយសម្រាប់មនុស្សម្នាក់ដែលមានទីបន្ទាល់ខ្សោយ ឬគ្មានចំណេះដឹងអំពីដំណឹងល្អ) ។
- តើគំរូអ្វីខ្លះដែលប៉ុលបានផ្តល់ឲ្យនៅក្នុង ខទី ១០ អំពីរបៀបមួយដែលការបរិភោគអាហារដែលបានថ្វាយដល់រូបព្រះអាចនឹងក្លាយជាថ្មជំពប់មួយ ? (ប្រសិនបើសមាជិកសាសនាចក្រម្នាក់ ដែលមានសេចក្តីជំនឿខ្សោយបានឃើញសមាជិកម្នាក់ទៀតបរិភោគអាហារនៅកន្លែងអាហារ ដែលជាប់នឹងវិហារជាហ្គានមួយក្នុងមូលដ្ឋាន នោះសមាជិកដែលមានជំនឿខ្សោយនោះក៏អាចនឹងជឿជងដែរថាគ្មានអ្វីខុសឆ្គងជាមួយនឹងការថ្វាយបង្គំរូបព្រះឡើយ) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ៨:១១–១៣ ឲ្យឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលចម្លើយរបស់ប៉ុលចំពោះសំណួរទាក់ទងនឹងការបរិភោគអាហារដែលថ្វាយដល់រូបព្រះ ។

- យោងតាម ខទី ១៣ តើប៉ុលបាននិយាយថា គាត់នឹងធ្វើអ្វីខ្លះបើគាត់ស្ថិតនៅក្នុងស្ថានភាពនេះ ? ហេតុអ្វី ? (សូមជួយសិស្សឲ្យយល់ថា*ជំពប់ដួល*នៅក្នុងខគម្ពីរនេះមានន័យជំពប់ដួលខាងវិញ្ញាណ អំពើបាប ឬបាត់សេចក្តីជំនឿ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះ អំពីរបៀបដែលយើងអាចចៀសវាងដឹកនាំអ្នកដទៃឲ្យជំពប់ដួលខាងវិញ្ញាណ ? (បន្ទាប់ពីសិស្សឆ្លើយរួច សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **យើងអាចបង្ហាញសេចក្តីសប្បុរសចំពោះមនុស្សដទៃទៀត តាមរយៈការចៀសវាងពីទង្វើដែលអាចដឹកនាំពួកគេឲ្យជំពប់ដួលខាងវិញ្ញាណ**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានពួកនូវដំណើររឿងបន្តទៀតរបស់អែលឌើរ ភែរី ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា អែលឌើរ ភែរី បានអនុវត្តគោលការណ៍នេះយ៉ាងដូចម្តេច ៖



« ខ្ញុំបានសម្រេចចិត្តថា ខ្ញុំត្រូវផឹកភេសជ្ជៈណាដែលបង្ហាញយ៉ាងច្បាស់ថា ខ្ញុំមិនមែនជាអ្នកផឹកគ្រឿងស្រវឹង ។ ខ្ញុំបានដើរទៅអ្នកក្រឡុកស្រា ហើយសុំទឹកដោះគោមួយកែវ ។ គាត់ពុំធ្លាប់ឃើញមានគេសុំបែបនេះឡើយ ។ គាត់បានចូលទៅក្នុងផ្ទះបាយ ហើយយកទឹកដោះគោមួយកែវឲ្យខ្ញុំ ។ ឥឡូវខ្ញុំមានភេសជ្ជៈមួយដែលខុសពីគ្រឿងស្រវឹងដែលមនុស្សដទៃទៀតកំពុងផឹក ។ . . .

« ទឹកដោះគោបានក្លាយជាភេសជ្ជៈជម្រើសរបស់ខ្ញុំនៅក្នុងកម្មវិធីស្រាក្រឡុក ។ មិនយូរប៉ុន្មាន ខ្ញុំត្រូវបានគេស្គាល់ជាទូទៅថាជាពួកមរមន ។ ខ្ញុំមានការភ្ញាក់ផ្អើលចំពោះការគោរព ដែលខ្ញុំបានទទួល ព្រមទាំងព្រឹត្តិការណ៍ដ៏គួរឲ្យចាប់អារម្មណ៍ក៏បានចាប់ផ្តើមកើតឡើងផងដែរ ។ មិនយូរប៉ុន្មាន មានមនុស្សផ្សេងទៀតបានចូលរួមជាមួយខ្ញុំផឹកទឹកដោះគោដែរ ! » (« The Tradition of a Balanced, Righteous Life » ទំព័រ ៤៩) ។

- តើគំរូផ្សេងទៀតពីរបៀបដែលយើងអាចបង្ហាញសេចក្តីសប្បុរសចំពោះមនុស្សដទៃទៀតដោយចៀសវាងពីទង្វើ ដែលអាចដឹកនាំពួកគេឲ្យជំពប់ដួលខាងវិញ្ញាណនោះមានអ្វីខ្លះ ?

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលសិស្សបានរកឃើញនៅថ្ងៃនេះ ហើយលើកទឹកចិត្តសិស្សឲ្យស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធខណៈពេលពួកគេព្យាយាមរស់នៅតាមសេចក្តីពិតទាំងនេះ ។

ប្រើដំណើររឿងដើម្បីជួយសិស្សយល់ដឹងពីគោលការណ៍

រឿងទាំងឡាយអាចជួយសិស្សឲ្យយល់អំពីគោលការណ៍ដំណឹងល្អដែលត្រូវបាន ប្រាប់នៅក្នុងបណ្តុំបទគម្ពីរ ។ តាមរយៈការបង្ហាញអំពីគោលការណ៍ដំណឹងល្អនៅក្នុងបរិបទទំនើបមួយ នោះរឿងទាំងឡាយក៏អាចជួយសិស្ស ឲ្យយល់អំពីរបៀបដែលគោលការណ៍នៃដំណឹងល្អមានទំនាក់ទំនងទៅនឹងជីវិតរបស់ពួកគេក៏ដូចជាជួយគេឲ្យមាន បំណងចង់អនុវត្តតាមផងដែរ ។

កូរិនថូសទី១ ៩–១០

សេចក្តីផ្តើម

ប៉ុលបានលើកឡើងអំពីកង្វល់មកពីពួកបរិសុទ្ធកូរិនថូស អំពីការប្រើធនធានរបស់សាសនាចក្រដើម្បីផ្គត់ផ្គង់សម្រាប់សេចក្តីត្រូវការខាងសាច់ឈាមរបស់ខ្លួន ។ លោកបានពន្យល់ថា គោលបំណងនៃការផ្សព្វផ្សាយរបស់លោក គឺដើម្បីនាំយកសេចក្តីសង្គ្រោះដល់កូនចៅរបស់ព្រះ ។ លោកបានជាស់តឿនពួកគេឲ្យចៀសវាងពីការធ្វើបាប ក៏ដូចជាការធ្វើឲ្យមនុស្សដទៃរវាទចិត្តនៅក្នុងជំនឿសាសនារបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ៩

ប៉ុលប្រកាសដំណឹងល្អដើម្បីលោក និងពួកអ្នកស្តាប់របស់លោកអាចទទួលបានការសង្គ្រោះ៖

សូមយកនាឡិកាកោទ៏មកថ្នាក់ ហើយលាក់វាកុំឲ្យសិស្សឃើញ ។ សូមដាក់វាឲ្យរោទ៏ភ្លាម បន្ទាប់ពីអ្នកចាប់ផ្តើមការបង្រៀន ។

ដើម្បីចាប់ផ្តើមមេរៀននេះ៖ សូមអញ្ជើញសិស្សឲ្យនឹកស្រមៃអំពីទិដ្ឋភាពនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ ចូរសុំឲ្យពួកគេសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីហេតុផលដែលជីវិតដ៏នៅអស់កល្បជានិច្ច គឺជាអ្វីមួយដែលពួកគេប្រាថ្នាចង់បាន ។ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យអានដល់សិស្សដទៃទៀត អំពីអ្វីដែលពួកគេបានសរសេរ ។

នៅជិតចុងបញ្ចប់នៃសកម្មភាពនេះ គួរបិទនាឡិកាកោទ៏ ។ នៅពេលវាកោទ៏ឡើង សូមឲ្យសិស្សស្ងៀងភក់ ហើយបិទសំឡេងកោទ៏នោះ ។

- **តើអ្នកមានអារម្មណ៍បែបណាដែរ នៅពេលអ្នកឮសំឡេងនោះ ?**

សូមឲ្យសិស្សគិតថា តើពួកគេធ្លាប់ឆ្លងកាត់នូវការលំបាកជាមួយនឹងការរោទ៏ដាស់ឲ្យក្រោកពីដំណេករបស់នាឡិកាកោទ៏ ហើយខកខានរឿងមួយដ៏សំខាន់ដែរឬទេ ។ ចូរអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយ ។

សូមពន្យល់ថា ដូចជាការលំបាកជាមួយនឹងការរោទ៏ដាស់ឲ្យក្រោកពីដំណេករបស់នាឡិកាកោទ៏ អាចធ្វើឲ្យយើងខកខាន ឬថែមទាំងបរាជ័យក្នុងការសម្រេចរឿងដ៏សំខាន់នានាដែរ ពិបាក « ក្រោកឡើង » នៅក្នុងជីវិត ហើយផ្លាស់ប្តូរឥរិយាបថជាក់លាក់មួយចំនួនអាចធ្វើឲ្យយើងខកខាន ក្នុងការសម្រេចរឿងដ៏សំខាន់បំផុតជាងគេបំផុត គឺជីវិតដ៏នៅអស់កល្បជានិច្ច ។

នៅពេលសិស្សសិក្សា កូរិនថូសទី១ ៩ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយដែលអាចជួយពួកគេឲ្យស្គាល់ពីរបៀបដើម្បីធ្វើឲ្យប្រាកដថា ពួកគេអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីសង្ខេបពីកូរិនថូសទី ១ ៩:១–២១ ឲ្យឮៗ ដូចតទៅនេះ ៖

ប៉ុលបានឆ្លើយសំណួរខុសៗគ្នាមកពីពួកបរិសុទ្ធនៅកូរិនថូស ។ លោកបានសរសេរថា ទោះបីជាសមាជិកសាសនាចក្រត្រូវផ្គត់ផ្គង់ចំពោះកង្វល់ខាងសាច់ឈាមរបស់លោកក្តី ក៏លោកពុំបានពឹងផ្អែកលើពួកគេសម្រាប់ការចាយវាយប្រចាំការរស់នៅរបស់លោកឡើយ ។ ប៉ុលបានពន្យល់ថា តាមរយៈការសម្របខ្លួនទៅតាមកាលៈទេសៈខុសៗគ្នា ដោយគ្មានការបន្ទាបដល់បទដ្ឋាននៃជំណឹងល្អ លោកអាចជួយពួកសាសន៍យូដា ពួកសាសន៍ដទៃ និងមនុស្សផ្សេងទៀតដែលមានភាពទន់ខ្សោយនៅក្នុងដំណឹងល្អឲ្យទទួលយកដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៩:១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានប្រកាសដំណឹងល្អយ៉ាងដូចម្តេច ។ អ្នកគួរពន្យល់ថា ឃ្លា « គង់តែមានការងារចែកចាយផ្ញើទុកនឹងខ្ញុំ » សំដៅទៅលើការដែលប៉ុលកំពុងបំពេញសិទ្ធិអនុញ្ញាត ឬកាតព្វកិច្ចរបស់លោកក្នុងការប្រកាសដំណឹងល្អ ។

- **តើប៉ុលបានប្រកាសដំណឹងល្អយ៉ាងដូចម្តេច ?**

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៩:២២–២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលហេតុផល ដែលប៉ុលបានប្រកាសដំណឹងល្អដោយស្ម័គ្រចិត្ត ។

- **ហេតុអ្វីប៉ុលបានប្រកាសដំណឹងល្អដោយស្ម័គ្រចិត្ត ?**

សូមអញ្ជើញសិស្សម្នាក់ដែលចូលរួមនៅក្នុងកម្មវិធីបំពាក់បំប៉នមួយជាទៀងទាត់ (ប្រហែលជាតន្ត្រីករ ឬអត្តពលកម្ម) ឲ្យឡើងមកកាន់ក្តារខៀន ។ សូមសួរសិស្សនោះនូវសំណួរខាងក្រោម ៖

- **តើកម្មវិធីបំពាក់បំប៉នរបស់ប្អូនមានលក្ខណៈបែបណាដែរ ?**
- **តើធ្លាប់មានគ្រាមួយដែលប្អូនបានអនុវត្ត ឬបំពាក់បំប៉នសម្រាប់ព្រឹត្តិការណ៍ ឬគោលដៅជាក់លាក់មួយដែរឬទេ ? តើការខិតខំឆ្ពោះទៅរកគោលដៅជាក់លាក់មួយបានលើកទឹកចិត្តប្អូនយ៉ាងដូចម្តេចដែរ ?**

សូមអរគុណដល់សិស្ស ហើយសុំឲ្យគេអង្គុយចុះ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៩:២៤–២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការប្រកួតអត្តពលកម្មដែលប៉ុលបានប្រើដើម្បីបង្រៀនដល់ពួកបរិសុទ្ធនៅកូរិនថូស ។

សេចក្តីសង្ខេប

សេចក្តីសង្ខេបអនុញ្ញាតឲ្យអ្នកសង្ខេបយ៉ាងលឿនពីចំណែកនៃបណ្តុំបទគម្ពីរ ។ ដោយការសង្ខេបសរុបវគ្គបណ្តុំបទគម្ពីរ ប្រសើរដោងការកាត់ឆាចោល អ្នកអាចជួយសិស្សឲ្យក្សាខ្សែរឿង និងបរិបទច្បាស់លាស់នៅក្នុងគំនិតរបស់គេ និង ផ្តល់គ្រឹះមួយសម្រាប់ការរកឃើញ និង ការយល់ដឹងអំពីគោលការណ៍ ឬ គោលលទ្ធិទាំងឡាយដែលនឹងលេចឡើង នៅពេលក្រោយទៀតនៅក្នុងបណ្តុំនោះ ។ ការសង្ខេបជួយការពារផងដែរនូវសេចក្តីសុចរិត និងលំហូរនៃសារលិខិតរបស់អ្នកសរសេរ ដែលបានបំផុសគំនិត ។

- តើការប្រកួតអត្តពលកម្មអ្វីដែលប៉ុលបានលើកឡើង ?
- តើគុណសម្បត្តិ ឬបុគ្គលិកលក្ខណៈអ្វីខ្លះដែលប៉ុលបាននិយាយថា ពួកអ្នករត់ប្រណាំងត្រូវការដើម្បីទទួលបានជោគជ័យ ? (សូមពន្យល់ថា ការ « ខំអត់សង្កត់ចិត្តគ្រប់ជំពូក » មានន័យថាការរៀនគ្រប់គ្រងលើខ្លួនឯង) ។
- តើមកុដមិនចេះពុករលួយដែលប៉ុលបានលើកឡើងថា វានឹងមានជារៀងរហូតនោះជាអ្វីទៅ ? (ជីវិតដ៏នៅអស់កល្បជានិច្ច) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីក្នុង ខទី ២៥ ស្តីអំពីកិច្ចការដែលយើងត្រូវធ្វើ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនោះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគួរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច យើងត្រូវរៀនគ្រប់គ្រងលើខ្លួនឯងនៅក្នុងគ្រប់កិច្ចការទាំងអស់** ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ សូមធ្វើឲ្យប្រាកដថា សិស្សយល់ថា ការគ្រប់គ្រងខ្លួនឯងគឺជារឿងដ៏ចាំបាច់ ប៉ុន្តែជីវិតដ៏នៅអស់កល្បជានិច្ចអាចកើតឡើងតែ « ដោយបុណ្យគុណ និងសេចក្តីមេត្តាករុណា និងព្រះគុណ » នៃព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ (នីហ្វៃទី២ ២:៨) ជាជាងតាមរយៈការគ្រប់គ្រងលើខ្លួនឯងរបស់យើងតែម្យ៉ាងប៉ុណ្ណោះ) ។
- ហេតុអ្វីអ្នកគិតថា ការរៀនគ្រប់គ្រងលើខ្លួនឯងគឺជារឿងចាំបាច់ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ៩:២៦–២៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបានពិពណ៌នាអំពីការខិតខំផ្ទាល់ខ្លួនរបស់លោកដើម្បីរៀនគ្រប់គ្រងលើខ្លួនឯងយ៉ាងដូចម្តេច ។

- យោងតាម ខទី ២៦តើប៉ុលបានពិពណ៌នាអំពីការខិតខំផ្ទាល់ខ្លួនរបស់លោកដើម្បីរៀនគ្រប់គ្រងលើខ្លួនឯងយ៉ាងដូចម្តេច ? (ដោយភាពជឿជាក់ ហើយដោយគ្មានការធ្វេសប្រហែស) ។
- យោងតាម ខទី ២៧ តើអ្នកគិតថា ប៉ុលចង់មានន័យបែបណា នៅពេលលោកបានសរសេរថា « ខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឲ្យចុះចូល » ?

ដើម្បីជួយសិស្សឲ្យយល់អំពីអ្វីដែលប៉ុលចង់មានន័យ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ព្រិកហាំ យ៉ង់ ៖



« អ្នកពុំអាចគ្រងលើជីវិតដ៏នៅអស់កល្បជានិច្ចបានឡើយ ដរាបណាសេចក្តីស្រេកឃ្លានរបស់អ្នកបានចុះចូលនឹងវិញ្ញាណដែលនៅក្នុងខ្លួនរបស់អ្នក ជាវិញ្ញាណដែលព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌បានប្រទានឲ្យ ។ ខ្ញុំចង់មានន័យថា ព្រះវរបិតានៃវិញ្ញាណរបស់អ្នក និងវិញ្ញាណទាំងឡាយដែលទ្រង់បានដាក់ចូលទៅក្នុងរូបកាយទាំងនេះ ។ រូបកាយទាំងឡាយត្រូវចុះចូលនឹងវិញ្ញាណនោះយ៉ាងល្អឥតខ្ចោះ ពុំនោះសោតទេរូបកាយរបស់អ្នកពុំអាចក្រោកឡើងដើម្បីគ្រងជីវិតដ៏នៅអស់កល្បជានិច្ចបានឡើយ ។ . . . សូមស្វែងរកដោយឧស្សាហ៍ រហូតដល់អ្នកនាំយកអ្វីៗទាំងអស់ឲ្យចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះគ្រីស្ទ ។ . . .

« . . . ប្រសិនបើវិញ្ញាណនោះងាកទៅរកបូរកាយ | វិញ្ញាណនោះ | ប្រែក្លាយជាពុករលួយ ប៉ុន្តែប្រសិនបើរូបកាយងាកទៅរកវិញ្ញាណនោះ | រូបកាយ | ប្រែក្លាយជាបរិសុទ្ធ ហើយពិសិដ្ឋ » (*Teachings of Presidents of the Church: Brigham Young* | ឆ្នាំ ១៩៩៧ | ទំព័រ២០៤–៥ ។

- តើកិច្ចការមួយចំនួនដែលយើងអាចធ្វើ ដើម្បីជួយរូបកាយរបស់យើងឲ្យងាកទៅរកវិញ្ញាណរបស់យើងមានអ្វីខ្លះ ?

កូរិនថូសទី១ ១០

ប៉ុលហាមដល់ពួកបរិសុទ្ធនៅកូរិនថូសឲ្យចៀសវាងពីអំពើបាប និងការធ្វើឲ្យមនុស្សជំទៃ វាទចិត្ត ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដែមស៍ អឺ ហ្វោស្ត នៃគណៈប្រធានទីមួយឲ្យឮៗ ៖

« រឿងមិនពិតដ៏ធំមួយនៅក្នុងជីវិតគឺនៅពេល | បុគ្គលទាំងឡាយ | គិតថា ពួកគេគឺជាមនុស្សខ្លាំងពូកែ ។ មានមនុស្សជាច្រើនគិតថា ពួកគេធ្វើឡើងពីដែកថែប រឹងមាំល្មមគ្រប់គ្រាន់ដើម្បីតតាំងនឹងការល្បួងទាំងឡាយ ។ ពួកបោកបញ្ឆោតខ្លួនឯងឲ្យចូលទៅក្នុងការគិតថា ‹ វាពុំអាចកើតឡើងចំពោះខ្ញុំបានឡើយ › » (« It Can't Happen to Me » *Ensign* ខែ ឧសភា ឆ្នាំ២០០២ ទំព័រ ៤៦) ។

- តើនៅក្នុងស្ថានភាពបែបណាខ្លះ ដែលមនុស្សអាចបណ្តោយឲ្យខ្លួនឯងបាត់បង់ការការពារប្រឆាំងនឹងការល្បួង ដោយគិតថា ពួកគេរឹងមាំល្មមគ្រប់គ្រាន់ដើម្បីតតាំងនឹងវានោះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

សូមពន្យល់ថា ប៉ុលបានលើកឡើងពីគំរូមកពីប្រវត្តិសាស្ត្ររបស់សាសន៍អ៊ីស្រាអែល ដើម្បីព្រមានពួកបរិសុទ្ធនៅកូរិនថូសអំពីការល្បួង និងអំពើបាប ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១០:១–៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលរឿងមួយចំនួន ដែលកូនចៅអ៊ីស្រាអែលបានជួបប្រទះនៅជំនាន់របស់ម៉ូសេ ដែលវាបានធ្វើឲ្យពួកគេមានភាពរឹងមាំខាងវិញ្ញាណ ។

- តើរឿងមួយចំនួនដែលកូនចៅអ៊ីស្រាអែលបានជួបប្រទះ ដែលវាបានធ្វើឲ្យពួកគេមានភាពរឹងមាំខាងវិញ្ញាណមានអ្វីខ្លះ ? (អ្នកគួរចង្អុលបង្ហាញថា ប៉ុលបានស្គាល់ « ថ្មដាខាងវិញ្ញាណ » ឬព្រះយេហូវ៉ាថាជាព្រះគ្រីស្ទ | សូមមើលជង្គង់ដែរ ចោទិយកថា ៣២:៣–៤ |) ។
- យោងតាម ខទី ៥តើព្រះមានព្រះទ័យយ៉ាងណាដែរ ចំពោះឥរិយាបថរបស់ពួកសាសន៍អ៊ីស្រាអែលទាំងនេះកាលពីបុរាណ ?

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង កូរិនថូសទី ១ ១០:៦–១១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថាប៉ុលចង់ឲ្យពួកបរិសុទ្ធនៅកូរិនថូសរៀនអ្វីខ្លះចេញពីគំរូនៃពួកសាសន៍អ៊ីស្រាអែលកាលពីបុរាណ ។

- តើអ្វីទៅជាគោលបំណងរបស់ប៉ុលនៅក្នុងការចែកចាយគំរូនៃពួកសាសន៍អ៊ីស្រាអែលក្នុងជំនាន់បុរាណ ? (ប៉ុលចង់ព្រមានដល់ពួកបរិសុទ្ធនៅកូរិនថូសឲ្យពួកគេចៀសវាងពីធ្វើអំពើបាបដូចគ្នានឹងពួកសាសន៍អ៊ីស្រាអែលកាលពីបុរាណ) ។

សូមអញ្ជើញសិស្សឲ្យក្រោកឈរឡើង ហើយអាន កូរិនថូសទី ១ ១០:១២ ឮៗរួមគ្នា ។

- តើអ្នកនឹងសង្ខេបសារលិខិតរបស់ប៉ុលនៅ ក្នុង ខទី ១២ជាពាក្យសម្តីរបស់អ្នកផ្ទាល់យ៉ាងដូចម្តេច ?

សូមឲ្យសិស្សអង្គុយចុះ ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១០:១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីការល្បួង ។

- តើប៉ុលបានបង្រៀនអ្វីខ្លះពីការល្បួង ?
- ប្រសិនបើព្រះពុំបានអនុញ្ញាតឲ្យយើងរងការល្បួងលើសពីសមត្ថភាពរបស់យើងអាចតតាំងបាន ហេតុអ្វីបានជាពួកអ៊ីស្រាអែលកាលពីបុរាណចុះចាញ់នឹងការល្បួង ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *ព្រះនឹងប្រទានផ្លូវមួយឲ្យយើងគេចពីការល្បួង ប៉ុន្តែយើងត្រូវតែ . . .*

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១០:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនឲ្យពួកបរិសុទ្ធនៅកូរិនថូសធ្វើអ្វីខ្លះ ។

- តើប៉ុលបានបង្រៀនពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ?
- តើ ខទី ១៤ បង្រៀនយើងអ្វីខ្លះអំពីតួនាទីរបស់យើងនៅក្នុងការគេចចេញពីការល្បួង ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមបំពេញសេចក្តីពិតនៅលើក្តារខៀនដើម្បីឲ្យសិស្សអាន ៖ **ព្រះនឹងប្រទានផ្លូវមួយឲ្យយើងគេចពីការល្បួង ប៉ុន្តែយើងត្រូវតែព្រើសរើសដើម្បីដកខ្លួនយើងចេញពីការល្បួងនោះ**) ។

អ្នកគួរផ្តល់យោបល់ឲ្យសិស្សសរសេរ *អាលម៉ា ១៣:២៨* នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ កូរិនថូសទី ១ ១០:១៣–១៤ ។ ចូរសុំឲ្យសិស្សម្នាក់អាន អាលម៉ា ១៣:២៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាយើងអាចធ្វើអ្វីខ្លះដើម្បីញែកខ្លួនចេញពីការល្បួង ។

- យោងតាម អាលម៉ា ១៣:២៨ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីអាចជួយយើងឲ្យញែកខ្លួនយើងចេញពីការល្បួង ?
- តើការបន្ទាបខ្លួនយើង និងការចាំយាម ព្រមទាំងការអធិស្ឋានជាបន្តបន្ទាប់អាចជួយយើងឲ្យញែកខ្លួនចេញពីការល្បួងបានយ៉ាងដូចម្តេច ?

សូមលើកកូនសៀវភៅ *កម្លាំងដើម្បីយុវជន* ឡើង ហើយសូមឲ្យសិស្សពន្យល់ថា ការរស់នៅស្របតាមបទដ្ឋានដែលមាននៅក្នុងកូនសៀវភៅនេះ ជួយយើងឲ្យញែកខ្លួនចេញពីការល្បួងបានយ៉ាងដូចម្តេច ។

សូមពន្យល់ថា សិស្សប្រហែលជាពុំអាចចៀសវាងពីការល្បួងបានជានិច្ចបានឡើយ ។ ដោយសារបញ្ហានេះហើយ ទើបយើងត្រូវសម្រេចចិត្តនៅពេលនេះ អំពីរបៀបដែលយើងនឹងធ្វើដើម្បីតតាំងនឹងការល្បួង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ស្តែនសើរ ដបុលយូ ឃីមបឹល ៖



« ការសម្រេចចិត្តត្រឹមត្រូវគឺជារឿងងាយធ្វើបំផុត នៅពេលយើងធ្វើការសម្រេចចិត្តទុកជាមុន ដោយគិតអំពីគោលដៅដ៏ខ្ពស់បំផុត ការធ្វើបែបនេះសង្គ្រោះការឈឺចិត្តជាច្រើន ។ នៅគ្រានៃការសម្រេចចិត្ត ។ នៅពេលយើងហត់នឿយ ហើយរងការល្បួងយ៉ាងខ្លាំង ។ . . .

« សូមអភិវឌ្ឍការលត់ដំខ្លួនឲ្យបានច្រើនដើម្បីកុំឲ្យបងប្អូនត្រូវសម្រេចចិត្ត ហើយត្រូវសម្រេចចិត្តជាថ្មីអំពីរឿងដែលបងប្អូននឹងត្រូវធ្វើ នៅពេលជួបប្រទះនឹងការល្បួងដូចគ្នាពីមួយគ្រាទៅមួយគ្រា ។ បងប្អូនត្រូវសម្រេចចិត្តពីរឿងមួយចំនួនតែ *ម្តង*ប៉ុណ្ណោះ ! . . .

« គ្រាដើម្បីចាកចេញពីផ្លូវអាក្រក់គឺមុនពេលវាចាប់ផ្តើម ។ រឿងអាថ៌កំបាំងនៃជីវិតល្អគឺស្ថិតនៅក្នុងការការពារ និងការរារាំង ។ ជនដែលងាកទៅរកអំពើអាក្រក់ ជាធម្មតាគឺជាជនដែលបានដាក់ខ្លួនឯងនៅក្នុងកន្លែងមួយដែលគ្មានការការពារ » (*Teachings of Presidents of the Church: Spencer W. Kimball* ឆ្នាំ ២០០៦ ទំព័រ ១០៨–៩) ។

ចូរចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ទាំងឡាយ ដែលសិស្សបានស្តាប់នៅថ្ងៃនេះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា ការល្បួងណាមួយដែលពួកគេកំពុងមានបញ្ហាខ្លាំងបំផុត ។ សូមអញ្ជើញឲ្យពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖

- តើការផ្លាស់ប្តូរអ្វីខ្លះ ដែលអ្នកអាចធ្វើដើម្បីចៀសវាងពីការល្បួង មុននឹងអ្នកតតាំងនឹងវា ?
- តើអ្នកយល់ព្រមធ្វើការផ្លាស់ប្តូរទាំងនេះដែរឬទេ ?

សូមអញ្ជើញសិស្សឲ្យបង្កើតផែនការមួយ ដែលពួកគេនឹងធ្វើតាមដើម្បីគេចចេញពីការល្បួង ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកជំនួយមកពីព្រះអម្ចាស់តាមរយៈការអធិស្ឋាន នៅពេលពួកគេខិតខំសម្រេចឲ្យបានផែនការរបស់ពួកគេ ។

សូមសង្ខេប កូរិនថូសទី ១ ១០:១៥–៣៣ ដោយពន្យល់ថា ប៉ុលបានទូន្មានពួកបរិសុទ្ធនៅកូរិនថូស ឲ្យគោរពដល់ការអនុវត្តសាសនារបស់មនុស្សដទៃទៀត ដោយគ្មានការបន្ទាបបទដ្ឋានសាសនារបស់ខ្លួន ហើយបានលើកឡើងជាថ្មីម្តងទៀតថា លោកកំពុងប្រកាសដំណឹងល្អ ដើម្បីជួយមនុស្សជាច្រើនឲ្យទទួលបានការសង្គ្រោះ ។

មេរៀន ១០៨

កូរិនថូស ទី១ ១១

សេចក្តីផ្តើម

ប៉ុលបានលើកឡើងពីការឈ្លោះប្រកែកនៅក្នុងចំណោមពួកបរិសុទ្ធនៅកូរិនថូសទាក់ទងនឹងទំនៀមទម្លាប់សាសនា ។ លោកបានគូសបញ្ជាក់ថា បុរស និងស្ត្រីមានតួនាទីដ៏ទេវភាព ហើយដ៏អស់កល្បជានិច្ច ហើយវាក៏ជាតួនាទីដ៏ចាំបាច់ចំពោះគ្នាទៅវិញទៅមកនៅក្នុងផែនការរបស់ព្រះអម្ចាស់ដែរ ។ លោកក៏បានបង្រៀនដល់សមាជិកសាសនាចក្រផងដែរអំពីការរៀបចំខ្លួនយ៉ាងត្រឹមត្រូវ ដើម្បីទទួលទានសាក្រាម៉ង់ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី ១ ១១:១–១៦

ប៉ុលបានលើកឡើងអំពីការឈ្លោះប្រកែកទាក់ទងទំនៀមទម្លាប់នៅក្នុងសម័យរបស់លោក



សូមដាក់តាំងរូបភាពស្វាមីភរិយាមួយគូដែលបានរៀបការ (ដូចជា Young Couple Going to the Temple, *Gospel Art Book* **| ឆ្នាំ ២០០៩ | ល.រ. ១២០ សូមមើលផងដែរ** LDS.org) ។ **សូមអានប្រយោគខាងក្រោមនេះឲ្យឮៗ ដើម្បីឆ្លុះបញ្ចាំងពីអារម្មណ៍ដែលបុគ្គលមួយចំនួនមានចំពោះអាពាហ៍ពិពាហ៍ ៖**

១. « ជោគជ័យនៅក្នុងអាជីពរបស់ខ្ញុំ គឺជារឿងដ៏មានន័យអស្ចារ្យចំពោះខ្ញុំ ។ ខ្ញុំមិនចង់បែងចែកការផ្តោតអារម្មណ៍រវាងគោលដៅការងារ និងអាពាហ៍ពិពាហ៍របស់ខ្ញុំឡើយ » ។

២. « ខ្ញុំមិនចង់មានទំនាក់ទនងមួយដ៏សឺីជម្រៅនោះទេ ។ ខ្ញុំខ្លាចធ្វើការសម្រេចចិត្តមួយ ដែលខ្ញុំនឹងមានវិប្បដិសារីនៅពេលក្រោយ » ។

៣. « អាពាហ៍ពិពាហ៍នឹងរឹតបន្តឹងដល់ខ្ញុំ ។ ខ្ញុំមិនអាចធ្វើអ្វីដែលខ្ញុំចង់ធ្វើបានទេ » ។

៤. « ខ្ញុំដឹងថា អាពាហ៍ពិពាហ៍គឺជាការសម្រេចចិត្តដ៏សំខាន់បំផុតដែលខ្ញុំពុំធ្លាប់ធ្វើពីមុនមក ហើយខ្ញុំទន្ទឹងរង់ចាំដើម្បីធ្វើវា » ។

ចូរអញ្ជើញសិស្សឲ្យពិចារណាថា ពួកគេមានអារម្មណ៍បែបណាដែរចំពោះអាពាហ៍ពិពាហ៍ ។ ចូរសុំឲ្យពួកគេរកមើលសេចក្តីពិតមួយ កាលពួកគេសិក្សា កូរិនថូសទី ១ ១១:១–១៦ ដែលអាចជួយពួកគេ និងមនុស្សដទៃទៀតឲ្យយល់ពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១១:៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វីដែលប៉ុលបានបង្រៀនអំពីទំនួលខុសត្រូវរបស់ស្វាមីម្នាក់ ។ អ្នកអាចពន្យល់ថា នៅក្នុងខគម្ពីរនេះពាក្យដែលបានបកប្រែថា « បុរស » ក៏អាចបកស្រាយថាជា « ស្វាមី » ដែរ រីឯពាក្យដែលបានបកស្រាយថា « ស្ត្រី » ក៏អាចប្រែថាជា « ភរិយា » ដែរ ។

- **តើតួនាទីរបស់ស្វាមីជាអ្វី ? (អ្នកគួរពន្យល់ថា ឃ្លា « ឯបុរសវិញនោះជាក្បាលនៃស្ត្រី » មានន័យថា ស្វាមីមានការទទួលខុសត្រូវពិសិដ្ឋធ្វើជាអធិបតីនៅក្នុងផ្ទះ ។ ការ *ធ្វើជាអធិបតី* មានន័យថា ការដឹកនាំ និងការណែនាំអ្នកដទៃដោយសុចរិតនៅក្នុងបញ្ហាខាងវិញ្ញាណ និងខាងសាច់ឈាម) ។**
- **តើនរណាជាអធិបតី ហើយណែនាំដល់ស្វាមី កាលគាត់ធ្វើជាអធិបតីលើគ្រួសារគាត់ ?**

សូមសង្ខេប កូរិនថូសទី ១ ១១:៤–១៦ ដោយពន្យល់ថា ប៉ុលបានលើកឡើងនូវសំណួរអំពីទំនៀមទម្លាប់សម្រាប់បុរស និងស្ត្រី នៅពេលពួកគេបានអធិស្ឋាន ឬព្យាករនៅក្នុងការប្រជុំថ្វាយបង្គំរបស់ពួកគេ ។

សូមជួយសិស្សឲ្យយល់ថា ពេលខ្លះពួកអ្នកអានព្រះគម្ពីរសញ្ញាថ្មីយល់ខុសពីការបង្រៀនរបស់ប៉ុលថា តួនាទីរបស់បុរសគឺសំខាន់ជាងតួនាទីរបស់ស្ត្រី ឬថា បុរសមានសិទ្ធិធំជាង ឬមានតម្លៃជាងស្ត្រី ។ សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« បុរស និង ស្ត្រីគឺស្មើគ្នានៅចំពោះព្រះនេត្ររបស់ព្រះ និង នៅចំពោះមុខនៃសាសនាចក្រ ប៉ុន្តែភាពស្មើគ្នានេះពុំមែនមានន័យថា ពួកគេដូចគ្នានោះទេ ។ ការទទួលខុសត្រូវ និង អំណោយទានដ៏ទេវភាពនានារបស់បុរស និង ស្ត្រី ផ្សេងៗពីគ្នាទៅតាមធម្មជាតិរបស់ខ្លួន ប៉ុន្តែមិនមែនទៅតាមភាពសំខាន់ ឬ ឥទ្ធិពលរបស់ខ្លួននោះឡើយ ។ គោលលទ្ធិសាសនាចក្រយើងបានដាក់ស្ត្រីឲ្យស្មើនឹងបុរស ប៉ុន្តែផ្សេងពីបុរស ។ ព្រះទ្រង់មិនចាត់ទុកថាភេទណាមួយប្រសើរ ឬសំខាន់ជាងមួយណានោះទេ » (« Men and Women in the Work of the Lord » *New Era* ខែ មេសា ឆ្នាំ ២០១៤ ទំព័រ ៤) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១១:១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពីអ្វីដែលប៉ុលបានបង្រៀនអំពីទំនាក់ទំនងរវាងស្វាមី និងភរិយា ។

- **តើសាវកប៉ុលបានបង្រៀនអ្វីខ្លះអំពីទំនាក់ទំនាក់រវាងស្វាមី និងភរិយា ?**

សូមប្រើវត្ថុនានាដើម្បីជួយសិស្សឲ្យយល់ដឹងពីសេចក្តីពិតខាងវិញ្ញាណ ។

វាអាចជារឿងដ៏ពិបាកដើម្បីបង្រៀនអំពីលក្ខណៈអប្បិយនៃដំណឹងល្អ ។ ការប្រើវត្ថុនានាដើម្បីលើកស្ទួយឲ្យមានការពិភាក្សាមួយ អាចជួយសិស្សឲ្យវិភាគ ហើយយល់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ហើយអាចបន្តែមដល់បរិយាកាសរៀនសូត្រដោយមានការចោទសួរសំណួរ ។

សូមចង្អុលបង្ហាញឃ្លា « ក្នុងព្រះអម្ចាស់ » ។ សូមពន្យល់ថា ឃ្លានេះសំដៅទៅលើផែនការរបស់ព្រះអម្ចាស់ដើម្បីជួយយើងឲ្យភ្ជាយដូចជាទ្រង់ ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

- តើខគម្ពីរនេះបង្រៀនគោលលទ្ធិអ្វីខ្លះអំពីបុរស និងស្ត្រីនៅក្នុងផែនការរបស់ព្រះអម្ចាស់ ? (សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ដោយប្រើពាក្យរបស់សិស្ស ៖ **នៅក្នុងផែនការរបស់ព្រះអម្ចាស់ បុរស និងស្ត្រីមិនអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដោយគ្មានគ្នាបានឡើយ ។** | សូមមើល គ. និង ស. ១៣១:១–៤ | ។

ដើម្បីជួយសិស្សឲ្យយល់ដឹងពីសេចក្តីពិតដែលបានបង្ហាញខាងលើ សូមលើក កន្ត្រៃ មួយឡើង ហើយចាប់ផ្តើមកាត់ក្រដាសមួយសន្លឹក ។ ចូរសុំឲ្យសិស្សនឹកស្រមៃថា មុខកន្ត្រៃទាំងពីរនោះបានដាច់ចេញពីគ្នា ។

- តើមនុស្សម្នាក់មានជោគជ័យបែបណាទៅ ប្រសិនបើគាត់ព្យាយាមកាត់ក្រដាសមួយសន្លឹកនឹងកន្ត្រៃដែលមានមុខតែម្ខាងនោះ ? តើកន្ត្រៃមួយប្រៀបដូចជាស្វាមី និងភរិយាធ្វើការរួមគ្នាយ៉ាងដូចម្តេចទៅ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« តាមរយៈការចងនាដ៏ទេវភាព បុរស និង ស្ត្រី ត្រូវបានតាំងចិត្តដើម្បីរីកចម្រើនជាមួយគ្នាឆ្ពោះទៅកាន់ភាពល្អឥតខ្ចោះ និង ភាពដ៏ពេញលេញនៃសិរីល្អ ។ ដោយសារភាពខុសគ្នានៃនិស្ស័យ និង សមត្ថភាពរបស់ខ្លួន បុរស និង ស្ត្រីគ្រប់រូបនាំមកកាន់ទំនាក់ទំនងអាពាហ៍ពិពាហ៍នូវទស្សនវិស័យ និង បទពិសោធន៍ដ៏ពិសេស ។ បុរស និង ស្ត្រីមានលក្ខណៈផ្សេងគ្នា ប៉ុន្តែមានភាពស្មើគ្នាតែមួយ និង សាមគ្គីភាព ដែលកិច្ចការទាំងនេះមិនអាចទទួលបានជោគជ័យបានតាមវិធីផ្សេងឡើយ ។ បុរសបំពេញ ហើយធ្វើឲ្យស្ត្រីបានល្អឥតខ្ចោះ ហើយស្ត្រីបំពេញ ហើយធ្វើឲ្យបុរសបានល្អឥតខ្ចោះ នៅពេលពួកគេរៀន ហើយពង្រឹងគ្នាទៅវិញទៅមក ព្រមទាំងផ្តល់ពរឲ្យគ្នាទៅវិញទៅមក » (« Marriage Is Essential to His Eternal Plan » *Ensign* ខែ មិថុនា ឆ្នាំ ២០០៦ ទំព័រ ៨៣–៨៤) ។

- តើចរិតលក្ខណៈ និងការទទួលខុសត្រូវផ្សេងៗគ្នារបស់បុរស និងស្ត្រីបានជួយបំពេញបង្រ្គប់ឲ្យគ្នាទៅវិញទៅមកនៅក្នុងគ្រួសារយ៉ាងដូចម្តេចដែរ ?

សូមរំឭកសិស្សនូវឥរិយាបថខុសគ្នាអំពីអាពាហ៍ពិពាហ៍ ដែលបានពិពណ៌នានៅក្នុងសេចក្តីថ្លែងការណ៍ដែលអ្នកបានអាននៅដើមដំបូងក្នុងមេរៀននេះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិត និងទីបន្ទាល់ពួកគេទាក់ទងនឹងសារៈសំខាន់នៃអាពាហ៍ពិពាហ៍នៅក្នុងផែនការរបស់ព្រះអម្ចាស់ ។ អ្នកគួរចែកចាយពីទីបន្ទាល់របស់អ្នកផងដែរ ។

កូរិនថូស ទី១ ១១:១៧–៣៤

ប៉ុលបង្រៀនពួកបរិសុទ្ធនៅកូរិនថូសឲ្យទទួលទានសាក្រាម៉ង់ដោយប្រុងប្រយ័ត្ន

សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន ៖ *បទពិសោធន៍ខាងវិញ្ញាណដ៏ពិតប្រាកដមួយ ការផ្លាស់ប្តូរថ្មីមួយដល់ព្រលឹង ផ្នែកសំខាន់ៗនៃថ្ងៃឈប់សម្រាករបស់ខ្ញុំ ។*

ចូរសុំឲ្យសិស្សសញ្ជឹងគិតពីបទពិសោធន៍ដែលទើបតែកើតឡើងថ្មីៗរបស់ពួកគេនៅក្នុងការទទួលទានសាក្រាម៉ង់ ហើយពិចារណាថាតើពួកគេនឹងប្រើឃ្លាណាមួយនៅលើក្តារខៀន ដើម្បីពិពណ៌នាពីបទពិសោធន៍របស់ខ្លួន ។ ចូរសុំឲ្យសិស្សរកមើលសេចក្តីពិតនានា នៅពេលពួកគេសិក្សា កូរិនថូសទី ១ ១១:១៧–៣៤ ដែលអាចជួយពួកគេដើម្បីធ្វើឲ្យការទទួលទានសាក្រាម៉ង់ក្លាយជាបទពិសោធន៍មួយកាន់តែមានន័យខាងវិញ្ញាណ ។

សូមពន្យល់ថា នៅក្នុងសម័យរបស់ប៉ុល សមាជិកសាសនាចក្របានរក្សាទំនៀមទម្លាប់មួយនូវការរំលឹកចងចាំដល់អាហារយប់ថ្ងៃចុងក្រោយ ។ ពួកគេបានបរិភោគអាហាររួមគ្នា រួចក្រោយមកបានទទួលទានសាក្រាម៉ង់ ។ សូមសង្ខេប កូរិនថូសទី ១ ១១:១៧–២២ ដោយពន្យល់ថា ប៉ុលបានកត់ចំណាំពីរបាយការណ៍មួយ ដែលលោកបានទទួលថា នៅពេលពួកបរិសុទ្ធនៅកូរិនថូសបានជួបជុំគ្នាទទួលទានសាក្រាម៉ង់ នោះមានការខ្វែងគំនិតគ្នា ឬការឈ្លោះប្រកែកគ្នានៅក្នុងចំណោមពួកគេ ។ ប៉ុលបានស្តីបន្ទោសដល់ពួកបរិសុទ្ធចំពោះការធ្វើឲ្យការជួបជុំទាំងនេះក្លាយទៅជាការបរិភោគអាហាររួមគ្នា ជាជាងការរក្សាភាពពិសិដ្ឋនៃពិធីបរិសុទ្ធសម្រាប់សាក្រាម៉ង់ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១១:២៣–២៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពីអ្វីដែលប៉ុលបានលើកទឹកចិត្តឲ្យសមាជិកសាសនាចក្រចងចាំអំពីសាក្រាម៉ង់ ។ អ្នកគួរពន្យល់ថា ពាក្យ *សម្រង់* នៅក្នុង ខទី ២៦ មានន័យថា ប្រកាសប្រាប់ដំណឹង ឬថ្លែងទីបន្ទាល់ ។

ចូរដាក់តាំងបង្ហាញរូបភាព អាហារយប់ថ្ងៃចុងក្រោយ (*Gospel Art Book* | ឆ្នាំ ២០០៩ | ល.រ. ៥៤សូមមើលផងដែរ LDS.org) ។



- តើប៉ុលបាននិយាយថា ព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សរបស់ទ្រង់ឲ្យចងចាំអ្វីខ្លះ នៅពេលពួកគេទទួលទានសាក្រាម៉ង់ ?
- តើការចងចាំដល់ព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គសង្គ្រោះនៅក្នុងពិធីសាក្រាម៉ង់ បានជួយដល់សមាជិកសាសនាចក្រដែលកំពុងខ្វែងគំនិតគ្នាយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១១:២៧–៣០ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការព្រមាន ដែលប៉ុលបានផ្តល់ដល់ពួកបរិសុទ្ធនៅកូរិនថូសអំពីសាក្រាម៉ង់ ។

- យោងតាម ខទី ២៧ និង ២៩តើប៉ុលបានព្រមានពួកបរិសុទ្ធកូរិនថូសអំពីអ្វីខ្លះ ?

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះក្នុងខគម្ពីរទាំងនេះអំពីអ្វីដែលកើតឡើង នៅពេលយើងទទួលទានសាក្រាម៉ង់ដោយមិនសក្តិសម ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ជនដែលទទួលទានសាក្រាម៉ង់ដោយមិនសក្តិសមនាំមកនូវការដាក់ទោស និងការជាប់ទោសដល់ខ្លួនឯង**) ។

សូមពន្យល់ថា យើង « ពុំចាំបាច់ល្អឥតខ្ចោះដើម្បីទទួលទានសាក្រាម៉ង់នោះទេ ប៉ុន្តែ | យើង | គួរមានស្មារតីនៃការបន្ទាបខ្លួន និងការប្រែចិត្តនៅក្នុងដួងចិត្ត | របស់យើង | » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* | ឆ្នាំ ២០០៤ | ទំព័រ ១៤៨ |) ។ ប្រសិនបើយើងទទួលទានសាក្រាម៉ង់កាលយើងមានអំពើបាបដ៏ធ្ងន់ធ្ងរ ឬមានដួងចិត្តដែលមិនព្រមប្រែចិត្ត គ្មានបំណងប្រាថ្នាដើម្បីចងចាំ ហើយធ្វើតាមព្រះអង្គសង្គ្រោះទេ នោះយើងកំពុងទទួលទានសាក្រាម៉ង់ដោយមិនសក្តិសមហើយ ។ សូមលើកទឹកចិត្តសិស្សឲ្យអធិស្ឋានទៅព្រះវរបិតាសួគ៌ ហើយនិយាយជាមួយប៊ីស្សពរបស់ពួកគេ (សូមមើល នីហ្វៃទី ៣ ១៨:២៦–២៩) ប្រសិនបើពួកគេមានសំណួរអំពីភាពសក្តិសមដើម្បីទទួលទានសាក្រាម៉ង់ ។

- ហេតុអ្វីអ្នកគិតថា ការទទួលទានសាក្រាម៉ង់ដោយមិនសក្តិសមនឹងនាំមកនូវការជាប់ទោសដល់ព្រលឹងរបស់យើង ?
- យោងតាម កូរិនថូសទី ១ ១១:២៨តើប៉ុលបានផ្តល់ពាក្យទូន្មានអ្វីខ្លះដល់សមាជិកសាសនាចក្រ ? (សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ដោយប្រើពាក្យរបស់សិស្ស ៖ **យើងគួរពិនិត្យមើលពីជីវិតរបស់យើង នៅពេលយើងទទួលទានសាក្រាម៉ង់**) ។

សូមចង្អុលបង្ហាញថា គោលបំណងនៃការពិនិត្យមើលពីជីវិតរបស់យើងគឺពុំមែនគ្រាន់តែដើម្បីពិចារណាថា តើយើងមានភាពសក្តិសមដើម្បីទទួលទានសាក្រាម៉ង់ដែរឬអត់នោះទេ ប៉ុន្តែយើងក៏ត្រូវពិចារណាថា យើងកំពុងខិតខំគោរពតាមសេចក្តីសញ្ញារបស់យើងជាមួយនឹងព្រះអម្ចាស់បានល្អដល់កម្រិតណាហើយ និងពីរបៀបដែលយើងអាចនឹងខិតខំប្រែចិត្ត ឬ ហើយធ្វើខ្លួនឲ្យកាន់តែប្រសើរឡើង ។

ចូរសុំសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ៖



« ខ្ញុំបានសួរសំណួរនេះដល់ខ្លួនឯង ៖ ‹ តើខ្ញុំបានដាក់ព្រះយ៉ាងខ្ពស់លើសពីអ្វីៗទាំងអស់ផ្សេងទៀត ហើយគោរពតាមរាល់ព្រះបញ្ញត្តិរបស់ទ្រង់ដែរឬទេ ? បន្ទាប់មក ការសញ្ជឹងគិត និងដំណោះស្រាយបានកើតមាន ។ ការចុះសេចក្តីសញ្ញាមួយជាមួយនឹងព្រះអម្ចាស់ដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ជានិច្ច គឺជាកាតព្វកិច្ចមួយដ៏ធំ ហើយការរំឭកសេចក្តីសញ្ញានោះដោយការទទួលទានសាក្រាម៉ង់ក៏ជាកាតព្វកិច្ចយ៉ាងធំដូចគ្នាដែរ ។ គ្រាដ៏ឱឡារិកនៃការគិតនោះ កាលសាក្រាម៉ង់ត្រូវបានចែកគឺមានសារៈសំខាន់ខ្លាំងណាស់ ។ វាគឺជាគ្រានៃការត្រួតពិនិត្យខ្លួនឯង ការពិចារណាមើលចិត្តខ្លួនឯង ការដឹងខុសត្រូវពីខ្លួនឯង—ជាគ្រាមួយដើម្បីសញ្ជឹងគិត ហើយដោះស្រាយ »
(« Thoughts on the Sacrament » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៧ ទំព័រ ២៥) ។

ដើម្បីជួយសិស្សឲ្យពិចារណាពីរបៀបដែលពួកគេអាចអនុវត្តសេចក្តីពិត ដែលពួកគេបានរកឃើញនៅក្នុង កូរិនថូសទី ១ ១១:២៨ សូមអញ្ជើញពួកគេឲ្យគិតពីសំណួរដែលពួកគេអាចគិតឃើញ នៅពេលពួកគេរៀបចំខ្លួនទទួលទានសាក្រាម៉ង់ ។ ឧទាហរណ៍ ពួកគេអាចសួរថា « តើខ្ញុំអាចក្លាយជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទកាន់តែប្រសើរឡើងតាមរបៀបណា ? » ចូរសុំឲ្យសិស្សចែកចាយសំណួរផ្សេងទៀត ដែលពួកគេអាចសួរដល់ខ្លួនឯង ។ អ្នកក៏អាចផ្តល់ជាសំណួររបស់អ្នកមួយចំនួនផងដែរ ។ សូមអញ្ជើញសិស្សឲ្យសរសេរសំណួរ ដែលពួកគេអាចសួរដល់ខ្លួនឯងនៅពិធីសាក្រាម៉ង់នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាសិក្សាព្រះគម្ពីររបស់ពួកគេ នៅពេលពួកគេពិនិត្យមើលពីភាពសក្តិសមរបស់ពួកគេ ។

នៅពេលសិស្សត្រួតពិនិត្យពីភាពសក្តិសមរបស់ពួកគេពីមុន និងពេលកំពុងទទួលទានសាក្រាម៉ង់ សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់អាចជួយពួកគេឲ្យដឹងពីរបៀបដែលពួកគេអាចបំពេញសេចក្តីសញ្ញារបស់ពួកគេកាន់តែប្រសើរឡើង ហើយមានគុណសម្បត្តិគ្រប់គ្រាន់ ដើម្បីទទួលបានពរជ័យដែលទ្រង់មានព្រះរាជបំណងប្រទានដល់ពួកគេ ។ ពរជ័យទាំងនេះរួមបញ្ចូលការជ្រះស្អាតពីអំពើបាបរបស់ពួកគេ និងការទទួលបានព្រះចេស្តាដ៏ធំធេងបំផុតមួយនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយទាក់ទងនឹងរបៀបដែលពួកគេនឹងត្រៀមខ្លួនកាន់តែប្រសើរឡើង សម្រាប់ការទទួលទានសាក្រាម៉ង់របស់ពួកគេនៅឱកាសក្រោយ ។

សូមសង្ខេប កូរិនថូសទី ១ ១១:៣៣–៣៤ ដោយពន្យល់ថា ប៉ុលបានផ្តល់នូវការណែនាំបន្ថែមដល់ពួកបរិសុទ្ធកូរិនថូសទាក់ទងនឹងអាហារ ដែលពួកគេបានដាក់បញ្ចូលជាមួយនឹងការចាត់ចែងពិធីសាក្រាម៉ង់ ។

សូមបញ្ចប់មេរៀននេះដោយថ្លែងទីបន្ទាល់ពីសេចក្តីពិត ដែលបានបង្ហាញនៅក្នុងកូរិនថូសទី ១ ១១ ។

កូរិនថូសទី១ ១២

សេចក្តីផ្តើម

ប៉ុលបានសរសេរអំពីអំណោយទានយ៉ាងច្រើននៃព្រះវិញ្ញាណ ។ លោកបានប្រៀបធៀបសាសនាចក្រទៅនឹងរូបកាយ ហើយបានពន្យល់ថា ដូចជារូបកាយត្រូវការគ្រប់ផ្នែកទាំងអស់ឲ្យដំណើរការត្រឹមត្រូវដែរ ដូច្នេះសមាជិកសាសនាចក្រម្នាក់ៗអាចប្រើអំណោយទាននៃព្រះវិញ្ញាណឲ្យចូលរួមចំណែក ហើយពង្រឹងដល់សាសនាចក្រ ។

ដឹកនាំសិស្សរបស់អ្នកតាមរយៈដំណើរការរៀនសូត្រ

សិស្សទាំងឡាយត្រូវបានស្អាងឡើង នៅពេលអ្នកដឹកនាំពួកគេឆ្លងកាត់ដំណើរការរៀនសូត្រមួយ ដែលដូចនឹងអ្វីដែលអ្នកមានបទពិសោធន៍ក្នុងការរៀបចំមេរៀន ។ សូមដឹកនាំពួកគេឲ្យស្វែងរកការយល់ដឹងពីបទគម្ពីរ ហើយរកឃើញនូវសេចក្តីពិតនៃដំណឹងល្អសម្រាប់ខ្លួនឯង ។ សូមផ្តល់ឱកាសឲ្យពួកគេពន្យល់ពីដំណឹងល្អជាសម្តីរបស់ពួកគេផ្ទាល់ ហើយចែកចាយ និងធ្វើទីបន្ទាល់អំពីអ្វីដែលពួកគេដឹង ហើយទទួលអារម្មណ៍ ។ ការណ៍នេះជួយពួកគេឲ្យនាំយកដំណឹងល្អមកសញ្ជឹងគិតក្នុងគំនិត និងដួងចិត្តរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ១២:១–១១

ប៉ុលបង្រៀនអំពីអំណោយទានខាងវិញ្ញាណ

សូមដាក់បង្ហាញរូបភាពថ្មដូចខាងក្រោមនេះ ៖



សូមឲ្យសិស្សម្នាក់អានអក្សរនៅផ្នែកខាងលើថ្មនោះឲ្យឮៗ ។ សូមពន្យល់ថា កាលប្រធានដេវីឌ អូ មិកឃៃ បានបម្រើបេសកកម្មមួយនៅប្រទេសស្កុតឡង់ លោកបានឃើញថ្មនេះនៅពីលើទ្វារនៃអគារមួយក្បែរប្រាសាទស្នើលីង ហើយបានបំផុសគំនិតដោយសារតែសារលិខិតរបស់វា (សូមមើល Francis M. Gibbons, *David O. McKay: Apostle to the World, Prophet of God* **| ឆ្នាំ ១៩៨៦ | ទំព័រ ៤៥) ។**

សូមពន្យល់ថា និមិត្តសញ្ញានីមួយៗនៅលើថ្មជ្រុងប្រាំបួនជុំនេះតំណាងឲ្យតម្លៃជាលេខមួយ ។ ចូរសុំឲ្យសិស្សបង្ហាញពីតម្លៃជាលេខនៃថ្មនីមួយៗ ។ (ពីឆ្វេងទៅស្តាំ និមិត្តសញ្ញាតំណាងលេខ ៥, ១០ និង ៣ នៅជួរខាងលើ និងលេខ ៤, ៦ និង ៨ នៅជួរកណ្តាល និងលេខ ៩, ២ និង ៧ នៅជួរខាងក្រោម) ។

- **តើផលបូកនៃលេខទាំងបីនៅជួរខាងលើតំណាងឲ្យអ្វី ? ជួរកណ្តាលតំណាងឲ្យអ្វី ? ជួរក្រោមតំណាងឲ្យអ្វី ?**

សូមពន្យល់ថា លេខនៅក្នុងជួរដេក ជួរឈរ ឬ អង្កត់ទ្រូងលើថ្មនេះតំណាងបូកបញ្ចូលគ្នាស្មើ ១៨ ។ ហេតុផលមួយដែលរាងទាំងនេះអាចដាក់បញ្ចូលឃ្លា « អ្វីក៏ដោយដែលអ្នករាល់គ្នាធ្វើ សូមធ្វើផ្នែករបស់អ្នកឲ្យល្អ » គឺថា ប្រសិនបើរាងទាំងនេះមានរាងណាមួយបានផ្លាស់ប្តូរ ឬប្រសិនបើតម្លៃរបស់វាផ្លាស់ប្តូរ នោះជួរដេក និងជួរឈរនៅលើថ្មនោះនឹងមិនស្មើ ១៨ ពីគ្រប់ទិសទាំងអស់ទៀតឡើយ ។

នៅពេលសិស្សសិក្សា កូរិនថូសទី១ ១២ **សូមអញ្ជើញពួកគេឲ្យពិចារណាថា** ក្នុងនាមយើងជាសមាជិកសាសនាចក្រ ប្រៀបបាននឹងរាងនៅលើថ្មនោះបានដោយរបៀបណា ។

សូមសង្ខេប កូរិនថូសទី១ ១២:១–២ **ដោយពន្យល់ថា** ប៉ុលចង់បង្រៀនសមាជិកសាសនាចក្រនៅកូរិនថូសអំពីអំណោយទានខាងវិញ្ញាណ ដែលពួកបរិសុទ្ធជាច្រើនបានយល់ខុស ។ ប៉ុលបានរំឭកពួកគេថា ពីមុនពួកគេបានប្រែចិត្តជឿ ពួកគេត្រូវបាននាំឲ្យវង្វេងដោយជំនឿអសារឥតការ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កូរិនថូសទី១ ១២:៣ ឮៗ **ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលយើងអាចដឹងដោយខ្លួនឯងថា** ព្រះយេស៊ូវគឺជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះតាមរបៀបណា ។ **សូមពន្យល់ថា** យ៉ូសែប ស៊្មីធ បានបង្រៀនថា ពាក្យ *នឹងថា* នៅក្នុង ខទី ៣ គួរតែយល់ថាជាពាក្យ *ដឹងថា* (នៅក្នុង *History of the Church* ៤:៦០២–៣) ។

- **យោងតាម** កូរិនថូសទី១ ១២:៣ **តើយើងអាចទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ មានតែតាមរយៈព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ដែលយើងអាចទទួលបានទីបន្ទាល់មួយផ្ទាល់ខ្លួនថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់យើង ។** អ្នកគួរពន្យល់ថា គោលការណ៍ដដែលនេះអនុវត្តចំពោះការទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនមួយអំពី យ៉ូសែប ស៊្មីធ ឬព្រះគម្ពីរមរមន) ។

ដើម្បីជួយឲ្យយល់សេចក្តីពិតនេះកាន់តែប្រសើរឡើង ចូរសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ឌៀថើរ អេស អ៊ុជដូហ្វ នៃគណៈប្រធានទីមួយឲ្យឮៗ ៖



« ទីបន្ទាល់មួយគឺជាទ្រព្យមួយដ៏មានតម្លៃបំផុត ដោយសារវាមិនបានតម្រូវឲ្យមានការពិចារណា ឬហេតុផលតែម្យ៉ាង វាមិនអាចទិញដោយទ្រព្យសម្បត្តិនៅលើផែនដីនេះ ហើយវាអាចឲ្យជាអំណោយ បុបានត្រងជាមរតកមកពីដូនជីតារបស់យើងបានឡើយ ។ យើងមិនអាចពឹងផ្អែកលើទីបន្ទាល់របស់អ្នកដទៃបានឡើយ ។ យើងត្រូវដឹងដោយខ្លួនឯង ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍ថា ‹ រាល់ពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងឡាយ មានទំនួលខុសត្រូវដើម្បីដឹងដោយខ្លួនឯងយ៉ាងច្បាស់លាស់លើសពីការសង្ស័យថា ព្រះយេស៊ូវ គឺជាព្រះរាជបុត្រាដែលបានរស់ឡើង

វិញ ដែលនៅមានព្រះជន្មរបស់ព្រះដ៏មានព្រះជន្មរស់នៅ › (‹ Fear Not to Do Good › *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៣ ទំព័រ ៨០) ។ . . .

« យើងទទួលបានទីបន្ទាល់នេះ នៅពេលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់វិញ្ញាណដែលនៅក្នុងខ្លួនយើង ។ យើងនឹងទទួលបានភាពស្ងប់ស្ងាត់មួយ និងភាពច្រាកដជាក់លាក់មួយដែលនឹងក្លាយជាប្រភពនៃទីបន្ទាល់ និងជំនឿរបស់យើង » (« The Power of a Personal Testimony » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៣៨) ។

- ហេតុអ្វីជារឿងសំខាន់ដើម្បីយល់ថា ទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទកើតឡើងតែតាមរយៈព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីយាងព្រះវិញ្ញាណបរិសុទ្ធឲ្យចូលមកក្នុងជីវិតរបស់យើង ?

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង កូរិនថូស ទី១ ១២:៤–៦ ប៉ុលបានបង្រៀនថា មានភាពខុសគ្នាមួយរវាងអំណោយទានខាងវិញ្ញាណទាំងឡាយដែលមានដំណើរការតាមរបៀបខុសៗគ្នា ប៉ុន្តែអំណោយទានទាំងអស់នោះមកពីព្រះតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកគ្រូពន្យល់ថា អំណោយទាននៃព្រះវិញ្ញាណគឺជាពរជ័យ ឬសមត្ថភាពដែលបានប្រទានឲ្យតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយថាព្រះបានប្រទានយ៉ាងហោចណាស់អំណោយទានមួយ ដល់សមាជិកសាសនាចក្រគ្រប់រូប (សូមមើល គ. និង ស. ៤៦:១១) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១២:៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីហេតុផលដែលអំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានដល់យើង ។ (ប្រសិនបើចាំបាច់ សូមពន្យល់ថា « ដើម្បីឲ្យកើតបានផល » មានន័យថា សេចក្តីល្អរួមនៃពួកបរិសុទ្ធគ្រប់រូប) ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ពីប៉ុលស្តីពីហេតុផលដែលអំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានដល់កូនចៅរបស់ព្រះវរបិតាសួគ៌ ? (សិស្សគួរឃើញសេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម ៖ **អំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានឲ្យ ដើម្បីជាប្រយោជន៍ដល់កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់ពីសេចក្តីពិតនេះ សូមចម្លងតារាងដូចខាងក្រោមនៅលើក្តារខៀន ហើយសុំឲ្យសិស្សចម្លងវាចូលទៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

អំណោយទាំងឡាយខាងវិញ្ញាណ	របៀបដែលអំណោយទានខាងវិញ្ញាណទាំងនេះ អាចជាប្រយោជន៍ដល់កូនចៅរបស់ព្រះ

សូមចែកសិស្សជាក្រុម ដែលមានគ្នាពីរ ឬបីនាក់ ។ សូមអញ្ជើញក្រុមនីមួយៗឲ្យសិក្សា កូរិនថូសទី១ ១២:៨–១១ ហើយធ្វើតាមសេចក្តីណែនាំដែលភ្ជាប់មកជាមួយ ។ អ្នកគួរសរសេរសេចក្តីណែនាំទាំងនេះនៅលើក្តារខៀន ឬ ចែកជាឯកសារដល់ពួកគេ ។

១. នៅក្នុងជួរឈរទីមួយនៃតារាងរបស់អ្នក សូមសរសេរអំណោយទានខាងវិញ្ញាណនីមួយៗដែលបានលើកឡើងនៅក្នុង កូរិនថូសទី១ ១២:៨–១១ ។

២. សូមពិភាក្សាពីអត្ថន័យ ឬឲ្យឧទាហរណ៍មួយនៃអំណោយទានខាងវិញ្ញាណនីមួយៗ ។

សូមអញ្ជើញក្រុមនីមួយៗឲ្យប្រាប់ពីអំណោយទានខាងវិញ្ញាណដែលពួកគេបានរកឃើញ និងអត្ថន័យនៃអំណោយទាននីមួយៗ ។ ប្រសិនបើចាំបាច់ សូមពន្យល់ថា « ពាក្យសំដីនៃប្រាជ្ញាវាងវៃ » (ខទី ៨) សំដៅទៅលើការវិនិច្ឆ័យល្អ និងការអនុវត្តចំណេះដឹងដ៏ត្រឹមត្រូវ « ពាក្យសំដីនៃចំណេះចេះស្ទាត់ » (ខទី ៨) សំដៅទៅលើចំណេះដឹងពីព្រះ និងក្រឹត្យវិន័យរបស់ទ្រង់ « សង្កេតស្គាល់អស់ទាំងវិញ្ញាណ » (ខទី ១០) សំដៅទៅលើការស្គាល់សេចក្តីពិត និងមិនពិត ព្រមទាំងយល់ដឹងអំពីសេចក្តីល្អ និងអំពើអាក្រក់នៅក្នុងអ្នកដទៃ និង « ចេះនិយាយភាសា » (ខទី ១០) សំដៅទៅលើសមត្ថភាពដើម្បីនិយាយភាសាបរទេស ឬភាសាដែលគេពុំចេះ ។

ចូរសុំឲ្យក្រុមនីមួយៗរើសយកអំណោយទានខាងវិញ្ញាណចំនួនពីរដែលបានលើកឡើងនៅក្នុង ខទី៨–១០ ហើយសរសេរនៅក្នុងជួរឈរទីពីរនៃតារាងពីរបៀប ដែលអំណោយទានទាំងនោះអាចជាប្រយោជន៍ដល់កូនចៅរបស់ព្រះ ។ បន្ទាប់ពីផ្តល់ពេលវេលាគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់ពីចម្លើយរបស់ពួកគេនៅក្នុងជួរឈរទីពីរមួយណាក៏បានទៅដល់សិស្សក្នុងថ្នាក់ ។

ចូរចង្អុលបង្ហាញថា អំណោយទានខាងវិញ្ញាណ ដែលបានលើកឡើងយ៉ាងជាក់លាក់នៅក្នុងខគម្ពីរទាំងនេះ គ្រាន់តែជាអំណោយទានមួយចំនួនតូចប៉ុណ្ណោះ ដែលយើងអាចទទួលបានតាមរយៈព្រះវិញ្ញាណ ។

- តើអំណោយទានផ្សេងទៀតណាខ្លះ ដែលអាចកើតមានចំពោះយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?
- តើអំណោយទានខាងវិញ្ញាណអ្វីខ្លះ ដែលអ្នកបានសម្គាល់ឃើញនៅក្នុងសមាជិកគ្រួសារ មិត្តភក្តិ និងមិត្តរួមថ្នាក់របស់អ្នក ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរកឃើញអំណោយទានខាងវិញ្ញាណរបស់យើង ? (ទូលសូមព្រះវរបិតាសួគ៌អំពីអំណោយទានទាំងនោះ នៅក្នុងការអធិស្ឋាន ហើយទទួលយក ព្រមទាំងសិក្សាពីពររបស់លោកអយ្យកោរបស់អ្នក) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអំណោយទានខាងវិញ្ញាណដែលពួកគេបានទទួល និងរបៀបដែលវាអាចជាប្រយោជន៍ដល់ពួកគេ ហើយប្រើវាដើម្បីផ្តល់ប្រយោជន៍ដល់មនុស្សដទៃ ។

កូរិនថូសទី១ ១២:១២–៣១

អំណោយទាននៃព្រះវិញ្ញាណបានប្រទានឲ្យ ដើម្បីសមាជិកសាសនាចក្រទាំងមូលបានពរ

សូមឲ្យសិស្សបួននាក់ឡើងមកកាន់ក្តារខៀន ។ សូមចាត់ពាក្យមួយខាងក្រោមនេះដល់សិស្សម្នាក់ៗដោយកុំឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់ស្តាប់ឮ ៖ *ជើង* *ដៃ* *ត្រចៀក*និង*ភ្នែក* ។ សូមណែនាំសិស្សម្នាក់ៗឲ្យគូររូបភាពមួយនៅលើក្តារខៀនអំពីពាក្យរបស់ខ្លួន ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់ទាយថា សិស្សម្នាក់ៗគូររូបអ្វី ។ បន្ទាប់ពីសិស្សក្នុងថ្នាក់ស្គាល់រូបភាពនោះត្រឹមត្រូវហើយ សូមអញ្ជើញសិស្សទាំងនោះឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយពួកគេវិញ ។ ចូរសុំឲ្យសិស្សពិចារណាថា ជើង ត្រចៀក និងភ្នែករួមចំណែកចំពោះកិច្ចការដែលរូបកាយធ្វើយ៉ាងដូចម្តេច ។

- តើអ្នកធ្លាប់ត្រូវរបួសត្រង់ផ្នែកតូចមួយនៃរូបកាយដូចជា ម្រាមដៃ ច្មេញ ឬម្រាមជើងដែរទេ ? តើរបួសតូចនេះបានជះឥទ្ធិពលយ៉ាងណាដែរ សូម្បីតែចំពោះការងារដ៏សាមញ្ញប្រចាំថ្ងៃ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១២:១២–១៤ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សៀងតាមរកមើលថា ប៉ុលបានប្រៀបធៀបរូបកាយ និងអវៈយវៈផ្សេងទៀតនឹងអ្វី ។

- តើប៉ុលបានប្រៀបធៀបរូបកាយ និងអវៈយវៈផ្សេងទៀតទៅនឹងអ្វី ? (សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ និងសមាជិកសាសនាចក្រ) ។

សូមសរសេរសេចក្តីយោងខគម្ពីរ និង សំណួរខាងក្រោមនៅលើក្តារខៀន ៖

កូរិនថូសទី១ ១២:១៥–២២, ២៥–៣០

តើប៉ុលបានប្រៀបធៀបរូបកាយទៅនឹងសាសនាចក្រយ៉ាងដូចម្តេច ?

សូមចែកសិស្សជាក្រុមដូចពីមុន ។ ចូរសុំឲ្យក្រុមនីមួយៗអាន កូរិនថូសទី១ ១២:១៥–២២, ២៥–៣០ ឮៗរួមគ្នា រកមើលវិធីដែលប៉ុលបានប្រៀបធៀបសមាជិកសាសនាចក្រទៅនឹងផ្នែកនៃរូបកាយ ។ អ្នកគួរណែនាំឲ្យសិស្សរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីរូបកាយ និងអវៈយវៈផ្សេងទៀតពីមុនបង្ហាញពីរបៀបដែលលោកបានប្រដូចអវៈយវៈទៅនឹងសមាជិកសាសនាចក្រ ។ ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- ហេតុអ្វីអ្នកគិតថា ប៉ុលបានពិភាក្សាពីតួនាទីរបស់សមាជិកសាសនាចក្រម្នាក់ៗ បន្ទាប់ពីលោកបានសរសេរអំពីអំណោយទានខាងវិញ្ញាណ ?
- តើសមាជិកសាសនាចក្រសព្វថ្ងៃអាចមានកង្វល់អ្វីខ្លះ ដែលអាចដោះស្រាយបានដោយការបង្រៀនរបស់ប៉ុលអំពីសមាជិកសាសនាចក្រប្រៀបដូចជាអវៈយវៈនៃរូបកាយ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុងការប្រៀបធៀបរបស់ប៉ុលអំពីសមាជិកសាសនាចក្រទៅនឹងអវៈយវៈនៃរូបកាយ ? (សូមប្រាកដថា សិស្សរកឃើញគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងប្រើអំណោយទានខាងវិញ្ញាណដ៏វិសេសរបស់យើងដើម្បីបម្រើមនុស្សដទៃ នោះយើងអាចពង្រឹងសាសនាចក្របាន ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ ចូរពិចារណាឯកសារនៃសេចក្តីថ្លែងការណ៍នេះដល់សិស្សម្នាក់ៗ ។



« យើងទាំងអស់គ្នាគឺនៅក្នុងការខិតខំដ៏អស្ចារ្យនេះរួមគ្នា ។ យើងនៅទីនេះដើម្បីជួយព្រះអបិតាយើងនៅក្នុងកិច្ចការរបស់ទ្រង់ និងសិរីល្អរបស់ទ្រង់ ‹ នាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស › (ម៉ូសេ ១:៣៩) ។ ទំនួលខុសត្រូវក្នុងការហៅបម្រើរបស់អ្នក សំខាន់ដូចជាទំហំនៃការទទួលខុសត្រូវរបស់ខ្ញុំក្នុងការហៅបម្រើរបស់ខ្ញុំដែរ ។ គ្មានការហៅបម្រើមួយណានៅក្នុងសាសនាចក្រ ដែលមិនសំខាន់នោះទេ ។ យើងទាំងអស់គ្នាខិតខំបំពេញតួនាទីរបស់យើង ដើម្បីប្រទានពរដល់ជីវិតរបស់អ្នកដទៃ » (« This Is the Work of the Master » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៥ ទំព័រ ៧១) ។

- តើពរជ័យនឹងកើតមានចំពោះសាសនាចក្រ ដោយសារតែអំណោយទានខាងវិញ្ញាណ និងការហៅខុសៗគ្នារបស់សមាជិកម្នាក់ៗយ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់ឃើញគ្រួសាររបស់អ្នក ថ្នាក់សិក្ខាសាលា ឃ្លួដ ឬសាខាមួយត្រូវបានពង្រឹងដោយអំណោយទានខាងវិញ្ញាណរបស់សមាជិកខ្លួនយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា ពួកគេអាចប្រើអំណោយទានខាងវិញ្ញាណរបស់ខ្លួនដើម្បីពង្រឹងដល់សាសនាចក្រ ហើយឲ្យពរដល់ជីវិតមនុស្សដទៃទៀតយ៉ាងដូចម្តេចដែរ ។

ចូរសុំឲ្យសិស្សអាន កូរិនថូសទី១ ១២:៣១ ដោយស្ងៀមស្ងាត់ ហើយរកមើលថា ប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធនៅកូរិនថូសធ្វើអ្វីខ្លះ ។

- តើប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធនៅកូរិនថូសធ្វើអ្វីខ្លះ ? (សូមពន្យល់ថា *សង្វាក* នៅក្នុងខគម្ពីរនេះមានន័យថា « ការស្វែងរកដោយស្មោះត្រង់ ») ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីស្វែងរក « អំណោយទានយ៉ាងវិសេស » នៃព្រះវិញ្ញាណដោយស្មោះត្រង់ (សូមមើលផងដែរ គ. និង ស. ៤៦:៨–៩) ?

សូមបង្ហាញទីបន្ទាល់ និងការដឹងគុណរបស់អ្នកចំពោះអំណោយទានខាងវិញ្ញាណ ហើយលើកទឹកចិត្តសិស្សឲ្យស្វែងរកដោយស្មោះត្រង់ ហើយប្រើអំណោយទានខាងវិញ្ញាណដើម្បីបម្រើ ហើយពង្រឹងដល់សាសនាចក្រ ។

កូរិនថូសទី១ ១៣–១៤

សេចក្តីផ្តើម

ប៉ុលបានបង្រៀនអំពីសារៈសំខាន់នៃសេចក្តីសប្បុរស ។ លោកបានទូន្មានពួកបរិសុទ្ធនៅកូរិនថូសឲ្យទទួលបាន ហើយស្វែងរកសេចក្តីសប្បុរស ព្រមទាំងអំណោយទានខាងវិញ្ញាណផ្សេងទៀត ។ ប៉ុលបានបង្រៀនថា អំណោយទាននៃការចេះព្យាករគឺធំជាងអំណោយទានខាងភាសា ហើយវាត្រូវបានប្រទានឲ្យដល់សមាជិកសាសនាចក្រ ដើម្បីពួកគេអាចពង្រឹងមនុស្សដទៃទៀតខាងវិញ្ញាណ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ១៣

ប៉ុលបង្រៀនអំពីសារៈសំខាន់នៃការមានសេចក្តីសប្បុរស

ពីមុនថ្នាក់ចាប់ផ្តើម សូមសរសេរសាច់រឿងខាងក្រោមនេះនៅលើ ក្តារខៀនឬចម្លងវាចែកដល់សិស្ស ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសាច់រឿងនីមួយៗឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់ពិចារណាថា នៅក្នុងចំណោមឃ្លាទាំងនេះ តើឃ្លាណាមួយប្រាប់អំពីពួកគេ ។

១. ជាញឹកញាប់អ្នកមិនចូលចិត្ត ហើយអាក់អន់ចិត្តដោយសារឥរិយាបថរបស់បង ឬប្អូនម្នាក់ ។

២. មិត្តរួមថ្នាក់ម្នាក់ប្រើពាក្យមិនល្អដាក់អ្នក ដូច្នេះវាធ្វើឲ្យអ្នកចង់និយាយពាក្យអាក្រក់តបទៅវិញ ។

៣. អ្នកមានចិត្តច្រណែនចំពោះទេពកោសល្យ និងភាពជោគជ័យរបស់មិត្តម្នាក់ ។

៤. ពេលខ្លះអ្នកឃើញថា ការនិយាយដើមគេ និងការនិយាយអាក្រក់អំពីមនុស្សដទៃជារឿងដ៏ងាយស្រួលនៅក្នុងភូរ៉ុមបព្វជិតភាព ឬថ្នាក់យុវនារីរបស់អ្នក ។

- តើមានលទ្ធផលអាក្រក់អ្វីខ្លះ ដែលអាចកើតចេញពីការមានលក្ខណៈ និងឥរិយាបថទាំងនេះ ?

នៅពេលសិស្សសិក្សា កូរិនថូសទី ១ ១៣ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត ដែលអាចជួយពួកគេឲ្យចៀសវាងពីលក្ខណៈ និងឥរិយាបថដែលអាចរំខានដល់សុភមង្គលផ្ទាល់ខ្លួន និងទំនាក់ទំនងជាមួយនឹងមនុស្សដទៃទៀត ។

សូមរំឭកសិស្សថា ពួកបរិសុទ្ធនៅកូរិនថូសកំពុងតែមានឥរិយាបថតាមរបៀបណាមួយ ដែលបានដឹកនាំពួកគេទៅរកការឈ្លោះប្រកែកគ្នា និងការបែកបាក់នៅក្នុងសាសនាចក្រ ។ នៅក្នុងសំបុត្ររបស់លោក ប៉ុលបានបង្រៀនថា អំណោយទានខាងវិញ្ញាណត្រូវបានប្រទានមក ដើម្បីជាប្រយោជន៍ដល់មនុស្សទាំងអស់ ហើយជួយសមាជិកសាសនាចក្រឲ្យបម្រើ ហើយពង្រឹងគ្នាទៅវិញទៅមក ។ ប៉ុលបានទូន្មានពួកបរិសុទ្ធទាំងនោះឲ្យខំប្រឹងស្វែងរកដោយចិត្តស្មោះទូរ « អំណោយទានយ៉ាងវិសេស » (សូមមើល កូរិនថូសទី១ ១២:៧–៣១) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៣:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលលក្ខណៈ និងអំណោយទានមួយនៃព្រះវិញ្ញាណដែលប៉ុលបានសរសើរយ៉ាងខ្លាំង ។

- តើចរិកលក្ខណៈ និងអំណោយទាននៃព្រះវិញ្ញាណអ្វីទៅដែលប៉ុលបានសរសើរយ៉ាងខ្លាំង ? (សេចក្តីសប្បុរស) ។

សូមពន្យល់ថា « សេចក្តីសប្បុរសគឺជាសេចក្តីស្រឡាញ់ដ៏ខ្ពស់បំផុត ឧត្តុង្គឧត្តមបំផុត ជាប្រភេទនៃសេចក្តីស្រឡាញ់ខ្លាំងបំផុត មិនត្រឹមតែការមានការចាប់ចិត្តប៉ុណ្ណោះនោះទេ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សប្បុរស ») ។

- តើប៉ុលបានពិពណ៌នាពីជនដែលមានអំណោយទានខាងវិញ្ញាណផ្សេងទៀត ប៉ុន្តែខ្វះសេចក្តីសប្បុរសយ៉ាងដូចម្តេចដែរ ?

សូមពន្យល់ថា ឃ្លា « លង្ហិនដែលឮខ្លរ » និង « ឈឹងដែលឮទ្រហឹង » នៅក្នុង ខទី ១ សំដៅទៅលើឧបករណ៍ដែលបន្លឺសំឡេងឮ ។ នៅក្នុងបរិបទនៃ ខទី ១ ឃ្លាទាំងនេះអាចផ្តល់ជាន័យមន័យទៅលើពាក្យសម្តីដែលគ្មានខ្លឹមសារ ពេលដែលអ្នកនិយាយពុំបានបន្លឺវាចាឡើងចេញមកពីសេចក្តីសប្បុរស ។

- ហេតុអ្វីអ្នកគិតថា យើងពុំជាអ្វីសោះដោយគ្មានសេចក្តីសប្បុរស ?
- តើមនុស្សម្នាក់អាចលះបង់រាល់ទ្រព្យសម្បត្តិទាំងអស់របស់ខ្លួន ដើម្បីផ្តល់អាហារដល់អ្នកក្រីក្រ ឬស្ម័គ្រចិត្តស្លាប់ដើម្បីសេចក្តីពិត ប៉ុន្តែនៅតែគ្មានសេចក្តីសប្បុរសបានដោយរបៀបណា ? (សូមពន្យល់ថា សេចក្តីសប្បុរសគឺលើសពីការមានចិត្តទូលាយ និងការស្លាប់ដើម្បីសេចក្តីពិតទៅទៀត) ។

សូមចម្លងតារាងខាងក្រោមដាក់លើ ក្តារខៀន ៖

រៀបចំមេរៀននីមួយៗដោយគិតអំពីសិស្ស

នៅពេលអ្នករៀបចំបង្រៀនមេរៀន សូមពិចារណាអំពីលទ្ធផលដែលអ្នកសង្ឃឹមនឹងកើតឡើងនៅក្នុងជីវិតរបស់សិស្ស ។ ប្រធាន ចូម៉ាស អេស ម៉នសុន បានរំឭកថា ៖ « គោលដៅនៃការបង្រៀនដ៏ណឹងល្អ . . . គឺមិនមែនដើម្បី ‘ ចាក់ព័ត៌មាន ’ ចូលទៅក្នុងគំនិតរបស់សមាជិកទាំងឡាយក្នុងថ្នាក់ឡើយ ។ . . . ***គោលដៅនោះគឺដើម្បីបំផុសគំនិតដល់បុគ្គលម្នាក់ៗឲ្យគិត ឲ្យមានអារម្មណ៍រំជឹង ហើយបន្ទាប់មក ឲ្យបញ្ចេញសកម្មភាពបែបណាមួយ អំពីការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ*** » (នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩៧០ ទំព័រ ១០៧) ។

សេចក្តីសប្បុរសជាអ្វី ឬមានសកម្មភាពបែបណា	សេចក្តីសប្បុរសពុំមែនជាអ្វី ឬពុំមានសកម្មភាពបែបណា

សូមពន្យល់ថា ប៉ុលបានពិពណ៌នាអំពីគុណសម្បត្តិ និងបុគ្គលិកលក្ខណៈនៃសេចក្តីសប្បុរស ដើម្បីជួយពួកបរិសុទ្ធថ្ងៃចុងក្រោយឲ្យយល់ពីអំណោយទាននេះកាន់តែប្រសើរ ។ សូមចែកសិស្សជាគូ ។ សូមអញ្ជើញសិស្សឲ្យអាន កូរិនថូសទី១ ១៣:៤–៨ ជាមួយនឹងដៃគូរបស់ពួកគេ ហើយរកមើលការពិពណ៌នារបស់ប៉ុលអំពីសេចក្តីសប្បុរស ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សឡើងមកក្តារខៀន ហើយសរសេរការពិពណ៌នារបស់ប៉ុលអំពីសេចក្តី សប្បុរសនៅក្រោមក្បាលរឿងត្រឹមត្រូវនៅលើតារាង ។ ប្រសិនបើចាំបាច់ សូមជួយសិស្សឲ្យយល់ពីការពិពណ៌នានីមួយៗ ។

- តើនរណាទៅដែលសក្តិសមនឹងពិពណ៌នា នៃចរិតលក្ខណៈនៃសេចក្តីសប្បុរសទាំងអស់នេះ ? (ព្រះយេស៊ូវគ្រីស្ទ) ។

សូមរំឭកសិស្សថា ព្យាការីមរមនបានបង្រៀនថា « សេចក្តីសប្បុរស គឺជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ » (មរ៉ូណៃ ៧:៤៧) ។ សូមពន្យល់ថា សេចក្តីសប្បុរសអាចពិពណ៌នាបានជារបៀបពីរសំខាន់ៗ ៖ (១) សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទចំពោះយើង និង (២) សេចក្តីស្រឡាញ់របស់យើងចំពោះមនុស្សដទៃឲ្យដូចជាព្រះគ្រីស្ទ ។ សូមឲ្យសិស្សជ្រើសយកការពិពណ៌នាពីរបីអំពីសេចក្តីសប្បុរសចេញពីតារាងនៅលើក្តារខៀន ហើយពន្យល់ទៅសិស្សក្នុងថ្នាក់អំពីរបៀបដែលវាពិពណ៌នាយ៉ាងល្អអំពីព្រះយេស៊ូវគ្រីស្ទ ។

- តើអ្នកគិតថាឃ្លា « សេចក្តីស្រឡាញ់មិនដែលផុតឡើយ » នៅក្នុង ខទី ៨ មានន័យដូចម្តេច ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ដៃវ្រ៊ី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖



« សេចក្តីសប្បុរស*ពិត* . . . ត្រូវបានបង្ហាញយ៉ាងច្បាស់ និងយ៉ាងបរិសុទ្ធនៅក្នុងសេចក្តីស្រឡាញ់ដ៏ពិតប្រាកដ ដ៏ខ្ពង់ខ្ពស់បំផុត និងដ៏ធ្ងន់របស់ព្រះគ្រីស្ទសម្រាប់យើង ។ . . . វាគឺជាសេចក្តីសប្បុរសនោះ—ជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធរបស់ទ្រង់មានសម្រាប់យើង—បើគ្មានវាទេ យើងនឹងគ្មានជាអ្វីទាំងអស់ គ្មានសង្ឃឹមទាំងអស់ ជាបុរស និងស្ត្រីដែលវេទនាបំផុត ។ . . .

« ជីវិតនឹងមាននូវការភ័យខ្លាច និងការបរាជ័យ ។ ពេលខ្លះរឿងទាំងឡាយនឹងជួបភាព បរាជ័យ ។ ពេលខ្លះមនុស្សធ្វើឲ្យយើងបរាជ័យ ឬសេដ្ឋកិច្ច ឬអាជីវកម្ម ឬក៏រដ្ឋាភិបាលធ្វើឲ្យយើងបរាជ័យ ។ ប៉ុន្តែរឿងមួយក្នុងជីវិតនេះ ឬក្នុងភាពអស់កល្បជានិច្ចដែលនឹង *ពុំ* ធ្វើឲ្យយើងបរាជ័យ—គឺជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ » (*Christ and the New Covenant* ៖ ឆ្នាំ ១៩៩៧ ៖ ទំព័រ ៣៣៧) ។

- តើវាអាចមានប្រយោជន៍យ៉ាងណាដែរ ដោយចងចាំថាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទនឹងពុំផុតរលត់ឡើយនោះ ?
- ដោយផ្អែកទៅលើអ្វីដែលយើងបានរៀននៅក្នុង កូរិនថូសទី១ ១៣:៤–៨ តើមានអ្វីកើតឡើងចំពោះយើង នៅពេលយើងមានអំណោយទាននៃសេចក្តីសប្បុរស ? (សិស្សអាចនឹងស្គាល់សេចក្តីពិតខុសៗគ្នា ប៉ុន្តែសូមបញ្ជាក់ឲ្យច្បាស់ថា **នៅពេលយើងស្វែងរកដើម្បីទទួលបានអំណោយទានខាងវិញ្ញាណនៃសេចក្តីសប្បុរស នោះយើងកាន់តែប្រែក្លាយដូចជាព្រះអង្គសង្គ្រោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមសង្ខេប កូរិនថូសទី ១ ១៣:៩–១២ ដោយពន្យល់ថា ប៉ុលបានបង្រៀនអំពីហេតុផល ដែលអំណោយទានខាងវិញ្ញាណនៃចំណេះដឹង និងការព្យាករនឹងរលាយបាត់នៅទីបំផុត ។ ប៉ុលបានសង្កេតឃើញថា ចំណេះដឹងដែលមាននៅក្នុងជីវិតនេះគ្មានភាពពេញលេញទេ ហើយថាយើងនឹងទទួលបានចំណេះដឹងដ៏ល្អឥតខ្ចោះមួយនៅក្នុងភាពអស់កល្បជានិច្ច ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៣:១៣ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអំណោយទានបីនៃព្រះវិញ្ញាណដែលប៉ុលបានបង្រៀនថានឹង *មាន* ដែលមានន័យថាទ្រាំទ្រ ឬ បន្តមានជានិច្ច ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើប៉ុលបានបង្រៀនថា អំណោយទានខាងវិញ្ញាណដែលធំជាងគេគឺជាអ្វី ? (សិស្សគួររកឃើញសេចក្តីពិតដូចតទៅនេះ ៖ **សេចក្តីសប្បុរសគឺជាអំណោយនៃព្រះវិញ្ញាណដ៏អស្ចារ្យបំផុត ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរសមានទំនាក់ទំនងអ្វីនឹងគ្នា ? (សេចក្តីជំនឿដឹកនាំទៅរកសេចក្តីសង្ឃឹម ហើយសេចក្តីសង្ឃឹមដឹកនាំទៅរកសេចក្តីសប្បុរស) ។
- ដោយផ្អែកលើអ្វីដែលយើងបានរៀននៅក្នុង កូរិនថូសទី១ ១៣ ហេតុអ្វីអ្នកគិតថា សេចក្តីសប្បុរសគឺជាអំណោយទានដ៏ធំជាងគេនៃព្រះវិញ្ញាណ ?

សូមចង្អុលបង្ហាញអំពីការទុន្មានរបស់ប៉ុលនៅក្នុង កូរិនថូសទី ១ ១៤:១ ឲ្យ« ដេញតាម សេចក្តីសប្បុរស » ។

- តើយើងអាចធ្វើអ្វីខ្លះដើម្បី « ដេញតាម » ឬទទួលបានអំណោយទាននៃសេចក្តីសប្បុរស ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន មរ៉ូណៃ ៧:៤៨ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាមរមនបានបង្រៀនប្រជាជនលោក ឲ្យធ្វើអ្វីខ្លះដើម្បីទទួលបានអំណោយទាននៃសេចក្តីសប្បុរស ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើការមានសេចក្តីសប្បុរសអាចកែលម្អទំនាក់ទំនងរបស់យើងជាមួយគ្រួសារ មិត្តភក្តិ និងមនុស្សមានឋានៈប្រហាក់ប្រហែលនឹងយើងបានយ៉ាងដូចម្តេច ?
- តើអ្នកអាចពិពណ៌នាអំពីគ្រាមួយ ដែលអ្នកបានមើលឃើញសេចក្តីសប្បុរសនៅក្នុងរបៀបមួយដែលមនុស្សម្នាក់បានប្រព្រឹត្តចំពោះអ្នក ឬមនុស្សដទៃបានទេ ? (សូមគិតពីការចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនអ្នក) ។

សូមអញ្ជើញសិស្សឲ្យសរសេររៀបរាប់ពីសេចក្តីសប្បុរសដែលពួកគេគិតថា វាពិបាកបំផុតសម្រាប់ពួកគេដើម្បីធ្វើតាម និងពីហេតុផលនៅលើក្រដាសមួយសន្លឹក ។ សូមលើកទឹកចិត្តសិស្សឲ្យសរសេរគោលដៅមួយទាក់ទងនឹងកិច្ចការ ដែលពួកគេនឹងធ្វើដើម្បីបន្តស្វែងរក ដើម្បីទទួលបានសេចក្តីសប្បុរសដែលធំជាង ។ សូមអញ្ជើញសិស្សឲ្យដាក់វានៅត្រង់កន្លែង ដែលពួកគេអាចមើលឃើញជារឿយៗ ហើយត្រូវបានរំឭកអំពីគោលដៅរបស់ពួកគេនោះ ។

កូរិនថូសទី១ ១៤

ប៉ុលបង្រៀនថា អំណោយទាននៃការព្យាករគឺធំជាងអំណោយទានខាងភាសា

សូមយកវត្ថុដែលអាចសង់ជាប៉មមួយ ដូចជា ដុំដុំមានរាងជាជ្រុង ប្រអប់ ប័ណ្ណ ឬសៀវភៅមកថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យប្រើវត្ថុដែលអ្នកបានយកមក ដើម្បីសង់ជាប៉មមួយឲ្យខ្ពស់តាមដែលអាចធ្វើទៅបានក្នុងរយៈពេលមួយនាទី ។ បន្ទាប់មក សូមអញ្ជើញសិស្សនោះឲ្យទៅអង្គុយវិញ ។ សូមឲ្យសិស្សក្នុងថ្នាក់អាន កូរិនថូសទី១ ១៤:១–៣ ដោយស្ងាត់ស្ងៀមរកមើលពាក្យនៅក្នុងខគម្ពីរទាំងនេះ ដែលទាក់ទងនឹងការបង្ហាញអំពីការសង់ប៉មមួយ ។

- នៅក្នុង ខទី ៣ តើពាក្យអ្វីទៅដែលទាក់ទងនឹងការសង់ប៉មមួយ ? (ការស្អាងចិត្ត ។ ប្រសិនបើចាំបាច់ សូមពន្យល់ថា *ស្អាងចិត្ត* មានន័យថា « ការសង់ឡើង » ដូចជាការពង្រឹង ឬការកែលម្អខាងវិញ្ញាណ) ។

នៅពេលសិស្សសិក្សា កូរិនថូសទី ១ ១៤ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលនឹងជួយពួកគេស្គាល់ថាពួកគេអាចស្អាងមនុស្សដទៃបានតាមរបៀបណា ។

សូមពន្យល់ថា ប៉ុលបានប្រាប់សមាជិកសាសនាចក្រនៅកូរិនថូសដែលកំពុងមានបទពិសោធន៍ពីអំណោយទានខាងភាសា ឬសមត្ថភាពដើម្បីនិយាយភាសាផ្សេងទៀត ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៤:១–៣ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធឲ្យស្វែងរកអំណោយទានខាងវិញ្ញាណអ្វីជំនួសវិញ ។

- តើប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធឲ្យមានបំណងប្រាថ្នា ហើយស្វែងរកអំណោយទានខាងវិញ្ញាណអ្វីជំនួសវិញ ?

សូមពន្យល់ថា « ការព្យាករមួយរួមមានពាក្យពេចន៍ ឬ ការសរសេរបំផុសគំនិតដ៏ទេវភាព ដែលមនុស្សម្នាក់ទទួលបានតាមរយៈវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ទីបន្ទាល់អំពីព្រះយេស៊ូវ គឺជាវិញ្ញាណនៃការព្យាករណ៍ (វិវរណៈ ១៩:១០) ។ នៅពេលមនុស្សម្នាក់ព្យាករ គាត់និយាយ ឬ សរសេរអ្វីដែលព្រះចង់ឲ្យគាត់ដឹង សម្រាប់ការណ៍ល្អផ្ទាល់ខ្លួន ឬការណ៍ល្អសម្រាប់អ្នកដទៃ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្យាករ, ការព្យាករ » scriptures.lds.org) ។

សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន ៖ *ការព្យាករ = ការបង្រៀន និងការថ្លែងទីបន្ទាល់តាមរយៈការបំផុសគំនិត*

- យោងតាម ខទី ៣ តើការបង្រៀន និងការថ្លែងទីបន្ទាល់តាមរយៈការបំផុសគំនិតអាចជួយយើង ឲ្យផ្តល់ពរដល់មនុស្សដទៃបានយ៉ាងដូចម្តេច ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្គាល់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **នៅពេលយើងបង្រៀន ហើយថ្លែងទីបន្ទាល់ប្រកបដោយការបំផុសគំនិត នោះយើងអាចជួយស្អាង ហើយលួងលោមដល់មនុស្សដទៃបាន**) ។
- តើអ្នកធ្លាប់ត្រូវបានស្អាង ហើយលួងលោមដោយការបង្រៀន និងទីបន្ទាល់ដ៏បំផុសគំនិតនៃមនុស្សម្នាក់ទៀតតាមរបៀបណា ?

សូមសង្ខេប កូរិនថូសទី ១ ១៤:៤–៣០ ដោយពន្យល់ថា ប៉ុលបានដាស់តឿនពួកបរិសុទ្ធនៅកូរិនថូសអំពីអំណោយទានខាងភាសា ។ ប៉ុលបានព្រមានថា ប្រសិនបើវាមិនបានប្រើក្នុងផ្លូវត្រឹមត្រូវទេនោះ អំណោយទានខាងភាសានឹងបរាជ័យក្នុងការស្អាងសាសនាចក្រ ហើយនឹងបំបែកសមាជិកចេញពីការស្វែងរកអំណោយទានខាងវិញ្ញាណដ៏មានប្រយោជន៍កាន់តែខ្លាំង ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៤:៣១, ៣៣, ៤០ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ពាក្យទូន្មានអ្វីទៅដែលប៉ុលបានឲ្យដល់ពួកបរិសុទ្ធអំពីការព្យាករ ។

- តើពាក្យទូន្មានអ្វីខ្លះ ដែលប៉ុលបានផ្តល់ឲ្យពួកបរិសុទ្ធអំពីការព្យាករ ? (មនុស្សទាំងអស់ ទាំងស្រីទាំងប្រុស ប្រហែលជាអាចព្យាករ ឬបង្រៀន ហើយថ្លែងទីបន្ទាល់ ។ ការណ៍នេះគួរធ្វើឡើងតាមលំដាប់លំដោយ ម្នាក់ម្តងៗ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះអំពីសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ មកពីខគម្ពីរទាំងនេះ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្គាល់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ អ្វីៗគ្រប់យ៉ាងត្រូវធ្វើឡើងតាមលំដាប់លំដោយ**) ។
- ហេតុអ្វីអ្នកគិតថា វាសំខាន់ដែលរឿងទាំងអស់នៅក្នុងសាសនាចក្រត្រូវធ្វើឡើងតាមលំដាប់លំដោយត្រឹមត្រូវ ?

សូមពន្យល់ថា ការសរសេររបស់ប៉ុលនៅក្នុង កូរិនថូសទី១ ១៤:៣៤–៣៥ ផ្តល់ជាឧទាហរណ៍មួយអំពីរបៀប ដែលលោកបានដឹកនាំពួកបរិសុទ្ធនៅកូរិនថូសឲ្យរក្សាសណ្តាប់ធ្នាប់នៅក្នុងសាសនាចក្រ ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៤:៣៤–៣៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានបង្រៀនអ្វីខ្លះដល់សមាជិកសាសនាចក្រនៅកូរិនថូស ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា វាពិបាកដើម្បីយល់ពីចេតនានៅក្នុងការទូន្មានរបស់ប៉ុល ដោយសារលោកពុំបានហាមពួកស្ត្រីមិនឲ្យអធិស្ឋាន ឬនិយាយនៅក្នុងការប្រជុំសាសនាចក្រឲ្យច្បាស់នោះទេ (សូមមើល កូរិនថូសទី ១ ១១:៥) ។ ការបកប្រែដោយយ៉ូសែប ស៊្មីធ ប្តូរពាក្យ *និយាយ* នៅក្នុង ខទី ៣៤ និង ៣៥ ជាមួយនឹងពាក្យ *ដឹកនាំ* ។ ការផ្លាស់ប្តូរពាក្យនេះបង្ហាញពីឱកាសថា ប៉ុលកំពុងព្យាយាមកែតម្រូវស្ថានភាពមួយដែលស្ត្រីនៅស្រុកកូរិនថូសមួយចំនួនខ្វះសណ្តាប់ធ្នាប់នៅក្នុងកម្មវិធីថ្វាយបង្គំ ឬស្វែងរកតំណែងដឹកនាំមិនត្រឹមត្រូវ ជាជាងគាំទ្រ ហើយធ្វើតាមថ្នាក់ដឹកនាំបព្វជិតភាព (សូមមើល *New Testament Student Manual* | Church Educational System manual ឆ្នាំ ២០១៤ | ទំព័រ ៣៨០) ។

សូមបញ្ចប់មេរៀននេះដោយថ្លែងទីបន្ទាល់ពីសេចក្តីពិតដែលបានបង្រៀននៅក្នុងកូរិនថូសទី១ ១៣–១៤ ។

មេរៀនសិក្សានៅផ្ទះ

កូរិនថូសទី ១ ៧–១៤ (មេរៀនទី ២២)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា កូរិនថូសទី ១ ៧–១៤ (មេរៀនទី ២២) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (កូរិនថូស ទី១ ៧–៨) ។

នៅក្នុងសេចក្តីណែនាំរបស់ប៉ុលទៅកាន់សមាជិកសាសនាចក្រដែលរៀបការរួចហើយ និងសមាជិកនៅលីវនៅកូរិនថូស សិស្សបានរៀនថា ភាពស្និទ្ធស្នាលខាងរូបកាយរវាងស្វាមី និងភរិយាគឺតាំងឡើងដោយព្រះ ហើយថាពួកអ្នកដើរតាមដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទមានឥទ្ធិពលមួយដ៏ត្រឹមត្រូវចំពោះក្រុមគ្រួសារខ្លួន ។ សិស្សក៏បានរៀនផងដែរថា យើងអាចបង្ហាញសេចក្តីសប្បុរសចំពោះមនុស្សដទៃទៀតតាមរយៈការចៀសវាងពីទង្វើដែលអាចដឹកនាំពួកគេឲ្យដាច់ឆ្ងាយខាងវិញ្ញាណ ។

ថ្ងៃទី ២ (កូរិនថូស ទី១ ៩–១០) ។

នៅពេលសិស្សបានបន្តការសិក្សារបស់ខ្លួនអំពីការទូន្មានរបស់ប៉ុលដល់ពួកបរិសុទ្ធនៅកូរិនថូស ពួកគេបានរៀនថា ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច នោះយើងត្រូវតែរៀនអនុវត្តគ្រប់គ្រងលើខ្លួនឯងនៅគ្រប់រឿងទាំងអស់ ។ ពួកគេក៏បានរកឃើញផងដែរថា ព្រះនឹងប្រទានផ្លូវមួយឲ្យយើងគេចពីការល្បួង ប៉ុន្តែយើងត្រូវតែជ្រើសរើសដើម្បីដកខ្លួនយើងចេញពីការល្បួងនោះ ។

ថ្ងៃទី ៣ (កូរិនថូសទី១ ១១)

សិស្សបានរៀនថា នៅក្នុងផែនការរបស់ព្រះអម្ចាស់ បុរស និងស្ត្រីមិនអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដោយគ្មានគ្នាបានឡើយ ។ ពួកគេក៏បានរៀនផងដែរថា ជនដែលទទួលទានសាក្រាម៉ង់ដោយមិនសក្តិសមនាំមកនូវការដាក់ទោស និងការដាប់ទោសដល់ខ្លួនឯង ។ ហេតុដូច្នេះហើយ យើងគួរនិច្ចឹយពីជីវិតរបស់យើង នៅពេលយើងទទួលទានសាក្រាម៉ង់ ។

ថ្ងៃទី ៤ (កូរិនថូសទី១ ១២–១៤)

នៅក្នុងការបង្រៀនរបស់ប៉ុលស្តីពីអំណោយទាននៃព្រះវិញ្ញាណ សិស្សបានរៀននូវសេចក្តីពិតដូចខាងក្រោមនេះ ៖ មានតែតាមរយៈព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ ដែលយើងអាចទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនមួយថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្គ្រោះរបស់យើង ។ នៅពេលយើងខិតខំដើម្បីទទួលបានអំណោយទានខាងវិញ្ញាណនៃសេចក្តីសប្បុរស នោះយើងប្រែក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះយើង គឺព្រះយេស៊ូវគ្រីស្ទ ។ សេចក្តីសប្បុរសគឺជាអំណោយនៃព្រះវិញ្ញាណដ៏អស្ចារ្យបំផុត ។ នៅពេលយើងបង្រៀនហើយថ្លែងទីបន្ទាល់ដោយការបំផុសគំនិត នោះយើងអាចជួយស្តាង ហើយលួងលោមដល់មនុស្សជាទៃ ។

សេចក្តីផ្តើម

ប៉ុលបានសរសេរអំពីអំណោយទាននៃព្រះវិញ្ញាណយ៉ាងច្រើន ។ លោកបានប្រៀបធៀបសាសនាចក្រទៅនឹងរូបកាយ ហើយបានពន្យល់ថា គឺដូចជារូបកាយត្រូវការគ្រប់អវៈយវៈទាំងអស់ឲ្យដំណើរការត្រឹមត្រូវដែរ សមាជិកសាសនាចក្រម្នាក់ៗអាចប្រើអំណោយទាននៃព្រះវិញ្ញាណចូលរួមចំណែក ហើយពង្រឹងដល់សាសនាចក្រ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី ១ ១២:១–១១

ប៉ុលបង្រៀនអំពីអំណោយទានខាងវិញ្ញាណ

សូមដាក់បង្ហាញរូបភាពថ្មដូចខាងក្រោមនេះ ៖



សូមឲ្យសិស្សម្នាក់អានអក្សរដែលចារឹកលើថ្មនោះឲ្យឮៗ ។ សូមពន្យល់ថា កាលប្រធាន ដេវីឌ អូ មិកយេបម្រើបេសកកម្មមួយនៅប្រទេសស្កុតលេន លោកបានឃើញថ្មនេះនៅពីលើទ្វារនៃអគារមួយក្បែរប្រាសាទស្នើលីង ហើយលោកត្រូវបានបំផុសគំនិតដោយសារតែសារបស់វា (សូមមើល Francis M. Gibbons, *David O. McKay: Apostle to the World, Prophet of God* [ផ្សាំ ១៩៨៦] ទំព័រ ៤៥) ។

សូមពន្យល់ថា និមិត្តសញ្ញានីមួយៗនៅលើថ្មជ្រុងប្រាំបួនដុំនោះ តំណាងឲ្យតម្លៃមួយចំនួន ។ ចូរសុំឲ្យសិស្សបង្ហាញពីតម្លៃលេខនៃថ្មនីមួយៗ ។ (ពីឆ្វេងទៅស្តាំ និមិត្តសញ្ញាតំណាងឲ្យលេខ ៥, ១០ និង ៣ នៅជួរដេកខាងលើ និងលេខ ៤, ៦ និង ៨ នៅជួរដេកកណ្តាល និងលេខ ៩, ២ និង ៧ នៅជួរខាងក្រោម) ។

- តើផលបូកនៃលេខទាំងបីនៅជួរដេកលើតំណាងឲ្យអ្វី ? ជួរដេកកណ្តាលតំណាងឲ្យអ្វី ? ជួរដេកក្រោមតំណាងឲ្យអ្វី ?

សូមពន្យល់ថា លេខទាំងបីនៅលើជួរដេក ជួរឈរ ឬអង្កត់ទ្រូងថ្មនេះតំណាងឲ្យលេខ ១៨ ។ ហេតុផលមួយដែលរាងទាំងនេះអាចដាក់បញ្ចូលឃ្លាថា « មិនថាអ្នកជានរណាទេ សូមធ្វើចំណែករបស់អ្នកឲ្យបានល្អ » គឺថា ប្រសិនបើរាងទាំងនេះមានរាងណាមួយបានផ្លាស់ប្តូរ ឬប្រសិនបើតម្លៃរបស់វាផ្លាស់ប្តូរ នោះជួរដេក និងជួរឈរនៅលើថ្មនោះនឹងមិនស្មើ ១៨ ពីគ្រប់ទិសទាំងអស់ទៀតឡើយ ។

នៅពេលសិស្សសិក្សា កូរិនថូសទី ១ ១២ សូមអញ្ជើញពួកគេឲ្យពិចារណាថា ក្នុងនាមយើងជាសមាជិកសាសនាចក្រប្រៀបបាននឹងរាងនៅលើថ្មនោះដោយរបៀបណា ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១២:៧ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពីហេតុផលដែលអំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានដល់យើង ។ (ប្រសិនបើចាំបាច់ សូមពន្យល់ថា « ដើម្បីឲ្យកើតបានផល » មានន័យថា សេចក្តីឈ្លួមនៃពួកបរិសុទ្ធគ្រប់រូប) ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះពីសារកប៉ុល ស្តីពីហេតុផលដែលអំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានដល់កូនចៅរបស់ព្រះអរិបិតាសួគ៌ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែស្តាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **អំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានឲ្យ ដើម្បីជាប្រយោជន៍ដល់កូនចៅទាំងអស់របស់ព្រះអរិបិតាសួគ៌ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១២:៨–១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអំណោយទានខាងវិញ្ញាណ ដែលប៉ុលបានលើកឡើង ។

សូមអញ្ជើញសិស្សឲ្យប្រាប់ពីអំណោយទានខាងវិញ្ញាណ ដែលពួកគេបានរកឃើញ និងអត្ថន័យនៃអំណោយទាននីមួយៗ ។ ប្រសិនបើចាំបាច់ សូមពន្យល់ថា « ពាក្យសម្តីនៃប្រាជ្ញាវាងវៃ » (ខទី ៨) សំដៅទៅលើការវិនិច្ឆ័យល្អ និងការអនុវត្តចំណេះដឹងដ៏ត្រឹមត្រូវ « ពាក្យសម្តីនៃចំណេះចេះស្ទាត់ » (ខទី ៨) សំដៅទៅលើចំណេះដឹងពីព្រះ និងក្រឹត្យវិន័យរបស់ទ្រង់ « សង្កេតស្គាល់អស់ទាំងវិញ្ញាណ » (ខទី ១០) សំដៅទៅលើការស្គាល់សេចក្តីពិត និងមិនពិត ព្រមទាំងការបញ្ជោតសេចក្តីល្អ និងអំពើអាក្រក់នៅក្នុងអ្នកដទៃ ហើយ « ចេះនិយាយភាសា » (ខទី ១០) សំដៅទៅលើសមត្ថភាពដើម្បីនិយាយភាសាបរទេស ឬភាសាដែលគេពុំចេះ ។

- តើអំណោយទានខាងវិញ្ញាណទាំងនេះអាចជាប្រយោជន៍ដល់កូនចៅរបស់ព្រះបានយ៉ាងដូចម្តេច ?

ចូរចង្អុលបង្ហាញថា អំណោយទានខាងវិញ្ញាណ ដែលបានលើកឡើងយ៉ាងជាក់លាក់នៅក្នុងខគម្ពីរទាំងនេះ គ្រាន់តែជាអំណោយទានមួយចំនួនប៉ុណ្ណោះដែលយើងអាចទទួលបានតាមរយៈព្រះវិញ្ញាណ ។

- តើអំណោយទានផ្សេងទៀតណាខ្លះដែលអាចកើតមានចំពោះយើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?
- តើអំណោយទានខាងវិញ្ញាណអ្វីខ្លះ ដែលអ្នកបានសម្គាល់ឃើញ នៅក្នុងសមាជិកគ្រួសារ មិត្តភក្តិ និងមិត្តរួមថ្នាក់របស់អ្នក?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរកឃើញអំណោយទានខាងវិញ្ញាណរបស់យើង ? (ទូលសូមព្រះវរបិតាសួគ៌អំពីអំណោយទានទាំងនោះ នៅក្នុងការអធិស្ឋាន ហើយទទួល និងសិក្សាពរនៃលោកអយ្យកោរបស់យើង) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីអំណោយទានខាងវិញ្ញាណ ដែលពួកគេបានទទួល និងរបៀបដែលវាអាចជាប្រយោជន៍ដល់ពួកគេ ហើយប្រើវាដើម្បីជាប្រយោជន៍ដល់មនុស្សដទៃ ។

កូរិនថូសទី ១ ១២:១២–៣១

អំណោយទាននៃព្រះវិញ្ញាណត្រូវបានប្រទានឲ្យ ដើម្បីសមាជិកសាសនាចក្រទាំងអស់បានពរជ័យ

សូមឲ្យសិស្សបួននាក់ឡើងមកកាន់ក្តារខៀន ។ សូមចាត់ពាក្យមួយខាងក្រោមនេះដល់សិស្សម្នាក់ៗ ដោយកុំឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់ស្តាប់ឮ ៖ *ដើង ដៃ ត្រចៀក*និង*ភ្នែក* ។ សូមណែនាំសិស្សម្នាក់ៗឲ្យគូររូបភាពមួយ នៅលើក្តារខៀនអំពីពាក្យរបស់ខ្លួន ហើយចូរសុំឲ្យសិស្សក្នុងថ្នាក់ទាយថា សិស្សម្នាក់ៗគូររូបអ្វី ។ បន្ទាប់ពីសិស្សក្នុងថ្នាក់ស្គាល់រូបភាពនោះត្រឹមត្រូវហើយ សូមអញ្ជើញសិស្សទាំងនោះឲ្យត្រឡប់ទៅកាន់កន្លែងអង្គុយពួកគេវិញ ។ ចូរសុំឲ្យសិស្សពិចារណាថា ជើង ដៃ ត្រចៀក និងភ្នែកចូលរួមចំណែកចំពោះកិច្ចការដែលរូបកាយធ្វើដូចម្តេចខ្លះ ។

- តើអ្នកធ្លាប់ត្រូវបួសត្រង់អវៈយវៈតូចមួយនៃរូបកាយ ដូចជា ម្រាមដៃ ធ្មេញ ឬម្រាមជើងដែរទេ ? តើបួសតូចនេះបានជះឥទ្ធិពលយ៉ាងណាដែរ សូម្បីតែចំពោះការងារសាមញ្ញប្រចាំថ្ងៃក្តីនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១២:១២–១៨ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រៀបធៀបរូបកាយ និងអវៈយវៈផ្សេងទៀតទៅនឹងអ្វី ។

- តើប៉ុលបានប្រៀបធៀបរូបកាយ និងអវៈយវៈផ្សេងទៀតនឹងអ្វី ? (សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ និងសមាជិកសាសនាចក្រ) ។

សូមសរសេរសេចក្តីយោងខគម្ពីរ និង សំណួរខាងក្រោមនៅលើក្តារខៀន ៖

កូរិនថូស ទី ១ ១២:១៥–២២, ២៥–៣០

តើប៉ុលបានប្រៀបធៀបរូបកាយទៅនឹងសាសនាចក្របានយ៉ាងដូចម្តេច ?

សូមចែកសិស្សជាក្រុម ដែលសិស្សមួយក្រុមៗមានគ្នាពីរ ឬបីនាក់ ។ ចូរសុំឲ្យក្រុមនីមួយៗអានកូរិនថូសទី១ ១២:១៥–២២, ២៥–៣១ រួមគ្នា រកមើលវិធីដែលប៉ុលបានប្រៀបធៀបសមាជិកសាសនាចក្រទៅនឹងអវៈយវៈរូបកាយ ។ អ្នកគួរណែនាំឲ្យសិស្សរកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីរូបកាយ និងអវៈយវៈផ្សេងទៀតពីមុន បង្ហាញពីរបៀបដែលលោកបានប្រដូចអវៈយវៈទៅនឹងសមាជិកសាសនាចក្រ ។ ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- ហេតុអ្វីអ្នកគិតថា ប៉ុលបានពិភាក្សាពីតួនាទីរបស់សមាជិកសាសនាចក្រម្នាក់ៗបន្ទាប់ពីលោកបានសរសេរអំពីអំណោយទានខាងវិញ្ញាណ ?
- តើសមាជិកសាសនាចក្រសព្វថ្ងៃអាចមានកង្វល់អ្វីខ្លះ ដែលអាចត្រូវបានដោះស្រាយបានតាមរយៈការបង្រៀនរបស់ប៉ុលអំពីសមាជិកសាសនាចក្រប្រៀបដូចជាអវៈយវៈនៃរូបកាយនោះ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុងការប្រៀបធៀបរបស់ប៉ុល អំពីសមាជិកសាសនាចក្រទៅនឹងអវៈយវៈនៃរូបកាយ ? (សិស្សអាចនឹងស្គាល់គោលការណ៍ផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងប្រើអំណោយទានខាងវិញ្ញាណដ៏វិសេសរបស់យើងដើម្បីបម្រើមនុស្សដទៃ នោះយើងអាចពង្រឹងសាសនាចក្រនេះបាន ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមចង្អុលទៅរូបភាពថ្មដែលបានដាក់តាំង នៅពេលចាប់ផ្តើមមេរៀន ។

- ក្នុងនាមជាសមាជិកសាសនាចក្រ តើយើងប្រៀបបានទៅនឹងទ្រង់ទ្រាយផ្សេងៗគ្នានៅលើថ្មនេះយ៉ាងដូចម្តេច ? (យើងម្នាក់ៗមានលក្ខណៈពិសេសខុសៗគ្នា ហើយយើងដើរតួមួយយ៉ាងសំខាន់ ទោះជាព្រះអម្ចាស់ហៅយើងឲ្យបម្រើនៅទីណាក៏ដោយ ។ នៅពេលយើងរួមផ្សំអំណោយទាន និងសមត្ថភាពរបស់យើងដើម្បីបម្រើព្រះអម្ចាស់ នោះសាសនាចក្រទាំងមូលនឹងទទួលបានពរជ័យ ។ អ្វីៗដែលយើងធ្វើ គឺជារឿងសំខាន់ណាស់ ហើយវាអាចសម្រេចកិច្ចការរបស់សាសនាចក្របាន) ។
- តើអ្នកធ្លាប់ឃើញគ្រួសាររបស់អ្នក ថ្នាក់សិក្ខាសាលា ថ្នាក់សាលាថ្ងៃអាទិត្យ ថ្នាក់យុវនារី ឬថ្នាក់បឋមវិនិតភាព ឬរួច ឬសាខាមួយត្រូវបានពង្រឹងដោយអំណោយទានខាងវិញ្ញាណរបស់សមាជិកខ្លួនយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា ពួកគេអាចប្រើអំណោយទានខាងវិញ្ញាណរបស់ខ្លួន ដើម្បីពង្រឹងដល់សាសនាចក្រ ហើយប្រទានពរដល់ជីវិតមនុស្សដទៃទៀតយ៉ាងដូចម្តេចដែរ ។ សូមចង្អុលបង្ហាញពីការទុទ្ទានរបស់ប៉ុលដែលបានកត់ត្រានៅក្នុង កូរិនថូសទី ១ ១២:៣១ ដើម្បី « សង្វាតឲ្យបានអំណោយទានយ៉ាងវិសេសទៅចុះ » ។ (សូមពន្យល់ថា *សង្វាត* នៅក្នុងខគម្ពីរនេះមានន័យថា « ការស្វែងរកដោយស្មោះត្រង់ ») ។

- តើយើងអាចធ្វើអ្វីខ្លះដើម្បីស្វែងរក« អំណោយទានយ៉ាងវិសេស » នៃព្រះវិញ្ញាណដោយស្មោះត្រង់ (សូមមើលផងដែរ គ. និង ស. ៤៦:៨–៩) ?

សូមបង្ហាញទីបន្ទាល់ និងការដឹងគុណរបស់អ្នកចំពោះអំណោយទានខាងវិញ្ញាណ ហើយលើកទឹកចិត្តសិស្សឲ្យខំប្រឹងស្វែងរក ហើយប្រើអំណោយទានខាងវិញ្ញាណរបស់ពួកគេដើម្បីបម្រើ ហើយពង្រឹងដល់សាសនាចក្រ ។

មេរៀនបន្ទាប់ (កូរិនថូសទី ១ ១៥–កូរិនថូសទី ២ ៧)

ចូរសុំឲ្យសិស្សពិចារណាសំណួរខាងក្រោមនេះ ៖ ខណៈពួកគេសិក្សាមេរៀនបន្ទាប់ ៖ ហេតុអ្វីប៉ុលបានលើកឡើងពីពិធីបុណ្យជ្រមុជទឹកសម្រាប់មណ្ឌល ? តើនរណានឹងបានរស់ឡើងវិញ ? តើសិរីល្អអ្វីខ្លះ ដែលកំពុងរង់ចាំមនុស្សដែលបានរស់ឡើងវិញ ? តើមនុស្សដែលបានរស់ឡើងវិញគ្រប់រូបនឹងមានសិរីល្អដូចគ្នាដែរឬទេ ? សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលផ្តល់សេចក្តីសង្ឃឹមដល់ពួកគេ ជាពិសេសនៅពេលពួកគេជួបភាពសោកសៅ ភាពបរាជ័យ ឬភាពខ្លោចផ្សា ។ សូមពន្យល់ថា នៅក្នុងមេរៀនបន្ទាប់ ពួកគេនឹងរៀនពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុងការបង្រៀនរបស់ប៉ុលដល់ពួកបរិសុទ្ធនៅកូរិនថូស ដែលអាចនាំសេចក្តីសុខសាន្ត និងសេចក្តីសង្ឃឹមដល់ពួកគេ ។

មេរៀន ១១១

កូរិនថូសទី ១ ១៥:១–២៩

សេចក្តីផ្តើម

ប៉ុលបានដឹងថា ប្រជាជននៅកូរិនថូសកំពុងបង្រៀនថា គ្មានការរស់ឡើងវិញពីស្លាប់នោះទេ ។ លោកបានថ្លែងទីបន្ទាល់ដល់សមាជិកសាសនាចក្រនៅកូរិនថូសថា ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញពីការសុគត ។ បន្ទាប់មក ប៉ុលបានពន្យល់បន្ថែមពីលើគោលលទ្ធិនៃការរស់ឡើងវិញ និងរឿងដែលពាក់ព័ន្ធនឹងបញ្ហានេះដល់កូនចៅទាំងអស់របស់ព្រះវរបិតាសួគ៌ ។ ប៉ុលបានលើកឡើងថា ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជននឹងក្លាយជាឥតន័យ ប្រសិនបើគ្មានការរស់ឡើងវិញនោះទេ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ១៥:១–១០

ប៉ុលផ្តល់កស្តុតាងនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖

« បងប្អូនប្រុសស្រីខ្ញុំអើយ យើងសើច យើងយំ យើងធ្វើការ យើងលេង យើងស្រឡាញ់ យើងរស់នៅ ។ ហើយបន្ទាប់មក យើងស្លាប់ ។ សេចក្តីស្លាប់គឺជាមរតកជាសកលរបស់យើង ។ យើងទាំងអស់គ្នាត្រូវតែដើរឆ្លងកាត់ខ្លោងទ្វារនៃសេចក្តីស្លាប់នេះ ។ សេចក្តីស្លាប់លេបត្របាក់យកជីវិតមនុស្សចាស់ជរា ជនដែលនឿយហត់ និងទ្រុឌទ្រោម ។ វាឆក់យកទាំងជីវិតរបស់យុវវ័យទៀតផង មិនថាពួកគេមានសេចក្តីសង្ឃឹម និងភាពរុងរឿងនៃការរំពឹងទុកប៉ុណ្ណានោះទេ ។ សូម្បីតែកុមារតូចៗក៏មិនអាចរួចផុតពីកណ្តាប់ដៃរបស់វាបានឡើយ » (« I Know That My Redeemer Lives! » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ២៤) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីគំនិត ឬអារម្មណ៍ដែលពួកគេធ្លាប់ដកពិសោធន៍ កាលមនុស្សម្នាក់ដែលពួកគេស្គាល់បានចែកឋានទៅ ។ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេ ប្រសិនបើពួកគេគិតថាអាចចែកចាយបាន ។

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍នានា ខណៈពេលពួកគេសិក្សា កូរិនថូសទី ១ ១៥:១–២៩ ដែលវាអាចជួយដល់ពួកគេនៅពេលមានមនុស្សម្នាក់ដែលពួកគេស្គាល់បានចែកឋានទៅ ។


សូមពន្យល់ថា នៅពេលប៉ុលបានបញ្ចប់សំបុត្ររបស់លោកដល់ពួកបរិសុទ្ធនៅកូរិនថូស លោកបានលើកឡើងនូវជំនឿខុសឆ្គងមួយដែលសមាជិកសាសនាចក្រមួយចំនួនបានបង្រៀន ។ សូមអញ្ជើញសិស្សម្នាក់អានកូរិនថូសទី ១ ១៥:១២ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកជំនឿខុសឆ្គងដែលបានបង្រៀននោះ ។

- **តើពួកបរិសុទ្ធមួយចំនួននៅកូរិនថូសបានបង្រៀនអ្វីខ្លះ ?** (**គ្មានការរស់ឡើងវិញពីសេចក្តីស្លាប់ទេ**) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១៥:៣–៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា សាវកប៉ុលបានសរសេរអ្វីខ្លះ ដើម្បីជួយដល់សមាជិកសាសនាចក្រឲ្យយល់ដឹងពីធាតុពិតនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ។

- **តើប៉ុលបានថ្លែងបន្ទាល់អំពីអ្វីខ្លះ ដើម្បីជួយសមាជិកសាសនាចក្រឲ្យយល់ដឹងពីធាតុពិតនៃបេសកកម្ម និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ?**
- **តើយើងអាចរៀននូវសេចក្តីពិតអ្វីខ្លះអំពីតួនាទីរបស់សាវកមកពីខគម្ពីរទាំងនេះ ?** (**សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ ពួកសាវកថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទបានសុគតសម្រាប់អំពើបាបរបស់យើង ហើយបានមានព្រះជន្មរស់ឡើងវិញពីការសុគត**) ។
- **តើទីបន្ទាល់របស់ពួកសាវកស្តីពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ អាចជួយដល់មនុស្សដែលស្មុគស្មាញជាមួយនឹងការជឿលើការរស់ឡើងវិញបានយ៉ាងដូចម្តេច ?**

ដើម្បីជួយសិស្សឲ្យយល់អំពីសេចក្តីពិត និងសារៈសំខាន់នៃសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវទីបន្ទាល់របស់ប្រធាន ថូម៉ាស អេស ម៉នសុន ដូចខាងក្រោមនេះ ។ (**អ្នកក៏គួរតែចែកចាយទីបន្ទាល់អំពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទដែលបានលើកឡើងដោយពួកសាវកផ្សេងទៀតនៅក្នុងសុន្ទរកថានៃសន្និសីទទូទៅផងដែរ**) ។



« ខ្ញុំបន្ទីសំឡេងរបស់ខ្ញុំថ្លែងទីបន្ទាល់ក្នុងនាមជាសាវកពិសេសមួយរូប និង សូមប្រកាសថា ព្រះមានព្រះជន្មរស់ដោយអស់ពីដួងចិត្តរបស់ខ្ញុំ និង អារម្មណ៍ភ្លឿវភ្លាំនៃព្រលឹងរបស់ខ្ញុំ ។ ព្រះយេស៊ូវ ជាព្រះរាជបុត្រារបស់ទ្រង់ ជាបុត្រាសំណព្វតែមួយគត់របស់ព្រះវរបិតានៅក្នុងសាច់ឈាម ។ ទ្រង់ជាព្រះប្រោសលោះរបស់យើង ទ្រង់ជាអង្គបង្រួបបង្រួមរបស់យើង ជាមួយនឹងព្រះវរបិតា ។ ទ្រង់គឺជាអង្គដែលបានសុគតនៅលើឈើឆ្កាង ដើម្បីធ្វើឲ្យឆ្ងននឹងអំពើបាបទាំងឡាយរបស់យើង ។ ទ្រង់បានក្លាយទៅជាផលដំបូងនៃការរស់ឡើងវិញ ។ ដោយសារតែទ្រង់បានសុគត នោះមនុស្សទាំងអស់នឹងបានរស់ឡើងវិញ » ។ ‹ នេះជាឃ្លាដែលមានបទដ៏ពិរោះ ៖ « ខ្ញុំដឹងថា ព្រះប្រោសលោះខ្ញុំនៅរស់ ! › » សូមឲ្យពិភពលោកទាំងមូលដឹងពីរឿងនេះ ហើយរស់នៅតាមចំណេះដឹងនោះ » (« I Know That My Redeemer Lives! » **ទំព័រ ២៥**) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា ទីបន្ទាល់របស់ពួកសាវកស្តីពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទបានជួយពង្រឹងសេចក្តីជំនឿរបស់ពួកគេទៅលើការរស់ឡើងវិញដោយរបៀបណា ។ អ្នកគ្រូតែអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយគំនិតរបស់ពួកគេ ។

កូរិនថូសទី១ ១៥:១១–២៩

ប៉ុលបានពន្យល់បន្ថែមពីគោលលទ្ធិនៃការរស់ឡើងវិញ

សូមសង្ខេប កូរិនថូសទី ១ ១៥:១១–១៥ ដោយពន្យល់ថា ប៉ុលបានសួរថា ហេតុអ្វីបានពួកបរិសុទ្ធនៅកូរិនថូសបានចាប់ផ្តើមសង្ស័យពីឆាតុពិតនៃការរស់ឡើងវិញ ។ លោកបានសួរថា ប្រសិនបើព្រះយេស៊ូវគ្រីស្ទពុំបានមានព្រះជន្មរស់ពីការសុគតវិញនោះទេ នោះរាល់សាក្សីទាំងអស់អំពីការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ គឺជារឿងក្លែងក្លាយ ហើយក៏គ្មានហេតុផលចំបាច់ដែលត្រូវប្រកាសដំណឹងល្អដែរ ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖

ប្រសិនបើព្រះយេស៊ូវពុំបានមានព្រះជន្មរស់ពីសុគតវិញទេនោះ . . . (សូមមើល កូរិនថូសទី ១ ១៥:១៦–១៩) ។

ដោយសារព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតវិញ . . . (សូមមើល កូរិនថូសទី ១ ១៥:២០–២២) ។

សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ឲ្យអាន កូរិនថូសទី១ ១៥:១៦–១៩ ដោយស្ងៀមស្ងាត់ ហើយរកមើលថាមានអ្វីនឹងអាចកើតឡើងប្រសិនបើព្រះយេស៊ូវពុំបានមានព្រះជន្មរស់ពីសុគតវិញនោះទេ ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ទៀតឲ្យ អាន កូរិនថូសទី១ ១៥:២០–២២ ដោយស្ងៀមស្ងាត់ ហើយរកមើលពរជ័យដែលកើតមានជាលទ្ធផលនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។

បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយនោះ ចូរសុំឲ្យពួកសិស្សដែលអាន កូរិនថូសទី១ ១៥:២០–២២ ប្រាប់ពីរបៀបដែលពួកគេបំពេញឃ្លានៅលើក្តារខៀននោះ ។ ចូរសុំឲ្យសិស្សម្នាក់សរសេរចម្លើយរបស់សិស្សទាំងនេះនៅលើក្តារខៀន ។

សូមពន្យល់ថាពាក្យ *ជលដំបូង* នៅក្នុង ខទី ២០ សំដៅទៅលើផ្នែកដំបូងនៃជលផ្លែដែលកសិករបានច្រូតកាត់ ។ ដូចជាជលផ្លែដំបូងដែលបានច្រូតកាត់ជលផ្លែដំបូងនៃជលផ្លែជាច្រើន ដែលត្រូវច្រូតកាត់នោះគឺព្រះយេស៊ូវគ្រីស្ទគឺជាតួអង្គដំបូងដែលបានរស់ឡើងវិញ ។

- យោងតាម ខទី ២២តើនឹងមានអ្វីខ្លះកើតឡើងចំពោះកូនចៅទាំងអស់របស់ព្រះវរបិតាស្ថគ៌ ដោយសារព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **ដោយសារការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ នោះមនុស្សគ្រប់រូបនឹងបានរស់ឡើងវិញដែរ**) ។

សូមអញ្ជើញឲ្យពួកសិស្សដែលអាន កូរិនថូសទី ១ ១៥:១៦–១៩ ប្រាប់ពីរបៀបដែលពួកគេបំពេញឃ្លាផ្សេងទៀតនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សម្នាក់សរសេរចម្លើយរបស់សិស្សទាំងនេះនៅលើក្តារខៀន ។

សូមពន្យល់ថានៅក្នុង ខទី ១៤–១៩ ប៉ុលបានសុំពួកបរិសុទ្ធឲ្យពិចារណាពីអ្វីដែលនឹងកើតឡើង « ប្រសិនបើព្រះគ្រីស្ទពុំបានមានព្រះជន្មរស់ឡើងវិញ » នោះទេ ។ ប៉ុលពន្យល់ថា រាល់ការប្រកាសដំណឹងល្អនឹងក្លាយជារឿងឥតប្រយោជន៍ ប្រសិនបើព្រះយេស៊ូវគ្រីស្ទពុំបានបង្ហាញថា ទ្រង់មានព្រះចេស្តាលើសេចក្តីស្លាប់ ហើយគ្មានលទ្ធភាពធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់យើងទេនោះ ។ ប៉ុន្តែដោយសារព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញពីការសុគត នោះយើងដឹងថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះ ហើយទ្រង់មានព្រះចេស្តានោះ ។

សូមយោងទៅប្រសាសន៍របស់ប៉ុលនៅក្នុង ខទី ១៩ « បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត » ។

- ហេតុអ្វីយើងនឹងជួបរឿងអកុសល ប្រសិនបើយើងមានសេចក្តីសង្ឃឹមលើព្រះយេស៊ូវគ្រីស្ទតែម្យ៉ាងនៅក្នុងជីវិត *នេះ* ឬប្រសិនបើសេចក្តីសង្ឃឹមរបស់យើងបានបាត់បង់ទៅបន្ទាប់ពីសេចក្តីស្លាប់របស់យើងនោះ ? (ប្រសិនបើគ្មានការរស់ឡើងវិញពីស្លាប់នោះទេ សេចក្តីសង្ឃឹមរបស់យើងលើព្រះយេស៊ូវគ្រីស្ទអាចកើតមានតែនៅក្នុងជីវិតនេះប៉ុណ្ណោះ ហើយគោលបំណងរបស់ផែនការនៃសេចក្តីសង្គ្រោះនឹងមិនអាចសម្រេចបានឡើយ) ។

យោងតាម ខទី ២០–២២តើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវបានផ្តល់សេចក្តីសង្ឃឹមដ៏ធំបែបណាទៅ ? (សេចក្តីសង្ឃឹមថាយើងទាំងអស់គ្នានឹងរស់ឡើងវិញបន្ទាប់ពីការស្លាប់ ។ បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ដោយសារការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងមានសេចក្តីសង្ឃឹម**) ។

- តើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទនាំមកនូវសេចក្តីសង្ឃឹមដល់យើងតាមរបៀបណា នៅពេលមនុស្សម្នាក់ដែលយើងស្គាល់បានចែកឋានទៅ ឬនៅពេលយើងភ័យខ្លាចចំពោះសេចក្តីស្លាប់ផ្ទាល់ខ្លួនរបស់យើងនោះ ?

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតអំពីសារៈសំខាន់នៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ឲ្យឮៗ ។ (ប្រសិនបើធ្វើទៅបាន សូមចែកឯកសារដែលមានសេចក្តីថ្លែងការណ៍នេះដល់សិស្ស) ។

« គោលការណ៍គ្រឹះនៃសាសនារបស់យើង គឺជាទីបន្ទាល់របស់ពួកសាវក និងព្យាការីទាំងឡាយដែលទាក់ទងទៅនឹងព្រះយេស៊ូវគ្រីស្ទថាទ្រង់បានសុគត ត្រូវបានគេបញ្ចុះសព និងបានរស់ឡើងវិញម្តងទៀតនៅថ្ងៃទីបី ហើយបានយាងឡើងទៅស្ថានសួគ៌វិញ ហើយរឿងផ្សេងទៀតទាំងឡាយដែលបានជាប់ទាក់ទងទៅនឹងសាសនារបស់យើងគឺគ្រាន់តែជារឿងបន្ទាប់បន្សំចំពោះការណ៍នេះប៉ុណ្ណោះ » (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ | ទំព័រ ៤៩) ។

> **កូរិនថូសទី ១ ១៥:២០–២២** គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើននូវការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះតាមរបៀបដាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកយោងទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

- តើយ៉ូសែប ស៊្មីធ បានថ្លែងថាអ្វីទៅជាគោលការណ៍ដ៏សំខាន់នៃសាសនារបស់យើង ?
- យោងតាមអ្វីដែលអ្នកបានរៀននៅក្នុងមេរៀននេះ តើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គឺជារឿងដ៏សំខាន់ចំពោះសេចក្តីពិតផ្សេងទៀតនៃដំណឹងល្អបានយ៉ាងដូចម្តេច ?

អ្នកគួរថ្លែងទីបន្ទាល់អំពីភាពពិតជាក់ស្តែងនៃការរស់ឡើងវិញ និងសារៈសំខាន់របស់វានៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាស្ងួត ។

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង កូរិនថូសទី ១១៥:២៣–២៤ ប៉ុលបានបង្រៀនថា នឹងមានលំដាប់លំដោយមួយចំពោះការរស់ឡើងវិញ ហើយថា ព្រះយេស៊ូវគ្រីស្ទនឹង « [ប្រគល់] នគរ » ដល់ព្រះវរបិតា បន្ទាប់ពីបញ្ចប់រាល់ « សិទ្ធិអំណាច និងអំណាច » លើផែនដី (ឬខាងលោកិយ) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៥:២៥–២៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់តាមរកមើលថា ប៉ុលបានបង្រៀនថា នៅទីបំផុតនឹងមានអ្វីខ្លះកើតឡើងដល់ខ្មាំងសត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ ។

- តើប៉ុលបាននិយាយថា នៅទីបំផុតនឹងមានអ្វីខ្លះកើតឡើងដល់ខ្មាំងសត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ ? (ពួកគេនឹងត្រូវបានដាក់ « នៅក្រោមព្រះបាទទ្រង់ » [ខទី ២៥] ឬត្រូវបំផ្លាញចោល) ។
- តើនរណា ឬអ្វីទៅដែលអាចចាត់ទុកថាជាខ្មាំងសត្រូវរបស់ព្រះយេស៊ូវគ្រីស្ទ ? (ឧទាហរណ៍អាចរួមមាន អំពើបាប អំពើពុករលួយ អំពើទុច្ចរិត និងមារសត្រូវ) ។
- តើអ្វីទៅជាខ្មាំងសត្រូវចុងក្រោយដែលព្រះយេស៊ូវនឹងបំផ្លាញចោល ?
- ហេតុអ្វីសេចក្តីស្លាប់អាចចាត់ទុកថាជាខ្មាំងសត្រូវមួយចំពោះព្រះយេស៊ូវគ្រីស្ទ និងចំពោះផែនការរបស់ព្រះវរបិតាស្ងួត ?

សូមរំឭកសិស្សថា សមាជិកសាសនាចក្រមួយចំនួននៅកូរិនថូសបានជឿថា មនុស្សស្លាប់មិនអាចរស់ឡើងវិញបានឡើយ ប៉ុន្តែប៉ុលបានចង្អុលបង្ហាញថា ពួកបរិសុទ្ធបានកំពុងធ្វើនូវរឿងមួយដែលបង្ហាញពីជំនឿរបស់ពួកគេទៅលើការរស់ឡើងវិញរបស់មរណជន ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៥:២៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពិធីបរិសុទ្ធដែលពួកបរិសុទ្ធនៅកូរិនថូសកំពុងធ្វើ ។ សូមឲ្យសិស្សប្រាប់អំពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកនឹងសង្ខេបអ្វី ដែលប៉ុលបានចោទសួរដល់ពួកបរិសុទ្ធអំពីការចូលរួមរបស់ពួកគេនៅក្នុងពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនដោយរបៀបណា ? (« ប្រសិនបើអ្នកពុំជឿលើការរស់ឡើងវិញទេ ហេតុអ្វីក៏អ្នកធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនដូច្នេះ ? »)

សូមចង្អុលបង្ហាញថា ពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជនគឺជាសាក្សីមួយអំពីជំនឿរបស់យើងទៅលើការរស់ឡើងវិញ ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ៖ **ជនដែលបានចែកឋានទៅដោយគ្មានពិធីបុណ្យជ្រមុជទឹក អាចនឹងទទួលពិធីបរិសុទ្ធដ៏សំខាន់នេះ ។**

សូមដាក់តាំងរូបភាពនៃព្រះវិហារបរិសុទ្ធមួយ ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖

« រាល់ព្រះវិហារបរិសុទ្ធ ទោះជាធំ ឬតូច ចាស់ ឬថ្មីក្តី វាគឺជាការបង្ហាញមួយអំពីទីបន្ទាល់របស់យើងថា ជីវិតលើសពីសេចក្តីស្លាប់គឺមានពិតប្រាកដមែន ដូចជាជីវិតរមែងស្លាប់ដែរ » (« This Peaceful House of God » *Ensign* ខែឧសភា ឆ្នាំ ១៩៩៣ ទំព័រ ៧៤) ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីគ្រាមួយដែលពួកគេបានធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់មរណជន ឬបានរៀបចំឈ្មោះដើម្បីយកទៅព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឆ្លើយសំណួរខាងក្រោមនេះ ៖

- តើអ្នកមានអារម្មណ៍បែបណា នៅពេលអ្នកបានរៀបចំឈ្មោះ ឬបានធ្វើកិច្ចការសម្រាប់ពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ ?
- តើបទពិសោធន៍របស់អ្នកជាមួយនឹងពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធបានពង្រឹងដល់សេចក្តីជំនឿរបស់អ្នកលើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ និងរបស់មនុស្សទាំងអស់ដោយរបៀបណា ?

សូមពិចារណាថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការធ្វើកិច្ចការពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ជនដែលបានចែកឋានទៅ ។ សូមលើកទឹកចិត្តសិស្សឲ្យបង្ហាញសេចក្តីជំនឿរបស់ពួកគេលើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ និងការរស់ឡើងវិញរបស់មនុស្សទាំងអស់លើកចុងក្រោយ តាមរយៈការចូលរួមឲ្យបានទៀងទាត់នៅក្នុងកិច្ចការពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធ ។

ចំណេះចំណានខគម្ពីរ—កូរិនថូសទី ១ ១៥:២០–២២

ដើម្បីជួយសិស្សឲ្យយល់ថា ការស្គាល់គោលលទ្ធិនៅក្នុង កូរិនថូសទី១ ១៥:២០–២២ អាចរៀបចំខ្លួនពួកគេឲ្យជួយដល់មនុស្សដទៃទៀតតាមរបៀបណានោះ សូមអញ្ជើញពួកគេឲ្យពិចារណាពីមនុស្សដែលពួកគេស្គាល់ ហើយបុគ្គលនោះបានបាត់បង់មនុស្សជាទីស្រឡាញ់របស់គាត់ ។ ចូរសុំឲ្យសិស្សសរសេរសំបុត្រខ្លីមួយទៅកាន់បុគ្គលម្នាក់នេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ដោយប្រើការយល់ដឹងរបស់ខ្លួនអំពីរឿងនេះដើម្បីបង្រៀន ហើយលួងលោមដល់បុគ្គលនេះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វី ដែលពួកគេបានសរសេរជាមួយសិស្សនៅក្នុងថ្នាក់ ។

កូរិនថូស ទី១ ១៥:៣០–១៦:២៤

សេចក្តីផ្តើម

ប៉ុលបានបន្តបង្រៀនពួកបរិសុទ្ធនៅកូរិនថូសអំពីការរស់ឡើងវិញ ។ លោកបានរីករាយនៅក្នុងជ័យជំនះរបស់ព្រះយេស៊ូវគ្រីស្ទលើសេចក្តីស្លាប់ ។ ប៉ុលក៏បានលើកទឹកចិត្តសមាជិកសាសនាចក្រនៅកូរិនថូស ឲ្យធ្វើការបរិច្ចាគសម្រាប់ពួកបរិសុទ្ធក្រីក្រនៅយេរូសាឡិម ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី១ ១៥:៣០–៥២

ប៉ុលបង្រៀនអំពីការរស់ឡើងវិញ

សូមសរសេរសំណួរខាងក្រោមនេះនៅលើក្តារខៀនពីមុនចាប់ផ្តើមបង្រៀន ៖ *តើមនុស្សអាចនឹងជ្រើសយកការមានជីវិតរស់នៅតាមរបៀបណា ប្រសិនបើពួកគេមិនបានជឿថា ពួកគេនឹងរស់ឡើងវិញម្តងទៀតបន្ទាប់ពីពួកគេបានស្លាប់ផងនោះ ?*

នៅពេលចាប់ផ្តើមថ្នាក់រៀន ចូរអញ្ជើញសិស្សឲ្យឆ្លើយសំណួរនៅលើក្តារខៀន ។

សូមសង្ខេប កូរិនថូសទី ១ ១៥:៣០–៣៨ ដោយពន្យល់ថា ប៉ុលបានសុំឲ្យពួកបរិសុទ្ធនៅកូរិនថូស (ដែលមួយចំនួនជឿខុសថា នឹងគ្មានការរស់ឡើងវិញទេ) ឲ្យពិចារណាពីហេតុផលដែលមនុស្សម្នាក់ ដែលបានជឿលើព្រះយេស៊ូវគ្រីស្ទ នឹងស៊ូទ្រាំនូវការបៀតបៀនហើយស៊ូស្លាប់ ប្រសិនបើគ្មានការរស់ឡើងវិញពីស្លាប់នោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១៥:៣២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាប៉ុលបានណែនាំពីលក្ខណៈអ្វីខ្លះដែលមនុស្សមួយចំនួនអាចមាន ប្រសិនបើគ្មានការរស់ឡើងវិញពីស្លាប់ទេនោះ ។

- យោងតាម ខទី ៣២ តើប៉ុលបានណែនាំពីលក្ខណៈអ្វីខ្លះ ដែលមនុស្សមួយចំនួនអាចមាន ប្រសិនបើពួកគេមិនជឿលើការរស់ឡើងវិញនោះ ?
- ដោយសារការរស់ឡើងវិញមានពិត ហេតុអ្វីលក្ខណៈនេះជារឿងគ្រោះថ្នាក់ ដើម្បីសម្របតាម ?

នៅពេលពួកគេសិក្សាផ្នែកដែលនៅសល់នៃ កូរិនថូសទី១ ១៥ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេឲ្យយល់ថា ការមានចំណេះដឹងមួយអំពីការរស់ឡើងវិញអាចជះឥទ្ធិពលដល់ការជ្រើសរើសរបស់ពួកគេនៅក្នុងជីវិតរមែងស្លាប់យ៉ាងដូចម្តេច ។ (*កំណត់ចំណាំ ៖* នៅពេលសេចក្តីពិតនានាបានបង្ហាញឡើង សូមសរសេរវានៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១៥:៣៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលសំណួរដែលមនុស្សទូទៅអាចសួរអំពីការរស់ឡើងវិញ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមសង្ខេប កូរិនថូសទី ១ ១៥:៣៦–៣៨ ដោយពន្យល់ថា ប៉ុលបានជួយឆ្លើយសំណួរទាំងនេះ ដោយប្រើគ្រាប់ពូជមួយធ្វើជាតំណាងឲ្យរូបកាយរមែងស្លាប់ បន្ទាប់ពីសេចក្តីស្លាប់ ហើយបញ្ចុះទៅក្នុងដីនឹងលេចចេញមកជាការរស់ឡើងវិញ ។

សូមដាក់បង្ហាញ (ឬ គូររូបនៅលើក្តារខៀន) រូបភាព ព្រះអាទិត្យ ព្រះចន្ទ និងផ្កាយមួយចំនួន ។



- ចេញពីទស្សនវិស័យរបស់យើងនៅលើផែនដីនេះ តើពន្លឺព្រះអាទិត្យខុសគ្នាពីពន្លឺព្រះចន្ទយ៉ាងដូចម្តេច ?
- តើពន្លឺព្រះចន្ទខុសពីពន្លឺផ្កាយយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានកូរិនថូសទី ១ ១៥:៣៩–៤២ ឲ្យឮៗ ។ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធនៅក្នុងខទី ៤០ចែងថា « ក៏មានរូបកាយទាំងឡាយខាងសេឡេស្ទាល និងរូបកាយទាំងឡាយខាងទេរេសទ្រាល និងរូបកាយទាំងឡាយខាងទេឡេស្ទាល ប៉ុន្តែសិរីល្អរបស់សេឡេស្ទាល នោះមួយ និងរបស់ទេរេសទ្រាល នោះមួយផ្សេងទៀត និងរបស់ទេឡេស្ទាលនោះមួយផ្សេងទៀត » ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានប្រើពន្លឺនៃព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ ដើម្បីពន្យល់ពីភាពខុសគ្នានៅក្នុងរូបកាយដែលបានរស់ឡើងវិញយ៉ាងដូចម្តេច ។ សូមពន្យល់ថានៅក្នុងបរិបទនេះ ពាក្យ*សិរីល្អ* អាចសំដៅទៅលើពន្លឺ ភាពរុងរឿង ឬប្រាជ្ញា ។

- តើប៉ុលបានប្រៀបធៀបសិរីល្អនៃព្រះអាទិត្យ ព្រះចន្ទ និងផ្កាយទៅនឹងអ្វី ? (សិរីល្អនៃរូបកាយដែលបានរស់ឡើងវិញ) ។

> **កូរិនថូសទី ១ ១៥:៤០–៤២** គឺជាចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។
>
> សម្រាប់ការពន្យល់អំពីចំណេះចំណានខគម្ពីរ និងបញ្ជីនៃសកម្មភាពបន្ថែម ដើម្បីជួយសិស្សឲ្យចេះចាំវគ្គបទគម្ពីរដម្រើសទាំងនេះ សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ ។

- តើភាពខុសគ្នានៅក្នុងពន្លឺ ឬសិរីល្អអាចបង្រៀនយើងអ្វីខ្លះ អំពីរូបកាយដែលបានរស់ឡើងវិញ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ពីគោលលទ្ធិខាងក្រោមនេះ ៖ **សិរីល្អសម្រាប់រូបកាយដែលបានរស់ឡើងវិញមានកម្រិតខុសៗគ្នា**) ។


សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌិង ស្ម៊ីធ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា តើសិរីល្អនៃរូបកាយដែលបានរស់ឡើងវិញនឹងខុសគ្នាយ៉ាងដូចម្តេច ។ ពីមុនសិស្សអាន សូមពន្យល់ថា កាលប្រធានស្ម៊ីធថ្លែងពី « រូបកាយសេឡេស្ទាល » លោកចង់សំដៅលើជនដែលទទួលបានកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាល (សូមមើល គ. និង ស. ១៣១:១–៤) ។



« នៅក្នុងការរស់ឡើងវិញនឹងមានប្រភេទរូបកាយខុសៗគ្នា រូបកាយទាំងនោះនឹងមិនដូចគ្នាឡើយ ។ រូបកាយដែលមនុស្សម្នាក់ទទួលបាន នឹងកំណត់អំពីកន្លែងរបស់គាត់នៅនាពេលក្រោយ ។ វានឹងមានជារូបកាយសេឡេស្ទាល រូបកាយទេរេស្ទ្រាល និងរូបកាយទេឡេស្ទាល ។ . . .

« . . . *មនុស្សមួយចំនួននឹងទទួលបានរូបកាយសេឡេស្ទាលជាមួយនឹងអំណាចនៃភាពតម្កើងឡើង និងការរីកចម្រើនដ៏អស់កល្បជានិច្ច* ។ រូបកាយទាំងនេះភ្លឺចែងចាំងដូចជាព្រះអាទិត្យ ដូចដែលព្រះអង្គសង្គ្រោះរបស់យើងមានដែរ ។ . . . ជនដែលចូលទៅក្នុងនគរទេរេស្ទ្រាលនឹងមានរូបកាយទេរេស្ទ្រាល ហើយវានឹងមិនជះរស្មីដូចជាព្រះអាទិត្យទេ ប៉ុន្តែវានឹងរុងរឿងជាងរូបកាយនៃជនដែលទទួលបានសិរីល្អទេឡេស្ទាល » (*Doctrines of Salvation* និពន្ធដោយ Bruce R. McConkie រ៉ុល ៣ | ឆ្នាំ ១៩៥៤–៥៦ | ២:២៨៦, ២៨៧) ។

- តើសិរីល្អនៃរូបកាយដែលបានរស់ឡើងវិញខុសគ្នាយ៉ាងដូចម្តេច ?



សូមសរសេរពាក្យ *សេរេឡេស្ទាល* នៅត្រង់គំនូរព្រះអាទិត្យ ពាក្យ *ទេរេស្ទ្រាល* នៅត្រង់ព្រះចន្ទ និងពាក្យ *ទេឡេស្ទាល* នៅត្រង់ផ្កាយលើក្តារខៀន ។ នៅក្រោមគំនូរ ឬ រូបភាពនីមួយៗ សូមគូរការពិពណ៌នាសាមញ្ញមួយនៃរាងកាយ ដោយរូបកាយសេឡេស្ទាលមានសិរីល្អច្រើនជាងរូបកាយទេរេស្ទ្រាល ហើយរូបកាយទេរេស្ទ្រាលមានសិរីល្អច្រើនជាងរូបកាយទេឡេស្ទាល ។

- យោងតាមប្រធាន ស្ម៊ីធ តើរូបកាយ ឬសិរីល្អដែលមនុស្សម្នាក់ទទួលបាននៅក្នុងការរស់ឡើងវិញនឹងកំណត់ពីអ្វីខ្លះ ?
- យោងតាមប្រធាន ស្ម៊ីធ តើជនដែលទទួលបានរូបកាយសេឡេស្ទាលនៅក្នុងកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាលនឹងទទួលបានអ្វីខ្លះ ជាផ្នែកមួយនៃសិរីល្អរបស់ពួកគេ ខុសពីជនដែលគ្មានរូបកាយសេឡេស្ទាល ? (សូមសរសេរ *អំណាចនៃការតម្កើងឡើង និងការរីកចម្រើនដ៏អស់កល្បជានិច្ច* នៅក្រោមគំនូររូបកាយសេឡេស្ទាល) ។

សូមពន្យល់ថា « អំណាចនៃការតម្កើងឡើង » រួមមានសមត្ថភាពដើម្បីរស់នៅក្នុងជីវិតដូចជាព្រះ ហើយ « ការរីកចម្រើនដ៏អស់កល្បជានិច្ច » គឺជាសមត្ថភាពដើម្បីបន្តមានកូនចៅនៅក្នុងភាពអស់កល្បជានិច្ច ។ ពរជ័យទាំងនេះមានតែចំពោះជនដែលត្រូវបានតម្កើងឡើងនៅក្នុងកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាលប៉ុណ្ណោះ (សូមមើល គ. និង ស. ១៣១:១–៤, ១៣២:១៩–២០) ។

ដើម្បីជួយសិស្សឲ្យយល់ពីអ្វីដែលយើងត្រូវធ្វើ ដើម្បីទទួលបានរូបកាយសេឡេស្ទាលនៅក្នុងការរស់ឡើងវិញ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:២១–២២ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានរូបកាយសេឡេស្ទាលមួយ ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានរូបកាយសេឡេស្ទាលមួយ ? (សូមពន្យល់ថា ដើម្បី « នៅជាប់ក្នុងក្រឹត្យវិន័យនៃនគរសេឡេស្ទាល » | ខទី ២២ | មានន័យថា ត្រូវទទួលបានពិធីបរិសុទ្ធទាំងអស់ ហើយធ្វើ និងរក្សារាល់សេចក្តីសញ្ញាដែលចាំបាច់ដើម្បីចូលទៅក្នុងនគរសេឡេស្ទាល) ។
- តើការដឹងអំពីសិរីល្អ និងពរជ័យដែលមានតែចំពោះមនុស្សដែលបានរស់ឡើងវិញនៅក្នុងកម្រិតខ្ពស់បំផុតនៃនគរសេឡេស្ទាល អាចជះឥទ្ធិពលដល់ការជ្រើសរើសរបស់មនុស្សម្នាក់នៅក្នុងជីវិតរមែងស្លាប់នេះយ៉ាងដូចម្តេច ?

សូមសង្ខេប កូរិនថូសទី ១ ១៥:៤២–៥២ ដោយពន្យល់ថា ប៉ុលបានបញ្ជាក់បន្ថែមទៀតអំពីលក្ខណៈនៃរូបកាយដែលបានរស់ឡើងវិញ ។ លោកបានហៅរូបកាយរមែងស្លាប់មួយថាជា « រូបកាយខាងសាច់ឈាម » (ខទី ៤៤, ៤៦) ហើយពុករលួយ និងរូបកាយដែលរស់ឡើងវិញជារូបកាយ « ខាងវិញ្ញាណ » (ខទី ៤៤, ៤៦) ហើយ « មិនពុករលួយ » (ខទី ៥២) មានន័យថា អមត: ឬពុំរងសេចក្តីស្លាប់ឡើយ ។

កូរិនថូសទី១ ១៥:៥៣–៥៨

ប៉ុលបានរីករាយនៅក្នុងជ័យជំនះរបស់ព្រះយេស៊ូវគ្រីស្ទលើសេចក្តីស្លាប់

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៥:៥៣ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា គោលលទ្ធិណាខ្លះ ដែលប៉ុលបានបង្រៀនអំពីគោលបំណងនៃរូបកាយរបស់យើង នៅពេលដែលយើងរស់ឡើងវិញ ។

- យោងតាម ខទី ៥៣ តើរូបកាយយើងបន្ទាប់ពីការរស់ឡើងវិញនឹងមានស្ថានភាពបែបណា? (សិស្សគួរកត់សម្គាល់ឃើញគោលលទ្ធិមួយដែលស្រដៀងគ្នានឹងគោលលទ្ធិខាងក្រោម ៖ **យើងនឹងរស់ឡើងវិញនៅក្នុងស្ថានភាពមួយដែលមានរូបកាយពុំពុករលួយ ហើយអតម:**) ។
- តើរូបកាយយើងដែលបានរស់ឡើងវិញនឹងពុំពុករលួយតាមរបៀបណា ? (វានឹងពុំពុករលួយ ឬស្លាប់ទៀតឡើយ) ។
- តើការដឹងថា យើងម្នាក់ៗនឹងមានរូបកាយដែលបានរស់ឡើងវិញ ហើយទទួលបានកម្រិតនៃសិរីល្អរបស់វាសម្រាប់ភាពអស់កល្បជានិច្ច អាចជះឥទ្ធិពលដល់ការសម្រេចចិត្តដែលយើងធ្វើនៅក្នុងជីវិតរមែងស្លាប់នេះយ៉ាងដូចម្តេច ?

ដើម្បីរៀបចំសិស្សឲ្យសិក្សាពីផ្នែកនៅសល់ស្តីពីសំបុត្រទីមួយរបស់ប៉ុលទៅដល់ពួកកូរិនថូស សូមអញ្ជើញពួកគេឲ្យលើកដៃឡើង ប្រសិនបើពួកគេធ្លាប់ត្រូវសត្វល្អិតទិច ។

- តើអ្នកនឹងរៀបរាប់យ៉ាងដូចម្តេច អំពីបទពិសោធន៍សត្វល្អិតទិចនោះ ?

ចូរសុំឲ្យសិស្សអាន កូរិនថូស ទី១ ១៥:៥៤–៥៥ ដោយស្ងៀមស្ងាត់ ហើយរកមើលថាអ្វីទៅ ដែលប៉ុលបាននិយាយថានឹងគ្មានទ្រនិចទៀតឡើយ ។

- តើអ្វីទៅដែលប៉ុលបាននិយាយថានឹងគ្មានទ្រនិចទៀតឡើយ ? (សេចក្តីស្លាប់ខាងរូបកាយ) ។
- តើសេចក្តីស្លាប់ខាងសាច់ឈាមអាចជា « ទ្រនិច » (ខទី ៥៥) ឬទំនងជាយកឈ្នះលើយើងបានយ៉ាងដូចម្តេច ?
- តើសេចក្តីស្លាប់ខាងសាច់ឈាមត្រូវ « សេចក្តីជ័យជំនះបានលេប » តាមរយៈព្រះយេស៊ូវគ្រីស្ទ (ខទី ៥៤) បានយ៉ាងដូចម្តេច ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងការបង្រៀនរបស់ប៉ុល អំពីហេតុផលដែលសេចក្តីស្លាប់ខាងសាច់ឈាមនឹងគ្មានទ្រនិចជាអចិន្ត្រៃយ៍ ឬគ្មានជ័យជំនះលើយើងទៀតឡើយនោះ ? (សូមធ្វើឲ្យប្រាកដថា សិស្សរកឃើញសេចក្តីពិតមួយស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **សេចក្តីស្លាប់ខាងសាច់ឈាមគ្មានជ័យជំនះលើយើងទៀតឡើយ ដោយសារតែការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ**) ។

សូមពន្យល់ថា ទោះបីជាការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទបានដកយកទ្រនិចដែលកើតមកពីសេចក្តីស្លាប់ខាងសាច់ឈាមក្តី ក៏វាអាចនៅមានទ្រនិចមួយទៀតនៅក្នុងសេចក្តីស្លាប់ដែរ ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ១ ១៥:៥៦ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលទ្រនិចដែលអាចនៅមាន នៅពេលយើងស្លាប់ទៅ ។

- តើទ្រនិចអាចនៅមាន នៅពេលយើងស្លាប់ទៅគឺជាអ្វី ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី១ ១៥:៥៧–៥៨ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានបង្រៀនថាអ្វីទៅ ដែលអាចដកយកទ្រនិចនៃសេចក្តីស្លាប់ដែលកើតចេញពីអំពើបាប ។

- តើប៉ុលបានបង្រៀនថាអ្វីទៅដែលអាចដកយកទ្រនិចនៃសេចក្តីស្លាប់ដែលកើតចេញពីអំពើបាបនោះ ?
- យោងតាម ខទី ៥៨ តើប៉ុលបានអញ្ជើញពួកអ្នកអានរបស់លោកឲ្យធ្វើអ្វីខ្លះ ដោយសារតែជ័យជំនះលើសេចក្តីស្លាប់របស់ព្រះយេស៊ូវគ្រីស្ទ ?
- តើយើងអាចស្គាល់គោលការណ៍អ្វីខ្លះ នៅក្នុង ខទី ៥៦–៥៨ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីចៀសវាងពីទ្រនិចនៃសេចក្តីស្លាប់ដែលកើតចេញពីអំពើបាបនោះ ? (សូមជួយសិស្សឲ្យបង្ហាញគោលការណ៍ស្រដៀងគ្នាមួយដូចនឹងគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងការរស់នៅតាមដំណឹងល្អ ចំណែកនៃសេចក្តីស្លាប់ដែលកើតចេញពីអំពើបាបត្រូវបានដកចេញតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ**) ។
- តើការខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងការរស់នៅតាមដំណឹងល្អមានន័យដូចម្តេច ?
- តើការប្រែចិត្តមានតួនាទីអ្វី នៅក្នុងការខ្ជាប់ខ្ជួន ហើយនឹងនរ ?

ដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍ពីសារៈសំខាន់នៃសេចក្តីពិតដែលពួកគេបានរៀន សូមយោងទៅសេចក្តីពិតនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយរបស់ពួកគេសម្រាប់សំណួរខាងក្រោមនេះនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នៅពេលពួកគេឆ្លើយនឹងសំណួរខាងក្រោម ៖ *តើអ្នកបានរៀនថា សេចក្តីពិតអ្វីខ្លះដែលអាចជួយអ្នកឲ្យចង់រស់នៅដោយសុចរិត ?* ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានសរសេរ ។

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយអំពីអ្វីមួយដែលពួកគេអាចធ្វើនៅថ្ងៃនេះ ដើម្បីមានភាពខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងការរស់នៅតាមដំណឹងល្អកាន់តែខ្លាំងឡើង ។

កូរិនថូសទី១ ១៦

ប៉ុលរៀបចំការរៃអង្គាសមួយ ដើម្បីជួយដល់ពួកក្រីក្រនៅក្រុងយេរូសាឡិម

សូមសង្ខេប កូរិនថូសទី១ ១៦:១–២៤ ដោយពន្យល់ថា ប៉ុលបានណែនាំពួកបរិសុទ្ធនៅកូរិនថូស ឲ្យជួយមើលថែដល់ជនក្រីក្រនៅក្រុងយេរូសាឡិម « ឲ្យមាំមួនក្នុងសេចក្តីជំនឿ » (ខទី ១៣) ហើយធ្វើរឿងទាំងអស់ « ដោយសេចក្តីស្រឡាញ់ » (ខទី ១៤) ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលសិស្សបានស្គាល់នៅក្នុងមេរៀននេះ ។

ចំណេះចំណានខគម្ពីរ—កូរិនថូសទី ១ ១៥:៤០–៤២

សូមអញ្ជើញសិស្សពីរនាក់ឲ្យយកព្រះគម្ពីររបស់ពួកគេឡើងមកខាងមុខក្តារខៀន ។ សូមឲ្យពួកគេចាត់ទុកថា អ្នកជាអ្នករៀនម្នាក់ ហើយពួកគេគឺជាដៃគូផ្សព្វផ្សាយសាសនា ដែលកំពុងបង្រៀនអ្នកអំពីផែនការនៃសេចក្តីសង្គ្រោះ ។ សូមឲ្យពួកគេពន្យល់ថា ពួកគេបានដឹងអ្វីខ្លះអំពីសេចក្តីស្លាប់ និងការរស់ឡើងវិញ ដោយប្រើចំណេះចំណានខគម្ពីរទាំងពីរនៅក្នុង កូរិនថូសទី ១ ១៥ និងខគម្ពីរផ្សេងទៀតដែលអាចមានប្រយោជន៍ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ចែកចាយអ្វីផ្សេងទៀត ដែលពួកគេចង់ពន្យល់អំពីសេចក្តីស្លាប់ និងការរស់ឡើងវិញទៅដល់អ្នករៀនថ្មីម្នាក់ ។

សេចក្តីផ្តើមអំពី

សំបុត្រទីពីររបស់ប៉ុលដល់ពួកកូរិនថូស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រទីពីររបស់ប៉ុលដល់ពួកកូរិនថូស បង្ហាញពីបាវចនារបស់ខ្លួនស្តីពីការលួងលោមនៅកណ្តាលនៃទុក្ខព្រួយ កម្លាំងនៅកណ្តាលនៃភាពទន់ខ្សោយ (គួយ៉ាងដូចជាប៉ុលខ្លួនឯងផ្ទាល់) និងការស្គាល់គ្រូបង្រៀនពិត និងគ្រូបង្រៀនក្លែងក្លាយ ។ គំរូ និងការបង្រៀនរបស់ប៉ុលដែលបានកត់ត្រានៅក្នុងកូរិនថូទី ២ អាចបំផុសគំនិតសិស្សឲ្យបន្តមានភក្តីភាព ហើយស្មោះត្រង់ចំពោះសេចក្តីសញ្ញាដ៏នៅអស់កល្បជានិច្ច ដែលពួកគេបានធ្វើជាមួយនឹងព្រះ ជាព្រះវរបិតាដ៏អស់កល្បជានិច្ច មិនថាស្ថិតក្នុងកាល:ទេស: ឬផលវិបាកបែបណានោះទេ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុលបានសរសេរសំបុត្រទីពីរទៅពួកកូរិនថូស (សូមមើល កូរិនថូសទី ២ ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

មិនយូរប៉ុន្មានបន្ទាប់ពីប៉ុលបានសរសេរកូរិនថូសទី ១ មានកុប្បកម្មមួយកើតឡើងនៅអេភេសូទាស់នឹងការបង្រៀនរបស់លោក (សូមមើល កិច្ចការ ១៩:២៣–៤១) ហើយលោកបានចេញទៅម៉ាសេដូន (សូមមើល កិច្ចការ ២០:១, កូរិនថូសទី ២ ២:១៣, ៧:៥) ។ លោកទំនងជាសរសេរកូរិនថូសទី ២ កាលលោកស្នាក់នៅម៉ាសេដូន ប្រមាណជា គ.ស. ៥៥–៥៧(សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។

តើគម្ពីរនេះត្រូវបាននិពន្ធឡើងសម្រាប់នរណា ហើយតើហេតុអ្វី ?

គម្ពីរកូរិនថូសទី ២ ត្រូវបានសរសេរទៅសមាជិកសាសនាចក្រនៅក្រុងកូរិនថូស ។ កាលប៉ុលស្នាក់នៅម៉ាសេដូនក្នុងដំណើរបេសកកម្មលើកទីបីរបស់លោក ទីតុសបាននាំដំណឹងល្អមកប្រាប់លោកថា សំបុត្រមួយច្បាប់មុនដែលលោកបានផ្ញើទៅត្រូវបានពួកបរិសុទ្ធនៅទីនោះទទួលយ៉ាងរីករាយ (សូមមើល កូរិនថូសទី ២ ៧:៦–១៣) ។ សាខាកូរិនថូសកំពុងមានការរីកចម្រើន ប៉ុន្តែប៉ុលក៏បានដឹងថា មានពួកគ្រូបង្រៀនក្លែងក្លាយនៅទីនោះ: ដែលកំពុងតែបង្ខូចដល់គោលលទ្ធិបរិសុទ្ធរបស់ព្រះគ្រីស្ទផងដែរ ។ បន្ទាប់ពីដំណើរទស្សនកិច្ចលើកដំបូងរបស់ប៉ុលទៅក្រុងកូរិនថូស ហើយប្រហែលជាវាជាដំណើរលើកទីពីរ (កូរិនថូសទី ២ ១:១៥–១៦) កាលប៉ុលបានស្តីបន្ទោសដល់ពួកបរិសុទ្ធ (សូមមើល កូរិនថូសទី ២ ២:១, ១២:២១) ពួកគ្រូគង្វាលមកពីក្រុងយេរូសាឡិមបានមកក្រុងកូរិនថូស ហើយបានចាប់ផ្តើមបង្រៀនពួកបរិសុទ្ធថា ពួកគេត្រូវតែសម្របខ្លួនទៅនឹងទំនៀមទម្លាប់របស់សាសន៍យូដា ដែលផ្ទុយនឹងការបង្រៀនរបស់ប៉ុល ។ ភាគច្រើននៅក្នុងកូរិនថូសទី ២ លើកឡើងពីបញ្ហានានាដែលបានបង្កើតឡើងដោយពួកគ្រូបង្រៀនក្លែងក្លាយទាំងនេះ ។

សំបុត្ររបស់ប៉ុលបានមានប្រសាសន៍ពីជនដែលប្រាថ្នាចង់រៀនពីពាក្យសម្តីរបស់លោកបន្ថែមទៀត (សូមមើល កូរិនថូសទី ២ ១–៩) និងជនដែលទើសទាល់ក្នុងការទទួលយកការបង្រៀនរបស់លោក (សូមមើល កូរិនថូសទី ២ ១០–១៣) ។ ជាទូទៅ អត្ថបទនៅក្នុងកូរិនថូសទី ២ បើកសម្តែងនូវគោលបំណងមួយចំនួនអំពីសំបុត្រនេះ ៖

1. ដើម្បីបង្ហាញអំណរគុណ ហើយពង្រឹងដល់ពួកបរិសុទ្ធដែលចុលចិត្តសំបុត្ររបស់លោកកាលពីលើកមុន
2. ដើម្បីព្រមានពីគ្រូបង្រៀនក្លែងក្លាយ ដែលបានបង្ខូចដល់គោលលទ្ធិរបស់ព្រះគ្រីស្ទ
3. ដើម្បីការពារកិត្តិនាមផ្ទាល់ និងសិទ្ធិអំណាចរបស់លោកក្នុងនាមជាសាវកបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល កូរិនថូសទី ២ ១០–១៣)
4. ដើម្បីលើកទឹកចិត្តពួកបរិសុទ្ធនៅក្រុងកូរិនថូស ឲ្យថ្វាយដង្វាយជាប្រាក់ដោយចិត្តសប្បុរសទៅដល់ពួកបរិសុទ្ធនៅក្រុងយេរូសាឡិមដែលកំពុងខ្វះខាត (សូមមើល កូរិនថូសទី ២ ៨–៩)

តើនៅក្នុងគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

កាលដែលសំបុត្រជាច្រើនរបស់ប៉ុលផ្តោតលើគោលលទ្ធិ ភាគច្រើននៃសំបុត្រនេះគូសបញ្ជាក់ពីទំនាក់ទំនងរបស់ប៉ុលជាមួយពួកបរិសុទ្ធនៅកូរិនថូស ព្រមទាំងសេចក្តីស្រឡាញ់របស់លោក និងកង្វល់របស់លោកចំពោះពួកគេ ។ ប៉ុន្តែប៉ុលបានមានជំហរយ៉ាងមុតមាំជំទាស់នឹងការទិតៀននៅក្នុងកូរិនថូសទី ២ ទាំងមូល យើងមើលឃើញលោកគឺជាថ្នាក់ដឹកនាំបព្វជិតភាពមួយរូបដ៏ទន់ភ្លន់ ដែលចេះយកចិត្តទុកដាក់ពីសុភមង្គល និងសុខុមាលភាពរបស់ពួកបរិសុទ្ធ ។ ប៉ុលក៏បានចែកចាយព័ត៌មានលម្អិតមួយចំនួនអំពីជីវប្រវត្តិរបស់លោក ហើយបានសរសេរពី « បន្លាមួយចាត់មកក្នុងសាច់ឈាមខ្ញុំ » (កូរិនថូសទី ២ ១២:៧) ។

នៅក្នុងបទពិសោធន៍ដ៏ពិសិដ្ឋមួយ ដែលបានកត់ត្រានៅក្នុងកូរិនថូសទី ២ ១២:២–៤ ប៉ុលបានពិពណ៌នាខ្លួនឯងថាជា « មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទ » ដែល « បានលើកឡើងទៅស្ថានសួគ៌នៅជាន់ទីបី » ជាកន្លែងដែលលោកបានឃើញ ហើយបានស្តាប់ឮរឿងដែលមិនអាចប្រាប់បាន ។ ការនិមិត្តនេះរួមជាមួយនឹងសេចក្តីថ្លែងការណ៍ខាងគោលលទ្ធិរបស់លោក កាលពីមុនស្តីពីភាពខុសគ្នានៅក្នុងសិរីល្អនៃរូបកាយដែលបានរស់ឡើងវិញ (សូមមើល កូរិនថូសទី ១ ១៥:៣៥–៤៤) អាចត្រូវបានមើលឃើញថាមានភាពស្រដៀងគ្នាមួយក្នុងព្រះគម្ពីរបីបទៅនឹងការនិមិត្ត ដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្តីសញ្ញា ៧៦ ។

គម្រោង

កូរិនថូសទី ២ ១–៥ ប៉ុលថ្លែងទីបន្ទាល់ថា ព្រះលួងលោមកូនចៅរបស់ទ្រង់ នៅក្នុងគ្រប់ការឈឺចាប់ខ្លោចផ្សារបស់ពួកគេ ។ លោកសំណូមពរឲ្យពួកបរិសុទ្ធចេះស្រឡាញ់គ្នា ហើយអត់ទោសឲ្យគ្នាទៅវិញទៅមក ។ ជំណឹងល្អ និងកិច្ចការនៃព្រះវិញ្ញាណរបស់ព្រះអម្ចាស់មានសិរីល្អដ៏ឆាងអក្សរនៅក្នុងក្រឹត្យវិន័យរបស់ម៉ូសេទៅទៀត ។ ប៉ុលលើកទឹកចិត្តពួកអ្នកអានរបស់លោក នៅក្នុងគ្រាលំបាករបស់ពួកគេ ហើយរំឭកពួកគេពីលក្ខណៈដ៏នៅអស់កល្បជានិច្ចនៃសេចក្តីស្រឡាញ់ និងសិរីល្អរបស់ព្រះ: ។ លោកបានជួយពួកអ្នកអានឲ្យយល់ពីសេចក្តីត្រូវការរបស់ពួកគេ ដើម្បីស្រុះស្រួលនឹងព្រះតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

កូរិនថូសទី ២ ៦–១៣ ខណៈពេលកំពុងប្រឈមមុខនឹងការទិតៀន និងការជំទាស់ពីពួកគ្រូបង្រៀនក្លែងក្លាយ ប៉ុលការពារសេចក្តីស្មោះរបស់លោកក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ ហើយអញ្ជើញពួកអ្នកអានរបស់លោកឲ្យញែកខ្លួនចេញពីលោកិយ ។ លោកបង្រៀនអំពី « សេចក្តីព្រួយ » (សូមមើល កូរិនថូសទី២ ៧:១០) ។ ប៉ុលថ្លែងអំណរគុណដល់ពួកបរិសុទ្ធនៅក្រុងកូរិនថូសចំពោះការបរិច្ចាគរបស់ពួកគេដល់ជនក្រីក្រនៅក្រុងយេរូសាឡិម ហើយលើកទឹកចិត្តពួកគេឲ្យបន្តផ្តល់ឲ្យដោយចិត្តសប្បុរស ។ លោកថ្លែងយ៉ាងមុតមាំទាស់នឹង « សាវកក្លែងក្លាយ » (កូរិនថូសទី២ ១១:១៣) ។ ប៉ុលទទួលសិរីល្អនៅក្នុងព្រះអម្ចាស់ ហើយចែកចាយសេចក្តីលម្អិតខាងជីវប្រវត្តិពីសេចក្តីឈឺចាប់ និងសេចក្តីជំនឿរបស់លោកទៅលើព្រះយេស៊ូវគ្រីស្ទ ។ លោកសរសេរនូវការនិមិត្តរបស់លោកអំពីស្ថានសួគ៌ទីបី ។ ប៉ុលអញ្ជើញពួកបរិសុទ្ធឲ្យពិនិត្យមើលខ្លួនឯង ហើយបង្ហាញខ្លួនឯងថាស្មោះត្រង់ ។

មេរៀន១១៣

កូរិនថូសទី ២ ១–៣

សេចក្តីផ្តើម

ប៉ុលបានសរសេរទៅពួកបរិសុទ្ធនៅកូរិនថូស ហើយបានពន្យល់ពីរបៀបដែលពួកគេអាចលួងលោមដល់មនុស្សដទៃទៀត ។ លោកក៏បានដាស់តឿនដល់ពួកគេឲ្យអភ័យទោសដល់ពួកអ្នកមានបានដែលបានមកក្នុងក្រុមជំនុំរបស់ពួកគេផងដែរ ។ ប៉ុលបានបង្រៀនពួកបរិសុទ្ធថា ប្រសិនបើពួកគេងាកទៅរកព្រះអម្ចាស់ ពួកគេនឹងប្រែក្លាយកាន់តែដូចជាព្រះ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូស ទី២ ១

ប៉ុលបង្រៀនពួកបរិសុទ្ធនៅកូរិនថូសពីរបៀបដើម្បីលួងលោមមនុស្សដទៃទៀត

សូមឲ្យសិស្សគិតពីពេលមួយកាលមនុស្សម្នាក់ ដែលពួកគេស្គាល់ បានជួបនឹងការសោកល្បួង ឬទុក្ខវេទនាដ៏លំបាកមួយ ។

- តើអ្នកបានធ្វើអ្វីខ្លះដើម្បីជួយដល់គាត់ ?
- តើអ្នកធ្លាប់មានបំណងចង់លួងលោមមនុស្សម្នាក់ ដែលកំពុងស្ថិតនៅក្នុងការសោកល្បួងមួយ ប៉ុន្តែពុំដឹងពីរបៀបធ្វើវាដែរទេ ?

នៅពេលសិស្សសិក្សា កូរិនថូសទី ២ ១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយឲ្យពួកគេស្គាល់ពីរបៀបដើម្បីលួងលោមដល់មនុស្សដទៃនៅក្នុងការសោកល្បួង និងទុក្ខលំបាករបស់ពួកគេ ។

សូមពន្យល់ថា បន្ទាប់ពីប៉ុលបានសរសេរ កូរិនថូសទី១ មានកុបកម្មមួយបានកើតឡើងនៅអេភេសូរ ដោយឆ្លើយតបនឹងការបង្រៀនរបស់លោក ។ (សូមមើល កិច្ចការ ១៩:២៣–៤១ ។ *កំណត់ចំណាំ ៖* ស្រុកអាស៊ីគឺជាខេត្តមួយរបស់រ៉ូម ដែលជាប្រទេសតួកគីនៅបច្ចុប្បន្ននេះ) ។ ប៉ុលបានចេញពីអេភេសូរទៅម៉ាសេដូនី ជាកន្លែងដែលទីតុសបាននាំយកដំណឹងប្រាប់លោកថា សំបុត្ររបស់ប៉ុលកាលពីលើកមុនត្រូវបានពួកបរិសុទ្ធនៅកូរិនថូសបានទទួលយកដោយអំណរ ។ ប៉ុលក៏បានដឹងផងដែរថា ពួកបរិសុទ្ធកំពុងជួបនូវសេចក្តីឈឺចាប់ ហើយបានដឹងថា មានគ្រូក្លែងក្លាយមួយចំនួននៅកូរិនថូសកំពុងតែបំផ្លាញគោលលទ្ធិពិតរបស់ព្រះគ្រីស្ទ ។ ប៉ុលបានសរសេរកូរិនថូសទី ២ ដើម្បីលួងលោមដល់ពួកបរិសុទ្ធ ហើយបានលើកឡើងពីបញ្ហាដែលគ្រូក្លែងក្លាយទាំងនេះបានបង្កឡើង ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង កូរិនថូសទី២ ១:១–៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប៉ុលបានប្រាប់អ្វីខ្លះដល់ពួកបរិសុទ្ធទាក់ទងនឹងសេចក្តីឈឺចាប់របស់ពួកគេ ។

- តើប៉ុលបានប្រាប់អ្វីខ្លះដល់ពួកបរិសុទ្ធអំពីព្រះនៅក្នុង ខទី ៣ ដែលវាបានលួងលោមពួកគេនៅក្នុងសេចក្តីឈឺចាប់របស់ពួកគេនោះ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង ខទី ៤ អំពីរឿងដែលយើងអាចធ្វើ នៅពេលយើងទទួលការលួងលោមពីព្រះវរបិតាសួគ៌ ? (សិស្សគួរអាចឃើញសេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម ៖ **នៅពេលព្រះវរបិតាសួគ៌លួងលោមយើងនៅក្នុងសេចក្តីឈឺចាប់របស់យើង នោះយើងអាចជួយមនុស្សដទៃទៀតឲ្យទទួលការលួងលោមរបស់ទ្រង់**) ។
- តើការទទួលបានការលួងលោមរបស់ព្រះនៅក្នុងការសោកល្បួងមួយ បានជួយអ្នកឲ្យជួយដល់មនុស្សម្នាក់ផ្សេងទៀតឲ្យទទួលបានការលួងលោមរបស់ទ្រង់បានយ៉ាងដូចម្តេច ? (សូមពិចារណាចែកចាយបទពិសោធន៍របស់អ្នកមួយ កាលសិស្សគិតពីបទពិសោធន៍របស់ពួកគេផ្ទាល់) ។

សូមសង្ខេប កូរិនថូសទី២ ១:៦–៨ ដោយពន្យល់ថា ប៉ុលបានបង្រៀនពួកបរិសុទ្ធនៅកូរិនថូស អំពីទុក្ខទោសដល់ជីវិតដែលលោក និងពួកដៃគូរបស់លោកបានជួប កាលកំពុងប្រកាសដំណឹងល្អនៅអេភេសូរ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ១:៩–១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាអ្វីទៅបានជួយប៉ុល និងពួកដៃគូរបស់លោកនៅក្នុងការសោកល្បួងរបស់ពួកលោក ។

- តើអ្វីទៅបានជួយប៉ុល និងពួកដៃគូរបស់លោកនៅក្នុងការសោកល្បួងរបស់ពួកលោក ?
- តើអ្នកអាចរកឃើញសេចក្តីពិតអ្វីនៅក្នុង ខទី ១១ អំពីរបៀបដែលយើងអាចជួយមនុស្សដែលកំពុងជួបការសោកល្បួង ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ការអធិស្ឋានរបស់យើងអាចជួយមនុស្សដែលកំពុងជួបការសោកល្បួងបាន**) ។
- តើការអធិស្ឋានរបស់យើងអាចជួយមនុស្សម្នាក់ ដែលកំពុងជួបការសោកល្បួងបានយ៉ាងដូចម្តេច ?
- តើការអធិស្ឋានរបស់មនុស្សដទៃធ្លាប់ជួយអ្នក នៅក្នុងការសោកល្បួងរបស់អ្នកបានយ៉ាងដូចម្តេច ?

សូមសង្ខេប កូរិនថូសទី២ ១:១២–២៤ ដោយពន្យល់ថា ប៉ុលបានរីករាយចំពោះអ្នកដែលបានទទួលពាក្យទូន្មាន ដែលលោកបានផ្តល់ឲ្យនៅក្នុងសំបុត្រទីមួយរបស់លោក ។ នៅក្នុង ខទី ១៥–២០ ប៉ុលបានឆ្លើយតបទៅអ្នកដែលបានចាប់កំហុសលោក កាលលោកបានផ្លាស់ប្តូរផែនការទៅសួរសុខទុក្ខពួកគេ ។ ការរិះគន់មួយចំនួនទៅលើប៉ុលនោះទំនងដោយសារតែលោកបានផ្លាស់ប្តូរផែនការធ្វើដំណើររបស់លោក ដែលធ្វើឲ្យពួកគេមិនអាចទុកចិត្តលោក ឬលើការបង្រៀនរបស់លោកទៀតឡើយ ។ ប៉ុលបានប្រកាសថា សារលិខិតនៃដំណឹងល្អគឺពិត មិនថាលោកផ្លាស់ប្តូរផែនការរបស់លោកយ៉ាងណានោះទេ ។

កូរិនថូសទី២ ២

ប៉ុលដាស់តឿនពួកបរិសុទ្ធនៅកូរិនថូសឲ្យអភ័យទោសដល់អ្នកមានបាប

សូមអញ្ជើញសិស្សឲ្យគិតពីគ្រាមួយដែលមនុស្សម្នាក់បានធ្វើឲ្យពួកគេ ឬមនុស្សដែលពួកគេស្រឡាញ់ឈឺចាប់ ឬរវាទចិត្ត ។

- ហេតុអ្វីវាពិបាកនឹងអភ័យទោសឲ្យមនុស្សម្នាក់នោះ ?

នៅពេលសិស្សសិក្សា កូរិនថូសទី ២ ២ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលនឹងជួយពួកគេឲ្យស្គាល់ពីហេតុផលថា ការអភ័យទោសដល់មនុស្សទូទៅគឺជារឿងដ៏សំខាន់ ។

សូមរំឭកសិស្សថា នៅក្នុងសំបុត្រទីមួយរបស់ប៉ុលទៅពួកកូរិនថូស លោកបានផ្ចាញ់ផ្ចាលពួកគេដោយសារតែការមិនគោរពប្រតិបត្តិ និងការខ្វះសេចក្តីជំនឿរបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ២:១–៤ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានសង្ឃឹមឲ្យពួកបរិសុទ្ធនៅកូរិនថូសបានស្គាល់អ្វីខ្លះទាក់ទងនឹងការស្តីបន្ទោសរបស់លោក ។

- យោងតាមខទី ៤ តើប៉ុលចង់ឲ្យបរិសុទ្ធស្គាល់អ្វីខ្លះ ទាក់ទងនឹងការជំរុញឲ្យលោកស្តីបន្ទោសដល់ពួកគេ ?
- តើការផ្ចាញ់ផ្ចាល ឬការកែតម្រូវអាចជាភស្តុតាងនៃការស្រឡាញ់របស់មនុស្សម្នាក់ចំពោះយើងបានយ៉ាងដូចម្តេច ?

សូមសង្ខេប កូរិនថូសទី ២ ២:៥–៦ ដោយពន្យល់ថា ប៉ុលបានសរសេរអំពីសមាជិកសាសនាចក្រម្នាក់ដែលមានបាបទាស់នឹងសមាជិកសាសនាចក្រផ្សេងទៀត ហើយរឿងនេះបានបណ្តាលឲ្យពួកគេមានទុក្ខព្រួយ ។ ជាលទ្ធផល សាសនាចក្របានដាក់វិន័យចំពោះបុរសម្នាក់នេះ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ២:៧–៨ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយអ្វីខ្លះអំពីរបៀបដែលពួកបរិសុទ្ធគួរប្រព្រឹត្តចំពោះបុរសម្នាក់នេះ ។

- តើពួកបរិសុទ្ធគួរប្រព្រឹត្តបែបណាទៅ ចំពោះបុរសដែលបានធ្វើឲ្យមានទុក្ខព្រួយយ៉ាងខ្លាំងនោះ ?

សូមពន្យល់ថា ទោះបីជាបុរសនេះមានបាបក្តី ក៏តម្លៃនៃព្រលឹងរបស់គាត់នៅតែអស្ចារ្យចំពោះព្រះនេត្រនៃព្រះដែរ (សូមមើល គ. និង ស. ១៨:១០) ។ ប៉ុលបានដាស់តឿនពួកបរិសុទ្ធឲ្យអត់ទោស លួងលោម ហើយស្រឡាញ់បុរសនេះដើម្បីជួយគាត់ឲ្យប្រែចិត្ត ។

សូមអញ្ជើញសិស្សឲ្យអាន កូរិនថូសទី២ ២:៩–១១ ដោយស្ងៀមស្ងាត់រកមើលហេតុផលដែលប៉ុលបាននិយាយថា ពួកបរិសុទ្ធគួរតែអភ័យទោសដល់មនុស្សដទៃ ។

- យោងតាមអ្វីដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធនៅក្នុង ខទី ១១ តើអ្វីទៅជាហេតុផលមួយទៀតដែលយើងគួរអភ័យទោសដល់មនុស្សដទៃ ? (ដោយប្រើពាក្យផ្ទាល់ខ្លួន សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **ប្រសិនបើយើងមិនអភ័យទោសដល់មនុស្សដទៃទេនោះ សាតាំងនឹងមានអំណាចមកលើយើង ។** អ្នកគួរឲ្យយោបល់សិស្សគូសចំណាំសេចក្តីពិតនេះនៅក្នុងខទី ១១) ។

ជួយសិស្សឲ្យអភិវឌ្ឍការយល់ដឹងអំពីគោលការណ៍នេះ

សិស្សត្រូវយល់ដឹងពីគោលលទ្ធិ ឬគោលការណ៍មួយពីមុនពួកគេអាចអនុវត្តវាបាន ។ អ្នកអាចជួយសិស្សឲ្យយល់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដោយសួរសំណួរដែលនាំទៅរកការយល់ដឹងច្បាស់លាស់មួយអំពីអត្ថន័យនៃគោលការណ៍ ឬគោលលទ្ធិជាក់លាក់មួយ ដែលលើកទឹកចិត្តសិស្សឲ្យគិតអំពីគោលការណ៍មួយនៅក្នុងបរិបទ សម័យទំនើប ឬដែលអញ្ជើញសិស្សឲ្យពន្យល់អំពីការយល់ដឹងរបស់ពួកគេអំពីគោលការណ៍មួយ ។

សូមសង្កត់ធ្ងន់បង្ហាញថា ការអភ័យទោសដល់មនុស្សដទៃពុំមែនមានន័យថា អ្នកមានបាបនោះមិនទទួលខុសត្រូវចំពោះទង្វើខ្លួននោះទេ ។ ហើយវាក៏ពុំមែនមានន័យថា យើងបន្តទ្រាំឲ្យមនុស្សធ្វើខុសចំពោះយើងដែរ ។ ផ្ទុយទៅវិញ ការអភ័យទោសដល់មនុស្សដទៃមានន័យថា ការប្រព្រឹត្តចំពោះមនុស្សដែលធ្វើខុសចំពោះយើងដោយសេចក្តីស្រឡាញ់ ហើយដោយមិនទុកការអាក់អន់ចិត្ត ឬកំហឹងក្នុងចិត្តរបស់ពួកគេឡើយ ។ យើងបានបង្គាប់ឲ្យអភ័យទោសដល់មនុស្សទាំងអស់ ។ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « អត់ទោស » scriptures.lds.org, គ. និង ស. ៦៤:៩–១១) ។

- តើអ្នកគិតថា សាតាំងមានអំណាចមកលើយើងបានដោយរបៀបណា នៅពេលយើងមិនអភ័យទោសដល់មនុស្សដទៃនោះ ?

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការអភ័យទោសដល់មនុស្សដទៃ ។ ចូរសុំឲ្យសិស្សគិតពីមនុស្សម្នាក់ដែលពួកគេត្រូវអភ័យទោសឲ្យ ។ សូមអញ្ជើញពួកគេឲ្យដាក់គោលដៅមួយដើម្បីអភ័យទោសដល់បុគ្គលម្នាក់នោះ ដើម្បីកុំឲ្យសាតាំងមានអំណាចមកលើពួកគេបាន ។

សូមពន្យល់ថា យើងអាននៅក្នុង កូរិនថូសទី២ ២:១៤ ថា ប៉ុលបានសរសេរថ្លែងអំណរគុណដល់ព្រះ ជាអង្គដែលតែងតែ « នាំ [លោក] ឲ្យមានជ័យជំនះក្នុងព្រះគ្រីស្ទ » ទោះជានៅក្នុងគ្រាដ៏លំបាកក្តី ។

កូរិនថូសទី២ ៣

ប៉ុលបានបង្រៀនពួកបរិសុទ្ធថា ប្រសិនបើពួកគេងាកទៅរកព្រះអម្ចាស់ នោះពួកគេនឹងប្រែក្លាយកាន់តែដូចជាព្រះ

សូមពន្យល់ថា កាលប៉ុលបានចាកចេញពីកូរិនថូស នោះមានពួកគ្រូក្លែងក្លាយមួយចំនួនបានចាប់ផ្តើមបដិសេធនូវការបង្រៀនរបស់ប៉ុល ហើយបានព្យាយាមមូលបង្កាច់ប៉ុល ដោយប្រាប់ពួកអ្នកប្រែចិត្តជឿថា ពួកគេនៅតែត្រូវធ្វើតាមក្រឹត្យវិន័យរបស់ម៉ូសេដដែល ។ សូមសង្ខេប កូរិនថូសទី២ ៣:១ ដោយពន្យល់ថា ជាការឆ្លើយតបចំពោះអ្នកដែលព្យាយាមមូលបង្កាច់រូបលោក ប៉ុលបានសួរទៅសមាជិកនៅ

កូរិនថូសដោយប្រើសំណួរត្រិះរិះថា ត្រូវឲ្យលោកផ្តល់ដល់ពួកគេនូវ « សំបុត្រផ្ទុកផ្តាក់ » មួយដែលជាភស្តុតាងពីបុគ្គលិកលក្ខណៈ និងភាពស្របច្បាប់របស់លោកក្នុងនាមជាសាវកពិតម្នាក់របស់ព្រះយេស៊ូវគ្រីស្ទមែនទេ ។ (សូមពន្យល់ថា នៅក្នុងសម័យរបស់ប៉ុល ពួកអ្នកមកថ្មីនៅក្នុងសហគមន៍មួយត្រូវមានសំបុត្រផ្ទុកផ្តាក់ជាមួយនឹងពួកគេ ។ សំបុត្រទាំងនេះឧទ្ទេសនាមពីអ្នកមកថ្មី ហើយបានបញ្ជាក់ពីបុគ្គលិកលក្ខណៈដ៏ល្អរបស់ពួកគេ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កូរិនថូសទី២ ៣:២–៣ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ប៉ុលបាននិយាយអ្វីខ្លះក្នុងសំបុត្រផ្ទុកផ្តាក់របស់លោក ។

- តើអ្វីទៅដែលបានដើរតួជាសំបុត្រផ្ទុកផ្តាក់របស់ប៉ុល ? (ជីវិតផ្លាស់ប្តូររបស់ពួកបរិសុទ្ធប្រៀបបាននឹងសំបុត្រមួយមកពីព្រះគ្រីស្ទផ្ទាល់) ។
- តើឃ្លាថា « មនុស្សទាំងអស់ក៏ដឹង ហើយអានមើលដែរ » នៅក្នុងខទី ២មានន័យដូចម្តេច ? (ដំបូងមនុស្សជាច្រើននឹងបានស្គាល់សាសនាចក្រ ហើយវិនិច្ឆ័យពីភាពពេញលេញនៃសេចក្តីពិតរបស់វា តាមរយៈការប្រព្រឹត្តផ្ទាល់ខ្លួន និងគំរូរបស់សមាជិកសាសនាចក្រទាំងឡាយ) ។

សូមចង្អុលបង្ហាញទៅឃ្លា « មិនមែនលើបន្ទះថ្មដែរ គឺក្នុងចិត្តខាងសាច់ឈាមវិញ » នៅក្នុង ខទី ៣ ហើយពន្យល់ថា នៅក្នុងសម័យរបស់ម៉ូសេ ព្រះបញ្ញត្តិទាំងឡាយត្រូវបានចារនៅលើបន្ទះថ្ម ។ ប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធនៅកូរិនថូសថា តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះបញ្ញត្តិបានចារនៅក្នុងដួងចិត្តរបស់ពួកគេ ។

សូមសង្ខេប កូរិនថូសទី ២ ៣:៥–១៣ ដោយពន្យល់ថា ប៉ុលបានចោទសួរថា ប្រសិនបើក្រឹត្យវិន័យចាស់របស់ម៉ូសេបានបញ្ចប់ទៅជាមួយនឹងភាពរុងរឿងរបស់វា នោះភាពរុងរឿងនៃសេចក្តីសញ្ញាក្នុងដំណឹងល្អដ៏នៅអស់កល្បគឺលើសពីនោះទៅទៀត ។ ប៉ុលបានរំឭកពួកបរិសុទ្ធនៅកូរិនថូសថា ម៉ូសេបានយកស្បៃមកបាំងមុខរបស់លោកកាលចុះមកពីសន្ទនានឹងព្រះអម្ចាស់នៅលើភ្នំស៊ីណាយវិញ ដោយសារកូនចៅអ៊ីស្រាអែលខ្លាចសិរីល្អដែលនៅលើមុខរបស់លោក ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ៣:១៤–១៥ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រៀបធៀបពួកអ៊ីស្រាអែលដែលខ្លាចដល់សិរីល្អដែលមាននៅលើមុខរបស់ម៉ូសេទៅនឹងពួកសាសន៍យូដានៅសម័យលោកតាមរបៀបណា ។

- តើប៉ុលបានប្រៀបធៀបពួកអ៊ីស្រាអែល ដែលបានបង្គាប់ឲ្យម៉ូសេយកស្បៃបាំងមុខរបស់លោកនោះ ទៅនឹងពួកសាសន៍យូដានៅសម័យរបស់លោកតាមរបៀបណា ?
- តើឃ្លាថា « ចិត្តគេបានរឹងទទឹង » នៅក្នុង ខទី ១៤ និង « [ពួកគេមាន] ស្បៃ. . . បាំងចិត្តគេ » ខទី ១៥ មានន័យដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៣:១៦–១៨ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា អ្វីទៅដែលប៉ុលបានសន្យា ថាវានឹងដកយកស្បៃនៃការយល់ខុសចេញពីដួងចិត្ត និងគំនិតរបស់ប្រជាជននោះ ។ សូមចង្អុលបង្ហាញថា ការបកប្រែដោយយ៉ូសែប ស៊្មីធ បានកែឃ្លា « កាលគេបានងាកបែរមកឯព្រះអម្ចាស់វិញ » នៅក្នុងខទី ១៦ទៅជា « កាលដួងចិត្តបានងាកបែរមកឯព្រះអម្ចាស់វិញ » (ការបកប្រែដោយ យ៉ូសែប ស៊្មីធ កូរិនថូសទី២ ៣:១៦) ។

- យោងតាមការបកប្រែដោយ យ៉ូសែប ស៊្មីធសម្រាប់ កូរិនថូសទី២ ៣:១៦ តើមនុស្សត្រូវធ្វើអ្វីខ្លះដើម្បីដកយកស្បៃនៃការយល់ខុសចេញ ?

សូមសរសេរនៅលើក្តារខៀន ៖ *នៅពេលយើងបែរដួងចិត្តយើងងាកមករកព្រះអម្ចាស់* . . .

- យោងតាម ខទី ១៨ តើមានអ្វីកើតឡើងចំពោះអស់អ្នកដែលបែរមករកព្រះអម្ចាស់ ហើយដោះស្បៃនៃការយល់ខុសនោះចេញ ? (សូមពន្យល់ថា ឃ្លា « ផ្លាស់ប្រែទៅ ឲ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ » សំដៅទៅលើការផ្លាស់ប្រែជាបន្តបន្ទាប់ដែលយើងទទួលបានតាមរយៈព្រះវិញ្ញាណដែលជួយយើងឲ្យប្រែក្លាយកាន់តែដូចជាព្រះ) ។

សូមបំពេញឃ្លានៅលើក្តារខៀន ដើម្បីឲ្យវាបានអានថា « **នៅពេលយើងបែរដួងចិត្តយើងងាកមករកព្រះអម្ចាស់ នោះយើងនឹងមានព្រះវិញ្ញាណដែលនឹងជួយយើងជាបន្តបន្ទាប់ឲ្យប្រែក្លាយកាន់តែដូចជាព្រះ** » ។

- តើអ្នកគិតថា ការបង្វែរចិត្តរបស់យើងទៅរកព្រះយេស៊ូវគ្រីស្ទមានន័យដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យចំណាយពេលមួយនាទី ដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវវិធីដែលមនុស្សអាចបង្វែរដួងចិត្តរបស់ពួកគេទៅរកព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបញ្ជីរបស់ពួកគេជាមួយនឹងសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា ព្រះវិញ្ញាណបានកែប្រែពួកគេ ឬមនុស្សម្នាក់ដែលពួកគេស្គាល់តាមរបៀបណា ។ សូមឲ្យសិស្សពីរបីនាក់ឲ្យចែកចាយនូវបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យគិតថា ពួកគេអាចធ្វើអ្វីខ្លះ ដើម្បីងាកទៅរកព្រះអម្ចាស់កាន់តែប្រសើរ ។ ចូរសុំឲ្យពួកគេដាក់គោលដៅមួយដើម្បីងាកទៅរកព្រះអម្ចាស់ ដើម្បីឲ្យពួកគេអាចទទួលបានព្រះវិញ្ញាណ ហើយប្រែក្លាយកាន់តែដូចជាព្រះ ។

កូរិនថូសទី២ ៤–៥

សេចក្តីផ្តើម

នៅក្នុងសំបុត្ររបស់លោកដល់ពួកបរិសុទ្ធនៅកូរិនថូស ប៉ុលបានបង្រៀនថា ការសោកល្បង និងការរងទុក្ខក្នុងជីវិតនេះគឺជារឿងបណ្តោះអាសន្នទេ ហើយវាតូចបំផុតបើប្រៀបទៅនឹងពរជ័យនៃភាពអស់កល្បជានិច្ច ។ លោកក៏បានបង្រៀនដល់ពួកបរិសុទ្ធផងដែរអំពីការកាត់សេចក្តី ហើយបានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទអាចធ្វើឲ្យយើងបានផ្សះផ្សារនឹងព្រះវិញបាន ។

សម្ភារ និង រូបភាពផ្សេងៗ

ជាញឹកញាប់ វាគឺជារឿងពិបាកដើម្បីបង្រៀនអំពីលក្ខណៈអរូបិយនៃដំណឹងល្អ ។ ការប្រើប្រាស់វត្ថុ និងរូបភាពអាចជាវិធីមួយដែលមានប្រសិទ្ធភាពដើម្បីជួយសិស្សឲ្យយល់គោលការណ៍ខាងវិញ្ញាណ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី២ ៤

ប៉ុលថ្លែងទីបន្ទាល់ថា ទោះជាលោកមានសេចក្តីវេទនាក្តី ក៏លោកមិនខ្លាច ឬព្រួយចិត្តឡើយ


សូមដាក់បង្ហាញ រូបភាពទី១ ។

- តើរូបភាពនេះបង្ហាញពីអ្វី ?
- តើអ្វីទៅដែលជំរុញឲ្យមនុស្សម្នាក់នេះគិតពីបុគ្គលដែលកំពុងរុញគាត់ ?

សូមដាក់បង្ហាញ រូបភាពទី ២ ។

- តើការមើលឃើញនូវរូបភាពទីមួយនៅក្នុងបរិបទមួយដ៏ធំ បានផ្លាស់ប្តូរការកាត់សេចក្តីរបស់អ្នកទៅលើអ្វីដែលវាបង្ហាញបានយ៉ាងដូចម្តេច ?





សូមពន្យល់ថា ប៉ុលបានសរសេរទៅកាន់ពួកបរិសុទ្ធនៅកូរិនថូសឲ្យជួយគ្នាមើលឃើញបរិបទដ៏ធំនៃសេចក្តីវេទនារបស់ពួកគេ ។ នៅពេលសិស្សសិក្សាកូរិនថូស ទី២ ៤សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធ ស្តីពីសេចក្តីវេទនារបស់ពួកគេ ។

សូមសង្ខេប កូរិនថូសទី២ ៤:១–៧ ដោយពន្យល់ថាប៉ុលបានអះអាងដល់ពួកបរិសុទ្ធថា លោកបានប្រកាសដំណឹងល្អដល់ពួកគេដោយសេចក្តីពិតពេញលេញ ។ លោកបានបង្រៀនថា សាតាំងដែលជា « ព្រះរបស់លោកិយ » (ខទី ៤) ខិតខំធ្វើការដើម្បីរារាំងមនុស្សមិនឲ្យទទួលយកដំណឹងល្អ ។ ប៉ុលបានប្រៀបធៀបខ្លួនលោក និងពួកអ្នកបម្រើផ្សេងទៀត ទៅនឹងថូដីដែលមាននូវ « ទ្រព្យសម្បត្តិ » នៃ « រស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ »(ខទី៦–៧) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៤:៨–៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាប៉ុលបានពិពណ៌នាពីឧបសគ្គនៃការងាររបស់លោកក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាយ៉ាងដូចម្តេច ។

- តើប៉ុលបានពិពណ៌នាពីឧបសគ្គនៃការងាររបស់លោកក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាយ៉ាងដូចម្តេច ?
- តើប៉ុលបានប្រើឃ្លាអ្វីខ្លះ ដើម្បីពិពណ៌នាពីរបៀបដែលលោកបានអនុវត្តតបនឹងឧបសគ្គទាំងនេះ ?
- ហេតុអ្វីអ្នកគិតថា ប៉ុលអាចនៅតែក្សាតវិយោបថវិជ្ជមានកាលលោកបានជួបនឹងឧបសគ្គទាំងនេះ ?

សូមសង្ខេប កូរិនថូសទី២ ៤:១១–១៤ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា ទោះបីជាមនុស្សខ្លះនឹងស្លាប់ដោយសារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទក្តី ក៏សេចក្តីស្លាប់របស់ពួកគេគ្រាន់តែជារឿងបណ្តោះអាសន្នប៉ុណ្ណោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៤:១៤–១៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានដឹងអ្វីខ្លះដែលបានជួយលោកឲ្យប្រឈមនឹងការសោកល្បង និងការបៀតបៀននោះ ។

- តើប៉ុលបានដឹងអ្វីខ្លះ ដែលវាបានជួយលោកឲ្យប្រឈមនឹងការសោកល្បង និងការបៀតបៀន ?
- តើឃ្លាថា « ទោះបើមនុស្សខាងក្រៅរបស់យើងខ្ញុំ កំពុងតែពុករលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែប្រែជាថ្មីឡើងរាល់ថ្ងៃជានិច្ចវិញ » (ខទី១៦) មានន័យដូចម្តេច ? (ទោះបីជាប៉ុល និងពួកដៃគូរបស់លោកនឹងស្លាប់ខាងរូបកាយក៏ពិតមែន ប៉ុន្តែវិញ្ញាណពួកលោកត្រូវបានពង្រឹងជារៀងរាល់ថ្ងៃ) ។

សូមចែកសិស្សជាគូ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអាន កូរិនថូសទី២ ៤:១៧–១៨ ឮៗរួមគ្នា រកមើលសេចក្តីពិតដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធអំពីការសោកល្បង និងការរងទុក្ខ ។ សូមឲ្យដៃគូនីមួយៗធ្វើការរួមគ្នាឆ្លើយនឹងសំណួរខាងក្រោមនេះ៖ នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ អ្នកអាចផ្តល់សំណួរនៅលើឯកសារចែកចាយ ឬ សរសេរវាដាក់លើក្តារខៀន៖

កូរិនថូសទី២ ៤:១៧–១៨

១. តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះអំពីការសាកល្បង និងការរងទុក្ខ ?

២. ហេតុអ្វីវាជារឿងសំខាន់ដើម្បីមើលឃើញការរងទុក្ខរបស់យើងនៅក្នុងបរិបទដ៏ធំនៃផែនការរបស់ព្រះវរបិតាសួគ៌ ?

៣. តើអ្នកធ្លាប់ឃើញមនុស្សម្នាក់បន្តមានជំហររឹងមាំនៅក្នុងការសាកល្បង ដោយសារពួកគេបានឃើញការរងទុក្ខរបស់ខ្លួន នៅក្នុងបរិបទដ៏ធំនៃផែនការរបស់ព្រះវរបិតាសួគ៌នៅពេលណាដែរ ?

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ ចូរសុំឲ្យសិស្សបីបួននាក់សរសេរចម្លើយរបស់ពួកគេចំពោះសំណួរទីមួយនៅលើក្តារខៀន ។ សិស្សអាចសរសេរសេចក្តីពិតមួយចំនួន រួមមានដូចខាងក្រោម ៖ **ការសាកល្បង និងការរងទុក្ខរបស់យើងនៅក្នុងជីវិតនេះ គឺមានភាពតូចតាចណាស់បើប្រៀបធៀបទៅនឹងពរជ័យ និងការកែចម្រើនដ៏អស់កល្ប ដែលអាចកើតមាននៅពេលយើងស៊ូទ្រាំវាដោយស្មោះត្រង់ ។ ដោយសារការរងទុក្ខបណ្តោះអាសន្ន អាចនាំមកនូវការកែចម្រើន និងសិរីល្អដ៏នៅអស់កល្បជានិច្ច នោះយើងមិនត្រូវអស់សង្ឃឹមនៅក្នុងគ្រាមានឧបសគ្គឡើយ ។ នៅក្នុងការរងទុក្ខរបស់យើង វាមាននូវគោលបំណងដ៏នៅអស់កល្ប សូម្បីតែនៅពេលយើងមិនអាចមើលឃើញវានៅក្នុងជីវិតរមែងស្លាប់នេះក្តី ។**

សូមឲ្យសិស្សបីបួននាក់ប្រាប់ចម្លើយរបស់ពួកគេចំពោះសំណួរទីពីរ ។ បន្ទាប់ពីពួកគេប្រាប់ពីចម្លើយរួច សូមពិចារណាសួរជាសំណួរតាមដានដូចខាងក្រោមនេះ ៖

- តើការសាកល្បង និងការរងទុក្ខរបស់យើងអាចនាំឲ្យមានការកែចម្រើនបានយ៉ាងដូចម្តេច ?
- តើការចងចាំពីសេចក្តីពិតទាំងនេះអាចជួយយើងឲ្យស៊ូទ្រាំនឹងការសាកល្បង និងការរងទុក្ខទាំងឡាយដោយស្មោះត្រង់តាមរបៀបណា ?

សូមឲ្យសិស្សបីបួននាក់ចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរទីបី ។ សូមពិចារណាចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយរបស់អ្នក ។

កូរិនថូសទី២ ៥

ប៉ុលបង្រៀនពួកបរិសុទ្ធអំពីការកាត់សេចក្តី និងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

សូមចែកក្រដាសមួយសន្លឹកដល់សិស្ស ។ ចូរសុំឲ្យសិស្សម្នាក់ៗបត់ក្រដាសនោះជាពីរ ហើយសរសេរឈ្មោះរបស់ខ្លួននៅផ្នែកម្ខាងនៃក្រដាសនោះ ហើយសរសេរពាក្យ*ព្រះវរបិតាសួគ៌*នៅម្ខាងទៀត ។ សូមពន្យល់ថា នៅពេលយើងចុះមកផែនដី យើងបានចាកចេញពីវត្តមានរបស់ព្រះវរបិតាសួគ៌ ។ សូមអញ្ជើញសិស្សឲ្យហែកក្រដាសខ្លួនចំកណ្តាលជាពីរផ្នែក ហើយដាក់ក្រដាសទាំងពីរនោះឲ្យដាច់ពីគ្នា ។

- តើក្រដាសដែលបានហែកនោះអាចតំណាងឲ្យអ្វីដែលបានកើតឡើង នៅពេលយើងបានចាកចេញពីវត្តមានរបស់ព្រះវរបិតាសួគ៌ ហើយចុះមកផែនដីដើម្បីដកពិសោធន៍នូវជីវិតរមែងស្លាប់យ៉ាងដូចម្តេច ?

នៅពេលសិស្សសិក្សា កូរិនថូសទី២ ៥ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលនឹងជួយពួកគេឲ្យយល់ដឹងថា ពួកគេត្រូវធ្វើអ្វីខ្លះដើម្បីត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌វិញ ។

សូមសង្កេប កូរិនថូសទី២ ៥:១–៦ ដោយពន្យល់ថា ប៉ុលបានទទួលស្គាល់ថា ទោះជានៅក្នុងជីវិតរមែងស្លាប់នេះ យើងបានបែកចេញឆ្ងាយពីព្រះ ហើយនឹងត្រូវស្លាប់ក៏ពិតមែនក្តី ប៉ុន្តែយើងនឹងបានរស់ឡើងវិញម្តងទៀត ។

សូមអញ្ជើញសិស្សអាន កូរិនថូសទី២ ៥:៦–៧ ដោយស្ងៀមស្ងាត់ រកមើលថា ប៉ុលបានបង្រៀនពួកបរិសុទ្ធគួរធ្វើអ្វីខ្លះ ដោយដឹងថាពួកគេបានបែកចេញពីព្រះនៅក្នុងជីវិតរមែងស្លាប់ ។

- តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះទាក់ទងនឹងរឿងដែលយើងបែកចេញពីព្រះនៅក្នុងជីវិតរមែងស្លាប់នេះ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់ពីសេចក្តីពិតដូចខាងក្រោម ៖ **ដោយសារយើងបែកចេញពីព្រះនៅក្នុងជីវិតរមែងស្លាប់នោះ យើងត្រូវដើរដោយសេចក្តីជំនឿ ពុំមែនដោយការមើលឃើញនោះទេ ។** សូមអញ្ជើញសិស្សម្នាក់ៗឲ្យសរសេរសេចក្តីពិតនេះនៅលើក្រដាសដែលមានឈ្មោះរបស់គាត់) ។
- តើការ « ដើរដោយជំនឿ មិនមែនដោយមើលឃើញ » មានន័យដូចម្តេច ? (ខទី ៧) ។
- តើឧទាហរណ៍នៃស្ថានភាព ឬការសម្រេចចិត្តមួយចំនួន ដែលអ្នកអាចជួបនោះមានអ្វីខ្លះ ដែលតម្រូវឲ្យអ្នកត្រូវដើរដោយជំនឿ មិនមែនដោយមើលឃើញនោះទេ ? (សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ ចម្លើយរបស់ពួកគេអាចរួមបញ្ចូលនូវបទដ្ឋានរបស់សាសនាចក្រដូចជា ការសម្រេចចិត្តចេញបម្រើបេសកកម្ម ឬការចែកចាយទីបន្ទាល់របស់ពួកគេ) ។

សូមអញ្ជើញសិស្សឲ្យគិតពីគ្រាមួយដែលពួកគេ (ឬមនុស្សម្នាក់ដែលពួកគេស្គាល់) បានដើរដោយជំនឿ មិនមែនដោយមើលឃើញ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីស្ថានភាព ឬការសម្រេចចិត្តមួយដែលពួកគេកំពុងជួបនៅពេលបច្ចុប្បន្ន ដែលធ្វើឲ្យពួកគេមានការលំបាកក្នុងការដើរដោយសេចក្តីជំនឿ ។ សូមលើកទឹកចិត្តពួកគេឲ្យដើរដោយសេចក្តីជំនឿនៅក្នុងស្ថានភាពនោះ និងនៅគ្រប់ស្ថានភាពទាំងអស់ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៥:៨–១០ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបាននិយាយថាយើងគួរធ្វើអ្វីខ្លះ៖ កាលយើងបានឃ្លាតឆ្ងាយពីព្រះនៅក្នុងជីវិតរមែងស្លាប់នេះ ។

- យោងតាម ខទី ៩ តើប៉ុលបាននិយាយថាយើងគួរធ្វើអ្វីខ្លះ៖ កាលយើងបានឃ្លាតឆ្ងាយពីព្រះនៅក្នុងជីវិតរមែងស្លាប់នេះ ?
- ដោយផ្អែកលើការបង្រៀនរបស់ប៉ុលដែលបានកត់ត្រានៅក្នុង ខទី ១០ តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះទាក់ទងនឹងហេតុផល ដែលយើងគួរធ្វើកិច្ចការល្អនៅក្នុងជីវិតនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **ព្រះយេស៊ូវគ្រីស្ទនឹងកាត់សេចក្តីយើងម្នាក់ៗ ស្របតាមអ្វីដែលយើងបានធ្វើនៅក្នុងជីវិតរមែងស្លាប់ ។** សូមអញ្ជើញសិស្សឲ្យពិចារណាគូសចំណាំឃ្លានៅក្នុង ខទី ១០ ដែលបង្រៀនពីសេចក្តីពិតនេះ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាការផ្លាស់ប្តូរនានា ដែលពួកគេត្រូវធ្វើដើម្បីត្រៀមខ្លួនសម្រាប់គ្រាដែលពួកគេនឹងទទួលការកាត់សេចក្តីពីព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើតាមការបំផុសគំនិតទាំងឡាយ ដែលពួកគេអាចនឹងទទួល ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៥:១៥–១៦ឲ្យឮៗ ។ ចូរសុំឲ្យសិស្សម្នាក់នេះអានឲ្យឮៗនៅក្នុងការបកប្រែដោយ យ៉ូសែប ស្ម៊ីធ កូរិនថូសទី២ ៥:១៦ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះសម្រាប់យើងដើម្បីឲ្យយើងអាចត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌វិញ ។

- យោងតាម ខទី ១៥ តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះសម្រាប់យើង ដើម្បីឲ្យយើងអាចត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌វិញបាន ?
- យោងតាម ខទី ១៥–១៦ តើពួកអ្នកជឿធ្វើអ្វីខ្លះដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ? (ពួកអ្នកជឿរស់នៅក្នុងជីវិតដែលផ្តោតលើព្រះគ្រីស្ទ ហើយមិនដើរតាមផ្លូវនៃលោកិយ ឬធ្វើតាមខាងសាច់ឈាមឡើយ ។ សូមអញ្ជើញសិស្សម្នាក់ៗឲ្យសរសេរឃ្លានេះនៅលើក្រដាសដែលមានឈ្មោះរបស់គាត់) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៥:១៧–១៩ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយពួកបរិសុទ្ធឲ្យត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌វិញបានយ៉ាងដូចម្តេច ។

- តើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយពួកបរិសុទ្ធឲ្យត្រឡប់ទៅកាន់វត្តមានរបស់ព្រះវរបិតាសួគ៌វិញបានយ៉ាងដូចម្តេច ? (បន្ទាប់ពីសិស្សឆ្លើយរួច សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចប្រែក្លាយជាមនុស្សថ្មី ហើយបានផ្សះផ្សានឹងព្រះ ។** សូមអញ្ជើញសិស្សម្នាក់ៗឲ្យសរសេរសេចក្តីពិតនេះនៅលើក្រដាសដែលមានពាក្យ « ព្រះវរបិតាសួគ៌ ») នៅលើនោះ ។
- តើអ្នកគិតថាឃ្លា « កើតជាថ្មី » មានន័យដូចម្តេច ? (ខទី១៧) ។

សូមអញ្ជើញសិស្សឲ្យអាន ម៉ូសាយ ២៧:២៣–២៦ រកមើលព័ត៌មានលម្អិតបន្ថែមទៀតដោយស្ងៀមស្ងាត់ អំពីអត្ថន័យនៃឃ្លាកើតជាថ្មី ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវការពន្យល់របស់លោកទាក់ទងនឹងរបៀបដែលយើងអាចកើតជាថ្មីបាន ។



« លក្ខណៈសំខាន់នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ តម្រូវឲ្យមានការផ្លាស់ប្តូរជាមូលដ្ឋាន និងជាអចិន្ត្រៃក្នុងចរិតធម្មជាតិរបស់យើង ដែលការផ្លាស់ប្តូរនេះអាចកើតឡើងតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ការប្រែចិត្តជឿពិតនាំឲ្យមានការផ្លាស់ប្តូរនៅក្នុងការជឿ ក្នុងដួងចិត្ត និងក្នុងជីវិតមនុស្សម្នាក់ឲ្យទទួលយក និងគោរពតាមព្រះហឫទ័យរបស់ព្រះ (សូមមើល កិច្ចការ ៣:១៩,នីហ្វៃទី ៣ ៩:២០) ហើយរួមទាំងមនសិការ ក្នុងការធ្វើជាសិស្សរបស់ព្រះគ្រីស្ទ ។

« . . . ពេលយើងគោរពដល់ពិធីបរិសុទ្ធ និង សេចក្តីសញ្ញានៃសេចក្តីសង្គ្រោះ និង ភាពលើកតម្កើង (សូមមើល គ. និង ស. ២០:២៥) ‹ ឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ › (នីហ្វៃទី ២ ៣១:២០) និង ស៊ូទ្រាំក្នុងជំនឿដល់ទីបញ្ចប់ (សូមមើល គ. និង ស. ១៤:៧) នោះយើងបានកើតជាថ្មីក្នុងព្រះគ្រីស្ទ (សូមមើល កូរិនថូសទី២ ៥:១៧) » (« Converted unto the Lord » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១០៧) ។

សូមឲ្យសិស្សម្នាក់ដាក់ក្រដាសទាំងពីរនោះចូលគ្នាវិញ ។ សូមពន្យល់ថា ការផ្សះផ្សាគឺជាការនាំភាគីទាំងពីរដែលបែកចេញពីគ្នាកាលពីមុនឲ្យមកជួបគ្នាវិញ ។ ដោយសារការផ្លាក់របស់លោកអ័ដាម ក៏ដូចជាអំពើបាបផ្ទាល់របស់យើងដែរ យើងបានបែកចេញខាងវិញ្ញាណពីព្រះវរបិតាសួគ៌របស់យើង ។ ព្រះយេស៊ូវគ្រីស្ទបានផ្សះផ្សាយើងជាមួយនឹងព្រះវរបិតាតាមរយៈដង្វាយធួនរបស់ទ្រង់ ហើយបានស្តារទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់ឡើងវិញ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៥:២០–២១ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលថា ប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ។

- តើប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ?
- តើប៉ុលបានបង្រៀនអ្វីខ្លះទាក់ទងនឹងព្រះយេស៊ូវគ្រីស្ទ ដូចដែលកត់ត្រានៅក្នុងខទី ២១ ? (ទោះបីជាព្រះយេស៊ូវគ្រីស្ទគ្មានអំពើបាបក្តី ក៏ទ្រង់បានរងទុក្ខសម្រាប់អំពើបាបរបស់យើងដែរ ដើម្បីធ្វើឲ្យយើងបានសុចរិត) ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលសិស្សបានស្គាល់នៅក្នុងមេរៀននេះ ។ ចូរសុំឲ្យសិស្សមើលបញ្ជីសេចក្តីពិតដែលពួកគេបានកត់ទុកឡើងវិញ ហើយពិចារណាថាពួកគេត្រូវធ្វើអ្វីខ្លះដើម្បីប្រែក្លាយ ឬបន្តបានផ្សះផ្សានឹងព្រះ ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើតាមការបំផុសគំនិតទាំងឡាយ ដែលពួកគេអាចនឹងទទួល ។

មេរៀន ១១៥

កូរិនថូស ទី២ ៦–៧

សេចក្តីផ្តើម

ប៉ុលបានបន្តនិយាយគាំទ្រចំពោះទង្វើរបស់លោក ក្នុងនាមជាអ្នកបម្រើការងាររបស់ព្រះទៅកាន់ពួកបរិសុទ្ធនៅកូរិនថូស ។ លោកបានដាស់តឿនពួកបរិសុទ្ធឲ្យញែកខ្លួនឯងចេញពីអំពើទុច្ចរិតទាំងអស់ ។ លោកបានបញ្ជាក់ពីការលះបង់របស់លោកទៅពួកបរិសុទ្ធ ហើយបានរីករាយដែលពួកគេបានសោកស្តាយ ហើយបានប្រែចិត្តពីអំពើបាបខ្លួន ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូស ទី២ ៦:១–១៣

ប៉ុលពិពណ៌នាពីបុគ្គលិកលក្ខណៈនៃពួកអ្នកបម្រើការងាររបស់ព្រះ

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីស្ថានភាពដូចខាងក្រោមនេះ ៖

- កាលអ្នក និងសមាជិកមួយចំនួនទៀតនៅក្នុងវួដ ឬសាខារបស់អ្នកកំពុងធ្វើការបម្រើមួយ មានមនុស្សមួយចំនួនបានដើរក្បែរ ហើយបាននិយាយពាក្យមិនល្អអំពីសាសនាចក្រ ។ តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នក និងសមាជិកផ្សេងទៀតក្នុងក្រុមអ្នកបានតបតនឹងពាក្យទ្រគោះបោះបោកនោះ ?

ចូរសុំឲ្យសិស្សគិតពីគ្រាដែលពួកគេអាចជួបប្រទះនឹងឧបសគ្គ ឬការចំអកកាលពួកគេកំពុងបម្រើព្រះអម្ចាស់ ។ នៅពេលសិស្សសិក្សាកូរិនថូសទី២ ៦:១–១៣ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយពួកគេនៅក្នុងគ្រាបែបនេះ ។

សូមសង្ខេប កូរិនថូសទី ២ ៦:១–២ ដោយពន្យល់ថា ប៉ុលបានហៅខ្លួនលោក និងពួកអ្នកបម្រើផ្សេងទៀតថា « អ្នកធ្វើការជាមួយនឹងព្រះ » (ខទី ១) មានន័យថា « អ្នកធ្វើការជាមួយនឹងព្រះគ្រីស្ទ » យោងតាមការបកប្រែដោយ យ៉ូសែប ស្ម៊ីធ សម្រាប់ កូរិនថូសទី ២ ៦:១ ។ ប៉ុលបានដកស្រង់ពាក្យសម្តីរបស់ព្យាការីអេសាយ (សូមមើល អេសាយ ៤៩:៨) ដើម្បីគូសបញ្ជាក់ថា ពេលវេលាបានមកដល់ហើយ ដែលពួកបរិសុទ្ធត្រូវពិចារណាពីសេចក្តីសង្គ្រោះខ្លួន ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៦:៣–៧ឲ្យឮៗ ។ ចូរសុំឲ្យសិស្សពាក់កណ្តាលថ្នាក់រកមើលពាក្យ ឬឃ្លាដែលពិពណ៌នាពីឧបសគ្គដែលប៉ុល និងពួកអ្នកបម្រើការងារផ្សេងទៀតបានជួបប្រទះ ។ ចូរសុំឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលពាក្យ ឬឃ្លាដែលពិពណ៌នាថា តើប៉ុល និងពួកអ្នកបម្រើការងារផ្សេងទៀតមានប្រតិកម្មយ៉ាងណាដែរចំពោះឧបសគ្គនោះ ។

- តើឧបសគ្គបែបណាដែលប៉ុល និងពួកអ្នកបម្រើការងារផ្សេងទៀតបានជួប ?
- តើពាក្យ ឬឃ្លាអ្វីខ្លះដែលបានពិពណ៌នាពីរបៀបដែលពួកលោកមានប្រតិកម្មចំពោះឧបសគ្គនោះ ?

សូមរំឭក ខទី ៣ ហើយពន្យល់ថា ពាក្យ *ការងារបម្រើ* សំដៅទៅលើកិច្ចការរបស់សាសនាចក្រ ។

- តើទង្វើរបស់សមាជិកសាសនាចក្រសព្វថ្ងៃនេះអាចជះឥទ្ធិពលដូចម្តេចខ្លះ ដល់ទស្សនៈរបស់មនុស្សដទៃអំពីសាសនាចក្រ ?
- តើអ្នកអាចសង្ខេបការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ៣–៧ ទៅជាគោលការណ៍មួយបានយ៉ាងដូចម្តេច ? (សិស្សគួរឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងតបតនឹងឧបសគ្គដោយសេចក្តីស្រឡាញ់ ចិត្តសប្បុរស និងសេចក្តីសុចរិត នោះយើងអាចជួយមនុស្សដទៃទៀតឲ្យមើលឃើញសាសនាចក្រនៅក្នុងផ្លូវវិជ្ជមានមួយ**) ។

សូមរំឭកសិស្សពីស្ថានភាពដែលបានលើកឡើងកាលពីដើមមេរៀន ។ សូមអញ្ជើញពួកគេឲ្យពន្យល់ថា មនុស្សម្នាក់អាចតបតទៅនឹងស្ថានភាពនោះតាមរបៀបដ៏សុចរិតមួយបានយ៉ាងដូចម្តេច ហើយថាអ្វីទៅជាផលដែលកើតចេញពីការធ្វើដូច្នេះ ។

កូរិនថូសទី២ ៦:១៤–១៨

ប៉ុលទូន្មានពួកបរិសុទ្ធឲ្យក្រោកចេញពីពួកទុច្ចរិត

សូមបំបែកសិស្សជាគូ ហើយចែក ឯកសារដែលភ្ជាប់មកជាមួយទៅដល់សិស្សម្នាក់ៗ ។

ល្បឿនបង្រៀន

ម្តងម្កាលអ្នកនឹងគ្មានពេលគ្រប់គ្រាន់ដើម្បីប្រើយោបល់សម្រាប់ការបង្រៀននៅក្នុងសៀវភៅសិក្សានេះអស់ទេ ។ អ្នកត្រូវតែសម្របសម្រួលផ្នែកនៃមេរៀននោះដោយសង្ខេបក្រុមខគម្ពីរនោះឲ្យខ្លី ឬតាមរយៈការនាំសិស្សឲ្យសំគាល់ឃើញគោលការណ៍ ឬ គោលលទ្ធិមួយយ៉ាងលឿន ពីមុនបន្តទៅក្រុមខគម្ពីរបន្ទាប់ទៀត ។ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណ ហើយពិចារណាប្រកបដោយការអធិស្ឋានពីតម្រូវការរបស់សិស្ស នៅពេលអ្នកកំណត់ថាផ្នែកណាមួយនៅក្នុងបណ្តុំបទគម្ពីរដែលត្រូវធ្វើការគូសបញ្ជាក់ ។

កូរិនថូសទី២ ៦:១៤–១៨

ទូន្មានដល់ពួកបរិសុទ្ធ	ការសន្យាមកពីព្រះអម្ចាស់

សូមឲ្យសិស្សអាន កូរិនថូសទី ២ ៦:១៤–១៨ ជាមួយនឹងដៃគូ ។ ចូរសុំសិស្សម្នាក់ពីដៃគូនីមួយៗ រកមើលពាក្យទូន្មានរបស់ប៉ុលទៅកាន់ពួកបរិសុទ្ធទាំងឡាយ ។ ចូរសុំឲ្យសិស្សម្នាក់ទៀតរកមើលការសន្យាមកពីព្រះអម្ចាស់ដែលនឹងត្រូវបំពេញ ប្រសិនបើពួកបរិសុទ្ធស្តាប់តាមពាក្យទូន្មានរបស់ប៉ុលនោះ ។ សូមអញ្ជើញពួកគេឲ្យប្រើអ្វីដែលពួកគេបានរកឃើញដើម្បីបំពេញតារាងនោះរួមគ្នា ។ អ្នកគួរពន្យល់ថា ពាក្យ *ត្រូវអ្វីនឹងគ្នា* មានន័យថាការប្រព្រឹត្តចុះសម្រុង *អារក្សរបាល* សំដៅទៅលើអំពើទុច្ចរិត (សូមមើល Bible Dictionary « Belial ») ហើយ *អ្នកដែលមិនជឿ* សំដៅទៅលើពួកអ្នកឥតជំនឿ ឬអ្នកដែលជឿលើរូបព្រះ ប៉ុន្តែមិនជឿលើព្រះអាទិតាស្ងគ៌ ។ លើសពីនេះទៀត កាលពីមុនប៉ុលធ្លាប់បានប្រៀបធៀបពួកបរិសុទ្ធនៅកូរិនថូសទៅនឹងព្រះវិហារបរិសុទ្ធរបស់ព្រះ ដូច្នេះពាក្យ*វិហារ*សំដៅទៅលើពួកគេ ។

សូមទុកពេលឲ្យដៃគូប្រាប់គ្នាពីអ្វីដែលពួកគេបានរកឃើញ ហើយបំពេញតារាងនោះ ។

សូមពន្យល់ថា ប៉ុលបានព្រមានជាពិសេសឲ្យពួកបរិសុទ្ធដកខ្លួនចេញពី « របស់ស្មោគគ្រោក » (ខទី ១៧)—រួមបញ្ចូលទាំង រឿងអបិយជំនឿ និងអ្នកដែលគោរពតាមវា—ដើម្បីការពារពួកគេពីអំពើបាប ។ រឿងអបិយជំនឿគឺជាការស្រឡាញ់ ឬថ្វាយបង្គំអ្វីដែលបង្កើតដោយមនុស្សច្រើនជាងរឿងមកពីព្រះ ។

សូមអញ្ជើញសិស្សឲ្យសរសេរពាក្យ *ប្រសិនបើ* នៅពីលើចំណងជើង « ទូន្មានដល់ពួកបរិសុទ្ធ » និងពាក្យ *នោះ* នៅពីលើចំណងជើង « ការសន្យាមកពីព្រះអម្ចាស់ » នៅក្នុងឯកសាររបស់ពួកគេ ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុងកូរិនថូសទី ២ ៦:១៤–១៨នេះ ? (សិស្សអាចនឹងរកឃើញគោលការណ៍មួយចំនួន ប៉ុន្តែត្រូវគូសបញ្ជាក់ថា**នៅពេលយើងដកខ្លួនចេញពីទម្លាប់ខុសឆ្គង និងរឿងស្មោគគ្រោក នោះព្រះអម្ចាស់នឹងទទួលយកយើង**) ។
- តើអ្វីទៅជាគំរូនៃទម្លាប់ខុសឆ្គង ឬរឿងស្មោគគ្រោកមួយចំនួននៅក្នុងសម័យរបស់យើង ?
- តើយើងអាចដកខ្លួនចេញពីរឿងទាំងនេះ និងអ្នកដែលចូលចិត្តអ្វីទាំងនោះបានយ៉ាងដូចម្តេច ?

សូមពន្យល់ថា គោលការណ៍នេះពុំមែនមានន័យថា យើងធ្វើដាក់មនុស្សដែលមានជំនឿផ្សេងដោយកោងកាច ឬមិនសេពគប់នឹងពួកគេនោះទេ ប៉ុន្តែសូមបញ្ជាក់ជំនឿយើងឡើងវិញដោយការគោរព ហើយចៀសវាងពីការចូលរួមនៅក្នុងសកម្មភាពនានាដែលដឹកនាំយើងទៅរកអំពើបាប ។

- តើអ្នកគិតថា ឃ្លាព្រះអម្ចាស់ « នឹងទទួល » យើង (កូរិនថូសទី ២ ៦:១៧)មានន័យដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីគ្រាមួយ ដែលពួកគេមានអារម្មណ៍ថា ព្រះអម្ចាស់បានគង់នៅជាមួយនឹងពួកគេ នៅពេលពួកគេបានដកខ្លួនចេញពីទម្លាប់ខុសឆ្គងដែលអាចនឹងដឹកនាំឲ្យពួកគេឃ្លាតឆ្ងាយពីព្រះអម្ចាស់ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យពិចារណាពីអ្វីដែលពួកគេត្រូវធ្វើ ដើម្បីដកខ្លួនចេញពីទម្លាប់ខុសឆ្គង និងរឿងស្មោគគ្រោកនានា ដើម្បីឲ្យពួកគេអាចទទួលបាននូវពរជ័យទាំងឡាយរបស់ព្រះអម្ចាស់ ។

កូរិនថូសទី២ ៧

ប៉ុលរីករាយដោយសារការប្រែចិត្តដ៏ពិតរបស់ពួកបរិសុទ្ធ

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសាច់រឿងដូចខាងក្រោមឲ្យឮៗ ៖

នៅក្នុងកិច្ចសម្ភាសន៍មួយសម្រាប់បណ្ណ័ចូលព្រះវិហារបរិសុទ្ធ ដើម្បីរៀបអាពាហ៍ពិពាហ៍ មានយុវនារីម្នាក់បានសារភាពពីអំពើបាបមួយចំនួនពីមុនដល់ប៊ីស្សពរបស់នាង ។ បន្ទាប់ពីការពិភាក្សាក្រោយមកទៀត ប៊ីស្សពនោះបានដឹងថា យុវនារីនោះពុំបានប្រែចិត្តពិតប្រាកដពីអំពើបាបនាងឡើយ ហើយថាអំពើបាបនាងគឺមានសភាពធ្ងន់ធ្ងរល្មម ដែលធ្វើឲ្យនាងគ្មានភាពសក្តិសមដើម្បីកាន់បណ្ណចូលព្រះវិហារបរិសុទ្ធ ។ ប៊ីស្សពរូបនោះពន្យល់ថា យុវនារីម្នាក់នឹងត្រូវតែរង់ចាំរហូតដល់នាងបានប្រែចិត្តពេញលេញសិន ដើម្បីទទួលបានប័ណ្ណនោះ ។ នាងបានភ័យខ្លាច ហើយក៏ប្រកាសថា នាងបានប្រែចិត្តហើយ ដោយសារនាងមិនបានធ្វើអំពើបាបទាំងនោះយូរមកហើយ ។ ប៊ីស្សពរូបនោះបានពន្យល់ថា ការគ្រាន់តែឈប់ពីអំពើបាបនោះ វាពុំមែនជាការប្រែចិត្តពេញលេញនោះទេ ហើយគាត់អញ្ជើញនាងឲ្យចាប់ផ្តើមដំណើរការនៃការប្រែចិត្តពិតប្រាកដដោយស្មោះត្រង់ ។

- តើអ្នកគិតថា យុវនារីនោះមានអារម្មណ៍បែបណាដែរនៅក្នុងកិច្ចសម្ភាសន៍ត្រង់ចំណុចនោះ ?

សូមអញ្ជើញសិស្សឲ្យបន្តអានសាច់រឿងនោះឲ្យឮៗ ៖

យុវនារីនោះពន្យល់ទៅប៊ីស្សពនាងថា នាងខកចិត្តខ្លាំងណាស់ដោយព្រោះតែសំបុត្រអញ្ជើញ សម្រាប់ពិធីមង្គលការនាងត្រូវបានផ្ញើចេញអស់ហើយ ។ នាងនិយាយថា នាងមិនអាចប្រឈមមុខនឹងសំណូរ និងភាពអាម៉ាស់ ដោយសារតែការពន្យារពេលមង្គលការរបស់នាងបានឡើយ ។ នាងសួរថា តើមានវិធីណាមួយផ្សេងទៀត ដែលនាងអាចផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធដូចដែលបានគ្រោងទុករួចហើយធ្វើការប្រែចិត្តតាមក្រោយបានទេ ។

- ដោយផ្អែកទៅលើការឆ្លើយតបរបស់យុវនារីនោះទៅកាន់ប៊ីស្សព តើអ្វីទៅដែលនាងទំនងជាខ្វល់ខ្វាយខ្លាំងជាងគេបំផុតនោះ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សា កូរិនថូសទី២ ៧ ដែលយុវនារីនៅក្នុងសាច់រឿងនោះត្រូវយល់ពីមុន នាងអាចប្រែចិត្តយ៉ាងពិតប្រាកដពីអំពើបាបរបស់នាង ។

សូមសង្ខេប កូរិនថូសទី ២ ៧:១–៧ ដោយពន្យល់ថា ប៉ុលបានបន្តទាស់ប្រឆាំងនឹងជនដែលចង់មូលបង្កាច់លោក ហើយបានអះអាងដល់ពួកបរិសុទ្ធនៅកូរិនថូសថា លោកមិនបានធ្វើខុសនឹងនរណាម្នាក់នោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ៧:៨–៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា សំបុត្រដំបូងមួយរបស់ប៉ុលបានជះឥទ្ធិពលដល់ពួកបរិសុទ្ធនៅកូរិនថូសដោយរបៀបណា ។

- តើសំបុត្រនោះបានជះឥទ្ធិពលដល់ពួកបរិសុទ្ធយ៉ាងដូចម្តេច ?
- ហេតុអ្វីប៉ុលរីករាយនៅក្នុងភាពសោកសៅរបស់ពួកគេ ?

សូមឲ្យសិស្សម្នាក់អាន កូរិនថូសទី២ ៧:១០–១១ ដោយស្ងាត់ស្ងៀម ។ អ្នកគួរណែនាំឲ្យពួកគេគូសចំណាំពីទុក្ខសោកពីរប្រភេទដែលប៉ុលបានលើកឡើង និងអ្វីដែលប្រភេទនីមួយៗដឹកនាំទៅរក ។

- តើអ្វីជាទុក្ខសោកពីរប្រភេទដែលប៉ុលបានលើកឡើង ?

សូមសរសេរចំណងជើង *សេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះ* និង *ការសោកសៅខាងលោកិយ* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ដែលបានពន្យល់ពីអត្ថន័យនៃពាក្យ « ការសោកសៅខាងលោកិយ » ៖



« ការឃើញថា បុរស និងស្ត្រីនៅក្នុងពិភពលោកនេះដែលមានអារម្មណ៍សោកស្តាយចំពោះរឿងដែលពួកគេធ្វើខុសនោះ វាជារឿងធម្មតាទេ ។ ពេលខ្លះ ការណ៍នេះគឺដោយសារទង្វើរបស់ពួកគេបានធ្វើឲ្យពួកគេ ឬអស់អ្នកដែលពួកគេស្រឡាញ់មានរឿងទុក្ខសោក និងទុក្ខវេទនាដ៏ធំ ។ ពេលខ្លះ ទុក្ខសោករបស់ពួកគេបានកើតឡើង ដោយសារពួកគេត្រូវចាប់បាន ហើយទទួលទណ្ឌកម្មដោយសារទង្វើរបស់ពួកគេ ។ អារម្មណ៍ខាងលោកិយបែបនេះពុំបានបង្កើត ‹ សេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះ › នោះទេ » (*Teachings of Presidents of the Church: Ezra Taft Benson* | ឆ្នាំ ២០១៤ | ទំព័រ ៨២) ។

- តើអ្នកនឹងសង្ខេបពីអត្ថន័យនៃការសោកសៅខាងលោកិយយ៉ាងដូចម្តេច ?
- យោងតាម ខទី ១០តើការសោកសៅខាងលោកិយអាចដឹកនាំទៅរកអ្វី ? (សូមពន្យល់ថា ពាក្យ *សេចក្តីស្លាប់* នៅក្នុង ខទី ១០ សំដៅទៅលើសេចក្តីស្លាប់ខាងវិញ្ញាណ មានន័យថា ការបែកចេញពីព្រះ ។ នៅក្រោមចំណងជើង « ការសោកសៅខាងលោកិយ » នៅលើក្តារខៀន សូមសរសេរសេចក្តីពិតដូចខាងក្រោម ៖ **ការសោកសៅខាងលោកិយអាចដឹកនាំទៅរកសេចក្តីស្លាប់ខាងវិញ្ញាណ ឬការបែកចេញពីព្រះ**) ។
- តើការសោកសៅខាងលោកិយអាចនាំមនុស្សម្នាក់ទៅរកសេចក្តីស្លាប់ខាងវិញ្ញាណយ៉ាងដូចម្តេច ? (វាអាចរារាំងមនុស្សម្នាក់មិនឲ្យប្រែចិត្តពិតប្រាកដ និងមិនឲ្យទទួលបានការអភ័យទោសពីព្រះវរបិតាសួគ៌) ។
- ដោយផ្អែកលើ ខទី ១០តើសេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះដឹកនាំទៅរកអ្វី ? (នៅក្រោមចំណងជើង « សេចក្តីព្រួយ » នៅលើក្តារខៀន សូមសរសេរសេចក្តីពិតដូចខាងក្រោម ៖ **សេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះដឹកនាំយើងទៅរកការប្រែចិត្តពីអំពើបាបរបស់យើង ហើយទទួលបានសេចក្តីសង្គ្រោះ**) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែប្រសើរឡើងពីហេតុផល ដែលសេចក្តីព្រួយដឹកនាំយើងទៅរកការប្រែចិត្ត សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ឲ្យឮៗ ៖



« សេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះគឺជាអំណោយទាននៃព្រះវិញ្ញាណ ។ វាគឺជាការយល់ដឹងដ៏ជ្រាលជ្រៅមួយថា ទង្វើរបស់យើងបានធ្វើឲ្យព្រះវរបិតារបស់យើង និងព្រះរបស់យើងរងាកព្រះទ័យ ។ វាគឺជាចំណេះដឹងដ៏មុតមាំ ហើយសក្ខីថា តរិយោបថរបស់យើងបានធ្វើឲ្យព្រះអង្គសង្គ្រោះ ដែលជាអង្គដែលគ្មានអំពើបាប ហើយជាអង្គដែលមហាស្ចារ្យលើសគេទាំងអស់ ឲ្យស្ងៀម្រាំនឹងការឈឺចាប់ និងការរងទុក្ខ ។ អំពើបាបរបស់យើងបានធ្វើឲ្យទ្រង់ហូរព្រះលោហិតនៅតាមគ្រប់រន្ធញើស ។ ការឈឺចាប់ខាងផ្លូវចិត្ត និងខាងវិញ្ញាណដ៏ពិតនេះគឺជាអ្វីដែលព្រះគម្ពីរបានលើកឡើងថា ការមាន ‹ ចិត្តសង្រេង និង វិញ្ញាណទន់ទាប › ។ . . . ស្មារតីមួយបែបនេះគឺជាលក្ខណៈពេញលេញសម្រាប់ការប្រែចិត្តពិត » (*Teachings: Ezra Taft Benson* ទំព័រ ៨៣) ។

- ហេតុអ្វីអ្នកគិតថា សេចក្តីព្រួយដឹកនាំយើងឲ្យមានការប្រែចិត្តពីអំពើបាបយើងយ៉ាងពិតប្រាកដ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីសាច់រឿងអំពីយុវនារី ដែលចង់បានបណ្ណូចូលព្រះវិហារបរិសុទ្ធនោះ ។

- នៅក្នុងការសម្ភាសរបស់យុវនារីនោះជាមួយនឹងប៊ីស្សព តើទង្វើអ្វីដែលបង្ហាញថានាងមិនបានមានសេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជំនួសការសោកសៅខាងលោកិយជាមួយនឹងសេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះ ?

ប្រសិនបើចាំបាច់ សូមជួយសិស្សឲ្យយល់ថា អារម្មណ៍នៃសេចក្តីពិតដែលយើងមាន នៅពេលយើងប្រែចិត្តអាចមានភាពខុសៗគ្នា អាស្រ័យលើភាពធ្ងន់ធ្ងរនៃអំពើបាបនោះ ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងមានសេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះលើសពីការសោកសៅខាងលោកិយចំពោះអំពើបាបនោះយើងនឹងអាចប្រែចិត្តយ៉ាងពិតប្រាកដ ជ្រះស្អាតពីអំពើបាបរបស់យើង ហើយនៅទីបំផុតបានទទួលសេចក្តីសង្គ្រោះ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះនៅក្នុងការខិតខំរបស់ពួកគេដើម្បីប្រែចិត្ត ។

សូមសង្ខេប កូរិនថូសទី ២ ៧:១២–១៦ ដោយពន្យល់ថា ប៉ុលបានបង្ហាញពីកង្វល់ និងទំនុកចិត្តរបស់លោកចំពោះពួកបរិសុទ្ធ ។

សូមរំឭកដោយសង្ខេបពីសេចក្តីពិត ដែលសិស្សបានរកឃើញសម្រាប់ការសិក្សារបស់ពួកគេនៅក្នុង កូរិនថូសទី២ ៦–៧ ហើយលើកទឹកចិត្តពួកគេឲ្យធ្វើតាមអារម្មណ៍ការបំផុតគំនិតដែលពួកគេមាន ដើម្បីអនុវត្តសេចក្តីពិតទាំងនេះ ។

មេរៀនសិក្សានៅផ្ទះ

កូរិនថូសទី ១ ១៥–កូរិនថូសទី ២ ៧ (មេរៀនទី ២៣)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា កូរិនថូសទី ១ ១៥–កូរិនថូសទី ២ ៧ (មេរៀនទី ២៣) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្សអ្នក ។

ថ្ងៃទី ១ (កូរិនថូសទី ១ ១៥:១–២៩)

នៅពេលសិស្សបានសិក្សា កូរិនថូសទី ១ ១៥ ៣ក់កណ្តាលដំបូង នោះពួកគេបានរៀនថា ពួកសាវកថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទបានសុគតសម្រាប់អំពើបាបរបស់យើង ហើយបានមានព្រះជន្មរស់ឡើងវិញពីសុគត ។ សិស្សក៏បានរៀនផងដែរថា ជនដែលបានចែកឋានទៅដោយគ្មានពិធីបុណ្យជ្រមុជទឹកអាចទទួលបានពិធីបរិសុទ្ធពិសេសនេះ ។

ថ្ងៃទី ២ (កូរិនថូសទី ១ ១៥:៣០–១៦:២៤)

នៅក្នុងមេរៀននេះ សិស្សបានបន្តសិក្សាការបង្រៀនរបស់ប៉ុលអំពីការរស់ឡើងវិញ ។ ពួកគេបានរៀនថា សិរីល្អសម្រាប់រូបកាយដែលបានរស់ឡើងវិញមានកម្រិតខុសៗគ្នា ។ លើសពីនេះទៀត ពួកគេបានរៀនថា ប្រសិនបើយើងខ្ជាប់ខ្ជួន ហើយនឹងនរនៅក្នុងការរស់នៅតាមដំណឹងល្អ នោះចំណងនៃសេចក្តីស្លាប់ដែលកើតចេញមកពីអំពើបាប នឹងត្រូវបានដកចេញតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ៣ (កូរិនថូសទី ២ ១–៣)

នៅក្នុងសំបុត្រទីពីររបស់ប៉ុលដល់ពួកកូរិនថូស សិស្សបានរៀនថា នៅពេលព្រះវរបិតាសួគ៌ល្បងលោមចិត្តយើងនៅក្នុងសេចក្តីឈឺចាប់របស់យើង នោះយើងអាចជួយមនុស្សដទៃទៀតឲ្យទទួលបានការលួងលោមរបស់ទ្រង់ ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងមិនអភ័យទោសដល់មនុស្សដទៃទេ នោះសាតាំងនឹងមានប្រៀបមកលើយើង ហើយនៅពេលយើងបង្វែរដួងចិត្តយើងទៅកព្រះអម្ចាស់ នោះយើងនឹងមានព្រះវិញ្ញាណដែលនឹងជួយយើងឲ្យប្រែក្លាយកាន់តែដូចជាព្រះបន្តិចម្តងៗ ។

ថ្ងៃទី ៤ (កូរិនថូសទី ២ ៤–៧)

នៅពេលសិស្សបានសិក្សាការពិពណ៌នារបស់ប៉ុលអំពីការងារបម្រើរបស់លោកនៅក្នុងមេរៀននេះ ពួកគេបានរកឃើញសេចក្តីពិតដូចខាងក្រោម ៖ ការសោកល្បង និងទុក្ខព្រួយទាំងឡាយរបស់យើងនៅក្នុងជីវិតនេះគឺតូចតាចណាស់ បើប្រៀបធៀបទៅនឹងពរជ័យ និងការកែចម្រើនដ៏អស់កល្បដែលអាចកើតមានឡើង នៅពេលយើងស៊ូទ្រាំវាដោយស្មោះត្រង់ ។ ដោយសារយើងបែកចេញពីព្រះនៅក្នុងជីវិតរមែងស្លាប់ នោះយើងត្រូវដើរដោយសេចក្តីជំនឿ ពុំមែនដោយការមើលឃើញនឹងភ្នែកនោះទេ ។ ព្រះយេស៊ូវគ្រីស្ទនឹងកាត់សេចក្តីយើងម្នាក់ៗ ស្របតាមអ្វីដែលយើងបានធ្វើនៅក្នុងជីវិតរមែងស្លាប់ ។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចប្រែក្លាយជាមនុស្សថ្មី ហើយបានផ្សះផ្សានឹងព្រះ ។ នៅពេលយើងដកខ្លួនយើងចេញពីទំនៀមទម្លាប់ខុសឆ្គង និងអ្វីៗដែលមិនស្អាតស្អំ នោះព្រះអម្ចាស់នឹងទទួលយកយើង ។

សេចក្តីផ្តើម

នៅក្នុងសំបុត្រទីពីររបស់លោកទៅពួកបរិសុទ្ធកូរិនថូស សាវកប៉ុលបានបញ្ជាក់ពីភក្តីភាពរបស់លោកចំពោះពួកគេ ហើយបានថ្លែងថា លោកបានមានក្តីរីករាយដោយដឹងថា ពួកគេបានទទួលយកការទុន្មានពីមុនរបស់លោក ។ លោកបានបង្រៀនថា សេចក្តីព្រួយចំពោះអំពើបាបដែលគាប់ព្រះទ័យដល់ព្រះ ដឹកនាំទៅរកការប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី២ ៧:៨–១១

ប៉ុលរីករាយដោយសារការប្រែចិត្តដ៏ពិតរបស់ពួកបរិសុទ្ធ

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសាច់រឿងដូចខាងក្រោមឲ្យឮៗ ៖

នៅក្នុងកិច្ចសម្ភាសន៍មួយសម្រាប់បណ្ណ័ចូលព្រះវិហារបរិសុទ្ធ ដើម្បីរៀបអាពាហ៍ពិពាហ៍ មានយុវនារីម្នាក់បានសារភាពអំពើបាបមួយចំនួនកាលពីអតីតកាលដល់ប៊ីស្សពរបស់នាង ។ បន្ទាប់ពីការពិភាក្សាក្រោយមកទៀត ប៊ីស្សពនោះបានដឹងថា យុវនារីនោះពុំបានប្រែចិត្តពិតប្រាកដពីអំពើបាបរបស់នាងឡើយ ហើយថាអំពើបាបនាងគឺមានភាពធ្ងន់ធ្ងរល្មមធ្វើឲ្យនាងគ្មានភាពសក្តិសម ដើម្បីនឹងកាន់បណ្ណចូលព្រះវិហារបរិសុទ្ធនោះទេ ។ ប៊ីស្សពនោះពន្យល់ថា យុវនារីម្នាក់នេះនឹងត្រូវតែរង់ចាំរហូតដល់នាងបានប្រែចិត្តពេញលេញសិន ដើម្បីទទួលបានប័ណ្ណនោះ ។ នាងបានភ័យខ្លាចដោយប្រកាសថា នាងបានប្រែចិត្តហើយ ដោយសារនាងមិនបានធ្វើអំពើបាបទាំងនោះម្តងទៀត ដាយូរណាស់មកហើយ ។ ប៊ីស្សពនោះបានពន្យល់ថា ការគ្រាន់តែឈប់ពីអំពើបាបនោះ វាពុំមែនជាការប្រែចិត្តពេញលេញនោះទេ ហើយគាត់អញ្ជើញនាងឲ្យចាប់ផ្តើមដំណើរការនៃការប្រែចិត្តពិតប្រាកដដោយស្មោះត្រង់ ។

- តើអ្នកគិតថា យុវនារីនោះមានអារម្មណ៍បែបណាដែរ នៅក្នុងកិច្ចសម្ភាសន៍ត្រង់ចំណុចនោះ ?

សូមអញ្ជើញសិស្សឲ្យបន្តអានសាច់រឿងនោះឲ្យឮៗ ៖

យុវនារីនោះពន្យល់ទៅប៊ីស្សពនាងថា នាងខកចិត្តខ្លាំងណាស់ ដោយសារតែលិខិតអញ្ជើញសម្រាប់ពិធីមង្គលការរបស់នាងត្រូវបានផ្ញើចេញអស់ហើយ ។ នាងនិយាយថា នាងមិនអាចទ្រាំទ្រនឹងសំណូរ និងភាពអាម៉ាស់ ដោយសារតែការពន្យារពេលមង្គលការនាងបាននោះឡើយ ។ នាងសួរថា តើមានវិធីណាមួយផ្សេងទៀតដែលនាងអាចផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធដូចដែលបានគ្រោងទុក រួចហើយធ្វើការប្រែចិត្តតាមក្រោយបានទេ ។

- ដោយផ្អែកទៅលើការឆ្លើយតបរបស់យុវនារីនោះទៅកាន់ប៊ីស្សព តើអ្វីទៅដែលនាងទំនងជាខ្វល់ខ្វាយជំនឿខ្លាំងបំផុតនោះ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សា កូរិនថូសទី ២ ៧:៨–១១ ដែលយុវនារីនៅក្នុងសាច់រឿងនោះត្រូវយល់ពីមុននាងអាចប្រែចិត្តពិតប្រាកដពីអំពើបាបរបស់នាង ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ៧:៨–៩ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា សំបុត្រដំបូងមួយរបស់ប៉ុលបានជះឥទ្ធិពលដល់ពួកបរិសុទ្ធកូរិនថូសដោយរបៀបណា ។

- តើសំបុត្រនោះបានជះឥទ្ធិពលដល់ពួកបរិសុទ្ធយ៉ាងដូចម្តេច ?
- ហេតុអ្វីប៉ុលរីករាយនៅក្នុងភាពសោកសៅរបស់ពួកគេ ?

សូមឲ្យសិស្សម្នាក់អាន កូរិនថូសទី ២ ៧:១០–១១ ដោយស្ងាត់ស្ងៀម ។ អ្នកគួរណែនាំឲ្យពួកគេគូសចំណាំពីទុក្ខសោកពីរប្រភេទដែលប៉ុលបានលើកឡើង និងប្រភេទទុក្ខសោកនីមួយៗដឹកនាំទៅរកលទ្ធផលយ៉ាងណា ។

- តើអ្វីជាទុក្ខសោកពីរប្រភេទដែលប៉ុលបានលើកឡើង ?

សូមសរសេរចំណងជើង *សេចក្តីព្រួយដែលគាប់ព្រះទ័យព្រះ* និង *ការសោកសៅខាងលោកិយ* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធានអ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់កេការពិពណ៌នារបស់លោកអំពីការសោកសៅខាងលោកិយ ។



« វាជារឿងធម្មតា ដោយរកឃើញថា បុរស និងស្ត្រីនៅក្នុងពិភពលោកនេះ មានអារម្មណ៍សោកស្តាយ ចំពោះរឿងដែលពួកគេធ្វើខុសនោះ ។ ពេលខ្លះ ការណ៍នេះកើតមានឡើង ដោយសារទង្វើរបស់ពួកគេបានធ្វើឲ្យពួកគេ ឬ មនុស្សដែលពួកគេស្រឡាញ់មានរឿងទុក្ខសោក និងទុក្ខវេទនាដ៏ធំ ។ ពេលខ្លះ ទុក្ខសោករបស់ពួកគេបានបង្កឡើង ដោយសារពួកគេត្រូវចាប់បាន ហើយទទួលទណ្ឌកម្មចំពោះទង្វើរបស់ពួកគេ ។ អារម្មណ៍ខាងលោកិយបែបនេះពុំបានបង្កើតឡើងនូវ ‹ សេចក្តីព្រួយដែលគាប់ព្រះទ័យព្រះ › នោះទេ » (*Teachings of Presidents of the Church: Ezra Taft Benson* [ឆ្នាំ ២០១៤] ទំព័រ ៨២) ។

- តើអ្នកនឹងសង្ខេបពីអត្ថន័យនៃសេចក្តីព្រួយរបស់លោកិយយ៉ាងដូចម្តេច ?
- យោងតាម កូរិនថូសទី ២ ៧:១០តើសេចក្តីព្រួយរបស់លោកិយអាចដឹកនាំទៅរកអ្វី ? (សូមពន្យល់ថា ពាក្យ *សេចក្តីស្លាប់* នៅក្នុង ខទី ១០ សំដៅទៅលើសេចក្តីស្លាប់ខាងវិញ្ញាណ មានន័យថា ការបែកចេញពីព្រះ ។ នៅក្រោមចំណងជើង « សេចក្តីព្រួយរបស់លោកិយ » នៅលើក្តារខៀន សូមសរសេរសេចក្តីពិតដូចខាងក្រោម ៖ **សេចក្តីព្រួយរបស់លោកិយអាចដឹកនាំទៅរកសេចក្តីស្លាប់ខាងវិញ្ញាណ ឬការបែកចេញពីព្រះ**) ។
- តើសេចក្តីព្រួយរបស់លោកិយអាចដឹកនាំមនុស្សម្នាក់ទៅរកសេចក្តីស្លាប់ខាងវិញ្ញាណយ៉ាងដូចម្តេច ? (វាអាចរារាំងមនុស្សម្នាក់មិនឲ្យប្រែចិត្តពិតប្រាកដ និងមិនឲ្យទទួលបានការអភ័យទោសពីព្រះវរបិតាសួគ៌) ។
- ដោយផ្អែកលើ ខទី ១០តើសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះដឹកនាំទៅរកអ្វី ? (នៅក្រោមចំណងជើង « សេចក្តីព្រួយដែលគាប់ព្រះទ័យព្រះ » នៅលើក្តារខៀន សូមសរសេរសេចក្តីពិតដូចខាងក្រោម ៖ **សេចក្តីព្រួយដែលគាប់ព្រះទ័យព្រះដឹកនាំយើងទៅរកការប្រែចិត្តពីអំពើបាបរបស់យើង ហើយទទួលបានសេចក្តីសង្គ្រោះ**) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីហេតុផលដែលសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះដឹកនាំយើងទៅរកការប្រែចិត្ត សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឺន ឲ្យឮៗ ៖



« សេចក្តីព្រួយដែលគាប់ព្រះទ័យព្រះគឺជាអំណោយទាននៃព្រះវិញ្ញាណ ។ វាគឺជាការយល់ដឹងដ៏ជ្រាលជ្រៅមួយថា ទង្វើរបស់យើងបានធ្វើឲ្យព្រះវរបិតារបស់យើង និងព្រះរបស់យើងមិនពេញព្រះទ័យ ។ វាគឺជាចំណេះដឹងដ៏មុតមាំ ហើយសកម្មថា តរិយាបថរបស់យើងបានធ្វើឲ្យព្រះអង្គសង្គ្រោះ ជាអង្គដែលគ្មានអំពើបាប ហើយជាអង្គដែលមហាអស្ចារ្យលើសគេទាំងអស់ ត្រូវស៊ូទ្រាំការឈឺចាប់ និងការរងទុក្ខ ។ អំពើបាបរបស់យើងបានធ្វើឲ្យទ្រង់ហូរព្រះលោហិតតាមគ្រប់ទ្វេញើស ។ ការឈឺចាប់ខាងផ្លូវចិត្ត និងខាងវិញ្ញាណដ៏ពិតជាក់ស្តែងនេះ គឺជាអ្វីដែលព្រះគម្ពីរបានលើកឡើងថា ការមាន ‹ ចិត្តសង្រេង និង វិញ្ញាណទន់ទាប › ។ . . . ស្មារតីមួយបែបនេះគឺជាលក្ខណៈពេញលេញសម្រាប់ការប្រែចិត្តពិត » (*Teachings: Ezra Taft Benson* ទំព័រ ៨៣) ។

- ហេតុអ្វីអ្នកគិតថា សេចក្តីព្រួយដែលគាប់ព្រះទ័យព្រះដឹកនាំយើងឲ្យមានការប្រែចិត្តពីអំពើបាបយើងយ៉ាងពិតប្រាកដ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីសាច់រឿងអំពីយុវនារីដែលចង់បានបណ្ណ័ចូលព្រះវិហារបរិសុទ្ធ ។

- នៅក្នុងពេលសម្ភាសរបស់យុវនារីនោះជាមួយនឹងប៊ីស្សព តើវាបង្ហាញថា នាងបានដកពិសោធន៍នូវសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះចំពោះអំពើបាបរបស់នាងដែរឬទេ ? ហេតុអ្វីមិនមែន ? (នាងបានខ្វល់ខ្វាយច្រើនចំពោះការពន្យារពេលពិធីមង្គលការរបស់នាង និងគំនិតរបស់មនុស្សដទៃទៀតគិតចំពោះនាង លើសពីការដែលនាងត្រូវមានការប្រែចិត្តដ៏ពិតប្រាកដ ហើយទទួលបានការអភ័យទោសពីព្រះវរបិតាសួគ៌) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីជំនួសការសោកសៅខាងលោកិយជាមួយនឹងសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះ ? (យើងអាចតមអាហារ ហើយអធិស្ឋាន ទូលសូមឲ្យព្រះវរបិតាសួគ៌ប្រទានពរដល់យើងនូវអំណោយទាននៃសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះ ។ យើងក៏អាចសិក្សាផងដែរអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយស្វែងរកការយល់ដឹងកាន់តែជ្រាលជ្រៅមួយអំពីរបៀប ដែលអំពើបាបយើងបានធ្វើឲ្យទ្រង់រងទុក្ខ) ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងមានសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះលើសពីសេចក្តីព្រួយរបស់លោកិយ ចំពោះអំពើបាបរបស់យើង នោះយើងនឹងអាចប្រែចិត្តពិតប្រាកដ ជ្រះស្អាតពីអំពើបាបរបស់យើង ហើយនៅទីបំផុតបានទទួលសេចក្តីសង្គ្រោះ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកសេចក្តីព្រួយដែលគាប់ព្រះទ័យព្រះនៅក្នុងការខិតខំរបស់ពួកគេដើម្បីប្រែចិត្ត ។

ប្រសិនបើមានពេល សូមអំពាវនាវដោយសង្ខេបពីសេចក្តីពិត ដែលសិស្សបានរកឃើញ នៅពេលពួកគេបានសិក្សានៅក្នុងមេរៀនទី ២៣ ហើយលើកទឹកចិត្តពួកគេឲ្យធ្វើតាមអាល់ការបំផុសគំនិតដែលពួកគេអាចមាន ដើម្បីអនុវត្តសេចក្តីពិតទាំងនេះ ។ អ្នកគួរតែរំឭកវគ្គចំណេះចំណានខគម្ពីរនៅក្នុង កូរិនថូសទី ១ ១៥:២០–២២ និង កូរិនថូសទី ១ ១៥:៤០–៤២ ។ សូមអញ្ជើញសិស្សឲ្យពន្យល់គោលលទ្ធិនៅក្នុងវគ្គគម្ពីរទាំងនេះ និងរបៀបដែលពួកគេអាចប្រើខគម្ពីរទាំងនេះ ដើម្បីបង្រៀនពីផែនការនៃសេចក្តីសង្គ្រោះដល់មនុស្សម្នាក់ទៀត ។

មេរៀនបន្ទាប់ (កូរិនថូសទី ២ ៨–អេភេសូរ ១)

ចូរសុំឲ្យសិស្សគិតពិចារណាអំពីសំណួរខាងក្រោម ៖ តើអ្នកដឹងអំពីពេលដែលអ្នកកំពុងមានអារម្មណ៍ពីព្រះវិញ្ញាណដោយរបៀបណា ? តើផលផ្លែ ឬ អារម្មណ៍នៃព្រះវិញ្ញាណគឺជាអ្វី ? តើពួកបរិសុទ្ធត្រូវបានតែងតាំងឲ្យទទួលអ្វីពីមុនមកលើផែនដី ? តើអ្វីទៅជាការទទួលខុសត្រូវរបស់យើងចំពោះជនដែលខ្វះសេចក្តីត្រូវការចាំបាច់មួយចំនួនក្នុងជីវិត ដូចជាអាហារ សំលៀកបំពាក់ និងទីជម្រក ? ចុះតើយើងខ្លួនយើងផ្ទាល់មានសេចក្តីត្រូវការមួយចំនួនដូចគ្នានេះដែរឬទេ ? សូមពន្យល់ថា នៅសប្តាហ៍ក្រោយ ពួកគេនឹងសិក្សាពីរបៀបដែលប៉ុលបានលើកឡើងនូវសំណួរទាំងនេះ និងសំណួរផ្សេងៗទៀត ។

មេរៀន ១១៦

កូរិនថូសទី ២ ៨–៩

សេចក្តីផ្តើម

ប៉ុលបានសរសេរទៅពួកបរិសុទ្ធនៅកូរិនថូស ដោយពន្យល់ថា សមាជិកនៅម៉ាសេដូនីបានជួយដល់ជនដែលក្រីក្រដោយសប្បុរស ។ លោកបានលើកទឹកចិត្តពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះផងដែរ តាមរយៈការជួយដល់ជនក្រីក្រ ។ ប៉ុលបានបង្រៀនអំពីពរជ័យដែលកើតមានចំពោះជនដែលជួយដល់ជនក្រីក្រដោយក្តីរីករាយ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី២ ៨

ប៉ុលទូន្មានពួកបរិសុទ្ធឲ្យមើលថែដល់ជនក្រីក្រ

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ (ដកស្រង់ចេញពី « Are We Not All Beggars? » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៤០) នៅលើ ក្តារខៀន ពីមុនថ្នាក់ចាប់ផ្តើម ប៉ុន្តែទុកចន្លោះនៅត្រង់៣ក្យ *ភាពក្រីក្រ* ។ សូមចាប់ផ្តើមមេរៀននេះដោយអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍នេះឮៗ ។

> *« ក្នុងប្រវត្តិសាស្ត្រភាពក្រីក្រ គឺត្រូវបានចាត់ថាជាឧបសគ្គដ៏ធំ និង ទូទៅបំផុតរបស់មនុស្សលោក ។ ជាទូទៅការរងទុក្ខស្តែងមកពីភាពក្រីក្រខាងសាច់ឈាម តែការខូចខាតខាងវិញ្ញាណ និងខាងសតិអារម្មណ៍ ដែលបណ្តាលមកពីភាពក្រីក្រអាចកាន់តែធ្លាក់ចុះដុនដាបទៅទៀត » ។*

ចូរសុំឲ្យសិស្សទាយ៣ក្យដែលបាត់នៅក្នុងឃ្លានោះ ។ បន្ទាប់មក សូមសរសេរដាក់៣ក្យ *ភាពក្រីក្រ* ។

- តើភាពក្រីក្រជាអ្វី ? (ស្ថានភាពមួយដែលមានប្រាក់តិចតួច របស់របរ ឬមធ្យោបាយនៃការផ្គត់ផ្គង់តិចតួច ឬគ្មានទាល់តែសោះ) ។
- ហេតុអ្វីភាពក្រីក្ររអាចជាការប្រឈមមួយដ៏ពិបាក ?

សូមលើកទឹកចិត្តសិស្សឲ្យគិតពីបុគ្គលដែលពួកគេស្គាល់ ដែលត្រូវការជំនួយ រួមទាំងខាងសាច់ឈាម ខាងផ្លូវចិត្ត ខាងសង្គម ឬខាងវិញ្ញាណ ។ នៅពេលសិស្សសិក្សា កូរិនថូសទី ២ ៨–៩ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេឲ្យយល់ ហើយបំពេញតួនាទីរបស់ខ្លួននៅក្នុងការជួយដល់ជនខ្វះខាត ។

សូមសង្ខេប កូរិនថូសទី ២ ៨:១–៨ ដោយពន្យល់ថា ប៉ុលបានប្រាប់ពួកបរិសុទ្ធនៅកូរិនថូសថា សមាជិកសាសនាចក្រនៅម៉ាសេដូបានបរិច្ចាគដោយចិត្តសប្បុរសដើម្បីជួយជនក្រីក្រដែលត្រូវការខាងសាច់ឈាម ។ (អ្នកគ្រូឲ្យសិស្សស្វែងរកកូរិនថូស និង ម៉ាសេដូ នៅលើផែនទីក្នុងព្រះគម្ពីរ ល.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា ») ។ ប៉ុលបានពន្យល់ថា សមាជិកនៅម៉ាសេដូបានធ្វើដូច្នោះ ដោយសារពួកគេចង់ធ្វើតាមព្រះទ័យរបស់ព្រះ ។ លោកបានលើកទឹកចិត្តពួកបរិសុទ្ធនៅកូរិនថូស ឲ្យធ្វើតាមគំរូនេះចំពោះការជួយផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់មនុស្សដទៃ ចេញពីសេចក្តីស្រឡាញ់ដ៏ស្មោះត្រង់ ។

សូមសរសេរពាក្យ *មាន* និង *ក្រីក្រ* នៅលើក្តារខៀន ។

សូមអញ្ជើញសិស្សអាន កូរិនថូសទី២ ៨:៩ ដោយស្ងៀមស្ងាត់ រកមើលថា ប៉ុលបាននិយាយថាព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះចំពោះពួកបរិសុទ្ធទាំងនោះ ។ ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមស្នើសំណួរខាងក្រោមនេះ ហើយសរសេរចម្លើយរបស់សិស្សដាក់នៅលើក្តារខៀននៅក្រោម៣ក្យ *មាន* និង *ក្រីក្រ* ។

- តើព្រះយេស៊ូវគ្រីស្ទជាអង្គដែលមានភាពឧត្តុង្គឧត្តមនៅក្នុងជីវិតមុនឆាកជីវិតនេះតាមរបៀបណា ? (ចម្លើយសិស្សអាចរួមមានដូចខាងក្រោម ៖ ព្រះយេស៊ូវគ្រីស្ទគឺជាបុត្រច្បងខាងវិញ្ញាណរបស់ព្រះវរបិតា ពីមុនទ្រង់ប្រសូតនៅក្នុងជីវិតរមែងស្លាប់ទៅទៀត ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះដែលគង់នៅក្បែរព្រះវរបិតាស្ទើរដោយមានសិទ្ធិអំណាច ព្រះចេស្តា និងសិរីល្អ ហើយបានបង្កើតពិភពជាច្រើននៅក្រោមការដឹកនាំរបស់ព្រះវរបិតា) ។
- តើទ្រង់ត្រូវបានគេចាត់ទុកថាក្រីក្រ កាលទ្រង់មានព្រះជន្មនៅក្នុងជីវិតរមែងស្លាប់នេះតាមរបៀបណា ? (ទ្រង់បានចាកចេញពីតួនាទីដ៏មានសិរីល្អរបស់ទ្រង់ ដើម្បីមកប្រសូត ហើយគង់នៅលើផែនដីនៅក្នុងកាលៈទេសៈដ៏ទន់ទាប ។
- តើអ្នកគិតថា នៅក្នុង ខទី ៩ ដែលចែងថា យើង « បានមានឡើង ដោយសារសេចក្តីកម្ររបស់ [ព្រះអង្គសង្គ្រោះ] » មានន័យយ៉ាងដូចម្តេច ? (ដោយសារព្រះយេស៊ូវគ្រីស្ទបានយាងចុះពីបល្ល័ង្កនៃជីវិតមុនផែនដីរបស់ទ្រង់ មកកាន់ផែនដីដើម្បីធ្វើការងារបម្រើធ្វើជាគំរូសម្រាប់យើង ហើយធ្វើជង្វាយធួន នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច) ។

អធិស្ឋានសម្រាប់សិស្សទាំងឡាយ

ដើម្បីឲ្យសិស្សទាំងឡាយទទួលអារម្មណ៍ពីឥទ្ធិពលនៃការស្តាំងឡើងវិញនៃព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងបទពិសោធន៍នៃការរៀនរបស់គេ នោះពួកគេក៏គួរតែ « ប្រុងប្រៀបនឹងស្តាប់តាមព្រះបន្ទូល » ដែរ (អាលម៉ា ៣២:៦) ។ អ្នកអាចទូលសូមដល់ព្រះអម្ចាស់ឲ្យចាក់ព្រះវិញ្ញាណរបស់ទ្រង់មកលើសិស្សទាំងឡាយរបស់អ្នក « ដើម្បីរៀបចំចិត្តគេឲ្យទទួលព្រះបន្ទូល . . . ដោយសេចក្តីអំណរ » (អាលម៉ា ១៦:១៦–១៧) ។

សូមពន្យល់សិស្សថា ពួកបរិសុទ្ធនៅកូរិនថូសត្រូវបានបង្គាប់ឲ្យប្រមូលមួយអាហារជួយដល់ពួកបរិសុទ្ធក្រីក្រនៅស្រុកយូដាយៈពេលប្រហែលជាមួយឆ្នាំមុន ។ សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ៨:១០–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានណែនាំពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ។

- តើប៉ុលបានណែនាំពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា ឃ្លា « ធ្វើ » និង « បំពេញការនោះ » មានន័យថា ប៉ុលបានដាស់តឿនពួកបរិសុទ្ធឲ្យបំពេញការតាំងចិត្តកាលពីមុនរបស់ពួកគេ ដើម្បីផ្តល់អ្វីដែលពួកគេអាចធ្វើបានដល់ពួកបរិសុទ្ធក្រីក្រ ដូចជាព្រះអង្គសង្គ្រោះបានប្រទានភាពមានបានដ៏នៅអស់កល្បជានិច្ចដល់ពួកគេដែរ ។

- តើមានអ្វីកើតឡើងដល់យើងម្នាក់ៗ នៅពេលយើងយល់អ្វីៗទាំងអស់ដែលព្រះអង្គសង្គ្រោះបានប្រទានដល់យើង ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងយល់អ្វីៗទាំងអស់ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់យើង នោះយើងនឹងមានឆន្ទៈកាន់តែខ្លាំងឡើង ដើម្បីផ្តល់ទ្រព្យសម្បត្តិរបស់យើងដល់មនុស្សដទៃ**) ។
- តើការសញ្ជឹងគិតពីអំណោយទានពីព្រះអង្គសង្គ្រោះដល់យើង អាចលើកទឹកចិត្តយើងឲ្យផ្តល់ដល់ជនដែលខ្វះខាតយ៉ាងដូចម្តេច ?
- តើអំណោយទានជាក់លាក់ណាខ្លះ ដែលព្រះអង្គសង្គ្រោះបានប្រទានដល់អ្នកដែលអាចបំផុសគំនិតអ្នកឲ្យផ្តល់ដល់មនុស្សដទៃ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ៨:១២–១៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសេចក្តីពិតបន្ថែមមួយ ដែលប៉ុលបានបង្រៀនប្រជាជនអំពីសារៈសំខាន់នៃការផ្គត់ផ្គង់គ្នាទៅវិញទៅមកខាងសាច់ឈាម ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង ខទី ១២–១៣ ? (សូមជួយសិស្សឲ្យស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **ព្រះសព្វព្រះទ័យចង់ឲ្យយើងមានឆន្ទៈចេះផ្តល់ឲ្យ ទោះជាពេលយើងគ្មានអ្វីផ្តល់ឲ្យក៏ដោយ**) ។

ដើម្បីជួយសិស្សឲ្យយល់ពីសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍អែលឌើរ ដៃហ្វ្រី អ័រ ហូឡិន ៖

« មានឬក្រ យើងត្រូវ ‹ ធ្វើអ្វីដែលយើងអាចធ្វើបាន › ពេលអ្នកផ្សេងទៀតត្រូវការជំនួយ » (« Are We Not All Beggars? » ទំព័រ ៤១) ។

- តើយើងអាចធ្វើអ្វីខ្លះដើម្បីជួយមនុស្សដទៃ ប្រសិនបើយើងគ្មានអ្វីផ្តល់ដល់ពួកគេផងនោះ ?
- យោងតាម ខទី ១៤–១៥ តើនរណាទៅនឹងទទួលបានអត្ថប្រយោជន៍ កាលពួកបរិសុទ្ធគ្រប់រូបជួយដល់ជនដែលខ្វះខាតជាទៀងទាត់នោះ ? (ជនណាដែលខ្វះខាត នៅគ្រប់ពេលទាំងអស់) ។
- តើវិធីមួយចំនួនដែលមនុស្សគ្រប់គ្នាទទួលបានអត្ថប្រយោជន៍ កាលយើងទាំងអស់គ្នាមានឆន្ទៈផ្តល់ឲ្យនោះមានអ្វីខ្លះ ?

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃសេចក្តីពិត និងគោលការណ៍ទាំងនេះ ហើយអនុវត្តតាម សូមអានឲ្យឮៗនូវសេចក្តីថ្លែងការណ៍អែលឌើរ ហូឡិនដូចខាងក្រោម ។ សូមអញ្ជើញសិស្សឲ្យស្តាប់មើលរបៀប ដែលព្រះអម្ចាស់អាចជួយយើងឲ្យប្រព្រឹត្តតបចំពោះជនក្រីក្រដោយចិត្តមេត្តាករុណា ។



« ខ្ញុំមិនដឹងប្រាកដថា បងប្អូនម្នាក់ៗគួរបំពេញកាតព្វកិច្ចរបស់បងប្អូនក្នុងការជួយដល់ពួកអ្នកដែលជានិច្চកាល មិនឬ មិនអាចជួយខ្លួនគេដោយរបៀបណានោះទេ ។ តែខ្ញុំដឹងថា ព្រះទ្រង់ជ្រាបដឹង ហើយទ្រង់នឹងជួយអ្នក ហើយដឹកនាំអ្នកក្នុងទង្វើដ៏ពេញដោយក្តីអាណិតអាសូរនៃភាពជាសិស្សនោះ បើអ្នកមានចេតនាចង់ធ្វើ ហើយអធិស្ឋាន ហើយរកមើលរបៀបកាន់តាមបទបញ្ញត្តិ ដែលទ្រង់ប្រទានដល់យើងម្តងហើយម្តងទៀតនោះ » (« Are We Not All Beggars? » ទំព័រ ៤១) ។

ប្រសិនបើមានពេល ហើយអ្នកអាចធ្វើទៅបាន សូមពិចារណាបង្ហាញវីដេអូនៃសុន្ទរកថារបស់អែលឌើរ ហូឡិនក្នុងសន្និសីទទូទៅ « Are We Not All Beggars? » (០:០០–៧:០៤) ។

- តើអែលឌើរ ហូឡិន បានមានប្រសាសន៍ថា យើងគួរធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនជួយដល់ជនក្រីក្រ និងខ្វះខាត ?
- តើវិធីមួយចំនួនដែលសាសនាចក្របានស្តាបនាឡើងដែលយើងអាចជួយបំពេញសេចក្តីត្រូវការរបស់ជនក្រីក្រមានអ្វីខ្លះ ? (តាមរយៈការតមអាហារ គម្រោងសេវាកម្មក្នុងមូលដ្ឋាន និងឱកាសសប្បុរសធម៌) ។

សូមលើកទឹកចិត្តសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាសិក្សាព្រះគម្ពីររបស់ពួកគេនូវរឿងមួយដែលពួកគេអាចធ្វើ ដោយផ្អែកលើអ្វីដែលប៉ុលបានបង្រៀនអំពីការផ្តល់ឲ្យដល់ជនក្រីក្រ និងជនខ្វះខាតនោះ ។

សូមសង្ខេប កូរិនថូសទី ២ ៨:១៦–២៤ ដោយពន្យល់ថា ប៉ុលបានថ្លែងទៅកាន់ពួកបរិសុទ្ធនៅកូរិនថូសអំពីទីតុស និងបងប្អូនប្រុសពីរនាក់ផ្សេងទៀត ដែលត្រូវបានបញ្ជូនឲ្យទៅប្រមូលការបរិច្ចាគសប្បុរសធម៌សម្រាប់ពួកបរិសុទ្ធនៅក្រុងយេរូសាឡិម ។ ប៉ុលបានថ្លែងអំពីទំនុកចិត្តរបស់លោកទៅលើពួកបរិសុទ្ធនៅកូរិនថូស ហើយបានពន្យល់ថា ការផ្តល់ឲ្យដ៏សប្បុរសរបស់ពួកគេនឹងក្លាយជាភស្តុតាងអំពីសេចក្តីស្រឡាញ់របស់ពួកគេចំពោះមនុស្សដទៃ ។

កូរិនថូសទី២ ៩

ប៉ុលបង្រៀនអំពីពរជ័យនៃការធ្វើជាអ្នកផ្តល់ឲ្យដ៏ស្មោះម្នាក់

សូមសង្ខេប កូរិនថូសទី ២ ៩:១–៥ ដោយពន្យល់ថា ប៉ុលបានបន្តសរសើរដល់ពួកបរិសុទ្ធនៅកូរិនថូស ។ លោកបានប្រាប់ពួកបរិសុទ្ធថា លោកបានបញ្ជូនទីតុស និងមនុស្សផ្សេងទៀតឲ្យបញ្ចាក់ពីឆន្ទៈផ្តល់ឲ្យដ៏សប្បុរសរបស់ពួកគេ ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា តើពួកគេធ្លាប់ផ្តល់អ្វីមួយដល់មនុស្សម្នាក់ ឬផ្តល់ការបម្រើមួយដល់មនុស្សម្នាក់ទាំងមានចិត្តទើសទាល់ដែរឬទេ ។

- ហេតុអ្វីពេលខ្លះវាជារឿងពិបាកដើម្បីមានចិត្តរីករាយក្នុងការផ្តល់ពេលវេលា ប្រាក់កាស ឬធនធានផ្សេងទៀតរបស់អ្នកដើម្បីជួយដល់មនុស្សដទៃ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ៩:៦–៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការប្រៀបធៀប ដែលប៉ុលបានប្រើដើម្បីបង្រៀនសមាជិកនៅកូរិនថូសអំពីការផ្តល់ឲ្យដ៏សប្បុរស ។

- តើការសាបព្រោះ មានអត្ថន័យយ៉ាងណាដែរ ? (ការដាំគ្រាប់ពូជ) ។
- តើប៉ុលបានប្រៀបធៀបអ្វីទៅនឹងការសាបព្រោះ ? (ការផ្តល់ឲ្យដល់មនុស្សដទៃ) ។

ចូរលើកគ្រាប់ពូជផ្លែឈើ ឬបន្លែមួយចំនួនឡើង ឬដាក់បង្ហាញរូបភាព នៃគ្រាប់ពូជមួយចំនួន ។



- តើអ្នកព្រោះពូជនៅក្នុងការប្រៀបធៀបនេះជានរណា ? (ពួកបរិសុទ្ធ ឬយើង) ។
- យោងតាម ខទី ៧តើព្រះអម្ចាស់រំពឹងឲ្យយើងសាបព្រោះ ឬផ្តល់ឲ្យតាមរបៀបណា ? (ដោយរីករាយ ដោយមិនទើសទាល់ ។ សូមមើលផងដែរ ម៉ាថាយ ៦:៨) ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *ប្រសិនបើយើងផ្តល់ដល់ជនខ្វះខាតដោយដួងចិត្តរីករាយ . . .*

- តើការផ្តល់ឲ្យមនុស្សដទៃប្រៀបបាននឹងការសាបព្រោះគ្រាប់ពូជនៅក្នុងទីវាលយ៉ាងដូចម្តេច ?
- តើមានអ្វីកើតឡើងប្រសិនបើយើងសាបព្រោះតែបន្តិចបន្តួចនោះ ?
- តើមានអ្វីកើតឡើងប្រសិនបើយើងសាបព្រោះដោយសទ្ធានោះ ?

សូមបញ្ចប់គោលការណ៍នៅលើក្តារខៀន ដើម្បីវានាំទៅរកសេចក្តីពិតដូចខាងក្រោម ៖ **ប្រសិនបើយើងផ្តល់ដល់ជនខ្វះខាតដោយដួងចិត្តរីករាយ នោះព្រះនឹងប្រទានពរដល់យើងដោយព្រះទ័យសប្បុរស ។**

- តើការផ្តល់ឲ្យមនុស្សដទៃដោយឥរិយាបថរីករាយ ពិតជាដឹកនាំឆ្ពោះទៅរកការទទួលបានពរជ័យ លើសពីដើមទុនដំបូងរបស់យើងតាមរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ៩:៨–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលពរជ័យដែលប៉ុលបានលើកឡើងថា នឹងកើតមានចំពោះពួកបរិសុទ្ធ ប្រសិនបើពួកគេបានផ្តល់ឲ្យដោយមានដួងចិត្តរីករាយ ។

- តើឃ្លាមួយចំនួនដែលប៉ុលធ្លាប់ប្រើ ដើម្បីរៀបរាប់ពីពរជ័យដែលព្រះអម្ចាស់ប្រទានដល់ជនដែលផ្តល់ឲ្យដោយដួងចិត្តរីករាយមានអ្វីខ្លះ ? (ចម្លើយអាចរួមមាន « គ្រប់ទាំងព្រះគុណបានចម្រើនដល់អ្នករាល់គ្នា » [ខទី ៨] « ឲ្យមានទាំងអស់គ្រប់គ្រាន់ជានិច្ច » [ខទី ៨] « សេចក្តីសុចរិតទ្រង់នៅជាប់អស់កល្បជានិច្ច » [ខទី ៩] និង « ចម្រើនផលពីការសុចរិតរបស់អ្នករាល់គ្នាផង » [ខទី ១០]) ។

សូមពន្យល់ថា ឃ្លាទាំងនេះប្រាប់ថា យើងនឹងទទួលបានព្រះគុណរបស់ព្រះអម្ចាស់ ដែលរួមបញ្ចូលទាំងពរជ័យខាងសាច់ឈាម យ៉ាងគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការរបស់យើង ។

- យោងតាម ខទី ១០ តើ « អ្នកផ្គត់ផ្គង់ពូជសម្រាប់អ្នកដែលព្រោះ » ជានរណា ? (ព្រះអម្ចាស់ ។ សូមដាក់បង្ហាញគ្រាប់ពូជនោះម្តងទៀត ហើយពន្យល់ថា យើងអាចផ្តល់ឲ្យដល់មនុស្សដទៃបាន ដោយសារព្រះអម្ចាស់បានប្រទានដល់យើងពីដំបូង) ។
- តើការចងចាំថា គ្រប់អ្វីដែលយើងមានបានមកពីណា អាចជួយយើងឲ្យបរិច្ចាគដោយរីករាយយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង កូរិនថូសទី ២ ៩:១១–១៥ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះ អំពីពួកបរិសុទ្ធដែលផ្តល់ឲ្យ ហើយទទួលដោយរីករាយ ។

- យោងតាម ខទី ១១–១៥ តើពួកបរិសុទ្ធដែលផ្តល់ឲ្យដោយសប្បុរស ហើយពួកបរិសុទ្ធដែលទទួលបានទ្រព្យពីគ្នាទៅវិញទៅមកមានអារម្មណ៍យ៉ាងដូចម្តេចចំពោះព្រះ ?

អ្នកអាចអញ្ជើញសិស្សឲ្យគិតធ្វើការគូសចំណាំឃ្លានានាស្តីពីការដឹងគុណ ដែលមាននៅក្នុងខគម្ពីរទាំងនេះដូចជា « ដែលនឹងបង្កើតសេចក្តីអរព្រះគុណដល់ព្រះ ដោយសារយើងរាល់គ្នា » (ខទី ១១) « ពាក្យគេអរព្រះគុណជាច្រើន » (ខទី ១២) « គេសរសើរតម្កើងដល់ព្រះ » (ខទី ១៣) ហើយ « អរព្រះគុណដល់ព្រះអង្គ ដោយព្រោះអំណោយទានទ្រង់ដ៏ក៏ថ្លៃងពុំបាន » (ខទី ១៥) ។

អ្នកគួរផ្តល់យោបល់ឲ្យសិស្សសរសេរសេចក្តីពិតខាងក្រោមនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ខទី ១១–១៥ ៖ **ការស្គាល់ពីព្រះទ័យសប្បុរសរបស់ព្រះនៅក្នុងការប្រទានពរជ័យដល់យើងអាចជួយយើងឲ្យមានការដឹងគុណចំពោះទ្រង់ ។**

- តើអ្នកធ្លាប់មានការដឹងគុណចំពោះព្រះនៅពេលណា បន្ទាប់ពីស្គាល់ពរជ័យដែលទ្រង់បានបញ្ជូនមកដល់អ្នកសម្រាប់ការបម្រើ និងការផ្តល់ឲ្យមនុស្សដទៃដោយចិត្តរីករាយនោះ ?

សូមថ្លែងទីបន្ទាល់ពីគោលការណ៍ និងសេចក្តីពិតដែលសិស្សបានស្គាល់នៅក្នុង កូរិនថូសទី២ ៨–៩ ។

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាពីវិធី ដែលពួកគេអាចជួយមនុស្សម្នាក់ដែលមានសេចក្តីត្រូវការនៅសប្តាហ៍នេះ ។ សូមអញ្ជើញពួកគេឲ្យកំណត់គោលដៅមួយដើម្បីជួយបុគ្គលនោះ ។

កូរិនថូសទី២ ១០–១៣

សេចក្តីផ្តើម

សាវកប៉ុលបានបង្រៀនអំពីសង្គ្រាមខាងវិញ្ញាណ ដែលកូនចៅរបស់ព្រះចូលប្រឡូក ។ លោកបាននិយាយការពារខ្លួនជំទាស់នឹងជនដែលបដិសេធលោក ។ លោកបានដំណាលម្តងទៀតអំពីរបៀបដែលលោកត្រូវបាននាំចូលទៅក្នុងស្ថានសួគ៌ទីបី ហើយបានពិពណ៌នាអំពីរបៀបដែលភាពទន់ខ្សោយរបស់លោកបានបង្ហាញថា ជាពរជ័យមួយ ។ ពីមុនបញ្ចប់សំបុត្ររបស់លោក ប៉ុលបានជាស់តឿនពួកបរិសុទ្ធនៅកូរិនថូសឲ្យត្រួតពិនិត្យមើលខ្លួនឯង ហើយបង្ហាញសេចក្តីស្មោះត្រង់របស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

កូរិនថូសទី២ ១០–១១

ប៉ុលសរសេរអំពីសុខុមាលភាពខាងវិញ្ញាណ ការបោកបញ្ឆោតរបស់សាតាំង និងសេចក្តីទុក្ខលំបាកផ្ទាល់ខ្លួនរបស់លោក

សូមសរសេរពាក្យ *សង្គ្រាម* នៅលើក្តារខៀន ។

- **តើយើងចូលប្រឡូកនៅក្នុងសង្គ្រាមជំទាស់នឹងសាតាំងបានយ៉ាងដូចម្តេច ?**
- **តើសង្គ្រាមដ៏លំបាកបំផុតមួយចំនួន ដែលយើងជួបនៅក្នុងសង្គ្រាមខាងវិញ្ញាណនេះមានអ្វីខ្លះ ?**

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ១០:៣–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានបង្រៀនថាយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមានជោគជ័យនៅក្នុងសង្គ្រាមជំទាស់នឹងសាតាំង ។

- **តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីមានជ័យជំនះនៅក្នុងសង្គ្រាមជំទាស់នឹងសាតាំង?**
- **តើអ្នកគិតថា ការនាំ « អស់ទាំងគំនិតឲ្យចុះចូលស្តាប់បង្គាប់ព្រះគ្រីស្ទ » មានន័យដូចម្តេច ? (ខទី ៥) ។**
- **តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុង ខទី ៥ អំពីរបៀបដើម្បីទទួលបានជោគជ័យ នៅក្នុងសង្គ្រាមជំទាស់នឹងសាតាំង? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **នៅពេលយើងគ្រប់គ្រងគំនិតដោយការស្តាប់បង្គាប់តាមព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងកាន់តែមានជោគជ័យនៅក្នុងសង្គ្រាមជំទាស់នឹងសាតាំង**) ។**
- **តើយើងអាចធ្វើអ្វីខ្លះ ដើម្បីគ្រប់គ្រងគំនិតរបស់យើង ? (ក្នុងចំណោមរឿងផ្សេងទៀត យើងអាចអធិស្ឋាន ទន្ទេញចាំបទគម្ពីរ ហើយច្រៀង ឬទន្ទេញចាំទំនុកតម្កើងព្រះ:) ។**


អ្នកគួរចែកចាយបទពិសោធន៍មួយ ដែលបង្ហាញអំពីរបៀបគ្រប់គ្រងគំនិតរបស់អ្នក ដោយការស្តាប់បង្គាប់តាមព្រះអង្គសង្គ្រោះ ឲ្យជួយអ្នក ឲ្យកឈ្នះលើឥទ្ធិពលរបស់សាតាំង ។ សូមពិចារណាអញ្ជើញសិស្សឲ្យចែកចាយពីបទពិសោធន៍ថ្មីៗរបស់ពួកគេផងដែរ ។ សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយ ដើម្បីគ្រប់គ្រងគំនិតរបស់ពួកគេឲ្យកាន់តែប្រសើរឡើង ដោយស្តាប់បង្គាប់តាមព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីសង្ខេបដូចខាងក្រោមឲ្យឮៗ ៖

នៅក្នុង កូរិនថូសទី២ ១០:៧–១៨ យើងរៀនថា ប៉ុលបានទទួលសិរីល្អនៅក្នុងព្រះអម្ចាស់ ហើយបានបង្រៀនថា ភាពទន់ខ្សោយរបស់លោកពុំគួរយកមកប្រើទុកជាដំណោះសារ ដោយការពុំស្តាប់តាមទ្រង់នោះឡើយ ។ នៅក្នុង កូរិនថូសទី២ ១១ យើងអានថា ប៉ុលបានលើកឡើងអំពីវិធីបន្ថែមទៀត ដែលសាតាំងខិតខំបំផ្លាញគំនិតរបស់យើង ហើយនាំយើងឲ្យឃ្លាតចេញពីព្រះយេស៊ូវគ្រីស្ទ រួមបញ្ចូលទាំងការប្រើព្រះគ្រីស្ទក្លែងក្លាយ និងពួកសាវកក្លែងក្លាយ ។ ប៉ុលបានដំណាលឡើងវិញពីការរងទុក្ខដែលលោកបានស៊ូទ្រាំ ក្នុងនាមជាសាវកដ៏ពិតមួយរបស់ព្រះអង្គសង្គ្រោះ ។

កូរិនថូសទី២ ១២

ប៉ុលបានដំណាលឡើងវិញពីការត្រូវបាននាំទៅស្ថានសួគ៌ ហើយបង្រៀនថា ការទទួលស្គាល់ភាពទន់ខ្សោយរបស់យើងអាចផ្តល់ប្រយោជន៍ដល់យើងយ៉ាងដូចម្តេច



សូមយកបន្លាមួយមកថ្នាក់រៀន ឬគូររូបភាពបន្លាមួយនៅលើក្តារខៀន ឲ្យស្រដៀងនឹងរូបដែលបានបង្ហាញនេះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាពីពេលដែលពួកគេធ្លាប់មុតនឹងបន្លា ។

- **តើបន្លាអាចធ្វើឲ្យជីវិតរបស់យើងមានការលំបាកយ៉ាងដូចម្តេច ?**

សូមពន្យល់ថា ប៉ុលបានប្រើទស្សនៈអំពីបន្លាជានិមិត្តរូបនៃការសាកល្បង ឬភាពទន់ខ្សោយមួយ ដែលលោកបានជួប ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ ហើយពិចារណាថាតើការសោកល្បង ឬភាពទន់ខ្សោយប្រភេទណាខ្លះ ដែលពួកគេ ឬមនុស្សជាទីស្រឡាញ់របស់ពួកគេធ្លាប់បានជួបប្រទះ ។

« មានមនុស្សខ្លះបានបាត់បង់មនុស្សជាទីស្រឡាញ់ ឬមើលថែមនុស្សពិការម្នាក់ ។ ខ្លះធ្លាប់រងរបួសដោយការលែងលះគ្នា ។ . . . រីឯខ្លះទៀតមានរូបកាយពិការ ឬការឈឺចាប់ខាងផ្លូវចិត្ត ។ ខ្លះបានប្រឈមនឹងការចាប់ចិត្តទៅលើភេទដូចគ្នា ។ ខ្លះមានអារម្មណ៍អាក្រក់ដោយសារការព្រួយចិត្តយ៉ាងខ្លាំង ឬគុណវិបត្តិ ។ តាមរបៀបណាមួយក្តី គឺមានមនុស្សជាច្រើនដែលមានបន្ទុកធ្ងន់ » (« He Heals the Heavy Laden » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៦) ។

នៅពេលសិស្សសិក្សាកូរិនថូសទី២ ១២សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេ នៅពេលពួកគេជួបការសោកល្បង និងភាពទន់ខ្សោយនានា ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ១២:១–៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការនិមិត្តមួយ ដែលបានកើតឡើងដល់ប៉ុល ។ (សូមពន្យល់ថា ខគម្ពីរទាំងនេះសំដៅទៅលើប៉ុលក្នុងនាមជាបុគ្គលទីបី) ។

- តើអ្នកគិតថា វាមានន័យយ៉ាងដូចម្តេចដែរ ចំពោះឃ្លាថាប៉ុលត្រូវបាននាំ « ឡើងទៅស្ថានសួគ៌នៅជាន់ទីបី » ? (ខទី ២) ។ (លោកមានការនិមិត្តមួយអំពីនគរសេឡេស្ទាល) ។

សូមពន្យល់ថា ឃ្លា « ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយ នោះខ្ញុំមិនដឹងទេ » (ខទី ២) មានន័យថា ប៉ុលពុំបានដឹងថា លោកត្រូវនាំទៅនគរសេឡេស្ទាល ឬបានមានការនិមិត្តមួយអំពីនគរនោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ១២:៥–៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានឆ្លើយតបទៅនឹងការនិមិត្តនេះយ៉ាងដូចម្តេច ។

- តើ ប៉ុលបានអនុវត្តយ៉ាងដូចម្តេច ទៅនឹងការនិមិត្តនេះ ?
- តើប៉ុលបានបារម្ភថាអាចនឹងមានអ្វីកើតឡើង ប្រសិនបើលោកបានលើកតម្កើងខ្លួនឯងនោះ ? (ប៉ុលបានព្រួយចិត្តថា មនុស្សដទៃអាចគិតថា លោកជាមនុស្សថ្កុំថ្កើងពេក កាលដែលលោកនៅមានឧបសគ្គនៅក្នុងជីវិតដែលត្រូវយកឈ្នះ) ។

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ១២:៧–៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានជួយប៉ុលឲ្យបន្តមានចិត្តរាបសាបានយ៉ាងដូចម្តេច ។ អ្នកគួរពន្យល់ថាការ « កើតមានចិត្តធំ » (ខទី ៧) មានន័យថា ការមានចិត្តអួតអាង ។

- តើព្រះអម្ចាស់បានជួយប៉ុលឲ្យបន្តមានចិត្តរាបសាបានយ៉ាងដូចម្តេច ?
- តើប៉ុលបានអធិស្ឋានប៉ុន្មានដងដើម្បីដកយក « បន្លា ១ ចាត់មកក្នុងសាច់ឈាម » ?

សូមចង្អុលបង្ហាញថា ថ្វីបើប៉ុលបានអធិស្ឋានយ៉ាងណាក្តី ក៏ព្រះអម្ចាស់ទំនងជាពុំជ្រើសយកការដកយក« បន្លា១ចាត់មកក្នុងសាច់ឈាម » របស់ប៉ុលចេញឡើយ ។

- តើយើងអាចរៀនពីប៉ុលអ្វីខ្លះ ទាក់ទងនឹងហេតុផលដែលព្រះអម្ចាស់ប្រហែលជាអនុញ្ញាតឲ្យយើងជួបនូវភាពទន់ខ្សោយ និងការសោកល្បង ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់អំពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់ប្រហែលជាអនុញ្ញាតឲ្យយើងជួបប្រទះនឹងភាពទន់ខ្សោយ និងការសោកល្បង ដើម្បីឲ្យយើងអាចរៀនបន្ទាបខ្លួន ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សអាន កូរិនថូសទី២ ១២:៩–១០ ដោយស្ងៀមស្ងាត់ ហើយរកមើលសេចក្តីពិតដែលប៉ុលបានរៀន ដែលវាបានជួយលោកឲ្យស៊ូទ្រាំនឹងភាពទន់ខ្សោយទាំងឡាយរបស់លោក ។ ចូរសុំឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេអំពីសេចក្តីពិត ដែលពួកគេស្គាល់ ។

- តើប៉ុលបានរៀនសេចក្តីពិតអ្វីខ្លះ ដែលវាបានជួយលោកឲ្យស៊ូទ្រាំនឹងភាពទន់ខ្សោយរបស់លោក ? (សិស្សអាចស្គាល់សេចក្តីពិតមួយចំនួនដូចខាងក្រោមនេះ ៖ **ព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទមានល្មមគ្រប់គ្រាន់ ដើម្បីពង្រឹងយើងនៅក្នុងភាពទន់ខ្សោយរបស់យើង ។ ជានិច្চកាល ព្រះអម្ចាស់ពុំរកយកការប្រឈមរបស់យើងចេញឡើយ ប៉ុន្តែទ្រង់នឹងពង្រឹងយើង កាលណាយើងស៊ូទ្រាំវាដោយស្មោះត្រង់**) ។

សូមរំឭកសិស្សថា *ព្រះគុណ* គឺជា « ជំនួយ និងកម្លាំងពីព្រះ » ដែលត្រូវបានប្រទានឲ្យតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ (Bible Dictionary « ព្រះគុណ ») ។

- តើឃ្លាដែលចែងថា ព្រះគុណរបស់ព្រះអង្គសង្គ្រោះមានល្មមគ្រប់គ្រាន់ ដើម្បីពង្រឹងយើងនៅក្នុងភាពទន់ខ្សោយរបស់យើងមានន័យដូចម្តេច ? (តាមរយៈកម្លាំងដែលយើងទទួលបានពីព្រះអង្គសង្គ្រោះ យើងអាចធ្វើកិច្চការទាំងអស់ដែលទ្រង់បានបញ្ជាឲ្យយើងធ្វើ) ។

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ឲ្យឮៗ ៖

« អំណាចនៃការព្យាបាលរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ—មិនថាវាបានដកយកបន្ទុកយើងចេញ ឬពង្រឹងយើងឲ្យស៊ូទ្រាំ ហើយរស់នៅជាមួយនឹងវាដូចជាសាវកប៉ុលនោះទេ—គឺមានសម្រាប់រាល់ការរងទុក្ខនៅក្នុងជីវិតរមែងស្លាប់នេះ » (« He Heals the Heavy Laden » ទំព័រ ៨) ។

- តើសេចក្តីពិតដែលយើងបានស្គាល់នៅក្នុង ខទី ៩–១០ អាចជួយយើង នៅពេលយើងជួបនឹងភាពទន់ខ្សោយ និងការសោកល្បងបានយ៉ាងដូចម្តេច ?

អញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់

អ្នកអាចលើកទឹកចិត្តសិស្សឲ្យថ្លែងទីបន្ទាល់អំពីសេចក្តីពិតដ៏ណឹងល្អតាមរយៈការសួរសំណួរដែលអញ្ជើញពួកគេឲ្យចែកចាយពីបទពិសោធន៍ និងជំនឿរបស់ពួកគេ ។ នៅពេលសិស្សថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៃដំណឹងល្អ ជារឿយៗព្រះវិញ្ញាណបរិសុទ្ធអាចដឹកនាំពួកគេឆ្ពោះទៅកាន់ទីបន្ទាល់មួយកាន់តែស៊ីជម្រៅអំពីរឿងដែលពួកគេកំពុងបង្ហាញ ។ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណ នោះពាក្យសម្តីរបស់ពួកគេក៏អាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើជួងចិត្តមិត្តភក្តិរបស់ពួកគេផងដែរ។

- តើអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់បានទទួលកម្លាំងមកពីព្រះអង្គសង្គ្រោះនៅពេលណា ? (សូមរំឭកសិស្សកុំឲ្យចែកចាយអ្វីដែលសម្ងាត់ផ្ទាល់ខ្លួន ឬឯកជនពេក) ។ តើបទពិសោធន៍នោះគឺជាពរជ័យមួយចំពោះអ្នក ឬពួកគេយ៉ាងដូចម្តេច ?

កូរិនថូសទី២ ១៣

ប៉ុលដាស់តឿនពួកបរិសុទ្ធឲ្យពិនិត្យមើលខ្លួនឯង ហើយបង្ហាញនូវភាពស្មោះត្រង់របស់ខ្លួនផ្ទាល់

សូមរំឭកសិស្សថា មានពួកគ្រូបង្រៀនក្លែងក្លាយនៅក្នុងចំណោមពួកបរិសុទ្ធនៅកូរិនថូស ដែលបានសួរដេញដោលឲ្យប៉ុលបង្ហាញសិទ្ធិអំណាចរបស់លោក ក្នុងនាមជាសាវកមួយរូប ។

- តើឧទាហរណ៍មួយចំនួនអំពីរបៀប ដែលប្រជាជនសព្វថ្ងៃអាចសួរដេញដោលអស់អ្នកដែលត្រូវបានហៅឲ្យបម្រើក្នុងតំណែងថ្នាក់ដឹកនាំក្នុងសាសនាចក្រមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី២ ១៣:៣ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា សមាជិកសាសនាចក្រនៅកូរិនថូសចង់ឃើញភស្តុតាងអ្វីខ្លះ ។

- តើសមាជិកសាសនាចក្រនៅកូរិនថូសចង់ឃើញភស្តុតាងអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន កូរិនថូសទី ២ ១៣:៥–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធនៅកូរិនថូសឲ្យធ្វើអ្វីខ្លះជាជាងសួរសំណួរថា ព្រះអម្ចាស់បានមានបន្ទូលតាមរយៈលោកជាសាវកដែរឬក៏អត់នោះ ។ សូមពន្យល់ថា ពាក្យ*ត្រូវភាគ់ចោលចេញ* គឺជាមនុស្សម្នាក់ដែលពុករលួយ ឬអសីលធម៌ ។

- យោងតាម ខទី៥ តើប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធនៅកូរិនថូសធ្វើអ្វីខ្លះ ? (អ្នកគួរលើកទឹកចិត្តសិស្សឲ្យគូសចំណាំខគម្ពីរនេះត្រង់ពាក្យ *ពិចារណាមើល ល្បងមើល* និង *យល់ឃើញ* នៅក្នុងខគម្ពីរនេះ) ។
- តើប៉ុលបាននិយាយថា ពួកបរិសុទ្ធទាំងនេះត្រូវពិចារណាមើលអ្វីខ្លះពីខ្លួនឯង ? (សូមពន្យល់ថាការ « ស្ថិតនៅក្នុងសេចក្តីជំនឿ » [ខទី ៥] មានន័យថាការស្មោះត្រង់ចំពោះសាសនាចក្ររបស់ព្រះអម្ចាស់) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីខគម្ពីរទាំងនេះថា យើងគួរធ្វើអ្វីខ្លះជំនួសឲ្យការរិះគន់ដល់ថ្នាក់ដឹកនាំសាសនាចក្រ ? (សិស្សគួរកត់ឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ជំនួសឲ្យការរិះគន់ដល់ថ្នាក់ដឹកនាំសាសនាចក្រ សមាជិកសាសនាចក្រគួរពិចារណាមើលពីសេចក្តីស្មោះត្រង់របស់ខ្លួន**) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ៖

« [ប្រសិនបើមនុស្សម្នាក់] ក្រោកឡើងប្តោលទោសដល់មនុស្សដទៃ ដោយស្វែងរកកំហុសជំទាស់នឹងសាសនាចក្រ ហើយនិយាយថាពួកគេគ្មានជម្រើសទេ ដោយសារគាត់ជាមនុស្សសុចរិត វាប្រាកដណាស់ថា មនុស្សម្នាក់នោះកំពុងស្ថិតនៅក្នុងផ្លូវឆ្ពោះទៅរកការក្បត់សាសនា ហើយប្រសិនបើគាត់ពុំប្រែចិត្តទេ នោះគាត់នឹងក្បត់សាសនាយ៉ាងពិតប្រាកដ ដរាបណាព្រះទ្រង់មានព្រះជន្ម» (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ៣១៨) ។

- តើនឹងមានអ្វីខ្លះកើតឡើង ប្រសិនបើយើងរិះគន់ថ្នាក់ដឹកនាំរបស់យើងជំនួសឲ្យការពិចារណាមើលពីភាពស្មោះត្រង់របស់ខ្លួននោះ ?

ដើម្បីជួយសិស្សឲ្យពិចារណាមើលអំពីភាព ស្មោះត្រង់ និងឥរិយាបថរបស់ខ្លួនចំពោះថ្នាក់ដឹកនាំសាសនាចក្រ សូមចែកសំណៅចម្លងសំណួរខាងក្រោមនេះដល់ពួកគេ ។ សូមទុកឲ្យសិស្សមានពេលគ្រប់គ្រាន់ដើម្បីអាន ហើយឆ្លើយសំណួរដោយស្ងៀមស្ងាត់ ។

---

១. ពីលេខ ១–១០ (១០ គឺល្អឥតខ្ចោះ) តើអ្នកធ្វើតាមការទូន្មានរបស់ថ្នាក់ដឹកនាំសាសនាចក្របានល្អដល់កម្រិតណា ?

២. តើបទដ្ឋានណាមួយដែលពួកព្យាការី និងពួកសាវកបានបង្រៀន ដែលអ្នកអាចធ្វើតាមបានយ៉ាងស្មោះត្រង់ ?

៣. ពីលេខ ១–១០ (១០ គឺគ្រប់ឱកាសដែលអ្នកមាន) តើអ្នកបានសម្តែងការដឹងគុណចំពោះថ្នាក់ដឹកនាំសាសនាចក្ររបស់អ្នកមិនថាដោយផ្ទាល់ ឬនៅក្នុងការអធិស្ឋាន បានញឹកញាប់ប៉ុណ្ណាដែរ ?

៤. តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញការដឹងគុណកាន់តែខ្លាំងចំពោះការលះបង់ និងការខិតខំដែលថ្នាក់ដឹកនាំរបស់អ្នកបានធ្វើ សម្រាប់ប្រយោជន៍របស់អ្នក ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- តើពរជ័យអ្វីខ្លះ ដែលអាចកើតចេញពីការធ្វើការពិចារណាមើលខ្លួនឯងខាងវិញ្ញាណបែបនេះជាទៀងទាត់ ?

សូមសង្ខេប កូរិនថូសទី២ ១៣:៧–១៤ ដោយពន្យល់ថា ប៉ុលបានដាស់តឿនពួកបរិសុទ្ធឲ្យចៀសចេញពីអំពើអាក្រក់ ហើយខិតខំឲ្យបានល្អឥតខ្ចោះ ។

ចូរថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលអ្នកបានពិភាក្សានៅក្នុងមេរៀននេះ ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅជាក់លាក់មួយ អំពីរបៀបដែលពួកគេនឹងអនុវត្តសេចក្តីពិតមួយក្នុងចំណោមសេចក្តីពិតទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

ការរំឭកចំណេះចំណានខគម្ពីរ

ការយល់របស់សិស្សអំពីវគ្គក្នុងព្រះគម្ពីរនឹងកើនឡើង នៅពេលពួកគេបង្កើតសំណួរផ្ទាល់ខ្លួនអំពីវគ្គទាំងនោះ ។ សូមចែកសិស្សជាពីរក្រុម (ឬច្រើន) ។ សូមអញ្ជើញក្រុមទាំងឡាយឲ្យសរសេរតម្រុយដែលចង្អុលបង្ហាញទៅរកវគ្គចំណេះចំណានខគម្ពីរដាក់លាក់ ។ (អ្នកអាចជ្រើសរើសក្រុមនៃវគ្គចំណេះចំណានខគម្ពីរមួយ ដែលអ្នកចង់ឲ្យសិស្សរៀន ឬ រំឭក) ។ សូមលើកទឹកចិត្តសិស្សកុំឲ្យបង្កើតតម្រុយសុគស្ញាញហួសហេតុពេក ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញក្រុមទាំងឡាយឲ្យប្តូរវេនគ្នាអានតម្រុយរបស់ខ្លួនឮៗដើម្បីចង់ដឹងថា តើតម្រុយរបស់ក្រុមមួយទៀតអាចបង្ហាញពីវគ្គត្រឹមត្រូវដែរឬទេ ។

កំណត់ចំណាំ ៖ ប្រសិនបើអ្នកមិនមានពេលប្រើសកម្មភាពនេះជាផ្នែកនៃមេរៀននេះទេ អ្នកអាចប្រើវានៅថ្ងៃក្រោយក៏បាន ។ (មេរៀនបន្ទាប់គឺជាមេរៀនខ្លី ។ អ្នកអាចមានពេលប្រើសកម្មភាពនេះ) ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់ពួកកាឡាទី

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្ររបស់ប៉ុលដល់ពួកកាឡាទី គឺជាការសរសេរទៅពួកគ្រីស្ទានជាសាសន៍យូដាដែលវង្វេងចេញពីព្រះអម្ចាស់ ព្រោះតែពឹងផ្អែកជាថ្មីទៅលើកិច្ចការនៃក្រឹត្យវិន័យរបស់ម៉ូសេ ។ សាវក ប៉ុលបានខិតខំកែតម្រូវបញ្ហានេះដោយគូសបញ្ជាក់ពីភាពខុសគ្នារវាង « នឹម » ដ៏ធ្ងន់នៃក្រឹត្យវិន័យរបស់ម៉ូសេដែលបានដឹកនាំទៅរកទាសភាពខាងវិញ្ញាណ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលដឹកនាំទៅរកសេរីភាពខាងវិញ្ញាណ ។ ការសិក្សាសំបុត្រនេះអាចជួយសិស្សឲ្យមានអំណរគុណកាន់តែខ្លាំងឡើងពីសេរីភាព ដែលមានតាមរយៈដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

សាវកប៉ុលបានសរសេរទៅពួកកាឡាទី (សូមមើល កាឡាទី ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ប៉ុលទំនងជាសរសេរសំបុត្ររបស់លោកទៅពួកកាឡាទី កាលលោកកំពុងធ្វើដំណើរឆ្លងកាត់ស្រុកម៉ាសេដូនៅក្នុងដំណើរផ្សាយសាសនាលើកទីបីរបស់លោកប្រមាណជា គ.ស. ៥៥–៥៧ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយតើហេតុអ្វី ?

« មានភាពមិនច្បាស់លាស់មួយចំនួនចំពោះព្រះវិហារទាំងឡាយដែលបានលើកឡើងនៅក្នុងសំបុត្រនេះ ។ ព្រះវិហារទាំងនោះអាចនៅភាគខាងជើងកាឡាទី ជាស្រុកក្នុងទីក្រុងអាន់ស៊ីរ៉ា ឬអាចនៅក្នុងស្រុកតាមព្រំប្រទល់រវាងស្រុកព្រីគា និងកាឡាទី ដែលប៉ុលបានទៅនៅក្នុងពេលការដំណើរផ្សព្វផ្សាយសាសនាលើកទីមួយរបស់លោក ។ នៅក្នុងករណីទាំងពីរនេះ បង្ហាញថាប៉ុលបានទៅព្រះវិហារនៅកាឡាទីនៅក្នុងការដំណើរដោលើកទីពីរ (កិច្ចការ ១៦:៦) និងដាលើកទីបី (កិច្ចការ ១៨:២៣) របស់លោក » (Bible Dictionary « Pauline Epistles: Epistle to the Galatians ») ។

ប៉ុលបានសរសេរសំបុត្រទៅពួកបរិសុទ្ធនៅកាឡាទីដោយសារលោកបានបារម្ភយ៉ាងខ្លាំងថា ពួកគេនឹងឃ្លាតឆ្ងាយពីព្រះអម្ចាស់ ដោយការធ្វើតាមការបង្រៀនរបស់ជនមួយចំនួនដែលចង់ « បង្ខូចដំណឹងល្អព្រះគ្រីស្ទ » (សូមមើល កាឡាទី ១:៦–៧) ។ ពួកគ្រីស្ទានជាសាសន៍យូដា កំពុងបង្រៀនពួកគ្រីស្ទានជាសាសន៍ដទៃពីគោលលទ្ធិខុសឆ្គងថា ពួកគេត្រូវតែកាត់ស្បែក ហើយគោរពតាមតម្រូវការតាមក្បួនតែនៃក្រឹត្យវិន័យរបស់ម៉ូសេដើម្បីឲ្យបានសេចក្តីសង្គ្រោះ (សូមមើល កាឡាទី ៦:១២, សូមមើលផងដែរ កិច្ចការ ១៥:១) ។ ពួកបរិសុទ្ធមួយចំនួននៅកាឡាទីបានឱបក្រសោបយកការបង្រៀនរបស់ជនទាំងនេះ (សូមមើល កាឡាទី ៤:១០) ។

គោលបំណងចម្បងរបស់ប៉ុលនៅក្នុងការសរសេរសំបុត្រនេះរួមមាន ៖

១. ការការពារខ្លួនលោកទាស់នឹងការចោទប្រកាន់របស់ពួកគ្រូបង្រៀនក្លែងក្លាយ ដែលបានបដិសេធលោក ។

២. ការបង្រៀនថាមនុស្សទាំងអស់ មិនថាជាសាសន៍យូដា ឬសាសន៍ដទៃទេ ត្រូវបានសង្គ្រោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ដោយការដាក់សេចក្តីជំនឿរបស់ពួកគេលើព្រះយេស៊ូវគ្រីស្ទជំនួសឲ្យការពឹងផ្អែកលើកិច្ចការនៃក្រឹត្យវិន័យរបស់ម៉ូសេ ។

៣. ការបញ្ជាក់ពីតួនាទីនៃក្រឹត្យវិន័យរបស់ម៉ូសេនៅក្នុងផែនការរបស់ព្រះ ។

៤. ភាពខុសគ្នារវាងសេចក្តីសញ្ញាចាស់ ដែលព្រះបានធ្វើតាមរយៈម៉ូសេ និងសេចក្តីសញ្ញាថ្មីនៅក្នុងព្រះគ្រីស្ទ ។

៥. ការអំពាវនាវឲ្យពួកបរិសុទ្ធរស់នៅដោយមានព្រះវិញ្ញាណ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

គម្ពីរកាឡាទីគឺជាសំបុត្រដ៏មានឥទ្ធិពលបំផុតរបស់ប៉ុល ដែលក្នុងសំបុត្រនេះលោកបានធ្វើការស្តីបន្ទោសត្រង់ៗមួយទៅសមាជិកសាសនាចក្រ ដែលកំពុងតែរង្វេង ហើយក៏បន្ទោសដល់ពួកគ្រូបង្រៀនដែលកំពុងតែដឹកនាំពួកគេឲ្យរង្វេងផងដែរ ។ កាឡាទីមាននូវការសរសេរដំបូងគេបង្អស់ប៉ុល ស្តីពីគោលលទ្ធិនៃការបានរាប់ជាសុចរិត—យើងមិនត្រូវបានរាប់ជាសុចរិតដោយសារកិច្ចការនៃក្រឹត្យវិន័យរបស់ម៉ូសេនោះទេ ប៉ុន្តែដោយសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទវិញ ។ សំបុត្រនេះមានភាពផ្ទុយគ្នារវាង « កិច្ចការខាងសាច់ឈាម » និង « ផលផ្លែនៃព្រះវិញ្ញាណ » (កាឡាទី ៥:១៦–២៥) ។

គម្រោង

កាឡាទី ១–២ ប៉ុលសរសេរដល់ពួកបរិសុទ្ធនៅកាឡាទីដោយសារពួកគេបានវង្វេងចេញពីព្រះអម្ចាស់ ហើយឱបក្រសោបយកការបង្រៀនខុសឆ្គងទាំងឡាយ ។ លោកការពារការហៅរបស់លោកក្នុងនាមជាសាវក ដោយរ៉ាយរ៉ាប់អំពីការទាស់ប្រឆាំងរបស់លោកនឹងសាសនាចក្រ និងការប្រែចិត្តជឿរបស់លោក ។ លោកគូសបញ្ជាក់ថាលោកបានទទួលវិវរណៈផ្ទាល់មកពីព្រះ ហើយបញ្ជាក់ថា ការងារបម្រើរបស់លោកដល់ពួកសាសន៍ដទៃត្រូវបានអនុម័តដោយពួកសាវក ។ លោកថ្លែងថា មានពេលមួយ លោកបានជំទាស់នឹងពេត្រុសទាក់ទងនឹងពួកបរិសុទ្ធដែលជាសាសន៍ដទៃ ។ លោកបង្រៀនថាមនុស្សមិនត្រូវបានរាប់ជាសុចរិតដោយសារកិច្ចការនៃក្រឹត្យវិន័យរបស់ម៉ូសេនោះទេ ប៉ុន្តែដោយសេចក្តីជំនឿលើព្រះគ្រីស្ទវិញ ។

កាឡាទី ៣–៤ ប៉ុលការពារសារលិខិតនៃដំណឹងល្អ ។ លោកបង្រៀនថា អ័ប្រាហាំគឺជាគំរូមួយនៃបុគ្គលម្នាក់ដែលបានរាប់ជាសុចរិតដោយសារសេចក្តីជំនឿ ហើយពុំមែនដោយសារកិច្ចការនៃក្រឹត្យវិន័យរបស់ម៉ូសេនោះទេ ។ តាមរយៈដង្វាយធួន នោះព្រះយេស៊ូវគ្រីស្ទបានប្រោសលោះមនុស្សលោកចេញពីបណ្តាសានៃក្រឹត្យវិន័យនេះ ។ គោលបំណងនៃក្រឹត្យវិន័យរបស់ម៉ូសេគឺដើម្បីធ្វើ « ជាអ្នកដឹកនាំយើងរាល់គ្នាទៅដល់ព្រះគ្រីស្ទ » ។ តាមរយៈសេចក្តីជំនឿ និងពិធីបុណ្យជ្រមុជទឹក នោះពួកបរិសុទ្ធទទួលពរជ័យនៃដង្វាយធួន ចូលក្នុងសេចក្តីសញ្ញានៃដំណឹងល្អ ក្លាយជាអ្នកគ្រងមរតកនៃព្រះតាមរយៈព្រះគ្រីស្ទ ហើយពុំមែនជាពួកបាវបម្រើទៀតឡើយ ប៉ុន្តែធ្វើជាកូនចៅនៃព្រះវិញ ។

កាឡាទី ៥–៦ ប៉ុលអំពាវនាវឲ្យពួកបរិសុទ្ធបន្តឹងមាំនៅក្នុងសេចក្តីសញ្ញានៃដំណឹងល្អដែលព្រះគ្រីស្ទបានប្រទានឲ្យ ។ ប៉ុលបង្ហាញពីភាពខុសគ្នារវាងជីវិតមនុស្សម្នាក់ដែលបានចូលប្រឡូកនៅក្នុង « កិច្ចការខាងសាច់ឈាម » និងមនុស្សម្នាក់ដែលរីករាយនឹង « ផលផ្លែនៃព្រះវិញ្ញាណ » ។ លោកបង្រៀនថា ពួកបរិសុទ្ធគួរតែជួយសម្រាលបន្ទុកគ្នាទៅវិញទៅមក ហើយមិនគួរនឿយហត់នៅក្នុងការធ្វើល្អឡើយ ។ យើងនឹងច្រូតកាត់នូវអ្វីដែលយើងបានសាបព្រោះ ។

កាឡាទី ១–៤

សេចក្តីផ្តើម

សាវកប៉ុលបានស្តីបន្ទោសដល់ពួកបរិសុទ្ធនៅកាឡាទីចំពោះការធ្វើតាមការបង្រៀនខុសឆ្គង ហើយបានបង្រៀនថា ពួកគេអាចក្លាយជាអ្នកគ្រងមរតករបស់ព្រះ តាមរយៈការមានសេចក្តីជំនឿ និងការធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

កាឡាទី ១–២

ប៉ុលបានស្តីបន្ទោសដល់ពួកបរិសុទ្ធចំពោះការធ្វើតាមគ្រូបង្រៀនខុសឆ្គង ហើយរលើកទឹកចិត្តពួកគេឲ្យត្រឡប់មកវិញ

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា បងប្អូន ឬមិត្តរបស់ពួកគេម្នាក់បានបង្ហាញប្រាប់ថា ពួកគេពុំប្រាកដថា ការបង្រៀនរបស់សាសនាចក្រគឺជាការពិតទៀតឡើយ ។ ជាលទ្ធផល បុគ្គលនេះបានឈប់ចូលរួមក្នុងសាសនាចក្រ ហើយឈប់រស់នៅតាមដំណឹងល្អតទៅទៀត ។ ចូរសុំឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេអំពីអ្វីដែលពួកគេនឹងនិយាយទៅកាន់បងប្អូន ឬមិត្តម្នាក់នេះ ដើម្បីជួយពួកគេឲ្យដឹងថា ការបង្រៀនរបស់សាសនាចក្រគឺពិត ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាកាឡាទី ១ដែលអាចជួយពួកគេឲ្យដឹងពីរបៀបដើម្បីទទួលស្គាល់ការបង្រៀនពិត ។

ចូរពន្យល់ថា កាឡាទីគឺជាតំបន់មួយនៅអាស៊ីតូចកណ្តាលភាគខាងជើង ដែលរួមមាននូវទីក្រុងជាច្រើន ដែលប៉ុលបានទៅសួរសុខទុក្ខអំឡុងការធ្វើដំណើរផ្សព្វផ្សាយសាសនាទីពីរ និងទីបីរបស់លោក (សូមមើលកិច្ចការ ១៦:៦,១៨:២៣) ។ (អ្នកគួរតែអញ្ជើញឲ្យសិស្សរកទីតាំងកាឡាទីនៅលើផែនទីក្នុងព្រះគម្ពីរបរិប ល.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា ») ។ សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ១:៦–៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលបញ្ហាមួយ ដែលកើតមាននៅក្នុងចំណោមពួកបរិសុទ្ធនៅកាឡាទី ។

- ហេតុអ្វីក៏មានពួកបរិសុទ្ធនៅកាឡាទីជាច្រើនងាកចេញពីដំណឹងល្អពិត ?

សូមពន្យល់ ថាអ្នកទាំងឡាយណាដែលរុកគួនដល់ពួកកាឡាទី ហើយបង្ខូចការបង្រៀនដំណឹងល្អបានកំពុងបង្កើតនូវភាពសង្ស័យ (សូមមើល កាឡាទី ១:៧) អំពីការបង្រៀនរបស់ប៉ុលថា សេចក្តីសង្គ្រោះកើតមានតែតាមរយៈព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។ គ្រូបង្រៀនខុសឆ្គងទាំងនេះ គឺជាពួកគ្រីស្ទានសាសន៍យូដាដែលបានអះអាងថាពួកបរិសុទ្ធកាឡាទីត្រូវតែកាត់ស្បែក (សូមមើល Bible Dictionary« Circumcision ») ហើយបានគោរពតាមក្បួនសាសនានៃក្រឹត្យវិន័យរបស់ម៉ូសេដើម្បីត្រូវបានសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ១:៨–៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើប៉ុលបាននិយាយដូចម្តេចអំពីអ្នកទាំងឡាយដែលផ្សាយដំណឹងល្អផ្ទុយទៅនឹងដំណឹងល្អ ដែលលោកបានផ្សាយក្នុងនាមជាសាវកមួយរូបរបស់ព្រះអម្ចាស់នោះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ១:១០–១២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថានរណាជាប្រភពនៃការបង្រៀនរបស់ប៉ុល ។

- យោងតាមខទី ១២តើនរណាទៅជាប្រភពនៃការបង្រៀនរបស់ប៉ុល ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីពាក្យសម្តីរបស់ប៉ុលនៅក្នុងខទី ១០–១២ អំពីគោលលទ្ធិពិត ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទបើកសម្តែងគោលលទ្ធិពិតដល់ពួកព្យាការីរបស់ទ្រង់**)។
- តើការចងចាំសេចក្តីពិតនេះ អាចជួយយើងនៅពេលយើងមានចម្ងល់អំពីការបង្រៀនរបស់ព្យាការីយ៉ាងដូចម្តេច ?

សូមពន្យល់ថា ដោយសារព្រះយេស៊ូវគ្រីស្ទបើកសម្តែងគោលលទ្ធិពិតដល់ពួកព្យាការីរបស់ទ្រង់ នោះទ្រង់ក៏អាចបើកសម្តែងដល់យើងនូវភាពពិតពេញលេញអំពីការបង្រៀនរបស់ព្យាការីផងដែរ ។

- តើយើងអាចធ្វើដូចម្តេចខ្លះ ដើម្បីទទួលបានវិវរណៈមកពីព្រះអម្ចាស់ដើម្បីយើងអាចដឹងដោយខ្លួនយើងថា ការបង្រៀនរបស់ព្យាការីគឺជាការពិត ?

សូមរំឭកសិស្សពីស្ថានភាពដែលបានណែនាំកាលពីខាងដើមមេរៀន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់ដល់សិស្សក្នុងថ្នាក់អំពីរបៀបដែលពួកគេនឹងប្រើសេចក្តីពិត ដែលពួកគេទើបតែបានស្គាល់អំពីវិវរណៈ ដើម្បីឆ្លើយតបទៅមនុស្សដែលមានចម្ងល់សង្ស័យអំពីការបង្រៀនរបស់សាសនាចក្រ ។

សូមថ្លែងទីបន្ទាល់ថា យើងអាចទទួលស្គាល់គោលលទ្ធិពិត នៅពេលយើងសិក្សាពីការបង្រៀនរបស់ព្យាការី ហើយស្វែងរកវិវរណៈមកពីព្រះអម្ចាស់ ។

ជួយសិស្សឲ្យយល់មាតិកា

មាតិកានៃបទគម្ពីរគឺជាខ្សែរឿងមនុស្ស ព្រឹត្តិការណ៍ ទេសនកថា និងការពន្យល់ដ៏បំផុសគំនិត ដែលបង្កើតជាអត្ថបទខាងបទគម្ពីរ ។ មាតិកាផ្តល់ជាចំណាប់អារម្មណ៍ និងព័ត៌មានទាក់ទងនឹងគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលមាននៅក្នុងបណ្តុំបទគម្ពីរមួយ ។ សូមជួយសិស្សឲ្យយល់ពីមាតិកាដើម្បីពួកគេអាចស្គាល់សេចក្តីពិតដ៏អស់កល្បជានិច្ចដែលមាននៅក្នុងអត្ថបទ ប៉ុន្តែចូរកុំគូសបញ្ជាក់ហួសហេតុអំពីដីវប្រវត្តិ និងព័ត៌មានលម្អិតដល់កម្រិតមួយដែលថា វាក្លាយទៅជាស្នូលមេរៀននោះឡើយ ។

សូមសង្ខេបកាឡាទី ១:១៣–២:២១ ដោយពន្យល់ថា ប៉ុលបានរៀបរាប់អំពីការផ្លាស់ប្រែចិត្តជឿរបស់លោក និងការធ្វើដំណើរផ្សព្វផ្សាយសាសនាកាលពីដំបូង ។ លោកក៏ពន្យល់ផងដែរថា សេចក្តីសង្គ្រោះពុំកើតមាននៅក្នុងក្រឹត្យវិន័យរបស់ម៉ូសេឡើយ ប៉ុន្តែយើងត្រូវបានអភ័យទោស ឬរាប់ជាសុចរិតតាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទទៅវិញទេ ។

កាឡាទី ៣–៤

ប៉ុលអញ្ជើញពួកកាឡាទីឲ្យទទួលពរជ័យទាំងអស់ ដែលបានសន្យាដល់អ័ប្រាហាំតាមរយៈព្រះយេស៊ូវគ្រីស្ទ

សូមអានស្ថានភាពដូចខាងក្រោមឮៗ ៖ បន្ទាប់ពីការអានឥរិយាបថមួយៗរួចហើយ ចូរសុំឲ្យសិស្សពន្យល់ថា ហេតុអ្វីក៏បុគ្គលម្នាក់ៗនៅក្នុងស្ថានភាពនោះអាចមានអារម្មណ៍ថា ឥតទទួលផលប្រយោជន៍នៅក្នុងការទទួលគ្រប់ពរជ័យរបស់ព្រះអម្ចាស់ បើប្រៀបធៀបទៅនឹងអ្នកដទៃទៀតនៅក្នុងសាសនាចក្រ ដែលស្មោះត្រង់ចំពោះដំណឹងល្អចាប់តាំងពីវ័យក្មេងមក ។

១. យុវជនម្នាក់បានធំឡើងនៅក្នុងគ្រួសារមិនសូវសកម្មមួយ ហើយមិនបានរៀនអំពីដំណឹងល្អកាលពីគាត់នៅក្មេងនោះទេ ។ គ្រួសារគាត់ឥឡូវនេះ បានត្រឡប់មកសកម្មក្នុងសាសនាចក្រ ហើយកំពុងចាប់ផ្តើមរៀន និងរស់នៅតាមដំណឹងល្អវិញ ។

២. ស្ត្រីម្នាក់រិះគន់សាសនាចក្រអស់ជាច្រើនឆ្នាំ ។ ថ្មីៗនេះ គាត់បានមានការផ្លាស់ប្តូរដួងចិត្ត ហើយបានទទួលបុណ្យជ្រមុជទឹក ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សា កាឡាទី ៣–៤ដែលអាចជួយយើងឲ្យយល់អំពីពរជ័យដែលមានចំពោះមនុស្សគ្រប់រូប ទោះជាពួកគេមានស្ថានភាព និងការជ្រើសរើសពីអតីតកាលយ៉ាងណាក៏ដោយ ។

ចូរពន្យល់ថា ពួកបរិសុទ្ធនៅកាឡាទីជាច្រើនគឺជាអ្នកផ្លាស់ប្រែចិត្តជឿសាសន៍ដទៃមកចូលគ្រីស្ទសាសនា ហើយដូច្នេះពួកគេពុំមែនជាពូជអំបូររបស់អ័ប្រាហាំ ដែលពរជ័យទាំងអស់របស់ព្រះត្រូវបានសន្យានោះទេ ។ សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ៣:៧–៩ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើប៉ុលបានបង្រៀនអ្វីខ្លះអំពីអ្នកទាំងឡាយដែល « មានសេចក្តីជំនឿ » (ខទី ៧) ឬដែលជឿទៅលើព្រះយេស៊ូវគ្រីស្ទ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះអំពីអ្នកទាំងឡាយដែលជឿទៅលើព្រះយេស៊ូវគ្រីស្ទ ?
- យោងតាមខទី ៨តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់អ័ប្រាហាំ ?
- យោងតាមខទី ៩តើមានអ្វីខ្លះនឹងកើតឡើងចំពោះអ្នកទាំងឡាយដែលមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ?

ចូរពន្យល់ថាដើម្បី « បានពរជាមួយនឹងលោកអ័ប្រាហាំ ដែលជាអ្នកជឿ » សំដៅទៅលើការទទួលបានប្រយោជន៍មកពីសេចក្តីសញ្ញាដែលព្រះបានចុះជាមួយអ័ប្រាហាំថា តាមរយៈលោក នោះមនុស្សទាំងអស់អាចរីករាយនឹងពរជ័យទាំងឡាយនៃដំណឹងល្អ (សូមមើល អ័ប្រាហាំ ២:១១) ។

សូមសង្ខេបកាឡាទី ៣:១០–២៥ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា ក្រឹត្យវិន័យរបស់ម៉ូសេមានបំណងចង់ជួយឲ្យពួកសាសន៍អ៊ីស្រាអែលមករកព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានរាប់ទុកជាសុចរិតតាមរយៈសេចក្តីជំនឿទៅលើទ្រង់ ។

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ៣:២៦–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្ទៀងតាម រកមើលអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងឡាយដែលបានសន្យាដល់លោកអ័ប្រាហាំ ។

- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលពរជ័យដែលបានសន្យាដល់លោកអ័ប្រាហាំ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *អស់អ្នកទាំងឡាយដែលអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយចូលក្នុងសេចក្តីសញ្ញានៃដំណឹងល្អនឹងភ្លាយជា. . .*

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ៣:២៨–២៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សផ្ទៀងតាម រកមើលពាក្យ ឬឃ្លាដែលគេអាចប្រើដើម្បីបំពេញសេចក្តីថ្លែងការណ៍អំពីគោលការណ៍នៅលើក្តារខៀនដែលមិនពេញលេញនោះ ។

- យោងតាមខទី ២៨តើបុគ្គលម្នាក់ៗមានការប្រែប្រួលយ៉ាងណា នៅពេលពួកគេចូលមកក្នុងសេចក្តីសញ្ញានៃដំណឹងល្អ ?
- យោងតាមខទី ២៩តើអ្នកទាំងឡាយដែលត្រូវបានរាប់បញ្ចូលនៅក្នុងចំណោមពូជអ័ប្រាហាំតាមរយៈព្រះយេស៊ូវគ្រីស្ទនឹងប្រែទៅជាយ៉ាងណាដែរ ?

ចូរពន្យល់ថា *អ្នកគ្រងមរតក* គឺជាមនុស្សម្នាក់ដែលមានសិទ្ធិតាមច្បាប់ដើម្បីទទួលអចលនទ្រព្យ ឬរបស់ផងរបស់អ្នកដទៃផ្សេងទៀត ។

សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ៤:៧ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើយើងអាចក្លាយជាអ្នកគ្រងមរតករបស់នរណា ។

- តើយើងអាចក្លាយជាអ្នកគ្រងមរតករបស់នរណា ? (សូមប្រើពាក្យរបស់សិស្ស ដើម្បីបំពេញសេចក្តីថ្លែងការណ៍អំពីគោលការណ៍នៅលើក្តារខៀន ដើម្បីវានាំទៅរកសេចក្តីពិតដូចខាងក្រោមនេះ ៖ **សិស្សក៏បានរៀនផងដែរថា អស់អ្នកទាំងឡាយដែលអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយទៅក្នុងសេចក្តីសញ្ញានៃដំណឹងល្អ នឹងប្រែក្លាយទៅជាតែមួយនៅក្នុងព្រះគ្រីស្ទ ហើយជាអ្នកគ្រងមរតករបស់ព្រះ**) ។
- ហេតុអ្វីក៏វាសំខាន់ដើម្បីដឹងថា ព្រះសន្យាពរជ័យទាំងនេះដល់មនុស្សគ្រប់គ្នាដែលបានចូលក្នុងសេចក្តីសញ្ញា មិនថាពួកគេមានកាលៈទេសៈយ៉ាងណានោះទេ ?

សូមថ្លែងទីបន្ទាល់ថា ការសន្យារបស់ព្រះវរបិតាសួគ៌ គឺសម្រាប់មនុស្សគ្រប់គ្នាដែលចូលទៅក្នុងសេចក្តីសញ្ញាដំណឹងល្អ ។ សូមលើកទឹកចិត្តសិស្សឲ្យស្មោះត្រង់ចំពោះសេចក្តីសញ្ញាទាំងឡាយដែលពួកគេបានធ្វើ ។

សូមសង្ខេប កាឡាទី៤:៨–៣១ ដោយពន្យល់ថា ប៉ុលបានអញ្ជើញពួកបរិសុទ្ធនៅកាឡាទីឲ្យត្រឡប់ទៅរកព្រះគ្រីស្ទ និងគេចចេញពីសេវកភាពដែលកើតមានមកពីការបូជាខ្លួនតាមក្រឹត្យវិន័យរបស់ម៉ូសេ ។

មេរៀន ១១៩

កាឡាទី ៥–៦

សេចក្តីផ្តើម


ប៉ុលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធនៅកាឡាទី ឲ្យស្ថាបនាសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទឡើងវិញ ហើយទុកចិត្តថា សេចក្តីសង្គ្រោះគឺអាចទទួលបានតែតាមរយៈទ្រង់ប៉ុណ្ណោះ ពុំមែនតាមរយៈការគោរពតាមក្រឹត្យវិន័យរបស់លោកម៉ូសេឡើយ ។ ប៉ុលបានបញ្ចប់សំបុត្ររបស់លោក ដោយការអញ្ជើញដល់សមាជិកសាសនាចក្រឲ្យប្រែក្លាយទៅជាសត្វលោកថ្មីតាមរយៈព្រះគ្រីស្ទ ហើយជួយអ្នកដទៃឲ្យធ្វើដូចគ្នានោះ ។

យោបល់សម្រាប់ការបង្រៀន

កាឡាទី ៥

ប៉ុលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធនៅកាឡាទីឲ្យស្ថាបនាសេចក្តីជំនឿរបស់ខ្លួនទៅលើព្រះយេស៊ូវគ្រីស្ទឡើងវិញ

សូមគូររូបភាពទាញព្រាត់នៅលើក្តារខៀន ។



- តើការទាញព្រាត់ជាអ្វី ? តើអ្នកអាចឈ្នះវាដោយរបៀបណា ?
- តើជីវិតរបស់យើងស្រដៀងគ្នានឹងការទាញព្រាត់តាមវិធីណា ?

ប្រសិនបើសិស្សពុំបានប្រាប់អំពីវាទេ សូមចង្អុលបង្ហាញថា ទិដ្ឋភាពមួយនៃជីវិតរបស់យើងដែលស្រដៀងគ្នាទៅនឹងការទាញព្រាត់ គឺការពុះពារបស់យើងទប់ទល់នឹងការល្បួង ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាកាឡាទី ៥ដែលអាចជួយពួកគេឲ្យដឹង អំពីរបៀបដើម្បីយកឈ្នះលើការពុះពារទប់ទល់នឹងការល្បួង ។

សូមរំឭកសិស្សថា ពួកគ្រីស្ទានដែលជាសាសន៍យូដាមួយចំនួន បានដឹកនាំពួកបរិសុទ្ធឲ្យភាន់ច្រឡំនៅក្នុងក្រុងកាឡាទី ដោយបង្រៀនពួកគេថា ពួកគេចាំបាច់ត្រូវរស់នៅតាមក្រឹត្យវិន័យរបស់ម៉ូសេ ហើយត្រូវកាត់ស្បែកដើម្បីអាចបានសង្គ្រោះ ។ ប៉ុលបានពិពណ៌នាអំពីការបង្រៀនខុសឆ្គងអំពីក្រឹត្យវិន័យលោកម៉ូសេទាំងនេះថា « ជាប់ចំណងជាបាវបម្រើ » (កាឡាទី ៤:១) ។

សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ៥:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើនរណាដែលប៉ុលបាននិយាយថានឹងនាំមកនូវសេរីភាពចេញពីការជាប់ចំណងជាបាវបម្រើនេះ ។

- តើនរណានាំមកនូវសេរីភាពចេញពីការជាប់ចំណងជាបាវបម្រើនេះ ?

សូមសង្ខេបកាឡាទី ៥:២–១៥ ដោយពន្យល់ថា ប៉ុលបានវាយផ្ចាលពួកបរិសុទ្ធនៅកាឡាទី ដោយសារការងាយនឹងងាកចេញពីសេរីភាពនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយត្រឡប់ទៅរកការជាប់ចំណងនៃក្រឹត្យវិន័យរបស់ម៉ូសេវិញនោះ ។ បន្ទាប់មកលោកបានបញ្ជាក់ថា ទោះជាអ្នកដើរតាមព្រះគ្រីស្ទបានសេរីភាព ចេញពីការជាប់ចំណងនៃក្រឹត្យវិន័យរបស់ម៉ូសេក្តី ក៏ការណ៍នោះពុំមែនមានន័យថា ពួកគេមានសេរីភាពដើម្បីប្រព្រឹត្តអំពើបាបដោយសេរីនោះទេ ។

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ៥:១៦–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលកម្លាំងប្រកួតប្រជែងពីរដែលប៉ុលបានពិពណ៌នា ។

- តើកម្លាំងប្រកួតប្រជែងពីរ ដែលប៉ុលបានពិពណ៌នាមានអ្វីខ្លះ ?

ចូរបង្កើតតារាងមួយនៅលើក្តារខៀនដោយគូសបន្ទាត់ឈរនៅត្រង់កណ្តាលនៃរូបភាពការទាញព្រាត់ ។ សូមសរសេរ*ដើរនៅក្នុងព្រះវិញ្ញាណ*នៅខាងលើផ្នែកម្ខាងនៃការទាញព្រាត់ ហើយសរសេរ*បំពេញសេចក្តីប៊ីងប្រាថ្នាខាងសាច់ឈាម*នៅខាងលើផ្នែកម្ខាងទៀត ។

- តើ « ការដើរនៅក្នុងព្រះវិញ្ញាណ » មានន័យដូចម្តេច ? (ខទី ១៦) ។ (ដើម្បីរស់នៅដោយសក្តិសម ហើយធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ) ។

- តើ « បំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម » (ខទី ១៦) សំដៅទៅលើអ្វី ? (ការល្បួងឲ្យធ្វើអំពើបាប) ។
- តើរឿងទាំងពីរនេះចាត់ទុកថាជាឋានពលប្រកួតប្រជែងយ៉ាងដូចម្តេច ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនចេញមកពីខទី ១៦អំពីរបៀបដែលយើងអាចយកឈ្នះលើការល្បួងខាងសាច់ឈាម ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងដើរនៅក្នុងព្រះវិញ្ញាណ នោះយើងនឹងយកឈ្នះលើការល្បួងនានាខាងសាច់ឈាម ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមឲ្យសិស្សសញ្ជឹងគិតថា តើពួកគេស្ថិតនៅខាងណាក្នុងការទាញព្រាត់នោះ ហើយតើកម្លាំងណាមួយកំពុងតែយកឈ្នះនៅក្នុងជីវិតរបស់ពួកគេ ។

កាឡាទី ៥:២២–២៣

គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះតាមរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

សូមចែកសិស្សជាក្រុម ដែលមានគ្នាពីរ ឬបីនាក់ ។ ចូរចាត់ឲ្យសិស្សក្នុងក្រុមពាក់កណ្តាលអានកាឡាទី ៥:១៩–២១ ឮៗជាមួយគ្នា ហើយរកមើលលទ្ធផលនៃ « [ការបំពេញតាម] សេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម » ។ សូមអញ្ជើញសិស្សពាក់កណ្តាលក្រុមទៀតឲ្យអានកាឡាទី៥:២២–២៣ ឮៗជាមួយគ្នា ហើយរកមើលលទ្ធផលនៃការដើរនៅក្នុងព្រះវិញ្ញាណ ។ នៅពេលអ្នកបញ្ចប់ការអាន សូមអញ្ជើញសមាជិកម្នាក់មកពីក្រុមនីមួយៗ ឲ្យសរសេរនៅក្នុងកូឡោនត្រឹមត្រូវនៅលើក្តារខៀន ឡូវចម្លើយមួយដែលពួកគេបានរកឃើញ ។ សូមអញ្ជើញពួកគេឲ្យបន្តសរសេរចម្លើយរបស់ពួកគេ រហូតដល់តារាងនោះឆ្លុះបញ្ចាំងទៅនឹងអ្វីដែលប៉ុលបានរៀបរាប់ ។ អ្នកអាចនឹងចង់យកវចនានុក្រមមកថ្នាក់រៀន ហើយអញ្ជើញសិស្សឲ្យរកមើលពាក្យណាដែលពិបាកយល់ ។

- យោងតាមខទី ២១តើប៉ុលបង្រៀនថាអ្វីខ្លះ នឹងកើតមានឡើងចំពោះមនុស្សដែលចុះចាញ់ « កិច្ចការខាងសាច់ឈាម » ?
- យោងតាមខទី ២២–២៣តើផលផ្លែ ឬលទ្ធផលអ្វីខ្លះ ដែលចង្អុលបង្ហាញថា នរណាម្នាក់កំពុងតែដើរនៅក្នុងព្រះវិញ្ញាណ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ផលផ្លែនៃព្រះវិញ្ញាណនោះគឺជាសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត និងដឹងខ្នាត ។** អ្នកអាចផ្តល់យោបល់ដល់សិស្សឲ្យគូសចំណាំសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

ចូរយោងទៅផ្នែកម្ខាងនៃតារាងត្រង់កន្លែងផលផ្លែនៃព្រះវិញ្ញាណដែលបានរៀបរាប់ ។

- ហេតុអ្វីពរជ័យទាំងនេះសក្តិសមនឹងមាន ?

នៅខាងក្រោមតារាងនោះ សូមគូសសញ្ញាព្រួញធំមួយចង្អុលទៅត្រង់កន្លែង ដែលសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមត្រូវបានរៀបរាប់ ។ សូមឲ្យសិស្សនឹកស្រមៃថា នៅក្នុងនិមិត្តរូបនៃការទាញព្រាត់នេះ យើងអនុញ្ញាតឲ្យខ្លួនយើងរំកិលទៅរកសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ។

- តើមានអ្វីកើតឡើងចំពោះផលផ្លែនៃព្រះវិញ្ញាណ នៅពេលយើងចុះចាញ់នឹងសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ? (យើងចាប់ផ្តើមបាត់បង់ផលផ្លែនៃព្រះវិញ្ញាណ) ។

សូមលុបសញ្ញាព្រួញចេញ ហើយគូសព្រួញមួយទៀតចង្អុលទៅរកផលផ្លែខាងវិញ្ញាណ ។ សូមឲ្យសិស្សនឹកស្រមៃថា ឥឡូវយើងអនុញ្ញាតឲ្យខ្លួនយើងរំកិលទៅខាងនេះ ។

- តើមានអ្វីកើតឡើងចំពោះកិច្ចការខាងសាច់ឈាម ពេលយើងដើរនៅក្នុងព្រះវិញ្ញាណ ? (វាឈប់មានចំណែកនៅក្នុងជីវិតយើងទៀតហើយ) ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេអំពីគ្រាមួយដែលពួកគេទទួលអារម្មណ៍ ឬមានបទពិសោធន៍អំពីផលផ្លែនៃព្រះវិញ្ញាណមួយក្នុងចំណោមផលផ្លែទាំងនេះ ។ ចូរសុំពួកគេឲ្យដាក់បញ្ចូលនូវអ្វីដែលពួកគេកំពុងធ្វើ ដើម្បីដើរនៅក្នុងព្រះវិញ្ញាណនៅគ្រានោះ ។ នៅពេលបញ្ចប់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ៥:២៤–២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីអ្វី ដែលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបានព្យាយាមធ្វើជាមួយនឹងសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ។

- តើពួកសិស្សរបស់ព្រះយេស៊ូវព្យាយាមធ្វើអ្វីខ្លះ ជាមួយនឹងសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមនេះ ? (ឆ្កាងវា ឬលុបបំបាត់វាចេញពីជីវិតរបស់ពួកគេ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីដើរកាន់តែពេញលេញនៅក្នុងព្រះវិញ្ញាណ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួល ដើម្បីពួកគេអាចរីករាយនឹងផលផ្លែខាងព្រះវិញ្ញាណ ។

កាឡាទី ៦

ប៉ុលអញ្ជើញពួកបរិសុទ្ធនៅកាឡាទីឲ្យផ្លាស់ប្តូរតាមរយៈព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សឲ្យគិតអំពីនរណាម្នាក់ ដែលពួកគេស្គាល់ថ្មីៗនេះ ដែលពុំបានទទួលពរជ័យនៃដំណឹងល្អ ទោះជាបុគ្គលនោះក្លាយជាសមាជិកនៃសាសនាចក្រហើយក្តី ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់រកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សាកាឡាទី ៦ដែលអាចដឹកនាំពួកគេនៅក្នុងកិច្ចខិតខំដើម្បីជួយមនុស្សម្នាក់ ដែលពួកគេបានគិតដល់នោះ ឲ្យទទួលបាននូវពរជ័យនៃដំណឹងល្អ ។

សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ៦:១–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើប៉ុលបានបង្រៀនអ្វីខ្លះអំពីរបៀបដែលសមាជិកនៃសាសនាចក្រគួរឆ្លើយតបទៅនរណាម្នាក់ ដែលបានធ្វើអំពើបាបនោះ ។ (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា « ធ្វើខុសអ្វីមួយ » [ខទី ១] មានន័យថាធ្វើអំពើបាប) ។

- យោងតាមប៉ុល តើសមាជិកនៃសាសនាចក្រគួរឆ្លើយតបចំពោះនរណាម្នាក់ ដែលបានធ្វើអំពើបាបយ៉ាងដូចម្តេច ? (« ស្តាបនា » មនុស្សនោះ ឬជួយពួកគេឲ្យត្រឡប់មកកាន់មាគ៌ានៃដំណឹងល្អវិញ) ។
- ហេតុអ្វីក៏វាសំខាន់ដើម្បីមាន « វិញ្ញាណស្លូតបូត » (ខទី ១) នៅពេលយើងជួយនរណាម្នាក់ឲ្យត្រឡប់មកកាន់មាគ៌ានៃដំណឹងល្អវិញ ?
- តើវិធីមួយចំនួនណាខ្លះដែលយើងអាច « ទទួលបន្ទុកគ្នាទៅវិញទៅមក. . . » ? (ខទី ២) ។

សូមសង្ខេបកាឡាទី ៦:៣–៥ដោយពន្យល់ថា ប៉ុលបានបង្រៀនថា យើងពុំគួរមានភាពឆ្មើងឆ្មៃ និងគិតសុចរិតតែខ្លួនឯង ហើយថា មនុស្សគ្រប់រូបនឹង « ត្រូវទទួលបន្ទុករបស់ [ពួកគេ] ផ្ទាល់ » (ខទី ៤) ឬត្រូវតែទទួលខុសត្រូវចំពោះជម្រើសរបស់ពួកគេនោះទេ ។

សូមបង្ហាញគ្រាប់ពូជផ្លែឈើ ឬគ្រាប់ពូជបន្លែមួយចំនួនដែលសិស្សងាយនឹងស្គាល់ ។ ចូរសួរពួកគេឲ្យប្រាប់ថា តើនោះជាគ្រាប់ពូជអ្វី ។

- តើអ្នកអាចរំពឹងចង់បានអ្វីខ្លះ បើអ្នកដាំគ្រាប់ពូជទាំងនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ៦:៧–៨ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើប៉ុលបានបង្រៀនអ្វីខ្លះ អំពីអ្វីដែលយើងអាចរំពឹងចង់បាន នៅពេលយើងដាំគ្រាប់ពូជ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះអំពីអ្វី ដែលយើងអាចរំពឹងចង់បាន នៅពេលយើងដាំគ្រាប់ពូជ ? (អ្វីដែលអ្នកដាំ ឬបណ្តុះ គឺជាអ្វីដែលអ្នកនឹងច្រូតកាត់ ឬប្រមូលផល ។ នេះត្រូវបានហៅថា ច្បាប់នៃការប្រមូលផល) ។
- តើច្បាប់នៃការប្រមូលផលទាក់ទងទៅនឹងការសម្រេចចិត្ត ដែលយើងធ្វើយ៉ាងដូចម្តេច ?

សូមឲ្យសិស្សអាន កាឡាទី ៦:៩–១០ ដោយស្ងៀមស្ងាត់ ។ ចូរសុំឲ្យពួកគេរកមើលថា ហេតុអ្វីប៉ុលបានបង្រៀនអំពីច្បាប់នៃការប្រមូលផល ។

- ហេតុអ្វីក៏អ្នកគិតថា ប៉ុលបានបង្រៀនអំពីច្បាប់នៃការប្រមូលផល បន្ទាប់ពីលោកបានអញ្ជើញឲ្យពួកកាឡាទីជួយគ្នាទៅវិញទៅមកឲ្យស្ថិតនៅលើ ឬត្រឡប់មកកាន់មាគ៌ានៃដំណឹងល្អវិញដូច្នេះ ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ អំពីការជួយអ្នកដទៃដែលពុំមានចិត្តរីករាយនឹងពរជ័យនៃដំណឹងល្អ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **ប្រសិនយើងយើងឧស្សាហ៍ព្យាយាមនៅក្នុងការធ្វើកិច្ចការល្អ នោះយើងនឹងច្រូតកាត់នូវពរជ័យនៃទង្វើរបស់យើង**) ។
- តើការសន្យាថា យើងនឹងច្រូតកាត់ « តាមពេលកំណត់ » អាចជួយយើងមិនឲ្យ « រសាយចិត្ត » (ខទី ៩) ឬបោះបង់ចោលការខិតខំរបស់យើងដើម្បីបម្រើដល់អ្នកដទៃ ហើយរស់នៅក្នុងដំណឹងល្អក្នុងជីវិតផ្ទាល់ខ្លួនរបស់យើងយ៉ាងដូចម្តេច ?
- តើនៅពេលណា ដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានឧស្សាហ៍ព្យាយាមក្នុងការធ្វើការល្អ ទោះជាអ្នកពុំបានទទួលពរជ័យភ្លាមៗក្តីនោះ ? (អ្នកក៏អាចពិចារណាក្នុងការចែកចាយបទពិសោធន៍មួយផងដែរ) ។

សូមសង្ខេបកាឡាទី ៦:១១–១៨ ដោយពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោកទៅកាន់ពួកបរិសុទ្ធនៅកាឡាទី ដោយប្រាប់ឡើងវិញថា សេចក្តីសុខសាន្ត និងក្តីមេត្តាករុណារបស់ព្រះយេស៊ូវគ្រីស្ទ គឺកើតមានលើមនុស្សទាំងអស់ ដែលបានក្លាយជាសត្វលោកថ្មីតាមរយៈសេចក្តីជំនឿទៅលើព្រះនាមទ្រង់ ។

សូមលើកទឹកចិត្តសិស្ស « កុំឲ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ » (ខទី ៩) ហើយឲ្យគិតពិចារណាប្រកបដោយការអធិស្ឋានអំពីនរណា ដែលពួកគេអាចជួយឲ្យត្រឡប់មកកាន់មាគ៌ារបស់ព្រះអម្ចាស់វិញ ។ សូមអញ្ជើញពួកគេឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេទទួលបានមកពីព្រះវិញ្ញាណបរិសុទ្ធដោយឧស្សាហ៍ព្យាយាម ។

ចំណេះចំណានខគម្ពីរ—កាឡាទី៥:២២–២៣

ដើម្បីជួយសិស្សឲ្យទន្ទេញចាំកាឡាទី ៥:២២–២៣ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យសូត្រវាមួយពាក្យម្តងៗ ម្តងម្នាក់ៗ ។ ឧទាហរណ៍ សិស្សទីមួយនឹងនិយាយថា « តែ » សិស្សទីពីរនិយាយថា « ឯ » សិស្សទីបីនឹងនិយាយថា « ផល » ជាដើម រហូតដល់ខទាំងពីរនេះត្រូវបានបញ្ចប់ ។ សូមកំណត់ម៉ោងសិស្ស ហើយឲ្យពួកគេព្យាយាមសូត្រវាជាច្រើនដង រហូតអស់ម៉ោងដែលកំណត់នោះ ។ នៅពេលដែលអ្នកធ្វើសកម្មភាពនេះម្តងហើយម្តងទៀត សូមគិតអំពីការឆ្លាស់វេណសិស្ស ដើម្បីឲ្យពួកគេនិយាយពាក្យខុសៗគ្នា ។ អ្នកក៏អាចផ្តល់យោបល់ឲ្យសិស្សហាត់វា នៅពេលចាប់ផ្តើមថ្នាក់ក្នុងរយៈពេលជាច្រើនថ្ងៃជាប់ៗគ្នា ដើម្បីឲ្យពួកគេអាចសូត្រវាក្នុងពេលកាន់តែខ្លីជាងដែរ ។ បន្ទាប់ពីសិស្សបានស្តាប់ឮបទគម្ពីរសូត្រឡើងវិញជាច្រើនដងហើយ សូមអញ្ជើញពួកគេឲ្យព្យាយាមសូត្រវាចេញមកពីការទន្ទេញចាំទៅដល់នរណាម្នាក់ ដែលអង្គុយនៅជិតពួកគេ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

កាឡាទី ៥:២៤ ។ « បានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល និងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង »

ការបង្រៀនរបស់ប៉ុលដែលថា « អស់អ្នកដែលជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល និងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង » គឺពុំមែនមានន័យថា អ្នកទាំងឡាយដែលធ្វើតាមព្រះគ្រីស្ទនឹងឈប់ជួបការល្បួងនោះទេ ។ តែវាមានន័យថា ពួកគេនឹងរៀនអំពីរបៀបដើម្បីយកឈ្នះលើការល្បួងទាំងឡាយរបស់ពួកគេវិញ ។

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់ពួកអេភេសូរ

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

« អេភេសូរគឺជាសំបុត្រមួយសម្រាប់មនុស្សគ្រប់គ្នានៅក្នុងពិភពលោកនេះ ទាំងពួកយូដា និងពួកសាសន៍ដទៃ ប្តី និងប្រពន្ធ ឪពុកម្តាយ កូន ចៅហ្វាយ និងបាវបម្រើ ។ វាគឺជាព្រះតំរិះ និងព្រះទ័យរបស់ព្រះនៅក្នុងជំនាន់របស់ប៉ុល វាជាសំឡេងនៃការបំផុសគំនិតនៅក្នុងជំនាន់របស់យើង វាជាសំបុត្រមួយនៃការអំពាវនាវ និងការអនុវត្តជាសកល ។

« . . . វាមាននូវការសរសេរដ៏ល្អៗមួយចំនួនរបស់ប៉ុល ហើយវាជាឯកសារមួយដែលទាក់ទងទៅនឹងមូលដ្ឋានគ្រឹះ ជាមួយនឹងដំណឹងល្អនៃព្រះនៅរាល់សិរីល្អនៃការសង្គ្រោះ » (Bruce R. McConkie, *Doctrinal New Testament Commentary* រំលែទី ៣ [ឆ្នាំ១៩៦៥–៧៣] ២:៨៨៩) ។

ការសិក្សាសំបុត្រដល់ពួកអេភេសូរនេះ អាចបំផុសគំនិតសិស្សឲ្យដាក់រឿងនៃលោកិយនេះមួយអន្លើ ហើយអាចជួយពួកគេឲ្យរីកចម្រើនខាងវិញ្ញាណ ហើយរៀនមានសាមគ្គីភាព និងការរាប់អាននៅក្នុងសាសនាចក្រកាន់តែពេញលេញ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

សាវកប៉ុលបានសរសេរសំបុត្រដល់ពួកអេភេសូរ (សូមមើល អេភេសូរ ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ប៉ុលបានថ្លែងថា លោកគឺជាអ្នកជាប់ទោសនៅពេលដែលលោកបានសរសេរសំបុត្រដល់ពួកអេភេសូរ (សូមមើល អេភេសូរ ៣:១, ៤:១, ៦:២០) ។ គម្ពីរអេភេសូរប្រហែលជាសរសេរឡើង នៅពេលប៉ុលជាប់ឃុំជាលើកដំបូងនៅក្រុងរ៉ូម ប្រមាណជា គ.ស. ៦០–៦២ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។ នៅពេលនេះប៉ុលត្រូវបានគេឃុំខ្លួននៅក្នុងផ្ទះ ប៉ុន្តែលោកមានសិទ្ធិទទួលអ្នកមកលេង ហើយបង្រៀនដំណឹងល្អ (សូមមើល កិច្ចការ ២៨:១៦–៣១) ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយតើហេតុអ្វី ?

នៅក្នុងកំណែព្រះគម្ពីរបឺបរបស់ស្តេចជេមស៍ អេភេសូរ ១:១ ចែងថា សំបុត្រដល់ពួកអេភេសូរត្រូវបានសរសេរទៅ « ពួកបរិសុទ្ធដែលនៅក្រុងអេភេសូរ » ។ ប៉ុន្តែ ឯកសារដើមរបស់អេភេសូរពុំមានពាក្យ « ដែលនៅក្រុងអេភេសូរ » ទេ ។ ការណ៍នេះអាចនិយាយបានថា ប៉ុលអាចមិនបានសរសេរសំបុត្រនេះទៅពួកអេភេសូរតែម្នាក់នោះទេ ប៉ុន្តែទៅដល់ក្រុមជំនុំនៃពួកបរិសុទ្ធ រួមទាំងពួកបរិសុទ្ធនៅក្រុងអេភេសូរដែរ ។ ក្រុងអេភេសូរជាទីស្នាក់ការអំឡុងពេលការផ្សព្វផ្សាយសាសនាលើកទីបីរបស់លោក (សូមមើល កិច្ចការ ១៩:៩–១០, ២០:៣១) ហើយលោកមានសេចក្តីស្រឡាញ់យ៉ាងខ្លាំងចំពោះប្រជាជនទាំងនេះ (សូមមើល កិច្ចការ ២០:១៧, ៣៤–៣៨) ។

នៅក្នុងសំបុត្រនេះ ប៉ុលបានលើកឡើងពីសមាជិកសាសនាចក្រដែលជាសាសន៍ដទៃ (សូមមើល អេភេសូរ ២:១១) ដែលប្រហែលជាពួកគេជាអ្នកប្រែចិត្តជឿថ្មី (សូមមើល អេភេសូរ ១:១៥) ។ លោកបានសរសេរដើម្បីអភិវឌ្ឍជីវភាពខាងវិញ្ញាណ និងទីបន្ទាល់របស់អស់អ្នកដែលជាសមាជិករួចហើយ ។

គម្រោង

អេភេសូរ ១:១–៤:១៦ ប៉ុលសរសេរពីការតែងតាំងពីមុនរបស់ពួកបរិសុទ្ធដើម្បីទទួលដំណឹងល្អ គ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ការផ្សារភ្ជាប់ដោយព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសញ្ញា សេចក្តីសង្គ្រោះដោយព្រះគុណ សាមគ្គីភាពរវាងពួកបរិសុទ្ធដែលជាសាសន៍ដទៃ និងសាសន៍យូដានៅក្នុងសាសនាចក្រព្រះអម្ចាស់តែមួយ ជំនឿតែមួយ ពិធីបុណ្យជ្រមុជទឹកតែមួយ គោលបំណងរបស់សាសនាចក្រ និងការរៀបចំរបស់សាសនាចក្រនៅលើគ្រឹះនៃពួកព្យាការី និងពួកសាវកទាំងឡាយ ដោយមានព្រះយេស៊ូវគ្រីស្ទជាថ្មដ្រុងយ៉ាងឯក ។ ប៉ុលបង្រៀនថា ព្រះនឹងប្រមូលអ្វីៗទាំងអស់មកក្នុងព្រះគ្រីស្ទនៅគ្រាកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នេះ ។

អេភេសូរ ៤:១៧–៦:២៤ ប៉ុលលើកទឹកចិត្តពួកបរិសុទ្ធឲ្យអនុវត្តគោលលទ្ធិពិត នៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ។ លោកលើកទឹកចិត្តពួកគេឲ្យលះបង់មនុស្សកាលពីមុន (អំពើបាបពីមុនរបស់ពួកគេ) ហើយប្រជាប់ខ្លួនជាមនុស្សថ្មី តាមរយៈព្រះគ្រីស្ទ ។ លោកផ្តល់ពាក្យទូន្មានដល់ភរិយា ស្វាមី កូនចៅ ឪពុកម្តាយ ពួកបាវបម្រើ ពួកចៅហ្វាយ និងក្រុមជំនុំ ។ លោកលើកទឹកចិត្តពួកបរិសុទ្ធឲ្យ « ពាក់គ្រប់គ្រឿងសឹករបស់ព្រះ » (អេភេសូរ ៦:១១) ។

អេភេសូរ ១

សេចក្តីផ្តើម

ប៉ុលបានសរសេរសំបុត្រមួយដល់ពួកបរិសុទ្ធនៅក្រុងអេភេសូរ ទាក់ទងនឹងការតែងតាំងពីមុនរបស់ពួកគេដើម្បីទទួលបានដំណឹងល្អ ។ លោកបានសរសេរអំពីការកាន់កាប់ត្រួតត្រាចុងក្រោយ ឬការកាន់កាប់ត្រួតត្រាដែលយើងរស់នៅសព្វថ្ងៃនេះ ។ ប៉ុលបានបង្រៀនថា យើងអាចស្គាល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទតាមរយៈវិវរណៈ ។

យោបល់សម្រាប់ការបង្រៀន

អេភេសូរ ១:១–៨

ប៉ុលបង្រៀនពួកបរិសុទ្ធថា ពួកគេបានតែងតាំងពីមុនដើម្បីទទួលបានដំណឹងល្អ

សូមអញ្ជើញសិស្សឲ្យពិចារណាពីគ្រាមួយ ដែលពួកគេយល់ព្រមទទួលយកការទទួលខុសត្រូវដ៏សំខាន់មួយ ហើយបានសន្យាថា ពួកគេនឹងបានរង់ចាំសម្រាប់ការបំពេញកិច្ចការនេះ ។

- នៅពេលកិច្ចការនោះកាន់តែមានការប្រឈមច្រើនឡើង។ តើចំណេះដឹងថា អ្នកបានធ្លាប់យល់ព្រមចំពោះកិច្ចការនេះ ហើយថាមានមនុស្សម្នាក់បានជឿជាក់ថា អ្នកអាចបំពេញវាបាននោះ បានជួយអ្នកយ៉ាងដូចម្តេច ?
- តើអ្នកត្រូវបានពរ ឬ បានរង់ចាំចំពោះការបំពេញតាមការទទួលខុសត្រូវរបស់អ្នកយ៉ាងដូចម្តេច ?

សូមពន្យល់ថា នៅក្នុងសំបុត្ររបស់លោក ដែលបានកត់ត្រានៅក្នុង អេភេសូរ ១–៦ សាវកប៉ុលបានលើកឡើងពីពួកបរិសុទ្ធដែលរស់នៅក្រុងអេភេសូរ និងតំបន់ជុំវិញនោះ ។ លោកមានបំណងដើម្បីពង្រឹងដល់អស់អ្នក ដែលជាសមាជិកសាសនាចក្រថ្មីហើយ ហើយជួយពួកអ្នកប្រែចិត្តជឿថ្មីឲ្យរីកចម្រើនឡើង ក្នុងចំណេះដឹងខាងវិញ្ញាណរបស់ពួកគេ ហើយបន្តស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ពួកគេ ។

សូមអញ្ជើញសិស្សបួនក្រាំនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង អេភេសូរ ១:៣–៨ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលសេចក្តីពិតដែលប៉ុលបានបង្រៀនពួកបរិសុទ្ធ ដើម្បីជួយពួកគេឲ្យនៅបន្តស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ពួកគេ ។

- តើសេចក្តីពិតអ្វីខ្លះ ដែលប៉ុលបានបង្រៀនដើម្បីជួយពួកគេឲ្យនៅបន្តស្មោះត្រង់ ? (នៅពេលសិស្សឆ្លើយតប អ្នកគួរអញ្ជើញពួកគេឲ្យពន្យល់ថា ការយល់ដឹងពីរបៀបដែលសេចក្តីពិត ដែលពួកគេលើកមកនិយាយអាចជួយពួកបរិសុទ្ធឲ្យបន្តស្មោះត្រង់) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណានៅក្នុង ខទី ៤ ដែលថាព្រះបានរើសយកមនុស្សមួយចំនួន « តាំងពីមុនកំណើតលោកីយ៍មក » ?

សូមពន្យល់ថា ឃ្លានេះ រួមជាមួយនឹង៣ក្យ *តម្រូវទុកជាមុន* និងឃ្លា « ឲ្យទ្រង់បានទទួលយើងជាកូនចិញ្ចឹមដោយសារព្រះយេស៊ូវគ្រីស្ទ » នៅក្នុង ខទី ៥សំដៅទៅលើជនដែលបានរើស ឬបានតែងតាំងពីមុននៅជីវិតមុនផែនដីដើម្បីទទួលដំណឹងល្អ ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ៖ **កូនចៅរបស់ព្រះត្រូវបានតែងតាំងពីមុន ដើម្បីទទួលពរជ័យនៃដំណឹងល្អ ។** ការទទួលបានពរជ័យទាំងនេះ គឺជាលក្ខខណ្ឌដែលអាស្រ័យទៅលើសេចក្តីស្មោះត្រង់របស់យើងនៅក្នុងជីវិតនេះ ។

ដើម្បីជួយសិស្សឲ្យយល់អំពីសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗពីឃ្លាដូចខាងក្រោមនេះ ៖

« ក្នុងពិភពវិញ្ញាណមុនផែនដី ព្រះបានចាត់វិញ្ញាណជាក់លាក់ទាំងឡាយ ឲ្យបំពេញបេសកកម្មជាក់លាក់នានា អំឡុងជីវិតរមែងស្លាប់របស់ពួកគេ ។ ការណ៍នេះត្រូវបានហៅថា ការតែងតាំងជាមុន ។


« ការតែងតាំងជាមុនពុំបានធានាថា បុគ្គលទាំងឡាយនឹងទទួលការហៅបម្រើ ឬ ការទទួលខុសត្រូវជាក់លាក់នោះទេ ។ ឱកាសបែបនោះចូលមកក្នុងជីវិត ជាលទ្ធផលមួយនៃការអនុវត្តយ៉ាងសុចរិតនូវសិទ្ធិជ្រើសរើស គឺដូចជាការតែងតាំងជាមុនបានមក ជាលទ្ធផលមួយនៃភាពសុចរិត ដែលនៅក្នុងជីវិតមុនផែនដីនេះដែរ ។ . . .

« គោលលទ្ធិអំពីការតែងតាំងជាមុនអនុវត្តចំពោះសមាជិកសាសនាចក្រទាំងអស់ គឺមិនគ្រាន់តែសម្រាប់ព្រះអង្គសង្គ្រោះ និងព្យាការីរបស់ទ្រង់ឡើយ ។ ពីមុនការបង្កើតផែនដី ស្ត្រីស្មោះត្រង់ជាច្រើនត្រូវបានប្រទានឲ្យនូវទំនួលខុសត្រូវច្បាស់លាស់ ហើយបុរសស្មោះត្រង់ជាច្រើនត្រូវបានតែងតាំងជាមុននូវកាតព្វកិច្ចបព្វជិតភាពច្បាស់លាស់ ។ ទោះបីជាអ្នកពុំចាំពីគ្រានោះក្តី អ្នកពិតជាបានយល់ព្រមដើម្បីបំពេញកិច្ចការដ៏សំខាន់នៅក្នុងការបម្រើដល់ព្រះវរបិតារបស់អ្នក ។ នៅពេលអ្នកបង្ហាញថា អ្នកស្មោះត្រង់ នោះអ្នកនឹងត្រូវបានប្រទានឱកាសឲ្យបំពេញកិច្ចការ ដែលអ្នកបានទទួលនៅពេលនោះ » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* | ឆ្នាំ ២០០៤ | ទំព័រ ៦៩–៧០) ។

- តើការយល់ដឹងថា យើងបានតែងតាំងពីមុនដើម្បីទទួលដំណឹងល្អ និងពរជ័យជាច្រើនរបស់វា អាចជួយយើងឲ្យបន្តស្មោះត្រង់នឹងសេចក្តីសញ្ញារបស់យើងយ៉ាងដូចម្តេច ?

ជួយសិស្សឲ្យយល់ពីគោលលទ្ធិគ្រឹះ៖
សិស្សនឹងរៀននូវគោលលទ្ធិគ្រឹះទាំងឡាយ នៅពេលពួកគេសិក្សា និងពិភាក្សាអំពីបទគម្ពីរ និងនៅពេលពួកគេចាំវគ្គចំណេះចំណានបទគម្ពីរគន្លឹះ ។ អ្នកពុំគួរបង្ខែងចេញពីការសិក្សាបទគម្ពីរតាមលំដាប់លំដោយ ដើម្បីផ្តោតទៅលើគោលលទ្ធិគ្រឹះនោះទេ ។ ផ្ទុយទៅវិញ អ្នកគួរតែផ្តល់ការយកចិត្តទុកដាក់ទៅលើគោលលទ្ធិទាំងនេះ នៅពេលវាប្រាកដឡើងនៅក្នុងបរិបទបទគម្ពីររបស់ពួកគេ ។ ឧទាហរណ៍នៅក្នុងមេរៀននេះ អ្នកអាចគូសបញ្ជាក់ពីគោលលទ្ធិនៃការកាន់កាប់ត្រួតត្រាមួយនៃដំណឹងល្អ ដែលទាក់ទងនឹងអ្វីដែលត្រូវបានបង្រៀននៅក្នុង អេភេសូរ១ ។

អេភេសូរ ១:៩–១២



ប៉ុលថ្លែងពីការកាន់កាប់ត្រួតត្រានៃពេលពេញកំណត់

សូមគូរ រូបភាព សាមញ្ញមួយអំពីទន្លេខុសៗគ្នាជាច្រើនបានហូរចូលគ្នាទៅជាទឹកមួយដ៏ធំ ។ សូមឲ្យសិស្សនឹកស្រមៃថា ទន្លេនីមួយៗតំណាងឲ្យការកាន់កាប់ត្រួតត្រាមួយនៃដំណឹងល្អ ។

- តើការកាន់កាប់ត្រួតត្រាមួយនៃដំណឹងល្អគឺជាអ្វី ?

អ្នកគួរអំពុកឡើងវិញនូវអត្ថន័យនៃ គ្រាកាន់កាប់ត្រួតត្រា នៃដំណឹងល្អ ដោយអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍នៅក្នុង Bible Dictionary ៖

« គ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អ គឺជារយៈកាលមួយដែលព្រះអម្ចាស់ទ្រង់មានអ្នកបម្រើ ដែលមានសិទ្ធិអំណាចយ៉ាងពិចម្នាក់នៅលើផែនដី ដែលកាន់កូនសោទាំងឡាយនៃបព្វជិតភាពដ៏បរិសុទ្ធ និង ជាអ្នកដែលមានការអនុញ្ញាតដ៏ទេវភាព ដើម្បីចែកចាយដំណឹងល្អទៅដល់ប្រជាជាតិនានានៅលើផែនដី ។ នៅពេលការណ៍នេះកើតឡើង ដំណឹងល្អត្រូវបានបើកសម្តែងសារជាថ្មី ដើម្បីកុំឲ្យមនុស្សដែលរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រានោះ ពឹងផ្អែកជាពិសេសលើចំណេះដឹងនៃផែនការនៃសេចក្តីសង្គ្រោះក្នុងគ្រាកាន់កាប់ត្រួតត្រាដែលបានកន្លងហួសទៅហើយ ។ ចាប់តាំងពីដើមមកមានន្ទគ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អជាច្រើន ។ ព្រះគម្ពីរប៊ីបបង្ហាញថា យ៉ាងហោចណាស់មានសម័យកាន់កាប់ត្រួតត្រាមួយ ដែលត្រូវបានសំគាល់ឃើញជាមួយនឹងអ័ដាម មួយទៀតជាមួយអេណុក មួយទៀតជាមួយណូអេ និងបន្តបន្ទាប់ទៀតជាមួយអ័ប្រាហាំ ម៉ូសេ និងព្រះយេស៊ូវជាមួយនឹងសាវកបស់ទ្រង់នៅក្នុងកាលដ៏ខ្ពង់ខ្ពស់បំផុត » (Bible Dictionary« Dispensations ») ។

សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ១:៩–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយសំដៅទៅលើគ្រាកាន់កាប់ត្រួតត្រាមួយណា ។ សូមពន្យល់ថា ឃ្លា « សេចក្តីអាថ៌កំបាំងនៃព្រះហឫទ័យទ្រង់ » នៅក្នុង ខទី ៩ សំដៅទៅលើផែនការនិងព្រះរាជបំណងរបស់ព្រះ ។

- តើប៉ុលបានលើកឡើងពីគ្រាកាន់កាប់ត្រួតត្រាណានៅក្នុង អេភេសូរ ១:១០ ?

សូមចង្អុលបង្ហាញថា សម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់គឺជាគ្រាកាន់កាប់ត្រួតត្រា ដែលយើងរស់នៅនាពេលនេះ ។

- តើសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់អាចប្រៀបបាននឹងទឹកទន្លេ ដែលហូរចាក់ចូលទៅក្នុងទន្លេនោះយ៉ាងដូចម្តេច ?
- តើប៉ុលបានព្យាករថានឹងមានអ្វីកើតឡើង នៅសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នោះ ? (សូមពន្យល់ថា នៅពេលប៉ុលសរសេរថា « គ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ » ទាំងនៅលើស្ថានសួគ៌ និងផែនដីនឹងត្រូវបាន ‹ បំព្រួម › [ខទី ១០] លោកសំដៅទៅលើការស្តារឡើងវិញ និងការប្រមូលផ្តុំនៃរាល់កូនសោ អំណាច និងសន្យាដែលព្រះបានបើកសម្តែងដល់កូនចៅរបស់ទ្រង់ ចាប់តាំងពីដើមកំណើតនៃលោកិយមកម្ល៉េះ រួមទាំងចំណេះដឹងផ្សេងទៀតដែលពុំទាន់បើកសម្តែងពីមុនផងដែរ [សូមមើល គ. និង ស. ១២៨:១៨] ។ សូមសរសេរគោលលទ្ធិខាងក្រោមនៅលើក្តារខៀន ៖ **នៅក្នុងសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ អ្វីៗទាំងអស់នៅគ្រាកាន់កាប់ត្រួតត្រាមុនៗ នឹងត្រូវបានស្តារឡើងវិញ**) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប៊ី អេច រ៉ូប៊ីត នៃក្រុមចិតសិបនាក់ ៖



« នេះគឺជាសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ហើយយើងឃើញថា យើងកំពុងរត់ចូលទៅក្នុងសម័យនោះ ដែលប្រៀបបាននឹងក្រុមទឹកស្ទឹងដែលមានកម្លាំងដ៏ធំហូរចាក់ចូលយ៉ាងលឿនទៅក្នុងមហាសមុទ្រ ជាគ្រាកាន់កាប់ត្រួតត្រាកាលពីមុននៅគ្រប់ជំនាន់ ដោយតយើងភ្ជាប់ជាមួយពួកគេ ហើយតពួកគេភ្ជាប់ជាមួយយើង ហើយយើងឃើញថា ព្រះមានព្រះរាជបំណងដ៏អស្ចារ្យតែមួយគត់តាំងពីដើមដំបូងមក ហើយវាគឺជាសេចក្តីសង្គ្រោះរបស់កូនចៅទ្រង់ ។ ហើយឥឡូវនេះថ្ងៃចុងក្រោយបានមកដល់ហើយ ជាគ្រាកាន់កាប់ត្រួតត្រាចុងក្រោយ កាលដែលសេចក្តីពិតនិងពន្លឺ ហើយនិងសេចក្តីសុចរិតត្រូវគ្របដណ្តប់ផែនដីទាំងមូល » (នៅក្នុង Conference Report ខែ តុលា ឆ្នាំ ១៩០៤ ទំព័រ ៧៣) ។

សូមអញ្ជើញសិស្សឲ្យឡើងមកក្តារខៀន ហើយសរសេរឃ្លាថាសេចក្តីពិត បទគម្ពីរ សេចក្តីសញ្ញា និងអំណាចមកពីគ្រាកាន់កាប់ត្រួតត្រាមុនដែលបានស្តារឡើងវិញ ឬបាននាំមកសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នៅត្រង់រួបទន្លេ ។ (ស្លាកពាក្យនោះអាចរួមមានអំណាចនៃការផ្សារភ្ជាប់ ពិធីបរិសុទ្ធនៃការសង្គ្រោះ ព្រះគម្ពីរមរមន ជាដើម សិស្សអាចគូររួបទន្លេបន្ថែមទៀត ប្រសិនបើចាំបាច់) ។

- តើការរស់នៅក្នុងសម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ គឺជាពរជ័យមួយសម្រាប់អ្នកយ៉ាងដូចម្តេចដែរ ?
- យោងតាមសេចក្តីថ្លែងរបស់អែលឌើរ រ៉ូប៊ីត តើរឿងអ្វីត្រូវកើតឡើងនៅគ្រាកាន់កាប់ត្រួតត្រានេះ ? (សេចក្តីពិត ពន្លឺ និងសេចក្តីសុចរិតត្រូវគ្របដណ្តប់ផែនដីទាំងមូល) ។
- តើធនធានអ្វីនៅគ្រាកាន់កាប់ត្រួតត្រារបស់យើងអាចជួយយើង ឲ្យពន្លិចផែនដីនេះដោយសេចក្តីពិត និងពន្លឺនៃដំណឹងល្អ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ ៖



« បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំអើយ កិច្ចការដែលសម្រេចបានយ៉ាងច្រើនមកដល់ពេលនេះ នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះដោយជ្យឫទ្ធផ្សាយសារលិខិតដំណឹងល្អតាមរយៈប្រព័ន្ធបណ្តាញសង្គម គឺជាការចាប់ផ្តើមមួយដ៏ល្អ—ប៉ុន្តែនៅតែតិចនៅឡើយ ។ ឥឡូវនេះ ខ្ញុំសូមបន្តការអញ្ជើញដល់អ្នកឲ្យជួយបំប្លែងដំណក់ទឹកនោះទៅជាទឹកជំនន់មួយ ។ . . . ខ្ញុំសូមដាស់តឿនបងប្អូនឲ្យចោសសម្អាតផែនដីនេះ ដោយសារលិខិតដែលពេញដោយសេចក្តីសុចរិត និងសេចក្តីពិត—ជាសារលិខិតដែលពិត មានប្រយោជន៍ ហើយសក្តិសម—ហើយពិតជាបណ្តាលឲ្យចោសផែនដីដូចជាទឹកជំនន់មែន » (« To Sweep the Earth as with a Flood » ⁄ Brigham Young University Campus Education Week devotional ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៤ ⁄ LDS.org) ។

សូមអញ្ជើញសិស្សឲ្យចែកចាយពីកិច្ចការ ដែលពួកគេកំពុងធ្វើដើម្បីជួយពន្លិចផែនដីនេះជាមួយនឹងសារលិខិត ដែលពេញដោយសេចក្តីសុចរិត និងសេចក្តីពិត ។

សូមសង្ខេប អេភេសូរ ១:១១–១២ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា តាមរយៈព្រះយេស៊ូវគ្រីស្ទ នោះពួកបរិសុទ្ធបានទទួល « កេរ្តិ៍អាករ » (ខទី ១១) នៅក្នុងនគរព្រះ ។

អេភេសូរ ១:១៣–២៣

ប៉ុលបង្រៀនអំពីព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យា

សូមឲ្យសិស្សម្នាក់អាន អេភេសូរ ១:១៣–១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យមួយ ដែលពួកបរិសុទ្ធបានទទួល ដោយព្រោះតែសេចក្តីស្មោះត្រង់របស់ពួកគេ ព្រមទាំងការទុកចិត្ត និងជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។

- **យោងតាម ខទី ១៣ តើពួកបរិសុទ្ធបានទទួលពរជ័យអ្វីខ្លះ ? (ពួកគេត្រូវបាន « ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ⁄ នៃសេចក្តីសន្យា ⁄ ») ។**

សូមពន្យល់ថា ការ« ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ⁄ នៃសេចក្តីសន្យា ⁄ » មានន័យថា ព្រះវិញ្ញាណបរិសុទ្ធ « ធ្វើជាសាក្សីដល់ព្រះវរបិតាថា ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះត្រូវបានធ្វើឡើងយ៉ាងត្រឹមត្រូវ ហើយថាសេចក្តីសញ្ញាដែលបានទាក់ទងជាមួយនឹងពួកគេត្រូវបានរក្សាទុក » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះវិញ្ញាណបរិសុទ្ធនៃសេចក្តីសន្យា »scriptures.lds.org ។ ព្រះវិញ្ញាណគឺជា « ទីបញ្ចាំចិត្តពីដំណើរកេរ្តិ៍អាករ » (ខទី ១៤) ។ វាមានន័យថា វត្តមាននៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើងគឺជាអ្វាន់ ជាការរំឭកចាំ និងជាការបង្ហាញមកពីព្រះថា ប្រសិនបើយើងស្មោះត្រង់ នោះយើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមសង្ខេប អេភេសូរ ១:១៥–១៦ ដោយពន្យល់ថា ប៉ុលបានប្រាប់ពួកបរិសុទ្ធថា លោកបានបន្តថ្លែងអំណរគុណចំពោះព្រះសម្រាប់ភាពស្មោះត្រង់របស់ពួកគេ ។

សូមឲ្យសិស្សម្នាក់អាន អេភេសូរ ១:១៧–១៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានអធិស្ឋានទូលសុំព្រះឲ្យប្រទានអ្វីខ្លះដល់ពួកបរិសុទ្ធ ។

- **តើប៉ុលបានអធិស្ឋានទៅព្រះឲ្យប្រទានអ្វីខ្លះដល់ពួកបរិសុទ្ធ ?**
- **តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ ដល់យើងអំពីរបៀបដែលយើងអាចស្គាល់ព្រះវរបិតាសួគ៌ ? (ដោយប្រើពាក្យផ្ទាល់ខ្លួន សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **<u>**យើងអាចស្គាល់ព្រះវរបិតាសួគ៌បាន តាមរយៈវិញ្ញាណនៃវិវរណៈ**</u>**) ។**

ដើម្បីជួយសិស្សយល់អំពីវិញ្ញាណនៃវិវរណៈ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណាឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកអត្ថន័យអំពីវិញ្ញាណនៃវិវរណៈ ។



« វិវរណៈគឺជាទំនាក់ទំនងរវាងព្រះ និងកូនចៅរបស់ទ្រង់នៅលើផែនដី ហើយជាពរជ័យដ៏ធំមួយដែលភ្ជាប់មកជាមួយនឹងអំណោយទាន និងគ្រកដ៏ខ្ពង់ខ្ពស់នៃព្រះវិញ្ញាណបរិសុទ្ធ ។ ព្យាការី យ៉ូសែប ស៊្មីធ បានបង្រៀនថា ‹ ព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកទទួលវិវរណៈ › ហើយ ‹ គ្មានមនុស្សណាម្នាក់អាចទទួលព្រះវិញ្ញាណបរិសុទ្ធដោយពុំទទួលវិវរណៈនោះទេ › (*Teachings of Presidents of the Church: Joseph Smith* ⁄ ឆ្នាំ ២០០៧ ⁄ ទំព័រ ១៣២) ។

« វិញ្ញាណនៃវិវរណៈមានសម្រាប់មនុស្សគ្រប់រូប ដែលបានទទួលពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះនៃបុណ្យជ្រមុជទឹក ដោយការជ្រមុជសម្រាប់ការផ្តាច់បាប និងការដាក់ដៃលើសម្រាប់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ តាមរយៈសិទ្ធិអំណាចបព្វជិតភាពដ៏ត្រឹមត្រូវ—និងអ្នកដែលអនុវត្តតាមក្នុងសេចក្តីជំនឿដើម្បីបំពេញតាមបង្គាប់នៃបព្វជិតភាពដើម្បី ‹ ទទួលព្រះវិញ្ញាណបរិសុទ្ធ › » (« The Spirit of Revelation » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៨៧) ។

- **តើវិញ្ញាណនៃវិវរណៈគឺជាអ្វី ?**
- **តើវិវរណៈតាមរយៈព្រះវិញ្ញាណបរិសុទ្ធអាចជួយយើង ឲ្យស្គាល់ព្រះវរបិតាសួគ៌បានយ៉ាងដូចម្តេច ?**

អ្នកគួរអញ្ជើញសិស្សឲ្យចែកចាយថា វិវរណៈតាមរយៈព្រះវិញ្ញាណបរិសុទ្ធបានជួយពួកគេឲ្យស្គាល់ព្រះវរបិតាសួគ៌កាន់តែប្រសើរឡើងតាមរបៀបណា ។ សូមគិតពីការចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនអ្នក ។ សូមលើកទឹកចិត្តសិស្សឲ្យខិតខំ ដើម្បីមានភាពសក្តិសមជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីពួកគេអាចបន្តស្គាល់ព្រះវរបិតាសួគ៌កាន់តែប្រសើរឡើង ។

សូមសង្ខេប អេភេសូរ ១:១៩–២៣ ដោយពន្យល់ថា ប៉ុលបានបន្តបង្រៀនអំពីមរតករបស់ពួកបរិសុទ្ធនៃសេចក្តីសន្យា និងតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទជាសិរសានៃសាសនាចក្ររបស់ទ្រង់ ។

មេរៀនសិក្សានៅផ្ទះ

កូរិនថូសទី២ ៨–អេភេសូរ ១ (មេរៀនទី ២៤)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា កូរិនថូសទី ២ ៨–អេភេសូរ ១ (មេរៀនទី ២៤) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (កូរិនថូសទី២ ៨–៩)

នៅក្នុងមេរៀននេះ សិស្សបានរៀនថា នៅពេលយើងយល់អំពីអ្វីគ្រប់យ៉ាងដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យយើង នោះយើងនឹងកាន់តែមានឆន្ទៈ ដើម្បីបរិច្ចាគធនធានរបស់យើងទៅឲ្យដល់មនុស្សដទៃ ។ សិស្សក៏បានរៀនផងដែរថា ព្រះសព្វព្រះទ័យឲ្យយើងមានឆន្ទៈចង់បរិច្ចាគ ទោះជាពេលយើងគ្មានអ្វីផ្តល់ឲ្យក៏ដោយ ។ លើសពីនោះ សិស្សបានរៀនថា ប្រសិនបើយើងផ្តល់ទៅឲ្យអ្នកទាំងឡាយដែលខ្វះខាតដោយដួងចិត្តពីរកាយ នោះព្រះនឹងប្រទានពរដល់យើងដោយសប្បុរស ហើយការទទួលស្គាល់សេចក្តីសប្បុរសរបស់ព្រះនៅក្នុងការប្រទានពរដ៏យដល់យើង អាចជួយយើងឲ្យមានអារម្មណ៍ដឹងគុណដល់ទ្រង់ ។

ថ្ងៃទី ២ (កូរិនថូសទី២ ១០–១៣)

ចេញមកពីការបង្រៀនរបស់ប៉ុលអំពីចម្បាំងខាងវិញ្ញាណ នោះសិស្សបានរៀនថា នៅពេលយើងគ្រប់គ្រងគំនិតរបស់យើងឲ្យគោរពប្រតិបត្តិតាមព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងកាន់តែបានដោគជ័យនៅក្នុងចម្បាំងទាស់នឹងសាតាំង ។ ចេញមកពីការបង្រៀនរបស់ប៉ុលអំពីបន្លាចាក់មកក្នុងសាច់ឈាមរបស់លោក នោះសិស្សបានរកឃើញថា ព្រះអម្ចាស់អនុញ្ញាតឲ្យយើងទទួលបទពិសោធន៍នៃភាពទន់ខ្សោយ និងការសោកល្បងដើម្បីឲ្យយើងអាចរៀនបន្ទាបខ្លួន ។ ព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ គឺល្មមគ្រប់គ្រាន់ដើម្បីពង្រឹងភាពទន់ខ្សោយយើង ហើយព្រះអម្ចាស់ពុំដកឧបសគ្គរបស់យើងចេញជានិច្ចកាលនោះទេ ប៉ុន្តែទ្រង់នឹងពង្រឹងយើង នៅពេលយើងស៊ូទ្រាំដោយស្មោះត្រង់ ។

ថ្ងៃទី ៣ (កាឡាទី)

នៅពេលសិស្សសិក្សាអំពីការបង្រៀនរបស់ប៉ុលទៅដល់ពួកកាឡាទី នោះពួកគេបានរៀនថា ព្រះយេស៊ូវបានបើកសម្តែងគោលលទ្ធិពិតដល់ពួកព្យាការីទាំងឡាយរបស់ទ្រង់ ។ សិស្សក៏បានរៀនផងដែរថា អស់អ្នកទាំងឡាយដែលអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយចូលទៅក្នុងសេចក្តីសញ្ញានៃដំណឹងល្អ ពួកគេនឹងប្រែក្លាយទៅជាតែមួយនៅក្នុងព្រះគ្រីស្ទ ហើយជាអ្នកគ្រងមរតករបស់ព្រះ ។ ពួកគេបានយល់ថា នៅពេលយើងដើរនៅក្នុងព្រះវិញ្ញាណ យើងនឹងយកឈ្នះលើការល្បួងទាំងឡាយខាងសាច់ឈាម ហើយថាប្រសិនបើយើងឧស្សាហ៍នៅក្នុងការធ្វើសេចក្តីល្អ នោះយើងនឹងច្រូតបានពរដ៏យពីទង្វើរបស់យើង ។

ថ្ងៃទី ៤ (អេភេសូរ ១)

ចេញមកពីដំពូកទីមួយនៃការបង្រៀនរបស់ប៉ុលទៅកាន់ពួកអេភេសូរ សិស្សបានរៀនថា កូនចៅរបស់ព្រះត្រូវបានតែងតាំងពីមុនកំណើតលោកិយមក ដើម្បីទទួលបានពរដ៏យនៃដំណឹងល្អ ។ ពួកគេក៏រៀនផងដែរថា អំឡុងគ្រាកាន់កាប់ត្រួតត្រាក្នុងពេលពេញកំណត់អ្វីៗគ្រប់យ៉ាងមកពីគ្រាកាន់កាប់ត្រួតត្រាពីអតីតកាល នឹងត្រូវបានស្តារឡើងវិញ ហើយថាយើងអាចបានស្គាល់ព្រះវរបិតាសួគ៌ តាមរយៈវិញ្ញាណនៃវិរាណៈ ។

សេចក្តីផ្តើម

សាវកប៉ុលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធកាឡាទី ឲ្យស្ថាបនាសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទឡើងវិញ ហើយទុកចិត្តថា សេចក្តីសង្គ្រោះអាចទទួលបាន តែតាមរយៈទ្រង់ប៉ុណ្ណោះ ពុំមែនតាមរយៈការគោរពតាមក្រឹត្យវិន័យរបស់ម៉ូសេឡើយ ។


យោបល់សម្រាប់ការបង្រៀន

កាឡាទី ៥

ប៉ុលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធកាឡាទី ឲ្យស្ថាបនាសេចក្តីជំនឿរបស់ខ្លួនទៅលើព្រះយេស៊ូវគ្រីស្ទឡើងវិញ ។

សូមគូររូបភាពទាញព្រាត់នៅលើក្តារខៀន ។

- តើការទាញព្រាត់ជាអ្វី ? តើអ្នកអាចឈ្នះដោយរបៀបណា ?



- តើជីវិតរបស់យើងស្រដៀងគ្នានឹងការទាញព្រាត់តាមវិធីណា ?

ប្រសិនបើសិស្សពុំបានប្រាប់អំពីវាទេ សូមចង្អុលបង្ហាញថា ទិដ្ឋភាពមួយនៃជីវិតរបស់យើងដែលស្រដៀងគ្នាទៅនឹងការទាញព្រាត់ គឺការពុះពារបស់យើងទប់ទល់នឹងការល្បួង ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅពេលពួកគេសិក្សាកាឡាទី ៥ដែលអាចជួយពួកគេដឹងអំពីរបៀប ដើម្បីឈ្នះលើការពុះពារទប់ទល់នឹងការល្បួង ។

សូមរំឭកសិស្សថា ពួកគ្រីស្ទានដែលជាសាសន៍យូដា បានដឹកនាំពួកបរិសុទ្ធនៅក្នុងក្រុងកាឡាទីឲ្យយល់ខុសឆ្គង ដោយបង្រៀនពួកគេថា ពួកគេចាំបាច់ត្រូវរស់នៅតាមក្រឹតវិន័យរបស់ម៉ូសេ ហើយត្រូវកាត់ស្បែកដើម្បីបានសង្គ្រោះ ។ សាវកប៉ុលបានពិពណ៌នាអំពីការបង្រៀនខុសឆ្គង អំពីក្រឹត្យវិន័យលោកម៉ូសេទាំងនេះថា « ជាប់ចំណងជាបាវបម្រើ » (កាឡាទី ៥:១) ។

សូមអញ្ជើញសិស្សម្នាក់អាន កាឡាទី ៥:១ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើនរណាដែលប៉ុលបាននិយាយថា នាំមកនូវសេរីភាពចេញពីការជាប់ចំណងជាបាវបម្រើនេះ ។

- តើនរណានាំមកនូវសេរីភាពចេញពីការជាប់ចំណងជាបាវបម្រើនេះ ?

សូមសង្កេបកាឡាទី ៥:២–១៥ដោយពន្យល់ថា ប៉ុលបានស្តីបន្ទោសពួកបរិសុទ្ធកាឡាទីចំពោះការងាយងាកចេញពីសេរីភាពនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយត្រឡប់ទៅរកការជាប់ចំណងនៃក្រឹត្យវិន័យរបស់ម៉ូសេវិញនោះ ។ បន្ទាប់មកលោកបានបញ្ជាក់ថា ទោះជាអ្នកដើរតាមព្រះគ្រីស្ទត្រូវបានដោះលែងពីការជាប់ចំណងនៃក្រឹត្យវិន័យរបស់ម៉ូសេក្តី ក៏នោះពុំមែនមានន័យថា ពួកគេមានសេរីភាពដើម្បីប្រព្រឹត្តអំពើបាបដោយសេរីនោះទេ ។

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ៥:១៦–១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលកម្លាំងប្រកួតប្រជែងពីរ ដែលប៉ុលបានពិពណ៌នា ។

- តើកម្លាំងប្រកួតប្រជែងពីរ ដែលប៉ុលបានពិពណ៌នាមានអ្វីខ្លះ ?

ចូរបង្កើតតារាងមួយនៅលើក្តារខៀនដោយគូសបន្ទាត់ឈរនៅត្រង់កណ្តាលនៃរូបភាពការទាញព្រាត់ ។ សូមសរសេរ*ដើរនៅក្នុងព្រះវិញ្ញាណ*នៅខាងលើផ្នែកម្ខាងនៃការទាញព្រាត់ ហើយ*សរសេរបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម*នៅខាងលើផ្នែកម្ខាងទៀត ។

- តើ « ការដើរនៅក្នុងព្រះវិញ្ញាណ » មានន័យដូចម្តេច ? (កាឡាទី៥:១៦) ។ (ដើម្បីរស់នៅសក្តិសម ហើយធ្វើតាមព្រះវិញ្ញាណបរិសុទ្ធ) ។
- តើ « បំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម » (កាឡាទី៥:១៦) សំដៅទៅលើអ្វី ? (ការល្បួងឲ្យធ្វើអំពើបាប) ។
- តើរឿងទាំងពីរនេះចាត់ទុកថាជាកម្លាំងប្រកួតប្រជែងយ៉ាងដូចម្តេច ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនចេញមកពីកាឡាទី ៥:១៦អំពីរបៀបដែលយើងអាចយកឈ្នះលើការល្បួងខាងសាច់ឈាម ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងដើរនៅក្នុងព្រះវិញ្ញាណ នោះយើងនឹងយកឈ្នះលើការល្បួងខាងសាច់ឈាមនានា ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ មែលវិន ជេ បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលសំណួរដែលអែលឌើរ បាឡឺត បានសុំឲ្យយើងគិតពិចារណា ។



« គ្រប់ការបំពានដែលមានសត្រូវនៃព្រលឹងរបស់យើងនឹងធ្វើ ដើម្បីចាប់ចងយើង គឺនឹងធ្វើតាមរយៈសាច់ឈាម ។ . . . មធ្យោបាយដែលវាធ្វើចំពោះយើងនឹងធ្វើតាមរយៈតណ្ហា សេចក្តីលោភ មហិច្ឆតាខាងសាច់ឈាម ។ គ្រប់ជំនួយដែលព្រះអម្ចាស់ផ្តល់ដល់យើង ដើម្បីជួយយើងនៅក្នុងការពុះពារនេះ នឹងកើតមានចំពោះយើងតាមរយៈវិញ្ញាណ ដែលស្ថិតនៅក្នុងរូបកាយនៃជីវិតមែងស្លាប់នេះ ។ ដូច្នេះកម្លាំងដ៏ធំពីរនេះ កំពុងប្រតិបត្តិការមកលើយើងតាមរយៈបណ្តាញទាំងពីរនេះ ។

« តើការច្បាំងនេះកើតមានចំពោះអ្នកយ៉ាងដូចម្តេច ? . . . នោះជាសំណួរមួយដ៏សំខាន់ណាស់ ។ ជម្លោះដ៏ធំបំផុតដែលគ្រប់បុរស និងស្ត្រី នឹងមាន (ខ្ញុំមិនខ្វល់ថា ចំនួនមារសត្រូវមានច្រើនប៉ុណ្ណាទេ) គឺជាចម្បាំងទៅនឹងខ្លួនឯង » (« Struggle for the Soul »*New Era*ខែ មីនា ឆ្នាំ ១៩៨៤ ទំព័រ ៣៥) ។

សូមឲ្យសិស្សសញ្ជឹងគិតថា តើពួកគេស្ថិតនៅខាងណាក្នុងការទាញព្រាត់នោះ ហើយតើកម្លាំងណាមួយកំពុងតែយកឈ្នះនៅក្នុងជីវិតរបស់ពួកគេ ។

សូមចែកសិស្សជាក្រុម ដែលមានគ្នាពីរ ឬបីនាក់ ។ ចូរចាត់ឲ្យសិស្សក្នុងក្រុមពាក់កណ្តាលអាន កាឡាទី ៥:១៩–២១ឮៗជាមួយគ្នា ហើយរកមើលលទ្ធផលនៃ « [ការបំពេញតាម] សេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម » ។ សូមអញ្ជើញសិស្សពាក់កណ្តាលក្រុមទៀតអាន កាឡាទី ៥:២២–២៣ឮៗជាមួយគ្នា ហើយរកមើលលទ្ធផលនៃការដើរនៅក្នុងព្រះវិញ្ញាណ ។ នៅពេលអ្នកបញ្ចប់ការអាន សូមអញ្ជើញសមាជិកម្នាក់មកពីក្រុមនីមួយៗ ឲ្យសរសេរចម្លើយមួយដែលពួកគេបានរកឃើញ នៅក្នុងកូឡោនត្រឹមត្រូវនៅលើក្តារខៀន ។ សូមអញ្ជើញពួកគេឲ្យបន្តសរសេរចម្លើយរបស់ពួកគេ រហូតដល់តារាងនោះឆ្លុះបញ្ចាំងនូវអ្វីដែលប៉ុលបានរៀបរាប់ ។ អ្នកអាចនឹងចង់នាំយកវចនានុក្រមមកថ្នាក់រៀន ហើយអញ្ជើញសិស្សឲ្យរកមើលពាក្យណាដែលពិបាកយល់ ។

- យោងតាមកាឡាទី ៥:២១តើប៉ុលបង្រៀនថា អ្វីខ្លះនឹងកើតមានឡើងចំពោះមនុស្សដែលចុះចាញ់ « កិច្ចការខាងសាច់ឈាម » ? (កាឡាទី៥:១៩) ។
- យោងតាមកាឡាទី ៥:២២–២៣តើផលផ្លែ ឬលទ្ធផលអ្វីខ្លះដែលចង្អុលបង្ហាញថា នរណាម្នាក់កំពុងតែដើរនៅក្នុងព្រះវិញ្ញាណ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ផលផ្លែនៃព្រះវិញ្ញាណនោះគឺជាសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត និងដឹងខ្នាត ។** អ្នកអាចនឹងចង់ផ្តល់យោបល់ដល់សិស្ស ឲ្យគូសចំណាំសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

ចូរយោងទៅផ្នែកម្ខាងនៃតារាង ត្រង់កន្លែងផលផ្លែនៃព្រះវិញ្ញាណត្រូវបានរៀបរាប់ ។

- ហេតុអ្វីពរជ័យទាំងនេះសក្តិសមនឹងមាន ?

នៅខាងក្រោមតារាងនោះ សូមគូសញ្ញាព្រួញធំមួយចង្អុលទៅត្រង់កន្លែងដែលរៀបរាប់ពីសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ។ សូមឲ្យសិស្សនឹកស្រមៃថា នៅក្នុងរូបភាពនៃការទាញព្រាត់នេះ យើងអនុញ្ញាតឲ្យខ្លួនយើងរំកិលទៅរកសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ។

- តើមានអ្វីកើតឡើងចំពោះផលផ្លែនៃព្រះវិញ្ញាណ នៅពេលយើងចុះចាញ់ព្រមធ្វើតាមសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ? (យើងចាប់ផ្តើមបាត់បង់ផលផ្លែនៃព្រះវិញ្ញាណ) ។

សូមលុបសញ្ញាព្រួញនោះចេញ ហើយគូសរូបសញ្ញាព្រួញមួយទៀត ដែលចង្អុលទៅរកផលផ្លែខាងវិញ្ញាណ ។ សូមឲ្យសិស្សនឹកស្រមៃថា ឥឡូវយើងអនុញ្ញាតឲ្យខ្លួនយើងរំកិលទៅខាងវិញ្ញាណនេះ ។

- តើមានអ្វីកើតឡើងចំពោះកិច្ចការខាងសាច់ឈាម ពេលយើងដើរនៅក្នុងព្រះវិញ្ញាណ ? (វាឈប់មានចំណែកនៅក្នុងជីវិតយើងទៀតហើយ) ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេអំពីគ្រាមួយ ដែលពួកគេទទួលអារម្មណ៍ ឬបានដឹកពិសោធន៍អំពីផលផ្លែមួយនៃផលផ្លែខាងព្រះវិញ្ញាណទាំងនេះ ។ ចូរសុំពួកគេឲ្យដាក់បញ្ចូលនូវអ្វី ដែលពួកគេកំពុងធ្វើដើម្បីដើរនៅក្នុងព្រះវិញ្ញាណនៅគ្រានោះ ។ នៅពេលពួកគេបញ្ចប់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីអ្វីដែលពួកគេបានសរសេរ ។

ចូរសុំឲ្យសិស្សម្នាក់អាន កាឡាទី ៥:២៤–២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីអ្វី ដែលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបានព្យាយាមធ្វើជាមួយនឹងសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ។

- តើពួកសិស្សរបស់ព្រះយេស៊ូវព្យាយាមធ្វើអ្វីខ្លះ ជាមួយនឹងសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមនេះ ? (ឆ្កាងវា ឬលុបបំបាត់វាចេញពីជីវិតរបស់ពួកគេ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វី ដែលពួកគេនឹងធ្វើដើម្បីដើរកាន់តែពេញលេញនៅក្នុងព្រះវិញ្ញាណ ។ សូមលើកទឹកចិត្តដល់ពួកគេឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួល ដើម្បីពួកគេអាចរីករាយនឹងផលផ្លែខាងព្រះវិញ្ញាណ ។

មេរៀនបន្ទាប់ (អេភេសូរ ២–កីលីព ៤)

សូមអញ្ជើញសិស្សឲ្យគិតពីការផ្លាស់ប្តូរគុណតម្លៃ ក្រឹត្យវិន័យ និងគំនិតនានាខាងលោកិយ ។ តើយើងអាចដឹងថាអ្វីត្រឹមត្រូវ និងខុសឆ្គងនៅក្នុងពិភពលោកមួយ ដែលគំនិតយោបល់មានការផ្លាស់ប្តូរយ៉ាងខ្លាប់ខ្លួននោះដោយរបៀបណា ? សាវកប៉ុលបានទូន្មានដល់ពួកបរិសុទ្ធ ហើយបានជួយពួកគេឲ្យយល់អំពីអ្វី ដែលព្រះអម្ចាស់បានប្រទានឲ្យ ដើម្បីប្រាកដថា យើងមិនត្រូវបាននាំចេញទៅដោយទស្សនៈវិជ្ជាខុសឆ្គងនៃលោកិយនេះទេ ។ ក៏សូមពន្យល់ផងដែរថា នៅពេលពួកគេបន្តសិក្សាការសរសេររបស់ប៉ុលអំឡុងសប្តាហ៍ក្រោយ នោះពួកគេនឹងរកឃើញចម្លើយចំពោះសំណួរដូចខាងក្រោមនេះ ៖ តើកុមារតូចៗគួរប្រព្រឹត្តនឹងឪពុកម្តាយរបស់ពួកគេយ៉ាងដូចម្តេច ? តើប៉ុលបាននិយាយអ្វីខ្លះ ដែលនឹង « លែងអស់ទាំងព្រួញឆេះរបស់ពួកទុច្ចរិត » (អេភេសូរ ៦:១៦) ?

អេភេសូរ ២–៣

សេចក្តីផ្តើម

ប៉ុលបានបង្រៀនពួកបរិសុទ្ធនៅក្រុងអេភេសូរថា អស់អ្នកដែលមានបាបអាចត្រូវបានសង្គ្រោះដោយព្រះគុណនៃព្រះ ហើយថាពួកសាសន៍យូដា និងសាសន៍ដទៃបានក្លាយទៅជាតែមួយនៅក្នុងក្រុមគ្រួសារនៃព្រះ ។ ប៉ុលក៏បានពន្យល់ផងដែរថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ត ត្រូវបានស្ថាបនាឡើងនៅលើគ្រឹះនៃពួកសាវក និងពួកព្យាការី ហើយលោកបានចែកចាយពីបំណងប្រាថ្នារបស់លោកថា ពួកបរិសុទ្ធនឹងទទួលបាននូវបទពិសោធន៍សេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ត ។

យោបល់សម្រាប់ការបង្រៀន

អេភេសូរ ២

ប៉ុលបង្រៀនអំពីរបៀប ដែលព្រះយេហូវ៉ាតរបស់ព្រះយេស៊ូវគ្រីស្តសង្គ្រោះទាំងពួកសាសន៍យូដា និងពួកសាសន៍ដទៃ

នៅពេលចាប់ផ្តើមថ្នាក់រៀន សូមអញ្ជើញសិស្សរបស់អ្នកម្នាក់ ឬច្រើននាក់ (អាស្រ័យទៅលើទំហំថ្នាក់របស់អ្នក) ឲ្យអង្គុយនៅលើកម្រាលឥដ្ឋនៅកន្លែងផ្សេងៗគ្នាក្នុងថ្នាក់រៀន ។ សូមដាក់ព្រំដែនមួយដែលខណ្ឌចែករវាងសិស្សទាំងនេះ និងសិស្សផ្សេងទៀត ដោយបិទបង់ស្អិត ឬខ្សែ បន្ទាប់មកណែនាំឲ្យសិស្សដែលបំបែកចេញនោះថា ពួកគេមិនអាចចូលរួមនិយាយស្តីក្នុងមេរៀននេះ (នៅឡើយទេ) ។ ចូរសួរដល់សិស្សផ្សេងទៀតក្នុងថ្នាក់ ៖

- តើស្ថានភាពនេះអាចប្រាប់ឲ្យដឹងអំពីទំនាក់ទំនងរវាងអ្នក និងសិស្សដែលបានបំបែកចេញយ៉ាងដូចម្តេច ? (ថា ក្រុមមួយគឺជាទីពេញចិត្តជាងក្រុមមួយទៀត) ។
- តើអ្នកគិតថា សិស្សដែលបានបំបែកចេញអាចមានអារម្មណ៍យ៉ាងដូចម្តេច ? ហេតុអ្វី ?

ចូរសុំឲ្យសិស្សគិតពិចារណា ប្រសិនបើពួកគេធ្លាប់មានអារម្មណ៍របៀបនេះក្នុងស្ថានភាពជីវិតជាក់លាក់ ។

សូមសរសេរពាក្យ *សាសន៍ដទៃ* និង*សាសន៍យូដា*នៅលើក្តារខៀន ដោយបង្កើតកូឡោនចំនួនពីរ ។

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀនអំពីស្ថានភាពសង្គមនៅក្នុងសាខាសាសនាចក្រមួយចំនួនអំឡុងពេលនៃការបម្រើរបស់ប៉ុល តើស្លាកមួយណា ដែលសក្តិសមចំពោះសិស្សដែលបំបែកចេញ ។ (សាសន៍ដទៃ) ។ តើស្លាកមួយណាដែលសក្តិសមនឹងសិស្សក្នុងថ្នាក់ ? (សាសន៍យូដា) ។
- តើកត្តាអ្វីដែលបណ្តាលឲ្យមានការបំបែកគ្នានេះ ? (ពួកសាសន៍យូដាមួយចំនួនជឿថា ដោយសារតែពួកគេគឺជាពួកអ៊ីស្រាអែលពីកំណើត ហើយបានកាត់ស្បែក នោះពួកគេត្រូវបានព្រះសព្វព្រះទ័យជាងគេ ហើយត្រូវធ្វើជាមេលើពួកអ្នកផ្លាស់ប្រែចិត្តជឿសាសន៍ដទៃទៀត) ។

សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ២:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលប៉ុលបានពិពណ៌នាអំពីស្ថានភាពខាងវិញ្ញាណរបស់ពួកបរិសុទ្ធសាសន៍ដទៃ (« អ្នក » និង « អ្នករាល់គ្នា » នៅក្នុងខទី ១–២) និងពួកបរិសុទ្ធសាសន៍យូដា (« យើងរាល់គ្នា » នៅក្នុងខទី ៣ពីមុនការផ្លាស់ប្រែចិត្តជឿរបស់ពួកគេចំពោះព្រះអង្គសង្គ្រោះ និងសាសនាចក្ររបស់ទ្រង់ ។ សូមពន្យល់ថា ឃ្លា « មេគ្រប់គ្រងរាជ្យលើអាកាស » នៅក្នុងខទី ២សំដៅទៅលើសេចក្តីអាក្រក់ និងឥទ្ធិពលរាលដាលរបស់វានៅក្នុងពិភពលោកនេះ ។

- យោងតាមខទី ១–២តើប៉ុលបានពិពណ៌នាអំពីពួកសាសន៍ដទៃពីមុនការផ្លាស់ប្រែចិត្តជឿរបស់ពួកគេយ៉ាងដូចម្តេច ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនក្រោមកូឡោន ដែលមានដាក់ស្លាកថា « សាសន៍ដទៃ ») ។
- យោងតាមខទី ៣តើប៉ុលបានពិពណ៌នាអំពីខ្លួនលោក និងពួកសាសន៍យូដាពីមុនការផ្លាស់ប្រែចិត្តជឿរបស់ពួកគេយ៉ាងដូចម្តេច ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនក្រោមកូឡោន ដែលមានដាក់ស្លាកថា « សាសន៍យូដា ») ។

សូមចង្អុលបង្ហាញថា ពួកសាសន៍ដទៃក៏ដូចជាពួកសាសន៍យូដាគឺបានស្លាប់ខាងវិញ្ញាណ ឬបំបែកចេញពីព្រះ ដោយសារតែអំពើបាបរបស់ពួកគេ (សូមមើល ខទី ១) ។

សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ២:៤–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលស្ថានភាពខាងវិញ្ញាណរបស់ពួកបរិសុទ្ធសាសន៍ដទៃ និងពួកសាសន៍យូដា បន្ទាប់ពីការផ្លាស់ប្រែចិត្តជឿរបស់ពួកគេ ។ សូមចង្អុលបង្ហាញថា ពាក្យ*ប្រោសឲ្យបានរស់*មានន័យថាធ្វើឲ្យរស់ឡើងវិញ ហើយពាក្យ*នៅស្ថានសួគ៌ដ៏ខ្ពស់*សំដៅទៅលើអាណាចក្រនៅស្ថានសួគ៌ដែលមនុស្សទទួលគ្រងជាមរតក ។

- តើប៉ុលបានពិពណ៌នាអំពីពួកបរិសុទ្ធ បន្ទាប់ពីការផ្លាស់ប្រែចិត្តជឿរបស់ពួកគេយ៉ាងដូចម្តេច ? (ព្រះអម្ចាស់បានប្រោសពួកគេឲ្យរស់ឬធ្វើឲ្យពួកគេបានរស់ឡើងវិញ មកពីសេចក្តីស្លាប់ខាងវិញ្ញាណ និងពីស្ថានភាពប្រកបដោយអំពើបាបរបស់ពួកគេ ។ សូមរំឭកសិស្សថា យើងសំដៅទៅលើការណ៍នេះថាជាការកើតជាថ្មីខាងវិញ្ញាណ [សូមមើល ម៉ូសាយ ២៧:២៤–២៦]) ។

សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ២:៧–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វី ដែលអាចធ្វើឲ្យពួកសាសន៍ដទៃ និងពួកសាសន៍យូដាធ្វើការផ្លាស់ប្រែនេះ ។

- តើអ្វីខ្លះដែលអាចធ្វើឲ្យពួកបរិសុទ្ធទាំងពីរក្រុមនេះធ្វើការផ្លាស់ប្រែនេះ ? (ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ) ។
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ អំពីព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ ដែលធ្វើឲ្យកើតមានឡើងសម្រាប់កូនចៅរបស់ព្រះទាំងអស់ ? (បន្ទាប់ពីសិស្សបានឆ្លើយហើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **តាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ នោះមនុស្សលោកអាចត្រូវបានសង្គ្រោះតាមរយៈសេចក្តីជំនឿលើទ្រង់**) ។

សូមចង្អុលបង្ហាញថា ប៉ុលបានគូសបញ្ជាក់ថា យើងមិនអាចត្រូវបានសង្គ្រោះ ដោយសារតែកិច្ចការរបស់យើងតែម្យ៉ាងនោះទេ ទោះជាកិច្ចការទាំងនោះល្អប៉ណ្ណាក៏ដោយ (សូមមើលខទី ៨–៩) ។ ដើម្បីជួយសិស្សក្នុងថ្នាក់ឲ្យយល់ពីសេចក្តីពិតដែលបានសំគាល់ឃើញនៅខាងលើកាន់តែប្រសើរឡើង សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធានឌៀថើរ អេហ្វ អុជដូហ្វ នៃគណៈប្រធានទីមួយឲ្យឮៗ ៖



« ដោយសារតែយើងទាំងអស់គ្នា ‹ បានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ › [រ៉ូម ៣:២៣] ហើយដោយសារតែ ‹ គ្មានអ្វីដែលមិនស្អាតអាចចូលទៅក្នុងនគររបស់ព្រះ › បាន [នីហ្វៃទី១ ១៥:៣៤] នោះយើងគ្រប់គ្នាពុំសក្តិសមនឹងត្រឡប់ទៅកាន់វត្តមាននៃព្រះវិញនោះឡើយ ។ . . .

« . . . យើងពុំអាចរកបានវិធីរបស់យើងត្រឡប់ទៅកាន់ស្ថានសួគ៌វិញទេ ការទាមទារនៃសេចក្តីយុត្តិធម៌ឈរជារាំងដែលយើងគ្មានអំណាចដើម្បីនឹងយកឈ្នះដោយខ្លួនឯងឡើយ ។

« ប៉ុន្តែ មនុស្សគ្រប់រូបមិនវិនាសបង់ឡើយ ។

« ព្រះគុណនៃព្រះគឺជាសេចក្តីសង្ឃឹមដ៏ធំ និងគ្មានទីបំផុត ។

« តាមរយៈពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ផែនការនៃសេចក្តីមេត្តាករុណា រំងាប់ដល់តម្រូវការនៃសេចក្តីយុត្តិធម៌ [សូមមើលអាលម៉ា ៤២:១៥] ‹ ហើយ [នាំមកនូវ] មធ្យោបាយទាំងឡាយដល់មនុស្ស ដើម្បីឲ្យគេមានសេចក្តីជំនឿចំពោះការប្រែចិត្ត › [អាលម៉ា ៣៤:១៥] ។

« ទោះបើអំពើបាបរបស់យើង អាចដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិម: [សូមមើលអេសាយ ១:១៨] ។ ដោយសារព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង ‹ បានថ្វាយព្រះអង្គទ្រង់ទុកជាថ្លៃលោះមនុស្សទាំងអស់ › [ធីម៉ូថេទី ១ ២:៦] នោះច្រកទ្វារមួយចូលទៅក្នុងនគរដ៏អស់កល្បជានិច្ចរបស់ទ្រង់ នឹងត្រូវបានប្រទានដល់យើង [សូមមើលពេត្រុសទី ២ ១:១១] ។

« ក្លោងទ្វារនោះត្រូវបានបើកហើយ ! . . .

« ដើម្បីទទួលគ្រងសិរីល្អ យើងត្រូវការលើសពីការបើកសោក្លោងទ្វារទៅទៀត យើងត្រូវតែចូលទៅតាមក្លោងទ្វារនោះ ដោយមានបំណងចិត្តដើម្បីផ្លាស់ប្តូរ—ជាការផ្លាស់ប្តូរមួយ ដែលព្រះគម្ពីរពិពណ៌នាថាជា ‹ ត្រូវតែកើតម្តងទៀតឡើយ មែនហើយ គឺកើតមកពីព្រះផ្លាស់ប្រែពី [ស្ថានភាពខាងលោកិយរបស់យើង] និងការធ្លាក់ទៅកាន់ស្ថានភាពនៃសេចក្តីសុចរិតវិញ ដោយបានព្រះទ្រង់ប្រោសលោះនោះនឹងក្លាយទៅជាបុត្រាបុត្រីរបស់ទ្រង់ › [ម៉ូសាយ ២៧:២៥] ។ . . .

« ព្រះគុណគឺជាអំណោយរបស់ព្រះ ហើយបំណងប្រាថ្នារបស់យើងដើម្បីគោរពតាមបញ្ញត្តិនីមួយៗរបស់ព្រះ គឺជាការលាតដៃក្នុងជីវិតរំមែងស្លាប់របស់យើងបង្ហាញដល់ព្រះវរបិតាសួគ៌ថា យើងចង់ទទួលអំណោយដ៏ពិសិដ្ឋនេះ » (« The Gift of Grace » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១០៨, ១១០) ។

- តើការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្តពីអំពើបាបរបស់យើងអាចជួយយើង ឲ្យទទួលបានអំណោយជាព្រះគុណយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទខាងប្រវត្តិសាស្ត្រអំពីទំនាក់ទំនងរបស់ពួកសាសន៍យូដា និងពួកសាសន៍ដទៃ ពីមុនដំណឹងល្អត្រូវបានផ្សាយទៅដល់កូនចៅទាំងអស់របស់ព្រះ សូមបង្ហាញនូវរូបភាពអំពី « ជញ្ជាំងដែលខាន់ » (អេភេសូរ ២:១៤) នៅទីធ្លាខាងក្រៅនៃព្រះវិហារបរិសុទ្ធនៅទីក្រុងយេរូសាឡិម (ឬអញ្ជើញសិស្សឲ្យបើកទៅរូបភាពព្រះគម្ពីរបឺប លេខ ៩« ព្រះវិហារហេរ៉ូឌ ») ។ ចូរពន្យល់ថា ពួកសាសន៍ដទៃដែលមិនបានចុះសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ ត្រូវបានហាមឃាត់មិនឲ្យចូលហួសពីជញ្ជាំងនេះដែលជាកន្លែងកាន់តែពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធនោះទេ ពួកគេត្រូវបានចាត់ទុកថា « ជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅ » (អេភេសូរ ២:១៩) ។ ជញ្ជាំងខាន់ខាងសាច់ឈាម ជានិមិត្តសញ្ញានៃការបំបែកខាងវិញ្ញាណ ដែលមានរវាងពួកសាសន៍យូដា និងពួកសាសន៍ដទៃពីមុនវិវរណៈរបស់ពេត្រុសដែលថា ដំណឹងល្អគឺត្រូវផ្សាយទៅដល់ពួកសាសន៍ដទៃ ។



សូមអញ្ជើញសិស្សពីរបីនាក់ដែលបំបែកចេញពីសិស្សក្នុងថ្នាក់ ឲ្យផ្លាស់វេណគ្នាអានឮៗចេញមកពីអេភេសូរ ២:១២–១៥ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើចំពោះរបាំងរវាងពួកសាសន៍យូដា និងពួកសាសន៍ដទៃនោះ ។ សូមចង្អុលបង្ហាញថា ពាក្យ*សេចក្តីខ្មាំង*មានន័យថា « សេចក្តីជំទាស់ សេចក្តីប្រឆាំង សេចក្តីស្អប់ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សេចក្តីខ្មាំង »scriptures.lds.org) ។

ជួយសិស្សឲ្យយល់អំពីបរិបទខាងប្រវត្តិសាស្ត្រ

គ្រឹះមួយនៃការបង្រៀន និងការរៀនសូត្រពីដំណឹងល្អ គឺត្រូវយល់ដឹងពីបរិបទខាងប្រវត្តិសាស្ត្រនៃបណ្តុំព្រះគម្ពីរ ។ បរិបទ រួមមានទាំងស្ថានភាព ឬផ្ទៃរឿងអំពីវគ្គបទគម្ពីរ ព្រឹត្តិការណ៍ និងដំណើររឿងជាក់លាក់មួយ។ នៅពេលអ្នកជួយសិស្សឲ្យយល់ពីបរិបទនៃព្រះគម្ពីរ នោះពួកគេនឹងរៀបចំខ្លួន ដើម្បីស្គាល់សារលិខិតរបស់អ្នកនិពន្ធដ៏បំផុសគំនិត ។

- តើអ្វីខ្លះបាននាំឲ្យពួកសាសន៍ដទៃ និងសាសន៍យូដារួបរួមគ្នា ? (តាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ទ ជញ្ជាំងដែលតំណាងឲ្យការបំបែកពួកសាសន៍យូដា និងពួកសាសន៍ដទៃខាងវិញ្ញាណ ត្រូវបានដកចេញ ហើយពួកគេបានក្លាយទៅជា « មនុស្សថ្មីតែមួយ » [អេភេសូរ ២:១៥] ឬរួបកាយរួមតែមួយនៅក្នុងព្រះគ្រីស្ទ ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានព្រះគុណរបស់ទ្រង់ នោះយើងបានក្លាយទៅជារួមគ្នាតែមួយជាមួយនឹងពួកបរិសុទ្ធទាំងឡាយនៃព្រះ**) ។


សូមដោះបង់ស្តិត ឬខ្សែ ដែលបំបែកសិស្សចេញពីគ្នាចេញ ហើយអញ្ជើញឲ្យសិស្សដែលបំបែកចេញពីគេនោះមករួមគ្នាជាមួយនឹងសិស្សផ្សេងទៀតក្នុងថ្នាក់ ។ សូមលើកទឹកចិត្តសិស្សដែលតំណាងឲ្យពួកសាសន៍យូដា ឲ្យអញ្ជើញពួកសិស្សដែលបានបំបែកចេញឲ្យមកអង្គុយនៅជិតពួកគេ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង អេភេសូរ ២:១៦–១៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលឃ្លាដែលគូសបញ្ជាក់បន្ថែមអំពីសេចក្តីពិតដែលថា នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានព្រះគុណរបស់ទ្រង់ នោះយើងអាចនឹងក្លាយទៅជារួមគ្នាតែមួយជាមួយនឹងពួកបរិសុទ្ធទាំងឡាយនៃព្រះ ។

- តើឃ្លាអ្វីខ្លះដែលអ្នកបានរកឃើញ ដែលគូសបញ្ជាក់បន្ថែមអំពីសេចក្តីពិតដែលថា នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានព្រះគុណរបស់ទ្រង់ នោះយើងអាចនឹងក្លាយទៅជារួមគ្នាតែមួយជាមួយនឹងពួកបរិសុទ្ធទាំងឡាយនៃព្រះ ?
- ហេតុអ្វីអ្នកគិតថា សេចក្តីពិតនេះសំខាន់ចំពោះយើងដើម្បីយល់ដឹង និងអនុវត្តនៅក្នុងសាសនាចក្រនាសព្វថ្ងៃនេះ ?
- តើយើងអាចជួយអ្នកដទៃឲ្យប្រែក្លាយ ឬមានអារម្មណ៍ដូចជា « ជាតិតែមួយ » ឡើងវិញ (ខទី ១៩) នៅក្នុងសាសនាចក្រជាជាង ដូចជាមនុស្សដទៃយ៉ាងដូចម្តេច ?
- តើនៅពេលណាដែលនរណាម្នាក់បានជួយអ្នកឲ្យមានអារម្មណ៍ថា ដូចជាជាជាតិតែមួយជាមួយនឹងពួកបរិសុទ្ធជាជាងដូចជាមនុស្សដទៃ ? តើនៅពេលណាដែលអ្នកបានព្យាយាមជួយដល់នរណាម្នាក់ឲ្យមានអារម្មណ៍បែបនេះ ?

សូមអញ្ជើញសិស្សឲ្យអានអេភេសូរ ២:២០–២២ឲ្យឮៗ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលបានបង្រៀនអ្វីខ្លះអំពីគ្រឹះនៃសាសនាចក្រនេះ ។

- តើសេចក្តីពិតអ្វីខ្លះ ដែលប៉ុលបានបង្រៀននៅក្នុងខគម្ពីរនេះ អំពីរចនាសម្ព័ន្ធក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យផ្សេងពីនោះ ប៉ុន្តែសូមជួយពួកគេឲ្យស្គាល់ថា **សាសនាចក្ររបស់ព្រះអម្ចាស់ត្រូវបានស្ថាបនាឡើងនៅលើពួកសាវក និងពួកព្យាការីទាំងឡាយ ដែលមានព្រះយេស៊ូវគ្រីស្ទជាថ្មជ្រុងយ៉ាងឯក**) ។



- តើថ្មជ្រុងគឺជាអ្វី ? (ថ្មធំមួយដែលដាក់នៅជ្រុងនៃគ្រឹះមួយ ដើម្បីផ្តល់ជាកម្លាំង និងលំនឹងរបស់សំណង់ទាំងមូល) ។

សូមគូររូបភាពសាមញ្ញមួយនៃថ្មជ្រុងដែលភ្ជាប់ជញ្ជាំងទាំងពីរ ។

- តើព្រះយេស៊ូវគ្រីស្ទជាថ្មជ្រុងយ៉ាងឯករបស់សាសនាចក្រតាមរបៀបណា ? យោងតាមខទី ២១តើមានអ្វីបានកើតឡើងចំពោះសាសនាចក្រទាំងមូលដោយសារតែថ្មជ្រុងនេះ ?
- តើពួកសាវក និងពួកព្យាការីសង់គ្រឹះដែលនៅសេសសល់ផ្សេងៗទាំងប៉ុន្មានរបស់សាសនាចក្រតាមរបៀបណា ?
- តើគ្រឹះនេះផ្តល់នូវលំនឹងដល់សាសនាចក្រ ហើយការពារវាទាស់នឹងការវាយប្រហាររបស់អារក្សយ៉ាងដូចម្តេច ?

អេភេសូរ ៣

ប៉ុលបង្ហាញអំពីក្តីប្រាថ្នារបស់លោកចំពោះពួកបរិសុទ្ធនៅអេភេសូរ

សូមសង្ខេបអេភេសូរ ៣:១–១ ៦ដោយពន្យល់ថា ប៉ុលបានផ្សាយអំពីព្រះយេស៊ូវគ្រីស្ទ ហើយបានបង្រៀនថា តាមរយៈទ្រង់ ពួកសាសន៍ដទៃអាចក្លាយជា « អ្នកគ្រងមរតក » (ខទី ៦) ជាមួយនឹងសាសន៍អ៊ីស្រាអែល ហើយជាអ្នកទទួលការសន្យាទាំងឡាយរបស់ព្រះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗក្នុង អេភេសូរ ៣:១៤–១៩ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើប៉ុលប្រាថ្នាចង់បានអ្វីផ្សេងទៀត ដើម្បីជួយដល់ពួកបរិសុទ្ធឲ្យបានស្គាល់ និងទទួលអារម្មណ៍ដឹង ។

- ស្របតាមខគម្ពីរទាំងនេះ តើប៉ុលចង់បានអ្វីខ្លះ ដើម្បីឲ្យពួកបរិសុទ្ធបានស្គាល់ និងទទួលអារម្មណ៍ដឹង ?

សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ៖ **ពួកសាវក និងពួកព្យាការីព្យាយាមជួយដល់កូនចៅរបស់ព្រះឲ្យស្គាល់ និងទទួលអារម្មណ៍ដឹងពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ ។**

សូមបង្ហាញទំព័រដែលបង្ហាញពីគណៈប្រធានទីមួយ និងក្រុមនៃពួកដប់ពីរនាក់ ចេញមកពីច្បាប់ទស្សនាវដ្តីសន្និសីទទូទៅថ្មីៗនេះ *Ensign* ឬ *Liahona* ។

- តើពួកសាវក និងពួកព្យាការីព្យាយាមជួយដល់កូនចៅរបស់ព្រះឲ្យស្គាល់ និងមានអារម្មណ៍ដឹងអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងជំនាន់របស់យើងយ៉ាងដូចម្តេច ?
- តើនៅពេលណាដែលការបង្រៀនរបស់ពួកសាវក និងពួកព្យាការីបានជួយអ្នកឲ្យស្គាល់ និងមានអារម្មណ៍ដឹងកាន់តែច្បាស់អំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទនោះ ?

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត ដែលបានពិភាក្សានៅក្នុងមេរៀន ឬអញ្ជើញសិស្សឲ្យធ្វើសកម្មភាពតាមសេចក្តីពិតទាំងនេះ ។

អេភេសូរ ៤

សេចក្តីផ្តើម

ប៉ុលបានបង្រៀនថា ព្រះអម្ចាស់បានស្តាបនាសាសនាចក្ររបស់ទ្រង់ ហើយបានហៅអ្នកដឹកនាំឲ្យធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះផង និងរួបរួមពួកបរិសុទ្ធផង ។ លោកក៏បានលើកទឹកចិត្តដល់សមាជិកសាសនាចក្រ ឲ្យបោះបង់ចោលនូវផ្លូវចាស់ ហើយរស់នៅតាមអ្វីដែលពួកគេបានដឹងថាជាការពិតផងដែរ ។

យោបល់សម្រាប់ការបង្រៀន

អេភេសូរ ៤:១–១៦

ប៉ុលបង្រៀនអំពីសារៈសំខាន់នៃសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីស្ថានភាពពីរដូចខាងក្រោមនេះ ៖

១. នៅសាលារៀន គ្រូបង្រៀនរបស់អ្នកបានសួរដល់សិស្សក្នុងថ្នាក់ឲ្យបង្ហាញពីទស្សនៈរបស់ពួកគេអំពីប្រធានបទចម្រូងចម្រាសមួយ ។ នៅពេលសិស្សចែកចាយអំពីគំនិតរបស់ពួកគេ អ្នកបានដឹងថា ពួកគេភាគច្រើនគាំទ្រដល់គោលជំហរមួយដែលខុសពីការបង្រៀនរបស់សាសនាចក្រ ។

២. អ្នកបង្កើតច្បាប់នៅក្នុងប្រទេសរបស់អ្នក បង្កើតច្បាប់សម្រាប់តរិយាបថថា អ្នកដឹកនាំសាសនាចក្របានបង្រៀនខុសឆ្គង ។

- ហេតុអ្វីក៏ស្ថានភាពនានាដូចនេះអាចជាការលំបាកសម្រាប់សមាជិកក្នុងសាសនាចក្រ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សា អេភេសូរ ៤:១–១៦អំពីរបៀបដែលយើងអាចដឹងថាអ្វីដែលត្រូវ និងអ្វីដែលខុសនៅក្នុងពិភពលោក ដែលមានការផ្លាស់ប្តូរគុណធម៌ និងជំនឿនោះ ។

សូមរំឭកសិស្សថា នៅក្នុងសំបុត្រច្បាប់នេះ ប៉ុលអាចនឹងបានសរសេរទៅកាន់សមាជិកថ្មីក្នុងសាសនាចក្រ ។ សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ៤:១–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថា តើប៉ុលបានបង្រៀនអ្វីខ្លះអំពីសាសនាចក្រ និងគោលលទ្ធិរបស់សាសនាចក្រ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះអំពីសាសនាចក្រ និងគោលលទ្ធិរបស់សាសនាចក្រ ?
- តើអ្នកគិតថា ប៉ុលចង់មានន័យដូចម្តេច នៅពេលលោកបង្រៀនថា « មានព្រះអម្ចាស់តែ១ សេចក្តីជំនឿតែ១ | និង | បុណ្យជ្រមុជតែ១ » ? (ខទី ៥) ។ (នៅក្នុងជំនាន់របស់ប៉ុល ក៏ដូចជានៅក្នុងជំនាន់របស់យើង មានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទពិតតែមួយគត់នៅលើផែនដីនេះ | សូមមើលគ. និង ស. ៩:៣០|) ។

សូមសង្កេតអេភេសូរ ៤:៧–១០ដោយពន្យល់ថា ប៉ុលបានបង្រៀនថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងទាំងអស់គ្នាត្រូវបានផ្តល់ឲ្យនូវអំណោយទាននៃព្រះគុណរបស់ទ្រង់ ។ លោកក៏បានបង្រៀនផងដែរថា ព្រះគ្រីស្ទ បានប្រទានអំណោយទានដទៃទៀតមកដល់មនុស្សលោក ។

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៤:១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលអ្វីដែលព្រះអម្ចាស់បានប្រទានដល់សាសនាចក្រ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើព្រះអម្ចាស់បានប្រទានអ្វីខ្លះដល់សាសនាចក្រ ?

ចូរពន្យល់ថា ឈ្មោះនៃតំណែងបព្វជិតភាពនៅក្នុងសាសនាចក្រសព្វថ្ងៃនេះ មិនអាចហៅដូចគ្នានឹងឈ្មោះដែលបានប្រើនៅក្នុងជំនាន់របស់ប៉ុលបានទេ ហើយសាសនាចក្រជំនាន់ដើមមិនអាចមានគ្រប់ការហៅបម្រើដែលសាសនាចក្រមាននៅសព្វថ្ងៃនេះដែរ ។ ឧទាហរណ៍ ព្យាការី យ៉ូសែប ស៊្មីធ បានបង្រៀនថា « ត្រូវផ្សាយដំណឹងល្អ គឺជាលោកអយ្យកោ » (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ | ទំព័រ ១៤០) ។ ត្រូវគង្វាលក៏ជាអ្នកគង្វាល ឬមនុស្សម្នាក់ដែលដឹកនាំក្រុម—ជាការពិពណ៌នាដ៏សមមួយនាសម័យទំនើបនេះគឺជា ប៊ីស្សព ប្រធានសាខា ប្រធានស្តេក និងប្រធានមណ្ឌលសម័យទំនើប ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *ព្រះអម្ចាស់បានហៅពួកសាវក ពួកព្យាការី និងអ្នកដឹកនាំសាសនាចក្រដទៃទៀតដើម្បីជួយ. . .*

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៤:១២–១៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលថាតើហេតុអ្វីបានជាព្រះអម្ចាស់ប្រទានដល់សាសនាចក្រនូវពួកសាវក ពួកព្យាការី និងអ្នកដឹកនាំដទៃទៀត ។

- តើព្រះអម្ចាស់ប្រទានដល់សាសនាចក្ររបស់ទ្រង់នូវពួកសាវក ពួកព្យាការី និងអ្នកដឹកនាំដទៃទៀតក្នុងគោលបំណងអ្វី ? (សូមបន្ថែម*ធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះ*ចូលទៅក្នុងបញ្ជីនៅលើក្តារខៀន) ។
- តើពួកសាវក ពួកព្យាការី និងអ្នកដឹកនាំដទៃទៀតក្នុងសាសនាចក្រជួយធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះដោយរបៀបណា ?

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៤:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលហេតុផលផ្សេងទៀតថា តើហេតុអ្វីបានជាព្រះអម្ចាស់ប្រទានដល់ពួកសាវក ពួកព្យាការី និងអ្នកដឹកនាំដទៃទៀតមកក្នុងសាសនាចក្ររបស់ទ្រង់ ។

អេភេសូរ ៤:១១–១៤ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថាសិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះតាមរបៀបដាក់លាក់មួយដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

- ហេតុអ្វីក៏ព្រះអម្ចាស់ប្រទានអ្នកដឹកនាំទាំងនេះសម្រាប់សមាជិកក្នុងសាសនាចក្រ ? (សូមបន្ថែម*ហើយការពារពួកគេពីគោលលទ្ធិខុសឆ្គង*នៅលើក្តារខៀន ដើម្បីឲ្យសេចក្តីពិតទាំងមូលអានដូចតទៅ ៖ **ព្រះអម្ចាស់បានហៅពួកសាវក ពួកព្យាការី និងពួកថ្នាក់ដឹកនាំដទៃទៀតក្នុងសាសនាចក្រដើម្បីជួយឲ្យពួកបរិសុទ្ធបានឥតខ្ចោះ និងការពារពួកគេពីគោលលទ្ធិខុសឆ្គង**) ។



ដើម្បីជួយសិស្សយល់ពីរូបភាពនៅក្នុងខទី ១៤សូមបង្ហាញរូបភាពទូកមួយនៅក្នុងកណ្តាលទឹកគួច ។ ឬអ្នក ឬសិស្សអាចគូររូបទូកមួយនៅក្នុងទឹកគួចនៅលើក្តារខៀន ។

- តើមានអ្វីខ្លះអាចកើតឡើងចំពោះទូកមួយ ដែលត្រូវបានបោកបក់ចុះឡើងនៅលើទឹកក្នុងពេលព្យុះកំណាចនោះ ?

សូមយោងត្រឡប់ទៅស្ថានភាព ដែលបានបង្ហាញនៅខាងដើមមេរៀនវិញ ។

- តើទូកមួយដែលត្រូវបានបោកបក់ចុះឡើងនៅលើទឹកគួច អាចទំនងដូចជានរណាម្នាក់ដែលត្រូវ « បោក ហើយជាត់យើងចុះឡើង » (ខទី ១៤) ដោយសារតែខ្យល់ផ្លាស់ប្តូរនៃការបង្រៀនខុសឆ្គង និងគំនិតសាធារណៈយ៉ាងដូចម្តេច ?
- តើការបង្រៀនរបស់ពួកសាវក ពួកព្យាការី និងអ្នកដឹកនាំសាសនាចក្រដទៃទៀត ជួយដល់អ្នកដើរតាមព្រះឲ្យធ្វើដំណើរលើទឹកកំណាចទាំងនេះ ហើយត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌ដោយសុវត្ថិភាពវិញយ៉ាងដូចម្តេច ?

សូមសរសេរការហៅក្នុងសាសនាចក្រដូចខាងក្រោមនៅលើក្តារខៀន ៖ *ពួកសាវក ពួកព្យាការី លោកអយ្យកោ ប៊ីស្សព* និង *គ្រូបង្រៀន* ។ សូមអញ្ជើញសិស្សឲ្យជ្រើសរើសការហៅពីរ ហើយសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីរបៀបដែលអ្នកដឹកនាំម្នាក់កាន់តំណែងនោះ បានជួយដល់ពួកគេឲ្យកែលម្អ ឬរីកចម្រើនខាងវិញ្ញាណ ឬបានជួយការពារពួកគេពីគោលលទ្ធិខុសឆ្គង និងការបោកបញ្ឆោតយ៉ាងដូចម្តេច ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍មួយដែលពួកគេបានសរសេរនោះ ។

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៤:១៥–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀបដែលអ្នកដឹកនាំសាសនាចក្ររបស់យើង គួរបង្រៀនយើងអំពីសេចក្តីពិតនៃដំណឹងល្អ ។

- តើអ្នកដឹកនាំសាសនាចក្ររបស់យើងគួរបង្រៀនយើងអំពីសេចក្តីពិតនៃដំណឹងល្អយ៉ាងដូចម្តេច ?

អេភេសូរ ៤:១៧–៣២

ប៉ុលបានលើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យបោះបង់ចោលអំពើអាក្រក់ ហើយក្លាយទៅជាមនុស្សថ្មីតាមរយៈព្រះយេស៊ូវគ្រីស្ទ

សូមនាំយកអាវរងារមួយមកថ្នាក់រៀន (ប្រហែលជាអាវចាស់ ឬ ដាច់រហែកមួយ) ។ បើអាចធ្វើទៅបាន ក៏សូមនាំយកអាវរងារមួយដែលនឹងអាចពាក់ទៅចូលរួមព្រឹត្តិការណ៍ដ៏ល្អមួយ ។ (បើអ្នកចង់បាន អ្នកអាចនាំអាវធម្មតាមួយមក និងអាវថ្មីស្អាតមួយមកជំនួសវិញ ។ សូមប្រាកដថា អាវទាំងពីរ គឺមានទំហំធំល្មមដើម្បីឲ្យសិស្សពាក់ពីលើខោអាវរបស់ពួកគេ) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកខាងមុខថ្នាក់ ហើយពាក់អាវរងារនោះ ។ ចូរសុំឲ្យសិស្សបែរមុខ ហើយបង្ហាញអាវរងារនោះដល់សិស្សក្នុងថ្នាក់ ។ បន្ទាប់មក ចូរសុំឲ្យពួកគេដោះអាវរងារចេញ បន្ទាប់មកពាក់អាវស្អាតវិញ ហើយបង្ហាញវាដល់សិស្សក្នុងថ្នាក់ ។ ចូរអរគុណដល់សិស្ស ហើយអញ្ជើញពួកគេឲ្យដោះអាវនោះចេញ ហើយត្រឡប់ទៅកន្លែងអង្គុយវិញ ។

- តើអាវរងារមួយណានៃអាវទាំងពីរនេះនឹងកាន់តែមានភាពសមរម្យនៅក្នុងព្រឹត្តិការណ៍ដ៏ល្អមួយ ?

សូមរំឭកសិស្សថា ប៉ុលអាចនឹងមានប្រសាសន៍ទៅកាន់អ្នកផ្លាស់ប្រែចិត្តជឿដែលមកក្នុងសាសនាចក្រនាពេលថ្មីៗ ។ សូមអញ្ជើញសិស្សឲ្យរកមើល នៅពេលពួកគេសិក្សាអេភេសូរ ៤:១៧–៣២ពីរបៀបដែលប៉ុលប្រើពាក្យប្រៀបធៀបអំពីការដោះអ្វីមួយចេញ ឬពាក់អ្វីមួយវិញ ដើម្បីបង្រៀនដល់អ្នកផ្លាស់ប្រែចិត្តជឿថ្មីៗទាំងនេះឲ្យធ្វើអ្វីដែលពួកគេចាំបាច់ត្រូវធ្វើក្នុងនាមជាពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៤:១៧–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាពាក្យ ឬឃ្លាដែលពិពណ៌នាអំពីស្ថានភាពខាងវិញ្ញាណរបស់ពួកសាសន៍ដទៃ ដែលពុំបានចូលរួមនៅក្នុងសាសនាចក្រ ។

- តើប៉ុលបានពិពណ៌នាយ៉ាងដូចម្តេច អំពីស្ថានភាពខាងវិញ្ញាណរបស់ពួកសាសន៍ដទៃទៀត ?
- តើប៉ុលបាននិយាយអ្វីខ្លះ ដែលជាមូលហេតុនាំឲ្យសាសន៍ដទៃស្ថិតនៅក្នុងស្ថានភាពខាងវិញ្ញាណនេះ ?

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៤:២១–២៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាអ្វីបានជួយដល់សមាជិកនៃសាសនាចក្រ ឲ្យប្រែក្លាយទៅជាខុសប្លែកពីមនុស្សដទៃទៀត ។

- យោងតាមខទី ២១តើមានអ្វីខ្លះបានជួយដល់សមាជិកនៃសាសនាចក្រ ឲ្យប្រែក្លាយជាមនុស្សខុសប្លែកពីមនុស្សដទៃ ?

យោងទៅលើសិស្សដែលបានពាក់អាវរងារទាំងពីរ ហើយសួរដល់សិស្សក្នុងថ្នាក់ថា តើសិស្សម្នាក់នោះត្រូវធ្វើអ្វីខ្លះ ពីមុនពួកគេមក អាចពាក់អាវរងារថ្មីស្អាតរបស់ពួកគេ ។

- តើប៉ុលបានប្រាប់ដល់សមាជិកសាសនាចក្រឲ្យ « ដោះចោល » អ្វីខ្លះ ? (ខទី ២២) ។ (អ្នកអាចនឹងចង់រំឭកសិស្សថា ពាក្យដែលបានបកប្រែថាជា*កិរិយាប្រព្រឹត្ត*ជាញឹកញាប់សំដៅទៅលើទង្វើរបស់មនុស្សម្នាក់ជារួម) ។
- តើវាមានន័យយ៉ាងណាដើម្បី « ប្រដាប់ខ្លួនដោយមនុស្សថ្មីវិញ » ? (ខទី ២៤) ។ (ដើម្បីបានកើតខាងវិញ្ញាណ [សូមមើល ម៉ូសាយ ២៧:២៥] ហើយរស់នៅដោយឧស្សាហ៍ព្យាយាមតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទប្រចាំថ្ងៃ) ។
- តើយើងអាចស្គាល់សេចក្តីពិតណាខ្លះ នៅក្នុងខគម្ពីរទាំងនេះទាក់ទងនឹងពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ពីសេចក្តីពិតមួយដែលស្រដៀងនឹងសេចក្តីពិតខាងក្រោមនេះ ៖ **ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទបានលះបង់ផ្លូវចាស់ដ៏ខុសឆ្គងរបស់ខ្លួន ហើយដើរតាមផ្លូវថ្មីដែលជាផ្លូវសុចរិតវិញ**) ។

សូមអញ្ជើញសិស្សឲ្យចម្លងតារាងដូចខាងក្រោមចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

មនុស្សចាស់	មនុស្សថ្មី

សូមបំបែកសិស្សទៅជាគូៗ ។ សូមអញ្ជើញគូនីមួយៗឲ្យអានអេភេសូរ ៤:២៥–៣២ ៗទាំងអស់គ្នា ។ ចូរសុំឲ្យពួកគេបំពេញក្នុងតារាងរបស់ពួកគេ នៅពេលពួកគេអាន ដែលសរសេរនៅក្រោម « មនុស្សចាស់ » ជារឿងដែលពួកសិស្សរបស់ព្រះគ្រីស្ទចាំបាច់ត្រូវ « ដោះចេញ » (ខទី ២២) ឬ « ដកចេញ » (ខទី ៣១) ហើយសរសេរនៅក្រោម « មនុស្សថ្មី » នូវអ្វីៗដែលពួកសិស្សរបស់ព្រះគ្រីស្ទចាំបាច់ត្រូវ « ប្រដាប់ខ្លួន » (ខទី ២៤) ។ សូមចង្អុលបង្ហាញទៅការបកប្រែ ដោយ យ៉ូសែប ស៊្មីធ សម្រាប់អេភេសូរ ៤:២៦ នៅក្នុងលេខយោង *ក* ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញដៃគូនីមួយៗឲ្យគិតអំពីស្ថានភាពមួយ ដែលបង្ហាញអំពីឥរិយាបទរបស់មនុស្សម្នាក់ដែលអាចមាន ដែលមិនព្រមបោះបង់ធម្មជាតិដែលប្រកបដោយអំពើបាបរបស់ពួកគេ ក្នុងផ្នែកមួយដែលប៉ុលបានពិពណ៌នានោះ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យគិតឯងដែរ អំពីស្ថានភាពដែលចង្អុលបង្ហាញអំពីរបៀបមនុស្សដដែលនេះអាចធ្វើសកម្មភាព ប្រសិនបើពួកគេមកករុណាព្រះគ្រីស្ទ ហើយក្លាយទៅជាមនុស្សថ្មីម្នាក់ ។ បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីរៀបផែនការហើយ សូមអញ្ជើញដៃគូរបីគូឲ្យឡើងមកខាងមុខថ្នាក់ ហើយពន្យល់អំពីស្ថានភាពរបស់ពួកគេ ។ បន្ទាប់ពីដៃគូពីបីគូបានធ្វើបទបង្ហាញរួចហើយ ចូរសួរដល់សិស្សក្នុងថ្នាក់ថា

- តើសមាជិកនៃសាសនាចក្រម្នាក់ដែលស្គាល់សេចក្តីពិត ប៉ុន្តែមិនរស់នៅតាមវា អាចប្រៀបដូចជាមនុស្សម្នាក់ដែលត្រូវបានអញ្ជើញឲ្យទៅចូលរួមក្នុងព្រឹត្តិការណ៍ដ៏ល្អមួយ ប៉ុន្តែមិនបានស្លៀកពាក់សំលៀកបំពាក់សមរម្យយ៉ាងដូចម្តេច ?
- តើយើងអាចជួបនឹងបញ្ហាអ្វីខ្លះ នៅពេលយើងព្យាយាមដោះចោលរូបចាស់ ដែលជាធម្មជាតិប្រកបដោយអំពើបាបរបស់យើងចេញ ហើយប្រែក្លាយជាមនុស្សថ្មី ជាពួកសិស្សរបស់ព្រះគ្រីស្ទនោះ ?
- ហេតុអ្វីក៏វាសំខាន់សម្រាប់សមាជិកនៃសាសនាចក្រចងចាំថា ការបោះចោលរបៀបចាស់របស់យើង ហើយធ្វើតាមព្រះយេស៊ូវគ្រីស្ទដោយពេញលេញ គឺជាដំណើរការជាបន្តបន្ទាប់មួយ ហើយពុំមែនជាព្រឹត្តិការណ៍ដែលកើតឡើងតែម្តងនោះឡើយ ?

ចូរពន្យល់ថា សម្រាប់មនុស្សជាច្រើន ការប្រដាប់ខ្លួនដោយនូវរបៀបថ្មីនៃសេចក្តីសុចរិតមានលក្ខណៈសាមញ្ញ ដូចជាការធ្វើការផ្លាស់ប្តូរតូចៗមួយ ដូចជាការមានចិត្តល្អជាងមុន ឬការអត់ធ្មត់ជាងមុន ការរក្សាបទបញ្ញត្តិមួយបានពេញលេញជាងមុន ឬការលុបបំបាត់ចោលទម្លាប់អាក្រក់ពីក្នុងជីវិតយើងជាដើម ។

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការបោះរបៀបចាស់ដែលប្រកបដោយអំពើបាបរបស់យើងចោល ហើយប្រដាប់ខ្លួនដោយរបៀបថ្មីនៃសេចក្តីសុចរិតវិញ ។ សូមអញ្ជើញសិស្សឲ្យសរសេរនូវរឿងមួយ ដែលពួកគេអាចធ្វើសព្វថ្ងៃនេះ ដើម្បីបោះចោលរបៀបចាស់របស់ពួកគេ ហើយបែរមកធ្វើតាមព្រះយេស៊ូវគ្រីស្ទដោយពេញលេញ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមអ្វីដែលពួកគេបានសរសេរ ។

ចំណេះចំណានខគម្ពីរ—អេភេសូរ ៤:១១–១៤

ដើម្បីជួយសិស្សឲ្យពន្យល់គោលលទ្ធិដែលបានបង្រៀននៅក្នុងអេភេសូរ ៤:១១–១៤ សូមអញ្ជើញសិស្សឲ្យងាកទៅរកដៃគូ ហើយប្រើការបង្រៀនរបស់ប៉ុលនៅក្នុង អេភេសូរ ៤:១១–១៤ ដើម្បីពន្យល់ពីមូលហេតុដែលព្រះអម្ចាស់បានស្តារបន្ទាសាសនាចក្ររបស់ទ្រង់ឡើង ហើយហៅអ្នកដឹកនាំទាំងឡាយឲ្យបម្រើក្នុងសាសនាចក្រ ។ បន្ទាប់មក អញ្ជើញសិស្សឲ្យពន្យល់អំពីរបៀបដែលពួកគេអាចប្រើគោលលទ្ធិនៅក្នុងអេភេសូរ ៤:១១–១៤ ដើម្បីជួយមិត្តម្នាក់ដែលជឿថា វាពុំចាំបាច់ដើម្បីមានសាសនាចក្រដែលត្រូវបានរៀបចំឡើងមួយនោះឡើយ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

អេភេសូរ ៤:១៣ ។ « ដល់ខ្នាតកំពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ »

តើការមក « ដល់ខ្នាតកំពស់នៃសេចក្តីពោរពេញផងព្រះគ្រីស្ទ » មានន័យយ៉ាងណា (អេភេសូរ ៤:១៣) ? អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ឌន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ថា វាសំដៅទៅលើ « ស្ថានភាពនៃសិរីល្អ និងការលើកតម្កើងដែលព្រះគ្រីស្ទទ្រង់ផ្តាល់បានរីកភាយ ។ ផែនការនៃសេចក្តីសង្គ្រោះទាំងមូល ត្រូវបានចនាឡើងដើម្បីឲ្យមនុស្សអាចបានប្រែក្លាយដូចជាព្រះ ។ អ្នកទាំងឡាយដែលបានទទួលភាពល្អឥតខ្ចោះដ៏អស់កល្បនឹងបានដូចជាព្រះគ្រីស្ទ ហើយទ្រង់បានដូចជាព្រះបិតា ។ (នីហ្វៃទី៣ ២៨:១០) ។ [ដូចជា *Lectures on Faith* បានថ្លែង] ៖ « សេចក្តីសង្គ្រោះមានជាប់ជាមួយនៅក្នុងសិរីល្អ សិទ្ធិអំណាច ឫទ្ធានុភាព ព្រះចេស្តា និងការគ្រប់គ្រងដែលព្រះយេហូវ៉ាមាន ដែលគ្មានអ្វីផ្សេងទៀតឡើយ ហើយគ្មានតួអង្គណាអាចមានវាក្រៅពីទ្រង់ផ្តាល់ ឬអ្នកដែលដូចជាទ្រង់នោះទេ » ។ [*Lectures on Faith* (ឆ្នាំ ១៩៨៥) ទំព័រ ៧៦] ។

« . . . ព្រះគ្រីស្ទ ‹ បានទទួលភាពពោរពេញនៃសិរីល្អរបស់ព្រះវរបិតា ហើយទ្រង់បានទទួលគ្រប់ព្រះចេស្តាទាំងអស់ ទាំងនៅលើស្ថានសួគ៌ និងនៅលើផែនដីផង ហើយសិរីល្អនៃព្រះវរបិតាបានស្ថិតនៅជាមួយនឹងព្រះអង្គ ដ្បិតទ្រង់គង់នៅក្នុងព្រះអង្គ › ។ (គ. និង ស. ៩៣:១៦–១៧) » ។ (*Doctrinal New Testament Commentary,* វ៉ុលទី ៣ [ឆ្នាំ ១៩៦៥–៧៣] ២:៥១១) ។

អេភេសូរ ៥–៦

សេចក្តីផ្តើម

ប៉ុលបានបង្រៀនពួកបរិសុទ្ធពីរបៀបដើម្បីតតាំងនឹងឥទ្ធិពលអាក្រក់ ។ លោកក៏បានបង្រៀនដល់ពួកគេផងដែរអំពីរបៀបដើម្បីពង្រឹងទំនាក់ទំនងគ្រួសារ ។ ប៉ុលបានបញ្ចប់សំបុត្ររបស់លោក ដោយដាស់តឿនពួកអ្នកដើរតាមរបស់ព្រះឲ្យ « ពាក់គ្រប់គ្រឿងសឹករបស់ព្រះ » (អេភេសូរ ៦:១១) ដើម្បីតតាំងនឹងការបោកបញ្ឆោតរបស់សាតាំង ។

ការកំណត់អំពីល្បឿន

សូមចៀសវាងកុំចំណាយពេលច្រើនពេកនៅផ្នែកទីមួយនៃមេរៀននេះ ហើយត្រូវប្រញាប់ប្រញាល់ដើម្បីបញ្ចប់មេរៀនដែលនៅសេសសល់ ។ នៅពេលអ្នករៀបចំខ្លួន សូមប៉ាន់ស្មានពីរយៈពេលដែលផ្នែកនីមួយៗនៅក្នុងមេរៀននេះត្រូវការ ដោយប្រើវិធីសាស្ត្របង្រៀនដែលអ្នកបានជ្រើសរើស ។ ស្ទើរតែជានិច្চកាល ដោយសារអ្នកមានឯកសារបង្រៀនដែលត្រូវការពេលច្រើន សូមកំណត់ថាតើផ្នែកណាមួយនៃបណ្តុំបទគម្ពីរដែលត្រូវគូសបញ្ជាក់ និង ត្រូវសង្ខេប ។

យោបល់សម្រាប់ការបង្រៀន

អេភេសូរ ៥:១–២០

ប៉ុលបង្រៀនពួកបរិសុទ្ធពីរបៀបតតាំងនឹងឥទ្ធិពលអាក្រក់

ប្រសិនបើអាចធ្វើទៅបាន សូមដាក់បង្ហាញវត្ថុមួយដែលសិស្សអាចដឹងថាវាទើបធ្វើ ឬទិញថ្មី ហើយសួរថា ៖

- តាមធម្មតា តើយើងប្រព្រឹត្តយ៉ាងដូចម្តេចចំពោះវត្ថុថ្មី ?

សូមរំឭកសិស្សថា អេភេសូរ ៤ មានន័យការទូន្មានរបស់ប៉ុលទៅកាន់ពួកសមាជិកថ្មីក្នុងសាសនាចក្រឲ្យ « ដោះមនុស្សចាស់ដែល[.]. . . ខូច » របស់ពួកគេចោល (ខទី ២២) ហើយ « ប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ » (ខទី ២៤) ឬចាប់ផ្តើមជីវិតថ្មីមួយ ជាពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ។

- តើជីវិតរបស់មនុស្សម្នាក់ដែលបានតាំងចិត្តដើរតាមព្រះយេស៊ូវគ្រីស្ទអាចរាប់ទុកថាជាជីវិតថ្មីបានយ៉ាងដូចម្តេច ?

នៅពេលសិស្សសិក្សា អេភេសូរ ៥–៦ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេឲ្យ « ប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ » ជាពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន អេភេសូរ ៥:១–៧ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើប៉ុលបានទូន្មានពួកបរិសុទ្ធឲ្យធ្វើ និងមិនឲ្យធ្វើអ្វីខ្លះ ក្នុងនាមជាពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ។

- តើប៉ុលបានទូន្មានពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទឲ្យធ្វើអ្វីខ្លះ ? តើលោកបានទូន្មានពួកគេមិនឲ្យធ្វើអ្វីខ្លះ ?
- តើយើងអាចស្គាល់សេចក្តីពិតអ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះទាក់ទងនឹងពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចរកឃើញសេចក្តីពិតខុសៗគ្នា ប៉ុន្តែសូមគូសបញ្ជាក់ថា **ពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទពុំទទួលរឿងអាក្រក់របស់លោកិយឡើយ**) ។
- យោងតាម ខទី ៥ តើជនដែលធ្វើរឿងអាក្រក់របស់លោកិយនឹងបាត់បង់សិទ្ធិអ្វីខ្លះ ?
- តើការទទួលរឿងអាក្រក់នៃលោកិយអាចជះឥទ្ធិពលដល់ជីវិតថ្មីរបស់មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទយ៉ាងដូចម្តេច ? តើគំរូរបស់បុគ្គលនេះ មានឥទ្ធិពលដល់មនុស្សដទៃទៀតយ៉ាងណាខ្លះ ?

សូមសង្ខេប អេភេសូរ ៥:៨–២០ ដោយពន្យល់ថា ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យ « ដើរដូចជាមនុស្សភ្លឺចុះ » (ខទី ៨) ឲ្យឈ្លាសវៃ ហើយឲ្យខិតខំស្គាល់ពីព្រះទំយរបស់ព្រះអម្ចាស់ដោយ « ឲ្យបានពេញជាព្រះវិញ្ញាណ » (ខទី១៨) ។

អេភេសូរ ៥:២១–៦:៩

ប៉ុលទូន្មានពួកអេភេសូរអំពីទំនាក់ទំនងក្នុងគ្រួសាររបស់ពួកគេ

សូមឲ្យសិស្សគិតពីឥទ្ធិពលទៅវិញទៅមកវាងពួកគេនិងសមាជិកគ្រួសារកាលពី ២៤ ម៉ោងមុន ហើយថាតើឥទ្ធិពលទៅវិញទៅមកទាំងនោះជារឿងវិជ្ជមាន ឬអវិជ្ជមាន ។ (ឧទាហរណ៍ តើឥទ្ធិពលទៅវិញទៅមកនេះវាជារឿងគួរឲ្យស្រឡាញ់ ឬជាការឈ្លោះប្រកែកគ្នា ? ជារឿងល្អ ឬជារឿងឈឺចាប់ ? ជាការលើកតម្កើង ឬ ជាការបន្ទុះបង្អាប់ ?)

- ហេតុអ្វីក៏ពេលខ្លះវាពិបាក ដើម្បីមានទំនាក់ទំនងគ្រួសារដ៏ល្អប្រសើរ ?

នៅពេលសិស្សសិក្សាអេភេសូរ ៥:២១–៦:៩សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍ ដែលអាចជួយពួកគេឲ្យពង្រឹងទំនាក់ទំនងក្រុមគ្រួសាររបស់ពួកគេ ។

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៥:២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ។

- តើប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ? (សូមពន្យល់ថា ការ « ចំណុះគ្នាទៅវិញទៅមក » មានន័យថា យើងគួរគិតពីមនុស្សដទៃ ពីមុនខ្លួនយើង ហើយការ « កោតខ្លាចដល់ព្រះ » សំដៅទៅលើសេចក្តីស្រឡាញ់ និងការគោរពរបស់យើងចំពោះទ្រង់ ។
- តើព្រះយេស៊ូវគ្រីស្ទបានបង្ហាញគំរូតរិយាបថនៃការចុះចូលនេះតាមរបៀបណា ?

- តើការគិតអំពីតម្រូវការរបស់មនុស្សដទៃពីមុនខ្លួនយើង អាចជួយពង្រឹងទំនាក់ទំនងគ្រួសាររបស់យើងបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ៥:២២–២៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើប៉ុលបានទូន្មានដល់ពួកស្វាមី និងភរិយាឲ្យធ្វើអ្វីខ្លះក្នុងទំនាក់ទំនងរបស់ពួកគេ ។

- តើទំនាក់ទំនងអ្វីខ្លះដែលប៉ុលបានទូន្មានដល់ភរិយា ឲ្យដាក់លំនាំទំនាក់ទំនងរបស់ពួកគេជាមួយស្វាមី ? (សូមពន្យល់ថា ប៉ុលបានបង្រៀនថា ភរិយាគួរ « ចំណុះ » ខ្លួននាងចំពោះស្វាមីនាង [ខទី ២២] ។ វាអាចបកប្រែថាជាការគាំទ្រ ការជ្រោមជ្រែង និងការគោរពដល់ស្វាមីនាង ដូចជានាងធ្វើចំពោះព្រះអម្ចាស់ដែរ ។ តួនាទីរបស់ស្វាមីដែលត្រូវបានតែងតាំងមកពីព្រះគឺ ដើម្បីធ្វើជាអធិបតី ឬមើលថែគ្រួសារ ដូចជាព្រះអង្គសង្គ្រោះមើលថែ ហើយដឹកនាំសាសនាចក្ររបស់ទ្រង់ដែរ) ។
- តើប៉ុលបានទូន្មានឲ្យស្វាមីធ្វើអ្វីខ្លះ ក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងភរិយា ?
- តើស្វាមីដែលស្រឡាញ់ភរិយាខ្លួនដូចជាព្រះអង្គសង្គ្រោះស្រឡាញ់សាសនាចក្រនឹងប្រព្រឹត្តចំពោះនាងយ៉ាងដូចម្តេច ? (គាត់នឹង « [ប្រគល់] » ខ្លួនគាត់ឲ្យនាង [ខទី ២៥] ឬគិតពីនាងមុនគិតពីខ្លួនឯង ហើយ « ថ្នាក់ថ្នម » នាង [ខទី ២៩]) ។
- តើយើងអាចស្គាល់សេចក្តីពិតអ្វីខ្លះ នៅក្នុងការបង្រៀនរបស់ប៉ុលទាក់ទងនឹងអ្វី ដែលអាចកើតឡើងនៅក្នុងក្រុមគ្រួសាររបស់យើង ប្រសិនបើយើងប្រើទំនាក់ទំនងរបស់ព្រះអង្គសង្គ្រោះជាមួយនឹងសាសនាចក្រជាមាគ៌ារបស់យើងនោះ ? (ដោយប្រើពាក្យសម្តីផ្ទាល់ខ្លួនរបស់ពួកគេ សិស្សគប្បីស្តាប់នូវគោលការណ៍មួយស្រដៀងគ្នាដូចតទៅនេះ ៖ **នៅពេលយើងប្រើទំនាក់ទំនងរបស់ព្រះអង្គសង្គ្រោះជាមួយនឹងសាសនាចក្រជាមាគ៌ារបស់យើង នោះយើងអាចពង្រឹងទំនាក់ទំនងគ្រួសាររបស់យើងបាន**) ។

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៥:៣០–៣៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលថាតើស្វាមី និងភរិយានឹងប្រែទៅជាយ៉ាងណា នៅពេលពួកគេបានរៀបការនឹងគ្នា ។

- យោងតាម ខទី ៣១តើស្វាមី និងភរិយានឹងប្រែទៅជាយ៉ាងណា នៅពេលពួកគេបានរៀបការនឹងគ្នា ? (ពួកគេបានក្លាយជា « សាច់តែមួយ » ឃ្លាមគ្នាខាងផ្លូវកាយ ផ្លូវចិត្ត និងខាងវិញ្ញាណ) ។
- តើការធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នៅក្នុងទំនាក់ទំនងរបស់ពួកគេអាចជួយស្វាមីភរិយា (និងគ្រួសារ) បង្កើនសេចក្តីស្រឡាញ់ និងសាមគ្គីភាពនៅក្នុងទំនាក់ទំនងរបស់ពួកគេយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន អេភេសូរ ៦:១–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ការប្រើគំរូរបស់ព្រះយេស៊ូវគ្រីស្ទជាមាគ៌ា អនុវត្តចំពោះទំនាក់ទំនងរបស់កូនម្នាក់ជាមួយនឹងឪពុកម្តាយរបស់គេយ៉ាងដូចម្តេច ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើកុមារម្នាក់ធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទដោយគោរពតាមឪពុកម្តាយរបស់គេយ៉ាងដូចម្តេច ?
- តើប៉ុលបានទូន្មានឲ្យឪពុកធ្វើអ្វីខ្លះ ទាក់ទងនឹងការចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេ ?

សូមឲ្យសិស្សសញ្ជឹងគិតថា ទំនាក់ទំនងគ្រួសាររបស់ពួកគេនឹងត្រូវបានពង្រឹងយ៉ាងដូចម្តេច ប្រសិនបើពួកគេប្រើទំនាក់ទំនងរបស់ពួកគេដោយមានព្រះអម្ចាស់ជាមាគ៌ារបស់ពួកគេនោះ ។ សូមអញ្ជើញពួកគេឲ្យជ្រើសយកទំនាក់ទំនងមួយដែលពួកគេចង់កែលម្អ ហើយសរសេរពីវិធីមួយចំនួនដែលពួកគេអាចកែលម្អទំនាក់ទំនងនេះដោយធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមអ្វី ដែលពួកគេបានសរសេរ ។

សូមសង្ខេប អេភេសូរ ៦:៥–៩ ដោយពន្យល់ថា ប៉ុលបានបង្រៀនអំពីទំនាក់ទំនងរវាងបាវបម្រើ និងចៅហ្វាយម្នាក់ ។ នៅក្នុងសម័យព្រះគម្ពីរសញ្ញាថ្មី ទាសភាពគឺជារឿងធម្មតានៅក្នុងចក្រភពរ៉ូម សូម្បីតែនៅក្នុងចំណោមសមាជិកមួយចំនួននៃសាសនាចក្រផងដែរ ។ ការទូន្មានរបស់ប៉ុលមិនបានបញ្ជាក់ថា លោកអនុម័តចំពោះការបង្កើតទាសភាពនេះឡើយ ។

អេភេសូរ ៦:១០–២៤

ប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធ « ពាក់គ្រប់គ្រឿងសឹករបស់ព្រះ »

សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែរិសរ៉ា ថាហ្វ ប៊ែនសឺន ៖ (សេចក្តីថ្លែងការណ៍នេះមាននៅក្នុង« The Power of the Word »*Ensign*ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៧៩) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍នេះឲ្យឮៗ ។


> *« សាតាំងកំពុងបង្កសង្គ្រាមទាស់នឹងសមាជិកសាសនាចក្រដែលមានទីបន្ទាល់ ហើយដែលកំពុងព្យាយាមគោរពតាមព្រះបញ្ញត្តិ » (ប្រធាន អែរិសរ៉ា ថាហ្វ ប៊ែនសឺន) ។*

- តើសាតាំងបង្កសង្គ្រាមទាស់នឹងយុវវ័យរបស់សាសនាចក្រតាមរបៀបណា ?

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៦:១០–១៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើប៉ុលបាននិយាយថាពួកបរិសុទ្ធនៅក្នុងជំនាន់របស់លោកកំពុងច្បាំងទាស់នឹងអ្វី ។ សូមពន្យល់ថា *ឧបាយកល* សំដៅទៅលើល្បិច ឬឧបាយកលដែលប្រើដើម្បីបោកបញ្ឆោត ឬដាក់អន្ទាក់ ។

- តើប៉ុលបាននិយាយថា ពួកបរិសុទ្ធនៅក្នុងជំនាន់របស់លោកកំពុងច្បាំងទាស់នឹងអ្វី ?
- តើអ្វីដែលប៉ុលបានរៀបរាប់នៅក្នុង ខទី ១២ ដូចគ្នានឹងអ្វីដែលយើងកំពុងច្បាំងទាស់ក្នុងជំនាន់របស់យើងយ៉ាងដូចម្តេចដែរ ?
- តើប៉ុលបានប្រាប់ដល់ពួកបរិសុទ្ធនៅជំនាន់លោកឲ្យបំពាក់អ្វីខ្លះ ដើម្បីពួកគេអាចទប់ទល់នឹងអំពើអាក្រក់ទាំងនេះបាន ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងពាក់គ្រប់ទាំងគ្រឿងសឹករបស់ព្រះ យើងនឹងអាចទប់ទល់នឹងអំពើអាក្រក់បាន**) ។

ពាក់គ្រប់គ្រឿងសឹករបស់ព្រះ



ចូរឲ្យសំណៅ ឯកសារដែលភ្ជាប់មកជាមួយដល់សិស្ស ។ សូមបំបែកសិស្សក្នុងថ្នាក់ជាប្រាំក្រុម ហើយចាត់តាំងក្រុមនីមួយ ៗនូវចំណែកមួយនៃអាវក្រោះដូចដែលបានរៀបរាប់នៅក្នុង អេភេសូរ ៦:១៤–១៧ ។ (ចូរកុំចាត់ឲ្យនូវផ្នែក « ដោយក្រវាត់សេចក្តីពិតនៅចង្កេះ » [ខទី ១៤] ។ ប្រសិនបើសិស្សរបស់អ្នកមានចំនួនតិច អ្នកគួរឲ្យបំបែកគ្រឿងសឹកលើសពីមួយដល់ក្រុមមួយចំនួន) ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

១. តើបំណែកគ្រឿងសឹកនេះត្រូវបានប្រើសម្រាប់អ្វី ?

២. តើប៉ុលបានហៅបំបែកគ្រឿងសឹកនេះថាជាអ្វី ?

៣. តើផ្នែកណានៃរូបកាយ ដែលអាចត្រូវបានការពារដោយគ្រឿងសឹក តំណាងឲ្យខាងវិញ្ញាណ ?

៤. តើការពាក់បំណែកនៃគ្រឿងសឹកខាងវិញ្ញាណនេះ អាចជួយអ្នកឲ្យទប់ទល់នឹងអំពើអាក្រក់បានយ៉ាងដូចម្តេច ?

ដើម្បីបង្ហាញសិស្សពីរបៀបបំពេញឯកសារ សូមអញ្ជើញឲ្យសិស្សម្នាក់អាន អេភេសូរ ៦:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលចម្លើយចំពោះសំណួរនៅលើក្តារខៀន នៅពេលពួកគេអនុវត្ត « ដោយក្រវាត់សេចក្តីពិតនៅចង្កេះ » រួចសរសេរចម្លើយនៅលើក្រដាសរបស់ពួកគេ ។

សូមពន្យល់ថា គ្រឿងសឹកដៃល « ក្រវាត់ » នឹងចង្កេះគឺជាខ្សែក្រវ៉ាត់ដែលរុំជុំវិញផ្នែកកណ្តាលនៃរាងកាយ ។ សិស្សអាចប្រាប់ចម្លើយស្រដៀងគ្នានឹងឃ្លាខាងក្រោម ៖ (១) វាបិទបាំងចង្កេះ (សរីរាង្គដ៏សំខាន់សម្រាប់ការបង្កើតកូន) ។ (២) សេចក្តីពិត ។ (៣) វាតំណាងឲ្យព្រហ្មចារីភាព ឬបរិសុទ្ធភាពខាងសីលធម៌របស់យើង ។ (៤) ការដឹងពីសេចក្តីពិតពេញលេញនៃដែនការនៃសេចក្តីសង្គ្រោះអាចទាក់ទាញចិត្តឲ្យបន្តមានភាពបរិសុទ្ធខាងសីលធម៌ ។

សូមអញ្ជើញសិស្សឲ្យធ្វើតាមគំរូនេះ នៅពេលពួកគអាន អេភេសូរ ៦:១៤–១៨ ជាមួយនឹងក្រុមខ្លួន ហើយបំពេញផ្នែកនៃឯកសារដែលភ្ជាប់មកជាមួយនឹងបំណែកគ្រឿងសឹក ដែលបានចាត់តាំងឲ្យពួកគេ ។ (សូមពន្យល់ថា ការពាក់ « ទុកជាស្បែកជើង » [ខទី ១៥] មានន័យថា ការពាក់ស្បែកជើង ឬគ្រឿងការពារជើងផ្សេងទៀត) ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរអញ្ជើញអ្នកតំណាងម្នាក់មកពីក្រុមនីមួយ ៗឲ្យប្រាប់ពីអ្វី ដែលពួកគេបានរៀនទៅដល់សិស្សក្នុងថ្នាក់ ។ នៅពេលក្រុមនីមួយ ៗប្រាប់ពីអ្វីដែលពួកគេបានរៀន សូមអញ្ជើញសិស្សឲ្យកត់ត្រាការរកឃើញរបស់ក្រុមនោះនៅក្នុងឯកសាររបស់ពួកគេ ។

- ហេតុអ្វីការការពារខ្លួនយើងដោយពាក់ *គ្រប់* ទាំងគ្រឿងសឹករបស់ព្រះគឺជារឿងដ៏សំខាន់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮ ៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមមកពី អែលឌើរ អិម វ៉ែលល បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយសុំឲ្យសិស្សស្តាប់ពីរបៀបដែលយើងពាក់គ្រឿងសឹក និងពង្រឹងដល់គ្រឿងសឹករបស់ព្រះ ។



« ខ្ញុំចូលចិត្តគិតអំពីអាវក្រោះខាងវិញ្ញាណនេះ ដែលពុំប្រៀបដូចជាបំណែកនៃលោហៈធាតុដែលសូន្យឡើងមួយដុំ ដើម្បីពាក់ឲ្យត្រូវរូបកាយនោះទេ ប៉ុន្តែវាដូចជាច្រវ៉ាក់ប្រទាក់គ្នាទៅវិញ ។ ច្រវ៉ាក់ប្រទាក់គ្នាមានដាប់បំណែកតូច ៗជាច្រើនផែនតភ្ជាប់នឹងគ្នា ដើម្បីអនុញ្ញាតឲ្យអ្នកប្រើអាចបត់បែនបានកាន់តែងាយស្រួលដោយមិនបាត់បង់នូវការការពារ ។ ខ្ញុំនិយាយដូច្នោះ ដោយសារវាជាបទពិសោធន៍របស់ខ្ញុំ ថាគ្មានអ្វីតែមួយដ៏ធំ ហើយអស្ចារ្យដែលយើងអាចធ្វើ ដើម្បីការពារខ្លួនយើងខាងវិញ្ញាណបាននោះឡើយ ។ អំណាចខាងវិញ្ញាណពិត ពឹងលើទង្វើតូច ៗជាច្រើន

វេញបញ្ចូលគ្នានៅក្នុងសាច់ក្រណាត់នៃការការពារខាងវិញ្ញាណ ដែលការពារ និងជាខែលទាស់នឹងរាល់សេចក្តីអាក្រក់ » (« Be Strong in the Lord »*Ensign* ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៨) ។

- តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីពាក់ ហើយពង្រឹងគ្រឿងសឹករបស់ព្រះជារៀងរាល់ថ្ងៃ ? តើការណ៍នេះបានជួយអ្នកឲ្យទប់ទល់នឹងអំពើអាក្រក់ ការល្បួង ឬការចោកបញ្ឆោតដោយរបៀបណា ?

សូមសរសេរសំណួរដូចខាងក្រោមនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយរបស់ពួកគេ ៖

តើបំណែកគ្រឿងសឹកខាងវិញ្ញាណរបស់អ្នកមួយណា ដែលអ្នកគិតថាមានភាពរឹងមាំ ?

តើបំណែកគ្រឿងសឹករបស់អ្នកមួយណាដែលខ្សោយបំផុត ?

តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីពង្រឹងផ្នែកនីមួយៗនៃគ្រឿងសឹកខាងវិញ្ញាណនៅក្នុងជីវិតរបស់អ្នក ?

សូមសង្ខេប អេភេសូរ ៦:១៩–២៤ ដោយពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោក ដោយសុំឲ្យពួកបរិសុទ្ធអធិស្ឋាន ដើម្បីឲ្យលោកត្រូវបានប្រទានឲ្យនូវ « ពាក្យសម្តី » (ខទី ១៩) ហើយអាចប្រកាសដំណឹងល្អដោយភាពក្លាហាន កាលកំពុងជាប់ឃុំ ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតដែលសិស្សបានស្គាល់នៅក្នុង អេភេសូរ ៥–៦ ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួលនៅក្នុងមេរៀននៅថ្ងៃនេះ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

អេភេសូរ ៥:២៥–២៨, ៦:៤ ។ « ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ »

ប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឺន បានចង្អុលបង្ហាញទៅគំរូរបស់ព្រះអង្គសង្គ្រោះ កាលលោកបានទូន្មានស្វាមីអំពីរបៀបដឹកនាំក្រុមគ្រួសាររបស់ពួកគេ ៖

« យើងពុំឃើញថា ព្រះអង្គសង្គ្រោះដឹកនាំសាសនាចក្ររបស់ទ្រង់ដោយភាពយង់ឃ្នង ឬព្រះហស្តគ្មានមេត្តានោះឡើយ ។ យើងពុំឃើញថា ព្រះអង្គសង្គ្រោះប្រព្រឹត្តចំពោះសាសនាចក្ររបស់ទ្រង់ ដោយមិនគោរព ឬមិនអើពើនោះឡើយ ។ យើងពុំឃើញថា ព្រះអង្គសង្គ្រោះប្រើកម្លាំង ឬការបង្ខិតបង្ខំ ដើម្បីសម្រេចនូវព្រះរាជបំណងរបស់ទ្រង់ឡើយ ។ យើងរកឃើញថា ព្រះអង្គសង្គ្រោះនឹងធ្វើអ្វីៗគ្រប់យ៉ាងដែលស្អាង លើកកម្ពស់ លួងលោម ហើយលើកតម្កើងដល់សាសនាចក្រ » (« To the Fathers in Israel » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ទំព័រ ៥០) ។

ប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល បានបង្រៀនអំពីឥទ្ធិពលដែលស្វាមីម្នាក់អាចមាន នៅពេលគាត់ស្រឡាញ់គ្រួសារគាត់ ដូចជាព្រះអង្គសង្គ្រោះស្រឡាញ់សាសនាចក្រ ។

« ព្រះគ្រីស្ទស្រឡាញ់សាសនាចក្រ និងប្រជាជនរបស់សាសនាចក្រយ៉ាងខ្លាំងអនេក រហូតដល់ទ្រង់បានស្ម័គ្រព្រះទ័យស៊ូទ្រាំនឹងការបៀតបៀនជួសពួកគេ បានរងនឹងការប្រមាថបន្ទាបបន្ថោកជួសពួកគេ បានអត់ទ្រាំនឹងការឈឺចាប់ និងការបំពានខាងរាងកាយជួសពួកគេ ហើយទីបំផុតបានប្រទាននូវព្រះជន្មដ៏មានតម្លៃថ្លៃថ្លារបស់ទ្រង់សម្រាប់ពួកគេ ។

« ពេលស្វាមីត្រៀមខ្លួនជាស្រេច ដើម្បីប្រព្រឹត្តចំពោះក្រុមគ្រួសារគាត់តាមលក្ខណៈបែបនោះ មិនមែនតែចំពោះភរិយានោះទេ តែចំពោះសមាជិកគ្រប់គ្នាក្នុងក្រុមគ្រួសារ នោះគាត់នឹងឆ្លើយតបទៅនឹងភាពជាអ្នកដឹកនាំរបស់គាត់ » (« Home: The Place to Save Society » *Ensign* ខែ មករា ឆ្នាំ ១៩៧៥ ទំព័រ ៥) ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

អេភេសូរ ៦:១១ ។ ការបង្ហាញវីដេអូ— « The Whole Armor of God »

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃការពាក់គ្រប់ទាំងគ្រឿងសឹករបស់ព្រះ សូមបង្ហាញវីដេអូ « The Whole Armor of God » (១៤:៣៥)ដែលរៀបរាប់ពីការអនុវត្តតាមការទូន្មានរបស់ប៉ុលនៅក្នុងសម័យទំនើប ។ វីដេអូនេះមាននៅក្នុង LDS.org ។

សេចក្តីណែនាំអំពី

សំបុត្ររបស់ប៉ុលដល់ពួកកីលីព

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងសំបុត្ររបស់លោកដល់ពួកកីលីព ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធនៅកីលីព ហើយបានដាស់តឿនពួកគេឲ្យខ្ជាប់ខ្ជួននៅក្នុងសាមគ្គីភាព ហើយធ្វើការរួមគ្នាដើម្បីការពារដល់សេចក្តីជំនឿ ។ ប្រហែលជាគោលការណ៍ដ៏សំខាន់មួយ ដែលប៉ុលបានបង្រៀននៅក្នុងកីលីពគឺថា ការអធិស្ឋានទៅព្រះ និងការទុកចិត្តទ្រង់នាំមកនូវ « សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត » (កីលីព ៤:៧) ។ ការសិក្សាសារលិខិតលើកទឹកចិត្តរបស់ប៉ុលនៅក្នុងសំបុត្រនេះ អាចជួយសិស្សនៅក្នុងការខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីកាន់ខ្ជាប់ជាប់ដល់ចុងបំផុតដោយស្មោះត្រង់ ។ នៅពេលសិស្សខិតខំធ្វើតាមព្រះគ្រីស្ទ នោះពួកគេក៏អាចមានទំនុកចិត្ត ហើយប្រកាសដូចជាប៉ុលផងដែរថា « ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ » (កីលីព ៤:១៣) ។

តើនរណាបានសរសេរសេរសេរគម្ពីរនេះ ?

ទោះបីជានៅត្រង់ពាក្យជម្រាបសួរនៅក្នុងសំបុត្រនេះមានឈ្មោះធីម៉ូថេ នៅជាមួយនឹងប៉ុលក្តី (សូមមើល កីលីព ១:១) ក៏ប៉ុលជាអ្នកសរសេរសំបុត្រនេះទៅពួកកីលីពដែរ ។ ការអះអាងនេះគឺដោយសារមានការប្រើសព្វនាមឯកវចនៈ ខ្ញុំ នៅក្នុងសំបុត្រនេះ ហើយនិយាយពីធីម៉ូថេ នៅក្នុង កីលីព ២:១៩ ។ ធីម៉ូថេ អាចធ្វើជាអ្នកសរសេររបស់ប៉ុល ដោយសរសេរសំបុត្រនេះនៅក្រោមការដឹកនាំរបស់ប៉ុល ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ប៉ុលទំនងជាសរសេរសំបុត្រទៅពួកកីលីពនៅចន្លោះ គ.ស. ៦០ និង ៦២ កាលលោកជាប់ឃុំនៅរ៉ូម (សូមមើល កីលីព ១:៧, ១៣, ១៧ សូមមើលផងដែរ កិច្ចការ ២៨:១៦–៣១, សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « កីលីព » scriptures.lds.org) ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយតើហេតុអ្វី ?

ក្រុងកីលីពគឺជាទីតាំងទីមួយនៅទ្វីបអឺរ៉ុប ដែលប៉ុលបានប្រកាសដំណឹងល្អជាផ្លូវការ ហើយបានស្ថាបនាសាខាមួយរបស់សាសនាចក្រឡើង (សូមមើល កិច្ចការ ១៦:១១–៤០ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ គោលបំណងមួយរបស់ប៉ុលនៅក្នុងការសរសេរសំបុត្រនេះ គឺដើម្បីបង្ហាញការដឹងគុណចំពោះសេចក្តីស្រឡាញ់ និងជំនួយខាងហិរញ្ញវត្ថុដែលពួកបរិសុទ្ធនៅកីលីពមានចំពោះលោកនៅក្នុងដំណើរទីពីររបស់សាវកប៉ុលទៅផ្សាយសាសនា និងការជាប់ឃុំរបស់លោកនៅក្រុងរ៉ូម (សូមមើល កីលីព ១:៣–១១, ៤:១០–១៩, សូមមើលផងដែរ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។

ប៉ុលក៏បានសរសើរដល់សមាជិកទាំងឡាយនៅកីលីពចំពោះសេចក្តីជំនឿរបស់ពួកគេលើព្រះយេស៊ូវគ្រីស្ទផងដែរ ហើយបានទូន្មានពួកគេ ដោយផ្អែកលើព័ត៌មានដែលលោកបានទទួលមកពីសិស្សម្នាក់ជាពួកកីលីពដែលមានឈ្មោះថា អេប៉ាប្រូឌីត (សូមមើល កីលីព ៤:១៨) ។ ពាក្យទូន្មានរបស់ប៉ុលបានរួមបញ្ចូលនូវការលើកទឹកចិត្តឲ្យមានចិត្តរាបសា និងមានសាមគ្គីភាព (សូមមើល កីលីព ២:១–១៨, ៤:២–៣) ។ ប៉ុលក៏បានព្រមានដល់ពួកកីលីពឲ្យប្រុងប្រយ័ត្នដល់ពួកគ្រីស្ទានដែលខុសឆ្គង ដូចជា ជនដែលបង្រៀនថា ការកាត់ស្បែកគឺជារឿងចាំបាច់សម្រាប់ការប្រែចិត្តជឿ ។ ជនទាំងនេះ (ជារឿយៗត្រូវបានហៅថាជាពួកអ្នកកាន់សាសនាយូដា) បានប្រកាសទាំងខុសឆ្គងថា ពួកអ្នកប្រែចិត្តជឿថ្មីត្រូវធ្វើតាមក្រឹត្យវិន័យពីបុរាណនៅក្នុងព្រះគម្ពីរសញ្ញាចាស់ពីការកាត់ស្បែក ពីមុនក្លាយជាពួកគ្រីស្ទាន (សូមមើល កីលីព ៣:២–៣) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ជារឿយៗ គម្ពីរកីលីពត្រូវបានហៅថាជាសំបុត្រនៅក្នុងគុក អមជាមួយគម្ពីរអេភេសូរ កូល៉ុស និងភីលេម៉ូន ។ ទោះបីជាវាត្រូវបានសរសេរឡើងនៅក្នុងគុកក្តី ក៏សំបុត្ររបស់ប៉ុលទៅកាន់ពួកកីលីពត្រូវបានរៀបរាប់ដោយពួកអ្នកប្រាជ្ញថា ជាការសរសេរដ៏រីករាយបំផុតរបស់លោកដែរ ។ ប៉ុលបានបង្ហាញការដឹងគុណ សេចក្តីស្រឡាញ់ និងទំនុកចិត្តចំពោះសមាជិកសាសនាចក្របានរៀបរាប់ពីការលះបង់ដែលលោកបានធ្វើដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ហើយបានណែនាំពួកបរិសុទ្ធនៅកីលីពពីគោលការណ៍នៃការរស់នៅដោយសុចរិត ។ សិស្សអាចនឹងស្គាល់នៅក្នុង កីលីព ៤:៨ នូវភាសាមួយចំនួនដែលបានប្រើនៅក្នុងមាត្រាទីដប់បីនៃសេចក្តីជំនឿ ដែលបានសរសេរដោយព្យាការី យ៉ូសែប ស្ម៊ីធ ។

ប៉ុលបានបរិយាយពីការបន្ទាបខ្លួនរបស់ព្រះអង្គសង្គ្រោះ អំពីភាពជាព្រះនៅជីវិតមុនផែនដី ជាទីកន្លែងដែលទ្រង់បានរងទុក្ខ « សុគតជាប់ឈើឆ្កាង » (សូមមើល កីលីព ២:៣–៨) ។ ដោយបានបំពេញបេសកកម្មដ៏ទេវភាពរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទឥឡូវនេះត្រូវបានតម្កើងឡើង ហើយថ្ងៃនោះនឹងមកដល់កាល « គ្រប់ទាំងជង្គង់ ត្រូវលុតចុះ » នៅចំពោះទ្រង់ ហើយ « គ្រប់ទាំងអណ្តាត . . . បានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ » (កីលីព ២:១០–១១) ។ ប៉ុលបានបើកសម្តែងថា ប្រភពនៃទំនុកចិត្ត និងកម្លាំងក្នុងចិត្តរបស់លោកកើតចេញពីព្រះយេស៊ូវគ្រីស្ទ (សូមមើល កីលីព ៤:១៣) ។

គម្រោង

កីលីព ១ ប៉ុលបង្ហាញពីការដឹងគុណចំពោះភាពរាប់អានរបស់ពួកបរិសុទ្ធនៅកីលីព ។ លោកបង្រៀនថា ឧបសគ្គដែលលោកបានជួបនៅក្នុងការបម្រើព្រះអម្ចាស់ រួមបញ្ចូលការដាប់ឃុំរបស់លោកផងដែរ បានជួយពន្លឿនដល់បុព្វហេតុនៃដំណឹងល្អ ។ លោកលើកទឹកចិត្តសមាជិកសាសនាចក្រ ឲ្យពង្រឹងសាមគ្គីភាពនៅក្នុងការការពារសេចក្តីជំនឿ ។

កីលីព ២ ប៉ុលលើកទឹកចិត្តបន្ថែមទៀតដល់សមាជិកសាសនាចក្រឲ្យមានសាមគ្គីភាព ហើយចង្អុលបង្ហាញពីគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលបានបន្ទាបខ្លួនមកកាន់ជីវិតរមែងស្លាប់ ថាជាគំរូនៃសេចក្តីស្រឡាញ់ ការគោរពប្រតិបត្តិ និងការបន្ទាបខ្លួន ។ មនុស្សគ្រប់រូបនៅថ្ងៃមួយនឹងទទួលស្គាល់ព្រះយេស៊ូវគ្រីស្ទថាជាព្រះអម្ចាស់ ។ ប៉ុលណែនាំសមាជិកសាសនាចក្រឲ្យស្វែងរកសេចក្តីសង្គ្រោះរបស់ពួកគេផ្ទាល់ ។

កីលីព ៣ ប៉ុលព្រមានពីពួកអ្នកកាន់សាសនាយូដា ។ លោករៀបរាប់ពីជីវិតពីមុនរបស់លោកក្នុងនាមជាពួកផារិស៊ីម្នាក់ និងរបៀបដែលលោកបានលះបង់ដោយស្ម័គ្រចិត្តនូវអ្វីៗទាំងអស់ ដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ។ លោកដាស់តឿនពួកបរិសុទ្ធឲ្យធ្វើតាមគំរូរបស់លោក នៅក្នុងការដើរឆ្ពោះទៅរកសេចក្តីសង្គ្រោះ ។ ប៉ុលពន្យល់ថា ព្រះយេស៊ូវគ្រីស្ទនឹងផ្លាស់ប្តូររូបកាយរមែងស្លាប់របស់យើងទៅជារូបកាយរុងរឿងដូចជាព្រះកាយរបស់ទ្រង់ដែរ ។

កីលីព ៤ ប៉ុលលើកទឹកចិត្តពួកបរិសុទ្ធឲ្យរីករាយនៅក្នុងព្រះអម្ចាស់ជានិច្ច ។ លោកទូន្មានពួកគេឲ្យជំនួសភាពព្រួយខ្លាចរបស់ពួកគេដោយការអធិស្ឋាន និងការថ្លែងអំណរគុណ ដោយសន្យាថា ពួកគេនឹងរីករាយនឹងសេចក្តីសុខសាន្តរបស់ព្រះ ដែលលើសពីការយល់ដឹងទាំងអស់ ។ ប៉ុលបានដាស់តឿនសមាជិកសាសនាចក្រឲ្យគិតពីរឿងស្មោះត្រង់ យុត្តិធម៌ ពិត បរិសុទ្ធ គួរឲ្យស្រឡាញ់ មានឈ្មោះល្អ ហើយមានគុណធម៌ ។ លោកទទួលស្គាល់ថា លោកអាចធ្វើរឿងទាំងអស់បានតាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលប្រទានកម្លាំងដល់លោក ។

មេរៀន ១២៤

កីលីព ១–៣

សេចក្តីផ្តើម

ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធនៅកីលីព ឲ្យសាមគ្គីគ្នានៅក្នុងការរស់នៅតាមដំណឹងល្អ ។ លោកបានទូន្មានពួកគេឲ្យធ្វើតាមគំរូនៃការបន្ទាបខ្លួន និងភាពមិនអាត្មានិយមរបស់ព្រះអង្គសង្គ្រោះ ហើយបានបង្រៀនថា ព្រះកំពុងធ្វើការនៅក្នុងពួកគេ ដើម្បីនាំមកនូវសេចក្តីសង្គ្រោះដល់ពួកគេ ។ ប៉ុលបានពិពណ៌នាអំពីការលះបង់ដែលលោកបានធ្វើ ដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

កីលីព ១

ប៉ុលពិពណ៌នាអំពីពរជ័យដែលកើតចេញមកពីការផ្ទុយ

ពីមុនថ្នាក់ចាប់ផ្តើម សូមសរសេរនៅលើ ក្តារខៀន នូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ព្រិកហាំ យ៉ង់ ។ (សេចក្តីថ្លែងការណ៍នេះមាននៅក្នុង *Discourses of Brigham Young,* sel. John A. Widtsoe | **ឆ្នាំ ១៩៥៤** | **ទំព័រ ៣៥១**) ។ សូមជំនួសពាក្យដែលគូសបន្ទាត់ពីក្រោមត្រង់កន្លែងបន្ទាត់ទទេ ៖

« រាល់ពេលអ្នកបៀតបៀន ‹ សាសន៍មរមន › អ្នករឹតតែធ្វើឲ្យវា រីកចម្រើន អ្នកនឹងមិនធ្វើឲ្យវា ចុះអន់ថយឡើយ ។ ព្រះអម្ចាស់ដ៏មានមហិទ្ធិឫទ្ធិដ៏កនាំវា » (ប្រធាន ព្រិកហាំ យ៉ង់) ។

សូមចាប់ផ្តើមមេរៀននេះ ដោយសួរ ៖

- តើគំរូមួយចំនួនអំពីមនុស្សដែលបៀតបៀន ឬបដិសេធសាសនាចក្ររបស់ព្រះអង្គសង្គ្រោះ និងពួកអ្នកដើរតាមទ្រង់មានអ្វីខ្លះ មិនថានៅក្នុងប្រវត្តិសាស្ត្រ ឬនៅជំនាន់របស់យើងនោះទេ ?

នៅពេលសិស្សសិក្សា កីលីព ១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយពួកគេឲ្យយល់ថា ការផ្ទុយអាចជះឥទ្ធិពលដល់កិច្ចការរបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ។

សូមពិចារណាអញ្ជើញសិស្សឲ្យស្វែងរកក្រុងកីលីពនៅលើផែនទីក្នុងព្រះគម្ពីរបឺប ល.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា » ដែលមាននៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។ សូមពន្យល់ថា ប៉ុលបានស្តាប់នាសាខាមួយរបស់សាសនាចក្រនៅកីលីពនៅក្នុងដំណើរជាលើកទីពីររបស់សាវកប៉ុលទៅផ្សាយសាសនា (សូមមើល កិច្ចការ ១៦) ។ ក្រោយមកលោកបានសរសេរសំបុត្រទៅពួកកីលីព កាលលោកជាប់ឃុំ ទំនងជានៅទីក្រុងរ៉ូម ។ សូមសង្ខេប កីលីព ១:១–១១ ដោយពន្យល់ថា ប៉ុលបានបង្ហាញពីការដឹងគុណ និងសេចក្តីស្រឡាញ់ចំពោះពួកបរិសុទ្ធនៅកីលីព ។

សូមអញ្ជើញសិស្សម្នាក់អានកីលីព ១:១២–១៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអំពីលទ្ធផលដែលកើតចេញពីការផ្ទុយ ដែលប៉ុលបានជួបនៅក្នុងកិច្ចការផ្សព្វផ្សាយសាសនារបស់លោក ។

- យោងតាមខទី ១២តើអ្វីបានកើតឡើងចេញពីការផ្ទុយដែលប៉ុលបានជួប ? (« | សេចក្តីចម្រើន | កាន់តែខ្លាំងនៃដំណឹងល្អ ») ។
- យោងតាម ខទី ១៣–១៤ តើការផ្ទុយនេះបានជួយចម្រើនដល់ដំណឹងល្អយ៉ាងដូចម្តេច ? (មនុស្សនៅក្នុង « វាំង » ទាំងមូល | ខទី ១៣ | ឬទីស្នាក់ការកណ្តាលរបស់ទ័ពបានដឹងថា ប៉ុលបានជាប់ឃុំដោយសារការផ្សាយអំពីព្រះយេស៊ូវគ្រីស្ទ ។ ការជាប់ឃុំរបស់ប៉ុលក៏បានបំផុសគំនិតដល់សមាជិកសាសនាចក្រ ឲ្យមានភាពក្លាហាននៅក្នុងការផ្សាយដំណឹងល្អដែរ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ ពីខគម្ពីរទាំងនេះអំពីលទ្ធផលដែលអាចកើតឡើង នៅពេលយើងជួបការផ្ទុយនៅក្នុងការដើរតាមព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់អំពីសេចក្តីពិតខាងក្រោមនេះ ៖ **ការផ្ទុយដែលយើងជួបនៅក្នុងការដើរតាមព្រះយេស៊ូវគ្រីស្ទអាចជួយពន្លឿនកិច្ចការរបស់ទ្រង់**) ។

សូមយោងទៅលើសេចក្តីថ្លែងការណ៍របស់ប្រធាន យ៉ង់ នៅលើក្តារខៀន ។ ចូរសួរសិស្សថាពួកគេប្រើពាក្យអ្វីដើម្បីបំពេញចន្លោះទាំងនោះ ។ សូមបំពេញចន្លោះទាំងនោះជាមួយនឹងពាក្យត្រឹមត្រូវ ។ អ្នកគួរពន្យល់ថា ពាក្យ *រីកចម្រើន* នៅក្នុងបរិបទនេះមានន័យថា ឆ្ពោះទៅមុខ ។

- តើគំរូអំពីរបៀបដែលការផ្ទុយបានជួយពន្លឿនកិច្ចការរបស់ព្រះអង្គសង្គ្រោះមានអ្វីខ្លះ ?

សូមសង្ខេប កីលីព ១:១៥–២៦ ដោយពន្យល់ថា ប៉ុលបានបង្ហាញថា ព្រះអង្គសង្គ្រោះនឹងធ្វើឲ្យចម្រើនឡើងតាមរយៈអ្វីដែលបានកើតឡើងចំពោះប៉ុល ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កីលីព ១:២៧–៣០ ឲ្យឮៗ ។ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែបស៊្មីធ កីលីព ១:២៨ ចែងថា « ឥតមានភ័យខ្លាច ចំពោះពួកទាស់ទទឹងនឹងដំណឹងល្អឡើយ ដំណើរនោះឯងនឹងនាំសេចក្តីបំផ្លិចបំផ្លាញដល់ពួកគេ ប៉ុន្តែអ្នករាល់គ្នា

ដែលទទួលយកដំណឹងល្អ សេចក្តីសង្គ្រោះ និងសម្តែងពីសេចក្តីនោះបានមកពីព្រះផង » ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្សៀងតាមរកមើលថា ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ។ សូមពន្យល់ថា ពាក្យ *ប្រព្រឹត្ត* (ខទី ២៧) សំដៅទៅលើចរិយាមាយាទ ។

- តើប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ?
- យោងតាម ខទី ២៩–៣០ តើសមាជិកសាសនាចក្រនឹងជួបអ្វីខ្លះជំនួសព្រះអង្គសង្គ្រោះ ?

សូមរំឭកសិស្សអំពីសេចក្តីពិតដែលពួកគេបានរកឃើញកាលពីមុន ។

- តើអ្នកគិតថា ពួកបរិសុទ្ធនៅភីលីពនឹងបានពរជ័យយ៉ាងណាដែរ ដោយសារតែការចងចាំថា ការជួយដែលពួកគេជួបនៅក្នុងការដើរតាមព្រះយេស៊ូវគ្រីស្ទនោះអាចជួយពន្លឿនដល់កិច្ចការរបស់ទ្រង់ ?

ភីលីព ២

ប៉ុលបង្រៀនអំពីការបន្ទាបខ្លួនរបស់ព្រះអង្គសង្គ្រោះ ហើយណែនាំពួកបរិសុទ្ធទាក់ទងនឹងសេចក្តីសង្គ្រោះរបស់ពួកគេ ។

សូមអញ្ជើញសិស្សអានភីលីព ២:២ដោយស្ងាត់ស្ងៀម រកមើលពាក្យទូន្មានរបស់ប៉ុលទៅកាន់ពួកបរិសុទ្ធនៅភីលីព ។

- តើអ្នកនឹងសង្ខេបពាក្យទូន្មានរបស់ប៉ុលដោយរបៀបណា ?

សូមចែកសិស្សជាគូ ។ សូមណែនាំដៃគូនីមួយៗឲ្យអាន ភីលីព ២:៣–៨ ឮៗរួមគ្នា រកមើលថាប៉ុលបានណែនាំឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ដើម្បីមានសាមគ្គីភាព ។ ចូរសុំសិស្សម្នាក់ពីដៃគូនីមួយៗឲ្យសរសេរពាក្យទូន្មានមួយ ដែលពួកគេបានរកឃើញដាក់នៅលើក្តារខៀន ។

- យោងតាមការបង្រៀនរបស់ប៉ុល តើព្រះយេស៊ូវគ្រីស្ទគឺជាគំរូនៃការបន្ទាបខ្លួន និងភាពមិនអាត្មានិយមយ៉ាងដូចម្តេច ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងការបង្រៀនរបស់ប៉ុលដែលអាចជួយយើងឲ្យមានសាមគ្គីភាព ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់គោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងធ្វើតាមគំរូនៃការបន្ទាបខ្លួន និងការខ្វល់ខ្វាយដល់មនុស្សដទៃដោយមិនគិតអំពីខ្លួនឯងរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចមានសាមគ្គីភាពកាន់តែខ្លាំងឡើង**) ។
- តើយើងអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទអំពីការបន្ទាបខ្លួន និងភាពមិនអាត្មានិយមនៅក្នុងក្រុមគ្រួសារយើង នៅសាលា ឃ្លួដ ឬសាខាតាមវិធីណាខ្លះ ?
- តើអ្នកធ្លាប់ឃើញមនុស្ស ដែលខ្វល់ខ្វាយអំពីសេចក្តីត្រូវការរបស់មនុស្សដទៃជាជាងសេចក្តីត្រូវការរបស់ខ្លួននៅពេលណា ? តើការខិតខំទាំងនេះបង្កើនសាមគ្គីភាពយ៉ាងដូចម្តេចដែរ ?

សូមពន្យល់ថា ដូចបានកត់ត្រានៅក្នុង ភីលីព ២:៩–១១ ប៉ុលបានបង្រៀនថា នៅទីបំផុតមនុស្សគ្រប់គ្នានឹងឱនចុះ ហើយ « ថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ » (ខទី ១១) ។ សូមអញ្ជើញសិស្សឲ្យពិចារណាថាពួកគេសង្ឃឹមថា បទពិសោធន៍នេះនឹងមានសភាពបែបណាចំពោះពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន ភីលីព ២:១២–១៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្សៀងតាម រកមើលថា តើប៉ុលបានទូន្មានឲ្យពួកភីលីពធ្វើអ្វីខ្លះ ដែលអាចជួយឲ្យបទពិសោធន៍របស់ពួកគេអំពីការបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់មានភាពរីករាយ ។ អ្នកគួរពន្យល់ថា « កោតខ្លាច ហើយញាប់ញ័រ » (ខទី ១២) សំដៅទៅលើការគោរពស្ងប់ស្ងែង និងភាពរីករាយ (សូមមើល ទំនុកដំកើង ២:១១, សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « កោតខ្លាច » scriptures.lds.org) ។

សូមចង្អុលបង្ហាញថា មានមនុស្សមួយចំនួនយល់ខុសពីពាក្យរបស់ប៉ុលនៅក្នុងភីលីព ២:១២មានន័យថា យើងបានសង្គ្រោះដោយសារកិច្ចការរបស់យើងផ្ទាល់ ។

- តើនរណាធ្វើឲ្យសេចក្តីសង្គ្រោះកើតមានចំពោះយើង ? តើដោយរបៀបណា ?
- យោងតាម ភីលីព ២:១៣ តើអ្វីទៅជាវិធីពីរយ៉ាងដែលព្រះជួយដល់អ្នកដែលកំពុងព្យាយាមធ្វើអ្វី ដែលចាំបាច់សម្រាប់សេចក្តីសង្គ្រោះ ? (ព្រះជួយពួកគេឲ្យ « ស្ម័គ្រចិត្ត » ឬមានបំណងប្រាថ្នា ហើយគោរពតាម « បំណងព្រះហឫទ័យល្អទ្រង់ » ឬប្រព្រឹត្តិរបស់ទ្រង់ ។ បន្ទាប់ពីសិស្សឆ្លើយតបហើយ សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ **ព្រះជួយយើងឲ្យមានបំណងប្រាថ្នា ហើយធ្វើអ្វីៗដែលបានតម្រូវឲ្យយើងធ្វើសម្រាប់សេចក្តីសង្គ្រោះ ដែលកើតមានតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ**) ។
- តើមានតម្រូវការអ្វីខ្លះដើម្បីបានសេចក្តីសង្គ្រោះ ដែលព្រះបានប្រទាន ហើយជួយយើងឲ្យបំពេញនោះ ? (អ្នកគួរអញ្ជើញសិស្សឲ្យមើលទៅមាត្រានៃសេចក្តីជំនឿទីបី និងទីបួន) ។

សូមចង្អុលបង្ហាញថា តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអាចជួយយើងឲ្យផ្លាស់ប្តូរ ហើយធ្វើឲ្យបំណងប្រាថ្នាយើងបានបរិសុទ្ធ ដើម្បីយើងចង់គោរពតាមទ្រង់ (សូមមើល ម៉ូសាយ ៥:២) ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា តើព្រះបានជួយផ្លាស់ប្តូរដួងចិត្តពួកគេ ដើម្បីឲ្យពួកគេចង់គោរពទ្រង់តាមរបៀបណា ហើយទ្រង់បានជួយពួកគេឲ្យកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់កាន់តែស្មោះត្រង់ដោយរបៀបណា ។

សូមសង្ខេប ភីលីព ២:១៤–៣០ ដោយពន្យល់ថា ប៉ុលបានរំឭកពួកបរិសុទ្ធថា ពួកគេ « ភ្លឺនៅកណ្តាលគេ ដូចជាតួពន្លឺនៅក្នុងលោក » (ខទី ១៥) ហើយប្រាប់ពួកគេថា លោកនឹងបញ្ជូនពួកអ្នកនាំសារឲ្យមកមើលពីសុខុមាលភាពរបស់ពួកគេ ។

ភីលីព ៣

ប៉ុលពិពណ៌នាអំពីការលះបង់ដែលលោកបានធ្វើដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីមួយដែលពួកគេ និងពិភពលោកនេះគិតថាមានតម្លៃ (ដូចជា គ្រួសារ មិត្តភក្តិ ការអប់រំ អាហារ បច្ចេកវិទ្យា ឬប្រាក់) ហើយប្រសិនបើអាចធ្វើបាន សូមដាក់បង្ហាញវត្ថុមួយដែលតំណាងឲ្យអ្វីដែលពួកគេបានគិត ។ ចូរសុំឲ្យពួកគេពិចារណាថា ពួកគេនឹងសុខចិត្តលះបង់ទ្រព្យដ៏មានតម្លៃទាំងនេះសម្រាប់អ្វីខ្លះ ។

នៅពេលសិស្សសិក្សា ភីលីព ៣ សូមអញ្ជើញពួកគេឲ្យរកមើលថា ប៉ុលបានលះបង់អ្វីខ្លះ ដើម្បីទទួលបានវត្ថុដ៏មានតម្លៃមួយដែលអាចមានសម្រាប់យើងដែរ ។

សូមសង្ខេប ភីលីព ៣:១–៣ ដោយពន្យល់ថា ប៉ុលបានព្រមានពួកភីលីពអំពីពួកគ្រូបង្រៀនបោកប្រាស់ដែលបានប្រកាសថា ពួកអ្នកប្រែចិត្តជឿក្នុងសាសនាចក្រគួរប្រតិបត្តិតាមទម្លាប់ជាក់លាក់របស់ពួកយូដា រួមបញ្ចូលទាំងការកាត់ស្បែក (សូមមើល *New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៤ [ទំព័រ ៤៣៦) ។

សូមអញ្ជើញសិស្សម្នាក់អាន ភីលីព ៣:៤–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលបាននិយាយអ្វីខ្លះអំពីកេរតំណែលជានៃពួកយូដារបស់លោក ។

- តើប៉ុលមានអត្តប្រយោជន៍អ្វីខ្លះក្នុងសង្គមពួកយូដា ទាំងខាងសង្គម និងខាងសាសនានោះ ? (ពង្សាវលីជាពួកអ៊ីស្រាអែលរបស់លោក តួនាទីជាពួកផារិស៊ី សេចក្តីសាទរសម្រាប់សាសនាយូដា និងការប្រតិបត្តិយ៉ាងតឹងរឹងចំពោះក្រឹត្យវិន័យ) ។

សូមអញ្ជើញសិស្សម្នាក់អាន ភីលីព ៣:៧–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលយល់យ៉ាងណាអំពីគុណប្រយោជន៍ដែលលោកធ្លាប់បានមាននៅក្នុងសង្គមពួកយូដា ។

- តើប៉ុលយល់យ៉ាងណាដែរ អំពីការលះបង់របស់លោកដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ?
- ហេតុអ្វីប៉ុលសុខចិត្ត « [ខាត] គ្រប់ទាំងអស់ » ? (ខទី ៨) ។ (ដើម្បីលោកអាចស្គាល់ព្រះយេស៊ូវគ្រីស្ទ « ឲ្យគេបានឃើញខ្ញុំនៅក្នុងទ្រង់ » [ខទី ៩ [ឬនៅក្នុងទំនាក់ទំនងសេចក្តីសញ្ញាដ៏ស្មោះត្រង់មួយជាមួយនឹងទ្រង់ ហើយជាផ្នែកមួយនៃការរស់ឡើងវិញនៃ « មនុស្សល្អ » ឬមនុស្សសុចរិត) ។

សូមអញ្ជើញសិស្សម្នាក់អាន ភីលីព ៣:១២–១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលបានស្គាល់អ្វីខ្លះ អំពីការកែចម្រើនខាងវិញ្ញាណរបស់លោក ។ សូមពន្យល់ថា*ជាប់*មានន័យថាទទួលបាន ។

- ជាជាងផ្តោតលើអ្វីដែលលោកបានលះបង់ចោល តើប៉ុលបានឆ្ពោះទៅមុខដើម្បីទទួលបានអ្វីខ្លះ ? (សូមពន្យល់ថា « រង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះ » [ខទី ១៤ [គឺជាជីវិតដ៏នៅអស់កល្បជានិច្ច) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ មកពីគំរូរបស់ប៉ុលទាក់ទងនឹងអ្វីដែលយើងត្រូវធ្វើ ដើម្បីមកស្គាល់ព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរក្រាកដថា ពួកគេគូរស្គាល់នូវគោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងលះបង់អ្វីៗដែលចាំបាច់ដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ហើយឆ្ពោះទៅមុខដោយសេចក្តីជំនឿ នោះយើងអាចស្គាល់ទ្រង់យ៉ាងជាក់ច្បាស់ ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវដំណើររឿងដូចតទៅនេះមកពីប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ដែលប្រាប់អំពីការប្រជុំរបស់លោកជាមួយនឹងមន្ត្រីទំពាំងទឹកម្នាក់ ដែលធ្វើដំណើរពីប្រទេសផ្សេងមកសហរដ្ឋអាមេរិកសម្រាប់ការបំពាក់បំប៉នថ្នាក់ជាន់ខ្ពស់ ហើយបានក្លាយជាសមាជិកសាសនាចក្រ កាលគាត់កំពុងស្នាក់នៅទីនោះ ។ ចូរសុំឲ្យសិស្សស្តាប់រកមើលថា យុវជននោះសុខចិត្តលះបង់អ្វីខ្លះដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ។



« មានគេណែនាំខ្ញុំឲ្យស្គាល់គាត់ ពីមុនគាត់ចេញទៅប្រទេសកំណើតវិញ ។ . . ខ្ញុំបាននិយាយ ៖ ‹ គ្រួសាររបស់អ្នកពុំមែនជាពួកគ្រីស្ទានទេ ។ តើនឹងមានអ្វីកើតឡើង នៅពេលអ្នកត្រឡប់ទៅផ្ទះវិញក្នុងនាមជាគ្រីស្ទានម្នាក់ ជាពិសេសគឺជាពួកមរមននោះ ? ›

« ទឹកមុខគាត់ឡើងស្រអាប់ ហើយបានតបថា ‹ គ្រួសារខ្ញុំនឹងខកចិត្ត ។ ពួកគេអាចនឹងបណ្តេញខ្ញុំចេញពីផ្ទះ ហើយចាត់ទុកថាខ្ញុំបានស្លាប់ហើយ ។ សម្រាប់អនាគត និងការងាររបស់ខ្ញុំ និងគ្រប់ឱកាសទាំងអស់ប្រហែលជាត្រូវបិទទ្វារចំពោះខ្ញុំ › ។

« ខ្ញុំបានសួរថា ‹ តើអ្នកសុខចិត្តលះបង់ដ៏មហិមាចំពោះដំណឹងល្អឬទេ ? ›

« គាត់បានតបទាំងស្រក់ទឹកភ្នែកថា ‹ វាគឺជាការពិត មែនទេ ? ›

« ខ្ញុំបានតបទាំងខ្មាស់ដោយបានសួរសំណួរនោះថា ‹ មែនហើយ វាគឺជាការពិត › ។

« គាត់ក៏តបថា ‹ ដូច្នេះតើមានអ្វីផ្សេងសំខាន់ជាងនេះទៅទៀតនោះ ? » (« It's True, Isn't It? » *Ensign* ខែ កក្កដា ឆ្នាំ ១៩៩៣ ទំព័រ ២) ។

- តើយុវជននេះសុខចិត្តលះបង់អ្វីខ្លះ ដើម្បីដើរតាមព្រះអង្គសង្គ្រោះ ?
- តើអ្នក (ឬមនុស្សដែលអ្នកស្គាល់) បានលះបង់អ្វីខ្លះដើម្បីដើរតាមព្រះអង្គសង្គ្រោះ ?
- ហេតុអ្វី រង្វាន់នៃការស្គាល់ព្រះយេស៊ូវគ្រីស្ទ និងការកែចម្រើនឆ្ពោះទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច មានតម្លៃឲ្យយើងធ្វើការលះបង់ ?

សូមកុំខ្លាចចំពោះការស្ងៀមស្ងាត់

នៅពេលអ្នកសួរសំណួរដ៏មានប្រសិទ្ធភាពមួយដល់សិស្ស ពួកគេអាចនឹងមិនឆ្លើយតបភ្លាមៗនោះទេ ។ ដរាបណាវាមិនយូរពេក អ្នកមិនគួរព្រួយអំពីការនៅស្ងៀមស្ងាត់នេះឡើយ ។ ជួនកាលសិស្សត្រូវការឱកាសមួយដើម្បីគិតអំពីអ្វីដែលពួកគេត្រូវបានសួរ និងគិតអំពីរបៀបដែលពួកគេអាចឆ្លើយតប ។ ការនឹកគិតបែបនេះអាចជួយឲ្យមានការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា តើមានអ្វីមួយដែលពួកគេត្រូវលះបង់ ដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទឲ្យកាន់តែពេញលេញដែរឬទេ ។ សូមអញ្ជើញពួកគេឲ្យសរសេរគោលដៅមួយ ដើម្បីធ្វើរឿងនោះ ។

សូមសង្ខេប ភីលីព ៣:១៥–២១ ដោយពន្យល់ថា ប៉ុលបានព្រមានអំពីការបំផ្លិចបំផ្លាញ ដែលកំពុងរង់ចាំជនដែលផ្តោតទាំងស្រុងទៅលើភាពត្រេកត្រអាលនៅលើផែនដីនេះ ។ លោកក៏បានបង្រៀនផងដែរថា ព្រះយេស៊ូវគ្រីស្ទនឹងផ្លាស់ប្តូររូបកាយដែលពុំល្អឥតខ្ចោះរបស់យើង ទៅជារូបកាយអតមៈដូចជាព្រះកាយរបស់ទ្រង់ដែរ ។

សូមបញ្ចប់មេរៀននេះដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានរកឃើញនៅក្នុងមេរៀននេះ ។

មេរៀន ១២៥

ភីលីព ៤

សេចក្តីផ្តើម

ប៉ុលបានណែនាំពួកបរិសុទ្ធនៅភីលីពឲ្យអធិស្ឋាន ហើយស្វែងរកអ្វីៗដែលសុចរិត ។ លោកក៏បានប្រកាសពីទំនុកចិត្តរបស់លោកទៅលើកម្លាំងដ៏ខ្លាំងក្លារបស់ព្រះយេស៊ូវគ្រីស្ទដែរ ។ ប៉ុលបានបញ្ចប់សំបុត្ររបស់លោកជាមួយនឹងការថ្លែងអំណរគុណមួយទៀតដល់ពួកបរិសុទ្ធនៅភីលីព សម្រាប់ការជួយជ្រោមជ្រែងដែលពួកគេបានផ្តល់ឲ្យលោកនៅក្នុងគ្រាដែលលោកត្រូវការ ។

យោបល់សម្រាប់ការបង្រៀន

ភីលីព ៤:១–១៤

ប៉ុលណែនាំពួកបរិសុទ្ធនៅភីលីពឲ្យអធិស្ឋាន ហើយស្វែងរកអ្វីៗដែលសុចរិត

ពីមុនថ្នាក់ចាប់ផ្តើម សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្រដាសផ្សេងៗគ្នា ហើយឲ្យក្រដាសនីមួយៗទៅសិស្សផ្សេងៗគ្នា ៖

« ខ្ញុំព្រួយបារម្ភពីការប្រឡងឲ្យជាប់នៅពេលខាងមុខនេះ » ។

« ខ្ញុំព្រួយបារម្ភពីសមាជិកគ្រួសារម្នាក់ដែលឈឺ » ។

« ខ្ញុំព្រួយបារម្ភពីការឈរការពារជំនឿរបស់ខ្ញុំ » ។

« ខ្ញុំព្រួយបារម្ភថា តើខ្ញុំអាចក្លាយជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ដ៏ជោគជ័យម្នាក់ឬទេ » ។

សូមចាប់ផ្តើមមេរៀនដោយសរសេរពាក្យ *ព្រួយបារម្ភ* នៅលើក្តារខៀន ។ ចូរចង្អុលបង្ហាញថា នៅពេញមួយជីវិតយើង យើងនឹងជួបឧបសគ្គ ឬកាលៈទេសៈដែលអាចនាំឲ្យយើងព្រួយបារម្ភ ។ សូមអញ្ជើញសិស្សដែលមានក្រដាសឲ្យក្រោកឈរឡើងអានឃ្លារបស់ពួកគេម្តងម្នាក់ៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់គិតពីគ្រាដែលពួកគេមានការព្រួយបារម្ភស្រដៀងគ្នានេះ ។

- តើមានការព្រួយបារម្ភអ្វីផ្សេងទៀតដែលយើងអាចជួបដោយសារឧបសគ្គ ឬកាលៈទេសៈពិបាកៗនោះ ?

ចូរសុំឲ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីឧបសគ្គមួយដែលពួកគេ ឬមនុស្សម្នាក់ដែលពួកគេស្គាល់ មានការព្រួយបារម្ភនោះ ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតមួយ នៅពេលពួកគេសិក្សាភីលីព ៤ដែលអាចជួយពួកគេបាន នៅពេលពួកគេព្រួយបារម្ភ ។

សូមរំឭកសិស្សថា នៅក្នុងសំបុត្ររបស់ប៉ុលសរសេរទៅកាន់សមាជិកសាសនាចក្រនៅភីលីព លោកបានសរសើរពីភាពស្មោះត្រង់របស់សមាជិកសាសនាចក្រ (សូមមើល ភីលីព ២:១២) ហើយបានបង្រៀនពួកគេអំពីរង្វាន់ដ៏នៅអស់កល្បជានិច្ច ដែលមានសម្រាប់ជនដែលលះបង់ ហើយស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ។ សូមសង្កេប ភីលីព ៤:១–៥ ដោយពន្យល់ថា ប៉ុលបានទូន្មានដល់ពួកបរិសុទ្ធឲ្យឈរឲ្យរឹងមាំនៅក្នុងសេចក្តីស្មោះត្រង់ចំពោះព្រះអម្ចាស់ រីករាយនៅក្នុងព្រះអម្ចាស់ ហើយចូរឲ្យភាពទន់ភ្លន់របស់ពួកគេ (នៅក្នុងភាសាក្រិកពាក្យថា ការចេះប្រមាណ ក៏បកប្រែថាជាភាពទន់ភ្លន់ដែរ) បានបង្ហាញដល់មនុស្សដទៃទៀត ។

សូមអញ្ជើញសិស្សម្នាក់អានប្រយោគទីមួយក្នុង ភីលីព ៤:៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យទូន្មានរបស់ប៉ុលទៅកាន់ពួកបរិសុទ្ធ ។ សូមពន្យល់ថាឃ្លា « កុំឲ្យខ្វល់ខ្វាយអ្វីឡើយ » មាននំយថាកុំឲ្យខ្វល់ខ្វាយពីអ្វីៗទាំងអស់ជ្រុលហួសហេតុពេក ។

សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន ៖ *ក្នុងនាមជាអ្នកដើរតាមរបស់ព្រះយេស៊ូវគ្រីស្ទ ប្រសិនបើ . . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឃ្លាដែលនៅសល់ក្នុង ភីលីព ៤:៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា តើប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ជាជាងការព្រួយបារម្ភ ។ អ្នកអាចពន្យល់ថា*ពាក្យសូមអង្វរ*គឺជាការស្នើមួយដ៏ស្មោះត្រង់ និងរាបសា ។

- តើអ្នកនឹងសង្ខេបការណែនាំរបស់ប៉ុលនៅក្នុងខទី ៦ យ៉ាងដូចម្តេច ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនថា ឃ្លា « ប្រសិនបើ » ស្រដៀងគ្នានឹងឃ្លាខាងក្រោម ៖ *ក្នុងនាមជាអ្នកដើរតាមដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទ ប្រសិនបើយើងអធិស្ឋានដោយពាក្យសូមអង្វរ និងការដឹងគុណ . . .*) ។

សូមបន្ថែមពាក្យ*បន្ទាប់មក*ទៅឃ្លានៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់អាន ភីលីព ៤:៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលពរជ័យ ដែលប៉ុលបានសន្យាសម្រាប់ការអធិស្ឋានដោយពាក្យសូមអង្វរ និងការដឹងគុណ ។ សូមពន្យល់ថា ពាក្យ *ការពារ* នៅក្នុងខគម្ពីរមាននំយថា ឃុំគ្រង ។

- តើអ្នកនឹងសង្ខេបពរជ័យដែលប៉ុលបានសន្យាយ៉ាងដូចម្តេច ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនបន្ទាប់ពីពាក្យ *នោះ* ។ សិស្សគួរតែឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ក្នុងនាមជាអ្នកដើរតាមដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទ ប្រសិនបើយើងអធិស្ឋានដោយពាក្យសូមអង្វរ និងការដឹងគុណ នោះព្រះនឹងប្រទានភាពសុខសាន្តរបស់ទ្រង់ដល់យើង**) ។

- នៅពេលយើងព្រួយបារម្ភ តើយើងអាចបង្ហាញការដឹងគុណនៅក្នុងការអធិស្ឋានរបស់យើង អាចជួយនាំយកភាពសុខសាន្តដល់យើងយ៉ាងដូចម្តេច ?
- តើភាពសុខសាន្តរបស់ព្រះយ៉ាងគ្រងចិត្ត និងគំនិតយើងពីអ្វីដែរ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កុត ជាកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកវិធីបន្ថែមទៀត ដែលភាពសុខសាន្តរបស់ព្រះអាចជួយដល់យើង ៖



« ដោយសារទ្រង់គោរពដល់សិទ្ធិជ្រើសរើសរបស់អ្នក នោះព្រះវរបិតាដែលគង់នៅស្ថានសួគ៌នឹងមិនបង្ខំអ្នកឲ្យអធិស្ឋានទៅទ្រង់ឡើយ ។ ប៉ុន្តែនៅពេលអ្នកអនុវត្តសិទ្ធិជ្រើសរើសនោះ ហើយដាក់បញ្ចូលទ្រង់នៅគ្រប់ទិដ្ឋភាពនៃជីវិតប្រចាំថ្ងៃរបស់អ្នក នោះដួងចិត្តរបស់អ្នកនឹងចាប់ផ្តើមពោរពេញដោយសេចក្តីសុខសាន្ត ជាសេចក្តីសុខសាន្តដ៏ភ្លៀវភ្លា ។ សេចក្តីសុខសាន្តនោះនឹងបញ្ចាំងពន្លឺដ៏អស់កល្បមួយទៅលើភាពស្មុគស្មាញរបស់អ្នក ។ វានឹងជួយអ្នកឲ្យគ្រប់គ្រងឧបសគ្គទាំងនោះ ដោយទស្សនៈដ៏អស់កល្បមួយ » (« Make the Exercise of Faith Your First Priority » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៩៣) ។

- យោងតាមអែលឌើរ ស្កុត តើសេចក្តីសុខសាន្តរបស់ព្រះអាចជួយយើងឲ្យយកឈ្នះលើឧបសគ្គនានា ដែលយើងជួបបានយ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់អធិស្ឋានដោយពាក្យសូមអង្វរ និងដោយការថ្លែងអំណរគុណនៅក្នុងគ្រាដែលព្រួយបារម្ភ ហើយត្រូវបានប្រទានឲ្យនូវសេចក្តីសុខសាន្តរបស់ព្រះនៅពេលណាដែរ ?

ចូរសុំឲ្យសិស្សមើលទៅពាក្យព្រួយបារម្ភ ដែលបានសរសេរនៅលើក្តារខៀនកាលពីដើមមេរៀននេះ ។ សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានដោយពាក្យសូមអង្វរ និងដោយការដឹងគុណ ជាជាងការព្រួយបារម្ភ ។ ប្រសិនបើសិស្សបានសរសេរអំពីការព្រួយបារម្ភរបស់មនុស្សម្នាក់ផ្សេងទៀត សូមលើកទឹកចិត្តពួកគេឲ្យចែកចាយគោលការណ៍នេះជាមួយនឹងបុគ្គលនោះ ។

ដើម្បីរៀបចំខ្លួនសិស្សឲ្យស្គាល់ពីគោលការណ៍មួយបន្ថែមទៀត ដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធនៅភីលីព សូមបំបែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ ចូរចាត់សិស្សមួយភាគបីនៅក្នុងថ្នាក់ ឲ្យគិតពីអាហារដែលពួកគេចូលចិត្ត មួយក្រុមទៀតគិតពីរូបភាព ឬរឿងកំប្លែងមួយ ហើយឲ្យក្រុមបន្ទាប់គិតពីរូបភាពស្តីពីបទសោធន៍នៅក្នុងព្រះវិហារបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យផ្តោតយកចិត្តទុកដាក់ទៅលើគំនិតនេះរយៈពេល ៣០ វិនាទី ។

- ប្រសិនបើមាន តើការផ្តោតនេះមានឥទ្ធិពលអ្វីខ្លះលើគំនិតដែលអ្នកមាន ?

ចូរចង្អុលបង្ហាញថា អ្វីដែលយើងគិតអាចជះឥទ្ធិពលដល់បំណងប្រាថ្នា និងឥរិយាបថរបស់យើង ។ សូមអញ្ជើញសិស្សម្នាក់អាន ភីលីព ៤:៨–៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធនៅភីលីពគិត ហើយធ្វើអ្វីខ្លះ ។ អ្នកអាចពន្យល់ថា ពាក្យ « ពិចារណា » មានន័យថា ការផ្តល់ជាគំនិតជាបន្តបន្ទាប់ដោយប្រុងប្រយ័ត្ន ។

សូមអញ្ជើញសិស្សឲ្យគូសចំណាំប្រភេទរឿងនីមួយៗ ដែលប៉ុលបានណែនាំពួកបរិសុទ្ធឲ្យផ្តោតគំនិតលើនោះ ។

- បន្ថែមពីលើការគិតអំពីរឿងទាំងនេះ តើប៉ុលបានទូន្មានសមាជិកសាសនាចក្រឲ្យធ្វើអ្វីខ្លះ ?
- តើប៉ុលបានសន្យាពរជ័យអ្វីខ្លះដល់ពួកបរិសុទ្ធ ប្រសិនបើពួកគេធ្វើតាមការបង្រៀនទាំងឡាយ និងគំរូរបស់លោក ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីអ្វី ដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធស្មោះត្រង់នៅក្នុង ភីលីព ៤:៨–៩ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើពួកបរិសុទ្ធស្មោះត្រង់ផ្តោតគំនិតពួកគេលើអ្វីៗដែលសុចរិត ហើយប្រសិនបើពួកគេធ្វើតាមពួកសាវក និងពួកព្យាការី នោះសេចក្តីសុខសាន្តរបស់ព្រះនឹងតើតមានដល់ពួកគេ**) ។
- តើការផ្តោតគំនិតរបស់យើងលើអ្វីៗដែលសុចរិត អាចជះឥទ្ធិពលដល់បំណងប្រាថ្នា និងឥរិយាបថរបស់យើងយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សបើកទៅមាត្រានៃសេចក្តីជំនឿនៅក្នុងមុក្តាដ៏មានតម្លៃមហិមា ។ សូមឲ្យសិស្សអានមាត្រានៃសេចក្តីជំនឿទីដប់បីឲ្យឮៗ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលភាពស្រដៀងគ្នាជាមួយនឹងភីលីព ៤:៨ ។

- តើភាពស្រដៀងគ្នាអ្វីខ្លះ ដែលអ្នកបានសម្គាល់ឃើញរវាងខគម្ពីរទាំងពីរនេះ ?

សូមចង្អុលបង្ហាញថា នៅពេលព្យាការីយ៉ូសែប ស៊្មីធ បានដកស្រង់ « ការទូន្មានរបស់ប៉ុល » ពី ភីលីព ៤:៨ នៅក្នុងមាត្រានៃសេចក្តីជំនឿទីដប់បី លោកបានផ្លាស់ប្តូរ ឃ្លា « ចូរពិចារណាពីសេចក្តីទាំងនោះចុះ » ឲ្យកាន់តែមានភាពស់រើកទៅជា « យើងខ្ញុំស្វែងរករបស់ផងទាំងនេះហើយ » ។

- តើអ្នកគិតថា ហេតុអ្វីក៏វាសំខាន់ចំពោះយើងដើម្បីស្វែងរកអ្វីដែលទៀងត្រង់ ត្រឹមត្រូវ បរិសុទ្ធ(ឬ ត្រឹមត្រូវ) គុណធម៌ គួរឲ្យស្រឡាញ់ ហើយឈោះល្អ ?
- តើការស្វែងរករបស់ទាំងអស់នេះនឹងជួយយើងឲ្យផ្តោតគំនិតរបស់យើងទៅលើរបស់ទាំងនេះបានដោយរបៀបណា ?

សូមបំបែកសិស្សជាក្រុមដែលមានគ្នាបី ឬបួននាក់ ។ សូមឲ្យកូនសៀវភៅ *កម្លាំងដើម្បីយុវជន* (កូនសៀវភៅ ឆ្នាំ ២០១១) និងឯកសារចែកចាយខាងក្រោមនេះដល់ក្រុមនីមួយៗ ។ សូមចាត់ដល់ក្រុមនីមួយៗនូវប្រធានបទពីរនៅក្នុង *កម្លាំងដើម្បីយុវជន* ដូចខាងក្រោម ៖ « ការដើរលេងជាគ្នា » « ការស្លៀកពាក់ និង អាកប្បកិរិយាខាងក្រៅ » « ការអប់រំ » « ការកម្សាន្ត និង ប្រព័ន្ធផ្សព្វផ្សាយ » « មិត្តភក្តិ » « ភាសា » និង « តន្ត្រី និងការរាំ » (សូមកែសម្រួលចំនួនសិស្សក្នុងក្រុម និងចំនួនប្រធានបទ ដោយផ្អែកទៅលើចំនួនសិស្ស) ។ សូមណែនាំសិស្សឲ្យធ្វើតាមសេចក្តីណែនាំនៅក្នុង ឯកសារចែកចាយនោះ ។

ភីលីព ៤:៨–៩

សូមសរសេរប្រធានបទដែលអ្នកបានចាត់ឲ្យនៅត្រង់នេះ ៖

ចំពោះប្រធានបទនីមួយៗ សូមពិភាក្សាសំណួរដូចតទៅ ៖

- តើយើងអាចប្រើការណែនាំរបស់ប៉ុលនៅក្នុង ភីលីព ៤:៨–៩ ដើម្បីដឹកនាំការជ្រើសរើសរបស់យើង ដែលទាក់ទងនឹងប្រធានបទនេះ យ៉ាងដូចម្តេច ?
- នៅពេលយើងព្យាយាមធ្វើតាមការណែនាំរបស់ប៉ុល តើយើងអាចជួបនឹងឧបសគ្គអ្វីខ្លះ ដែលទាក់ទងនឹងប្រធានបទនេះ ?

បន្ទាប់មក សូមពិភាក្សាសំណួរដូចខាងក្រោមនេះ ៖

- ហេតុអ្វីការមានសេចក្តីសុខសាន្តរបស់ព្រះនៅជាមួយនឹងយើង មានតម្លៃសក្តិសមចំពោះការខិតខំស្វែងរកអ្វីដែលសុចរិត និងការធ្វើតាមពួកសាវក និងពួកព្យាការី ?

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សម្នាក់ពីក្រុមនីមួយៗឲ្យប្រាប់ដល់សិស្សក្នុងថ្នាក់ពីអ្វី ដែលក្រុមខ្លួនបានពិភាក្សាសម្រាប់សំណួរនីមួយៗ ។

- នៅពេលអ្នកផ្តោតគំនិតរបស់អ្នកទៅលើរឿងសុចរិតនានា តើព្រះនៃសេចក្តីសុខសាន្តបានបង្ហាញថា ទ្រង់គង់នៅជាមួយនឹងអ្នកតាមរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យសរសេរពីវិធីមួយដែលពួកគេអាចកែលម្អការខិតខំរបស់ពួកគេ ដើម្បីផ្តោតគំនិតលើរឿងសុចរិត ហើយធ្វើតាមពួកសាវក និងពួកព្យាការីរបស់ព្រះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។

សូមសង្ខេប ភីលីព ៤:១០ ដោយពន្យល់ថា ប៉ុលបានអរគុណដល់ពួកបរិសុទ្ធនៅភីលីពសម្រាប់ការជួយជ្រោមជ្រែង និងការមើលថែដែលពួកគេបានផ្តល់ឲ្យលោក កាលលោកជួបប្រទះនឹងការសាកល្បង ។

សូមឲ្យសិស្សម្នាក់អាន ភីលីព ៤:១១–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ប៉ុលបានប្រាប់ដល់ពួកបរិសុទ្ធថាលោកបានរៀនអ្វីខ្លះ ។

- តើប៉ុលបានរៀនធ្វើអ្វីខ្លះនៅគ្រប់កាលៈទេសៈ ?

សូមអញ្ជើញសិស្សម្នាក់ អានភីលីព ៤:១៣–១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថានរណាទៅ ជាប្រភពនៃកម្លាំងរបស់ប៉ុល ។

- តើប៉ុលបាននិយាយថា នរណាទៅដែលជាប្រភពនៃកម្លាំងរបស់លោក ?

សូមពន្យល់ថា សម្តីរបស់ប៉ុលនៅក្នុង ខទី ១៣ ទាក់ទងនឹងសមត្ថភាពរបស់លោកនៅក្នុងកម្លាំង ដែលព្រះយេស៊ូវគ្រីស្ទបានប្រទានឲ្យ ដើម្បីធ្វើអ្វីៗគ្រប់យ៉ាងដែលព្រះបានតម្រូវឲ្យធ្វើ ហើយធ្វើឲ្យទ្រង់សព្វព្រះទ័យ រួមបញ្ចូលទាំងការរីករាយនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង ខទី ១៣ ? (ដោយប្រើពាក្យផ្ទាល់ខ្លួន សិស្សគួរស្គាល់សេចក្តីពិតខាងក្រោមនេះ ៖ **យើងអាចធ្វើអ្វីៗគ្រប់យ៉ាងតាមរយៈព្រះយេស៊ូវគ្រីស្ទ ដែលជាអង្គប្រទានកម្លាំងដល់យើង** (សូមមើលផងដែរ អាលម៉ា ២៦:១២)) ។
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីទទួលបានកម្លាំងដែលព្រះយេស៊ូវគ្រីស្ទប្រទានឲ្យនោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា កម្លាំងនេះអាចជួយឲ្យយើងធ្វើអ្វីខ្លះ ៖

« ព្រះចាក់ស្រោចពរជ័យនៃថាមពល និងកម្លាំង ដោយជួយយើងឲ្យសម្រេចរឿងទាំងឡាយ ដែលយើងមិនអាចធ្វើបានដោយសមត្ថភាពខ្លួនឯង ។ ដោយសារតែព្រះគុណដ៏អស្ចារ្យនៃព្រះ ទើបកូនចៅនៃទ្រង់អាចយកឈ្នះទៅលើការល្បួងដ៏គ្រោះថ្នាក់នៃមេកុហកឆបោក និងការលាក់ខ្លួនរបស់អ្នកបញ្ឆោត ឈប់ប្រព្រឹត្តបាប ហើយ ‹ បានល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ › [មរ៊ីណៃ ១០:៣២] » (« The Gift of Grace » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១០៨) ។

- តើយើងអាចដកពិសោធន៍កម្លាំង ឬព្រះគុណនេះតាមរបៀបណា ? (ចម្លើយដែលអាចមានរួមបញ្ចូលទាំងភាពភ្លៀវភ្លា ការតាំងចិត្ត ភាពក្លាហាន ការអត់ធ្មត់ ការខិតខំជាបន្តបន្ទាប់ ការអំណត់ និងថាមពលខាងសាច់ឈាម ខាងផ្លូវចិត្ត ឬខាងវិញ្ញាណ) ។
- តើព្រះយេស៊ូវគ្រីស្ទធ្លាប់ប្រទានកម្លាំងដល់អ្នកឲ្យធ្វើអ្វីមួយដែលល្អនៅពេលណា ? (ចូរពិចារណាចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនផងដែរ) ។

ភីលីព ៤:១៣

គឺជាវគ្គចំណោះចំណានខគម្ពីរ ។ ការសិក្សាចំណោះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណោះចំណានខគម្ពីរនេះក្នុងរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកយោងទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណោះចំណានខគម្ពីរបស់ពួកគេ ។

ភីលីព ៤:១៥–២៣

ប៉ុលបញ្ចប់សំបុត្ររបស់លោកដល់ពួកភីលីពដោយការថ្លែងអំណរគុណ

សូមសង្ខេប ភីលីព ៤:១៥–២៣ ដោយពន្យល់ថា ប៉ុលបានថ្លែងអំណរគុណម្តងទៀតដល់ពួកបរិសុទ្ធនៅភីលីពសម្រាប់ការជួយជ្រោមជ្រែងរបស់ពួកគេដល់លោក កាលលោកជួបប្រទះនឹងទុក្ខលំបាក ។ អំណោយរបស់ពួកបរិសុទ្ធគឺជាដង្វាយដ៏រីករាយមួយចំពោះព្រះ ហើយប៉ុលបានសន្យាថា ព្រះនឹងបំពេញសេចក្តីត្រូវការរបស់ពួកគេផងដែរ ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយ ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

ចំណេះចំណានខគម្ពីរ—ភីលីព ៤:១៣

សូមជួយសិស្សឲ្យទន្ទេញចាំ ភីលីព ៤:១៣ ដោយសរសេរខគម្ពីរនេះនៅលើក្តារខៀន ហើយអានវាឮៗរួមគ្នា ។ សូមលុបពាក្យមួយ ហើយអានខគម្ពីរនេះឮៗម្តងទៀត ។ សូមធ្វើបែបនេះរហូតដល់លុបពាក្យទាំងនោះអស់ ។

មេរៀនសិក្សានៅផ្ទះ

អេភេសូរ ២–កីលីព ៤ (មេរៀនទី ២៥)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សរបស់អ្នកបានរៀន ខណៈពេលពួកគេបានសិក្សា អេភេសូរ ២–កីលីព ៤ (មេរៀនទី ២៥) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អេភេសូរ ២–៣)

សាវកប៉ុលបានបន្តសុន្ទរកថារបស់លោកទៅកាន់សមាជិកសាសនាចក្រនៅអេភេសូរ ដោយបង្រៀនពួកគេថា ដោយសារតែព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ ទើបមនុស្សលោកទាំងអស់អាចបានសេចក្តីសង្គ្រោះតាមរយៈសេចក្តីជំនឿលើទ្រង់ ហើយថាកាលយើងមករកព្រះយេស៊ូវគ្រីស្ទ ហើយទទួលយកព្រះគុណរបស់ទ្រង់ នោះយើងបានមករួបរួមនឹងពួកបរិសុទ្ធនៃព្រះ ។ ប៉ុលក៏បានបង្រៀនផងដែរថា សាសនាចក្ររបស់ព្រះអម្ចាស់បានចាក់គ្រឹះនៅលើពួកសាវក និងពួកព្យាការីទាំងឡាយ ដោយមានព្រះយេស៊ូវគ្រីស្ទជាថ្មជ្រុងយ៉ាងឯក ហើយថាពួកសាវក និងពួកព្យាការីខិតខំជួយកូនចៅទាំងអស់របស់ព្រះឲ្យស្គាល់ ហើយទទួលអារម្មណ៍សេចក្តីស្រឡាញ់ពីព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ២ (អេភេសូរ ៤–៦)

តាមរយៈការបង្រៀនជាបន្តបន្ទាប់របស់ប៉ុលស្តីពីការរៀបចំសាសនាចក្រ នោះសិស្សបានរៀនថា ព្រះអម្ចាស់បានហៅពួកសាវក ពួកព្យាការី និងថ្នាក់ដឹកនាំសាសនាចក្រផ្សេងទៀតដើម្បីជួយធ្វើឲ្យពួកបរិសុទ្ធបានល្អឥតខ្ចោះ ហើយការពោរពួកគេពីគោលលទ្ធិខុសឆ្គង ។ ប៉ុលក៏បានបង្រៀនដល់ពួកបរិសុទ្ធផងដែរថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទត្រូវលះបង់ផ្លូវចាស់ដ៏ខុសឆ្គងរបស់ខ្លួន ហើយដើរតាមផ្លូវថ្មីសុចរិតវិញ ។

ថ្ងៃទី ៣ (កីលីព ១–៣)

នៅក្នុងសំបុត្ររបស់ប៉ុលដល់ពួកបរិសុទ្ធនៅកីលីព ពួកសិស្សបានរៀនថា រឿងផ្ទុយដែលយើងជួបនៅក្នុងការដើរតាមព្រះយេស៊ូវគ្រីស្ទអាចជួយដល់កិច្ចការរបស់ទ្រង់បន្ថែមទៀត ហើយថាប្រសិនបើយើងធ្វើតាមគំរូនៃការបន្ទាបខ្លួន និងការខ្វល់ខ្វាយចំពោះអ្នកដទៃរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចមានសាមគ្គីភាពកាន់តែខ្លាំងឡើង ។ ប៉ុលក៏បានបង្រៀនផងដែរថា ព្រះជួយយើងឲ្យមានបំណងប្រាថ្នាធ្វើអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានសេចក្តីសង្គ្រោះ ដែលអាចកើតមានឡើងតាមរយៈជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយប្រសិនបើយើងលះបង់អ្វីៗទាំងអស់ដែលចាំបាច់ដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ ហើយដើរឆ្ពោះទៅមុខដោយសេចក្តីជំនឿ នោះយើងអាចមកស្គាល់ទ្រង់ ហើយទទួលបានជីវិតជំនៅអស់កល្បជានិច្ច ។

ថ្ងៃទី ៤ (កីលីព ៤)

នៅពេលពួកគេបន្តការសិក្សារបស់ពួកគេអំពីសំបុត្ររបស់ប៉ុលទៅកាន់ពួកបរិសុទ្ធនៅក្រុងកីលីព សិស្សបានរកឃើញថា ក្នុងនាមជាពួកអ្នកដើរតាមដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទ ប្រសិនបើយើងអធិស្ឋានដោយពាក្យទូលសូមអង្វរ និងការថ្លែងអំណរគុណ នោះព្រះនឹងប្រទានពរដោយសេចក្តីសុខសាន្តដល់យើង ហើយប្រសិនបើពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ផ្តោតលើគំនិតរបស់ពួកគេពីអ្វីក៏ដោយដែលជារឿងសុចរិត ហើយប្រសិនបើពួកគេដើរតាមពួកសាវក និងពួកព្យាការីទាំងឡាយ នោះព្រះនៃសេចក្តីសុខសាន្តនឹងគង់នៅជាមួយនឹងពួកគេ ។ ប៉ុលបានបញ្ចប់សំបុត្ររបស់លោកដោយបង្រៀនថា យើងអាចធ្វើនូវអ្វីៗគ្រប់យ៉ាងតាមរយៈព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលប្រទានកម្លាំងដល់យើង ។

សេចក្តីផ្តើម

បន្ទាប់ពីបង្រៀនពួកបរិសុទ្ធនៅអេភេសូរថា ពួកគេគួរលះបង់ផ្លូវចាស់របស់ពួកគេចោល ហើយធ្វើជាមនុស្សថ្មី ជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ នោះសាវកប៉ុលបានបង្រៀនពួកគេថា ពួកគេក៏គួរពាក់គ្រឿងសឹកទាំងមូលនៃព្រះផងដែរ ។

យោបល់សម្រាប់ការបង្រៀន

អេភេសូរ ៦:១០–២៤

ប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធពាក់ « គ្រប់គ្រឿងសឹករបស់ព្រះ »

សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្វ ថែនសឺន ។ (សេចក្តីថ្លែងការណ៍នេះ មាននៅក្នុង« The Power of the Word »*Ensign*ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៧៩) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍នេះឲ្យឮៗ ។


> *« សាតាំងកំពុងបង្កសង្គ្រាមទាស់នឹងសមាជិកសាសនាចក្រ ដែលមានទីបន្ទាល់ ហើយដែលកំពុងព្យាយាមគោរពតាមព្រះបញ្ញត្តិទាំងឡាយ » (ប្រធាន អែសរ៉ា ថាហ្វ ថែនសឺន) ។*

- តើសាតាំងបង្កសង្គ្រាមទាស់នឹងយុវវ័យរបស់សាសនាចក្រតាមរបៀបណា ?

សូមប្រាប់ឲ្យសិស្សម្នាក់អាន អេភេសូរ ៦:១០–១៣ ឲ្យឮៗ ។ ចុះសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយថាពួកបរិសុទ្ធនៅក្នុងជំនាន់របស់លោកកំពុងច្បាំងទាស់នឹងអ្វី ។ សូមពន្យល់ថា *ឧបាយកល* សំដៅទៅលើល្បិច ឬកលដែលប្រើដើម្បីបោកបញ្ឆោត ឬជាក់អន្ទាក់ ។

- តើប៉ុលបាននិយាយថា ពួកបរិសុទ្ធនៅក្នុងជំនាន់របស់លោកកំពុងច្បាំងទាស់នឹងអ្វី ?
- តើអ្វីដែលប៉ុលបានរៀបរាប់នៅក្នុង ខទី ១២ ដូចគ្នានឹងអ្វីដែលយើងកំពុងច្បាំងទាស់ក្នុងជំនាន់របស់យើងយ៉ាងដូចម្តេចដែរ ?
- តើប៉ុលបានប្រាប់ដល់ពួកបរិសុទ្ធនៅជំនាន់លោកឲ្យពាក់អ្វី ដើម្បីពួកគេអាចទប់ទល់នឹងអំពើអាក្រក់ទាំងនេះ ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងពាក់គ្រប់ទាំងគ្រឿងសឹករបស់ព្រះ យើងនឹងអាចទប់ទល់នឹងអំពើអាក្រក់បាន**) ។

ពាក់គ្រប់គ្រឿងសឹករបស់ព្រះ



ចូរ ឯកសារចែកចាយដែលភ្ជាប់មកជាមួយដល់សិស្ស ។ សូមបំបែកសិស្សក្នុងថ្នាក់ជាប្រាំក្រុម ហើយចាត់តាំងក្រុមនីមួយៗនូវចំណែកមួយនៃអាវក្រោះដែលបានរៀបរាប់ក្នុង អេភេសូរ ៦:១៤–១៧ ។ (សូមកុំចាត់តាំងកិច្ចការ « ដោយក្រវាត់សេចក្តីពិតនៅចង្កេះ » [ខទី ១៤] ឲ្យធ្វើឡើយ ។ ប្រសិនបើចំនួនសិស្សរបស់អ្នកតិច អ្នកគួរឲ្យបំបែកគ្រឿងសឹកលើសពីមួយដល់ក្រុមមួយចំនួន) ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

១. តើបំណែកគ្រឿងសឹកនេះប្រើសម្រាប់អ្វី ?

២. តើប៉ុលបានហៅបំបែកគ្រឿងសឹកនេះថាជាអ្វី ?

៣. តើផ្នែកណាមួយនៃរូបកាយដែលអាចត្រូវបានការពារដោយគ្រឿងសឹក ដែលតំណាងឲ្យខាងវិញ្ញាណយ៉ាងណា ?

៤. តើការពាក់បំណែកនៃគ្រឿងសឹកខាងវិញ្ញាណនេះអាចជួយអ្នកឲ្យទប់ទល់នឹងអំពើអាក្រក់បានយ៉ាងដូចម្តេច ?

ដើម្បីបង្ហាញសិស្សពីរបៀបបំពេញឯកសារ សូមអញ្ជើញសិស្សម្នាក់អាន អេភេសូរ ៦:១៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម កេរមើលចម្លើយទៅនឹងសំណួរនៅលើក្តារខៀន នៅពេលពួកគេអនុវត្ត « ដោយក្រវាត់សេចក្តីពិតនៅចង្កេះ » រួចសរសេរចម្លើយនៅលើក្រដាសឯកសារបស់ពួកគេ ។

សូមពន្យល់ថា គ្រឿងសឹកដែល « ក្រវាត់ » នឹងចង្កេះគឺជាខ្សែក្រវាត់ដែលរុំផ្នែកកណ្តាលនៃរាងកាយ ។ បន្ទាប់មក សូមឲ្យសិស្សបីបួននាក់ប្រាប់ចម្លើយរបស់ពួកគេដល់មិត្តរួមថ្នាក់ ។ សិស្សអាចប្រាប់ចម្លើយស្រដៀងគ្នានឹងឃ្លាខាងក្រោម ៖ (១) វាប្រើដើម្បីបិទបាំងចង្កេះ (សរីរាង្គដ៏សំខាន់សម្រាប់បង្កើតកូន) ។ (២) ប៉ុលបានហៅវាថាជា « សេចក្តីពិត » ។ (៣) វាតំណាងឲ្យព្រហ្មចារីភាព ឬបរិសុទ្ធភាពខាងសីលធម៌របស់យើង ។ (៤) ការដឹងពីសេចក្តីពិតពេញលេញនៃផែនការនៃសេចក្តីសង្គ្រោះអាចការពារយើងពីការបោកបញ្ឆោត ហើយជួយយើងឲ្យបន្តមានភាពបរិសុទ្ធខាងសីលធម៌ ។

សូមអញ្ជើញសិស្សឲ្យធ្វើតាមគន្លងនេះ នៅពេលពួកគេអាន អេភេសូរ ៦:១៤–១៨ ជាមួយក្រុមរបស់ខ្លួន ហើយបំពេញផ្នែកនៃឯកសារ ដែលភ្ជាប់មកជាមួយនឹងបំណែកគ្រឿងសឹកដែលពួកគេបានចាត់ឲ្យ ។ (សូមពន្យល់ថា ការពាក់ « ទុកជាស្បែកជើង » [ខទី ១៥] មានន័យថាការពាក់ស្បែកជើង ឬគ្រឿងការពារជើងផ្សេងទៀត) ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរអញ្ជើញអ្នកតំណាងម្នាក់មកពីក្រុមនីមួយៗឲ្យប្រាប់អំពីអ្វីដែលពួកគេបានរៀនទៅដល់សិស្សក្នុងថ្នាក់ ។ នៅពេលក្រុមនីមួយៗប្រាប់ពីអ្វីដែលពួកគេបានរៀនហើយ សូមអញ្ជើញសិស្សឲ្យកត់ត្រាការរកឃើញរបស់ក្រុមនោះនៅក្នុងឯកសាររបស់ពួកគេ ។

- ហេតុអ្វីការការពារខ្លួនយើងដោយពាក់ *គ្រប់* ទាំងគ្រឿងសឹករបស់ព្រះ វាគឺជារឿងដ៏សំខាន់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សស្តាប់មើលពីរបៀបដែលយើងពាក់ ហើយពង្រឹងគ្រឿងសឹករបស់ព្រះ ។

« តើយើងពាក់គ្រប់ទាំងគ្រឿងសឹករបស់ព្រះដោយរបៀបណា ដើម្បីឲ្យយើងអាច ‹ ទប់ទល់ក្នុងថ្ងៃអាក្រក់បាន › ដូចដែលប៉ុលបានសន្យា ?

« ខ្ញុំចូលចិត្តគិតអំពីគ្រឿងសឹកខាងវិញ្ញាណនេះ ដែលវាពុំដូចជាបំណែកនៃការសូន្យលោហៈជាតុមួយដុំឡើង ដើម្បីពាក់ឲ្យត្រូវនឹងរូបកាយឡើយ ប៉ុន្តែវាដូចជាច្រវាក់ប្រទាក់គ្នាទៅវិញ ។ ច្រវាក់ប្រទាក់គ្នា មាននូវចំណែកវង្វង់កងដៃតូចល្អិតៗរាប់រយវេញបញ្ចូលគ្នា ដើម្បីអនុញ្ញាតឲ្យអ្នកប្រើអាចបត់បែនបានកាន់តែល្អដោយមិនបាត់នូវការការពារ ។ ខ្ញុំនិយាយដូច្នោះ ដោយសារវាជាបទពិសោធន៍របស់ខ្ញុំ ថាគ្មានអ្វីធំធំ និងអស្ចារ្យដែលយើងអាចធ្វើ ដើម្បីការពារខ្លួនយើងខាងវិញ្ញាណឡើយ ។ អំណាចខាងវិញ្ញាណពិត ពឹងលើទង្វើតូចតាចជាច្រើនវេញបញ្ចូលគ្នាទៅជាសាច់ក្រណាត់នៃការការពារខាងវិញ្ញាណដែលការពារ និងជាខែលទាស់នឹងសេចក្តីអាក្រក់គ្រប់បែបយ៉ាង » (« Be Strong in the Lord » *Ensign* ខែ កក្កដា ឆ្នាំ ២០០៤ ទំព័រ ៨) ។

- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីពាក់ ហើយពង្រឹងគ្រឿងសឹករបស់ព្រះជារៀងរាល់ថ្ងៃ ?
- តើការណ៍នេះបានជួយអ្នកឲ្យទប់ទល់នឹងអំពើអាក្រក់ ការល្បួង ឬការបោកបញ្ឆោតដោយរបៀបណា ?

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យឆ្លើយសំណួរទាំងនេះក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

តើគ្រឿងសឹកខាងវិញ្ញាណរបស់អ្នកផ្នែកមួយណា ដែលអ្នកគិតថាមានភាពរឹងមាំ ?

តើគ្រឿងសឹករបស់អ្នកផ្នែកមួយណាដែលខ្សោយបំផុត ?

តើអ្នកអាចធ្វើអ្វីខ្លះដើម្បីពង្រឹងផ្នែកនីមួយៗនៃគ្រឿងសឹកខាងវិញ្ញាណនៅក្នុងជីវិតរបស់អ្នក ?

សូមសង្ខេប អេភេសូរ ៦:១៩–២៤ ដោយពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោក ដោយសុំឲ្យពួកបរិសុទ្ធអធិស្ឋានឲ្យលោកទទួលបាននូវ « ពាក្យសម្តី » (ខទី ១៩) ហើយអាចប្រកាសដំណឹងល្អដោយភាពក្លាហានកាលកំពុងជាប់ឃុំ ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត ដែលបានបង្ហាញនៅក្នុងមេរៀនថ្ងៃនេះ ហើយលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសគំនិតដែលពួកគេអាចទទួលបាន ។

មេរៀនបន្ទាប់ (កូល៉ុស–ធីម៉ូថេទី ១)

សូមអញ្ជើញសិស្សរកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ នៅពេលពួកគេបន្តសិក្សាពីការសរសេរបស់ប៉ុលនៅសប្តាហ៍ក្រោយ ។ តើប៉ុលបាននិយាយអ្វីខ្លះពីការស្រឡាញ់ប្រាក់ ? តើយើងអាចចៀសវាងពីការបោកបញ្ឆោតដោយទម្លាប់ខុសឆ្គង ដោយរបៀបណា ? យោងតាមប៉ុល តើអ្វីទៅដែលត្រូវកើតឡើងពីមុនការយាងមកជាលើកទីពីរ ? តើយើងនឹងដឹងថា វាបានកើតឡើងតាមរបៀបណា ?

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់កូល៉ុស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

ប៉ុលបានសរសេរសំបុត្ររបស់លោកទៅដល់ពួកកូល៉ុស ដោយសារបាយការណ៍មួយថា ពួកគេកំពុងធ្លាក់ចូលទៅក្នុងកំហុសដ៏ធ្ងន់ធ្ងរ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ ការបង្រៀន និងទម្លាប់ខុសឆ្គងនៅកូល៉ុស កំពុងតែជះឥទ្ធិពលទៅលើពួកបរិសុទ្ធនៅទីនោះ ហើយកំពុងតែគំរាមកំហែងដល់សេចក្តីជំនឿរបស់ពួកគេ ។ សម្ពាធខាងវប្បធម៌ស្រដៀងគ្នានេះដែរ បង្កើតជាការប្រឈមចំពោះសមាជិកសាសនាចក្រនាសព្វថ្ងៃនេះ ។ ផ្នែកមួយនៃតម្លៃរបស់សំបុត្រនេះគឺជារបៀបដែលវាបង្ហាញ ហើយពន្យល់ពីភាពខុសឆ្គងការគួសបញ្ជាក់ពីទេវភាព និងកិច្ចការសង្គ្រោះរបស់ព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈការសិក្សាគម្ពីរកូល៉ុស សិស្សអាចមានការប្រែចិត្តជឿកាន់តែខ្លាំងទៅលើព្រះអង្គសង្គ្រោះ ហើយទទួលបានកិច្ចការពារពីការបោកបញ្ឆោត និងអំពើបាប ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុល និងធីម៉ូថេបានផ្ញើសំបុត្រដល់ពួកកូល៉ុស (សូមមើល កូល៉ុស ១:១, ២៣, ៤:១៨) ។ ប៉ុលទំនងជាសរសេរពាក្យជំរាបសួររបស់លោកដោយផ្ទាល់នៅចុងបញ្ចប់នៃសំបុត្រនេះ (សូមមើល កូល៉ុស ៤:១៨) ដោយចង្អុលបង្ហាញថា អ្នកសរសេរប្រហែលជាធីម៉ូថេ ដែលបានជួយលោកនៅក្នុងការសរសេរតួសេចក្តីនៃសំបុត្រនោះ ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ប៉ុលបានសរសេរសំបុត្រនេះនៅក្នុងការជាប់ឃុំលើកដំបូងរបស់លោកនៅរ៉ូម ប្រមាណជា គ.ស. ៦០–៦២ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។ ប៉ុលប្រហែលជាបានសរសេរសំបុត្រដល់ពួកកូល៉ុសប្រហាក់ប្រហែលនឹងពេលដែលលោកសរសេរសំបុត្រដល់ពួកកីលីព អេភេសូរ និងកីលេម៉ូនដែរ ។

តើគម្ពីរនេះត្រូវបានសរសេរចំពោះនរណា ហើយតើហេតុអ្វី ?

សំបុត្រនេះបានសរសេរទៅពួកបរិសុទ្ធស្មោះត្រង់នៅកូល៉ុស ដែលជាតំបន់មួយនៅប្រទេសតួកគីនៅសម័យបច្ចុប្បន្ននេះ ។ ប៉ុលបានណែនាំពួកបរិសុទ្ធនៅកូល៉ុស ឲ្យចែកចាយសំបុត្រនេះជាមួយនឹងសមាជិកសាសនាចក្រនៅក្បែរក្រុងឡៅឌីសេដែរ (សូមមើល កូល៉ុស ៤:១៦) ។

ប៉ុលបានសរសេរសំបុត្រនេះ « ក្រោយពីលោកអេប៉ាប្រាស ជាគ្រូគង្វាលនៃសាសនាចក្រ [កូល៉ុស] បានមកជួបនឹងលោក [សូមមើល កូល៉ុស ១:៧–៨] ។ អេប៉ាប្រាសប្រាប់ប៉ុលថា ពួកកូល៉ុសកំពុងតែធ្លាក់ទៅក្នុងកំហុសដ៏ធ្ងន់ — គេគិតថាខ្លួនគេគ្រាន់បើជាងមនុស្សឯទៀត ពីព្រោះគេកាន់តាមពិធីបរិសុទ្ធខាងក្រៅខ្លះៗ យ៉ាងខ្ជាប់ខ្ជួន [សូមមើល កូល៉ុស ២:១៦] ដោយបដិសេធនូវសេចក្តីប្រាថ្នាខាងសាច់ឈាមខ្លះ ហើយថ្វាយបង្គំពួកទេវតា [សូមមើល កូល៉ុស ២:១៨] ។ អំពើទាំងនេះធ្វើឲ្យពួកកូល៉ុសគិតថា ខ្លួនគេបានញែកចេញជាបរិសុទ្ធ ។ គេក៏គិតថា គេយល់នូវការអាថ៌កំបាំងនៃសាកលលោក ជាងសមាជិកដទៃទៀតក្នុងសាសនាចក្រ ។ នៅក្នុងសំបុត្រលោក នោះប៉ុលបានកែតម្រូវគេដោយបង្រៀនគេថា សេចក្តីប្រោសលោះបានមកតែតាមរយៈព្រះគ្រីស្ទប៉ុណ្ណោះ ហើយពួកយើងត្រូវមានប្រាជ្ញាវាងវៃ ហើយបម្រើទ្រង់ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « កូល៉ុស, សំបុត្រដល់ពួក » scriptures.lds.org) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

នៅក្នុងសំបុត្ររបស់ប៉ុលដល់ពួកកូល៉ុស ប៉ុលបានឆ្លើយតបនឹងការបង្រៀនខុសឆ្គងនៅក្នុងកូល៉ុសដោយគូសបញ្ជាក់ពីទេវភាព បេសកកម្មនៃសេចក្តីសង្គ្រោះ និងភាពខ្ពង់ខ្ពស់របស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល កូល៉ុស ១:១៥–២៣) ។ លោកបានបង្រៀនថា ព្រះគ្រីស្ទដែលមានរូបរាងដូចជាព្រះ ជាព្រះវរបិតា ព្រះបង្កបង្កើត សិរសានៃសាសនាចក្រ អង្គដំបូងដែលបានមានព្រះជន្មរស់ឡើងវិញ និងជាព្រះប្រោសលោះ ។ ទ្រង់គឺជា « សិរសាលើអស់ទាំងពួកគ្រប់គ្រង និងអំណាចទាំងប៉ុន្មាន » (កូល៉ុស ២:១០) ហើយទ្រង់បំពេញបេសកកម្មដ៏ទេវភាពរបស់ទ្រង់នៅក្រោមការដឹកនាំរបស់ព្រះវរបិតា (សូមមើល កូល៉ុស ១:១៩, ៣:១) ។

ប៉ុលបានព្រមានទាស់នឹងជនដែលបានបង្រៀនថា ជីវភាពខាងផ្លូវវិញ្ញាណពិតគឺបានទទួលតាមរយៈការធ្វើពិធីបុណ្យ និងរបបអាហារពិសេស (សូមមើល កូល៉ុស ២:១៦–១៨, ២០, ២៣) ។ លោកបានបង្រៀនជំនួសវិញថា ភាពធំធាត់ខាងវិញ្ញាណ និងចំណេះដឹងពីព្រះគឺបង្ហាញឡើងតាមរយៈការដាក់ « ចិត្តទៅឯសេចក្តីទាំងអស់ដែលនៅខាងលើ » (កូល៉ុស ៣:២) ដោយលុបបំបាត់ទង្វើទុច្ចរិតនានា (សូមមើល កូល៉ុស ៣:៥–៩) ហើយអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ (សូមមើល កូល៉ុស ៣:១២–១៧) ។ ប៉ុលបានប្រឹក្សាដល់ពួកអ្នកអានរបស់លោកឲ្យ « តាំងនៅជាប់លាប់ ហើយមាំមួន » ក្នុងជំនឿដ៏ល្អ (កូល៉ុស ១:២៣) រួមទាំង « ចាក់ឫស ហើយស្អាងឡើងក្នុង [ព្រះយេស៊ូវគ្រីស្ទ] ទាំងតាំងនៅខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿ » ផង (កូល៉ុស ២:៧) ។

គម្រោង

កូល៉ុស ១:១–២៣ ប៉ុលបានជំរាបសួរដល់ពួកបរិសុទ្ធនៅកូល៉ុស ហើយប្រកាសថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះ ជាបុត្រច្បងនៅក្នុងចំណោមនៃការបង្កបង្កើតមនុស្សលោក ជាព្រះបង្កបង្កើត និងជាព្រះអម្ចាស់នៃរាល់ភាពល្អឥតខ្ចោះ ជាអង្គដែលធ្វើឲ្យមានការផ្សះផ្សានៃសកលលោក ។ ប៉ុលជាស់តឿនពួកបរិសុទ្ធឲ្យស្ថាបនាសេចក្តីជំនឿរបស់ខ្លួនទៅលើព្រះយេស៊ូវគ្រីស្ទ ។

កូល៉ុស ១:២៤–២:២៣ ប៉ុលព្រមានទាស់នឹងការជឿលើទស្សនៈវិជ្ជា ឬប្រពៃណីនានាដែលខុសឆ្គងរបស់មនុស្ស រួមបញ្ចូលទាំងការថ្វាយបង្គំពួកទេវតា និងបដិសេធតម្រូវការមូលដ្ឋានខាងសាច់ឈាមរបស់បុគ្គលខ្លួនឯងហួសហេតុពេក ដើម្បីជាការដោះវិន័យខាងវិញ្ញាណ ។

កូល៉ុស ៣:១–៤:១៨ ប៉ុលបានជាស់តឿនពួកបរិសុទ្ធឲ្យដាក់ដួងចិត្តរបស់ពួកគេនៅលើរឿងទាំងអស់នៅខាងលើ ឲ្យលះបង់អំពើបាបនៅក្នុងជីវិតរបស់ពួកគេកាលពីមុន ហើយមានចិត្តមេត្តាដល់គ្នាទៅវិញទៅមក ។ លោកផ្តល់ការណែនាំអំពីរបៀបដែលពួកបរិសុទ្ធគួរថ្វាយបង្គំ រួចផ្តល់ការទុន្មានដល់ប្រពន្ធ ប្តី កូនៗ ឪពុកម្តាយ ពួកបាវបម្រើ និងពួកចៅហ្វាយទាំងឡាយ ។ លោកបានបញ្ចប់សំបុត្រដល់ពួកកូល៉ុសនេះដោយនឹងការសរសើរការជំរាបសួរ និងការណែនាំ និងពរជ័យចុងក្រោយផ្សេងៗ ។

កូល៉ុស

សេចក្តីផ្តើម

ប៉ុលបានបង្រៀនអំពីភាពខ្ពង់ខ្ពស់របស់ព្រះយេស៊ូវគ្រីស្ទ (ភាពឧត្តុង្គឧត្តម, ភាពអស្ចារ្យ ឬភាពវិសេសវិសាល) ហើយបានព្រមានទាស់នឹងគោលលទ្ធិខុសឆ្គង ។ លោកបានលើកទឹកចិត្តដល់ពួកបរិសុទ្ធនៅកូល៉ុសឲ្យជាក់សេចក្តីស្រឡាញ់របស់ពួកគេទៅលើរឿងខាងសូគ៌ា ហើយអភិវឌ្ឍចរិតលក្ខណៈដូចព្រះគ្រីស្ទ ។ ប៉ុលក៏បានណែនាំពួកគេឲ្យប្រកបដោយព្រះគុណ ហើយឈ្លាសវៃនៅក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃផងដែរ ។

ការប្រើប្រាស់ក្តារខៀន

ការប្រើក្តារខៀនដី–ស ឬក្តារខៀនហ្វឺត ឲ្យមានប្រសិទ្ធភាពអំឡុងពេលបង្រៀន អាចរៀបចំសិស្សឲ្យរៀន និងអញ្ជើញឲ្យមានការចូលរួមប្រកបដោយអត្ថន័យជាពិសេសសម្រាប់អ្នកទាំងឡាយណាដែលរៀនចូលដោយការមើលរូបភាព ។ នៅលើក្តារខៀន គ្រូបង្រៀនអាចសង្ខេបចំណុចសំខាន់ ឬគោលការណ៍ទាំងឡាយនៃមេរៀន គូសតារាងគោលលទ្ធិមួយ គូសផែនទី បង្កើតតារាង ដាក់តាំង ឬគូរូបនៃវត្ថុដែលមាននៅក្នុងខគម្ពីរ ឬធ្វើសកម្មភាពចម្រុះដទៃទៀតជាច្រើន ដែលនឹងអភិវឌ្ឍន៍ការរៀនសូត្រ ។

យោបល់សម្រាប់ការបង្រៀន

កូល៉ុស ១–២

ប៉ុលបង្រៀនអំពីភាពខ្ពង់ខ្ពស់របស់ព្រះយេស៊ូវគ្រីស្ទ ហើយបានព្រមានទាស់នឹងគោលលទ្ធិខុសឆ្គង

សូមគូរូបភាពដូចខាងក្រោមនេះនៅលើក្តារខៀន ។

- **ប្រសិនបើមានខ្យល់គួចខ្លាំងមកដល់ តើដើមឈើទាំងនេះមួយណា ដែលនឹងទំនងជារលំដួល ? ហេតុអ្វី ?**


សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឲ្យឮៗមកពីអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា ខ្យល់គួចអ្វីដែលយើងចាំបាច់ត្រូវប្រុងប្រយ័ត្ន ។

« កង្វល់ដែលធំជាងការរញ្ជួយដី និងសង្គ្រាមដែលបានព្យាករណ៍ទុកទៅទៀតនោះគឺ ខ្យល់គួចខាងវិញ្ញាណដែលអាចផ្តាច់អ្នកចេញពីគ្រឹះខាងវិញ្ញាណរបស់អ្នក ហើយដាក់វិញ្ញាណអ្នកឲ្យនៅទីកន្លែង ដែលអ្នកនឹកស្មានមិនដល់ ពេលខ្លះអ្នកមិនបានទាំងដឹងខ្លួនថា អ្នកត្រូវបានផ្តាច់ចេញឡើយ (« Spiritual Whirlwinds » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ១៨) ។

- **តើឧទាហរណ៍មួយចំនួនអំពីខ្យល់គួចខាងវិញ្ញាណអ្វីខ្លះ ដែលអាចដក ឬបំបែកយើងឲ្យចេញពីសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ? (អ្នកអាចនឹងចង់អញ្ជើញឲ្យសិស្សសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀនជិតនឹងគំនូរខ្យល់គួច) ។**
- **ហេតុអ្វីក៏ខ្យល់គួចខាងវិញ្ញាណទាំងនេះ អាចមានបញ្ហាខ្លាំងជាងឧបសគ្គខាងរូបកាយ ដូចជាការរញ្ជួយដី ឬសង្គ្រាមដូច្នេះ ?**

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីខ្យល់គួចខាងវិញ្ញាណអ្វីខ្លះ ដែលអាចនឹងជះឥទ្ធិពលដល់ពួកគេ ។

ចូរពន្យល់ថា ប៉ុលបានសរសេរសំបុត្រមួយទៅកាន់សមាជិកសាសនាចក្រនៅក្រុងកូល៉ុស (សំដៅទៅលើប្រជាជនកូល៉ុស) បន្ទាប់ពីបានដឹងអំពីឥទ្ធិពល និងការបង្រៀនខុសឆ្គងនៅទីនោះ ដែលបានគម្រាមគំហែងដើម្បីផ្តាច់ពួកគេចេញពីសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ (អ្នកអាចនឹងចង់អញ្ជើញឲ្យសិស្សរកទីតាំង ក្រុងឡៅឌីសេ ដែលនៅមិនឆ្ងាយប៉ុន្មានពីភាគខាងលិចនៃក្រុងកូល៉ុស នៅលើផែនទីក្នុងព្រះគម្ពីរ ល.រ. ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា ») ។ សូមអញ្ជើញសិស្សឲ្យរកមើលពីរបៀប ដែលប៉ុលបានព្យាយាមពង្រឹងសេចក្តីជំនឿលើព្រះគ្រីស្ទរបស់សមាជិកសាសនាចក្រ និងពរជ័យនៃការមានគ្រឹះនៃសេចក្តីជំនឿរឹងមាំលើព្រះគ្រីស្ទនៅពេលពួកគេសិក្សាគម្ពីរកូល៉ុស ។



សូមសង្ខេប កូល៉ុស ១:៩–១១ដោយពន្យល់ថា បន្ទាប់ពីការជម្រាបសួរដល់ពួកបរិសុទ្ធនៅក្រុងកូល៉ុសហើយ ប៉ុលបានទទួលស្គាល់សេចក្តីស្មោះត្រង់របស់ពួកគេ ហើយបានពន្យល់ថា ដំណឹងល្អនាំមកនូវផលផ្លែ ឬពរជ័យនៅក្នុងជីវិតនៃអ្នកទាំងឡាយណាដែលទទួលយក ហើយរស់នៅតាមដំណឹងល្អ ។ បន្ទាប់មក ប៉ុលបានបង្រៀនពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង កូល៉ុស ១:១២–១៩ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសេចក្តីពិតដែលប៉ុលបានបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ (អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ « មើលមិនឃើញ » នៅក្នុងខទី ១៥ត្រូវបានបកប្រែមកពីភាសាក្រិច ពាក្យ *aoratos* ដែលអាចមានន័យថា « មើលមិនឃើញ » ផងដែរ ។ សូមកត់ចំណាំថា ហេព្រើរ ១១:២៧បញ្ជាក់ថា ម៉ូសេបានឃើញ « ព្រះដ៏មើលមិនឃើញ » មានន័យថាតាមធម្មតាគឺមើលមិនឃើញ [សូមមើលផងដែរគ. និងស. ៦៧:១១]) ។

- **តើប៉ុលបានបង្រៀនអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ? (សូមសរសេរសេចក្តីពិតនៅលើក្តារខៀន ក្រោមដើមឈើ ដែលមានឫសចាក់យ៉ាងជ្រៅ ដោយប្រើពាក្យសម្តីរបស់សិស្ស) ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះ ជាបុត្រច្បងខាងវិញ្ញាណរបស់ព្រះអបិតាសួគ៌ ជាព្រះបង្កបង្កើតរបស់សព្វសារពើ ជាសិរសានៃសាសនាចក្រ និងជាគ្រឹះអង្គដំបូងគេបង្អស់ដែលបានរស់ឡើងវិញ) ។**
- **ហេតុអ្វីក៏អ្នកគិតថា វាសំខាន់សម្រាប់យើងដើម្បីដឹង ហើយជឿលើសេចក្តីពិតទាំងនេះអំពីព្រះយេស៊ូវគ្រីស្ទ? តើការដឹង និងការស្គាល់សេចក្តីពិតទាំងនេះអាចពង្រឹងដល់សេចក្តីជំនឿរបស់យើងទៅលើទ្រង់យ៉ាងដូចម្តេច ?**

សូមយោងទៅពាក្យ *ព្រះប្រោសលោះ*នៅក្នុងសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ហើយពន្យល់ថា ប៉ុលបានរំឭកដល់ពួកបរិសុទ្ធនៅកូល៉ុស អំពីមូលហេតុដែលពួកគេត្រូវការព្រះប្រោសលោះមួយអង្គ ។

សូមអញ្ជើញសិស្សម្នាក់អាន កូល៉ុស ១:២០–២២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធនៅកូល៉ុសអំពីការត្រូវការព្រះប្រោសលោះរបស់ពួកគេ ។

- យោងតាមខទី ២១ តើនរណាម្នាក់អាចត្រូវពង្រាត់ចេញ ឬបំបែកចេញពីព្រះយ៉ាងដូចម្តេច ?
- តើពាក្យ *ផ្សះផ្សា* នៅក្នុង ខទី ២០ មានន័យយ៉ាងណា ? (ដើម្បីនាំមកនូវការចុះសម្រុង ឬសុខដុមរមនាវិញ) ។
- យោងតាមខទី ២០និង២២តើព្រះយេស៊ូវគ្រីស្ទផ្សះផ្សាយើងនឹងព្រះយ៉ាងដូចម្តេច ? (ចូរពន្យល់ថា ឃ្លា « តាំងស្ពានមេត្រីដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់ » សំដៅទៅលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ) ។

ចូរពន្យល់ថា ពរជ័យនៃការផ្សះផ្សានឹងព្រះមានលក្ខខណ្ឌ ។ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *យើងអាចត្រូវបានផ្សះផ្សានឹងព្រះ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រសិនបើ. . .*

សូមអញ្ជើញសិស្សម្នាក់អាន កូល៉ុស ១:២៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលតម្រូវឲ្យធ្វើ ដើម្បីបានផ្សះផ្សានឹងព្រះ ។

- តើវាតម្រូវឲ្យមានអ្វីខ្លះនៅចំណែករបស់យើងដើម្បីបានផ្សះផ្សានឹងព្រះ ?
- តើពាក្យ « បានតាំងនៅជាប់លាប់ ហើយមាំមួននៅក្នុងសេចក្តីជំនឿ » មានន័យយ៉ាងណាចំពោះយើង ? (ដើម្បីបន្តនៅខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ) ។
- ផ្អែកលើអ្វីដែលយើងបានរៀនមកពី ខទី ២៣ តើអ្នកនឹងបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀនយ៉ាងដូចម្តេច ? (សូមបំពេញគោលការណ៍ដូចខាងក្រោមនេះនៅលើក្តារខៀនដោយប្រើពាក្យរបស់សិស្ស ៖ **យើងអាចត្រូវបានផ្សះផ្សានឹងព្រះ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រសិនបើយើងបានតាំងនៅជាប់លាប់ ហើយមាំមួននៅក្នុងសេចក្តីជំនឿរបស់យើង**) ។

ចូរបង្ហៃអារម្មណ៍របស់សិស្សមកផ្តោតលើគំនូរនៅលើក្តារខៀន ហើយសួរថា

- តើអ្នកស្គាល់នរណាម្នាក់ទៀត ដែលប្រៀបដូចជាដើមឈើដែលមានឫសចាក់ជ្រៅ— ដែលបានតាំងនៅជាប់លាប់ ហើយមាំមួននៅក្នុងសេចក្តីជំនឿរបស់ពួកគេឬទេ ?
- តើគំរូរបស់ពួកគេគ្លាយជាពរជ័យដល់អ្នកយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យអានកូល៉ុស ២:៤, ៨ដោយស្ងាត់ស្ងៀម ហើយរកមើលខ្យល់គួចខាងវិញ្ញាណដែលគម្រាមគំហែងដកពួកបរិសុទ្ធនៅកូល៉ុសឲ្យអស់ទាំងឫស ។

- តើខ្យល់គួចខាងវិញ្ញាណដែលបានគម្រាមគំហែងដកពួកបរិសុទ្ធនៅកូល៉ុសឲ្យអស់ទាំងឫសមានអ្វីខ្លះ ? (សូមពន្យល់ថា មានទស្សនវិជ្ជា និងទំនៀមទម្លាប់ជាច្រើនត្រូវបានបង្រៀនដោយមនុស្សមួយចំនួន ដែលកំពុងព្យាយាមកាត់បន្ថយសារៈសំខាន់របស់ព្រះយេស៊ូវគ្រីស្ទ) ។
- ហេតុអ្វីក៏ការជឿទៅលើការបង្រៀនខុសឆ្គង រួមមានទាំងការបង្រៀនដែលកាត់បន្ថយសារៈសំខាន់របស់ព្រះយេស៊ូវគ្រីស្ទ ធ្វើឲ្យវាងាយស្រួលក្នុងការដកទាំងឫសខាងវិញ្ញាណរបស់នរណាម្នាក់ដូច្នេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន កូល៉ុស ២:៥–៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការទូន្មានរបស់ប៉ុលផ្តល់ទៅឲ្យពួកបរិសុទ្ធ ដើម្បីជួយពួកគេឲ្យចៀសវាងពីការដឹកនាំឲ្យវង្វេងដោយទស្សនវិជ្ជា និងទំនៀមទម្លាប់ខាងលោកិយនានា ។

- តើកូល៉ុស ២:៥–៧បង្រៀនអ្វីខ្លះ ដែលអាចជួយយើងឲ្យចៀសវាងពីការដឹកនាំឲ្យវង្វេង ដោយសារតែទស្សនវិជ្ជាខាងលោកិយ ការបង្រៀនខាងសាសនា ឬទំនៀមទម្លាប់ទាំងឡាយនោះ ? (សិស្សអាចនឹងប្រើពាក្យផ្ទាល់ខ្លួន ដើម្បីប្រាប់ពីគោលការណ៍មួយដែលស្រដៀងនឹងគោលការណ៍ខាងក្រោមនេះ ៖ **តាមរយៈការចាក់ឫស ហើយរឹងមាំនៅក្នុងព្រះយេស៊ូវគ្រីស្ទ យើងអាចចៀសវាងពីការដឹកនាំឲ្យវង្វេងដោយទស្សនវិជ្ជា និងទំនៀមទម្លាប់ខាងលោកិយ**) ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើអ្នកជឿថា អ្វីខ្លះគឺជារឿងដ៏សំខាន់បំផុតមួយ ដែលយើងអាចធ្វើដើម្បីចាក់ឫស ហើយរឹងមាំនៅក្នុងព្រះយេស៊ូវគ្រីស្ទ ? ហេតុអ្វីអ្នកជឿថា រឿងមួយនេះគឺសំខាន់ខ្លាំងដូច្នេះ ?

សូមបំបែកសិស្សជាក្រុមដែលមានគ្នាបី ឬបួននាក់ ។ សូមអញ្ជើញសិស្សម្នាក់ៗ ឲ្យពន្យល់អំពីចម្លើយរបស់ពួកគេចំពោះសំណួរនៅលើក្តារខៀនទៅដល់សមាជិកក្រុម ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីអ្វីដែលពួកគេបានរៀនពីសមាជិកក្រុម ។

សូមអញ្ជើញសិស្សឲ្យរំឭកមើលខ្យល់គួចខាងវិញ្ញាណផ្ទាល់ខ្លួន ដែលពួកគេបានពិចារណាតាំងពីដើមមេរៀនមក ។ សូមអញ្ជើញពួកគេឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីដែលពួកគេនឹងធ្វើដើម្បីបន្តចាក់ឫស ហើយស្ថាបនាយ៉ាងរឹងមាំនៅក្នុងព្រះយេស៊ូវគ្រីស្ទ ហើយចៀសវាងពីការដកទាំងឫសដោយសារខ្យល់គួចខាងវិញ្ញាណ ។

កូល៉ុស ៣–៤

ប៉ុលបានលើកទឹកចិត្តដល់ពួកកូល៉ុសឲ្យដាក់សេចក្តីស្រឡាញ់របស់ពួកគេទៅលើរឿងខាងសួគ៌ា ហើយឈ្លាសវៃ

សូមសង្ខេបកូល៉ុស ៣–៤ដោយពន្យល់ថា ប៉ុលបានដាស់តឿនដល់ពួកបរិសុទ្ធនៅកូល៉ុសឲ្យឈប់ពីសេចក្តីមិនសុចរិត ហើយអភិវឌ្ឍចរិតលក្ខណៈដូចព្រះយេស៊ូវគ្រីស្ទ ។ លោកក៏បានលើកទឹកចិត្តពួកគេឲ្យអធិស្ឋាន និងឈ្លាសវៃ ជាពិសេសនៅក្នុងការប្រាស្រ័យទាក់ទងរបស់ពួកគេជាមួយនឹងអ្នកដែលពុំមែនជាគ្រីស្ទសាសនិកផងដែរ ។ បន្ទាប់មក លោកបានបន្តជម្រាបសួរដល់ពួកអ្នកបម្រើដែលជាបងប្អូនលោកជាច្រើនទៀត រួមមានទាំងលូកាផងដែរ ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយ ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

សេចក្តីផ្តើមអំពី

សំបុត្រទីមួយរបស់ប៉ុលដល់ពួកថែស្សាឡូនិច

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រទីមួយដល់ពួកថែស្សាឡូនិចត្រូវបានគេជឿថាជាសំបុត្រដំបូងគេបង្អស់របស់ប៉ុល ហើយជាគម្ពីរចាស់ជាងគេបង្អស់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ការបង្រៀនរបស់ប៉ុលនៅក្នុងសំបុត្រនេះផ្តោតសំខាន់ទៅលើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ រួមមាននូវការលំបាកដែលពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទនឹងជួបប្រទះ: មុននឹងការយាងមករបស់ទ្រង់ (សូមមើល ថែស្សាឡូនីចទី ១ ៣:៣) ការរស់ឡើងវិញរបស់ពួកគ្រីស្ទាននៅឯការយាងមកជាលើកទីពីរ (សូមមើល ថែស្សាឡូនីចទី ១ ៤:១៣–១៤) និងកាលវេលានៃការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ (សូមមើល ថែស្សាឡូនីចទី ១ ៥:១–២) ។ តាមរយៈការសិក្សារបស់ពួកគេនៅក្នុងគម្ពីរនេះ: សិស្សនឹងរៀនពីការយាងមកជាលើកទីពីរ ហើយទទួលបានការលើកទឹកចិត្តដើម្បីបន្តមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុលបានសរសេរគម្ពីរថែស្សាឡូនីចទី ១ (សូមមើល ថែស្សាឡូនីចទី ១ ១:១ សូមមើលផងដែរ ២:១៨) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

« ប៉ុលបានសរសេរសំបុត្រដល់ពួកថែស្សាឡូនីច កាលលោកនៅកូរិនថូសក្នុងដំណើរផ្សព្វផ្សាយសាសនាជាលើកទីពីររបស់លោក » ប្រមាណជា គ.ស. ៥០–៥១ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។

តើគម្ពីរនេះត្រូវបានសរសេរចំពោះនរណា ហើយតើហេតុអ្វី ?

ប៉ុលបានសរសេរថែស្សាឡូនីចទី ១ ដល់សមាជិកសាសនាចក្រនៅថែស្សាឡូនិច ។ ថែស្សាឡូនិចគឺជាទីក្រុងមួយដ៏ល្បីឈ្មោះ ហើយចំរុងចម្រើនបំផុតនៅក្នុងនគរក្រិកកាលពីបុរាណនៃម៉ាសេដូន ដោយសារកត្តាសំខាន់ពីរយ៉ាង ៖ ទីក្រុងនោះបានសង់ឡើងនៅលើឆ្នេរសមុទ្រដែលមានធម្មជាតិល្អបំផុតនៅក្នុងសមុទ្រអាដ្រីអាន់ ហើយវាមានទីតាំងនៅលើវិថីធំដែលភ្ជាប់ទៅនឹងទីក្រុងរ៉ូម និងទ្វីបអាស៊ី ។

នៅក្នុងដំណើរផ្សព្វផ្សាយសាសនាជាលើកទីពីររបស់ប៉ុល ព្រះវិញ្ញាណបានដឹកនាំប៉ុល និងដៃគូលោក—ស៊ីឡាស, ធីម៉ូថេ និងលូកា—ឲ្យធ្វើដំណើរឆ្លងកាត់សមុទ្រអេជីអាន់ចូលទៅក្នុងស្រុកម៉ាសេដូនី (សូមមើល កិច្ចការ ១៦:៦–១២) ។ ដំណើរនេះបានចាប់ផ្តើមការប្រកាសដំណឹងល្អនៅអឺរ៉ុប ។ បន្ទាប់ពីការប្រកាសដំណឹងល្អនៅកីលីពមក (សូមមើល កិច្ចការ ១៦:១២–៤០) ប៉ុល និងស៊ីឡាសបានធ្វើដំណើរទៅថែស្សាឡូនីច ។

ប៉ុលបានធ្វើការជាមួយនឹងស៊ីឡាសនៅថែស្សាឡូនីច ប៉ុន្តែពួកគាត់ត្រូវពួកអ្នកដឹកនាំយូដាបណ្តេញចេញពីទីក្រុងនោះ: (សូមមើល កិច្ចការ ១៧:១–៩) ។ ក្រោយមកទៀត ធីម៉ូថេបានរាយការណ៍ប្រាប់ប៉ុលថា ពួកបរិសុទ្ធនៅថែស្សាឡូនីចបានបន្តនៅស្មោះត្រង់ ទោះបីជាមានការបៀតបៀនយ៉ាងណាក្តី ហើយក៏ប្រាប់ថា ឥទ្ធិពលសុចរិតរបស់ពួកគេកំពុងតែរីកសាយភាយ (សូមមើល កិច្ចការ ១៨:៥, ថែស្សាឡូនីចទី ១ ១:៧–៨, ៣:៦–៨) ។

ពួកអ្នកប្រែចិត្តជឿនៅថែស្សាឡូនីចគឺជាពួកអឺរ៉ុបមួយចំនួនដំបូងដែលបានទទួលយកដំណឹងល្អ ហើយជាលទ្ធផលពួកគេបានជួបនឹងការបៀតបៀន ។ ពួកគេក៏មានសំណួរជាច្រើនអំពីការយាងមកជាលើកទីពីរផងដែរ ។ ហេតុដូច្នេះហើយ នៅក្នុងសំបុត្ររបស់លោកដល់ថែស្សាឡូនីច ប៉ុលបានសរសេរពាក្យលើកទឹកចិត្ត និងបានពង្រឹងពួកគេ ហើយបានឆ្លើយនឹងសំណួររបស់ពួកគេអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ប្រធានបទសំខាន់មួយនៅក្នុងសំបុត្រដំបូងរបស់លោកដល់ថែស្សាឡូនីចគឺការយាងមកជាលើកទីពីរ ។ លោកបានផ្តោតលើការចូលរួមរបស់ពួកសុចរិតនៅក្នុងព្រឹត្តិការណ៍នៃការយាងមកជាលើកទីពីរ ជាពិសេសពួកបរិសុទ្ធដែលបានចែកឋានទៅកាលពីមុន (សូមមើល ថែស្សាឡូនីចទី ១ ២:១៩, ៣:១៣, ៤:១៣–១៧, ៥:១–១០) ។ មិនដូចជាសំបុត្ររបស់ប៉ុលជាច្រើនផ្សេងទៀតឡើយ ថែស្សាឡូនីចទី ១ គ្មាននូវការស្តីបន្ទោសធ្ងន់ធ្ងរណាមួយទេ ប៉ុន្តែផ្ទុយទៅវិញមានតែពាក្យកោតសរសើរចំពោះពួកបរិសុទ្ធនៅថែស្សាឡូនិច ។

គម្រោង

ថែស្សាឡូនីចទី ១ ១–៣ ប៉ុលបង្ហាញការដឹងគុណចំពោះពួកបរិសុទ្ធនៅថែស្សាឡូនីច ។ លោកកត់ឮពួកអ្នកអានរបស់លោកអំពីការងារបម្រើដ៏សប្បុរសរបស់លោកដល់ពួកគេ ហើយបង្ហាញអំណរចំពោះភាពស្មោះត្រង់របស់ពួកគេ ។ លោកលើកទឹកចិត្តពួកបរិសុទ្ធឲ្យបង្កើនសេចក្តីស្រឡាញ់ចំពោះគ្នា និងចំពោះមនុស្សទាំងអស់ ។

ថែស្សាឡូនីចទី ១ ៤–៥ ប៉ុលប្រាប់ពួកបរិសុទ្ធឲ្យមានចិត្តបរិសុទ្ធ ហើយធ្វើឲ្យខ្លួនឯងបានបរិសុទ្ធ ។ លោកពន្យល់ថា នៅពេលព្រះអម្ចាស់យាងមកម្តងទៀត ពួកបរិសុទ្ធដែលស្មោះត្រង់នៅក្នុងទីបន្ទាល់ខ្លួនអំពីព្រះគ្រីស្ទទាំងជនដែលបានចែកឋានទៅ និងជនដែលនៅរស់ទាំងឡាយ នឹងក្រោកឡើង ហើយជួបនឹងព្រះអម្ចាស់ ។ សារករុបនេះរំឭកសមាជិកសាសនាចក្រឲ្យត្រៀមខ្លួនហើយទន្ទឹងរង់ចាំថ្ងៃនៃការយាងមករបស់ព្រះគ្រីស្ទ ។

មេរៀន ១២៧

ថែស្សាឡូនីចទី១ ១–២

សេចក្តីផ្តើម

ប៉ុលបានសរសេរទៅកាន់ពួកបរិសុទ្ធនៅថែស្សាឡូនីច បន្ទាប់ពីបានដឹងថា ពួកគេបានស្មោះត្រង់ចំពោះដំណឹងល្អនៅកណ្តាលសេចក្តីបៀតបៀន ។ លោកបានសរសើរដល់សេចក្តីស្មោះត្រង់ និងឆន្ទៈដើម្បីបង្រៀនដំណឹងល្អរបស់ពួកគេ ។ ប៉ុលបានពិពណ៌នាអំពីមូលហេតុ ដែលលោកបានផ្ញើរទៅកាន់ពួកបរិសុទ្ធនៅថែស្សាឡូនីច ។

យោបល់សម្រាប់ការបង្រៀន

ថែស្សាឡូនីចទី១ ១

ប៉ុលសរសើរដល់សេចក្តីស្មោះត្រង់របស់ពួកបរិសុទ្ធនៅថែស្សាឡូនីចក្នុងការរងទុក្ខរបស់ខ្លួន

សូមអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍វិជ្ជមានដែលពួកគេមាន ខណៈពេលកំពុងព្យាយាមចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ។

- **តើឧបសគ្គមួយចំនួនដែលយើងអាចជួប នៅពេលយើងព្យាយាមចែកចាយដំណឹងល្អមានអ្វីខ្លះ ?**

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាថែស្សាឡូនីចទី១ ១–២ ដែលអាចជួយពួកគេនៅក្នុងការខិតខំចែកចាយដំណឹងល្អរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យរកមើលថែស្សាឡូនីច នៅក្នុងផែនទីព្រះគម្ពីរប៊ីបលេខ ១៣ « ដំណើរទាំងឡាយដែលសាវកប៉ុលទៅផ្សាយសាសនា »មាននៅក្នុងសេចក្តីបន្ថែមព្រះគម្ពីរប៊ីប ។ ចូរសុំសិស្សម្នាក់ឲ្យអានឮៗនូវការពិពណ៌នាអំពីពួកបរិសុទ្ធនៅក្នុងក្រុងថែស្សាឡូនីចដូចខាងក្រោម ៖

ពួកបរិសុទ្ធនៅក្រុងថែស្សាឡូនីច មានមួយចំនួនគឺជាអ្នកថ្លាស់ប្រែចិត្តជឿជនជាតិអ៊ីរ៉ុបជំនាន់ដើម ដែលចូលមកក្នុងសាសនាចក្រ ។ ប៉ុល ស៊ីឡាស និងធីម៉ូថេ បានផ្សាយដំបូងគេនៅទីនោះ អំឡុងពេលការធ្វើដំណើរផ្សព្វផ្សាយសាសនាជាលើកទីពីររបស់ប៉ុល ប៉ុន្តែត្រូវបានបណ្តេញចេញពីទីក្រុង ដោយពួកអ្នកដឹកនាំសាសន៍យូដាមួយចំនួន (សូមមើល កិច្ចការ ១៧:៥–១៥) ។ ពួកបរិសុទ្ធថែស្សាឡូនីចត្រូវបានគេបៀតបៀនជាបន្តបន្ទាប់ ទោះបីជាបន្ទាប់ពីពេលដែលប៉ុល និងដៃគូរបស់គាត់បានចាកចេញទៅហើយក្តី ។ ក្រោយមក ប៉ុលបានសរសេរសំបុត្ររបស់លោកទៅកាន់ពួកបរិសុទ្ធ ដើម្បីលើកទឹកចិត្តពួកគេ នៅពេលពួកគេជួបនឹងការបៀតបៀន ។

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីច ទី១ ១:២–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាហេតុអ្វីប៉ុលបានរីករាយនឹងពួកបរិសុទ្ធនៅក្រុងថែស្សាឡូនីច ។

- **ហេតុអ្វីប៉ុលបានរីករាយនឹងពួកបរិសុទ្ធនៅក្រុងថែស្សាឡូនីច ?**

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីច ទី១ ១:៥–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលបានផ្សាយដំណឹងល្អទៅកាន់ពួកថែស្សាឡូនីចដោយរបៀបណា អំឡុងពេលដែលលោកទៅដូចកាលពីលើកមុននោះ ។

- **យោងតាមខ ៥តើប៉ុលបានផ្សាយដំណឹងល្អទៅកាន់ពួកថែស្សាឡូនីចយ៉ាងដូចម្តេច ? (ដោយព្រះបន្ទូល និងដោយព្រះចេស្តានៃព្រះ) ។**

ចូរសុំសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់មើលថា តើពាក្យ និងព្រះចេស្តានៃដំណឹងល្អដែលសំដៅទៅលើនោះជាអ្វី ។



« ដំណឹងល្អពិតមានន័យរឿងពីរយ៉ាង ៖ ព្រះបន្ទូល និងព្រះចេស្តា ។ មនុស្សគ្រប់រូបអាចទទួលបានព្រះបន្ទូល ហើយគម្ពីរដែលមានសរសេរព្រះបន្ទូលនេះជាច្រើនគឺអាចរកបាននៅទូទាំងសាកលលោក ។ ប៉ុន្តែព្រះចេស្តាត្រូវតែកើតចេញមកពីព្រះ ហើយត្រូវតែបានប្រគល់ឲ្យ ស្របទៅតាមព្រះទ័យ និងព្រះឆន្ទៈរបស់ទ្រង់ ចំពោះអ្នកទាំងឡាយដែលគោរពតាមក្រឹត្យវិន័យ ដែលបានប្រគល់ដល់ពួកគេដើម្បីទទួលយក ។

« បន្ទូលនៃដំណឹងល្អគឺជាដំណើររឿងដែលបាននិយាយ ឬបានសរសេរអំពីអ្វី ដែលមនុស្សត្រូវតែធ្វើដើម្បីបានសង្គ្រោះ ។ . . .

« ប៉ុន្តែសេចក្តីសង្គ្រោះពិតកើតមាន នៅពេលដែលព្រះចេស្តានៃព្រះត្រូវបានទទួល និងបានប្រើ ហើយព្រះចេស្តានេះគឺជាអំណាចនៃបព្វជិតភាព និងព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ » (*Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ៣:៤២–៤៣) ។

- **យោងតាមអែលឌើរ ម៉ាក់ខន់ឃី តើព្រះបន្ទូលនៃដំណឹងល្អសំដៅទៅលើអ្វី ? តើព្រះចេស្តានៃដំណឹងល្អសំដៅទៅលើអ្វី ?**
- **យោងតាមខ ៦តើពួកថែស្សាឡូនីចបានធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេត្រូវបានបង្រៀនដំណឹងល្អដោយព្រះបន្ទូល និងព្រះចេស្តានៃព្រះហើយនោះ ? (ពួកគេបានក្លាយទៅជាអ្នកដើរតាមព្រះអម្ចាស់ និងជាពួកអ្នកបម្រើរបស់ទ្រង់) ។**

- តើអ្នកនឹងសង្ខេបការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ៥–៦ទៅជាគោលការណ៍មួយបានយ៉ាងដូចម្តេច ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដោយព្រះបន្ទូល និងព្រះចេស្តានៃព្រះ នោះយើងអាចជួយមនុស្សដទៃឲ្យក្លាយជាពួកអ្នកដើរតាមព្រះអម្ចាស់ និងជាពួកអ្នកបម្រើរបស់ទ្រង់បាន**) ។
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរៀបចំខ្លួនយើងបង្រៀនដំណឹងល្អដោយព្រះបន្ទូល និងព្រះចេស្តានៃព្រះ ?

សូមអញ្ជើញសិស្សម្នាក់អាន ថៃស្សាឡូនីច ទី១ ១:៧–៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថា តើមានអ្វីខ្លះទៀតដែលពួកបរិសុទ្ធថៃស្សាឡូនីចបានធ្វើ បន្ទាប់ពីពួកគេបានទទួលយកដំណឹងល្អហើយ ។

- តើមានអ្វីខ្លះទៀតដែលពួកបរិសុទ្ធនៅថៃស្សាឡូនីចបានធ្វើ បន្ទាប់ពីពួកគេបានទទួលយកដំណឹងល្អហើយ ? តើគំរូរបស់ពួកគេបានជះឥទ្ធិពលដល់អ្នកជឿដទៃទៀតនៅជុំវិញពួកគេយ៉ាងដូចម្តេច ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីខគម្ពីរទាំងនេះ អំពីរបៀបដែលយើងអាចចែកចាយដំណឹងល្អ ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតដូចខាងក្រោមនេះ ៖ **យើងអាចចែកចាយដំណឹងល្អតាមរយៈគំរូរបស់យើង**) ។

ដើម្បីជួយឲ្យសិស្សយល់ពីសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយឲ្យឮៗ ៖



« វិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីផ្សាយដំណឹងល្អ គឺតាមរយៈគំរូ ។ ប្រសិនបើយើងរស់នៅស្របតាមសេចក្តីជំនឿរបស់យើង នោះមនុស្សនឹងកត់សម្គាល់ ។ ប្រសិនបើព្រះភក្ត្ររបស់ព្រះយេស៊ូវគ្រីស្ទបង្ហាញពន្លឺនៅក្នុងជីវិតរបស់យើង (សូមមើលអាលម៉ា ៥:១៤) ប្រសិនបើយើងមានអំណរ និងក្តីសុខសាន្តនៅក្នុងលោកិយនេះ នោះមនុស្សនឹងចង់ដឹងថាហេតុអ្វី ។ ទេសនកថាដ៏មហិមាបំផុតមួយ ដែលបានថ្លែងអំពីកិច្ចការផ្សព្វផ្សាយសាសនា គឺជាគំនិតដ៏សាមញ្ញនេះ ដែលបានផ្តល់ទៅដល់បរិសុទ្ធជន ព្រ្យេនស៊ីស នៃក្រុងអាសស៊ីស៊ី ៖ ‹ ផ្សាយដំណឹងល្អនៅគ្រប់ពេល ហើយប្រសិនបើចាំបាច់ សូមប្រើព្រះបន្ទូលទាំងឡាយ › (នៅក្នុង William Fay and Linda Evans Shepherd, *Share Jesus without Fear* (ឆ្នាំ ១៩៩៩) ទំព័រ ២២) » (« Waiting on the Road to Damascus » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៧៧) ។

សួរសំណួរឡើងវិញ

ពេលខ្លះសិស្សអាចនឹងពិបាកដើម្បីឆ្លើយសំណួរមួយ ដោយសារពួកគេពុំយល់នូវអ្វីដែលត្រូវបានសួរឡើយ ។ អ្នកអាចនឹងចាំបាច់ត្រូវសួរសំណួរឡើងវិញ ឬ សួរសិស្ស បើសិនជាពួកគេយល់ពីអ្វីដែលបានសួរនោះឬទេ ។ សូមចៀសវាងពីការសួរសំណួរជាប់ៗគ្នាដោយមិនអនុញ្ញាតឲ្យសិស្សមានពេលគ្រប់គ្រាន់ ដើម្បីគិតឲ្យបានច្បាស់លាស់ពីចម្លើយត្រឹមត្រូវឡើយ ។

- តើការធ្វើជាគំរូល្អអាចជាវិធីកាន់តែមានប្រសិទ្ធភាពមួយ ក្នុងការចែកចាយដំណឹងល្អ ជាងការនិយាយតែអំពីដំណឹងល្អដោយរបៀបណា?
- តើគំរូរបស់មនុស្សម្នាក់បានជួយអ្នកឲ្យទទួលយកដំណឹងល្អ ឬកាន់តែរស់នៅតាមដំណឹងល្អ ដោយពេញលេញយ៉ាងដូចម្តេច ?

ថៃស្សាឡូនីចទី១ ២

ប៉ុលពិពណ៌នាអំពីរបៀបដែលគាត់ និងដៃគូរបស់គាត់បានបម្រើដល់ពួកថៃស្សាឡូនីច

សូមពន្យល់ថា បន្ទាប់ពីប៉ុលបានសរសើរដល់ពួកបរិសុទ្ធនៅថៃស្សាឡូនីចចំពោះគំរូសុចរិតរបស់ពួកគេហើយ នោះលោកបានរំឭកពួកគេអំពីសេចក្តីស្រឡាញ់របស់លោកចំពោះពួកគេ និងអំពីគំរូដែលលោកបានធ្វើ នៅពេលលោកបានផ្សាយដំណឹងល្អទៅកាន់ពួកគេកាលពីមុន ។

សូមសរសេរសេចក្តីយោងខគម្ពីរ និងសំណួរខាងក្រោមនៅលើក្តារខៀន ៖

ថៃស្សាឡូនីចទី១ ២:១–១៣

- *តើមានពាក្យ ឬឃ្លាអ្វីខ្លះ ដែលបានពិពណ៌នាអំពីគំរូសុចរិតរបស់ប៉ុល និងដៃគូរបស់លោកដែលបានធ្វើសម្រាប់ពួកថៃស្សាឡូនីច ?*

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យផ្លាស់វេណគ្នាអានឮៗចេញមកពីថៃស្សាឡូនីចទី ១ ២:១–១៣ ខណៈដែលសិស្សក្នុងថ្នាក់ធ្វើការផ្ទៀងតាម ។ ឬ ជំនួសឲ្យការអញ្ជើញសិស្សឲ្យអានឮៗ អ្នកអាចអញ្ជើញពួកគេឲ្យស្រាវជ្រាវខគម្ពីរទាំងនេះក្នុងក្រុមតូចៗ ជាដៃគូ ឬជាបុគ្គល ។ ចូរសុំឲ្យសិស្សរកមើលពាក្យ ឬឃ្លាដែលបានពិពណ៌នាអំពីគំរូសុចរិតរបស់ប៉ុល និងដៃគូរបស់លោក ដែលបានធ្វើសម្រាប់ពួកថៃស្សាឡូនីច ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យមកកាន់ក្តារខៀនសរសេរពាក្យ ឬឃ្លាមួយ ឬពីរ ដែលពួកគេបានរកឃើញ ។ ចូរសុំឲ្យពួកគេពន្យល់អំពីរបៀបដែលពាក្យ ឬឃ្លាទាំងនេះ អាចដឹកនាំការខំប្រឹងប្រែងរបស់យើងដើម្បីធ្វើជាគំរូសុចរិតដល់អ្នកដទៃ ។

សូមសង្ខេបថៃស្សាឡូនីច ទី១ ២:១៤–១៨ ដោយពន្យល់ថា ប៉ុលបាននិយាយទៅកាន់ពួកបរិសុទ្ធនៅក្រុងថៃស្សាឡូនីច ដែលត្រូវបានគេបៀតបៀនចំពោះការទទួលយកដំណឹងល្អ ។ លោកបានប្រាប់ដល់ពួកបរិសុទ្ធថា លោកបានព្យាយាមទៅជួបពួកគេម្តងទៀត ប៉ុន្តែត្រូវបាន « ឃាត់ » ដោយពួកមារសត្រូវ (ខ ១៨) ។

សូមអញ្ជើញសិស្សម្នាក់អាន ថៃស្សាឡូនីច ទី១ ២:១៩–២០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថា តើប៉ុលបានពិពណ៌នាអ្វីខ្លះដែលជា « សេចក្តីសង្ឃឹម ឬអំណរ ឬ . . .ការរីករាយ » របស់លោក (ខ ១៩) ។

- តើប៉ុលបានពិពណ៌នាអ្វីខ្លះថាជា « សេចក្តីសង្ឃឹម ឬអំណរ ឬ . . .ការរីករាយ » របស់លោក ?
- តើសេចក្តីសង្ឃឹម អំណរ និងការរីករាយរបស់ប៉ុលបានបង្ហាញសេចក្តីសង្ឃឹម អំណរ និងការរីករាយរបស់ព្រះវរបិតាសួគ៌ចំពោះយើងយ៉ាងដូចម្តេច ?

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្ហាញនៅក្នុងមេរៀននេះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេអាចចែកចាយដំណឹងល្អដោយការនិយាយអំពីវា និងការធ្វើជាគំរូសុចរិត ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេទទួលបាន ។

មេរៀន ១២៨

ថែស្សាឡូនីចទី១ ៣–៥

សេចក្តីផ្តើម

សាវកប៉ុលមានបំណងចង់ពង្រឹងសេចក្តីជំនឿរបស់សមាជិកសាសនាចក្រនៅថែស្សាឡូនីច ។ លោកបានបង្រៀនពួកគេអំពីការរស់ឡើងវិញរបស់មនុស្សស្លាប់នៅឯការយាងមកជាលើកទីពីរ របស់ព្រះយេស៊ូវគ្រីស្ទ ហើយបានបង្រៀនពួកគេអំពីរបៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

យោបល់សម្រាប់ការបង្រៀន

ថែស្សាឡូនីចទី១ ៣–៤:១២

ប៉ុលមានបំណងចង់ពង្រឹងសេចក្តីជំនឿរបស់សមាជិកសាសនាចក្រនៅថែស្សាឡូនីច

សូមចែក ក្រដាស លំហាត់ ពិត–មិនពិតខាងក្រោមនេះស្តីពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទដល់សិស្ស ហើយសូរពួកគេឲ្យជ្រើសយកចម្លើយ *ពិត* ឬ *មិនពិត* នៅក្បែរសំណួរនីមួយៗ ៖

ថែស្សាឡូនីចទី១ ៣–៥

ព / ម ១. ពួកបរិសុទ្ធស្មោះត្រង់ដែលស្លាប់ពីមុនការយាងមកជាលើកទីពីរ នឹងពុំបានរស់ឡើងវិញឡើយរហូតដល់ចុងបញ្ចប់នៃសហសវត្សរ៍ ។

ព / ម ២. ពួកបរិសុទ្ធស្មោះត្រង់ដែលមានជីវិតនៅឯការយាងមកជាលើកទីពីរនឹងបាននាំយកទៅជួបនឹងព្រះគ្រីស្ទ កាលទ្រង់យាងមក ។

ព / ម ៣. ការយាងមកជាលើកទីពីរនឹងធ្វើឲ្យមនុស្សគ្រប់គ្នាភ្ញាក់ផ្អើល ដូចជាចោរមកនៅពេលយប់ ។

ប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នា

សូម្បីតែបច្ចេកទេសនៃការបង្រៀនដ៏មានឥទ្ធិពលមួយ ក៏អាចក្លាយទៅជាពុំមានប្រសិទ្ធភាព ឬប្រែជាធុញទ្រាន់ដៃ បើប្រើច្រើនពេកនោះ ។ កាលអ្នកពុំគួរជ្រើសយកវិធីសាស្ត្របង្រៀនសម្រាប់តែប្រយោជន៍នៃការបង្រៀនខុសៗគ្នាតែម្យ៉ាងនោះ អ្នកនឹងក្លាយជាគ្រូបង្រៀនមួយកាន់តែមានប្រសិទ្ធភាព ប្រសិនបើអ្នកធ្វើឲ្យវិធីដែលអ្នកបង្រៀនពីមួយថ្ងៃទៅមួយថ្ងៃខុសៗគ្នា ។ ការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា អាចជួយអ្នកឲ្យជួយដល់សិស្សដែលរៀនតាមរបៀបផ្សេងៗគ្នា ។

សូមពន្យល់ថា អ្នកនឹងពុំផ្តល់ចម្លើយសម្រាប់លំហាត់នាពេលនេះទេ ប៉ុន្តែសិស្សអាចរកចម្លើយត្រឹមត្រូវនៅក្នុងមេរៀននាថ្ងៃនេះ ។ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេសិក្សា ថែស្សាឡូនីចទី១ ៣–៥ ។

សូមរំឭកសិស្សថា បន្ទាប់ពីការប្រកាសដំណឹងល្អក្នុងរយៈពេលដ៏ខ្លីនៅថែស្សាឡូនីច ប៉ុល ស៊ីឡាស និងធីម៉ូថេត្រូវពួកអ្នកដឹកនាំសាសន៍យូដាបង្ខំឲ្យចេញពីក្រុងនោះ (សូមមើល កិច្ចការ ១៧:៥–១៥) ។ ក្រោយមកទៀត ប៉ុលបានបញ្ជូនធីម៉ូថេឲ្យត្រឡប់ទៅថែស្សាឡូនីចវិញដើម្បីមើលពួកអ្នកប្រែចិត្តជឿថ្មី ហើយពង្រឹងដល់សេចក្តីជំនឿរបស់ពួកគេ ។ នៅក្នុង ថែស្សាឡូនីចទី ១ ៣:១–៧ យើងរៀនថា ធីម៉ូថេបានរាយការណ៍ទៅប៉ុលថា ពួកបរិសុទ្ធនៅទីនោះបានបន្តស្មោះត្រង់ ថ្វីបើមានការបៀតបៀនក៏ដោយ ។ ធីម៉ូថេក៏ទំនងជារាយការណ៍ផងដែរថា ពួកបរិសុទ្ធមានសំណួរជាច្រើនអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ប៉ុលបានសរសេរសំបុត្ររបស់លោកដល់ពួកបរិសុទ្ធនៅថែស្សាឡូនីច ដើម្បីឆ្លើយសំណួររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី ១ ៣:៩–១០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយថាលោកបានអធិស្ឋានសូមអ្វីខ្លះ កាលលោកបានអវត្តមានពីពួកបរិសុទ្ធនៅថែស្សាឡូនីច ។

- តើប៉ុលបាននិយាយថាលោកបានអធិស្ឋានសូមអ្វីខ្លះ កាលលោកបានអវត្តមាននោះ ?
- តើឃ្លាថា « បំពេញសេចក្តីអ្វីដែលខ្វះ ខាងឯសេចក្តីជំនឿរបស់អ្នករាល់គ្នា » ក្នុង ខទី ១០ មានន័យដូចម្តេច ? (ប៉ុលមានបំណងចង់ពង្រឹងសេចក្តីជំនឿរបស់សមាជិកសាសនាចក្រនៅថែស្សាឡូនីច) ។

សូមពន្យល់ថា វិធីមួយដែលប៉ុលបានខិតខំពង្រឹងសេចក្តីជំនឿរបស់សមាជិកសាសនាចក្រនៅថែស្សាឡូនីច គឺដើម្បីជួយពួកគេឲ្យយល់កាន់តែប្រសើរឡើងពីរបៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។ សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី ១ ៣:១១–១៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានសង្ឃឹមថាព្រះអម្ចាស់នឹងធ្វើអ្វីខ្លះ សម្រាប់ពួកបរិសុទ្ធដើម្បីរៀបចំខ្លួនពួកគេសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។

- តើប៉ុលបានសង្ឃឹមថា ព្រះអម្ចាស់នឹងធ្វើអ្វីខ្លះសម្រាប់ពួកបរិសុទ្ធ ដើម្បីរៀបចំខ្លួនពួកគេសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី ១ ៤:១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធនៅថែស្សាឡូនីចឲ្យធ្វើអ្វីខ្លះដើម្បីរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

- តើប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធនៅថែស្សាឡូនីចធ្វើអ្វីខ្លះ ដើម្បីរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ?

សូមចាត់សិស្សម្នាក់ៗនៅក្នុងថ្នាក់នូវសេចក្តីយោងមួយដូចខាងក្រោម (ដោយផ្អែកលើទំហំថ្នាក់របស់អ្នក អាចចាត់សេចក្តីយោងដូចគ្នាដល់សិស្សលើសពីម្នាក់) ៖ ថែស្សាឡូនីចទី១ ៤:២–៥, ៤:៦–៨, ៤:៩–១២ ។ ចូរសុំឲ្យសិស្សអានសេចក្តីយោងរបស់ពួកគេ ហើយឆ្លើយសំណួរខាងក្រោម (អ្នកគួរសរសេរសំណួរទាំងនេះលើក្តារខៀន) ៖

- តើប៉ុលបានដាស់តឿនឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យព្រះអម្ចាស់សព្វព្រះទ័យ ?
- តើអ្នកគិតថា ការរស់នៅតាមការបង្រៀននោះនឹងជួយពួកគេឲ្យត្រៀមខ្លួន សម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្តេច ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្រាប់ចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។

ថែស្សាឡូនីចទី១ ៤:១៣–១៨

ប៉ុលបង្រៀនអំពីការរស់ឡើងវិញនៃមនុស្សស្លាប់ នៅឯការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ

ចូរដាក់បង្ហាញរូបភាព ការយាងមកជាលើកទីពីរ (*Gospel Art Book* | ឆ្នាំ ២០០៩ | ល.រ. ៦៦, សូមមើលផងដែរ LDS.org) ។



សូមពន្យល់ថា ពួកបរិសុទ្ធនៅថែស្សាឡូនីចយល់ខុសទិដ្ឋភាពមួយចំនួននៃការយាងមកជាលើកទីពីរ ។ ពួកគេព្រួយបារម្ភថា សមាជិកសាសនាចក្រនៅថែស្សាឡូនីចដែលបានស្លាប់នឹងពុំអាចស្គាល់ពរជ័យនៃការយាងមកជាលើកទីពីរបានឡើយ ។

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី១ ៤:១៣–១៤, ១៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះអំពីពួកបរិសុទ្ធស្មោះត្រង់ ដែលស្លាប់ពីមុនការយាងមកជាលើកទីពីរ ។ សូមពន្យល់ថា ប៉ុលបានប្រើពាក្យ *ដេកលក់* សំដៅទៅលើជនដែលស្លាប់ ។

- តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះអំពីពួកបរិសុទ្ធស្មោះត្រង់ ដែលស្លាប់ពីមុនការយាងមកជាលើកទីពីរ ? (សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **ពួកបរិសុទ្ធស្មោះត្រង់ ដែលស្លាប់មុនការយាងមកជាលើកទីពីរ នឹងបានរស់ឡើងវិញ នៅពេលព្រះគ្រីស្ទយាងមកម្តងទៀត**) ។
- តើឃ្លាថា « ព្រះទ្រង់នឹងនាំអស់អ្នក ដែលដេកលក់ទៅក្នុងព្រះយេស៊ូវ ឲ្យបានមកជាមួយនឹងទ្រង់ » នៅក្នុង ខទី ១៤ មានន័យដូចម្តេច ? (ពួកបរិសុទ្ធស្មោះត្រង់ដែលបានរស់ឡើងវិញ នៅឯការយាងមកជាលើកទីពីរ នឹងត្រូវបាននាំយកទៅជួបនឹងព្រះយេស៊ូវគ្រីស្ទ ហើយនឹងចុះមកជាមួយទ្រង់នៅក្នុងសិរីល្អ | សូមមើល គ. និង ស. ៨៨:៩៧–៩៨ |) ។

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី ១ ៤:១៥, ១៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានបង្រៀនអ្វីខ្លះ អំពីពួកបរិសុទ្ធស្មោះត្រង់ដែលនឹងមានជីវិតនៅពេលព្រះគ្រីស្ទយាងមកម្តងទៀត ។ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ នៅក្នុង ខទី ១៥ បានផ្លាស់ប្តូរឃ្លាចុងក្រោយ ដើម្បីឲ្យវាអានថា « ពួកគេដែលរស់នៅជាប់ដរាបដល់ព្រះអម្ចាស់យាងមក នោះមិនរាំងពួកអ្នកដែលបាននៅសល់ចំពោះការយាងមករបស់ព្រះអម្ចាស់ ជាពួកអ្នកដែលបានដេកលក់ទៅហើយនោះទេ ។ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធ នៅក្នុង ខទី ១៧ បានផ្លាស់ប្តូរខគម្ពីរនេះទៅជា « រួចពួកគេដែលកំពុងតែរស់នៅក៏នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ជាមួយនឹងពួកអ្នកដែលនៅសល់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះយើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ ។ អ្នកគួរចង្អុលបង្ហាញថា ការបកប្រែដោយយ៉ូសែប ស៊្មីធ ប្តូរពាក្យ *យើង* នៅក្នុងខគម្ពីរទាំងនេះទៅជា *ពួកគេ* ដោយឆ្លុះបញ្ចាំងថា ការយាងមកជាលើកទីពីរនឹងពុំកើតឡើងនៅជំនាន់របស់ប៉ុលនោះទេ ។

- តើប៉ុលបានបង្រៀនសេចក្តីពិតអ្វីខ្លះអំពីពួកបរិសុទ្ធស្មោះត្រង់ ដែលមានជីវិតពីមុនការយាងមកជាលើកទីពីរ ? (សិស្សគួរស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **ពួកបរិសុទ្ធស្មោះត្រង់ ដែលមានជីវិតនៅឯការយាងមកជាលើកទីពីរនឹងត្រូវបាននាំយកទៅជួបនឹងព្រះយេស៊ូវគ្រីស្ទ កាលទ្រង់យាងមក**) ។

សូមអញ្ជើញសិស្សឲ្យអាន ថែស្សាឡូនីចទី ១ ៤:១៨ ដោយស្ងាត់ស្ងៀម ហើយរកមើលថាប៉ុលបានសង្ឃឹមថាពួកបរិសុទ្ធនឹងធ្វើអ្វីខ្លះ បន្ទាប់ពីស្តាប់ឮសេចក្តីពិតទាំងនេះអំពីការយាងមកជាលើកទីពីរ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នករកឃើញការលួងលោមអ្វីខ្លះ នៅក្នុងគោលលទ្ធិទាំងនេះអំពីការយាងមកជាលើកទីពីរ ?

ថែស្សាឡូនីចទី ១ ៥

ប៉ុលបង្រៀនសមាជិកសាសនាចក្រនៅថែស្សាឡូនីច អំពីរបៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី១ ៥:១–៣ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរឿងប្រៀបប្រដូចពីរ ដែលប៉ុលបានប្រើដើម្បីពិពណ៌នាពីកាលវេលានៃការយាងមកជាលើកទីពីរ ។

- តើរឿងប្រៀបប្រដូចពីរដែលប៉ុលបានប្រើ ដើម្បីពិពណ៌នាពីកាលវេលានៃការយាងមកជាលើកទីពីរមានរឿងអ្វីខ្លះ ? (« ចោរមកនៅពេលយប់ » | ខទី ២ | និង « ស្ត្រីមានគភ៌ឈឺនឹងសំរាល » | ខទី ៣ |) ។

សូមពន្យល់ថា ចោរមកនៅពេលយប់ជាធម្មតាវាមក « ដោយពុំបានប្រាប់ទុកជាមុនឡើយ » (Bruce R. McConkie *Doctrinal New Testament Commentary* វ៉ុលទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ៣:៥៤) ។

- តើរឿងប្រៀបប្រដូចរបស់ប៉ុលអំពីចោរមកនៅពេលយប់ បង្រៀនយើងអ្វីខ្លះទាក់ទងនឹងការយាងមកជាលើកទីពីរ ?
- តើរឿងប្រៀបប្រដូចរបស់ប៉ុលអំពីស្ត្រីមានគភ៌ឈឺនឹងសំរាល បង្រៀនយើងអ្វីខ្លះទាក់ទងនឹងការយាងមកជាលើកទីពីរ ?

បន្ទាប់ពីសិស្សបានឆ្លើយនឹងសំណួរទាំងពីរចុងមក អ្នកគួរចង្អុលបង្ហាញថា អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្រុមនៃពួកសាវកដប់ពីរ នាក់បានបង្រៀនអំពីរឿងប្រៀបប្រដូចទាក់ទងនឹងស្ត្រីមានគភ៌ឈឺនឹងសំរាលដូចតទៅ ៖ « នាងពុំដឹងពីម៉ោង ឬនាទីដែលកូននាងនឹងកើតឡើយ ប៉ុន្តែនាងដឹងពីពេលប្រហាក់ប្រហែល » (*Doctrinal New Testament Commentary* ៣:៥៤) ។ ដោយផ្អែកលើរឿងប្រៀបប្រដូចនេះ យើងក៏អាចគិតពិចារណាអំពីរបៀប ដែលការសោកល្បួងពីមុនការយាងមកជាលើកទីពីរស្រដៀងគ្នានឹងការឈឺចាប់នៃការសំរាលកូនដែរ ។ ប៉ុន្តែខណៈពេលកូនកើតមក វាគឺជាពេលវេលាមួយដ៏អស្ចារ្យ ដូចគ្នានេះដែរ ការយាងមកជាលើកទីពីរនឹងក្លាយជាពេលវេលាដ៏អស្ចារ្យសម្រាប់មនុស្សសុចរិត ។

សូមអញ្ជើញសិស្សម្នាក់អាន ថៃស្សាឡូនីចទី ១ ៥:៤–៦ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ហេតុអ្វីបានជាពួកបរិសុទ្ធនឹងពុំភ្ញាក់ផ្អើលចំពោះការយាងមកជាលើកទីពីរឡើយ ។

- ហេតុអ្វីបានជាពួកបរិសុទ្ធនឹងពុំភ្ញាក់ផ្អើលចំពោះការយាងមកជាលើកទីពីរ ?
- តើការក្លាយជា « ពួកនៃពន្លឺ » មានន័យដូចម្តេច ? (ឃ្លាថា « ពួកនៃពន្លឺ » នៅក្នុង ខទី ៥ សំដៅទៅលើសមាជិកសាសនាចក្រ ស្មោះត្រង់ដែល « ដោះចោលអស់ទាំងការរបស់សេចក្តីងងឹតចេញ » [រ៉ូម ១៣:១២] មានភាពជាដៃគូមកពីព្រះវិញ្ញាណបរិសុទ្ធ ហេតុដូច្នេះហើយនឹងបានត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីរ [សូមមើល គ. និង ស. ១០៦:៤–៥]) ។
- តើឃ្លាថា « ត្រូវចាំយាម ហើយដឹងខ្លួន » មានន័យយ៉ាងណា ? (ថៃស្សាឡូនីចទី១ ៥:៦) ។
- តើអ្នកនឹងសង្ខេបអ្វី ដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធនៅថៃស្សាឡូនីចអំពីរបៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្តេច ? (សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ដោយប្រើពាក្យរបស់សិស្ស ៖ **ប្រសិនបើយើងស្មោះត្រង់ ហើយរង់ចាំមើលទីសម្គាល់ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងបានត្រៀមខ្លួនកាលទ្រង់យាងមកម្តងទៀត**) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន យ៉ូសែប ហ្វ៊ីលឌីង ស្ម៊ីធ ហើយសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា តើយើងអាចត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្តេច ។



« ផែនដីពោរពេញដោយវិបត្តិភ័យ និងបញ្ហា ។ ដួងចិត្តមនុស្សកំពុងចុះខ្សោយដោយសារភ្លើងទាំងនេះ ។ យើងឃើញទីសម្គាល់នានា កាលយើងឃើញដើមល្វាមានផលផ្លែ ហើយដោយដឹងថាពេលវេលានេះជិតមកដល់ហើយ វាបង្ហាញដល់ខ្ញុំ និងអ្នក ព្រមទាំងមនុស្សទាំងអស់នៅលើផែនដីនេះឲ្យ *ស្តាប់តាមបន្ទូលរបស់ព្រះគ្រីស្ទ ដល់ពួកសាវករបស់ទ្រង់ ហើយចាំយាម* ពីព្រោះយើងពុំដឹងអំពីថ្ងៃ ឬម៉ោងនៃពេលវេលានោះឡើយ » (*Doctrines of Salvation,* និពន្ធដោយ Bruce R. McConkie វ៉ុលទី ៣ [ឆ្នាំ ១៩៥៤–៥៦] ៣:៥២–៥៣) ។

- យោងតាមប្រធាន ស្ម៊ីធ តើយើងអាចរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យរំឭកឡើងវិញពីប្រយោគពិត–មិនពិត និងចម្លើយដែលពួកគេបានសរសេរនៅពេលចាប់ផ្តើមមេរៀននេះ ។

- ដោយផ្អែកលើសេចក្តីពិតដែលអ្នកបានរៀននៅក្នុងមេរៀននេះ តើអ្នកនឹងផ្លាស់ប្តូរចម្លើយណាមួយរបស់អ្នកដែរឬទេ ? (ចម្លើយ ៖ [១] មិនពិត, [២] ពិត, [៣] មិនពិត) ។

សូមសង្ខេប ថៃស្សាឡូនីចទី១ ៥:៧–២២ ដោយពន្យល់ថា ប៉ុលបានទូន្មានបន្ថែមទៀតដល់ពួកបរិសុទ្ធ អំពីរបៀបរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

សូមអញ្ជើញសិស្សអាន ថៃស្សាឡូនីចទី១ ៥:១២–២២ ដោយស្ងាត់ស្ងៀម ហើយរកមើលថាប៉ុលបានបង្រៀនពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះដើម្បីរៀបចំខ្លួនឯង និងមនុស្សដទៃទៀតដើម្បីជួបនឹងព្រះអង្គសង្គ្រោះនៅឯការយាងមកជាលើកទីពីរ ។ សូមលើកទឹកចិត្តសិស្សឲ្យជ្រើសយកការទូន្មានមួយ ដែលធ្វើឲ្យពួកគេចាប់អារម្មណ៍ខ្លាំង ។ សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ (អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះលើក្តារខៀន) ។

- តើការទូន្មានណានៅក្នុង ថៃស្សាឡូនីចទី១ ៥:១២–២២ ដែលធ្វើឲ្យអ្នកចាប់អារម្មណ៍ខ្លាំង ?
- តើការរស់នៅតាមការទូន្មាននេះអាចជួយអ្នក និងមនុស្សដទៃទៀតឲ្យរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរយ៉ាងដូចម្តេច ?
- តើអ្នកនឹងលើកទឹកចិត្តមនុស្សម្នាក់ឲ្យប្រើការទូន្មាននេះនៅក្នុងជីវិតប្រចាំថ្ងៃយ៉ាងដូចម្តេច ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ពីចម្លើយរបស់ពួកគេទៅមិត្តរួមថ្នាក់ម្នាក់ ។

សូមអញ្ជើញសិស្សម្នាក់អាន ថៃស្សាឡូនីចទី ១ ៥:២៣–២៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយថាព្រះនឹងធ្វើអ្វីខ្លះសម្រាប់ពួកបរិសុទ្ធស្មោះត្រង់របស់ទ្រង់ កាលពួកគេរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

- តើព្រះនឹងធ្វើអ្វីខ្លះសម្រាប់ពួកបរិសុទ្ធស្មោះត្រង់របស់ទ្រង់ កាលពួកគេរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ?

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់ពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ហើយអញ្ជើញសិស្សឲ្យរៀបចំខ្លួនដោយស្មោះត្រង់សម្រាប់ការយាងមកជាលើកទីពីរ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ថែស្សាឡូនីចទី១ ៤:១៧ ។ « បានលើកឡើង ទៅជាមួយគ្នា »

« ការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់ ថែស្សាឡូនីចទី១ ៤:១៧ ចែងថា ‹ រួច *ពួកគេដែល* កំពុងតែរស់នៅក៏នឹងបានលើកឡើង*ទៅក្នុង ពពកជាមួយគ្នាទាំងអស់* ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះយើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជារៀងទៅ ›) ។

មានពួកគ្រីស្ទានជាច្រើនប្រើពាក្យ *ភាពរីករាយជាខ្លាំង* (មកពីពាក្យឡាតាំងមានន័យ ‹ លើកឡើងទៅ ›) នៅពេលលើកឡើងអំពីគ្រាដែលមនុស្សសុចរិតនឹងបានលើកឡើងទៅជួបនឹងព្រះអង្គសង្គ្រោះនៅឯការយាងមកវិញរបស់ទ្រង់ » (*New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៤] ទំព័រ ៤៥០) ។

សេចក្តីផ្តើមអំពី

សំបុត្រទីពីររបស់ប៉ុលដល់ពួកថែស្សាឡូនិច

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងសំបុត្រទីពីររបស់លោកដល់ពួកថែស្សាឡូនិច ប៉ុលបានសរសេរពាក្យទុន្មាន និងការបញ្ជាក់ទៅដល់សមាជិកសាសនាចក្រ ដែលយល់ខុសពីកត្តាជាក់លាក់នៃការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ការសិក្សាលើការបង្រៀនរបស់លោកអាចជួយសិស្សឲ្យយល់ដឹងពីលក្ខណៈនៃការក្បត់សាសនា និងរបៀបត្រៀមខ្លួនឲ្យបានត្រឹមត្រូវសម្រាប់ការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុលបានសរសេរថែស្សាឡូនីចទី ២ (សូមមើល ថែស្សាឡូនីចទី ២ ១:១ សូមមើលផងដែរ ថែស្សាឡូនីចទី ២ ២:៥, ៣:១៧) ។ នៅដើមសំបុត្រនេះក៏មាននូវពាក្យស្វាគមន៍មួយមកពីស៊ីឡាស និងធីម៉ូថេផងដែរ (ថែស្សាឡូនីចទី ២ ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

« ប៉ុលបានសរសេរសំបុត្រនេះដល់ពួកថែស្សាឡូនីច កាលលោកនៅកូរិនថូសក្នុងដំណើរផ្សព្វផ្សាយសាសនាលើកទីពីររបស់លោក » ប្រមាណជា គ.ស. ៥០–៥១ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។

តើគម្ពីរនេះត្រូវបានសរសេរចំពោះនរណា ហើយតើហេតុអ្វី ?

ប៉ុលបានសរសេរថែស្សាឡូនីចទី ២ ដល់សមាជិកសាសនាចក្រនៅថែស្សាឡូនីច ។ ប្រធានបទនៃថែស្សាឡូនីចទី ១ និងថែស្សាឡូនីចទី ២ គឺមានភាពស្រដៀងគ្នាដោយបង្ហាញថា ប៉ុលបានសរសេរថែស្សាឡូនីចទី ២ ដើម្បីគូសបញ្ជាក់ ហើយពន្យល់អំពីសំបុត្រទីមួយរបស់លោក ។ វាទំនងដូចជាពួកថែស្សាឡូនីចបានទទួលសំបុត្រក្លែងក្លាយមួយ ដែលអះអាងថាជាសំបុត្រមកពីប៉ុល ហើយទំនងជាសំបុត្រនេះបានបណ្តាលឲ្យមនុស្សមួយចំនួនជឿថា ការយាងមកជាលើកទីពីរបានកើតឡើងរួចហើយ (សូមមើល ថែស្សាឡូនីចទី ២ ២:២) ។

« នៅក្នុងការសម្រាករយៈពេលខ្លីនៅចន្លោះសំបុត្រទាំងពីរ សាសនាចក្របានទទួលរងនូវការបៀតបៀន (២ ថែស្សា. ១:៤) ទិដ្ឋភាពនៃការយាងមកភ្លាមៗមួយរបស់ព្រះអម្ចាស់បានបង្កើតឲ្យមានការរំជើបរំជួលដ៏អពមង្គលមួយ (២:២) » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ ប៉ុលបានសរសេរថែស្សាឡូនីចទី ២ ដើម្បីពង្រឹងដល់សេចក្តីជំនឿរបស់សមាជិកទាំងនេះ ហើយកែតម្រូវនូវការយល់ខុសពីគោលលទ្ធិនានា ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

សំបុត្រទីពីរដល់ពួកថែស្សាឡូនីចទី ២ ផ្តល់ព័ត៌មានលម្អិតដ៏សំខាន់អំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ឧទាហរណ៍មួយចំនួនរួមមានទាំងគំនិតថា ព្រះអម្ចាស់នឹងយាងត្រឡប់មកវិញក្នុង « អណ្តាតភ្លើង » ហើយថាមនុស្សទុច្ចរិតនឹង « រងទុក្ខទោស ជាសេចក្តីហិនវិនាសអស់កល្បជានិច្ច ឃ្លាតពីព្រះភក្ត្រនៃព្រះអម្ចាស់ » (ថែស្សាឡូនីចទី ២ ១:៨–៩) ។

នៅក្នុងសំបុត្រនេះ យើងបានអានថា ប៉ុលក៏បានព្យាករពីការក្បត់សាសនាជំពូក ដោយបង្រៀនថា សាសនាចក្រនឹងស្ថិតក្នុង « សេចក្តីក្បត់សាសនា » ឃ្លាតចេញពីដំណឹងល្អ ពីមុនការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ (សូមមើល ថែស្សាឡូនីចទី ២ ២:២–១២) ។ ការបង្រៀនរបស់ប៉ុលអំពីការក្បត់សាសនា រំឭកដល់សមាជិកសាសនាចក្រសម័យបច្ចុប្បន្នពីហេតុផលដែលការស្តារឡើងវិញនៃដំណឹងល្អនាថ្ងៃចុងក្រោយមានភាពចាំបាច់ ។

គម្រោង

ថែស្សាឡូនីចទី ២ ១ ប៉ុលថ្លែងពាក្យស្វាគមន៍ ហើយឲ្យយោបល់ដល់ពួកបរិសុទ្ធនៅស្រុកថែស្សាឡូនីច ។ លោកបង្រៀនថា មនុស្សទុច្ចរិតនឹងដកពិសោធន៍នូវការសងសឹករបស់ព្រះអម្ចាស់នៅឯការយាងមកជាលើកទីពីរ ។

ថែស្សាឡូនីចទី ២ ២ ប៉ុលកែតម្រូវគំនិតខុសឆ្គងដែលថា ការយាងមកជាលើកទីពីរបានកើតឡើងរួចហើយ ហើយបានព្យាករថា ការក្បត់សាសនាមួយនឹងកើតមាន មុននឹងការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់ ។ លោកលើកទឹកចិត្តពួកបរិសុទ្ធនៅថែស្សាឡូនីចឲ្យបន្តស្មោះត្រង់ ។

ថែស្សាឡូនីចទី ២ ៣ ប៉ុលទូន្មានសមាជិកសាសនាចក្រឲ្យធ្វើការដើម្បីផ្គត់ផ្គង់ដល់សេចក្តីត្រូវការខាងសាច់ឈាមរបស់ពួកគេ ហើយកុំឲ្យសោយចិត្តខាងឯការល្អឡើយ ។

ថែស្សាឡូនីចទី ២

សេចក្តីផ្តើម

មិនយូរប៉ុន្មានក្រោយពីសរសេរសំបុត្រទីមួយរបស់លោកដល់ពួកបរិសុទ្ធនៅថែស្សាឡូនីច ហើយ ប៉ុលបានសរសេរសំបុត្រទីពីរដល់ពួកគេ ដែលលោកបានបញ្ជាក់នូវសេចក្តីពិតអំពីការយាងមកជាលើកទីពីរ ។ លោកបានបង្រៀនថា ព្រះអង្គសង្គ្រោះនឹងមិនយាងមកម្តងទៀតឡើយ រហូតបន្ទាប់ពីការក្បត់សាសនាមួយបានកើតឡើង ។ បន្ទាប់មក ប៉ុលបានប្រកាសទាស់នឹងការខ្ជិលច្រអូស ហើយបានទូន្មានដល់ពួកបរិសុទ្ធ « កុំឲ្យរសាយចិត្តខាងឯការល្អឡើយ » (ថែស្សាឡូនីចទី ២ ៣:១៣) ។

យោបល់សម្រាប់ការបង្រៀន

ថែស្សាឡូនីច ទី២ ១–២

ប៉ុលលើកទឹកចិត្តពួកបរិសុទ្ធដោយព្យាករពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីប្រកាសដោយអែលឌើរ ដៃប្រ៊ី អ័រ ហូឡិន ក្នុងកម្រិមនៃពួកសាវកដប់ពីរនាក់ដូចខាងក្រោមនេះ ៖

« ខ្ញុំសូមនិយាយទៅកាន់មនុស្សទាំងអស់ ជាពិសេសដល់យុវវ័យនៃសាសនាចក្រថា បើសិនជាអ្នកពុំទាន់បានត្រៀមខ្លួននៅឡើយទេ នៅថ្ងៃមួយ អ្នកនឹងឃើញថា ខ្លួនអ្នកត្រូវបានហៅឲ្យការពារជំនឿអ្នក ឬប្រហែលជាស៊ូទ្រាំនឹងការបំពានផ្ទាល់ខ្លួនខ្លះ ។ ជាសាមញ្ញ ពីព្រោះតែអ្នកគឺជាសមាជិកមួយរូបនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទថ្ងៃចុងក្រោយ » (« The Cost—and Blessings—of Discipleship » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៦) ។

ចូរសុំឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេធ្លាប់ការពារសេចក្តីជំនឿរបស់ខ្លួន ឬបានស៊ូទ្រាំនឹងការផ្ទុយ ដោយសារតែពួកគេជាសមាជិកនៅក្នុងសាសនាចក្រ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។

សូមពន្យល់ថា ប៉ុលបានសរសេរសំបុត្រទីពីរដល់ពួកបរិសុទ្ធនៅថែស្សាឡូនីច ហើយបានថ្លែងពីប្រធានបទមួយចំនួន រួមទាំងការផ្ទុយដែលពួកបរិសុទ្ធកំពុងជួបប្រទះផងដែរ ។ នៅពេលសិស្សសិក្សា ថែស្សាឡូនីចទី ២ ១ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយដែលអាចជួយពួកគេឲ្យស៊ូទ្រាំនឹងការផ្ទុយ និងការឈឺចាប់ដែលពួកគេអាចនឹងជួបក្នុងនាមជាសមាជិកសាសនាចក្រ ។

សូមអញ្ជើញសិស្សម្នាក់អាន ថែស្សាឡូនីចទី ២ ១:៣–៥ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពីហេតុផល ដែលប៉ុលបានសរសើរដល់ពួកបរិសុទ្ធនៅថែស្សាឡូនីច ។

- **ហេតុអ្វីប៉ុលសរសើរដល់ពួកបរិសុទ្ធនៅថែស្សាឡូនីច ?**
- **យោងតាម ខទី ៥ តើពួកបរិសុទ្ធទាំងនោះនឹងទទួលបានរង្វាន់អ្វីខ្លះពេលស៊ូទ្រាំនឹងការផ្ទុយ និងទុក្ខវេទនាដោយ « អំណត់ និងសេចក្តីជំនឿ » ?**
- **តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះទាក់ទងនឹងរបៀបដែលយើងនឹងបានពរជ័យ ប្រសិនបើយើងស៊ូទ្រាំនឹងការផ្ទុយ និងទុក្ខវេទនាដោយអំណត់ អត់ធ្មត់ និងសេចក្តីជំនឿនោះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ ប្រសិនបើយើងស៊ូទ្រាំនឹងការផ្ទុយ និងទុក្ខវេទនាដោយអំណត់ និងសេចក្តីជំនឿ នោះយើងនឹងបានរាប់ថាសក្តិសមនឹងនគរព្រះហើយ) ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរអេស.អុជដូហ្វ នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកអត្ថន័យនៃការស៊ូទ្រាំដោយអំណត់ ៖



« ការអត់ធ្មត់ពុំមែនជាការចាំរងតែអំពើ ឬក៏ពុំមែនជាការពុំធ្វើអ្វីសោះ ដោយសារតែការភ័យខ្លាចរបស់យើងនោះឡើយ ។ «ការអត់ធ្មត់មានន័យថាជាការរង់ចាំ និង ការស៊ូទ្រាំយ៉ាងសកម្ម ។ វាមានន័យថា ការនៅជាប់នឹងអ្វីមួយ ហើយធ្វើឲ្យអស់ពីលទ្ធភាពរបស់យើង—ធ្វើការ មានសង្ឃឹម ហើយអនុវត្តសេចក្តីជំនឿ ទ្រាំទ្រនឹងការលំបាកដោយចិត្តមុតមាំ សូម្បីតែវាត្រូវពន្យាពេលចំពោះបំណងប្រាថ្នានៅក្នុងដួងចិត្តយើងក្តី ។ ការអត់ធ្មត់ពុំគ្រាន់តែជាការប្រកាន់ខ្ជាប់ដោយធម្មតានោះទេ វាគឺជាប្រកាន់ខ្ជាប់បានយ៉ាងល្អ ! » (« Continue in Patience » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៥៧) ។

- **យោងតាមប្រធាន អុជដូហ្វ តើការស៊ូទ្រាំដោយអំណត់មានន័យដូចម្តេច ?**
- **ហេតុអ្វីយើងត្រូវការសេចក្តីជំនឿដើម្បីស៊ូទ្រាំនឹងការផ្ទុយ និងទុក្ខវេទនាដោយអំណត់ ?**

សូមអញ្ជើញសិស្សឲ្យពិចារណាពីមនុស្សម្នាក់ដែលពួកគេស្គាល់ ឬធ្លាប់អានពីគាត់ពីក្នុងព្រះគម្ពីរ ដែលគាត់បានស៊ូទ្រាំនឹងការលំបាក និងទុក្ខវេទនាដោយស្មោះត្រង់ និងអំណត់ ។

- **តើអ្នកគិតថានរណាបានបង្ហាញពីរបៀបការស៊ូទ្រាំនឹងឧបសគ្គ និងទុក្ខវេទនាដោយស្មោះត្រង់ និងអំណត់អត់ធ្មត់ ?**

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីឧបសគ្គ និងទុក្ខវេទនាដែលពួកគេកំពុងជួបប្រទះនៅសព្វថ្ងៃនេះ ហើយកំណត់ពីរបៀបដែលពួកគេអាចស៊ូទ្រាំនឹងការប្រឈមទាំងនេះដោយអំណត់ និងសេចក្ដីជំនឿ ។ សូមលើកទឹកចិត្តឲ្យពួកគេអធិស្ឋានសូមជំនួយ ។

សូមពន្យល់ថា ដូចដែលបានកត់ត្រាទុកនៅក្នុង ថៃស្សាឡូនីចទី ២ ១:៦–១០ ប៉ុលបានពន្យាករអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមចែកសិស្សជាក្រុម ដែលមួយក្រុម។មានគ្នាពីរ ឬបីនាក់ ។ សូមអញ្ជើញក្រុមនីមួយ។ឲ្យអាន ថៃស្សាឡូនីចទី ២ ១:៦–១០ រួមគ្នា ហើយពិភាក្សាសំណួរទាំងឡាយខាងក្រោម ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន ឬ ចែកក្រដាសដល់ពួកគេ) ។ សូមឲ្យសិស្សកត់ត្រាចម្លើយរបស់ពួកគេចូលក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើពាក្យ និងឃ្លាអ្វីខ្លះ ដែលប៉ុលបានប្រើ ដើម្បីពិពណ៌នាអំពីការយាងមកជាលើកទីពីរ ?
- តើនឹងមានអ្វីកើតឡើងចំពោះមនុស្សសុចរិត នៅពេលការយាងមកជាលើកទីពីរមកដល់ ?
- តើនឹងមានអ្វីកើតឡើងចំពោះមនុស្សទុច្ចរិត នៅពេលការយាងមកជាលើកទីពីរមកដល់ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់អំពីការរកឃើញរបស់ក្រុមពួកគេដល់សិស្សក្នុងថ្នាក់ ។ សូមសរសេរសេចក្ដីពិតនេះនៅលើក្តារខៀន ៖ **នៅការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សសុចរិតនឹងបានសង្រ្គោះ ហើយមនុស្សទុច្ចរិតនឹងត្រូវបំផ្លាញចោល ។**

- តើអ្នកគិតថា ពួកសុចរិតនឹងបានសង្រ្គោះពីអ្វី ?
- តើគោលលទ្ធិនេះអាចលួងលោមចិត្តអ្នក ដែលកំពុងស៊ូទ្រាំនឹងការលំបាកនៅបច្ចុប្បន្ននេះ ដោយសារតែការតាំងចិត្តចំពោះព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេចដែរ ?

ចូរសុំឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេធ្លាប់ងឿងឆ្ងល់ថា តើការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទនឹងមកដល់នៅពេលណា ។ សូមពន្យល់ថា ពួកបរិសុទ្ធនៅថៃស្សាឡូនីចបានងឿងឆ្ងល់ពីរឿងនេះដែរ ហើយប៉ុលបានព្រួយចិត្តខ្លាចថា ពួកគេអាចយល់ខុស ។

សូមអញ្ជើញសិស្សម្នាក់អានថៃស្សាឡូនីចទី ២ ២:១–២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល តើប៉ុលបានគិតថា អ្វីទៅដែលពួកបរិសុទ្ធនៅថៃស្សាឡូនីចអាចនឹងធ្វើការសន្និដ្ឋានអំពីពេលវេលានៃការយាងមកជាលើកទីពីរ ។

- តើប៉ុល *មិន* ចង់ឲ្យពួកថៃស្សាឡូនីចជឿលើអ្វីខ្លះ ដែលទាក់ទងនឹងពេលវេលានៃការយាងមកជាលើកទីពីរ ? (ថាវានឹងកើតឡើងឆាប់ៗ) ។

ចូរសុំឲ្យសិស្សអាន ថៃស្សាឡូនីចទី ២ ២:៣ ដោយស្ងាត់ស្ងៀមរកមើលថាតើប៉ុលបានថ្លែងថាអ្វីខ្លះនឹងកើតឡើងពីមុនការយាងមកជាលើកទីពីរ ។ សូមពន្យល់ថា ឃ្លា « ថ្ងៃនោះ » សំដៅទៅលើការយាងមកជាលើកទីពីរ ហើយ « សេចក្ដីក្បត់ » សំដៅលើការក្បត់សាសនា ។

- តើយើងអាចរៀនសេចក្ដីពិតអ្វីខ្លះ អំពីអ្វីដែលនឹងកើតឡើងពីមុនការយាងមកជាលើកទីពីរមកពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែស្គាល់សេចក្ដីពិតមួយដែលស្រដៀងគ្នានេះ ៖ **ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ មានការក្បត់សាសនាមួយនឹងកើតឡើង**) ។

សូមចង្អុលបង្ហាញថា នៅក្នុងខគម្ពីរទាំងនេះ ប៉ុលបានណែនាំឲ្យសមាជិកសាសនាចក្រនៅក្នុងជំនាន់របស់លោក គួរតែខ្វល់ខ្វាយឲ្យបានច្រើនពីការក្បត់សាសនាដែលបានចាប់ផ្តើមរួចទៅហើយនៅក្នុងចំណោមពួកគេ ជាជាងអំពីពេលវេលានៃការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។

ដើម្បីជួយសិស្សឲ្យយល់បន្ថែមទៀតអំពីអត្ថន័យនៃការក្បត់សាសនា សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវការពន្យល់ខាងក្រោមនេះ ៖

« បន្ទាប់ពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទុច្ចរិតបានធ្វើទុក្ខបុកម្នេញដល់សាវក និង សមាជិកនៃសាសនាចក្រ និង បានសំឡាប់ពួកគេជាច្រើននាក់ទៀតផង ។ ជាមួយនឹងសេចក្ដីស្លាប់របស់សាវក កូនសោនៃបព្វជិតភាព និងការដឹកនាំសិទ្ធិអំណាចបព្វជិតភាពត្រូវបានដកចេញពីផែនដី ។ សាវកបានរក្សាគោលលទ្ធិនៃដំណឹងល្អឲ្យនៅបរិសុទ្ធ និងការពាររបៀបរៀបរយ និងបទដ្ឋាននៃភាពសក្តិសមសម្រាប់សមាជិកសាសនាចក្រ ។ ដោយសារគ្មានសាវក ក្រោយមកគោលលទ្ធិត្រូវបានកែប្រែ ហើយមានការផ្លាស់ប្តូរដោយគ្មានការអនុញ្ញាតនៅក្នុងការរៀបចំសាសនាចក្រ និងពិធីបរិសុទ្ធនៃបព្វជិតភាព ដូចជាពិធីបុណ្យជ្រមុជទឹក និងការប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ » (*ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* | ឆ្នាំ ២០០៤ | ទំព័រ ៣៥) ។

- ដោយផ្អែកទៅលើការយល់ដឹងអំពីការក្បត់សាសនានេះ ហេតុអ្វីការស្តារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងសាសនាចក្ររបស់ទ្រង់គឺជារឿងចាំបាច់ ?

សូមពន្យល់ថា « មនុស្សដែលជាគ្ងូបាប » ដែលបានលើកឡើងនៅក្នុង ថៃស្សាឡូនីចទី ២ ២:៣ សំដៅទៅលើសាតាំង ។ ការស្តារឡើងវិញនៃដំណឹងល្អ រួមបញ្ចូលទាំងការចេញមកនៃព្រះគម្ពីរមរមន បាន « លេចមក » (ខទី ៣) នូវការបោកបញ្ឆោតរបស់សាតាំង និងពួកពលបរិវាររបស់វា ។

សូមសង្ខេប ថៃស្សាឡូនីចទី ២ ២:៤–១៧ ដោយពន្យល់ថា ប៉ុលបានព្យាករថា ព្រះអម្ចាស់នឹងអនុញ្ញាតឲ្យសាតាំងបោកបញ្ឆោតដល់ពួជពង្សរបស់ផែនដីរហូតដល់ការយាងមកជាលើកទីពីរ ។ ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យ « មាំមួន »នៅក្នុងកិច្ចការដែលលោកបានបង្រៀនដល់ពួកគេ (ខទី ១៥) ។

ថៃស្សាឡូនីចទី ២

២:១–៣ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើននូវការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ឲ្យសិស្សគូសចំណាំចំណេះចំណានខគម្ពីរនេះតាមរបៀបដាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកយោងទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

ថៃស្សាឡូនីច ទី ២ ៣

ប៉ុលព្រមានដល់ជនខ្វះវិន័យ ហើយប្រកាសពីភាពខ្លួនទីពឹងខ្លួន

សូមពន្យល់ថា នៅគ្រានោះប៉ុលបានសរសេរសំបុត្រទីពីររបស់លោកដល់ពួកថៃស្សាឡូនីច ដែលសមាជិកសាសនាចក្របានធ្វើពិធីបរិភោគអាហារភ្ជាប់ជាមួយនឹងការទទួលទានសាក្រាម៉ង់ជាទៀងទាត់ ។ ប៉ុន្តែមានសមាជិកមួយចំនួននៅថៃស្សាឡូនីចបានចូលរួមនៅក្នុងពិធីបរិភោគអាហារនោះ ប៉ុន្តែមិនព្រមជួយផ្គត់ផ្គង់ ឬរៀបចំអាហារឡើយ ។

- តើបញ្ហាអ្វីដែលអាចកើតចេញមកពីស្ថានភាពនេះ ?

សូមសង្ខេប ថៃស្សាឡូនីចទី ២ ៣:១–៩ ដោយពន្យល់ថា ប៉ុលបានប្រាប់ដល់ពួកបរិសុទ្ធស្មោះត្រង់ ហើយបានព្រមានពួកគេអំពីការសេពគប់នឹងជនដែល « ប្រព្រឹត្តខុសរបៀប » ឬគ្មានវិន័យ (ខទី ៦) ។ ប៉ុលក៏បានសរសេរផងដែរថា លោក និងដៃគូលោកបានធ្វើជាគំរូពីភាពខ្លួនទីពឹងខ្លួនខាងសាច់ឈាមដោយការធ្វើការផ្គត់ផ្គង់ដល់ខ្លួនឯង ។

សូមអញ្ជើញសិស្សម្នាក់អាន ថៃស្សាឡូនីចទី ២ ៣:១០–១៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យរៀងតាមរកមើលថា តើប៉ុលបានណែនាំឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះទាក់ទងនឹងជនដែលមិនព្រមធ្វើការ ។

- យោងតាម ខទី ១២តើប៉ុលបានឲ្យដំបូន្មានអ្វីខ្លះ ដល់ជនដែលមិនព្រមធ្វើការ ? (ការ« បរិភោគបាយរបស់ខ្លួនគេចុះ ទាំងធ្វើការ » ឬការមានភាពខ្លួនពឹងខ្លួនដោយផ្គត់ផ្គង់សម្រាប់សេចក្តីត្រូវការរបស់ខ្លួនឯង) ។
- យោងតាម ខទី ១៣តើប៉ុលបានផ្តល់ឱវាទអ្វីបន្ថែមទៀតទៅដល់ពួកបរិសុទ្ធស្មោះត្រង់ ?
- តើឃ្លាថា « កុំឲ្យរសាយចិត្តខាងឯការល្អឡើយ » មានន័យដូចម្តេច ?
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនមកពីខគម្ពីរទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរតែស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានេះ ៖ **យើងត្រូវបានបង្គាប់ឲ្យខិតខំដើម្បីមានភាពខ្លួនទីពឹងខ្លួន ហើយជួយដល់មនុស្សដទៃទៀត**) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមមកពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ឲ្យឮៗ ។ សូមឲ្យសិស្សស្តាប់រកវិធីដែលយើងអាចខិតខំដើម្បីមានភាពខ្លួនទីពឹងខ្លួនបាន ។

« ពរជ័យមួយក្នុងចំណោមពរជ័យជាច្រើននៃការងារ គឺការអភិវឌ្ឍន៍ ការពឹងផ្អែកលើខ្លួនឯង ។ នៅពេលដែលអ្នកពឹងផ្អែកលើខ្លួនឯង អ្នកប្រើពរជ័យទាំងឡាយ និង សមត្ថភាពដែលព្រះបានប្រទានដល់អ្នកឲ្យថែរក្សាខ្លួនអ្នក និងគ្រួសាររបស់អ្នក និងដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់អ្នកផ្ទាល់ ។ ការពឹងផ្អែកលើខ្លួនឯងមិនមែនមានន័យថា អ្នកត្រូវតែមានលទ្ធភាពធ្វើអ្វីៗទាំងអស់ដោយខ្លួនអ្នកផ្ទាល់នោះទេ ។ ដើម្បីមានភាពពឹងផ្អែកលើខ្លួនឯងពិតប្រាកដ នោះអ្នកត្រូវតែរៀនពីរបៀបដើម្បីធ្វើការជាមួយនឹងអ្នកដទៃ និងងាកទៅរកព្រះអម្ចាស់សម្រាប់ជំនួយ និងកម្លាំងរបស់ទ្រង់ ។

« ចូរចងចាំថា ព្រះមានកិច្ចការដ៏មហិមាឲ្យអ្នកធ្វើ ។ ទ្រង់នឹងប្រទានពរជ័យដល់អ្នកនៅក្នុងកិច្ចខិតខំរបស់អ្នក ដើម្បីសម្រេចកិច្ចការនោះ » (*ដើម្បីកម្លាំងនៃយុវជន* | កូនសៀវភៅ ឆ្នាំ ២០១១ | ទំព័រ ៤១) ។

- តើយើងអាចខិតខំឲ្យមានភាពខ្លួនទីពឹងខ្លួនបានយ៉ាងដូចម្តេច ?
- តើពរជ័យមួយចំនួននៃភាពខ្លួនទីពឹងខ្លួនមានអ្វីខ្លះ ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងខិតខំឲ្យមានភាពខ្លួនទីពឹងខ្លួន នោះព្រះអម្ចាស់នឹងជួយយើងឲ្យបំពេញសេចក្តីត្រូវការរបស់យើង ហើយជួយយើងឲ្យរកឃើញដំណោះស្រាយសម្រាប់បញ្ហារបស់យើង ។

ចូរសុំឲ្យសិស្សពិចារណាថាពួកគេអាចធ្វើអ្វីខ្លះ ដើម្បីប្រែជាកាន់តែមានភាពខ្លួនទីពឹងខ្លួននៅពេលនេះ និងពេលអនាគត ។ សូមអញ្ជើញពួកគេឲ្យដាក់គោលដៅមួយដែលនឹងជួយពួកគេឲ្យប្រែជាកាន់តែមានភាពខ្លួនទីពឹងខ្លួន ហើយលើកទឹកចិត្តពួកគេឲ្យស្វែងរកជំនួយរបស់ព្រះអម្ចាស់នៅក្នុងការសម្រេចគោលដៅនោះ ។

សូមសង្ខេប ថៃស្សាឡូនីចទី ២ ៣:១៤–១៨ ដោយពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោកដោយទូន្មានដល់ពួកបរិសុទ្ធកុំឲ្យខ្ជិលច្រអូស ហើយដកខ្លួនពីមនុស្សខ្ជិល ហើយមនុស្សរំខានឆាឆៅ ។ ប៉ុន្តែពួកបរិសុទ្ធមិនត្រូវចាត់ទុកពួកគេជាសត្រូវឡើយ ប៉ុន្តែទុកពួកគេជាបងប្អូនប្រុសស្រីនៅក្នុងដំណឹងល្អវិញ ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

ចំណេះចំណានខគម្ពីរ—ថៃស្សាឡូនីចទី ២ ២:១–៣

សូមអញ្ជើញសិស្សម្នាក់ៗឲ្យប្រើជំនួយការសិក្សាព្រះគម្ពីរ (ដូចជា សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ដើម្បីស្វែងរកបទគម្ពីរមួយទៀតក្រៅពី ថៃស្សាឡូនីចទី ២ ២:១–៣ ដែលបង្រៀនអំពីការក្បត់សាសនា ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទគម្ពីរដែលពួកគេបានរកឃើញ ហើយពន្យល់ពីអ្វីដែលបទគម្ពីរទាំងនេះបង្រៀនអំពីការក្បត់សាសនា ។ អ្នកគួរសរសេរសេចក្តីយោងដែលពួកគេបានរកឃើញនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យជ្រើសយកបទគម្ពីរមួយជាសេចក្តីយោងបទគម្ពីរទៅនឹង ថៃស្សាឡូនីចទី ២ ២:១–៣ ។ អ្នកអាចនឹងចង់ណែនាំឲ្យពួកគេសរសេរសេចក្តីយោងនេះនៅរឹមទំព័រនៃព្រះគម្ពីររបស់ពួកគេក្បែរថៃស្សាឡូនីចទី ២ ២:១–៣ ។ សូមពន្យល់ថា ចំណេះចំណានបទគម្ពីរនេះតែងតែត្រូវបានប្រើដើម្បីបង្រៀនអំពីការក្បត់សាសនា និងពីសេចក្តីត្រូវការនៃការស្តារឡើងវិញ ។ សូមអញ្ជើញសិស្សឲ្យប្រើ ថៃស្សាឡូនីចទី ២ ២:១–៣ និងសេចក្តីយោងបទគម្ពីរមួយដែលបានសរសេរនៅលើក្តារខៀនដើម្បីបង្រៀនអំពីការក្បត់សាសនា ។

សេចក្តីណែនាំអំពី

សំបុត្រទីមួយរបស់ប៉ុលដល់ពួកធីម៉ូថេ

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងគម្ពីរធីម៉ូថេទី ១ យើងអានថា ប៉ុលបានទុទ្ទានដល់ធីម៉ូថេ ជាថ្នាក់ដឹកនាំសាសនាចក្រម្នាក់នៅអេភេសូរ ដើម្បីធ្វើឲ្យប្រាកដថា គោលលទ្ធិត្រឹមត្រូវត្រូវបានបង្រៀន ហើយមិនអនុញ្ញាតឲ្យភាពខុសឆ្គងដែលពេញនិយមមកអុសទាញយើងឲ្យឃ្លាតចេញពីការបង្រៀននៃដំណឹងល្អនោះទេ ។ លោកបានបង្រៀនធីម៉ូថេអំពីតំណែងជាបឹស្សព និងឪកុន ហើយបានពិភាក្សាពីគុណសម្បត្តិសម្រាប់អស់អ្នកដែលបានបម្រើនៅក្នុងតួនាទីទាំងនេះ ។ ប៉ុលក៏បានរ៉ាយរ៉ាប់ពីការដឹងគុណដ៏ជ្រាលជ្រៅរបស់លោកចំពោះសេចក្តីមេត្តាករុណា ដែលលោកបានទទួលពីព្រះយេស៊ូវគ្រីស្ទ កាលលោកបានប្រែចិត្តជឿផងដែរ ។ ការសិក្សាធីម៉ូថេទី ១ អាចជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីសារៈសំខាន់នៃការបង្រៀនគោលលទ្ធិត្រឹមត្រូវនៅក្នុងសាសនាចក្រ ។ សិស្សក៏អាចមានការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសេចក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ និងចំពោះតួនាទីដ៏សំខាន់របស់បឹស្សព និងថ្នាក់ដឹកនាំផ្សេងទៀតក្នុងសាសនាចក្រផងដែរ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុលសរសេរធីម៉ូថេទី ១ (សូមមើល ធីម៉ូថេទី ១ ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

សំបុត្រទីមួយរបស់ប៉ុលដល់ធីម៉ូថេទំនងជាត្រូវបានសរសេរឡើងប្រមាណជាចន្លោះពេល គ.ស. ៦៤ និង ៦៥ ប្រហែលជាកាលដែលប៉ុលនៅម៉ាសេដូនី (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org, ធីម៉ូថេទី ១ ១:៣) ។ ពីមុនសរសេរសំបុត្រនេះ ប៉ុលត្រូវបានដោះលែងពីការដាប់ឃុំរយៈពេលពីរឆ្នាំរបស់លោក (ជាប់ឃុំនៅក្នុងផ្ទះ) នៅរ៉ូម ហើយទំនងជាធ្វើដំណើរទៅតំបន់ជាច្រើនដែលលោកបានស្ថាបនាសាខារបស់សាសនាចក្រកាលពីមុន (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល») ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយតើហេតុអ្វី ?

ប៉ុលបានសរសេរសំបុត្រនេះដល់ធីម៉ូថេ ដែលធ្លាប់បម្រើជាមួយនឹងលោកនៅក្នុងដំណើរផ្សាយសាសនាលើកទីពីររបស់លោក (សូមមើល កិច្ចការ ១៦:៣) ។ បន្ទាប់ពីបេសកកម្មរបស់ពួកលោក ធីម៉ូថេបានបន្តធ្វើជាអ្នកផ្សព្វផ្សាយសាសនា និងជាថ្នាក់ដឹកនាំសាសនាចក្រម្នាក់ជំស្នេះត្រង់មួយរូប (សូមមើល កិច្ចការ ១៩:២២, ភីលីព ២:១៩) និងជាមនុស្សម្នាក់ដែលប៉ុលទុកចិត្តបំផុត (សូមមើល កូរិនថូសទី១ ៤:១៧) ។ ប៉ុលបានហៅធីម៉ូថេថា « ជាកូនពិតក្នុងសេចក្តីជំនឿ » របស់លោក (ធីម៉ូថេទី ១ ១:២) ។ ឪពុករបស់ធីម៉ូថេគឺជាសាសន៍ដទៃម្នាក់ដែលជាជនជាតិក្រិក ប៉ុន្តែគាត់មានម្តាយ និងដីដូនជីស្មោះត្រង់ដែលជាសាសន៍យូដា ដែលបានបង្រៀនគាត់ ហើយបានជួយគាត់ឲ្យរៀនពីបទគម្ពីរ (សូមមើល កិច្ចការ ១៦:១, ធីម៉ូថេទី ២ ១:៥, ៣:១៥) ។

នៅគ្រាដែលលោកសរសេរសំបុត្រនេះ ធីម៉ូថេកំពុងបម្រើជាថ្នាក់ដឹកនាំសាសនាចក្រម្នាក់នៅអេភេសូរ (សូមមើល ធីម៉ូថេទី១ ១:៣) ។ ប៉ុលបានឲ្យតម្រុយថា មានសមាជិកមួយចំនួនបានសង្ស័យពីសមត្ថភាពដឹកនាំរបស់ធីម៉ូថេ ដោយសារគាត់នៅក្មេង (សូមមើល ធីម៉ូថេទី ១ ៤:១២) ។ ប៉ុលបានមានបំណងចង់ទៅលេងធីម៉ូថេដោយផ្ទាល់ ប៉ុន្តែលោកមិនប្រាកដថា លោកនឹងអាចធ្វើវាបានដៃឬអត់នោះទេ (សូមមើល ធីម៉ូថេទី ១ ៣:១៤ , ៤:១៣) ។ ប៉ុលបានសរសេរសំបុត្រទៅធីម៉ូថេ ដើម្បីជួយឲ្យថ្នាក់ដឹកនាំសាសនាចក្រវ័យក្មេងរូបនេះយល់ពីភាពឮកិច្ចការរបស់ខ្លួនកាន់តែប្រសើរ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

សំបុត្ររបស់ប៉ុលដែលគេស្គាល់ថាជាធីម៉ូថេទី១ ធីម៉ូថេទី២ និងទីតុស ជារឿយៗត្រូវបានគេហៅថាជាសំបុត្រគ្រូគង្វាល ដោយសារវាមាននូវពាក្យទុទ្ទានរបស់ប៉ុលទៅកាន់ពួកគ្រូគង្វាល ឬថ្នាក់ដឹកនាំទាំងឡាយក្នុងសាសនាចក្រ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ *គ្រូគង្វាល* ជាពាក្យចេញពី ពាក្យឡាតាំងថា « អ្នកគង្វាលចៀម » ។

ប៉ុលបានប្រាប់ពីសេចក្តីណែនាំ ដើម្បីជួយធីម៉ូថេឲ្យរកឃើញបុគ្គលសក្តិសមដើម្បីបម្រើជាបឹស្សព ឬឪកុន (សូមមើល ធីម៉ូថេទី១ ៣) ។ សេចក្តីណែនាំរបស់ប៉ុលបានជួយបង្ហាញពីការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំសាសនាចក្រដើម្បីផ្តត់ផ្តង់ដល់សេចក្តីត្រូវការខាងសាច់ឈាម និងខាងវិញ្ញាណរបស់សមាជិក (សូមមើល ធីម៉ូថេទី១ ៥) ។ ប៉ុលបានលើកឡើងពីគំនិតខុសឆ្គងរួមនៃការអនុវត្តនេះផងដែរ—ជាជំនឿជឿថាជីវភាពខាងផ្លូវវិញ្ញាណដ៏ធំអាចទទួលបានតាមរយៈការជំកពិសោធន៍ដោយខ្លួនឯងយ៉ាងតឹងរឹង ។ ឧទាហរណ៍ ប៉ុលបានព្រមានថា សមាជិកសាសនាចក្រមួយចំនួននឹងក្បត់សាសនា ហើយលើកកម្ពស់ជំនឿថា អាពាហ៍ពិពាហ៍គួរតែត្រូវបានហាមឃាត់ (សូមមើល ធីម៉ូថេទី ១ ៤:១–៣) ។ ដើម្បីតទល់នឹងរឿងនេះ និងឥទ្ធិពលក្រៅសាសនាផ្សេងទៀត ប៉ុលបានណែនាំដល់ធីម៉ូថេឲ្យបង្រៀនអំពីគោលលទ្ធិត្រឹមត្រូវ (សូមមើល ធីម៉ូថេទី១ ១:៣–៤, ១០, ៤:១–៦, ១៣, ១៦) ។

គម្រោង

ធីម៉ូថេទី១ ១ ប៉ុលព្រមានទាស់នឹងការបង្រៀនខុសឆ្គងនានា ។ លោករុងរឿងនៅក្នុងព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលបង្ហាញប្រទានសេចក្តីមេត្តាករុណាដ៏ធំដើម្បីសង្គ្រោះលោក ។ ប៉ុលហៅខ្លួនលោកថាជាអ្នកធ្វើបាប « លេខ ១ » ឬអាក្រក់បំផុត (ធីម៉ូថេទី១ ១:១៥) ឬដោយនិយាយបញ្ជៀងពីការបដិសេធរបស់លោកទៅលើពួកគ្រីស្ទាន ពីមុនលោកបានប្រែចិត្តជឿ ។ ប៉ុលបានអះអាងជាថ្មីដល់មនុស្សជំទៃថា សេចក្តីមេត្តាករុណារបស់ព្រះគ្រីស្ទក៏នឹងជួយដល់ពួកគេផងដែរ ។

ធីម៉ូថេទី១ ២–៣ ប៉ុលបង្រៀនអំពីសេចក្តីត្រូវការចំពោះការអធិស្ឋាន និងការថ្វាយបង្គំត្រឹមត្រូវ ។ លោកបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាថ្លៃលោះសម្រាប់មនុស្សទាំងអស់គ្នា ហើយជាអង្គបង្រួបបង្រួមជាមួយនឹងព្រះវរបិតា ។ លោកណែនាំដល់បុរសស្ត្រីពីរបៀបរៀបចំតំរិយាបថនៅក្នុងពេលថ្វាយបង្គំ ។ លោកគូសបញ្ជាក់ពីគុណសម្បត្តិសម្រាប់បឹស្សព និងឪកុន ។ លោកពន្យល់ថា អាថ៌កំបាំងនៃព្រះគឺជាការបន្ទាបខ្លួនរបស់ព្រះយេស៊ូវគ្រីស្ទ ព្រះជន្មដ៏ល្អឥតខ្ចោះរបស់ទ្រង់នៅលើផែនដី និងការយាងឡើងទៅរកសិរីល្អរបស់ទ្រង់ ។

ធីម៉ូថេទី១ ៤ ប៉ុលព្រមានធីម៉ូថេថា មនុស្សមួយចំនួននឹងត្រូវបានបោកបញ្ឆោត ដោយការបង្រៀនខុសឆ្គងទាក់ទងនឹងអាពាហ៍ពិពាហ៍ និងទម្លាប់នៃ ការបរិភោគអាហារតំណម ។ លោកថ្លែងពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ និងពីការទទួលយកការបង្កបង្កើតរបស់ព្រះដោយអំណរគុណ ។ ប៉ុលបង្រៀនធីម៉ូថេពីរបៀបប្រឈមមុខនឹងការបង្រៀនខុសឆ្គងនៅជំនាន់គាត់ និងជំនាន់ក្រោយៗទៀត ។

ធីម៉ូថេទី១ ៥–៦ ប៉ុលផ្តល់ការណែនាំដល់ធីម៉ូថេដើម្បីជួយគាត់ឲ្យធ្វើការងារបម្រើស្របតាមសេចក្តីត្រូវការរបស់ជនចាស់ជរា យុវជន ស្ត្រីមេម៉ាយ ពួកចាស់ទុំ និងពួកបាវបម្រើ ។ ប៉ុលពិពណ៌នាប្រាប់ធីម៉ូថេពីគ្រូបង្រៀនក្លែងក្លាយទាំងឡាយ ។ លោកព្រមានថា « ការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង » (ធីម៉ូថេទី១ ៦:១០) ហើយលោកណែនាំធីម៉ូថេពីរបៀបដែលពួកបរិសុទ្ធអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

ធីម៉ូថេទី ១

សេចក្តីផ្តើម

ប៉ុលបានសរសេរទៅធីម៉ូថេ ដែលជាថ្នាក់ដឹកនាំបព្វជិតភាពម្នាក់នៅអេភេសូរ ហើយបានទូន្មានគាត់ឲ្យធ្វើឲ្យប្រាកដថា គោលលទ្ធិពិតត្រូវបានបង្រៀន ។ លោកបានបង្កើតជាលក្ខណៈសម្បត្តិសម្រាប់ប៊ីស្សព និងឌីកុន ហើយទូន្មានដល់ធីម៉ូថេឲ្យធ្វើជាគំរូដល់ពួកអ្នកជឿ ។ ប៉ុលជាស់តឿនដល់ពួកបរិសុទ្ធឲ្យមើលថែជនក្រីក្រ និងស្ត្រីមេម៉ាយ ។ លោកបានបញ្ចប់សំបុត្ររបស់លោកដោយបង្រៀនថា « ការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង » (ធីម៉ូថេទី១ ៦:១០) ។

យោបល់សម្រាប់ការបង្រៀន

ធីម៉ូថេទី១ ១–៣

ប៉ុលបានណែនាំធីម៉ូថេអំពីការទទួលខុសត្រូវរបស់គាត់នៅក្នុងការគ្រប់គ្រងលើសាសនាចក្រ

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវដំណើររឿងដូចខាងក្រោម ដែលប្រាប់ដោយប្រធាន ថូម៉ាស អេស ម៉នសុន ៖



« ខ្ញុំនឹកចាំអំពីបទពិសោធន៍មួយ ដែលខ្ញុំមានកាលពីជាច្រើនឆ្នាំកន្លងទៅ ពេលខ្ញុំបានបម្រើជាប៊ីស្សព ។ អំឡុងពេលបើកកម្មវិធីការប្រជុំបព្វជិតភាពរបស់យើងនាព្រឹកថ្ងៃអាទិត្យមួយ យើងបានកំពុងរៀបចំដើម្បីតែងតាំងយុវជនម្នាក់ឲ្យកាន់តំណែងសង្ឃ ។ ទីប្រឹក្សាជាន់ខ្ពស់មួយរូបបានមកជួរដរបស់យើងនាថ្ងៃនោះ ដែលគាត់បានបម្រើជាអ្នកធ្វើការក្នុងព្រះវិហារបរិសុទ្ធផងដែរ ។ នៅពេលខ្ញុំរៀបចំឲ្យយុវជននោះអង្គុយចុះបែរមុខទៅរកក្រុមជំនុំ ដើម្បីយើងអាចចាប់ផ្តើមការតែងតាំង ស្រាប់តែទីប្រឹក្សាជាន់ខ្ពស់រូបនោះបានបញ្ឈប់ខ្ញុំ ហើយបាននិយាយថា ‹ ប៊ីស្សព ខ្ញុំតែងតែឲ្យអ្នកទាំងឡាយដែលត្រូវទទួលការតែងតាំងបែរមុខទៅរកព្រះវិហារបរិសុទ្ធ › ។ គាត់បានរៀបកៅអីឡើងវិញដើម្បីឲ្យយុវជននោះ អង្គុយបែរមុខទៅរកព្រះវិហារបរិសុទ្ធ ។ រំពេចនោះខ្ញុំបានដឹងថា វាជាការអនុវត្តដែលគ្មានការអនុញ្ញាត » (« Opening Remarks » [worldwide leadership training meeting ខែ វិច្ឆិកា ឆ្នាំ ២០១០] lds.org/broadcasts) ។

ចូរពន្យល់ថា ក្នុងនាមជាប៊ីស្សព ប្រធាន ម៉នសុន ត្រូវបានអនុញ្ញាតឲ្យធ្វើជាអធិបតីលើកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងវួដរបស់គាត់ ពុំមែនទីប្រឹក្សាជាន់ខ្ពស់នោះទេ ។

- តើអ្វីនឹងអាចជាគ្រោះថ្នាក់ដ៏ខ្លាំងបំផុតដល់ប៊ីស្សព ឬប្រធានសាខាដែលអនុញ្ញាតឲ្យមានការអនុវត្តដែលគ្មានការអនុញ្ញាតដូច្នេះ ?

ចូរពន្យល់ថា សាវកប៉ុលបានសរសេរសំបុត្រទៅកាន់ធីម៉ូថេ ដែលជាអ្នកដឹកនាំបព្វជិតភាពវ័យក្មេងម្នាក់នៅក្រុងអេភេសូរ ។ នៅក្នុងសាខានៃសាសនាចក្រដែលគាត់ធ្វើជាអធិបតី ធីម៉ូថេបានប្រឈមនឹងឧបសគ្គនានា ដែលស្រដៀងគ្នានឹងបញ្ហាទាំងឡាយដែលប្រធាន ម៉នសុន បានជួបដែរ ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗចេញមកពី ធីម៉ូថេទី១ ១:៣–៧ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ការទទួលខុសត្រូវអ្វីខ្លះ ដែលប៉ុលបានផ្តល់ទៅឲ្យធីម៉ូថេ ។ ចូរពន្យល់ថា៣ពាក្យ*រឿងរ៉ាវ*(ខទី ៤) សំដៅទៅលើការបង្រៀនក្លែងក្លាយ ការស្តាប់តាម « ពង្សាវតាដែលមិនចេះអស់មិនចេះហើយ » (ខទី ៤) សំដៅទៅលើទំនៀមទម្លាប់ក្លែងក្លាយ ដែលសេចក្តីសង្គ្រោះកើតមានតែចំពោះអ្នកទាំងឡាយណា ដែលជាជម្រើសមកពីព្ងជរបស់អ័ប្រាហាំ ដែលជាញឹកញាប់ត្រូវបានគេស្គាល់តាមរយៈពង្សាវតាដ៏វែងអន្លាយឬមិនចេះចប់មិនចេះហើយ និង៣ពាក្យ « សម្តីដែលឥតប្រយោជន៍ » (ខទី ៦) សំដៅទៅលើការពិភាក្សាឥតន័យ ។

- យោងតាមខទី ៣–៤តើការទទួលខុសត្រូវអ្វីខ្លះ ដែលប៉ុលបានផ្តល់ដល់ធីម៉ូថេ ?
- យោងតាមខទី ៦–៧ហេតុអ្វីក៏វាសំខាន់សម្រាប់ធីម៉ូថេ ដើម្បីបំពេញតាមការទទួលខុសត្រូវនេះ ?
- តើសេចក្តីពិតអ្វីដែលយើងអាចរៀនមកពីដំបូន្មានរបស់ប៉ុលទៅកាន់ធីម៉ូថេ អំពីការទទួលខុសត្រូវរបស់អ្នកដឹកនាំបព្វជិតភាព ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់ពីសេចក្តីពិតមួយដែលស្រដៀងនឹងសេចក្តីពិតខាងក្រោមនេះ ៖ **អ្នកដឹកនាំបព្វជិតភាពមានការទទួលខុសត្រូវមើលឲ្យប្រាកដថា គោលលទ្ធិពិត និងការអនុវត្តត្រឹមត្រូវបានបង្រៀន ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមរំឭកសិស្សអំពីស្ថានភាពរបស់ប្រធានម៉នសុន ដែលលោកបានជួបប្រទះកាលលោកជាប៊ីស្សព ។ ចូរអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងរបស់លោកបញ្ចប់ឲ្យឮៗ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលរបៀបដែលប្រធាន ម៉នសុន បានឆ្លើយតបទៅកាន់ទីប្រឹក្សាជាន់ខ្ពស់រូបនោះ ៖

« ខ្ញុំអាចមើលឃើញពីសក្តានុពលដែលវាប្រែក្លាយទៅជាការអនុវត្តរាល់ដាលកាន់តែធំឡើងៗ ។ ទោះជាខ្ញុំនៅក្មេងជាងទីប្រឹក្សាជាន់ខ្ពស់ច្រើនក្តី ក៏ខ្ញុំបានដឹងពីអ្វីដែលចាំបាច់ត្រូវធ្វើដែរ ។ ខ្ញុំបានបែរកៅអីត្រឡប់មកវិញ ដើម្បីដាក់វាបែរទៅក្រុមជំនុំវិញ រួចនិយាយទៅគាត់ថា ‹ នៅក្នុងវួដរបស់យើង យើងដាក់កៅអីបែរមុខទៅរកក្រុមជំនុំ › » (« Opening Remarks,» lds.org/broadcasts) ។

- តើយើងមានពរជ័យយ៉ាងណាដែលមានអ្នកដឹកនាំបព្វជិតភាព ដែលធ្វើការដើម្បីប្រាកដថា គោលលទ្ធិពិត និងការអនុវត្តត្រឹមត្រូវត្រូវបានបង្រៀននៅក្នុងសាសនាចក្រនោះ ?

សូមសង្ខេបធីម៉ូថេទី១ ១:៨–១១ ដោយពន្យល់ថា ប៉ុលបានព្រមានទាស់នឹងអ្នកទាំងឡាយ ដែលមានបំណងធ្វើជាគ្រូបង្រៀនអំពីក្រឹត្យវិន័យរបស់ព្រះ ប៉ុន្តែពុំមានការយល់ដឹងត្រឹមត្រូវអំពីវា ។

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី១ ១:១២–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ហេតុអ្វីប៉ុលបានបង្ហាញនូវការដឹងគុណចំពោះព្រះយេស៊ូវគ្រីស្ទ ។

- ហេតុអ្វីប៉ុលបង្ហាញការដឹងគុណចំពោះព្រះយេស៊ូវគ្រីស្ទ ?
- ស្របតាមខទី ១៥–១៦ តើប៉ុលគឺជា « ក្បូន » ដល់ពួកអ្នកជឿទៅលើព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?

សូមសង្ខេបធីម៉ូថេទី១ ១:១៧–ធីម៉ូថេទី១ ៣ដោយពន្យល់ថា ប៉ុលបានទូន្មានដល់ធីម៉ូថេ ឲ្យកាន់ខ្ជាប់ទៅនឹងសេចក្តីជំនឿរបស់គាត់ ។ ប៉ុលបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាអង្គសង្រ្គោះរបស់យើង ហើយលោកបានទូន្មានដល់សមាជិកសាសនាចក្រស្តីពីរបៀបដើម្បីដឹកនាំខ្លួនគេ ។ លោកក៏បានបង្កើតលក្ខណៈភាពសក្តិសមនានារបស់ប៊ីស្សព និង ឌីកុនផងដែរ ។

ធីម៉ូថេទី១ ៤–៥

ប៉ុលរៀបរាប់ពីបុគ្គលិកលក្ខណៈនៃអ្នកបម្រើដ៏ស្មោះត្រង់ម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ

សូមដាក់ប្រដាប់ខ្ចាស់ក្រដាសមួយ ខ្សែមួយសរសៃ ស្អុត និងមេដែកមួយមកថ្នាក់ ។ សូមចងចុងខ្សែមួយទៅនឹងប្រដាប់ខ្ចាស់ក្រដាស រួចបិទចុងម្ខាងទៀតទៅនឹងតុមួយ ។ សូមដាក់មេដែកឲ្យជិតនឹងប្រដាប់ខ្ចាស់ក្រដាសនោះ ដោយធ្វើកុំឲ្យវាប៉ះគ្នា ។ កម្លាំងមេដែកនោះគួរទាញប្រដាប់ខ្ចាស់ក្រដាសនោះឲ្យមករកវា ។ សូមរំកិលមេដែកនោះទៅឆ្វេងទៅស្តាំ ដើម្បីបង្ហាញពីឥទ្ធិពលរបស់វាទៅលើការបំលាស់ទីរបស់ប្រដាប់ខ្ចាស់ក្រដាសនោះ ។

- ប្រសិនបើប្រដាប់ខ្ចាស់ក្រដាសនោះតំណាងឲ្យមនុស្សម្នាក់ តើមេដែកនោះអាចតំណាងឲ្យអ្វីទៅ ?

សូមឲ្យសិស្សពិចារណាថា តើពួកគេប្រៀបបាននឹងមេដែកនោះ ហើយមានឥទ្ធិពលលើមនុស្សដទៃទៀតតាមរបៀបណា ។ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សាធីម៉ូថេទី១ ៤ ដែលបង្រៀនយើង ពីរបៀបដែលឲ្យយើងអាចមានឥទ្ធិពលវិជ្ជមានមួយនៅក្នុងជីវិតរបស់មនុស្សដទៃទៀតបាន ។

សូមសង្ខេប ធីម៉ូថេទី១ ៤:១–១១ ដោយពន្យល់ថា ប៉ុលបានព្យាករថា នៅ « គ្រាជាន់ក្រោយបង្អស់ »(ខទី ១) សមាជិកសាសនាចក្រមួយចំនួននឹងចាកចេញពីសេចក្តីជំនឿនេះ ហើយធ្វើតាមការបង្រៀន និងទំនៀមទម្លាប់ខុសឆ្គងដូចជាការ « ហាមមិនឲ្យយកប្តីប្រពន្ធ » (ខទី ៣) ។ ប៉ុលបានដាស់តឿនធីម៉ូថេឲ្យបីបាច់ពួកបរិសុទ្ធជាមួយនឹងគោលលទ្ធិពិត ។

ចូរសុំឲ្យសិស្សអាន ធីម៉ូថេទី១ ៤:១២ ដោយស្ងៀមស្ងាត់ ហើយរកមើលថា ប៉ុលបានទូន្មានឲ្យធីម៉ូថេក្លាយជាអ្វី ។ សូមពន្យល់ថា ៣ក្យ *ភិរិយាប្រព្រឹត្ត* នៅក្នុងខគម្ពីរនេះសំដៅលើការប្រព្រឹត្តិ ឬឥរិយាបថ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថាការ « ធ្វើជាគំរូដល់ពួកអ្នកជឿ » មានន័យយ៉ាងណា ? (អ្នកអាចផ្តល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។
- តើប៉ុលបានទូន្មានធីម៉ូថេ ឲ្យធ្វើជាគំរូដល់ពួកអ្នកជឿតាមរបៀបណា ? សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី ១ ៤:១៣–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើល ការទូន្មានបន្ថែមទៀត ដែលប៉ុលបានផ្តល់ឲ្យដើម្បីជួយធីម៉ូថេឲ្យធ្វើជាគំរូដល់ពួកអ្នកជឿ ។

- តើអ្វីទៅជាការទូន្មានបន្ថែមទៀត ដែលប៉ុលបានផ្តល់ឲ្យដើម្បីជួយធីម៉ូថេឲ្យធ្វើជាគំរូដល់ពួកអ្នកជឿ ?
- យោងតាមខទី ១៥ ហេតុអ្វីប៉ុលបានប្រាប់ធីម៉ូថេឲ្យឧស្សាហ៍ប្រព្រឹត្តតាមគោលលទ្ធិដែលប៉ុលបានបង្រៀន ហើយធ្វើឲ្យខ្លួនគាត់រស់នៅតាមវាទាំងស្រុង ? (ដើម្បីឲ្យមនុស្សដទៃអាចឃើញថា ការធ្វើបែបនេះបានផ្តល់ប្រយោជន៍ដល់ធីម៉ូថេយ៉ាងណាខ្លះ) ។
- ដោយផ្អែកលើការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ១៦ នៅពេលយើងខិតខំធ្វើជាគំរូដល់ពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ តើនឹងមានអ្វីកើតឡើង ? (ដោយប្រើ៣ក្យរបស់សិស្ស ចូរសរសេរគោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងធ្វើជាគំរូដល់ពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចជួយនាំយកសេចក្តីសង្រ្គោះសម្រាប់ខ្លួនឯង និងមនុស្សដទៃទៀត**) ។
- តើការធ្វើជាគំរូដល់ពួកអ្នកជឿ ចំពោះមនុស្សម្នាក់ដែលជឿ ហើយដើរតាមព្រះយេស៊ូវគ្រីស្ទអាចជួយនាំយកសេចក្តីសង្រ្គោះមកដល់មនុស្សដទៃបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យរំឭកឡើងវិញនូវតារាងនៅលើក្តារខៀន ហើយពិចារណាពីរបៀបដែលធីម៉ូថេបានធ្វើជា « គំរូដល់ពួកអ្នកជឿ » (ធីម៉ូថេទី១ ៤:១២) ។ សូមឲ្យសិស្សរៀបរាប់ពីរបៀប ដែលមនុស្សម្នាក់អាចធ្វើជាគំរូនៅក្នុងផ្នែកនីមួយៗ ។

- តើថ្នាប់មាននរណាម្នាក់ធ្វើជាគំរូដល់អ្នកតាមរបៀបមួយដែលប៉ុលបានលើកឡើងនៅពេលណា ? (អ្នកក៏គួរចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយផងដែរ) ។

ការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន

បទពិសោធន៍ការរៀនសូត្រដ៏មានអត្ថន័យ និងមានឥទ្ធិពលបំផុតមួយចំនួនកើតឡើង នៅពេលគ្រូបង្រៀនអញ្ជើញសិស្សឲ្យចែកចាយរឿងទាំងឡាយ ដែលចេញពីជីវិតរស់នៅផ្ទាល់ខ្លួនរបស់ពួកគេ ដែលបង្ហាញពីសេចក្តីពិតនៃគោលការណ៍ដ៏ណឹងល្អមួយ ។ តាមរយៈការដាក់គោលការណ៍ដ៏ណឹងល្អចូលក្នុងបរិបទទំនើបមួយ ឲ្យស្របទៅនឹងបរិបទខាងបទគម្ពីរ នោះសិស្សអាចយល់ដឹងបានកាន់តែល្អប្រសើរ អំពីរបៀបដែលវាទាក់ទងទៅនឹងជីវិតរស់នៅរបស់ពួកគេ ហើយមានអារម្មណ៍ចង់អនុវត្តតាមវា ។

សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ទាក់ទងនឹងរបៀប ដែលពួកគេអាចធ្វើជាគំរូដល់ពួកអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ ហើយជួយនាំយកសេចក្តីសង្គ្រោះដល់ខ្លួនឯង និងមនុស្សដទៃទៀត ។

សូមសង្ខេបធីម៉ូថេទី១ ៥ដោយពន្យល់ថា ប៉ុលបានណែនាំធីម៉ូថេអំពីរបៀបដែលពួកបរិសុទ្ធត្រូវមើលថែដល់អ្នកដែលខ្វះខាត រួមទាំងស្ត្រីមេម៉ាយផង ។

ធីម៉ូថេទី១ ៦

ប៉ុលជាស់គឿនធីម៉ូថេឲ្យជួយអ្នកជំទៃស្វែងរកទ្រព្យដ៏អស់កល្បជានិច្ច

សូមបង្ហាញក្រដាសប្រាក់មួយសន្លឹកដល់សិស្សក្នុងថ្នាក់ ។

- តើអ្នកគិតថា ប្រាក់អាចនាំឆ្ពោះទៅកាន់ទង្វើកាន់តែអាក្រក់ ឬកាន់តែល្អ ? ហេតុអ្វី ?

ចូរពន្យល់ថាធីម៉ូថេទី១ ៦កត់ត្រាថា ប៉ុលបានទូន្មានដល់ធីម៉ូថេអំពីប្រាក់ ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី ១ ៦:៦–១០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានបង្រៀន និងបានព្រមានអ្វីខ្លះអំពីទ្រព្យសម្បត្តិ ។

- តើការបង្រៀន ឬការព្រមានមកពីប៉ុលអ្វីខ្លះ ដែលលេចឆ្លើចំពោះអ្នក ? ហេតុអ្វី ?
- តើអ្នកគិតថាឃ្លា « ការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង » មានន័យយ៉ាងណា ? (ធីម៉ូថេទី១ ៦:១០) ។
- យោងតាមខទី ៩–១០ តើការស្រឡាញ់ប្រាក់នាំទៅរកអ្វីខ្លះ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **ការស្រឡាញ់ប្រាក់ដឹកនាំទៅរកសេចក្តីទុច្ចរិត និងការក្បត់សាសនា**) ។
- ហេតុអ្វីក៏អ្នកគិតថា ការស្រឡាញ់ប្រាក់ដឹកនាំទៅរកអំពើទុច្ចរិត និងការក្បត់សាសនា ?

ដើម្បីជួយសិស្សឲ្យយល់ថា វាគឺជា « ការស្រឡាញ់ » ប្រាក់ជាជាងប្រាក់ផ្ទាល់ទេតើ ដែលដឹកនាំទៅរកសេចក្តីទុច្ចរិត សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អ្នក ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖



« គ្មានអ្វីអាក្រក់ជាប់ជាមួយនឹងប្រាក់នោះទេ ។ សាសន៍សាម៉ារីចិត្តល្អ បានប្រើប្រាក់ដូចគ្នានោះ ដើម្បីបម្រើដល់បងប្អូនរបស់គាត់ ដែលយូដាសបានប្រើវាទៅក្បត់លោកចៅហ្វាយ ។ វាគឺជា *‹ការស្រឡាញ់ប្រាក់›* ទេតើ [ដែល] ជាមេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង › ។ (ធីម៉ូថេទី ១ ៦:១០; អក្សរទ្រេតបានបន្ថែម) ។ ភាពខុសគ្នាដ៏ខ្លាំងគឺកម្រិតនៃជីវភាពខាងវិញ្ញាណ ដែលយើងអនុវត្តដើម្បីមើល វាយតម្លៃ និងគ្រប់គ្រងរឿងទាំងឡាយក្នុងលោកិយនេះ » (« Spirituality »*Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ទំព័រ ៦៣) ។

សូមសរសេរសេចក្តីយោងបទគម្ពីរ និងសំណួរដូចខាងក្រោមនៅលើក្តារខៀន ឬផ្តល់ក្រដាសចែកចាយដល់ពួកគេ ៖

ធីម៉ូថេទី១ ៦:១១–១២, ១៧–១៩

តើប៉ុលបានផ្តល់ដំបូន្មានអ្វីខ្លះ ទៅឲ្យធីម៉ូថេ និងអស់អ្នកដែលមានទ្រព្យច្រើនទាំងនោះ ?

តើដំបូន្មាននេះអាចជួយយើងឲ្យមានអាកប្បកិរិយាត្រឹមត្រូវចំពោះការស្វែងរកទ្រព្យសម្បត្តិ និងការប្រើទ្រព្យសម្បត្តិយ៉ាងដូចម្តេច ?

សូមចែកសិស្សជាគូ ។ សូមអញ្ជើញសិស្សឲ្យអានសេចក្តីយោង ហើយពិភាក្សានូវសំណួរទាំងឡាយជាមួយនឹងដៃគូរបស់ពួកគេ ។ បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សជាច្រើនឲ្យចែកចាយនូវអ្វីដែលពួកគេបានពិភាក្សា ។

- ប្រសិនបើពួកបរិសុទ្ធបានទុកចិត្តទៅលើព្រះ ហើយសន្សំទុកទ្រព្យជាច្រើននៅក្នុងកិច្ចការល្អ តើប៉ុលបាននិយាយថា ពួកគេអាចទទួលបានអ្វីខ្លះ ស្របតាមខទី ១៩?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីការបង្រៀនរបស់ប៉ុល អំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលជីវិតអស់កល្បជានិច្ច ? (ទោះបីសិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវក្រាកដថា ពួកគេស្គាល់គោលការណ៍មួយ ដែលស្រដៀងគ្នាដូចខាងក្រោម ៖ **ប្រសិនបើយើងទុកចិត្តលើព្រះដ៏មានព្រះជន្មរស់ ហើយខិតខំធ្វើកិច្ចការល្អ នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច**) ។
- ប្រសិនបើការទុកចិត្តទៅលើព្រះ និងការធ្វើតាមសេចក្តីសុចរិត គឺជាអាទិភាពដ៏ធំបំផុតរបស់យើង តើរឿងនោះអាចជះឥទ្ធិពលទៅលើរបៀបដែលយើងមើល ស្វែងរក និងប្រើប្រាស់ទ្រព្យសម្បត្តិយ៉ាងដូចម្តេច ?

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ថា ការទទួលបានជីវិតដ៏អស់កល្បជានិច្ចធ្វើឲ្យមនុស្សម្នាក់មានទ្រព្យដ៏ច្រើនពិត ។ សូមលើកទឹកចិត្តដល់សិស្សឲ្យដាក់ការធ្វើតាមសេចក្តីសុចរិតជាអាទិភាពធំបំផុតរបស់ពួកគេ ដើម្បីពួកគេអាចទទួលបានទ្រព្យសម្បត្តិដ៏ពិតនៃជីវិតដ៏នៅអស់កល្បជានិច្ច ។

មេរៀនសិក្សានៅផ្ទះ

កូល៉ុស–ធីម៉ូថេទី ១ (មេរៀនទី ២៦)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា កូល៉ុស–ធីម៉ូថេទី ១ (មេរៀនទី ២៦) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតលើគោលលទ្ធិ និងគោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី១ (កូល៉ុស)

នៅក្នុងសំបុត្ររបស់លោកដល់ពួកបរិសុទ្ធនៅកូល៉ុស ប៉ុលបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះ ជាបុត្រច្បងនៃកូនចៅវិញ្ញាណរបស់ព្រះវរបិតាសួគ៌ ជាព្រះដ៏បង្កបង្កើតនៃរបស់សព្វសារពើ ជាសិរសៅនៃសាសនាចក្រ និងជាអង្គដំបូងដែលមានព្រះជន្មរស់ឡើងវិញ ។ សិស្សក៏បានរៀនផងដែរថា យើងអាចបានផ្សះផ្សានឹងព្រះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រសិនបើយើងបន្តឹងមាំនៅក្នុងសេចក្តីជំនឿរបស់យើង ។ លើសពីនេះទៀត តាមរយៈការចាក់ឫស ហើយរឹងមាំនៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះយើងអាចចៀសវាងពីការនាំឲ្យវង្វេងដោយទស្សនវិជ្ជា និងទំនៀមទម្លាប់នានាខាងលោកិយ ។

ថ្ងៃទី ២ (ថៃស្សាឡូនីចទី ១)

នៅក្នុងសំបុត្រនេះដល់ពួកបរិសុទ្ធនៅថៃស្សាឡូនីច ប៉ុលបានសរសើរពួកគេពីសេចក្តីស្មោះត្រង់របស់ពួកគេ ហើយបានបង្រៀនពួកគេនូវសេចក្តីពិតនានាអំពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។ កាលកំពុងសិក្សាសំបុត្រនេះ សិស្សបានរៀនសេចក្តីពិតដូចតទៅ ៖ នៅពេលយើងបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដោយព្រះបន្ទូល និងព្រះចេស្តានៃព្រះ យើងអាចជួយមនុស្សដទៃឲ្យក្លាយជាពួកអ្នកដើរតាមព្រះអម្ចាស់ និងជាពួកអ្នកបម្រើរបស់ទ្រង់ ។ យើងអាចចែកចាយដំណឹងល្អតាមរយៈគំរូរបស់យើង ។ ពួកបរិសុទ្ធស្មោះត្រង់ ដែលស្លាប់មុនការយាងមកជាលើកទីពីរ នឹងបានរស់ឡើងវិញ នៅពេលព្រះគ្រីស្ទយាងមកម្តងទៀត ។ ពួកបរិសុទ្ធស្មោះត្រង់ដែលមានជីវិតរស់ នៅឯការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទនឹងបាននាំយកទៅជួបនឹងទ្រង់ កាលទ្រង់យាងមក ។ ប្រសិនបើយើងស្មោះត្រង់ ហើយរង់ចាំមើលទីសម្គាល់ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងបានត្រៀមខ្លួនកាលទ្រង់យាងមកម្តងទៀត ។

ថ្ងៃទី ៣ (ថៃស្សាឡូនីចទី ២)

នៅក្នុងការសិក្សាសំបុត្ររបស់ប៉ុលដល់ពួកបរិសុទ្ធនៅថៃស្សាឡូនីច ដែលបានបញ្ជាក់នូវសេចក្តីពិតអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ សិស្សបានរៀនថា ប្រសិនបើយើងស៊ូទ្រាំនឹងឧបសគ្គដោយស្មោះត្រង់ ហើយស៊ូទ្រាំនឹងសេចក្តីទុក្ខលំបាកដោយភាពអត់ធ្មត់ និងសេចក្តីជំនឿ នោះយើងអាចនឹងបានរាប់ថាសក្តិសមនៅក្នុងនគរព្រះ ។ ប៉ុលបានបង្រៀនថា នៅការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សសុចរិតនឹងបានសម្រាក ហើយមនុស្សទុច្ចរិតនឹងត្រូវបំផ្លាញចោល ។ លោកក៏បានបង្រៀនផងដែរថា ពីមុនការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ការក្បត់សាសនាមួយនឹងកើតឡើង ។ សិស្សក៏បានរៀនផងដែរថា យើងត្រូវបានបង្គាប់ឲ្យខិតខំដើម្បីមានភាពខ្ជួនទីពឹងខ្លួន ហើយជួយដល់មនុស្សដទៃទៀត ។

ថ្ងៃទី ៤ (ធីម៉ូថេទី ១)

នៅក្នុងសំបុត្ររបស់ប៉ុលដល់ធីម៉ូថេ ជាថ្នាក់ដឹកនាំបព្វជិតភាពវ័យក្មេងម្នាក់នៅអេភេសូរ សិស្សបានរៀនថា ថ្នាក់ដឹកនាំបព្វជិតភាពមានការទទួលខុសត្រូវដើម្បីធ្វើឲ្យប្រាកដថាមាននូវការបង្រៀនអំពីគោលលទ្ធិពិត និងអំពីការអនុត្តត្រឹមត្រូវ ។ ពួកគេក៏បានរៀនផងដែរថា ការស្រឡាញ់ប្រាក់ដឹកនាំទៅកេអំពើទុច្ចរិត និងការក្បត់សាសនា ។ ម្យ៉ាងវិញទៀត ប្រសិនបើយើងទុកចិត្តលើព្រះដ៏មានព្រះជន្មរស់ ហើយខិតខំធ្វើកិច្ចការល្អ នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សេចក្តីផ្តើម

ប៉ុលបានសរសេរទៅធីម៉ូថេ ជាថ្នាក់ដឹកនាំបព្វជិតភាពម្នាក់នៅអេភេសូរ ហើយបានទូន្មានគាត់ឲ្យធ្វើជាគំរូដល់ពួកអ្នកជឿ ។

យោបល់សម្រាប់ការបង្រៀន

កំណត់ចំណាំ ៖ នៅក្នុងមេរៀននេះ សិស្សបានសិក្សាពីវគ្គចំណេះចំណានខគម្ពីរថៃស្សាឡូនីចទី ២ ២:១–៣ ។ អ្នកអាចរំឭកវគ្គនេះឡើងវិញជាមួយសិស្ស ដោយសុំឲ្យពួកគេសង្ខេបពីសេចក្តីពិតដែលវាបានបង្រៀន ។ ដើម្បីជួយសិស្សឲ្យចងចាំពីផ្នែកមួយនៃវគ្គនេះ អ្នកគួរសូត្រ ខទី៣ ពីរបីដងជាមួយសិស្សក្នុងថ្នាក់ ។

ធីម៉ូថេទី១ ៤

ប៉ុលរៀបរាប់ពីចរិតលក្ខណៈនៃអ្នកបម្រើដ៏ស្មោះត្រង់ម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ

សូមយកប្រដាប់ខ្ចាស់ក្រដាសមួយ ខ្សែមួយសរសៃ បង់ស្អិត និងមេដៃកមួយមកថ្នាក់ ។ សូមចងចុងខ្សែមួយទៅនឹងប្រដាប់ខ្ចាស់ក្រដាស រួចបិទចុងម្ខាងទៀតទៅនឹងតុមួយ ។ សូមដាក់មេដៃកឲ្យជិតនឹងប្រដាប់ខ្ចាស់ក្រដាសនោះ ដោយធ្វើកុំឲ្យវាប៉ះគ្នា ។ កម្លាំងមេដៃកនោះធ្វើឲ្យប្រដាប់ខ្ចាស់ក្រដាសនោះរំកិលទៅរកមេដៃកឆក់ ។ សូមរំកិលមេដៃកនោះទៅឆ្វេងទៅស្តាំ ដើម្បីបង្ហាញពីឥទ្ធិពលរបស់វាទៅលើចលនាកំរើករបស់ប្រដាប់ខ្ចាស់ក្រដាសនោះ ។

- ប្រសិនបើប្រដាប់ខ្ចាស់ក្រដាសនោះតំណាងឲ្យមនុស្សម្នាក់ តើមេដៃកនោះអាចតំណាងឲ្យអ្វីទៅ ?

សូមឲ្យសិស្សគិតថា តើពួកគេប្រៀបបាននឹងមេដៃកនោះ ហើយមានឥទ្ធិពលលើមនុស្សដទៃទៀតតាមរបៀបណា ។ នៅពេលសិស្សសិក្សា ធីម៉ូថេទី ១ ៤ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលបង្រៀនយើងពីរបៀបដែលយើងអាចមានឥទ្ធិពលវិជ្ជមានមួយនៅក្នុងជីវិតរបស់មនុស្សដទៃទៀតបានយ៉ាងដូចម្តេច ។

សូមសង្ខេប ធីម៉ូថេទី ១ ៤:១–១១ ដោយពន្យល់ថា ប៉ុលបានព្យាករថា នៅ« គ្រាជាន់ក្រោយបង្អស់ »(ខទី ១) សមាជិកសាសនាចក្រមួយចំនួននឹងចាកចេញពីសេចក្តីជំនឿនេះ ហើយធ្វើតាមការបង្រៀន និងទំនៀមទម្លាប់ខុសឆ្គង ដូចជាការ « ហាមមិនឲ្យយកប្តីប្រពន្ធ » (ខទី ៣) ។ ប៉ុលបានជាស់តឿនធីម៉ូថេឲ្យបីបាច់ពួកបរិសុទ្ធជាមួយនឹងគោលលទ្ធិពិត ។

ចូរសុំឲ្យសិស្សអាន ធីម៉ូថេទី ១ ៤:១២ ដោយស្ងៀមស្ងាត់ ហើយរកមើលថា តើប៉ុលបានទូន្មានឲ្យធីម៉ូថេក្លាយជាអ្វី ។ សូមពន្យល់ថា ពាក្យ *កិរិយាប្រព្រឹត្ត* នៅក្នុងខគម្ពីរនេះសំដៅលើការប្រព្រឹត្ត ឬ *ឥរិយាបថ* ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថាការ « ធ្វើជាគំរូដល់ពួកអ្នកជឿ » មានន័យដូចម្តេច ? (អ្នកអាចផ្តល់យោបល់ដល់សិស្សឲ្យគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។
- តើប៉ុលបានទូន្មានធីម៉ូថេឲ្យធ្វើជាគំរូដល់ពួកអ្នកជឿតាមរបៀបណា ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី១ ៤:១៣–១៦ ឲ្យឮៗ ។ ចុះសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ការទូន្មានបន្ថែមទៀតដែលប៉ុលបានផ្តល់ឲ្យ ដើម្បីជួយធីម៉ូថេឲ្យធ្វើជាគំរូដល់ពួកអ្នកជឿ ។

- តើអ្វីទៅជាការទូន្មានបន្ថែមទៀតដែលប៉ុលបានផ្តល់ឲ្យ ដើម្បីជួយធីម៉ូថេឲ្យធ្វើជាគំរូដល់ពួកអ្នកជឿ ?
- យោងតាមខទី ១៥ ហេតុអ្វីប៉ុលបានប្រាប់ធីម៉ូថេឲ្យឧស្សាហ៍ប្រព្រឹត្តតាមគោលលទ្ធិដែលប៉ុលបានបង្រៀន ហើយធ្វើឲ្យខ្លួនគាត់រស់នៅតាមវាទាំងស្រុង ? (ដើម្បីឲ្យមនុស្សជុំវិញអាចឃើញថា ការធ្វើបែបនេះបានផ្តល់ប្រយោជន៍ដល់ធីម៉ូថេយ៉ាងណាខ្លះ) ។
- ដោយផ្អែកលើការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ១៦ នៅពេលយើងខិតខំធ្វើជាគំរូដល់ពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ តើនឹងមានអ្វីកើតឡើង ? (ដោយប្រើពាក្យរបស់សិស្ស ចូរសរសេរគោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងជាគំរូដល់ពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចជួយនាំយកសេចក្តីសង្គ្រោះសម្រាប់ខ្លួនឯង និងមនុស្សដទៃទៀត**) ។
- តើការធ្វើជាគំរូមួយដល់មនុស្សម្នាក់ដែលជឿ ហើយដើរតាមព្រះយេស៊ូវគ្រីស្ទអាចជួយនាំយកសេចក្តីសង្គ្រោះដល់មនុស្សដទៃបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យរំឭកឡើងវិញនូវតារាងនៅលើក្តារខៀន ហើយពិចារណាពីរបៀបដែលធីម៉ូថេធ្វើជា « គំរូដល់ពួកអ្នកជឿ » (ធីម៉ូថេទី ១ ៤:១២) ។ សូមឲ្យសិស្សរៀបរាប់ពីរបៀបដែលមនុស្សម្នាក់អាចធ្វើជាគំរូនៅក្នុងផ្នែកនីមួយៗ ។

អ្នកគួរពិចារណាបង្ហាញវីដេអូមួយដូចខាងក្រោមនេះ ៖ « No Cussing Club » (**៤:៥៧**) **ឬ** « The Lost Purse » (**២:៤០**) **។ វីដេអូទាំងនេះមាននៅក្នុង** LDS.org **។ សូមឲ្យសិស្សរកមើលវិធីដែលយុវជន ឬយុវនារីនៅក្នុងវីដេអូនោះ គឺជាគំរូមួយដល់ពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ ។**

- តើធ្លាប់មាននរណាម្នាក់ធ្វើជាគំរូដល់ពួកអ្នកជឿសម្រាប់អ្នក តាមរបៀបមួយដែលប៉ុលបានលើកឡើងនៅពេលណា ? (អ្នកក៏គួរចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយផងដែរ) ។

សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ទាក់ទងនឹងរបៀបដែលពួកគេអាចធ្វើជាគំរូដល់ពួកអ្នកជឿដល់ព្រះយេស៊ូវគ្រីស្ទ ហើយជួយនាំយកសេចក្តីសង្គ្រោះមកដល់ខ្លួនឯង និងមនុស្សដទៃទៀត ។

មេរៀនបន្ទាប់ (ធីម៉ូថេទី ២ ១–ហេព្រើរ ៤)

សូមអញ្ជើញសិស្សឲ្យពិចារណាពីការប្រឈមមុខចំនួននៃការធ្វើជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទនៅសព្វថ្ងៃនេះ ។ សូមពន្យល់ថា នៅពេលពួកគេបន្តសិក្សាពីការបង្រៀនរបស់ប៉ុលនៅសប្តាហ៍ក្រោយ ពួកគេនឹងរៀនពីសេចក្តីពិតដែលនឹងជួយពួកគេឲ្យបន្តស្មោះត្រង់ ថ្វីបើមានការលំបាក និងការបៀតបៀនក៏ដោយ ។

សេចក្តីណែនាំអំពី

សំបុត្រទីពីររបស់ប៉ុលដល់ធីម៉ូថេ

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រទីពីររបស់ប៉ុលដល់ធីម៉ូថេគួសបញ្ជាក់ពីអំណាច ដែលកើតចេញពីការមានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ (សូមមើល ធីម៉ូថេទី ២ ១:៧–៨) ។ វាក៏មាននូវការព្យាករមួយអំពី « គ្រាលំបាកណាស់ » ដែលនឹងកើតមាននៅជំនាន់របស់ប៉ុល និងធីម៉ូថេ ក៏ដូចជានៅថ្ងៃចុងក្រោយផងដែរ (សូមមើល ធីម៉ូថេទី ២ ៣:១–៧) ។ ដើម្បីជួយធីម៉ូថេជាមួយនឹងឧបសគ្គដែលគាត់បានជួបប្រទះ ប៉ុលបានលើកទឹកចិត្តគាត់ឲ្យទុកចិត្តលើបទគម្ពីរ និងថ្នាក់ដឹកនាំសាសនាចក្រ (សូមមើល ធីម៉ូថេទី ២ ៣:១៤–១៧) ហើយពឹងផ្អែកលើគោលលទ្ធិពិត (សូមមើល ធីម៉ូថេទី ២ ៤:២) ។ តាមរយៈការសិក្សាគម្ពីរនេះ សិស្សនឹងរៀនពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលអាចជួយពួកគេឲ្យរស់នៅដោយស្មោះត្រង់ កាលពួកគេជួបប្រទះនឹងគ្រាដ៏លំបាកនៅថ្ងៃចុងក្រោយនេះ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុលបានសរសេរធីម៉ូថេទី ២ (សូមមើល ធីម៉ូថេទី ២ ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

សំបុត្រទីពីររបស់ប៉ុលដល់ធីម៉ូថេទំនងជាត្រូវបានសរសេរឡើងប្រមាណក្នុងចន្លោះ គ.ស. ៦៤ និង ៦៥ (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។ ប៉ុលបានសរសេរសំបុត្រនេះ នៅពេលលោកជាប់ឃុំជាលើកទីពីរនៅរ៉ូម ពីមុនការធ្វើទុក្ករកម្មរបស់លោកបន្តិច (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។

កាលប៉ុលជាប់ឃុំ ហើយត្រូវគេដាក់ច្រវាក់នោះ (សូមមើល ធីម៉ូថេទី២ ១:១៦, ២:៩) លោកទំនងជានៅក្នុងគុក ឬនៅក្នុងគុកក្រោមដី ហើយត្រូវដាក់នៅក្នុងកន្លែងដែលស្ថិតក្នុងសភាពគ្រោះថ្នាក់ជាច្រើន (សូមមើល ធីម៉ូថេទី២ ៤:១៣, ២១) ហើយមិត្តភក្តិរបស់លោករកលោកមិនឃើញឡើយ (សូមមើល ធីម៉ូថេទី ២ ១:១៧) ។ លូកាទំនងជាមនុស្សតែម្នាក់គត់ដែលមកសួរសុខទុក្ខលោកជាទៀងទាត់ (សូមមើល ធីម៉ូថេទី២ ៤:១១) ហើយប៉ុលបានរំពឹងថា ជីវិតរបស់លោកនឹងជិតដល់ពេលបញ្ចប់ហើយ (សូមមើល ធីម៉ូថេទី២ ៤:៦–៨) ។

តើគម្ពីរនេះត្រូវបានសរសេរចំពោះនរណា ហើយតើហេតុអ្វី ?

នៅក្នុងសំបុត្រនេះ ប៉ុលបានលើកទឹកចិត្តធីម៉ូថេ ហើយបានផ្តល់កម្លាំងដើម្បីជួយគាត់ឲ្យបន្តទៅទៀត បន្ទាប់ពីការស្លាប់របស់ប៉ុលបានមកដល់ ។ ប៉ុលបានដឹងថា ពេលវេលារបស់លោកខ្លីណាស់ ហើយលោកមានបំណងចង់ជួបធីម៉ូថេ ជាអ្នកដែលប៉ុលបានហៅថា « កូនស្ងួនភ្ងា » (ធីម៉ូថេទី២ ១:២) ។

នៅចុងបញ្ចប់នៃសំបុត្ររបស់លោក ប៉ុលបានស្នើឲ្យធីម៉ូថេ និងម៉ាកុសមកជួបលោក ហើយយករបស់មួយចំនួនដែលលោកមិនបានយកមកជាមួយនឹងលោក (សូមមើល ធីម៉ូថេទី២ ៤:៩–១៣) ។ ទោះបីជាសំបុត្ររបស់លោកនិយាយយ៉ាងជាក់លាក់ទៅកាន់ធីម៉ូថេក្តី ក៏ការទូន្មានរបស់វាអាចយកមកអនុវត្តចំពោះអស់អ្នកដែលបានរស់នៅក្នុង « ថ្ងៃចុងក្រោយ »ដែរ (ធីម៉ូថេទី២ ៣:១) ដោយសារប៉ុលបានបង្រៀនអំពីឧបសគ្គ និងជំណោះស្រាយដែលទាក់ទងនឹងជំនាន់របស់យើង និងជំនាន់របស់លោកផងដែរ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

សំបុត្រនេះគឺជាសំបុត្រមួយនៃសំបុត្ររបស់គ្រូគង្វាល រួមជាមួយធីម៉ូថេទី១ និងទីតុសផងដែរ ហើយវា « មាននូវពាក្យសំដីចុងក្រោយបង្អស់របស់ប៉ុល ហើយបង្ហាញនូវសេចក្តីភ្លាហាន និងការទុកចិត្តដ៏អស្ចារ្យ នៅពេលលោកប្រឈមមុខនឹងសេចក្តីស្លាប់ » (សូមមើល សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ តាមកាលប្រវត្តិ ធីម៉ូថេទី២ ទំនងជាសំបុត្រចុងក្រោយរបស់ប៉ុលនៅក្នុងព្រះគម្ពីរសញ្ញាថ្មី (សូមមើល ធីម៉ូថេទី២ ៤:៦) ។

សំបុត្រនេះមាននូវការឆ្លុះបញ្ចាំងមួយចំនួនរបស់ប៉ុលអំពីពរជ័យ និងសេចក្តីលំបាកនៃ ការបម្រើដា « អ្នកប្រកាសប្រោសជំណឹងល្អនោះ និងជាសាវក ហើយជាគ្រូបង្រៀនដល់សាសន៍ដទៃ » (ធីម៉ូថេទី២ ១:១១) ។ ប៉ុលបានប្រកាសថា « ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាសេចក្តីជំនឿទៅហើយ ពីនេះទៅមុខ នឹងមានមកុដនៃសេចក្តីសុចរិត » (ធីម៉ូថេទី២ ៤:៧–៨) ដោយចង្អុលបង្ហាញថា លោកមានការអះអាងផ្ទាល់ខ្លួនមួយថា លោកនឹងគ្រងជីវិតជំនៅអស់កល្បជានិច្ច ។ ក្នុងនាមជាមនុស្សម្នាក់ដែលបានធ្វើការងារបម្រើដល់ព្រះយេស៊ូវគ្រីស្ទអស់រយៈពេលជាង៣០ ឆ្នាំ ប៉ុលមានភាពសក្តិសមបំផុត ដើម្បីណែនាំធីម៉ូថេពីរបៀបបម្រើដោយមានប្រសិទ្ធភាពនៅក្នុងការពង្រឹងដល់សេចក្តីជំនឿរបស់មនុស្សដទៃទៀត (សូមមើល ធីម៉ូថេទី២ ២:១៥–១៧, ២២–២៦, ៤:១–២, ៥) ។

គម្រោង

ធីម៉ូថេទី២ ១ ប៉ុលលើកឡើងពីអំណោយទាន និងព្រះចេស្តានៃព្រះដែលទទួលបានតាមរយៈការតែងតាំងបព្វជិតភាព ។ លោកបង្រៀនថា « វិញ្ញាណដែលតែងតែភ័យខ្លាច » (ធីម៉ូថេទី២ ១:៧) ពុំមែនមកពីព្រះទេ ហើយថាយើងមិនគួរខ្មាស់អៀនចំពោះទីបន្ទាល់របស់យើងអំពីព្រះយេស៊ូវគ្រីស្ទឡើយ ។ ប៉ុលថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទបានហៅលោកឲ្យប្រកាសដំណឹងល្អ (សូមមើល ធីម៉ូថេទី២ ១:១១) ។

ធីម៉ូថេទី២ ២ ប៉ុលប្រើរូបភាពនៃទំព័ល្អ អត្តពលករដ៏មានជោគជ័យ និងកសិករដ៏ឧស្សាហ៍ព្យាយាមម្នាក់ ដើម្បីបង្ហាញពីសេចក្តីត្រូវការនៅក្នុងការស៊ូទ្រាំនឹងសេចក្តីលំបាក ដើម្បីទទួលបានសិរីល្អដ៏នៅអស់កល្ប ។ លោកបង្ហាញពីភាពខុសគ្នារវាងគ្រូបង្រៀនពិត និងគ្រូបង្រៀនក្លែងក្លាយ ព្រមទាំងគ្រឿងដែលប្រសើរ និងគ្រឿងដែលអាប់ឱន ។ លោកព្រមានដល់ធីម៉ូថេឲ្យចៀសវាងពីការមានវិវាទនឹងគ្នា ហើយបង្រៀនជនដែលត្រូវប្រែចិត្តដោយភាពអត់ធ្មត់ ។

ធីម៉ូថេទី២ ៣–៤ ប៉ុលពិពណ៌នាពីលក្ខខណ្ឌអាក្រក់នៃថ្ងៃចុងក្រោយ ហើយលើកទឹកចិត្តធីម៉ូថេឲ្យប្រើបទគម្ពីរនៅក្នុងតួនាទីរបស់គាត់ជាថ្នាក់ដឹកនាំបព្វជិតភាពម្នាក់ ។ លោកសរសេរពីសេចក្តីស្លាប់របស់លោកដែលនឹងមកដល់ ហើយប្រកាសថា « ខ្ញុំបានរក្សាសេចក្តីជំនឿទៅហើយ » (ធីម៉ូថេទី២ ៤:៧) ។ ប៉ុលថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងប្រោសលោកនៅ « ស្ថានសួគ៌ » (ធីម៉ូថេទី២ ៤:១៨) ។

មេរៀន ១៣១

ធីម៉ូថេទី២ ១–២

សេចក្តីផ្តើម

នៅក្នុងសំបុត្រទីពីររបស់លោកដល់ធីម៉ូថេ ប៉ុលបានបង្រៀនថា សេចក្តីភ័យខ្លាចពុំមែនកើតមកពីព្រះទេ ហើយបានទូន្មានធីម៉ូថេកុំឲ្យខ្មាស់អៀនចំពោះទីបន្ទាល់របស់គាត់អំពីព្រះយេស៊ូវគ្រីស្ទ ឡើយ ។ ប៉ុលបានលើកទឹកចិត្តធីម៉ូថេឲ្យស៊ូទ្រាំនឹងការសោកល្វងដោយស្មោះត្រង់ ហើយបានណែនាំគាត់ឲ្យបង្រៀនដល់ពួកបរិសុទ្ធឲ្យប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

ធីម៉ូថេទី២ ១

ប៉ុលទូន្មានធីម៉ូថេកុំឲ្យខ្មាស់អៀនចំពោះដំណឹងល្អឡើយ

សូមសរសេរពាក្យ *សេចក្តីភ័យខ្លាច* នៅលើក្តារខៀន រួចសុំឲ្យសិស្សពិចារណាថា សេចក្តីភ័យខ្លាចអាចមានឥទ្ធិពលមកលើយើងយ៉ាងដូចម្តេច ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖



« នៅក្នុងចំណោមយើងរាល់គ្នា តើមាននរណាម្នាក់មិនភ័យខ្លាចទេឬ ? ខ្ញុំដឹងថា មនុស្សគ្រប់រូបមានការភ័យខ្លាច ។ ពិតណាស់ មានមនុស្សខ្លះជួបសេចក្តីភ័យខ្លាចខ្លាំងជាងមនុស្សដទៃទៀត ។ មនុស្សខ្លះអាចយកឈ្នះវាយ៉ាងរហ័ស ប៉ុន្តែមានមនុស្សខ្លះទៀតត្រូវបានសង្កត់ជាប់ ហើយបានទាញទម្លាក់ដោយសេចក្តីភ័យខ្លាចនេះ ហើយថែមទាំងត្រូវបានបង្ខំឲ្យចុះចាញ់ទៀតផង ។ យើងរងទុក្ខដោយសារសេចក្តីភ័យខ្លាចនៃការចំអក សេចក្តីភ័យខ្លាចនៃការបរាជ័យ សេចក្តីខ្លាចនៃភាពឯកោ សេចក្តីខ្លាចនៃភាពអវិជ្ជា ។ មានមនុស្សខ្លះខ្លាចចំពោះបច្ចុប្បន្នកាល រីឯខ្លះទៀតខ្លាចអនាគតកាល ។ មនុស្សទ្រុបទ្នុកនៃអំពើបាប ហើយសុខចិត្តលះបង់ស្ទើរតែអ្វីៗគ្រប់យ៉ាង ដើម្បីឲ្យខ្លួនរួចផុតពីបន្ទុកទាំងនោះ ប៉ុន្តែខ្លាចនឹងផ្លាស់ប្តូរជីវិតរបស់ពួកគេ » (« God Hath Not Given Us the Spirit of Fear » *Ensign* ខែ តុលា ឆ្នាំ ១៩៨៤ ទំព័រ ២) ។

- **យោងតាមប្រធាន ហ៊ិងគ្លី តើសេចក្តីភ័យខ្លាចមានឥទ្ធិពលលើយើងយ៉ាងដូចម្តេច ?**
- **តើសេចក្តីភ័យខ្លាចអាចមានឥទ្ធិពលលើសមត្ថភាពរបស់យើង ដើម្បីរស់នៅតាមដំណឹងល្អយ៉ាងដូចម្តេច ?**

នៅពេលសិស្សសិក្សាធីម៉ូថេទី២ ១សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយដែលអាចជួយពួកគេឲ្យយកឈ្នះលើសេចក្តីភ័យខ្លាច ។

សូមពន្យល់ថា ពីមុនប៉ុលស្លាប់មិនយូរប៉ុន្មាន លោកបានសរសេរសំបុត្រទីពីររបស់លោកដល់ធីម៉ូថេ កាលជាប់ឃុំនៅរ៉ូម ។ សូមសង្ខេបធីម៉ូថេទី ២ ១:១–៥ ដោយពន្យល់ថា ប៉ុលបានបានសម្តែងបំណងប្រាថ្នារបស់លោកចង់ជួបធីម៉ូថេ ហើយនឹកឃើញអំពីសេចក្តីជំនឿស្មោះត្រង់របស់ធីម៉ូថេ ។

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ១:៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានរំឭកធីម៉ូថេឲ្យធ្វើអ្វីខ្លះ ។

- **តើប៉ុលបានរំឭកធីម៉ូថេឲ្យធ្វើអ្វីខ្លះ ?**

សូមពន្យល់ថា « អំណោយទានរបស់ព្រះ » ដែលបានទទួលដោយការដាក់ដៃលើ ទំនងជាសំដៅទៅលើព្រះវិញ្ញាណបរិសុទ្ធ ។ ការ « ដាស់តឿន » មានន័យថា ការស្តារឡើងវិញ ឬការប្រោស ។ ប៉ុលបានដាស់តឿនធីម៉ូថេឲ្យស្តារអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធឡើងវិញ ឬស្វែងរកដើម្បីមានព្រះវិញ្ញាណបរិសុទ្ធឲ្យគង់នៅជាមួយគាត់ដោយស្មោះត្រង់ ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនេះដាក់លើក្តារខៀន ៖ *នៅពេលយើងស្វែងរកដើម្បីមានព្រះវិញ្ញាណឲ្យគង់នៅជាមួយយើងដោយស្មោះត្រង់* . . .

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ១:៧–៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលអាចកើតមានពីការមានព្រះវិញ្ញាណគង់នៅជាមួយនឹងយើង ។

- **យោងតាម ខទី ៧ តើពរជ័យអ្វីខ្លះ អាចកើតចេញពីការមានព្រះវិញ្ញាណគង់នៅជាមួយនឹងយើង ?**
- **តើពរជ័យទាំងនេះជួយយើងឲ្យយកឈ្នះលើអ្វី ?**

សូមពន្យល់ថា ប៉ុលបានហៅសេចក្តីភ័យខ្លាចខាងលោកិយ ដែលវាបង្កើតនូវការចង់បារម្ភ ថាជាភាពពុំពិតប្រាកដ និងការរំជើបរំជួលហើយខុសពីអ្វីដែលបទគម្ពីរហៅថាជា « សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា » (សុភាសិត ៩:១០) ។ ការកោតខ្លាចដល់ព្រះអម្ចាស់គឺជាការ « មានចិត្តគោរពកោតក្រែង និងស្ងើចស្ងែងដល់ទ្រង់ ហើយគោរពតាមបញ្ញត្តិទាំងឡាយរបស់ទ្រង់ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « កោតខ្លាច » scriptures.lds.org) ។

- **យោងតាម ខទី ៨ តើប៉ុលបានអញ្ជើញឲ្យធីម៉ូថេធ្វើអ្វីខ្លះ ជាមួយការយល់ដឹងថា ព្រះវិញ្ញាណអាចជួយគាត់ឲ្យយកឈ្នះសេចក្តីភ័យខ្លាចបាន ?**

សូមសួរសិស្សថា ពួកគេនឹងបំពេញឃ្លានៅលើក្តារខៀនបែបណាដែរ ដោយប្រើការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ៧–៨ ។ សូមប្រើពាក្យសម្តីរបស់សិស្សដើម្បីបំពេញសេចក្តីថ្លែងការណ៍នេះ៖ ដើម្បីឲ្យវានាំទៅរកគោលការណ៍ដូចតទៅនេះ៖ **នៅពេលយើងខិតខំឲ្យមានព្រះវិញ្ញាណគង់នៅជាមួយយើង នោះយើងអាចយកឈ្នះលើសេចក្តីភ័យខ្លាច ហើយពុំខ្មាស់អៀនអំពីទីបន្ទាល់របស់យើងអំពីព្រះយេស៊ូវគ្រីស្ទឡើយ ។**

- តើអំណាច សេចក្តីស្រឡាញ់ និងសេចក្តីល្អដែលយើងបានទទួលពីព្រះតាមរយៈព្រះវិញ្ញាណអាចជួយយើងឲ្យយកឈ្នះសេចក្តីភ័យខ្លាចយ៉ាងដូចម្តេច ?
- តើយើងអាចបង្ហាញថា យើងពុំខ្មាស់អៀនចំពោះទីបន្ទាល់របស់យើងអំពីព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ?
- តើព្រះវិញ្ញាណធ្លាប់ជួយអ្នកឲ្យយកឈ្នះលើសេចក្តីភ័យខ្លាច ឬធ្លាប់លើកទឹកចិត្តអ្នកឲ្យឈរយ៉ាងរឹងមាំនៅក្នុងទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទនៅពេលណាដែរ ?

សូមឲ្យសិស្សសញ្ជឹងគិតពីអ្វី ដែលពួកគេអាចធ្វើដើម្បីយាងព្រះវិញ្ញាណឲ្យគង់នៅជាមួយនឹងពួកគេ ដើម្បីឲ្យពួកគេអាចយកឈ្នះលើសេចក្តីភ័យខ្លាច ហើយពុំខ្មាស់អៀនពីទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។

សូមសង្ខេប ធីម៉ូថេទី ២ ១:៩–១៨ ដោយពន្យល់ថា ប៉ុលបានដាស់តឿនធីម៉ូថេឲ្យបន្តស្មោះត្រង់ចំពោះគោលលទ្ធិពិត ។ ប៉ុលក៏បានបញ្ជាក់ផងដែរថា ការក្បត់សាសនាដ៏ធំកំពុងរីករាលដាលនៅក្នុងសាសនាចក្រ (សូមមើល ធីម៉ូថេទី២ ១:១៥) ។

ធីម៉ូថេទី២ ២


ប៉ុលណែនាំធីម៉ូថេឲ្យស៊ូទ្រាំនឹងការលំបាកដោយស្មោះត្រង់

សូមអញ្ជើញសិស្សឲ្យអាន ធីម៉ូថេទី២ ២:១ ដោយស្ងាត់ស្ងៀម រកមើលពាក្យទុន្មានរបស់ប៉ុលដល់ធីម៉ូថេ ។

- តើប៉ុលបានណែនាំអ្វីខ្លះទៅធីម៉ូថេ ? (សូមពន្យល់ថា យើងទទួលបានព្រះគុណ ឬជំនួយដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទតាមរយៈសេចក្តីជំនឿរបស់យើង [សូមមើល រ៉ូម ៥:២]) ។
- ហេតុអ្វីមនុស្សម្នាក់អាចរកឃើញថា វាគឺជារឿងដ៏លំបាកដើម្បីបន្តមានចិត្តរឹងមាំនៅក្នុងសេចក្តីជំនឿរបស់គាត់លើព្រះយេស៊ូវគ្រីស្ទ ?

សូមពន្យល់ថា ប៉ុលបានទូន្មានធីម៉ូថេឲ្យនៅរឹងមាំតាមរយៈព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទ ដោយសារលោកបានដឹងថា ធីម៉ូថេនឹងជួបការរងទុក្ខ និងការបៀតបៀនក្នុងនាមជាសិស្សម្នាក់របស់ព្រះគ្រីស្ទ ។

សូមដាក់បង្ហាញ រូបភាព អំពីទាហាន អត្តពលករ និងកសិករម្នាក់ ។ (ឬ អ្នកអាចអញ្ជើញសិស្សឲ្យគូររូបមនុស្សបីប្រភេទនេះនៅលើក្តារខៀន) ។



សូមពន្យល់ថា ប៉ុលបានប្រើពាក្យប្រៀបធៀបអំពីទាហាន អត្តពលករ និងអ្នកចម្ការ (ឬកសិករ) ដើម្បីបង្រៀនធីម៉ូថេពីរបៀបដើម្បីបន្តរឹងមាំនៅក្នុងសេចក្តីជំនឿទោះជាជួបការលំបាកក្តី ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យចម្លងវាចូលទៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ឬចែកចាយឯកសារនោះឲ្យពួកគេ ៖

ការប្រៀបធៀប	ការពិពណ៌នា	តើការប្រៀបធៀបនេះបង្រៀនអ្វីខ្លះអំពីការបន្តរឹងមាំនៅក្នុងសេចក្តីជំនឿ
ទាហាន		

ការប្រៀបធៀប	ការពិពណ៌នា	តើការប្រៀបធៀបនេះបង្រៀនអ្វីខ្លះអំពីការបន្តរឹងមាំនៅក្នុងសេចក្តីជំនឿ
អត្តពលករ		
អ្នកចម្ការ (កសិករ)		

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ២:៣–៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាតើប៉ុលបានរៀបរាប់ពីទាហាន អត្តពលករ និងកសិករយ៉ាងដូចម្តេច ។ សូមពន្យល់ថា ពាក្យ *ទុក្ខលំបាក* (ខទី ៣) សំដៅទៅលើការរងទុក្ខ ឬការលំបាក ហើយឃ្លា « ប្រយុទ្ធគ្នាក្នុងព្រំត្រ » (ខទី ៥) សំដៅទៅលើការប្រកួតនៅក្នុងអត្តពលកម្ម ។

- យោងតាមការបង្រៀនរបស់ប៉ុលនៅក្នុង ខទី ៣–៤ តើទាហានល្អម្នាក់ធ្វើអ្វីខ្លះ ? (សូមសរសេរប្រយោគខាងក្រោមនេះនៅក្នុងប្រអប់ទីមួយក្រោមពាក្យ « ការពិពណ៌នា » លើតារាង ៖ *ទាហានល្អម្នាក់ស៊ូទ្រាំនឹងការលំបាកដោយឧស្សាហ៍ ហើយទុកចោលកិច្ចការផ្សេងទៀតមួយអន្លើរ ដើម្បីធ្វើឲ្យមេរបស់គាត់ពេញចិត្ត*) ។
- នៅក្នុង ខទី ៥ កាលដែលអត្តពលករម្នាក់នឹងពុំបាន « ពាក់ភ្លុងជ័យ » ដរាបណាគាត់ប្រយុទ្ធ ឬប្រកួត « តាមច្បាប់ » មានន័យដូចម្តេច ? (សូមសរសេរប្រយោគខាងក្រោមនេះនៅក្នុងប្រអប់ទីពីរក្រោមពាក្យ « ការពិពណ៌នា » ៖ *អត្តពលករម្នាក់អាចមានជ័យជំនះ ដរាបណាគាត់គោរពតាមច្បាប់ប៉ុណ្ណោះ*) ។
- យោងតាម ខទី ៦ តើអ្វីទៅជារង្វាន់សម្រាប់កសិករម្នាក់ដែលខិតខំធ្វើការប្រតិកាត់ផលរបស់គាត់ ? (សូមសរសេរប្រយោគខាងក្រោមនេះ នៅក្នុងប្រអប់ទីបីក្រោមពាក្យ « ការពិពណ៌នា » ៖ *កសិករម្នាក់ត្រូវខិតខំធ្វើការដើម្បីរីករាយនឹងផលផ្លែនៃការងាររបស់គាត់*) ។

ទុកចិត្តសិស្សរបស់អ្នក

សូមមានសេចក្តីជំនឿថា ជាមួយនឹងការណែនាំដ៏ត្រឹមត្រូវ និងការលើកទឹកចិត្ត នោះសិស្សអាចយល់ពីព្រះគម្ពីរ ស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ ពន្យល់ជំណឹងល្អដល់អ្នកដទៃ និងអនុវត្តតាមការបង្រៀនជំណឹងនៅក្នុងជីវិតរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យបំពេញតារាងរបស់ពួកគេ ដោយសរសេរនៅក្នុងជួរឈរទីបីនូវអ្វីដែលការប្រៀបធៀបនីមួយៗបង្រៀនអំពីការបន្តរឹងមាំនៅក្នុងសេចក្តីជំនឿ ។ សូមឲ្យសិស្សពីរបីនាក់ប្រាប់ពីចម្លើយរបស់ពួកគេ ។

សូមពន្យល់ថា ប៉ុលបានពោលថា លោកបានជួបនឹងការសាកល្បងជាច្រើនក្នុងការធ្វើជាសិស្សរបស់ព្រះគ្រីស្ទ (សូមមើល ធីម៉ូថេទី ២ ២:៩) ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ២:១០–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ប៉ុលបានពោលអ្វីខ្លះអំពីហេតុផលដែលលោកបានស៊ូទ្រាំនឹងការលំបាកទាំងនេះ ។ សូមពន្យល់ថា « ពួកជើសតាំង » (ខទី ១០) សំដៅទៅលើសមាជិកសាសនាចក្រដ៏ស្មោះត្រង់ ហើយថាពាក្យ *ទ្រាំទ្រ* នៅក្នុង ខទី ១២ សំដៅទៅលើការស៊ូទ្រាំ និងការបន្តខ្ជាប់ខ្ជួនជានិច្ច ។

- យោងតាមពាក្យសម្តីរបស់ប៉ុលនៅក្នុង ខទី ១០ និង ១២ ហេតុអ្វីលោកសុខចិត្តស៊ូទ្រាំនឹងការលំបាក ហើយបន្តស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះពីប៉ុល នូវអ្វីដែលអាចកើតឡើង នៅពេលយើងស៊ូទ្រាំនឹងការលំបាក ហើយបន្តស្មោះត្រង់នឹងព្រះអម្ចាស់ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរតែប្រាប់នូវគោលការណ៍ស្រដៀងគ្នានេះដូចតទៅ ៖ **នៅពេលយើងស៊ូទ្រាំនឹងការលំបាក ហើយបន្តស្មោះត្រង់នឹងព្រះអម្ចាស់ យើងអាចជួយខ្លួនឯង និងមនុស្សដទៃទៀតឲ្យទទួលបានសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើការស៊ូទ្រាំនឹងការសាកល្បងដោយស្មោះត្រង់របស់យើង អាចជួយមនុស្សដទៃឲ្យទទួលបានសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្តេច ?

សូមសង្ខេប ធីម៉ូថេទី២ ២:១៣–១៩ ដោយពន្យល់ថា ប៉ុលបានទន្ទានធីម៉ូថេឲ្យរំឭកពួកបរិសុទ្ធឲ្យចៀសវាងការឈ្លោះប្រកែកគ្នា ហើយ « ថយចេញពីសេចក្តីទុច្ចរិត » (ខទី ១៩) ។

សូមដាក់បង្ហាញ រូបភាពវត្ថុដាក់ទឹកផ្សេងៗគ្នា ដូចជា ចានគោម ពែង និងថូមួយ ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ២:២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាមានគ្រឿងប្រដាប់ប្រភេទណាខ្លះ « នៅក្នុងផ្ទះធំ » ។

- យោងតាមប៉ុល តើមានគ្រឿងប្រដាប់ប្រភេទណាខ្លះ « នៅក្នុងផ្ទះធំ » ?

សូមពន្យល់ថា ប៉ុលបានប្រើគ្រឿងប្រដាប់ ឬវត្ថុដាក់ទឹកប្រភេទខុសៗគ្នា ជាការប្រៀបធៀបមួយសម្រាប់សមាជិកអំពីផ្ទះ ឬសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ២:២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាអ្វីទៅដែលធ្វើឲ្យមនុស្សម្នាក់ក្លាយជា « ប្រដាប់. . .មានប្រយោជន៍ដល់ម្ចាស់ » ។

- យោងតាមប៉ុល តើយើងអាចធ្វើអ្វីខ្លះដើម្បី« មានប្រយោជន៍ដល់ម្ចាស់ » ?

សូមចង្អុលបង្ហាញថា ឃ្លា « សំអាតខ្លួនពីសេចក្តីទាំងនោះ » (ខទី ២១) សំដៅលើការប្រែក្លាយជាស្អាតទាំងស្រុងចេញពីសេចក្តីទុច្ចរិត (សូមមើល ខទី ១៩) ។

- ដោយផ្អែកលើការប្រៀបធៀបរបស់ប៉ុលដោយប្រើគ្រឿងប្រដាប់ តើយើងអាចរៀនគោលការណ៍អ្វីខ្លះទាក់ទងនឹងអ្វី ដែលយើងអាចធ្វើដើម្បីបម្រើព្រះអម្ចាស់ឲ្យបានប្រសើរ ? (សិស្សគួរឃើញគោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ខាងក្រោម ៖ **ប្រសិនយើងសម្អាតខ្លួនយើងចេញពីសេចក្តីទុច្ចរិត នោះយើងអាចបម្រើព្រះអម្ចាស់កាន់តែប្រសើរ**) ។
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីសម្អាតខ្លួនយើងចេញពីសេចក្តីទុច្ចរិត ?

សូមអញ្ជើញសិស្សឲ្យអាន ធីម៉ូថេទី២ ២:២២ ដោយស្ងៀមស្ងាត់ រកមើលថាយើងអាចធ្វើអ្វីខ្លះទៀត ដើម្បីសម្អាតខ្លួនយើងចេញពីសេចក្តីទុច្ចរិត ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើការសម្អាតខ្លួនយើងចេញពីសេចក្តីទុច្ចរិត អាចជួយយើងអាចឲ្យបម្រើព្រះអម្ចាស់កាន់តែប្រសើរឡើងតាមរបៀបណា ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយរៃមខ្មែរ ជែប្រ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកថាគោលការណ៍នេះអនុវត្តចំពោះជន ដែលបម្រើព្រះអម្ចាស់ដូចជាពួកអ្នកផ្សព្វផ្សាយសាសនាយ៉ាងដូចម្តេច ៖



« គ្មានអ្នកផ្សព្វផ្សាយសាសនាណាអាចមិនប្រែចិត្តពីអំពើរំលងខាងផ្លូវភេទ ឬភាសាអាសគ្រាម ឬបណ្តោយខ្លួនតាមរូបភាពអាសគ្រាម រួចហើយមករំពឹងទុកឲ្យអ្នកដទៃប្រែចិត្តចំពោះរឿងទាំងអស់នេះនោះទេ ! អ្នកមិនអាចធ្វើដូច្នោះបានឡើយ ។ ព្រះវិញ្ញាណនឹងពុំគង់នៅនឹងអ្នកឡើយ ហើយពាក្យទាំងឡាយនឹងត្រូវស្លាក់នៅក្នុងបំពង់កអ្នក ពេលអ្នកថ្លែងវាចេញមក ។ អ្នកមិនអាចធ្វើដំណើរតាមផ្លូវដែលលីហៃបានហៅថាជា ‹ ផ្លូវហាមឃាត់ទាំងឡាយ › [នីហ្វៃទី១ ៨:២៨] ហើយរំពឹងថានឹងដឹកនាំមនុស្សដទៃឲ្យដើរតាមផ្លូវ ‹ ត្រង់ ហើយចង្អៀត › [នីហ្វៃទី២ ៣១:១៨] បាននោះទេ—វាពុំអាចធ្វើដូច្នោះបានឡើយ » ។

« . . . មិនថាអ្នកជានរណា ឬអ្នកបានធ្វើអ្វីនោះទេ អ្នកអាចត្រូវបានអភ័យទោសឲ្យ ។ . . . វាគឺជាអព្ភូតហេតុនៃការអភ័យទោស វាគឺជាអព្ភូតហេតុនៃដង្វាយធួនរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។ ប៉ុន្តែ អ្នកពុំអាចធ្វើវាដោយគ្មានការតាំងចិត្តដ៏សកម្មមួយ ចំពោះដំណឹងល្អនោះទេ ហើយអ្នកពុំអាចធ្វើវាដោយគ្មានការប្រែចិត្ត ពេលដែលវាចាំបាច់តម្រូវឲ្យមាននោះទេ ។ ខ្ញុំកំពុងសុំឲ្យអ្នក. . . សកម្ម ហើយស្អាតស្អំ ។ ប្រសិនបើវាតម្រូវ ខ្ញុំកំពុងស្នើសុំឲ្យអ្នក*សកម្ម* ហើយ*ស្អាតស្អំ* » (« We Are All Enlisted » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៤៥) ។

- ហេតុអ្វីក៏វាចាំបាច់ ដើម្បីមានភាពស្អាតស្អំពីអំពើបាប នៅពេលប្រកាសដំណឹងល្អ ?

សូមបញ្ចប់ដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិតដ៏ពេញលេញនៃគោលការណ៍នេះ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីរាល់អំពើបាបដែលពួកគេត្រូវធ្វើការប្រែចិត្ត ដើម្បីពួកគេអាចបម្រើព្រះអម្ចាស់បានកាន់តែប្រសើរ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ធីម៉ូថេទី២ ១:៧–៨ ។ « ដូច្នេះ មិនត្រូវឲ្យអ្នកមានសេចក្តីខ្មាស់ ចំពោះការធ្វើបន្ទាល់ពីព្រះអម្ចាស់នៃយើងនោះឡើយ » ។

សិស្ស៊ែរ បូនី អិល អូស្ការសុន ប្រធានយុវនារីទូទៅ បានចែកចាយពីដំណើររឿងដូចខាងក្រោមនេះអំពី ម៉ារី ម៉ាឌេលីន ខាឆិន ជាអ្នកប្រែចិត្តជឿថ្មីរបស់ក្មេងម្នាក់នៅប្រទេសអ៊ីតាលី ដែលបានបង្ហាញភាពក្លាហាននៅក្នុងការការពារសេចក្តីជំនឿថ្មីរបស់នាង ៖

« ថ្មីៗនេះ ខ្ញុំបានអានរឿងរបស់ ម៉ារី ម៉ាឌេលីន ខាឆិន ជាមួយគ្រួសារគាត់ដែលបានទទួលសារលិខិតនៃដំណឹងល្អដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ តាមរយៈអ្នកផ្សព្វផ្សាយសាសនាដំបូងគេ ដែលបានហៅឲ្យបម្រើនៅក្នុងប្រទេសអ៊ីតាលី ក្នុងឆ្នាំ ១៨៥០ ។ គាត់ជាយុវនារីមានវ័យ ១៧ ឬ ១៨ ឆ្នាំ ពេលពួកគាត់បានទទួលបុណ្យជ្រមុជទឹក ។ នៅថ្ងៃអាទិត្យមួយ ពេលគ្រួសារកំពុងធ្វើកម្មវិធីថ្វាយបង្គំនៅគេហដ្ឋានរបស់ពួកគាត់ នៅលើភ្នំខ្ពស់នៃប្រទេសអ៊ីតាលីប៉ែកខាងជើង នោះមានមនុស្សកំណាចមួយក្រុមដែលខឹងសម្បារ មានទាំងគ្រូគង្វាលក្នុងតំបន់មួយចំនួន បានមកផ្តុំគ្នានៅមុំវិញផ្ទះ រួចចាប់ផ្តើមស្រែកគំហកខ្លាំងៗ ហើយហៅឲ្យអ្នកផ្សព្វផ្សាយសាសនាឲ្យចេញទៅក្រៅផ្ទះ ។ ខ្ញុំមិនគិតថា ពួកគេអន្ទះសាចិត្តទទួលការបង្រៀនដំណឹងល្អទេ—តែពួកគេមានបំណងចង់ធ្វើបាបខាងរូបកាយ ។ ក្មេងស្រី ម៉ារី បានចេញទៅក្រៅផ្ទះប្រឈមនឹងពួកមនុស្សអាក្រក់ ។

« ពួកគេបានបន្តស្រែកយ៉ាងសាហាវ ឲ្យយកអ្នកផ្សព្វផ្សាយសាសនាចេញមកខាងក្រៅ ។ ម៉ារី បានលើកព្រះគម្ពីរបឺបឡើង ហើយបញ្ជាពួកគេឲ្យចេញទៅ ។ នាងបានប្រាប់ពួកគេថា ពួកអែលឌើរគឺស្ថិតនៅក្រោមការការពាររបស់នាង ហើយពួកគេពុំអាចប៉ះពាល់ដល់អ្នកផ្សាយសាសនា សូម្បីតែសក់មួយសរសៃឡើយ ។ សូមស្តាប់នូវពាក្យរបស់គាត់ផ្ទាល់ ៖ ‹ មនុស្សទាំងអស់ឈរស្រឡាំងកាំង ។ . . . ព្រះគង់នៅនឹងខ្ញុំ ។ ទ្រង់ឲ្យខ្ញុំនិយាយ បើមិនដូច្នោះខ្ញុំពុំអាចនិយាយបានទេ ។ មនុស្សទាំងអស់នៅស្ងៀមមួយរំពេច ។ មនុស្សសាហាវមានធំៗទាំងនោះបានឈរទ្រឹងនៅពីមុខក្មេងស្រីទន់ខ្សោយ ភ័យញ័រ តែគ្មានភាពភ័យខ្លាចនោះទេ › ។ គ្រូគង្វាលបានសុំឲ្យពួកមនុស្សអាក្រក់ចាកចេញ ដែលពួកគេបានចេញទៅដោយស្ងាត់ស្ងៀមដោយខ្មាស់អៀន ភ័យខ្លាច និងវិប្បដិសារី ។ ក្រុមតូចនោះបានបញ្ចប់ការប្រជុំរបស់ពួកគេដោយសុខសាន្ត ។

« តើអ្នកអាចនឹកស្មានដល់ទេ ដែលយុវនារីក្លាហាន មានវ័យស្របាលអ្នក ឈរចំពោះមនុស្សអាក្រក់ ហើយការពារជំនឿដែលនាងបានរកឃើញថ្មីៗដោយភាពក្លាហាន និងដោយមានជំនឿចិត្តនោះ ? » (« Defenders of the Family Proclamation » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១៤ ។

ធីម៉ូថេ ទី២ ៣–៤

សេចក្តីផ្តើម

ប៉ុលបានសរសេរទៅកាន់ធីម៉ូថេ ហើយបានពន្យល់ថា ការក្បត់សាសនា និងអំពើទុច្ចរិតនឹងរាលដាលពាសពេញនៅក្នុងជំនាន់របស់ពួកគេក៏ដូចជានៅថ្ងៃចុងក្រោយផងដែរ ។ លោកបានណែនាំ ធីម៉ូថេ ឲ្យបន្តស្មោះត្រង់ចំពោះសេចក្តីពិត ដែលលោកធ្លាប់បានបង្រៀនរួចមកហើយ ។ ប៉ុលបានបង្រៀនអំពីគោលបំណងនៃបទគម្ពីរ ។ ប៉ុលបញ្ចប់សំបុត្ររបស់លោកដោយលើកទឹកចិត្តធីម៉ូថេ ឲ្យខំប្រឹងបំពេញការងារបម្រើរបស់ខ្លួន ។

យោបល់សម្រាប់ការបង្រៀន

ធីម៉ូថេ ទី២ ៣

ប៉ុលពិពណ៌នាពីគ្រាដ៏លំបាកនៅថ្ងៃចុងក្រោយ

ពីមុនថ្នាក់ចាប់ផ្តើម ចូរសុំឲ្យសិស្សពីរ ឬបីនាក់ដែលបានមកដល់ដំបូងគេឲ្យគូររូបនៅលើក្តារខៀនស្តីពីស្ថានភាពដ៏គ្រោះថ្នាក់ ឬ ហានិភ័យមួយ ។ បន្ទាប់ពីថ្នាក់ចាប់ផ្តើម សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកនឹងប្រើពាក្យអ្វី ដើម្បីពិពណ៌នាពីស្ថានភាពដែលបានគូរនៅលើក្តារខៀន ?

សូមពន្យល់ថា ជាផ្នែកមួយនៃសំបុត្រទីពីររបស់លោកដល់ធីម៉ូថេ ប៉ុលបានព្យាករពីស្ថានភាពនៅក្នុងជំនាន់លោក និងជំនាន់របស់យើង ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ៣:១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាប៉ុលបានរៀបរាប់ពីគ្រាដែលយើងរស់នៅយ៉ាងដូចម្តេច ។

- តើប៉ុលបានរៀបរាប់ពីគ្រាដែលយើងរស់នៅយ៉ាងដូចម្តេច ? (ប្រសិនបើចាំបាច់ សូមពន្យល់ថា ពាក្យ *ដ៏លំបាក* មានន័យថា ពោរពេញដោយគ្រោះថ្នាក់ ឬហានិភ័យ) ។
- តើហានិភ័យ ឬគ្រោះថ្នាក់ខាងវិញ្ញាណ ឬខាងសីលធម៌មួយចំនួនអ្វីខ្លះ ដែលអ្នកធ្លាប់ឃើញនៅក្នុងជំនាន់របស់យើង ?

សូមបំបែកសិស្សទៅជាគូៗ ។ សូមចែកច្បាប់ចម្លងអំពីតារាងនៅខាងក្រោមឲ្យដៃគូនីមួយៗ ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអានធីម៉ូថេទី ២ ៣:២–៧ ហើយឆ្លើយសំណួរនៅក្នុងតារាង ។ សូមណែនាំពួកគេឲ្យប្រើសេចក្តីយោងជាជំនួយសម្រាប់ពាក្យពិបាកៗ ។

ធីម៉ូថេទី ២ ៣:២–៧

តើឧទាហរណ៍មួយចំនួនអំពីស្ថានភាពនៅថ្ងៃចុងក្រោយ ដែលប៉ុលបានរៀបរាប់មានអ្វីខ្លះ ?	នៅក្នុងចំណោមស្ថានភាពទាំងនេះ តើស្ថានភាពណាមួយដែលអ្នកធ្លាប់បានឃើញនៅសម័យរបស់យើង ? (ប្រាប់អំពីស្ថានភាពទាំងនោះឲ្យបានពីរ ឬបី) ។ ហេតុអ្វីស្ថានភាពទាំងនេះមានគ្រោះថ្នាក់ខ្លាំងម្ល៉េះ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ដល់សិស្សក្នុងថ្នាក់ពីអ្វីដែលពួកគេបានពិភាក្សា រួមបញ្ចូលទាំងហេតុផលដែលស្ថានភាពទាំងនេះមានគ្រោះថ្នាក់ខ្លាំងម្ល៉េះ ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា ពួកគេធ្លាប់ជ្រួយបារម្ភ ថាពួកគេអាចនឹងរងឥទ្ធិពលគ្រោះថ្នាក់មួយចំនួនដែលប៉ុលបានលើកឡើងនៅក្នុងខគម្ពីរដែលពួកគេបានសិក្សាដែរឬទេ ។

- យោងតាមចំណុចបញ្ចប់នៃ ធីម៉ូថេទី ២ ៣:៥តើប៉ុលលើកទឹកចិត្តធីម៉ូថេឲ្យធ្វើអ្វីខ្លះ ដែលវាក៏អាចជួយនៅជំនាន់របស់យើងផងដែរនោះ ? (យើងគួរងាកចេញពីអំពើទុច្ចរិត) ។

សូមសង្ខេប ធីម៉ូថេទី ២ ៣:៨–១១ ដោយពន្យល់ថា ប៉ុលបានប្រាប់ធីម៉ូថេថា អស់អ្នកដែលតោងជាប់នឹងសេចក្តីពិតនឹងមើលឃើញពីភាពល្ងង់ខ្លៅរបស់ពួកគេ ។ លោកក៏បានសរសេរអំពីគ្រោះថ្នាក់ និងការបៀតបៀនជាច្រើនដែលលោកបានស៊ូទ្រាំ ដោយសារការខិតខំដើម្បីរស់នៅតាមដំណឹងល្អរបស់លោក ។

សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី ២ ៣:១២–១៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា តើប៉ុលបានព្យាករថាអ្វីខ្លះនឹងកើតឡើងដល់អស់អ្នកដែលរស់នៅតាមដំណឹងល្អ ។

- តើប៉ុលបានព្យាករថានឹងមានអ្វីខ្លះកើតឡើងដល់អស់អ្នក ដែលរស់នៅតាមដំណឹងល្អ ?

សូមពន្យល់ថា ថ្វីបើស្ថានភាពដ៏អាក្រក់ទាំងនេះមានភាពធ្ងន់ធ្ងរក្តី ក៏យើងអាចរកបានជំនួយ និងការការពារផងដែរ ។ សូមអញ្ជើញសិស្សម្នាក់អានធីម៉ូថេទី ២ ៣:១៤–១៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា តើប៉ុលបានបង្រៀនថាមានអ្វីខ្លះអាចជួយយើងឲ្យបែរចេញពីគ្រោះថ្នាក់ទាំងនេះ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះអំពីការតតាំងនឹងគ្រោះថ្នាក់ដែលលោកបានរៀបរាប់ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណានៅក្នុង ខទី ១៤ ដែលថា « ឲ្យអ្នកនៅជាប់ក្នុងសេចក្តីដែលអ្នកបានរៀន ហើយជឿជ្រាកដវិញ » នោះ ?

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃ ឃ្លានេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដៃវ្រីឌ អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ក្នុងវេលានៃការភ័យខ្លាច ឬការសង្ស័យ ឬពេលដែលមានបញ្ហា សូមកាន់ខ្ជាប់ជំហរដែលអ្នកបានយកឈ្នះរួចមកហើយនោះ ។ . . .ពេលគ្រាទាំងនោះមកដល់ ហើយបញ្ហាផុសចេញមក ដំណោះស្រាយមិនអាចកើតមានភ្លាមៗទេ *សូមកាន់ខ្ជាប់ទៅនឹងអ្វីដែលអ្នកបានដឹងរួចហើយ ហើយឈរយ៉ាងរឹងមាំ រហូតដល់ចំណេះដឹងបន្ថែមទៀតមកដល់* » (« ខ្ញុំជឿហើយ លោកម្ចាស់អើយ » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៣–៩៤) ។

សូមចង្អុលបង្ហាញថាឃ្លា « ដោយដឹងថា អ្នកបានរៀនសេចក្តីនោះពីអ្នកណា » នៅក្នុង ខទី ១៤ ។ សូមពន្យល់ថា យើងអាចរៀនហើយទទួលការអះអាងនៃសេចក្តីពិតមកពីប្រភពដែលទុកចិត្តបានដូចជា ពួកព្យាការី ពួកថ្នាក់ដឹកនាំ ពួកគ្រូបង្រៀន ឪពុកម្តាយ និងព្រះវិញ្ញាណបរិសុទ្ធ ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពី ខទី ១៤–១៥ អំពីរបៀបយកឈ្នះលើគ្រោះថ្នាក់ខាងវិញ្ញាណនៅថ្ងៃចុងក្រោយ ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងបន្តនៅក្នុងសេចក្តីពិតដែលយើងបានរៀនមកពីប្រភពដែលទុកចិត្ត និងនៅក្នុងបទគម្ពីរ នោះយើងអាចយកឈ្នះគ្រោះថ្នាក់ខាងវិញ្ញាណនៅថ្ងៃចុងក្រោយបាន**) ។
- តើការពឹងផ្អែកលើបទគម្ពីរ និងសេចក្តីពិតដែលយើងបានរៀន អាចជួយយើងឲ្យយកឈ្នះលើគ្រោះថ្នាក់នៅជំនាន់របស់យើងយ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់ជ្រើសរើសពឹងផ្អែកលើសេចក្តីពិត ដែលអ្នកបានរៀននៅពេលណា ? តើអ្នកបានទទួលពរ ដោយព្រោះការធ្វើដូច្នោះយ៉ាងដូចម្តេច ? (ដំបូង អ្នកអាចឲ្យសិស្សឆ្លើយនឹងសំណួរទាំងនេះ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬសៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ រួចហើយអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានសរសេរ) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអាន ធីម៉ូថេទី ២ ៣:១៦–១៧ ឮៗ ហើយឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើលថាតើប៉ុលបានបង្រៀនអ្វីខ្លះអំពីបទគម្ពីរ ។ អ្នកអាចផ្តល់យោបល់ឲ្យ សិស្សគូរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះ អំពីការសិក្សាបទគម្ពីរ ដែលអាចជួយនៅក្នុងជំនាន់របស់យើង ? (សូមជួយសិស្សឲ្យរកឃើញនូវគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងសិក្សាព្រះគម្ពីរ យើងអាចរៀនពីគោលលទ្ធិ ហើយទទួលបាននូវការកែតម្រូវ និងការណែនាំដែលនឹងជួយយើងឲ្យរីកចម្រើនឆ្ពោះទៅរកភាពល្អឥតខ្ចោះ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមគូសរង្វង់លើពាក្យ *គោលលទ្ធិ ការកែតម្រូវ* និង *ការណែនាំ* នៅក្នុងសេចក្តីថ្លែងការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សគិតពីគ្រាមួយដែលបទគម្ពីរបានជួយពួកគេនៅក្នុងរបៀបមួយដូចខាងក្រោមនេះ ៖ (១) ដើម្បីយល់ដឹងពីគោលលទ្ធិមួយនៃដំណឹងល្អ (២) ដោយផ្តល់ជាភស្តុតាងសារជាថ្មី ឬការកែតម្រូវទាក់ទងនឹងរឿងមួយនៅក្នុងការគិត ការជ្រើសរើស ឬឥរិយាបថរបស់ពួកគេដែលមិនត្រឹមត្រូវ ឬ (៣) ដោយផ្តល់ជាចម្លើយមួយចំពោះការអធិស្ឋាន ឬការផ្តល់ការណែនាំអំពីរបៀប ដែលពួកគេអាចដោះស្រាយបញ្ហាមួយបាន ។ ចូរទុកពេលឲ្យសិស្សគិតពីបទពិសោធន៍នានា រួចហើយអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេគិតដល់សិស្សក្នុងថ្នាក់ ។ (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬឯកជនពេក រួមទាំងអំពើបាបពីអតីតកាលផងដែរ) ។

- ចំពោះអ្វីដែលយើងបានរៀនអំពីតម្លៃនៃបទគម្ពីរ ហេតុអ្វីអ្នកគិតថា យើងត្រូវបានលើកទឹកចិត្តឲ្យសិក្សាវាជាប្រចាំថ្ងៃ ?

ចូរឲ្យសំណៅដល់សិស្សអំពីសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កត ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សម្នាក់អានវាឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យទូន្មាន និងការសន្យារបស់អែលឌើរ ស្កត ទាក់ទងនឹងការសិក្សាព្រះគម្ពីរ ។

ធីម៉ូថេទី ២ ៣:១៥–១៧ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ឲ្យសិស្សគូរគូសចំណាំចំណេះចំណានខគម្ពីរនេះ តាមរបៀបជាក់លាក់មួយដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

សម្រាប់ការពន្យល់អំពីចំណេះចំណានខគម្ពីរ និងបញ្ជីនៃសកម្មភាពបន្ថែមដើម្បីជួយសិស្សឲ្យចេះចាំនូវគម្ពីរជម្រើសទាំងនេះ សូមមើលឧបសម្ព័ន្ធនៃសៀវភៅសិក្សានេះ ។



« សូមកុំជឿពាក្យកុហករបស់សាតាំងថា បងប្អូនគ្មានពេលសិក្សាព្រះគម្ពីរឲ្យសោះ ។ សូមជ្រើសយកពេលសិក្សាព្រះគម្ពីរទាំងនោះ ។ ការទទួលទានបន្ទូលព្រះជារៀងរាល់ថ្ងៃគឺសំខាន់ជាងការដេក សាលារៀន ការងារ កម្មវិធីទូរទស្សន៍ វីដេអូហ្គេម ឬបណ្តាញសង្គមទៅទៀត ។ បងប្អូនត្រូវស្គាល់ពីអាទិភាពខ្លួន ដើម្បីមានពេលសិក្សាបន្ទូលព្រះ។ ប្រសិនបើដូច្នេះមែន សូមធ្វើចុះ !

« . . . ពេលបងប្អូនលះបង់ពេលវេលារាល់ថ្ងៃ ទាំងពេលផ្ទាល់ខ្លួន និងជាគ្រួសារដើម្បីសិក្សាបន្ទូលព្រះ នោះសេចក្តីសុខសាន្តនឹងកើតមានក្នុងជីវិតបងប្អូន » (« Make the Exercise of Faith Your First Priority » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៩៣) ។

សូមថ្លែងទីបន្ទាល់អំពីសុវត្ថិភាព និងសេចក្តីសុខសាន្តដែលកើតមានដល់អស់អ្នកដែលបន្តនៅក្នុងសេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរ ។ សូមអញ្ជើញសិស្សឲ្យពិចារណាថាពួកគេមានអារម្មណ៍យ៉ាងណា ពេលពួកគេអាចអនុវត្តគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅមួយដោយផ្អែកទៅលើការបំផុសគំនិតដែលពួកគេបានទទួល ។

ធីម៉ូថេទី ២ ៤

ប៉ុលប្រកាសថា លោកបានតយុទ្ធយ៉ាងល្អ ហើយប្រាប់ធីម៉ូថេឲ្យបន្តការផ្សព្វផ្សាយដំណឹងល្អ

សូមឲ្យសិស្សលើកដៃ ប្រសិនបើពួកគេធ្លាប់មានអារម្មណ៍ថាចង់ចុះចាញ់ចំពោះការងារមួយដែលលំបាក ។

- តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះ នៅពេលអ្នកស៊ូទ្រាំ ទោះជាអ្នកបានចង់ចុះចាញ់ក្តី ?

សូមពន្យល់ថា ធីម៉ូថេទី ២ ទំនងជាសំបុត្រចុងក្រោយ ដែលប៉ុលបានសរសេរពីមុនលោកស្លាប់ ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ឲ្យអាន ធីម៉ូថេទី២ ៤:១–៥ ដោយស្ងាត់ស្ងៀម ហើយរកមើលពាក្យទូន្មានរបស់ប៉ុលទៅដល់ធីម៉ូថេ ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ទៀតឲ្យអានបទគម្ពីរដូចគ្នា ហើយរកមើលការព្យាករបស់ប៉ុលអំពីអនាគតនៃសាសនាចក្រគ្រីស្ទានកាលពីបុរាណ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើលេខយោងដើម្បីជួយពួកគេឲ្យយល់ពីអ្វីដែលពួកគេអាន ។ បន្ទាប់ពីពួកគេបានអានហើយ សូមអញ្ជើញសិស្សមកពីក្រុមនីមួយៗប្រាប់ថាពួកគេរកឃើញអ្វីខ្លះ ។

សូមពន្យល់ថា ខទី ៣–៤ កត់ត្រានូវការអត្តាធិប្បាយរបស់ប៉ុលស្តីពីការក្បត់សាសនាដែលកំពុងចាប់ផ្តើមកើតឡើងនៅក្នុងសាសនាចក្រ ។ ឥរិយាបថដូចជាអ្វីដែលប៉ុលបានរៀបរាប់នោះដឹកនាំទៅរកការក្បត់សាសនាដ៏ធំ ដូច្នោះវាជាការចាំបាច់ដែលត្រូវមានការស្តារឡើងវិញនៃដំណឹងល្អ ។

- ហេតុអ្វីអ្នកគិតថាប៉ុលបានលើកទឹកចិត្តធីម៉ូថេឲ្យបន្តប្រកាសដំណឹងល្អ ហើយធ្វើការបម្រើដល់ប្រជាជន ទោះជាលោកបានដឹងថាមានមនុស្សជាច្រើននឹងងាកចេញពីសេចក្តីពិតនោះ ?

ចូរអញ្ជើញសិស្សម្នាក់ឲ្យអាន ធីម៉ូថេទី ២ ៤:៦–៨ ឮៗ ហើយឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើលថាតើប៉ុលបានសរសេរអ្វីខ្លះអំពីការខិតខំរបស់លោកក្នុងការប្រកាសដំណឹងល្អ ។

- តើប៉ុលបាននិយាយអ្វីខ្លះ អំពីការខិតខំរបស់លោកក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ ? (សូមចង្អុលបង្ហាញថា ពាក្យប្រៀបធៀបរបស់ប៉ុលអំពីការតយុទ្ធយ៉ាងល្អ និងការរត់ប្រណាំងជាស្រេច ពិពណ៌នាពីរបៀបដែលលោកបញ្ចប់បេសកកម្មរបស់លោកដោយស្មោះត្រង់) ។
- យោងតាម ខទី ៨តើប៉ុលបានដឹងថាមានអ្វីខ្លះកំពុងរង់ចាំលោកក្រោយពីសេចក្តីស្លាប់ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះចេញមកពីខគម្ពីរទាំងនេះអំពីការខិតខំរបស់យើង ដើម្បីបន្តស្មោះត្រង់នៅក្នុងការធ្វើអ្វីដែលព្រះអម្ចាស់តម្រូវឲ្យយើងធ្វើ ? (សិស្សគួរតែរកឃើញនូវអ្វីដែលមានដូចតទៅនេះ ៖ **ប្រសិនបើយើងបន្តស្មោះត្រង់ចំពោះអ្វីៗ ដែលព្រះអម្ចាស់តម្រូវឲ្យយើងធ្វើ នោះយើងនឹងទទួលបានមកុដនៃសេចក្តីសុចរិត ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមពន្យល់ថា ការទទួលបាន « មកុដនៃសេចក្តីសុចរិត » រួមមានទាំងការប្រែក្លាយដូចជាព្រះវរបិតាសួគ៌ផងដែរ ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្តារខៀន អំពីតម្រូវការមួយចំនួនដែលព្រះអម្ចាស់បានប្រទានដល់យុវវ័យនៃសាសនាចក្រនេះ ដើម្បីជួយពួកគេឲ្យប្រែក្លាយដូចជាព្រះវរបិតាពួកគេដែលនៅគង់នៅស្ថានសួគ៌ ។

- ហេតុអ្វីយុវវ័យអាចនឹងជ្រើសយកការចុះចាញ់ ក្នុងការមានភាពស្មោះត្រង់ចំពោះតម្រូវការមួយចំនួនទាំងនេះ ?
- តើអ្នកមានស្គាល់នរណាម្នាក់ ដែលជាគំរូល្អមួយនៃការបន្តស្មោះត្រង់ដូចជាប៉ុល ទោះជាមានការលំបាកក្តីឬទេ ? តើពួកគេបានធ្វើអ្វីខ្លះ ដែលបង្ហាញពីគោលការណ៍នេះ ?

សូមសង្ខេប ធីម៉ូថេទី ២ ៤:៩–២២ ដោយពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោកដោយពន្យល់ថា ទោះជាលោកមានអារម្មណ៍ឯកោខ្លះៗនៅក្នុងកិច្ចការរបស់លោកក្តី ក៏ព្រះអម្ចាស់បានគង់នៅជាមួយនឹងលោក ហើយបានពង្រឹងលោកដែរ ។

សូមលើកទឹកចិត្តសិស្សឲ្យបន្តស្មោះត្រង់ នៅក្នុងការធ្វើអ្វីដែលព្រះអម្ចាស់តម្រូវឲ្យពួកគេធ្វើ ។

ចំណេះចំណានខគម្ពីរ—ធីម៉ូថេទី២ ៣:១៥–១៧

សូមឲ្យសិស្សបត់ក្រដាសជាបីផ្ទាត់ ដោយបង្កើតជាជួរឈរបី ។ សូមពន្លាតក្រដាសនោះមកវិញ ហើយសរសេរពាក្យ *គោលលទ្ធិ* នៅផ្នែកខាងលើនៃជួរឈរទីមួយ *ផ្តល់ជាភស្តុតាងថ្មី និងការកែតម្រូវ* នៅផ្នែកខាងលើនៃជួរឈរទីពីរ និង *ការណែនាំនៅក្នុងសេចក្តីសុចរិត* នៅផ្នែកខាងលើនៃជួរឈរទីបី ។

សូមអញ្ជើញសិស្សឲ្យប្រើក្រដាសនេះជាវត្ថុសិក្ខាំក្នុងសៀវភៅមួយ នៅក្នុងព្រះគម្ពីរបស់ពួកគេរយៈពេលមួយសប្តាហ៍ ដោយសរសេរផ្នែកដ៏សមរម្យ រាល់ពេលពួកគេអាននូវបទគម្ពីរមួយ ដែលវាបំពេញតាមគោលបំណងមួយនៅក្នុងចំណោមគោលបំណងទាំងនេះ ។ ឧទាហរណ៍ នៅក្រោមចំណងជើង *គោលលទ្ធិ* សិស្សអាចសរសេរសេចក្តីយោងបទគម្ពីរ និងគោលលទ្ធិ ឬគោលការណ៍ដែលពួកគេរៀននៅក្នុងខគម្ពីរទាំងនោះ ។ នៅក្រោមចំណងជើង *ផ្តល់ជាភស្តុតាងថ្មី និងការកែតម្រូវ* សិស្សអាចសរសេរសេចក្តីយោងបទគម្ពីរ និងរបៀបដែលបទគម្ពីរនោះកែតម្រូវគំនិតខុសឆ្គង ឬការជ្រើស និងឥរិយាបថនានារបស់ពួកគេ ។ ហើយនៅក្រោម *ការណែនាំនៅក្នុងសេចក្តីសុចរិត* សិស្សអាចកត់ត្រាបទគម្ពីរដែលផ្តល់ជាគំនិតចំពោះកិច្ចការល្អៗដែលពួកគេអាចធ្វើបាន ។

សូមលើកទឹកចិត្តសិស្សឲ្យយកក្រដាសនេះមកវិញក្នុងរយៈពេលមួយសប្តាហ៍ ដើម្បីបរិយាយប្រាប់ពីបទពិសោធន៍របស់ពួកគេ ។ អ្នកអាចនឹងចង់ដាក់ការរំឭកមួយនៅក្នុងព្រះគម្ពីរ ឬសៀវភៅសិក្សារបស់អ្នក ដើម្បីមានការពិភាក្សាខ្លីមួយក្នុងមួយសប្តាហ៍ ដើម្បីរំឭកចំណេះចំណានខគម្ពីរនេះឡើងវិញ ។

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់ទីតុស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្ររបស់ប៉ុលដល់ទីតុស គឺដូចគ្នានឹងសំបុត្ររបស់លោកដល់ធីម៉ូថេដែរ វាមាននូវការទូន្មានពុំចេះចប់មកពីសាវកប៉ុលទៅកាន់ថ្នាក់ដឹកនាំក្នុងមូលដ្ឋានរបស់សាសនាចក្រ ។ ប៉ុលបានសរសេរថា « សេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច » ដើមឡើយព្រះបានសន្យានៅក្នុងជីវិតមុនផែនដី « មុនអស់ទាំងកល្ប » (ទីតុស ១:២) ។ លោកបានបង្រៀនថា ពួកបរិសុទ្ធគួរតែទន្ទឹងរង់ចាំ « សេចក្តីសង្ឃឹមដ៏មានពរ » នៃភាពតម្កើងឡើងនោះ និងចំពោះការយាងមកជាលើកទីពីរ (ទីតុស ២:១៣) ។ ប៉ុលក៏បានសរសេរដល់ទីតុសផងដែរអំពី « ការប្រោសជាថ្មីឡើងវិញនៃព្រះវិញ្ញាណបរិសុទ្ធ » ដោយនិយាយសំដៅទៅលើពិធីបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹក និងឥទ្ធិពលបរិសុទ្ធនៃការទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ដែលពិធីបរិសុទ្ធទាំងពីរនេះគឺជាការរៀបចំខ្លួនសម្រាប់ការធ្វើ « ជាអ្នកគ្រងមរតកតាមសេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច » (ទីតុស ៣:៥, ៧) ។ តាមរយៈការសិក្សាអំពីការទូន្មានដ៏បំផុសគំនិតរបស់ប៉ុលដល់ទីតុស នោះសិស្សអាចបង្កើនសេចក្តីជំនឿរបស់ពួកគេថា គោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អនាំមកនូវសេចក្តីសង្ឃឹមសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

គម្ពីរទីតុសត្រូវបានសរសេរឡើងដោយប៉ុល (សូមមើល ទីតុស ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

វាទំនងដូចជាប៉ុលបានសរសេរសំបុត្រទៅទីតុសនៅចន្លោះពេលនៃការសរសេរធីម៉ូថេទី ១ និងទី ២ ប្រមាណជា គ.ស. ៦៤–៦៥ (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ សំបុត្ររបស់ប៉ុល scriptures.lds.org) ។ ប៉ុលបានសរសេរសំបុត្រដល់ទីតុសបន្ទាប់ពីការជាប់ឃុំឃាំងលើកដំបូងរបស់ប៉ុលនៅរ៉ូម ។ ប៉ុលមិនបានបង្ហាញពីទីកន្លែង ដែលលោកស្នាក់នៅកាលលោកបានសរសេរសំបុត្រទៅទីតុសនោះទេ ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយតើហេតុអ្វី ?

ប៉ុលបានសរសេរសំបុត្រនេះទៅទីតុស ជាមនុស្សដែលប៉ុលហៅថា « កូនពិតតាមសេចក្តីជំនឿ ដែលយើងកាន់ជាមួយគ្នា » (ទីតុស ១:៤) ។ ទីតុសគឺជាជនជាតិក្រិក (កាឡាទី ២:៣) ហើយបានប្រែចិត្តជឿចំពោះដំណឹងល្អតាមរយៈប៉ុល (សូមមើល Bible Dictionary, « Titus ») ។ បន្ទាប់ការប្រែចិត្តជឿរបស់គាត់ ទីតុសបានប្រកាសចែកចាយដំណឹងល្អ ហើយរៀបចំសាសនាចក្រជាមួយប៉ុល (សូមមើល Bible Dictionary, « Titus ») ។ គាត់បានជួយប្រមូលដង្វាយសម្រាប់ជនក្រីក្រនៅក្នុងក្រុងយេរូសាឡិម (សូមមើល កូរិនថូសទី ២ ៨:៦, ១៦–២៣) ហើយក៏បានរួមដំណើរជាមួយប៉ុលទៅការប្រជុំក្រុមប្រឹក្សានៅក្រុងយេរូសាឡិមផងដែរ (សូមមើល កាឡាទី ២:១) ។ ប៉ុលបានទុកចិត្តទីតុសឲ្យនាំយកសំបុត្រទីមួយរបស់ប៉ុលទៅដល់ពួកបរិសុទ្ធដែលរស់នៅកូរិនថូស (សូមមើល កូរិនថូសទី ២ ៧:៥–១៥) ។ ប៉ុលបានសរសេរទៅទីតុសដើម្បីពង្រឹងគាត់នៅក្នុងកិច្ចការរបស់គាត់ដើម្បីដឹកនាំ ហើយមើលថែសាខានៃសាសនាចក្រនៅកោះក្រេត ទោះជាមានការជំទាស់ក្តី (សូមមើល ទីតុស ១:៥, ១០–១១, ២:១៥, ៣:១០) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

សំបុត្រនេះគឺជាសំបុត្រអ្នកគង្វាលមួយ (ដល់អ្នកគង្វាល ឬថ្នាក់ដឹកនាំក្នុងសាសនាចក្រ) រួមជាមួយនឹងធីម៉ូថេទី ១ និងទី ២ (សូមមើល Bible Dictionary, « Pauline Epistles ») ។ សំបុត្ររបស់ទីតុសផ្តល់នូវភស្តុតាងដំបូងបង្អស់ថា សាសនាចក្រត្រូវបានស្ថាបនាឡើងនៅកោះក្រេតនៃប្រទេសក្រិកនៃសមុទ្រមេឌីទែរ៉ាណេ (សូមមើល ទីតុស ១:៥) ។ ទីតុសទទួលខុសត្រូវក្នុងការហៅប៊ីស្សពថ្មីៗនៅលើកោះនោះ ។ ប៉ុលបានសរសេរពីលក្ខណៈសម្បត្តិខាងវិញ្ញាណមួយចំនួនសម្រាប់ប៊ីស្សព (សូមមើល ទីតុស ១:៦–៩) ។ លើសពីនេះទៀត ប៉ុលបានផ្តល់ការណែនាំជាក់លាក់ដល់បុរស ស្ត្រី និងពួកបាវបម្រើស្តីពីតំរិយាបថដ៏ត្រឹមត្រូវក្នុងនាមជាពួកបរិសុទ្ធ (សូមមើល ទីតុស ២:២–១០) ។

គម្រោង

ទីតុស ១ ប៉ុលណែនាំទីតុសឲ្យតែងតាំងថ្នាក់ដឹកនាំសាសនាចក្រ ហើយបានសរសេរពីលក្ខណៈសម្បត្តិមួយចំនួនដើម្បីធ្វើជាប៊ីស្សព ។ លោកបានណែនាំទីតុសឲ្យកែតម្រូវការបង្រៀន ហើយស្តីបន្ទោសដល់ពួកគ្រូបង្រៀនក្លែងក្លាយដែល « ប្រកាសថា គេស្គាល់ព្រះ តែកិរិយាប្រព្រឹត្តរបស់គេមិនព្រមស្គាល់ព្រះទេ » (ទីតុស ១:១៦) ។

ទីតុស ២ ប៉ុលលើកទឹកចិត្តទីតុសឲ្យណែនាំសមាជិកសាសនាចក្រចាស់ៗឲ្យធ្វើជាគំរូដល់ពួកបរិសុទ្ធវ័យក្មេង ។ លោកក៏សុំឲ្យទីតុសបង្រៀនពួកបាវបម្រើទាំងឡាយឲ្យធ្វើតាមចៅហ្វាយខ្លួន ។ ប៉ុលពន្យល់ពីតំរិយាបថដែលពួកសិស្សគួរស្រស់នៅ កាលពួកគេរៀបចំខ្លួនសម្រាប់ការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់ ។ លោករៀបរាប់ពីការប្រោសលោះ ដែលកើតមានតាមរយៈព្រះយេស៊ូវគ្រីស្ទ ។

ទីតុស ៣ ប៉ុលបង្រៀនថា សមាជិកសាសនាចក្រត្រូវធ្វើជាពលរដ្ឋល្អ និងជាអ្នកដើរតាមដ៏សុចរិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ តាមរយៈពិធីបុណ្យជ្រមុជទឹក នោះយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈព្រះគុណរបស់ព្រះអម្ចាស់ ។

ទីតុស

សេចក្តីផ្តើម

នៅក្នុងសំបុត្ររបស់ប៉ុលទៅកាន់ទីតុស ដែលជាអ្នកដឹកនាំក្នុងមូលដ្ឋានម្នាក់របស់សាសនាចក្រនៅកោះក្រេត នោះប៉ុលបានដាស់តឿនគាត់ឲ្យប្រើគោលលទ្ធិត្រឹមត្រូវ ដើម្បីបង្រៀន និងកែតម្រូវអ្នកដទៃ ។ ប៉ុលក៏បានទូន្មានដល់ទីតុសឲ្យបង្រៀនដល់ពួកបរិសុទ្ធឲ្យធ្វើជាគំរូសុចរិត ឲ្យមានសង្ឃឹមចំពោះការប្រោសលោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងបន្តនៅក្នុងការធ្វើកិច្ចការល្អផងដែរ ។ (*កំណត់ចំណាំ* ៖ នៅក្នុងការរៀបចំសម្រាប់មេរៀននេះ វាអាចនឹងជាជំនួយដើម្បីឮកគោលការណ៍នានានៅគេហទំព័រ seektruth.lds.org) ។

យោបល់សម្រាប់ការបង្រៀន

ទីតុស ១

ប៉ុលជាដាស់តឿនទីតុសឲ្យប្រើគោលលទ្ធិត្រឹមត្រូវដើម្បីបង្រៀន និងកែតម្រូវពួកបរិសុទ្ធ និងអ្នកដទៃទៀតនៅកោះក្រេត

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ពេលដែលពួកគេបានស្តាប់ឮនរណាម្នាក់និយាយទាស់នឹងសាសនាចក្រ ឬទាស់នឹងគោលលទ្ធិសាសនាចក្រ ។

- តើវិធីដ៏ត្រឹមត្រូវមួយដើម្បីការពារសាសនាចក្រ និងគោលលទ្ធិសាសនាចក្រ នៅពេលដែលមនុស្សម្នាក់និយាយទាស់នឹងសាសនាចក្រគឺជាអ្វី ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាគម្ពីរទីតុស ដែលអាចជួយពួកគេឲ្យដឹងអំពីរបៀបការពារសាសនាចក្រ និងគោលលទ្ធិសាសនាចក្រដោយត្រឹមត្រូវ នៅពេលនរណាម្នាក់និយាយទាស់នឹងសាសនាចក្រ ។

សូមអញ្ជើញសិស្សឲ្យរកមើលកោះក្រេតនៅក្នុងផែនទីព្រះគម្ពីរបឺប លេខ ១៣ « ដំណើរទាំងឡាយដែលសាវកប៉ុលទៅផ្សាយសាសនា » ។ ចូរពន្យល់ថា នៅជិតនឹងចុងបញ្ចប់នៃជីវិតរបស់ប៉ុល នោះប៉ុលបានសរសេរសំបុត្រមួយច្បាប់ទៅកាន់ទីតុស ដែលកំពុងបម្រើជាអ្នកដឹកនាំសាសនាចក្រនៅកោះក្រេត ។ ទីតុស ត្រូវបានផ្លាស់ប្រែចិត្តជឿដោយសារប៉ុលកាលពីប៉ុន្មានឆ្នាំមុន ហើយបន្ទាប់ពីបុណ្យជ្រមុជទឹករបស់គាត់ នោះគាត់បានបម្រើជាមួយប៉ុលនៅក្នុងកិច្ចការផ្សេងៗ ។ នៅក្នុងសំបុត្ររបស់លោក ប៉ុលបានលើកទឹកចិត្តដល់ទីតុស ហើយទូន្មានគាត់អំពីការហៅបម្រើរបស់គាត់ ។

សូមសង្ខេបទីតុស ១:១–៦ ដោយពន្យល់ថា ប៉ុលបានថ្លែងទីបន្ទាល់អំពីសេចក្តីសង្ឃឹម ដែលគាត់មានចំពោះជីវិតអស់កល្បជានិច្ចដោយសារតែការសន្យារបស់ព្រះនៅក្នុងជីវិតមុនជីវិតលើផែនដីរបស់យើង ។ ប៉ុលក៏បានពន្យល់ផងដែរថា លោកបានបញ្ជូនទីតុសទៅកោះក្រេត ដើម្បីរៀបចំសាសនាចក្រឲ្យមានសណ្តាប់ធ្នាប់នៅទីនោះ ។ កាតព្វកិច្ចមួយរបស់ទីតុសគឺដើម្បីហៅបុរសៗឲ្យបម្រើជាប៊ីស្សព ។

សូមអញ្ជើញសិស្សឲ្យអានទីតុស ១:៧–៨ ដោយស្ងាត់ស្ងៀម ហើយរកមើលចរិតលក្ខណៈដែលប៊ីស្សពម្នាក់គួរមាន ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំអ្វី ដែលពួកគេបានរកឃើញ ។

- យោងតាមខគម្ពីរទាំងនេះ តើចរិតលក្ខណៈរបស់ប៊ីស្សពគួរតែមានអ្វីខ្លះ ? (អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា*ចិត្តវិលទទឹង*មានន័យថាចចេស ឬឆ្មើងឆ្មៃ ហើយពាក្យថា « សឺសំណូក » សំដៅទៅលើប្រាក់ដែលបានទទួលដោយភាពមិនស្មោះត្រង់ ឬដោយមធ្យោបាយមិនសុចរិតផ្សេងទៀត) ។
- ហេតុអ្វីអ្នកគិតថា វាសំខាន់ដែលប៊ីស្សពគួរតែមានចរិតលក្ខណៈទាំងនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ទីតុស ១:៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលចរិតលក្ខណៈផ្សេងទៀតដែលប៊ីស្សពគួរតែមាន ។ ចូរពន្យល់ថា « សេចក្តីបង្រៀនដ៏ត្រឹមត្រូវ » សំដៅទៅលើគោលលទ្ធិពិត ។

- តើចរិតលក្ខណៈផ្សេងទៀតអ្វីខ្លះ ដែលប៊ីស្សពគួរតែមាន ?
- តើអ្នកគិតថា « [ទាំង] កាន់ខ្ជាប់ » តាមព្រះបន្ទូលនៃព្រះ មានន័យដូចម្តេច ?
- យោងតាមខទី ៩ ហេតុអ្វីបានជាវាសំខាន់ចំពោះប៊ីស្សព ដើម្បីកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ ? (ដើម្បីអាចប្រើគោលលទ្ធិពិតដើម្បីលើកទឹកចិត្តអ្នកដទៃទៀតឲ្យរស់នៅតាមដំណឹងល្អ ហើយឆ្លើយបដិសេធនឹង « ពួកអ្នកដែលស្រដីទទឹង » ។ អ្នកដែលស្រដីទទឹង គឺជាមនុស្សម្នាក់ដែលនិយាយទាស់ ឬបដិសេធគំនិតមួយ [នៅក្នុងករណីនេះ គឺនិយាយទាស់នឹងភាពពិតពេញលេញនៃដំណឹងល្អ] ។ អ្នកដែលស្រដីទទឹង អាចជាសមាជិក និងមិនមែនជាសមាជិកនៃសាសនាចក្រ) ។
- ដូចជាប៊ីស្សពដែរ តើយើងអាចធ្វើអ្វីបានខ្លះ នៅពេលយើងកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថា ពួកគេគួរស្គាល់គោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ នោះយើងនឹង**

អាចប្រើគោលលទ្ធិពិត ដើម្បីលើកទឹកចិត្តមនុស្សដទៃឲ្យរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយឆ្លើយបដិសេធចំពោះជនដែលទាស់នឹងវា ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៏ ឃេ ផាកកឺ នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលអំណាច ដែលគោលលទ្ធិពិតមាននៅក្នុងការជួយដល់បុគ្គលម្នាក់ៗរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

« គោលលទ្ធិពិត ពេលត្រូវបានយល់ច្បាស់ វាកែប្រែឥរិយាបថ និង ចរិតរបស់មនុស្ស ។

« ការសិក្សាពីគោលលទ្ធិនៃដំណឹងល្អ នឹងកែលម្អឥរិយាបថបានលឿនជាងការសិក្សាពីឥរិយាបថ ដើម្បីកែលម្អឥរិយាបថទៅទៀត ។ . . .នោះហើយជាមូលហេតុ ដែលយើងសង្កត់ធ្ងន់ជាខ្លាំងទៅលើការសិក្សាពីគោលលទ្ធិទាំងឡាយនៃដំណឹងល្អ » (« Little Children » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ១៧) ។

- យោងតាមប្រធាន ផាកកឺ ហេតុអ្វីក៏វាសំខាន់ដើម្បីសិក្សា ហើយរៀនអំពីគោលលទ្ធិពិត ?

ការពិភាក្សាជាក្រុមតូចៗ

ពេលខ្លះ វាគឺជាជំនួយដើម្បីបែងចែកសិស្សជាក្រុមតូចៗ ដូច្នេះសិស្សអាចចូលរួមនៅក្នុងការពិភាក្សារួមគ្នាបាន ។ ការពិភាក្សាជាក្រុមតូចៗ អាចជួយដល់សិស្សណា ដែលបាត់បង់ចំណាប់អារម្មណ៍ និង បាត់បង់ការសញ្ជឹងគិត ឲ្យមកចូលរួមយ៉ាងមានប្រសិទ្ធភាព ហើយវាអាចជួយសិស្សឲ្យអភិវឌ្ឍជំនាញទំនាក់ទំនង និង ពង្រឹងទំនាក់ទំនងខាងសង្គម និង ទំនាក់ទំនងខាងវិញ្ញាណបានល្អត្រឹមត្រូវ ។

សូមបំបែកសិស្សជាក្រុម ដែលមានគ្នាពីរ ឬបីនាក់ ។ សូមអញ្ជើញក្រុមនីមួយៗឲ្យធ្វើការរួមគ្នាឆ្លើយនឹងសំណួរខាងក្រោម ហើយសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកំណាត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមគិតពីការសរសេរសំណួរនេះនៅលើក្តារខៀន ។

១. តើយើងអាចធ្វើអ្វីខ្លះ ដើម្បីត្រៀមខ្លួនបង្រៀនគោលលទ្ធិពិត ដើម្បីយើងអាចលើកទឹកចិត្តដល់អ្នកដទៃឲ្យរស់នៅតាមដំណឹងល្អ ? (សូមមើល អាលម៉ា ១៧:២–៤ ។

២. តើមានឧទាហរណ៍មួយចំនួនណាខ្លះ ចេញមកពីបទគម្ពីរអំពីគ្រាទាំងឡាយ នៅពេលដែលមាននរណាម្នាក់បង្រៀនគោលលទ្ធិពិតទៅមនុស្សម្នាក់ទៀត ដែលបង្ហាញពីការសង្ស័យ ឬកំហឹងចំពោះសាសនាចក្រ និងគោលលទ្ធិ ? (សូមបញ្ចូលឧទាហរណ៍យ៉ាងហោចណាស់មួយ អំពីគ្រាដែលនរណាម្នាក់បានប្រែចិត្ត ដោយសារពួកគេត្រូវបានបង្រៀនអំពីគោលលទ្ធិពិត) ។

៣. តើនៅពេលណាដែលការរៀនពីគោលលទ្ធិពិតបានជួយបញ្ចុះបញ្ចូលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ឲ្យរស់នៅកាន់តែពេញលេញក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្រាប់ចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។ បន្ទាប់ពីពួកគេរៀបរាប់ហើយ ចូរពន្យល់ថា ខណៈដែលសេចក្តីពិតអាចជួយយើងឲ្យលើកទឹកចិត្តដល់អ្នកដទៃឲ្យរស់នៅតាមដំណឹងល្អ ហើយបដិសេធអ្នកទាំងឡាយ ដែលជំទាស់នឹងសាសនាចក្រក្តី ក៏ពុំមែនមនុស្សទាំងអស់នឹងទទួលយកសេចក្តីពិតនោះទេ ។ ដោយសារតែបុគ្គលគ្រប់រូបមានសិទ្ធិសេរីភាព នោះពួកគេអាចជ្រើសរើសទទួលយក ឬក៏បដិសេធគោលលទ្ធិពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីវគ្គចំណេះចំណានខាងគោលលទ្ធិ ដែលពួកគេបានរៀនកន្លងមកនៅក្នុងឆ្នាំនេះ ។

- តើវគ្គចំណេះចំណានខាងគោលលទ្ធិមួយណា ដែលអាចជួយលើកទឹកចិត្តដល់អ្នកដទៃ ឲ្យរស់នៅតាមដំណឹងល្អជាពិសេសនោះ ?
- តើវគ្គចំណេះចំណានខាងគោលលទ្ធិមួយណា អាចជួយឆ្លើយបដិសេធនឹងអស់អ្នកដែលជំទាស់នឹងសាសនាចក្រ ?

សូមលើកទឹកចិត្តដល់សិស្សឲ្យបន្តទន្ទេញចាំវគ្គបទគម្ពីរសំខាន់ៗ ដូច្នេះពួកគេនឹងត្រៀមខ្លួនដើម្បីបង្រៀនគោលលទ្ធិពិតដល់អ្នកដទៃ ។

ចូរសង្ខេបទីតុស ១:១០–១៦ដោយពន្យល់ថា ប៉ុលបានបង្រៀនទីតុសថា ប៊ីស្សពចាំបាច់ត្រូវពឹងផ្អែកទៅលើគោលលទ្ធិពិត ដោយសារមានអ្នកបោកបញ្ឆោត និងគ្រូក្លែងក្លាយជាច្រើននៅក្នុងចំណោមពួកគេ ។ លោកបានទូន្មានដល់ទីតុសឲ្យជ្រាញ់ជ្រាលដល់គ្រូបង្រៀនក្លែងក្លាយ ដើម្បីឲ្យពួកគេបោះបង់ចោលកំហុសឆ្គងរបស់ពួកគេ ហើយ « មានសេចក្តីជំនឿត្រឹមត្រូវវិញ » (ខទី ១៣) ។ ប៉ុលក៏បានពន្យល់ផងដែរថា អ្នកកខ្វក់ទាំងឡាយដែលអះអាងថា ពួកគេស្គាល់ព្រះ ប៉ុន្តែគេបានបដិសេធទ្រង់តាមកិច្ចការរបស់ពួកគេ ។

ទីតុស ២

ប៉ុលបានទូន្មានទីតុសឲ្យបង្រៀនពួកបរិសុទ្ធនៅកោះក្រេតឲ្យរស់នៅតាមគោលលទ្ធិពិត

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ទីតុស ២:១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលនូវអ្វីផ្សេងទៀតដែលប៉ុលណែនាំដល់ទីតុស ឲ្យធ្វើជាមួយនឹងគោលលទ្ធិពិត ។

- តើប៉ុលបានណែនាំដល់ទីតុសឲ្យធ្វើអ្វីខ្លះទៀតជាមួយនឹងគោលលទ្ធិពិត ? (បង្រៀនវាទៅដល់ពួកបរិសុទ្ធនៅកោះក្រេត) ។

សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖ *បុរស ស្ត្រី យុវនារី និង យុវជន ។*

សូមអញ្ជើញយុវនារីនៅក្នុងថ្នាក់ឲ្យអានទីតុស ២:៣–៥ដោយស្ងាត់ស្ងៀម ហើយរកមើលការទូន្មានរបស់ប៉ុល អំពីរបៀបដែលស្ត្រីវ័យចំណាស់គួរអនុវត្តន៍ និងអ្វីដែលពួកគេគួរបង្រៀនដល់ស្ត្រីវ័យក្មេង ។ សូមអញ្ជើញយុវជនឲ្យអានទីតុស ២:២, ៦–៨ដោយស្ងាត់ស្ងៀម ហើយរកមើលការទូន្មានរបស់ប៉ុលអំពីរបៀបដែលបុរសចំណាស់ និងបុរសវ័យក្មេងគួរអនុវត្តន៍តាម ។

កំណត់ចំណាំ ៖ ប្រសិនបើមានសំណួរលើកឡើងអំពីអត្ថន័យនៃស្ត្រីដែល « ចុះចូលចំពោះប្តី » (ខ ៥) អ្នកអាចយោងទៅលើឯកសារនៅក្នុងមេរៀនសម្រាប់អេភេសូរ ៥–៦ ។

- យោងតាមប៉ុល តើបុរសវ័យចំណាស់គួរអនុវត្តន៍ដោយរបៀបណា ? ចុះស្ត្រីវ័យចំណាស់វិញ ? រីឯស្ត្រីវ័យក្មេងវិញនោះ ? ហើយចុះបុរសវ័យក្មេងវិញនោះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនក្រោមក្បាលរឿងឆ្លើយឆ្លងគ្នា ឬសុំឲ្យសិស្សឡើងមកសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ អ្នកអាចនឹងចាំបាច់ត្រូវជួយដល់សិស្សឲ្យយល់ពីអត្ថន័យនៃពាក្យមួយចំនួន ។

ឧទាហរណ៍ ពាក្យ*ចិត្តធ្ងន់ធ្ងរ* មានន័យថា ស្ងប់ស្ងាត់ ឬហ្មត់ចត់ ពាក្យ*ដឹងខ្នាត*មានន័យថា គ្រប់គ្រងលើខ្លួនឯង ហើយពាក្យមាន*ចិត្តនឹងធឹង*មានន័យថាប្រកបដោយការគោរព) ។

- តើឃ្លា « ត្រូវឲ្យអ្នកសំដែងខ្លួន ទុកជាគំរូពីការល្អគ្រប់ជំពូក » មានន័យយ៉ាងណា ? (ខទី ៧) ។ (ធ្វើជាគំរូល្អមួយក្នុងការរស់នៅតាមដំណឹងល្អ) ។
- អាស្រ័យទៅលើដំបូន្មានរបស់ប៉ុលទៅកាន់ទីតុស តើពួកអ្នកដើរតាមរបស់ព្រះយេស៊ូវគ្រីស្ទត្រូវធ្វើអ្វីខ្លះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែចូរប្រាកដថាពួកគេស្គាល់សេចក្តីពិតដូចខាងក្រោមនេះ ៖ **អ្នកដើរតាមព្រះយេស៊ូវគ្រីស្ទគួរធ្វើជាគំរូល្អដល់អ្នកដទៃ**) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីសមាជិកវ័យចំណាស់ក្នុងវួដ ឬសាខារបស់ពួកគេ ដែលបានធ្វើជាគំរូល្អក្នុងការរស់នៅតាមដំណឹងល្អ ហើយបានលះបង់ចំពោះដំណឹងល្អ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីមនុស្សម្នាក់ ដែលពួកគេគិតដល់ ហើយពន្យល់អំពីរបៀបដែលបុគ្គលម្នាក់នោះបានជួយពួកគេ ។

សូមអញ្ជើញសិស្សឲ្យជ្រើសរើសឥរិយាបទមួយ ដែលបានសរសេរនៅលើក្តារខៀន ហើយរៀបចំគោលដៅមួយ ដើម្បីភ្ជាប់ឥរិយាបទនោះទៅក្នុងជីវិតរស់នៅរបស់ពួកគេឲ្យបានកាន់តែល្អប្រសើរ ដើម្បីឲ្យគំរូល្អរបស់ពួកគេអាចប្រទានពរដល់អ្នកដទៃ ។

សូមសង្ខេបទីតុស ២:៩–១០ ដោយពន្យល់ថា ប៉ុលបានទូន្មានដល់ទីតុសឲ្យបង្រៀនដល់សមាជិកសាសនាចក្រ ដែលធ្វើការជាពួកអ្នកបម្រើឲ្យមានភាពស្មោះត្រង់ ហើយស្រុះស្រួលនៅក្នុងការទំនាក់ទំនងរបស់ពួកគេជាមួយនឹងចៅហ្វាយនាយរបស់ពួកគេ ។ តាមរយៈភាពស្មោះត្រង់ និងភាពស្រុះស្រួល នោះសមាជិកសាសនាចក្រទាំងនេះនឹងគោរពដល់ព្រះ ហើយធ្វើជាគំរូល្អដល់ពួកចៅហ្វាយនាយរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ទីតុស ២:១១–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សនេះ អានការបកប្រែដោយយ៉ូសែប ស៊្មីធ ទីតុស ២:១១) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើព្រះគុណរបស់ព្រះមានអានុភាពដូចម្តេចខ្លះ ដល់មនុស្សទាំងអស់ ហើយរកមើលអ្វីដែលព្រះគ្រីស្ទបានធ្វើសម្រាប់យើងទាំងអស់គ្នា ។

- តើព្រះគុណរបស់ព្រះបានមានអានុភាពដូចម្តេចខ្លះដល់មនុស្សទាំងអស់ ?
- យោងតាមខទី ១២ តើពួកបរិសុទ្ធគប្បីធ្វើអ្វីខ្លះ ដើម្បីទទួលបានព្រះគុណនៃព្រះ ?
- តើយើងរៀនអ្វីខ្លះមកពីការបង្រៀនរបស់ប៉ុលនៅក្នុងខទី ១៤អំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់យើង ? (សិស្សគួរកត់សម្គាល់ឃើញសេចក្តីពិតស្រដៀងគ្នាមួយនឹងសេចក្តីពិតដូចខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទបានលះបង់អង្គទ្រង់សម្រាប់យើង ដើម្បីទ្រង់អាចប្រោសលោះយើង ហើយធ្វើឲ្យយើងបានបរិសុទ្ធ ។** ចូរពិចារណាធ្វើការអញ្ជើញសិស្សឲ្យគូសចំណាំឃ្លានៅក្នុងខទី ១៤ ដែលបង្រៀនពីសេចក្តីពិតនេះ) ។

សូមចង្អុលបង្ហាញថា « រាស្ត្ររបស់ផងទ្រង់ » (ខទី ១៤) សំដៅទៅលើរាស្ត្រដ៏ល្អ ដែលទ្រង់បានទិញ ឬបានប្រោសលោះ (សូមមើលពេត្រុសទី ១:១៨–១៩,២:៩) និងអ្នកដែលចុះសេចក្តីសញ្ញាដើម្បីរក្សាបទបញ្ញត្តិរបស់ទ្រង់ (សូមមើលនិក្ខមនំ ១៩:៥–៦) ។

ទីតុស ៣

ប៉ុលបានប្រាប់ទីតុសអំពីអ្វីដែលពួកបរិសុទ្ធនៅកោះក្រេតត្រូវធ្វើ បន្ទាប់ពីពួកគេបានទទួលបុណ្យជ្រមុជទឹក

សូមសង្ខេបទីតុស ៣:១–២ ដោយពន្យល់ថា ប៉ុលបានទូន្មានទីតុសឲ្យបង្រៀនពួកបរិសុទ្ធនៅកោះក្រេត ឲ្យគោរពតាមច្បាប់ដែនដី ហើយមានចិត្តទន់ភ្លន់ និងរាបសានៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងអ្នកដទៃ ។

សូមអញ្ជើញសិស្សជាច្រើននាក់ប្តូរវេនគ្នាអានឲ្យឮៗចេញមកពី ទីតុស៣:៣–៨ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវអ្វីដែលប៉ុលបាននិយាយអំពីរបៀបដែលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ បានផ្លាស់ប្តូរគាត់ និងពួកបរិសុទ្ធនៅកោះក្រេត ។

- យោងតាមខទី ៣តើប៉ុលបានពិពណ៌នាខ្លួនគាត់ និងសមាជិកសាសនាចក្រដទៃទៀតថាយ៉ាងដូចម្តេច ពីមុនពេលពួកគេបានរៀនអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?
- យោងតាមខទី ៥–៦ តើអ្វីខ្លះបានផ្លាស់ប្តូរប្រជាជន ?
- ស្របតាមខទី ៧តើមានអ្វីនឹងកើតឡើងចំពោះប្រជាជន ដែលជាលទ្ធផលមកពីការផ្លាស់ប្តូរតាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សឲ្យគិតពិចារណាអំពីរបៀបដែលពួកគេបានផ្លាស់ប្តូរ ដោយសារតែដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

- យោងតាមខទី ៨តើប៉ុលបានទូន្មានឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ បន្ទាប់ពីពួកគេបានផ្លាស់ប្តូរ ហើយទទួលបុណ្យជ្រមុជទឹក ?

សូមសង្ខេបទីតុស ៣:៩–១៥ ដោយពន្យល់ថា ប៉ុលបានផ្តល់ដំបូន្មានដល់ពួកបរិសុទ្ធឲ្យចៀសវាងពីការឈ្លោះប្រកែកជាមួយនឹងមនុស្សលាក់ពុត ។ ប៉ុលក៏បានស្នើសុំឲ្យទីតុសមកជួបនឹងលោកនៅខេត្តម៉ាសេដូន ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្ហាញនៅក្នុងមេរៀននេះ ។

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់កីលេម៉ូន

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រដល់កីលេម៉ូនមាននូវការទុទ្ទានផ្ទាល់មកពីប៉ុល ស្តីពីស្ថានភាពមួយជាមួយនឹងអូនេស៊ីមដែលជាបាវបម្រើរបស់កីលេម៉ូន ។ នៅពេលសិស្សសិក្សាសំបុត្រនេះ ពួកគេអាចរៀនថា កាលមនុស្សចូលរួមក្នុងសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទ ពួកគេប្រែក្លាយជាបងប្អូនប្រុសស្រីនៅក្នុងដំណឹងល្អ (សូមមើល កីលេម៉ូន ១:១៦) ។ សិស្សក៏អាចទទួលអារម្មណ៍ពីសារៈសំខាន់នៃភាតព្វកិច្ច ដែលពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបង្កើនសេចក្តីមេត្តា និងការអភ័យទោសដល់មនុស្សដទៃទៀត (សូមមើល កីលេម៉ូន ១:១៦–១៧) ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ប៉ុលបានសរសេរសំបុត្រទៅកាន់កីលេម៉ូន (សូមមើល កីលេម៉ូន ១:១) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ប៉ុលបានត្រៀមសំបុត្រសម្រាប់កីលេម៉ូន នៅអំឡុងការដាប់ឃុំឃាំងលើកដំបូងរបស់សាវកនៅក្នុងទីក្រុងរ៉ូម ប្រមាណជា គ.ស. ៦០–៦២ (សូមមើល កីលេម៉ូន ១:១, ៩សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយតើហេតុអ្វី ?

« សំបុត្រនេះគឺជាសំបុត្រផ្ទាល់ខ្លួនមួយអំពីអូនេស៊ីម ជាបាវបម្រើម្នាក់ដែលបានប្តន់ចៅហ្វាយខ្លួន កីលេម៉ូន ហើយរត់គេចខ្លួនទៅក្រុងរ៉ូម » (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ កីលេម៉ូនទំនងជាអ្នកប្រែចិត្តជឿជនជាតិក្រិកម្នាក់ ហើយជាអ្នកស្រុកកូឡុស (សូមមើល កូឡុស ៤:៩) ។ គាត់បានអនុញ្ញាតឲ្យក្រុមជំនុំមួយរបស់សាសនាចក្រជួបជុំគ្នានៅក្នុងផ្ទះរបស់គាត់ (សូមមើល កីលេម៉ូន ១:២, ៥) ។ បន្ទាប់ពីបានរត់គេចខ្លួន អូនេស៊ីមបានចូលរួមក្នុងសាសនាចក្រ ហើយក្លាយជា « ប្អូនស្ងួនភ្ងា . . . ក្នុងព្រះអម្ចាស់ » (កីលេម៉ូន ១:១៦ សូមមើល កីលេម៉ូន ១:១០–១២) ។

ប៉ុលបានសរសេរទៅកីលេម៉ូនដើម្បីលើកទឹកចិត្តគាត់ឲ្យទទួលយកអូនេស៊ីមត្រឡប់ជាប្អូនប្រុសម្នាក់នៅក្នុងដំណឹងល្អ ដោយគ្មានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ដែលជាទូទៅត្រូវដាក់ទៅបាវបម្រើដែលរត់គេចខ្លួននោះ (សូមមើល កីលេម៉ូន ១:១៧) ។ ប៉ុលថែមទាំងសុខចិត្តសងប្រាក់ដែលអូនេស៊ីមបានលួចពីកីលេម៉ូនទៀតផង (សូមមើល កីលេម៉ូន ១:១៨–១៩) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

កីលេម៉ូនគឺប្រហែលជាសំបុត្រខ្លីជាងគេ ហើយមានរឿងផ្ទាល់ខ្លួនជាងគេបំផុតរបស់ប៉ុល ។ វាគឺជាសំបុត្រមួយអំពីរឿងផ្ទាល់ខ្លួន ហើយវាពុំបានដាក់បញ្ចូលនូវមាតិកាខាងគោលលទ្ធិច្រើននោះទេ ។ ទោះជាយ៉ាងណាក្តី ការអង្វររបស់ប៉ុលដើម្បីឲ្យកីលេម៉ូនលើកលែងទោសដល់បាវបម្រើអូនេស៊ីម បង្ហាញពីរបៀបដែលគោលលទ្ធិនៃដំណឹងល្អអនុវត្តចំពោះជីវិតប្រចាំថ្ងៃ—នៅក្នុងករណីនេះ វាបង្រៀនថា ទំនាក់ទំនងយើងជាមួយនឹងព្រះយេស៊ូវគ្រីស្ទនាំយើងឲ្យចូលទៅក្នុងទំនាក់ទំនងស្និទ្ធស្នាលមួយជាមួយនឹងពួកអ្នកដើរតាមព្រះគ្រីស្ទផ្សេងទៀត ហើយគួសបង្ហាញពីសារៈសំខាន់នៃសេចក្តីមេត្តា និងការអភ័យទោស ។

គម្រោង

កីលេម៉ូន ១ ប៉ុលសរសើរកីលេម៉ូនចំពោះសេចក្តីស្រឡាញ់ដែលគាត់បានបង្ហាញដល់ពួកបរិសុទ្ធទាំងឡាយ ។ ប៉ុលប្រាប់កីលេម៉ូនថា អ្នកបម្រើគាត់ដែលបានរត់គេចខ្លួន ឈ្មោះអូនេស៊ីមបានប្រែចិត្តជឿចំពោះដំណឹងល្អ ។ ប៉ុលសុំឲ្យកីលេម៉ូនទទួលអូនេស៊ីមជាប្អូនប្រុសនៅក្នុងព្រះអម្ចាស់វិញ ។ ប៉ុលសុខចិត្តបង់សងប្រាក់ឲ្យកីលេម៉ូនចំពោះប្រាក់ដែលអូនេស៊ីមបានលួចពីគាត់នោះ ។

មេរៀន ១៣៤

ភីលេម៉ូន

សេចក្តីផ្តើម

ប៉ុលបានសរសើរដល់ភីលេម៉ូនចំពោះសេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះអង្គសង្គ្រោះ និងបងប្អូនសមាជិកសាសនាចក្រ ។ ប៉ុលបានទូន្មានដល់ភីលេម៉ូនឲ្យទទួលយកទាសកររបស់គាត់ ឈ្មោះ អូនេស៊ីម ដែលបានរត់គេចខ្លួនទុកជាប្អូនប្រុសក្នុងជំណឹងល្អវិញ ។

យោបល់សម្រាប់ការបង្រៀន

ភីលេម៉ូន ១

ប៉ុលទូន្មានដល់ភីលេម៉ូនឲ្យទទួលយកទាសករដែលបានរត់គេចខ្លួនពីម្ចាស់របស់គាត់ ឈ្មោះ អូនេស៊ីម ទុកជាប្អូនប្រុសក្នុងជំណឹងល្អវិញ

ចូរសុំឲ្យសិស្សនឹកគិតអំពីយុវវ័យនៅក្នុងវួដ ឬសាខារបស់ពួកគេ ។ សូមចង្អុលបង្ហាញថា ក្នុងនាមជាសមាជិកនៃសាសនាចក្រ យើងមានឱកាសដើម្បីប្រាស្រ័យទាក់ទងដោយជិតស្និទ្ធនឹងមនុស្សដែលខុសពីយើង ។

- តើយុវវ័យនៅក្នុងវួដ ឬសាខារបស់អ្នកខុសពីគ្នាយ៉ាងដូចម្តេច ? (សូមរំឭកសិស្សឲ្យនិយាយដោយការគោរពដល់គ្នាទៅវិញទៅមក) ។

សូមចង្អុលបង្ហាញថា ក្នុងនាមជាសមាជិកនៃសាសនាចក្រ យើងក៏បានជួបប្រទះនឹងមនុស្សថ្មីៗជាញឹកញាប់ផងដែរ ។ ចូរសុំឲ្យសិស្សស្រមៃថា មានមនុស្សថ្មីម្នាក់មកចូលរួមក្នុងវួដ ឬសាខារបស់ពួកគេ ។

- តើមនុស្សម្នាក់អាចប្រឈមមុខនឹងបញ្ហាទំនាក់ទំនងខាងសង្គមយ៉ាងណា នៅពេលគេមកចូលរួមក្នុងសាសនាចក្រ ឬផ្លាស់ចូលមកក្នុងវួដ ឬសាខាថ្មីមួយនោះ ? (ប្រសិនបើមានសិស្សណាបានចូលមកក្នុងសាសនាចក្រ ឬបានផ្លាស់ចូលមកវួដ ឬសាខាថ្មីក្នុងឆ្នាំថ្មីៗនេះ សូមអញ្ជើញពួកគេឲ្យពិពណ៌នាអំពីបញ្ហាទំនាក់ទំនងខាងសង្គមនានាដែលពួកគេបានជួបប្រទះ) ។

សូមឲ្យសិស្សពិចារណាអំពីសំណួរខាងក្រោម ៖

- តើអ្នកប្រព្រឹត្តនឹងសមាជិកសាសនាចក្រដែលមានឥរិយាបទផ្សេង ចំណាប់អារម្មណ៍ផ្សេង ឬនៅក្នុងក្រុមទំនាក់ទំនងខាងសង្គមផ្សេងពីអ្នកយ៉ាងដូចម្តេច ?
- តើអ្នកប្រព្រឹត្តនឹងសមាជិកថ្មីក្នុងវួដ ឬសាខារបស់អ្នកយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាពីសំបុត្ររបស់ប៉ុលផ្ញើទៅកាន់ភីលេម៉ូន ដែលអាចដឹកនាំពួកគេនៅក្នុងការប្រាស្រ័យទាក់ទងរបស់ពួកគេជាមួយនឹងបងប្អូនសមាជិកសាសនាចក្រ ។

សូមពន្យល់ថា ប៉ុលស្ថិតនៅក្នុងគុកនៅពេលគាត់សរសេរសំបុត្រទៅកាន់ភីលេម៉ូន ដែលប្រហែលជាអ្នកផ្លាស់ប្តែចិត្តជឿជនជាតិក្រិកមកក្នុងសាសនាចក្រ ។ សូមសង្កេតភីលេម៉ូន ១:១–៣ដោយពន្យល់ថា ប៉ុលបានចាប់ផ្តើមសំបុត្ររបស់លោកដោយជម្រាបសួរដល់ភីលេម៉ូន និងអ្នកដទៃទៀត រួមទាំងក្រុមជំនុំដែលបានជួបនៅផ្ទះភីលេម៉ូនផងដែរ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ភីលេម៉ូន ១:៤–៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលហេតុផលដែលប៉ុលបានសរសើរដល់ភីលេម៉ូន ។ សូមពន្យល់ថា នៅក្នុងបរិបទនេះ ពាក្យថា*សេចក្តីប្រកប*សំដៅទៅលើការចូលរួម និងភាពរាក់ទាក់ និងឃ្លា « បានកើតការឡើងឲ្យបានយល់ព្រមតាម » មានន័យថាប្រែក្លាយទៅជាសកម្ម ឬមានឥទ្ធិពលកើតឡើង ។

- ហេតុអ្វីប៉ុលបានសរសើរដល់ភីលេម៉ូន ? (ដោយសារសេចក្តីជំនឿរបស់ភីលេម៉ូន និងសេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះអង្គសង្គ្រោះ និងបងប្អូនសមាជិកសាសនាចក្ររបស់គាត់ ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា នៅពេលប៉ុលបាននិយាយថា « ចិត្តនៃពួកបរិសុទ្ធបានស្បើយល្ហែដោយសារអ្នក » [ខទី ៧] គាត់មានន័យថា ដួងចិត្តរបស់ពួកគេត្រូវបានធ្វើឲ្យសប្បាយដោយសារភីលេម៉ូន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវព័ត៌មានដូចខាងក្រោមអំពីស្ថានភាពមួយ ដែលប៉ុលបានថ្លែងនៅក្នុងសំបុត្រនេះ ៖

ភីលេម៉ូនមានអ្នកបម្រើ ឬទាសកម្នាក់ ឈ្មោះថា អូនេស៊ីម ដែលបានរត់គេចខ្លួន ហើយប្រហែលជាបានលួចរបស់អ្វីមួយពីភីលេម៉ូន (សូមមើលភីលេម៉ូន ១:១៨) ។ ទាសភាព មិនត្រូវបានមើលឃើញថាជាការអាក្រក់នៅក្នុងវប្បធម៌របស់គ្រីស្ទានសាសន៍យូដាក្នុងគម្ពីរសញ្ញាថ្មីទេ ហើយត្រូវបានគាំទ្រដោយច្បាប់ម៉ូម ។ ទណ្ឌកម្មចំពោះទាសកដែលរត់គេចខ្លួន រួមមានទាំងការវាយដំជាទម្ងន់ ឬបោះត្រានៅលើថ្ងាស ឬអាចត្រូវសម្លាប់ចោលទៀតផង ។ បន្ទាប់ពីការរត់គេចខ្លួន អូនេស៊ីម បានទៅជួបនឹងសាវកប៉ុល ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ភីលេម៉ូន ១:៨–១២ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលនូវអ្វីដែលប៉ុលបានអង្វរ ឬអង្វរករសុំឲ្យភីលេម៉ូនធ្វើ ។ បើចាំបាច់ សូមពន្យល់ថា នៅក្នុងខទី ៨ពាក្យ*បង្គាប់*មានន័យថាបញ្ជា ហើយពាក្យ*រឿងការដែលគួរគប្បី*មានន័យថាត្រឹមត្រូវ ឬសម ។

- តើប៉ុលបានសុំឲ្យភីលេម៉ូនធ្វើអ្វីខ្លះ ?
- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ភីលេម៉ូន តើអ្នកអាចនឹងមានគំនិត ឬអារម្មណ៍យ៉ាងណាដែរ នៅពេលអ្នកបានទទួលសំណើររបស់ប៉ុល ?

សូមចង្អុលបង្ហាញឃ្លាថា « ដែលខ្ញុំបានបង្កើតក្នុងវេលាជាប់ចំណង » (ខទី ១០) ។ ចូរពន្យល់ថា អត្ថន័យមួយនៃកិរិយាសព្ទ*បង្កើត*គឺដើម្បីផ្តល់ជីវិតដល់នរណាម្នាក់ ។

- តើអ្នកគិតថា ប៉ុលចង់មានន័យយ៉ាងណាចំពោះឃ្លានេះ ? (ខណៈដែលប៉ុលស្ថិតនៅក្នុងគុក នោះលោកបានជួយដល់អូនេស៊ីមឲ្យចាប់ផ្តើមជីវិតថ្មីក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទមួយរូប) ។

សូមសង្ខេបភីលេម៉ូន ១:១៣–១៤ដោយពន្យល់ថា ប៉ុលចង់រក្សាអូនេស៊ីមឲ្យស្នាក់នៅជាមួយគាត់ ដើម្បីឲ្យអូនេស៊ីមអាចជួយដល់គាត់ ប៉ុន្តែប៉ុលមិនចង់ធ្វើដូច្នោះ ដោយគ្មានការយល់ព្រមពីភីលេម៉ូននោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន ភីលេម៉ូន ១:១៥–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាប៉ុលបានលើកទឹកចិត្តភីលេម៉ូនយ៉ាងណាខ្លះ ដើម្បីឲ្យមើលពីទំនាក់ទំនងរបស់គាត់ជាមួយនឹងអ្នកផ្លាស់ប្រែចិត្តជឿថ្មីឈ្មោះ អូនេស៊ីម ។

- យោងតាមខទី ១៦តើភីលេម៉ូនមើលទៅអូនេស៊ីមយ៉ាងដូចម្តេច ?
- ហេតុអ្វីក៏ការមើលទៅអូនេស៊ីមទុកជា « ប្អូនស្លួនភ្ងា » អាចមានការលំបាកសម្រាប់ភីលេម៉ូន ? (ចម្លើយដែលអាចទៅរួច អាចរួមមានថា ពួកគេស្ថិតនៅក្នុងឋានៈខាងសង្គម និងខាងសេដ្ឋកិច្ចខុសពីគ្នា ហើយថាអូនេស៊ីមអាចនឹងធ្វើខុសចំពោះភីលេម៉ូនយោងទៅតាមទំនៀមទម្លាប់នៃជំនាន់នោះ) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះចេញមកពីខទី ១៦អំពីទំនាក់ទំនងរបស់យើងជាមួយគ្នាដោយសារតែដំណឹងល្អ ? (សូមជួយសិស្សឲ្យប្រាប់ពីសេចក្តីពិតស្រដៀងគ្នាមួយដូចខាងក្រោម ៖ **យើងគឺជាបងប្អូនប្រុសស្រីនៅក្នុងដំណឹងល្អ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើអ្វីដែលធ្វើឲ្យយើងក្លាយជាបងប្អូនប្រុសស្រីនៅក្នុងដំណឹងល្អ ?

ប្រសិនបើចាំបាច់ សូមពន្យល់ថា យើងទាំងអស់គ្នាគឺជាកូនចៅវិញ្ញាណរបស់ព្រះវរបិតាសួគ៌ (សូមមើលហេព្រើរ ១២:៩) ហេតុដូច្នេះហើយ យើងគឺជាបងប្អូនប្រុសស្រីនឹងគ្នា ។ លើសពីនោះ តាមរយៈពិធីបរិសុទ្ធនានានៃពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ នោះការអនុវត្តសេចក្តីជំនឿជាបន្តបន្ទាប់ទៅលើព្រះយេស៊ូវគ្រីស្ទ គោរពប្រតិបត្តិ ហើយប្រែចិត្តដោយខ្ជាប់ខ្ជួន នោះយើងនឹងបានកើតឡើងវិញខាងវិញ្ញាណ ។ តាមរបៀបនេះ យើងប្រែក្លាយទៅជាបុត្រា និងបុត្រីរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូសាយ ៥:៧) ហេតុដូច្នោះយើងគឺជាបងប្អូនប្រុសស្រីនៅក្នុងគ្រួសារនៃសេចក្តីសញ្ញារបស់ទ្រង់ ។ មិនថាភេទ អាយុ ជីវប្រវត្តិ ឬស្ថានភាពសង្គមរបស់យើងយ៉ាងណាទេ យើងប្រែក្លាយទៅជាមានភាពស្មើគ្នានៅក្នុងនគររបស់ព្រះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយ ប្រធាន ស្តែនស៊ើរ ដបុលយូ ឃីមប៊ីល ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើល របៀបដែលសេចក្តីពិតដែលពួកគេទើបបានរកឃើញ អាចជះឥទ្ធិពលទៅលើរបៀប ដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ជាពិសេសសមាជិកថ្មីក្នុងសាសនាចក្រ ។



« ខ្ញុំតែងតែត្រូវបានលើកតម្កើងដោយការអានសំបុត្រខ្លីរបស់ប៉ុល ទៅកាន់ភេលីម៉ូន វាបង្រៀនយើងនូវគោលការណ៍និងវិញ្ញាណមួយអំពីភាតរភាពក្នុងដំណឹងល្អ ។ . . .

« វាគឺជាការបំផុសគំនិត និងអំណរដើម្បីមើលតាមវិញ្ញាណដូចគ្នានេះចំពោះការងារនៅក្នុងសាសនាចក្រ ដើម្បីមើលឃើញពួកបរិសុទ្ធឱបក្រសោបយក និងជួយ និងគាំទ្រ ហើយនិងអធិស្ឋានសម្រាប់អ្នកទាំងឡាយ ដែលចូលមកក្នុងនគរព្រះរបស់យើងប្រចាំថ្ងៃនោះ ។ សូមបន្តជួយគ្នាទៅវិញទៅមក—ហើយមានមនុស្សកាន់តែច្រើនទៀតនឹងចូលមកក្នុងសាសនាចក្រនេះ ។ សូមស្វាគមន៍ពួកគេ ស្រឡាញ់ ហើយនិងរាក់ទាក់នឹងពួកគេ ។

« គួរឲ្យសោកស្តាយ មានរឿងខ្លះៗដែលពួកយើងមួយចំនួនមិនបានធ្វើដូច្នោះ ក៏មានដំណើររឿងអំពីមនុស្សមួយចំនួន ដែលបានបដិសេធអស់អ្នកដែលព្រះអម្ចាស់បានទទួលយកដោយពិធីបុណ្យជ្រមុជទឹក ។ ប្រសិនបើព្រះអម្ចាស់ ‹ មិនខ្មាសនឹងហៅគេជាបងប្អូនទេ › (ហេព្រើរ ២:១១) ហេតុដូច្នោះហើយ ចូរយើង . . . ដឹកដៃបងប្អូនប្រុសស្រីរបស់យើង ហើយលើកពួកគេឡើង ចូលមកក្នុងរង្វង់នៃក្តីស្រឡាញ់ និងការខ្វល់ខ្វាយរបស់យើង » (« Always a Convert Church: Some Lessons to Learn and Apply This Year » *Ensign* ខែកញ្ញា ឆ្នាំ ១៩៧៥ ទំព័រ ៤) ។

- ស្របតាមប្រធាន ឃីមប៊ីល តើបងប្អូនប្រុសស្រីគួរប្រព្រឹត្តនឹងគ្នានៅក្នុងដំណឹងល្អយ៉ាងដូចម្តេច ?

សូមរំឭកដល់សិស្សអំពីសំណួរនានា ដែលពួកគេត្រូវបានអញ្ជើញឲ្យពិចារណានៅខាងដើមមេរៀន ស្តីអំពីរបៀបដែលពួកគេគួរប្រព្រឹត្តចំពោះសមាជិកសាសនាចក្រដែលទីទៃពីពួកគេ ឬដែលថ្មីនៅក្នុងវួដ ឬសាខារបស់ពួកគេ ។

- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីយល់ថា យើងគឺជាបងប្អូនប្រុសស្រីនឹងគ្នានៅក្នុងដំណឹងល្អ ?
- តើអ្នកធ្លាប់ឃើញនរណាម្នាក់ប្រព្រឹត្តចំពោះអ្នកដទៃ ដូចជាបងប្អូនប្រុសស្រីនៅក្នុងដំណឹងល្អនៅពេលណា ?

ដើម្បីរៀបចំសិស្សឲ្យស្តាប់សេចក្តីពិតបន្ថែម ដែលបានចង្អុលបង្ហាញនៅក្នុងសំបុត្ររបស់ប៉ុល ទៅកាន់ភីលេម៉ូន ចូរសុំឲ្យពួកគេគិតអំពីគ្រាមួយ ដែលមាននរណាម្នាក់អាក់អន់ចិត្ត ឬធ្វើខុសដាក់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់អាន ភីលេម៉ូន ១:១៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាប៉ុលបានទូន្មានភីលេម៉ូនឲ្យធ្វើអ្វីខ្លះ ។

- តើប៉ុលបានទូន្មានភីលេម៉ូនឲ្យធ្វើអ្វីខ្លះ ?

ចូរពន្យល់ថា ប៉ុលកំពុងសុំទៅភីលេម៉ូនឲ្យទទួលអូនេស៊ីមដូចគ្នានឹងរបៀប ដែលភីលេម៉ូននឹងទទួលប៉ុល ។ នៅក្នុងការណែនាំនៅខាងក្រោមនេះ ភីលេម៉ូននឹងលើកលែងចំពោះការដាក់ទោសធ្ងន់ធ្ងរ លើទាសករដែលរត់គេចធម្មតាត្រូវទទួលនោះ ។

- ដូចបានចង្អុលបង្ហាញនៅក្នុងការណែនាំរបស់ប៉ុលទៅកាន់ភីលេម៉ូន តើសិស្សទាំងអស់របស់ព្រះយេស៊ូវគ្រីស្ទមានការទទួលខុសត្រូវអ្វីខ្លះ ចំពោះអ្នកទាំងឡាយ ដែលធ្វើឲ្យគេអាក់អន់ចិត្ត ឬធ្វើខុសនឹងគេនោះ ? (សូមជួយសិស្សឲ្យស្គាល់ពីសេចក្តីពិតដូចតទៅនេះ ៖ **សិស្សរបស់ព្រះយេស៊ូវគ្រីស្ទបង្ហាញសេចក្តីមេត្តា និងការអភ័យទោសដល់មនុស្សដទៃ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- ហេតុអ្វីពេលខ្លះអាចជាការលំបាកដើម្បីបង្ហាញសេចក្តីមេត្តា និងការអភ័យទោសដល់មនុស្សដទៃ ?

ចូរចង្អុលបង្ហាញថា ការបង្ហាញសេចក្តីមេត្តា និងការអភ័យទោសដល់មនុស្សដែលបានធ្វើខុសនឹងយើង ពុំចាំបាច់មានន័យថា ត្រូវអនុញ្ញាតឲ្យពួកគេចៀសផុតពីផលវិបាកនៃទង្វើរបស់ពួកគេ ឬមានន័យថា ត្រូវស្តារឡើងវិញភ្លាមៗនូវការទុកចិត្តរបស់យើងទៅលើពួកគេនោះទេ ។ ផ្ទុយទៅវិញ វាមានន័យថា យើងបង្ហាញក្តីមេត្តាចំពោះអ្នកដទៃ ហើយឈប់មានការអាក់អន់ចិត្ត ឈប់មានកំហឹង ឬឈប់មានការឈឺចាប់ដែលយើងមាន។ នៅពេលណាសមរម្យ យើងក៏អាចអនុញ្ញាតឲ្យអ្នកទាំងឡាយ ដែលបានធ្វើខុសចំពោះយើងទទួលបាននូវការទុកចិត្តរបស់យើងវិញផងដែរ ។ ថ្វីដ្បិតតែការអភ័យទោសដល់អ្នកដទៃប្រហែលជាលំបាកក្តី ក៏យើងអាចអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌សុំជំនួយ ហើយទ្រង់នឹងជួយយើង ។

សូមអញ្ជើញសិស្សម្នាក់អាន ភីលេម៉ូន ១:១៨–២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើប៉ុលបានស្នើសុំធ្វើអ្វីខ្លះជំនួសអូនេស៊ីម ។

- តើប៉ុលបានស្នើសុំធ្វើអ្វីខ្លះជំនួសអូនេស៊ីម ? (បង់សងថ្លៃប្រាក់កាសទៅភីលេម៉ូន ដែលភីលេម៉ូនបានបាត់បង់ ដោយសារតែទង្វើរបស់អូនេស៊ីម) ។
- តើកិច្ចខិតខំរបស់ប៉ុលជំនួសអូនេស៊ីម ស្រដៀងគ្នានឹងសកម្មភាពរបស់ព្រះអង្គសង្គ្រោះដែលមានជំនួសយើងយ៉ាងដូចម្តេច ? (ក៏ដូចជាប៉ុលបានជួយសុំទោសជំនួសអូនេស៊ីម នោះព្រះយេស៊ូវគ្រីស្ទបានជួយសុំទោសជំនួសយើង ហើយបានទូលអង្វរដល់ព្រះវរបិតាសួគ៌ដើម្បីបព្វហេតុរបស់យើង [សូមមើលគ. និងស. ៤៥:៣–៥] ។ ព្រះយេស៊ូវគ្រីស្ទក៏បានបង់ថ្លៃបំណុលខាងវិញ្ញាណ ដែលយើងជំពាក់ដោយសារអំពើបាបរបស់យើងផងដែរ) ។
- តើការចងចាំអំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានធ្វើជំនួសយើង អាចជួយយើងឲ្យបង្ហាញក្តីមេត្តា និងការអភ័យទោសដល់អ្នកដទៃយ៉ាងដូចម្តេច ?

សូមបំបែកសិស្សជាក្រុមដែលមានគ្នាបី ឬបួននាក់ (ឬ បញ្ចប់សកម្មភាពនេះរួមគ្នាក្នុងថ្នាក់ ប្រសិនបើអ្នកពុំមានសិស្សល្មមដើម្បីបំបែកជាក្រុមទេនោះ) ។ សូមផ្តល់សំណៅនៃការណែនាំដូចខាងក្រោមទៅដល់ក្រុមនីមួយៗ ដូចជាក្រដាសចែកចាយ ៖

ភីលេម៉ូន ១

ចូរពិភាក្សាអំពីសំណួរដូចខាងក្រោមជាមួយគ្នាក្នុងក្រុមរបស់អ្នក ។ នៅក្នុងចម្លើយរបស់អ្នក ចូរប្រាកដថាមិនត្រូវចែកចាយនូវអ្វីដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ។

- ដូចជាភីលេម៉ូនដែរ តើនៅពេលណា ដែលអ្នកចាំបាច់ត្រូវបង្ហាញក្តីមេត្តា និងការអភ័យទោសដល់នរណាម្នាក់ទៀត ? តើអ្នកអាចផ្តល់ក្តីមេត្តា និងអភ័យទោសដល់មនុស្សម្នាក់នេះយ៉ាងដូចម្តេច ? តើអ្នកបានទទួលពរ ពេលធ្វើដូច្នោះដោយរបៀបណា ?
- ដូចជាអូនេស៊ីមដែរ តើនៅពេលណាដែលអ្នកសង្ឃឹមថា អ្នកទទួលបានក្តីមេត្តា និងការអភ័យទោសមកពីមនុស្សដទៃទៀត ? តើអ្នកស្វែងរកក្តីមេត្តា និងការអភ័យទោសពីបុគ្គលរូបនេះយ៉ាងដូចម្តេច ? តើអ្នកបានទទួលពរ ពេលធ្វើដូច្នោះដោយរបៀបណា ?
- ដូចជាប៉ុល តើនៅពេលណាដែលអ្នកបានបម្រើជាអ្នកសម្រុះសម្រួលរវាងនរណាម្នាក់ដែលស្វែងរកការអភ័យទោស និងមនុស្សម្នាក់ទៀតដែលចាំបាច់ត្រូវផ្តល់នូវការអភ័យទោស និងក្តីមេត្តា ? តើអ្នកអាចជួយអ្នកធ្វើខុសឲ្យទទួលបានការអភ័យទោស ហើយជួយមនុស្សដែលរងទុក្ខឲ្យអភ័យទោសដល់អ្នកធ្វើខុសយ៉ាងដូចម្តេច ?

បន្ទាប់ពីសិស្សបានពិភាក្សាសំណួរទាំងនេះនៅក្នុងក្រុមរបស់ពួកគេហើយ សូមអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗ ឲ្យចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់អំពីបទពិសោធន៍ផ្ទាល់ខ្លួនពួកគេនៅក្នុងស្ថានភាពមួយនៃស្ថានភាពទាំងនេះ ឬបទពិសោធន៍មួយរបស់សមាជិកនៃក្រុមរបស់ពួកគេ (ដោយមានការយល់ព្រមពីសមាជិកក្រុម) ។ (វិធីសាស្ត្រជម្រើសគឺត្រូវផ្តល់សំណៅសំណួរដល់សិស្សម្នាក់ៗ ឬបង្ហាញសំណួរនៅលើក្តារខៀន ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ក្រោយពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សមួយចំនួនដែលស្ម័គ្រចិត្តធ្វើដូច្នោះ ឲ្យចែកចាយជាមួយសិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានសរសេរ ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីរបស់ពួកគេអំពីអ្វី ដែលពួកគេអាចធ្វើដើម្បីផ្តល់នូវក្តីមេត្តា និងការអភ័យទោសដល់អ្នកដទៃ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តតាមអ្វីដែលពួកគេបានសរសេរ ។

ជ្រើសរើសសកម្មភាពរៀនសូត្រដោយប្រុងប្រយ័ត្ន

សូមដឹងថា សកម្មភាពរៀនសូត្រផ្សេងគ្នាអាចជំរុញឲ្យមានអារម្មណ៍ និងគំរោយបថផ្សេងគ្នាចំពោះសិស្ស ។ សិស្សខ្លះអាចនឹងទទួលផលមកពីថាមពលដែលបង្កើតឡើងតាមរយៈការពិភាក្សាជាក្រុមតូចៗ ខណៈដែលសិស្សផ្សេងទៀតអាចនឹងទទួលផលច្រើនមកពីការពិចារណា និងការសរសេរដាលក្តួណៈបុគ្គលផ្ទាល់ខ្លួន ។ ចូរពិចារណាអំពីមាតិកានៃបណ្តុំបទគម្ពីរ ស្វែងរកការដឹកនាំរបស់ព្រះវិញ្ញាណ ហើយប៉ាន់ប្រមាណមើលដោយត្រឹមត្រូវអំពីតម្រូវការរបស់សិស្សអ្នក នៅពេលអ្នកកំណត់ថា សកម្មភាពរៀនសូត្រណាមួយដែលល្អបំផុតសម្រាប់ពួកគេ ។

សេចក្តីផ្តើមអំពី

សំបុត្ររបស់ប៉ុលដល់ពួកហេព្រើរ

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

គម្ពីរហេព្រើរថ្លែងទីបន្ទាល់ពីភាពឧត្តុង្គឧត្តមរបស់ព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់ជំជាងពួកទេវតាទាំងឡាយ ហើយមានព្រះនាមល្អឥតខ្ចោះ និងការហៅមួយដ៏ខ្ពស់ ។ ពួកទេវតាគឺជាពួកអ្នកបម្រើរបស់ព្រះ ប៉ុន្តែព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រានៃព្រះ ។ គម្ពីរនេះក៏បង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជំជាងម៉ូសេ ហើយថាភាពងារបម្រើរបស់ទ្រង់បាននាំមកនូវសេចក្តីសញ្ញាថ្មីដ៏ខ្ពស់មួយ ជំនួសឲ្យសេចក្តីសញ្ញាចាស់នៅក្រោមក្រឹត្យវិន័យរបស់លោកម៉ូសេ ។ ក្នុងនាមជាសង្ឃជាន់ខ្ពស់ដ៏អស្ចារ្យនៃបព្វជិតភាពមិលគីស្សាដែក បព្វជិតភាពរបស់ទ្រង់ជំជាងសង្ឃជាន់ខ្ពស់នៅក្រោមក្រឹត្យវិន័យរបស់លោកម៉ូសេ ។

កាលបទគម្ពីរពោរពេញដោយសេចក្តីយោងអំពីពលិកម្មធួនរបស់ព្រះយេស៊ូវគ្រីស្ទ ការមានព្រះជន្មឡើងវិញរបស់ទ្រង់ និងការយាងឡើងទៅស្ថានសួគ៌របស់ទ្រង់ នោះគម្ពីរហេព្រើរគួរសបញ្ជាក់កិច្ចការជាបន្តបន្ទាប់របស់ព្រះប្រោសលោះ នៅក្នុងជីវិតនៃជនគ្រប់រូបដែលងាកមករកទ្រង់ដោយការគោរពប្រតិបត្តិ និងដោយសេចក្តីជំនឿ ។ ការសិក្សាគម្ពីរហេព្រើរអាចជួយសិស្សឲ្យយល់កាន់តែប្រសើរអំពីគោលលទ្ធិនៃជង្វាយធួន ហើយបំផុសគំនិតពួកគេឲ្យរស់នៅដោយសេចក្តីជំនឿលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

ពួកបរិសុទ្ធថ្ងៃចុងក្រោយភាគច្រើនចាត់ទុកប៉ុលថា ជាអ្នកនិពន្ធគម្ពីរហេព្រើរ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល ») ។ ប៉ុន្តែ មានមនុស្សមួយចំនួនមានសំណួរថា តើប៉ុលពិតជាបានសរសេរសំបុត្រនេះដែរឬទេ ដោយសារបៀប និងពាក្យពេចន៍របស់វាខុសពីសំបុត្រផ្សេងទៀតរបស់ប៉ុល ។ ជាទូទៅ វាត្រូវបានគេយល់ស្របថា ទោះបីជាការសរសេរមិនដូចនឹងការសរសេររបស់ប៉ុលក្តី ប៉ុន្តែគោលលទ្ធិនៅក្នុងគម្ពីរហេព្រើរត្រូវគ្នានឹងគោលលទ្ធិដែលមាននៅក្នុងសំបុត្ររបស់ប៉ុលផ្សេងទៀត ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានអះអាងថាពាក្យពេចន៍នៅក្នុងគម្ពីរហេព្រើរគឺជាពាក្យសម្តីរបស់សាវកប៉ុល (សូមមើល *Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ១០៥) ។ សម្រាប់គោលបំណងនៃសៀវភៅសិក្សានេះ នោះយើងទទួលស្គាល់ប៉ុលជាអ្នកសរសេរ ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

យើងពុំបានដឹងថា សំបុត្រដែលប៉ុលសរសេរដល់ពួកហេព្រើរត្រូវបានសរសេរឡើងនៅទីណានោះទេ ។ ហើយយើងក៏ពុំដឹងពីពេលវេលាជាក់លាក់ដែលវាត្រូវបានសរសេរឡើងដែរ ។ ប៉ុន្តែភាគច្រើនត្រូវបានសន្មត់ថា វាត្រូវបានសរសេរឡើងប្រមាណជា គ.ស. ៦០–៦២ ក្បែរនឹងពេលតែមួយ ដែលប៉ុលបានសរសេរសំបុត្រទៅពួកកីលីព ពួកកូល៉ុស ពួកអេភេសូរ និង កីលេម៉ូន (សូមសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សំបុត្ររបស់ប៉ុល » scriptures.lds.org) ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

ប៉ុលបានសរសេរសំបុត្រដល់ពួកហេព្រើរ ដើម្បីលើកទឹកចិត្តសមាជិកសាសនាបក្រ ដែលជាសាសន៍យូដាឲ្យក្បាសេចក្តីជំនឿរបស់ពួកគេលើព្រះយេស៊ូវគ្រីស្ទ ហើយកុំត្រឡប់ទៅរកផ្លូវពីមុនរបស់ពួកគេឡើយ (សូមមើល ហេព្រើរ ១០:៣២–៣៨) ។

នៅក្រោមសម្ពាធនៃការរងទុក្ខខុសៗគ្នា ពួកគ្រីស្ទានដែលជាសាសន៍យូដាទាំងនេះភាគច្រើនបានដកខ្លួនចេញពីសាសនាបក្រ ហើយត្រឡប់ទៅរកការថ្វាយបង្គំរបស់សាសន៍យូដាដ៏មានសុវត្ថិភាពនៅឯសាលាប្រជុំវិញ (សូមមើល ហេព្រើរ ១០:២៥, ៣៨–៣៩) ។ ប៉ុលមានបំណងប្រាថ្នាដើម្បីបង្ហាញពួកគ្រីស្ទានដែលជាសាសន៍យូដាទាំងនេះថា ក្រឹត្យវិន័យរបស់លោកម៉ូសេបានចង្អុលបង្ហាញទៅរកព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ថាជាប្រភពពិតនៃសេចក្តីសង្គ្រោះ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ហេព្រើរគឺជាការបង្រៀនបន្ថែមមួយដែលយោងទៅបទគម្ពីរ និងទម្លាប់អនុវត្តរបស់អ៊ីស្រាអែលម្តងហើយម្តងទៀត ពុំមែនគ្រាន់តែជាសំបុត្រដ៏តឹងរឹងមួយតែប៉ុណ្ណោះនោះទេ ។ វាគឺជាការបង្រៀនដ៏វែងជាងគេបំផុតនៅ ក្នុងព្រះគម្ពីរអំពីហេតុផល និងរបៀបដែលព្រះយេស៊ូវគ្រីស្ទគឺជំជាងរបស់សព្វសារពើទាំងអស់ ។

ហេព្រើរបង្រៀនថា ព្រះយេស៊ូវគ្រីស្ទជំជាងក្រឹត្យវិន័យនោះ ដោយសារទ្រង់បានប្រទាននូវក្រឹត្យវិន័យនោះ ។ ហេព្រើរក៏បង្រៀនផងដែរថា ពួកព្យាការីបានទទួលអំណាចតាមរយៈសេចក្តីជំនឿលើទ្រង់ ថាទ្រង់គឺជាសង្ឃជាន់ខ្ពស់ដ៏អស្ចារ្យ ដែលថានៅក្នុងទ្រង់ ការបូជានៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ត្រូវបានបំពេញ ថាទ្រង់ជំជាងពួកទេវតា ហើយថាតាមរយៈពលិកម្មធួនរបស់ទ្រង់ទើបយើងអាចនឹងបានទទួលការផ្តាច់បាប ។

គម្ពីរហេព្រើរគឺជាគម្ពីរមួយក្នុងចំណោមគម្ពីរមួយចំនួននៅក្នុងព្រះគម្ពីរបើបដែលយើងអាចអានអំពីព្យាការីមិលគីស្សាដែក (សូមមើល ហេព្រើរ ៧:១–៨) និងបព្វជិតភាពដែលបានដាក់ឈ្មោះតាមលោក (សូមមើល ហេព្រើរ ៥:៥–៦, ១០, ៦:២០, ៧:១១–១៧) ។ ហេព្រើរបង្រៀនថា បព្វជិតភាពមិលគីស្សាដែកជំជាងបព្វជិតភាពអើរ៉ុន ហើយវាបង្ហាញថា សេចក្តីសង្គ្រោះពុំមាននៅក្នុងក្រឹត្យវិន័យរបស់លោកម៉ូសេ ឬនៅក្នុងពិធីបរិសុទ្ធដែលធ្វើឡើងដោយពួកសង្ឃលេវីនោះទេ ប៉ុន្តែនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងពិធីបរិសុទ្ធនៃបព្វជិតភាពមិលគីស្សាដែកទៅវិញ (សូមមើល ហេព្រើរ ៧:៥–២៨) ។ ហេព្រើរ ១១:១–១២:៤ ផ្តល់ការបង្រៀនមួយដែលគួរឲ្យកត់សម្គាល់អំពីសេចក្តីជំនឿ ហើយបង្រៀនអំពីរបៀបដែលបុគ្គលទាំងឡាយអាចទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ ។ (សូមមើល Bible Dictionary « Pauline Epistles: Epistle to the Hebrews ») ។

គម្រោង

ហេព្រើរ ១–៦ ព្រះយេស៊ូវគ្រីស្ទមានកិនភាគដូចជាព្រះវរបិតា ។ ទ្រង់ជំជាងពួកទេវតា និងពួកព្យាការីទាំងអស់ដែលមកពីមុនទ្រង់ រួមទាំងម៉ូសេផងដែរ ។ ពួកអ៊ីស្រាអែលកាលពីបុរាណដែលត្រូវបាននាំចេញពីស្រុកអេស៊ីព្ទពុំបានចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់ឡើយ ដោយសារពួកគេមានចិត្តរឹងរូសទាស់នឹងព្រះយេស៊ូវគ្រីស្ទ និងអ្នកបម្រើរបស់ទ្រង់ គឺម៉ូសេ ។ ក្នុងនាមជាសង្ឃជាន់ខ្ពស់ដ៏អស្ចារ្យ ព្រះយេស៊ូវគឺជំជាងរាល់ពួកសង្ឃជាន់ខ្ពស់ក្នុងក្រឹត្យវិន័យរបស់ម៉ូសេទាំងអស់ ។ តាមរយៈការរងទុក្ខរបស់ទ្រង់ នោះព្រះគ្រីស្ទត្រូវបានធ្វើឲ្យល្អឥតខ្ចោះ ។ យើងអាចចូលទៅទីសម្រាករបស់ព្រះអម្ចាស់ ហើយ « ជឿនទៅមុខដរាបដល់ពេញខ្នាត »តាមរយៈគោលលទ្ធិ និងពិធីបរិសុទ្ធទាំងឡាយនៃដំណឹងល្អ (ហេព្រើរ ៦:១) ។

ហេព្រើរ ៧–១៣ បព្វជិតភាពមិលគីស្សាដែកចាត់ចែងដំណឹងល្អ ហើយជំជាងបព្វជិតភាពអើរ៉ុន ។ រោងឧបោសថ និងពិធីបរិសុទ្ធក្នុងក្រឹត្យវិន័យរបស់ម៉ូសេបង្ហាញទុកជាមុនពីការងារបម្រើរបស់ព្រះគ្រីស្ទ ។ ព្រះយេស៊ូវគ្រីស្ទបានបំពេញក្រឹត្យវិន័យរបស់លោកម៉ូសេតាមរយៈការបង្ហូរព្រះលោហិតរបស់ទ្រង់ ដើម្បីឲ្យយើងអាចទទួលបាននូវសេចក្តីសង្គ្រោះ និងការផ្តាច់បាប ។ ដោយសារសេចក្តីជំនឿ ពួកព្យាការី និងបុរសស្ត្រីផ្សេងទៀតបានធ្វើកិច្ចការសុចរិត និងអព្ភូតហេតុនានា ។

មេរៀន ១៣៥

ហេព្រើរ ១–៤

សេចក្តីផ្តើម

ប៉ុលបង្រៀនពួកបរិសុទ្ធអំពីលក្ខណៈពិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកក៏បានបង្រៀនដល់ពួកគេអំពីជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង ពរជ័យមួយចំនួនដែលកើតឡើងដោយសារតែជង្វាយធួនផងដែរ ។ ប៉ុលបានចែកចាយពីបទពិសោធន៍របស់ពួកអ៊ីស្រាអែលពីបុរាណ ដែលដើរសាត់ព្រាត់នៅក្នុងទីរហោស្ថាន ដើម្បីបង្រៀនដល់ពួកបរិសុទ្ធនូវអ្វីដែលពួកគេត្រូវធ្វើ ដើម្បីចូលក្នុងទីសម្រាកនៃព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

ហេព្រើរ១

ប៉ុលបង្រៀនអំពីនិស្ស័យនៃព្រះយេស៊ូវគ្រីស្ទ

សូមអានស្តានភាពដូចខាងក្រោមឲ្យឮៗ ៖

១. យុវនារីម្នាក់មានការធុញទ្រាន់ក្នុងការធ្វើជា « ក្មេងស្រីល្អ » ដោយសារនាងពុំបានចូលរួមសកម្មភាពមួយចំនួនជាមួយមិត្តភក្តិរបស់ពួកគេ ។ នាងគិតអំពីការបន្ទាបបន្ទាបរបស់នាង ដើម្បីមានចំណែកក្នុងក្រុមនោះ ។

២. យុវជនម្នាក់ ដែលកំពុងបម្រើបេសកកម្មពេញម៉ោងដឹងថា កិច្ចការផ្សព្វផ្សាយសាសនាមានការលំបាកជាងអ្វីដែលគាត់បានរំពឹងគិតទុកជាមុន ហើយគាត់កំពុងគិតពីការត្រឡប់ទៅផ្ទះវិញ ។

- តើសាច់រឿងទាំងនេះមានចំណុចអ្វីខ្លះដូចគ្នា ?
- តើមានហេតុផលណាខ្លះ ដែលមនុស្សអាចគិតបោះបង់ចោលនូវការខិតខំ ដើម្បីធ្វើអ្វីដែលពួកគេដឹងថាត្រឹមត្រូវនោះ ?

សូមណែនាំដោយសង្ខេបអំពីគម្ពីរហេព្រើរ ដោយពន្យល់ថា នៅក្រោមសម្ពាធនៃការរងទុក្ខផ្សេងៗពួកអ្នកជ្លាស់ប្រែចិត្តជឿយ៉ាងខ្លះៗ (សំដៅទៅលើពួកហេព្រើរ) បានដកខ្លួនចេញពីការប្រជុំសាសនាចក្រ ហើយត្រឡប់ទៅចូលរួមនឹងការថ្វាយបង្គំរបស់យូដាតាមទំនៀមទម្លាប់មុន ដែលមិនបានរួមបញ្ចូលនូវការជឿទៅលើព្រះយេស៊ូវគ្រីស្ទឡើយ (សូមមើលហេព្រើរ១០:២៥, ៣៨–៣៩) ។ ប៉ុលបានសរសេរសំបុត្ររបស់លោកលើកទឹកចិត្តសមាជិកសាសនាចក្រទាំងនេះ ឲ្យបន្តនៅស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅពេលពួកគេសិក្សាគម្ពីរហេព្រើរ ដើម្បីអាចជួយពួកគេឲ្យបន្តស្មោះត្រង់ចំពោះព្រះគ្រីស្ទ ទោះជាពួកគេអាចមានអារម្មណ៍ថាចង់បោះបង់ចោលក្តី ។

សូមអញ្ជើញសិស្សឲ្យអាន ហេព្រើរ១:១–៣, ១០ ដោយស្ងាត់ស្ងៀម ហើយរកមើលគោលលទ្ធិដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធសាសន៍យូដាអំពីព្រះយេស៊ូវគ្រីស្ទ ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ សូមអញ្ជើញសិស្សច្រើននាក់ឲ្យសរសេរនៅលើក្តារខៀនអំពីសេចក្តីពិតដែលពួកគេបានរកឃើញ ។ សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែត្រូវប្រាកដថា សេចក្តីថ្លែងការណ៍ទាំងនោះស្រដៀងគ្នាទៅនឹងសេចក្តីពិតដូចខាងក្រោម ដែលបានសរសេរនៅលើក្តារខៀន ៖

ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និងផែនដី (សូមមើលហេព្រើរ ១:២, ១០) ។

ព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលជំនួសព្រះវរបិតា (សូមមើលហេព្រើរ ១:២) ។

ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកគ្រងមរតករបស់ព្រះវរបិតា (សូមមើលហេព្រើរ១:២) ។

ព្រះយេស៊ូវគ្រីស្ទគឺរូបភាពនៃអង្គព្រះវរបិតា (សូមមើលហេព្រើរ ១:៣) ។

ព្រះយេស៊ូវគ្រីស្ទទ្រទ្រង់គ្រប់គ្រងរបស់ទាំងអស់ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តារបស់ទ្រង់ (សូមមើលហេព្រើរ ១:៣) ។

ព្រះយេស៊ូវគ្រីស្ទបានសម្អាតអំពើបាបរបស់យើង (សូមមើលហេព្រើរ ១:៣) ។

ព្រះយេស៊ូវគ្រីស្ទគ្រងរាជ្យនៅខាងស្តាំព្រះហស្តនៃព្រះវរបិតា (សូមមើលហេព្រើរ ១:៣) ។

អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា ឃ្លា « ជារូបភាពនៃព្រះវរបិតា » មានន័យថាព្រះយេស៊ូវគ្រីស្ទ មានរូបអង្គខាងសាច់ឈាម និងខាងវិញ្ញាណតំណាងឲ្យព្រះវរបិតាសួគ៌ ហើយមានចំណែកនៃលក្ខណៈដ៏ទេវភាពរបស់ទ្រង់ និងឃ្លា « ទ្រទ្រង់គ្រប់គ្រងរបស់ទាំងអស់ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តានៃទ្រង់ » ចង្អុលបង្ហាញថា ព្រះយេស៊ូវគ្រីស្ទមានគ្រប់ព្រះចេស្តា ។

- តើការដឹងអំពីសេចក្តីពិតទាំងនេះអាចជួយនរណាម្នាក់ ដែលមានការលំបាកឲ្យបន្តនៅស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើសេចក្តីពិតណាមួយនៃសេចក្តីពិតទាំងនេះ អាចជាប្រយោជន៍ដល់ពួកគេ ប្រសិនបើពួកគេត្រូវបានល្បួងឲ្យងាកចេញពីការធ្វើតាមព្រះទ័យរបស់ព្រះអម្ចាស់នោះ ។

ស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

គោលបំណងសំខាន់មួយរបស់ព្រះគម្ពីរ គឺដើម្បីបង្រៀនគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ការប្រាប់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ នៅពេលពួកគេរកឃើញនៅក្នុងបទគម្ពីរ គឺជាគ្រឹះមួយនៃមូលដ្ឋានគ្រឹះនៃការបង្រៀន និងការរៀនសូត្រដ៏ល្អ ។ ការរៀនសូត្រពីរបៀបដើម្បីស្គាល់ វាតម្រូវឲ្យមានការខិតខំ និង ការអនុវត្តយ៉ាងខ្លាំង ។ វាសំខាន់ថា នៅពេលគោលលទ្ធិ និងគោលការណ៍ទាំងឡាយត្រូវបានប្រាប់ នោះវាត្រូវបានថ្លែងយ៉ាងច្បាស់ និងសមញ្ញដើម្បីប្រាកដថាសេចក្តីពិតទាំងនេះត្រូវបានយល់យ៉ាងច្បាស់នៅក្នុងគំនិតរបស់សិស្ស ។

សូមពន្យល់ថា បាវចនាមួយនៅក្នុងគម្ពីរហេព្រើរ គឺជាឧត្តមភាពរបស់ព្រះយេស៊ូវគ្រីស្ទ ។ ឧទាហរណ៍នៅក្នុង ហេព្រើរ ១:៤–១៤ ប៉ុលបានបង្ហាញថា ព្រះយេស៊ូវគ្រីស្ទគឺអស្ចារ្យជាងពួកទេវតា ។ នៅក្នុងជំពូកបន្តបន្ទាប់ទៀត លោកបានបន្តបង្ហាញពីភាពឧត្តុង្គឧត្តម និងភាពអស្ចារ្យរបស់ព្រះគ្រីស្ទ ។

- ហេតុអ្វីការដឹងថា ព្រះយេស៊ូវគ្រីស្ទអស្ចារ្យជាងអ្វីៗទាំងអស់ នឹងជួយមនុស្សម្នាក់ដែលកំពុងមានការលំបាកឲ្យបន្តនៅស្មោះត្រង់ចំពោះទ្រង់បាន ?

សូមលើកទឹកចិត្តសិស្សឲ្យបន្តមើលបាវចនានេះ នៅពេលពួកគេសិក្សាគម្ពីរហេព្រើរដែលនៅសល់ទាំងប៉ុន្មាន ។

ហេព្រើរ២

ប៉ុលបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាមេនៃសេចក្តីសង្គ្រោះរបស់យើង

ចូរសុំឲ្យសិស្សពិចារណាអំពីរបៀបដែលពួកគេនឹងជ្រើសរើសមេ ឬ អ្នកដឹកនាំសម្រាប់ក្រុមផ្សេងៗ ដែលពួកគេអាចចូលរួម (ឧទាហរណ៍ អត្តពលកម្ម ការតស៊ូមតិ ការសម្តែងល្ខោន ឬ ក្លឹបនៅសាលារៀន) ។

- តើគុណសម្បត្តិអ្វីខ្លះដែលអ្នករកមើល នៅពេលជ្រើសរើសមេ ឬអ្នកដឹកនាំ ?

សូមពន្យល់ថា នៅក្នុង ហេព្រើរ ២ សាវកប៉ុលបានពន្យល់បន្ថែមទៀតអំពីនិស្ស័យ និង អត្តសញ្ញាណរបស់ព្រះយេស៊ូវគ្រីស្ទដល់សាសន៍យូដាដែលប្រែចិត្តជឿ ដើម្បីជួយពួកគេឲ្យយល់ពីមូលហេតុដែលពួកគេគួរតែបន្តដើរតាមទ្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានហេព្រើរ២:១០ឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលរបៀបដែលប៉ុលបានរៀបរាប់សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ។

- តើព្រះយេស៊ូវគ្រីស្ទជាមេលើអ្វី ? (សូមសរសេរសេចក្តីពិតដូចខាងក្រោមនៅលើក្តារខៀន ៖**ព្រះយេស៊ូវគ្រីស្ទគឺជាមេនៃសេចក្តីសង្គ្រោះរបស់យើង**) ។
- តើព្រះយេស៊ូវគ្រីស្ទជាមេនៃសេចក្តីសង្គ្រោះរបស់យើងតាមរបៀបណា ?

សូមបំបែកសិស្សជាគូៗ ហើយចាត់ឲ្យសិស្សម្នាក់អានហេព្រើរ ២:៨–១៣ ហើយឲ្យសិស្សដទៃទៀតអានហេព្រើរ ២:១៤–១៨។ សូមអញ្ជើញសិស្សឲ្យរកមើលឃ្លាដែលពិពណ៌នាអំពីមូលហេតុដែលព្រះអង្គសង្គ្រោះមានគុណសម្បត្តិធ្វើជាមេនៃសេចក្តីសង្គ្រោះរបស់យើង ។ (សូមពន្យល់ថា ឃ្លា « ប្រយោជន៍នឹងថ្វាយដង្វាយឲ្យឆ្ងននឹងបាបរបស់ប្រជាជនទាំងឡាយ » នៅក្នុងខទី ១៧មានន័យថា ព្រះគ្រីស្ទបានធ្វើឲ្យឆ្ងននឹងអំពើបាបរបស់យើង ដែលអនុញ្ញាតឲ្យយើងត្រូវបានផ្សះផ្សារ ឬមានទំនាក់ទំនងសុខដុមជាមួយព្រះវរបិតាសួគ៌) ។

ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ ចូរសុំសិស្សឲ្យប្រាប់ពីអ្វីដែលពួកគេបានរកឃើញទៅដល់ដៃគូរបស់ពួកគេ ។ បន្ទាប់មក សូមសួរសិស្ស ៖

- យោងតាម ខទី ៩ តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះសម្រាប់មនុស្សទាំងអស់ ?
- យោងតាម ខទី ១៤ តើទ្រង់បានយកឈ្នះលើនរណាខ្លះ តាមរយៈដង្វាយឆ្ងនរបស់ទ្រង់ ?

សូមចង្អុលបង្ហាញថា ប៉ុលពុំគ្រាន់តែសំដៅលើព្រះអង្គសង្គ្រោះថាជាមេនៃសេចក្តីសង្គ្រោះរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែលោកក៏បានហៅទ្រង់ថាជា « សម្តេចសង្ឃ ដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់ » ដែរ (ខទី ១៧) ។ ប៉ុលបានប្រដូចព្រះយេស៊ូវគ្រីស្ទទៅនឹងសម្តេចសង្ឃម្នាក់របស់សាសន៍យូដា ដោយសារសម្តេចសង្ឃត្រូវបានចាត់ទុកថាជាអ្នកនៅកណ្តាលរវាងមនុស្ស និង ព្រះ ។

- យោងតាមខទី ១៧តើអ្វីដែលធ្វើឲ្យព្រះយេស៊ូវអាចជាសម្តេចសង្ឃ ដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់ ?
- យោងតាម ហេព្រើរ ២:១៨ ហេតុអ្វីព្រះអង្គសង្គ្រោះអាចជួយយើងបាន ? (សូមមើលដងដែរ អាលម៉ា ៧:១១–១៣) ។

សូមពន្យល់ថា នៅក្នុង ហេព្រើរ៤:១៤–១៦ ប៉ុលបានផ្តល់នូវគំនិតបន្ថែមដល់ការបង្រៀនរបស់លោក អំពីរបៀបដែលព្រះអង្គសង្គ្រោះគឺជាសម្តេចសង្ឃ ដែលមានព្រះទ័យមេត្តាករុណា ហើយក៏ស្មោះត្រង់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានខគម្ពីរទាំងនេះឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលធ្វើឲ្យព្រះយេស៊ូវគ្រីស្ទជាសម្តេចសង្ឃដ៏អស្ចារ្យដូច្នេះ ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- ផ្អែកទៅលើអ្វីដែលអ្នកបានរៀនមកពីហេព្រើរ ២:១៤–១៨និង ៤:១៤–១៦ ហេតុអ្វីព្រះយេស៊ូវគ្រីស្ទអាចយល់អំពីយើងយ៉ាងឥតខ្ចោះ ហើយមានក្តីអាណិតអាសូរចំពោះភាពទន់ខ្សោយ និងភាពមិនល្អឥតខ្ចោះរបស់យើង ? (សូមជួយសិស្សឲ្យស្គាល់សេចក្តីពិតដូចខាងក្រោម ៖ **ដោយសារព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយត្រូវបានល្បងនៅគ្រប់រឿងទាំងអស់ នោះទ្រង់យល់ពីយើងយ៉ាងច្បាស់ ហើយអាចជួយយើងនៅក្នុងគ្រាដែលយើងត្រូវការ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- យោងតាមហេព្រើរ ៤:១៦តើការយល់ដឹងអំពីសេចក្តីពិតនេះអាចជួយយើងឲ្យធ្វើអ្វីខ្លះ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីមកដល់បល្ល័ង្កនៃព្រះគុណដោយក្លាហាន ?

សូមអញ្ជើញសិស្សឲ្យចែកចាយអំពីអារម្មណ៍របស់ពួកគេ អំពីរបៀបដែលសេចក្តីពិតនៅក្នុង ហេព្រើរ ២អាចជួយពួកគេឲ្យមានទំនុកចិត្តទៅលើការសម្រេចចិត្តរបស់ពួកគេដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ ដែលជាអ្នកដឹកនាំរបស់ពួកគេ ។

ហេព្រើរ៣–៤

ប៉ុលបង្រៀនពីរបៀប ដែលយើងអាចចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ អំពីអ្វីដែលធ្វើឲ្យពួកគេខ្វល់ខ្វាយ ឬចង់បារម្ភខាងសាច់ឈាម ឬខាងវិញ្ញាណ ។

- តើយើងអាចរកបានសេចក្តីសុខសាន្ត ហើយសម្រាកពីកង្វល់ទាំងនេះ ឬ ភាពជ្រួលច្របល់ និង ការអស់សង្ឃឹមផ្សេងទៀត យ៉ាងដូចម្តេច ?

សូមរំឭកសិស្សថា ពួកបរិសុទ្ធសាសន៍យូដា បានជួបនឹងការបៀតបៀនចំពោះការរស់នៅតាមដំណឹងល្អ ។ សូមពន្យល់ថានៅក្នុងហេព្រើរ ៣ និង៤ ប៉ុលបាននិយាយពីបទពិសោធន៍ចេញពីគម្ពីរសញ្ញាចាស់ ដើម្បីបង្រៀនពួកបរិសុទ្ធអំពីរបៀបស្វែងរកទីសម្រាកនៅក្នុងជីវិតនេះ និង ជីវិតបន្ទាប់ ។

សូមពន្យល់ថា បន្ទាប់ពីមានសេរីភាពពីប្រទេសអេស៊ីប្ទ នោះប្រជាជនសាសន៍អ៊ីស្រាអែលពីបុរាណបានធ្វើឲ្យព្រះអម្ចាស់ទ្រង់ព្រះពិរោធ ហេតុដូច្នេះពួកគេមិនអនុញ្ញាតឲ្យចូលទៅក្នុងកន្លែងសម្រាករបស់ព្រះអម្ចាស់ទេ (សូមមើលជនគណនា ១៤,យ៉ាកុប ១:៧–៨, អាលម៉ា ១២:៣៣–៣៧,១៣:៦, ១២–១៣, ២៨–២៩) ។ សូមអញ្ជើញសិស្សឲ្យគូសចំណាំឃ្លា « ផ្លូវរបស់យើងសោះ » នៅក្នុង ហេព្រើរ ៣:១១ ។

សូមចង្អុលបង្ហាញថាអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បានពន្យល់អំពីអត្ថន័យដើម្បីចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ម៉ាក់ខន់ឃី ឲ្យឮៗ ហើយសុំឲ្យសិស្សស្តាប់រកមើលអត្ថន័យនៃការចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់ ។



« ពួកបរិសុទ្ធដ៏ពិតប្រាកដចូលទៅក្នុងសេចក្តីសម្រាកនៃព្រះអម្ចាស់ ខណៈដែលនៅក្នុងជីវិតនេះ ហើយដោយការនៅជាប់នឹងសេចក្តីពិត នោះពួកគេបន្តនៅក្នុងស្ថានភាពដ៏មានពរជ័យនោះ រហូតដល់ពួកគេចូលក្នុងសេចក្តីសម្រាកជាមួយព្រះអម្ចាស់នៅស្ថានសួគ៌ ។ . . . ខណៈដែលជីវិតរមែងស្លាប់មានការខ្វល់ខ្វាយ ទីសម្រាករបស់ព្រះអម្ចាស់ជាទីទទួលបាននូវចំណេះដឹងដ៏ឥតខ្ចោះនៃភាពជាព្រះនៃកិច្ចការដ៏មហិមានៃថ្ងៃចុងក្រោយ ។ . . . នៅក្នុងភាពអស់កល្បជានិច្ច ទីសម្រាកនៃព្រះអម្ចាស់គឺការដែលបានគ្រងជីវិតដ៏នៅអស់កល្បជានិច្ច ទទួលបាននូវភាពពេញលេញនៃសិរីរុងរឿងរបស់ព្រះអម្ចាស់ ។ (គ. និង ស. ៨៤:២៤) »។ (*Mormon Doctrine* កែសម្រួលលើកទី ២ [ឆ្នាំ ១៩៦៦] ទំព័រ ៦៣៣) ។

- តើវាមានន័យយ៉ាងណាសម្រាប់យើង ដើម្បីចូលក្នុងទីសម្រាករបស់ព្រះអម្ចាស់ក្នុងជីវិតនេះ ? ចុះបន្ទាប់ពីយើងស្លាប់ទៅ ?

សូមអាន ហេព្រើរ ៤:១ ឲ្យឮៗ ហើយសុំឲ្យសិស្សធ្វើតាម ហើយរកមើលអ្វីដែលប៉ុលបានបារម្ភថា សមាជិកសាសនាចក្រមួយចំនួនពុំបានធ្វើវា ។

- តើការបារម្ភរបស់ប៉ុលមានអ្វីខ្លះ ? (ថាសមាជិកសាសនាចក្រមួយចំនួននឹងមិនអាចចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់បានឡើយ) ។

សូមសរសេរបទគម្ពីរដូចខាងក្រោមនៅលើក្តារខៀន ៖ *ហេព្រើរ៣:៧–៨, ១២–១៥, ១៨–១៩; ៤:២–៣, ៦–៧, ១១* ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់អានខគម្ពីរទាំងនេះដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលប៉ុល បានបង្រៀនអំពីរបៀបដែលយើងអាចចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់បាន ។ (សូមលើកទឹកចិត្តសិស្សឲ្យអានការបកប្រែរបស់ យ៉ូសែប ស៊្មីធ ហេព្រើរ ៤:៣នៅក្នុងសេចក្តីបន្ថែមព្រះគម្ពីរចប់) ។ ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់អំពីអ្វីដែលពួកគេបានរកឃើញ ។

- តើអ្នកគិតថាឃ្លា « បើយើងរាល់គ្នាកាន់ខ្ជាប់ តាមសេចក្តីជំនឿដើម ដរាបដល់ចុងបំផុត » (ហេព្រើរ ៣:១៤) មានន័យដូចម្តេច ?
- តើអ្នកគិតថាឃ្លា « កុំឲ្យតាំងចិត្តរឹងរូស » មានន័យយ៉ាងណា ? (ហេព្រើរ៣:១៥; ៤:៧) ។ (ដើម្បីបន្តបើកដួងចិត្តរបស់យើង ស្ម័គ្រចិត្ត និងគោរពប្រតិបត្តិតាមព្រះ និងបទបញ្ញត្តិទាំងឡាយរបស់ទ្រង់) ។
- តើប៉ុលបង្រៀនអ្វីខ្លះអំពីរបៀប ដើម្បីចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់ ? (ចេញពីចម្លើយរបស់សិស្ស សូមសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **ប្រសិនបើយើងបន្តនៅស្មោះត្រង់ចំពោះព្រះអង្គសង្គ្រោះ ហើយគ្មានចិត្តរឹងរូស នោះយើងនឹងចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់**) ។
- តើការបើកដួងចិត្តរបស់យើងចំពោះព្រះរាជបំណង និងផែនការរបស់ព្រះសម្រាប់យើង អាចរៀបចំយើងចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ?
- តើយើងអាចត្រូវបានប្រទានពរនៅក្នុងជីវិតនេះ តាមរយៈការព្យាយាមចូលទៅក្នុងទីសម្រាករបស់ព្រះអម្ចាស់យ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សពិចារណាអំពីរបៀបដែលការស្មោះត្រង់ចំពោះព្រះអង្គសង្គ្រោះ និងការបើកដួងចិត្តរបស់យើងចំពោះទ្រង់ បានជួយពួកគេឲ្យស្វែងរកទីសម្រាក ទោះជាពួកគេមានបញ្ហា ឬការព្រួយបារម្ភច្រើនក្តី ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ អំពីអ្វីដែលពួកគេនឹងធ្វើដើម្បីបន្តនៅស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ហើយបើកដួងចិត្តរបស់អ្នកចំពោះទ្រង់ជានិច្ច ។

មេរៀនសិក្សានៅផ្ទះ

ធីម៉ូថេទី២ ១—ហេព្រើរ៤ (មេរៀនទី ២៧)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ធីម៉ូថេ ទី២ ១–ហេព្រើរ ៤ (មេរៀនទី ២៧) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី១ (ធីម៉ូថេទី២)

នៅក្នុងសំបុត្ររបស់ប៉ុលទៅកាន់ធីម៉ូថេ សិស្សបានរៀនពីសេចក្តីពិតដូចតទៅ ៖ នៅពេលយើងខិតខំឲ្យមានព្រះវិញ្ញាណគង់នៅជាមួយយើង នោះយើងអាចយកឈ្នះលើសេចក្តីភ័យខ្លាច ហើយពុំខ្មាសអៀនអំពីទីបន្ទាល់របស់យើងលើព្រះយេស៊ូវគ្រីស្ទឡើយ ។ នៅពេលយើងស៊ូទ្រាំនឹងការលំបាក ហើយបន្តស្មោះត្រង់នឹងព្រះអម្ចាស់ យើងអាចជួយខ្លួនយើង និងមនុស្សដទៃទៀតឲ្យទទួលបានសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើយើងសម្អាតខ្លួនយើងចេញពីសេចក្តីទុច្ចរិត នោះយើងអាចបម្រើព្រះអម្ចាស់កាន់តែប្រសើរឡើង ។ ប្រសិនបើយើងបន្តស្មោះត្រង់ចំពោះរាល់អ្វីៗដែលព្រះអម្ចាស់តម្រូវឲ្យយើងធ្វើ នោះយើងនឹងទទួលបានមកុដនៃសេចក្តីសុចរិត ។ សិស្សក៏រៀនផងដែរអំពីគ្រោះថ្នាក់នៅជំនាន់របស់យើង និងតម្លៃនៃព្រះគម្ពីរ ។

ថ្ងៃទី២ (ទីតុស)

នៅពេលសិស្សបានសិក្សាសំបុត្ររបស់ប៉ុលដល់ទីតុស ដែលជាថ្នាក់ដឹកនាំសាសនាចក្រម្នាក់នៅកោះក្រេត នោះពួកគេបានរៀនថា នៅពេលយើងកាន់ខ្ជាប់ទៅនឹងព្រះបន្ទូល យើងនឹងអាចប្រើគោលលទ្ធិពិតដើម្បីលើកទឹកចិត្តមនុស្សដទៃឲ្យរស់នៅតាមជំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយឆ្លើយបដិសេធចំពោះជនដែលទាស់នឹងវា ។ ប៉ុលបានលើកទឹកចិត្តពួកអ្នកជើរតាមព្រះយេស៊ូវគ្រីស្ទ ឲ្យធ្វើជាគំរូល្អដល់មនុស្សដទៃ ។ លោកក៏បានថ្លែងទីបន្ទាល់ផងដែរថា ព្រះយេស៊ូវគ្រីស្ទបានលះបង់អង្គទ្រង់ដើម្បីយើង ដើម្បីទ្រង់អាចប្រោសលោះយើង ហើយធ្វើឲ្យយើងបរិសុទ្ធ ។

ថ្ងៃទី ៣ (ភីលេម៉ូន)

នៅក្នុងការសិក្សាពីការអង្វររបស់ប៉ុលដល់ភីលេម៉ូនឲ្យចាត់ទុកបាវបម្រើដែលគេចខ្លួនហើយផ្លាស់ប្រែចិត្តជឿថ្មីម្នាក់ ជាបងប្អូនប្រុសម្នាក់នៅក្នុងជំណឹងល្អ នោះសិស្សបានរៀនថា យើងគឺជាបងប្អូនប្រុសស្រីនឹងគ្នានៅក្នុងជំណឹងល្អ ។ ពួកគេក៏រៀនផងដែរថា សិស្សរបស់ព្រះយេស៊ូវគ្រីស្ទបង្ហាញសេចក្តីមេត្តា និងការអភ័យទោសដល់មនុស្សដទៃ ។

ថ្ងៃទី៤ (ហេព្រើរ១–៤)

នៅពេលសិស្សបានសិក្សាសំបុត្ររបស់ប៉ុលដល់ពួកហេព្រើរ ពួកគេបានរៀនពីគោលលទ្ធិជាច្រើនអំពីព្រះអង្គសង្គ្រោះ រួមមានទាំងតួនាទីរបស់ទ្រង់ជាព្រះដ៏បង្កបង្កើត និងភាពដូចគ្នារបស់ទ្រង់ទៅនឹងព្រះវរបិតាសួគ៌ ។ គោលលទ្ធិទាំងនេះបានដឹកនាំសិស្សឲ្យស្គាល់សេចក្តីពិតថា ព្រះយេស៊ូវគ្រីស្ទគឺជាមេទ័ពនៃសេចក្តីសង្គ្រោះរបស់យើង ។ ពួកគេក៏បានរៀនផងដែរថា ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ហើយត្រូវបានល្បួងនៅគ្រប់រឿងទាំងអស់ ទ្រង់យល់ពីយើងយ៉ាងច្បាស់ ហើយអាចជួយយើងនៅគ្រាចាំបាច់ ។

សេចក្តីផ្តើម

មេរៀននេះក្រុកការព្យាករបស់ប៉ុលអំពីគ្រោះថ្នាក់ ដែលមាននៅថ្ងៃចុងក្រោយក៏ដូចជានៅជំនាន់របស់លោកដែរ ។ ប៉ុលបានណែនាំធីម៉ូថេ និងពួកអ្នកអាននាពេលអនាគត ឲ្យបន្តស្មោះត្រង់ចំពោះសេចក្តីពិតដែលពួកគេបានរៀន ហើយប្រើបទគម្ពីរដោយប្រភពនៃការយល់ដឹង ការកែតម្រូវ និងការណែនាំនៅក្នុងគ្រាគ្រោះថ្នាក់ទាំងនេះ ។

យោបល់សម្រាប់ការបង្រៀន

ធីម៉ូថេទី២ ៣

ប៉ុលពិពណ៌នាពីគ្រាដ៏លំបាកនៅថ្ងៃចុងក្រោយ

ពីមុនថ្នាក់ចាប់ផ្តើម ចូរសុំឲ្យសិស្សពីរ ឬបីនាក់បានមកដល់ដំបូងគេឲ្យគូរូបនៅលើក្តារខៀនស្តីពីស្ថានភាពដ៏គ្រោះថ្នាក់ ឬមានហានិភ័យមួយ ។ បន្ទាប់ពីថ្នាក់ចាប់ផ្តើម សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកនឹងប្រើពាក្យអ្វីដើម្បីពិពណ៌នាពីស្ថានភាពដែលបានគូរនៅលើក្តារខៀន ?

សូមពន្យល់ថា ជាផ្នែកមួយនៃសំបុត្រទីពីររបស់លោកដល់ធីម៉ូថេ ប៉ុលបានព្យាករពីលក្ខខណ្ឌនៅក្នុងជំនាន់លោក និងជំនាន់របស់យើង ។ សូមអញ្ជើញសិស្សម្នាក់អាន ធីម៉ូថេទី២ ៣:១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាប៉ុលបានរៀបរាប់ពីគ្រាដែលយើងរស់នៅយ៉ាងដូចម្តេច ។

- តើប៉ុលបានពិពណ៌នាពីគ្រាដែលយើងរស់នៅយ៉ាងដូចម្តេច ? (ប្រសិនបើចាំបាច់ សូមពន្យល់ថា ពាក្យ *ដ៏លំបាក* មានន័យថាពោរពេញដោយគ្រោះថ្នាក់ ឬហានិភ័យ) ។
- តើហានិភ័យ ឬ គ្រោះថ្នាក់ខាងវិញ្ញាណ ឬខាងសីលធម៌មួយចំនួនដែលអ្នកឮឃើញនៅក្នុងជំនាន់របស់យើងមានអ្វីខ្លះ ?

សូមបំបែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗនូវច្បាប់ចម្លងមួយនៃ តារាងដូចខាងក្រោម ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអាន ធីម៉ូថេទី២ ៣:២–៧ ហើយឆ្លើយសំណួរនៅលើតារាង ។ សូមណែនាំពួកគេឲ្យប្រើសេចក្តីយោងជាជំនួយសម្រាប់ពាក្យពិបាកៗ ។

ធីម៉ូថេទី២ ៣:២–៧

តើគំរូមួយចំនួននៃលក្ខខណ្ឌនៅថ្ងៃចុងក្រោយ ដែលប៉ុលបានរៀបរាប់មានអ្វីខ្លះ ?	តើក្នុងចំណោមលក្ខខណ្ឌទាំងនេះ តើលក្ខខណ្ឌណាមួយដែលអ្នកធ្លាប់បានឃើញនៅសម័យរបស់យើង ? (បង្ហាញលក្ខខណ្ឌទាំងនោះឲ្យបានពីរ ឬបី) ។ ហេតុអ្វីលក្ខខណ្ឌទាំងនេះមានគ្រោះថ្នាក់ខ្លាំងម្ល៉េះ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់ដល់សិស្សក្នុងថ្នាក់ថាពួកគេឆ្លើយយ៉ាងណាចំពោះសំណួរនៅក្នុងតារាងនោះ រួមបញ្ចូលទាំងហេតុផលដែលលក្ខខណ្ឌទាំងនេះមានគ្រោះថ្នាក់ខ្លាំងណាស់ម្ល៉េះ ។

ចូរសុំឲ្យសិស្សសញ្ជឹងគិតថា ពួកគេធ្លាប់ជ្រួយបារម្ភដែរឬទេថាពួកគេអាចនឹងរងគ្រោះពីលក្ខខណ្ឌមួយចំនួន ដែលប៉ុលបានលើកឡើងនៅក្នុងខគម្ពីរដែលពួកគេបានសិក្សានោះ ។

- យោងតាមចុងបញ្ចប់នៃ ធីម៉ូថេទី ២ ៣:៥តើប៉ុលបានលើកទឹកចិត្តធីម៉ូថេឲ្យធ្វើអ្វីខ្លះ ដែលវាក៏អាចជួយយើងនៅជំនាន់របស់យើងផងដែរនោះ ? (យើងគួរងាកចេញពីអំពើទុច្ចរិត) ។

សូមពន្យល់ថា ថ្វីបើមានភាពធ្ងន់ធ្ងរនៃលក្ខខណ្ឌដ៏ខ្មៅទាំងនេះក្តី ក៏យើងអាចរកឃើញជំនួយ និងការការពារបានដែរ ។ សូមអញ្ជើញសិស្សម្នាក់អានធីម៉ូថេទី២ ៣:១៤–១៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាប៉ុលបានបង្រៀនថាអ្វីខ្លះអាចជួយយើងឲ្យងាកចេញពីគ្រោះថ្នាក់ទាំងនេះ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះ អំពីការតតាំងនឹងគ្រោះថ្នាក់ដែលលោកបានពិពណ៌នា ?
- តើអ្នកគិតថា វាមានន័យយ៉ាងណានៅក្នុង ខទី១៤ ដើម្បី « ឲ្យអ្នកនៅជាប់ក្នុងសេចក្តីដែលអ្នកបានរៀន ហើយជឿប្រាកដវិញ » ?

សូមអញ្ជើញសិស្សឲ្យរកគោលការណ៍មួយនៅក្នុង ធីម៉ូថេទី២ ៣:១៤–១៥ អំពីរបៀបដើម្បីយកឈ្នះលើគ្រោះថ្នាក់ខាងវិញ្ញាណនាថ្ងៃចុងក្រោយ ។ (បន្ទាប់ពីសិស្សឆ្លើយរួច សូមសរសេរឃ្លាដូចតទៅនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងបន្តនៅក្នុងសេចក្តីពិត ដែលយើងបានរៀនមកពីប្រភពដែលទុកចិត្ត និងនៅក្នុងបទគម្ពីរ នោះយើងអាចយកឈ្នះលើគ្រោះថ្នាក់ខាងវិញ្ញាណនាថ្ងៃចុងក្រោយនេះបាន**) ។

- តើការពឹងផ្អែកលើបទគម្ពីរ និងនៅលើសេចក្តីពិតដែលយើងបានរៀន អាចជួយយើងឲ្យយកឈ្នះលើគ្រោះថ្នាក់នៅជំនាន់របស់យើងយ៉ាងដូចម្តេច ?
- តើអ្នកធ្លាប់ជ្រើសរើសពឹងផ្អែកលើសេចក្តីពិត ដែលអ្នកបានរៀននៅពេលណាដែរ ? តើអ្នកបានទទួលពរ ដោយព្រោះការធ្វើដូច្នោះយ៉ាងដូចម្តេចដែរ ? (អ្នកអាចឲ្យសិស្សឆ្លើយនឹងសំណួរទាំងនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ រួចហើយអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយថាពួកគេបានសរសេរអ្វីខ្លះជាមួយនឹងសិស្សក្នុងថ្នាក់) ។

សូមកត់ចំណាំថា ធីម៉ូថេទី ២ ៣:១៥–១៧ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ចូរអញ្ជើញសិស្សម្នាក់ឲ្យអាន ធីម៉ូថេទី២ ៣:១៥–១៧ ឮៗ ហើយឲ្យសិស្សក្នុងថ្នាក់ឲ្យរកមើលថាប៉ុលបានបង្រៀនអ្វីខ្លះអំពីបទគម្ពីរ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំពោះអ្វីដែលពួកគេរកឃើញ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះ អំពីការសិក្សាបទគម្ពីរដែលអាចជួយយើងនៅក្នុងជំនាន់របស់យើង ? (សូមជួយសិស្សឲ្យស្គាល់គោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងសិក្សាព្រះគម្ពីរ យើងអាចរៀនពីគោលលទ្ធិ ហើយទទួលការកែតម្រូវ និងការណែនាំដែលនឹងជួយយើងឲ្យរីកចម្រើនឆ្ពោះទៅរកភាពល្អឥតខ្ចោះ** ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ចូរសុំឲ្យសិស្សគិតពីគ្រាមួយដែលបទគម្ពីរ—ប្រហែលជាវគ្គដែលពួកគេបានសិក្សានៅក្នុងព្រះគម្ពីរសញ្ញាថ្មី—បានជួយពួកគេនៅក្នុងរបៀបមួយដូចខាងក្រោមនេះ ៖

១. ដើម្បីយល់ដឹងពីគោលលទ្ធិមួយនៃដំណឹងល្អ

២. ដោយផ្តល់ជាការស្តីបន្ទោស ឬការកែតម្រូវទាក់ទងនឹងអ្វីមួយនៅក្នុងការគិត ការជ្រើសរើស ឬឥរិយាបថរបស់ពួកគេដែលមិនត្រឹមត្រូវ

៣. ដោយផ្តល់ចម្លើយចំពោះការអធិស្ឋាន ឬផ្តល់ការណែនាំពីរបៀបដោះស្រាយបញ្ហាមួយ

ចូរទុកពេលឲ្យសិស្សគិតពីបទពិសោធន៍នានា រួចហើយអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេគិតដល់ជាមួយសិស្សក្នុងថ្នាក់ ។

- ដោយពិចារណាចំពោះអ្វីដែលយើងបានរៀនអំពីតម្លៃនៃបទគម្ពីរ ហេតុអ្វីអ្នកគិតថា យើងត្រូវបានលើកទឹកចិត្តឲ្យសិក្សាវាជាប្រចាំថ្ងៃ ?

ចូរឲ្យសំណៅនៃសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កតក្នុង ក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សម្នាក់អានវាឲ្យឮៗ ហើយឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យទូន្មាន និងការសន្យារបស់អែលឌើរ ស្កត ទាក់ទងនឹងការសិក្សាព្រះគម្ពីរ ។



« សូមកុំជឿពាក្យកុហករបស់សាតាំងថា បងប្អូនគ្មានពេលសិក្សាព្រះគម្ពីរឲ្យសោះ ។ សូមជ្រើសយកពេលសិក្សាព្រះគម្ពីរទាំងនោះ ។ ការទទួលទានព្រះបន្ទូលរបស់ព្រះរៀងរាល់ថ្ងៃគឺសំខាន់ជាងការដេក ការទៅសាលារៀន ការធ្វើការងារ កម្មវិធីទូរទស្សន៍ វីដេអូហ្គេម ឬបណ្តាញសង្គមទៅទៀត ។ បងប្អូនត្រូវរៀបចំនូវអាទិភាពខ្លួនម្តងទៀត ដើម្បីមានពេលសិក្សាបន្ទូលព្រះរបស់ព្រះ ។ ប្រសិនបើដូច្នេះមែន សូមធ្វើបែបនោះចុះ ! « . . . ពេលបងប្អូនលះបង់ពេលរាល់ថ្ងៃ ទាំងពេលផ្ទាល់ខ្លួន និង គ្រួសារ ដើម្បីសិក្សាបន្ទូលព្រះនោះសេចក្តីសុខសាន្តនឹងកើតមានក្នុងជីវិតបងប្អូន » (« Make the Exercise of Faith Your First Priority » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៩៣) ។

សូមថ្លែងទីបន្ទាល់ពីសុវត្ថិភាព និងសេចក្តីសុខសាន្តដែលកើតមានដល់ជនដែលបន្តនៅក្នុងសេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរ ។

សូមអញ្ជើញសិស្សឲ្យបត់ក្រដាសជាបីភាគ ដោយបង្កើតជាជួរឈរបី ។ សូមឲ្យពួកគេពន្លាតក្រដាសនោះវិញ ហើយសរសេរពាក្យ *គោលលទ្ធិ* នៅផ្នែកខាងលើនៃជួរឈរទីមួយ *ផ្តល់ជាភស្តុតាងជាថ្មី និងការកែតម្រូវ* នៅផ្នែកខាងលើនៃជួរឈរទីពីរ និង *ការណែនាំនៅក្នុងសេចក្តីសុចរិត* នៅផ្នែកខាងលើនៃជួរឈរទីបី ។

សូមអញ្ជើញសិស្សឲ្យប្រើក្រដាសនេះជាវត្ថុសិក្សាចំណាំ នៅក្នុងព្រះគម្ពីរបស់ពួកគេសម្រាប់មួយសប្តាហ៍ ដោយសរសេរនៅក្នុងផ្នែកដ៏សមរម្យ រាល់ពេលពួកគេអានបទគម្ពីរមួយដែលបំពេញឲ្យគោលបំណងនៅក្នុងចំណោមគោលបំណងទាំងនេះ ។ ឧទាហរណ៍ នៅក្រោមចំណងជើង « គោលលទ្ធិ » សិស្សអាចសរសេរសេចក្តីយោងបទគម្ពីរ និងគោលលទ្ធិ ឬគោលការណ៍មួយដែលពួកគេរៀននៅក្នុងសេចក្តីយោងនោះ ។ នៅក្រោមចំណងជើង ផ្តល់ជា « ការស្តីបន្ទោស និងការកែតម្រូវ » ពួកគេអាចសរសេរសេចក្តីយោងបទគម្ពីរ និងរបៀបដែលបទគម្ពីរនោះកែតម្រូវគំនិតខុសឆ្គងនានា ។ ហើយនៅក្រោម « ការណែនាំនៅក្នុងសេចក្តីសុចរិត » ពួកគេអាចកត់ត្រាបទគម្ពីរដែលផ្តល់ជាគំនិតចំពោះកិច្ចការល្អៗ ដែលពួកគេអាចធ្វើ ។

សូមលើកទឹកចិត្តសិស្សឲ្យយកក្រដាសនេះមកវិញក្នុងរយៈពេលមួយសប្តាហ៍ ដើម្បីប្រាប់ពីបទពិសោធន៍របស់ពួកគេ ។ អ្នកគួរដាក់ការព្រួតមួយនៅក្នុងព្រះគម្ពីរ ឬសៀវភៅសិក្សារបស់អ្នកដើម្បីមានការពិភាក្សាខ្លីៗដោយរំឭកឡើងវិញពីរបៀប ដែលពួកគេបានអនុវត្តចំណេះចំណានខគម្ពីរនេះ ។

មេរៀនបន្ទាប់ (ហេព្រើរ៥–យ៉ាកុប១)

សូមលើកទឹកចិត្តសិស្សឲ្យរកចម្លើយសម្រាប់សំណួរដូចតទៅ នៅពេលពួកគេសិក្សាមេរៀនបន្ទាប់ ៖ តើយុវជនត្រូវហៅឲ្យទទួលបព្វជិតភាពយ៉ាងដូចម្តេច ? តើបុគ្គលដែលបានលើកឡើងនៅក្នុងហេព្រើរថា ជាអ្នកមានសេចក្តីជំនឿដ៏អស្ចារ្យនោះជានរណា ? តើនៅក្នុងមេរៀននេះអ្នកស្គាល់បុរសស្ត្រីណាម្នាក់ នៅក្នុងមេរៀនដែលអ្នកបានរៀនដែរឬទេ ? តើខគម្ពីរអ្វីទៅដែល យ៉ូសែប ស្ម៊ីធ បានអាន ហើយវាបានដឹកនាំលោកឲ្យ « សូមដល់ព្រះ » ហើយធ្វើឲ្យការនិមិត្តដំបូងកើតមានឡើង ? តើសាសនាដែលបរិសុទ្ធជាអ្វី ?

ហេព្រើរ ៥–៦

សេចក្តីផ្តើម

ប៉ុលបានបង្រៀនថា អស់អ្នកដែលទទួលបព្វជិតភាពត្រូវតែបានហៅដោយព្រះ ហើយថាព្រះយេស៊ូវគ្រីស្ទត្រូវ « ព្រះបានតាំងងារទ្រង់ [ជា] សម្តេចសង្ឃ (សង្ឃជាន់ខ្ពស់) តាមរបៀបលោកមិលគីស្សាដែក » (ហេព្រើរ ៥:១០) ។ ប៉ុលបានលើកទឹកចិត្តសមាជិកសាសនាចក្រ ឲ្យមាននូវការឧស្សាហ៍ព្យាយាម មានសេចក្តីជំនឿ ការអត់ធ្មត់ និង សេចក្តីសង្ឃឹមក្នុងការទទួលបាននូវការសន្យារបស់ព្រះ ។

បង្កើតបរិយាកាសនៃសេចក្តីស្រឡាញ់ និង ការគោរព

នៅពេលសិស្សទទួលអារម្មណ៍នូវក្តីស្រឡាញ់ ទុកចិត្ត និង ការឲ្យតម្លៃមកពីរូបអ្នក និងមិត្តរួមថ្នាក់របស់ពួកគេ នោះពួកគេនឹងមកកាន់ថ្នាក់រៀនដោយបើកដួងចិត្តចំពោះឥទ្ធិពលនៃព្រះវិញ្ញាណ និងមានបំណងប្រាថ្នាចូលរួមកាន់តែខ្លាំង ។ ការបង្ហាញនូវចំណាប់អារម្មណ៍ពិតទៅលើជីវិតរបស់សិស្ស និងការផ្តល់ឱកាសដល់សិស្សម្នាក់ៗឲ្យចូលរួមអាចជួយពួកគេឲ្យទទួលបានអារម្មណ៍នូវក្តីស្រឡាញ់ និងការគោរពរបស់អ្នកចំពោះពួកគេ ។

យោបល់សម្រាប់ការបង្រៀន

ហេព្រើរ ៥

ប៉ុលបង្រៀនថា អស់អ្នកដែលទទួលបព្វជិតភាពត្រូវបានហៅមកពីព្រះ

ពីមុនថ្នាក់រៀន សូមសរសេរចំណងជើងនីមួយៗដូចខាងក្រោមនៅលើក្រដាសផ្សេងៗគ្នា ៖ *វេជ្ជបណ្ឌិត*និង*មន្ត្រីប្រតិបត្តិច្បាប់* ។ សូមអញ្ជើញសិស្សពីរនាក់ឲ្យមកខាងមុខភ្លាមៗ ហើយផ្តល់ក្រដាសមួយដល់សិស្សម្នាក់ៗ ។ បន្ទាប់មក សូមសួរសំណួរខាងក្រោមនេះ ៖

- **ទោះជាសិស្សទាំងនេះកាន់ក្រដាស ដែលបង្ហាញពីចំណងជើងត្រឹមត្រូវក្តី តើអ្នកនឹងមានកង្វល់អ្វីខ្លះ បើ [ប្រើឈ្មោះរបស់សិស្សដែលកាន់ក្រដាស « វេជ្ជបណ្ឌិត »] ចង់ធ្វើការវះកាត់ឲ្យអ្នក បន្ទាប់ពីអ្នកមានឧប្បទ្ទវហេតុ ?**
- **តើអ្នកនឹងឆ្លើយតបយ៉ាងដូចម្តេច ប្រសិនបើ [ប្រើឈ្មោះរបស់សិស្សដែលកាន់ក្រដាស « មន្ត្រីប្រតិបត្តិច្បាប់ »] ព្យាយាមដើម្បីផ្តល់ការជាក់ពិនិយដល់អ្នក?**
- **ហេតុអ្វីអ្នកមានការស្ទាក់ស្ទើរក្នុងការអនុញ្ញាតឲ្យសិស្សទាំងនេះធ្វើកិច្ចការ ដែលមានទាក់ទងនឹងប្រធានបទដែលពួកគេមាននោះ ? (សិស្សទាំងនេះខ្វះសិទ្ធិអំណាច និងសមត្ថភាពដើម្បីធ្វើកិច្ចការទាំងនេះ) ។**

សូមពន្យល់ថា ដូចជាសង្គមដែលបានបង្កើតជាលក្ខណៈសម្បត្តិចាំបាច់ និងរបៀបជាច្រើនដើម្បីទទួលបានសិទ្ធិអំណាចដើម្បីអនុវត្តន៍នូវការទទួលខុសត្រូវជាក់លាក់ដែរ នោះព្រះបានបង្កើតលក្ខណៈសម្បត្តិចាំបាច់នានា (ដូចជាភាពស្មោះត្រង់ និង ភាពសក្តិសម) និងវិធីនានាដើម្បីទទួលបានសិទ្ធិអំណាចដើម្បីអនុវត្តការទទួលខុសត្រូវជាក់លាក់នៅក្នុងសាសនាចក្ររបស់ទ្រង់ ។ នៅពេលសិស្សសិក្សាហេព្រើរ ៥ សូមអញ្ជើញពួកគេឲ្យរកមើលលំនាំដែលព្រះបានបង្កើតឡើង ដើម្បីទទួលបានសិទ្ធិអំណាចនេះ ។

សូមរំឭកសិស្ស ដូចបានកត់ត្រានៅក្នុងហេព្រើរ ៤:១៤–១៦ ប៉ុលបានពិពណ៌នាថា ព្រះអង្គសង្គ្រោះជា « សម្តេចសង្ឃយ៉ាងធំ១អង្គ » (ខទី ១៤) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៥:១–៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើប៉ុលបានបង្រៀនអ្វីខ្លះ អំពីតួនាទីរបស់សម្តេចសង្ឃនៅក្នុងសាសន៍អ៊ីស្រាអែល ។

- **តើតួនាទីរបស់សម្តេចសង្ឃនៅក្នុងចំណោមពួកសាសន៍អ៊ីស្រាអែលមានអ្វីខ្លះ ?**

សូមពន្យល់ថា តំណែងសម្តេចសង្ឃនៅក្នុងខគម្ពីរទាំងនេះ គឺជាតំណែងជាអធិបតីនៅក្នុងបព្វជិតភាពអើរ៉ុន ស្ថិតនៅក្រោមក្រឹត្យវិន័យម៉ូសេ ។ អើរ៉ុនដែលជាប្អូនប្រុសរបស់ម៉ូសេ គឺជា « សង្ឃជាន់ខ្ពស់ដំបូងគេនៃលំដាប់បព្វជិតភាពអើរ៉ុន » ។ តំណែងនេះត្រូវបានផ្តល់ឲ្យជាតំណពូជ បន្ទាប់ពីជំនាន់របស់អើរ៉ុន សង្ឃជាន់ខ្ពស់ត្រូវបានជ្រើសរើសនៅក្នុងចំណោមកូនច្បងក្នុងពូជពង្សរបស់អើរ៉ុន និងកូនប្រុសរបស់គាត់ ។ ជាទូទៅ សង្ឃជាន់ខ្ពស់បម្រើពេញមួយជីវិតរបស់ខ្លួន ប៉ុន្តែទីបំផុតតំណែងនេះត្រូវបានរឹបអូសយកដោយពួកទុច្ចរិត ។ « សង្ឃជាន់ខ្ពស់ត្រូវបានតែងតាំង និង ដកចេញដោយមិនត្រឹមត្រូវទៅតាមព្រះទ័យរបស់ស្តេចហេរ៉ូឌ និង ពួករ៉ូម ។ តំណែងនេះត្រូវបានដាក់បំពេញដោយបុរសចំនួន ២៨ រូបនៅចន្លោះឆ្នាំ ៣៧ មុន គ. ស. និង គ. ស. ៦៨ » (Bible Dictionary « High priest ») ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៥:៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើសង្ឃជាន់ខ្ពស់ត្រូវបានជ្រើសរើសតាមរបៀបណា ។

- **តើសង្ឃជាន់ខ្ពស់ត្រូវបានជ្រើសរើសតាមរបៀបណា ?**

ដើម្បីជួយសិស្សយល់អំពីរបៀបដែលអើរ៉ុនត្រូវបាន « ព្រះទ្រង់ហៅ » (ខទី ៤) សូមអញ្ជើញសិស្សឲ្យអាននិក្ខមនំ ២៨:១ឮៗ ។ ពីមុនសិស្សអានខគម្ពីរនេះ សូមពន្យល់ថា ការប្រាស្រ័យទាក់ទងនេះបានកើតមានឡើងរវាងព្រះ និងម៉ូសេនៅលើភ្នំស៊ីណាយ ។

- **តើអើរ៉ុនដែលព្រះទ្រង់ហៅ ត្រូវបានតែងតាំងបព្វជិតភាពយ៉ាងដូចម្តេច ?**
- **ហេតុអ្វីវាសំខាន់ថា ព្រះប្រទានការណែនាំនេះដល់ម៉ូសេជាជាងដល់អ្នកផ្សេងទៀត ? (ម៉ូសេគឺជាព្យាការី ហេតុដូច្នោះហើយ លោកមានសិទ្ធិអំណាចដើម្បីទទួលវិវរណៈបែបនោះ ហើយគ្រប់គ្រងការប្រើប្រាស់បព្វជិតភាពនៅលើផែនដី) ។**
- **តើអ្វីត្រូវកើតឡើងដើម្បីឲ្យមនុស្សម្នាក់បានទទួលការតែងតាំងបព្វជិតភាព ? (សិស្សអាចនឹងប្រើពាក្យសម្តីផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចខាងក្រោម ៖ *អស់អ្នកដែលត្រូវបានតែងតាំងនូវបព្វជិតភាពត្រូវតែបានហៅពីព្រះ តាមរយៈវិវរណៈដោយអ្នកបម្រើដែលមានសិទ្ធិអំណាចរបស់ទ្រង់* ។ អ្នកអាចនឹងចង់ពន្យល់ថា នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ អ្នក**

ដឹកនាំបព្វជិតភាពដែលមានសិទ្ធិអំណាចត្រូវសម្អាតបុគ្គលម្នាក់ៗសម្រាប់ការតែងតាំង ហើយស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីកំណត់ថាតើបុគ្គលនោះបានត្រៀមខ្លួនជាស្រេច និង មានភាពសក្តិសមដែរឬយ៉ាងណា ដើម្បីទទួលបានការតែងតាំងបព្វជិតភាព ។ សូមមើលផងដែរ យ៉ូហាន ១៥:១៦) ។

- តើសេចក្តីពិតនេះទាក់ទងនឹងដំណើរការនៃការហៅមនុស្សឲ្យបម្រើនៅក្នុងតំណែងនានាក្នុងសាសនាចក្រយ៉ាងដូចម្តេច ?

សូមឲ្យសិស្សអានមាត្រានៃសេចក្តីជំនឿទីប្រាំឲ្យឮៗ ៖ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើសេចក្តីពិតដែលពួកគេបានប្រាប់នៅក្នុងហេព្រើរ ៥:៤ឆ្លុះបញ្ចាំងនៅក្នុងមាត្រានៃសេចក្តីជំនឿទីប្រាំយ៉ាងដូចម្តេច ។ ចូរពន្យល់ថា *ការព្យាការ* សំដៅលើវិវរណៈ ។

- យោងតាមមាត្រានៃសេចក្តីជំនឿនេះ តើមានអ្វីផ្សេងទៀតដែលត្រូវកើតមានឡើង ដើម្បីឲ្យនរណាម្នាក់ដែលមានសិទ្ធិ « ដើម្បីផ្សាយដំណឹងល្អ និងបម្រើនៅក្នុងពិធីបរិសុទ្ធនានា » ?



សូមដាក់បង្ហាញរូបភាព ម៉ូសេផ្តល់បព្វជិតភាពដល់អើរ៉ុន (*Gospel Art Book* ⁄ ឆ្នាំ ២០០៩ ⁄ ល.រ. ១៥, សូមមើលផងដែរ LDS.org) ។ សូមចង្អុលបង្ហាញថា ទាំងក្នុងព្រះគម្ពីរសញ្ញាចាស់ និងគម្ពីរសញ្ញាថ្មីកត់ត្រាថា ព្យាការី អ្នកកាន់បព្វជិតភាព និងគ្រូបង្រៀនដំណឹងល្អទាំងឡាយទទួលការហៅរបស់ពួកគេ តាមរយៈការដាក់ដៃលើដោយអ្នកកាន់បព្វជិតភាពដែលមានសិទ្ធិអំណាច (សូមមើល ជនគណនា ២៧:១៨–២៣, កិច្ចការ ៦:៦, ១៣:២–៣, ធីម៉ូថេទី ១ ៤:១៤) ។

- តើដំណើរការនៃការហៅមនុស្សឲ្យបម្រើក្នុងតំណែងនានានៅក្នុងសាសនាចក្រសព្វថ្ងៃនេះ ឆ្លុះបញ្ចាំងពីលំនាំដែលបានបង្កើតឡើងនៅក្នុងព្រះគម្ពីរដោយរបៀបណា ?
- ហេតុអ្វីវាសំខាន់ដើម្បីដឹងថា សិទ្ធិអំណាចបព្វជិតភាពអាចទទួលបានតែតាមវិធីនេះប៉ុណ្ណោះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៥:៥–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថា នរណាដែលបានប្រទានព្រះអង្គសង្គ្រោះនូវសិទ្ធិអំណាចរបស់ទ្រង់ ។ សូមចង្អុលបង្ហាញថាខទី ៥ដកស្រង់នូវ ទំនុកដំកើង ២:៧ហើយថាខទី ៦ដកស្រង់ពីទំនុកដំកើង ១១០:៤។

- តើនរណាប្រទានដល់ព្រះអង្គសង្គ្រោះនូវសិទ្ធិអំណាចរបស់ទ្រង់ ? (ព្រះវរបិតាសួគ៌) ។
- តើព្រះយេស៊ូវគ្រីស្ទកាន់បព្វជិតភាពអ្វី ? (បព្វជិតភាពមិលគីស្សាដែក ។ សូមចង្អុលបង្ហាញថា បព្វជិតភាពនេះត្រូវបានដាក់ឈ្មោះពីដើមតាមព្រះអង្គសង្គ្រោះ ⁄ សូមមើលគ. និង ស. ១០៧:២–៤⁄) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៥:៧–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើព្រះយេស៊ូវគ្រីស្ទក្លាយទៅជាអ្វី ។ សូមពន្យល់ថា ហេព្រើរ៥:៧–៨ សំដៅលើមិលគីស្សាដែក ជាព្យាការី និង ស្តេចដែលបានរស់នៅជំនាន់អ័ប្រាហាំ ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែមិលគីស្សាដែកគឺជាគំរូមួយ តាមគំរូរបស់ព្រះគ្រីស្ទ នោះខគម្ពីរទាំងនេះក៏រៀបរាប់អំពី ព្រះអង្គសង្គ្រោះផងដែរ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Doctrinal New Testament Commentary,* វ៉ុលទី ៣ ⁄ ឆ្នាំ១៩៦៥–៧៣ ⁄ ៣:១៥៧) ។

- យោងតាម ហេព្រើរ ៥:៩ តើព្រះអង្គសង្គ្រោះក្លាយទៅជាអ្វី ?
- តើព្រះយេស៊ូវគ្រីស្ទជា « មេបង្កើតនៃសេចក្តីសង្គ្រោះដ៏នៅអស់កល្បជានិច្ច » ចំពោះអស់អ្នកដែលគោរពទ្រង់យ៉ាងដូចម្តេច ?

សូមសង្កេប ហេព្រើរ ៥:១១–១៤ ដោយពន្យល់ថា ប៉ុលបានបង្ហាញអំពីបំណងប្រាថ្នា ដើម្បីបង្រៀនបន្ថែមទៀតអំពីប្រធានបទនេះ ប៉ុន្តែបានមានប្រសាសន៍ថា ប្រជាជនខ្លះនឹងយល់ដឹង និង ភាពចាស់ទុំខាងវិញ្ញាណ ដើម្បីយល់បន្ថែមពីការបង្រៀនដ៏អស្ចារ្យផ្សេងទៀត ។

ហេព្រើរ ៦

ពួកបរិសុទ្ធត្រូវបានលើកទឹកចិត្តឲ្យមានភាពឧស្សាហ៍ព្យាយាម មានសេចក្តីជំនឿ ការអត់ធ្មត់ និង សេចក្តីសង្ឃឹមក្នុងការទទួលបាននូវការសន្យារបស់ព្រះ

- តើឧទាហរណ៍អំពីពរជ័យទាំងឡាយ ដែលព្រះបានសន្យាចំពោះកូនចៅរបស់ទ្រង់មានអ្វីខ្លះ ? (ចម្លើយដែលអាចមានរួមមានសេចក្តីសុខសាន្ត សុភមង្គល ការអភ័យទោស ចម្លើយចំពោះការអធិស្ឋាន ពរជ័យនានាដែលមាននៅក្នុងពរជ័យនៃលោកអយ្យកោ ការរស់ឡើងវិញ និងជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមចង្អុលបង្ហាញថា ពរជ័យមួយចំនួនគឺមានលក្ខខណ្ឌតាមការជ្រើសរើសរបស់យើង) ។
- តើមានឧទាហរណ៍អំពីស្ថានភាពអ្វីខ្លះ ដែលយើងអាចនឹងងឿងឆ្ងល់ថា តើយើងនឹងទទួលបានពរជ័យដែលបានសន្យាជាក់លាក់ឬយ៉ាងណា ?

ចូរសុំឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ឬនៅលើសន្លឹកក្រដាសមួយអំពីពរជ័យដែលបានសន្យាមួយ ដែលពួកគេទន្ទឹងរង់ចាំទទួល ។ សូមអញ្ជើញពួកគេឲ្យស្វែងរកសេចក្តីពិតនៅក្នុងហេព្រើរ ៦ដែលអាចជួយពួកគេឲ្យទទួលបានពរជ័យនានាដែលព្រះបានសន្យា ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៦:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធឲ្យបន្តធ្វើអ្វីខ្លះ ។ សូមចង្អុលបង្ហាញថា ការបកប្រែ ដោយយ៉ូសែប ស៊្មីធ ហេព្រើរ ៦:១ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ថ្លែងថា « ដូច្នេះដោយវុឹបែរចេញពីគោលការណ៍ទាំងឡាយនៃគោលលទ្ធិរបស់ព្រះគ្រីស្ទ » (បន្ថែមអក្សរទ្រេត) ហើយថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ ហេព្រើរ ៦:៣(នៅក្នុងសេចក្តីបន្ថែមព្រះគម្ពីរប៊ីប) ថ្លែងថា « ហើយយើងរាល់គ្នានឹងជឿនទៅមុខទៅរកភាពល្អឥតខ្ចោះ បើសិនជាព្រះទ្រង់អនុញ្ញាតឲ្យ » ។

- យោងតាមខទី ១តើប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធឲ្យបន្តធ្វើអ្វីខ្លះ ? (ចូរពន្យល់ថា ភាពល្អឥតខ្ចោះសំដៅទៅលើស្ថានភាព « បានអភិវឌ្ឍពេញលេញ ពេញមូល ឬ ទាំងស្រុង ។ . . . ពួកអ្នកដើរតាមដ៏ពិតរបស់ព្រះគ្រីស្ទ អាចក្លាយទៅជាល្អឥតខ្ចោះបាន តាមរយៈព្រះគុណ និងដង្វាយធួនរបស់ទ្រង់ » [សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ល្អឥតខ្ចោះ » scriptures.lds.org]) ។
- តើគោលលទ្ធិអ្វីខ្លះ ដែលបានប្រាប់នៅក្នុងខគម្ពីរទាំងនេះ ដែលបង្កើតជាគ្រឹះដើម្បីយើងសង់នៅលើ នៅពេលយើងធ្វើការឆ្ពោះទៅកាន់ភាពល្អឥតខ្ចោះ ?

សូមសង្ខេបហេព្រើរ ៦:៤–៨ ដោយពន្យល់ថា ប៉ុលបានពិពណ៌នាអំពីអ្នកទាំងឡាយដែលជាកូនអន្តរធាន ដែលមានចំណេះដឹងដ៏ឥតខ្ចោះអំពីព្រះ តែបែរជាងាកចេញពីសេចក្តីពិតនេះ បះបោរទាស់នឹងព្រះអង្គសង្គ្រោះ ហើយបដិសេធពុំប្រែចិត្ត (សូមមើលគ. និង ស. ២៩:៤៤–៤៥,៧៦:៣១–៣៨) ។ ប៉ុលបានប្រាប់ពីភាពផ្ទុយគ្នានៃបុគ្គលទាំងនេះ ជាមួយនឹងពួកបរិសុទ្ធស្មោះត្រង់ ដែលលោកបានថ្លែងនៅក្នុងសំបុត្រនេះ ។

សូមអញ្ជើញសិស្សឲ្យអានហេព្រើរ ៦:៩–១០ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលប៉ុលបានសរសើរដល់ពួកបរិសុទ្ធនៅហេព្រើរ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សច្រើននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង ហេព្រើរ៦: ១១–១៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវអ្វីដែលប៉ុលប្រាថ្នាចង់បានពីពួកបរិសុទ្ធ ។

- តើប៉ុលប្រាថ្នាចង់បានអ្វីខ្លះពីពួកបរិសុទ្ធ ?

សូមពន្យល់ថា ឃ្លា « បានសម្តែងចេញជាចិត្តឧស្សាហ៍ដូចគ្នាទាំងអស់ ប្រយោជន៍ឲ្យបានសេចក្តីជំនឿដ៏ពេញលេញរបស់សេចក្តីសង្ឃឹម » (ខទី ១១) សំដៅលើការមានចិត្តឧស្សាហ៍រហូតដល់យើងទទួលបានពរជ័យរបស់ព្រះដែលបានសន្យា ។

- តើអ័ប្រាហាំគឺជាគំរូនៃការមានចិត្តឧស្សាហ៍ សេចក្តីជំនឿ និង ការអត់ធ្មត់នៅក្នុងការព្យាយាមស្វែងរកពរជ័យរបស់ព្រះដែលបានសន្យាយ៉ាងដូចម្តេច ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនអំពីកិច្ចការ ដែលយើងត្រូវធ្វើដើម្បីទទួលគ្រងពរជ័យទាំងឡាយដែលព្រះបានសន្យា ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែគួរតែប្រាប់នូវគោលការណ៍ដូចខាងក្រោម **៖តាមរយៈការឧស្សាហ៍រហូតដល់ទីបំផុត ការមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងការអត់ធ្មត់ នោះយើងអាចទទួលបានពរជ័យរបស់ព្រះដែលបានសន្យា ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។


សូមគូសបន្ទាត់ពីក្រោមពាក្យ*ឧស្សាហ៍ព្យាយាម សេចក្តីជំនឿ* និង*ការអត់ធ្មត់*នៅលើក្តារខៀន ។ ចូរសុំសិស្សឲ្យនិយមន័យនៃពាក្យទាំងនេះនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សមួយចំនួនឲ្យរៀបរាប់ពីអ្វី ដែលពួកគេបានសរសេរ ។

- តើវាអាចមានឧបសគ្គអ្វីខ្លះ ក្នុងការបង្ហាញនូវលក្ខណៈទាំងនេះ ?
- ហេតុអ្វីអ្នកគិតថា យើងត្រូវការនូវលក្ខណៈទាំងនេះដើម្បី « រឿនទៅមុខទៅរកភាពល្អឥតខ្ចោះ » ? (ហេព្រើរ ៦:១) ។
- តើនៅពេលណាដែលអ្នកបានទទួលពរជ័យដែលបានសន្យា តាមរយៈការមានភាពឧស្សាហ៍ព្យាយាម សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងការអត់ធ្មត់ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៦:១៦–២០ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលប៉ុលបានបង្រៀនអំពីសេចក្តីសង្ឃឹម និងការសន្យាទាំងឡាយរបស់ព្រះ ។ អ្នកអាចនឹងចាំបាច់ត្រូវពន្យល់ថា *ដ៏មិនចេះប្រែប្រួល* (ខទី ១៨) មានន័យថាមិនផ្លាស់ប្តូរ ។

- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនមកពីការបង្រៀនរបស់ប៉ុលអំពីសេចក្តីសង្ឃឹម ? (សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេប្រាប់ពីសេចក្តីពិតដូចខាងក្រោម **៖សេចក្តីសង្ឃឹមរបស់យើងនៅក្នុងការសន្យារបស់ព្រះ គឺជាយុថ្កាខាងវិញ្ញាណសម្រាប់ព្រលឹងយើង ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ចូរពន្យល់ថា ដូចបានប្រើនៅក្នុងបទគម្ពីរ *សេចក្តីសង្ឃឹម*មានន័យថាជា « ការរំពឹងទុកដ៏មានទំនុកចិត្ត និងការទន្ទឹងរង់ចាំដល់ពរជ័យដែលបានសន្យានៃសេចក្តីសុចរិត » (សេចក្តីណែនាំដល់ព្រះគម្ពីរ « សេចក្តីសង្ឃឹម » scriptures.lds.org) ។



- ផ្អែកទៅលើការបង្រៀនរបស់ប៉ុលអំពីព្រះនៅក្នុងខទី ១៧–១៨ហេតុអ្វីក៏យើងអាចមានទំនុកចិត្តលើការសន្យាទាំងឡាយរបស់ព្រះ ?
- តើសេចក្តីសង្ឃឹមរបស់យើងទៅលើការសន្យារបស់ព្រះអាចជួយយើងឲ្យមានភាពឧស្សាហ៍ព្យាយាម ហើយអត់ធ្មត់ និងមានសេចក្តីជំនឿ ជាពិសេសនៅពេលយើងជួបនឹងការលំបាកយ៉ាងដូចម្តេច ?

ចូរអញ្ជើញសិស្សម្នាក់ឲ្យគូររូបយុថ្កា មួយនៅលើក្តារខៀន ។

- តើយុថ្កាធ្វើអ្វីសម្រាប់នាវាមួយ ?
- តើសេចក្តីសង្ឃឹមរបស់អ្នក នៅក្នុងការសន្យារបស់ព្រះបានក្លាយជាយុថ្កាខាងវិញ្ញាណសម្រាប់អ្នកយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយ ដើម្បីអភិវឌ្ឍភាពឧស្សាហ៍ព្យាយាម សេចក្តីជំនឿ ការអត់ធ្មត់ និងសេចក្តីសង្ឃឹមកាន់តែពេញលេញ ។ អ្នកអាចនឹងលើកទឹកចិត្តពួកគេឲ្យចាប់ផ្តើមសរសេរដែនការមួយ ដើម្បីអភិវឌ្ឍលក្ខណៈទាំងនេះមួយ រួចហើយផ្តោតទៅលើការអភិវឌ្ឍលក្ខណៈមួយទៀត ។ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។

មេរៀន ១៣៧

ហេព្រើរ ៧–១០

សេចក្តីផ្តើម

ប៉ុលបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកកណ្តាលនៃ « សេចក្តីសញ្ញាថ្មី » (ហេព្រើរ ៨:៨) ។ លោកបានពន្យល់ថា ពលិកម្មរបស់ព្រះគ្រីស្ទគឺជាឧត្តមភាពចំពោះយញ្ញបូជារបស់លោកម៉ូសេ ហើយថាពិធីបរិសុទ្ធរបស់លោកម៉ូសេ គឺចង់បង្ហាញដល់មនុស្សឲ្យងាកទៅរកព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន



ហេព្រើរ ៧–៨

ប៉ុលបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកកណ្តាលនៃសេចក្តីសញ្ញាថ្មី

ការប្រើភ្លើងពិលបង្កើតជាស្រមោលនៃវត្ថុតូចមួយ (ដូចជាកូនសោ ឬកន្ត្រែ) នៅលើក្តារខៀន ។ ចូរសួរដល់សិស្សបើពួកគេស្គាល់វត្ថុនោះ តាមរយៈការមើលឃើញតែស្រមោល ។ ចូរចង្អុលបង្ហាញថា ជាញឹកញាប់យើងអាចកំណត់ថាវត្ថុនោះជាអ្វី ដោយការមើលឃើញតែស្រមោល ។

ចូរបង្ហាញរូបភាពព្រះយេស៊ូវអធិស្ឋាននៅសួនច្បារគែតសេម៉ានី (*Gospel Art Book*, ឆ្នាំ ២០០៩ , លេខ ៥៦, សូមមើលផងដែរ LDS.org) ។ សូមពន្យល់ថា ព្រះគម្ពីរសញ្ញាចាស់កត់ត្រាអំពីពិធីការ និងពិធីបរិសុទ្ធនានាដែលដំណើរការដូចជាប្រភេទ និងស្រមោល ឬជានិមិត្តរូប និងជាប្រផ្នូលអំពីព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ។

- **តើឧទាហរណ៍អ្វីខ្លះដែលបានកត់ត្រានៅក្នុងព្រះគម្ពីរសញ្ញាចាស់អំពីលក្ខណៈគំរូ និងស្រមោលអំពីព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ?**

ចូរពន្យល់ថា គ្រប់ទិដ្ឋភាពនៃក្រឹត្យវិន័យរបស់ម៉ូសេ គឺមានចេតនាដំណើរការជាប្រភេទឬការបង្ហាញជាស្រមោលដែលចង្អុលប្រាប់ពួកអ៊ីស្រាអែលឲ្យទៅកាន់ព្រះយេស៊ូវគ្រីស្ទ និងការពលិកម្មធួនរបស់ទ្រង់ (សូមមើលនីហ្វៃទី២ ១១:៤, យ៉ាកុប ៤:៤–៥) ។ ប៉ុលបានពន្យល់ពីរបៀបដែលផ្នែកជាច្រើននៃក្រឹត្យវិន័យនេះបានសម្រេចនូវការណ៍នេះ ។ លោកចង់ជួយពួកបរិសុទ្ធសាសន៍យូដា ឲ្យបន្តនៅស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ជាជាងត្រឡប់ទៅធ្វើតាមក្រឹត្យវិន័យលោកម៉ូសេវិញ ។

សូមសង្ខេបហេព្រើរ ៧:១–២២ ដោយពន្យល់ថា ប៉ុលបាននិយាយពីការព្យាករនៅក្នុងព្រះគម្ពីរសញ្ញាចាស់ អំពីការយោងមកនៃសង្ឃម្នាក់ « តាមរបៀបលោកមិលគីស្សាដែក » (ទំនុកដំកើង ១១០:៤, សូមមើលផងដែរហេព្រើរ ៧:១) ។ លោកបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទបានបំពេញតាមការព្យាករនេះ ។ មិលគីស្សាដែកគឺជាស្តេចសុចរិត ហើយជាសង្ឃជាន់ខ្ពស់ ដែលធ្វើជាអធិបតីលើអ័ប្រាហាំ (សូមមើលការបកប្រែដោយយ៉ូសែប ស្ម៊ីធ លោកុប្បត្តិ ១៤:២៥–៤០ ; នៅក្នុង the Bible appendix); អាលម៉ា ១៣:១៤–១៩; Bible Dictionary « Melchizedek ») ។ ប៉ុលបានប្រើមិលគីស្សាដែកជាប្រភេទ និងស្រមោលរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទ និងបព្វជិភាពរបស់ទ្រង់ គឺចាំបាច់ណាស់ ដោយសារបព្វជិតភាពពួកលេវី ព្រមជាមួយនឹងក្រឹត្យវិន័យរបស់ម៉ូសេដែលវាបានធ្វើការបម្រើនោះ ពុំអាចធ្វើឲ្យកូនចៅរបស់ព្រះល្អឥតខ្ចោះនោះទេ (សូមមើលហេព្រើរ ៧:១១) ។ អ្នកអាចនឹងចង់ពន្យល់ថា បព្វជិតភាពរបស់លេវីសំដៅទៅលើសិទ្ធិអំណាចនៃបព្វជិតភាពអើរ៉ុន ដែលកាន់ដោយសមាជិកនៃអំបូររបស់លេវី (សូមមើល Bible Dictionary, « Aaronic Priesthood »)


សូមបង្ហាញរូបភាព ម៉ូសេផ្តល់បព្វជិតភាពដល់អើរ៉ុន (*Gospel Art Book,* លេខ ១៥; សូមមើលផងដែរ LDS.org) ស្របនឹងរូបភាព ព្រះយេស៊ូវកំពុងអធិស្ឋាននៅក្នុងសួនច្បារគែតសេម៉ានី ។ សូមពន្យល់ថា ដូចបានកត់ត្រានៅក្នុងហេព្រើរ ៧ប៉ុលបានប្រៀបធៀបសង្ឃលេវីទៅនឹងព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចពន្យល់ថា តួនាទីមួយរបស់សង្ឃលេវី គឺត្រូវធ្វើជាអ្នកកណ្តាល ឈរជានិមិត្តរូបរវាងមនុស្ស និងព្រះដើម្បីដោះស្រាយភាពខុសគ្នា ។

ចូរសរសេរ*ហេព្រើរ ៧:២៣–២៨* នៅលើក្តារខៀន ។ សូមបំបែកសិស្សជាគូ ហើយអញ្ជើញឲ្យដៃគូនីមួយៗអានខទាំងនេះឮៗជាមួយគ្នា ។ ចូរសុំឲ្យពួកគេអានការបកប្រែដោយ យ៉ូសែប ស្ម៊ីធ ហេព្រើរ ៧:២៥–២៦ ផងដែរ ។ បទគម្ពីរនេះមាននៅក្នុងសេចក្តីបន្ថែមព្រះគម្ពីរបឺប ។ សូមអញ្ជើញសិស្សម្នាក់ក្នុងដៃគូនីមួយៗឲ្យរកមើលឃ្លាដែលពិពណ៌នាអំពីពួកសង្ឃលេវី ហើយសុំឲ្យសិស្សដទៃទៀតពីដៃគូនោះរកមើលឃ្លាដែលពិពណ៌នាអំពីព្រះយេស៊ូវគ្រីស្ទ ។ ចូរពន្យល់ថា ពាក្យ*រគ*នៅក្នុងហេព្រើរ ៧:២៣សំដៅទៅលើពួកសង្ឃ ។

ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យរកមើលឃ្លាដែលពិពណ៌នាអំពីពួកសង្ឃ ហើយប្រាប់អំពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀននៅក្រោមរូបភាពរបស់ម៉ូសេ និងអើរ៉ុន ។ (ចម្លើយរបស់ពួកគេអាចរួមមានដូចខាងក្រោម ៖ ពួកសង្ឃចាំបាច់ត្រូវជំនួសដោយពួកសង្ឃដទៃទៀត នៅពេលពួកគេស្លាប់ [សូមមើលហេព្រើរ ៧:២៣] ពួកគេថ្វាយយញ្ញបូជាប្រចាំថ្ងៃសម្រាប់អំពើបាបផ្ទាល់ខ្លួន និងអំពើបាបរបស់មនុស្សដទៃ [សូមមើលហេព្រើរ ៧:២៧] ហើយពួកសង្ឃមានសេចក្តីកំសោយ [សូមមើលហេព្រើរ ៧:២៨] ។

សូមជួយសិស្សឲ្យយល់អំពីនិមិត្តរូបខាងបទគម្ពីរ

« ព្រះគម្ពីរមានពោរពេញទៅដោយនិមិត្តសញ្ញា និងការបង្ហាញជាលក្ខណៈរូបភាព ។ ពិធីបុណ្យ និងពិធីបរិសុទ្ធគឺជានិមិត្តសញ្ញានៅក្នុងការធ្វើពិធីទាំងនោះ ហើយពិធីទាំងអស់នោះធ្វើបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ . . . ពិធីបុណ្យនៅរោងឧបោសថ គឺជានិមិត្តសញ្ញានៃអ្វីៗដ៏អស់កល្បជានិច្ច (ហេព្រើរ ៨–១០) ដូចជាក្រឹត្យវិន័យលោកម៉ូសេទាំងស្រុងដែរ ដោយមាននូវគំរូ និង ស្រមោលអំពីព្រះគ្រីស្ទ » (Bible Dictionary « Symbolism ») ។ នៅពេលអ្នកជួយសិស្សឲ្យយល់ពីប្រភេទ និងស្រមោលទាំងនេះ នោះការយល់ដឹង និងការស្រឡាញ់របស់ពួកគេចំពោះដំណឹងល្អនឹងមានកាន់តែភាពជ្រាលជ្រៅ ។



សូមអញ្ជើញសិស្សដែលរកមើលឃ្លា ដែលពិពណ៌នាអំពីព្រះយេស៊ូវគ្រីស្ទឡើងវិញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀននៅក្រោមរូបភាពរបស់ព្រះយេស៊ូវគ្រីស្ទ ។ (ចម្លើយរបស់ពួកគេគួរតែមានន័យសេចក្តីថ្លែងការណ៍ដូចខាងក្រោម ៖ ព្រះយេស៊ូវគ្រីស្ទ និងបព្វជិតភាពរបស់ទ្រង់ គឺ « ឥតផ្លេរឡើយ » ឬនៅជាប់អស់កល្បជានិច្ច [ហេព្រើរ ៧:២៤] ទ្រង់អាចសង្គ្រោះអ្នកទាំងឡាយដែល « ចូលទៅឯព្រះដោយសារទ្រង់ » [ហេព្រើរ ៧:២៤] ទ្រង់មានព្រះជន្មរស់ដើម្បី « ជួយអង្វរជំនួស [យើង] » [ហេព្រើរ ៧:២៥] ទ្រង់គ្មានអំពើបាប ដូច្នេះហើយ « មិនចាំបាច់នឹងថ្វាយយញ្ញបូជាដោយព្រោះបាបរបស់ទ្រង់នោះទេ » [ហេព្រើរ ៧:២៦] ទ្រង់ចាំបាច់ត្រូវថ្វាយយញ្ញបូជាតែមួយគត់ គឺ « ដោយព្រោះបាបរបស់ជនទាំងឡាយវិញ » [ហេព្រើរ ៧:២៦] ហើយទ្រង់ « បានគ្រប់លក្ខណ៍នៅអស់កល្បជានិច្ច » [ហេព្រើរ ៧:២៨]) ។

ចូរពន្យល់ថា ឃ្លា « ទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរជំនួសគេ » (ហេព្រើរ ៧:២៥) មានន័យថា បេសកកម្មរបស់ព្រះអង្គសង្គ្រោះគឺធ្វើអន្តរាគមន៍ជំនួសយើង ដើម្បីជួយយើងឲ្យត្រឡប់ទៅកាន់ព្រះវិញ ។

- តើអ្នកនឹងពន្យល់អំពីភាពខុសគ្នារវាងព្រះយេស៊ូវគ្រីស្ទ និង ពួកសង្ឃលេវីយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ៨:១–៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអ្វីដែលសង្ឃជាន់ខ្ពស់ទាំងអស់ រួមទាំងព្រះយេស៊ូវគ្រីស្ទត្រូវបានតែងតាំង ឬបានហៅឲ្យធ្វើ ។

- តើសង្ឃជាន់ខ្ពស់ត្រូវបានតែងតាំងឲ្យធ្វើអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស៊្មីធ ហេព្រើរ ៨:៤ ( ) ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលពលិកម្មដែលព្រះយេស៊ូវគ្រីស្ទបានថ្វាយ ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ មកពីខគម្ពីរនេះ អំពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់យើង ? (សិស្សគួរប្រាប់អំពីសេចក្តីពិតដូចខាងក្រោមនេះ ដោយប្រើពាក្យសម្តីរបស់ពួកគេផ្ទាល់ ៖ **ព្រះយេស៊ូ វគ្រីស្ទបានថ្វាយព្រះជន្មរបស់ទ្រង់ផ្ទាល់ជាពលិកម្មមួយដើម្បីអំពើបាបរបស់យើង**) ។
- តើឃ្លាអ្វីខ្លះដែលបានរៀបរាប់នៅលើក្តារខៀន ជួយយើងឲ្យយល់ពីមូលហេតុដែលព្រះយេស៊ូវគ្រីស្ទអាចថ្វាយព្រះជន្មទ្រង់ផ្ទាល់ ជាពលិកម្មមួយសម្រាប់អំពើបាបរបស់យើង ?

សូមអញ្ជើញសិស្សឲ្យពិចារណាថា តើពលិកម្មជួនរបស់ព្រះយេស៊ូវគ្រីស្ទមានន័យយ៉ាងដូចម្តេចចំពោះពួកគេ ។ ចូរសុំឲ្យសិស្សបំពេញសេចក្តីថ្លែងការណ៍មួយដូចខាងក្រោមនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់របស់ពួកគេ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖


១. ខ្ញុំមានអំណរគុណចំពោះព្រះអង្គសង្គ្រោះ ដោយសារ . . .

២. ខ្ញុំដឹងថា ព្រះអង្គសង្គ្រោះស្រឡាញ់ខ្ញុំ ដោយសារ . . .

៣. ខ្ញុំត្រូវបានប្រទានពរដោយដង្វាយធួន ដោយសារ. . .

ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយនូវអ្វីដែលពួកគេបានសរសេរ ប្រសិនបើពួកគេមានអារម្មណ៍ថាវាមិនឯកជនខ្លាំងពេក ។

សូមសង្ខេបហេព្រើរ ៨:៥–១៣ ដោយពន្យល់ថា ពីព្រោះតែពលិកម្មរបស់ទ្រង់ នោះព្រះយេស៊ូវគ្រីស្ទបានក្លាយជា « ជាអ្នកកណ្តាលរបស់សេចក្តីសញ្ញា១ដ៏ប្រសើរជាង » (ខទី ៦) ជាសេចក្តីសញ្ញាមួយដែលនឹងជួយពួកគេឲ្យមក « ស្គាល់ព្រះអម្ចាស់ » ប្រសិនបើសេចក្តីសញ្ញានោះត្រូវបានប្រជាជនទទួលយក (ខទី ១១) ហើយត្រូវបានលាងសម្អាតពីអំពើទុច្ចរិតរបស់ពួកគេ ។



ហេព្រើរ ៩–១០

ប៉ុលបានបង្ហាញពីរបៀបដែលពិធីបរិសុទ្ធរបស់លោកម៉ូសេចង្អុលទៅរកដង្វាយធួន

មុនចាប់ផ្តើមថ្នាក់ សូមគូរ ឌីយ៉ាក្រាម ខាងក្រោមនៅលើក្តារខៀន ។

សូមពន្យល់ថា ដូចបានកត់ត្រានៅក្នុង ហេព្រើរ ៩–១០ ប៉ុលបានបន្តប្រៀបធៀបសង្ឃជាន់ខ្ពស់លេវីទៅនឹងព្រះយេស៊ូវគ្រីស្ទ ដោយបានពិភាក្សាពីកាតព្វកិច្ចដែលពួកសង្ឃទាំងនោះបានធ្វើនៅថ្ងៃនៃដង្វាយធួន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានកថាខណ្ឌដូចខាងក្រោមឲ្យឮៗ ៖

មួយឆ្នាំម្តងនៅក្នុងថ្ងៃបរិសុទ្ធរបស់សាសន៍យូដា ដែលហៅថាជាថ្ងៃនៃដង្វាយធួន (គេក៏ហៅថា យ៉ុម គីផ្លួរ ផងដែរ) សង្ឃជាន់ខ្ពស់ត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងទីដ៏បរិសុទ្ធបំផុត (គេក៏ហៅថា បរិសុទ្ធលើទីបរិសុទ្ធ ឬ ទីដ៏បរិសុទ្ធបំផុត) នៅក្នុងរោងឧបោសថ ឬ ក្រោយមកជាព្រះវិហារបរិសុទ្ធយេរូសាឡិម ។ នៅទីនោះ ពួកសង្ឃជាន់ខ្ពស់ថ្វាយយញ្ញបូជាគោឈ្មោល និងពពែឈ្មោល ។ គាត់នឹងប្រោះឈាមសត្វនៅកន្លែងដែលបានរៀបចំនៅក្នុងកន្លែងដែលបរិសុទ្ធបំផុត ជានិមិត្តរូបនៃដង្វាយធួនរបស់ព្រះគ្រីស្ទសម្រាប់អំពើបាបរបស់ពួកសង្ឃ និងអំពើបាបរបស់មនុស្ស ។ ក្រោយមកសង្ឃជាន់ខ្ពស់ធ្វើនិមិត្តរូបនៃការផ្ទេរអំពើបាបរបស់មនុស្សបានផ្ទេរទៅសត្វពពែឈ្មោលមួយទៀត (ដែលហៅថាពពែរងកំហុស) បន្ទាប់មកបណ្តេញវាចេញឲ្យទៅក្នុងទីរហោស្ថាន ជានិមិត្តរូបនៃការដកចេញនូវអំពើបាបរបស់ប្រជាជន ។ គាត់ក៏ធ្វើយញ្ញបូជាសត្វចៀមឈ្មោលពីរក្បាលជាដង្វាយដុតសម្រាប់ខ្លួនគាត់ និងមនុស្សផងដែរ ។ (សូមមើល Bible Dictionary, « Fasts »; សូមមើលផងដែរ លេវីវិន័យ ១៦:២២) ។

សូមចាត់សិស្សពាក់កណ្តាលឲ្យអានហេព្រើរ ៩:១១, ១២, ២៤, ២៨ហើយសិស្សពាក់កណ្តាលទៀតអានហេព្រើរ ១០:១, ៤, ១០–១២ ។ ចូរសុំឲ្យក្រុមនីមួយៗអានខគម្ពីរដែលបានចាត់ឲ្យពួកគេដោយស្ងាត់ស្ងៀម ហើយរកមើលពីរបៀបដែលព្រឹត្តិការណ៍ទាំងឡាយនៅថ្ងៃនៃដង្វាយធួនគឺជាប្រភេទ និងស្រមោលនៃពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ។ ក្រោយពីទុកពេលឲ្យគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សមកពីក្រុមនីមួយៗប្រាប់ថា តើពួកគេរកឃើញអ្វីខ្លះ ។ បន្ទាប់មកសួរសួរ ៖

- ក៏ដូចជាពួកសង្ឃជាន់ខ្ពស់បានចូលទៅក្នុងទីដ៏បរិសុទ្ធបំផុតនៃរោងឧបោសថនៅថ្ងៃនៃដង្វាយធួនផងដែរ តើ « ទីបរិសុទ្ធ » អ្វី (ហេព្រើរ ៩:១២) ដែលព្រះអង្គសង្គ្រោះអាចចូលដោយសារតែដង្វាយធួនរបស់ទ្រង់ ? (វត្តមានរបស់ព្រះវរបិតាសួគ៌ ឬសិរីល្អសេឡេស្ទាល) ។
- តើការបូជារបស់ព្រះយេស៊ូវគ្រីស្ទអាចធ្វើកិច្ចការអ្វីខ្លះ ដែល « ឈាមគោឈ្មោល និងពពែឈ្មោល » (ហេព្រើរ ១០:៤) ពុំអាចធ្វើបាន ?
- បន្ទាប់មក ហេតុអ្វីបានជាសង្ឃជាន់ខ្ពស់ធ្វើយញ្ញបូជាទាំងនេះនៅថ្ងៃនៃដង្វាយធួន ? (ដើម្បីបង្ហាញ « ស្រមោលពីសេចក្តីល្អដែលត្រូវមក » [ហេព្រើរ ១០:១] ឬដើម្បីចង្អុលបង្ហាញទៅកាន់ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១០:១៧–២០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលថា តើដង្វាយធួនធ្វើឲ្យមានអ្វីខ្លះកើតឡើងបាន ។

- យោងតាមខទី ១៩ តើយើងអាចចូលទៅកន្លែងណា ដោយសារតែពលិកម្មរបស់ព្រះយេស៊ូវ ? (កន្លែង « បរិសុទ្ធបំផុត » ឬវត្តមានរបស់ព្រះនៅក្នុងនគរសេឡេស្ទាល) ។
- យោងតាមខទី ២០តើយើងចូលទៅក្នុងវត្តមានរបស់ព្រះយ៉ាងដូចម្តេច ?

ចូរពន្យល់ថាឃ្លា « ជាផ្លូវថ្មី ហើយរស់ » សំដៅទៅលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ឬផែនការដែលយើងអាចត្រូវបានអភ័យទោស ហើយញែកចេញជាបរិសុទ្ធតាមរយៈដង្វាយធួនរបស់ទ្រង់ ហើយតាមរយៈដង្វាយធួននោះ យើងនឹងមានភាពសក្តិសមដើម្បីត្រឡប់ទៅកាន់វត្តមានរបស់ព្រះវិញ ។

សូមសរសេរសេចក្តីថ្លែងការណ៍មិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖*ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចចូលទៅក្នុងនគរសេឡេស្ទាលបាន ប្រសិនបើ. . .*

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១០:២២–២៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យើងត្រូវធ្វើអ្វីខ្លះ ដើម្បីចូលទៅនគរសេឡេស្ទាលបាន ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ដើម្បីអានដូចតទៅ ៖**ដោយសារដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចចូលទៅក្នុងនគរសេឡេស្ទាលបាន ប្រសិនបើយើងកាន់ខ្ជាប់ទៅនឹងសេចក្តីជំនឿរបស់យើងទៅលើទ្រង់ ។**

- តើអ្នកគិតថា « កាន់ខ្ជាប់ » មានន័យដូចម្តេច (ខទី ២៣) ចំពោះសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១០:៣៥–៣៨ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលការប្រឹក្សារបស់ប៉ុលដែលអាចជួយយើងឲ្យកាន់ខ្ជាប់ចំពោះសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ។

- តើយើងអាចធ្វើអ្វីខ្លះដើម្បីកាន់ខ្ជាប់ចំពោះសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ?
- តើអ្នកគិតថា « កុំឲ្យបោះបង់ចោល . . . សេចក្តីក្លាហានរបស់អ្នករាល់គ្នា » មានន័យដូចម្តេច ? (ខទី៣៥) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ដៃវ្រ៊ី អ័រ ហូឡិន ក្នុងក្លឹមនៃពួកសាវកដប់ពីរនាក់ ដែលលោកបានពន្យល់អំពីអត្ថន័យនៃ « កុំឲ្យបោះបង់ចោលសេចក្តីក្លាហាន [របស់យើង] » ៖



« នៅក្នុងការនិយាយរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយគឺថា ប្រាកដណាស់វាមានការលំបាក—ពីមុនអ្នកចូលរួមក្នុងសាសនាចក្រ ខណៈដែលអ្នកកំពុងព្យាយាមចូលរួម និងបន្ទាប់ពីអ្នកបានចូលរួម ។ ប៉ុលបាននិយាយថា នេះជារបៀបដែលវាតែងតែកើតឡើង ប៉ុន្តែចូរកុំរុញរាធ្វើតាមវាឡើយ ។ ចូរកុំភិតភ័យ និងដកខ្លួនចេញ ។ ចូរកុំបោះបង់សេចក្តីក្លាហានរបស់អ្នក ។ ចូរកុំតួចពីអារម្មណ៍ដ៏អស្ចារ្យមួយដែលអ្នកធ្លាប់មាន ។ ចូរកុំខ្វល់ពីបទពិសោធន៍ដែលអ្នកធ្លាប់មានឡើយ ។ ការតស៊ូស្ងិតស្ងាញនោះ គឺជាឧបករណ៍មួយដែលបានជួយសង្គ្រោះម៉ូសេ និង យ៉ូសែប ស្ម៊ីធ នៅពេលមានសត្រូវបានប្រឈមមុខជាមួយពួកលោក ហើយវាក៏ជាអ្វីដែលនឹងជួយសង្គ្រោះអ្នកផងដែរ » (« Cast Not Away Therefore Your Confidence » *Ensign* ខែ មិនា ឆ្នាំ ២០០០ ទំព័រ ៨) ។

- តើមាននរណាម្នាក់ដែលអ្នកស្គាល់ ដែលជាគំរូល្អនៃការកាន់ខ្ជាប់ទៅនឹងសេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទដែរឬទេ ?

សូមអញ្ជើញសិស្សឲ្យគិតធ្វើការតាំងចិត្តពួកគេកាន់ខ្ជាប់ ទៅនឹងជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។ ចូរសុំឲ្យពួកគេកត់ទុកនូវរបៀបដែលពួកគេនឹងបង្កើនការតាំងចិត្តរបស់ពួកគេ និងសមត្ថភាពរបស់ពួកគេដើម្បីធ្វើកិច្ចការនេះ ។

ហេព្រើរ ១១

សេចក្តីផ្តើម

ប៉ុលបានបង្រៀនដល់សមាជិកសាសនាចក្រអំពីសេចក្តីជំនឿ ។ លោកបានថ្លែងពីគំរូរបស់បុរស និង ស្ត្រីជំសុចរិតនានាមកពីព្រះគម្ពីរសញ្ញាចាស់ ដែលបានអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយបានធ្វើអព្ភូតហេតុ បានស៊ូទ្រាំនឹងការលំបាកនានា ហើយបានទទួលពរជ័យដ៏មហិមា ។

យោបល់សម្រាប់ការបង្រៀន

ហេព្រើរ ១១:១–៦

ប៉ុលបានបង្រៀនដល់សមាជិកសាសនាចក្រអំពីសេចក្តីជំនឿ

សូមអានដំណើររឿងដូចខាងក្រោមអំពី យុវនារីម្នាក់មកពីប្រទេសហ្វីលីពីន ។ សូមអញ្ជើញសិស្សឲ្យស្តាប់រកមើលរបៀប ដែលយុវនារីនោះបានអនុវត្តសេចក្តីជំនឿ ។

ជំនួសឲ្យការអានដំណើររឿងនោះ អ្នកអាចបង្ហាញវីដេអូ « Pure and Simple Faith » (៥:២២) ដែលដំណើររឿងដូចខាងក្រោមត្រូវបានកែសម្រួល ។ វីដេអូនេះមាននៅក្នុង LDS.org ។ សូមបញ្ឈប់វីដេអូ បន្ទាប់ពីយុវនារីនោះទទួលការបំផុសគំនិតឲ្យទិញអ្វីៗដែលនាងត្រូវការ (លេខកូដម៉ោង ២:៣៦) ។

យុវនារីម្នាក់មកពីប្រទេសហ្វីលីពីន បានពន្យល់ថា កាលពីរដូវក្តៅមួយឪពុករបស់នាងបានទៅធ្វើការនៅទីឆ្ងាយ ។ នៅពេលគាត់បានបើកប្រាក់ខែ នោះគាត់បានផ្ញើប្រាក់នោះទៅឲ្យគ្រួសារគាត់នៅផ្ទះ ។ នាថ្ងៃសៅរ៍មួយ គ្រួសារនោះបានចាយប្រាក់នោះអស់ នៅសល់តែពីរសន្លឹកប៉ុណ្ណោះ ដែលមួយសន្លឹកមានតម្លៃស្មើនឹងទឹកប្រាក់ ២០ ពេសូ ។ នៅពេលយុវនារីនោះបានមើលទៅបញ្ជីទំនិញដែលគ្រួសារនាងត្រូវការ នោះនាងបានដឹងថា ពួកគេនឹងគ្មានប្រាក់គ្រប់គ្រាន់ដើម្បីទិញទំនិញទាំងអស់នោះ ហើយបង់ថ្លៃធ្វើដំណើរដើម្បីដឹកគ្រួសាររបស់នាងទៅព្រះវិហារនៅថ្ងៃបន្ទាប់ឡើយ ។ នាងបានសួរម្តាយនាងថា នាងគួរធ្វើបែបណា ។ ម្តាយរបស់នាងបានប្រាប់ថា ឲ្យទៅទិញទំនិញទាំងនោះ ហើយថាព្រះនឹងប្រទានមធ្យោបាយសម្រាប់ថ្លៃធ្វើដំណើរ ។

យុវនារីនោះបានអធិស្ឋានថា នាងអាចទិញទំនិញតាមបញ្ជីនោះ ហើយនៅតែមានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃធ្វើដំណើរទៅព្រះវិហារនៅថ្ងៃបន្ទាប់ ។ ដំបូងនាងត្រូវទិញឆ្អឹង ដើម្បីឲ្យគ្រួសារនាងអាចមានឆ្អឹងចំអិនអាហារ ។ នាងមានការភ្ញាក់ផ្អើលនៅពេលនាងបានឃើញថា តម្លៃឆ្អឹងមួយបាវបានកើនឡើងទ្វេដងគឺពី ៥ ពេសូ ទៅជា ១០ ពេសូវិញ ។ ដោយដឹងថា គ្រួសាររបស់នាងត្រូវការឆ្អឹងដើម្បីយកទៅចម្អិនអាហារ នោះនាងបានទិញឆ្អឹងពីរបាវដែលមានតម្លៃស្មើនឹង ២០ ពេសូ ។ យុវនារីនេះបានអធិស្ឋានដោយស្មោះត្រង់ថែមទៀតថា គ្រួសារនាងនឹងនៅតែអាចទៅព្រះវិហារបាន ។ នៅពេលនាងបានអធិស្ឋាន នោះមានសំឡេងមួយបានខ្សឹបប្រាប់នាងថា ៖ « ចូរទៅ ហើយទិញទំនិញផ្សេងៗទៀតដែលអ្នកត្រូវការចុះ ។ វានឹងមិនអីទេ » ។ ដូច្នេះនាងបានបន្តទៅតាមផ្លូវរបស់នាងដោយមានតែ ២០ ពេសូប៉ុណ្ណោះ ។ (បានកែសម្រួលចេញមកពីវីដេអូ « Pure and Simple Faith » LDS.org) ។

- តើយុវនារីម្នាក់នេះបានអនុវត្តសេចក្តីជំនឿតាមវិធីណា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១១:១ និង ការបកប្រែដោយ យ៉ូសែប ស៊្មីធ ហេព្រើរ ១១:១ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលប៉ុលបានបង្រៀនអំពីសេចក្តីជំនឿ ។

- យោងតាម ខទី ១ តើជំនឿគឺជាអ្វី ? (សិស្សអាចប្រើពាក្យសម្តីផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចខាងក្រោម ៖**សេចក្តីជំនឿ គឺជាការរះអាងអំពីអ្វីៗដែលសង្ឃឹមចង់បាន ជាភស្តុតាងនៃអ្វីដែលមើលមិនឃើញ**) ។

សូមពន្យល់ថា អែលឌើរ ដេវីឌ អេ បែដណា ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់បានប្រើ ហេព្រើរ ១១:១ ព្រមទាំងធនធានផ្សេងៗទៀត (អាលម៉ា ៣២:២១; *Lectures on Faith*) ដើម្បីពន្យល់ពីធាតុគ្រឹះបីចាំបាច់នៃសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមរបស់អែលឌើរ បែដណា ឲ្យឮៗ ៖



« ការបង្រៀនទាំងនេះ គួសបញ្ជាក់នូវធាតុគ្រឹះបីនៃសេចក្តីជំនឿ ៖ (១) សេចក្តីជំនឿដូចជា *ការធានារះអាងមួយ* នៃអ្វីៗដែលសង្ឃឹមថាពិត (២) សេចក្តីជំនឿដូចជា *ភស្តុភាង* នៃអ្វីៗដែលមើលមិនឃើញ និង (៣) សេចក្តីជំនឿគឺជាគោលការណ៍នៃ *សកម្មភាព* នៅក្នុងគ្រប់ទម្រង់ទាំងអស់នៃបញ្ញា ។ ខ្ញុំសូមពិពណ៌នាពីធាតុនៃសេចក្តីជំនឿលើព្រះអង្គសង្គ្រោះទាំងបីនេះ ដែលប្រឈមមុខព្រមៗគ្នានឹងអនាគតដោយសម្លឹងមើលទៅអតីតកាល ហើយចាប់ផ្តើមសកម្មភាពនៅក្នុងពេលបច្ចុប្បន្ន » (« Seek Learning by Faith, » *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៦២) ។

សូមសរសេរដូចខាងក្រោមនៅលើក្តារខៀន ៖*ការរះអាង—ប្រឈមមុខនឹងអនាគត, ភស្តុតាង—មើលទៅអតីតកាល, សកម្មភាព—ផ្តួចផ្តើមសកម្មភាពក្នុងពេលបច្ចុប្បន្ន* ។ សូមពន្យល់ថា អែលឌើរ បែដណា បានបង្រៀនថា ធាតុទាំងបីនៃសេចក្តីជំនឿនេះ—មានការរះអាង ភស្តុតាង និងសកម្មភាព—ធ្វើការរួមគ្នា នៅពេលយើងប្រឈមមុខនឹងអនាគតកាល មើលទៅអតីតកាល ហើយធ្វើសកម្មភាពក្នុងពេលបច្ចុប្បន្ន ។

- តើការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ខុសពីការគ្រាន់តែជឿលើទ្រង់យ៉ាងដូចម្តេច ?
- តើដំណើររឿងរបស់យុវនារីហ្ស៊ីលីពីននោះបង្ហាញធាតុទាំងបីនៃសេចក្តីជំនឿដែលអែលឌើរ បែដណា បានពិពណ៌នាយ៉ាងដូចម្តេច ?
- តើអ្វីខ្លះអាចកើតមានឡើង នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១១:២–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលគំរូដែលប៉ុលបានប្រើ ដើម្បីបង្ហាញអំពីអ្វី ដែលអាចកើតមានឡើង នៅពេលមនុស្សអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។

- តើមានអ្វីខ្លះកើតមានឡើង នៅពេលមនុស្សទាំងនេះអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សឲ្យអាន ហេព្រើរ ១១:៦ ដោយស្ងាត់ស្ងៀម ហើយរកមើលនូវអ្វីដែលប៉ុលបានបង្រៀនអំពីសេចក្តីជំនឿ ។

- តើប៉ុលបានបង្រៀនអ្វីខ្លះអំពីសេចក្តីជំនឿ ?
- ផ្អែកទៅលើអ្វីដែលប៉ុលបានបង្រៀន តើយើងត្រូវធ្វើអ្វីខ្លះដើម្បីផ្គាប់ព្រះទ័យព្រះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា វាច្បាស់លាស់ថា **ដើម្បីផ្គាប់ព្រះទ័យព្រះ យើងត្រូវអនុវត្តសេចក្តីជំនឿរបស់យើង តាមរយៈការមកកាន់ទ្រង់ ជឿលើទ្រង់ ហើយជឿថា ទ្រង់នឹងប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់ដោយឧស្សាហ៍ព្យាយាម ។** អ្នកអាចនឹងចង់ឲ្យយោបល់សិស្សឲ្យគូសចំណាំសេចក្តីពិតនេះនៅក្នុងខទី ៦។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវទីបញ្ចប់នៃដំណើររឿងរបស់យុវនារីហ្ស៊ីលីពីន ។ ចូរសុំឲ្យសិស្សស្តាប់មើលនូវអ្វីដែលបានកើតឡើង ដោយសារតែយុវនារីនោះបានអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។

ប្រសិនបើអ្នកជ្រើសរើសបង្ហាញវីដេអូជំនួសវិញ សូមចាក់បង្ហាញវីដេអូ« Pure and Simple Faith »បន្ត (លេខកូដម៉ោង ២:៣៦ រហូតដល់ចប់) ។

នៅពេលយុវនារីនោះបានទៅបង់ថ្លៃសម្រាប់ទំនិញផ្សេងៗទៀត នាងបានលូកទៅក្នុងហោប៉ៅរបស់នាង ហើយប៉ះនឹងក្រដាសមួយដុំធំ ។ ពេលនាងបើកវាមើល នាងបានឃើញក្រដាសប្រាក់ ២០ ពេស្យាប្រាំសន្លឹកទៀត ដែលដាក់រុំក្រដាសប្រាក់ ២០ ពេស្យារបស់នាងដែលនៅសល់នោះ ។ នៅគ្រានោះ នាងបានដឹងថា នាងមានប្រាក់គ្រប់គ្រាន់ដើម្បីទិញទំនិញសម្រាប់គ្រួសារនាងត្រូវការ និងអាចបង់ថ្លៃការធ្វើដំណើរសម្រាប់គ្រួសារនាងទៅព្រះវិហារបានហើយ ។ យុវនារីនេះបានពន្យល់ថា អំឡុងពេលនៃបទពិសោធន៍នោះ នាងមានអារម្មណ៍ថា ព្រះជួយនាង ហើយស្រឡាញ់នាង ។ នៅពេលនាងបានត្រឡប់ទៅដល់ផ្ទះ នាងបានថ្លែងអំណរគុណដល់ព្រះវរបិតាសួគ៌ចំពោះអព្ភូតហេតុនោះ ។ (បានកែសម្រួលចេញមកពី « Pure and Simple Faith, » LDS.org) ។

- តើមានអ្វីខ្លះកើតមានឡើង នៅពេលយុវនារីនេះអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ?
- តើបទពិសោធន៍នេះអាចជួយយុវនារីនេះឲ្យអនុវត្តសេចក្តីជំនឿនាពេលអនាគតយ៉ាងដូចម្តេច ? (ដោយសារនាងបានទទួលស្គាល់ភស្តុតាងថា ព្រះកំពុងជួយនាងក្នុងបទពិសោធន៍នេះ នោះនាងអាចអះអាងថា ព្រះនឹងជួយនាងម្តងទៀតនៅពេលអនាគត ។ ដោយសារភស្តុតាង និងការអះអាងនេះដែលនាងបានទទួល នោះនាងអាចមានសេចក្តីជំនឿដើម្បីធ្វើសកម្មភាពនៅក្នុងពេលបច្ចុប្បន្ននេះ ។ ប្រសិនបើនាងបន្តធ្វើសកម្មភាព នោះដំណើរការនៃការធ្វើសកម្មភាពដោយសេចក្តីជំនឿនេះនឹងបន្តទៅមុខ ហើយសេចក្តីជំនឿរបស់នាងនឹងរីកចម្រើនកាន់តែខ្លាំងឡើង) ។

ចូរសុំឲ្យសិស្សគិតអំពីពេលមួយ នៅពេលពួកគេអនុវត្តសេចក្តីជំនឿ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ខ្លួន ។

- តើបទពិសោធន៍នោះបានផ្តល់ភស្តុតាងដល់អ្នកថា ព្រះនឹងជួយអ្នកនាពេលអនាគតយ៉ាងដូចម្តេច ?

ហេព្រើរ ១១:៧–៤០

ប៉ុលបានប្រាប់អំពីគំរូនៃមនុស្សសុចរិត ដែលបានអនុវត្តសេចក្តីជំនឿខ្លួនចេញពីគម្ពីរសញ្ញាចាស់

- តើមានស្ថានភាពណាខ្លះ ដែលអ្នកជួបពេលបច្ចុប្បន្ននេះ ឬ នឹងជួបនាពេលខាងមុខ ដែលតម្រូវឲ្យអ្នកអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតនៅពេលពួកគេសិក្សាហេព្រើរ ១១:៧–៤០ ដែលអាចជួយពួកគេឲ្យស្គាល់ពរជ័យនានា ដែលពួកគេអាចទទួល នៅពេលពួកគេអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។

សូមសរសេរពាក្យ*ដោយសារសេចក្តីជំនឿ*និង*តាមរយៈសេចក្តីជំនឿ*នៅលើក្តារខៀន ហើយពន្យល់ថា ប៉ុលបានប្រាប់ពីគំរូរបស់មនុស្សសុចរិតនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានអនុវត្តសេចក្តីជំនឿ ដើម្បីអះអាងដល់អ្នកស្តាប់របស់គាត់ថា ពួកគេក៏ត្រូវបានប្រទានពរផងដែរ តាមរយៈការអនុវត្តសេចក្តីជំនឿនោះ ។ សូមអញ្ជើញសិស្សឲ្យមើល ហេព្រើរ ១១ ដោយត្រួសៗ ហើយរកមើលឃ្លា « ដោយសារសេចក្តីជំនឿ » និង « តាមរយៈសេចក្តីជំនឿ » ។ អ្នកអាចនឹងចង់ស្នើឲ្យ សិស្សគួរតែគូសចំណាំឃ្លាទាំងនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១១:៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ហើយរកមើលរបៀបដែលណូអេអនុវត្តសេចក្តីជំនឿរបស់គាត់ទៅលើព្រះ ។ (អ្នកអាចនឹងចង់ពន្យល់ថា ឃ្លា « សេចក្តីកោតខ្លាច » មានន័យថា ណូអេបានធ្វើសកម្មភាពដោយសេចក្តីសង្ឃឹម និងការអះអាង ដែលបានពឹងផ្អែកទៅលើការដឹកនាំរបស់ព្រះ ។

- តើណូអេបានអនុវត្តសេចក្តីជំនឿទៅលើព្រះយ៉ាងដូចម្តេច ?

ការគូសចំណាំ និងការកត់ត្រាបទគម្ពីរ

របៀបងាយដំណួយបំផុតមួយសម្រាប់គ្រូបង្រៀន និង សិស្សទាំងឡាយដើម្បីរក្សាទុកនូវអ្វីដែលពួកគេបានរៀន គឺដោយការគូសចំណាំ និងការកត់ត្រាបទគម្ពីរ ។ សូមពិចារណាធ្វើការអញ្ជើញសិស្សឲ្យគូសចំណាំពាក្យ ឃ្លា ឬខគម្ពីរសំខាន់ៗ នៅក្នុងគម្ពីររបស់ពួកគេ ។ អ្នកក៏អាចអញ្ជើញពួកគេឲ្យគូសចំណាំគោលលទ្ធិ និងគោលការណ៍នានាផងដែរ ។ នៅពេលអ្នកអញ្ជើញសិស្សឲ្យគូសចំណាំខគម្ពីររបស់ពួកគេ ចូរកុំលើកទឹកចិត្តឲ្យប្រើរបៀបជាក់លាក់ណាមួយនៃការគូសចំណាំខគម្ពីរឡើយ ។ សូមចងចាំថា សិស្សមិនគួរបង្ខំឲ្យគូសចំណាំគម្ពីររបស់ពួកគេ ។

- តើធាតុនៃសេចក្តីជំនឿណាខ្លះ ដែលបានពិពណ៌នាដោយអែលឌើរ បែដណា (ការបញ្ជាក់អះអាង ភស្តុតាង និងសកម្មភាព) ត្រូវបានបង្ហាញឡើងនៅក្នុងដំណើររឿងរបស់ណូអេ ?
- តើវាបង្ហាញឡើងដោយរបៀបណា ?

ចូរសរសេរសេចក្តីយោងបទគម្ពីរដូចខាងក្រោមនៅលើក្តារខៀន ៖ *ហេព្រើរ ១១:៨–១០, ១១–១២, ១៧–១៩, ២០–២២, ២៣–២៨, ២៩–៣១* ។ សូមបែកចែងសិស្សក្នុងថ្នាក់ជាក្រុមមួយក្រុម ហើយចាត់ឲ្យក្រុមនីមួយៗនូវសេចក្តីយោងមួយ ។ (ប្រសិនបើអ្នកមានសិស្សតិច សូមចាត់ឲ្យសិស្សម្នាក់ៗនូវសេចក្តីយោងមួយ ឬចែកសិស្សជាគូៗ ហើយចាត់ឲ្យដៃគូនីមួយៗមានសេចក្តីយោងច្រើនជាងមួយ) ។ សូមអញ្ជើញក្រុមនីមួយៗឲ្យអានសេចក្តីយោងដែលបានចាត់ទៅឲ្យពួកគេជាមួយគ្នា ស្វែងរកមើលចម្លើយចំពោះសំណួរដូចខាងក្រោម (អ្នកអាចនឹងចង់សរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖

តើនរណាបានអនុវត្តសេចក្តីជំនឿ ?

តើធាតុនៃសេចក្តីជំនឿទាំងបី (ការអះអាង ភស្តុតាង និងសកម្មភាព) បង្ហាញជាគំរូតាមវិធីណា ?

តើស្ថានភាពអ្វីខ្លះដែលយើងបានជួបនៅសព្វថ្ងៃនេះ ដែលតម្រូវឲ្យមានសេចក្តីជំនឿស្រដៀងគ្នានេះ ?

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗឲ្យប្រាប់ពីចម្លើយរបស់ពួកគេទៅដល់សិស្សក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ ១១:១៣–១៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមហើយរកមើលនូវអ្វី ដែលយើងអាចរៀនចេញពីគំរូរបស់អ័ប្រាហាំ សារ៉ាយ និង មនុស្សដទៃទៀតអំពីការអនុវត្តសេចក្តីជំនឿ ។ ចូរពន្យល់ថា ឃ្លា « ស្រុកមួយដ៏ប្រសើរ » (ខទី ១៦) សំដៅលើជីវិតដ៏នៅអស់កល្បជានិច្ច ។

- ស្របតាមខទី ១៣តើអ្វីខ្លះបានកើតឡើងចំពោះអ័ប្រាហាំ និងភរិយារបស់លោក សារ៉ាយ ក៏ដូចជាមនុស្សស្មោះត្រង់ដទៃទៀតដែរ ?
- ហេតុអ្វីពួកគេបានបន្តស្មោះត្រង់ ទោះបីជាពួកគេពុំបានទទួលការសន្យារបស់ព្រះទាំងអស់នៅក្នុងជីវិតនេះក្តី ? (អ្នកអាចនឹងចង់ពន្យល់ថា ដើម្បីមើលឃើញពរជ័យដែលត្រូវបានសន្យា « ពីចម្ងាយ » មានន័យថា មានសេចក្តីសង្ឃឹម និងទំនុកចិត្តថានឹងទទួលបានពរជ័យទាំងនោះ បន្ទាប់ពីពួកគេស្លាប់ទៅ) ។
- តើគំរូរបស់ពួកគេអាចជួយយើងឲ្យបន្តនៅស្មោះត្រង់យ៉ាងដូចម្តេច ?

សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាច. . .* សូមអញ្ជើញសិស្សឲ្យសរសេរឃ្លានេះនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗពីក្នុង ហេព្រើរ ១១: ៣២–៤០ ។ ចូរសុំឲ្យសិស្សអានការបកប្រែដោយ យ៉ូសែបស្ម៊ីធ ហេព្រើរ ១១:៣៥ ( ) ហើយអញ្ជើញសិស្សដទៃទៀតឲ្យអានការបកប្រែដោយ យ៉ូសែប ស្ម៊ីធ ហេព្រើរ ១១:៤០ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមហើយរកមើលរបៀប ដែលពួកគេអាចបញ្ចប់ឃ្លាដែលពួកគេបានសរសេរ ។ អ្នកអាចនឹងចង់ផ្តល់យោបល់ឲ្យសិស្សគូសចំណាំ៣ក្យ និង ឃ្លានានានៅក្នុងគម្ពីររបស់ពួកគេដែលលេចធ្លោចំពោះពួកគេ ។

ចូរសុំសិស្សឲ្យបំពេញឃ្លា យោងតាម ខទី ៣២–៤០ ។ ក្រោយពីទុកពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សមួយចំនួនឲ្យរៀបរាប់ពីអ្វី ដែលពួកគេបានសរសេរ ។ សូមសង្ខេបចម្លើយរបស់សិស្សដោយសរសេរគោលការណ៍ដូចខាងក្រោមនៅលើក្តារខៀន ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចស៊ូទ្រាំនឹងការលំបាកទុក្ខ សម្រេចអព្ភូតហេតុ ទទួលការសន្យាមកពីព្រះ ពង្រឹងទីបន្ទាល់របស់យើងអំពីទ្រង់ ហើយដើរឆ្ពោះទៅរកភាពល្អឥតខ្ចោះ ។**

- តើមានវិធីអ្វីខ្លះ ដែលយើងអាចអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ?
- តើអ្នកធ្លាប់បានឃើញពរជ័យអ្វីខ្លះ ដែលកើតមានឡើងដល់ជីវិតមនុស្សម្នាក់ ដោយសារតែគាត់បានអនុវត្តសេចក្តីជំនឿ ?

សូមអញ្ជើញសិស្សឲ្យគិតម្តងទៀតអំពីស្ថានភាពនានា ដែលតម្រូវពីពួកគេ ឬនឹងតម្រូវពីពួកគេឲ្យអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។

សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅមួយ ដើម្បីអនុវត្តសេចក្តីជំនឿទៅលើព្រះអម្ចាស់ក្នុងស្ថានភាពទាំងនោះ ។ សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅដោយបំពេញឃ្លាថា « ដោយសារសេចក្តីជំនឿ ខ្ញុំនឹង . . . »

ហេព្រើរ ១២–១៣

សេចក្តីផ្តើម

ប៉ុលបានទូន្មានសមាជិកសាសនាចក្រដែលជាសាសន៍យូដា ឲ្យដើរនៅលើផ្លូវនៃភាពជាសិស្ស ដោយធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកក៏បានពន្យល់អំពីពរជ័យនៃការទទួលការផ្តាច់ផ្តាលរបស់ព្រះអម្ចាស់ ។ ប៉ុលបានជាប់តឿនពួកបរិសុទ្ធឲ្យធ្វើតាមព្រះទ័យរបស់ព្រះ ដើម្បីពួកគេអាចធ្វើឲ្យបានល្អឥតខ្ចោះតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

កំណត់ចំណាំ ៖ មេរៀនទី ១៤០ ផ្តល់នូវឱកាសមួយសម្រាប់សិស្សពីរនាក់ឲ្យឡើងមកបង្រៀន ។ សូមជ្រើសរើសសិស្សពីរនាក់ទុកជាមុន ហើយចម្លងឲ្យពួកគេនូវផ្នែកដែលបានចាត់ឲ្យពួកគេបង្រៀននៅក្នុងមេរៀនទី ១៤០ ដើម្បីឲ្យពួកគេអាចត្រៀមខ្លួន ។ សូមលើកទឹកចិត្តពួកគេឲ្យសិក្សាមេរៀននោះប្រកបដោយការអធិស្ឋាន ហើយស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការរៀបចំខ្លួនពួកគេដើម្បីបង្រៀន ។

យោបល់សម្រាប់ការបង្រៀន

ហេព្រើរ ១២

ប៉ុលទូន្មានពួកបរិសុទ្ធឲ្យដើរនៅលើផ្លូវនៃជីវិតនេះដោយសេចក្តីជំនឿ និងការអត់ធ្មត់



សូមគូរ គំនូរ បន្ទាត់ដ៏សាមញ្ញមួយនៃអ្នករត់ប្រណាំងនៅលើក្តារខៀន ។ សូមឲ្យសិស្សពិពណ៌នាអំពីការលំបាកដែលអ្នករត់ប្រណាំងម្នាក់អាចជួប កាលគាត់រត់នៅក្នុងការប្រកួតចម្ងាយឆ្ងាយនោះ ។ (អ្នកក៏អាចសួរថា មានសិស្សក្នុងថ្នាក់ណាម្នាក់ធ្លាប់រត់ប្រណាំងចម្ងាយឆ្ងាយដែរឬទេ រួចហើយសួរសិស្សម្នាក់ថានរណាទៅដែលមានការលំបាកដែលគាត់បានជួប កាលរត់ប្រណាំងចម្ងាយឆ្ងាយមួយ) ។

- តើអ្វីទៅដែលអាចលើកទឹកចិត្តអ្នករត់ប្រណាំងម្នាក់ឲ្យបន្តរត់ ទោះជានៅពេលគាត់ជួបនឹងការអស់កម្លាំង ឬការលំបាកផ្សេងទៀតក្តី ?
- តើជីវិតក្នុងនាមជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទប្រៀបបាននឹងការស៊ូទ្រាំ នៅក្នុងការរត់ប្រណាំងមួយយ៉ាងដូចម្តេច ?
- តើយើងប្រហែលជាជួបការលំបាកអ្វីខ្លះក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សគិតអំពីការលំបាកនានាដែលពួកគេជួប (ឬធ្លាប់ជួប)ក្នុងនាមជាពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ ។ នៅពេលសិស្សសិក្សាហេព្រើរ ១២ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេឲ្យបន្តដើរតាមព្រះយេស៊ូវគ្រីស្ទ ទោះជានៅពេលវាមានភាពលំបាកក្តី ។

សូមអញ្ជើញសិស្សម្នាក់អាន ហេព្រើរ១២:១ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានប្រាប់ពួកបរិសុទ្ធថាពួកគេត្រូវធ្វើអ្វីខ្លះ ដើម្បីដើរនៅលើផ្លូវនៃភាពជាសិស្សប្រកបដោយជោគជ័យ ។

- តើប៉ុលបានប្រាប់ពួកបរិសុទ្ធថា ពួកគេត្រូវធ្វើអ្វីខ្លះ ដើម្បីដើរនៅលើផ្លូវនៃភាពជាសិស្សប្រកបដោយជោគជ័យ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀន ហើយឲ្យគាត់ស្តាយកាបូបស្តាយមួយ ។ សូមយកដុំថ្មដាក់នៅក្នុងកាបូបស្តាយនោះ រួចហើយសូមឲ្យសិស្សពន្យល់ថា ការស្តាយកាបូបដែលមានសុទ្ធតែដុំថ្មនឹងជះឥទ្ធិពលដល់អ្នករត់ប្រណាំងម្នាក់យ៉ាងដូចម្តេច ។

- តើអំពើបាបរបស់យើងប្រៀបបាននឹងកាបូបស្តាយមួយ ដែលមានសុទ្ធតែដុំថ្មនោះយ៉ាងដូចម្តេច ?

សូមឲ្យសិស្សដោះកាបូបស្តាយនោះចេញ ហើយត្រឡប់ទៅកន្លែងអង្គុយវិញ ។

- តើការដើរនៅលើផ្លូវនៃភាពជាសិស្សដោយភាពអត់ធ្មត់មានន័យដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ហេព្រើរ១២:២–៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ប៉ុលបានប្រាប់ពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះដើម្បីជួយពួកគេឲ្យបោះបង់ចោលអំពើបាបរបស់ពួកគេ ហើយស៊ូទ្រាំនឹងការផ្ចុយដោយអត់ធ្មត់នោះ ។ សូមពន្យល់ថា ពាក្យ *រត់ទទឹងទទែង* នៅក្នុង ខទី ៣ សំដៅទៅលើការបដិសេធ ។

- ដោយផ្អែកទៅលើអ្វីដែលប៉ុលបានបង្រៀនដល់ពួកបរិសុទ្ធ តើអ្វីទៅដែលអាចជួយយើងឲ្យបោះបង់ចោលអំពើបាបរបស់យើង ហើយស៊ូទ្រាំនឹងការផ្ចុយដោយអត់ធ្មត់ ? (សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែត្រូវធ្វើឲ្យប្រាកដថា ពួកគេស្គាល់គោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងមើលទៅគំរូរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចរកឃើញកម្លាំងដើម្បីបោះបង់ចោលអំពើបាបរបស់យើង ហើយស៊ូទ្រាំនឹងការផ្ចុយដោយអត់ធ្មត់**) ។
- យោងតាម ខទី ២ តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះ ទើបប៉ុលបានប្រាប់ពួកបរិសុទ្ធឲ្យមើលទៅទ្រង់ទុកជាគំរូ ?



សូមដាក់បង្ហាញរូបភាព ការឆ្កាង (*Gospel Art Book* ⁄ ឆ្នាំ ២០០៩ ⁄ ល.រ. ៥៧, សូមមើលផងដែរ LDS.org) ហើយពន្យល់ថា ប៉ុលបានប្រាប់ពួកបរិសុទ្ធថា ព្រះយេស៊ូវបានព្រមរងទុក្ខនឹងសេចក្តីស្លាប់នៅលើឈើឆ្កាង ហើយស៊ូទ្រាំនឹងភាពអាម៉ាស់នៃលោកិយនេះ ដោយសារទ្រង់បានជ្រាបអំពីអំណរដែលទ្រង់នឹងទទួលបាន ប្រសិនបើទ្រង់បន្តស្មោះត្រង់ចំពោះព្រះវរបិតាសួគ៌ ។

- តើអ្នកគិតថា ការយកគំរូតាមព្រះយេស៊ូវគ្រីស្ទអាចជួយយើងបានយ៉ាងដូចម្តេច កាលយើងបានជួបការរងទុក្ខ និងឧបសគ្គទាំងឡាយនោះ ?

សូមឲ្យសិស្សគិតអំពីការប្រឈមនានាពេលបច្ចុប្បន្នរបស់ពួកគេ ហើយថាការមើលទៅគំរូរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយពួកគេជាមួយនឹងការប្រឈមទាំងនោះយ៉ាងដូចម្តេច ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយអែលឌើរ ដៃវ្រ៊ី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា គំរូរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយពួកគេឲ្យបោះបង់ចោលអំពើបាបរបស់យើង ហើយបន្តដោយភាពអត់ធ្មត់ដោយរបៀបណា ។



« ដើម្បីឲ្យដង្វាយធួនរបស់ទ្រង់គ្មានទីបញ្ចប់ ហើយមានភាពអស់កល្ប ទ្រង់ត្រូវទទួលអារម្មណ៍ ពីការដកពិសោធន៍ទាំងខាងសាច់ឈាម និងខាងវិញ្ញាណថាតើសេចក្តីស្លាប់មានសភាពបែបណា ដើម្បីញាណដឹងថាតើការបាត់បង់ព្រះវិញ្ញាណនៃព្រះដោយបន្សល់ទុកនូវអារម្មណ៍ឯកោទាំងស្រុង ហើយអស់សង្ឃឹមនោះមានសភាពបែបណាដែរ ។

« ប៉ុន្តែព្រះយេស៊ូវបានស៊ូទ្រាំ ។ ទ្រង់បានបន្តទៅមុខ ។ សេចក្តីល្អនៅក្នុងទ្រង់បានអនុញ្ញាតឲ្យសេចក្តីជំនឿមានជ័យជំនះ ទោះជាស្ថិតនៅក្នុងស្ថានភាពមួយពោរពេញដោយការឈឺចាប់ដ៏ខ្លាំងក្តី ។ ការទុកចិត្តដែលទ្រង់បានរស់នៅតាមបានប្រាប់ទ្រង់ ទោះជាទ្រង់មានព្រះទ័យយ៉ាងណាក្តី ថាសេចក្តីមេត្តាករុណាមកពីព្រះគឺ ពុំដុតរលត់ឡើយ ថាព្រះគឺស្មោះត្រង់ជានិច្ច ថាទ្រង់ពុំគេចចេញ ឬធ្វើឲ្យយើងបរាជ័យឡើយ » (« None Were with Him » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៨៨) ។

សូមលើកទឹកចិត្តសិស្សឲ្យលះបង់ពេលវេលាជារៀងរាល់ថ្ងៃ ប្រហែលជាផ្នែកមួយនៃការសិក្សាព្រះគម្ពីររបស់ពួកគេ ឲ្យមើលទៅគំរូរបស់ព្រះយេស៊ូវគ្រីស្ទដើម្បីពួកគេអាចរកឃើញកម្លាំងដើម្បីបោះបង់ចោលអំពើបាបរបស់ពួកគេ ហើយស៊ូទ្រាំការផ្ទុយដោយអត់ធ្មត់ ។

ដើម្បីរៀបចំសិស្សឲ្យស្គាល់អំពីគោលការណ៍មួយទៀតដែលប៉ុលបានបង្រៀននៅក្នុង ហេព្រើរ ១២ សូមអញ្ជើញពួកគេឲ្យគិតអំពីគ្រាមួយដែលមនុស្សម្នាក់បានកែតម្រូវពួកគេ ។ សូមឲ្យពួកគេរំឭកឡើងវិញថា ពួកគេបានមានប្រតិកម្មយ៉ាងណាដែរចំពោះការកែតម្រូវនោះ ។

- ហេតុអ្វីវាជារឿងដ៏លំបាកដើម្បីទទួលការកែតម្រូវមកពីមនុស្សម្នាក់ ?
- តើហេតុផលណាខ្លះដែលអាចគិតថាមនុស្សប្រហែលជាចង់កែតម្រូវអ្នក ជាពិសេសនៅពេលមនុស្សទាំងនោះដឹងថា យើងអាចនឹងពុំចូលចិត្តការកែតម្រូវរបស់ពួកគេឡើយ ?

ហេព្រើរ ១២:៩ គឺជាចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀនៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សូមពន្យល់ថា នៅពេលយើងដើរនៅលើផ្លូវនៃភាពជាសិស្ស យើងអាចរំពឹងទុកដើម្បីទទួលបានការផ្ចាញ់ផ្ចាល ឬការកែតម្រូវ ។ សូមអញ្ជើញសិស្សម្នាក់អាន ហេព្រើរ ១២:៦–៩ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថានរណានឹងកែតម្រូវយើង ហើយហេតុអ្វី ។ នៅក្នុងបរិបទនេះ ពាក្យ *កូនឥតខាន់ស្លា* នៅក្នុង ខទី ៨ មានន័យថា ជាមនុស្សដែលបានកើតចេញពីឪពុកម្តាយពុំបានរៀបការនឹងគ្នាតាមច្បាប់ ហើយពុំត្រូវបានគេចាត់ទុកថាជាកូនស្របច្បាប់ឡើយ ។

- តើនរណានឹងកែតម្រូវយើង នៅពេលយើងរត់ប្រណាំងនៅលើផ្លូវនៃភាពជាសិស្ស ?
- យោងតាមប៉ុល ហេតុអ្វីព្រះវរបិតាសួគ៌ផ្ចាញ់ផ្ចាល ឬកែតម្រូវយើង ?
- តើការផ្ចាញ់ផ្ចាលរបស់ព្រះវរបិតាសួគ៌ គឺជាការបង្ហាញមួយអំពីសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះកូនចៅរបស់ទ្រង់យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យចំណាយពេល ៣០ វិនាទី សរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេអំពីរបៀបមួយចំនួនដែលព្រះវរបិតាសួគ៌អាចកែតម្រូវយើង ។ សូមឲ្យសិស្សបីបួននាក់ប្រាប់ដល់សិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានសរសេរ ។ សូមធ្វើឲ្យសិស្សយល់ថា ទោះបីជាការផ្ចាញ់ផ្ចាលអាចកើតឡើងក្នុងរបៀបជាច្រើនក្តី ក៏វាល់ការសាកល្បង ឬការរងទុក្ខដែលយើងជួបពុំមែនសុទ្ធតែមកពីព្រះនោះទេ ។

- នៅក្នុង ខទី ៩ តើប៉ុលបាននិយាយថា យើងគួរធ្វើអ្វីខ្លះ នៅពេលព្រះវរបិតាសួគ៌កែតម្រូវ ហើយផ្ចាញ់ផ្ចាលយើងនោះ ?
- តើការ « ត្រូវចុះចូល » ឬការប្រតិបត្តិតាមព្រះវរបិតាសួគ៌មានន័យដូចម្តេច ? (ការមានចិត្តរាបសា ងាយបង្រៀន ហើយព្រមផ្លាស់ប្តូរនៅក្នុងជីវិតរបស់យើងឲ្យស្របនឹងព្រះទ័យរបស់ទ្រង់) ។

សូមសរសេរឃ្លាមិនពេញលេញដូចតទៅនេះនៅលើក្តារខៀន ៖ *ប្រសិនបើយើងចុះចូលនឹងការផ្ចាញ់ផ្ចាលមកពីព្រះវរបិតាសួគ៌ នោះយើងនឹង* . . .

សូមពន្យល់ថា នៅក្នុង ខទី ១០ ប៉ុលបានទទួលស្គាល់ថា ឪពុករបស់យើងនៅលើផែនដីនេះ ពេលខ្លះអាចនឹងផ្ចាញ់ផ្ចាលយើងតាមរបៀបដែលពុំត្រឹមត្រូវ ប៉ុន្តែការផ្ចាញ់ផ្ចាលរបស់ព្រះវរបិតាសួគ៌គឺល្អឥតខ្ចោះ ហើយបានរៀបចំឡើងដើម្បីជាប្រយោជន៍របស់យើង ។ សូមអញ្ជើញសិស្សម្នាក់អាន ហេព្រើរ ១២:១០–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់តាមរកមើលថា ប៉ុលបានបង្រៀនថានឹងមានអ្វីខ្លះកើតឡើងប្រសិនបើយើងចុះចូលនឹងការផ្ចាញ់ផ្ចាលមកពីព្រះវរបិតាសួគ៌ ។ សូមពន្យល់ថា ឃ្លា « ដើម្បីឲ្យយើងបានសេចក្តីបរិសុទ្ធរបស់ទ្រង់ » នៅក្នុង ខទី ១០ សំដៅទៅលើការប្រែក្លាយកាន់តែដូចជាទ្រង់ ។

- តើពាក្យរបស់ប៉ុលនៅក្នុង ខទី ១១ បានពិពណ៌នាយ៉ាងណាខ្លះអំពីអារម្មណ៍ដែលយើងប្រហែលជាមាន នៅពេលយើងទទួលបានការផ្ចាញ់ផ្ចាលលើកដំបូង ?
- យោងតាម ខទី ១០–១១ តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងចុះចូលតាមការផ្ចាញ់ផ្ចាលមកពីព្រះវរបិតាសួគ៌ ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមបំពេញឃ្លានៅលើក្តារខៀនដូចតទៅ ៖ **ប្រសិនបើយើងចុះចូលនឹងការផ្ចាញ់ផ្ចាលមកពីព្រះវរបិតាសួគ៌ នោះយើងនឹងប្រែក្លាយកាន់តែដូចទ្រង់ ហើយមានសេចក្តីសុខសាន្តដែលកើតចេញពីសេចក្តីសុចរិត**) ។

សូមពិចារណាចែកចាយបទពិសោធន៍មួយអំពីពេលដែលអ្នកបានចុះចូលនឹងការផ្ចាញ់ផ្ចាលមកពីព្រះវរបិតាសួគ៌ ហើយមានអារម្មណ៍ថាមានពរដោយបានធ្វើដូច្នោះ ។ (សូមកុំចែកចាយអ្វីដែលគួរឲ្យភ័យខ្លាច ឬថ្ពាល់ខ្លួនខ្លាំងពេក) ។ សូមឲ្យសិស្សគិតអំពីពេលមួយដែលពួកគេបានមានអារម្មណ៍ថា ពួកគេត្រូវបានផ្ចាញ់ផ្ចាលដោយព្រះវរបិតាសួគ៌ ។ សូមឲ្យពួកគេគិតអំពីរបៀបដែលពួកគេបានឆ្លើយតបនឹង

ការកែតម្រូវនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យសម្រេចចិត្តនៅពេលនេះ ដើម្បីចុះចូលនឹងការផ្ចាញ់ផ្ចាលរបស់ព្រះវរបិតាសួគ៌ ដែលពួកគេអាចនឹងទទួលបាននៅពេលអនាគត ។

សូមសង្ខេប ហេព្រើរ ១២:១២–២៩ ដោយពន្យល់ថា ប៉ុលបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យពង្រឹងសមាជិកផ្សេងទៀតក្នុងសាសនាចក្រ នៅក្នុងសេចក្តីជំនឿ ។ សូមដាស់តឿនពួកគេឲ្យចៀសវាងពីអំពើបាប ដើម្បីកុំឲ្យពួកគេបាត់សិទ្ធិទទួលបានពរជ័យរបស់ព្រះដូចជាអេសាវ និងកូនចៅនៃអ៊ីស្រាអែលនៅលើភ្នំស៊ីណាយ ។ ប៉ុលបានពន្យល់ថា ពួកបរិសុទ្ធដែលបន្តស្មោះត្រង់ ហើយបម្រើព្រះនឹងទទួលបានសិរីល្អដែលពុំអាចប្រៀបផ្ទឹមបាន និងទទួលបានកន្លែងមួយនៅក្នុងនគររបស់ទ្រង់ ។

ហេព្រើរ ១៣

ប៉ុលផ្តល់ការទូន្មានផ្សេងៗគ្នាដល់ពួកបរិសុទ្ធ

សូមពន្យល់ថា ប៉ុលបានបញ្ចប់សំបុត្ររបស់លោកដល់ពួកបរិសុទ្ធនៅហេព្រើរ ដោយផ្តល់ការទូន្មានដល់ពួកគេអំពីប្រធានបទខុសៗគ្នា ។ សូមចែកសិស្សជាក្រុម ដែលមួយក្រុមតូចៗមានគ្នាពីរ ឬបីនាក់ ។ សូមអញ្ជើញពួកគេអាន ហេព្រើរ១៣:១–៩, ១៧ រួមគ្នារកមើលការទូន្មានដែលប៉ុលបានផ្តល់ឲ្យពួកបរិសុទ្ធ ។ សូមណែនាំសិស្សឲ្យពិភាក្សាជាមួយនឹងក្រុមរបស់ពួកគេនូវសំណួរខាងក្រោមនេះ នៅពេលពួកគេបានបញ្ចប់ការអាន ។ អ្នកគប្បីសរសេរសំណួរទាំងនេះលើក្តារខៀន ។

- តើអ្នកគិតថា ការទូន្មានណាមួយដែលយើងត្រូវការបំផុតនៅក្នុងជំនាន់របស់យើង ? ហេតុអ្វី ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបួនក្រាំនាក់ប្រាប់អំពីរបៀប ដែលពួកគេឆ្លើយនឹងសំណួរទាំងនោះ ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា ផ្នែកណាមួយនៃការទូន្មានរបស់ប៉ុល ដែលពួកគេអាចយកមកអនុវត្តបានយ៉ាងប្រសើរនៅក្នុងជីវិតរបស់ពួកគេ ។

សូមសង្ខេប ហេព្រើរ ១៣:១០–១២ ដោយពន្យល់ថា ប៉ុលបានបង្រៀនថា នៅសម័យព្រះគម្ពីរសញ្ញាចាស់ សត្វដែលត្រូវបានគេយកទៅបូជា ជាការថ្វាយនៃអំពើបាបត្រូវបានគេដុតនៅក្រៅជំរំរបស់អ៊ីស្រាអែល ។ ស្រដៀងគ្នានេះដែរ ព្រះយេស៊ូវបានធ្វើការបូជានៅខាងក្រៅក្រុងយេរូសាឡិម ។ សូមពន្យល់ថា បន្ទាប់ពីព្រះយេស៊ូវគ្រីស្ទបានបំពេញដង្វាយធួន ការបូជាសត្វគឺពុំបានតម្រូវឲ្យមានទៀតឡើយ (សូមមើល នីហ្វៃទី៣ ៩:១៨–២០) ។

សូមអញ្ជើញសិស្សម្នាក់អាន ហេព្រើរ១៣:១៣–១៦ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ប៉ុលបាននិយាយឲ្យពួកបរិសុទ្ធគួរបូជាអ្វីជំនួសឲ្យការបូជាសត្វ ។ សូមពិចារណាអញ្ជើញសិស្សឲ្យគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើប៉ុលបាននិយាយថា យើងគួរបូជាអ្វីខ្លះ ?
- ហេតុអ្វីអ្នកគិតថា ការបូជាបែបនេះនឹងធ្វើឲ្យព្រះសព្វព្រះទ័យ ?

សូមសង្ខេប ហេព្រើរ ១៣:១៧–២៥ ដោយពន្យល់ថា ប៉ុលបានទូន្មានពួកបរិសុទ្ធឲ្យគោរពតាមថ្នាក់ដឹកនាំខាងវិញ្ញាណរបស់ពួកគេ ហើយអធិស្ឋានឲ្យពួកគាត់ ។ ប៉ុលបានអធិស្ឋានថា ព្រះនឹងប្រទានន្ទូវអ្វីដែលចាំបាច់ដល់ពួកបរិសុទ្ធ ដើម្បីសម្រេចតាមព្រះទ័យរបស់ទ្រង់ ។

អ្នកគួរតែបញ្ចប់ដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលសិស្សបានស្គាល់នៅក្នុងហេព្រើរ ១២–១៣ ។

ចំណេះចំណានខគម្ពីរ—ហេព្រើរ ១២:៩

សូមជួយសិស្សឲ្យទន្ទេញចាំ ហេព្រើរ១២:៩ ដោយអញ្ជើញពួកគេឲ្យសរសេរតួអក្សរដំបូងនៃពាក្យនីមួយៗ នៅក្នុងខគម្ពីរនោះនៅលើក្រដាសមួយសន្លឹក ។ សូមរំឭកបទគម្ពីរនេះឲ្យបានច្រើនដងជាមួយនឹងសិស្សរបស់អ្នក រហូតពួកគេអាចសូត្រខគម្ពីរនេះដោយប្រើតួអក្សរដំបូងនៃពាក្យនីមួយៗ ។

- តើយើងអាចរៀនគោលលទ្ធិអ្វីខ្លះពីក្នុងខគម្ពីរទាំងនេះអំពីទំនាក់ទំនងរបស់យើង និងព្រះវរបិតាសួគ៌ ? (សិស្សគួរស្គាល់គោលលទ្ធិដូចតទៅនេះ ៖ **ព្រះវរបិតាសួគ៌គឺជាបិតានៃវិញ្ញាណរបស់យើង**) ។
- ហេតុអ្វីក៏វាសំខាន់ដើម្បីជឿថា យើងជាកូនរបស់ព្រះ ?

សូមថ្លែងទីបន្ទាល់ថា យើងពិតជាកូនចៅរបស់ព្រះមែន ។

សេចក្តីផ្តើមអំពី

សំបុត្រទូទៅរបស់យ៉ាកុប

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រទូទៅរបស់យ៉ាកុបត្រូវគេបានស្គាល់យ៉ាងល្បីល្បាញ នៅក្នុងចំណោមសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ សម្រាប់វគ្គដ៏សំខាន់នៅក្នុង យ៉ាកុប១:៥ ដែលបានដឹកនាំយុវជន យ៉ូសែប ស្ម៊ីធ ឲ្យស្វែងរកសេចក្តីពិតមកពីព្រះ ។ នៅក្នុងសំបុត្ររបស់លោក យ៉ាកុបបានគូសបញ្ជាក់ថា យើងត្រូវធ្វើជាអ្នក « ប្រព្រឹត្តតាមព្រះបន្ទូលទៅ កុំឲ្យគ្រាន់តែស្តាប់ប៉ុណ្ណោះ » (យ៉ាកុប ១:២២) ។ ការសិក្សាគម្ពីរនេះអាចជួយសិស្ស ឲ្យយល់ពីសារៈសំខាន់នៃការបង្ហាញសេចក្តីជំនឿរបស់ពួកគេតាមរយៈ « កិច្ចការ » ឬ សកម្មភាពរបស់ពួកគេ (សូមមើល យ៉ាកុប ២:១៤–២៦) ហើយបំផុសគំនិតពួកគេឲ្យស្វែងរក « មកុដនៃជីវិតដែលព្រះអម្ចាស់ទ្រង់សន្យានឹងប្រទានឲ្យដល់អស់អ្នកណាដែលស្រឡាញ់ទ្រង់ » (យ៉ាកុប ១:១២) ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

សំបុត្រនេះចែងថា វាត្រូវបានសរសេរឡើងដោយ « យ៉ាកុប ជាបាវបម្រើរបស់ព្រះ ហើយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ » (យ៉ាកុប ១:១) ។

តាមទម្លាប់ពួកគ្រីស្ទានបានចាត់ទុកថា យ៉ាកុបរូបនេះដូចជាយូដាសដែរ គឺជាកូនប្រុសរបស់យ៉ូសែប និងម៉ារា ហើយដូច្នេះលោកគឺជាប្អូនប្រុសពោះតែមួយរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ាថាយ ១៣:៥៥, ម៉ាកុស ៦:៣, កាឡាទី ១:១៩) ។ ការពិតដែលថា យ៉ាកុបត្រូវបានលើកឈ្មោះឡើងដំបូងគេនៅក្នុងបញ្ជីជាប្អូនរបស់ព្រះយេស៊ូវនៅក្នុង ម៉ាថាយ ១៣:៥៥នោះអាចបង្ហាញថា ទ្រង់គឺជាកូនប្រុសច្បងនៃបងប្អូនប្រុសពោះតែមួយទាំងនោះ ។ ដូចគ្នានឹងប្អូនប្រុសពោះតែមួយផ្សេងទៀតរបស់ព្រះយេស៊ូវដែរ ដើមឡើយ យ៉ាកុបពុំបានក្លាយជាសិស្សម្នាក់របស់ព្រះយេស៊ូវនោះទេ (សូមមើល យ៉ូហាន៧:៣–៥) ។ ប៉ុន្តែ បន្ទាប់ពីព្រះយេស៊ូវបានមានព្រះជន្មឡើងវិញ នោះយ៉ាកុបគឺជាមនុស្សម្នាក់ ដែលព្រះគ្រីស្ទបានបង្ហាញអង្គទ្រង់ឲ្យឃើញក្នុងនាមជាតួអង្គដែលបានរស់ឡើងវិញ (សូមមើល កូរិនថូស ទី១ ១៥:៧) ។

ក្រោយមកទៀត យ៉ាកុបបានក្លាយជាសាវកមួយរូប ហើយយោងតាមពួកអ្នកនិពន្ធគ្រីស្ទានកាលពីបុរាណ លោកគឺជាប៊ីស្សពដំបូងរបស់សាសនាចក្រនៅក្រុងយេរូសាឡិម (សូមមើល កិច្ចការ ១២:១៧, ២១:១៨, កាឡាទី ១:១៨–១៩, ២:៩) ។ ក្នុងនាមជាថ្នាក់ដឹកនាំម្នាក់ក្នុងសាសនាចក្រ លោកបានដើរតួយ៉ាងសំខាន់ក្រៃលែងនៅក្នុងក្រុមប្រឹក្សាដែលធ្វើឡើងនៅក្រុងយេរូសាឡិម (កិច្ចការ ១៥:១៣) ។ ពិតណាស់ ឥទ្ធិពលរបស់លោកនៅក្នុងសាសនាចក្រត្រូវបានពង្រឹងដោយសារលោកជាប់សាច់ញាតិនឹងព្រះយេស៊ូវ ប៉ុន្តែយ៉ាកុបបានបង្ហាញការអោបសាដោយមិនបានណែនាំខ្លួនលោកក្នុងនាមជា *ប្អូនប្រុស* របស់ព្រះយេស៊ូវនោះទេ ប៉ុន្តែជា *អ្នកបម្រើ* ម្នាក់របស់ព្រះអម្ចាស់ (សូមមើល យ៉ាកុប ១:១) ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

គ្មាននរណាម្នាក់ដឹងថា យ៉ាកុបសរសេរសំបុត្រនេះនៅពេលណានោះទេ ។ ដោយសារយ៉ាកុបបានរស់នៅក្នុងក្រុងយេរូសាឡិម ហើយមើលការខុសត្រូវលើកិច្ចការរបស់សាសនាចក្រនៅទីនោះ ដូច្នេះលោកទំនងជាបានសរសេរសំបុត្ររបស់លោកមកពីទីកន្លែងនោះ ។

ភាពពិតដែលយ៉ាកុបពុំបានលើកឡើងអំពីសន្និសីទនៅយេរូសាឡិមប្រមាណជា គ.ស. ៥០ (សូមមើល កិច្ចការ១៥) អាចបង្ហាញថា សំបុត្រនេះត្រូវបានសរសេរឡើងពីមុនសន្និសិទប្រាព្ធឡើង ។ ប្រសិនបើសំបុត្រនេះពិតជាបានសរសេរឡើងពីមុនសន្និសីទនៅយេរូសាឡិមកើតឡើងមែន នោះវាគឺជាសំបុត្រមួយក្នុងចំណោមសំបុត្រដំបូង នៅក្នុងព្រះគម្ពីរសញ្ញាថ្មីដែលបានសរសេរឡើង ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

យ៉ាកុបបានផ្ញើសំបុត្ររបស់លោក « ដល់ពូជអំបូរទាំង ១២ ដែលត្រូវខ្ចាត់ខ្ចាយ » (យ៉ាកុប ១:១) មានន័យថា រាល់ពូជពង្សអ៊ីស្រាអែលទាំងអស់ លោកបានអញ្ជើញពួកគេឲ្យ « ទទួលដំណឹងល្អ . . . [ហើយ] ចូលមកក្នុងហ្វូងនៃព្រះគ្រីស្ទ » (Bruce R. McConkie *Doctrinal New Testament Commentary* វ៉ុលទី ៣ [ឆ្នាំ១៩៦៥–៧៣] ៣:២៤៣) ។ យ៉ាកុបបានណែនាំសមាជិកសាសនាចក្រឲ្យរស់នៅក្នុងជីវិតមួយ ដែលបង្ហាញពីសេចក្តីជំនឿរបស់ពួកគេលើព្រះយេស៊ូវគ្រីស្ទ ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ពេលខ្លះ សំបុត្រទូទៅរបស់យ៉ាកុបត្រូវបានចាត់ទុកជាគិតនៃអក្សរសាស្ត្រ ដែលស្រដៀងគ្នាទៅនឹងគម្ពីរសុភាសិតក្នុងព្រះគម្ពីរសញ្ញាចាស់ដែរ ។ អត្ថបទក្នុងសំបុត្រនេះមាននូវការពន្យល់ខ្លីៗ អំពីគោលការណ៍សម្រាប់ការរស់នៅជាគ្រីស្ទាន ។ លើសពីនេះទៀត វាមាននូវរឿងប្រៀបប្រដូចស្រដៀងគ្នារវាងទេសនកថារបស់ព្រះអង្គសង្គ្រោះនៅលើភ្នំដែលបានកត់ត្រានៅក្នុង ម៉ាថាយ៥–៧ និងពាក្យពេចន៍នានារបស់យ៉ាកុប ។ ប្រធានបទស្រដៀងគ្នាមួយចំនួន រួមមានការសុំទ្រាំនឹងការបៀតបៀន (សូមមើល យ៉ាកុប១:២–៣, ១២, ម៉ាថាយ ៥:១០–១២) ការក្លាយជា « ល្អឥតខ្ចោះ » ឬក៏ចម្រើនខាងវិញ្ញាណ (សូមមើល យ៉ាកុប ១:៤, ២:២២, ម៉ាថាយ ៥:៤៨) ការទូលសូមព្រះ (សូមមើល យ៉ាកុប ១:៥, ម៉ាថាយ ៧:៧–៨) ការធ្វើតាមព្រះទ័យរបស់ព្រះ (សូមមើល យ៉ាកុប ១:២២, ម៉ាថាយ ៧:២១–២៥) ការស្រឡាញ់មនុស្សដទៃ (សូមមើល យ៉ាកុប ២:៨, ម៉ាថាយ ៥:៤៣–៤៤, ៧:១២) ការស្គាល់សេចក្តីល្អ និងសេចក្តីអាក្រក់ដោយសារផលផ្លែរបស់វា (សូមមើល យ៉ាកុប ៣:១១–១២, ម៉ាថាយ ៧:១៥–២០) ការធ្វើជាអ្នកផ្សះផ្សា (សូមមើល យ៉ាកុប ៣:១៨, ម៉ាថាយ ៥:៩) និងការពុំត្រូវស្បថ (សូមមើល យ៉ាកុប ៥:១២, ម៉ាថាយ ៥:៣៤–៣៧) ។.

គម្រោង

យ៉ាកុប ១–២ យ៉ាកុបបានជម្រាបសួរដល់ពួកអ្នកអានរបស់លោក ហើយបានណែនាំពីប្រធានបទសំខាន់ៗមួយចំនួនក្នុងសំបុត្ររបស់លោក រួមមានការសុំទ្រាំនឹងការសាកល្បង ការស្វែងរកប្រាជ្ញា និងការរស់នៅជាប់លាប់ស្របនឹងសេចក្តីជំនឿរបស់មនុស្ស ។ ពួកអ្នកស្តាប់តាមបន្ទូលរបស់ព្រះក៏ត្រូវជាអ្នកធ្វើតាមបន្ទូលនោះដែរ ។ យ៉ាកុបឲ្យនិយមន័យ « សាសនាបរិសុទ្ធ » ថាជាការមើលថែពួកកំព្រា និងពួកមេម៉ាយ ហើយនិងការខិតខំរស់នៅឲ្យឆ្ងាយពីអំពើបាប (សូមមើល យ៉ាកុប ១:២៧) ។ ពួកបរិសុទ្ធត្រូវតែស្រឡាញ់ពួកអ្នកជិតខាងខ្លួន ហើយត្រូវបង្ហាញសេចក្តីជំនឿរបស់ពួកគេតាមរយៈកិច្ចការរបស់ពួកគេ ។

យ៉ាកុប ៣–៤ យ៉ាកុបបង្ហាញលក្ខណៈដែលបំផ្លិចបំផ្លាញនៃការមិនចេះគ្រប់គ្រងពាក្យសម្តី ហើយថាវាខុសពីផលផ្លែនៃសេចក្តីសុចរិតនៃជនដែលនាំមកនូវសេចក្តីសុខសាន្ត ។ លោកហាមពួកអ្នកអានរបស់លោកកុំឲ្យសេពគប់នឹងលោកិយ ប៉ុន្តែត្រូវតតាំងនឹងអារក្ស ហើយខិតទៅជិតព្រះ ។

យ៉ាកុប ៥ យ៉ាកុបព្រមានដល់ពួកអ្នកមានដែលទុច្ចរិត ។ លោកបញ្ចប់សំបុត្ររបស់លោកជាមួយចំណុចខ្លីៗ ស្តីពីការទូន្មានទាក់ទងនឹងការទទួលខុសត្រូវរបស់ពួកបរិសុទ្ធចំពោះសមាជិកផ្សេងទៀតក្នុងសាសនាចក្រ ។ លោកទូន្មានពួកបរិសុទ្ធឲ្យស៊ូទ្រាំដោយអត់ធ្មត់រហូតដល់ការយាងមករបស់ព្រះអម្ចាស់ ហើយត្រូវស្មោះត្រង់នៅក្នុងរាល់ការសន្ទនាទាំងឡាយរបស់ពួកគេ ។ យ៉ាកុបលើកទឹកចិត្តអ្នកឈឺឲ្យហៅពួកអែលឌើរឲ្យចាក់ប្រេងតាំងពួកគេ ។

យ៉ាកុប ១

សេចក្តីផ្តើម

យ៉ាកុបបានសរសេរសំបុត្រមួយទៅរង្សអ៊ីស្រាអែលដែលខ្ចាត់ព្រាត់ ដោយលើកទឹកចិត្តពួកគេឲ្យមានចិត្តអត់ធ្មត់នៅក្នុងការរងទុក្ខរបស់ខ្លួន ហើយស្វែងរកប្រាជ្ញាមកពីព្រះវរបិតាសួគ៌ ។ យ៉ាកុបក៏បានបង្រៀនពួកគេផងដែរឲ្យតតាំងនឹងការល្បួង ធ្វើជាអ្នកធ្វើតាមព្រះបន្ទូល បម្រើមនុស្សដទៃ ហើយរស់នៅដោយស្អាតស្អំខាងវិញ្ញាណ ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ១:១–១១

យ៉ាកុបលើកទឹកចិត្តពួកអ៊ីស្រាអែលដែលខ្ចាត់ព្រាត់ឲ្យមានចិត្តអត់ធ្មត់នៅក្នុងការរងទុក្ខរបស់ខ្លួន ហើយស្វែងរកប្រាជ្ញាមកពីព្រះ

ពីមុនថ្នាក់ចាប់ផ្តើម សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនេះលើក្តារខៀន ៖ *ខ្ញុំចង់ឲ្យខ្លួនឯងឆ្លាតជាងនេះ !* នៅពេលថ្នាក់ចាប់ផ្តើម សូមអញ្ជើញសិស្សឲ្យពិចារណាពីឃ្លានៅលើក្តារខៀន ។ សូមអញ្ជើញពួកគេឲ្យប្រើសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ដើម្បីសរសេរប្រធានបទ ឬស្ថានភាពផ្ទាល់ខ្លួនដែលពួកគេចង់មានប្រាជ្ញា ។ អ្នកអាចណែនាំឲ្យពួកគេដាក់បញ្ចូលប្រធានបទដំណឹងល្អ និងសំណួរសំខាន់ៗនៃជីវិតនៅក្នុងបញ្ជីរបស់ពួកគេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយប្រធានបទ ឬសំណួរមួយចំនួនដែលពួកគេបានសរសេរ ។ (សូមរំឭកពួកគេកុំឲ្យចែកចាយអ្វីដែលជារឿងផ្ទាល់ខ្លួនពេក) ។



ចូរដាក់បង្ហាញរូបភាពយ៉ូសែប ស៊្មីធ ស្វែងរកប្រាជ្ញានៅក្នុងព្រះគម្ពីរបរិសុទ្ធ (*Gospel Art Book* ⌊២០០៩⌋ ល.រ. ៨៩, សូមមើលផងដែរ LDS.org) ។

- តើសំណួរសំខាន់ៗអ្វីខ្លះទៅដែលធ្វើឲ្យ យ៉ូសែប ស៊្មីធ ពិបាកនឹងដោះស្រាយ កាលលោកនៅក្មេង ? (ប្រសិនបើសិស្សត្រូវការជំនួយ សូមឲ្យពួកគេបើកទៅ យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៩–១០) ។

សូមពន្យល់ថា យ៉ូសែបកំពុងអានសំបុត្ររបស់យ៉ាកុប កាលលោកបានរកឃើញពីរបៀបរកបានចម្លើយចំពោះសំណួររបស់លោក ។ យ៉ាកុបគឺជាសាវកមួយរូបរបស់ព្រះយេស៊ូវគ្រីស្ទ និងជាប៊ីស្សពម្នាក់នៅក្រុងយេរូសាឡិម ។ ទំនៀមទម្លាប់ពួកគ្រីស្ទានក៏ជឿដែរថា យ៉ាកុបគឺជាកូនប្រុសរបស់ម៉ារា និងយ៉ូសែប ដូច្នេះហើយលោកគឺជាបងប្អូនពោះតែមួយរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:១–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ាកុបបានបង្រៀនអ្វីខ្លះដល់រង្សអ៊ីស្រាអែលអំពីឧបសគ្គ និងការរងទុក្ខវេទនារបស់ពួកគេ ។ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ខទី ២ ផ្លាស់ប្តូរឃ្លា « សេចក្តីល្បួងផ្សេងៗ » ទៅជា « សេចក្តីទុក្ខវេទនាដ៏ច្រើន » ។

- តើយ៉ាកុបបានបង្រៀនរង្សអ៊ីស្រាអែលអំពីឧបសគ្គ និងសេចក្តីវេទនារបស់ពួកគេអ្វីខ្លះ ?
- ហេតុអ្វីវាជារឿងសំខាន់ ដើម្បីមានភាពអត់ធ្មត់នៅគ្រាមានឧបសគ្គ និងការរងទុក្ខវេទនា ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ១:៥–៦ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ូសែប ស៊្មីធ បានរកឃើញអ្វីខ្លះដែលបានជួយលោកឲ្យរកឃើញចម្លើយចំពោះសំណួររបស់លោក ។

- តើយ៉ាកុបបានទូន្មានពួកអ្នកអានរបស់លោកឲ្យធ្វើអ្វីខ្លះ ដើម្បីរកឃើញចម្លើយសម្រាប់សំណួររបស់ពួកគេ ?
- តើឃ្លាថាព្រះប្រទាន « ដោយសទ្ធា » ហើយ « ឥតបន្ទោស » ផងនោះមានន័យដូចម្តេច ? (ខទី ៥) ។ (*ដោយសទ្ធា* មានន័យថា ដោយសេរី និងដោយសប្បុរស ។ *បន្ទោស* មានន័យថា ស្តីថា ឬរិះគន់) ។

> **ម៉ាថាយ ១:៥–៦** គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀនសរសេរគោលការណ៍មួយ ដែលយើងអាចរៀននៅក្នុង យ៉ាកុប ១:៥–៦ ។ សិស្សអាចនឹងប្រើពាក្យខុសគ្នា ប៉ុន្តែគួរស្គាល់គោលការណ៍មួយស្រដៀងនឹងគោលការណ៍ ដូចតទៅនេះ ៖ **ព្រះប្រទានប្រាជ្ញាដោយសទ្ធាដល់ជនដែលទូលសូមដល់ទ្រង់ដោយសេចក្តីជំនឿ ។**

- តើឃ្លា « សូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ » មានន័យដូចម្តេច ? (ខទី ៦) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យពន្យល់ពីរបៀបដែល យ៉ាកុប ១:៥–៦ បានជះឥទ្ធិពលដល់យុវជន យ៉ូសែប ស៊្មីធ កាលលោកបានស្រាវជ្រាវរកចម្លើយ (សូមមើល យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១២) ។ សូមឲ្យសិស្សម្នាក់ទៀតទន្ទេញចាំនូវលទ្ធផលនៃការអធិស្ឋានដ៏ស្មោះត្រង់របស់ យ៉ូសែប ស៊្មីធ នៅក្នុងព្រៃក្បែរផ្ទះរបស់លោក ។

- តើព្រះវរបិតាសួគ៌ធ្លាប់ឆ្លើយតបការអធិស្ឋានរបស់អ្នកដោយសទ្ធានៅពេលណា បន្ទាប់ពីអ្នកបានធ្វើការអធិស្ឋានទៅកាន់ទ្រង់ដោយសេចក្តីជំនឿនោះ ?

សូមថ្លែងទីបន្ទាល់ថា ព្រះប្រទានប្រាជ្ញាដោយសន្ធាដល់អស់អ្នកណា ដែលសូមពីទ្រង់ដោយសេចក្តីជំនឿ ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមគំរូរបស់ យ៉ូសែប ស៊្មីធ ដោយអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ ដើម្បីឲ្យពួកគេអាចទទួលបានប្រាជ្ញា ដែលពួកគេត្រូវការមកពីព្រះវរបិតាសួគ៌ ។

សូមសង្ខេប យ៉ាកុប ១:៧–១១ ដោយពន្យល់ថា យ៉ាកុបបានព្រមានទាស់នឹងការមានចិត្តពីរ ឬងាករេនៅក្នុងភាពស្មោះត្រង់ និងការតាំងចិត្តចំពោះព្រះអម្ចាស់ ។ យ៉ាកុបក៏បានសរសេរផងដែរថា ពួកអ្នកមានគួរមានចិត្តរាបសា ដោយសារទ្រព្យសម្បត្តិនៅលើផែនដីគ្រាន់តែជាទ្រព្យបណ្តោះអាសន្នប៉ុណ្ណោះ ហើយមិនយូរប៉ុន្មានវានឹងរលាយបាត់ ។

កំណត់ចំណាំ ៖ សូមពិចារណាអញ្ជើញសិស្សពីរនាក់ឲ្យបង្រៀនបណ្តុំបទគម្ពីរដូចខាងក្រោម ។ វាពិតជាមានប្រយោជន៍ល្អ ប្រសិនបើឲ្យកិច្ចការនេះទៅសិស្សដែលបង្រៀន មួយថ្ងៃ ឬពីរថ្ងៃមុនមេរៀននេះ ដើម្បីពួកគេអាចត្រៀមខ្លួន ។ អ្នកអាចអញ្ជើញសិស្សម្នាក់ៗ ដែលបង្រៀនឲ្យបង្រៀនដល់សិស្សក្នុងថ្នាក់ទាំងមូល ។ ឬ អ្នកអាចបំបែកសិស្សក្នុងថ្នាក់ជាពីរក្រុម សូមអញ្ជើញសិស្សម្នាក់ ដែលត្រូវបង្រៀនឲ្យបង្រៀនបណ្តុំបទគម្ពីររបស់គាត់ទៅសិស្សពាក់កណ្តាលថ្នាក់ រួចហើយសូមសិស្សម្នាក់ទៀត (ឬ សិស្សក្នុងថ្នាក់) ឲ្យប្តូរវេនគ្នា ដើម្បីពួកគេអាចបង្រៀនដល់សិស្សមួយក្រុមទៀត ។

សិស្សទី ១ ដែលត្រូវបង្រៀន—យ៉ាកុប ១:១២–២១

យ៉ាកុបបង្រៀនអំពីការល្បួង

សូមសួរសិស្ស ៖

- តើយុវវ័យសព្វថ្ងៃនេះជួបប្រទះនឹងការល្បួងអ្វីខ្លះ ? (អ្នកគួរសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។
- ហេតុអ្វីក៏ពេលខ្លះវាពិបាកដើម្បីតតាំងនឹងការល្បួង ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:១២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពរជ័យដែលបានសន្យាដល់ជនដែលស្រឡាញ់ព្រះអម្ចាស់ ហើយតតាំងនឹងការល្បួង ។ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធសម្រាប់ខគម្ពីរនេះ៖ ផ្លាស់ប្តូរឃ្លា « ស៊ូទ្រាំនឹងសេចក្តីល្បួង » ទៅជា « តតាំងនឹងសេចក្តីល្បួង » ។

- តើនឹងមានពរជ័យអ្វីកើតឡើងដល់ជនដែលស្រឡាញ់ព្រះអម្ចាស់ ហើយតតាំងនឹងការល្បួង ? (បន្ទាប់ពីសិស្សឆ្លើយតប ចូរសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **យើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះអម្ចាស់ដោយតតាំងនឹងការល្បួង ដែលជាកិច្ចតម្រូវមួយ ដើម្បីទទួលបានមកុដនៃជីវិតដ៏នៅអស់កល្បជានិច្ច**) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប១:១៣–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើការល្បួងមកពីណា ហើយមិនមកពីណា ។

- យោងតាម ខទី១៣តើនរណាទៅដែល*ពុំមែន* ជាប្រភពនៃការល្បួងរបស់យើង ?

សូមពន្យល់ថា ពាក្យ *ក្រាក្ខា* នៅក្នុង ខទី ១៤ សំដៅទៅលើបំណងឥតបរិសុទ្ធដែលយើងអាចមាន ដោយសារតែនិស្ស័យជាមនុស្សរបស់យើង ។ សាតាំងអូសទាញយើងឲ្យបន្ធន់ចិត្តតាមបំណងឥតបរិសុទ្ធទាំងនេះ ។

សូមអញ្ជើញសិស្សឲ្យពិចារណាការល្បួងដែលពួកគេកំពុងមានបញ្ហា ។

- តើយើងអាចទទួលបានអំណាចខាងវិញ្ញាណយ៉ាងដូចម្តេច ដើម្បីតតាំងនឹងការល្បួង ?
- តើការតតាំងនឹងការល្បួងបង្ហាញថា យើងស្រឡាញ់ព្រះអម្ចាស់បានយ៉ាងដូចម្តេច ?

សូមថ្លែងទីបន្ទាល់ពីសេចក្តីពិតដ៏ពេញលេញនៃគោលការណ៍ដែលសិស្សបានស្គាល់នៅក្នុង យ៉ាកុប ១:១២ ។ សូមអញ្ជើញពួកគេឲ្យពិចារណាថាពួកគេនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីតតាំងនឹងការល្បួងដែលពួកគេកំពុងជួបប្រទះនោះ ។

សូមសង្ខេប យ៉ាកុប ១:១៧–២១ ដោយពន្យល់ថា យ៉ាកុបបានបង្រៀនថា រាល់អំណោយទានល្អៗកើតចេញមកពីព្រះ ហើយថាពួកបរិសុទ្ធគួរលះបង់ « សេចក្តីស្មោកគ្រោក » ហើយទទួលបន្ទូលរបស់ព្រះអម្ចាស់ « ដោយចិត្តសុភាព » (ខទី ២១) ។

សិស្សទី ២ ដែលត្រូវបង្រៀន—យ៉ាកុប ១:២២–២៥

យ៉ាកុបអញ្ជើញពួកអ្នកអានរបស់លោកឲ្យធ្វើជាអ្នកស្តាប់ និងអ្នកប្រព្រឹត្តតាមព្រះបន្ទូល

សូមអញ្ជើញសិស្សម្នាក់អានដំណើររឿងខាងក្រោមនេះ ដោយរៃលរឌើរ ឃ្វីនថិន អិល ឃុក ក្នុងភ្ញៀវកិត្តិយសនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ថ្មីៗនេះ ខ្ញុំបានជួបនឹងយុវជនដ៏ប្រពៃម្នាក់ ។ គោលដៅរបស់គាត់គឺការទៅបម្រើបេសកកម្ម បញ្ចប់ការសិក្សា រៀបការក្នុងព្រះវិហារបរិសុទ្ធ ហើយមានក្រុមគ្រួសារអរិភាពដ៏ស្មោះត្រង់មួយ ។ . . . ខ្ញុំឃើញថាគាត់ពិតជាចង់ទៅបម្រើបេសកកម្ម ហើយចៀសវាងរាល់អំពើរំលងធ្ងន់ធ្ងរនានា ដែលនឹងរារាំងគាត់ពីបេសកកម្ម ប៉ុន្តែការប្រព្រឹត្តរបស់គាត់ពីមួយថ្ងៃទៅមួយថ្ងៃពុំរៀបចំខ្លួនគាត់សម្រាប់ឧបសគ្គខាងសាច់ឈាម សតិអារម្មណ៍ សង្គម បញ្ញា និងខាងវិញ្ញាណដែលគាត់នឹងជួបប្រទះឡើយ ។ គាត់ពុំទាន់ចេះធ្វើការដោយព្យាយាមនៅឡើយទេ ។ គាត់ពុំយកចិត្តទុកដាក់នឹងការសិក្សា ឬចូលថ្នាក់សិក្ខាសាលាឡើយ ។ គាត់ទៅព្រះវិហារ តែពុំអានព្រះគម្ពីរមរមនឡើយ ។ គាត់ចំណាយពេលច្រើនលេងហ្គេមវីដេអូ និងប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ។ គាត់ទំនងជាគិតថា ការចេញបម្រើបេសកកម្មដ៏សាមញ្ញមួយគឺគ្រប់គ្រាន់ហើយមើលទៅ » (« Choose Wisely » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៤៧) ។

- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់អែលឌើរ ឃុក តើអ្នកមានក្តីបារម្ភអ្វីខ្លះចំពោះកង្វះខាតនៃការត្រៀមខ្លួនទៅបេសកកម្មរបស់យុវជននោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ាកុបបានបង្រៀនអ្វីខ្លះ ដែលវាអាចជួយយុវជននៅក្នុងដំណើរជឿងរបស់អែលឌើរ ឃុកនោះ ។

- តើយ៉ាកុបបានបង្រៀនអ្វីខ្លះ ដែលវាអាចជួយដល់យុវជននោះ ?

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង យ៉ាកុប ១:២៣–២៤ យ៉ាកុបបានប្រៀបប្រដូចមនុស្សម្នាក់ដែលស្តាប់ ប៉ុន្តែពុំមែនជាអ្នកប្រព្រឹត្តតាម ទៅនឹងមនុស្សដែលឆ្លុះកញ្ចក់មើលខ្លួនឯង ប៉ុន្តែភ្លេចថាខ្លួនគាត់មានភិនភាគយ៉ាងណា កាលគាត់ដើរចេញទៅ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាមានអ្វីកើតឡើងចំពោះជនដែលជ្រើសរើសធ្វើតាមសេចក្តីពិតដែលពួកគេបានស្តាប់ឮ ។

- តើមានអ្វីកើតឡើងចំពោះជនដែលស្តាប់ ហើយប្រព្រឹត្តតាម ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **នៅពេលយើងស្តាប់ ហើយធ្វើតាមព្រះបន្ទូលទ្រង់នឹងប្រទានពរយើងនៅក្នុងការប្រព្រឹត្តរបស់យើង**) ។

សូមអញ្ជើញសិស្សឲ្យវាយតម្លៃខ្លួនឯងថា ជាអ្នកស្តាប់ និងអ្នកប្រព្រឹត្តតាមព្រះបន្ទូលដោយពិចារណាពីសំណួរខាងក្រោមនេះ ។ អ្នកគួរអានសំណួរទាំងនេះឲ្យឮៗ ឬសរសេរវាដាក់លើក្តារខៀន ។

១. តើខ្ញុំជឿលើសេចក្តីពិតដែលខ្ញុំកំពុងរៀននៅក្នុងព្រះគម្ពីរ នៅផ្ទះ នៅព្រះវិហារ និងនៅថ្នាក់សិក្ខាសលាខ្លាំងប៉ុណ្ណាដែរ ?

២. តើខ្ញុំដាក់គោលដៅខាងវិញ្ញាណ ដើម្បីធ្វើតាមសេចក្តីពិតដែលខ្ញុំនឹងរៀនញឹកញាប់ប៉ុណ្ណាដែរ ? តើខ្ញុំសម្រេចវាបានញឹកញាប់ប៉ុណ្ណាដែរ ? តើខ្ញុំភ្លេចវាញឹកញាប់ប៉ុណ្ណាដែរ ?

៣. តើខ្ញុំអាចធ្វើអ្វីខ្លះ ឲ្យកាន់តែប្រសើរឡើង ដើម្បីធ្វើជាអ្នកប្រព្រឹត្តតាមព្រះបន្ទូល និងពុំគ្រាន់តែជាអ្នកស្តាប់ប៉ុណ្ណោះ ?

សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយ ដែលបានមកនៅពេលយើងធ្វើតាមអ្វីដែលយើងរៀន ។

យ៉ាកុប ១:២៦–២៧

យ៉ាកុបទូន្មានពួកបរិសុទ្ធឲ្យរមែលថៃទាំដល់មនុស្សដទៃ

បន្ទាប់ពីសិស្សពីរនាក់បានបង្រៀនបណ្តុំបទគម្ពីររបស់ពួកគេរួច សូមឲ្យសិស្សបីបួននាក់សង្ខេបថា ពួកគេបានរៀនអ្វីខ្លះ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:២៦–២៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលការផ្តល់យោបល់របស់យ៉ាកុបចំពោះរបៀបដែលយើងអាចរស់នៅតាមសាសនារបស់យើង ។

- យោងតាមយ៉ាកុប តើអ្វីទៅជាវិធីមួយចំនួន ដែលយើងអាចរស់នៅតាមសាសនារបស់យើង ឬបង្ហាញការលះបង់របស់យើងចំពោះព្រះ ?

សូមពន្យល់ថា យ៉ាកុបបានប្រើគំនិតនៃការ « ទៅសួរពួកកំព្រា និងពួកមេម៉ាយ » ដែលខ្វះខាតជាឧទាហរណ៍មួយនៃការមើលថៃទាំដល់មនុស្សដទៃ ។ ការ « រក្សាខ្លួនមិនឲ្យប្រឡាក់ដោយលោកីយ៍ » (ខទី ២៧) មានន័យថាការបន្តស្អាតស្អំខាងវិញ្ញាណ សូម្បីនៅក្នុងពិភពលោកមួយដែលសេចក្តីទុច្ចរិតកាន់តែមានច្រើនឡើង ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង ខទី ២៧ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែចូរធ្វើឲ្យប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **យើងបង្ហាញពីសាសនាដែលបរិសុទ្ធ នៅពេលយើងខ្វល់ខ្វាយពីមនុស្សដទៃ ហើយរក្សាខ្លួនយើងឲ្យស្អាតស្អំខាងវិញ្ញាណ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

- តើការខ្វល់ខ្វាយចំពោះមនុស្សដទៃ ហើយរក្សាខ្លួនយើងឲ្យស្អាតស្អំខាងវិញ្ញាណ អាចជាការបង្ហាញដ៏សំខាន់អំពីការលះបង់របស់យើងចំពោះព្រះតាមរបៀបណា ?

- តើអ្នកស្គាល់នរណាដែលជាគំរូដ៏ល្អមួយនៃការបង្ហាញពី « សាសនាដែលបរិសុទ្ធ » នៅក្នុងជីវិតប្រចាំថ្ងៃរបស់គាត់ឬទេ ? តើបុគ្គលនេះធ្វើអ្វីខ្លះដែលបំផុសគំនិតអ្នក ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្រដាសនូវការប្រព្រឹត្តមួយ ឬពីរដែលពួកគេនឹងធ្វើ នៅសប្តាហ៍ក្រោយដើម្បីមើលថែមនុស្សម្នាក់ដែលខ្វះខាត ឬរក្សាខ្លួនពួកគេ « មិនឲ្យប្រឡាក់ដោយលោកីយ៍ » ។ សូមអញ្ជើញពួកគេឲ្យធ្វើជាអ្នកប្រព្រឹត្តតាមព្រះបន្ទូលដោយអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ ។

📖 ចំណេះចំណានខគម្ពីរ—យ៉ាកុប ១:៥–៦

សូមពន្យល់ថា ការទន្ទេញចាំ យ៉ាកុប ១:៥–៦ នឹងជួយសិស្សនៅក្នុងជីវិតរបស់ពួកគេ នៅពេលពួកគេមានសំណួរអំពីដំណឹងល្អ នៅពេលពួកគេស្វែងរកជំនួយរបស់ព្រះអម្ចាស់នៅក្នុងការសម្រេចចិត្ត និងនៅពេលពួកគេបង្រៀនដំណឹងល្អដល់មនុស្សដទៃ ។

សូមប្រើសកម្មភាពការទន្ទេញចាំមួយនៅក្នុងឧបសម្ព័ន្ធ ឬបង្កើតសកម្មភាពផ្ទាល់ខ្លួនមួយរបស់អ្នក ដើម្បីជួយសិស្សឲ្យទន្ទេញចាំបទគម្ពីរនេះ ។ សូមចងចាំដើម្បីរំឭកសារឡើងវិញនូវគ្នាចំណេះចំណានខគម្ពីរ ដែលបានទន្ទេញចាំឡើងវិញជាញឹកញាប់ជាមួយនឹងសិស្ស ដើម្បីជួយពួកគេឲ្យនៅចាំអ្វីដែលពួកគេបានរៀន ។ សូមពិចារណារៀបចំពេលវេលានៅក្នុងមេរៀនខាងមុខ ដើម្បីរំឭកឡើងវិញនូវបទគម្ពីរនេះ ហើយអញ្ជើញសិស្សឲ្យសូត្រវា ។

មេរៀនសិក្សានៅផ្ទះ

ហេព្រើរ ៥–យ៉ាកុប១ (មេរៀនទី ២៨)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ហេព្រើរ៥–យ៉ាកុប១ (មេរៀនទី ២៨) ពុំត្រូវយកមកបង្រៀន ជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី១ (ហេព្រើរ ៥–៦)

នៅក្នុងការសរសេររបស់ប៉ុលអំពីសិទ្ធិអំណាចបព្វជិតភាព សិស្សបានរៀនថា ជនដែលទទួលបានការតែងតាំងសម្រាប់បព្វជិតភាពត្រូវមានការហៅមកពីព្រះដោយវិរាណៈតាមរយៈពួកអ្នកបម្រើរបស់ទ្រង់ដែលមានសិទ្ធិអំណាច ។ សិស្សក៏រៀនផងដែរនូវសេចក្តីពិតដូចតទៅនេះ ៖ តាមរយៈភាពឧស្សាហ៍ព្យាយាមរហូតដល់ទីបញ្ចប់ សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងការអត់ធ្មត់ យើងអាចគ្រងពរជ័យដែលព្រះបានសន្យា ។ សេចក្តីសង្ឃឹមរបស់យើងលើការសន្យារបស់ព្រះគឺជាយុថ្កាខាងវិញ្ញាណមួយសម្រាប់ព្រលឹងយើង ។

ថ្ងៃទី ២ (ហេព្រើរ៧–១០)

នៅពេលសិស្សសិក្សា ហេព្រើរ ៧–១០ ពួកគេបានរៀនថា ព្រះយេស៊ូវគ្រីស្ទបានថ្វាយព្រះជន្មទ្រង់ផ្ទាល់ជាដង្វាយសម្រាប់អំពើបាបរបស់យើង ហើយថាដោយសារតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចចូលទៅក្នុងនគរសេឡេស្ទាលបាន ប្រសិនបើយើងកាន់ខ្ជាប់ទៅនឹងសេចក្តីជំនឿរបស់យើងលើទ្រង់ ។

ថ្ងៃទី៣ (ហេព្រើរ ១១)

នៅក្នុងការសិក្សារបស់ពួកគេស្តីពីការបង្រៀនរបស់ប៉ុលអំពីសេចក្តីជំនឿ សិស្សបានរៀនថា សេចក្តីជំនឿគឺជាការអះអាងថានឹងបាន នូវអ្វីដូចជាសង្ឃឹមទុក ជាភស្តុតាងនៃរឿងដែលមើលមិនឃើញ ។ ពួកគេក៏បានរៀនដូចតទៅនេះផងដែរ ៖ ដើម្បីធ្វើឲ្យព្រះសព្វព្រះទ័យ យើងត្រូវតែអនុវត្តសេចក្តីជំនឿរបស់យើងដោយការមកកន្ទ្រង់ ជឿលើទ្រង់ ហើយជឿថាទ្រង់នឹងប្រទានរង្វាន់ដល់ជនដែលខិតខំរកទ្រង់ដោយឧស្សាហ៍ ។ នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចស៊ូទ្រាំនឹងការរងទុក្ខធ្វើអព្ភូតហេតុ ទទួលការសន្យាមកពីព្រះ ពង្រឹងទីបន្ទាល់របស់យើងអំពីទ្រង់ ហើយដើរឆ្ពោះទៅរកភាពល្អឥតខ្ចោះ ។

ថ្ងៃទី ៤ (ហេព្រើរ១២–យ៉ាកុប១)

នៅពេលសិស្សសិក្សានៅផ្នែកចុងបញ្ចប់នៃសំបុត្ររបស់ប៉ុលរហូតដល់ហេព្រើរ ពួកគេបានរៀនថា នៅពេលយើងមើលទៅគំរូរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចរកឃើញកម្លាំងដើម្បីបោះបង់ចោលអំពើបាបរបស់យើង ហើយស៊ូទ្រាំនឹងការផ្ទុយដោយអត់ធ្មត់ ។ ពួកគេក៏បានរៀនផងដែរថា ប្រសិនបើយើងចុះចូលនឹងការផ្ចាញ់ផ្ចាលមកពីព្រះវរបិតាសួគ៌ យើងនឹងប្រែក្លាយកាន់តែដូចទ្រង់ ហើយមានសេចក្តីសុខសាន្តដែលកើតចេញពីសេចក្តីសុចរិត ។ នៅក្នុងការសិក្សារបស់ពួកគេអំពី យ៉ាកុប១ សិស្សបានរៀនថា ព្រះប្រទានប្រាជ្ញាដោយសប្បុរសដល់ជនដែលទូលសូមទ្រង់ដោយសេចក្តីជំនឿ ។

សេចក្តីផ្តើម

សាវកយ៉ាកុបបានទូន្មានពួកអ្នកប្រព្រឹត្តតាមព្រះបន្ទូលឲ្យបម្រើដល់មនុស្សជាទៃ ហើយបន្តមានភាពស្អាតស្អំខាងវិញ្ញាណ ។

គោលបំណងសម្រាប់ការបង្រៀន

គំណត់ចំណាំ ៖ សិស្សបានរៀនគ្នាចំណេះចំណានខគម្ពីរចំនួនពីរនៅក្នុងមេរៀននេះ—ហេព្រើរ ១២:៩ និងយ៉ាកុប ១:៥–៦ ។ អ្នកគួរអាន ឬសូត្រគ្នាទាំងនេះរួមគ្នាជាមួយសិស្ស ហើយអញ្ជើញឲ្យសិស្សពន្យល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលគ្នានេះបង្រៀន ។

យ៉ាកុប១:២២–២៧

យ៉ាកុបអញ្ជើញពួកអ្នកអានរបស់លោកឲ្យធ្វើជាអ្នកស្តាប់ និងអ្នកប្រព្រឹត្តតាមព្រះបន្ទូល ហើយបម្រើដល់មនុស្សជាទៃ

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមនេះដោយអែលឌើរ ឃ្វីនថិន អិល ឃុក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ៖



« ថ្មីៗនេះ ខ្ញុំបានជួបនឹងយុវជនដ៏ប្រពៃម្នាក់ ។ គោលដៅរបស់គាត់គឺការទៅបម្រើបេសកកម្ម បញ្ចប់ការសិក្សា រៀបការក្នុងព្រះវិហារបរិសុទ្ធ ហើយមានក្រុមគ្រួសារីករាយជាមួយគ្នា ។ ខ្ញុំពេញចិត្តគោលដៅរបស់គាត់ ។ ប៉ុន្តែនៅពេលបន្តការពិភាក្សា វាបង្ហាញថាការប្រព្រឹត្ត និងជម្រើសរបស់គាត់ពុំស្របទៅនឹងគោលដៅគាត់ឡើយ ។ ខ្ញុំឃើញថាគាត់ពិតជាចង់ទៅបម្រើបេសកកម្ម ហើយចៀសវាងពីអំពើរំលងធ្ងន់ធ្ងរនានា ដែលនឹងបង្អាក់គាត់ពីបេសកកម្ម ប៉ុន្តែការប្រព្រឹត្តរបស់គាត់ពីមួយថ្ងៃទៅមួយថ្ងៃពុំរៀបចំខ្លួនគាត់សម្រាប់ឧបសគ្គខាងសាច់ឈាម សតិអារម្មណ៍ សង្គម បញ្ញា និងខាងវិញ្ញាណដែលគាត់នឹងជួបប្រទះឡើយ ។ គាត់ពុំទាន់ចេះធ្វើការដោយព្យាយាមនៅឡើយទេ ។ គាត់ពុំយកចិត្តទុកដាក់នឹងការសិក្សា ឬចូលថ្នាក់សិក្ខាសាលាឡើយ។ គាត់ទៅព្រះវិហារ តែពុំអានព្រះគម្ពីរមមនឡើយ ។ គាត់ចំណាយពេលច្រើនលេងវីដេអូហ្គេម និងប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ។ គាត់ទំនងជាគិតថា ការចេញបម្រើបេសកកម្មដ៏សាមញ្ញមួយគឺគ្រប់គ្រាន់ហើយមើលទៅ » (« Choose Wisely » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៤៧) ។

- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់អែលឌើរ ឃុក តើអ្នកមានក្តីបារម្ភអ្វីខ្លះចំពោះកង្វះខាតនៃការត្រៀមខ្លួនទៅបេសកកម្មរបស់យុវជននោះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប១:២២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ាកុបបានបង្រៀនអ្វីខ្លះ ដែលវាអាចជួយយុវជននោះនៅក្នុងដំណើររឿងរបស់អែលឌើរ ឃុក ។

- តើយ៉ាកុបបានបង្រៀនអ្វីខ្លះដែលវាអាចជួយយុវជននោះ ?

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង យ៉ាកុប ១:២៣–២៤ យ៉ាកុបបានប្រៀបប្រដូចមនុស្សម្នាក់ដែលស្តាប់ ប៉ុន្តែពុំបានប្រព្រឹត្តតាម ទៅនឹងមនុស្សដែលឆ្លុះកញ្ចក់មើលខ្លួនឯង ប៉ុន្តែភ្លេចថាខ្លួនគាត់មានកិនភាគយ៉ាងណា កាលគាត់ដើរចេញទៅ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:២៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាមានអ្វីកើតឡើងចំពោះជនដែលជ្រើសរើសធ្វើតាមសេចក្តីពិតដែលពួកគេបានស្តាប់ឮ ។

- តើមានអ្វីកើតឡើងចំពោះជនដែលស្តាប់ ហើយប្រព្រឹត្តតាម ? (បន្ទាប់ពីសិស្សឆ្លើយ សូមសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **នៅពេលយើងស្តាប់ ហើយធ្វើតាមព្រះបន្ទូល ទ្រង់នឹងប្រទានពរដល់យើងនៅក្នុងការប្រព្រឹត្តតាមរបស់យើង**) ។

សូមអញ្ជើញសិស្សឲ្យវាយតម្លៃខ្លួនឯងថាជាអ្នកស្តាប់ និងអ្នកប្រព្រឹត្តតាមព្រះបន្ទូល ដោយពិចារណាពីសំណួរខាងក្រោមនេះ ។ អ្នកគួរអានសំណួរទាំងនេះឲ្យឮៗ ឬសរសេរវាដាក់លើក្តារខៀន ។

- តើខ្ញុំជឿលើសេចក្តីពិតដែលខ្ញុំកំពុងរៀននៅក្នុងព្រះគម្ពីរ នៅផ្ទះ នៅព្រះវិហារ និងនៅថ្នាក់សិក្ខាសាលាខ្លាំងប៉ុណ្ណាដែរ ?
- តើខ្ញុំជាក់គោលដៅខាងវិញ្ញាណ ដើម្បីធ្វើតាមសេចក្តីពិតដែលខ្ញុំនឹងរៀនញឹកញាប់ប៉ុណ្ណាដែរ ? តើខ្ញុំសម្រេចវាបានញឹកញាប់ប៉ុណ្ណាដែរ ? តើខ្ញុំភ្លេចវាជាញឹកញាប់ប៉ុណ្ណាដែរ ?
- តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បីឲ្យវាប្រសើរឡើង ក្នុងការធ្វើជាអ្នកប្រព្រឹត្តតាមព្រះបន្ទូល ពុំគ្រាន់តែជាអ្នកស្តាប់ម្នាក់នោះទេ ?

សូមថ្លែងទីបន្ទាល់អំពីពរជ័យទាំងឡាយដែលបានមក នៅពេលយើងធ្វើតាមអ្វីដែលយើងរៀន ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ១:២៦–២៧ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមកេមើលការផ្តល់យោបល់របស់យ៉ាកុប ចំពោះរបៀបដែលយើងអាចរស់នៅតាមសាសនារបស់យើង ។

- យោងតាមយ៉ាកុប តើអ្វីទៅជាវិធីមួយចំនួនដែលយើងអាចរស់នៅ តាមសាសនារបស់យើង ឬបង្ហាញការលះបង់របស់លោកចំពោះព្រះ ?

សូមពន្យល់ថា ខទី ២៧ យ៉ាកុបបានប្រើគំនិតនៃការ « ទៅសួរពួកកំព្រា និងពួកមេម៉ាយ » ដែលខ្វះខាតជាគំរូមួយនៃការមើលថែមនុស្សដទៃ ហើយថាការ « រក្សាខ្លួនមិនឲ្យប្រឡាក់ដោយលោកីយ៍ » មានន័យថាការបន្តស្អាតស្អំខាងវិញ្ញាណ សូម្បីនៅក្នុងពិភពលោកមួយ ដែលសេចក្តីទុច្ចរិតកាន់តែមានច្រើនឡើងក្តី ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុង យ៉ាកុប១:២៧ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែចូរធ្វើឲ្យប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **យើងបង្ហាញពីសាសនាដែលបរិសុទ្ធ នៅពេលយើងខ្វល់ខ្វាយពីមនុស្សដទៃ ហើយរក្សាខ្លួនយើងឲ្យស្អាតស្អំខាងវិញ្ញាណ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើការខ្វល់ខ្វាយចំពោះមនុស្សដទៃ ហើយរក្សាខ្លួនយើងឲ្យស្អាតស្អំខាងវិញ្ញាណ អាចជាការបង្ហាញដ៏សំខាន់អំពីការលះបង់របស់យើងចំពោះព្រះតាមរបៀបណា ?
- តើអ្នកស្គាល់នរណា ដែលជាគំរូដ៏ល្អម្នាក់នៃការបង្ហាញ « សាសនាដែលបរិសុទ្ធ » នៅក្នុងជីវិតប្រចាំថ្ងៃរបស់គាត់ដែរឬទេ ? តើបុគ្គលនេះធ្វើអ្វីខ្លះដែលបំផុសគំនិតអ្នក ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្រដាសនូវការប្រព្រឹត្តមួយ ឬពីរដែលពួកគេនឹងធ្វើនៅសប្តាហ៍ក្រោយ ដើម្បីមើលថែមនុស្សម្នាក់ ដែលខ្វះខាត ឬរក្សាខ្លួនពួកគេ « មិនឲ្យប្រឡាក់ដោយលោកីយ៍ » ។ សូមអញ្ជើញពួកគេឲ្យធ្វើជាអ្នកប្រព្រឹត្តតាមព្រះបន្ទូល ដោយយកគោលការណ៍នេះមកអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនបន្ទាប់ (យ៉ាកុប ២–ពេត្រុសទី១ ៥)

សូមពន្យល់សិស្សថា នៅពេលពួកគេសិក្សា យ៉ាកុប ២–ពេត្រុសទី១ ៥ ពួកគេនឹងរៀនពីចម្លើយសម្រាប់សំណួរដូចតទៅនេះ ៖ តើយ៉ាកុបបានទូន្មានពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ប្រសិនបើពួកគេបានឃើញបងប្អូនប្រុស ឬស្រីម្នាក់ដែល « អាក្រាត ព្រមទាំងខ្វះអាហារបរិភោគរាល់ថ្ងៃ » ? (យ៉ាកុប២:១៥) ។ ចុះបើយើងពុំបានធ្វើអ្វីសោះ ដើម្បីជួយជនខ្វះខាតវិញនោះ ? ហេតុអ្វីយ៉ាកុបបាននិយាយថា « ពីព្រោះសេចក្តីជំនឿ បើគ្មានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ » ? (យ៉ាកុប ២:២៦) ។ តើផ្នែកអ្វីខ្លះនៃរូបកាយដែលយ៉ាកុបបានថ្លែងថាជា « ភ្លើង » ហើយអាច « ធ្វើឲ្យរូបកាយទាំងមូលស្មោកគ្រោក » ? (យ៉ាកុប៣:៦) ។ តើពរជ័យអ្វីកំពុងរង់ចាំជនដែលជួយប្រែចិត្តមនុស្សមានបាបម្នាក់ « ឲ្យត្រឡប់ពីផ្លូវវង្វេងមកវិញ » ? (យ៉ាកុប ៥:២០) ។ តើពេត្រុសបានផ្តល់ហេតុផលអ្វីខ្លះ សម្រាប់ការប្រកាសដំណឹងល្អដល់ពួកមនុស្សស្លាប់ ? សូមអញ្ជើញសិស្សឲ្យរកមើលចម្លើយសម្រាប់សំណួរទាំងនេះ នៅពេលពួកគេសិក្សាខគម្ពីរបន្ទាប់ទៀត ។

យ៉ាកុប ២

សេចក្តីផ្តើម

យ៉ាកុបបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យឈោងទៅជួយអ្នកដែលត្រូវគេជិះជាន់ ហើយលោកបានបង្រៀនថា ពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទពុំត្រូវពេញចិត្តអ្នកមានច្រើនជាងអ្នកក្រីក្រឡើយ ។ យ៉ាកុបក៏បានបង្រៀនផងដែរអំពីទំនាក់ទំនងរវាងសេចក្តីជំនឿ និងការប្រព្រឹត្តតាម ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ២:១–១៣

យ៉ាកុបបង្រៀនថាពួកអ្នកដើរតាមព្រះគ្រីស្ទពុំគួរបង្ហាញការនិយមចូលចិត្តតែចំពោះអ្នកមានឡើយ

សូមជ្រើសសិស្សម្នាក់ដោយចៃដន្យ ហើយឲ្យស្ករគ្រាប់តូចមួយដល់គាត់ ។ សូមប្រាប់ដល់សិស្សក្នុងថ្នាក់ថា អ្នកបានឲ្យស្ករមួយគ្រាប់ដល់សិស្សម្នាក់នេះដោយសារមានហេតុផលមួយចំនួន ដែលបានជ្រើសរើសតាមចិត្ត (ឧទាហរណ៍ ដោយសារសិស្សនោះបានស្លៀកពាក់ខោអាវមានពណ៌ដែលអ្នកចូលចិត្ត ឬ ដោយសារគាត់បានយកវត្ថុដ៏ជាក់លាក់មួយមកថ្នាក់រៀន) ។

- **តើការប្រព្រឹត្តរបស់ខ្ញុំទៅលើសិស្សម្នាក់នេះធ្វើឲ្យអ្នករាល់គ្នាមានអារម្មណ៍បែបណាដែរ ?**
- **ហេតុអ្វីពេលខ្លះមនុស្សបង្ហាញនូវការនិយមចូលចិត្ត ?**

សូមឲ្យសិស្សគិតអំពីគ្រាផ្សេង ដែលពួកគេធ្លាប់បានឃើញមនុស្សម្នាក់ត្រូវបានគេយកចិត្តទុកដាក់ច្រើនជាងមនុស្សដទៃទៀត ហើយពិចារណាថា វាធ្វើឲ្យពួកគេមានអារម្មណ៍បែបណាដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ២:១–៤ ឲ្យឮៗ ។ សូមឲ្យសិស្សនេះអានការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ យ៉ាកុប ២:១ ផងដែរ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ាកុបបានព្រមានពួកបរិសុទ្ធអំពីអ្វីខ្លះ ។

- **តើយ៉ាកុបបានព្រមានពួកបរិសុទ្ធអំពីអ្វីខ្លះ ?**

សូមចង្អុលបង្ហាញថាការ « រើសមុខអ្នកណា »(ការបកប្រែដោយ យ៉ូសែប ស៊្មីធ យ៉ាកុប ២:១) មានន័យថា ការបង្ហាញការនិយមចូលចិត្តចំពោះមនុស្សម្នាក់ ឬមនុស្សមួយក្រុមកាលប្រព្រឹត្តផ្ទុយគ្នាចំពោះមនុស្សផ្សេងទៀត ដោយសារតែកាលៈទេសៈ ឬចរិតលក្ខណៈរបស់ពួកគេ ។

- **តើយ៉ាកុបបានចែកឧទាហរណ៍អ្វីខ្លះអំពីការនិយមចូលចិត្ត ?**
- **តើឧទាហរណ៍អ្វីខ្លះនៅក្នុងជំនាន់របស់យើងអំពីបុគ្គលដែលបង្ហាញការនិយមចូលចិត្តចំពោះមនុស្សមួយចំនួន ការប្រព្រឹត្តផ្ទុយគ្នាចំពោះមនុស្សផ្សេងទៀត ដោយសារតែកាលៈទេសៈ ឬចរិតលក្ខណៈរបស់ពួកគេនោះ ?**

សូមសង្ខេប យ៉ាកុប ២:៥–៧ ដោយពន្យល់ថា យ៉ាកុបបានបន្តស្តីបន្ទោសដល់ពួកបរិសុទ្ធដែលបានបង្ហាញការនិយមចូលចិត្តចំពោះអ្នកមាន ។ លោកបានបង្រៀនពួកគេថា ព្រះបានជ្រើសអ្នកក្រីក្រឲ្យធ្វើជាអ្នកមាននៅក្នុងសេចក្តីជំនឿ ហើយគ្រងមរតកក្នុងនគររបស់ទ្រង់ ។ យ៉ាកុបក៏បានរំឭកពួកបរិសុទ្ធផងដែរថា គឺអ្នកមានដែលបានជិះជាន់ពួកគេ ហើយប្រមាថទាស់នឹងព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ២:៨ ដោយស្ងៀមស្ងាត់រកមើលថាយ៉ាកុបបានរំឭកពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ដែលវានឹងជួយពួកគេឲ្យបញ្ឈប់ការនិយមចូលចិត្ត ។

- **តើយ៉ាកុបបានរំឭកពួកបរិសុទ្ធធ្វើអ្វីខ្លះ ?**
- **ហេតុអ្វីអ្នកគិតថា បទបញ្ញត្តិនេះត្រូវបានហៅថាជា « ក្រឹត្យវិន័យដ៏ប្រសើរ » ? (យ៉ាកុប ២:៨) ។**
- **តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ចេញពីខគម្ពីរទាំងនេះ អំពីរបៀបដែលពួកសិស្សដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទប្រព្រឹត្តចំពោះមនុស្សទូទៅ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីគោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ពួកសិស្សស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទស្រឡាញ់មនុស្សទាំងអស់ដោយពុំគិតពីកាលៈទេសៈរបស់ពួកគេឡើយ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។**
- **នៅក្នុងការងារបម្រើរបស់ទ្រង់ក្នុងជីវិតមែងស្លាប់ តើព្រះអង្គសង្គ្រោះគឺជាគំរូនៃការស្រឡាញ់មនុស្សដទៃ ដោយពុំគិតពីកាលៈទេសៈរបស់ពួកគេបានដោយរបៀបណា ?**

សូមឲ្យសិស្សគិតពីមនុស្សម្នាក់ដែលខិតខំស្រឡាញ់មនុស្សទូទៅ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់ពីមនុស្សដែលពួកគេគិតឃើញ និងពីហេតុផល ។

សូមឲ្យសិស្សពិចារណាពីរបៀបដែលពួកគេប្រព្រឹត្តចំពោះមនុស្សដទៃ ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលឱកាសដើម្បីធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះអំពីការស្រឡាញ់មនុស្សដទៃ ។

សូមអញ្ជើញសិស្សស្រមៃថា បន្ទាប់ពីស្តាប់ឮការបង្រៀនរបស់យ៉ាកុបអំពីការស្រឡាញ់ដល់មនុស្សទូទៅ ពួកគេស្តាប់ឮមនុស្សម្នាក់និយាយថា វាពុំជាបញ្ហាសំខាន់នោះទេ ប្រសិនបើយើងបង្ហាញការនិយមចូលចិត្តចំពោះមនុស្សមួយចំនួន ខណៈដែលប្រព្រឹត្តដាក់មនុស្សដទៃពុំគប្បី ។ បុគ្គលនេះក៏បាននិយាយផងដែរថា មានរឿងដ៏អាក្រក់ដែលយើងអាចធ្វើបានច្រើនជាងនេះទៀត ។

- តើបញ្ហាអ្វីខ្លះអាចកើតចេញពីការមានគំនិតបែបនេះ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប២:៩–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ហេតុអ្វីវាជាបញ្ហាមួយដ៏ធ្ងន់ធ្ងរដែលពុំស្រឡាញ់មនុស្សទូទៅដោយមិនគិតពីកាលៈទេសៈរបស់ពួកគេ ។

- ហេតុអ្វីវាជាបញ្ហាមួយដ៏ធំដែលពុំស្រឡាញ់មនុស្សទូទៅ ដោយមិនគិតពីកាលៈទេសៈរបស់ពួកគេ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីការបង្រៀនរបស់យ៉ាកុបនៅក្នុងខគម្ពីរទាំងនេះ ? (សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ប្រសិនបើយើងធ្វើអំពើបាបសូម្បីតែមួយ យើងនឹងមានកំហុសចំពោះព្រះ**) ។
- យោងតាម យ៉ាកុប ២:១០ តើអ្វីទៅជាផលប៉ះពាល់ដ៏នៅអស់កល្បជានិច្ចនៃការបំពាន សូម្បីតែបទបញ្ញត្តិតែមួយរបស់ព្រះក្តី ? (យើងក្លាយជា « មានទោសចំពោះក្រឹត្យវិន័យទាំងមូល » ដោយសារយើងគ្មានភាពស្អាតស្អំ ហេតុដូច្នេះហើយ យើងពុំអាចរស់នៅជាមួយនឹងព្រះបានឡើយ [សូមមើលផងដែរ នីហ្វៃទី១ ១០:២១]) ។
- ហេតុអ្វីយើងអាចនៅតែមានសង្ឃឹម ទោះបីជាការពុំគោរពប្រតិបត្តិតាមព្រះធ្វើឲ្យយើងពុំស្អាតស្អំដើម្បីរស់នៅជាមួយនឹងព្រះក្តី ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗដោយប្រធាន ឌៀថើរ អេហ្វ អ៊ុជដូហ្វ នៃគណៈប្រធានទីមួយ ៖



« មនុស្សគ្រប់រូបមិនវិនាសបង់ឡើយ ។

« ព្រះគុណនៃព្រះគឺជាសេចក្តីសង្ឃឹមដ៏ធំ និងគ្មានទីបំផុត ។

« តាមរយៈពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ នោះផែនការនៃសេចក្តីមេត្តាករុណារំងាប់ដល់តម្រូវការនៃសេចក្តីយុត្តិធម៌ [សូមមើលអាលម៉ា ៤២:១៥] ‹ ហើយ [នាំមកនូវ] មធ្យោបាយទាំងឡាយដល់មនុស្ស ដើម្បីឲ្យគេមានសេចក្តីជំនឿចំពោះការប្រែចិត្ត › [អាលម៉ា ៣៤:១៥] ។

« ទោះបើអំពើបាបរបស់យើង អាចពណ៌ក្រហមទៃង ក៏ដោយ គង់តែនឹងបានសដូចហិមៈ [សូមមើលអេសាយ ១:១៨] ។ ដោយសារព្រះអង្គសង្គ្រោះជាទីស្រឡាញ់របស់យើង ‹ បានថ្វាយព្រះអង្គទ្រង់ទុកជាថ្លៃលោះមនុស្សទាំងអស់ › [ធីម៉ូថេទី១ ២:៦] នោះវាជាប្រកទ្វារមួយចូលទៅក្នុងនគរដ៏អស់កល្បរបស់ទ្រង់ ដែលបានប្រទានដល់យើង [សូមមើលពេត្រុសទី២ ១:១១] » (« The Gift of Grace » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ១០៨) ។

- តើយើងត្រូវធ្វើអ្វីខ្លះដើម្បីមានភាពសក្តិសមចំពោះការចូលទៅក្នុងនគររបស់ព្រះអម្ចាស់ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?
- តើគោលការណ៍ដែលយើងបានស្គាល់នៅក្នុង ខទី ១០ នេះអាចជួយយើងឲ្យមានអំណរគុណកាន់តែពេញលេញ ចំពោះដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេចខ្លះ ?

សង្ខេប យ៉ាកុប ២:១១–១៣ ដោយពន្យល់ថា យ៉ាកុបបានផ្តល់ជាឧទាហរណ៍មួយអំពីគោលការណ៍ដែលបានបង្រៀននៅក្នុង ខទី ១០ ។ បន្ទាប់មក លោកបានលើកទឹកចិត្តពួកអ្នកជឿឲ្យប្រព្រឹត្តចំពោះមនុស្សដទៃទៀតដោយចិត្តមេត្តា ពីព្រោះជនដែលប្រព្រឹត្តចំពោះមនុស្សដទៃដោយគ្មានមេត្តានឹងត្រូវបានកាត់សេចក្តីដោយគ្មានមេត្តាដែរ ។

យ៉ាកុប ២:១៤–២៦

យ៉ាកុបបង្រៀនអំពីតួនាទីនៃសេចក្តីជំនឿ និងការប្រព្រឹត្តតាមនៅក្នុងសេចក្តីសង្គ្រោះរបស់យើង

សូមអញ្ជើញសិស្សឲ្យគិតថា មានយុវជនម្នាក់បានដឹងថាគាត់មានអំពើបាប ។ គាត់ជឿលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងលើសមត្ថភាពរបស់ព្រះអង្គសង្គ្រោះដើម្បីសង្គ្រោះគាត់ ។ គាត់ពោលថា អ្វីៗទាំងអស់ដែលគាត់ត្រូវធ្វើគឺជឿ ហើយព្រះអម្ចាស់នឹងអត់ទោសឲ្យគាត់ ដោយគាត់ពុំបាច់ធ្វើអ្វីទៀតឡើយ ។

សូមឲ្យសិស្សពិចារណាថា តើជំនឿរបស់យុវជននោះតែម្យ៉ាងនោះ វាល្មមគ្រប់គ្រាន់ដើម្បីគាត់អាចបានការអត់ទោសចំពោះអំពើបាបរបស់ខ្លួនដែរឬទេ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ២:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ាកុបបានសួរអ្វីខ្លះដល់ពួកបរិសុទ្ធទាក់ទងនឹងសេចក្តីជំនឿ ។

- តើយ៉ាកុបបានសួរអ្វីខ្លះដល់ពួកបរិសុទ្ធទាក់ទងនឹងសេចក្តីជំនឿ ?
- តើអ្នកគិតថា ការប្រព្រឹត្តបែបណាខ្លះដែលយ៉ាកុបចង់លើកឡើង ?

សូមពន្យល់ថា យ៉ាកុបកំពុងកែតម្រូវគំនិតខុសឆ្គងមួយអំពីសេចក្តីជំនឿ ។ មានមនុស្សមួយចំនួនបានយល់ខុសថា សេចក្តីជំនឿគឺគ្រាន់តែជាការបង្ហាញឲ្យឃើញមួយអំពីជំនឿតាមរយៈពាក្យសម្តី ។ នៅក្នុងបរិបទនៃ យ៉ាកុប ២:១៤ យ៉ាកុបបានប្រើពាក្យ *ការប្រព្រឹត្តតាម* ខុសពីរបៀបដែលសាវកប៉ុលបានប្រើ ។ នៅពេលប៉ុលបានប្រើពាក្យ *ការប្រព្រឹត្តតាម* លោកបានសំដៅទៅលើការប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ម៉ូសេ ។ នៅពេលយ៉ាកុបបានប្រើពាក្យ *ការប្រព្រឹត្តតាម* លោកសំដៅទៅលើសកម្មភាពនៃការលះបង់ ឬកិច្ចការនៃសេចក្តីសុចរិត ។

ដូចដែលបានកត់ត្រានៅក្នុងយ៉ាកុប ២:១៥–១៦ យ៉ាកុបបានប្រើរឿងប្រៀបធៀបមួយដើម្បីបង្ហាញចម្លើយសម្រាប់សំណួររបស់លោកនៅក្នុង ខទី ១៤ ។ សូមអញ្ជើញសិស្សពីរនាក់ឲ្យឡើងមកខាងមុខក្តារខៀន ។ សូមឲ្យសិស្សម្នាក់ដើរតួជាអ្នកសុំទានម្នាក់ដែលកំពុងសុំអាហារ សម្លៀកបំពាក់ និងទីជម្រកដែលគាត់ត្រូវការដើម្បីមានជីវិតរស់ ។ សូមអញ្ជើញម្នាក់ទៀតឲ្យដើរតួជាមនុស្សម្នាក់ ដែលអាចជួយដល់អ្នកសុំទាននោះបាន ។ សូមអញ្ជើញសិស្សទីបីឲ្យអាន យ៉ាកុប ២:១៥–១៦ ឮៗ កាលសិស្សពីរនាក់ផ្សេងទៀតដើរតួតាមសាច់រឿងដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

- តើមានអ្វីខុសឆ្គងជាមួយនឹងចម្លើយ ដែលបានផ្តល់ឲ្យទៅសិស្សដែលជាអ្នកសុំទាននោះ ? តើចម្លើយរបស់សិស្សម្នាក់ទៀតនឹងល្មមគ្រប់គ្រាន់ ដើម្បីសង្គ្រោះដល់អ្នកសូមទានម្នាក់ដែរឬទេ ?

យ៉ាកុប ២:១៧–១៨

គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ាកុប ២:១៧–១៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ាកុបបានបង្រៀនអ្វីខ្លះអំពីសេចក្តីជំនឿ ។

- តើអ្នកគិតថាឃ្លា « សេចក្តីជំនឿបើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់ » (ខទី ១៧) មានន័យដូចម្តេច ?
- តើរឿងប្រៀបធៀបរបស់យ៉ាកុបអំពីអ្នកសុំទាននោះជួយយើង ឲ្យយល់អំពីអត្ថន័យនៃឃ្លានោះយ៉ាងដូចម្តេច ?
- យោងតាម ខទី ១៧ តើយ៉ាកុបបានបង្រៀនសេចក្តីពិតអ្វីខ្លះទាក់ទងនឹងសេចក្តីពិតលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្ទាល់អំពីសេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **សេចក្តីជំនឿពិតលើព្រះយេស៊ូវគ្រីស្ទគឺបង្ហាញឡើងតាមរយៈកិច្ចការសុចរិតរបស់យើង ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ២:១៩–២០ ឲ្យឮៗ ។ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់យ៉ាកុប ២:១៩ ចែងថា « អ្នកជឿថា មានព្រះតែមួយ នោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ អ្នកបានធ្វើឲ្យខ្លួនដូចជាពួកវាដោយពុំបានរាប់ថាសុចរិតឡើយ » ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវឧទាហរណ៍ដែលយ៉ាកុបបានប្រើដើម្បីបង្ហាញថា ការជឿលើព្រះ វាពុំមែនមានន័យថាមានសេចក្តីជំនឿលើព្រះឡើយ ។

- តើឧទាហរណ៍អ្វីខ្លះដែលយ៉ាកុបបានប្រើដើម្បីបង្ហាញថា ការជឿលើព្រះ វាពុំចាំបាច់មានន័យថាមានសេចក្តីជំនឿលើព្រះឡើយនោះ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« សេចក្តីជំនឿពិតគឺផ្តោតនៅក្នុង និងទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយតែងតែដឹកនាំទៅរកសកម្មភាពសុចរិត ។ . . . សកម្មភាពតែម៉្យាងពុំមែនជាសេចក្តីជំនឿលើព្រះអង្គសង្គ្រោះទេ ប៉ុន្តែការធ្វើសកម្មភាពស្របតាមគោលការណ៍ត្រឹមត្រូវ គឺជាធាតុមួយដ៏សំខាន់នៃសេចក្តីជំនឿ » (« Ask in Faith » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៩៥) ។

- យោងតាមអែលឌើរ បែដណា តើអ្វីទៅជា « ធាតុមួយដ៏សំខាន់នៃសេចក្តីជំនឿ » ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីយល់ថា សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទមានន័យថា ត្រូវជឿលើទ្រង់ និងប្រព្រឹត្តតាមគោលការណ៍ត្រឹមត្រូវ ?

សូមរំឭកសិស្សអំពីយុវជននៅក្នុងសាច់រឿងនៅដើមផ្នែកនៃមេរៀននេះ ។

- តើការយល់ដឹងថា សេចក្តីជំនឿរួមបញ្ចូលទាំងការជឿ និងការប្រព្រឹត្តតាម អាចជួយមនុស្សម្នាក់ដែលស្វែងរកការអត់ទោសសម្រាប់អំពើបាបរបស់គាត់យ៉ាងដូចម្តេច ?

សូមសង្ខេប យ៉ាកុប ២:២១–២៦ ដោយពន្យល់ថា យ៉ាកុបបានលើកឡើងពីអ័ប្រាហាំ និងរ៉ាហាប ជាឧទាហរណ៍នៃមនុស្សពីរនាក់ដែលសេចក្តីជំនឿរបស់ពួកលោកលើព្រះបានបង្ហាញឲ្យឃើញដោយការប្រព្រឹត្តតាម ។ (ដំណើររឿងនៃស្ត្រីដ៏ក្លាហាន ឈ្មោះរ៉ាហាប មាននៅក្នុង យ៉ូស្វេ ២:១–២២) ។

សូមអញ្ជើញសិស្សឲ្យប្រើសៀវភៅសរសេរ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេសរសេរអំពីគ្រាមួយ ដែលពួកគេបានបង្ហាញសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទតាមរយៈការប្រព្រឹត្តតាមរបស់ពួកគេ និងរបៀបដែលពួកគេទទួលបានពរជ័យសម្រាប់ការធ្វើដូច្នេះ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់បញ្ចូលទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ និងរបៀបដែលពួកគេនឹងបង្ហាញជំនឿនោះតាមរយៈសកម្មភាពរបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វី ដែលពួកគេបានសរសេរជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យពិចារណាប្រកបដោយការអធិស្ឋានថា ពួកគេអាចអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទឲ្យកាន់តែពេញលេញតាមរយៈការគោរពតាមទ្រង់បានដោយរបៀបណា ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើតាមការបំផុសគំនិតទាំងឡាយ ដែលពួកគេទទួលបាន ។

ចំណេះចំណានខគម្ពីរ—យ៉ាកុប ២:១៧–១៨

ដើម្បីជួយសិស្សឲ្យអនុវត្តសេចក្តីពិត ដែលបានបង្រៀននៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ សូមផ្តល់ឲ្យសិស្សម្នាក់ៗនូវក្រដាសមួយបំណែកតូច ។ សូមអញ្ជើញឲ្យពួកគេសរសេរពាក្យនៃវគ្គខគម្ពីរនេះនៅផ្នែកម្ខាងនៃក្រដាសនោះ ។ បន្ទាប់មក សូមឲ្យពួកគេបំពេញប្រយោគដូចតទៅនេះនៅផ្នែកម្ខាងទៀតនៃក្រដាស ៖ *ខ្ញុំនឹងបង្ហាញព្រះអម្ចាស់អំពីសេចក្តីជំនឿរបស់ខ្ញុំលើទ្រង់ដោយ* . . . សូមលើកទឹកចិត្តសិស្សឲ្យរក្សាទុកក្រដាសនេះនៅក្នុងហោប៉ៅរបស់ពួកគេពេញមួយថ្ងៃ ហើយបន្តសរសេរនូវបញ្ជីគំនិតក្នុងការបង្ហាញសេចក្តីជំនឿរបស់ពួកគេចំពោះព្រះអម្ចាស់ ។ នៅពេលពួកគេបន្ថែមគំនិតនៅក្នុងបញ្ជីរបស់ពួកគេ ពួកគេអាចមើលឡើងវិញនូវវគ្គចំណេះចំណានខគម្ពីរនោះ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់ក្រដាសនោះនៅត្រង់កន្លែងដែលពួកគេអាចមើលឃើញជារឿយៗ ហើយវាជួយរំឭកពួកគេពីគោលដៅនោះ ។

យ៉ាកុប ៣

សេចក្តីផ្តើម

យ៉ាកុបបានបង្រៀនពួកបរិសុទ្ធអំពីសារៈសំខាន់នៃការគ្រប់គ្រងការនិយាយរបស់ពួកគេ ។ បន្ទាប់មក លោកបានបង្ហាញពីភាពខុសគ្នារវាងប្រាជ្ញារបស់លោកិយ និងប្រាជ្ញាដែលកើតចេញមកពីព្រះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប៣:១–១២


យ៉ាកុបបង្រៀនពួកបរិសុទ្ធអំពីសារៈសំខាន់នៃការគ្រប់គ្រងការនិយាយរបស់ពួកគេ

សូមយកថ្នាំដុសធ្មេញមួយបំពង់មកកាន់ថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យច្របាច់ថ្នាំដុសធ្មេញឲ្យចេញមកក្រៅ (ឬសូមឲ្យសិស្សនឹកស្រមៃពីទិដ្ឋភាពនេះ) ។ សូមឲ្យសិស្សម្នាក់ទៀតសាកល្បងយកថ្នាំដុសធ្មេញទាំងអស់ដាក់ក្នុងបំពង់នោះវិញ ។ បន្ទាប់ពីមានការពិបាកក្នុងការធ្វើកិច្ចការនេះមក សូមសួរ ៖

- តើថ្នាំដុសធ្មេញនៅក្នុងលំហាត់នេះ អាចប្រៀបបាននឹងពាក្យសម្តីដែលយើងនិយាយចេញទៅយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា ពួកគេធ្លាប់និយាយអ្វី ដែលធ្វើឲ្យពួកគេមានការសោកស្តាយនៅពេលក្រោយដែរឬទេ ។ នៅពេលសិស្សសិក្សា យ៉ាកុប ៣:១–១២ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតដែលនឹងជួយពួកគេ ឲ្យជ្រើសរើសចេះប្រើពាក្យសម្តីរបស់ពួកគេដោយឈ្លាសវៃ ។


សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗក្នុង យ៉ាកុប៣:២–៤ និងប្រយោគទីមួយនៅក្នុង យ៉ាកុប ៣:៥ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ាកុបបានរៀបរាប់ពីជនដែលពុំបានធ្វើឲ្យមនុស្សដទៃវាទទិតនឹងពាក្យសម្តីរបស់ខ្លួនបែបណាដែរ ។ សូមពន្យល់ថាឃ្លា « យើងទាំងអស់គ្នាក៏ជំពប់ជាញយៗ » នៅក្នុង ខទី ២ មានន័យថា យើងទាំងអស់គ្នាធ្វើខុស ហើយពន្យល់ថា យ៉ាកុបបានប្រើពាក្យ *អណ្តាត* ដើម្បីសំដៅទៅលើពាក្យដែលយើងនិយាយ ។



- តើយ៉ាកុបបានរៀបរាប់ពីជនដែលអាចគ្រប់គ្រងពាក្យសម្តីរបស់ពួកគេយ៉ាងដូចម្តេច ?

សូមពិចារណាដាក់បង្ហាញ ឬគូរលើក្តារខៀននូវរូបភាពស្តីពី ដែកបង្ខាំ និង ចង្កូតសំពៅ ។ អ្នកគួរពន្យល់ថា *ដែកបង្ខាំ* មួយ (ខទី ៣) គឺជាបន្ទះដែកតូចមួយដាក់នៅត្រង់មាត់សេះដើម្បីភ្ជាប់វាទៅនឹងខ្សែបង្ខៀរ ដោយអនុញ្ញាតឲ្យអ្នកជិះបញ្ជាសេះនោះបាន ។ នៅក្នុងខគម្ពីរនេះ ពាក្យ *ចង្កូត* (ខទី៤) សំដៅទៅលើចង្កូតសំពៅដែលជួយមនុស្សម្នាក់ឲ្យតម្រង់ ឬបត់នាវានោះបាន ។

- យោងតាមយ៉ាកុប តើដែកបង្ខាំសេះ និងចង្កូតសំពៅមានអ្វីដូចគ្នា ? (ឧបករណ៍ទាំងពីរជារបស់តូចដូចគ្នា ហើយវាតម្រង់ ឬគ្រប់គ្រងអ្វីដែលធំជាង ដែលភ្ជាប់ទៅនឹងវា) ។
- តើការប្រៀបធៀបរបស់យ៉ាកុបអំពីឧបករណ៍ទាំងនេះទៅនឹងអណ្តាត ឬ ពាក្យសម្តីដែលយើងនិយាយ អាចជួយយើងឲ្យយល់ពីអំណាចនៃពាក្យសម្តីរបស់យើងយ៉ាងដូចម្តេច ?
- តើយើងអាចស្គាល់គោលការណ៍អ្វីខ្លះមកពីខគម្ពីរទាំងនេះ ទាក់ទងនឹងអ្វីដែលអាចកើតឡើង នៅពេលយើងរៀនគ្រប់គ្រងការនិយាយរបស់យើងនោះ ? (សិស្សគួរស្គាល់គោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងរៀនគ្រប់គ្រងការនិយាយរបស់យើង នោះយើងអាចរៀនគ្រប់គ្រងសកម្មភាពផ្សេងទៀតរបស់យើងបាន**) ។



- ហេតុអ្វីការគ្រប់គ្រងការនិយាយរបស់យើងអាចជួយយើងឲ្យគ្រប់គ្រងសកម្មភាពផ្សេងទៀតរបស់យើងបាន ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវប្រយោគចុងក្រោយនៅក្នុង យ៉ាកុប៣:៥ និង យ៉ាកុប៣:៦ផងដែរ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើយ៉ាកុបបានប្រៀបធៀបការនិយាយរបស់យើងទៅនឹងអ្វីផ្សេងទៀត ។ សូមពន្យល់ថាពាក្យ *ព្រៃធំៗ* សំដៅទៅលើព្រៃព្រឹក្សា ។

- តើយ៉ាកុបបានប្រៀបធៀបការនិយាយរបស់យើងទៅនឹងអ្វីផ្សេងទៀត ?
- តើកត្តាអ្វីខ្លះនៅក្នុងជីវិតរបស់យើង ដែលអាចទទួលរងនូវការ « បញ្ឆេះ » (ខទី ៦) ឬ គ្រោះថ្នាក់ដោយសារការប្រើពាក្យសម្តីមិនឈ្លាសវៃរបស់យើង ?

សូមពន្យល់ថា ឃ្លា « ផ្លូវជីវិត » នៅក្នុង ខទី ៦ អាចសំដៅទៅលើឆាកជីវិតរបស់មនុស្សម្នាក់ ។

- តើពាក្យសម្តីដែលយើងនិយាយអាចជះឥទ្ធិពលលើឆាកជីវិតរបស់យើងយ៉ាងដូចម្តេច ?
- តើការធ្វើការផ្លាស់ប្តូរតិចតួចនៅក្នុងពាក្យសម្តីដែលយើងនិយាយ អាចជះឥទ្ធិពលដល់ឆាកជីវិតរបស់យើង និងជីវិតមនុស្សដទៃទៀតនៅក្នុងផ្លូវវិជ្ជមានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ាកុប ៣:៧–១២ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើយ៉ាកុបបានប្រៀបធៀបការនិយាយរបស់យើងទៅនឹងអ្វីផ្សេងទៀត ។

- តើយ៉ាកុបបានប្រៀបធៀបការនិយាយរបស់យើងនឹងអ្វីផ្សេងទៀត ? (សត្វមួយក្បាលដែលត្រូវមានការផ្សាំង [សូមមើល ខទី ៧–៨] « ពិសដែលនាំឲ្យស្លាប់ » [ខទី ៨] រន្ធទឹកមួយដែល « ចេញទឹកជាប្រៃផង [ទឹក] «សាបផង » នៅ « រន្ធទឹកតែមួយ » [ខទី ១១–១២] ដើមល្វាចេញផ្លែអូលីវជំនួសឲ្យផ្លែល្វា ហើយដើមទំពាំងបាយជូរបង្កើតផ្លែល្វា [សូមមើល ខទី ១២]) ។

ដើម្បីជួយសិស្សឲ្យយល់អំពីមាតិកានៃខគម្ពីរទាំងនេះ សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។



« ពិតណាស់យ៉ាកុបពុំចង់មានន័យថាអណ្តាតរបស់យើង *ជាទិព្វភាព* និយាយតែរឿងអយុត្តិធម៌ ឬថា *អ្វីៗគ្រប់យ៉ាង* ដែលយើងនិយាយគឺ ‹ មានពេញដោយពិសដែលនាំឲ្យស្លាប់ › នោះឡើយ ។ ប៉ុន្តែលោកចង់បញ្ជាក់ថា យ៉ាងហោចណាស់ ពាក្យសម្តីមួយចំនួនដែលយើងនិយាយអាចក្លាយជាពាក្យសម្តីបំផ្លិចបំផ្លាញ ព្រមទាំងមានពិសទៀតផង—ហើយនោះគឺជាការអះអាងមួយដ៏គួរឲ្យភ័យខ្លាចសម្រាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ! សំឡេងដែលថ្លែងទីបន្ទាល់បានយ៉ាងល្អ ការអធិស្ឋានដ៏ភ្លឺវិលា និងការប្រៀងទំនុកតម្កើងនៃសិយ៉ូន *អាចជា* សំឡេងតែមួយដែលស្តីបន្ទោស ហើយរិះគន់ ធ្វើឲ្យអាម៉ាស់ ហើយបន្ទាបបន្ទោក ធ្វើឲ្យមានការឈឺចាប់ និងការបំផ្លិចបំផ្លាញវិញ្ញាណរបស់ខ្លួនឯង និងមនុស្សដទៃទៀតនៅក្នុងដំណើរការនេះ ។ . . .

« . . . ចូរយើងព្យាយាមប្រែក្លាយជាបុរសស្ត្រីដ៏ ‹ឥតខ្ចោះ › យ៉ាងហោចណាស់ក្នុងរបៀបមួយដោយ—មិនប្រើពាក្យសម្តីធ្វើឲ្យអាក់អន់ចិត្ត ឬប្រើពាក្យកាន់តែរំជួលមាន ដោយនិយាយភាសាថ្មី គឺភាសានៃពួកទេវតា ។ ពាក្យសម្តីរបស់យើង ក៏ដូចជាទង្វើរបស់យើងដែរ វាគួរត្រូវបានបំពេញដោយសេចក្តីជំនឿ និងសេចក្តីសង្ឃឹម ព្រមទាំងសេចក្តីសប្បុរស ជាបទបញ្ញត្តិធំបីរបស់ពួកគ្រីស្ទាន ដែលពិភពលោកសព្វថ្ងៃនេះត្រូវការយ៉ាងខ្លាំង ។ ជាមួយនឹងពាក្យសម្តីបែបនេះ ដែលនិយាយឡើងនៅក្រោមព្រះចេស្តានៃព្រះវិញ្ញាណ វានឹងគ្មានការបង្ហូរទឹកភ្នែក តែវានាំមកនូវការព្យាបាលដួងចិត្ត ការលើកកម្ពស់ជីវិត ការមានសេចក្តីសង្ឃឹមឡើងវិញ និងភាពជឿជាក់អាចយកជ័យបាន » (« The Tongue of Angels » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១៦, ១៨) ។

- តើយើងអាចស្គាល់សេចក្តីពិតអ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះទាក់ទងនឹងការនិយាយស្តីដែលពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទគួរធ្វើ ? (ដោយប្រើពាក្យសម្តីរបស់ពួកគេផ្ទាល់ សិស្សគួរស្គាល់សេចក្តីពិតមួយស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ពួកអ្នកដើរតាមព្រះត្រូវខិតខំប្រើពាក្យសម្តីរបស់ពួកគេសម្រាប់គោលបំណងសុចរិត ពុំមែនសាយភាយអំពើអាក្រក់ឡើយ**) ។
- ហេតុអ្វីវាគឺជាបញ្ហាមួយដ៏ធ្ងន់ធ្ងរ ប្រសិនបើពួកបរិសុទ្ធថ្ងៃចុងក្រោយប្រើពាក្យសម្តីរបស់ពួកគេសម្រាប់គោលបំណងអាក្រក់ ឬធ្វើឲ្យមនុស្សដទៃឈឺចាប់ ឬខូចចិត្តនោះ ?
- តើរឿងមួយចំនួនដែលយើងអាចធ្វើដើម្បីឲ្យកាន់តែ « ល្អឥតខ្ចោះ » ថែមទៀត (យ៉ាកុប ៣:២) នៅក្នុងការប្រើពាក្យសម្តីរបស់យើងមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យពន្យល់ថា ការរស់នៅតាមសេចក្តីពិតដែលពួកគេបានស្គាល់នៅក្នុង យ៉ាកុប ៣:៩–១០ នឹងដឹកនាំទង្វើរបស់ពួកគេនៅក្នុងស្ថានភាពខាងក្រោមនេះយ៉ាងដូចម្តេច ៖

១. អ្នកកំពុងសរសេរសារ ឬកំពុងប្រើបណ្តាញសង្គម ។

២. អ្នកគឺជាសង្ឃម្នាក់ដែលប្រសិទ្ធពរពិធីសាក្រាម៉ង់នៅថ្ងៃអាទិត្យ ។ នៅសាលារៀន មិត្តរបស់អ្នកចាប់ផ្តើមសើចចំអកដាក់សិស្សម្នាក់ទៀត ។

៣. អ្នកគឺជាយុវនារីម្នាក់ដែលកាលពីមុនធ្លាប់និយាយមិនល្អអំពីយុវនារីម្នាក់ទៀតនៅក្នុងវួដ ឬសាខារបស់អ្នក ។

៤. មិត្តរួមក្រុមរបស់អ្នកប្រើពាក្យសម្តីមិនល្អ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមមកពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ឲ្យឮៗ ៖

« របៀបដែលអ្នកទំនាក់ទំនង គួរតែឆ្លុះបញ្ចាំងអត្តសញ្ញាណរបស់អ្នកក្នុងនាមជាបុត្រា ឬ បុត្រីម្នាក់របស់ព្រះ ។ ពាក្យសម្តីដែលស្អាតស្អំ និងមានបញ្ញា គឺជាភស្តុតាងនៃចិត្តដែលឆ្លាត និងរីករាយ ។ ពាក្យសម្តីដែលលើកតម្កើង លើកទឹកចិត្ត និងសរសើរអ្នកដទៃអញ្ជើញព្រះវិញ្ញាណឲ្យគង់នៅជាមួយអ្នក ។ ពាក្យសម្តីរបស់យើង ក៏ដូចជាទង្វើរបស់យើង គួរតែត្រូវបានពោរពេញដោយសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស » (*ដើម្បីកម្លាំងនៃយុវជន* [កូនសៀវភៅឆ្នាំ ២០១១ [ទំព័រ ២០) ។

- តើពាក្យសម្តីរបស់មនុស្សម្នាក់ធ្លាប់លើកតម្កើង ឬលើកទឹកចិត្តអ្នកនៅពេលណា ?
- តើអ្នកធ្លាប់បានទទួលពរ នៅពេលអ្នកខំព្យាយាមលើកតម្កើង ឬលើកទឹកចិត្តមនុស្សដទៃជាមួយនឹងពាក្យសម្តីរបស់អ្នកតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យសរសេរគោលដៅមួយនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់រៀន ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ទាក់ទងនឹងកិច្ចការដែលពួកគេនឹងធ្វើដើម្បីគ្រប់គ្រងការនិយាយរបស់ពួកគេឲ្យកាន់តែប្រសើរ ហើយប្រើពាក្យសម្តីរបស់ពួកគេសម្រាប់គោលបំណងសុចរិត ។ សូមអញ្ជើញពួកគេឲ្យធ្វើសកម្មភាពសម្រាប់គោលដៅដែលពួកគេបានសរសេរនៅសប្តាហ៍ក្រោយ ។

> ***តាមដានការអញ្ជើញដើម្បីធ្វើសកម្មភាព***
>
> អ្នកអាចលើកទឹកចិត្តសិស្សឲ្យអនុវត្តគោលការណ៍ទាំងឡាយនៃដំណឹងល្អដោយតាមដានការអញ្ជើញដើម្បីធ្វើសកម្មភាព ។ សូមធ្វើការកត់ចំណាំមួយដើម្បីតាមដានជាមួយសិស្សទាក់ទងនឹងគោលដៅដែលពួកគេបានដាក់នៅក្នុងមេរៀននេះ ។ អ្នកក៏គួរអញ្ជើញពួកគេឲ្យប្រាប់ពីបទពិសោធន៍ដែលពួកគេមាននៅពេលពួកគេធ្វើតាមគោលដៅរបស់ពួកគេ ។

យ៉ាកុប ៣:១៣–១៨

យ៉ាកុបបង្ហាញពីភាពខុសគ្នារវាងប្រាជ្ញារបស់លោកិយ និងប្រាជ្ញាដែលកើតចេញមកពីព្រះ

សូមសង្ខេប យ៉ាកុប ៣:១៣–១៨ ដោយពន្យល់ថា យ៉ាកុបបានបង្ហាញពីភាពខុសគ្នារវាងប្រាជ្ញារបស់លោកិយ និងប្រាជ្ញាដែលមកពីព្រះ ។ ប្រាជ្ញារបស់លោកិយដឹកនាំទៅរក « វឹកវរ » (ខទី ១៦) និង « សេចក្តីគំនុំ » (ខទី ១៤) កាលប្រាជ្ញា« ដែលមកពីស្ថានលើ » គឺ « បរិសុទ្ធ » ហើយ « ពេញដោយសេចក្តីមេត្តាករុណា » (ខទី១៧) ។

សូមថ្លែងទីបន្ទាល់អំពីគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀនថ្ងៃនេះ ។

យ៉ាកុប ៤–៥

សេចក្តីផ្តើម

យ៉ាកុបបានទូន្មានដល់ពួកបរិសុទ្ធឲ្យតតាំងនឹងអារក្ស ឲ្យខិតទៅកាន់តែជិតព្រះ ហើយស៊ូទ្រាំនឹងការរងទុក្ខដោយអត់ធ្មត់ កាលកំពុងរង់ចាំការយាងមកជាលើកទីពីរបស់ព្រះអង្គសង្គ្រោះ ។ លោកបានបង្រៀនថា អ្នកឈឺគួរ « ហៅពួកចាស់ទុំក្នុងពួកជំនុំ » (យ៉ាកុប ៥:១៤) ឲ្យព្យាបាលពួកគេ ។ យ៉ាកុបក៏បានបង្រៀនផងដែរអំពីសារៈសំខាន់នៃការជួយពួកអ្នកមានបាបឲ្យប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ៤

យ៉ាកុបទូន្មានពួកបរិសុទ្ធឲ្យខិតកាន់តែជិតព្រះ ហើយតតាំងនឹងអារក្ស

សូមអញ្ជើញសិស្សឲ្យគិតអំពីសមាជិកគ្រួសារ ឬមិត្តម្នាក់ដែលពួកគេមានអារម្មណ៍ស្និទ្ធស្នាល ។

- តើអ្នកបានគិតដល់នរណាដែរ ? ហេតុអ្វីអ្នកមានអារម្មណ៍ស្និទ្ធស្នាលនឹងបុគ្គលនេះ ?
- តើអ្នកមានភាពស្និទ្ធស្នាលនឹងបុគ្គលនេះតាមរបៀបណា ?

ចូរអញ្ជើញសិស្សឲ្យពិចារណាថា ពួកគេមានអារម្មណ៍នៅជិតនឹងព្រះកម្រិតណាដែរ ។

- តើជីវិតរបស់យើងនឹងមានពរយ៉ាងណាដែរ តាមរយៈការមានទំនាក់ទំនងដ៏រឹងមាំមួយជាមួយនឹងព្រះ ?

នៅពេលសិស្សសិក្សាយ៉ាកុប ៤ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេឲ្យពង្រឹងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះ ។

សូមសង្ខេប យ៉ាកុប ៤:១–៣ ដោយពន្យល់ថា យ៉ាកុបបានស្តីបន្ទោសដល់ពួកបរិសុទ្ធចំពោះទោរទន់របស់ពួកគេតាមបំណងប្រាថ្នាខាងលោកិយ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ៤:៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលប្រភេទនៃមិត្តភាព ដែលយ៉ាកុបបានព្រមានដល់ពួកបរិសុទ្ធ ។ ចូរពន្យល់ថា ពាក្យ*ស្អប់*មានន័យថា ការជំទាស់ ឬការស្អប់ខ្ពើម ។

- តើប្រភេទមិត្តភាពបែបណាទៅដែលយ៉ាកុបបានព្រមានដល់ពួកបរិសុទ្ធ ?
- តើអ្នកគិតថា ការ « ស្រឡាញ់ដល់លោកីយ៍ » មានន័យដូចម្តេច ? (ប្រសិនបើចាំបាច់ សូមពន្យល់ថា ពាក្យទូន្មានរបស់យ៉ាកុបនៅក្នុង ខទី ៨ពុំមែនមានន័យថា យើងពុំគួរសេពគប់នឹងបុគ្គលដែលពុំមែនជាសមាជិកសាសនាចក្រនេះនោះទេ ។ ផ្ទុយទៅវិញ យើងគួរចៀសវាងការឱបក្រសោបការបង្រៀនខុសឆ្គង និងបំណងប្រាថ្នា បទដ្ឋាន និងការអនុវត្តទុច្ចរិតនានារបស់លោកិយ) ។
- យោងតាមយ៉ាកុប តើមានអ្វីកើតឡើងចំពោះមនុស្សម្នាក់ដែលសេពគប់នឹងលោកិយ ?

ចូរសុំឲ្យសិស្សអាន យ៉ាកុប ៤:៦–៨ ដោយស្ងៀមស្ងាត់ ហើយរកមើលថា យ៉ាកុបបានទូន្មានឲ្យពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ។

- តើយ៉ាកុបបានទូន្មានឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ?
- តើការយើងចុះចូលចំពោះព្រះអាចជួយយើងឲ្យតតាំងនឹងអារក្សបានយ៉ាងដូចម្តេច ?
- យោងតាម ខទី ៨តើយើងត្រូវធ្វើអ្វីខ្លះ ប្រសិនបើយើងចង់នៅជិតព្រះ ? (នៅពេលសិស្សឆ្លើយរួច ចូរសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងខិតទៅជិតព្រះអម្ចាស់ នោះទ្រង់នឹងចូលមកជិតយើង**) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីខិតទៅជិតព្រះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់នូវវិធីមួយដែលយើងអាចខិតទៅជិតព្រះ សូមចង្អុលបង្ហាញការណែនាំរបស់ប៉ុលឲ្យ « លាងដៃឲ្យស្អាត » ហើយ « សម្អាតចិត្តឡើង » (យ៉ាកុប ៤:៨) ។ សូមពន្យល់ថា ដូចដែលប្រើនៅក្នុងបទគម្ពីរ ដៃអាចតំណាងឲ្យការប្រព្រឹត្តរបស់យើង ហើយចិត្តអាចតំណាងឲ្យបំណងប្រាថ្នារបស់យើង ។

- តើអ្នកគិតថា ការមានដៃស្អាត ហើយចិត្តបរិសុទ្ធជួយយើងឲ្យខិតទៅជិតព្រះបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ៤:៩–១២, ១៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលពាក្យទូន្មានបន្ថែមទៀត ដែលយ៉ាកុបបានផ្តល់ឲ្យពួកបរិសុទ្ធ ដើម្បីជួយពួកគេឲ្យខិតកាន់តែជិតព្រះ ។ សូមពន្យល់ថា ឃ្លា « សូមឲ្យសំណើចរបស់អ្នករាល់គ្នាត្រឡប់ជាដំងូរ » (ខទី ៩) សំដៅទៅលើសេចក្តីព្រួយដែលគាប់ព្រះទ័យដល់ព្រះសម្រាប់អំពើបាប ។

- តើពាក្យទូន្មានអ្វីខ្លះទៀតដែលយ៉ាកុបបានផ្តល់ឲ្យដើម្បីជួយមនុស្សម្នាក់ឲ្យខិតកាន់តែជិតព្រះ ?
- យោងតាម ខទី ១៧តើយ៉ាកុបបានបង្រៀនថា អ្វីខ្លះគឺជាអំពើបាប ? (បន្ទាប់ពីសិស្សឆ្លើយរួច សូមសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងដឹងថាត្រូវធ្វើល្អ ប៉ុន្តែជ្រើសរើសពុំធ្វើវា នោះយើងប្រព្រឹត្តអំពើបាបហើយ**) ។
- ហេតុអ្វីអ្នកគិតថា វាគឺជាអំពើបាបមួយ នៅពេលយើងដឹងថាយើងគួរធ្វើកិច្ចការល្អ ប៉ុន្តែយើងរើសមិនធ្វើវានោះ ។

មេរៀនដ៏គួរឲ្យចាប់អារម្មណ៍ មានការទាក់ទងគ្នា និង មានការស្អាងឡើង

នៅពេលអ្នកបង្ហាញមេរៀនដែលមានការស្អាងឡើងជាប់លាប់ នោះសិស្សនឹងបង្កើនការពឹងទុកមួយថា ពួកគេនឹងរៀនអ្វីមួយ ដែលមានតម្លៃគ្រប់ពេល ដែលពួកគេចូលរួមក្នុងថ្នាក់ ។ ប្រធាន ប៊ែយដំ ឃេ ផាកគឺ ក្នុងក្លុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា សិស្ស « នឹងមិនត្រឡប់មកវិញដោយមានចិត្តក្លៀវក្លានោះទេ លើកលែងតែពួកគេត្រូវបានបង្រៀនអ្វីមួយពីថ្នាក់នោះ ។ ពួកគេត្រូវតែបានរៀនអ្វីមួយ ដែលធ្វើឲ្យចង់ត្រឡប់មកវិញ ។ ពួកគេនឹងមកកាន់ថ្នាក់មួយដោយស្ម័គ្រចិត្ត ដោយសេចក្តីស្រេកឃ្លាន . . . ចំពោះអ្វីដែលពួកគេត្រូវបានផ្តល់ឲ្យ » (*Teach Ye Diligently*[ឆ្នាំ ១៩៧៥] ទំព័រ ១៥៣–៥៤) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដែមស៍ អឺ ហ្វោស្ត ដែលបានបម្រើក្នុងគណៈប្រធានទីមួយ ឲ្យឮៗ ៖



« ខ្ញុំខ្លាចក្រែងថា អំពើបាបដ៏ធំបំផុតមួយចំនួនរបស់យើងគឺជាអំពើបាបនៃការធ្វេសប្រហែស ។ អំពើបាបទាំងនេះគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយចំនួននៃក្រឹត្យវិន័យ ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា យើងមិនត្រូវទុកចោលដោយមិនធ្វើវានោះឡើយ (សូមមើល ម៉ាថាយ ២៣:២៣) ។ អំពើបាបទាំងនេះគឺជាទង្វើដែលចេះគិតពិចារណា ហើយបរាជ័យពុំបានធ្វើ ហើយធ្វើឲ្យមានអារម្មណ៍ថាសោកស្តាយយ៉ាងខ្លាំងចំពោះការពុំបានធ្វើកិច្ចការទាំងនោះ: ។

« កាលជាក្មេងប្រុសម្នាក់រស់នៅកសិដ្ឋានអំឡុងរដូវក្តៅ ខ្ញុំនៅចាំថាជីដូនរបស់ខ្ញុំឈ្មោះ ម៉ារី ហ្វីនលីនសុន បានចម្អិនអាហារយ៉ាងឆ្ងាញ់សម្រាប់យើងនៅលើចង្ក្រានប្រើអុសមួយ ។ កាលធុងដាក់អុសនៅក្បែរចង្ក្រាននោះអស់ ជីដូនខ្ញុំបានយកធុងដ៏ស្រាលនោះចេញទៅខាងក្រៅ ហើយរើសមែកឈើមកដាក់បំពេញក្នុងនោះ: ហើយយកវាទៅទុកក្នុងផ្ទះវិញ ។ ខ្ញុំជាប់ចិត្តការសន្ទនានៅក្នុងផ្ទះបាយជាខ្លាំង ខ្ញុំបានអង្គុយនៅទីនោះ: ហើយទុកឲ្យជីដូនខ្ញុំរើសអុសដាក់ក្នុងធុងនោះតែម្នាក់ឯង ។ ខ្ញុំមានអារម្មណ៍ខ្មាស់ខ្លួនឯង ហើយសោកស្តាយចំពោះការធ្វេសប្រហែសរបស់ខ្ញុំអស់មួយជីវិត ។ ខ្ញុំសង្ឃឹមថា នៅថ្ងៃណាមួយខ្ញុំនឹងសូមឲ្យគាត់អភ័យទោសដល់ខ្ញុំ » («The Weightier Matters of the Law: Judgment, Mercy, and Faith » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៥៩) ។

- តើទង្វើល្អអ្វីទៅដែលប្រធាន ហ្វោស្ត ពុំបានធ្វើកាលពីនៅក្មេង ? តើលោកមានអារម្មណ៍បែបណាដែរ ?
- តើអ្វីទៅជាគំរូស្តីពីអំពើបាបនៃការធ្វេសប្រហែស ដែលអាចរារាំងយើងពីការខិតទៅជិតព្រះ: ?
- តើអ្វីទៅអាចរារាំងយើងមិនឲ្យធ្វើកិច្ចការល្អ ដែលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបានបង្រៀនឲ្យយើងធ្វើនោះ: ?
- តើអ្នកធ្លាប់ខិតទៅជិតព្រះដោយការធ្វើល្អ នៅពេលអ្នកទទួលការបង្រៀនឲ្យធ្វើដូច្នោះនៅពេលណាដែរ ?

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ នូវរឿងដែលពួកគេនឹងធ្វើដើម្បីបានខិតទៅកាន់តែជិតព្រះ: ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេទទួលបាន ។

យ៉ាកុប ៥

យ៉ាកុបបង្រៀនពួកបរិសុទ្ធឲ្យស៊ូទ្រាំដោយអត់ធ្មត់ចំពោះទុក្ខលំបាក ហើយណែនាំដល់អ្នកឈឺឲ្យហៅរកពួកចាស់ទុំ ។

សូមសង្ខេប យ៉ាកុប ៥:១–៦ ដោយពន្យល់ថា យ៉ាកុបបានថ្កោលទោសដល់អ្នកមានដែលប្រើទ្រព្យសម្បត្តិរបស់ពួកគេខុស ហើយបៀតបៀនដល់មនុស្សសុចរិត ។ លោកបានព្រមានថា សេចក្តីទុក្ខវេទនា និងការជំនុំជម្រះកំពុងរង់ចាំពួកគេ ។

សូមអញ្ជើញសិស្សពីរបីនាក់ឬរវេនគ្នាអានឮៗនៅក្នុង យ៉ាកុប ៥:៧–១១ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា យ៉ាកុបបានណែនាំឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ: នៅពេលពួកគេជួបនឹងទុក្ខលំបាក កាលកំពុងរង់ចាំការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

- យោងតាម ខទី ៧–៨ តើយ៉ាកុបបានណែនាំឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ: នៅពេលពួកគេរង់ចាំការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ?
- យោងតាម ខទី ១០ តើពួកបរិសុទ្ធគួរមើលទៅនរណា សម្រាប់គំរូនៃមនុស្សដែលបានស៊ូទ្រាំនឹងទុក្ខវេទនាដោយអត់ធ្មត់ ?
- តើមានគំរូអ្វីខ្លះនៅក្នុងព្រះគម្ពីរស្តីពីពួកព្យាការី ដែលបានស៊ូទ្រាំនឹងទុក្ខលំបាកដោយអត់ធ្មត់ ?

សូមពន្យល់ថា យ៉ាកុប ៥:១៣–១៦ កត់ត្រាពាក្យទូន្មានរបស់យ៉ាកុបដល់អ្នកឈឺ និងអ្នករងទុក្ខ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសាច់រឿងដូចខាងក្រោមឮៗ ។

មានមិត្តម្នាក់បានពោលថា « ខ្ញុំមានអារម្មណ៍មិនល្អសោះ ។ ខ្ញុំឈឺជាងមួយសប្តាហ៍ហើយ ។ ខ្ញុំបានទៅជួបវេជ្ជបណ្ឌិត ហើយបានប្រើថ្នាំ ប៉ុន្តែខ្ញុំនៅតែមិនបានប្រសើរសោះ: ។ ខ្ញុំពុំដឹងថាត្រូវធ្វើអ្វីទៀតនោះទេ » ។

សូមអញ្ជើញសិស្សឲ្យពិចារណាថា ពួកគេនឹងនិយាយអ្វីខ្លះទៅមិត្តម្នាក់នេះ: ។ សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ៥:១៣–១៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ាកុបបានទូន្មានអ្នកឈឺ និងអ្នករងទុក្ខឲ្យធ្វើអ្វីខ្លះ: ។

- តើយ៉ាកុបបានទូន្មានឲ្យអ្នកឈឺ និងអ្នករងទុក្ខឲ្យធ្វើអ្វីខ្លះ: ?
- តើយ៉ាកុបបានណែនាំពួកអែលឌើរឲ្យធ្វើអ្វីខ្លះចំពោះអ្នកឈឺ ? (បម្រើអ្នកឈឺដោយសិទ្ធិអំណាចនៃបព្វជិតភាព ហើយចាក់ប្រេងតាំងដល់ពួកគេ) ។

សូមពន្យល់ថា អែលឌើរ ដាលីន អេក អូក ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « នៅពេលពួកអែលឌើរលាបប្រេងតាំងដល់អ្នកឈឺម្នាក់ ហើយផ្សារភ្ជាប់ការតាំងប្រេងនោះ: ពួកគេបើកបង្ហួចស្ថានសួគ៌ថ្វាយព្រះអម្ចាស់ ឲ្យចាក់ស្រោចពរដ៏ឃើដែលទ្រង់មានសម្រាប់អ្នកឈឺនោះ: » (« Healing the Sick » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៤៨) ។

- បន្ថែមពីលើអំណាចនៃបព្វជិតភាព តើយ៉ាកុបបាននិយាយថា អ្វីផ្សេងទៀតដែលនឹងសង្គ្រោះ: ឬព្យាបាលដល់អ្នកឈឺ ? (« ពាក្យអធិស្ឋាននៃសេចក្តីជំនឿ » (យ៉ាកុប៥:១៥)) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីយ៉ាកុប អំពីរបៀបដែលអ្នកឈឺអាចទទួលបានការព្យាបាល ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់នូវសេចក្តីពិតដូចតទៅនេះ: ៖ **តាមរយៈការអធិស្ឋាននៃសេចក្តីជំនឿ និងអំណាចនៃបព្វជិតភាព នោះអ្នកឈឺអាចទទួលបានការព្យាបាល ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់អំពីសេចក្តីពិតនេះ សូមចែកឯកសារស្តីពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដាលិន អេក អូក ដល់សិស្សម្នាក់ៗ ។ សូមចែកសិស្សជាគូ ហើយអញ្ជើញដៃគូនីមួយៗឲ្យអានសេចក្តីថ្លែងការណ៍នោះឮៗរួមគ្នា ។ សូមឲ្យពួកគេរកមើលថាអែលឌើរ អូក បានបង្រៀនអ្វីខ្លះអំពីការអធិស្ឋាននៃសេចក្តីជំនឿ និងអំណាចព្យាបាលនៃបព្វជិតភាព ។



« នៅពេលយើងអនុវត្តអំណាចបព្វជិតភាពនៃព្រះដោយឥតសង្ស័យ និងនៅពេលយើងឱបក្រសោបសេចក្តីសន្យារបស់ទ្រង់ ថាទ្រង់នឹងឮ និងឆ្លើយតបការអធិស្ឋានដោយសេចក្តីជំនឿនោះ យើងត្រូវតែចងចាំជានិច្ចថា សេចក្តីជំនឿ និងអំណាចបព្វជិតភាពនៃការព្យាបាលមិនអាចមានលទ្ធផលមួយផ្ទុយទៅនឹងព្រះឆន្ទៈរបស់ទ្រង់ ដែលទ្រង់ជាម្ចាស់នៃបព្វជិតភាពនោះឡើយ ។ . . .

« . . . ទោះបីជាអ្នកបម្រើរបស់ព្រះអម្ចាស់ ដែលមានការអនុវត្តអំណាចដ៏ទេវភាពរបស់ទ្រង់នៅក្នុងកាលៈទេសៈមួយដែលមានសេចក្តីជំនឿគ្រប់គ្រាន់ដើម្បីត្រូវបានព្យាបាលក្តី ក៏មិនអាចទទួលបានពរជ័យបព្វជិតភាពមួយ ដែលនឹងបណ្តាលឲ្យបុគ្គលម្នាក់បានជាសះស្បើយដែរ ប្រសិនបើការព្យាបាលនោះមិនមែនជាឆន្ទៈរបស់ព្រះអម្ចាស់ ។

« ក្នុងនាមជាបុត្ររបស់ព្រះ ដោយដឹងពីសេចក្តីស្រឡាញ់ដ៏មហិមារបស់ទ្រង់ និងចំណេះដឹងដ៏គ្មានកម្រិតរបស់ទ្រង់អំពីអ្វីដែលល្អបំផុតសម្រាប់សុខុមាលភាពដ៏អស់កល្បរបស់យើង នោះយើងនឹងទុកចិត្តលើទ្រង់ ។ គោលការណ៍ទីមួយនៃដំណឹងល្អ គឺជាសេចក្តីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ហើយសេចក្តីជំនឿមានន័យថាការទុកចិត្ត ។ . . . ខ្ញុំទទួលអារម្មណ៍ដឹងពីទំនុកចិត្តដូចគ្នានេះ នៅក្នុងពាក្យសម្តីរបស់ឪពុក នៃកូនស្រីម្នាក់បានជាសះជាជីវិត ដោយសារជំងឺមហារីកនៅក្នុងយុវវ័យរបស់នាង ។ គាត់បានប្រកាសថា ‹ សេចក្តីជំនឿរបស់គ្រួសារយើងគឺនៅក្នុងព្រះយេស៊ូវគ្រីស្ទ ហើយវាមិនពឹងផ្អែកទៅលើលទ្ធផលណាមួយនោះទេ › ។ ការបង្រៀនទាំងនោះស្តាប់ទៅពិតណាស់ចំពោះខ្ញុំ ។ យើងធ្វើនូវអ្វីៗទាំងអស់ដែលយើងអាចធ្វើ ដើម្បីព្យាបាលដល់មនុស្សជាទីស្រឡាញ់របស់យើង រួចហើយយើងទុកចិត្តទៅលើព្រះអម្ចាស់ចំពោះលទ្ធផលនោះ » (« Healing the Sick » ទំព័រ ៥០) ។

- តើការបង្រៀនរបស់អែលឌើរ អូក ជួយយើងឲ្យយល់អំពីអំណាចព្យាបាលនៃបព្វជិតភាពយ៉ាងដូចម្តេច ?
- ហេតុអ្វីវាសំខាន់សម្រាប់សេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ដោយពុំពឹងផ្អែកលើលទ្ធផលនៃការប្រសិទ្ធពរនៃបព្វជិតភាព ?

សូមអញ្ជើញសិស្សឲ្យស្ម័គ្រចិត្តអំពីបទពិសោធន៍ដែលពួកគេ ឬមនុស្សដែលពួកគេស្គាល់ ធ្លាប់មានពរតាមរយៈការអធិស្ឋានដោយសេចក្តីជំនឿ និងអំណាចនៃបព្វជិតភាព ។ សូមឲ្យសិស្សចែកចាយអំពីរបៀបដែលបទពិសោធន៍ទាំងនេះបានពង្រឹងសេចក្តីជំនឿ និងទីបន្ទាល់របស់ពួកគេ ។ (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬពិសិដ្ឋពេកនោះទេ) ។

សូមចង្អុលបង្ហាញនៅក្នុង ខទី ១៥ ពីទំនាក់ទំនងរវាងការព្យាបាលអ្នកឈឺ និងការអភ័យទោសពីអំពើបាប ។ ប្រភេទនៃសេចក្តីរាបសា និងសេចក្តីជំនឿដែលតម្រូវឲ្យយើងមាន ដើម្បីទទួលបានការព្យាបាលខាងរាងកាយគឺជាប្រភេទនៃសេចក្តីរាបសា និងសេចក្តីជំនឿដូចគ្នាដែលតម្រូវឲ្យយើងមានដើម្បីទទួលបានការអភ័យទោសដែរ (សូមមើល Bruce R. McConkie *Mormon Doctrine* កំណែទី ២ | ឆ្នាំ ១៩៦៦ | ទំព័រ ២៩៧–៩៨) ។

សូមសង្ខេប យ៉ាកុប ៥:១៧–២០ ដោយពន្យល់ថា យ៉ាកុបបានហៅព្យាការីអេលីយ៉ាថាជាគំរូនៃមនុស្សម្នាក់ ដែលបានប្រើអំណាចនៃការអធិស្ឋានដោយចិត្តក្លៀវក្លា ។ លោកក៏បានទូន្មានពួកបរិសុទ្ធឲ្យជួយពួកអ្នកមានបាបឲ្យប្រែចិត្តផងដែរ ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

យ៉ាកុប ៤:៨ ។ « ចូរលាងដៃឲ្យស្អាតចុះ . . . ចូរសំអាតចិត្តឡើង »

អែលឌើរ ដេវីឌ អេ បែដណា ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់បានពន្យល់អំពីរបៀបដែលយើងអាចលាងដៃឲ្យស្អាត ហើយមានចិត្តបរិសុទ្ធ ៖

« ដៃត្រូវបានសម្អាតដោយសារជំណើរការនៃការសម្រាតចេញនូវនិស្ស័យខាងសាច់ឈាម និងដោយការយកឈ្នះលើអំពើបាប និងឥទ្ធិពលអាក្រក់ទាំងឡាយនៅក្នុងជីវិតរបស់យើងតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ជួងចិត្តបានបរិសុទ្ធ នៅពេលយើងទទួលបានព្រះចេស្តាជ៏ជាកម្លាំងរបស់ទ្រង់ឲ្យធ្វើការល្អ ហើយធ្វើខ្លួនឲ្យកាន់តែប្រសើរឡើង » (« Clean Hands and a Pure Heart » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៨២) ។

សេចក្តីផ្តើមអំពី

សំបុត្រទូទៅទីមួយរបស់ពេត្រុស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

បាវចនាមួយដែលបានរកឃើញនៅក្នុងសំបុត្រទីមួយរបស់ពេត្រុសគឺថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះពួកបរិសុទ្ធរបស់ព្រះអង្គសង្គ្រោះអាចស៊ូទ្រាំដោយស្មោះត្រង់ ហើយអាចឆ្លើយតបចំពោះការរងទុក្ខ និងការបៀតបៀន ។ គ្រប់ជំពូកនៅក្នុងពេត្រុសទី ១ ថ្លែងអំពីការសោកល្បង និងការរងទុក្ខ ហើយពេត្រុសបានបង្រៀនថា ការស៊ូទ្រាំនឹងការសោកល្បងដោយអត់ធ្មត់គឺ « វិសេសជាង. . . មាស » ហើយនឹងជួយពួកអ្នកជឿឲ្យទទួលបាន « សេចក្តីសង្គ្រោះដល់ព្រលឹង [របស់ពួកគេ] » (ពេត្រុសទី១ ១:៧, ៩) ។ ពេត្រុសក៏បានរំឭកពួកបរិសុទ្ធផងដែរអំពីអត្តសញ្ញាណរបស់ពួកគេក្នុងនាមជា « ពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ » (ពេត្រុសទី១ ២:៩) ។ តាមរយៈការសិក្សាពាក្យទូន្មានដែលប៉ុលបានផ្តល់ឲ្យនៅក្នុងសំបុត្រនេះ នោះសិស្សអាចទទួលបាននូវសេចក្តីសង្ឃឹម ការលើកទឹកចិត្ត និងកម្លាំងដែលអាចជួយពួកគេជាមួយនឹងការប្រឈមនានាដែលពួកគេនឹងជួប ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

អ្នកសរសេរសំបុត្រនេះគឺជា « ពេត្រុស ជាសាវកនៃព្រះយេស៊ូវគ្រីស្ទ » (ពេត្រុសទី១ ១:១) ។ « ពីដើមគេស្គាល់ពេត្រុសថាជាសិម្មាន ឬស៊ីម៉ូន (ពេត្រុសទី២ ១:១) គឺជាអ្នកនេសាទពីស្រុកបេតសៃដា រស់នៅក្រុង កាពើណិមជាមួយនឹងប្រពន្ធលោក ។ . . . ពេត្រុសត្រូវបានហៅជាមួយនឹង អនទ្រេ ជាប្អូនប្រុសឲ្យធ្វើជាសិស្សនៃព្រះយេស៊ូវគ្រីស្ទ (ម៉ាថាយ ៤:១៨–២២, ម៉ាកុស ១:១៦–១៨, លូកា៥:១–១១) ។ . . .

« . . . ព្រះអម្ចាស់ទ្រង់បានរើសតាំង [ពេត្រុស] ឲ្យកាន់កូនសោទាំងឡាយនៃនគរនៅលើផែនដី (ម៉ាថាយ ១៦:១៣–១៨) ។ . . .

« ពេត្រុសជាមេសាវកនៅសម័យលោក » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ពេត្រុស » scriptures.lds.org) ។

ការសរសេររបស់ពេត្រុសបង្ហាញពីការកែចម្រើនរបស់លោកចេញពីអ្នកនេសាទសាមញ្ញម្នាក់ទៅជាសាវកដ៏អស្ចារ្យមួយរូប ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

ពេត្រុសទំនងជាសរសេរសំបុត្រទីមួយរបស់លោកនៅចន្លោះ គ.ស. ៦២ និង ៦៤ ។ លោកបានសរសេរពីក្រុង « បាប៊ីឡូន » (ពេត្រុសទី១ ៥:១៣) ប្រហែលជានិមិត្តសញ្ញាមួយអំពីរ៉ូម ។

វាត្រូវបានគេទទួលយកជាទូទៅថា ពេត្រុសបានស្លាប់នៅក្នុងរជ្ជកាលនៃស្តេចរ៉ូមឈ្មោះ ណេរ៉ូ—ទំនងជាក្រោយ គ.ស. ៦៤ កាលស្តេចណេរ៉ូបានចាប់ផ្តើមបៀតបៀនដល់ពួកគ្រីស្ទាន (សូមមើល Bible Dictionary « Peter, Epistles of ») ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

ពេត្រុសសរសេរសំបុត្រនេះទៅសមាជិកសាសនាចក្រដែលរស់នៅខេត្តទាំងប្រាំនៃក្រុងរ៉ូម នៅអាស៊ីតូចដែលមានទីតាំងនៅប្រទេសតួគីនាសម័យបច្ចុប្បន្ន (សូមមើល ពេត្រុសទី១ ១:១) ។ ពេត្រុសចាត់ទុកពួកអ្នកអានរបស់លោកជា « អ្នករើសតាំង » នៃព្រះ (ពេត្រុសទី១ ១:២) ។ លោកបានសរសេរសំបុត្រនេះឡើងដើម្បីពង្រឹង ហើយលើកទឹកចិត្តពួកបរិសុទ្ធនៅក្នុង« ការសោកសេចក្តីជំនឿ [របស់ពួកគេ] » (ពេត្រុសទី ១ ១:៧) ហើយរៀបចំខ្លួនពួកគេ « ដោយភ្លើងដ៏ក្តៅក្រហាយ » (ពេត្រុសទី១ ៤:១២) ។ សារលិខិតរបស់ពេត្រុសក៏បានបង្រៀនពួកគេ អំពីរបៀបឆ្លើយតបនឹងការបៀតបៀនផងដែរ (សូមមើល ពេត្រុសទី ១ ២:១៩–២៣, ៣:១៤–១៥ , ៤:១៣) ។

ការទូន្មានរបស់ពេត្រុសគឺចំពេលល្អណាស់ ដោយសារសមាជិកសាសនាចក្រហៀបនឹងចូលទៅក្នុងគ្រាមួយដែលមានការបៀតបៀនដ៏ខ្លាំង ។ រហូតប្រមាណជា គ.ស. ៦៤ គឺប្រហែលជាពេលដែលពេត្រុសបានសរសេរសំបុត្រនេះ នោះរដ្ឋាភិបាលរ៉ូមបានអធ្យាស្រ័យដល់ពួកគ្រីស្ទានទាំងអស់ ។ ក្នុងខែកក្កដា នាឆ្នាំនោះ មានភ្លើងបានឆេះបំផ្លាញក្រុងរ៉ូមស្ទើរតែទាំងស្រុង ហើយមានពាក្យចចាមអារាមថាស្តេចណេរ៉ូបានចេញបង្គាប់ឲ្យដុតភ្លើងនោះឡើង ។ ដើម្បីបំបែរឥនពីការស្តីបន្ទោសចំពោះគ្រោះមហន្តរាយនេះ មានពួកមន្ត្រីរ៉ូមមួយចំនួនបានចោទប្រកាន់ទៅពួកគ្រីស្ទានចំពោះការធ្វើឲ្យមានភ្លើងនេះឆេះឡើង ។ ការណ៍នេះបាននាំទៅដល់ការបៀតបៀនយ៉ាងខ្លាំងទៅលើពួកគ្រីស្ទាននៅក្នុងអាណាចក្ររ៉ូមទាំងមូល ។ ពេត្រុសបានចង្អុលបង្ហាញថា នៅពេលពួកបរិសុទ្ធ « រងទុក្ខដោយព្រោះជាពួកគ្រីស្ទាន » (ពេត្រុសទី១ ៤:១៦) នោះពួកគេអាចមានអំណរដោយដឹងថាពួកគេកំពុងដើរតាមព្រះយេស៊ូវគ្រីស្ទ (សូមមើល ពេត្រុសទី១ ២:១៩–២៣, ៣:១៥–១៨, ៤:១២–១៩) ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

នៅកណ្តាលនៃទុក្ខវេទនា និងការបៀតបៀននេះដែលពួកបរិសុទ្ធបានជួបនៅសម័យរបស់លោក ពេត្រុសបានដាស់តឿនពួកគេឲ្យងាកទៅរកគ្នាដោយសេចក្តីស្រឡាញ់ និងភាពទន់ភ្លន់ (សូមមើល ពេត្រុសទី១ ១:២២, ៣:៨–៩) ។ លើសពីនេះទៀត យើងបានអាននៅក្នុង ពេត្រុសទី១ ៥ ថា ពេត្រុសបានពន្យល់អំពីរបៀបដែលថ្នាក់ដឹកនាំសាសនាចក្រគួរពង្រឹងដល់ក្រុមជំនុំរបស់ខ្លួន ។

សំបុត្រនេះប្រហែលជាមាននូវសេចក្តីយោងដ៏ច្បាស់លាស់បំផុតពីព្រះគម្ពីរប៊ើបទៅនឹងពិភពវិញ្ញាណ និងកិច្ចការនៃសេចក្តីសង្គ្រោះដែលមាននៅទីនោះ ។ ពេត្រុសបានលើកឡើងដោយសង្ខេបថា ព្រះយេស៊ូវគ្រីស្ទបានយាងទៅពិភពវិញ្ញាណ ដើម្បីប្រកាសដំណឹងល្អដល់វិញ្ញាណទាំងឡាយដែលខ្វះការគោរពប្រតិបត្តិ ដែលស្លាប់បានរស់នៅក្នុងសម័យរបស់ណូអេ (សូមមើល ពេត្រុសទី១ ៣:១៨–២០) ។ លោកបានបន្ថែមថា ដំណឹងល្អត្រូវបានប្រកាសដល់មនុស្សស្លាប់ ដើម្បីឲ្យពួកគេមានឱកាសទទួលបានការកាត់សេចក្តីក្នុងលក្ខខណ្ឌស្មើគ្នានឹងពួកមនុស្សដែលមានជីវិតដែរ (សូមមើល ពេត្រុសទី១ ៤:៥–៦) ។ នៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់យើង ប្រធានយ៉ូសែប អេហ្វ ស្ម៊ីធ កាលលោកកំពុងសញ្ជឹងគិតអំពីអត្ថន័យនៃពេត្រុសទី១ ៣:១៨–២០ និង ពេត្រុសទី១ ៤:៦ នោះលោកបានទទួលវិវរណៈមួយដែលបញ្ជាក់ពីគោលលទ្ធិទាក់ទងនឹងពិភពវិញ្ញាណ (សូមមើល គ. និង ស. ១៣៨) ។

គម្រោង

ពេត្រុសទី១ ១:១–២:១០ ពេត្រុសសរសេរពីអ្វីដែលពួកបរិសុទ្ធត្រូវការ ដើម្បីរីកចម្រើនខាងវិញ្ញាណ ដើម្បីទទួលបានរង្វាន់ដ៏នៅអស់កល្បជានិច្ច ។ ការសន្យានៃសេចក្តីសង្គ្រោះអាចកើតមានឡើង តាមរយៈព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ។ ពួកបរិសុទ្ធគឺជា «ពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរអាកររនៃព្រះ » (ពេត្រុសទី១ ២:៩) ដែលបានទទួលសេចក្តីមេត្តាករុណារបស់ព្រះ ។

ពេត្រុសទី១ ២:១១–៣:១២ ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទស្វែងរកឲ្យកិត្តិយសដល់មនុស្សទាំងអស់ ហើយធ្វើតាមមន្ត្រីសិរីល និងច្បាប់ ។ ពេត្រុសលើកឡើងពីក្រុមជាក់លាក់នៃពួកបរិសុទ្ធ ៖ ជនសេរី ពួកបាវបម្រើ ពួកភរិយា និងពួកស្វាមី ។

ពេត្រុសទី១ ៣:១៣–៥:១៤ នៅពេលការបៀតបៀនធ្វើឲ្យពួកបរិសុទ្ធរងទុក្ខ នោះពួកគេត្រូវចងចាំដល់គំរូរបស់ព្រះយេស៊ូវគ្រីស្ទដែលបានរងទុក្ខ ហើយដែលបន្ទាប់មកបានទទួលការលើកតម្កើង ។ ព្រះយេស៊ូវគ្រីស្ទបានប្រកាសដំណឹងល្អដល់មនុស្សស្លាប់ ដើម្បីឲ្យពួកគេអាចទទួលបានការកាត់សេចក្តីដ៏យុត្តិធម៌មួយ ។ ថ្នាក់ដឹកនាំសាសនាចក្រធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការមើលថែដល់ហ្វូងកូនចៀមរបស់ព្រះ ។ ពួកបរិសុទ្ធត្រូវបន្ទាបខ្លួន ហើយទុកការព្រួយបារម្ភរបស់ពួកគេលើព្រះ ។

ពេត្រុសទី១ ១–២

សេចក្តីផ្តើម


ពេត្រុសបានសរសេរសំបុត្រដើម្បីពង្រឹងសេចក្តីជំនឿពួកបរិសុទ្ធ នៅពេលពួកគេកំពុងរងទុក្ខដោយសារការបៀតបៀនយ៉ាងខ្លាំងមកពីអាណាចក្រូម ។ លោកបានគូសបញ្ជាក់ថា ពួកគេត្រូវបានប្រោសលោះតាមរយៈព្រះលោហិតដ៏មានតម្លៃរបស់ព្រះយេស៊ូវគ្រីស្ទ និងរំឭកពួកគេពីមរតកនៃភាពជាព្រះរបស់ពួកគេ ក្នុងនាមជាស្ត្រេងដ៏ជាកេរ្តិ៍អាករនៃព្រះ ។ ពេត្រុសបានណែនាំពួកបរិសុទ្ធឲ្យសរសើរតម្កើងដល់ព្រះនៅក្នុងចំណោមមនុស្ស ហើយស៊ូទ្រាំនឹងការរងទុក្ខ ដូចជាព្រះយេស៊ូវគ្រីស្ទបានធ្វើ ។

កំណត់ចំណាំ ៖ សូមមើលនៅផ្នែកម្ខាងទៀតនៃទំព័រ « ការរៀបចំទុកជាមុន »ដើម្បីរៀបចំសម្រាប់មេរៀនទី ១៤៤ ។

យោបល់សម្រាប់ការបង្រៀន

ពេត្រុសទី១ ១

ពេត្រុសបង្រៀនដល់ពួកបរិសុទ្ធអំពីសក្តានុពលនៃមរតករបស់ពួកគេ និង ភាពចាំបាច់នៃការសាកល្បង



សូមបង្ហាញ ឬគូររូបភាព ឡ ហើយពន្យល់ថា ឡគឺជាកន្លែងមួយសម្រាប់ដុតដែក ឬ លោហធាតុផ្សេងទៀតដើម្បីបន្សុទ្ធវា នោះមានន័យថាដែក ឬ លោហធាតុនោះត្រូវបានដុត ហើយត្រូវបានរំលាយដើម្បីដកចេញនូវធាតុមិនសុទ្ធ ហើយបង្កើនភាពរឹងមាំដល់ជលិតផលចុងក្រោយ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដែលថ្លែងដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« នៅពេលខ្ញុំធ្វើដំណើរទូទាំងសាសនាចក្រ នោះខ្ញុំឃើញថា សមាជិកត្រូវបានសាកល្បងនៅក្នុងឡនៃសេចក្តីទុក្ខវេទនារបស់ពួកគេ » (« Hyrum Smith: ‹ Firm As the Pillars of Heaven › » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៩) ។

- តើអ្នកគិតថាអែលឌើរ បាឡឺដ ចង់មានន័យយ៉ាងណា តាមរយៈពាក្យ « ឡនៃសេចក្តីទុក្ខវេទនា » នោះ ? (ការសាកល្បងយ៉ាងលំបាក ឬសេចក្តីវេទនាក្នុងជីវិត) ។

ចូរពន្យល់ថា ពេត្រុសបានសរសេរសំបុត្រទីមួយរបស់លោក ដើម្បីពង្រឹង និងលើកទឹកចិត្តដល់ពួកបរិសុទ្ធ នៅពេលពួកគេជួបប្រទះនឹងឡនៃសេចក្តីទុក្ខវេទនា ។ ចូរពន្យល់ថា រហូតដល់ប្រហែលជាឆ្នាំ ៦៤ នៃ គ. ស. គឺជាគ្រាដែលពេត្រុសបានសរសេរសំបុត្រនេះ ជាពេលដែលរដ្ឋាភិបាលរ៉ូមបានបង្ហាញការអត់ឱនដល់ពួកគ្រីស្ទានៅឡើយ ។ នៅក្នុងខែកក្កដានាឆ្នាំដដែលនោះ មានភ្លើងមួយបានឆេះបំផ្លាញអាណាចក្រូម៉ាយ៉ាងធ្ងន់ធ្ងរ ។ អ្នកមានមុខមាត់សាសន៍រ៉ូមមួយចំនួនបានចោទប្រកាន់ពួកគ្រីស្ទានថា ជាអ្នកដើមអគ្គីភ័យនោះ ។ ការណ៍នេះបានធ្វើឲ្យមានការបៀតបៀនយ៉ាងខ្លាំងក្លាទៅលើពួកគ្រីស្ទានទូទាំងអាណាចក្រូម ។ ពួកគ្រីស្ទានមួយចំនួនបានជួបនូវការធ្វើបាបមកពីសំណាក់មិត្តភក្តិ និង អ្នកជិតខាងពីមុនៗរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត នៅពេលពួកគេសិក្សាពេត្រុសទី១ ១–២ ដែលអាចជួយយើងឲ្យបន្តស្មោះត្រង់ នៅពេលយើងត្រូវបានសាកល្បងនៅក្នុងឡនៃសេចក្តីទុក្ខវេទនារបស់យើង ។

សូមសង្ខេបពេត្រុសទី១ ១:១–២ ដោយពន្យល់ថា ពេត្រុសបានទទួលស្វាគមន៍ពួកបរិសុទ្ធនៅក្នុងបណ្តាខេត្តអាណាចក្រូម៉ានៃអាស៊ីតូច (ជាប្រទេសទួគី នៅសព្វថ្ងៃនេះ) ហើយបានរំឭកដាស់តឿនពួកគេថា ពួកគេគឺជាប្រជាជនជម្រើស មានន័យថា ពួកគេត្រូវបានជ្រើសរើសដើម្បីឲ្យទទួលពរជ័យពិសេស នៅពេលពួកគេរស់នៅដោយស្មោះត្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី១ ១:៣–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើពេត្រុសបានរំឭកដល់ពួកបរិសុទ្ធអ្វីខ្លះ អំពីអ្វីដែលព្រះគ្រីស្ទបានធ្វើ និងពរជ័យដែលបានសន្យាដល់ពួកបរិសុទ្ធនាពេលអនាគត ។

- តើពរជ័យនាពេលអនាគតអ្វីខ្លះ ដែលពួកបរិសុទ្ធនឹងទទួលបាន ប្រសិនបើពួកគេបន្តស្មោះត្រង់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់អានពេត្រុសទី១ ១:៦ ឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលនូវរបៀប ដែលពួកបរិសុទ្ធបានឆ្លើយតបចំពោះការសន្យាអំពីពរជ័យនាពេលអនាគតទាំងនេះ ។ សូមពន្យល់ថា ពាក្យ*ការល្បួង*នៅក្នុងខទី ៦សំដៅទៅលើការសាកល្បង និង សេចក្តីទុក្ខវេទនា ។

- តើពួកបរិសុទ្ធបានឆ្លើយតបទៅនឹងការសន្យាអំពីពរជ័យនាពេលអនាគតទាំងនេះយ៉ាងដូចម្តេច ? (ពួកគេបានរីករាយយ៉ាងខ្លាំង) ។
- តើគោលការណ៍អ្វីដែលយើងអាចរៀនមកពី ខទី៣–៦នេះ ? (សិស្សគួរស្គាល់គោលការណ៍ស្រដៀងគ្នាដូចតទៅ ៖ **ទោះបីជាយើងជួបប្រទះការសាកល្បងក្តី ក៏យើងអាចរីករាយនៅក្នុងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង ពរជ័យនាពេលអនាគត ដែលព្រះបានសន្យាថានឹងប្រទានដល់យើងដែរ ។**

ការរៀបចំទុកជាមុន

មេរៀនទី ១៤៤ រួមបញ្ចូលទាំងយោបល់សម្រាប់ការបង្រៀន ដែលជាក់សិស្សឲ្យចូលរួមក្នុងការទទួលសំបុត្រ ។ ប្រសិនបើអ្នកប្រើយោបល់សម្រាប់ការបង្រៀននេះ អ្នកនឹងចាំបាច់ត្រូវរៀបចំប៉ុន្មានថ្ងៃមុន។ សូមទាក់ទងទៅឪពុកម្តាយរបស់សិស្សម្នាក់ៗ ឬថ្នាក់ដឹកនាំសាសនាចក្រក្នុងមូលដ្ឋាន ហើយអញ្ជើញពួកគាត់ឲ្យសរសេរសំបុត្រខ្លីមួយទៅកាន់សិស្ស ដើម្បីសម្តែងពីក្តីអំណររបស់ពួកគាត់ ក្នុងកាលដែលគាត់បានឃើញការខិតខំរស់នៅតាមដំណឹងល្អរបស់សិស្ស ។ សូមប្រមូលសំបុត្រមក ហើយត្រូវប្រាកដថាសិស្សម្នាក់ៗមានសំបុត្រមួយច្បាប់នៅពេលអ្នកបង្រៀនមេរៀនទី ១៤៥ ។

- តើយើងអាចចងចាំអំពីពរជ័យនាពេលខាងមុខ ដែលព្រះបានសន្យាថាប្រទានដល់យើងដើម្បីជួយយើងឲ្យមានអំណរ ទោះជាយើងជួបប្រទះនឹងការសាកល្បងយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី១ ១:៧–៩ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា តើពេត្រុសបានបង្រៀនអ្វីខ្លះអំពីការសាកល្បងសេចក្តីជំនឿរបស់ពួកបរិសុទ្ធ ។

- យោងតាមពេត្រុសទី១ ១:៧ តើពេត្រុសប្រៀបធៀបការសាកល្បង ការពិសោធន៍ ឬសេចក្តីជំនឿរបស់ពួកបរិសុទ្ធទៅនឹងអ្វី ?
- តើការសាកល្បងសេចក្តីជំនឿគឺដូចជាមាសដោយវិធីណា ? (សេចក្តីជំនឿដែលត្រូវបានសាកល្បង គឺដូចជាមាសដ៏មានតម្លៃ) ។ ទោះជាយ៉ាងណា សេចក្តីជំនឿគឺមានតម្លៃវិសេសជាងមាសទៅទៀត ដោយសារមាសចេះ « ខូច » (ខទី ៧) ខណៈដែលសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទនាំទៅរកសេចក្តីសង្គ្រោះ (សូមមើល ខទី ៩) ដែលវាអស់កល្បជានិច្ច ។ លើសពីលើនោះ មាសគឺត្រូវបន្សុទ្ធដោយភ្លើង ។ ស្រដៀងគ្នានេះដែរ **សេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ត្រូវបានសាកល្បង ហើយបន្សុទ្ធ នៅពេលយើងស៊ូទ្រាំនឹងការសាកល្បងដោយស្មោះត្រង់ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងក្លឹមនៃពួកសាវកដប់ពីរនាក់ ដែលបានពន្យល់អំពីរបៀបដែលយើងអាចបន្តខ្ជាប់ខ្ជួន ហើយនឹងនរអំឡុងពេលនៃការសាកល្បងសេចក្តីជំនឿ ។



« តើអ្នកអាចនៅតែ ‹ ខ្ជាប់ខ្ជួន ហើយមុតមាំ › (អាលម៉ា ១:២៥) ក្នុងអំឡុងពេលនៃការសាកល្បងសេចក្តីជំនឿរបស់អ្នកដោយរបៀបណា ? អ្នកបានជ្រមុជខ្លួននៅក្នុងគ្រប់អ្វីៗ ដែលបានជួយកសាងស្នូលនៃសេចក្តីជំនឿរបស់អ្នក ៖ អ្នកអនុវត្តសេចក្តីជំនឿទៅលើព្រះគ្រីស្ទ អ្នកអធិស្ឋាន អ្នកពិចារណាបទគម្ពីរ អ្នកប្រែចិត្ត អ្នកកាន់តាមព្រះបញ្ញត្តិទាំងឡាយ ហើយអ្នកបម្រើអ្នកដទៃ ។

« នៅពេលអ្នកជួបនឹងការសាកល្បងនៃសេចក្តីជំនឿ—ទោះជាអ្នកធ្វើអ្វីក៏ដោយអ្នកមិនត្រូវដើរចេញពីសាសនាចក្រនេះឡើយ ! ការដកខ្លួនអ្នកចេញពីនគរព្រះ អំឡុងពេលការសាកល្បងនៃសេចក្តីជំនឿមួយ គឺប្រៀបដូចជាការចាកចេញពីតំបន់សុវត្ថិភាពការពារព្យុះ ពេលមានព្យុះសង្ឃរាមួយបានមកដល់ដូច្នោះដែរ » (« Trial of Your Faith » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៤០) ។

- តើអែលឌើរ អាន់ឌើរសិន បានលើកទឹកចិត្តដល់យើងឲ្យធ្វើអ្វីខ្លះ នៅក្នុងការសាកល្បងនៃសេចក្តីជំនឿរបស់យើង ?
- ហេតុអ្វីអ្នកគិតថា វាសំខាន់ដើម្បីធ្វើអ្វីៗទាំងនេះ នៅពេលសេចក្តីជំនឿរបស់យើងកំពុងត្រូវបានសាកល្បង ?

សូមចង្អុលបង្ហាញថា ពួកបរិសុទ្ធមួយចំនួនដែលប៉ុលបានសរសេរសំបុត្រទៅ អាចនឹងត្រូវបានល្បួងឲ្យបោះបង់សេចក្តីជំនឿរបស់ខ្លួនចោល នៅពេលពួកគេជួបប្រទះនឹងការបៀតបៀនខាងសាសនា ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានពេត្រុសទី ១ ១:១៣–១៧ ដោយស្ងាត់ស្ងៀម ហើយរកមើលការដាស់តឿនដែលពេត្រុសបានផ្តល់ឲ្យ ដើម្បីជួយពួកបរិសុទ្ធឲ្យស៊ូទ្រាំនឹងការសាកល្បងរបស់ពួកគេដោយស្មោះត្រង់ ។ សូមពិចារណាធ្វើការអញ្ជើញសិស្សឲ្យគូសចំណាំនូវអ្វីដែលពួកគេរកឃើញ ។

- តើពេត្រុសបានដាស់តឿនដល់ពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ?
- តើការប្រឹក្សារបស់ពេត្រុសអាចជួយពួកគេ ឲ្យស៊ូទ្រាំដោយស្មោះត្រង់ក្នុងការសាកល្បងរបស់ពួកគេយ៉ាងដូចម្តេច ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន ពេត្រុសទី១ ១:១៨–២១ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលសេចក្តីពិតបន្ថែមទៀត ដែលពេត្រុសបានបង្រៀនដល់ពួកបរិសុទ្ធ ដើម្បីជួយពួកគេឲ្យស៊ូទ្រាំនឹងការសាកល្បងរបស់ខ្លួនដោយស្មោះត្រង់ ជាជាងបោះបង់សេចក្តីជំនឿរបស់ខ្លួនចោល ។

- តើពេត្រុសបានបង្រៀនសេចក្តីពិតអ្វីខ្លះ ដល់ពួកបរិសុទ្ធក្នុងខគម្ពីរទាំងនេះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់សេចក្តីពិតមួយ ឬច្រើនដូចខាងក្រោម ៖ **យើងត្រូវបានប្រោសលោះ តាមរយៈព្រះលោហិតដ៏មានតម្លៃរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដោយសារព្រះយេស៊ូវគ្រីស្ទបានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប នោះទ្រង់អាចថ្វាយព្រះអង្គទ្រង់ជាការបូជាដ៏ល្អឥតខ្ចោះសម្រាប់យើង ។ ព្រះយេស៊ូវគ្រីស្ទត្រូវបានតែងតាំងពីមុនកំណើតលោកិយ ដើម្បីឲ្យក្លាយជាព្រះប្រោសលោះរបស់យើង**) ។
- តើការចងចាំពីសេចក្តីពិតទាំងនេះ ប្រហែលជាបានជួយពួកបរិសុទ្ធឲ្យស៊ូទ្រាំនឹងការសាកល្បងរបស់ពួកគេដោយស្មោះត្រង់តាមរបៀបណា ?

ដើម្បីជួយសិស្សដឹងអំពីសារៈសំខាន់នៃសេចក្តីពិតទាំងឡាយ ដែលពួកគេបានស្គាល់នៅក្នុង ពេត្រុសទី១ ១សូមអញ្ជើញពួកគេឲ្យគិតអំពីគ្រាមួយដែលពួកគេ ឬនរណាម្នាក់ដែលពួកគេស្គាល់ បានជ្រើសរើសស៊ូទ្រាំនឹងការសាកល្បងដោយសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ ចូរសុំឲ្យសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីបន្តស្មោះត្រង់ នៅពេលពួកគេត្រូវបានសាកល្បងនៅក្នុងឡនៃសេចក្តីទុក្ខវេទនា ។

សូមសង្ខេប ពេត្រុសទី១ ១:២២–២៥ ដោយពន្យល់ថា ពេត្រុសបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយចងចាំថា ពួកគេបានកើតមកម្តងទៀតតាមរយៈការឱបក្រសោបយកព្រះបន្ទូលរបស់ព្រះ ដែលស៊ូទ្រាំជារៀងរហូត ។

សូមផ្តល់ពេលវេលាឲ្យសិស្សឆ្លើយ

សិស្សអាចនឹងមិនឆ្លើយសំណួរភ្លាមៗទេ ប៉ុន្តែសូមកុំបារម្ភចំពោះការស្ងៀមស្ងាត់នេះ ។ ពេលខ្លះសិស្សគ្រាន់តែត្រូវការឱកាសមួយ ដើម្បីសញ្ជឹងគិតពីសំណួរនោះ និងរបៀបដើម្បីឆ្លើយតប ។ ការសញ្ជឹងគិតនេះអាចជួយឲ្យមានការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ ។

ពេត្រុសទី ១ ២:១–១២

ពេត្រុសគូសបញ្ជាក់អំពីការទទួលខុសត្រូវរបស់ពួកបរិសុទ្ធ

- តើសមាជិកសាសនាចក្រខុសប្លែកពីមនុស្សក្នុងលោកិយតាមរបៀបណាខ្លះ ?
- តើមានឧបសគ្គអ្វីខ្លះ ដែលយើងអាចជួបប្រទះ ដោយសារយើងមានភាពខុសប្លែកពីពួកគេនោះ ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សាពេត្រុសទី ១ ២ដែលនឹងពង្រឹងដល់បំណងប្រាថ្នារបស់ពួកគេ ដើម្បីឲ្យមានភាពខុសប្លែករវាងមនុស្សក្នុងពិភពលោក និងពួកសមាជិកនៃសាសនាចក្រ ។

សូមសង្ខេបពេត្រុសទី១ ២:១–៨ ដោយពន្យល់ថា ពេត្រុសបានបង្រៀនថា ពួកបរិសុទ្ធគឺដូចជាថ្មរស់ ហើយថាព្រះយេស៊ូវគ្រីស្ទគឺដូចជាថ្មជ្រុងយ៉ាងឯក ឬជាគ្រឹះរបស់ពួកស្មោះត្រង់ ។ ប៉ុន្តែអ្នកទាំងឡាយដែលមិនគោរពប្រតិបត្តិ ទ្រង់គឺជា « ជាថ្មដំពប់ ហើយជាថ្មដាដែលនាំឲ្យរវាតចិត្ត » (ខទី ៨) មានន័យថា ពួកគេបានខកចិត្តនឹងទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី ១ ២:៩–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលរបៀប ដែលពេត្រុសបានពិពណ៌នាអំពីពួកបរិសុទ្ធស្មោះត្រង់ ។

- តើពេត្រុសបានពិពណ៌នាអំពីពួកបរិសុទ្ធស្មោះត្រង់យ៉ាងដូចម្តេច ?

សូមចង្អុលបង្ហាញថា ពាក្យ*ដ៏ជាកេរ្តិ៍អាករនៃព្រះ*នៅក្នុងខទី ៩ត្រូវបានបកប្រែមកពីពាក្យក្រិកមានន័យថា បានទិញ ឬបានរក្សាទុក ហើយឆ្លើយឆ្លងនឹងពាក្យរបស់ហេព្រើរនៅក្នុង និក្ខមនំ ១៩:៥ ដែលចង្អុលបង្ហាញថា រាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះគឺជាទ្រព្យសម្បត្តិដ៏ពិសេស ឬទ្រព្យដ៏មានតម្លៃចំពោះទ្រង់ ។

- តើពាក្យដែលពេត្រុសបានប្រើពិពណ៌នាអំពីពួកបរិសុទ្ធនៅក្នុង ខទី ៩–១០ បានជួយពួកគេមានចិត្តក្លាហានបែបណា នៅពេលពួកគេជួបនូវការបៀតបៀនខាងសាសនាយ៉ាងដូចម្តេច ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន ពេត្រុសទី១ ២:១១–១២ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើពេត្រុសបានអង្វរពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ក្នុងនាមជាវាស្រ្តដ៏ជាកេរ្តិ៍អាកនៃព្រះអម្ចាស់ ។ សូមពន្យល់ថា ពេត្រុសអាចហៅពួកបរិសុទ្ធថា « ពួកប្រទេសក្រៅ » ឬ « អ្នកគ្រាន់តែសំណាក់ » ដោយសារពួកគេបានរស់នៅក្នុងចំណោមមនុស្សដែលមានវប្បធម៌ និង សាសនាផ្សេងពីពួកបរិសុទ្ធ ឬដោយសារពួកគេស្ថិតនៅឆ្ងាយពីផ្ទះសួគ៌របស់ពួកគេ ដោយរស់នៅក្នុងជីវិតរមែងស្លាប់នេះជាបណ្តោះអាសន្ន ។

- យោងតាមខទី ១១តើពេត្រុសបាននិយាយថា ពួកបរិសុទ្ធត្រូវធ្វើអ្វីខ្លះ ដើម្បីញែកខ្លួនចេញពីលោកិយ ?
- យោងតាមខទី ១២តើពេត្រុសនិយាយថា ពួកបរិសុទ្ធអាចមានឥទ្ធិពលដូចម្តេចខ្លះទៅលើអ្នកដទៃ ក្នុងនាមជាវាស្រ្តជម្រើស និងជាវាស្រ្តដ៏ជាកេរ្តិ៍អាកនៃព្រះ ?
- តើយើងរៀនសេចក្តីពិតអ្វីខ្លះ មកពីពេត្រុស អំពីអ្វីដែលព្រះហៅពួកបរិសុទ្ធរបស់ទ្រង់ឲ្យធ្វើនោះ ? (សិស្សគួរស្គាល់សេចក្តីពិតមួយស្រដៀងគ្នាដូចខាងក្រោម ៖ **ព្រះហៅពួកបរិសុទ្ធរបស់ទ្រង់ឲ្យនៅដាច់ដោយឡែក ហើយខុសពីលោកិយ ប្រយោជន៍ឲ្យអ្នកដទៃអាចមើលឃើញពីគំរូរបស់ពួកគេ ហើយសរសើរតម្កើងដល់ទ្រង់ ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយស៊ីស្ទើរ អេលែន អេស ដាល់ថុន ដែលបានបម្រើជាប្រធានអង្គការយុវនារីទូទៅ ៖

« ប្រសិនបើអ្នកមានបំណងធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងពិភពលោកនេះ *អ្នកត្រូវធ្វើខុសប្លែកពីលោកិយនេះ*» (« Now Is the Time to Arise and Shine! » *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ ២០១២ ទំព័រ ១២៤) ។

- តើការជ្រើសរើសរបស់អ្នកដើម្បីនៅដាច់ដោយឡែក និង ធ្វើខុសប្លែកពីលោកិយនេះ ជះឥទ្ធិពលដល់អ្នកដទៃសម្រាប់សេចក្តីល្អ ឬជួយដឹកនាំពួកគេឲ្យទៅរកព្រះយ៉ាងដូចម្តេច ?

សូមលើកទឹកចិត្តសិស្សឲ្យពិចារណាអំពីអ្វី ដែលពួកគេអាចធ្វើឲ្យបានល្អប្រសើរ ដើម្បីនៅដាច់ដោយឡែក និង ធ្វើខុសប្លែកពីលោកិយនេះ ប្រយោជន៍ឲ្យពួកគេអាចក្លាយជាគំរូនោះ ។ សូមអញ្ជើញពួកគេឲ្យធ្វើតាមការបំផុសគំនិត ដែលពួកគេបានទទួល ។

ពេត្រុសទី១ ២:១៣–២៥

ពេត្រុសទូន្មានពួកបរិសុទ្ធឲ្យស៊ូទ្រាំនឹងការរងទុក្ខដូចដែលព្រះអង្គសង្គ្រោះបានរងទុក្ខដែរ

សូមសង្ខេប ពេត្រុសទី១ ២:១៣–១៨ ដោយពន្យល់ថា ពេត្រុសបានបង្រៀនពួកបរិសុទ្ធឲ្យចុះចូលខ្លួនពួកគេទៅនឹងច្បាប់ និង អាជ្ញាធរដ្ឋប្បវេណី ដែលគ្រប់គ្រងពួកគេ (រួមទាំង អធិរាជចក្រពត្តិរ៉ូម ដែលជម្រុញឲ្យមានការបៀតបៀនប្រឆាំងនឹងពួកគេដែរ, សូមមើលផងដែរ គ. និង ស. ៥៨:២១–២២) ។ លោកបានលើកទឹកចិត្តដល់អស់អ្នកដែលរងទុក្ខជាខ្លាំង ក្នុងនាមជាអ្នកបម្រើឲ្យស៊ូទ្រាំនឹងការរងទុក្ខរបស់ខ្លួន ដោយការអត់ធ្មត់ ហើយចងចាំថាព្រះជ្រាបដឹងពីការរងទុក្ខទាំងនោះ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន ពេត្រុសទី១ ២:១៩–២០ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើពេត្រុសប្រឹក្សាដល់ពួកបរិសុទ្ធ អំពីរបៀបដែលពួកគេគប្បីស៊ូទ្រាំនឹងការរងទុក្ខយ៉ាងដូចម្តេច ។

- តើពេត្រុសប្រឹក្សាអ្វីខ្លះ អំពីរបៀបដែលពួកបរិសុទ្ធគប្បីស៊ូទ្រាំនឹងការរងទុក្ខរបស់ពួកគេ ?

ចូរសុំឲ្យសិស្សអាន ពេត្រុសទី ១ ២:២១–២៥ ដោយស្ងាត់ស្ងៀម រកមើលការពិពណ៌នារបស់ពេត្រុស អំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានឆ្លើយតបចំពោះការបៀតបៀន ។

- តើព្រះគ្រីស្ទឆ្លើយតបចំពោះការបៀតបៀនយ៉ាងដូចម្តេច ?
- យោងតាមខទី ២១តើមូលហេតុមួយ ដែលព្រះអង្គសង្គ្រោះបានរងទុក្ខសម្រាប់យើងគឺជាអ្វី ?
- តើយើងអាចស្គាល់សេចក្តីពិតអ្វីខ្លះចេញមកពីខទី ២១–២៥ អំពីការស៊ូទ្រាំនឹងការសាកល្បង ? (សិស្សគប្បីស្គាល់សេចក្តីពិតស្រដៀងគ្នាដូចខាងក្រោម ៖**យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះនៅក្នុងការស៊ូទ្រាំនឹងការសាកល្បងដោយអត់ធ្មត់**)។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះអង្គសង្គ្រោះ ហើយអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពួកគេអាចធ្វើកាន់តែល្អប្រសើរ ដើម្បីធ្វើតាមគំរូរបស់ទ្រង់នៅក្នុងការស៊ូទ្រាំនឹងការសាកល្បងដោយអត់ធ្មត់ ។

ពេត្រុសទី ១ ៣–៥

សេចក្តីផ្តើម


ពេត្រុសបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យត្រៀមខ្លួនជានិច្ច ដើម្បីថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅដោយសុចរិត ដើម្បីពួកគេអាចបណ្តេញនូវការចោទប្រកាន់ខុសឆ្គង ដែលបានធ្វើឡើងប្រឆាំងនឹងពួកគេ ។ លោកបានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទបានផ្សាយដំណឹងល្អនៅក្នុងពិភពវិញ្ញាណ បន្ទាប់ពីទ្រង់សុគត ។ ពេត្រុសក៏បានទូន្មានពួកអែលឌើរនៃសាសនាចក្រផងដែរ ឲ្យមើលថែទាំហ្វូងចៀមរបស់ព្រះ ឲ្យដូចជាការមើលថែទាំរបស់ព្រះយេស៊ូវគ្រីស្ទដែរ ដែលទ្រង់ជាប្រធាននៃអ្នកគង្វាល ។

យោបល់សម្រាប់ការបង្រៀន

ពេត្រុសទី១ ៣:១–១៧

ពេត្រុសទូន្មានឲ្យពួកបរិសុទ្ធមានភាពសាមគ្គីគ្នានៅក្នុងភាពសុចរិត ហើយត្រៀមខ្លួនជានិច្ចដើម្បីថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉ុនសុន ៖



« យើងនឹងមានឱកាសនានាពេញមួយជីវិតយើង ដើម្បីចែកចាយជំនឿរបស់យើង ទោះបីជាយើងមិនបានដឹងពីពេលដែលយើងនឹងត្រូវបានហៅឲ្យធ្វើយ៉ាងដូច្នេះជានិច្ចក្តី ។ ឱកាសមួយបែបនេះបានកើតមានចំពោះខ្ញុំក្នុងឆ្នាំ ១៩៥៧ កាលខ្ញុំធ្វើការក្នុងអាជីពផ្នែកបោះពុម្ព ហើយត្រូវបានសុំឲ្យទៅទីក្រុង ដាឡាស រដ្ឋ តិចសាស | ស.រ.អា. | ពេលខ្លះត្រូវបានហៅថា ‹ ទីក្រុងដែលមានព្រះវិហារច្រើន › ដើម្បីថ្លែងសុន្ទរកថាក្នុងការប្រជុំមុខជំនួញ ។ បន្ទាប់ពីបញ្ចប់សុន្ទរកថាខ្ញុំបានជិះឡានក្រុងមើលទេសភាពតាមជាយក្រុងក្នុងទីក្រុងនោះ ។ ពេលយើងបានឆ្លងកាត់ព្រះវិហារមួយចំនួន តែកុងឡានបាននិយាយថា ‹ នៅខាងឆ្វេងដៃ អ្នកនឹងឃើញព្រះវិហារមេតូឌីស › ឬ ‹ នៅខាងស្តាំដៃគឺជាព្រះវិហារកាតូលិក › ។

ពេលយើងឆ្លងកាត់អគារឥដ្ឋពណ៌ក្រហមដ៏ស្រស់ស្អាតមួយដែលសង់នៅលើភ្នំ តែកុងឡានបាននិយាយថា ‹ អគារនោះគឺជាកន្លែងដែលពួកមរមនប្រជុំគ្នា › ។ មានស្ត្រីម្នាក់នៅក្នុងឡានក្រុងផ្នែកខាងក្រោយបានស្រែកឡើងថា ‹ តែកុងឡាន តើអ្នកអាចប្រាប់ពួកយើងបន្ថែមទៀតពីពួកមរមនបានទេ ? ›

តែកុងឡាននោះបានឈប់ឡានក្រុងនៅក្បែរតែមផ្លូវ ហើយបានងាកមកក្រោយដោយនិយាយថា ‹ អ្នកស្រី អ្វីដែលខ្ញុំដឹងពីពួកមរមនគឺថា ពួកគេជួបជុំគ្នានៅក្នុងអគារឥដ្ឋក្រហមនោះ ។ តើមាននរណាម្នាក់នៅលើឡាននេះដឹងរឿងបន្ថែមទៀតពីពួកមរមនដែរឬទេ ? › »
(« Dare to Stand Alone » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៦៧) ។

- ប្រសិនបើអ្នកនៅក្នុងឡានក្រុងនោះ តើអ្នកនឹងធ្វើអ្វីខ្លះ ?
- ហេតុអ្វីពេលខ្លះវាអាចជាការលំបាក ដើម្បីប្រាប់មនុស្សដទៃអំពីជំនឿរបស់យើង ?

សូមអញ្ជើញសិស្សឲ្យរកមើលគោលការណ៍មួយ នៅពេលពួកគេសិក្សា ពេត្រុសទី ១ ៣:១–១៧ ដែលនឹងជួយដឹកនាំពួកគេ នៅពេលពួកគេមានឱកាសជាច្រើនដើម្បីចែកចាយដំណឹងល្អជាមួយអ្នកដទៃ ។

សូមសង្ខេបពេត្រុសទី ១ ៣:១–១១ ដោយពន្យល់ថា ពេត្រុសបានដាស់តឿនភរិយាទាំងឡាយឲ្យជួយដល់ស្វាមីដែលពុំជឿលើព្រះគ្រីស្ទតាមរយៈទង្វើសុចរិតរបស់ពួកគេ ។ លោកបានទូន្មានស្វាមីឲ្យគោរពស្រឡាញ់ភរិយារបស់ខ្លួន ។ លោកក៏បានទូន្មានដល់សមាជិកទាំងឡាយឲ្យរស់នៅស្របតាមបទដ្ឋានដំណឹងល្អផងដែរ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន ពេត្រុសទី១ ៣:១៤–១៦ ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលថាតើពេត្រុសទូន្មានដល់ពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ នៅពេលពួកគេរងនូវការបៀតបៀន ដោយសារតែពួកគេរស់នៅដោយសុចរិតនោះ ។

- **តើពេត្រុសទូន្មានដល់ពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ នៅពេលពួកគេរងទុក្ខនូវការបៀតបៀនដោយសារតែពួកគេរស់នៅដោយសុចរិតនោះ ?**
- **យោងតាមខទី ១៥តើពេត្រុសបានមានប្រសាសន៍ថា ពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទគួរធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនជានិច្ចនោះ ?**
- **តើទិដ្ឋភាពនៃដំណឹងល្អអ្វីខ្លះ ដែលអ្នកគិតថាបានផ្តល់សេចក្តីសង្ឃឹមដល់មនុស្ស ?**


សូមពន្យល់ថាពាក្យ *ឆ្លើយតប* នៅក្នុង ខទី ១៥ អាចបកប្រែថា « ការពារ » ផងដែរ ។ ពេត្រុសបានទូន្មានពួកបរិសុទ្ធឲ្យចែកចាយ និង ការពារជំនឿសាសនារបស់ពួកគេ ។

- **តើពាក្យនៅក្នុងខទី ១៥អ្វីខ្លះ ដែលពិពណ៌នាអំពីរបៀបដែលយើងគួរចែកចាយ និងការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?**
(អ្នកអាចនឹងចង់ពន្យល់ថា ពាក្យ *ភ័យខ្លាច*មានន័យថា គារវភាព ឬស្ញើចសរសើរនៅក្នុងបរិបទនេះ) ។
- **តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីពេត្រុសទី ១ ៣:១៥អំពីអ្វីដែលយើងគួរព្យាយាមធ្វើដើម្បីត្រៀមខ្លួនជានិច្ច ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទនោះ ?** (សិស្សគួរស្តាប់សេចក្តីពិតស្រដៀងគ្នាមួយ ដូចខាងក្រោម ៖ **ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ**

យើងគប្បីព្យាយាមត្រៀមខ្លួនជានិច្ចដើម្បីចែកចាយ និង ការពារជំនឿរបស់យើងដោយចិត្តសុភាពរាបសា និង ការគោរព ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

- តើអ្នកគិតថា ហេតុអ្វីវាសំខាន់ដើម្បីចែកចាយជំនឿរបស់យើងដោយចិត្តសុភាពរាបសា និង ការគោរពនោះ ?

ដើម្បីបង្ហាញអំពីសេចក្តីពិតនៅលើក្តារខៀន សូមអញ្ជើញសិស្សម្នាក់ឲ្យអានពូ ៗអំពីដំណើររឿងរបស់ប្រធាន ម៉នសុន អំពីបទពិសោធន៍របស់លោកនៅលើឡានក្រុង ៖



« ខ្ញុំបានចាំមើលក្រែងមាននរណាម្នាក់ឆ្លើយតប ។ ខ្ញុំបានក្រឡេកមើលទៅទឹកមុខរបស់មនុស្សគ្រប់គ្នា រកមើលសញ្ញានៃការស្គាល់ពូកមរមន និងចំណងរបស់អ្នកខ្លះដែលអាចចង់បញ្ចេញយោបល់ ។ គ្មានសោះ ។ ខ្ញុំបានដឹងថា វាអាស្រ័យលើខ្ញុំ ដើម្បីធ្វើដូចជាសាវកពេត្រុស បានផ្តល់ដំបូន្មាន ‹ ចូរប្រុងប្រៀបជានិច្ច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុផលនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា › ។ ខ្ញុំក៏ដឹងពីសេចក្តីពិតដែលបាននិយាយថា ‹ នៅពេលវេលានៃការសម្រេចចិត្តមកដល់ នោះពេលនៃការត្រៀមខ្លួនគឺបានកន្លងហួសបាត់ទៅហើយ › ។

« អស់រយៈពេល ១៥ នាទីក្រោយមក ខ្ញុំមានឯកសិទ្ធិចែកចាយជាមួយអស់អ្នកដែលនៅលើឡាននោះ ដោយថ្លែងទីបន្ទាល់របស់ខ្ញុំអំពីសាសនាចក្រ និង ជំនឿរបស់យើង ។ ខ្ញុំមានអំណរគុណចំពោះទីបន្ទាល់របស់ខ្ញុំ ហើយមានអំណរគុណដែលខ្ញុំបានត្រៀមខ្លួនជាស្រេចដើម្បីចែកចាយវា » (« Dare to Stand Alone » ទំព័រ ៦៧) ។

- តើមានអ្វីខ្លះដែលអ្នកអាចធ្វើ ដើម្បីត្រៀមខ្លួនជានិច្ចដើម្បីចែកចាយជំនឿរបស់អ្នក ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពូកគេមានអំណរគុណ ដែលពូកគេបានត្រៀមខ្លួនដើម្បីចែកចាយជំនឿ ឬ ទីបន្ទាល់របស់ពូកគេ ។ ចូរសុំឲ្យសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់ពូកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីអ្វីដែលពូកគេនឹងធ្វើដើម្បីត្រៀមខ្លួនជានិច្ច ដើម្បីចែកចាយ និងការពារដល់សេចក្តីជំនឿរបស់ពូកគេ ។ សូមលើកទឹកចិត្តពូកគេធ្វើសកម្មភាព តាមការបំផុសគំនិតដែលពូកគេបានទទួល ។

ពេត្រុសទី១ ៣:១៨–៤:១៩

ព្រះយេស៊ូវគ្រីស្ទបានផ្សាយដំណឹងល្អនៅក្នុងពិភពវិញ្ញាណ បន្ទាប់ពីទ្រង់សុគត

សូមអញ្ជើញសិស្សឲ្យនឹកស្រមៃថា ពូកគេជាអ្នកផ្សព្វផ្សាយសាសនា ដែលកំពុងបង្រៀនដល់មនុស្សម្នាក់ដែលនិយាយដូចតទៅនេះ ៖

« ខ្ញុំជឿលើអ្វីដែលអ្នកកំពុងបង្រៀនខ្ញុំថាជាការពិត ប៉ុន្តែខ្ញុំងឿងឆ្ងល់អំពីមនុស្សដែលស្លាប់ទៅដោយពុំមានឱកាសស្តាប់ឮសេចក្តីពិតនោះ ។ វាហាក់បីដូចជាមិនយុត្តិធម៌ទេ ដែលព្រះដាក់ទោសពូកគេ ឬរាំងពូកគេមិនឲ្យរស់នៅជាមួយទ្រង់ម្តងទៀត ប្រសិនបើពូកគេពុំធ្លាប់មានឱកាសដើម្បីរៀនអំពីផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់សោះនោះ » ។

សូមសុំឲ្យសិស្សពិចារណាថា តើពូកគេនឹងឆ្លើយតបយ៉ាងណា ។

សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ឲ្យអានពេត្រុសទី ១ ៣:១៨–២០ ដោយស្ងាត់ស្ងៀម រួមទាំងការបកប្រែដោយ យ៉ូសែបស៊្មីធ ។ រួចសុំឲ្យពាក់កណ្តាលទៀតអានពេត្រុសទី ១ ៤:៥–៦ ដោយស្ងាត់ស្ងៀម រួមមានទាំងការបកប្រែដោយ យ៉ូសែប ស៊្មីធ ។ចូរសុំសិស្សឲ្យរកមើលសេចក្តីពិតដែលពេត្រុសបង្រៀន ដើម្បីពូកគេអាចចែកចាយជាមួយនឹងមនុស្សនៅក្នុងស្ថានភាពនេះ ។ សូមពន្យល់ថា ឃ្លា « ពូកវិញ្ញាណដែលជាប់ឃុំ » នៅក្នុង ពេត្រុសទី១ ៣:១៩ សំដៅទៅលើអស់អ្នកនៅក្នុងពិភពវិញ្ញាណ ដែលពុំបានទទួលយកដំណឹងល្អ ឬមានឱកាសស្តាប់ឮពីដំណឹងល្អកាលនៅក្នុងជីវិតរមែងស្លាប់នេះ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- តើយើងរៀនអ្វីខ្លះចេញពីខគម្ពីរទាំងនេះ អំពីអស់អ្នកនៅក្នុងពិភពវិញ្ញាណ ដែលពុំបានទទួលយកដំណឹងល្អ ឬ មានឱកាសទទួលយកដំណឹងល្អកាលនៅក្នុងជីវិតនេះ ?



ចូរដាក់បង្ហាញរូបភាព ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ (*សៀវភៅសិល្បៈដំណឹងល្អ* | ឆ្នាំ ២០០៩), ទំព័រ ១២៧ សូមមើលផងដែរ LDS.org). សូមពន្យល់ថា ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានពិចារណាអំពីអត្ថន័យនៅក្នុងពេត្រុសទី១ ៣:១៨–២០ និង ពេត្រុសទី១ ៤:៦ កាលលោកបានទទួលវិវរណៈ និង ការនិមិត្តអំពីការយាងទៅជួបពិភពវិញ្ញាណរបស់ព្រះអង្គសង្គ្រោះ ។ លោកបានមើលឃើញព្រះយេស៊ូវគ្រីស្ទ នៅចន្លោះពេលនៃការសុគត និងការរស់ឡើងវិញរបស់ទ្រង់ លោកបានបង្រៀនដំណឹងល្អ ហើយបានបម្រើដោយផ្ទាល់ដល់ពូកវិញ្ញាណសុចរិត ។ បន្ទាប់មកព្រះយេស៊ូវគ្រីស្ទបានរៀបចំ និង ផ្តល់អំណាចដល់អ្នកបម្រើសុចរិតនានា ឲ្យបង្រៀនដំណឹងល្អដល់វិញ្ញាណនៅក្នុងស្ថានឃុំវិញ្ញាណ (សូមមើល គ. និង ស. ១៣៨:១–១១, ២៩–៣០) ។

- យោងតាម ពេត្រុសទី១ ៤:៦ ហេតុអ្វីដំណឹងល្អត្រូវផ្សព្វផ្សាយដល់មរណជនដូច្នេះ ? (ដើម្បីនាំមកនូវការជំនុំជម្រះដោយសុចរិត និងយុត្តិធម៌ដល់កូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ តាមរយៈការផ្តល់នូវឱកាសដល់ពូកគេស្តាប់ និងរស់នៅស្របតាមក្រឹត្យវិន័យរបស់ព្រះ) ។
- តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចស្គាល់មកពីការបង្រៀនរបស់ពេត្រុស អំពីដំណឹងល្អដែលត្រូវបានបង្រៀនដល់មរណជន ? (សិស្សអាចនឹងប្រើសម្ភីរបស់ពូកគេផ្ទាល់ ប៉ុន្តែត្រូវប្រាកដថា ពូកគេស្គាល់សេចក្តីពិតស្រដៀងគ្នាដូចខាងក្រោម ៖**ដំណឹងល្អត្រូវបានផ្សាយដល់អ្នកទាំងឡាយដែលបានទទួលមរណភាព ដើម្បីពូកគេអាចមានឱកាសដូចគ្នានឹងអស់អ្នកដែលបានស្តាប់ឮដំណឹងល្អក្នុងជីវិតរមែងស្លាប់នេះដែរ**)។

📖 **ពេត្រុសទី១ ៤:៦** គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ ការសិក្សាចំណេះចំណានខគម្ពីរនឹងជួយសិស្សបង្កើនការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រឹះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះ ដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងរកវាឃើញ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

សូមរំឭកដោយសង្ខេបអំពីស្ថានភាព ដែលបានបង្ហាញនៅខាងដើមនៃបណ្តុំបទគម្ពីរនេះ រួច ហើយសួរ ៖

- តើគោលលទ្ធិនៃសេចក្តីសង្គ្រោះសម្រាប់មរណជន គឺជាភស្តុតាងនៃសេចក្តីមេត្តាករុណារបស់ព្រះចំពោះកូនចៅទ្រង់ដោយរបៀបណា ?

សូមសង្ខេប ពេត្រុសទី ១ ៤:៧–១៩ តាមរយៈការពន្យល់ថា ពេត្រុសបានដាស់តឿនដល់ពួកបរិសុទ្ធឲ្យមានសេចក្តីសប្បុរសដ៏ភ្លៀវក្លា ដោយសារសេចក្តីសប្បុរសគ្រប់បាំង ឬទប់ស្កាត់ពីអំពើបាបជាច្រើន (សូមមើលការបកប្រែដោយ យ៉ូសែប ស៊្មីធ ពេត្រុសទី ១ ៤:៨ ។ ពេត្រុសក៏បានបង្រៀនពួកបរិសុទ្ធឲ្យរីករាយផងដែរ នៅពេលពួកគេរងទុក្ខក្នុងការសាកល្បង និងការស្តីបន្ទោស ដោយសារតែពួកគេជឿទៅលើព្រះយេស៊ូវគ្រីស្ទនោះ ។

ពេត្រុសទី១ ៥

ពេត្រុសបានប្រឹក្សាដល់ពួកអែលឌើរឲ្យមើលថែទាំហ្វូងចៀមរបស់ព្រះ ហើយបានលើកទឹកចិត្តឲ្យពួកបរិសុទ្ធបន្តកាន់ខ្ជាប់នៅក្នុងសេចក្តីជំនឿ

សូមពន្យល់ថា ដើម្បីជួយរៀបចំពួកបរិសុទ្ធសម្រាប់ការសាកល្បងដែលពួកគេនឹងជួប នោះពេត្រុសបានបង្រៀនពួកអែលឌើរនៃសាសនាចក្រអំពីការទទួលខុសត្រូវរបស់ពួកគេ ក្នុងនាមជាថ្នាក់ដឹកនាំសាសនាចក្រ ។ សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី១ ៥:១–៣ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនូវការប្រឹក្សារបស់ពេត្រុសដល់ពួកអែលឌើរក្នុងសាសនាចក្រ ។

- តើពេត្រុសបានផ្តល់ការប្រឹក្សាអ្វីខ្លះដល់ពួកអែលឌើរក្នុងសាសនាចក្រ ?

សូមពន្យល់ថា « ហ្វូងចៀមរបស់ព្រះ » (ខទី ២) មានន័យថា មើលថែទាំ និងថែរក្សាសមាជិកសាសនាចក្រ ។ ថ្នាក់ដឹកនាំសាសនាចក្រត្រូវបម្រើដោយស្មោះពីចិត្ត និង ដោយក្តីស្រឡាញ់ ជាជាងដោយបម្រើដោយអរិវ៉ាទាំ ឬ ដោយមានចិត្តចង់បានរង្វាន់ ។ ពួកគេត្រូវធ្វើជាគំរូដល់សមាជិកនានា ជាជាងធ្វើជា « អ្នកមានអំណាច » (ខទី ៣) លើពួកគេ ។

- ចេញមកពីការប្រឹក្សារបស់ពេត្រុសដល់ពួកអែលឌើរក្នុងសាសនាចក្រ តើមានសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនអំពីការទទួលខុសត្រូវរបស់អ្នកដឹកនាំសាសនាចក្រ ? (សូមជួយសិស្សឲ្យស្គាល់សេចក្តីពិតមួយស្រដៀងគ្នាដូចខាងក្រោម ៖ **ថ្នាក់ដឹកនាំសាសនាចក្រមានការទទួលខុសត្រូវ ដើម្បីថែទាំ និងឃ្លាំមើលដល់ហ្វូងចៀមរបស់ព្រះដោយសេចក្តីស្រឡាញ់ និងគំរូ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យអាន ពេត្រុសទី១ ៥:៤ ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបដែលពេត្រុសបានថ្លែងអំពីព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សរាយការណ៍អំពីអ្វីដែលពួកគេរកឃើញ ។



សូមដាក់បង្ហាញរូបភាព ព្រះយេស៊ូវលើកព្រះរៀមដែលបាត់ *Gospel Art Book* | ឆ្នាំ ២០០៩ | លេខ៦៤, សូមមើលផងដែរ LDS.org) រួចសួរថា

- ហេតុអ្វីក៏អ្នកគិតថា ព្រះអង្គសង្គ្រោះត្រូវបានពិពណ៌នាជាញឹកញាប់ថាជាអ្នកគង្វាលដូច្នេះ ?
- តើគុណសម្បត្តិ និង បុគ្គលិកលក្ខណៈដូចជាព្រះគ្រីស្ទអ្វីខ្លះ ដែលអាចជួយថ្នាក់ដឹកនាំសាសនាចក្រឲ្យមើលថែ និង ថែទាំដល់សមាជិកសាសនាចក្រនោះ ?
- តើអ្នកធ្លាប់បានទទួលពរជ័យ ដោយសារតែថ្នាក់ដឹកនាំសាសនាចក្រមានសេចក្តីស្រឡាញ់ ឬ គំរូដូចជាព្រះគ្រីស្ទយ៉ាងដូចម្តេច ?

សូមសង្ខេបពេត្រុសទី ១ ៥:៧–១៤ ដោយពន្យល់ថា ពេត្រុសបានបង្រៀនដល់ពួកបរិសុទ្ធឲ្យទុកចង្កូល់ (មានន័យថា ការមានចិត្តអន្ទះសា) របស់ពួកគេមកលើព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ហើយបន្តនៅខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿរបស់ពួកគេ ទោះជាមានការរងទុក្ខជាច្រើនក្តី ។ ពេត្រុសបានអះអាងនឹងពួកគេថា ប្រសិនបើពួកគេធ្វើបែបនោះបាន នោះព្រះនឹងធ្វើឲ្យពួកគេបានគ្រប់លក្ខណ៍ និង មានភាពរឹងមាំ ។

សូមបញ្ចប់ដោយលើកទឹកចិត្តដល់សិស្សឲ្យទុកចិត្ត និងធ្វើតាមអ្នកទាំងឡាយដែលព្រះអម្ចាស់បានហៅឲ្យជួយឃ្វាល ហើយមើលថែពួកគេខាងវិញ្ញាណ ។

ចំណេះចំណានខគម្ពីរ—ពេត្រុសទី១ ៤:៦

ដើម្បីលើកទឹកចិត្តដល់សិស្សឲ្យចូលរួមនៅក្នុងកិច្ចការនៃសេចក្តីសង្គ្រោះដល់ជីដូនជីតារបស់ពួកគេ សូមរំឭកពេត្រុសទី ១ ៤:៦ ជាមួយពួកគេ រួចហើយសួរ ៖

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយជីដូនជីតារបស់អ្នកដែលបានទទួលដំណឹងល្អនៅពិភពវិញ្ញាណ ហើយកំពុងរង់ចាំដើម្បីបានរំដោះឲ្យមានសេរីភាពពីស្ថានឃុំវិញ្ញាណវិញ ?
- តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលអ្នកត្រូវបានប្រទានពរតាមរយៈការធ្វើពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធសម្រាប់ជីដូនជីតារបស់អ្នកនោះ ?

សូមអញ្ជើញសិស្សឲ្យស្វែងរកឱកាស ដើម្បីធ្វើការស្រាវជ្រាវពង្សប្រវត្តិអំពីជីដូនជីតារបស់ពួកគេ ហើយចូលរួមក្នុងពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធ ជំនួសឲ្យជីដូនជីតាទាំងឡាយនោះ ។

មេរៀនសិក្សានៅផ្ទះ

យ៉ាកុប ២–ពេត្រុសទី ១ ៥ (មេរៀនទី ២៩)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍ គោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា យ៉ាកុប ២–ពេត្រុសទី១ ៥ (មេរៀនទី ២៩) ពុំត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី១ (យ៉ាកុប ២–៣)

សិស្សបានរៀនចេញពីការបង្រៀនរបស់យ៉ាកុបនៅក្នុងជំពូកនេះថា ពួកសិស្សស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្តស្រឡាញ់មនុស្សគ្រប់រូប មិនថាពួកគេមានស្ថានភាពបែបណាទេ ហើយក៏រៀនថាប្រសិនបើយើងធ្វើអំពើបាបសូម្បីតែមួយ យើងនឹងមានកំហុសចំពោះព្រះ ។ ពួកគេក៏បានរៀនផងដែរថា សេចក្តីជំនឿពិតលើព្រះយេស៊ូវគ្រីស្តគឺបង្ហាញឡើងដោយកិច្ចការសុចរិតរបស់យើង ។ នៅពេលពួកគេសិក្សាពីការបង្រៀនរបស់យ៉ាកុបស្តីពីការគ្រប់គ្រងពាក្យលើសម្តីរបស់យើង សិស្សបានរកឃើញថា ការរៀនគ្រប់គ្រងពាក្យសម្តីរបស់យើងអាចមានឥទ្ធិពលដ៏ធំមួយមកលើជីវិតរបស់យើង ហើយថាពួកអ្នកដើរតាមព្រះខិតខំប្រើពាក្យសម្តីរបស់ខ្លួនសម្រាប់គោលបំណងសុចរិត ពុំមែនដើម្បីពង្រីកអំពើអាក្រក់នោះទេ ។

ថ្ងៃទី២ (យ៉ាកុប ៤–៥)

នៅពេលសិស្សបានសិក្សាជំពូកទាំងនេះនៅក្នុងយ៉ាកុប ពួកគេបានរៀនពីសេចក្តីពិតដូចតទៅ ៖ នៅពេលយើងខិតទៅជិតព្រះ នោះទ្រង់នឹងខិតមកជិតយើង ។ ប្រសិនបើយើងដឹងថា យើងត្រូវតែធ្វើការល្អ ប៉ុន្តែជ្រើសរើសពុំធ្វើវាវិញ នោះយើងធ្វើអំពើបាបហើយ ។ តាមរយៈការអធិស្ឋានដោយសេចក្តីជំនឿ និងអំណាចនៃបព្វជិតភាព អ្នកឈឺអាចទទួលបានការព្យាបាល ។

ថ្ងៃទី៣ (ពេត្រុសទី១ ១–២)

នៅក្នុងការសិក្សារបស់ពួកគេអំពីការបង្រៀនរបស់ពេត្រុស សិស្សបានរៀនសេចក្តីពិតដូចតទៅនេះ ៖ ទោះជាយើងជួបនឹងការសាកល្បងក្តី យើងអាចរីកចម្រើនក្នុងជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត និងនៅក្នុងពរជ័យនៅពេលខាងមុខ ដែលព្រះបានសន្យានឹងប្រទានឲ្យយើង ។ សេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្តត្រូវបានល្បងហើយពង្រឹង នៅពេលយើងស៊ូទ្រាំនឹងការសាកល្បងទាំងឡាយដោយស្មោះត្រង់ ។ យើងអាចទទួលបានការប្រោសលោះ តាមរយៈព្រះលោហិតដ៏មានតម្លៃនៃព្រះយេស៊ូវគ្រីស្ត ។ ដោយសារព្រះយេស៊ូវគ្រីស្តបានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប ទ្រង់អាចថ្វាយព្រះជន្មទ្រង់ទុកជាការបូជាដ៏ល្អឥតខ្ចោះមួយសម្រាប់យើង ។ ព្រះយេស៊ូវគ្រីស្ត ត្រូវបានតែងតាំងពីមុនកំណើតលោកិយ ដើម្បីឲ្យក្លាយជាព្រះប្រោសលោះរបស់យើង ។ ព្រះទ្រង់ហៅពួកបរិសុទ្ធរបស់ទ្រង់ដើម្បីឲ្យញែកចេញ ហើយខុសប្លែកពីលោកិយនេះ ដើម្បីឲ្យមនុស្សដទៃទៀតអាចឃើញពីគំរូរបស់ពួកគេ ហើយថ្វាយសិរីល្អចំពោះទ្រង់ ។ យើងអាចធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នៅក្នុងការស៊ូទ្រាំនឹងការសាកល្បងដោយអត់ធ្មត់ ។

ថ្ងៃទី៤ (ពេត្រុសទី១ ៣–៥)

សិស្សបានរៀនចេញពីការលើកទឹកចិត្តរបស់ពេត្រុសដល់ពួកបរិសុទ្ធនៅជំនាន់របស់លោកថា ក្នុងនាមជាពួកអ្នកដើរតាមព្រះយេស៊ូវគ្រីស្ត យើងគួរខិតខំធ្វើការត្រៀមខ្លួនជាស្រេចដើម្បីចែកចាយ ហើយការពារជំនឿរបស់យើងដោយចិត្តរាបសា និងគារវភាពជានិច្ច ។ សិស្សក៏រៀនផងដែរថា ដំណឹងល្អត្រូវបានផ្សាយដល់អស់អ្នកទាំងឡាយណា ដែលបានស្លាប់ទៅ ដូច្នេះពួកគេអាចមានឱកាសដូចគ្នានឹងអស់អ្នកទាំងឡាយណា ដែលបានឮដំណឹងល្អនៅក្នុងជីវិតរមែងស្លាប់ដែរ ។ ពេត្រុសបានបង្រៀនថា ថ្នាក់ដឹកនាំសាសនាចក្រមានការទទួលខុសត្រូវថែទាំ ហើយមើលថែកូនចៀមរបស់ព្រះដោយសេចក្តីស្រឡាញ់ និងដោយគំរូ ។

សេចក្តីផ្តើម

សាវកយ៉ាកុបបានពន្យល់បញ្ជាក់ពីការយល់ខុសមួយចំនួន នៅក្នុងចំណោមពួកបរិសុទ្ធអំពីអត្ថន័យនៃសេចក្តីជំនឿពិត ។ លោកក៏បានបង្រៀនផងដែរអំពីទំនាក់ទំនងរវាងសេចក្តីជំនឿ និងការប្រព្រឹត្តតាម ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប២:១៤–២៦

យ៉ាកុបបង្រៀនពីតួនាទីនៃសេចក្តីជំនឿ និងការប្រព្រឹត្តតាមនៅក្នុងសេចក្តីសង្គ្រោះរបស់យើង

សូមអញ្ជើញសិស្សឲ្យគិតថា មានយុវជនម្នាក់បានទទួលស្គាល់ថាគាត់បានប្រព្រឹត្តអំពើបាប ។ គាត់ជឿលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ត និងលើសមត្ថភាពរបស់ព្រះអង្គសង្គ្រោះដើម្បីសង្គ្រោះគាត់ ។ គាត់ពោលថា អ្វីដែលគាត់ត្រូវធ្វើគឺជឿ ហើយព្រះអម្ចាស់នឹងអត់ទោសឲ្យគាត់ ដោយគាត់ពុំបាច់ធ្វើអ្វីទាំងអស់ ។

សូមឲ្យសិស្សពិចារណាថា តើជំនឿរបស់យុវជននោះតែម្យ៉ាងនោះវាល្មមគ្រប់គ្រាន់ ដើម្បីឲ្យគាត់អាចបានការអត់ទោសពីអំពើបាបរបស់ខ្លួនដែរឬទេ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប២:១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ាកុបបានសួរអ្វីខ្លះដល់ពួកបរិសុទ្ធទាក់ទងនឹងសេចក្តីជំនឿ ។

- តើយ៉ាកុបបានសួរអ្វីខ្លះដល់ពួកបរិសុទ្ធទាក់ទងនឹងសេចក្តីជំនឿ ?
- តើអ្នកគិតថា យ៉ាកុបចង់សំដៅលើការប្រព្រឹត្តបែបណាខ្លះ ?

សូមរំឭកសិស្សថា នៅពេលពួកគេសិក្សាមេរៀនក្នុង យ៉ាកុប ២ ពួកគេបានរៀនថា សាវកយ៉ាកុបបានកែតម្រូវគំនិតខុសឆ្គងមួយអំពីសេចក្តីជំនឿ ។ មានមនុស្សមួយចំនួនបានយល់ខុសថា សេចក្តីជំនឿគឺគ្រាន់តែជាការបង្ហាញឲ្យឃើញមួយពីជំនឿតាមរយៈពាក្យសម្តី ។ នៅក្នុងបរិបទនៃយ៉ាកុប ២:១៤ យ៉ាកុបបានប្រើពាក្យ *ការប្រព្រឹត្តតាម* ខុសពីសាវកប៉ុលបានប្រើ ។ នៅពេលប៉ុលបានប្រើពាក្យ *ការប្រព្រឹត្តតាម* លោកសំដៅទៅលើការប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ម៉ូសេ ។ នៅពេលយ៉ាកុបបានប្រើពាក្យ *ការប្រព្រឹត្តតាម* លោកសំដៅទៅលើសកម្មភាពនៃការលះបង់ ឬកិច្ចការនៃ សេចក្តីសុចរិត ។

សូមពន្យល់ថា យ៉ាកុបបានប្រើរឿងប្រៀបធៀបមួយ ដើម្បីបង្ហាញចម្លើយសម្រាប់សំណួររបស់លោកនៅក្នុង ខទី ១៤ ។

សូមអញ្ជើញសិស្សពីរនាក់ឲ្យឡើងមកខាងមុខថ្នាក់។ សូមឲ្យសិស្សម្នាក់ដើរតួជាអ្នកសុំទានម្នាក់ដែលកំពុងសុំអាហារ សម្លៀកបំពាក់ និងទីជម្រកដែលគាត់ត្រូវការដើម្បីមានជីវិតរស់ ។ សូមអញ្ជើញម្នាក់ទៀតឲ្យដើរតួជាមនុស្សម្នាក់ ដែលអាចជួយដល់អ្នកសុំទាននោះបាន ។ សូមអញ្ជើញ

សិស្សទីបីឲ្យអាន យ៉ាកុប ២:១៥–១៦ ឮៗ កាលសិស្សពីរនាក់ផ្សេងទៀតដើរតួតាមសាច់រឿងដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

- តើមានអ្វីខុសឆ្គងជាមួយនឹងចម្លើយ ដែលត្រូវបានផ្តល់ឲ្យទៅសិស្សដែលជាអ្នកសុំទាននោះ ?
- តើចម្លើយរបស់សិស្សម្នាក់ទៀតល្មមគ្រប់គ្រាន់ ដើម្បីជួយដល់អ្នកសុំទានម្នាក់នោះដែរឬទេ ?

សូមឲ្យសិស្សក្នុងថ្នាក់អានឮៗ ឬសូត្រ យ៉ាកុប ២:១៧–១៨ រួមគ្នា ដោយរកមើលថាតើយ៉ាកុបបានបង្រៀនអ្វីខ្លះអំពីសេចក្តីជំនឿ ។ សូមរំឭកពួកគេថា យ៉ាកុប ២:១៧–១៨គឺជាវគ្គចំណេះចំណានបទគម្ពីរមួយ ។

- តើអ្នកគិតថាឃ្លា « សេចក្តីជំនឿបើគ្មានការប្រព្រឹត្តតាមទេ នោះក៏ស្លាប់នៅតែឯង » (ខទី១៧) មានន័យដូចម្តេច ?
- តើរឿងប្រៀបធៀបរបស់យ៉ាកុបអំពីអ្នកសុំទាននោះ ជួយយើងឲ្យយល់ពីអត្ថន័យនៃឃ្លានោះយ៉ាងដូចម្តេច ?
- យោងតាម ខទី១៧ តើយ៉ាកុបបានបង្រៀនសេចក្តីពិតអ្វីខ្លះទាក់ទងនឹងសេចក្តីជំនឿពិតលើព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **សេចក្តីជំនឿពិតលើព្រះយេស៊ូវគ្រីស្ទគឺ បង្ហាញឡើងតាមរយៈកិច្ចការសុចរិតរបស់យើង ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប២:១៩–២០ ឲ្យឮៗ ។ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់យ៉ាកុប២:១៩ ចែងថា « អ្នកជឿថា មានព្រះតែមួយ នោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ អ្នកបានធ្វើឲ្យខ្លួនដូចជាពួកវា ដោយពុំបានរាប់ថាសុចរិតឡើយ » ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ហើយរកមើលនូវឧទាហរណ៍ដែលយ៉ាកុបបានប្រើដើម្បីបង្ហាញថា ការជឿលើព្រះពុំចាំបាច់មានន័យថាមានសេចក្តីជំនឿលើព្រះឡើយ ។

- តើទាហរណ៍អ្វីខ្លះ ដែលយ៉ាកុបបានប្រើដើម្បីបង្ហាញថា ការជឿលើព្រះពុំចាំបាច់មានន័យថាមានសេចក្តីជំនឿលើព្រះឡើយ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្តារមនៃពួកសាវកដប់ពីរនាក់ ៖



« សេចក្តីជំនឿពិតគឺផ្តោតនៅក្នុង និងទៅលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយតែងតែដឹកនាំទៅរកសកម្មភាពសុចរិត ។ . . . សកម្មភាពតែម្យ៉ាងពុំមែនជាសេចក្តីជំនឿលើព្រះអង្គសង្គ្រោះទេ ប៉ុន្តែការធ្វើសកម្មភាពស្របតាមគោលការណ៍ត្រឹមត្រូវគឺជាធាតុមួយដ៏សំខាន់នៃសេចក្តីជំនឿ ។ ដូច្នេះ ‹ សេចក្តីជំនឿដែលឥតមានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ › (យ៉ាកុប២:២០) » (« Ask in Faith » *Ensign* ឬ *Liahona* ខែឧសភា ឆ្នាំ ២០០៨ ទំព័រ ៩៥) ។

- យោងតាមអែលឌើរ បែដណា តើអ្វីទៅជា « ធាតុមួយដ៏សំខាន់នៃសេចក្តីជំនឿ » ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីយល់ថា សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទមានន័យទាំងការជឿលើទ្រង់ និងការប្រព្រឹត្តតាមគោលការណ៍ត្រឹមត្រូវ ?

សូមរំឭកសិស្សអំពីយុវជននៅក្នុងសាច់រឿងនៅដើមមេរៀននេះ ។

- តើការយល់ដឹងថា សេចក្តីជំនឿដែលរួមបញ្ចូលទាំងការជឿ និងសកម្មភាពអាចជួយមនុស្សម្នាក់ឲ្យស្វែងរកការអត់ទោស សម្រាប់អំពើបាបរបស់គាត់យ៉ាងដូចម្តេច ?

សូមសង្ខេប យ៉ាកុប ២:២១–២៦ ដោយពន្យល់ថា យ៉ាកុបបានលើកឡើងពីអ័ប្រាហាំ និងរ៉ាហាប ជាឧទាហរណ៍នៃមនុស្សពីរនាក់ដែលសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទរបស់ខ្លួនបានបង្ហាញឲ្យឃើញដោយការប្រព្រឹត្តតាម ។ (ដំណើររឿងនៃស្ត្រីដ៏ក្លាហាន ឈ្មោះរ៉ាហាប មាននៅក្នុង យ៉ូស្វេ ២:១–២២) ។

សូមអញ្ជើញសិស្សឲ្យប្រើសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេសរសេរអំពីគ្រាមួយ ដែលពួកគេបានបង្ហាញសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ តាមរយៈការប្រព្រឹត្តតាមរបស់ពួកគេ និងពរជ័យនានាពួកគេទទួលបានក្នុងការធ្វើដូច្នេះ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់បញ្ចូលទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ និងរបៀបដែលពួកគេនឹងបង្ហាញជំនឿនោះតាមរយៈសកម្មភាពរបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វី ដែលពួកគេបានសរសេរជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យពិចារណាប្រកបដោយការអធិស្ឋានថា ពួកគេអាចអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទឲ្យកាន់តែពេញលេញបាន តាមរយៈការគោរពតាមទ្រង់បានដោយរបៀបណា ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើតាមការបំផុសគំនិតទាំងឡាយ ដែលពួកគេទទួលបាន ។

មេរៀនបន្ទាប់ (ពេត្រុសទី ២–យូដាស)

សូមសួរសិស្សថា ហេតុអ្វីបានជាពួកគេគិតថា មនុស្សជ្រើសយកអំពើបាប ទោះជាពួកគេដឹងថាវាខុសក្តី ។ នៅពេលសិស្សសិក្សា ពេត្រុសទី ២ រហូតដល់ យូដាស នៅអំឡុងសប្តាហ៍ក្រោយ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតនានា ដែលអាចជួយពួកគេឲ្យឆ្លើយសំណួរដូចតទៅនេះ ៖ តើយើងអាចចៀសវាងកុំឲ្យចាញ់បោកគោលលទ្ធិក្លែងក្លាយដូចម្តេច ? តើយ៉ូហានបាននិយាយថា អ្វីទៅនឹងបណ្តេញសេចក្តីភ័យខ្លាចឲ្យចេញទៅ ? តើយើងគួរបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះតាមរបៀបណា ? តើលក្ខណៈដូចជាព្រះអ្វីខ្លះ ដែលយើងត្រូវអភិវឌ្ឍដើម្បីទទួលមរតកនៃជីវិតអស់កល្បជានិច្ច ? តើមានការព្រមានអ្វីខ្លះទាក់ទងនឹងមនុស្សដែលយើងជ្រើសរើសសេពគប់ជាមួយ ?

សេចក្តីផ្តើមអំពី

សំបុត្រទីពីររបស់ពេត្រុស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងថា « ពេត្រុសបានសរសេរប្រើភាសាជ្រៅៗដ៏ប្រសើរបំផុតលើសពីព្យាការីណាៗទាំងអស់ » (នៅក្នុង *History of the Church* ៥:៣៩២) ។ *ដ៏ប្រសើរបំផុត*មានន័យថា បានលើកតម្កើងនៅក្នុងគំនិត មានតម្លៃដ៏ធំអនេក ហើយមានទំនោរដើម្បីបំផុសឲ្យមានការសរសើរ ។

ក្នុងនាមជាសាក្សីមួយរូបនៃការប្រែរូបរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ពេត្រុសទី២ ១:១៦–១៨) ពេត្រុសបានដាស់តឿនពួកអ្នកអានរបស់លោកឲ្យរីកចម្រើននៅក្នុងចំណេះដឹងអំពីព្រះគ្រីស្ទ ហើយស្វែងរកដើម្បីទទួលបានគុណលក្ខណៈនៃព្រះ ដើម្បីពួកគេអាចទទួលបាន « និស្ស័យនៃព្រះ » (សូមមើល ពេត្រុសទី២ ១:៤–៨) ។ លោកបានជានាដល់ពួកអ្នកអានរបស់លោកថា ការរីកចម្រើនខាងវិញ្ញាណនេះនឹងជួយពួកគេឲ្យ « ដំណើរដែលទ្រង់ហៅ ហើយរើសតាំង[របស់ពួកគេ] បានពិតប្រាកដឡើង » (ពេត្រុសទី២ ១:១០) ។ « ពេត្រុសបានបញ្ជាក់ជាថ្មីថា ព្រះអម្ចាស់នឹងយាងចុះមកពីស្ថានសួគ៌នៅក្នុងសិរីល្អដ៏អស្ចារ្យ ហើយកាត់សេចក្តីដល់ផែនដីនេះ » (Bible Dictionary « Peter, Epistles of ») ។ តាមរយៈការសិក្សាសំបុត្រទីពីររបស់ពេត្រុស នោះសិស្សអាចអភិវឌ្ឍសេចក្តីជំនឿកាន់តែខ្លាំងលើព្រះយេស៊ូវគ្រីស្ទ ហើយទទួលការណែនាំ និងការបំផុសគំនិត ដែលអាចជួយពួកគេឲ្យប្រែក្លាយកាន់តែដូចជាទ្រង់ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

អ្នកនិពន្ធសំបុត្រទីពីររបស់ពេត្រុសគឺជា សិម៉ូន ពេត្រុស សាវកវៀមច្បងរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ពេត្រុសទី២ ១:១) ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

យើងពុំដឹងច្បាស់លាស់អំពីពេលវេលា និងទីកន្លែងដែលសំបុត្រត្រូវបានសរសេរឡើងឡើយ ។ មានការសន្និដ្ឋានរួមមួយថា ពេត្រុសបានសរសេរសំបុត្រនេះនៅរ៉ូម បន្ទាប់ពីសំបុត្រដែលគេហៅជាពេត្រុសទី ១ នោះមក ហើយដែលវាទំនងជាសរសេរឡើងប្រមាណជា គ.ស. ៦៤ (សូមមើល Bible Dictionary « Peter, Epistles of ») ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

ប៉ុលបានថ្លែងថា លោកកំពុងសរសេរទៅ « ពួកអ្នកដែលបានទទួលសេចក្តីជំនឿដ៏វិសេស ត្រូវគ្នានឹងយើងខ្ញុំដែរ » (ពេត្រុសទី២ ១:១) ។ ការណ៍នេះអាចបង្ហាញថា ពួកអ្នកអានរបស់ពេត្រុសគឺជាពួកគ្រីស្ទានដែលជាសាសន៍យូដាតែមួយ ដែលបានទទួលសំបុត្រទីមួយរបស់ពេត្រុស (សូមមើល ពេត្រុសទី២ ៣:១) ។ មាតិកានៃ ពេត្រុសទី២ ១:១២–១៥ បង្ហាញថា ពេត្រុសមានបំណងចង់ឲ្យសំបុត្រនេះក្លាយទៅជាសារលិខិតលាគ្នាមួយ ទៅកាន់ពួកអ្នកអានរបស់លោក ។

មិនដូចជាសំបុត្រទីមួយរបស់ពេត្រុស ដែលបានជួយពួកបរិសុទ្ធឲ្យតតាំងនឹងការបៀតបៀនពីខាងក្រៅនោះឡើយ សំបុត្រទីពីររបស់ពេត្រុសបានលើកឡើងពីការក្បត់សាសនានៅខាងក្នុង ដែលបានគម្រាមកំហែងដល់អនាគតរបស់សាសនាចក្រ ។ ពួកព្យាការី និងពួកគ្រូបង្រៀនក្លែងក្លាយកំពុងពង្រីក « [ការបង្រៀនខុសឆ្គង] ដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ » (ពេត្រុសទី២ ២:១) ។ ពេត្រុសបានសរសេរសំបុត្រនេះ ដើម្បីលើកទឹកចិត្តពួកបរិសុទ្ធឲ្យរីកចម្រើននៅក្នុងចំណេះដឹងរបស់ពួកគេអំពីព្រះអម្ចាស់ និងដើម្បីធ្វើឲ្យ« ដំណើរដែលទ្រង់ហៅ ហើយរើសតាំង[របស់ពួកគេ] បានពិតប្រាកដឡើង » (ពេត្រុសទី២ ១:១០) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

« សំបុត្រទីពីរនេះទំនងជាសរសេរទៅព្រះវិហារតែមួយដូចជានៅក្នុងសំបុត្រទីមួយដែរ ([ពេត្រុសទី ២] ៣:១) ។ វាត្រូវបានសរសេរឡើងពីមុនការស្លាប់របស់ពេត្រុស ([ពេត្រុសទី២] ១:១៤) » (Bible Dictionary « Peter, Epistles of ») ។ វាក៏មាននូវពាក្យព្រមានដ៏មានប្រសិទ្ធភាពបំផុត និងទីបន្ទាល់ចុងក្រោយរបស់ពេត្រុសផងដែរ ។

បាវចនាដ៏សំខាន់មួយនៅក្នុងពេត្រុសទី ២ គឺជាសារៈសំខាន់នៃការទទួលបានចំណេះដឹងពីព្រះយេស៊ូវគ្រីស្ទ ។ ពេត្រុសបានសន្យាដល់ពួកអ្នកអានរបស់លោកថា ប្រសិនបើពួកគេខិតខំស្វែងរកចរិកលក្ខណៈរបស់ព្រះ ហើយអភិវឌ្ឍនិស្ស័យនៃព្រះ នោះពួកគេនឹង « មិននៅទំនេរ ឬឥតផលខាងឯដំណើរស្គាល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាឡើយ » (ពេត្រុសទី២ ១:៨) ហើយនឹង « ធ្វើឲ្យដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នា បានពិតប្រាកដឡើង » (ពេត្រុសទី២ ១:១០) ។

ពេត្រុសបានបង្ហាញពីភាពខុសគ្នារវាងដំណឹងល្អពិតពីព្រះយេស៊ូវគ្រីស្ទ និងចំណេះដឹងក្លែងក្លាយ ហើយនិងការបង្រៀនដែលបានផ្សព្វផ្សាយដោយពួកក្បត់សាសនា (សូមមើល ពេត្រុសទី២ ២) ។ នៅចុងបញ្ចប់នៃសំបុត្រនេះ ពេត្រុសបានផ្តល់ការអញ្ជើញជាចុងក្រោយមួយឲ្យពួកបរិសុទ្ធ « ចំរើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា » (ពេត្រុសទី២ ៣:១៨) ។

គម្រោង

ពេត្រុសទី ២ ១ ពេត្រុសពន្យល់ថា ការសន្យារបស់ព្រះយេស៊ូវគ្រីស្ទអនុញ្ញាតឲ្យពួកបរិសុទ្ធឲ្យក្លាយទៅជាអ្នក « បានចំណែកជានិស្ស័យនៃព្រះ: » (ពេត្រុសទី២ ១:៤) ។ លោកបានលើកទឹកចិត្តពួកគេឲ្យធ្វើឲ្យ « ដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នា បានពិតប្រាកដឡើង » (ពេត្រុសទី២ ១:១០) ។ ពេត្រុសនឹកចាំពីបទពិសោធន៍របស់លោកនៅលើភ្នំប្រែរូប កាលលោកបានឃើញព្រះគ្រីស្ទដ៏រុងរឿង ហើយស្តាប់ឮព្រះសូរសៀងរបស់ព្រះវរបិតា ។ ពេត្រុសពោលថា លោក « មានពាក្យទំនាយដ៏ពិតជាង » (ពេត្រុសទី២ ១:១៩) ។

ពេត្រុសទី២ ២ ពេត្រុសព្រមានសមាជិកសាសនាចក្រពីពួកព្យាការី និងពួកគ្រូបង្រៀនក្លែងក្លាយទាំងឡាយដែលនឹងមកនៅក្នុងចំណោមពួកគេ ហើយព្យាយាមនាំពួកបរិសុទ្ធឲ្យវង្វេង ។ ពួកគ្រូបង្រៀនទុច្ចរិតទាំងនេះនឹងបដិសេធព្រះអម្ចាស់ ហើយពោលពាក្យអាក្រក់ពី « ផ្លូវពិត »ពេត្រុសទី២ ២:២) ។ ពេត្រុសបង្រៀនថា វាប្រសើរជាង បើយើងមិនទទួលយកដំណឹងល្អ ជាជាងបានធ្វើសេចក្តីសញ្ញាហើយ តែមិនបានរស់នៅតាមវានោះ ។

ពេត្រុសទី ២ ៣ ពេត្រុសបញ្ជាក់ពីភាពប្រាកដប្រជាថា ព្រះគ្រីស្ទនឹងយាងមកនៅក្នុងកាលវេលារបស់ទ្រង់ ដោយសម្អាតផែនដីនេះដោយភ្លើង បំផ្លាញពួកទុច្ចរិត ហើយសង្គ្រោះដល់ជនឧស្សាហ៍ និងស្មោះត្រង់ ។ ពេត្រុសលើកទឹកចិត្តដល់ពួកបរិសុទ្ធឲ្យ « ចំរើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់. . . ព្រះយេស៊ូវគ្រីស្ទ » (ពេត្រុសទី២ ៣:១៨) ។

ពេត្រុសទី២ ១

សេចក្តីផ្តើម

ពេត្រុសបានលើកទឹកចិត្តពួកបរិសុទ្ធ ឲ្យខិតខំប្រែក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ ។ ពេត្រុសបានបញ្ជាក់ដល់ពួកគេថា ការកែចម្រើនខាងវិញ្ញាណនេះនឹងជួយដល់ « ដំណើរដែលទ្រង់ហៅ ហើយរើសតាំង[របស់ពួកគេ] បានពិតប្រាកដឡើង » (ពេត្រុសទី២ ១:១០) ។ ពេត្រុស ក៏បានថ្លែងអំពីបទពិសោធន៍របស់លោកនៅលើភ្នំប្រែរូប ហើយបានបញ្ជាក់ថា ព្រះបានបំផុសគំនិតឲ្យមានបទគម្ពីរ ។

ខិតខំជួយសិស្សឲ្យក្លាយជាអ្នកប្រែចិត្តជឿ

ប្រធាន ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយបានបង្រៀនថា « ដំណឹងល្អដ៏បរិសុទ្ធរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវតែចូលជ្រៅទៅក្នុងដួងចិត្តរបស់សិស្សទាំងឡាយដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ . . . គោលដៅរបស់យើងត្រូវតែធ្វើឲ្យពួកគេបានប្រែក្លាយជាអ្នកប្រែចិត្តជឿយ៉ាងពេញលេញចំពោះដំណឹងល្អ ដែលបានស្តារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ខណៈពេលពួកគេនៅជាមួយនឹងយើង » (« We Must Raise Our Sights » [សន្និសីទ សឹ អឹ អេស អំពីព្រះគម្ពីរមេនថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០១] ទំព័រ២) ។

យោបល់សម្រាប់ការបង្រៀន

ពេត្រុសទី២ ១:១–១១

ពេត្រុសបង្រៀនអំពីរបៀបដើម្បីបានចំណែកជានិស្ស័យនៃព្រះរបស់ព្រះយេស៊ូវគ្រីស្ទ

ពីមុនចាប់ផ្តើមថ្នាក់ សូមសរសេរឃ្លាខាងក្រោមនេះនៅលើក្តារខៀន (« The Will Within » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៧ ទំព័រ ៦៨) ៖

«ការងាររបស់យើងគឺដើម្បីក្លាយជាមនុស្សដ៏ប្រសើរបំផុត » (ប្រធាន ថូម៉ាស អេស ម៉នសុន) ។

សូមចែកសិស្សជាគូ ។ សូមអញ្ជើញពួកគេឲ្យអានឃ្លានៅលើក្តារខៀន ហើយពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូរបស់ខ្លួន ៖

- **តើអ្នកគិតថា ប្រធាន ម៉នសុន ចង់មានន័យដូចម្តេចដោយពោលឡើងថាឲ្យ « ក្លាយជាមនុស្សដ៏ប្រសើរបំផុត » ?**
- **ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីក្លាយជាមនុស្សដ៏ប្រសើរបំផុត ?**
- **តើអ្វីទៅដែលរារាំងយើងពុំឲ្យក្លាយជាមនុស្សដ៏ប្រសើរបំផុត ?**

នៅពេលសិស្សសិក្សា ពេត្រុសទី២ ១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយឲ្យពួកគេស្គាល់ អំពីរបៀបក្លាយជាមនុស្សដ៏ប្រសើរបំផុត ។

សូមសង្ខេប ពេត្រុសទី២ ១:១–២ ដោយពន្យល់ថា ពេត្រុសបានសរសេរទៅពួកសមាជិកសាសនាចក្រ ដែលបានទទួលសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ១:៣–៤ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាប៉ុលបានបង្រៀនអ្វីខ្លះ ដើម្បីជួយពួកបរិសុទ្ធឲ្យបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។

- **យោងតាមខគម្ពីរទាំងនេះ តើពេត្រុសបានបង្រៀនពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ?**
- **តើការ « បានចំណែកជានិស្ស័យនៃព្រះ » មានន័យដូចម្តេច ? (ខទី ៤) ។**

សូមអញ្ជើញសិស្សឲ្យអាន ពេត្រុសទី ២ ១:៥–៧ ដោយស្ងាត់ស្ងៀម រកមើលលក្ខណៈនៃព្រះយេស៊ូវគ្រីស្ទ ដែលពេត្រុសបានអញ្ជើញពួកបរិសុទ្ធឲ្យអភិវឌ្ឍ ។ សូមឲ្យសិស្សសរសេរលក្ខណៈដែលពួកគេរកឃើញនៅលើក្តារខៀន ។ សូមពិចារណាអញ្ជើញសិស្សឲ្យរកមើលនៅក្នុងវចនានុក្រមនូវនិយមន័យនៃលក្ខណៈទាំងនេះ ដែលពួកគេចង់យល់ឲ្យបានប្រសើរ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីគំរូ កាលដែលព្រះអង្គសង្គ្រោះបានបង្ហាញពីលក្ខណៈដ៏ទេវភាពមួយ ។ សូមឲ្យសិស្សបីបួននាក់ប្រាប់អំពីគំនិតរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

សូមសរសេរគោលការណ៍ពុំពេញលេញដូចតទៅនេះនៅលើក្តារខៀន ៖ *នៅពេលយើងអភិវឌ្ឍលក្ខណៈដ៏ទេវភាពនៅក្នុងខ្លួនយើង នោះយើងអាច . . .*

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី ២ ១:៨–៩ ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាម រកមើលពរជ័យមួយដែលយើងអាចទទួលបាន នៅពេលយើងអភិវឌ្ឍបរិតលក្ខណៈដ៏ទេវភាពរបស់ព្រះអង្គសង្គ្រោះ ។

- **តើយើងអាចទទួលបានពរជ័យអ្វីខ្លះ នៅពេលយើងអភិវឌ្ឍលក្ខណៈដ៏ទេវភាព ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមបំពេញឃ្លានៅលើក្តារខៀនដើម្បីឲ្យវាមានន័យដូចតទៅ ៖ **នៅពេលយើងអភិវឌ្ឍលក្ខណៈដ៏ទេវភាពនៅក្នុងខ្លួនយើង នោះយើងអាចស្គាល់ព្រះយេស៊ូវគ្រីស្ទ**) ។**
- **ហេតុអ្វីអ្នកគិតថា ការអភិវឌ្ឍលក្ខណៈដ៏ទេវភាពជួយយើងឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទ ?**

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ១:១០–១១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលពរជ័យមួយទៀតដែលអាចកើតមានចំពោះជនដែលឧស្សាហ៍នៅក្នុងការអភិវឌ្ឍលក្ខណៈដ៏ទេវភាព ។

- **តើពរជ័យអ្វីអាចកើតមានចំពោះជនដែលឧស្សាហ៍នៅក្នុងការអភិវឌ្ឍលក្ខណៈដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ? (សូមពន្យល់ថា ឃ្លា « ធ្វើឲ្យដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នា បានពិតប្រាកដឡើង » [ខទី ១០] មានន័យថា ដើម្បីទទួលបាននៅក្នុង**

ជីវិតនេះនូវការបញ្ជាក់របស់ព្រះថា អ្នកនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ពេត្រុសក៏ហៅវាថាជាការ « មានពាក្យទំនាយដ៏ពិតជាង » ផងដែរ (ពេត្រុសទី២ ១:១៩) ។ សូមមើលផងដែរ គ. និង ស. ១៣១:៥) ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះអំពីហេតុផលដែលយើងគួរតែព្យាយាមនៅក្នុងការអភិវឌ្ឍសក្តានុពលដ៏ទេវភាពរបស់យើង ? (សិស្សគួរស្គាល់គោលការណ៍ដូចតទៅ ៖ **ប្រសិនបើយើងឧស្សាហ៍នៅក្នុងការអភិវឌ្ឍសក្តានុពលដ៏ទេវភាពរបស់យើងនៅក្នុងជីវិតនេះ នោះយើងអាចទទួលបាននូវការបញ្ជាក់របស់ព្រះអំពីជីវិតដ៏នៅអស់កល្បជានិច្ច ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមពិចារណាចែកចាយទីបន្ទាល់របស់អ្នកថា ការអភិវឌ្ឍលក្ខណៈដ៏ទេវភាព នឹងជួយយើងឲ្យមកស្គាល់ព្រះយេស៊ូវគ្រីស្ទ ហើយរៀបចំខ្លួនយើងឲ្យទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវលក្ខណៈដ៏ទេវភាពមួយដែលពួកគេចង់អភិវឌ្ឍបំផុត ។ សូមឲ្យពួកគេសរសេរសេកម្មភាពជាក់លាក់មួយដែលពួកគេអាចធ្វើដើម្បីអភិវឌ្ឍលក្ខណៈនោះ ។

ពេត្រុសទី២ ១:១២–២១

ពេត្រុសចែកចាយសាក្សីរបស់លោកអំពីព្រះយេស៊ូវគ្រីស្ទ ហើយបង្រៀនអំពីបទគម្ពីរ

សូមពិចារណាសរសេរអាយុរបស់សាវកនាពេលបច្ចុប្បន្នមួយចំនួន ដែលមានវ័យចំណាស់ជាងគេបំផុតនៅលើក្តារខៀន ។ សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« អ្នកខ្លះពោលថា យើងចាស់ពេកហើយ ។ អូ ពិតណាស់ គឺមានសាវកប្រាំបួនរូបដែលមានវ័យចាស់ជាង ៨០ ឆ្នាំ ! ខ្ញុំមានវ័យ ៨៥ ឆ្នាំហើយ » (« Be Still, and Know That I Am God » | Church Educational System devotional ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៤ | broadcasts.lds.org) ។

- ហេតុអ្វីអ្នកគិតថា មនុស្សមួយចំនួនចង់រិះគន់អំពីវ័យរបស់ពួកព្យាការី និងពួកសាវកមួយចំនួន ?
- តើអ្នកនឹងឆ្លើយតបតាមរបៀបណា ចំពោះការរិះគន់ថា ពួកព្យាការី និងពួកសាវកសម័យទំនើបមានវ័យចំណាស់ពេកដែលពុំសូវមានប្រសិទ្ធភាព ?

នៅពេលសិស្សបន្តសិក្សា ពេត្រុសទី២ ១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយអំពីពួកព្យាការី និងពួកសាវកដែលសំខាន់ជាងវ័យរបស់ពួកលោក ។

សូមពន្យល់ថានៅក្នុង ពេត្រុសទី ២ ១:១២–១៩ ពេត្រុសបានចែកចាយសាក្សីរបស់លោកអំពីព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី ២ ១:២០–២១ ឲ្យឮៗ ហើយបន្ទាប់ពីសិស្សបានបញ្ចប់ការអានហើយ សូមចង្អុលបង្ហាញថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ពេត្រុសទី ២ ១:២០ ចែងថា « ដោយដឹងសេចក្តីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណាក្នុងគម្ពីរ ដែលថ្លែងឡើងបានតាមតែចិត្តរបស់មនុស្សនោះឡើយ » ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមអកមើលថាប៉ុលបានបង្រៀនអ្វីខ្លះ អំពីតួនាទីនៃ « មនុស្សបរិសុទ្ធរបស់ព្រះ » ដែលនៅក្នុងករណីនេះមានន័យថា ពួកព្យាការី ។

- តើពេត្រុសបានបង្រៀនអ្វីខ្លះអំពីតួនាទីរបស់ពួកព្យាការី ? (សិស្សគួរស្គាល់សេចក្តីពិតដូចតទៅ ៖ **ពួកព្យាការីទទួលបទគម្ពីរតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃបទគម្ពីរ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឲ្យឮៗ ៖

« [ព្រះគម្ពីរគឺជា] ពាក្យពេចន៍ ព្រមទាំងពាក្យសរសេរ និងពាក្យនិយាយ ដោយពួកបុរសបរិសុទ្ធនៃព្រះ កាលបានសណ្តែតដោយព្រះវិញ្ញាណបរិសុទ្ធ » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្រះគម្ពីរ » scriptures.lds.org, សូមមើលផងដែរ គ. និង ស. ៦៨:២–៤) ។ បទគម្ពីរមួយចំនួនត្រូវបានក្លាយជាកាណុង ។ កាណុងគឺ « ជាប្រជុំគម្ពីរដ៏ពិសិដ្ឋៗ ដែលត្រូវបានទទួលស្គាល់ ហើយមានសិទ្ធិអំណាច ។ នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយនោះ គម្ពីរកាណុងទាំងប៉ុន្មានហៅថា គម្ពីរបមាណីយ ហើយមានទាំងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មី ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្តីសញ្ញា ព្រមទាំងមុក្តាដ៏មានតម្លៃមហិមា (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « កាណុង » scriptures.lds.org) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកសាក្សីរបស់លោកថា ពួកព្យាការីនៅតែបន្តទទួលបទគម្ពីរនាសព្វថ្ងៃនេះ ។

« [ពួកព្យាការីគឺជា] បណ្តាញដែលព្រះបានមានបន្ទូលទៅកាន់កូនចៅរបស់ទ្រង់ តាមរយៈបទគម្ពីរកាលពីបុរាណ ។ ហើយវាគឺជាបណ្តាញដែលទ្រង់បានមានបន្ទូលនៅបច្ចុប្បន្ននេះតាមរយៈការបង្រៀន និងពាក្យទូន្មាននៃពួកព្យាការី និងពួកសាវកនៅរស់ ព្រមទាំងថ្នាក់ដឹកនាំដ៏បំផុសគំនិតផ្សេងទៀត » (« Two Lines of Communication » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៨៤) ។

- ហេតុអ្វីក៏អ្នកគិតថា វាជារឿងសំខាន់ដើម្បីដឹងថា ព្រះប្រើគន្លងនេះដើម្បីបង្កើតបទគម្ពីរសម្រាប់កូនចៅទ្រង់ ?
- តើការយល់ពីគន្លងនេះផ្តល់ការជឿជាក់យ៉ាងខ្លាំងដល់អ្នកយ៉ាងដូចម្តេចដែរ នៅក្នុងការថ្លែង និងការសរសេរអំពីព្យាការីទាំងឡាយទាំងសម័យបុរាណ និងសម័យទំនើប ?

ចូរអានសំណួរដូចខាងក្រោមនេះឲ្យឮៗ ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើវគ្គបទគម្ពីរណាដែលបានជះឥទ្ធិលមកលើជីវិតរបស់អ្នក មិនថាវាមកពីព្យាការីពីបុរាណ ឬពីព្យាការីសព្វថ្ងៃនេះទេ ? តើអ្នកធ្លាប់បានទទួលពរជ័យ តាមរយៈបទគម្ពីរទាំងនោះយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេនៅក្នុងថ្នាក់ ។ អ្នកក៏គួរចែកចាយឧទាហរណ៍មួយផងដែរថាអ្នកធ្លាប់មានពរតាមរយៈបទគម្ពីរយ៉ាងណាដែរ ។

សូមលើកឡើងអំពីប្រសាសន៍ខាងក្រោម របស់អែលឌើរ អ្នក ហើយអញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់ដល់សិស្សដទៃទៀត ដូចដែលព្រះវិញ្ញាណដឹកនាំអំពីភាពពិតនៃពួកព្យាការី និងបទគម្ពីរ ។

ពេត្រុសទី២ ២–៣

សេចក្តីផ្តើម

ពេត្រុសបានព្រមានថា ពួកព្យាការី និងពួកគ្រូបង្រៀនក្លែងក្លាយនឹងដឹកនាំប្រជាជនឲ្យវង្វេង ។ លោកបានព្យាករថា នៅថ្ងៃចុងក្រោយ មនុស្សទុច្ចរិតនឹងចំអកដល់មនុស្សសុចរិតដែលជឿថា ព្រះយេស៊ូវគ្រីស្ទនឹងយាងមកវិញ ។ ពេត្រុសបានលើកទឹកចិត្តពួកបរិសុទ្ធ ឲ្យព្យាយាមរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

យោបល់សម្រាប់ការបង្រៀន

ពេត្រុសទី២ ២

ពេត្រុសព្រមានអំពីការបោកបញ្ឆោតរបស់ពួកគ្រូបង្រៀនក្លែងក្លាយ

សូមសរសេរសំណួរដូចតទៅនេះនៅលើក្តារខៀន ៖ *ហេតុអ្វីមនុស្សជ្រើសយកអំពើបាប ទោះជាពួកគេដឹងថា រឿងដែលពួកគេកំពុងធ្វើគឺជារឿងខុសឆ្គងក្តី ?*

សូមអញ្ជើញសិស្សឲ្យពិចារណាពីសំណួរនេះ រួចហើយសូមឲ្យពួកគេពីរបីនាក់ប្រាប់ពីចម្លើយរបស់ពួកគេ ។

សូមពន្យល់ថា នៅក្នុង ពេត្រុសទី ២ ២ យើងអានថា សាវកពេត្រុសបានព្រមានពួកបរិសុទ្ធ អំពីមនុស្សដែលកំពុងស្វែងរកបោកបញ្ឆោតពួកគេ ។ នៅពេលសិស្សសិក្សា ពេត្រុសទី ២ ២ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយពួកគេឲ្យស្គាល់ ហើយចៀសវាងពីការបោកបញ្ឆោតដែលដឹកនាំទៅរកអំពើបាប ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ២:១–៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលការព្រមានរបស់ពេត្រុស អំពីជនដែលនឹងព្យាយាមបោកបញ្ឆោតពួកបរិសុទ្ធ ។

- **តើពេត្រុសបានព្រមានពួកបរិសុទ្ធអំពីនរណា ?**
- **តើពួកព្យាការី និងពួកគ្រូបង្រៀនក្លែងក្លាយទាំងនេះបង្រៀនអំពីអ្វី ? (សូមពន្យល់ថា « បក្សពួកដែលបង្ខូចបំផ្លាញ » [ខទី ១] គឺជាការបង្រៀនក្លែងក្លាយ ហើយបំផ្លិចបំផ្លាញ) ។**
- **តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះមកពីពេត្រុសថា ពួកគ្រូបង្រៀនក្លែងក្លាយខិតខំធ្វើអ្វីខ្លះដល់យើង ? (សូមជួយសិស្សឲ្យស្គាល់សេចក្តីពិតមួយស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ពួកគ្រូបង្រៀនក្លែងក្លាយស្វែងរកបោកបញ្ឆោតយើង ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយរំលេចខ្លឹម អ៊ីម រំសុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា ពួកគ្រូបង្រៀនក្លែងក្លាយបង្រៀនអ្វីខ្លះនៅសព្វថ្ងៃនេះដើម្បីបោកបញ្ឆោតយើង ។



« ពួកព្យាការីក្លែងក្លាយ និងពួកគ្រូបង្រៀនក្លែងក្លាយ គឺជាពួកអ្នកដែលប្រកាសថា ព្យាការី យ៉ូសែប ស៊្មីធ ជាអ្នកបោកប្រាស់ចម្លងសំណៅ ពួកគេមានការសង្ស័យថាការនិមិត្តដំបូងជាបទពិសោធន៍ដ៏ពិតមួយឬយ៉ាងណា ។ ពួកគេប្រកាសថា ព្រះគម្ពីរមរមន និងកិច្ចការផ្សេងៗទៀតដែលមានចែងក្នុងសាសនា ពុំមែនជាបញ្ជីព្រះគម្ពីរមកពីបុរាណនោះទេ ។ ពួកគេក៏ព្យាយាមប្រឌិតនិយមន័យធម្មជាតិនៃក្រុមព្រះផងដែរ ហើយពួកគេបដិសេធថា ព្រះបានប្រទាន និងបន្តប្រទានវិវរណៈនៅសព្វថ្ងៃនេះដល់ព្យាការីរបស់ទ្រង់ដែលត្រូវបានតែងតាំង និងគាំទ្រ ។ . . .

« ពួកព្យាការីក្លែងក្លាយ និងគ្រូបង្រៀនក្លែងក្លាយក៏ជាពួកអ្នកដែលព្យាយាមផ្លាស់ប្តូរគោលលទ្ធិដែលព្រះប្រទាន និងគោលលទ្ធិដែលផ្អែកលើព្រះគម្ពីរ ដែលការពារភាពស័ក្តិសិទ្ធិនៃអាពាហ៍ពិពាហ៍ លក្ខណៈដ៏ទេវភាពនៃក្រុមគ្រួសារ និងគោលលទ្ធិចាំបាច់សម្រាប់សីលធម៌ផ្ទាល់ខ្លួនផងដែរ ។ « ពួកគេគាំទ្រដល់ការផ្តល់និយមន័យជាថ្មីដល់សីលធម៌ ដើម្បីដំណោះសារចំពោះអំពើកាមគុណ ជិតក្បត់ និងទំនាក់ទំនងភេទដូចគ្នា » (« Beware of False Prophets and False Teachers » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៦៣, ៦៤) ។


សូមអញ្ជើញសិស្សឲ្យពិចារណាពីគ្រា ដែលពួកគេធ្លាប់ជួបប្រទះនឹងការបង្រៀន ឬសារលិខិតមកពីពួកគ្រូបង្រៀនក្លែងក្លាយ ។

- **ហេតុអ្វីក៏វាជារឿងមានប្រយោជន៍ដើម្បីដឹងពីសារលិខិត និងការបង្រៀនរបស់ពួកគ្រូបង្រៀនក្លែងក្លាយ ?**

សូមសង្ខេប ពេត្រុសទី ២ ២:៤–១៧ ដោយពន្យល់ថា ពេត្រុសបានផ្តល់ជាឧទាហរណ៍បីបួនអំពីរឿងដែលបានកើតឡើងចំពោះប្រជាជន ដែលបានដើរតាមពួកគ្រូបង្រៀនក្លែងក្លាយកាលពីបុរាណ ។ ពេត្រុសក៏បានផ្តល់ជាឧទាហរណ៍អំពីបុគ្គល ដែលពុំបានរងឥទ្ធិពលពីពួកគ្រូបង្រៀនក្លែងក្លាយផងដែរ ។ បន្ទាប់មក ពេត្រុសបានរៀបរាប់ពីឥរិយាបថទុច្ចរិតរបស់ពួកគ្រូបង្រៀនក្លែងក្លាយ ។

ឧបករណ៍សម្រាប់មេរៀន

សូមរកមើលវិធីប្រើឧបករណ៍ ដែលនឹងជួយសិស្សឲ្យយល់ពីគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ តាមរយៈឧបករណ៍សម្រាប់មេរៀនដ៏មានប្រសិទ្ធភាព អ្នកអាចជួយសិស្សឲ្យមើលឃើញ វិភាគ និងយល់ពីបទគម្ពីរទាំងឡាយ ។ អ្នកក៏អាចប្រើឧបករណ៍សម្រាប់មេរៀនផ្សេងៗ ដើម្បីជម្រុញការពិភាក្សាផងដែរ ។



សូមដាក់បង្ហាញដងសន្ធូចមួយ និងនុយខ្លះៗ ឬដាក់បង្ហាញ ឬគូររូបភាពមួយអំពីវត្ថុទាំងនេះនៅលើក្តារខៀន ។ (ប្រសិនបើវិធីចាប់ត្រីមួយទៀតងាយនឹងធ្វើឲ្យសិស្សរបស់អ្នកយល់ជាង សូមប្រើវត្ថុ ឬរូបភាពដែលបង្ហាញពីវិធីនោះ) ។

សូមពន្យល់ថា វិធីមួយដែលអ្នកស្ទូចត្រីចាប់ត្រីបានគឺ ដោយការប្រើនុយដើម្បីទាក់ទាញត្រីឲ្យចូលទៅក្នុងអន្ទាក់ ឬខាំផ្លែសន្ធូច) ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា វិធីសាស្ត្ររបស់អ្នកស្ទូចត្រីម្នាក់ គឺដូចគ្នាទៅនឹងជនដែលជាគ្រូបង្រៀនក្លែងក្លាយយ៉ាងដូចម្តេច ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ២:១៨–១៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ពួកគ្រូបង្រៀនក្លែងក្លាយអួសទាញពួកបរិសុទ្ធឲ្យធ្វើតាមការបង្រៀនរបស់ពួកគេយ៉ាងដូចម្តេច ។

- តើពួកគ្រូបង្រៀនក្លែងក្លាយអួសទាញ ហើយបោកបញ្ឆោតសមាជិកសាសនាចក្រយ៉ាងដូចម្តេច ? (សូមចង្អុលបង្ហាញថា ពួកគ្រូបង្រៀនក្លែងក្លាយមួយចំនួនអាចមានចិត្តស្មោះត្រង់ ប៉ុន្តែបានបោកបញ្ឆោតខ្លួនឯង) ។
- តើការបង្រៀនទាំងឡាយរបស់ពួកព្យាការី និងពួកគ្រូបង្រៀនក្លែងក្លាយ ដូចគ្នានឹងនុយចាប់ត្រីយ៉ាងដូចម្តេច ?
- យោងតាម ខទី ១៩ តើពួកគ្រូបង្រៀនក្លែងក្លាយទាំងនេះ:សន្យាអ្វីខ្លះ ? (« ឥស្សរភាព » ។ និយាយម្យ៉ាងទៀត គឺពួកគេបង្រៀនថា អំពើបាបដឹកនាំទៅរកសេរីភាពធំជាងការគោរពប្រតិបត្តិតាមបទបញ្ញត្តិ) ។

សូមដាក់បន្ថែមទៅលើសេចក្តីពិតនៅលើក្តារខៀន ដើម្បីឲ្យមានន័យដូចតទៅនេះ ៖ **ពួកគ្រូបង្រៀនក្លែងក្លាយស្វែងរកបោកបញ្ឆោតយើងឲ្យជឿថា អំពើបាបដឹកនាំទៅរកឥស្សរភាពដ៏កាន់តែអស្ចារ្យ ។**

សូមអញ្ជើញសិស្សឲ្យអាន ខទី ១៩ ម្តងទៀតដោយស្ងៀមស្ងាត់ រកមើលថាមានរឿងអ្វីបានកើតឡើងចំពោះប្រជាជន ដែលធ្លាក់ខ្លួនក្រោមឥទ្ធិពលនៃការបង្រៀនក្លែងក្លាយ និងអំពើបាប ។

- តើមានរឿងអ្វីបានកើតឡើងចំពោះប្រជាជនដែលធ្លាក់ខ្លួនក្រោមឥទ្ធិពលនៃការបង្រៀនក្លែងក្លាយ និងអំពើបាប ? (ពួកគេក្លាយជាទាសករចំពោះរឿងទាំងនោះ) ។
- តើការបង្រៀនក្លែងក្លាយមួយចំនួនដែលទំនងជាលើកកម្ពស់ដល់សេរីភាព ប៉ុន្តែតាមពិតទៅវាដឹកនាំទៅរកសេរភាពវិញនោះមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ២:២០–២២ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា ពេត្រុសបានបង្រៀនអ្វីខ្លះ អំពីជនដែលត្រឡប់ទៅរកអំពើបាប បន្ទាប់ពីបានរួចផុតពីវាម្តងហើយ ។

- ហេតុអ្វីអ្នកគិតថា ជនដែល « បានរួចពីសេចក្តីស្មោកគ្រោករបស់លោកីយ៍នេះ ដោយបានស្គាល់ព្រះ . . . យេស៊ូវគ្រីស្ទ » (ខទី ២០) អាចនឹងត្រូវបានល្បួងឲ្យត្រឡប់ទៅផ្លូវនៃអំពើបាបរបស់ពួកគេវិញ ?
- តើអ្នកនឹងផ្តល់៣ក្យទូន្មានអ្វីខ្លះ ដើម្បីជួយមនុស្សម្នាក់ឲ្យបន្តស្មោះត្រង់នឹងព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ជាជាងត្រឡប់ទៅរកអំពើបាបពីមុនវិញ ?

ពេត្រុសទី២ ៣

ពេត្រុសថ្លែងទីបន្ទាល់អំពីការយាងមកជាលើកទីពីរ

សូមពន្យល់ថា នៅពេលពេត្រុសបានបញ្ចប់សំបុត្ររបស់លោក លោកបានរំឭកពួកបរិសុទ្ធអំពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ហើយបានបង្រៀនពួកគេថាត្រូវត្រៀមខ្លួនសម្រាប់ព្រឹត្តិការណ៍នោះយ៉ាងដូចម្តេច ។ សូមសង្ខេប ពេត្រុសទី២ ៣:១–៩ ដោយពន្យល់ថា ពេត្រុសបានបង្រៀនថា នៅថ្ងៃចុងក្រោយ មនុស្សមួយចំនួននឹងសើចចំអកដាក់ជនដែលជឿលើការយាងមកជាលើកទីពីរ ។

សូមឲ្យសិស្សពីរបីនាក់ពន្យល់ថា ហេតុអ្វីបានជាពួកគេជឿលើការយាងមកជាលើកទីពីរ ទោះជាមានមនុស្សជាច្រើនពុំបានជឿពីរឿងនេះក្តី ?

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ៣:១០–១៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ពេត្រុសបានបង្រៀនអ្វីខ្លះអំពីការយាងមកជាលើកទីពីរ ។ សូមពន្យល់ថា *កិរិយា* នៅក្នុង ខទី ១១ មានន័យថា ការប្រព្រឹត្ត ហើយ « ការទន្ទឹងចាំ » នៅក្នុង ខទី ១២ មានន័យថា ការរង់ចាំអ្វីមួយយ៉ាងអន្ទះសា ។

- យោងតាម ខទី១០តើពេត្រុសបានបង្រៀនអ្វីខ្លះ អំពីការយាងមកជាលើកទីពីរ ?
- យោងតាម ខទី ១១–១៤ តើពេត្រុសបានទូន្មានអ្វីខ្លះ ដល់ពួកបរិសុទ្ធដើម្បីរៀបចំខ្លួនពួកគេសម្រាប់ការយាងមកជាលើកទីពីរ ? (ខំប្រឹងរស់នៅក្នុងជីវិតបរិសុទ្ធ និងរង់ចាំដោយអន្ទះសាដល់ការយាងមកជាលើកទីពីរ ហើយខិតខំដោយឧស្សាហ៍ដើម្បីបានរកឃើញជា « ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន » [ខទី ១៤]) ។

សូមពន្យល់ថាឃ្លា « ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន » (ខទី ១៤) មានន័យថា ការជ្រះស្អាតពីអំពើបាប ។ ជនដែលជ្រះស្អាតពីអំពើបាបត្រូវបានផ្សះផ្សានឹងព្រះ ហើយនឹងរកឃើញនូវសេចក្តីសុខសាន្តជាមួយនឹងព្រះអង្គសង្គ្រោះ កាលទ្រង់នឹងយាងមក ។

- តើអ្នកនឹងសង្ខេបគោលការណ៍ដែលពេត្រុសបានបង្រៀន អំពីរបៀបដែលយើងអាចរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះយ៉ាងដូចម្តេច ? (សូមជួយសិស្សឲ្យស្គាល់គោលការណ៍ស្រដៀងគ្នាមួយនឹងគោលការណ៍ដូចតទៅនេះ ៖ **យើងអាចរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ដោយការរស់នៅក្នុងជីវិតដែលគោរពដល់ព្រះ ហើយរង់ចាំនូវការយាងមករបស់ទ្រង់ដោយអន្ទះសា** ។ សូមពន្យល់ថា « ការចាំមើល » អាចមានន័យថា យើងកំពុងរង់ចាំ ដោយអន្ទះសាដល់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ) ។

- តើរឿងមួយចំនួនដែលយើងអាចធ្វើដើម្បីរស់នៅក្នុងជីវិតដែលគោរពដល់ព្រះ នៅពេលយើងរង់ចាំដោយអន្ទះសាដល់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះមានអ្វីខ្លះ ?

សូមសង្ខេប ពេត្រុសទី ២ ៣:១៥–១៨ ដោយពន្យល់ថា ពេត្រុសបានព្រមានអំពីការធ្លាក់ចូលទៅក្នុងអំពើទុច្ចរិត ។ លោកបានអញ្ជើញពួកបរិសុទ្ធឲ្យ « ចំរើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ [ព្រះអម្ចាស់] » (ខទី ១៨) ។

សូមបញ្ចប់មេរៀនដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងពេត្រុសទី២ ២–៣ ។ សូមអញ្ជើញសិស្សឲ្យខិតខំដើម្បីស្គាល់ ហើយចៀសវាងពីការបង្រៀនក្លែងក្លាយ ហើយព្យាយាមរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីរ ។

សេចក្តីផ្តើមអំពី

សំបុត្រទូទៅទីមួយរបស់យ៉ូហាន

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងសំបុត្រនេះ យ៉ូហានបានលើកឡើងអំពីការរាលដាលដ៏គ្រោះថ្នាក់នៃការក្បត់សាសនា ដែលកំពុងរីកសាយភាយក្នុងសាសនាចក្រ ។ លោកបានព្រមានពួកបរិសុទ្ធកុំឲ្យចុះសម្រុងនឹងសេចក្តីងងឹត ហើយបន្តនៅក្នុងទីសុវត្ថិភាពនៃពន្លឺនៃដំណឹងល្អ ។ ការសិក្សាយ៉ូហានទី ១ អាចជួយសិស្សឲ្យយល់ដឹងកាន់តែច្បាស់ពីការបង្រៀនភ្លែងភ្លាយនានាអំពីព្រះយេស៊ូវគ្រីស្ទ និងការធ្វើតាមការទូន្មានរបស់យ៉ូហានអាចជួយពួកគេ ឲ្យរក្សាភាពជិតស្និទ្ធនឹងព្រះអម្ចាស់ កាលពួកគេកាន់ខ្ជាប់នៅក្នុងសេចក្តីពិតនោះ ។ លើសពីនេះទៀត ការសិក្សាគម្ពីរនេះអាចជួយសិស្សឲ្យយល់ដឹងអំពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យ ដែលព្រះវរបិតាសួគ៌មានចំពោះកូនចៅរបស់ទ្រង់ម្នាក់ៗ ដែលទ្រង់បានបង្ហាញដោយប្រទានព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជាពលិកម្មមួយសម្រាប់មនុស្សលោកគ្រប់រូប ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

« នៅក្នុងសំបុត្រទាំងបីនេះ អ្នកសរសេរពុំបានដាក់ឈ្មោះខ្លួនឡើយ ប៉ុន្តែតាមប្រពៃណី វាត្រូវបានគេចាត់ទុកថាជារបស់យ៉ូហាន » ជាសាវកដើមមួយរូបក្នុងចំណោមសាវកទាំងពីរ (Bible Dictionary « John, Epistles of ») ។

អ្នកសរសេរសំបុត្រយ៉ូហាន គឺជាសាក្សីមួយរូបអំពីព្រះអង្គសង្គ្រោះដែលមានព្រះជន្មឡើងវិញ ដែលពិតជាសាវកយ៉ូហាន (សូមមើល យ៉ូហានទី១ ១:១–៤, ៤:១៤) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

គ្មាននរណាម្នាក់ដឹងពិតប្រាកដពីពេលវេលា និងទីកន្លែងដែលយ៉ូហានទី១ ត្រូវសរសេរឡើងនោះទេ ។ វាទំនងជាត្រូវបានសរសេរឡើងប្រមាណជាចុងសតវត្សរ៍ទីមួយនៃ គ.ស. ។

ទោះបីជាយ៉ូហានបានចំណាយពេលយ៉ាងច្រើននៅក្នុងជីវិតរបស់លោក កាលពីក្មេងនៅស្រុកប៉ាឡេស្ទីនក្តី ក៏តំបន់នេះជាសត្រូវនឹងពួកគ្រីស្ទាន និងពួកសាសន៍យូដាដែរ ដែលបន្សល់នូវការបំផ្លិចបំផ្លាញក្រុងយេរូសាឡិម និងព្រះវិហារបរិសុទ្ធនៅទីនោះក្នុង គ.ស. ៧០ ។ តាមប្រពៃណីចែងថា យ៉ូហានបានចាកចេញពីស្រុកប៉ាឡេស្ទីនទៅរស់នៅក្រុងអេភេសូរ កាលលោកមានវ័យចំណាស់ ។ ប្រសិនបើដូច្នេះមែន យ៉ូហានអាចសរសេរសំបុត្រនេះនៅក្រុងអេភេសូរចន្លោះ គ.ស. ៧០ និង ១០០ ។

តើគម្ពីរនេះត្រូវបានសរសេរឡើងទៅកាន់នរណា ហើយតើហេតុអ្វីដែរ ?

ពួកអ្នកអានរបស់យ៉ូហានទី១ ពុំបានអធិប្បាយឲ្យច្បាស់លាស់នោះទេ ប៉ុន្តែវាទំនងដូចជាយ៉ូហានសរសេរទៅពួកអ្នកជឿ (សូមមើល យ៉ូហានទី១ ១:៣–៤, ២:១២–១៤) ប្រហែលជាប្រជាជននៅក្នុងអាស៊ីតូច (ប្រទេសតួគីបច្ចុប្បន្ន) ជាកន្លែងដែលប្រភពនៃប្រវត្តិសាស្ត្រមួយចំនួនពោលថា យ៉ូហានធ្លាប់បានរស់នៅ ហើយធ្វើការងារបម្រើនៅក្នុងចុងសតវត្សរ៍ទីមួយ គ.ស. ។

នៅពេលនេះ ពួកគ្រូបង្រៀនភ្លែងភ្លាយបានបង្កើតកលល្បិច ឬការបែងចែកមួយនៅក្នុងចំណោមពួកបរិសុទ្ធក្នុងភូមិភាគនោះ (សូមមើល យ៉ូហានទី១ ២:១៨–១៩, ២២, ២៦, ៤:១) ហើយការក្បត់សាសនាកំពុងរីកសាយភាយក្នុងសាសនាចក្រ ។ ទស្សនវិជ្ជាដ៏ជាក់លាក់មួយ ដែលកំពុងទទួលបានប្រជាប្រិយភាពគឺការបង្រៀនដូសិត ។ ការបង្រៀនដូសិតគឺជាផ្នែកមួយនៃចលនាមួយដ៏ធំដែលត្រូវគេស្គាល់ថា សាសនាង៉ូស្ទីក ។ ការបង្រៀនដ៏សំខាន់មួយនៅក្នុងទម្រង់ជាច្រើននៃសាសនាង៉ូស្ទីកគឺថា វិញ្ញាណគឺល្អទាំងស្រុង ហើយរូបធាតុនោះរួមបញ្ចូលថា រូបកាយខាងសាច់ឈាម គឺអាក្រក់ទាំងស្រុង ។

ពួកអ្នកដើរតាមសាសនាង៉ូស្ទីកបានជឿថា សេចក្តីសង្គ្រោះពុំអាចសម្រេចបានដោយការរួចផុតពីអំពើបាបឡើយ ប៉ុន្តែផ្ទុយទៅវិញគឺតាមរយៈការធ្វើឲ្យវិញ្ញាណរួចផុតពីរូបធាតុ មានន័យថារូបកាយ ។ ពួកគេក៏ជឿផងដែរថា សេចក្តីសង្គ្រោះត្រូវបានសម្រេចបានតាមរយៈចំណេះដឹងពិសេស *(ជ្ញ៉ូស៊ីស)* ជាជាងតាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។

ពួកអ្នកដើរតាមសាសនាដូសិតបានគូសបញ្ជាក់ហួសពីនិស្ស័យខាងវិញ្ញាណរបស់ព្រះយេស៊ូវ ទៅដល់ចំណុចដែលថា ពួកគេបានបដិសេធគំនិតថា ទ្រង់មិនបានយាងមកផែនដីនៅក្នុងរូបកាយជាសាច់ និងឈាមនោះទេ ។ ពួកគេបានជឿថា ព្រះគឺគ្មានរូបរាង អមត: ត្រាស់ដឹងសព្វសារពើ ហើយជាវិញ្ញាណ ហើយពួកគេបានចាត់ទុកថាពិភពលោកនេះ និងរូបកាយមានភាពពុករលួយ ហើយអាក្រក់ ។ ហេតុដូច្នេះហើយ ពួកគេបានជឿថា ដោយសារព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ព្រះ នោះទ្រង់ពុំអាចមានបទពិសោធន៍របស់មនុស្សលោកដែលកំណត់នោះបានទេ ។ នៅក្នុងទស្សនៈរបស់ពួកគេ ព្រះយេស៊ូវគ្រីស្ទពុំបានប្រសូតមកនៅក្នុងសាច់ឈាមនោះទេ ហើយទ្រង់ក៏គ្មានរូបកាយ ដែលហូរឈាម រងទុក្ខ សុគត ឬរស់ឡើងវិញបានដែរ—ទ្រង់ទំនងជាអង្គដែលបង្កើតអ្វីៗទាំងនេះប៉ុណ្ណោះ ។ *សាសនាដូសិត* កើតចេញពីភាសាក្រិកថា *ដូកេអូ* មានន័យថា « ទំនង » ឬ « ប្រហាក់ប្រហែល » ។

ទោះបីជាយ៉ូហានទី១ ឆ្លើយបដិសេធពីការបង្រៀនខុសឆ្គងទាំងនេះក៏ដោយ ក៏វាពុំបានលះបង់ ហើយវាបានលបជ្រៀតចូលទៅក្នុងសមាជិកភាពរបស់សាសនាចក្រ ។ គោលលទ្ធិខុសឆ្គងទាំងនេះ និងគោលលទ្ធិផ្សេងទៀតគឺជាផ្នែកនៃអ្វី ដែលបានដឹកនាំទៅរកការក្បត់សាសនាដ៏ធំ ។

តើមានលក្ខណៈពិសេសអ្វីខ្លះ នៅក្នុងគម្ពីរនេះ ?

ក្នុងនាមជាសាវកមួយរូបរបស់ព្រះយេស៊ូវគ្រីស្ទ យ៉ូហានគឺជាសាក្សីពិសេសមួយរូបអំពីព្រះអង្គសង្គ្រោះ ដែលមានព្រះជន្មឡើងវិញ ។ យ៉ូហានបានចាប់ផ្តើមប្រកាសថា លោកបានឃើញ បានស្តាប់ ហើយបាន៣ល់ព្រះយេស៊ូវគ្រីស្ទដោយផ្ទាល់ ។ តាមរយៈការលើកឡើងបន្ថែមទៀតស្តីពីសាក្សីផ្ទាល់ខ្លួននេះ យ៉ូហានបានអញ្ជើញពួកអ្នកស្តាប់របស់លោកឲ្យមាន « សេចក្តីប្រកប . . . នឹងព្រះវរបិតា ហើយនឹងព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាទ្រង់ » (យ៉ូហានទី១ ១:៣) ។ សេចក្តីស្រឡាញ់គឺជាប្រធានបទដ៏សំខាន់មួយ នៅក្នុងសំបុត្រទីមួយរបស់យ៉ូហាន ។ យ៉ូហានបានគូសបញ្ជាក់ថា ជនដែលនិយាយថាស្រឡាញ់ព្រះ ប៉ុន្តែពុំបានស្រឡាញ់មនុស្សនៅជុំវិញខ្លួនគឺជាមនុស្សកុហក (សូមមើល យ៉ូហានទី១ ៤:២០–២១) ។

គម្រោង

យ៉ូហានទី ១ ១–៣ យ៉ូហានបង្រៀនថា តាមរយៈការគោរពប្រតិបត្តិ នោះយើងអាចស្គាល់ព្រះ មានសេចក្តីប្រកបនឹងទ្រង់ ហើយប្រែក្លាយដូចជាទ្រង់ ។ នៅថ្ងៃចុងក្រោយ ពួកអ្នកទាស់នឹងព្រះគ្រីស្ទនឹងកើនឡើង ។ សេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះយើងត្រូវបានបង្ហាញ តាមរយៈពលិកម្មធួនរបស់ទ្រង់ ។

យ៉ូហានទី១ ៤–៥ យ៉ូហានលើកទឹកចិត្តពួកបរិសុទ្ធឲ្យកំណត់ថា តើគ្រូបង្រៀនម្នាក់គឺមកព្រះឬទេ ។ ព្រះគឺជាសេចក្តីស្រឡាញ់ ហើយដោយសារតែសេចក្តីស្រឡាញ់ដ៏ធំរបស់ទ្រង់ចំពោះយើង នោះទ្រង់បានបញ្ជូនព្រះរាជបុត្រាទ្រង់ឲ្យមករងទុក្ខជំនួសយើង ។ ជនដែលស្រឡាញ់ព្រះនឹងគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ ជនដែលជឿលើព្រះយេស៊ូវគ្រីស្ទ ហើយកើតមកពីព្រះនឹងយកឈ្នះលើលោកិយនេះ ។

មេរៀន ១៤៨

យ៉ូហានទី ១

សេចក្តីផ្តើម

យ៉ូហានបានអញ្ជើញសមាជិកសាសនាចក្រឲ្យស្វែងរកភាពស្និទ្ធស្នាលជាមួយព្រះវរបិតា និងព្រះរាជបុត្រា ។ លោកបានគូសបញ្ជាក់អំពីសេចក្តីត្រូវការ ដើម្បីគោរពតាមបទបញ្ញត្តិរបស់ព្រះដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះទ្រង់ ។ យ៉ូហានក៏បានរំឭកសមាជិកសាសនាចក្រឲ្យស្រឡាញ់មនុស្សដទៃផងដែរ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហានទី១ ១–៥

យ៉ូហានពន្យល់អំពីសារៈសំខាន់នៃការគោរពតាមបទបញ្ញត្តិ និងការចេះស្រឡាញ់គ្នាទៅវិញទៅមក

សូមចែកសិស្សមួយគូៗ ។ សូមសរសេរពាក្យ *ការក្បត់សាសនា* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យបែរទៅរកដៃគូខ្លួន ហើយពន្យល់ដោយសង្ខេបអំពីអត្ថន័យនៃ *ការក្បត់សាសនា* ។ បន្ទាប់មក សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀនសរសេរនិយមន័យនៃពាក្យ *ការក្បត់សាសនា* ។ និយមន័យនោះគួរតែបង្ហាញថា *ការក្បត់សាសនា*មានន័យថា ការងាកចេញឆ្ងាយពីសេចក្តីពិត (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ការក្បត់សាសនា » scriptures.lds.org) ។

សូមពន្យល់ថា សាវកយ៉ូហានបានសរសេរសំបុត្រនៃយ៉ូហានទី១ នៅគ្រាមួយដែលការក្បត់សាសនាកំពុងតែគំរាមកំហែងដល់សាសនាចក្រ ។ នៅក្នុងសំបុត្រនេះ យ៉ូហានបានព្រមានពួកបរិសុទ្ធដែលទទឹងនឹងព្រះគ្រីស្ទ (សូមមើល យ៉ូហានទី១ ២:១៨–២៦, ៤:៣) ។ អ្នកទទឹងនឹងព្រះគ្រីស្ទគឺជា « អ្នកណា ឬក៏អ្វីមួយដែលក្លែងបន្លំផែនការនៃសេចក្តីសង្គ្រោះនៃដំណឹងល្អដ៏ពិត ហើយដែលប្រឆាំងនឹងព្រះគ្រីស្ទដោយបើកចំហ ឬដោយសម្ងាត់ » និងសិទ្ធិអំណាច និងការបង្រៀនរបស់ពួកអ្នកបម្រើដែលទ្រង់បានជ្រើសរើស (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « អ្នកទទឹងនឹងព្រះគ្រីស្ទ » scriptures.lds.org) ។ ពួកអ្នកទទឹងនឹងព្រះគ្រីស្ទមួយចំនួននៅក្នុងជំនាន់របស់យ៉ូហានកំពុងបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគ្មានរូបកាយសាច់ឈាមកាលគង់នៅលើផែនដី ប៉ុន្តែមើលទៅទំនងដូចជាមនុស្សធម្មតាម្នាក់ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី១ ១:១–៤ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា យ៉ូហានបានថ្លែងទីបន្ទាល់អំពីអ្វីខ្លះ ដើម្បីឆ្លើយបដិសេធការបង្រៀនខុសឆ្គងនេះ ។ សូមពន្យល់ថាឃ្លា « បន្ទូលនៃជីវិត » (ខទី១) សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ។

- តើប៉ុលបានប្រើពាក្យសម្តីអ្វីខ្លះ ដើម្បីឆ្លើយបដិសេធគំនិតខុសឆ្គងថា ព្រះយេស៊ូវគ្រីស្ទគ្មានព្រះកាយជាសាច់ឈាមទេ ?
- យោងតាម ខទី៣–៤ហេតុអ្វីយ៉ូហានបានចែកចាយសាក្សីពិសិដ្ឋរបស់លោកអំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងសមាជិកសាសនាចក្រ ? (លោកចង់ឲ្យពួកគេមានភាពស្និទ្ធស្នាលនឹងថ្នាក់ដឹកនាំរបស់សាសនាចក្រ ដែលមានភាពស្និទ្ធស្នាលនឹងព្រះវរបិតាសួគ៌ ព្រមទាំងព្រះយេស៊ូវគ្រីស្ទផងដែរ ។ លោកក៏មានបំណងប្រាថ្នាឲ្យពួកគេដកពិសោធន៍នូវអំណរដ៏ពេញលេញមួយផងដែរ) ។

សូមពន្យល់ថា ការមានភាពស្និទ្ធស្នាលមានន័យថា ការរីករាយនឹងទំនាក់ទនងនៃការទុកចិត្ត ការរួបរួមគ្នា និងគោលបំណងរួម ។ យើងអាចមានភាពស្និទ្ធស្នាលនឹងថ្នាក់ដឹកនាំសាសនាចក្រ នៅពេលយើងទទួលយក ហើយធ្វើតាមការបង្រៀន និងពាក្យទូន្មានរបស់ពួកលោក ។

សូមសរសេរឃ្លាពុំពេញលេញដូចតទៅនេះនៅលើក្តារខៀន ៖ *ប្រសិនបើយើងទទួលយក ហើយធ្វើតាមការបង្រៀនរបស់ពួកព្យាការី និងពួកសាវក នោះយើងអាច* . . .

- ដោយផ្អែកលើការបង្រៀនរបស់យ៉ូហាននៅក្នុង យ៉ូហាន១:៣ តើអ្នកនឹងបំពេញឃ្លានេះដើម្បីបង្កើតជាគោលការណ៍មួយបានយ៉ាងដូចម្តេច ? (ដោយប្រើពាក្យសម្តីរបស់សិស្ស សូមបំពេញឃ្លានៅលើក្តារខៀន ដើម្បីបង្វែរវាឲ្យក្លាយទៅជាគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងទទួលយក ហើយធ្វើតាមការបង្រៀនរបស់ពួកព្យាការី និងពួកសាវក នោះយើងអាចទទួលបានភាពស្និទ្ធស្នាលជាមួយព្រះវរបិតាសួគ៌ និងព្រះរាជបុត្រា**) ។

សូមដាក់បង្ហាញ រូបភាពអំពីប្រធានសាសនាចក្របច្ចុប្បន្ន និងពួកព្យាការី ព្រមទាំងពួកសាវកដទៃទៀត ។

- តើការធ្វើតាមការបង្រៀនរបស់ពួកព្យាការី និងពួកសាវកជួយយើងឲ្យទទួលបានភាពស្និទ្ធស្នាលជាមួយព្រះវរបិតាសួគ៌យើង និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី១ ១:៥–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាអ្វីទៅដែលរារាំងយើងពុំឲ្យមានភាពស្និទ្ធស្នាលជាមួយព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ។

- តើអ្វីទៅដែលរារាំងយើងពុំឲ្យមានភាពស្និទ្ធស្នាលនឹងព្រះវរបិតាយើងដែលគង់នៅស្ថានសួគ៌ ?

សូមចង្អុលបង្ហាញថា កាលយ៉ូហានប្រើពាក្យ *សេចក្តីងងឹត* គឺលោកចង់សំដៅទៅលើសេចក្តីងងឹតខាងវិញ្ញាណ ។

- តើអ្នកគិតថា ការដើរនៅក្នុងសេចក្តីងងឹតខាងវិញ្ញាណមានន័យដូចម្តេច ?

បង្រៀនដូចជាព្រះអង្គសង្គ្រោះបានបង្រៀន

ប្រធាន ចិយដ៍ ឃេ ផាកគី ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់បានអញ្ជើញគ្រូបង្រៀនដំណឹងល្អឲ្យខិតខំបង្រៀនឲ្យដូចជាព្រះអង្គសង្គ្រោះបានបង្រៀន ៖ « នៅពេលយើងចាប់ផ្តើមវិភាគខ្លួនឯង ហើយពិនិត្យមើលដើម្បីកែលម្អខ្លួនឯងក្នុងនាមជាគ្រូបង្រៀន តើគំរូដ៏ល្អប្រសើរបែបណាទៅដែលយើងអាចរកឃើញ ? តើការសិក្សាអ្វីដែលយើងអាចរៀនបានប្រសើរជាងការវិភាគលើគំនិត និង គោលដៅ និង វិធីសាស្ត្រទាំងឡាយរបស់យើង ហើយប្រៀបធៀបអ្វីៗទាំងនោះជាមួយនឹងរបៀបរបស់ព្រះយេស៊ូវគ្រីស្ទ ? » (*Teach Ye Diligently* បោះពុម្ពកំណែថ្មី [ឆ្នាំ ១៩៩១] ទំព័រ ២២) ។

សូមអញ្ជើញសិស្សឲ្យសិក្សា យ៉ូហានទី១ ១:៧–១០; ២:១–៦ ហើយរកមើលសេចក្តីពិត ដែលយ៉ូហានបានបង្រៀន ដែលវាអាចជួយយើងឲ្យស្គាល់អំពីរបៀបដើរនៅក្នុងពន្លឺនៃដំណឹងល្អ ។ សូមពន្យល់ថាពាក្យ *ដង្ហាយធូន* ក្នុង យ៉ូហានទី១ ២:២ មានន័យថា ពលិកម្មធួនដែលបំពេញសេចក្តីយុត្តិធម៌របស់ព្រះ ។ សូមអញ្ជើញសិស្សឲ្យសិក្សាខគម្ពីរទាំងនេះដោយស្ងៀមស្ងាត់តែម្នាក់ឯង ឬជាមួយនឹងដៃគូ ឬជាក្រុមតូចៗ ។

- តើអ្នកបានរកឃើញសេចក្តីពិតអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ? (សូមពិចារណាសរសេរចម្លើយរបស់សិស្សលើក្តារខៀន ។ សេចក្តីពិតទាំងនេះរួមបញ្ចូលនូវសេចក្តីពិតដូចតទៅ ៖ **ព្រះយេស៊ូវគ្រីស្ទបានធួននឹងអំពើបាបរបស់យើងរាល់គ្នា ។ នៅពេលយើងគោរពតាមបទបញ្ញត្តិរបស់ព្រះ សេចក្តីស្រឡាញ់របស់យើងចំពោះព្រះគឺត្រូវបានល្អឥតខ្ចោះ**) ។
- ហេតុអ្វីអ្នកគិតថា សេចក្តីស្រឡាញ់របស់យើងចំពោះព្រះកាន់តែល្អឥតខ្ចោះ ឬពេញលេញ នៅពេលយើងគោរពតាមបទបញ្ញត្តិទ្រង់ ?
- តើអ្នកធ្លាប់ដកពិសោធន៍នូវសេចក្តីស្រឡាញ់ដ៏ជំធេងមួយចំពោះព្រះ នៅពេលអ្នកបានខិតខំគោរពតាមបទបញ្ញត្តិរបស់ទ្រង់នៅពេលណាដែរ ?

សូមអានឮៗនូវការពិពណ៌នាខាងក្រោមនេះអំពីយុវវ័យពីរនាក់នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ សូមអញ្ជើញសិស្សឲ្យស្តាប់រកបទបញ្ញត្តិជាក់លាក់មួយ ដែលយុវវ័យទាំងពីរនេះមានការលំបាកក្នុងការគោរពតាម ។

១. យុវជនម្នាក់អានព្រះគម្ពីររៀងរាល់ថ្ងៃ ហើយអនុវត្តដោយស្មោះត្រង់នូវភាតពូកិច្ចបព្វជិតភាពជាច្រើនរបស់គាត់ ប៉ុន្តែជារឿយៗគាត់គ្មានចិត្តល្អដាក់ប្អូនប្រុសរបស់គាត់ ។

២. យុវនារីម្នាក់ចូលរួមការប្រជុំព្រះវិហារជាទៀងទាត់ ហើយបានទទួលការទទួលស្គាល់នូវភាពជាយុវនារីរបស់នាង ។ ប៉ុន្តែ ជារឿយៗនាងបានសរសេរពាក្យសម្តីមិនល្អអំពីមិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់នាងមួយចំនួននៅលើប្រព័ន្ធបណ្តាញសង្គម ។

- តើបទបញ្ញត្តិអ្វីទៅដែលយុវវ័យពីរូបនេះពិបាកគោរពតាម ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីស្ថានភាពដែលពួកគេអាចជួបបញ្ហាក្នុងការបង្ហាញសេចក្តីស្រឡាញ់ចំពោះមនុស្សដទៃ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ូហានទី១ ២:៩–១១; ៤:៧–១១, ១៩–២១ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ូហានបានបង្រៀនអ្វីខ្លះអំពីសេចក្តីស្រឡាញ់ ។ អ្នកគួរអញ្ជើញសិស្សឲ្យពិចារណាគូសចំណាំការបង្រៀននានានៅក្នុងខគម្ពីរទាំងនេះដែលមានសារៈសំខាន់ចំពោះពួកគេ ។

- តើការបង្រៀនណាមួយរបស់យ៉ូហានអំពីសេចក្តីស្រឡាញ់ ដែលមានសារៈសំខាន់ចំពោះអ្នក ? ហេតុអ្វី ?
- តើយើងអាចស្គាល់គោលការណ៍អ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ អំពីអ្វីដែលយើងត្រូវធ្វើ នៅពេលយើងស្រឡាញ់ព្រះ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរស្គាល់គោលការណ៍មួយដែលស្រដៀងនឹងគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងស្រឡាញ់ព្រះ យើងនឹងស្រឡាញ់មនុស្សដទៃ**) ។
- ហេតុអ្វីអ្នកគិតថា យើងនឹងបង្ហាញសេចក្តីស្រឡាញ់របស់យើងដល់មនុស្សដទៃ ប្រសិនបើយើងពិតជាស្រឡាញ់ព្រះមែននោះ ?

សូមចង្អុលបង្ហាញថា កាលយ៉ូហានបានប្រើពាក្យ *ស្អប់* ក្នុង យ៉ូហានទី១ ៤:២០ មាននូវវិធីជាច្រើនដែលយើងអាចដកយកសេចក្តីស្រឡាញ់ ឬសណ្តានចិត្តរបស់យើងចេញពីមនុស្សដទៃក្រៅពីការស្អប់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យពន្យល់អំពីអ្វីដែលពួកគេគិតថាជាវិធីមួយចំនួននោះ ។

សូមអញ្ជើញសិស្សម្នាក់អានយ៉ូហានទី១ ៣:១៧–១៨ឲ្យឮៗ ហើយសុំសិស្សក្នុងថ្នាក់ឲ្យរកមើលថា យើងគួរបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះមនុស្សដទៃតាមរបៀបណា ។ សូមឲ្យសិស្សប្រាប់អំពីអ្វីដែលពួកគេរកឃើញ ។ សិស្សគួររកឃើញនូវសារៈសំខាន់នៃការស្រឡាញ់ត្រូវបង្ហាញទាំង « ដោយពាក្យសម្តី » និង « ដោយការប្រព្រឹត្ត » ផងដែរ ។

- ហេតុអ្វីអ្នកគិតថា វាជារឿងដ៏សំខាន់ ដែលយើងត្រូវបង្ហាញសេចក្តីស្រឡាញ់របស់យើងតាមរយៈការប្រព្រឹត្តរបស់យើង ហើយពុំមែនតាមរយៈពាក្យសម្តីរបស់យើងតែប៉ុណ្ណោះនោះទេ ?
- តើអ្នកស្គាល់នរណាដែលជាគំរូដ៏ល្អមួយនៃការបង្ហាញសេចក្តីស្រឡាញ់ចំពោះមនុស្សដទៃឬទេ ? តើបុគ្គលម្នាក់នេះបានធ្វើអ្វីខ្លះក្នុងការបង្ហាញសេចក្តីស្រឡាញ់របស់ខ្លួនចំពោះមនុស្សដទៃ ?

សូមអញ្ជើញសិស្សឲ្យគិតអំពីមនុស្សម្នាក់នៅក្នុងជីវិតរបស់ពួកគេ ដែលពួកគេអាចបង្ហាញសេចក្តីស្រឡាញ់កាន់តែច្រើនថែមទៀត ។ សូមឲ្យពួកគេសរសេរឈ្មោះបុគ្គលនោះនៅលើក្រដាសមួយសន្លឹកអមជាមួយនឹងអ្វីមួយជាក់លាក់ ដែលពួកគេអាចធ្វើដើម្បីបង្ហាញសេចក្តីស្រឡាញ់ ឬចិត្តសប្បុរសដល់បុគ្គលនោះ ។ សូមពន្យល់ថា ពួកគេគំរាំត្រូវបង្ហាញសេចក្តីស្រឡាញ់របស់ពួកគេតាមរបៀបមិនពិតឡើយ ហើយពន្យល់ថា សេចក្តីសប្បុរស និងសណ្តានចិត្តបន្ទិចបន្ទួច ហើយសាមញ្ញ ជារឿយៗវាគឺជារឿងដ៏មានន័យបំផុត ។ សូមអញ្ជើញពួកគេឲ្យយកក្រដាសនោះទៅផ្ទះ ហើយធ្វើតាមអ្វីដែលពួកគេបានសរសេរ ។

សូមចង្អុលបង្ហាញថា នៅពេលយើងបង្ហាញសេចក្តីស្រឡាញ់របស់យើង តាមរយៈការប្រព្រឹត្តរបស់យើង នោះយើងកំពុងធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទហើយ (សូមមើល យ៉ូហានទី១ ២:៦; ៣:១–៣) ។ អ្នកគួរបញ្ចប់មេរៀននេះ ដោយចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិត ដែលសិស្សបានស្គាល់នៅក្នុងការសិក្សារបស់ពួកគេអំពីយ៉ូហានទី១ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

យ៉ូហានទី១ ៤:៧–១១ ។ បទបង្ហាញវីដេអូ— « Two Brothers Apart »

ដើម្បីជួយសិស្សឲ្យទទួលអារម្មណ៍ពីសេចក្តីពិត និងសារៈសំខាន់នៃគោលការណ៍ថា **នៅពេលយើងស្រឡាញ់ព្រះ នោះយើងនឹងស្រឡាញ់មនុស្សដទៃ** សូមពិចារណាបង្ហាញវីដេអូ « Two Brothers Apart » (៦:១២) ។ វីដេអូនេះបង្ហាញទំនាក់ទំនងរវាងបងប្អូនប្រុសពីរនាក់អស់រយៈពេលជាច្រើនឆ្នាំ នៅពេលពួកគេរៀនយល់ ហើយស្រឡាញ់គ្នា ។ វីដេអូនេះមាននៅក្នុង LDS.org ។

សេចក្តីផ្តើមអំពី

សំបុត្រទីពីររបស់យ៉ូហាន

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងសំបុត្រទីពីររបស់លោក យ៉ូហានបានបង្ហាញកង្វល់អំពីឥទ្ធិពលនៃការក្បត់សាសនានៅក្នុងសាសនាចក្រ ។ ទន្ទឹមនឹងគ្នានេះ លោកក៏បានបង្ហាញអំណរចំពោះសមាជិកសាសនាចក្រដែលបានបន្តមានចិត្តរឹងមាំ ហើយមានភក្តីភាពចំពោះដំណឹងល្អ (សូមមើល យ៉ូហានទី២ ១:៤) ។ ពាក្យទាំងនេះបង្ហាញពីអំណរ និងការដឹងគុណដែលថ្នាក់ដឹកនាំសាសនាចក្រមានចំពោះជនដែលបន្តមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ ។ នៅពេលសិស្សសិក្សាយ៉ូហានទី ២ ពួកគេអាចទទួលបានភាពរឹងមាំ ដោយការរំឭករបស់យ៉ូហានឲ្យចេះស្រឡាញ់គ្នា គោរពតាមព្រះបញ្ញត្តិរបស់ព្រះ ហើយរស់នៅដោយស្មោះត្រង់តាមគោលលទ្ធិនៃព្រះគ្រីស្ទ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

អ្នកនិពន្ធបានបង្ហាញខ្លួនលោកជា « អ្នកចាស់ទុំ » (យ៉ូហានទី២ ១:១) ហើយយោងតាមប្រពៃណី នោះគឺយ៉ូហានដែលជាសាវកមួយរូបក្នុងចំណោមពួកសាវកដើមទាំងដប់ពីរនាក់បានសរសេរសំបុត្រនេះ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « យ៉ូហាន, កូនប្រុសរបស់សេបេដេ ») ។

តើគម្ពីរនេះត្រូវបានសរសេរនៅពេលណា និងនៅកន្លែងណា ?

គ្មាននរណាម្នាក់ដឹកពិតប្រាកដពីពេលវេលា និងទីកន្លែងដែលយ៉ូហានទី២ ត្រូវសរសេរឡើងនោះទេ ។

ប្រសិនបើទម្លាប់នៃការស្នាក់នៅជិយូររបស់យ៉ូហាននៅអេភេសូរត្រឹមត្រូវ នោះលោកអាចសរសេរសំបុត្រនេះនៅទីនោះនៅចន្លោះ គ.ស. ៧០ និង ១០០ ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

សំបុត្រទីពីររបស់យ៉ូហានបានសរសេរទៅកាន់ « លោកស្រីជ័រសតាំង និងកូនចៅរបស់លោកស្រី » (យ៉ូហានទី២ ១:១) ។ យើងមិនបានដឹងថា យ៉ូហានកំពុងតែលើកមកនិយាយអំពីគ្រួសារលោក ឬមនុស្សមួយក្រុមផ្សេងទៀតជាក់លាក់ ឬកំពុងថ្លែងទៅកាន់សាសនាចក្រដែលប្រើជាពាក្យប្រៀបធៀបនោះទេ ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់បានសរសេរថា យ៉ូហានទី ២ និងយ៉ូហានទី ៣ ប្រហែលជាសំបុត្រដែលយ៉ូហានសរសេរទៅសមាជិកគ្រួសារលោកផ្ទាល់ (សូមមើល *Doctrinal New Testament Commentary* វ៉ុល ៣ [ឆ្នាំ ១៩៦៥–៧៣] ៣:៤០៩–១០, ៤១២–១៤) ។

គេអាចនិយាយម្យ៉ាងទៀតបានថា « លោកស្រីជ័រសតាំង » គឺសំដៅទៅលើក្រុមជំនុំសាសនាគ្រីស្តមួយ (សូមមើលយ៉ូហានទី២ ១:១៣) ។ ពាក្យក្រិកសម្រាប់ *ព្រះវិហារ* ជានាមកេទស្រី ហើយវាជារឿងសមញ្ញ ដែលប្រដូចសាសនាចក្រទៅនឹងស្ត្រីម្នាក់ (សូមមើល អេភេសូរ ៥:២៥–២៧, ៣២, ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ, វិវរណៈ ១២:១–៣, ៧ [នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ], វិវរណៈ ១៩:៧–៨) ។

ដូចជានៅក្នុងយ៉ូហានទី១ ដែរ យ៉ូហានទំនងជាសរសេរសំបុត្រនេះដើម្បីឆ្លើយតបនឹងការបង្រៀនខុសឆ្គងថា ព្រះយេស៊ូវគ្រីស្ទមិនបានយាងមកកាន់ផែនដីនេះក្នុងរូបកាយជាសាច់ឈាមនោះទេ ។ សូមពន្យល់ថា សមាជិកដែលបានបង្រៀនថា ព្រះគ្រីស្តគ្មានព្រះកាយខាងសាច់ឈាមនោះ មិនគួរឲ្យទទួលចូលទៅក្នុងផ្ទះ ឬក្រុមជំនុំរបស់នរណាម្នាក់ឡើយ (សូមមើល យ៉ូហានទី២ ១:៧–១០) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

នៅក្នុងសំបុត្រនេះ យ៉ូហានបានព្រមានអំពីគ្រូបង្រៀនក្លែងក្លាយដែលបានចូលទៅក្នុងសាសនាចក្រ ។ លោកបានណែនាំមិនឲ្យសមាជិកសាសនាចក្រស្តាប់ ឬសេពគប់នឹងបុគ្គលទាំងនេះឡើយ ។

គម្រោង

យ៉ូហានទី ២ ១ យ៉ូហានរំឭកសាសនាចក្រពីព្រះបញ្ញត្តិឲ្យចេះស្រឡាញ់គ្នា ។ លោកព្រមានពីពួកគ្រូបង្រៀនក្លែងក្លាយ និងពួកបោកបញ្ឆោតទាំងឡាយដែលមាននៅក្នុងសាសនាចក្រ ហើយទូន្មានដល់សមាជិកសាសនាចក្រថា កុំបណ្តោយឲ្យពួកគេបន្តនៅក្នុងក្រុមជំនុំរបស់ខ្លួនឡើយ ។

សេចក្តីផ្តើមអំពី

សំបុត្រទីបីរបស់យ៉ូហាន

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងសំបុត្រខ្លីនេះ យ៉ូហានបានសរសើរដល់កៃយុស ជាសមាជិកសាសនាចក្រម្នាក់ ដែលមានភក្តីភាពក្នុងអំឡុងពេលនៃការបះបោរប្រឆាំងមួយទាស់នឹងថ្នាក់ដឹកនាំសាសនាចក្រ ។ ការបង្រៀនរបស់យ៉ូហានអាចជួយសិស្សឲ្យយល់កាន់តែប្រសើរឡើងពីការក្បត់សាសនា ដែលបានកើតឡើងក្នុងសាសនាចក្រនៅជំនាន់ព្រះគម្ពីរសញ្ញាថ្មី ហើយអាចបំផុសគំនិតពួកគេឲ្យបន្តស្មោះត្រង់ចំពោះថ្នាក់ដឹកនាំសាសនាចក្រ មិនថាមានការបដិសេធជំទាស់បែបណានោះទេ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

អ្នកនិពន្ធបានបង្ហាញខ្លួនលោកថាជា « អ្នកចាស់ទុំ » (យ៉ូហានទី៣ ១:១) ហើយតាមទម្លាប់ត្រូវបានស្គាល់ថាជាសាវក យ៉ូហាន ។

តើគម្ពីរនេះត្រូវបានសរសេរនៅពេលណា និងនៅកន្លែងណា ?

គ្មាននរណាម្នាក់ដឹកពិតប្រាកដអំពីពេលវេលា និងទីកន្លែងដែលគម្ពីរយ៉ូហានទី ៣ ត្រូវសរសេរឡើងនោះទេ ។

ប្រសិនបើទម្លាប់នៃការស្នាក់នៅជិយូររបស់យ៉ូហាននៅអេភេសូរត្រឹមត្រូវ នោះលោកអាចសរសេរសំបុត្រនេះនៅទីនោះនៅចន្លោះ គ.ស. ៧០ និង ១០០ ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

សំបុត្រទីបីរបស់យ៉ូហានត្រូវបានសរសេរទៅកៃយុស ជាសមាជិកសាសនាចក្រម្នាក់ដែលយ៉ូហានបានសរសើរ ដោយសារគាត់បានបង្ហាញភក្តីភាពស្មោះស្ម័គ្រចំពោះបុព្វហេតុនៃព្រះគ្រីស្ទ ដោយផ្តល់ការស្នាក់នៅដល់ពួកអ្នកបម្រើរបស់ព្រះពេលពួកគាត់ធ្វើដំណើរ (សូមមើល យ៉ូហានទី៣ ១:៥–៨) ។

យ៉ូហានក៏បានព្រមានដល់កៃយុសផងដែរអំពីមនុស្សម្នាក់ដែលមានឈ្មោះ ឌីអូត្រេព ជាអ្នកដែលមានតួនាទីជាថ្នាក់ដឹកនាំម្នាក់ក្នុងមូលដ្ឋានរបស់សាសនាចក្រ ។ ឌីអូត្រេពបានបដិសេធយ៉ូហាន និងថ្នាក់ដឹកនាំផ្សេងទៀតរបស់សាសនាចក្រដោយបើកចំហ ហើយថែមទាំងរារាំងសមាជិកសាសនាចក្រក្នុងមូលដ្ឋានដែលបានប្រាថ្នាចង់ទទួលពួកគាត់មិនឲ្យចូលរួមការប្រជុំសាសនាចក្រ (សូមមើល យ៉ូហានទី៣ ១:៩–១០) ។ យ៉ូហានបានលើកទឹកចិត្តកៃយុសឲ្យបន្តធ្វើសេចក្តីល្អ ហើយថ្លែងថា លោករំពឹងទុកថា លោកនឹងទៅលេងនឹងកៃយុសឆាប់ៗនេះ (សូមមើល យ៉ូហានទី៣ ១:១១–១៤) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

នៅក្នុងយ៉ូហានទី៣ យើងឃើញនូវកង្វល់របស់យ៉ូហានស្តីពីឥទ្ធិពលនៃការក្បត់សាសនានៅក្នុងសាសនាចក្រ ។ យើងក៏ឃើញផងដែរពីសេចក្តីស្រឡាញ់របស់យ៉ូហានចំពោះមនុស្សដទៃទៀត និងអំណរដែលលោកមានចំពោះជនដែលជ្រើសយកជីវិតនៃការគោរពប្រតិបត្តិ (សូមមើល យ៉ូហានទី៣ ១:៤) ។

គម្រោង

យ៉ូហានទី៣ ១ យ៉ូហានសរសើរកៃយុសចំពោះសេចក្តីស្មោះត្រង់របស់គាត់ ហើយបានព្រមានប្រឆាំងថ្នាក់ដឹកនាំម្នាក់ដែលបានបដិសេធយ៉ូហាន និងថ្នាក់ដឹកនាំដទៃទៀតរបស់សាសនាចក្រ ។

យ៉ូហានទី ២–យ៉ូហានទី៣

សេចក្តីផ្តើម

យ៉ូហានបានព្រមានពួកបរិសុទ្ធអំពីមនុស្សដែលបោកបញ្ឆោត និងប្រកាសថា ព្រះយេស៊ូវគ្រីស្ទពុំបានយាងមកក្នុងរូបកាយនោះទេ ។ លោកក៏បានសរសើរកៃយុសចំពោះសេចក្តីស្មោះត្រង់របស់គាត់ ។

កំណត់ចំណាំ ៖ មេរៀននេះរួមមាននូវយោបល់សម្រាប់ការបង្រៀនមួយនៃយ៉ូហានទី៣ ដែលតម្រូវឲ្យសិស្សទទួលសំបុត្រមកពីឪពុកម្តាយ ឬថ្នាក់ដឹកនាំសាសនាចក្រ ។ ប្រសិនបើអ្នកជ្រើសប្រើយោបល់សម្រាប់ការបង្រៀននេះ អ្នកនឹងត្រូវរៀបចំបីបួនថ្ងៃទុកជាមុន ។ សូមអញ្ជើញឪពុកម្តាយ ឬប្រសិនបើចាំបាច់ ថ្នាក់ដឹកនាំសាសនាចក្រក្នុងមូលដ្ឋានរបស់សិស្សម្នាក់ៗឲ្យសរសេរសំបុត្រខ្លីមួយដល់សិស្សដោយបង្ហាញអំណរ ដែលពួកគាត់ធ្លាប់មាន នៅពេលពួកគាត់បានឃើញការខិតខំរបស់សិស្សដើម្បីរស់នៅតាមដំណឹងល្អ ។ សូមប្រាកដថាអ្នកមានសំបុត្រមួយសម្រាប់សិស្សម្នាក់ៗមកពីឪពុកម្តាយ ឬថ្នាក់ដឹកនាំសាសនាចក្ររបស់ពួកគេនៅថ្ងៃដែលអ្នកបង្រៀនមេរៀននេះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ូហាន ទី២

យ៉ូហាន ព្រមានអំពីមនុស្សដែលបង្រៀនគោលលទ្ធិខុសឆ្គង

សូមប្រាប់ឈ្មោះអត្តពលករដ៏ល្បីល្បាញម្នាក់ ដែលសិស្សភាគច្រើនស្គាល់ ។

- តើអត្តពលកររូបនេះអាចធ្វើអ្វីខ្លះ ដើម្បីបន្តមានសុខភាពល្អដើម្បីធ្វើការប្រកួតឲ្យកាន់តែល្អនោះ ?
- តើអ្វីអាចកើតឡើង ប្រសិនបើអត្តពលករម្នាក់នេះឈប់ទៅកន្លែងហាត់ប្រាណ ហើយចាប់ផ្តើមបរិភោគអាហារមិនល្អ មើលទូរទស្សន៍យូរៗ លេងវីដេអូហ្គេម និងប្រើគ្រឿងញៀន ដែលប៉ះពាល់ដល់រាងកាយ បន្ទាប់ពីការខិតខំធ្វើឲ្យរូបកាយបានរឹងមាំមកនោះ ?

សូមអញ្ជើញ សិស្សឲ្យពិចារណាពីរបៀបដែលអត្តពលករដ៏ជោគជ័យនោះត្រូវធ្វើកិច្ចការ ដើម្បីរក្សារូបកាយឲ្យមាំមួនអាចប្រៀបបាននឹងកិច្ចការ ដែលសមាជិកសាសនាចក្រត្រូវធ្វើដើម្បីរក្សាពរជ័យនានាដែលពួកគេបានទទួលតាមរយៈដំណឹងល្អដែរ ។ នៅពេលពួកគេសិក្សាយ៉ូហានទី ២ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍មួយ ដែលអាចជួយពួកគេឲ្យរក្សាពរជ័យដែលពួកគេបានទទួលក្នុងនាមជាសមាជិកសាសនាចក្រ ។

សូមសង្ខេប យ៉ូហានទី២ ១:១–៤ ដោយពន្យល់ថា សាវកយ៉ូហានបានចាប់ផ្តើមសរសេរសំបុត្ររបស់លោកដោយលើកឡើងអំពី « លោកស្រីរ៉ើសតាំង និងកូនចៅរបស់លោកស្រី » ដែលជាការលើកឡើងដោយផ្ទាល់ទៅកាន់សមាជិកស្ត្រីម្នាក់ក្នុងសាសនាចក្រ និងកូនចៅរបស់គាត់ ឬ ជាភាសាតំណាង ដើម្បីពិពណ៌នាពីក្រុមជំនុំមួយក្នុងសាសនាចក្រ ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី២ ១:៥–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលបទបញ្ញត្តិ ដែលយ៉ូហានបានរំឭកដល់ពួកបរិសុទ្ធ ។

- តើបទបញ្ញត្តិអ្វីទៅដែលយ៉ូហានបានរំឭកដល់ពួកបរិសុទ្ធ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី២ ១:៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលហេតុផលដែលយ៉ូហានបានទូន្មានសមាជិកសាសនាចក្រឲ្យ « ប្រព្រឹត្តតាម » (យ៉ូហានទី ២ ១:៦) ឬប្រតិបត្តិតាមបទបញ្ញត្តិនោះ ។

- ហេតុអ្វីយ៉ូហានទូន្មានឲ្យសមាជិកសាសនាចក្រប្រតិបត្តិតាមបទបញ្ញត្តិ ?
- តើ « អ្នកប្រវ័ញ្ចបញ្ឆោត » (ខទី ៧) កំពុងបង្រៀនអំពីអ្វីខ្លះ ?

សូមពន្យល់ថា នៅពេលយ៉ូហានសរសេរសំបុត្រនេះ មានទស្សនវិទូខាងដូសេតម្នាក់កំពុងទទួលបានប្រជាប្រិយភាព ។ ពួកដូសេតបានជឿថា ព្រះត្រូវបានលើកតម្កើងយ៉ាងខ្ពស់ រហូតដល់ទ្រង់លែងរងទុក្ខ លែងសុគត ឬលែងមានបទពិសោធន៍នៃជីវិតរមែងស្លាប់ផ្សេងទៀត ។ ហេតុដូច្នេះហើយ ពួកគេបានសន្មតថា ព្រះយេស៊ូវគ្រីស្តក្នុងនាមជាបុត្រានៃព្រះពុំបានយាងមកក្នុងសាច់ឈាមទេ ប៉ុន្តែមានតែវិញ្ញាណរបស់ទ្រង់ប៉ុណ្ណោះ *ទំនង* ជាធ្វើកិច្ចការដែលមនុស្សនឹងធ្វើ ឬដកពិសោធន៍ ។

- តើអ្វីទៅជាគំរូមួយចំនួននៃការបង្រៀនខុសឆ្គងនៅជំនាន់របស់យើងដែលផ្ទុយពីសេចក្តីពិតនៃដំណឹងល្អ ?
- ហេតុអ្វីការបង្រៀនទាំងនេះមានគ្រោះថ្នាក់ខាងវិញ្ញាណ ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី២ ១:៨ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ូហានបានដាស់តឿនឲ្យសមាជិកសាសនាចក្រធ្វើអ្វីខ្លះ នៅក្នុងពន្លឺនៃការបង្រៀនខុសឆ្គងទាំងនេះ ។ សូមពន្យល់ថា ឃ្លា « ត្រូវឲ្យអ្នករាល់គ្នាប្រយ័ត្ន » មានន័យថា ឲ្យប្រយ័ត្នប្រយែងខ្លួនកុំឲ្យសម្របតាមការបង្រៀនខុសឆ្គង ហើយពាក្យ *បានអ្វី* អាចមានន័យថាបានអនុវត្ត ឬទទួល ។

- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីការបង្រៀនរបស់យ៉ូហាននៅក្នុង ខទី ៦–៨ អំពីរបៀបដែលយើងអាចបន្តរីករាយនឹងពរជ័យនៃដំណឹងល្អដែលយើងបានទទួល ? (ដោយប្រើពាក្យសម្តីរបស់ពួកគេផ្ទាល់ សិស្សគួរស្គាល់គោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ដូចតទៅ ៖ **នៅពេលយើងគោរពបទបញ្ញត្តិ ហើយប្រុងប្រយ័ត្ន នោះយើងអាចបន្តរីករាយនឹងពរជ័យនៃដំណឹងល្អដែលយើងធ្លាប់ទទួលបាន ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យសរសេរជាបញ្ជីមួយអំពីពរជ័យនៃដំណឹងល្អ ដែលពួកគេបានទទួលរួចហើយ ឬសង្ឃឹមថានឹងបានទទួលនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យចែកចាយអ្វី ដែលពួកគេបានសរសេរជាមួយសិស្សនៅក្នុងថ្នាក់ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

- តើការសម្របតាមការបង្រៀនខុសឆ្គងអាចរារាំងយើងមិនឲ្យទទួលបាន និងបន្តរីករាយនឹងពរជ័យនៃដំណឹងល្អទាំងនេះយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី២ ១:៩ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាអ្វីទៅដែលយ៉ូហានបានបង្រៀនថានឹងកើតឡើងចំពោះជនដែលរស់នៅតាមគោលលទ្ធិរបស់ព្រះគ្រីស្ទ ឬបន្តនៅជិត ហើយស៊ូទ្រាំនៅក្នុងដំណឹងល្អ ។

- តើជនដែលរស់នៅតាមគោលលទ្ធិនៃព្រះគ្រីស្ទនឹងទទួលបានអ្វីខ្លះ ? (បន្ទាប់ពីសិស្សឆ្លើយតបរួច ចូរសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងរស់នៅតាមគោលលទ្ធិរបស់ព្រះគ្រីស្ទ យើងនឹងមានព្រះវរបិតា និងព្រះរាជបុត្រាគង់នៅជាមួយនឹងយើង**) ។

សូមចង្អុលបង្ហាញថា វិធីមួយដែលយើងមានព្រះវរបិតា និងព្រះរាជបុត្រាគង់នៅជាមួយនឹងយើង គឺតាមរយៈទ្រូកនៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមឲ្យសិស្សសញ្ជឹងគិតពីការខិតខំរបស់ពួកគេ ដើម្បីគោរពតាមបទបញ្ញត្តិ មានការប្រុងប្រយ័ត្ន ហើយរស់នៅតាមដំណឹងល្អ ។ សូមអញ្ជើញពួកគេឲ្យសរសេរនូវហេតុផល ដែលពួកគេចង់រក្សាពរជ័យដែលពួកគេបានទទួលតាមរយៈដំណឹងល្អ និងកិច្ចការមួយដែលពួកគេនឹងធ្វើថ្ងៃនេះ ដើម្បីមានភាពស្មោះត្រង់ និងភាពទៀងទាត់កាន់តែច្រើននៅក្នុងការគោរពតាមបទបញ្ញត្តិ ។

សូមសង្ខេប យ៉ូហានទី ២ ១:១០–១៣ ដោយពន្យល់ថា យ៉ូហានបានលើកទឹកចិត្តពួកបរិសុទ្ធឲ្យចៀសវាងពីមនុស្សដែលប្រកាសគោលលទ្ធិក្លែងក្លាយ ។ លោកក៏បានបង្ហាញអំពីចំណងក្រាថ្នាររបស់លោក ដើម្បីទៅសួរសុខទុក្ខដោយផ្ទាល់ដល់ពួកបរិសុទ្ធដែលលោកបានសរសេរសំបុត្រទៅដែរ ។

យ៉ូហានទី៣

លោកបានសរសើរកៃយុសចំពោះសេចក្តីស្មោះត្រង់របស់គាត់

សូមយកដុំក្រួសតូចមួយ និងចានសម្លធំមួយ ដែលមានទឹកពេញមកថ្នាក់រៀន ។ សូមឲ្យសិស្សម្នាក់ទម្លាក់ដុំក្រួសនោះចូលទៅក្នុងទឹកដោយកុំធ្វើឲ្យវារឡើ ។

- ហេតុអ្វីវាជារឿងដ៏សំខាន់ ដើម្បីកុំឲ្យក្រួសនោះធ្វើឲ្យទឹករឡើ ?
- ក្រៅពីខ្លួនអ្នកទៅ តើមានមនុស្សណាផ្សេងទៀត ដែលអាចរងឥទ្ធិពលវិជ្ជមានតាមរយៈការជ្រើសរើសរបស់អ្នកដើម្បីរស់នៅតាមដំណឹងល្អនោះឬទេ ?

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង យ៉ូហានទី ៣ យ៉ូហានបានលើកឡើងអំពីសមាជិកសាសនាចក្រដ៏ស្មោះត្រង់ម្នាក់ឈ្មោះ កៃយុស ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ូហានទី៣ ១:១–៤ ឲ្យឮៗ ។ ចូរឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលរបៀប ដែលយ៉ូហានបានរងឥទ្ធិពលពីកៃយុសតាមរយៈសេចក្តីស្មោះត្រង់របស់គាត់ក្នុងការរស់នៅតាមដំណឹងល្អ ។ សូមពន្យល់ថា *ពួកកូន* នៅក្នុង ខទី ៤ អាចនឹងសំដៅទៅលើសមាជិកសាសនាចក្រដែលយ៉ូហានបានជួយឲ្យប្រែចិត្តជឿលើដំណឹងល្អ ។

- តើយ៉ូហានបានរងឥទ្ធិពលពីកៃយុស តាមរយៈសេចក្តីស្មោះត្រង់របស់គាត់ក្នុងការរស់នៅតាមដំណឹងល្អយ៉ាងដូចម្តេចខ្លះ ?
- តើអ្នកនឹងសង្ខេបសេចក្តីពិតមួយ នៅក្នុងខគម្ពីរទាំងនេះអំពីរបៀបដែលការរស់នៅតាមដំណឹងល្អអាចជះឥទ្ធិពលដល់ខ្លួនយើង និងមនុស្សដទៃទៀតយ៉ាងដូចម្តេច ? (សិស្សអាចនឹងរកឃើញសេចក្តីពិត ខុសគ្នាមួយ ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ការរស់នៅតាមដំណឹងល្អនាំមកនូវអំណរ មិនត្រឹមតែចំពោះខ្លួនយើងប៉ុណ្ណោះទេ ប៉ុន្តែដល់មនុស្សដទៃផងដែរ**) ។
- តើអ្នកធ្លាប់ដកពិសោធន៍នូវអំណរ ដោយសារមនុស្សម្នាក់ផ្សេងទៀតបានរស់នៅតាមដំណឹងល្អដោយស្មោះត្រង់នៅពេលណាដែរ ?

ដើម្បីបង្ហាញបន្ថែមទៀតអំពីសេចក្តីពិតនេះ ប្រសិនបើអ្នកជ្រើសឲ្យមានឪពុកម្តាយ ឬថ្នាក់ដឹកនាំសាសនាចក្រសរសេរសំបុត្រដល់សិស្ស សូមចែកសំបុត្រទាំងនោះនៅពេលនេះ ។ សូមធ្វើឲ្យប្រាកដថា សិស្សម្នាក់ៗ មានសំបុត្រមួយមកពីឪពុកម្តាយ ឬថ្នាក់ដឹកនាំសាសនាចក្ររបស់គាត់ ហើយអនុញ្ញាតឲ្យសិស្សមានពេលអានសំបុត្រនោះ ។

សូមសង្ខេប យ៉ូហានទី ៣ ១:៥–១៤ ដោយពន្យល់ថា យ៉ូហានបានសរសើរកៃយុស ចំពោះឆន្ទៈរបស់គាត់ដើម្បីទទួលថ្នាក់ដឹកនាំសាសនាចក្រ ឬពួកអ្នកផ្សព្វផ្សាយដែលបានធ្វើដំណើរ ហើយគាត់បានរិះគន់ដល់ថ្នាក់ដឹកនាំក្នុងមូលដ្ឋានម្នាក់ឈ្មោះ ឌីអូត្រេព ដែលពុំបានទទួលយ៉ូហាន និងដៃគូរបស់លោកទេ ។

សូមរំឭកឡើងវិញនូវសេចក្តីពិតដែលបានបង្ហាញនៅក្នុងមេរៀននេះ ។ សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតទាំងនេះ ហើយអញ្ជើញសិស្សឲ្យអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។

សូមអញ្ជើញសិស្សទាំងអស់ឲ្យចូលរួម

សូមរិះរកវិធីដ៏សមរម្យដើម្បីអញ្ជើញសិស្សទាំងអស់ឲ្យចូលរួមនៅក្នុងមេរៀននេះ ។ ការអញ្ជើញឪពុកម្តាយ ឬថ្នាក់ដឹកនាំរបស់សិស្សម្នាក់ៗឲ្យសរសេរសំបុត្រមួយអាចធ្វើឲ្យសិស្សគ្រប់គ្នាចូលរួម សូម្បីតែសិស្សដែលធម្មតាមានការស្ទាក់ស្ទើរ ឬមិនព្រមចូលរួមយ៉ាងសកម្មក្តី ។

សេចក្តីផ្តើមអំពី

សំបុត្រទូទៅរបស់យូដាស

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

សំបុត្រទូទៅរបស់យូដាសពិពណ៌នាអំពីកម្លាំងនៃការក្បត់សាសនា ដែលបានកើតមាននៅក្នុងសាសនាចក្រកាលពីសម័យបុរាណ ។ កាលសិស្សសិក្សាសំបុត្រនេះ ពួកគេអាចរៀនពីរបៀបដើម្បីដឹងពីជនដែលស្វែងកេងប្លែងពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទឲ្យឃ្លាតឆ្ងាយពីសេចក្តីជំនឿ ។ សិស្សក៏អាចទទួលបានអារម្មណ៍ពីសារៈសំខាន់នៃការខិតខំប្រយុទ្ធដើម្បីការពារសេចក្តីជំនឿ និងការបន្តមានភក្តីភាពចំពោះសេចក្តីជំនឿនោះផងដែរ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

អ្នកនិពន្ធសំបុត្រនេះបង្ហាញខ្លួនឯងថាជា « យូដាស ជាបាវបំរើរបស់ព្រះយេស៊ូវគ្រីស្ទ ហើយជាប្អូនយ៉ាកុប » (យូដាស ១:១) ។ ជាទូទៅ អ្នកនិពន្ធនេះត្រូវបានគេជឿថាជាបងប្អូនពោះតែមួយរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ាថាយ ១៣:៥៥, ម៉ាកុស ៦:៣ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « យូដាស ») ។ ពិតប្រាកដណាស់ យូដាសគឺជាសមាជិកសាសនាម្នាក់ដែលមានគេគោរពរាប់អានច្រើននៅយេរូសាឡិម ហើយលោកប្រហែលជាធ្វើដំណើរទៅផ្សាយសាសនា (សូមមើល កិច្ចការ ១:១៣–១៤, កូរិនថូសទី១ ៩:៥) ។ គ្មានការបញ្ជាក់ណាមួយពីតំណែងបព្វជិតភាពដែលយូដាសបានកាន់ឡើយ ប៉ុន្តែសំបុត្រនេះប្រាប់ថា លោកមានតួនាទីជាអ្នកមានសិទ្ធិអំណាចមួយរូប ទើបធ្វើឲ្យលោកអាចសរសេរសំបុត្រទូន្មានបាន ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

យើងពុំដឹងពីទីកន្លែង ដែលសំបុត្ររបស់យូដាសត្រូវបានសរសេរឡើងឡើយ ។ ប្រសិនបើសំបុត្រនេះពិតជានិពន្ធដោយយូដាស ដែលជាប្អូនរបស់ព្រះយេស៊ូវមែន នោះវាប្រហែលជាសរសេរឡើងនៅចន្លោះ គ.ស. ៤០ និង ៨០ ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

សំបុត្ររបស់យូដាសបានលើកឡើងទៅកាន់ពួកគ្រីស្ទានដ៏ស្មោះត្រង់— « ជាពួកអ្នកសូនភ្ញាក្នុងព្រះដ៏ជាព្រះវរបិតា ដែលបំរុងទុកក្នុងព្រះយេស៊ូវគ្រីស្ទ » (យូដាស ១:១) ។ យូដាសបាននិយាយថា គោលបំណងរបស់ លោកគឺដើម្បីលើកទឹកចិត្តពួកអ្នកអានរបស់លោកឲ្យ « ខំតយុទ្ធ ដើម្បីការពារសេចក្តីជំនឿ » ទាស់នឹងពួកគ្រូបង្រៀនខាងលោកិយដែលបានចូលក្នុងសាសនាចក្រ ហើយកំពុងតែលើកកម្ពស់ដល់តំរិយាបថអសីលធម៌ និងការបង្រៀនខុសឆ្គងដែលបានបដិសេធដល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ (យូដាស ១:៣) ។

តើគម្ពីរនេះមានលក្ខណៈពិសេសអ្វីខ្លះ ?

ទោះវាជាគម្ពីរមួយខ្លីដាងគេនៅក្នុងព្រះគម្ពីរសញ្ញាថ្មីក្តី ក៏សំបុត្ររបស់យូដាសមាននូវព័ត៌មានដែលគ្មាននៅកន្លែងណាផ្សេងទៀតក្នុងព្រះគម្ពីរបឺបដែរ ។ យូដាសបានសរសេរអំពី « ពួកទេវតាដែលមិនបានរក្សាសណ្ឋានដើមរបស់ខ្លួន » (ខទី ៦, សូមមើលផងដែរ អ័ប្រាហាំ ៣:២៦) នៃការប្រឈមមុខមួយរវាងមីកែល និងលូស៊ីហ្វើរចំពោះរូបកាយរបស់ម៉ូសេ (ខទី ៩) និងពីការព្យាករមួយរបស់អេណុកអំពីការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ (ខទី១៤–១៥, សូមមើលផងដែរ ម៉ូសេ ៧:៦៥–៦៦) ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងក្បួមនៃពួកសាវកដប់ពីរនាក់ បានកត់សម្គាល់ពីលក្ខណៈពិសេសមួយចំនួននៃសំបុត្ររបស់យូដាស ៖

« នៅក្នុងព្រះគម្ពីរបឺបទាំងមូល មានតែយូដាសម្នាក់គត់ ដែលបានរក្សាទុកដល់យើងនូវគំនិតថា ជីវិតមុនគឺជាសណ្ឋានទីមួយរបស់យើង ហើយថាមានពួកទេវតាមួយចំនួនមិនបានជាប់ការសាកល្បងនោះទេ ។

« មានតែលោកប៉ុណ្ណោះ ដែលយើងបានរកឃើញចំណេះដឹងពីជម្លោះរវាងមីកែល និងលូស៊ីហ្វើរអំពីរូបកាយរបស់ម៉ូសេ ។

« មានតែលោកម្នាក់គត់ ដែលកត់ត្រាពីការព្យាករដ៏រុងរឿងរបស់អេណុក អំពីការយាងមកជាលើកទីពីរនៃកូនមនុស្ស » (*Doctrinal New Testament Commentary* រ៉ែល ៣ [ឆ្នាំ១៩៦៥–៧៣] ៣:៤១៥) ។

ពាក្យរបស់យូដាសទាស់ត្រង់ៗចំពោះអ្នកដែលបដិសេធព្រះ និងពួកអ្នកបម្រើរបស់ទ្រង់ ហើយជំទាស់នឹងអ្នកដែលកំពុងធ្វើការថ្វាយបង្គំផាហ្គានដែលអសីលធម៌ និងកំពុងប្រកាសថា ខ្លួនលែងត្រូវការគោរពតាមព្រះបញ្ញត្តិ រួមទាំងច្បាប់ព្រហ្មចារីភាពផងដែរ ។ យូដាសបានរៀបរាប់ពីអាកប្បកិរិយាមួយចំនួនរបស់បុគ្គលទុច្ចរិតទាំងនេះ ។

គម្រោង

យូដាស ១ យូដាសដាស់តឿនសមាជិកសាសនាចក្រឲ្យ « ខំតយុទ្ធ ដើម្បីការពារសេចក្តីជំនឿ » (យូដាស ១:៣) ។ លោកពន្យល់ថា មនុស្សបានលបចូលដោយឈ្លាសវៃនៅក្នុងចំណោមពួកបរិសុទ្ធ ហើយកំពុងផ្សព្វផ្សាយគោលលទ្ធិខុសឆ្គង ហើយលើកកម្ពស់ទម្លាប់អាក្រក់ ។ យូដាសព្រមានពីការកាត់សេចក្តីដែលកើតមានចំពោះអ្នកដែលងាកចេញពីព្រះ ។ យូដាសទូន្មានសមាជិកសាសនាចក្រឲ្យស្ថាបនាសេចក្តីជំនឿរបស់ពួកគេ ហើយ « ស្អាងចិត្តឡើងក្នុងសេចក្តីជំនឿដ៏បរិសុទ្ធបំផុត [របស់ពួកគេ] » (យូដាស ១:២១) ។

យូដាស

សេចក្តីផ្តើម

យូដាសបានដាស់តឿនសមាជិកសាសនាចក្រឲ្យខំតយុទ្ធ ដើម្បីការពារសេចក្តីជំនឿទាស់នឹងពួកគ្រូបង្រៀនក្លែងក្លាយនានា ។ លោកបានពិពណ៌នាអំពីគ្រូបង្រៀនក្លែងក្លាយ ហើយបានទូន្មានពួកបរិសុទ្ធឲ្យស្ថាបនាជីវិតរបស់ពួកគេលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ តាមប្រពៃណី យូដាសត្រូវបានគេយល់ថាជាប្អូនប្រុសពោះតែមួយរបស់ព្រះយេស៊ូវគ្រីស្ទ(សូមមើល ម៉ាថាយ ១៣:៥៥) ។ យូដាសទំនងជាសមាជិកសាសនាចក្រដ៏សកម្ម ហើយមានកិត្តិយឧត្តស់ម្នាក់នៅក្រុងយេរូសាឡិម ។

សូមឲ្យមានសេចក្តីជំនឿលើព្រះអម្ចាស់ និង ព្រះវិញ្ញាណ

ការទទួលខុសត្រូវដើម្បីបង្រៀនគោលការណ៍នៃដំណឹងល្អដល់យុវវ័យអាចទទួលអារម្មណ៍អំពីការសោកល្បួង និងការលើសលប់ ។ សូមចងចាំថា វាគឺជាកិច្ចការរបស់ព្រះអម្ចាស់ ហើយថាទ្រង់នឹងជួយអស់អ្នកដែលមានសេចក្តីជំនឿទៅលើទ្រង់ (សូមមើល ម៉ូរ៉ូណៃ ៧:៣៣) ។ ក៏សូមជឿផងដែរថា ព្រះវិញ្ញាណបរិសុទ្ធអាចបន្ទន់ចិត្តរបស់សិស្ស ហើយបំផុសពួកគេឲ្យអនុវត្តសេចក្តីពិតនៃដំណឹងល្អ ស្របតាមសេចក្តីត្រូវការ និងកាលៈទេសៈរបស់ពួកគេ (សូមមើល អាលម៉ា ២៤:៨, គ. និង ស. ៥០:១៨) ។

យោបល់សម្រាប់ការបង្រៀន

យូដាស ១:១–១៩

យូដាសដាស់តឿនសមាជិកសាសនាចក្រ ឲ្យខំតយុទ្ធដើម្បីការពារសេចក្តីជំនឿទាស់នឹងពួកគ្រូបង្រៀនក្លែងក្លាយ

សូមអានស្ថានភាពខាងក្រោមឮៗ ហើយសូមឲ្យសិស្សគិតថា ពួកគេនឹងឆ្លើយតបចំពោះស្ថានភាពទាំងនោះយ៉ាងដូចម្តេច ៖

១. នៅក្នុងប្រព័ន្ធសង្គមមួយ មានមិត្តម្នាក់បានសរសេរប្រយោគរិះគន់ដល់គោលជំហររបស់សាសនាចក្រស្តីពីការរៀបការភេទដូចគ្នា ។

២. មានអ្នកជិតខាងម្នាក់ដឹងថា អ្នកគឺជាសមាជិកសាសនាចក្រ ។ គាត់ប្រាប់អ្នកថា គាត់បានអានព្រះគម្ពីរមរមន ហើយទទួលអារម្មណ៍ថាវាគឺជាសៀវភៅដែលលើកស្ទួយចិត្តមួយក្បាលដ៏មានប្រយោជន៍ ប៉ុន្តែពុំមែនជាបន្ទូលរបស់ព្រះទេ ។

៣. នៅឯការពិភាក្សាក្នុងថ្នាក់មួយនៅសាលារៀន មានមិត្តម្នាក់បានប្រកែកថា ការមើលរូបភាពអាសគ្រាមគឺជារឿងធម្មតា ហើយវាពុំគួរហាមឃាត់នោះទេ ។

- **តើវិធីខុសៗគ្នាបែបណាខ្លះ ដែលមនុស្សម្នាក់អាចឆ្លើយតបចំពោះស្ថានភាពទាំងនេះ ?**

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ូដាស ១:៣–៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយូដាសបានព្រមានសមាជិកសាសនាចក្រអំពីអ្វីខ្លះ ។

- **យោងតាម ខទី ៤តើយូដាសបានព្រមានសមាជិកសាសនាចក្រអំពីអ្វីខ្លះ ?**

សូមជួយសិស្សឲ្យយល់ថា « មនុស្សទមិលល្មើស » ដែលមានបំណងអាក្រក់បានក្លាយជាផ្នែកមួយនៃសមាជិកភាពក្នុងសាសនាចក្រ ។ សមាជិកទាំងនេះក្នុងសាសនាចក្របានលើកកម្ពស់ទម្លាប់ពុករលួយ ហើយអសីលធម៌ដោយបង្រៀនថា គោលលទ្ធិនៃព្រះគុណបានអនុញ្ញាតឲ្យធ្វើអំពើបាប ដោយសារព្រះនឹងអត់ទោសដោយសេចក្តីមេត្តាករុណា ។ ពួកគេក៏បានបដិសេធសេចក្តីពិតជាក់លាក់អំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទផងដែរ ។ ឃ្លាថា « ពួកអ្នកដែលមានទោសកត់ទុក តាំងពីដើមមក » (ខទី ៤) មានន័យថា ការដាក់ទោសដល់មនុស្សបែបនេះត្រូវបានសរសេរទុកជាយូរមកហើយ ។

- **នៅក្នុងពន្លឺនៃការបង្រៀនខុសឆ្គង និងការប្រព្រឹត្តអំពើពុករលួយ ដែលមនុស្សទាំងនេះកំពុងធ្វើឲ្យសាយភាយ តើយូដាសបានទូន្មានឲ្យសមាជិកសាសនាចក្រស្មោះត្រង់ធ្វើអ្វីខ្លះ ? (« ឲ្យខំតយុទ្ធដើម្បីការពារសេចក្តីជំនឿ » | ខទី៣ |) ។**

សូមពន្យល់ថា « សេចក្តីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច » (ខទី ៣) សំដៅទៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ—សេចក្តីពិត ក្រឹត្យវិន័យ និងពិធីបរិសុទ្ធ ដែលព្រះអង្គសង្គ្រោះ និងពួកសាវករបស់ទ្រង់បានបង្រៀន ។

- **តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះ អំពីការទទួលខុសត្រូវនៃពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងប្រឈមនឹងការបង្រៀនខុសឆ្គង និងការប្រព្រឹត្តអំពើពុករលួយទាំងឡាយ ? (សិស្សអាចប្រើពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីបង្ហាញអំពីសេចក្តីពិតដូចតទៅនេះ ៖ **ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្ទគួរខំតយុទ្ធ ដើម្បីការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទទាស់នឹងការបង្រៀនខុសឆ្គង និងការប្រព្រឹត្តអំពើពុករលួយ**) ។**

- **តើអ្នកគិតថា ការខំតយុទ្ធដើម្បីការពារដំណឹងល្អមានន័យយ៉ាងណា ? (យើងត្រូវបង្រៀន ហើយថ្លែងទីបន្ទាល់អំពីដំណឹងល្អដោយភាពក្លាហាន ។ ប៉ុន្តែ យើងត្រូវធ្វើកិច្ចការនេះដោយមានចិត្តមេត្តា គ្មានជិះជាន់ ឬការទាស់ទែងគ្នាឡើយ | សូមមើល អាលម៉ា ៣៨:១២, នីហ្វៃទី៣ ១១:២៩ |) ។**

- **តើយើងអាចការពារដំណឹងល្អ ដោយគ្មានការទាស់ទែងគ្នាបានយ៉ាងដូចម្តេច ?**

ចូររំឭកសិស្សអំពីស្ថានភាពដែលបានលើកឡើងខាងដើមក្នុងមេរៀននេះ ។

- **នៅក្នុងស្ថានភាពទាំងនេះ និងស្ថានភាពស្រដៀងគ្នាដែរ តើវិធីណាខ្លះ ដែលយើងអាចការពារដំណឹងល្អទាស់នឹងការបង្រៀនខុសឆ្គង និងការប្រព្រឹត្តអំពើពុករលួយទាំងឡាយ ?**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានដំណើររឿងខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា យុវនារីនោះបានតយុទ្ធការពារដំណឹងល្អយ៉ាងដូចម្តេច ។

« ថ្មីៗនេះ ខ្ញុំបាននិយាយជាមួយនឹងក្មេងស្រីថ្នាក់ឡូរ៉ែលម្នាក់ រស់នៅសហរដ្ឋអាមេរិក ។ ខ្ញុំសូមដកស្រង់ពីអ៊ីម៉ែលរបស់នាង ៖

« ‹ កាលពីឆ្នាំមុន មិត្តភក្តិរបស់ខ្ញុំនៅលើហ្វេសប៊ុកមួយចំនួន បានចាប់ផ្តើមប្រកាសអំពីគោលជំហររបស់ពួកគេអំពីរឿងអាពាហ៍ពិពាហ៍ ។ មនុស្សជាច្រើនពេញចិត្តនឹងអាពាហ៍ពិពាហ៍ភេទដូចគ្នា ហើយពួកយុវវ័យអិលឌីអេសជាច្រើនបានបង្ហាញថា ពួកគេបាន « ចូលចិត្ត » ការប្រកាសទាំងនោះ ។ ខ្ញុំមិនបានបញ្ចេញមតិអ្វីសោះឡើយ ។

« ‹ ខ្ញុំបានសម្រេចចិត្តប្រកាសអំពីជំនឿខ្ញុំ លើការរៀបការបែបប្រពៃណី តាមវិធីដ៏ប្រុងប្រយ័ត្នមួយ ។

« ‹ ដោយដាក់រូបភាពលើប្រូហ្វាលរបស់ខ្ញុំ ខ្ញុំបានបន្ថែមចំណងជើងថា « ខ្ញុំជឿលើអាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់ » ។ មិនបានមួយសន្ទុះផង ខ្ញុំបានចាប់ផ្តើមទទួលបានសារជាច្រើន ។ « អ្នកអាត្មានិយមពេកហើយ » ។ « អ្នកកំពុងតែកាត់សេចក្តីគេ » ។ មានម្នាក់នោះ បានប្រៀបធៀបខ្ញុំទៅនឹងម្ចាស់ទាសករម្នាក់ ។ ហើយខ្ញុំបានទទួលការបង្ហោះនេះមកពីមិត្តដ៏សំខាន់ម្នាក់របស់ខ្ញុំ ដែលជាសមាជិកនៃសាសនាចក្រដ៏រឹងមាំម្នាក់ ៖ « ឯងត្រូវរស់នៅតាមកាលសម័យ ។ អ្វីៗប្រែប្រួល ហើយឯងក៏គួរតែប្រែប្រួលដែរ » ។

នាងបានថ្លែងថា « ‹ ខ្ញុំមិនបានឈ្លោះតបវិញទេ តែខ្ញុំក៏មិនបានដកយកពាក្យសំដីខ្ញុំចេញវិញដែរ › ។

« នាងបានបញ្ចប់ថា ‹ ពេលខ្លះ ដូចជាប្រធានម៉នសុន បានមានប្រសាសន៍ថា « បងប្អូនត្រូវតែឈរម្នាក់ឯង » ។ ខ្ញុំសង្ឃឹមថា ក្នុងនាមជាយុវវ័យ យើងនឹងឈរមួយគ្នាមានភក្តីភាពចំពោះព្រះ និងចំពោះការបង្រៀនទាំងឡាយរបស់ព្យាការីនៅរស់របស់ទ្រង់ › » (« Spiritual Whirlwinds » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ១៩–២០) ។

- តើយុវនារីនេះបានការពារដំណឹងល្អយ៉ាងដូចម្តេច ?
- តើអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់ធ្លាប់ការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនៅពេលណា ? តើអ្នកបានរៀនអ្វីខ្លះតាមរយៈបទពិសោធន៍នោះ ?

សូមឲ្យសិស្សសញ្ជឹងគិតថា ពួកគេអាចធ្វើអ្វីខ្លះ ដើម្បីខំតយុទ្ធការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើតាមការបំផុសគំនិតទាំងឡាយ ដែលពួកគេទទួលបាន ។

សូមសង្ខេប យូដាស ១:៥–៧ ដោយពន្យល់ថា យូដាសបានប្រៀបធៀបសមាជិកសាសនាចក្រ ដែលបះបោរទាំងនេះទៅនឹងប្រជាជននៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ដែលបានបះបោរទាស់នឹងព្រះ ហើយរងគ្រោះដោយការកាត់សេចក្តីរបស់ទ្រង់ ។ មនុស្សទាំងនេះរួមបញ្ចូលទាំងកូនចៅអ៊ីស្រាអែលជាច្រើន ដែលត្រូវបានបំផ្លាញចោលនៅក្នុងទីរហោស្ថាន និងប្រជាជននៃទីក្រុងស៊ូដុំម និង ក្រុងកូម៉ូរ៉ា ដែលត្រូវបានបំផ្លាញចោលដោយភ្លើង ។ យូដាសក៏បានប្រៀបធៀបសមាជិកសាសនាចក្រដែលបះបោរ ទៅនឹងជនដែលបះបោរទាស់នឹងព្រះនៅក្នុង « សណ្ឋានដើមរបស់ខ្លួន » ឬជីវិតមុនផែនដី ហើយត្រូវបានបណ្តេញចេញពីវត្តមានរបស់ទ្រង់ (យូដាស ១:៦, សូមមើលផងដែរ អ័ប្រាហាំ ៣:២២–២៦) ។

ចូរសរសេរចំណងជើងដូចខាងក្រោមនៅលើក្តារខៀន ៖ *បុគ្គលិកលក្ខណៈនៃពួកគ្រូបង្រៀនក្លែងក្លាយ* ។

សូមពន្យល់ថា នៅក្នុង យូដាស ១:៨–១៦យើងបានអានអំពីការពិពណ៌នារបស់យូដាសទាក់ទងនឹងបុគ្គលិកលក្ខណៈជាច្រើន ដែលនឹងជួយសមាជិកសាសនាចក្រស្គាល់ជនដែលកំពុងបង្រៀនទស្សនវិជ្ជា និងការប្រព្រឹត្តអំពើពុករលួយនៅក្នុងសាសនាចក្រ ។ ដើម្បីបង្ហាញអំពីគំនិតនេះ សូមចង្អុលបង្ហាញឃ្លា « គេជាពពកឥតទឹក ដែលត្រូវខ្យល់បក់ជាត់ទៅមក » និង « ជាដើមឈើឥតផ្លែ » នៅក្នុង យូដាស ១:១២ ។

- តើពួកគ្រូបង្រៀនក្លែងក្លាយអាចប្រៀបបាននឹងពពកឥតទឹក និងដើមឈើឥតផ្លែបានយ៉ាងដូចម្តេច ?

សូមបំបែកសិស្សជាក្រុមដែលមានគ្នាបី ឬបួននាក់ ។ សូមណែនាំឲ្យសិស្សអាន យូដាស ១:៨, ១០, ១៤–១៩ ជាមួយសមាជិកក្រុមរបស់ពួកគេ រកមើលបុគ្គលិកលក្ខណៈបន្ថែមទៀតនៃពួកគ្រូបង្រៀនក្លែងក្លាយ ។ សូមឲ្យសិស្សពិចារណាពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចនឹងត្រូវពន្យល់ថា « ជាន់ក្រោយបង្អស់ » (ខទី ១៨) សំដៅទៅលើគ្រាដែលយូដាសបានរស់នៅ ក៏ដូចជាថ្ងៃ ចុងក្រោយដែលយើងរស់នៅផងដែរ ។

បន្ទាប់ពីឲ្យពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យឡើងមក ក្តារខៀន ហើយសរសេរបុគ្គលិកលក្ខណៈនៃពួកគ្រូបង្រៀនក្លែងក្លាយដែលពួកគេបានរកឃើញ ។ បុគ្គលិកលក្ខណៈដែលសិស្សអាចសរសេររួមមានដូចតទៅ (អ្នកអាចនឹងត្រូវប្រើឃ្លាទាំងនេះមួយចំនួន ដើម្បីជួយសិស្សឲ្យយល់អំពីអ្វីដែលពួកគេបានអាន) ៖

បុគ្គលិកលក្ខណៈនៃពួកគ្រូបង្រៀនក្លែងក្លាយ

ធ្វើឲ្យខ្លួនស្មោកគ្រោកនឹងរឿងអសីលធម៌ (ខទី ៨)

មើលងាយសិទ្ធិអំណាច ហើយជេរប្រមាថដល់ពួកប្រសើរឧត្តម (ខទី ៨)

ជេរប្រមាថដល់ទាំងអ្វីៗ ដែលគេមិនយល់ (ខទី ១០)

បង្ខូចខ្លួនដោយរស់នៅតាមចំណេះដឹងខាងសាច់ឈាមដែលពួកគេមាន (ខទី ១០)

ប្រព្រឹត្តធ្វើដោយចិត្តល្មើស (ខទី ១៥)

ពោលពាក្យប្រមាថទាស់នឹងព្រះ (ខទី ១៥)

រអ៊ូរទាំ ហើយត្អូញត្អែរ (ខទី ១៦)

ដើរតាមតែសេចក្តីប៉ងប្រាថ្នារបស់ខ្លួន (ខទី ១៦)

អួតអាង (ខទី ១៦) ។

សរសើរមនុស្សដទៃដើម្បីបានប្រយោជន៍ផ្ទាល់ខ្លួន (ខទី ១៦)

ចំអកឲ្យសាសនាចក្ររបស់ព្រះអម្ចាស់ និងបទដ្ឋានរបស់សាសនាចក្រ (ខទី ១៨)

ញែកខ្លួនពួកគេចេញពីពួកអ្នកជឿ (ខទី ១៩)

គិតហើយធ្វើតាមអរបៀបខាងសាច់ឈាម (ខទី ១៩)

គ្មានព្រះវិញ្ញាណទេ (ខទី ១៩)

- តើការគ្មានព្រះវិញ្ញាណដឹកនាំទៅរកការអភិវឌ្ឍបុគ្គលិកលក្ខណៈ ដែលមាននៅលើក្តារខៀនយ៉ាងដូចម្តេច ?
- ហេតុអ្វីក៏វាសំខាន់ដើម្បីស្គាល់បុគ្គលិកលក្ខណៈរបស់ពួកគ្រូបង្រៀនក្លែងក្លាយ ?

សូមជួយសិស្សឲ្យយល់ថា ពុំមែនមនុស្សគ្រប់គ្នាដែលមានបុគ្គលិកលក្ខណៈមួយ ឬច្រើននៃបុគ្គលិកលក្ខណៈទាំងនេះ ឬអ្នកដែលបង្រៀនពុំត្រឹមត្រូវគឺជាគ្រូបង្រៀនក្លែងក្លាយទាំងអស់ ដូចដែលយូដាសបានពិពណ៌នានោះទេ ។ បុគ្គលបែបនេះអាចធ្វើខុសដោយអចេតនា នៅក្នុងការយល់ឃើញរបស់គាត់អំពីប្រធានបទមួយ ។ ប៉ុន្តែ បុគ្គលិកលក្ខណៈទាំងនេះអាចជួយយើងឲ្យស្គាល់ពីគ្រូបង្រៀនក្លែងក្លាយ ដែលមានបំណងធ្វើឲ្យសេចក្តីជំនឿ និងការគោរពប្រតិបត្តិរបស់មនុស្សដទៃចុះខ្សោយដោយបោកបញ្ឆោតពួកគេ ហើយលើកកម្ពស់អំពើអាក្រក់ឡើង ។

សូមឲ្យសិស្សរំឭកឡើងវិញនូវ យូដាស ១:១៧–១៨ ដោយស្ងៀមស្ងាត់ ។

- តើនរណាធ្លាប់ព្រមានដល់សមាជិកសាសនាចក្រ កាលពីមុនអំពីពួកគ្រូបង្រៀនក្លែងក្លាយ ?
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ទាក់ទងនឹងរបៀបដែលពួកសាវក និងពួកព្យាការីអាចជួយយើងនៅក្នុងការខិតខំរបស់យើងឲ្យតយុទ្ធទាស់នឹងពួកគ្រូបង្រៀនក្លែងក្លាយ ? (សិស្សអាចនឹងប្រើពាក្យផ្ទាល់ខ្លួន ប៉ុន្តែពួកគេគួរស្គាល់សេចក្តីពិតមួយដូចតទៅនេះ ៖ **ពួកសាវក និងពួកព្យាការីព្រមានយើង ហើយជួយយើងឲ្យស្គាល់ជន ដែលខិតខំធ្វើឲ្យសេចក្តីជំនឿ និងការគោរពប្រតិបត្តិរបស់យើងចុះខ្សោយ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា ប្រសាសន៍របស់លោកឆ្លុះបញ្ចាំងអំពីសេចក្តីពិតនេះយ៉ាងដូចម្តេច ។

« នៅថ្ងៃនេះ យើងព្រមានបងប្អូនថា មានពួកព្យាការី និងពួកគ្រូបង្រៀនក្លែងក្លាយជាច្រើន ហើយប្រសិនបើយើងពុំប្រយ័ត្នប្រយែងទេ សូម្បីតែជនដែលស្ថិតនៅក្នុងចំណោមសមាជិកស្មោះត្រង់ក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយក៏ដោយ ក៏នឹងធ្លាក់ខ្លួនក្លាយជាជនរងគ្រោះដោយការបោកបញ្ឆោតរបស់ពួកគេដែរ » (« Beware of False Prophets and False Teachers » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៦២) ។

- ដោយពិចារណាពីសេចក្តីពិតនេះ ហេតុអ្វីក៏វាសំខាន់ដើម្បីសិក្សាប្រសាសន៍របស់ពួកសាវក និងពួកព្យាការីទាំងឡាយ ?
- តើការបង្រៀនក្លែងក្លាយមួយចំនួន ដែលពួកព្យាការី និងពួកសាវកបច្ចុប្បន្នបានព្រមានដល់យើងមានអ្វីខ្លះ ?

យូដាស ១:២០–២៥

យូដាសទូន្មានពួកបរិសុទ្ធឲ្យស្ថាបនាជីវិតរបស់ពួកគេនៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយជួយសង្គ្រោះដល់មនុស្សដទៃ

ចូរសរសេរឃ្លាពុំពេញលេញដូចតទៅនេះនៅលើក្តារខៀន ៖ *យើងអាចបន្តស្មោះចំពោះសេចក្តីជំនឿតាមរយៈ . . .*

សូមអញ្ជើញសិស្សម្នាក់អាន យូដាស ១:២០–២១ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា យូដាសបានទូន្មានឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ ដើម្បីបន្តស្មោះចំពោះសេចក្តីជំនឿនោះ ។ អ្នកអាចនឹងត្រូវពន្យល់ថា « ទាំងអធិស្ឋាន ដោយនូវព្រះវិញ្ញាណបរិសុទ្ធ » មានន័យថា ការអធិស្ឋានដោយសុំជំនួយនៃការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។

- យោងតាម ខទី ២០–២១ តើអ្នកនឹងបំពេញឃ្លានៅលើក្តារខៀនយ៉ាងដូចម្តេច ? (របៀបមួយដែលសិស្សអាចបំពេញឃ្លានោះគឺដូចតទៅនេះ ៖ **យើងអាចបន្តស្មោះចំពោះសេចក្តីជំនឿដោយស្ថាបនាជីវិតរបស់យើង នៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ**) ។
- តើការធ្វើតាមការណែនាំបន្ថែមទៀតរបស់យូដាសនៅក្នុងខទី ២០–២១អាចជួយយើងឲ្យស្ថាបនាជីវិតរបស់យើង នៅលើដំណឹងល្អបានយ៉ាងដូចម្តេច ?
- ហេតុអ្វីការបន្តស្មោះចំពោះសេចក្តីជំនឿ គឺជាការខិតខំដ៏មានតម្លៃ ?
- តើការរស់នៅតាមពាក្យទូន្មានរបស់យូដាសធ្លាប់បានជួយអ្នក ឬមនុស្សដែលអ្នកស្គាល់ឲ្យបន្តស្មោះចំពោះសេចក្តីជំនឿយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យសរសេរអំពីវិធីមួយ ដែលពួកគេអាចកែលម្អ នៅក្នុងការធ្វើតាមពាក្យទូន្មានរបស់ប៉ុលនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬសៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។

សូមសង្ខេប យូដាស ១:២២–២៥ ដោយពន្យល់ថា យូដាសបានទូន្មានដល់សមាជិកសាសនាចក្រដ៏ស្មោះត្រង់ ឲ្យជួយមនុស្សដទៃដែលកំពុងដួលបញ្ហាខាងវិញ្ញាណ ដែលអាចនឹងកើតឡើង ដោយសារឥទ្ធិពលនៃពួកគ្រូបង្រៀនក្លែងក្លាយ ហើយបានថ្វាយការសរសើរចំពោះព្រះ ។

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយ ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

សូមចាត់វគ្គចំណេះចំណានខគម្ពីរខុសៗគ្នាមួយឲ្យសិស្សម្នាក់ៗ ។ សូមណែនាំសិស្សឲ្យសរសេរអំពីសាច់រឿងជីវិតពិតមួយនៅលើក្រដាសមួយសន្លឹក ដែលអាចមានន័យវគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ដែលបានចាត់ឲ្យពួកគេអាន: ។ បន្ទាប់ពីសិស្សបញ្ចប់ការសរសេរហើយ សូមប្រមូលសាច់រឿងរបស់ពួកគេ ។ សូមអានសាច់រឿងពីរបី ហើយអញ្ជើញសិស្សឲ្យចែកចាយអំពីរបៀបដែលគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៅក្នុងវគ្គចំណេះចំណានខគម្ពីរអាចយកទៅប្រើ ហើយអនុវត្តដល់សាច់រឿងនីមួយៗ ។ អ្នកអាចបង្ហាញសាច់រឿងមួយចំនួននៅដើម ឬ ចុងមេរៀននៅសប្តាហ៍ក្រោយ ។

មេរៀនសិក្សានៅផ្ទះ

ពេត្រុសទី២–យូដាស (មេរៀនទី ៣០)

ការរៀបចំសម្រាប់គ្រូបង្រៀន ដល់ សិស្ស ដែល សិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃព្រឹត្តិការណ៍ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ពេត្រុសទី២–យូដាស (មេរៀនទី ៣០) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និងគោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការសិស្សរបស់អ្នក ។

ថ្ងៃទី ១ (ពេត្រុសទី ២)

សាវកពេត្រុសបានសរសេរសំបុត្រនេះដល់ពួកបរិសុទ្ធ ដើម្បីជួយពួកគេដែលកំពុងជួបប្រទះ នឹងការបៀតបៀន ការសាកល្បង និងការក្បត់សាសនានៅក្នុងសាសនាចក្រ ។ នៅពេលសិស្សសិក្សាពាក្យសម្តីរបស់ពេត្រុស ពួកគេបានរៀនថា ពួកព្យាការីទទួលបទគម្ពីរតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ហើយថាពួកគ្រូក្លែងក្លាយខិតខំបោកបញ្ឆោតយើងឲ្យជឿថា អំពើបាបដឹកនាំទៅកេវស្សភាពដ៏ធំ ។ សិស្សក៏រៀនផងដែរថា យើងអាចរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ដោយរស់នៅក្នុងជីវិតដែលគោរពដល់ព្រះ ហើយទន្ទឹងរង់ចាំដោយចិត្តស្មោះចំពោះការយាងមករបស់ទ្រង់ ។

ថ្ងៃទី២ (យ៉ូហានទី ១)

នៅក្នុងយ៉ូហានទី ១ សិស្សបានរៀនថា ប្រសិនបើយើងទទួល ហើយធ្វើតាមការបង្រៀនរបស់ពួកព្យាការី និងពួកសាវក យើងអាចទទួលបានភាពស្និទ្ធស្នាលជាមួយព្រះវរបិតា និងព្រះរាជបុត្រា ។ លើសពីនេះទៀត ពួកគេបានរៀនថា នៅពេលពួកគេស្រឡាញ់ព្រះ យើងនឹងស្រឡាញ់ដល់មនុស្សដទៃទៀត ។

ថ្ងៃទី៣ (យ៉ូហានទី ២–យ៉ូហានទី ៣)

នៅក្នុងសំបុត្រពីរផ្សេងទៀតរបស់សាវកយ៉ូហានដល់ពួកបរិសុទ្ធ លោកបានបន្តបង្ហាញកង្វល់អំពីឥទ្ធិពលក្បត់សាសនានៅក្នុងសាសនាចក្រ ។ នៅក្នុងសំបុត្រទាំងពីរនេះ សិស្សបានរៀនថា នៅពេលយើងគោរពបទបញ្ញត្តិ ហើយប្រែងប្រយ័ត្ន យើងអាចបន្តរីករាយនូវពរជ័យនៃដំណឹងល្អដែលយើងបានទទួល ហើយប្រសិនបើយើងអនុវត្តតាមគោលលទ្ធិនៃព្រះគ្រីស្ទ នោះយើងនឹងមានព្រះវរបិតា និងព្រះរាជបុត្រាគង់នៅជាមួយយើង ។ សិស្សក៏រៀនផងដែរថា ការរស់នៅតាមដំណឹងល្អនាំមកនូវអំណរមិនត្រឹមតែចំពោះយើងប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះមនុស្សដទៃទៀតផងដែរ ហើយថាសមាជិកសាសនាចក្រគួរទទួលយក ហើយគាំទ្រពួកអ្នកបម្រើរបស់ព្រះអម្ចាស់គ្រប់រូប ។

ថ្ងៃទី៤ (យូដាស)

នៅពេលសិស្សសិក្សាសំបុត្ររបស់យូដាសដល់ពួកបរិសុទ្ធដែលកំពុងជួបការផ្ទុយយ៉ាងធ្ងន់ធ្ងរ ពួកគេបានរៀនថា ពួកសិស្សរបស់ព្រះយេស៊ូវគ្រីស្តគួរការពារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្តដោយចិត្តស្មោះប្រឆាំងទាស់នឹងការបង្រៀនក្លែងក្លាយ និងទម្លាប់ពុករលួយនានា ។ សិស្សក៏បានរៀនផងដែរថា ពួកសាវក និងពួកព្យាការីព្រមានយើង ហើយជួយយើងឲ្យស្គាល់ជនដែលខំធ្វើឲ្យសេចក្តីជំនឿ និងការគោរពប្រតិបត្តិរបស់យើងចុះខ្សោយ ហើយថាយើងអាចបន្តនៅពិតចំពោះសេចក្តីជំនឿដោយស្ថាបនាជីវិតរបស់យើងនៅលើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

សេចក្តីផ្តើម

សាវកពេត្រុសបានលើកទឹកចិត្តយើងឲ្យពង្រីកចំណេះដឹងរបស់ពួកគេ អំពីព្រះយេស៊ូវគ្រីស្ទ ដោយខិតខំប្រែក្លាយដូចជាទ្រង់ ។ លោកបានអះអាងដល់ពួកគេថា ការរីកចម្រើនខាងវិញ្ញាណនេះនឹងជួយដល់ « ដំណើរដែលទ្រង់ហៅ ហើយរើសតាំង[ពួកគេ] បានពិតប្រាកដឡើង » (ពេត្រុសទី២ ១:១០) ។

យោបល់សម្រាប់ការបង្រៀន

ពេត្រុសទី២ ១:១–១១

ពេត្រុសបង្រៀនអំពីរបៀបបានចំណែកជានិស្ស័យនៃព្រះរបស់ព្រះយេស៊ូវគ្រីស្ទ

កំណត់ចំណាំ ៖ នៅក្នុងការពិភាក្សាគោលការណ៍ និងវគ្គបទគម្ពីរខាងក្រោមនេះ សូមកុំពិភាក្សាប្រធានបទពាក់ព័ន្ធនឹងពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ និងគោលលទ្ធិនានាឡើយ ។

ពីមុនចាប់ផ្តើមថ្នាក់ សូមសរសេរឃ្លាខាងក្រោមនេះនៅលើ ក្តារខៀន (ឯកស្រង់ពី« The Will Within » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៧ ទំព័រ ៦៨) ៖

> *« ការកិច្ចរបស់យើងគឺដើម្បីក្លាយជាមនុស្សដ៏ប្រសើរបំផុត » (ប្រធាន ជូម៉ាស អេស ម៉ូនសុន) ។*

សូមចែកសិស្សជាគូៗ ។ សូមអញ្ជើញពួកគេអានឃ្លានៅលើក្តារខៀន ហើយពិភាក្សាសំណួរខាងក្រោម ជាមួយនឹងដៃគូរបស់ខ្លួន ៖

- តើអ្នកគិតថា ប្រធាន ម៉ូនសុន ចង់មានន័យដូចម្តេចដោយមានប្រសាសន៍ថា ឲ្យ « ក្លាយជាមនុស្សដ៏ប្រសើរបំផុត » ?
- ហេតុអ្វីក៏អ្នកគិតថា វាសំខាន់ដើម្បីក្លាយជាមនុស្សដ៏ប្រសើរបំផុត ?
- តើអ្វីទៅដែលរារាំងយើងពុំឲ្យក្លាយជាមនុស្សដ៏ប្រសើរបំផុត ?

នៅពេលសិស្សសិក្សា ពេត្រុសទី២ ១ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយ ដែលអាចជួយឲ្យពួកគេស្គាល់អំពីរបៀបដើម្បីក្លាយជាមនុស្សដ៏ប្រសើរបំផុត ។

សូមសង្ខេប ពេត្រុសទី ២ ១:១–២ ដោយពន្យល់ថា ពេត្រុសបានសរសេរទៅសមាជិកសាសនាចក្រដែលបានទទួលសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែត្រូវឈ្លួងឲ្យត្រឡប់ទៅផ្លូវដ៏អាក្រក់នៃលោកិយវិញ ។

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ១:៣–៤ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថាប៉ុលបានបង្រៀនអ្វីខ្លះ ដើម្បីជួយពួកបរិសុទ្ធឲ្យនៅបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។

- យោងតាមខគម្ពីរទាំងនេះ តើពេត្រុសបានបង្រៀនពួកបរិសុទ្ធឲ្យធ្វើអ្វីខ្លះ ?
- តើការ « បានចំណែកជានិស្ស័យនៃព្រះ » មានន័យដូចម្តេច ? (ពេត្រុសទី២ ១:៤) ។

សូមអញ្ជើញសិស្សឲ្យអាន ពេត្រុសទី២ ១:៥–៧ ដោយស្ងាត់ស្ងៀមរកមើលលក្ខណៈនៃព្រះយេស៊ូវគ្រីស្ទដែលពេត្រុសបានអញ្ជើញពួកបរិសុទ្ធឲ្យអភិវឌ្ឍ ។ បន្ទាប់មក សូមឲ្យសិស្សរសេរលក្ខណៈដែលពួកគេរកឃើញនៅលើក្តារខៀន ។ សូមពិចារណាអញ្ជើញសិស្សឲ្យរកមើលនិយមន័យនៃលក្ខណៈទាំងនេះនៅក្នុងវចនានុក្រមដែលពួកគេចង់យល់កាន់តែច្បាស់ ។

សូមអញ្ជើញសិស្សឲ្យគិតពីគំរូ កាលដែលព្រះអង្គសង្គ្រោះបានបង្ហាញអំពីលក្ខណៈដ៏ទេវភាពមួយ ។ សូមឲ្យសិស្សបីបួននាក់ប្រាប់គំនិតរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

សូមសរសេរគោលការណ៍ពុំពេញលេញដូចតទៅនេះនៅលើក្តារខៀន ៖ *នៅពេលយើងអភិវឌ្ឍលក្ខណៈដ៏ទេវភាពនៅក្នុងខ្លួនយើង នោះយើងអាច . . .*

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ១:៨–៩ឲ្យឮៗ ។ សូមអញ្ជើញសិស្សឲ្យផ្ទៀងតាមរកមើលពរជ័យមួយដែលយើងអាចទទួលបាន នៅពេលយើងអភិវឌ្ឍលក្ខណៈមកពីព្រះរបស់ព្រះអង្គសង្គ្រោះ ។

- តើយើងអាចទទួលបានពរជ័យអ្វីខ្លះ នៅពេលយើងអភិវឌ្ឍលក្ខណៈដ៏ទេវភាព ? (បន្ទាប់ពីសិស្សឆ្លើយហើយ សូមបំពេញឃ្លានៅលើក្តារខៀនដែលមានអត្ថន័យដូចតទៅ ៖ **នៅពេលយើងអភិវឌ្ឍលក្ខណៈដ៏ទេវភាពនៅក្នុងខ្លួនយើង នោះយើងអាចស្គាល់ព្រះយេស៊ូវគ្រីស្ទ**) ។
- ហេតុអ្វីអ្នកគិតថា ការអភិវឌ្ឍលក្ខណៈដ៏ទេវភាពជួយយើងឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់អាន ពេត្រុសទី២ ១:១០–១១ ឲ្យឮៗ ។ ចុះសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលពរជ័យមួយទៀតដែលអាចកើតមានចំពោះជនដែលឧស្សាហ៍នៅក្នុងការអភិវឌ្ឍលក្ខណៈដ៏ទេវភាពទាំងឡាយ ។

- តើពរជ័យអ្វីអាចកើតមានចំពោះជន ដែលឧស្សាហ៍នៅក្នុងការអភិវឌ្ឍក្ខណៈដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ? (សូមពន្យល់ថា ឃ្លា « ធ្វើឲ្យដំណើរដែលទ្រង់ហៅ ហើយរើសតាំងអ្នករាល់គ្នាបានពិតប្រាកដឡើង » [ខទី ១០] មានន័យថា ការទទួលបាននៅក្នុងជីវិតនេះនូវការអះអាងរបស់ព្រះថា អ្នកនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ពេត្រុសក៏ហៅវាថាជាការ « មានការទំនាយដ៏ពិតជាង » ផងដែរ [ពេត្រុសទី២ ១:១៩] ។ សូមមើលផងដែរ គ. និង ស. ១៣១:៥) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះអំពីហេតុផលដែលយើងគួរមានភាពឧស្សាហ៍នៅក្នុងការអភិវឌ្ឍសក្តានុពលដ៏ទេវភាពរបស់យើង ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់នូវគោលការណ៍ដូចតទៅ ៖ **ប្រសិនបើយើងឧស្សាហ៍នៅក្នុងការអភិវឌ្ឍសក្តានុពលដ៏ទេវភាពរបស់យើងនៅក្នុងជីវិតនេះ នោះយើងអាចទទួលបានការអះអាងរបស់ព្រះអំពីជីវិតដ៏នៅអស់កល្បជានិច្ច ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីមនុស្សដែលពួកគេស្គាល់ ដែលបានខិតខំឧស្សាហ៍ព្យាយាមអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទ ។

- តើមនុស្សដែលអ្នកបានគិតដល់ធ្លាប់អភិវឌ្ឍលក្ខណៈដូចជាព្រះគ្រីស្ទមួយណាដែរ ?
- តើការខិតខំ និងលក្ខណៈរបស់ពួកគេបានជួយពួកគេ និងមនុស្សដទៃទៀតនៅជុំវិញខ្លួនពួកគេតាមរបៀបណា ?

អ្នកគួរចែកចាយទីបន្ទាល់របស់អ្នកថា ការអភិវឌ្ឍលក្ខណៈដ៏ទេវភាពជួយយើងឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទ ហើយរៀបចំខ្លួនយើងឲ្យទទួលជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេនូវលក្ខណៈដ៏ទេវភាពមួយដែលពួកគេចង់អភិវឌ្ឍបំផុត ។ សូមឲ្យពួកគេសរសេរសកម្មភាពជាក់លាក់មួយដែលពួកគេអាចធ្វើដើម្បីអភិវឌ្ឍលក្ខណៈនោះ ។

មេរៀនបន្ទាប់ (វិវរណៈ ១–១១)

ចូរសួរដល់សិស្សប្រសិនបើពួកគេធ្លាប់ឮពាក្យអាប៉ូកាលីព ។ សូមពន្យល់ថា គម្ពីរវិវរណៈជារឿយៗត្រូវបានហៅថា អាប៉ូកាលីព ដែលភាសាក្រិកមានន័យថា « ការពន្យល់ប្រាប់ » ។ នៅក្នុងគម្ពីរវិវរណៈ សាវកយ៉ូហានបានពិពណ៌នាអំពីការនិមិត្តមួយដែលលោកបានឃើញ ហើយវាមាននូវការព្យាករជាច្រើនអំពីជំនាន់របស់យើង និងព្រឹត្តិការណ៍នាពេលអនាគត រួមទាំងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ និងចុងបញ្ចប់នៃផែនដីផងដែរ ។ ការនិមិត្តរបស់យ៉ូហានភាគច្រើនរួមមាននូវនិមិត្តសញ្ញា ។ សូមអញ្ជើញសិស្សឲ្យចាំមើលនិមិត្តសញ្ញាដែលបង្ហាញអំពីជ័យជំនះចុងក្រោយនៃសេចក្តីល្អ ដែលយកឈ្នះលើសេចក្តីអាក្រក់ នៅពេលពួកគេសិក្សាគម្ពីរវិវរណៈ ។

សេចក្តីផ្តើមអំពី

វិវរណៈរបស់យ៉ូហាន

ហេតុអ្វីត្រូវសិក្សាគម្ពីរនេះ ?

ដូចដែល « សេចក្តីដែលព្រះយេស៊ូវគ្រីស្ទបានបើកឲ្យឃើញ » (វិវរណៈ ១:១) គម្ពីរនេះពេលខ្លះត្រូវបានហៅថាអាប៉ូកាលីព ដែលភាសាក្រិកមានន័យថា វិវរណៈ ការបើកបង្ហាញ ឬការបើកឲ្យឃើញនៃអ្វីដែលបានលាក់ទុក (សូមមើល Bible Dictionary « Revelation of John ») ។ គម្ពីរនេះគឺជាការបើកសម្តែងមួយពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ និងជាវិវរណៈនៃសិទ្ធិអំណាច ព្រះចេស្តា និងតួនាទីដ៏ឧត្តុង្គឧត្តមរបស់ទ្រង់ នៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតា ។ គម្ពីរនេះក៏បើកសម្តែងពីព័ត៌មានដ៏សំខាន់ជាច្រើនអំពីព្រឹត្តិការណ៍នានា ដែលដឹកនាំឆ្ពោះទៅការយាងមកជាលើកទីពីរ និងសហស័ក្ស ។

ការសិក្សាគម្ពីរវិវរណៈអាចជួយសិស្សឲ្យទទួលបានការយល់ដឹងដ៏ជ្រាលជ្រៅអំពីព្រះរាជបុត្រានៃព្រះ ដែលមានព្រះជន្មឡើងវិញ ហើយរុងរឿង និងទំនាក់ទំនងរបស់ទ្រង់ជាមួយនឹងកូនចៅរបស់ព្រះនៅគ្រប់ជំនាន់នៃប្រវត្តិសាស្ត្រលើផែនដីនេះ ជាពិសេសនៅថ្ងៃចុងក្រោយនេះ ។ គម្ពីរនេះបន្ថែមសារលិខិតនៃសេចក្តីសង្ឃឹមមួយដល់មនុស្សសុចរិត ហើយអាចលើកទឹកចិត្តសិស្សឲ្យបន្តស្មោះត្រង់ចំពោះទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះនៅកណ្តាលការបៀតបៀន និងការសោកល្បង ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

សាវ័កយ៉ូហាន ដែលជាសិស្សសំណប់របស់ព្រះយេស៊ូវគ្រីស្ទ គឺជាអ្នកសរសេរគម្ពីរនេះ ។ ព្រះគម្ពីរមេរៀនបញ្ជាក់ថា យ៉ូហានត្រូវបានតែងតាំងពីមុនដើម្បីសរសេររឿងដែលបានកត់ត្រានៅក្នុងគម្ពីរវិវរណៈ (សូមមើល នីហ្វៃទី១ ១៤:១៨–២៧, អេធើរ ៤:១៦) ។

តើនៅពេលណា និង នៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

គម្ពីរវិវរណៈត្រូវបានសរសេរឡើងនៅគ្រាមួយ ដែលពួកគ្រីស្ទានកំពុងប្រឈមនឹងការបង្រៀនខុសឆ្គង ភាពព្រងើយកន្តើយ និងការបៀតបៀនដ៏ធ្ងន់ធ្ងរ (សូមមើល វិវរណៈ ១:៩, ២:៤, ១០, ១៤–១៥, ៣:១៦, ៦:៩) ។ ការបៀតបៀននេះទំនងជាកើតឡើងដោយសារពួកមន្ត្រីរ៉ូមនៅក្នុងពីរទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទីមួយ គ.ស. ។ យ៉ូហានបានសរសេរចេញពីភោះប៉ាត់ម៉ុស នៅសមុទ្រអេហ្គាន ប្រមាណជា (១០០ គីឡូម៉ែត្រ) ភាគនិរតីនៃក្រុងអេភេសូរ (សូមមើល វិវរណៈ ១:៩) ។

តើគម្ពីរនេះត្រូវបានសរសេរឡើងសម្រាប់នរណា ហើយតើហេតុអ្វីដែរ ?

យ៉ូហានបានសរសេរសារលិខិតមួយអំពីសេចក្តីសង្ឃឹម និងការលើកទឹកចិត្តដល់ពួកបរិសុទ្ធនៅជំនាន់របស់លោក (សូមមើល វិវរណៈ ១:៤, ១១) និងជនដែលនៅថ្ងៃចុងក្រោយ ។ ជំពូកបីដំបូងនៃវិវរណៈត្រូវបានលើកឡើងជាក់លាក់ទៅសាខាទាំងប្រាំពីររបស់សាសនាចក្រនៅអាស៊ីតូច (សូមមើល វិវរណៈ ១:៤, ១១, ២–៣) ។ ដោយសារមានការបៀតបៀនដ៏ខ្លាំងនោះពួកបរិសុទ្ធត្រូវការសារលិខិតលើកទឹកចិត្តយ៉ាងខ្លាំង ដែលមាននៅក្នុងគម្ពីរវិវរណៈ ។ លើសពីនេះទៀត ព្យាការីនីហ្វៃ បានថ្លែងទីបន្ទាល់ថា « ព្រះទ្រង់បានតែងតាំងសាវក » យ៉ូហានឲ្យសរសេរអំពីចុងបញ្ចប់នៃពិភពលោកនេះ (នីហ្វៃទី១ ១៤:២៥) ហើយថាសម្តីរបស់លោកនឹងចេញទៅដល់ពួកសាសន៍ដទៃ និងពួជពង្សសំណល់នៃអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ (សូមមើល នីហ្វៃទី១ ១៣:២០–២៤, ៣៨, ១៤:១៩–២៧) ។

តើមានលក្ខណៈពិសេសអ្វីខ្លះ នៅក្នុងគម្ពីរនេះ ?

ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា « គម្ពីរវិវរណៈគឺជាគម្ពីរដ៏ច្បាស់មួយដែលព្រះពុំធ្លាប់បណ្តាលឲ្យសរសេរពីមុនមក » (នៅក្នុង *History of the Church* ៥:៣៤២) ។ ទោះជាមាននូវការប្រៀបធៀបយ៉ាងបិនប្រសប់ និងរូបតំណាងដែលពុំតែងតែងាយឲ្យអ្នកអាននៅក្នុងសម័យទំនើបយល់ក្តី ក៏ប្រធានបទនៃគម្ពីរនេះសាមញ្ញ ហើយបំផុសគំនិត ។

យ៉ូហានបានពិពណ៌នាពីលក្ខខណ្ឌនៃសាសនាចក្រនៅក្នុងសម័យរបស់លោក (សូមមើល វិវរណៈ ២–៣) ហើយសរសេរអំពីព្រឹត្តិការណ៍នានាពីអតីតកាល និងនៅអនាគត (សូមមើល វិវរណៈ ៤–២២) ។ គម្ពីរវិវរណៈមាននូវវគ្គមួយក្នុងចំណោមវគ្គមួយចំនួននៅក្នុងបទគម្ពីរ ដែលរៀបរាប់ពីសង្គ្រាមនៅស្ថានសួគ៌ (សូមមើល វិវរណៈ ១២:៧–១១) ហើយបង្ហាញនូវទិដ្ឋភាពទូទៅដ៏បំផុសគំនិតមួយពីប្រវត្តិសាស្ត្រនៃពិភពលោកដោយផ្តោតជាពិសេសលើថ្ងៃចុងក្រោយ និងសហស័ក្ស ។ ប្រធានបទដ៏សំខាន់រួមមានតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងការអនុវត្តផែនការរបស់ព្រះ ព្រះហស្តរបស់ព្រះនៅក្នុងប្រវត្តិសាស្ត្ររបស់ផែនដីនេះ ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ និងការបំផ្លាញរបស់អារក្ស និងការសន្យាថា នៅទីបំផុតផែនដីនឹងក្លាយទៅជានគរសេឡេស្ទាល ។ គម្ពីរនេះក៏ពន្យល់ផងដែរថា នឹងមាន« ជ័យជំនះជាអចិន្ត្រៃយ៍នៃសេចក្តីល្អឈ្នះលើសេចក្តីអាក្រក់ . . . [និង] នៃនគរព្រះឈ្នះលើនគរមនុស្ស និងសាតាំង » (Bible Dictionary « Revelation of John ») ។

គម្រោង

វិវរណៈ ១–៣ យ៉ូហានឃើញការនិមិត្តមួយអំពីព្រះយេស៊ូវគ្រីស្ទ ។ លោកសរសេរសារលិខិតដាច់ដោយឡែកទៅព្រះវិហារទាំងប្រាំពីរនៅតំបន់អាស៊ី សារលិខិតទាំងនេះរួមមាននូវការសរសើរ ការទូន្មាន និងការសន្យាដល់ពួកបរិសុទ្ធស្មោះត្រង់នៅក្នុងសាខានីមួយៗ ។

វិវរណៈ ៤–១១ យ៉ូហានឃើញការនិមិត្តមួយអំពីកាលដែលព្រះគង់លើបល្ល័ង្កក្នុងនគរសេឡេស្ទាល កូនចៀមនៃព្រះ និងសៀវភៅមួយបានបិទត្រាដោយត្រាប្រាំពីរ ។ យ៉ូហានឃើញការនិមិត្តទាក់ទងនឹងការបើកត្រានីមួយៗនៃត្រាទាំងប្រាំពីរនោះ ។ ជនដែលមានត្រារបស់ព្រះនៅលើថ្ងាសនឹងទទួលបានការការពាររបស់ព្រះនៅថ្ងៃចុងក្រោយ ។ យ៉ូហានឃើញពីសង្គ្រាម ជំងឺ និងព្រឹត្តិការណ៍ជាច្រើនផ្សេងទៀតនៅថ្ងៃចុងក្រោយ ដែលនឹងកើតឡើងពីមុនការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។

វិវរណៈ ១២–១៦ យ៉ូហានឃើញការនិមិត្តមួយពីសង្គ្រាមនៅស្ថានសួគ៌ពីមុនជីវិតនៅលើផែនដី និងការបន្តនៃសង្គ្រាមនោះនៅលើផែនដី ។ លោកបង្រៀនថាកម្លាំងអាក្រក់ខំព្យាយាមបំផ្លាញនគរព្រះនៅលើផែនដី ។ នៅថ្ងៃចុងក្រោយ ដំណឹងល្អនឹងត្រូវបានស្តារឡើងវិញនៅលើផែនដីក្នុងភាពពេញលេញ ដោយការងារបម្រើរបស់ទេវតា ។ ការរៀបចំនានានឹងត្រូវធ្វើឡើងសម្រាប់សង្គ្រាមនៃអើម៉ាគេដូន ។

វិវរណៈ ១៧–២២ បាប៊ីឡូនខាងវិញ្ញាណនឹងរីកសាយនៅទូទាំងផែនដី ។ បន្ទាប់ពីពួកបរិសុទ្ធដ៏សុចរិតបានប្រមូលផ្តុំគ្នា នោះបាប៊ីឡូននឹងដួលរលំ ហើយនឹងទួញយំដោយពួកអ្នកគាំទ្ររបស់វា ។ មនុស្សសុចរិតនឹងបានគេអញ្ជើញឲ្យទៅពិធីមង្គលរបស់កូនចៀមនៃព្រះ ។ សាតាំងនឹងត្រូវបានជាប់ច្រវាក់ សហសវត្សរ៍នឹងចាប់ផ្តើម ហើយព្រះគ្រីស្ទនឹងគ្រងរាជ្យដោយផ្ទាល់នៅលើផែនដីនេះ ។ ពួកអ្នកស្លាប់នឹងទទួលការកាត់សេចក្តី ។ ផែនដីនឹងទទួលបានសិរីល្អសេឡេស្ទាលរបស់វា ។

វិវរណៈ ១

សេចក្តីផ្តើម

កាលនៅលើកោះប៉ាត់ម៉ុស យ៉ូហានបានសរសេរសំបុត្រមួយអំពីការលើកទឹកចិត្តទៅពួកជំនុំទាំងប្រាំពីររបស់សាសនាចក្រដោយពិពណ៌នានូវវិវរណៈដែលលោកបានទទួល ។ យ៉ូហានបានថ្លែងទីបន្ទាល់អំពីអ្វីដែលទេវតា និងព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលដល់លោក ។ យ៉ូហានក៏បានកត់ត្រាព័ត៌មានលម្អិតអំពីការនិមិត្តរបស់លោកអំពីព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទផងដែរ ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ១:១–១១

យ៉ូហានបានថ្លែងទីបន្ទាល់អំពីការនិមិត្តរបស់លោក

ពីមុនថ្នាក់ចាប់ផ្តើម សូមដាក់វត្ថុមួយនៅលើតុ ឬកៅអីនៅពីមុខសិស្សក្នុងថ្នាក់ ។ សូមគ្របវត្ថុនោះ ដើម្បីកុំឲ្យសិស្សដឹងថាវាគឺជាអ្វី ។ នៅពេលថ្នាក់ចាប់ផ្តើម សូមអញ្ជើញសិស្សឲ្យទស្សន៍ទាយថាវត្ថុនោះគឺជាអ្វី ។ បន្ទាប់ពីសិស្សបីឬនួនាក់បានទស្សន៍ទាយរួច សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកក្តារខៀន ហើយឲ្យគាត់បើកមើលវត្ថុនោះឲ្យឃើញតែម្នាក់ឯងបានហើយ ។ សូមឲ្យសិស្សនោះពិពណ៌នាអំពីវត្ថុនោះប្រាប់ដល់សិស្សក្នុងថ្នាក់ ។

- តើសិស្សដែលបានពិពណ៌នាអំពីវត្ថុនោះអាចតំណាងឲ្យតួនាទីមួយរបស់ពួកព្យាការី និងពួកសាវកបានយ៉ាងដូចម្តេច ?

សូមឲ្យសិស្សនោះទៅកាន់កន្លែងអង្គុយវិញ ។ សូមអញ្ជើញសិស្សឲ្យបើកទៅគម្ពីរវិវរណៈ ។ សូមពន្យល់ថា គម្ពីរនេះក៏ត្រូវបានគេស្គាល់ថាជាអាប៉ូកាលីពដែរ ហើយនៅក្នុងភាសាក្រិកមានន័យថា វិវរណៈ ការពន្យល់ប្រាប់ ឬការបើកសម្តែងអំពីអ្វីដែលបានលាក់បាំង ។ នៅក្នុងគម្ពីរនេះ សាវកប៉ុលបានកត់ត្រាទុកនូវសេចក្តីពិតទាំងឡាយ ដែលត្រូវបានបើកសម្តែងមកកាន់លោកអំពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ តួនាទីរបស់ទ្រង់នៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ព្រឹត្តិការណ៍ដែលនឹងនាំឆ្ពោះទៅកាន់ការយាងមកជាលើកទីពីរ និងរជ្ជកាលនៃសហស្សវត្សរ៍របស់ទ្រង់ ។

សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិត ដែលត្រូវបានបើកសម្តែងដល់យ៉ូហាន នៅពេលពួកគេសិក្សាគម្ពីរវិវរណៈ ។

សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស៊្មីធ វិវរណៈ ១:១–៣ ឲ្យឮៗ ដែលមាននៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថាយ៉ូហានបានបង្រៀនអ្វីខ្លះអំពីវិវរណៈដែលលោកបានទទួល ។

- ហេតុអ្វីវិវរណៈនេះត្រូវបានប្រទានឲ្យទៅយ៉ូហាន ?
- តើយ៉ូហានចង់ឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះជាមួយនឹងវិវរណៈនេះ ?

ដើម្បីជួយសិស្សឲ្យយល់អំពីហេតុផល ដែលយ៉ូហានបានលើកឡើងទាំងជនដែលស្តាប់ឮពាក្យសម្តីរបស់លោក និងជនដែលអានពាក្យសម្តីរបស់លោក សូមពន្យល់ថា នៅក្នុងជំនាន់របស់យ៉ូហាន មានពួកបរិសុទ្ធជាច្រើនពុំចេះអានអក្សរទេ ដូច្នេះពួកគេបានស្តាប់គម្ពីរវិវរណៈតាមរយៈការស្តាប់មនុស្សដទៃទៀតអានគម្ពីរនេះឮៗ ។

- តើយ៉ូហានបាននិយាយអ្វីខ្លះ អំពីមនុស្សដែលនឹងអាន ស្វែងរកការយល់ដឹង ហើយគោរព (ប្រតិបត្តិតាម) ការបង្រៀនដែលបានកត់ត្រានៅក្នុងគម្ពីរវិវរណៈនេះ ?
- តើអ្នកអាចសង្ខេបការបង្រៀនរបស់យ៉ូហាននៅក្នុង វិវរណៈ ១:៣ទៅជាគោលការណ៍មួយបានយ៉ាងដូចម្តេច ? (សិស្សគួរស្គាល់គោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងអាន ស្វែងយល់ដឹង ហើយគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ យើងនឹងមានពរ**) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១:៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ូហានបាននិយាយអំពីនរណាខ្លះនៅក្នុងសំបុត្ររបស់លោក ។

- តើយ៉ូហានបាននិយាយអំពីនរណាខ្លះនៅក្នុងសំបុត្ររបស់លោក ? (សូមពន្យល់ថា « ពួកជំនុំទាំង ៧ នៅស្រុកអាស៊ី » សំដៅទៅលើក្រុមជំនុំទាំងប្រាំពីរក្នុងសាសនាចក្រ ប្រៀបបាននឹងវួដ និងសាខានៅថ្ងៃសព្វថ្ងៃនេះដែរ ដែលមានទីតាំងនៅក្នុងតំបន់ភាគខាងលិចនៃប្រទេសតួគីនាពេលបច្ចុប្បន្ននេះ ។ « ព្រះវិញ្ញាណទាំង ៧ » សំដៅទៅលើថ្នាក់ដឹកនាំនៃក្រុមជុំនំទាំងនោះ) ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ១:៥–៨ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលអ្វីដែលយ៉ូហាន បាទីស្ទ ចង់ឲ្យមនុស្សដឹងអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមពិចារណាអញ្ជើញសិស្សឲ្យគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើយ៉ូហានចង់ឲ្យពួកជំនុំទាំងប្រាំពីរនោះដឹងអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ?
- តើឃ្លាណាមួយអំពីព្រះយេស៊ូវគ្រីស្ទក្នុងខគម្ពីរទាំងនេះ មានអត្ថន័យពិសេសចំពោះអ្នក ? ហេតុអ្វី ? (អ្នកគួរចង្អុលបង្ហាញថា អាល់ផា និង អូមេកា គឺជាតួអក្សរដំបូង និងចុងក្រោយបង្អស់នៃតួអក្សររបស់ក្រិក ។ ចំណងជើងនេះចង្អុលបង្ហាញថា តួនាទីរបស់ព្រះគ្រីស្ទនៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌រួមមានអ្វីៗទាំងអស់ តាំងពីដំបូងរហូតដល់ចុងបញ្ចប់ ។ [សូមមើលផងដែរ វិវរណៈ ២២:១៣]) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១:៩–១១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ូហានៅទីណាពេលលោកបានទទួលវិវរណៈនេះ និងទីតាំងនៃពួកជំនុំទាំងប្រាំពីរ ។

- តើយ៉ូហាននៅទីណាពេលលោកបានទទួលវិវរណៈនេះ ? តើពួកក្រុមជំនុំទាំងប្រាំពីរនោះមានទីតាំងនៅទីណា ?

សូមពិចារណាឲ្យសិស្សបើកទៅផែនទីក្នុងព្រះគម្ពីរប៊ីប លេខ ១៣ « ដំណើររបស់សាវកប៉ុលទៅផ្សាយសាសនា » ដើម្បីរកប៉ាត់ម៉ុស និងក្រុងមួយចំនួនក្នុងចំណោមក្រុងទាំងប្រាំពីរដែលមាននៅក្នុង វិវរណៈ ១:១១ ។

ដើម្បីជួយសិស្សឲ្យយល់អំពីទិដ្ឋភាពនៃប៉ាតម៉ុស សូមពិចារណាអញ្ជើញពួកគេឲ្យស្វែងរកឃ្លាបថតអំពីព្រះគម្ពីរប៊ីបទី ៣២ « កោះប៉ាត់ម៉ុស » ។

- យោងតាម វិវរណៈ ១:៩ ហេតុអ្វីយ៉ូហាននៅលើកោះប៉ាត់ម៉ុស ?

សូមពន្យល់ថា យ៉ូហានបានទទួលវិវរណៈនេះនៅក្នុងគ្រាលំបាកមួយសម្រាប់សមាជិកសាសនាចក្រ ។ នៅក្នុងគ្រានេះ មានការបៀតបៀនដ៏ធំមកលើពួកបរិសុទ្ធ ហើយមានការក្បត់សាសនា និងការបែកបាក់ផ្សេងៗនៅក្នុងចំណោមសមាជិកសាសនាចក្រ ។ លើសពីនេះទៀត ពួកសាវកគ្រប់រូបលើកលែងតែយ៉ូហានត្រូវបានគេសម្លាប់ ។ គម្ពីរវិវរណៈប្រហែលជាសរសេរនៅក្នុងសម័យនៃស្តេចរ៉ូមឈ្មោះ ដូមីត ដែលបានបង្កើតការថ្វាយបង្គំដល់ស្តេចឡើងវិញនៅទូទាំងអាណាចក្ររ៉ូម ហើយបាននិរទេស ឬបានសម្លាប់ជនដែលមិនព្រមថ្វាយបង្គំរូបព្រះ ដែលបានអនុម័តដោយរដ្ឋាភិបាលរបស់រ៉ូម ។ មានមនុស្សជាច្រើនជឿថា យ៉ូហានត្រូវបានគេនិរទេសទៅកោះប៉ាតម៉ុសដោយសារតែហេតុផលនោះ ។

- យោងតាម វិវរណៈ ១:១០ តើយ៉ូហានបានពិពណ៌នាអំពីស្ថានភាពរបស់លោក កាលលោកបានទទួលវិវរណៈនេះយ៉ាងដូចម្តេច ?
- តើអ្នកគិតថាឃ្លា « ខ្ញុំបានត្រឡប់ជានៅដោយវិញ្ញាណ » មានអត្ថន័យដូចម្តេចដែរ ?
- យោងតាម ខទី ១១តើព្រះយេស៊ូវគ្រីស្ទបានបង្គាប់យ៉ូហានឲ្យធ្វើអ្វីខ្លះ ?

សូមពន្យល់ថា យើងរៀននៅក្នុងព្រះគម្ពីរមរមនថា នីហ្វៃមានការនិមិត្តមួយស្រដៀងគ្នានឹងការនិមិត្តរបស់យ៉ូហានដែរ ។ នីហ្វៃបានឃើញព្រឹត្តិការណ៍នៃថ្ងៃចុងក្រោយ (រួមបញ្ចូលទាំងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ សហស្សវត្សរ៍ និងការបញ្ចប់កិច្ចការរបស់ព្រះនៅលើផែនដីនេះ) ប៉ុន្តែលោកត្រូវបានបង្គាប់កុំឲ្យសរសេរអំពីវា ដោយសារយ៉ូហានត្រូវបានតែងតាំងពីមុនផែនដីដើម្បីធ្វើរឿងនេះ (សូមមើល នីហ្វៃទី១ ១៤:២៤–២៥) ។

- ហេតុអ្វីវាមានសារៈសំខាន់សម្រាប់យើង ដើម្បីសិក្សាពាក្យពេចន៍របស់យ៉ូហាននៅក្នុងវិវរណៈ ?

នៅពេលសិស្សបន្តសិក្សាគម្ពីរវិវរណៈ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតអំពីថ្ងៃចុងក្រោយ ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ សហស្សវត្សរ៍ និងការបញ្ចប់កិច្ចការរបស់ព្រះនៅលើផែនដីនេះ ។

វិវរណៈ:១:១២–២០

យ៉ូហានឃើញព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទនៅក្នុងការនិមិត្តមួយ

ដើម្បីណែនាំអំពីគំនិតនៃនិមិត្តសញ្ញា សូមបង្ហាញ (ឬគូរនៅលើក្តារខៀន) រូបភាពនៃសញ្ញាមួយចំនួនតូចដែលគេអាចស្គាល់ទូទៅនៅក្នុងវប្បធម៌របស់អ្នក ដែលអាចងាយយល់ដោយពុំចាំបាច់ប្រើពាក្យ ។ ឧទាហរណ៍ អ្នកអាចដាក់បង្ហាញសញ្ញាចរាចរ ឬ សញ្ញាហាមឃាត់ ។ សូមឲ្យសិស្សពន្យល់អំពីគោលបំណងនៃសញ្ញាទាំងនេះ ។

សូមពន្យល់ថា នៅក្នុងគម្ពីរវិវរណៈ យ៉ូហានបានប្រើនិមិត្តសញ្ញា និងរូបភាពដើម្បី បង្រៀននូវសារលិខិតដ៏សំខាន់អំពីដំណឹងល្អ ។ និមិត្តសញ្ញានានាអាចជាឧបករណ៍បង្រៀនដ៏មានឥទ្ធិពល ដោយសារវាអាចបញ្ជូនព័ត៌មានទៅកាន់មនុស្សនៅក្នុងជំនាន់ និងវប្បធម៌ខុសៗគ្នា ។ វាក៏អាចបញ្ជូនសារលិខិតខុសគ្នាមួយចំនួនតូចផងដែរ ។

សូមចែកសិស្សទៅជាគូ ។ សូមអញ្ជើញគូនីមួយៗឲ្យអាន វិវរណៈ ១:១២–១៨ ឮៗរួមគ្នារកមើលនិមិត្តសញ្ញាដែលយ៉ូហានបានប្រើដើម្បីពិពណ៌នាអំពីវិវរណៈរបស់លោក ។ អ្នកគួរឲ្យយោបល់សិស្សគូសចំណាំនិមិត្តសញ្ញាដែលពួកគេបានអាន ។

- តើយ៉ូហានបានប្រើនិមិត្តសញ្ញាអ្វី ដើម្បីពិពណ៌នាអំពីវិវរណៈរបស់លោក ?

សូមផ្តល់ ឯកសារ នៃតារាងខាងក្រោម (ឬបង្កើតតារាងថ្មីនៅលើក្តារខៀន) ដល់សិស្ស ។ សូមអញ្ជើញដៃគូនីមួយៗឲ្យអានសេចក្តីយោងបទគម្ពីរ ឬនៅក្នុងជួរឈរខាងស្តាំនៃតារាង ហើយសរសេរនៅក្នុងជួរឈរនោះនូវអត្ថន័យដែលអាចមានសម្រាប់និមិត្តសញ្ញានីមួយៗដែលយ៉ូហានបានប្រើ ។

និមិត្តសញ្ញានៅក្នុង វិវរណៈ ១

និមិត្តសញ្ញា	អត្ថន័យដែលអាចមាន
វិវរណៈ ១:១២—ចង្កៀងមាសប្រាំពីរ	វិវរណៈ ១:២០; នីហ្វៃទី៣ ១៨:២៤—
វិវរណៈ ១:១៦–១៧—ព្រះហស្តស្តាំ	ម៉ាកុស ១៦:១៩—

និមិត្តសញ្ញា	អត្ថន័យដែលអាចមាន
វិវរណៈ ១:១៦—ផ្កាយប្រាំពីរ	ផ្កាយប្រាំពីរគឺជាពួកអ្នកបម្រើនៃពួកជំនុំទាំងប្រាំពីរ (Joseph Smith Translation, Revelation ១:២០) ។
វិវរណៈ ១:១៦—ដាវមុខពីរដ៏មុត	ហេព្រើរ ៤:១២—
វិវរណៈ ១:១៨—កូនសោនៃសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់	នីហ្វៃទី២ ៩:១០–១៣—

បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ប្រាប់អំពីអត្ថន័យដែលអាចមាននៃនិមិត្តសញ្ញានីមួយៗ ដែលយ៉ូហានបានប្រើ ។ ប្រសិនបើចាំបាច់ សូមជួយពួកគេឲ្យស្គាល់ថា ចង្កៀងទាំងប្រាំពីរតំណាងឲ្យពួកជំនុំទាំងប្រាំពីរដែលត្រូវលើកពន្លឺនៃដំណឹងល្អឡើង ព្រះហស្តស្តាំតំណាងឲ្យព្រះចេស្តា និងការអនុមតិរបស់ព្រះ ផ្កាយប្រាំពីរតំណាងឲ្យពួកអ្នកបម្រើ ឬថ្នាក់ដឹកនាំគ្រប់គ្រងពួកជំនុំទាំងប្រាំពីរដែលដឹកនាំដោយព្រះអម្ចាស់ ដាវតំណាងឲ្យបន្ទូលព្រះ ការប្រកាសកាត់សេចក្តីចំពោះជនទុច្ចរិត និងការដោះលែងជនគ្មានទោស ហើយកូនសោនៃស្ថានឃុំព្រលឹង និងសេចក្តីស្លាប់តំណាងឲ្យព្រះចេស្តារបស់ព្រះអម្ចាស់ដើម្បីយកឈ្នះលើសេចក្តីស្លាប់ខាងវិញ្ញាណ និងខាងសាច់ឈាម ។

- ដោយផ្អែកលើសារលិខិតដែលព្រះអម្ចាស់បានបើកសម្តែងដល់ពួកបរិសុទ្ធតាមរយៈយ៉ូហាន តើយើងអាចរៀននូវសេចក្តីពិតអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ និងទំនាក់ទំនងរបស់ទ្រង់នឹងពួកអ្នកដើរតាមដ៏ស្មោះត្រង់របស់ទ្រង់ ? (សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតមួយដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទឃុំគ្រង ហើយមើលថែពួកអ្នកដើរតាមដ៏ស្មោះត្រង់របស់ទ្រង់**) ។

សូមរំឭកសិស្សអំពីការប្រឈម ដែលសមាជិកសាសនាចក្រនៅក្នុងជំនាន់របស់យ៉ូហានបានជួបប្រទះ ។

- ហេតុអ្វីក៏វាសំខាន់ឲ្យសមាជិកសាសនាចក្រនៅជំនាន់របស់យ៉ូហានដឹងថា ព្រះយេស៊ូវគ្រីស្ទបានបន្តឃុំគ្រង ហើយមើលថែដល់ពួកគេ ?
- ហេតុអ្វីបានជាវាសំខាន់ចំពោះយើងដើម្បីចងចាំពីសេចក្តីពិតដូចគ្នានេះ ?

សូមអញ្ជើញសិស្សឲ្យគិតអំពីគ្រាមួយ ដែលពួកគេបានមានអារម្មណ៍ថា ព្រះយេស៊ូវគ្រីស្ទបានឃុំគ្រង ហើយមើលថែដល់ពួកគេ ។ សូមឲ្យពួកគេពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។ សូមពិចារណាចែកចាយបទពិសោធន៍មួយរបស់អ្នកផងដែរ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន វិវរណៈ ១:១៧–១៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាព្រះអង្គសង្គ្រោះបានមានបន្ទូលអ្វីខ្លះទៅកាន់យ៉ូហាន ។

- តើយើងអាចរៀនគោលលទ្ធិអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទដោយផ្អែកលើអ្វី ដែលទ្រង់បានមានបន្ទូលទៅយ៉ូហាន ? (សិស្សអាចនឹងប្រើពាក្យផ្សេងគ្នា ប៉ុន្តែពួកគេគួរស្គាល់គោលលទ្ធិដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាអង្គដែលមានព្រះជន្មរស់ឡើងដ៏រុងរឿង ដែលមានព្រះចេស្តាយកឈ្នះលើសេចក្តីស្លាប់ និងស្ថាននរក**) ។
- តើគោលលទ្ធិនេះបាននាំយកសេចក្តីសង្ឃឹមអ្វីខ្លះ ទៅឲ្យពួកបរិសុទ្ធនៅជំនាន់របស់យ៉ូហាន ?
- តើគោលលទ្ធិនេះបាននាំយកសេចក្តីសង្ឃឹមអ្វីខ្លះមកឲ្យយើង ?
- តើគោលលទ្ធិនេះបានបង្រៀនយើងអ្វីខ្លះអំពីលទ្ធផលចុងបញ្ចប់នៃចម្បាំងរវាងអំពើល្អ និងអំពើអាក្រក់ដែលកើតមានពាសពេញផែនដីនេះ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមអំពីគម្ពីរវិវរណៈ ៖

« សារលិខិតនៃវិវរណៈគឺដូចជាក្នុងគ្រប់បទគម្ពីរ ៖ នឹងមានជោគជ័យរបស់ព្រះអម្ចាស់នៅលើផែនដីនេះនៅទីបំផុត យកឈ្នះលើអារក្សជាជ័យជំនះដ៏និរន្តន៍មួយនៃសេចក្តីល្អលើសេចក្តីអាក្រក់ ជាជ័យជំនះរបស់ពួកបរិសុទ្ធលើពួកបៀតបៀនពួកគេ ជាជ័យជំនះរបស់នគរព្រះលើនគរមនុស្ស និងសាតាំង » (Bible Dictionary, « Revelation of John ») ។

សូមចង្អុលបង្ហាញថា ដោយសារយើងដឹងថានៅទីបំផុត អំពើល្អនឹងយកឈ្នះលើអំពើអាក្រក់ ប៉ុន្តែអ្វីដែលសំខាន់គឺថា តើយើងជ្រើសយកនៅខាងណា ខាងសាតាំង ឬខាងព្រះ ។ អ្នកគួរថ្លែងទីបន្ទាល់អំពីជ័យជំនះរបស់ព្រះអង្គសង្គ្រោះលើសេចក្តីស្លាប់ និងស្ថាននរក និងអំពីធាតុពិត ដោយសារតែទ្រង់ទើបយើងអាចជ្រើសយកនៅខាងព្រះនៅក្នុងចម្បាំងរវាងអំពើល្អ និងអំពើអាក្រក់នេះ ។

សូមអញ្ជើញសិស្សឲ្យ ពិចារណា អ្វីដែលពួកគេអាចធ្វើ ដើម្បីជ្រើសរើសកាន់ពេញលេញថែមទៀតដើម្បីនៅខាងព្រះ ។ សូមលើកទឹកចិត្តពួកគេធ្វើសកម្មភាព តាមការបំផុសគំនិតណាមួយដែលពួកគេបានទទួល ។

ជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ

សូមទុកពេលឲ្យសិស្សនៅក្នុងថ្នាក់ដើម្បីស្ងើងស្មាត គិតពិចារណា ឬសរសេរអំពីអ្វីដែលពួកគេយល់ និងមានអារម្មណ៍ ហើយពិចារណាពីសកម្មភាពជាក់លាក់ដែលពួកគេគួរធ្វើដើម្បីអនុវត្តនូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុងជីវិតរបស់ពួកគេ ។ នៅក្នុងពេលដូច្នេះ សូមលើកទឹកចិត្តសិស្សឲ្យទូលសូមការដឹកនាំ និងការវិវរណៈមកពីព្រះអម្ចាស់ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ១:១៩ ឲ្យឮ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ព្រះអម្ចាស់បានប្រាប់យ៉ូហានឲ្យសរសេរអ្វីខ្លះ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា វិវរណៈ ១ កត់ត្រានូវអ្វីដែលយ៉ូហានបានសរសេរអំពីការនិមិត្តរបស់លោកអំពីព្រះអង្គសង្គ្រោះ ។ ដូចដែលបានកត់ត្រានៅក្នុង វិវរណៈ ២–៣ យ៉ូហានបានសរសេរអំពី« សេចក្តីដែលមាន » (វិវរណៈ ១:១៩) ឬស្ថានភាពរបស់សាសនាចក្រនៅជំនាន់របស់លោក ។ វិវរណៈ ៤–២២ កត់ត្រាអំពីអ្វីដែលយ៉ូហានបានសរសេរ « សេចក្តីទាំងប៉ុន្មាន ដែលត្រូវកើតមកតាមក្រោយ » (វិវរណៈ ១:១៩) ឬនាពេលអនាគត ។

វិវរណៈ ២–៣

សេចក្តីផ្តើម

យ៉ូហានបានសរសេរដល់ពួកទេវតាទាំងប្រាំពីរអង្គ ឬពួកអ្នកបម្រើនៃក្រុមជំនុំរបស់សាសនាចក្រនៅអាស៊ីតូច ហើយបានបង្ហាញអំពីបន្ទូលរបស់ព្រះអម្ចាស់អំពីការសរសើរ ការកែតម្រូវ និងការព្រមានដល់ពួកបរិសុទ្ធ ។ យ៉ូហានក៏បានដាក់បញ្ចូលអំពីការសន្យានៃភាពតម្កើងឡើងដល់ជនដែលយកឈ្នះបានផងដែរ ។

យោបល់សម្រាប់ការបង្រៀន

ត្រូវប្រុងប្រយ័ត្នចំពោះគំរិយាបថរបស់សិស្ស ហើយឆ្លើយតបដោយសមរម្យ ។

ចូរយល់ដឹងពីការចូលរួមរបស់សិស្សនៅក្នុងមេរៀននេះ ហើយឆ្លើយតបនៅក្នុងរបៀបដ៏ត្រឹមត្រូវមួយ ។ ប្រសិនបើសិស្សមើលទៅហាក់ដូចជាធុញទ្រាន់ ឬ គ្មានន័យវាអាចបណ្តាលមកពីពួកគេពុំបានចូលរួមនៅក្នុងមេរៀន ឬដោយសារពួកគេពុំយល់ពីអ្វី ដែលអ្នកកំពុងបង្រៀន ឬ ពីរបៀបដែលមេរៀននោះអនុវត្តចំពោះពួកគេ ។ ដើម្បីជួយសិស្សឲ្យផ្តោតអារម្មណ៍ អ្នកត្រូវកែប្រែចំណុចមួយចំនួននៅក្នុងបទបង្ហាញមេរៀន ។

វិវរណៈ ២–៣

យ៉ូហានសរសេរអំពីព្រះបន្ទូលទាំងឱ្យាយរបស់ព្រះយេស៊ូវគ្រីស្ទដល់ពួកថ្នាក់ដឹកនាំនៃពួកជំនុំទាំងប្រាំពីរ

សូមអញ្ជើញសិស្សម្នាក់អានឲ្យឮៗនូវដំណើររឿងខាងក្រោមដោយសិស្ទើរ ស៊ីដនី អេស រេណលស៍ អតីតសមាជិកមួយរូបនៅក្នុងគណៈប្រធានអង្គបឋមសិក្សាទូទៅ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា ពួកគេអាចរៀនអ្វីខ្លះចេញពីក្នុងដំណើររឿងអំពីព្រះអម្ចាស់នេះ: ។



« សិស្ទើរ ហ្គេល ក្លេត នៃគណៈប្រធានអង្គបឋមសិក្សាទូទៅ និងស្វាមីគាត់បានរស់នៅក្នុងប្រទេសប្រេស៊ីលអស់រយៈពេលជាច្រើនឆ្នាំ ។ ថ្មីៗនេះ: គាត់មានកិច្ចការមួយខាងអង្គការបឋមសិក្សានៅប្រទេសជប៉ុន ។ នៅពេលគាត់ដើរចូលទៅក្នុងសាលាជំនុំនៅថ្ងៃអាទិត្យ គាត់បានសង្កេតឃើញគ្រួសារជនជាតិប្រេស៊ីលមួយគ្រួសារនៅក្នុងចំណោមពួកបរិសុទ្ធជប៉ុន ។ . . . គាត់មានពេលតែមួយនាទីដើម្បីរាក់ទាក់នឹងពួកគេ ហើយបានដឹងថា ម្តាយ និងកូនៗចូលចិត្តខ្លាំងណាស់ ប៉ុន្តែសង្កេតឃើញថាឪពុកអង្គុយយ៉ាងស្ងៀមស្ងាត់ ។ ‹ ខ្ញុំនឹងមានឱកាសនិយាយនឹងពួកគេក្រោយពីការប្រជុំ › គាត់បានគិត នៅពេលគាត់បានប្រញាប់ឡើងទៅអង្គុយនៅលើវេទិកា ។ គាត់បានថ្លែងសុន្ទរកថារបស់គាត់ជាភាសាអង់គ្លេស ហើយត្រូវបានគេបកប្រែជាភាសាជប៉ុន រួចគាត់បានទទួលការបំផុសឲ្យថ្លែងទីបន្ទាល់ជាភាសាព័រទុយហ្គាយផងដែរ ។ គាត់រៀងស្ទាក់ស្ទើរដោយសារគ្មានអ្នកបកប្រែសម្រាប់ភាសាព័រទុយហ្គាយ ហើយមនុស្ស ៩៨ ភាគរយនឹងពុំយល់អំពីអ្វីដែលគាត់នឹងនិយាយឡើយ ។

« បន្ទាប់ពីការប្រជុំនោះ: ឪពុកដែលជាជនជាតិប្រេស៊ីលរូបនោះបានដើរមករកគាត់ ហើយពោលថា ‹ សិស្ទើរ ទំនៀមទម្លាប់នៅទីនេះមានភាពខុសប្លែកខ្លាំងណាស់ ហើយខ្ញុំបានឯកោតែឯង ។ ការមកព្រះវិហារដោយពុំបានយល់អ្វីសោះនោះ វាគឺជារឿងពិបាកណាស់ ។ ពេលខ្លះខ្ញុំគិតថា វានឹងប្រសើរជាង ប្រសិនបើខ្ញុំនៅផ្ទះអានព្រះគម្ពីរវិញនោះ ។ ខ្ញុំបានប្រាប់ភរិយារបស់ខ្ញុំថា « ខ្ញុំនឹងសាកល្បងម្តងទៀត » ហើយខ្ញុំបានមកនៅថ្ងៃនេះ ដោយគិតថាវាគឺជាលើកចុងក្រោយសម្រាប់ខ្ញុំ ។ នៅពេលអ្នកថ្លែងទីបន្ទាល់របស់អ្នកជាភាសាព័រទុយហ្គាយ ព្រះវិញ្ញាណបានប៉ះដល់ដួងចិត្តខ្ញុំ ហើយខ្ញុំបានដឹងថា នេះគឺជាកន្លែងដែលខ្ញុំត្រូវមក ។ ព្រះជ្រាបថាខ្ញុំនៅទីនេះ ហើយទ្រង់នឹងជួយខ្ញុំ › » (« He Knows Us; He Loves Us » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ៧៦) ។

- តើយើងអាចរៀនអ្វីខ្លះអំពីព្រះអម្ចាស់ចេញពីក្នុងដំណើររឿងនេះ ?

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ដោយសារព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ* . . . នៅពេលសិស្សសិក្សាវិវរណៈ ២–៣ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតដែលជួយពួកគេឲ្យយល់ថា ព្រះអម្ចាស់អាចធ្វើអ្វីខ្លះសម្រាប់ពួកគេ ដោយសារទ្រង់ស្គាល់ពួកគេនោះ: ។

សូមពន្យល់ថា វិវរណៈ ២–៣ មាននូវកំណត់ត្រារបស់សាវកយ៉ូហាន អំពីបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទទៅពួកជំនុំទាំងប្រាំពីររបស់សាសនាចក្រនៅអាស៊ីតូច (ប្រទេសតួរគីបច្ចុប្បន្ន) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២:១–៣, ៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានជ្រាបដឹងអ្វីខ្លះអំពីពួកបរិសុទ្ធក្នុងអេភេសូរ ។

- តើព្រះអម្ចាស់បានជ្រាបអ្វីខ្លះ អំពីពួកបរិសុទ្ធនៅអេភេសូរ ? (សូមពន្យល់ថា ពាក្យ *ពួកនីកូឡាស* (ខទី ៦) អាចសំដៅទៅលើក្រុមដែលសមាជិករបស់ខ្លួនបានប្រកាសថា ពួកគេអាចធ្វើអំពើបាបខាងផ្លូវភេទដោយគ្មានការដាក់ទោស ដោយសារតែព្រះគុណរបស់ព្រះនឹងសង្គ្រោះពួកគេ (សូមមើល Bible Dictionary « Nicolaitans »)) ។

សូមចង្អុលបង្ហាញថា ខគម្ពីរទាំងនេះកត់ត្រាថា ព្រះអម្ចាស់បានសរសើរពួកបរិសុទ្ធចំពោះកិច្ចការល្អរបស់ពួកគេ ។ សូមដាក់បន្ថែមទៅនឹងឃ្លានៅលើក្តារខៀន ដើម្បីឲ្យវាមានន័យដូចតទៅនេះ ៖ *ដោយសារព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ នោះទ្រង់អាចប្រទាននូវការសរសើរដោយផ្ទាល់ដល់យើង* . . .

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២:៤–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានជ្រាបអំពីអ្វីខ្លះទៀតអំពីពួកបរិសុទ្ធក្នុងអេភេសូរ ។

- តើព្រះអម្ចាស់បានជ្រាបអ្វីខ្លះទៀត អំពីពួកបរិសុទ្ធនៅអេភេសូរ ?

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់កំពុងប្រទានការកែតម្រូវដល់ពួកបរិសុទ្ធ ដោយសារតែអំពើបាបរបស់ពួកគេ ។ សូមបំពេញឃ្លានៅលើក្តារខៀន ដើម្បីឲ្យបង្ហាញនូវសេចក្តីពិតដូចតទៅនេះ ៖ **ដោយសារព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ នោះទ្រង់អាចប្រទាននូវការសរសើរ និងការកែតម្រូវដោយផ្ទាល់ដល់យើង ។**

- តើវិធីអ្វីខ្លះដែលយើងអាចទទួលបានការសរសើរ និងការកែតម្រូវដោយផ្ទាល់មកពី ព្រះអម្ចាស់ ?
- តើការដឹងថា ព្រះអម្ចាស់អាចប្រទានការសរសើរ និងការកែតម្រូវដល់យើង អាចជះឥទ្ធិពលដល់របៀបដែលយើងធ្វើការសិក្សាព្រះគម្ពីរ និងការអធិស្ឋានផ្ទាល់ខ្លួនរបស់យើងយ៉ាងដូចម្តេច ? តើវាអាចជះឥទ្ធិពលទៅលើរបៀបដែលយើងឆ្លើយតបចំពោះពាក្យទូន្មានរបស់ថ្នាក់ដឹកនាំសាសនាចក្រ និងឪពុកម្តាយរបស់យើងយ៉ាងដូចម្តេចដែរ ?
- ហេតុអ្វីយើងគួរមានន័យការខិតខំមួយដើម្បីស្វែងរកការសរសើរ និងការកែតម្រូវដោយផ្ទាល់មកពីព្រះអម្ចាស់ ?
- តើអ្នកធ្លាប់ដកពិសោធន៍នូវការសរសើរ ឬការកែតម្រូវដោយផ្ទាល់មកពីព្រះអម្ចាស់នៅពេលណាដែរ ? តើបទពិសោធន៍នេះបានជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់ស្គាល់អ្នកម្នាក់ៗជាបុគ្គលយ៉ាងដូចម្តេចដែរ ? (សូមហាមសិស្សកុំឲ្យចែកចាយបទពិសោធន៍ដែលពិសិដ្ឋឬឯកជនពេក) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសកម្មភាពដែលពួកគេគិតថា ព្រះអម្ចាស់អាចនឹងសរសើរដល់ពួកគេ ក៏ដូចជាគំនិត ឬឥរិយាបថដែលព្រះអម្ចាស់អាចនឹងកែតម្រូវដល់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅមួយដើម្បីប្រែចិត្ត នៅពេលព្រះអម្ចាស់កែតម្រូវដល់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២:៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ជនដែលយកឈ្នះ ឬស៊ូទ្រាំដោយស្មោះត្រង់ដរាបដល់ចុងបំផុត ។

- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ជនដែលយកឈ្នះ ឬជនដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុតនៅក្នុងសេចក្តីសុចរិត ?
- តើអ្នកគិតថា « ការបរិភោគផ្លែរបស់ដើមជីវិត » មានន័យដូចម្តេច ? (ខទី ៧) ។
- តើការស្តាប់ឮពរជ័យដែលបានសន្យានេះ បន្ទាប់ពីទទួលបានការកែតម្រូវដោយផ្ទាល់មានប្រយោជន៍យ៉ាងណាដែរ ដល់ពួកបរិសុទ្ធនៅអេភេសូរ ?

សូមរំឭកសិស្សថា បន្ថែមពីលើការមានបន្ទូលទៅកាន់ពួកជំនុំរបស់សាសនាចក្រនៅអេភេសូរ ព្រះអម្ចាស់បានមានបន្ទូលទៅពួកជំនុំផ្សេងទៀតរបស់សាសនាចក្រនៅអាស៊ីតូច ។

សូមបំបែកសិស្សក្នុងថ្នាក់ជាប្រាំក្រុម ហើយចាត់បទគម្ពីរមួយឲ្យក្រុមនីមួយៗដូចខាងក្រោមនេះ ៖

១. វិវរណៈ ២:៨–១១

២. វិវរណៈ ២:១២–១៧

៣. វិវរណៈ ២:១៨–២៩, ការបកប្រែដោយយ៉ូសែប ស៊្មីធ វិវរណៈ ២:២៦–២៧ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។

៤. វិវរណៈ ៣:១–៦(សូមផ្តល់សំណៅនៃការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់វិវរណៈ ៣:១–២ ដល់ក្រុមដែលទទួលបានបទគម្ពីរយោងនេះ ៖ « ចូរសរសេរផ្ញើទៅពួកអ្នកបម្រើនៃពួកជំនុំដែលនៅក្រុងសើដេសថា ព្រះដ៏មានព្រះវិញ្ញាណទាំងប្រាំពីរ ដែលជាពួកអ្នកបម្រើទាំងប្រាំពីររបស់ព្រះ ទ្រង់មានព្រះបន្ទូលនូវសេចក្តីទាំងនេះថា យើងស្គាល់ការដែលអ្នករាល់គ្នាប្រព្រឹត្តហើយ គឺដែលអ្នករាល់គ្នាមានឈ្មោះថារស់ តែអ្នករាល់គ្នាស្លាប់ទេ ។ ហេតុដូច្នេះហើយ ចូរប្រុងប្រយ័ត្ន ហើយចម្រើនកម្លាំងដល់អ្វីៗដែលនៅសល់ ដែលរៀបនឹងស្លាប់នោះដែរ ដ្បិតយើងមិនបានឃើញការដែលអ្នករាល់គ្នាប្រព្រឹត្តនោះ ជាពេញខ្នាតនៅចំពោះព្រះនៃយើងទេ) ។

៥. វិវរណៈ ៣:៧–១៣

សូមអញ្ជើញសិស្សឲ្យអានខគម្ពីរដែលពួកគេត្រូវបានចាត់ឲ្យដល់ក្រុមនីមួយៗ ហើយរកមើលថា តើព្រះអម្ចាស់បានទូន្មានឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ និងរកមើលពរជ័យដែលទ្រង់បានសន្យាថាពួកគេនឹងទទួលបាន ប្រសិនបើពួកគេធ្វើដូច្នោះ ។

បន្ទាប់ពីផ្តល់ពេលឲ្យគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗឲ្យប្រាប់អំពីអ្វីដែលក្រុមរបស់គាត់បានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរនៅលើក្តារខៀន (នៅខាងក្រោមពរជ័យដែលបានសន្យានៅក្នុង វិវរណៈ ២:៧) ពរជ័យសន្យាដែលក្រុមនីមួយៗបានរកឃើញ (សូមមើល វិវរណៈ ២:១១, ១៧, ២៦, ៣:៥, ១២) ។ បន្ទាប់ពីបានធ្វើចប់សព្វគ្រប់ សូមចង្អុលបង្ហាញថា ការសន្យានីមួយៗនៃការសន្យាទាំងនេះសំដៅទៅលើការទទួលបានពរជ័យនៃភាពតម្កើងឡើង ដែលវាសមស្របទៅនឹងការកាន់ខ្ជាប់ដ៏ស្មោះត្រង់របស់យើងដរាបដល់ចុងបំផុត ។

- តើយើងអាចស្គាល់គោលការណ៍អ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ អំពីអ្វីដែលយើងត្រូវធ្វើ ដើម្បីទទួលបានពរជ័យនៃភាពតម្កើងឡើង ? (សូមជួយសិស្សឲ្យស្គាល់គោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងយកឈ្នះ នោះយើងអាចទទួលបានពរជ័យនៃភាពតម្កើងឡើង**) ។
- តើអ្នកគិតថាយើងត្រូវយកឈ្នះអ្វីខ្លះ ដើម្បីទទួលបានពរជ័យនៃភាពតម្កើងឡើង ?

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ៣:១៤–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលលក្ខខណ្ឌមួយ ដែលសមាជិកសាសនាចក្រនៅក្រុងឡៅឌីសេថាត្រូវយកឈ្នះដើម្បីទទួលបានភាពតម្កើងឡើង ។

- តើលក្ខខណ្ឌអ្វីទៅដែលសមាជិកសាសនាចក្រនៅក្រុងឡៅឌីសេថាត្រូវយកឈ្នះ ?
- តើអ្នកគិតថា ការដែលសមាជិកសាសនាចក្រទាំងនេះគឺជាពួកសិស្សដែលគ្រាន់តែស្មើរៗចំពោះព្រះយេស៊ូវគ្រីស្ទនោះមានន័យដូចម្តេច ? (ខទី ១៥) ។ (ពាក្យ *ក្តៅ* អាចត្រូវបានប្រើដើម្បីពិពណ៌នាអំពីមនុស្សម្នាក់ ដែលបានប្តេជ្ញាចិត្តទាំងស្រុងចំពោះដំណឹងល្អ ហើយពាក្យ *ត្រជាក់* អាចត្រូវបានប្រើដើម្បីពិពណ៌នាអំពីមនុស្សម្នាក់ ដែលបដិសេធចោលទាំងស្រុងចំពោះការបង្រៀន

និងសេចក្តីសញ្ញាទាំងឡាយនៃដំណឹងល្អ ។ សិស្សដែលគ្រាន់តែស្មើរៗម្នាក់អាចជាមនុស្សម្នាក់ដែលជឿដំណឹងល្អថាពិត ប៉ុន្តែពុំបានតាំងចិត្តពេញលេញដើម្បីរស់នៅតាមនោះទេ) ។

- នៅក្នុងទស្សនៈរបស់អ្នក តើកិច្ចការណាខ្លះដែលពួកសិស្ស ដែលគ្រាន់តែស្មើររបស់ព្រះយេស៊ូវគ្រីស្តអាចនឹងធ្វើ និងពុំធ្វើ ?

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វី ដែលពួកគេបានធ្វើដើម្បីដើរតាមព្រះយេស៊ូវគ្រីស្តកាលពីប៉ុន្មានថ្ងៃមុននេះ ហើយថាតើពួកគេគឺជាសិស្សដែលក្តៅ ត្រជាក់ ឬគ្រាន់តែស្មើររបស់ព្រះយេស៊ូវគ្រីស្ត ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៣:១៩ ឲ្យឮ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាម រកមើលហេតុផលដែលព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់កំពុងកែតម្រូវពួកបរិសុទ្ធនៅក្រុងឡៅឌីសេថា ។

- ដោយផ្អែកទៅលើអ្វីដែលព្រះអម្ចាស់មានបន្ទូលទៅពួកបរិសុទ្ធនៅក្រុងឡៅឌីសេ ថាហេតុអ្វីទ្រង់កែតម្រូវយើង ? (សូមជួយសិស្សឲ្យស្គាល់សេចក្តីពិតមួយ ដែលស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ដោយសារព្រះអម្ចាស់ស្រឡាញ់យើង ទើបទ្រង់កែតម្រូវយើង ដើម្បីឲ្យយើងនឹងប្រែចិត្ត**) ។



សូមដាក់បង្ហាញ រូបភាព ព្រះយេស៊ូវគង់នៅឯមាត់ទ្វារ (*Gospel Art Book* ⁄ ឆ្នាំ ២០០៩ ⁄ ល.រ. ៦៥, សូមមើលផងដែរ LDS.org) ។

- តើព្រះអង្គសង្គ្រោះកំពុងធ្វើអ្វីនៅក្នុងរូបភាពនេះ ?

សូមអានឮៗនូវសំណួរខាងក្រោម ហើយឲ្យសិស្សសញ្ជឹងគិតអំពីចម្លើយរបស់ពួកគេដោយស្ងៀមស្ងាត់ ៖

- តើអ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកស្តាប់ឮការគោះទ្វារនៅផ្ទះរបស់អ្នក ហើយដឹងថាព្រះអង្គសង្គ្រោះជាអ្នកគោះទ្វារនោះ ?
- តើអ្នកនឹងបើកទ្វារនោះដែរឬទេ ?

សូមចង្អុលបង្ហាញថា រូបភាពនេះបង្ហាញអំពីបន្ទូលដែលព្រះអម្ចាស់បានលើកមកបង្រៀនដល់សាសនាចក្រនៅក្រុងឡៅឌីសេថា ។ សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៣:២០ ឲ្យឮ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលពរជ័យ ដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនៅក្រុងឡៅឌីសេថា និងអ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលបានវា ។

- តើពរជ័យអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានដល់ពួកបរិសុទ្ធនៅក្រុងឡៅឌីសេថា ?
- តើពួកគេត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានពរជ័យនោះ ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុង ខទី ២០ ? (សិស្សអាចប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថាពួកគេស្គាល់គោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងបើកទ្វារថ្វាយព្រះអង្គសង្គ្រោះ ទ្រង់នឹងយាងចូល ហើយគង់នៅជាមួយនឹងយើង**) ។

ដើម្បីជួយសិស្សឲ្យយល់អំពីអត្ថន័យនៃការនៅជាមួយនឹងព្រះអង្គសង្គ្រោះ សូមពន្យល់ថា ប្រពៃណីនៅតំបន់ក្បែរទិសខាងកើតកាលពីបុរាណ ការបរិភោគអាហារជាមួយនឹងមនុស្សម្នាក់គឺជាសញ្ញានៃការរាប់អាន ។ វាបញ្ជាក់ថា មានចំណងមិត្តភាព និងភាពសុខសាន្ត ឬយ៉ាងហោចណាស់មានន័យថា ភាពសុខសាន្តត្រូវបានផ្តល់ឲ្យ ។

- តើអ្នកគិតថា ការបើកទ្វារដែលបានលើកឡើងនៅក្នុង ខទី ២០ តំណាងឲ្យអ្វី ?

សូមពន្យល់ថា មនុស្សដែលបើកទ្វារថ្វាយព្រះអង្គសង្គ្រោះ ហើយទទួលទានអាហារជាមួយទ្រង់គឺជាបុគ្គលដែលប្រែចិត្តពីអំពើបាបខ្លួន ហើយក្លាយមិត្តទ្រង់ និងព្រះវរបិតាសួគ៌របស់យើង ។

ដើម្បីជួយសិស្សយល់ថា ការបើកទ្វារនោះតំណាងឲ្យអ្វីទៅ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវដំណើររឿងដូចខាងក្រោមដោយប្រធាន ស្តែនសើរ ដបុលយូ ឃីមបឹល ៖



« មានថ្ងៃមួយ ⁄ វិចិត្រករម្នាក់ឈ្មោះ ហូលមិន ហាន់ ⁄ កំពុងបង្ហាញរូបភាពរបស់ខ្លួនអំពី ‹ ព្រះគ្រីស្តកំពុងគោះទ្វារ › ដល់មិត្តម្នាក់ ហើយរំពេចនោះមិត្តម្នាក់នោះបានស្រែកឡើងថា ‹ រូបភាពរបស់ឯងដូចជាមានបញ្ហាអ្វីមួយ › ។

« វិចិត្រករនោះបានសួរថា ‹ តើវាមានបញ្ហាអ្វីដែរ ? ›

« មិត្តនោះក៏តបថា ‹ ទ្វារដែលព្រះយេស៊ូវគោះនោះគ្មានដៃទ្វារទេ › ។

« លោកហាន់ បានតបថា ‹ ទេ នោះពុំមែនជាកំហុសទេ ។ ឯងឃើញទេ នេះគឺជាទ្វារចូលទៅក្នុងដួងចិត្តរបស់មនុស្ស ។ វាអាចបើកបានតែពីខាងក្នុងប៉ុណ្ណោះ › ។

« ហើយវាគឺជារឿងពិត ។ ព្រះយេស៊ូវអាចឈរ ហើយគោះទ្វារ ប៉ុន្តែយើងម្នាក់ៗគឺជាអ្នកសម្រេចចិត្តថាតើគួរបើក ឬក៏អត់ » (*The Miracle of Forgiveness* ⁄ ឆ្នាំ ១៩៦៩ ⁄ ទំព័រ ២១២) ។

- តើអ្នកគិតថា យើងអាចបើកដួងចិត្តរបស់យើងថ្វាយព្រះអង្គសង្គ្រោះតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យអាន វិវរណៈ ៣:២១–២២ ដោយស្ងៀមស្ងាត់ រកមើលការសន្យា និងបន្ទូលទូន្មានរបស់ព្រះអម្ចាស់ទៅកាន់ពួកបរិសុទ្ធនៅក្រុងឡៅឌីសេថា ។

- យោងតាមខទី ២២តើព្រះអម្ចាស់បានប្រទានពាក្យទូន្មានអ្វីខ្លះ ?

សូមអញ្ជើញសិស្សឲ្យ « ស្តាប់សេចក្តីដែលព្រះវិញ្ញាណមានបន្ទូល » (ខទី ២២) ដោយសញ្ជឹងគិតអំពីអ្វីដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតដែលពួកគេបានទទួល ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

វិវរណៈ ២:២៨ ។ « យើងនឹងឲ្យផ្កាយព្រឹកដល់អ្នកនោះ »

« ‹ ផ្កាយព្រឹក › គឺជានិមិត្តសញ្ញាមួយនៃព្រះយេស៊ូវគ្រីស្ទ (វិវរណៈ ២:២៨; ២២:១៦) ។ ការសន្យានៃ ‹ ផ្កាយព្រឹក › ត្រូវបានប្រគល់ដល់ជន ‹ ដែលឈ្នះ ហើយកាន់តាមការណ៍យើង ជារហូតដល់ចុងបំផុត › (វិវរណៈ ២:២៦) » (*New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៤] ទំព័រ ៥៣៥) ។

វិវរណៈ ៤–៥

សេចក្តីផ្តើម

សាវកយ៉ូហានបានឃើញតួអង្គដ៏មានសិរីល្អកំពុងថ្វាយបង្គំព្រះវរបិតាសួគ៌ កាលទ្រង់គង់នៅលើបល្ល័ង្ករបស់ទ្រង់ ។ យ៉ូហានក៏បានឃើញសៀវភៅមួយដែលត្រូវបានជាប់ត្រាប្រាំពីរ ហើយបានឃើញកូនចៀម ឬព្រះយេស៊ូវគ្រីស្ទដែលសក្តិសមដើម្បីបើកសៀវភៅនោះ ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ៤

យ៉ូហានឃើញតួអង្គដ៏មានសិរីល្អកំពុងថ្វាយបង្គំព្រះវរបិតាសួគ៌

ចូរពិចារណាច្រៀងបទ « សរសើរដល់ព្រះដ៏ខ្ពស់ » (*ទំនុកតម្កើង* ល.រ. ២៧) ជាទំនុកតម្កើងបើក ឬច្រៀងទំនុកតម្កើងមួយទៀតដែលសរសើរ ហើយគោរពដល់ព្រះ ។

សូមឲ្យសិស្សនីកស្រមៃថា ពួកគេកំពុងស្ថិតនៅក្នុងនគរសេឡេស្ទាល ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យពិពណ៌នាថា តើពួកគេគិតថានគរសេឡេស្ទាលមានទិដ្ឋភាពបែបណា ។

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង វិវរណៈ ៤–៥ សាវកយ៉ូហានបានឃើញការនិមិត្តមួយអំពីផ្នែកនៃនគរសេឡេស្ទាល ។ សូមសិស្សស្ម័គ្រចិត្តម្នាក់ឲ្យឡើងមកគូររូបនៅលើក្តារខៀន ។ សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ៤:១–៨ ហើយឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាយ៉ូហានបានឃើញអ្វីខ្លះ ។ សូមណែនាំដល់សិស្សស្ម័គ្រចិត្តឲ្យគូររូប កាលខគម្ពីរទាំងនេះត្រូវបានគេអានឮអ្វីដែលយ៉ូហានបានឃើញ ។ សិស្សដែលអានប្រហែលជាត្រូវផ្អាកអានម្តងម្កាល ដើម្បីឲ្យសិស្សដែលគូររូបមានពេលបញ្ចប់ផ្នែកនីមួយៗនៃគំនូរនោះ ។ (សូមប្រាប់អ្នកស្ម័គ្រចិត្តឲ្យមបញ្ចូលត្រង់ឃ្លា « មាន ១ អង្គ | ដែល | គង់នៅលើបល្ល័ង្ក » | ខទី ២ | ឬព្រះវរបិតាសួគ៌ដើម្បីបង្ហាញការគោរពចំពោះទ្រង់ ។ សម្រាប់ការចូលរួមបន្ថែមទៀត អ្នកអាចអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាគូររូប) ។

សូមពន្យល់ថា ការ « នៅដោយវិញ្ញាណ » (ខទី ២) មានន័យថា ការទទួលរងនូវព្រះចេស្តានៃព្រះវិញ្ញាណនៅក្នុងស្ថានភាពទទួលវិវរណៈ ឬការនិមិត្តមួយ ហើយពន្យល់ថា ត្បូង « មណីជោតិ » នៅក្នុង ខទី ៣ អាចបង្ហាញអំពីត្បូងពណ៌ ឬពេជ្រមួយគ្រាប់ ហើយថា « ត្បូងទទឹម » (ខទី ៣) គឺជាត្បូងដ៏មានតម្លៃដែលជាធម្មតាមានពណ៌ក្រហម ឬពណ៌ស្លាទុំ ។

សូមពន្យល់ថា វិវរណៈសម័យទំនើបជួយយើងឲ្យយល់បន្ថែមទៀតអំពីអ្វីដែលយ៉ូហានបានឃើញ ។ ឧទាហរណ៍ ព្រះអម្ចាស់បានប្រទានវិវរណៈដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និងសេចក្តីសញ្ញា ៧៧ បន្ទាប់ពីព្យាការីយ៉ូសែប ស៊្មីធ បានទូលសូមទ្រង់ដើម្បីបកស្រាយពីនិមិត្តសញ្ញា និងព្រឹត្តិការណ៍មួយចំនួនដែលបានកត់ត្រានៅក្នុង វិវរណៈ ១–១១ ។

សូមបំបែកសិស្សជាក្រុមដែលមានគ្នាពីរ ឬបីនាក់ ហើយផ្តល់ឲ្យក្រុមនីមួយៗនូវឯកសារដូចខាងក្រោមនេះ ។ សូមអញ្ជើញសិស្សនៅក្នុងក្រុមនីមួយៗឲ្យអានវគ្គសេចក្តីយោងបទគម្ពីរឲ្យឮៗរួមគ្នា ហើយសរសេរនៅលើតារាងនោះនូវព័ត៌មានបន្ថែមដែលពួកគេរកឃើញអំពីអ្វីដែលយ៉ូហានបានឃើញ ។

វិវរណៈ ៤

រឿងដែលយ៉ូហានបានឃើញ	សេចក្តីយោងបទគម្ពីរ	ព័ត៌មានបន្ថែម
បល្ល័ង្ក (វិវរណៈ ៤:២–៣)	គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៧:១–៤	
អ្នកចាស់ទុំម្តៃបួននាក់មានមកុដលើក្បាល (វិវរណៈ ៤:៤)	គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៥	
ញ្ញាណទាំងប្រាំពីររបស់ព្រះ (វិវរណៈ ៤:៥)	ការបកប្រែដោយយ៉ូសែប ស៊្មីធ សម្រាប់ខគម្ពីរនេះប្តូរ « ផ្កាយ ៧ » ទៅជា « ពួកអ្នកបម្រើទាំង ៧ » ។ នៅក្នុងវគ្គនៃការកែសម្រួលអត្ថបទ គឺជាពួកអ្នកបម្រើនៃពួកជំនុំទាំងប្រាំពីរ) ។	

រឿងដែលយ៉ូហានបានឃើញ	សេចក្តីយោងបទគម្ពីរ	ព័ត៌មានបន្ថែម
សមុទ្រកែវ (វិវរណៈ ៤:៦)	គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:១; ១៣០:៦–៩	
តួមានជីវិតបួន (វិវរណៈ ៤:៦–៧)	គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:២–៣	
តួមានភ្នែកច្រើន និងស្លាបប្រាំមួយ (វិវរណៈ ៤:៨)	គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៤	

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យប្រាប់អំពីព័ត៌មានបន្ថែមដែលពួកគេបានរកឃើញ ។ ប្រសិនបើចាំបាច់ សូមប្រើចម្លើយដើម្បីបញ្ជាក់ ឬបន្ថែមដល់ការយល់ដឹងរបស់សិស្ស ៖ ព្រះគង់នៅលើបល្ល័ង្កក្នុងនគរសេឡេស្ទាល អ្នកចាស់ទុំ ២៤ នាក់មានមកុដលើក្បាល គឺជាពួកអែលឌើរដ៏ស្មោះត្រង់ដែលនៅក្នុងពួកជំនុំទាំងប្រាំពីរ ពួកអ្នកបម្រើទាំងប្រាំពីររបស់ព្រះត្រូវបានលើកឡើងពុំមែនវិញ្ញាណទាំងប្រាំពីរទេ សមុទ្រកែវគឺជាផែនដីនៅក្នុងភាពរុងរឿងរបស់វា ស្ថានភាពសេឡេស្ទាល តួទាំងបួនគឺជាសត្វពិតដែលតំណាងឲ្យក្រុម (ឬប្រភេទ) នៃតួអង្គដែលមានសិរីល្អ ភ្នែកតួតំណាងឲ្យពន្លឺ និងចំណេះដឹងយ៉ាងអស្ចារ្យ ហើយស្លាបរបស់តួតំណាងឲ្យអំណាចដើម្បីផ្លាស់ទី ហើយធ្វើសកម្មភាព ។

សូមអញ្ជើញឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ៤:៨–១១ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាជនទាំងនោះដែលបានប្រមូលផ្តុំគ្នានៅជុំវិញព្រះវរបិតាសួគ៌បានថ្លែង ហើយធ្វើអ្វីខ្លះ: ។

- តើជនទាំងនោះដែលបានប្រមូលផ្តុំគ្នានៅជុំវិញព្រះវរបិតាសួគ៌បានថ្លែងអ្វីខ្លះអំពីទ្រង់ ? តើពួកគេបានធ្វើអ្វីខ្លះ: ?
- តើពួកអ្នកចាស់ទុំដាក់មកុដខ្លួនចុះថ្វាយនៅចំពោះមុខបល្ល័ង្ករបស់ព្រះវរបិតាសួគ៌អាចតំណាងឲ្យអ្វី ? (ចម្លើយអាចរួមមានការទទួលស្គាល់របស់ពួកគេចំពោះភាពដ៏មហិមារបស់ព្រះវរបិតាសួគ៌ ការទទួលស្គាល់របស់ពួកគេថា ពួកគេជំពាក់ទ្រង់នូវភាពតម្កើងឡើងរបស់ពួកគេ ព្រមទាំងការគោរព ការសរសើរ និងការលះបង់ដ៏ស្ម័គ្រស្មោះរបស់ពួកគេចំពោះទ្រង់ផងដែរ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះមកពីដំណើររឿងនេះថា តើការទទួលស្គាល់ភាពដ៏មហិមារបស់ព្រះវរបិតាសួគ៌អាចជះឥទ្ធិពលដល់យើងយ៉ាងដូចម្តេច ? (សិស្សអាចប្រើពាក្យផ្សេងៗ ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់គោលការណ៍ដូចតទៅនេះ: ៖ **នៅពេលយើងទទួលស្គាល់ភាពដ៏មហិមារបស់ព្រះវរបិតាសួគ៌ យើងមានបំណងប្រាថ្នាថ្វាយបង្គំ ហើយសរសើរតម្កើងទ្រង់**) ។
- តើអ្វីទៅអាចជួយយើងឲ្យទទួលស្គាល់ភាពដ៏មហិមារបស់ព្រះវរបិតាសួគ៌ ?

វិវរណៈ ៥

យ៉ូហានឃើញសៀវភៅមួយបានបិទត្រាប្រាំពីរ និងកូនចៀមដែលមានភាពសក្តិសមដើម្បីបើកវា

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗពី វិវរណៈ ៥:១–៤ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ូហានបានឃើញអ្វីនៅក្នុងព្រះហស្តរបស់ព្រះវរបិតាសួគ៌ ។

- តើយ៉ូហានបានឃើញអ្វីនៅក្នុងព្រះហស្តរបស់ព្រះវរបិតាសួគ៌ ? (សៀវភៅ ឬរមូរមួយដែលមានត្រាប្រាំពីរ) ។

សូមពន្យល់ថា កាលពីបុរាណ ឯកសារសំខាន់ៗត្រូវបានបិទភ្ជាប់នឹងត្រាធ្វើពីដីឥដ្ឋ ឬក្រមួន ។ មានតែម្ចាស់ឯកសារនោះ: និងជនដែលម្ចាស់ឯកសារនោះបានផ្តល់សិទ្ធិឲ្យប៉ុណ្ណោះ: ដែលត្រូវបានអនុញ្ញាតឲ្យបំបែកត្រាទាំងនោះ: ហើយអានអត្ថបទនោះ: ។

- យោងតាម ខទី ២តើបុគ្គលដែលអាចបើកសៀវភៅនោះត្រូវមានគុណសម្បត្តិបែបណាខ្លះ: ?

សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៦–៧ ដោយស្ងាត់ស្ងៀម រកមើលនិយមន័យនៃសៀវភៅ និងត្រា ។

- តើសៀវភៅនោះមានអ្វីខ្លះ: ?

សូមពន្យល់ថា រយៈពេល ៧០០០ ឆ្នាំ សំដៅទៅលើត្រា ចាប់តាំងពីការធ្លាក់នៃលោកអ័ដាម និង អេវ៉ាមកម្ល៉ះ: ។ វាពុំមែនសំដៅទៅលើអាយុកាលពិតប្រាកដនៃផែនដី រួមទាំងអាយុកាលនៃការបង្កបង្កើតនោះទេ ។

- យោងតាម គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៧ តើត្រាប្រាំពីរតំណាងឲ្យអ្វី ? (រយៈពេលប្រាំពីរពាន់ឆ្នាំនៃការកើតមានលោកិយដែលគិតត្រឹមពីការធ្លាក់របស់អ័ដាម រហូតដល់ចុងបញ្ចប់សតវត្សរ៍) ។

សូមចង្អុលបង្ហាញថា ការពិចារណាអំពីអត្ថន័យនៃសៀវភៅ និងត្រា នៅពេលវាទំនងថា គ្មាននរណាម្នាក់សក្តិសមដើម្បីបើកសៀវភៅនោះ: យ៉ូហានប្រហែលជាបានគិតថាព្រះទ័យ និងកិច្ចការរបស់ព្រះនឹងពុំត្រូវបានបើកសម្តែង ឬអនុវត្តឡើយ ។

- តើនឹងមានអ្វីអាចកើតឡើងចំពោះកូនចៅរបស់ព្រះវរបិតាសួគ៌ ប្រសិនបើផែនការរបស់ទ្រង់សម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេមិនអាចអនុវត្តបាននោះ: ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៥:៥–៧ ឲ្យឮៗ ។ សូមពន្យល់ថា ការបកប្រែដោយយ៉ូសែប ស៊្មីធសម្រាប់ ខទី ៦*ប្តូរសេចក្តីយោងទាំងអស់សម្រាប់លេខប្រាំពីរទៅលេខដប់ពីរវិញ* ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ហេតុអ្វីយ៉ូហានត្រូវបានប្រាប់កុំឲ្យយំ ។

អ្នកគួរពន្យល់ថា នៅក្នុងបទគម្ពីរ ជារឿយៗ ស្នែងគឺជានិមិត្តសញ្ញាមួយនៃអំណាច ឬសិទ្ធិអំណាច ភ្នែកអាចតំណាងឲ្យពន្លឺ និងចំណេះដឹង ហើយលេខដប់ពីរអាចតំណាងឲ្យការគ្រប់គ្រង និងការរៀបចំមកពីព្រះ ឬបព្វជិតភាព ។

- ហេតុអ្វីយ៉ូហានត្រូវបានប្រាប់កុំឲ្យយំ ?
- តើងារដែលបានប្រើសម្រាប់ព្រះយេស៊ូវគ្រីស្ទ ដូចដែលបានកត់ត្រានៅក្នុង វិវរណៈ ៥:៦ បើកសម្តែងអ្វីខ្លះអំពីទ្រង់ ? (ទ្រង់គឺជាដង្វាយថ្វាយដែលត្រូវបានប្រទានឲ្យ ដើម្បីធួនសម្រាប់កូនចៅរបស់ព្រះ ; សូមមើលផងដែរ អេសាយ ៥៣:៧; កូរិនថូសទី ១ ៥:៧ ; ពេត្រុសទី១ ១:១៨–១៩) ។ អ្នកគួរពន្យល់ថា « កូនចៀម ១ ដែលមើលទៅដូចជាបានសំឡាប់ហើយ » (វិវរណៈ ៥:៦) សំដៅទៅលើកូនចៀមកំពុងបង្ហាញដានគំនូសនៃការត្រូវបានគេធ្វើគុត ។ សូមចង្អុលបង្ហាញថា យ៉ូហាន បាទីស្ទ បានហៅព្រះអង្គសង្គ្រោះជា « កូនចៀមនៃព្រះ » (យ៉ូហាន ១:២៩, ៣៦)) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៥:៨–១០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលអំពីរបៀបដែលមនុស្សនៅជុំវិញបល្ល័ង្ករបស់ព្រះវរបិតាសួគ៌បានសរសើរដល់កូនចៀមនោះ ។ អ្នកអាចពន្យល់ថា « ដែលពេញដោយគ្រឿងក្រអូបរៀងខ្លួន » (ខទី ៨) សំដៅទៅលើកាទឹក ឬ ចានសម្លធំដែលសុទ្ធតែធូប ។

- តើមនុស្សទាំងនេះបានសរសើរតម្កើងកូនចៀម ឬព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?
- ដោយផ្អែកលើអ្វីដែលយ៉ូហានបានឃើញ ហើយស្តាប់ពុំអំពីកូនចៀម តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាអង្គតែមួយគត់ដែលសក្តិសម ហើយអាចប្រោសលោះយើងបាន**) ។
- ហេតុអ្វីព្រះយេស៊ូវគ្រីស្ទគឺជាព្រះតែមួយអង្គគត់ដែលសក្តិសម ហើយអាចប្រោសលោះយើងបាន ?
- យោងតាម ខទី ១០ តើមនុស្សដែលព្រះយេស៊ូវគ្រីស្ទប្រោសលោះនឹងក្លាយទៅជាអ្វី ? (ពួកស្តេច និងពួកសង្ឃ ដែលរួមបញ្ចូលស្ត្រីជាម្ចាស់ក្សត្រី និងស្ត្រីសង្ឃ ; សូមមើល Bruce R. McConkie *Mormon Doctrine* កំណែទី ២ (ឆ្នាំ ១៩៦៦) ទំព័រ ៦១៣)) ។

សូមឲ្យសិស្សពិចារណាពីអត្ថន័យនៃផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ និងតួនាទីរបស់ព្រះអង្គសង្គ្រោះនៅក្នុងផែនការនោះចំពោះពួកគេផ្ទាល់ ។ សូមអញ្ជើញសិស្សឲ្យសរសេរគំនិត និងអារម្មណ៍របស់ពួកគេចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមប្រាប់ពួកគេថា ពួកគេនឹងត្រូវបានអញ្ជើញឲ្យចែកចាយអ្វី ដែលពួកគេបានសរសេរនៅពេលក្រោយនៅក្នុងមេរៀននេះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗពីក្នុង វិវរណៈ ៥:១១–១៤ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអំពីរបៀបដែលមនុស្សដទៃទៀតបានចូលរួមនៅក្នុងការថ្វាយបង្គំ និងការសរសើរតម្កើងដល់ព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាសួគ៌ ។

- បន្ទាប់ពីកូនចៀមយកសៀវភៅនោះមកពីព្រះហស្តរបស់ព្រះវរបិតាសួគ៌ ហេតុអ្វីតួអង្គដែលមានសិរីរុងរឿងទាំងនោះ និងសត្វលោកទាំងអស់ថ្វាយបង្គំ ហើយសរសើរតម្កើងចំពោះទ្រង់ទាំងពីរអង្គ ? (តួអង្គទាំងនោះបានទទួលស្គាល់អំពីភាពដ៏មហិមារបស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយមានអំណរគុណចំពោះតួនាទីរបស់កូនចៀមនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌) ។
- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះអំពីរឿងដែលអាចដឹកនាំយើងឲ្យថ្វាយបង្គំ ហើយសរសើរតម្កើងដល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ដូចជាតួអង្គ និងសត្វលោកដែលយ៉ូហានបានឃើញ ? (សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្គាល់គោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងទទួលស្គាល់ ហើយមានអំណរគុណចំពោះអ្វីដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់យើង នោះយើងមានបំណងប្រាថ្នាថ្វាយបង្គំ ហើយសរសើរតម្កើងទ្រង់**) ។

សូមចង្អុលបង្ហាញថា តួអង្គដែលមានសិរីល្អរុងរឿង និងសត្វលោកទាំងអស់បានថ្វាយបង្គំព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទនៅក្នុងចម្រៀង ។ ស្រដៀងគ្នានេះដែរ យើងច្រៀងទំនុកតម្កើងដើម្បីថ្វាយបង្គំ ហើយសរសើរតម្កើងដល់ទ្រង់ទាំងពីរអង្គ ។ សូមអញ្ជើញសិស្សឲ្យច្រៀង « ឱ! អស់ធម្មជាតិនៃព្រះយើងអើយ » (*ទំនុកតម្កើង* ល.រ. ៦២) ឬទំនុកតម្កើងមួយទៀតដែលសរសើរ ឬថ្វាយសិរីល្អចំពោះព្រះ ហើយសូមឲ្យពួកគេគិតអំពីរបៀបដែលទំនុកតម្កើងនោះទាក់ទងនឹង វិវរណៈ ៥:៩–១៤ ។

- បន្ថែមពីលើការថ្វាយបង្គំព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទតាមរយៈតន្ត្រី តើយើងអាចធ្វើអ្វីខ្លះទៀតដើម្បីថ្វាយបង្គំទ្រង់ទាំងពីរអង្គ ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់នូវអ្វី ដែលលោកបានបង្រៀនអំពីការថ្វាយបង្គំ ៖



« សេចក្តីពិត និងការថ្វាយបង្គំដ៏ឥតខ្ចោះ រួមមាននៅក្នុងការដើរតាមជំហាននានានៃព្រះរាជបុត្រានៃព្រះ, វាមាននៅក្នុងការរក្សាព្រះបញ្ញត្តិ ព្រមទាំងការគោរពតាមព្រះឆន្ទៈនៃព្រះវរបិតា ទៅនឹងកម្រិតដែលយើងរីកចម្រើនពីព្រះគុណមួយទៅព្រះគុណមួយ រហូតដល់យើងបានសិរីរុងរឿងនៅក្នុងព្រះគ្រីស្ទ ដូចដែលទ្រង់មានសិរីរុងរឿងនៅក្នុងព្រះវរបិតាទ្រង់ដែរ ។ វាលើសពីការគ្រាន់តែការអធិស្ឋាន និងទេសនកថា ព្រមទាំងចម្រៀងទៅទៀត ។ វាគឺជាការរស់នៅតាម ហើយធ្វើតាម និង គោរពតាម ។ វាគឺជាការប្រឹងធ្វើតាមជីវិតនៃអង្គជាគំរូដ៏អស្ចារ្យ » (« How to Worship » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៧១ ទំព័រ ១៣០) ។

- តើការបង្រៀនរបស់អែលឌើរ ម៉ាក់ខន់ឃីបន្ថែមការយល់ដឹងរបស់អ្នកអំពីរបៀបដែលយើងអាចថ្វាយបង្គំចំពោះព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្តេច ?
- តើយើងមានពរយ៉ាងណាតាមរយៈការថ្វាយបង្គំ និងការសរសើរតម្កើងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

សូមសួរសំណួរតាមដាន

ការសួរនូវសំណួរតាមដានអាចជួយអ្នកឲ្យយល់ពីចម្លើយរបស់សិស្សកាន់តែប្រសើរឡើង ។ ឧទាហរណ៍អំពីសំណួរតាមដានរួមមាន « តើអ្នកអាចជួយខ្ញុំឲ្យយល់អំពីអ្វីដែលអ្នកចង់ មានន័យបានទេ ? » និង « តើអ្នកអាចផ្តល់ឧទាហរណ៍មួយអំពីអ្វីដែលចង់មានន័យបានទេ ? » សំណួរទាំងនេះអញ្ជើញសិស្សឲ្យចែកចាយគំនិតនិងអារម្មណ៍របស់ពួកគេ ហើយអញ្ជើញវិញ្ញាណនៃទីបន្ទាល់ចូលទៅក្នុងចម្លើយរបស់សិស្ស ។

- **ហេតុអ្វី យើងមានបំណងថ្វាយបង្គំ ហើយសរសើរតម្កើងព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ? (សូមអញ្ជើញសិស្សឲ្យចែកចាយគំនិត និងអារម្មណ៍មួយចំនួន ដែលពួកគេបានសរសេរកាលពីមុន) ។**

សូមពិចារណាចែកចាយអារម្មណ៍របស់អ្នកអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ដោយដាក់បញ្ចូលនូវហេតុផលដែលអ្នកយល់ព្រមថ្វាយបង្គំទ្រង់ទាំងពីរអង្គ ។

សូមអញ្ជើញសិស្សសញ្ជឹងគិត ហើយឆ្លើយនឹងសំណួរខាងក្រោម នៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- **តើយើងអាចធ្វើអ្វីខ្លះទៀតដើម្បីថ្វាយបង្គំព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ?**

បន្ទាប់ពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីសរសេរហើយ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តអ្វីដែលពួកគេបានសរសេរ ។

វិវរណៈ ៦–១១ ភាគ ១

សេចក្តីផ្តើម

យ៉ូហានបានឃើញការនិមិត្តអំពីកូនចៀមរបស់ព្រះ កំពុងបើកត្រាប្រាំមួយដំបូងនៃក្រាំងដែលបិទត្រានោះ ។ នៅក្នុងត្រាទីប្រាំមួយ យ៉ូហានបានឃើញអ្នកបម្រើរបស់ព្រះដែល « បោកអាវ . . . ក្នុងឈាមរបស់កូនចៀម » (វិវរណៈ ៧:១៤) ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ៦

យ៉ូហានបានឃើញកូនចៀមរបស់ព្រះ កំពុងបើកត្រាប្រាំមួយដំបូងនៃក្រាំងដែលបិទត្រា

សូមអញ្ជើញសិស្សឲ្យចែកចាយកង្វល់នានា ដែលពួកគេមានអំពីការរស់នៅក្នុងថ្ងៃចុងក្រោយ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ ។ ចូរសុំឲ្យសិស្សស្តាប់រកថា ពួកព្យាការីកាលពីបុរាណមានអារម្មណ៍បែបណាដែរអំពីជំនាន់របស់យើង ៖

« ពួកព្យាការី ពួកសង្ឃ និងពួកស្តេច . . . បានទន្ទឹងរង់ចាំដោយសេចក្តីសង្ឃឹមដ៏រីករាយចំពោះសម័យដែលយើងរស់នៅ ហើយបានរីករាយដោយសេចក្តីសង្ឃឹមពីសូគ៌ាដោយអំណរអបត់ដល់ពួកគេបានច្រៀង សរសេរ ហើយព្រមទាំងបានព្យាករពីជំនាន់របស់យើងនេះ » (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ | ទំព័រ ១៨៦) ។

- **តើព្យាការីកាលពីបុរាណមានអារម្មណ៍បែបណាដែរអំពីជំនាន់របស់យើង ?**

សូមចង្អុលបង្ហាញថា យ៉ូហានដែលជាអ្នកទទួលវិវរណៈ គឺជាព្យាការីម្នាក់ដែលបានដឹងអំពីព្រឹត្តិការណ៍នាជំនាន់ចុងក្រោយនេះ ហើយបានព្យាករអំពីជំនាន់របស់យើងជាមួយនឹងការទន្ទឹងរង់ចាំដោយអំណរ ។

នៅពេលសិស្សសិក្សា វិវរណៈ ៦–៧ សូមអញ្ជើញពួកគេឲ្យរកមើលហេតុផលដែលពួកព្យាការីបានទន្ទឹងរង់ចាំជំនាន់របស់យើងដោយអំណរ ។

សូមរំឭកសិស្សថា ដូចដែលបានកត់ត្រានៅក្នុង វិវរណៈ ៥:១–៥ យ៉ូហានបានឃើញក្រាំងមួយដែលមានបិទត្រាទាំងប្រាំពីរ ដែលមានតែកូនចៀមរបស់ព្រះប៉ុណ្ណោះ ដែលសក្តិសមបើកវាបាន ។ សូមពន្យល់ថា នៅក្នុងការនិមិត្តរបស់លោក យ៉ូហានបានឃើញរូបតំណាងនៃព្រឹត្តិការណ៍សំខាន់ៗមួយចំនួនទាក់ទងនឹងរយៈពេលនីមួយៗស្មើមួយពាន់ឆ្នាំ ដែលបានតំណាងដោយត្រាទាំងប្រាំពីរ ។

សូមសរសេរបញ្ជីខាងក្រោមនេះនៅលើ ក្តារខៀន (សូមពិចារណាធ្វើកិច្ចការនេះពីមុនថ្នាក់ចាប់ផ្តើម) ៖

ត្រាទីមួយ (វិវរណៈ ៦:១–២)

ត្រាទីពីរ (វិវរណៈ ៦:៣–៤)

ត្រាទីបី (វិវរណៈ ៦:៥–៦)

ត្រាទីបួន (វិវរណៈ ៦:៧–៨)

ត្រាទីប្រាំ (វិវរណៈ ៦:៩–១១)

សូមចែកក្រដាសមួយសន្លឹកដល់សិស្ស ។ សូមចាត់ត្រាមួយដល់សិស្សម្នាក់ៗ (ត្រានីមួយៗអាចត្រូវបានចាត់ដល់សិស្សច្រើននាក់) ។ សូមឲ្យសិស្សអានសេចក្តីយោងទាំងឡាយ ដែលទាក់ទងនឹងត្រាដែលពួកគេបានចាត់ឲ្យ ហើយគូររូបអំពីព្រឹត្តិការណ៍មួយចំនួន ដែលបានយ៉ូហានបានឃើញទាក់ទងនឹងត្រានោះ ។

បន្ទាប់ពីផ្តល់ពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យបង្ហាញគំនូររបស់ពួកគេទៅសិស្សផ្សេងទៀតតាមលំដាប់លំដោយ ដោយចាប់ផ្តើមជាមួយនឹងសិស្សដែលមានត្រាទីមួយ ។ សូមអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗឲ្យប្រើគំនូររបស់ខ្លួនពន្យល់អំពីអ្វីដែលយ៉ូហានបានឃើញ នៅពេលត្រានោះត្រូវបានបើកឡើង ។ នៅពេលសិស្សប្រាប់ សូមការបង្ហាញរបស់គ្រូបង្រៀន

បទបង្ហាញរបស់គ្រូ

កាលសិស្សត្រូវចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការរៀនសូត្រនេះដើម្បីយល់បទគម្ពីរកាន់តែប្រសើរ ហើយអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ វាគឺជារឿងដ៏សំខាន់ដែលអ្នកនៅតែត្រូវពន្យល់ បញ្ជាក់ ហើយបង្ហាញក្នុងពេលដ៏សមរម្យ ដើម្បីសិស្សអាចយល់ពីបរិបទ និងមាតិកាអំពីវគ្គបទគម្ពីរជាក់លាក់មួយកាន់តែច្បាស់បន្ថែមទៀត ។ចែកចាយការបកស្រាយដ៏ចតុទៅនេះដែលបានផ្តល់ជាយោបល់ពីអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ូមនៃពួកសាវកដប់ពីរនាក់ ។ អ្នកគួរលើកទឹកចិត្តសិស្សឲ្យសរសេរព័ត៌មាននេះនៅក្នុងសៀវភៅកត់ចំណាំក្នុងថ្នាក់ ឬក្នុងសៀវភៅកត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

ត្រាទីមួយ (ប្រហែលឆ្នាំ ៤០០០ ដល់ ៣០០០ មុន គ. ស.)	សេះស = ជ័យជំនះ ធ្នូ = ចម្បាំង មកុដ = អ្នកឈ្នះ អែលឌើរ ម៉ាក់ខន់ឃី បានណែនាំថា ខទី ១–២ ពិពណ៌នាអំពីជំនាន់របស់ហេណុក ហើយថាអ្នកជិះសេះនោះគឺហេណុក (សូមមើល *Doctrinal New Testament Commentary* វ៉ុលទី ៣ [ឆ្នាំ ១៩៦៦–៧៣] ៣:៤៧៦–៧៨) ។
ត្រាទីពីរ (ប្រហែលឆ្នាំ ៣០០០ ដល់ ២០០០ មុន គ. ស.)	សេះក្រហម = ការបង្ហូរឈាម ដាវ = សង្គ្រាម និង ការបំផ្លិចបំផ្លាញ អែលឌើរ ម៉ាក់ខន់ឃី បានផ្តល់យោបល់ថា ខទី ៣–៤ ពិពណ៌នាអំពីជំនាន់ណូអេ នៅពេលអំពើទុច្ចរិតបានកើតមានពាសពេញផ្ទៃផែនដី ។ អ្នកជិះសេះក្រហមនោះអាចជាអារក្ស ឬប្រហែលជា « បុគ្គលម្នាក់ដែលតំណាងឲ្យអ្នកចម្បាំងដែលបានសម្លាប់មនុស្សជាច្រើន » (សូមមើល *Doctrinal New Testament Commentary* ៣:៤៧៨–៧៩) ។
ត្រាទីបី (ប្រហែលឆ្នាំ ២០០០ ដល់ ១០០០ មុន គ. ស.)	សេះខ្មៅ = គ្រោះទុរភិក្ស ជញ្ជីង = អាហារមានតម្លៃថ្លៃ អែលឌើរ ម៉ាក់ខន់ឃី បានផ្តល់យោបល់ថា ខទី ៥–៦ ពិពណ៌នាអំពីជំនាន់របស់អ័ប្រាហាំ នៅពេលមានមនុស្សជាច្រើនបានស្លាប់ដោយសារការស្រេកឃ្លាន (សូមមើល *Doctrinal New Testament Commentary* ៣:៤៧៩–៨០) ។ មនុស្សម្នាក់អាចទិញអាហារបានគ្រាន់តែសម្រាប់រស់ដោយប្រាក់ខែពេញមួយថ្ងៃរបស់ខ្លួន ដែលនេះបង្ហាញពីតម្លៃអាហារដ៏ថ្លៃ ។
ត្រាទីបួន (ប្រហែលឆ្នាំ ១០០០ មុន គ. ស. រហូតដល់កំណើតរបស់ព្រះគ្រីស្ទ)	សេះសម្បុរស្លាំង = សេចក្តីស្លាប់ សេចក្តីស្លាប់ និង ស្ថានឃុំព្រលឹងមនុស្សស្លាប់ = ការបំផ្លិចបំផ្លាញមនុស្សទុច្ចរិត និង ការទទួលពួកគេឲ្យចូលទៅក្នុងស្ថានឃុំវិញ្ញាណ (សូមមើល អេសាយ ៥:១៤) អែលឌើរ ម៉ាក់ខន់ឃី បានផ្តល់យោបល់ថា ខទី ៧–៨ សំដៅលើ « សហស្សវត្សរ៍នៃនគរ និង ប្រជាជាតិដ៏អស្ចារ្យទាំងនោះដែលមានសង្គ្រាម និង ការធ្វើទុក្ខបុកម្នេញប្រឆាំង ព្រមទាំងការឪកាលដាលប្រឆាំង [អ៊ីស្រាអែល] ម្តងហើយម្តងទៀត » (សូមមើល *Doctrinal New Testament Commentary* ៣:៤៨១) ។ ប្រជាជាតិទាំងនោះរួមមាន បាប៊ីឡូន ពើស៊ី អេស៊ីព្ទ ក្រិក និង រ៉ូម ។
ត្រាទីប្រាំ (ប្រហែលចាប់តាំងពីកំណើតរបស់ព្រះគ្រីស្ទរហូតដល់ឆ្នាំ ១០០០ គ. ស.) ។	អាសនា =ការបូជា ព្រលឹងរបស់មនុស្ស=ការធ្វើឃាតដោយសាសនា ពួកគ្រីស្ទានត្រូវបានសម្លាប់ព្រោះជំនឿរបស់ពួកគេ អែលឌើរ ម៉ាក់ខន់ឃី បានផ្តល់យោបល់ថា ខទី ៩–១១ សំដៅលើពួកគ្រីស្ទានពីជំនាន់ដើមជាច្រើន រួមមានពួកសាវកជំនាន់ដើមភាគច្រើនបំផុត ដែលបានស្លាប់ដោយសារសាសនា (សូមមើល *Doctrinal New Testament Commentary* ៣:៤៨២–៨៣) ។ ដោយសារពួកបរិសុទ្ធទាំងនេះបានលះបង់ជីវិតរបស់ពួកគេ « ដោយព្រោះកាន់តាមព្រះបន្ទូល និងសេចក្តីបន្ទាល់ » (វិវរណៈ ៦:៩) ពួកគេត្រូវបានប្រទានឲ្យនូវ « អាវសរុង » ជានិមិត្តសញ្ញានៃភាពបរិសុទ្ធ (សូមមើល វិវរណៈ ៧:១៣–១៤; នីហ្វៃទី៣ ២៧:១៩) ។

បន្ទាប់ពីក្រុមនីមួយៗបានឆ្លើយហើយ សូមពន្យល់ថា ត្រាទីប្រាំមួយតំណាងឲ្យជំនាន់របស់យើង និងព្រឹត្តិការណ៍នានាដែលនឹងដឹកនាំទៅរកសហស្សវត្សរ៍ កាលព្រះយេស៊ូវគ្រីស្ទនឹងគ្រងរាជដោយផ្ទាល់នៅលើផែនដីនេះ (សូមមើល *Doctrinal New Testament Commentary* ៣:៤៨៥–៨៦) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ៦:១២–១៧ហើយពន្យល់ថា ការបកប្រែដោយ យ៉ូសែប ស៊្មីធ សម្រាប់ខទី ១៤ បានចែងថា « ហើយផ្ទៃមេឃបានបើកដូចជាក្រាំងត្រូវបានបើក នៅពេលវាត្រូវបានគេរមូរទៅវិញ ហើយគ្រប់ទាំងភ្នំ កោះ ត្រូវបានរំកិលចេញពីទីតាំងរបស់វា ។ សូមឲ្យសិស្សក្នុងថ្នាក់ធ្វើតាមអកមើលព្រឹត្តិការណ៍ ដែលយ៉ូហានបានឃើញទុកជាមុន ។

- **តើត្រាទីប្រាំមួយបើកនៅពេលណា ? តើយ៉ូហានបានឃើញព្រឹត្តិការណ៍អ្វីខ្លះ ? (សូមពន្យល់ថា ព្រឹត្តិការណ៍ដ៏គ្រោះថ្នាក់ទាំងនេះគឺជាទីសម្គាល់នៃថ្ងៃចុងក្រោយ) ។**
- **យោងតាម ខទី ១៦ តើជនដែលខិតខំរត់គេចពី « សេចក្តីក្រោធ » របស់ព្រះនឹងប្រាថ្នាចង់បានអ្វី ?**
- **តើសំណួរអ្វីទៅត្រូវបានកត់ត្រាទុកនៅក្នុងខទី ១៧ ?**

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ តើនរណាខ្លះនឹងមានលទ្ធភាពអាចឈរបាន ?

សូមពន្យល់ថា វិវរណៈ ៧ ជួយយើងឲ្យយល់ថា តើនរណាដែលនឹងអាចឈរបាន ឬនៅជាមួយនឹងគ្រោះភ័យនៃត្រាទីប្រាំមួយបាន ។

វិវរណៈ ៧

យ៉ូហានបានឃើញអ្នកបម្រើរបស់ព្រះ ដែលបានលាងជម្រះសម្លៀកបំពាក់របស់ពួកគេនៅក្នុងឈាមរបស់កូនចៀម

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៧:១ ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៨ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលអ្វីផ្សេងទៀតដែលយ៉ូហានបានឃើញនៅក្នុងត្រាទីប្រាំមួយ ។

- តើទេវតាទាំងបួនកំពុងធ្វើអ្វី ? (សូមចង្អុលបង្ហាញថា ខ្យល់ដែលកំពុងបក់បោកទប់នោះ មានអំណាចបំផ្លាញជីវិតនៅលើផែនដី ។ សូមមើលផងដែរ គ. និង ស. ៨៦:៥–៧) ។

សូមអញ្ជើញសិស្សម្នាក់អានវិវរណៈ ៧:២–៣ឲ្យឮៗ ហើយឲ្យសិស្សម្នាក់ទៀតអានគោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៩ឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលអ្វី ដែលទេវតាមួយអង្គទៀតមានបន្ទូលទៅកាន់ទេវតាទាំងបួនអង្គនោះ ។

- យោងតាម គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៩តើទេវតា « ឡើងមកពីទិសថ្ងៃរះ » ជានរណា ? (វិវរណៈ ៧:២) ។

សូមពន្យល់ថា ពាក្យ *អេលីយ៉ា* នៅក្នុងឧទាហរណ៍នេះគឺជា « ងារសម្រាប់អ្នកដែលបេសកកម្មរបស់គាត់ [គឺ] ដើម្បីប្រគល់កូនសោ និងអំណាចដល់មនុស្សនៅគ្រាកាន់កាប់ត្រួតត្រាចុងក្រោយនេះ » (*Doctrinal New Testament Commentary* ៣:៤៩១–៩២; សូមមើលផងដែរ Bible Dictionary « Elias ») ។

- តើទេវតាអង្គនេះបានមានបន្ទូលអ្វីខ្លះទៅកាន់ទេវតាទាំងបួនអង្គ ?

សូមពន្យល់ថា « ការបោះត្រា ឬការគូសចំណាំ ‹ នៅត្រង់ថ្ងាសនៃពួកបាវបម្រើរបស់យើង › គឺជាពាក្យប្រៀបធៀបមួយអំពីការលះបង់ការបម្រើ និងទ្រព្យសម្បត្តិរបស់ពួកគេថ្វាយព្រះ (វិវរណៈ ៧:៣, សូមមើលផងដែរ វិវរណៈ ៩:៤; ១៤:១) ។ . . .

« ព្យាការី យ៉ូសែប ស្ម៊ីធ បានបង្រៀនថា ការបោះត្រាលើថ្ងាសនៃពួកស្មោះត្រង់ ‹ គឺមានន័យថា ជាការផ្សារភ្ជាប់ពរជ័យលើក្បាលរបស់ពួកគេ ដែលជាសេចក្តីសញ្ញាអស់កល្បជានិច្ច ហេតុដូច្នោះហើយធ្វើឲ្យការហៅ និង ការរើសតាំងរបស់ពួកគេបានពិតប្រាកដឡើង › (នៅក្នុង *History of the Church* ៥:៥៣០) » (*New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៨] ទំព័រ ៥៨៤) ។

សូមពន្យល់ថា ដូចដែលបានកត់ត្រានៅក្នុង វិវរណៈ ៩ យ៉ូហានបានឃើញនូវអ្វីដែលនឹងកើតឡើងចំពោះជនដែលគ្មានត្រានេះ ។ សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៩:៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលស្ថានភាពរបស់អស់អ្នកដែលគ្មានត្រានេះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សឲ្យអាន វិវរណៈ ៧:៤ ដោយស្ងៀមស្ងាត់ រកមើលថាតើមានមនុស្សប៉ុន្មាននាក់ ដែលត្រូវបានទេវតានេះបោះត្រានៅលើថ្ងាស ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា ព្រះអម្ចាស់បានមានបន្ទូលប្រាប់ព្យាការីយ៉ូសែប ស្ម៊ីធ ថា « ចំនួន ១៤៤,០០០ ដែលបានចែងនៅក្នុង វិវរណៈ ៧:៤–៨ គឺជាចំនួននៃសង្ឃជាន់ខ្ពស់ដែលត្រូវបានតែងតាំងនៅក្នុងចំណោមពូជអំបូរអ៊ីស្រាអែលទាំងដប់ពីរ ដែលនឹងជួយមនុស្សដទៃទៀតឲ្យទទួលបានភាពតម្កើងឡើងរបស់ពួកគេ [សូមមើល គ. និង ស. ៧៧:១១] ។ អ្នកខ្លះបានជឿថា វាមិនមែនជាចំនួនសរុបរបស់មនុស្សដែលនឹងត្រូវបានតម្កើងឡើងឡើយ » (*New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៨] ទំព័រ ៥៨៤) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ៧:៩–១០ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថាយ៉ូហានបានឃើញនរណាទៀត ។

- តើយ៉ូហានបានឃើញនរណា ?
- តើហ្វូងមនុស្សនេះពាក់ ហើយកាន់អ្វី ? (អ្នកគួរពន្យល់ថា ធាងចាកអាចតំណាងឲ្យជោគជ័យ និងអំណរ) ។

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ៧:១៣–១៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា យ៉ូហានបានរៀនអ្វីខ្លះអំពីមនុស្សទាំងនេះ ។

- តើមនុស្សទាំងនេះបានស៊ូទ្រាំនឹងអ្វីខ្លះ ?
- តើអាវវែងរបស់ពួកគេបានប្រែទៅជាពណ៌សដោយរបៀបណា ? (តាមរយៈ « ព្រះលោហិតនៃកូនចៀម »—តំណាងនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ) ។
- យោងតាម ខទី ១៥–១៧ តើប្រជាជនទាំងនេះបានទទួលពរជ័យអ្វីខ្លះ ដោយសារតែពួកគេត្រូវបានធ្វើឲ្យបរិសុទ្ធ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ? (អ្នកអាចចង្អុលបង្ហាញថា ខគម្ពីរទាំងនេះពិពណ៌នាពីអំណរ សេចក្តីសុខសាន្ត និងការលះបង់របស់ជនដែលគ្រងសិរីល្អសេឡេស្ទាល) ។
- តើយើងអាចស្គាល់គោលការណ៍អ្វីខ្លះពីក្នុងខគម្ពីរទាំងនេះ អំពីរបៀបដែលយើងអាចគ្រងសិរីល្អសេឡេស្ទាល ? (សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែត្រូវធ្វើឲ្យប្រាកដថា ពួកគេស្គាល់គោលការណ៍មួយស្របជៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងស៊ូទ្រាំនឹងសេចក្តីទុក្ខលំបាកដោយស្មោះត្រង់ ហើយឲ្យបានបរិសុទ្ធតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងរីករាយនូវសិរីល្អសេឡេស្ទាលជាមួយនឹងព្រះ** ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតថា តើពួកគេនឹងមានអារម្មណ៍បែបណា ដែលត្រូវឈរ ហើយធ្វើឲ្យបរិសុទ្ធនៅក្នុងវត្តមានរបស់ព្រះនោះ ។

- តើអារម្មណ៍ទាំងនេះប្រៀបធៀបទៅនឹងអារម្មណ៍របស់មនុស្ស ដែលបានពិពណ៌នានៅក្នុង វិវរណៈ ៦:១៦ យ៉ាងដូចម្តេច ?
- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យព្រះអង្គសង្គ្រោះអាចបន្សុទ្ធយើងតាមរយៈដង្វាយធួនរបស់ទ្រង់ ?
- តើការចងចាំពីពរជ័យនៃសិរីល្អសេឡេស្ទាលបានជួយអ្នក នៅក្នុងការខិតខំដើម្បីស៊ូទ្រាំនឹងសេចក្តីទុក្ខលំបាក ហើយប្រែជាបរិសុទ្ធ យ៉ាងដូចម្តេច ?

សូមអំពាវនាវសិស្សអំពីបញ្ជីនៃកង្វល់ ដែលបានសរសេរនៅលើក្តារខៀនកាលពីដើមមេរៀន ។ សូមអញ្ជើញពួកគេឲ្យពិចារណាថា គោលការណ៍ដែលបានសរសេរនៅលើក្តារខៀនអាចជួយពួកគេបានដោយរបៀបណា នៅពេលពួកគេមានការព្រួយបារម្ភអំពីការរស់នៅក្នុងថ្ងៃចុងក្រោយនេះ ។ សូមអញ្ជើញសិស្សស្ម័គ្រចិត្តពីរបីនាក់ ឲ្យចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សឲ្យចំណាយពេលពីរបីនាទី សញ្ជឹងគិតអំពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍ដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យកត់ត្រាពីការបំផុសគំនិតទាំងឡាយ ដែលពួកគេទទួល ។

វិវរណៈ ៦–១១ ភាគ ២

សេចក្តីផ្តើម

យ៉ូហានបានឃើញការបើកត្រាទាំងប្រាំពីរ ហើយបានរៀនអំពីបេសកកម្មរបស់លោក ដើម្បីចូលរួមនៅក្នុងការប្រមូលផ្តុំសាសន៍អ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។

សូមលើកទឹកចិត្តសិស្សឲ្យសិក្សាព្រះគម្ពីររៀងរាល់ថ្ងៃ ហើយអានអត្ថបទសម្រាប់វគ្គសិក្សានេះ ។

នៅដើមវគ្គសិក្សានេះ សិស្សត្រូវបានលើកទឹកចិត្តឲ្យអានព្រះគម្ពីរសញ្ញាថ្មីទាំងមូល ។ ចូរសើបសួរមើលថា សិស្សរបស់អ្នកកំពុងធ្វើតាមគោលដៅនេះដល់កម្រិតណា ហើយផ្តល់ការគាំទ្រ និងការលើកទឹកចិត្តប្រសិនបើចាំបាច់ ។ នៅពេលសិស្សបញ្ចប់គោលដៅនេះ សូមលើកទឹកចិត្តពួកគេឲ្យបន្តសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ដើម្បីពួកគេអាចបន្តទទួលបានពរជ័យដែលកើតឡើងមកពីការធ្វើកិច្ចការនេះ ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ៨–៩

យ៉ូហានឃើញការបើកត្រាទាំងប្រាំពីរ

សូមចែកសិស្សជាគូ ហើយឲ្យសិស្សពន្យល់ទៅដៃគូរបស់ពួកគេនូវអ្វី ដែលពួកគេបានរៀននៅក្នុងការសិក្សារបស់ពួកគេក្នុង វិវរណៈ ៦–៧ ដែលអាចជួយពួកគេឲ្យបន្តមានចិត្តរីករាយ ហើយមានភាពវិជ្ជមាននៅក្នុងភាពមិនប្រាកដប្រជា និងភាពច្របូកច្របល់ ។


សូមសរសេរនៅលើក្តារខៀននូវគោលការណ៍ដូចតទៅនេះ ដែលបានស្គាល់នៅក្នុងមេរៀនមុន ៖ **ប្រសិនបើយើងស៊ូទ្រាំនឹងសេចក្តីទុក្ខលំបាកដោយស្មោះត្រង់ ហើយឲ្យបានបរិសុទ្ធតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងរីករាយនឹងសិរីល្អសេឡេស្ទាលជាមួយនឹងព្រះ** ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលអំពីរបៀប ដែលគោលការណ៍នេះទាក់ទងនឹងព្រឹត្តិការណ៍ដែលពួកគេនឹងរៀននៅក្នុងមេរៀននៅថ្ងៃនេះ ។

សូមរៀបចំតារាងខាងក្រោមជាក្រដាសសម្រាប់ចែក ឬ គូរវានៅលើក្តារខៀន ៖

- យោងតាមតារាងនេះ តើមានខគម្ពីរប៉ុន្មាននៅក្នុងគម្ពីរវិវរណៈ ដែលមានព្រឹត្តិការណ៍នៃត្រាប្រាំមួយដំបូង ? (២៥) ។
- តើមានខគម្ពីរប៉ុន្មាន ដែលមានព្រឹត្តិការណ៍នៃត្រាទីប្រាំពីរ ? (២១១ + ១៥ = ២២៦) ។

ការនិមិត្តរបស់ យ៉ូហាន អំពីត្រាទាំងប្រាំពីរនៅក្នុងគម្ពីរវិវរណៈ

ត្រាទីមួយៗតំណាងឲ្យរយៈពេលមួយពាន់ឆ្នាំនៃជីវិតលើផែនដី (សូមមើល គ. និង ស. ៧៧:៦-៧) ។



- ហេតុអ្វីអ្នកគិតថា យ៉ូហានបានផ្តោតការសរសេររបស់លោកលើព្រឹត្តិការណ៍នៃត្រាទីប្រាំពីរ ?

សូមសង្កេប វិវរណៈ ៨:១–៦ ដោយពន្យល់ថា ខគម្ពីរទាំងនេះពិពណ៌នាអំពីព្រះអង្គសង្គ្រោះបើកត្រាទីប្រាំពីរ ។ យ៉ូហានបានឃើញទេវតាទីប្រាំពីរដែលទទួលបានត្រែប្រាំពីរ ។ កាលពីបុរាណ ត្រែត្រូវបានប្រើដើម្បី « ប្រកាសភាពអាសន្ន ឲ្យសញ្ញា [កងទ័ព] សម្រាប់ចម្បាំង ឬប្រកាសការមកដល់របស់ស្តេច » (Gerald N. Lund, « Seeing the Book of Revelation as a Book of Revelation » *Ensign* ខែ ធ្នូ ឆ្នាំ ១៩៨៧ ទំព័រ ៥០) ។ នៅក្នុងឧទាហរណ៍នេះ ការផ្លុំត្រែនឹងឲ្យសញ្ញានូវការចាប់ផ្តើមនៃការញាំញី និងការបំផ្លិចបំផ្លាញនៅក្នុងការរៀបចំសម្រាប់រជ្ជកាលនៃសហស្សវត្សរ៍របស់ព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សឲ្យសរសេរ « ត្រាទីប្រាំពីរ » នៅផ្នែកខាងលើនៃក្រដាសមួយសន្លឹក ឬនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ហើយគូររូបត្រែប្រាំពីរនៅគែមទំព័រផ្នែកខាងក្រោម ។

សូមសរសេរសេចក្តីយោងខាងក្រោមនេះនៅលើក្តារខៀន ប៉ុន្តែលុបចោលសំណួរដែលមានបន្ទាប់ពីសេចក្តីយោងនីមួយៗ ។ សូមអញ្ជើញសិស្សឲ្យសរសេរសេចក្តីយោងនោះនៅក្បែរត្រែលើក្រដាសរបស់ពួកគេ ៖



ទីមួយ—វិវរណៈ ៨:៧ ។ តើមានអ្វីបានកើតឡើងជាលទ្ធផលនៃ « ព្រិល ហើយភ្លើង » ដែលបានធ្លាក់ចុះមកផែនដី កាលទេវតាទីមួយបានផ្លុំត្រែរបស់ខ្លួន ?



ទីពីរ—វិវរណៈ ៨:៨–៩ ។ តើរឿងបីយ៉ាងដែលត្រូវទទួលរងនៅពេលត្រែទីពីរត្រូវបានបន្លឺឡើងជាអ្វីទៅ ?



ទីបី—វិវរណៈ ៨:១០–១១ ។ តើផ្កាយដែលធ្លាក់មកនោះឈ្មោះអ្វី ? (សូមពន្យល់ថា ស្លែង គឺជារុក្ខជាតិល្វីងមួយប្រភេទដែលប្រើដើម្បីតំណាងឲ្យ « ភយន្តរាយដ៏ល្វីងជូរចត់ ឬភាពសោកសៅ » ។ Bible Dictionary, « Wormwood » ។) ។ តើមានអ្វីកើតឡើងនៅពេលវាធ្លាក់មក ?



ទីបួន—វិវរណៈ ៨:១២ ។ បន្ទាប់ពីការបន្លឺសំឡេងនៃត្រែទីបួន តើអ្វីទៅជារឿងបីយ៉ាងដែលមានភាពងងឹតខ្លះៗនោះ ?



ទីប្រាំ—វិវរណៈ ៩:១–៣ ។ តើអ្វីទៅដែលចេញមកពីបាតរណ្តៅ កាលទេវតាទីប្រាំបើកវា ?



ទីប្រាំមួយ—វិវរណៈ ៩:១៣–១៦, ១៨ ។ តើមានទាហានជាច្រើននាក់ដែលបានចូលរួមនៅក្នុងចម្បាំងដ៏ធំ ដែលយ៉ូហានបានឃើញបន្ទាប់ពីត្រែទីប្រាំមួយបានបន្លឺសំឡេងឡើង ? តើផ្នែកអ្វីនៃខ្លួនរបស់មនុស្សដែលលោកបានឃើញថា ត្រូវបានសម្លាប់នៅក្នុងចម្បាំងនេះ ?



ទីប្រាំពីរ—វិវរណៈ ១១:១៥ ។

សូមចែកសិស្សជាប្រាំមួយក្រុម ហើយចាត់ឲ្យក្រុមនីមួយៗនូវសេចក្តីយោងបទគម្ពីរមួយក្នុងចំណោមសេចក្តីយោងទាំងប្រាំមួយ ដែលមាននៅលើក្តារខៀន (ប្រសិនបើមានសិស្សតិច អ្នកគួរឲ្យសេចក្តីយោងច្រើនឲ្យដល់ក្រុមមួយចំនួន) ។ សូមឲ្យក្រុមទាំងឡាយអានបទគម្ពីររបស់ខ្លួនរួមគ្នាឮៗ រកមើលអ្វីដែលបានកើតឡើងបន្ទាប់ពីការបន្លឺសំឡេងនៃត្រែទាំងឡាយ ។ សូមអញ្ជើញពួកគេឲ្យសរសេរអ្វីដែលពួកគេរកឃើញនៅក្បែរត្រែដែលត្រឹមត្រូវលើក្រដាសរបស់ពួកគេ ។

បន្ទាប់ពីផ្តល់ពេលឲ្យគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗឲ្យប្រាប់អំពីអ្វីដែលពួកគេបានរកឃើញ ។ សូមអញ្ជើញសិស្សឲ្យសរសេរការរកឃើញរបស់ក្រុមនីមួយៗ នៅក្បែរត្រែដែលត្រឹមត្រូវលើក្រដាសរបស់ពួកគេ ។ នៅពេលសិស្សប្រាប់ពីចម្លើយប្រសិនបើចាំបាច់ សូមសួរសំណួរដែលភ្ជាប់នឹងសេចក្តីយោងបទគម្ពីរដែលពួកគេមាន ។

- តើគោលការណ៍ដែលយើងស្គាល់នៅក្នុងមេរៀនមុន អាចជួយយើងឲ្យជួយជនដែលកំពុងរស់នៅក្នុងព្រឹត្តិការណ៍នៃត្រាទីប្រាំពីរបានយ៉ាងដូចម្តេច ?

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ៩:២០–២១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ពួកទុច្ចរិត ដែលរួចផុតពីការញាំញីទាំងនេះ នឹងឆ្លើយតបយ៉ាងដូចម្តេច ។ សូមអញ្ជើញសិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើការណ៍នេះបង្រៀនយើងអ្វីខ្លះ អំពីសេចក្តីទុច្ចរិតរបស់មនុស្សទាំងនេះ ?

វិវរណៈ ១០

ទេវតាមួយអង្គណែនាំយ៉ូហានអំពីបេសកកម្មរបស់លោកនៅថ្ងៃចុងក្រោយ

សូមពន្យល់ថា វិវរណៈ ១០ មានន័យការដ្ឋាកមួយនៅក្នុងរឿងនិទានអំពីការបន្លឺសំឡេងត្រែទាំងប្រាំពីរ និងសេចក្តីទុក្ខវេទនាដែលទាក់ទង។ យើងអាននៅក្នុងជំពូកនេះថា យ៉ូហានត្រូវបានណែនាំដោយទេវតាមួយអង្គទៀត ។

សូមសរសេរពាក្យ *ផ្អែម* និង *ជូរចត់*នៅលើក្តារខៀន ។

- តើបទពិសោធន៍ណាខ្លះនៅក្នុងជីវិត ដែលអាចលើកមកពិចារណាថាមានទាំងភាពផ្អែមល្ហែម និងភាពជូរចត់ ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១០:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ទេវតានោះកំពុងកាន់អ្វី ។

- តើទេវតានោះកំពុងកាន់អ្វី ?

សូមអញ្ជើញឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ១០:៨–១១ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា យ៉ូហានបានប្រាប់ឲ្យធ្វើអ្វីខ្លះជាមួយនឹងសៀវភៅនោះ ។

- តើយ៉ូហានបានប្រាប់ឲ្យធ្វើអ្វីខ្លះជាមួយនឹងសៀវភៅនោះ ? តើវាមានរសជាតិយ៉ាងណាដែរ ?

ចូរអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:១៤ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាការបរិភោគសៀវភៅរបស់យ៉ូហានតំណាងឲ្យអ្វី ។

- យោងតាមខគម្ពីរនេះ តើការបរិភោគសៀវភៅរបស់យ៉ូហានតំណាងឲ្យអ្វី ? (ការទទួលយករបស់យ៉ូហាននូវបេសកកម្មរបស់លោកដើម្បីជួយ « ប្រមូលផ្តុំពូជអំបូរនៃអ៊ីស្រាអែល » ហើយ « ស្តារឡើងគ្រប់យ៉ាងឡើងវិញ » នៅថ្ងៃចុងក្រោយ) ។

សូមចង្អុលបង្ហាញថា យ៉ូហានមានពរដោយសារលោកពុំបានស្លាប់ទេ ដើម្បីលោកអាចនាំយកបុគ្គលទាំងឡាយទៅកាន់ព្រះអង្គសង្គ្រោះ (សូមមើល គ. និង ស. ៧:១–៤) ។

- តើអ្វីទៅដែលយ៉ូហានអាចនឹងជួបនៅក្នុងការបំពេញបេសកកម្មរបស់លោក ដែលនឹងជាភាពផ្អែមល្ហែម ? តើអ្វីទៅអាចនឹងមានភាពជូរចត់ ?

វិវរណៈ ១១

យ៉ូហានឃើញព្យាការីពីររូបត្រូវបានសម្លាប់នៅយេរូសាឡិម និងការបន្លឺសំឡេងនៃត្រែទីប្រាំពីរ

សូមពន្យល់ថា វិវរណៈ ១១ ចាប់ផ្តើមជាមួយនឹងការពិពណ៌នារបស់យ៉ូហានអំពីព្រឹត្តិការណ៍ដែលនឹងកើតមុនការបន្លឺសំឡេងនៃត្រែទីប្រាំពីរ និងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ នៅពេលគ្រានេះ ជនទុច្ចរិតនឹងមានអំណាចច្រើន ហើយគ្រប់គ្រងលើផែនដី ហើយកងទ័ពមួយក្រុមនឹងឱតខំវាយលុកក្រុងយេរូសាឡិម ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១១:៣–៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាតើសាក្សីពីរនាក់នឹងធ្វើអ្វីខ្លះ នៅក្នុងយេរូសាឡិមនៅគ្រានោះ ។

- តើសាក្សីពីរនាក់នេះនឹងធ្វើអ្វីខ្លះ ?
- តើឃ្លា « ភ្លើង [នឹងចេញ] ពីមាត់គេមក » អាចនឹងមានន័យយ៉ាងណា ? (ខទី ៥) ។ (ឃ្លានេះអាចជានិមិត្តសញ្ញាអំពីឥទ្ធិពលនៃទីបន្ទាល់ដែលពួកគេនឹងថ្លែង [សូមមើល យេរេមា ៥:១៤, ២០:៩]) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាសាក្សីពីរនាក់នោះនឹងជានរណា ។ សូមឲ្យសិស្សរាយការណ៍ពីអ្វី ដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១១:៧–១២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាអ្វីនឹងកើតឡើងចំពោះពួកព្យាការីទាំងនេះបន្ទាប់ពីពួកលោកបញ្ចប់ការងារបម្រើរបស់លោកនៅក្នុងចំណោមពួកយូដា ។

- តើជនទុច្ចរិតនឹងមានប្រតិកម្មបែបណា នៅពេលសាក្សីទាំងពីររូបនេះត្រូវបានគេសម្លាប់ ?
- តើនឹងមានអ្វីកើតឡើងចំពោះសាក្សីទាំងពីររូបនេះ បន្ទាប់ពីស្លាប់បានបីថ្ងៃកន្លះមក ?
- តើប្រជាជននោះនឹងមានប្រតិកម្មយ៉ាងណា នៅពេលសាក្សីទាំងពីររូបនោះរស់ពីស្លាប់វិញ ហើយត្រូវបាននាំទៅកាន់ស្ថានសួគ៌ ?

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ១១:១៣–១៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថានឹងមានអ្វីកើតឡើងពីមុន និងនៅពេលត្រែទីប្រាំពីរត្រូវបានបន្លឺសំឡេងឡើង ។ សូមអញ្ជើញសិស្សឲ្យសរសេរអ្វីដែលពួកគេរកឃើញនៅលើក្រដាសរបស់ពួកគេក្បែរត្រែទីប្រាំពីរ ។

- បន្ទាប់ការបន្លឺសំឡេងនៃត្រែទីប្រាំពីរ តើនរណានឹងគ្រង « នគរទាំងប៉ុន្មាននៅលោកីយ៍នេះ » ? (ខទី ១៥) ។

សូមសង្ខេប វិវរណៈ ១១:១៦–១៩ ដោយពន្យល់ថា មានពួកអែលឌើរ ២៤ នាក់បានថ្លែងអំណរគុណ ហើយសរសើរព្រះដែលបានប្រទានរង្វាន់ដល់មនុស្សសុចរិត ហើយដាក់ទោសដល់ជនទុច្ចរិត ។ យ៉ូហានក៏បានឃើញនៅក្នុងការនិមិត្តផងដែរ អំពីព្រះវិហារបរិសុទ្ធនៃព្រះនៅស្ថានសួគ៌ និងហឹបនៃសេចក្តីសញ្ញាដែលតំណាងឲ្យវត្តមានរបស់ព្រះ ។

សូមបញ្ចប់មេរៀននៅថ្ងៃនេះដោយចែកចាយអារម្មណ៍របស់អ្នកផ្ទាល់អំពីអំណរគុណ ហើយសរសើរចំពោះព្រះសម្រាប់សេចក្តីល្អ និងយុត្តិធម៌របស់ទ្រង់ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

វិវរណៈ ៨–១១ ។ សេចក្តីអធិប្បាយបន្ថែម

សម្រាប់ព័ត៌មានបន្ថែមស្តីពីមាតិកានៃ វិវរណៈ ៨–១១ សូមមើលសេចក្តីអធិប្បាយសម្រាប់ជំពូកទាំងនេះដែលមាននៅក្នុង *New Testament Student Manual* (Church Educational System manual ឆ្នាំ ២០១៨) ទំព័រ ៥៨៥–៨៩ ។

វិវរណៈ ១០:១–៣, ៨–១១ ។ ក្រាំងតូចដែលយ៉ូហានបានប្រទានឲ្យបរិភោគ

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកម្រងនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖

« ទង្វើរបស់យ៉ូហាននៃការបរិភោគក្រាំងមួយដែលមាននូវបន្ទូលព្រះចំពោះលោក វាគឺជាការគោរពតាមប្រពៃណី និងទំនៀមទម្លាប់ពីបុរាណរបស់អ៊ីស្រាអែល ។ ទង្វើនោះបានបង្ហាញយ៉ាងសំខាន់ថា លោកកំពុងបរិភោគនូវនំបុ័ងនៃជីវិត ថាលោកកំពុងទទួលទាននៃបន្ទូលល្អរបស់ព្រះ ថាលោកកំពុងទទួលទានបន្ទូលរបស់ព្រះគ្រីស្ទ—ដែល ‹ មានភាពផ្អែមល្ហែមដូចជាទឹកឃ្មុំនៅក្នុងមាត់របស់លោក › ។ ប៉ុន្តែវា ‹ ពោះរបស់លោកឈឺ › នោះគឺជាការកាត់សេចក្តី និងការញ៉ាំញីដែលបានសន្យាចំពោះជនដែលបន្ទូលរបស់ព្រះអម្ចាស់ត្រូវបានបញ្ជូនទៅ ហើយធ្វើឲ្យលោកអស់សង្ឃឹម និងមានភាពសោកសៅក្នុងព្រលឹង » (*Doctrinal New Testament Commentary* វ៉ុលទី ៣ [ឆ្នាំ ១៩៦៥–៧៣] ៣:៥០៧) ។

« ក្រាំងនោះ ‹ ផ្អែមដូចទឹកឃ្មុំ › នៅក្នុងមាត់របស់យ៉ូហាន ប៉ុន្តែ ‹ ល្វីង › នៅក្នុងពោះរបស់លោក (វិវរណៈ ១០:១០) អាចនឹងប្រាប់ថា បេសកកម្មរបស់លោកនឹងទាក់ទងជាមួយបទពិសោធន៍ផ្អែមល្ហែម ហើយរីករាយជាច្រើន ប៉ុន្តែក៏មានបទពិសោធន៍នៃការបដិសេធ និងឈឺចាប់ផងដែរ (សូមមើលផងដែរ ទំនុកដំកើង ១១៩:១០៣) » (*New Testament Student Manual* [Church Educational System manual ឆ្នាំ ២០១៨] ទំព័រ ៥៤៨) ។

មេរៀនសិក្សានៅផ្ទះ

វិវរណៈ ១–១១ (មេរៀនទី ៣១)

ការរៀបចំសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីព្រឹត្តិការណ៍គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា វិវរណៈ ១–១១ (មេរៀនទី ៣១) ពុំមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (វិវរណៈ ១–៣)

នៅពេលសិស្សសិក្សាអំពីវិវរណៈរបស់សាវកយ៉ូហាន ពួកគេបានរៀនថា នៅពេលយើងអាន ស្វែងរកការយល់ដឹង ហើយគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះយើងនឹងបានពរ ។ យ៉ូហានបានបង្រៀនសមាជិកសាសនាចក្រថា ព្រះយេស៊ូវគ្រីស្ទឃុំគ្រងហើយមើលថែពួកអ្នកដើរតាមដ៏ស្មោះត្រង់របស់ទ្រង់ ហើយថាទ្រង់គឺជាអង្គដែលមានព្រះជន្មឡើងវិញជាំរុងរឿង ដែលមានព្រះចេស្តាលើសេចក្តីស្លាប់ និងស្ថាននរក ។ សិស្សក៏បានរៀនផងដែរថា នៅពេលយើងបើកទ្វារទទួលយកព្រះអង្គសង្គ្រោះ ទ្រង់នឹងយាងចូលមករកយើង ហើយបរិភោគជាមួយនឹងយើង ។

ថ្ងៃទី ២ (វិវរណៈ ៤–៥)

នៅក្នុងមេរៀននេះ សិស្សអានអំពីការនិមិត្តរបស់យ៉ូហានអំពីកូនចៀមរបស់ព្រះ ហើយរៀននូវសេចក្តីពិតដូចតទៅនេះ ៖ នៅពេលយើងស្គាល់អំពីមហិទ្ធិឫទ្ធិរបស់ព្រះវរបិតាសួគ៌ នោះយើងមានបំណងចង់ថ្វាយបង្គំ ហើយសរសើរតម្កើងទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទគឺជាព្រះតែមួយអង្គគត់ដែលសក្តិសម ហើយអាចប្រោសលោះយើងបាន ។ នៅពេលយើងស្គាល់ ហើយមានអំណរគុណចំពោះអ្វីដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់យើង នោះយើងមានបំណងចង់ថ្វាយបង្គំ ហើយសរសើរតម្កើងចំពោះទ្រង់ទាំងពីរអង្គ ។

ថ្ងៃទី ៣ (វិវរណៈ ៦–៧)

នៅពេលសិស្សបានរៀនអំពីត្រាទាំងប្រាំពីរ ពួកគេបានរកឃើញថា ប្រសិនបើយើងស៊ូទ្រាំនឹងសេចក្តីទុក្ខលំបាកដោយស្មោះត្រង់ ហើយប្រែក្លាយជាបរិសុទ្ធតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងរីករាយនឹងសិរីល្អសេឡេស្ទាលជាមួយនឹងព្រះ ។

ថ្ងៃទី ៤ (វិវរណៈ ៨–១១)

សិស្សបានរំឭកឡើងវិញនូវគោលការណ៍ដែលបានស្គាល់នៅក្នុងមេរៀនសម្រាប់ថ្ងៃទី ៣ នៅពេលពួកគេបានរៀនអំពីការនិមិត្តរបស់យ៉ូហាន ទាក់ទងនឹងការបើកត្រាទាំងប្រាំពីរនោះ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់នូវអ្វីដែលព្រះអម្ចាស់នឹងធ្វើសម្រាប់យើង ដោយសារទ្រង់ស្គាល់ ហើយស្រឡាញ់យើង ។ លើសពីនេះទៀត វាអាចជួយសិស្សឲ្យស្គាល់ថា តើពួកគេត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ២–៣

យ៉ូហានសរសេរអំពីបន្ទូលទាំងឱ្យាយរបស់ព្រះយេស៊ូវគ្រីស្ទដល់ថ្នាក់ដឹកនាំនៃក្រុមជំនុំទាំងប្រាំពីរ ។

កំណត់ចំណាំ ៖ សម្រាប់ព័ត៌មានបន្ថែមអំពីសេចក្តីណែនាំរបស់ព្រះអម្ចាស់ដល់ក្រុមជំនុំទាំងប្រាំពីររបស់សាសនាចក្រ អ្នកគួរមើលនៅក្នុង *New Testament Student Manual* (Church Educational System manual ឆ្នាំ ២០១៤) ទំព័រ ៥៣១–៣២ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវដំណើររឿងខាងក្រោមដោយសិស្ទើរ ស៊ីឌនី អេស រណលស៍ អតីតសមាជិកមួយរូបនៅក្នុងគណៈប្រធានអង្គបឋមសិក្សាទូទៅ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលថា តើពួកគេអាចរៀនអ្វីខ្លះនៅក្នុងដំណើររឿងនេះអំពីព្រះអម្ចាស់ ។



« សិស្ទើរ ហ្គេល ក្លេត នៃគណៈប្រធានអង្គបឋមសិក្សាទូទៅ និងស្វាមីគាត់បានរស់ក្នុងប្រទេសប្រេស៊ីលអស់រយៈពេលជាច្រើនឆ្នាំ ។ ថ្មីៗនេះ គាត់មានកិច្ចការមួយខាងអង្គការបឋមសិក្សានៅប្រទេសជប៉ុន ។ នៅពេលគាត់ដើរចូលទៅក្នុងសាលាជំនុំនៅថ្ងៃអាទិត្យ គាត់បានសង្កេតឃើញគ្រួសារជនជាតិប្រេស៊ីលមួយគ្រួសារនៅក្នុងចំណោមពួកបរិសុទ្ធជប៉ុន ។ . . . គាត់មានពេលតែមួយនាទីដើម្បីរាក់ទាក់និងពួកគេ ហើយបានដឹងថា ម្តាយ និងកូនៗមានចិត្តសោមនស្សខ្លាំងណាស់ ប៉ុន្តែសង្កេតឃើញថាឪពុកអង្គុយយ៉ាងស្ងៀមស្ងាត់ ។ ‹ ខ្ញុំនឹងមានឱកាសនិយាយនឹងពួកគេក្រោយពីការប្រជុំ › គាត់បានគិត នៅពេលគាត់បានប្រញាប់ឡើងទៅអង្គុយនៅលើវេទិកា ។ គាត់បានថ្លែងសុន្ទរកថារបស់គាត់ជាភាសាអង់គ្លេស ហើយត្រូវបានគេបកប្រែជាភាសាជប៉ុន រួចគាត់បានទទួលការបំផុសឲ្យថ្លែងទីបន្ទាល់ជាភាសាព័រទុយហ្គាល់ផងដែរ ។ គាត់រៀងស្ទាក់ស្ទើរដោយសារគ្មានអ្នកបកប្រែជាភាសាព័រទុយហ្គាយ ហើយមនុស្ស ៩៨ ភាគរយនឹងពុំយល់អំពីអ្វីដែលគាត់នឹងនិយាយឡើយ ។

« បន្ទាប់ពីការប្រជុំនោះ ឪពុកដែលជាជនជាតិប្រេស៊ីលរូបនោះបានដើរមករកគាត់ ហើយពោលថា ‹ សិស្ទើរ ទំនៀមទម្លាប់នៅទីនេះមានភាពខុសប្លែកខ្លាំងណាស់ ហើយខ្ញុំបានឯកោតែឯង ។ ការមកព្រះវិហារដោយពុំបានយល់អ្វីសោះនោះ វាគឺជារឿងពិបាកណាស់ ។ ពេលខ្លះខ្ញុំគិតថា វានឹងប្រសើរជាង ប្រសិនបើខ្ញុំនៅផ្ទះអានព្រះគម្ពីរវិញនោះ ។ ខ្ញុំបានប្រាប់ភរិយារបស់ខ្ញុំថា « ខ្ញុំនឹងសាកល្បងម្តងទៀត » ហើយខ្ញុំបានមកនៅថ្ងៃនេះដោយគិតថា វាគឺជាលើកចុងក្រោយសម្រាប់ខ្ញុំ ។ នៅពេលអ្នកថ្លែងទីបន្ទាល់របស់អ្នកជាភាសាព័រទុយហ្គាល់ ព្រះវិញ្ញាណបានប៉ះដល់ដួងចិត្តខ្ញុំ ហើយខ្ញុំបានដឹងថា នេះគឺជាកន្លែងដែលខ្ញុំត្រូវមក ។ ព្រះជ្រាបថាខ្ញុំនៅទីនេះ ហើយទ្រង់នឹងជួយខ្ញុំ › » (« He Knows Us; He Loves Us » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ៧៦) ។

- តើយើងអាចរៀនអ្វីខ្លះអំពីព្រះអម្ចាស់នៅក្នុងដំណើររឿងនេះ ?

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ ដោយសារព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ . . . នៅពេលសិស្សសិក្សា វិវរណៈ ២–៣ សូមអញ្ជើញសិស្សឲ្យរកមើលសេចក្តីពិតដែលជួយពួកគេឲ្យយល់ថា ព្រះអម្ចាស់អាចធ្វើអ្វីខ្លះសម្រាប់ពួកគេ ដោយសារទ្រង់ស្គាល់ពួកគេនោះ ។

សូមពន្យល់ថា វិវរណៈ ២–៣ មាននូវកំណត់ត្រារបស់សាវកយ៉ូហានអំពីបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទទៅពួកជំនុំទាំងប្រាំពីររបស់សាសនាចក្រនៅអាស៊ីតូច (ប្រទេសតួគីបច្ចុប្បន្ន) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២:១–៣, ៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ព្រះអម្ចាស់បានជ្រាបអ្វីខ្លះអំពីពួកបរិសុទ្ធក្នុងអេភេសូរ ។

- តើព្រះអម្ចាស់បានជ្រាបអ្វីខ្លះអំពីពួកបរិសុទ្ធនៅអេភេសូរ ? (សូមពន្យល់ថា ពាក្យ *ពួកនីកូឡាស* នៅក្នុង ខទី ៦ អាចសំដៅទៅលើក្រុមដែលសមាជិករបស់ខ្លួនបានប្រកាសថា ពួកគេអាចធ្វើអំពើបាបខាងផ្លូវភេទដោយគ្មានការដាក់ទោស ដោយសារតែព្រះគុណរបស់ព្រះ និងសង្គ្រោះពួកគេ [សូមមើល Bible Dictionary « Nicolaitans »]) ។

សូមចង្អុលបង្ហាញថា ខគម្ពីរទាំងនេះកត់ត្រាថា ព្រះអម្ចាស់បានសរសើរពួកបរិសុទ្ធចំពោះកិច្ចការល្អរបស់ពួកគេ ។ សូមដាក់បន្ថែមទៅនឹងឃ្លានៅលើក្តារខៀនដើម្បីឲ្យវាមានន័យដូចតទៅនេះ ៖ *ដោយសារព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ ទ្រង់អាចប្រទាននូវការសរសើរដោយផ្ទាល់ដល់យើង . . .*

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២:៤–៥ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានជ្រាបអ្វីខ្លះទៀតអំពីពួកបរិសុទ្ធក្នុងអេភេសូរ ។

- តើព្រះអម្ចាស់បានជ្រាបអ្វីខ្លះទៀត អំពីពួកបរិសុទ្ធនៅអេភេសូរ ?

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់កំពុងប្រទានការកែតម្រូវដល់ពួកបរិសុទ្ធ ដោយសារតែអំពើបាបរបស់ពួកគេ ។ សូមបំពេញឃ្លានៅលើក្តារខៀនដើម្បីឲ្យវាបង្ហាញនូវសេចក្តីពិតដូចតទៅនេះ ៖ **ដោយសារព្រះអម្ចាស់ស្គាល់យើងម្នាក់ៗ ទ្រង់អាចប្រទាននូវការសរសើរ និងការកែតម្រូវដោយផ្ទាល់ដល់យើង ។**

- តើមានវិធីអ្វីខ្លះដែលយើងអាចទទួលបានការសរសើរ និងការកែតម្រូវដោយផ្ទាល់មកពីព្រះអម្ចាស់ ? (តាមរយៈការអធិស្ឋាន ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់យើង តាមរយៈពាក្យទូន្មានមកពីថ្នាក់ដឹកនាំសាសនាចក្រ និងឪពុកម្តាយ ព្រមទាំងពររបស់លោកអយ្យកោ) ។
- តើការដឹងថា ព្រះអម្ចាស់អាចប្រទានដល់យើងនូវការសរសើរ និងការកែតម្រូវ អាចជះឥទ្ធិពលដល់របៀបដែលយើងធ្វើការសិក្សាព្រះគម្ពីរ និងការអធិស្ឋានផ្ទាល់ខ្លួនរបស់យើងយ៉ាងដូចម្តេច ? តើវាអាចជះឥទ្ធិពលទៅលើរបៀប ដែលយើងឆ្លើយតបចំពោះពាក្យទូន្មានរបស់ថ្នាក់ដឹកនាំសាសនាចក្រ និងឪពុកម្តាយរបស់យើងយ៉ាងដូចម្តេចដែរ ?
- ហេតុអ្វីយើងគួរមាននូវការខិតខំមួយដើម្បីស្វែងរកការសរសើរ និងការកែតម្រូវដោយផ្ទាល់មកពីព្រះអម្ចាស់ ?
- តើអ្នកធ្លាប់ជួកពិសោធន៍នូវការសរសើរ ឬការកែតម្រូវដោយផ្ទាល់មកពីព្រះអម្ចាស់នៅពេលណាដែរ ? តើបទពិសោធន៍នេះបានជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់ស្គាល់អ្នកម្នាក់ៗយ៉ាងដូចម្តេចដែរ ? (សូមហាមសិស្សកុំឲ្យចែកចាយបទពិសោធន៍ដែលពិសិដ្ឋឬ ឯកជនពេក) ។ អ្នកក៏គួរចែកចាយបទពិសោធន៍មួយផងដែរ) ។

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីសកម្មភាពដែលពួកគេគិតថា ព្រះអម្ចាស់អាចនឹងសរសើរដល់ពួកគេ ក៏ដូចជាគំនិត ឬគំរិយាបថដែលព្រះអម្ចាស់អាចនឹងកែតម្រូវដល់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅមួយដើម្បីប្រែចិត្ត នៅពេលព្រះអម្ចាស់កែតម្រូវដល់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២:៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ជនដែលយកឈ្នះ ឬជនដែលស៊ូទ្រាំដោយស្មោះត្រង់ដរាបដល់ចុងបំផុតនោះ ។

- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ជនដែលយកឈ្នះ ឬជនដែលកាន់ខ្ជាប់ដរាបដល់ចុងបំផុតនៅក្នុងសេចក្តីសុចរិត ?
- តើអ្នកគិតថា « ការបរិភោគផ្លែរបស់ដើមជីវិត » មានន័យដូចម្តេច ? (ខទី ៧) ។
- តើការស្តាប់ឮពរជ័យដែលបានសន្យានេះ បន្ទាប់ពីទទួលបានការកែតម្រូវដោយផ្ទាល់មានប្រយោជន៍យ៉ាងណាដែរ ដល់ពួកបរិសុទ្ធនៅអេភេសូរ ?

សូមរំឭកសិស្សថា បន្ថែមពីលើការមានបន្ទូលទៅកាន់ពួកជំនុំរបស់សាសនាចក្រនៅអេភេសូរ ព្រះអម្ចាស់បានមានបន្ទូលទៅពួកជំនុំផ្សេងទៀតរបស់សាសនាចក្រនៅអាស៊ីតូច ។

សូមបំបែកសិស្សក្នុងថ្នាក់ជាប្រាំក្រុម ហើយចាត់ឲ្យក្រុមនីមួយៗនូវបទគម្ពីរមួយដូចខាងក្រោមនេះ ៖

១. វិវរណៈ ២:៨–១១

២. វិវរណៈ ២:១២–១៧

៣. វិវរណៈ ២:១៨–២៩, ការបកប្រែដោយយ៉ូសែប ស្ម៊ីធ វិវរណៈ ២:២៦–២៧ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ)

៤. វិវរណៈ ៣:១–៦(សូមផ្តល់សំណៅនៃការបកប្រែដោយយ៉ូសែប ស្ម៊ីធ សម្រាប់វិវរណៈ ៣:១–២ ដល់ក្រុមដែលទទួលបានបទគម្ពីរយោងនេះ ៖ « ចូរសរសេរធ្វើទៅពួកអ្នកបម្រើនៃពួកជំនុំដែលនៅក្រុងសើដេសថា ព្រះដ៏មានព្រះវិញ្ញាណទាំងប្រាំពីរ ដែលជាពួកអ្នកបម្រើទាំងប្រាំពីររបស់ព្រះ ទ្រង់មានព្រះបន្ទូលនូវសេចក្តីទាំងនេះថា យើងស្គាល់ការដែលអ្នករាល់គ្នាប្រព្រឹត្តហើយ គឺដែលអ្នករាល់គ្នាមានឈ្មោះថារស់ តែអ្នករាល់គ្នាស្លាប់ទេ ។ ហេតុដូច្នេះហើយ ចូរប្រុងប្រយ័ត្ន ហើយចម្រើនកម្លាំងដល់អ្វីៗដែលនៅសល់ ដែលរៀបនឹងស្លាប់នោះដែរ ដ្បិតយើងមិនបានឃើញការដែលអ្នករាល់គ្នាប្រព្រឹត្តនោះ ជាពេញខ្នាតនៅចំពោះព្រះនៃយើងទេ) ។

៥. វិវរណៈ ៣:៧–១៣

សូមអញ្ជើញសិស្សឲ្យអានខគម្ពីរដែលបានចាត់ដល់ពួកគេជាក្រុម ហើយរកមើលថា ព្រះអម្ចាស់បានទូន្មានឲ្យពួកបរិសុទ្ធធ្វើអ្វីខ្លះ និងពរជ័យដែលទ្រង់បានសន្យាថាពួកគេនឹងទទួលបាន ប្រសិនបើពួកគេធ្វើដូច្នោះ ។ សូមពន្យល់ថា អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « នំម៉ាន៉ាដ៏លាក់កំបាំង » នៅក្នុង វិវរណៈ ២:១៧ គឺជា « នំប៉័ងនៃជីវិត ជាគោលលទ្ធិអំពីទ្រង់ ដែលជានំប៉័ងនៃជីវិត—ដែលបានលាក់កំបាំងពីគំនិតខាងសាច់ឈាម [ឬខាងលោកិយ] ។ ហេតុដូច្នេះហើយ ជនដែលបរិភោគនឹងពុំឃ្លានទៀតឡើយ ជីវិតដ៏នៅអស់កល្បជានិច្ចគឺជាមរតករបស់ពួកគេនៅថ្ងៃចុងក្រោយ » (*Doctrinal New Testament Commentary* រុំលទី ៣ [ឆ្នាំ១៩៦៥–៧៣] ៣:៤៥១) ។

បន្ទាប់ពីផ្តល់ពេលឲ្យគ្រប់គ្រាន់ហើយ ចូរអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗឲ្យប្រាប់អំពីអ្វីដែលក្រុមរបស់គាត់បានរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរនៅលើក្តារខៀន (នៅក្រោមពរជ័យដែលបានសន្យានៅក្នុង វិវរណៈ ២:៧) ពរជ័យសន្យាដែលក្រុមនីមួយៗបានរកឃើញ (សូមមើល វិវរណៈ ២:១១, ១៧, ២៦, ៣:៥, ១២) ។ បន្ទាប់ពីបានធ្វើចប់សព្វគ្រប់ហើយ សូមចង្អុលបង្ហាញថា ការសន្យាទាំងនេះនីមួយៗសំដៅទៅលើការទទួលបានពរជ័យនៃភាពតម្កើងឡើង ដែលវាសមស្របទៅនឹងការកាន់ខ្ជាប់ដ៏ស្មោះត្រង់របស់យើងដរាបដល់ចុងបំផុត ។

- តើយើងអាចស្គាល់គោលការណ៍អ្វីខ្លះ នៅក្នុងខគម្ពីរទាំងនេះ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យនៃភាពតម្កើងឡើង ? (សូមជួយសិស្សឲ្យស្គាល់គោលការណ៍មួយដែលស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងយកឈ្នះបាន នោះយើងអាចទទួលបានពរជ័យនៃភាពតម្កើងឡើង**) ។

សូមពន្យល់ថា ជនដែលទទួលបានពរជ័យនៃភាពតម្កើងឡើងគឺជាអស់អ្នកដែលយកឈ្នះដោយព្រះគុណរបស់ព្រះលើរាល់ឧបសគ្គទាំងឡាយដែលអាចរារាំងពួកគេពុំឲ្យត្រឡប់ទៅរកទ្រង់វិញ ។ ឧបសគ្គទាំងនេះរួមមាន ទម្លាប់ខាងលោកិយ ការសោកល្បង អំពើបាប និងសេចក្តីស្លាប់ ។

សូមឲ្យសិស្សពិចារណាថាពួកគេត្រូវយកឈ្នះលើអ្វីខ្លះនៅក្នុងជីវិតរបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យអធិស្ឋានសូមជំនួយពីព្រះវរបិតាសួគ៌ ដើម្បីយកឈ្នះលើឧបសគ្គដែលអាចរារាំងពួកគេពុំឲ្យត្រឡប់ទៅរកទ្រង់វិញ ។ សូមថ្លែងទីបន្ទាល់អំពីព្រះចេស្តារបស់ព្រះវរបិតាសួគ៌ដើម្បីជួយពួកគេឲ្យយកឈ្នះលើឧបសគ្គនានា ។

មេរៀនបន្ទាប់ (វិវរណៈ ១២–២២)

សូមសួរសិស្សថា ពួកគេធ្លាប់ងឿងឆ្ងល់អំពីសេចក្តីជំនុំជម្រះចុងក្រោយ និងព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅក្នុងជីវិតមុនឆាកជីវិតនេះទេ ។ តើសាវកយ៉ូហានបានសរសេរអ្វីខ្លះ អំពីសង្គ្រាមនៅស្ថានសួគ៌ ? តើមានវិញ្ញាណប៉ុន្មាននាក់ ដែលត្រូវបណ្តេញចេញជាមួយនឹងសាតាំង ? តើសេចក្តីជំនុំជម្រះចុងក្រោយនឹងមានទិដ្ឋភាពបែបណា ? តើយើងនឹងទទួលការកាត់សេចក្តីតាមរយៈអ្វី នៅពេលយើងឈរនៅចំពោះព្រះ ? តើយ៉ូហានបានពិពណ៌នាភាពរុងរឿងសេឡេស្ទាលយ៉ាងដូចម្តេច ? សូមពន្យល់ថា នៅពេលពួកគេសិក្សា វិវរណៈ ១២–២២ នៅសប្តាហ៍ក្រោយ នោះពួកគេនឹងរៀនអំពីចម្លើយចំពោះសំណួរទាំងនេះ ។

វិវរណៈ ១២–១៣

សេចក្តីផ្តើម

យ៉ូហានបានឃើញការនិមិត្តមួយអំពីនាគមួយកំពុងគម្រាមកំហែងដល់ស្ត្រីម្នាក់ និងកូនរបស់នាង ដែលតំណាងឲ្យបំណងរបស់សាតាំងដើម្បីបំផ្លាញសាសនាចក្ររបស់ព្រះអម្ចាស់ និងសមាជិកដ៏ស្មោះត្រង់ ។ យ៉ូហានបានសរសេរអំពីសង្គ្រាមនៅស្ថានសួគ៌ និងអំពីនគរទាំងឡាយរបស់លោកិយដែលប្រឈមទ្វេទាស់នឹងពួកអ្នកដើរតាមព្រះ ។

សិក្សាបណ្តុំបទគម្ពីរពីមុនអ្នកបង្រៀន

ប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន បានបង្រៀន ៖ « ពីមុនអ្នកអាចពង្រឹងសិស្សរបស់អ្នក វាគឺជារឿងសំខាន់ដែលអ្នកត្រូវសិក្សាគោលលទ្ធិនៃនគរ ហើយរៀនដំណឹងល្អ *ទាំង* ដោយការសិក្សា និងដោយសេចក្តីជំនឿ » (« The Gospel Teacher and His Message » [សុន្ទរកថាទៅកាន់ពួកគ្រូបង្រៀនខាងសាសនា ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ១៩៧៦] ទំព័រ ៥, Church History Library, Salt Lake City) ។ សូមសិក្សាបណ្តុំបទគម្ពីរក្នុងមេរៀននីមួយៗដោយប្រុងប្រយ័ត្ន ហើយសញ្ជឹងគិតពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលមាននៅក្នុងនោះ ។ សូមស្វែងរកដើម្បីបង្កើតសេចក្តីជំនឿរបស់អ្នកនៅក្នុងសេចក្តីពិតទាំងនោះ ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ១២

យ៉ូហានបានបង្ហាញឲ្យឃើញថា សាតាំង និងបរិវាររបស់វាតែងប្រឆាំងទាស់នឹងព្រះអម្ចាស់ និង សាសនាចក្ររបស់ទ្រង់ជានិច្ច ។

មុនចាប់ផ្តើមថ្នាក់ សូមចម្លងសកម្មភាពផ្គូរផ្គងខាងក្រោមនេះដាក់នៅលើ ក្តារខៀន ៖ ក្រោយពីថ្នាក់ចាប់ផ្តើម សូមអញ្ជើញសិស្សពីរបីនាក់ឲ្យគូសបន្ទាត់ភ្ជាប់ការគម្រាមកំហែងនីមួយៗនៅជួរឈរខាងឆ្វេង ទៅនឹងរបៀបដើម្បីតស៊ូនឹងវាដែលមាននៅជួរឈរខាងស្តាំ ។

ការគម្រាម	របៀបដើម្បីតស៊ូនឹងការគម្រាម
រលកនឹងកម្តៅថ្ងៃ	សេចក្តីពិតនៅក្នុង វិវរណៈ ១២
ពួកទ័ពសត្រូវ	ថ្នាំពេទ្យ ឬការសម្រាក
ជំងឺ	ឡេការពារ ឬសម្លៀកបំពាក់ការពារកម្តៅថ្ងៃ
អំពើបាប និងកំហុស	ការប្រែចិត្ត និងការទុកចិត្តលើព្រះយេស៊ូវគ្រីស្ទ
ឥទ្ធិពលរបស់សាតាំង	គ្រឿងសព្វាវុធសង្គ្រាម

- **តើក្នុងចំណោមការគម្រាមកំហែងទាំងនេះ ការគម្រាមណាមួយ ដែលអ្នកបានតតាំងជាមួយនៅពេលថ្មីៗនេះ ? តើអ្នកគិតថា ការគម្រាមមួយណាគ្រោះថ្នាក់បំផុត ? ហេតុអ្វី ?**

នៅពេលសិស្សសិក្សាវិវរណៈ ១២សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតដែលអាចជួយពួកគេឲ្យតតាំងនឹងឥទ្ធិពលរបស់សាតាំង ។ សូមពន្យល់ថា វិវរណៈ ១២–១៤ កត់ត្រានូវចន្លោះពេល ឬការផ្អាកនៅក្នុងការនិមិត្តរបស់យ៉ូហានអំពីព្រឹត្តិការណ៍នៃត្រាទីប្រាំពីរ ។ ព្រះអម្ចាស់ប្រហែលជាជួយយ៉ូហានឲ្យយល់ពីអត្ថន័យនៃឃ្លា « នគរទាំងប៉ុន្មាននៅលោកីយ៍ » និង « នគររបស់ព្រះអម្ចាស់ »នៅក្នុង វិវរណៈ ១១:១៥ ។



សូមបង្ហាញសិស្ស រូបភាព របស់ស្ត្រីម្នាក់ដែលមាននាគនៅពីក្រោយខ្នងនាង ។ សូមអញ្ជើញសិស្សឲ្យពិចារណាថា និមិត្តរូបទាំងនេះតំណាងឲ្យអ្វីខ្លះ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១២:១–២, ៥ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាមានរឿងអ្វីបានកើតឡើងដល់ស្ត្រីនោះ ។ សូមពន្យល់ថា ការបកប្រែដោយ យ៉ូសែប ដាក់ ខទី ៥ ដោយផ្ទាល់បន្ទាប់ពី ខទី ២ ។

- **តើមានរឿងអ្វីកើតឡើងចំពោះ ស្ត្រីនោះ ? (នាងសំរាលបានកូនប្រុស « ដែលត្រូវឃ្វាលគ្រប់អស់ទាំងសាសន៍ » [ខទី ៥]) ។**
- **តើអ្នកគិតថាវានំយដូចម្តេច កាលដែលទ្រង់ « ត្រូវឃ្វាលគ្រប់អស់ទាំងសាសន៍ដោយដំបងដែក » ? (ខទី ៥) ។ (កូននោះនឹងប្រើដំបងដែក ដែលអាចតំណាងឲ្យដំណឹងល្អ បព្វជិតភាព និងព្រះបន្ទូល ព្រមទាំងព្រះចេស្តានៃព្រះ ដើម្បីគ្រប់គ្រងប្រជាជាតិនៅក្នុងពិភពលោកនេះដោយសុចរិត [សូមមើល** Bruce R. McConkie *Doctrinal New Testament Commentary* **វ៉ុលទី ៣ (ឆ្នាំ១៩៦៥–៧៣) ៣:៥១៧]) ។**

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១២:៣–៤ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលនិមិត្តរូបដែលបានរៀបរាប់នៅក្នុងខគម្ពីរទាំងនេះ ។

- **តើអ្នកគិតថា និមិត្តរូបដែលបានរៀបរាប់នៅក្នុង ខទី ១–៥អាចតំណាងឲ្យអ្វី ?**

សូមអញ្ជើញសិស្សឲ្យអានការបកប្រែដោយ យ៉ូសែប ស្ម៊ីធ វិវរណៈ ១២:៧–៨ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលថា នាគ ស្ត្រី និងកូននោះតំណាងឲ្យអ្វី ។

- **យោងតាម ការបកប្រែដោយ យ៉ូសែប ស្ម៊ីធ វិវរណៈ ១២:៧–៨ តើនាគ ស្ត្រី និងកូននៅក្នុងការនិមិត្តរបស់យ៉ូហានតំណាងឲ្យអ្វី ? (នាគតំណាងឲ្យសាតាំង [សូមមើល ខទី ៨] ស្ត្រីតំណាងឲ្យ « សាសនាចក្រនៃព្រះ » ហើយកូនតំណាងឲ្យ « នគរនៃព្រះ និង**

ព្រះគ្រីស្ទរបស់យើង » (ខទី ៧) ដែលជាន គរមួយ ដែលព្រះអម្ចាស់នឹងស្ថាបនាឡើងនៅសហស វត្សរ៍ ដែលទ្រង់នឹងដឹកនាំគ្រប់ជាតិសាសន៍ទាំងអស់ ។ (សូមមើល *New Testament Student Manual* (Church Educational System manual ឆ្នាំ ២០១៤) ទំព័រ ៥៥០–៥២ សម្រាប់ការពន្យល់បន្ថែមពីនិមិត្តរូបនៅក្នុងវគ្គទាំងនេះ)) ។

- យោងតាម វិវរណៈ ១២:៨ តើនាគនោះមានបំណងចង់ធ្វើអ្វី ? ហេតុអ្វីអ្នកគិតថា សាតាំងខិតខំយ៉ាងខ្លាំងដើម្បីបំផ្លាញនគរព្រះ និងព្រះគ្រីស្ទ ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១២:៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ស្ត្រីនោះបានធ្វើអ្វីខ្លះ ដោយសារតែនាគដ៏គម្រាមកំហែងនោះ ។

- តើមានរឿងអ្វីកើតឡើងចំពោះ ស្ត្រីនោះ ? តើការណ៍នេះអាចតំណាងឲ្យអ្វី ? (ស្ត្រីបានរត់គេចខ្លួនចូលទៅក្នុងទីរហោស្ថានតំណាងឲ្យសាសនាចក្រ ដែលចូលទៅក្នុងការក្បត់សាសនាដ៏ធំ និងបព្វជិតភាពត្រូវបានដកចេញពីផែនដីនេះ បន្ទាប់ពីការស្លាប់របស់ពួកសាវកទាំងឡាយ (សូមមើលផងដែរ គ. និង ស. ៨៦:៣)) ។

សូមពន្យល់ថា បន្ទាប់ពីយ៉ូហានបានឃើញនាគនោះគម្រាមកំហែងដល់ស្ត្រី និងកូននាង លោកបានឃើញសង្គ្រាមនៅស្ថានសួគ៌រវាងសាតាំង និងពួកបរិសុទ្ធនៃព្រះ ។ សូមអញ្ជើញសិស្សផ្សេងទៀតឲ្យប្តូរវេនគ្នាអានឮៗនៅក្នុងការបកប្រែដោយយ៉ូសែប ស៊្មីធ វិវរណៈ ១២:៦–១១ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សពាក់កណ្តាលថ្នាក់រកមើលរឿង ដែលបានកើតឡើងដល់សាតាំង នៅក្នុងសង្គ្រាមនៅស្ថានសួគ៌ ហើយពាក់កណ្តាលទៀតរកមើលថាពួកបរិសុទ្ធនៃព្រះបានយកឈ្នះលើសាតាំង និងពួកបរិវាររបស់វាបានយ៉ាងដូចម្តេច ។

- តើមានរឿងអ្វីបានកើតឡើងដល់សាតាំង និងពួកបរិវាររបស់វា ? (អ្នកអាចចង្អុលបង្ហាញថា វិវរណៈ ១២:៤ ចែងថា កន្ទុយនាគនោះ « ទាញផ្កាយនៅលើមេឃមួយភាគក្នុងបីត្រវាត់ចោលទៅផែនដី » ។ នេះគឺជានិមិត្តរូបនៃចំនួនដ៏ច្រើននៃកូនវិញ្ញាណរបស់ព្រះវរបិតាសួគ៌ ដែលជ្រើសដើរតាមសាតាំង ។ អ្នកក៏គួរពន្យល់ផងដែរថា « មីកែល និងពួកទេវតារបស់លោក » (ការបកប្រែដោយយ៉ូសែប ស៊្មីធ វិវរណៈ ១២:៦) គឺលោកអ័ដាម និងកូនចៅវិញ្ញាណសុចរិតផ្សេងទៀតរបស់ព្រះ)) ។
- យោងតាម ខទី ១១ តើពួកពលបរិវារស្ថានសួគ៌ដ៏សុចរិតបានយកឈ្នះសាតាំងយ៉ាងដូចម្តេច ? (« ដោយសារឈាមនៃកូនចៀម » ឬ តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ហើយដោយបន្ទូលស្មោះត្រង់ចំពោះទីបន្ទាល់របស់ពួកគេអំពីដំណឹងល្អ ។ សូមសរសេរចម្លើយទាំងនេះនៅលើក្តារខៀន)) ។
- យោងតាម ខទី ៨ តើសាតាំង និងពួកបរិវាររបស់វាត្រូវបានបញ្ជូនទៅទីណាបន្ទាប់ពីការបះបោររបស់ពួកគេមក ?

សូមអញ្ជើញសិស្សម្នាក់អានការបកប្រែដោយយ៉ូសែប ស៊្មីធ វិវរណៈ ១២:១២, ១៧ (នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា សាតាំងធ្វើសង្គ្រាមទាស់នឹងនរណាបន្ទាប់ពីវាត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ។

- តើសាតាំងបានធ្វើសង្គ្រាមទាស់នឹងនរណា បន្ទាប់ពីវាត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ?
- ដោយផ្អែកលើអ្វី ដែលយើងបានរៀននៅក្នុង ខទី ១១ តើយើងអាច ធ្វើអ្វីខ្លះ ដើម្បីយកឈ្នះលើឥទ្ធិពល និងការវាយប្រហាររបស់សាតាំងនៅជំនាន់របស់យើង ? (សូមជួយសិស្សឲ្យស្គាល់គោលការណ៍មួយ ដែលស្រដៀងគ្នានឹងគោលការណ៍ដូចតទៅ ៖ **យើងអាចយកឈ្នះលើឥទ្ធិពលរបស់សាតាំងតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និងដោយបន្ទូលស្មោះត្រង់ចំពោះទីបន្ទាល់របស់យើងអំពីដំណឹងល្អ ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន)) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដេម ជេ ហាមូឡា នៃពួកចិតសិបនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា សាតាំងកំពុងវាយប្រហារមកលើជំនាន់របស់យើងយ៉ាងដូចម្តេច ។



« បុត្រាបុត្រីដ៏ក្លាហាន ហើយស្ងាហាប់មួយចំនួនរបស់ព្រះវរបិតា ត្រូវបានរក្សាទុកសម្រាប់ថ្ងៃចុងក្រោយនេះ ហើយធ្វើការសម្រាប់ព្រះវរបិតារបស់យើង និងព្រះរាជបុត្រារបស់ទ្រង់ ។ ភាពក្លាហាន និងភាពស្ងាហាប់របស់ពួកគេបានបង្ហាញនៅក្នុងចម្បាំងជាមួយនឹងសាតាំង កាលពីជីវិតមុនផែនដីនេះ ។ . . .

« ដោយមាននគរព្រះបានស្ថាបនាឡើងវិញនៅលើផែនដីនេះ និងការចាប់កំណើតរបស់បងប្អូនមកលើផែនដីនេះ សាតាំងដឹងថា ‹ ពេលវេលាវាខ្លីណាស់ហើយ › (វិវរណៈ ១២:១២) ។ ដូច្នេះហើយ សាតាំងកំពុងត្រៀមរាល់ធនធាន ដែលវាមានដើម្បីអូសទាញបងប្អូនឲ្យធ្លាក់ចូលក្នុងអំពើរំលង ។ វាដឹងថា ប្រសិនបើវាអាចនាំបងប្អូនចូលទៅក្នុងអំពើរំលងបាន វាអាចរារាំងបងប្អូនពីការបម្រើបេសកកម្មពេញម៉ោង ការរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ និងការការពារកូនចៅរបស់បងប្អូននាពេលអនាគតនៅក្នុងសេចក្តីជំនឿ ហើយអ្វីៗទាំងនេះនឹងធ្វើឲ្យបងប្អូន និងសាសនាចក្រចុះអន់ថយ ។ វាដឹងថា គ្មានអ្វីអាចផ្តួលរំលំនគរព្រះបានឡើយ ‹ លើកលែងតែអំពើរំលងនៃរាស្ត្រ (របស់ទ្រង់) ប៉ុណ្ណោះ › (ម៉ូសាយ ២៧:១៣) ។ និយាយមិនខុសមែន—ឥឡូវនេះការជ្កោតនៃសង្គ្រាមរបស់វាគឺទៅលើបងប្អូន » (« Winning the War against Evil » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៥០, ៥១) ។

- តើសាតាំង និងពួកបរិវារវាខិតខំធ្វើឲ្យយើងចុះខ្សោយតាមរបៀបណា ?

សូមអញ្ជើញសិស្សឲ្យពិចារណាពីរបៀប ដែលសាតាំងកំពុងធ្វើសង្គ្រាមទាស់នឹងពួកគេដោយផ្ទាល់ ។

- តើមានរឿងណាខ្លះដែលយើងអាចធ្វើ ដើម្បីបង្កើនសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទ ហើយពង្រឹងទីបន្ទាល់របស់យើងអំពីទ្រង់ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន)) ។

សូមអានប្រយោគពីរខាងក្រោមនេះឲ្យឮៗ ហើយអញ្ជើញសិស្សឲ្យឆ្លើយសំណួរមួយ ក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ៖

១. សូមសរសេរអំពីបទពិសោធន៍មួយ កាលដែលទីបន្ទាល់របស់អ្នក និងសេចក្តីជំនឿរបស់អ្នកលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ បានជួយអ្នកឲ្យតស៊ូនឹងឥទ្ធិពលរបស់សាតាំង ។

២. សូមកត់ត្រាទីបន្ទាល់របស់អ្នកអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយពន្យល់ថា ដង្វាយធួនអាចជួយយើងនៅក្នុងសង្គ្រាមរបស់យើងប្រឆាំងសាតាំង និងបរិវារបស់វាបានយ៉ាងដូចម្តេច ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអំពីអ្វីដែលពួកគេបានសរសេរ ។

សូមលើកទឹកចិត្តសិស្សឲ្យជ្រើសយកគំនិតមួយ ឬច្រើនដែលមានសរសេរនៅលើក្តារខៀន ហើយអនុវត្តវានៅក្នុងចម្បាំងរបស់ពួកគេទាស់នឹងសាតាំង និងបរិវារវា ។

វិវរណៈ ១៣

យ៉ូហានសរសេរអំពីនគរទាំងឡាយនៅលើផែនដីថានឹងទទួលអំណាចមកពីសាតាំង

សូមសង្ខេប វិវរណៈ ១៣ ដោយអញ្ជើញសិស្សម្នាក់អានសេចក្តីសង្ខេបសម្រាប់ជំពូកនោះឮៗ ។ (ប្រសិនបើអ្នកចង់ធ្វើ អ្នកអាចពន្យល់ថា យ៉ូហានបានឃើញការនិមិត្តមួយអំពីសត្វសាហាវ ដែលតំណាងឲ្យនគរទុច្ចរិតនៅលើផែនដីដែលសាតាំងគ្រប់គ្រង ។ យ៉ូហានក៏បានឃើញថា តាមរយៈនគរទាំងនេះ សាតាំងនឹងធ្វើកិច្ចការដ៏អស្ចារ្យ និងអព្ភូតហេតុក្លែងក្លាយដើម្បីបោកបញ្ឆោតកូនចៅមនុស្សទាំងអស់លើផែនដី ។

ការរំឭកពីចំណេះចំណានខគម្ពីរ

អំឡុងសប្តាហ៍ចុងក្រោយនៃថ្នាក់សិក្ខាសាលា ចូរពិចារណាធ្វើការផ្តល់ការប្រឡងចំណេះចំណានខគម្ពីរចុងក្រោយដល់សិស្ស ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសិក្សានៅផ្ទះ ឬ សិក្សាភ្លាមៗពីមុនការប្រឡង ។ ខាងក្រោមនេះ គឺជាការប្រឡងពីរបីប្រភេទដែលអ្នកអាចប្រើ (អ្នកអាចសម្របគំនិតទាំងនេះដើម្បីបំពេញតាមសេចក្តីត្រូវការរបស់សិស្ស) ៖

ការប្រឡងអំពីសេចក្តីយោង ៖ផ្តល់តម្រុយដល់សិស្សចេញមកពីវគ្គបទគម្ពីរចំណេះចំណានបទគម្ពីរ ។ តម្រុយទាំងនេះអាចជាពាក្យគោលលទ្ធិ ឬគោលការណ៍គន្លឹះ ឬសេចក្តីសង្ខេបនៃអត្ថន័យរបស់វគ្គបទគម្ពីរ ។ សូមអញ្ជើញសិស្សឲ្យសរសេរសេចក្តីយោងទៅវគ្គបទគម្ពីរនៅលើក្រដាសមួយសន្លឹក បន្ទាប់ពីអ្នកផ្តល់នូវតម្រុយនីមួយៗហើយ ។

ការប្រឡងគោលលទ្ធិ ៖ សរសេរគោលលទ្ធិគ្រឹះនៅលើក្តារខៀន ។ ចូរសុំឲ្យសិស្សសរសេរសេចក្តីយោងចំណេះចំណានខគម្ពីរឆ្លើយឆ្លងគ្នានៅក្រោមគោលលទ្ធិនីមួយៗ ។ ពួកគេអាចធ្វើកិច្ចការនេះ ដោយរំឭកពីវគ្គចំណេះចំណានខគម្ពីរចេញពីការចងចាំ ឬដោយប្រើបញ្ជីមួយនៃចំណេះចំណានខគម្ពីរ ។

ការប្រឡងទន្ទេញចាំ ៖ សូមអញ្ជើញសិស្សឲ្យប្រើពាក្យ ដែលបានទន្ទេញចាំ និងគោលការណ៍ទាំងឡាយចេញមកពីវគ្គចំណេះចំណានខគម្ពីរ ដើម្បីពន្យល់អំពី គោលលទ្ធិគ្រឹះមួយចំនួន ។ សូមអញ្ជើញពួកគេឲ្យសរសេរនូវការពន្យល់របស់ពួកគេ ហើយអានវាឲ្យឮៗដល់សិស្សក្នុងថ្នាក់ ។

សូមចាំថា អ្នកត្រូវសរសើរដល់សិស្សក្នុងថ្នាក់របស់អ្នកចំពោះកិច្ចខិតខំរបស់ពួកគេ ក្នុងការទន្ទេញចាំវគ្គបទគម្ពីរគន្លឹះ និងគោលលទ្ធិគ្រឹះទាំងនេះ ។ ចូរថ្លែងទីបន្ទាល់អំពីព្រះចេស្តាខាងវិញ្ញាណ និងទីបន្ទាល់ដែលយើងអាចទទួលបាន នៅពេលយើងទន្ទេញចាំវគ្គចំណេះចំណានខគម្ពីរ និងគោលលទ្ធិនានា ។

សេចក្តីអធិប្បាយ និង ព័ត៌មានសាច់រឿង

វិវរណៈ ១៣ ។ សត្វសាហាវ

ក្រៅពីចំណេះដឹងថា សត្វសាហាវទាំងនោះតំណាងឲ្យនគរខាងលោកិយ យើងគ្មានការបកស្រាយណាមួយមកពីព្រះអម្ចាស់ទាក់ទងនឹងវាឡើយ ។ កាលកំពុងនិយាយពីអាថ៌កំបាំងនៃគម្ពីរវិវរណៈ ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងដូចតទៅ ៖

« នៅពេលណាក៏ដោយដែលព្រះបានប្រទានការនិមិត្តអំពីរូបភាព ឬ សត្វ ឬ រូបអ្វីក៏ដោយ នោះទ្រង់មានទំនួលខុសត្រូវដោយអង្គទ្រង់ផ្ទាល់ដើម្បីប្រទានវិវរណៈ ឬ ការបកស្រាយអំពីអត្ថន័យនៃរូបទាំងនោះ បើមិនដូច្នោះទេ យើងពុំទទួលខុសត្រូវចំពោះជំនឿរបស់យើងលើការនិមិត្តនោះឡើយ ។ . . .

« . . . ចូរកុំខ្វល់ខ្វាយពីការនិមិត្តនៃសត្វ និង ប្រធានបទដែលអ្នកពុំយល់នោះឡើយ » (នៅក្នុង *History of the Church*, ៥:៣៤៣, ៣៤៤) ។

វិវរណៈ ១៣:៨ ។ « កូនចៀមដែលត្រូវគេសំឡាប់ តាំងពីកំណើតលោកីយ៍មក »

ឃ្លាថា « កូនចៀមដែលត្រូវគេសំឡាប់ តាំងពីកំណើតលោកីយ៍មក » (វិវរណៈ ១៣:៨) សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។ « តាំងពីកំណើតលោកីយ៍មក » សំដៅទៅលើដំណាក់កាលមុនផែនដី ពីមុនពិភពលោកនេះត្រូវបានបង្កើតមកម៉្លេះ ។ ដូច្នេះហើយ យើងអាចយល់ចេញពីខគម្ពីរនេះបានថា ឥទ្ធិពលនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះគឺត្រូវបានបង្កើតឡើងពីមុនព្រះយេស៊ូវបានប្រសូតមកទៅទៀត ។ ឧទាហរណ៍ មនុស្សដែលបានរស់នៅពីមុនដំនាន់ព្រះគ្រីស្ទអាចអនុវត្តសេចក្តីជំនឿលើព្រះគ្រីស្ទ ប្រែចិត្ត ហើយទទួលបានការអភ័យទោសពីអំពើបាប តាមរយៈអំណាចនៃដង្វាយធួនរបស់ទ្រង់ ទោះជាព្រះអង្គសង្គ្រោះពុំទាន់បានប្រសូតក្តី (សូមមើល គ. និង ស. ២០:២៥–២៦) ។

វិវរណៈ ១៤–១៦

សេចក្តីផ្តើម

នៅក្នុងការនិមិត្តមួយ សាវកយ៉ូហានបានឃើញទេវតាមួយអង្គស្តារឡើងវិញនូវដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងថ្ងៃចុងក្រោយ ។ លោកក៏បានឮសំឡេងមកពីលើមេឃ ដែលពិពណ៌នាអំពីពរជ័យដែលកើតមានដល់អស់អ្នក ដែលបានស្លាប់ទៅក្នុងភាពស្មោះត្រង់ចំពោះព្រះអម្ចាស់ ។ យ៉ូហានបានឃើញការប្រមូលផ្តុំនៃពួកសុចរិត និង ការប្រមូលផ្តុំនៃពួកទុច្ចរិត នៅក្នុងថ្ងៃចុងក្រោយ ព្រមទាំងការជនុំជម្រះរបស់ព្រះដែលចាក់ស្រោចលើពួកទុច្ចរិត ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ១៤

យ៉ូហានឃើញអំពីការស្តារឡើងវិញនៃដំណឹងល្អ និង ការប្រមូលផ្តុំនៃពួកសុចរិត និង ពួកទុច្ចរិត

សូមសរសេរសំណួរដូចតទៅនេះនៅលើក្តារខៀន ៖ *តើវាអាចទៅរួចទេ ដើម្បីរីករាយនឹងភាពសុខសាន្ត ទោះបីជាពិភពលោកនេះពោរពេញដោយអំពើទុច្ចរិត ភយន្តរាយ និង អំពើហិង្សានោះ ?*

សូមអញ្ជើញឲ្យសិស្សមួយចំនួនឆ្លើយនឹងសំណួរ ហើយពន្យល់ពីចម្លើយរបស់ពួកគេ ៖

សូមឲ្យពួកគេរកមើលសេចក្តីពិត នៅពេលពួកគេសិក្សា វិវរណៈ ១៤–១៦ ដែលអាចជួយនាំភាពសុខសាន្តដល់ពួកគេ អំឡុងពេលរស់នៅក្នុងពិភពលោកដែលទុច្ចរិត និង ច្របូកច្របល់នេះពីមុនការយាងមកលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមពន្យល់ថា ដូចបានកត់ត្រានៅក្នុង វិវរណៈ ១៤:១–១៣ សាវកយ៉ូហានបានឃើញការនិមិត្តមួយអំពីថ្ងៃចុងក្រោយ ។ នៅក្នុងការនិមិត្តរបស់លោក នោះលោកបានឃើញគ្រោះមហន្តរាយ ដែលនឹងកើតមានមកលើពួកទុច្ចរិត ។ លោកក៏បានឃើញអំពីអ្វីដែលនឹងនាំភាពសុខសាន្តដល់ជនសុចរិតផងដែរ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១៤:១–៥ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលអ្វីដែលយ៉ូហានបានឃើញថានឹងកើតឡើងនៅថ្ងៃចុងក្រោយ ។



- **តើយ៉ូហានបានឃើញអ្វីនឹងកើតឡើងនៅថ្ងៃចុងក្រោយ ?**

សូមរំឭកប្រាប់សិស្សថា មនុស្ស ១៤៤000 នាក់គឺជាពួកសង្ឃជាន់ខ្ពស់នៃពូជអំបូរទាំងដប់ពីរអ៊ីស្រាអែល ដែលនឹងត្រូវបានតែងតាំងពីគ្រប់សាសន៍ ដើម្បីចាត់ចែងដំណឹងល្អ និង នាំមនុស្សមកកាន់សាសនាចក្រ (សូមមើល វិវរណៈ ៧:៤–៨, គ. និង ស. ៧៧:១១) ។

- **យោងតាម ខទី ៤–៥ តើយ៉ូហានបានពិពណ៌នាអំពីសង្ឃជាន់ខ្ពស់ទាំង ១៤៤000 នាក់ ដែលនឹងចាត់ចែងដំណឹងល្អនៅទូទាំងពិភពលោកយ៉ាងដូចម្តេច ? (សូមពន្យល់ថាឃ្លា « មិនបានបង្ខូចខ្លួននឹងស្រីឡើយ » [ខទី ៤] មានន័យថាពួកគេនៅបរិសុទ្ធ ឃ្លា « មិនឃើញមានសេចក្តីភូតភរនៅក្នុងមាត់គេឡើយ » [ខទី ៥] មានន័យថា ពួកគេទៀងត្រង់ ហើយស្មោះសរ ហើយឃ្លា « ឥតសៅហ្មង » [ខទី ៥] មានន័យថាពួកគេជ្រះស្អាតពីអំពើបាប) ។**
- **តើអ្នកគិតថា ហេតុអ្វីការមានភាពបរិសុទ្ធ ភាពទៀងត្រង់ និង ស្អាតបាតពីអំពើបាប នឹងជួយពួកសង្ឃជាន់ខ្ពស់ ១៤៤000 នាក់នោះឲ្យនាំយកដំណឹងល្អទៅកាន់អ្នកដទៃ ?**

សូមពន្យល់ថា អំឡុងពេលនៃការនិមិត្តរបស់យ៉ូហានអំពីថ្ងៃចុងក្រោយ លោកបានឃើញទេវតាបីអង្គ ។ សូមអញ្ជើញសិស្សបីនាក់ឲ្យតំណាងជាទេវតាបីអង្គនោះ (សិស្សទាំងនេះអាចបន្តអង្គុយនៅកៅអីរបស់ពួកគេ) ។ សូមអញ្ជើញសិស្សដែលតំណាងឲ្យទេវតាទីមួយអាន វិវរណៈ ១៤:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលថាទេវតានោះមានអ្វី ។

- **តើទេវតានោះមានអ្វី ?**

សូមអញ្ជើញសិស្សដែលតំណាងឲ្យទេវតាទីមួយអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៣:៣៦–៣៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម ដោយរកមើលអ្វីដែលទេវតានោះបានធ្វើជាមួយដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ច ។

- **តើទេវតានោះបានធ្វើអ្វីជាមួយដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ច ?**

សូមដាក់បង្ហាញរូបភាព ម៉ូរ៉ូណៃបានបង្ហាញកាយដល់យ៉ូសែប ស៊្មីធ នៅក្នុងបន្ទប់របស់លោក (*Gospel Art Book* | ឆ្នាំ ២០០៩ | លេខ ៩១, សូមមើលផងដែរ LDS.org) ។ សូមឲ្យសិស្សម្នាក់រំឭកអំពីអ្វីដែលបានកើតឡើង អំឡុងពេលម៉ូរ៉ូណៃមកជួបយ៉ូសែប ស៊្មីធលើកដំបូង ។ (ប្រសិនបើសិស្សត្រូវការការរំឭកអំពីព្រឹត្តិការណ៍ទាំងនេះ អ្នកអាចសូមឲ្យសិស្សម្នាក់អាន យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២៩–៣៥ ឲ្យឮៗ) ។

- **ក្រោមការដឹកនាំរបស់ព្រះ តើម៉ូរ៉ូណៃបានឲ្យអ្វីដល់យ៉ូសែប ស៊្មីធ ដើម្បីជួយស្តារដំណឹងល្អមកកាន់ផែនដីវិញនោះ ? (កំណត់ត្រានោះរួមមានព្រះគម្ពីរមរមន) ។**



សូមបង្ហាញរូបភាពព្រះវិហារបរិសុទ្ធមួយ ដែលមានរូបចម្លាក់ទេវតាម៉ូរ៉ូណៃនៅលើកំពូល ដូចជារូបភាព ព្រះវិហារបរិសុទ្ធ សលត៍ លេក ដែលមាននៅក្នុង *Gospel Art Book* (លេខ ១១៩, សូមមើលផងដែរ LDS.org) ។

- ហេតុអ្វីអ្នកគិតថា រូបចម្លាក់ទេវតាម៉ូរ៉ូណៃត្រូវបានដាក់នៅលើកំពូលព្រះវិហារបរិសុទ្ធជាច្រើនរបស់យើង ?

សូមពន្យល់ថា នៅក្នុងសន្និសីទមួយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានដកស្រង់ វិវរណៈ ១៤:៦ ហើយក្រោយមកបានប្រកាសថា « ទេវតានោះបានយាងមកហើយ ។ ព្រះនាមរបស់ទ្រង់គឺ ម៉ូរ៉ូណៃ » (« Stay the Course Keep the Faith » *Ensign* ខែ វិច្ឆិកា ១៩៩៥ ទំព័រ ៧០) ។ ទេវតាក៏អាចតំណាងឲ្យក្រុមមួយនៃសារទូតជាច្រើនរបស់ស្ថានសួគ៌មួយមាន ម៉ូរ៉ូណៃ ដែលបានជួយស្តារដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយ (សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Doctrinal New Testament Commentary* ភាគទី ៣ | ឆ្នាំ ១៩៦៥–៧៣ | ៣:៥២៩–៣១, សូមមើលផងដែរ គ. និង ស. ១៣, ១១០:១១–១៦, ១២៨:២០–២១) ។

សូមអញ្ជើញសិស្សដែលតំណាងឲ្យទេវតាទីមួយអាន វិវរណៈ ១៤:៧ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ដោយរកមើលអ្វីដែលទេវតានោះបានមានបន្ទូល ។

- តើទេវតានោះបានមានបន្ទូលដូចម្តេច ?
- តើឃ្លា « ពេលដែលទ្រង់ត្រូវជំនុំជម្រះ នោះបានមកដល់ហើយ » មានអត្ថន័យដូចម្តេច ? (ជាពេលដែលនឹងមកដល់ នៅពេលព្រះយេស៊ូវគ្រីស្ទនឹងជំនុំជម្រះមនុស្សទាំងអស់នៅលើផែនដីនេះ ។ ការជំនុំជម្រះរបស់ទ្រង់នឹងកើតមានឡើងទាំងនៅគ្រានៃការយាងមកជាលើកទីពីរ | សូមមើល ម៉ាឡាគី ៣:១–៥| និង គ្រានៃសេចក្តីជំនុំជម្រះចុងក្រោយ | សូមមើល ឌីវ៉ាយទី២ ៩:១៥|) ។
- ផ្អែកលើអ្វីដែលយើងបានរៀន តើអ្វីទៅជាហេតុផលមួយដែលព្រះស្តារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ ? (សិស្សគប្បីរកឃើញសេចក្តីពិតដូចតទៅនេះ ៖ **ព្រះបានស្តារឡើងវិញនូវដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីរៀបចំពួជពង្សមនុស្សនៅលើផែនដីសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ**) ។
- តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ រៀបចំមនុស្សសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់តាមរបៀបណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ជួយនាំភាពសុខសាន្តដល់ពួកគេអំឡុងពេលរស់នៅក្នុងពិភពលោកដែលទុច្ចរិត និង ច្របូកច្របល់នេះ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគំនិតរបស់ពួកគេជាមួយសិស្សនៅក្នុងថ្នាក់ ។

សូមអញ្ជើញសិស្សដែលតំណាងឲ្យទេវតាទីពីរអាន វិវរណៈ ១៤:៨ ឲ្យឮៗ ហើយឲ្យសិស្សតំណាងឲ្យទេវតាទីបីអាន វិវរណៈ ១៤:៩–១១ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ដោយរកមើលអ្វីដែលទេវតានោះបានមានបន្ទូល ។

- យោងតាម ខទី ៨ តើទេវតាទីពីរបានមានបន្ទូលថាដូចម្តេច ? (សូមពន្យល់ថា អត្ថន័យមួយនៃឃ្លា « ក្រុងបាប៊ីឡូនដ៏ជាធំ បានរលំហើយ » គឺថាថ្ងៃនោះនឹងមកដល់ នៅពេលអំពើទុច្ចរិតនៃពិភពលោកនេះនឹងបញ្ចប់ ។
- តើការដឹងថា អំពើទុច្ចរិតនៃពិភពលោកនេះនឹងបញ្ចប់ នាំឲ្យយើងមានភាពសុខសាន្តយ៉ាងដូចម្តេច ?
- យោងតាម ខទី ៩–១១ តើទេវតាទីបីបានមានបន្ទូលថា អ្វីនឹងកើតឡើងដល់អស់ដែលធ្វើតាម « សត្វនោះ » (ខទី ៩) ឬ សាតាំង ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចតទៅនេះដោយព្យាការី យ៉ូសែប ស៊្មីធ ឲ្យឮ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រករបៀបដែលព្យាការីបានពន្យល់អំពីទារុណកម្មដែលពួកទុច្ចរិតនឹងជួបប្រទះ បន្ទាប់ពីពួកគេស្លាប់ទៅ ។



« សេចក្តីវេទនាដ៏ធំធេងនៃវិញ្ញាណ ដែលបានលាចាកលោកនេះទៅកាន់ពិភពវិញ្ញាណ ជាកន្លែងដែលពួកគេទៅបន្ទាប់ពីពួកគេស្លាប់ គឺការដឹងថាពួកគេពុំទទួលបានសិរីរុងរឿង ដែលមនុស្សដទៃរីករាយ ហើយថាពួកគេអាចមានក្តីរីករាយចំពោះខ្លួនពួកគេ ហើយពួកគេគឺជាអ្នកចោទប្រកាន់ខ្លួនឯង » (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ | ទំព័រ ២២៤) ។

« មនុស្សម្នាក់គឺជាម្ចាស់នៃអំពើបាបខ្លួន ហើយក៏ជាអ្នកកាត់ទោសខ្លួនឯងដែរ ។ ហេតុដូច្នេះហើយ ពួកគេនឹងទៅក្នុងបឹងដែលឆេះជាភ្លើង និងស្ពាន់ធ័រ | សូមមើល វិវរណៈ ២១:៨ | ។ ការដាក់ទោសនៃការខកចិត្តនៅក្នុងចិត្តរបស់មនុស្សម្នាក់ គឺធំអនេកប្រៀបដូចជាបឹងដែលឆេះជាភ្លើង និងស្ពាន់ធ័រ (*Teachings of Presidents of the Church: Joseph Smith* ទំព័រ ២២៤) ។

- យោងតាមព្យាការី យ៉ូសែប ស៊្មីធ តើទារុណកម្មអ្វីដែលពួកទុច្ចរិតនឹងជួបបន្ទាប់ពីពួកគេស្លាប់ទៅ ?

សូមចង្អុលបង្ហាញថា បន្ទាប់ពីដឹងអំពីអ្វីដែលពួកទុច្ចរិតនឹងជួបប្រទះ បន្ទាប់ពីពួកគេស្លាប់ហើយ នោះយ៉ូហានបានឮសំឡេងមួយមកពីលើមេឃ ដោយរៀបរាប់អំពីអ្វីដែលពួកសុចរិតនឹងជួបប្រទះ បន្ទាប់ពីពួកគេស្លាប់ទៅ ។

សូមឲ្យសិស្សម្នាក់អាន វិវរណៈ ១៤:១២–១៣ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ធ្វើតាម ដោយរកមើលអ្វីដែលពួកសុចរិតនឹងជួបប្រទះ បន្ទាប់ពីពួកគេស្លាប់ទៅ ។

- តើពួកសុចរិតនឹងជួបបទពិសោធន៍អ្វី បន្ទាប់ពីពួកគេស្លាប់ ?
- តើអ្នកគិតថា « ឈប់សម្រាកពីគ្រប់ទាំងការនឿយហត់របស់គេ » មានន័យដូចម្តេច ? (ខទី ១៣) ។
- តើអ្នកនឹងសង្ខេបការបង្រៀនរបស់យ៉ូហាននៅក្នុង ខទី ១២–១៣ ឲ្យទៅជាគោលការណ៍មួយយ៉ាងដូចម្តេច ? (សិស្សអាចប្រើពាក្យផ្សេងគ្នា ប៉ុន្តែត្រូវប្រាកដថា ពួកគេស្តាប់គោលការណ៍ស្រដៀងគ្នាដូចតទៅនេះ ៖ **ប្រសិនបើយើងរស់នៅដោយសុចរិត នោះយើងនឹងមានពរចំពោះកិច្ចការរបស់យើង ហើយបានសម្រាកពីការងាររបស់យើងបន្ទាប់ពីយើងស្លាប់ទៅ**) ។
- តើគោលការណ៍នេះអាចនាំភាពសុខសាន្តដល់យើង សូម្បីតែពេលដែលយើងត្រូវបានហ៊ឺពំទ្ងដោយភាពទុច្ចរិតយ៉ាងដូចម្តេច ?

សូមគិតអំពីការចែកចាយទីបន្ទាល់របស់អ្នក អំពីសារៈសំខាន់នៃការជ្រើសរើសរស់នៅដោយសុចរិតនៅក្នុងពិភពលោកដ៏ទុច្ចរិតនេះ ។ សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពី អ្វីដែលពួកគេអាចធ្វើនៅក្នុងជីវិតរបស់ពួកគេ ដើម្បីប្រាកដថាពួកគេនឹងមិនរងនឹងការឈឺចាប់ចំពោះទារុណកម្មនៃអំពើទុច្ចរិត ប៉ុន្តែរីករាយនឹងភាពសុខសាន្តនៃអំពើសុចរិតវិញនោះ ។ សូមអញ្ជើញពួកគេឲ្យធ្វើតាមការបំផុសគំនិតដែលពួកគេបានទទួល ។

សូមសង្ខេប វិវរណៈ ១៤:១៤–២០ ដោយពន្យល់ថា យ៉ូហានបានពិពណ៌នាអំពីចម្រូតពីរ ។ នៅក្នុងការនិមិត្តរបស់លោក យ៉ូហានបានឃើញថា នៅក្នុងអំឡុងពេលចម្រូតទីមួយ មនុស្សសុចរិតត្រូវបានប្រមូលផ្តុំមកពីពួកទុច្ចរិត (សូមមើល ខទី ១៤–១៦) ហើយថា នៅអំឡុងពេលចម្រូតទីពីរ ពួកទុច្ចរិតនឹងត្រូវបានប្រមូលផ្តុំ ហើយទីបំផុតនឹងត្រូវបំផ្លាញចោល (សូមមើល ខទី ១៧–២០) ។

វិវរណៈ ១៥–១៦

យ៉ូហានឃើញពួកសុចរិតនៅក្នុងនគរសេឡេស្ទាល ហើយឃើញមានសេចក្តីវេទនាចំនួនប្រាំពីរនៅថ្ងៃចុងក្រោយ

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១៥:១ ឲ្យឮៗ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម ដោយរកមើលអ្វីផ្សេងទៀតដែលយ៉ូហានបានឃើញថានឹងកើតឡើងនៅថ្ងៃចុងក្រោយ ។ សូមឲ្យសិស្សរៀបរាប់អំពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា ដូចបានកត់ត្រានៅក្នុង វិវរណៈ ១៥–១៦ យ៉ូហានបានពិពណ៌នាអំពីសេចក្តីវេទនាទាំងប្រាំពីរ ដែលនឹងដាក់ទោសដល់ពួកទុច្ចរិតនៅថ្ងៃចុងក្រោយ ។ ប៉ុន្តែពីមុនលោកបានរៀបរាប់អំពីសេចក្តីវេទនាទាំងប្រាំពីរនោះ យ៉ូហានបានផ្អាកបន្តិច ដើម្បីបញ្ជាក់ឡើងវិញអំពីពរជ័យនានាដែលពួកសុចរិតនឹងទទួលបាន ។ សូមសង្ខេប វិវរណៈ ១៥:២–៤ ដោយពន្យល់ថា យ៉ូហានបានឃើញការនិមិត្តមួយអំពីអស់អ្នកដែលនឹងយកឈ្នះលើសាតាំង ហើយសរសើរដល់ព្រះនៅក្នុងនគរសេឡេស្ទាល ។

សូមគូររូបចានកន្ទោង ឬ ចានគោមប្រាំពីរនៅលើក្តារខៀន ហើយដាក់លេខរៀងពីលេខ ១ ដល់ ៧ (ឬ សរសេរលេខនៅលើក្តារខៀន) ។ សូមពន្យល់ថា នៅក្នុងការនិមិត្តរបស់លោក នោះយ៉ូហានបានឃើញចានកន្ទោង ឬ ចានគោមប្រាំពីរដែលមានសេចក្តីវេទនាទាំងប្រាំពីរ ។

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ១៦:២–៤, ៨–១២, ១៦–២១ ។ សូមសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមដោយរកមើលរបៀបដែលយ៉ូហានបានពិពណ៌នាអំពីសេចក្តីវេទនាទាំងប្រាំពីរ ។ សូមឈប់បន្តិចបន្ទាប់ពីចប់ការពិពណ៌នាអំពីសេចក្តីវេទនានីមួយៗ ហើយសូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរសេចក្តីវេទនានោះនៅលើក្តារខៀន ដែលនៅពីក្រោមត្រូវនឹងរូបចានកន្ទោង (ឬ លេខ) នៅលើក្តារខៀន ។

បន្ទាប់មកសូមអញ្ជើញសិស្សម្នាក់ឲ្យអានការពិពណ៌នារបស់យ៉ូហានអំពីសេចក្តីវេទនាទីបី សូមអញ្ជើញសិស្សម្នាក់ឲ្យអាន វិវរណៈ ១៦:៦ ឲ្យឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុមួយ ដែលមនុស្សនឹងរងទុក្ខដោយសារសេចក្តីវេទនានៅថ្ងៃចុងក្រោយ ។

- តើមូលហេតុអ្វីដែលមនុស្សនឹងរងទុក្ខ ដោយសារសេចក្តីវេទនានេះនៅថ្ងៃចុងក្រោយ ?

បន្ទាប់ពីសិស្សអានការពិពណ៌នាអំពីសេចក្តីវេទនាទីប្រាំមួយហើយ សូមពន្យល់ថា អំឡុងពេលនៃសេចក្តីវេទនានេះ ទន្លេអឺប្រាតនឹងរីងស្ងួត ដើម្បីរៀបចំសម្រាប់ការប្រមូលផ្តុំស្តេចនៃពិភពលោកសម្រាប់ចម្បាំងនៅ អើម៉ាគេដូន (សូមមើល វិវរណៈ ១៦:១២–១៦ , សូមមើលផងដែរ សាការី ១២:១១) ។ នៅពេលសង្គ្រាមចប់ ព្រះអង្គសង្គ្រោះនឹងបង្ហាញព្រះកាយទ្រង់ដល់ប្រជាជននៅក្នុងក្រុងយេរូសាឡិម (សូមមើល គ. និង ស. ៤៥:៤៧–៥៣) និង ដល់មនុស្សទាំងអស់នៃផែនដី (សូមមើល ម៉ាថាយ ២៤:៣០, គ. និង ស. ១០១:២៣) ។

> ***ថ្លែងទីបន្ទាល់***
>
> រឿងដ៏សំខាន់បំផុតមួយ ដែលអ្នកអាចធ្វើនោះគឺថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៃដំណឹងល្អ និង សេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រារបស់ទ្រង់ ។ ទីបន្ទាល់របស់អ្នកអាចជួយពង្រឹងសេចក្តីជំនឿរបស់សិស្ស ហើយលួងលោមពួកគេ នៅពេលពួកគេជួបនឹងការលំបាកក្នុងការរស់នៅក្នុងពិភពលោកដ៏ទុច្ចរិតនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន វិវរណៈ ១៦:១៥ ឲ្យឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលយើងអាចធ្វើដើម្បីរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថាឃ្លា « រក្សាសម្លៀកបំពាក់ខ្លួន ដើម្បីមិនឲ្យដើរអាក្រាត » សំដៅលើការត្រៀមខ្លួនជាស្រេចខាងវិញ្ញាណ ។

- យោងតាម ខទី ១៥ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ? (សិស្សគួរស្គាល់គោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងចាំយាម ហើយត្រៀមខ្លួនខាងវិញ្ញាណ នោះយើងនឹងបានត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ**) ។
- តើយើងអាចត្រៀមខ្លួនជាស្រេចខាងវិញ្ញាណតាមរបៀបណាខ្លះ?

សូមថ្លែងទីបន្ទាល់ ថាព្រះអម្ចាស់ស្រឡាញ់រាស្ត្ររបស់ទ្រង់ ហើយមានព្រះទ័យឲ្យយើងរៀបចំខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រុងប្រយ័ត្ន ហើយត្រៀមខ្លួនខាងវិញ្ញាណជាស្រេច ប្រយោជន៍ឲ្យពួកគេអាចទទួលពរជ័យពីព្រះអម្ចាស់ ។

វិវរណៈ ១៧–១៩

សេចក្តីផ្តើម

យ៉ូហានបានមើលឃើញថា បាប៊ីឡូនខាងវិញ្ញាណ ឬកពន្លៃមនុស្សទុច្ចរិត នឹងច្បាំងទាស់នឹងកូនចៀមនៃព្រះ ហើយថាកូនចៀមនឹងមានជ័យជំនះលើអារក្ស ។ ពួកបរិសុទ្ធត្រូវបានហៅឲ្យចេញពីបាប៊ីឡូនខាងវិញ្ញាណ ហើយអ្នកដែលស្អាតស្អំ ហើយសុចរិតនឹងត្រូវបានហៅឲ្យចូលរួមពិធីលាងសោយកោជក្នុងពិធីរៀបអភិសេកនៃកូនចៀម ។ យ៉ូហានបានមើលឃើញព្រះយេស៊ូវគ្រីស្ទយាងមក នៅក្នុងព្រះចេស្តាដ៏អស្ចារ្យដើម្បីបំផ្លាញជនដែលទាស់នឹងទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ១៧–១៨

យ៉ូហានបានឃើញទុកជាមុនពីការបំផ្លិចបំផ្លាញនៃបាប៊ីឡូនខាងវិញ្ញាណ

ចូរសរសេរនៅលើ ក្តារខៀន នូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ លីន ជី រ៉ូប៊ីន ក្នុងពួកចិតសិបនាក់ ហើយអញ្ជើញសិស្សឲ្យអានវាឮៗ ។ (សេចក្តីថ្លែងការណ៍មាននៅក្នុង « Avoid It » | ការប្រជុំធម្មនិដ្ឋាននៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៣ | ទំព័រ ១, speeches.byu.edu) ។

« ការគេចចេញពីការល្បួងគឺងាយស្រួលជាងការតតាំងនឹងវា » (អែលឌើរ លីន ជី រ៉ូប៊ីន) ។

- ហេតុអ្វីអ្នកគិតថា ការគេចវេសចេញពីការល្បួងគឺងាយស្រួលជាងការតតាំងនឹងវា ?
- តើអាចមានអ្វីកើតឡើង ប្រសិនបើយើងដាក់ខ្លួនឯងនៅក្នុងស្ថានភាពដែលយើងត្រូវតែតតាំងនឹងការល្បួងជានិច្ចនោះ: ?

នៅពេលសិស្សសិក្សា វិវរណៈ ១៧–១៨ សូមអញ្ជើញពួកគេឲ្យរកមើលពី សេចក្តីពិតដែលនឹងជួយពួកគេឲ្យស្គាល់ពីរបៀបចៀសវៀងពីការល្បួង និងអំពើបាបជាច្រើននៃពិភពលោកនេះ: ។

សូមរំឭកសិស្សថា យ៉ូហានបានឃើញនៅក្នុងការនិមិត្តនូវទេវតាប្រាំពីរអង្គដែលនឹងចាក់គ្រោះចង្រៃលើមនុស្សទុច្ចរិតនៅថ្ងៃចុងក្រោយ (សូមមើល វិវរណៈ ១៦) ។ សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១៧:១ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថា ទេវតាមួយអង្គក្នុងចំណោមទេវតាទាំងប្រាំពីរបានមានបន្ទូលថានឹងបង្ហាញអ្វីខ្លះដល់យ៉ូហាន ។

- តើទេវតាអង្គនោះបានមានបន្ទូលថា ទ្រង់នឹងបង្ហាញអ្វីខ្លះដល់យ៉ូហាន ?

សូមអញ្ជើញសិស្សឲ្យអានវិវរណៈ ១៧:១៥ ដោយស្ងាត់ស្ងៀម ហើយរកមើលថាដែនទឹកដ៏ច្រើននោះតំណាងឲ្យអ្វី ។

- យោងតាម ខទី ១៥តើទឹកដ៏ច្រើនដែលស្ត្រីនោះអង្គុយលើតំណាងឲ្យអ្វី ? (ប្រជាជន និងជាតិសាសន៍ដែលនាងមានអំណាច និងឥទ្ធិពលលើ | សូមមើលផងដែរ នីហ្វៃទី ១ ១៤:១១ |) ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ១៧:២–៦ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលពាក្យ និងឃ្លានានាដែលពិពណ៌នាអំពីស្ត្រីនោះ: និងឥទ្ធិពលរបស់នាងទៅលើពិភពលោកនេះ: ។

- តើពាក្យ ឬឃ្លាណាខ្លះដែលពិពណ៌នាពីស្ត្រីនោះ: ?
- យោងតាម ខទី ២ តើឥទ្ធិពលរបស់ស្ត្រីនោះទៅលើពួកអ្នកដឹកនាំ និងប្រជាជននៅលើផែនដីនេះត្រូវបានរៀបរាប់យ៉ាងដូចម្តេច ?
- នៅក្នុង ខទី ៦ ការដែលស្ត្រីនោះស្រវឹងនឹងឈាមនៃពួកបរិសុទ្ធ និងពួកទុក្ករបុគ្គល តើអ្នកគិតថាវាតំណាងឲ្យអ្វី ? (នៅគ្រប់សម័យកាល មនុស្សសុចរិតជាច្រើនត្រូវបានមនុស្សទុច្ចរិតសម្លាប់ ហើយពាក្យនៅក្នុងបទគម្ពីរបានណែនាំថា ការសម្លាប់មនុស្សសុចរិតមានឥទ្ធិពលដ៏ញៀនស្រវឹងចំពោះអស់អ្នកដែលប្រព្រឹត្តឃាតកម្ម) ។

សូមពន្យល់ថា សត្វដែលបានរៀបរាប់នៅក្នុង ខទី ៣ អាចនឹងតំណាងឲ្យក្រុងរ៉ូមនៅជំនាន់របស់យ៉ូហាន ក៏ដូចជាឯគរ និងប្រជាជាតិដ៏ពុករលួយនៅថ្ងៃចុងក្រោយផងដែរ (សូមមើល វិវរណៈ ១៧:៨–១៣) ។

សូមឲ្យសិស្សពិចារណាថា នរណា ឬអ្វីទៅដែលតំណាងឲ្យស្ត្រីដែលបានរៀបរាប់នៅក្នុង ខទី ១–៦ ។ សូមអញ្ជើញសិស្សឲ្យអាន វិវរណៈ ១៧:១៨ ដោយស្ងៀមស្ងាត់ ហើយរកមើលថា ស្ត្រីនោះតំណាងឲ្យអ្វី ។

- យោងតាមខទី ១៨តើស្ត្រីនោះតំណាងឲ្យអ្វី ?

សូមពន្យល់ថា « ទីក្រុងដ៏ធំ » (ខទី ១៨) សំដៅទៅលើបាប៊ីឡូនខាងវិញ្ញាណ (សូមមើល គ. និង ស. ១៣៣:១៤) ។ ដោយសារតែរឿងខាងលោកិយ និងភាពពុករលួយនៃបាប៊ីឡូនកាលពីបុរាណ និងដោយសារតែវាគឺជាកន្លែងមួយដែលកូនចៅអ៊ីស្រាអែលត្រូវជាប់ក្នុងសេរភាព ដូចបានប្រើប្រៀបធៀបនៅក្នុងព្រះគម្ពីរជារឿយៗតំណាងឲ្យអំពើបាប រឿងលោកិយ ឥទ្ធិពលនៃអំពើអាក្រក់នៅលើផែនដី និងសេរភាពខាងវិញ្ញាណ (សូមមើលផងដែរ នីហ្វៃទី១ ១៣:១–៩, ១៤:៩–១០) ។

សូមសរសេរនៅលើក្តារខៀន ៖ *ស្ត្រីនោះ: = បាប៊ីឡូន ឬអំពើទុច្ចរិតនៃលោកិយ*

សូមអញ្ជើញសិស្សឲ្យអាន វិវរណៈ ១៧:១៤ ដោយស្ងៀមស្ងាត់ ហើយរកមើលថាបាប៊ីឡូននឹងច្បាំងទាស់នឹងនរណា ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្វីទៅនឹងក្លាយជាលទ្ធផលនៃសង្គ្រាមនេះ ? (បន្ទាប់ពីសិស្សឆ្លើយតប ចូរសរសេរសេចក្តីពិតដូចតទៅនៅលើក្តារខៀន ៖ **នៅថ្ងៃចុងក្រោយ ព្រះយេស៊ូវគ្រីស្ទនឹងយកឈ្នះលើអំពើទុច្ចរិតនៃលោកិយ**) ។
- តើការដឹងពីសេចក្តីពិតនេះអាចជួយអ្នកយ៉ាងណាដែរ នៅក្នុងនាមជាអ្នកដើរតាមម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ?

សូមសង្ខេប វិវរណៈ ១៨:១–៣ ដោយពន្យល់ថា មានទេវតាមួយអង្គទៀតបានប្រកាសពីការធ្លាក់នៃបាប៊ីឡូនដ៏ទុច្ចរិតនោះ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១៨:៤ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់បានបង្គាប់ឲ្យរាស្ត្ររបស់ទ្រង់ធ្វើអ្វីខ្លះ ។

- តើព្រះអម្ចាស់បានបង្គាប់ឲ្យរាស្ត្ររបស់ទ្រង់ធ្វើអ្វីខ្លះ ?
- តើហេតុផលអ្វីទៅដែលព្រះអម្ចាស់បានបង្គាប់ឲ្យរាស្ត្ររបស់ទ្រង់ចេញពីបាប៊ីឡូនដូច្នេះ ? (ដើម្បីចៀសវាងពីអំពើបាបនៃលោកិយ និងគ្រោះចង្រៃ ឬការកាត់សេចក្តីដែលកើតមានដល់ពួកទុច្ចរិត) ។
- តើយើងអាចស្គាល់ សេចក្តីពិត អ្វីខ្លះនៅក្នុងសេចក្តីបង្គាប់របស់ព្រះអម្ចាស់ដល់រាស្ត្ររបស់ទ្រង់ ឲ្យញែកខ្លួនពួកគេចេញពីអំពើទុច្ចរិតនៃលោកិយ ? (ទោះបីជាសិស្សប្រើពាក្យខុសគ្នាក្តី សូមធ្វើឲ្យប្រាកដថា ពួកគេស្គាល់សេចក្តីពិតមួយស្រដៀងគ្នានឹងសេចក្តីពិតដូចតទៅនេះ ៖ **ការញែកខ្លួនយើងចេញពីអំពើទុច្ចរិតនៃលោកិយអាចជួយយើងឲ្យចៀសវាងពីអំពើបាប និងការកាត់សេចក្តីដែលនឹងកើតមានដល់មនុស្សទុច្ចរិតនៅថ្ងៃចុងក្រោយ ។** អ្នកគួរឲ្យយោបល់សិស្សឲ្យគូសចំណាំពាក្យនៅក្នុង២ទី ៤ដែលបង្រៀនពីសេចក្តីពិតនេះ) ។

សូមចែកសិស្សជាក្រុម ដែលមានគ្នាពីរទៅបួននាក់ ។ សូមផ្តល់ សំណួរ ដូចខាងក្រោមនេះដល់ក្រុមនីមួយៗជាសំណៅចែក ហើយណែនាំសិស្សឲ្យពិភាក្សាសំណួរទាំងនោះជាមួយក្រុមពួកគេ ៖

ការញែកខ្លួនយើងចេញពីបាប៊ីឡូនខាងវិញ្ញាណ

- តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលត្រូវបានស្តារឡើងវិញ ជួយយើងឲ្យញែកខ្លួនយើងពីអំពើទុច្ចរិតនៃលោកិយយ៉ាងដូចម្តេច ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីញែកចេញខ្លួនយើងចេញពីអំពើទុច្ចរិតខាងលោកិយ ពេលយើងបន្តរស់នៅក្នុងចំណោមសេចក្តីស្រឡាញ់ ហើយទាក់ទងនឹងជនដែលមានបទដ្ឋានខុសពីយើង ?
- តើការញែកខ្លួនចេញពីឥទ្ធិពល និងការអនុវត្តទុច្ចរិតបានជួយអ្នក ឬមនុស្សដទៃទៀតដែលអ្នកស្គាល់ឲ្យចៀសវាងពីការល្បួង និងអំពើបាបមួយចំនួននៃលោកិយបានយ៉ាងដូចម្តេច ?

បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយនោះ សូមឲ្យសិស្សបីបួននាក់ ឲ្យចែកចាយដល់សិស្សក្នុងថ្នាក់នូវអ្វីដែលពួកគេបានពិភាក្សា ។ សូមអញ្ជើញសិស្សឲ្យសរសេរនៅលើក្រដាស (១) ឥទ្ធិពល ឬការអនុវត្តទុច្ចរិតដែលពួកគេត្រូវញែកខ្លួនពួកគេចេញ និង (២) របៀបដែលពួកគេធ្វើកិច្ចការនេះ ។ សូមអញ្ជើញពួកគេឲ្យទុកក្រដាសនោះនៅកន្លែងដែលពួកគេអាចផ្ទៀងមើលជាញឹកញាប់ ហើយលើកទឹកចិត្តពួកគេឲ្យអនុវត្តនូវអ្វីដែលពួកគេបានសរសេរ ។

សូមសង្ខេប វិវរណៈ ១៨:៥–២៤ ដោយពន្យល់ថា យ៉ូហានបានឃើញពីការធ្លាក់នៃបាប៊ីឡូនទុច្ចរិត និងភាពសោកសៅនៃពួកអ្នកគាំទ្ររបស់វា ។

វិវរណៈ ១៩

យ៉ូហានឃើញព្រះយេស៊ូវគ្រីស្ទយាងមកនៅក្នុងព្រះចេស្តា ដើម្បីបំផ្លាញជនដែលទាស់នឹងទ្រង់ ។

សូមបង្ហាញរូបភាពមួយនៃកូនកំលោះ និងកូនក្រមុំមួយគូ ។ សូមសួរសិស្សថា អំណោយអ្វីទៅជាអំណោយដ៏ល្អបំផុត ដែលពួកគេអាចផ្តល់ឲ្យទៅស្វាមី ឬភរិយារបស់ពួកគេនាពេលអនាគតនៅថ្ងៃមង្គលការរបស់ពួកគេ ។ បន្ទាប់ពីសិស្សឆ្លើយតប សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដែរ្រី អ័រ ហូឡិន ក្នុងក្លូមែននៃពួកសាវកដប់ពីរនាក់ ៖

« នៅថ្ងៃមង្គលការរបស់អ្នក អំណោយដ៏ល្អបំផុតដែលអ្នកអាចផ្តល់ឲ្យដៃគូដ៏នៅអស់កល្បជានិច្ចរបស់អ្នកនោះគឺចរិតលក្ខណៈដ៏ល្អបំផុតរបស់អ្នក—ស្អាតស្អំ ហើយបរិសុទ្ធ ហើយសក្តិសមនឹងទទួលបានមកវិញនូវបរិសុទ្ធភាព » (« Personal Purity » *Ensign* ខែវិច្ឆិកា ឆ្នាំ១៩៩៨ ទំព័រ ៧៧) ។

- ហេតុអ្វីអ្នកគិតថាការស្អាតស្អំ ហើយបរិសុទ្ធគឺជាអំណោយដ៏ល្អបំផុតដែលអ្នកអាចផ្តល់ឲ្យស្វាមី ឬភរិយារបស់អ្នកនៅថ្ងៃមង្គលការ ?

សូមពន្យល់ថា វិវរណៈ ១៩ កត់ត្រារឿងប្រៀបប្រដូចមួយអំពីអាពាហ៍ពិពាហ៍ដែលត្រូវបានប្រើ ដើម្បីបរិយាយពីការយាងមកជាលើកទីពីរ ។ សូមសង្ខេប វិវរណៈ ១៩:១–៦ ដោយពន្យល់ថា យ៉ូហានបានឃើញថា មនុស្សសុចរិតនឹងសរសើរព្រះចំពោះការកាត់សេចក្តីរបស់ទ្រង់ទាស់នឹងមនុស្សទុច្ចរិត ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១៩:៧ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាទេវតាបានប្រកាសដល់យ៉ូហានអំពីអាពាហ៍ពិពាហ៍របស់នរណា ។

ផ្តោតលើគោលការណ៍នៃការប្រែចិត្តជឿ

នៅពេលកំណត់ថាត្រូវបង្រៀនពីអ្វីនៅក្នុងបណ្តុំបទគម្ពីរ សូមផ្តោតលើសេចក្តីពិតដែលនឹងជួយសិស្សឲ្យខិតមកជិតព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះ ។ អែលឌើរ ហិនរី ប៊ី អាវរិង ក្នុងគណៈប្រធានទីមួយបានទូន្មាន ៖ « នៅពេលអ្នករៀបចំមេរៀនមួយ សូមរកគោលការណ៍នៃការផ្លាស់ប្រែចិត្តជឿនៅក្នុងមេរៀននោះ ។ . . . គោលការណ៍នៃការផ្លាស់ប្រែចិត្តជឿ គឺជាគោលការណ៍មួយដែលដឹកនាំទៅកាន់ការគោរពប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះ » (« Converting Principles » [ល្ងាចមួយជាមួយអែលឌើរ អិលថម គែរី ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦] ទំព័រ ១, si.lds.org) ។

- តើទេវតាបានប្រកាសដល់យ៉ូហានអំពីអាពាហ៍ពិពាហ៍របស់នរណា ?
- តើយ៉ូហានបានរៀនអ្វីខ្លះអំពីភរិយារបស់កូនចៀម ?

សូមពន្យល់ថា « ពេលរៀបវិវាហមង្គលនៃកូនចៀម » (វិវរណៈ ១៩:៧) សំដៅទៅលើការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗអំពីសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកថា កូនក្រមុំរបស់កូនចៀមជានរណា ។

« នៅក្នុងគ្រាកាន់កាប់ត្រួតត្រានេះ កូនកំលោះដែលជាកូនចៀមរបស់ព្រះនឹងយាងមកប្រកាសរកកូនក្រមុំរបស់ទ្រង់ ដែលជាសាសនាចក្រដែលមានពួកបរិសុទ្ធស្មោះត្រង់ ដែលបានទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ទ្រង់ » (*Mormon Doctrine* កំណែទី២ | ឆ្នាំ ១៩៦៦ | ទំព័រ ៤៦៩) ។

- តើទំនាក់ទំនងអាពាហ៍ពិពាហ៍មួយគឺជានិមិត្តរូបមួយដ៏សមរម្យ សម្រាប់ទំនាក់ទំនងនៃសេចក្តីសញ្ញារបស់យើងជាមួយនឹងព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ? (អ្នករអាចពន្យល់ថា អាពាហ៍ពិពាហ៍គឺជាទំនាក់ទំនងមួយ ដែលតម្រូវឲ្យភាពស្មោះត្រង់ ការលះបង់ សេចក្តីស្រឡាញ់ ការតាំងចិត្ត និងការទុកចិត្ត) ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ១៩:៨–៩ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថាពួកបរិសុទ្ធអាចធ្វើអ្វីខ្លះ ដើម្បីត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។ អ្នករអាចពន្យល់ថា សំពត់ទេស–សរអាចតំណាងឲ្យភាពបរិសុទ្ធ ភាពស្អាតស្អំ និងសេចក្តីសុចរិត ។

- ដូចដែលបានតំណាងឲ្យសំលៀកបំពាក់នៃភរិយារបស់កូនចៀម តើយើងត្រូវធ្វើអ្វីខ្លះដើម្បីត្រៀមខ្លួនយើងសម្រាប់ការយាងមករបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ? (បន្ទាប់ពីសិស្សបានឆ្លើយ សូមសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ **ប្រសិនបើយើងស្អាតស្អំ ហើយសុចរិត នោះយើងនឹងត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមករបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ**) ។

ចូរពន្យល់ថា ពាក្យ *ប្រទាន* នៅក្នុង ខទី ៨ មានន័យថាបានផ្តល់ឲ្យ ឬយល់ព្រម ។ ការស្អាតស្អំពីអំពើបាប ហើយបានធ្វើឲ្យសុចរិតគឺជាអំណោយទានមួយមកពីព្រះ ។

- តើព្រះបានធ្វើអ្វីខ្លះ ដើម្បីប្រទានផ្លូវមួយឲ្យយើងបានស្អាតស្អំពីអំពើបាប ហើយក្លាយជាសុចរិត ?
- ហេតុអ្វីអ្នកគិតថា ការមានភាពស្អាតស្អំ ហើយសុចរិតគឺជាអំណោយទានមួយដ៏ល្អបំផុតដែលយើងអាចថ្វាយព្រះអង្គសង្គ្រោះ នៅពេលទ្រង់យាងមកម្តងទៀត ?

សូមអញ្ជើញសិស្សអាន វិវរណៈ ១៩:១០ ដោយស្ងាត់ស្ងៀម ហើយរកមើលពីប្រតិកម្មដែលយ៉ូហានមាន បន្ទាប់ពីស្តាប់ឮរឿងដែលទេវតាបានប្រកាសដល់លោក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- តើទេវតាបានប្រកាសដល់យ៉ូហានថា ទ្រង់ (ទេវតា) និងពួកអ្នកបម្រើផ្សេងទៀតរបស់ព្រះមានអ្វីខ្លះ ? (ទីបន្ទាល់ពីព្រះយេស៊ូវដែលជាវិញ្ញាណនៃសេចក្តីទំនាយ) ។

សូមពន្យល់ថា « វិញ្ញាណនៃសេចក្តីទំនាយ » (ខទី ១០) សំដៅទៅលើអំណោយទាននៃវិវរណៈ និងការបំផុសគំនិតមកពីព្រះ ដែលអនុញ្ញាតឲ្យមនុស្សម្នាក់ទទួល ហើយនិយាយពីបន្ទូលរបស់ព្រះ (សូមមើលសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « ព្យាករ, ការព្យាករ » scriptures.lds.org) ។

- តើមនុស្សម្នាក់ដែលមានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទអាចត្រៀមខ្លួន សម្រាប់យាងមកជាលើកទីពីរយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង វិវរណៈ ១៩:១១–១៦ ដែលមាននៅក្នុងការបកប្រែដោយ យ៉ូសែប ស៊្មីធ វិវរណៈ ១៩:១៥ (នៅក្នុង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ) ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលពាក្យ ឬឃ្លាទាំងឡាយដែលពិពណ៌នាអំពីព្រះអង្គសង្គ្រោះនៅការយាងមកជាលើកទីពីររបស់ទ្រង់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា សេះសដែលបានលើកឡើងនៅក្នុង ខទី ១១ គឺជានិមិត្តរូបនៃជោគជ័យ និង ជ័យជំនះ ។ ព្រះអង្គសង្គ្រោះនឹងយាងមកផ្ចាញ់អំពើបាប និងសេចក្តីទុច្ចរិត ។

- យោងតាម ខទី ១៣ តើព្រះពស្តរបស់ព្រះអង្គសង្គ្រោះត្រូវបានពិពណ៌នាយ៉ាងដូចម្តេច ? (សូមពន្យល់ថា ឃ្លា « ជ្រលក់ដោយឈាម » មានន័យថាព្រះពស្តរបស់ទ្រង់នឹងមានពណ៌ក្រហមឆ្អៅដូចជាឈាម ។ ពណ៌នេះតំណាងឲ្យការបំផ្លិចបំផ្លាញដល់មនុស្សទុច្ចរិតនៅការយាងមករបស់ទ្រង់ | សូមមើល គ. និង ស. ១៣៣:៤៦–៥១ | ហើយក៏អាចរំឭកដល់យើងឲ្យដឹងពីការរងទុក្ខដែលទ្រង់បានជួបនៅគ្រានៃដង្ហាយធួនរបស់ទ្រង់) ។

សូមចង្អុលបង្ហាញថា ការបកប្រែដោយ យ៉ូសែបសម្រាប់វិវរណៈ ១៩:១៥ បានបញ្ជាក់យ៉ាងច្បាស់ថា យ៉ូហានបានឃើញថា នៅពេលព្រះអង្គសង្គ្រោះបានយាងមកជាស្តេចនៃអស់ទាំងស្តេច និងជាព្រះអម្ចាស់នៃអស់ទាំងព្រះអម្ចាស់ នោះទ្រង់នឹងដឹកនាំប្រជាជាតិទាំងឡាយដោយបន្ទូលនៃព្រះ ។ សូមសង្ខេប វិវរណៈ ១៩:១៧–២១ ដោយពន្យល់ថា យ៉ូហានបានឃើញការបំផ្លិចបំផ្លាញនៃជនដែលទាស់ប្រឆាំងនឹងកូនចៀមនៃព្រះ (សូមមើលការបកប្រែដោយ យ៉ូសែប ស៊្មីធ វិវរណៈ ១៩:១៨) ។

សូមបញ្ចប់ដោយសូមឲ្យសិស្សសញ្ជឹងគិតពីរឿង ដែលពួកគេត្រូវធ្វើដើម្បីត្រៀមខ្លួនសម្រាប់ការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តឲ្យពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេទទួលបាន ។

វិវរណៈ ២០

សេចក្តីផ្តើម

យ៉ូហានបានឃើញព្រឹត្តិការណ៍ជាច្រើនដែលនឹងកើតឡើងភ្លាមៗពីមុន និងនៅក្នុងរជ្ជកាលនៃសហស្សវត្សរ៍របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការនិមិត្ត ។ លោកក៏បានឃើញផងដែរអំពីចម្បាំងចុងក្រោយរវាងសាតាំង និងទ័ពរបស់ព្រះនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ហើយលោកបានឃើញការកាត់សេចក្តីចុងក្រោយ ជាគ្រាដែលព្រះនឹងកាត់សេចក្តីមនុស្សគ្រប់គ្នាចេញពីសៀវភៅដែលបានកត់ត្រាទុក ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ២០:១–៦

យ៉ូហានឃើញអ្វីដែលនឹងកើតឡើងភ្លាមៗពីមុន និងនៅក្នុងរជ្ជកាលនៃសហស្សវត្សរ៍របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការនិមិត្ត

សូមឲ្យសិស្សគិតអំពីការប្រកួតមួយ (ដូចជាព្រឹត្តិការណ៍ខាងសិល្បៈ ឬខាងអត្តពលកម្ម) ដែលពួកគេបានចូលរួម ទោះបីជាពួកគេដឹងខ្លួនថា ពួកគេនឹងត្រូវចាញ់ក៏ដោយ ។ បន្ទាប់មកសូមឲ្យពួកគេគិតអំពីគ្រាមួយដែលពួកគេបានចូលរួមនៅក្នុងការប្រកួតមួយដែលពួកគេជឿថា ពួកគេនឹងឈ្នះ ។

- តើការរំពឹងទុករបស់អ្នកអំពីលទ្ធផលនៃការប្រកួតមួយអាចផ្លាស់ប្តូរការខិតខំរបស់អ្នកយ៉ាងដូចម្តេច ?
- ហេតុអ្វីមនុស្សសុខចិត្តបោះបង់ចោលការប្រកួត នៅពេលពួកគេគិតថាពួកគេនឹងចាញ់នោះ ? តើនៅពេលណាដែរ ដែលអ្នកគិតថាអ្នកនឹងចាញ់ ប៉ុន្តែបែរជាឈ្នះវិញ ?

សូមពន្យល់សិស្សថា នៅពេលពួកគេសិក្សា វិវរណៈ ២០ ពួកគេនឹងរៀនបន្ថែមទៀតអំពីចម្បាំងរវាងអំពើល្អ និងអំពើអាក្រក់ និងលទ្ធផលចុងក្រោយនៃចម្បាំងនោះ ។ នៅពេលសិស្សសិក្សា វិវរណៈ ២០ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលអាចលើកទឹកចិត្តពួកគេឲ្យបន្តស្មោះត្រង់ចំពោះព្រះអង្គសង្គ្រោះនៅក្នុងចម្បាំងនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើនឹងមានអ្វីកើតឡើងដល់សាតាំងនៅពេលសហស្សវត្សរ៍ ។

- តើនឹងមានអ្វីកើតឡើងដល់សាតាំងនៅពេលសហស្សវត្សរ៍ ? (សូមពន្យល់ថា ជង្ហុកធំតំណាងឲ្យស្ថាននរក) ។
- យោងតាមខទី ៣តើអ្វីទៅដែលសាតាំងពុំអាចធ្វើបាន ដោយព្រោះ វាត្រូវបានចាប់ចង ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:៤–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា តើយ៉ូហានបានឃើញថានរណាខ្លះទទួលបានការកាត់សេចក្តី ។

- យោងតាម ខទី ៤ តើយ៉ូហានបានឃើញថានរណាខ្លះទទួលបានការកាត់សេចក្តី ?
- តើប្រជាជនទាំងនេះបានទទួលរង្វាន់អ្វីខ្លះ ដោយសារតែសេចក្តីស្មោះត្រង់របស់ពួកគេ ?
- តើពួកគេនឹងមានចំណែកអ្វីខ្លះនៅសហស្សវត្សរ៍ ? (ការរស់ឡើងវិញលើកទីមួយ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុង វិវរណៈ ២០:៤–៦ អំពីពរជ័យដែលយើងអាចទទួល ប្រសិនបើយើងស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទនោះ ? (សិស្សអាចនឹងប្រើពាក្យផ្សេងៗ ប៉ុន្តែពួកគេគួរស្គាល់គោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ យើងនឹងមានចំណែកនៅក្នុងការរស់ឡើងវិញលើកទីមួយ ហើយគ្រងរាជ្យជាមួយនឹងព្រះគ្រីស្ទនៅក្នុងអំឡុងពេលសហស្សវត្សរ៍**) ។

សូមពន្យល់ថា ការរស់ឡើងវិញលើទីមួយបានចាប់ផ្តើមជាមួយនឹងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ព្រមទាំងជាមួយពួកសុចរិតដែលបានស្លាប់ពីមុនការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ (សូមមើល ម៉ូសាយ ១៥:២១–២៥, អាលម៉ា ១១:១៦–២០) ។ ពួកបរិសុទ្ធភាគច្រើនដែលបានស្លាប់ បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទនឹងបានរស់ឡើងវិញនៅឯការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល James E. Talmage *The Articles of Faith* កំណែទី ១២ | ឆ្នាំ ១៩២៤ | ទំព័រ ៣៨៥) ។ ពួកទុច្ចរិត និងជនដែលពុំប្រែចិត្តនឹងពុំបានរស់ឡើងវិញឡើយ រហូតដល់ការរស់ឡើងវិញជាលើកទីពីរ ដែលនឹងកើតឡើងនៅចុងបញ្ចប់នៃសហស្សវត្សរ៍ (សូមមើល គ. និង ស. ៧៦:៨៥) ។

- តើការដឹងថា អ្នកអាចមានចំណែកនៅក្នុងការរស់ឡើងវិញលើកទីមួយ ហើយគ្រងរាជ្យជាមួយនឹងព្រះយេស៊ូវគ្រីស្ទនៅសហស្សវត្សរ៍ អាចជួយអ្នកឲ្យស្មោះត្រង់នៅពេលនេះ នៅក្នុងចម្បាំងទាស់នឹងអំពើអាក្រក់បានយ៉ាងដូចម្តេច ?

សូមថ្លែងទីបន្ទាល់ថា ជនដែលបន្តស្មោះត្រង់នឹងមានចំណែកមួយនៅក្នុងការរស់ឡើងវិញលើកទីមួយ ហើយគ្រងរាជ្យជាមួយព្រះអង្គសង្គ្រោះនៅក្នុងសហស្សវត្សរ៍ ។

វិវរណៈ ២០:៧–១១

យ៉ូហានឃើញចម្បាំងចុងក្រោយរវាងសាតាំង និងទ័ពនៃព្រះនៅចុងបញ្ចប់នៃសហស្សវត្សរ៍

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនេះ៖ នៅលើក្តារខៀន ៖ *នៅចុងបញ្ចប់នៃសហស្សវត្សរ៍* . . .

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:៧–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលព្រឹត្តិការណ៍ ដែលយ៉ូហានបានពិពណ៌នាថានឹងកើតឡើងនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ។

- តើយ៉ូហានបានពិពណ៌នាអំពីព្រឹត្តិការណ៍អ្វីខ្លះ ? (សូមពន្យល់ថា ឈ្មោះ *សាសន៍កុក* និង *សាសន៍ម៉ាកុក* នៅក្នុង ខទី ៨ សំដៅទៅលើពលទ័ព ដែលសាតាំងនឹងប្រើនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ដើម្បីច្បាំងជាលើកចុងក្រោយទាស់នឹងរាស្ត្ររបស់ព្រះអម្ចាស់ (សូមមើល គ. និង ស. ៨៨:១១០–១៤)) ។
- បន្ទាប់ពីចម្បាំងនេះ តើនឹងមានអ្វីខ្លះកើតឡើងចំពោះអារក្ស និងពួកពលបរិវាររបស់វា ? (បន្ទាប់ពីសិស្សឆ្លើយរួច សូមបំពេញឃ្លានៅលើក្តារខៀនដើម្បីឲ្យវាមានន័យដូចតទៅនេះ ៖ **នៅចុងបញ្ចប់នៃសហស្សវត្សរ៍ ទ័ពរបស់ព្រះនឹងយកឈ្នះលើសាតាំង និងពួកពលបរិវាររបស់វា**) ។
- ហេតុអ្វីវាគឺជារឿងដ៏សំខាន់ដែលយើងត្រូវដឹងពីលទ្ធផលចុងក្រោយនៃចម្បាំងរវាងព្រះ និងសាតាំង ?

វិវរណៈ ២០:១២–១៥

យ៉ូហានឃើញសេចក្តីជំនុំជម្រះចុងក្រោយ

សូមពន្យល់ថា ជាផ្នែកមួយនៅក្នុងដែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ មនុស្សគ្រប់រូបដែលធ្លាប់រស់នៅលើផែនដីនេះនឹងឈរទទួលការកាត់សេចក្តីនៅចំពោះព្រះ ។ សូមឲ្យសិស្សនឹកស្រមៃពីទិដ្ឋភាពនៃសេចក្តីជំនុំជម្រះចុងក្រោយ ។

- តើអ្នកសង្ឃឹមចង់គិត ហើយទទួលអារម្មណ៍បែបណា នៅពេលអ្នកឈរនៅចំពោះព្រះ ដើម្បីទទួលការកាត់សេចក្តី ?

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ២០:១២–១៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាម រកមើលថា តើព្រះនឹងកាត់សេចក្តីយើងយ៉ាងដូចម្តេច ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងខទី ១២ អំពីរបៀបដែលយើងនឹងទទួលការកាត់សេចក្តី ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្តាប់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះនឹងកាត់សេចក្តីយើងចេញពីសៀវភៅ ដែលបានសរសេរទុកស្របតាមការប្រព្រឹត្តរបស់យើង**) ។
- តើយ៉ូហានបានឃើញសៀវភៅអ្វីខ្លះ ? (ព្រះគម្ពីរ កំណត់ត្រាសាសនាចក្រដែលកត់ត្រាពិធីបរិសុទ្ធនៃការសង្គ្រោះ ហើយប្រហែលជាទង្វើផ្សេងៗទៀត និងសៀវភៅជីវិត (សូមមើល នីហ្វៃទី២ ២៩:១០–១១, គ. និង ស. ១២៨:៦–៧)) ។

ចូរអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមអំពីបញ្ជីជីវិតឲ្យឮៗ ៖

« តាមន័យមួយ សៀវភៅជីវិតគឺជាការសរុបនូវគំនិត និងកិច្ចការរបស់ជនម្នាក់–គឺជាបញ្ជីអំពីជីវិតរបស់គេ ។ ក៏ប៉ុន្តែគម្ពីរបានចែងថា មានបញ្ជីនៅស្ថានសួគ៌មួយច្បាប់ ដែលបានរក្សាទុកសម្រាប់ពូកមនុស្សស្មោះត្រង់ គឺមានទាំងឈ្មោះគេ និងដំណើររឿងអំពីការប្រព្រឹត្តដ៏សុចរិតទាំងឡាយរបស់គេផងដែរ (គ. និង ស. ៨៨:២; ១២៨:៧) » (សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ « សៀវភៅជីវិត ») ។

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានបើកសម្តែងដល់ព្យាការីយ៉ូសែប ស៊្មីធថា បន្ថែមពីលើការប្រព្រឹត្តរបស់យើង យើងនឹងទទួលការកាត់សេចក្តីស្របតាមបំណងប្រាថ្នានៃដួងចិត្តរបស់យើង (សូមមើល គ. និង ស. ១៣៧:៩, សូមមើលផងដែរ អាលម៉ា ៤១:៣–៥) ។

- យោងតាម វិវរណៈ ២០:១៣ តើនឹងមានអ្វីកើតឡើងពីមុនយើងទទួលការកាត់សេចក្តី ? (ប្រសិនបើចាំបាច់ សូមពន្យល់ថា « សមុទ្រ នោះបានប្រគល់ពូកមនុស្សស្លាប់ ដែលនៅក្នុងទឹកមកវិញ ហើយសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ប្រគល់ពូកមនុស្សស្លាប់ដែលនៅឯណោះមកវិញដែរ » សំដៅទៅលើការរស់ឡើងវិញរបស់មនុស្សគ្រប់រូប) ។
- តើអ្វីទៅដែលអាចជាការចាំបាច់ចំពោះយើង ដែលត្រូវរស់ឡើងវិញពីមុនយើងឈរទទួលការកាត់សេចក្តីនៅចំពោះព្រះ ?

សូមថ្លែងទីបន្ទាល់ថា យើងម្នាក់នឹងឈរចំពោះព្រះដើម្បីទទួលការកាត់សេចក្តី ហើយថាសកម្មភាពរបស់យើងនៅពេលនេះនឹងកំណត់នូវអ្វី ដែលបទពិសោធន៍នោះនឹងកើតមានចំពោះយើង ។ ចូរអានសំណួរដូចខាងក្រោមនេះឲ្យឮៗ ហើយអញ្ជើញសិស្សឲ្យសរសេរចម្លើយនៅក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពូកគេ ៖

- តើអ្នកអាចធ្វើអ្វីខ្លះឲ្យបានប្រសើរឡើងនៅក្នុងជីវិតរបស់អ្នក ដើម្បីត្រៀមខ្លួនទទួលការកាត់សេចក្តីរបស់ព្រះអម្ចាស់ ?

ចំណេះចំណានខគម្ពីរ—វិវរណៈ ២០:១២

សូមពិចារណាអញ្ជើញសិស្សឲ្យប្រើឧបករណ៍ជំនួយការសិក្សាបទគម្ពីរ ដូចជា លេខយោងបទគម្ពីរ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ (ដែលមាននៅលើ scriptures.lds.org) និង Topical Guide ដើម្បីស្វែងរកបទគម្ពីរបន្ថែមទៀត ដែលបង្រៀនអំពីសេចក្តីជំនុំជម្រះចុងក្រោយ ។ សិស្សអាចសរសេរសេចក្តីយោងបទគម្ពីរបន្ថែមទាំងនេះនៅក្នុងព្រះគម្ពីររបស់ពូកគេក្បែរ វិវរណៈ ២០:១២ ។ សូមអញ្ជើញសិស្សឲ្យប្រាប់ដល់សិស្សក្នុងថ្នាក់នូវសេចក្តីពិតបន្ថែមអំពីសេចក្តីជំនុំជម្រះចុងក្រោយ ដែលពូកគេរៀនតាមរយៈសកម្មភាពនេះ ។

វិវរណៈ ២០:១២ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ ការសិក្សាចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យបង្កើននូវការយល់ដឹងរបស់ពួកគេអំពីគោលលទ្ធិគ្រិះ ហើយត្រៀមខ្លួនដើម្បីបង្រៀនវាទៅដល់អ្នកដទៃ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចំណេះចំណានខគម្ពីរនេះ ដោយរបៀបជាក់លាក់មួយ ដើម្បីពួកគេងាយស្រួលនឹងកត់ឃើញ ។ សូមបើកយោងទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរបស់ពួកគេ ។

វិវរណៈ ២១–២២

សេចក្តីផ្តើម

យ៉ូហានបានឃើញស្ថានសួគ៌ថ្មីមួយ និងផែនដីថ្មីមួយ ព្រមទាំងក្រុងយេរូសាឡិមថ្មីចុះមកពីស្ថានសួគ៌ ។ លោកក៏បានឃើញផងដែរថា ព្រះនឹងគង់នៅ ហើយលួងលោមអស្ត្រេរបស់ទ្រង់ ហើយថាក្រុងសេឡេស្ទាលរបស់ព្រះនឹងត្រូវបានបង្កើតឡើងនៅលើផែនដីនេះ ។ យ៉ូហានបានឃើញថា ជនដែលមានឈ្មោះសរសេរនៅក្នុងសៀវភៅជីវិតនឹងចូលទៅក្នុងទីក្រុងនោះ ហើយរស់នៅនឹងព្រះក្នុងសិរីល្អ ។ យ៉ូហានបានបញ្ចប់ការនិមិត្តរបស់លោក ដោយទូលអង្វរឲ្យព្រះអម្ចាស់ត្រឡប់មកផែនដីវិញ ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ២១

យ៉ូហានបានឃើញស្ថានសួគ៌ថ្មីមួយ និងផែនដីថ្មីមួយ ព្រមទាំងក្រុងសេឡេស្ទាលរបស់ព្រះ:

សូមអញ្ជើញសិស្សឲ្យគិតអំពីពេលវេលានៅក្នុងជីវិតរបស់ពួកគេ ដែលពួកគេបានជួបប្រទះនឹងភាពសោកសៅ ឬការឈឺចាប់ ។

- តើរឿងណាខ្លះនៅក្នុងជីវិតដែលអាចធ្វើឲ្យយើងមានភាពសោកសៅ ឬការឈឺចាប់ធ្ងន់ធ្ងរ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។

នៅពេលសិស្សសិក្សាវិវរណៈ ២១សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលអាចលួងលោមចិត្តពួកគេនៅក្នុងគ្រាដ៏លំបាក ។

សូមពន្យល់ទៅសិស្សថា វិវរណៈ ២១–២២ គឺជាដំណើរបន្តនៃការនិមិត្តរបស់យ៉ូហានអំពីព្រឹត្តិការណ៍ដែលនឹងកើតឡើង បន្ទាប់ពីការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២១:១–២ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ូហានបានឃើញអ្វីខ្លះនឹងកើតឡើង ។

- តើយ៉ូហានបានឃើញអ្វីខ្លះនឹងកើតឡើង ?

សូមអញ្ជើញសិស្សពីរនាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះឮៗ ៖

សេចក្តីថ្លែងទី ១

កាលព្រះយេស៊ូវគ្រីស្ទយាងមកម្តងទៀត ហើយសហស្សវត្សរ៍ចាប់ផ្តើម ផែនដីនឹងផ្លាស់ប្តូរទៅស្ថានភាពពីមុនការធ្លាក់របស់អ័ដាម និងអេវ៉ា ។ ពីមុនការធ្លាក់ ផែនដីនេះស្ថិតនៅក្នុងស្ថានភាពទេរេស្ទ្រាល ឬបរមសុខ (ស្ថានភាពនៃភាពបរមសុខ) ។ បន្ទាប់ពីសហស្សវត្សរ៍ ផែនដីនេះនឹងផ្លាស់ប្តូរម្តងទៀតទៅស្ថានភាពសេឡេស្ទាល ដែលបានរៀបចំសម្រាប់វត្តមានរបស់ព្រះ ។ ការផ្លាស់ប្តូរទាំងនេះអាចជាអ្វីដែលយ៉ូហានបានឃើញថានឹងកើតឡើងពេលលោកបានឃើញ « ស្ថានសួគ៌ថ្មីមួយ និងផែនដីថ្មីមួយ » (វិវរណៈ ២១:២) ។

សេចក្តីថ្លែងទី ២

ក្រុងយេរូសាឡិមថ្មីដែលយ៉ូហានបានឃើញចុះមកពីស្ថានសួគ៌ គឺជាក្រុងសេឡេស្ទាលរបស់ព្រះ ។ ក្រុងនេះនឹងទំនងដាក់បញ្ចូលនូវក្រុងរបស់អេណុកដែលបានប្រែរូប ហើយបានលើកឡើងទៅស្ថានសួគ៌ ។ « ក្រុងបរិសុទ្ធ » នេះនឹងឡើង ហើយរួមនឹងក្រុងយេរូសាឡិមថ្មី ឬក្រុងស៊ីយ៉ូនដែលពួកបរិសុទ្ធនឹងស្ថាបនានៅលើផែនដី (សូមមើល ម៉ូសេ ៧:៦២–៦៤) ។

- តើអ្នកគិតថា យ៉ូហានអាចនឹងមានអារម្មណ៍បែបណាដែរ នៅពេលលោកបានឃើញរឿងទាំងនេះកាលលោកត្រូវបាននិរទេសដោយសារសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សម្នាក់អានវិវរណៈ ២១:៣–៤ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះនឹងធ្វើអ្វីខ្លះដល់រាស្ត្ររបស់ទ្រង់ ។

- តើព្រះនឹងធ្វើអ្វីខ្លះដល់រាស្ត្ររបស់ទ្រង់ ? (សិស្សអាចនឹងស្គាល់សេចក្តីពិតដូចតទៅនេះ ៖ **ព្រះនឹងគង់នៅ ហើយលួងលោមដល់រាស្ត្រទ្រង់ ហើយពួកគេនឹងលែងជួបប្រទះសេចក្តីស្លាប់ ភាពសោកសៅ ឬការឈឺចាប់ទៀតហើយ ។** សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមនិយាយអំពីបញ្ជីនៅលើក្តារខៀនទាក់ទងនឹងរឿង ដែលអាចនាំមកឲ្យយើងនូវភាពសោកសៅ ឬការឈឺចាប់ ។

- តើការដឹងថា ព្រះនឹងលួងលោមអាស្ត្រេទ្រង់ ហើយដកយកភាពសោកសៅ និងការឈឺចាប់របស់ពួកគេអាចជួយយើង នៅពេលយើងជួបនឹងឧបសគ្គនៅពេលនេះយ៉ាងដូចម្តេច?

អ្នកគួរចែកចាយទីបន្ទាល់របស់អ្នកអំពីសមត្ថភាពរបស់ព្រះដើម្បីលួងលោមយើង ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២១:៧ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថា ព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ជនដែលយកឈ្នះដោយស្មោះត្រង់ ។

- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះដល់ជនដែលយកឈ្នះ ?

- ដោយផ្អែកលើអ្វីដែលអ្នកបានរៀនអំពីឧបសគ្គដែលកើតមាន ហើយនឹងកើតមានមុនការយាងមកជាលើកទីពីរ តើប្រជាជនទាំងនេះនឹងត្រូវយកឈ្នះ លើរឿងប្រភេទណាខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២១:៨ ឲ្យឮៗ ។ អ្នកគួរពន្យល់ថា ត្រូអាបធ្មប់ម្នាក់គឺជាមនុស្សម្នាក់ ដែលចូលរួមនៅក្នុងសកម្មភាពដែលអញ្ជើញឥទ្ធិពលនៃវិញ្ញាណអាក្រក់ ហើយមនុស្សកំផិតគឺជាមនុស្សម្នាក់ ដែលប្រព្រឹត្តកាមគុណ ឬអំពើកំផិត ។

- តើអ្វីទៅជាបទពិសោធន៍ដែលបានរៀបរាប់នៅក្នុង ខទី ៨ ? (សេចក្តីស្លាប់ទីពីរ) ។

សូមពន្យល់ថា សេចក្តីស្លាប់ទីពីរគឺជាសេចក្តីស្លាប់ខាងវិញ្ញាណ ឬការបែកចេញពីព្រះ ថាជនដែលបះបោរប្រឆាំងនឹងពន្លឺ និងសេចក្តីពិតដោយចេតនានឹងជ្រុងរឿងទាំងនេះ បន្ទាប់ពីសេចក្តីជំនុំជម្រះចុងក្រោយ (សូមមើល ហេលេមិន ១៤:១៦–១៩) ។

សូមសង្ខេប វិវរណៈ ២១:៩–២១ ដោយពន្យល់ថា យ៉ូហានបានពិពណ៌នាអំពីក្រុងសេឡេស្ទាលរបស់ព្រះ ។ លោកបានឃើញថា ទីក្រុងនោះមានកំផែងដ៏ធំដែលមានក្លោងទ្វារចំនួន១២ ហើយចាំយាមដោយទេវតាទាំង ១២ ។

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអានឲ្យឮៗនៅក្នុង វិវរណៈ ២១:២២–២៧ ។ សូមឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាយ៉ូហានបានរៀនអ្វីខ្លះអំពីក្រុងសេឡេស្ទាលនេះ ។


- តើយ៉ូហានបានរៀនអ្វីខ្លះអំពីក្រុងសេឡេស្ទាលនេះ ?
- យោងតាម ខទី ២៧ តើនរណានឹងត្រូវបានអនុញ្ញាតឲ្យចូល ? (មានតែជនដែលមានឈ្មោះនៅលើសៀវភៅជីវិតរបស់កូនចៀមប៉ុណ្ណោះ) ។

វិវរណៈ ២២

យ៉ូហានបញ្ចប់ការនិមិត្តរបស់លោក

នៅពេលសិស្សសិក្សា វិវរណៈ ២២ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិតមួយដែលអាចជួយពួកគេ ឲ្យដឹងអំពីរបៀបដើម្បីឲ្យឈ្មោះពួកគេត្រូវបានចារនៅលើសៀវភៅជីវិតរបស់កូនចៀម ហើយត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងក្រុងសេឡេស្ទាលនេះ ។

ចូរពិចារណាបង្ហាញរូបភាពមួយអំពីបល្ល័ង្ក ឬគូរវានៅលើក្តារខៀន ។



សូមឲ្យសិស្សម្នាក់ឡើងមកក្តារខៀន ហើយគូរអ្វីផ្សេងទៀតដែលយ៉ូហានបានឃើញបន្ថែមទៀតអំពីបល្ល័ង្ក នៅពេលសិស្សម្នាក់ទៀតអាន វិវរណៈ ២២:១–២ ឲ្យឮៗ ។

- តើយ៉ូហានបានឃើញអ្វីផ្សេងទៀត នៅក្នុងក្រុងសេឡេស្ទាលរបស់ព្រះ ?

សូមអញ្ជើញសិស្សនោះឲ្យត្រឡប់ទៅកន្លែងអង្គុយវិញ ។

- យោងតាម ខទី ២ តើយ៉ូហានបានពិពណ៌នាបែបណាអំពីដើមជីវិត ? (ដើមនោះឲ្យផលគ្រប់រដូវទាំងអស់ ហើយស្លឹករបស់វាអាចព្យាបាលប្រជាជាតិនានាបាន) ។

សូមរំឭកសិស្សថា ព្រះគម្ពីរមរមនកត់ត្រាថា ទាំងលីហៃ និងនីហ្វៃបានឃើញការនិមិត្តមួយអំពីដើមជីវិត ។ នីហ្វៃបានរៀនថា ដើមនោះនិងប្រភពនៃទឹករស់តំណាងឲ្យសេចក្តីស្រឡាញ់នៃព្រះ (សូមមើល នីហ្វៃទី១ ១១:២៥) ។ សូមសរសេរពាក្យ *សេចក្តីស្រឡាញ់នៃព្រះ* ក្បែរដើមឈើ និងទន្លេនៅក្នុងគំនូររបស់សិស្ស ។

- តើការបើកសម្តែងដ៏ធំបំផុតអំពីសេចក្តី ស្រឡាញ់នៃព្រះគឺជាអ្វី ? (ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ | សូមមើល យ៉ូហាន ៣:១៦; យ៉ូហានទី១ ៤:៩ | ។ ផលផ្លែនៃដើមនោះក៏អាចតំណាងឲ្យពរជ័យនៃដង្វាយធួនផងដែរ) ។

សូមសង្ខេប វិវរណៈ ២២:៣–១០ ដោយពន្យល់ថា បន្ថែមពីលើការឃើញក្រុងសេឡេស្ទាលនេះ យ៉ូហានក៏បានទទួលសាក្សីមួយមកពីទេវតាអង្គនោះដែលមានបន្ទូលមកលោកថា រឿងទាំងឡាយបានបើកសម្តែងដល់លោកគឺជារឿងពិត ។

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ២២:១១–១៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាម រកមើលថាព្រះអម្ចាស់នឹងធ្វើអ្វីខ្លះ នៅពេលទ្រង់យាងមកម្តងទៀត ។

- តើព្រះអម្ចាស់នឹងធ្វើអ្វីខ្លះនៅពេលទ្រង់យាងមកម្តងទៀត ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២២:១៤ ឲ្យឮ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលថាយើងត្រូវធ្វើ អ្វីខ្លះដើម្បីទទួលបានការអនុញ្ញាតឲ្យចូលទៅក្នុងនគរសេឡេស្ទាល ។

- តើយើងត្រូវធ្វើអ្វីខ្លះដើម្បីចូលទៅក្នុងនគរសេឡេស្ទាលបាន ?

សូមពន្យល់ថា ដើម្បី « ឲ្យបានច្បាប់ដល់ដើមជីវិត » មានន័យថា ត្រូវសក្តិសមដើម្បីទទួលរាល់ពរជ័យនៃដង្វាយធួន រួមទាំងជីវិតដ៏នៅអស់កល្បជានិច្ចផង ។

- តើយើងអាចស្គាល់សំគាល់ឃើញនូវគោលការណ៍អ្វីខ្លះនៅក្នុង ខទី ១៤ ? (សិស្សអាចនឹងប្រើពាក្យផ្សេង ប៉ុន្តែពួកគេគួរស្គាល់គោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងអាចទទួលបានពរជ័យទាំងអស់នៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយចូលទៅក្នុងនគរសេឡេស្ទាល ។** សូមពន្យល់ថា ការគោរពតាមបទបញ្ញត្តិរបស់ទ្រង់ រួមមានទាំងការទទួលរាល់ពិធីបរិសុទ្ធចាំបាច់សម្រាប់ការចូលទៅក្នុងនគរសេឡេស្ទាល) ។

សូមពន្យល់ថា ទោះបីជាពរជ័យមួយចំនួននៃដង្វាយធួន—ដូចជាអំណោយទាននៃការរស់ឡើងវិញ—ត្រូវបានប្រទានឲ្យដោយឥតគិតថ្លៃដល់កូនចៅរបស់ព្រះគ្រប់រូបក្តី ពរជ័យផ្សេងទៀត—ដូចជាជីវិតដ៏នៅអស់កល្បជានិច្ច—មានតែចំពោះជនដែលខិតខំដោយឧស្សាហ៍ដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ហើយធ្វើតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ប៉ុណ្ណោះ ។

សូមសរសេរសំណួរខាងក្រោមនេះនៅលើ ក្តារខៀន ៖

តើបទបញ្ញត្តិ និងការបង្រៀនអ្វីខ្លះដែលអ្នកបានរៀននៅក្នុងការសិក្សារបស់អ្នកអំពីព្រះគម្ពីរសញ្ញាថ្មី ហើយបានព្យាយាមអនុវត្តនៅក្នុងជីវិតរបស់អ្នក ?

តើការខិតខំរបស់អ្នកដើម្បីអនុវត្តបទបញ្ញត្តិទាំងនេះ បានជួយអ្នកឲ្យទទួលពរជ័យរបស់ព្រះអម្ចាស់ ហើយបានរៀបចំអ្នកឲ្យត្រឡប់ទៅរកវត្តមានរបស់ព្រះវរបិតារបស់អ្នក ដែលគង់នៅស្ថានសួគ៌វិញយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សឲ្យពិចារណាអំពីរបៀបដែលពួកគេនឹងឆ្លើយសំណួរទាំងពីរនេះ ដោយការពិនិត្យមើលសារឡើងវិញនូវអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ អ្វីដែលពួកគេបានកត់ចំណាំ ឬគូសចំណាំនៅក្នុងព្រះគម្ពីររបស់ពួកគេ និងចំណេះចំណានខគម្ពីរដែលពួកគេបានសិក្សានៅឆ្នាំនេះ ។ សូមអញ្ជើញពួកគេឲ្យសរសេរចម្លើយរបស់ពួកគេចំពោះសំណួរទាំងពីរនេះចូលក្នុងសៀវភៅកំណត់ចំណាំក្នុងថ្នាក់ ឬសៀវភៅកំណត់ត្រាការសិក្សាព្រះគម្ពីររបស់ពួកគេ ។

បន្ទាប់ពីទុកពេលគ្រប់គ្រាន់ហើយនោះ សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេបានសរសេរជាមួយនឹងសិស្សក្នុងថ្នាក់ ។ (សូមរំឭកសិស្សកុំឲ្យចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬ ឯកជនពេក) ។

សូមសង្ខេប វិវរណៈ ២២:១៥–១៩ ដោយពន្យល់ថា ជនដែលពុំបានគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់នឹងពុំអាចចូលទៅក្នុងក្រុងសេឡេស្ទាលនោះបានទេ ។ ព្រះយេស៊ូវគ្រីស្ទបានថ្លែងទីបន្ទាល់ថា ទ្រង់បានប្រទានវិវរណៈនេះដល់យ៉ូហាន ហើយយ៉ូហានបានអញ្ជើញមនុស្សទាំងអស់ឲ្យមកផឹកទឹកជីវិតនោះដោយឥតគិតថ្លៃ ។ យ៉ូហានបានព្រមានពួកអ្នកអានរបស់លោកកុំឲ្យកែប្រែសារលិខិតនៅក្នុងគម្ពីរដែលលោកបានសរសេរទុកនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២២:២០ ឲ្យឮ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលការទូលអង្វររបស់យ៉ូហាន ។

- តើអ្វីទៅជាការទូលអង្វររបស់យ៉ូហាន ?
- ដោយផ្អែកលើអ្វីដែលអ្នកបានរៀននៅក្នុងគម្ពីរវិវរណៈ ហេតុអ្វីអ្នកគិតថា យ៉ូហានទទូចសូមឲ្យព្រះអម្ចាស់យាងមកវិញ ?

សូមបញ្ចប់ ដោយថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលសិស្សបានស្គាល់នៅក្នុងវិវរណៈ ២១–២២ ។

សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ

មានកិច្ចការមួយចំនួន ដែលអ្នកអាចធ្វើដែលនឹងកាន់តែមានអំណាច និងឥទ្ធិពលដ៏ឃ្លាតឆ្ងាយបន្ថែមទៀតសម្រាប់ជាសេចក្តីល្អនៅក្នុងជីវិតសិស្ស ដាច់ការគ្រាន់តែជួយពួកគេឲ្យរៀនស្រឡាញ់ព្រះគម្ពីរ ហើយសិក្សាពីវាជារៀងរាល់ថ្ងៃ ។ អ្នកអាចលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ដោយអញ្ជើញសិស្សឲ្យអានគម្ពីររបស់ពួកគេដោយខ្លាប់ខ្លួន ទោះជាពេលដែលគ្មានថ្នាក់សិក្ខាសាលាក្តី ។ សូមអញ្ជើញសិស្សឲ្យដាក់គោលដៅ ដើម្បីអានព្រះគម្ពីរមមេនដែលពួកគេនឹងសិក្សានៅឆ្នាំក្រោយក្នុងថ្នាក់សិក្ខាសាលា ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

វិវរណៈ ២១:៤ ។ « ព្រះ ទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ »

អែលឌើរ យ៉ូសែប ប៊ី វ៉ៃតលីន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា នៅក្នុងកាលវេលាផ្ទាល់របស់ព្រះអម្ចាស់ ភាពសោកសៅរបស់ជនស្មោះត្រង់នឹងត្រូវបានជំនួសដោយអំណរ ៖

« ព្រះអម្ចាស់ឲ្យងារដល់ពួកស្មោះត្រង់ចំពោះរាល់ការបាត់បង់ទាំងអស់ ។ អ្វីដែលត្រូវបានដកចេញពីអ្នកទាំងឡាយណាដែលស្រឡាញ់ព្រះអម្ចាស់ នឹងត្រូវបានផ្តល់បន្ថែមដល់ពួកគេវិញតាមមាគ៌ារបស់ទ្រង់ផ្ទាល់ ។ ខណៈដែលវាពុំកើតមាននៅគ្រាដែលយើងប្រាថ្នាចង់បាននោះពួកអ្នកស្មោះត្រង់នឹងដឹងថា រាល់គ្រប់ដំណក់ទឹកភ្នែកនឹងត្រឡប់ទៅជាដំណក់ទឹកភ្នែកនៃអំណរ និងការដឹងគុណរាប់មិនអស់វិញ » (« Come What May, and Love It » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២៨) ។

វិវរណៈ:២២:១៨ ។ « បើអ្នកណាបញ្ចូលអ្វីក្នុងសេចក្តីទាំងនេះ »

មានមនុស្សខ្លះបានបដិសេធព្រះគម្ពីរមមេន និងព្រះគម្ពីរផ្សេងទៀតដោយសារតែពួកគេជឿថា ព្រះអម្ចាស់បានបញ្ចប់ការបើកសម្តែងបទគម្ពីរដល់កូនចៅរបស់ទ្រង់ហើយ ។ មានមនុស្សជាច្រើនបានប្រើ វិវរណៈ ២២:១៨ ខុស ដើម្បីប្រកាសថា ព្រះអម្ចាស់នឹងពុំប្រទានបទគម្ពីរបន្ថែមទៀតឡើយ ក្រៅពីព្រះគម្ពីរប៊ីប ហើយថាមនុស្សណាម្នាក់ដែលអះអាងថាបានទទួលបទគម្ពីរបន្ថែមទៀតនឹងទទួលការដាក់ទោសដែលយ៉ូហានបានព្រមាន ។ អែលឌើរ ដែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានលើកឡើងពីការបកស្រាយខុសនេះ ៖

« ឥឡូវនេះមាននូវឯកច្ឆន្ទដ៏លើសលុបនៅក្នុងចំណោមពួកអ្នកប្រាជ្ញខាងគម្ពីរប៊ីបស្ទើរតែគ្រប់រូបថា ខគម្ពីរនេះអនុវត្តតែចំពោះគម្ពីរវិវរណៈប៉ុណ្ណោះ *ពុំមែន* ព្រះគម្ពីរប៊ីបទាំងមូលនោះទេ ។ ពួកអ្នកប្រាជ្ញទាំងនោះនៅក្នុងជំនាន់របស់យើងបានទទួលស្គាល់ថា ‹ គម្ពីរ › ជាច្រើននៅក្នុងព្រះគម្ពីរសញ្ញាថ្មី ភាគច្រើនត្រូវបានសរសេរឡើងយ៉ាងពិតប្រាកដ *បន្ទាប់ពី* យ៉ូហានបានទទួលវិវរណៈនៅលើកោះប៉ាត់ម៉ុស ។ នៅក្នុងវិវរណៈនេះយ៉ាងហោចណាស់មាននូវគម្ពីរយូដាសំបុត្រទាំងបីរបស់យ៉ូហាន ហើយប្រហែលជាដំណឹងល្អរបស់យ៉ូហានទាំងមូលផងដែរ ។ វាប្រហែលជាមានលើសពីនេះទៅទៀត ។

« ប៉ុន្តែមានចម្លើយដ៏សាមញ្ញមួយចំពោះសំណួរថាហេតុអ្វីបទគម្ពីរនោះនៅក្នុងគម្ពីរចុងក្រោយបង្អស់នៃព្រះគម្ពីរសញ្ញាថ្មីបច្ចុប្បន្ន ពុំអាចអនុវត្តចំពោះព្រះគម្ពីរប៊ីបទាំងមូលបាន ។ ដូចដែលយើងបានដឹងថា ដោយសារព្រះគម្ពីរប៊ីបទាំងមូល—ដែលការប្រមូលផ្តុំនៃអត្ថបទដែលបានចងក្រងនៅក្នុងសៀវភៅតែមួយ—ពុំបានកើតឡើងនៅពេលដែលខគម្ពីរនោះត្រូវបានសរសេរឡើងនោះឡើយ ។ អស់រយៈពេលជាច្រើនសតវត្សរ៍ បន្ទាប់ពីយ៉ូហានបានធ្វើការសរសេរបស់លោក នោះគម្ពីរនីមួយៗនៅក្នុងព្រះគម្ពីរសញ្ញាថ្មីមានលក្ខណៈដាច់តែឯង ឬប្រហែលជាចងក្រងនឹងអត្ថបទមួយចំនួនផ្សេងទៀត ប៉ុន្តែភាគច្រើន *ពុំមែន* ជាការប្រមូលផ្តុំមួយពេញលេញនោះទេ ។ នៅក្នុងកម្រងទាំងមូលនៃការសរសេរក្នុងព្រះគម្ពីរសញ្ញាថ្មីជាភាសាក្រិចចំនួន ៥,៣៦៦ មានតែ ៣៥ប៉ុណ្ណោះ ដែលបានសរសេរបោះពុម្ពក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូលដែលយើងមាននៅពេលនេះ និង ៣៨ នៃគម្ពីរដែលត្រូវបានដាក់បញ្ចូលគ្នាបន្ទាប់ពី គ.ស. ១០០០ » (« My Words . . . Never Cease » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៩១–៩២) ។

មេរៀនសិក្សានៅផ្ទះ

វិវរណៈ ១២–២២ (មេរៀនទី ៣២)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមស្តីពីព្រឹត្តិការណ៍គោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា វិវរណៈ ១២–២២ (មេរៀនទី ៣២) ពុំមានត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើគោលលទ្ធិ និង គោលការណ៍តែពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (វិវរណៈ ១២–១៣)

នៅពេលសិស្សបានសិក្សាការនិមិត្តរបស់យ៉ូហានអំពីនាគ និងស្ត្រីមានគភ៌ ពួកគេបានរៀនថា សាតាំងដែលតំណាងដោយសត្វនាគ ស្វែងរកបំផ្លាញសាសនាចក្រ និងនគររបស់ព្រះរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ សង្គ្រាមនេះបានចាប់ផ្តើមនៅជីវិតមុនកើតមកលើផែនដីនេះ ។ សិស្សបានរៀនថា យើងអាចយកឈ្នះលើគំទ្វិពលរបស់សាតាំងតាមរយៈជង្វាយធួនរបស់ព្រះអង្គសង្គ្រោះ និងដោយបន្តមានចិត្តស្មោះចំពោះទីបន្ទាល់របស់យើងអំពីដំណឹងល្អ ។

ថ្ងៃទី ២ (វិវរណៈ ១៤–១៦)

នៅក្នុងការនិមិត្តរបស់យ៉ូហានអំពីការមើលឃើញទេវតាមួយអង្គយាងមកផែនដីវិញ នៅថ្ងៃចុងក្រោយ សិស្សបានរៀនថា ហេតុផលមួយដែលព្រះបានស្តារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទឡើងវិញ គឺដើម្បីរៀបចំមនុស្សលោកនៅលើផែនដីនេះសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេក៏រៀននូវគោលការណ៍ដូចតទៅនេះផងដែរ ៖ ប្រសិនបើយើងរស់នៅដោយសុចរិត នោះយើងនឹងមានពរចំពោះកិច្ចការរបស់យើង ហើយសម្រាកពីការងាររបស់យើងបន្ទាប់ពីយើងស្លាប់ទៅ ។ ប្រសិនបើយើងចាំយាម ហើយត្រៀមខ្លួនខាងវិញ្ញាណ នោះយើងនឹងបានត្រៀមខ្លួនសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ៣ (វិវរណៈ ១៧–១៩)

សិស្សបានរៀនថា នៅថ្ងៃចុងក្រោយ ព្រះយេស៊ូវគ្រីស្ទនឹងឈ្នះលើអំពើទុច្ចរិតនៃលោកិយនេះ ។ ពួកគេក៏រៀនផងដែរថា ការញែកខ្លួនយើងចេញពីអំពើទុច្ចរិតនៃលោកិយអាចជួយយើងឲ្យចៀសផុតពីអំពើបាប និងការកាត់សេចក្តីដែលនឹងកើតមានដល់មនុស្សទុច្ចរិតនៅថ្ងៃចុងក្រោយ ។ នៅពេលសិស្សប្រៀបធៀបអាពាហ៍ពិពាហ៍ទៅនឹងការយាងមកជាលើកទីពីរ ពួកគេបានរៀនថា ប្រសិនបើយើងស្អាតស្អំ ហើយសុចរិត នោះយើងនឹងត្រៀមខ្លួនជាស្រេចសម្រាប់ការយាងមករបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ៤ (វិវរណៈ ២០–២២)

នៅជំពូកបញ្ចប់នៃការនិមិត្តរបស់យ៉ូហាន សិស្សបានរៀននូវសេចក្តីពិតដូចតទៅ ៖ ព្រះនឹងកាត់សេចក្តីយើងចេញពីសៀវភៅដែលបានសរសេរទុកស្របតាមការប្រព្រឹត្តរបស់យើង ។ ព្រះនឹងគង់នៅ ហើយលួងលោមមាស្ត្រទ្រង់ ហើយពួកគេនឹងលែងជួបសេចក្តីស្លាប់ ភាពសោកសៅ ឬការឈឺចាប់ទៀតហើយ ។ ប្រសិនបើយើងគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងអាចទទួលបាននូវរាល់ពរជ័យនៃជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយចូលទៅក្នុងនគរសេឡេស្ទាល ។

សេចក្តីផ្តើម

សាវកយ៉ូហានបាននិមិត្តឃើញព្រឹត្តិការណ៍ជាច្រើនដែលនឹងកើតឡើងភ្លាមៗ ពីមុននិងនៅក្នុងរជ្ជកាលនៃសហស្សវត្សរ៍របស់ព្រះយេស៊ូវគ្រីស្ទ ។ លោកក៏បានឃើញផងដែរអំពីចម្បាំងចុងក្រោយរវាងសាតាំង និងទ័ពរបស់ព្រះនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ហើយលោកបានឃើញការកាត់សេចក្តីចុងក្រោយ ជាគ្រាដែលព្រះនឹងកាត់សេចក្តីមនុស្សគ្រប់គ្នាចេញពីសៀវភៅដែលបានកត់ត្រាទុក ។

យោបល់សម្រាប់ការបង្រៀន

វិវរណៈ ២០:១–៦

យ៉ូហានឃើញអ្វីដែលនឹងកើតឡើងភ្លាមៗពីមុន និងនៅក្នុងរជ្ជកាលនៃសហស្សវត្សរ៍របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការនិមិត្ត

សូមឲ្យសិស្សគិតអំពីការប្រកួតមួយ (ដូចជាព្រឹត្តិការណ៍ខាងសិល្បៈ ឬខាងអត្តពលកម្ម) ដែលពួកគេបានចូលរួម ទោះបីជាពួកគេបានដឹងខ្លួនជាមុនថា ពួកគេនឹងត្រូវចាញ់ក៏ដោយ ។ បន្ទាប់មក សូមឲ្យពួកគេគិតអំពីគ្រាមួយដែលពួកគេបានចូលរួមនៅក្នុងការប្រកួតមួយដែលពួកគេជឿថាពួកគេនឹងឈ្នះ ។

- តើការរំពឹងទុករបស់អ្នកអំពីលទ្ធផលនៃការប្រកួតមួយអាចផ្លាស់ប្តូរការខិតខំរបស់អ្នកយ៉ាងដូចម្តេច ?
- ហេតុអ្វីមនុស្សសុខចិត្តបោះបង់ចោលការប្រកួត នៅពេលពួកគេគិតថាពួកគេនឹងចាញ់នោះ ? តើនៅពេលណាដែរ ដែលអ្នកគិតថា អ្នកនឹងចាញ់ ប៉ុន្តែបែរជាឈ្នះវិញនោះ ?

សូមពន្យល់សិស្សថា នៅពេលពួកគេសិក្សា វិវរណៈ ២០ ពួកគេនឹងរៀនបន្ថែមទៀតអំពីចម្បាំងរវាងអំពើល្អ និងអំពើអាក្រក់ និងលទ្ធផលចុងក្រោយនៃចម្បាំងនោះ ។ នៅពេលសិស្សសិក្សា វិវរណៈ ២០ សូមអញ្ជើញពួកគេឲ្យរកមើលសេចក្តីពិត ដែលអាចទាក់ទាញចិត្តពួកគេឲ្យបន្តស្មោះត្រង់ចំពោះព្រះអង្គសង្គ្រោះនៅក្នុងចម្បាំងនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:១–៣ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថានឹងមានអ្វីកើតឡើងដល់សាតាំងនៅពេលសហស្សវត្សរ៍ ។

- តើនឹងមានអ្វីកើតឡើងដល់សាតាំងអំឡុងពេលសហស្សវត្សរ៍ ?
- យោងតាមខទី ៣តើអ្វីទៅដែលសាតាំងពុំអាចធ្វើបាន ដោយសារតែត្រូវបានចាប់ចង ?

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:៤–៦ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្សេងតាមរកមើលថាតើយ៉ូហានបានឃើញថានណាខ្លះទទួលបានការកាត់សេចក្តី ។

- យោងតាម ខទី ៤ តើយ៉ូហានបានឃើញថា នរណាខ្លះទទួលបានការកាត់សេចក្តី ?
- តើប្រជាជនទាំងនេះបានទទួលរង្វាន់អ្វីខ្លះ ដោយសារតែសេចក្តីស្មោះត្រង់របស់ពួកគេ ?
- តើពួកគេនឹងមានចំណែកអ្វីខ្លះនៅសហស្សវត្សរ៍ ? (ការរស់ឡើងវិញលើកទីមួយ) ។
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះនៅក្នុង វិវរណៈ ២០:៤–៦ អំពីពរជ័យដែលយើងអាចទទួលបាន ប្រសិនបើយើងស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ ? (សិស្សអាចនឹងប្រើពាក្យផ្សេងប៉ុន្តែពួកគេគួរស្តាល់គោលការណ៍មួយស្រដៀងគ្នានឹងគោលការណ៍ដូចតទៅនេះ ៖ **ប្រសិនបើយើងស្មោះត្រង់ចំពោះព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងមានចំណែកនៅក្នុងការរស់ឡើងវិញលើកទីមួយ ហើយត្រូវគង់រាជ្យជាមួយនឹងព្រះគ្រីស្ទនៅសហស្សវត្សរ៍**) ។

សូមពន្យល់ថា ការរស់ឡើងវិញលើកទីមួយបានចាប់ផ្តើមជាមួយនឹងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ហើយបានរួមបញ្ចូលពួកសុចរិត ដែលបានស្លាប់ពីមុនការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ (សូមមើល ម៉ូសាយ ១៥:២១–២៥, អាលម៉ា ៤០:១៦–២០) ។ ពួកបរិសុទ្ធភាគច្រើនដែលបានស្លាប់ បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទនឹងបានរស់ឡើងវិញនៅឯការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល Bruce R. McConkie, *Mormon Doctrine* កំណែទី ២ [ឆ្នាំ ១៩៦៦] ទំព័រ ៦៣៩; James E. Talmage *The Articles of Faith* កំណែទី ១២ [ឆ្នាំ ១៩២៤] ទំព័រ ៣៨៥) ។

អស់អ្នកដែលនឹងលេចមកនៅក្នុងការរស់ឡើងវិញលើកទីមួយ រួមមាន « ពួកព្យាការី និងអស់អ្នកណាដែលបានជឿតាមពាក្យសម្តីរបស់គេ » (ម៉ូសាយ ១៥:២២) ជនដែលបានស្លាប់ទៅនៅក្នុងភាពលិតលង់ ដោយគ្មាន « អ្នកណាប្រកាសប្រាប់អំពីសេចក្តីសង្គ្រោះដល់គេ » (ម៉ូសាយ ១៥:២៤, សូមមើលផងដែរ គ. និង ស. ៤៥:៥៤) និងពួកក្មេងតូចៗដែលបានស្លាប់ពីមុនវ័យចេះទទួលខុសត្រូវ (សូមមើល ម៉ូសាយ ១៥:២៥, មរ៉ូណៃ ៨:៨–២៤) ។ ពួកទុច្ចរិត និងជនដែលពុំប្រែចិត្តនឹងពុំបានរស់ឡើងវិញឡើយ រហូតដល់ការរស់ឡើងវិញជាលើកទីពីរដែលនឹងកើតឡើងនៅចុងបញ្ចប់នៃសហស្សវត្សរ៍ (សូមមើល គ. និង ស. ៧៦:៨៥) ។

- តើការដឹងថា អ្នកអាចមានចំណែកនៅក្នុងការរស់ឡើងវិញលើកទីមួយ ហើយគ្រងរាជ្យជាមួយនឹងព្រះយេស៊ូវគ្រីស្ទនៅសហស្សវត្សរ៍ អាចជួយអ្នកឲ្យស្មោះត្រង់នៅពេលនេះនៅក្នុងចម្បាំងទាស់នឹងអំពើអាក្រក់បានយ៉ាងដូចម្តេច ?

សូមថ្លែងទីបន្ទាល់ថា ជនដែលបន្តស្មោះត្រង់នឹងមានចំណែកមួយនៅក្នុងការរស់ឡើងវិញលើកទីមួយ ហើយគ្រងរាជ្យនឹងព្រះអង្គសង្គ្រោះនៅក្នុងសហស្សវត្សរ៍ ។

វិវរណៈ ២០:៧–១១

យ៉ូហានឃើញចម្បាំងចុងក្រោយរវាងសាតាំង និងទ័ពនៃព្រះនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ។

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនេះ នៅលើក្តារខៀន ៖*នៅចុងបញ្ចប់នៃសហស្សវត្សរ៍ . . .*

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២០:៧–១០ ឲ្យឮៗ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមរកមើលព្រឹត្តិការណ៍ ដែលយ៉ូហានបានពិពណ៌នាថានឹងកើតឡើងនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឡើងមកក្តារខៀនសរសេរអំពីអ្វីដែលពួកគេបានរកឃើញ ។ បន្ទាប់មក សួរពួកគេនូវសំណួរខាងក្រោមនេះ ៖

- តើយ៉ូហានបានពិពណ៌នាអំពីព្រឹត្តិការណ៍អ្វីខ្លះ ? (សូមពន្យល់ថា ឈ្មោះ *សាសន៍កុក និង សាសន៍ម៉ាកុក* នៅក្នុង ខទី ៨ សំដៅទៅលើទ័ពដែលសាតាំងនឹងប្រើនៅចុងបញ្ចប់នៃសហស្សវត្សរ៍ ដើម្បីច្បាំងជាលើកចុងក្រោយទាស់នឹងរាស្ត្ររបស់ព្រះអម្ចាស់ [សូមមើល គ. និង ស. ៨៨:១១០–១១៤]) ។
- បន្ទាប់ពីចម្បាំងនេះ តើនឹងមានអ្វីខ្លះកើតចំពោះអារក្ស និងពួកបរិវាររបស់វា ? (បន្ទាប់ពីសិស្សឆ្លើយរួច សូមបំពេញឃ្លានៅលើក្តារខៀនដើម្បីឲ្យវាមានន័យដូចតទៅនេះ ៖ **នៅចុងបញ្ចប់នៃសហស្សវត្សរ៍ ទ័ពរបស់ព្រះនឹងយកឈ្នះលើសាតាំង និងពួកពលបរិវាររបស់វា**) ។
- ហេតុអ្វីវាគឺជារឿងដ៏សំខាន់ដែលយើងត្រូវដឹងអំពីលទ្ធផលចុងក្រោយនៃចម្បាំងរវាងព្រះ និងសាតាំង ?

វិវរណៈ ២០:១២–១៥

យ៉ូហានឃើញសេចក្តីជំនុំជម្រះចុងក្រោយ

សូមពន្យល់ថា ជាផ្នែកមួយនៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌ មនុស្សគ្រប់រូបដែលធ្លាប់រស់នៅលើផែនដីនេះនឹងឈរទទួលការកាត់សេចក្តីនៅចំពោះព្រះ ។ សូមឲ្យសិស្សនឹកស្រមៃអំពីទិដ្ឋភាពនៃសេចក្តីជំនុំជម្រះចុងក្រោយ ។

- តើអ្នកចង់គិត ហើយទទួលអារម្មណ៍អំពីអ្វីដែរ នៅពេលអ្នកឈរទទួលការកាត់សេចក្តីនៅចំពោះមុខព្រះនោះ ?

ចូរសុំឲ្យសិស្សម្នាក់អាន វិវរណៈ ២០:១២–១៣ ឲ្យឮៗ ។ ចូរសុំសិស្សក្នុងថ្នាក់ឲ្យផ្ទៀងតាមរកមើលថា ព្រះនឹងកាត់សេចក្តីយើងយ៉ាងដូចម្តេច ។

- តើយើងអាចរៀនសេចក្តីពិតអ្វីខ្លះនៅក្នុងខទី ១២ អំពីរបៀបដែលយើងនឹងទទួលការកាត់សេចក្តី ? (សិស្សអាចនឹងប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរស្គាល់ពីសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះនឹងកាត់សេចក្តីយើងចេញពីសៀវភៅដែលបានសរសេរទុកស្របតាមការប្រព្រឹត្តរបស់យើង**) ។
- តើយ៉ូហានបានឃើញសៀវភៅអ្វីខ្លះ ? (ព្រះគម្ពីរ និងកំណត់ត្រាសាសនាចក្រដែលកត់ត្រាពិធីបរិសុទ្ធនៃការសង្គ្រោះ ហើយប្រហែលជាទង្វើផ្សេងៗទៀត និងបញ្ជីជីវិត [សូមមើល នីហ្វៃទី ២ ២៩:១០–១១, គ. និង ស. ១២៨:៦–៧, Bible Dictionary « Book of life »]) ។
- តើអ្នកបានរៀនអ្វីខ្លះទៀតអំពីសេចក្តីជំនុំជម្រះចុងក្រោយ ? (*កំណត់ចំណាំ ៖* នៅក្នុងមេរៀនទី ៣២ ៖ ថ្ងៃទី ៤ លំហាត់ទី ៣ សិស្សបានរកឃើញបទគម្ពីរបន្ថែមទៀតដែលបង្រៀនអំពីសេចក្តីជំនុំជម្រះចុងក្រោយ) ។

សូមចង្អុលបង្ហាញថា ព្រះអម្ចាស់បានបើកសម្តែងដល់ព្យាការីយ៉ូសែប ស្ម៊ីធថា បន្ថែមពីលើការប្រព្រឹត្តរបស់យើង យើងនឹងទទួលការកាត់សេចក្តីស្របតាមបំណងប្រាថ្នានៃដួងចិត្តរបស់យើង (សូមមើល គ. និង ស. ១៣៧:៩, សូមមើលផងដែរ អាលម៉ា ៤១:៣–៥) ។

- តើការដឹងថា យើងនឹងទទួលបានការកាត់សេចក្តីស្របតាមបំណងប្រាថ្នានៃដួងចិត្តរបស់យើងនោះ ជះឥទ្ធិពលទៅលើអ្វីដែលយើងធ្វើយ៉ាងដូចម្តេចដែរ ?

សូមថ្លែងទីបន្ទាល់អំពីគោលលទ្ធិនេះ និងរបៀបដែលវាជះឥទ្ធិពលដល់ការជ្រើសរើសរបស់អ្នក ។

សូមអញ្ជើញសិស្សម្នាក់អាន វិវរណៈ ២២:១៤ ឲ្យឮ ។ ចូរសុំឲ្យសិស្សក្នុងថ្នាក់ផ្ទៀងតាមហើយចងចាំអំពីគោលការណ៍ ដែលពួកគេបានរៀនមកពីខគម្ពីរនេះនៅក្នុងការសិក្សារបស់ពួកគេនៅផ្ទះ ។

- តើអ្នកបានរៀនអ្វីខ្លះនៅក្នុងខគម្ពីរនេះ ? (**ប្រសិនបើយើងគោរពតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់ នោះយើងអាចទទួលបាននូវាល់ពរជ័យនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយចូលទៅក្នុងនគរសេឡេស្ទាល** ។ សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- ហេតុអ្វីក៏ការណ៍នេះគឺជាសេចក្តីពិតដ៏ត្រឹមត្រូវមួយ ដើម្បីបញ្ចប់ការសិក្សារបស់យើងអំពីព្រះគម្ពីរសញ្ញាថ្មី ?

សូមពិចារណាអញ្ជើញសិស្សឲ្យចែកចាយសេចក្តីពិតមួយចំនួន ដែលបានជះឥទ្ធិពលដល់ពួកគេនៅក្នុងការសិក្សារបស់ពួកគេនាឆ្នាំនេះអំពីព្រះគម្ពីរសញ្ញាថ្មី ។ សូមអញ្ជើញសិស្សម្នាក់ណាក៏បានដែលមានបំណងចង់ចែកចាយទីបន្ទាល់របស់ខ្លួនអំពីសេចក្តីពិតទាំងនេះ និងអំពីភាពជាព្រះរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។

សូមលើកទឹកចិត្តសិស្សឲ្យបន្តសិក្សាព្រះគម្ពីរទៅទាំងឡាយជារៀងរាល់ថ្ងៃ ។ ប្រសិនបើពួកគេចូលថ្នាក់សិក្ខាសាលានៅឆ្នាំក្រោយ ឬប្រសិនបើពួកគេកំពុងរៀបចំខ្លួនទៅបេសកកម្ម សូមអញ្ជើញពួកគេឲ្យចាប់ផ្តើមអានព្រះគម្ពីរមេរមនៅថ្ងៃនេះ ។



ឧបសម្ព័ន្ធ

តារាងអានព្រះគម្ពីរ

យើងជួយបំពេញគោលបំណងនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា នៅពេលយើងលើកទឹកចិត្តសិស្សឲ្យ (១) អាន និង សិក្សាព្រះគម្ពីររាល់ថ្ងៃ និង (២) អានព្រះគម្ពីរសម្រាប់វគ្គសិក្សា ។ (តារាងសម្រាប់តាមដានការអានព្រះគម្ពីរនៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូលអាចមាននៅជាមួយនឹង ប័ណ្ណចំណេះចំណានខគម្ពីរព្រះគម្ពីរសញ្ញាថ្មី នៅលើ LDS.org និងនៅលើ store.lds.org [ទំនិញ ល.រ. ១០៤៨០]) ។

អ្នកគួរឲ្យតារាងសម្រាប់ការអានដល់សិស្ស ដើម្បីជួយពួកគេឲ្យតាមដានពីការរីកចម្រើនរបស់ខ្លួន ។ ប្រសិនបើអ្នកចង់រាយការណ៍ពីការអានព្រះគម្ពីរប្រចាំថ្ងៃរបស់សិស្ស សូមធ្វើតាមការណែនាំនៅក្នុង Scripture Reading Reporting Instructions ។ សូមរកមើលសេចក្តីណែនាំទាំងនេះនៅក្នុងគេហទំព័រ si.lds.org ដោយប្រើឃ្លា « scripture reading reporting instructions » ។

តារាងសម្រាប់ការអានព្រះគម្ពីរសញ្ញាថ្មី

ម៉ាថាយ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
		១៨	១៩	២០	២១	២២	២៣	យ.ស.—ម៉ាថាយ ១				២៥	២៦	២៧	២៨	
ម៉ាកុស	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
លូកា	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
		១៨	១៩	២០	២១	២២	២៣	២៤								
យ៉ូហាន	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
		១៨	១៩	២០	២១											
កិច្ចការ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
		១៨	១៩	២០	២១	២២	២៣	២៤	២៥	២៦	២៧	២៨				
រ៉ូម	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
កូរិនថូសទី ១	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
កូរិនថូសទី ២	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣			
កាឡាទី	១	២	៣	៤	៥	៦										
អេភេសូរ	១	២	៣	៤	៥	៦										
ភីលីព	១	២	៣	៤												
កូល៉ុស	១	២	៣	៤												
ថែស្សាឡូនីចទី ១	១	២	៣	៤	៥											
ថែស្សាឡូនីចទី ២	១	២	៣													
ធីម៉ូថេទី ១	១	២	៣	៤	៥	៦										
ធីម៉ូថេទី ២	១	២	៣	៤												
ទីតុស	១	២	៣													
ភីលេម៉ូន	១															
ហេព្រើរ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣			
យ៉ាកុប	១	២	៣	៤	៥											
ពេត្រុសទី ១	១	២	៣	៤	៥											
ពេត្រុសទី ២	១	២	៣													
យ៉ូហានទី ១	១	២	៣	៤	៥											
យ៉ូហានទី ២	១															
យ៉ូហានទី ៣	១															
យូដាស	១															
វិវរណៈ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣	១៤	១៥	១៦
		១៨	១៩	២០	២១	២២										

តារាងអានព្រះគម្ពីរប្រចាំថ្ងៃ

មករា	កុម្ភៈ	មីនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
១	១	១	១	១	១	១	១	១	១	១	១
២	២	២	២	២	២	២	២	២	២	២	២
៣	៣	៣	៣	៣	៣	៣	៣	៣	៣	៣	៣
៤	៤	៤	៤	៤	៤	៤	៤	៤	៤	៤	៤
៥	៥	៥	៥	៥	៥	៥	៥	៥	៥	៥	៥
៦	៦	៦	៦	៦	៦	៦	៦	៦	៦	៦	៦
៧	៧	៧	៧	៧	៧	៧	៧	៧	៧	៧	៧
៨	៨	៨	៨	៨	៨	៨	៨	៨	៨	៨	៨
៩	៩	៩	៩	៩	៩	៩	៩	៩	៩	៩	៩
១០	១០	១០	១០	១០	១០	១០	១០	១០	១០	១០	១០
១១	១១	១១	១១	១១	១១	១១	១១	១១	១១	១១	១១
១២	១២	១២	១២	១២	១២	១២	១២	១២	១២	១២	១២
១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣
១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤
១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥
១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦
១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧
១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨
១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩
២០	២០	២០	២០	២០	២០	២០	២០	២០	២០	២០	២០
២១	២១	២១	២១	២១	២១	២១	២១	២១	២១	២១	២១
២២	២២	២២	២២	២២	២២	២២	២២	២២	២២	២២	២២
២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣
២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤
២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥
២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦
២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧
២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨
២៩	(២៩)	២៩	២៩	២៩	២៩	២៩	២៩	២៩	២៩	២៩	២៩
៣០		៣០	៣០	៣០	៣០	៣០	៣០	៣០	៣០	៣០	៣០
៣១		៣១		៣១		៣១	៣១		៣១		៣១

ការណែនាំអំពីល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ

កាលវិភាគដែលបានណែនាំសម្រាប់ ៣៦ សប្តាហ៍នៃឆ្នាំសិក្សា

សប្តាហ៍	មេរៀន	បណ្តុំបទគម្ពីរ
១	ថ្ងៃទី ១ ៖ មេរៀនទី ១ សេចក្តីផ្តើមនៃព្រះគម្ពីរសញ្ញាថ្មី ថ្ងៃទី ២ ៖ មេរៀនទី ២ ផែនការនៃសេចក្តីសង្គ្រោះ ថ្ងៃទី ៣ ៖ មេរៀនទី ៣ គន្លាទីរបស់សិស្ស ថ្ងៃទី ៤ ៖ មេរៀនទី ៤ ការសិក្សាព្រះគម្ពីរ ថ្ងៃទី ៥ ៖ មេរៀនទី ៥ បរិបទ និង ទិដ្ឋភាពទូទៅនៃព្រះគម្ពីរសញ្ញាថ្មី	
២	ថ្ងៃទី ១ ៖ មេរៀនទី ៦ ម៉ាថាយ ១–២ ថ្ងៃទី ២ ៖ មេរៀនទី ៧ ម៉ាថាយ ៣ ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៤ ៖ មេរៀនទី ៨ ម៉ាថាយ ៤ ថ្ងៃទី ៥ ៖ មេរៀនទី ៩ ម៉ាថាយ ៥:១-១៦	ម៉ាថាយ ១:១-៥:១៦
៣	ថ្ងៃទី ១ ៖ មេរៀនទី ១០ ម៉ាថាយ ៥:១៧-៤៨ ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៣ ៖ មេរៀនទី ១១ ម៉ាថាយ ៦ ថ្ងៃទី ៤ ៖ មេរៀនទី ១២ ម៉ាថាយ ៧ ថ្ងៃទី ៥ ៖ មេរៀនទី ១៣ ម៉ាថាយ ៨-១០	ម៉ាថាយ ៥:១៧–១០:៤២
៤	ថ្ងៃទី ១ ៖ មេរៀនទី ១៤ ម៉ាថាយ ១១-១២ ថ្ងៃទី ២ ៖ មេរៀនទី ១៥ ម៉ាថាយ ១៣:១-២៣ ថ្ងៃទី ៣ ៖ មេរៀនទី ១៦ ម៉ាថាយ ១៣:២៤-៥៨ ថ្ងៃទី ៤ ៖ មេរៀនទី ១៧ ម៉ាថាយ ១៤ ថ្ងៃទី ៥ ៖ មេរៀនទី ១៨ ម៉ាថាយ ១៥	ម៉ាថាយ ១១-១៥
៥	ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ២ ៖ មេរៀនទី ១៩ ម៉ាថាយ ១៦ ថ្ងៃទី ៣ ៖ មេរៀនទី ២០ ម៉ាថាយ ១៧ ថ្ងៃទី ៤ ៖ មេរៀនទី ២១ ម៉ាថាយ ១៨ ថ្ងៃទី ៥ ៖ មេរៀនទី ២២ ម៉ាថាយ ១៩-២០	ម៉ាថាយ ១៦-២០
៦	ថ្ងៃទី ១ ៖ មេរៀនទី ២៣ ម៉ាថាយ ២១:១-១៦ ថ្ងៃទី ២ ៖ មេរៀនទី ២៤ ម៉ាថាយ ២១:១៧-២២:១៤ ថ្ងៃទី ៣ ៖ មេរៀនទី ២៥ ម៉ាថាយ ២២:១៥-៤៦ ថ្ងៃទី ៤ ៖ មេរៀនទី ២៦ ម៉ាថាយ ២៣ ថ្ងៃទី ៥ ៖ មេរៀនទី ២៧ យ៉ូសែប ស្ម៊ីធ—ម៉ាថាយ, ម៉ាថាយ ២៤	ម៉ាថាយ ២១-២៤
៧	ថ្ងៃទី ១ ៖ មេរៀនទី ២៨ ម៉ាថាយ ២៥:១-១៣ ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៣ ៖ មេរៀនទី ២៩ ម៉ាថាយ ២៥:១៤-៤៦ ថ្ងៃទី ៤ ៖ មេរៀនទី ៣០ ម៉ាថាយ ២៦:១-៣០ ថ្ងៃទី ៥ ៖ មេរៀនទី ៣១ ម៉ាថាយ ២៦:៣១-៧៥	ម៉ាថាយ ២៥-២៦
៨	ថ្ងៃទី ១ ៖ មេរៀនទី ៣២ ម៉ាថាយ ២៧:១-៥០ ថ្ងៃទី ២ ៖ មេរៀនទី ៣៣ ម៉ាថាយ ២៧:៥១-២៨:២០ ថ្ងៃទី ៣ ៖ មេរៀនទី ៣៤ ម៉ាកុស ១ ថ្ងៃទី ៤ ៖ មេរៀនទី ៣៥ ម៉ាកុស ២–៣ ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន)	ម៉ាកុស ២៧–ម៉ាកុស ៣
៩	ថ្ងៃទី ១ ៖ មេរៀនទី ៣៦ ម៉ាកុស ៤-៥ ថ្ងៃទី ២ ៖ មេរៀនទី ៣៧ ម៉ាកុស ៦ ថ្ងៃទី ៣ ៖ មេរៀនទី ៣៨ ម៉ាកុស ៧-៨ ថ្ងៃទី ៤ ៖ មេរៀនទី ៣៩ ម៉ាកុស៩:១-២៩ ថ្ងៃទី ៥ ៖ មេរៀនទី ៤០ ម៉ាកុស ៩:៣០-៥០	ម៉ាកុស ៤-៩

សប្តាហ៍	មេរៀន	បណ្តុំបទគម្ពីរ
១០	ថ្ងៃទី ១ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ២ ៖ មេរៀនទី ៤១ ម៉ាកុស ១០ ថ្ងៃទី ៣ ៖ មេរៀនទី ៤២ ម៉ាកុស ១១-១៦ ថ្ងៃទី ៤ ៖ មេរៀនទី ៤៣ លូកា ១ ថ្ងៃទី ៥ ៖ មេរៀនទី ៤៤ លូកា ២	ម៉ាកុស ១០–លូកា ២
១១	ថ្ងៃទី ១ ៖ មេរៀនទី ៤៥ លូកា ៣-៤ ថ្ងៃទី ២ ៖ មេរៀនទី ៤៦ លូកា ៥ ថ្ងៃទី ៣ ៖ មេរៀនទី ៤៧ លូកា ៦:១-៧:១៨ ថ្ងៃទី ៤ ៖ មេរៀនទី ៤៨ លូកា ៧:១៨-៥០ ថ្ងៃទី ៥ ៖ មេរៀនទី ៤៩ លូកា ៨-៩	ម៉ាកុស ៣-៩
១២	ថ្ងៃទី ១ ៖ មេរៀនទី ៥០ លូកា ១០:១-៣៧ ថ្ងៃទី ២ ៖ មេរៀនទី ៥១ លូកា ១០:៣៨-១២:៥៩ ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៤ ៖ មេរៀនទី ៥២ លូកា ១៣-១៤ ថ្ងៃទី ៥ ៖ មេរៀនទី ៥៣ លូកា ១៥	លូកា ១០-១៥
១៣	ថ្ងៃទី ១ ៖ មេរៀនទី ៥៤ លូកា ១៦ ថ្ងៃទី ២ ៖ មេរៀនទី ៥៥ លូកា ១៧ ថ្ងៃទី ៣ ៖ មេរៀនទី ៥៦ លូកា ១៨-២១ ថ្ងៃទី ៤ ៖ មេរៀនទី ៥៧ លូកា ២២ ថ្ងៃទី ៥ ៖ មេរៀនទី ៥៨ លូកា ២៣	លូកា ១៦-២៣
១៤	ថ្ងៃទី ១ ៖ មេរៀនទី ៥៩ លូកា ២៤ ថ្ងៃទី ២ ៖ មេរៀនទី ៦០ យ៉ូហាន ១ ថ្ងៃទី ៣ ៖ មេរៀនទី ៦១ យ៉ូហាន ២ ថ្ងៃទី ៤ ៖ មេរៀនទី ៦២ យ៉ូហាន ៣ ថ្ងៃទី ៥ ៖ មេរៀនទី ៦៣ យ៉ូហាន ៤	លូកា ២៤–យ៉ូហាន ៤
១៥	ថ្ងៃទី ១ ៖ មេរៀនទី ៦៤ យ៉ូហាន ៥ ថ្ងៃទី ២ ៖ មេរៀនទី ៦៥ យ៉ូហាន ៦ ថ្ងៃទី ៣ ៖ មេរៀនទី ៦៦ យ៉ូហាន ៧ ថ្ងៃទី ៤ ៖ មេរៀនទី ៦៧ យ៉ូហាន ៨:១-៣០ ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន)	យ៉ូហាន ៥-៨:៣០
១៦	ថ្ងៃទី ១ ៖ មេរៀនទី ៦៨ យ៉ូហាន ៨:៣១-៥៩ ថ្ងៃទី ២ ៖ មេរៀនទី ៦៩ យ៉ូហាន ៩ ថ្ងៃទី ៣ ៖ មេរៀនទី ៧០ យ៉ូហាន ១០ ថ្ងៃទី ៤ ៖ មេរៀនទី ៧១ យ៉ូហាន ១១ ថ្ងៃទី ៥ ៖ មេរៀនទី ៧២ យ៉ូហាន ១២	យ៉ូហាន ៨:៣១-១២:៥០
១៧	ថ្ងៃទី ១ ៖ មេរៀនទី ៧៣ យ៉ូហាន ១៣ ថ្ងៃទី ២ ៖ មេរៀនទី ៧៤ យ៉ូហាន ១៤ ថ្ងៃទី ៣ ៖ មេរៀនទី ៧៥ យ៉ូហាន ១៥ ថ្ងៃទី ៤ ៖ មេរៀនទី ៧៦ យ៉ូហាន ១៦ ថ្ងៃទី ៥ ៖ មេរៀនទី ៧៧ យ៉ូហាន ១៧	យ៉ូហាន ១៣-១៧
១៨	ថ្ងៃទី ១ ៖ មេរៀនទី ៧៨ យ៉ូហាន ១៨-១៩ ថ្ងៃទី ២ ៖ មេរៀនទី ៧៩ យ៉ូហាន ២០ ថ្ងៃទី ៣ ៖ មេរៀនទី ៨០ យ៉ូហាន ២១ ថ្ងៃទី ៤ ៖ ថ្ងៃអាចផ្លាស់ប្តូរបាន (អនុសាសន៍អំពីរយៈពេលនៅក្នុងថ្នាក់ចាប់ផ្តើមធ្វើ *ការចាត់វិធី* « ការវាយតម្លៃការរៀនសូត្រពីព្រះគម្ពីរសញ្ញាថ្មីសម្រាប់ ម៉ាថាយ–យ៉ូហាន ») ថ្ងៃទី ៥ ៖ ថ្ងៃអាចផ្លាស់ប្តូរបាន (អនុសាសន៍អំពីរយៈពេលនៅក្នុងថ្នាក់ចាប់ផ្តើម *ការរំឭករឡើងវិញ* « ការវាយតម្លៃការរៀនសូត្រពីព្រះគម្ពីរសញ្ញាថ្មីសម្រាប់ ម៉ាថាយ–យ៉ូហាន »)	យ៉ូហាន ១៨-២១

សប្តាហ៍	មេរៀន	បណ្តុំបទគម្ពីរ
១៩	ថ្ងៃទី ១ ៖ មេរៀនទី ៨១ កិច្ចការ ១:១-៨ ថ្ងៃទី ២ ៖ មេរៀនទី ៨២ កិច្ចការ ១:៩-២៦ ថ្ងៃទី ៣ ៖ មេរៀនទី ៨៣ កិច្ចការ ២ ថ្ងៃទី ៤ ៖ មេរៀនទី ៨៤ កិច្ចការ ៣ ថ្ងៃទី ៥ ៖ មេរៀនទី ៨៥ កិច្ចការ ៤-៥	កិច្ចការ ១-៥
២០	ថ្ងៃទី ១ ៖ មេរៀនទី ៨៦ កិច្ចការ ៦-៧ ថ្ងៃទី ២ ៖ មេរៀនទី ៨៧ កិច្ចការ ៨ ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៤ ៖ មេរៀនទី ៨៨ កិច្ចការ ៩ ថ្ងៃទី ៥ ៖ មេរៀនទី ៨៩ កិច្ចការ ១០-១១	កិច្ចការ ៦-១១
២១	ថ្ងៃទី ១ ៖ មេរៀនទី ៩០ កិច្ចការ ១២ ថ្ងៃទី ២ ៖ មេរៀនទី ៩១ កិច្ចការ ១៣-១៤ ថ្ងៃទី ៣ ៖ មេរៀនទី ៩២ កិច្ចការ ១៥ ថ្ងៃទី ៤ ៖ មេរៀនទី ៩៣ កិច្ចការ ១៦ ថ្ងៃទី ៥ ៖ មេរៀនទី ៩៤ កិច្ចការ ១៧	កិច្ចការ ១២-១៧
២២	ថ្ងៃទី ១ ៖ មេរៀនទី ៩៥ កិច្ចការ ១៨-១៩ ថ្ងៃទី ២ ៖ មេរៀនទី ៩៦ កិច្ចការ ២០-២២ ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៤ ៖ មេរៀនទី ៩៧ កិច្ចការ ២៣-២៦ ថ្ងៃទី ៥ ៖ មេរៀនទី ៩៨ កិច្ចការ ២៧-២៨	កិច្ចការ ១៨-២៨
២៣	ថ្ងៃទី ១ ៖ មេរៀនទី ៩៩ រ៉ូម ១-៣ ថ្ងៃទី ២ ៖ មេរៀនទី ១០០ រ៉ូម ៤-៧ ថ្ងៃទី ៣ ៖ មេរៀនទី ១០១ រ៉ូម ៨-១១ ថ្ងៃទី ៤ ៖ មេរៀនទី ១០២ រ៉ូម ១២-១៦ ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន)	រ៉ូម ១-១៦
២៤	ថ្ងៃទី ១ ៖ មេរៀនទី ១០៣ កូរិនថូសទី១ ១-២ ថ្ងៃទី ២ ៖ មេរៀនទី ១០៤ កូរិនថូសទី១ ៣-៤ ថ្ងៃទី ៣ ៖ មេរៀនទី ១០៥ កូរិនថូសទី១ ៥-៦ ថ្ងៃទី ៤ ៖ មេរៀនទី ១០៦ កូរិនថូសទី១ ៧-៨ ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន)	កូរិនថូសទី១ ១-៨
២៥	ថ្ងៃទី ១ ៖ មេរៀនទី ១០៧ កូរិនថូសទី១ ៩-១០ ថ្ងៃទី ២ ៖ មេរៀនទី ១០៨ កូរិនថូសទី១ ១១ ថ្ងៃទី ៣ ៖ មេរៀនទី ១០៩ កូរិនថូសទី១២ ថ្ងៃទី ៤ ៖ មេរៀនទី ១១០ កូរិនថូសទី១ ១៣-១៤ ថ្ងៃទី ៥ ៖ មេរៀនទី ១១១ កូរិនថូសទី១ ១៥:១-២៩	កូរិនថូសទី១ ៩-១៥:២៩
២៦	ថ្ងៃទី ១ ៖ មេរៀនទី១១២ កូរិនថូសទី១ ១៥:៣០-១៦:២៤ ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៣ ៖ មេរៀនទី១១៣ កូរិនថូសទី២ ១-៣ ថ្ងៃទី ៤ ៖ មេរៀនទី ១១៤ កូរិនថូសទី២ ៤-៥ ថ្ងៃទី ៥ ៖ មេរៀនទី ១១៥ កូរិនថូសទី២ ៦-៧	កូរិនថូសទី១ ១៥:៣០–កូរិនថូសទី ២ ៧
២៧	ថ្ងៃទី ១ ៖ មេរៀនទី១១៦ កូរិនថូសទី២ ៨-៩ ថ្ងៃទី ២ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៣ ៖ មេរៀនទី ១១៧ កូរិនថូសទី២ ១០-១៣ ថ្ងៃទី ៤ ៖ មេរៀនទី ១១៨ កាឡាទី ១-៤ ថ្ងៃទី ៥ ៖ មេរៀនទី ១១៩ កាឡាទី ៥-៦	កូរិនថូសទី ២ ៨–កាឡាទី ៦

សប្តាហ៍	មេរៀន	បណ្តុំបទគម្ពីរ
២៨	ថ្ងៃទី ១ ៖ មេរៀនទី ១២០ អេភេសូរ ១ ថ្ងៃទី ២ ៖ មេរៀនទី ១២១ អេភេសូរ ២-៣ ថ្ងៃទី ៣ ៖ មេរៀនទី ១២២ អេភេសូរ ៤ ថ្ងៃទី ៤ ៖ មេរៀនទី ១២៣ អេភេសូរ ៥–៦ ថ្ងៃទី ៥ ៖ មេរៀនទី ១២៤ ភីលីព ១-៣	អេភេសូរ ១–ភីលីព ៣
២៩	ថ្ងៃទី ១ ៖ មេរៀនទី១២៥ ភីលីព ៤ ថ្ងៃទី ២ ៖ មេរៀនទី១២៦ កូល៉ុស ថ្ងៃទី ៣ ៖ មេរៀនទី១២៧ ថែស្សាឡូនីចទី១ ១-២ ថ្ងៃទី ៤ ៖ មេរៀនទី១២៨ ថែស្សាឡូនីចទី១ ៣-៥ ថ្ងៃទី ៥ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន)	ភីលីព ៤–ថែស្សាឡូនីច ទី១ ៥
៣០	ថ្ងៃទី ១ ៖ មេរៀនទី ១២៩ ថែស្សាឡូនីចទី២ ថ្ងៃទី ២ ៖ មេរៀនទី ១៣០ ធីម៉ូថេទី១ ថ្ងៃទី ៣ ៖ មេរៀនទី ១៣១ ធីម៉ូថេទី២ ១-២ ថ្ងៃទី ៤ ៖ មេរៀនទី ១៣២ ធីម៉ូថេទី២ ៣-៤ ថ្ងៃទី ៥ ៖ មេរៀនទី ១៣៣ ទីតុស	ថែស្សាឡូនីចទី ២ ១–ទីតុស ៣
៣១	ថ្ងៃទី ១ ៖ មេរៀនទី ១៣៤ ភីលេម៉ូន ថ្ងៃទី ២ ៖ មេរៀនទី ១៣៥ ហេព្រើរ ១-៤ ថ្ងៃទី ៣ ៖ មេរៀនទី ១៣៦ ហេព្រើរ ៥-៦ ថ្ងៃទី ៤ ៖ មេរៀនទី ១៣៧ ហេព្រើរ ៧-១០ ថ្ងៃទី ៥ ៖ មេរៀនទី ១៣៨ ហេព្រើរ ១១	ភីលេម៉ូន ១–ហេព្រើរ ១១
៣២	ថ្ងៃទី ១ ៖ មេរៀនទី ១៣៩ ហេព្រើរ ១២-១៣ ថ្ងៃទី ២ ៖ មេរៀនទី ១៤០ យ៉ាកុប ១ ថ្ងៃទី ៣ ៖ មេរៀនទី ១៤១ យ៉ាកុប ២ ថ្ងៃទី ៤ ៖ មេរៀនទី ១៤២ យ៉ាកុប ៣ ថ្ងៃទី ៥ ៖ មេរៀនទី ១៤៣ យ៉ាកុប ៤-៥	ហេព្រើរ ១២–យ៉ាកុប ៥
៣៣	ថ្ងៃទី ១ ៖ មេរៀនទី ១៤៤ ពេត្រុសទី ១ ១-២ ថ្ងៃទី ២ ៖ មេរៀនទី ១៤៥ ពេត្រុសទី ១ ៣-៥ ថ្ងៃទី ៣ ៖ ថ្ងៃដែលអាចផ្លាស់ប្តូរបាន (សូមមើល យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន) ថ្ងៃទី ៤ ៖ មេរៀនទី ១៤៦ ពេត្រុសទី២ ១ ថ្ងៃទី ៥ ៖ មេរៀនទី ១៤៧ ពេត្រុសទី២ ២-៣	ពេត្រុសទី១–ពេត្រុសទី២
៣៤	ថ្ងៃទី ១ ៖ មេរៀនទី ១៤៨ យ៉ូហានទី១ ថ្ងៃទី ២ ៖ មេរៀនទី ១៤៩ យ៉ូហានទី២-យ៉ូហានទី ៣ ថ្ងៃទី ៣ ៖ មេរៀនទី ១៥០ យូដាស ថ្ងៃទី ៤ ៖ មេរៀនទី ១៥១ វិវរណៈ ១ ថ្ងៃទី ៥ ៖ មេរៀនទី ១៥២ វិវរណៈ ២–៣	យ៉ូហានទី ១–វិវរណៈ ៣
៣៥	ថ្ងៃទី ១ ៖ មេរៀនទី ១៥៣ វិវរណៈ ៤–៥ ថ្ងៃទី ២ ៖ មេរៀនទី ១៥៤ វិវរណៈ ៦–១១,ផ្នែកទី ១ ថ្ងៃទី ៣ ៖ មេរៀនទី ១៥៥ វិវរណៈ ៦–១១,ផ្នែកទី ២ ថ្ងៃទី ៤ ៖ មេរៀនទី ១៥៦ វិវរណៈ ១២-១៣ ថ្ងៃទី ៥ ៖ មេរៀនទី ១៥៧ វិវរណៈ ១៤-១៦	វិវរណៈ ៤-១៦
៣៦	ថ្ងៃទី ១ ៖ មេរៀនទី ១៥៨ វិវរណៈ ១៧-១៩ ថ្ងៃទី ២ ៖ មេរៀនទី ១៥៩ វិវរណៈ ២០ ថ្ងៃទី ៣ ៖ មេរៀនទី ១៦០ វិវរណៈ ២១–២២ ថ្ងៃទី ៤ ៖ ថ្ងៃអាចផ្លាស់ប្តូរបាន (អនុសាសន៍អំពីរយៈពេលនៅក្នុងថ្នាក់ចាប់ផ្តើម *ការរាជាត់ចែង* « ការវាយតម្លៃការរៀនសូត្រពីព្រះគម្ពីរសញ្ញាថ្មីសម្រាប់ កិច្ចការ–វិវរណៈ ») ថ្ងៃទី ៥ ៖ ថ្ងៃអាចផ្លាស់ប្តូរបាន (អនុសាសន៍អំពីរយៈពេលនៅក្នុងថ្នាក់ចាប់ផ្តើម *ការវិលត្រឡប់វិញ* « ការវាយតម្លៃការរៀនសូត្រពីព្រះគម្ពីរសញ្ញាថ្មីសម្រាប់ កិច្ចការ–វិវរណៈ »)	វិវរណៈ ១៧-២២

យោបល់សម្រាប់បណ្ដាថ្ងៃដែលអាចផ្លាស់ប្ដូរបាន

ការណែនាំពីល្បឿនបង្រៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន គឺផ្អែកទៅលើកាលវិភាគ ៣៦សប្ដាហ៍ ឬ ១៨០ ថ្ងៃនៃឆ្នាំសិក្សា ។ សៀវភៅសិក្សានេះមាន ១៦០ មេរៀនដែលជាមេរៀនប្រចាំថ្ងៃ ដោយទុក ២០ ថ្ងៃទៀតគ្មានសម្ភារមេរៀនឡើយ ។ « ថ្ងៃដែលអាចផ្លាស់ប្ដូរបាន » ទាំង ២០ ថ្ងៃនោះ គួរតែប្រើដោយឆ្លាតវៃសម្រាប់គោលដៅ និង សកម្មភាពនានាដែលមានតម្លៃរួមមានដូចខាងក្រោមនេះ ៖

១. ការវាយតម្លៃ ។ គោលបំណងនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា គឺដើម្បី « ជួយដល់យុវវ័យ និងមន្ត្រីមវ័យក្មេងឲ្យយល់ និងពឹងផ្អែកទៅលើការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មានលក្ខណៈសម្បត្តិនឹងទទួលពរជ័យនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួនពួកគេផ្ទាល់ ក្រុមគ្រួសាររបស់ពួកគេ និងអ្នកដទៃទៀត សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ជាមួយនឹងព្រះវរបិតាសួគ៌របស់ពួកគេ » ។ ដោយគិតពីគោលបំណងនេះ ស. & វ. បានរៀបចំការវាយតម្លៃការរៀនសូត្រ ។ ការវាយតម្លៃទាំងនេះមានបំណងដើម្បីជួយសិស្សឲ្យយល់ ពន្យល់ ជឿ ហើយរស់នៅតាមអ្វីដែលពួកគេកំពុងតែរៀននៅក្នុងថ្នាក់ ។

ក្នុងឆ្នាំ ២០១៤ តម្រូវការសម្រាប់ការបញ្ចប់ថ្នាក់សិក្ខាសាលាបានកែតម្រូវ ដោយសិស្សត្រូវតែប្រឡងឲ្យជាប់សម្រាប់ការវាយតម្លៃការរៀនសូត្រសម្រាប់វគ្គសិក្សានីមួយៗ ដើម្បីអាចទទួលបានសញ្ញាបត្រ ។ អ្នកគួរធ្វើការវាយតម្លៃការរៀនសូត្រម្ដង រៀងរាល់ពាក់កណ្ដាលនៃឆ្នាំសិក្សា ។ ការវាយតម្លៃនីមួយៗមានពីរផ្នែក (១) ការមានការវាយតម្លៃដែលនឹងចំណាយពេលប្រមាណជា ៤០ នាទី ឬ ពេលសម្រាប់ថ្នាក់មួយថ្ងៃ និង (២) ការកែតម្រូវ និងការពិភាក្សាពីការវាយតម្លៃជាមួយនឹងសិស្សនៅម៉ោងសិក្សាលើកក្រោយ ។ ការពិនិត្យមើលនេះគឺជាផ្នែកមួយដ៏ចាំបាច់ ដើម្បីជួយសិស្សឲ្យរៀនពីបទពិសោធន៍នោះ ។ ប្រសិនបើថ្នាក់របស់អ្នកមានរយៈប្រើនជាង ៦០ នាទី អ្នកគួរតែចំណាយពេលតែម្ដងគត់ក្នុងថ្នាក់ដើម្បីចាត់ចែង និងពិនិត្យការវាយតម្លៃនេះ ។

ការវាយតម្លៃត្រូវតែយកមកប្រើដើម្បីជួយសិស្ស ។ កាលប្រកាសពីការបន្ថែមនៃការវាយតម្លៃការរៀនសូត្រសម្រាប់តម្រូវការនៃការបញ្ចប់ថ្នាក់សិក្ខាសាលា អែលឌើរ ប៉ុល វ.ី ចនសុន នៃពួកចិតសិបនាក់បានថ្លែងថា « ឥរិយាបថរបស់គ្រូបង្រៀនម្នាក់នឹងធ្វើឲ្យមានការខុសប្លែកយ៉ាងខ្លាំង ។ ប្រសិនបើគ្រូបង្រៀនអាចមើលឃើញពីរបៀប ដែលការណ៍នេះផ្ដល់ពរជ័យដល់ជីវិតរបស់សិស្ស នោះពួកគេនឹងមើលឃើញការវាយតម្លៃនេះថាជាវិធីមួយដើម្បីជួយដល់សិស្សរបស់ពួកគេ ។ . . . ខ្ញុំគិតថា ប្រសិនបើមានការដោស់គឿនមួយ នោះវាអាចជាអ្វីដែលយើងពុំចង់ឲ្យគ្រូបង្រៀនចាត់ទុកច្បាប់នេះជាឧបករណ៍ ឬ ព្រនង់ដែលបានរៀបចំឡើងឡើយ—ប្រហែលជាពាក្យដែលមានន័យពីរយ៉ាងគឺ—ជាឧបករណ៍ទាលសម្រាប់វាយសំពងនរណាម្នាក់ ឬ ជាក្រុមសម្រាប់តែសិស្សពិសេសមួយចំនួន ។ យើងចង់ឲ្យពួកគេមើលឃើញការវាយតម្លៃនេះជាអ្វីមួយ ដែលនឹងផ្ដល់ពរជ័យដល់ជីវិតរបស់ពួកគេយ៉ាងប្រាកដ » (« Elevate Learning Announcement » [Seminaries and Institutes of Religion global faculty meeting ខែ មិថុនា ឆ្នាំ២០១៤] si.lds.org) ។

កំណត់ចំណាំ ៖ ការវាយតម្លៃជម្រើសផ្សេងទៀតអាចរកឃើញដោយការស្វែងរកនៅក្នុងបិសាយរបស់ ស. & វ. (si.lds.org) ដោយប្រើពាក្យគន្លឹះថា *ការវាយតម្លៃ* ។

២. កែសម្រួលមេរៀនប្រចាំថ្ងៃ ។ អ្នកអាចចំណាយពេលបន្ថែមទៀតលើមេរៀនមួយ ដែលអាចប្រើពេលច្រើន ដើម្បីបង្រៀនឲ្យមានប្រសិទ្ធភាព ។ អ្នកក៏អាចប្រើគំនិតសម្រាប់ការបង្រៀនបន្ថែម ដែលមាននៅចុងបញ្ចប់នៃមេរៀនមួយចំនួន ឬ ចំណាយពេលឆ្លើយសំណួរសិស្សអំពីវគ្គបទគម្ពីរពិសេស ឬ ប្រធានបទនៃដំណឹងល្អ ។ បណ្ដាថ្ងៃដែលអាចផ្លាស់ប្ដូរបាន ធ្វើឲ្យអ្នកទទួលប្រយោជន៍នៃឱកាសទាំងនេះ ដោយការរក្សាល្បឿននៃកាលវិភាគរបស់អ្នក ហើយបំពេញការចាត់តាំងរបស់អ្នក ដើម្បីបង្រៀនខគម្ពីរដោយបន្តបន្ទាប់ ។

៣. ចេះស្វាត់នូវវគ្គបទគម្ពីរសំខាន់ៗ និង គោលលទ្ធិគ្រឹះទាំងឡាយ ។ អ្នកអាចប្រើសកម្មភាពរំឭកសម្រាប់វគ្គចំណេះចំណានខគម្ពីរ ដែលមាននៅក្នុងសៀវភៅសិក្សា និង ក្នុងឧបសម្ព័ន្ធ ។ អ្នកអាចបង្កើតសកម្មភាពរំឭកចំណេះចំណានខគម្ពីរបន្ថែម ដែលបំពេញតាមសេចក្ដីត្រូវការ និងចំណាប់អារម្មណ៍ជាក់លាក់របស់សិស្សនៅក្នុងថ្នាក់របស់អ្នក ។ អ្នកក៏អាចប្រើម៉ោងនៃថ្ងៃដែលអាចផ្លាស់ប្ដូរបានសម្រាប់សកម្មភាពនានា ដែលជួយសិស្សឲ្យរំឭក និង យល់កាន់តែជ្រៅជ្រះអំពីគោលលទ្ធិគ្រឹះនានា ។

៤. រំឭកមេរៀនមុនៗ ។ វាមានប្រយោជន៍សម្រាប់សិស្សឲ្យរំឭកម្ដងម្កាលអំពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនមុនៗ ឬ មកពីគម្ពីរដោក់លាក់មួយ ។ អ្នកអាចផ្ដល់ឱកាសមួយដល់សិស្ស ឲ្យពន្យល់សេចក្ដីពិតមួយពីមេរៀនមុនៗ ហើយចែកចាយពីរបៀបដែលសេចក្ដីពិតនោះបានមានឥទ្ធិពលលើជីវិតរបស់ពួកគេ ។ អ្នកអាចបង្កើត ហើយធ្វើសំណួរ ឬ បង្កើតសកម្មភាពការរៀនសូត្រនានា ដែលរំឭកមេរៀនមុនៗ ។

៥. អនុញ្ញាតឲ្យមានការរំខាននានាចំពោះកាលវិភាគ ។ សកម្មភាព ឬ ការប្រជុំនៅសាលារៀន ព្រឹត្តិការណ៍ក្នុងសហគមន៍ អាកាសធាតុ និង ការរំខានផ្សេងទៀត ដែលអាចតម្រូវឲ្យអ្នកលុបចោលការបង្រៀន ឬ បន្ថយម៉ោងបង្រៀនម្ដងម្កាល ។ ថ្ងៃដែលអាចផ្លាស់ប្ដូរបាន អាចត្រូវបានប្រើសម្រាប់ការរំខានបែបនោះ ។

ការណែនាំអំពីល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនសិក្សានៅផ្ទះ

សៀវភៅសិក្សានេះមាន ៣២ មេរៀនសម្រាប់ថ្នាក់សិក្សានៅផ្ទះ ដែលត្រូវនឹង ៣២ មេរៀននៅក្នុង *សៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ សិស្សថ្នាក់សិក្ខាសាលាដែលសិក្សានៅផ្ទះ* ។ អ្នកអាចនឹងត្រូវដាក់ផែនការមួយសម្រាប់បួនថ្នាក់បន្ថែមទៀត ដើម្បីចាត់ចែង ហើយរំឭកឡើងវិញនូវការវាយតម្លៃការរៀនសូត្រដែលតម្រូវឲ្យមាន ដើម្បីមានចំនួនសរុប ៣៦ ថ្នាក់ ។ អ្នកអាចសម្របមេរៀននេះ និង ល្បឿននៃការបង្រៀនទៅតាមតម្រូវការនៃចំនួនសប្តាហ៍ ដែលអ្នកមានដើម្បីបង្រៀនសិស្សរបស់អ្នក ។

មេរៀន	មេរៀនសិក្សានៅផ្ទះ
មេរៀនទី ១	ថ្ងៃទី ១ ៖ ផែនការនៃសេចក្តីសង្គ្រោះ ថ្ងៃទី ២ ៖ តួនាទីរបស់សិស្ស ថ្ងៃទី ៣ ៖ ការសិក្សាព្រះគម្ពីរ ថ្ងៃទី ៤ ៖ សេចក្តីផ្តើម និង បរិបទនៃព្រះគម្ពីរសញ្ញាថ្មី *មេរៀនសម្រាប់គ្រូបង្រៀន ៖ ផែនការនៃសេចក្តីសង្គ្រោះ–សេចក្តីផ្តើម និង បរិបទនៃព្រះគម្ពីរសញ្ញាថ្មី*
មេរៀនទី ២	ថ្ងៃទី ១ ៖ ម៉ាថាយ ១–២ ថ្ងៃទី ២ ៖ ម៉ាថាយ ៣ ថ្ងៃទី ៣ ៖ ម៉ាថាយ ៤ ថ្ងៃទី ៤ ៖ ម៉ាថាយ ៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាថាយ ១–៥*
មេរៀនទី ៣	ថ្ងៃទី ១ ៖ ម៉ាថាយ ៦-៧ ថ្ងៃទី ២ ៖ ម៉ាថាយ ៨-១០ ថ្ងៃទី ៣ ៖ ម៉ាថាយ ១១-១២ ថ្ងៃទី ៤ ៖ ម៉ាថាយ ១៣:១-២៣ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាថាយ ៦:១–១៣:២៣*
មេរៀនទី ៤	ថ្ងៃទី ១ ៖ ម៉ាថាយ ១៣:២៤–៥៨ ថ្ងៃទី ២ ៖ ម៉ាថាយ ១៤ ថ្ងៃទី ៣ ៖ ម៉ាថាយ ១៥ ថ្ងៃទី ៤ ៖ ម៉ាថាយ ១៦-១៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាថាយ ១៣:២៤–១៧:២៧*
មេរៀនទី ៥	ថ្ងៃទី ១ ៖ ម៉ាថាយ ១៨-២០ ថ្ងៃទី ២ ៖ ម៉ាថាយ ២១:១-១៦ ថ្ងៃទី ៣ ៖ ម៉ាថាយ ២១:១៧–២២:១៤ ថ្ងៃទី ៤ ៖ ម៉ាថាយ ២២:១៥-៤៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាថាយ ១៨-២២*
មេរៀនទី ៦	ថ្ងៃទី ១ ៖ ម៉ាថាយ ២៣ ថ្ងៃទី ២ ៖ យ៉ូសែប ស៊្មីធ—ម៉ាថាយ, ម៉ាថាយ ២៤ ថ្ងៃទី ៣ ៖ ម៉ាថាយ ២៥ ថ្ងៃទី ៤ ៖ ម៉ាថាយ ២៦:១-៣០ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាថាយ ២៣:១–២៦:៣០*
មេរៀនទី ៧	ថ្ងៃទី ១ ៖ ម៉ាថាយ ២៦:៣១-៧៥ ថ្ងៃទី ២ ៖ ម៉ាថាយ ២៧-២៨ ថ្ងៃទី ៣ ៖ ម៉ាកុស ១ ថ្ងៃទី ៤ ៖ ម៉ាកុស ២-៣ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាថាយ ២៦:៣១–ម៉ាកុស ៣:៣៥*
មេរៀន ទី ៨	ថ្ងៃទី ១ ៖ ម៉ាកុស ៤-៥ ថ្ងៃទី ២ ៖ ម៉ាកុស ៦-៨ ថ្ងៃទី ៣ ៖ ម៉ាកុស ៩: ១-២៩ ថ្ងៃទី ៤ ៖ ម៉ាកុស ៩:៣០-៥០ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាកុស ៤-៩*
មេរៀនទី ៩	ថ្ងៃទី ១ ៖ ម៉ាកុស ១០-១៦ ថ្ងៃទី ២ ៖ លូកា ១ ថ្ងៃទី ៣ ៖ លូកា ២ ថ្ងៃទី ៤ ៖ លូកា ៣-៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ាកុស ១០-លូកា ៤*
មេរៀនទី ១០	ថ្ងៃទី ១ ៖ លូកា ៥ ថ្ងៃទី ២ ៖ លូកា ៦:១-៧:១៨ ថ្ងៃទី ៣ ៖ លូកា ៧:១៨-៥០ ថ្ងៃទី ៤ ៖ លូកា ៨:១-១០:៣៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ លូកា ៥:១-១០:៣៧*
មេរៀនទី ១១	ថ្ងៃទី ១ ៖ លូកា ១០:៣៨–១២:៥៩ ថ្ងៃទី ២ ៖ លូកា ១៣-១៥ ថ្ងៃទី ៣ ៖ លូកា ១៦ ថ្ងៃទី ៤ ៖ លូកា ១៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ លូកា ១០:៣៨–១៧:៣៧*
មេរៀនទី ១២	ថ្ងៃទី ១ ៖ លូកា ១៨-២១ ថ្ងៃទី ២ ៖ លូកា ២២ ថ្ងៃទី ៣ ៖ លូកា ២៣-២៤ ថ្ងៃទី ៤ ៖ យ៉ូហាន ១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ លូកា ១៨-យ៉ូហាន ១*
មេរៀនទី ១៣	ថ្ងៃទី ១ ៖ យ៉ូហាន ២ ថ្ងៃទី ២ ៖ យ៉ូហាន ៣ ថ្ងៃទី ៣ ៖ យ៉ូហាន ៤ ថ្ងៃទី ៤ ៖ យ៉ូហាន ៥–៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ យ៉ូហាន ២-៦*
មេរៀនទី ១៤	ថ្ងៃទី ១ ៖ យ៉ូហាន ៧ ថ្ងៃទី ២ ៖ យ៉ូហាន ៨ ថ្ងៃទី ៣ ៖ យ៉ូហាន ៩ ថ្ងៃទី ៤ ៖ យ៉ូហាន ១០ *មេរៀនសម្រាប់គ្រូបង្រៀន ៖ យ៉ូហាន ៧-១០*
មេរៀនទី ១៥	ថ្ងៃទី ១ ៖ យ៉ូហាន ១១ ថ្ងៃទី ២ ៖ យ៉ូហាន ១២ ថ្ងៃទី ៣ ៖ យ៉ូហាន ១៣ ថ្ងៃទី ៤ ៖ យ៉ូហាន ១៤-១៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ យ៉ូហាន ១១-១៥*
មេរៀនទី ១៦	ថ្ងៃទី ១ ៖ យ៉ូហាន ១៦ ថ្ងៃទី ២ ៖ យ៉ូហាន ១៧ ថ្ងៃទី ៣ ៖ យ៉ូហាន ១៨-១៩ ថ្ងៃទី ៤ ៖ យ៉ូហាន ២០-២១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ យ៉ូហាន ១៦-២១*
អនុសាសន៍អំពីរយៈពេលក្នុងថ្នាក់ចាប់ផ្តើមធ្វើ *ការចាត់ចែង* « ការវាយតម្លៃការរៀនសូត្រពីព្រះគម្ពីរសញ្ញាថ្មីសម្រាប់ ម៉ាថាយ–យ៉ូហាន »	

មេរៀន	មេរៀនសិក្សានៅផ្ទះ
អនុសាសន៍អំពីរយៈពេលក្នុងថ្នាក់ចាប់ផ្តើមធ្វើ *ការរំឭកឡើងវិញ* « ការវាយតម្លៃការរៀនសូត្រពីព្រះគម្ពីរសញ្ញាថ្មីសម្រាប់ម៉ាថាយ–យ៉ូហាន »	
មេរៀនទី ១៧	ថ្ងៃទី ១ ៖ កិច្ចការ ១-៨ ថ្ងៃទី ២ ៖ កិច្ចការ ១:៩-២៦ ថ្ងៃទី ៣ ៖ កិច្ចការ ២ ថ្ងៃទី ៤ ៖ កិច្ចការ ៣-៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កិច្ចការ ១–៥*
មេរៀនទី ១៨	ថ្ងៃទី ១ ៖ កិច្ចការ ៦-៧ ថ្ងៃទី ២ ៖ កិច្ចការ ៨ ថ្ងៃទី ៣ ៖ កិច្ចការ ៩ ថ្ងៃទី ៤ ៖ កិច្ចការ ១០–១២ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កិច្ចការ ៦-១២*
មេរៀនទី ១៩	ថ្ងៃទី ១ ៖ កិច្ចការ ១៣-១៤ ថ្ងៃទី ២ ៖ កិច្ចការ ១៥ ថ្ងៃទី ៣ ៖ កិច្ចការ ១៦-១៧ ថ្ងៃទី ៤ ៖ កិច្ចការ ១៨-១៩ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កិច្ចការ ១៣-១៩*
មេរៀនទី ២០	ថ្ងៃទី ១ ៖ កិច្ចការ ២០-២២ ថ្ងៃទី ២ ៖ កិច្ចការ ២៣-២៨ ថ្ងៃទី ៣ ៖ រ៉ូម ១-៣ ថ្ងៃទី ៤ ៖ រ៉ូម ៤-៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កិច្ចការ ២០-រ៉ូម ៧*
មេរៀនទី ២១	ថ្ងៃទី ១ ៖ រ៉ូម ៨-១១ ថ្ងៃទី ២ ៖ រ៉ូម ១២-១៦ ថ្ងៃទី ៣ ៖ កូរិនថូសទី១ ១-២ ថ្ងៃទី ៤ ៖ កូរិនថូសទី១ ៣-៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ រ៉ូម ៨-កូរិនថូសទី១ ៦*
មេរៀនទី ២២	ថ្ងៃទី ១ ៖ កូរិនថូសទី១ ៧-៨ ថ្ងៃទី ២ ៖ កូរិនថូសទី១ ៩-១០ ថ្ងៃទី ៣ ៖ កូរិនថូសទី១ ១១ ថ្ងៃទី ៤ ៖ កូរិនថូសទី១ ១២-១៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កូរិនថូសទី១ ៧-១៤*
មេរៀនទី ២៣	ថ្ងៃទី ១ ៖ កូរិនថូសទី១ ១៥:១–២៩ ថ្ងៃទី ២ ៖ កូរិនថូសទី១ ១៥:៣០–១៦:២៤ ថ្ងៃទី ៣ ៖ កូរិនថូសទី២ ១-៣ ថ្ងៃទី ៤ ៖ កូរិនថូសទី២ ៤-៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កូរិនថូសទី១ ១៥-កូរិនថូសទី២ ៧*
មេរៀនទី ២៤	ថ្ងៃទី ១ ៖ កូរិនថូស ទី២ ៨-៩ ថ្ងៃទី ២ ៖ កូរិនថូស ទី២ ១០-១៣ ថ្ងៃទី ៣ ៖ កាឡាទី ថ្ងៃទី ៤ ៖ អេភេសូរ ១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កូរិនថូស ទី២ ៨–អេភេសូរ ១*
មេរៀនទី ២៥	ថ្ងៃទី ១ ៖ អេភេសូរ ២-៣ ថ្ងៃទី ២ ៖ អេភេសូរ ៤-៦ ថ្ងៃទី ៣៖ ភីលីព ១-៣ ថ្ងៃទី ៤ ៖ ភីលីព ៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អេភេសូរ ២–ភីលីព ៤*
មេរៀនទី ២៦	ថ្ងៃទី ១ ៖ កូល៉ុស ថ្ងៃទី ២ ៖ ថែស្សាឡូនីចទី១ ថ្ងៃទី ៣ ៖ ថែស្សាឡូនីចទី២ ថ្ងៃទី ៤ ៖ ធីម៉ូថេទី១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ កូល៉ុស–ធីម៉ូថេទី១*
មេរៀនទី ២៧	ថ្ងៃទី ១ ៖ ធីម៉ូថេទី២ ថ្ងៃទី ២ ៖ ទីតុស ថ្ងៃទី ៣ ៖ ភីលេម៉ូន ថ្ងៃទី ៤ ៖ ហេព្រើរ ១–៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ធីម៉ូថេទី២ ១–ហេព្រើរ ៤*
មេរៀនទី ២៨	ថ្ងៃទី ១ ៖ ហេព្រើរ ៥-៦ ថ្ងៃទី ២ ៖ ហេព្រើរ ៧-១០ ថ្ងៃទី ៣ ៖ ហេព្រើរ ១១ ថ្ងៃទី ៤ ៖ ហេព្រើរ ១២–យ៉ាកុប ១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ហេព្រើរ៥-យ៉ូហាន១*
មេរៀនទី ២៩	ថ្ងៃទី ១ ៖ យ៉ាកុប ២-៣ ថ្ងៃទី ២ ៖ យ៉ាកុប ៤-៥ ថ្ងៃទី ៣ ៖ ពេត្រុសទី១ ១-២ ថ្ងៃទី ៤ ៖ ពេត្រុសទី១ ៣-៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ យ៉ាកុប២-ពេត្រុសទី១ ៥*
មេរៀនទី ៣០	ថ្ងៃទី ១ ៖ ពេត្រុសទី២ ថ្ងៃទី ២ ៖ យ៉ូហានទី១ ថ្ងៃទី ៣ ៖ យ៉ូហានទី២-យ៉ូហានទី៣ ថ្ងៃទី ៤ ៖ យូដាស *មេរៀនសម្រាប់គ្រូបង្រៀន ៖ ពេត្រុសទី២–យូដាស*
មេរៀនទី ៣១	ថ្ងៃទី ១ ៖ វិវរណៈ ១-៣ ថ្ងៃទី ២ ៖ វិវរណៈ ៤-៥ ថ្ងៃទី ៣ ៖ វិវរណៈ ៦-៧ ថ្ងៃទី ៤ ៖ វិវរណៈ ៨-១១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ វិវរណៈ ១-១១*
មេរៀនទី ៣២	ថ្ងៃទី ១ ៖ វិវរណៈ ១២-១៣ ថ្ងៃទី ២ ៖ វិវរណៈ ១៤-១៦ ថ្ងៃទី ៣ ៖ វិវរណៈ ១៧-១៩ ថ្ងៃទី ៤ ៖ វិវរណៈ ២០-២២ *មេរៀនសម្រាប់គ្រូបង្រៀន ៖ វិវរណៈ ១២-២២*
អនុសាសន៍អំពីរយៈពេលក្នុងថ្នាក់ចាប់ផ្តើម *ការចាត់ចែង* « ការវាយតម្លៃការរៀនសូត្រព្រះគម្ពីរសញ្ញាថ្មីសម្រាប់ កិច្ចការ–វិវរណៈ: »	
អនុសាសន៍អំពីរយៈពេលក្នុងថ្នាក់ចាប់ផ្តើម *ការរំឭកឡើងវិញ* « ការវាយតម្លៃការរៀនសូត្រព្រះគម្ពីរសញ្ញាថ្មីសម្រាប់ កិច្ចការ–វិវរណៈ: »	

សេចក្តីណែនាំស្តីពីចំណេះចំណានខគម្ពីរ

ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនាបានជ្រើសរើសវគ្គចំណេះចំណានខគម្ពីរចំនួន ២៥ សម្រាប់វគ្គនីមួយៗនៃថ្នាក់សិក្ខាសាលាទាំងបួនវគ្គ ។ វគ្គគម្ពីរទាំងនេះ ផ្តល់សារៈសំខាន់ជាមូលដ្ឋានមួយ ខាងបទគម្ពីរសម្រាប់ការយល់ដឹង និង ការចែកចាយដំណឹងល្អ និង សម្រាប់ការពង្រឹងសេចក្តីជំនឿ ។ វគ្គចំណេះចំណានខគម្ពីរសម្រាប់វគ្គសិក្សាព្រះគម្ពីរសញ្ញាថ្មីមានដូចខាងក្រោមនេះ ៖

- ម៉ាថាយ ៥:១៨–១៦
- ម៉ាថាយ ១១:២៨–៣០
- ម៉ាថាយ ១៦:១៥–១៩
- ម៉ាថាយ ២២:៣៦–៣៩
- ម៉ាថាយ ២៨:១៩–២០
- លូកា ២៤:៣៦–៣៩
- យ៉ូហាន ៣:៥
- យ៉ូហាន ១៤:៦
- យ៉ូហាន ១៤:១៥
- យ៉ូហាន ១៧:៣
- កិច្ចការ ២:៣៦–៣៨
- កិច្ចការ ៣:១៩–២១
- កូរិនថូស ទី១ ៦:១៩–២០
- កូរិនថូសទី១ ១៥:២០-២២
- កូរិនថូស ទី១ ១៥:៤០-៤២
- កាឡាទី ៥:២២–២៣
- អេភេសូរ ៤:១១–១៤
- ភីលីព ៤:១៣
- ថែស្សាឡូនីចទី២ ២:១–៣
- ធីម៉ូថេទី២ ៣:១៥–១៧
- ហេព្រើរ ១២:៩
- យ៉ាកុប ១:៥–៦
- យ៉ាកុប ២:១៧–១៨
- ពេត្រុស ទី១ ៤:៦
- វិវរណៈ ២០:១២

សិស្សថ្នាក់សិក្ខាសាលាត្រូវបានលើកទឹកចិត្តឲ្យសូត្រ « ចាំស្ទាត់ » វគ្គខគម្ពីរទាំងនេះ ។ អ្នកអាចជួយដល់សិស្សទាំងឡាយរបស់អ្នកកាន់តែប្រសើរ ប្រសិនបើអ្នកសូត្រវគ្គខគម្ពីរទាំងនេះឲ្យចាំស្ទាត់យ៉ាងល្អផងដែរ ។ ការសូត្រចាំស្ទាត់ខគម្ពីរនេះរួមមាន ៖

- ទីតាំង នៃខគម្ពីរទាំងនេះ ដោយការស្គាល់សេចក្តីរៀបចំព្រះគម្ពីរដែលទាក់ទងគ្នា
- ការយល់ ពីបរិបទ និង មាតិកានៃវគ្គបទគម្ពីរទាំងនេះ
- ការអនុវត្តតាម គោលការណ៍ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អដែលបានបង្រៀននៅក្នុងវគ្គបទគម្ពីរទាំងនេះ
- ការទន្ទេញឲ្យចាំ វគ្គបទគម្ពីរ

ភាពខ្ជាប់ខ្ជួន ការរំពឹងទុក និង វិធីសាស្ត្រនានា

នៅពេលអ្នកដាក់ផែនការជួយសិស្សឲ្យសូត្រចាំវគ្គបទគម្ពីរ នោះអ្នកនឹងមានជោគជ័យកាន់តែខ្លាំង ប្រសិនបើអ្នកយោងទៅលើវគ្គចំណេះចំណានខគម្ពីរដោយខ្ជាប់ខ្ជួន រក្សាការរំពឹងទុកដ៏សមហេតុផល និង ប្រើវិធីសាស្ត្រនានា ដែលទាក់ទាញឲ្យមានរបៀបរៀនខុសប្លែកពីគ្នា ។

ភាពខ្ជាប់ខ្ជួន និង ការសូត្រដដែលៗនៅក្នុងការបង្រៀនចំណេះចំណានខគម្ពីរ នឹងជួយសិស្សឲ្យចងចាំពីសេចក្តីពិតបានយូអង្វែងសម្រាប់ប្រើនាពេលអនាគត ។ វាអាចមានប្រយោជន៍ ដើម្បីរៀបគម្រោងវគ្គសិក្សាសម្រាប់ឆ្នាំសិក្សា ហើយបង្កើតគម្រោងដើម្បីផ្តល់ឱកាសឲ្យបានដាប់លាប់ដល់សិស្សក្នុងថ្នាក់ ដើម្បីសូត្រចាំវគ្គខគម្ពីរទាំងឡាយ ។ សូមមានភាពឆ្លាតវៃក្នុងការសម្រេចចិត្តពីភាពញឹកញាប់ និង ការប្រើប្រាស់ពេលច្រើនប៉ុណ្ណា ក្នុងការជួយសិស្សឲ្យរៀនវគ្គចំណេះចំណានខគម្ពីរទាំងនេះ ។ សូមប្រាកដថា សកម្មភាពចំណេះចំណានខគម្ពីរនេះ ពុំយកម៉ោងពីការសិក្សាព្រះគម្ពីរតាមលំដាប់ប្រចាំថ្ងៃនោះឡើយ ។ អ្នកអាចសម្រេចចិត្តដើម្បីចំណាយពេលពីរបីនាទីរាល់ថ្ងៃ រំឭកវគ្គចំណេះចំណានខគម្ពីរនេះជាមួយសិស្សរបស់អ្នក ។ ឬ អ្នកអាចសម្រេចចិត្តធ្វើសកម្មភាពចំណេះចំណានខ្លីម្តង ឬ ពីរដងក្នុងសប្តាហ៍នីមួយៗដោយប្រើពេល ១០ ទៅ ១៥ នាទី ។ មិនថាអ្នកដាក់ផែនការជួយសិស្សឲ្យរៀនវគ្គចំណេះចំណានខគម្ពីរតាមរបៀបណានោះទេ សូមប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួន និង សមរម្យ ។

សូមផ្តោតការរំពឹងទុករបស់អ្នកអាស្រ័យលើសមត្ថភាពរបស់សិស្សម្នាក់ៗសម្រាប់ចំណេះចំណានខគម្ពីរ ។ វគ្គចំណេះចំណានខគម្ពីរតម្រូវឲ្យមានការខិតខំប្រឹងប្រែងនៅក្នុងចំណែករបស់សិស្ស ។ សូមប្រាប់សិស្សថា ភាពជោគជ័យជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ គឺអាស្រ័យលើអត្តចរិត និងឆន្ទៈដ៏មោះមុតរបស់ពួកគេក្នុងការអនុវត្ត ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅ ដែលនឹងជំរុញសមត្ថភាពពួកគេទៅកាន់កម្រិតកាន់តែខ្ពស់ជាងនេះ ។ សូមស្តាប់ពីសិស្សណាដែលអាចមានការពិបាកក្នុងការទន្ទេញ ហើយសូមមានឆន្ទៈសម្របការរំពឹងទុក និង វិធីសាស្ត្របង្រៀនរបស់អ្នកឲ្យស្របទៅតាមតម្រូវការរបស់សិស្សអ្នក ។

ដើម្បីធ្វើឲ្យបុគ្គលិកលក្ខណៈ និង វិធីសាស្ត្រអ្នកអាចផ្លាស់ប្តូរនោះមានវិធីសាស្ត្រផ្សេងៗទៀតជាច្រើនដើម្បីជួយសិស្សឲ្យសូត្រចាំស្ទាត់វគ្គបទគម្ពីរទាំងនោះ ។ នៅក្នុងគ្រប់ការបង្រៀន និង ការរៀនសូត្រដំណឹងល្អទាំងអស់ សូមជ្រើសរើសយកសកម្មភាពនានាដោយឆ្លាតវៃ ដើម្បីឲ្យព្រះវិញ្ញាណបរិសុទ្ធអាចជួយឲ្យសិស្សសូត្រចាំស្ទាត់នូវខគម្ពីរ និង គោលលទ្ធិ ។ អ្នកនឹងរកឃើញវិធីសាស្ត្របង្រៀនចំណេះចំណានខគម្ពីរសមរម្យមួយចំនួននៅក្នុងរៀននានាក្នុងសៀវភៅសិក្សានេះ ។ សម្រាប់វិធីសាស្ត្របង្រៀនចំណេះចំណានខគម្ពីរបន្ថែមទៀត សូមមើលវគ្គ « សកម្មភាពចំណេះចំណានខគម្ពីរ » នៅក្នុងឧបសម្ព័ន្ធនេះ ។

ចំណេះចំណានខគម្ពីរនៅក្នុងកម្មវិធីសិក្សា

ចំណេះចំណានខគម្ពីរត្រូវបានសរសេរក្នុងកម្មវិធីសិក្សាតាមរបៀបជាច្រើន ។ និមិត្តសញ្ញាចំណេះចំណានខគម្ពីរ បង្ហាញពីសកម្មភាពនៃវគ្គចំណេះចំណានខគម្ពីរនៅក្នុងមេរៀន ។ វគ្គចំណេះចំណានខគម្ពីរត្រូវបានណែនាំប្រាប់ និង ពិភាក្សានៅក្នុងបរិបទនៃជំពូកដែលមាននៅក្នុងមេរៀននោះ ។ គំនិតបន្ថែមសម្រាប់ការបង្រៀនវគ្គចំណេះចំណានខគម្ពីរមានដាក់នៅចុងមេរៀន ។ គំនិតបន្ថែមសម្រាប់ការបង្រៀនទាំងនេះ ជួយធ្វើឲ្យជាតុទាំងបួននៃចំណេះចំណានខគម្ពីរ (ទីតាំង ការយល់ ការអនុវត្តតាម និង ការទន្ទេញឲ្យចាំ) មានភាពស្មើគ្នា ដែលវាទាក់ទងនឹងវគ្គខគម្ពីរនីមួយៗ ។ ឧទាហរណ៍ ប្រសិនបើមេរៀនជួយសិស្សឲ្យយល់ ហើយអនុវត្តវគ្គចំណេះចំណានខគម្ពីរ នោះគំនិតបន្ថែមសម្រាប់ការបង្រៀននឹងជួយពួកគេឲ្យរកទីតាំង ឬទន្ទេញឲ្យចាំវគ្គខគម្ពីរនោះ ។

កម្មវិធីសិក្សាក៏ផ្តល់យ៉ាងទៀងទាត់ដើម្បីរំឭកចំណេះចំណានខគម្ពីរ ដែលអាចប្រើបានទៅតាមពេលវេលាអំណោយផលឲ្យ ហើយស្របតាមគោលដៅនៃចំណេះចំណានខគម្ពីរនៅក្នុងថ្នាក់របស់អ្នក ។ ការរំឭកទាំងនេះ អាចត្រូវបានដាក់បន្ថែមជាមួយសកម្មភាពចំណេះចំណានខគម្ពីរដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធនេះ ។ អ្នកអាចចំណាយពេលបន្ថែមនៅពេលចាប់ផ្តើម ឬពេលបញ្ចប់មេរៀនសង្ខេបខ្លី ដើម្បីធ្វើសកម្មភាពរំឭកទាំងនេះ ណាមួយ។

វិធីសាស្ត្រនានាដែលបានផ្តល់ឲ្យសម្រាប់រៀនចំណេះចំណានខគម្ពីរ

ដើម្បីជួយសិស្សឲ្យជំនាញ រកទីតាំងខគម្ពីរ នោះអ្នកអាចដាក់ផែនការណែនាំវគ្គចំណេះចំណានខគម្ពីរទាំង ២៥ នៅជិតពេលចាប់ផ្តើមវគ្គសិក្សា ហើយក្រោយមកខិតខំសូត្រចំណេះចំណានខគម្ពីរទាំងនេះតាំងពីដើមរហូតដល់ចប់វគ្គសិក្សា ។ ឬ អ្នកណែនាំវគ្គខគម្ពីរពីរបីរាល់ខែ ហើយផ្តោតលើការសូត្រឲ្យចាំនូវវគ្គបទគម្ពីរទាំងនោះអំឡុងខែនោះ ។ ការណែនាំបែបនោះអាចរួមបញ្ចូលនូវ ការផ្តល់យោបល់ឲ្យសិស្សគូសចំណាំវគ្គចំណេះចំណានខគម្ពីរនៅក្នុងព្រះគម្ពីរឲ្យរៀងៗខ្លួនរបស់ពួកគេ ការជួយសិស្សឲ្យគិតអំពីរបៀបចាំពាក្យ និង វគ្គគម្ពីរយោងគន្លឹះ ហើយការពន្យល់គោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងវគ្គបទគម្ពីរនីមួយៗ ។ អ្នកក៏អាចណែនាំវគ្គចំណេះចំណានខគម្ពីរដល់សិស្ស ដោយចាត់តាំងពួកគេឲ្យប្រើវគ្គខគម្ពីរទាំងនោះនៅក្នុងការប្រជុំធម្មនិដ្ឋានរបស់ពួកគេ ឬ ដោយអញ្ជើញពួកគេឲ្យបង្រៀនគ្នាទៅវិញទៅមកពីរបៀបដើម្បីចងចាំ ហើយវិធីរកទីតាំងនៃវគ្គខគម្ពីរទាំងនោះ ។ សូមផ្តល់នូវទំនួលខុសត្រូវក្នុងការចងចាំពីវគ្គចំណេះចំណានខគម្ពីរដោយមួយសកម្មភាពចំណោទសំណួរ និង ការស្វែងរកខគម្ពីរទាំងនោះ (សូមមើលសកម្មភាពវគ្គចំណេះចំណានខគម្ពីរនៅក្នុងឧបសម្ព័ន្ធនេះ សម្រាប់ជាឧទាហរណ៍) ។ បញ្ជីនៃវគ្គចំណេះចំណានខគម្ពីរទាំង ២៥ សម្រាប់វគ្គសិក្សានេះអាចរកបាននៅក្នុងវត្ថុស័កក្នុងសៀវភៅសម្រាប់ចំណាំរបស់សិស្ស និង កាតចំណេះចំណានខគម្ពីរ ។

ដើម្បីជួយសិស្សឲ្យ យល់ ពីវគ្គចំណេះចំណានខគម្ពីរ សូមគូសបញ្ជាក់វគ្គបទគម្ពីរទាំងនេះ នៅពេលវាប្រាកដឡើងនៅក្នុងមេរៀនប្រចាំថ្ងៃរបស់អ្នក ។ អ្នកអាចប្រើសកម្មភាពចំណេះចំណានខគម្ពីរនៅក្នុងឧបសម្ព័ន្ធនេះ ដើម្បីបង្កើនចំណេះដឹង និង សមត្ថភាពរបស់សិស្ស ដើម្បីពន្យល់ពីសេចក្តីពិតដែលមាននៅក្នុងវគ្គបទគម្ពីរនានា ។ សូមផ្តល់ឱកាសដល់សិស្សនៅក្នុងការប្រជុំធម្មនិដ្ឋាន ឬ អំឡុងពេលរៀនដើម្បីពន្យល់ពីរបៀបដែលសេចក្តីពិតនៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ ជួយពួកគេឲ្យយល់កាន់តែប្រសើរឡើងពីគោលលទ្ធិគ្រឹះ ។

ដើម្បីគាំទ្រសិស្សក្នុង ការអនុវត្ត សេចក្តីពិតដែលមាននៅក្នុង វគ្គចំណេះចំណានខគម្ពីរនោះ៖ សូមលើកទឹកចិត្តពួកគេឲ្យធ្វើ តាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ ឲ្យយល់ពីរបៀប ដែលសេចក្តីពិតនៅក្នុងវគ្គបទគម្ពីរទាំងនេះអនុវត្តក្នុងជីវិត របស់ពួកគេ ។ ដើម្បីជួយសិស្សឲ្យអនុវត្តតាមសេចក្តីពិតដែល ពួកគេរៀន អ្នកអាចសរសេរបញ្ហាមួយដែលទាក់ទងនឹងវគ្គ ចំណេះចំណានខគម្ពីរ នៅលើក្តារខៀនបិទប្រកាសនៅក្នុង ថ្នាក់ម្តងម្កាល ។ ឬ អ្នកអាចផ្តល់ឱកាសឲ្យសិស្សអំឡុងពេល រៀន ឲ្យអនុវត្តការបង្រៀនគោលលទ្ធិ និង គោលការណ៍នៃ ដំណឹងល្អដោយប្រើវគ្គចំណេះចំណានខគម្ពីរ (សូមមើល សកម្មភាពចំណេះចំណានខគម្ពីរនៅក្នុងឧបសម្ព័ន្ធនេះសម្រាប់ ជាយោបល់) ។ អ្នកក៏អាចអញ្ជើញសិស្សឲ្យអនុវត្តគោលការណ៍ ដែលពួកគេរៀននៅក្នុងមេរៀនដែលមានវគ្គចំណេះចំណាន ខគម្ពីរទាំងនេះផងដែរ ។ សូមផ្តល់ឱកាសដល់សិស្ស—នៅក្នុង ការប្រជុំជម្មនិដ្ឋាន ឬ ឱកាសផ្សេងទៀត—ឲ្យរាយការណ៍ពី បទពិសោធន៍របស់ពួកគេ ។ ការធ្វើបែបនេះនឹងជួយពួកគេឲ្យ បង្កើនទីបន្ទាល់របស់ខ្លួន អំពីសេចក្តីពិតដែលពួកគេបានរៀនពី វគ្គចំណេះចំណានខគម្ពីរទាំងឡាយ ។

ដើម្បីជួយសិស្ស ទន្ទេញឲ្យចាំ វគ្គចំណេះចំណានខគម្ពីរទាំង ២៥ នេះ អ្នកអាចដាក់ផែនការដើម្បីប្តេជ្ញាចិត្តសូត្រវគ្គបទគម្ពីរ ពីរ ឬបីរៀងរាល់ខែនៅក្នុងថ្នាក់ ។ អ្នកក៏អាចអញ្ជើញសិស្ស ឲ្យសូត្រវគ្គខគម្ពីរជាក់លាក់នានានៅផ្ទះ៖ (ពួកគេអាចសូត្រវា ជាមួយគ្រួសារខ្លួន ឬ សូត្រវគ្គបទគម្ពីរទាំងនេះទៅជិពុកម្តាយ ឬ សមាជិកគ្រួសារស្តាប់) ។ អ្នកអាចធ្វើឲ្យការសូត្រនេះក្លាយ ជាផ្នែកមួយនៃការប្រជុំជម្មនិដ្ឋានប្រចាំថ្ងៃ ដោយសុំឲ្យសិស្ស សូត្រវគ្គបទខគម្ពីរមួយ ឬដោយទុកពេលឲ្យសិស្សទន្ទេញវាជា គូៗ ។ ការផ្តល់ឱកាសឲ្យសិស្សសូត្រវគ្គចំណេះចំណានខគម្ពីរ ជាគូៗ ឬជាក្រុមតូចៗ ឬនៅមុខក្តារខៀន អាចជួយពួកគេមាន ទំនួលខុសត្រូវចំពោះការខិតខំរបស់ពួកគេផងដែរ ។ សកម្មភាព ចំណេះចំណានខគម្ពីរនៅក្នុងឧបសម្ព័ន្ធនេះ រួមមានវិធីសាស្ត្រ ទន្ទេញជាច្រើនផ្សេងៗគ្នា ។ សូមយកចិត្តទុកដាក់បន្ថែមបន្ថយ លើការរំពឹងទុកនៃការទន្ទេញឲ្យចាំ ទៅតាមសមត្ថភាព និង កាលៈទេសៈរបស់សិស្សម្នាក់ៗ ។ មិនគួរធ្វើឲ្យសិស្សខ្មាស់អៀន ឬ អន់ចិត្តឡើយ បើសិនជាពួកគេមិនអាចទន្ទេញចាំវគ្គបទគម្ពីរ មួយនោះ ។

សកម្មភាពចំណេះចំណានខគម្ពីរ

សេចក្តីផ្តើម

ផ្នែកនេះផ្តល់គំនិតមួយចំនួន ដែលអ្នកអាចប្រើដើម្បីជួយសិស្ស ឲ្យទន្ទេញចាំវគ្គបទគម្ពីរគន្លឹះ ។ នៅពេលអ្នកជួយ និង លើក ទឹកចិត្តសិស្សឲ្យបង្កើនការប៉ិនប្រសប់ទាំងនេះ អ្នកកំពុងជួយ ពួកគេឲ្យមានភាពខ្លួនទីពឹងខ្លួននៅក្នុងការសិក្សាព្រះគម្ពីរបស់ ពួកគេ ។ សិស្សអាចប្រើជំនាញចំណេះចំណានទាំងនេះពេញ មួយជីវិតរបស់ពួកគេដើម្បីស្វែងរក យល់ អនុវត្ត និង ទន្ទេញចាំ វគ្គបទគម្ពីរនៅក្នុងព្រះគម្ពីរបានកាន់តែប្រសើរឡើង ។ យោបល់ បង្រៀនសម្រាប់ផ្នែកនីមួយៗ នៃចំណេះចំណានខគម្ពីរ មាន រៀបរាប់ដូចខាងក្រោម ។ ការប្រើប្រាស់សកម្មភាពផ្សេងៗទាំង នេះ អាចជួយសិស្សឲ្យកាន់តែមានដោគដ័យលើការទន្ទេញចាំ វគ្គបទគម្ពីរទាំងនេះ ។

សកម្មភាពដែលជួយសិស្សឲ្យ *រកទីតាំង* នៃវគ្គ ចំណេះចំណានខគម្ពីរ

ការគូសចំណាំវគ្គបទគម្ពីរ

ការគូសចំណាំវគ្គចំណេះចំណានខគម្ពីរអាចជួយសិស្សឲ្យចាំវគ្គ បទគម្ពីរទាំងនេះ ហើយរកឃើញទីតាំងវាបានយ៉ាងលឿន ។ សូមគិតពីការលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គគន្លឹះទាំងនេះ នៅក្នុងព្រះគម្ពីររបស់គេ តាមរបៀបមួយដែលញែកចេញពី ខគម្ពីរដទៃ ដែលពួកគេគូសចំណាំ ។

ការដឹងអំពីគម្ពីរទាំងឡាយ

ការទន្ទេញចាំឈ្មោះ និងលំដាប់នៃគម្ពីរនៅក្នុងព្រះគម្ពីរសញ្ញា ថ្មី អាចជួយសិស្សឲ្យរកឃើញវគ្គចំណេះចំណានខគម្ពីរកាន់តែ លឿន ។ ឧទាហរណ៍ខាងក្រោមនេះគឺឧទាហរណ៍មួយចំនួននៃ សកម្មភាព ដែលអាចជួយសិស្សឲ្យស្គាល់គម្ពីរនៅក្នុងព្រះគម្ពីរ សញ្ញាថ្មី ៖

- ស្វែងរកតារាងមាតិកា—សូមជួយសិស្សឲ្យស្គាល់ កាន់តែច្បាស់ពីតារាងមាតិកានៅក្នុងព្រះគម្ពីរបឹប ដើម្បីជួយ ពួកគេឲ្យរកឃើញគម្ពីរដែលមានសេចក្តីយោងនៃចំណេះ ចំណានខគម្ពីរ ។
- ច្រៀងចម្រៀង—សូមដំនូរទំនុកច្រៀងនៃទំនុកតម្កើង ស្រដៀងគ្នាមួយ ឬចម្រៀងកុមារជាមួយនឹងឈ្មោះគម្ពីរនៃ ព្រះគម្ពីរសញ្ញាថ្មី ។ សូមបង្រៀនចម្រៀងនោះដល់សិស្ស របស់អ្នក (ឬ ប្រើចម្រៀង « The Books in the New Testament » [*Children's Songbook* ទំព័រ ១១៦–១៧]) ។ សុំឲ្យសិស្សច្រៀងចម្រៀងនេះឲ្យ ទៀងទាត់ពេញមួយឆ្នាំដើម្បីជួយពួកគេឲ្យចងចាំឈ្មោះ និង លំដាប់លំដោយនៃគម្ពីរនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។
- ប្រើតួអក្សរទីមួយ—សូមសរសេរតួអក្សរទីមួយនៃគម្ពីរ ទាំងឡាយនៅលើក្តារខៀន (ដូចជា ម, ម, ល, យ ជាដើម) ។ សូមឲ្យសិស្សអនុវត្តនិយាយឈ្មោះគម្ពីរដែល ត្រូវនឹងអក្សរនីមួយៗ ។ សូមធ្វើសកម្មភាពនេះម្តងហើយ ម្តងទៀត រហូតដល់ពួកគេអាចសូត្រឈ្មោះគម្ពីរចេញពីការ ចងចាំរបស់ពួកគេបាន ។
- តាមកេគម្ពីរ—សូមនិយាយគម្ពីរមួយដែលមានវគ្គចំណេះ ចំណានខគម្ពីរ ហើយឲ្យសិស្សបើកព្រះគម្ពីររបស់ពួកគេទៅ ទំព័រណាមួយក៏បាននៅក្នុងគម្ពីរនោះ ។ សូមផ្អៀងម៉ោងថា តើវាចំណាយពេលអស់ប៉ុន្មានដើម្បីឲ្យសិស្សរកឃើញគម្ពីរ នីមួយៗ ។ សកម្មភាពនេះអាចធ្វើឡើងវិញម្តងទៀត ដើម្បី ផ្តល់ឱកាសដល់សិស្សឲ្យទទួលបានអត្ថប្រយោជន៍កាន់តែ ច្រើនដោយការចងចាំ និងការរកឃើញគម្ពីរនៅក្នុងព្រះគម្ពីរ សញ្ញាថ្មី ។

ការចងចាំសេចក្តីយោង និង មាតិកា

នៅពេលសិស្សរៀនរកទីតាំង និង បរិបទនៃវគ្គចំណេះចំណាន ខគម្ពីរ នោះព្រះវិញ្ញាណបរិសុទ្ធអាចជួយពួកគេឲ្យចងចាំ សេចក្តីយោងព្រះគម្ពីរតាមការចាំបាច់ (សូមមើល យ៉ូហាន ១៤:២៦) ។ ពាក្យ ឬឃ្លាដ៏សំខាន់ ដូចជា « កើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ » (យ៉ូហាន ៣:៥) និង « ផលផ្លែនៃ ព្រះវិញ្ញាណ » (កាឡាទី ៥:២២–២៣) អាចជួយសិស្សឲ្យ ចងចាំមាតិកា និងការបង្រៀនពីគោលលទ្ធិនៃវគ្គនីមួយៗ ។ វិធីសាស្ត្រខាងក្រោមនេះ អាចជួយសិស្សឲ្យភ្ជាប់អត្ថន័យ សេចក្តីយោងនៃចំណេះចំណានខគម្ពីរទៅនឹងបរិបទ ឬ ពាក្យ គន្លឹះរបស់វា ។ (អ្នកអាចទុកសកម្មភាពដែលទាក់ទងនឹង ការប្រកួតប្រជែង ការប្រណាំង ឬ ការធ្វើឲ្យទាន់ពេល នៅពេល ក្រោយនៅក្នុងឆ្នាំសិក្សា បន្ទាប់ពីសិស្សបានបង្ហាញថា ពួកគេ ស្គាល់កន្លែងនៃវគ្គចំណេះចំណានខគម្ពីរទាំងនោះហើយ ។ សកម្មភាពបែបនោះ នឹងជួយពួកគេពង្រឹងអ្វីៗដែលពួកគេបាន រៀនរួចមក) ។

- សេចក្តីយោង និង ពាក្យគន្លឹះ—លើកទឹកចិត្តសិស្សឲ្យ ទន្ទេញចាំសេចក្តីយោង និង ពាក្យគន្លឹះនៃវគ្គចំណេះចំណាន ខគម្ពីរនីមួយៗ ដែលមាននៅលើកាតចំណេះចំណាន ខគម្ពីរ ។ (កាតចំណេះចំណានខគម្ពីរ អាចបញ្ជាទិញបាន តាមអ៊ិនធើណែតនៅគេហទំព័រ store.lds.org ។ អ្នកក៏ អាចឲ្យសិស្សបង្កើតឈុតនៃកាតចំណេះចំណានខគម្ពីរផ្ទាល់ ខ្លួនពួកគេផងដែរ) ។ សូមទុកពេលឲ្យសិស្សសិក្សាកាត នោះជាមួយដៃគូ ហើយក្រោយមកសួរគ្នាទៅវិញទៅមក ។ សូមលើកទឹកចិត្តសិស្សឲ្យចេះច្នៃប្រឌិតក្នុងរបៀបសិក្សារួមគ្នា របស់ពួកគេ ហើយសួរគ្នាទៅវិញទៅមក ។ នៅពេលពួកគេ ចេះកាន់តែចាំស្ទាត់នូវវគ្គចំណេះចំណានខគម្ពីរហើយនោះ អ្នកអាចអញ្ជើញពួកគេឲ្យប្រើតម្រុយនានា ដែលទាក់ទងនឹង បរិបទ ឬ ការអនុវត្តនៃគោលលទ្ធិ និង គោលការណ៍នានា ចេញពីវគ្គបទគម្ពីរទាំងនោះ ។ អ្នកដែលត្រូវបានគេសួរ អាច ឆ្លើយដោយផ្ទាល់មាត់ ឬដោយការសរសេរ ។
- កាតចំណេះចំណានខគម្ពីរ—សកម្មភាពនេះអាចត្រូវបាន ប្រើដើម្បីណែនាំ ឬ រំឭកឈុតនៃវគ្គចំណេះចំណានខគម្ពីរ ។ សូមជ្រើសរើសកាតចំណេះចំណានខគម្ពីរមួយចំនួន ហើយ រៀបចំចែកវាទៅសិស្សរបស់អ្នក ។ (សូមប្រាកដថា មាន កាតនីមួយៗឲ្យច្រើន ដូច្នេះអ្នកនឹងមានសិស្សច្រើនទទួល បានវគ្គចំណេះចំណានខគម្ពីរដែលដូចគ្នា ។ អ្នកអាច មានកាតគ្រប់គ្រាន់សម្រាប់សិស្សម្នាក់ៗ ដើម្បីមានវគ្គ បទគម្ពីរពីរ ឬ បីផ្សេងៗគ្នា) ។ សូមចែកកាតនោះឲ្យ សិស្ស ។ សូមទុកពេលឲ្យសិស្សសិក្សាវគ្គចំណេះចំណាន ខគម្ពីរ សេចក្តីយោង ពាក្យគន្លឹះ សេចក្តីថ្លែងការណ៍នៃ បរិបទ គោលលទ្ធិ ឬ គោលការណ៍ និង គំនិតអនុវត្ត នានានៅលើកាតនីមួយៗ ។ សូមនិយាយតម្រុយមួយ ចំនួនក្នុងកាតទាំងនោះ (ឧទាហរណ៍ ពាក្យនានាមកពីវគ្គ ចំណេះចំណានខគម្ពីរ ឬ ពាក្យគន្លឹះ បរិបទ គោលលទ្ធិ ឬ គោលការណ៍ ឬ ការអនុវត្ត) ។ សិស្សដែលមានកាតដែល ទាក់ទងនឹងតម្រុយនោះគួរតែក្រោកឈរឡើង ហើយប្រាប់ពី សេចក្តីយោងនៃចំណេះចំណានខគម្ពីរនោះឲ្យឮៗ ។
- ការដេញរកខគម្ពីរ—សូមប្រើតម្រុយនានា ដើម្បីជួយសិស្ស ឲ្យហាត់បើករកវគ្គបទគម្ពីរនោះយ៉ាងលឿន នៅក្នុងព្រះគម្ពីរ របស់ពួកគេ ។ សម្រាប់តម្រុយ អ្នកអាចប្រើពាក្យគន្លឹះ សេចក្តីថ្លែងការណ៍នៃបរិបទ គោលលទ្ធិ និង គោលការណ៍ និង គំនិតអនុវត្តនានាមកពីកាតចំណេះចំណានខគម្ពីរ ។ អ្នកក៏អាចបង្កើតតម្រុយនោះបានដោយខ្លួនឯងផងដែរ ។ សកម្មភាពបើកដេញរកខគម្ពីរប្រណាំងគ្នា ដែលសិស្ស ជំណើមគ្នាបើករកវគ្គបទគម្ពីរ អាចជួយពួកគេឲ្យចូលរួម យ៉ាងសកម្ម នៅក្នុងការរៀនវគ្គចំណេះចំណានខគម្ពីរ ។ នៅពេលប្រើសកម្មភាពសួរបើកដេញរកខគម្ពីរប្រណាំងគ្នា ដើម្បីជួយក្នុងការរៀនពីចំណេះចំណានខគម្ពីរ សូមធ្វើវាតាម របៀបមួយដែលពុំធ្វើឲ្យមានអារម្មណ៍ឈឺចាប់ ឬ ប៉ះទង្គិច ដល់ព្រះវិញ្ញាណឡើយ ។ សូមជួយសិស្សឲ្យចៀសវាងពី ការប្រព្រឹត្តិចំពោះព្រះគម្ពីររបស់ខ្លួនដោយគ្មានគោរវភាព ឬ ដូចជាមានការប្រកួតប្រជែងជ្រុលហួសហេតុពេក ។ សូម គិតពីការឲ្យសិស្សប្រកួតប្រជែងនឹងបទដ្ឋានមួយ ពុំមែន ប្រកួតប្រជែងរវាងគ្នា និង គ្នានោះទេ ។ ឧទាហរណ៍ សិស្ស អាចប្រកួតជាមួយគ្រូបង្រៀន ឬ អ្នកអាចឲ្យពួកគេប្រកួត ដើម្បីមើលថា ប្រសិនបើភាគរយពិតប្រាកដនៃសិស្សក្នុងថ្នាក់ អាចរកឃើញវគ្គបទគម្ពីរដាក់លាក់មួយ នៅក្នុងពេលកំណត់ មួយ ។
- ការសួរដេញរកដំណើររឿង—សូមផ្តល់តម្រុយ ដោយ ប្រឌិតស្ថានភាពឡើង ដែលបង្ហាញពីទំនាក់ទំនងនៃវគ្គ ចំណេះចំណានខគម្ពីរទៅនឹងជីវិតប្រចាំថ្ងៃ ។ ឧទាហរណ៍ ជាតម្រុយសម្រាប់ ម៉ាថាយ ២៨:១៩–២០ ឬ កីលីព ៤:១៣ អ្នកអាចនិយាយថា « ដានីយ៉ែលមានសិទ្ធិបម្រើ បេសកកម្ម ហើយមានអារម្មណ៍ថា វាគឺដាក់ពន្ធកិច្ច បព្វជិតភាពរបស់គាត់ដើម្បីអនុវត្តកិច្ចការនេះ ប៉ុន្តែគាត់បារម្ភ ថា គាត់គ្មានចំណេះដឹងគ្រប់គ្រាន់ ដើម្បីបង្រៀនដំណឹងល្អ ឲ្យបានល្អឡើយ ។ គាត់ក៏បារម្ភផងដែរថា វានឹងពិបាកនៅ ក្នុងការនិយាយជាមួយនឹងមនុស្សចម្លែកណាស់ ។ នៅពេល គាត់អធិស្ឋានទូលសូមការអះអាង គាត់ចងចាំថា បន្ទាប់ពី ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មឡើងវិញ នោះទ្រង់បាន បង្គាប់ដល់ពួកសាវករបស់ទ្រង់ឲ្យ ‹ ទៅបញ្ចុះបញ្ចូលឲ្យមាន សិស្សនៅគ្រប់ទាំងសាសន៍ › ហើយថា ព្រះអម្ចាស់នឹងគង់ នៅជាមួយនឹងពួកគាត់ជានិច្ច ។ ដានីយ៉ែលក៏បានគិតពី ពាក្យរបស់ប៉ុលផងដែរថា ‹ ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចម្រើនកម្លាំងដល់ខ្ញុំ › ។ នៅពេលសិស្សស្តាប់នូវស្ថានភាពប្រឌិតនោះ សូមឲ្យពួកគេ បើករកវគ្គចំណេះចំណានខគម្ពីរដែលទាក់ទងនេះនៅក្នុង ព្រះគម្ពីររបស់ខ្លួន ។
- សំណួរ និង ការប្រឡង—សូមផ្តល់ឱកាសឲ្យសិស្ស សាកល្បងពីការចងចាំនៃវគ្គចំណេះចំណានខគម្ពីររបស់

ពួកគេ ។ តម្រុយអាចរួមមាន ៣ក្យគន្លឹះ ឬ សេចក្តីយោងព្រះគម្ពីរ ការដកស្រង់ពីវគ្គបទគម្ពីរ ឬ ស្ថានភាពប្រឌិតដែលគូសបង្ហាញពីសេចក្តីពិត ដែលបានបង្រៀននៅក្នុងវគ្គបទគម្ពីរទាំងនោះ ។ សំណួរ និង ការប្រឡងនានាអាចត្រូវធ្វើឡើងដោយផ្ទាល់មាត់ នៅលើក្តារខៀន ឬនៅលើក្រដាស ។ បន្ទាប់ពីសិស្សបានឆ្លើយសំណួរ ឬធ្វើការប្រឡងហើយ សូមគិតពីការចាប់គូសិស្សដែលបានពិន្ទុខ្ពស់ជាមួយសិស្សដែលបានពិន្ទុទាប ។ សិស្សដែលបានពិន្ទុខ្ពស់អាចដើរតួធ្វើជាគ្រូ ដើម្បីជួយសិស្សដែលមានពិន្ទុទាបឲ្យសិក្សា និង កែលម្អឲ្យប្រសើរឡើង ។ ក្នុងផ្នែកមួយនៃការធ្វើកិច្ចការនេះ ដៃគូក៏អាចដាក់ជាគោលដៅមួយ ដើម្បីទទួលបានពិន្ទុបូកបញ្ចូលគ្នាកាន់តែខ្ពស់ សម្រាប់ការប្រឡងលើកក្រោយ ។ សូមគិតពីការបង្កើតតារាង ឬ ក្តារខៀនបិទប្រកាស ដើម្បីបង្ហាញគោលដៅ និង ការទទួលស្គាល់ការរីកចម្រើនរបស់ពួកគេ ។

សកម្មភាពដែលជួយសិស្សឲ្យ *យល់* វគ្គចំណេះចំណានខគម្ពីរ

ផ្តល់និយមន័យឲ្យពាក្យ និង ឃ្លានានា

ការផ្តល់និយមន័យឲ្យពាក្យ និង ឃ្លានានានៅក្នុងវគ្គចំណេះចំណានខគម្ពីរ (ឬ ការជួយសិស្សឲ្យផ្តល់និយមន័យដល់ពាក្យ និង ឃ្លាទាំងនោះ) នឹងជួយសិស្សឲ្យយល់ពីអត្ថន័យនៃវគ្គបទគម្ពីរទាំងមូល ។ នៅពេលនិយមន័យបែបនោះពិតជាចាំបាច់ដើម្បីយល់ពីគោលលទ្ធិ និង គោលការណ៍នានានៅក្នុងវគ្គបទគម្ពីរ នោះអ្នកអាចណែនាំសិស្សឲ្យសរសេរនិយមន័យទាំងនោះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សូមរំឭកអត្ថន័យនៃពាក្យ និង ឃ្លាទាំងនោះ នៅពេលអ្នករំឭកវគ្គចំណេះចំណានខគម្ពីរនានា ។

ការស្វែងរកបរិបទ

ការស្វែងរកបរិបទនៃវគ្គបទគម្ពីរ អាចជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីអត្ថន័យនៃវគ្គបទគម្ពីរនោះ ។ បរិបទរួមមានព័ត៌មានដែលទាក់ទងនឹងមនុស្សដែលនិយាយទៅនរណាម្នាក់ និង មូលហេតុអ្វីមួយ ទីតាំងនៃដំណើររឿងនៃវគ្គបទគម្ពីរ (ប្រវត្តិសាស្ត្រ ប្បធម៌ និង ភូមិសាស្ត្រ) និង សំណួរ ឬ ស្ថានភាពដែលមានវគ្គបទគម្ពីរនោះ ។ ឧទាហរណ៍ ការបង្រៀនរបស់ព្រះអម្ចាស់នៅក្នុង យ៉ូហាន ៣:៥ គឺជាផ្នែកមួយនៃការសន្ទនារវាងព្រះយេស៊ូវគ្រីស្ទ និងពួកផារិស៊ីជំមានសណ្តានចិត្តម្នាក់ឈ្មោះនីកូដេម ដែលបានមករកព្រះអង្គសង្គ្រោះនៅវេលាយប់ ដើម្បីទូលសួរអំពីគោលលទ្ធិរបស់ទ្រង់ ។ ព្រះអម្ចាស់បានមានបន្ទូលប្រាប់នីកូដេមថា លុះត្រាយើង « កើតជាថ្មី » នោះយើង « មិនអាចឃើញនគរព្រះបានទេ » (យ៉ូហាន ៣:៣) ។ ដោយមានការភ័ន្តច្រឡំ នីកូដេមបានទូលសួរថា មនុស្សចំណាស់ម្នាក់អាចកើតជាថ្មីបានយ៉ាងដូចម្តេច ។ យ៉ូហាន ៣:៥ មាននូវចម្លើយរបស់ព្រះអម្ចាស់ចំពោះសំណួររបស់នីកូដេម ។ ដោយដឹងថាព័ត៌មាននេះអាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីសំណួរ ដែលព្រះអម្ចាស់បានលើកឡើង កាលទ្រង់បានប្រកាសថា « បើមិនបានកើតអំពីទឹក ហើយអំពីវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ » ។ នៅពេលអ្នកបង្រៀនមេរៀនដែលមានវគ្គចំណេះចំណានខគម្ពីរ សូមគូសបញ្ជាក់ពីបរិបទដែលនៅជុំវិញវគ្គបទគម្ពីរទាំងនោះ ។ សកម្មភាពបន្ថែមដូចខាងក្រោមនេះ អាចជួយសិស្សឲ្យយល់ពីវគ្គបទគម្ពីរគន្លឹះទាំងនេះ ៖

- ការស្វែងរកបរិបទ—សូមសរសេរពាក្យខាងក្រោមនេះនៅផ្នែកខាងលើនៃក្តារខៀន ៖ *អ្នកនិយាយ អ្នកស្តាប់ គោលបំណង* និង *ការយល់ដឹងដែលមានប្រយោជន៍ផ្សេងទៀត* ។ សូមចែកសិស្សជាក្រុម ហើយចាត់តាំងក្រុមនីមួយៗនូវវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមអញ្ជើញពួកគេឲ្យស្វែងរកបរិបទនៃវគ្គបទគម្ពីរ ដែលខ្លួនត្រូវបានចាត់តាំង ដោយស្វែងរកព័ត៌មានដែលត្រូវនឹងពាក្យនានានៅលើក្តារខៀន ។ សូមឲ្យពួកគេសរសេរចម្លើយរបស់ពួកគេលើក្តារខៀន ។ បន្ទាប់មក សូមឲ្យក្រុមនីមួយៗពន្យល់ពីបរិបទនៃវគ្គបទគម្ពីរដែលបានចាត់តាំងឲ្យនោះ និង របៀបដែលព័ត៌មាននេះទាក់ទងនឹងការយល់ដឹងរបស់ពួកគេអំពីសេចក្តីពិតនៅក្នុងវគ្គបទគម្ពីរនីមួយៗ ។ ដើម្បីធ្វើឲ្យសកម្មភាពនេះកាន់តែទូលំទូលាយ អ្នកអាចអញ្ជើញសិស្សឲ្យទាយស្មានសេចក្តីយោងចំណេះចំណានខគម្ពីរ ដោយផ្អែកលើការពិពណ៌នានៅលើក្តារខៀន ពីមុនពេលក្រុមនីមួយៗពន្យល់អ្វីដែលពួកគេបានសរសេរ ។

ការវិភាគ

ការវិភាគទាក់ទងនឹងការស្វែងរកគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងវគ្គបទគម្ពីរ ។ វាក៏ជួយសិស្សឲ្យយល់អំពីរបៀបដែលសេចក្តីពិតទាំងនេះទាក់ទងនឹងពួកគេផងដែរ ។ ការណ៍នេះនាំឲ្យមានការអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងនេះកាន់តែជ្រាលជ្រៅនៅក្នុងជីវិតរបស់ពួកគេ ។ សកម្មភាពខាងក្រោមអាចជួយសិស្សឲ្យចេះវិភាគវគ្គចំណេះចំណានខគម្ពីរ ៖

- សរសេរតម្រុយ—នៅពេលសិស្សកាន់តែស្គាល់វគ្គចំណេះចំណានខគម្ពីរ សូមអញ្ជើញពួកគេឲ្យបង្កើតសំណួរជំណាលរឿង ឬ តម្រុយផ្សេងទៀតដែលបង្ហាញពីគោលលទ្ធិ និង គោលការណ៍នានាដែលបានបង្រៀននៅក្នុងវគ្គបទគម្ពីរនោះ ។ វិធីទាំងនេះគួរប្រើដើម្បីសួរសិស្ស ។

ការពន្យល់

ការសុំឲ្យសិស្សពន្យល់ពីវគ្គបទគម្ពីរ នឹងជួយសិស្សឲ្យយល់កាន់តែសឹងជម្រៅ ហើយពង្រីកសមត្ថភាពរបស់គេក្នុងការបង្រៀនគោលលទ្ធិ និង គោលការណ៍នានាពីព្រះគម្ពីរ ។ ខាងក្រោមនេះគឺជាវិធីសាស្ត្រពីរយ៉ាង ដែលអាចជួយសិស្សឲ្យរៀនពន្យល់វគ្គចំណេះចំណានខគម្ពីរ ៖

- ៣ក្យ និង ឃ្លាគន្លឹះ—សូមអញ្ជើញសិស្សឲ្យអានវគ្គបទគម្ពីរដូចគ្នាដោយខ្លួនឯង ហើយស្វែងរក៣ក្យ ឬ ឃ្លាដែលពួកគេគិតថាពិតជាសំខាន់ចំពោះអត្ថន័យនៃវគ្គបទគម្ពីរនោះ ។ បន្ទាប់មក សូមអញ្ជើញសិស្សឲ្យអានវគ្គបទគម្ពីរដល់សិស្សហើយផ្តល់ការគូសបញ្ជាក់ពី៣ក្យ ឬ ឃ្លាដែលគាត់បានជ្រើសរើស ។ សូមឲ្យសិស្សពន្យល់ពីមូលហេតុដែល៣ក្យ ឬ ឃ្លានោះ សំខាន់ចំពោះការយល់ដឹងពីវគ្គបទគម្ពីរនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យធ្វើដូច្នេះផងដែរ ។ សិស្សអាចជ្រើសរើសៗ៣ក្យ ឬ ឃ្លាផ្សេងៗគ្នានៅក្នុងវគ្គបទគម្ពីរដដែល ។ នៅពេលសិស្សផ្សេងទៀតក្នុងថ្នាក់ឮទស្សនៈផ្សេងៗគ្នាទាំងនេះ ពួកគេអាចទទួលបានការយល់ដឹងកាន់តែជ្រៅជ្រះពីវគ្គបទគម្ពីរនោះ ។
- រៀបចំសម្រាប់ការប្រជុំជម្មនិដ្ឋាន—សូមផ្តល់ឱកាសឲ្យសិស្សប្រើវគ្គចំណេះចំណានខគម្ពីរនៅពេលពួកគេរៀបចំ និង បង្ហាញនៅក្នុងការប្រជុំជម្មនិដ្ឋាន នៅពេលចាប់ផ្តើមថ្នាក់ ។ សូមជួយពួកគេឲ្យរៀបចំសង្ខេបបរិបទ ពន្យល់គោលលទ្ធិ និង គោលការណ៍ ចែកចាយបទពិសោធន៍ ឬ ឧទាហរណ៍ដ៏មានអត្ថន័យ ហើយថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និង គោលការណ៍នៅក្នុងវគ្គបទគម្ពីរនោះ ។ អ្នកអាចនឹងចង់ផ្តល់យោបល់ឲ្យសិស្សគិតពីការប្រើកម្មវត្ថុនៃមេរៀន ដើម្បីពន្យល់ពីគំនិតនៅក្នុងវគ្គបទគម្ពីរនោះ ។

ការមានអារម្មណ៍ពីសារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍

សូមជួយសិស្សឲ្យយល់ និង ទទួលបានទីបន្ទាល់ខាងវិញ្ញាណអំពីគោលលទ្ធិ និង គោលការណ៍ដែលបានបង្រៀននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ។ អែលឌើរ រ៉ូបឺត ឌី ហែល ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា « គ្រូបង្រៀនពិតម្នាក់ នៅពេល [គាត់] បានបង្រៀនការពិត [នៃដំណឹងល្អ] . . . នោះបានជួយ [សិស្ស] ឲ្យបោះជំហានចូលកាន់តែជិតដើម្បីទទួលបានសាក្សីខាងវិញ្ញាណ និង ការយល់ដឹងនៅក្នុងដួងចិត្តរបស់ខ្លួន ដែលនាំឲ្យធ្វើសកម្មភាព និង ធ្វើកិច្ចការនោះ » (« Teaching by Faith« [សុន្ទរកថាចំពោះគ្រូបង្រៀនសាសនានៃប្រព័ន្ធអប់រំព្រះវិហារ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០០២] ទំព័រ ៥, si.lds.org, សូមមើលផងដែរ *Teaching Seminary: Preservice Readings* [ឆ្នាំ ២០០៤] ទំព័រ ៩២) ។ នៅពេលសិស្សទទួលអារម្មណ៍ពីសេចក្តីពិត ភាពសំខាន់ និង ភាពបន្ទាន់នៃគោលការណ៍ ឬ គោលលទ្ធិតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណ នោះបំណងប្រាថ្នារបស់ពួកគេដើម្បីអនុវត្តសេចក្តីពិតនោះនៅក្នុងជីវិតរបស់ពួកគេក៏រីកចម្រើនផងដែរ ។ គ្រូបង្រៀនអាចជួយសិស្សឲ្យអញ្ជើញ និង បណ្តុះអារម្មណ៍ទាំងនេះ ដោយការផ្តល់ឱកាសឲ្យពួកគេចែកចាយបទពិសោធន៍នានា ដែលពួកគេមានក្នុងការរស់នៅតាមគោលការណ៍នៃដំណឹងល្អ ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ។ ការណ៍នេះនឹងជួយសិស្សឲ្យយល់សេចក្តីពិត ដែលបានបង្រៀននៅក្នុងវគ្គចំណេះចំណានខគម្ពីរបានកាន់តែប្រសើរ ហើយវាធានាថា សេចក្តីពិតទាំងនេះបានដក់ជាប់នៅក្នុងដួងចិត្តរបស់សិស្ស ។ សកម្មភាពខាងក្រោមនេះ អាចជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ដែលបានបង្រៀននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ៖

- ស្តាប់រកមើលវគ្គបទគម្ពីរ—សូមអញ្ជើញសិស្សឲ្យស្តាប់រកមើលវគ្គបទគម្ពីរនៅក្នុងការឡើងនិយាយ និង មេរៀននៅព្រះវិហារ នៅក្នុងសុន្ទរកថានៃសន្និសីទទូទៅ និង នៅក្នុងការពិភាក្សានានាជាមួយគ្រួសារ និង មិត្តភក្តិ ។ យូរៗម្តង សូមអញ្ជើញសិស្សឲ្យរាយការណ៍ពីវគ្គបទគម្ពីរណាដែលពួកគេបានស្តាប់ឮ របៀបដែលគេប្រើវគ្គបទគម្ពីរនោះ សេចក្តីពិតអ្វីខ្លះដែលត្រូវបានបង្រៀន និង បទពិសោធន៍អ្វីខ្លះដែលពួកគេមាន ឬ មនុស្សដទៃទៀតមានពីសេចក្តីពិតដែលត្រូវបានបង្រៀននោះ ។ សូមរកមើលឱកាសនានាដើម្បីថ្លែងទីបន្ទាល់ (ហើយអញ្ជើញសិស្សឲ្យថ្លែងទីបន្ទាល់) ពីសេចក្តីពិតដែលបានបង្រៀនដោយវគ្គចំណេះចំណានខគម្ពីរ ។

សកម្មភាពដែលជួយសិស្សឲ្យ *អនុវត្ត* វគ្គចំណេះចំណានខគម្ពីរ

ការបង្រៀន

វគ្គចំណេះចំណានខគម្ពីរ និង គោលលទ្ធិគ្រឹះត្រូវបានបង្កើតឡើងជាមួយគ្នា ហើយមានបំណងស្របគ្នាសម្រាប់ជាប្រយោជន៍ដល់សិស្ស ។ (វគ្គចំណេះចំណានខគម្ពីរត្រូវបានដាក់ពេញក្នុងឯកសារនៃគោលលទ្ធិគ្រឹះនេះ) ។ នៅពេលសិស្សរៀន និង បង្ហាញគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ នោះពួកគេក៏នឹងរៀន ហើយបង្ហាញពីគោលលទ្ធិគ្រឹះផងដែរ ។ ហើយនៅពេលសិស្សរៀនដើម្បីបង្ហាញពីគោលលទ្ធិគ្រឹះជាពាក្យសម្តីខ្លួនផ្ទាល់ នោះពួកគេអាចពឹងផ្អែកលើការទន្ទេញចាំវគ្គចំណេះចំណានខគម្ពីរ ដើម្បីជួយដល់ពួកគេ ។ ការផ្តល់ឱកាសដល់សិស្សឲ្យបង្រៀនគោលលទ្ធិ និង គោលការណ៍នៃដំណឹងល្អដោយប្រើវគ្គចំណេះចំណានខគម្ពីរ អាចបង្កើនទំនុកចិត្តក្នុងខ្លួនពួកគេ ព្រមទាំងបង្កើនចំណេះដឹងរបស់ពួកគេអំពីព្រះគម្ពីរផងដែរ ។ នៅពេលសិស្សបង្រៀន និង ថ្លែងទីបន្ទាល់ពីគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ នោះពួកគេក៏អាចពង្រឹងទីបន្ទាល់របស់ខ្លួនផងដែរ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើវគ្គចំណេះចំណានខគម្ពីរដើម្បីបង្រៀន និង ពន្យល់ដំណឹងល្អនៅក្នុងថ្នាក់ និង ក្នុងការសន្ទនាជាមួយមិត្តភក្តិ គ្រួសារ និង មនុស្សជាទៃទៀត ។

- បង្ហាញសារលិខិត—សូមចាត់តាំងសិស្សឲ្យរៀបចំការឡើងនិយាយពីបីទៅប្រាំនាទី ឬ រៀបចំមេរៀនដែលផ្តោតលើវគ្គចំណេះចំណានខគម្ពីរ ។ សុំឲ្យពួកគេរៀបចំវានៅថ្នាក់រៀន ឬ នៅផ្ទះ ។ ក្រៅពីវគ្គចំណេះចំណានខគម្ពីរ នោះពួកគេអាចប្រើធនធានផ្សេងៗទៀត ដើម្បីជួយពួកគេឲ្យរៀបចំដូចជា កាតចំណេះចំណានខគម្ពីរ Topical Guide សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ឬ *ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* ។ ការឡើងនិយាយ ឬ មេរៀននីមួយៗគួរតែរួមបញ្ចូលនូវបុព្វកថាវគ្គចំណេះចំណានខគម្ពីរ រឿងមួយ ឬ ឧទាហរណ៍អំពីគោលការណ៍ដែលត្រូវបង្រៀន និង ទីបន្ទាល់របស់សិស្ស ។ សិស្សអាចស្ម័គ្រចិត្តបង្ហាញសារលិខិតរបស់ខ្លួននៅក្នុងថ្នាក់ រាត្រីជួបជុំក្រុមគ្រួសារ ឬ នៅក្នុងក្លឹម ឬ ថ្នាក់នានាដែលជាផ្នែកមួយនៃកិច្চការមកពីសៀវភៅកាតព្វកិច្চចំពោះព្រះ ឬ ការអភិវឌ្ឍន៍ខ្លួន ។ ប្រសិនបើសិស្សបង្ហាញការឡើងនិយាយ ឬ មេរៀនរបស់ពួកគេក្រៅថ្នាក់រៀន នោះសូមគិតពីការអញ្ជើញពួកគេឲ្យប្រាប់ពីបទពិសោធន៍របស់ពួកគេ ។
- ការដើរតួសម្តែងជាអ្នកផ្សព្វផ្សាយសាសនា— សូមរៀបចំកាតមួយចំនួនដែលមានសំណួរផ្សេងៗ ដែលសាសនាគន់គាំអាចសួរ ដែលអាចមានចម្លើយមកពីវគ្គចំណេះចំណានខគម្ពីរ (ឧទាហរណ៍ « តើសមាជិកក្នុងសាសនាចក្ររបស់អ្នកជឿអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ ? ») ។ សូមអញ្ជើញសិស្សជាគូៗឲ្យឡើងមកខាងមុខក្តារខៀន ដើម្បីឆ្លើយនឹងសំណួរ ដែលពីរសចេញមកពីកាតទាំងនោះ ។ ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាអាចឆ្លើយសំណួរស្រដៀងនេះ អ្នកអាចផ្តល់យោបល់ពីវិធីសាស្ត្របង្រៀនមួយចំនួន ដែលមានប្រសិទ្ធភាពដូចជា (១) និយាយពីបរិបទនៃវគ្គបទគម្ពីរ (២) ពន្យល់ពីគោលលទ្ធិ ឬ គោលការណ៍ (៣) សួរសំណួរដើម្បីដឹងថា តើអស់អ្នកដែលពួកគេបង្រៀននោះយល់ ឬ ជឿអ្វីខ្លះដែលពួកគេបង្រៀន (៤) ចែកចាយបទពិសោធន៍ និង ទីបន្ទាល់ និង (៥) អញ្ជើញអ្នកដែលពួកគេបង្រៀនឲ្យអនុវត្តតាមសេចក្តីពិតដែលបានបង្រៀននោះ ។ សូមឲ្យសិស្សផ្តល់មតិយោបល់វិះគន់ក្នុងន័យស្ថាបនា ចំពោះអ្វីដែលពួកគេចូលចិត្តពីរបៀបដែលដៃគូនីមួយៗបានឆ្លើយតបសំណួររបស់គេ ។
- ថ្លែងទីបន្ទាល់—សូមអញ្ជើញសិស្សឲ្យអានវគ្គចំណេះចំណានខគម្ពីរតាំងពីដើមដល់ចប់ ហើយជ្រើសរើសចំណេះចំណានខគម្ពីរមួយដែលមានគោលលទ្ធិ និង គោលការណ៍ដែលពួកគេអាចថ្លែងទីបន្ទាល់បាន ។ សូមអញ្ជើញពួកគេឲ្យថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលពួកគេបានជ្រើសរើស ហើយចែកចាយបទពិសោធន៍ដែលនាំឲ្យពួកគេអាចថ្លែងទីបន្ទាល់ពីវាបាន ។ នៅពេលសិស្សចែកចាយទីបន្ទាល់របស់ពួកគេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់សេចក្តីពិតនៃគោលលទ្ធិ និង គោលការណ៍ដែលពួកគេកំពុងថ្លែងទីបន្ទាល់នោះ ។ ទីបន្ទាល់របស់ពួកគេអាចបំផុសគំនិតដល់មនុស្សជាទៃទៀតឲ្យអនុវត្តដោយសេចក្តីជំនឿដែរ ។

កំណត់ចំណាំ ៖ ឱកាសនានាដែលសិស្សអាចចែកចាយទីបន្ទាល់របស់ពួកគេគួរតែធ្វើឡើងដោយស្ម័គ្រចិត្ត ។ សិស្សមិនគួរត្រូវបានបង្ខំឲ្យចែកចាយទីបន្ទាល់របស់ពួកគេ ឬ ត្រូវបានធ្វើឲ្យមានអារម្មណ៍ថាពួកគេត្រូវតែថ្លែងប្រកាសចំណេះដឹង ដែលពួកគេមានអារម្មណ៍ថា ពួកគេមិនមាននោះឡើយ ។ ក្រៅពីនោះ សិស្សមួយចំនួនស្ទាក់ស្ទើរក្នុងការចែកចាយទីបន្ទាល់របស់ខ្លួនដោយសារពួកគេគិតខុសថា ពួកគេត្រូវតែចាប់ផ្តើមការនិយាយរបស់ខ្លួនដោយនិយាយថា « ខ្ញុំចង់ថ្លែងទីបន្ទាល់របស់ខ្ញុំ. . . » ឬ ថាការបង្ហាញទីបន្ទាល់របស់ពួកគេត្រូវតែធ្វើឡើងដោយការសម្តែងនូវមនោសញ្ចេតនា ។ សូមជួយសិស្សឲ្យយល់ថានៅពេលពួកគេថ្លែងទីបន្ទាល់ នោះពួកគេអាចចែកចាយយ៉ាងសាមញ្ញពីគោលលទ្ធិ ឬ គោលការណ៍នានាដែលពួកគេដឹងថាវាពិត ។ ការចែកចាយទីបន្ទាល់អាចធ្វើឡើងដោយសាមញ្ញដូចជានិយាយថា « ខ្ញុំជឿថាការណ៍នេះពិត » ឬ « ខ្ញុំដឹងការណ៍នេះពិត » ឬ « ខ្ញុំជឿលើការណ៍នេះអស់ពីដួងចិត្តរបស់ខ្ញុំ » ។

ការរស់នៅតាម

ការស្វើពីរបៀបដែលសិស្សអាចអនុវត្តគោលលទ្ធិ និង គោលការណ៍ដែលមាននៅក្នុងវគ្គបទគម្ពីរ (ឬ សូមអញ្ជើញសិស្សឲ្យគិតពីរបៀបនានា) ផ្តល់ឱកាសឲ្យពួកគេរៀនដោយការអនុវត្តសេចក្តីជំនឿ ។

អែលឌើរ ដាវីឌ អេ បែដណា ក្នុងក្លឹមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា

« អ្នករៀនសូត្រដែលកំពុងអនុវត្តសិទ្ធិជ្រើសរើសរបស់ពួកគេតាមរយៈការប្រព្រឹត្តស្របទៅតាមគោលការណ៍ត្រឹមត្រូវនោះ កំពុងតែបើកដួងចិត្តពួកគេឲ្យព្រះវិញ្ញាណបរិសុទ្ធ ហើយអញ្ជើញការបង្រៀនរបស់ទ្រង់ អំណាចនៃការថ្លែងទីបន្ទាល់ និង សាក្សីបញ្ជាក់របស់ទ្រង់ ។ ការរៀនសូត្រតាមរយៈសេចក្តីជំនឿតម្រូវឲ្យមានការខិតខំខាងវិញ្ញាណ ខាងសតិអារម្មណ៍ និង ខាងរូបកាយ មិនមែនគ្រាន់តែទទួលយកដោយអកម្មប៉ុណ្ណោះនោះទេ ។ វាស្ថិតទៅលើសកម្មភាពដែលបំផុសសេចក្តីជំនឿរបស់យើងដោយស្មោះត្រង់ និងខ្ជាប់ខ្ជួនទេតើ ដែលយើងបង្ហាញដល់ព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ នូវឆន្ទៈរបស់យើងដើម្បីរៀនសូត្រ ហើយទទួលការបង្រៀនមកពីព្រះវិញ្ញាណបរិសុទ្ធ » (« Seek Learning by Faith » *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៦៤) ។

សូមផ្តល់ឱកាសឲ្យសិស្សចែកចាយ និង ធ្វើទីបន្ទាល់អំពីបទពិសោធន៍ ដែលពួកគេបានមានក្នុងការអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងនោះ ។ ខាងក្រោមនេះគឺជារបៀបមួយ ដើម្បីលើកទឹកចិត្តសិស្សឲ្យអនុវត្តវគ្គចំណេះចំណានខគម្ពីរនៅក្នុងជីវិតរបស់គេ ៖

- ជាក់គោលដៅ—ដោយផ្អែកលើផ្នែកនៃការអនុវត្តប័ណ្ណនានានៃចំណេះចំណានខគម្ពីរ សូមអញ្ជើញសិស្សឲ្យជាក់គោលដៅជាក់លាក់ ដើម្បីរស់នៅតាមគោលការណ៍ ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះឲ្យបានកាន់តែប្រសើរឡើង ។ សូមឲ្យពួកគេសរសេរគោលដៅរបស់ខ្លួននៅលើក្រដាសមួយសន្លឹក ដែលយកតាមខ្លួន ដើម្បីជាការរំឭក ។ នៅពេលសមរម្យ សូមអញ្ជើញសិស្សឲ្យប្រាប់ពីភាពជោគជ័យរបស់ពួកគេ ។

សកម្មភាពដែលជួយសិស្សឲ្យ *ទន្ទេញចាំ* វគ្គចំណេះចំណានខគម្ពីរ

ការទន្ទេញចាំ

ការទន្ទេញចាំវគ្គបទគម្ពីរអាចធ្វើឲ្យការយល់ និង ការពង្រីកសមត្ថភាពរបស់សិស្សកាន់តែជ្រាលជ្រៅដើម្បីបង្រៀនដំណឹងល្អ ។ នៅពេលសិស្សទន្ទេញចាំខគម្ពីរ នោះព្រះវិញ្ញាណបរិសុទ្ធអាចនាំយ៉ា និង គំនិតនានាឲ្យពួកគេចាំនៅពេលចាំបាច់ (សូមមើល យ៉ូហាន ១៤:២៦; គ. និង ស. ១១:២១) ។ សូមចងចាំដើម្បីសម្របការទន្ទេញចាំនេះ ទៅតាមសមត្ថភាពរបស់សិស្ស ។

អែលឌើរ រីឆាត ជី ស្កត នៃក្លឹមនៃពួកសាវកដប់ពីរនាក់បានលើកទឹកចិត្តឲ្យមានការទន្ទេញចាំខគម្ពីរ នៅពេលលោកថ្លែង ៖

« អំណាចដ៏អស្ចារ្យ អាចមកពីការទន្ទេញចាំខគម្ពីរទាំងឡាយ ។ ដើម្បីទន្ទេញចាំខគម្ពីរមួយ គឺត្រូវបង្កើតមិត្តភាពមួយថ្មី ។ វាគឺដូចជាការកេងបន្លំនូវបុគ្គលថ្មីម្នាក់ ដែលអាចជួយបាននៅពេលត្រូវការ ដោយផ្តល់នូវការបំផុស និង ការលួងលោម ព្រមទាំងជាប្រភពនៃការជំរុញទឹកចិត្ត ដើម្បីធ្វើការផ្លាស់ប្តូរដែលត្រូវការ » (« The Power of Scripture »*Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៦) ។

សកម្មភាពខាងក្រោមនីមួយៗអាចធ្វើដដែលៗបីបួនថ្ងៃផ្ទួនៗគ្នា នៅពេលចាប់ផ្តើមថ្នាក់ ឬ ពេលបញ្ចប់ដើម្បីជួយសិស្សឲ្យទន្ទេញចាំវាបានយូរ ៖

- ប្រដេញពាក្យ—សូមអញ្ជើញសិស្សឲ្យសូត្រវគ្គចំណេះចំណានខគម្ពីរ ម្នាក់មួយពាក្យម្តង ។ ឧទាហរណ៍ នៅពេលជួយសិស្សឲ្យទន្ទេញ ម៉ាថាយ ៥:១៤-១៦ សិស្សទីមួយនឹងនិយាយពាក្យ *អ្នករាល់គ្នា* សិស្សទីពីរនឹងនិយាយពាក្យ *ជា* សិស្សទីបី នឹងនិយាយថា *ពន្លឺ* ហើយនិយាយរហូតដល់ចប់ខគម្ពីរនេះ ។ សូមកំណត់ម៉ោងឲ្យសិស្ស ហើយឲ្យពួកគេព្យាយាមសូត្រាឲ្យបានច្រើនដង រហូតអស់ម៉ោងដែលកំណត់នោះ ។ នៅពេលដែលអ្នក

ធ្វើសកម្មភាពនេះម្តងហើយម្តងទៀត សូមគិតពីការឆ្លាស់វេណសិស្សឲ្យនិយាយពាក្យខុសៗគ្នា ។

- អក្សរដំបូង—សូមសរសេរអក្សរដំបូងនៃពាក្យនីមួយៗពីក្នុងវគ្គចំណេះចំណានខគម្ពីរ ។ សូមចង្អុលអក្សរនោះនៅពេលសិស្សសូត្រវគ្គបទគម្ពីរនោះជាមួយអ្នក ដោយប្រើព្រះគម្ពីរបស់ពួកគេតាមដែលត្រូវការ ។ សូមធ្វើសកម្មភាពនេះដដែលៗ រហូតដល់សិស្សមានអារម្មណ៍ទុកចិត្តលើសមត្ថភាពខ្លួន ដើម្បីសូត្រវគ្គបទគម្ពីរនោះដោយប្រើតែតួអក្សរដំបូងដើម្បីជួយប៉ុណ្ណោះ ។ អ្នកអាចលុបអក្សរពីរបីរាល់ពេលដែលសិស្សសូត្រវគ្គបទគម្ពីរនោះ ។ ការធ្វើបែបនេះនឹងបង្កើនឧបសគ្គសន្សឹមៗ រហូតដល់សិស្សអាចសូត្រវគ្គបទគម្ពីរឡើងវិញ ដោយពុំប្រើតួអក្សរដំបូងឡើយ ។
- ផ្គុំបញ្ជីពាក្យ—សូមសរសេរ ឬ សុំឲ្យសិស្សសរសេរពាក្យនៃវគ្គចំណេះចំណានខគម្ពីរនៅលើបន្ទាត់នៃក្រដាសមួយសន្លឹក ។ សូមកាត់បញ្ជីពាក្យនោះជាជម្រៀក ដោយទុកបន្ទាត់ជួរនៃខគម្ពីរឲ្យនៅជាប់គ្នា ។ សូមកាត់ជម្រៀកពាក្យមួយចំនួនឲ្យខ្លីដើម្បីបញ្ចូលពីរ ឬ បីពាក្យនៃវគ្គបទគម្ពីរលើជម្រៀកពាក្យនីមួយៗ ។ ច្របល់ជម្រៀកពាក្យនោះចូលគ្នា ហើយឲ្យសិស្សចាប់ជាគូៗ ឬ ជាក្រុមតូចៗ ។ សូមអញ្ជើញឲ្យសិស្សរៀបចំជម្រៀកពាក្យនោះតាមលំដាប់ ដោយប្រើព្រះគម្ពីរបស់ពួកគេជាមគ្គុទេស៍ ។ សូមឲ្យពួកគេអនុវត្តវា រហូតដល់ពួកគេឈប់ប្រើព្រះគម្ពីរបស់ខ្លួន ។ បន្ទាប់ពីពួកគេរៀបចប់អស់ហើយ សូមឲ្យពួកគេសូត្រវគ្គបទគម្ពីរនោះឲ្យៗ ។ អ្នកអាចកំណត់ម៉ោងសិស្សដើម្បីដឹងថា តើក្រុមមួយណា ដែលអាចតម្រៀបជម្រៀកពាក្យនោះបានត្រឹមត្រូវតាមលំដាប់បានលឿនជាងគេ ។ ឬ អ្នកអាចដាក់ម៉ោងកំណត់ដល់សិស្សទាំងអស់ ដើម្បីឃើញថាតើក្រុមទាំងនោះប្រើពេលយូរប៉ុណ្ណាដើម្បីផ្គុំជម្រៀកពាក្យនោះចប់ (នៅពេលក្រុមទីមួយចប់ សូមឲ្យពួកគេជួយក្រុមដែលយឺតជាង) ។

វគ្គចំណេះចំណានខគម្ពីរទាំង ១០០

ព្រះគម្ពីរសញ្ញាចាស់	ព្រះគម្ពីរសញ្ញាថ្មី	ព្រះគម្ពីរមរមន	គោលលទ្ធិ និង សេចក្តីសញ្ញា
ម៉ូសេ ១:៣៩	ម៉ាថាយ ៥:១៤–១៦	នីហ្វៃទី១ ៣:៧	ប្រ.— យ.ស. ១:១៥–២០
ម៉ូសេ ៧:១៨	ម៉ាថាយ ១១:២៨–៣០	នីហ្វៃទី២ ២:២៥	គ. និង ស. ១:៣៧–៣៨
អ័ប្រាហាំ ៣:២២–២៣	ម៉ាថាយ ១៦:១៥–១៩	នីហ្វៃទី២ ២:២៧	គ. និង ស. ៦:៣៦
លោកុប្បត្តិ១:២៦–២៧	ម៉ាថាយ ២២:៣៦–៣៩	នីហ្វៃទី២ ៩:២៨–២៩	គ. និង ស. ៨:២-៣
លោកុប្បត្តិ ២:២៤	ម៉ាថាយ ២៨:១៩-២០	នីហ្វៃទី២ ២៥:២៣, ២៦	គ. និង ស. ១០:៥
លោកុប្បត្តិ ៣៩:៩	លូកា ២៤:៣៦-៣៩	ហ្សៃទី២ ២៨:៧-៩	គ. និង ស. ១៣:១
និក្ខមនំ ១៩:៥–៦	យ៉ូហាន ៣:៥	នីហ្វៃទី២ ៣១:១៩-២០	គ. និង ស. ១៨:១០–១១
និក្ខមនំ ២០:៣-១៧	យ៉ូហាន ១៤:៦	នីហ្វៃទី ២ ៣២:៣	គ. និង ស. ១៨:១៥–១៦
យ៉ូស្វេ ២៤:១៥	យ៉ូហាន ១៤:១៥	នីហ្វៃទី ២ ៣២:៨-៩	គ. និង ស. ១៩:១៦–១៩
សាំយ៉ូអែលទី១ ១៦:៧	យ៉ូហាន ១៧:៣	ម៉ូសាយ ២:១៧	គ. និង ស. ១៩:២៣
ទំនុកតម្កើង ២៤:៣–៤	កិច្ចការ ២:៣៦–៣៨	ម៉ូសាយ ៣:១៩	គ. និង ស. ២៥:១៣
ទំនុកតម្កើង ១១៩:១០៥	កិច្ចការ ៣:១៩–២១	ម៉ូសាយ ៤:៣០	គ. និង ស. ៤៦:៣៣
ទំនុកតម្កើង ១២៧:៣	កូរិនថូសទី១ ៦:១៩–២០	អាលម៉ា ៧:១១–១៣	គ. និង ស. ៥៨:២៧
សុភាសិត៣:៥–៦	កូរិនថូសទី១ ១៥:២០-២២	អាលម៉ា ៣២:២១	គ. និង ស. ៥៨:៤២-៤៣
អេសាយ ១:១៨	កូរិនថូសទី១ ១៥:៤០-៤២	អាលម៉ា ៣៧:៣៥	គ. និង ស. ៦៤:៩-១១
អេសាយ ៥:២០	កាឡាទី ៥:២២–២៣	អាលម៉ា ៣៩:៩	គ. និង ស. ៧៦:២២-២៤
អេសាយ ២៩:១៣–១៤	អេភេសូរ ៤:១១–១៤	អាលម៉ា ៤១:១០	គ. និង ស. ៧៦:៤០-៤១
អេសាយ ៥៣:៣-៥	ភីលីព ៤:១៣	ហេលេមិន ៥:១២	គ. និង ស. ៧៨:១៩
អេសាយ ៥៨:៦-៧	ថែស្សាឡូនីចទី ២ ២:១–៣	នីហ្វៃទី៣ ១២:៤៨	គ. និង ស. ៨២:១០
អេសាយ ៥៨:១៣–១៤	ធីម៉ូថេទី២ ៣:១៥–១៧	នីហ្វៃទី៣ ១៨:១៥, ២០–២១	គ. និង ស. ៨៨:១២៤
យេរេមា ១:៤–៥	ហេព្រើរ ១២:៩	អេធើរ ១២:៦	គ. និង ស. ៨៩:១៨-២១
អេសេគាល ៣៧:១៥–១៧	យ៉ាកុប ១:៥–៦	អេធើរ ១២:២៧	គ. និង ស. ១០៧:៨
អេម៉ុស ៣:៧	យ៉ាកុប ២:១៧–១៨	ម៉រ៉ូណៃ ៧:៤១	គ. និង ស. ១២១:៣៦, ៤១–៤២
ម៉ាឡាគី ៣:៨–១០	ពេត្រុសទី១ ៤:៦	ម៉រ៉ូណៃ ៧:៤៥, ៤៧–៤៨	គ. និង ស. ១៣០:២២-២៣
ម៉ាឡាគី ៤:៥-៦	វិវរណៈ ២០:១២	ម៉រ៉ូណៃ ១០:៤–៥	គ. និង ស. ១៣១:១-៤

សេចក្តីណែនាំអំពីគោលលទ្ធិគ្រឹះ

គោលលទ្ធិគ្រឹះខាងក្រោមនេះ គួរត្រូវបានគូសបញ្ជាក់នៅក្នុងថ្នាក់សិក្ខាសាលា ៖

- ក្រុមព្រះ
- ផែនការនៃសេចក្តីសង្គ្រោះ
- ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ
- គ្រាកាន់តាប់ត្រួតត្រា ការស្បត់សាសនា និងការស្ដារឡើងវិញ
- ព្យាការី និង វិវរណៈ
- បព្វជិតភាព និង កូនសោនៃបព្វជិតភាព
- ពិធីបរិសុទ្ធ និងសេចក្តីសញ្ញាទាំងឡាយ
- អាពាហ៍ពិពាហ៍ និង គ្រួសារ
- ព្រះបញ្ញត្តិទាំងឡាយ

គ្រូបង្រៀនជួយសិស្សឲ្យស្គាល់ យល់ ជឿ ពន្យល់ ហើយអនុវត្តតាមគោលលទ្ធិគ្រឹះនៃដំណឹងល្អទាំងនេះ នៅពេលពួកគេសិក្សាព្រះគម្ពីរ ។ ការធ្វើដូច្នោះនឹងជួយសិស្សឲ្យពង្រឹងទីបន្ទាល់ ហើយបង្កើនអំណរគុណរបស់ពួកគេ ចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញនេះ ។ ការរៀនសូត្រពីគោលលទ្ធិគ្រឹះទាំងនេះ ក៏នឹងជួយសិស្សឲ្យរៀបចំខ្លួនបានយ៉ាងប្រសើរ ដើម្បីរស់នៅតាមដំណឹងល្អ និង បង្រៀនពីសារៈសំខាន់នៃសេចក្តីពិតទាំងនេះដល់អ្នកដទៃទៀតផងដែរ ។ មេរៀននៅក្នុងសៀវភៅសិក្សានេះ ត្រូវបានបង្កើតឡើងជាមួយនឹងគោលលទ្ធិគ្រឹះទាំងនេះនៅក្នុងគំនិត ។ វាសំខាន់ដើម្បីទទួលស្គាល់ថា គោលលទ្ធិសំខាន់ផ្សេងទៀតនៃដំណឹងល្អ ក៏នឹងត្រូវបានគូសបញ្ជាក់ផងដែរនៅក្នុងសៀវភៅសិក្សានេះ ទោះបីជាគោលលទ្ធិនោះពុំបានកត់ត្រាក្នុងគោលលទ្ធិគ្រឹះក៏ដោយ ។ ការបង្រៀនពីគោលលទ្ធិគ្រឹះនៃដំណឹងល្អកើតឡើង នៅពេលអ្នកសិក្សាព្រះគម្ពីរាល់ថ្ងៃជាមួយសិស្ស និងនៅពេលអ្នកជួយពួកគេឲ្យសូត្រចាំនូវខគម្ពីរគន្លឹះទាំងនេះ ។ ការយល់ដឹង ការជឿ និងការរស់នៅតាមគោលលទ្ធិគ្រឹះកាន់តែច្រើនគឺជាជំណើរការមួយ ដែលកើតឡើងពេញទាំងបួនឆ្នាំក្នុងថ្នាក់សិក្ខាសាលា ហើយបន្តពេញមួយជីវិតរបស់សិស្ស ។ អ្នកគួរតែផ្តល់ដល់សិស្សនូវបញ្ជីគោលលទ្ធិគ្រឹះ ។

ការវាយតម្លៃគោលលទ្ធិគ្រឹះ

ការវាយតម្លៃគោលលទ្ធិគ្រឹះត្រូវបានបង្កើតឡើងដើម្បីផ្តល់ព័ត៌មានដល់គ្រូបង្រៀន ដែលពួកគេអាចប្រើវាដើម្បីប្រទានពរដល់សិស្សរបស់ខ្លួនកាន់តែច្រើនឡើង ។ យើងសូមផ្តល់ជាអនុសាសន៍ថា គ្រូបង្រៀនធ្វើការវាយតម្លៃនេះ អំឡុងសប្តាហ៍ដំបូងនៃថ្នាក់រៀន ហើយម្តងទៀតនៅចុងឆ្នាំសិក្សា ។ ដើម្បីកែការវាយតម្លៃគោលលទ្ធិគ្រឹះ និងការវាយតម្លៃផ្សេងទៀតនៅលើគេហទំព័រ ស. និង វ. បាន (si.lds.org) សូមស្រាវជ្រាវដោយប្រើពាក្យគន្លឹះ *ការវាយតម្លៃ* ។

គ្រូបង្រៀនដែលបានបញ្ចូនលទ្ធផលនៃការវាយតម្លៃរបស់សិស្សខ្លួនទៅកាន់ការិយាល័យស្រាវជ្រាវនៃ ស. & វ. នឹងទទួលបានរបាយការណ៍មួយ ដែលនឹងជួយសម្រួលការបង្រៀនរបស់ខ្លួន ដើម្បីបំពេញតម្រូវការរបស់សិស្ស ។ ឧទាហរណ៍ ប្រសិនបើលទ្ធផលបង្ហាញថា សិស្សពុំយល់គោលលទ្ធិនៃការប្រែចិត្ត នោះមេរៀនមួយចំនួននៅក្នុងកម្មវិធីឆ្នាំសិក្សាអាចត្រូវបានវិភាគបន្ថែម ដើម្បីអាចជួយសិស្សឲ្យយល់បន្ថែមទៀតអំពីគោលលទ្ធិនេះ ។ នៅពេលគ្រូបង្រៀនប្រើព័ត៌មាននេះ នៅក្នុងការបង្រៀនព្រះគម្ពីរតាមលំដាប់លំដោយប្រកបដោយការអធិស្ឋាន នោះយុវវ័យ និងយុវមជ្ឈិមវ័យរបស់យើងនឹងត្រៀមខ្លួនបានកាន់តែប្រសើរ ដើម្បីសម្រេចបាននូវគោលបំណងរបស់ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនា ។

គោលលទ្ធិគ្រឹះ

គោលលទ្ធិគ្រឹះគួរតែត្រូវបានបង្ហាញទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ។ គ្រូបង្រៀនទាំងឡាយត្រូវជួយសិស្ស ឲ្យស្គាល់ យល់ ជឿ ពន្យល់ ហើយអនុវត្តគោលលទ្ធិគ្រឹះនៃដំណឹងល្អទាំងនេះ ។ ការធ្វើដូច្នោះនឹងជួយសិស្សឲ្យពង្រឹងទីបន្ទាល់ទាំងឡាយ ហើយបង្កើនអំណរគុណរបស់ពួកគេចំពោះដំណឹងល្អដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ ការសិក្សាគោលលទ្ធិគ្រឹះទាំងនេះ ក៏នឹងជួយសិស្សឲ្យរៀបចំបានយ៉ាងប្រសើរ ដើម្បីបង្រៀនពីសារៈសំខាន់នៃសេចក្ដីពិតទាំងនេះដល់អ្នកដទៃទៀតផងដែរ ។

ភាគច្រើននៃវគ្គចំណេះចំណានខគម្ពីរទាំង ១០០ ដែលបានជ្រើសរើសដោយថ្នាក់សិក្ខាសាលា និងវិទ្យាស្ថានសាសនាគឺត្រូវបានជ្រើសរើស ដើម្បីជាជំនួយដល់ការយល់ដឹងពីគោលលទ្ធិគ្រឹះរបស់សិស្សទាំងឡាយ ។ សេចក្ដីយោងបទគម្ពីរភាគច្រើនដែលមានក្នុងឯកសារនេះ សំដៅទៅរកវគ្គចំណេះចំណានខគម្ពីរ ។ វគ្គចំណេះចំណានខគម្ពីរទាំងនេះ ត្រូវបានដាក់បញ្ចូលដើម្បីបង្ហាញពីរបៀប ដែលខទាំងនោះទាក់ទងទៅនឹងគោលលទ្ធិគ្រឹះទាំងឡាយ ។

១. ក្រុមព្រះ

មានតួអង្គបីអង្គ ដែលមានរូបអង្គដាច់ដោយឡែកពីគ្នានៅក្នុងក្រុមព្រះ ៖ ព្រះជាព្រះវរបិតាដ៏អស់កល្ប ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធ (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ៖ ១:១៥—២០) ។ ព្រះវរបិតា និង ព្រះរាជបុត្រាមាននូវរូបកាយជាសាច់ និងឆ្អឹងពិត ហើយព្រះវិញ្ញាណបរិសុទ្ធគឺជាតួអង្គនៃវិញ្ញាណ (សូមមើល គ. និង ស. ១៣០:២២–២៣) ។ ទ្រង់ទាំងបីអង្គមានព្រះរាជបំណង និងគោលលទ្ធិតែមួយ ។ ទ្រង់ទាំងបីអង្គរួមសាមគ្គីគ្នាជិតស្និទ្ធ: ក្នុងការនាំមកនូវផែនការនៃសេចក្ដីសង្គ្រោះដ៏ទេវភាពរបស់ព្រះវរបិតា ។

ព្រះជាព្រះវរបិតា

ព្រះវរបិតាគឺជាអង្គគ្រប់គ្រងដ៏ខ្ពស់បំផុតនៃសាកលលោកនេះ ។ ទ្រង់គឺជាបិតានៃវិញ្ញាណរបស់យើង (សូមមើល ហេព្រើរ ១២:៩) ។ ទ្រង់ល្អឥតខ្ចោះ: មានគ្រប់ទាំងព្រះចេស្ដា និងជ្រាបដឹងនូវគ្រប់ការណ៍ទាំងអស់ ។ ទ្រង់ក៏ជាព្រះនៃក្ដីមេត្តាករុណា សណ្ដោសប្រណី និងក្ដីសប្បុរសដ៏ឥតខ្ចោះផងដែរ ។

ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទគឺជាបុត្រច្បងរបស់ព្រះវរបិតាខាងវិញ្ញាណ ហើយជាព្រះរាជបុត្របង្កើតតែមួយគត់របស់ព្រះវរបិតាខាងសាច់ឈាម ។ ទ្រង់គឺជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់ និងជាព្រះមែស៊ីនៃគម្ពីរសញ្ញាថ្មី ។

ព្រះយេស៊ូវគ្រីស្ទបានរស់នៅក្នុងជីវិតដែលគ្មានអំពើបាប និងបានធ្វើដង្វាយធួនដ៏ល្អឥតខ្ចោះសម្រាប់បាបនៃមនុស្សលោកទាំងអស់ (សូមមើល អាលម៉ា ៧:១១–១៣) ។ ជីវិតរបស់ទ្រង់គឺជាគំរូដ៏ឥតខ្ចោះ: អំពីរបៀបដែលមនុស្សទាំងអស់គួររស់នៅតាម (សូមមើល យ៉ូហាន ១៤:៦, នីហ្វៃទី៣ ១២:៤៨) ។ ទ្រង់គឺជាមនុស្សជំបូងគេបង្អស់ ដែលបានរស់ឡើងវិញនៅលើផែនដីនេះ (សូមមើល កូរិនថូសទី១ ១៥:២០–២២) ។ ទ្រង់នឹងយាងមកម្ដងទៀតដោយព្រះចេស្ដា និងភាពរុងរឿង ហើយនឹងគ្រងលើផែនដីនេះក្នុងអំឡុងពេលសហស្សវត្សរ៍ ។

ការអធិស្ឋាន ពរជ័យ និង ពិធីបរិសុទ្ធនៃបព្វជិតភាពទាំងឡាយត្រូវបានធ្វើឡើងដោយ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ (សូមមើល នីហ្វៃទី៣ ១៨:១៥, ២០–២១) ។

ខគម្ពីរយោងដែលទាក់ទង ៖ ហេលេមិន ៥:១២, គ. និង ស. ១៩:២៣, គ. និង ស. ៧៦:២២–២៤

ព្រះវិញ្ញាណបរិសុទ្ធ

ព្រះវិញ្ញាណបរិសុទ្ធគឺជាសមាជិកទីបីនៃក្រុមព្រះ: ។ ទ្រង់គឺជាតួអង្គនៃវិញ្ញាណដោយគ្មានរូបកាយជាសាច់ និងឆ្អឹងទេ ។ ជាទូទៅទ្រង់ត្រូវបានគេស្គាល់ថាជាព្រះវិញ្ញាណ ជាព្រះវិញ្ញាណបរិសុទ្ធ ជាព្រះវិញ្ញាណនៃព្រះ: ជាព្រះវិញ្ញាណនៃព្រះអម្ចាស់ និង ជាអង្គលួងលោម ។

ព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់អំពីព្រះវរបិតា និងព្រះរាជបុត្រា សម្ដែងសេចក្ដីពិតនៃការណ៍គ្រប់យ៉ាង និងញែកអ្នកទាំងឡាយណាដែលបានប្រែចិត្ត និងទទួលបុណ្យជ្រមុជទឹកឲ្យបានបរិសុទ្ធ (សូមមើល ម៉ូរ៉ូណៃ ១០:៤–៥) ។

ខគម្ពីរយោងដែលទាក់ទង ៖ កាឡាទី ៥:២២–២៣, គ. និង ស. ៨:២–៣

២. ផែនការនៃសេចក្ដីសង្គ្រោះ

នៅក្នុងជីវិតមុនផែនដីនេះ: ព្រះវរបិតាបានបង្ហាញផែនការមួយដើម្បីជួយយើងឲ្យប្រែក្លាយទៅដូចជាទ្រង់ និង ទទួលបានជីវិតអមត និង ជីវិតដ៏នៅអស់កល្បជានិច្ច (សូមមើល ម៉ូសេ ១:៣៩) ។ ព្រះគម្ពីរជាច្រើនបាននិយាយអំពីផែនការនេះថាជាផែនការនៃសេចក្ដីសង្គ្រោះ: ផែនការនៃសុភមង្គលដ៏មហិមា ផែនការនៃសេចក្ដីប្រោសលោះ និង ផែនការនៃក្ដីមេត្តាករុណា ។

ផែនការនៃសេចក្ដីសង្គ្រោះរួមមាន ការបង្កបង្កើត ការធ្លាក់ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ក្រឹត្យវិន័យទាំងអស់ ពិធីបរិសុទ្ធទាំងឡាយ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អ ។ សិទ្ធិជ្រើសរើស—គឺជាលទ្ធភាពដើម្បីជ្រើសរើស និងប្រព្រឹត្តចំពោះខ្លួនយើងផ្ទាល់— គឺជាផ្នែកដ៏សំខាន់នៅក្នុងផែនការនៃព្រះវរបិតាផងដែរ (សូមមើល នីហ្វៃទី២ ២:២៧) ។ ដោយសារផែនការនេះ នោះយើងអាចត្រូវបានធ្វើឲ្យល្អឥតខ្ចោះតាមរយៈដង្វាយធួន ទទួលបានក្ដីអំណរដ៏ពេញលេញ ហើយរស់នៅជារៀងរហូតនៅក្នុងវត្តមាននៃព្រះ: (សូមមើល នីហ្វៃទី៣ ១២:៤៨) ។ ទំនាក់ទំនងគ្រួសាររបស់យើងអាចមានរហូតដល់អស់កល្បជានិច្ច ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូហាន ១៧:៣, គ. និង ស. ៥៨:២៧

ជីវិតមុនឆាកជីវិតនេះ:

ពីមុនយើងបានកើតមកលើផែនដីនេះ: យើងបានរស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌របស់យើង ក្នុងនាមជាកូនចៅវិញ្ញាណរបស់ទ្រង់ (សូមមើល អ័ប្រាហាំ ៣:២២–២៣) ។ នៅក្នុងជីវិតមុនផែនដី យើងបានចូលរួមនៅក្នុងក្រុមប្រឹក្សាមួយជាមួយនឹងកូនចៅវិញ្ញាណផ្សេងទៀតរបស់ព្រះវរបិតាសួគ៌ ។ ក្នុងអំឡុងពេលប្រជុំក្រុមប្រឹក្សានោះ: ព្រះវរបិតាសួគ៌បានបង្ហាញដល់យើងនូវផែនការរបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទពីមុនជីវិតលើផែនដីនេះបានធ្វើសេចក្ដីសញ្ញាដើម្បីធ្វើជាអង្គសង្គ្រោះ: ។

យើងបានប្រើប្រាស់សិទ្ធិជ្រើសរើសរបស់យើង ដើម្បីធ្វើតាមផែនការព្រះវរបិតាសួគ៌ ។ យើងបានរៀបចំខ្លួនដើម្បីមកកាន់ផែនដី ជាទីកន្លែងដែលយើងអាចបន្តវិកចម្រើន ។

អស់អ្នកណាដែលបានធ្វើតាមព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទត្រូវបានអនុញ្ញាតឲ្យមកកាន់ផែនដីនេះ: ដើម្បីទទួលបទពិសោធន៍នៃជីវិតរមែងស្លាប់ និង ហើយរីកចម្រើនទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។ លូស៊ីហ្វើរ ជាកូនវិញ្ញាណនៃព្រះម្នាក់ទៀត ដែលបានដំទាស់ប្រឆាំងនឹងផែនការនេះ: ។ វាបានក្លាយទៅជាសាតាំង ហើយវា និងពួកពលបរិវារទាំងឡាយរបស់វាត្រូវបានបណ្ដេញចេញពីស្ថានសួគ៌ ហើយមិនបានទទួលឯកសិទ្ធិនៃការទទួលបានរូបកាយ និង បទពិសោធន៍នៃជីវិតរមែងស្លាប់ឡើយ ។

ខគម្ពីរយោងដែលទាក់ទង ៖ យេរេមា ១:៤–៥

ការបង្កបង្កើត

ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និង ផែនដីក្រោមការដឹកនាំរបស់ព្រះវរបិតា ។ ផែនដីមិនមែនបង្កើតឡើងពីភាពទទេនោះទេ គឺវាត្រូវបានបង្កើតឡើងពីអ្វីៗដែលមានរួចហើយ ។ ព្រះយេស៊ូវបានបង្កើតពិភពដ៏ច្រើនឥតគណនា (សូមមើល គ. និង ស. ៧៦:២២–២៤) ។

ការបង្កើតផែនដីគឺជាផ្នែកមួយដ៏សំខាន់នៃផែនការរបស់ព្រះ: ។ ផែនដីផ្ដល់ឲ្យយើងនូវកន្លែងដែលយើងអាចទទួលបានរូបកាយ ត្រូវបានសាកល្បង និង ទទួលបទពិសោធន៍ ព្រមទាំងអភិវឌ្ឍនូវតំរិយាបថដ៏ទេវភាព ។

យើងត្រូវតែប្រើប្រាស់នូវធនធានលើផែនដីនេះដោយឈ្លាសវៃ សុភវិនិច្ឆ័យ និង អំណរគុណ (សូមមើល គ. និង ស. ៧៨:១៩) ។

អ័ដាមគឺជាមនុស្សជំបូងគេ ដែលត្រូវបានបង្កើតនៅលើផែនដីនេះ: ។ ព្រះបានបង្កើតអ័ដាម និង អេវ៉ា តាមរូបរាងរបស់អង្គទ្រង់ផ្ទាល់ ។ គ្រប់មនុស្សលោកទាំងអស់—ប្រុស និង ស្រី—ត្រូវបានបង្កើតតាមរូបរាងរបស់ព្រះ: (សូមមើល លោកុប្បត្តិ ១:២៦–២៧) ។

ការធ្លាក់

នៅក្នុងសួនច្បារអេដែន ព្រះបានបញ្ជាដល់អ័ដាម និង អេវ៉ា ថាមិនត្រូវបរិភោគផ្លែឈើដឹងខុស និង ត្រូវឡើយ ព្រោះលទ្ធផលនៃការធ្វើដូច្នោះគឺនឹងត្រូវស្លាប់ខាងវិញ្ញាណ និង ខាងរូបកាយ ។ សេចក្ដីស្លាប់ខាងវិញ្ញាណគឺជាការបែកចេញពីព្រះ: ។ ការស្លាប់ខាងរូបកាយគឺជាការបំបែកចេញរវាងវិញ្ញាណនិងរូបកាយរមែងស្លាប់ ។ ដោយសារតែ អ័ដាម និង អេវ៉ា បានរំលងនូវបញ្ញត្តិរបស់ព្រះ: នោះពួកគេត្រូវបានបណ្ដេញចេញពីវត្តមានរបស់ទ្រង់ ហើយបានក្លាយទៅជាជីវិតរមែងស្លាប់ ។ ការរំលងរបស់ អ័ដាម និង អេវ៉ា ព្រមទាំងលទ្ធផលនៃការផ្លាស់ប្ដូរដែលពួកគេបានជក

ពិសោធន៍ រួមទាំងសេចក្តីស្លាប់ខាងវិញ្ញាណ និង សេចក្តីស្លាប់ខាងរូបកាយ ត្រូវបានហៅថាការធ្លាក់ ។

ដោយសារលទ្ធផលនៃការធ្លាក់ នោះអ័ដាម និង អេវ៉ា និងពូជពង្សរបស់ពួកគេអាចទទួលបាននូវភាពរីករាយ និង ទុក្ខព្រួយ ដឹងខុស និង ត្រូវ ហើយមានកូនចៅ (សូមមើល នីហ្វៃទី២ ២:២៥) ។ ក្នុងនាមជាកូនចៅរបស់ អ័ដាម និង អេវ៉ា នោះយើងទទួលបាននូវលក្ខខណ្ឌនៃការធ្លាក់ក្នុងអំឡុងពេលជីវិតរមែងស្លាប់នេះ: ។ យើងត្រូវបានបែកចេញពីវត្តមាននៃព្រះអម្ចាស់ និងត្រូវតែស្លាប់ខាងរូបកាយ ។ យើងក៏ត្រូវបានសាកល្បងដោយភាពលំបាកនៃជីវិត និង ការល្បួងនៃមាសត្រូវផងដែរ ។ (សូមមើល ម៉ូសាយ ៣:១៩) ។

ការធ្លាក់គឺជាផ្នែកមួយដ៏សំខាន់នៃផែនការសង្គ្រោះរបស់ព្រះវរបិតាសួគ៌ទាំងមូល។ វាមានទិសដៅពីរ—ចុះក្រោម ប៉ុន្តែទៅមុខ ។ ក្រៅពីនាំឲ្យមានការស្លាប់ខាងរូបកាយ និង វិញ្ញាណការធ្លាក់បានផ្តល់ឲ្យយើងនូវឱកាសដើម្បីកើតមកលើផែនដីនេះ ដើម្បីរៀន និង រីកចម្រើន ។

ជីវិតរមែងស្លាប់

ជីវិតរមែងស្លាប់គឺជាពេលវេលានៃការរៀនសូត្រ នៅពេលយើងអាចរៀបចំសម្រាប់ជីវិតដ៏នៅអស់កល្ប និង ដើម្បីបង្ហាញថា យើងនឹងប្រើប្រាស់នូវសិទ្ធិជ្រើសរើសរបស់យើង ដើម្បីធ្វើអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា ។ ក្នុងអំឡុងពេលនៃជីវិតរមែងស្លាប់នេះ: យើងត្រូវតែស្រឡាញ់ និង បម្រើគ្នាទៅវិញទៅមក (សូមមើល ម៉ូសាយ ២:១៧, ម៉រ៉ូណៃ ៧:៤៥, ៤៧–៤៨) ។

នៅក្នុងជីវិតរមែងស្លាប់ វិញ្ញាណរបស់យើងត្រូវបានរួមគ្នាជាមួយនឹងរូបកាយរបស់យើង ដោយផ្តល់ឲ្យយើងនូវឱកាសដើម្បីរីកចម្រើន និង អភិវឌ្ឍតាមវិធីជាច្រើនដែលមិនអាចកើតមានបានឡើយនៅក្នុងជីវិតមុនផែនដីនេះ: ។ រូបកាយរបស់យើងគឺជាផ្នែកមួយដ៏សំខាន់នៃផែនការនៃសេចក្តីសង្គ្រោះ: ហើយថារូបកាយនេះគួរតែត្រូវបានគោរពដោយយកចិត្តទុកដាក់ ថាជាអំណោយមួយមកពីព្រះវរបិតាសួគ៌របស់យើង (សូមមើល កូរិនថូសទី ១ ៦:១៩–២០) ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូស្វេ ២៤:១៥, ម៉ាថាយ ២២:៣៦–៣៩, នីហ្វៃទី ២ ២៨:៧–៩, អាលម៉ា ៤១:១០, គ. និង ស. ៥៨:២៧

ជីវិតក្រោយការស្លាប់

នៅពេលយើងស្លាប់ វិញ្ញាណរបស់យើងចូលទៅក្នុងពិភពវិញ្ញាណ ហើយរង់ចាំការរស់ឡើងវិញ ។ វិញ្ញាណនៃពួកសុចរិតត្រូវបានទទួលចូលទៅក្នុងស្ថានភាពនៃសុភមង្គល ដែលត្រូវបានហៅថា ស្ថានបរមសុខ ។ មានពួកអ្នកស្មោះត្រង់ជាច្រើននឹងផ្សាយដំណឹងល្អទៅកាន់អ្នកទាំងនោះនៅក្នុងស្ថានឃុំព្រលឹង ។

ស្ថានឃុំព្រលឹងគឺជាកន្លែងបណ្តោះអាសន្ន នៅក្នុងពិភពក្រោយពីជីវិតរមែងស្លាប់ សម្រាប់អ្នកទាំងឡាយណា ដែលស្លាប់ទៅដោយមិនបានដឹងអំពីសេចក្តីពិត និង សម្រាប់អ្នកទាំងឡាយណាដែលមិនបានគោរពប្រតិបត្តិនៅក្នុងជីវិតរមែងស្លាប់ ។ នៅទីនោះ: វិញ្ញាណទាំងឡាយត្រូវបានបង្រៀនដំណឹងល្អ ហើយមានឱកាសដើម្បីប្រែចិត្ត និងទទួលពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ: ដែលត្រូវបានធ្វើឡើងសម្រាប់ពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ (សូមមើល ពេត្រុសទី១ ៤:៦) ។ អ្នកទាំងឡាយណាដែលទទួលយកដំណឹងល្អ នឹងរស់នៅក្នុងស្ថានបរមសុខរហូតដល់ការរស់ឡើងវិញ ។

ការរស់ឡើងវិញគឺជាការរួមបញ្ចូលគ្នាវិញនៃរូបកាយជាវិញ្ញាណរបស់យើង ជាមួយនឹងរូបកាយជាសាច់ និងឆ្អឹងរបស់យើង (សូមមើល លូកា ២៤:៣៦–៣៩) ។ ក្រោយពីការរស់ឡើងវិញ វិញ្ញាណ និង រូបកាយនឹងមិនបែកចេញពីគ្នាទៀតឡើយ ហើយយើងនឹងក្លាយទៅជាអមតៈ ។ មនុស្សគ្រប់រូបកើតមកលើផែនដីនឹងត្រូវបានរស់ឡើងវិញ ពីព្រោះព្រះយេស៊ូវគ្រីស្ទបានយកឈ្នះលើសេចក្តីស្លាប់ (សូមមើល កូរិនថូសទី ១ ១៥:២០–២២) ។ ពួកសុចរិតនឹងរស់ឡើងវិញមុនពួកទុច្ចរិត ហើយពួកគេរស់ឡើងវិញនៅក្នុងដំណើរអស់ឡើងវិញទីមួយ ។

សេចក្តីជំនុំជម្រះចុងក្រោយ នឹងកើតឡើងបន្ទាប់ពីការរស់ឡើងវិញ ។ ព្រះយេស៊ូវគ្រីស្ទនឹងកាត់សេចក្តីមនុស្សគ្រប់រូប ដើម្បីកំណត់នូវសេចក្តីរុងរឿងដ៏អស់កល្បដែលបុគ្គលនោះនឹងទទួលបាន ។ ការកាត់សេចក្តីនេះនឹងផ្អែកទៅលើការគោរពប្រតិបត្តិរបស់បុគ្គលម្នាក់ៗតាមព្រះបញ្ញត្តិរបស់ព្រះ: (សូមមើល វិវរណៈ ២០:១២, ម៉ូសាយ ៤:៣០) ។

មាននគរនៃសិរីល្អបី (សូមមើល កូរិនថូសទី ១ ១៥:៤០–៤២) ។ នគរដែលខ្ពស់ជាងគេនោះគឺនគរសេឡេស្ទាល ។ អ្នកទាំងឡាយណាដែលមានសេចក្តីភ្លាហាន ក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង គោរពប្រតិបត្តិតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ នឹងរស់នៅក្នុងនគរសេឡេស្ទាលក្នុងវត្តមាននៃព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ (សូមមើល គ. និង ស. ១៣១:១–៤) ។

នគរទីពីរនៃនគរសិរីល្អទាំងបីគឺនគរទេវរេសទ្រាល ។ អ្នកទាំងឡាយណាដែលរស់នៅក្នុងនគរនេះនឹងជាបុរស និង ស្ត្រីណាដែលរស់នៅដោយសុចរិតទៀងត្រង់ តែមិនមានសេចក្តីភ្លាហានក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវ ។

នគរទេឡេស្ទាលគឺជានគរដែលខាងបំផុតក្នុងចំណោមនគរនៃសិរីល្អទាំងបី ។ អ្នកទាំងឡាយណាដែលទទួលបាននគរនេះនឹងជាអស់អ្នកដែលជ្រើសរើសសេចក្តីទុច្ចរិតជាជាងជ្រើសរើសសេចក្តីសុចរិត កាលរស់នៅក្នុងជីវិតរមែងស្លាប់របស់ពួកគេ ។ បុគ្គលទាំងនេះនឹងទទួលសិរីល្អរបស់ពួកគេ បន្ទាប់ពីត្រូវបានសង្គ្រោះពីស្ថានឃុំព្រលឹង ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូហាន ១៧:៣

៣. ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

ការធ្វើឲ្យធួនគឺរងទារណ្ឌកម្មនៃអំពើបាប ហេតុដូច្នេះហើយ តាមរយៈការណ៍នេះ: វាជាកន្លែងនូវតិទ្ធលនៃអំពើបាបចេញពីអ្នកប្រែចិត្តពីអំពើបាប និងអនុញ្ញាតឲ្យបុគ្គលនោះត្រូវបានផ្សះផ្សារឡើងវិញជាមួយនឹងព្រះ: ។ មានតែព្រះយេស៊ូវគ្រីស្ទមួយអង្គគត់ ដែលមានសមត្ថភាពធ្វើដង្វាយធួនដ៏ឥតខ្ចោះសម្រាប់មនុស្សលោកទាំងអស់ ។ ដង្វាយធួនរបស់ទ្រង់គឺរួមមាន ការរងទុក្ខរបស់ទ្រង់ក្នុងសួនច្បារគែតសេម៉ានី សម្រាប់អំពើបាបនៃមនុស្សលោកទាំងអស់ ការបង្ហូរព្រះលោហិតរបស់ទ្រង់ ការរងការឈឺចាប់ និង ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង និងការរស់ឡើងវិញពីផ្នូររបស់ទ្រង់ (សូមមើល លូកា ២៤:៣៦–៣៩, គ. និង ស. ១៩:១៦–១៩) ។ ព្រះអង្គសង្គ្រោះមានសមត្ថភាពធ្វើដង្វាយធួននេះ: ពីព្រោះទ្រង់បានក្បាអង្គទ្រង់ចៀសពីអំពើបាប និងមានអំណាចឈ្នះលើសេចក្តីស្លាប់ ។ ដោយសារទ្រង់មានមាតាដែលមានជីវិតរមែងស្លាប់ នោះទ្រង់ទទួលមរតកនៃសេចក្តីស្លាប់ ។ ដោយសារទ្រង់មានបិតាដែលមានជីវិតអមត នោះទ្រង់មានអំណាចដើម្បីនឹងយកព្រះជន្មរបស់ទ្រង់មកវិញម្តងទៀត ។

តាមរយៈព្រះគុណ នោះដង្វាយធួនរបស់ព្រះអង្គសង្គ្រោះធ្វើឲ្យមនុស្សទាំងអស់នឹងរស់ឡើងវិញ ហើយទទួលបាននូវជីវិតអមតៈ ។ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទក៏អាចធ្វើឲ្យយើងទទួលបាននូវជីវិតដ៏អស់កល្បផងដែរ (សូមមើល ម៉ូរ៉ូណៃ ៧:៤១) ។ ដើម្បីទទួលបាននូវអំណោយទាននេះ: យើងត្រូវតែរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលរួមមាន ការមានសេចក្តីជំនឿលើទ្រង់ ការប្រែចិត្តពីអំពើបាបរបស់យើង ការទទួលបុណ្យជ្រមុជទឹក ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និងប្រកាន់ខ្ជាប់ដោយស្មោះត្រង់រហូតដល់ទីបំផុត (សូមមើល យ៉ូហាន ៣:៥) ។

ជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ នោះព្រះយេស៊ូវគ្រីស្ទ មិនត្រឹមតែរងទុក្ខសម្រាប់អំពើបាបរបស់យើងប៉ុណ្ណោះទេ ថែមទាំងលើកមកដាក់លើព្រះអង្គទ្រង់នូវការឈឺចាប់ ជម្ងឺ និងពេគាទាំងឡាយរបស់មនុស្សគ្រប់រូប (សូមមើល អាលម៉ា ៧:១១–១៣) ។ ទ្រង់យល់អំពីការឈឺចាប់របស់យើង ពីព្រោះទ្រង់បានទទួលនូវបទពិសោធន៍នៃការឈឺចាប់នោះ: ។ ព្រះគុណ ឬអំណាចដែលអាចធ្វើទៅបានរបស់ទ្រង់ ពង្រឹងយើងដើម្បីអាចរងនូវបន្ទុក និង សម្រេចបានកិច្ចការមួយចំនួន ដែលយើងមិនអាចធ្វើដោយខ្លួនយើងផ្ទាល់ (សូមមើល ម៉ាថាយ ១១:២៨–៣០, កីលីព ៤:១៣, អេធើរ ១២:២៧) ។

ខគម្ពីរយោងដែលទាក់ទង ៖ យ៉ូហាន ៣:៥, កិច្ចការ ៣:១៩–២១

សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ

សេចក្តីជំនឿគឺជា « សេចក្តីសង្ឃឹមទៅលើអ្វីៗដែលមើលមិនឃើញ ហើយដែលពិត » (អាលម៉ា ៣២:២១, សូមមើលផងដែរ អេធើរ ១២:៦) ។ វាជាអំណោយទានពីព្រៈ ។

សេចក្តីជំនឿត្រូវតែផ្តោតទៅលើព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យសេចក្តីជំនឿនោះដឹកនាំបុគ្គលនោះទៅរកសេចក្តីសង្គ្រោះ: ។ ការមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទមានន័យថា ការពឹងផ្អែកទាំងស្រុងទៅលើទ្រង់ និង ទុកចិត្តលើដង្វាយធួន អំណាច និងសេចក្តីស្រឡាញ់ដ៏គ្មានដែនកំណត់របស់ទ្រង់ ។ វារួមទាំងការជឿលើការបង្រៀនរបស់ទ្រង់ និង ការជឿមួយ សូម្បីតែយើងមិនយល់អំពីអ្វីៗទាំងអស់ដែលទ្រង់ធ្វើក៏ដោយ (សូមមើល សុភាសិត ៣:៥–៦, គ. និង ស. ៦:៣៦) ។

សេចក្តីជំនឿត្រូវបង្ហាញតាមរបៀបដែលយើងរស់នៅ ជាជាងសេចក្តីជំនឿដែលគ្មានការប្រព្រឹត្ត (សូមមើល យ៉ាកុប ២:១៧–១៨) ។ សេចក្តីជំនឿអាចរីកចម្រើនឡើង នៅពេលយើងអធិស្ឋាន សិក្សាព្រះគម្ពីរ និងគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រៈ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយក៏មានសេចក្តីជំនឿលើព្រះវរបិតា ព្រះវិញ្ញាណបរិសុទ្ធ និងអំណាចបព្វជិតភាព ព្រមទាំងចំណុចសំខាន់ៗដទៃទៀតនៃដំណឹងល្អ ដែលបានស្តារឡើងវិញផងដែរ ។ សេចក្តីជំនឿជួយយើងឲ្យទទួលបាននូវការព្យាបាលខាងវិញ្ញាណ និងខាងរូបកាយ ដើម្បីឈានទៅមុខ ប្រឈមមុខនឹងការលំបាករបស់យើង និង យកឈ្នះទៅលើសេចក្តីល្បួង (សូមមើល នីហ្វៃទី២ ៣១:១៩–២០) ។ ព្រះអម្ចាស់នឹង

សម្តែងនូវអត្ថហេតុដ៏អស្ចារ្យនៅក្នុងជីវិតរបស់យើង ស្របតាមសេចក្តីជំនឿរបស់យើង ។

តាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះបុគ្គលម្នាក់អាចទទួលបាននូវការផ្តាច់បាប ហើយនៅទីបំផុតអាចនឹងរស់នៅក្នុងវត្តមាននៃព្រះ ។

ខគម្ពីរយោងដែលទាក់ទង ៖ ម៉ាថាយ ១១:២៨–៣០

ការប្រែចិត្ត

ការប្រែចិត្តគឺជាការផ្លាស់ប្តូរនៃគំនិត និង ចិត្តដែលផ្តល់ដល់យើងនូវទិដ្ឋភាពថ្មីអំពីព្រះ អំពីខ្លួនរបស់យើងផ្ទាល់ និង អំពីពិភពលោកនេះ ។ វារួមមានការបែរចេញពីអំពើបាប ហើយបែរទៅរកព្រះសម្រាប់ការអភ័យទោស ។ វាត្រូវបានទាក់ទាញទឹកចិត្តដោយសេចក្តីស្រឡាញ់ចំពោះព្រះ និងបំណងប្រាថ្នាដ៏ពិតប្រាកដដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

អំពើបាបរបស់យើងធ្វើឲ្យយើងមិនស្អាត—មិនសក្តិសមដើម្បីត្រឡប់ទៅ និង រស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌របស់យើងវិញ ។ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះព្រះវរបិតាដែលគង់នៅឋានសួគ៌របស់យើងបានប្រទាននូវវិធីតែមួយគត់ដល់យើង ដើម្បីទទួលបានការអភ័យបាប (សូមមើល អេសាយ ១:១៨) ។

ការប្រែចិត្តរួមមានទាំងអារម្មណ៍នៃការសោកស្តាយចំពោះការប្រព្រឹត្តអំពើបាប សារភាពទៅកាន់ព្រះវរបិតាសួគ៌របស់យើង និងទៅកាន់អ្នកដទៃទៀតដែលចាំបាច់ លះបង់ចោលអំពើបាប ស្វែងរកការស្តារឡើងវិញតាមដែលអាចធ្វើទៅបានចំពោះអ្វីៗដែលបានខូចខាតដោយសារអំពើបាបរបស់នរណាម្នាក់ និង រស់នៅដោយគោរពតាមព្រះបញ្ញត្តិរបស់ព្រះ (សូមមើល គ. និង ស. ៥៨:៤២–៤៣) ។

ខគម្ពីរយោងដែលទាក់ទង ៖ អេសាយ ៥៣:៣–៥, យ៉ូហាន ១៤:៦, នីហ្វៃទី២ ២៥:២៣, ២៦, គ. និង ស. ១៨:១០–១១, គ. និង ស. ១៩:២៣, គ. និង ស. ៣៦:៤០–៤១

៤. គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និងការស្តារឡើងវិញ

គ្រាកាន់កាប់ត្រួតត្រា

គ្រាកាន់កាប់ត្រួតត្រា គឺជាអំឡុងពេលដែលព្រះអម្ចាស់ត្រាស់សម្តែងគោលលទ្ធិ ពិធីបរិសុទ្ធនានា និង បព្វជិតភាពរបស់ទ្រង់ ។ វាគឺជាអំឡុងពេលមួយ ដែលយ៉ាងហោចណាស់ ព្រះអម្ចាស់មានអ្នកបម្រើដែលបានទទួលសិទ្ធិអំណាចម្នាក់នៅលើផែនដី ដែលកាន់បព្វជិតភាពបរិសុទ្ធ និង ជាអ្នកដែលមាននូវការអនុញ្ញាតពីព្រះដើម្បីចែកចាយដំណឹងល្អ និង ដើម្បីចាត់ចែងពិធីបរិសុទ្ធដែលមានក្នុងដំណឹងល្អនោះ ។ សព្វថ្ងៃនេះ យើងកំពុងរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយ—ជាគ្រាកាន់កាប់ត្រួតត្រាដែលពេញកំណត់ ដែលបានចាប់ផ្តើមជាមួយនឹងវិវរណៈនៃដំណឹងល្អទៅកាន់ យ៉ូសែប ស៊្មីធ ។

គ្រាកាន់កាប់ត្រួតត្រាមុនៗត្រូវបានគេស្គាល់ថាជាគ្រាកាន់កាប់ត្រួតត្រាជាមួយ អ័ដាម ណូអេ អ័ប្រាហាំ ម៉ូសេ និង ព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះ មាននូវគ្រាកាន់កាប់ត្រួតត្រាជាទៃផ្សេងទៀតជាច្រើន រួមមាននូវគ្រាកាន់កាប់ត្រួតត្រាក្នុងចំណោមសាសន៍នីហ្វៃ និង សាសន៍យ៉ារ៉ែឌ ។ ផែនការនៃសេចក្តីសង្គ្រោះ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានបើកសម្តែង និងបង្រៀននៅក្នុងគ្រប់គ្រាកាន់កាប់ត្រួតត្រាទាំងអស់ ។

ការក្បត់សាសនា

នៅពេលមនុស្សបែរចេញពីគោលការណ៍នៃដំណឹងល្អ និងមិនមានកូនសៅនៃបព្វជិតភាពទេនោះ ពួកគេស្ថិតនៅក្នុងការក្បត់សាសនា ។

ពេលវេលាការក្បត់សាសនាទូទៅ បានកើតឡើងពេញអស់ទាំងប្រវត្តិសាស្ត្រនៃពិភពលោក ។ ឧទាហរណ៍មួយគឺការក្បត់សាសនាដ៏ធំ ដែលបានកើតឡើងបន្ទាប់ពីព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្ររបស់ទ្រង់ (សូមមើល ថែស្សាឡូនិចទី ២ ២:១–៣) ។ បន្ទាប់ពីការស្លាប់នៃពួកសាវករបស់ព្រះអង្គសង្គ្រោះ គោលការណ៍ទាំងឡាយនៃដំណឹងល្អត្រូវបានខូចបង់ ហើយការផ្លាស់ប្តូរដែលគ្មានការអនុញ្ញាតបានកើតឡើងនៅក្នុងអង្គការសាសនាចក្រ និង ពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាព ។ ដោយសារការរីករាលដាលនៃភាពទុច្ចរិតនោះ ព្រះអម្ចាស់បានដកយកសិទ្ធិអំណាច និង កូនសោទាំងឡាយនៃបព្វជិតភាពចេញពីផែនដី ។

ក្នុងអំឡុងពេលនៃការក្បត់សាសនាដ៏ធំនេះ គឺមនុស្សរស់នៅដោយគ្មាននូវការដឹកនាំពីព្រះតាមរយៈព្យាការីនៅរស់នោះទេ ។ មានព្រះវិហារជាច្រើនត្រូវបានស្ថាបនាឡើង ប៉ុន្តែពួកគេគ្មាននូវសិទ្ធិអំណាចដើម្បីប្រគល់នូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ឬ ធ្វើពិធីបរិសុទ្ធនៃបព្វជិតភាពផ្សេងៗទៀតបានឡើយ ។ ផ្នែកមួយចំនួននៃព្រះគម្ពីរបរិសុទ្ធត្រូវបានខូច និងបាត់បង់ ហើយមនុស្សលែងមាននូវភាពត្រឹមត្រូវនៃការយល់ដឹងពីព្រះទៀតហើយ ។

ការក្បត់សាសនានេះបានកើតឡើងរហូតដល់ពេលព្រះវរបិតាសួគ៌ និង ព្រះរាជបុត្រាសំណព្វទ្រង់បានយាងមកជួប យ៉ូសែប ស៊្មីធ និង បានចាប់ផ្តើមការស្តារភាពពេញលេញនៃដំណឹងល្អឡើងវិញ ។

ការស្តារឡើងវិញ

ការស្តារឡើងវិញគឺជាការកោះស្ថាបនាឡើងវិញរបស់ព្រះនៃសេចក្តីពិត និង ពិធីបរិសុទ្ធនៃដំណឹងល្អរបស់ទ្រង់ក្នុងចំណោមកូនចៅរបស់ទ្រង់នៅលើផែនដីនេះ (សូមមើល កិច្ចការ ៣:១៩–២១) ។

នៅក្នុងការរៀបចំសម្រាប់ការស្តារឡើងវិញ ព្រះអម្ចាស់បានលើកពួកបុរសសុចរិតឡើងក្នុងអំឡុងពេលមួយដែលគេហៅថា ការសាងឡើងវិញ ។ ពួកគេបានមកបំណងដើម្បីបែរទៅរកគោលលទ្ធិ ការអនុវត្ត និងការរៀបចំសាសនាទៅតាមរបៀបដែលព្រះអង្គសង្គ្រោះបានស្ថាបនាឡើង ។ ទោះជាយ៉ាងនោះក្តី ពួកគេពុំមានបព្វជិតភាព ឬភាពពេញលេញនៃដំណឹងល្អនោះទេ ។

ការស្តារឡើងវិញបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៨២០ នៅពេលព្រះជាព្រះវរបិតា និងព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ បានបង្ហាញអង្គទ្រង់ដល់ យ៉ូសែប ស៊្មីធ ក្នុងការឆ្លើយតបចំពោះការអធិស្ឋានរបស់លោក (សូមមើល យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១៥–២០) ។ ព្រឹត្តិការណ៍សំខាន់ៗមួយចំនួនទៀតការស្តារឡើងវិញ គឺការបកប្រែព្រះគម្ពីរមរមន ការស្តារឡើងវិញនៃបព្វជិតភាពអើរ៉ុន និង មិលគីស្សាដែក និង ការរៀបចំសាសនាចក្រនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។

បព្វជិតភាពអើរ៉ុនត្រូវបានស្តារឡើងវិញដល់យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ដោយ យ៉ូហាន បាទីស្ទ នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៨២៩ ។ បព្វជិតភាពមិលគីស្សាដែក និង កូនសោទាំងឡាយនៃនគរត្រូវបានស្តារឡើងវិញនៅក្នុងឆ្នាំ ១៨២៩ នៅពេលដែលសាវក ពេត្រុស យ៉ាកុប និង យ៉ូហាន បានប្រគល់កូនសោទាំងនោះដល់ យ៉ូសែប ស៊្មីធ និង អូលីវើរ ខៅឌើរី ។

ភាពពេញលេញនៃដំណឹងល្អត្រូវបានស្តារឡើងវិញ ហើយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជា « សាសនាចក្រតែមួយដែលពិត ហើយសកម្មនៅលើផ្ទៃផែនដីទាំងមូល » (គ. និង ស. ១:៣០) ។ នៅទីបំផុត សាសនាចក្រនឹងមានពាសពេញផ្ទៃផែនដី និងឈរឡើងជារៀងរហូត ។

ខគម្ពីរយោងដែលទាក់ទង ៖ អេសាយ ២៩:១៣–១៤, អេសេគាល ៣៧:១៥–១៧, អេភេសូ ៤:១១–១៤, យ៉ាកុប ១:៥–៦

៥. ព្យាការី និង វិវរណៈ

ព្យាការីគឺជាមនុស្សម្នាក់ដែលត្រូវបានហៅដោយព្រះ ដើម្បីនិយាយជំនួសទ្រង់ (សូមមើល អេម៉ុស ៣:៧) ។ ពួកព្យាការីទាំងឡាយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងបង្រៀនដំណឹងល្អរបស់ទ្រង់ ។ ពួកលោកបង្ហាញឲ្យស្គាល់នូវព្រះហឫទ័យ និងចរិតលក្ខណៈពិតរបស់ព្រះ ។ ពួកលោកប្រាប់អំពីអំពើបាប និងព្រមានអំពីផលវិបាកនៃអំពើបាប ។ ជាច្រើនលើក ពួកលោកបានព្យាករពីព្រឹត្តិការណ៍នាពេលអនាគត (សូមមើល គ. និង ស. ១:៣៧–៣៨) ។ ការបង្រៀនជាច្រើនរបស់ព្យាការីគឺមាននៅក្នុងព្រះគម្ពីរនានា ។ នៅពេលយើងសិក្សាប្រសាសន៍របស់ព្យាការី នោះយើងអាចរៀនសេចក្តីពិត និងទទួលបាននូវការណែនាំ (សូមមើល នីហ្វៃទី២ ៣២:៣) ។

យើងគាំទ្រប្រធាននៃសាសនាចក្រជា ព្យាការី អ្នកមើលធុត និង ជាអ្នកទទួលវិវរណៈ និង ជាបុរសតែម្នាក់គត់នៅលើផែនដី ដែលទទួលបានវិវរណៈដើម្បីដឹកនាំសាសនាចក្រនេះទាំងមូល ។ យើងក៏គាំទ្រដល់ទីប្រឹក្សាទាំងឡាយនៅក្នុងគណៈប្រធានទីមួយ និង សមាជិកនៃក្រុមនៃពួកសាវកដប់ពីរនាក់ជាព្យាការី អ្នកមើលធុត និង ជាអ្នកទទួលវិវរណៈផងដែរ ។

វិវរណៈគឺជាទំនាក់ទំនងរវាងព្រះទៅកាន់កូនចៅរបស់ទ្រង់ ។ នៅពេលព្រះអម្ចាស់បើកសម្តែងព្រះឆន្ទៈរបស់ទ្រង់ទៅកាន់សាសនាចក្រ នោះទ្រង់មានព្រះបន្ទូលតាមរយៈព្យាការីរបស់ទ្រង់ ។ ព្រះគម្ពីរនានា—ព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន គោលលទ្ធិ និង សេចក្តីសញ្ញា និង មុក្តាដ៏មានតម្លៃមហិមា—មាននូវវិវរណៈទាំងឡាយ ដែលបានផ្តល់ឲ្យតាមរយៈព្យាការីពីបុរាណ និង ព្យាការីថ្ងៃចុងក្រោយ ។ ប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជាព្យាការីរបស់ព្រះនៅលើផែនដីនាសព្វថ្ងៃនេះ ។

បុគ្គលម្នាក់ៗអាចទទួលវិវរណៈដើម្បីជួយពួកគេជាមួយនឹងសេចក្តីត្រូវការ ការទទួលខុសត្រូវ និង សំណួរដាក់លាក់ទាំងឡាយរបស់ពួកគេ និង ដើម្បីជួយពង្រឹងទីបន្ទាល់របស់ពួកគេ ។ វិវរណៈដែលកើតមានចំពោះពួកអ្នកដឹកនាំ និងសមាជិកសាសនាចក្រ ភាគច្រើនកើតឡើងតាមរយៈចំណាប់អារម្មណ៍ និង គំនិតទាំងឡាយដែលបានមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលទៅកាន់គំនិត និង ដួងចិត្តរបស់យើងជាសំឡេងដ៏តូចរហៀង (សូមមើល គ. និង ស. ៨:២–៣) ។ វិវរណៈអាចកើតមានតាមរយៈការនិមិត្ត សុបិន និង ការយាងមកជួបពីពួកទេវតាផងដែរ ។

ខគម្ពីរយោងដែលទាក់ទង ៖ ទំនុកដំកើង ១១៩:១០៥, អេភេសូ ៤:១១–១៤, ធីម៉ូថេទី២ ៣:១៥–១៧, យ៉ាកុប១:៥–៦, មរ៉ូណៃ ១០:៤–៥

៦. បព្វជិតភាព និង កូនសៅនៃបព្វជិតភាព

បព្វជិតភាពគឺជាអំណាច និង ជាសិទ្ធិអំណាចដ៏អស់កល្ប របស់ព្រះ ។ តាមរយៈបព្វជិតភាព ព្រះបានបង្កើត និង គ្រប់គ្រងស្ថានសួគ៌ព្រមទាំងផែនដីផងដែរ ។ តាមរយៈអំណាច នេះ នោះទ្រង់បានប្រោសលោះ និងតម្កើងកូនចៅរបស់ទ្រង់ ដើម្បីនាំឲ្យមាន « អមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ដល់មនុស្ស » (ម៉ូសេ ១:៣៩) ។

ព្រះប្រទានសិទ្ធិអំណាចបព្វជិតភាពដល់បុរសជាសមាជិកនៃ សាសនាចក្រដែលសក្តិសម ដូច្នេះពួកគេអាចធ្វើកិច្ចការក្នុងនាម របស់ទ្រង់ សម្រាប់សេចក្តីសង្គ្រោះដល់កូនចៅទាំងឡាយរបស់ ទ្រង់ ។ កូនសៅនៃបព្វជិតភាពគឺជាសិទ្ធិនៃគណៈប្រធាន ឬ ជាអំណាចដែលត្រូវបានផ្តល់ឲ្យដល់ពួកបុរសដោយព្រះដើម្បី គ្រប់គ្រង និង ដឹកនាំនគរព្រះនៅលើផែនដីនេះ (សូមមើល ម៉ាថាយ ១៦:១៥–១៩) ។ តាមរយៈកូនសៅទាំងនេះ អ្នក កាន់អំណាចបព្វជិតភាពអាចទទួលបាននូវការអនុញ្ញាតដើម្បី ផ្សាយដំណឹងល្អ និង ចាត់ចែងពិធីបរិសុទ្ធទាំងឡាយនៃសេចក្តី សង្គ្រោះ ។ ចំពោះអស់អ្នកទាំងឡាយណាដែលបម្រើនៅក្នុង សាសនាចក្រ គឺត្រូវបានហៅក្រោម ការដឹកនាំរបស់បុគ្គលម្នាក់ ដែលកាន់កូនសៅបព្វជិតភាព ។ ដូច្នេះ ពួកគេមានសិទ្ធិទទួល បានអំណាចដែលចាំបាច់ដើម្បីបម្រើ និងបំពេញការទទួលខុស ត្រូវទាំងឡាយនៃការហៅរបស់ពួកគេ ។

ខគម្ពីរយោងដែលទាក់ទង ៖ គ. និង ស. ១២១:៣៦, ៤១–៤២

បព្វជិតភាពអើរ៉ុន

ជាទូទៅ បព្វជិតភាពអើរ៉ុនត្រូវបានហៅថាជាបព្វជិតភាព បម្រុង ។ មុខតំណែងនៃបព្វជិតភាពអើរ៉ុនមាន ឪកុន គ្រូ សង្ឃ និង ប៊ីស្សព ។ នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ សមាជិក ប្រុសៗដែលសក្តិសមអាចចាប់ផ្តើមទទួលបព្វជិតភាពអើរ៉ុននៅ អាយុ ១២ ឆ្នាំ ។

បព្វជិតភាពអើរ៉ុន « កាន់កូនសៅទាំងឡាយអំពីការបម្រើនៃ ពួកទេវតា និង អំពីដំណឹងល្អនៃការប្រែចិត្ត និង អំពីបុណ្យ ជ្រមុជទឹក » (គ. និង ស. ១៣:១) ។

បព្វជិតភាពមិលគីស្សាដែក

បព្វជិតភាពមិលគីស្សាដែកជាបព្វជិតភាពខ្ពស់ជាង ឬធំជាង និងដើម្បីចាត់ចែងការណ៍ទាំងឡាយខាងវិញ្ញាណ (សូមមើល គ. និង ស. ១០៧:៨) ។ បព្វជិតភាពដ៏ប្រសើរជាងនេះត្រូវ បានផ្តល់ឲ្យដល់អ័ដាម ហើយមាននៅលើផែនដី នៅពេលណា ដែលព្រះអម្ចាស់បានបើកសម្តែងដំណឹងល្អរបស់ទ្រង់ ។

ដំបូងបព្វជិតភាពនេះត្រូវបានហៅថាជា « បព្វជិតភាពដ៏បរិសុទ្ធ តាមរបៀបនៃព្រះរាជបុត្រានៃព្រះ »(គ. និង ស. ១០៧:៣) ។ ក្រោយមកបព្វជិតភាពនេះត្រូវបានស្គាល់ថា ជា បព្វជិតភាព មិលគីស្សាដែក ដែលត្រូវបានដាក់ឈ្មោះតាមសង្ឃជាន់ខ្ពស់ដ៏ អស្ចារ្យម្នាក់ ដែលបានរស់នៅក្នុងអំឡុងពេលនៃជំនាន់ព្យាការី អ័ប្រាហាំ ។

នៅក្នុងបព្វជិតភាពមិលគីស្សាដែកមាននូវមុខតំណែងដូចជា អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និង សាវក ។ ប្រធាននៃបព្វជិតភាពមិលគីស្សាដែកគឺជាប្រធាន សាសនាចក្រ ។

ខគម្ពីរយោងដែលទាក់ទង ៖ អេភេសូរ ៤:១១–១៤

៧. ពិធីបរិសុទ្ធ និង សេចក្តីសញ្ញាទាំងឡាយ

ពិធីបរិសុទ្ធទាំងឡាយ

នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ ពិធីបរិសុទ្ធគឺពិសិដ្ឋ ជាពិធីផ្លូវការដែលមានអត្ថន័យខាង វិញ្ញាណ ។ ពិធីបរិសុទ្ធនីមួយៗត្រូវបានបង្កើតឡើងដោយ ព្រះ ដើម្បីបង្រៀនពីសេចក្តីពិតនានាខាងវិញ្ញាណ ។ ពិធីបរិសុទ្ធទាំង ឡាយនៃសេចក្តីសង្គ្រោះ ត្រូវបានធ្វើឡើងដោយសិទ្ធិអំណាច នៃបព្វជិតភាព និងក្រោមការដឹកនាំនៃអស់អ្នកដែលកាន់ កូនសោបព្វជិតភាព ។ ពិធីបរិសុទ្ធមួយចំនួន គឺសំខាន់ចំពោះ ភាពលើកតម្កើង និងត្រូវបានគេហៅថាជា ពិធីបរិសុទ្ធសម្រាប់ ការសង្គ្រោះ ។

ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះដំបូងគេនៃដំណឹងល្អគឺ ពិធី បុណ្យជ្រមុជទឹកដោយការជ្រមុជទៅក្នុងទឹកដោយអ្នកមាន សិទ្ធិអំណាច ។ បុណ្យជ្រមុជទឹកគឺចាំបាច់សម្រាប់បុគ្គលម្នាក់ៗ ដើម្បីក្លាយជាសមាជិកនៃសាសនាចក្រ ដើម្បីចូលទៅក្នុងនគរ សេឡេស្ទាល (សូមមើល យ៉ូហាន ៣:៥) ។

ពាក្យថា *បុណ្យជ្រមុជទឹក* មកពីភាសាក្រិក មានន័យថា ជ្រលក់ ឬជ្រមុជ ។ ការជ្រមុជគឺជានិមិត្តរូបនៃសេចក្តីស្លាប់នៃជីវិត ដែលមានអំពើបាបរបស់មនុស្សម្នាក់ និងការកើតជាថ្មីក្នុងជីវិត ខាងវិញ្ញាណ ដែលបានឧទ្ទិសដល់ការបម្រើព្រះ និងកូនចៅ ទាំងឡាយរបស់ទ្រង់ ។ វាក៏ជានិមិត្តរូបនៃសេចក្តីស្លាប់ និង ការរស់ឡើងវិញផងដែរ ។

បន្ទាប់ពីមនុស្សម្នាក់ត្រូវបានជ្រមុជទឹកហើយ នោះអ្នកកាន់ បព្វជិតភាពមិលគីស្សាដែកម្នាក់ ឬច្រើននាក់នឹងដាក់ដៃ លើក្បាលបុគ្គលនោះ ហើយបញ្ជាក់គាត់ថាជាសមាជិកនៃ សាសនាចក្រនេះ ។ ជាផ្នែកនៃពិធីបរិសុទ្ធនេះ ដែលត្រូវបាន ហៅថា ពិធីបញ្ជាក់ បុគ្គលនោះត្រូវបានគេផ្តល់ឲ្យនូវអំណោយ ទាននៃព្រះវិញ្ញាណបរិសុទ្ធ ។

អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ គឺខុសពីឥទ្ធិពលនៃ ព្រះវិញ្ញាណបរិសុទ្ធ ។ ពីមុនការជ្រមុជទឹក បុគ្គលម្នាក់អាច ទទួលអារម្មណ៍នៃឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធម្តងម្កាល ហើយ តាមរយៈឥទ្ធិពលនោះ នោះបុគ្គលម្នាក់នោះអាចទទួលបាននូវ ទីបន្ទាល់នៃសេចក្តីពិតមួយ (សូមមើល មរ៉ូណៃ ១០:៤–៥) ។ បើសិនបុគ្គលនោះកាន់តាមព្រះបញ្ញត្តិទាំងឡាយ បន្ទាប់ពីទទួល បានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធនោះ បុគ្គលនោះមាន សិទ្ធិដើម្បីមានភាពជាដៃគូដ៏ជាប់លាប់របស់ទ្រង់ ។

ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះផ្សេងទៀតរួមមាន ការតែង តាំងបព្វជិតភាពមិលគីស្សាដែក (សម្រាប់បុរស) អំណោយ ទានពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធនិង អាពាហ៍ពិពាហ៍នៃការ ផ្សារភ្ជាប់ (សូមមើល គ. និង ស. ១៣១:១–៤) ។ គ្រប់ ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះនៃបព្វជិតភាពទាំងអស់គឺមាន សេចក្តីសញ្ញា ។ នៅក្នុងព្រះវិហារបរិសុទ្ធ ពិធីបរិសុទ្ធសម្រាប់ ការសង្គ្រោះទាំងនេះអាចនឹងត្រូវបានធ្វើឡើងជំនួសមរណជន ។ ពិធីបរិសុទ្ធជំនួសអាចមានប្រសិទ្ធភាពបាន លុះត្រាតែបុគ្គល ដែលបានស្លាប់នោះទទួលយកពិធីទាំងនេះនៅក្នុងពិភពវិញ្ញាណ ហើយគោរពតាមសេចក្តីសញ្ញាដែលមានពាក់ព័ន្ធតែប៉ុណ្ណោះ ។

ពិធីបរិសុទ្ធដទៃទៀតដូចជា ការប្រសិទ្ធពរអ្នកឈឺ និង ការដាក់ ឈ្មោះ និង ការប្រសិទ្ធពរកុមារ ក៏ជាកិច្ចការសំខាន់ផងដែរ សម្រាប់ការអភិវឌ្ឍខាងវិញ្ញាណរបស់យើង ។

ខគម្ពីរយោងដែលទាក់ទង ៖ កិច្ចការ ២:៣៦–៣៨

សេចក្តីសញ្ញា

សេចក្តីសញ្ញាគឺជាកិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយរវាងព្រះ និង មនុស្ស ។ ព្រះប្រទានលក្ខខណ្ឌទាំងឡាយសម្រាប់សេចក្តី សញ្ញា ហើយយើងយល់ព្រមដើម្បីធ្វើនូវអ្វីដែលទ្រង់ប្រាប់ឲ្យ យើងធ្វើ បន្ទាប់មកព្រះសន្យាដល់យើងនូវពរជ័យជាក់លាក់មួយ ចំនួន នៅពេលយើងគោរពប្រតិបត្តិតាម (សូមមើល គ. និង ស. ៨២:១០) ។

រាល់ពិធីបរិសុទ្ធសម្រាប់ការសង្គ្រោះនៃបព្វជិតភាព គឺរួមមាន សេចក្តីសញ្ញា ។ យើងចុះសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ នៅពេលធ្វើបុណ្យជ្រមុជទឹក និង ព្រឹកសេចក្តីសញ្ញាទាំងនោះ ឡើងវិញ ដោយការទទួលទានសាក្រាម៉ង់ ។ បងប្អូនប្រុសដែល ទទួលបព្វជិតភាពមិលគីស្សាដែកនឹងបានចូលទៅក្នុងសម្បថ និង សេចក្តីសញ្ញានៃបព្វជិតភាព ។ យើងបានធ្វើសេចក្តីសញ្ញា បន្ថែមទៀតនៅក្នុងព្រះវិហារបរិសុទ្ធ ។

ខគម្ពីរយោងដែលទាក់ទង ៖ និក្ខមនំ ១៩:៥–៦, ទំនុកតម្កើង ២៤:៣–៤, នីហ្វៃទី២ ៣១:១៩–២០, គ. និង ស. ២៥:១៣

៨. អាពាហ៍ពិពាហ៍ និង គ្រួសារ

អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី គឺត្រូវបានតែងតាំងឡើង ដោយព្រះ ហើយគ្រួសារគឺជាផ្នែកដ៏សំខាន់ចំពោះផែនការ នៃសេចក្តីសង្គ្រោះ និង សុភមង្គលរបស់យើង ។ សុភមង្គល នៅក្នុងជីវិតគ្រួសារអាចកើតឡើងបាន នៅពេលយើងធ្វើតាម ការបង្រៀនរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។

អំណាចដ៏ពិសិដ្ឋនៃការបង្កើតកូនចៅ ប្រើបានសម្រាប់តែប្រុស និង ស្រីដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់ជាប្តីប្រពន្ធតែ ប៉ុណ្ណោះ ។ ឪពុកម្តាយត្រូវបង្កើតកូនឲ្យចម្រើនជាច្រើនឡើងឲ្យ មានពេញពាសលើផែនដី ចិញ្ចឹមបីបាច់កូនចៅរបស់ពួកគេដោយ សេចក្តីស្រឡាញ់ និង សេចក្តីសុចរិត និង ផ្តល់នូវសេចក្តីត្រូវការ ខាងរូបកាយ និង ខាងវិញ្ញាណដល់កូនចៅរបស់ពួកគេ ។

ស្វាមី និង ភរិយាមាននូវការទទួលខុសត្រូវដ៏ឧឡារិកដើម្បី ស្រឡាញ់ និង ថែរក្សាគ្នាទៅវិញទៅមក ។ ឪពុកជាអ្នកដឹកនាំ ក្នុងក្រុមគ្រួសាររបស់ពួកគេប្រកបដោយសេចក្តីស្រឡាញ់ និង សេចក្តីសុចរិត និង ផ្តល់នូវសេចក្តីត្រូវការដ៏ចាំបាច់នានាសម្រាប់ ជីវិត ។ ម្តាយមានភារកិច្ចសំខាន់ ដើម្បីថែរក្សាបីបាច់កូនចៅ របស់ខ្លួន ។ នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះ ឪពុក និង ម្តាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូ ស្មើគ្នា ។

ផែនការនៃសុភមង្គលដ៏ទេវភាពនេះផ្តល់លទ្ធភាពដល់ទំនាក់ ទំនងក្រុមគ្រួសារឲ្យបន្តទៅហួសពីសេចក្តីស្លាប់ ។ ផែន ដីត្រូវបានបង្កើតឡើង ហើយដំណឹងល្អត្រូវបានបើកសម្តែង ដូច្នេះក្រុមគ្រួសារត្រូវបានបង្កើតឡើង ត្រូវបានផ្សារភ្ជាប់ និង ត្រូវបានតម្កើងឡើងដ៏អស់កល្បជានិច្ច ។ (កែសម្រួល ពី « The Family: A Proclamation to the

World » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩, សូមមើលផងដែរនៅគេហទំព័រ LDS.org/topics/family-proclamation) ។

ខគម្ពីរយោងដែលទាក់ទង ៖ លោកុប្បត្តិ ២:២៤, ទំនុកតម្កើង ១២៧:៣, ម៉ាឡាគី ៤:៥–៦, គ. និង ស. ១៣១:១–៤

៩. ព្រះបញ្ញត្តិទាំងឡាយ

បទបញ្ញត្តិទាំងឡាយគឺជាក្រឹត្យវិន័យ និងជាតម្រូវការដែលព្រះបានប្រទានដល់មនុស្សលោក ។ យើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះទ្រង់ ដោយការគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ (សូមមើល យ៉ូហាន ១៤:១៥) ។ ការរក្សានូវបទបញ្ញត្តិទាំងឡាយនឹងនាំមកនូវពរជ័យពីព្រះអម្ចាស់ (សូមមើល គ. និង ស. ៨២:១០) ។

បទបញ្ញត្តិគ្រឹះពីរដ៏សំខាន់បំផុតគឺ « ស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។ . . . ហើយ. . . ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » (ម៉ាថាយ ២២:៣៦–៣៩) ។

ក្រឹត្យវិន័យទាំងដប់ប្រការគឺជាផ្នែកមួយដ៏សំខាន់នៃដំណឹងល្អ ហើយជាគោលការណ៍ដ៏នៅអស់កល្ប ដែលចាំបាច់សម្រាប់ភាពតម្កើងឡើងរបស់យើង (សូមមើល និក្ខមនំ ២០:៣–១៧) ។ ព្រះអម្ចាស់បានបើកសម្តែងក្រឹត្យវិន័យទាំងនោះដល់ម៉ូសេកាលពីសម័យបុរាណ ហើយទ្រង់បានលើកឡើងម្តងទៀតនៅក្នុងវិវរណៈថ្ងៃចុងក្រោយ ។

ព្រះបញ្ញត្តិផ្សេងទៀត រួមមានការអធិស្ឋានប្រចាំថ្ងៃ (សូមមើល នីហ្វៃទី ២ ៣២:៨–៩), ការបង្រៀនដំណឹងល្អដល់អ្នកដទៃ (សូមមើល ម៉ាថាយ ២៨:១៩–២០), ការកាន់តាមច្បាប់ព្រហ្មចារីយភាព (សូមមើល គ. និង ស. ៤៦:៣៣), ការបង់ដង្វាយមួយភាគដប់ពេញលេញ (សូមមើល ម៉ាឡាគី ៣:៨–១០), ការតមអាហារ (សូមមើល អេសាយ ៥៨:៦–៧), ការអភ័យទោសដល់អ្នកដទៃ (សូមមើល គ. និង ស. ៦៤:៩–១១), ការមានវិញ្ញាណនៃសេចក្តីអំណរគុណ (សូមមើល គ. និង ស. ៧៨:១៩) និង ការធ្វើតាមពាក្យសម្តីនៃប្រាជ្ញាវាងវៃ (សូមមើល គ. និង ស. ៨៩:១៨–២១) ។

ខគម្ពីរយោងដែលទាក់ទង ៖ លោកុប្បត្តិ ៣៩:៩; អេសាយ ៥៨:១៣–១៤; នីហ្វៃទី១ ៣:៧; ម៉ូសាយ ៤:៣០; អាលម៉ា ៣៧:៣៥; អាលម៉ា ៣៩:៩; គ. និង ស. ១៨:១៥–១៦; គ. និង ស. ៨៨:១២៤

សម្រាប់ព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះ សូមចូលទៅកាន់គេហទំព័រ LDS.org ការបង្រៀន, ប្រធានបទនៃដំណឹងល្អ; ឬ សូមមើល *ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងនៃដំណឹងល្អ* (ឆ្នាំ ២០០៤) ។

ការបង្រៀនដំណឹងល្អព្រមគ្នា

យើងសូមចេញអនុសាសន៍ឲ្យអ្នកប្រើសៀវភៅសិក្សានេះ តាមដែលវាបានសរសេរឡើង ហើយបង្រៀនដំណឹងល្អទាំងបួនតាមលំដាប់លំដោយ ។ ប៉ុន្តែ អ្នកអាចជ្រើសដើម្បីបង្រៀនដំណឹងល្អនៅក្នុងព្រះគម្ពីរសញ្ញាថ្មី « ព្រមគ្នា » មានន័យថា បង្រៀនពីព្រឹត្តិការណ៍នៃព្រះជន្មរបស់ព្រះអង្គសង្គ្រោះតាមលំដាប់កាលវេលា ដោយដាក់បញ្ចូលគ្នានូវឯកសារមកពីដំណឹងល្អនីមួយៗ ។ សម្រាប់ព័ត៌មាន និងធនធាននានាស្តីពីការបង្រៀនដំណឹងល្អព្រមគ្នា សូមមើលទៅឧបសម្ព័ន្ធនៅក្នុងកំណែទីដប់ថ្លៃនៃសៀវភៅសិក្សានេះនៅលើ LDS.org និងនៅក្នុងកម្មវិធីបណ្ណាល័យដំណឹងល្អសម្រាប់ឧបករណ៍ចល័ត ។



ការងារបម្រើនៅក្នុងជីវិតរមែងស្លាប់សំខាន់ៗនៃព្រះយេស៊ូវគ្រីស្ទ



ត្រាស់ហៅពួកសាវក



បង្រៀនរឿងប្រៀបប្រដូចអំពីនគរ



តែងតាំងពួកសាវកដប់ពីរនាក់



ធ្វើឲ្យសមុទ្រស្ងប់



ធ្វើឲ្យទឹកក្លាយជាស្រាទំពាំងបាយជូរ



បង្រៀន ហើយព្យាបាល
ទូទាំងស្រុកកាលីឡេ



ទេសនកថានៅលើភ្នំ



ព្យាបាលស្ត្រីម្នាក់ដែលមានជំងឺធ្លាក់ឈាម



ត្រូវបានបដិសេធនៅភូមិណាសារ៉ែត




ព្យាបាលអ្នកបម្រើរបស់មេបញ្ជាការ



ប្រោសកូនស្រីរបស់ជៃរ៉ុស



បង្រៀនស្ត្រីម្នាក់នៅឯអណ្តូងទឹក



បានល្បួងដោយអារក្ស



ចូលរួមបុណ្យរំលងនៅយេរូសាឡិម



ព្យាបាលបុរសម្នាក់នៅ
ស្រះទឹកបេថែសដា



ការសម្អាតព្រះវិហារ
បរិសុទ្ធលើកទីមួយ



ពិធីបុណ្យជ្រមុជទឹក

ស្រុកកាលីឡេ

ក្រុងកាពើណិម •

• កូមិណាសារ៉ែត

សាសន៍សាម៉ារី

• សាសន៍សាម៉ារី


ស្រុកពេរៀ
យូដា

• ក្រុងយេរូសាឡិម

• កូមិបេថ្លេហិម

ឆ្នាំទីមួយនៃការងារបម្រើ

ឆ្នាំទីពីរនៃការងារបម្រើ



ប្រទានអាហារដល់មនុស្ស
ជាង ៤000 នាក់



ហៅ ហើយបញ្ជូនពួកចិតសិបនាក់ចេញទៅ



ការបង្រៀនអំពីនំប៉័ងជីវិត



សន្យាដល់ពេត្រុសអំពីកូនសោនៃនគរ



យាងនៅលើទឹក



ភ្នំប្រែរូប



ប្រទានអាហារដល់មនុស្ស
ជាង ៥000 នាក់



ត្រូវបានបដិសេធដោយ
ពួកសាសន៍សាម៉ារី



ព្យាបាលមនុស្សឃ្លង់ទាំងដប់នាក់



ជូបនឹងសាខេ



បដិសេធមិនថ្កោលទោសស្ត្រី
ដែលប្រព្រឹត្តសហាយស្មន់







បង្រៀនរឿងប្រៀបប្រដូច
អំពីវត្ថុដែលបាត់

អញ្ជើញកម្លោះអ្នកមាន

បង្រៀនរឿងប្រៀបប្រដូចអំពីសាសន៍សាម៉ារីដ៏ល្អ



ការយាងចូលដោយជោគជ័យ
និង សប្តាហ៍ចុងក្រោយ



ជូបម៉ារា និង ម៉ាថា



ប្រោសឡាសារឲ្យរស់ឡើងវិញ

© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។

រូបភាពដែលបានជ្រើសរើសសម្រាប់ព្រះគម្ពីរសញ្ញាថ្មី

ដើមល្វា (សូមមើល ម៉ាថាយ ២១:១៨–២២)

© Jose Ramiro Laguna/Shutterstock.com



ម៉ាក ឌីង អេលីសាប៊ែត (សាស្ត្រាចារ្យ ល្អក) ។



ពីឡាត់ទទួលស្គាល់ថា ព្រះយេស៊ូវគ្មានទោស (សូមមើល យ៉ូហាន ១៨–១៩)



ព្រះយេស៊ូវគ្រីស្ទមើលថែទាំពួកអ្នកដើរតាមដ៏ស្មោះត្រង់របស់ទ្រង់ (សូមមើល វិវរណៈ ១:១២–១៦)



ការនិមិត្តរបស់យ៉ូហានអំពីស្ត្រី និងនាគដ៏ធំ (សូមមើល វិវរណៈ ១២)